ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Dec-22, 12:37
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier Nº. 002/19-09-2007-ECCC/SC

| | |
|---|---|
| **ចំពោះមុខ:** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele MWACHANDE-MUMBA** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Phillip Rapoza** |
| | **ចៅក្រម យ៉ា ណារិន** |
| **ក្រឡាបញ្ជី:** | **Peace MALLENI  ស៊ា ម៉ៅ  ផន ធឿន** |
| **កាលបរិច្ឆេទ:** | **ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២២** |
| **ភាសា:** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ:** | **សាធារណៈ** |

# សាលដីកា (សំណុំរឿង ០០២/០២)

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Fergal GAYNOR(Reserve)

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាង</u>**
**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Falguni DEBNATH

**<u>សហមេធាវីជនជាប់ចោទ</u>**
**<u>ខៀវ សំផន</u>**
គង់ សំអុន
Anta GUISSÉ

# មាតិកា

I. សេចក្តីផ្តើម .................... 20

ក. សាវតារ .................... 20

ខ. ប្រវត្តិនីតិវិធី .................... 23

គ. បណ្តឹងសាទុក្ខរបស់ ខៀវ សំផន .................... 30

ឃ. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា .................... 30

II. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ .................... 31

ក. សេចក្តីផ្តើម .................... 31

ខ. ការចោទប្រកាន់កំហុសអង្គច្បាប់ .................... 33

គ. ការចោទប្រកាន់កំហុសអង្គហេតុ .................... 35

ឃ. ការជំទាស់ទៅនឹងសេចក្តីសម្រេចភ្លាមៗ .................... 37

ង. បញ្ហាដែលមានសារៈសំខាន់ទូទៅ .................... 39

ច. បទដ្ឋានសម្រាប់ការបដិសេធចោលភ្លាមៗដោយពុំចាំបាច់ពិនិត្យបន្ថែម .................... 40

ឆ. សេចក្តីសន្និដ្ឋាន .................... 41

III. បញ្ហាបឋម .................... 42

ក. វចនាសម្ព័ន្ធនៃសារណាបណ្តឹងសាទុក្ខ .................... 42

ខ. តម្លៃនៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក. .................... 45

IV. ការចោទប្រកាន់កំហុសក្នុងការចេញ និងការប្រកាសសាលក្រម .................... 49

V. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី .................... 65

ក. គោលការណ៍នីត្យានុកូលភាព .................... 68

ខ. ការកែប្រែប្រភេទគតិយុត្តនៃបទចោទ .................... 73

១. ការចោទប្រកាន់អំពីការបញ្ចូលធាតុផ្សំថ្មីនៃបទចោទ .................... 77

២. ការលើកឡើងអំពីកង្វះនៃការជូនដំណឹង .................... 80

៣. សេចក្តីសន្និដ្ឋាន ........................................................................................................ 82

**គ. ការចោទប្រកាន់ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង**....................................... 82

១. ការលើកឡើងអំពីការខកខានដោះស្រាយការចោទប្រកាន់នូវភាពលម្អៀង ............................ 83

២. ការចោទប្រកាន់ការផ្ទេរនូវការយល់ឃើញពីសំណុំរឿង ០០២/០១..................................... 85

**៣. ការចោទប្រកាន់ការផ្ទេរភស្តុតាងពីសំណុំរឿង ០០២/០១** .................................................. 90

ក. ឆោម សែ ................................................................................................................ 99

ខ. អែម អឿន............................................................................................................. 102

គ. គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក.................................................................. 106

៤. ការយល់ឃើញដទៃទៀតដែលបង្ហាញភាពលម្អៀង............................................................ 113

**ឃ. ការចោទប្រកាន់កំហុសក្នុងសេចក្តីសម្រេចលើភស្តុតាងដែលបានធ្វើឡើងក្នុងអំឡុងពេលនៃការជំនុំជម្រះ** ........................................................................................................................... 116

១. សេចក្តីសម្រេចស្តីពីការចូលបង្ហាញខ្លួនរបស់សាក្សី ........................................................ 117

**២. ការបង្ហាញភស្តុតាងសំណុំរឿង ០០៣ និង ០០៤** ........................................................... 132

ក. ការចោទប្រកាន់កំហុសអង្គច្បាប់.................................................................................. 139

ខ. ការចោទប្រកាន់អំពីការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ ............. 146

**៣. ការទទួលយកភស្តុតាងក្នុងពេលជំនុំជម្រះ**........................................................................ 153

ក. ការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះស្របតាមវិធាន ៨៧(៤) ........... 155

នៃវិធានផ្ទៃក្នុង.............................................................................................................. 155

ខ. ការទទួលយកឯកសារនៃសំណុំរឿង ០០៣ និង ០០៤ ......................................................... 156

គ. ការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរដែលមាន“តម្លៃជាភស្តុតាងទាប និងពាក់ព័ន្ធតិចតួច” និង“សៀវភៅទាំងមូល”............................................................................................ 161

ឃ. ការចោទប្រកាន់អំពីព្យសនកម្មៈ “ការពន្យារពេលឥតសមស្រប”........................................ 166

**៤. ការទទួលយកឯកសារមានប្រភពចេញពី Christopher Goscha**............................. 168

ក. ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលបានឯកសារ GOSCHA.......... 175

ខ. ការជំទាស់ទៅនឹងការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសាររបស់ Christopher GOSCHA.......... 179

គ. ការជំទាស់ទៅនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសារ Christopher GOSCHA.......... 182

៥. ការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១.......... 185

**៦. ការខកខានក្នុងការកោះឡើងវិញ Stephen HEDER, François PONCHAUD និង Philip SHORT**.......... 190

ក. Stephen HEDER និង François PONCHAUD.......... 194

ខ. Philip SHORT.......... 203

៧. ការខកខានក្នុងការបើកកិច្ចដំណើរការនីតិវិធីឡើងវិញដើម្បីទទួលយកភស្តុតាងរបស់សាក្សីពីររូប.......... 210

**ង. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងវិធីសាស្ត្របង្ហាញភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង**.......... 214

**១. ការជំទាស់ទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង**.......... 214

ក. បន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង.......... 214

ខ. ការផ្តល់សំអាងហេតុដែលផ្អែកលើការសន្និដ្ឋានពុំត្រូវបានអនុញ្ញាត ការសន្និដ្ឋានពង្រីក និងការសន្និដ្ឋានជាទូទៅ.......... 217

គ. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងភស្តុតាងដោះបន្ទុក.......... 231

ឃ. ចំនួននៃភស្តុតាង និងតម្លៃជាភស្តុតាង.......... 241

ង. ការបញ្ជាក់បន្ថែម.......... 246

ច. ភាពមិនស៊ីសង្វាក់គ្នា.......... 250

ឆ. ការលម្អៀងនៃវប្បធម៌.......... 253

ជ. ពាក្យចចាមអារ៉ាម ........................................................................................ 258

**២. ការវាយតម្លៃលើភស្តុតាងជាឯកសារ** .................................................................. 264

**ក. ការវាយតម្លៃលើភស្តុតាងជាឯកសារនៅសម័យនោះ** ............................................ 264

i. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា .................................................................. 265

ii. កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ...................................................... 268

**ខ. បទសម្ភាសន៍ ចម្លើយ និងឯកសារផ្សព្វផ្សាយរបស់ ខៀវ សំផន** ............................... 271

i. កិច្ចសម្ភាសន៍របស់ ខៀវ សំផន .................................................................. 272

ii. ចម្លើយ និងឯកសារផ្សព្វផ្សាយរបស់ ខៀវ សំផន ............................................. 275

គ. ចម្លើយក្រៅក្របខ័ណ្ឌតុលាការ ........................................................................ 276

ឃ. ការឃោសនា ..................................................................................................... 280

ង. ភស្តុតាងទទួលបានតាមរយៈការធ្វើទារុណកម្ម ....................................................... 283

**ច. ភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី** ................................................. 289

i. ចម្លើយជាលាយលក្ខណ៍អក្សររបស់សាមីជនដែលពុំបានមកផ្តល់សក្ខីកម្ម................ 289

ii. ការវាយតម្លៃលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ............................................ 301

ឆ. ឯកសារដែលទទួលបានសច្ចធារណ៍.................................................................. 304

ជ. ភស្តុតាងរបស់អ្នកជំនាញ ................................................................................ 307

**VI. ការចោទប្រកាន់កំហុសក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ** ........................................................................................................................ 308

**ក. វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ** ............................................................ 308

**១. អង្គច្បាប់**.......................................................................................................... 308

ក. ការចោទប្រកាន់កំហុសក្នុងការកំណត់ចរិតលក្ខណៈលើសំណើសុំពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរថា ជាអញ្ញត្រកម្ម.......................................................................... 310

ខ. ការចោទប្រកាន់អំពីឱកាសនិយមនៃការកំណត់ចរិតលក្ខណៈអញ្ញត្រកម្ម..................... 321

គ. ការចោទប្រកាន់អំពីភាពមិនយុត្តិធម៌ .................................................... 328

**២. ការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងការយល់ឃើញពាក់ព័ន្ធ** .................................................... 334

ក. បទដ្ឋានគតិយុត្តសម្រាប់កំណត់អង្គសេចក្តីនៃរឿងក្តី .................................................... 336

ខ. ការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងការយល់ឃើញពាក់ព័ន្ធនោះ .................................................... 338

**ខ. បទចោទដែលពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ក្នុងដីកាដំណោះស្រាយ** .................................................... 345

១. ការស្លាប់ដោយសារការអត់អាហារក្នុងសហករណ៍ត្រាំកក់ .................................................... 348

២. "ការប្រព្រឹត្តដោយរើសអើង"ទៅលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់ .................................................... 350

៣. "ការប្រព្រឹត្តដោយរើសអើង"ទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងសហករណ៍ត្រាំកក់ .................................................... 352

**គ. កង្វះការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុសត្យានុម័តដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២** .................................................... 356

១. ការចោទប្រកាន់កំហុសក្នុងបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការជូនដំណឹងបទចោទ .................................................... 356

**២. ការលើកឡើងនូវកំហុសពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់** .................................................... 359

ក. សហករណ៍ត្រាំកក់ .................................................... 363

ខ. ការដ្ឋានទំនប់ត្រពាំងថ្ម .................................................... 368

គ. ការដ្ឋានទំនប់១មករា .................................................... 370

ឃ. ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង .................................................... 372

ង. ក្រាំងតាចាន់ .................................................... 373

ច. អូរកន្សែង .................................................... 375

ឆ. ភ្នំក្រោល .................................................... 376

**៣. ការចោទប្រកាន់កំហុសពាក់ព័ន្ធនឹងក្រុមជាក់លាក់** .................................................... 378

ក. ជនជាតិចាម ........................................................................ 378

ខ. ជនជាតិវៀតណាម ........................................................................ 382

គ. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ........................................ 384

**ឃ. អង្គហេតុដែលត្រូវបានដកចេញពីសំណុំរឿង ០០២/០២ បន្ទាប់ពីការបំបែកសំណុំរឿង** .......... 387

១. ការចោទប្រកាន់អំពីនត្តិភាពវិសាលភាពសម្រាប់អង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំ ...................... 389

២. ការចោទប្រកាន់អំពីនត្តិភាពវិសាលភាពនៃអង្គហេតុទាក់ទងទៅនឹងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ...................... 393

៣. ការចោទប្រកាន់អំពីនត្តិភាពនៃវិសាលភាពអង្គហេតុទាក់ទងទៅនឹងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់ ................ 399

៤. វិសាលភាពនៃការជំនុំជម្រះមិនច្បាស់លាស់ និងរយៈពេលយូរ ........................................ 405

**ង. ភស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព** ........................................................ 408

**VII. ការចោទប្រកាន់កំហុសពាក់ព័ន្ធនៅនឹងបទឧក្រិដ្ឋជាមូលដ្ឋាន** ........................................ 420

**ក. អំពើមនុស្សឃាតដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ................................ 420

១. ថាតើ *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល* គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា ........................................................................ 422

២. ថាតើ ជនជាប់ចោទអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងអំពី *ធាតុផ្សំអត្តនោម័តិ* ដែលរួមបញ្ចូល *ចេតនាប្រយោល* នោះ ដែរ ឬយ៉ាងណា ........................................ 436

៣. ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធនឹងអំពើល្មើសអកម្ម ដែរ ឬយ៉ាងណា.... 438

៤. ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវាយតម្លៃយុត្តាធិការពេលវេលា ដែរ ឬយ៉ាងណា ........................................................................ 442

**៥. ថាតើ អំពើមនុស្សឃាតត្រូវបានបង្ហាញនៅទីតាំងខាងក្រោម ដែរ ឬយ៉ាងណា** ...................... 444

ក. សហករណ៍ត្រាំកក់ ........................................................................ 444

ខ. ការដ្ឋានទំនប់ត្រពាំងថ្ម ........................................................ 452

គ. ការដ្ឋានទំនប់១មករា ........................................................ 454

ឃ. ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង........................................................ 466

ង. មន្ទីរសន្តិសុខភ្នំក្រោល ........................................................ 467

**ខ. ការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........................................................ 475

**១. ការសម្លាប់រង្គាលជនជាតិចាម**........................................................ 475

ក. ការសម្លាប់ជនជាតិចាមនៅភូមិទ្រា........................................................ 476

ខ. ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន ........................................................ 480

គ. ការកំណត់អំពីតួលេខនៃការសម្លាប់ ........................................................ 486

ឃ. ចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ ........................................................ 488

**២. ការសម្លាប់រង្គាលជនជាតិវៀតណាម** ........................................................ 492

ក. ការសម្លាប់ជនជាតិវៀតណាមនៅខេត្តស្វាយរៀង ........................................................ 494

ខ. ការសម្លាប់ជនជាតិវៀតណាមលើដែនទឹកកម្ពុជាប្រជាធិបតេយ្យ ........................................................ 496

គ. ការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តកំពង់ឆ្នាំង........................................................ 500

ឃ. ការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់........................................................ 503

ង. ការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តក្រចេះ ........................................................ 506

ច. ការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់នៅអូរកន្សែង........................................................ 508

ឆ. ថាតើ អំពើមនុស្សឃាតនោះអាចស្មើនឹងការសម្លាប់រង្គាល ដែរ ឬយ៉ាងណា........................................................ 510

**គ. បទឧក្រិដ្ឋនៃការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........................................................ 514

ការដាក់ឱ្យទៅជាទាសករនៅភ្នំក្រោល........................................................ 514

**ឃ. ការនិរទេសដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........................................................ 516

១. សហករណ៍ត្រាំកក់........................................................ 517

២. ខេត្តព្រៃវែង ........................................................ 528

**ង. ការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........ 537

ការធ្វើទារុណកម្មលើជនជាតិចាម ........ 537

**ច. ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........ 539

**១. ច្បាប់ជាធរមាន** ........ 539

ក. ថាតើ គោលបំណងក្នុងការដកក្រុមមួយចេញពីសង្គម គឺជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា ........ 540

ខ. ថាតើ ការប្រព្រឹត្តទៅលើដូចៗគ្នាដែលមានផលប៉ះពាល់ជាពិសេសលើបុគ្គលមួយប្រភេទអាច ស្មើនឹងការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា ........ 545

**២. ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ** ........ 548

**ក. ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម** ........ 548

i. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងធាតុផ្សំសត្យានុម័ត ........ 549

ii. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិ ........ 551

iii. ថាតើ ការចាប់ខ្លួនអាចត្រូវបានយោងទៅលើក្នុងការបង្ហាញនូវកម្រិតនៃភាពធ្ងន់ធ្ងរដែលជា លក្ខខណ្ឌតម្រូវ ដែរ ឬយ៉ាងណា ........ 554

**ខ. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើ“សត្រូវពិត ឬតាមការសន្មត”** ..... 556

i. ថាតើ “សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា” គឺជាក្រុមដែលអាចកំណត់ បានច្បាស់លាស់ ដែរ ឬយ៉ាងណា ........ 557

**ii. សហករណ៍ត្រាំកក់** ........ 565

- *អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* ........ 567
- ***ប្រជាជនថ្មី*** ........ 569

ក) របបអាហារ ........ 569

ខ) លក្ខខណ្ឌការងាររួមទាំងនៅក្នុងកងចល័តយុវជន ........ 573

គ) ការធ្វើបាបយ៉ាងលំបាកវេទនា ........ 575

ឃ) ការតាមដាន និងការចាប់ខ្លួន ........................................................ 576

iii. ការដ្ឋានទំនប់ត្រពាំងថ្ម ........................................................ 580

**iv. ការដ្ឋានទំនប់១មករា** ........................................................ 585

- *ប្រជាជនថ្មី* ........................................................ 586

- *អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* ........................................................ 589

v. មន្ទីរសន្តិសុខស-២១ ........................................................ 593

vi. មន្ទីរសន្តិសុខអូរកន្សែង ........................................................ 596

**៣. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា** ........................................................ 601

**ក. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើជនជាតិចាម** ........................................................ 601

i. អំពើធ្វើទុក្ខបុកម្នេញ ........................................................ 603

**ii. ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា** ........................................................ 608

- *ការដ្ឋានទំនប់១មករា* ........................................................ 609

- *នៅទីកន្លែងផ្សេងក្នុងប្រទេសកម្ពុជា* ........................................................ 614

iii. ថាតើ ការរឹតត្បិតលើសេរីភាពផ្នែកសាសនាត្រូវបានអនុញ្ញាត ដែរ ឬយ៉ាងណា ......... 618

iv. ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញបានរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា ............. 620

v. ថាតើ ការរឹតត្បិតលើការប្រតិបត្តិសាសនា និងវប្បធម៌បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែរ ឬយ៉ាងណា ........................................................ 622

vi. ថាតើ មានចេតនាក្នុងការរើសអើងដោយសារមូលហេតុនៃសាសនា ដែរ ឬយ៉ាងណា .. 624

vii. ថាតើ កម្រិតនៃភាពធ្ងន់ធ្ងរត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា ........................................................ 627

**ខ. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនា** ................ 630

i. ការចោទប្រកាន់អំពីកង្វះភស្តុតាងទាក់ទងទៅនឹងផលប៉ះពាល់លើរូបកាយ ឬផ្លូវចិត្តនៃអំពើធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិក ........................................................ 632

**ii. ការចោទប្រកាន់នត្ថិភាពនៃការប្រព្រឹត្តដោយរើសអើងទៅលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជាទូទៅ ........ 638**

- *ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនារើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា ........ 639*

- *ថាតើ អំពើប្រព្រឹត្តទៅលើពុទ្ធសាសនិកជាទូទៅបានរើសអើងជាក់ស្តែង និងថាតើ មានអត្ថិភាពនៃចេតនារើសអើង ដែរ ឬយ៉ាងណា........ 643*

**៤. ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍ ........ 646**

ក. សហករណ៍ត្រាំកក់........ 647

ខ. មន្ទីរសន្តិសុខស-២១ ........ 652

គ. មន្ទីរសន្តិសុខអូរកន្សែង ........ 657

**ឃ. ខេត្តព្រៃវែង និងស្វាយរៀង ........ 660**

i. ការស្តែងចេញឱ្យឃើញនៃក្រុម........ 662

ii. ថាតើ អំពើធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា ........ 664

iii. ថាតើ អំពើនោះជាការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា........ 666

iv. ថាតើ ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅទុកជាមុន ដែរ ឬយ៉ាងណា........ 668

**ឆ. អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ........ 671**

**១. ការវាយតម្លៃលើនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀត........ 673**

ក. ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលការណ៍នីត្យានុកូលភាព ........ 673

ខ. លក្ខខណ្ឌតម្រូវដែលរងការចោទប្រកាន់ថា រំលោភបំពានលើការហាមឃាត់ក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ........ 677

**២. ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ........ 683**

ក. សហករណ៍ត្រាំកក់........ 684

ខ. មន្ទីរសន្តិសុខក្រាំងតាចាន់........ 687

គ. មន្ទីរសន្តិសុខភ្នំក្រោល ........................................................................ 694

**៣. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ........................................................................ 699

**ក. នីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........................................................................ 699

**i. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ........................................................................ 701

- *អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ........................................................................ 703
- *"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ"* ........................................................................ 708
- *នីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ* ........................................................................ 714
- *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា(ejusdem generis)* ........................................................................ 719

**ii. ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ........................................................................ 725

- *ការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ* ........................................................................ 726
- *"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ"* ........................................................................ 736
- *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា(ejusdem generis)* ........................................................................ 741

iii. សេចក្តីសន្និដ្ឋាន ........................................................................ 746

**ខ. ការយល់ឃើញផ្នែកអង្គហេតុស្តីពីបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍** ........................................................................ 746

i. សេចក្តីផ្តើម ........................................................................ 746

**ii. គោលបំណងនៃគោលនយោបាយ** ........................................................................ 747

- *ការបង្កើនចំនួនប្រជាជន* ........................................................................ 748
- *ការគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទក្រៅការរៀបអាពាហ៍ពិពាហ៍* ........................................................................ 756
- *ភាពផ្ទុយគ្នារវាងគោលបំណងនៃគោលនយោបាយ* ........................................................................ 763

**iii. ធាតុផ្សំបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍** ........................................................................ 768

- *គោលការណ៍ការស្ម័គ្រចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការរៀបអាពាហ៍ពិពាហ៍* 769

- *ការរៀបអាពាហ៍ពិពាហ៍របស់យោធិនពិការ* ........................................ 790

- *ពិធីរៀបអាពាហ៍ពិពាហ៍*............................................................................ 797

- ***ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ***................. 802

ក) ការយល់ឃើញស្តីពីការរួមភេទដោយបង្ខំ................................................ 803

ខ) ថាតើ មាន“គោលនយោបាយ”នៃរួមភេទដោយបង្ខំ ដែរ ឬយ៉ាងណា ................ 806

**គ) បរិយាកាសបង្ខិតបង្ខំ**.............................................................................. 808

(i) ការតាមដានដោយកងឈ្លបប្រដាប់អាវុធក្រោយពិធីរៀបអាពាហ៍ពិពាហ៍........ 808

(ii) អំពើនៃ“ការរំលោភសេពសន្ថវៈ”ដែលជាការដាក់ទោស.............................. 816

(iii) កង្វះការបង្ហាញច្បាស់លាស់អំពីកាលៈទេសៈបង្ខិតបង្ខំ ............................. 820

ឃ) ការលាក់បាំងការមិនរួមដំណេក ............................................................ 823

**iv. ការអនុវត្តន៍បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍** ............................. 827

- *សេចក្តីណែនាំចេញពីថ្នាក់លើឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ និងការយល់ព្រមទៅលើការផ្គូរផ្គងដែលបានរៀបចំដោយកម្មាភិបាលថ្នាក់ក្រោម* ................................ 828

- *របាយការណ៍ស្តីពីការរៀបអាពាហ៍ពិពាហ៍ផ្ញើទៅថ្នាក់លើ*............................. 833

- *របាយការណ៍ស្តីពីការតាមដានការរួមដំណេកការរៀបអាពាហ៍ពិពាហ៍* .............. 835

- ***ការជាប់ពាក់ព័ន្ធផ្ទាល់របស់ ខៀវ សំផន នៅក្នុងបទបញ្ជារៀបអាពាហ៍ពិពាហ៍***...... 837

ក) ការសំអាងជាចម្បង ឬតែទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ............. 838

ខ) ភាពពុំស៊ីសង្វាក់គ្នាក្នុងភស្តុតាងរបស់ ជា ឌៀប ......................................... 844

គ) ការបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងដទៃទៀត ........................................ 847

ឃ) ការយល់ឃើញទូទៅស្តីពីការសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប..................................................................................................... 852

**គ. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ........ 852

i. សេចក្តីផ្តើម ........ 853

**ii. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ........ 854

*ធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ........ 855

- *ការពាក់ព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ជាមួយនឹងការវាយតម្លៃលើភាពធ្ងន់ធ្ងរ* ........ 861

- ***ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត*** ........ 866

ក) បទដ្ឋានសម្រាប់ការវាយតម្លៃព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ . 868

ខ) ការសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ 870

គ) នត្ថិភាពនៃការប្រតិបត្តិតាមប្រពៃណីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ........ 872

ឃ) ព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តដទៃទៀត ........ 875

ង) ការបង្កើតមនោសញ្ចេតនាក្នុងអំឡុងពេលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ .... 877

ច) ភាពគួរឱ្យជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន និង មុំ វុន ........ 884

ឆ) ស៊ូ សុធារី ........ 886

**iii. ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ........ 888

- *អំពើនៃការរួមភេទដោយបង្ខំ* ........ 888

- ***ជនរងគ្រោះជាស្ត្រី៖ បណ្តឹងសាទុក្ខរបស់ ខៀវ សំផន*** ........ 892

ក) ការជាប់ពាក់ព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ........ 894

ខ) ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ........ 896

(i) នត្ថិភាពនៃការអះអាងច្បាស់លាស់អំពីព្យសនកម្ម ........ 897

(ii) "ការរំលោភសេពសន្ថវៈ"ដែលជាផ្នែកនៃបរិយាកាសបង្ខិតបង្ខំ .................... 900

(iii) ការជំទាស់ទៅនឹងភាពគួរជឿជាក់បាន .................... 901

(iv) ស៊ូ សុធារី .................... 902

គ) ភស្តុតាងនៃព្យសនកម្មដែលពុំត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ... 904

- *ជនរងគ្រោះជាបុរស៖ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា* .................... 907

ក) ថាតើ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យពិចារណាលើព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា .................... 909

ខ) ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត .................... 913

គ) សេចក្តីថ្លៃថ្នូររបស់មនុស្ស .................... 923

**ជ. អំពើប្រល័យពូជសាសន៍** .................... 939

**អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម** .................... 939

**ក. ថាតើ *ធាតុផ្សំសត្យានុម័ត*ត្រូវបានបង្ហាញត្រឹមត្រូវ ដែរ ឬយ៉ាងណា** .................... 939

i. ថាតើ សមាជិកនៃក្រុមដែលទទួលបានការការពារត្រូវបានកំណត់គោលដៅ ដែរ ឬយ៉ាងណា .................... 939

ii. ថាតើ សមាជិកនៃក្រុមដែលទទួលបានការការពារត្រូវបានសម្លាប់ ដែរ ឬយ៉ាងណា.. 942

**ខ. ថាតើ *ធាតុផ្សំអត្តនោម័តិ*ត្រូវបានបង្ហាញត្រឹមត្រូវ ដែរ ឬយ៉ាងណា** .................... 944

i. ថាតើ មានចេតនាក្នុងការបំផ្លាញក្រុមដែលត្រូវបានការពារបែបនោះ ដែរ ឬយ៉ាងណា 945

ii. ថាតើ មានចេតនាក្នុងការបំផ្លាញផ្នែកខ្លះ ឬទាំងមូលនៃក្រុមដែលត្រូវបានការពារ ដែរ ឬយ៉ាងណា .................... 956

**VIII. ការចោទប្រកាន់កំហុសទាក់ទងនៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល** .................... 959

**ក. តួនាទី និងមុខតំណែងរបស់ ខៀវ សំផន** .................... 959

**១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការនៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា** ........ 959

ក. សមាជជាតិពិសេសខែ មេសា ឆ្នាំ ១៩៧៥ និងសមាជជាតិលើកទីបីខែ ធ្នូ ឆ្នាំ ១៩៧៥ ..... 959

ខ. កិច្ចប្រជុំជាមួយកម្មាភិបាលយោធាក្នុងទីក្រុងភ្នំពេញ ........ 962

**២. ប្រធានគណៈប្រធានរដ្ឋ** ........ 963

ក. ការតែងតាំង ........ 963

ខ. តួនាទី និងការទទួលខុសត្រូវ ........ 964

គ សុន្ទរកថា ........ 968

**៣. សមាជិកនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម** ........ 975

**ក. សមាជិកភាពក្នុងគណៈមជ្ឈិម** ........ 975

i. សមាជិកភាព ........ 976

ii. វិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់គណៈមជ្ឈិម ........ 980

iii. ការសន្មតសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិម ........ 987

iv. វត្តមានក្នុងសមាជ ........ 995

**ខ. វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍** ........ 1003

i. តួនាទីដែលមាន“លក្ខណៈពិសេស”នៅក្នុងបក្ស ........ 1003

ii. វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ........ 1007

គ. គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ ........ 1014

**៤. តួនាទីបន្ទាប់បន្សំ** ........ 1017

ក. ការចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលអប់រំ ........ 1017

ខ. សមាជិកមន្ទីរ ៨៧០ ........ 1028

**គ. ការគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្ម** ........ 1034

i. ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម ........ 1034

ii. វណ្ណៈបណ្ដាលសម្រាប់កម្មាភិបាលពាណិជ្ជកម្ម ............................................ 1040

ឃ. ការទទួលខុសត្រូវសម្រាប់ក្រសួងការបរទេស ............................................ 1043

**ខ. សហឧក្រិដ្ឋកម្មរួម** ............................................ 1046

១. ច្បាប់ជាធរមាន ............................................ 1048

២. លក្ខណៈល្មើសនៃគោលបំណងរួម ............................................ 1054

៣. គោលនយោបាយបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ............ 1058

៤. គោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការ............................ 1066

**៥. គោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់**............................................ 1073

ក. ជនជាតិវៀតណាម............................................ 1074

ខ. ជនជាតិចាម............................................ 1081

គ. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ............................................ 1087

ឃ. ពុទ្ធសាសនិក............................................ 1091

**៦. គោលនយោបាយនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍**............................................ 1091

៧. ការរួមចំណែករបស់ ខៀវ សំផន ............................................ 1092

**៨. ការដឹង និងចេតនារបស់ ខៀវ សំផន** ............................................ 1101

ក. ការអះអាងថា ជាចេតនា“របស់អ្នកដទៃ” ............................................ 1106

ខ. ការដឹងដែលបង្ហាញនូវចេតនា ............................................ 1109

គ. សហករណ៍ និងការដ្ឋានធ្វើការ ............................................ 1116

ឃ. មន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការបោសសម្អាត ............................................ 1126

ង. ក្រុមជាក់លាក់ ............................................ 1137

ច. បទបញ្ជារៀបអាពាហ៍ពិពាហ៍ ............................................ 1147

**៩. បញ្ហាលើកឡើងតាមគំនិតផ្តួចផ្តើមរបស់ខ្លួនពាក់ព័ន្ធទៅនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល** ........................................ 1149

ក. ថាតើ គោលបំណងរួមបានរួមបញ្ចូលអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ដែរ ឬយ៉ាងណា ........................................ 1161

ខ. ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមរបស់ ខៀវ សំផន សម្រាប់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល .................. 1164

**IX. ការប្រកាសទោស**........................................ 1169

**ក. ច្បាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសមេដឹកនាំជាន់ខ្ពស់**........................................ 1172

១. គោលការណ៍នីត្យានុកូលភាព ........................................ 1173

២. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ សមាមាត្រ និងគោលការណ៍ឯកត្តកម្មនៃទោស ... 1178

**ខ. ការបំភ្លឺពាក់ព័ន្ធទៅនឹងការដាក់ទោសកម្រិតទីពីរលើ ខៀវ សំផន** ........................................ 1192

**គ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខសម្រាប់ការដាក់ទោស** .......................... 1199

**ឃ. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងការដាក់ទោស**........................................ 1199

១. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការពិចារណាលើការរំលោភសេពសន្ថវៈក្នុងមន្ទីរសន្តិសុខ ........................................ 1206

២. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការគិតពីរដងនៃការរំលោភតួនាទីនៃសិទ្ធិអំណាច និងឥទ្ធិពល ........................................ 1208

**ង. ផលប៉ះពាល់នៃការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលការដាក់ទោស**................ 1212

**X. ផ្នែកសម្រេចសេចក្តី៖**........................................ 1216

**XI. ឧបសម្ព័ន្ធ I÷ សន្ទានុក្រម និងពាក្យសរសេរកាត់**........................................ 1221

**XII. ឧបសម្ព័ន្ធ II÷ តារាងសំអាងផ្លូវច្បាប់**........................................ 1222

# I. សេចក្តីផ្តើម

1. អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.") ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង ខៀវ សំផន[1] ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ និងបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[2]។

## ក. សាវតារ

2. ព្រឹត្តិការណ៍ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខនេះ កើតឡើងនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") បានពង្រឹង ក្តោបក្តាប់ និងប្រើប្រាស់អំណាចលើរបបកម្ពុជាប្រជាធិបតេយ្យដែលជាឈ្មោះទើបបង្កើតថ្មី (កាលពីមុនត្រូវបានស្គាល់ថាជាសាធារណរដ្ឋកម្ពុជា និងពីមុននេះទៀត ត្រូវបានស្គាល់ថា ជាព្រះរាជាណាចក្រកម្ពុជា) និងប្រជាជនតាមរយៈការរំលាយស្ថាប័នរបស់រដ្ឋដែលមានស្រាប់ និងបានបង្កើតស្ថាប័នស្របនឹងស្ថាប័នរដ្ឋ និងរចនាសម្ព័ន្ធដោយស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខរបស់បក្សកុម្មុយនីស្តកម្ពុជា[3]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប.ក.ក. បានចាប់ផ្តើមប្រតិបត្តិការពង្រឹងគោលនយោបាយដែល*ក្នុងនោះ* មានការលុបបំបាត់កម្មសិទ្ធិឯកជន និងសេដ្ឋកិច្ចប្រើប្រាស់រូបិយប័ណ្ណ[4]។ គម្រោងបង្កើតសហករណ៍ ព្រលានយន្តហោះ ទំនប់ មន្ទីរសន្តិសុខ និងការដ្ឋានធ្វើការ ត្រូវបានបង្កើតឡើងទូទាំងប្រទេស ក្នុងគោលដៅគ្រប់គ្រងប្រជាជន និងបង្កើតការតស៊ូវណ្ណៈ[5]។ ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិលត្រូវបានដកហូតនូវសិទ្ធិសេរីភាពជាសារវន្ត និងត្រូវបានដាក់ឱ្យស្ថិតក្រោមការរីករាលដាលនៃអំពើឃោរឃៅធ្ងន់ធ្ងរ រួមទាំងការ

---

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50 ("បណ្តឹងសាទុក្ខរបស់សហព្រះជាអាជ្ញា (F50)")។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54 ("សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54)")។

[2] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465 ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465)")។

[3] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៦។

[4] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៩។

[5] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៩។

បំផ្លិចបំផ្លាញជីវិតគ្រួសារ និងវប្បធម៌នៃការធ្វើឱ្យភ័យខ្លាចតាមរយៈការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម អំពើហិង្សាលើរូបកាយ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើពលកម្មដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀតដែលស្ថានភាពដ៏អាក្រក់របស់ប្រជាជនទំនងជាបានកើតឡើងដោយសារការមិនយកចិត្តទុកដាក់ទាំងស្រុងពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[6]។ មានអំពើជាច្រើនដែលជាការរើសអើង[7]។ ដោយសារផលវិបាកដែលកើតចេញពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទើបបណ្តាលឱ្យប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានសម្លាប់ ឬស្លាប់ ខណៈពេលរាប់សែននាក់ទៀតបានរត់គេចពីប្រទេសរបស់ខ្លួន[8]។

3. ខៀវ សំផន កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ នៅឃុំចេក ឬរំចេក ស្រុករំដួល ខេត្តស្វាយរៀង[9]។ គាត់បានទទួលការអប់រំក្នុងប្រទេសកម្ពុជា និងប្រទេសបារាំង។ ដំបូង គាត់គឺជាមេធាវី និងក្រោយមកបានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីសកលវិទ្យាល័យក្រុងប៉ារីសក្នុងឆ្នាំ ១៩៥៩[10]។ ខៀវ សំផន បានចូលប្រឡូកឆាកនយោបាយ និងត្រូវបានគេស្គាល់ទូទៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាយូរ[11]។ ក្រោយពីមានការធ្វើទុក្ខបុកម្នេញដោយរាជរដ្ឋាភិបាលសម្តេចនរោត្តមសីហនុយ៉ាងខ្លាំងប្រឆាំងនឹងអ្នកឆ្វេងនិយមក្នុងឆ្នាំ ១៩៦០ ខៀវ សំផន បានគេចខ្លួន និងចូលរួមក្រុមសម្ងាត់[12]។ ក្រោយពេលសម្តេចនរោត្តមសីហនុត្រូវបានទម្លាក់ពីអំណាចក្នុងឆ្នាំ ១៩៧០ ខៀវ សំផន បានចូលរួមរដ្ឋាភិបាលខ្មែរក្រហមដែលគាំទ្រអ្នករាជនិយមក្នុងប្រទេសចិន កន្លែងដែលក្នុងចំណោមតួនាទីដទៃទៀត គាត់បានធ្វើជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ (“GRUNK”) និងរដ្ឋមន្ត្រីក្រសួងការពារជាតិ[13]។ ចាប់តាំងពីដើមឆ្នាំ ១៩៧៦ គាត់មានតួនាទីជាអ្នកតំណាងជាសាធារណៈឱ្យរបបកម្ពុជាប្រជាធិបតេយ្យក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ[14]។ ភារកិច្ចរបស់គាត់ រួមមានការតំណាងឱ្យថ្នាក់ដឹកនាំរដ្ឋ ការទំនាក់ទំនងការទូត និងជាទូទៅ ការលើកស្ទួយមាគ៌ា

---

[6] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៩, ២៩៦។

[7] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៦។

[8] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៦-២៩៧។

[9] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦៤។

[10] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦៤-៥៦៧។

[11] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៨២, ៦២៤ និងផ្នែកសម្រេចសេចក្តី។

[12] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦៩, ៥៧២។

[13] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧៦។

[14] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧៦, ៥៨២, ៥៩១-៥៩២, ៥៩៤, ៥៩៦-៥៩៩, ៦២៤, ៤២៥៧ និងផ្នែកសម្រេចសេចក្តី។

របស់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈការថ្លែងសុន្ទរកថា និងសេចក្តីថ្លែងការណ៍នានា[15]។ គាត់ត្រូវបានគេឃើញថា ជាបុគ្គលមានអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីថ្ងៃដំបូងនៃការបង្កើតខ្មែរក្រហម ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា តួនាទីគាត់បានពង្រីកចូលជ្រៅក្នុងកិច្ចប្រតិបត្តិការស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលនោះ[16]។ មន្ទីរ ៨៧០ គឺជាការិយាល័យធ្វើការរបស់គាត់ និងជាមជ្ឈមណ្ឌលប្រតិបត្តិការសំខាន់របស់រដ្ឋាភិបាល[17]។ គាត់បានធ្វើការ និងរស់នៅដោយជិតស្និទ្ធជាមួយបុគ្គលជាន់ខ្ពស់បំផុតក្នុងបក្សកុម្មុយនីស្តកម្ពុជា និងបានរួចផុតពីការបោសសម្អាតរាល់លើករបស់ថ្នាក់លើ[18]។ គាត់គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់ និងជាអ្នកសមគំនិតជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត[19]។ គាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដ៏មានអំណាច និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលពិភាក្សាលើបញ្ហាសំខាន់ៗ និងធ្វើសេចក្តីសម្រេចចាំបាច់នានាក្នុងកម្រិតនៃការគ្រប់គ្រងខ្ពស់បំផុត[20]។

4. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[21]។ ខៀវ សំផន ក៏ត្រូវបានសម្រេចដាក់ពិរុទ្ធភាពផងដែរពីបទប្រល័យពូជសាសន៍ដោយសារការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម[22] និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវស្តីពីការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កដោយចេតនានូវការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬ

[15] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៧ ដល់ ៥៩៩, ៦២៤ និងផ្នែកសម្រេចសេចក្តី។

[16] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៧, ៦១៩-៦២១, ៦២៤ និងផ្នែកសម្រេចសេចក្តី។

[17] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៨, ៦១៦, ៦១៩។

[18] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៨៩, ៦០៣-៦០៤។

[19] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦-៤៣០៧។

[20] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០០ ដល់ ៦០៤, ៦២៤ និងផ្នែកសម្រេចសេចក្តី។

[21] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៣ ដល់ ៤៣០៦, ៤៣៣១, ៤៣២៦ និងផ្នែកសម្រេចសេចក្តី។

[22] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩៣-៤២៩៤, ៤៣៣០-៤៤០៣ និងផ្នែកសម្រេចសេចក្តី។

ជនស៊ីវិលក្នុងការទទួលការជំនុំជម្រះដោយត្រឹមត្រូវ និងទៀងទាត់ និងការបង្ខាំងខុសច្បាប់លើជនស៊ីវិល[23] ។

5. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចប្រកាសទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត[24]។ ដោយពិចារណាលើការដាក់ទោសអស់មួយជីវិតលើ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលទោសទាំងពីរទៅជាការដាក់ទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិត [25]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងព្យសនកម្មដោយសារបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាព ហើយជាលទ្ធផល អង្គជំនុំជម្រះបានទទួលយកផ្នែកខ្លះនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដោយបានសម្រេចយល់ព្រមលើគម្រោងសាងសង់រូបសំណាករម្លឹកតាមឃុំជាក់លាក់ចំនួន ១៣[26]។

## ខ. ប្រវត្តិនីតិវិធី

6. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន និងសហជនជាប់ចោទ នួន ជា នៅពេលនោះ និងបានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទទាំងពីរពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ ហើយបានសម្រេចដាក់ទោសជនជាប់ចោទទាំងពីរជាប់ពន្ធនាគារអស់មួយជីវិត[27]។ នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានចេញសេចក្តីសង្ខេបនៃការយល់ឃើញដោយបានបញ្ជាក់ថា ផ្នែកយល់ឃើញដែលមានអានុភាពផ្លូវច្បាប់នឹងត្រូវជូនដំណឹងតាមពេលវេលាសមស្រប ហើយសាលក្រមជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញ ត្រូវបានជូនដំណឹងជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩[28]។ បីថ្ងៃក្រោយបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខភ្លាមៗស្នើសុំឱ្យអង្គជំនុំជម្រះតុលា

---

[23] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩១, ៤២៩៥ និងផ្នែកសម្រេចសេចក្តី។

[24] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤០០, ៤៤០២ និងផ្នែកសម្រេចសេចក្តី។

[25] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤០២ និងផ្នែកសម្រេចសេចក្តី។

[26] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤៥៥-៤៤៦៧ និងផ្នែកសម្រេចសេចក្តី។

[27] ប្រតិចារឹកថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 (“ការប្រកាសសេចក្តីសង្ខេបនៃសាលក្រមក្នុងសំណុំរឿង ០០២/០២”) ERN 01589681-01589683 ទំព័រ ៣៨-៤០។

[28] ប្រតិចារឹកថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 (“ការប្រកាសសេចក្តីសង្ខេបនៃសាលក្រមក្នុងសំណុំរឿង ០០២/០២”)។

ការកំពូលមោឃៈសេចក្តីសង្ខេបសាលក្រមនោះ ដោយសារមិនពេញលក្ខណៈតាមទម្រង់ និងស្នើសុំឱ្យប្រកាសសាលក្រមដែលមានសំអាងហេតុពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេញក្រោយមកនោះ ថា គ្មានសុពលភាព[29]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធបណ្តឹងសាទុក្ខភ្លាមៗនេះ[30]។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃៈសេចក្តីសម្រេចនេះដោយបានអះអាងថា សមាសភាពចៅក្រមរបស់តុលាការពុំត្រឹមត្រូវតាមច្បាប់[31]។ គាត់បានលើកឡើងថា ចៅក្រមបម្រុងនៃអង្គជំនុំជម្រះតុលាការកំពូល ចៅក្រម RAPOZA ពុំត្រូវបានចាត់តាំងត្រឹមត្រូវជាចៅក្រមពេញសិទ្ធិនៅពេលចេញសេចក្តីសម្រេចដែលរងការជំទាស់នោះ[32]។ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើសុំនោះ ដោយបានសន្និដ្ឋានថា នៅពេលដែលសេចក្តីសម្រេចដែលរងការជំទាស់នោះត្រូវបានចេញ ចៅក្រម RAPOZA ត្រូវបានចាត់តាំងដោយសុពលភាព និងបានចូលស្បថជាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលរួចហើយ និងដូច្នេះ កាលប្បវត្តិនៃការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានកំណត់ពុំត្រឹមត្រូវទាក់ទងទៅនឹងការចាត់តាំងចៅក្រម[33]។

7. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សំណើសុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរៀងៗខ្លួន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[34]។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតបន្ថែមពេលវេលា និង

---

[29] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1 ("បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1)")។

[30] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ឯកសារលេខ E463/1/3 ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3)")។

[31] សំណើរបស់ ខៀវ សំផន សុំមោឃភាពសេចក្តីសម្រេចលេខ E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗរបស់គាត់ប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ ឯកសារលេខ E463/1/4 ("សំណើរបស់ ខៀវ សំផន សុំមោឃភាព (E463/1/4)")។

[32] សំណើរបស់ ខៀវ សំផន សុំមោឃភាព (E463/1/4)។

[33] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំមោឃៈភាពសេចក្តីលេខ E463/1/3 ពីបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ E463/1/5។

[34] សំណើសុំបន្ទាន់ទីមួយរបស់ នួន ជា សុំបន្ថែមទំព័រ និងពេលវេលាដាក់សេចក្តីសជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ F40/1.1 ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩។ សំណើរបស់មេធាវីការពារក្តី ខៀវ សំ

ទំព័រ[35]។ នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំឱ្យធ្វើការពិចារណាឡើងវិញលើសេចក្ដីសម្រេចនេះ និងបានអះអាងថា អង្គជំនុំជម្រះពុំបានពិចារណាលើសារណារបស់គាត់ទាំងអស់នោះឡើយ[36]។ នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំនេះ ដោយផ្ដល់មូលហេតុថា ការជំទាស់របស់ ខៀវ សំផន ទៅនឹងសេចក្ដីសម្រេចដែលរងការជំទាស់នោះ ពុំបានបង្ហាញនូវកំហុស ឬកាលៈទេសៈដែលអាចធ្វើយុត្តិកម្មលើការពិនិត្យឡើងវិញដើម្បីជៀសវាងភាពមិនយុត្តិធម៌នោះទេ[37]។

8. នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដោយលើកទឡ្ហីករណ៍បណ្ដឹងសាទុក្ខតែមួយគត់[38]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និង/ឬអង្គហេតុដោយសារបានយល់ឃើញថា ជនរងគ្រោះជាបុរសនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានបង្ខិតបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការយល់ព្រមដោយសេរី ពុំមែនជាជនរងគ្រោះនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត[39]។ នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរៀងៗខ្លួនប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះ

---

ផន សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1។

[35] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43។

[36] សំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញនូវសេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៩ ឯកសារលេខ F44។

[37] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ F44/1។

[38] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ E465/2/1 (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E465/2/1)”)។

[39] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E465/2/1) កថាខណ្ឌ ២។

សាលាដំបូង[40]។ នួន ជា បានរៀបរាប់ទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួន ៣៥១[41] ចំណែក ខៀវ សំផន បានលើកកំហុសយ៉ាងតិចចំនួន ១.៨២៤ ដោយចោទថា បានប្រព្រឹត្តឡើងដោយអង្គជំនុំជម្រះសាលាដំបូង[42]។ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[43]។ ដប់ពីរថ្ងៃក្រោយមក នួន ជា បានទទួលមរណភាពនៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតក្រុងភ្នំពេញ[44]។ ពីរថ្ងៃក្រោយមកទៀត សហមេធាវីការពារក្ដី នួន ជា បានស្នើសុំអង្គជំនុំជម្រះឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹង នួន ជា ឬជាជម្រើស អនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខបន្តដោយផ្អែកលើអត្ថប្រយោជន៍យុត្តិធម៌[45]។ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់រាល់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង នួន ជា និងបានប្រកាសថា អង្គជំនុំជម្រះនៅរក្សាការទទួលយកពិនិត្យលើសំណើសុំរបស់មេធាវីការពារក្ដីពាក់ព័ន្ធទៅនឹង*ក្នុងចំណោមនោះ* ផលប៉ះពាល់នៃមរណភាពរបស់ នួន ជា លើសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងការសម្រេចដាក់ពិរុទ្ធភាពជាមូលដ្ឋាន[46]។ ក្នុងសេចក្ដីសម្រេចក្រោយចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩ អង្គជំនុំជម្រះបានបញ្ជាក់ថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង នួន ជា ពុំបានធ្វើឱ្យសាលក្រមទៅជាមោឃៈ និងថា មរណភាពរបស់គាត់បានរារាំងការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខនោះ[47]។

---

[40] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1 (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា (E465/3/1)”)។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1 (“សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (E465/4/1)”)។

[41] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា (E465/3/1) ទំព័រ ៣-៦០។

[42] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (E465/4/1) កថាខណ្ឌ ១៥ ដល់ ៣៥។

[43] សំណើទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រ ដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F47។

[44] សំបុត្រមរណភាពរបស់ នួន ជា ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1.1។ *សូមមើលផងដែរ* សារណារបស់សហព្រះរាជអាជ្ញាស្ដីពីមរណភាពរបស់ នួន ជា ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1។

[45] សំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខនៃមរណភាពរបស់ នួន ជា មុនពេលចេញសាលដីកាលើបណ្ដឹងសាទុក្ខ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2។

[46] សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/3។

[47] សេចក្ដីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខនៃមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកាលើបណ្ដឹងសាទុក្ខ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/4/2។

9. សារណាបណ្ដឹងសាទុក្ខ នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[48] និងនៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សារណាតប[49]។ នៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានដាក់សារណាទាក់ទងទៅនឹងសារណាតបរបស់ ខៀវ សំផន ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[50]។ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ខៀវ សំផន បានជំទាស់ទៅនឹងការដាក់សារណានេះ និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ឱ្យបដិសេធសារណារបស់សហមេធាវីនាំមុខដោយសារសហមេធាវីនាំមុខផ្អែកតាមនីតិវិធី ពុំត្រូវបានអនុញ្ញាតឱ្យដាក់សារណារបស់ខ្លួនជាការឆ្លើយតបទៅនឹងសារណាតបរបស់ ខៀវ សំផន ដែលតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ[51]។ នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ អង្គជំនុំជម្រះបានទទួលយកសំណើសុំរបស់ ខៀវ សំផន ប៉ុន្តែបានយល់ឃើញថា "សហមេធាវី [...] ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ អាចត្រូវបានអញ្ជើញលើកសារណាផ្ទាល់មាត់នៅពេលសវនាការបណ្ដឹងសាទុក្ខ [...]"[52]។

10. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំការទទួលយកភស្តុតាងបន្ថែមរបស់ សាក្សី ឯក ហេន និង ជួន ធី និងកំណត់ហេតុជាខ្សែអាត់ថតសំឡេង[53]។ នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើសុំនេះ[54] និងនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ខៀវ សំ

---

[48] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50)។

[49] សារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1 ("សារណាតបរបស់ ខៀវ សំផន (F50/1)")។

[50] សារណារបស់សហមេធាវីនាំមុខពាក់ព័ន្ធទៅនឹងសារណាតបរបស់ ខៀវ សំផន (F50/1) ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1។

[51] សំណើរបស់ ខៀវ សំផន សុំបដិសេធសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី (F50/1/1) អនុលោមតាមសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1/1។

[52] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបដិសេធសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ F50/1/1/2 កថាខណ្ឌ ១៣។

[53] សំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51។

[54] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម (F51) ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51/1។

ផន បានឆ្លើយតប[55]។ នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតតាមសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម[56]។

11. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់បណ្តឹងជំទាស់ដោយគតិត្តចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលជំនុំជម្រះលើសំណុំរឿង ០០២/០១[57]។ នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខទទួលជោគជ័យក្នុងការស្នើសុំការពន្យារពេលដាក់សារណាតបរៀងៗខ្លួនទៅនឹងសំណើរបស់ ខៀវ សំផន និងជាលទ្ធផលបានដាក់នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩[58]។ នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០ ក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃ អ.វ.ត.ក. (“ក្រុមប្រឹក្សាជំនុំជម្រះពិសេស”) ដែលមានសមាសភាពចៅក្រម ប្រាក់ គីមសាន(ប្រធាន) ចៅក្រម Olivier BEAUVALLET ចៅក្រម ន័យ ថុល ចៅក្រម BAIK Kang Jin ចៅក្រម ហួត វុទ្ធី ចៅក្រម ស៊ិន រិទ្ធ និងចៅក្រម Steven BWANA បានសម្រេចបដិសេធបណ្តឹងរបស់ ខៀវ សំផន ប្តឹងជំទាស់ចៅក្រមទាំងមូលនៃអង្គជំនុំជម្រះតុលាការកំពូល[59]។

12. នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាបារាំង[60]។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាបានដាក់សំណើសុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលមានទឡ្ហីករណ៍បន្ថែមនៅក្នុងអំណះអំណាងដែលបាន

---

[55] ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ F51/2។

[56] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ F51/3 (“សេចក្តីសម្រេចស្តីពីការទទួលយកភស្តុតាងបន្ថែម (F51/3)”)។

[57] បណ្តឹងរបស់ ខៀវ សំផន ប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានជំនុំជម្រះលើសំណុំរឿង ០០២/០១ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F53 (“បណ្តឹងរបស់ ខៀវ សំផន ប្តឹងជំទាស់ចៅក្រម (F53)”)។

[58] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន លើចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F53/4។ សារណាតបរបស់សហមេធាវីនាំមុខទៅនឹងបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន លើចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F53/5។

[59] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន លើចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានជំនុំជម្រះលើសំណុំរឿង ០០២/០១ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០ ឯកសារលេខ ១១ (“សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន (១១)”)។

[60] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54)។

លើកកាលពីមុន[61]។ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០ អង្គជំនុំជម្រះបានទទួលយកសំណើរបស់សហព្រះរាជអាជ្ញា[62]។ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ ការបកប្រែជាភាសាអង់គ្លេសនូវឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានដាក់[63]។ សំណៅបកប្រែជាភាសាខ្មែរ និងអង់គ្លេសនៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានជូនដំណឹងនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០ និង ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០២០[64]។ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាបានដាក់សារណាតបជាភាសាអង់គ្លេស ដែលសំណៅជាភាសាខ្មែរ និងបារាំងបានដាក់តាមក្រោយនៅថ្ងៃទី ២៤ និង ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០[65]។ សហមេធាវីនាំមុខបានដាក់សារណាតបនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ជាភាសាអង់គ្លេស ហើយសំណៅជាភាសាខ្មែរ និងបារាំងបានដាក់នៅថ្ងៃទី ១៦ និង ២៣ ខែ មីនា ឆ្នាំ ២០២១ រៀងៗខ្លួន[66]។

13. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្ដឹងសាទុក្ខដែលត្រូវធ្វើឡើងនៅថ្ងៃទី ១៧ ដល់ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១[67]។ ទោះជាយ៉ាង

---

[61] សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ F55។

[62] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០ ឯកសារលេខ F55/3 ("សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា (F55/3)")។

[63] ឧបសម្ព័ន្ធ ក៖ សេចក្ដីសង្ខេបទឡ្ហីករណ៍សម្រាប់បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ ឯកសារលេខ F54.1.1 ("ឧបសម្ព័ន្ធ ក នៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1)")។

[64] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54)។

[65] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ឯកសារលេខ F54/1 ("សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1)")។

[66] សារណាតបរបស់សហមេធាវីនាំមុខទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F54/2 ("សារណាតបរបស់សហមេធាវីនាំមុខ (F54/2)")។

[67] អនុស្សរណៈអន្តរការិយាល័យ៖ 'សេចក្ដីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុងក្នុង" ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F58។

ណាក្តី សវនាការត្រូវបានផ្អាកបណ្តោះអាសន្នដោយសារការរាតត្បាតជំងឺកូវីដ-១៩[68]។ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ សវនាការត្រូវបានគ្រោងឡើងវិញ និងត្រូវបានធ្វើឡើងថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ២០២១[69]។

14. នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់កាលបរិច្ឆេទប្រកាសសាលដីកាលើបណ្តឹងសាទុក្ខដែលត្រូវធ្វើឡើងនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២២[70]។

## គ. បណ្តឹងសាទុក្ខរបស់ ខៀវ សំផន

15. ខៀវ សំផន បានប្តឹងសាទុក្ខលើផ្នែកជាច្រើននៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដោយបានចោទប្រកាន់កំហុសប្រមាណ ១.៨២៤ ក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[71]។ សារណាសំខាន់របស់គាត់លើបណ្តឹងសាទុក្ខ បានលើកការជំទាស់ផ្នែកនីតិវិធីទៅនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង នូវសេចក្តីសង្ខេបសាលក្រមរបស់ខ្លួន ដោយពុំបានជូនដំណឹងនូវសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៅថ្ងៃតែមួយនោះ និងបានអះអាងថា ចំណាត់ការបែបនេះបានធ្វើឱ្យសាលក្រមទៅជាមោឃៈ និងគ្មានសុពលភាព។ ជាជម្រើស គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដែលតម្រូវឱ្យការដាក់ពិរុទ្ធភាព និងទោសនោះត្រូវបដិសេធចោល[72]។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបានឆ្លើយតបថា បណ្តឹងសាទុក្ខរបស់ ខៀវ សំផន គប្បីត្រូវបដិសេធចោល ហើយការដាក់ពិរុទ្ធភាព និងទោសនោះត្រូវតម្កល់។

## ឃ. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

16. សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខតែមួយគត់។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរួមភេទ ឬការរួមដំណេកដោយបង្ខំក្នុងបរិបទនៃ

---

[68] អនុស្សរណៈអន្តរការិយាល័យ'សេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ១០៨(៣)នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១ ឯកសារលេខ F62។

[69] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ F66 ទំព័រ ៤-៥។

[70] ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលដីកា ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២ ឯកសារលេខ F72។

[71] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (E465/4/1) កថាខណ្ឌ ១៥-៣៥។

[72] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩-៧៩។

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំមែនជាអំពើអមនុស្សធម៌ដទៃទៀតសម្រាប់ហេតុការណ៍ដែលជនរងគ្រោះជាបុរសនោះទេ។ សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការកំណត់លើការរងទុក្ខ ឬព្យសនកម្មផ្នែករូបកាយ ឬផ្លូវចិត្ត ព្រមទាំងសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានអះអាងថា កំហុសទាំងនេះបានធ្វើឱ្យសេចក្ដីសម្រេចនេះមោឃៈ និងបានបណ្ដាលឱ្យមានភាពមិនយុត្តិធម៌[73]។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យបដិសេធការយល់ឃើញនេះ និងថា ការដាក់ពិរុទ្ធភាពសម្រាប់អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែបានកែប្រែដោយរួមបញ្ចូលអំពើហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរស[74]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដំណោះស្រាយដែលបានស្នើសុំគឺស្របតាមវិធាន ១១០(៤) នៃវិធានផ្ទៃក្នុង ពីព្រោះ ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពរួចហើយពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត[75]។

17. ខៀវ សំផន បានឆ្លើយតបថា ជាការដែលពុំអាចធ្វើទៅរួចក្នុងការសន្និដ្ឋានពីបញ្ហាអង្គច្បាប់ និងអង្គហេតុថា ការរងទុក្ខដែលជនរងគ្រោះជាបុរសនៃអំពើហិង្សាផ្លូវភេទក្នុងគ្រួសារបានឆ្លងកាត់នោះ មានភាពធ្ងន់ធ្ងរគ្រប់គ្រាន់អាចស្មើទៅនឹងអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា ជាលទ្ធផល បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា គប្បីបដិសេធចោល។

## II. មូលដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ

### ក. សេចក្ដីផ្ដើម

18. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យធ្វើបណ្ដឹងបណ្ដឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រម ឬសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ផ្អែកលើមូលដ្ឋានពីរៈ "កំហុសអង្គច្បាប់ដែលធ្វើឱ្យសាលក្រមមោឃៈ [...] ឬកំហុសអង្គហេតុដែលបណ្ដាលឱ្យមានភាពមិនយុត្តិធម៌"[76]។ ម្ចាស់បណ្ដឹងសាទុក្ខអាចធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើឡើងក្នុងអំឡុងពេលជំនុំជម្រះ[77]។ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញត្រឹមត្រូវនូវបទ

---

[73] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២។

[74] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣, ៤០។

[75] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៤០។

[76] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(វិធនកម្មលើកទី ៩) ដែលធ្វើឡើងនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[77] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

ដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ដែលអាចអនុវត្តបានចំពោះប្រភេទនីមួយៗនៃកំហុស ហើយពុំមានភាគីណាមួយនៃបណ្តឹងសាទុក្ខបច្ចុប្បន្ន បានស្នើសុំឱ្យអង្គជំនុំជម្រះអនុវត្តប្រាសចាកពីបទដ្ឋាននេះឡើយ។

19. ម្ចាស់បណ្តឹងសាទុក្ខត្រូវកំណត់អត្តសញ្ញាណកំហុសដែលបានចោទប្រកាន់ ត្រូវលើកអំណះអំណាង និងប្រភពគាំទ្រទទ្បីករណ៍នីមួយៗ បន្ទាប់មកត្រូវបង្ហាញនូវមូលហេតុដូចម្តេចបានជាកំហុសអង្គច្បាប់ ឬអង្គហេតុនីមួយៗនេះ ធ្វើឱ្យសាលក្រមទៅជាមោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌[78]។ បណ្តឹងសាទុក្ខត្រូវកំណត់អត្តសញ្ញាណនៃការយល់ឃើញ ឬការសម្រេចដែលរងការចោទប្រកាន់នោះដោយមានការយោងជាក់លាក់ទៅលើលេខទំព័រ និងកថាខណ្ឌនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[79]។ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចវាយតម្លៃលើបណ្តឹងសាទុក្ខបាន ម្ចាស់បណ្តឹងសាទុក្ខត្រូវបានរំពឹងឱ្យបង្ហាញនូវទទ្បីករណ៍នៃបណ្តឹងសាទុក្ខឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងសមស្រប[80]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំត្រូវបានរំពឹងឱ្យពិចារណាស៊ីជម្រៅលើសារណានោះទេ ប្រសិនបើមានលក្ខណៈមិនច្បាស់លាស់ ផ្ទុយគ្នា ស្រពេចស្រពិល ឬមិនពេញលេញ[81]។

20. ម្ចាស់បណ្តឹងសាទុក្ខមិនអាចលើកអំណះអំណាងនៅពេលជំនុំជម្រះមកតវ៉ា*សាជាថ្មី* ឬតវ៉ាថា សេចក្តីសម្រេច ឬការយល់ឃើញណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសឡើយ លើកលែងតែម្ចាស់បណ្តឹងសាទុក្ខអាចបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើអំណះអំណាងដែលបានលើកឡើងចំពោះមុខនោះ គឺជាកំហុសដែលតម្រូវចាំបាច់ឱ្យមានការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល[82]។

---

[78] វិធាន ១០៥(២)(៣) នៃវិធានផ្ទៃក្នុង។

[79] វិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង។

[80] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 ("សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ (F49)") កថាខណ្ឌ ១៥ និង ១៧។

[81] សាលដីកាសំណុំរឿង ០០២/០១ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ("សាលដីកាសំណុំរឿង ០០២/០១ (F36)") កថាខណ្ឌ ១០១។ សាលដីកាសំណុំរឿង ០០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 ("សាលដីកាសំណុំរឿង ០០១ (F28)") កថាខណ្ឌ ២០ ដកស្រង់សាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Stakić* អង្គជំនុំជម្រះឧទ្ធរណ៍ (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY")) សំណុំរឿងលេខ IT-97-24-A សាលដីកា ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ("សាលដីការឿងក្តី *Stakić* (ICTY)") កថាខណ្ឌ ១២។

[82] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១ ដល់ ១០២។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០ ដកស្រង់រឿងក្តី *Stakić* (ICTY) កថាខណ្ឌ ១២។

បន្ថែមលើនេះ អំណះអំណាងដែលពុំអាចធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់នោះត្រូវបដិសេធចោល ឬកែប្រែ អាចត្រូវបដិសេធចោលភ្លាមៗដោយអង្គជំនុំជម្រះតុលាការកំពូលដោយពុំចាំបាច់ពិចារណាលើអង្គសេចក្តីឡើយ[83]។

21. ក្នុងការសម្រេចលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលអាចតម្កល់ មោឃៈ ឬកែប្រែសេចក្តីសម្រេចទាំងមូល ឬផ្នែកខ្លះ[84]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចូលជាស្ថាពរ និងពុំអាចបង្វិលត្រឡប់ទៅអង្គជំនុំជម្រះសាលាដំបូងឡើយ[85]។

22. ខៀវ សំផន ក្នុងរឿងក្តីបច្ចុប្បន្នបានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម និងសេចក្តីសម្រេចបន្ទាន់បង្ខំរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើកំហុសអង្គច្បាប់ និងអង្គហេតុ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវអនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញស្របតាមប្រភេទនៃកំហុសនីមួយៗតាមលំដាប់លំដោយ។

## ខ. ការចោទប្រកាន់កំហុសអង្គច្បាប់

23. នៅពេលម្ចាស់បណ្តឹងសាទុក្ខលើកកំហុសអង្គច្បាប់ អង្គជំនុំជម្រះតុលាការកំពូលដែលជា“តុលាការចុងក្រោយនៃអង្គច្បាប់ដែលអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. តាមគោលការណ៍ ត្រូវបានចងកាតព្វកិច្ចក្នុងការកំណត់លើបញ្ហា ថាតើកំហុសអង្គច្បាប់ ជាក់ស្តែងត្រូវបានប្រព្រឹត្តឡើងលើផ្នែកនីតិវិធី ឬអង្គសេចក្តី ដែរ ឬយ៉ាងណា”[86]។ ដើម្បីពិនិត្យឡើងវិញលើការយល់ឃើញផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលត្រូវអនុវត្តបទដ្ឋាន“ដើម្បីកំណត់មិនត្រឹមតែ ថាតើការយល់ឃើញផ្នែកអង្គច្បាប់សមហេតុផលប៉ុណ្ណោះទេ ថែមទាំងថាតើត្រឹមត្រូវ ដែរ ឬយ៉ាងណា”[87]។ បើទោះបីជាអំណះអំណាងរបស់

---

[83] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១ ដល់ ១០២។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។

[84] វិធាន ១០៤(២) នៃវិធានផ្ទៃក្នុង។

[85] វិធាន ១០៤(៣) នៃវិធានផ្ទៃក្នុង។

[86] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៥។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៤ ដកស្រង់សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-97-25-A សាលដីកាចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ (“សាលដីការឿងក្តី *Krnojelac*(ICTY)”) កថាខណ្ឌ ១០។

[87] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៥។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៤ ដកស្រង់សាលដីការឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ១០។

ភាគីពុំបានលើកគ្រប់ជ្រុងជ្រោយក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាលើហេតុផលដទៃទៀតក្នុងការយល់ឃើញថា កំហុសអង្គច្បាប់បានកើតឡើង[88]។

24. បញ្ហាថាតើ កំហុសត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលកើតឡើងដោយសារការអនុវត្តន៍បទដ្ឋានផ្លូវច្បាប់ពុំត្រឹមត្រូវ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់នូវបទដ្ឋានផ្លូវច្បាប់កែតម្រូវ និងពិនិត្យឡើងវិញលើការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូង[89]។ ក្នុងការអនុវត្តន៍បទដ្ឋានកែតម្រូវនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវផ្អែកលើសេចក្តីសម្រេចពីមុនៗរបស់ខ្លួនដែលកំណត់ថា អង្គជំនុំជម្រះ៖

> […] មិនត្រឹមតែកែតម្រូវលើកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ថែមទាំងអនុវត្តបទដ្ឋានផ្នែកអង្គច្បាប់កែតម្រូវចំពោះភស្តុតាងដែលមាននៅក្នុងកំណត់ត្រានៃការជំនុំជម្រះ ក្នុងករណីចាំបាច់ និងត្រូវកំណត់ថា តើអង្គជំនុំជម្រះជឿជាក់លើបទដ្ឋានពាក់ព័ន្ធស្តីពីការបង្ហាញភស្តុតាង ដែរ ឬយ៉ាងណា ចំពោះការយល់ឃើញផ្នែកអង្គហេតុដែលជំទាស់ដោយភាគី នៅមុនពេលដែលការយល់ឃើញនេះត្រូវបានតម្កល់នៅដំណាក់កាលបណ្តឹងសាទុក្ខ[90]។

25. បទដ្ឋាននៃការពិនិត្យឡើងវិញមានកម្រិតខ្ពស់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែលកំហុសផ្នែកអង្គច្បាប់នោះ បានធ្វើឱ្យសាលក្រម ឬសេចក្តីសម្រេចទៅជាមោឃៈប៉ុណ្ណោះ[91]។ អាស្រ័យហេតុនេះ ពុំមែនរាល់កំហុសអង្គច្បាប់ដែលត្រូវបានកំណត់អត្តសញ្ញាណនោះសុទ្ធតែនាំទៅរកការបដិសេធ ឬការកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ សាលក្រមមួយត្រូវបានចាត់ទុកជាមោឃៈបានដោយសារមានកំហុសអង្គច្បាប់ នៅពេលណាបង្ហាញថា ក្នុងករណីគ្មានកំហុស សាលក្រមមួយផ្សេងទាំងស្រុង ឬផ្នែកខ្លះអាចត្រូវបានធ្វើឡើង[92]។ ក្នុងកា

---

[88] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៥។

[89] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៦។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៦។

[90] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៦។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៦ ដកស្រង់សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-60-A សាលដីកាចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៧ ("សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* (ICTY)") កថាខណ្ឌ ៨។

[91] *សូមមើល* វិធាន ១០៤(១)(ក) និង ១០៥(២)(ក) នៃវិធានផ្ទៃក្នុង។

[92] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៩ ដកស្រង់សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Popović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-88-A សាលដីកាចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ("សាលដីការឿងក្តី *Popović និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ១៧ និងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គ

លៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចលើកបញ្ហានេះ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[93] ឬស្តាប់បណ្តឹងសាទុក្ខនៅពេលម្ចាស់បណ្តឹងសាទុក្ខបានលើកបញ្ហាអង្គច្បាប់ដែលពុំបាននាំទៅរកការមោឃៈសាលក្រម ប៉ុន្តែមានសារៈសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក.[94]។

## គ. ការចោទប្រកាន់កំហុសអង្គហេតុ

26. ដូចមានចែងក្នុងវិធាន ១០៤ នៃវិធានផ្ទៃក្នុង មានតែកំហុសអង្គហេតុទាំងនោះប៉ុណ្ណោះដែលបង្ហាញថាមានភាពមិនយុត្តិធម៌ ដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលកែប្រែសាលក្រមអង្គជំនុំជម្រះសាលាដំបូងទាំងមូល ឬផ្នែកខ្លះ[95]។ ការបង្កឱ្យមានភាពមិនយុត្តិធម៌ត្រូវបានកំណត់និយមន័យថា“ជាលទ្ធផលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ”[96]។ ក្នុងការបង្កឱ្យមានភាពមិនយុត្តិធម៌ កំហុសអង្គហេតុត្រូវតែ“មានលក្ខណៈចាំបាច់បំផុតចំពោះការធ្វើសេចក្តីសម្រេច”[97]។ ជាលទ្ធផល បណ្តឹងសាទុក្ខប្រ

---

ជំនុំជម្រះឧទ្ធរណ៍ (តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”)) សំណុំរឿងលេខ ICC-01/04-01/06 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អយ្យការ និងជនជាប់ចោទ Thomas Lubanga Dyilo ប្រឆាំងនឹង“សេចក្តីសម្រេចស្តីពីការដាក់ទោសស្របតាមមាត្រា ៧៦ នៃលក្ខន្តិកៈ” ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ (“សាលដីកាវឿងក្តី *Lubanga* ប្រឆាំងនឹងសេចក្តីសម្រេចដាក់ទោស (ICC)”) កថាខណ្ឌ ១៩។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៦។

[93] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៥ ដកស្រង់សាលដីកាវឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ៦។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៨ (“ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា”) មាត្រា ៤០៥ ដល់ ៤០៦ និង ៤៤០ ដល់ ៤៤១។

[94] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១៣៨-១១៤២។ សាលដីកាវឿងក្តី ០០១ (F28) កថាខណ្ឌ ១៥ ដកស្រង់សាលដីកាវឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Galić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-29-A សាលដីកាចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ (“សាលដីកាវឿងក្តី *Galić* (ICTY)”) កថាខណ្ឌ ៦។

[95] *សូមមើល* វិធាន ១០៤(១)(ខ) និង ១០៥(២)(គ) នៃវិធានផ្ទៃក្នុង។

[96] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៩ ដកស្រង់សាលដីកាវឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Furundžija* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-17/1-A សាលដីកាចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ (“សាលដីកាវឿងក្តី *Furundžija* (ICTY)”) កថាខណ្ឌ ៣៧ យោងទៅលើវចនានុក្រមផ្នែកច្បាប់ Black“s Law បោះពុម្ពលើកទី ៧ ឆ្នាំ ១៩៩៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៩។

[97] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៩ ដកស្រង់សាលដីកាវឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kupreškić និងជនជាប់ចោទដទៃទៀត* (ICTY) សំណុំរឿងលេខ សាលដីកាចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១ (“សាលដីកាវឿងក្តី *Kupreškić* (ICTY)”) កថាខណ្ឌ ២៩។

ឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពមួយត្រូវតែបង្ហាញថា "កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបង្កើតឱ្យមានវិមតិសង្ស័យចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ"[98]។

27. អង្គជំនុំជម្រះតុលាការកំពូលអនុវត្តបទដ្ឋានខ្ពស់ ក្នុងការពិនិត្យឡើងវិញលើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ បទដ្ឋាននេះពិនិត្យលើបញ្ហា ថាតើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការយល់ឃើញមួយដែលពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើបាន ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល"នឹងពុំធ្វើការរំខានងាយៗដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង"[99] និងយល់ស្របជាមួយនឹងវិធីសាស្ត្រទូទៅដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (តុលាការ ICTY) ក្នុងការផ្តល់អាទិភាពក្នុងកម្រិតមួយដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង និងបានយល់ឃើញថា៖

> អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ កាតព្វកិច្ចសវនាការ ការវាយតម្លៃ និងការថ្លឹងថ្លែងភស្តុតាងដែលដាក់នៅពេលជំនុំជម្រះ ត្រូវផ្តល់ជាចម្បងទៅឱ្យអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ អង្គជំនុំជម្រះឧទ្ធរណ៍ ត្រូវផ្តល់អាទិភាពក្នុងកម្រិតមួយចំពោះការយល់ឃើញផ្នែកអង្គហេតុដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។ មានតែក្នុងករណីភស្តុតាងដែលបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង ពុំអាចទទួលយកបានដោយតុលាការអង្គហេតុសមហេតុផលណាមួយ ឬក្នុងករណីដែលការវាយតម្លៃនៃភស្តុតាងនោះ "មានកំហុសទាំងស្រុង" ទើបអង្គជំនុំជម្រះឧទ្ធរណ៍អាចដាក់ការយល់ឃើញផ្ទាល់ខ្លួនជំនួសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបាន។
>
> [...]
>
> មូលហេតុដែលអង្គជំនុំជម្រះឧទ្ធរណ៍មិនត្រូវធ្វើការរំខានងាយដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានទទួលស្គាល់ជាទូទៅ។ អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈអំណោយផលក្នុងការសង្កេតសាក្សីដោយផ្ទាល់ និងស្ថិតក្នុងតួនាទីប្រសើរជាងអង្គជំនុំជម្រះឧទ្ធរណ៍ក្នុងការវាយតម្លៃលើភាពអាចទទួលយកបាន និងភាពអាចជឿជាក់បាននៃភស្តុតាង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានតួនាទីចម្បងក្នុងការកំណត់ថា តើសាក្សីនោះគួរឱ្យជឿជាក់បាន ដែរ ឬយ៉ាងណា និងសម្រេចថា សក្ខីកម្មរបស់សាក្សីមួយណា

[98] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩១។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៉។

[99] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧ ដកស្រង់សាលដីការឿងក្តី *Furundžija* (ICTY) កថាខណ្ឌ ៣៧។

ដែលខ្លួនពេញចិត្តជាង ដោយពុំចាំបាច់បញ្ជាក់ពីការសំអាងតាមជំហានទីមួយៗដើម្បីឈានដល់ការសម្រេចលើចំណុចទាំងនោះឡើយ។ ទោះជាយ៉ាងណាក្តី ឆន្ទានុសិទ្ធិនេះ ត្រូវបានកម្រិតដោយករណីយកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ទទួលខុសត្រូវផ្តល់សំអាងហេតុពេញលេញ [...][100]។

អំណះអំណាងដែលលើកត្រឹមការមិនយល់ស្របជាមួយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ហើយសារណាដែលផ្អែកលើការបកស្រាយមួយបែបផ្សេងលើភស្តុតាងតែមួយ និងគ្មានផ្តល់មូលដ្ឋានគាំទ្រ ពុំមានលក្ខណៈគ្រប់គ្រាន់អាចបដិសេធការយល់ឃើញផ្នែកអង្គហេតុរបស់តុលាការអង្គហេតុបានឡើយ[101]។

28. កម្រិតនៃការផ្តល់អាទិភាពចំពោះការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង "ត្រូវបានកម្រិតដោយករណីយកិច្ចទទួលខុសត្រូវក្នុងការផ្តល់សំអាងហេតុពេញលេញ"[102]។ ជាលទ្ធផល ក្នុងការកំណត់លើបញ្ហា ថាតើការអន្តរាគមន៍ត្រូវបានតម្រូវឱ្យពិនិត្យឡើងវិញលើការយល់ឃើញដែលរងការជំទាស់នោះ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិនិត្យដោយប្រុងប្រយ័ត្នលើសំអាងហេតុដែលបានផ្តល់ក្នុងការគាំទ្រការយល់ឃើញផ្នែកសំអាងហេតុ និងអនុវត្តតាមវិធានទូទៅដែលចែងថា "ក្នុងករណីដែលភស្តុតាងជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានផ្នែកអង្គហេតុទំនងជានៅខ្សោយ តម្រូវឱ្យផ្តល់សំអាងហេតុច្រើនជាងការដែលភស្តុតាងនោះមានមូលដ្ឋានសមស្រប"[103]។

## ឃ. ការជំទាស់ទៅនឹងសេចក្តីសម្រេចភ្លាមៗ

29. នៅក្នុងបណ្តឹងសាទុក្ខបច្ចុប្បន្ន ខៀវ សំផន បានជំទាស់ទៅលើសេចក្តីសម្រេចមួយចំនួនដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនៃការជំនុំជម្រះ។

30. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង បានកំណត់លទ្ធភាពពីរដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់យុត្តាធិការបណ្តឹងសាទុក្ខភ្លាមៗ។ ទីមួយ ម្ចាស់បណ្តឹងសាទុក្ខអាចធ្វើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានថា សេចក្តីសម្រេចនោះ ស្ថិតក្នុង

---

[100] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧ ដកស្រង់សាលដីការឿងក្តី *Kupreškić និងជនជាប់ចោទដទៃទៀត* កថាខណ្ឌ ៣០ និង ៣២។

[101] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០ ដកស្រង់រឿងក្តីមួយចំនួនរបស់តុលាការ ICTY និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR")។

[102] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧ ដកស្រង់សាលដីការឿងក្តី *Kupreškić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៣២។

[103] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០ ដកស្រង់រឿងក្តីមួយចំនួនរបស់តុលាការ ICTY និង ICTR។

ចំណោមសេចក្ដីសម្រេចទាំងបួនប្រភេទនោះដែលបានកំណត់ក្នុងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង[104]។ ដើម្បីឱ្យបណ្ដឹងសាទុក្ខភ្លាមៗអាចទទួលយកបានតាមទម្រង់ ទឡ្ហីករណ៍នីមួយៗនៃបណ្ដឹងសាទុក្ខត្រូវបញ្ជាក់ច្បាស់លាស់៖

ក) កំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ ឬ

ខ) ផ្អែកលើមូលដ្ឋាននៃការភ័ន្ដច្រឡំ ដែលស្ដែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិម្ចាស់បណ្ដឹងសាទុក្ខ ឬ

គ) កំហុសអង្គហេតុ ដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ មានភាពមិនយុត្តិធម៌[105]។

31. ទីពីរម្ចាស់បណ្ដឹងសាទុក្ខអាចជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលពុំស្ថិតក្នុងចំណោមសេចក្ដីសម្រេចទាំងនោះ ប៉ុន្ដែនេះត្រឹមតែអាចធ្វើឡើង“ដំណាលគ្នាជាមួយបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដីតែប៉ុណ្ណោះ”[106]។ ដើម្បីឱ្យបណ្ដឹងសាទុក្ខនេះអាចទទួលយកបានត្រឹមត្រូវតាមទម្រង់ ម្ចាស់បណ្ដឹងសាទុក្ខត្រូវបង្ហាញផងដែរនូវ*ការប៉ះពាល់យូរអង្វែង*មកលើសាមីខ្លួន ដើម្បីបង្ហាញនូវទំនាក់ទំនងរវាងសេចក្ដីសម្រេចបន្ទាន់បង្ខំដែលរងការជំទាស់ ជាមួយនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលនៅតែជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខចុងក្រោយ[107]។ ដូចគ្នាទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗ ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខលើសាលក្រមអាចលើកកំហុសអង្គច្បាប់ អង្គហេតុ និង/ឬកំហុសដែលស្ដែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ការចោទប្រកាន់កំហុសអង្គច្បាប់ និងអង្គហេតុត្រូវបង្ហាញនូវមូលហេតុដូចម្ដេចដែលនាំធ្វើឱ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬបណ្ដាលឱ្យមាន

---

[104] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង៖ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងខាងក្រោមបើកផ្លូវឱ្យប្ដឹងសាទុក្ខភ្លាមៗ៖

ក) សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។

ខ) សេចក្ដីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន ៨២។

គ) សេចក្ដីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤) (គ) និង

ឃ) សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)។

[105] *សូមមើល*វិធាន ១០៥(២) នៃវិធានផ្ទៃក្នុង។

[106] *សូមមើល*វិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង។

[107] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១៣៤។ សេចក្ដីសម្រេចក្នុងសំណុំរឿង ០០២/០១ លើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាតប និងសារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ១៦។

ភាពមិនយុត្តិធម៌[108]។ ការចោទប្រកាន់កំហុសថាបានប្រព្រឹត្តឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលប្រើប្រាស់ឆន្ទានុសិទ្ធិ ត្រូវបង្ហាញពីផលប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខ និងថា ផលប៉ះពាល់នេះមានអត្ថិភាពដោយផ្អែកលើកិច្ចដំណើរការនីតិវិធីទាំងមូល ដែលនេះបណ្តាលឱ្យមានភាពមិនយុត្តិធម៌។ ក្នុងការកំណត់បញ្ហា ថាតើកំហុសឆន្ទានុសិទ្ធិនេះបណ្តាលឱ្យមានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង ដែរ ឬយ៉ាងណាអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើរាល់ដំណាក់នីមួយៗនៃកិច្ចដំណើរការនីតិវិធី ព្រមទាំងវិធានការនានានៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខផងដែរ[109]។

## ង. បញ្ហាដែលមានសារៈសំខាន់ទូទៅ

32. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង បានគូសបង្ហាញយុត្តាធិការបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលលើសាលក្រម ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលមាន"កំហុសអង្គច្បាប់ដែលធ្វើឱ្យសាលក្រមមោឃៈ ឬកំហុសអង្គហេតុដែលបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌" បានកើតឡើង[110]។ បើទោះបីជាសិទ្ធិអំណាចនៃបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល ត្រូវបានប្រើប្រាស់ក្នុងកម្រិតតែលើបញ្ហាដែលត្រូវបានប្តឹងសាទុក្ខក៏ដោយ ក៏អង្គជំនុំជម្រះដូចគ្នានឹងអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានកំណត់ថា ក្នុងករណីពិសេស អង្គជំនុំជម្រះឧទ្ធរណ៍អាចដោះស្រាយបញ្ហាដែលមានសារៈសំខាន់ទូទៅដើម្បីជាយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[111] ក្នុងករណីដែលបញ្ហានេះពុំត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ដោយភាគីណាមួយ ហើយសាលក្រមពុំទទួលរងផលប៉ះពាល់ឡើយ។

33. ដោយពិចារណាឃើញថា សាលក្រមពុំទទួលរងនូវផលប៉ះពាល់ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថានេះជាការចាំបាច់ក្នុងការដោះស្រាយបញ្ហាដែលមានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដែលកើតចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលនេះពុំត្រូវបានលើកឡើងដោយភាគីណាមួយនៅក្នុងបណ្តឹងសាទុក្ខឡើយ[112]។

---

[108] វិធាន ១០៤(១) និងវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[109] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០០។

[110] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[111] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សាលដីការឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ៦។

[112] *សូមមើលខាងក្រោមផ្នែក* VIII.ខ.៩ (បញ្ហា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*ពាក់ព័ន្ធទៅនឹងការអនុវត្តន៍សហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយ *ចេតនាប្រយោល*)។

## ច. បទដ្ឋានសម្រាប់ការបដិសេធចោលភ្លាមៗដោយពុំចាំបាច់ពិនិត្យបន្ថែម

34. អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY មានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើ សារណាណាខ្លះរបស់ភាគីស័ក្តិសមទទួលបានសំអាងហេតុសមស្របជាលាយលក្ខណ៍អក្សរ ហើយអង្គជំនុំជម្រះអាចបដិសេធអំណះអំណាងណាដែលគ្មានការលើកមូលដ្ឋានគ្រប់គ្រាន់ ដោយពុំចាំបាច់ផ្ដល់សំអាងហេតុលម្អិតជាលាយលក្ខណ៍អក្សរឡើយ[113]។ ក្នុងការបង្ហាញនូវកំហុសដែលអាចប្ដឹងឧទ្ធរណ៍បាន ភាគីត្រូវកំណត់គ្រប់គ្រាន់នូវកំហុសដែលបានចោទប្រកាន់នេះ លើកអំណះអំណាងដែលមានមូលដ្ឋានគ្រប់គ្រាន់ និងសំអាងផ្លូវច្បាប់ជាក់លាក់ដើម្បីគាំទ្រទឡ្ហីករណ៍នីមួយនោះ[114]។ លក្ខខណ្ឌតម្រូវនេះគឺក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាពផ្នែកនីតិវិធី និងថា ភាគីដែលពាក់ព័ន្ធអាចយល់ដឹងច្បាស់លាស់នូវចំណុចដែលត្រូវឆ្លើយតប[115]។ ពាក់ព័ន្ធបញ្ហានេះ ផ្អែកតាមវិធានទូទៅ ភាគីត្រូវបានរំពឹងថា នឹងលើកមូលដ្ឋានគាំទ្រគ្រប់គ្រាន់នូវទឡ្ហីករណ៍នៃបណ្ដឹងឧទ្ធរណ៍ក្នុងលក្ខណៈបង្រួញសេចក្ដីច្បាស់លាស់ និងសមស្របបំពេញតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋាននេះ[116]។ ភាគីពុំគ្រាន់តែលើកច្រំដែលនូវអំណះអំណាងនៃបណ្ដឹងឧទ្ធរណ៍ដែលពុំទទួលបានជោគជ័យនៅពេលជំនុំជម្រះឡើយ លើកលែងតែភាគីអាចបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើអំណះអំណាងនោះគឺជាកំហុសដែលចាំចាច់ត្រូវមានការអន្តរាគមន៍នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍[117]។

---

[113] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Strugar* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-42-A សាលដីកា ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("សាលដីការឿងក្ដី *Strugar* (ICTY)") កថាខណ្ឌ ១៦។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Orić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-03-68-A សាលដីកា ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ ("សាលដីការឿងក្ដី *Orić* (ICTY)") កថាខណ្ឌ ១៣។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Halilović* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-48-A សាលដីកា ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៧ ("សាលដីការឿងក្ដី *Halilović* (ICTY)") កថាខណ្ឌ ១២។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Brđanin* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-99-36-A សាលដីកា ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ ("សាលដីការឿងក្ដី *Brđanin* (ICTY)") កថាខណ្ឌ ១៦។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-2001-64-A សាលដីកា ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ ("សាលដីការឿងក្ដី *Gacumbitsi* (ICTR)") កថាខណ្ឌ ១០។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kamuhanda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-54A-A សាលដីកា ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ("សាលដីការឿងក្ដី *Kamuhanda* (ICTR)") កថាខណ្ឌ ១០។

[114] វិធាន ១០៥(២) (៣) នៃវិធានផ្ទៃក្នុង។

[115] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៤១។

[116] *សូមមើល* សេចក្ដីសម្រេចស្ដីពីសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ (F49) កថាខណ្ឌ ១៥, ១៧។

[117] សាលដីការឿងក្ដី *Strugar* (ICTY) កថាខណ្ឌ ១៦។ សាលដីការឿងក្ដី *Halilović* (ICTY) កថាខណ្ឌ ១២។ សាលដីការឿងក្ដី *Brđanin* (ICTY) កថាខណ្ឌ ១៦។ សាលដីការឿងក្ដី *Gacumbitsi* (ICTR) កថាខណ្ឌ ៩។

35. អង្គជំនុំជម្រះតុលាការកំពូលអាចបដិសេធបន្ថែមទៀតនូវសារណាដែល "មិនច្បាស់លាស់ មានលក្ខណៈផ្ទុយគ្នា ស្រពេចស្រពិល ឬពុំមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញឱ្យឃើញជាផ្លូវ" និងដែលអាចត្រូវបានប្រកាសថា មានកំហុសផ្នែកនីតិវិធីស្របតាមវិធាន ១១១(២) នៃវិធានផ្ទៃក្នុង[118]។ ផ្អែកលើគោលការណ៍មូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ប្រភេទនៃសារណាដែលពុំត្រឹមត្រូវនៃបណ្តឹងសាទុក្ខដែលតម្រូវឱ្យបដិសេធចោលដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តី។

36. បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ប្រភេទនៃកំហុសដែលបានចោទប្រកាន់ខាងក្រោមក៏ដោយ ក៏អង្គជំនុំជម្រះបដិសេធកំហុសនោះភ្លាមៗដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តីនៅក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះដោយសារ៖ (១) ការលើកច្រំដែលនៃអំណះអំណាងដែលពុំទទួលបានជោគជ័យពេលជំនុំជម្រះ (២) អំណះអំណាងដែលពុំបានបង្ហាញនូវការយល់ឃើញដែលរងការជំទាស់នោះ និងបំភ្លៃការយល់ឃើញទាំងនោះ ឬពុំអើពើលើការយល់ឃើញពាក់ព័ន្ធដទៃទៀត (៣) ការអះអាងដែលគ្មានភស្តុតាងគាំទ្រ ការអះអាងដែលពុំមានការលើកបញ្ជាក់ពេញលេញ ឬការខកខានក្នុងការបង្ហាញកំហុស និង (៤) ការជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុដែលការដាក់ពិរុទ្ធភាពពុំបានផ្អែកទៅលើ ឬការយល់ឃើញផ្នែកអង្គច្បាប់ដែលពុំអាចមោឃៈសាលក្រមបាន។

## ឆ. សេចក្តីសន្និដ្ឋាន

37. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលហេតុណាមួយក្នុងការប្រាសចាកពីបទដ្ឋានដែលបានលើកឡើងខាងលើ ហើយភាគីពុំបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើដូច្នេះដែរ។ នៅក្នុងសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានយោងទៅលើយុត្តិសាស្ត្រថ្មីៗរបស់ អ.វ.ត.ក.[119] និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC")[120] ក្នុងការពន្យល់នូវការបកស្រាយរបស់ខ្លួនលើបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើប

---

[118] វិធាន ១១១(២) នៃវិធានផ្ទៃក្នុងចែងថា ("ក្នុងករណីដែលអង្គជំនុំជម្រះយល់ឃើញថា បណ្តឹងសាទុក្ខដាក់យឺតពេល ឬមានកំហុសផ្នែកនីតិវិធី អង្គជំនុំជម្រះអាចប្រកាសបណ្តឹងសាទុក្ខនោះពុំអាចទទួលយកបានទម្រង់")។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០ និង ៤១។ សាលដីការឿងក្តី *Galic* (ICTY) កថាខណ្ឌ ១១។

[119] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ៣៣-៣៤, ៣៦-៣៨, ៤០-៤១ និង ៤៤។

[120] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ៣៤-៣៥, ៣៩ និង ៤១-៤៤ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/05-01/08 A សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ Jean-Pierre Bemba Gombo ប្រឆាំងនឹង"សាលក្រមអង្គជំនុំជម្រះសាលាដំបូង III ស្របតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨។

ណ្តឹងសាទុក្ខ។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ពុំបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកែប្រែបទដ្ឋាននៃការពិនិត្យឡើងវិញនេះ និងពុំបានលើកអំណះអំណាងណាមួយគាំទ្រការប្រាសចាកពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដែលបានបង្កើតឡើងនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងបន្តធ្វើការវាយតម្លៃលើកំហុសដែលបានលើកឡើង ដោយអនុវត្តតាមបទដ្ឋានដែលបានបញ្ជាក់លម្អិតខាងលើ។

## III. បញ្ហាបឋម

### ក. រចនាសម្ព័ន្ធនៃសារណាបណ្តឹងសាទុក្ខ

38. សារណាបណ្តឹងសាទុក្ខចំនួន ៧៥០ ទំព័ររបស់ ខៀវ សំផន បានចោទប្រកាន់កំហុស ១.៨២៤ ក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានប្រព្រឹត្តមកលើរូបគាត់។ គាត់ត្រឹមតែពន្យល់ធម្មតាអំពីរចនាសម្ព័ន្ធនៃសារណាបណ្តឹងសាទុក្ខរបស់គាត់ថា "ពុំមានពេលវេលាគ្រប់គ្រាន់"។ គួរកត់សម្គាល់សារណាបណ្តឹងសាទុក្ខរបស់គាត់ពុំបានរចនាឡើងក្នុងលក្ខណៈដូចគ្នាទៅនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខឡើយ[121]។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីរបស់គាត់បានជ្រើសរើសលើកបណ្តឹងសាទុក្ខយកតាម"ទម្រង់នៃសំអាងហេតុសាលក្រម" ខណ្ឌពេលទទួលស្គាល់ថា "កំហុសជាច្រើនដែលត្រូវបានរកឃើញក្នុងផ្នែកផ្សេងៗនៃសំអាងហេតុសាលក្រម ត្រួតគ្នា"[122]។ វិធីសាស្ត្រនេះជាពិសេសនៅពេលធ្វើបណ្តឹងសាទុក្ខជំទាស់យ៉ាងទូលំទូលាយទៅនឹងសាលក្រមក្នុងទំហំដ៏ធំបែបនេះ បានបណ្តាលឱ្យមានការត្រួតគ្នា ភាពច្រំដែល និងពុំស៊ីសង្វាក់គ្នា ក្នុងសារណាបណ្តឹងសាទុក្ខនោះ។

39. ដូចបានលម្អិតក្នុងសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូលជាញឹកញាប់បានព្យាយាមកំណត់ខ្លឹមសារនៃអំណះអំណាងរបស់ ខៀវ សំផន ដែលជូនកាលលើកបង្ហាញជាផ្នែកៗ និង/ឬពុំមានមូលដ្ឋានគាំទ្រ ដែលធ្វើឱ្យមានការលំបាកក្នុងការបកស្រាយអត្ថន័យនៃអំណះអំណាងនេះ ដោយពុំទាន់គិតអំពីបញ្ហាគតិយុត្តដែលមេធាវីការពារក្តីចង់បង្ហាញនៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលបានរចនាឡើង និងកំណត់ច្បាស់លាស់នៅចំពោះមុខតុលាការ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើការដាក់បញ្ចូលជាញឹកញាប់របស់ ខៀវ សំផន នូវសារណាពីមុនៗរបស់គាត់នៅក្នុងសារណាបណ្តឹងសាទុក្ខ ០០២/០១ និងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយ

---

[121] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧។

[122] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧។

នឹង ខៀវ សំផន ថា នេះអាចជាវិធីសាស្ត្រមានអត្ថប្រយោជន៍ក្នុងការជៀសវាងការលើកច្រំដែលក៏ដោយ[123] ក៏ពុំបានបណ្តាលឱ្យអំណះអំណាងនោះត្រូវបានទទួលយកជាស្វ័យប្រវត្តិដែរ នៅពេលពុំមានការបង្ហាញអំណះអំណាងថ្មី និងគ្មានមូលដ្ឋានត្រឹមត្រូវអំពីកំហុសដែលអាចប្តឹងសាទុក្ខបាននោះ[124]។ បើទោះបីជាទាំងនេះជាក្តីបារម្ភក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានខិតខំអស់ពីលទ្ធភាពក្នុងសិទ្ធិអំណាចដែលខ្លួនមានក្នុងការកំណត់ និងឆ្លើយតបទៅនឹងអំណះអំណាងក្នុងលក្ខណៈដែលបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ និងសិទ្ធិរបស់ ខៀវ សំផន ធ្វើបណ្តឹងសាទុក្ខ។ នៅពេលប្រឈមនឹងអំណះអំណាងដែលត្រួតគ្នា អង្គជំនុំជម្រះតុលាការកំពូលបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនឆ្លើយតបទៅនឹងអំណះអំណាងនោះក្នុងផ្នែកនៃសាលដីកានេះ ដែលអង្គជំនុំជម្រះចាត់ទុកថាសមស្របបំផុត ដោយពិចារណាលើកម្មវត្ថុនៃរឿងក្តីដែលពាក់ព័ន្ធ និងរចនាសម្ព័ន្ធនៃសាលដីកានេះ។

40. ខៀវ សំផន បានភ្ជាប់ឧបសម្ព័ន្ធ ៧៥ ទំព័រទៅនឹងសារណាបណ្តឹងសាទុក្ខរបស់គាត់[125] ដើម្បីជួយតម្រង់ទិសអង្គជំនុំជម្រះតុលាការកំពូល និងភាគីតាមរយៈការយោងទៅលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[126]។ ឧបសម្ព័ន្ធនោះមានទម្រង់នៃសារណាបណ្តឹងសាទុក្ខដែលមានចំណងជើង ព្រមទាំងប្រអប់សេចក្តី"សង្ខេប" ដែលនីមួយៗឆ្លើយតបទៅនឹងផ្នែកនៃសារណាបណ្តឹងសាទុក្ខ។ ខ្លឹមសារនៃឧបសម្ព័ន្ធនោះព្យាយាមកំណត់និងបញ្ជាក់អំពីទឡ្ហីករណ៍បណ្តឹងសាទុក្ខ ផ្នែកនៃសាលក្រមអង្គជំនុំជម្រះដែលរងបណ្តឹងសាទុក្ខ កំហុសដែលចោទប្រកាន់ និងការរំលោភបំពានលើសិទ្ធិ និងផលប៉ះពាល់លើសាលក្រម។ អង្គជំនុំជម្រះតុលាការកំពូលបានពិភាក្សា និងសំអាងទៅលើឧបសម្ព័ន្ធនេះដែលចាំបាច់ក្នុងការកំណត់អំពីកំហុសដែលបានចោទប្រកាននោះ ដូចបានបង្ហាញក្នុងសាលដីកានេះ។

41. ដើម្បីសម្រួលតាមវិធីសាស្ត្រនៃការឆ្លើយតបទៅនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សហព្រះរាជអាជ្ញាបានសម្រេចដាក់លេខរៀងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលរៀបរាប់ក្នុងឧបសម្ព័ន្ធនោះចាប់ពីទឡ្ហីករណ៍ទី ១ ដល់ ២៥៦ និងបានផ្តល់ការឆ្លើយតបជាក់លាក់ទៅនឹងទឡ្ហីករណ៍នីមួយៗនោះ[127]។ បញ្ជីលេខ

[123] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២១។

[124] *សូមមើលខាងលើ* ផ្នែក **II.ច**។

[125] ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1)។

[126] សារណាតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ F55/1 កថាខណ្ឌ ៤-៥។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រ (F55/3) កថាខណ្ឌ ២០។

[127] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦។

រឿងទទ្បីករណ៍បណ្តឹងសាទុក្ខនេះមាននៅក្នុងឧបសម្ព័ន្ធ គ នៃសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន[128]។ ក្នុងការដោះស្រាយទទ្បីករណ៍នៃបណ្តឹងសាទុក្ខដែលត្រួតគ្នា សារណាតបរបស់សហព្រះរាជអាជ្ញាបានដាក់ជាក្រុមនូវទទ្បីករណ៍ដែលមានខ្លឹមសារច្រំដែលក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។ សារណាតបនេះឆ្លុះបញ្ចាំងទាំងស្រុងនូវជំពូកក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ វិសាលភាពនៃការជំនុំជម្រះ ឧក្រិដ្ឋកម្ម ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល និងការដាក់ទោស។

42. សារណាតបរបស់សហមេធាវីនាំមុខ ពុំបានប្រើប្រាស់វិធីសាស្ត្រដូចសហព្រះរាជអាជ្ញាទេក្នុងការឆ្លើយតបទៅនឹងទទ្បីករណ៍នៃបណ្តឹងសាទុក្ខនីមួយៗនោះ ផ្ទុយទៅវិញបានធ្វើការឆ្លើយតបខ្លីៗនៅនឹងបញ្ហាដែលពាក់ព័ន្ធទៅនឹងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាការជំទាស់ទៅនឹងភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គោលការណ៍នីត្យានុកូលភាព ការយល់ឃើញគន្លឹះផ្នែកអង្គហេតុ ដែលជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម និងផលប៉ះពាល់លើដើមបណ្តឹងរដ្ឋប្បវេណី និងការចោទប្រកាន់អំពីភាពលម្អៀង។ សហមេធាវីនាំមុខបានពន្យល់ថា ដើម្បីឱ្យស៊ីសង្វាក់គ្នា សហមេធាវីនាំមុខបានអនុម័តតាមការប្រើប្រាស់របស់សហព្រះរាជអាជ្ញានូវពាក្យ“ទទ្បីករណ៍”ដែលមានដាក់លេខរៀងក្នុងឧសម្ព័ន្ធ **គ** របស់សហព្រះរាជអាជ្ញា[129]។ សហមេធាវីបានគូសបង្ហាញនូវនត្ថិភាពនៃទំនាក់ទំនងរវាងសារណាបណ្តឹងសាទុក្ខ ជាមួយនឹងឧបសម្ព័ន្ធ **ក** និងបានអះអាងថា បានធ្វើឱ្យមានការភាន់ច្រឡំរវាងកថាខណ្ឌក្នុងសារណាបណ្តឹងសាទុក្ខ និង“ទទ្បីករណ៍”ណាខ្លះដែលបានរួមបញ្ចូលគ្នានៅក្នុងឧបសម្ព័ន្ធ **ក**[130]។ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់នេះ សហមេធាវីនាំមុខបានភ្ជាប់ឧបសម្ព័ន្ធមួយទៅនឹងសារណាតបរបស់ខ្លួន ដែលមានតារាងបញ្ជីបង្ហាញអំពីកថាខណ្ឌណាខ្លះនៅក្នុងសារណាបណ្តឹងសាទុក្ខនោះដែលពួកគេជឿជាក់ថា ត្រូវបានគ្របដណ្តប់ដោយ“ទទ្បីករណ៍”ជាក់លាក់នោះ ដូចគ្នាទៅនឹងការដាក់លេខរៀងក្នុងឧបសម្ព័ន្ធ **គ** របស់សហព្រះរាជអាជ្ញា ព្រមទាំងការកំណត់សម្គាល់សម្រាប់ចំណុចក្នុងសារណាបណ្តឹងសាទុក្ខ ដែលទំនងជាពុំត្រូវបានគ្របដណ្តប់ដោយ“ទទ្បីករណ៍”ណាមួយនោះ[131]។

[128] ឧបសម្ព័ន្ធ គ ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា (F54/1)។

[129] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៣។

[130] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៣។

[131] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៣។

43. សហមេធាវីនាំមុខបានដាក់ជាក្រុម និងដោះស្រាយអំណះអំណាងនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលទំនងជាផ្អែកលើមូលដ្ឋានរួមដើម្បីសម្រួលដល់ការឆ្លើយតបរបស់ពួកគេទៅនឹងទឡ្ហីករណ៍ដែលត្រួតគ្នាជាច្រើននៃបណ្តឹងសាទុក្ខ[132]។ ផ្នែកដាច់ដោយឡែកត្រូវបានកំណត់ទុកសម្រាប់ការឆ្លើយតបទៅនឹងអំណះអំណាងជាក់លាក់របស់ ខៀវ សំផន ដែលជំទាស់ទៅនឹងភស្តុតាង និងភាពគួរឱ្យជឿជាក់បាននៃដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងផ្នែកដាច់ដោយឡែកនេះ បានដោះស្រាយបញ្ហាផ្សេងៗដែលពុំស្ថិតក្នុងវិសាលភាពនៃប្រធានបទដែលបានគ្របដណ្តប់ក្នុងសារណាតបរបស់ខ្លួន[133]។

44. ចុងក្រោយ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខដែលលើកទឡ្ហីករណ៍តែមួយដែលជំទាស់ទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំមែនជាបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងករណីដែលមានជនរងគ្រោះជាបុរស។ ផ្អែកតាមលក្ខណៈនៃបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយក្នុងផ្នែកនៃសាលដីកានេះពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[134]។

## ខ. តម្លៃនៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក.

45. ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ពាសពេញសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានព្យាយាមជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកទៅលើសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[135]។ នៅពេល ខៀវ សំផន បានព្យាយាមច្រានចោលការយល់ឃើញទាំងនេះ គាត់បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រាសចាកពីយុត្តិសាស្ត្ររបស់ខ្លួន។ នេះបានបង្កើតជាបញ្ហានៃយុត្តិសាស្ត្រនៅ អ.វ.ត.ក.។

46. សហព្រះរាជអាជ្ញាបានអះអាងថា សារណារបស់ ខៀវ សំផន គប្បីបដិសេធចោលពីព្រោះគាត់ពុំបានលើកអំណះអំណាងណាមួយដែលបង្ហាញអំពីការប្រែប្រួលនៅក្នុងយុត្តិសាស្ត្រដែលរងការជំទាស់នោះ ឬផ្តល់

---

[132] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១១។

[133] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១១។

[134] *សូមមើលខាងក្រោម* ផ្នែក VII.ឆ.៣.គ.iii។

[135] *សូមមើល ឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥០, ២៩៨-២៩៩, ៣២០-៣២២, ៥៥០-៥៥១។

មូលដ្ឋានណាមួយសម្រាប់ការពិចារណាឡើងវិញ ឬការបដិសេធនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ[136]។

47. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងប្រព័ន្ធច្បាប់ស៊ីវិលដូចនៅកម្ពុជា ឬ អ.វ.ត.ក. គោលការណ៍ច្បាប់នៃការតម្កល់ការសម្រេចរួចហើយ *stare decisis* ឬយុត្តិសាស្ត្រដែលចងកាតព្វកិច្ច ពុំអាចអនុវត្តជាផ្លូវការបានឡើយ[137]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអនុវត្តន៍តាមយុត្តិសាស្ត្របានបង្កឱ្យមានការអនុវត្តន៍ស្របគ្នានៃច្បាប់ លើកកម្ពស់សច្ចភាពផ្នែកច្បាប់ និងធានាបាននូវសិទ្ធិរបស់ជនជាប់ចោទស្មើភាពគ្នាចំពោះមុខច្បាប់ ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[138]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលជាដរាបបានសំអាង និងយោងទៅលើការយល់ឃើញពីមុនៗរបស់ខ្លួនស្តីពីនីតិរដ្ឋ និងគោលការណ៍ច្បាប់[139]។ យុត្តិសាស្ត្រអន្តរជាតិបានបង្ហាញនូវការអនុវត្តន៍ជាទូទៅប្រហាក់ប្រហែលគ្នានេះនូវយុត្តិសាស្ត្រក្នុងការស្វែងរកការបំភ្លឺនៃច្បាប់ និងភាពស្របគ្នា[140]។ ជាឧទាហរណ៍ សាលដីកាក្នុងរឿងក្តី *Aleksovski* នៃតុលាការ ICTY បានទទួលស្គាល់ថា៖

---

[136] *សូមមើល ឧ.* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤៦, ២២១, ២២៦, ២៣៨។

[137] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ D308/3 ("ដីកាដំណោះស្រាយសំណុំរឿង ០០៤/០១ (D308/3)") កថាខណ្ឌ ១០។ សេចក្តីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត សុំការបំភ្លឺពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងទំនាក់ទំនងជម្លោះប្រដាប់អាវុធ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ D87/2/1.7/1 កថាខណ្ឌ ១៣, ១៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-16-T សាលក្រម ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ("សាលក្រមរឿងក្តី *Kupreškić និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ៥៤០ ("និយាយជាទូទៅ និងផ្អែកតាមអានុភាពចងកាតព្វកិច្ចនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌ ទៅលើអង្គជំនុំជម្រះសាលាដំបូង តុលាការព្រហ្មទណ្ឌអន្តរជាតិពុំអាចអនុវត្តតាមគោលការណ៍នៃយុត្តិសាស្ត្រដែលចងកាតព្វកិច្ច(តម្កល់ការសម្រេចរួចហើយ) ដែលត្រូវអនុវត្តតាមក្នុងប្រទេសប្រើប្រាស់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង [...] ពិតណាស់ យុត្តិសាស្ត្ររបស់តុលាការពុំមែនជាប្រភពផ្សេងនៃច្បាប់ក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ")។

[138] វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង។

[139] *សូមមើល ឧ.* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៧, ៦៦៩, ៦៧៩-៦៨០, ៦៩០, ៧៤៤, ៧៦១-៧៦២, ១១០៧-១១០៨។

[140] *សូមមើល ឧ.* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Aleksovski* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14/1-A សាលដីកាចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០ ("សាលដីកា*រឿងក្តី Aleksovski* (ICTY)") កថាខណ្ឌ ៩៣-៩៥ ("ជាទូទៅ បើទោះបីជាយុត្តិសាស្ត្រប្រព័ន្ធច្បាប់ស៊ីវិលពុំបានទទួលស្គាល់គោលការណ៍នៃការតម្កល់ការសម្រេចរួចហើយ ឬយុត្តិសាស្ត្រដែលចងកាតព្វកិច្ចក៏ដោយ ក៏តាមការអនុវត្តន៍ តុលាការជាន់ខ្ពស់បំផុតជាទូទៅអនុវត្តតាមសេចក្តីសម្រេចពីមុនរបស់ខ្លួន។ [...] បើទោះបីជា

គោលការណ៍ដែលជាមូលដ្ឋាននៃនិន្នាការទូទៅនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងអង់គ្លូសាក់សុង ដែលតុលាការជាន់ខ្ពស់បំផុត បើទោះបីជាបញ្ហានៃគោលការណ៍ ឬការអនុវត្តក៏ដោយ ក៏តាមធម្មតាត្រូវអនុម័តតាមសេចក្តីសម្រេចពីមុនៗ និងអាចប្រាសចាកតែក្នុងករណីពិសេសប៉ុណ្ណោះ *គឺជាតម្រូវការចាំបាច់សម្រាប់ភាពស៊ីសង្វាក់គ្នា សច្ចភាព និងភាពអាចកំណត់ជាមុនបាន*[141]។

គោលការណ៍យុត្តិសាស្ត្រពុំបានប្រតិបត្តិជាផ្លូវការក្នុងតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សក៏ដោយ ក៏'តាមការអនុវត្តន៍ទូទៅ និងភាពចាំបាច់ជាក់ស្តែង គណៈកម្មការបានចាត់ទុកសាលក្រមតុលាការដែលចងកាតព្វកិច្ចថា មានអនុភាពផ្លូវច្បាប់ស្ពាពរលើការបកស្រាយនៃអនុសញ្ញា"។ [...] បើទោះបីជាអត្ថិភាពនៃភាពគ្មានអានុភាពនៃគោលការណ៍តម្កល់ការសម្រេចរួចហើយពាក់ព័ន្ធទៅនឹងតុលាការយុត្តិធម៌អន្តរជាតិក៏ដោយ ក៏សេចក្តីសម្រេចពីមុនៗរបស់តុលាការនេះត្រូវបានផ្តល់តម្លៃយ៉ាងសំខាន់ផងដែរ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Gbagbo និង Blé Goudé* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-02/11-01/15 សំអាងហេតុសម្រាប់"សេចក្តីសម្រេចលើសំណើសុំទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះដែលត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងរឿងក្តី ដើម្បីចូលរួមដោយស្វ័យប្រវត្តិក្នុងបណ្តឹងឧទ្ធរណ៍ភ្លាមៗដែលបានកើតឡើងក្នុងរឿងក្តីនោះ និងជាជម្រើស សំណើសុំចូលរួមក្នុងបណ្តឹងឧទ្ធរណ៍នោះប្រឆាំងនឹងសេចក្តីសម្រេចទីប្រាំបួនស្តីពីការឃុំខ្លួនជនជាប់ចោទ Gbagbo (សំណុំរឿងលេខ ICC-02/11-01/15-134-Red3)" ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន *Gbagbo និង Blé Goudé* (ICC)") កថាខណ្ឌ ១៤ ("មាត្រា ២១ (២) នៃលក្ខន្តិកៈចែងថា 'តុលាការអាចអនុវត្តគោលការណ៍ និងនីតិរដ្ឋដូចបានបកស្រាយក្នុងសេចក្តីសម្រេចពីមុនៗរបស់ខ្លួន"។ ដូច្នេះ អង្គជំនុំជម្រះឧទ្ធរណ៍ ពុំតម្រូវឱ្យអនុវត្តតាមការបកស្រាយពីមុនៗរបស់ខ្លួននូវគោលការណ៍ និងនីតិរដ្ឋតាមរយៈគោលការណ៍តម្កល់ការសម្រេចរួចហើយដែលចងកាតព្វកិច្ចនោះ ផ្ទុយទៅវិញតុលាការត្រូវបានផ្តល់នូវឆន្ទានុសិទ្ធិថាតើត្រូវធ្វើដូច្នោះដែរ ឬយ៉ាងណា។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះឧទ្ធរណ៍បានបញ្ជាក់ពីដំបូងថា ដោយសារនត្ថិភាពនៃ"សំអាងហេតុគួរជឿជាក់បាន" តុលាការពុំអាចប្រាសចាកពីយុត្តិសាស្ត្រពីមុនៗរបស់ខ្លួនឡើយ។ ដូច្នេះ ជាគោលការណ៍ បើទោះបីជាអង្គជំនុំជម្រះឧទ្ធរណ៍មានឆន្ទានុសិទ្ធិក្នុងការប្រាសចាកពីយុត្តិសាស្ត្រពីមុនៗរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះនៅពុំទាន់រួចរាល់ធ្វើដូច្នេះបាន ដោយសារតម្រូវការចាំបាច់ធានាបាននូវភាពប្រាកដប្រជានៃច្បាប់ និងភាពត្រឹមត្រូវនៃការជំនុំជម្រះក្នុងការលើកកម្ពស់ការជឿទុកចិត្តរបស់សធារណជនលើសេចក្តីសម្រេចរបស់ខ្លួន")។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Semanza* អង្គជំនុំជម្រះឧទ្ធរណ៍ (យន្តការគេរដំណែលសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("IRIRMCT")) សំណុំរឿងលេខ IRMCT-13-36-R សេចក្តីសម្រេចលើសំណើសុំចូលមើល និងពិនិត្យឯកសារ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៨ ("សេចក្តីសម្រេចនៃរឿងក្តី *Semanza* ស្តីពីសំណើសុំពិនិត្យឯកសារ (IRIRMCT)") កថាខណ្ឌ ១៥ ("ចុងក្រោយ អង្គជំនុំជម្រះឧទ្ធរណ៍ពិចារណាឃើញថា អង្គជំនុំជម្រះតម្រូវឱ្យបកស្រាយលក្ខន្តិកៈ និងវិធានផ្ទៃក្នុងស្របតាមយុត្តិសាស្ត្ររបស់តុលាការ ICTR និង តុលាការ ICTY។ ជាលទ្ធផល បើទោះបីជាពុំត្រូវបានចងកាតព្វកិច្ចដោយយុត្តិសាស្ត្ររបស់តុលាការ ICTR ឬ តុលាការ ICTY អង្គជំនុំជម្រះឧទ្ធរណ៍ត្រូវបានបំភ្លឺដោយគោលការណ៍ដែលថា ដើម្បីអត្ថប្រយោជន៍នៃសច្ចភាពផ្នែកច្បាប់ និងភាពប្រាកដប្រជា អង្គជំនុំជម្រះគប្បីអនុវត្តតាមសេចក្តីសម្រេចពីមុនៗនៃអង្គជំនុំជម្រះឧទ្ធរណ៍តុលាការ ICTR ឬ តុលាការ ICTY និងអាចប្រាសចាកបានសម្រាប់ហេតុផលសមស្របដើម្បីអត្ថប្រយោជន៍យុត្តិធម៌")។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Semanza* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-97-23-A សេចក្តីសម្រេចចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ៩២។

[141] សាលដីការឿងក្តី *Aleksovski* (ICTY) កថាខណ្ឌ ៩៧ (សេចក្តីបញ្ជាក់បន្ថែម)។

ទោះជាយ៉ាងណាក្ដី យុត្តិសាស្ត្រដដែលនេះបានបង្ហាញថា ការអនុវត្តន៍យ៉ាងតឹងរ៉ឹងនូវយុត្តិសាស្ត្រ ពុំត្រូវបានធានា និងថា អង្គជំនុំជម្រះឧទ្ធរណ៍គប្បីអាចប្រាសចាកពីការសម្រេចពីមុនៗរបស់ខ្លួនលើបញ្ហាអង្គច្បាប់សម្រាប់ហេតុផលសមស្របដើម្បីអត្ថប្រយោជន៍យុត្តិធម៌[142]។ ហេតុផលនោះអាចកើតមាន ជាឧទាហរណ៍ កាលណាបើសេចក្ដីសម្រេចពីមុនៗបានផ្អែកលើការបកស្រាយពុំត្រឹមត្រូវនៃគោលការណ៍ច្បាប់ ឬចៅក្រមទទួលបានព័ត៌មានពុំច្បាស់លាស់អំពីច្បាប់ជាធរមាន[143]។

48. អង្គជំនុំជម្រះតុការកំពូលយល់ស្រប និងសន្និដ្ឋានថា ការអនុវត្តតាមយុត្តិសាស្ត្រគឺដើម្បីអត្ថប្រយោជន៍នៃសច្ចភាពផ្នែកច្បាប់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលអាចប្រាសចាកពីការយល់ឃើញពីមុនៗរបស់ខ្លួនស្ដីពីនីតិរដ្ឋ និងគោលការណ៍គតិយុត្ត បន្ទាប់ពីការពិនិត្យដោយប្រុងប្រយ័ត្នលើច្បាប់ និងសម្រាប់ហេតុផលសមស្របដើម្បីអត្ថប្រយោជន៍យុត្តិធម៌។ ការប្រាសចាកពីយុត្តិសាស្ត្រដែលត្រូវបានដោះស្រាយត្រឹមត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល ពុំមានភាពចាំបាច់ ដោយសារ ខៀវ សំផន ត្រឹមតែលើកច្រំដែល

---

[142] *សូមមើល ឧ.* សាលដីការឿងក្ដី *Aleksovski* (ICTY) កថាខណ្ឌ ១០៧-១១១ (“អង្គជំនុំជម្រះឧទ្ធរណ៍គប្បីអនុវត្តតាមសេចក្ដីសម្រេចពីមុនៗរបស់ខ្លួន ប៉ុន្តែគប្បីមានសេរីភាពក្នុងការប្រាសចាកពីសេចក្ដីសម្រេចនេះសម្រាប់ហេតុផលសមស្របដើម្បីអត្ថប្រយោជន៍យុត្តិធម៌។ [...] ជាការចាំបាច់ក្នុងការបញ្ជាក់ថា វិធានធម្មតា គឺថា សេចក្ដីសម្រេចពីមុនៗត្រូវតែអនុវត្តតាម ហើយការប្រាសចាកនោះគឺជាករណីលើកលែង។ អង្គជំនុំជម្រះឧទ្ធរណ៍អាចប្រាសចាកពីសេចក្ដីសម្រេចពីមុនៗបានបន្ទាប់ពីមានការពិចារណាដោយប្រុងប្រយ័ត្នបំផុតត្រូវបានធ្វើឡើង ទាំងលើផ្នែកអង្គច្បាប់ និងអង្គហេតុរួមទាំងសំអាងផ្លូវច្បាប់ដែលបានដកស្រង់នោះ ”)។ សេចក្ដីសម្រេចនៃរឿងក្ដី *Semanza* ស្ដីពីសំណើសុំពិនិត្យឡើងវិញ (IRMCT) កថាខណ្ឌ ១៥។ ការអនុវត្តន៍អនុសញ្ញាស្ដីពីការរារាំង និងដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (រឿងក្ដី ប្រទេសក្រូអាត ទល់នឹង ប្រទេសស៊ែប៊ៀ) អញ្ញត្រកម្មសាលក្រម របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ២០០៨ ទំព័រ ៤១២ កថាខណ្ឌ ៥៣ (“ដរាបណាសេចក្ដីសម្រេចនោះមានការយល់ឃើញអំពីច្បាប់ តុលាការត្រូវចាត់ទុកដូចជាបានអនុវត្តតាមសេចក្ដីសម្រេចពីមុនៈ មានន័យថា បើទោះបីជាសេចក្ដីសម្រេចទាំងនោះពុំចងកាតព្វកិច្ចលើតុលាការក៏ដោយ ក៏តុលាការពុំអាចប្រាសចាកពីយុត្តិសាស្ត្រដែលត្រូវបានដោះស្រាយរបស់ខ្លួនឡើយលើកលែងតែមានហេតុផលជាក់លាក់ត្រូវធ្វើដូច្នោះ”)។ សេចក្ដីសម្រេចស្ដីពីការឃុំខ្លួន *Gbagbo និង Blé Goudé* (ICC)”) កថាខណ្ឌ ១៤។ រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Šainović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87-A សាលដីកាចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ (“សាលដីការឿងក្ដី *Šainović និងជនជាប់ចោទដទៃទៀត* (ICTY)”) កថាខណ្ឌ ១៦២២ ជើងទំព័រ ៥៣១៩ យោងទៅលើសាលដីការឿងក្ដី *Aleksovski* (ICTY) កថាខណ្ឌ ១១១។

[143] *សូមមើល ឧ.* សាលដីការឿងក្ដី *Aleksovski* (ICTY) កថាខណ្ឌ ១០១-១០២, ១០៧-១០៩ (“ឧទាហរណ៍ស្ថានការណ៍ដែលហេតុផលសមស្របដោយសារអត្ថប្រយោជន៍យុត្តិធម៌តម្រូវឱ្យប្រាសចាកពីសេចក្ដីសម្រេចពីមុន រួមបញ្ចូលរឿងក្ដីដែលសេចក្ដីសម្រេចពីមុនត្រូវបានសម្រេចដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ច្បាប់ដែលពុំត្រឹមត្រូវ ឬរឿងក្ដី ដែលសេចក្ដីសម្រេចពីមុនពុំត្រូវបានពិចារណាត្រឹមត្រូវលើអង្គច្បាប់ ដែលនេះគឺជាសេចក្ដីសម្រេចរបស់តុលាការដែលត្រូវបាន‘សម្រេចពុំត្រឹមត្រូវ តាមធម្មតាដោយសារចៅក្រមពុំទទួលបានព័ត៌មានច្បាស់លាស់អំពីច្បាប់ជាធរមាន”)។

នូវអំណះអំណាងដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យរួចរាល់ ឬត្រឹមតែអះអាងថា ការសម្រេចពីមុនរបស់អង្គជំនុំជម្រះមានកំហុស ដោយពុំបានបញ្ជាក់លម្អិត ឬយោងទៅលើការវិវឌ្ឍន៍ថ្មីនៃច្បាប់ឡើយ។

## IV. ការចោទប្រកាន់កំហុសក្នុងការចេញ និងការប្រកាសសាលក្រម

49. ខៀវ សំផន បានចាប់ផ្ដើមដំបូងគេនៃបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងតាមរយៈការដាក់សារណាបឋមដែលសំដៅទៅលើសារណាសំខាន់របស់គាត់ ដែលក្នុងនោះគាត់បានជំទាស់ទៅនឹងការចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូងជាពីរដំណាក់កាល។ សារៈសំខាន់នៃសារណានេះមានដូចតទៅ៖

> “ដោយសារការខកខានចេញសំអាងហេតុនៃសាលក្រមនៅថ្ងៃដែលប្រកាសសាលក្រម អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែលនាំឱ្យសាលក្រមដែលត្រូវបានប្រកាសពុំត្រឹមត្រូវតាមច្បាប់នោះ ទៅជាមោឃៈដោយសារការមិនគោរពតាមវិធានបញ្ញត្តិ។ ការចេញសំអាងហេតុតាមក្រោយ ពុំអាចលុបលាងកំហុសនេះបានឡើយ”[144]។

គាត់បានលើកឡើងថា ក្របខ័ណ្ឌនីតិវិធីនៅ អ.វ.ត.ក. បានហាមឃាត់វិធីសាស្ត្រក្នុងការចេញជាពីរដំណាក់កាល និងបានកំណត់ថា សំអាងហេតុនៃសាលក្រមត្រូវចេញនៅថ្ងៃតែមួយជាមួយនឹងការប្រកាសសាលក្រម និងលើកឡើងបន្ថែមថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តតាមលក្ខខណ្ឌគតិយុត្តបានបណ្ដាលឱ្យមានកំហុសអង្គច្បាប់ដែលនាំឱ្យសាលក្រមនោះទៅជាមោឃៈ[145]។

50. ខៀវ សំផន បានអះអាងបន្ថែមថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងលែងមានសិទ្ធិអំណាចតទៅទៀតនៅពេលសាលក្រមមានសំអាងពេញលេញត្រូវបានចេញ និងថា សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញសាលក្រមមានសំអាងហេតុពេញលេញនោះ គឺជាការប្រព្រឹត្តតាមអំពើចិត្ត និងហួសពីសិទ្ធិអំណាចរបស់ខ្លួន[146]។ គាត់បានអះអាងថា ប្រសិនបើសារណានេះទទួលបានជោគជ័យ ដូចនេះ ផ្នែកដទៃទៀតនៃបណ្ដឹងសាទុក្ខរបស់គាត់លែងមានភាពចាំបាច់ត្រូវពិចារណាបន្ថែមទៀត ដោយសារទោស ឬនិរទោសរបស់គាត់ពុំត្រូវបានជំនុំជម្រះត្រឹមត្រូវតាមច្បាប់ឡើយ[147]។

---

[144] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០។

[145] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩, ៣២។

[146] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២, ៦៧។

[147] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩។

51. ប្រវត្តិនីតិវិធីនៃសារណានេះ បានបង្ហាញនូវចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលដែលអង្គជំនុំជម្រះបានចេញសាលក្រមសង្ខេបនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ហើយសាលក្រមមានសំអាងហេតុពេញលេញបានចេញតាមក្រោយនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩។ តាមការលើកឡើងត្រឹមត្រូវរបស់ ខៀវ សំផន ដែលថា សំអាងហេតុជាអ្នកកំណត់សាលក្រម និងដើរតួនាទីសំខាន់ក្នុងការប្រើប្រាស់សិទ្ធិធ្វើបណ្តឹងសាទុក្ខរបស់គាត់ក្នុងការស្វែងរកដំណោះស្រាយចំពោះពិរុទ្ធភាពរបស់គាត់ និងការប្រកាសទោសនោះ[148]។ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាកំណត់កាលបរិច្ឆេទស្តីពីការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨ និងបានជូនដំណឹងដល់ភាគី និងសាធារណជនអំពីគោលបំណងក្នុងការចេញសាលក្រមជាពីរដំណាក់កាលថា៖[149]

> "យោងតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងប្រកាសសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន និងផ្នែកសម្រេចសេចក្តីនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ [...] ខៀវ សំផន នៅថ្ងៃទី សុក្រ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ក្នុងបន្ទប់សវនាការធំនៃ អ.វ.ត.ក. នៅម៉ោង ៩ និង ៣០ នាទីព្រឹក៖
>
> ជូនដំណឹងភាគីថា សំអាងហេតុពេញលេញនៃសាលក្រម នឹងជូនដំណឹងតាមពេលវេលាសមស្រប"។

ជាលទ្ធផល ភាគីទាំងអស់ត្រូវបានជូនដំណឹងថា សាលក្រមមានសំអាងហេតុពេញលេញពុំត្រូវបានចេញនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នោះទេ។ បើទោះបីជារយៈជិតប្រាំបីសប្តាហ៍ចាប់តាំងពីពេលជូនដំណឹងអំពីគោលបំណងនោះ និងការចេញសេចក្តីសង្ខេបនៃសាលក្រមក៏ដោយ ក៏ពុំមានសំណើណាមួយត្រូវបានធ្វើឡើងជំទាស់ទៅនឹងចំណាត់ការដែលបានស្នើឡើងបែបនោះដែរ។ ជាពិសេស ខៀវ សំផន ពុំបានលើកបង្ហាញថា ចំណាត់ការនោះនឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ណាមួយឡើយ។

52. ដូចបានកំណត់ក្នុងដីកាកំណត់កាលបរិច្ឆេទនោះ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ សេចក្តីសង្ខេបនៃសាលក្រមដែលមានចំនួន ៣១ ទំព័រ ត្រូវបានអាននៅក្នុងសវនាការសាធារណៈ។ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

---

[148] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧១។

[149] ដីកាកំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E462 ទំព័រ ២ (ដែលបង្គាប់ថា សេចក្តីសម្រេចនេះត្រូវបានជូនដំណឹងដល់ភាគី និងការិយាល័យរដ្ឋបាល និងត្រូវផ្សព្វផ្សាយក្នុងគេហទំព័រផ្លូវការរបស់ អ.វ.ត.ក.)។

"អង្គជំនុំជម្រះសូមជម្រាបដល់ភាគី និងសាធារណជនថា នៅពេលនេះអង្គជំនុំជម្រះប្រកាសត្រឹមតែសេចក្តីសង្ខេបនៃសាលក្រមរបស់ខ្លួនប៉ុណ្ណោះ។ អានុភាពផ្លូវច្បាប់នៃការយល់ឃើញនេះ មានតែនៅក្នុងសាលក្រមមានសំអាងហេតុពេញលេញប៉ុណ្ណោះ ដែលមានជាភាសាខ្មែរ អង់គ្លេស និងបារាំងតាមពេលវេលាសមស្រប"[150]។

53. សេចក្តីសង្ខេបនេះមានផ្នែកសម្រេចសេចក្តីដែលបានលើកឡើងថា ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត[151]។ សេចក្តីសង្ខេបនេះ ដែលសំដៅទាំងស្រុងទៅលើសាលក្រមបានបញ្ជាក់ថាៈ

"សាលក្រមនេះអាចប្តឹងសាទុក្ខបានដោយភាគីតាមវិធានផ្ទៃក្នុង។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះ**បញ្ជាក់**ថា យោងតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក. កាលបរិច្ឆេទដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ប្រសិនបើមាន គិតចាប់ពីថ្ងៃទីមួយនៃប្រតិទិនបន្ទាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតរបស់ អ.វ.ត.ក. ដូចបានជ្រើសដោយភាគីនីមួយៗស្របតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្ត"[152]។

54. បីថ្ងៃក្រោយមក នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងការប្រកាសសាលក្រមសង្ខេបដោយអះអាងថា មានកំហុសផ្នែកនីតិវិធី និងកង្វះសំអាងហេតុ ហើយបានស្នើសុំឱ្យចាត់ទុកសាលក្រមនេះជាមោឃៈ[153]។ អំណះអំណាង និងការស្វែងរកដំណោះស្រាយក្នុងបណ្តឹងសាទុក្ខភ្លាមៗ ភាគច្រើនដូចគ្នាទៅនឹងអ្វីដែលបានលើកឡើងក្នុង"សារណាសំខាន់"បច្ចុប្បន្នរបស់ម្ចាស់បណ្តឹងសាទុក្ខ ដូចជាថា "ដោយសារការខកខានក្នុងការផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះបានរំលោភបំពានលើវិធានផ្ទៃក្នុង(១) និងបង្កើតឱ្យមានការភាន់

---

[150] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 ("ការប្រកាសសេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២") ទំព័រ ៣។

[151] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 ("ការប្រកាសសេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២") ទំព័រ ៣៨ ដល់ ៤១។

[152] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 ("ការប្រកាសសេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២") ទំព័រ ៤១-៤២។

[153] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៣។

ច្រឡំផ្នែកនីតិវិធី និងភាពមិនប្រាកដប្រជាផ្នែកច្បាប់(២) និងបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនទៅជាមោឃៈ(៣) និងបានរំលោភបំពានលើសិទ្ធិជាសារវ័ន្ត និងផ្នែកនីតិវិធីរបស់ គាត់ដោយបានបង្កឱ្យរងព្យសនកម្មធ្ងន់ធ្ងរ(៤)[154]។ គាត់បានស្នើសុំឱ្យមានការប្រកាសមួយថា សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនោះត្រូវប្រកាសថា ជាមោឃៈ[155]។

55. ក្នុងបណ្តឹងសាទុក្ខភ្លាមៗនោះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានវិធានផ្ទៃក្នុង ជាពិសេសវិធាន ១០១, ១០៥(១)(ខ), ១០៥(២) និង ១០៤(៤)(ក) ដោយសារការខកខានផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៅថ្ងៃដែលសាលក្រមត្រូវបានប្រកាស[156]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា គាត់"ពុំអាចដឹងច្បាស់លាស់បានអំពីផលប៉ះពាល់ផ្នែកនីតិវិធីនៃសេចក្តីសម្រេចដែលអង្គជំនុំជម្រះបានធ្វើឡើងដោយផ្ទាល់មាត់នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨"[157]។ ជាជម្រើសគាត់បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល "លើកកាលបរិច្ឆេទចាប់ផ្តើមបណ្តឹងសាទុក្ខរហូតទាល់តែមានការជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងជាបីភាសាផ្លូវការរបស់ អ.វ.ត.ក. ឬរហូតទាល់តែមានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើសេចក្តីសម្រេចនេះចេញក្រោយពេលជូនដំណឹងអំពីសំអាងហេតុនោះ"[158]។

56. នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា បណ្តឹងសាទុក្ខនោះពុំត្រឹមត្រូវតាមទម្រង់[159] និងបានផ្តល់សំអាងហេតុមួយចំនួនដូចខាងក្រោមថា៖ (១) សំណើសុំនេះពុំមែនជាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងស្របតាមវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង[160] (២) នៅពេលអង្គជំនុំជម្រះសាលាដំបូងប្រកាសសេចក្តីសង្ខេបនៃសាលក្រមនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ថា អានុភាពផ្លូវច្បាប់នៃការយល់ឃើញមានតែនៅក្នុងសាលក្រមមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ដែលនឹងចេញក្នុងពេលសមស្រប[161] (៣) ការជំទាស់

---

[154] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៤។

[155] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៧៣។

[156] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៦-៧, ១០-២៧។

[157] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៩។

[158] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) កថាខណ្ឌ ៧៣។

[159] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ ១០-១៨។

[160] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ ១០-១២។

[161] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ កថាខណ្ឌ ១១។

ផ្នែកនីតិវិធីបានធ្វើឡើងមុនពេលកំណត់ និងពុំអាចលើកដោយផ្អែកលើវិធាន ១០៥(១)(ខ) ឬវិធាន ១០៥(២) ឬ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងបានឡើយ ដោយសារការប្រកាសផ្អែកសម្រេចសេចក្តីនោះពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ឬប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យលើអង្គសេចក្តីនៃការសម្រេចដាក់ពិរុទ្ធភាព និងការប្រកាសទោស[162] និង (៤) អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនប្រើប្រាស់យុត្តាធិការដែលខ្លួនមាន និងយល់ឃើញថា ដោយហេតុថា សាលក្រមមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរចុងក្រោយ និងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខដែលត្រូវបានរំពឹងទុក នៅពុំទាន់បានបញ្ចប់នៅឡើយ ទើបអង្គជំនុំជម្រះពុំអាចទទួលយកបញ្ហាមកដោះស្រាយដោយតម្រូវឱ្យប្រើប្រាស់យុត្តាធិការរបស់ខ្លួននោះឡើយ[163]។

57. សាលក្រមមានសំអាងហេតុពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានចេញនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ជាបីភាសាផ្លូវការរបស់ អ.វ.ត.ក.។ ទោះជាយ៉ាងណាក្តី សាលក្រមនេះបានចុះកាលបរិច្ឆេទនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ និងចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះសាលាដំបូង។ ជាការពុំចាំបាច់ដែលត្រូវលើកសាឡើងវិញនូវសំណើពុំទទួលបានជោគជ័យបន្តបន្ទាប់ជាច្រើនរបស់ ខៀវ សំផន ដែលជំទាស់ទៅនឹងសុពលភាពនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលប្រកាសបណ្តឹងសាទុក្ខភ្លាមៗនោះថាពុំត្រឹមត្រូវតាមទម្រង់ ផ្អែកលើមូលដ្ឋាននៃការជំទាស់ទៅនឹងការចាត់តាំងសមាសភាពចៅ

---

162 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ ១២-១៥។

163 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ ១៦-១៨ (អង្គជំនុំជម្រះតុលាការកំពូលបានឆ្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា យុត្តាធិការដែលមានជាប់ជាមួយរបស់អង្គជំនុំជម្រះ គឺត្រូវប្រើប្រាស់ក្នុងកាលៈទេសៈដែលមានភាពចាំបាច់ក្នុងការធានានូវរដ្ឋបាលតុលាការត្រឹមត្រូវយុត្តិធម៌ និងបានយល់ឃើញថា មេធាវីការពារក្តីខកខានក្នុងការបង្ហាញថា ការប្រកាសសេចក្តីសង្ខេប និងការយល់ឃើញនៅមុនការចេញសាលក្រមមានសំអាងហេតុ បានប៉ះពាល់ដល់សិទ្ធិរបស់ ខៀវ សំផន ជាមូលដ្ឋានក្នុងការប្តឹងសាទុក្ខ និងបន្ថែមទៀតថា ការរំលោភបំពានលើសិទ្ធិផ្នែកនីតិវិធី នៅតែជាសម្មតិកម្មសុទ្ធសាធ។ ការអន្តរាគមន៍របស់អង្គជំនុំជម្រះ ពុំត្រូវបានតម្រូវក្នុងការការពារកិច្ចដំណើរការនីតិវិធីនោះទេ)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) កថាខណ្ឌ ២៨-៣៣ ("យុត្តាធិការដែលមានជាប់ជាមួយនេះ "ត្រូវបានប្រើប្រាស់ក្នុងករណីចាំបាច់ដើម្បីធានានូវកិច្ចការរដ្ឋបាលតុលាការត្រឹមត្រូវយុត្តិធម៌ រួមបញ្ចូលការគោរពសិទ្ធិមនុស្សពេញលេញ [...] អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើអន្តរាគមន៍ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ [...] ត្រង់ចំណុចដែលថា ដូចបានពិភាក្សាខាងក្រោម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលធ្វើឱ្យមោឃភាពសេចក្តីសម្រេចរបស់ខ្លួន និងរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន"។

ក្រុមអង្គជំនុំជម្រះតុលាការកំពូល និងក្រោយមកការធ្វើបណ្តឹងមិនពេញចិត្តសមាសភាពចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ផ្អែកលើមូលដ្ឋាននៃភាពលម្អៀងតាមការសន្មត[164]។

58. តាមប្រវត្តិនីតិវិធី ខៀវ សំផន បច្ចុប្បន្នបានលើកសាជាថ្មីនូវអំណះអំណាងពីមុននៃបណ្តឹងសាទុក្ខភ្លាមៗក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន និងបានជំទាស់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងនៃការប្រកាសសាលក្រមរបស់ខ្លួនតាមរយៈការចេញតែសេចក្តីសង្ខេបសាលក្រមនោះ បានរំលោភបំពានលើវិធាន ១០១, ១០២ និង ១០៧ នៃវិធានផ្ទៃក្នុង ដែលចែងថា ខុសគ្នាពីសេចក្តីសម្រេច សាលក្រមត្រូវតែរៀបចំជាលាយលក្ខណ៍អក្សរ និងប្រកាសនៅថ្ងៃតែមួយដើម្បីធ្វើជាចំណុចចាប់ផ្តើមនៃកាលបរិច្ឆេទបណ្តឹងសាទុក្ខ[165]។ ខៀវ សំផន បានលើកឡើងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការគោរពតាមវិធានផ្ទៃក្នុងនេះ គឺជាកំហុសធ្ងន់ធ្ងរផ្នែកអង្គច្បាប់ ដែលបានធ្វើឱ្យសាលក្រមមានសំអាងហេតុពេញលេញដែលចេញតាមក្រោយនោះទៅជាមោឃៈ ក៏ដូចគ្នាទៅនឹងរាល់វិធានការទាំងឡាយដែលបានធ្វើឡើងក្រោយពេលចេញផ្នែកសម្រេចសេចក្តី និងបានធ្វើឱ្យការប្រកាសទោសទៅជាមោឃៈ គ្មានសុពលភាព ខុសច្បាប់ និងតាមអំពើចិត្ត[166]។ គាត់បានអះអាងបន្ថែមទៀតថា លក្ខណៈនៃការចេញសាលក្រម ជាពិសេស"ការចុះកាលបរិច្ឆេទថយក្រោយ"លើសាលក្រមមានសំអាងហេតុពេញលេញនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ បានចោទជាបញ្ហាដល់សុចរិតភាពនៃដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការ[167]។

59. ខៀវ សំផន បានសន្និដ្ឋានថា សិទ្ធិជាមូលដ្ឋានរបស់គាត់ រួមមានសិទ្ធិទទួលបានការស្តាប់ដោយតុលាការព្រហ្មទណ្ឌដែលបង្កើតឡើងដោយច្បាប់ និងទទួលបានការការពារខ្លួនដោយប្រសិទ្ធភាព និងសច្ចភាពផ្នែកច្បាប់ និងសាលក្រមមានសំអាងហេតុពេញលេញ និងកិច្ចដំណើរការនីតិវិធីមានតម្លាភាពនោះ ត្រូវបាន

[164] សំណើរបស់ ខៀវ សំផន សុំមោឃភាព (E463/1/4)។ បណ្តឹងរបស់ ខៀវ សំផន ប្តឹងមិនពេញចិត្តចៅក្រម (F53)។

[165] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០-៣២, ៤៨, ៥១, ៥៥, ៦៨។ វិធាន ១០១, ១០២, និង ១០៧ នៃវិធានផ្ទៃក្នុង។

[166] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២-៥៦។

[167] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩, ៧០។

វំលោភបំពានដោយសារការប្រព្រឹត្តពុំត្រឹមត្រូវខាងលើ[168]។ អាស្រ័យហេតុនេះ ពិរុទ្ធភាពរបស់គាត់ពុំត្រូវបានកំណត់ត្រឹមត្រូវតាមច្បាប់ឡើយ[169]។

60. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ទឡ្ហីករណ៍នេះគប្បីត្រូវបដិសេធចោលភ្លាមៗពុំចាំបាច់ពិចារណាបន្ថែមទៀតឡើយដោយសារ ខៀវ សំផន បានត្រឹមតែលើក ប៉ុន្តែពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយពុំគោរពតាមវិធាន ១០១ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានអះអាងថា ពុំមានបទប្បញ្ញត្តិណាមួយក្នុងវិធាន ១០១, ១០២ ឬ ១០៧ នៃវិធានផ្ទៃក្នុងចែងថា សាលក្រមទៅជាមោឃៈ ប្រសិនបើសាលក្រមជាលាយលក្ខណ៍អក្សរ ពុំត្រូវបានចេញក្នុងពេលតែមួយជាមួយនឹងការប្រកាសនោះឡើយ[170]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចរាល់លើបញ្ហានេះក្នុងបណ្តឹងសាទុក្ខភ្លាមៗ និងបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់រួចហើយថា មានតែសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរដែលនឹងត្រូវចេញតាមពេលវេលាសមស្របប៉ុណ្ណោះដែលមានអានុភាពផ្លូវច្បាប់ និងថា កាលបរិច្ឆេទសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខគិតចាប់ពីពេលចេញសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរនោះ[171]។ ចំណាត់ការនេះបានការពារពេញលេញនូវសិទ្ធិជាមូលដ្ឋានរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌[172]។

61. សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះនៃ អ.វ.ត.ក. បានលើកពេលចេញសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរជាច្រើនករណី និងថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការពន្យារពេលដោយចេញសេចក្តីសង្ខេប និងផ្នែកសម្រេចសេចក្តីមុនការចេញសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនោះ ពុំមែនជាការរំលោភបំពានផ្នែកនីតិវិធីឡើយ[173]។ សហព្រះរាជអាជ្ញាបានបន្ថែមថា ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅលើសុចរិតភាពនៃដំណើរការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រួមមានការចុះកាលបរិច្ឆេទថយក្រោយនៃសាលក្រមនៅចន្លោះពេលនៃការប្រកាសសេចក្តីសង្ខេបសាលក្រម និងការជូនដំណឹងសំអាងហេតុជាលាយលក្ខណ៍អក្សរ គឺជាការប៉ាន់ស្មាន ជាពិសេសដោយសារវិធាន ៩៦(១) នៃវិធានផ្ទៃក្នុងធានាថា ការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជាការ

---

[168] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥, ៧៩។

[169] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២, ៥៧, ៦៦, ៧០, ៧៩។

[170] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤-២៦។

[171] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៥។

[172] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤-២៦, ២៨។

[173] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៦។

សម្ងាត់ ហើយពុំមានភស្តុតាងបង្ហាញថា មានការកែប្រែលើសំអាងហេតុនៅក្នុងរយៈពេលនោះឡើយ[174]។ អាស្រ័យហេតុនេះ ការអះអាងរបស់ ខៀវ សំផន ដែលថា សាលក្រមគ្មានមូលដ្ឋានច្បាប់ ពុំមានមូលដ្ឋានត្រឹមត្រូវគាំទ្រឡើយ[175]។

62. សហព្រះរាជអាជ្ញាបានបដិសេធការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបាន"បង្កើតឡើងដោយច្បាប់" និងថា ថៅក្រម"លែងមានសិទ្ធិអំណាច" ឬ"ប្រើប្រាស់សិទ្ធិអំណាចហួសដែនកំណត់" [176]។ សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងបណ្តឹងសាទុក្ខភ្លាមៗបានបញ្ជាក់ថា ពុំមានកាលៈទេសៈគួរឱ្យជឿជាក់បានដែលរារាំងអង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមមានសំអាងហេតុពេញលេញ និងពុំបានបង្ហាញថា ថៅក្រមអង្គជំនុំជម្រះសាលាដំបូងលែងមាន*សិទ្ធិអំណាច* ឬ *ប្រើប្រាស់ហួសដែនកំណត់* នៅពេលចេញសាលក្រមមានសំអាងហេតុនោះឡើយ[177]។ ខៀវ សំផន ពុំបានបង្ហាញថា កំហុសនោះបណ្តាលឱ្យមានភាពមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ បើពិចារណាជារួមលើដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ព្រមទាំងបណ្តឹងសាទុក្ខផងដែរនោះ[178]។ ផលវិបាកសំខាន់តែមួយគត់ដែលកើតចេញពីចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូង គឺថា ខៀវ សំផន បច្ចុប្បន្នត្រូវបានផ្តល់ពេលវេលា*បន្ថែម*រៀបចំបណ្តឹងសាទុក្ខរបស់ខ្លួន[179]។

63. ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ភាគីត្រូវបានជូនដំណឹងថា មានតែសេចក្តីសង្ខេបនៃសាលក្រមជាមួយនឹងផ្នែកសម្រេចសេចក្តីប៉ុណ្ណោះដែលត្រូវបានប្រកាស និងថា សារណាជាមូលដ្ឋានរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ដែលថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន ១០២ នៃវិធានផ្ទៃក្នុង បានបណ្តាលឱ្យសាលក្រមដែលចេញនៅពេលក្រោយនោះទៅជាមោឃៈឡើយ[180]។

[174] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៦

[175] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧។

[176] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧។

[177] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៥, ២៨។

[178] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨។

[179] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨។

[180] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០-៣១, ៥២, ៥៥-៥៧, ៧៩។

64. សហមេធាវីនាំមុខបានគាំទ្រសារណាតបរបស់សហព្រះរាជអាជ្ញា[181]។

65. ពិតណាស់នេះទំនងជាថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តប្រាសចាកពីខ្លឹមសារទូទៅនៃវិធាន ១០២(១) នៃវិធានផ្ទៃក្នុងដែលបានបញ្ញត្តិអំពីការប្រកាសសាលក្រមក្នុងសវនាការសាធារណៈ និងបានតម្រូវថា៖

> "គ្រប់សាលក្រមទាំងអស់ ត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកសង្ខេបនៃសំអាងហេតុ និងផ្នែកសម្រេចសេចក្តី ត្រូវអានដោយសម្លេងខ្លាំងដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬសមាជិកនៃអង្គជំនុំជម្រះណាម្នាក់។ ចៅក្រមដែលមានយោបល់ផ្ទុយ អាចអានដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបគំនិតផ្ទុយរបស់ខ្លួន។ ក្រឡាបញ្ជីត្រូវផ្តល់សាលក្រមចម្លងមួយច្បាប់ទៅឱ្យភាគីទាំងឡាយ និងត្រូវធានាថា សាលក្រមត្រូវបានផ្សព្វផ្សាយដោយការិយាល័យរដ្ឋបាល តាមមធ្យោបាយសមស្រប"។

66. តាមការពិនិត្យជាក់លាក់លើវិធាន ១០២(១) នៃវិធានផ្ទៃក្នុង ហាក់បីដូចជាមានន័យសាមញ្ញ និងពុំមានការកំណត់អំពីលក្ខខណ្ឌតម្រូវក្នុងន័យថាត្រូវតែចេញសេចក្តីសង្ខេប និងសាលក្រមក្នុងពេលតែមួយនាពេលសវនាការសាធារណៈ។ ផ្ទុយទៅនឹងអំណះអំណាងចម្បងរបស់ ខៀវ សំផន វិធាននេះ ឬវិធានដទៃទៀតពុំបានចែងថា សេចក្តីសង្ខេប និងសាលក្រមត្រូវចេញក្នុងពេលតែមួយ បើទោះបីជាការពិតថា បញ្ហានេះបានក្លាយជាទម្លាប់ធម្មតារហូតមកដល់បច្ចុប្បន្ន ដូចបានបញ្ជាក់តាមរយៈការអនុវត្តន៍ជាក់ស្តែងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញសាលក្រមពីរលើករួចមកហើយក្នុងសំណុំរឿង ០០១ និង ០០២/០១ ដែលនៅក្នុងថ្ងៃដដែលនោះសេចក្តីសង្ខេបនៃសាលក្រមត្រូវបានប្រកាសក្នុងសវនាការសាធារណៈ[182]។ វិធាន ១០២(១) នៃវិធានផ្ទៃក្នុង ជាវិធានមួយស្ថិតក្នុងចំណោមវិធានស្តីពីនីតិវិធីជាច្រើនដែលដោះស្រាយលើមាតិកា និងទម្រង់នៃសាលក្រម អានុភាពសាលក្រមលើជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងលក្ខណៈដែលសាលក្រមត្រូវប្រកាសនៅក្នុងសវនាការជាសាធារណៈ។ វិធាននេះពុំមានការដាក់ទណ្ឌកម្មចំពោះការមិនគោរពតាម ឬការអនុវត្តន៍ប្រាសចាកនោះឡើយ។ តាមការយល់ជាសត្យាម័ត ពុំមានការរំពឹងទុកណាមួយថា

---

181 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៩។

182 ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០១។ ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E1/241.1 ទំព័រ ២ (អង្គជំនុំជម្រះចេញសេចក្តីសង្ខេបនៃសាលក្រមនៅពេលសវនាការ និងបានបញ្ជាក់ថា អានុភាពផ្លូវច្បាប់នៃការយល់ឃើញនេះ មានតែនៅក្នុងសាលក្រមមានសំអាងហេតុពេញលេញប៉ុណ្ណោះ ដែលមានជាភាសាខ្មែរ អង់គ្លេស និងបារាំងក្នុងពេលឆាប់ៗបន្ទាប់ពីសវនាការនេះ)។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងពុំបានអានសេចក្តីសង្ខេបនៃសាលក្រមនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ និងបានចេញសាលក្រមពេញលេញក្នុងថ្ងៃតែមួយ។

ការមិនគោរពតាមវិធាននេះដែលមានពាក្យពេចន៍ពុំសូវជាក់លាក់ នឹងនាំទៅរកផលវិបាកផ្នែកច្បាប់ច្រើនសន្ធឹកសន្ធាប់ ឬការរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់ ខៀវ សំផន នោះឡើយ។

67. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានទទួលសំណើជាច្រើនលើកឡើងថា ការខកខានចេញសេចក្តីសង្ខេប និងសាលក្រមចុងក្រោយក្នុងពេលតែមួយ បានធ្វើឱ្យ*ក្នុងចំណោមនោះ* ខៀវ សំផន បាត់បង់សិទ្ធិធ្វើបណ្តឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ កង្វះទម្រង់ជាលាយលក្ខណ៍អក្សរបានធ្វើឱ្យដំណើរការនីតិវិធីទៅជាមោឃៈ ការចេញសេចក្តីសង្ខេបពុំមានសំអាងហេតុពេញលេញ *ក្នុងចំណោមនោះ* បានធ្វើឱ្យចៅក្រម*លែងមានសិទ្ធិអំណាច* ចំណាត់ការនៃការចេញសេចក្តីសង្ខេបបានរំលោភបំពានការបែងចែងសិទ្ធិអំណាច ចៅក្រម*ប្រើប្រាស់សិទ្ធិអំណាចហួសដែនកំណត់* ចៅក្រមពុំអើពើទៅនឹងប្រព័ន្ធនីតិរដ្ឋ និងបានធ្វើឱ្យប៉ះពាល់ដល់ធម្មានុរូបរបស់ អ.វ.ត.ក.។ ខៀវ សំផន បានអះអាងយ៉ាងម៉ឺងម៉ាត់ថា ផលវិបាកទាំងនេះបានកើតចេញពីសាលក្រមដែលត្រូវបានចេញជាពីរផ្នែក ដែលមានការពន្យារពេលរហូតដល់បួនខែគិតចាប់ពីពេលចេញសេចក្តីសង្ខេបចំនួន ៣១ ទំព័រ រហូតដល់ពេលចេញសាលក្រមមានសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងចំនួន ២.២៦៨ ទំព័រជាភាសាអង់គ្លេស ៣.៩០១ ទំព័រជាភាសាខ្មែរ និង ២៦៩៦ ទំព័រជាភាសាបារាំង។

68. ខៀវ សំផន បានបង្ហាញត្រឹមត្រូវនូវឧទាហរណ៍ដែលអង្គជំនុំជម្រះនានានៅ អ.វ.ត.ក. បានចេញសេចក្តីសម្រេចជាពីរផ្នែក និងបានលើកឡើងដោយស្របជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូលថា វិធីសាស្ត្រនៃការចេញបែបនេះ អាចត្រូវបានអនុញ្ញាត ដោយសារ*សេចក្តីសម្រេច*ទាំងនោះពុំបើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ ដែលខុសគ្នាពី*សាលក្រម* ហើយសេចក្តីសម្រេចនោះពុំធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ទៅលើកិច្ចដំណើរការនីតិវិធីទាំងមូលឡើយ។ បញ្ហានៅទីនេះ គឺពុំមែនជាការសម្រេច ឬសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗណាមួយនោះទេ ប៉ុន្តែជាបញ្ហាថាតើ មានកំហុសផ្នែកនីតិវិធីដែលបានបង្កើតឱ្យមានព្យសនកម្មដល់ ខៀវ សំផន ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ដែរ ឬយ៉ាងណា[183]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទៅលើបញ្ហាផ្នែកនីតិវិធី និងនៅពេលពិនិត្យលើសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ អង្គជំនុំជម្រះតុលាការកំពូលបានជ្រើសរើសយកវិធីសាស្ត្រផ្តល់អាទិភាព និងធ្វើអន្តរាគមន៍ដរាបណាការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស "ដែលស្តែងចេញឱ្យឃើញច្បាស់លាស់ [...] ដែលបណ្តាលឱ្យមានព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខតែប៉ុណ្ណោះ"[184]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវ

[183] *សូមមើលខាងលើ* ផ្នែក II.ឃ។

[184] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៦ ដល់ ៩៧ យោងទៅលើវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរខាងលើ* ផ្នែក II.គ។

ពិចារណាលើបញ្ហាថាតើ ព្យសនកម្មនោះបានកើតឡើងក្នុងអំឡុងពេលនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា និងផ្អែកតាមទិដ្ឋភាពនៃកិច្ចដំណើរការនីតិវិធីទាំងមូល គឺជាការបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដែលត្រូវបានកំណត់និយមន័យថា ជា"លទ្ធផលមិនយុត្តិធម៌ទាំងស្រុងក្នុងកិច្ចដំណើរការនីតិវិធីតុលាការ"[185]។

69. ជាការឆ្លើយតបទៅនឹងសារណារបស់ ខៀវ សំផន ដែលលើកឡើងថា សេចក្តីសង្ខេបនោះមិនគោរពតាមវិធានបញ្ញត្តិ ទើបធ្វើឱ្យសាលក្រមពេញលេញដែលចេញតាមក្រោយជាការខុសច្បាប់ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យឯកសារទាំងពីរនេះ និងពិចារណាឃើញថា សេចក្តីសង្ខេបជាក់ស្តែងត្រឹមតែជាការលើកបង្ហាញត្រួសៗនៃការយល់ឃើញសំខាន់ៗរបស់អង្គជំនុំជម្រះសាលាដំបូង។ ច្បាស់ណាស់ នេះពុំមែនជាសាលក្រមដែលមានអានុភាពផ្លូវច្បាប់តាមរយៈការប្រកាស ចំណងជើង ភិនភាគខាងក្រៅ ឬខ្លឹមសារខាងក្នុងឡើយ។ ផ្ទុយទៅវិញ សាលក្រមមានសំអាងពេញលេញគឺជាប្រភេទសៀវភៅកម្រាស់ក្រាស់ពិតប្រាកដជិត ២.២៦៨ ទំព័រជាភាសាអង់គ្លេសដែលមានមាតិកាលម្អិត និងជើងទំព័រប្រមាណ ១៤.៤៤៦ និង ៣.៩០១ ទំព័រជាភាសាខ្មែរដែលត្រូវបានបកប្រែពេញលេញនៅពេលចេញនោះ។ ការបកប្រែជាភាសាបារាំង ២.៦៩៦ ទំព័រ បានធ្វើតាមក្រោយឆាប់ៗក្រោយមក។ សាលក្រមនេះដោះស្រាយលម្អិតលើបញ្ហាដែលបានជំទាស់ ព្រមទាំងការយល់ឃើញផ្នែកអង្គហេតុ និងសេចក្តីសន្និដ្ឋាន។ ពិតណាស់នេះគឺជាសាលក្រម មិនមែនសេចក្តីសង្ខេបនោះទេ។

70. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការឆ្លៀតឱកាសគោរពច្បាប់ហួសហេតុរបស់ ខៀវ សំផន បានបង្ហាញឱ្យឃើញនៅទីនេះ។ ជាការគួរឱ្យសង្ស័យថា ការលើកឡើងអំពីការរំលោភបំពានក្នុងកម្រិតមួយដែលពុំសមាមាត្រចំពោះការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពន្យល់អំពីការប្រាសចាកបន្តិចបន្តួចពីការអនុវត្តន៍តាមវិធានស្តីពីនីតិវិធីនោះ គឺជាការប្រឌិតឡើង។ បើទោះបីជាការប្រព្រឹត្តរបស់អង្គជំនុំជម្រះសាលាដំបូងអាចត្រូវបានទិតៀនសម្រាប់ការពុំបានផ្តល់សំអាងហេតុក៏ដោយ ក៏ចេតនាក្នុងការចេញសាលក្រមសង្ខេបជាមុន ត្រូវបានជូនដំណឹងច្បាស់លាស់ និងមានតម្លាភាពត្រឹមត្រូវ ហើយផ្អែកតាមបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងទំនងជាប្រើប្រាស់ឆន្ទានុសិទ្ធិសម្រាប់ហេតុផលសមស្រប។ ការពុំបានពន្យល់នូវការប្រាសចាកចេញពីវិធាន ១០២(១) នៃវិធានផ្ទៃក្នុង ពុំមានផលវិបាកកើតឡើង ឬក្នុងកម្រិតធ្ងន់ធ្ងរដែលតម្រូវឱ្យការចេញសាលក្រមបន្ទាប់នោះទៅជាមោឃៈ និងគ្មានសុពលភាពឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងថា ក្នុងការកំណត់ថាតើ ទម្រង់ការនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

---

[185] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០០។ *សូមមើលផងដែរខាងលើ* ផ្នែក II.ឃ។

សាលាដំបូងដែលបានចេញជាលក្ខណៈអនុស្សរណៈ បានធ្វើឱ្យសេចក្ដីនោះគ្មានសុពលភាពដោយសារការមិនគោរពតាមនីតិវិធី ដែរ ឬយ៉ាងណា៖ "លើកលែងតែច្បាប់បានតម្រូវឱ្យមានទម្រង់ការជាក់លាក់ ឬការកំណត់នៃចំណាត់ការរបស់តុលាការ ការអនុវត្តន៍ដែលងាកចេញពីទម្រង់បែបបទរបស់តុលាការ និងនិមិត្តសញ្ញា ពុំបានធ្វើឱ្យចំណាត់ការនោះទៅជាគ្មានសុពលភាពឡើយ។ ផ្ទុយទៅវិញ ចំណាត់ការនោះត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យឡើងវិញផ្អែកលើទិដ្ឋភាពត្រឹមត្រូវយុត្តិធម៌ ដើម្បីបញ្ជាក់ច្បាស់លាស់គ្រប់គ្រាន់ទាក់ទងទៅនឹងអត្ថិភាព ខ្លឹមសារ និងផលវិបាកផ្នែកនីតិវិធី"[186]។ ទាក់ទងទៅនឹងបញ្ហានេះ ចេតនារបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសេចក្ដីសង្ខេបមុនសាលក្រមមានសំអាងហេតុពេញលេញ ត្រូវបានជូនដំណឹងច្បាស់លាស់ និងមានតម្លាភាព និងផ្អែកតាមការជូនដំណឹងជាមុនគ្រប់គ្រាន់ ពុំមែនជាការប្រព្រឹត្តតាមអំពើចិត្ត ដូចការលើកឡើងរបស់ ខៀវ សំផន នោះឡើយ។ គាត់មានឱកាសជំទាស់ទៅនឹងចេតនាបើកចំហជាសាធារណៈរបស់ប្រធានអង្គជំនុំជម្រះ។ ប្រសិនបើគាត់បានសន្មតដឹងថា ការប្រព្រឹត្តដោយចេតនារបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការរំលោភបំពានវិធានធ្ងន់ធ្ងរ ឬបានប៉ះពាល់ដល់អត្ថប្រយោជន៍ណាមួយនោះគាត់គប្បីលើកការជំទាស់ឡើង។ ប៉ុន្តែ ដោយសារការនៅស្ងៀមអស់រយៈពេលជិតប្រាំបីសប្ដាហ៍ គាត់បានជ្រើសរើសយកការបោះបង់សិទ្ធិនោះ និងបានយល់ស្របតាមការប៉ុនប៉ងប្រើប្រាស់វិធីសាស្ត្រពីរដំណាក់កាលក្នុងការចេញសាលក្រមនេះ។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមផែនការរបស់ខ្លួនដែលបានជូនដំណឹងពីដំបូងជាសាធារណៈ ហើយបានចេញត្រឹមតែសេចក្ដីសង្ខេបប៉ុណ្ណោះ។

71. បើទោះបីជា នេះអាចជាការល្អប្រសើរសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមពេញលេញរបស់ខ្លួនក្នុងថ្ងៃតែមួយជាមួយនឹងការប្រកាសសាលក្រមក្នុងសវនាការសាធារណៈក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអនុវត្តប្រាសចាកពីវិធានបន្តិចបន្តួច ពុំបានបង្កឱ្យមានព្យសនកម្មដល់ ខៀវ សំផន ដែលបណ្ដាលឱ្យមានលទ្ធផលមិនយុត្តិធម៌ទាំងស្រុងក្នុងកិច្ចដំណើរការនីតិវិធីទាំងមូលនោះឡើយ។

72. បើទោះបីជា អង្គជំនុំជម្រះតុលាការកំពូល និងភាគីពុំអាចដឹងពីមូលហេតុនៃការចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏ប្រសិនបើមានការស្នើសុំដោយភាគី អង្គជំនុំជម្រះសាលាដំបូងប្រហែលជាអាចផ្ដល់មូលហេតុរបស់ខ្លួនបានដឹង។ តាមទិដ្ឋភាពទូទៅ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ

---

[186] សេចក្ដីសម្រេចក្នុងសំណុំរឿង ០០២/០១ លើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E163/5/1/13 ("សេចក្ដីសម្រេចបំបែកសំណុំរឿងលើកទីមួយ (E163/5/1/13)") កថាខណ្ឌ ៣០។

សាលាដំបូងអាចដោយសារបញ្ហាបកប្រែ ឬក៏អាចដោយសារបញ្ហាសុខភាពរបស់ នួន ជា (ជនជាប់ចោទដទៃទៀតនៅក្នុងការជំនុំជម្រះ) ដែលមានសភាពធ្ងន់ធ្ងរនាពេលនោះ និងបានទទួលមរណភាពបួនខែបន្ទាប់ពីការចេញសាលក្រមមានសំអាងហេតុពេញលេញ។ តាមធម្មតា ពុំដឹងពីមូលហេតុនោះឡើយ។

73. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមនេះ។ កន្លងមក នួន ជា និង ខៀវ សំផន បានជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា កំហុសនីតិវិធីត្រូវបានចាត់ទុកថា ជាកំហុសផ្នែកអង្គច្បាប់ ឬអង្គហេតុសម្រាប់គោលបំណងបណ្តឹងសាទុក្ខ[187]។ អង្គជំនុំជម្រះតុលាការកំពូលបានញែកដាច់ចេញពីគ្នារវាងកំហុសផ្នែកនីតិវិធី និងការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការអនុវត្តន៍តាមវិធានស្តីពីនីតិវិធី និងបានបញ្ជាក់ក្នុងសំណុំរឿង ០០២/០១ ថា៖

ការជំទាស់ទៅនឹងសេចក្តីសម្រេចស្តីពីនីតិវិធី

> [..] ៩៧. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងជានិច្ចកាលប្រើប្រាស់ឆន្ទានុសិទ្ធិពាក់ព័ន្ធទៅនឹងបញ្ហាផ្នែកនីតិវិធី។ ដោយស្របជាមួយនឹងគោលការណ៍ដែលបានកំណត់នៅក្នុងប្រយោគចុងក្រោយនៃវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលអនុម័តយកវិធីសាស្ត្រផ្តល់អាទិភាពដោយមិនពិនិត្យឡើងវិញលើសេចក្តីសម្រេចដែលជាឆន្ទានុសិទ្ធិ និងធ្វើអន្តរាគមន៍លើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែលមាន"កំហុសដែលស្តែងឱ្យឃើញជាក់ស្តែង [...] ដែលបណ្តាលឱ្យមានការប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខប៉ុណ្ណោះ"។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY, ICTR និង ICC បានអនុម័តវិធីសាស្ត្រផ្តល់អាទិភាពមិនពិនិត្យឡើងវិញទាក់ទងទៅនឹងសេចក្តីសម្រេចដែលជាឆន្ទានុសិទ្ធិឡើយ។ ឧទាហរណ៍ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICC បានបញ្ជាក់ថា៖
>
> *៨០. មុខនាទីរបស់អង្គជំនុំជម្រះឧទ្ធរណ៍បានពន្លាតដល់ការពិនិត្យឡើងវិញលើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ ដើម្បីធានាថា អង្គជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះឧទ្ធរណ៍នឹងមិនធ្វើការជ្រៀតជ្រែកទៅលើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ [...] លើកលែងតែមានការបង្ហាញថា ការសម្រេចនោះមានកំហុសអង្គច្បាប់ ឬអង្គហេតុ ឬកំហុសផ្នែកនីតិវិធី និងតែក្នុងករណីដែលកំហុសធ្វើឱ្យប៉ះពាល់ជាសត្យានុម័តលើការសម្រេចនោះ។ នេះមានន័យថា អង្គជំនុំជម្រះឧទ្ធរណ៍នឹងធ្វើការជ្រៀតជ្រែកសេចក្តីសម្រេចដែលជាឆន្ទានុសិទ្ធិ តែក្នុងលក្ខខណ្ឌមានកម្រិតប៉ុណ្ណោះ។ យុត្តិ*

---

[187] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៦-៩៨។

*សាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងតុលាការក្នុងស្រុកបានគាំទ្រគោលជំហរនេះ។ តុលាការទាំងនេះបានកំណត់លក្ខខណ្ឌដែលអាចធ្វើយុត្តិកម្មដើម្បីពិនិត្យឡើងវិញនៅបណ្ដឹងឧទ្ធរណ៍ ដូចជា៖ (១) ក្នុងករណីប្រើប្រាស់ឆន្ទានុសិទ្ធិធ្វើការបកស្រាយអង្គច្បាប់ដោយពុំត្រឹមត្រូវ (២) ក្នុងករណីមានការប្រើប្រាស់ក្នុងការធ្វើសេចក្ដីសន្និដ្ឋានអង្គហេតុដោយពុំត្រឹមត្រូវច្បាស់ក្រឡែត ឬ (៣) ក្នុងករណីដែលសេចក្ដីសម្រេចមានភាពមិនយុត្តិធម៌ និងពុំសមហេតុផល ដែលបង្កើតឱ្យមានការរំលោភឆន្ទានុសិទ្ធិនោះ។*

98. អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY និង ICTR បានបញ្ជាក់ច្បាស់លាស់នូវបទដ្ឋានរៀងៗខ្លួននៃការពិនិត្យឡើងវិញលើសេចក្ដីសម្រេចដែលជាឆន្ទានុសិទ្ធិក្នុងករណីប្រហាក់ប្រហែលគ្នានេះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បទដ្ឋានផ្តល់អាទិភាពពុំពិនិត្យឡើងវិញដែលបានអនុម័តដោយតុលាការព្រហ្មទណ្ឌទាំងនេះ មានលក្ខណៈសមស្របស្មើគ្នាដូចនៅក្នុងបរិបទនៃ អ.វ.ត.ក. និងត្រូវវាយតម្លៃលើការចោទប្រកាន់កំហុសនៅក្នុងសេចក្ដីសម្រេចដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដោយធៀបនឹងបទដ្ឋាននោះ[188]។

74. អង្គជំនុំជម្រះតុលាការកំពូលនឹងប្រើប្រាស់ការវិភាគនេះនៃការពិនិត្យឡើងវិញដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៅក្នុងការសម្រេចលើការជំទាស់នេះ។ សម្រាប់អត្ថប្រយោជន៍នៃអំណះអំណាង ប្រសិនបើអង្គជំនុំជម្រះទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចមានកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលចេញសាលក្រមជាពីរដំណាក់កាលកន្លងមក និងដោយសារកពុំឃើញថា មានការប៉ះពាល់ដល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការធ្វើបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះនៅតែពុំអាចកំណត់អត្តសញ្ញាណនៃមូលហេតុដែលគួរឱ្យជឿជាក់បាន ដើម្បីបដិសេធការប្រើប្រាស់សិទ្ធិអំណាចជាឆន្ទានុសិទ្ធិនោះបានដែរ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ផ្អែកលើរយៈពេលនៃការជូនដំណឹងដែលបានផ្ដល់ដល់ភាគីនៅមុនពេលការចេញសេចក្ដីសង្ខេបថា សាលក្រមមានសំអាងហេតុពេញលេញ ជាក់លាក់ និងមានអានុភាពផ្លូវច្បាប់ ត្រូវចេញតាមក្រោយក្នុងពេលសមស្រប "សេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ និងមិនសមហេតុផល ដែលបង្កើតបានជាការរំលោភឆន្ទានុសិទ្ធិ"។ ពុំមានហេតុផលសមស្របដែលតម្រូវឱ្យប្រាសចាកពីការផ្ដល់អាទិភាពដល់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ។

75. បើទោះបីជាអំណះអំណាងភាគច្រើនអាចនឹងពុំចាំបាច់ត្រូវលើកឡើង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុសម្រាប់សេចក្ដីសម្រេចរបស់ខ្លួនក្នុងការចេញសាលក្រមពេញលេញប៉ុន្មានខែក្រោយក៏ដោយ ក៏ចាំបាច់ត្រូវពិនិត្យផ្អែកលើបរិបទនោះដែរ។ ដូចបានកត់សម្គាល់ពីដំបូង ខៀវ សំផន បានដឹង

---

[188] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៦-៩៨។

ច្បាស់លាស់នូវចេតនាក្នុងការចេញសាលក្រមជាពីរដំណាក់កាល។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងពីគោលបំណងរបស់ខ្លួន និងផ្ដល់ឱកាសគ្រប់គ្រាន់ដល់ភាគី និងជាពិសេសជនជាប់ចោទលើកការជំទាស់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសដែលស្ដែងចេញច្បាស់លាស់ពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

76. អង្គជំនុំជម្រះតុលាការកំពូលពិនិត្យលើការជំទាស់របស់ ខៀវ សំផន ដែលថា ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្កើតជាកំហុសផ្នែកនីតិវិធី ដែលនាំឱ្យរាល់ចំណាត់ការទាំងអស់ដែលនៅក្រោយៗនោះទៅជាមោឃៈ៖ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការលើកឡើងបែបនេះពុំមានមូលដ្ឋានត្រឹមត្រូវ។ ពុំមានការយោងទៅលើយុត្តិសាស្ត្រណាមួយ ឬវិធានស្ដីពីនីតិវិធីដែលគាំទ្រមូលដ្ឋាន និងការចោទប្រកាន់នោះឡើយ។ មានការតវ៉ាជាយ៉ាងច្រើនដែលបានលើកឡើង៖ ទីមួយជំទាស់ថា ការខកខានមិនគោរពតាមយ៉ាងតឹងរ៉ឹងនូវលក្ខខណ្ឌតម្រូវនៃវិធាន ១០២(១) នៃវិធានផ្ទៃក្នុង ដែលបញ្ញត្តិអំពីវិធីសាស្ត្រនៃការចេញសាលក្រមនោះ គឺជាកំហុសអង្គច្បាប់ដែលនាំឱ្យសាលក្រមមោឃៈ និងគ្មានសុពលភាព។ ការវិភាគទៅលើការសន្មតដែលថា កំហុសផ្នែកនីតិវិធីត្រូវបានបកស្រាយទៅជាកំហុសផ្នែកអង្គច្បាប់ដែលនាំឱ្យចំណាត់ការក្រោយៗនោះទៅជាមោឃៈដោយសារការមិនគោរពតាមនីតិវិធី គឺជាអំណះអំណាងលើកតគ្នាដែលគ្មានសុពលភាព។ នេះជាវិធីសាស្ត្រមានហានិភ័យ និងគ្មានអត្ថប្រយោជន៍ក្នុងការធ្វើប្រមាណវិធីទាញយកការសន្និដ្ឋានឆ្លងពីចំណុចមួយទៅចំណុចមួយទៀត ដោយគ្មានការលើកឡើងមូលដ្ឋានគាំទ្រ។ នេះជាការពុំគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ និងទទួលយកការសន្មតនេះឡើយ។ ដូចបានពិនិត្យខាងលើ វិធានផ្ទៃក្នុងបានកំណត់ថាតើការរំលោភបំពានលើវិធានស្ដីពីនីតិវិធីណាខ្លះមានផលវិបាកធ្ងន់ធ្ងរ[189]។ នៅគ្រប់ករណី ការខកខានក្នុងការផ្ដល់ហេតុផល ថាតើសេចក្ដីសម្រេចនោះត្រូវបានបង្កើតឡើងយ៉ាងដូចម្ដេច ត្រូវបានចាត់ទុកថា ជាកំហុសផ្នែកនីតិវិធីដែលមានសារៈសំខាន់នាំឱ្យសេចក្ដីសម្រេចនោះគ្មានសុពលភាព ប៉ុន្តែ ខៀវ សំផន ពុំបានបង្ហាញថា គាត់បានទទួលរងព្យសនកម្មដោយសារកិច្ចដំណើរការនីតិវិធីទាំងមូល ដែលនាំឱ្យមានភាពមិនយុត្តិធម៌នោះឡើយ។

77. បើទោះបីជាការលើកឡើងរបស់ ខៀវ សំផន អំពីព្យសនកម្ម និងការរំលោភបំពានមានអត្ថិភាពពាសពេញសារណារបស់ខ្លួនដែលថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវបានចោទប្រកាន់យ៉ាងខ្លាំងៗពីការបង្ក

[189] *សូមមើលខាងលើ* ផ្នែក II.ឃ។

"អនាធិបតេយ្យផ្នែកនីតិវិធី"ក៏ដោយ ក៏ការពិតនៅតែបង្ហាញថា ការតវ៉ាទាមទារដើម្បីអត្ថប្រយោជន៍ខ្លួននោះ ពុំមានមូលដ្ឋានផ្នែកច្បាប់គាំទ្រត្រឹមត្រូវឡើយ[190]។

78. ពុំមានការបង្ហាញថា សាលក្រមនោះបានបាត់បង់អានុភាពទាំងស្រុងដោយសារការពន្យារពេលក្នុងការចេញផ្នែកដែលមានអានុភាពផ្លូវច្បាប់ ភ្លាមៗបន្ទាប់ពីការអាននូវសេចក្ដីសង្ខេបនៃសាលក្រមនេះ ដោយផ្អែកលើវិធានផ្ទៃក្នុងនោះឡើយ។

79. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា សេចក្ដីសង្ខេបដែលបានចេញក្នុងសវនាការសាធារណៈមុនការចេញសាលក្រមមានសំអាងហេតុពេញលេញ គឺជាសាលក្រមមួយដែលស្របតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុងនោះទេ។ ក្នុងវិធាននេះពុំមានការបញ្ជាក់ជាក់លាក់ថា ការផ្ដល់ ឬការបោះពុម្ពផ្សាយសាលក្រមមានសំអាងហេតុពេញលេញត្រូវធ្វើឡើងនៅក្នុងថ្ងៃតែមួយដូចការប្រកាសសាលក្រមក្នុងសវនាការសាធារណៈឡើយ។ ជាក់ស្ដែង នេះជាការអនុវត្តន៍ធម្មតាក្នុងរឿងក្ដីព្រហ្មទណ្ឌអន្តរជាតិដែលមានទំហំធំ ក្នុងការចេញសេចក្ដីសង្ខេបសាលក្រមផ្ទាល់មាត់ជាមុន ដោយទុកសាលក្រមជាលាយលក្ខណ៍អក្សរពេញលេញចេញតាមក្រោយដើម្បីឱ្យការកែតម្រូវ និង/ឬការបកប្រែបានចប់សព្វគ្រប់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានផ្លូវច្បាប់គាំទ្រការអះអាងដែលថា កំហុសនីតិវិធីនោះមានផលប៉ះពាល់ដល់ផ្នែកសម្រេចសេចក្ដី សាលក្រម ឬសេចក្ដីសម្រេចនោះឡើយ។ ពុំមានភស្តុតាងបង្ហាញអំពីព្យសនកម្មណាមួយលើ ខៀវ សំផន។ បន្ថែមលើនេះ សាលក្រមមានសំអាងហេតុ និងស្របច្បាប់ដែលអាចប្ដឹងសាទុក្ខបាននោះត្រូវបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ជាលក្ខណៈសង្ខេប ហើយសាលក្រមមានសំអាងហេតុពេញលេញត្រូវបានចែកចាយ និងបោះពុម្ពផ្សាយនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩។ សិទ្ធិរបស់គាត់ក្នុងការពិនិត្យលើសេចក្ដីសម្រេចដែលជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាព និងការដាក់ទោសលើរូបគាត់ នៅតែមានសុពលភាពទាំងស្រុង បន្ទាប់ពីការចែកចាយ និងបោះពុម្ពផ្សាយសាលក្រមពេញលេញនោះ ដូចបានបង្ហាញតាមរយៈការជំនុំជម្រះបច្ចុប្បន្នលើបណ្ដឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនេះ។

80. ជាសរុប ខៀវ សំផន ពុំបានបង្ហាញថា ការចេញសេចក្ដីសង្ខេបក្នុងសវនាការសាធារណៈ គឺជាការចេញសាលក្រមដែលគ្មានសុពលភាព ដោយសារកំហុសផ្នែកនីតិវិធីនោះឡើយ។ ដោយហេតុថា អំណះអំណាងជាចម្បងរបស់ ខៀវ សំផន មានកំហុស ដូច្នេះពុំចាំបាច់ត្រូវពិនិត្យលើអំណះអំណាងដទៃទៀតដែលបានផ្អែក

[190] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦២។

ទៅលើនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងពុំមែនជាកំហុសធ្ងន់ធ្ងរ ដែលបណ្តាលឱ្យសាលក្រមមោឃៈ និងគ្មានសុពលភាពដោយសារកំហុសផ្នែកនីតិវិធីនេះឡើយ។ សារណាសំខាន់ជាងគេនេះរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## V. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

81. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងយ៉ាងខ្លាំងប្រឆាំងនឹងរូបគាត់ និងបានរំលោភបំពានជារឿយៗលើសិទ្ធិជាមូលដ្ឋានរបស់គាត់ ដែលធ្វើឱ្យការជំនុំជម្រះទាំងមូលពុំត្រឹមត្រូវ និងតម្រូវអង្គជំនុំជម្រះតុលាការកំពូលបដិសេធការដាក់ពិរុទ្ធភាព និងទោសរបស់គាត់[191]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិនិត្យពិច័យដោយឥតលម្អៀងទៅលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងជាង ៤០ ឆ្នាំកន្លងផុតទៅនៃអំឡុងពេលដ៏ឈឺចាប់ និងស្មុគស្មាញនៃប្រវត្តិសាស្ត្រកម្ពុជា និងខកខានក្នុងការអនុវត្តច្បាប់ដែលមានអានុភាពនៅពេលនោះ[192]។

82. ក្នុងការគាំទ្រទឡ្ហីករណ៍បន្តបន្ទាប់នៃបណ្តឹងសាទុក្ខដែលជំទាស់ទៅនឹងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះត្រឹមត្រូវ និងឥតលម្អៀង ខៀវ សំផន បានលើកមូលដ្ឋានដូចគ្នានេះនៅក្នុងសារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ ដែលថា "ផ្ទុយទៅនឹងអ្វីដែលចៅក្រមយុត្តិធម៌ និងសមហេតុផលបានធ្វើ អង្គជំនុំជម្រះសាលាដំបូងបានសន្មតថា ខៀវ សំផន មានពិរុទ្ធ និងក្រោយមកបានជ្រើសរើសដាក់ដោយឡែក និងបានបំភ្លៃភស្តុតាងដើម្បីបញ្ជាក់អះអាងការកំណត់ពីដំបូងរបស់ខ្លួន"[193]។ គាត់បានបកស្រាយលម្អិតថា "ដើម្បីបង្កើតការយល់ឃើញអំពីទោស និងពិរុទ្ធភាព វិធីសាស្ត្រអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង គឺដូចគ្នានៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១" តាមរយៈ"ការរំលោភបំពានជាប្រព័ន្ធលើគោលការណ៍នីត្យានុកូលភាពដោយពុំអើពើលើច្បាប់ដែលអាចអនុវត្តបាននៅពេលពាក់ព័ន្ធនោះ [...] ជាពិសេសក្នុងការកំណត់និយមន័យបទឧក្រិដ្ឋដែលបានចោទប្រកាន់ ការអនុវត្តន៍ច្បាប់ និងដំណើរការនីតិវិធីពុំ

---

[191] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧, ៣៣២-៣៣៣។

[192] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤។

[193] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥ ដកស្រង់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមដែលត្រូវបានប្រកាសក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ F17 ("សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17)") កថាខណ្ឌ ៤។

ត្រឹមត្រូវដែលសូម្បីតែខ្លួនឯងបានកំណត់គោលការណ៍ត្រឹមត្រូវរួចហើយ និងដោយផ្ទុយទៅនឹងកាតព្វកិច្ចនៃភាពឥតលម្អៀង បានធ្វើការបកស្រាយអង្គហេតុក្នុងលក្ខណៈជាការដាក់បន្ទុកជាដរាប”[194]។

83. ការចោទប្រកាន់អំពីភាពលម្អៀងបានពន្លាតបន្ថែមទៀតដល់ការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះពីរដាច់ដោយឡែកពីគ្នា រួមមាន៖ ការជំនុំជម្រះពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ និងការខកខានរបស់អង្គជំនុំជម្រះក្នុងការដោះស្រាយការចោទប្រកាន់របស់គាត់អំពីភាពលម្អៀងដែលត្រូវបានលើកឡើងនៅពេលជំនុំជម្រះ, កង្វះការជូនដំណឹងដែលផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលធ្វើការកែប្រែប្រភេទបទល្មើសក្នុងសំណុំរឿង ០០២/០២ ដែលបានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនដំណឹងអំពីបទចោទនោះមកលើរូបគាត់[195], ការគូសបង្ហាញពុំច្បាស់លាស់អំពីបទចោទក្នុងសំណុំរឿង ០០២/០២ បានបណ្តាលឱ្យ ខៀវ សំផន ត្រូវទទួលការដាក់ពិរុទ្ធភាពពីរដងចំពោះបទល្មើសតែមួយ[196], ការផ្ទេរការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពីសំណុំរឿង ០០២/០១ ចូលមកក្នុងសំណុំរឿង ០០២/០២, និងការសំអាងរបស់អង្គជំនុំជម្រះទៅលើភស្តុតាងដែលពុំត្រូវបានសួរដេញដោលក្នុងសំណុំរឿង ០០២/០២[197]។

84. ទាក់ទងទៅនឹងការចោទប្រកាន់អំពីភាពលម្អៀង ភាគីត្រូវប្រឈមនឹងបន្ទុកខ្ពស់ក្នុងការបង្ហាញភស្តុតាងដើម្បីជំទាស់ចំពោះចេតនា... 

ដើម្បីជំរុញចិត្តសច្ចធារណ៍ឥតលម្អៀងរបស់ចៅក្រម និងត្រូវផ្តល់ភស្តុតាងគួរជឿជាក់ថា ផ្នត់គំនិតចៅក្រមមាន ឬអាចមានជាប់ពាក់ព័ន្ធទៅនឹងទំនោរចិត្តទុកជាមុន ក្នុងការដោះស្រាយបញ្ហានានានៅចំពោះមុខខ្លួនក្នុងលក្ខណៈបុរេវិនិច្ឆ័យ[198]។ ការពិនិត្យនេះជាចម្បងពុំមែនសំដៅលើការបង្ហាញថា តើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណានោះទេ ប៉ុន្តែថាតើ សំអាងហេតុរបស់អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញកង្វះអនាគតិ ដែរ ឬយ៉ាងណា[199]។ ក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ទាំងមូល ខៀវ សំផន បានលើក

[194] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦។

[195] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥-១៥៧។

[196] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤។

[197] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨-១៦៧។

[198] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១២។

[199] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១២។ *សូមមើល* សំអាងហេតុបន្ថែមសម្រាប់សេចក្តីសម្រេចស្តីពីសំណើសុំជំទាស់ចៅក្រម ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ឯកសារលេខ E314/12/1 (“សេចក្តីសម្រេចលើបណ្តឹងជំទាស់ (E314/12/1)”) កថាខណ្ឌ ៣៦។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសំណើរបស់ អៀង ធីរិទ្ធ សុំជំទាស់ចៅក្រម សោម សិរីវឌ្ឍ សម្រាប់

ការចោទប្រកាន់ទូទៅជាច្រើនអំពីភាពលម្អៀងដែលពុំបានបំពេញតាមលក្ខខណ្ឌតម្រូវកម្រិតខ្ពស់ក្នុងការជំរុញចិត្តសច្ចធារណ៍ឥតលម្អៀងរបស់ចៅក្រម និងពុំមានមូលដ្ឋានគ្រប់គ្រាន់គាំទ្រដែលបង្ហាញអំពីកំហុសអង្គច្បាប់ ឬអង្គហេតុដែលជាឆន្ទានុសិទ្ធិ។ ក្នុងករណីដែលលក្ខខណ្ឌតម្រូវពុំត្រូវបានបំពេញ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ពិចារណាលើទឡ្ហីករណ៍នេះបន្ថែមទៀតទេក្នុងបរិបទនៃការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ទឡ្ហីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខបានលើកសារណាពីមុនដដែលៗ ក្នុងការជំទាស់ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ និង ០០២/០២ ព្រមទាំងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងដែលមានលក្ខណៈរួមគ្នាក្នុងការជំនុំជម្រះទាំងពីរ។ នេះពុំមែនជាបញ្ហាថ្មីនោះទេ និងត្រូវបានដោះស្រាយពេញលេញដោយក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានជ្រើសតាំងជាពិសេស និងដាក់ឱ្យស្ថិតក្រោមការតវ៉ាយ៉ាងទូលំទូលាយមុនពេលសេចក្តីសម្រេចស្តាពរត្រូវបានធ្វើឡើង។ បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខអនុវត្តចំពោះអំណះអំណាងដែលបានកំណត់ និងផ្តល់មូលដ្ឋានគាំទ្រកំហុសដែលអាចប្តឹងសាទុក្ខបាន។ ការដែលខកខានក្នុងការបំពេញតាមបទដ្ឋានតម្រូវនោះ ដូចជាការលើកច្រំដែលនូវអំណះអំណាងដែលពុំទទួលបានជោគជ័យកន្លងមក ត្រូវបដិសេធចោលភ្លាមៗដោយពុំចាំបាច់ពិនិត្យបន្ថែមទៀតឡើយ។

85. ខៀវ សំផន បានអះអាងថា ផលប៉ះពាល់បូកបញ្ចូលគ្នានៃការរំលោភបំពាន និងកំហុស បានបណ្តាលឱ្យការជំនុំជម្រះពុំមានភាពយុត្តិធម៌ និងបានស្នើសុំការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលឱ្យបដិសេធការដាក់ពិរុទ្ធភាព និងការដាក់ទោសមកលើរូបគាត់។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្តីបារម្ភចម្បងរបស់តុលាការគឺត្រូវវាយតម្លៃភាពត្រឹមត្រូវជារួមនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ផលប៉ះពាល់ត្រួតគ្នានៃការរំលោភបំពានលើការជំនុំជម្រះត្រឹមត្រូវ ត្រូវតែជាការរំលោភបំពានធ្ងន់ធ្ងរ និងខុសប្លែកពីធម្មតា ហើយការអនុវត្តន៍តាមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះត្រឹមត្រូវត្រូវតែពិនិត្យតាមករណីជាក់ស្តែងនៃរឿងក្តីនីមួយៗ ដោយពិចារណាលើការវិវឌ្ឍន៍នៃកិច្ចដំណើរការនីតិវិធីទាំងមូល ជាជាងផ្អែកលើមូលដ្ឋាននៃការពិចារណាដាច់ដោយឡែកលើទិដ្ឋភាពជាក់លាក់មួយ ឬហេតុការណ៍ជាក់លាក់មួយនោះ។ ការពិចារណាដ៏សំខាន់សម្រាប់អង្គជំនុំជម្រះតុលាការកំពូល គឺត្រូវវាយតម្លៃលើវិធានការនានាដែលត្រូវបានអនុវត្តឡើង

---

ការកង្វះឯករាជភាព ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ 1/4 កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ ខៀវ សំផន (១១) កថាខណ្ឌ ១០១។

ដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់សំណងដល់ការរំលោភបំពានណាមួយដែលបានកើតឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។

## ក. គោលការណ៍នីត្យានុកូលភាព

86. នីត្យានុកូលភាពគឺមូលដ្ឋានគ្រឹះសម្រាប់សាលក្រមសុពលភាព និងការផ្តល់ធម្មានុរូបនៃការដាក់ពិរុទ្ធភាពទាំងអស់។ ដោយស្របជាមួយនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីនូវការបកស្រាយរបស់ខ្លួនអំពីគោលការណ៍នីត្យានុកូលភាពនេះ។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិ និងរបស់កម្ពុជាដែលជាប់ពាក់ព័ន្ធទៅនឹងគោលការណ៍ទូទៅស្តីពីភាព*គ្មានទោសបើគ្មានច្បាប់ចែង* និង*គ្មានបទល្មើសបើគ្មានច្បាប់ចែង* តម្រូវថា ច្បាប់ដែលបញ្ញត្តិអំពីបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវតែច្បាស់លាស់ ប្រាកដប្រជា និងគ្មានលក្ខណៈប្រតិសកម្ម[200]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា បរិបទជាក់លាក់របស់ អ.វ.ត.ក. តម្រូវថា បទល្មើស និងការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នោះត្រូវបានទទួលស្គាល់ស្របតាមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ រួមទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ ដែលមានអត្ថិភាពក្នុងអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ និងអាចដឹងគ្រប់គ្រាន់ជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែង[201]។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តតាមការបញ្ជាក់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដែលថា បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវត្រូវតែអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស"ក្នុងន័យទូទៅ"ដោយផ្អែកលើ"ការវិភាគជាសត្យានុម័ត"[202]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណានានារបស់ ខៀវ សំផន ដែលបានលើកឡើងនៅពេលជំនុំជម្រះដោយជំទាស់ទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីគោលការណ៍នីត្យានុកូលភាពក្នុងសំណុំរឿង ០០២/០១[203]។

---

[200] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១ យោងទៅលើសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៩១។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313)") កថាខណ្ឌ ១៦។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦១។

[201] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១, ២៧។

[202] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦១។

[203] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២-២៣។

87. នៅបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា ដោយផ្អែកលើវិធីសាស្ត្រពុំត្រឹមត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យត្រឹមត្រូវផ្នែកច្បាប់ដែលគួរបង្ហាញអំពីការអនុវត្តខ្ជាប់ខ្ជួនតាមគោលការណ៍នីត្យានុកូលភាព[204]។ គាត់បានជំទាស់ជាពិសេសថា អង្គជំនុំជម្រះសាលាដំបូង៖ (១) បានបំភ្លៃគោលបំណងនៃគោលការណ៍នេះ ដែលតម្រូវឱ្យមានការដឹងជាមុនថាមានច្បាប់ចែង និងជាបទល្មើសក្នុងអត្ថន័យនៃការកំណត់និយមន័យបច្ចេកទេសលើបទល្មើសនៅពេលពាក់ព័ន្ធនោះ រួមទាំងលក្ខណៈជាក់លាក់ដែលបទឧក្រិដ្ឋអាចដាក់ទោសបាន[205] (២) បានផ្តល់សំអាងហេតុពុំត្រឹមត្រូវពាក់ព័ន្ធទៅនឹងអំពើរបស់ជនជាប់ចោទជាជាងលក្ខខណ្ឌតម្រូវនៃច្បាប់ដោយផ្ទុយទៅនឹងរឿងក្តីយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[206] និង (៣) បានធ្វើការពិនិត្យដោយត្រួសៗលើលក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងដែលតម្រូវឱ្យធ្វើការពិចារណា"ដោយហ្មត់ចត់សម្រាប់ជនជាប់ចោទនីមួយៗជាលក្ខណៈបុគ្គល"[207]។

88. ពាក់ព័ន្ធបញ្ហានេះ ខៀវ សំផន បានបញ្ជាក់សាជាថ្មីថា ប្រព័ន្ធច្បាប់កម្ពុជាគឺជាប្រព័ន្ធទ្វិកនិយមដែលរារាំងយ៉ាងប្រសិទ្ធិភាពនូវការអនុវត្តន៍បទដ្ឋានអន្តរជាតិផ្ទាល់ទៅលើច្បាប់ក្នុងស្រុក។ អាស្រ័យហេតុនេះ ប្រជាជនកម្ពុជាក្នុងទសវត្សរ៍ ១៩៧០ ត្រឹមតែអាចរំពឹងនូវការអនុវត្តន៍ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ប៉ុណ្ណោះដែលពុំបានរួមបញ្ចូលបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមរហូតដល់ឆ្នាំ ២០០៩[208]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា ការប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិកាលពី ៤០ ឆ្នាំមុន មានហានិភ័យជាក់លាក់ និងជាពិសេសដោយសារមានការបកស្រាយប្រាសចាកគ្នាក្នុងចំណោមចៅក្រមអាជីពរបស់ស្ថាប័នច្បាប់ដែលប្រែប្រួលឥតឈប់ឈរ ដែលនេះពុំអាចសន្និដ្ឋានបានថាប្រជាជនកម្ពុជាក្នុងទសវត្សរ៍ ១៩៧០ បានដឹងច្បាស់លាស់គ្រប់គ្រាន់នូវអំពើសកម្ម ឬអកម្មអ្វីខ្លះដែលនាំឱ្យខ្លួនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[209]។

---

[204] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥០-៥៧៤។

[205] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥១-៥៥៧។

[206] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥១, ៥៥៨-៥៦៥ យោងទៅលើរឿងក្តី *Vasiliauska ទល់នឹង Lithuania* អង្គជំនុំជម្រះនៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECtHR") សំណើសុំលេខ 35343/05 សាលក្រមថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៥ ("សាលក្រមរឿងក្តី *Vasiliauska ទល់នឹង Lithuania* (ECtHR)") កថាខណ្ឌ ១៦៧-១៨៦, ១៩១។

[207] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥១,៥៦៦-៥៧៤។

[208] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៦៨។

[209] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៦៩-៥៧១។

89. សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសនៅក្នុងការបញ្ជាក់ ឬការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូងតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព[210]។

90. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំណះអំណាងភាគច្រើនរបស់ ខៀវ សំផន គឺជាការលើកសាឡើងវិញនូវសារណាដែលបានលើករួចមកហើយ និងត្រូវបានពិចារណាក្នុងសំណុំរឿង ០០២/០១ និងចុងក្រោយត្រូវបានបដិសេធចោល ដោយអង្គជំនុំជម្រះសាលាដំបូង និងដោយអង្គជំនុំជម្រះតុលាការកំពូល។ ក្នុងចំណោមអំណះអំណាងដែល ខៀវ សំផន បានបញ្ជាក់សាជាថ្មី និងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូលមានដូចតទៅ៖ ភាពអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែង តម្រូវឱ្យមានការយោងទៅលើបទប្បញ្ញត្តិជាក់លាក់ដែលចែងអំពីការកំណត់និយមន័យបច្ចេកទេសនៃបទល្មើស និងការប្រកាសទោស[211] និងលក្ខណៈវិនិច្ឆ័យនៃភាពអាចដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើស ពុំអាចត្រូវបានបំពេញត្រឹមតែតាមរយៈការដែលថា បទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវមានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ប៉ុណ្ណោះនោះទេ[212] និងប្រព័ន្ធច្បាប់ទ្វិកនិយមក្នុងកម្ពុជាមានន័យថា ដោយសារនត្ថិភាពការអនុវត្តន៍ក្នុងស្រុក ពុំមានបទដ្ឋានអន្តរជាតិណាមួយជាផ្នែកនៃច្បាប់កម្ពុជា[213] និងការកំណត់និយមន័យបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ រួមបញ្ចូលនូវធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង ពុំអាចដឹងជាមុនបានថា ជាបទល្មើស ឬមានច្បាប់ចែងក្នុងឆ្នាំ ១៩៧៥[214]។

91. ពុំមានអំណះអំណាងថ្មីត្រូវបានបង្ហាញដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ ក្នុងការអនុវត្តខុសពីយុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ ស្តីពីគោលការណ៍នីត្យានុកូលភាព និងខុសពីវិធីសាស្ត្រដ៏ស៊ីសង្វាក់គ្នានៅ អ.វ.ត.ក. ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រកាន់ខ្ជាប់ក្នុងរឿងក្តីបច្ចុប្បន្ន។ ចំណុចនេះមានលក្ខណៈគ្រប់គ្រាន់ខ្លួនឯងសម្រាប់ការបដិសេធចោលទាំងស្រុងនូវការជំទាស់នៃបណ្តឹងសាទុក្ខនេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវយុត្តិសាស្ត្រទាំងពីរក្នុងសំណុំរឿង ០០១ និង ០០២/០១ ព្រមទាំងយុត្តិសាស្ត្រដទៃទៀត ដូចជា របស់តុលាការ ICTY ដែលថា ជនជាប់ចោទប្រាកដជាអាចយល់ដឹងថា អំពើនោះគឺជា

---

[210] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩-៣៧។

[211] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦២។

[212] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦២។

[213] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៥៩, ៧៦៣។

[214] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៥៩, ៧៦៤។

បទល្មើសក្នុងន័យទូទៅដោយពុំចាំបាច់យោងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ[215]។ ការបកស្រាយអំពីគោលការណ៍នីត្យានុកូលភាពថ្មីៗនេះបានប្រើប្រាស់ជាវិធីសាស្ត្រដោយអង្គជំនុំជម្រះឯកទេសនៅកូសូវ៉ូ ("KSC") ដែលក្នុងនោះក្រុមប្រឹក្សាអង្គជំនុំជម្រះឧទ្ធរណ៍ បានគាំទ្រយ៉ាងច្បាស់លាស់នូវការយល់ឃើញនីមួយៗរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០១[216]។ ប្រហាក់ប្រហែលគ្នានេះដែរ ចៅក្រមអង្គបុរេជំនុំជម្រះនៅ KSC ដើម្បីវាយតម្លៃលើគោលការណ៍នីត្យានុកូលភាពទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ និងបន្ទាប់ពីបានបញ្ជាក់សាជាថ្មីថា ជនជាប់ចោទប្រាកដជាអាចយល់ដឹងថា អំពើរបស់ខ្លួនគឺជាបទល្មើស ដោយពុំចាំបាច់យោងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយ បានសន្និដ្ឋានថា ពុំមានលក្ខខណ្ឌតម្រូវឱ្យបង្ហាញបទប្បញ្ញត្តិដែលប្រើប្រាស់ពាក្យពេចន៍ដូចគ្នានៅពេលបញ្ជាក់អំពីភាពអាចដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើសនូវទម្រង់នៃការទទួលខុសត្រូវនីមួយៗឡើយ[217]។

92. ការបកស្រាយខាងលើពុំបានច្រានចោលលក្ខខណ្ឌតម្រូវដែលថា បទឧក្រិដ្ឋត្រូវតែបានបញ្ជាក់ច្បាស់លាស់ក្នុងច្បាប់នោះឡើយ។ ការយល់ដឹងថា "ច្បាប់"មានច្បាប់ជាតិ ឬអន្តរជាតិ និងពន្លាតដល់ច្បាប់ជាលាយលក្ខណ៍អក្សរ និងគ្មានជាលាយលក្ខណ៍អក្សរ ត្រូវបានឆ្លុះបញ្ចាំងក្នុងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ("ECtHR") ដោយបានរួមបញ្ចូលនៅក្នុងរឿងក្ដី *Vasiliauskas ទល់នឹង Lithuania* ដែលត្រូវបានយោងទៅលើដោយ ខៀវ សំផន[218] និងត្រូវបានពង្រឹងបន្ថែមដោយតុលាការ ICTY, អ.វ.ត.ក. និងថ្មីៗ

---

[215] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៩០។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦២។ រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និង Kubura* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-47-AR72 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងយុត្តាធិការពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៤។

[216] ក្រុមប្រឹក្សានៃអង្គជំនុំជម្រះឧទ្ធរណ៍ (អង្គជំនុំជម្រះឯកទេសនៅកូសូវ៉ូ) ("KSC") សំណុំរឿងលេខ KSC-BC-2020-06 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹង"សេចក្ដីសម្រេចលើសំណើដែលជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះពិសេស"ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ ("សេចក្ដីសម្រេចលើសំណើស្ដីពីយុត្តាធិការ (KSC)") កថាខណ្ឌ ២១២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188)") កថាខណ្ឌ ៣១។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៦០។

[217] រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Thaçi និងជនជាប់ចោទដទៃទៀត* ចៅក្រមអង្គបុរេជំនុំជម្រះឯកទេស (KSC) សំណុំរឿងលេខ KSC-BC-2020-06 សេចក្ដីសម្រេចលើសំណើជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ ("សេចក្ដីសម្រេចរឿងក្ដី*Thaçi និងជនជាប់ចោទដទៃទៀត* (KSC)") កថាខណ្ឌ ១៩៣។

[218] សាលក្រមរឿងក្ដី *Vasiliauskas ទល់នឹង Lithuania* (ECtHR) កថាខណ្ឌ ១៥៤។ រឿងក្ដី *S. W. ទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សំណើសុំលេខ 20166/92 សាលក្រម ថ្ងៃទី ២២ វិច្ឆិកា ឆ្នាំ ១៩៩៥ ("សាលក្រមរឿងក្ដី *S. W. ទល់នឹង ចក្រ*

នេះដោយតុលាការ KSC។ ក្នុងបរិបទនៃច្បាប់អន្តរជាតិ ជាឧទាហរណ៍ ក្រុមប្រឹក្សាអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ KSC បានយល់ស្របតាមជំហរដែលបានបង្កើតឡើងក្នុងសំណុំរឿង ០០១ ដែលថា ការវាយតម្លៃអំពីភាពអាចដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើស គប្បីពិចារណាលើលក្ខណៈពិសេសនៃច្បាប់អន្តរជាតិ រួមទាំងការសំអាងទៅលើទំនៀមទម្លាប់ដែលគ្មានជាលាយលក្ខណ៍អក្សរ និងថា ការដឹងជាមុនថា ជាបទល្មើស អាចត្រូវបានបង្ហាញតាមរយៈអត្ថិភាពនៃសន្ធិសញ្ញាជាធរមាន ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធនោះ[219]។ ប្រហាក់ប្រហែលគ្នានេះដែរ ចៅក្រមអង្គបុរេជំនុំជម្រះនៅតុលាការ KSC បានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អាចត្រូវបានបង្ហាញក្នុងច្បាប់ដែលគ្មានជាលាយលក្ខណ៍អក្សរ និងក្នុងរឿងក្ដីយុត្តិសាស្ត្រ[220] និងបានរំឭកនូវការយល់ឃើញរបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុងរឿងក្ដី *Milutinović និងជនដទៃទៀត* ដែលបានបញ្ជាក់ថា ដោយសារច្បាប់ទំនៀមទម្លាប់ជានិច្ចកាលពុំត្រូវបានបង្ហាញក្នុងច្បាប់ជាលាយលក្ខណ៍អក្សរ ភាពអាចដឹងជាមុនថា ជាបទល្មើស អាចពុំមានលក្ខណៈត្រង់ៗដូចជាអត្ថិភាពនៃក្រមព្រហ្មទណ្ឌអន្តរជាតិ[221]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានទទួលស្គាល់ថា វិធានស្ដីពីច្បាប់ទំនៀមទម្លាប់អាចផ្ដល់ការបំភ្លឺគ្រប់គ្រាន់ដល់បុគ្គលណាមួយទាក់ទងទៅនឹងបទដ្ឋាននៃការរំលោភបំពានដែលអាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[222] ជាពិសេស នៅពេលបទឧក្រិដ្ឋដែលរងការចោទប្រកាន់នោះមានលក្ខណៈគួរឱ្យរន្ធត់ ដែលអាចដើរតួនាទីក្នុងការកំណត់ថាតើ ជនជាប់ចោទបានដឹងអំពីលក្ខណៈល្មើសនៃអំពើរបស់ខ្លួន ដែរ ឬយ៉ាងណា[223]។ ការបំភ្លឺនេះកន្លងមកត្រូវបានអនុម័តដោយអង្គជំនុំ

---

*ភពអង់គ្លេស* (ECtHR)") កថាខណ្ឌ ៣៥។ រឿងក្ដី *Cantoni ទល់នឹង ប្រទេសបារាំង* តុលាការ ECtHR សំណើសុំលេខ 17862/91 សាលក្រមថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៩។

[219] សេចក្ដីសម្រេចលើសំណើជំទាស់នឹងយុត្តាធិការ (KSC) កថាខណ្ឌ ២១២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០១ (E188) កថាខណ្ឌ ៣១។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៦០។

[220] សេចក្ដីសម្រេចរឿងក្ដី *Thaçi និងជនជាប់ចោទដទៃទៀត* (KSC) កថាខណ្ឌ ១៩៣។

[221] រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Milutinović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-00-37-AR72 សេចក្ដីសម្រេចលើសំណើរបស់ Dragoljub *Ojdanić* ដែលជំទាស់ទៅនឹងយុត្តាធិការ សហឧក្រិដ្ឋកម្មរួម ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ("សេចក្ដីសម្រេចរឿងក្ដី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ៤១។

[222] សេចក្ដីសម្រេចក្នុងរឿងក្ដី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៤១។

[223] សេចក្ដីសម្រេចក្នុងរឿងក្ដី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៤២។

ជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[224] និងចុងក្រោយត្រូវបានបញ្ជាក់ដោយចៅក្រមអង្គបុរេជំនុំជម្រះនៅតុលាការ KSC[225]។

93. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ដូចគ្នាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញថា ជាឧក្រិដ្ឋកម្មអន្តរជាតិក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. និងថា ធាតុផ្សំតាមបរិបទ ត្រូវបានចែងក្នុងលិខិតុបករណ៍ក្នុងស្រុក និងអន្តរជាតិច្រើននៅក្រោយសង្គ្រាមលោកលើកទីពីរ និងបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥[226]។ ការផ្ដល់សច្ចាប័នរបស់កម្ពុជាលើអនុញ្ញាទីក្រុងហ្សឺណែវទាំងបួននៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៥៨ បានធ្វើឱ្យមានការហាមឃាត់នូវការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទាំងបួននោះ ព្រមទាំងធាតុផ្សំតាមបរិបទ ច្បាប់ជាធរមាន និងការចងកាតព្វកិច្ចលើកម្ពុជា។ ប្រហាក់ប្រហែលគ្នានេះការទទួលស្គាល់ជាផ្លូវការរបស់កម្ពុជានូវអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៥០ បានធ្វើឱ្យមានការហាមឃាត់នូវអំពើប្រល័យពូជសាសន៍ដែលអាចអនុវត្តបាន និងចងកាតព្វកិច្ចលើកម្ពុជា។ បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមរួមទាំងធាតុផ្សំនោះមានអត្ថិភាពដែល ខៀវ សំផន អាចដឹងជាមុនបានគ្រប់គ្រាន់ថា មានច្បាប់ចែង និងជាបទល្មើស ក្នុងនាមជាសមាជិកនៃរដ្ឋអំណាចគ្រប់គ្រងកម្ពុជាចាប់តាំងពីឆ្នាំ ១៩៧៥។

94. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការជំទាស់នៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងគោលការណ៍នីត្យានុកូលភាព ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ និងត្រូវបដិសេធចោលទាំងស្រុង។

## ខ. ការកែប្រែប្រភេទគតិយុត្តនៃបទចោទ

95. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រផ្ទាល់របស់ អ.វ.ត.ក. អង្គជំនុំជម្រះអាចកែប្រែការកំណត់ប្រភេទបទល្មើសនៃអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយបានគ្រប់ពេល"រហូតដល់មានសាលក្រម និងរួមទាំងនៅក្នុងសាលក្រមផងដែរ"[227]។ នេះត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ រួមទាំងការដែលអង្គជំនុំជម្រះសាលាដំបូង

[224] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦២។

[225] សេចក្ដីសម្រេចក្នុងរឿងក្ដី *Thaçi និងជនជាប់ចោទដទៃទៀត* (KSC) កថាខណ្ឌ ១៩២។

[226] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦៤ (ការយោងលុបចោល)។

[227] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៣។

"អនុវត្តក្នុងវិសាលភាពនៃអង្គហេតុដែលបានកំណត់ក្នុងដីកាដំណោះស្រាយ" និងថា ជនជាប់ចោទ"ត្រូវតែទទួលបានការជូនដំណឹងអំពីការកែប្រែប្រភេទគតិយុត្តនោះ"[228]។ អង្គជំនុំជម្រះសាលាដំបូងជាពិសេសបានពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះអាចកែប្រែប្រភេទគតិយុត្តពីបទសម្លាប់រង្គាលទៅបទមនុស្សឃាតជាពិសេសដោយចេតនាប្រយោល នូវអង្គហេតុក្នុងដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងការស្លាប់ប្រជាជនក្នុងទ្រង់ទ្រាយធំនៅតាមទីតាំងឧក្រិដ្ឋកម្មដោយសារលក្ខខណ្ឌនៃការរស់នៅ និងធ្វើការដែលបានដាក់លើពួកគេដែរ ឬយ៉ាងណា[229]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដែលថា អង្គហេតុមួយចំនួនដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយអាចត្រូវបានកែប្រែពីបទសម្លាប់រង្គាលទៅជាបទមនុស្សឃាតដោយចេតនាប្រយោល "ត្រូវបានជូនដំណឹងដល់ភាគីដោយប្រសិទ្ធភាពនៅខែ វិច្ឆិកា ឆ្នាំ ២០១៦" អំពីលទ្ធភាពនៃការកែប្រែប្រភេទគតិយុត្តនឹងកើតមាន[230]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានផងដែរថា ការកែប្រែប្រភេទគតិយុត្តនេះពុំបានរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ[231]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការស្លាប់ដោយសារលក្ខខណ្ឌការងារ និងការរស់នៅនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា ការដ្ឋានទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង(ជារួមហៅ"ទីតាំងទាំងបួន") បានបំពេញតាមលក្ខខណ្ឌនៃធាតុផ្សំសត្យានុម័ត និងអត្តនោម័តិនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយចេតនាប្រយោល និងអាស្រ័យហេតុនេះកែប្រែប្រភេទគតិយុត្តលើអង្គហេតុដែលបានចោទប្រកាន់នោះ[232]។

96. នៅបណ្ដឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងអនុវត្តច្បាប់ពុំត្រឹមត្រូវស្ដីពីការកែប្រែប្រភេទគតិយុត្តនោះ[233]។ ជាពិសេស គាត់បានអះអាងថា ការកែប្រែប្រភេទគតិយុត្តនៃអង្គហេតុដែលបានចោទប្រកាន់ពីការសម្លាប់រង្គាល ទៅជាការធ្វើមនុស្សឃាតដោយចេតនាប្រយោល ស្មើនឹងការបញ្ចូល

---

[228] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៤។

[229] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៤។

[230] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៥-១៥៧ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៦២។

[231] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៧។

[232] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៤-១១៤៥, ១៣៨៨-១៣៩០, ១៦៧២-១៦៧៣, ១៨០៥-១៨០៦។

[233] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥-១៥៧។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ២២ ដល់ ២៧។

ធាតុផ្សំចាំបាច់ថ្មីនៃបទចោទក្នុងដីកាដំណោះស្រាយ ពីព្រោះការសម្លាប់រង្គាល និងអំពើមនុស្សឃាតគឺជាបទឧក្រិដ្ឋពីរដាច់ដោយឡែកពីគ្នាដែលមានធាតុផ្សំចាំបាច់ផ្សេងគ្នា[234]។ ជាលទ្ធផលគាត់ត្រូវប្រឈមទៅនឹងការចោទប្រកាន់ពីបទនៃការសម្លាប់រង្គាល និងពុំអាចមានលទ្ធភាពការពារខ្លួនប្រឆាំងនឹង"ធាតុផ្សំអត្តនោម័តិកម្រិតទាបជាង" ជាពិសេសក្នុងកម្រិតដែលពុំដែលមាននៅក្នុងការកំណត់និយមន័យនៃបទសម្លាប់រង្គាល[235]។ តាមការលើកឡើងរបស់ ខៀវ សំផន បានឱ្យដឹងថា ដូច្នេះ គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទចោទដែលគាត់ពុំត្រូវបានចោទប្រកាន់[236] និងបានអះអាងបន្ថែមទៀតថា ការផ្តល់សំណាងចំពោះផលប៉ះពាល់នៅដំណាក់កាលបណ្តឹងសាទុក្ខ នឹងធ្វើឱ្យគាត់រងព្យសនកម្មដោយសារអង្គជំនុំជម្រះតុលាការកំពូលគឺជាតុលាការចុងក្រោយ[237]។

97. ពាក់ព័ន្ធទៅនឹងកង្វះនៃការជូនដំណឹងដែលរងការជំទាស់ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើទៅនឹង"ភាពខុសគ្នាជាមូលដ្ឋានរវាងសំណុំរឿង ០០២/០១ និង ០០២/០២ បន្ទាប់ពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធី"[238] និងបានអះអាងថា ការកែប្រែប្រភេទគតិយុត្តនៃបទចោទក្នុងរឿងក្តីមួយដោយអង្គជំនុំជម្រះណាមួយ ពុំអាចឱ្យអង្គជំនុំជម្រះសាលាដំបូងរួចផុតពី"កាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងជនជាប់ចោទនូវគោលបំណងរបស់ខ្លួនក្នុងការកែប្រែប្រភេទបទចោទនេះ" ក្នុងរឿងក្តីចំពោះមុខឡើយ[239]។ ទាក់ទងនឹងបញ្ហានេះ ខៀវ សំផន បានលើកឡើងថា ជនជាប់ចោទត្រូវទទួលបានការជូនដំណឹងលម្អិតពេញលេញអំពីបទចោទប្រឆាំងនឹងខ្លួន រួមទាំងការកំណត់ប្រភេទបទចោទដែលតុលាការអាចកែប្រែ និងឱកាសក្នុងការរៀបចំការការពារខ្លួនចំពោះបទចោទថ្មីដោយប្រសិទ្ធភាព និងទាន់ពេល[240]។ ផ្អែកតាមទស្សនៈរបស់ ខៀវ សំផន ថា ឱកាសនេះពុំត្រូវបានផ្តល់ឱ្យគាត់នៅពេលណាមួយឡើយនៅមុនពេលសាលក្រមត្រូវបានប្រកាស ដូច្នេះ ជាការរារាំងមិនឱ្យគាត់មានលទ្ធភាពការពារខ្លួនប្រឆាំងនឹងបទចោទនៃអំពើ

---

[234] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩-១៥២។

[235] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៣។ *សូមមើល* ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ ទំព័រ ២២-២៤, ២៦។

[236] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥-១៥៦។

[237] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ២៧។

[238] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៨។

[239] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៨-១៣៩។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ២៦-២៧។

[240] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០-១៤១។

01717974



មនុស្សឃាតដោយចេតនាប្រយោលដែលត្រូវបានកែប្រែនោះ[241]។ អាស្រ័យហេតុនេះ ខៀវ សំផន បានស្នើឡើងថា ការសម្រេចដាក់ពិរុទ្ធភាពលើគាត់ដែលបានផ្អែកលើការកែប្រែប្រភេទបទចោទនៃការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតដោយចេតនាប្រយោលនោះត្រូវបដិសេធចោល[242]។

98. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកែប្រែប្រភេទគតិយុត្តនៃអង្គហេតុដែលជាមូលដ្ឋាននៃបទសម្លាប់រង្គាល ទៅជាបទមនុស្សឃាតដោយចេតនាប្រយោល[243] និងបានលើកឡើងថា បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា សាលដីកាសំណុំរឿង ០០២/០១ ពុំបានផ្ដល់ដំណឹងគ្រប់គ្រាន់អំពីការកែប្រែប្រភេទបទចោទដែលអាចកើតមានក៏ដោយ ក៏"កំហុសផ្នែកនីតិវិធី"ពុំបានធ្វើឱ្យសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅជាមោឃៈបានឡើយ[244]។ សហមេធាវីនាំមុខគាំទ្រសារណាតបរបស់សហព្រះរាជអាជ្ញា[245]។

99. វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងក្នុងផ្នែកដែលពាក់ព័ន្ធចែងថា "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"[246]។ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យវាយតម្លៃលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តច្បាប់ត្រឹមត្រូវ ដែរ ឬយ៉ាងណា[247]។ ជាការឆ្លើយតប អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិនិត្យលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូល"ធាតុផ្សំថ្មីនៃបទចោទ" ដែរ ឬយ៉ាងណា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងធ្វើការកែប្រែប្រភេទអង្គហេតុពីការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតដោយចេតនាប្រយោលនោះ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលកំណត់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដូច្នោះមែន បញ្ហានៃការជូនដំណឹងដល់ភាគីត្រូវចាត់ទុកជាអសារបង់។

---

[241] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤២-១៤៧, ១៥៣-១៥៤។

[242] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥ និងជើងទំព័រ ១៧៧។

[243] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤-៩១។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៤៣-៤៤។

[244] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦។

[245] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៨-៨៩។

[246] វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ *សូមមើល* វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

[247] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៤, ១៦។

១. ការចោទប្រកាន់អំពីការបញ្ចូលធាតុផ្សំថ្មីនៃបទចោទ

100. ខៀវ សំផន បានលើកឡើងថា ការកែប្រែប្រភេទអង្គហេតុពីការសម្លាប់រង្គាលទៅជាបទឧក្រិដ្ឋនៃអំពើមនុស្សឃាតដោយចេតនាប្រយោល គឺស្មើនឹងការបញ្ចូលធាតុផ្សំថ្មីនៃបទចោទតាមរយៈដំណើរការកែប្រែប្រភេទបទល្មើសនេះ ដោយសារបទឧក្រិដ្ឋពីរនេះមានលក្ខណៈខុសគ្នា[248]។ គាត់បានអះអាងថា ចេតនាប្រយោលពុំមែនជា"ធាតុផ្សំដែលជាប់មកជាមួយ"បទឧក្រិដ្ឋនៃការសម្លាប់រង្គាល ប៉ុន្តែគឺជា"ធាតុផ្សំមកពីខាងក្រៅ និងត្រូវដកចេញពីបទឧក្រិដ្ឋនេះ"[249]។ ការជំទាស់របស់ ខៀវ សំផន គឺផ្តោតជាក់លាក់ទៅលើលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិសម្រាប់បទឧក្រិដ្ឋដែលត្រូវបានកែប្រែ ដែលជាចេតនាប្រយោលសម្រាប់អំពើមនុស្សឃាត និងតាមការអះអាងរបស់គាត់ថា ពុំត្រូវបានជំនួសដោយចេតនាផ្ទាល់ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្លាប់រង្គាលបានឡើយ[250]។

101. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សិទ្ធិអំណាចអង្គជំនុំជម្រះសាលាដំបូងក្នុងការផ្លាស់ប្តូរស្របតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ត្រូវបានកម្រិតត្រឹមអង្គហេតុក្នុងដីកាដំណោះស្រាយ ពុំមែនធាតុផ្សំនៃបទចោទដែលបានរៀបរាប់នៅក្នុងនោះទេ[251]។ ដូច្នេះ បើទោះបីជាដីកាដំណោះស្រាយដែលមានបទចោទនៃការសម្លាប់រង្គាលត្រូវបានពិនិត្យឃើញថា អនុញ្ញាតសម្រាប់តែការសម្លាប់រង្គាល *ដោយចេតនាផ្ទាល់*ប៉ុណ្ណោះក៏ដោយ ក៏ការពិពណ៌នានៃអង្គហេតុដែលជាមូលដ្ឋានក្នុងការកំណត់ប្រភេទបទល្មើសនេះ នៅតែអនុញ្ញាតឱ្យបញ្ចូលលទ្ធភាពនៃការយល់ឃើញអំពី*ចេតនាប្រយោល*ដែរ[252]។ បើទោះបីនេះការពិតដូចការចង្អុលបង្ហាញរបស់ ខៀវ សំផន ថា ក្នុងដីកាដំណោះស្រាយ និងក្នុងអំឡុងពេលភាគច្រើននៃការជំនុំជម្រះ គាត់បានប្រឈមមុខតែបទចោទនៃការសម្លាប់រង្គាលប៉ុណ្ណោះ ជាជាងបទចោទ

---

[248] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩-១៥៤។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ២៣-២៤។

[249] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២។

[250] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ២៣-២៤, ២៥-២៦។

[251] ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដែលថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថា "មិនបញ្ចូលធាតុផ្សំថ្មីនៃបទចោទឡើយ [...] ការកែប្រែបទចោទត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះប៉ុណ្ណោះ"។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០១ កថាខណ្ឌ (E188) ៤៩៤។

[252] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 ("ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427)") កថាខណ្ឌ ១៣៨៨-១៣៨៩។

នៃអំពើមនុស្សឃាតពាក់ព័ន្ធនឹងទីតាំងទាំងបួននោះ[253]ក៏ដោយ ក៏នេះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូល"ធាតុផ្សំថ្មីនៃបទចោទ" ឬអង្គហេតុថ្មីទៅក្នុងរឿងក្តីបច្ចុប្បន្ននេះដែរ។ បញ្ហាគតិយុត្តនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលគឺថាតើ អង្គហេតុនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានគាំទ្របទចោទសក្តានុពល នៃអំពើមនុស្សឃាតដោយចេតនាប្រយោល ជាជាងការសម្លាប់រង្គាលចេតនាផ្ទាល់ ដែរឬយ៉ាងណា។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា អង្គហេតុដែលមានក្នុងដីកាដំណោះស្រាយនោះបានគាំទ្រការយល់ឃើញនៃអំពើមនុស្សឃាតដោយចេតនាប្រយោល ព្រមទាំងការសម្លាប់រង្គាលផងនោះ ការកែប្រែប្រភេទបទល្មើសដោយអង្គជំនុំជម្រះសាលាដំបូងបង្ហាញថាត្រូវត្រឹមតាមច្បាប់។ ម្យ៉ាងវិញទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលអង្គហេតុ ដែលពុំមានអត្ថិភាពក្នុងដីកាដំណោះស្រាយការកែប្រែប្រភេទបទល្មើសពុំត្រឹមត្រូវតាមច្បាប់ឡើយ។

102. ដីកាដំណោះស្រាយបានពិព័ណនាអំពីលក្ខខណ្ឌការងារ និងការរស់នៅ នៅតាមទីតាំងទាំងបួននោះ និងការដឹងអំពីលក្ខខណ្ឌនោះ រួមទាំងការចុះទស្សនកិច្ចរបស់ ខៀវ សំផន ដូចបានអះអាងនៅតាមការដ្ឋានទាំងនោះ[254]។ ដីកាដំណោះស្រាយនេះបានពិព័ណនាផងដែរនូវអត្ថិភាពនៃភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា ខៀវ សំផន "តាមរយៈអំពើសកម្ម និងអកម្មរបស់ខ្លួនបានប្រព្រឹត្ត(តាមរយៈសហឧក្រិដ្ឋកម្មរួម) បង្កើតផែនការ ញុះញង់ បញ្ជា ឬជួយទំនុកបម្រុង ឬដាក់ឱ្យទទួលខុសត្រូវតាមរយៈការទទួលខុសត្រូវជាមេដឹកនាំជាន់ខ្ពស់"សម្រាប់*ក្នុងចំណោមនោះ* ជាពិសេសបទឧក្រិដ្ឋនៃអំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[255]។

103. ជាពិសេស ដីកាដំណោះស្រាយ និងភស្តុតាងបញ្ជាក់ និងក្រោយមកត្រូវបានបង្ហាញក្នុងពេលជំនុំជម្រះ បានពិព័ណនាអំពីទីតាំងទាំងបួននោះថា៖ (១) មានប្រជាជនស្លាប់ដោយសារការខ្វះអាហារ ធ្វើការលើសកម្លាំង ជំងឺ និងខ្វះថ្នាំពេទ្យ[256] (២) ប្រព័ន្ធនៃការផ្តល់របបអាហារចាំបាច់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានដាក់

---

[253] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៦-១៤៧។

[254] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១០-៣១៤, ៣១៨ (សហករណ៍ត្រាំកក់), ៣៥៩-៣៦៣, ៣៦៧ (ការដ្ឋានទំនប់១មករា), ៣៣៦-៣៤៣, ៣៤៧ (ទំនប់ត្រពាំងថ្ម), ៣៨៩, ៣៩១-៣៩២, ៣៩៥ (ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង)។

[255] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៦១៣។

[256] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១១-៣១៤(សហករណ៍ត្រាំកក់), ៣៥៩-៣៦៣, ៣៦៧ (ការដ្ឋានទំនប់១មករា), ៣៣៦-៣៤៣, ៣៤៧ (ទំនប់ត្រពាំងថ្ម), ៣៨៩, ៣៩១-៣៩២, ៣៩៥ (ការដ្ឋានសាងសងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង)។ *សូមមើលផងដែរ* ឧទាហរណ៍ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១១-

កម្រិតរបបអាហារផ្សេងៗគ្នាតាមប្រភេទមនុស្សផ្សេងៗគ្នា និង'ខ្លាំង'បរិមាណតិចតួចផ្តល់ឱ្យអ្នកដែលត្រូវបានចាត់ទុកថាជាពួកប្រតិកិរិយា ត្រូវបានអនុវត្តឡើង[257] (៣) អ្នកធ្វើការត្រូវបានគំរាមកំហែងដករបបអាហារ កាលណាបើពួកគេមិនបានបំពេញតាមផែនការកំណត់[258] និង (៤) អ្នកជំងឺ រួមទាំងនៅតាមមន្ទីរពេទ្យ ត្រូវបានផ្តល់របបអាហារតិចជាង ដោយសារពួកគេមិនបានបង្កបង្កើនផល[259]។

104. បន្ថែមលើនេះ ភស្តុតាងបានបង្ហាញផងដែរថា៖ (១) រចនាសម្ព័ន្ធរាយការណ៍ជាប្រព័ន្ធខ្សែឈរនៅក្នុងលំដាប់ថ្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា មានន័យថា គណៈមជ្ឈិម និងជាពិសេសគណៈអចិន្ត្រៃយ៍បានទទួលព័ត៌មានស្តីពីបញ្ហាដែលប៉ះពាល់ដល់ការរស់នៅរបស់កម្មករ និងកសិករនៅតាមសហករណ៍ និងការដ្ឋានធ្វើការ[260] (២) តួនាទីសំខាន់របស់ ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា មានន័យថា គាត់អាចចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលពេលនោះគាត់ត្រូវបានរាយការណ៍អំពីស្ថានការណ៍ថ្នាក់មូលដ្ឋាន[261] (៣) ខៀវ សំផន ប្រហែលជាបានធ្វើទស្សនកិច្ចតាមទីកន្លែងខ្លះក្នុងចំណោមទីតាំងទាំងបួននោះដោយផ្ទាល់[262] (៤) បើទោះបីជាមានទុរភិក្សពាសពេញប្រទេស បក្សកុម្មុយនីស្តកម្ពុជាបាននាំចេញស្រូវអង្ករក្នុងបរិមាណយ៉ាងច្រើនដើម្បីបង្កើនទុន[263] (៥) កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានដឹងអំពីលក្ខខណ្ឌនៃ

---

១០១២, ១០១៤, ១០១៧-១០២០, ១០៤៥, ១០៤៧ (និងភស្តុតាងមូលដ្ឋានក្នុងជើងទំព័រនីមួយៗ), ១៥៨១-១៦១០, ១៦២៤-១៦២៩ (និងភស្តុតាងមូលដ្ឋានដែលមានក្នុងជើងទំព័រនីមួយៗ) ១២៧០-១២៧៤, ១២៩៧-១៣០៤,១៣២០-១៣២៣, ១៣២៥, ១៣២៧-១៣២៩, ១៣៧៥-១៣៧៦, ១៣៨៤ (និងភស្តុតាងមូលដ្ឋានដែលមានក្នុងជើងទំព័រនីមួយៗ), ១៧៤៧-១៧៥៨ (និងភស្តុតាងមូលដ្ឋានដែលមានក្នុងជើងទំព័រនីមួយៗ)។

[257] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៥-៣០៦, ៣៤៣, ៣៦០, ៣៨៩-៣៩០។ *សូមមើផងដែរ ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០០៩, ១៣០៤, ១៥៥៨ (និងភស្តុតាងមូលដ្ឋានដែលមានក្នុងនោះ)។

[258] *សូមមើល ជាឧទាហរណ៍* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៩៣-១២៩៤។

[259] *សូមមើល ជាឧទាហរណ៍* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៤៧, ១៣២៦។

[260] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤១-៤២, ៧១-៧២, ៣០៧-៣០៩។ *សូមមើផងដែរ ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១២-៣៩១៣។

[261] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤១-៤២, ៤៥, ៣២៨, ៣៨៥, ១១៣២-១១៥២, ១១៦៤-១១៧១។ *សូមមើផងដែរ ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤, ៤២០១, ៤២០៨។

[262] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៣៣, ៣៥៧, ៣៨៨។ *សូមមើលផងដែរ ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣៥-១១៣៧។

[263] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៤។

ការរស់នៅ និងការធ្វើការនៅទីតាំងទាំងបួន[264] និង (៦) កម្មាភិបាលទាំងនេះបានទទួលយកការស្លាប់របស់ប្រជាពលករ និងកសិករដែលជាផលវិបាកនៃការអនុវត្តន៍គោលនយោបាយ'មហាលោតផ្លោះមហាអស្ចារ្យ'[265]។

105. យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គហេតុដែលបានពិពណ៌នាក្នុងដីកាដំណោះស្រាយ នៅពេលវាយតម្លៃត្រួតគ្នាជាមួយនឹងភស្តុតាងដែលបានបង្ហាញក្នុងដីកានោះ និងជាលទ្ធផលត្រូវបានបញ្ជាក់នៅពេលជំនុំជម្រះ បានរួមបញ្ចូលភស្តុតាងនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនៅទីតាំងទាំងបួននោះ ជាជាងភស្តុតាងនៃការសម្លាប់រង្គាលដោយចេតនាផ្ទាល់ប៉ុណ្ណោះទេ។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះបានបញ្ចូលធាតុផ្សំថ្មីនៃបទចោទតាមរយៈការផ្លាស់ប្តូរបទចោទពីការសម្លាប់រង្គាល ទៅជាការធ្វើមនុស្សឃាតដោយចេតនាប្រយោល។

## ២. ការលើកឡើងអំពីកង្វះនៃការជូនដំណឹង

106. អង្គជំនុំជម្រះតុលាការកំពូល ត្រូវពិនិត្យលើការលើកឡើងអំពីកង្វះនៃការជូនដំណឹងស្តីពីការផ្លាស់ប្តូរបទចោទដល់ ខៀវ សំផន។ អង្គជំនុំជម្រះតុលាការកំពូលនៅពុំទាន់បានសម្រេចលើទិដ្ឋភាពនៃការជូនដំណឹងក្នុងករណីនៃការផ្លាស់ប្តូរបទចោទ។ ទាក់ទងនឹងបញ្ហានេះ មានតែនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដែលបានបញ្ជាក់ថា លក្ខខណ្ឌតម្រូវក្នុងការផ្តល់ឱ្យជនជាប់ចោទនូវលទ្ធភាពសម្រាប់ការប្រើប្រាស់សិទ្ធិការពារខ្លួន'ដោយមានប្រសិទ្ធិភាព និងជាពិសេសក្នុងពេលសមស្រប'មានន័យថា ជនជាប់ចោទត្រូវបានជូនដំណឹងអំពីលទ្ធភាពនៃការកែប្រែប្រភេទបទល្មើស និងត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការការពារខ្លួន[266]។

107. ផ្អែកតាមសេចក្តីសម្រេចរបស់តុលាការ ECtHR ដែលអង្គជំនុំជម្រះសាលាដំបូង និង ខៀវ សំផន បានសំអាងទៅលើ មានការបំភ្លឺផងដែរ។ តុលាការនេះបានបញ្ជាក់ច្បាស់លាស់ថា ក្នុងករណីដែលមានការកែប្រែប្រភេទបទចោទ បើទោះបីជានៅពេលដែលតុលាការខ្លួនឯងផ្ទាល់កំពុងធ្វើការពិចារណាក៏ដោយ ក៏ភាគី

---

[264] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩៥០-៩៥១, ៩៥៥, ១១៣៥-១១៣៧, ១៣០៧, ១៣២៣, ១៦៣១, ១៦៣៤, ៣៩១២, ៣៩២០, ៤២០៨។

[265] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៥៦-១៥៩.។ *សូមមើលផងដែរ ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១២, ៤២០៨, ៤២១២, ៤២១៨។

[266] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៩៨, ៥០២ (ក្នុងបរិបទនៃការទទួលខុសត្រូវជាក់លាក់នៃការកែប្រែប្រភេទគតិយុត្តពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលទៅជាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម)។

ត្រូវតែទទួលបានការជូនដំណឹងអំពីយថាភាពនោះដើម្បីឱ្យពួកគេអាចលើកសារណាបានទាន់ពេល និងដោយប្រសិទ្ធិភាព[267]។ សិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ គឺជាទិដ្ឋភាពនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមលក្ខណៈរៀបចំការការពារខ្លួន[268]។ តុលាការអឺរ៉ុបនេះបានបញ្ជាក់បន្ថែមថា ពុំមានលក្ខខណ្ឌតម្រូវពិសេសផ្លូវការទាក់ទងទៅនឹងទម្រង់ដែលជនជាប់ចោទត្រូវទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងខ្លួននោះឡើយ[269]។ ទោះជាយ៉ាងណាក្តី ព័ត៌មានដែលបានផ្តល់នោះត្រូវតែ "ពេញលេញ" និង"លម្អិត" ហើយស្ថានភាពនៃអង្គហេតុនីមួយៗចាំបាច់ត្រូវធ្វើការវាយតម្លៃផ្អែកតាមលក្ខណៈជាក់ស្តែង[270]។ បន្ថែមលើនេះ តុលាការមានករណីយកិច្ចផ្តល់ព័ត៌មានដល់ជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុប្រឆាំងនឹងខ្លួន ព្រមទាំងការកំណត់ប្រភេទគតិយុត្ត[271]។

---

[267] *សូមមើល* រឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* អង្គជំនុំជម្រះតុលាការ ECtHR សំណើសុំលេខ 25444/94 សាលក្រម ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ ("សាលក្រមរឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* (ECtHR)") កថាខណ្ឌ ៥១-៥២។ រឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* ផ្នែកទីពីរនៃតុលាការ ECtHR សំណើសុំលេខ 73529/01 សាលក្រម ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ("សាលក្រមរឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* (ECtHR)") កថាខណ្ឌ ៣២។ រឿងក្តី *Mattei ទល់នឹង ប្រទេសបារាំង* ផ្នែកទីពីរនៃតុលាការ ECtHR សំណើសុំលេខ 34043/02 សាលក្រមថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ("សាលក្រមរឿងក្តី *Mattei ទល់នឹង ប្រទេសបារាំង* (ECtHR)") កថាខណ្ឌ ៣៦។ រឿងក្តី *Mattoccia ទល់នឹងប្រទេសអ៊ីតាលី* អង្គជំនុំជម្រះតុលាការ ECtHR សំណើសុំលេខ 23969/94 សាលក្រមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ("សាលក្រមរឿងក្តី *Mattoccia ទល់នឹងប្រទេសអ៊ីតាលី* (ECtHR)") កថាខណ្ឌ ៦១។

[268] *សូមមើល* សាលក្រមរឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៥១-៥២។ សាលក្រម រឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៣២។ សាលក្រមរឿងក្តី *Mattei ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៣៦។ សាលក្រមរឿងក្តី *Mattoccia ទល់នឹង ប្រទេសអ៊ីតាលី* (ECtHR) កថាខណ្ឌ ៦១។

[269] សាលក្រមរឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៥៣។ សាលក្រមរឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៣២, ៣៦។ សាលក្រម*រឿងក្តី Mattocia ទល់នឹង ប្រទេសអ៊ីតាលី* (ECtHR) កថាខណ្ឌ ៦០។

[270] សាលក្រមរឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៥១-៥៣។ សាលក្រមរឿងក្តី *Mattocia ទល់នឹង ប្រទេសអ៊ីតាលី* (ECtHR) កថាខណ្ឌ ៥៩-៦១។

[271] សាលក្រមរឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៣២, ៣៦។ តុលាការ ECtHR បានបញ្ជាក់ថា ពាក្យថា "ត្រឹមតែការពិត"ដែលថា សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីសំដៅទៅលើបទឧក្រិដ្ឋដែលត្រូវបានកែប្រែប្រភេទគតិយុត្តមានអត្ថិភាពក្នុងសំណុំរឿងរបស់តុលាការ "ពុំអាចគ្រប់គ្រាន់ បំពេញតាមលក្ខខណ្ឌតម្រូវ"នៃមាត្រា ៦(៣)(ក) នៃអនុសញ្ញាសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន *ចូលជាធរមាន* ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៥៣ 213 U.N.T.S. 221 (ECtHR)។ សាលក្រមរឿងក្តី *Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* (ECtHR) កថាខណ្ឌ ៥៥។

108. ក្នុងរឿងក្តីនេះ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការកែប្រែប្រភេទបទចោទត្រូវតែពិនិត្យជារួម។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកសាលដីកានៃសំណុំរឿង ០០២/០១ ស្តីពីបទឧក្រិដ្ឋនៃការសម្លាប់រង្គាល ថាជាការជូនដំណឹងដល់ជនជាប់ចោទក្នុងរឿងក្តីនេះ ដែលបញ្ជាក់ថា រឿងក្តីទាំងពីរមានដីកាដំណោះស្រាយរួមគ្នា មេធាវីការពារក្តីដូចគ្នា និងភាគីដូចគ្នាក៏ដោយ ក៏អង្គជំនុំជម្រះនៅតែបានអញ្ជើញភាគីដាក់សារណាលើផលប៉ះពាល់ ប្រសិនបើមាន នៃសាលដីកានៃសំណុំរឿង ០០២/០១ ក្នុងការបញ្ចប់នៃកិច្ចដំណើរការនីតិវិធីលើភស្តុតាង[272]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការពិសេសពិភាក្សាបញ្ហានេះ និងផ្សេងៗទៀត[273]។ ការកែប្រែប្រភេទអង្គហេតុក្នុងកាលៈទេសៈដូចគ្នានេះក្នុងរឿងក្តីនេះ គឺជាបញ្ហាសំខាន់ផ្នែកច្បាប់ និងភស្តុតាងនៅក្នុងសាលក្រមនោះ។ ដូច្នេះ អាចសន្និដ្ឋានសមហេតុផលថា ការអញ្ជើញឱ្យដាក់សារណាបានរួមបញ្ចូលបញ្ហានៃការកែប្រែប្រភេទអង្គហេតុពីការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតដោយចេតនាប្រយោលសម្រាប់ទីតាំងទាំងបួននោះ។ ដូច្នេះ ក្នុងបរិបទនៃភាគីដូចគ្នាតែមួយ និងដីកាដំណោះស្រាយដដែល ការកែប្រែប្រភេទគតិយុត្តពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូលលើឧក្រិដ្ឋកម្មដដែលនៃការសម្លាប់រង្គាល អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ភាគីត្រូវបានជូនដំណឹងថា ការកែប្រែប្រភេទបទចោទស្រដៀងគ្នានេះនឹងអាចកើតមាន។

### ៣. សេចក្តីសន្និដ្ឋាន

109. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ចូលធាតុផ្សំថ្មីនៃបទចោទទៅក្នុងអង្គហេតុ នៅពេលអង្គជំនុំជម្រះសាលាដំបូងធ្វើការកែប្រែប្រភេទបទឧក្រិដ្ឋនៃការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាតដោយចេតនាប្រយោលនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា មានការជូនដំណឹងគ្រប់គ្រាន់អំពីលទ្ធភាពនៃការកែប្រែប្រភេទបទចោទនោះ។ អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកែប្រែប្រភេទគតិយុត្តនោះ ត្រូវបដិសេធចោល។

## គ. ការចោទប្រកាន់ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង

---

[272] *សូមមើល* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០១ 'សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និង កិច្ចប្រជុំរៀបចំសវនាការ' ឯកសារលេខ E449 (ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦) កថាខណ្ឌ ៣ (សេចក្តីបញ្ជាក់បន្ថែម)។

[273] *សូមមើល* ជាទូទៅកិច្ចប្រជុំរៀបចំសវនាការ ឯកសារលេខ E1/509.1 ទំព័រ ១៥-១៦ (ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦)។

110. ខៀវ សំផន បានលើកការចោទប្រកាន់ជាច្រើនអំពីភាពលម្អៀងដែលកើតចេញពីការជំនុំជម្រះពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ដូចជា ការដែលអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការដោះស្រាយការចោទប្រកាន់របស់គាត់អំពីភាពលម្អៀងដែលត្រូវបានលើកឡើង[274] និងថា ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញតាមរយៈការផ្ទេរដោយស្វ័យប្រវត្តិនូវការយល់ឃើញរបស់ខ្លួន និងភស្តុតាងចេញពីសំណុំរឿង ០០២/០១ ចូលទៅក្នុងសំណុំរឿង ០០២/០២[275]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយការចោទប្រកាន់នេះតាមលំដាប់លំដោយ។

១. ការលើកឡើងអំពីការខកខានដោះស្រាយការចោទប្រកាន់នូវភាពលម្អៀង

111. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសំអាងហេតុពេញលេញ "ដោយសារពុំបានដោះស្រាយ ឬដោះស្រាយពុំបានគ្រប់គ្រាន់នូវការចោទប្រកាន់អំពីភាពលម្អៀង"ដែលកើតចេញពីការជំនុំជម្រះពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១[276]។ គាត់បានអះអាងជាពិសេសថា អង្គជំនុំជម្រះសាលាដំបូង"ពុំបានរំឭក និងពុំបានយោងទៅលើអំណះអំណាងដែលបានលើកឡើងក្នុង"សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់[277] និងបានយោងទៅលើសារណាពីដំបូងរបស់គាត់ស្ដីពីបញ្ហានេះ[278] និងបានជំទាស់ថា បន្ទាប់ពីជំនុំជម្រះលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងពុំអាចថា គ្មានភាពលម្អៀងក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២ នោះទេ[279]។

112. សហព្រះរាជអាជ្ញាបានឆ្លើយតបថា សារណារបស់ ខៀវ សំផន ត្រូវបានលើកឡើងរួចហើយ និងត្រូវបានបដិសេធចោលដោយក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូង និងដូច្នេះលែងជាកម្មវត្ថុនៃ

[274] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧-១២៩។

[275] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧, ១២៩-១៣៣, ១៥៨-១៦៤។

[276] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧។

[277] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧ យោងទៅលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន សំណុំរឿង ០០២/០២ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ កែសម្រួលនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧ ឯកសារលេខ E457/6/4/1 ("សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1)") កថាខណ្ឌ ៦៥១-៦៥៨។

[278] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨ និងការយោងដកស្រង់នៅទីនោះ។

[279] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧-១២៩។

បណ្ដឹងសាទុក្ខតទៅទៀតឡើយ[280]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញា[281]។

113. វិធាន ៣៤ នៃវិធានផ្ទៃក្នុងចែងថា ការចោទប្រកាន់អំពីភាពលម្អៀងរបស់តុលាការត្រូវតែបានដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលពុំមានសមាសភាពចៅក្រមដែលរងការចោទប្រកាន់នោះ។ សំណើផ្លូវការសុំជិតចិត្ត គឺជាលក្ខខណ្ឌដំបូងចំពោះការពិចារណាលើសារណានោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា អង្គជំនុំជម្រះពុំអាចជំនុំជម្រះការចោទប្រកាន់របស់ ខៀវ សំផន អំពីភាពលម្អៀងនៅក្នុងសាលក្រមរបស់ខ្លួនឡើយ[282]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើការចោទប្រកាន់ភាគច្រើនរបស់ ខៀវ សំផន អំពីភាពលម្អៀង ដែលត្រូវបានបដិសេធចោលរួចហើយដោយក្រុមប្រឹក្សាពិសេសរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានជ្រើសតាំងបន្ទាប់ពីការដាក់សំណើរបស់គាត់សុំជិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង ឬក្រៅពីនេះគប្បីត្រូវបានលើកឡើងដោយស្របតាមនីតិវិធីស្ដីពីបណ្ដឹងជិតចិត្តក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុងខាងលើ[283]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបដិសេធការចោទប្រកាន់នានាអំពីភាពលម្អៀង រួមទាំងសារណាដែលថា សាលក្រមសំណុំរឿង ០០២/០១ បានធ្វើបុរេវិនិច្ឆ័យសំណុំរឿង ០០២/០២[284] និងបានបញ្ជាក់ថា៖

បណ្ដឹងជិតចិត្តនោះខកខានក្នុងការបង្ហាញថា អ្នកសង្កេតសមហេតុផលអាចដឹងថា ចៅក្រមនោះប្រហែលជាពុំអាចមានផ្នត់គំនិតឥតលម្អៀងចំពោះសំណុំរឿង ០០២/០២ ពីព្រោះចៅក្រមបានបង្កើតការយល់ឃើញដោយផ្អែកលើភស្តុតាងក្នុងសំណុំរឿង ០០២/០១[285]។

114. ដោយសារអំណះអំណាងដែលបានលើកឡើងក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ត្រឹមតែបង្ហាញការមិនយល់ស្របជាមួយនឹងសេចក្ដីសម្រេចមតិភាគច្រើនរបស់ក្រុមប្រឹក្សាពិសេស និងដោយហេតុថា សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាពិសេសបិទផ្លូវតវ៉ា[286] អង្គជំនុំជម្រះសាលាដំបូងពុំត្រូវ

[280] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ F1/9.1 ទំព័រ ៤១។

[281] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨២។

[282] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣, ១១៥។

[283] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣-១១៥។

[284] សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តចៅក្រម (E314/12/1) កថាខណ្ឌ ៧១-១០៦។

[285] សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តចៅក្រម (E314/12/1) កថាខណ្ឌ ១០៦។

[286] វិធាន ៣៤(៨) នៃវិធានផ្ទៃក្នុង។

ឬអាចដោះស្រាយការចោទប្រកាន់អំពីភាពលម្អៀងនោះបាន និងត្រូវបានប្រកាន់ខ្ជាប់តាមក្របខ័ណ្ឌការងារជាក់លាក់ដែលកំណត់លើការចោទប្រកាន់នេះ។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធមិនដោះស្រាយបន្ថែមទៀតនូវការចោទប្រកាន់អំពីភាពលម្អៀងនោះ។

២. ការចោទប្រកាន់ការផ្ទេរនូវការយល់ឃើញពីសំណុំរឿង ០០២/០១

115. ខៀវ សំផន បានលើកឡើងថា "ជាក់ស្ដែងអង្គជំនុំជម្រះមិនអាចផ្ដាច់ចេញពីសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ដែលខ្លួនបានធ្វើឡើងរួចមកហើយក្នុងសំណុំរឿង ០០២/០១ ឡើយ"[287] និងថា អង្គជំនុំជម្រះសាលាដំបូងពុំដែលជ្រះស្រឡះពីទស្សនៈ"មិនងាករេ"របស់ខ្លួនដែលចាត់ទុកសំណុំរឿង ០០២/០១ និង ០០២/០២ ថា ជាការជំនុំជម្រះតែមួយ ដោយប្រើប្រាស់សំណុំរឿងទីមួយធ្វើជា"មូលដ្ឋានទូទៅ"សម្រាប់សំណុំរឿងបន្ទាប់[288]។ គាត់បានអះអាងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចធារណ៍និរទោស និងការជំនុំជម្រះតុលាការឥតលម្អៀង[289]។

116. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងនឹងភាពលម្អៀងពុំទទួលបានជោគជ័យ ដោយសារបានផ្អែកទៅលើទស្សនៈពុំត្រឹមត្រូវរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមួយដែលបានដាក់ពិរុទ្ធភាពលើជនជាប់ចោទក្នុងរឿងក្ដីពាក់ព័ន្ធគ្នាពីមុននោះ ពុំអាចវិនិច្ឆ័យដោយឥតលម្អៀងលើ

[287] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧។

[288] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១-១៣៣។ ខៀវ សំផន បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពលើគាត់ក្នុងសំណុំរឿង ០០២/០២ ពីបទឧក្រិដ្ឋដែលគាត់ត្រូវបានដាក់ពិរុទ្ធភាពរួចរាល់ហើយក្នុងសំណុំរឿង ០០២/០១ និងបានសំអាងទៅលើអំណះអំណាងដែលបានធ្វើឡើងក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ពាក់ព័ន្ធនឹងការដាក់ពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤ យោងទៅលើកថាខណ្ឌ ៥៣៨-៥៤៦។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងទាំងនេះនៅផ្នែក VI.ឃ.១ (ការចោទប្រកាន់អំពីនត្ថិភាពនៃវិសាលភាពអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីប្រជាជនដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ) នៃសាលដីកានេះ។

[289] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧។

រឿងក្តីបន្ទាប់ដែលប្រឆាំងនឹងជនជាប់ចោទដដែលនោះបានឡើយ[290]។ សហមេធាវីនាំមុខបានយល់ស្រប ជាមួយនឹងសហព្រះរាជអាជ្ញា[291]។

117. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការចោទប្រកាន់របស់ ខៀវ សំផន ដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងបានបុរេវិនិច្ឆ័យពិរុទ្ធភាពរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ត្រូវបានបដិសេធចោលដោយសេចក្តីសម្រេចបិទផ្លូវតវ៉ារបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលបានសន្និដ្ឋានដោយផ្អែកលើការពិនិត្យឡើងវិញនូវសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ទាំងមូលថា "ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានយល់ដឹងអំពីការយល់ឃើញរបស់ខ្លួនដែលត្រូវបានកម្រិតត្រឹមសំណុំរឿង ០០២/០១"[292]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបញ្ជាក់ផងដែរថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ពុំបានបង្ហាញនូវការសន្មតអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់ចូលក្នុងសំណុំរឿង ០០២/០២[293]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យចាត់ទុកសំណុំរឿង ០០២/០១ និង ០០២/០២ ដាច់ដោយឡែកពីគ្នា និងមិនត្រូវផ្ទេរការយល់ឃើញផ្នែកអង្គហេតុណាមួយដោយគ្មានការវិភាគសាឡើងវិញលើភស្តុតាងនោះដែរ[294]។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីដំបូងថា ការបំបែកសំណុំរឿង ០០២ បានបង្កើតរឿងក្តី និងការជំនុំជម្រះដាច់ដោយឡែកពីគ្នា[295] ខណៈពេលនោះបានយោងទៅ

---

[290] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ (F54) ៤១-៤៤។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ F1/9.1 ទំព័រ ៤១-៤៣។

[291] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨១-៨៥។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ F1/9.1 ទំព័រ ៥៦-៥៨។

[292] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចៅក្រម (E314/12/1) កថាខណ្ឌ ៧០, ១០៦។

[293] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចៅក្រម (E314/12/1) កថាខណ្ឌ ៩៣, ៩៧។

[294] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកបន្ថែមនូវសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1/1/3 ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3)") កថាខណ្ឌ ៨៥។

[295] ដីកាបំបែកក្នុងសំណុំរឿង ០០២ ស្របតាមវិធាន *៨៩ស្ទួនពីរ* ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E124 ("ដីកាសម្រេចបំបែកសំណុំរឿង ០០២ (E124)") កថាខណ្ឌ ២។ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សេចក្តីថ្លែងបើក និងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E131 ("ដីកាកំណត់កាលបរិច្ឆេទ (E131)") ទំព័រ ២។ សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងវិសាលភាពនៃសំណុំរឿង ០០២ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1 ("សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1)") កថាខណ្ឌ ២, ២៤, ២៩។

លើដីកាបំបែកសំណុំរឿងនេះថា ជាវិធីសាស្ត្រគ្រប់គ្រងការជំនុំជម្រះ និងទៅលើដំណាក់កាលតជាប់គ្នា ឬផ្នែកនៃការជំនុំជម្រះដូចគ្នា[296]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងផងដែរទៅលើសំណុំរឿង ០០២/០១ ដើម្បីធ្វើជា"មូលដ្ឋានទូទៅ"សម្រាប់ការពិនិត្យលើបទចោទក្នុងសំណុំរឿង ០០២/០២[297]។

118. ដោយកត់សម្គាល់លើភាពពុំស៊ីសង្វាក់គ្នាក្នុងចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងនៃរឿងក្តីដែលត្រូវបានបំបែកថា ដាច់ដោយឡែកពីគ្នា ឬតជាប់គ្នា អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺថា "ពាក្យពេចន៍ក្នុងមាត្រា ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ប្រកាសថា ការបំបែកសំណុំរឿងគឺជាការផ្តាច់ចេញពីគ្នា(ឬការបំបែក)នៃកិច្ចដំណើរការនីតិវិធី ដែលជាលទ្ធផលបង្កើតបានរឿងក្តីព្រហ្មទណ្ឌពីរ ឬច្រើន"[298]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាបន្ថែមទៀតលើ"ភាពចម្រូងចម្រាសជុំវិញសញ្ញាណនៃ'មូលដ្ឋានទូទៅ'" និងបានបញ្ជាក់ថា ជាការពុំអាច"ទទួលយកបានសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្ទេរការសន្និដ្ឋានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌណាមួយក្នុងសំណុំរឿង ០០២/០១ ចូលទៅក្នុងការជំនុំជម្រះនាពេលអនាគតឡើយ"[299]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "បើទោះបីជាភស្តុតាងជាផ្លូវការមានលក្ខណៈរួមគ្នាចំពោះរឿងក្តីដែលត្រូវបានបំបែកក៏ដោយ ក៏លក្ខណៈរួមគ្នានេះពុំបានពន្លាតដល់ការយល់ឃើញ ហើយធាតុផ្សំផ្នែកអង្គហេតុរួមក្នុងរឿងក្តីទាំងអស់ដែលកើតចេញពីសំណុំរឿង ០០២ ត្រូវតែបង្ហាញសាជាថ្មី"[300]។ ផ្អែកលើការបំភ្លឺនេះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការភាន់ច្រំពីមុនៗទាក់ទងទៅនឹងផលវិបាកផ្នែកនីតិវិធីនៃការបំបែកបន្ថែមនៃសំណុំរឿ ០០២ ទៅជាសំណុំរឿង ០០២/០២ ត្រូវបានដោះស្រាយ[301]។

---

[296] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការបំភ្លឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីសម្រាប់ការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញឡើងវិញពីសំណុំរឿង ០០២/០១ ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារលេខ E302/5 ("អនុស្សរណៈបំភ្លឺរបស់អង្គជំនុំជម្រះសាលាដំបូង (E302/5)") កថាខណ្ឌ ៥, ៧។ សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ២, ១៤, ២៣, ២៩។

[297] *សូមមើល ក្នុងចំណោមនោះ* ដីកាកំណត់កាលបរិច្ឆេទ (E131) ទំព័រ ២។ អនុស្សរណៈបំភ្លឺរបស់អង្គជំនុំជម្រះសាលាដំបូង (E302/5) កថាខណ្ឌ ៥, ៧។ សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ២៣, ៤២។

[298] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៤២។

[299] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៨៥។

[300] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៨៥។

[301] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៨៦, ៨៨។

119. ទាក់ទងនឹងបញ្ហានេះ ការបំភ្លឺនេះបានឆ្លុះបញ្ចាំងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថា៖

> មិនមានការចម្លងនូវការទទួលខុសត្រូវព្រហ្មទណ្ឌពីសំណុំរឿងមួយទៅសំណុំរឿងមួយទៀតនោះទេ ហើយផ្នែកសំអាងហេតុមិនត្រូវបានដកស្រង់ពីក្នុងសំណុំរឿង ០០២/០១ មកបញ្ចូលក្នុងសំណុំរឿង ០០២/០២ នោះដែរ។ ក្នុងបរិបទនេះ ទោះបីជាមានចំណុចរួមគ្នាដោយផ្នែកៗរវាងភ័ស្តុតាងផ្ទាល់មាត់ និងភ័ស្តុតាងជាឯកសារនៅក្នុងសំណុំរឿងនីមួយៗក៏ដោយ តែនៅពេលនេះអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើសម្ភារៈទាំងអស់ដែលមាននៅចំពោះមុខខ្លួននោះ៖ អាចមានការធ្វើសេចក្ដីសន្និដ្ឋានផ្សេងគ្នា រួមទាំងទៅលើភ័ស្តុតាង និងអង្គសេចក្ដីនានាដែលពាក់ព័ន្ធរួមគ្នា។ នៅពេលវាយតម្លៃទៅលើសម្ភារៈពីក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងបញ្ហានានានៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះជឿជាក់ថា សិទ្ធិតទល់ពេញលេញក្នុងរឿងក្ដីត្រូវបានការពារ។ ក្នុងចំណុចនេះ ពាក់ព័ន្ធនឹងការវាយតម្លៃទៅលើភ័ស្តុតាងផ្ទាល់មាត់ដែលបានស្ដាប់នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះនឹងពិចារណាថាតើភាគីត្រូវបានរារាំងមិនឱ្យពិនិត្យទៅលើការបំភ្លឺលើបញ្ហានានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នៅក្នុងតុលាការ ដែរ ឬទេ[302]។

អង្គជំនុំជម្រះបានបញ្ជាក់ផងដែរថា "ទោះបីជាអង្គជំនុំជម្រះប្រើប្រាស់ពាក្យពេចន៍ស្រដៀងគ្នា ឬដូចគ្នាទៅនឹងសំណុំរឿង ០០២/០១ ក៏ដោយ ក៏នេះគ្រាន់តែបង្ហាញថា បន្ទាប់ពីធ្វើការវិភាគទៅលើភ័ស្តុតាងសាជាថ្មី សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដូចគ្នាទៅនឹងសេចក្ដីសន្និដ្ឋានដែលអង្គជំនុំជម្រះបានធ្វើនៅក្នុងសំណុំរឿង ០០២/០១"[303]។ បើទោះបីជា ខៀវ សំផន បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល[304]ក៏ដោយ ក៏គាត់បានអះអាងជាសំខាន់ថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្ដែងពុំបានអនុវត្តវិធីសាស្ត្រនេះទេ[305]។

120. ផ្ទុយទៅវិញ គាត់បានអះអាងថា តាមការពិនិត្យលើសាលក្រមបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង"មិនត្រឹមតែបានសម្រេចក្នុងសំណុំរឿង ០០២/០២ ក្នុងលក្ខណៈដូចគ្នាលើបញ្ហាស្រដៀងគ្នាទៅនឹងបញ្ហាដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចរាល់ហើយក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះទេ អង្គជំនុំជម្រះថែមទាំងអនុវត្ត

---

[302] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦។

[303] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦ និងជើងទំព័រ ៨៣។

[304] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៣ និងជើងទំព័រ ១៥២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦។

[305] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧, ១២៩-១៣៣។

តាមការយល់ឃើញដែលបានធ្វើឡើងជាមុនសម្រាប់សំណុំរឿង ០០២/០២"[306]។ គាត់បានចង្អុលបង្ហាញជាឧទាហរណ៍ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ដែលថា បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍គឺជាគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[307]។ គាត់បានសំដៅផងដែរទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹង *ក្នុងចំណោមនោះ* បញ្ហាទាក់ទងទៅនឹងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម សហករណ៍ និងការដ្ឋានធ្វើការ និងតួនាទីរបស់គាត់ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[308]។

121. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា លើកលែងតែការយល់ឃើញស្តីពីអត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីបទបញ្ជាការរៀបអាពាហ៍ពិពាហ៍ ខៀវ សំផន ខកខានក្នុងការបង្ហាញជាក់លាក់គ្រប់គ្រាន់ ឬយោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ នូវការយល់ឃើញជាក់លាក់ដែលគាត់អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្ទេរចូលក្នុងសំណុំរឿង ០០២/០២ ឡើយ[309]។ គាត់ពុំបានផ្តល់ភស្តុតាងគាំទ្របន្ថែមដល់ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំបានបង្កើតការយល់ឃើញ"ស្រដៀងគ្នា"ទាំងនេះដោយមានការវិភាគសាជាថ្មីលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ រួមទាំងពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីបទបញ្ជាការរៀបអាពាហ៍ពិពាហ៍។ ផ្ទុយទៅវិញ តាមការពិនិត្យលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហាក្នុងសំណុំរឿង ០០២/០២ បានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដាច់ដោយឡែកពីគ្នា និងបានផ្អែកលើមូលដ្ឋាននៃភស្តុតាងថ្មីដែលពុំត្រូវបានពិចារណាក្នុងសំណុំរឿង ០០២/០១ ឡើយ[310]។

[306] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩ (ការដកស្រង់លុបចោល)។

[307] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១២៨-១៣០។

[308] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩ និងជើងទំព័រ ១៤២-១៤៣។

[309] *សូមមើលខាងលើ* ផ្នែក II កថាខណ្ឌ ១៩ ("បណ្តឹងសាទុក្ខត្រូវកំណត់នូវការយល់ឃើញ ឬការសម្រេចដែលរងការជំទាស់ដោយមានការយោងជាក់លាក់ទៅលើលេខទំព័រ និងកថាខណ្ឌនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង")។

[310] ខៀវ សំផន បានទទួលស្គាល់ក្នុងសារណារបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញក្នុងសំណុំរឿង ០០២/០១ ស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"នៅមុនការពិចារណាលើភស្តុតាងក្នុងសំណុំរឿង ០០២/០២"។ *សូមមើល* សារណាសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០។

122. បន្ថែមលើនេះ ត្រឹមតែការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការសន្និដ្ឋានស្រដៀងគ្នាលើបញ្ហាប្រហាក់ប្រហែលគ្នានៃការជំនុំជម្រះទាំងពីរ ពុំបានបង្ហាញថា ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងជាចាំបាច់មានភាពលម្អៀង ឬអាចសន្មតបានថា ជាការបុរេវិនិច្ឆ័យទៅលើ ខៀវ សំផន នោះទេនិងអាស្រ័យហេតុនេះ ជាការពុំគ្រប់គ្រាន់ក្នុងការបដិសេធសច្ចធារណ៍នៃអនាគតិបានឡើយ។ រឿងក្ដីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ដែលក្រុមប្រឹក្សាជំនុំជម្រះពិសេសបានផ្អែកទៅលើ បានបង្ហាញលើចំណុចនេះថា ចៅក្រមវិជ្ជាជីវៈអាចត្រូវបានផ្ដល់ទំនុកចិត្តក្នុងការសម្រេចដោយត្រឹមត្រូវលើបញ្ហាចំពោះមុខដោយផ្អែកលើភស្តុតាងដែលបានបង្ហាញក្នុងរឿងក្ដីជាក់លាក់នោះ និងអាស្រ័យហេតុនេះចៅក្រមពុំត្រូវដកខ្លួនចេញពីការជំនុំជម្រះរឿងក្ដីពីរ ឬច្រើនដែលកើតចេញពីព្រឹត្តិការណ៍ជាច្រើនដូចគ្នា និងពាក់ព័ន្ធទៅនឹងភស្តុតាងស្រដៀងគ្នានោះឡើយ[311]។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះត្រូវបដិសេធចោល។

### ៣. ការចោទប្រកាន់ការផ្ទេរភស្តុតាងពីសំណុំរឿង ០០២/០១

123. ខៀវ សំផន បានបង្ហាញផងដែរនូវឧទាហរណ៍នៃភាពលម្អៀងទាក់ទងទៅនឹងការផ្ទេរការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង"ចេញពីទិដ្ឋភាពនៃភស្តុតាង"[312]។ តាមរយៈឧទាហរណ៍ គាត់បានយោងទៅលើការសន្មតដោយពុំត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងនូវសុន្ទរកថាបើកសម័យប្រជុំដោយសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ថា ជារបស់គាត់ ដែលនេះជាការសន្និដ្ឋានមួយត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[313]។ គាត់បានលើកឡើងផងដែរថា ផ្នែកនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿងស្ដីពីរចនាសម្ព័ន្ធរដ្ឋបាល"ជាក់ស្ដែងបានចម្លង"ចេញពីសំណុំរឿង ០០២/០១[314]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបង្ហាញឱ្យឃើញដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានជឿជាក់ថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការដេញដោលពេញលេញចំពោះមុខ ត្រូវបានការពារនៅពេលវាយតម្លៃលើភស្តុតាងចេញពីសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងបញ្ហាក្នុងកិច្ចដំណើរការនីតិវិធីសំណុំ

---

[311] *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ (E314/12/1) កថាខណ្ឌ ៦៦-៧០ និងការយោងដែលបានដកស្រង់នៅទីនោះ។

[312] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨-១៧៤។

[313] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៩។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣២-២៣៣។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ១៦។

[314] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

រឿង ០០២/០២ នោះឡើយ[315]។ ផ្ទុយទៅវិញ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើចម្លើយរបស់សាក្សីដែលត្រូវបានស្តាប់ក្នុងសំណុំរឿង ០០២/០១ ស្តីពីបញ្ហាស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ខណៈពេលដែលគាត់ពុំអាចសួរដេញដោលពួកគេលើបញ្ហានេះ[316]។ គាត់បានអះអាងថា ដោយសារគ្មានការសួរដេញដោល ទើបសក្ខីកម្មសំណុំរឿង ០០២/០១ មានតម្លៃស្មើទៅនឹងចម្លើយជាលាយលក្ខណ៍អក្សរ[317] និងបានសំដៅទៅលើសក្ខីកម្មរបស់ ឆោម សែ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខអូរកន្សែង និង ឯម អឿន ក្នុងចំណោមនោះដើម្បីគាំទ្រការអះអាងរបស់គាត់[318]។ ទាក់ទងទៅនឹងការបង្ហាញខ្លួនរបស់សាក្សីទាំងអស់ក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន បានអះអាងថា គាត់ពុំចាំបាច់"ចំណាយពេលឥតប្រយោជន៍"សួរដេញដោលអ្នកទាំងនេះពាក់ព័ន្ធទៅនឹងអង្គហេតុដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នោះទេ[319]។

124. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងពុំត្រឹមត្រូវលើភស្តុតាងចេញពីសំណុំរឿង ០០២/០១ ឬថាតើ កំហុសដែលបានចោទប្រកាន់នោះធ្វើឱ្យសាលក្រមមោឃៈដូចម្តេចឡើយ[320]។ សហមេធាវីនាំមុខបានលើកឡើងស្រដៀងគ្នា

---

[315] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨, ១៦០-១៦៤។

[316] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៣។

[317] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១-១៦២។

[318] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៣-១៦៤។

[319] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៤។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៤៨។ ខៀវ សំផន បានយោងផងដែរទៅលើ Stephen HEDER, François PONCHAUD និង Philip SHORT ដែលបានផ្តល់សក្ខីកម្មតែក្នុងសំណុំរឿង ០០២/០១ និងអង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនកោះហៅក្នុងសំណុំរឿង ០០២/០២ បើទោះបីជាមានសំណើសុំពីរគាត់ក៏ដោយ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥-១៧៣។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសារណារបស់គាត់ពាក់ព័ន្ធទៅនឹងសាក្សីទាំងនេះក្នុងផ្នែក V.ឃ.៦ (ការខកខានក្នុងការកោះហៅឡើងវិញនូវសាក្សី Stephen HEDER, François PONCHAUD និង Philip SHORT) នៃសាលដីកានេះ។

[320] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣-៥៥។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៤៧។

នេះថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសដែលតម្រូវឱ្យមានការអន្តរាគមន៍លើបណ្តឹងសាទុក្ខពាក់ព័ន្ធបញ្ហានេះឡើយ[321]។

125. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ខៀវ សំផន នួន ជា ប៉ុល ពត និង អៀង ធីរិទ្ធ និងមេដឹកនាំដទៃទៀតបានចូលរួមសម័យប្រជុំលើកទីមួយនៃសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើឡើងនៅថ្ងៃទី ១១ ដល់ ១៣ ខែ មេសា ឆ្នាំ ១៩៧៦"[322] និងថា "ខៀវ សំផន បានថ្លែងសុន្ទរកថាបើកសម័យប្រជុំនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ដោយបានអះអាងថា ការបោះឆ្នោតទុកចិត្ត និងយុត្តិធម៌ត្រូវបានធ្វើឡើង និងបានគាំទ្រគោលនយោបាយពាក់ព័ន្ធទៅនឹងការដ្ឋានធ្វើការ សហករណ៍ និងការតស៊ូវណ្ណៈដែលមានអត្ថិភាព"[323]។ នៅបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានសុន្ទរកថាសម្តោធថា ជារបស់ ខៀវ សំផន និងបានបញ្ជាក់ថា៖

> បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើឯកសារបកប្រែជាភាសាអង់គ្លេសនៃកំណត់ហេតុកិច្ចប្រជុំសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ ដែលបានបញ្ជាក់ថា អ្នកថ្លែងសុន្ទករថានោះជា"ប្រធានគណៈប្រធានរដ្ឋ"ក៏ដោយ ក៏សំណៅដើមជាភាសាខ្មែរ និងភាសាបារាំងបានសំដៅលើ"ប្រធានគណៈអធិបតី" ថា ជាអ្នកថ្លែងសុន្ទរកថាទៅវិញទេ។ ឈ្មោះ ខៀវ សំផន ត្រូវបានលើកឡើងតែម្តងទាក់ទងទៅនឹងការជ្រើសតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ។ ពុំមានការបញ្ជាក់នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះថា ខៀវ សំផន បានបំពេញតួនាទីជា"ប្រធានគណៈអធិបតី" និងថ្លែងសុន្ទរកថាបើកសម័យប្រជុំនោះឡើយ[324]។

---

[321] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២១៥, ២៤៣-២៤៦, ២៤៩។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៥៨។

[322] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៧៦៥ (សេចក្តីបញ្ជាក់បន្ថែម) យោងទៅលើកំណត់ហេតុកិច្ចប្រជុំសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/165 ERN 00053610-00053617។

[323] សាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៥ (សេចក្តីបញ្ជាក់បន្ថែម) យោងទៅលើកំណត់ហេតុកិច្ចប្រជុំសន្និបាតរបស់សភា ឯកសារលេខ E3/165 ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ទំព័រ ៩-២០ ERN 00053610-00053617។

[324] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០២៣ (ជើងទំព័រលុបចោល)។

126. បើទោះបីជាមានកំហុសផ្នែកអង្គហេតុនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានពិចារណាឃើញថា "ការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានរួមចំណែក'សំខាន់'ក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ពុំមានកំហុសឡើយ"[325]។

127. ក្នុងសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "គោលបំណងនៃការសម្រេចបាននូវ'មហាលោតផ្លោះ មហាអស្ចារ្យ' ត្រូវបានជំរុញជាថ្មីម្តងទៀតដោយ ខៀវ សំផន ក្នុងសម័យប្រជុំលើកទី ១ នៃសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើឡើងនៅចន្លោះពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦" និងថា "នៅក្នុងកិច្ចប្រជុំនោះដែលមាន ប៉ុល ពត នួន ជា អៀង ធីរិទ្ធ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតបានចូលរួម ខៀវ សំផន បានគាំទ្រអាទិភាពនៃការកសាង និងការពារប្រទេសដោយឯករាជ្យខ្លួនទីពឹងខ្លួនឱ្យបានឆាប់រហ័សដោយនៅតែបន្តការតស៊ូវណ្ណៈប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយម និង'វណ្ណៈជិះជាន់ផ្សេងទៀត'"[326]។

128. ដោយសារអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ពុំបានលើកចំៗថា ខៀវ សំផន បានថ្លែងសុន្ទរកថាបើកសម័យប្រជុំ ទើបពុំមានភាពច្បាស់លាស់ថាតើ អង្គជំនុំជម្រះសាលាដំបូងចង់សំដៅទៅលើការសន្មតនូវសុន្ទរកថានោះថា ជារបស់គាត់ ឬថាតើ អង្គជំនុំជម្រះពិចារណាឃើញថា គាត់តាមរយៈវត្តមានរបស់គាត់ ខៀវ សំផន បានជម្រុញ និងគាំទ្រគោលបំណងដែលបានលើកឡើងក្នុងសុន្ទរកថានោះ ដែរ ឬយ៉ាងណា។ បន្ទាប់ពីការពិនិត្យបន្ថែមទៀតឃើញថា មានការពិចារណាសំខាន់ៗបីចំណុច។ ទីមួយ នួន ជា បានចូលរួមផងដែរក្នុងពិធីសម្ពោធនោះ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំបានសន្មតថា ជាសុន្ទរកថារបស់គាត់ និងពុំបានយល់ឃើញថា គាត់បានជម្រុញ ឬគាំទ្រខ្លឹមសារនោះផ្អែកលើវត្តមានគាត់ឡើយ[327]។ ទីពីរ ដូចក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការបកប្រែកំណត់ហេតុកិច្ចប្រជុំនោះជាភាសាអង់គ្លេស។ ទីបី អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញនេះក្នុងការ

---

[325] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៣០។

[326] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៩ យោងទៅលើឯកសារស្តីពីអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជនកម្ពុជា ឯកសារលេខ E3/165 ចុះថ្ងៃទី ១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ERN 00053610-00053617។

[327] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១២៥ ("នៅក្នុងពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៦ នួន ជា បានចូលរួមវគ្គទីមួយនៃកិច្ចប្រជុំសភាតំណាងប្រជាជនដែលនៅពេលនោះ ខៀវ សំផន បានផ្សព្វផ្សាយពីគោលបំណងក្នុងការសម្រេច "មហាលោតផ្លោះ មហាអស្ចារ្យ" និងបានអនុម័តការងារអាទិភាពក្នុងការកសាង និងការពារប្រទេសដោយឯករាជ្យ និងខ្លួនទីពឹងខ្លួនឲ្យបានឆាប់រហ័ស ក្នុងខណៈពេលបន្តការតស៊ូវណ្ណៈប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយម និង "វណ្ណៈជិះជាន់" ផ្សេងទៀត")។

សន្និដ្ឋានថា ខៀវ សំផន "បានជម្រុញយ៉ាងសកម្មនិងដោយវោហារសាស្ត្រ និងជាសាធារណៈ បានបញ្ជាក់ និងគាំទ្រគោលបំណងរួមទាំងនៅក្នុងស្រុក និងលើឆាកអន្តរជាតិ"[328]។ អាស្រ័យហេតុនេះ ដោយសារពុំមានការបញ្ជាក់បន្ថែម និងផ្អែកតាមខ្លឹមសារការពិចារណាទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលអាចសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានបំណងសន្មតសុន្ទរកថានោះថា ជារបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២។

129. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា ការបកប្រែជាភាសាអង់គ្លេសនៃកំណត់ហេតុកិច្ចប្រជុំសភាតំណាងប្រជាជនរបស់របបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញវាគ្មិននោះគឺជា"ប្រធានគណៈប្រធានរដ្ឋ" ចំណែកភាសាខ្មែរ និងបារាំង បានសំដៅវាគ្មិនថា ជា"ប្រធានគណៈប្រតិភូ"។ ដោយសារពុំមានភស្តុតាងថ្មីដែលបង្ហាញថា ខៀវ សំផន បានកាន់កាប់តួនាទីជា"ប្រធានគណៈប្រតិភូ" អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារបានសន្មតសុន្ទរកថានោះថា ជារបស់ ខៀវ សំផន[329]។ ទោះជាយ៉ាងណាក្តី កំហុសដាច់ដោយឡែកផ្នែកអង្គហេតុនេះ ពុំគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានផ្ទេរជាប្រព័ន្ធនូវការយល់ឃើញផ្នែកអង្គហេតុពីសំណុំរឿង ០០២/០១ ចូលក្នុងសំណុំរឿង ០០២/០២ ឡើយ។

130. ទាក់ទងទៅនឹងសារណារបស់ ខៀវ សំផន ដែលថា ផ្នែកស្តីពីរចនាសម្ព័ន្ធរដ្ឋបាលជាក់ស្តែងត្រូវបាន"កាត់យកមកដាក់"[330]នោះ ការប្រើប្រាស់ពាក្យពេចន៍របស់អង្គជំនុំជម្រះសាលាដំបូងជួនកាលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬដូចគ្នាទៅនឹងពាក្យពេចន៍ដែលបានប្រើក្នុងសំណុំរឿង ០០២/០១ ជាពិសេសនៅពេលពិភាក្សាលើប្រធានបទដែលរួមគ្នានៃការជំនុំជម្រះទាំងពីរ ដូចជារចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធទំនាក់ទំនង និងសារតារ។ នៅគ្រប់ករណី បន្ទាប់ពីការពិនិត្យឡើងវិញលើការយល់ឃើញក្នុងផ្នែកស្តីពីរចនាសម្ព័ន្ធរបស់

[328] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៤ (សេចក្តីបញ្ជាក់បន្ថែម)។

[329] អង្គជំនុំជម្រះតុលាការកំពូលសង្កេតបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការយល់ឃើញផ្នែកអង្គហេតុពុំត្រឹមត្រូវក្នុងការគាំទ្រការសន្និដ្ឋានថា ខៀវ សំផន បានរួមចំណែកក្នុងគោលបំណងរួម និងបានរួមចំណែកយ៉ាងសំខាន់ក្នុងនោះ។ *សូមមើល* សាលក្រមសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៣, ៤២៦៤។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើកំហុសនេះនៅពេលវាយតម្លៃលើការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់គាត់ក្រោមសហឧក្រិដ្ឋកម្មរួម និងបានសន្និដ្ឋាននូវហេតុផលដែលបានពន្យល់ពេញលេញខាងក្រោមថា ការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើភស្តុតាងជាច្រើនដទៃទៀតដែលបង្ហាញថា គាត់បានរួមចំណែកគោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួម និងរួមចំណែកជាសំខាន់ក្នុងនោះ ពុំមានកំហុសឡើយ។ *សូមមើលខាងក្រោម* ផ្នែក VIII. ឃ។

[330] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

បក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងបន្ថែម[331] បានកែប្រែសេចក្តីសន្និដ្ឋានមួយចំនួន[332] និងបានពង្រីកលើប្រធានបទមួយចំនួន[333]។ នេះពុំបានគាំទ្រការជំទាស់របស់ ខៀវ សំផន ដែលថា ការយល់ឃើញនោះត្រឹមតែ"ជាការកាត់យកមកដាក់"ចេញពីសំណុំរឿង ០០២/០១ ដោយគ្មានការវិភាគសាឡើងវិញលើភស្តុតាងនោះឡើយ។

131. នៅពេលវាយតម្លៃលើភស្តុតាងចេញពី សំណុំរឿង ០០២/០១ ដើម្បីកំណត់បញ្ហាក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះជឿជាក់ថា "សិទ្ធិទទួលបានការដេញដោលចំពោះមុខពេញលេញត្រូវបានគោរព"[334]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង"បានពិចារណាបញ្ហាថាតើភាគីត្រូវបានរារាំងក្នុងការសួរសំណួរក្នុងតុលាការស្តីពីបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ ឬយ៉ាងណា" នៅពេលវាយតម្លៃលើភស្តុតាងផ្ទាល់មាត់ដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០១[335]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការបំបែកសំណុំរឿង ០០២/០១ ពុំបានចូលជាស្ថាពររហូតទាល់តែមានការបិទកិច្ចដំណើរការនីតិវិធីលើភស្តុតាងសំណុំរឿង ០០២ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣[336]។ ជាផលវិបាក "ភស្តុតាងបានកើនឡើងរហូតដល់ចំណុចមួយរួមគ្នានៃសំណុំរឿង ០០២ ទាំងមូល" និងភស្តុតាងដែលត្រូវបានបង្ហាញក្នុងសំណុំរឿង ០០២/០១ នៅតែជាផ្នែកនៃ

---

[331] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៤, ៣៤៥ (បន្ថែមលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧៦ អង្គជំនុំជម្រះបានសំអាងទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១)។

[332] *ប្រៀបធៀប ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ២០០ ("នេះទំនងជាថា លក្ខន្តិកៈទីពីរត្រូវបានអនុម័តដោយសមាជបក្សលើកទីបីនៅក្នុង ឬប្រហែលខែ សីហា ឆ្នាំ ១៩៧១") ជាមួយនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣ ("លក្ខន្តិកៈទីពីរត្រូវបានអនុវម័តិដោយសមាជបក្សលើកទីបីក្នុងខែ សីហា ឆ្នាំ ១៩៧១")។

[333] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១, ៣៤២ (ការបន្ថែមលើប្រយោគ"អត្ថិភាពនៃបក្សកុម្មុយនីស្តកម្ពុជា និងការដឹកត្រូវបានបង្ហាញដល់ប្រជាជនកម្ពុជាជាសាធារណៈ(ខាងក្រៅសមាជិកបក្សកុម្មុយនីស្តកម្ពុជា) ព្រមទាំងពិភពលោកខាងក្រៅនៅពិធីរំឭកខួបលើកទី ១៧ របស់បក្សក្នុងខែ កញ្ញា ឆ្នាំ ១៩៧៧"), ៣៤៤ (ការកត់សម្គាល់បឋមពាក់ព័ន្ធនឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា, ៣៤៧-៣៥៤ (បញ្ហាបឋមពាក់ព័ន្ធទៅនឹងកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍), ៣៥៦។

[334] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦។

[335] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦។

[336] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៧៤ (ជើងទំព័រលុបចោល)។

សំណុំរឿង ០០២/០២[337]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ដោយសារការប្រែប្រួលលើកម្មវត្ថុនៃរឿងក្តី និងបទចោទ "លក្ខណៈរួមគ្នាជាផ្លូវការនៃភស្តុតាងដែលត្រូវបានបង្ហាញក្នុងការជំនុំជម្រះលើកដំបូង ពុំបានបុរេវិនិច្ឆ័យសំណួរដែលជាប់ពាក់ព័ន្ធ ឬឱកាសគ្រប់គ្រាន់ក្នុងការសួរដេញដោលទាក់ទងទៅនឹងបទចោទក្នុងការជំនុំជម្រះលើកទីពីរឡើយ"[338]។ គួរកត់សម្គាល់ ដោយហេតុថា សំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹងបទចោទដែលទាក់ទងទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទី ១ និង ២[339] សំណុំរឿង ០០២/០២ ជាប់ពាក់ព័ន្ធទៅនឹងបទចោទទូលំទូលាយ ដែលទាក់ទងទៅនឹងការអនុវត្តន៍នៃគោលនយោបាយដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅមុនការចាប់ផ្តើមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីថា "សក្ខីកម្មទាំងអស់ដែលត្រូវបានស្នើសុំនៅពេលជំនុំជម្រះ(បើទោះបីជាពីសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី) នឹងត្រូវបានកម្រិតត្រឹមសក្ខីកម្មដែលពាក់ព័ន្ធទៅនឹងការកំណត់អំពីអង្គហេតុក្នុងសំណុំរឿង ០០២/០១"[340]ប៉ុណ្ណោះ និងថា "ពុំមានការអនុញ្ញាតឱ្យសួរសំណួរលើប្រធានបទដែល

---

337 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៧៤ (ជើងទំព័រលុបចោល)។

338 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៧៥ (សេចក្តីបញ្ជាក់បន្ថែម)។ (អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺផងដែរនូវផលវិបាកផ្នែកនីតិវិធីនៃការបំបែកត្រង់ថា "ពាក្យពេចន៍នៃវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុងបានប្រកាសរួចរាល់ថា ការបំបែកនេះគឺជាការផ្តាច់ចេញពីគ្នា(ឬកាត់ផ្តាច់ចេញ) នៃកិច្ចដំណើរការនីតិវិធីដែលក្រោយមកនោះជំនួសឱ្យរឿងក្តីព្រហ្មទណ្ឌតែមួយ មានរឿងក្តីព្រហ្មទណ្ឌពីរ ឬច្រើន"។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៤២ (សេចក្តីបញ្ជាក់បន្ថែម))។

339 *សូមមើល ឧ.* សេចក្តីសម្រេចសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញលើលក្ខខណ្ឌនៃដីកាបំបែករបស់អង្គជំនុំជម្រះសាលាដំបូង (E1242) និងញត្តិពាក់ព័ន្ធ និងឧបសម្ព័ន្ធ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E124/7 ("សេចក្តីសម្រេចសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញា (E124/7)") ("ជាលទ្ធផលឃើញថា អង្គជំនុំជម្រះនៅក្នុងការជំនុំជម្រះផ្នែកដំបូងនឹងត្រូវពិចារណាលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងទៅនឹងគោលនយោបាយទាំងអស់ពាក់ព័ន្ធទៅនឹងដីកាបញ្ជូនទៅជំនុំជម្រះទាំងមូល ប៉ុន្តែនឹងត្រូវផ្តល់ការពិចារណាលម្អិតផ្នែកអង្គហេតុក្នុងការជំនុំជម្រះលើកដំបូងជាសំខាន់ទៅលើលក្ខណៈពិសេសនៃដីកាបញ្ជូនទៅជំនុំជម្រះដែលបានប៉ះពាល់ជាក់ស្តែងលើជនរងគ្រោះទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ(ដូចជា ការផ្លាស់ទីប្រជាជនដំណាក់កាលទីមួយ និងទីពីរ)")។

340 ការជូនដំណឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើញត្តិផ្សេងទៀតនៅមុនការជំនុំជម្រះ (E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការបំភ្លឺបន្ថែមទៀតដល់សហមេធាវីនាំមុខ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ E145 ("ការជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (E145)") ទំព័រ ២។

ស្ថិតក្រៅវិសាលភាពនៃការជំនុំជម្រះនេះ [...]"[341]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហមេធាវីនាំមុខថា បើទោះបីជាភស្តុតាងដែលត្រូវបានស្តាប់នៅមុនការបំបែកសំណុំរឿង ០០២/០១ ជាផ្លូវការគឺជាផ្នែកមួយសំណុំរឿង ០០២ ទាំងមូលក៏ដោយ ក៏ភស្តុតាងនេះ"ត្រូវតែធ្វើការវាយតម្លៃដោយផ្អែកលើសំណួរដែលត្រូវបានអនុញ្ញាតក្នុងអំឡុងពេលនៃសវនាការទាំងនោះ"នៅពេលត្រូវបានសំអាងទៅលើក្នុងសំណុំរឿង ០០២/០២ ដែរ[342]។

132. ទាក់ទងនឹងបញ្ហានេះ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានហាមឃាត់ក្នុងការពិចារណាលើភស្តុតាងដែលពុំត្រូវបានសួរដេញដោល[343]។ ផ្ទុយទៅវិញ ភស្តុតាងនេះត្រូវតែបានផ្តល់ទម្ងន់តិចជាង និងជាសំខាន់"ការដាក់ពិរុទ្ធភាពមិនអាចផ្អែកដើម្បីធ្វើសេចក្តីសម្រេចតែទៅលើភស្តុតាងរបស់សាក្សីដែលមេធាវីការពារក្តីពុំមានឱកាសសួរដេញដោល លើកលែងតែមានកត្តាដែលថ្លឹងថ្លែងគ្រប់គ្រាន់ជាអត្ថិភាព"[344]។

---

[341] ការជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (E145) ទំព័រ ៣។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ចំណងជើងថា "ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីនៅមុនការជំនុំជម្រះ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំក្រៅផ្លូវការជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E141 ("អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E141)") ទំព័រ ២។

[342] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៤៣។

[343] វិធាន ៨៧ នៃវិធានផ្ទៃក្នុងចែងថា ជាគោលការណ៍ ភស្តុតាងទាំងអស់អាចទទួលយកបានក្នុងកិច្ចដំណើរការនីតិវិធីនៅមុខ អ.វ.ត.ក.។

[344] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាទល់នឹង Martić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-11-AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភស្តុតាងរបស់សាក្សី Milan Babić ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី *Martić* ស្តីពីភស្តុតាង(ICTY)") កថាខណ្ឌ ១៩ ("អង្គជំនុំជម្រះឧទ្ធរណ៍ពិចារណាឃើញថា យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(ECtHR)បានផ្តល់ប្រភពមានអត្ថប្រយោជន៍នៃការបំភ្លឺសម្រាប់ការបកស្រាយនូវសិទ្ធិក្នុងការសួរដេញដោល និងវិសាលភាពនៃការអនុញ្ញាត")។ យុត្តិសាស្ត្ររបស់តុលាការ ECtHR បានបង្កើតបទដ្ឋានមួយដែលមានបីផ្នែកក្នុងការកំណត់លើបញ្ហាថាតើ ការជំនុំជម្រះអាចត្រឹមត្រូវ ដែរ ឬទេ បើទោះបីជាភស្តុតាងរបស់សាក្សី ត្រូវបានទទួលយកដោយគ្មានការផ្តល់ឱកាសឱ្យជនជាប់ចោទសួរដេញដោលនោះ៖ (១) តើមានហេតុផលសមស្របសម្រាប់ការពុំចាំបាច់មានការចូលរួមរបស់សាក្សី និងជាលទ្ធផល ការទទួលយកចម្លើយរបស់សាក្សីធ្វើជាភស្តុតាងដោយគ្មានការសួរដេញដោលសាក្សី ដែរ ឬទេ។ (២) តើភស្តុតាងរបស់សាក្សីដែលអវត្តមាននោះ គឺជាមូលដ្ឋានសំខាន់ ឬតែមួយគត់សម្រាប់ការដាក់ពិរុទ្ធភាពលើជនជាប់ចោទ និង/ឬ (៣) មានកត្តាថ្លឹងថ្លែងគ្រប់គ្រាន់ដើម្បីផ្តល់ដំណោះស្រាយលើព្យសនកម្មកើតមានចំពោះជនជាប់ចោទដោយសារការទទួលយកភស្តុតាងដែលពុំត្រូវបានសួរដេញដោល និងធានាថា ការជំនុំជម្រះ *ដោយពិចារណាជារួម* ត្រឹមត្រូវ ដែរ ឬទេ។ អ្នកនិពន្ធ Clooney និង Philippa Webb *សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវតាមច្បាប់អន្តរជាតិ* (បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ២០២១) ទំព័រ ៥១៦, ៥២៨-៥២៩ យោងទៅលើតុលាការ ECtHR រឿងក្តី *Al-Khawaja ទល់នឹង ចក្រភពអង់គ្លេស* អង្គជំនុំជម្រះនៃតុលាការ

ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា គោលការណ៍នៃកិច្ចដំណើរការនីតិវិធីដេញដោលចំពោះមុខពុំបានតម្រូវឱ្យភាគីត្រូវតែពិនិត្យជាក់ស្តែង ឬលើកសារណាទាក់ទងទៅនឹងភស្តុតាងណាមួយឡើយ"បើទោះបីជាភាគីនីមួយៗមានឱកាសធ្វើដូច្នោះក៏ដោយ"[345]។

133. ទាក់ទងទៅនឹងទម្ងន់ដែលបានផ្តល់ទៅឱ្យសេក្តីកម្មសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសដោយសារការបដិសេធការជំទាស់របស់ ខៀវ សំផន ដែលថា ភស្តុតាងផ្ទាល់មាត់ក្នុងសំណុំរឿង ០០២/០១ តាមរយៈប្រតិចារឹក ក្លាយជាភស្តុតាងជាឯកសារក្នុងសំណុំរឿង ០០២/០២[346]។ បើទោះបីជា ខៀវ សំផន បានចង្អុលបង្ហាញទៅលើហេតុការណ៍ពីរដូចជា "ករណីដែលសាក្សីក្នុងសំណុំរឿង ០០២/០១ បានត្រឡប់ធ្វើជាសាក្សីក្នុងសំណុំរឿង ០០២/០២ ឬនៅពេលសាក្សីក្នុងសំណុំរឿង ០០២/០១ បានផ្តល់សក្ខីកម្មផងដែរទាក់ទងទៅនឹងអង្គហេតុដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ០០២/០២ និងត្រូវបានសួរដេញដោលលើអង្គហេតុទាំងនោះ"[347]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភស្តុតាងដែលបានបង្ហាញក្នុងសំណុំរឿង ០០២/០១ នៅតែជាផ្នែកនៃសំណុំរឿង ០០២/០២ និងអាចត្រូវបានសំអាងទៅលើក្នុងករណីជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងអាចវាយតម្លៃលើអត្តចរិតទូទៅ និងគួរឱ្យជឿជាក់បានរបស់បុគ្គលនៅពេលបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១។ លើកលែងតែក្នុងករណីដែលភាគីត្រូវ

---

ECtHR សំណើសុំលេខ 26766/05 និង 22228/06 សាលក្រមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ១១៨-១១៩។ រឿងក្តី *Schatschaschwili ទល់នឹង ប្រទេសអាល្លឺម៉ង់* អង្គជំនុំជម្រះនៃតុលាការ ECtHR សំណើសុំលេខ 9154/10 សាលក្រមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ ("សាលក្រមរឿងក្តី *Schatschaschwili ទល់នឹង ប្រទេសអាល្លឺម៉ង់* (ECtHR)") កថាខណ្ឌ ១០៧, ១៣០-១៣១, ១៥៦។ រឿងក្តី *Gani ទល់នឹង ប្រទេសអេស្ប៉ាញ* ផ្នែកទីបីនៃតុលាការ ECtHR សំណើសុំលេខ 61800/08 សាលក្រមថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ១១, ៤៣-៤៨ (ពុំមានការរំលោភបំពាននៅពេលជនជាប់ចោទមានឱកាសលើជាសំណួរសួរសាក្សីក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបសួរនៃកិច្ចដំណើរការនីតិវិធី)។ រឿងក្តី *Isgrò ទល់នឹង ប្រទេសអ៊ីតាលី* តុលាការ ECtHR សំណើសុំលេខ 11339/85 សាលក្រមថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩១ កថាខណ្ឌ ២៤-២៥, ៧៣-៧៦ (ពុំមានការរំលោភបំពាននៅពេលជនជាប់ចោទអាចសួរសំណួរសាក្សីក្នុងដំណើរការនីតិវិធីសួរដេញដោលមុនការជំនុំជម្រះ)។ *ធៀបនឹង* សាលក្រមរឿងក្តី *Schatschaschwili ទល់នឹង ប្រទេសអាល្លឺម៉ង់* (ECtHR) កថាខណ្ឌ ១៥៧-១៥៩ (មានការរំលោភបំពាននៅពេលជនជាប់ចោទពុំត្រូវបានផ្តល់សិទ្ធិសួរសំណួរសាក្សីនៅដំណាក់កាលស៊ើបអង្កេតផងដែរ ហើយនេះគឺជាសាក្សីឃើញផ្ទាល់ភ្នែកចំពោះបទល្មើសនោះ)។

[345] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១៨៥ (ជើងទំព័រលុបចោល)។

[346] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១-១៦២។

[347] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១។

បានរារាំងក្នុងការសួរដេញដោលសាក្សីលើបញ្ហាជាក់លាក់ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ទើបសក្ខីកម្មផ្នែកជាក់លាក់នោះគប្បីត្រូវបានផ្តល់ទម្ងន់តិចជាង និងមានតែផ្នែកជាក់លាក់ដែលពុំបានដាក់ឱ្យសួរដេញដោលចំពោះមុខប៉ុណ្ណោះ ជាជាងសក្ខីកម្មទាំងមូលនោះទេ។

134. ក្នុងការគាំទ្រការលើកឡើងរបស់ខ្លួនដែលថា គាត់ពុំអាចសួរដេញដោលសាក្សីមួយចំនួនស្តីពីបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ខៀវ សំផន បានយោងជាពិសេសទៅលើ ឆោម សែ ដែលជាប់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខអូរកន្សែង និង អែម អឿន ស្តីពីបញ្ហាពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងពុទ្ធសាសនា[348]។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនលើអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិកពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងផ្អែកលើសក្ខីកម្មរបស់សាក្សីដែលបានស្តាប់ក្នុងសំណុំរឿង ០០២/០១ ដោយហេតុថាសាក្សីទាំងនេះពីដំបូងបានផ្តល់សក្ខីកម្មតែលើបញ្ហាពុទ្ធសាសនាក្នុងបរិបទជាប្រវត្តិពាក់ព័ន្ធទៅនឹងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ[349]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយការចោទប្រកាន់ទាំងនេះតាមលំដាប់លំដោយ។

## ក. ឆោម សែ

135. ឆោម សែ គឺជាអតីតប្រធានមន្ទីរសន្តិសុខអូរកន្សែង ហើយសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ជាចម្បងពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[350]។ គាត់បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២។ ទាក់ទងទៅនឹងវិសាលភាពដែលត្រូវបានអនុញ្ញាតសម្រាប់ការសួរដេញដោលគាត់ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យភាគីសួរសំណួរ ឆោម សែ អំពីបញ្ហាទាក់ទងទៅនឹង

[348] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៣។

[349] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៣។

[350] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1។ ប្រតិចារឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1។ សេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់ក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E312 (“សេចក្តីសម្រេចស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (E312)”) កថាខណ្ឌ ៤១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា “ការណែនាំដល់ភាគីបន្ទាប់ពីសវនាការ ថ្ងៃទី ២១ ខែ កញ្ញា” ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E233 កថាខណ្ឌ ៥។

រចនាសម្ព័ន្ធ ប្រព័ន្ធនៃការទំនាក់ទំនង និងវិធីសាស្ត្រនៃការរាយការណ៍នៅមន្ទីរសន្តិសុខអូរកន្សែង[351]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងជាទូទៅបានកម្រិតវិសាលភាពនៃការសួរដេញដោលរបស់ភាគីត្រឹមវិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០១។ ជាឧទាហរណ៍ បន្ទាប់ពីការជំទាស់ទាក់ទងទៅនឹងវិសាលភាពនៃការសួរដេញដោលរបស់សហព្រះរាជអាជ្ញា[352]ប្រធានអង្គជំនុំជម្រះសាលាដំបូងបានណែនាំសហព្រះរាជអាជ្ញាឱ្យតាំងសំណួរសាឡើងវិញដោយផ្តោតទៅលើលក្ខណៈនៃការទំនាក់ទំនង ពុំមែន"លើមុខងារនៃរចនាសម្ព័ន្ធអូរកន្សែងនោះទេ"[353]។ ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកមេធាវីការពារក្តី នួន ជា ថា "មន្ទីរសន្តិសុខអូរកន្សែង ពុំមែនជាការផ្តោតចម្បងនៃសវនាការនេះទេ" និងថាសំណួរគប្បីត្រូវបានកម្រិតត្រឹមរចនាសម្ព័ន្ធ និងទំនាក់ទំនងធ្វើការងារតែប៉ុណ្ណោះ[354]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាភាគីអាចសួរសំណួរ ឆោម សែ ពេញលេញទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធា រួមទាំងការទំនាក់ទំនង និងការរាយការណ៍នៅអូរកន្សែងក៏ដោយ ក៏ការសួរដេញដោលលើប្រធានបទដទៃទៀតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកម្រិតដោយការ

[351] *សូមមើល ឧ. សូមមើលឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៧៥-៧៦ ("សំណួរពុំជាប់ពាក់ព័ន្ធទៅនឹងមន្ទីរកែប្រែនៅអូរកន្សែង ប៉ុន្តែជាប់ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា")។ ប្រតិចារឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ១៧ ("ពីព្រោះសំណួរនេះជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពការទំនាក់ទំនង ដូច្នេះការជំទាស់ពុំមានសុពលភាព")។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦០។ សេចក្តីសម្រេចស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (E312) កថាខណ្ឌ ៥១។

[352] ប្រតិចារឹក ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៦ ("ខ្ញុំជំទាស់ចំពោះការតាំងសំណួរបែបនេះ ដោយសារថា វាមិនស្ថិតក្នុងវិសាលភាពក្នុងរចនាសម្ព័ន្ធនោះទេ។ នេះគឺនិយាយអំពីការកាប់សម្លាប់ និងមន្ទីរសន្តិសុខដែលខ្ញុំយល់ឃើញថា វាស្ថិតនៅក្រៅវិសាលភាពនេះ")។

[353] ប្រតិចារឹក ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៦ ("លោកតំណាងសហព្រះរាជអាជ្ញា គប្បីរៀបចំសំណួរឡើងវិញ ហើយសំណួរកម្រិតត្រឹមតែបង្ហាញអំពីប្រព័ន្ធទំនាក់ទំនងការងារបានហើយ ជៀសវាងការតាំងសំណួរស៊ីជម្រៅរហូតដល់ទៅសកម្មភាពជាក់ស្តែនៃដំណើរការប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខអូរកន្លែងនោះ")។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៧៥ (ចំណុចដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួននឹងមិននិយាយ"លាតសន្ធឹងទាក់ទងទៅដល់លក្ខខណ្ឌឃុំឃាំងនោះទេ ពីព្រោះយើងនៅតែក្នុងក្របខ័ណ្ឌជំនុំជម្រះយើងនេះទេ")។

[354] ប្រតិចារឹក ថ្ងៃទី០៨ ខែ មេសា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ៥៥ ("មន្ទីរសន្តិសុខអូរកន្សែងពុំមែនជាគោលដៅជាកម្មវត្ថុនៃកិច្ចពិភាក្សានេះទេ។ យើងកម្រិតត្រឹមតែរចនាសម្ព័ន្ធ និងទំនាក់ទំនងការងារតែប៉ុណ្ណោះ។ អីចឹងសូមឱ្យធ្វើការវែកញែកឱ្យបានច្បាស់លាស់រវាងសំណួរណាដែលពាក់ព័ន្ធទៅនឹងអង្គហេតុកំណត់ឱ្យធ្វើសវនាការ")។

ណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង និងវិសាលភាពនៃបទចោទដែលត្រូវបានកម្រិតក្នុងសំណុំរឿង ០០២/០១[355]។

136. ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មសំណុំរឿង ០០២/០១ របស់ ឆោម សែ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា៖

> ឆោម សែ អតីតប្រធានមន្ទីរនេះបានផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធរដ្ឋបាលនិងទំនាក់ទំនងពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនេះ ប៉ុន្តែពុំអាចកោះហៅសាជាថ្មីបាននៅក្នុងសំណុំរឿង ០០២/០២ ដោយសារតែគាត់បានទទួលមរណភាពនៅមុនពេលបង្ហាញខ្លួនជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសួរសំណួរមួយចំនួនដល់សាក្សីដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬជាយថាហេតុទៅនឹងវិសាលភាពសំណុំរឿង ០០២/០២ ។ ត្រង់ចំណុចខ្លឹមសារនៃចម្លើយតបដែលត្រូវបានភាគីសួរដេញដោលនៅក្នុងតុលាការនោះ អង្គជំនុំជម្រះបានសំអាងលើចម្លើយរបស់សាក្សី ដើម្បីទាញសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកនេះ[356]។

137. ទាក់ទងទៅនឹងបញ្ហានេះ តាមការសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើភស្តុតាងរបស់ ឆោម សែ ជាចម្បងក្នុងការគាំទ្រការយល់ឃើញដែលស្ថិតក្នុងវិសាលភាពដែលត្រូវបានអនុញ្ញាតក្នុងការសួរសំណួរក្នុងអំឡុងពេលសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/០១។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ ឆោម សែ ក្នុងផ្នែកស្តីពី“ការបង្កើត និងរចនាសម្ព័ន្ធរាយការណ៍”នៃមន្ទីរសន្តិសុខអូរកន្សែង[357] រួមទាំងការយល់ឃើញពាក់ព័ន្ធទៅនឹងកងពល ៨០១ និងការគ្រប់គ្រងមន្ទីរសន្តិសុខ[358] កាលបរិច្ឆេទនៃការប្រតិបត្តិការមន្ទីរ[359] ការយល់ឃើញដែលថា ឆោម សែ បានបម្រើការនៅអូរ

---

[355] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ២៨-២៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩០២ (“យោងតាមសាក្សី ឆោម សែ អ្នកសួរចម្លើយ “មិនត្រូវបានអនុញ្ញាតឲ្យធ្វើទារុណកម្មទៅលើអ្នកទោសឡើយ“។ នៅក្នុងពេលឆ្លើយតបចំពោះសំណួររបស់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០១ អំពីបញ្ហាថា តើបុគ្គលិកមន្ទីរសន្តិសុខអាច “ធ្វើទារុណកម្ម” ឬវាយដំនៅពេលសួរចម្លើយបានដែរឬអត់នោះ សាក្សីបានផ្តល់សក្ខីកម្មថា អ្នកសួរចម្លើយ“ការសាកសួរហើយសាកល្បងសាចុះសាឡើង តែមើលនឹងកលល្បិចរបស់សាមីខ្លួន ដែលជនជាប់ចោទនេះវាបានពេញលក្ខណៈ មិនពេញលក្ខណៈបាទ។ ដល់អ៊ីចឹងទៅវាមានម្តង ពីរដង មកបញ្ជាក់ថែមទៀត។ ចំណុចណាដែលចាប់បានហើយមិនព្រមប្រាប់ ហ្នឹងក៏យើងអាចធ្វើដែរ”។ (សេចក្តីបញ្ជាក់បន្ថែម)។

[356] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦០ (ជើងទំព័រលុបចោល) (សេចក្តីបញ្ជាក់បន្ថែម)។

[357] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦៣-២៨៨៤។

[358] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦៣-២៨៦៦, ២៨៦៩-២៨៧១។

[359] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦៧ និងជើងទំព័រ ៩៧៨៧, ៩៧៩១។

កន្លែងចាប់តាំពីចុងឆ្នាំ ១៩៧៦ រហូតដល់ដើមឆ្នាំ ១៩៧៩[360] និងការយល់ឃើញមួយចំនួនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងកងពល ៨០១ ដោយអគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា និងដោយគណៈភូមិភាគឦសាន[361]។

138. ចំពោះភស្តុតាងដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបទចោទក្នុងសំណុំរឿង ០០២/០២[362] អង្គជំនុំជម្រះសាលាដំបូងបានស្វែងរកការបញ្ជាក់បន្ថែមពីសាក្សីដទៃបន្ថែមទៀតមុនពេលសំអាងទៅលើសក្ខីកម្មរបស់ ឆោម សែ ក្នុងសំណុំរឿង ០០២/០១។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា សក្ខីកម្មរបស់ ឆោម សែ ដែលថា "អ្នកសួរចម្លើយបានបង្ខំអ្នកជាប់ឃុំឱ្យបង្ហាញ'ល្បិចកល' ឬ'យុទ្ធសាស្ត្រ'" [...] ត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងរបស់សាក្សី មឿង ចាន់ឌី ដែលឆ្លើយថា លោកស្រីត្រូវបានសួរដដែលៗអំពីការជាប់ពាក់ព័ន្ធជាមួយយួនដែលលោកស្រីបានបដិសេធច្បាស់លាស់"[363]។ នៅពេលប្រឈមជាមួយនឹងភាពពុំស៊ីសង្វាក់គ្នារវាងចម្លើយរបស់ ឆោម សែ ពាក់ព័ន្ធទៅនឹងការធ្វើបាបអ្នកជាប់ឃុំក្នុងពេលសួរចម្លើយ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវការកម្រិតនៃសក្ខីកម្មនេះ និងបានយល់ឃើញថា "ភស្តុតាងរបស់គាត់ពុំត្រូវបានសួរដេញដោលបន្ថែមទៀតក្នុងវគ្គសវនាការក្រោយក្តី" និងបានសំអាងទៅលើសាក្សីផ្សេងទៀត ដើម្បីបញ្ជាក់បន្ថែមលើការរៀបរាប់អំពីការធ្វើបាបដោយអ្នកសួរចម្លើយ[364]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងការសំអាងទៅលើសក្ខីកម្មរបស់ ឆោម សែ ក្នុងសំណុំរឿង ០០២/០១ នៅពេលបង្កើតការយល់ឃើញក្នុងសំណុំរឿង ០០២/០២។ ការចោទប្រកាន់ជាក់លាក់របស់គាត់អំពីការសំអាងទៅលើសក្ខីកម្មរបស់ ឆោម សែ ក្នុងសំណុំរឿង ០០២/០១ នៅពេលធ្វើការសន្និដ្ឋានពាក់ព័ន្ធទៅនឹងការសម្លាប់របស់ជនជាតិវៀតណាមនៅអូរកន្សែង និងការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាម នឹងត្រូវដោះស្រាយក្នុងផ្នែកពាក់ព័ន្ធខាងក្រោម[365]។

## ខ. អែម អឿន

---

[360] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦៨ និងជើងទំព័រ ៩៧៩២។

[361] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៧៣, ២៨៧៤, ២៨៧៨ និងជើងទំព័រ ៩៨១៩, ៩៨២៦, ៩៨៣៣។

[362] ប្រតិចារឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ១៣-១៩ (*ឧទាហរណ៍* ទាក់ទងទៅនឹងការចាប់ខ្លួន និងការសម្លាប់ក្រុមជនជាតិចារ៉ាយ)។

[363] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៩៩។

[364] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩០២។

[365] *សូមមើលខាងក្រោម* ផ្នែក VII.ខ.២.ច (ការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់នៅអូរកន្សែង)។

139. ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សក្ខីកម្មរបស់ អែម អឿន អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានកំណត់អត្តសញ្ញាណជាចម្បងដើម្បីផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងការដឹងរបស់គាត់ស្តីពីក្រសួងឃោសនាការ និងការអប់រំផ្នែកនយោបាយដោយជនជាប់ចោទ[366]។ ទោះជាយ៉ាងណាក្តី ក្នុងអំឡុងពេលនៃការជំនុំជម្រះទាំងពីរ គាត់បានផ្តល់សក្ខីកម្មស្តីពីប្រធានបទដទៃទៀតពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២[367] រួមបញ្ចូលគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងពុទ្ធសាសនា[368]។ កំណត់ត្រាការជំនុំជម្រះបង្ហាញថា បន្ទាប់ពីសក្ខីកម្មរបស់ អែម អឿន លើប្រធានបទស្តីពីពុទ្ធសាសនា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យ អែម អឿន និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលសួរសំណួរត្រូវកម្រិតសំណួរ និងចម្លើយរបស់ខ្លួនត្រឹមវិសាលភាពសំណុំរឿង ០០២/០១ និងត្រូវចងចាំថា "យើងបច្ចុប្បន្នកំពុងពិនិត្យលើអង្គហេតុពាក់ព័ន្ធទៅនឹងដំណាក់កាលទីមួយ និងទីពីរនៃការផ្លាស់ទីប្រជាជន"[369]។ ប្រហាក់ប្រហែលគ្នានេះ

[366] សេចក្តីសម្រេចស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (F312) កថាខណ្ឌ ៣៦។

[367] សេចក្តីសម្រេចស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (F312) កថាខណ្ឌ ៣៦។ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1។ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/116.1។ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ (នង សុផង់) ឯកសារលេខ E1/117.1។

[368] ប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៦១ ("ខ្ញុំស្រឡាញ់ណាស់ព្រះពុទ្ធសាសនានៅពេលនោះ គឺខ្ញុំជាយុវជនដែរនៅពេលនោះ ខ្ញុំស្រឡាញ់ណាស់ព្រះពុទ្ធសាសនា ប៉ុន្តែបក្សតម្រូវឱ្យបំផ្លាញវត្តអារាម ឬក៏មិនឱ្យព្រះសង្ឃបួស តើឲ្យខ្ញុំដោះស្រាយ បើខ្ញុំមិនធ្វើខ្ញុំមានបញ្ហាដល់បក្ស [...]។ បំផ្លាញគឺការចាប់ផ្តើមពីមិនឲ្យយុវជនទៅបួសមួយ។ [...] មិនឲ្យចាស់ទុំសាងវត្តអារាម")។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ៧-៩។

[369] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៦២ ("លោក អែម អឿន លោកគប្បីកំហិតនូវចម្លើយរបស់លោកតបត្រឹមតែភាពចាំបាច់ទៅនឹងសំណួរដែលសួរបានហើយ។ ចៀសវាងការធ្វើអត្ថាធិប្បាយលាតត្រដាងផុតពីឆ្ងាយផុតពីសំណួរ គោលបំណងនៃការសួរ។ ហើយលោកមេធាវីទទួលសិទ្ធិដូចគ្នា។ លោកមានពេលសរុបទាំងសហព្រះរាជអាជ្ញាគឺមានពេល១ថ្ងៃ បូកជាមួយនឹងមួយភាគបួនថ្ងៃ។ ហើយអង្គហេតុដែលធ្វើសវនាការនេះគឺចាប់ផ្តើមពី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ០៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយយើងបានកំហិតត្រឹមតែសំណុំរឿង ០០២/០១។ នេះជាអង្គហេតុដែលត្រូវធ្វើសវនាការ។ ចៀសវាងសំណួរចាកឆ្ងាយពីអង្គហេតុដែលមិនជាប់ពាក់ព័ន្ធ វានឹងមិនមាន នឹងមិនរួមវិភាគទានអ្វីក្នុងការស្វែងរកការពិតទេ ក្នុងដំណើរការដេញដោលនេះ ប្រសិនបើវាមិនចូលទៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ចំពោះជនជាប់ចោទ")។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ៩-១០ ("អង្គជំនុំជម្រះចង់រំឭកសហព្រះរាជអាជ្ញាផងដងដែរថា ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ពុំមែនជាផ្នែកនៃកិច្ចដំណើរការជំនុំជម្រះ។

ដែរ បន្ទាប់ពីសក្ខីកម្មរបស់ អែម អឿន ស្តីពីការរៀបអាពាហ៍ពិពាហ៍របស់គាត់ដោយបង្ខំ[370] ភាគីជាថ្មីម្តងទៀតត្រូវបានណែនាំឱ្យកម្រិតសំណួររបស់ខ្លួនត្រឹមវិសាលភាពនៃសំណុំរឿង ០០២/០១[371]។ បើទោះបីជា អៀង សារី និង ខៀវ សំផន អាចសួរសំណួរ អែម អឿន អំពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការលែងលះក្រោយមក និងការរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធទីពីរ[372]ក៏ដោយ ក៏សំណួរទាំងនេះជាប់ពាក់ព័ន្ធទៅនឹងភាពពុំស៊ីសង្វាក់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ជាជាងការសួរដេញដោលខ្លឹមសារលើប្រធានបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែរ។

140. បើទោះបីជានេះជាការត្រឹមត្រូវដែលថា ខៀវ សំផន និងភាគីដទៃទៀត ត្រូវបានហាមឃាត់សមស្របក្នុងការសួរសំណួរ អែម អឿន ពេញលេញអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់គាត់ និងការដឹងអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងពុទ្ធសាសនិកក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ ដោយសារបញ្ហានេះពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះទីមួយក៏ដោយ ក៏ពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានហាមឃាត់ក្នុងការពិចារណាលើសក្ខីកម្មរបស់ អែម អឿន ស្តីពីប្រធានបទទាំងនេះនៅក្នុងការជំនុំជម្រះលើកទីពីរដែលមានភស្តុតាងជាប់ពាក់ព័ន្ធគ្នានោះដែរ[373]។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានកម្រិតត្រឹមជាប់ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបាន

---

យើងបច្ចុប្បន្នកំពុងពិភាក្សា ឬសួរសំណួរលើការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ [...] និងការជម្លៀសប្រជាជន ដំណាក់កាលទី ១ និងទី ២")(សេចក្តីបញ្ជាក់បន្ថែម)។

[370] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៨០-៨១។

[371] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩២ ("មេធាវីការពារក្តី នៅពេលយើងពិភាក្សាអំពីដំណាក់កាលទីមួយនៃការជំនុំជម្រះ អំពើមនុស្សអនុស្សធម៌ដទៃទៀតត្រូវបានដកចេញរួចហើយពីដំណាក់កាលទីមួយនេះ។ បច្ចុប្បន្ន យើងកំពុងផ្តោតទៅលើការផ្លាស់ទីដោយបង្ខំដំណាក់កាល ១ និង ២។ ដូច្នេះ យើងសូមមេធាវីការពារក្តីកំហិតសំណួររបស់ខ្លួនត្រឹមផ្នែកទីមួយនៃការជំនុំជម្រះសំណុំរឿង ០០២/០១")(សេចក្តីបញ្ជាក់បន្ថែម)។

[372] ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/116.1 ទំព័រ ៦១-៦៤, ៧១-៧២។

[373] ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២ ("អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គួរតែត្រូវបានគិតគូរពិចារណានូវកម្រិតនៃសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានបំបែកមកធ្វើសវនាការកម្រិតក្នុងសំណុំរឿង ០០២/០១ បានហើយ ចៀសវាងការចេញឆ្ងាយពីអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការនេះ។ សូមានការចាប់អារម្មណ៍លើចំណុចនេះឱ្យខ្លាំងដើម្បីបង្កើននូវប្រសិទ្ធិភាពនៃកិច្ចដំណើរការសវនាការរបស់យើង")។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ១០ ("កាលពីធ្វើសវនាការសប្តាហ៍មុន កត់សម្គាល់ថា [...] សហមេធាវីនាំមុខ មានអង្គហេតុ មានសំណួរជាច្រើនក្រៅអង្គហេតុ។ អីចឹងហើយបានជារំឭកបញ្ហានេះ។ យើងព្យាយាមមិនកាត់ទេ យើងព្យាយាមរំឭក")។

ផ្អែកលើសក្ខីកម្មរបស់ អែម អឿន បន្ថែមលើនេះត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងដទៃទៀតក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញហេតុការណ៍ក្នុងករណីអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងវិធីសាស្ត្ររបស់ខ្លួន។ ជាឧទាហរណ៍ នៅក្នុងការយល់ឃើញអំពី"ភស្តុតាងនៃពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានកើតឡើងក្នុងទីតាំងផ្សេងៗទូទាំងប្រទេសកម្ពុជាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង [...] ខេត្តព្រៃវែង"[374] អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែបានសំអាងទៅលើ អែម អឿន ប៉ុណ្ណោះទេ ថែមទាំងលើ ម៉ី សារឿន ដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[375] ហើយសក្ខីកម្មរបស់អ្នកទាំងពីរនេះត្រូវបានដាក់ឱ្យស្ថិតក្រោមការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន[376]។

141. បន្ថែមលើនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនជាចុងក្រោយបានយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយសារក្រោយពីបានបដិសេធជាច្រើនលើកពីដំបូង ពួកគេត្រូវបានគំរាមកំហែងដោយរដ្ឋអំណាច"[377] ពុំមែនផ្អែកតែទៅលើសក្ខីកម្មរបស់ អែម អឿន ប៉ុណ្ណោះទេ ថែមទាំងចម្បងលើសាក្សីបីនាក់ដទៃទៀត ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ហើយសក្ខីកម្មរបស់ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមការសួរដេញដោលក្នុងវិសាលភាពនៃរឿងក្តីនេះ និងបានគាំទ្រការយល់ឃើញនោះ[378]។ ចំពោះផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានផ្តល់សក្ខីកម្មក្នុងតុលាការអំពីបទពិសោធន៍គួរឱ្យរន្ធត់ និងអារម្មណ៍អវិជ្ជមាននៅពេលដែលពួកគេបានដឹងថា ត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលខ្លួនពុំដែលបាន

---

[374] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៧។

[375] ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ (ម៉ី សារឿន) ឯកសារលេខ E1/459.1 ទំព័រ ១៩។

[376] ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ (ម៉ី សារឿន) ឯកសារលេខ E1/459.1 ទំព័រ ៦៤-៦៥, ៦៩-៧០។

[377] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២១។

[378] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២១ និងជើងទំព័រ ១២០៩២ យោងទៅលើប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៧០។ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/461.1 ទំព័រ ៧២។ ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ (ចៅ ឡាង) ឯកសារលេខ E1/339.1 ទំព័រ ៥៥, ៥៩។

ស្គាល់។ ពួកគាត់ភាគច្រើនបានរំឭកថា បានបង្ហូរទឹកភ្នែក និងសោកសៅ ខកចិត្ត និងភ័យព្រួយក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍[379]។

ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានផ្អែកលើសក្ខីកម្មរបស់សាក្សីជាច្រើនក្រៅតែពី អែម អឿន ម្នាក់នោះ[380]។ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងចេញពីសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក នឹងត្រូវពិភាក្សាខាងក្រោមនេះ។

### គ. គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក

142. ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសាក្សីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ក្នុងការយល់ឃើញថា គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិកមានអត្ថិភាពពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានអះអាងថា ការកំណត់បែបនេះពុំអាចធ្វើទៅបាន ដោយសារវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានកម្រិតត្រឹមការស្តាប់សក្ខីកម្មស្តីពុទ្ធសាសនាដែលជាប់ពាក់ព័ន្ធតែទៅនឹងបរិបទនៃសាវតាររបស់កម្ពុជាប្រជាធិបតេយ្យ[381]។ គាត់បានយោងទៅលើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ អែម អឿន, ពាន ឃាន, យុន គីម, ខៀវ អេន, ហ៊ុន ឈុនលី, ពិន យ៉ាថៃ, នូ ម៉ៅ, គីម វ៉ាន់ឌី, ស៊ឹម ហោ, អុង ចុងហៀង, ក្លាន វុិត និង សូផាន់ សូវណ្ណី[382]។

143. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដូចការអះអាងត្រឹមត្រូវរបស់ ខៀវ សំផន វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានកម្រិតត្រឹមការវិវឌ្ឍន៍នៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិកនៅក្នុងបរិបទសាវតារ។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា៖

> គោលបំណងនៃការរួមបញ្ចូលការយោងទៅលើ[គោលនយោបាយនានាជាជាងគោលនយោបាយពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ] នៅក្នុងការជំនុំជម្រះលើកទីមួយ គឺដើម្បីបង្ហាញនូវលក្ខណៈដែលគោល

---

[379] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩។

[380] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ និងជើងទំព័រ ១២២៧៤ យោងទៅលើ*ក្នុងចំណោមនោះ* ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ២៩-៣២។ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ (ប៉ែន សុចាន់) ឯកសារលេខ E1/482.1 ទំព័រ ៥១។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (កុល ណែម) ឯកសារលេខ E1/488.1 ទំព័រ ៦៩-៧០។

[381] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៤។

[382] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងជើងទំព័រ ១៨៦។

នយោបាយនោះត្រូវបានបង្កើតឡើង។ អាស្រ័យហេតុនេះ អ្វីដែលរំពឹងទុកនោះគឺការបង្ហាញទូទៅនូវគោលនយោបាយប្រាំ បើទោះបីជាបញ្ញាសត្យានុម័តសម្រាប់ការសួរដេញដោលក្នុងការជំនុំជម្រះលើកដំបូងត្រូវបានកម្រិតត្រឹមការផ្លាស់ទីប្រជាជនដោយបង្ខំ(ដំណាក់កាលទីមួយ និងទីពីរ)ក៏ដោយ។ ដូច្នេះ ពុំមានការសួរដេញដោលអំពីការអនុវត្តន៍គោលនយោបាយនានា ជាជាងគោលនយោបាយពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដោយបង្ខំ(ដំណាក់កាលទីមួយ និងទីពីរ)[383]។

144. ទោះជាយ៉ាងណាក្តី តាមការជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតច្រើនលើកឱ្យសួរសំណួរពាក់ព័ន្ធទៅនឹងពុទ្ធសាសនា ឬសាសនាផ្សេងៗក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជាឧទាហរណ៍ ពាន ឃាន ត្រូវបានសួរសំណួរស្តីពីការដឹងរបស់គាត់អំពីការប្រព្រឹត្តទៅលើព្រះសង្ឃ និងវត្តអារាមក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[384] និងសក្ខីកម្មរបស់ យុន គីម ទាក់ទងទៅនឹងពុទ្ធសាសនា បានជាប់ពាក់ព័ន្ធទៅនឹងរយៈពេលនៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[385]។ ពុំមានភាគីណាមួយបានជំទាស់ទៅនឹងវិសាលភាពនៃការសួរដេញដោលនេះ ហើយភាគីទាំងអស់ត្រូវបានផ្តល់ឱកាសសួរសំណួរនោះ[386]។ បន្ថែមលើនេះ មេធាវីការពារក្តី នួន ជា ជាពិសេសបានសួរសំណួរ យុន គីម ទាក់ទងទៅនឹងការ

---

[383] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E141) ទំព័រ ២។

[384] ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ (ពាន ឃាន) ឯកសារលេខ E1/71.1 ទំព័រ ៤១ (“តើព្រះសង្ឃលោកដែលឃើញព្រះសង្ឃអីនៅតាមវត្តទេ? ឆ៖ កាលមុនរំដោះភ្នំពេញ គឺមានវត្តអារាមធម្មតា។ លោក មានលោក មានវត្ត មានអីធម្មតា ហើយប្រជាជនតែងតែគោរពបូជាធម្មតានៅពេលនោះមុន ៧៥។ ស៖ ចៅក្រោយមក? ឆ៖ ក្រោយ៧៥ គឺអត់មានទេ អត់មាន អស់ហើយលោក វត្តអារាមអី ក៏កន្លែងខ្លះក៏រុះរើអីចឹងលោកអាចារ្យអីអត់មានទេ អស់រលីងហើយ។ ស៖ លោកបានដឹងថា តើគេយកព្រះសង្ឃហ្នឹងទៅណាដែរ តើលោកដឹងទេ? ឆ៖ ខ្ញុំក៏មិនបានដឹងថា គេយកព្រះសង្ឃទៅកន្លែងណាទេ ប៉ុន្តែតាមដឹង និយាយតៗគ្នាថា ប្រជាជនដឹងថា លោកហ្នឹងត្រូវសឹក ត្រូវសឹកទាំងអស់ មិនឱ្យមានលោកទៀតទេ”)។

[385] ប្រតិចារឹក ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ (យុន គីម) ឯកសារ E1/88.1 ទំព័រ ៤០ (“ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះរវាងខែ មេសា ឆ្នាំ ១៩៧៥ រហូត មករា ឆ្នាំ ១៩៧៩ តើមប្រជាជននៅខេត្តក្រចេះ ត្រូវបានអង្គការគេឱ្យប្រតិបត្តិជំនឿសាសនាដែរ ឬទេ?” ឆ៖ ព្រះពុទ្ធសាសនានៅក្នុងខេត្តក្រចេះ បានត្រូវបញ្ចប់នៅឆ្នាំ ១៩៧៦។ ក្រោយពីយើងរំដោះនៅមានទេ នៅមានព្រះសង្ឃទេ។ ព្រះសង្ឃនៅវត្តខ្ញុំហើយ ឆ្នាំ ៧៦ ប្រហែលជារវាងខែ ៧ ខែ ៨ ហ្នឹង នៅសល់មួយអង្គ ហើយនិងនៅក្រគរហ្នឹង វត្តក្រគរពីរបីអង្គ ព្រោះខ្ញុំជូនលោកវត្តខ្ញុំហ្នឹងមកក្រគរ ដើម្បីរកកាណូតជូនលោកឱ្យទៅស្រុកលោកវិញ ស្រុកពាមជាំង អូររាំងឪ។ ដល់ចឹងខ្ញុំមក គ្រាន់តែឃើញលោកនៅវត្តក្រចេះនេះពីរបីអង្គ លោកតាៗ អីចឹងបានន័យថា នៅខេត្តក្រចេះនេះវាអាចអស់ព្រះសង្ឃនៅឆ្នាំ ១៩៧៦។ ឯនៅ ៧៥ អីនៅមានទេ នៅមានព្រះសង្ឃទេ ប៉ុន្តែដឹងថាដល់ ៧៦ ហ្នឹគឺបញ្ចប់។ ៧៦ មិនមែនដើមទៀត ប្រហែលចុង ៧៦”)។

[386] *សូមមើល ឧ.* ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ (យុន គីម) ឯកសារលេខ E1/89.1 ទំព័រ ៧១-៨៤ (ការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន)។

ចាប់ផ្សឹកព្រះសង្ឃ[387] ហើយ ខៀវ សំផន ក៏មានឱកាសដូចគ្នាផងដែរ។ ភស្តុតាងរបស់ ហ៊ុន ឈុនលី ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់វត្តអារាមធ្វើជាមន្ទីរឃុំឃាំង ឬកន្លែងបណ្តុះបណ្តាលត្រូវបានសួរដោយមេធាវីការពារក្តី នួន ជា ក្នុងបរិបទនៃសំណួរអំពីការជម្លៀសប្រជាជនក្នុងខេត្តបាត់ដំបងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[388]។

145. ភស្តុតាងរបស់ គីម វ៉ាន់ឌី ទាក់ទងទៅនឹងការបោះបង់/ការហាមឃាត់ពិធីបុណ្យសពតាមពុទ្ធសាសនាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្តល់ក្នុងបរិបទនៃការជម្លៀសទីក្រុងភ្នំពេញ និងការស្លាប់ម្តាយរបស់គាត់ក្រោយមក[389]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន អាចពិនិត្យសាក្សីនេះក្នុងបរិបទនៃសំណួរដែលបានតាំងឡើងដោយភាគី ប៉ុន្តែគាត់បានជ្រើសរើសពុំធ្វើដូច្នោះ[390]។ បន្ថែមលើនេះ ពិន យ៉ាថៃ ត្រូវបានសួរនូវអ្វីដែលបានកើតឡើងចំពោះព្រះសង្ឃជាពិសេសក្នុងវត្តមួយក្នុងបរិបទនៃការផ្លាស់ពីប្រជាជនដោយបង្ខំក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[391] និងការសួរសំណួរលើ ស៊ឹម ហោ បានជាប់ពាក់ព័ន្ធទៅនឹង*ក្នុងចំណោមនោះ* រចនាសម្ព័ន្ធនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ[392]។ ក្នុងបរិបទនេះ គាត់ត្រូវបានសួរដេញដោលអំពីបទបញ្ជាពីថ្នាក់លើ

---

[387] ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ (យុន គីម) ឯកសារលេខ E1/89.1 ទំព័រ ៦១-៦៧។

[388] *ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ (ហ៊ុន ឈុនលី) ឯកសារលេខ E1/150.1 ទំព័រ ២៣ (ដោយលើកឡើងថា ក្នុងខេត្តបាត់ដំបង "វត្តព្រះពុទ្ធសាសនាមួយចំនួន គឺថាធ្វើជាគុក១ដាក់អ្នកទោស ហើយវត្តមួយទៀតធ្វើជាកន្លែងឃុំឃាំង ឧទាហរណ៍ មានវត្តមួយជាកន្លែងគេរៀនសូត្រនះកាត់")។ *សូមមើលបន្ថែម* ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ (ហ៊ុន ឈុនលី) ឯកសារលេខ E1/149.1 ទំព័រ ៤៧-៤៨។

[389] ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ (គីម វ៉ាន់ឌី) ឯកសារលេខ E1/149.1 ទំព័រ ១០ ("ស្លាប់ហ្នឹង បើតាមយើងគិតពីជំនាន់មុនហើយមកជំនាន់ហ្នឹង គឺវាខុសគ្នាសឹងតែថាដូចមេឃ និងដី។ ស្លាប់ជំនាន់មុន យើងមានលោកមានអី បង្សុកូល សូត្រ ត្រឹមត្រូវ។ ដល់ពេលជំនាន់ហ្នឹង គឺស្លាប់ដូចសត្វ ដូចធាតុអញ្ចឹង")។

[390] ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ (គីម វ៉ាន់ឌី) ឯកសារលេខ E1/149.1 ទំព័រ ២២-២៣។

[391] ប្រតិចារឹក ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ១៨-១៩។

[392] សេចក្តីសម្រេចស្តីពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (F312) កថាខណ្ឌ ៤២ (សក្ខីកម្មរបស់ ស៊ឹម ហោ ពាក់ព័ន្ធ*ក្នុងចំណោមនោះ* លើលក្ខណៈពិសេសជាច្រើននៃរចនាសម្ព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ)។ ប្រតិចារឹកថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ឹម ហោ) ឯកសារលេខ E1/206.1 ទំព័រ ៦៤ ("ការពិត កិច្ចប្រជុំធ្វើឡើងក្នុងវត្ត។ គេប្រាប់យើងឱ្យមើលលើ និងឃើញផ្ទាំងគំនូរក្នុងវត្ត។ មានគំនូរូបព្រះពុទ្ធ និងព្រះសង្ឃ និងគាត់ប្រាប់ថា គ្មានប្រយោជន៍ទុកគំនូរនេះទេ។ ពីរបីថ្ងៃក្រោយមក វត្តអារាមនៅភ្នំពេញត្រូវបានដាក់មីនបំផ្លាយ ហើយខ្មែរក្រហមប្រើឱ្យព្រះសង្ឃបំផ្លាញវត្តទួលទំពូងដើម្បីយកថ្មទៅធ្វើផ្លូវ")។

របស់គាត់ឱ្យកម្ទេចផ្ទាំងគំនូរ និងអាគារក្នុងវត្តទួលទំពូងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[393]។ ពុំមានភាគីណាបានជំទាស់ទៅនឹងវិសាលភាពនៃការសួរសំណួរ និងក្រោយមក គាត់ត្រូវបានសួរដេញដោល ដោយមេធាវីការពារក្តី ខៀវ សំផន[394]។

146. ទាក់ទងទៅនឹង អែម អឿន អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ពីដំបូងថា បន្ទាប់ពីមានសំណួរមួយចំនួនទាក់ទងទៅនឹងពុទ្ធសាសនា អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ភាគីឱ្យកម្រិតសំណួររបស់ខ្លួនត្រឹមវិសាលភាពនៃរឿងក្តី និងផ្តោតទៅលើការផ្លាស់ទីប្រជាជន[395]។ ប្រហាក់ប្រហែលគ្នានេះ ក្នុងអំឡុងពេលការផ្តល់សក្ខីកម្មរបស់ ក្លាន វិត ភាគីត្រូវបានរំឭកជាថ្មីម្តងទៀតឱ្យលើកសំណួរណាដែលពាក់ព័ន្ធតែវិសាលភាពសំណុំរឿង ០០២/០១[396]។ សក្ខីកម្មរបស់ ក្លាន វិត ដែលថា គាត់ពុំត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិសាសនា

---

393 ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ (ស៊ឹម ហោ) ឯកសារ E1/206.1 ទំព័រ ៧៩-៨០។

394 ប្រតិចារឹក ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E1/207.2។

395 ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៦២ (“លោក អែម អឿន លោកគប្បីកំហិតនូវចម្លើយរបស់លោកតបត្រឹមតែភាពចាំបាច់ទៅនឹងសំណួរដែលសួរបានហើយ។ ចៀសវាងការធ្វើអត្ថាធិប្បាយលាតត្រដាងផុតពីឆ្ងាយផុតពីសំណួរ គោលបំណងនៃការសួរ។ ហើយលោកមេធាវីទទួលសិទ្ធិដូចគ្នា។ លោកមានពេលសរុបទាំងសហព្រះរាជអាជ្ញាគឺមានពេល១ថ្ងៃ បូកជាមួយនឹងមួយភាគបួនថ្ងៃ។ ហើយអង្គហេតុដែលធ្វើសវនាការនេះគឺចាប់ផ្តើមពី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ០៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយយើងបានកំហិតត្រឹមតែសំណុំរឿង ០០២/០១។ នេះជាអង្គហេតុដែលត្រូវធ្វើសវនាការ។ ចៀសវាងសំណួរចាកឆ្ងាយពីអង្គហេតុដែលមិនជាប់ពាក់ព័ន្ធ វានឹងមិនមាន នឹងមិនរួមវិភាគទានអ្វីក្នុងការស្វែងរកការពិតទេ ក្នុងដំណើរការដេញដោលនេះ ប្រសិនបើវាមិនចូលទៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ចំពោះជនជាប់ចោទ”)។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ៩-១០ (“អង្គជំនុំជម្រះចង់រំឭកសហព្រះរាជអាជ្ញាផងដងដែរថា ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ពុំមែនជាផ្នែកនៃកិច្ចដំណើរការជំនុំជម្រះ។ យើងបច្ចុប្បន្នកំពុងពិភាក្សា ឬសួរសំណួរលើការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ […] និងការជម្លៀសប្រជាជន ដំណាក់កាលទី ១ និងទី ២”)។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២ (“អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គួរតែត្រូវបានគិតគូរពិចារណានូវកម្រិតនៃសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានបំបែកមកធ្វើសវនាការកម្រិតក្នុងសំណុំរឿង ០០២/០១ បានហើយ ចៀសវាងការចេញឆ្ងាយពីអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការនេះ។ សូមានការចាប់អារម្មណ៍លើចំណុចនេះឱ្យខ្លាំងដើម្បីបង្កើននូវប្រសិទ្ធិភាពនៃកិច្ចដំណើរការសវនាការរបស់យើង”)។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ១០ (“កាលពីធ្វើសវនាការសប្តាហ៍មុន កត់សម្គាល់ថា […] សហមេធាវីនាំមុខ មានអង្គហេតុ មានសំណួរជាច្រើនក្រៅអង្គហេតុ។ អីចឹងហើយបានជារំឭកបញ្ហានេះ។ យើងព្យាយាមមិនកាត់ទេ យើងព្យាយាមរំឭក”)។

396 ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ (ក្លាន វិត) ឯកសារលេខ E1/17.1 ទំព័រ ៤៩ (“យើងសូមរំឭកថា សក្ខីកម្មនេះត្រូវតែជាប់ពាក់ព័ន្ធទៅនឹងសវនាការនៅដំណាក់កាលទីមួយ។ មិនមែនគ្រាន់តែអត្ថិភាពឯកសារនៅក្នុងសំណុំរឿងលើកត្រង់ណាក៏បាន

បានជាប់ពាក់ព័ន្ធទៅនឹងរយៈពេលនៅមុនកម្ពុជាប្រជាធិបតេយ្យ និងដូច្នេះ ត្រូវបានចាត់ទុកថា ស្ថិតក្នុងវិសាលភាពនៃសំណួរសំណុំរឿង ០០២/០១[397]។ តាមការសង្កេតឃើញថា ខៀវ សំផន បានជ្រើសរើសពុំសួរដេញដោលសាក្សីនេះទាល់តែសោះ[398]។ ប្រហាក់ប្រហែលគ្នានេះ សក្ខីកម្មរបស់ នូ ម៉ៅ និង ខៀវ អេន ពាក់ព័ន្ធទៅនឹងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ និងអាស្រ័យហេតុនេះ អាចស្ថិតក្នុងវិសាលភាពនៃសំណួរសំណុំរឿង ០០២/០១[399]។

147. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងរបស់ ខៀវ សំផន ដែលថា គាត់"បានផ្ដោតទៅលើអង្គហេតុក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងជាក់ស្ដែងពុំចំណាយពេលដែលត្រូវបានផ្ដល់ឱ្យ [...] ក្នុងការសួរដេញដោលសាក្សីទាំងនេះអំពីពុទ្ធសាសនាក្រោយឆ្នាំ ១៩៧៥" ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ ដោយសារការសួរដេញដោលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីខាងលើស្ថិតក្នុងវិសាលភាពនៃសំណួរដែលត្រូវបានអនុញ្ញាតក្នុងសំណុំរឿង ០០២/០១ ឬបានផុសចេញពីលំនាំនៃសំណួរក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ក្នុងបរិបទនៃការសួរសំណួរទាក់ទងទៅនឹងការផ្លាស់ទីប្រជាជន ឬស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ប៉ុន្តែត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូង។ ទោះជា

---

នោះទេ។ វាត្រូវតែជ្រើសរើសនូវភាពពាក់ព័ន្ធមកនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងកិច្ចដំណើរការសម្រាប់ធ្វើសវានាការទីមួយ។ ដូច្នេះកម្មវត្ថុសំខាន់នៃផ្នែកនេះគឺការជម្លៀសភ្នំពេញដំណាក់កាលដំបូង")(សេចក្ដីបញ្ជាក់បន្ថែម)។ ប្រតិចារឹក ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១១ (ក្លាន រ៉ុត) ឯកសារលេខ E1/17.1 ទំព័រ ៥១ ("ទីពីរ គឺការដែលពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយរបស់មេធាវីរបស់ នួន ជា បានកត់សម្គាល់ គឺប្រសិនជាអង្គហេតុនោះកើតឡើងនៅក្នុងអំឡុងឆ្នាំ ៧៨-៧៩ ទំនងជាឆ្ងាយពីអង្គហេតុដែលយើងកំណត់សម្រាប់ធ្វើសវនាការនេះ។ ពីព្រោះសវនាការនេះកំណត់នៅក្នុងអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងដំណាក់កាលនៃជម្លៀសទីមួយ និងទីពីរ។ គឺជម្លៀសទីក្រុងភ្នំពេញ ហើយនិងជម្លៀសទីពីរ គឺបណ្ដាលខេត្តមួយចំនួន ពីភូមិភាគកណ្ដាល ពីភូមិភាគនិរតីទៅកាន់ភូមិភាគពាយព្យ ហើយនិងភូមិភាគឧត្តរ។ នេះជាផែនការ អ៊ីចឹងរយៈពេលនេះ គឺមិនចូលទៅដល់ ៧៨ ឬក៏ ៧៧-៧៨ នោះទេ។ [...] សូមកំណត់សួរច្បាស់លាស់កាលបរិច្ឆេទនៃសំណួរផង ពីព្រោះបើសិនណា យើងប្រើសំណួរណាដែលហួសពីវិសាលភាពនៃអង្គហេតុដែលមានកំណត់សម្រាប់ធ្វើសវានាការលើកទីមួយនេះ វានឹងអាចនាំឱ្យមានកំហុសប្រាសចាក...") (សេចក្ដីបញ្ជាក់បន្ថែម)។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ក្លាង រ៉ុត) ឯកសារលេខ E1/25.1 ទំព័រ ៤៣-៤៤ ("អង្គហេតុពាក់ព័ន្ធនឹងសំណុំរឿងនេះ [សំណុំរឿង ០០២/០១] ត្រូវបានអនុញ្ញាតឱ្យសួរដេញដោលសាក្សី")។

[397] ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ (ក្លាន រ៉ុត) ឯកសារលេខ E1/17.1 ទំព័រ ៧៥-៧៦។ ឯកសារលេខ E1/24.1 ទំព័រ ៧៥។

[398] ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ក្លាង រ៉ុត) ឯកសារលេខ E1/25.1 ទំព័រ ៦៧។

[399] ប្រតិចារឹក ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៥៥។ ប្រតិចារឹក ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ (ខៀវ អេន) ឯកសារលេខ E1/128.1 ទំព័រ ៦៨-៦៩។

យ៉ាងណាក្ដី ខៀវ សំផន ជារឿយៗបានជ្រើសរើសមិនសួរដេញដោលសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនទាល់តែសោះ[400]។

148. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការយល់ឃើញថា "គោលនយោបាយដែលបង្កើតឡើងដោយមជ្ឈិមដើម្បីលុបបំបាត់ និងហាមឃាត់ការប្រតិបត្តិពុទ្ធសាសនាក្នុងកម្ពុជាប្រជាធិបតេយ្យមានអត្ថិភាពពេញមួយអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ"[401] បានផ្អែកលើសក្ខីកម្មរបស់សាក្សីជាច្រើនដែលត្រូវបានដកស្រង់ និងត្រូវបានស្ដាប់ក្នុងសំណុំរឿង ០០២/០២ បន្ថែមលើភស្តុតាងដែលត្រូវបានពិភាក្សាក្នុងផ្នែកស្ដីពីសហករណ៍ត្រាំកក់[402] និងសក្ខីកម្មរបស់សាក្សីដែល ខៀវ សំផន បានព្យាយាមជំទាស់។ ក្នុងការយល់ឃើញថា ភស្តុតាងបានបង្ហាញ"លំនាំស៊ីសង្វាក់ និងរីករាលដាលនៃការចាប់ផ្សឹកព្រះសង្ឃដោយបង្ខំក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មុនការបណ្ដេញចេញពីវត្តទូទាំងប្រទេស"[403] បន្ថែមលើសាក្សីប្រាំមួយនាក់ដែលបានផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសាក្សី១៧នាក់ទៀតដែលបានផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ដែលភស្តុតាងរបស់ពួកគាត់ត្រូវបានដាក់ឱ្យសួរដេញដោល ដោយមេធាវីការពារក្ដី ខៀវ សំផន[404]។ ជាឧទាហរណ៍ រៀល សន បានអះអាងថា ព្រះសង្ឃជាងមួយរយអង្គត្រូវបាន"ជម្លៀស"ចេញពីទីក្រុងភ្នំពេញ និងនៅកន្លែងផ្សេងទៀត ឱ ហូ បានផ្ដល់សក្ខីកម្មអំពីការចាប់ផ្សឹកព្រះសង្ឃក្នុងខេត្តកំពង់ធំ មាស ឡៃហួរ បានអះអាងថា ព្រះសង្ឃទាំងអស់ត្រូវចាប់ផ្សឹក(បើទោះបីជាលោកស្រីពុំអាចចាំឆ្នាំពិតប្រាកដ) ហ៊ុន សិត្ថានី បានជួបព្រះសង្ឃមួយអង្គដែលត្រូវបានបញ្ជាឱ្យសឹកក្នុងស្រុកបារ៉ាយ ឈិត យឿក បានផ្ដល់សក្ខីកម្មថា ព្រះសង្ឃត្រូវបានចាប់ផ្សឹកក្នុងស្រុកព្រះនេត្រព្រះ និងសាក្សីជាច្រើនដទៃទៀតបានផ្ដល់សក្ខីកម្មអំពីការចាប់ផ្សឹកព្រះសង្ឃក្នុងទីតាំងដទៃទៀត[405]។ ប្រហាក់ប្រហែលគ្នានេះ ក្នុងការយល់ឃើញថា "ភស្តុតាងបានបង្ហាញផងដែរនូវការបិទ និងការបំផ្លាញវត្ត" អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ កែវ លឿ ក្នុងសំណុំរឿង ០០២/០២ ដែលថា "គេប្រាប់

[400] ប្រតិចារឹក ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ (ខៀវ អេន) ឯកសារលេខ E1/128.1 ទំព័រ ៥៩។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (ក្លាង រិត) ឯកសារលេខ E1/25.1 ទំព័រ ៦៧។ ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ (គឹម វ៉ាន់ឌី) ឯកសារលេខ E1/149.1 ទំព័រ ២២-២៣។ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ (សូផាន់ សូវណ្ណី) ឯកសារលេខ E1/199.1 ទំព័រ ៥៥។

[401] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៧។

[402] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥។

[403] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥។

[404] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១៧, ៤០១៥ និងជើងទំព័រ ១៣៣០០។

[405] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣០០។

គាត់ថា វត្តនៅសម័យភូមិក្រោយត្រូវកម្ទេចចោល"[406] អ៊ុំ ស៊ន់ ដែលបានផ្តល់សក្ខីកម្មអំពីការបំផ្លាញវត្តក្នុងខេត្តសៀមរាប និង សុះ វំលី ដែលបានផ្តល់សក្ខីកម្មអំពីការបិទវត្ត"អមប្បវន្ត"[407]។

149. ទាក់ទងទៅនឹងការយល់ឃើញដែលថា វត្តអារាមត្រូវបានប្រើប្រាស់សម្រាប់គោលបំណងក្រៅពីសាសនា ដូចជា ធ្វើជាមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ឃ្លាំង និងការដ្ឋានធ្វើការ កន្លែងស្នាក់អាស្រ័យ និងសម្រាប់គោលបំណងកិច្ចការរដ្ឋបាល និងការប្រើប្រាស់ដែលជាការប្រមាថវត្ថុសក្តិសិទ្ធ[408] បន្ថែមលើចម្លើយរបស់សាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសាក្សីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[409] រួមទាំង ឱ ហូ ដែលបានផ្តល់សក្ខីកម្មអំពីការប្រែក្លាយវត្តទៅជាមន្ទីរសន្តិសុខក្នុងខេត្តកំពង់ធំ អ៊ុំ ស៊ន់ ដែលបានអះអាងថា វត្តមួយចំនួនក្នុងខេត្តសៀមរាបត្រូវបានប្រើប្រាស់ជារោងដាក់ស្រូវ ស៊ាន ស៊ង់ ដែលបានផ្តល់សក្ខីកម្មថា វត្តក្នុងខេត្តសៀមរាបត្រូវបានប្រើប្រាស់ជាកន្លែងស្នាក់នៅរបស់កងចល័ត បាន សៀក ដែលបានផ្តល់សក្ខីកម្មថា មន្ទីរពាណិជ្ជកម្មរបស់តំបន់ ៤២ មានទីតាំងស្ថិតនៅក្នុងវត្តខេត្តកំពង់ស្ពឺ និងសក្ខីកម្មដទៃទៀតបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[410]។ ការយល់ឃើញដទៃទៀតដែលរងការជំទាស់ស្តីពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនា ត្រូវបានគាំទ្រផងដែរដោយភស្តុតាងរបស់សាក្សីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[411]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ យុន គីម ដែលបានពិពណ៌នាអំពីការបំផ្លាញពុទ្ធសាសនាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/០១[412]។ ដូចបានពិភាក្សាខាងលើ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតការសួរដេញ

---

406 ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ (កែ លឿ) ឯកសារលេខ E1/316.1 ទំព័រ ២៥។

407 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣០១។

408 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥។

409 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣០២-១៣៣០៦។

410 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ ជើងទំព័រ ១៣៣០២-១៣៣០៦។

411 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥, ជើងទំព័រ ១៣៣០៧-១៣៣១២។

412 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣១៣។

ដោលទាក់ទងទៅនឹងបទចោទសំណុំរឿង ០០២/០២ រួមទាំងការសួរដោយមេធាវីការពារក្តី នួន ជា[413]។ បន្ថែមលើនេះ ការយល់ឃើញនេះត្រូវបានគាំទ្រដោយសាក្សីបន្ថែមទៀត[414]។

150. អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់សក្ខីកម្មរបស់ អែម អឿន ដើម្បីគូសបង្ហាញនូវការប៉ះទង្គិចផ្លូវចិត្តរបស់គាត់ដោយសារការបញ្ជាឱ្យកម្ទេចព្រះបដិមា[415]។ ដូចបានពិភាក្សាខាងលើ ដោយសារការសួរដេញដោលត្រូវបានកម្រិតត្រឹមវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយផ្តោតទៅលើប្រធានបទនៃការផ្លាស់ទីប្រជាជន ខៀវ សំផន ពុំអាចសួរ អែម អឿន ឱ្យបានពេញលេញស្តីពីប្រធានបទនេះទេ។ ដោយសារការដកស្រង់នេះត្រឹមតែជាការគូសបង្ហាញ និងការយល់ឃើញដែលថា "ព្រះបដិមា និងវត្ថុតំណាងសាសនាជាញឹកញាប់ត្រូវបានបំផ្លាញនោះ" ត្រូវបានគាំទ្រដោយភស្តុតាងបន្ថែមនោះ[416] ដូច្នេះពុំមានផលវិបាកកើតឡើងចំពោះការខ្វះឱកាសក្នុងការសួរដេញដោល អែម អឿន នោះឡើយ។

151. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសនៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មក្នុងសំណុំរឿង ០០២/០១ របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ស្តីពីប្រធានបទព្រះពុទ្ធសាសនា។ ពុំមានការបង្ហាញនូវភាពលម្អៀងនៅក្នុងសំអាងហេតុច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងវិធីសាស្ត្រអនុវត្តលើភស្តុតាងសំណុំរឿង ០០២/០១ ឡើយ។

### ៤. ការយល់ឃើញដទៃទៀតដែលបង្ហាញភាពលម្អៀង

---

[413] ប្រតិចារឹក ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ (យុន គីម) ឯកសារ E1/88.1 ទំព័រ ៤០ ("ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ រវាងខែ មេសា ឆ្នាំ ១៩៧៥ រហូត មករា ឆ្នាំ ១៩៧៩ តើមប្រជាជននៅខេត្តក្រចេះ ត្រូវបានអង្គការគេឱ្យប្រតិបត្តិជំនឿសាសនាដែរ ឬទេ?" ឆ៖ ព្រះពុទ្ធសាសនានៅក្នុងខេត្តក្រចេះ បានត្រូវបញ្ចប់នៅឆ្នាំ ១៩៧៦។ ក្រោយពីយើងរំដោះនៅមានទេ នៅមានព្រះសង្ឃទេ។ ព្រះសង្ឃនៅវត្តខ្ញុំហើយ ឆ្នាំ ៧៦ ប្រហែលជារវាងខែ ៧ ខែ ៨ ហ្នឹង នៅសល់មួយអង្គ ហើយនិងនៅក្រគរហ្នឹង វត្តក្រគរពីរបីអង្គ ព្រោះខ្ញុំជូនលោកវត្តខ្ញុំហ្នឹងមកក្រគរ ដើម្បីរកកាណូតជូនលោកឱ្យទៅស្រុកលោកវិញ ស្រុកពាមជាំង អូររាំងឪ។ ដល់ចឹងខ្ញុំមក គ្រាន់តែឃើញលោកនៅវត្តក្រចេះនេះពីរបីអង្គ លោកតា១ អីចឹងបានន័យថា នៅខេត្តក្រចេះនេះវាអាចអស់ព្រះសង្ឃនៅឆ្នាំ ១៩៧៦។ ឯនៅ ៧៥ អីនៅមានទេ នៅមានព្រះសង្ឃទេ ប៉ុន្តែដឹងថាដល់៧៦ហ្នឹគឺបញ្ចប់។ ៧៦ មិនមែនដើមទៀត ប្រហែលចុង៧៦")។ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ (យុន គីម) ឯកសារលេខ E1/89.1 ទំព័រ ៦១-៦៧។ (សំណួរត្រូវបានសួរដោយមេធាវីការពារក្តី នួន ជា)។

[414] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣១២។

[415] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៦។

[416] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥ និងជើងទំព័រ ១៣៣១០។

152. ចុងក្រោយ ផ្សេងគ្នាពីអំណះអំណាងរបស់គាត់ដែលចោទប្រកាន់អំពីភាពលម្អៀងចេញពីការបង្កើតការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន បានអះអាងថា កំហុសអង្គច្បាប់ ឬអង្គហេតុមួយចំនួនបានបង្ហាញអំពីភាពលម្អៀងក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការសួរដេញដោលភស្តុតាងទាំងមូល[417] វិធីសាស្ត្រលម្អៀងចំពោះអង្គច្បាប់[418] និងលម្អៀងក្នុងការដាក់ទោស[419]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ពុំបានបង្ហាញនូវភាពលម្អៀងជាក់ស្តែងក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់[420]។ សហមេធាវីនាំមុខបានឆ្លើយតបថា នេះជាការចោទប្រកាន់ដោយ“គ្មានការគិតគូរពិចារណា” និងគ្មានមូលដ្ឋានគាំទ្រ[421] ដែលអាចមានសក្តានុពលធ្វើឱ្យប៉ះពាល់ដល់ធម្មានុរូបរបស់តុលាការឡើយ។ផ្អែកតាមទស្សនៈរបស់សហមេធាវីនាំមុខបានឱ្យដឹងថា ការចោទប្រកាន់អំពីភាពលម្អៀងគប្បីត្រូវបានធ្វើឡើងដោយសុភវិនិច្ឆ័យ និងមូលដ្ឋានគាំទ្រគ្រប់គ្រាន់[422]។ សហមេធាវីនាំមុខបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មិនត្រឹមតែបដិសេធចោលនូវទឡ្ហីករណ៍បណ្តឹងសាទុក្ខទាក់ទងទៅនឹងភាពលម្អៀងប៉ុណ្ណោះទេ ថែមទាំងឱ្យបញ្ជាក់ច្បាស់ថា ការចោទប្រកាន់ដដែលៗគ្មានអ្វីប្លែកនូវភាពលម្អៀងពាសពេញបណ្តឹងសាទុក្ខ គ្មានមូលដ្ឋានគាំទ្រ[423]។

153. ឧទាហរណ៍នៃការចោទប្រកាន់ច្រំដែលនេះលើកឡើង*ក្នុងចំណោមនោះ*ថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវភាពលម្អៀង៖

- តាមរយៈកង្វះនៃការវិភាគ ឬការកំណត់និយមន័យផ្នែកច្បាប់ដែលនាំទៅរកការដាក់ទោសនៅពេលបង្កើតការយល់ឃើញថា “អាជ្ញាធរស្រុកត្រាំកក់បានប្រព្រឹត្តអំពើមនុស្សឃាតដោយសារ‘ការមិន’ចាត់វិធានការសមស្រប ដើម្បីកែប្រែ ឬសម្រាលលក្ខខណ្ឌនោះ”[424]

[417] *សូមមើល ឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥៧, ១២១១, ១២១៤, ១២២៩, ១២៣៩, ១២៤៤, ១២៥៩។

[418] *សូមមើល ឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៥។

[419] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤៥-២១៤៦។

[420] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥១។

[421] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨០, ៨៦-៨៧។

[422] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៦-៨៧។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៦៨-៦៩។

[423] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៦-៨៧។

[424] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៥។

- តាមរយៈ"ការមិនអើពើទាំងស្រុង"នូវការសួរដេញដោលរបស់មេធាវីការពារក្តីទាក់ទងទៅនឹងការយល់ឃើញដែលពុំត្រឹមត្រូវថា យាយ ហាយ និង តា យុត ត្រូវបានសម្លាប់ ដែលនេះបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់[425]
- តាមរយៈការបំភ្លៃសុន្ទរកថារបស់ ប៉ុល ពត ដែលគូសបង្ហាញគោលនយោបាយ"មួយទល់នឹង ៣០" និងការខកខានក្នុងការពិចារណាលើចម្លើយលម្អិតដែលបញ្ជាក់បន្ថែមរបស់អតីតកម្មាភិបាលយោធា "ដែលបានពន្យល់ថា សុន្ទរកថានេះក្នុងគោលបំណងលើកទឹកចិត្តកងកម្លាំងកម្ពុជាប្រជាធិបតេយ្យដែលមានចំនួនតិចជាង"[426]
- នៅក្នុងការវិភាគរបស់ខ្លួនលើចម្លើយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានលាក់បាំងភស្តុតាងសំខាន់ៗអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងការកំណត់យកជាករណីទូទៅដោយផ្អែកលើករណីជាក់លាក់[427]
- តាមរយៈការវាយតម្លៃលើភស្តុតាងដែលនាំទៅរកការសន្និដ្ឋានថា ការឈឺចាប់ដែលបានបណ្តាលមកពីការរួមភេទដោយបង្ខំ ឈានដល់កម្រិតមួយធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងកម្រិតនៃបទឧក្រិដ្ឋជាក់លាក់ទាំងនោះក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[428]
- តាមរយៈការបកស្រាយផ្សេងពីរដ្ឋធម្មនុញ្ញទៅតាមការចង់បានដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន[429]
- តាមរយៈការបំភ្លៃសេចក្តីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ដើម្បីបង្កើតការយល់ឃើញអំពីសិទ្ធិអំណាចបញ្ជាការកម្ទេចក្នុងបរិបទនៃការបោសសម្អាត[430]
- តាមរយៈការសំអាងដោយពុំត្រឹមត្រូវលើសុន្ទរកថាបីដែលគាំទ្រការយល់ឃើញរបស់ខ្លួនស្តីពីគោលបំណងរួម[431] និង
- តាមរយៈការបកស្រាយ និងវិធីសាស្ត្រអនុវត្តលើភស្តុតាងទាក់ទងទៅនឹងការដឹងរបស់ ខៀវ សំផន អំពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាលើពុទ្ធសាសនិកក្នុងស្រុកត្រាំកក់[432]។

---

[425] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៧ ជើងទំព័រ ១៨៦១។

[426] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣០។

[427] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៦, ១១៥៨។

[428] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១២។

[429] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥៥។

[430] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៣០។

[431] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០២។

[432] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១៨។

154. អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ការចោទប្រកាន់ទាំងនេះដែលមានអត្ថិភាពពាសពេញសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជាប់ពាក់ព័ន្ធទៅនឹងភាពលម្អៀងដែលកើតចេញពីសេចក្តីសម្រេចរបស់តុលាការ។ អង្គជំនុំជម្រះតុលាការកំពូលរំឮកថា "ការបង្ហាញអំពីភាពលម្អៀង ឬអត្ថិភាពនៃភាពលម្អៀង អាចត្រូវបានធ្វើឡើង*ក្នុងចំណោមនោះ*ដោយផ្អែកទៅលើការលើកឡើងដែលមាននៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចរបស់តុលាការដែលចោទជាបញ្ហានោះ" និងថា ការចោទប្រកាន់ត្រូវកំណត់គោលដៅលើការបង្ហាញថាតើ សំអាងហេតុនេះបានបង្ហាញកង្វះអនាគតិ ដែរ ឬយ៉ាងណា[433]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការចោទប្រកាន់របស់ ខៀវ សំផន ដោយសារការចោទប្រកាន់នេះត្រឹមតែមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ឬបានចោទប្រកាន់កំហុសអង្គហេតុ ឬអង្គច្បាប់ដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខប៉ុណ្ណោះ[434] ដែលនឹងត្រូវដោះស្រាយក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញជាធរមាន។ ការចោទប្រកាន់នេះទោះជាយ៉ាងណាក្តីពុំបានបង្ហាញការយល់ឃើញទាំងនេះត្រូវបានបង្កើតឡើងដោយសារការបុរេវិនិច្ឆ័យប្រឆាំងនឹង ខៀវ សំផន។

## ឃ. ការចោទប្រកាន់កំហុសក្នុងសេចក្តីសម្រេចលើភស្តុតាងដែលបានធ្វើឡើងក្នុងអំឡុងពេលនៃការជំនុំជម្រះ

155. ខៀវ សំផន បានអះអាងថា កង្វះអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញបន្ថែមទៀតក្នុង"វិធីសាស្ត្រលម្អៀងលើភស្តុតាង" ដែលបណ្តាលឱ្យមានកំហុសជាច្រើននៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីការទទួលយក និងការស្តាប់ភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ។ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធគ្នានេះបានចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីលំដាប់លំដោយនៃការបង្ហាញខ្លួនសាក្សី ការបង្ហាញភស្តុតាងចេញពីសំណុំរឿង ០០៣ និង ០០៤ ការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ រួមទាំងការខកខានក្នុងការបើកសវនាការឡើងវិញដើម្បីទទួលយកភស្តុតាងបន្ថែម និងការបដិសេធសំណើសុំកោះហៅឡើងវិញនូវសាក្សីមួយចំនួនដែលត្រូវបានស្តាប់ក្នុងសំណុំរឿង ០០២/០១។ គាត់បានលើកឡើងថា កំហុសនេះបានបណ្តាលឱ្យមានព្យសនកម្មលើរូបគាត់តាមរយៈការរំលោភបំពានលើសិទ្ធិជាច្រើននៃការទទួលបានការជំនុំជម្រះត្រឹមត្រូវ រួមទាំងសិទ្ធិទទួលបានការការពារ

---

[433] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១២។

[434] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងជំទាស់ដិតចិត្តថៅក្រម (E314/12/1) កថាខណ្ឌ ៣៦ ("ការពុំយល់ស្របជាមួយនឹងខ្លឹមសារនៃសេចក្តីសម្រេចគឺជាបញ្ហានៃបណ្តឹងសាទុក្ខជាជាងសំណើសុំដិតចិត្ត")។ សេចក្តីសម្រេចលើសំណើសុំដិតចិត្តរបស់ ខៀវ សំផន (១១) កថាខណ្ឌ ១០១។

ក្តីដោយប្រសិទ្ធភាព តម្លាភាពនៃកិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចមានសំអាងហេតុពេញលេញ ការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមស្រប និងសមភាពកម្លាំងតទល់ផ្លូវច្បាប់។

## ១. សេចក្តីសម្រេចស្តីពីការចូលបង្ហាញខ្លួនរបស់សាក្សី

156. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដែលស្តែងឱ្យឃើញតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដែលបណ្តាលឱ្យមានព្យសនកម្មលើគាត់តាមរយៈការសម្រេចស្តីពីលំដាប់លំដោយនៃការបង្ហាញខ្លួនរបស់សាក្សីខណៈពេលការជំនុំជម្រះកំពុងដំណើរការ ដែលខុសគ្នាទៅនឹងពេលចាប់ផ្តើមនៃការជំនុំជម្រះ និងតាមរយៈការពន្យារពេលចេញសំអាងហេតុសម្រាប់សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃការបង្ហាញខ្លួនសាក្សីនេះរហូតដល់ការបញ្ចប់សវនាការលើអង្គសេចក្តី[435]។

157. ខៀវ សំផន បានអះអាងថា "នៅពេលចោទប្រកាន់អំពីកង្វះតម្លាភាពរបស់អង្គជំនុំជម្រះសាលាដំបូង" និង "បានស្នើសុំជាច្រើនលើកនូវបញ្ជីឈ្មោះសរុបរបស់សាក្សីដែលត្រូវកោះហៅ" គាត់បាន"ពន្យល់អំពីការលំបាកដែលបង្កឡើងដោយសារការត្រៀមខ្លួនក្នុងរយៈពេលវែង ឬពេលខ្លី"[436]។ ប្រសិនបើបញ្ជីឈ្មោះសរុបរបស់សាក្សីត្រូវបានប្រគល់ឱ្យនោះ គាត់នឹងអាចសួរដេញដោលសាក្សី"ទៅតាមអ្នកដែលត្រូវចូលមកបង្ហាញខ្លួនមុន" ហើយភាគីទាំងអស់"នឹងអាចស្នើសុំឱ្យទទួលយកឯកសារពាក់ព័ន្ធទៅនឹងការពិនិត្យនៅពេលចាប់ផ្តើមការជំនុំជម្រះ" [437]។ ផ្ទុយទៅវិញ សំណើរបស់ភាគីជាច្រើនដែលសុំឱ្យចូលមកបង្ហាញខ្លួន"បានពន្យារពេលកិច្ចដំណើរការនីតិវិធីនៃកិច្ចពិភាក្សាលើអង្គសេចក្តី និងចំណាយពេលវេលាសន្ធឹកសន្ធាប់ឥតប្រយោជន៍"[438]
។

158. តាមការលើកឡើងរបស់គាត់បានឱ្យដឹងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង"មានហានិភ័យចំពោះការរំលោភបំពានជាច្រើន" ដោយសារបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់"សំណើថ្មីសុំឱ្យចូលបង្ហាញខ្លួនផ្អែកលើភស្តុតាងដែលត្រូវបានស្តាប់រួចរាល់ហើយ និងនៅពេលភស្តុតាងនោះពុំដូចការចង់បានរបស់ខ្លួន"[439]។ អង្គជំនុំជម្រះសាលាដំបូងបានឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីដំណើរការនេះតាមរយៈ

---

[435] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥-១៨១។ ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ឯកសារលេខ F54.1.1 ទំព័រ ៦-៧។

[436] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧។

[437] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧។

[438] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧។

[439] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨។

ការកោះហៅសាក្សីដទៃទៀតដែលចម្លើយរបស់ពួកគេចេញពីសំណុំរឿង ០០៣ និង ០០៤ "ត្រូវបានបង្ហាញដោយខុសច្បាប់ដោយសហព្រះរាជអាជ្ញាទាំងដុលពាសពេញរឿងក្តី"[440]។ បន្ថែមលើនេះ ខៀវ សំផន បានអះអាងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួនលើការចូលបង្ហាញខ្លួនរបស់សាក្សី នៅពេលកើតមានភាពពុំជាក់លាក់ជុំវិញវិសាលភាពនៃសំណុំរឿង ០០២/០២ ជាពិសេសលើកម្មវត្ថុនៃ"ការបោសសម្អាតផ្ទៃក្នុង"[441]។ ខៀវ សំផន បានអះអាងបន្ថែមថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងការពន្យារពេលចេញសំអាងហេតុនោះ គឺជាវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការព្យាយាមបញ្ចូលភស្តុតាងដាក់បន្ទុក "ដើម្បីឱ្យឈានទៅដល់ការយល់ឃើញអំពីទោស និងពិរុទ្ធភាព"[442] ដោយបានរំលោភបំពានសច្ចធារណ៍និរទោស និងសិទ្ធិរបស់គាត់ក្នុងការទទួលបានតុលាការព្រហ្មទណ្ឌឥតលម្អៀង និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី[443]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែបានផ្តល់សំអាងហេតុទាក់ទងទៅនឹងមូលហេតុដែលខ្លួនជ្រើសរើសពុំស្តាប់បុគ្គលមួយចំនួនប៉ុណ្ណោះ ប៉ុន្តែពុំបានពន្យល់មូលហេតុដែលខ្លួនបានជ្រើសរើសបុគ្គលដទៃ ដែលនេះផ្អែកតាមទស្សនៈរបស់គាត់ថា "ហាក់បីដូច [...] ជាបង្ហាញនូវការចង់បានតែភស្តុតាងដាក់បន្ទុក"[444]។

159. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិស្តីពីបញ្ហាទាក់ទងទៅនឹងចំណាត់ការនៃការជំនុំជម្រះ ឬថា អង្គជំនុំជម្រះបានបង្កឱ្យគាត់ទទួលរងព្យសនកម្មណាមួយ និងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុទូលំទូលាយ និងទាន់ពេលសម្រាប់សេចក្តីសម្រេចរបស់គាត់ស្តីពីការចូលបង្ហាញខ្លួនរបស់សាក្សីដែលត្រូវបានអនុញ្ញាតតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[445]។

160. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងបានបន្ថែមថា ខៀវ សំផន ពុំបានអើពើលើបរិបទដែលក្នុងនោះការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងបានកើតឡើង និងលើរយៈ

---

[440] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨។

[441] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩។

[442] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥-៨៦, ១៧៣, ១៧៨, ១៨០។

[443] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧ ជើងទំព័រ ២០៣ (បានយោងជាក់លាក់ទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៦៦០-៦៦៥ ដែលក្នុងគាត់បានចោទប្រកាន់ថា សំណុំរឿង ០០២/០២ "បានក្លាយជាដំណើការរុករកភស្តុតាងដាក់បន្ទុក") កថាខណ្ឌ ១៨០។

[444] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០។

[445] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤២-៥០។

ពេលនៃការជំនុំជម្រះ វ័យចាស់ជរារបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងការលំបាកក្នុងការធានានូវការចូលបង្ហាញខ្លួនរបស់អ្នកជំនាញ[446]។

161. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដោយផ្អែកតាមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ចែងកិច្ចដំណើរការនីតិវិធី និងទទួលបានឆន្ទានុសិទ្ធិទូលំទូលាយចំពោះការរៀបចំកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ពុំមានលក្ខខណ្ឌតម្រូវផ្លូវការក្នុងក្របខ័ណ្ឌការងារផ្នែកនីតិវិធីរបស់ អ.វ.ត.ក. ដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ ដែលអង្គជំនុំជម្រះមានគោលបំណងកោះហៅនៅមុនការចាប់ផ្តើមការជំនុំជម្រះឡើយ ហើយពិតណាស់នេះពុំអាចអនុវត្តបានជាក់ស្តែងឡើយ[447]។ ទោះជាយ៉ាងណាក្តី ឆន្ទានុសិទ្ធិទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់ចែងការជំនុំជម្រះ ត្រូវបានកម្រិតដោយកាតព្វកិច្ចក្នុងការធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែលរួមបញ្ចូលការពិចារណាលើការពន្លឿននីតិវិធី និងតម្រូវការចាំបាច់ធានាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់[448]។

162. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅថ្ងៃទី ០៨ និង ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ភាគីបានដាក់បញ្ជីឈ្មោះដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើឡើងដើម្បីឱ្យចូលបង្ហាញខ្លួនក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២[449]។ នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤

---

[446] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៩០, ៩២។

[447] វិធាន ៩១ នៃវិធានផ្ទៃក្នុង (វិធាននេះត្រឹមតែចែងថា អង្គជំនុំជម្រះសាលាដំបូង"ត្រូវស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនគិតថាមានអត្ថប្រយោជន៍")។

[448] វិធាន ២១ នៃវិធានផ្ទៃក្នុង (១)(ក)។

[449] បញ្ជីសាក្សីដែលបានធ្វើបច្ចុប្បន្នភាព និងសេចក្តីសង្ខេបនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើង [នួន ជា] ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/4 ("បញ្ជីសាក្សីរបស់ នួន ជា (E305/4)")។ សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តី ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/5 ("បញ្ជីសាក្សីរបស់ ខៀវ សំផន (E305/5)")។ បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន៥៖ I, II, II ក, III និង III ក) ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/6 ("បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា (E305/6)")។ បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងតាមវិធាន ៨០ នៃវិធានផ្ទៃក្នុងដោយសហមេធាវីនាំមុខសម្រាប់សំណុំរឿង ០០២/០២ ដែលមានឧបសម្ព័ន្ធសម្ងាត់ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/7 ("បញ្ជីសាក្សីសហមេធាវីនាំមុខ (E305/7)")។ សេចក្តីបន្ថែមទៅលើបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបាន

បន្ទាប់ពីការដាក់សារណារបស់ភាគី[450] អង្គជំនុំជម្រះសាលាដំបូងបានចេញ"សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២"[451] ដែលក្នុងនោះអង្គជំនុំជម្រះបានអនុម័តវិធីសាស្ត្រតាមដំណាក់កាលចំពោះការស្តាប់ភស្តុតាង និងបានបង្គាប់លំដាប់លំដោយខាងក្រោមនៃសំណុំរឿង ០០២/០២៖ សហករណ៍[452] ការដ្ឋានធ្វើការ[453] ការប្រព្រឹត្តទៅលើក្រុមគោលដៅ[454] មន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង[455] បទបញ្ជារៀបអាពាហ៍ពិពាហ៍(ទូទាំងប្រទេស) លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ[456]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា៖

> ពុំមានខ្សែបន្ទាត់គូសបញ្ជាក់ច្បាស់លាស់អាចត្រូវបានធ្វើឡើងរវាងប្រធានបទដែលត្រូវបែងចែកការជំនុំជម្រះដាក់លាក់ឡើយ។ បើទោះបីជាមានលំដាប់លំដោយត្រូវបានអនុម័តក៏ដោយ ក៏ទំនងជាថា សាក្សីដែលត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មលើប្រធានបទជាក់លាក់មួយ នឹងត្រូវផ្តល់ភស្តុតាងទាក់ទងទៅនឹងប្រធានបទទៀតដែរ។ ដូច្នេះ ទាក់ទងទៅនឹងលំដាប់លំដោយណាមួយដែលត្រូវបានអនុម័តសម្រាប់ការចាត់ចែងការជំនុំជម្រះ ភាគីគប្បីចាត់ទុកថា ជាការបង្ហាញ ឬគោលការណ៍ណែនាំនៃលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងស្តាប់ភស្តុតាងក្នុងករណីនេះ។ ភាគីទាំងអស់ចាំបាច់ត្រូវបង្ហាញភាពបត់បែនក្នុងកម្រិតមួយទាក់ទងនឹងបញ្ហានេះ។ បន្ថែមលើនេះ លំដាប់លំដោយនៃប្រធានបទ និងសាក្សី គឺស្ថិតក្រោមការកែប្រែអាស្រ័យលើ*ក្នុងចំណោមនោះ*ភាពចាំបាច់នៃការគ្រប់គ្រងរឿងក្តី និង/ឬអត្ថិភាពនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ព្រមទាំងសុខភាពរបស់ជនជាប់ចោទ[457]។

---

ស្នើឡើងតាមវិធាន ៨០ នៃវិធានផ្ទៃក្នុងដោយសហមេធាវីនាំមុខសម្រាប់សំណុំរឿង ០០២/០២ ដែលមានឧបសម្ព័ន្ធសម្ងាត់ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារលេខ E305/7/4។

[450] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារលេខ E1/240.1 (សវនាការបឋមបន្ថែម)។ បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា (E305/6) កថាខណ្ឌ ១៦-១៨។ បញ្ជីសាក្សីសហមេធាវីនាំមុខ (E305/7)។

[451] សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E315 ("សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315)")។

[452] នៅសហករណ៍ត្រាំកក់ ដោយរួមបញ្ចូលការប្រព្រឹត្តទៅលើពុទ្ធសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់ដែលពាក់ព័ន្ធ។

[453] ទំនប់១មករា ទំនប់ត្រពាំងថ្ម និងការសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

[454] ការប្រព្រឹត្តទៅលើជនជាតិចាម ការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងអតីតអ្នករដ្ឋកាលនៃរបបសាធារណរដ្ឋខ្មែរ។

[455] នៅអូរកន្សែង ភ្នំក្រោល និងមន្ទីរស-២១។

[456] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315) កថាខណ្ឌ ១៤។

[457] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315) កថាខណ្ឌ ៧។

នៅក្នុងសេចក្តីសម្រេចដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកបន្ថែមនូវឆន្ទានុសិទ្ធិទូលំទូលាយរបស់ខ្លួនអំពីបញ្ហាដែលទាក់ទងទៅនឹងការចាត់ចែងការជំនុំជម្រះ[458] និងថា អង្គជំនុំជម្រះនឹង"ចេញដីកាបង្គាប់ស្តីពីលំដាប់លំដោយរបស់សាក្សីដែលនឹងត្រូវស្តាប់ទាក់ទងទៅនឹងប្រធានបទនីមួយៗក្នុងពេលសមស្រប"[459]។ ប្រាំពីរថ្ងៃក្រោយមក នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីតាមរយៈអ៊ីមែលអំពីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញលើកដំបូងដែលអង្គជំនុំជម្រះមានបំណងស្តាប់ទាក់ទងទៅនឹងការជំនុំជម្រះផ្នែកទីមួយ[460]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់បច្ចុប្បន្នភាពបន្ថែមនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤[461] និងថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤[462] នៅមុនពេលការទំនាក់ទំនងបញ្ជីឈ្មោះចុងក្រោយនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤[463]។ សាក្សីដំបូងក្នុងសំណុំរឿង ០០២/០២ ត្រូវបានស្តាប់នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥[464]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីជាមុនអំពីសាក្សីដែលខ្លួនមានបំណងចង់ស្តាប់ក្នុងការជំនុំជម្រះផ្នែកនីមួយៗ[465]។

---

[458] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315) កថាខណ្ឌ ៨។

[459] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315) កថាខណ្ឌ ១២។

[460] អ៊ីម៉ែលចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញលើកទីមួយ"ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E316/2.1.1។

[461] ឧបសម្ព័ន្ធទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.12 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុៈ"ព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤)។

[462] ឧបសម្ព័ន្ធទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.12 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុៈ"ព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ប្រធានបទ១" ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤)។

[463] ដីកាកំណត់កាលបរិច្ឆេទសម្រាប់កិច្ចដំណើរការនីតិវិធីលើភស្តុតាង ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E328 ទំព័រ ២-៣។ អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E328.1។ ប្រតិចារឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារលេខ E1/247.1 ទំព័រ ១៦-១៧។

[464] ប្រតិចារឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារលេខ E1/247.1 ទំព័រ ១-២ (សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ត្រូវបានចាប់ផ្តើមនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤។ មេធាវីការពារក្តី ខៀវ សំផន បានបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរហូតក្រោយពេលដាក់សារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ នេះបានបណ្តាលឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥។ *សូមមើល ខ.* ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ E1/246.1 ទំព័រ ១)។

[465] *សូមមើល ខ.* ឧបសម្ព័ន្ធ ១៦ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.16 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុៈ"ទំនប់១មករា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី"ថ្ងៃទី ១៧ ខែ

163. បន្ទាប់ពីទទួលបានសំណើរបស់ ខៀវ សំផន សុំបញ្ជីឈ្មោះសរុបរបស់សាក្សីទាំងអស់ដែល អង្គជំនុំជម្រះសាលាដំបូងមានបំណងកោះហៅ[466] អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា អង្គជំនុំជម្រះបានអនុម័តវិធីសាស្ត្រតាមដំណាក់កាលរួចហើយក្នុងការកំណត់ថាតើ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញមួយណានឹងត្រូវផ្តល់សក្ខីកម្មលើប្រធានបទជាក់លាក់សម្រាប់ហេតុផលផ្សេងៗរួមមាន៖

> ភាពពុំអាចដឹងជាមុនថាតើ សាក្សីដែលត្រូវបានទាក់ទងនៅពេលចាប់ផ្តើមការជំនុំជម្រះនឹងមានវត្តមានផ្តល់សក្ខីកម្មតាមកាលបរិច្ឆេទនៅពេលខាងមុខ ដែរ ឬទេ និងធនធានមានកម្រិតរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការទាក់ទងបុគ្គលនីមួយៗដែលបានស្នើឡើងនោះ។ អង្គជំនុំជម្រះជាទូទៅបានជូនដំណឹងដល់ភាគីយ៉ាងតិចបួនសប្តាហ៍ជាមុនអំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលអង្គជំនុំជម្រះមានបំណងស្តាប់លើប្រធានបទនៃការជំនុំជម្រះណាមួយនោះ។ អង្គជំនុំជម្រះបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីដើម្បីត្រៀមខ្លួនសម្រាប់ការសួរដេញដោលសាក្សីផ្អែកលើការចូលរួមរបស់ពួកគេក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្តីនេះ។ ការផ្តល់បញ្ជីឈ្មោះសរុបសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅពេលនោះ ពុំមែនជាការអនុវត្តន៍ជាក់ស្តែង និងពុំចាំបាច់ចំពោះការចាត់ចែងសមស្របនៃកិច្ចដំណើរការនីតិវិធីទាំងនេះឡើយ[467]។

---

កុម្ភៈ ឆ្នាំ ២០១៥)។ អ៊ីម៉ែលផ្ញើពីមន្ត្រីច្បាប់ជាន់ខ្ពស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ៖ ការប្រព្រឹត្តទៅលើជនជាតិចាម" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E366/1.2។ ឧបសម្ព័ន្ធ ១ ទៅនឹងអ៊ីម៉ែលផ្ញើពីមន្ត្រីច្បាប់ជាន់ខ្ពស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទបន្តសវនាការបន្ទាប់ពីការផ្អាកពិធីបុណ្យភ្ជុំបិណ្ឌ" ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E448.1.1 (ជម្លោះប្រដាប់អាវុធ)។

[466] សារណារបស់មេធាវីការពារក្តី ខៀវ សំផន ស្តីពីកាតព្វកិច្ចក្នុងការបង្ហាញរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E363 ("សារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ (E363)") កថាខណ្ឌ ៤៨។ *សូមមើលផងដែរ* ចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំស្តាប់សក្ខីកម្មរបស់សាក្សីបីរូបថែមទៀត ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាម និងសំណើសុំបញ្ជីសាក្សីសរុបដែលត្រូវចូលខ្លួនបង្ហាញក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E366/1 កថាខណ្ឌ ៤, ២២-២៥, ២៨។ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យផ្ញើបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់ដំណាក់កាលចុងក្រោយសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារលេខ E421/2។

[467] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចក្នុងការបង្ហាញរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ E363/3 ("សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3)") កថាខណ្ឌ ២៦។

អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវ"ការអនុវត្តន៍ដែលបានបង្កើតឡើងយូរមកហើយ"នៃការទំនាក់ទំនងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាមួយភាគីនៅមុនសវនាការលើផ្នែកជាក់លាក់មួយ ក្នុងគោលបំណងផ្តល់ឱ្យ"ភាគីនូវបញ្ជីឈ្មោះអាទិភាពរបស់បុគ្គលដែលតុលាការចាត់ទុកថា ពាក់ព័ន្ធបំផុតទៅនឹងផ្នែកនីមួយៗ និងដូច្នេះត្រូវស្តាប់នៅពេលជំនុំជម្រះ"[468]។ បន្ទាប់ពីការបញ្ចប់សវនាការលើភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានចេញ"សេចក្តីសម្រេចស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើឡើងដើម្បីស្តាប់ក្នុងសំណុំរឿង ០០២/០២" ដែលរួមបញ្ចូលហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះហៅសាក្សីមួយចំនួនដែលត្រូវបានស្នើឡើងដោយភាគីដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២[469]។

164. ផ្អែកលើសំអាងហេតុខាងលើរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការគ្រប់គ្រងចាត់ចែងសវនាការស្តីពីភស្តុតាង។ សំអាងហេតុដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងបង្ហាញនូវវិធីសាស្ត្របត់បែនដែលត្រូវបានពិចារណាអំពីការគ្រប់គ្រងនូវការអនុវត្តន៍ជាក់ស្តែងក្នុងការជ្រើសរើស និងស្តាប់សាក្សីរាប់រយនាក់ដែលសក្ខីកម្មរបស់ពួកគេជាប់ពាក់ព័ន្ធទៅនឹងផ្នែកជាច្រើននៃការជំនុំជម្រះ។ វិធីសាស្ត្រដែលបានគិតទុកជាមុន និងហេតុផលនៅពីក្រោយនោះ ត្រូវបានជូនដំណឹងដល់ភាគីច្បាស់លាស់ ហើយអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ពេលវេលាគ្រប់គ្រាន់អំពីសាក្សីដែលអង្គជំនុំជម្រះមានបំណងកោះហៅជាមុននៅក្នុងការជំនុំជម្រះផ្នែកនីមួយៗ[470]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានលើកការតវ៉ាដូចគ្នានៅពេលជំនុំជម្រះ និងបានស្នើសុំបញ្ជីឈ្មោះសរុបរបស់សាក្សីក្នុងផ្នែកនីមួយៗនៃការជំនុំជម្រះនៅមុនការចាប់ផ្តើមសវនាការលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធថា "ជាការពុំអាចធ្វើទៅបានជាក់ស្តែង និងពុំចាំបាច់ចំពោះការចាត់ចែងសមស្របនៃកិច្ចដំណើរការនីតិវិធីទាំងនេះ"[471]។ សំអាងហេតុរបស់អង្គជំនុំជម្រះបានពន្យល់អំពីភាពពុំអាចដឹងជាមុនបានថាតើ សាក្សីដែលបានទាក់ទងនៅពេលចាប់ផ្តើមការជំនុំជម្រះនោះនឹងនៅតែអាចមកផ្តល់សក្ខីកម្មនៅពេលក្រោយយូរមកទៀត ដែរ ឬទេ ហើយបន្ទុកនៃ

---

[468] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធទៅនឹងសាក្សីដែលបានស្នើឡើងសម្រាប់ផ្នែកស្តីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៦ E425/2 កថាខណ្ឌ ៥ (សេចក្តីបញ្ជាក់បន្ថែម)។

[469] សេចក្តីសម្រេចស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងសម្រាប់ស្តាប់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ E459 ("សេចក្តីសម្រេចស្តីពីសាក្សីដែលបានស្នើឡើង (E459)")។

[470] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២៦។

[471] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២៦។

ដំណើរការនេះនឹងផ្តាក់ទៅលើអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការទំនាក់ទំនងបុគ្គលនីមួយៗដែលត្រូវបានស្នើឡើងនោះ[472]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញទៅលើភាពចាំបាច់នៃការគ្រប់គ្រងរឿងក្តី និងសុខភាពរបស់ជនជាប់ចោទដែលជាហេតុផលជាសក្តានុពលក្នុងការប្រែប្រួលលំដាប់លំដោយសាក្សី និង/ឬផ្នែកនៃការជំនុំជម្រះ[473]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគ្រប់គ្រាន់គាំទ្រកំហុសណាមួយក្នុងសំអាងហេតុនោះដែលបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចអនុម័តវិធីសាស្ត្រតាមដំណាក់កាលមួយៗចំពោះការជ្រើសរើសសាក្សី និងត្រឹមតែមិនយល់ស្របជាមួយវិធីសាស្ត្រនេះប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសំអាងហេតុជាការត្រឹមត្រូវ និងសមហេតុផលដោយបានពិចារណាលើភាគីរួមទាំងលទ្ធភាពរបស់ ខៀវ សំផន ក្នុងការត្រៀមរៀបចំសម្រាប់រឿងក្តីរបស់ខ្លួននៃការជំនុំជម្រះផ្នែកនីមួយៗ។

ទាក់ទងទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានបង្កការលំបាកដល់លទ្ធភាពក្នុងការដឹងពេលវែងដើម្បីត្រៀមខ្លួនសម្រាប់ការជំនុំជម្រះ[474] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដោយផ្អែកលើសំណើសុំស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលចែងអំពីការទទួលយកភស្តុតាងក្នុងពេលជំនុំជម្រះ[475] បុគ្គលដែលត្រូវបានជ្រើសរើសមកផ្តល់សក្ខីកម្មត្រូវបានដកចេញពីបញ្ជីឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើឡើង និងត្រូវបានកែសម្រួលដោយភាគីដែលបានដាក់នៅដើមខែ ឧសភា ឆ្នាំ ២០១៤[476]។ បញ្ជីឈ្មោះទាំងនេះបានរួមបញ្ចូលសេចក្តីសង្ខេបនៃសក្ខីកម្មដែលបានស្នើឡើង[477] និងលំដាប់លំដោយនៃសាក្សីសម្រាប់ការជំនុំជម្រះផ្នែកនីមួ

[472] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២៦។

[473] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315) កថាខណ្ឌ ៧។

[474] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧។

[475] *សូមមើល ឧ.* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងការចូលបង្ហាញខ្លួនសាក្សី 2-TCW-987 (E364) ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ E364/1។

[476] បញ្ជីសាក្សីរបស់ នួន ជា (E305/4)។ បញ្ជីសាក្សីរបស់ ខៀវ សំផន (E305/5)។ បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា (E305/6)។ បញ្ជីសាក្សីសហមេធាវីនាំមុខ (E305/7)។

[477] *សូមមើល ឧ.* ឧបសម្ព័ន្ធ III: បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាដែលត្រូវបានធ្វើបច្ចុប្បន្នភាព និងសេចក្តីសង្ខេប ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/6.4។ ឧបសម្ព័ន្ធ ខ៖ សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (គ្មានការស្នើសុំវិធានការការពារ) របស់ក្រុមមេធាវីការពារក្តី នួន ជា ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/4.2 ("សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពស្តីពីសាក្សីរបស់ នួន ជា")។

យៗដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ[478]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីពីដំបូងអំពីផ្នែកផ្សេងៗនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤[479] នៅពេលសាក្សីដំបូងបានចូលមកបង្ហាញខ្លួននៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ដែលនេះបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីក្នុងការត្រៀមខ្លួនដើម្បីសួរដេញដោលអ្នកដែលត្រូវបានកោះហៅមកធ្វើសក្ខីកម្មនោះ[480]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បន្ទាប់ពីត្រូវបានជូនដំណឹងអំពីលំដាប់លំដោយនៃផ្នែកផ្សេងៗនៃការជំនុំជម្រះ និងការទទួលបានបញ្ជីឈ្មោះសាក្សីដែលត្រូវបានស្នើឡើង ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ក្នុងការអះអាងថា មានការប៉ះពាល់ដល់លទ្ធភាពត្រៀមខ្លួនរយៈពេលវែងសម្រាប់ការជំនុំជម្រះនោះឡើយ។

165. ទាក់ទងទៅនឹងលទ្ធភាពត្រៀមខ្លួនរយៈពេលខ្លី អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីជាមុនគ្រប់គ្រាន់អំពីផ្នែកដែលពាក់ព័ន្ធទៅនឹងអត្តសញ្ញាណសាក្សីដែលគ្រោងដើម្បីចូលមកបង្ហាញខ្លួន។ ជាឧទាហរណ៍ ទាក់ទងទៅនឹងការជំនុំជម្រះផ្នែកទីពីរពាក់ព័ន្ធទៅនឹងការដ្ឋានធ្វើការ ដូចជា ទំនប់១មករា ទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ បានជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន និងលំដាប់លំដោយនៃការចូលបង្ហាញខ្លួនដែលត្រូវបានរំពឹងទុកទាក់ទងទៅនឹងទំនប់១មករា[481] និងបានផ្តល់បញ្ជីឈ្មោះចុងក្រោយដែលត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥[482]។ សវនាការលើភស្តុតាងពាក់ព័ន្ធនឹងទំនប់១មករាបានចាប់ផ្តើមនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥[483]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីសាក្សីទាក់ទង

---

[478] ឧបសម្ព័ន្ធ I៖ បញ្ជីសរុបសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង ០០២/០២ តាមផ្នែកនៃជំនុំជម្រះ និងការបង្ហាញខ្លួន ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/6.1។ ឧបសម្ព័ន្ធ IV៖ លំដាប់លំដោយនៃផ្នែកជំនុំជម្រះដែលបានស្នើឡើងដោយសហមេធាវីនាំមុខ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/7.1.4។

[479] សេចក្តីសម្រេចស្តីពីលំដាប់លំដោយ (E315)។

[480] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ឯកសារលេខ E1/247.1 ទំព័រ ១-២។

[481] ឧបសម្ព័ន្ធទៅនឹង ១៦ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ F54.1.16 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "ទំនប់១មករា៖ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥)។

[482] ឧបសម្ព័ន្ធ ១៩ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.19 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "លំដាប់លំដោយ និងការបែងចែកពេលវេលាសម្រាប់ទំនប់១មករា" ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥)។

[483] ប្រតិចារឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/301.1 ទំព័រ ១។

ទៅនឹងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៥[484] និងទាក់ទងទៅនឹងទំនប់ត្រពាំងថ្មនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥[485]។ សវនាការលើភស្តុតាងទាក់ទងទៅនឹងប្រធានបទទាំងនេះបានចាប់ផ្ដើមនៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ និង ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ រៀងៗខ្លួន[486]។

166. ទាក់ទងទៅនឹងការជំនុំជម្រះផ្នែកទីបីស្ដីពីការប្រព្រឹត្តទៅលើក្រុមកំណត់គោលដៅ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីលំដាប់លំដោយដែលត្រូវបានរំពឹងទុក និងការបែងចែកពេលវេលានៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥ ទាក់ទងទៅនឹងជនជាតិចាម[487] និងនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ ទាក់ទងទៅនឹងជនជាតិវៀតណាម[488]។ សាក្សីដំបូងបានចូលបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ និងថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ផ្សេងៗគ្នា[489]។ បើទោះបីជាលំដាប់លំដោយនិងកាលបរិច្ឆេទនៃការចូលបង្ហាញខ្លួនរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងផ្នែកជំនុំជម្រះពិសេសនេះត្រូវបានកែប្រែជាញឹកញាប់ក៏ដោយ[490] ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈ

---

[484] ឧបសម្ព័ន្ធ ២០ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.20 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកម្មវត្ថុ៖ "ឆ្លើយតប៖ លំដាប់លំដោយ និងការបែងចែកពេលវេលាសម្រាប់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង" ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៥។

[485] ឧបសម្ព័ន្ធ ២១ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.21 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកម្មវត្ថុ៖ "លំដាប់លំដោយ និងការបែងចែកពេលវេលាសម្រាប់ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម" ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥)។

[486] ប្រតិចារឹកថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E1/312.1 ទំព័រ ១។ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E1/323.1 ទំព័រ ២។

[487] លិខិតថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E366/1.2 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "បញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ៖ ការប្រព្រឹត្តទៅលើជនជាតិចាម" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥)។

[488] ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E381.1.1 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "បញ្ជីសាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ការប្រព្រឹត្តទៅលើជនជាតិវៀតណាម" ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥)។

[489] ប្រតិចារឹកចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារលេខ E1/342.1 ទំព័រ ៣៥។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ E1/357.1 ទំព័រ ៣៣-៣៤។

[490] ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E381.1.1 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "បញ្ជីសាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ការប្រព្រឹត្តលើជនជាតិវៀតណាម" ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ

ដែលនាំទៅរកការកែប្រែនោះ គឺហួសពីការគ្រប់គ្រងរបស់អង្គជំនុំជម្រះសាលាដំបូង[491] ដូចជាបញ្ហាសុខភាព[492] និងមរណភាពរបស់សាក្សីមួយចំនួនដែលត្រូវបានគ្រោងទុកនោះ[493]។ នៅពេលការកែប្រែចំពោះកាលវិភាគរបស់សាក្សីត្រូវបានតម្រូវ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីជាមុនគ្រប់គ្រាន់[494]។

២០១៥)។ ឧបសម្ព័ន្ធ ២២ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.22 (អ៊ីម៉ែលអង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "ការឆ្លើយតប: ការជូនដំណឹងសាក្សីបន្ទាប់" ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥)។ ឧបសម្ព័ន្ធ ៣ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E381.1.3 (អ៊ីម៉ែលពី Ken Roberts មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "កាលបរិច្ឆេទចាប់តាំងពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥" ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥)។ លិខិត ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E364.1.1 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ការឆ្លើយតប៖ សំណើសុំការបំភ្លឺស្តីពីចំណាត់ការនៃការកំណត់កាលបរិច្ឆេទបន្ថែមនៃផ្នែកស្តីពីការប្រព្រឹត្តលើក្រុមគោលដៅ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥)។

[491] *សូមមើល ឧ.* ប្រតិចារឹកថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E1/350.1 ទំព័រ ៣៦។ ឧបសម្ព័ន្ធ ៣ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E381.1.3 (អ៊ីម៉ែលពី Ken Roberts មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទចាប់តាំងពីថ្ងៃទី ៣០ ខែ វិច្ឆិក ឆ្នាំ ២០១៥" ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥)។

[492] លិខិតបញ្ជាក់មរណភាព ឃុន ម៉ុន (សម្ងាត់) (2-TCW-958) ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E29/506។ លិខិតមរណភាព ឡង់ ហែល (សម្ងាត់) (2-TCW-927) ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារលេខ E29/507 (សាក្សីទាំងពីរដំបូងមាននៅក្នុងបញ្ជីបណ្តោះអាសន្នសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានជ្រើសរើសមកផ្តល់សក្ខីកម្មលើប្រធានបទស្តីពីការប្រព្រឹត្តទៅលើជនជាតិវៀតណាម)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E381.1.1 (អ៊ីម៉ែលពី Ken Roberts មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ "បញ្ជីឈ្មោះសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការប្រព្រឹត្តទៅលើជនជាតិវៀតណាម" ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥)។

[493] *សូមមើល ឧ.* ឧបសម្ព័ន្ធ ២២ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ (អ៊ីម៉ែលអង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "ឆ្លើយតប៖ ការជូនដំណឹងសាក្សីបន្ទាប់(បន្ត)" ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥) (ហេតុផលសម្ភារៈសម្រាប់កែប្រែដីកាកោះហៅសាក្សី)។ លិខិត ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E364/2/1.1.1 (អ៊ីម៉ែលផ្ញើពីមន្ត្រីជាន់ខ្ពស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ឆ្លើយតប៖ សំណើសុំបំភ្លឺលើចំណាត់ការនៃការកំណត់កាលបរិច្ឆេទបន្ថែមនៃផ្នែកស្តីពីការប្រព្រឹត្តទៅលើក្រុមគោលដៅ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥)។

[494] ប្រតិចារឹកថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ E1/358.1 ទំព័រ ៥៨-៥៩ (ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ថា អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ២២ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.22 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "ឆ្លើយតប៖ ការជូនដំណឹងសាក្សីបន្ទាប់(បន្ត)" ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥)។

167. ទាក់ទងទៅនឹងការជំនុំជម្រះផ្នែកដទៃទៀតពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង បទបញ្ញារៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងប្រហាក់ប្រហែលគ្នាបានជូនដំណឹងជាមុនគ្រប់គ្រាន់អំពីកាលវិភាគ និងលំដាប់លំដោយនៃការចូលបង្ហាញខ្លួនរបស់សាក្សី[495] និងការកែប្រែណាមួយដោយផ្អែកលើបញ្ហាសុខភាពរបស់សាក្សី ឬបញ្ហាដទៃទៀតនៃកាលវិភាគ[496]។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ក្រៅពីការ

[495] ឧបសម្ព័ន្ធ ២៣ ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.23 (របាយការណ៍៖"សាក្សីសម្រាប់មន្ទីរសន្តិសុខអូរកន្សែង" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ២៤ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.24 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកម្មវត្ថុ៖ "កាលបរិច្ឆេទសម្រាប់មន្ទីរសន្តិសុខអូរកន្សែង" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦)។ លិខិត ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E405.1.1 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "ការកែប្រែកាលបរិច្ឆេទពីថ្ងៃទី ២៩ ខែ កុម្ភៈ ដល់ ថ្ងៃទី ១៧ ខែ មីនា" ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦)។ អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "មន្ទីរស-២១ ការបែងចែកពេលវេលាសម្រាប់សាក្សី 2-TCE-88 និងដីកាកំណត់កាលបរិច្ឆេទសម្រាប់សប្ដាហ៍ថ្ងៃទី ២១-២៤ ខែ មីនា" ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E408/6.1) (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "ការបោសសម្អាតផ្ទៃក្នុង៖ បញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ" ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E390/1.1.1 (ឯកសារលេខ E408/6.1។ អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖"មន្ទីរសន្តិសុខភ្នំក្រោល៖ បញ្ជីសាក្សី និងការបែងចែកពេលវេលា" ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ១ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E431/2.2 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "បញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញស្ដីពីបទបញ្ញារៀបអាពាហ៍ពិពាហ៍" ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ២ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E434.1.2 (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ៖ លក្ខណៈនៃជម្លោះប្រដាប់អាវុធ" ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ២ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E453/1.2 (អ៊ីម៉ែលផ្ញើពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "បញ្ជីឈ្មោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ប្រធានបទជំនុំជម្រះស្ដីពីតួនាទីរបស់ជនជាប់ចោទ"ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦)។

[496] ឧបសម្ព័ន្ធ ២៧ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.27 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកម្មវត្ថុ៖ "បញ្ហានៃកាលបរិច្ឆេទ" ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៦ (បទបញ្ញារៀបអាពាហ៍ពិពាហ៍)។ ឧបសម្ព័ន្ធ ២៨ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.28 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកម្មវត្ថុ៖ "កាលបរិច្ឆេទសម្រាប់សប្ដាហ៍ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦" ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ (បទបញ្ញារៀបអាពាហ៍ពិពាហ៍))។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E448.1.1 (អ៊ីម៉ែលផ្ញើពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគី ចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទសវនាការបន្តក្រោយពេលសម្រាកបុណ្យភ្ជុំបិណ្ឌ" ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ (ជម្លោះប្រដាប់អាវុធ)។ ឧបសម្ព័ន្ធ ២៩ នៃសារ

លើកឡើងជាទូទៅថា៖ "ប្រសិនបើមេធាវីការពារក្តីមានបញ្ជីឈ្មោះនោះ ខ្លួននឹងត្រៀមសម្រាប់បញ្ហានេះ"[497] ខៀវ សំផន ពុំបានបង្ហាញនូវព្យសនកម្មជាក់លាក់ណាមួយ ឬឧទាហរណ៍នៃការដែលវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ឬការកែប្រែកាលវិភាគឡើងវិញបានប៉ះពាល់ដល់លទ្ធភាពត្រៀមខ្លួនសម្រាប់ការជំនុំជម្រះដូចម្តេចឡើយ ជាឧទាហរណ៍ តាមរយៈការបង្ហាញនូវសក្ខីកម្មរបស់សាក្សីជាក់លាក់ដែល គាត់ត្រូវបានរារាំងក្នុងការសួរដេញដោលជាដើម។ តាមការពិចារណាខាងលើ ការចោទប្រកាន់របស់ ខៀវ សំផន ទាក់ទងទៅនឹងការដែលពុំមានលទ្ធភាពគ្រប់គ្រាន់របស់គាត់ក្នុងការត្រៀមខ្លួនសួរដេញដោលសាក្សីនោះត្រូវបដិសេធចោល។

168. ទាក់ទងទៅនឹងការចោទប្រកាន់អំពីការពន្យារពេលឥតសមស្រប ក្នុងការផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងរហូតដល់ក្រោយការបិទកិច្ចដំណើរការនីតិវិធីជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើឡើងដើម្បីស្តាប់ក្នុងសំណុំរឿង ០០២/០២ បានលើកបង្ហាញនូវ"ភាពសមហេតុផលសម្រាប់ការមិនកោះហៅបុគ្គលមួយចំនួនដែលត្រូវបានស្នើឡើងដោយភាគី ដែលបុគ្គលនោះពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២"[498]។ ស្របតាមក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសសាក្សីដែលទំនងបំផុតក្នុងការបញ្ជាក់ការពិត និង"ត្រូវស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញតាមរបៀបដែលអង្គជំនុំជម្រះចាត់ទុកថា មានអត្ថប្រយោជន៍"[499]។ ដោយផ្អែកលើការចាំបាច់នៃស្ថានការណ៍ជាពិសេសក្នុងករណីដែលមានមរណភាព ឬជំងឺកើតឡើងដែលអាចធ្វើឱ្យបញ្ហានេះស្ថិតក្នុងស្ថានភាពពុំច្បាស់លាស់ អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចកោះហៅសាក្សីបន្ថែមនៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំអាចធ្វើការកំណត់ស្ពាពរបាន ឬផ្តល់សំអាងហេតុពាក់ព័ន្ធទៅនឹងការដែលថាតើ សាក្សីមួយណា ឬពុំចាំបាច់កោះរហូតដល់ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធី។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញការពន្យារពេលពុំសមហេតុ

---

ណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.29 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "ឆ្លើយតប៖ កាលបរិច្ឆេទសម្រាប់សប្តាហ៍ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦" ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦។ ឧបសម្ព័ន្ធ ៣០ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54.1.30 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ៖ "បញ្ជូនត៖ ការជំនួសសាក្សី 2-TCW-871" ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៦)។

[497] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧។

[498] សេចក្តីសម្រេចស្តីពីសាក្សីដែលបានស្នើឡើង (E459) កថាខណ្ឌ ១ (សេចក្តីបញ្ជាក់បន្ថែម)។

[499] វិធាន ៩១ នៃវិធានផ្ទៃក្នុង។

ផលណាមួយ ឬព្យសនកម្មនៅពេលសវនាការលើភស្តុតាងដែលបានបញ្ចប់នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ ហើយអង្គជំនុំជម្រះសាលាដំបូងបានចេញសំអាងហេតុរបស់ខ្លួននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧។ នេះពុំមែនជាការមិនសមហេតុផលដោយផ្អែកលើទិដ្ឋភាពនៃទំហំសេចក្តីសម្រេច ដែលបានរួមបញ្ចូលសំអាងហេតុសម្រាប់ការមិនកោះហៅសាក្សីជាច្រើននាក់ ព្រមទាំងការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងបាន និងកំពុងពិភាក្សាសម្រេចលើសាលក្រមនៅពេលតែមួយនោះ។

169. ទាក់ទងទៅនឹងភាពលម្អៀងដែលរងការចោទប្រកាន់ អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ខៀវ សំផន ខកខានក្នុងការលើកមូលដ្ឋានគាំទ្រការអះអាងមុតមាំរបស់ខ្លួនប្រឆាំងនឹងសំអាងហេតុច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះ ដែលអនុវត្តចំពោះការស្តាប់សាក្សីពេញមួយអំឡុងពេលនៃការជំនុំជម្រះ។ ទាក់ទងទៅនឹងការចោទប្រកាន់ការរំលោភបំពានដែលកើតចេញពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេស ការទទួលយកភស្តុតាងនៅចុងបញ្ចប់នៃសវនាការលើភស្តុតាង និងការកោះហៅសាក្សីថ្មី[500] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើរបស់សហព្រះរាជអាជ្ញា ឬរបស់ភាគីដទៃទៀត សុំការចូលបង្ហាញខ្លួនរបស់សាក្សីថ្មី ឬការទទួលយកភស្តុតាងថ្មីក្នុងអំឡុងពេលនៃការជំនុំជម្រះស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលចែងថា “ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់ជួយបញ្ជាក់ការពិត”[501]។ ដោយពុំគិតថាតើ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់បញ្ជីឈ្មោះសរុបរបស់សាក្សីនៅមុនពេលការជំនុំជម្រះ ដែរ ឬយ៉ាងណានោះទេ អនុលោមតាមវិធាននេះ ភាគីនៅតែអាចស្នើសុំសាក្សីបន្ថែមដែលពុំមានឈ្មោះក្នុងបញ្ជីនោះ។ ទាក់ទងទៅនឹងសំណើសុំផ្អែកតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ខ្លឹមសារនៃសំណើរបស់សហព្រះរាជអាជ្ញាត្រូវបានកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលកំណត់វិធាននេះ ដែលត្រូវបានវាយតម្លៃ និងផ្តល់សំអាងហេតុដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនផ្អែកលើសំណើទាំងនេះ[502]។ ការសំអាងរបស់សហព្រះរាជអាជ្ញាលើវិធាននេះពុំបានបង្ហាញការ

---

[500] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨។

[501] វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

[502] *សូមមើល ឧ.* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពាក់ព័ន្ធសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងលំដាប់លំដោយនៃការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E319/7 (“សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ (E319/7)”)។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)

រំលោភបំពានណាមួយឡើយ។ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តន៍របស់ខ្លួនតាមលក្ខណៈវិនិច្ឆ័យនៃសំណើផ្អែកតាមវិធាន ៨៧(៤) នឹងត្រូវដោះស្រាយក្នុងសាលដីកានេះ[503]។

170. ទាក់ទងទៅនឹងការចោទប្រកាន់អំពីភាពមិនប្រាកដប្រជាពាក់ព័ន្ធទៅនឹងវិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០២ ជាពិសេស លើប្រធានបទនៃការបោសសម្អាតផ្ទៃក្នុង[504] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងភ្លាមៗនោះបានដោះស្រាយសំណើរបស់ ខៀវ សំផន សុំការបំភ្លឺ និងបានពន្យល់ថា "លំដាប់លំដោយនៃប្រធានបទជំនុំជម្រះ ឬកាលវិភាគរបស់សាក្សីជាក់លាក់ដែលត្រូវស្ដាប់ជាធម្មតាស្ថិតក្រោមប្រធានបទជំនុំជម្រះមួយជាជាងផ្សេងទៀត ពុំបានកែប្រែវិសាលភាពនៃសំណុំរឿង ០០២/០២" និងថា "អាស្រ័យហេតុនេះ វិសាលភាពនៃសំណុំរឿង ០០២/០២ នៅដដែលដូចការគូសបង្ហាញក្នុងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង"[505]។ ខៀវ សំផន

(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកសាក្សីជំនុំជម្រះបន្ថែមទាក់ទងទៅនឹងស្រុកត្រាំកក់/ផ្នែកស្ដីពីក្រាំងតាចាន់នៃសំណុំរឿង ០០២/០២ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៥ ឯកសារលេខ E319/17/1 ("សេចក្ដីសម្រេចលើសំណើអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1)")។ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ E319/22/1 ("សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/22/1)")។ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាមដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ E319/32/1 ("សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយ (E319/32/1)")។ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង និងកោះហៅសាក្សីបួននាក់បន្ថែមទៀតសម្រាប់ផ្នែកបន្តទៀតនៃសំណុំរឿង ០០២/០២ ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E319/36/2 ("សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយ និងកោះហៅសាក្សី (E319/36/2)")។

[503] *សូមមើលខាងក្រោម* ផ្នែក V.ឃ.៣.ក។

[504] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩ និងជើងទំព័រ ២០៨ យោងទៅលើសំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឱ្យផ្ដល់ការបំភ្លឺអំពីវិសាលភាពនៃបណ្ដឹងទៅអង្គជំនុំជម្រះពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E420។

[505] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ ខៀវ សំផន សុំការបំភ្លឺលើវិសាលភាពនៃសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង"ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២១ ឯកសារលេខ E420/1 កថាខណ្ឌ ៩។

ខកខានក្នុងការបង្ហាញថាតើ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការជ្រើសរើសសាក្សី បានបង្កភាពពុំប្រាកដប្រជាដូចម្តេចចំពោះគាត់ឡើយ។ ការចោទប្រកាន់ដទៃទៀតរបស់ ខៀវ សំផន ទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះ និងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវដោះស្រាយនៅក្នុងសាលដីកានេះ[506]។

171. ចុងក្រោយ ជាការឆ្លើយតបទៅនឹងការចោទប្រកាន់អំពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់នូវមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះជ្រើសរើសស្តាប់បុគ្គលមួយចំនួន[507] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានកោះហៅបុគ្គលទាំងនោះដោយសារអង្គជំនុំជម្រះពិចារណាឃើញថា អាចជួយបញ្ជាក់ការពិតបាន និងថា អង្គជំនុំជម្រះបានផ្តល់ប្រធានបទសំខាន់នៃសក្ខីកម្មរបស់សាក្សីនៅមុនការស្តាប់បុគ្គលដែលត្រូវបានស្នើឡើង[508]។ បន្ថែមលើនេះ សាក្សីដែលត្រូវបានកោះហៅ ត្រូវបានជ្រើសរើសចេញពីបញ្ជីឈ្មោះដែលបានស្នើឡើងដោយភាគី ដែលបានរួមបញ្ចូលព័ត៌មានស្តីពីភាពពាក់ព័ន្ធរបស់សក្ខីកម្មរបស់សាក្សីនោះ។ ផ្អែកតាមសំអាងហេតុខាងលើ ខៀវ សំផន ខកខានក្នុងការបង្ហាញការរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ និងការសម្រួលសម្រាប់ការត្រៀមការការពារខ្លួនរបស់គាត់ ការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃបទចោទប្រឆាំងនឹងគាត់ និងសច្ចភាពផ្លូវច្បាប់ និងផ្នែកនីតិវិធី និងសេចក្តីសម្រេចមានសំអាងហេតុ[509]។

## ២. ការបង្ហាញភស្តុតាងសំណុំរឿង ០០៣ និង ០០៤

172. កិច្ចស៊ើបសួរកំពុងបន្តក្នុងសំណុំរឿង ០០៣ និង ០០៤ បានកើតធ្វើឡើងស្របគ្នាជាមួយនឹងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ដែលបានបណ្តាលឱ្យមានឯកសារថ្មីៗជាច្រើនត្រូវបង្ហាញក្នុងសំណុំរឿង ០០២/០២។

---

[506] *សូមមើលខាងក្រោម* ផ្នែក VI.ឃ។

[507] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០។

[508] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីសម្រេចលើសំណើសាជាថ្មីរបស់មេធាវីការពារក្តី ខៀវ សំផន សុំស្តាប់ Stephen HEDER (2-TCE-87) និង François PONCHAUD (2-TCE-99)" ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E408/6/2 ("សេចក្តីសម្រេចលើសំណើសុំស្តាប់ HEDER និង PONCHAUD (E408/6/2)")។ សេចក្តីសម្រេចស្តីពីសាក្សីដែលបានស្នើឡើង (E459)។

[509] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០-១៨១។

173. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការណែនាំសហព្រះរាជអាជ្ញាឱ្យបង្ហាញតែភស្តុតាងណាដែលមានសក្តានុពលដោះបន្ទុក និងខកខានក្នុងការដកចេញនូវឯកសារដែលបានបង្ហាញ "ខុសច្បាប់"ចេញពីសំណុំរឿង[510]។ បើទោះបីជាបានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់វិធានការធានាថា ភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យលើភស្តុតាងនោះក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏គាត់បានលើកឡើងថា វិធានការនេះ"បានរំលោភបំពានកាន់តែខ្លាំងលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមស្រប"[511] និងបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា"បង្កើតភស្តុតាងដាក់បន្ទុកយ៉ាងច្រើនសន្ធឹកសន្ធាប់"[512]។ ទាក់ទងនឹងបញ្ហានេះ គាត់បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូង"បានបដិសេធជារឿយៗក្នុងការណែនាំអយ្យការឱ្យបញ្ជាក់ជាក់លាក់ ថាតើភស្តុតាងថ្មីណាខ្លះដែលដោះបន្ទុក" បើទោះបីជាមានការបង្កើតនូវ"នីតិវិធីបំភ្លឺ"ដោយសហចៅក្រមស៊ើបអង្កេតសម្រាប់សំណើសុំការបង្ហាញ ដែលតម្រូវឱ្យសហព្រះរាជអាជ្ញាត្រូវរួមបញ្ចូល"ព័ត៌មានលម្អិតទាក់ទងទៅនឹងចំណុចណាខ្លះដែលខ្លួនចាត់ទុកថា ជាភស្តុតាងដោះបន្ទុកសក្តានុពល"ក៏ដោយ[513]។

174. ខៀវ សំផន បានលើកឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបាន"ប្រព្រឹត្តផ្ទុយខ្លួនឯង" និងដោយអសុទ្ធចិត្តនៅពេលធ្វើសេចក្តីសម្រេចទទួលយក និងស្តាប់ភស្តុតាងដែលចេញពីឯកសារដែលត្រូវបានបង្ហាញនោះ ពីព្រោះអង្គជំនុំជម្រះមានភស្តុតាងគ្រប់គ្រាន់រួចហើយនៅក្នុងសំណុំរឿង ០០២/០២ ក្នុងការសម្រេចស្តីពីការទទួលខុសត្រូវរបស់ជនជាប់ចោទដោយពុំចាំបាច់បង្កឱ្យមានភាពស្មុគស្មាញ និងអូសបន្លាយការជំនុំជម្រះឡើយ[514]។ សេចក្តីសម្រេចនោះបានរួមបញ្ចូល៖ (១) ការទទួលយកសំណើរបស់សហព្រះរាជអាជ្ញាសុំការបង្ហាញកោះហៅបុគ្គលជាប់ពាក់ព័ន្ធ"ដែលគួរឱ្យសង្ស័យ"ដោយផ្អែកលើឯកសារដែលបានបង្ហាញនោះ ដូចជា សុន វុត[515] (២) ការខកខានក្នុងការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិក្នុងការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ព្រាប សុឃឿន បន្ទាប់ពីផុតកំណត់កាលបរិច្ឆេទសម្រាប់សំណើសុំឱ្យទទួល

---

[510] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១, ២០៥។

[511] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៨។

[512] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២-២០៣។

[513] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥-២០៧។

[514] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១០, ២១៤។

[515] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១១។

យកភស្តុតាងថ្មី[516] និង (៣) ការធ្វើសេចក្តីសម្រេចដោយផ្អែកលើមូលដ្ឋាននៃឯកសារដែលត្រូវបានបង្ហាញ ប៉ុន្តែពុំត្រូវបានទទួលយកជាឧទាហរណ៍ទាក់ទងទៅនឹងការបង្ហាញខ្លួនរបស់ មុយ វ៉ាន់នី និង ឡុង សាត[517]។

175. ខៀវ សំផន បានលើកឡើងថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមស្រប ការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃបទចោទមកលើរូបគាត់ សច្ចភាពផ្នែកច្បាប់ និងនីតិវិធី តុលាការព្រហ្មទណ្ឌឥតលម្អៀង ពេលវេលាគ្រប់គ្រាន់ និងការសម្រួលផ្សេងដល់ការត្រៀមរៀបចំការការពារខ្លួន ការជំនុំជម្រះដេញដោលចំពោះមុខ ការស្តាប់របស់តុលាការ ការការពារខ្លួនដោយប្រសិទ្ធភាព សំអាងហេតុពេញលេញ និងសមភាពតទល់ផ្លូវច្បាប់[518]។

176. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពាន ឬមានកំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិនោះ[519]។

177. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[520]។

178. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អំណះអំណាងរបស់ ខៀវ សំផន មួយចំនួនមានការភាន់ច្រឡំរវាងនីតិវិធីផ្សេងគ្នាដែលបញ្ញត្តិលើការបង្ហាញឯកសារដល់ភាគី និងការទទួលយកភស្តុតាង។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា វិធាន ៥៣(៤) និង ៨៧(៤) នៃវិធានផ្ទៃក្នុងបានបង្កើតរបបដាច់ដោយឡែកទាក់ទងទៅនឹងការបង្ហាញ និងទទួលយកភស្តុតាងក្នុងអំឡុងពេលជំនុំជម្រះ ដូចបានបញ្ជាក់ជារឿយៗដោយអង្គជំនុំជម្រះសាលាដំបូង[521]។ បើទោះបីជា វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងជាប់ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញឯកសារមួយចំនួនដល់អង្គជំនុំជម្រះ

[516] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១២។

[517] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៣-២១៤។

[518] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៨-២០៩, ២១៥។

[519] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨-៧០។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៤៦។

[520] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៩៤-១០១។

[521] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២០។ សេចក្តីសម្រេចលើសំណើសុំពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារលេខ E421/4 (សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៨៧(៤) (E421/4) ) កថាខណ្ឌ ៩។

សាលាដំបូង និងភាគីក៏ដោយ ក៏វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងបានកំណត់ការទទួលយកភស្តុតាងថ្មីក្នុងអំឡុងពេលនៃការជំនុំជម្រះ និង"ចែងនូវលក្ខខណ្ឌនៃការទទួលយកភស្តុតាងថ្មី"ដែរ[522]។

179. ការបង្ហាញភស្តុតាងថ្មីបានកំណត់ក្នុងវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងដែលចែងថា "ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេតនូវភស្តុតាងទាំងឡាយដែលសហព្រះរាជអាជ្ញាបានដឹង ដែលនឹងអាចបង្ហាញនូវភាពគ្មានពិរុទ្ធ ឬការសម្រាលពិរុទ្ធភាពរបស់ជនសង្ស័យ ឬជនត្រូវចោទ ឬការធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងរបស់អយ្យការ"[523]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងថា វិធាននេះបានដាក់កាតព្វកិច្ចជាអចិន្ត្រៃយ៍លើសហព្រះរាជអាជ្ញាឱ្យបង្ហាញដល់អង្គជំនុំជម្រះ និងភាគីនូវភស្តុតាងណាមួយដែលខ្លួនមានដែលអាចបង្ហាញនូវភាពគ្មានទោស ឬការសម្រាលទោសរបស់ជនជាប់ចោទ ឬការប៉ះពាល់ដល់ភាពជឿទុកចិត្តបាននៃភស្តុតាង[524]។ ដូច្នេះ កាតព្វកិច្ចនៃការបង្ហាញភស្តុតាងនេះ គឺជាមូលដ្ឋានក្នុងការរារាំងភាពមិនយុត្តិធម៌តាមរយៈការធានាថា គ្រប់ភាគី និងចៅក្រមត្រូវទទួលបានព័ត៌មានអំពីភស្តុតាងដែលអាចបង្ហាញនូវភាពគ្មានពិរុទ្ធ ឬការសម្រាលទោសរបស់ជនជាប់ចោទ និងត្រូវបានកម្រិតត្រឹមការបង្ហាញភស្តុតាងដោះបន្ទុកដែលមានសក្តានុពល។ ដូចបានបញ្ជាក់ខាងលើដោយអង្គជំនុំជម្រះតុលាការកំពូល កាតព្វកិច្ចក្នុងការបង្ហាញភស្តុតាង គឺជា"សមាសភាគមួយនៃការជំនុំជម្រះត្រឹមត្រូវ និងស្របតាមតួនាទីរបស់អយ្យការក្នុងការជួយតុលាការបញ្ជាក់ការពិត"[525]។

180. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការសមស្របក្នុងការគូសបង្ហាញបរិបទពាក់ព័ន្ធដែលការបង្ហាញនៃឯកសារក្នុងសំណុំរឿង ០០៣ និង ០០៤ បានកើតឡើង។ អង្គជំនុំជម្រះតុលាការកំពូលសង្កេត

---

[522] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២០។

[523] វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។

[524] សេចក្តីសម្រេចលើសំណើទីបីរបស់ នួន ជា សុំឱ្យទទួលយក និងពិចារណាលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/2 ("សេចក្តីសម្រេចលើសំណើសុំភស្តុតាងបន្ថែម (F2/4/2)") កថាខណ្ឌ ១៧ យោងទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការបង្ហាញចម្លើយរបស់សាក្សីដែលអាចមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E127/4 ("អនុស្សរណៈជូនដំណឹងអំពីការបង្ហាញចម្លើយរបស់សាក្សី (E127/4)") (អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើវិធាននេះក្នុងសំណុំរឿង ០០២/០១៖ "វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងបានដាក់កាតព្វកិច្ចបន្តលើសហព្រះរាជអាជ្ញាក្នុងការបង្ហាញភស្តុតាងដល់អង្គជំនុំជម្រះសាលាដំបូងដែលខ្លួនមានអាចបង្ហាញអំពីនិរទោស ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចប៉ះពាល់ដល់ការជឿទុកចិត្តបាននៃភស្តុតាង")។

[525] សេចក្តីសម្រេចលើសំណើសុំភស្តុតាងបន្ថែម (F2/4/2) កថាខណ្ឌ ១៧ យោងទៅលើមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

ឃើញថា ខ្លឹមសារពាក់ព័ន្ធ និងការត្រួតគ្នានៃក្របខ័ណ្ឌពេលវេលា ទីតាំងភូមិសាស្ត្រ និងទីតាំងបទឧក្រិដ្ឋនៃកិច្ចស៊ើបសួរដែលកំពុងបន្តក្នុងសំណុំរឿង ០០៣ និង ០០៤ *តាមសេចក្តីបញ្ជាក់ដំបូង*បានបណ្តាលឱ្យមានភស្តុតាងពាក់ព័ន្ធថ្មីដែលមានអត្ថិភាពក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២[526]។ ដោយសារខ្លួនជាភាគីតែមួយគត់ដែលអាចចូលមើលសំណុំរឿងសម្ងាត់ ០០៣ និង ០០៤ បាន សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតដើម្បីបង្ហាញភស្តុតាងមួយចំនួនដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាអន្តរជាតិបានពន្យល់ថា៖

> ដោយសារកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ កំពុងដំណើរការ ការិយាល័យសហចៅក្រមស៊ើបអង្កេតជាទៀងទាត់ដាក់បន្ថែមភស្តុតាងថ្មីចូលក្នុងសំណុំរឿង ០០៣ និង ០០៤។ នៅពេលទទួលបានការជូនដំណឹងអំពីឯកសារទាំងនេះ សហព្រះរាជអាជ្ញាបានពិនិត្យដើម្បីកំណត់ថាតើ ឯកសារនោះស្ថិតក្រោមកាតព្វកិច្ចនៃការបង្ហាញ ដែរ ឬយ៉ាងណា។ បន្ទាប់មកសហព្រះរាជអាជ្ញាបានដាក់សំណើទៅសហចៅក្រមស៊ើបអង្កេតសុំការអនុញ្ញាតបង្ហាញផ្នែកខ្លះដែលខ្លួនបានរកឃើញថា ត្រូវដាក់បង្ហាញទៅអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ និងភាគី។ [...] នៅពេលសហព្រះរាជអាជ្ញាបានទទួលការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតឱ្យបង្ហាញឯកសារនេះក្នុងសំណុំរឿង ០០២ (ដែលជួនកាលត្រឹមតែបានអនុញ្ញាតជាទម្រង់កោសលុបប៉ុណ្ណោះ) សហព្រះរាជអាជ្ញាបានដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូងសុំការបង្ហាញឯកសារទាំងនេះ [...][527]។

181. នៅចន្លោះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ និងថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញា អន្តរជាតិបានដាក់សំណើសុំការបង្ហាញនៅមុខអង្គជំនុំជម្រះសាលាដំបូង ដែលមានចម្លើយ និងឯកសារដទៃទៀតចេញពីសំណុំរឿង ០០៣ និង ០០៤[528]។ នៅក្នុងសំណើនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ និង

---

[526] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០។

[527] ព័ត៌មាន និងការបំភ្លឺពាក់ព័ន្ធទៅនឹងដំណើរការនៃការបង្ហាញក្នុងសំណុំរឿង ០០២/០២ ក្នុងបរិបទនៃកិច្ចស៊ើបសួរកំពុងបន្តក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ E319/14 កថាខណ្ឌ ៧។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤១។

[528] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ E319 ("ការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319)")។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងផ្នែកទីមួយនៃការជំនុំជម្រះសំណុំរឿង ០០២/០២ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារលេខ E319/8។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ D319/12។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿងលេខ 004-D193/11 ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ

យល់ឃើញថា កាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញឯកសារស្របតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងបានរួមបញ្ចូល“ភស្តុតាងពាក់ព័ន្ធដែលដាក់បន្ទុក ឬដោះបន្ទុក”[529]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើផ្សេងគ្នាស្នើសុំការទទួលយកឯកសារមួយចំនួនដែលត្រូវបានបង្ហាញស្របតាមវិធាន ៨៧(៣) និង ៨៧(៤) ដែលកំណត់អំពីការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ[530]។

២០១៥ ឯកសារលេខ E319/13។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមវសំណុំរឿងលេខ 004-D193/13 ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ E319/15។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/15 ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E319/13។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/16 ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E319/20។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/21 ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារលេខ E319/21។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវ៖ ១) ចម្លើយពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង ២) ឯកសារពីសំណុំរឿង ០០៣ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 003-D100/9 ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E319/23។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/24 ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E319/24។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/28 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥, ឯកសារលេខ E319/25។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/30 ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E319/26។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 003-D100/12 និង 004-D193/33 ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E319/27។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/34 ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E319/28។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវចម្លើយចេញពីសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ស្របតាមសំណុំរឿង 004-D193/37 ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E319/29។

[529] *សូមមើល ឧ.* ការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319) កថាខណ្ឌ ១។

[530] *សូមមើល ឧ.* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពាក់ព័ន្ធទៅនឹងនៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ស្របតាមវិធាន ៨៧(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ E319/5 (“សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ (E319/5)”)។

182. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ ខៀវ សំផន បានដាក់សារណាពាក់ព័ន្ធនឹងកាតព្វកិច្ចនៃការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញា[531] ដែលក្នុងនោះគាត់បានអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ *ក្នុងចំណោមនោះ* បានបំភ្លៃច្បាប់ជាធរមានតាមរយៈការបង្ហាញភស្តុតាងទាំងអស់ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ជាជាងកម្រិតការបង្ហាញត្រឹមតែភស្តុតាងដោះបន្ទុកប៉ុណ្ណោះ[532]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានទទួលបានភស្តុតាងដោះបន្ទុកជាសក្តានុពល" និងបានបញ្ជាក់សាជាថ្មីថា វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង បានដាក់កាតព្វកិច្ចជាអចិន្ត្រៃយ៍ឱ្យបង្ហាញភស្តុតាងនោះដែលមានអានុភាពក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[533]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នេះគឺជាការទទួលខុសត្រូវដាច់មុខរបស់សហព្រះរាជអាជ្ញាក្នុងការកំណត់ដោយសុចរិតភាពនូវព័ត៌មានអ្វីខ្លះដែលអាចជាភស្តុតាងដោះបន្ទុក និងបានពិចារណាថា "ភាពមិនប្រាកដប្រជាដែលពុំស្របទៅនឹងទ្រឹស្តីជាក់លាក់របស់ក្រុមមេធាវីការពារក្តី ពុំអាចជាការដោះសារ ដើម្បីប្រើប្រាស់វិធីសាស្ត្រទូលំទូលាយហួសហេតុក្នុងការបង្ហាញភស្តុតាងនោះទេ ហើយក៏ពុំអាចធ្វើយុត្តិកម្មការបញ្ចូលភស្តុតាងដាក់បន្ទុកនៅក្នុងការបង្ហាញនេះដែលស្របតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងបានដែរ"[534]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "តាមរយៈការដាក់បញ្ចូលនូវការបង្ហាញក្នុងសំណុំរឿង ០០៣ និង ០០៤ នៃភស្តុតាងណាមួយដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ រួមទាំងភស្តុតាងដាក់បន្ទុក សហព្រះរាជអាជ្ញាបានធ្វើការបកស្រាយទូលំទូលាយហួសហេតុលើវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង"[535]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ការបង្ហាញភស្តុតាងបន្ថែមនេះពុំមែនជាការរំលោភបំពាន

---

[531] សារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ (E363)។

[532] សារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ (E363) កថាខណ្ឌ ៦-១០។

[533] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ ឯកសារលេខ E363/3 កថាខណ្ឌ ២២ យោងទៅលើអនុស្សរណៈជូនដំណឹងអំពីការបង្ហាញចម្លើយរបស់សាក្សី (E127/4)។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីសម្រេចលើសំណើសុំពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E421/3 ទំព័រ ២។ សេចក្តីសម្រេចលើសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4) កថាខណ្ឌ ៩។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "គោលការណ៍ណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបង្ហាញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០៣ និង០០៤ ក្នុងសំណុំរឿង ០០២/០២" ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E319/14/2។

[534] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២៤។

[535] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣១។

លើសិទ្ធិរបស់ជនជាប់ចោទនោះទេ" បើទោះបីជាក្នុងករណីដែលមានឯកសារក្នុងចំនួនដ៏ច្រើនលើសលប់ត្រូវបានផ្តល់ទៅឱ្យក៏ដោយ ដរាបណាមានការសម្របសម្រួលត្រូវបានធ្វើឡើង"[536]។

183. ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានណែនាំសហព្រះរាជអាជ្ញាឱ្យកម្រិត"ការបង្ហាញទាំងអស់ពេលអនាគតត្រឹមភស្តុតាងដោះបន្ទុក និងចម្លើយរបស់បុគ្គលដែលបានផ្តល់សក្ខីកម្ម ឬត្រូវបានស្នើសុំឱ្យផ្តល់សក្ខីកម្ម"ក្នុងសំណុំរឿង ០០២/០២[537]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យារការកំណត់កាលបរិច្ឆេទដល់ថ្ងៃ ៣០ ខែ មករា ឆ្នាំ ២០១៦ សម្រាប់សហព្រះរាជអាជ្ញាស្នើសុំការទទួលយកឯកសារដែលត្រូវបានបង្ហាញពីដំបូង[538] និងបានផ្តល់សំណងបន្ថែមដោយសារទំហំនៃការបង្ហាញភស្តុតាងនោះ[539]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកកិច្ចដំណើរការនីតិវិធីអស់រយៈពេលជាច្រើនសប្តាហ៍ដើម្បីអនុញ្ញាតឱ្យភាគីធ្វើការពិនិត្យលើភស្តុតាងនោះ និងបានពន្យារសវនាការលើសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ និងបានចេញគោលការណ៍ណែនាំឱ្យកម្រិតវិសាលភាពនៃការបង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានជួយសម្រួលដល់ក្រុមមេធាវីការពារក្តីទទួលបានធនធានផ្នែកហិរញ្ញវត្ថុបន្ថែម[540]។ ដោយអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តបង្ហាញភស្តុតាងចេញពីសំណុំរឿង ០០៣ និង ០០៤ និងបានស្នើសុំដាច់ដោយឡែកពីគ្នានូវការទទួលយកភស្តុតាងមួយចំនួនស្របតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។

184. បន្ទាប់ទៅនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយៈ (១) កំហុសអង្គច្បាប់ដែលរងការចោទប្រកាន់ក្នុងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង និងការអនុវត្តន៍តាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង និង (២) បញ្ហាថាតើ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្ហាញភស្តុតាងបានរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ ដែរ ឬយ៉ាងណា។

### ក. ការចោទប្រកាន់កំហុសអង្គច្បាប់

185. នៅបណ្តឹងសាទុក្ខ តាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ខៀវ សំផន បានអះអាងថាអង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវដោយផ្អែកលើវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ធ្វើការណែនាំសហ

[536] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣១។

[537] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៦។

[538] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៥។

[539] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៨។

[540] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៨។

ព្រះរាជអាជ្ញាឱ្យបង្ហាញតែភស្តុតាងដោះបន្ទុកប៉ុណ្ណោះ[541] ដើម្បីដកភស្តុតាងដែលត្រូវបានបង្ហាញ“ដោយខុសច្បាប់”ចេញពីសំណុំរឿង[542] និងណែនាំ*សហព្រះរាជអាជ្ញា* ឱ្យផ្តល់ព័ត៌មានស្តីពីឯកសារដែលដោះបន្ទុកដាក់លាក់នៅក្នុងឯកសារដែលត្រូវបានបង្ហាញនោះ[543]។

186. ទាក់ទងទៅនឹងសារណាទីមួយ និងផ្អែកលើសេចក្តីណែនាំច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យកម្រិតរាល់ការបង្ហាញ*នាពេលអនាគត*ត្រឹមតែភស្តុតាងដោះបន្ទុក និងចម្លើយរបស់បុគ្គលដែលបានផ្តល់សក្ខីកម្ម ឬដែលត្រូវបានស្នើឡើងឱ្យផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[544] អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការចោទប្រកាន់នេះត្រូវបានដោះស្រាយយ៉ាងមានប្រសិទ្ធភាពដោយ*អង្គជំនុំជម្រះសាលាដំបូង* និងពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់[545]។ បន្ថែមលើនេះ សារណានៃបណ្តឹងសាទុក្ខនេះបានលើកច្រំដែលនូវអំណះអំណាងដែលបានលើករួចហើយក្នុងអំឡុងពេលនៃការជំនុំជម្រះ ដោយគ្មានការបង្ហាញថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយ ឬអនុវត្តវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងដូចម្តេចឡើយ។

187. បន្ថែមលើនេះ ក្នុងផ្នែកមួយនៃសារណារបស់គាត់ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង“ជាញឹកញាប់បានបដិសេធក្នុងការផ្តល់សេចក្តីណែនាំដល់[សហព្រះរាជអាជ្ញា] ឱ្យបញ្ជាក់ថាតើ ភស្តុតាងណាខ្លះដែលដោះបន្ទុក”[546] ខៀវ សំផន ទំនងជាចង់លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យណែនាំសហព្រះរាជអាជ្ញាឱ្យពិនិត្យភស្តុតាងទាំងអស់ដែលត្រូវបានបង្ហាញពីមុន ដោយផ្តោតលើការកំណត់អត្តសញ្ញាណនៃភស្តុតាងដែលពុំបានបំពេញតាមការកំណត់និយមន័យនៃភស្តុតាងដោះបន្ទុក។ ទាក់ទងទៅនឹងការបង្ហាញភស្តុតាងពីមុនទាំងនោះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ការពិនិត្យប្រតិសកម្មលើការបង្ហាញពីមុន“ទំនងជាបង្កើនបន្ទុកជាជាងកាត់បន្ថយដល់មេធាវីការពារក្តី ក៏ដូចជាភាគីដទៃទៀតដែរ”[547]

[541] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១។

[542] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥។

[543] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥។

[544] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៦។

[545] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១។

[546] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥។

[547] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥ យោងទៅលើសេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៥។

និងបានបញ្ជាក់ថា នេះពុំមានភាពចាំបាច់"សម្រាប់គោលបំណងនៃការបញ្ជាក់ការពិត"[548]។ ដោយយោងទៅលើយុត្តិសាស្ត្រអន្តរជាតិស្តីពីបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កាតព្វកិច្ចក្នុងការវាយតម្លៃលើភស្តុតាងដែលជាកម្មវត្ថុនៃការបង្ហាញ គឺជារបស់សហព្រះរាជអាជ្ញាដែលអាចចូលមើលសំណុំរឿងសម្ងាត់ ០០៣ និង ០០៤ និងត្រូវបានសន្មតថា បានអនុវត្តដោយសុចរិត លើកលែងតែមានការបង្ហាញផ្សេងពីនេះ[549]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បន្ទុកគឺជារបស់ ខៀវ សំផន ក្នុងការលើកភាពមិនសមស្របពីសំណាក់សហព្រះរាជអាជ្ញា និងយល់ស្របជាមួយការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់ខកខានក្នុងការយកចិត្តទុកដាក់លើកបង្ហាញនូវការបកស្រាយទូលំទូលាយ ឬសហេតុរបស់សហព្រះរាជអាជ្ញាលើវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងបានទាន់ពេល។ តាមការពិនិត្យលើ

---

[548] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៥។

[549] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២២។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Hassan Ngeze សុំការយល់ព្រមបើកកិច្ចស៊ើបសួរបន្ថែមលើព័ត៌មានជាក់លាក់ទាក់ទងទៅនឹងភស្តុតាងបន្ថែមរបស់សាក្សីសក្តានុពល ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៧។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Jean-Bosco Barayagwiza សុំការអនុញ្ញាតបង្ហាញភស្តុតាងបន្ថែមស្របតាមវិធាន ១១៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ១១, ៣៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14-A សេចក្តីម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំបង្កើតសម្ភារៈ ការផ្អាក ឬពន្យារពេលនៃកាលបរិច្ឆេទដាក់សារណា និងឯកសារបន្ថែម កថាខណ្ឌ ៣៩។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Bralo* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-17-A សេចក្តីសម្រេចលើញត្តិសុំពិនិត្យផ្នែកនៃកំណត់ត្រាលើបណ្តឹងឧទ្ធរណ៍ និងការបង្ហាញឯកសារសម្រាលទោស ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ ៣០។ "ការកំណត់ថាតើ ភស្តុតាងអ្វីខ្លះបំពេញ ... លក្ខខណ្ឌនៃការបង្ហាញជាចម្បងត្រូវបានបង្កើតឡើង និងស្ថិតក្រោមការទទួលខុសត្រូវរបស់អយ្យការ"។ "អង្គជំនុំជម្រះឧទ្ធរណ៍នឹងពុំធ្វើអន្តរាគមន៍នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អយ្យការ លើកលែងតែមានការបង្ហាញថា អយ្យការបានរំលោភបំពាននោះ និងក្នុងករណីពុំមានភស្តុតាងបង្ហាញផ្ទុយ អង្គជំនុំជម្រះសន្មតថា អយ្យការបានអនុវត្តដោយសុចរិត"។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Jean-Bosco Barayagwiza ស្នើសុំថា ការបង្ហាញរបស់អយ្យការនូវកិច្ចសម្ភាសន៍របស់ Michel Bagaragaza ត្រូវដកចេញពីសំណុំរឿង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦ កថាខណ្ឌ ៦។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-44-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗពាក់ព័ន្ធទៅនឹងតួនាទីរបស់អយ្យការក្នុងការបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការបំពេញកាតព្វកិច្ចនៃការបង្ហាញឯកសារ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Karemera និងជនជាប់ចោទដទៃទៀត* (ICTR)") កថាខណ្ឌ ៩។

ប្រវត្តិនីតិវិធីបង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិដំបូងបានបង្ហាញភស្តុតាងពាក់ព័ន្ធដោយរួមបញ្ចូលដាក់បន្ទុក នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ ខៀវ សំផន ពុំបានបង្ហាញនូវការជំទាស់រហូតដល់ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ បន្ទាប់ពីការបង្ហាញបន្តបន្ទាប់ក្រោយមកចំនួន ១៤ ឯកសារដែលពាក់ព័ន្ធ រួមទាំងភស្តុតាងដាក់បន្ទុក។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសលើមូលដ្ឋាននៃសំអាងហេតុ និងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

188. ក្នុងការដោះស្រាយសារណាទីពីរដែលពាក់ព័ន្ធទៅនឹងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដកភស្តុតាងដែលត្រូវបានបង្ហាញ"ដោយខុសច្បាប់"ចេញពីសំណុំរឿង[550] អង្គជំនុំជម្រះតុលាការកំពូល រំឭកថា ភស្តុតាងដែលត្រូវបានបង្ហាញតាមវិធាន ៥៣(៤) ពុំត្រូវបានទទួលយកជាស្វ័យប្រវត្តិទៅក្នុងសំណុំរឿងឡើយ។ ជាច្រើនលើកច្រើនសា អង្គជំនុំជម្រះសាលាដំបូងបានរំឭកភាគីថា ឯកសារដែលត្រូវបានបង្ហាញនោះពុំអាចត្រូវបានទទួលជាស្វ័យប្រវត្តិ ឬដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ[551]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា "អ្វីដែលមាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ [...] ពុំទាន់ត្រូវបានទទួលយកភស្តុតាង និងពុំមានក្នុងកំណត់ត្រាជំនុំជម្រះឡើយ។ ការដែលបានធ្វើដូច្នេះ គឺដើម្បីផ្ទុកឯកសាររបស់ភាគីដែលចង់ដាក់"[552] ដើម្បីឱ្យ"ក្លាយជាកម្មវត្ថុនៃសំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ប្រសិនបើពុំធ្វើដូច្នេះទេ ពុំមែនជាផ្នែកនៃសំណុំរឿង និងពុំអាច [...] ក្លាយជាមូលដ្ឋាននៃការសម្រេចណាមួយឡើយ"[553]។ បន្ថែមលើនេះ បើទោះបីជាសហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការបង្ហាញឯកសារដោះបន្ទុកដល់មេធាវីការពារក្តីស្របតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សហព្រះរាជអាជ្ញាអាចស្នើសុំការទទួលយកភស្តុតាងដាក់បន្ទុកតាមវិធាន ៨៧(៤)។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "បើទោះបីជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញត្រូវបានកម្រិតត្រឹមព័ត៌មានដោះបន្ទុកក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែអាចស្នើសុំការទទួលយកភស្តុតាងថ្មីដែលខ្លួនចាត់ទុកថា

---

[550] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥។

[551] សេចក្តីសម្រេចលើសំណើសុំស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4) កថាខណ្ឌ ៩។ ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/454/1.1 ទំព័រ ១៦, ១៨, ២០។

[552] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/454/1.1 ទំព័រ ១៦, ១៨។

[553] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/454/1.1 ទំព័រ ២០។

បានជួយដល់ការបញ្ជាក់ការពិត រួមទាំងភស្តុតាងដាក់បន្ទុកចេញពីសំណុំរឿង ០០៣ និង ០០៤ ឬប្រភពដទៃទៀត”[554] តាមរយៈសំណើសុំមានហេតុផលស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងផងដែរ[555]។

189. ការបង្ហាញភស្តុតាងទូលំទូលាយដំបូងរបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៥៣(៤) ពុំបានបណ្តាលឱ្យមានការដាក់បញ្ចូលក្នុងសំណុំរឿងនូវឯកសារ“ខុសច្បាប់”ឡើយ។ ក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. បានផ្តល់នីតិវិធីដាច់ដោយឡែកស្របតាមវិធាន ៨៧(៣) និង(៤) នៃវិធានផ្ទៃក្នុង សម្រាប់ការទទួលយកភស្តុតាងថ្មីក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ ក្នុងរឿងក្តីនេះ នៅពេលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំដាក់ឯកសារថ្មីចូលសំណុំរឿង អង្គជំនុំជម្រះសាលាដំបូងបានណែនាំសហព្រះរាជអាជ្ញាឱ្យស្នើសុំការទទួលយកភស្តុតាងនៃសំណុំរឿង ០០៣ និង ០០៤ ដែលពុំស្ថិតក្នុងការបង្ហាញពីរប្រភេទតាមរយៈការដាក់សំណើសុំស្របតាមវិធាន ៨៧(៤) និងតាមរយៈការផ្តល់មូលហេតុដែលឯកសារទាំងនោះគប្បីត្រូវទទួលយក និងតាមរយៈការភ្ជាប់ជាមួយនូវឯកសារដែលបានស្នើសុំនោះ[556]។ ជាលទ្ធផល ភស្តុតាងសំណុំរឿង ០០៣ និង ០០៤ ដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងត្រូវបានបង្ហាញសម្រាប់តែគោលបំណងនៃការទទួលយកដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនៅក្នុងសំណើសុំផ្អែកតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[557]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបែងចែកយ៉ាងជាក់ច្បាស់លាស់រវាងសំណើសុំទាំងនោះ និងសំណើសុំការបង្ហាញ និងបានផ្តល់ព័ត៌មានបន្ថែមទាក់ទងទៅនឹងបញ្ហាថាតើ ឯកសារដែលត្រូវបានបង្ហាញនោះមានភស្តុតាងដោះបន្ទុក ឬចម្លើយពីមុន ដែរ ឬយ៉ាងណា[558]។ ប្រហាក់ប្រហែលគ្នានេះ វិធាន ៨៧(៤) បានអនុញ្ញាតឱ្យ ខៀវ សំផន ស្នើសុំឱ្យទទួលយកភស្តុតាងដោះបន្ទុកជាសក្តានុពល បន្ទាប់ពីការបង្ហាញនូវភស្តុតាងចេញពីសំណុំរឿង ០០៣ និង ០០៤។ អាស្រ័យហេតុនេះ

---

554 សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ២៨។

555 សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៦។

556 សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៦។

557 *សូមមើល ឧ.* សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E319/47។

558 *សូមមើល ឧ.* ឧបសម្ព័ន្ធ ក៖ ឯកសារសវនាការសាធារណៈ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E319/40.2។ ឧបសម្ព័ន្ធ ក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/41.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/44.2។ ឧបសម្ព័ន្ធ ក ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/45.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/44.2។ ឧបសម្ព័ន្ធ ក៖ ឯកសារសវនាការសាធារណៈ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/45.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/46.2។

អង្គជំនុំជម្រះតុលាការកំពូលពិចារណាពុំឃើញថា ឯកសារនោះត្រូវបានបង្ហាញដោយ“ខុសច្បាប់” ឬថា នេះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបង្កើន“ភស្តុតាងដាក់បន្ទុកច្រើនសន្ធឹកសន្ធាប់នោះឡើយ”។

190. ទាក់ទងទៅនឹងសារណាទីបីពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការណែនាំសហព្រះរាជអាជ្ញាឱ្យផ្តល់ព័ត៌មានស្តីពីភស្តុតាងដោះបន្ទុកជាក់លាក់ *ពីការដាក់កំណត់សម្គាល់*នៅក្នុងឯកសារដែលត្រូវបានបង្ហាញ[559] ខៀវ សំផន បានសំអាងទៅលើយុត្តិសាស្ត្រអន្តរជាតិត្រង់ចំណុចថា អយ្យការត្រូវពិនិត្យដោយសកម្មលើភស្តុតាងក្នុងដៃសម្រាប់ការដោះបន្ទុក និងថា ជាការពុំគ្រប់គ្រាន់សម្រាប់អយ្យការ“ត្រឹមដាក់ភស្តុតាងទាំងមូលចូលនៅក្នុងកន្លែងប្រមូលផ្តុំផ្ទុកឯកសារប៉ុណ្ណោះទេ”[560]។ បើទោះបីជាការលើកឡើងនេះត្រឹមត្រូវក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយដោយប្រសិទ្ធភាពលើការបង្ហាញយ៉ាងទូលំទូលាយរបស់សហព្រះរាជអាជ្ញា នៅពេលដែលបញ្ហានេះបានលើកឡើង ហើយនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឱ្យសហព្រះរាជអាជ្ញាកម្រិតការបង្ហាញឯកសារនាពេលអនាគតត្រឹមភស្តុតាងដោះបន្ទុក និងចម្លើយពីមុនៗ និងតាមរយៈការណែនាំឱ្យបង្កើតវិធានការនានា ដើម្បីគ្រប់គ្រងការបង្ហាញភស្តុតាងដែលមានទំហំធំនោះ[561]។ នេះត្រូវបានធ្វើឡើងដើម្បីធានាថា ជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យលើឯកសារពាក់ព័ន្ធដែលត្រូវបានបង្ហាញ និងធ្វើការសម្រេចថាតើ ត្រូវស្នើសុំឱ្យទទួលជាភស្តុតាង ដែរ ឬយ៉ាងណា។ ចាប់ពីពេលនោះមក ការបង្ហាញបន្តបន្ទាប់ក្រោយមករបស់សហព្រះរាជអាជ្ញា បានរួមបញ្ចូលនូវមូលហេតុជាក់លាក់សម្រាប់ការបង្ហាញឯកសារនីមួយៗ ជាឧទាហរណ៍ ឯកសារ“មានភស្តុតាងដោះបន្ទុកជាសក្ខីកម្មដើម ក្ខានុពល” ឬជា“ចម្លើយរបស់សាក្សីដែលត្រូវបានជ្រើសរើសនោះ”[562]។ ក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ នួន ជា សុំឱ្យណែនាំសហព្រះរាជអាជ្ញាដាក់កំណត់សម្គាល់ឯកសារដែលត្រូវបានបង្ហាញនៅក្នុងផ្នែកជាក់លាក់ដែលសហព្រះរាជអាជ្ញាចាត់ទុកថា ជាភស្តុតាងដោះបន្ទុក។ អង្គជំនុំ

[559] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥។

[560] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥ យោងទៅលើសារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ (E363) កថាខណ្ឌ ២០-២១ យោងទៅលើសារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ កថាខណ្ឌ ២០-២១។

[561] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣៨។

[562] *សូមមើល ឧ.* ឧបសម្ព័ន្ធ កៈ ឯកសារសវនាការសាធារណៈ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E319/40.2។ ឧបសម្ព័ន្ធ ក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/41.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/42.2។ ឧបសម្ព័ន្ធ ក ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E319/43.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/44.2។ ឧបសម្ព័ន្ធ កៈ ឯកសារសវនាការសាធារណៈ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/45.2។ ឧបសម្ព័ន្ធ ១ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ E319/46.2។

ជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា គាត់ខកខានក្នុងការ"បង្ហាញនូវយុត្តិសាស្រ្តណាមួយដែលដាក់លក្ខខណ្ឌលើសហព្រះរាជអាជ្ញា បន្ថែមលើកាតព្វកិច្ចក្នុងការបង្ហាញ ក្នុងការដាក់កំណត់សម្គាល់ផ្នែកនៃឯកសារដែលត្រូវបានបង្ហាញដែលចាត់ទុកថា ជាភស្តុតាងដោះបន្ទុកមានសក្តានុពលនោះឡើយ"[563]។ ក្នុងបណ្តឹងសាទុក្ខ ខៀវ សំផន ត្រឹមតែយោងទៅលើសំណើរបស់ នួន ជា ដែលត្រូវបានបដិសេធចោល និងពុំបានបង្ហាញនូវកំហុសណាមួយក្នុងវិធីសាស្រ្តរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

191. បន្ថែមលើនេះ យុត្តិសាស្រ្តអន្តរជាតិបានគាំទ្រសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សហព្រះរាជអាជ្ញាត្រូវបង្ហាញមេធាវីការពារក្តីនូវអត្ថិភាពនៃភស្តុតាងដោះបន្ទុក ប៉ុន្តែពុំមែនថា ជាកាតព្វកិច្ចក្នុងការបង្ហាញផ្នែកនោះនៅក្នុងឯកសារដែលត្រូវបានបង្ហាញនោះទេ[564]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("តុលាការ ICTR") បានពិចារណាថា កាតព្វកិច្ចរបស់អយ្យការក្នុងការបង្ហាញ"បានពន្លាតហួសពីការត្រឹមតែការប្រមូលផ្តុំឯកសារទាំងអស់ទុកក្នុងកន្លែងដែលអាចមើលបាន"[565] និងតម្រូវឱ្យ"ពិនិត្យសមស្របនូវឯកសារដែលមាននោះដើម្បីរកមើលភស្តុតាងដោះបន្ទុក និង *យ៉ាងហោចណាស់*ត្រូវជូនដំណឹងជនជាប់ចោទអំពីអត្ថិភាពនៃឯកសារនោះ"[566]។ អង្គជំនុំជម្រះនៃតុលាការ ICTY តាមការអនុវត្តន៍ជាក់ស្តែង បានជម្រុញឱ្យអយ្យការបង្ហាញថាតើ មានឯកសារណាខ្លះដែលខ្លួនបានបង្ហាញស្របតាមវិធានពាក់ព័ន្ធសម្រាប់ភស្តុតាងដោះបន្ទុក"ដើម្បីធានាបាននូវការជំនុំជម្រះត្រឹមត្រូវ និងឆាប់រហ័ស"[567]។ កាតព្វកិច្ចនោះពុំបានរួមបញ្ចូលនូវការធ្វើជាបញ្ជីឈ្មោះនៃឯកសារដែលត្រូវបានបង្ហាញ

---

[563] សេចក្តីសម្រេចលើសំណើ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4) កថាខណ្ឌ ១០ (អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នួន ជា "ខកខានក្នុងការបង្ហាញយុត្តិសាស្រ្តដែលដាក់ឱ្យសហព្រះរាជអាជ្ញាបន្ថែមលើកាតព្វកិច្ចក្នុងការបង្ហាញនូវកាតព្វកិច្ចក្នុងការគូសបង្ហាញចំណុចក្នុងឯកសារដែលត្រូវបង្ហាញថា ជាការដោះបន្ទុកសក្តានុពល។ ពុំមានការបង្ហាញថា សហព្រះរាជអាជ្ញាបានប្រព្រឹត្តដោយមិនសុចរិត ឬបង្ហាញថា ទំហំ និងរបៀបនៃការបង្ហាញបានធ្វើឱ្យប៉ះពាល់ជាសត្យានុម័តលើជនជាប់ចោទឡើយ")(សេចក្តីបញ្ជាក់បន្ថែម)។

[564] *សូមមើល ឧ.* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី*Karemera និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១០។

[565] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី*Karemera និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១០។

[566] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី*Karemera និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១០។

[567] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krajišnik និង Plavšić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-00-39 សេចក្តីសម្រេចលើញត្តិរបស់ជនជាប់ចោទ Momčilo KrajiÈnik ក្នុងការជម្រុញឱ្យបង្ហាញភស្តុតាងដោះបន្ទុកស្របតាមវិធាន ៦៨ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ ("ដោយពិចារណាឃើញថា (ក) វិធាន ៦៨ ពុំបានតម្រូវដាក់លាក់ឱ្យអយ្យការក្នុងការកំណត់ឯកសារពាក់ព័ន្ធ ប៉ុន្តែត្រឹមតែបង្ហាញប៉ុណ្ណោះ (ខ) ទោះជាយ៉ាងណាក្តី តាមការអនុវត្តន៍ជាក់ស្តែង និងដើម្បីធានាការជំនុំជម្រះឆាប់រហ័ស និងយុត្តិធម៌ អយ្យការគប្បីបង្ហាញតាមធម្មតាឯកសារណាខ្លះដែលខ្លួនមាន ស្របតាមវិធាន និងពុំអាចនិយាយថា មេធាវីការពារក្តីស្ថិតក្នុងតួនាទីប្រសើរជាងក្នុងការបង្ហាញនោះទេ")។

នោះឡើយ[568]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Karadžić* នៃតុលាការ ICTY បានពិចារណាឃើញថា អយ្យការបានបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលឯកសារដែលត្រូវបានបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវបានដាក់ក្នុងកន្លែងពិសេសមួយសម្រាប់ភស្តុតាងដោះបន្ទុក[569]។

ខ. ការចោទប្រកាន់អំពីការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ

192. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ដោយពិចារណាលើពេលវេលា និងធនធានបន្ថែមដែលត្រូវបានផ្តល់ឱ្យមេធាវីការពារក្តី ព្រមទាំងការកម្រិតផ្នែកនីតិវិធី និងខ្លឹមសារដែលបានដាក់ទៅលើសហព្រះរាជអាជ្ញា ដំណើរការនៃការបង្ហាញភស្តុតាងពុំបានរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទក្នុងការត្រៀមលក្ខណៈការការពារខ្លួនដោយប្រសិទ្ធភាព និងពុំបានលម្អៀងទៅរកសហព្រះរាជអាជ្ញាឡើយ"[570]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា អង្គជំនុំជម្រះបានដោះស្រាយផលប៉ះពាល់ជាសក្តានុពលនៃការបង្ហាញភស្តុតាង *ក្នុងចំណោមនោះ* តាមរយៈការផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីអនុញ្ញាតឱ្យភាគីពិនិត្យលើឯកសារដែលត្រូវបានបង្ហាញ ការពន្យារពេលសវនាការលើសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ ការចេញគោលការណ៍ណែនាំដែលកម្រិតវិសាលភាពនៃការបង្ហាញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងតាមរយៈការជួយសម្រួលដល់ក្រុមមេធាវីការពារក្តីក្នុងការទទួលបានធនធានហិរញ្ញវត្ថុបន្ថែម[571]។

193. ក្នុងបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា "លក្ខណៈពុំគ្រប់គ្រាន់ និងយឺតពេលនៃវិធានការទាំងនេះបានសម្រាលតិចតួចប៉ុណ្ណោះដល់ការរំលោភបំពានលើ[សិទ្ធិរបស់គាត់ក្នុងការត្រៀមលក្ខណៈដោយប្រសិទ្ធ

[568] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Halilović* អង្គជំនុំជម្រះសាលាដំបូង I ផ្នែក ក (ICTY) សំណុំរឿងលេខ IT-01-48-T សេចក្តីសម្រេចលើញត្តិសុំអនុវត្តដីកាតុលាការពាក់ព័ន្ធនឹងការបង្ហាញឯកសារតាមប្រព័ន្ធអេឡិចត្រូនិក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ("ពិចារណាឃើញថា វិធានពុំបានអនុញ្ញាតរៀបចំជាបញ្ជីនៃឯកសារដែលត្រូវបានបង្ហាញ ឬពាក់ព័ន្ធដែលមានដល់មេធាវីការពារក្តីឡើយ" [...] អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អយ្យការអនុវត្តស្របតាមកាតព្វកិច្ចបង្ហាញឯកសារ និងជូនដំណឹងមេធាវីការពារក្តីនៅពេលមានឯកសារថ្មីដាក់ចូលក្នុងសំណុំឯកសាររួម Halilovic")។

[569] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krajišnik* អង្គជំនុំជម្រះសាលាដំបូង(ICTY) សំណុំរឿងលេខ IT-95-5/18-PT សេចក្តីសម្រេចលើញត្តិសុំបង្ហាញឯកសារតាមវិធាន ៦៨ និងការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីការជួយសម្រួលគ្រប់គ្រាន់ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២០ (អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "អង្គជំនុំជម្រះជឿជាក់ថា អត្ថិភាពនៃឯកសារដោះបន្ទុកស្របតាមវិធាន ៦៨ នៅក្នុងប្រព័ន្ធអេឡិចត្រូនិក ត្រូវបានជនជាប់ចោទដឹង និងថា គាត់អាចចូលមើលឯកសារនេះបានសមស្រប")
។

[570] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៨។

[571] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៥។

ភាពក្នុងការការពារខ្លួន និងសមភាពកម្លាំងតទល់ផ្លូវច្បាប់] និងបានធ្វើឱ្យការរំលោភបំពានកាន់តែធ្ងន់ធ្ងរលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមស្រប”[572]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង“គប្បីបានផ្តល់អាទិភាពដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះគ្មានការពន្យារពេលឥតសមស្រប ជាជាងការអនុញ្ញាតវិធានការឱ្យពន្យារពេលការជំនុំជម្រះ”[573]។

194. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ចាប់តាំងពីដើមដំបូង សហព្រះរាជអាជ្ញាបានជូនដំណឹងភាគីអំពីចំនួននៃឯកសារដែលត្រូវបង្ហាញខាងមុខ[574] និងថា អង្គជំនុំជម្រះសាលាដំបូងបានជួយសម្រួលដល់ការពិភាក្សាលើដំណើរការបង្ហាញភស្តុតាងដែលកំពុងបន្ត តាមរយៈកិច្ចប្រជុំរៀបចំសវនាការ[575]។ ក្នុងកិច្ចប្រជុំនោះ នួន ជា បានសង្កត់ធ្ងន់អំពីការជាប់ពាក់ព័ន្ធសំខាន់នៃឯកសារដែលត្រូវបានបង្ហាញរហូតមកដល់ពេលនោះ និងបានស្នើសុំអង្គជំនុំជម្រះសាលាដំបូង“បង្គាប់អយ្យការធ្វើការស្នើសុំការបង្ហាញភស្តុតាងនេះដែលពាក់ព័ន្ធដទៃទៀត ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន” និងបានស្នើសុំការផ្អាកសវនាការដើម្បីពិនិត្យឯកសារដែលត្រូវបានបង្ហាញនោះ[576]។ ខៀវ សំផន បានស្នើសុំពេលវេលាបន្ថែមដើម្បីពិនិត្យភស្តុតាងដែលត្រូវ

---

[572] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៨។

[573] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២។

[574] ប្រតិចារឹកចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ E1/243.1 ទំព័រ ៩-១០។

[575] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E1/272.5។

[576] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E1/272.5 ទំព័រ ៥ (មេធាវីការពារក្តី នួន ជា៖ “ផ្អែកលើអ្វីដែលយើងអាចបានពិនិត្យភស្តុតាងទាំងអស់នោះ វាគឺមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿងរបស់យើង គឺសំណុំរឿង ០០២/០២ ទាំងស្រុងតែម្តង។ ហើយក៏ជាបញ្ហាមួយដែលយើងត្រូវប្រឈម។ ហើយឥឡូវនេះ យើងកំពុងតែធ្វើការប្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១។ ភស្តុតាងមួយចំនួន គឺប៉ះពាល់ជាមូលដ្ឋានទៅលើភស្តុតាងអ្វីដែលយើងមានក្នុងសំណុំរឿង អំពីបញ្ហាសំខាន់ៗជាច្រើន ដែលត្រូវបានជំទាស់នៅក្នុងសំណុំរឿងនេះ និងត្រូវបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ”), ទំព័រ ៧-៨ (មេធាវីការពារក្តី នួន ជា៖ “លោកប្រធាន នៅពេលដែលយើងពិនិត្យមើលទៅលើឯកសារដែលបានបង្ហាញទាំងអស់នេះឱ្យបានលម្អិត គឺយើងឃើញថា ឯកសារទាំងអស់នោះហាក់ដូចជាមានព័ត៌មានដែលមានភាពពាក់ព័ន្ធយ៉ាងសំខាន់ទៅលើចំណុចជាច្រើននៃសំណុំរឿងរបស់មេធាវីការពារក្តី មិនមែនត្រឹមតែសាក្សីជាក់លាក់ ឬក៏ហេតុការណ៍ជាក់លាក់ដែលយើងត្រូវធ្វើការពិនិត្យនៅក្នុងផ្នែកនៃការជំនុំជម្រះជាក់លាក់ណាមួយនោះឡើយ។ ភស្តុតាងទាំងអស់នេះតម្រូវឱ្យមានការវិភាគបន្ថែមទៀត មុនពេលដែលផ្នែកនៃការជំនុំជម្រះបច្ចុប្បន្នហ្នឹងអាចបន្តទៅមុខបាន។ [...] វាគឺជាសិទ្ធិរបស់ជនជាប់ចោទដើម្បីមានពេលវេលាក្នុងការពិនិត្យទៅលើភស្តុតាងទាំងអស់នេះ ហើយពិចារណាថា តើវាប៉ះពាល់យ៉ាងណា ដោយមិនមែនត្រឹមតែពិចារណាទៅលើហេតុការណ៍ ដែលបានជំទាស់នៅក្នុងផ្នែកនៃការជំនុំជម្រះបច្ចុប្បន្ននោះទេប៉ុន្តែថា តើវាប៉ះពាល់យ៉ាងណាទៅដល់យុត្តិសាស្ត្រក្នុងការការពារក្តីទាំងមូលតែម្តង”), ទំព័រ ១១-១២ (“យើងត្រូវស្នើសុំឱ្យអង្គជំនុំជម្រះដើម្បីបង្គាប់ដល់សហចៅក្រម សហព្រះរាជអាជ្ញាឱ្យជម្រាបមកយើងថា តើវាមាន

បានបង្ហាញ[577] ប៉ុន្តែត្រឹមតែលើកការជំទាស់របស់គាត់ទៅនឹងការបង្ហាញជារួមរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥[578]។ នៅពេលនោះ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតវិធានការនានាដើម្បីសម្របសម្រួលភាគីក្នុងការពិនិត្យភស្តុតាងដែលត្រូវបានបង្ហាញ និងការពារសិទ្ធិរបស់ភាគីក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបង្ហាញនូវឯកសារចំនួនច្រើនសន្ធឹកសន្ធាប់ដែលចេញពីសំណុំរឿង ០០៣ និង ០០៤ ពុំបានរំលោភបំពាន*ដោយផ្ទាល់*លើសិទ្ធិរបស់ជនជាប់ចោទ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានបង្កើតវិធានការសមស្រប និងមានប្រសិទ្ធភាពក្នុងការការពារលទ្ធភាពជនជាប់ចោទអាចពិនិត្យឯកសារដែលត្រូវបានបង្ហាញ។

195. ខៀវ សំផន បានចោទប្រកាន់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានដកសិទ្ធិរបស់គាត់ក្នុងការទទួលបានការសួរដេញដោលចំពោះមុខ និងសិទ្ធិត្រូវបានស្តាប់ដោយតុលាការទាក់ទងទៅនឹងសំណើសុំបញ្ជាក់របស់សហព្រះរាជអាជ្ញា និងសំណើសុំឱ្យទទួលយកជាភស្តុតាង[579]។

196. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកភស្តុតាងស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមានករណីលើកលែងឯកសារមួយចំនួន[580] សហចៅក្រមស៊ើបអង្កេតបានកំណត់នីតិវិធីមួយដែលតម្រូវឱ្យសហព្រះរាជអាជ្ញាត្រូវស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងក្នុងការស្នើសុំបង្ហាញឯកសារក្នុងសំណុំរឿង ០០៣ និង ០០៤ ពីសហចៅក្រមស៊ើបអង្កេត[581]។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "ការអនុញ្ញាតនេះ [...] ត្រឹមតែទុកឱ្យអង្គជំនុំជម្រះ និងមេធាវីការពារក្តីធ្វើការវាយតម្លៃថាតើ ឯកសារដែលត្រូវបានស្នើសុំនោះស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលយកភស្តុតាងថ្មីដែលបានកំណត់ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា"[582]។ អង្គជំនុំ

---

ប្រភេទនៃភស្តុតាងដទៃទៀត ឬក៏អត់ ប្រសិនបើដូច្នេះ យើងស្នើសុំដល់អង្គជំនុំជម្រះដើម្បីបង្គាប់សហព្រះរាជអាជ្ញាដើម្បីស្នើសុំឱ្យមានការបង្ហាញនូវភស្តុតាងនេះឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន")។

[577] ប្រតិចារឹកចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E1/272.5 ទំព័រ ១៤-១៥, ១៧។

[578] សារណារបស់ ខៀវ សំផន ស្តីពីការបង្ហាញឯកសារ (E363)។

[579] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៨-២០៩។

[580] សេចក្តីសម្រេចលើសំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4)។

[581] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបង្កើតកាលវិភាគសម្រាប់សំណើសុំបង្ហាញក្នុងសំណុំរឿង ០០៤ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E319/62 ("សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ (E319/62)")។

[582] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ (E319/62) កថាខណ្ឌ ៣០ (ក)(ii) (សេចក្តីបញ្ជាក់បន្ថែម)។

ជម្រះសាលាដំបូងអាចស្នើសុំការបង្ហាញឯកសារផ្ទាល់ពីសហចៅក្រមស៊ើបអង្កេត ឬបញ្ជាក់លើសំណើរបស់សហព្រះរាជអាជ្ញាសុំការបង្ហាញឯកសារ[583] ដែលបន្ទាប់មកនឹងត្រូវបានពិចារណាដោយសហចៅក្រមស៊ើបអង្កេត"ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបានដោយមានដាក់លក្ខខណ្ឌសមស្របដើម្បីការពារការសម្ងាត់នៃកិច្ចស៊ើបសួរសំណុំរឿង ០០៣ និង ០០៤ ដែលជាកម្មវត្ថុនៃសារណាតបណាមួយដោយមេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលអាចធ្វើឡើង"[584]។

197. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ខៀវ សំផន ពុំមានមូលដ្ឋានក្នុងការជំទាស់ការបញ្ជាក់របស់សហព្រះរាជអាជ្ញា ឬសំណើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នីតិវិធីសុំការបញ្ជាក់ដូចបានរៀបរាប់ដោយសហចៅក្រមស៊ើបអង្កេត បានតម្រូវឱ្យមានដំណើរការនីតិវិធីពីរដំណាក់កាលៈ (១) សហព្រះរាជអាជ្ញាត្រូវសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងដើម្បីស្នើសុំការបង្ហាញឯកសារថ្មី ឬស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស្នើសុំការបង្ហាញនេះដោយផ្ទាល់ពីសហចៅក្រមស៊ើបអង្កេត (២) បន្ទាប់មក សំណើនេះនឹងត្រូវបានវាយតម្លៃដោយសហចៅក្រមស៊ើបអង្កេត ដែលជាកម្មវត្ថុនៃសារណាតបដោយមេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤។ បើទោះបីជា ខៀវ សំផន ពុំមានមូលដ្ឋានក្នុងការជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបង្ហាញចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលជាកម្មវត្ថុនៃសារណាតបដោយក្រុមមេធាវីការពារក្តីសំណុំរឿង ០០៣ និង ០០៤ ប៉ុណ្ណោះក៏ដោយ ក៏នេះពុំបានរារាំង ខៀវ សំផន ក្នុងការជំទាស់ទៅនឹងសំណើសុំបញ្ជាក់/ការអនុញ្ញាតដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ[585]។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការណែនាំឱ្យសហព្រះរាជអាជ្ញា "លើកបង្ហាញឯកសារនានាដែលខ្លួនមានបំណងចង់ស្នើសុំការបង្ហាញ [...] ទៅអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល និងមេធាវីការពារក្តីក្នុងសំណុំរឿង ០០២ ក្រោមលក្ខខណ្ឌ*សម្ងាត់បំផុត*"[586] គឺដើម្បីឱ្យមេធាវីការពារក្តី ធ្វើការជំទាស់មិនត្រឹមតែលើការទទួលក្រោយមកជាភស្តុតាងនៃឯកសារនានាប៉ុណ្ណោះទេ

[583] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ (E319/62) កថាខណ្ឌ ៣០ (ក)(iii) ("អង្គជំនុំជម្រះពាក់ព័ន្ធអាចបញ្ជាក់ទៅអយ្យការនូវការអនុវត្តន៍តាម ហើយអយ្យការត្រូវដាក់សំណើសុំបង្ហាញរួមជាមួយនឹងការបញ្ជាក់ ឬអង្គជំនុំជម្រះអាចស្នើសុំបង្ហាញដោយផ្ទាល់")។

[584] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ (E319/62) កថាខណ្ឌ ៣០ (ក)(iv)។

[585] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីសម្រេចលើការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ (E319/63)" ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E319/63/2។

[586] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ (E319/62) កថាខណ្ឌ ៣០ (ក)(ii)។

ថែមទាំងឱ្យមេធាវីការពារក្តីធ្វើការវាយតម្លៃថាតើ សហព្រះរាជអាជ្ញាបានអនុវត្តតាមការណែនាំនៃការបង្ហាញឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា។ ដោយហេតុថា បន្ទុកនេះគឺជារបស់មេធាវីការពារក្តីក្នុងការលើកភាពពុំសមស្របណាមួយទាក់ទងទៅនឹងការអនុវត្តនៃការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ដែលត្រូវបានសន្មតថា ត្រូវធ្វើឡើងដោយសុចរិតភាព ខៀវ សំផន គប្បីត្រូវបានផ្តល់ឱកាសឱ្យឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់របស់សហព្រះរាជអាជ្ញា។

198. បន្ថែមលើនេះ តាមការសង្កេតឃើញថា សំណើសុំការបញ្ជាក់របស់សហព្រះរាជអាជ្ញាពុំត្រូវបានកម្រិតត្រឹមសំណើសុំការបង្ហាញឯកសារប៉ុណ្ណោះទេ ថែមទាំងអាចស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យទទួលយកឯកសារមួយចំនួនចូលក្នុងសំណុំរឿងផងដែរ[587]។ អាស្រ័យហេតុនេះ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ត្រឹមត្រូវថា ខៀវ សំផន មានសិទ្ធិជំទាស់ទៅនឹងការទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ នូវឯកសារណាមួយដែលត្រូវបានបង្ហាញចេញពីសំណុំរឿង ០០៣ និង ០០៤ ក៏ដោយ ក៏អង្គជំនុំជម្រះបានបញ្ជាក់ពុំត្រឹមត្រូវថា "ពុំទាន់មានសំណើសុំឱ្យទទួលយកនេះត្រូវបានធ្វើឡើងនៅឡើយទេ"[588]។ នៅក្នុងសំណើសុំបង្ហាញឯកសាររបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យ"ទទួលយកចម្លើយរបស់សាក្សីដែលបានផ្តល់សក្ខីកម្មដូចបានពិពណ៌នាក្នុងឧបសម្ព័ន្ធក្នុងសំណុំរឿង ០០២"[589] ហើយនៅក្នុងអនុស្សរណៈមួយក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើសុំឱ្យទទួលយកជាភស្តុតាងនូវឯកសារទាំងនោះ ខណៈពេលបញ្ជាក់ថា អង្គជំនុំជម្រះពុំបានទទួលសារណាតបណាមួយឡើយ[590]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នេះបានរារាំង ខៀវ សំផន ក្នុងការជំទាស់

---

[587] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E319/63 ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារ (E319/63)") កថាខណ្ឌ ៦(ខ)។ *សូមមើលផងដែរ* ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារលេខ E319/68 ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារ (E319/68)")។

[588] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីសម្រេចលើការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ (E319/63) ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E319/63/២ កថាខណ្ឌ ៣។

[589] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារ (E319/63) កថាខណ្ឌ ៦(ខ)។ *សូមមើលផងដែរ* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារ (E319/68)។

[590] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានបង្ហាញថ្មីៗចេញពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២"

ដោយប្រសិទ្ធភាពលើនីតិវិធីនៃការបង្ហាញឯកសារ និងសំណើសុំឱ្យទទួលយកជាភស្តុតាងនូវឯកសារក្នុងសំណើសុំចំនួនបីស្តីពីការបង្ហាញឯកសារ។ តាមការពិនិត្យលើព្យសនកម្មដែលបានបង្កឡើងលើ ខៀវ សំផន ឃើញថា សំណើសុំបង្ហាញ និងសុំឱ្យទទួលជាភស្តុតាង ជាប់ទាក់ទងទៅនឹងចម្លើយមួយចំនួនតូចរបស់សាក្សី និងបុគ្គលដែលបានផ្តល់សក្ខីកម្មរួចរាល់ក្នុងសំណុំរឿង ០០២/០២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានទទួលព្យសនកម្មជាសត្យានុម័តតាមរយៈការទទួលយកជាភស្តុតាងនូវចម្លើយទាំងនេះឡើយ។

199. ខៀវ សំផន បានចោទប្រកាន់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តដោយអសុទ្ធចិត្តតាមរយៈការធ្វើ"សេចក្តីសម្រេចដោយផ្អែកលើមូលដ្ឋាននៃឯកសារដែលត្រូវបានបង្ហាញតាមធម្មតា បើសូម្បីតែពុំត្រូវបានទទួលយកផងនោះ"[591]។ គាត់បានផ្អែកអំណះអំណាងទៅលើសេចក្តីសម្រេចតាមការផ្តួចផ្តើមគំនិតរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចូលបង្ហាញខ្លួនរបស់សាក្សី មុយ វ៉ាន់នី និង ឡុង សាត នៅមុនការទទួលយកភស្តុតាងនូវចម្លើយរបស់ពួកគេ[592]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការអនុវត្តបែបនេះត្រូវបានធ្វើឡើងដោយស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលចែងថា អង្គជំនុំជម្រះសាលាដំបូងអាច"តាមគំនិតផ្តួចផ្តើមរបស់ខ្លួន"សម្រេចកោះហៅ ឬស្តាប់ភាគីណាមួយ ឬទទួលយកភស្តុតាងថ្មីណាមួយដែលខ្លួនចាត់ទុកថា ជួយបញ្ជាក់ការពិត។ ខៀវ សំផន ត្រូវបានផ្តល់ឱកាសធ្វើការអធិប្បាយលើការចូលបង្ហាញខ្លួនរបស់សាក្សីទាំងនេះ[593] និងខកខានក្នុងការបង្ហាញកំហុសនៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់កោះហៅពួកគេ[594]។ អាស្រ័យហេតុនេះ ការចោទប្រកាន់អំពីអសុទ្ធចិត្តពីសំណាក់អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធចោល។

---

ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E319/67 យោងទៅលើសំណើសុំឱ្យទទួលយកភស្តុតាងក្នុងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារ (E319/63) កថាខណ្ឌ ៦(ខ)។ *សូមមើលផងដែរ* ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E319/66។

[591] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៣។

[592] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៣-២១៤។

[593] *សូមមើល ឧ.* សេចក្តីជំទាស់របស់មេធាវីការ ខៀវ សំផន ទៅនឹងការកោះហៅសាក្សី 2-TCW-987 ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E364 (មុយ វ៉ាន់នី)។ ប្រតិចារឹកចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E1/474.1 ទំព័រ ៥២-៥៣ (ឡុង សាត)។

[594] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចសម្រេចលើសេចក្តីជំទាស់របស់មេធាវីការ ខៀវ សំផន ទៅនឹងការកោះហៅសាក្សី 2-TCW-987 (ឯកសារលេខ E3៦៤) ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ E364/1 (មុយ វ៉ាន់នី)។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E1/479.1 (ឡុង សាត) ទំព័រ ៣។ សេចក្តីសម្រេចស្តីពីសាក្សី

200. ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ឯកសារទំហំធំដែលត្រូវបានបង្ហាញចេញពីសំណុំរឿង ០០៣ និង ០០៤ គឺជាការលំបាកដល់ភាគីនានា និងពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយគ្រប់គ្រាន់លើក្តីបារម្ភរបស់ភាគី និងតម្រូវការចាំបាច់ក្នុងការការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់ នួន ជា ដែលបានស្នើសុំការបង្ហាញបន្ថែមចេញពីសំណុំរឿង ០០៣ និង ០០៤[595]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា "តាមរយៈការបង្ហាញធម្មតាឱ្យភាគីដទៃទៀតបានដឹង" នូវឯកសារដែលបានបង្ហាញនោះ ពុំមែនជាការទទួលយកជាភស្តុតាងទេ ដែលនេះបានកាត់បន្ថយព្យសនកម្មដែលត្រូវបានចោទប្រកាន់ដោយ ខៀវ សំផន[596]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា វិធានការនេះពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវឡើយ។

---

ដែលបានស្នើឡើង (E459) និងជើងទំព័រ ៤៦៤ (ឡុង សាត)។ ឧបសម្ព័ន្ធ ២៨ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ E457/6/3.1.28 (អ៊ីម៉ែលផ្ញើពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖"ការកំណត់កាលបរិច្ឆេទបន្តសវនាការក្រោយការសម្រាកវិស្សមកាលភ្ជុំបិណ្ឌ" ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦)។

[595] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញ (E363/3) កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E1/272.5 ទំព័រ ៥ (មេធាវីការពារក្តី នួន ជា៖ "ផ្អែកលើអ្វីដែលយើងអាចបានពិនិត្យភស្តុតាងទាំងអស់នោះ វាគឺមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿងរបស់យើង គឺសំណុំរឿង ០០២/០២ ទាំងស្រុងតែម្តង។ ហើយក៏ជាបញ្ហាមួយដែលយើងត្រូវប្រឈម។ ហើយឥឡូវនេះ យើងកំពុងតែធ្វើការប្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១។ ភស្តុតាងមួយចំនួនគឺប៉ះពាល់ជាមូលដ្ឋានទៅលើភស្តុតាងអ្វីដែលយើងមានក្នុងសំណុំរឿង អំពីបញ្ហាសំខាន់ៗជាច្រើន ដែលត្រូវបានជំទាស់នៅក្នុងសំណុំរឿងនេះ និងត្រូវបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ"), ទំព័រ ៧-៨ (មេធាវីការពារក្តី នួន ជា៖ "លោកប្រធាន នៅពេលដែលយើងពិនិត្យមើលទៅលើឯកសារដែលបានបង្ហាញទាំងអស់នេះឱ្យបានលម្អិត គឺយើងឃើញថា ឯកសារទាំងអស់នោះហាក់ដូចជាមានព័ត៌មានដែលមានភាពពាក់ព័ន្ធយ៉ាងសំខាន់ទៅលើចំណុចជាច្រើននៃសំណុំរឿងរបស់មេធាវីការពារក្តី មិនមែនត្រឹមតែសាក្សីជាក់លាក់ ឬក៏ហេតុការណ៍ជាក់លាក់ដែលយើងត្រូវធ្វើការពិនិត្យនៅក្នុងផ្នែកនៃការជំនុំជម្រះជាក់លាក់ណាមួយនោះឡើយ។ ភស្តុតាងទាំងអស់នេះតម្រូវឱ្យមានការវិភាគបន្ថែមទៀត មុនពេលដែលផ្នែកនៃការជំនុំជម្រះបច្ចុប្បន្នហ្នឹងអាចបន្តទៅមុខបាន។ [...] វាគឺជាសិទ្ធិរបស់ជនជាប់ចោទដើម្បីមានពេលវេលាក្នុងការពិនិត្យទៅលើភស្តុតាងទាំងអស់នេះ ហើយពិចារណាថា តើវាប៉ះពាល់យ៉ាងណា ដោយមិនមែនត្រឹមតែពិចារណាទៅលើហេតុការណ៍ ដែលបានជំទាស់នៅក្នុងផ្នែកនៃការជំនុំជម្រះបច្ចុប្បន្ននោះទេប៉ុន្តែថា តើវាប៉ះពាល់យ៉ាងណាទៅដល់យុត្តិសាស្ត្រក្នុងការការពារក្តីទាំងមូលតែម្តង"), ទំព័រ ១១-១២ ("យើងត្រូវស្នើសុំឱ្យអង្គជំនុំជម្រះដើម្បីបង្គាប់ដល់សហចៅក្រម សហព្រះរាជអាជ្ញាឱ្យជម្រាបមកយើងថា តើវាមានប្រភេទនៃភស្តុតាងដទៃទៀត ឬក៏អត់ ប្រសិនបើដូច្នេះ យើងស្នើសុំដល់អង្គជំនុំជម្រះដើម្បីបង្គាប់សហព្រះរាជអាជ្ញាដើម្បីស្នើសុំឱ្យមានការបង្ហាញនូវភស្តុតាងនេះឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន"), ទំព័រ ៨ ("ចំពោះសំអាងហេតុទាំងអស់នេះហើយ ទើបយើងស្នើសុំឱ្យមានការផ្អាកសវនាការក្នុងពេល ចាប់ពីពេលឥឡូវនេះ")។

[596] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) កថាខណ្ឌ ៣២។

## ៣. ការទទួលយកភស្តុតាងក្នុងពេលជំនុំជម្រះ

201. បើទោះបីជាភាគីអាចស្នើសុំការទទួលយកភស្តុតាងនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏ភស្តុតាងទាំងអស់ដែលបានស្នើឡើង និងពុំមាននៅពេលចាប់ផ្តើមការជំនុំជម្រះ ត្រូវបានចាត់ទុកថា ជាភស្តុតាង"ថ្មី" និងត្រូវផ្អែកលើលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) ដែលចែងថា៖

> ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។

202. លក្ខណៈវិនិច្ឆ័យដែលមានក្នុងវិធាន ៨៧(៣) ប្រើប្រាស់ជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យសុំឱ្យពិនិត្យភស្តុតាង បើអង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនោះ៖

ក. មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ. មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ. មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ. ច្បាប់មិនអនុញ្ញាត ឬ

ង. មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

203. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការអនុវត្តន៍ត្រឹមត្រូវតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅពេលសម្រេចលើសំណើមួយចំនួនសុំឱ្យទទួលភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ ដែលគាត់បានអះអាងថា បាននាំមានកំហុសបន្តទៀត ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបង្កព្យសនកម្មលើរូបគាត់[597]។ គាត់បានអះអាងថា កំហុសអង្គច្បាប់បានកើតឡើង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការទទួលស្គាល់"លក្ខណៈពិសេស"វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលគាត់លើកឡើងថា បានតម្រូវឱ្យភាគីស្នើសុំការទទួលយកភស្តុតាងដោយត្រូវបំពេញតាម"លក្ខខណ្ឌដែលមានកម្រិតខ្ពស់បំផុត" ដោយត្រូវបង្ហាញថា ភស្តុតាងពុំមានអត្ថិភាព

[597] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២-១៨៧។ ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទំព័រ ៨។

នៅមុនការជំនុំជម្រះ និងថា ការទទួលយកភស្តុតាងយឺតពេល គឺ"មានសារៈសំខាន់" ឬ"ចាំបាច់"ដើម្បីអត្ថប្រយោជន៍យុត្តិធម៌[598]។ ដោយសារការខកខានក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យនេះ អង្គជំនុំជម្រះសាលាដំបូងបាន"បើកដៃ"ឱ្យសហព្រះរាជអាជ្ញាបង្ហាញភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងអំឡុងពេលនៃការជំនុំជម្រះ ដែលបានពន្យារពេលកិច្ចដំណើរការនីតិវិធីពុំចាំបាច់ និងរំលោភបំពានលើសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ និងការសម្រួលសម្រាប់ការត្រៀមលក្ខណៈក្នុងការការពារខ្លួន សច្ចភាពផ្នែកនីតិវិធី និងផ្លូវច្បាប់ និងការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមហេតុផល[599]។

204. ខៀវ សំផន បានអះអាងថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូង"បានវិលទៅរកសភាពដើមគោរពតាមស្មារតី និងខ្លឹមសារវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង"នៅចុងបញ្ចប់នៃការជំនុំជម្រះនៅពេលដែលសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបានដាក់ឱ្យស្ថិតក្រោម"ការពិនិត្យពិច័យហ្មត់ចត់"ក៏ដោយ ក៏តាមការលើកឡើងរបស់គាត់ថា វិធីសាស្ត្រនេះគប្បីបានអនុម័តតាំងពីដើមដំបូងនៃការជំនុំជម្រះ[600]។ សារណារបស់គាត់បានផ្តោតទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក៖

(i) យកចម្លើយជាលាយលក្ខណ៍អក្សរចេញពីសំណុំរឿង ០០៣ និង ០០៤[601]

(ii) ឯកសារផ្សេងៗដែល"មានតម្លៃជាភស្តុតាងទាប (និងការជាប់ពាក់ព័ន្ធតិចតួច)"[602] និង

(iii) "សៀវភៅទាំងមូលច្រើនក្បាល"របស់អ្នកជំនាញ NAKAGAWA Kasumi និង LEVINE Peg ដែលបានផ្តល់សក្ខីកម្មស្តីពីបទបញ្ហារៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[603]។

205. ទាក់ទងទៅនឹងព្យសនកម្ម គាត់បានលើកឡើងថា "មិនត្រឹមតែប៉ះពាល់ដល់ការត្រៀមរៀបចំសវនាការលើអង្គសេចក្តីប៉ុណ្ណោះទេ ថែមទាំងគាត់ត្រូវចំណាយពេលជាច្រើនជំទាស់ទៅនឹងសំណើសុំឱ្យទទួលយកភស្តុ

---

[598] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨-១៨៩ (សេចក្តីបញ្ជាក់បន្ថែម)។

[599] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩, ១៩៧។

[600] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១-១៩២។

[601] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩ ជើងទំព័រ ២២១។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សារណាពាក់ព័ន្ធគ្នារបស់ ខៀវ សំផន ដែលទាក់ទងទៅនឹងការបង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ត្រូវបានពិចារណាខាងកលើក្នុងផ្នែក V.ឃ.២។

[602] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២។

[603] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៤ ជើងទំព័រ ២៣០។

តាង" និង"ត្រូវត្រៀមខ្លួនសម្រាប់សវនាការក្នុងអំឡុងពេលនៃការជំនុំជម្រះ" ដែលមានផលប៉ះពាល់អវិជ្ជមានដល់ការពន្លឿនកិច្ចដំណើរការនីតិវិធី[604]។ បន្ថែមលើនេះ បើទោះបីជាមាន"ភស្តុតាងរាប់ពាន់ត្រូវបានទទួលយករួចហើយក៏ដោយក្នុងសំណុំរឿង ០០២/០២" ក៏តាមការអះអាងរបស់គាត់ថា ការទទួលយកភស្តុតាងនោះ ពុំមាន"សារៈសំខាន់" ឬ"ចាំបាច់"ណាស់ណាទេដើម្បីអត្ថប្រយោជន៍យុត្តិធម៌នោះ[605]។ ដូចគ្នានេះដែរ គាត់បានកត់សម្គាល់ថា ឯកសារថ្មីជាច្រើនដែលត្រូវបានទទួលយកក្នុងអំឡុងពេលនៃការជំនុំជម្រះពុំត្រូវបានយោងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រម ដូច្នេះនេះបញ្ជាក់ពីលក្ខណៈពុំសូវសំខាន់នៃឯកសារនោះ[606]។

206. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយ ឬព្យសនកម្មដែលបណ្តាលមកពីការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងថ្មីឡើយ[607]។

207. សហមេធាវីនាំមុខបានយល់ស្របជាមួយសហព្រះរាជអាជ្ញា[608]។

### ក. ការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

208. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងអំឡុងពេលនៃការជំនុំជម្រះរយៈពេលវែងដែលជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងអស់រយៈពេលយូរនៅក្នុងជម្លោះមួយ ជាការជៀសពុំរួចថាមានព័ត៌មានថ្មីកើតឡើងដែលបណ្តាលឱ្យមានការជំទាស់ និងការពន្យារពេល។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងបានរំពឹងទុកនូវការកើតឡើងបែបនេះ និងបានចែងនូវនីតិវិធីដែលសមស្រប។ ជានិច្ចកាលតែងតែមានពេលខ្លះដែលប្រធានត្រូវសម្រេចភ្លាមៗ និងពេលខ្លះទៀតចាំបាច់ត្រូវមានការពិភាក្សាសម្រេចរយៈពេលយូរ និងការដាក់សារណា និងសំណើសុំជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រឈម និងត្រូវចាត់ចែងបញ្ហាបន្ទាន់កើតឡើងដោយចៃដន្យនេះ។ នៅគ្រប់ករណី អង្គជំនុំជម្រះសាលាដំបូងត្រូវបានបំភ្លឺដោយគោលការណ៍ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងក្នុងការស្វែងរកការពិត ដរាបណាភាគី និងជាពិសេសជន

[604] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦។

[605] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩០។

[606] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦។

[607] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១-៧៨។

[608] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៥០-២៥៤។

ជាប់ចោទមានពេលវេលា និងធនធានគ្រប់គ្រាន់ក្នុងការពិនិត្យភស្តុតាងថ្មី និងសម្របសម្រួលយុទ្ធសាស្ត្រនៃការសួរសំណួររបស់ខ្លួន។ ខៀវ សំផន ពុំបានចង្អុលបង្ហាញទៅលើករណីដែលការទទួលយកភស្តុតាងថ្មីនោះពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពជាប់ពាក់ព័ន្ធនៃភស្តុតាង ឬករណីដែលការយល់ឃើញអំពីពិរុទ្ធភាពត្រូវបានផ្អែកទៅលើភស្តុតាងថ្មីនោះដែលធ្វើឱ្យប៉ះពាល់ដល់ខ្លួនគាត់ឡើយ។ ការត្រឹមតែលើបន្តិចបន្តួចនូវចំណុចនៃសេចក្តីសម្រេចទទួលយកភស្តុតាងដោយគ្មានការលើកមូលដ្ឋានលម្អិតបន្ថែមនោះ គឺជាទង្វើដែលខ្ជះខ្ជាយពេលវេលា និងពុំបាននាំទៅរកការទទួលបានសំណងជាដុំកំភួន និងត្រឹមតែជាការឥតប្រយោជន៍។ ទទ្បីករណ៍នៃបណ្តឹងសាទុក្ខនេះដែលចោទប្រកាន់កំហុសដោយសារអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការចាត់ទុកភស្តុតាងថ្មី និងជាប់ពាក់ព័ន្ធនោះថា ករណីពិសេស ជាជាងអនុលោមតាមលក្ខខណ្ឌវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពុំទទួលជោគជ័យឡើយ។

## ខ. ការទទួលយកឯកសារនៃសំណុំរឿង ០០៣ និង ០០៤

209. ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា នៅពេលសម្រេចលើសំណើសុំរបស់ភាគីតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារ“ [...] បានកម្រិតសំអាងហេតុរបស់ខ្លួនត្រឹមការជាប់ពាក់ព័ន្ធ(ដែលចោទជាបញ្ហា)”នៃភស្តុតាងដែលត្រូវបានស្នើសុំឱ្យទទួលយក និងតាមរយៈការប្រដូចការជាប់ពាក់ព័ន្ធនេះ ស្មើនឹងអត្ថប្រយោជន៍ក្នុងការជួយបញ្ជាក់ការពិត[609]។ គាត់បានជំទាស់ជាក់លាក់ទៅនឹងការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរចេញពីសំណុំរឿង ០០៣ និង ០០៤[610] ជាពិសេសភស្តុតាងដែលត្រូវបានទទួលយកតាមរយៈអនុស្សរណៈឯកសារលេខ E319/7, E319/17/1, E319/22/1, E319/32/1 និង E319/36/2[611]។

---

[609] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩។

[610] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩ និងជើងទំព័រ ២២១។

[611] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩ និងជើងទំព័រ ២២២ យោងទៅលើសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319/7) កថាខណ្ឌ ១០។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1) កថាខណ្ឌ ៤។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/22/1) កថាខណ្ឌ ៥។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/32/1) កថាខណ្ឌ ១០។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ២១-២២, ២៦-២៧, ៣០, ៤០-៤១។

210. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ខ្លឹមសារដែលជាប់ពាក់ព័ន្ធស្ទើតែដូចគ្នា និងការត្រួតគ្នានៃអំឡុងពេល ទីតាំងភូមិសាស្ត្រ និងទីតាំងឧក្រិដ្ឋកម្មនៃកិច្ចស៊ើបសួរដែលកំពុងដំណើរការក្នុងសំណុំរឿង ០០៣ និង ០០៤ *តាមសេចក្តីបញ្ជាក់ដំបូង* បានបណ្តាលឱ្យមានភស្តុតាងជាប់ពាក់ព័ន្ធគ្នាមានអត្ថិភាពពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២[612]។ អាស្រ័យហេតុនេះ សំណើសុំឱ្យទទួលយកជាច្រើនរបស់ភាគីស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង គឺជាប់ពាក់ព័ន្ធទៅនឹងចម្លើយ និងឯកសារចេញពីសំណុំរឿងនោះ។ ទោះជាយ៉ាងណាក្តី ក្នុងករណីជាច្រើន អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ត្រូវសំអាងទៅលើករណីលើកលែងនៃអត្ថប្រយោជន៍យុត្តិធម៌ឡើយ[613]។ ឯកសារដែលចេញពីសំណុំរឿង ០០៣ និង ០០៤ ត្រូវបានបង្កើតឡើងក្រោយសវនាការបឋម (មុនការបំបែកសំណុំរឿង)ក្នុងសំណុំរឿង ០០២ ក្នុងខែ មិថុនា ឆ្នាំ ២០១១ ដែលជាកាលបរិច្ឆេទប្រតិបត្តិការសម្រាប់ការពិចារណាថាតើ ភស្តុតាងមានអត្ថិភាពនៅមុនការចាប់ផ្តើមការជំនុំជម្រះ និងមានអត្ថិភាពនៅក្រោយពេលសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតការបង្ហាញតែប៉ុណ្ណោះ ដែរ ឬយ៉ាងណា[614]។ ដោយហេតុថា សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់សមស្របក្នុងការស្នើសុំការទទួលយកឯកសារទាំងនោះ ទើបសំណើសុំនោះបានបំពេញទាំងស្រុងតាមលក្ខខណ្ឌតម្រូវនៃវិធាន

---

[612] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០។

[613] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ (E319/5)។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319/7)។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពាក់ព័ន្ធសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់អនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (សម្ងាត់) ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ E319/11/1។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1) កថាខណ្ឌ ៤។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/22/1)។ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំឱ្យទទួលយកទម្រង់បែបបទនៃព័ត៌មាន និងឯកសារពាក់ព័ន្ធ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ E319/31/2 កថាខណ្ឌ ៥-៦។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ (E319/32/1) កថាខណ្ឌ ៨-១០, ១២។

[614] សេចក្តីសម្រេចស្តីពីកាតព្វកិច្ចក្នុងការបង្ហាញឯកសារ (E363/3) និងជើងទំព័រ ៦៤ (“ភស្តុតាងចេញពីកិច្ចស៊ើបសួរសម្ងាត់ក្នុងសំណុំរឿង ០០៣ និង ០០៤ ពុំមានអត្ថិភាពសម្រាប់គោលបំណងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង រហូតទាល់តែការិយាយសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាផ្តល់ទៅភាគីក្នុងសំណុំរឿង ០០២/០២”)។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ៩ (“ឯកសារដែលកើតចេញពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ពុំត្រូវបានចាត់ទុកថា “មានអត្ថិភាព”ក្នុងវិសាលភាពនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរហូតទាល់តែការបង្ហាញត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ”)។

៨៧(៤) នៃវិធានផ្ទៃក្នុង និងពុំស្ថិតក្រោមករណីលើកលែងនៃអត្ថប្រយោជន៍យុត្តិធម៌ឡើយ[615]។ មានតែក្នុងករណីមួយចំនួនប៉ុណ្ណោះដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសំណើដាក់យឺតពេល[616] ដោយសារអត្ថប្រយោជន៍យុត្តិធម៌សំខាន់ជាងការពន្យារពេលក្នុងការស្នើសុំឱ្យទទួលយកឯកសារនោះ[617]។

211. ក្រោយពីការពិនិត្យលើអនុស្សរណៈឯកសារលេខ E319/7, E319/17/1 និង E319/22/1 អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានហេតុផលត្រូវធ្វើការរិះគន់លើនីតិវិធីនេះដែលបានប្រើប្រាស់សម្រាប់ទទួលយកភស្តុតាងថ្មីនោះឡើយ[618]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាង (១) *តាមសេចក្តីបញ្ជាក់ដំបូង* ជាប់ពាក់ព័ន្ធ (២) ពុំមានអត្ថិភាពមុនពេលចាប់ផ្តើមការជំនុំជម្រះ (៣) ជួយដល់ការបញ្ជាក់ការពិត និង (៤) ពុំមានភាគីណាមួយបានជំទាស់ទៅនឹងការទទួលយកភស្តុតាងនេះ[619]។ អង្គជំនុំជម្រះ

---

615 សេចក្តីសម្រេចពាក់ព័ន្ធនឹងឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E190 កថាខណ្ឌ ៣៦។ សេចក្តីសម្រេចលើសំណើរួមគ្នារបស់ភាគីសុំការបំភ្លឺពាក់ព័ន្ធទៅនឹងការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង(ឯកសារលេខ E307) និងការជូនដំណឹងរបស់មេធាវីការពារក្តី នួន ជា អំពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារលេខ E305/3) ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៤ ឯកសារលេខ E307/1។ សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេចឡើងវិញលើការអនុវត្តន៍វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ E307/1/២។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ និងមន្ទីរស្ថិសុខក្រាំងតាចាន់ដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ E319/5។

616 *សូមមើល ឧ.* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ១៧, ២១, ២៥, ៣០, ៣៤, ៣៩, ៤៣, ៤៥។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E319/47/3 ("សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី (E319/47/3)") កថាខណ្ឌ ២០។ សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចម្លើយ និងឧបសម្ព័ន្ធ ១ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ E319/30/1។

617 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ១៧, ២៤, ៣១, ៣៧, ៤១, ៤៣, ៤៦។

618 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319/7) កថាខណ្ឌ ១០។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1) កថាខណ្ឌ ៤។

619 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319/7) កថាខណ្ឌ ៧, ១០។ សេចក្តីសម្រេចលើសំណើសុំអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1) កថាខណ្ឌ ១, ៤។ សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកចម្លើយ (E319/22/1) កថាខណ្ឌ ១, ៣-៦។

សាលាដំបូងបានសង្កេតផងដែរថា សំណើរបស់សហព្រះរាជអាជ្ញាសុំការទទួលយកភស្តុតាងបានដាក់ទាន់ពេល[620]។

212. ពាក់ព័ន្ធទៅនឹងចម្លើយជាលាយលក្ខណ៍អក្សរចំនួន ២១ ដែលត្រូវបានទទួលយកតាមរយៈអនុស្សរណៈឯកសារលេខ E319/32/1 អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា (១) ចម្លើយជាលាយលក្ខណ៍អក្សរនេះពុំមានអត្ថិភាពនៅមុនការចាប់ផ្តើមការជំនុំជម្រះ (២) ចម្លើយជាលាយលក្ខណ៍អក្សរនេះ*តាមសេចក្តីបញ្ជាក់ដំបូង*បានបំពេញតាមបទដ្ឋាននៃការជាប់ពាក់ព័ន្ធ ការជឿទុកចិត្ត និងភាពត្រឹមត្រូវនៃឯកសារ (៣) ចម្លើយជាលាយលក្ខណ៍អក្សរនេះជាប់ពាក់ព័ន្ធ និងជួយនាំទៅរកការបញ្ជាក់ការពិតពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាម និងប្រធានបទដទៃទៀតនៃការជំនុំជម្រះសំណុំរឿង ០០២/០២ រួមទាំងបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ ការបោសសម្អាតផ្ទៃក្នុង និងការប្រព្រឹត្តទៅលើជនជាតិវៀតណាម និង (៤) សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់សមស្របក្នុងការស្នើសុំឱ្យទទួលយកភស្តុតាង[621]។

213. ចុងក្រោយ ទាក់ទងទៅនឹងភស្តុតាងដែលត្រូវបានទទួលយកតាមរយៈអនុស្សរណៈឯកសារលេខ E319/36/2 អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សំណើសុំមួយចំនួនសម្រាប់ការទទួលយកភស្តុតាង ត្រូវបានដាក់ទាន់ពេល ខ្លះទៀតដាក់យឺតពេល[622]។ ទាក់ទងទៅនឹងសំណើសុំឱ្យទទួលយកភស្តុតាងដែលបានដាក់ទាន់ពេល អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា ភស្តុតាង (១) ពុំមានអត្ថិភាពនៅមុនការចាប់ផ្តើមការជំនុំជម្រះ និង (២) ជាប់ពាក់ព័ន្ធទៅនឹងប្រធានបទផ្សេងៗនៃការជំនុំជម្រះ[623]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងដោយផ្អែកលើមូលដ្ឋាននេះ។ ទាក់ទងទៅនឹងសំណើសុំដែលដាក់យឺតពេល អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ភស្តុតាងមានការជាប់ពាក់ព័ន្ធទៅនឹងឯកសារដទៃទៀតក្នុងសំណុំរឿង ០០២/០២ និងអត្ថប្រយោជន៍យុត្តិធម៌បានតម្រូវឱ្យប្រភពនេះត្រូវធ្វើការវាយតម្លៃរួមគ្នា និងថា

---

[620] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E319/7) កថាខណ្ឌ ១០។ សេចក្តីសម្រេចលើសំណើសុំអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (E319/17/1) កថាខណ្ឌ ៤។

[621] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ (E319/32/1) កថាខណ្ឌ ៨-១០។

[622] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ (E319/36/2) កថាខណ្ឌ ១៤, ១៧, ១៩, ២៥, ៣០, ៣៤, ៣៩, ៤៣, ៤៥។

[623] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ១៤-១៦, ១៩-២០, ២៥-២៦, ៣៩-៤០។

ខៀវ សំផន ពុំបានជំទាស់ទៅនឹងការទទួលយកភស្តុតាង[624]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រាសចាកពីវិសាលភាពនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង តាមរយៈការប្រដូចការជាប់ពាក់ព័ន្ធ ស្មើទៅនឹងការនាំទៅរកការបញ្ជាក់ការពិតនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសណាមួយក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលអង្គជំនុំជម្រះបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ។

214. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា វិធីសាស្ត្រនៃ“ការពិនិត្យពិច័យហ្មត់ចត់” គប្បីត្រូវបានប្រើប្រាស់តាំងពីពេលចាប់ផ្តើម មិនមែននៅចុងបញ្ចប់នៃការជំនុំជម្រះនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលជំហរនេះពុំបានអើពើទៅលើបរិបទដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានអនុម័តវិធីសាស្ត្រនេះ។ នៅចុងបញ្ចប់នៃការជំនុំជម្រះក្នុងខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា អង្គជំនុំជម្រះនឹង៖ (១) កំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់ការដាក់សំណើសុំឱ្យទទួលយកភស្តុតាងស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[625] (២) ដាក់សំណើនេះឱ្យស្ថិតក្រោមការពិនិត្យពិច័យហ្មត់ចត់និងដោយផ្អែកលើដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី[626]។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យមានករណីលើកលែងពីរចំពោះកាលបរិច្ឆេទនោះ៖ សម្រាប់សំណើសុំឱ្យទទួលយកភស្តុតាងថ្មី ដើម្បីអាចជំទាស់ទៅនឹងភស្តុតាងដោះបន្ទុកជាសក្ខានុពលដែលត្រូវបានស្នើ

---

[624] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងកោះហៅសាក្សី (E319/36/2) កថាខណ្ឌ ១៧, ២១-២៤, ២៧-២៩, ៣១-៣២, ៣៥-៣៧, ៤១, ៤៣, ៤៥-៤៦។

[625] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើង៖ ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E421 កថាខណ្ឌ ៣។

[626] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី (E319/47/3) កថាខណ្ឌ ២៣។ សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (ឯកសារលេខ E319/51 និងឯកសារលេខ E319/52) ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E319/52/4 (“សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកឯកសារ (E319/52/4)”) កថាខណ្ឌ ១២។

សុំឱ្យបង្ហាញដោយមេធាវីការពារក្ដី[627] និងសម្រាប់សំណើសុំពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញដែលពុំទាន់បានស្ដាប់ដោយតុលាការនៅឡើយ[628]។

215. ការពិចារណាជាគន្លឹះនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់កាលបរិច្ឆេទនេះ និងដាក់សំណើសុំការទទួលយកភស្តុតាងថ្មីឱ្យស្ថិតក្រោម"ការពិនិត្យពិច័យហ្មត់ចត់" គឺថា អង្គជំនុំជម្រះពុំអាចរង់ចាំការបញ្ចប់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ និងអាស្រ័យហេតុនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា "ត្រូវតែមានពេលមួយដែលភាគីអាចសំអាងទៅលើកំណត់ត្រាជាភស្តុតាងដែលត្រូវបានបង្កើតឡើងពេញមួយអំឡុងពេលនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះក្នុងរឿងក្ដីនេះ"[629]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា តម្លៃជាសក្ដានុពលនៃភស្តុតាងបន្ថែមនៅក្នុងការបញ្ជាក់ការពិតត្រូវតែថ្លឹងថ្លែងធៀបនឹងសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងឆ្លើយតបទៅនឹងភស្តុតាងថ្មីណាមួយ និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមស្រប។ អាស្រ័យហេតុនេះ ប្រសិនបើពុំមានការបង្ហាញថា ភស្តុតាងថ្មីនោះមានការដោះបន្ទុក ឬចាំបាច់ដាច់ខាតក្នុងការបញ្ជាក់ការពិតនោះទេ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធការទទួលយកភស្តុតាងថ្មីនៅដំណាក់កាលចុងក្រោយនេះនៃកិច្ចដំណើរការនីតិវិធី ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ[630]។

216. ផ្អែកតាមគោលការណ៍បំភ្លឺច្បាស់លាស់ និងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិធានការធ្វើឡើង និងគោលការណ៍ដែលត្រូវបានអនុវត្តពេញមួយអំឡុងពេលនៃការជំនុំជម្រះ និងជាពិសេសក្នុងដំណាក់កាលចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការតវ៉ានេះពុំមានមូលដ្ឋានគ្រប់គ្រាន់ និងដូច្នេះសារណារបស់ ខៀវ សំផន ស្ដីពីការទទួលឯកសារចេញពីសំណុំរឿង ០០៣ និង ០០៤ ត្រូវបដិសេធចោល។

### គ. ការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរដែលមាន"តម្លៃជាភស្តុតាងទាប និងពាក់ព័ន្ធតិចតួច" និង "សៀវភៅទាំងមូល"

[627] សេចក្ដីសម្រេចលើសំណើពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារលេខ E421/4 កថាខណ្ឌ ១៩។

[628] សេចក្ដីសម្រេចលើសំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4) កថាខណ្ឌ ២០។

[629] សេចក្ដីសម្រេចលើសំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4) កថាខណ្ឌ ១៧-១៨។ សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី (E319/47/3) កថាខណ្ឌ ២៣។

[630] សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី (E319/47/3) កថាខណ្ឌ ២៣។

217. ខៀវ សំផន អះអាងថា វិធីសាស្ត្រ"ពិនិត្យពិច័យហ្មត់ចត់"របស់អង្គជំនុំជម្រះសាលាដំបូងនៅគ្រប់ពេលពុំបានរារាំងអង្គជំនុំជម្រះនូវការទទួលយកឯកសារដែលមានតម្លៃជាភស្តុតាងទាប និងមានការជាប់ពាក់ព័ន្ធតិចតួច ព្រមទាំង "សៀវភៅទាំងមូល"នៅចុងបញ្ចប់នៃការជំនុំជម្រះ[631]។ ទាក់ទងទៅនឹងចម្លើយជាលាយលក្ខណ៍អក្សរ គាត់ពុំបានលម្អិត ឬពន្យល់ការចោទប្រកាន់របស់គាត់អំពីកំហុសនេះឡើយ ប៉ុន្តែត្រឹមតែយោងទៅលើសាលដីការឿងក្តី *Kordić និង Čerkez*[632]។ បន្ទុកនៃការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការទទួលយកភស្តុតាង គឺជារបស់ភាគីដែលចោទប្រកាន់កំហុស និងក្នុងឧទាហរណ៍នេះ ខៀវ សំផន ខកខានក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃការលើកមូលដ្ឋានគាំទ្រគ្រប់គ្រាន់។

218. ទាក់ទងទៅនឹងការទទួលយក"សៀវភៅទាំងមូលច្រើនក្បាល" ខៀវ សំផន បានចង្អុលបង្ហាញអង្គជំនុំជម្រះតុលាការកំពូលនូវការទទួលយកសៀវភៅពីរក្បាលដែលនិពន្ធដោយសាក្សីជំនាញ ដែលបានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូងស្តីពីបទបញ្ហារៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ (១) *ភាពជាមាតាពេលសង្គ្រាម៖ ការមានគភ៌ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម៖ ប្រវត្តិសាស្ត្រផ្ទាល់មាត់ និពន្ធ* NAKAGAWA Kasumi[633] និង (២) *ស្នេហា និងការភ័យខ្លាចក្នុងកម្ពុជា៖ ការរៀបអាពាហ៍ពិពាហ៍ ការផ្តល់កំណើត និងការលុបបំបាត់ពិធីសែនព្រេនក្រោមរបបខ្មែរក្រហម និពន្ធដោយ* LEVINE Peg[634]។

219. សៀវភៅទីមួយចំណងជើងថា *ភាពជាមាតាពេលសង្គ្រាម* ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៥ ហើយសហព្រះរាជអាជ្ញាបានស្នើសុំការទទួលយកសៀវភៅនេះជាភស្តុតាងនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ នៅមុនកាលបរិច្ឆេទថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់ការដាក់សំណើសុំអនុលោមតាមវិធាន ៨៧(៤)

---

631 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២, ១៩៤។

632 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣ និងជើងទំព័រ ២២៩ យោងទៅលើអង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) ក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Dario Kordić និង Mario Cerkez* សំណុំរឿងលេខ IT-95-14/2-A សាលដីកា ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ ("សាលដីការឿងក្តី *Kordić និង Cerkez* (ICTY)") កថាខណ្ឌ ២២១-២២២។

633 អ្នកនិពន្ធ Nagakawa Kasumi៖ ភាពជាមាតាពេលសង្គ្រាម៖ ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម ប្រវត្តិសាស្ត្រផ្ទាល់មាត់ (បោះពុម្ពផ្សាយលើកទីមួយឆ្នាំ ២០១៥) ឯកសារលេខ E3/10655។

634 អ្នកនិពន្ធ Peg Levine ៖ ស្នេហា និងការស្លាប់ក្នុងកម្ពុជា៖ ការរៀបអាពាហ៍ពិពាហ៍ ការផ្តល់កំណើត និងគ្មានពិធីសែនព្រេនក្រោមរបបខ្មែរក្រហម (បោះពុម្ពផ្សាលើកទីមួយឆ្នាំ ២០១០) ឯកសារលេខ E3/10677។

នៃវិធានផ្ទៃក្នុង[635]។ ក្នុងអំឡុងពេលនៃការជំនុំជម្រះ ខៀវ សំផន បានលើកឡើងថា ការទទួលយកនេះគប្បីត្រូវបានកម្រិតត្រឹមផ្នែកដែលពាក់ព័ន្ធទៅនឹងបទបញ្ញារៀបអាពាហ៍ពិពាហ៍ដោយផ្អែកលើមូលដ្ឋានថា "ពុំមានអត្ថប្រយោជន៍ក្នុងការសួរដេញដោលអ្នកជំនាញលើចំណុចដែលពុំបានលើកឡើងក្នុងបទចោទ"[636]។ ក្នុងការសម្រេចលើបញ្ហាថាតើ ត្រូវទទួលយកសៀវភៅនេះជាភស្តុតាង ដែរ ឬយ៉ាងណា ជាដំបូងអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហាថាតើ សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់សមស្រប ដែរ ឬទេ និងបានបញ្ជាក់ថា សៀវភៅនេះមានអត្ថិភាពយ៉ាងតិចប្រាំបីខែមុនការដាក់សំណើសុំឱ្យទទួលយកជាភស្តុតាង ដូច្នេះអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សំណើសុំនោះបានដាក់យឺតពេល[637]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អង្គជំនុំជម្រះទទួលយកសៀវភៅនេះទាំងមូលដើម្បីអត្ថប្រយោជន៍យុត្តិធម៌ ពីព្រោះមានការជាប់ពាក់ព័ន្ធទៅនឹងជំនាញឯកទេសរបស់អ្នកនិពន្ធ NAKAGAWA Kasumi និងជាប់ពាក់ព័ន្ធយ៉ាងច្រើនទៅនឹងសក្ខីកម្មលើអង្គសេចក្តី ដែលលោកស្រីត្រូវបានរំពឹងថា នឹងផ្តល់ក្នុងតុលាការ[638]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរថា សៀវភៅនេះបានផ្តល់មូលដ្ឋានបន្ថែមសម្រាប់ភាគីសួរដេញដោលលើជំនាញឯកទេសរបស់គាត់[639]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីជាសៀវភៅនោះមានអត្ថិភាពក្នុងរយៈពេលប្រាំបីខែមុនសំណើសុំរបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏អ្នកជំនាញ NAKAGAWA Kasumi ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦[640] បីខែមុនសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកនោះ និងបានជ្រើសតាំងជាអ្នកជំនាញ

---

[635] អ្នកនិពន្ធ Nagakawa Kasumi៖ ភាពជាមាតាពេលសង្គ្រាម៖ ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម ប្រវត្តិសាស្ត្រផ្ទាល់មាត់ (បោះពុម្ពផ្សាយលើកទីមួយ) ឯកសារលេខ E3/10655។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារពីរដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងសក្ខីកម្មខាងមុខរបស់សាក្សី 2-TCE-82 ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E431/1។

[636] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E1/469.1 ទំព័រ ១២។ សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចស្តីពីសំណើសុំឱ្យទទួលយកឯកសារដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង និងសំណើសុំរបស់ នួន ជា អនុលោមតាមវិធាន ៨៣ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ NAKAGAWA Kasumi (2-TCE-82) ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E431/5 ("សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចលើសំណើ (E431/5)") កថាខណ្ឌ ២៣។

[637] សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចលើសំណើ (E431/5) កថាខណ្ឌ ២៦។

[638] សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចលើសំណើ (E431/5) កថាខណ្ឌ ២៧-២៨។

[639] សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចលើសំណើ (E431/5) កថាខណ្ឌ ២៨។

[640] ឧបសម្ព័ន្ធ ១ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E431/2.2 (អ៊ីម៉ែលចំណងជើងថា "បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញស្តីពីបទបញ្ញាការរៀបអាពាហ៍ពិពាហ៍" ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦។

នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦[641]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណើសុំរបស់សហព្រះរាជអាជ្ញាបានដាក់យឺតពេលនោះ ជាការពុំត្រឹមត្រូវ។ នៅគ្រប់ករណី អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងលទ្ធផលនៃសេចក្តីសម្រេច និងភាពចាំបាច់សម្រាប់ការទទួលយកសៀវភៅទាំងមូលធ្វើជាភស្តុតាងដោយសារហេតុផលដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង។

220. សៀវភៅទីពីរដែល ខៀវ សំផន ជំទាស់នោះ ចំណងជើងថា *ស្នេហា និងការភ័យខ្លាចក្នុងកម្ពុជា* ដែលត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១០ និងជាសំណៅដែលត្រូវបានកែសម្រួលនៃនិក្ខេបបទស្រាវជ្រាវរបស់អ្នកនិពន្ធ Peggy LEVINE ដែលត្រូវបានទទួលយករួចរាល់ជាភស្តុតាងនៅពេលដាក់សំណើសុំទទួលយកភស្តុតាង[642]។ សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានដាក់ដោយសហមេធាវីនាំមុខនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦[643]។ នៅពេលដាក់សំណើសុំនេះ Peggy LEVINE ត្រូវបានរំពឹងថានឹងមកផ្តល់សក្ខីកម្មជាអ្នកជំនាញ[644] ហើយសហមេធាវីនាំមុខ បានស្នើសុំឱ្យទទួលយកផ្នែកមួយចំនួនក្នុងសៀវភៅដូចជា ជំពូក ១, ២, ៤, ៥ និង ៩[645]។ សហមេធាវីនាំមុខបានលើកឡើងថា ផ្នែកនេះ*តាមសេចក្តីបញ្ជាក់ដំបូង* អាចជឿទុកចិត្តបាន និងជាប់ពាក់ព័ន្ធ និងរួមចំណែកជួយដល់ការបញ្ជាក់ការពិត[646]។ នៅពេលសវនាការលើសំណើសុំទទួលយកភស្តុតាង សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងសំណើសុំនេះទេ ប៉ុន្តែបានលើកឡើងថា ទំនងជាមាន"ភាពខុសគ្នាបន្តិចបន្តួច និងចំណុចខ្លះអាចសំខាន់"រវាងសៀវភៅនេះ និង

---

[641] សេចក្តីសម្រេចស្តីពីការដកខ្លួនរបស់សាក្សី 2-TCE-82 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E431។

[642] អ្នកនិពន្ធ Peg Levine ៖ ស្នេហា និងការស្លាប់ក្នុងកម្ពុជា៖ ការរៀបអាពាហ៍ពិពាហ៍ ការផ្តល់កំណើត និងគ្មានការសែនព្រេនក្រោមរបបខ្មែរក្រហម (ការបោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ២០១០) ឯកសារលេខ E3/10677។ សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងសាក្សី 2-TCE-81 ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E433/3 ("សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E433/3)") កថាខណ្ឌ ៦។

[643] សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E433/3)។

[644] សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E433/3) កថាខណ្ឌ ៥។

[645] សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E433/3) កថាខណ្ឌ ៨-១០។ ឧបសម្ព័ន្ធ ក ៖ ឯកសារដែលត្រូវបានស្នើសុំឱ្យទទួលយកដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសម្រាប់សាក្សី 2-TCE-81 ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E433/3.1។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E1/480.1 ទំព័រ ៣។

[646] សំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E433/3) កថាខណ្ឌ ៧-១០។

និក្ខេបបទដើម[647]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានស្នើដោយផ្ទាល់សុំឱ្យទទួលយកសៀវភៅនេះទាំងមូលជាភស្តុតាង[648]។ ខៀវ សំផន បានយល់ស្របជាមួយនឹងសហមេធាវីនាំមុខ ប៉ុន្តែបានជំទាស់ទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា និងបានលើកឡើងថា ពុំមានភាពចាំបាច់ត្រូវទទួលយកសៀវភៅទាំងមូលនេះទេ ពីព្រោះ"មានផ្នែកត្រួតគ្នាទាក់ទងទៅនឹងនិក្ខេបបទនេះ ដូច្នេះ ជំពូកដែលសហមេធាវីនាំមុខបានបង្ហាញនោះហាក់បីដូចជាគ្រប់គ្រាន់ហើយ"[649]។

221. តាមការកត់សម្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលកត់សង្គាល់ឃើញថា សៀវភៅនេះត្រូវបានបោះពុម្ពជាកូនសៀវភៅតូច បន្ទាប់ពីបានស្តាប់ភាគី និងក្នុងការពិចារណាលើបញ្ហាថាតើ ត្រូវទទួលយកសៀវភៅនេះ *ស្នេហា និងការភ័យខ្លាចក្នុងកម្ពុជា* ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាសំណើរបស់សហមេធាវីនាំមុខសុំឱ្យទទួលយកនោះបានដាក់យឺតពេលក៏ដោយ ក៏ទោះជាយ៉ាងណាក្តីអង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អង្គជំនុំជម្រះត្រូវទទួលយកសៀវភៅនេះទាំងមូលដើម្បីអត្ថប្រយោជន៍យុត្តិធម៌[650]។ ក្នុងការសម្រេចដូច្នោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា នៅពេលនិក្ខេបបទ និងសៀវភៅត្រូវបានពិចារណាជាមួយគ្នា ឯកសារទាំងពីរនេះអាចឱ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃ"ពេញលេញ និងល្អិតល្អន់"នូវសក្ខីកម្មរបស់អ្នកជំនាញ LEVINE[651]។ តាមការសង្កេតឃើញថា ភស្តុតាងអ្នកជំនាញ គឺជាករណីលើកលែងមួយក្នុងចំណោមពីរនោះសម្រាប់កាលបរិច្ឆេទត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់ដាក់សំណើសុំដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដែលបានដាក់នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦[652]។ ដោយពិចារណាលើសំអាងហេតុដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកសំណើនីមួយៗនេះ និងដោយសារគ្មានការលើកមូលដ្ឋានគាំទ្រពីសំណាក់ ខៀវ សំផន ដើម្បីបង្ហាញនូវ

[647] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E1/480.1 ទំព័រ ៣។

[648] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E1/480.1 ទំព័រ ៤។

[649] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E1/480.1 ទំព័រ ៥។

[650] សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងអ្នកជំនាញ Peg LEVINE (2-TCE-81) ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E433/4 ("សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំស្តាប់អ្នកជំនាញ (E433/4)") កថាខណ្ឌ ៤។

[651] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំស្តាប់អ្នកជំនាញ (E433/4) កថាខណ្ឌ ៥។

[652] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខសុំស្តាប់អ្នកជំនាញ (E433/4) កថាខណ្ឌ ២០។

កំហុសដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។

ឃ. ការចោទប្រកាន់អំពីព្យសនកម្ម៖ "ការពន្យារពេលឥតសមស្រប"

222. បញ្ហាចុងក្រោយដែលត្រូវពិចារណាគឺថាតើ ខៀវ សំផន បានទទួលរងព្យសនកម្មដោយសារការទទួលយកឯកសារបន្ថែមនេះ ដែរ ឬយ៉ាងណា។ គាត់បានទាញចំណាប់អារម្មណ៍ជាពិសេសរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើហេតុការណ៍មួយដែលជាប់ពាក់ព័ន្ធទៅនឹងឯកសារជាលាយលក្ខណ៍អក្សរពីរដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង[653]ដែលត្រូវបានចាត់ទុកថា"'ជាប់ពាក់ព័ន្ធបន្ថែម'ទៅនឹងសកម្មភាព និងទង្វើរបស់ជនជាប់ចោទ" ប៉ុន្តែថា "ឯកសារនោះអាចត្រូវបានប្រើប្រាស់ជាភស្តុតាងសម្រាប់គោលបំណងនេះបានតែក្នុងករណីដែលសាមីជននោះ បានផ្តល់សក្ខីកម្មចំពោះមុខតុលាការប៉ុណ្ណោះ"[654]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះ"ទាញចំណាប់អារម្មណ៍របស់ភាគីទៅលើការជាប់ពាក់ព័ន្ធបន្ថែមនេះជាសក្តានុពល ប្រសិនបើភាគីមានបំណងដាក់សំណើសុំកោះហៅសាក្សីទាំងនេះ"[655]។ ខៀវ សំផន បានអះអាងថា ដោយសារលទ្ធផលនៃការលើកឡើងនេះរបស់អង្គជំនុំជម្រះសាលាដំបូង ទើបសហព្រះរាជអាជ្ញា"បានប្រញាប់ប្រញាល់" និងបានដាក់សំណើភ្លាមៗសុំកោះហៅសាក្សីឱ្យមកផ្តល់សក្ខីកម្មលើបញ្ហានៃតួនាទីរបស់គាត់[656]។ ខៀវ សំផន បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានបដិសេធសំណើសុំនោះ ប៉ុន្តែទោះជាយ៉ាងណាក្តីគាត់បានអះអាងថា ពេលវេលាត្រូវបានចំណាយទៅលើសវនាការស្តាប់សំណើសុំនៅចុងបញ្ចប់នៃការជំនុំជម្រះ ដែលបានបង្កឱ្យមានការពន្យារពេលឥតសមស្រប[657]។

223. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នៅពេលភស្តុតាងថ្មីត្រូវបានបង្ហាញយឺតពេលក្នុងកិច្ចដំណើរការនីតិវិធី ភស្តុតាងនេះអាចប៉ះពាល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការឆ្លើយតប និងពិនិត្យលើភស្តុតាង

---

[653] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥។

[654] ការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបំភ្លឺពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E319/52/4 ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E319/52/5 ("ការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន (E319/52/5)") កថាខណ្ឌ ៣។

[655] ការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន (E319/52/5) កថាខណ្ឌ ៣។

[656] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥។

[657] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥។

នោះ និងជាសក្តានុពលចំណាយពេលដ៏មានតម្លៃ និងធនធាន និងជាសក្តានុពលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ[658]។ សិទ្ធិទាំងនោះអនុវត្តចំពោះអយ្យការ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងជនជាប់ចោទ និងត្រូវបានថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន។ ភាគីពុំអាចរំពឹងទុក ឬអាចគ្រប់គ្រងពេញលេញបានថា ការជំនុំជម្រះមួយដោយរលូនដែលសាក្សី និងឯកសារមានអត្ថិភាពនៅពេលសមស្រប និងមានការបកប្រែភាសា និងការគាំទ្របច្ចេកទេសទាំងអស់រួចជាស្រេច អាចកើតឡើងបាននោះទេ។ ដូចបានលើកឡើងខាងដើម ភាពចៃដន្យបានកើតឡើងដោយឥតគ្រោងទុក និងបញ្ហាបច្ចេកទេសនានាបានកើតឡើងសូម្បីតែនៅក្នុងការជំនុំជម្រះដែលបានប្រិតប្រៀងបំផុតក៏ដោយ។ ដូច្នេះ ប្រាកដជាមានការលើកលែងក្នុងកម្រិតមួយសម្រាប់ព្រឹត្តិការណ៍ទាំងនេះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ពេលវេលាដែលបានចំណាយដោយ ខៀវ សំផន ក្នុងការជំទាស់ទៅនឹងសំណើសុំឱ្យទទួលយកភស្តុតាង ឬកោះហៅសាក្សីនោះ តាមធម្មតាគឺជាផលវិបាកនៃការអនុវត្តន៍សិទ្ធិស្តីពីការការពារខ្លួនគាត់ក្នុងការដោះស្រាយសំណើសុំស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងពុំមែនជាការពន្យារពេលដោយឥតសមស្របនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការពន្យារពេលឥតសមស្របនាំឱ្យមានព្យសនកម្ម និងថា នេះពុំមែនជាការពន្យារពេលចាំបាច់ដោយសារភាពចៃដន្យដែលបានកើតឡើងដោយឥតរំពឹងទុកនោះទេ។ សហព្រះរាជអាជ្ញាបានប្រើប្រាស់សិទ្ធិរបស់ខ្លួនស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យកោះហៅសាក្សី ឬទទួលយកភស្តុតាងស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ នៅពេលគ្រប់ភាគីត្រូវបានផ្តល់ឱកាសឱ្យលើកសារណា និងពេលវេលាពិចារណាលើភស្តុតាងថ្មី ឬត្រៀមលក្ខណៈសម្រាប់ការបង្ហាញសាក្សីថ្មី ការពន្យារពេលដែលបានកើតឡើងក្នុងការអនុវត្តន៍សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ ពុំអាចត្រូវបានពិពណ៌នាថា ជាការពន្យារពេលឥតសមស្របនោះឡើយ។

224. ក្រៅពីការលើកឡើងខាងលើ ខៀវ សំផន បានអះអាងថា ដោយសារអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការប្រើប្រាស់ភស្តុតាងថ្មីក្នុងសាលក្រម នេះបញ្ជាក់ថា ការទទួលយកភស្តុតាងដែលយឺតពេលនោះពុំមានភាពចាំបាច់ ឬសំខាន់ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ឡើយ និងថា ភស្តុតាងនោះពុំជាប់ពាក់ព័ន្ធ និងអាស្រ័យហេតុនេះ បានពន្យារពេលការជំនុំជម្រះដោយឥតចាំបាច់[659]។

---

[658] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១៦២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delalić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-96-21-A សាលដីកាចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ ("សាលដីការឿងក្តី *Delalić និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ២៩០។

[659] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦។

225. អំណះអំណាងនេះបានលើកច្រំដែលនូវការតវ៉ាងពីមុនពាក់ព័ន្ធទៅនឹងការទទួលយកឯកសារដ៏ច្រើនចេញពីសំណុំរឿង ០០៣ និង ០០៤ និងភស្តុតាងថ្មី។ ការតវ៉ាបន្ថែមបានលើកឡើងថា នេះជាការឥតប្រយោជន៍ ដោយសារការពិតថា ភស្តុតាងថ្មីនេះពុំត្រូវបានយោងទៅលើនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ។ នេះគឺជាការសម្តែងមតិ និងពុំមែនជាមូលដ្ឋានសុពលភាពសម្រាប់បណ្តឹងសាទុក្ខចំពោះអង្គជំនុំជម្រះតុលាការកំពូល។

226. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រព្រឹត្តកំហុសអង្គច្បាប់ក្នុងការអនុវត្តន៍តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងពុំបានប្រព្រឹត្តកំហុសបន្តបន្ទាប់ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិទទួលយកភស្តុតាងស្របតាមវិធាននេះឡើយ។

### ៤. ការទទួលយកឯកសារមានប្រភពចេញពី Christopher Goscha

227. ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកជាភស្តុតាងនូវឯកសារថ្មីចំនួន ១៣ ដែលជាច្បាប់ចម្លងទាំងស្រុងនៃកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៧ (“កំណត់ហេតុ”) ព្រមទាំងកំណត់ហេតុចេញពីកិច្ចប្រជុំថ្នាក់លើដទៃទៀតដូចជា មន្ទីរ ៨៧០ ឬគណៈកម្មាធិការយោធា[660]។ ការទទួលយកឯកសារទាំងនេះដែលមានប្រភពចេញពីសំណើសុំរបស់សហព្រះរាជអាជ្ញាទៅអង្គជំនុំជម្រះសាលាដំបូង ឱ្យធ្វើការទាក់ទងទៅអ្នកនិពន្ធនាយកសៀវភៅចំណងជើងថា *ប្រល័យពូជសាសន៍ក្នុងកម្ពុជា* ដែលសំដៅទៅលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីទទួលបានច្បាប់ចម្លងពេញលេញបន្ថែមទៀតនៃកំណត់ហេតុនោះ[661]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយសារកំណត់ហេតុគណៈអចិន្ត្រៃយ៍ដទៃទៀតក្នុងសំណុំរឿងបានចុះកាលបរិច្ឆេទឆ្នាំ ១៩៧៥ ឬ ១៩៧៦ ទើបកំណត់ហេតុនេះគឺជាកំណត់ត្រាពិសេសជាសក្ខានុពលនៃសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុងទូទាំងប្រទេស[662]។ ផ្អែកតាមបរិបទនៃការជំទាស់

---

[660] សេចក្តីសម្រេចលើសំណើសុំពាក់ព័ន្ធទៅនឹងឯកសារចម្លងនៃឯកសារភាសាវៀតណាមមានប្រភពសាស្ត្រាចារ្យ Christopher Goscha ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/7 (“សេចក្តីសម្រេចស្តីពីឯកសារ Christopher GOSCHA (E327/4/7)”) កថាខណ្ឌ ១៥-២៨។ អង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២ ជើងទំព័រ ៩៨០។

[661] ការជំទាស់ និងការរក្សាសិទ្ធិរបស់សហព្រះរាជអាជ្ញា ចំពោះបញ្ជីឯកសារដែលបានស្នើឡើងដោយភាគី ក្នុងការឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E327 និងសំណើសុំឱ្យទទួលយកឯកសាររបស់សហព្រះរាជអាជ្ញា ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ E327/4 (“សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា (E327/4)”) កថាខណ្ឌ ៩, ១០។

[662] សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា(ឯកសារលេខ E327/4) កថាខណ្ឌ ៩។

របស់សហព្រះរាជអាជ្ញាដែលថា មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យទទួលយកជាភស្តុតាងតែផ្នែកដក ស្រង់នៃកំណត់ហេតុនេះដែលជាផ្នែកនៃភស្តុតាងឯកសារដែលទទួលបានក្នុងអំឡុងពេលនៃ"ការជំនុំជម្រះ" ឆ្នាំ ១៩៧៩ របស់ប្រជាជនបដិវត្តន៍ប្រឆាំងនឹង ប៉ុល ពត និង អៀង សារី ដែលបានធ្វើឡើងដោយកំបាំងមុខ ភ្លាមៗបន្ទាប់ពីការដួលរលំរបបខ្មែរក្រហម/កម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងបានទទួល យកសំណើនោះនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥[663]។

228. អង្គជំនុំជម្រះសាលាដំបូងបន្ទាប់មកបានបង្គាប់ក្រឡាបញ្ជីរបស់ខ្លួនឱ្យធ្វើការទាក់ទងទៅបុគ្គលជាច្រើន និង វិទ្យាស្ថាននានា រួមទាំង Philip SHORT ដែលបានមកផ្តល់សក្ខីកម្មជាអ្នកជំនាញក្នុងសំណុំរឿង ០០២/០១ និង Christopher GOSCHA នៃសកលវិទ្យាល័យ Québec ដែលអ្នកទាំងពីរបានបញ្ជាក់ថា ច្បាប់ចម្លង ពេញលេញនៃកំណត់ហេតុនេះទំនងជាត្រូវបានរក្សាទុកក្នុងបណ្ណាល័យកងទ័ពរបស់ប្រជាជន("បណ្ណាល័យ ") ទីក្រុងហាន់ណូយប្រទេសវៀតណាម[664]។ Christopher GOSCHA បានជូនដំណឹងអង្គជំនុំជម្រះថា គាត់បានចូលទៅមើលបណ្ណាល័យនោះក្នុងទីក្រុងហាន់ណូយកាលពី ២៥ ឆ្នាំមុន និងធ្វើការចម្លងឯកសារ ទាំងនោះដោយផ្ទាល់ដៃ[665]។ គាត់បានអះអាងផងដែរថា គាត់បានបរិច្ចាគច្បាប់ចម្លងឱ្យទៅបណ្ណសារសាក លវិទ្យាល័យបច្ចេកវិជ្ជានៅរដ្ឋតិចសាស ("បណ្ណសារតាមប្រព័ន្ធអ៊ីនធឺណិត") និងបានផ្តល់អាសយដ្ឋានដែល អាចចូលមើលតាមប្រព័ន្ធអ៊ីនធឺណិតសាធារណៈដែលគាត់បានបញ្ជាក់ថា អាចមានឯកសារមួយចំនួនមាន

---

[663] ឧបសម្ព័ន្ធ គ៖ ឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា សុំឱ្យដាក់ចំពោះមុខអង្គជំនុំជម្រះ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E/305/17.3។

[664] ឧបសម្ព័ន្ធ ៦៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយលោក Philip SHORT ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឯកសារលេខ E327/4/3.6 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ "ការស៊ើបសួរដែលត្រូវផ្ញើទៅសាក្សី Philip SHORT សំណុំរឿង ០០២/០១" ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ៧៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.7 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ "កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យរបស់ Christopher GOSCHA" ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦)។

[665] ឧបសម្ព័ន្ធ ៦៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយលោក Philip SHORT ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.6 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ "ការស៊ើបសួរដែលត្រូវផ្ញើទៅសាក្សី Philip SHORT សំណុំរឿង ០០២/០១" ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ៧៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.7 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ "កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យរបស់ Christopher GOSCHA") ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦។

ប្រភពពីប្រទេសកម្ពុជា និងនៅសម័យរបបរបបកម្ពុជាប្រជាធិបតេយ្យនៅទីនោះ[666]។ អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ និងបានជូនដំណឹងភាគីអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដែលកំពុងបន្តស្វែងរកច្បាប់ចម្លងពេញលេញនៃកំណត់ហេតុទាំងនោះ និងបានភ្ជាប់ជាមួយនូវការទំនាក់ទំនងតាមអ៊ីមែលជាមួយ Christopher GOSCHA និងបានបញ្ចូលការតភ្ជាប់ទំនាក់ទំនងជាសាធារណៈទៅបណ្ណសារតាមប្រព័ន្ធអ៊ីនធឺណិតនោះផងដែរ[667]។

229. នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងតាមរយៈអ៊ីមែលបានស្នើសុំព័ត៌មានបន្ថែមទៀតពី Christopher GOSCHA ទាក់ទងទៅនឹងច្បាប់ចម្លងនៃកំណត់ហេតុនោះដែលគាត់បានបរិច្ចាគឱ្យទៅបណ្ណសារនោះ ជាពិសេសថាតើ ឯកសារដើមជាភាសាវៀតណាម ដែរ ឬយ៉ាងណា និងថាតើកំណត់ហេតុនោះត្រូវបានចម្លងដូចច្បាប់ដើមទាំងស្រុង និងថាតើ ត្រូវបានបកប្រែជាភាសាដទៃទៀត ដែរ ឬយ៉ាងណា[668]។ Christopher GOSCHA បានបញ្ជាក់ថា រាល់ឯកសារទាំងនោះដែលគាត់បានចម្លងចេញត្រូវបានបកប្រែជាភាសាវៀតណាម និងថា គាត់ពុំដែលឃើញសំណៅដើមជាភាសាខ្មែរឡើយ[669]។ គាត់

---

[666] ឧបសម្ព័ន្ធ ៦៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយលោក Philip SHORT ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.6 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ “ការស៊ើបសួរដែលត្រូវផ្ញើទៅសាក្សី Philip SHORT សំណុំរឿង ០០២/០១” ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៦)។ ឧបសម្ព័ន្ធ ៧៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.7 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ “កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យរបស់ Christopher GOSCHA”) ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦។

[667] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ ការបកប្រែសំណៅឯកសារភាសាវៀតណាមដែលទទួលបានពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យាប្រភពដើមចេញពីសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5 (“អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង (E327/4/5)”) កថាខណ្ឌ ៥។ ឧបសម្ព័ន្ធ ៧៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.7 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ “កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យរបស់ Christopher GOSCHA”ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦)។

[668] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ៣។ ឧបសម្ព័ន្ធ ៤៖ ការទំនាក់ទំនងតាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ និងអ្នកជំនាញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5.4 (អ៊ីម៉ែលស្តីពីកម្មវត្ថុ “សំណួរបន្ថែមស្តីពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យា” ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦)។

[669] ឧបសម្ព័ន្ធ ៤៖ ការទំនាក់ទំនងតាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ និងអ្នកជំនាញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5.4 (អ៊ីម៉ែលស្តីពីកម្មវត្ថុ “សំណួរបន្ថែមស្តីពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យា” ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦)។

បានបន្ថែមថា បើទោះបីជាគាត់ពុំបានបកប្រែទៅជាភាសាផ្សេងក៏ដោយ ក៏គាត់បានផ្តល់ឯកសារទាំងនោះឱ្យទៅលោក Philip SHORT ដែលបានបកប្រែឯកសារខ្លះទៅជាភាសាបារាំង[670]។ តាមការណែនាំរបស់អង្គជំនុំជម្រះ ក្រឡាបញ្ជីក៏បានពិនិត្យលើបញ្ជីឯកសារជាភាសាអង់គ្លេសបានរកឃើញនៅក្នុងបណ្ណសារនោះ និងបានជ្រើសរើសឯកសារ ១៥ ក្នុងចំណោម ៧៤ សម្រាប់ការបកប្រែពីភាសាវៀតណាមទៅជាភាសាអង់គ្លេស[671]។ នៅពេលការបកប្រែភាគច្រើនត្រូវបានបញ្ចប់ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីការទាក់ទងដែលបានលើកឡើងខាងលើជាមួយ Christopher GOSCHA នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ដោយបានពន្យល់ថា ខណៈពេលស្រាវជ្រាវរកកំណត់ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីឯកសារនេះមានប្រភពមកពី Christopher GOSCHA (“ឯកសារ GOSCHA”) និងបានជ្រើសរើសយក ១៥ ឯកសារដែល“បង្ហាញតាមរយៈចំណងជើងនីមួយៗថា មានការជាប់ពាក់ព័ន្ធគ្រប់គ្រាន់សម្រាប់ការបកប្រែជាភាសាអង់គ្លេស”[672]។ អង្គជំនុំជម្រះសាលាដំបូងបានដាក់ឯកសារទាំង ១៥ នេះនៅក្នុងកន្លែងផ្ទុកឯកសាររួមក្នុងប្រព័ន្ធកុំព្យូទ័រ ដែលមានឯកសារប្រាំបួនត្រូវបានបកប្រែជាភាសាអង់គ្លេស ហើយផ្សេងទៀតនឹងបកប្រែតាមក្រោយ និងបានអញ្ជើញភាគីឱ្យដាក់សារណាស្តីពីភាពអាចទទួលយកបាននៃឯកសារនេះ[673]។

230. បន្ទាប់មក ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចមានសំអាងហេតុសម្រាប់ចំណាត់ការស្រាវជ្រាវនីមួយៗដែលខ្លួនបានធ្វើឡើងក្នុងការទទួលបានឯកសារនេះ និងថា អង្គជំនុំជម្រះគប្បីសម្រេចផងដែរថា រាល់ច្បាប់ចម្លងនៃឯកសារពុំអាចទទួលយកបានទេ[674]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់នូវមូលហេតុដែលខ្លួនសម្រេចទទួលយកឯកសារដែលត្រូវបានធ្វើប្រតិចារឹកដោយ Christopher GOSCHA និងហេតុដូចម្តេចបានជា“ភាគីត្រូវបានផ្តល់ឱកាសលើកសារណាស្តីពីភាពអាចទទួលយកបាននៃឯកសារនេះ ដែលចុងក្រោយទទួលបាន ហើយអង្គជំនុំជម្រះបានពិចារណាឃើញថា សិទ្ធិ

---

670 ឧបសម្ព័ន្ធ ៤៖ ការទំនាក់ទំនងតាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ និងអ្នកជំនាញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5.4 (អ៊ីម៉ែលស្តីពីកម្មវត្ថុ “សំណួរបន្ថែមស្តីពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យា” ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦)។

671 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E327/4/5) កថាខណ្ឌ ២។

672 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E327/4/5) កថាខណ្ឌ ២។

673 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E327/4/5) កថាខណ្ឌ ២។

674 សារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននូវឯកសារដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង (E327/4/5) ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/6 (“សារណារបស់ ខៀវ សំផន ស្តីពីភាពអាចទទួលយកបាន (E327/4/6)”) កថាខណ្ឌ ៣៣។

ទាំងអស់របស់ជនជាប់ចោទស្តីពីនីតិវិធីត្រូវបានគោរព"[675]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការទទួលយកឯកសារ ១៥ នេះជាភស្តុតាងដែលមានឯកសារត្រួតគ្នាពីរ គឺដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងបានយល់ឃើញថា តាមសេចក្តីបញ្ជាក់ដំបូង ឯកសារនេះគួរជឿជាក់បាន មានភាពត្រឹមត្រូវ ព្រមទាំងពាក់ព័ន្ធ និងរួមចំណែកជួយដល់ការបញ្ជាក់ការពិតបាន[676]។

231. អង្គជំនុំជម្រះសាលាដំបូងបានរកឃើញភាពប្រហាក់ប្រហែលគ្នារវាងឯកសារដែលត្រូវបានចាត់ទុកថា ជាកំណត់ហេតុទាំងនោះដែលមានប្រភពមកពី Christopher GOSCHA និងកំណត់ហេតុដែលបានប្រើប្រាស់ក្នុងការជំនុំជម្រះដោយតុលាការប្រជាជនបដិវត្តន៍ ដែលត្រូវបានចាត់ទុកថា "កំណត់ហេតុ"នៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ មានដូចជាកម្មវត្ថុនៃការពិភាក្សាដូចគ្នា អ្នកចូលរួមដូចគ្នានៃកិច្ចប្រជុំ និងការអនុម័តខ្លឹមសារសេចក្តីសម្រេចទាក់ទងទៅនឹង"សត្រូវផ្ទៃក្នុង"[677]។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា ខ្លឹមសារនៃឯកសារមួយចំនួនរបស់ Christopher GOSCHA ត្រូវបានបញ្ជាក់បន្ថែមដោយទស្សនាវដ្តីទង់បដិវត្ត ដែលប្រើប្រាស់"ដើម្បីបញ្ជាក់ការយល់ឃើញនូវភាពត្រឹមត្រូវនៃឯកសារ Christopher GOSCHA ខែ មករា ឆ្នាំ ១៩៧៨"[678]។ ទោះជាយ៉ាងណាក្តី ដោយសារមានការលំបាកក្នុងការបង្ហាញនូវប្រវត្តិនៃការទុកដាក់ឯកសារ និងផ្ទៀងផ្ទាត់ភាពពេញលេញនៃការធ្វើប្រតិចារឹកដោយដៃនៃការបកប្រែភាសាវៀតណាមនោះ "ដែលអាចប៉ះពាល់ជាសក្តានុពលលើភាពអាចជឿទុកចិត្តបាននៃឯកសារ" អង្គជំនុំជម្រះសាលាដំបូងបានកម្រិតការប្រើប្រាស់ឯកសាររបស់ Christopher GOSCHA សម្រាប់គោលបំណងត្រឹមតែជាការបញ្ជាក់បន្ថែមប៉ុណ្ណោះ[679]។

232. នៅបណ្តឹងសាទុក្ខ ខៀវ សំផន បានជំទាស់ទៅនឹងការទទួលយកបានរបស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសារ និងសេចក្តីសម្រេចទទួលយកឯកសារនេះជាភស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ និងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីតម្លៃជាភស្តុតាង[680]។ គាត់បានសំអាងទៅលើអំណះអំណាងរបស់គាត់នៅពេលជំនុំជម្រះដែលគាត់បានជំទាស់ទៅនឹងកង្វះសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង និងតម្លាភាពពាក់ព័ន្ធទៅនឹងចំណាត់ការដែលអង្គជំនុំជម្រះបានធ្វើឡើងក្នុងការទទួលបានឯកសារស្របតាមវិធាន ៩៣ នៃវិធាន

---

[675] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ១៩។

[676] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ១៥-២៧។

[677] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

[678] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

[679] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣-៣៥៤។

[680] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៦-២២៥។

ផ្ទៃក្នុង។ គាត់បានលើកឡើងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិតាមរយៈការសន្និដ្ឋានថា "រាល់សិទ្ធិទាំងអស់របស់ជនជាប់ចោទផ្នែកនីតិវិធីត្រូវបានគោរព"នៅគ្រប់ចំណាត់ការក្នុងការទទួលបានឯកសារនោះ[681]។ ក្នុងការបដិសេធការយល់ឃើញនេះ គាត់បានលើកអំណះអំណាងពីរ៖ ទីមួយថា អង្គជំនុំជម្រះសាលាដំបូង"ខកខានក្នុងការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួននូវចំណាត់ការដែលបានប្រើប្រាស់ក្នុងការទទួលបានឯកសារស្របតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង" និងទីពីរថា "ចំណាត់ការស្រាវជ្រាវ [...] ដើម្បីទទួលបានឯកសារពី Christopher GOSCHA បានធ្វើហួសពីសំណើរបស់អយ្យការដែលសុំត្រឹមតែឱ្យស្រាវជ្រាវរកផ្នែកដកស្រង់ចេញពីកំណត់ហេតុប៉ុណ្ណោះ"[682]។ ផ្អែកលើមូលដ្ឋាននេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិរបស់គាត់ផ្នែកនីតិវិធី និងបានបង្ហាញនូវភាពលម្អៀង[683]។ បន្ថែមលើការអះអាងថា អង្គជំនុំជម្រះសាលាដំបូងខ្វះតម្លាភាព សារណារបស់គាត់បានចោទប្រកាន់អង្គជំនុំជម្រះសាលាដំបូងផងដែរអំពីការអនុវត្តន៍ដោយ"អសុទ្ធចិត្ត" នៅពេលអង្គជំនុំជម្រះ"បានបញ្ជាក់ថា មេធាវីការពារក្តីខកខានក្នុងការជំទាស់ទៅនឹងសំណើរបស់អយ្យការសុំឱ្យស្វែងរកផ្នែកដកស្រង់ចេញពីកំណត់ហេតុនោះ"[684]។

233. ទីពីរ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសមួយបន្ថែមទៀតដែលស្តែងចេញឱ្យឃើញតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដោយបានសម្រេចទទួលយកឯកសារ ដែលគាត់អះអាងថា ពុំអាចជឿទុកចិត្តបាន និងពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបានដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[685]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីបាន"ពិចារណាហ្មត់ចត់"លើកត្តាដែលប៉ះពាល់ដល់ភាពអាចជឿទុកចិត្តបាននៃឯកសារ ដូចជានត្ថិភាពនៃលទ្ធភាពក្នុងការតាមដានប្រវត្តិនៃការទុកដាក់ឯកសារ និងការពិតដែលថា ឯកសារដើមពុំត្រូវបានរកឃើញ និងលទ្ធភាពនៃកំហុសក្នុងការចម្លងដោយដៃ[686]។ គាត់បានអះអាងជាក់លាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភាពអាចជឿទុកចិត្តបាននៃឯកសារ ដោយបានបញ្ជាក់ថា ឯកសារនេះត្រូវបានចម្លង"ដូចដើមទាំងស្រុង" និងថា ឯកសារមួយចំនួនមានឈ្មោះអ្នកបកប្រែ និងកាលបរិច្ឆេទនៃការបក

---

[681] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៨។

[682] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧-២១៨។

[683] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២០។

[684] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៩។

[685] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧។

[686] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២១-២២២។

ប្រែ[687]។ យោងតាម ខៀវ សំផន បានឱ្យដឹងថា ពុំមានតុលាការអង្គហេតុសមហេតុផលអាចយល់ឃើញថា ឯកសារនោះ*តាមសេចក្តីបញ្ជាក់ដំបូង*គួរឱ្យជឿទុកចិត្តបាន និងត្រឹមត្រូវ និងដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានទទួលយកផ្អែកតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[688]។

234. ចុងក្រោយ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការពិចារណា និងប្រើប្រាស់ឯកសារសម្រាប់ការបញ្ជាក់បន្ថែមក្នុងករណីដែលតម្លៃជាភស្តុតាងនៃឯកសារនោះគឺស្មើនឹង"សូន្យ"[689]។ ផ្អែកតាមទស្សនៈរបស់គាត់បានឱ្យដឹងថា កំហុសអង្គច្បាប់ជាប់ពាក់ព័ន្ធទៅនឹងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឯកសារនេះមានតម្លៃជាការបញ្ជាក់បន្ថែមនោះ គាត់បានយោងទៅលើអំណះអំណាងពីមុនរបស់គាត់ដែលជំទាស់ទៅនឹងភាពអាចជឿទុកចិត្តបាន និងការយល់ឃើញស្តីពីភាពត្រឹមត្រូវនៃឯកសារដែលគាត់បានអះអាងថា ជាអំពើមិនសមគួរ និងបានផ្អែកទៅលើភាពស៊ីសង្វាក់គ្នានៃតួលេខតែមួយគត់រវាងឯកសារនោះ ជាមួយនឹងភស្តុតាងក្នុងសំណុំរឿង[690]។ បន្ថែមលើនេះ ខៀវ សំផន បានចោទប្រកាន់អង្គជំនុំជម្រះសាលាដំបូងអំពីការ"បំភ្លៃភស្តុតាង"តាមរយៈការព្យាយាមសម្របសម្រួលខ្លឹមសារនៃឯកសារពីរផ្សេងគ្នាឱ្យឃើញថា ឯកសារពីរនេះជាប់ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំតែមួយ[691]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានប្រើប្រាស់ឯកសារសម្រាប់ការបញ្ជាក់អះអាងបន្ថែមដោយសារតែមានភាពពុំអាចជឿទុកចិត្តបាន និងតម្លៃជាភស្តុតាងទាប ហើយគាត់បានស្នើសុំថា ការយល់ឃើញដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ ត្រូវដកចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង[692]។

235. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការលើកមូលដ្ឋានគាំទ្រការចោទប្រកាន់កំហុសក្នុងការទទួលបានឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ការទទួលយក និងការប្រើប្រាស់នូវឯកសារដែល

---

[687] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២២។

[688] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៣។

[689] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៤, ១៤៦៣។

[690] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៤។

[691] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៥។

[692] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៦៣។

រងការជំទាស់នោះ និងថា គាត់ខកខានក្នុងការបង្ហាញហេតុដូចម្តេចបានជាការប្រើប្រាស់នោះបណ្តាលឱ្យការយល់ឃើញពុំសមហេតុផល ឬបណ្តាលឱ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងគ្មានសុពលភាព[693]។

ក. ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលបានឯកសារ GOSCHA

236. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានបញ្ជាក់សាឡើងវិញនូវអំណះអំណាងរបស់គាត់នៅពេលជំនុំជម្រះដែលបានជំទាស់ទៅនឹងធម្មានុរូប និងតម្លាភាពនៃចំណាត់ការបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ដើម្បីទទួលបានឯកសារផ្សេងៗស្របតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង[694] ដែលកំណត់ដំណើរការនៃការបើកកិច្ចស៊ើបសួរបន្ថែម ដែលអង្គជំនុំជម្រះសាលាដំបូងអាចផ្តួចផ្តើមបើកកិច្ចស៊ើបសួរបន្ថែមនៅគ្រប់ពេល។ វិធាន ៩៣ នៃវិធានផ្ទៃក្នុង ពុំបានចែងថាត្រូវមានការជូនដំណឹងផ្លូវការ ឬការអនុញ្ញាតចេញពីភាគីណាមួយឡើយ។

237. ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តួចផ្តើមកិច្ចស៊ើបសួរបន្ថែមពុំបានបង្ហាញនូវការរំលោភបំពានលើសិទ្ធិផ្នែកនីតិវិធីរបស់ជនជាប់ចោទ។ ក្នុងករណីនេះ ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបង្ហាញដល់ភាគី ដែលត្រូវបានផ្តល់ឱកាសឱ្យបញ្ចេញមតិយោបល់ផងដែរ។ ក្នុងការដោះស្រាយការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តន៍តាមលក្ខខណ្ឌវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា៖

> អង្គជំនុំជម្រះអាចបង្គាប់ក្រឡាបញ្ជី ឬ[អង្គភាពគាំពារសាក្សី និងអ្នកជំនាញ] ឱ្យចាត់វិធានការដែលត្រូវបានកម្រិតត្រឹមការទាក់ទងបុគ្គល ឬវិទ្យាស្ថានដើម្បីទទួលបានព័ត៌មានជាក់លាក់ផ្អែកតាមសំណើសុំរបស់ភាគី ឬតាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះដោយពុំចាំបាច់មានការផ្តួចផ្តើមបើកកិច្ចស៊ើបសួរផ្លូវការតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងឡើយ[695]។

238. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ចំណាត់ការបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការជំទាស់នេះ បានរួមបញ្ចូលការស៊ើបសួររកព័ត៌មានបន្ថែមតាមរយៈអ៊ីមែលពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះពី Christopher GOSCHA បន្ទាប់ពីគាត់បានផ្តល់អាសយដ្ឋានទំនាក់ទំនងភ្ជាប់ទៅបណ្ណសារតាមប្រព័ន្ធអ៊ីនធឺណិត ដែលអាចមានកំណត់ហេតុនោះដែលជាកម្មវត្ថុនៃសំណើសុំរបស់សហព្រះរាជអាជ្ញារួមទាំងឯកសារ

---

[693] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៨៩-១៩៣។

[694] សារណារបស់ ខៀវ សំផន ស្តីពីភាពអាចទទួលយកបាន (E327/4/6) កថាខណ្ឌ ៧-១៦។

[695] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ១៦, ១៧។

ដទៃទៀតនៅសម័យនោះ។ ក្រឡាបញ្ជីបានពន្យល់ក្នុងអ៊ីមែលថា គាត់បានពិនិត្យលើឯកសារដែលមានក្នុងបណ្ណសារនោះ និងថា ឯកសារមួយចំនួនទំនងជា"មានសារៈសំខាន់ជាសក្ខានុពលចំពោះកិច្ចដំណើរការនីតិវិធីជំនុំជម្រះ"បើផ្អែកតាមចំណងជើង[696]។ ដោយកត់សម្គាល់ថា ឯកសារនោះមានតែជាភាសាវៀតណាម ក្រឡាបញ្ជីបានស៊ើបសួររកឯកសារភាសាដើមពី Christopher GOSCHA ប្រសិនបើមានជាភាសាដទៃទៀតនោះ និងការដែលលោកសាស្ត្រាចារ្យធ្វើការចម្លងដូចម្ដេចខ្លះ[697]។ វិធានការទាំងនេះត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យឯកសារសំខាន់ជាសក្ខានុពលទាំងនេះមានអត្ថិភាពចំពោះភាគីជាភាសាផ្លូវការរបស់តុលាការ ដែលអនុញ្ញាតឱ្យភាគីដាក់សារណាស្ដីពីភាពអាចទទួលយកបាននៃឯកសារនេះ។ លក្ខណៈនៃការស៊ើបសួរព័ត៌មានបន្ថែមបានបញ្ជាក់លើចំណុចនេះ ដូចគ្នានឹងការពិតដែលថា នៅពេលឯកសារភាគច្រើនត្រូវបានបកប្រែភាសាអង់គ្លេស អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីអំពីអត្ថិភាពនៃឯកសារនេះ និងបានដាក់ឯកសារទាំងនេះក្នុងកន្លែងផ្ទុកឯកសាររួមក្នុងប្រព័ន្ធកុំព្យូទ័រ និងបានអញ្ជើញភាគីឱ្យដាក់សារណាស្ដីពីភាពអាចទទួលយកបាន[698]។

239. អង្គជំនុំជម្រះតុលាការកំពូលមានការជឿជាក់ស្ទើរតែទាំងស្រុងក្នុងការគាំទ្រចំណាត់ការត្រឹមត្រូវតាមច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកឯកសារ Christopher GOSCHA និងការស៊ើបសួរហ្មត់ចត់អំពីការដែលឯកសារនេះត្រូវបានបង្កើតឡើង ពីប្រភព និងបកប្រែដូចម្ដេចខ្លះ។ ការមិនអើពើលើភស្តុតាងដែលពាក់ព័ន្ធខ្លាំងជាសក្ខានុពល និងមានអត្ថិភាពនៅសម័យនោះ ដែលបានទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការស្រាវជ្រាវរកនោះ គឺជាការខ្ជីខ្ជា។ បន្ទាប់ពីស្ដាប់សារណារបស់ភាគី អង្គជំនុំជម្រះសាលាដំបូងបានទទួលយកឯកសារចំនួន ១៣ ជាភស្តុតាងដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងបានយល់ឃើញថា៖

> ខ្លឹមសារនៃឯកសារចម្លងទាំងអស់ជាប់ពាក់ព័ន្ធទៅនឹងការពិភាក្សា និងសកម្មភាពដែលដឹកនាំដំណោះស្រាយបានពិពណ៌នាថា ស្ថាប័នកំពូលធ្វើសេចក្ដីសម្រេចនៃកម្ពុជាប្រជាធិបតេយ្យ គឺជាគណៈអចិន្ត្រៃយ៍ ឬស្ថាប័ន

---

[696] ឧបសម្ព័ន្ធ ៤៖ ការទំនាក់ទំនងតាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ និងអ្នកជំនាញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5.4 (អ៊ីម៉ែលស្ដីពីកម្មវត្ថុ "សំណួរបន្ថែមស្ដីពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យា" ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦)។

[697] ឧបសម្ព័ន្ធ ៤៖ ការទំនាក់ទំនងតាមរយៈអ៊ីម៉ែលពីមន្ត្រីច្បាប់ និងអ្នកជំនាញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/5.4 (អ៊ីម៉ែលស្ដីពីកម្មវត្ថុ "សំណួរបន្ថែមស្ដីពីបណ្ណសាររដ្ឋតិចសាសនៃសកលវិទ្យាល័យបច្ចេកវិទ្យា" ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦)។ សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (ឯកសារលេខ E327/4/7) កថាខណ្ឌ ៣។

[698] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E327/4/5)។

ពាក់ព័ន្ធ ឬមន្ទីរ ៨៧០។ ឯកសារនោះមានអានុភាពលើសកម្មភាព និងការដឹងរបស់ជនជាប់ចោទក្នុងរឿងក្ដីនេះ[699]។

240. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីចំណាត់ការបន្ថែមដែលបានស្នើឡើង នៅពេលឯកសារភាគច្រើនត្រូវបានបកប្រែជាភាសាដែលអាចពិនិត្យបាន និងដើម្បីឱ្យឯកសារនោះមានអត្ថិភាពសម្រាប់ភាគីពិគ្រោះពិភាក្សា និងពិនិត្យមុនពេលដាក់សារណាស្ដីពីភាពអាចទទួលយកបាន។ សម្រាប់ហេតុផលនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ដល់សំអាងហេតុសម្រាប់ការធ្វើចំណាត់ការបន្ថែមនេះ ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ខៀវ សំផន បានលើកអំណះអំណាងបន្ថែមដែលពុំមានសារៈសំខាន់ដោយចោទប្រកាន់នូវកង្វះតម្លាភាពពាក់ព័ន្ធទៅនឹងចំណាត់ការបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានស្នើឡើងនោះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីការទាក់ទងដំបូងជាមួយ Christopher GOSCHA ដើម្បីទទួលបានកំណត់ហេតុកិច្ចប្រជុំនេះ និងបានភ្ជាប់មកជាមួយនូវការឆ្លើយឆ្លងតាមអ៊ីមែល ដែលបានរួមបញ្ចូលការភ្ជាប់ទំនាក់ទំនងអាសយដ្ឋានតាមប្រព័ន្ធអ៊ីធឺណិតទៅបណ្ណសារនោះ[700]។ អាស្រ័យហេតុនេះ នៅពេលនោះភាគីអាចចូលមើលឯកសារនោះបាន និងអាចស្នើសុំឱ្យទទួលយកជាភស្តុតាងប្រសិនបើខ្លួនគិតថា ឯកសារនោះជាប់ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២។ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ បន្ទាប់ពីឯកសារមួយភាគធំត្រូវបានបកប្រែរួចរាល់ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីអំពីវិធីសាស្ត្រនៃការស្រាវជ្រាវរកកំណត់ហេតុនេះ ដែលនាំឱ្យអង្គជំនុំជម្រះអាចដឹងអំពីឯកសារដទៃទៀតដែលមានប្រភពចេញពី Christopher GOSHCA និងបានភ្ជាប់មកជាមួយនូវការឆ្លើយឆ្លងជាថ្មីម្ដងទៀត និងបានពន្យល់មូលហេតុដែលខ្លួនជ្រើសរើសយក ១៥ ឯកសារនេះ និងបានអញ្ជើញភាគីដាក់សារណាអំពីភាពអាចទទួលយកបាន។ ចុងក្រោយ នៅក្នុងការឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុបន្ថែមសម្រាប់ចំណាត់ការរបស់ខ្លួននៅក្នុងសេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃឯកសារទាំង ១៥ នេះនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ ចំណាត់ការដំបូងបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូ

[699] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (ឯកសារលេខ E327/4/7) កថាខណ្ឌ ២០។

[700] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង (E327/4/5) កថាខណ្ឌ ៥។ ឧបសម្ព័ន្ធ ៧៖ ការទំនាក់ទំនងតាមអ៊ីម៉ែលរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងជាមួយសាស្ត្រាចារ្យ Christopher GOSCHA ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E327/4/3.7 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងលើកម្មវត្ថុ "កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍កម្ពុជាប្រជាធិបតេយ្យរបស់ Christopher GOSCHA"ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦)។

ងបានធ្វើឡើងដោយសមហេតុផលក្នុងការជូនដំណឹងភាគីអំពីសកម្មភាពរបស់ខ្លួននៅពេលអង្គជំនុំជម្រះបានចាត់ទុកថា ការធ្វើដូច្នោះជាការសមស្រប។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចំណាត់ការដែលបានពិពណ៌នានោះបានផ្តល់នូវតម្លាភាព និងពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាដេញដោលចំពោះមុខតាមរយៈការសម្រួលនូវការបកប្រែជាភាសាប្រើប្រាស់ផ្លូវការរបស់តុលាការ និងបានអញ្ជើញភាគីឱ្យដាក់សារណាស្តីពីភាពអាចទទួលយកបាននៃឯកសារនោះ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើផ្ទាល់មាត់របស់ ខៀវ សំផន សុំពន្យារពេលកាលបរិច្ឆេទដែលបានកំណត់សម្រាប់ការដាក់សារណាស្តីពីភាពអាចទទួលយកបាន ដើម្បីឱ្យគាត់មានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ និងឆ្លើយតបទៅនឹងឯកសារដទៃទៀត[701]។ ខៀវ សំផន បានទាញយកផលចំណេញនៃឱកាសនោះធ្វើការស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា រាល់ឯកសារទាំងនោះពុំអាចទទួលយកបាន និងផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចក្នុងការទទួលយកឯកសារដទៃទៀតនោះ។ សារណារបស់ ខៀវ សំផន ខកខានក្នុងការពន្យល់ថាតើ ចំណាត់ការខាងលើបានបណ្តាលឱ្យមានព្យសនកម្មលើរូបគាត់ដូចម្តេចឡើយ។

241. ចុងក្រោយ ក្នុងការដោះស្រាយអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តដោយអសុទ្ធចិត្តនោះនៅពេលដែលអង្គជំនុំជម្រះបានបញ្ជាក់ថា "មេធាវីការពារក្តី ខៀវ សំផន ពុំបានជំទាស់ណាមួយឡើយរហូតទាល់តែអង្គជំនុំជម្រះបានទទួលកំណត់ហេតុកិច្ចប្រជុំចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៧" បើទោះបីជាត្រូវបានជូនដំណឹងអំពីចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលបានឯកសារនោះក៏ដោយ[702]។ គួរកត់សម្គាល់ថា ការឆ្លើយឆ្លងដែលបានយោងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការគាំទ្រការលើកឡើងនេះ ជាប់ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់អង្គជំនុំជម្រះសាលាដំបូង រកកំណត់ហេតុនេះ មិនមែនឯកសារបន្ថែមដែលមានប្រភពមកពី Christopher GOSCHA នោះទេ ពីព្រោះការឆ្លើយឆ្លងនេះបានធ្វើឡើងមុនការរកឃើញឯកសារនោះ។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា បើទោះបីជាការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអាចទាមទារឱ្យមានលក្ខណៈច្បាស់លាស់ជាងនេះក៏ដោយ ក៏ពុំមានភស្តុតាងបង្ហាញថា នេះបានធ្វើឡើងដោយចេតនាអសុទ្ធចិត្តដែរ។

---

[701] សារណារបស់ ខៀវ សំផន ស្តីពីភាពអាចទទួលយកបាន (E327/4/5) កថាខណ្ឌ ៤ ជើងទំព័រ ៥-៦ យោងទៅលើអ៊ីម៉ែលពីមេធាវីការពារក្តី Anta GUISSÉ ផ្ញើនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង ៨:៣៥ ព្រឹក ចំណងជើងថា "សំណើពីរបន្ទាប់ពីអនុស្សរណៈ E327/4/5 និងចុងក្រោយ ៨៧-៤ នៃសហព្រះរាជអាជ្ញា" និងប្រតិចារឹកសវនាការថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ សំណៅមិនទាន់កែប្រែនៅម៉ោង[១០:១០: ២២] និង [១០:៣៦:៥៧]។

[702] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ១៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៩។

ភាគីត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យ និងឆ្លើយតបទៅនឹងឯកសារនោះ។ នេះទំនងជាពុំអាចគាំទ្រការចោទប្រកាន់អំពីអសុទ្ធចិត្ត ឬភាពលម្អៀងឡើយ។

242. យោងតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានរំលោភបំពានឆន្ទានុសិទ្ធិក្នុងចំណាត់ការបន្ថែមដើម្បីទទួលបានឯកសារ GOSCHA នោះ ឡើយ។

ខ. ការជំទាស់ទៅនឹងការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសាររបស់ Christopher GOSCHA

243. នៅមុនពេលទទួលយកឯកសារ Christopher GOSCHA អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើកត្តាមួយចំនួន រួមទាំងខ្លឹមសារ ភាពត្រឹមត្រូវ និងប្រភពនៃឯកសារ និងបានយល់ឃើញថា អង្គជំនុំជម្រះបានជឿជាក់ថា ឯកសារនោះ*តាមសេចក្តីបញ្ជាក់ដំបូង*បានបំពេញតាមបទដ្ឋាននៃការជាប់ពាក់ព័ន្ធ ភាពជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃឯកសារ[703]។ អង្គជំនុំជម្រះបានធ្វើការយោងទៅលើលក្ខណៈអត្ថិភាពឯកសារសម័យនោះ ជាពិសេសប្រភពចេញពីគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ដែលអង្គជំនុំជម្រះចាត់ទុកថា "ជាភស្តុតាងសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ដោយសារមានការជាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេច និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅកម្រិតកំពូល"[704]។ បើទោះបីជាឯកសារនេះមានអត្ថិភាពនៅពេលចាប់ផ្តើមការជំនុំជម្រះ និងអាចរកបានតាមរយៈការយកចិត្តទុកដាក់សមស្របក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការទទួលយកឯកសារនេះ គឺដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងបានកត់សម្គាល់ថា៖

> បើទោះបីជាអង្គជំនុំជម្រះកំពុងខិតទៅជិតការបញ្ចប់កិច្ចដំណើរការនីតិវិធីលើភស្តុតាងក្នុងរឿងក្តីនេះក៏ដោយ ក៏ភាគីនឹងមានឱកាសយ៉ាងយូរបំផុតក្នុងការលើកនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន និងក្នុងសេចក្តីថ្លែងស្តីពីតម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅលើឯកសារចម្លងនោះដែរ[705]។

244. ខៀវ សំផន បានលើកច្រំដែលនូវសារណារបស់គាត់ស្តីពីភាពជឿទុកចិត្តបានរបស់ Christopher GOSCHA ដែលបានលើកឡើងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផ្អែកលើមូលដ្ឋានថា សារណានោះស័ក្តិសមនឹងទទួលបានការពិចារណាជិតដល់បន្ថែមទៀត ជាពិសេសលើប្រវត្តិនៃការទុកដាក់ឯកសារ និងការ

---

[703] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២០-២៧។

[704] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៧។

[705] សេចក្តីសម្រេចស្តីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៧។

ចម្លងនៃឯកសារ លទ្ធភាពនៃកំហុសក្នុងការចម្លង ភាពពុំស៊ីសង្វាក់គ្នាទាក់ទងទៅនឹងកាលបរិច្ឆេទនៃឯកសារមួយចំនួន និងកង្វះកិច្ចសហការពីរដ្ឋាភិបាលវៀតណាមជួយដល់អង្គជំនុំជម្រះសាលាដំបូង[706]។ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះបានពិចារណាលើកត្តាដែលបានលើកឡើងពីដំបូងដោយ ខៀវ សំផន និងបានយល់ឃើញថា បើទោះបីជានត្ថិភាពឯកសារដើម និងដំណើរការនៃការចម្លងឯកសារដោយដៃអាចមានផលប៉ះពាល់មួយចំនួនលើភាពជាក់លាក់ត្រឹមត្រូវក៏ដោយ ក៏កត្តាទាំងនេះពុំបានរារាំងអង្គជំនុំជម្រះក្នុងការយល់ឃើញថា ឯកសារដែលរងការជំទាស់នេះ*តាមសេចក្ដីបញ្ជាក់ដំបូង*គួរជឿទុកចិត្តបាន និងត្រឹមត្រូវដែរ[707]។ អង្គជំនុំជម្រះបានកត់សម្គាល់ជាពិសេសថា កត្តាទាំងនេះត្រូវបានពិចារណានៅក្នុងការវាយតម្លៃលើតម្លៃជាភស្តុតាងនៃឯកសារ និងថា ភាគីនឹងមានឱកាសលើកសារណាស្ដីពីទម្ងន់ដែលត្រូវផ្ដល់ទៅលើឯកសារនោះក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្ដីថ្លែងរបស់ខ្លួន[708]។

245. ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភាពអាចជឿទុកចិត្តបាននៃភស្តុតាង ខៀវ សំផន បានចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ពាក្យ"មួយចំនួន"មានឈ្មោះអ្នកបកប្រែ និងកាលបរិច្ឆេទនៃការបកប្រែនៅពេលដែលមានតែឯកសារពីរគត់ដែលមានឈ្មោះអ្នកបកប្រែ និងមានតែមួយមានការចុះកាលបរិច្ឆេទនៃការបកប្រែ[709]។ បើទោះបីនេះជាការប្រើប្រាស់គុណនាមពុំសូវសមស្របក៏ដោយ ក៏តាមធម្មតាពុំមែនជាកំហុសធ្ងន់ធ្ងរដែលតម្រូវឱ្យមានការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខដែរ។ នេះបានកើតឡើងដូចគ្នាទៅនឹងការចោទប្រកាន់របស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា Christopher GOSCHA បានធ្វើការចម្លងឯកសារ"ដើមទាំងស្រុង" បើទោះបីជាការអះអាងរបស់លោកសាស្ត្រាចារ្យថា គាត់"ស្ទើរតែ [...] បានចម្លងពេញទាំងស្រុង"[710]។ នៅពេលកំណត់ថាតើ ឯកសារនោះបានបំពេញតាមបទដ្ឋាន*សេចក្ដីបញ្ជាក់ដំបូង* អំពីភាពអាចជឿជាក់បាន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាពិសេសទៅលើដំណើរការនៃការចម្លងរបស់ Christopher GOSCHA នូវឯកសារដោយដៃ រួមទាំងផលប៉ះពាល់ណាមួយជាសក្ដានុពលលើភាពត្រឹមត្រូវនោះ[711]។

---

[706] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២១។

[707] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៦-២៧។

[708] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៧។

[709] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២២។

[710] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២២។

[711] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៦។

246. នេះទំនងជាថា ខៀវ សំផន ពុំបានអើពើទៅលើកត្តាដទៃទៀតដែលបានជះឥទ្ធិពលលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកឯកសារនោះ។ ឧទាហរណ៍ ការបញ្ជាក់អះអាងរបស់ Christopher GOSCHA ថា គាត់បានធ្វើទស្សនកិច្ចក្នុងបណ្ណាល័យកងទ័ពរបស់ប្រជាជននៅទីក្រុងហាន់ណូយ ហើយបាន"ធ្វើការចម្លងឯកសារទាំងស្រុងជាភាសាវៀតណាម" និងការអះអាងរបស់សាក្សីជំនាញ Philip SHORT ថា Christopher GOSCHA មាន"សិទ្ធិអំណាចលើបញ្ហានោះ [...]។ តាមខ្ញុំដឹង គាត់គឺជាជនបរទេសម្នាក់គត់ដែលត្រូវបានអនុញ្ញាតឱ្យធ្វើការនៅទីនោះ[ក្នុងបណ្ណាល័យកងទ័ពរបស់ប្រជាជន]"[712]។ ការពិចារណាលើកត្តាទាំងនេះបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានបានថា ឯកសារនេះគឺជា"ការបកប្រែតាមវិធីសាស្ត្រដែលត្រូវរក្សាទុកក្នុងសារមន្ទីរដែលទំនងជា ដើម្បីការពារសុចរិតភាពនៃឯកសារចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ"[713]។ គាត់ពុំបានអើពើថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកខ្លឹមសារនៃឯកសារនោះថា មានសារៈសំខាន់ និងជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងកិច្ចដំណើរការជំនុំជម្រះ ពីព្រោះឯកសារនោះមានព័ត៌មាននៅសម័យនោះទាក់ទងទៅនឹងកិច្ចការផ្ទៃក្នុងរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ព្រមទាំងមន្ទីរ ៨៧០ ដែលនេះមាន"អានុភាពលើសកម្មភាព និងការដឹងរបស់ជនជាប់ចោទក្នុងរឿងក្ដីនេះ"[714]។

247. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សារណារបស់ ខៀវ សំផន ត្រូវបានកម្រិតត្រឹមការបង្ហាញបញ្ហាដែលប៉ះពាល់ទៅលើភាពអាចជឿទុកចិត្តបាននៃឯកសារ បន្ទាប់ពីត្រូវបានដាក់បញ្ចូលរួចហើយក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកឯកសារ។ សារណានេះពុំបានអើពើថា ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងគឺជាប់ពាក់ព័ន្ធទៅនឹងឯកសារក្នុងការបញ្ជាក់ការពិត និងកត្តាដែលគាំទ្រភាពជឿទុកចិត្តបាន និងភាពត្រឹមត្រូវជាសក្ខានុពល។ អំណះអំណាងរបស់គាត់ត្រឹមតែបានផ្ដល់ការវាយតម្លៃជាជម្រើសមួយផ្សេងនៃកត្តានេះចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយគ្មានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ឬបង្កព្យសនកម្មដល់រូបគាត់ឡើយ។ ការវាយតម្លៃ និងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះបានផ្ដល់ទម្ងន់សមស្របទៅលើកត្តាទាក់ទងទៅនឹងភាពជាប់ពាក់ព័ន្ធ ភាពអាចជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃឯកសារ និងថា អង្គជំនុំជម្រះបានពន្យល់គ្រប់គ្រាន់នូវមូលដ្ឋានដែលខ្លួនបានយល់ឃើញថា ឯកសារនេះបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល

---

[712] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៥។

[713] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២៥-២៦។

[714] សេចក្ដីសម្រេចស្ដីពីឯកសារ GOSCHA (E327/4/7) កថាខណ្ឌ ២០, ២៤, ២៧។

យល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយ ឬព្យសនកម្មដែលជាផលវិបាកនោះ ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកឯកសារនោះ។

គ. ការជំទាស់ទៅនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសារ Christopher GOSCHA

248. ទាក់ទងទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុដោយសារបានសំអាងទៅលើឯកសារ Christopher GOSCHA សម្រាប់ការបញ្ជាក់បន្ថែម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងការកំណត់តម្លៃជាភស្តុតាងនៃឯកសារ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើ៖ (១) លក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង (២) កាលៈទេសៈជុំវិញការបង្កើត ឬការធ្វើកំណត់ត្រាភស្តុតាង (៣) បញ្ហាថាតើ ឯកសារដែលត្រូវបានទទួលយកនោះជាឯកសារដើម ឬឯកសារចម្លង (៤) ភាពច្បាស់លាស់អាចពិនិត្យបាននៃឯកសារ ភាពពុំស៊ីសង្វាក់ជាមួយនឹងសំណៅដទៃទៀត (៥) ថាតើ ភាគីមានឱកាសដេញដោលភស្តុតាងនោះដែរ ឬទេ និង (៦) ការបង្ហាញដទៃទៀតនៃភាពអាចជឿទុកចិត្តបាន រួមទាំងប្រវត្តិនៃការទុកដាក់ឯកសារ និងប្រភពដើម[715]។

249. ជាការឆ្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារផ្តល់តម្លៃនៃការបញ្ជាក់បន្ថែមទៅលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ បើទោះបីជាមានភាពពុំអាចជឿជាក់បានយ៉ាងណាក៏ដោយ តាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាវិជ្ជមាន និងអវិជ្ជមានទាក់ទងទៅនឹងភាពអាចជឿទុកចិត្តបាននៃឯកសារ និងថា អង្គជំនុំជម្រះបានធ្វើការប្រៀបធៀបរវាងកំណត់ហេតុមានប្រភពមកពី

---

[715] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការជំទាស់ទៅលើឯកសារដែលត្រូវបានស្នើឡើងឱ្យដាក់ចំពោះមុខអង្គជំនុំជម្រះក្នុងឧបសម្ព័ន្ធសហព្រះរាជអាជ្ញា ក១-ក៥ និងទៅនឹងឯកសារដែលត្រូវបានដកស្រង់ក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងផ្នែកនៃការជំនុំជម្រះពីរនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E185 ("សេចក្តីសម្រេចស្តីពីការជំទាស់ទៅលើឯកសារ (E185)") កថាខណ្ឌ ៣០, ៣៤ និងជើងទំព័រ ៤៩។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងភាពមិនប្រក្រតីដែលបានចោទប្រកាន់កើតមានក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ (E221, E223, E224, E224/2, E234, E234/2, E241 និង E241/1) ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E251 កថាខណ្ឌ ២៦, ២៨, ៣៦។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសារណារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងការទទួលយកចម្លើយរបស់សាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E96/7 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសារណារបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង (E96/7)") កថាខណ្ឌ ១៧, ២៥-២៩។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦, ៣២៨-៣២៩, ៣៧៥។

Christopher GOSCHA ជាមួយនឹងភស្តុតាងក្នុងសំណុំរឿងក្នុងការកំណត់របស់ខ្លួន[716]។ ក្នុងការវាយតម្លៃនោះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខ្លឹមសារមួយចំនួននៃកំណត់ហេតុនោះត្រូវបានបញ្ជាក់បន្ថែមដោយទស្សនាវដ្តីទង់បដិវត្ត និងបានយល់ឃើញថា ឯកសារទាំងពីរនេះជាក់ពាក់ព័ន្ធទៅនឹងអំឡុងពេលតែមួយ និងមានការសំដៅទៅលើការសម្លាប់ ឬការធ្វើឱ្យរបួសសត្រូវ ២៩.០០០ នាក់[717]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបាន“បញ្ជាក់”ភាពត្រឹមត្រូវនៃឯកសារនេះដោយផ្អែកលើភាពស៊ីសង្វាក់គ្នានៃតួលេខតែមួយគត់នោះ អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានសន្និដ្ឋានថា ភាពស៊ីសង្វាក់គ្នានៃតួលេខប្រើប្រាស់ដើម្បី“គាំទ្របន្ថែម”ការយល់ឃើញនៃភាពត្រឹមត្រូវនោះព្រមទាំងការកំណត់សម្គាល់លើអំឡុងពេលដូចគ្នានៃឯកសារទាំងពីរនេះ[718]។

250. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបាន“ព្យាយាមយោងឆ្លងទៅលើ”ឯកសារមួយនៃឯកសារ Christopher GOSCHA លេខE3/10693 ដើម្បីបញ្ជាក់បន្ថែមលើឯកសារលេខ E3/7328 នៅក្នុងសំណុំរឿងដទៃទៀត[719] ការប្រៀបធៀបឯកសារពីរបានបង្ហាញថា ឯកសារលេខ E3/10693 ជាការបកប្រែរបស់ Christopher GOSCHA នៃកំណត់ហេតុក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី ១០, ១១ និង ១៣ ខែ មេសា ឆ្នាំ ១៩៧៧ ខណៈពេល ឯកសារលេខ E3/7328 ដែលត្រូវបានប្រើប្រាស់ពីមុននៅក្នុងការជំនុំជម្រះរបស់តុលាការប្រជាជនបដិវត្តន៍ក្នុងឆ្នាំ ១៩៨០ [720] មានសេចក្តីដកស្រង់ចេញពីកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៧។ បើទោះបីជាពុំមានលក្ខណៈដូចទាំងស្រុងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា តាមការប្រៀបធៀបរវាងឯកសារទាំងពីរឃើញថា មានអត្ថិភាពកម្មវត្ថុនៃការពិភាក្សាដូចគ្នា អ្នកចូលរួមជាច្រើនដូចគ្នានៃកិច្ចប្រជុំនោះ និងការអនុម័តសេចក្តីសម្រេចលើខ្លឹមសារពាក់ព័ន្ធទៅនឹង“សត្រូវផ្ទៃក្នុង”[721]។ ក្នុងការបំភ្លឺការសំដៅទៅលើ“ខ្លឹមសារនៃសេចក្តីសម្រេច”ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញមានអត្ថិភាពក្នុងឯកសារទាំងពីរ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ក្នុងជើងទំព័រមួយដែលមានការដកស្រង់ឯកសារទាំងពីរសម្រាប់ធ្វើការប្រៀបធៀបដូចខាងក្រោម៖

---

[716] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២-៣៥៤។

[717] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

[718] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

[719] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៥។

[720] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

[721] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២។

- ឯកសារលេខ E3/10693៖ "ការបន្តប្រយុទ្ធប្រឆាំងនឹងពួកប្រតិកិរិយា និងស្វែងរកពួកប្រតិកិរិយានៅក្នុងនាយកដ្ឋានរបស់យើង និងតាមមូលដ្ឋាន ដើម្បីលើកកម្ពស់ និងជំរុញបេសកកម្មក្នុងឆ្នាំ ១៩៧៧"[722]។

- E3/7328: "គ្រប់អង្គភាព សេវាកម្ម និងក្រសួងទាំងអស់គប្បីមានគំនិតផ្តួចផ្តើមនៅក្នុងអង្គភាពរបស់ខ្លួនក្នុងការបន្តបោសសម្អាត និងកម្ចាត់ចោលអ្នកប្រឆាំង ហើយទន្ទឹមគ្នានេះដែរ ត្រូវអនុវត្តសកម្មភាពជាធម្មតា"[723]។

បន្ទាប់ពីបានពិនិត្យឯកសារនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការដកស្រង់ចេញពីឯកសារ E3/10693 គឺជាការដកស្រង់ចេញពីកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៧[724] មិនមែនថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៧[725]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំហុសតូចតាចនេះពុំមានអានុភាពទៅលើការបកស្រាយនៃសេចក្តីសម្រេចពាក់ព័ន្ធទៅនឹង"សត្រូវផ្ទៃក្នុង" និងថា នេះជាកត្តាតែមួយក្នុងចំណោមជាច្រើនដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការវាយតម្លៃរបស់ខ្លួន[726]។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសអង្គច្បាប់ដែលតម្រូវឱ្យមានការអន្តរាគមន៍លើបណ្តឹងសាទុក្ខនៅក្នុងវិធីសាស្ត្រនៃការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពគួរឱ្យជឿទុកចិត្តបាននៃឯកសារ និងតម្លៃជាភស្តុតាងនោះ។

251. បើទោះបីជា ខៀវ សំផន បានរៀបរាប់ការយល់ឃើញផ្សេងៗដែលត្រូវបានបដិសេធដោយសារលទ្ធផលនៃកំហុសអង្គច្បាប់ក្នុងជើងទំព័រក៏ដោយ ក៏គាត់ខកខានក្នុងការពន្យល់នូវមូលហេតុដូចម្តេចបានជាការប្រើប្រាស់ឯកសារសម្រាប់គោលបំណងបញ្ជាក់អះអាងបន្ថែមនោះ ធ្វើឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈឡើយ[727]។ ខៀវ សំផន បានរៀបរាប់លម្អិតពីរចំណុចក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយោងទៅលើកំណត់ហេតុដែលត្រូវបានចម្លងដោយសារ Christopher GOSCHA ដែលពាក់ព័ន្ធទៅនឹងកិច្ចប្រជុំពិភាក្សាអំពីការតាមរក និងការប្រព្រឹត្តលើបណ្តាញ

---

[722] សាលក្រមអង្គជំនុំជម្រះសាលាដំបូង និងជើងទំព័រ ៩៨៣។

[723] សាលក្រមអង្គជំនុំជម្រះសាលាដំបូង និងជើងទំព័រ ៩៨៣។

[724] *សូមមើល* កំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំលេខា និងអនុលេខកងពល និងកងវរសេនាធំ (ចម្លងដោយ C.E. Goscha) ឯកសារលេខ E3/10693 ចុះថ្ងៃទី១០, ១១, ១៣ ខែ មេសា ឆ្នាំ ១៩៧៧ ទំព័រ ៤-៦ ERN 01338228-01338230 ។

[725] *សូមមើល* កំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ (E3/10693) ទំព័រ ៥។

[726] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២-៣៥៤។

[727] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៥។

គិញ និងខ្លាំង[728]។ នៅក្នុងការស្នើសុំឱ្យដកខ្លឹមសារនៃកំណត់ហេតុទាំងនេះចេញ ខៀវ សំផន បានលើកច្រំដែលនូវការតវ៉ាពីដំបូងរបស់គាត់អំពីលក្ខខណ្ឌដែលកំណត់ហេតុនេះត្រូវបានចម្លង និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និង"មានកំហុសក្នុងការប្រើប្រាស់ខ្លឹមសារនោះ"[729]។ លើសពីនេះ គាត់ខកខានក្នុងការលើកមូលដ្ឋានគាំទ្រ ឬពន្យល់ថា ការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសារនេះនៅក្នុងការយល់ឃើញផ្នែកអង្គហេតុ ពុំមានតុលាការអង្គហេតុសមហេតុផលអាចធ្វើទៅបាន។ តាមការពិនិត្យលើចំណុចពីរនេះបង្ហាញថា ក្នុងករណីនីមួយៗដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើឯកសារ GOSCHA អង្គជំនុំជម្រះសាលាដំបូងបានកម្រិតជាក់ច្បាស់នូវការប្រើប្រាស់របស់ខ្លួននៃឯកសារ GOSCHA ត្រឹម"កម្មវត្ថុ បរិបទ និងគោលបំណងទូទៅ ដោយពុំបានផ្តល់ទម្ងន់ឥតសមស្របចំពោះអត្ថន័យនៃពាក្យ ឬឃ្លាជាក់លាក់នោះឡើយ"[730]។ វិធីសាស្ត្រនេះស្របជាមួយនឹងការប្រើប្រាស់ឯកសារសម្រាប់ការបញ្ជាក់បន្ថែម។

252. យោងតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ណាមួយពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក និងប្រើប្រាស់ឯកសារ GOSCHA។

## ៥. ការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១

253. Walter HEYNOWSKI បានបង្កើតខ្សែភាពយន្តឯកសារ *Die Angkar* ដែលគាត់បានបង្ហាញឯកសារដើមដែលរកឃើញក្នុងមន្ទីរសន្តិសុខស-២១ ក្នុងឆ្នាំ ១៩៧៩ រួមទាំងកូនសៀវភៅពណ៌ទឹកក្រូច ដែលមានកំណត់ហេតុអ្នកជាប់ឃុំ *ហៅថា* ("សៀវភៅកំណត់ហេតុមន្ទីរស-២១")[731]។ ជំនួសឱ្យការស្តាប់សក្ខីកម្មរបស់ Walter HEYNOWSKI ក្រោយពីមេធាវីការពារក្តី នួន ជា បានស្នើសុំនោះ អង្គជំនុំជម្រះសាលាដំបូងបានស្វែងរកព័ត៌មានពីលោកសាស្ត្រាចារ្យពាក់ព័ន្ធនឹងការយល់ដឹងរបស់គាត់អំពីឯកសារដើមដែលបានបង្ហាញក្នុង

---

[728] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨០៥, ៣៨១៤។

[729] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៦៣។

[730] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨០៥, ៣៨១៤។

[731] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើង "ឯកសារទទួលបានពី Walter Heynowski" ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E443/2 ("ឯកសារ Walter HEYNOWSKI (E443/2 )") កថាខណ្ឌ ១។ សំណើទីបួនរបស់ នួន ជា សម្រាប់ផ្នែកស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុងនៃសំណុំរឿង ០០២/០២ (ប្រតិបត្តិការមន្ទីរស-២១ និងភស្តុតាងជាឯកសារ) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E412 ("សំណើរបស់ នួន ជា សុំកោះហៅសាក្សី (E412)") កថាខណ្ឌ ៣១-៣២។

ភាពយន្ត *Die Angkar*[732]។ អង្គជំនុំជម្រះសាលាដំបូងបន្ទាប់មកបានទទួលសៀវភៅកំណត់ហេតុមន្ទីរស-២១ ពី Walter HEYNOWSKI[733]។ ក្រោយមកអង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគីពិនិត្យឯកសារនេះ និងផ្តល់យោបល់ស្តីពីភាពអាចទទួលយកបាន[734]។ ក្នុងអំឡុងពេលសវនាការ ខៀវ សំផន បានលើកឡើងថា ប្រសិនបើសៀវភៅកំណត់ហេតុមន្ទីរស-២១ ត្រូវបានទទួលយក អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែកោះហៅឡើងវិញ សួស ធី និង ឌុច ប៉ុណ្ណោះទេ ថែមទាំង Walter HEYNOWSKI និងសួរគាត់អំពីប្រវត្តិនៃការទុកដាក់ឯកសារ និងចំណារលើឯកសារនោះ[735]។ ខៀវ សំផន បានជំទាស់ផងដែរលើតម្លៃជាភស្តុតាងនៃសៀវភៅកំណត់ហេតុមន្ទីរស-២១ នេះ និងបានអះអាងថា ឯកសារមួយដែលបានលើកឡើងពីមុននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមានព័ត៌មានដែលខុសពីសៀវភៅកំណត់ហេតុមន្ទីរស-២១[736]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ខៀវ សំផន ក្នុងការកោះហៅ សួស ធី និង ឌុច ពីព្រោះបានអ្នកទាំងពីបានផ្តល់សក្ខីកម្មស្តីពីសៀវភៅកំណត់ហេតុមន្ទីរស-២១ ក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ តាមរយៈការបង្ហាញនូវសេចក្តីដកស្រង់នៃខ្សែភាពយន្ត *Die Angkar* ហើយភាគីមានឱកាសសួរសំណួរសាក្សីទាំងនេះលើខ្លឹមសារក្នុងទំព័រជាច្រើនស្រដៀងគ្នា[737]។ បើទោះបីជា Walter HEYNOWSKI បានបង្ហាញនូវឆន្ទៈមកផ្តល់សក្ខីកម្មក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពុំស្តាប់សក្ខីកម្មរបស់គាត់ដោយសារ“ការលំបាកខាងបច្ចេកទេសមួយចំនួន និងការចំណាយពេលផ្នែកនីតិវិធីនៅក្នុងកិច្ចសហប្រតិបត្តិការតាមផ្លូវតុលាការ”[738]។ សៀវភៅកំណត់ហេតុមន្ទីរស-២១ ត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូងពីព្រោះមានការ“ជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្មក្នុងវិសាលភាពនៃការជំនុំជម្រះបច្ចុប្ប

---

[732] សំណើរបស់ នួន ជា សុំកោះហៅសាក្សី (E412) កថាខណ្ឌ ៣១-៣២។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សាក្សីបន្ថែមអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E391, E392, E395, E412, និង E426) ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E443 (“សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា (E443)”) កថាខណ្ឌ ១។

[733] ឯកសារ Walter HEYNOWSKI (E443/2 ) កថាខណ្ឌ ៦។

[734] ឯកសារ Walter HEYNOWSKI (E443/2 ) កថាខណ្ឌ ៩។

[735] ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E1/510.1 ទំព័រ ១២។

[736] ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E1/510.1 ទំព័រ ១១។

[737] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកសៀវភៅកំណត់ហេតុ និងកោះហៅសាក្សីពីរនាក់ឡើងវិញពាក់ព័ន្ធនឹងមន្ទីរស-២១ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E443/3 (“សេចក្តីសម្រេចស្តីពីសៀវភៅកំណត់ហេតុមន្ទីរស-២១ (E443/3)”) កថាខណ្ឌ ៣-៤។

[738] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា “ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនស្តាប់សាក្សី 2-TCE-946 (Walter Heynowski)” ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E443/7 កថាខណ្ឌ ៤។

ន្ទ” និង“*តាមសេចក្តីបញ្ជាក់ដំបូង* មានការជាប់ពាក់ព័ន្ធ និងភាពគួរជឿទុកចិត្តបាន (រួមទាំងភាពត្រឹមត្រូវ)”[739]។

254. នៅបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើសារណារបស់គាត់ស្តីពីកំហុសនៅក្នុងការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១ និងតម្លៃជាភស្តុតាងទាបនៃសៀវភៅនេះ[740]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១ នៅចុងបញ្ចប់នៃការជំនុំជម្រះដោយគ្មានការកោះហៅឡើងវិញ សួស ធី និង កាំង ហ្កេចអ៊ាវ *ហៅ*ឌុច និងការកោះហៅ Walter HEYNOWSKI និងថា ការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១ បានបង្ហាញនូវការលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង បើទោះបីជាការពិតថា ភាពត្រឹមត្រូវ និងភាពគួរជឿទុកចិត្តបានពុំអាចត្រូវបានផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយនោះ[741]។ គាត់បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកទៅលើសៀវភៅបញ្ជីឈ្មោះ មន្ទីរស-២១ ត្រូវចាត់ទុកជាមោឃៈ និងបដិសេធចោល[742]។

255. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១ និងការបដិសេធមិនកោះហៅសាក្សីដែលបានស្នើឡើងទាំងនេះ[743]។

256. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ពុំមានភាពចាំបាច់ក្នុងការកោះហៅ សួស ធី ពីព្រោះ ខៀវ សំផន មានឱកាសសួរគាត់“ទាក់ទងទៅនឹងខ្លឹមសារនៃទំព័រជាច្រើនស្រដៀងគ្នា”ដែលមានអត្ថិភាពនៅពេលផ្តល់សក្ខីកម្មរបស់គាត់[744]។ ទាក់ទងទៅនឹងអំណះអំណាងរបស់គាត់ដែលថា ទំព័របញ្ជីឈ្មោះនេះ ពុំអាចប្រៀប

---

[739] សេចក្តីសម្រេចស្តីពីសៀវភៅកំណត់ហេតុមន្ទីរស-២១ (E443/3) កថាខណ្ឌ ៣-៤។ របាយការណ៍ប្រចាំថ្ងៃនៃបញ្ជីឈ្មោះអ្នកជាប់ឃុំមន្ទីរស-២១ ឯកសារលេខ E3/10770។

[740] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៦។

[741] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៦, ២២៦។ ឧបសម្ព័ន្ធ ក ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1) ទំព័រ ៩។

[742] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៦។ ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1) ទំព័រ ៩។

[743] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៩៤, ២០១-២០២។

[744] សេចក្តីសម្រេចស្តីពីសៀវភៅកំណត់ហេតុមន្ទីរស-២១ (E443/3) កថាខណ្ឌ ៤។

ធៀបនឹងចំនួន ២៥០ ទំព័រនៃសៀវភៅកំណត់ហេតុមន្ទីរស-២១ ដែលគាត់គ្មានឱកាសសួរសំណួរ សួស ធី[745] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំបានជំទាស់ទៅនឹង សួស ធី ទាក់ទងទៅនឹងសៀវភៅកំណត់ហេតុមន្ទីរស-២១ នៅពេលសួរដេញដោលនោះឡើយ[746]។ បន្ថែមលើនេះ ខៀវ សំផន ពុំបានជំទាស់ថា សួស ធី បានរក្សាទុកសៀវភៅកំណត់ហេតុមន្ទីរស-២១ ក្នុងអំឡុងពេលដែលគាត់ធ្វើការនៅមន្ទីរស-២១[747]។ ខៀវ សំផន ខកខានក្នុងការបង្ហាញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះហៅ សួស ធី សាឡើងវិញ គឺជាកំហុសអង្គច្បាប់ដែលធ្វើឱ្យការយល់ឃើញគ្មានសុពលភាពឡើយ។

257. ដូចគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះ ហ្កេចអ៊ាវ *ហៅ* ឌុច និងថា នេះជាការពុំចាំបាច់ដោយសារគាត់បានផ្តល់សក្ខីកម្មថា គាត់“ពុំដែលឃើញសៀវភៅប្រភេទនោះ” និងពុំស្គាល់នោះឡើយ[748]។

258. ក្នុងករណី Walter HEYNOWSKI អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែបានទទួលព័ត៌មានពីគាត់ជំនួសឱ្យការស្តាប់សក្ខីកម្មផ្ទាល់របស់គាត់ប៉ុណ្ណោះទេ ថែមទាំងបានទទួលការបញ្ជាក់ពីគាត់ថា គាត់មានឆន្ទៈមកផ្តល់សក្ខីកម្ម[749]។ គួររំឭកថា សវនាការនៅពេលនោះត្រូវបានបញ្ចប់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កិច្ចដំណើរនីតិវិធីពុំអាចត្រូវបានបើកសាឡើងវិញដើម្បីស្តាប់ Walter HEYNOWSKI ដោយសារការលំបាកផ្នែកបច្ចេកទេសពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មតាមរយៈវីដេអូឆ្លើយឆ្លង និងភាពចាំបាច់ក្នុងការធានាបាននូវការពន្លឿនកិច្ចដំណើរការនីតិវិធី និងដូច្នេះ បានសម្រេចមិនកោះហៅគាត់[750]។

[745] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១១៨៩-១១៩១។

[746] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ (សួស ធី) ឯកសារលេខ E1/432.1 ទំព័រ ៦០។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ (សួស ធី) ឯកសារលេខ E1/433.1 ទំព័រ ១៣-៣០។

[747] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១១៨៩។

[748] សេចក្តីសម្រេចស្តីពីសៀវភៅកំណត់ហេតុមន្ទីរស-២១ (E443/3) កថាខណ្ឌ ៤។ ប្រតិចារឹកចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/438.1 ទំព័រ ៦១-៦២។

[749] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា (E443) កថាខណ្ឌ ១។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា “ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនស្តាប់សាក្សី 2-TCE-946 (Walter Heynowski)” ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E443/7 កថាខណ្ឌ ៤។

[750] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា “ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនស្តាប់សាក្សី 2-TCE-946 (Walter Heynowski)” ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E443/7 កថាខណ្ឌ ៣-៤។

259. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា៖ (១) អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិពាក់ព័ន្ធទៅនឹងបញ្ហាផ្នែកនីតិវិធី[751] (២) មានការកម្រិតសិទ្ធិក្នុងការសួរដេញដោលសាក្សី[752] ហើយ (៣) ខៀវ សំផន ពុំអាចលើកសាជាថ្មីនូវអំណះអំណាងពេលជំនុំជម្រះ ឬលើកការតវ៉ានានាលើកលែងតែគាត់អាចបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើអំណះអំណាងរបស់គាត់គឺជាកំហុសដែលតម្រូវឱ្យមានការចូលអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង គឺស្ថិតក្នុងវិសាលភាពនៃសិទ្ធិអំណាចជាឆន្ទានុសិទ្ធិក្នុងការទទួលយកសៀវភៅកំណត់ហេតុមន្ទីរស-២១ ដោយពុំចាំបាច់កោះហៅ សួស ធី និង ហ្កេចអ៊ាវ *ហៅ* ឌុច សាឡើងវិញ និងការកោះហៅ Walter HEYNOWSKI។

260. ពាក់ព័ន្ធទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបាន“សំអាងយ៉ាងខ្លាំង” ទៅលើសៀវភៅកំណត់ហេតុមន្ទីរស-២១ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការផ្តល់មូលដ្ឋានគាំទ្រអំណះអំណាងរបស់គាត់ដែលថា មានអត្ថិភាពនៃកំហុសនោះ និងដូច្នេះ ខកខានក្នុងការបំពេញតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ។ ជាការពុំគ្រប់គ្រាន់ដោយត្រឹមតែចង្អុលបង្ហាញទៅលើចំណុចនៅក្នុងសាលក្រមដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសៀវភៅកំណត់ហេតុមន្ទីរស-២១ ដោយគ្មានការបង្ហាញថាតើបានធ្វើឱ្យសាលក្រមទៅជាមោឃៈទាំងស្រុង ឬក្នុងផ្នែកខ្លះដូចម្តេចនោះ[753]។ នៅគ្រប់កាលៈទេសៈ តាមការពិនិត្យលើសាលក្រមបង្ហាញថា លើកលែងចំណុចមួយដែល ខៀវ សំផន បានយោងទៅលើនោះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមផ្អែកតែមួយមុខទៅលើសៀវភៅកំណត់ហេតុមន្ទីរស-២១ នោះទេ ថែមទាំងលើភស្តុតាងដទៃទៀត រួមទាំងបញ្ជីឈ្មោះគ្រប់គ្រងអ្នកជាប់ឃុំដែលស្រដៀងទៅនឹងបញ្ជីឈ្មោះសៀវភៅកំណត់ហេតុមន្ទីរស-២១[754]។ មានករណីលើកលែងតែមួយគត់ដែលជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញដែលថា “ក្នុងខែ ឧសភា និងខែ មិថុនា នៅមន្ទីរស-២១ បានបង្ហាញនូវការកើនឡើងនៃការកម្ទេចអ្នកជាប់ឃុំ និងការដកចេញពីក្រសួងរបស់រដ្ឋនៃក្រសួងពាណិជ្ជ

---

[751] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៧៥។

[752] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៨៦-២៨៧។

[753] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៩, ១៤៦៧, ២១១៥-២១១៦, ២១២២-២១២៣, ២២៨៩, ២២៩៦-២២៩៧, ២២៩៩, ២៣៦៩, ២៣៩៧, ២៤៣៦, ២៤៤៣, ២៥០៥, ២៥៤៩-២៥៥១, ២៨៨៦, ៣០៥៤, ៣០៥៨។

[754] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៩, ១៤៦៧, ២១១៤-២១១៦, ២១២២-២១២៣, ២២៨៩, ២២៩៦-២២៩៧, ២៤៣៦, ២៤៤៣, ២៥០៥, ២៥៤៩-២៥៥១, ២៨៨៦, ៣០៥៤, ៣០៥៨។

កម្ម"ដែល ខៀវ សំផន ពុំបានសួរដេញដោល និងដូច្នេះ ពុំគ្រប់គ្រាន់ក្នុងការមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានឡើយ[755]។

261. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាជាច្រើនទាក់ទងទៅនឹងភាពគួរឱ្យជឿទុកចិត្តបាននៃសៀវភៅតំណត់ហេតុមន្ទីរស-២១ រួមទាំងការបញ្ជាក់ត្រឹមត្រូវដោយ សួស ធី ដែលបានផ្តល់សក្ខីកម្មថា គាត់ធ្លាប់មានសៀវភៅនោះក្នុងដៃ និងបានគ្រប់គ្រង និងប្រើប្រាស់ដើម្បីបូកសរុបចំនួនអ្នកជាប់ឃុំប្រចាំថ្ងៃនៅមន្ទីរស-២១, ការបញ្ជាក់អះអាងរបស់ Walter HEYNOWSKI ដែលថា គាត់បានយកសៀវភៅនេះចេញពីមន្ទីរស-២១, សក្ខីកម្មរបស់ សួស ធី និង ហ៊ុចអ៊ាវ *ហៅ*ឌុច ស្តីពីទិដ្ឋភាពផ្សេងៗ រួមទាំងបញ្ជីឈ្មោះគ្រប់គ្រងប្រចាំថ្ងៃដែលត្រូវបានរក្សាទុកក្នុងមន្ទីរស-២១, ភាពស៊ីសង្វាក់គ្នានៃខ្លឹមសារ និងទម្រង់ជាមួយនឹងបញ្ជីឈ្មោះដទៃទៀតក្នុងសំណុំរឿង រួមទាំងលក្ខណៈដូចគ្នាបេះបិទនៃបញ្ជីឈ្មោះគ្រប់គ្រងប្រចាំថ្ងៃដែលបំពេញការខ្វះចន្លោះនៃពេលវេលានៅដើម និងចុងឆ្នាំ ១៩៧៧ និងថា ភាគីមានឱកាសសួរសំណួរសាក្សីទាក់ទងទៅនឹងខ្លឹមសារនៃទំព័រប្រហាក់ប្រហែលគ្នាជាច្រើនដែលខ្លួនមាននៅពេលផ្តល់សក្ខីកម្មរបស់គាត់នោះ[756]។ ខៀវ សំផន ពុំបានបង្កើតអំណះអំណាងថ្មីណាមួយដែលគាំទ្រការអះអាងរបស់គាត់ដែលថាសៀវភៅកំណត់ហេតុមន្ទីរស-២១ មាន"តម្លៃជាភស្តុតាងទាប"ដែលនេះតម្រូវឱ្យមានការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលឡើយ។

262. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទទួលយក និងសំអាងទៅលើសៀវភៅកំណត់ហេតុមន្ទីរស-២១។

### ៦. ការខកខានក្នុងការកោះឡើងវិញ Stephen HEDER, François PONCHAUD និង Philip SHORT

263. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិពុំត្រឹមត្រូវតាមរយៈការបដិសេធមិនកោះហៅ Stephen HEDER, François PONCHAUD និង Philip SHORT មកផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/0២ បើទោះបីពួកគាត់បានផ្តល់សក្ខីកម្មក្នុងការជំនុំជម្រះសំណុំ

[755] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៩៧។

[756] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១១៥-២១១៩, ២១២៣។ សេចក្តីសម្រេចស្តីពីសៀវភៅកំណត់ត្រាមន្ទីរស-២១ ឯកសារលេខ E443/3។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង "ឯកសារទទួលបានពីសាស្ត្រាចារ្យ Walter HEYNOWSKI" ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ E443/2។

រឿង ០០២/០១[757]។ គាត់បានលើកឡើងថា កំហុសនេះបានកើតឡើងតាមរយៈការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តន៍“បទដ្ឋានដូចគ្នាស្តីពីភាពជាប់ពាក់ព័ន្ធ” លើសំណើរបស់គាត់សុំការចូលបង្ហាញខ្លួនបុគ្គលទាំងនេះ បើប្រៀបជាមួយសាក្សីដែលបានស្នើឡើងដោយភាគីដទៃទៀត[758]។ គាត់បានលើកឡើងថា ការសួរដេញដោលឡើងវិញលើអ្នកជំនាញសាក្សីនេះ មានសារៈសំខាន់ជាគន្លឹះដល់រឿងក្តីរបស់គាត់ និងបានជំទាស់ទៅនឹងមូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការបដិសេធចោលដោយសារ“ជាការពុំត្រឹមត្រូវ”។ គាត់បានលើកឡើងថា កំហុសនេះបានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសមភាពកម្លាំងតទល់ផ្លូវច្បាប់ ការដេញដោលចំពោះមុខ សេចក្តីសម្រេចមានសំអាងហេតុ ការត្រូវបានស្តាប់ដោយតុលាការ តុលាការព្រហ្មទណ្ឌឥតលម្អៀង និងការជំនុំជម្រះដោយឥតពន្យារពេល[759]។

264. ខៀវ សំផន បានជំទាស់ទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចបដិសេធការកោះហៅសាក្សីទាំងនេះ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពីព្រោះពួកគេបានចូលបង្ហាញខ្លួនពីមុនរួចហើយក្នុងសំណុំរឿង ០០២/០១ សក្ខីកម្មរបស់ពួកគេសំណុំរឿង ០០២/០២ នឹងមានលក្ខណៈច្រំដែល និងបង្កការពន្យារពេលឥតសមស្របក្នុងកិច្ចដំណើរការនីតិវិធី[760]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង“ពុំបានអើពើទាំងស្រុង”ចំពោះការដែលគាត់ពុំអាចសួរដេញដោលសាក្សីទាំងនេះក្នុងសំណុំរឿង ០០២/០១ លើបញ្ហាក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយបានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការដេញដោលចំពោះមុខ[761]។ ខៀវ សំផន បានបញ្ជាក់ថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅ Stephen HEDER និង François PONCHAUD ពុំត្រូវបានធ្វើ“យុត្តិកម្មសមស្រប”ត្រង់ថា អង្គជំនុំជម្រះធ្លាប់សម្រេចផ្អែកតាម*គាមគំនិតផ្តួចផ្តើម*របស់ខ្លួនក្នុងការកោះហៅសាក្សីឡើងវិញដែលបានស្តាប់ក្នុងសំណុំរឿង ០០២/០១ មានដូចជា ផន វ៉ាន់ និង សៅ សារុន “បើទោះបីជាសៅ សារុន ស្ថិតក្នុងចំណោមមនុស្សតិចតួចដែលត្រូវបានស្តាប់សំណុំរឿង ០០២/០១”លើបញ្ហាទាំងអស់ក្នុង

---

[757] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៦-១៧២។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

[758] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១-១៧២ ជើងទំព័រ ៨០៥។

[759] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤។

[760] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៦-១៦៧។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

[761] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៨។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

វិសាលភាពសំណុំរឿង ០០២ ក៏ដោយ[762]។ គាត់បានលើកឡើងថា "នេះបង្ហាញឱ្យឃើញច្បាស់លាស់អំពីភាពលម្អៀងរបស់អង្គជំនុំជម្រះ" ជាពិសេសដោយសារអង្គជំនុំជម្រះសាលាដំបូង"បានរំពឹងថា សៅ សារុន [...] នឹងមានភស្តុតាងដាក់បន្ទុកពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍"[763]។

265. ខៀវ សំផន បានលើកឡើងថា Stephen HEDER និង François PONCHAUD "ដែលមានបទពិសោធន៍មិនត្រឹមតែនៅក្នុងកម្ពុជាប៉ុណ្ណោះទេ ថែមទាំងក្នុងករណី [Stephen HEDER] លើដំណើរការនីតិវិធី អ.វ.ត.ក. អាចនឹងមានអត្ថប្រយោជន៍ខ្ពស់ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាជនជាតិចាម"[764] និងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើចម្លើយរបស់ពួកគាត់បើទោះបីជាការពិតថា គាត់ពុំមានឱកាសសួរសំណួរលើបញ្ហានេះក៏ដោយ[765]។ គាត់បានអះអាងថា Stephen HEDER និង François PONCHAUD "មានចំណុចជាច្រើនត្រូវប្រាប់អំពីគោលការណ៍សីលធម៌ពាក់ព័ន្ធទៅនឹងគោលនយោបាយរៀបអាពាហ៍ពិពាហ៍" និងពាក់ព័ន្ធសហករណ៍ និង"វិធីសាស្ត្រក្នុងការបង្កបង្កើតផលស្រូវ"[766]។ ទាក់ទងទៅនឹង Philip SHORT ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនកោះហៅគាត់សាឡើងវិញដោយផ្អែកលើមូលដ្ឋានថា សំណួរជាច្រើនត្រូវបានអនុញ្ញាតឱ្យសួរយ៉ាងទូលំទូលាយក្នុងសំណុំរឿង ០០២/០១។ ទោះជាយ៉ាងណាក្តី ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានអនុវត្តផ្ទុយខ្លួនឯងលើការអនុញ្ញាតឱ្យភាគីផ្សេងៗសួរសំណួរ Philip SHORT ក្រៅវិសាលភាពបញ្ហាពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ថា ដើម្បីធានានូវការពន្លឿនកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះ[767] ប៉ុន្តែបានបដិសេធការទទួលយកភស្តុតាងពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ទាក់ទងទៅនឹងការចូលមកបង្ហាញខ្លួនរបស់ Philip SHORT ដោយផ្អែកលើមូលដ្ឋានថា អំពើប្រល័យពូជសាសន៍ពុំមែនជាផ្នែកនៃបទចោទដែលអង្គជំនុំជម្រះត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ នោះទេ[768]។

[762] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១-៣២។

[763] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣២។

[764] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣២។

[765] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣២។

[766] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣២។

[767] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០ និងជើងទំព័រ ១៩៥។

[768] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០។

266. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបដិសេធការកោះហៅសាក្សីទាំងនេះ[769]។

267. ពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងលើប្រធានបទដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ និង ០០២/០២ រួមទាំងរចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនង និងយោធា សាវតារប្រវត្តិ គោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម និងតួនាទី និងអត្តចរិតរបស់ជនជាប់ចោទ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ដោយសារវិសាលភាពមានកម្រិតនៃសំណុំរឿង ០០២/០១ "បញ្ហាមួយចំនួននេះពុំអាចត្រូវបានពិនិត្យដោយពេញលេញ"[770] និងបានពិចារណាទាក់ទងទៅនឹងការកោះហៅឡើងវិញនូវសាក្សីសក្តានុពលក្នុងសំណុំរឿង ០០២/០២ ឃើញថា៖

> វិធានផ្ទៃក្នុងបានបង្ហាញរួចរាល់នូវក្របខ័ណ្ឌគតិយុត្តសម្រាប់ការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ជាពិសេសវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះនឹងត្រូវពិចារណាលើបញ្ហាថាតើ *ភាគីត្រូវបានរារាំង ឬពុំមានឱកាសសួរដេញដោលពេញលេញបុគ្គលដែលភាគីមានបំណងចង់កោះហៅឡើងវិញក្នុងតុលាការដោយសារវិសាលភាពមានកម្រិតនៃសំណុំរឿង ០០២/០១ ដែរ ឬយ៉ាងណា*៖ អង្គជំនុំជម្រះសាលាដំបូងបានរំឮកភាគីថា អង្គជំនុំជម្រះអាចបដិសេធសំណើសុំភស្តុតាងដែលខ្លួនយល់ឃើញថា មិនជាប់ពាក់ព័ន្ធ ឬច្រំដែលស្របតាមវិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង[771]។

268. អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយសារណារបស់ ខៀវ សំផន ដើម្បីកំណត់ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដោយសម្រេចសំណើសុំកោះហៅ (ក) Stephen HEDER, François PONCHAUD និង (ខ) Philip SHORT ដែរ ឬយ៉ាងណា។ សម្រាប់គោលបំណងនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា Stephen HEDER ត្រូវបានចាត់ទុកថាជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលនាំមុខគេដែលមានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ការវិវឌ្ឍន៍ និងរចនាសម្ព័ន្ធរដ្ឋអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បាននិពន្ធសៀវភៅ អត្ថបទសិក្សា និងកិច្ចការស្រាវជ្រាវជាច្រើនស្តីពីខ្មែរក្រហម និងបានធ្វើកិច្ចសម្ភាសន៍ជាមួយកម្មាភិបាល និងមេ

---

[769] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦០-៦១។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៥៣-៥៤។

[770] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៤២។

[771] អនុស្សរណៈបំភ្លឺអង្គជំនុំជម្រះសាលាដំបូង (E302/5) កថាខណ្ឌ ៨។

ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាច្រើន រួមទាំង ខៀវ សំផន ផងដែរ។ François PONCHAUD បានរស់នៅក្នុងកម្ពុជាចាប់តាំងពីឆ្នាំ ១៩៦៥ និងស្ថិតក្នុងចំណោមជនបរទេសចុងក្រោយដែលបានចាកចេញពីប្រទេសកម្ពុជានៅប៉ុន្មានសប្តាហ៍ក្រោយពេលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ។ គាត់បានរក្សាទុកឯកសារផ្សព្វផ្សាយជាច្រើនពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងសំណុំរឿង ០០២/០១ គាត់បានផ្តល់សក្ខីកម្មថាបានឃើញព្រឹត្តិការណ៍ពាក់ព័ន្ធនៅពេលចាប់ផ្តើម និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីការចាកចេញរបស់គាត់ពីប្រទេសកម្ពុជានៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៥ គាត់បានសម្ភាសន៍ជនភៀសខ្លួនក្នុងប្រទេសថៃ និងប្រទេសបារាំង និងបានតាមដានការវិវឌ្ឍន៍ស្ថានការណ៍តាមរយៈការស្តាប់ព័ត៌មានផ្សព្វផ្សាយតាមរយៈវិទ្យុខ្មែរក្រហម[772]។ ក្នុងនាមជាអ្នកសារព័ត៌មាន និងអ្នកនិពន្ធ Philip SHORT បានធ្វើបទសម្ភាសន៍ជាមួយមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំង ខៀវ សំផន អៀង សារី និង សុន សេន។ គាត់គឺជាអ្នកនិពន្ធសៀវភៅចំណងជើងថា៖ “*ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់*” ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង[773]។ បើទោះបីជាការយល់ដឹងទូលំទូលាយរបស់បុគ្គលទាំងនេះនៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ Stephen HEDER និង François PONCHAUD ពុំបានផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញក្នុងសំណុំរឿង ០០២/០១ ដែរ[774]។ Philip SHORT ត្រូវបានកោះហៅក្នុងនាមជាអ្នកជំនាញ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គាត់“អាចត្រូវបានសួរផងដែរលើអង្គហេតុដែលស្ថិតក្នុងវិសាលភាពចំណេះដឹងរបស់គាត់ផ្ទាល់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១”[775]។

### ក. Stephen HEDER និង François PONCHAUD

[772] *សូមមើល ឧ.* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៩២។

[773] *សូមមើល* សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកជំនាញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ E215 (“សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកជំនាញ (E215)”) កថាខណ្ឌ ៨។

[774] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង“សេចក្តីជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣” ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E288 កថាខណ្ឌ ៤។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងសំណុំរឿង ០០២/០១ “TCE-33, HEDER, Stephen Russel” ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E202/82/1។

[775] សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកជំនាញ (E215) កថាខណ្ឌ ១៨។

269. នៅមុនចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ខៀវ សំផន ស្នើសុំការផ្ដល់សក្ខីកម្មរបស់ Stephen HEDER លើប្រធានបទយ៉ាងទូលំទូលាយ រួមទាំងប្រព័ន្ធនៃការទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា វិធានការដែលត្រូវបានធ្វើឡើងប្រឆាំងនឹងជនជាតិចាម និងពុទ្ធសាសនិក សហករណ៍ និងការដ្ឋានធ្វើការ មន្ទីរសន្ដិសុខ និងទីតាំងសម្លាប់មនុស្ស អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[776]។ ខៀវ សំផន បានស្នើផងដែរឱ្យ François PONCHAUD មកផ្ដល់សក្ខីកម្មលើប្រធានបទស្ដីពីសារតារ ជម្លោះប្រដាប់អាវុធ សហករណ៍ និងការដ្ឋានធ្វើការ វិធានការប្រឆាំងនឹងជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ព្រមទាំងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[777]។

270. ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ខៀវ សំផន បានលើកសំណើសុំស្ដាប់ Stephen HEDER និង François PONCHAUD ជំនួសឱ្យ Michael VICKERY (2-TCE-94)[778] ខណៈពេល នួន ជា បានស្នើសុំ Stephen HEDER ឬ Stephen MORRIS (2-TCE-98) ជំនួសឱ្យ CHANDA Nayan (2-TCE-83) ក្នុងការបំភ្លឺលើប្រធានបទស្ដីពីជម្លោះប្រដាប់អាវុធ[779] និងពីព្រោះ រហូតមកដល់ពេលនោះ ពុំមានអ្នកជំនាញណាម្នាក់ដែលបានស្នើឡើងដោយមេធាវីការពារក្ដី ត្រូវបានស្ដាប់ឡើយ[780]។ សហព្រះរាជអាជ្ញាបានយល់ស្របថា អង្គជំនុំជម្រះសាលាដំបូងគប្បីព្យាយាមជួយសម្រួលមេធាវីការពារក្ដី និងកោះហៅសាក្សីម្នាក់ ឬច្រើនដែលត្រូវបានស្នើឡើងនោះ[781]។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសយក Stephen MORRIS ធ្វើជាអ្នកជំនាញក្នុងប្រធាននៃការជំនុំជម្រះស្ដីពីជម្លោះប្រដាប់អាវុធ[782]។

---

[776] ឧបសម្ព័ន្ធ III៖ បច្ចុប្បន្នភាពសេចក្ដីសង្ខេបនៃសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញដែលពុំស្នើសុំវិធានការការពារ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ឯកសារលេខ E305/5.2 ទំព័រ ៥។

[777] ឧបសម្ព័ន្ធ III៖ បច្ចុប្បន្នភាពសេចក្ដីសង្ខេបនៃសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញដែលពុំស្នើសុំវិធានការការពារ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ឯកសារលេខ E305/5.2 ទំព័រ ៦។

[778] សំណើសាជាថ្មីរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំស្ដាប់សក្ខីកម្មសាក្សី 2-TCE-87 និង 2-TCE-99 ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E408/6។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/458.1 ទំព័រ ២៣-២៤។

[779] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/458.1 ទំព័រ ១៨-២៣។

[780] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/458.1 ទំព័រ ២២។

[781] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/458.1 ទំព័រ ២៥-២៦។

[782] សេចក្ដីសម្រេចតែងតាំងអ្នកជំនាញ 2-TCE-98 ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E445 កថាខណ្ឌ ១ យោងទៅលើអ៊ីម៉ែលពីមន្ត្រីច្បាប់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦។

271. នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ខៀវ សំផន បានដាក់សំណើបន្ថែមទៀតសុំការបំភ្លឺអំពីអង្គជំនុំជម្រះសាលាដំបូងលើបញ្ហាថាតើ អង្គជំនុំជម្រះមានបំណងស្ដាប់ Stephen HEDER និង François PONCHAUD ដែរ ឬយ៉ាងណា[783]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំផ្នែកលើមូលដ្ឋានថា៖

> Stephen HEDER (2-TCE-87) និង François PONCHAUD (2-TCE-99) បានផ្ដល់សក្ខីកម្មជាសាក្សីក្នុងសំណុំរឿង ០០២/០១ និង [...] សក្ខីកម្មនីមួយៗរបស់គាត់នៅតែជាផ្នែកនៃភស្តុតាងដែលមានអត្ថិភាពក្នុងសំណុំរឿង ០០២/០២ (E318 កថាខណ្ឌ ៣(ខ))។ Stephen HEDER (2-TCE-87) បានផ្ដល់សក្ខីកម្មអស់រយៈពេល ៧ ថ្ងៃ គ្របដណ្ដប់លើប្រធានបទផ្សេងៗដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ រួមទាំងរចនាសម្ព័ន្ធរដ្ឋបាលខ្មែរក្រហម មនោគមវិជ្ជាខ្មែរក្រហម គោលនយោបាយខ្មែរក្រហម និងការអនុវត្តទៅលើជនជាតិវៀតណាម និងជនជាតិចាម ព្រមទាំងការបោសសម្អាតផ្ទៃក្នុង (ប្រតិចារឹកថ្ងៃទី ៩-១១ ខែ កក្កដា ឆ្នាំ ២០១៣ និងប្រតិចារឹកថ្ងៃទី ១៥-១៨ ខែ កក្កដា ឆ្នាំ ២០១៣)។ François PONCHAUD (2-TCE-99) បានផ្ដល់សក្ខីកម្មអស់រយៈពេល ០៣ ថ្ងៃគ្របដណ្ដប់លើប្រធានបទផ្សេងៗ រួមទាំងសហករណ៍ និងការដ្ឋានធ្វើការ ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងថ្នាក់ដឹកនាំខ្មែរក្រហម (ប្រតិចារឹកថ្ងៃទី ៩-១១ ខែ មេសា ឆ្នាំ ២០១៣)។ បន្ថែមលើនេះ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសអ្នកជំនាញដទៃទៀត Stephen MORRIS (2-TCE-98) ដែលត្រូវបានស្ដាប់លើបញ្ហានៃប្រធានបទជំនុំជម្រះទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ (*សូមមើល* ប្រតិចារឹកថ្ងៃទី ១៨-២០ ខែ តុលា ឆ្នាំ ២០១៦ (សេចក្ដីព្រាង))។ យោងទៅលើប្រធានបទដែលត្រូវបានគ្របដណ្ដប់រួចរាល់ហើយក្នុងអំឡុងពេលនៃសក្ខីកម្មរបស់ Stephen HEDER (2-TCE-87) និង François PONCHAUD (2-TCE-99) ក្នុងសំណុំរឿង ០០២/០១ ព្រមទាំងការជ្រើសរើស Stephen MORRIS (2-TCE-98) អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការច្រំដែលក្នុងការកោះហៅ Stephen HEDER 2-TCE-87 និង François PONCHAUD (2-TCE-99) មកផ្ដល់សក្ខីកម្មម្ដងទៀតក្នុងសំណុំរឿង ០០២/០២។ បន្ថែមលើនេះ អង្គជំនុំជម្រះយល់ឃើញថា ការកោះហៅឡើងវិញបុគ្គលទាំងនេះជាការពន្យារពេលឥតសមស្របដល់កិច្ចដំណើរការនីតិវិធី[784]។

272. អង្គជំនុំជម្រះសាលាដំបូងបានរំឭកបន្ថែមទៀតថា ក្នុងការជ្រើសរើសសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ អង្គជំនុំជម្រះត្រូវបានដឹកនាំដោយកាតព្វកិច្ចក្នុងការបញ្ជាក់ការពិត និងថា "បើទោះបីជាអង្គជំនុំ

---

783 សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឱ្យមានការបំភ្លឺពាក់ព័ន្ធទៅនឹង 2-TCE-87 និង 2-TCE-99 ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E408/6/1។

784 សេចក្ដីសម្រេចលើសំណើសុំស្ដាប់ HEDER និង PONCHAUD (E408/6/2) កថាខណ្ឌ ៦ (សេចក្ដីបញ្ជាក់បន្ថែម)។

ជម្រះត្រូវស្តាប់បុគ្គលដែលបានស្នើឡើងដោយភាគីទាំងអស់ក៏ដោយ ក៏ពុំមានលក្ខខណ្ឌតម្រូវឱ្យធានាបាននូវសមាមាត្រពាក់ព័ន្ធបញ្ហានេះដែរ”[785]។

273. នៅក្នុងការបដិសេធសំណើសុំរបស់ ខៀវ សំផន ក្នុងការកោះហៅ Stephen HEDER និង François PONCHAUD ដោយផ្អែកលើមូលដ្ឋានថា សក្ខីកម្មរបស់ពួកគាត់នឹងមានលក្ខណៈច្រំដែល អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានបំភ្លឺតាមរយៈការពិចារណាសំខាន់ពីរចំណុចថា (១) Stephen HEDER និង François PONCHAUD បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ លើប្រធានបទដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ និង (២) ការជ្រើសរើស Stephen MORRIS ធ្វើជាអ្នកជំនាញមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលនៃការជំនុំជម្រះលើប្រធានបទអំពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ។

274. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា François PONCHAUD បានផ្តល់សក្ខីកម្មអស់រយៈពេលបីថ្ងៃក្នុងនាមជាសាក្សីក្នុងអំឡុងពេលនៃកិច្ចដំណើរការសំណុំរឿង ០០២/០១[786]។ សក្ខីកម្មរបស់គាត់ជាពិសេសបានគ្របដណ្តប់សាវតារប្រវត្តិនៃគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា និងការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ François PONCHAUD ត្រូវបានកោះហៅជាចម្បងដើម្បីផ្តល់សក្ខីកម្មលើព្រឹត្តិការណ៍ដែលគាត់បានឃើញដោយផ្ទាល់នៅមុនឆ្នាំ ១៩៧៥ និងរហូតដល់ថ្ងៃទី ០៦ ឬ ០៧ ខែឧសភា ឆ្នាំ ១៩៧៥ នៅពេលគាត់ត្រូវបានបង្ខំឱ្យចាកចេញពីប្រទេសកម្ពុជា[787]។ បន្ថែមលើនេះ គាត់ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងទៅនឹងឯកសារក្នុងសំណុំរឿង ដែលគាត់បាននិពន្ធ រួមទាំងចម្លើយរបស់

---

785 សេចក្តីសម្រេចលើសំណើសុំស្តាប់ HEDER និង PONCHAUD (E408/6/2) កថាខណ្ឌ ៥។

786 ប្រតិចារឹកចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/178.1។ *សូមមើលបន្ថែម* ប្រតិចារឹកចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤៨ (“លោក PONCHAUD ត្រូវបានកោះហៅក្នុងនាមជាសាក្សី ហេតុដូច្នេះហើយអង្គជំនុំជម្រះបានសម្រេចថា ពិចារណាទៅលើសំណួរដែលពាក់ព័ន្ធទៅលើគាត់ ក៏ដូចជាការពិនិត្យទៅលើតម្លៃនៃភស្តុតាងផងដែរ។ [...] សក្ខីកម្មរបស់គាត់ត្រូវបានផ្តល់ព័ត៌មានដោយសារការសរសេរសៀវភៅរបស់គាត់ក៏ដូចជាបទពិសោធន៍ដែលទទួលបានពីការដឹងផ្ទាល់ខ្លួនរបស់គាត់ ប៉ុន្តែយ៉ាងណាក៏ដោយយើងមិនចាត់ទុកគាត់ជាអ្នកជំនាញក្នុងលក្ខណៈបច្ចេកទេសនោះឡើយ គឺថា នៅក្នុងសវនាការនេះ គាត់មិនមែនជាអ្នកជំនាញនោះទេ”) (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/179.1 ទំព័រ ១២។

787 ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤៨។

ជនភៀសខ្លួនដែលបានប្រមូលផ្តុំក្នុងប្រទេសថៃ បារាំង និងទីកន្លែងដទៃទៀត[788]។ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង សក្ខីកម្មរបស់គាត់បានផ្តោតលើប្រធានបទមួយចំនួនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ រួមទាំងសហករណ៍ និងការដ្ឋានធ្វើការ ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងថ្នាក់ដឹកនាំខ្មែរក្រហម[789]។ ឧទាហរណ៍ François PONCHAUD ត្រូវបានសួរត្រួសៗអំពីការបោសសម្អាតក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ ពាក់ព័ន្ធទៅនឹងរបាយការណ៍ដែលគាត់បាននិពន្ធ។ គាត់ត្រូវបានសួរសំណួរផងដែរ*ក្នុងចំណោមនោះ*ស្តីពីរឿងរ៉ាវនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើពុទ្ធសាសនិក និងជនជាតិចាមដែលទទួលបានពីជនភៀសខ្លួន និងបានបង្ហាញក្នុងរបាយការណ៍នៅពេលនោះ និងអត្ថបទកាសែត[790] រួមទាំងការសួរដោយមេធាវីការពារក្តី នួន ជា ផងដែរ[791]។ ពុំមានភាគីណាបានជំទាស់ទៅនឹងវិសាលភាពនៃការសួរសំណួរនោះឡើយ។

275. ប្រហាក់ប្រហែលគ្នានេះដែរ Stephen HEDER ត្រូវបានកោះហៅធ្វើជាសាក្សីជាចម្បងដើម្បីឆ្លើយអំពីឯកសារជាច្រើននៅក្នុងសំណុំរឿងដែលគាត់បាននិពន្ធ[792]។ ក្នុងអំឡុងពេលនៃសក្ខីកម្មពីរថ្ងៃរបស់គាត់ សំណួរត្រូវបានផ្តោតជាចម្បងទៅលើភស្តុតាងដែលគាត់ប្រមូលបាន"ក្នុងអំឡុងពេលនៃការធ្វើបទសម្ភាសន៍របស់គាត់ ឬភស្តុតាងដែលគាត់បានប្រមូលទុកក្នុងពេលស្រាវជ្រាវដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការនិពន្ធសៀវភៅ ឬអត្ថបទរបស់គាត់"[793]។ គាត់បានផ្តល់ភស្តុតាងជាចម្បងលើព្រឹត្តិការណ៍នៅមុនឆ្នាំ ១៩៧៥ លក្ខណៈពិសេសជាច្រើនរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ[794]។ ប្រធាន

[788] ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤៨។

[789] សំណុំរឿង ០០២/០១ សេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់ក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E312 ("សេចក្តីសម្រេចសំណុំរឿង ០០២/០១ ស្តីពីសាក្សី (E312)") កថាខណ្ឌ ៣១, ៦០។ *សូមមើល ខ.* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤០-៤១ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។

[790] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤០-៤១។

[791] ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/180.1 ទំព័រ ២៤-២៦។

[792] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សេចក្តីជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣" ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសរលេខ E288 កថាខណ្ឌ ៤ ("អនុស្សរណៈ៖ សេចក្តីជូនដំណឹងអំពីសាវនាការ") កថាខណ្ឌ ៤។

[793] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/221.1 ទំព័រ ៤០។

[794] សេចក្តីសម្រេចសំណុំរឿង ០០២/០១ ស្តីពីសាក្សី (F312) កថាខណ្ឌ ៣១, ៤២។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៤១។

បទនេះស្ថិតទាំងស្រុងក្នុងវិសាលភាពនៃការសួរសំណួរក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែមានការជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ផងដែរ។ បន្ថែមលើនេះ សក្ខីកម្មរបស់ Stephen HEDER ក្នុងសំណុំរឿង ០០២/០១ ជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជាគោលនយោបាយខ្មែរក្រហម និងការអនុវត្តន៍ទៅលើជនជាតិវៀតណាម និងជនជាតិចាម ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។

276. ផ្អែកតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាភាគី ស្ថិតក្រោមការណែនាំទូទៅឱ្យផ្តោតប្រធានបទសំណួររបស់ខ្លួនក្នុងវិសាលភាពសំណុំរឿង ០០២/០១ ក៏ដោយ ក៏ភាគីអាចសួរសំណួរ Stephen HEDER និង François PONCHAUD បានលើប្រធានបទមួយចំនួនទាំងពីរសំណុំរឿងពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ដែរ។ ពិតណាស់ សិទ្ធិទទួលបានការសួរដេញដោលចំពោះមុខត្រូវបានអនុវត្តពេញលេញ និងការពារពាក់ព័ន្ធទៅនឹងប្រធានបទទាំងនោះ។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា សាក្សីទាំងនេះពុំត្រូវបានសួរដេញដោលលម្អិតលើប្រធានបទទាំងអស់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "លក្ខណៈវិនិច្ឆ័យសំខាន់បំផុតសម្រាប់ការពិចារណាទាក់ទងទៅនឹងបញ្ហាថាតើ ត្រូវកោះហៅសាក្សី ដែរ ឬយ៉ាងណា ដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ គឺជាបញ្ហាជាប់ពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលត្រូវបានរំពឹងទុកអំពីព្រឹត្តិការណ៍ដែលជាកម្មវត្ថុនៃបទចោទ។ នៅពេលជាមួយគ្នានោះ និងជាពិសេសនៅពេលសាក្សីសក្តានុពលមួយចំនួន ឬមធ្យោបាយដទៃទៀតក្នុងការទទួលបានភស្តុតាងមានអត្ថិភាពទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលចោទជាបញ្ហានោះ អង្គជំនុំជម្រះនឹងត្រូវជ្រើសរើសសាក្សីចាំបាច់ជាងគេដែលត្រូវកោះហៅ ដើម្បីជៀសវាងភាពច្រំដែល និងការពន្យារពេលដោយផ្អែកលើទិដ្ឋភាពនៃការធានាបាននូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី"[795]។

277. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា François PONCHAUD មានវត្តមានក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ជម្លៀសទីក្រុងភ្នំពេញ និងបានផ្តល់សក្ខីកម្មថាបានឃើញព្រឹត្តិការណ៍ផ្ទាល់នៅមុនពេលចាប់ផ្តើមភ្លាមៗ និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី ការដឹងរបស់គាត់លើប្រធានបទសំណុំរឿង ០០២/០២ កើតចេញជាចម្បងពីការសម្ភាសន៍ និងចម្លើយដែលប្រមូលបានពីជនភៀសខ្លួន និងតាមរយៈការស្តាប់ការផ្សព្វផ្សាយតាមវិទ្យុខ្មែរក្រហម និងតាមរយៈការអានឯក

795 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១៤៤។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៤៧។

សារ[796]។ ប្រហាក់ប្រហែលគ្នានេះ Stephen HEDER ត្រូវបានកោះហៅជាចម្លងដើម្បីឆ្លើយចំពោះឯកសារជាច្រើនដែលគាត់បាននិពន្ធនៅក្នុងសំណុំរឿង ០០២។ ព័ត៌មាននេះមាននៅក្នុងសំណុំរឿង ហើយមេធាវីការពារក្ដីក្នុងសំណុំរឿង ០០២/០១ អាចសួរដេញដោល Stephen HEDER និង François PONCHAUD លើវិធីសាស្ត្ររបស់ពួកគាត់ក្នុងការទទួលបាន និងកត់ត្រាព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២។ បន្ថែមលើនេះ សាក្សីបានផ្ដល់សក្ខីកម្មយ៉ាងទូលំទូលាយលើសារតារប្រវត្តិ ការវិវឌ្ឍន៍គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា និងប្រធានបទដទៃទៀតពាក់ព័ន្ធទៅនឹងរឿងក្ដីទាំងពីរ។

278. មួយក្នុងចំណោមហេតុផលចម្បងសម្រាប់សំណើររបស់ ខៀវ សំផន សុំកោះហៅ Stephen HEDER និង François PONCHAUD ក្នុងសំណុំរឿង ០០២/០២ គឺជាប់ពាក់ព័ន្ធទៅនឹងការសង្កេតរបស់ពួកគាត់ទាក់ទងទៅនឹងជនជាតិចាម[797] និងការអះអាងរបស់ពួកគាត់ថា វិធានការប្រឆាំងនឹងជនជាតិចាមពុំមែនជាអំពើប្រល័យពូជសាសន៍ ឬការធ្វើទុក្ខបុកម្នេញ[798]។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មេធាវីការពារក្ដី ខៀវ សំផន ក្នុងអំឡុងពេលនៃសក្ខីកម្មរបស់ Stephen HEDER បានជំទាស់ទៅនឹងសំណួរទាក់ទងទៅនឹងផលប៉ះពាល់នៃការអនុវត្តន៍គោលនយោបាយប្រឆាំងជនជាតិចាមដោយសារ

---

796 *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤៨, ៥៦-៧២។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៩, ១៧-១៩, ២២-២៣, ២៦-២៨, ៣៩-៤៥, ៤៧-៥១, ៦៥, ៦៩-៧២, ៧៥-៧៦។

797 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៧៣។

798 *សូមមើល ឧ.* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៥១ ("អំពីបងប្អូនចាម ឥឡូវនេះខ្ញុំមានព័ត៌មានផ្សេង ខ្ញុំបានព័ត៌មានដូចអ្នកស្រីបានប្រាប់ខ្ញុំមិនយល់ថា ខ្មែរក្រហមបៀតបៀនចាមព្រោះសាសនា។ ដូច្នេះអត់មានការប្រកាន់ប្រល័យពូជសាសន៍អំពីរឿងសាសនា។ ចាមគេមានប្រពៃណីផ្ទាល់ខ្លួន ហើយខាងខ្មែរក្រហម គេចង់ឱ្យប្រជាជនទាំងអស់ដូចៗគ្នា។ [...] ខ្ញុំប្រាកដអំពីសាសនាគ្រិស្ដក៏ដូចជាខាងព្រះពុទ្ធសាសនាមានអ្នកស្លាប់មួយការកាប់សម្លាប់ ប៉ុន្តែការកាប់សម្លាប់មិនមែនដោយសារតែមូលដ្ឋានសាសនានោះទេ ដោយសារតែគេចាត់ទុកថាជាខ្មាំង ហើយដោយសារតែមានការប្រឆាំងទៅនឹងបញ្ហារបស់អង្គការ។ ដូច្នេះ ខ្ញុំមិនពណ៌នាអំពើទាំងអស់នេះថា ជាការប្រល័យពូជសាសន៍ ឬក៏ការធ្វើទុក្ខបុកម្នេញនោះឡើយ។ ព្រោះថា មានការកាប់សម្លាប់មិនមែនដោយសារតែមូលហេតុសាសនានោះទេ ដោយសារតែមូលហេតុខ្មាំងរបស់អង្គការ។ មានការកើតឡើងចំពោះជនជាតិចាមផងដែរ។ មនោគមវិជ្ជាខ្មែរក្រហមគឺជារឿងឆ្កួតលាលី ត្រូវតែទទួលយក។ ប្រសិនបើមិនទទួលយកទេ នឹងត្រូវលុបបំបាត់ចោល"។ ហេតុនេះហើយអ្នកដែលសុខចិត្តធ្វើការគំរូរបស់ ខ្មែរក្រហម គេរួចខ្លួន។ ចាម ខ្មែរ វៀតណាមអត់បញ្ហា ប៉ុន្តែអ្នកមិនព្រមត្រូវកើតគ្រោះថ្នាក់។ តាំពីឆ្នាំ ១៩៧៨ សភាពការណ៍ខុសប្លែកនេះគេបៀតបៀនចាម ជាពិសេស ខាងកើតទន្លេមេគង្គ ព្រោះមានរឿងសង្គ្រាម និងវៀតណាម បានជាចាមគាំទ្រវៀតណាមប្រឆាំងខ្មែរក្រហម។ គឺគេសង្ស័យ ថាគាំទ្រវៀតណាម")។

សំណួរនេះបាននាំទៅរកការវិភាគផ្ទាល់ខ្លួនរបស់សាក្សី ដែលគាត់ពុំត្រូវបានកោះហៅក្នុងនាមជាអ្នកជំនាញនោះទេ។

279. Michael VICERY គឺជាអ្នកប្រវត្តិសាស្ត្រដែលត្រូវបានចាត់តាំងជាអ្នកជំនាញដោយផ្អែកលើ*ក្នុងចំណោមនោះ*បទពិសោធន៍ទូលំទូលាយរបស់គាត់អំពីប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ដែលបានរស់នៅក្នុងកម្ពុជាមុនឆ្នាំ ១៩៧៥ បានប្រមូលចម្លើយផ្ទាល់ពីជនភៀសខ្លួនកម្ពុជាក្នុងឆ្នាំ ១៩៨០ និងបានបោះពុម្ពផ្សាយឯកសារស្ដីពីខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ[799] ត្រូវបានស្នើដោយ ខៀវ សំផន ដើម្បីផ្តល់សក្ខីកម្មលើ"ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន និងមជ្ឈិម (ជាពិសេសពាក់ព័ន្ធទៅនឹងកម្រិតស្វយ័តនៃមេបញ្ជាការមូលដ្ឋាន ព្រមទាំងក្រុមប្រឆាំងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ) សិទ្ធិអំណាចរបស់ជនជាប់ចោទ*តាមផ្លូវច្បាប់ និងតាមជាក់ស្ដែង* ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ការចោទប្រកាន់ផ្អែកអង្គហេតុអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ(ការផ្លាស់ទីប្រជាជន សហករណ៍ និងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សព្រមទាំងការប្រព្រឹត្តទៅលើក្រុមជាក់លាក់)" និងត្រូវបានស្នើឡើងដោយមេធាវីការពារក្ដី នួន ជា ស្ដីពី"លក្ខខណ្ឌក្នុងសហករណ៍ និងការដ្ឋានធ្វើការ លក្ខខណ្ឌរស់នៅជាទូទៅ ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម រចនាសម្ព័ន្ធសិទ្ធិអំណាចមួយបែបផ្សេងទៀតក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រការបែកបាក់របស់កម្មាភិបាលជាន់ខ្ពស់ក្នុងបក្សកុម្មុយនីស្តកម្ពុជា [...] ការបែកបាក់ផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា(ជាពិសេសក្នុងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម) និងការកំណត់ភិនភាគជនក្បត់ និងការបោសសម្អាតផ្ទៃក្នុង"[800]។ Michael VICERY ក្រោយមកបានបដិសេធការផ្ដល់សក្ខីកម្ម[801]។ បន្ទាប់មក ខៀវ សំផន បានស្នើសុំឱ្យ Stephen HEDER និង François PONCHAUD ជំនួស Michael VICKERY (2-TCE-94)[802]។ ក្នុងការឆ្លើយតប អង្គជំនុំជម្រះសាលា

---

[799] សេចក្ដីសម្រេចតែងតាំងអ្នកជំនាញ 2-TCE-94 (Michael Vickery) ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E408 ។

[800] ឧបសម្ព័ន្ធ ខ៖ បច្ចុប្បន្នភាពសេចក្ដីសង្ខេបនៃសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ (គ្មានការស្នើសុំវិធានការការពារ) ក្រុមមេធាវីការពារក្ដី នួន ជា ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/4.2 ទំព័រ ២២-២៣។

[801] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "បញ្ហាសំខាន់ៗពាក់ព័ន្ធទៅនឹងអ្នកជំនាញ Michael Vickery (2-TCE-94) ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E408/5។

[802] សំណើសាជាថ្មីរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំស្ដាប់សក្ខីកម្មសាក្សី 2-TCE-87 និង 2-TCE-99 ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E408/6។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ E1/458.1 ទំព័រ ២៣-២៤។

ដំបូងបានកត់សម្គាល់ថា ប្រធានបទដែលស្នើឡើងសម្រាប់ Stephen HEDER និង François PONCHAUD "ខុសប្លែកគ្នាជាច្រើនចំណុចពីប្រធានបទដែល Michael VICKERY (2-TCE-94) ត្រូវផ្តល់សក្ខីកម្ម" និងថា អ្នកជំនាញពីរនាក់ដែលបានស្នើឡើងនេះពុំអាចជំនួស Michael VICKERY ទាក់ទងនឹងបញ្ហាខ្លឹមសារដែលត្រូវដោះស្រាយ[803]។ Stephen MORRIS ដែលត្រូវបានជ្រើសរើសជំនួស Michael VICKERY ត្រូវបានស្នើផងដែរដោយ នួន ជា ដើម្បីផ្តល់សក្ខីកម្មលើជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម និងប្រធានបទដទៃទៀតស្រដៀងគ្នាទៅនឹង Michael VICKERY [804]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំង Stephen MORRIS ជាអ្នកជំនាញដោយផ្អែកលើបទពិសោធន៍ស្រាវជ្រាវទូលំទូលាយរបស់គាត់ និងចំណេះដឹងឯកទេសអំពីទំនាក់ទំនងកម្ពុជាវៀតណាមក្នុងអំឡុងពេលជាប់ពាក់ព័ន្ធ រួមទាំងសៀវភៅរបស់គាត់ចំណងជើងថា "*មូលហេតុដែលវៀតណាមឈ្លានពានកម្ពុជា វប្បធម៌នយោបាយ និងមូលហេតុនៃសង្គ្រាម*"[805]។

280. ផ្អែកតាមការពិនិត្យទូលំទូលាយលើព្រឹត្តិការណ៍ និងសារណាទាំងនេះបាននាំឱ្យអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូង និងសំអាងហេតុពុំបានបង្ហាញកំហុសណាមួយ។ បញ្ហាខ្លឹមសារដែលត្រូវដោះស្រាយដោយ Stephen MORRIS ស្រដៀងគ្នាច្រើនជាងបញ្ហាដែល Michael VICKERY នឹងត្រូវដោះស្រាយជាពិសេសពាក់ព័ន្ធទៅនឹងប្រធានបទដែលគ្របដណ្តប់ជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ បន្ថែមលើនេះ ជំនាញរបស់ Stephen MORRIS ពុំត្រូវបានស្តាប់ក្នុងសំណុំរឿង ០០២/០១ និងជំនាញរបស់គាត់បានគ្របដណ្តប់លើប្រធានបទផ្សេងដែលទំនងជាពុំមែនជាការច្រំដែលឡើយ។

281. យោងតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់ ខៀវ សំផន សុំកោះហៅ Stephen HEDER និង François PONCHAUD។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុច្បាស់លាស់ក្នុងសេចក្តីសម្រេចរបស់ខ្លួនដោយពិចារណាលើការពិតដែលថា សាក្សីទាំងពីរបានផ្តល់សក្ខីកម្មយ៉ាងទូលំទូលាយក្នុងសំណុំរឿង ០០២/០១ លើប្រធានបទពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ និងថា ពួកគាត់ត្រូវបាន

---

[803] សេចក្តីសម្រេចលើសំណើសុំស្តាប់ HEDER និង PONCHAUD (E408/6/2) កថាខណ្ឌ ៥។

[804] ឧបសម្ព័ន្ធ ខ៖ បច្ចុប្បន្នភាពសេចក្តីសង្ខេបនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (គ្មានការស្នើសុំវិធានការការពារ) ក្រុមមេធាវីការពារក្តី នួន ជា ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E305/4.2 ទំព័រ ១៩-២០។

[805] អ្នកនិពន្ធ Stephen J. Morris ៖ *ហេតុអ្វីបានវៀតណាមឈ្លានពានកម្ពុជា វប្បធម៌នយោបាយ និងមូលហេតុនៃសង្គ្រាម* (បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ១៩៩៩)។

សួរដេញដោល បើទោះបីជាក្នុងកម្រិតមួយតិចជាងក៏ដោយ លើប្រធានបទដែលជាប់ពាក់ព័ន្ធជាក់លាក់ទៅនឹងសំណុំរឿង ០០២/០២ និងថា សក្ខីកម្មនីមួយៗរបស់ពួកគាត់នៅតែជាផ្នែកនៃភស្តុតាងក្នុងសំណុំរឿង ០០២/០២។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សាក្សីទាំងពីរជាចម្បងត្រូវបានកោះហៅឱ្យពិភាក្សាលើវិធីសាស្ត្រនៃកត់ត្រាឯកសារដែលពួកគាត់បាននិពន្ធនៅក្នុងសំណុំរឿង និងថា ភាគីទាំងអស់មានឱកាសសួរសំណួរទូលំទូលាយលើ Stephen HEDER និង François PONCHAUD ពាក់ព័ន្ធបញ្ហានេះ។

282. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្របនឹងការបំភ្លឺរបស់ខ្លួនដែលបានលើកឡើងដំបូងថា អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហាថាតើ ភាគីត្រូវបានរារាំងក្នុងការសួរសំណួរពេញលេញលើបុគ្គល ដែរ ឬយ៉ាងណា ប៉ុន្តែក៏បានរំឭកភាគីថា អង្គជំនុំជម្រះអាច"បដិសេធសំណើសុំភស្តុតាងដែលខ្លួនយល់ឃើញថា ពុំជាប់ពាក់ព័ន្ធ ឬច្រំដែលស្របតាមវិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង"[806]។ គួររំឭកថា "ក្តីបារម្ភទូទៅអំពីភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីបានកំហិតសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន [...] ភស្តុតាងដើម្បីការពារខ្លួនក្នុងករណីដែលសំណើសុំភស្តុតាងជាក់ស្តែងពុំមែនដើម្បីការការពារខ្លួន ដូចបានកំណត់ក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងថា ភស្តុតាងដែលស្នើសុំនោះពុំជាប់ពាក់ព័ន្ធ ច្រំដែល ឬសំណើសុំក្នុងគោលបំណងអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធី"[807]។ ទាក់ទងទៅនឹងប្រធានបទដែល ខៀវ សំផន ចង់សួរដេញដោលពេញលេញជាងនេះ គួរកត់សម្គាល់ថា សាក្សីមួយចំនួនដទៃទៀត និងភស្តុតាងជាឯកសារជាពិសេសត្រូវបានសួរតម្រង់ទៅរកបញ្ហាពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាមក្នុងសំណុំរឿង ០០២/០២ ការដ្ឋានធ្វើការ និងសហករណ៍ និងគោលការណ៍រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ចុងក្រោយ ទោះបីជាភាគីត្រូវបានណែនាំជាទូទៅឱ្យផ្តោតប្រធានបទនៃការសួរសំណួរក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដោយ ក៏ទោះជាយ៉ាងណាក្តីភាគីអាចសួរសំណួរ Stephen HEDER និង François PONCHAUD លើប្រធានបទមួយចំនួនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ដែរ។ ផ្អែកតាមការលើកឡើងខាងលើ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវការរំលោភបំពានលើសិទ្ធិទទួលបានការសួរដេញដោលចំពោះមុខ ឬព្យសនកម្មដែលបានកើតឡើងដោយសារលទ្ធផលនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

### ខ. Philip SHORT

[806] អនុស្សរណៈបំភ្លឺអង្គជំនុំជម្រះសាលាដំបូង (E302/5) កថាខណ្ឌ ៨។

[807] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១៦២ (ជើងទំព័រលុបចោល)។

283. ខៀវ សំផន បានតវ៉ាថា គាត់បានស្នើសុំស្តាប់សក្ខីកម្មរបស់ Philip SHORT ក្នុងនាមជាអ្នកជំនាញលើប្រធានបទនៃបរិបទសាវតារប្រវត្តិ រចនាសម្ព័ន្ធរដ្ឋបាល ជម្លោះប្រដាប់អាវុធ សហករណ៍ និងការដ្ឋានធ្វើការ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស វិធានការប្រឆាំងនឹងក្រុមជាក់លាក់ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[808]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ ខៀវ សំផន សុំស្តាប់ Philip SHORT ផ្អែកលើមូលដ្ឋានថា៖

> មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យ Philip SHORT (2-TCE-92) មកផ្តល់សក្ខីកម្មជាអ្នកជំនាញលើប្រវត្តិនៅមុនឆ្នាំ ១៩៧៥ របស់បក្សកុម្មុយនីស្តកម្ពុជា និងការបង្កើតជាស្ថាប័ន។ អង្គជំនុំជម្រះកត់សម្គាល់ថា Philip SHORT (2-TCE-92) បានផ្តល់សក្ខីកម្មជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅមុនឆ្នាំ ១៩៧៥ និងថា សក្ខីកម្មរបស់គាត់បង្កើតបានជាផ្នែកមួយនៃភស្តុតាងឯកសារជាច្រើនពាក់ព័ន្ធទៅនឹងប្រធានបទនេះដែលត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះកត់សម្គាល់ថា Philip SHORT (2-TCE-92) ស្ថិតក្នុងចំណោមអ្នកជំនាញដែលត្រូវបានស្នើសុំនៅមុនការបំបែកសំណុំរឿង ០០២ និងអាស្រ័យហេតុនេះ អង្គជំនុំជម្រះអនុញ្ញាតសម្រាប់ការសួរសំណួរទូលំទូលាយជាងក្នុងវិសាលភាពពិសេសនៃជំនាញរបស់គាត់ ដើម្បីជៀសវាងការកោះហៅឡើងវិញដែលពុំចាំបាច់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពិចារណាឃើញថា ការស្តាប់ភស្តុតាង Philip SHORT (2-TCE-92) លើកទីពីរ ទំនងជាមានលក្ខណៈច្រំដែលច្រើននៃភស្តុតាងក្នុងសំណុំរឿង រួមទាំងសក្ខីកម្មក្នុងសំណុំរឿង ០០២/០១ របស់ François PONCHAUD (2-TCE-99), Stephen HEDER (2-TCE-87) និង David CHANDLER (2-TCE-84)[809]។

284. ខៀវ សំផន បានអះអាងថា សេចក្តីសម្រេចនេះពុំស៊ីសង្វាក់គ្នាជាមួយនឹងសំអាងហេតុដោយសារអង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងពុំបានអនុញ្ញាតឱ្យភាគីសួរសំណួរ Philip SHOR ហួសពីសំណុំរឿង ០០២/០១ និងបានបដិសេធការសុំឱ្យទទួលយកឯកសារទាក់ទងទៅនឹងបទចោទប្រល័យពូជសាសន៍ និងបានកាត់សំដីនៃសក្ខីកម្មរបស់គាត់នៅពេលត្រូវបានសួរអំពីប្រធានបទនេះ[810]។

---

[808] ឧបសម្ព័ន្ធ III៖ បច្ចុប្បន្នភាពសេចក្តីសង្ខេបនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ គ្មានការស្នើសុំវិធានការការពារ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E305/5.2ទំព័រ ៣។

[809] សេចក្តីសម្រេចស្តីពីសាក្សីដែលបានស្នើឡើង (E459) កថាខណ្ឌ ១៩៣ (សេចក្តីបញ្ជាក់បន្ថែម)។

[810] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០។

285. អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គហេតុគប្បីត្រូវបានបង្ហាញច្បាស់លាស់ជាងនេះ។ ដំបូង អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១ បានស្នើសុំឱ្យស្តាប់ Philip SHORT លើប្រធានបទផ្សេងៗ រួមទាំងលើប្រវត្តិនៅមុនឆ្នាំ ១៩៧៥ របស់បក្សកុម្មុយនីស្តកម្ពុជា និងការវិវឌ្ឍន៍នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួមទាំងការគាបសង្កត់លើសាសនា[811]។ Philip SHORT ត្រូវបានស្នើសុំក្នុងនាមជាអ្នកជំនាញស្តីពីការវិវឌ្ឍន៍នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងពុំមែនលើការអនុវត្តន៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកនៃសំណុំរឿង ០០២/០២ នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យចាត់តាំង Philip SHORT ជាអ្នកជំនាញ"ស្របតាមការចាត់តាំងដែលបានរៀបរាប់ក្នុងសេចក្តីសម្រេចនេះ"[812]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក Philip SHORT និង Elizabeth BECKER ដោយផ្អែកលើការស្រាវជ្រាវ និងការផ្សព្វផ្សាយសៀវភៅរបស់ពួកគាត់លើអំឡុងពេលពាក់ព័ន្ធថា៖

> មានចំណេះដឹងពិសេសក្នុងវិស័យនៃជំនាញរបស់ខ្លួន។ អង្គជំនុំជម្រះកត់សម្គាល់ថា ពួកគាត់ជាចម្បងត្រូវបានស្នើសុំដោយភាគី ដោយសារចំណេះដឹងផ្ទាល់ខ្លួនអំពីអង្គហេតុពាក់ព័ន្ធទៅនឹងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈវត្តមានរបស់ពួកគាត់ក្នុងកម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធដែលគ្របដណ្តប់ដោយសំណុំរឿង ០០២/០១ ឬតាមរយៈកិច្ចសម្ភាសន៍របស់ពួកគាត់ជាមួយនឹងមេដឹកនាំ ឬកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង អៀង សារី និង ខៀវ សំផន។ អាស្រ័យហេតុនេះ ពួកគាត់ត្រូវបានកោះហៅក្នុងនាមជាអ្នកជំនាញបើទោះបីជាត្រូវបានសួរសំណួរផងដែរលើអង្គហេតុស្ថិតក្នុងវិសាលភាពចំណេះដឹងផ្ទាល់ខ្លួនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១[813]។

286. បន្ថែមលើនេះ ដើម្បីជៀសវាងការកោះហៅដោយឥតចាំបាច់ និងធានាបាននូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា បុគ្គលមួយចំនួន រួមទាំង Philip SHORT "អាចត្រូវបានសួរសំណួរលើបញ្ហាទាំងអស់ក្នុងវិសាលភាពចំណេះដឹង ឬជំនាញពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយទាំងមូលក្នុងសំណុំរឿង ០០២"[814]។ អង្គជំនុំជម្រះសាលាដំបូងក្រោយមកបានរំឭកភាគីថា ការផ្តោតចម្បង

---

[811] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ៩ យោងទៅលើឧបសម្ព័ន្ធ ១៖ "សេចក្តីសង្ខេបស្តីពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលមានចំណុចនៃដីកាបញ្ជូនទៅជំនុំជម្រះរបស់សហព្រះរាជអាជ្ញា" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/13.1។

[812] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) ផ្នែកសម្រេចសេចក្តី។

[813] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ១៨ (សេចក្តីបញ្ជាក់បន្ថែម)។

[814] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ៤។

នៃសំណួរគប្បីលើកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដើម្បីធានាបានការពន្លឿនកិច្ចដំណើរការនីតិវិធី[815]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា "ការសួរសំណួរលើបញ្ហាក្រៅវិសាលភាពនេះគប្បីត្រូវបានកម្រិតត្រឹមបញ្ហាដែលភាគីពិចារណាឃើញថា បុគ្គលទាំងនេះមានចំណេះដឹងពិសេសអាចឆ្លើយបាន"[816]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា Philip SHORT "អាចត្រូវបានសួរសំណួរលើបញ្ហាទាំងអស់ក្នុងវិសាលភាពចំណេះដឹង ឬជំនាញពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១"[817]។

287. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចមោឃៈដីកាបំបែកកិច្ចដំណើរការនីតិវិធីចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១[818] ផ្អែកលើមូលដ្ឋានដែលថា ភាគីពុំត្រូវបានពិគ្រោះពិភាក្សា។ ផលវិបាកភ្លាមៗនៃសេចក្តីសម្រេចនេះគឺថា សំណុំរឿង ០០២ លែងត្រូវបានកម្រិតត្រឹមវិសាលភាពដែលត្រូវបានកំណត់ពីដំបូងក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ តទៅទៀត[819]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូង"បានស្នើឱ្យបន្តស្តាប់ [...] បុគ្គលទាំងអស់ដែលត្រូវបានគ្រោងចូលមកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃវិសាលភាពការជំនុំជម្រះដូចបានកំណត់ក្នុងដីកាបំបែក[សំណុំរឿង ០០២/០១] និងសេចក្តីសម្រេចពាក់ព័ន្ធ"[820]។ នេះបានរួមបញ្ចូលសក្ខីកម្មឆាប់ៗខាងមុខរបស់ Elizabeth BECKER និង Philip SHORT។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំភាគីថា "អ្នកជំនាញទាំងពីរអាចត្រូវបានសួរសំណួរលើសំណុំរឿង ០០២ ទាំងមូលអំពីបញ្ហាក្នុងវិសាលភាព

[815] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ៤។

[816] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ៤។

[817] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ៤។

[818] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿងលើកដំបូង (E163/5/1/13)។

[819] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថាៈ "សេចក្តីណែនាំភាគីដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (E163/5/1/13)" ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E163/5/1/13/1 ("ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងដល់ភាគីដោយសារផលវិបាកនៃការបំបែកសំណុំរឿង (E163/5/1/13/1)") កថាខណ្ឌ ២។

[820] ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងដល់ភាគីដោយសារផលវិបាកនៃការបំបែកសំណុំរឿង (E163/5/1/13/1) កថាខណ្ឌ ៣(v)។

ចំណេះដឹងរបស់អ្នកជំនាញ ប៉ុន្តែភាគីត្រូវបានជម្រុញទឹកចិត្តឱ្យផ្តោតសំណួររបស់ខ្លួនទៅលើបញ្ហាដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទជាបញ្ហាក្នុងសំណុំរឿង ០០២/០១"[821]។

288. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសក្នុងតុលាការថា អង្គជំនុំជម្រះបានសម្រេចបំបែកសំណុំរឿង ០០២ ឡើងវិញ[822] ដោយមានសំអាងហេតុតាមក្រោយនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[823]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការត្រឡប់ទៅរកទម្រង់ដើមនៃសំណុំរឿង ០០២/០១ "ស្របតាមវិសាលភាពនៃការជំនុំជម្រះដែលភាគីទាំងអស់បានដឹងពីដំបូង"នឹងអាចជួយសម្រាលក្តីបារម្ភពាក់ព័ន្ធទៅនឹងសច្ចភាពផ្លូវច្បាប់[824] និងបានបង្គាប់ឱ្យ"បន្តកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ចាប់ពីចំណុចដែលអង្គជំនុំជម្រះបានបំបែកពីមុនមកនៅពេលដែលសេចក្តីសម្រេច[អង្គជំនុំជម្រះតុលាការកំពូល]បានចេញនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣"[825]។

289. បន្ទាប់មក Philip SHORT បានផ្តល់សក្ខីកម្មនៅថ្ងៃទី ០៦ ដល់ ០៩ ខែ ឧសភា ឆ្នាំ ២០១៣[826]។ នៅមុនពេលចាប់ផ្តើមសក្ខីកម្មរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានរំឭកភាគីថា Philip SHORT អាចត្រូវបានសួរលើបញ្ហាទាំងអស់ដែលគាត់អាចឆ្លើយបាន"អាស្រ័យលើចំណេះដឹងរបស់គាត់"[827] និងបានជម្រុញភាគីឱ្យសួរសំណួរអ្នកជំនាញដោយផ្អែកលើការបំបែកសំណុំរឿងទីពីរនៃសំណុំរឿង ០០២ (E284)។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "វិសាលភាពសម្រាប់ការសួរសំណួរសាក្សីនេះមានលក្ខណៈទូលំទូលាយនៅក្នុងសំណុំរឿង ០០២ [...] ទោះជាយ៉ាងណាក្តី ភាគីទាំងអស់គប្បីផ្តោតសំណួររបស់ខ្លួនលើផ្នែក

---

[821] ឧបសម្ព័ន្ធ ១៖ អ៊ីម៉ែលពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគីនៃសំណុំរឿង ០០២ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ E264/1/2/1/1.2 (អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកម្មវត្ថុ "សេចក្តីណែនាំដល់ភាគីក្រោយពីសវនាការលើការបំបែកសំណុំរឿង" ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣)។

[822] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ E1/176.1 ទំព័រ ២-៤។

[823] សេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង ០០២ ក្រោយពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E284 ("សេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង ០០២ លើកទីពីរ (E284)")។

[824] សេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង ០០២ លើកទីពីរ (E284) កថាខណ្ឌ ៨៨។

[825] សេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង ០០២ លើកទីពីរ (E284) កថាខណ្ឌ ៩០។

[826] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1។ ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1។ ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/192.1។

[827] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ១។

ពាក់ព័ន្ធនៃសំណុំរឿងដែលត្រូវបានបំបែកជាពិសេសសំណុំរឿង ០០២/០១”[828]។ ប្រតិចារឹកបានបង្ហាញថា បើទោះបីជាភាគីជាទូទៅត្រូវបានណែនាំឱ្យផ្តោតទៅលើសំណុំរឿង ០០២/០១ ក៏ដោយ ក៏ការសួរសំណួរទូលំទូលាយនោះស្ថិតក្នុងតែវិសាលភាពនៃជំនាញរបស់ Philip SHORT ដែរ។ នេះជាការប្រើប្រាស់ឆន្ទានុសិទ្ធិដោយសមហេតុផល និងជាក់ស្តែងនៃការគ្រប់គ្រងសវនាការជាពិសេសដោយពិចារណាលើភាពស្មុគស្មាញដែលកើតចេញពីការបំបែកសំណុំរឿងនោះ។ គួរកត់សម្គាល់បន្ថែមថា ការណែនាំនេះត្រូវបានប្រកាសដឹងឮដល់ភាគីនៅមុនការសួរដេញដោលអ្នកជំនាញទាំងនេះ។

290. ក្នុងការគាំទ្រសារណារបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុញ្ញាតឱ្យសួរសំណួរ Philip SHORT ហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ខៀវ សំផន បានចង្អុលបង្ហាញទៅលើការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពើប្រល័យពូជសាសន៍ដែលបានស្នើឡើងដោយ នួន ជា ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃសម្រាប់ការប្រើប្រាស់នៅក្នុងការសួរសំណួរ Philip SHORT[829]។ ឯកសារនោះជាប់ពាក់ព័ន្ធទៅនឹងអត្ថបទរបស់អ្នកនិពន្ធ Blythe YEE ចំណងជើងថា “ការតម្រង់ទិសក្នុងភាពងងឹត”ដែលក្នុងនោះ Philip SHORTបានពិភាក្សាវិធីសាស្ត្រនៃការស្រាវជ្រាវដែលគាត់បានប្រើប្រាស់ក្នុងការនិពន្ធសៀវភៅរបស់គាត់“ប៉ុលពត៖ ការវិភាគនៃសុបិនអាក្រក់” និងប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ Philip SHORT ដែលបានធ្វើឡើងដោយ Charlie ROSE នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៥ អត្ថបទចំណងជើងថា “កម្ពុជាប្រឈមមុខនឹងពាក្យ‘ល័យពូជសាសន៍’”និពន្ធដោយ Brendan BRADY ស្តីពីបញ្ហាថាតើអំពើប្រល័យពូជសាសន៍បានកើតឡើងក្នុងកម្ពុជា និងការរាយការណ៍របស់ទូរទស្សន៍សារព័ត៌មានចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីសេចក្តីសម្រេចក្នុងការចោទប្រកាន់បទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាប់ចោទ ដែលក្នុងនោះ Philip SHORT ត្រូវបានដកស្រង់ថាបានធ្វើការអធិប្បាយអំពីបទចោទនេះ[830]។ តាមការសង្កេតឃើញថា ក្នុងអំឡុងពេលនៃកិច្ចដំណើរ

[828] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ១។

[829] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា៖ “ការឆ្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងសុំដាក់ឯកសារថ្មីក្នុងសំណុំរឿងពាក់ព័ន្ធទនឹងសក្ខីកម្មរបស់សាក្សី François PONCHAUD និង Sydney SCHANBERG (E243) និងអ្នកជំនាញ Philip SHORT (E226, E226/1 និង E230) និង Elizabeth BECKER (E232 និង E232/1)” ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E260 (“អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E260)”) កថាខណ្ឌ ៧-៨។ សំណើស្របតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងសុំប្រើប្រាស់ឯកសារក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី Philip SHORT ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E226។

[830] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E260) កថាខណ្ឌ ៧។

ការនីតិវិធីសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំឱ្យទទួលយកភស្តុតាង និងបានផ្តល់សំអាងហេតុថាៈ

> "ដោយសារអំពើប្រល័យពូជសាសន៍ពុំមែនជាផ្នែកនៃបទចោទក្នុងរឿងក្តីបច្ចុប្បន្ន និងដោយសារ Philip SHORT នឹងត្រូវផ្តល់សក្ខីកម្ម និងដូច្នេះភាគីអាចសួរសំណួរគាត់បានអំពីវិធីសាស្ត្រនៃការស្រាវជ្រាវ អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់ថា មានភាពជាប់ពាក់ព័ន្ធ ឬចាំបាច់ក្នុងការទទួលយកឯកសារទាំងនេះ"[831]។

អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមថា ឯកសារមួយចំនួនចោទបានជាបញ្ហានៃភាពអាចជឿទុកចិត្តបាន ពីព្រោះទំនងជាត្រូវបានរៀបចំដោយមេធាវីការពារក្តី នួន ជា ផ្ទាល់"ដោយសន្មតថា តាមរយៈការចម្លងខ្លឹមសារនៃឯកសារដើមឡើងវិញ"[832]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីជាឯកសារទាំងនោះពុំត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០១ និងពុំត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលនៃការសួរ Philip SHORT ក៏ដោយ ក៏ឯកសារជាច្រើនទាំងនេះចុងក្រោយត្រូវបានដាក់ចូលសំណុំរឿងដែលជាផ្នែកនៃបញ្ជីឯកសាររបស់ ខៀវ សំផន តាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុងដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងការរៀបចំសម្រាប់ការជំនុំជម្រះសំណុំរឿង ០០២/០២[833]។ អង្គជំនុំជម្រះសាលាដំបូបានទទួលយកឯកសារដែលត្រូវបានស្នើឡើងនេះ ដោយសារអាចឱ្យអង្គជំនុំជម្រះពិចារណាក្នុងសំណុំរឿង ០០២/០២[834]។

291. បន្ថែមលើនេះ សក្ខីកម្មរបស់ Philip SHORT ក្នុងសំណុំរឿង ០០២/០១ ត្រូវបានកាត់សំដីបន្ទាប់ពីការលើកឡើងរបស់គាត់ ដែលប្រើប្រាស់ពាក្យប្រល័យពូជសាសន៍ក្នុងការពិពណ៌នានូវអ្វីបានកើតឡើងលើជនជាតិចាម[835]។ បញ្ហានេះបានកើតឡើងដោយសារបទចោទប្រល័យពូជសាសន៍ពុំមែនជាផ្នែកនៃសំណុំរឿង ០០២/០១ និងពីព្រោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អំពើប្រល័យពូជសាសន៍ គឺជា"ជា

---

[831] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E260) កថាខណ្ឌ ៨។

[832] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៨។

[833] ឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី ខៀវ សំផន សម្រាប់ការជំនុំជម្រះសំណុំរឿង ០០២/០២ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារលេខ E305/12។

[834] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារដែលបានស្នើឡើងឱ្យដាក់ចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ E305/17 ("សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារក្នុងសំណុំរឿង ០០២/០២ (E305/17)") ("អង្គជំនុំជម្រះសាលាដំបូងពិចារណានៅចំពោះមុខ [...] រាល់ឯកសារដែលរៀបរាប់ក្នុងឧបសម្ព័ន្ធ ឃ នៃសេចក្តីសម្រេចនេះ ដែលរួមបញ្ចូលឯកសារដែលត្រូវបានស្នើឡើងក្នុងបញ្ជីឯកសាររបស់ ខៀវ សំផន")។

[835] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៤៦-៤៧។

សញ្ញាណផ្នែកច្បាប់" និង"សម្រាប់ថៅក្រម"ដែលជាអ្នកកំណត់[836]។ ទោះជាយ៉ាងណាក្តីគាត់ត្រូវបានសួរត្រួសៗលើប្រធានបទនេះដោយមេធាវីការពារក្តី នួន ជា[837]។

292. សំខាន់ជាងនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា Philip SHORT ត្រូវបានចាត់តាំងជាអ្នកជំនាញស្តីពីការវិវឌ្ឍន៍ដំបូងនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួមទាំងការគាបសង្កត់សាសនា ជាជាងការទាក់ទងទៅនឹងការអនុវត្តន៍ក្រោយឆ្នាំ ១៩៧៥។ Philip SHORT ត្រូវបានសួរយ៉ាងទូលំទូលាយលើប្រធានបទនេះ ដែលជាប់ពាក់ព័ន្ធផងដែរទៅនឹងសំណុំរឿង ០០២/០២ និងលើវិធីសាស្ត្រនៃការស្រាវជ្រាវរបស់គាត់។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធការកោះហៅ Philip SHORT ដោយផ្អែកលើមូលដ្ឋានថា សក្ខីកម្មរបស់គាត់ទំនងជាន់គ្នា។ យោងតាមទិដ្ឋភាពខាងលើ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវការរំលោភបំពានលើសិទ្ធិទទួលបានការសួរដេញដោលចំពោះមុខ ឬថា ព្យសនកម្មបានកើតឡើងដោយ សារសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

៧. ការខកខានក្នុងការបើកកិច្ចដំណើរការនីតិវិធីឡើងវិញដើម្បីទទួលយកភស្តុតាងរបស់សាក្សីពីររូប

293. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ ដោយសារខកខានក្នុងការបើកកិច្ចដំណើរការនីតិវិធីឡើងវិញទទួលយកចម្លើយជាលាយលក្ខណ៍អក្សរដែលបានបង្ហាញពីសំណុំរឿង ០០៣ និង ០០៤ របស់ ឯក ហេន និង ជួន ធី ក្រោយពីសវនាការបានបញ្ចប់[838] និងថា ចម្លើយនេះ"មានផលប៉ះពាល់សំខាន់លើការវាយតម្លៃអំពីភាពអាចជឿជាក់ និងទុកចិត្តបាននៃភស្តុតាងរបស់គាត់" និងថា ឱកាសបានបាត់បង់ក្នុងការពិភាក្សាលើអំណះអំណាងដែលបានលើកឡើងពាក់ព័ន្ធទៅនឹងភាពពុំស៊ីសង្វាក់គ្នារបស់ ឯក ហេន និងភស្តុតាងដោះបន្ទុករបស់ ជួន ធី"[839]។ ខៀវ សំផន បានអះអាងថា ការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូង ដូចបានបង្ហាញក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[840] គឺត្រូវទទួលយកចម្លើយពីមុនទាំងអស់របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែល

---

[836] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៤៦-៤៧។

[837] ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/192.1 ទំព័រ ១១-១២។

[838] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤-២៤៦។

[839] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៦។

[840] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥១។

ត្រូវបានបង្ហាញពីសំណុំរឿង ០០៣ និង ០០៤ នៅពេលបុគ្គលទាំងនេះត្រូវបានស្តាប់នៅពេលជំនុំជម្រះ[841]។ ផ្អែកតាមទស្សនៈរបស់គាត់បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តផ្ទុយទៅនឹងការអនុវត្តន៍ពីមុនរបស់ខ្លួន នៅពេលដែលខកខានក្នុងការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធីដើម្បីទទួលយកចម្លើយរបស់ ជួន ធី និង ឯក ហេន បន្ទាប់ពីការបង្ហាញចុងក្រោយនៃចម្លើយចេញពីសំណុំរឿង ០០៣ និង ០០៤[842]។ គាត់បានអះអាងថា ការមិនបើកឡើងវិញនេះបានរារាំងគាត់ក្នុងការពិភាក្សាខ្លឹមសារនៃចម្លើយដោះបន្ទុក ឬភាពអាចជឿជាក់បានរបស់សាក្សី ឯក ហែន និង ជួន ធី[843] ពីព្រោះភាគីមិនអាចលើកសារណាក្នុងអំឡុងពេលនៃកិច្ចពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកលើវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង[844]។ បើទោះបីគាត់បានទទួលស្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកចម្លើយនេះនៅបណ្តឹងសាទុក្ខក៏ដោយ ក៏ទោះជាយ៉ាងណាក្តីគាត់បានអះអាងថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានបណ្តាលឱ្យមានព្យសនកម្មដោយសារគាត់បាន“បាត់បង់ឱកាសលើករឿងក្តីរបស់គាត់នៅចំពោះមុខយុត្តាធិការជាន់ដំបូងដែរ”[845]។

294. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និង/ឬរំលោភបំពានលើឆន្ទានុសិទ្ធិដោយសារពុំបានបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធីទទួលយកចម្លើយរបស់ ឯក ហេន និង ជួន ធី ដែលនៅក្នុងគ្រប់កាលៈទេសៈត្រូវបានទទួលយកនៅបណ្តឹងសាទុក្ខ[846]។ សហមេធាវីនាំមុខបានយល់ស្របជាមួយ[847]។

295. តាមការអះអាងរបស់ ខៀវ សំផន បានឱ្យដឹងថា ពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង“បានទទួលយកចម្លើយពីមុនទាំងអស់របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញពីសំណុំរឿង ០០៣ និង ០០៤ នៅពេលបុគ្គលទាំងនេះត្រូវបានស្តាប់នៅពេលជំនុំជម្រះ”[848]

---

[841] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤។

[842] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤-២៤៥។ ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1) ទំព័រ ១២។

[843] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៥-២៤៦។

[844] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៥។

[845] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៦។

[846] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៩-៨៣។

[847] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១០២-១០៥។

[848] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥១។

។ ការអនុវត្តន៍នេះត្រូវបានធ្វើឡើងដើម្បីអត្ថប្រយោជន៍យុត្តិធម៌ក្នុងការផ្តល់ឱ្យ"ភាគីនូវឱកាសសួរដេញដោលបុគ្គលទាំងនេះដែលមានភាពពុំស៊ីសង្វាក់គ្នាដែលរងការចោទប្រកាន់រវាងភស្តុតាងផ្ទាល់មាត់នៅពេលសវនាការ និងចម្លើយពីមុន"[849]។ ខៀវ សំផន បានតវ៉ាថា ការអនុវត្តន៍នេះពុំមានអានុភាពចំពោះឯកសារដែលត្រូវបានបង្ហាញក្រោយការបិទកិច្ចដំណើរការនីតិវិធីលើភស្តុតាង និងក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដេញដោល[850]។

296. ឯកសារនេះជាប់ពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ ជួន ធី និង ឯក ហេន ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងបរិបទនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ និង ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ នីមួយៗ[851]។ កំណត់ហេតុស្តាប់ចម្លើយនេះត្រូវបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨[852]ភ្លាមៗនៅមុនការប្រកាស

---

[849] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥១។ *សូមមើលផងដែរ:* សេចក្តីសម្រេចលើសំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E421/4)។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានបង្ហាញថ្មីៗចេញពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២" ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ ឯកសារលេខ E319/68/១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានបង្ហាញថ្មីៗចេញពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២" ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ E319/69។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានបង្ហាញថ្មីៗចេញពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២" ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ E319/67។

[850] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៤-២៤៦។

[851] កំណត់ហេតុស្តាប់ចម្លើយសាក្សី (ជួន ធី) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ [បកប្រែភាសាអង់គ្លេស ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧] ឯកសារលេខ E319/71.2.4។ កំណត់ហេតុស្តាប់ចម្លើយសាក្សី (ឯក ហេន) ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ [បកប្រែភាសាអង់គ្លេស ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧] ឯកសារលេខ E319/71.2.7។

[852] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារដែលបានស្នើឡើងពីសំណុំរឿង ០០៣ និង ០០៤ ៣ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E319/71។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចំណងជើងថា "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារសំណុំរឿង ០០៣ និង ០០៤ (សម្ងាត់)" ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E319/71/1។ សេចក្តីសម្រេចលើសំណើសុំបង្ហាញឯកសារលេខ E319/71/1 ដែលបានណែនាំដោយអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E319/71/2។ សេចក្តីសម្រេចលើសំណើសុំបង្ហាញ ឯកសារលេខ E319/71/1 ដែលបានណែនាំដោយអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E319/71/3។

សាលក្រមសង្ខេបនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨[853] និងចំពេលនៃការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបន្ទាប់ពីការបិទកិច្ចដំណើរការនីតិវិធីលើភស្តុតាង[854]។

297. វិធាន ៩៦(២) នៃវិធានផ្ទៃក្នុងដែលបញ្ញត្តិអំពីការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចែងថា "នៅក្នុងដំណាក់កាលនេះ គ្មានពាក្យសុំណាមួយអាចត្រូវបានលើកយកមកសំអាងទៀតទេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងគ្មានសេចក្តីសន្និដ្ឋានណាមួយអាចទទួលយកបានទៀតដែរ។ អំឡុងពេលពិភាក្សាសម្រេច *ចៅក្រមអាចបើកនីតិវិធីឡើងវិញបាន*"[855]។ ពាក្យ"អាច"បង្ហាញនូវលក្ខណៈឆន្ទានុសិទ្ធិនៃសិទ្ធិអំណាចរបស់តុលាការ និងភាពចៃដន្យនៃការលើកឡើងនោះ។ ជាក់ស្តែង មានការទទួលយកភស្តុតាងដែលពុំមានអត្ថិភាពពីដំបូងដែលអាចប៉ះពាល់ដល់ភស្តុតាងដែលត្រូវបានស្តាប់រួចហើយ។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញអង្គជំនុំជម្រះតុលាការកំពូលនូវសេចក្តីសម្រេចរបស់ តុលាការ ICTY[856] ដែលបានបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូង"ត្រូវតែពិចារណាលើបញ្ហាថាតើតម្លៃជាភស្តុតាងនៃឯកសារនោះមានសារៈសំខាន់ជាងការពន្យារពេលដែលបានបង្កឡើងតាមរយៈការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធី ដោយពិចារណាលើដំណាក់កាលនៃការជំនុំជម្រះដែលសំណើនេះត្រូវបានធ្វើឡើង ដែរ ឬយ៉ាងណា"[857]។ ក្នុងករណីនេះ ចម្លើយរបស់សាក្សីពីរនាក់នោះពុំមានអត្ថិភាពរហូតដល់ការពិភាក្សាសម្រេចត្រូវបានបញ្ចប់។ ពុំមានការរិះគន់ណាមួយកើតឡើងពីសំណាក់មេធាវីការពារក្តី ខៀវ សំផន និងពុំមានភាពមិនយុត្តិធម៌កើតឡើងតាមរយៈអង្គជំនុំជម្រះសាលាដំបូងដែលស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការសរសេរសាលក្រម។ លើកលែងតែចម្លើយសាក្សីថ្មីមានលក្ខណៈចាំបាច់បំផុត ដែលក្នុងករណីនេះច្បាស់លាស់មិនមែនដូច្នោះឡើយ ទើបអង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនបើកឡើងវិញនូវកិច្ចដំណើការនីតិវិធីជំនុំជម្រះ។

298. បើទោះបីជាចម្លើយនោះពុំបានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ក្នុងការកែប្រែការអនុវត្តន៍របស់ខ្លួនក៏ដោយ ក៏បច្ចុប្បន្នស្ថិតចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលសម្រាប់ការពិចារណា។ អង្គជំនុំជម្រះតុលាការ

---

[853] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1 ("ការប្រកាសសេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២")។

[854] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ E1/528.1 ទំព័រ ២៩។

[855] វិធាន ៩៦(២) នៃវិធានផ្ទៃក្នុង (សេចក្តីបញ្ជាក់បន្ថែម)។

[856] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨១។

[857] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨១ យោងទៅលើសាលដីការឿងក្តី *Čelebići* (ICTY) កថាខណ្ឌ ២៨៣។

កំពូលរំឭកថា នៅក្នុងសេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកចម្លើយទាំងនេះនៅបណ្តឹងសាទុក្ខបានបញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិពុំមានកំហុស“សម្រាប់ការផ្ទេរនៅពេលនោះនូវភស្តុតាងដែលចោទជាបញ្ហានោះដើម្បីបង្ហាញឡើយ”[858] និងថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងជាខ្សែអាត់ថតសម្លេងជាភស្តុតាងដោយផ្អែកលើមូលដ្ឋានថា “ឯក ហេន និង ជួន ធី គឺជាសាក្សីគន្លឹះចំពោះការយល់ឃើញមួយចំនួន” និងពីព្រោះ“មេធាវីការពារក្តី ខៀវ សំផន បានផ្តល់តម្លៃយ៉ាងខ្លាំងទៅលើលក្ខណៈដោះបន្ទុកជាសក្តានុពលនៃភស្តុតាង”[859]។ អាស្រ័យហេតុនេះ ចម្លើយដែលចោទជាបញ្ហានេះ គឺជាផ្នែកនៃសំណុំរឿង និងត្រូវបានពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងអំឡុងពេលនៃដំណាក់កាលបណ្តឹងសាទុក្ខនៃកិច្ចដំណើរការនីតិវិធីទាំងនេះ។ គួររំឭកថា ក្នុងការកំណត់ថាតើ ព្យសនកម្មបានកើតឡើងដែលនាំទៅរក “លទ្ធផលមិនយុត្តិធម៌ទាំងស្រុងក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ” ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាវាល់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងវិធានការដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃដំណាក់កាលបណ្តឹងសាទុក្ខ[860]។ អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវព្យសនកម្មណាមួយបានកើតឡើង ហើយសារណារបស់គាត់ដែលថាគាត់បានបាត់បង់ឱកាសក្នុងការលើកបញ្ហានេះចំពោះមុខយុត្តាធិការកម្រិតណាមួយ ពុំមានមូលដ្ឋានគាំទ្រត្រឹមត្រូវ[861]។

## ង. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងវិធីសាស្ត្របង្ហាញភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង

### ១. ការជំទាស់ទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង

#### ក. បន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង

[858] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងបន្ថែម (F51/3) កថាខណ្ឌ ៣៣។

[859] សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងបន្ថែម (F51/3) កថាខណ្ឌ ៣៧។

[860] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០០។

[861] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៦។

299. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានលើកបង្ហាញត្រឹមត្រូវនូវបទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ការដាក់ពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យ ប៉ុន្តែថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តន៍គោលការណ៍នេះ[862]។

300. គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ពុំត្រឹមត្រូវនូវគោលគំនិតជំនឿឥស្សរចិត្តក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងជាក់ស្តែងបានប្រើប្រាស់បទដ្ឋានកម្រិតទាបជាងដែលអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ[863]។ ប្រសិនបើអង្គជំនុំជម្រះបានអនុវត្តបទដ្ឋានផ្នែកច្បាប់ត្រឹមត្រូវ អង្គជំនុំជម្រះ"ពុំអាចជឿជាក់ថា ខៀវ សំផន មានពិរុទ្ធឡើយ"[864] និងអាស្រ័យហេតុនេះ ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃៈការដាក់ពិរុទ្ធភាព និងការដាក់ទោសនេះ[865]។

301. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញកំហុស[866]។

302. នៅចំពោះមុខ អ.វ.ត.ក. សច្ចធារណ៍និរទោស និងបន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង ត្រូវបានចែងនៅក្នុងវិធាន ២១(ឃ) និង ៨៧(១) នៃវិធានផ្ទៃក្នុង[867]។ ច្បាប់កម្ពុជាផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិល ដែលមានសញ្ញាណនៃជំនឿឥស្សរចិត្តរបស់ចៅក្រម។ សញ្ញាណនេះមានក្នុងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងនៃសំណៅជាភាសាបារាំង ចំណែកសំណៅជាភាសាខ្មែរ និងអង់គ្លេសបង្ហាញថា ការយល់ឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ តម្រូវថា អង្គជំនុំជម្រះត្រូវជឿជាក់ឱ្យហួសពីវិមតិសង្ស័យ។

303. ក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

---

[862] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៩, ២៣៧។

[863] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៧-២៣០។

[864] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣១។

[865] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣១។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ១៨, ៣២ និងប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ទំព័រ ៣៧។

[866] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៥-១០១។

[867] វិធាន ២១(ឃ) ចែងក្នុងផ្នែកពាក់ព័ន្ធថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"។ វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

ជនជាប់ចោទត្រូវបានចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់ មិនទាន់ត្រូវបានរកឃើញ។ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាង។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវមានជំនឿដោយ"គ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ" [...] បន្ទាប់ពីវាយតម្លៃដោយមានសំអាងហេតុលើភស្តុតាង អង្គជំនុំជម្រះត្រូវបកស្រាយអត្ថិភាពនៃវិមតិសង្ស័យណាមួយទាក់ទងទៅនឹងពិរុទ្ធភាពជាប្រយោជន៍ជនជាប់ចោទ[868]។

304. ដូច្នេះ បើទោះបីជាការបំភ្លឺរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលគំនិតប្រព័ន្ធច្បាប់ស៊ីវិលនៃជំនឿឥស្សរចិត្តក្នុងកម្រិតណាក៏ដោយ ក៏អង្គជំនុំជម្រះបានបង្ហាញត្រឹមត្រូវនូវបន្ទុក និងបទដ្ឋានជាធរមាននៃភស្តុតាងដូចបានបញ្ជាក់ថា "អង្គហេតុទាំងអស់ដែលជាមូលដ្ឋាននៃធាតុផ្សំឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នោះ ព្រមទាំងអង្គហេតុដែលចាំបាច់ខានពុំបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពនោះ [...] ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ"[869]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ត្រឹមត្រូវបន្ថែមទៀតថា "នេះត្រូវតែបានគាំទ្រដោយការផ្តល់សំអាងហេតុសមស្របដែលផ្អែកលើភស្តុតាងទាំងមូល ដោយពុំចាំបាច់អនុវត្តនូវបទដ្ឋាននៃការបង្ហាញភស្តុតាង"ឱ្យហួសពីវិមតិសង្ស័យ"តាមលក្ខណៈជាផ្នែកៗឡើយ"[870]
។

305. ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសអង្គច្បាប់ក្នុងការយល់ ឬការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីសច្ចធារណ៍និរទោស និងបន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង។ ទាក់ទងទៅនឹងការអនុវត្តន៍ក្នុងការវាយតម្លៃលើភស្តុតាង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន ជាទូទៅបានសំដៅទៅលើការយល់ឃើញ"ដោយឥតសមហេតុផល" ដែលគាត់បានជំទាស់ថា "ត្រូវបានបង្ហាញក្រោមកម្រិតនៃជំនឿឥស្សរចិត្តនេះ" ដោយពុំបានផ្តល់ភាពជាក់លាក់បន្ថែមទៀតនោះឡើយ[871]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នេះជាកាតព្វកិច្ចរបស់ភាគីនៅបណ្តឹងសាទុក្ខក្នុងការលើកមូលដ្ឋានគាំទ្រការចោទប្រកាន់កំហុសនៅក្នុងសាលក្រមដែលរងការជំទាស់នេះ។ ក្នុងករណីដែលការចោទប្រកាន់កំហុសនោះ ពុំត្រូវបានបង្ហាញច្បាស់លាស់ ឬមានលក្ខណៈជាក់លាក់ អង្គជំនុំជម្រះពុំមានកាតព្វកិច្ចផ្តល់សំអាងហេតុទូលំទូលាយ ឬអាចតាមឆន្ទានុសិទ្ធិបដិសេធមិនធ្វើការយល់ឃើញណាមួយឡើយ។ ផ្ទុយទៅវិញ ក្នុង

---

[868] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨ (ដើងទំព័រលុបចោល)។

[869] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០។

[870] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១ ដែលមានលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់អំពីតម្លៃជាភស្តុតាង)។

[871] *សូមមើល* ឧ. សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៩, ២៣៧ យោងទៅលើកថាខណ្ឌ ១៤២១។

ករណីដែលការអះអាងទាំងនោះបានបង្ហាញគ្រប់គ្រាន់នៅក្នុងផ្នែកដទៃទៀតនៃទឡ្ហីករណ៍បណ្ដឹងសាទុក្ខ ការអះអាងនោះនឹងត្រូវបានដោះស្រាយនៅក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះ។

306. អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះត្រូវបដិសេធចោល។

### ខ. ការផ្ដល់សំអាងហេតុដែលផ្អែកលើការសន្និដ្ឋានពុំត្រូវបានអនុញ្ញាត ការសន្និដ្ឋានពង្រីក និងការសន្និដ្ឋានជាទូទៅ

307. ខៀវ សំផន បានលើកឡើងថា ការសន្និដ្ឋានដែលបានទាញចេញពីភស្តុតាង"ត្រូវតែស្របជាមួយនឹងទោសរបស់ជនជាប់ចោទ"[872]។ ការធ្វើដូច្នេះ"បានរារាំងការសន្និដ្ឋានបំផ្លើសក្នុងការបង្កើតការយល់ឃើញដែលត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ"[873]។ គាត់បានអះអាងថា បើទោះបីជាបានបង្ហាញត្រឹមត្រូវនូវបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការផ្ដល់សំអាងហេតុផ្អែកលើការសន្និដ្ឋានដែលពុំត្រូវបានអនុញ្ញាត និងការសន្និដ្ឋានបំផ្លើសចេញពីភស្តុតាងដែលត្រូវបានសន្និដ្ឋានទូទៅក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំត្រឹមត្រូវលើគោលការណ៍ទាំងនេះ។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង"បានអនុវត្តផ្ទុយខ្លួនឯង [...] តាមរយៈការបង្កើតការយល់ឃើញដោយផ្អែកលើការសន្និដ្ឋានយកទូទៅ និងការសន្និដ្ឋានបំផ្លើសដែលពុំមានអត្ថិភាពក្នុងសាលក្រមនៃរឿងក្ដីព្រហ្មទណ្ឌឡើយ"[874]។ បទដ្ឋានទាំងនេះបានតម្រូវផងដែរឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើលទ្ធភាពនៃការពន្យល់មួយបែបផ្សេង ដែលបានជាប្រយោជន៍ដល់រូបគាត់[875]។

308. ផ្អែកលើមូលដ្ឋាននេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមាន"កំហុសជាច្រើនផ្នែកអង្គច្បាប់ដែលបានបណ្ដាលឱ្យមានការមោឃៈ" និងថា អង្គជំនុំជម្រះតុលាការកំពូលត្រូវប្រកាសការជំនុំជម្រះរបស់គាត់ថា មានភាពមិនយុត្តិធម៌[876]។ ក្នុងការគាំទ្រទឡ្ហីករណ៍ទាំងនេះ គាត់បានយោងទៅលើកថាខណ្ឌ ៦៤ និង ៦៥ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងបានដាក់បញ្ចូលតាមរយៈការយោងនូវឧទាហរណ៍

[872] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៨។

[873] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៩។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1) ទំព័រ ១១។

[874] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៩។

[875] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤-៦៥។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៩៨។

[876] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៨-២៣៩។

ដែលទាញចេញពីកថាខណ្ឌ ៦៩៥, ៩១០, ១៦១១, ១៨២៩ ដល់ ១៨៣៥ និង ១៨៨១ នៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួន[877]។

309. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ការជំទាស់របស់ ខៀវ សំផន គប្បីបដិសេធចោល[878]។

310. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដើម្បីដាក់ពិរុទ្ធ“រាល់ការសន្និដ្ឋានសមហេតុផលទាំងអស់ដែលអាចទាញចេញពីភស្តុតាងត្រូវតែស្របជាមួយនឹងទោសរបស់ជនជាប់ចោទ”[879]។ បន្ថែមលើនេះអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសាលដីកាសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះតុលាការកំពូលបានសង្កេតថា៖

> ក្នុងរឿងក្តីដែលពាក់ព័ន្ធនឹងបទល្មើសធំធេង ការកោះហៅសាក្សីទាំងអស់មកផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍ជាច្រើនដែលចោទជាបញ្ហានោះ គឺពុំអាចធ្វើទៅបានឡើយ។ ក្នុងស្ថានភាពបែបនេះ តុលាការអង្គហេតុអាចត្រូវបានតម្រូវឱ្យទាញយកសេចក្តីសន្និដ្ឋានចេញពីភស្តុតាង [របស់បុគ្គលមួយចំនួនតូចដែលត្រូវបានស្តាប់] ដែលមានបទពិសោធន៍ទូលំទូលាយជាង[880]។

311. ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “សេចក្តីសន្និដ្ឋានជាទូទៅអាចត្រូវបានទាញចេញពីភស្តុតាងជាក់លាក់របស់សាក្សីមួយចំនួន *ប៉ុន្តែសម្រាប់តែក្នុងករណីដែលការយល់ឃើញជាទូទៅនោះត្រូវបានបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យប៉ុណ្ណោះ*”[881]។

---

[877] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៨ ជើងទំព័រ ៣៣៣ (ការដាក់បញ្ចូលតាមរយៈការយោងគ្មានការបញ្ជាក់ជាក់លាក់បន្ថែម “ឧទាហរណ៍ផ្នែកអង្គហេតុ”ក្នុងកថាខណ្ឌ ៦៩៥, ៩១០, ១៦១១ និង ១៨៨១។ សារណាបណ្តឹងសាទុក្ខ របស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៩ ជើងទំព័រ ២៣៦ (ប្រហាក់ប្រហែលគ្នានេះ បានរួមបញ្ចូលតាមរយៈការយោងនូវឧទាហរណ៍“ផ្នែកអង្គហេតុ”ដែលមាននៅក្នុងកថាខណ្ឌ ១៨២៩-១៨៣៥ នៃសារណាបណ្តឹងសាទុក្ខ នៅពេលបានបន្ថែមថា “សេចក្តីសន្និដ្ឋានស្តីពីការដឹងនូវកន្លែងធ្វើការសហករណ៍៖ ការដឹងរបស់ជនជាប់ចោទអំពីសហករណ៍ខេត្តព្រះវិហារ ស្របជាមួយនឹងការដឹងអំពីស្ថានការណ៍ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”)។

[878] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៥-១១១, ១១៥-១១៦។

[879] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤។

[880] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៩៨។

[881] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤ (បញ្ជាក់បន្ថែម)។

312. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា "នៅមុនការទាញយកសេចក្ដីសន្និដ្ឋានផ្ទុយណាមួយចេញពីភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ អង្គជំនុំជម្រះត្រូវពិចារណាទៅលើភាពសមស្របនៃការពន្យល់មួយបែបផ្សេងទៀត រួមទាំងការពន្យល់ដែលអាចជាប្រយោជន៍ដល់ជនជាប់ចោទ"[882]។

313. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីអង្គច្បាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្ដីសន្និដ្ឋានសមស្រប ឬការផ្ដល់នូវការពន្យល់មួយបែបផ្សេងដែលត្រូវបានទាញចេញពីភស្តុតាងនោះ។ បើទោះបីជាទឡ្ហីករណ៍ទាំងនេះបានចោទប្រកាន់នូវកំហុសអង្គច្បាប់ក៏ដោយ ក៏សារណានេះខកខានក្នុងការបញ្ជាក់ជាក់លាក់នូវការមិនគោរពតាមវិធានបញ្ញត្តិណាមួយក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។

314. នៅពេលចោទប្រកាន់កំហុសអង្គហេតុ ជនជាប់ចោទមានកាតព្វកិច្ចក្នុងការបង្ហាញថា សេចក្ដីសន្និដ្ឋានពង្រីកណាមួយនោះដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាជម្រះដំបូងក្នុងការបង្កើតការយល់ឃើញ ពុំសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ដោយប្រុងប្រយ័ត្នថា "អំណះអំណាងដែលកម្រិតត្រឹមតែការមិនយល់ស្របជាមួយនឹងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាដែលបានផ្អែកលើការបកស្រាយមួយបែបផ្សេងលើភស្តុតាងដូចគ្នាដោយគ្មានមូលដ្ឋានគាំទ្រ ពុំមានលក្ខណៈគ្រប់គ្រាន់អាចបដិសេធការយល់ឃើញផ្អែកអង្គហេតុរបស់តុលាការអង្គហេតុបានឡើយ"[883]។

315. ក្នុងការគាំទ្រការជំទាស់របស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំត្រឹមត្រូវនូវបទដ្ឋានគតិយុត្ត ឬបានធ្វើការសន្និដ្ឋានពុំត្រឹមត្រូវផ្អែកអង្គហេតុ ខៀវ សំផន បានយោងទៅលើឧទាហរណ៍នៃ (១) ការផ្លាស់ទីដោយបង្ខំជនជាតិវៀតណាមចេញពីស្រុកត្រាំកក់[884] (២) ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន[885] (៣) ការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា[886] (៤) ការសន្និដ្ឋានដែលបានធ្វើឡើងដោយ

---

[882] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥។

[883] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០។ *សូមមើលផងដែរខាងលើ* ផ្នែក II.គ។

[884] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩៥។

[885] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១០។

[886] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១១។

អង្គជំនុំជម្រះទាក់ទងទៅនឹងការដឹងរបស់គាត់អំពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងនោះ[887] និង (៥) ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីលក្ខខណ្ឌរស់នៅក្នុងខេត្តព្រះវិហារ[888]។

316. ឧទាហរណ៍ទាំងនេះជាញឹកញាប់ពុំបានបំពេញតាមលក្ខខណ្ឌបន្ទុកចាំបាច់នៃភាពជាក់លាក់នេះទេ។ ខៀវ សំផន បានត្រឹមតែដាក់បញ្ចូលតាមរយៈការយោងទៅលើផ្នែកដទៃទៀតនៃសារណាបណ្ដឹងសាទុក្ខរបស់គាត់។ អង្គជំនុំជម្រះតុលាការកំពូលកម្រិតការសង្កេតរបស់ខ្លួននៅចំណុចនេះត្រឹមការចោទប្រកាន់កំហុសនៅក្នុងវិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងនៃការវាយតម្លៃលើភស្តុតាង តែក្នុងករណីដែលកំហុសទាំងនេះអាចកំណត់បានក្នុងសារណារបស់គាត់ប៉ុណ្ណោះ។

317. ក្នុងឧទាហរណ៍ទីមួយដែលត្រូវបានដាក់បញ្ចូលតាមរយៈការយោងពាក់ព័ន្ធទៅនឹងការជំទាស់ទាំងនេះ[889] បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្ដីសន្និដ្ឋានគ្មានមូលដ្ឋានគាំទ្រចេញពីភស្តុតាងដែលមានពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនវៀតណាមក្នុងទ្រង់ទ្រាយធំចេញពីស្រុកត្រាំកក់ក្នុងចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦[890]។ នៅក្នុងការចោទប្រកាន់នេះ ខៀវ សំផន ពុំបានបង្ហាញនូវផ្នែកជាក់លាក់នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ហើយកថាខណ្ឌនៅជាប់ខាងលើនោះបានជំទាស់ទៅនឹងផ្នែកដែលត្រូវបានគូសបង្ហាញក្នុងកថាខណ្ឌ ១១៥៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ កថាខណ្ឌនេះជារួមបានលើកឡើងថាៈ

> ភស្តុតាងបង្ហាញពីការណែនាំយ៉ាងច្បាស់លាស់ឱ្យសម្លាប់ប្រជាជនវៀតណាម ពីថ្នាក់ស្រុក និងបានប្រមូលប្រជាជនវៀតណាមយ៉ាងច្រើនក្នុងរយៈពេលតែប៉ុន្មានថ្ងៃ នៅក្នុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦។ ទោះជាយ៉ាងនេះក្ដី ភស្តុតាងបច្ចុប្បន្នខកខានមិនបានបង្ហាញពីករណីជាក់លាក់នៃការសម្លាប់ប្រជាជនវៀតណាម ជាពិសេសក្នុងអំឡុងពេលនោះឡើយ។ *អង្គជំនុំជម្រះក៏មិនមានភស្តុតាងដើម្បីឱ្យខ្លួនអាចដឹងឱ្យបានច្បាស់លាស់ពីជោគវាសនារបស់ប្រជាជនវៀតណាមដែលត្រូវបានប្រមូលនៅក្នុងពេលនោះដែរ។ បើទោះបីជាមានកង្វះភស្តុតាងដូចនេះក្ដី ក៏អង្គជំនុំជម្រះជឿជាក់ថា ការសន្និដ្ឋានប្រកបដោយហេតុផលតែមួយគត់ពីភស្តុតាងជារួមគឺថា យ៉ាងហោចណាស់ប្រជាជនវៀតណាមយ៉ាងច្រើន ត្រូវបានបង្ខំឱ្យទៅរស់នៅក្នុងប្រទេសវៀតណា*

[887] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨១។

[888] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២៩-១៨៣៥។

[889] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩៥។

[890] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៩-៦៩៥ (បានពិពណ៌នាផ្សេងៗនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ត្រូវបានធ្វើឱ្យមោឃៈដោយសារ“ការសន្និដ្ឋានផ្ទុយ”“ចន្លោះប្រហោងនៃភស្តុតាង” និង“ពុំស៊ីសង្វាក់គ្នា”)។

*មកវិញ ដូចបានបញ្ជាក់តាមរយៈការវាយតម្លៃរបស់អង្គជំនុំជម្រះ ដោយផ្អែកលើទស្សនាវដ្ដីទង់បដិវត្ត ច្បាប់ចេញផ្សាយនៅខែ មេសា ឆ្នាំ ១៩៧៦ និងអំណះអំណាងរបស់អង្គជំនុំជម្រះទាក់ទងនឹងការដោះដូរដែលមាននៅពេលនោះ ដោយខ្មែរក្រោមបានទៅដល់ស្រុកត្រាំកក់ដើម្បីជំនួសប្រជាជនវៀតណាមដែលបានចាកចេញពីស្រុកនេះ ។ ចំណុចនេះធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ប្រជាជនវៀតណាមមួយចំនួនដែលត្រូវបានប្រមូលនៅស្រុកត្រាំកក់បានឆ្លងព្រំដែនអន្តរជាតិ និងត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម ហើយថាមានការបញ្ជាក់ពីចេតនាយ៉ាងខ្លាំងក្នុងការបញ្ជូនប្រជាជនទាំងនោះឲ្យហួសព្រំដែនកម្ពុជា*[891]។

318. ផ្អែកលើផ្នែកដែលបានធ្វើកំណត់សម្គាល់នៃកថាខណ្ឌនេះ ខៀវ សំផន បានចោទជាសំណួរថាតើ អង្គជំនុំជម្រះអាចសន្និដ្ឋានបានយ៉ាងដូចម្ដេចថា ប្រជាជនវៀតណាមជាច្រើនត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលពុំអាចឱ្យអង្គជំនុំជម្រះ ធ្វើការកំណត់វាសនារបស់ជនជាតិវៀតណាមជាក់លាក់ក្នុងស្រុកត្រាំកក់នោះ[892]។ ក្នុងសារណារបស់គាត់បានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង"បានផ្អែកតែទៅលើភស្តុតាងប្រយោលក្នុងការសន្និដ្ឋានហួសពីអ្វីដែលបានកើតឡើងចំពោះប្រជាជនវៀតណាមដែលចេញពីស្រុកត្រាំកក់"[893]។

319. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមូលដ្ឋានក្នុងការស្របតាមសារណានេះ។ សេចក្ដីសន្និដ្ឋានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមនៅស្រុកត្រាំកក់ បានកើតចេញពីការពិនិត្យយ៉ាងទូលំទូលាយលើភស្តុតាងទាំងមូលពាក់ព័ន្ធទៅនឹងការផ្លាស់ទី និងការនិរទេសដោយបង្ខំ។ ភស្តុតាងនេះត្រូវបានទាយចេញពីប្រភពជាច្រើន មានដូចជា សក្ខីកម្មរបស់សាក្សីជាច្រើនដែលបានឃើញផ្ទាល់នូវការប្រព្រឹត្តទៅលើជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ និងទីកន្លែងផ្សេង កំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ ព្រមទាំងឯកសារដែលមាននៅសម័យខ្មែរក្រហម ដូចជា កំណត់ត្រាស្រុកត្រាំកក់[894]

---

[891] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៨ (សេចក្ដីបញ្ជាក់បន្ថែម)។ ផ្នែកដែលត្រូវបានបញ្ជាក់នៃកថាខណ្ឌនេះ ឆ្លើយតបទៅនឹងផ្នែកនៃកថាខណ្ឌដែលរងការជំទាស់នោះក្នុងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩០-៦៩១។

[892] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩២។

[893] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៩៥។

[894] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (465) កថាខណ្ឌ ១១១០-១១២៥ (មួយក្នុងផ្នែកជាច្រើនក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម) បានផ្អែកលើសក្ខីកម្មរបស់សាក្សីជាច្រើន កំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងឯកសារនៅសម័យខ្មែរក្រហមនោះ ដូចជាទង់បដិវត្ត និងកូនសៀវភៅកត់ត្រាក្រាំងតាចាន់ និងកំណត់ត្រាស្រុកត្រាំកក់សម័យនោះ (បានយោងផ្សេងៗគ្នាក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (465) ជើងទំព័រ ៣៧០៧-៣៧៤៨)។

។ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជនជាតិវៀតណាមជាច្រើនត្រូវបានប្រមូលផ្ដុំក្នុងស្រុកត្រាំកក់ចាប់តាំងពីចុងឆ្នាំ ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៦ ដោយមានការបណ្ដេញចេញជាច្រើន និង/ត្រូវបានធ្វើឱ្យបាត់ខ្លួន[895]។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា នេះបានកើតឡើងស្របពេលជាមួយនឹងបរិយាកាសបង្ខិតបង្ខំដែលក្នុងនោះប្រជាជនវៀតណាមដែលពាក់ព័ន្ធ បើទោះបីបានរស់នៅដោយស្របច្បាប់នៅពេលនោះក៏ដោយ ក៏គ្មានជម្រើសពិតប្រាកដក្រៅតែពីចាកចេញ[896]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា មានកិច្ចព្រមព្រៀងរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងអាជ្ញាធរវៀតណាមក្នុងការដោះដូរមនុស្ស និងថា ខ្មែរក្រោមបានមករស់នៅស្រុកត្រាំកក់ ជំនួសប្រជាជនវៀតណាមដែលបានចាកចេញពីស្រុកនេះ[897]។ ទាក់ទងទៅនឹងការសន្និដ្ឋានដែលទាញចេញពីភស្តុតាងជារួម អង្គជំនុំជម្រះសាលាដំបូងលើកបង្ហាញមុនគេនូវការយល់ឃើញដែលថា ជនជាតិវៀតណាមនៅស្រុកត្រាំកក់ ជាអប្បបរមា ត្រូវបានបណ្ដេញទៅប្រទេសវៀតណាម។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានតុលាការអង្គហេតុសមហេតុផលអាចជំទាស់ទៅនឹងចំណុចតូចតាចនៃការសន្និដ្ឋាននោះឡើយ។ ពិតណាស់ ខៀវ សំផន ពុំបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញថា ការយល់ឃើញទាំងនេះពុំមានមូលដ្ឋានគាំទ្រ ឬថា ជាការសន្និដ្ឋានពុំសមហេតុផលចេញពីភស្តុតាងទាំងមូលនោះឡើយ។ ការអះអាងរបស់ ខៀវ សំផន ដែលថា សេចក្ដីសន្និដ្ឋានទាំងនេះត្រូវបានធ្វើឡើងតាមរយៈការសន្និដ្ឋានបំផ្លើសដោយគ្មានភស្តុតាងគាំទ្រត្រូវបដិសេធចោល។

320. ក្នុងឧទាហរណ៍ទីពីររបស់គាត់[898] ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ជនជាតិចាមត្រូវបានឃុំឃាំងនៅវត្តអូរត្រកួន នៅមុនពេលត្រូវបានយកចេញទៅក្នុងទ្រង់ទ្រាយធំ។ ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គាត់បានអះអាងថា "ភស្តុតាងប្រយោលទាំងនេះពុំអាចបង្ហាញ និងពុំគ្រប់គ្រាន់ក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជនជាតិចាមត្រូវបានកម្ទេចនោះឡើយ"[899]។

---

[895] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១២៥។

[896] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៧។ *សូមមើលផងដែរខាងក្រោម* ផ្នែក VII.ឃ.១។

[897] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១០-១១២៥, ១១៥៦-១១៥៩, ៣៤២៩-៣៤៤០, និង ៣៥០២-៣៥០៧។

[898] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១០។

[899] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១០ ជើងទំព័រ ១៦៥១ និង ១៦៥២ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០២, ៣៣០៦)។

321. សាលក្រមអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា បើទោះបីជា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្តាប់ដោយអង្គជំនុំជម្រះពុំបានឃើញដោយផ្ទាល់នូវការសម្លាប់ក៏ដោយ ក៏អង្គជំនុំជម្រះមានចម្លើយចចាមអារ៉ាមជាច្រើននៅចំពោះមុខនៃការសម្លាប់នៅវត្តអូរត្រកួនអ្នកដែលត្រូវបានសន្មតថា ជាខ្មាំង រួមមានជនស៊ីវិលជនជាតិចាម ដែលត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ[900]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងផ្ទាល់ចេញពីអ្នកភូមិនៃស្រុកកងមាស ព្រមទាំងពីសមាជិកនៃកងសន្តិសុខ និងឈ្លបដែលប្រតិបត្តិការនៅវត្តអូរត្រកួនអំពីជនជាតិចាមត្រូវបានប្រមូលផ្តុំជាប្រព័ន្ធតាមភូមិផ្សេងៗនៃស្រុកកងមាស និងត្រូវបានឈ្លបនាំទៅវត្តអូរត្រកួន។ អង្គជំនុំជម្រះបានស្តាប់ផងដែរនូវចម្លើយរបស់ប្រជាជនចាមដែលត្រូវបានចង និងឃុំឃាំងនៅវត្តនៅមុនពេលនាំចេញទៅក្នុងទ្រង់ទ្រាយធំ បានឮសម្លេងស្រែកចេញពីរណ្តៅ និងហៅឱ្យជួយ និងការចាក់មេក្រូនៅពេលយប់ឱ្យលុបសម្លេងស្រែកដែលគេវាយនោះ។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មនុស្សជាច្រើនដែលភាគច្រើនជាជនជាតិចាមមកពីស្រុកកងមាស តំបន់ ៤១ ត្រូវបានចាប់ខ្លួន និងនាំយកទៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧ កន្លែងដែលពួកគេត្រូវបានសម្លាប់[901]។

322. ខៀវ សំផន ពុំបានបញ្ជាក់ជាក់លាក់ហេតុដូចម្តេចបានជាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញរបស់ខ្លួនក្រៅតែពីការអះអាងតាមធម្មតាថា ភស្តុតាងនោះពុំគ្រប់គ្រាន់។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃយ៉ាងទូលំទូលាយលើភស្តុតាងមុនពេលឈានទៅដល់ការយល់ឃើញរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងទូលំទូលាយលើភស្តុតាងផ្ទាល់មាត់របស់អ្នកភូមិប្រាំពីរនាក់ និងកងសន្តិសុខ ដែលបានប្រតិបត្តិការនៅវត្តអូរត្រកួនពាក់ព័ន្ធនឹងការចាប់ខ្លួន និងសម្លាប់ជនជាតិចាមនៅវត្តនោះ[902]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា កំណត់ហេតុស្តាប់ចម្លើយលាយលក្ខណ៍អក្សរជាច្រើន និងឯកសារដទៃទៀតបានគាំទ្របន្ថែមលើការសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំនៅវត្តអូរត្រកួន[903]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មនុស្សជាច្រើនដែលត្រូវបាន

[900] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០២។

[901] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៦។

[902] ឆ្លើយតបទៅនឹងផ្នែក ១៣.២.៩.២.២. (ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន) សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465)។ សក្ខីកម្មនេះបានយោងយ៉ាងទូលំទូលាយក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១១៦០-១១២២០ និងអត្ថបទភ្ជាប់ជាមួយ។

[903] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១២១៥-១១២២០ (យោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី)។

សន្មតថា ជាខ្មាំង រួមទាំងជនជាតិចាមមកពីភូមិនានានៃស្រុកកងមាស តំបន់ ៤១ ត្រូវបានចាប់ខ្លួនជាប្រព័ន្ធ និងសម្លាប់នៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧[904]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងរបស់ ខៀវ សំផន ដោយសារគ្មានមូលដ្ឋានគាំទ្រពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងទាក់ទងទៅនឹងវត្តមានរបស់ជនជាតិចាម និងការសម្លាប់ពួកគេនៅវត្តអូរត្រកួននោះ។

323. ឧទាហរណ៍ទីបីរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានបោសសម្អាត[905]។ ក្នុងនោះ ជនជាប់ចោទបានកត់សម្គាល់ថា អង្គជំនុំជម្រះបានវាយតម្លៃលើស្ថានការណ៍របស់កម្មាភិបាលជាច្រើននៃបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានបោសសម្អាត ប៉ុន្តែនៅចំណុចនេះអង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញនូវទំនាក់ទំនងរវាងវត្តមានរបស់ពួកគេនៅមន្ទីរស-២១ ជាមួយនឹង ខៀវ សំផន ឡើយ[906]។ ក្នុងកថាខណ្ឌនេះ ជនជាប់ចោទបានសំអាងផងដែរទៅលើការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកិច្ចប្រជុំមួយជាមួយ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នៅមុនពេលការមកដល់របស់វៀតណាម ដែលប្រធានមន្ទីរស-២១ បានផ្តល់ចម្លើយផ្ទុយ ហើយក្នុងសារណារបស់ជនជាប់ចោទខកខានក្នុងការបង្ហាញនូវទំនាក់ទំនងរវាង ខៀវ សំផន ជាមួយនឹងមន្ទីរស-២១។ ផ្អែកលើមូលដ្ឋាននេះ ជនជាប់ចោទបានអះអាងថា ក្រៅពីភស្តុតាងមិនផ្ទាល់នៅក្នុងសំអាងហេតុរបស់ខ្លួនអំពីការបោសសម្អាតនោះ អង្គជំនុំជម្រះពុំអាចបង្ហាញវត្តមានរបស់ ខៀវ សំផន នៅមន្ទីរស-២១ ឬការដឹងរបស់គាត់អំពីមន្ទីរនោះឡើយ[907]។

---

[904] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៦ (កត់សម្គាល់បន្ថែមថា ការចាប់ខ្លួនជាប្រព័ន្ធ និងការសម្លាប់ទ្រង់ទ្រាយធំជនជាតិចាម នៅវត្តអូរត្រកួនស្របជាមួយនឹងភស្តុតាងដែលបង្ហាញនូវលំនាំប្រហាក់ប្រហែលគ្នានៃអំពើក្នុងផ្នែកស្តីពីតំបន់ ៤១ ជាពិសេសក្នុងស្រុកកំពង់សៀម)។

[905] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១១។

[906] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១១ ជើងទំព័រ ៣០៨១ និង ៣០៨២ (យោងលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០០, ២៣១២ និង ២៣២០)។ ក្នុងជើងទំព័រ ៣០៨១ នៃសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានដាក់បញ្ចូលផ្នែកបន្ថែមនៃបណ្តឹងសាទុក្ខរបស់ខ្លួនតាមរយៈការយោង។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥១-១៨៥៣ និង ១៨៦២-១៨៧៣។ កថាខណ្ឌទាំងនេះដែលពាក់ព័ន្ធទៅនឹងការដឹងរបស់ជនជាប់ចោទអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងមន្ទីរសន្តិសុខ និងកន្លែងដទៃទៀត ត្រូវបានវាយតម្លៃនៅក្នុងផ្នែក VIII.ខ.៨ (ការដឹង និងចេតនារបស់ ខៀវ សំផន) នៃសាលដីកានេះ។

[907] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១១ ជើងទំព័រ ៣០៨៣ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៧៣ និង ២៥៥៧-២៥៥៨។

324. ការយោងរបស់ ខៀវ សំផន ពុំអាចថាមិនស្របជាមួយនឹងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន នោះឡើយ[908]។ បើទោះបីបានយល់ឃើញថា ខៀវ សំផន ពុំដែលបានទៅមន្ទីរស-២១ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាអំពីកិច្ចប្រជុំរវាង ខៀវ សំផន និង កាំង ហ្កេចអ៊ាវ *ហៅ* ឌុច និងបានកត់សម្គាល់ថា គាត់បានផ្ដល់ការណែនាំដល់ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច នៅមុនការមកដល់កងទ័ពវៀតណាមក្នុងទីក្រុងភ្នំពេញ[909]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានផងដែរថា ផ្អែកតាមវត្តមានទៀងទាត់របស់គាត់ និងការចូលរួមនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ទំនងជាថា ខៀវ សំផន បានដឹងអំពីការធ្វើទារុណកម្មនៅមន្ទីរស-២១។ ពាក់ព័ន្ធទៅនឹងការដឹងរបស់ជនជាប់ចោទអំពីការបោសសម្អាត កថាខណ្ឌទាំងនេះបានពិពណ៌នាផងដែរអំពីការចាប់ខ្លួនកម្មាភិបាលជាច្រើននៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងលេខាភូមិភាគដែលប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ក្នុងការចាប់ខ្លួនសាច់ញាតិរបស់ ខៀវ សំផន[910]។ ក្រៅពីការមិនយល់ស្របជាមួយនឹងកថាខណ្ឌទាំងនេះ គាត់ពុំបានបង្ហាញនូវភាពពុំសមហេតុផលនៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ការចោទប្រកាន់ពុំបានអើពើផងដែរលើការវាយតម្លៃយ៉ាងទូលំទូលាយជារួមលើភស្តុតាងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់ និងចេតនា តួនាទី និងភារកិច្ច និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[911]។

325. បន្ថែមលើនេះ ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម[912]។ ខៀវ សំផន បានអះអាងថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាមក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានកំហុស និង"បានផ្អែកតែលើការទាញសេចក្ដីសន្និដ្ឋានតគ្នា និងលើភស្តុតាងមិនផ្ទាល់ដែលត្រូវបានសន្និដ្ឋាន និងត្រូវបានប្រើជំនួសវិញធ្វើជាចំណុចចាប់ផ្ដើមសម្រាប់ការសន្និដ្ឋាន

---

[908] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦១១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០០, ២៣១៣, ២៣២០, ២៣៧៣, និង ២៥៥៧-២៥៥៨។

[909] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៧២, ២៥៥៧-២៥៥៨។

[910] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣២០ (យោងទៅលើ កង ចាប ដែលការប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ក្រោយមកបណ្ដាលឱ្យមានការដាក់ទោសដោយ ប៉ុល ពត។ កង ចាប ដែលត្រូវបានចាប់ខ្លួន និងត្រូវបានសួរយកចម្លើយនៅមន្ទីរស-២១ ត្រូវបានកម្ទេចនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៧៨)។

[911] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ។ ៥៦២-៦២៤ (តួនាទី និងការទទួលខុសត្រូវ) និង ៤២០១-៤៣២៩ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ)។

[912] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៨។

មួយផ្សេងទៀតជាដើម"[913]។ បើទោះបីជាបានទទួលស្គាល់នូវលទ្ធភាពនៃការបង្ហាញការដឹងដោយប្រើប្រាស់ភស្តុតាងមិនផ្ទាល់ក៏ដោយ ក៏គាត់បានអះអាងថា អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ដោយសារការបង្កើតការយល់ឃើញអំពីការដឹងក្នុងលក្ខណៈមួយ"ទូទៅស្រពេចស្រពិល និងបូកសរុបជារួមតាមរយៈការប្រើប្រាស់ឃ្លា 'ឧក្រិដ្ឋកម្មខ្លះៗ' ឬ 'ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ' ដោយគ្មានការបញ្ជាក់ជាក់លាក់នូវឧក្រិដ្ឋកម្មដែល ខៀវ សំផន បានដឹង ហើយសំខាន់ជាងនេះទៀត ថាតើគាត់បានដឹងអំពីឧក្រិដ្ឋកម្ម ដែរ ឬយ៉ាងណា។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុលើភស្តុតាងមិនផ្ទាល់នីមួយៗដែលអង្គជំនុំជម្រះបានសំអាងទៅលើក្នុងការបង្កើតការយល់ឃើញស្តីពីការដឹងរបស់ ខៀវ សំផន ដោយគ្មានការពន្យល់នូវមូលហេតុដូចម្តេចបានជាការយល់ឃើញរបស់ខ្លួនគឺជាការយល់ឃើញ ដែលសមហេតុផលតែមួយគត់តាមដែលអាចធ្វើទៅបាន"[914]។

326. ក្នុងការគាំទ្រការអះអាងទាំងនេះ ខៀវ សំផន បានចង្អុលបង្ហាញទៅលើកថាខណ្ឌតែមួយក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការកំណត់គោលដៅលើជនជាតិចាមដែលថា៖

> អង្គជំនុំជម្រះសូមរំលឹកឡើងវិញនូវសំអាងហេតុរបស់ខ្លួនថា ប.ក.ក. បានកំណត់គោលដៅជាក់លាក់លើជនជាតិចាមពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៃគោលនយោបាយដែលវិវត្តពីពេលមួយទៅពេលមួយ ។ ខណៈអង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការថែរក្សា"ផ្តែផ្តាបដិវត្តន៍និងជាតិសាសន៍កម្ពុជាឲ្យបានជារៀងរហូត" នៅពេលដែលកម្មាភិបាល ប.ក.ក. នៅភូមិភាគកណ្តាលនិងភូមិភាគបូព៌ាតាមបណ្តោយទន្លេមេគង្គ កំពុងអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ដើម្បីបំផ្លិចបំផ្លាញក្រុមជាតិពន្ធុចាមនិងសាសនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុន្ទរកថាទាំងនេះបានកើតឡើងស្រប គ្នាជាមួយនឹងការបំផ្លាញពូជសាសន៍ ជាតិសាសន៍ និងជាតិពន្ធុវៀតណាមនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលមានឋានៈពិសេសនៅក្នុងមជ្ឈិមបក្ស ខៀវ សំផន បានគាំទ្រគោលបំណងរួមនិងដឹងអំពីការអនុវត្តន៍គោលនយោបាយក្នុងការបន្សុទ្ធសង្គមខ្មែរតែមួយ ដែលមានតែកម្មករ-កសិករ។ គោលនយោបាយនានាដែលផ្តោតគោលដៅលើក្រុមជាក់លាក់ រួមទាំងប្រជាជនចាមផងនោះ គឺពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសដោយផ្អែកលើហេតុផលនៃការរើសអើងក្នុងគោលបំណងដើម្បី

---

913 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៦។

914 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨១។

សម្រេចបាននូវសង្គមគ្មានជំនឿសាសនា។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[915]។

327. ទោះជាយ៉ាងណាក្តី កថាខណ្ឌនេះពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងលក្ខណៈមួយស្រពេចស្រពិលថា ជនជាប់ចោទបានដឹងអំពី"ឧក្រិដ្ឋកម្មខ្លះៗ" ដូចការអះអាងរបស់ជនជាប់ចោទឡើយ។ បន្ថែមលើនេះ ជនជាប់ចោទពុំបានអើពើទៅលើការវិភាគលើភស្តុតាងយ៉ាងទូលំទូលាយដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងដើម្បីឈានដល់ការសន្និដ្ឋានទាំងនេះ[916]។ គាត់ពុំបានបញ្ជាក់ជាក់លាក់ថាតើការសន្និដ្ឋានណាមួយបានផ្អែកទៅលើលក្ខណៈទូទៅដែលមានកំហុស ឬបង្ហាញថាតើការយល់ឃើញទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលដូចម្តេចឡើយ។ គាត់ពុំបានផ្តល់សេចក្តីសន្និដ្ឋានដែលទំនងសមស្របមួយផ្សេង និងពុំបានពន្យល់មូលហេតុដែលពុំមានតុលាការអង្គហេតុសមហេតុផលអាចធ្វើសេចក្តីសន្និដ្ឋានបានដូចអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងទាំងនេះដោយសារពុំមានមូលដ្ឋានគាំទ្រ។

328. ជាចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលរងបណ្តឹងសាទុក្ខនេះ ដោយបានយោងទៅកំហុសទាំងនេះទាក់ទងទៅនឹងការដឹងរបស់គាត់អំពីលក្ខខណ្ឌរស់នៅក្នុងខេត្តព្រះវិហារ[917]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធក្នុងការវាយតម្លៃលើរាល់អំណះអំណាងដែលមាននៅក្នុងនោះ ដោយផ្អែកលើមូលដ្ឋានថា អំណះអំណាងជាច្រើនពុំបានបញ្ជាក់ជាក់លាក់គ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះកំណត់បាននូវការចោទប្រកាន់ជាក់លាក់ណាមួយនូវកំហុស[918]។ ការបញ្ជាក់ជាក់លាក់នៃកំហុសដែលបានចោទប្រកាន់ក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានវាយតម្លៃក្នុងសាលដីកានេះ[919]។ ពាក់ព័ន្ធនឹងបញ្ហានេះ កំហុសទាំងនេះត្រូវបានពិចារណាតែត្រង់ចំណុចណាដែលបានបង្ហាញថា វិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសចំពោះការវាយតម្លៃលើភស្តុតាងប៉ុណ្ណោះ។

---

[915] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៦ (ជើងទំព័រលុបចោល)។

[916] *សូមមើលផងដែរខាងក្រោម* ផ្នែក VIII.ខ.៨.ក។

[917] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២៩-១៨៣៥។

[918] *សូមមើល ឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៩ ជើងទំព័រ ៣៣៦ ដែលបង្ហាញថា៖ "សូមមើលឧទាហរណ៍ផ្នែកអង្គហេតុខាងក្រោម៖ ១៨២៩-១៨៣៥។ សេចក្តីសន្និដ្ឋានស្តីពីការដឹងនូវកន្លែងសហករណ៍៖ ការដឹងរបស់ជនជាប់ចោទអំពីសហករណ៍នៅខេត្តព្រះវិហារ ស្របជាមួយនឹងការដឹងអំពីស្ថានការណ៍ពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ"។

[919] *សូមមើលខាងក្រោម* ផ្នែក VIII.ខ.៨.គ។

329. ការចោទប្រកាន់ទាំងនេះបានជំទាស់ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន អំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុង ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការដឹងរបស់គាត់នូវមន្ទីរសន្តិសុខ ការដ្ឋានធ្វើការ និងសហករណ៍នានា។ ខៀវ សំផន បានលើកឡើងថា ពុំមានអ្វីនៅក្នុងចម្លើយរបស់ មាស វឿន អាចឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានបានថា គាត់បានដឹងនូវព្រឹត្តិការណ៍នៅក្នុងសហករណ៍ និងដូច្នេះ ជាការពុំត្រឹមត្រូវដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គាត់បានដឹងអំពីលក្ខខណ្ឌធ្វើការយ៉ាងអាក្រក់នៅតាមសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសារណារបស់គាត់ លើកឡើងថា ការសន្និដ្ឋាននេះ“បានផ្អែកតែទៅលើការប៉ាន់ស្មាន និងលើការបំភ្លៃភស្តុតាង” ដូច្នេះគប្បីបដិសេធចោល[920]។

330. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដូចខាងក្រោមថា៖

> ដោយស្របជាមួយនឹងការដឹងរបស់ ខៀវ សំផន នៅពេលនេះអំពីលក្ខខណ្ឌនៃការរស់នៅក្នុងសហករណ៍ក្នុងខេត្តព្រះវិហារ ព្រមទាំងក្នុងការទទួលស្គាល់របស់គាត់ក្នុងឆ្នាំ ១៩៧៨ ថា មានប្រជាជន ២០.០០០ នាក់ “បានស្លាប់ដោយសារជំងឺ និងកង្វះអាហារក្នុងអំឡុងពេលបីឆ្នាំទូទាំងប្រទេស” អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន បានដឹងអំពីលក្ខខណ្ឌលំបាកវេទនានៅតាមសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[921]។

331. ក្នុងការសន្និដ្ឋានទាក់ទងទៅនឹងការដឹងរបស់ ខៀវ សំផន អំពីលក្ខខណ្ឌរស់នៅក្នុងខេត្តព្រះវិហារ អង្គជំនុំជម្រះបានសំអាងទៅលើសក្ខីកម្មរបស់ មាស វឿន និងភស្តុតាងជាឯកសារ រួមទាំងឯកសារបោះពុម្ពផ្សាយដែលនិពន្ធដោយ ខៀវ សំផន ខ្លួនឯងផ្ទាល់ ព្រមទាំងបទសម្ភាសន៍ជាលាយលក្ខណ៍អក្សររបស់គាត់[922]។ ដូច

---

[920] *សូមមើល* ខៀវ សំផន កថាខណ្ឌ ១៨៣១-១៨៣៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦, ៤២៣៣, ៤២៣៥។

[921] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦ (ការដកស្រង់ខាងក្នុងលុបចោល)។

[922] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦ យោងទៅលើឯកសារបោះពុម្ពផ្សាយកម្ពុជាប្រជាធិបតេយ្យរបស់ ខៀវ សំផន “តើមានការពិត និងយុត្តិធម៌អ្វីខ្លះ អំពីការចោទប្រកាន់នានាទៅលើកម្ពុជាប្រជាធិបតេយ្យចំពោះការសម្លាប់រង្គាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ នោះ ?” ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៨៧ ឯកសារលេខ E3/703 (ដែលបានទទួលស្គាល់ថាប្រជាជន ២០.០០០ បានស្លាប់ដោយសារជំងឺ និងអត់អាហារ ក្នុងរយៈពេលបីឆ្នាំនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យទូទាំងប្រទេស) និង ៤២៣២-៤២៣៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/130.1។ កំណត់ហេតុស្តាប់ចម្លើយរបស់ មាស វឿន ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ E3/424 និង កំណត់ហេតុស្តាប់ចម្លើយ

ការកត់សម្គាល់ត្រឹមត្រូវរបស់គាត់ថា សក្ខីកម្មរបស់ មាស វឿន ជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌដែលមានអត្ថិភាពក្នុងខេត្តព្រះវិហារ ពុំមែនទូទៅក្នុងឃុំដទៃទៀត និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យឡើយ។ ទោះជាយ៉ាងណាក្តី មាស វឿន បានផ្តល់ភស្តុតាងគួរឱ្យជឿជាក់ថា នៅចុងឆ្នាំ ១៩៧៨ គាត់បានរាយការណ៍ទៅ ខៀវ សំផន អំពីលក្ខខណ្ឌនៅមន្ទីរសន្តិសុខដែលបងស្រីប្រពន្ធរបស់គាត់ និងសាច់ញាតិដទៃទៀត ត្រូវបានឃុំឃាំងក្នុងខេត្តព្រះវិហារ ព្រមទាំងលក្ខខណ្ឌទូទៅក្នុងខេត្តនោះ។ មានការបង្ហាញផងដែរថា ខ្មែរក្រហមពុំបានទុកជីវិតនរណាម្នាក់ឡើយ សូម្បីតែអ្នកដែលជាប់សាច់ញាតិជិតស្និទ្ធជាមួយនឹងថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ដោយសារអ្នកទាំងនេះត្រូវបានចាត់ទុកថា រារាំងដល់ការសម្រេចគោលដៅរបស់អង្គការ។

332. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការទទួលស្គាល់របស់ ខៀវ សំផន ក្នុងឆ្នាំ ១៩៨៧ ដែលថាប្រជាជន ២០.០០០ នាក់បានស្លាប់ដោយសារជំងឺ និងការអត់អាហារនោះ ស្របជាមួយនឹងការដឹងរបស់គាត់អំពីលក្ខខណ្ឌការងារដ៏អាក្រក់នៅសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[923]។ ដូច្នេះ ប្រភពទាំងនេះបានជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា គាត់ពុំបានដឹងអំពីការចាប់ខ្លួន និងការឃុំឃាំងជនស៊ីវិល ឬលក្ខខណ្ឌដែលប្រជាជនបានប្រឈមទូទាំងប្រទេសនោះ[924]។

333. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា ព័ត៌មានដែលបានផ្តល់ក្រោយការស៊ើបអង្កេតជាក់លាក់ក្នុងខេត្តព្រះវិហារដោយខ្លួនឯងផ្ទាល់ ពុំអាចនាំទៅរកការសន្និដ្ឋានបានថា ខៀវ សំផន បានដឹងអំពីលក្ខខណ្ឌដ៏អាក្រក់ក្នុងឃុំដទៃទៀត និងការដ្ឋានធ្វើការពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានផ្អែកការយល់ឃើញទូទៅរបស់ខ្លួនពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន អំពីលក្ខខណ្ឌក្នុងការដ្ឋានធ្វើការ និងសហករណ៍តែលើសក្ខីកម្មរបស់ មាស វឿន ប៉ុណ្ណោះទេ។ ការយល់ឃើញជារួមរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការដឹងផ្ទុយទៅវិញបាន

---

របស់ ខៀវ សំផន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ E3/210។ លិខិតរបស់ ខៀវ សំផន ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ E3/205 ERN 00002796។

[923] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៤២៣៣ ជើងទំព័រ ១៣៨១៩ យោងទៅលើឯកសារបោះពុម្ពផ្សាយកម្ពុជាប្រជាធិបតេយ្យ "តើមានការពិត និងយុត្តិធម៌អ្វីខ្លះ អំពីការចោទប្រកាន់នានាទៅលើកម្ពុជាប្រជាធិបតេយ្យ ចំពោះការសម្លាប់រង្គាល ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ នោះ?" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៧ ឯកសារលេខ E3/703។

[924] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៤ (កត់សម្គាល់ផងដែរនូវកម្រិតដែល ឥទ្ធិពល និងសិទ្ធិអំណាចនៃតួនាទីរបស់ ខៀវ សំផន អាចឱ្យគាត់ចូលអន្តរាគមន៍ក្នុងកិច្ចការបក្សបាន)។

យកតាមការវាយតម្លៃទូលំទូលាយលើប្រភពជាច្រើននៃភស្តុតាង ដែលក្នុងនោះ អង្គជំនុំជម្រះបានពិចារណាជារួមលើចម្លើយរបស់ ខៀវ សំផន និងទង្វើរបស់គាត់ រួមទាំងការលើកឡើងដែលបានធ្វើក្រោយការដួលរលំកម្ពុជាប្រជាធិបតេយ្យ ក្នុងការវាយតម្លៃលើវិសាលភាពនៃការដឹងនៅពេលនោះអំពីបទឧក្រិដ្ឋទាំងនេះ[925]។ ដូចការបញ្ជាក់គ្រប់គ្រាន់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងថា ការដឹងរបស់ ខៀវ សំផន អំពីបទឧក្រិដ្ឋ និងលក្ខខណ្ឌក្នុងការដ្ឋានធ្វើការ និងសហករណ៍ជានិច្ចកាលទទួលបានតាមរយៈតួនាទីរបស់គាត់ ជាប្រមុខរដ្ឋ និងមុខនាទីដែលគាត់បានបំពេញជាផលវិបាកនៃកាតព្វកិច្ច រួមទាំងការចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍[926]។

334. ជាសរុប ការផ្តោតដាច់ដោយឡែកតែទៅលើកថាខណ្ឌមួយនៃសាលក្រម អាចនាំឱ្យមានការចាប់អារម្មណ៍ថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានជាទូទៅនូវការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងការដ្ឋានធ្វើការ និងសហករណ៍ ទៅលើប្រភពមួយដែលពាក់ព័ន្ធនឹងខេត្តព្រះវិហារតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី តាមការពិនិត្យសាលក្រមជារួមពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានរបស់ខ្លួនផ្អែកលើមូលដ្ឋានដែលពុំត្រូវបានអនុញ្ញាត ការសន្និដ្ឋានជាទូទៅ ឬការសន្និដ្ឋានពង្រីកឡើយ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន នៅពេលនោះអំពីលក្ខខណ្ឌការរស់នៅតាមសហករណ៍នានា និងការដ្ឋានធ្វើការ ផ្ទុយទៅវិញបានយកតាមការវាយតម្លៃទូលំទូលាយលើប្រភពជាច្រើននៃភស្តុតាង ដែលបានវាយតម្លៃជារួមនូវចម្លើយរបស់ ខៀវ សំផន និងទង្វើរបស់គាត់ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បន្ថែមលើតួនាទី និងការទទួលខុសត្រូវរបស់គាត់ជាថ្នាក់លើជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា[927]។ អាស្រ័យហេតុនេះ អំណះអំណាងត្រូវបដិសេធចោល។

---

[925] *សូមមើល ឧ.* បន្ថែមទៅនឹងប្រភពដែលបានយោងនៅក្នុងកថាខណ្ឌខាងលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦២-៦២៤ (រៀបរាប់លម្អិតអំពីតួនាទី និងការទទួលខុសត្រូវ) ៤២០១-៤៣១៩ (រៀបរាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) និង កថាខណ្ឌ ៤២៣៥ (បង្ហាញដោយផ្អែកលើប្រភពទាំងនេះ និងភស្តុតាងជារួម ថា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការបោសសម្អាតពាសពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ)។

[926] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៥ (បញ្ជាក់ដោយផ្អែកលើមូលដ្ឋាននៃប្រភពទាំងនេះ និងភាពជារួមនៃភស្តុតាងដែលថា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុងពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ)។

[927] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦២-៦២៤ (រៀបរាប់លម្អិតអំពីតួនាទី និងការទទួលខុសត្រូវ) ៤២០១-៤៣១៩ (រៀបរាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) និងកថាខណ្ឌ ៤២៣៥ (បង្ហាញដោយផ្អែកលើប្រភព

## គ. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងភស្តុតាងដោះបន្ទុក

335. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវគោលការណ៍ដែលអង្គជំនុំជម្រះបានបញ្ជាក់ពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភស្តុតាងដោះបន្ទុក[928]។ គាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើការពន្យល់ដទៃទៀតដែលគួរឱ្យជឿជាក់បាន រួមទាំងភស្តុតាងដោះបន្ទុកជាសក្តានុពល ឬលទ្ធភាពដែលថា ភស្តុតាងនោះអាចដាក់បន្ទុកសម្រាប់បញ្ហាជាក់លាក់ផ្សេង ប៉ុន្តែដោះបន្ទុកសម្រាប់ជនជាប់ចោទចំពោះបញ្ហាដទៃទៀត[929]។ ជាពិសេសតាមការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដោះបន្ទុកជំនួសឱ្យរូបគាត់ដោយសារបានបដិសេធមិនកោះហៅសាក្សីអត្តចរិតរបស់គាត់ចេញពីសំណុំរឿង ០០២/០១ និងខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវបទដ្ឋានគតិយុត្តដែលត្រូវបានបង្ហាញត្រឹមត្រូវក្នុងការវាយតម្លៃលើភស្តុតាង[930] និងថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ស្តង់ដាពីរនៅក្នុងការវាយតម្លៃលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដែលនេះបានបង្កឱ្យមានភាពមិនជាក់លាក់ផ្នែកច្បាប់ដល់គាត់ និងបានរំលោភបំពាន "លើសិទ្ធិទាំងអស់នៃកិច្ចដំណើរការនីតិវិធី"[931]។

336. ក្នុងការគាំទ្រការចោទប្រកាន់ទាំងនេះ ខៀវ សំផន បានដាក់បញ្ចូលតាមរយៈការយោងទៅលើផ្នែកផ្សេងៗជាច្រើននៃសារណាបណ្តឹងសាទុក្ខរបស់គាត់ និងបានអះអាងថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដោះបន្ទុកក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងគោលការណ៍ដែលបានលើកឡើងក្នុងកថាខណ្ឌ ៦៥ នោះ។ មានកថាខណ្ឌជាច្រើនដែលត្រូវបានដាក់បញ្ចូលតាមរយៈការយោងនោះដែលពាក់ព័ន្ធទៅនឹងប្រធានបទជាច្រើនផ្សេងៗ រួមទាំងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីបន្ទុកនៃការបង្ហាញភស្តុតាង ការបញ្ជាក់បន្ថែមនៃភស្តុតាង និងការវាយតម្លៃលើឯក

---

ទាំងនេះ និងភស្តុតាងជារួមថា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុងពាសពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ)។

[928] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៥ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥)។

[929] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៦ (យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤១៨)។

[930] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៦ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៩៩)។

[931] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៤។

សារបោះពុម្ពផ្សាយ អត្ថបទរបស់អ្នកជំនាញ និងចម្លើយជាលាយលក្ខណ៍អក្សរ ដែលទាំងអស់នេះត្រូវបាន ពិចារណានៅក្នុងសាលដីកានេះ[932]។

337. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានបំភ្លេចចោលនូវភស្តុតាងដោះបន្ទុកក្នុងការវាយតម្លៃរបស់ខ្លួនលើភស្តុតាង[933]។ គាត់ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើក្នុងការពិចារណាលើភស្តុតាងអត្តចរិត ដែលត្រូវបានស្តាប់រួចហើយក្នុងសំណុំរឿង ០០២/០១ ក្នុងអំឡុងពេលនៃការពិភាក្សាសម្រេចក្នុងរឿងក្តីនេះ។ ការដែលអង្គជំនុំជម្រះសាលាដំបូងពុំបានកែប្រែការវាយតម្លៃលើភស្តុតាងនេះក្នុងសំណុំរឿង ០០២/០២ ពុំមែនមានន័យថា អង្គជំនុំជម្រះបានបំភ្លេច ឬមិនអើពើលើភស្តុតាងដោះបន្ទុកតាមការចោទប្រកាន់នោះទេ។ អង្គជំនុំជម្រះសាលាដំបូងតាមធម្មតាពុំបានយល់ឃើញថា ភស្តុតាងនេះមានលក្ខណៈគ្រប់គ្រាន់ដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់របស់ខ្លួននូវការដាក់ទោសសមស្របដោយផ្អែកលើទិដ្ឋភាពនៃភាពធ្ងន់ធ្ងរបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធនោះ[934]។ បន្ថែមលើនេះ ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងដែលគាត់ព្យាយាមសំអាងទៅលើនោះ។ សាក្សីដែលអះអាងថា បានផ្តល់ភស្តុតាងអំពីអត្តចរិតល្អ ឬ"សុទ្ធតែស្ញើចសរសើរ"ជំនួសឱ្យ ខៀវ សំផន ជាក់ស្តែងពុំបានធ្វើដូច្នោះឡើយ[935]។ អំណះអំណាងផ្សេងទៀតរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះត្រូវបានលើកឡើងដោយ

---

[932] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៤ យោងទៅលើតាមរយៈឧទាហរណ៍ និងការដាក់បញ្ចូលតាមរយៈការយោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤១-២៤២, ២៩៣-៣០៥, ៣១២-៣១៣, ៣២៤-៣១៩, ៣២៩-៣៣០, ៧៥៦, ៨៩១, ៩២២, ៩៩៩, ១១៩៥, ១២៣៥, ១២៧៩-១២៨០, ១៣៨៣, ១៥២៩, ១៧៥២ និងជើងទំព័រ ៣៤០០។

[933] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១២។

[934] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៣។

[935] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៣ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៦ និង ២១៧៧-២១៨៣។ សហព្រះរាជអាជ្ញាបានអះអាងថា សាក្សីដោះបន្ទុកជាក់ស្តែងទាក់ទងទៅនឹង ខៀវ សំផន ពុំបានរៀបរាប់ថា "គួរឱ្យស្ញើចសរសើរ"នោះទេ។ François PONCHAUD បានផ្តល់សក្ខីកម្មថា ពេញមួយអំឡុងពេលនៃឆ្នាំ ១៩៧០ គាត់បានស្ញើចសរសើរ ខៀវ សំផន ប៉ុន្តែថា "អ្វីដែលបានកើតឡើងក្រោយមកនោះ ជារឿងផ្សេង"។ សក្ខីកម្មរបស់ Philip SHORT ប្រហាក់ប្រហែលគ្នាដែរមិនច្បាស់លាស់ក្នុងការសរសើរនោះដែរ។ នូវ ហ៊ាន់ បានផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ ខៀវ សំផន ដោយសំដៅទៅលើសុភាសិតខ្មែរថា "ត្រីមួយកន្ត្រក់ស្អុយមួយស្អុយទាំងអស់" និងបានផ្តល់សក្ខីកម្មថា នៅពេល ខៀវ សំផន ទៅរស់នៅជាមួយខ្មែរក្រហមចិត្តខ្មៅ គាត់ស្ថិតក្នុងចំណោមត្រីស្អុយនោះ។ គាត់បានផ្តល់សក្ខីកម្មផងដែរថា ខៀវ សំផន ពុំបានស្រឡាញ់ប្រទេសជាតិរបស់ខ្លួនទេ ប៉ុន្តែផ្ទុយទៅវិញបានបំផ្លិចបំផ្លាញ។ សាក្សីដទៃទៀតបានទទួលស្គាល់ថា ពុំបានដឹងអំពីសកម្មភាពរបស់ ខៀវ សំផន ក្នុងកម្ពុជាប្រជាធិបតេយ្យ ឬពុំមានទំនាក់ទំនងជាមួយគាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង/

ពុំត្រឹមត្រូវប្រហាក់ប្រហែលគ្នានេះ និងពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លេចភស្តុតាងដោះបន្ទុកឡើយ[936]។

338. យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ខៀវ សំផន ខកខានផងដែរក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុដោយសារបានអនុវត្តស្តង់ដាពីរក្នុងការវាយតម្លៃលើភស្តុតាងដោះបន្ទុក និងដាក់បន្ទុក[937]។ ការចោទប្រកាន់កំហុសអង្គច្បាប់ និងអង្គហេតុពុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់។ ផ្ទុយទៅវិញ គាត់បានអះអាងទូលំទូលាយ និងគ្មានការលើកអំណះអំណាងគាំទ្រការចោទប្រកាន់កំហុសឱ្យលើសពីការត្រឹមតែយោងទៅលើកថាខណ្ឌជាច្រើននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងសារណាបណ្តឹងសាទុក្ខរបស់គាត់ប៉ុណ្ណោះ[938]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយភស្តុតាងដោះបន្ទុក ដោយបានទទួលយក និងបដិសេធរួចរាល់ហើយ[939]។

339. សហព្រះរាជអាជ្ញាបានបន្ថែមថា ការដាក់បញ្ចូលរបស់ ខៀវ សំផន នូវផ្នែកផ្សេងៗជាច្រើននៃបណ្តឹងសាទុក្ខរបស់គាត់តាមរយៈការយោងនោះ ជាញឹកញាប់ដោយគ្មានការលើកឡើងបន្ថែម បានបណ្តាលឱ្យមានអំណះអំណាងត្រួតគ្នាជាច្រើនពាសពេញការចោទប្រកាន់ដ៏ច្រើនរបស់គាត់។ ការយោងឆ្លងពីផ្នែកមួយទៅផ្នែកមួយទៀតជាច្រើនក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ ត្រូវបានវាយតម្លៃលម្អិតតែក្នុងករណីដែលអំណះ

ឬថា ពួកគេពុំបានស្គាល់ ខៀវ សំផន ដោយផ្ទាល់នោះឡើយ។ *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០៥-១៣០៦។

[936] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៤ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៣៦, ៧៥៦ និង ១២៧៩-១២៨០។

[937] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២០។

[938] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២១ ជើងទំព័រ ៤៦១ (កត់សម្គាល់ថា ការយោងទៅលើសាលក្រមបានផ្តោះបញ្ចាំងតែលើក្របខ័ណ្ឌការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើភស្តុតាង ខណៈពេលការយោងក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់តាមធម្មតាប្រាប់អ្នកអាននូវកថាខណ្ឌជាច្រើនបន្ថែមទៀតនៃសារណាបណ្តឹងសាទុក្ខ)។

[939] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (465) កថាណ្ឌ ១០០៧, ១១៣៥, ១៣៤៦ និង ១៣៧៣-១៣៧៤។

អំណាងនោះអាចកំណត់បានជាក់លាក់ទាក់ទងទៅនឹងវិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាងដោះបន្ទុកប៉ុណ្ណោះ[940]។

340. ក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> មុននឹងទាញសេចក្ដីសន្និដ្ឋានផ្ទុយណាមួយចេញពីភស្តុតាងដែលត្រូវបានដាក់បង្ហាញនៅក្នុងសវនាការ អង្គជំនុំជម្រះត្រូវពិចារណាទៅលើភាពសមស្របនៃការពន្យល់ផ្សេងៗទៀតជាមុនសិន រួមទាំងការពន្យល់ដែលអាចជាប្រយោជន៍ដល់ជនជាប់ចោទ។ ឧទាហរណ៍ សេចក្ដីថ្លែងការណ៍ទាំងឡាយដែលបានធ្វើឡើងក្នុងគោលបំណងឃោសនា អាចបន្ថយភាពគួរឱ្យជឿជាក់បាននៃសេចក្ដីថ្លែងការណ៍ទាំងនោះ។ លើសពីនេះទៀត ជាការចាំបាច់ដែលអង្គជំនុំជម្រះបង្ហាញអត្តសញ្ញាណ និងពិចារណាទៅលើភស្តុតាងដោះបន្ទុក រួមទាំងភស្តុតាងដាក់បន្ទុកលើបញ្ហាណាមួយផងដែរ[941]។

341. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ខៀវ សំផន បានយោងទៅលើនោះថា "តុលាការអង្គហេតុត្រូវតែជឿជាក់ហួសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងជារួមថា អង្គហេតុដែលបង្កើតជាធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ត្រូវបានបង្ហាញ ព្រមទាំងអង្គហេតុដែលសំខាន់បំផុតសម្រាប់ការដាក់ពិរុទ្ធភាព"[942]។

342. ពុំមានកំហុសដែលស្ដែងឱ្យឃើញដូចបានចោទប្រកាន់ដោយ ខៀវ សំផន ទាក់ទងទៅនឹងកថាខណ្ឌទាំងនេះ។ ផ្ទុយទៅវិញ ការអះអាងរបស់ ខៀវ សំផន អំពីកំហុសនោះកើតចេញពីការតវ៉ារបស់គាត់ដែលថា ដោយសារខកខានក្នុងការកោះហៅសាក្សីអត្តចរិតមួយចំនួនជំនួសឱ្យគាត់ អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដោះបន្ទុក និងមានកំហុសក្នុងការកំណត់អំពីការដាក់ទោស។

343. ក្នុងកថាខណ្ឌ ៤៣៩៩ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធទៅនឹងសាក្សីអត្តចរិត អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា "ពុំមានសាក្សីអត្តចរិតត្រូវបានស្ដាប់ដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធ នួន ជា ឬ ខៀវ សំផន"។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ក្នុងជើង

---

[940] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២២-១២៧ (ការកំណត់តែលើកថាខណ្ឌ ៩៩៩ និង ១៣៨៣ នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) ដើម្បីបំពេញតាមលក្ខខណ្ឌនេះ ប៉ុន្តែបដិសេធអង្គសេចក្ដីនៃអំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលមាននៅទីនោះ)។

[941] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (465) កថាខណ្ឌ ៦៥ (សេចក្ដីយោងលុបចោល)។

[942] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤១៨។

ទំព័រកថាខណ្ឌនោះថា អង្គជំនុំជម្រះបានពិចារណាពីដំបូងរួចហើយលើភស្តុតាងរបស់សាក្សីអត្តចរិតប្រាំនាក់នោះដែលបានផ្តល់សក្ខីកម្មជំនួសឱ្យ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១[943]។

344. អង្គជំនុំជម្រះសាលាដំបូងបានរំឭកបន្ថែមថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានស្តាប់សាក្សីទាំងនេះ និងបានសន្និដ្ឋានថា ខៀវ សំផន បានប្រព្រឹត្តល្អទៅលើប្រពន្ធរបស់គាត់ និងអ្នកដទៃក្នុងហេតុការណ៍ជាក់លាក់ដោយផ្អែកលើភស្តុតាងនេះ[944]។ ទោះជាយ៉ាងណាក្តី សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា កត្តាទាំងនេះពុំអាចដើរតួនាទីសំខាន់ក្នុងការសម្រាលទោសនៃបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធភាពនោះទេ។ ផ្អែកលើទិដ្ឋភាពនៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០១ បានសម្រេចមិនផ្តល់ទម្ងន់ទៅលើភស្តុតាងនេះ[945]។

345. ការយល់ឃើញទាំងនេះក្នុងសំណុំរឿង ០០២/០១ ត្រូវបានតម្កល់នៅបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងនោះថា គ្មានមូលដ្ឋានក្នុងការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើអត្តចរិតល្អរបស់ ខៀវ សំផន[946]។ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា ជាការពិតដែល អង្គជំនុំជម្រះសាលាដំបូងពិតជាបានធ្វើការពិចារណាលើអត្តចរិតរបស់ ខៀវ សំផន ថា ជាកត្តាសម្រាលទោសសក្តានុពលៈ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានសម្រេចមិនផ្តល់ទម្ងន់ទៅលើភស្តុតាងនោះ[947]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានភាពផ្ទុយគ្នានៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បុគ្គលទូទៅអាចមានចិត្តល្អសប្បុរសធម៌ក្នុងហេតុការណ៍ជាក់លាក់ ខណៈពេលបានយល់ឃើញផងដែរថា នេះពុំបានធ្វើឱ្យគាត់ទទួលបានការ

---

943 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១៤១៩០។ ម្ចាស់បណ្តឹងសាទុក្ខបានកំណត់ត្រឹមត្រូវអំពីសាក្សីទាំងនេះ ដូចជា ស្វ សុជាតិ, ទន់ សឿន, សុខ រឿ, Philippe JULLIAN-GAUFRES និង ចៅ សុគន្ធ ក្នុងកថាខណ្ឌ ២១៧៨ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧៨ និងជើងទំព័រ ៤១៧៩។

944 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១៤១៩០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១១០៣។

945 សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១១០៣។

946 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១១៥។

947 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១១៥។

សម្រាលទោសជាសំខាន់ទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលគាត់ត្រូវបានដាក់ពិរុទ្ធភាពនោះឡើយ[948]។

346. បើទោះបីជា ខៀវ សំផន បានកត់សម្គាល់ត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងពុំបានកោះហៅសាឡើងវិញនូវសាក្សីទាំងនេះក្នុងសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របថា អង្គជំនុំជម្រះសាលាដំបូង"បានផ្តល់សុពលភាពទៅលើការពិនិត្យពុំត្រឹមត្រូវដែលបានធ្វើកន្លងមក ជាជាងអនុវត្តតាមការវាយតម្លៃហ្មត់ចត់លើតម្លៃដែលត្រូវផ្តល់ទៅលើសក្ខីកម្មទាំងនោះ"[949]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធរួចហើយនូវការចោទប្រកាន់កំហុសក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាង ក្នុងការកំណត់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវក្នុងការផ្តល់តម្លៃតិចតួចទៅលើអត្តចរិតល្អរបស់ ខៀវ សំផន ធ្វើជាកត្តាសម្រាលទោសក្នុងការដាក់ទោស។ គាត់ពុំបានផ្តល់មូលដ្ឋានគួរជឿជាក់បានសម្រាប់អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាឡើងវិញលើការវាយតម្លៃពីមុនរបស់ខ្លួន។

347. ផ្អែកលើទិដ្ឋភាពនៃតម្លៃតិចតួចដែលបានផ្តល់ទៅលើភស្តុតាងដូចគ្នានេះក្នុងសំណុំរឿង ០០២/០១ និងការយល់ស្របរបស់អង្គជំនុំជម្រះតុលាការកំពូលទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិត្រឹមត្រូវក្នុងការសម្រេចមិនកោះហៅសាក្សីទាំងនេះក្នុងសំណុំរឿង ០០២/០២។ ដោយសារការស្តាប់សាក្សីទាំងនេះឡើងវិញក្នុងសំណុំរឿង ០០២/០២ នៅគ្រប់ករណីពុំអាចប៉ះពាល់ជាសត្យានុម័តលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរក្នុងសាលដីកានេះថា ភស្តុតាងដែល ខៀវ សំផន បានចាត់ទុកថា "ជាការស្ញើចសរសើរ"នោះជាក់ស្តែងគ្មានទេ។ នៅគ្រប់ករណី អង្គជំនុំជម្រះសាលាដំបូងពុំបានព្រងើយកន្តើយលើភស្តុតាងនេះទេ[950]។

---

[948] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១១៥។

[949] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧៨ (ការយោងលុបចោល)។

[950] ទាក់ទងបញ្ហានេះ សហព្រះរាជអាជ្ញាបានកត់សម្គាល់ត្រឹមត្រូវថា សាក្សីដោះបន្ទុកជាក់ស្តែងទាក់ទងទៅនឹង ខៀវ សំផន ពុំបានរៀបរាប់ថា "គួរឱ្យស្ញើចសរសើរ"។ François PONCHAUD បានផ្តលស់ក្ខីកម្មថា ពេញមួយអំឡុងពេលនៃឆ្នាំ ១៩៧០ គាត់បានស្ញើចសរសើរ ខៀវ សំផន ប៉ុន្តែថា "អ្វីដែលបានកើតឡើងក្រោយមកនោះ ជារឿងផ្សេង"។ សក្ខីកម្មរបស់ Philip SHORT ប្រហាក់ប្រហែលគ្នាដែរមិនច្បាស់លាស់ក្នុងការសរសើរនោះដែរ។ នួន ហ៊ាន់ បានផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ ខៀវ សំផន ដោយសំដៅទៅលើសុភាសិតខ្មែរថា "ត្រីមួយកន្ត្រក់ស្អុយមួយស្អុយទាំងអស់" និងបានផ្តល់សក្ខីកម្មថា នៅពេល ខៀវ សំផន ទៅរស់នៅជាមួយខ្មែរក្រហមចិត្តខ្មៅ គាត់ស្ថិតក្នុងចំណោមត្រីស្អុយនោះ។ គាត់បានផ្តល់សក្ខីកម្មផងដែរថា ខៀវ សំផន ពុំបានស្រឡាញ់ប្រទេសជាតិរបស់ខ្លួនទេ ប៉ុន្តែផ្ទុយទៅវិញបានបំផ្លិចបំផ្លាញ។ សាក្សីដទៃទៀតបានទទួលស្គាល់ថា ពុំបានដឹងអំពី

348. កថាខណ្ឌដទៃទៀតនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលគាត់បានយោងទៅលើក្នុងការជំទាស់នេះដោយគ្មានការពន្យល់បន្ថែម ពុំបានបង្ហាញនូវការខកខានក្នុងការពិចារណា ឬវាយតម្លៃស៊ីសង្វាក់គ្នាលើភស្តុតាងដោះបន្ទុកនោះឡើយ និងលើសពីនេះទៀត ត្រូវបានវាយតម្លៃក្នុងសាលដីកានេះផងដែរ[951]។

349. ខៀវ សំផន បានដាក់បញ្ចូលតាមរយៈការយោងទៅលើកថាខណ្ឌបន្ថែមជាច្រើនក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ ធ្វើជាការបំភ្លឺអំពីស្តង់ដាពីរក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដោះបន្ទុក*ធៀបនឹង*ភស្តុតាងដាក់បន្ទុក[952]។ ភាគច្រើននៃកថាខណ្ឌទាំងនេះពុំបានលើកបញ្ហាជាក់លាក់ណាមួយពាក់ព័ន្ធទៅនឹងការវាយតម្លៃភស្តុតាងដោះបន្ទុក ឬជាអំណះអំណាងដែលត្រូវបានវាយតម្លៃពេញលេញរួចហើយក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាតែលើអំណះអំណាងដែល ខៀវ សំផន បានយោងទៅលើក្នុងកថាខណ្ឌ ៩៩៩ និង ១៣៨៣ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់ បន្ថែមទៀតនៅពេលប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនពិចារណាលើការចោទប្រកាន់ដែលពុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ឬខកខានក្នុងការបង្ហាញនូវកំហុសដែលស្តែងឱ្យឃើញជាក់លាក់គ្រប់គ្រាន់។ ទោះជាយ៉ាងណាក្តីអំណះអំណាងនេះមានកំហុសជាច្រើនដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោល។

---

សកម្មភាពរបស់ ខៀវ សំផន ក្នុងកម្ពុជាប្រជាធិបតេយ្យ ឬពុំមានទំនាក់ទំនងជាមួយគាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬថា ពួកគេពុំបានស្គាល់ ខៀវ សំផន ដោយផ្ទាល់នោះឡើយ។ *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០៥-១៣០៦។

[951] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧៧ (យោងក្នុងកថាខណ្ឌ ២៣៦, ជើងទំព័រ ៣២១) ដាក់បញ្ចូលតាមរយៈការយោងនូវអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើបញ្ហាសុខភាពរបស់គាត់។ ពុំមានកំហុសដែលបង្ហាញឱ្យឃើញ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (465) កថាខណ្ឌ ៤៣៩៨ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការដាក់ទោសសមស្របជានិច្ចកាលត្រូវតែសម្រេចដោយផ្អែកលើអង្គហេតុនៃរឿងក្តីជាក់លាក់ និងកម្រិតនៃការទទួលខុសត្រូវរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ និងបានសន្និដ្ឋានថា កាលៈទេសៈនៃរឿងក្តីនេះពុំមែនជាករណីលើកលែងដែលតម្រូវឱ្យពិចារណាលើបញ្ហាសុខភាពថា ជាកត្តាសម្រាលទោសនោះទេ)។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៦ (ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមនៅស្រុកត្រាំកក់ត្រូវបានប្រមូលផ្តុំ និរទេស និង/ឬធ្វើឱ្យបាត់ខ្លួន។ កថាខណ្ឌនេះ ពុំបានលើកបញ្ហាណាមួយនៃភស្តុតាងដោះបន្ទុកឡើយ។ អំណះអំណាងក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧៩-១២៨០ ដែលជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំបានលើកបញ្ហាច្បាស់លាស់ណាមួយពាក់ព័ន្ធទៅនឹងភស្តុតាងដោះបន្ទុកឡើយ។

[952] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ៣១៦ យោងទៅលើកថាខណ្ឌ ២៤១-២៤២, ២៩៣-៣០៥, ៣១២-៣១៣, ៣១៤-៣១៩, ៣២៩-៣៣០, ៨៩១, ៩២២, ៩៩៩, ១១៩៥, ១២៣៥, ១៣៨៣, ១៥២៩ និង ១៧៥២ និងជើងទំព័រ ៣៤០០។

350. ខៀវ សំផន បានជំទាស់ក្នុងកថាខណ្ឌ ៩៩៩ នៃសារណាបណ្ដឹងសាទុក្ខរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងពុំត្រឹមត្រូវទៅលើឯកសារចម្លងនៃរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ថា មានតម្លៃជាភស្តុតាងទាប។ គាត់បានជំទាស់ដោយគ្មានការបង្ហាញ ឬបញ្ជាក់លម្អិតលើការយល់ឃើញដែលរងការជំទាស់នោះថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនស៊ីវិលជនជាតិវៀតណាមជាច្រើននាក់បានស្លាប់ដោយសារការលិចកាណូតនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ នោះ"ពុំមែនជាការយល់ឃើញសមហេតុផលមួយដែលអាចធ្វើបាននោះទេ" និងថា នេះបង្ហាញឱ្យឃើញនូវ"ស្តង់ដាពីរក្នុងការវាយតម្លៃរបស់ [អង្គជំនុំជម្រះសាលាដំបូង] លើភស្តុតាង"[953]។

351. មូលដ្ឋានសម្រាប់ការចោទប្រកាន់របស់ ខៀវ សំផន អំពីភាពមិនស៊ីសង្វាក់គ្នាគឺថា ក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការសម្លាប់ជនជាតិវៀតណាមដទៃទៀតពុំអាចផ្អែកទៅលើមូលដ្ឋាននៃទូរលេខពីភូមិភាគបស្ចិមចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ដោយហេតុថា ទូរលេខតែមួយមុខពុំគ្រប់គ្រាន់ក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យនូវហេតុការណ៍ដាច់ដោយឡែកមួយ ឬច្រើននៃការសម្លាប់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានការប្រយ័ត្នប្រយែង គឺដោយសារទូរលេខពុំបានផ្ដល់ព័ត៌មានជាក់លាក់គ្រប់គ្រាន់អំពីកាលៈទេសៈពិតប្រាកដនៃការសម្លាប់ ពុំមានប្រភពច្បាស់លាស់អំពីចំនួននៃការស្លាប់ដែលបានរាយការណ៍ និងពុំមានភស្តុតាងផ្សេងបញ្ជាក់បន្ថែម[954]។

352. បើទោះបីជា ខៀវ សំផន ពុំបានបង្ហាញផ្នែកដែលរងការជំទាស់នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏គាត់ទំនងជាសំដៅទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងផ្នែក **១៣.៣.៩.១** ចំណងជើងថា ការចាប់កាណូតជនជាតិវៀតណាម និងជាពិសេស កថាខណ្ឌ ៣៤៦០ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង[955]។

353. ក្នុងកថាខណ្ឌ ៣៤៦០ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើរបាយការណ៍កងពល ១៦៤ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ដែលក្នុងនោះ មាស មុត បានរាយការណ៍ទៅ សុន សេន អំពីហេតុការណ៍ពីរករណី

---

[953] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៨ និង ៩៩៩។

[954] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៩ និងជើងទំព័រ ១៨៤០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧១។

[955] ផ្នែកនេះមានកថាខណ្ឌ ៣៤៥៦-៣៤៦១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ដែលមានក្នុងផ្នែក ១៣.៣.៩ ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិលជនជាតិវៀតណាមក្រៅខេត្តព្រៃវែង និងស្វាយរៀង។

ដែលជាប់ពាក់ព័ន្ធទៅនឹងកាណូតជនជាតិវៀតណាម បន្ទាប់ពីការពិនិត្យលើកថាខណ្ឌចំនួនប្រាំនៃប្រភពភស្តុតាងជាច្រើននោះ។ ក្នុងហេតុការណ៍ទីមួយ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ កងពល ១៦៤ បានបាញ់ទៅលើកាណូតជនជាតិវៀតណាមដែលស្ថិតនៅចម្ងាយមួយគីឡូម៉ែត្រភាគខាងត្បូងកោះខ្យងបណ្តាលឱ្យលិចកាណូតនោះ។ ហេតុការណ៍ទីពីរដែលបានកើតឡើងនៅកោះតាងនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ និងពាក់ព័ន្ធទៅនឹងការចាប់កាណូតជនជាតិវៀតណាមចំនួនពីរ។ យោងតាមរបាយការណ៍ ជនជាតិវៀតណាម ៧៦ នាក់ មានកុមារ និងមនុស្សចាស់ ប្រុស ស្រី ត្រូវបានចាប់ចង និងនាំមកលើគោក និងមានមនុស្សពីរនាក់បាត់ខ្លួនក្នុងទឹកដោយសារ"កាណូតតូចបានក្រឡាប់លិច"[956]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូង "ជឿជាក់ថា កាណូតជនជាតិវៀតណាមដែលចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាប់ជាប្រព័ន្ធ ឬកំណត់គោលដៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថា អ្នកនេសាទជនជាតិវៀតណាមជាច្រើន និងជនភៀសខ្លួនត្រូវបានសម្លាប់នៅហ្នឹងកន្លែង ឬភ្លាមៗបន្ទាប់ពីពួកគេឡើងគោក"[957]។

354. ជាលទ្ធផល កថាខណ្ឌ ៣៤៦០ ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដាពីរក្នុងការវាយតម្លៃលើភស្តុតាងដោះបន្ទុក និងដាក់បន្ទុក។ ការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងមួយចំនួនមានលក្ខណៈគ្រប់គ្រាន់ក្នុងការគាំទ្រការយល់ឃើញក្នុងហេតុការណ៍មួយ ខណៈពេលបានយល់ឃើញថា ភស្តុតាងដទៃទៀតពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងហេតុផ្សេងនោះ ពុំមែនបង្ហាញមានស្តង់ដាពីរ ឬពុំស៊ីសង្វាក់គ្នានោះទេ។ ក្នុងកថាខណ្ឌខាងលើបន្ទាប់កថាខណ្ឌ ៣៤៦០ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើប្រភពជាច្រើននៃភស្តុតាង រួមទាំងសក្ខីកម្មរបស់មេបញ្ជាការយោធា និងសមាជិកកងពល ១៦៤ ព្រមទាំងរបាយការណ៍កម្ពុជាប្រជាធិបតេយ្យឯកសារលេខ E3/997 ធ្វើជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានទូទៅក្នុងកថាខណ្ឌ ៣៤៩៣។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អង្គជំនុំជម្រះជឿជាក់ថា អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមត្រូវបានសម្លាប់ដោយចេតនាដោយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា ជាច្រើនលើក រួមទាំងនៅថ្ងៃទី "១៩ ខែ មីនា ឆ្នាំ ១៩៧៨ ដូចបានរាយការណ៍ដោយកងពល ១៦៤"[958]។

---

[956] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៦០ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២០ មីនា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/997 ERN 00020982។

[957] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៦១។

[958] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៣។

355. របាយការណ៍កម្ពុជាប្រជាធិបតេយ្យឯកសារលេខ E3/997 គឺជាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលបានបង្កើតឡើងតាមរយៈឋានានុក្រមបទបញ្ជាយោធា ដែលពុំមែនជាឯកសារមានតម្លៃជាភស្តុតាងទាបឡើយ។ ខៀវ សំផន ពុំអាចផ្តាច់សច្ចធារណ៍នៃភាពជាប់ពាក់ព័ន្ធ និងភាពជឿទុកចិត្តបានរួមទាំងភាពត្រឹមត្រូវនៃឯកសារដែលជាប់មកជាមួយនឹងឯកសារនេះនោះបានទេ និងដោយសារនត្ថិភាពនៃការប្រឹងប្រែងនៅពេលជំនុំជម្រះក្នុងការស្នើសុំ ឬពិនិត្យឯកសារដើមនោះនៅមជ្ឈមណ្ឌលតម្កល់ឯកសារកម្ពុជា ("មជ្ឈមណ្ឌល DC-Cam") គាត់ពុំបានផ្តល់មូលដ្ឋានគាំទ្រការតវ៉ានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលថា ឯកសារនេះគ្រាន់តែជាឯកសារចម្លងនោះទេ។

356. ការប៉ាន់ស្មានរបស់ ខៀវ សំផន អំពីវាសនារបស់ជនជាតិវៀតណាមដែលបាត់ខ្លួនពេលកាណូតលិច ដូចបានកត់ត្រាក្នុងរបាយការណ៍កម្ពុជាប្រជាធិបតេយ្យឯកសារលេខ E3/997 ពុំមានលក្ខណៈគ្រប់គ្រាន់ផងដែរក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូង[959]។ បន្ថែមលើនេះ គាត់ពុំបានបង្ហាញថា កំហុសណាមួយដែលបានចោទប្រកាន់នោះមានលក្ខណៈសំខាន់ចំពោះសាលក្រម ឬបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានសំអាងត្រឹមត្រូវទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យឯកសារលេខ E3/997 នៅពេលពិនិត្យរួមជាមួយនឹងភស្តុតាងដទៃទៀត ហើយគាត់មានបន្ទុកក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដាពីរក្នុងការវាយតម្លៃលើភស្តុតាងដោះបន្ទុក និងដាក់បន្ទុក។

357. ខៀវ សំផន បានលើកឡើងដោយគ្មានការបញ្ជាក់ជាក់លាក់បន្ថែមថា អង្គជំនុំជម្រះសាលាដំបូង"បានបដិសេធជាប្រព័ន្ធនូវចម្លើយទាំងអស់ដែលបានផ្តល់ដោយកម្មាភិបាល លើកលែងតែករណីដែលពួកគាត់ផ្តល់ភស្តុតាងដែលអង្គជំនុំជម្រះចាត់ទុកថា ជាបទល្មើស ឬការដាក់បន្ទុក"[960]។ គាត់បានជំទាស់ដោយគ្មានបញ្ជាក់ជាក់លាក់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ស្តង់ដាពីរនៅក្នុងការវាយតម្លៃលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ ទោះជាយ៉ាងណាក្តី គាត់ពុំបានបង្ហាញករណីដែលអង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើភស្តុតាងរបស់កម្មាភិបាលដែលត្រូវបានបញ្ជាក់បន្ថែមគ្រប់គ្រាន់ ខណៈពេល "ទទួលយកជាប្រព័ន្ធនូវការជឿជាក់នៃចម្លើយទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី" បើទោះបីជាមានលក្ខណៈពុំស៊ីសង្វាក់គ្នា ដាច់ដោយឡែក ឬពុំត្រូវបានបញ្ជាក់បន្ថែមក៏ដោយ[961]។

---

[959] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៨។

[960] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៨៣។

[961] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៨៣។

358. ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាពេញលេញលើអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់បានជំទាស់ថា មានភាពមិនស៊ីសង្វាក់គ្នា[962] ។ បន្ទាប់ពីបានពិចារណាដោយប្រុងប្រយ័ត្ន ភាពមិនស៊ីសង្វាក់គ្នានេះត្រូវបានកំណត់ថា ជាបញ្ហាតូចតាច ដែលពុំអាចមានអានុភាពប៉ះពាល់លើភាពពុំគួរឱ្យជឿជាក់បានជារួមរបស់ពួកគេឡើយ[963]។ បន្ថែមលើនេះ អំណះអំណាងរបស់គាត់ជាសំខាន់ត្រូវបានលើកច្រំដែលទាក់ទងទៅនឹងការជំទាស់ដទៃទៀត។

359. ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដោះបន្ទុក ឬប្រើប្រាស់ស្តង់ដាពីរនៅក្នុងការវាយតម្លៃជារួមលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ ផ្អែកលើមូលដ្ឋាននេះ ជាការពុំអាចធ្វើទៅបានក្នុងការសន្និដ្ឋានថា សិទ្ធិផ្នែកនីតិវិធីរបស់គាត់ត្រូវបានរំលោភបំពាន។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់ត្រូវបដិសេធចោលពាក់ព័ន្ធបញ្ហានេះ។

### ឃ. ចំនួននៃភស្តុតាង និងតម្លៃជាភស្តុតាង

360. សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានធ្វើផ្ទុយគ្នានៅក្នុងសំអាងហេតុរបស់ខ្លួននៃសំណុំរឿង ០០២/០២ និងដោយសារខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវគោលការណ៍ ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវពាក់ព័ន្ធនឹងការវាយតម្លៃ និងតម្លៃជាភស្តុតាងនៃប្រភេទជាច្រើននៃភស្តុតាង។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានកាតព្វកិច្ចរបស់ខ្លួនក្នុងការវាយតម្លៃលើភស្តុតាងទាំងមូល និងជៀសវាងការវាយតម្លៃតាមផ្នែកៗ និងជៀសវាង"ការបូកបន្ថែម"ភស្តុតាងដើម្បីឱ្យបំពេញតាមលក្ខខណ្ឌស្តីពីបន្ទុកក្នុងការបង្ហាញភស្តុតាង[964]។ ខៀវ សំផន បានសំដៅជាចម្បងទៅលើកថាខណ្ឌ ២០២៦ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់ និងកថាខណ្ឌ ៤២៧១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងការគាំទ្រការអះអាងទាំងនេះ[965]។

---

[962] *សូមមើល ឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៨៦-១៣៨៨ (ពិពណ៌នាអំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន រួមទាំង អ៊ុំ យឿន, ព្រាប សុខឿន និង មុំ វុន ថា មាន"ការភ្លេចភ្លាំង" និង"ឃើតយ៉ាវកែតម្រូវចុងក្រោយ")។

[963] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៨-៣៦៦១។

[964] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០ និងជើងទំព័រ ៩៦-៩៩។

[965] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៣៧ និង ៣៣៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០ និង ៤២៧១ រួមទាំងជើងទំព័រ ៩៦-៩៩, ១៣៩៣៨, ១៣៩៣៩ និងការយោងជាច្រើនបន្ថែមទៀតនៅទី

361. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសការវាយតម្លៃនោះឡើយ[966]។

362. ផ្អែកតាមកថាខណ្ឌ ៤២៧១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងថា៖

> ខៀវ សំផន គាំទ្រយ៉ាងពេញទំហឹងចំពោះគោលនយោបាយរបស់ ប.ក.ក. ពាក់ព័ន្ធនឹងការនិរទេសជនជាតិវៀតណាម។ នៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ គាត់មានវត្តមាននិងឧទ្ទេសនាមផ្ទាល់នៅក្នុងព្រឹត្តិការណ៍ដែលគូសបញ្ជាក់អំពីសារៈសំខាន់នៃ"ការជម្លៀស"ប្រជាជនវៀតណាមទាំងអស់ពីកម្ពុជា។ នៅពេលនោះ គាត់បានឧទ្ទេសនាមជាក់លាក់ដល់អ្នកត្រឡប់ពីបរទេសមកកម្ពុជា អំពីគោលបំណងរួម រួមមាន "ប្រជាជនទាំងអស់នៅកម្ពុជាត្រូវធ្វើកសិកម្ម" ហើយបានកត់សម្គាល់ថាអ្នកដែលមិនអាច "ជាពិសេសវៀតណាម"នឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ។ គាត់បានអំពាវនាវម្តងហើយម្តងទៀត នៅក្នុងខែមេសា ឆ្នាំ ១៩៧៨ ដែលនៅពេលនោះ គោលនយោបាយរបស់ ប.ក.ក. បានវិវត្តពីការនិរទេសទៅជាការកម្ទេចវិញ។ បន្ទាប់ពីការផ្លាស់ប្តូរគោលនយោបាយ ប.ក.ក. ចំពោះជនជាតិវៀតណាមនៅឆ្នាំ ១៩៧៧ ខៀវ សំផន បានឧទ្ទេសនាមនៅក្នុងវគ្គបំពាក់បំប៉នថា "យើងត្រូវសាមគ្គីគ្នា" ហើយថា "ប្រទេសខ្មែរអត់មានយួន" ខណៈពេលនោះគាត់ក៏បានចូលរួម និងឧទ្ទេសនាមក្នុងវគ្គអប់រំនយោបាយផងដែរ ដោយបានថ្កោលទោសវៀតណាម និង "គិញ"របស់ពួកគេថា ជាខ្មាំង[967]។

363. ក្នុងកថាខណ្ឌ ២០២៦ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់ និងកថាខណ្ឌដទៃទៀតដែលបានយោងនៅទីនោះ ខៀវ សំផន បានអះអាងថា ការយល់ឃើញផ្អែកអង្គហេតុជាច្រើនដែលពាក់ព័ន្ធទៅនឹងអ្វីដែលគាត់ត្រូវបានចោទប្រកាន់ថា បាននិយាយអំពីជនជាតិវៀតណាម និងប្រធានមន្ទីរស-៧១ ឈ្មោះ ឈឹម សំអោក *ហៅ* ប៉ង់ បានផ្អែកដោយពុំត្រឹមត្រូវទៅលើសក្ខីកម្មរបស់ ឯក ហេន ដែលគាត់បានលើកឡើងថា មានលក្ខណៈផ្ទុយគ្នា និងខ្វះភាពគួរឱ្យជឿជាក់បាន[968]។ ឯក ហេន ដែលជាអ្នកធ្វើការក្នុងកងកាត់ដេរដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ បានផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាលដែលបានដឹកនាំដោយ ខៀវ

---

នោះ។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ៣៣៨ យោងទៅលើផ្អែកដទៃទៀតនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១៧, ៣៣៨៥, ៣៣៩០, ៣៣៩១, ៣៣៩៦ និង ជើងទំព័រ ១១៤៣៦។

[966] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៨-១៣០។

[967] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧១ (ការដកស្រង់លុបចោល)។

[968] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២៦ យោងបន្ថែមទៅលើកថាខណ្ឌ ១០៧៥, ១៧៥៩, និង ១៨៩២-១៨៩៤)។

សំផន ថា លោកស្រីបានចូលរួម មានអ្នកចូលរួមប្រមាណពី ៤០០ ទៅ ៥០០ នាក់ដែលក្នុងនោះ ខៀវ សំផន បានពន្យល់ថា "យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន [...]"[969]។

364. ខៀវ សំផន ពុំបានពន្យល់អំពីមូលហេតុដែលភស្តុតាងរបស់ ឯក ហេន គប្បីផ្តល់ភាពគួរជឿជាក់តិចតួចក្រៅតែពីការអះអាងពុំត្រឹមត្រូវថា ឯក ហេន គឺប្រភពភស្តុតាងតែមួយគត់ពាក់ព័ន្ធនឹងបទឧទ្ទេសនាមរបស់គាត់[970]។ ជាក់ស្តែង ភស្តុតាងរបស់លោកស្រីពាក់ព័ន្ធនឹងបទឧទ្ទេសនាមរបស់ ខៀវ សំផន និងខ្លឹមសារនោះ ត្រូវបានបញ្ជាក់បន្ថែមដោយប្រភពជាច្រើនដទៃទៀតដែលបានយោងទៅលើនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[971]។ នៅក្នុងផ្នែកដទៃទៀតនៃសារណាបណ្តឹងសាទុក្ខរបស់គាត់ដែលបានយោងឆ្លងតាមរយៈការជំទាស់នេះឃើញថា ភស្តុតាងរបស់ ឯក ហេន ត្រូវបានពិពណ៌នាផ្សេងៗថា "ខ្វះភាពគួរឱ្យជឿជាក់បាន" "មានភាពពុំស៊ីសង្វាក់គ្នា" និងអាចបកស្រាយបានផ្សេងៗទៀត[972]។ ឯក ហេន ត្រូវបានពិពណ៌នាថាមានការភាន់ច្រឡំ និងចងចាំពុំបានល្អ[973]។ ផ្ទុយទៅនឹងការពិពណ៌នារបស់ ខៀវ សំផន លើភស្តុតាងរបស់លោកស្រី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ព័ត៌មានលម្អិតដែលបានផ្តល់ដោយ ឯក ហេន ជាពិសេសពាក់ព័ន្ធទៅនឹងមីទ្ទីង និងការបណ្តុះបណ្តាលនយោបាយដែលដឹកនាំដោយ ខៀវ សំផន មានអត្ត

---

[969] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ យោងទៅលើប្រតិចារឹកថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤, ៣៦, ៤០។

[970] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៣៨។

[971] កិច្ចប្រជុំនយោបាយ វគ្គបណ្តុះបណ្តាល និងបទឧទ្ទេសនាមដោយ ខៀវ សំផន ត្រូវបានពិពណ៌នាដោយសាក្សីផ្សេងៗក្នុងផ្នែកជាច្រើននៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២។ *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៧, ៣៣៩០ (កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់"សាក្សីជាច្រើន"(រួមទាំង ឯក ហេន) ពាក់ព័ន្ធទៅនឹងការបង្រៀនដោយ ខៀវ សំផន និងសហជនជាប់ចោទដទៃទៀត ដែលបានចាត់ទុកជនជាតិវៀតណាមជាសត្រូវ), ៣៤០៦, ៣៧៣៩, ៣៩១៦, ៣៩៦១ (ពិពណ៌នាអំពីការរៀបរាប់បញ្ជាក់បន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រា ឆុន ដែលបានប្រាប់អង្គជំនុំជម្រះថា ក្នុងពេលថ្លែងសុន្ទរកថាទៅកាន់ក្រុមអ្នកដែលត្រូវបានជម្លៀសក្នុងភូមិភាគបូព៌ានៅផ្សារច្បារអំពៅក្នុងឆ្នាំ ១៩៧៧ ខៀវ សំផន បានលើកឡើងថា គោលបំណងនៃបដិវត្តន៍គឺដើម្បីលុបបំបាត់របប លន់ នល់ ព្រមទាំងពួកមូលធន សក្តិភូមិ និងបញ្ញវន្ត (ប្រតិចារឹកថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ព្រាប ឆុន) ឯកសារលេខ E1/504.1 ទំព័រ ៦៩, ៧៣-៧៤)), ៣៩៦៨ និង ៤២៧២)។

[972] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧៥។

[973] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៩ និង ១៨៩៣។

ប្រយោជន៍ និងគួរឱ្យជឿជាក់បាន[974]។ ពុំមានកំណត់ត្រានៃការជំនុំជម្រះ ឬសារណារបស់គាត់បានបង្ហាញនូវភាពមិនស៊ីសង្វាក់គ្នាជាក់លាក់ណាមួយឡើយនៅក្នុងការរៀបរាប់របស់ ឯក ហេន អំពីព្រឹត្តិការណ៍ដែលលោកស្រីបានចូលរួម និងបានរំឭកឡើងវិញ ហើយអង្គជំនុំជម្រះតុលាការកំពូលទទួលយកការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មនេះ។

365. ចុងក្រោយ ខៀវ សំផន បានរិះគន់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការព្យាយាមបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់ ឯក ហេន ពីប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ នៅ សារឹម ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក និងបានអះអាងថា ចម្លើយនេះត្រូវបានធ្វើឡើងក្រៅវិសាលភាពរបស់តុលាការ និងមានតម្លៃជាភស្តុតាងតិចតួចណាស់[975]។ គាត់បានអះអាងបន្ថែមទៀតថា ពុំមានភាពច្បាស់លាស់ថាតើ ខ្លឹមសារនៃកិច្ចសម្ភាសន៍នោះអាចបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់ ឯក ហេន យ៉ាងដូចម្តេចឡើយ បើវគ្គបណ្តុះបណ្តាលដែល ឯក ហេន បានចូលរួម គឺនៅក្នុងពាក់កណ្តាលឆ្នាំ ១៩៧៨ ហើយ នៅ សារឹម នៅចុងឆ្នាំ ១៩៧៦។ ខៀវ សំផន បានជំទាស់ថា ជាការដែលពុំអាចធ្វើទៅបានសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញដោយផ្អែកលើភស្តុតាងនេះថា ពាក្យសំដីរបស់គាត់ "បានឆ្លុះបញ្ចាំងខ្លឹមសារ ទម្រង់ និងការអនុវត្តន៍ចុងក្រោយនៃគោលបំណងរួមក្នុងការនិរទេសជនជាតិវៀតណាមឆ្លងកាត់ព្រំប្រទល់ក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦"[976]។ បន្ថែមលើនេះ និងបើទោះបីជាចម្លើយនោះបានឆ្លុះបញ្ចាំងគោលបំណងរួមនៃការនិរទេសជនជាតិវៀតណាមក៏ដោយក៏"នេះពុំបានអនុញ្ញាតឱ្យអង្គជំនុំជម្រះបង្ហាញថា គាត់បានដឹងថា ប្រជាជនវៀតណាមនៅក្នុងស្រុកត្រាំកក់ត្រូវបាននិរទេសនៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦ និងក្នុងខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ ដែរ។ ដោយសារនត្ថិភាពនៃភស្តុតាង អង្គជំនុំជម្រះពុំអាចយល់ឃើញថា ខៀវ សំផន បានដឹងថា បទឧក្រិដ្ឋនៃការនិរទេសត្រូវបានប្រព្រឹត្តទៅលើជនជាតិវៀតណាមក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ"ឡើយ[977]។

---

[974] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៣៩០ និង ៤២៧២ ជើងទំព័រ ១១៤៣៧ និង ១៣៩៤៦ (ពិពណ៌នាបន្ថែមលើសក្ខកម្មក្នុងតុលាការរបស់ ឯក ហេន ដែលត្រូវបានបញ្ជាក់បន្ថែមដោយកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ (E3/474))។

[975] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩៤ និងជើងទំព័រ ៣៦៧១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ និងជើងទំព័រ ១១៤៣៧។

[976] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៧។

[977] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩៤។

366. អំណះអំណាងទាក់ទងទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន អំពីកង្វះការដឹងពាក់ព័ន្ធទៅនឹងឧក្រិដ្ឋនកម្ម នៃការនិរទេសជនជាតិវៀតណាមត្រូវបានដោះស្រាយពេញលេញក្នុងសាលដីកានេះ[978]។ សម្រាប់គោលបំណងនៃការជំទាស់នេះ ជាការគ្រប់គ្រាន់ក្នុងការកត់សម្គាល់ថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងបញ្ហានេះពុំមែនផ្អែកលើសក្ខីកម្មរបស់សាក្សីតែមួយគត់នោះទេ ប៉ុន្តែបានផ្អែកលើប្រភពភស្តុតាងជាច្រើន។

367. ទាក់ទងទៅនឹងមូលដ្ឋានសម្រាប់ការវាយតម្លៃលើភស្តុតាងទាំងមូល អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគលើភស្តុតាងយ៉ាងទូលំទូលាយដើម្បីបង្ហាញអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន រួមទាំងការដឹង និងចេតនារបស់គាត់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តទៅលើជនជាតិវៀតណាម[979]។ កថាខណ្ឌ ៤២៧១ និងផ្នែកពាក់ព័ន្ធនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើចំណុចជាច្រើននៃផ្នែក ១៣.៣៖ ការប្រព្រឹត្តទៅលើជនជាតិវៀតណាម ដែលទាំងអស់នេះសំដៅទៅលើចំនួនជាច្រើននៃភស្តុតាង និងប្រភពដែលបញ្ជាក់បន្ថែមលើនោះ[980]។ ផ្ទុយពីការបង្ហាញនូវវិធីសាស្ត្របែបជ្រើសរើសផ្នែកៗចំពោះភស្តុតាងដូចបានចោទប្រកាន់ដោយ ខៀវ សំផន សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងផ្នែកនោះបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃលម្អិត និងផ្ចិតផ្ចង់លើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន ដោយផ្អែកលើប្រភពភស្តុតាងជាច្រើនដែលគួរឱ្យជឿជាក់បាន។

368. ខៀវ សំផន ខកខានក្នុងការកាត់បន្ថយតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់សាក្សី ដូចជា ឯក ហេន និងប្រភពដទៃទៀតនៃភស្តុតាងដែលបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីគាំទ្រការយល់ឃើ ញពាក់ព័ន្ធទៅនឹងការគាំទ្ររបស់គាត់ដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ខៀវ សំផន ខកខានផងដែរក្នុងការបង្ហាញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកតែទៅលើការជ្រើសរើសផ្នែកៗនៃភស្តុតាង ឬចំនួនដ៏ច្រើននៃភស្តុតាងដែលមានតម្លៃជាភស្តុតាងទាប។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការសន្និដ្ឋានរបស់ខ្លួនលើការវិភាគលម្អិតលើភស្តុតាងជារួម។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសណាមួយក្នុងការវាយតម្លៃជារួមរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនោះ។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

---

[978] *សូមមើល* ផ្នែក VIII.ខ.៨.គ។

[979] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦២-៦២៤ (តួនាទី និងមុខតំណែង), ៤២០១-៤៣២៩ (ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ) និង ៣៩៦១។ *សូមមើលផងដែរខាងក្រោម* ផ្នែក VIII.ខ.៨.គ។

[980] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១៣៩៣៦-១៣៩៣៩ យោងទៅលើផ្នែក ១៣:៣: ការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងយោងទៅលើជាពិសេសកថាខណ្ឌ ៣៤០០, ៣៤១៦, ៣៣៩០, ៣៥១៧។

## ង. ការបញ្ជាក់បន្ថែម

369. ទាក់ទងទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់បន្ថែមដែល ខៀវ សំផន ពុំបានជំទាស់ជាទូទៅ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តផ្ទុយខ្លួនឯងនៅក្នុងសំអាងហេតុរបស់ខ្លួនដោយសារខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវគោលការណ៍ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ[981]។ គាត់បានលើកឡើងថា ការជំនុំជម្រះសំណុំរឿង ០០២/០២ តម្រូវឱ្យមានការពិនិត្យហ្មត់ចត់ជាពិសេស ដោយសារព្រឹត្តិការណ៍បានកើតឡើងជាង ៤០ ឆ្នាំកន្លងទៅហើយ និងភស្តុតាងដែលត្រូវបានបង្ហាញនោះ អាចធ្វើឱ្យភាន់ច្រឡំបាន[982]។ ក្នុងការគាំទ្រការអះអាងរបស់គាត់ ខៀវ សំផន បានផ្អែកទៅលើកថាខណ្ឌ ៤៩ និង ៥៣ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងឧទាហរណ៍ផ្នែកអង្គហេតុដែលបានទាញចេញពីកថាខណ្ឌចំនួនប្រាំនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់[983]។

370. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស[984]។

371. កថាខណ្ឌ ៤៩ នៃសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> ក្នុងឋានៈពិសេសរបស់ពួកគាត់ តុលាការពុំតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថនោះទេ។ អង្គជំនុំជម្រះពិនិត្យលើភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ តាមករណីជាក់ស្តែងនីមួយៗ ដោយផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្មនិងដោយការពិចារណាផ្អែកលើកត្តាមួយចំនួន ដូចជា អត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីសង្វាក់គ្នា និងភាពមិនស៊ីសង្វាក់គ្នាទាក់ទងទនឹងអង្គហេតុសំខាន់ៗការជំរុញពីខាងក្រៅដែលអាចមានការអះអាងបញ្ជាក់ និងកាលៈទេសៈទាំងអស់នៃរឿងក្តីនេះ[985]។

372. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមក្នុងកថាខណ្ឌ ៥៣ នៃសាលក្រមរបស់ខ្លួនថា៖

---

[981] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤១-២៤២។

[982] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤២។

[983] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៤១ និង ៣៤២ យោងទៅលើកថាខណ្ឌ ២៣៨, ៣១២-៣១៣, ៧៨១ និង ៨៦៦ នៃសារណាបណ្តឹងសាទុក្ខ។

[984] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣៤។

[985] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៩ (ការយោងខាងក្នុងលុបចោល)។

ទាក់ទងនឹងបញ្ហាពាក់ព័ន្ធ មេធាវីការពារក្តី នួន ជា បានលើកឡើងអំពីបញ្ហានៃការអនុវត្តន៍ជាក់ស្តែងដែលបានប្រើនៅក្នុងពេលសួរសំណួរខ្លះៗ ដើម្បីរម្លឹកដល់ការចងចាំរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដោយលើកឡើងពីការដកស្រង់ចម្លើយមុនៗរបស់ពួកគាត់នៅក្នុងអំឡុងការផ្តល់សក្ខីកម្ម។ មេធាវីការពារក្តី នួន ជា បានលើកឡើងថា ការអនុវត្តបែបនេះត្រូវបានចាត់ទុកថាជាការសួរសំណួរនាំមុខដល់សាក្សីឬដើមបណ្តឹងរដ្ឋប្បវេណីហេតុនេះវាធ្វើឱ្យសក្ខីកម្មរបស់បុគ្គលទាំងនេះ មិនគួរឱ្យទុកចិត្តបាន។ អង្គជំនុំជម្រះសង្កេតឃើញថា ការជំទាស់ទាំងនេះត្រូវបានបដិសេធ ក្នុងករណីដែលសំណួរបើកត្រូវបានសួរជាមុន និងនៅពេលដែលសម្រង់នានាត្រូវបានលើកឡើងក្នុងគោលបំណងសួរដេញដោលដល់អ្នកផ្តល់ភ័ស្តុតាង ដោយប្រើប្រាស់ចម្លើយផ្ទាល់របស់អ្នកផ្តល់ភ័ស្តុតាងនោះ។ អង្គជំនុំជម្រះរម្លឹកបន្ថែមទៀតថា ភាពអាចជឿជាក់បាននៃសក្ខីកម្ម ត្រូវវាយតម្លៃទៅតាមករណីជាក់ស្តែង ដោយពិចារណាទៅលើកត្តាមួយចំនួន ដូចជា ភាពស៊ីសង្វាក់គ្នាឬមិនស៊ីសង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ ការអះអាងបញ្ជាក់ និងកាលៈទេសៈនានានៃរឿងក្តី។ ការប្រើសំណួរនាំមុខ ដូចជាការប្រើប្រាស់ចម្លើយពីមុនរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជួយរម្លឹកដល់ការចងចាំរបស់ពួកគេក៏ជាប់ពាក់ព័ន្ធផងដែរជាមួយនឹងភាពគួរឱ្យជឿជាក់បាន និងភាពគួរឱ្យទុកចិត្តបាននៃសក្ខីកម្ម ដែលអង្គជំនុំជម្រះនឹងយកមកពិចារណា[986]។

373. ខណៈពេលយល់ស្របជាមួយនឹងគោលការណ៍ដែលត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌទាំងនេះ ខៀវ សំផន បានជំទាស់ដោយយោងទៅលើកថាខណ្ឌ ៧៨១ និង ៨៦៦ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវបទដ្ឋានទាំងនេះ។

374. កថាខណ្ឌ ៧៨១ នៃសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានជំទាស់ទៅនឹងទិដ្ឋភាពនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការស្លាប់មួយចំនួននៅការដ្ឋានធ្វើការបានកើតឡើងដោយចេតនា ជាពិសេសការបាក់ដីសង្កត់ស្លាប់អ្នកធ្វើការនៅទីនោះ។ គាត់បានចោទប្រកាន់ថា សក្ខីកម្មរបស់ នួន ណារុំ ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការគាំទ្រសេចក្តីសន្និដ្ឋាននេះ ដោយសារគាត់បានអះអាងក្នុងភស្តុតាងរបស់គាត់ថា ដោយបានធ្វើការនៅទីកន្លែងនោះអស់រយៈពេលប្រាំមួយ ឬប្រាំពីរខែ គ្មានឃើញនរណាស្លាប់[987]។ ផ្អែកតាមទស្សនៈរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើសក្ខីកម្មរបស់លោកស្រី នួន ណារុំ ក្នុងការយល់ឃើញថា មានការស្លាប់បានកើតឡើងនោះបានឡើយ។ ខៀវ សំផន បានបដិសេធ

---

[986] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៣។

[987] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨១ ជើងទំព័រ ១៣៩៧ យោងទៅលើប្រតិចារឹកថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ (នួន ណារុំ) ឯកសារលេខ E1/304.1 នៅចន្លោះម៉ោង ១០.៤៩.៣៩ ដល់ ម៉ោង ១០.៥១.៥៦។

ប្រហាក់ប្រហែលគ្នានូវសក្ខីកម្មរបស់ ហ៊ុន សិត្ថានី, អ៊ុន រ៉ន និង អ៊ុត សេង ថា "ត្រឹមតែជាពាក្យចចាមអារ៉ាម" និងដូច្នេះ ពុំអាច"ប្រើប្រាស់ធ្វើជាសក្ខីកម្មបញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹងការស្លាប់បុគ្គលដោយសារបាក់ដីសង្កត់ស្លាប់នោះ ពីព្រោះភស្តុតាងរបស់សាក្សីនេះមានលក្ខណៈពុំគ្រប់គ្រាន់"[988]។

375. ការយល់ឃើញទាំងនេះមាននៅក្នុងផ្នែក ១១.២.១២ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារ និងការដាក់កំណត់ការងារ។ ផ្នែកនេះបានពិពណ៌នាអំពីលក្ខខណ្ឌការងារដ៏លំបាកនៅការដ្ឋានទំនប់១មករា។ កថាខណ្ឌ ១៥៣៥ បានសង្ខេបសក្ខីកម្មពាក់ព័ន្ធទៅនឹងការបាក់ដីសង្កត់ស្លាប់ ឬរបួសអ្នកធ្វើការមួយចំនួន។ បើទោះបីជាចម្លើយរបស់សាក្សីមួយចំនួនមានពាក្យចចាមអារ៉ាមក៏ដោយ[989] ក៏ពុំមានការហាមឃាត់ដាច់ខាតមិនឱ្យប្រើប្រាស់ភស្តុតាងនោះឡើយ ដរាបណាបានធ្វើឡើងដោយប្រុងប្រយ័ត្ន។ បន្ថែមលើនេះ ចម្លើយរបស់សាក្សីមានលក្ខណៈគួរឱ្យជឿជាក់បាននៅពេលពិនិត្យដោយផ្អែកលើលក្ខខណ្ឌការងារគួរឱ្យសង្វេគនៅតាមការដ្ឋានធ្វើការ និងសហករណ៍នានា។ ចម្លើយនោះមានការបង្ហាញផងដែរនូវភាពគួរឱ្យជឿទុកចិត្តបានដោយសារមានលក្ខណៈច្បាស់លាស់ក្នុងការពិពណ៌នានូវអ្វីដែលសាក្សីបានសង្កេត និងជាប្រភពនៃព័ត៌មាន។

376. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងរបស់សាក្សីផ្ទាល់ដូចជា នួន ណារុំ និងភស្តុតាងចចាមអារ៉ាម អ៊ុន រ៉ន និងដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ផងដែរថា ផ្នែកនៃសាលក្រមដែលរងការជំទាស់នោះបានយោងទៅលើផ្នែកខ្លះនៃចម្លើយរបស់សាក្សីនៅក្នុងជើងទំព័រតែមួយនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ជាការលំបាកក្នុងការយល់ឃើញថាតើកំហុសដែលបានចោទប្រកាន់នោះ បើទោះបីជាមានមូលដ្ឋានគាំទ្រក៏ដោយ អាចប៉ះពាល់ដូចម្តេចទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យមានលក្ខណៈគ្រប់គ្រាន់តម្រូវឱ្យមានការអន្តរាគមន៍កែតម្រូវពីអង្គជំនុំជម្រះតុលាការកំពូលនោះ។

---

[988] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨១ និង ជើងទំព័រ ១៤០១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៥២៣៦។

[989] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ៥២៣៦ យោងទៅលើប្រតិចារឹកថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ (អ៊ុន រ៉ន) ឯកសារលេខ E1/307 ទំព័រ ១១, ៦១-៦២ (អះអាងថា លោកស្រីបានឮផងដែរអំពីការបាក់ដីដែលសង្កត់អ្នកធ្វើការបីនាក់ ស្លាប់ម្នាក់នៅហ្នឹងកន្លែង។ ប៉ុន្តែ លោកស្រីពុំបានសង្កេតឃើញថា ហេតុការណ៍នោះបានកើតឡើងឆ្ងាយពីកន្លែងលោកស្រីធ្វើការ និងរោងដេក)។

377. កថាខណ្ឌ ៨៦៦ នៃសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្លុង ដុស និង សុខ អ៊ែល ក្នុងការយល់ឃើញអំពីការសម្លាប់មួយចំនួននៅមន្ទីរសន្តិសុខភ្នំក្រោលបានកើតឡើង[990]។ គាត់បានចោទប្រកាន់បន្ថែមលើអង្គជំនុំជម្រះសាលាដំបូងដោយសារខកខានក្នុងការពិចារណាលើកាលៈទេសៈដែលក្នុងនោះចម្លើយទាំងនេះត្រូវបានកត់ត្រា[991]។ អំណះអំណាងទាំងនេះនឹងត្រូវដោះស្រាយក្នុងផ្នែកនៃសាលដីកានេះដែលដោះស្រាយលើអំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅភ្នំក្រោល[992]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញស្តីពីអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅភ្នំក្រោល ដែលបានផ្អែកទៅលើចម្លើយជាលាយលក្ខណ៍អក្សរទាំងនេះ។

378. ចុងក្រោយ ខៀវ សំផន បានជំទាស់ដោយគ្មានការបង្ហាញនូវកំហុសជាក់លាក់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងថា ការបញ្ជាក់បន្ថែមគឺជាគោលការណ៍ណែនាំនៅក្នុងច្បាប់ស្តីពីភស្តុតាង និងនីតិវិធីព្រហ្មទណ្ឌ។ នេះគឺដោយសារគោលការណ៍នេះបានតម្រូវឱ្យភស្តុតាងត្រូវដាក់ឱ្យសួរដេញដោល និងបានហាមឃាត់ការធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើពាក្យចចាមអារ៉ាម[993]។ ក្នុងការគាំទ្រការអះអាងនេះ គាត់បានយោងទៅលើកថាខណ្ឌ ២៣៨ និង ៣១២-៣១៣ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់។ ដោយសារអំណះអំណាងក្នុងកថាខណ្ឌនេះ ត្រូវបានដោះស្រាយពេញលេញក្នុងសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់វាយតម្លៃបន្ថែមទៀតលើកថាខណ្ឌទាំងនេះនៅក្នុងការជំទាស់នោះឡើយ[994]។

379. យោងតាមសំអាងហេតុខាងលើ ខៀវ សំផន ពុំបានបង្ហាញថា សាលក្រមអង្គជំនុំអង្គជំនុំជម្រះសាលាដំបូងត្រូវបានធ្វើឱ្យប៉ះពាល់ផ្នែកខ្លះ ឬទាំងមូល ដោយសារគាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើគោលការណ៍បង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងការបញ្ជាក់បន្ថែមនោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

---

[990] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៥-៨៦៦ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ្លុង ដុស ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E3/6260 និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុខ អ៊ែល ឯកសារលេខ E3/6314។

[991] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៦ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤៣០។

[992] *សូមមើលខាងក្រោម* ផ្នែក VII.ក.៥.ង។

[993] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤២។

[994] *សូមមើលខាងលើ* ផ្នែក V.ង.១.ខ និងផ្នែក*ខាងក្រោម* V.ង.១.ជ។

## ច. ភាពមិនស៊ីសង្វាក់គ្នា

380. ក្នុងកថាខណ្ឌ ២៤៣ នៃសារណាបណ្ដឹងសាទុក្ខ ខៀវ សំផន បានយោងទៅលើក្របខ័ណ្ឌដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើភស្តុតាងក្នុងកថាខណ្ឌ ៤៩-៥៤ និង ៦១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង[995]។ បើទោះបីជាស្របជាមួយនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌទាំងនេះក៏ដោយ ក៏គាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានធ្វើផ្ទុយនៅនឹងក្របខ័ណ្ឌនៅក្នុងសំអាងហេតុរបស់ខ្លួន និងដោយសារខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវក្របខ័ណ្ឌនេះ[996]។ ក្នុងការគាំទ្រការអះអាងនេះ ខៀវ សំផន បានយោងទៅលើចំណុចដែលចោទប្រកាន់ថាផ្ទុយគ្នានៅក្នុងភស្តុតាងរបស់ អែម អឿន ដូចបានពិពណ៌នាក្នុងកថាខណ្ឌ ១៧៥៧-១៧៥៨ នៃសារណាបណ្ដឹងសាទុក្ខ[997]។

381. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសណាមួយក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពផ្ទុយគ្នា ឬភាពពុំស៊ីសង្វាក់គ្នាដែលបានចោទប្រកាន់នៅក្នុងភស្តុតាងនោះ[998]។

382. ក្របខ័ណ្ឌគតិយុត្តដែលបានដកស្រង់ដោយ ខៀវ សំផន ក្នុងកថាខណ្ឌ ៤៩-៥៤ និង ៦១ ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពុំមានទំនាក់ទំនងជាក់ស្ដែងទៅនឹងការជំទាស់នេះ និងលើកច្រំដែលនៅក្នុងអំណះអំណាងខាងលើ។

383. ក្នុងកថាខណ្ឌ ១៧៥៧-១៧៥៨ នៃសារណាបណ្ដឹងសាទុក្ខ ខៀវ សំផន ត្រឹមតែលើកសាឡើងវិញថា អែម អឿន ពុំមែនជាសាក្សីគួរឱ្យជឿជាក់បាន។ គាត់បានអះអាងថា សក្ខីកម្មរបស់សាក្សីនេះ"មានភាពផ្ទុយគ្នា និងភាពពុំស៊ីសង្វាក់គ្នាជាច្រើន" និងបានពិពណ៌នាថា "ការចងចាំគ្រប់ម៉ាត់"នូវបទឧទ្ទេសនាមរបស់គាត់

---

[995] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៣ យោងទៅលើវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ សេចក្ដីសម្រេចក្នុងសំណុំរឿង ០០២ ស្ដីពីសារណារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង (E96/7)។ សំណុំរឿង ០០២ សេចក្ដីសម្រេចលើការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រតិចារឹកសំណុំរឿង ០០១ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ឯកសារលេខ E299។ សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារក្នុងសំណុំរឿង ០០២/០២ (E305/17)។

[996] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៣។

[997] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៤៣, ជើងទំព័រ ៣៤៧។

[998] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣៩-១៤២។

ដែលថាអំពាវនាវឱ្យស្វែងរកខ្លាំង ជាការ“ពុំគួរឱ្យជឿ”[999]ឡើយ។ អែម អឿន ត្រូវបានចាត់ទុកផងដែរថាមានការភាន់ច្រឡំពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនៃព្រឹត្តិការណ៍ និងថា បានផ្ដល់“ការពន្យល់ផ្សេងៗគ្នាជាច្រើន” អាស្រ័យលើអ្នកសួរសំណួរគាត់[1000]។ ជាលទ្ធផល ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង“ពុំអាចសំអាងដោយសមហេតុផលទៅលើសក្ខីកម្មរបស់ អែម អឿន”បានឡើយ និងថា ការមិនអើពើលើភាពផ្ទុយគ្នានេះបើទោះបីជាត្រូវបានគូសបញ្ជាក់ក្នុងពេលសួរសំណួរយ៉ាងណាក៏ដោយ ក៏ជាការខកខានរបស់អង្គជំនុំជម្រះក្នុងបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីផ្ដល់សេចក្ដីសម្រេចដែលមានមូលដ្ឋានគាំទ្រសមស្រប[1001]។

384. ផ្នែកតែមួយគត់ដែលត្រូវបានជំទាស់ដោយ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ មានក្នុងជើងទំព័រ ១៩០៤ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង[1002]។ ទោះជាយ៉ាងណាក្ដី គាត់ពុំបានបង្ហាញកំហុសជាក់លាក់ទាក់ទងទៅនឹងការយោងលម្អិត និងទូលំទូលាយដែលមាននៅក្នុងនោះ[1003]។ ជើងទំព័រនេះរកឃើញក្នុងកថាខណ្ឌ

[999] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៧។

[1000] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៨។

[1001] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៨។

[1002] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៣៨៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១៩០៤។ ប្រតិចារឹកថ្ងៃទីទី ២៧ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២០-២៩ និង ៣៦-៣៧។

[1003] ជើងទំព័រ ១៩០៤ ដកស្រង់ទាំងមូលថា៖ ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ (ពាន ឃាន) ឯកសារលេខ E1/73.1 ទំព័រ ១៧-១៨ (បញ្ជាក់ថាគាត់ឃើញ “អ៊ំ ហែម” ចូលរួមដឹកនាំ “ការអប់រំនយោបាយជាន់ខ្ពស់” នៅឯបុរីកីឡា ដល់កម្មាភិបាល និងបានរម្លឹកដាស់តឿនពីរឿងការកសាងប្រទេស ធ្វើម៉េចឲ្យរីកចម្រើន ហើយមានសហករណ៍ ហើយណែនាំពីការកុំឲ្យភ្លើតភ្លើនក្នុងការរស់នៅ)។ ប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (រ៉ចាម គុន ហៅ ភី ភួន) ឯកសារលេខ E1/96.1 ទំព័រ ៧០-៧១ (រម្លឹកពីវគ្គរៀនសូត្រដឹកនាំដោយ ខៀវ សំផន នៅ “សាលាបច្ចេកទេសសូវៀត” ដែលក្នុងវគ្គនោះ ស្ថានភាពនយោបាយខាងក្រៅ និងផ្ទៃក្នុង និង “ខ្មាំងទូទៅ” ត្រូវបានយកមកពិភាក្សា)។ ប្រតិចារឹក ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ (រ៉ចាម គុន ហៅ ភី ភួន) ឯកសារលេខ E1/100.1 ទំព័រ ៨២-៨៣ (រម្លឹកពីអ្នកចូលរួមវគ្គអប់រំចំនួន ៤០ នាក់ នៅសាលាបច្ចេកទេស សូវៀត ដែលក្នុងនោះរួមមានកម្មាភិបាលដែលត្រូវចូលមន្ទីរ ៨៧០ និងក្រសួងការបរទេស កម្មាភិបាលនិងយុទ្ធជននានា)។ ប្រតិចារឹក ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ (អ៊ុង ចុងហឿង) ឯកសារលេខ E1/103.1 ទំព័រ ៨៤-៨៥ (រម្លឹកថាប្រពន្ធរបស់គាត់បានប្រាប់គាត់ថា បានចូលរួមវគ្គអប់រំមួយរបស់ ខៀវ សំផន នៅវិទ្យាស្ថានបច្ចេកវិទ្យា (ក-១៥) បន្ទាប់ពីពួកគេត្រឡប់មកប្រទេសកម្ពុជា)។ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៧១-៧៧, ៨៣-៨៤ (រម្លឹកពីការពិភាក្សាពី “មហាលោតផ្លោះ មហាអស្ចារ្យ” នៅបុរីកីឡា ជាមួយ ប៉ុល ពត នួន ជា និង ខៀវ សំផន ដែលជាអ្នកថ្លែងរួមជាមួយ ហ៊ូ នឹម ដែលថ្លែងទៅកាន់ “អ្នកចូលរួមប្រហែល ២.០០០ នាក់” រួមទាំងអ្នកដែលមានឋានៈ “ទាបបំផុត” លេខា ឬអនុលេខាស្រុក)។ ប្រតិចារឹក ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២១-២៩, ៣៦-៣៧ (បញ្ជាក់ថា ខៀវ សំផន មាន

៦០៧ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាវត្តមានរបស់ ខៀវ សំផន និងការបង្រៀនរបស់គាត់នៅក្នុងវគ្គបណ្តុះបណ្តាលនយោបាយដែលរៀបចំឡើងនៅបុរីកីឡា (ក-៦) និងវិទ្យាស្ថានបច្ចេកវិទ្យាមិត្តភាពខ្មែរ-សូវៀត(ក-១៥) នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ១៩៧៨ ខណៈពេលមានវត្តមានរបស់ នួន ជា និង មេដឹកនាំកម្មាភិបាលដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា។ អ្នកចូលរួមនៅវគ្គបណ្តុះបណ្តាលនោះមានចំនួនជិត ១០០ នាក់។ ពួកគេត្រូវបានណែនាំផ្សេងៗអំពីគោលការណ៍បដិវត្តន៍ សហករណ៍ បច្ចេកទេសកសិកម្ម និងបញ្ហាសេដ្ឋកិច្ច ដែលខណៈនោះ ខៀវ សំផន បានបង្រៀនអំពីការកំណត់មុខសញ្ញា“ខ្មាំង” និងតាមរក“ជនក្បត់”។

385. ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ដែលជាអតីតគ្រូពេទ្យ បានចូលរួមវគ្គបណ្តុះបណ្តាលមួយក្នុងចំណោមវគ្គបណ្តុះបណ្តាលទាំងនោះនៅបុរីកីឡា ដែល ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត

---

វត្តមាននៅក្នុងវគ្គណែនាំរបស់ ប៉ុល ពត អំពី “មហាលោតផ្លោះ មហាអស្ចារ្យ” ហើយអ្នកដែលមិនអនុវត្តតាម “មហាលោតផ្លោះ មហាអស្ចារ្យ” ត្រូវចាត់ទុកថាជាខ្មាំង ហើយ ខៀវ សំផន បានថ្លែងអំពី “ការស្វែងរកជនក្បត់បដិវត្តនិងខ្មាំងបង្កប់”)។ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/116.1 ទំព័រ ៤ (បញ្ជាក់ថាគាត់បានចូលរួមក្នុងវគ្គរៀនសូត្រនៅបុរីកីឡា នៅចុងឆ្នាំ១៩៧៧)។ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ (ជា សាយ) ឯកសារលេខ E1/124.1 ទំព័រ ២៥-៣៣, ៥៩ (បានរម្លឹកពីវគ្គរៀនសូត្រ ត្រូវបានប្រព្រឹត្តទៅរយៈពេលពីបីទៅបួនថ្ងៃ នៅបុរីកីឡា ឬវិទ្យាស្ថានបច្ចេកទេស ដែលបង្រៀនដោយ នួន ជា និង ខៀវ សំផន អំពីការសន្សំសំចៃ ខិតខំការងារដើម្បីកសាងប្រទេស)។ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៦២-៦៣ (លើកឡើងអំពីវគ្គបំពាក់បំប៉នខាងផ្នែកនយោបាយ ដែលបានបង្រៀនដោយ ខៀវ សំផន និង នួន ជា អំពីប្រធានបទជាច្រើន រួមមានបញ្ហាកងទ័ព សេដ្ឋកិច្ច ការទូត និងនយោបាយ)។ ប្រតិចារឹក ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ១៥-១៦ ដកស្រង់ពីសៀវភៅនិពន្ធដោយ P. Short៖ ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ ឯកសារលេខ E3/9 ទំព័រ 316-317 ERN 00396524-00396525 (ភាសាអង់គ្លេស) (និយាយអំពីការអប់រំនយោបាយដល់អ្នកត្រឡប់មកវិញ)។ ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤-៤១, ៥៣, ៦៦-៧១, ៧៧, ៨១-៨៦ (រម្លឹកអំពីវគ្គរៀនសូត្រពីរ ធ្វើឡើងនៅឆ្នាំ១៩៧៦ ឬ១៩៧៧ និងឆ្នាំ១៩៧៨ ដែលក្នុងវគ្គនោះ ខៀវ សំផន បានបង្រៀនដល់អ្នកចូលរួមប្រហែល ៤០០ ទៅ ៥០០ នាក់ អំពីទំហំការងារ គឺការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតា និងអំពីអ្នកចូលដៃជាមួយវៀតណាម)។ សូមមើលផងដែរ ប្រតិចារឹកថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/82.1 ទំព័រ ១៤-១៥ (រម្លឹកពីវគ្គរៀនសូត្រនៅបុរីកីឡា និងប្រហែលជាអាចនៅវិទ្យាស្ថានបច្ចេកទេស “កន្លែងមួយនៅចន្លោះបុរីកីឡា និងផ្លូវសហព័ន្ធរុស្សី”] ដែលក្នុងវគ្គនេះ គាត់បានឃើញឈ្មោះ ខៀវ សំផន ជាអ្នកចូលរួមម្នាក់ ប៉ុន្តែគាត់ចាំថាបានឃើញតែ នួន ជា ប៉ុណ្ណោះ)។ ប្រតិចារឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧៦-៧៨ (រម្លឹកពីព្រឹត្តិការណ៍ពីរ ដែលគាត់បានឃើញ ខៀវ សំផន ដែលម្តងនៅវត្តឧណ្ណាលោម និងម្តងទៀតនៅបុរីកីឡា)។ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ (រ៉ចាម តុន ហៅ ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ៨១ (បញ្ជាក់ថា “ការបណ្តុះគំនិតដឹកនាំ និងគោលជំហរមនោគមន៍វិជ្ជា និងនយោបាយ គឺជាភារកិច្ចរបស់ការិយាល័យនយោបាយ” ដូចជាគណៈកម្មាធិការអចិន្ត្រៃយ៍។

មានវត្តមាន។ បើទោះបីជា អែម អឿន ត្រូវបានដកស្រង់ជាច្រើនចំណុចនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏ភស្តុតាងរបស់គាត់ត្រូវបានវាយតម្លៃហ្មត់ចត់បំផុតក្នុងកថាខណ្ឌ ៦០៧, ៣៩៤២, ៣៩៤៣ និង ៣៩៦៧៖ ផ្នែកនៃសាលក្រមដែលពាក់ព័ន្ធទៅនឹងមីទ្ទីង និងវគ្គបណ្តុះបណ្តាលនយោបាយ និងជាពិសេសការកំណត់មុខសញ្ញា និងការតាមរកខ្មាំង។ ក្នុងកថាខណ្ឌទាំងនេះ និងក្នុងការយល់ឃើញពាក់ព័ន្ធ អែម អឿន គឺជាប្រភពមួយក្នុងចំណោមប្រភពជាច្រើនដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការឈានដល់ការធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងខ្លឹមសារនៃបទចោទសនាមរបស់ ខៀវ សំផន និងការចូលរួមរបស់គាត់ក្នុងវគ្គបណ្តុះបណ្តាលអប់រំ។ តាមការលើកឡើងរបស់ ខៀវ សំផន ថា មានភាពផ្ទុយគ្នាក្នុងភស្តុតាងរបស់ អែម អឿន ដែលគាត់បានចង្អុលបង្ហាញនៅពេលជំនុំជម្រះ តាមការសន្មតត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការពិភាក្សាសម្រេច និងបានថ្លឹងថ្លែងនៅពេលឈានទៅដល់ការសម្រេចនោះ។

386. ជាការលំបាកក្នុងការទទួលយកថា ជាកំហុសទូទៅតាមរយៈវិធីសាស្ត្រកាត់ជាដុំៗរបស់ ខៀវ សំផន ទៅលើភស្តុតាងរបស់ អែម អឿន ដែលផ្ទុយពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលសន្និដ្ឋានភស្តុតាងជារួមនៅក្នុងសំណុំរឿង ០០២/០២។ ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ឆ. ការលម្អៀងនៃវប្បធម៌

387. ខៀវ សំផន បានលើកឡើងថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញភាពលម្អៀងនៃវប្បធម៌នៅពេលសំដៅទៅលើលក្ខខណ្ឌរស់នៅ និងអនាម័យនៅទំនប់ត្រពាំងថ្ម។ បន្ថែមលើនេះ និងដើម្បីជៀសវាងការបំភ្លៃ អង្គជំនុំជម្រះសាលាដំបូងគប្បីសំអាងទៅលើការបំភ្លឺរបស់សហការីជនជាតិខ្មែរក្នុងការវាយតម្លៃព្រឹត្តិការណ៍ដែលបានកើតឡើងនៅចន្លោះពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តែលើចំណុចស្តីពីវប្បធម៌ខ្មែរនៅពេលនោះ ជាជាងតាមរយៈចក្ខុវិស័យសម័យបច្ចុប្បន្ន[1004]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តន៍គោលការណ៍ទាំងនេះ ជាក់ស្តែងភាគច្រើនបំផុតនៅក្នុងការយល់ឃើញស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែល "ពុំបានអើពើទាំងស្រុងនូវបរិបទនៃវប្បធម៌សង្គម"[1005]។

---

[1004] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២, ១២៩៨ និង ជើងទំព័រ ៤៦៤៨។

[1005] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៦ យោងទៅលើកថាខណ្ឌ ១១៤០-១១៤៤ និង ១១៥៧-១១៦២។

388. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវឧទាហរណ៍ណាមួយដែលក្នុងនោះចៅក្រមបានបំភ្លៃការពិតដោយសារភាពលម្អៀងនៃរបបធម៌ឡើយ[1006]។

389. សាលក្រមអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ក្នុងកថាខណ្ឌ ៦២ សាលក្រមរបស់ខ្លួនថា៖ "អង្គជំនុំជម្រះបានផ្អែកទៅលើការបំភ្លឺរបស់សហការីជនជាតិខ្មែរក្នុងការវាយតម្លៃលើភាពគួរឱ្យជឿជាក់ បានរបស់សាក្សីដើម្បីជៀសវាងភាពលម្អៀងផ្នែករបបធម៌"[1007]។

390. ខៀវ សំផន បានលើកឡើងថា ក្នុងការផ្តល់អានុភាពទៅលើគោលការណ៍នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការយល់ឃើញជាក់លាក់ជាច្រើននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទីមួយទៅនឹងលក្ខខណ្ឌអាហារ និងអនាម័យនៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន និងទីពីរលក្ខណៈនៃការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

391. ទាក់ទងទៅនឹងលក្ខខណ្ឌអាហារ និងអនាម័យ ខៀវ សំផន បានយោងដោយពុំត្រឹមត្រូវទៅលើកថាខណ្ឌ ១២៩៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ផ្នែកត្រឹមត្រូវក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺកថាខណ្ឌ ១៣២៧ ទៅវិញនោះទេ ដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "មានរុយច្រើនរោមអាហាររាល់ពេល"[1008]។

392. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអាហារគ្មានអនាម័យពុំបានឆ្លុះបញ្ចាំងភាពលម្អៀងផ្នែករបបធម៌ឡើយ ប៉ុន្តែផ្ទុយទៅវិញបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវភស្តុតាងរបស់សាក្សីជាច្រើនដែលបានផ្តល់សក្ខីកម្មក្នុងតុលាការពាក់ព័ន្ធទៅនឹងលក្ខខណ្ឌទាំងនេះ[1009]។

---

[1006] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៥២-១៥៥។

[1007] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២។

[1008] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣២៧ និងជើងទំព័រ ៤៥៤៨។

[1009] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣២៧ និងជើងទំព័រ ៤៥៤៨ យោងទៅលើប្រតិចារឹកថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ (ឈុំ សេង) ឯកសារលេខ E1/331.1 ទំព័រ ៤៨។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ (សែន សុផុន) ឯកសារលេខ E1/323.1 ៥៧ (ពន្យល់ថា "បើនិយាយពីរុយវិញរោមបបរឡើងជិតឈឹង")។ ប្រតិចារឹក ថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០១៥ (តក់ ប៊ុយ) ឯកសារលេខ E1/333.1 ទំព័រ ៤៦-៤៧ ERN 01450462-63។ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ (សម សាក់) ឯកសារលេខ E1/340.1 ទំព័រ ៣០ ERN 01479115 ("រុយរោមឡើងខ្មៅ រុយរោមខ្មៅអស់ហើយ") ។

393. ទីពីរ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធទៅនឹងភាពលម្អៀងនៃវប្បធម៌ដោយបានផ្អែកលើមូលដ្ឋាននៃសារណាដែលមានក្នុងកថាខណ្ឌ ១១៤០-១១៤៤ និង ១១៥៧-១១៦២ នៃសារណាបណ្តឹងសាទុក្ខ។ អំណះអំណាងនេះត្រូវបានពិចារណាលើខ្លឹមសារនៅក្នុងសាលដីកានេះទាក់ទងទៅនឹងបទបញ្ហារៀបអាពាហ៍ពិពាហ៍។ កថាខណ្ឌទាំងនេះត្រូវបានវាយតម្លៃត្រង់ចំណុចដែលបង្ហាញនូវវិធីសាស្ត្រជាទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការវាយតម្លៃលើភស្តុតាងពាក់ព័ន្ធទៅនឹងភាពចាំបាច់ក្នុងការជៀសវាងភាពលម្អៀងនៃវប្បធម៌។

394. ក្នុងកថាខណ្ឌ ១១៤០-១១៤៤ និង ១១៥៧-១១៦២ នៃសារណាបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា ការចាត់ទុកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើសក្នុងបរិបទកម្ពុជាបានចោទជាបញ្ហាពាក់ព័ន្ធទៅនឹងសកលនិយមធៀបនឹងភាពជាក់ស្តែង[1010]។ បើទោះបីជាសញ្ញាណនៃការរៀបអាពាហ៍ពិពាហ៍ដែលសាមីខ្លួនទាំងពីរបានស្ម័គ្រចិត្តបច្ចុប្បន្នស្ទើរក្លាយជាការបញ្ញត្តិជាសកលក៏ដោយ ក៏នេះពុំមែនជាករណីនៅក្នុងប្រទេសកម្ពុជានៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ[1011]។ ក្នុងសារណារបស់ ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការអនុម័តនូវវិធីសាស្ត្រគតិយុត្ត/មនុស្សសាស្ត្រដែលងាយនឹងវិវឌ្ឍ និងដោយសារពុំអើពើទៅលើភាពស្រដៀងគ្នាជាសំខាន់នៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងការរៀបអាពាហ៍ពិពាហ៍ដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ[1012]។ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃពុំត្រឹមត្រូវថា សម្ពាធសង្គម និងឪពុកម្តាយពុំអនុញ្ញាតឱ្យបុគ្គលជំទាស់ទៅនឹងជម្រើសឪពុកម្តាយរបស់ខ្លួនអំពីការជ្រើសរើសប្តីប្រពន្ធឡើយ និងដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានទស្សនៈលម្អៀងទៅរកការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានបង្កើតការរៀប

---

[1010] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤០។

[1011] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤១ (កត់សម្គាល់ថា ក្រមរដ្ឋប្បវេណីកម្ពុជាបញ្ញត្តិការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដោយមានការយោងតែការឯកភាពពីឪពុកម្តាយ)។

[1012] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤៤-១១៤៥ (សំអាងទៅលើភស្តុតាងរបស់អ្នកជំនាញ Peg LEVINE ដែលពិពណ៌នាការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ថាជា "កេណ្ឌ" ជាជាង"ការបង្ខំ" (ប្រតិចារឹកថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ (Peg LEVINE) ឯកសារលេខ E1/481.1 ទំព័រ ៤-៥)) និង ១១៥៧-១១៦០ (កត់សម្គាល់ថា បើទោះបីជាសិទ្ធិអំណាចផ្លាស់ប្តូរក្នុងកម្ពុជាប្រជាធិបតេយ្យពីឪពុកម្តាយទៅអជ្ញាធរមូលដ្ឋាន និងអង្គការក៏ដោយ ក៏ដំណើរការ"មានលក្ខណៈស្រដៀងគ្នាទៅនឹងការរៀបចំធ្វើឡើងស្របតាមប្រពៃណី")។

ផ្ទៀបមិនពិតអំពីភាពខុសប្លែកគ្នានៃការរៀបអាពាហ៍ពិហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1013]។ ផ្អែកលើបរិបទនៃវប្បធម៌ អង្គជំនុំជម្រះសាលាដំបូងគប្បីវាយតម្លៃលើលក្ខណៈនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំថា ជាផ្នែកមួយសំខាន់នៃវប្បធម៌កម្ពុជាយូរលង់មកហើយមុនរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែផ្ទុយទៅវិញបានកំណត់ពុំត្រឹមត្រូវនូវចរិតលក្ខណៈនៃការរងទុក្ខសោកដែលកើតឡើងដោយសារការរៀបអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរបៀបផ្សេងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1014]។

395. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ពុំបានផ្អែកទៅលើសញ្ញាណពុំត្រឹមត្រូវនៃសកលនិយម ឬភាពជាក់ស្តែងនៃវប្បធម៌ឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃពុំត្រឹមត្រូវលើភស្តុតាងដោយផ្អែកលើទស្សនៈសម័យបច្ចុប្បន្ន ឬចក្ខុវិស័យមិនពិតដទៃទៀតប្រហាក់ប្រហែលនោះឡើយ។ ផ្ទុយទៅវិញ ការយល់ឃើញទាំងនេះបានផ្អែកលើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលបានឆ្លងកាត់បទពិសោធន៍ទាំងនេះ និងបាននិយាយអំពីបញ្ហាថាតើ ការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានដាក់បទបញ្ជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះស្របតាមប្រពៃណីដែលត្រូវបានរំពឹងទុកនោះ ដែរ ឬយ៉ាងណា។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានអះអាងផងដែរអំពីផលប៉ះពាល់នៃពិធីរៀបអាពាហ៍ពិពាហ៍ដែលបានរៀបចំឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបអាពាហ៍ពិពាហ៍ផ្ទាល់តែម្តង[1015]។

---

[1013] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦១ (បានពិចារណាបន្ថែមលើការទទួលបានការយល់ព្រមពីប្តីប្រពន្ធ បន្ថែមលើការយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងការបង្ហាញដំណើរការ បើទោះបីជាបទបញ្ញារៀបអាពាហ៍ពិពាហ៍អាចត្រូវបានដោយត្រឹមត្រូវ)។

[1014] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦២។

[1015] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩ ជើងទំព័រ ១២០៨១-១២០៨៣ យោងទៅលើប្រតិចារឹកថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 ទំព័រ ៥១-៥៤។ ប្រតិចារឹកថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ (ឃិន រ៉ាត) ឯកសារលេខ E1/325.1 ទំព័រ ៦៨ និងប្រតិចារឹកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ (ឃិន រ៉ាត) ឯកសារលេខ E1/326.1 ទំព័រ ៨-៩។ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (សៀង ចាន់ធី) ឯកសារលេខ E1/394.1 ទំព័រ ១៥។ ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធារី) ឯកសារលេខ E1/462.1 ទំព័រ ៣១, ៧០។ ប្រតិចារឹកថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ៨។ ប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៥៣, ៧៦-៧៧ និងប្រតិចារឹកថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៥៥។ ប្រតិចារឹកថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ១១។ ប្រតិចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ (ប៉ែន សុចាន់) ឯកសារលេខ E1/482.1 ទំព័រ ៥៤។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ (ង៉ែត ចាត) ឯកសារលេខ E1/488.1 ទំព័រ ៩៤។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/488.1 ទំព័រ ៦២។ ប្រតិចារឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ (សេង ស៊្រុន) ឯកសារលេខ E1/346.1 ទំព័រ ៤៥-៤៦។

396. បន្ថែមលើនេះ អំណះអំណាងដែល ខៀវ សំផន បានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ ត្រូវបានបង្ហាញពេញលេញនៅមុខអង្គជំនុំជម្រះសាលាដំបូង និងត្រូវបានបដិសេធចោលក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ កថាខណ្ឌ ៣៦៨៧ នៃសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា ការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យជាចាំបាច់ស្រដៀងគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍ដែលរៀបចំតាមប្រពៃណីកម្ពុជាដែរ។ នៅក្នុងសារណារបស់គាត់លើកឡើងថា ការរៀបអាពាហ៍ពិពាហ៍ទាំងនេះពុំបានឆ្លើយតបទៅនឹងទិដ្ឋភាពនៃការរៀបអាពាហ៍ពិពាហ៍របស់លោកខាងលិចឡើយ ប៉ុន្តែផ្ទុយទៅវិញគឺជាការព្រមព្រៀងរវាងគ្រួសារពីរដែលក្នុងនោះអារម្មណ៍នៃសេចក្តីស្រលាញ់ និងការឯកភាពរបស់អនាគតប្តីប្រពន្ធពុំបានដើរតួនាទីសំខាន់នោះទេ[1016]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាៈ

> ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ការរៀបការតាមការផ្សំផ្គុំនៅក្នុងវប្បធម៌របស់កម្ពុជាខុសគ្នាយ៉ាងខ្លាំងទៅនឹងការរៀបការដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលដីកាដំណោះស្រាយបានធ្វើការចោទប្រកាន់។ ការរៀបការតាមការផ្សំផ្គុំនៅក្នុងវប្បធម៌កម្ពុជានៅមុនរបបកម្ពុជាប្រជាធិបតេយ្យផ្អែកលើជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្តាយនិងកូន។ [...] អង្គជំនុំជម្រះទទួលយកជំហររបស់ក្រុមមេធាវីការពារក្តីទាំងពីរដែលថា ការរៀបការនៅក្នុងវប្បធម៌កម្ពុជាមិនដូចគ្នាទៅនឹងទស្សនៈលោកខាងលិចអំពីការរៀបការនោះឡើយ។ [...] នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ ការវាយតម្លៃនិងការជ្រើសរើសនេះត្រូវបានផ្ទេរសិទ្ធិដោយកូនៗទៅឲ្យឪពុកម្តាយ ដោយផ្អែកលើការជឿទុកចិត្ត។ ជាទូទៅ ការរៀបការតាមការផ្សំផ្គុំមិនមានសមាសធាតុនៃការបង្ខំឡើយ។ មិនមានភ័ស្តុតាងបង្ហាញថា ការប្រគល់សិទ្ធិដែលផ្អែកលើការជឿទុកចិត្តនេះ និងអត្ថិភាពនៃប្រព័ន្ធគ្រួសារដែលមានការយកចិត្តទុកដាក់ និងដំណើរការត្រឹមត្រូវនោះ ត្រូវបានប្រគល់ដោយស្ម័គ្រចិត្តទៅឲ្យបក្ស(អង្គការ)នោះឡើយ នៅក្នុងរបបអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ចុងក្រោយ សម្ពាធសង្គមមានឥទ្ធិពលកម្រិតណា និងញឹកញាប់ប៉ុណ្ណា នៅក្នុងការរៀបការបែបប្រពៃណីទៅលើលទ្ធភាពក្នុងការយល់ព្រមដោយសេរីនោះ គឺមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះឡើយ។ ភ័ស្តុតាងដែលបានលើកឡើងនៅក្នុងផ្នែកនេះបង្ហាញយ៉ាងច្បាស់ពីការអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានភាពខុសគ្នាយ៉ាងខ្លាំងពីការរៀបអាពាហ៍ពិពាហ៍តាម

---

ប្រតិចារឹកថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/461.1 ទំព័រ ៧៤។ ប្រតិចារឹកថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ១៦។ ប្រតិចារឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ (សុន វុត) ឯកសារលេខ E1/411.1 ទំព័រ៦០។ ប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៣៨ និងប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៣៦-៣៨, ៤០។

[1016] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៧។

ប្រពៃណីខ្មែរដោយគ្រួសាររបស់អនាគតប្ដីប្រពន្ធមិនបានចូលរួមទាល់តែសោះ នៅក្នុងការជជែកពិភាក្សាសហគមន៍មិនបានចូលរួមមិនមានទំនៀមទម្លាប់ប្រពៃណីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ហើយបុគ្គលម្នាក់ៗយល់ព្រមរៀបការដោយសារតែភ័យខ្លាចបក្សដាក់ទណ្ឌកម្ម។ [...] អំណះអំណាងរបស់មេធាវីការពារក្ដីពាក់ព័ន្ធចំណុចនេះត្រូវបដិសេធចោល[1017]។

397. ទាក់ទងទៅនឹងភស្តុតាងរបស់អ្នកជំនាញ Peg LEVINE ដែល ខៀវ សំផន បានសំអាងទៅលើក្នុងការគាំទ្រអំណះអំណាងនេះ[1018] អង្គជំនុំជម្រះសាលាដំបូងបានបដិសេធភស្តុតាងនេះក្នុងផ្នែកខ្លះសម្រាប់ហេតុផលប្រហាក់ប្រហែលគ្នានេះ និងកត់សម្គាល់ថា៖

> "ឯកសារដែលអ្នកជំនាញមាន គឺមានចំនួនតិចជាងភ័ស្តុតាងទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងករណីដែលយោបល់របស់អ្នកជំនាញផ្អែកលើហេតុផល ដែលផ្ទុយនឹងភ័ស្តុតាងដែលមានសារៈសំខាន់ខ្លាំងនៅចំពោះមុខអង្គជំនុំជម្រះ ជាពិសេស ផ្ទុយនឹងឯកសារដែលសេសសល់ពីរបបនោះទាក់ទងនឹងបទប្បញ្ញត្តិរបស់ ប.ក.ក. ស្តីពីការរៀបអាពាហ៍ពិពាហ៍និងចម្លើយក្នុងសវនាការរបស់អ្នកដែលធ្លាប់មានបទពិសោធន៍រៀបការក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះនឹងច្រានចោលយោបល់នោះ ដោយចាត់ទុកថាមិនត្រឹមត្រូវ"[1019]។

398. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញខាងលើនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឱ្យប៉ះពាល់ដោយភាពលម្អៀងនៃវប្បធម៌ឡើយ។ អំណះអំណាងនេះត្រូវបដិសេធចោល។

## ជ. ពាក្យចចាមអារ៉ាម

[1017] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៨-៣៦៨៩, ៣៦៩១ (កត់សម្គាល់ថា ក្នុងករណីជាច្រើន ឪពុកម្ដាយរបស់សាមីខ្លួនពុំជាប់ពាក់ព័ន្ធក្នុងពិធីរៀបអាពាហ៍ពិពាហ៍ពិធីសែនព្រេនត្រូវបានបោះបង់ចោល និងគូស្រករច្រើនគូរៀបការក្នុងពេលតែមួយ)។

[1018] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣០ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ (Peg LEVINE) ឯកសារលេខ E1/481.1 (ពិពណ៌នាការរៀបការក្រោមរបបកម្ពុជាប្រជាធិបតេយ្យថា ជា"ការកេណ្ឌ" និងថាប្រជាជនពុំត្រូវបានបង្ខំឱ្យរៀបការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានសន្និដ្ឋានថា ពុំមានគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍នៅពេលចាប់ផ្ដើមរបបនោះ បើទោះបីជារចនាសម្ព័ន្ធនៃគោលនយោបាយទាក់ទងទៅនឹងពិធីរៀបអាពាហ៍ពិពាហ៍ និងដំណើរការបានវិវឌ្ឍឡើងត្រឹមឆ្នាំ ១៩៧៨)។

[1019] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣១។

399. បើទោះបីជា ខៀវ សំផន យល់ស្របជាមួយនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពចាំបាច់សម្រាប់ការប្រយ័ត្នប្រយែងនៅពេលវាយតម្លៃភស្តុតាងចចាមអារ៉ាមក៏ដោយ ក៏គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តផ្ទុយខ្លួនឯងក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដោយសារខកខានក្នុងការអនុវត្តស៊ីសង្វាក់គ្នានូវគោលការណ៍នេះ[1020]។ គាត់បានអះអាងថា ក្នុងពេលជំនុំជម្រះ សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងពុំ"ចាប់អារម្មណ៍លើប្រភពនៃ [...] ពាក្យចចាមអារ៉ាម ដែលត្រូវបានស្តាប់ក្នុងតុលាការ" ដោយអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តផ្ទុយគ្នាក្នុងការយល់ឃើញថា ជនជាតិវៀតណាមដែលមកពីភូមិពោធិ៍ចិន្តាំត្រូវបាននិរទេសទៅប្រទេសវៀតណាម[1021]។

400. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃ និងសំអាងទៅលើភស្តុតាងចចាមអារ៉ាម[1022]។

401. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នូវបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ការវាយតម្លៃអំពីភស្តុតាងចចាមអារ៉ាមដូចខាងក្រោមថា៖

> នៅក្នុងការវាយតម្លៃទៅលើភ័ស្តុតាង អង្គជំនុំជម្រះពិចារណាទៅលើចំណុចដែលថាប្រភព នៃពាក្យចចាមអារ៉ាមមិនត្រូវបានសួរដេញដោលនោះទេ រួមទាំង "កាលៈទេសៈផ្សេងៗដែលកើតជុំវិញភ័ស្តុតាងចចាមអារ៉ាមនោះ" ។ ហេតុដូច្នេះ ភ័ស្តុតាងចចាមអារ៉ាមត្រូវបានទទួលយកដោយប្រុងប្រយ័ត្ន[1023]។

402. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងដោយប្រុងប្រយ័ត្នថា "ទម្ងន់ និងតម្លៃជាភស្តុតាងដែលត្រូវបានផ្តល់ទៅឱ្យភស្តុតាង[ចចាមអារ៉ាម] ជាធម្មតាមានកម្រិតតិចជាងការផ្តល់ទៅឱ្យភស្តុតាងរបស់សាក្សី

---

[1020] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១២ (យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩០៨, ៩១៩, ៩២១, ៩៣១, ៩៣៥, ៩៨៧, ៩៩១-៩៩២, ១០០៤-១០០៥, ១០០៧, ១០១១, ១០១៣-១០១៤, ១០៤៤, ១០៩៥, ១២៦៦, ១៧៦២ និង ១៨៦៨)។

[1021] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១២-៣១៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥-៣៥០៧។

[1022] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៥៦-១៦០។

[1023] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០២ ដកស្រង់សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karera* (ICTR) អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-01-74-A សាលដីកា ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សាលដីការឿងក្តី *Karera* (ICTR)") កថាខណ្ឌ ៣៩។ សាលដីការឿងក្តី *Popović និងជនជាប់ចោទផ្សេងទៀត* (ICTY) កថាខណ្ឌ ១៣០៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kalimanzira* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-05-88-A សាលដីកា ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ("សាលដីការឿងក្តី *Kalimanzira* (ICTR)") កថាខណ្ឌ ៩៦។

ដែលបានផ្តល់ភស្តុតាងក្រោមការធ្វើសម្បថ និងត្រូវបានសួរដេញដោល"[1024]។ កថាខណ្ឌដូចគ្នានៃសាលដីកាសំណុំរឿង ០០២/០១ ទោះជាយ៉ាងណាក្តីបានសង្កេតឃើញថា៖

> នេះជាយុត្តិសាស្ត្រដែលត្រូវបានទទួលស្គាល់ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិមិនអចិន្ត្រៃយ៍ដែលថា ភស្តុតាងចចាមអារ៉ាមអាចទទួលយកបាន លុះត្រាតែមានតម្លៃជាភស្តុតាង និងថា អង្គជំនុំជម្រះសាលាដំបូងមួយអាចសំអាងទៅលើភស្តុតាងចចាមអារ៉ាមដែលពុំមានការបញ្ជាក់បន្ថែម ក្នុងការបង្ហាញពីអត្ថិភាពនៃធាតុផ្សំបទឧក្រិដ្ឋឡើយ បើទោះបីជាការប្រុងប្រយ័ត្ន គឺជាលក្ខខណ្ឌតម្រូវនៅក្នុងកាលៈទេសៈបែបនេះក៏ដោយ។ [...] សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការពិចារណាដោយប្រុងប្រយ័ត្ន និងជឿជាក់លើភស្តុតាងចចាមអារ៉ាមសម្រាប់ធ្វើជាមូលដ្ឋាន ឬជាការគាំទ្រក្នុងការសម្រេចដាក់ពិរុទ្ធភាព ហើយភាគីម្ចាស់បណ្តឹងសាទុក្ខត្រូវមានកាតព្វកិច្ចក្នុងការបង្ហាញឱ្យឃើញថា ពុំមានតុលាការអង្គហេតុសមស្របណាមួយដែលអាចយកភស្តុតាងបែបនេះ មកធ្វើសំអាងហេតុជាក់លាក់នោះឡើយ[1025]។

---

[1024] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០២ យោងទៅលើសាលដីការឿងក្តី *Kalimanzira* (ICTR) កថាខណ្ឌ ៩៦ ដកស្រង់សាលដីការឿងក្តី *Karera* (ICTR) កថាខណ្ឌ ៣៩។

[1025] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០២។ *សូមមើលផងដែរ* កថាខណ្ឌ ៨៨៩ នៃសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨៩ ដែលអង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយោងនៃភស្តុតាងចចាមអារ៉ាមអនាមិកក្នុងអនុស្សរណៈរដ្ឋាភិបាលសហរដ្ឋអាមេរិក ផ្អែកលើមូលដ្ឋានថា អនុស្សរណៈទាំងនេះបានបង្ហាញប្រភព និងអាចត្រូវបានសន្មតដោយត្រឹមត្រូវដើម្បីឆ្លុះបញ្ចាំងខ្លឹមសារនៃប្រភេទ និងចរិតលក្ខណៈចចាមអារ៉ាមពុំបានប៉ះពាល់ដល់ភាពគួរឱ្យជឿទុកចិត្តបានជាទូទៅ។ បន្ថែមលើនេះ អនុស្សរណៈនេះអាចត្រូវបានវាយតម្លៃដោយផ្អែកលើភស្តុតាងបញ្ជាក់បន្ថែម ជាពិសេស អត្ថបទកាសែតជាច្រើន ដែលបានបង្ហាញក្នុងឯកសារការផ្សព្វផ្សាយផ្សេងៗ និងត្រូវបាននិពន្ធដោយអ្នកសារព័ត៌មានផ្សេងៗ និងការពិពណ៌នានោះស៊ីសង្វាក់គ្នាទៅវិញទៅមក និងដូច្នេះបានពង្រឹងបន្ថែមនូវភាពគួរឱ្យជឿជាក់បានតាមរយៈការបញ្ជាក់បន្ថែមទៅវិញទៅមក។ *សូមមើល* ឧទាហរណ៍ផ្ទុយក្នុងសាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ndindabahizi* (ICTR) អង្គជំនុំជម្រះឧទ្ធរណ៍ សំណុំរឿងលេខ ICTR-01-71-A សាលដីកាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ១១៥។ សាលដីការឿងក្តី *Kalimanzira* (ICTR) កថាខណ្ឌ ៧៧-៨០ (បដិសេធការដាក់ពិរុទ្ធភាពដោយផ្អែកលើសក្ខីកម្មរបស់សាក្សីដែលពុំត្រូវបានលម្អិតទាក់ទងទៅនឹងកាលៈទេសៈជាក់ស្តែងពាក់ព័ន្ធ និងពុំច្បាស់លាស់ថាតើ ការរៀបរាប់នោះគឺភស្តុតាងចចាមអារ៉ាម ដែរ ឬយ៉ាងណា)។ សាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Muvunyi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-2000-55A-A សាលដីកាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨ ("សាលដីការឿងក្តី *Muvunyi* (ICTR)") កថាខណ្ឌ ៦៨-៧០ (យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំបានអនុវត្តសមស្រប និងក្នុងកម្រិតដែលតម្រូវក្នុងការផ្អែកការដាក់ពិរុទ្ធភាពទាំងស្រុងទៅលើភស្តុតាងមិនផ្ទាល់ចចាមអារ៉ាមគ្មានការលម្អិត និងកត់សម្គាល់ថា ពុំមានតុលាការអង្គហេតុសមហេតុផលអាចធ្វើការសន្និដ្ឋានផ្អែកអង្គហេតុដោយផ្អែកតែលើពាក្យចចាមអារ៉ាមមិនច្បាស់លាស់ ក្នុងករណីដែលពុំមានភាពជាក់លាក់បង្ហាញនូវភាពគួរឱ្យជឿទុកចិត្តបាននៃចម្លើយដែលបានយោងទៅលើរបស់សាក្សី ត្រូវបានផ្តល់ឡើយ)។

403. នៅក្នុងសាលដីកាសំណើរឿង ០០២/០១ ខៀវ សំផន ត្រូវបានរកឃើញថា "ត្រឹមតែអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើពាក្យចចាមអារ៉ាម ប៉ុន្តែពុំបានផ្តល់ការយោងជាក់លាក់គាំទ្រអំណះអំណាងនេះឡើយ"[1026]។ ក្នុងកថាខណ្ឌ ៣០៤ នៃសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា៖

> ការដែលគ្រាន់តែអះអាងពីកំហុស ដោយគ្មានការបង្ហាញភស្តុតាងគាំទ្របន្ថែមឱ្យបានច្បាស់លាស់នោះ គឺពុំបានបំពេញតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខឡើយ។ បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចត្រូវផ្តល់សំអាងហេតុពេញលេញក៏ដោយ ក៏អង្គជំនុំជម្រះពុំបានតម្រូវឱ្យបញ្ជាក់អះអាងគ្រប់ជំហាននៃការផ្តល់សំអាងហេតុរបស់ខ្លួនឱ្យបានពិស្តារនោះឡើយ ហើយអង្គជំនុំជម្រះត្រូវបានសន្មតថាបានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវរាល់ភស្តុតាងទាំងអស់នៅចំពោះមុខខ្លួន ដរាបណាគ្មានការបង្ហាញណាមួយថាអង្គជំនុំជម្រះពុំបានពិចារណាពេញលេញលើភស្តុតាងជាក់លាក់ណាមួយនោះ [...]។ ខៀវ សំផន បានចង្អុលបង្ហាញផងដែរទៅលើការយល់ឃើញផ្អែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកដោយពុំត្រឹមត្រូវ តាមការអះអាងរបស់គាត់ ទៅលើភស្តុតាងចចាមអារ៉ាម [...] អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាលើអំណះអំណាងទាំងនេះ[1027]។

404. នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ខៀវ សំផន ប្រហាក់ប្រហែលគ្នានេះបានយោងទៅលើកថាខណ្ឌចំនួនដប់ប្រាំបួននៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដោយពុំបានផ្តល់អំណះអំណាងបន្ថែម និងត្រឹមតែពិពណ៌នាភស្តុតាងនោះថា ជាពាក្យចចាមអារ៉ាម និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើបានឡើយ[1028]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចមិនធ្វើការពិចារណាលើអំណះអំណាងទាំងនេះដោយផ្អែកលើទិដ្ឋភាពនៃលក្ខខណ្ឌតម្រូវថា នេះជាកាតព្វកិច្ចរបស់ម្ចាស់បណ្តឹងសាទុក្ខដែលត្រូវបង្ហាញជាក់លាក់សមស្របនូវមូលហេតុដូចម្តេចបានជាពុំមានតុលាការអង្គហេតុសមហេតុផលអាចធ្វើការយល់ឃើញជាក់លាក់បែបនេះបាន។

---

[1026] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០៤។

[1027] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០៤។

[1028] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩០៨, ៩១៩, ៩២១, ៩៣១, ៩៣៥, ៩៨៧, ៩៩១-៩៩២, ១០០៤-១០០៥, ១០០៧, ១០១១, ១០១៣-១០១៤, ១០៤៤, ១០៩៥, ១២៦៦, ១៣៦២ និង ១៨៦៨។

405. ទោះជាយ៉ាងណាក្តី ខៀវ សំផន បានបញ្ជាក់ជាក់លាក់ថា កថាខណ្ឌ ៣៥០៥, ៣៥០៧ និង ៣៤៣១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង មានកំហុស[1029]។ ក្នុងកថាខណ្ឌ ៣៥០៥ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា៖

> សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ពីដំណើររឿងអំពីការបានឃើញឬបានឮថាមានចំនួនជនជាតិវៀតណាមជាច្រើននាក់ត្រូវប្រមូលនិងជម្លៀសចេញ ហើយមិនដែលបានឃើញវិលត្រឡប់ទៅភូមិរបស់ពួកគេនៅក្នុងខេត្តព្រៃវែងវិញទេ។ ករណីជាក់ស្តែងនីមួយៗនៃក្រុមគ្រួសារ វៀតណាមដែលត្រូវបានប្រមូល បញ្ជូនចេញ និងឃើញមានការចាកចេញតាមទូក ត្រូវបានបង្ហាញនៅភូមិអន្លង់ទ្រា ឃុំព្រែកជ្រៃ ស្រុកកំពង់លាវ នៅភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង និងនៅភូមិអង្គរយស ឃុំព្រែកអន្ទះ ស្រុកព្រៃវែង។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា វាទំនងជាថា ប្រជាជនវៀតណាមមួយចំនួនត្រូវបាននិរទេសចេញពីខេត្តស្វាយរៀងទៅកាន់ប្រទេសវៀតណាម ប៉ុន្តែ ភ័ស្តុតាងដែលមាន មិនបានបំពេញតាមបទដ្ឋានតម្រូវក្នុងការបង្ហាញពីករណីជាក់លាក់នៃការជម្លៀសប្រជាជនវៀតណាមដោយបង្ខំឱ្យហួសពីវិមតិសង្ស័យ នៅក្នុងខេត្តស្វាយរៀងចាប់ពីឆ្នាំ១៩៧៥ នោះឡើយ[1030]។

406. ទាក់ទងទៅនឹងកថាខណ្ឌទាំងនេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិវៀតណាមដែលមកពីភូមិពោធិ៍ចិន្តាំត្រូវបាននិរទេសទៅប្រទេសវៀតណាមវិញ ដោយសារការសន្និដ្ឋាននេះបានផ្អែកតែទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ភស្តុតាងចចាមអារ៉ាម[1031]។ ជាពិសេស គាត់បានជំទាស់ទៅនឹងកថាខណ្ឌ ៣៤៣១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានបញ្ជាក់ថា៖

---

[1029] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៧។

[1030] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥។ *សូមមើលផងដែរ* កថាខណ្ឌ ៣៥០៧ ដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះជឿជាក់ថា បទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញដោយសារមានអត្ថិភាពនៃគោលនយោបាយចាប់តាំងពីឆ្នាំ ១៩៧៥ រហូតដល់ចុងឆ្នាំ ១៩៧៦ ក្នុងការបណ្តេញជនជាតិវៀតណាមដែលរស់នៅក្នុងកម្ពុជា និងថា ប្រជាជនវៀតណាមក្នុងចំនួនដ៏ច្រើនមកពីខេត្តព្រៃវែងត្រូវបានបណ្តេញចេញក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ និងមានចេតនាផ្លាស់ទីជនជាតិវៀតណាមឆ្លងកាត់ព្រំប្រទល់ប្រទេសកម្ពុជា។

[1031] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣ និង ៣៤៣១ និង សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៧។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣ ដែលបញ្ជាក់ថា "ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីពុំត្រូវបានបង្កើតឡើងដោយស្ថាប័នតុលាការ និងអាស្រ័យហេតុនេះពុំទទួលបានសច្ចធារណ៍នៃភាពគួរឱ្យជឿទុកចិត្តបាន និងតម្លៃជាភស្តុតាងតិចតួចប្រសិនបើមាន"។

ចាប់ពីឆ្នាំ១៩៧៥ មក ឈ្មោះ ដួង អឿន ដែលរស់នៅភូមិពោធិ៍ចិន្ដាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង បានឮថា ជនជាតិវៀតណាមដែលរស់នៅក្នុងតំបន់របស់គាត់នោះ ត្រូវតែត្រឡប់ទៅវៀតណាមវិញ ហើយថា តាគី យាយម៉ាន់ និងកូនចៅរបស់ពួកគាត់បានត្រឡប់ទៅវៀតណាមវិញ។ ប៉ុន្តែលក្ខណៈនៃការត្រឡប់ទៅវៀណាមវិញនេះ មិនត្រូវបានពិភាក្សាបន្ថែមឡើយនៅក្នុងតុលាការ[1032]។

407. ដោយបានទទួលស្គាល់ថា កាលៈទេសៈជុំវិញការត្រឡប់ទៅវិញរបស់ពួកគេពុំត្រូវបានបំភ្លឺបន្ថែម និងគ្មានការពន្យល់ហេតុដូចម្តេចបានអង្គជំនុំជម្រះបានឈានដល់ការយល់ឃើញបែបនេះ ខៀវ សំផន បានលើកឡើងថា "ដោយសារគ្មានភស្តុតាងផ្ទាល់ ឬលម្អិត ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែល[ថាជនជាតិវៀតណាមដែលមកពីពោធិ៍ចិន្តាំ ត្រូវបាននិរទេសទៅប្រទេសវៀតណាមវិញ] បានផ្អែកតែទៅលើព័ត៌មានតិចតួច និងគ្មានមូលដ្ឋានគាំទ្រ [និង] ត្រូវទាត់ចោល"[1033]។

408. ដូចបានពិភាក្សាក្នុងផ្នែក **VII.ឃ.២** នៃសាលដីនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា ការនិរទេសបានកើតឡើងជាក់លាក់នៅភូមិពោធិ៍ចិន្តាំ។ ទោះជាយ៉ាងណាក្តី ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងចចាមអារ៉ាមរបស់ ដួង អឿន រួមជាមួយនឹងភស្តុតាងដទៃទៀតទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូបានពិចារណាក្នុងការបង្កើតការយល់ឃើញដែលថា ជនជាតិវៀតណាមត្រូវបាននិរទេសចេញពីខេត្តព្រៃវែង។ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាលើភស្តុតាងចចាមអារ៉ាមនេះធ្វើជាការបញ្ជាក់បន្ថែមលើភស្តុតាងដទៃទៀតនៃការនិរទេសចេញពីខេត្តព្រៃវែងឡើយ។

409. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការកំណត់អំពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការវាយតម្លៃលើភស្តុតាងចចាមអារ៉ាម។ អង្គជំនុំ

---

[1032] *សូមមើល ឧ.* ប្រតិចារឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ (ដួង អឿន) ឯកសារលេខ E1/381.1 ទំព័រ ៥, ៦-៧, ១០ ("សៈ នៅពេលចូលដល់របបខ្មែរក្រហម ឆ្នាំ១៩៧៥ តើលោកស្រីមានធ្លាប់ឮព័ត៌មានណាថា ឲ្យប្រជាជនវៀតណាមដែលរស់នៅលើដីខ្មែរ ឬក៏នៅក្នុងស្រុកភូមិរបស់លោកស្រីហ្នឹង ឲ្យត្រឡប់ទៅវៀតណាមវិញទេ? មានទេ? ឆៈ មាន ប៉ុន្តែខ្ញុំ គាត់មិនទៅ ខ្ញុំបបួលគាត់ដែរ គាត់មិនទៅទេ គាត់ថាសុខចិត្តនៅងាប់ស្រុកខ្មែរចុះ។ គាត់អត់វិលទៅវិញទេ") ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ (ដួង អឿន) ឯកសារលេខ E1/381.1 ទំព័រ ១០ ("សៈ តើលោកស្រីមានដឹងថា មានក្រុមគ្រួសារវៀតណាមដែលគេត្រឡប់ទៅវៀតណាមទេ នៅពេលដែលមានការប្រកាសឲ្យប្រជាជនវៀតណាមត្រឡប់ទៅវៀតណាមហ្នឹង? មានស្គាល់គ្រួសារណាទេ? ឆៈ មាន តាគី, យាយម៉ាន់ កូនចៅគាត់ទៅវៀតណាមអស់វិញទាំងអស់។ ដល់ទៅហើយ គាត់ត្រឡប់មកវិញមក។ ត្រឡប់មកវិញហ្នឹង គាត់ស្លាប់ទៅតាហ្នឹង")។

[1033] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៧។

ជម្រះសាលាដំបូងពុំមានកំហុសក្នុងការវាយតម្លៃជាក់លាក់គ្រប់គ្រាន់លើភស្តុតាងដែលត្រូវបានជំទាស់ដោយ ខៀវ សំផន។ អាស្រ័យហេតុនេះ អំណះអំណាងត្រូវបដិសេធចោល។

## ២. ការវាយតម្លៃលើភស្តុតាងជាឯកសារ

410. ខៀវ សំផន បានជំទាស់ទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងជាឯកសារ ដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាច្រើនទៅក្នុងការកំណត់អំពីភាពអាចជឿទុកចិត្តបាន ភាពត្រឹមត្រូវ និងការជាប់ពាក់ព័ន្ធនៃ៖ (១) ឯកសារនៅសម័យនោះ (២) ការថ្លែងរបស់ ខៀវ សំផន និងឯកសារបោះពុម្ពផ្សាយ (៣) ចម្លើយក្រៅតុលាការ (៤) ការឃោសនា (៥) ភស្តុតាងដែលបានទទួលយកតាមរយៈការធ្វើទារុណកម្ម (៦) ភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី (៧) ឯកសារដែលទទួលបានការសន្មតថា ត្រឹមត្រូវ និង (៨) ភស្តុតាងរបស់អ្នកជំនាញ[1034]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ អង្គហេតុ ឬឆន្ទានុសិទ្ធិក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងជាឯកសារដែលបានលើកឡើងនោះ[1035]។ បញ្ហានីមួយៗនេះនឹងត្រូវដោះស្រាយដោយអង្គជំនុំជម្រះតុលាការកំពូលតាមលំដាប់លំដោយ។

### ក. ការវាយតម្លៃលើភស្តុតាងជាឯកសារនៅសម័យនោះ

411. អង្គជំនុំជម្រះសាលាដំបូងបានពន្យល់វិធីសាស្ត្ររបស់ខ្លួនក្នុងការវាយតម្លៃលើភស្តុតាងជាឯកសារដែលបានបង្ហាញចំពោះមុខ[1036]។ ក្នុងការវាយតម្លៃលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីទាក់ទងទៅនឹងតម្លៃជាភស្តុតាងនៃឯកសារដែលបានលើកឡើងនៅពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើវិធាន ៨៧(២) នៃវិធានផ្ទៃក្នុងដែលតម្រូវថា ភស្តុតាងដែលត្រូវបានផ្អែកនៅក្នុងការយល់ឃើញ ត្រូវបានដាក់ឱ្យពិភាក្សាដេញដោល[1037]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញកត្តាពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភស្តុតាងជាឯកសារ ដូចជា លក្ខណៈវិនិច្ឆ័យតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង កាលៈទេសៈនៃភស្តុតាងជាឯកសារ បញ្ហាថាតើឯកសារនោះជាឯកសារដើម ឬថតចម្លង ភាពច្បាស់លាស់ដែលអាចឱ្យយល់បាន ភាពពុំស៊ីសង្វាក់គ្នា និងការខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ បញ្ហាថាតើ ភាគីអាចជំទាស់ទៅនឹងភស្តុ

---

[1034] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២២៤-២២៦, ២៥៧-៣១១, ៣១៤-៣៣០, ១៨១៩-១៨២៨, ១៨៧៥។

[1035] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦១-២៤៤។

[1036] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១-៦៧។

[1037] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។

តាង និងព័ត៌មានគាំទ្រដទៃទៀតនៃភាពជឿទុកចិត្តបាន ដែរ ឬយ៉ាងណា[1038]។ អង្គជំនុំជម្រះសាលាដំបូងក៏បានវាយតម្លៃផងដែរលើអត្តសញ្ញាណ ការពិនិត្យ ភាពលម្អៀង ប្រភព និងការជម្រុញនៃប្រភពភស្តុតាង[1039]។

412. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានអនុវត្តពុំស៊ីសង្វាក់គ្នានូវលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ក្នុងការវាយតម្លៃលើតម្លៃជាភស្តុតាងនៃឯកសារសម័យនោះ[1040]។ គាត់បានចង្អុលបង្ហាញជាក់លាក់ទៅលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងកំណត់ហេតុកិច្ចប្រជុំរបស់គណៈមជ្ឈិមដែលត្រូវបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam ជាប្រព័ន្ធអេឡិត្រូនិក[1041]។

413. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ត្រឹមតែមិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាង និងថា អំណះអំណាងរបស់គាត់គប្បីត្រូវបានបដិសេធចោល[1042]។

414. សហមេធាវីនាំមុខបានយល់ស្របជាមួយសារណាតបរបស់សហព្រះរាជអាជ្ញា[1043]។

### i. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា

[1038] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។

[1039] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។

[1040] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៣-៣២៤។

[1041] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៥-៣២៨។ ខៀវ សំផន បានចង្អុលបង្ហាញលើឯកសារផ្តល់ដោយ Christopher GOSCHA សៀវភៅកំណត់ត្រាមន្ទីរស-២១ និងបទសម្ភាសន៍ចំនួនបីរបស់ ខៀវ សំផន។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៤ និងជើងទំព័រ ៥១៨ យោងទៅលើកថាខណ្ឌ ២១៧-២២៥ (ឯកសាររបស់ GOSCHA), ២២៦, ១៤៦៤ (សៀវភៅកំណត់ត្រាមន្ទីរស-២១), ១៨១៩-១៨២៨, ១៨៧៥ (បទសម្ភាសន៍)។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការជំទាស់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការវាយតម្លៃលើឯកសាររបស់ GOSCHA និងសៀវភៅកំណត់ត្រាមន្ទីរស-២១ នៅក្នុងសាលដីកានេះ និងដូច្នេះពុំចាំបាច់បញ្ជាក់សាឡើងវិញនៅទីនេះ។ *សូមមើលខាងលើ* ផ្នែក V.ឃ.៤ និងផ្នែក V.ឃ.៥។ អំណះអំណាងពាក់ព័ន្ធទៅនឹងបទសម្ភាសន៍ចំនួនបីដែលនឹងត្រូវដោះស្រាយក្នុងផ្នែកខាងក្រោម។ *សូមមើលខាងក្រោម* ផ្នែក V.ង.២.ខ។

[1042] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦១-១៦៤។

[1043] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៨១-១៨៣។

415. អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ ត្រូវបានបញ្ជាក់ថាត្រឹមត្រូវដោយសាក្សីជាច្រើន រួមទាំង កាំង ហ្គេចអ៊ាវ *ហៅ* ឌុច និង នួន ជា ព្រមទាំងលក្ខណៈប្រហាក់ប្រហែលគ្នានៃពាក្យពេចន៍ដែលប្រើប្រាស់ក្នុងសំណៅឆ្នាំ ១៩៧១ និងឆ្នាំ ១៩៧៦[1044]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដោយសារសាមីជននៃឯកសារឆ្នាំ ១៩៧២ ដែលមានសេចក្ដីព្រាងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១ ពុំត្រូវបានស្គាល់ អង្គជំនុំជម្រះនឹងត្រូវធ្វើការពិចារណាដោយប្រុងប្រយ័ត្ន និងសំអាងទៅលើខ្លឹមសារនៃឯកសារទាំងនេះត្រង់ចំណុចដែលមានការបញ្ជាក់បន្ថែមប៉ុណ្ណោះ[1045]។

416. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារៈ (១) បានបញ្ជាក់ថា នួន ជា បានបញ្ជាក់ភាពត្រឹមត្រូវនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ (២) ការសំអាងទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ បើទោះបីជាខ្វះកាលបរិច្ឆេទក៏ដោយ និង (៣) ការប្រៀបធៀបលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៦០, ១៩៧១ និង ១៩៧៦[1046]។ គាត់បានអះអាងថា ក្នុងអំឡុងពេលនៃការជំនុំជម្រះ នួន ជា ត្រឹមតែបានបង្ហាញទម្រង់នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ ប៉ុន្តែពុំបានអះអាងថា ឯកសារនោះ (E3/130) គឺជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ នោះទេ[1047]។ គាត់បានជំទាស់បន្ថែមទៀតថា ដោយសារលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៦០ ពុំមាននៅក្នុងសំណុំរឿង អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើដើម្បីប្រៀបធៀបលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១ និង ១៩៧៦ បានឡើយ។ ដូច្នេះ ការយល់ឃើញដែលបានផ្អែកលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានេះគ្មានសុពលភាព[1048]។

417. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការចោទប្រកាន់របស់ ខៀវ សំផន អំពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាពុំមានមូលដ្ឋានគាំទ្រ[1049]។

418. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ "ត្រូវបានបញ្ជាក់នូវភាពត្រឹមត្រូវដោយសាក្សីជាច្រើន"រួមទាំង នួន ជា ដោយសារអង្គ

---

1044 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤។

1045 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤។

1046 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៥។

1047 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៥។

1048 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៥ និងជើងទំព័រ ៥២៣ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩៩, ៣៩៨។

1049 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៨។

ជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ច្បាស់លាស់ថា នួន ជា “បានបញ្ជាក់ថា ឯកសារលេខ E3/130 ស៊ីសង្វាក់ជាមួយនឹងការចងចាំរបស់គាត់អំពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែលមាន ៣០ មាត្រា និង ៨ ជំពូក” និង“បានផ្តល់យោបល់លើគោលគំនិតនៃ‘ប្រជាធិបតេយ្យប្រមូលផ្តុំ’មានក្នុងមាត្រា ៦ នៃលក្ខន្តិកៈកប្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦”[1050]។ បន្ថែមលើនេះ ខៀវ សំផន ពុំបានអើពើលើការពិតដែលថា កាំង ហ្កេចអ៊ាវ *ហៅ* ឌុច និង នី កន បានបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារនេះ ហើយ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច បានបញ្ជាក់ជាក់លាក់ថា ឯកសារនោះគឺជាសំណៅឆ្នាំ ១៩៧៦។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើឯកសារនេះ ដែលជាសំណៅលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦ ផ្អែកលើភស្តុតាងទាំងអស់នៅក្នុងកំណត់ត្រានោះឡើយ។

419. បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧០ ចំពោះមុខក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើសក្ខីកម្មរបស់ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច និងឯកសារបោះពុម្ពផ្សាយទង់បដិវត្តក្នុងការប្រៀបធៀបលក្ខណៈវិនិច្ឆ័យសម្រាប់សមាជិកភាពបក្ស ដែលមានក្នុងលក្ខន្តិកៈផ្សេងទៀត[1051]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើសក្ខីកម្មរបស់ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច ឬឯកសារផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងថា អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យពិភាក្សាលើឯកសារចម្លងនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៦០ សម្រាប់ការវិភាគរបស់ខ្លួន និងថា កំហុសដែលជាសម្មតិកម្មពាក់ព័ន្ធបញ្ហានេះអាចមោឃៈការយល់ឃើញទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបទប្បញ្ញត្តិ

---

[1050] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤ និងជើងទំព័រ ៩៥១ យោងទៅលើ*ក្នុងចំណោមនោះ* ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ឯកសារលេខ E1/21.1 ទំព័រ ១៤-១៥ (បញ្ជាក់ថា ឯកសារដូចគ្នាទៅនឹងការចងចាំរបស់គាត់អំពីលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ដែលមាន ៣០ មាត្រា និង ៨ ជំពូក)។ ប្រតិចារឹកចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ជនជាប់ចោទ នួន ជា) ឯកសារលេខ E1/23.1 ទំព័រ ៣០-៣៣។ ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ (នី កន) ឯកសារលេខ E1/76.1ទំព័រ ៧១-៧២ (“[ឯកសារលេខ E3/130] គឺជាលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា”)។ ប្រតិចារឹកចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ) ឯកសារលេខ E1/52.1 ទំព័រ ៥៣-៥៤។

[1051] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨ យោងទៅលើ*ក្នុងចំណោមនោះ* ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (កាំង ហ្កេកអ៊ាវ) ឯកសារលេខ E1/52.1 ទំព័រ ៥៧ (នៅពេលគាត់បានសំដៅទៅលើលក្ខន្តិកៈដែលពិភាក្សាលក្ខណៈវិនិច្ឆ័យសម្រាប់តួនាទីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងបានបញ្ជាក់ថា លក្ខន្តិកៈឆ្នាំ ១៩៧១ និង ១៩៧៦ ខុសប្លែកគ្នាពីលក្ខន្តិកៈឆ្នាំ ១៩៦០ ពាក់ព័ន្ធទៅនឹងលក្ខណៈវិនិច្ឆ័យ)។ ទង់បដិវត្ត ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/747 ERN 00064626-00064628 ទំព័រ ៥-៨)។

នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឡើយ។ បន្ថែមលើនេះ បើទោះបីជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់អាចផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសម្រាប់សមាជិកភាពបក្សកុម្មុយនីស្តកម្ពុជាដែលមានក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧៦០ ក៏ដោយ ក៏ ខៀវ សំផន ពុំបានបង្ហាញថាតើ កំហុសពាក់ព័ន្ធបញ្ហានេះអាចបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដូចម្តេចឡើយ។ អាស្រ័យហេតុនេះ ការចោទប្រកាន់ទាំងនេះត្រូវបដិសេធចោល។

ii. កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍

420. អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើភាពគួរឱ្យជឿទុកចិត្តបាននៃកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលតុលាការទទួលបានពីប្រភពផ្សេងៗជាច្រើន[1052]។ ការជំទាស់របស់ ខៀវ សំផន បានផ្តោតទៅលើប្រភពទាំងនោះដែលបានផ្តល់ដោយមជ្ឈមណ្ឌលតម្កល់ឯកសារកម្ពុជា(“DC-Cam”) តាមរយៈប្រព័ន្ធអេឡិចត្រូនិក[1053]។

421. មុនពេលពិភាក្សាលើអំណះអំណាងជាក់លាក់របស់ ខៀវ សំផន ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវរំឭកឡើងវិញនូវចំណុចនេះដូចខាងក្រោម។ ដំបូង អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញទស្សនៈរបស់ខ្លួន និងវិធីសាស្ត្រសម្រាប់ការវាយតម្លៃលើភាពគួរឱ្យជឿទុកចិត្តបាននៃឯកសារដែលបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam (រួមទាំងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍) ក្នុងសំណុំរឿង ០០២/០១។ ក្នុងសេចក្តីសម្រេចភ្លាមៗដែលបានបដិសេធការជំទាស់របស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ឯកសារនេះទទួលបានសច្ចធារណ៍គួរឱ្យជឿទុកចិត្តបាន*តាមការបញ្ជាក់ដំបូង* ឬដែលអាចជំទាស់បាន (រួមទាំងការបញ្ជាក់នូវភាពត្រឹមត្រូវ)[1054]។ នេះបានផ្អែកលើផ្នែកសំខាន់នៃសក្ខីកម្មរបស់ ឆាង យុ ប្រធានមជ្ឈមណ្ឌល DC-Cam អំពីវិធីសាស្ត្រដែល មជ្ឈមណ្ឌលនេះបានប្រមូល និងតម្កល់ឯកសារទាំងនេះ និងថា មជ្ឈមណ្ឌល DC-Cam បានត្រៀមលក្ខណៈជួយដល់ភាគីនូវការ

---

[1052] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ៥.១.២ “រចនាសម្ព័ន្ធរដ្ឋបាល៖ រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា៖ គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម៖ បញ្ហាបឋមពាក់ព័ន្ធទៅនឹងកំណត់ហេតុគណៈអចិន្ត្រៃយ៍”។

[1053] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៦-៣២៨។

[1054] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើឡើងឱ្យដាក់ចំពោះមុខអង្គជំនុំជម្រះស្តីពីឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា ក១-ក៥ និងទៅនឹងឯកសារដែលបានដកស្រង់ក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងការជំនុំជម្រះពីរផ្នែកដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E185 (“សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ (E185)”) កថាខណ្ឌ ២៨។ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ មានក្នុងសំណើសុំច្បាប់ដើមនៃឯកសារសម័យនោះឱ្យចម្លងឡើងវិញនៅចំពោះមុខអង្គជំនុំជម្រះ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ E168។

បញ្ជាក់ភាពត្រឹមត្រូវនៃឯកសារថតចម្លងនៅក្នុងសំណុំរឿង ដោយផ្តល់ឱកាសឱ្យផ្ទៀងផ្ទាត់ឯកសារដើមតាមការស្នើសុំ[1055]។

422. វិធីសាស្ត្រនេះត្រូវបានទទួលយកដោយអង្គជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា៖

> នេះអាស្រ័យលើភាគីដែលជំទាស់ភាពត្រឹមត្រូវនៃឯកសារដែលត្រូវបានសន្មតដោយតុលាការថា ត្រឹមត្រូវ *តាមការបញ្ជាក់ដំបូង* ក្នុងការជំទាស់សច្ចធារណ៍នេះ ហើយការផ្ទៀងផ្ទាត់អាចត្រូវបានស្នើឡើងដោយភាគីដែលធ្វើការជំទាស់នោះ [...] តាមរយៈការបញ្ជូនក្រុមមេធាវីការពារក្តីរបស់ខ្លួនទៅមជ្ឈមណ្ឌល DC-Cam ដើម្បីពិនិត្យផ្ទៀងផ្ទាត់ច្បាប់ដើមនៃឯកសារដែលត្រូវបានជំទាស់តាមការស្នើសុំ”[1056]។

ដោយសារពុំមានម្ចាស់បណ្តឹងសាទុក្ខណាម្នាក់បានផ្តល់ភស្តុតាងហេតុផលសម្រាប់ជំទាស់សច្ចធារណ៍នៃភាពត្រឹមត្រូវនៃឯកសារទាំងនោះ ក្រៅតែពីការជំទាស់ជារួមនោះ សច្ចធារណ៍នេះនៅតែមានអត្ថិភាព ហើយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធនេះត្រូវបដិសេធចោល[1057]។

423. អង្គជំនុំជម្រះសាលាដំបូងបានអនុម័តសំអាងហេតុដូចគ្នានេះដែរពាក់ព័ន្ធទៅនឹងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលផ្តល់ដោយមជ្ឈមណ្ឌល DC-Cam ក្នុងសំណុំរឿង ០០២/០២[1058]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញពីដំបូងរបស់ខ្លួនថា ពិធីការរបស់មជ្ឈមណ្ឌល DC-Cam សម្រាប់ការប្រមូល និងតម្កល់ឯកសារ ពុំបានបង្ហាញនូវការធ្វើឱ្យខុសសភាពដើម ការបំភ្លៃ ឬការបន្លំឡើយ[1059]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ភាគីណាមួយដែលមានក្តីបារម្ភចំពោះភាពត្រឹមត្រូវនៃច្បាប់ចម្លងនៅក្នុងសំណុំរឿង ឬប្រភព ឬភាពគួរឱ្យជឿទុកចិត្តបាននៃឯកសារអាចស្នើសុំធ្វើការពិនិត្យឯកសារដើមនៅមជ្ឈមណ្ឌល DC-Cam បាន[1060]។ ដោយសារពុំបានទទួលហេតុផលបន្ថែម ឬអំណះអំណាងថ្មីពីភាគីពាក់

---

[1055] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២៨។ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះមានក្នុងសំណើសុំច្បាប់ដើមនៃឯកសារសម័យនោះឱ្យចម្លងឡើងវិញនៅចំពោះមុខអង្គជំនុំជម្រះ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ E168។

[1056] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៧៥។

[1057] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៧៥-៣៧៦។

[1058] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨។

[1059] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨ យោងទៅលើ*ក្នុងចំណោមនោះ*សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២៨។

[1060] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨។

ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា កំណត់ហេតុនេះមានលក្ខណៈត្រឹមត្រូវ និងជាឯកសារនៅសម័យនោះដែលមាន"តម្លៃជាភស្តុតាងសំខាន់"[1061]។

424. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានផ្តល់ភាពគួរឱ្យជឿទុកចិត្តបាន*តាមការបញ្ជាក់ដំបូង* ទៅលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam ពីព្រោះអង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញ ឬពន្យល់"ថាតើ មជ្ឈមណ្ឌល DC-Cam បានប្រើប្រាស់នីតិវិធីនៃការទទួលបានភស្តុតាងនេះដូចម្តេចឡើយ" ដើម្បីលុបបំបាត់លទ្ធភាពសម្រាប់ការជ្រៀតជ្រែកខាងក្រៅ និងផ្តល់"ការធានាគ្រប់គ្រាន់ផ្នែកនីតិវិធីតាមផ្លូវតុលាការ"[1062]។ ខៀវ សំផន បានរំឭកថា ឆាង យុ ប្រធានមជ្ឈមណ្ឌល DC-Cam ពុំចង់បង្ហាញនៅពេលផ្តល់សក្ខីកម្មអំពីទីកន្លែងផ្ទាល់នៃឯកសារដើមដោយសារហេតុផលសុវត្ថិភាព និងសន្តិសុខ និងបានលើកឡើងបន្ថែមថា ហេតុទាំងនេះពុំត្រូវបានពន្យល់គ្រប់គ្រាន់ដល់ភាគីឡើយ[1063]។ ចុងក្រោយ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារដើមផ្ទាល់ ឬតាមរយៈអ្នកជំនាញដែលចាត់តាំងដោយតុលាការឡើយ[1064]។ គាត់បានអះអាងថា ការយល់ឃើញដែលផ្អែកលើភស្តុតាងនេះគប្បីត្រូវចាត់ទុកជាមោឃៈ[1065]។

425. សហព្រះរាជអាជ្ញាបានរំឭកថា ពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីឱ្យកោះហៅសាក្សីដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារ និងថា មានតែឯកសារដើមដែលត្រូវដាក់ចូលសំណុំរឿងធ្វើជាភស្តុតាងនោះទេ។ ផ្ទុយទៅវិញ នេះអាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់លើទម្ងន់ដែលត្រូវផ្តល់ទៅលើភស្តុតាងចំពោះមុខដោយផ្អែកលើភស្តុតាងទាំងមូល[1066]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានលើកអំណះអំណាងអំពីកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលផ្តល់ដោយមជ្ឈមណ្ឌល DC-Cam ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធក្នុងសំណុំរឿង ០០២/០១ ដោយពុំបានបង្ហាញកំហុសនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពគួរឱ្យជឿទុកចិត្តបាននៃកំណត់ហេតុទាំងនេះដែលទទួលបានពី

---

1061 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០។

1062 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៦។

1063 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៧-៣២៨ យោងទៅលើប្រតិចារិកចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ) ឯកសារលេខ E1/38.1 ទំព័រ ៨-៩។

1064 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៨។

1065 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២៨ ជើងទំព័រ ៥៣០។

1066 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៣។

ប្រភពផ្សេងៗ[1067]។ ខៀវ សំផន ពុំចាំបាច់ត្រូវដឹងអំពីទីកន្លែងនៃឯកសារដើមដែលទទួលបានដោយមជ្ឈមណ្ឌល DC-Cam ដែលនេះបានផ្តល់ឱកាសឱ្យគាត់ស្នើសុំពិនិត្យបាន និងតាមការអះអាងរបស់សហព្រះរាជអាជ្ញាថា គាត់ពុំបានបង្ហាញថា គាត់បានព្យាយាមធ្វើដូច្នោះ ប៉ុន្តែពុំបានជោគជ័យនោះឡើយ[1068]។ ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាបូងមានកំហុសក្នុងការបញ្ជាក់ថា កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលផ្តល់ដោយមជ្ឈមណ្ឌល DC-Cam គួរឱ្យជឿទុកចិត្តបានគ្រប់គ្រាន់ដោយផ្អែកលើមូលដ្ឋាននៃការយល់ឃើញនៃអង្គហេតុតាមផ្លូវតុលាការ[1069]។

426. អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលត្រូវប្រាសចាកពីសំអាងហេតុដំបូងរបស់ខ្លួនស្តីពីចំណុចនេះ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានទទួលការជូនដំណឹងច្បាស់លាស់អំពីវិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលអនុម័តចំពោះភស្តុតាងនេះ និងពេលវេលាគ្រប់គ្រាន់ក្នុងការស្នើសុំពិនិត្យលើឯកសារ រួមទាំងការជួយពីអ្នកជំនាញ ប្រសិនបើគាត់ជឿថា នេះជាការចាំបាច់សម្រាប់ការការពារខ្លួននោះ។ គាត់ពុំបានដាក់សំណើសុំ និងបង្ហាញមូលហេតុ ឬអំណះអំណាងដែលអាចច្រានចោលសច្ចធារណ៍ដែលទទួលយកភាពគួរជឿទុកចិត្តបាននៃកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ទីកន្លែងនៃឯកសារដើមនេះពុំជាប់ពាក់ព័ន្ធដោយសារ ខៀវ សំផន អាចស្នើសុំធ្វើការពិនិត្យបាន និងចាត់ទុកហេតុផលរបស់ ឆាង យុ ដែលបដិសេធក្នុងការបង្ហាញទីកន្លែងផ្ទាល់ជាការពន្យល់លក្ខណៈបុគ្គ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

### ខ. បទសម្ភាសន៍ ចម្លើយ និងឯកសារផ្សព្វផ្សាយរបស់ ខៀវ សំផន

[1067] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៩ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៦៩-៣៧៥។

[1068] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៥។

[1069] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៤, ១៦៩។

### i. កិច្ចសម្ភាសន៍របស់ ខៀវ សំផន

427. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើប្រតិចារឹកនៃបទសម្ភាសន៍របស់គាត់ចំនួនបី (E3/4050, E3/4043 និង E3/4041)[1070]។ យោងតាមគាត់បានឱ្យដឹងថា ប្រតិចារឹកបទសម្ភាសន៍ទាំងនេះ ខ្វះ"ព័ត៌មានដែលអាចធ្វើការផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវបាននោះឡើយ"[1071] ដោយសារពុំមានកាលបរិច្ឆេទដែលបទសម្ភាសន៍នោះបានធ្វើឡើង និងឈ្មោះសាមីជនដែលធ្វើប្រតិចារឹកឡើងវិញ និងពុំបានពេញលេញ ដោយសារបានធ្វើប្រតិចារឹកតែការឆ្លើយតបរបស់គាត់ទៅនឹងអ្នកយកបទសម្ភាសន៍ ប៉ុន្តែពុំមានប្រតិចារឹកលើសំណួរសួរឡើយ[1072]។

428. យោងតាម ខៀវ សំផន បានឱ្យដឹងថា កាលបរិច្ឆេទនៃបទសម្ភាសន៍នោះមានសារៈសំខាន់ដោយសារគាត់បានទទួលព័ត៌មានថ្មីៗអំពីរបបនោះតាមរយៈការអានអត្ថបទនិពន្ធរបស់ Philip SHORT[1073]។ បន្ថែមលើនេះ នៅក្នុងសេចក្តីដកស្រង់គ្មានចំណុចណាបញ្ជាក់ថា គាត់បាននិយាយអំពីការដឹងរបស់គាត់ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលខុសគ្នាពីការដឹងដែលគាត់បានទទួលក្រោយព្រឹត្តិការណ៍នោះ[1074]។ គាត់បានលើកឡើងថា ដោយសារពុំអាចដឹងអំពីសំណួរដែលគេសួរគាត់ ព្រមទាំងការដកស្រង់របស់អង្គជំនុំជម្រះសាលាដំបូងតាមបែបជ្រើសរើសមានន័យថា បរិបទសំខាន់នោះត្រូវបាត់បង់ក្នុងការបង្ហាញអំពីអ្វីជាក់លាក់ដែលគាត់ចង់សំដៅទៅលើនោះ និង ដូច្នេះ ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើការប៉ាន់ស្មាន និងការបំភ្លៃ[1075]។ ទាក់ទងទៅនឹងឯកសារលេខ E3/4041 គាត់បានលើកឡើងថា ឯកសារដែលបាន

---

[1070] ប្រតិចារឹកកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ឯកសារលេខ E3/4050 ពុំមានចុះកាលបរិច្ឆេទ ទំព័រ ១ ERN 00786553-00786554។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារលេខ E3/4043 ពុំមានចុះកាលបរិច្ឆេទ។ ប្រតិចារឹកបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ឯកសារលេខ E3/4041 ពុំមានចុះកាលបរិច្ឆេទ ERN 00782543-00782544។

[1071] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨១៩-១៨២៨, ១៨៧៥។

[1072] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២០។

[1073] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២០-១៨២១, ១៨២៤, ១៨៧៥។

[1074] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២០, ១៨៧៥។

[1075] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨១៩។

ធ្វើប្រតិចារឹកនោះប្រើប្រាស់វង់ក្រចកក្នុងឃ្លាមួយចំនួនដែលចង់មានន័យថា "ពុំមែនជាសំដីដើម"របស់គាត់[1076]។ គាត់បានលើកឡើងថា ការយល់ឃើញទាំងអស់ដែលទាញចេញពីឯកសារទាំងនេះគប្បីមោឃៈ[1077]។

429. យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ការចោទប្រកាន់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងឯកសារលេខ E3/4050 និង E3/4043 ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ ដោយសារគាត់ពុំបានអើពើទៅលើភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការកំណត់ការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម ដែលអង្គជំនុំជម្រះសាលាដំបូងអះអាងថា បានបញ្ជាក់បន្ថែមលើបទសម្ភាសន៍ទាំងនេះ[1078]។ តាមការពិនិត្យដោយយុត្តិធម៌លើបទសម្ភាសន៍ទាំងនេះអាចធ្វើការសន្និដ្ឋានបានថា កិច្ចសម្ភាសន៍ទាំងនេះត្រូវបានផ្អែកទាំងស្រុងទៅលើការចងចាំរបស់ ខៀវ សំផន នូវព្រឹត្តិការណ៍ ពុំមែនជាការស្រាវជ្រាវរបស់គាត់នោះទេ[1079]។ សហព្រះរាជអាជ្ញាបានអះអាងថា ការតវ៉ារបស់ ខៀវ សំផន អំពីការចោទប្រកាន់នូវលុបរបស់អង្គជំនុំជម្រះសាលាដំបូងនូវផ្នែកខ្លះនៅក្នុងសេចក្តីដកស្រង់ និងកង្វះការកត់ត្រានូវសំណួរ ពុំជាប់ពាក់ព័ន្ធទៅនឹងសារៈសំខាន់នៃសេចក្តីដកស្រង់ និងពុំបានប៉ះពាល់ដល់"ខ្លឹមសារនៃចម្លើយដែលបង្ហាញឱ្យឃើញច្បាស់លាស់ដោយខ្លួនឯង"នោះឡើយ[1080]។ សហព្រះរាជអាជ្ញាពុំបានឆ្លើយតបទៅនឹងសារណារបស់ ខៀវ សំផន ពាក់ព័ន្ធឯកសារ E3/4041។

430. អង្គជំនុំជម្រះតុលាការកំពូលរំឮកថា "ភាពត្រឹមត្រូវនៃឯកសារជាប់ពាក់ព័ន្ធទៅនឹងការបញ្ជាក់ថាតើ ឯកសារនោះ គឺជាឯកសារដើម ឬជាប្រភពដើម ដែរ យ៉ាងណា"[1081]។ ខៀវ សំផន ពុំបានបដិសេធការផ្តល់បទសម្ភាសន៍របស់គាត់ កំណត់ត្រាខ្សែអាត់ថតសម្លេងដែលមាននៅក្នុងសំណុំរឿង ឬកំហុសណាមួយនៅក្នុងប្រតិចារឹកនោះឡើយ។ អាស្រ័យហេតុនេះ បញ្ហាដែលគាត់បានលើកឡើង ពុំមែនជាសញ្ញាណបញ្ជាក់ភាព

---

[1076] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២០-១៨២៨, ១៨៧៥។

[1077] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣១។

[1078] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២០, ១៨២៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៤-៤២១៨ និងជើងទំព័រ ១៣៧៥៧-១៣៧៥៨។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣១។

[1079] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៦។

[1080] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៦។

[1081] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ IT-04-74-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់ Jadranko Prlić ប្រឆាំងនឹង'សេចក្តីម្រេចលើញត្តិរបស់មេធាវីការពារក្តី Prlić ស្នើសុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចស្តីពីការទទួលយកភស្តុតាងជាឯកសារ'ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៤។

ត្រឹមត្រូវនៃឯកសារ ដូច្នេះ អំណះអំណាងរបស់គាត់ពុំជាប់ពាក់ព័ន្ធបញ្ហានេះទេ។ ទាក់ទងបញ្ហានេះ គាត់ពុំបានផ្តល់ការពន្យល់អំពីមូលហេតុដូចម្តេចបានជាអត្តសញ្ញាណនៃអ្នកធ្វើប្រតិចារឹកមានលក្ខណៈសំខាន់ អាស្រ័យហេតុនេះ សារណានេះពុំចាំបាច់ពិចារណាបន្ថែមទៀតឡើយ។

431. ការជំទាស់របស់ ខៀវ សំផន ដែលថា គាត់ពុំបាននិយាយតាមការចងចាំផ្ទាល់ខ្លួននោះទេ ប៉ុន្តែបានផ្អែកលើការស្រាវជ្រាវដែលគាត់បានធ្វើឡើងនៅក្រោយព្រឹត្តិការណ៍នោះ ពុំមានភស្តុតាងគាំទ្រឡើយ។ ក្នុងចំណុចទីមួយ (E3/4050) ខៀវ សំផន បានពន្យល់អំពីគោលគំនិតរបស់ថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យរួមទាំងខ្លួនគាត់ផ្ទាល់ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ទាក់ទងនឹងមូលហេតុដែលអ្នកជម្លៀសត្រូវទៅធ្វើការ[1082]។ ក្នុងចំណុចទីពីរ (E3/4043) ខៀវ សំផន បានអះអាងច្បាស់លាស់ថា "នោះគឺជាអ្វីដែលគាត់បានឃើញ"[1083]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អត្ថបទនោះមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់តាមការបង្ហាញខាងក្រៅ ដូច្នេះ នត្ថិភាពនៃសំណួរ ដែលនៅគ្រប់ករណីពុំសូវសួរជាញឹកញាប់នៅក្នុងការឆ្លើយដែលមានលក្ខណៈវែងភាគច្រើននោះ ពុំមានន័យថា ខ្លឹមសារអត្ថបទដ៏សំខាន់នោះត្រូវបានបាត់បង់នោះទេ។ ដូចគ្នាដែរ អត្ថបទដែលខៀវ សំផន បានបន្ថែមចូលដោយមានការផ្តល់យុត្តិកម្មរបស់គាត់អំពីការរងទុក្ខវេទនាដែលបានបង្កទៅលើប្រជាជនដោយបក្សកុម្មុយនីស្តកម្ពុជា ពុំអាចប៉ះពាល់ដល់ការដឹងជាក់ស្តែងច្បាស់លាស់របស់គាត់បានឡើយ។ ផ្ទុយទៅនឹងការចោទប្រកាន់របស់គាត់ ដែលថា ឃ្លាមួយចំនួនក្នុងវង់ក្រចកក្នុងកិច្ចសម្ភាសន៍លេខឯកសារ E3/4041 "ពុំមែនជាសំដីដើមរបស់គាត់"[1084] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានពាក្យតែមួយគត់នៅក្នុងវង់ក្រចកដែលត្រូវបានប្រើប្រាស់ដើម្បីកែតម្រូវកំហុសវេយ្យាករណ៍ប៉ុណ្ណោះ[1085]។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មានភស្តុតាងជាច្រើនសន្ធឹកសន្ធាប់បង្ហាញនូវការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មនោះ និងថា ខៀវ សំផន ពុំបានព្យាយាមទាល់តែសោះក្នុងការបង្ហាញថា បទសម្ភាសន៍ទាំងបីនេះមានសារៈសំខាន់ចំពោះការដាក់ពិរុទ្ធភាពលើគាត់ ដូចជាការបង្ហាញនូវភាពមិនយុត្តិធម៌ណាមួយនោះឡើយ។

---

[1082] ប្រតិចារឹកនៃបទសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4050 ERN 00786553 ("ប្រសិនបើយើងស្ទាក់ស្ទើរ មានមនុស្សច្រើននឹងត្រូវស្លាប់។ ដូច្នេះ អ្នកឈឺ និងអ្នកជាត្រូវធ្វើការទាំងអស់គ្នា។ អ្នកដែលឈឺល្មមក៏ធ្វើការដែរ")។

[1083] ប្រតិចារឹកនៃបទសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4043 ERN 00780960-00780961។

[1084] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៥។

[1085] ប្រតិចារឹកនៃបទសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4041 ERN 00782543-00782544 ("អ្នកដែលត្រូវចាប់ខ្លួន នៅក្នុងក្របខ័ណ្ឌបក្សកុម្មុយនីស្តកម្ពុជា")។

432. អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍របស់គាត់ E3/4050, E3/4043 និង E3/4041 ត្រូវបដិសេធចោល។

ii. ចម្លើយ និងឯកសារផ្សព្វផ្សាយរបស់ ខៀវ សំផន

433. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានអនុម័ត "ក្របខ័ណ្ឌការងារផ្សេងនៃការវិភាគ"ក្នុងការវាយតម្លៃលើសក្ខីកម្មផ្ទាល់គាត់ និងឯកសារផ្សព្វផ្សាយ[1086]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន គ្មានមូលគាំទ្រគ្រប់គ្រាន់[1087]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ត្រឹមតែសង្ខេបការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិធីសាស្ត្រទាក់ទងបញ្ហានេះ ប៉ុន្តែពុំបានលម្អិតបន្ថែមនូវមូលហេតុដែលមានកំហុស ឬនូវអ្វីផ្សេងពីនេះ និងដូចម្តេចឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការពិចារណាលើសារណានេះ។

434. ក្នុងចំណុចទីពីរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន"ប្រព្រឹត្តផ្ទុយខ្លួនឯង [...] បានបំភ្លៃ និងបំផ្លើសសំដីរបស់គាត់ ឬឯកសារ ឬបានប្រើប្រាស់សម្រាប់គោលបំណងដាក់បន្ទុកទាំងស្រុង"[1088]។ សម្រាប់ការអះអាងនេះ គាត់បានយោងឆ្លងទៅលើផ្នែកជាច្រើនដទៃទៀតនៃសារណាបណ្តឹងសាទុក្ខរបស់គាត់[1089]។ តាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើកថាខណ្ឌចំនួន ១៩ ដែលបានដកស្រង់នោះ ឃើញថា មានការយោងតែមួយគត់ទៅលើសក្ខីកម្មរបស់គាត់ ដែលក្នុងនោះគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/០១ ស្តីពីការទិទៀន និងស្វ័យទិទៀន[1090]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ផ្នែកដែល ខៀវ សំផន អះអាងថា ជាការបំភ្លៃនោះ គឺជាការ

[1086] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៩២-១៩៥។

[1087] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៧៥-១៧៦។

[1088] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៧ ជើងទំព័រ ៣៨៥។

[1089] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៧ ជើងទំព័រ ៣៨៥ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៤, ១៣៩៥-១៣៩៨, ១៥២៦-១៥៤០។

[1090] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៧ ជើងទំព័រ ៣៨៥ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៣៦។

ដកស្រង់ទាំងស្រុងចេញពីសក្ខីកម្មរបស់គាត់ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកការដកស្រង់នេះជាការបំភ្លៃឡើយ[1091]។

## គ. ចម្លើយក្រៅក្របខ័ណ្ឌតុលាការ

435. អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញវិធីសាស្ត្រនៃការវាយតម្លៃលើចម្លើយក្រៅក្របខ័ណ្ឌតុលាការដូចខាងក្រោម៖

> កំណត់ហេតុដែលត្រូវបានធ្វើឡើងនៅខាងក្រៅក្របខណ្ឌនីតិវិធីតុលាការ ដូចជា កំណត់ហេតុដែលបានកត់ត្រាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍ រឿងរ៉ាវរបស់ជនភៀសខ្លួនដែលពុំបានធ្វើសម្បថ អត្ថបទសារព័ត៌មាន មានតម្លៃជាភ័ស្តុតាងតិច ។ ក្នុងករណីដែលសំអាងហេតុត្រូវបានផ្អែកលើផ្នែកខ្លះនៃកំណត់ហេតុបែបនេះ ទឡ្ហីករណ៍នៃសំអាងហេតុត្រូវតែពន្យល់ឲ្យបានច្បាស់លាស់ ជាពិសេស ប្រសិនបើការផ្តន្ទាទោសពឹងផ្អែកទៅលើភ័ស្តុតាងបែបនេះទាំងស្រុងឬជាសំខាន់ ។ ដើម្បីពិនិត្យទៅលើភាពត្រឹមត្រូវនៃចម្លើយរបស់សាក្សី អង្គជំនុំជម្រះអាចពិចារណាថា តើចម្លើយនោះស៊ីសង្វាក់គ្នាជាមួយនឹងភ័ស្តុតាងផ្សេងទៀតដែរឬទេ និងពិចារណាទៅលើលក្ខណៈនៃភ័ស្តុតាងនោះ ប្រសិនបើចម្លើយស៊ីសង្វាក់គ្នា។ ជាមួយគ្នានេះផងដែរ អង្គជំនុំជម្រះអាចពិចារណាថា តើចម្លើយពីមុនរបស់សាក្សីស៊ីសង្វាក់គ្នាដែរឬទេ ហើយថាតើភាពមិនស៊ីសង្វាក់គ្នាត្រូវបានពន្យល់ឲ្យបានគ្រប់គ្រាន់ដែរឬទេ[1092]។

436. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលអង្គជំនុំជម្រះ "បានពិចារណាថា ជាការដែលអាចធ្វើទៅបានក្នុងការសំអាងការដាក់ពិរុទ្ធភាពទៅលើចម្លើយក្រៅក្របខ័ណ្ឌតុលាការ [...] ដរាបណាសំអាងហេតុត្រូវបានពន្យល់ច្បាស់លាស់"[1093]។ យោងតាម ខៀវ សំផន បានឱ្យដឹងថា "ក្របខ័ណ្ឌគតិយុត្តបែបនេះបានរំលោភបំពានលើសិទ្ធិស្តីពីនីតិវិធី" និង"ពុំត្រូវបានអនុញ្ញាដោយច្បាប់ឡើយ"[1094]។ ក្នុងការគាំទ្រការអះអាងនេះ ដំបូង ខៀវ សំផន បានយោងទៅលើសំអាងផ្លូវច្បាប់ពីររបស់ អ.វ.ត.ក . ក្នុងការបញ្ជាក់ថា ចម្លើយក្រៅក្របខ័ណ្ឌតុលាការពុំទទួលបានសច្ចធារណ៍នៃភាពគួរឱ្យជឿទុកចិត្តបាន

---

[1091] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦៧។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ឯកសារលេខ E1/198.1 ទំព័រ ១៧។

[1092] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩ (សេចក្តីដកស្រង់ត្រូវលុបចោល)។

[1093] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៧។

[1094] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៧។

ឡើយ[1095]។ ទីពីរ គាត់បានដកស្រង់សេចក្តីសម្រេចភ្លាមៗរបស់តុលាការ ICC ដែលបញ្ជាក់ថា តើឯកសារនោះត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា គឺជាកត្តាមួយចំណោមកត្តាជាច្រើនដែលពាក់ព័ន្ធសម្រាប់ការវាយតម្លៃលភាពគួរជឿទុកចិត្តបាន[1096]។ ទីបី ខៀវ សំផន បានយោងទៅលើសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[1097] ដែលក្នុងការគូសបង្ហាញវិធីសាស្ត្ររបស់ខ្លួនសម្រាប់ការវាយតម្លៃលើភាពសមហេតុផលនៃការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> នៅពេលប្រឈមជាមួយនឹង […] ភស្តុតាងដែលមានតម្លៃទាប (ដូចជា ចម្លើយក្រៅក្របខ័ណ្ឌតុលាការ […]) ទំនងជាថា ការពន្យល់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះឈានដល់ការសន្និដ្ឋានផ្នែកអង្គហេតុណាមួយដោយផ្អែកលើភស្តុតាងដែលចោទជាបញ្ហានោះ នឹងមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការកំណត់ថាតើ ការសន្និដ្ឋាននោះសមហេតុផល ដែរ ឬយ៉ាងណា។ ផ្អែកតាមវិធានទូទៅ ក្នុងករណីដែលភស្តុតាងជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានផ្នែកអង្គហេតុបើមើលទៅទំនងជាខ្សោយតម្រូវឱ្យមានការពន្យល់បន្ថែមច្រើនជាងការដែលមានមូលដ្ឋានផ្អែកលើភស្តុតាងមានតម្លៃខ្ពស់នោះ[1098]។

437. ខៀវ សំផន បានដកស្រង់ឧទាហរណ៍ចំនួនបួនដែលគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បានផ្អែកការដាក់ពិរុទ្ធភាពតែទៅលើចម្លើយក្រៅក្របខ័ណ្ឌតុលាការប៉ុណ្ណោះ"[1099]។ ឧទាហរណ៍នេះជាប់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសារស្រាវជ្រាវ និងចម្លើយរបស់សាក្សីដែលបានកត់ត្រាដោយមជ្ឈមណ្ឌល DC-Cam ដើម្បីគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី (១) ភាពខុសគ្នាក្នុងការទទួលបានរបបអាហារ[1100] (២) ជាតិពន្ធុសែស្រឡាយខាងម្តាយ[1101] (៣) រចនាសម្ព័ន្ធទំនាក់ទំនងសម្រាប់គោលនយោ

---

[1095] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៧-៣០៨ យោងទៅលើសេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង (E96/7) កថាខណ្ឌ ២៩។ ដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (D308/3) កថាខណ្ឌ ១០៣-១០៨។

[1096] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៩ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* អង្គជំនុំជម្រះសាលាដំបូង II (ICC) សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្តីពីតារាងបញ្ជីភស្តុតាងថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ២៧។

[1097] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១០។

[1098] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០។

[1099] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១១ ជើងទំព័រ ៤៨១។

[1100] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣១។

[1101] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤៤-១០៤៥។

បាយបក្សកុម្មុយនីស្តកម្ពុជា[1102] និង (៤) អត្ថិភាពនៃ"មន្ទីរសន្តិសុខយ៉ាងតិច ២០០ កន្លែង"[1103]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការ"បញ្ជាក់ជាក់លាក់នូវប្រភពនៃឯកសារនោះ [...] និងពុំបានបង្ហាញនូវភាពជាប់ពាក់ព័ន្ធ និងភាពគួរឱ្យជឿទុកចិត្តបាន"[1104]។

438. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន គប្បីបដិសេធចោល ពីព្រោះគាត់ខកខានក្នុងការបង្ហាញនូវកំហុសនៅក្នុងក្របខ័ណ្ឌគតិយុត្តរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើចម្លើយក្រៅក្របខ័ណ្ឌតុលាការ ការអនុវត្តន៍នៃក្របខ័ណ្ឌការងារនោះ ឬការវាយតម្លៃលើភស្តុតាងដែលបានយោងទៅលើនោះ[1105]។

439. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានដោះស្រាយចំណុចនេះនៃអង្គច្បាប់ក្នុងសាលដីកាសំណុំរឿង ០០២/០១ ថា៖

> ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពុំបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគី ជាទូទៅត្រូវផ្តល់តម្លៃទាបជាងភស្តុតាងរបស់សាក្សីដែលបានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ ជាគោលការណ៍ តម្លៃជាភស្តុតាងទាបត្រូវផ្តល់ទៅឱ្យភស្តុតាងដែលពុំទទួលបានជាក់លាក់សម្រាប់គោលបំណងការជំនុំជម្រះព្រហ្មទណ្ឌ ដែលខុសពីកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត[1106]។

ការសំអាងទៅលើយុត្តិសាស្ត្រគួរឱ្យជឿជាក់បាននៃតុលាការ ECtHR អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ការដាក់ពិរុទ្ធភាពពុំអាចផ្អែកតែមួយមុខ ឬជាសំខាន់ទៅលើភស្តុតាងរបស់សាក្សីដែលមេធាវីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ ដរាបណាមានការកត្តាថ្លឹងថ្លែងតុល្យភាពជាអត្ថិភាព ដើម្បីឱ្យជនជាប់ចោទមានឱកាសដោយប្រសិទ្ធភាពក្នុងការជំទាស់ទៅនឹងភស្តុតាងដាក់បន្ទុកលើខ្លួន"[1107]។

440. ខៀវ សំផន ពុំបានចង្អុលបង្ហាញទៅលើសំអាងផ្លូវច្បាប់ណាមួយដែលពុំស៊ីសង្វាក់ជាមួយនឹងបទដ្ឋាននេះ។ ពិតណាស់ សេចក្តីសម្រេចដែលគាត់បានពិភាក្សាបានបញ្ជាក់ថា ត្រូវមានការប្រុងប្រយ័ត្នជាពិសេសនៅ

---

[1102] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤២៩-១៤៣០។

[1103] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២៥។

[1104] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១១។

[1105] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៧០-១៧៣។

[1106] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[1107] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

ពេលវាយតម្លៃលើភាពគួរឱ្យជឿទុកចិត្តបាននៃចម្លើយក្រៅក្របខ័ណ្ឌតុលាការ និងជាការប្រសើរបើសិនតុលាការគួរសបញ្ជាក់ពេញលេញនូវសំអាងហេតុរបស់ខ្លួនទាក់ទងបញ្ហានេះ។ ដូចក្នុងរឿងក្តី ០០២/០១[1108] ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើតម្រូវការចាំបាច់ក្នុងការផ្អែកការយល់ឃើញរបស់ខ្លួនទៅលើភស្តុតាងដែលត្រូវដាក់ឱ្យស្ថិតក្រោមការពិភាក្សាដេញដោល និងបានស្តាប់សារណាលម្អិតរបស់ភាគីទាក់ទងបញ្ហានេះ[1109]។ អង្គជំនុំជម្រះសាលាដំបូងដឹងច្បាស់លាស់ថា មេធាវីការពារក្តីពុំមានឱកាសសួរដេញដោលសាមីជននៃចម្លើយជាលាយលក្ខណ៍អក្សរ និងថា នេះមានផលប៉ះពាល់ទៅលើទម្ងន់ដែលត្រូវផ្តល់ទៅឱ្យភស្តុតាងនោះ[1110]។ ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់។

441. ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាទៅលើការជំទាស់ទីពីររបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការដាក់ពិរុទ្ធភាពតែទៅលើចម្លើយក្រៅក្របខ័ណ្ឌតុលាការ "ដោយគ្មានការវិភាគផ្លូវច្បាប់ហ្មត់ចត់ និងការវាយតម្លៃលម្អិត"ចំនួនបួនលើក[1111]។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាជនថ្មីបានទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាន បានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ដែលការរៀបរាប់របស់ពួកគាត់ត្រូវបានបញ្ជាក់បន្ថែមដោយបទសម្ភាសន៍របស់ រៀល សន ជាមួយមជ្ឈមណ្ឌល DC-Cam[1112]។ ប្រហាក់ប្រហែលគ្នានេះដែរ ការយល់ឃើញពាក់ព័ន្ធទៅនឹងជាតិពន្ធុសែស្រឡាយខាងម្តាយ ជាចម្បង បានផ្អែកលើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន[1113]។ ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញ ការយល់ឃើញនេះបានផ្អែកតែមួយមុខ ឬជាសំខាន់ទៅលើចម្លើយក្រៅក្របខ័ណ្ឌតុលាការ។ ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើទូរលេខបក្សកុម្មុយនីស្តកម្ពុជាដែលបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានដោះស្រាយយ៉ាងលម្អិតលើការជំទាស់របស់មេធាវីការពារក្តី ទៅនឹងសច្ចធារណ៍នៃភាពគួរឱ្យជឿទុកចិត្តបានដែលបានផ្តល់ឱ្យឯកសារពីមជ្ឈមណ្ឌល DC-Cam នៅក្នុងបណ្តឹង

---

1108 *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

1109 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។

1110 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

1111 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១១។

1112 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣១។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៦។

1113 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤៤-១០៤៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤២៤ ជើងទំព័រ ១១៥៤៧។

សាទុក្ខនេះ និងក្នុងសំណុំរឿង ០០២/០១[1114] ហើយអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃបន្ថែមលើភាពគួរឱ្យជឿទុកចិត្តបាននៃទូរលេខ ដែលបានផ្តល់ដោយមជ្ឈមណ្ឌល DC-Cam[1115]។ ចុងក្រោយ បើទោះបីជាសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានមន្ទីរសន្តិសុខយ៉ាងតិច ២០០ កន្លែង បានផ្អែកជាសំខាន់លើរបាយការណ៍របស់មជ្ឈមណ្ឌល DC-Cam[1116]ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការវាយតម្លៃលើភាពគួរឱ្យជឿទុកចិត្តបាននៃរបាយការណ៍នោះដែរ[1117]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការវាយតម្លៃទាំងនេះជាការសមហេតុផល និងកត់សម្គាល់ថា នៅក្នុងគ្រប់ករណី ខៀវ សំផន ខកខានក្នុងការបញ្ជាក់ជាក់លាក់ថា តើការដាក់ពិរុទ្ធភាពនោះបានផ្អែកទៅលើភស្តុតាងនេះ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ អំណះអំណាងទាំងនេះត្រូវបដិសេធចោល។

### ឃ. ការឃោសនា

442. នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងសម្រាប់គោលបំណងឃោសនា អាចកាត់បន្ថយភាពគួរឱ្យជឿទុកចិត្តបាន”[1118]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការផ្សព្វផ្សាយតាមវិទ្យុ និងទស្សនាវដ្តីទង់បដិវត្ត និងយុវជនបដិវត្ត គឺជាឧបករណ៍ប្រើប្រាស់ក្នុងគោលបំណងផ្សព្វផ្សាយជាសាធារណៈ និងថា អង្គជំនុំជម្រះបានដឹងច្បាស់លាស់អំពីបញ្ហានេះនៅពេលការវាយតម្លៃលើភស្តុតាងនេះ[1119]។

443. ខៀវ សំផន បានយល់ស្របជាមួយនឹងវិធីសាស្ត្រដែលបានគូសបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើភស្តុតាងដែលមានក្នុងការឃោសនា ប៉ុន្តែបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារពុំបានអនុវត្តសមស្របលើភស្តុតាងចំពោះមុខ[1120]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង“បានប្រព្រឹត្តផ្ទុយខ្លួនឯងដោយពុំបានពិចារណាថា ឯកសារនៃការឃោស

---

[1114] *សូមមើលខាងលើ* ផ្នែក V.ង.២.ក.ii។

[1115] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩៥៥។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤២៩-១៤៣០។

[1116] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤៩។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២៥។

[1117] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤៨-៣៩៤៩, ៣៩៥១។

[1118] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E៤៦៥) កថាខណ្ឌ ៦៥។

[1119] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E៤៦៥) កថាខណ្ឌ ៤៧២, ៤៧៩។

[1120] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២។

នាមានភាពគួរឱ្យជឿទុកចិត្តបានតិចតួចតាមរយៈការបកស្រាយលើសុន្ទរកថាឃោសនាត្រង់ ដែលនេះជាការធ្វើសេចក្ដីសន្និដ្ឋានអវិជ្ជាមាន"[1121]។ ជាឧទាហរណ៍ជាក់លាក់ ខៀវ សំផន បានយោងទៅលើ (១) "សុន្ទរកថាដែលគាត់បានថ្លែងពាក់ព័ន្ធនឹងជនជាតិវៀតណាមនៅក្នុងពិធីរំឭលខួបមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[1122] និង (២) ការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូងថា ពុំមែនជាការឃោសនានៃ"វិធានដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីទង់បដិវត្តដែលថា ស្វាមីភរិយារៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត [...] បើទោះបីជាវិធាននេះស្ថិតក្នុងចំណោមគោលការណ៍សីលធម៌ទាំង ១២ ប្រការដែលសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាគ្រប់រូបត្រូវតែគោរព"[1123]។ គាត់បានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបាន"សំអាងតែទៅលើឯកសារឃោសនាដើម្បីដាក់ពិរុទ្ធ ដែលនេះមានន័យថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន និងថា ការយល់ឃើញនោះត្រូវចាត់ទុកជាមោឃៈ"[1124]។

444. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា ខៀវ សំផន ពុំបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាថា ការថ្លែងដែលបានធ្វើឡើងសម្រាប់គោលបំណងឃោសនា អាចកាត់បន្ថយជាអប្បបរមានូវភាពគួរឱ្យជឿទុកចិត្តបាន[1125]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ស៊ីសង្វាក់គ្នាថា ការវាយតម្លៃរបស់ខ្លួនបានពិចារណាទៅលើភស្តុតាងមួយចំនួនដែលមានលក្ខណៈឃោសនា[1126]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នេះអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើបញ្ហាថាតើ ប្រភពនៃការថ្លែងនោះជាក់ស្ដែងបានកាត់បន្ថយជាអប្បបរមានៃភាពគួរឱ្យជឿទុកចិត្តបាននៃភស្តុតាង ដែរ ឬយ៉ាងណា ដូចបានបញ្ជាក់តាមរយៈពាក្យថា "អាច" ដោយពិចារណាលើកាលៈទេសៈ ប្រភពនៃភស្តុតាង និងប្រភពនៃការជម្រុញទឹកចិត្ត[1127]។

445. ឧទាហរណ៍ជាក់លាក់របស់ ខៀវ សំផន ដែលបានលើកឡើងនោះពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តនូវវិធីសាស្ត្ររបស់ខ្លួនឡើយ។ គាត់ពុំបានបង្ហាញចំណុចជាក់លាក់គ្រប់គ្រាន់នៃ "សុន្ទរកថារបស់គាត់ដែលបានថ្លែងពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមនៅក្នុងពិធីរំឭកខួបក្នុងកម្ពុជាប្រជាធិ

---

[1121] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២។

[1122] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២ យោងទៅលើកថាខណ្ឌ ១៥៥១-១៥៦០។

[1123] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២ យោងទៅលើកថាខណ្ឌ ១១៩៣។

[1124] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២។

[1125] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៨៦។

[1126] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥, ២៨២, ៤៧២, ៤៧៩, ៣៧៤៧។

[1127] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១។

បតេយ្យ”[1128] និងផ្អែកតាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើកថាខណ្ឌដែលបានដកស្រង់នោះ ពុំឃើញមានសុន្ទរកថាដែលគាត់ចង់សំដៅទៅលើ ឬមូលហេតុដូចម្ដេចខ្លះដែលអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើនោះឡើយ។ ពាក់ព័ន្ធទៅនឹងឧទាហរណ៍ទីពីររបស់គាត់ ខៀវ សំផន ត្រឹមតែបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីយល់ឃើញថា ខ្លឹមសារនៃទស្សនាវដ្ដីទង់បដិវត្តខែវិច្ឆិកា ឆ្នាំ ១៩៧៨ មានតម្លៃជាភស្តុតាង បើទោះបីជាត្រូវបានចាត់ទុកថា ជាឧបករណ៍ឃោសនាក៏ដោយ[1129]។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ឧទាហរណ៍នេះហាក់បីដូចជាផ្ទុយគ្នាទៅនឹងការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវាយតម្លៃលើសេចក្ដីថ្លែងការណ៍ដែលបានធ្វើឡើងសម្រាប់គោលបំណងឃោសនានោះថា ពុំអាចជឿទុកចិត្តបាន។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយប្រុងប្រយ័ត្នលើភស្តុតាងដែលមានអត្ថិភាពទាំងអស់ រួមទាំងទស្សនាវដ្ដីទង់បដិវត្ត និងបានឈានដល់ការធ្វើសេចក្ដីសន្និដ្ឋានសមស្របថា “បើទោះបីជាការស្ម័គ្រចិត្តរបស់បុគ្គល គឺជាផ្នែកនៃគោលការណ៍រៀបអាពាហ៍ពិពាហ៍របស់បក្សក៏ដោយ ក៏ជាក់ស្ដែងការយល់ពីរបស់សាមីជនទាំងពីរពុំសូវសំខាន់ដូចការគោរពតាមការណែនាំរបស់អង្គការដែរ”[1130]។ ខៀវ សំផន ពុំបានបង្ហាញនូវកំហុសក្នុងការវាយតម្លៃលើឯកសារឃោសនានេះ។

446. ការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង“បានសំអាងតែទៅលើឯកសារឃោសនាក្នុងការដាក់ពិរុទ្ធ”បង្ហាញឱ្យឃើញនូវលក្ខណៈផ្ទុយគ្នា និងពុំសមហេតុផល ពីព្រោះមានការពិចារណាបានធ្វើឡើងជាងមួយរយទំព័រដោយប្រុងប្រយ័ត្នលើភស្តុតាងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ គាត់ខកខានផងដែរក្នុងការបញ្ជាក់ជាក់លាក់ថា ការដាក់ពិរុទ្ធភាពបានផ្អែកទៅលើការឃោសនា និងត្រឹមតែអះអាងថា អង្គជំនុំជម្រះសាលាដំបូង“បានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន និងថា [...] ការយល់ឃើញនោះត្រូវចាត់ទុកជាមោឃៈ”[1131]។ បន្ថែមលើនេះ សារណានេះពុំបានលើកឧទាហរណ៍ជាក់លាក់អំពីការយល់ឃើញដែលបានសំអាងទៅលើសុន្ទរកថារបស់គាត់ដែលគ្មានការបញ្ជាក់ច្បាស់លាស់ពាក់ព័ន្ធនឹងជនជាតិវៀតណាម និងទង់បដិវត្តខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ នៅក្នុងឧទាហរណ៍ទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូងបាន

---

[1128] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២ ជើងទំព័រ ៤៣៨ យោងទៅលើកថាខណ្ឌ ១៥៥១-១៥៦០។

[1129] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២, ១១៩៣។

[1130] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨។

[1131] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២។

សំអាងទៅលើភស្តុតាងជាច្រើនរួមទាំងការឃោសនា[1132]។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ង. ភស្តុតាងទទួលបានតាមរយៈការធ្វើទារុណកម្ម

447. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “ភស្តុតាងជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មពុំអាចប្រើប្រាស់សម្រាប់បញ្ជាក់ការពិតនៃខ្លឹមសារនោះបានឡើយ”[1133]។ ករណីមានហានិភ័យនៃភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា “ភស្តុតាងនេះត្រូវដកចេញពីកិច្ចដំណើរការនីតិវិធីលើកលែងតែៈ (១) ភាគីបានតវ៉ាសច្ចធារណ៍នេះដោយផ្អែកលើអត្ថិភាពនៃភស្តុតាងដទៃទៀត ឬ (២) ការប្រើប្រាស់ភស្តុតាងនេះគឺជាករណីលើកលែងដូចមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម(“CAT”)[1134]។ យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា ភស្តុតាងដែលពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម អាចទទួលយកបានប្រសិនបើការប្រើប្រាស់នោះពុំបានបំពានលើការហាមឃាត់ការសំអាងទៅលើខ្លឹមសារដើម្បីបញ្ជាក់ការពិត[1135]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់បន្ថែមថា បើទោះបីជាមានហានិភ័យពិតប្រាកដថា ចម្លើយសារភាពនៅមន្ទីរសន្តិសុខក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មក៏ដោយ ក៏ព័ត៌មានជាសត្យានុម័តមួយចំនួនដែលមានក្នុងចម្លើយសារភាពនោះ ពុំមែនជាផ្នែកនៃចម្លើយសារភាពនោះទេ អាស្រ័យហេតុនេះពុំត្រូវដកចេញឡើយ[1136]។ ព័ត៌មានដែលត្រូវអនុញ្ញាតរួមមានអត្តសញ្ញាណ និងកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់អ្នកជាប់ឃុំ ការឃុំឃាំង ឬការកម្ទេចដែលត្រូវបានកត់ត្រាក្នុងអំឡុងពេលចុះឈ្មោះនៅមន្ទីរសន្តិសុខ ឬនៅពេល

---

[1132] ការដាក់ពិរុទ្ធភាពរបស់ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម និងបទប្រល័យពូជសាសន៍ជនជាតិវៀតណាម បានផ្អែកលើប្រភពផ្សេងៗនៃភស្តុតាងក្រៅពីសុន្ទរកថាមិនជាក់លាក់របស់គាត់ និងការឃោសនា។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ទំព័រ ១៧១៤-១៧៤២។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២ ជើងទំព័រ ៤៣៨ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩២ ជើងទំព័រ ៤៣៨ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១៧។

[1133] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤។

[1134] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤។

[1135] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៥។

[1136] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៦។

ចាប់ផ្តើមនៃឯកសារដែលមានចម្លើយសារភាព ប៉ុន្តែពុំមែននៅក្នុងចម្លើយសារភាពនោះខ្លួនឯងទេ[1137]។ មតិចៅក្រម FENZ នៃអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា ភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញព្រឹត្តិការណ៍ជាជាងការពិត ប៉ុន្តែត្រឹមតែដើម្បីបង្ហាញថាតើ មានសកម្មភាពអ្វីខ្លះដែលត្រូវបានធ្វើឡើងជាការឆ្លើយតបទៅនឹងចម្លើយសារភាពនោះ[1138]។

448. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការបកស្រាយរបស់ខ្លួនលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនៅពេលអង្គជំនុំជម្រះបានទទួលយកភស្តុតាងចេញពីសៀវភៅកំណត់ហេតុ ឬបញ្ជីឈ្មោះអ្នកជាប់ឃុំនៃមន្ទីរសន្តិសុខដែលទទួលបាន និងបន្ទាប់មកបានសំអាងទៅលើភស្តុតាងនោះដើម្បីបង្កើតការយល់ឃើញទាក់ទងទៅនឹងការនិរទេសជនជាតិវៀតណាម និងព្រឹត្តិការណ៍ដំបូងនៃការបោសសម្អាតភូមិភាគបូព៌ា[1139]។ គាត់បានអះអាងថា ដោយហេតុថាកំហុសនេះមោឃៈ"ការយល់ឃើញមួយចំនួន"ទាក់ទងទៅនឹង"សញ្ញាណនៃគោលនយោបាយកម្ទេចសត្រូវ"[1140] អង្គជំនុំជម្រះតុលាការកំពូល"ជាចាំបាច់ត្រូវដោះស្រាយបញ្ហានេះដើម្បីសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក. "[1141]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានយល់ឃើញថាការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម អាចធ្វើទៅបានដរាបណាពុំត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ការពិត[1142] ដែលផ្ទុយគ្នាទៅនឹងយុត្តិសាស្ត្រអន្តរជាតិដែលហាមឃាត់ការប្រើប្រាស់ចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្ម[1143]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងដោយពុំត្រឹមត្រូវទៅលើសៀវភៅកំណត់ហេតុ ឬបញ្ជីឈ្មោះអ្នកជាប់ឃុំនៃមន្ទីរសន្តិសុខ និងបានយល់ឃើញថា ឯកសារទាំងនោះដែលមានសេចក្តីសង្កេតរបស់អ្នកធ្វើទារុណកម្ម ត្រូវបានអនុញ្ញាតដរាបណាឯកសារនោះពុំត្រូវបានប្រើប្រាស់ដើម្បីបង្ហាញការពិតនៃចម្លើយសារភាពរបស់ជនរងគ្រោះនៃការ

---

[1137] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៦។

[1138] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៧។

[1139] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៩-២៨៧, ២៨៩-២៩០។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣០-៣១។

[1140] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៣១។

[1141] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៥៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៨៨។

[1142] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៦៣-២៨៧។

[1143] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៦៩។

ធ្វើទារុណកម្ម[1144]។ គាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសៀវភៅកំណត់ហេតុមន្ទីរសន្តិសុខក្រាំងតាចាន់ ដើម្បីបញ្ជាក់បន្ថែមលើការនិរទេសជនជាតិវៀតណាម និងសៀវភៅកំណត់ហេតុរបស់ ពូល ផាលី នៅមន្ទីរ ស-២១ ដើម្បីគាំទ្រការចាប់ខ្លួន និងការសួរយកចម្លើយរបស់ សួស នៅ *ហៅ* ឈូក លេខាតំបន់ ២៤ នៃភូមិភាគបូព៌ា នៅមន្ទីរស-២១ ក្នុងខែ សីហា ដល់កញ្ញា ឆ្នាំ ១៩៧៦[1145] ដូច្នេះការយល់ឃើញផ្អែកលើភស្តុតាងនោះគប្បីបដិសេធចោល[1146]។

449. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងពុំបានពិពណ៌នាគ្រប់គ្រាន់នូវព្យសនកម្មដែលទទួលរង[1147]។ សហព្រះរាជអាជ្ញាបានអះអាងថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មានលក្ខណៈស្របគ្នាជាមួយនឹងគោលបំណងនៃអនុសញ្ញានេះ និងការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា "ព័ត៌មានដែលកើតចេញពីបុគ្គលដែលពុំមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ដូចជា អ្នកធ្វើទារុណកម្ម អាចប្រើប្រាស់បាន"[1148]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវថា យុត្តិសាស្ត្រពុំបានបង្ហាញច្បាស់លាស់ទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មដែលបានប្រព្រឹត្តឡើងដោយផ្ទាល់ដោយបុគ្គលដទៃដែលជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមដែលបង្កើតបានជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពលើជនជាប់ចោទដោយសារការធ្វើទារុណកម្ម[1149]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់តាមរយៈការប្រើប្រាស់សៀវភៅកំណត់ហេតុ និងសៀវភៅកត់ត្រាដែលត្រូវបាន

---

[1144] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៨៩។

[1145] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៥, ២២៧៤។ សៀវភៅកំណត់ត្រាក្រាំងតាចាន់ ឯកសារលេខ E3/5860 ពុំមានកាលបរិច្ឆេទ ERN 00270815-00270816, 00270876, 00270874-00270881, 00270883, 00068026, 00270891, 00270895, 00270896។ សៀវភៅកំណត់ត្រារបស់ ពូល ផាលី នៅមន្ទីរសន្តិសុខ ស-២១ ឯកសារលេខ E3/8368។

[1146] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩០។

[1147] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២០៣-២០៤, ២១៦-២១៨។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ F1/9.1 ទំព័រ ៤៨-៤៩។

[1148] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២០៥-២០៧។

[1149] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២០៩-២១០។

សួរដេញដោល និងថា សៀវភៅទាំងនេះ“គឺជាការសួរយកចម្លើយ ជាជាងចំណារស្តីពីការសួរយកចម្លើយ” [1150]។

450. សហមេធាវីនាំមុខយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[1151]។

451. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ឡើងវិញនូវការសម្រេចពីដំបូងរបស់ខ្លួនថា “លើកលែងករណីពិសេសដែលបានកំណត់ក្នុងប្រយោគទីពីរនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ព័ត៌មានដែលទទួលបានដោយសារលទ្ធផលនៃការធ្វើទារុណកម្ម ពុំអាចទទួលយកបានជាភស្តុតាងនោះទេ”[1152]។ ទាក់ទងទៅនឹងករណីលើកលែងក្នុងមាត្រា ១៥ នោះ ភស្តុតាងអាចទទួលយកបានប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងបង្ហាញនូវអត្ថិភាពនៃចម្លើយសារភាពនោះ[1153]។ គួរកត់សម្គាល់ ករណីលើកលែងនេះអនុវត្តតែក្នុងកាលៈទេសៈដែលបុគ្គលនោះមានលក្ខណៈគ្រប់គ្រាន់“ដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម” ហើយចម្លើយសារភាពនោះត្រឹមតែអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថា បានធ្វើឡើងក្រោយការធ្វើទារុណកម្មប៉ុណ្ណោះ[1154]។

452. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញផងដែរថា ដោយផ្អែកលើគោលបំណងនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម អង្គជំនុំជម្រះតុលាការកំពូលបដិសេធការបកស្រាយណាមួយលើមាត្រា ១៥ ដែលនឹងកាត់បន្ថយអានុភាពដាច់ខាត និងពុំអាចរំលោភបំពានបាននៃការឃាមឃាត់ និងការរាំងការធ្វើទារុណកម្ម [1155] និងថា ករណីលើកលែងនោះគប្បីត្រូវបានបកស្រាយក្នុងន័យរឹតត្បិត[1156]។ ទោះជាយ៉ាងណាក្តី ការបកស្រាយរឹតត្បិតលើមាត្រា ១៥ នេះ ពុំបានតម្រូវឱ្យ“ដកចេញនូវឯកសារទាំងមូលជុំវិញការសួរយកចម្លើយ

[1150] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២១១។

[1151] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៨១-១៨៣។

[1152] សេចក្តីសម្រេចលើការជំទាស់ទៅនឹងបញ្ជីឯកសាររៀបរាប់សំអាងហេតុពេញលេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F26/12 កថាខណ្ឌ ៤៧ (“សេចក្តីសម្រេចលើការជំទាស់ (F26/12)”)។

[1153] មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើបទ្មាបបន្ថោក ឬការដាក់ទណ្ឌកម្ម មហាសន្និបាត សេចក្តីមស្រេចលេខ 39/46 ឯកសារអង្គការសហប្រជាជាតិលេខ A/39/51 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមានថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧។

[1154] អ្នកនិពន្ធ Lene Wendland៖ *កូនសៀវភៅស្តីពីកាតព្វកិច្ចរបស់រដ្ឋក្រោមអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម* (ឆ្នាំ ២០០២) ទំព័រ ៥៦។

[1155] សេចក្តីសម្រេចលើសេចក្តីជំទាស់ កថាខណ្ឌ ៤០។

[1156] សេចក្តីសម្រេចលើសេចក្តីជំទាស់ កថាខណ្ឌ ៦៧។

របស់ជនរងគ្រោះនៃការធ្វើទារុណកម្ម”[1157]។ អាស្រ័យហេតុនេះ ប្រសិនបើកំណត់ត្រាសួរយកចម្លើយមានព័ត៌មានចេញពីបុគ្គលដែលពុំមែនជាជនរងគ្រោះ ឯកសារនេះអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញ“សំណួរដែលត្រូវបានសួរ បុគ្គលដែលមានវត្តមាន ឬអំឡុងពេលនៃព្រឹត្តិការណ៍ និងការធ្វើទារុណកម្មជាពិសេស”[1158]។

453. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្របជាមួយនឹងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា “ភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្មពុំអាចត្រូវបានប្រើប្រាស់សម្រាប់បញ្ជាក់ការពិតនៃខ្លឹមសារនោះឡើយ”[1159]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ភស្តុតាងដែលទទួលបានពីចម្លើយពាក់ព័ន្ធនឹងការធ្វើទារុណកម្ម អាចទទួលយកបានដរាបណាការប្រើប្រាស់នោះពុំបានបំពានលើការហាមឃាត់នូវការសំអាងទៅលើខ្លឹមសារនៃចម្លើយពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្នុងការបញ្ជាក់ការពិត[1160]។ ម្យ៉ាងវិញទៀត កម្រិតនៃការបង្កឱ្យឈឺចាប់អាចបង្កើតចម្លើយមិនពិតចេញពីអ្នកជាប់ឃុំដែលត្រូវបានធ្វើទារុណកម្ម។ ជាឧទាហរណ៍ មានករណីជាច្រើនដែលអ្នកជាប់ឃុំបានសារភាពថា ជាភ្នាក់ងារ CIA, KGB និងវៀតណាម។ ចម្លើយសារភាពនោះអាចត្រូវបានពិចារណាសមហេតុផលថា ជាចម្លើយដែលធ្វើឡើងក្រោមធ្វើទារុណកម្ម ឬការបង្ខិតបង្ខំតាមលក្ខណៈច្រើនសណ្ឋានចេញពីអំពើឃោរឃៅលើរូបកាយ និងការបង្កនូវការឈឺចាប់តាមរយៈការដាក់វំខានការដេកដោយសម្លេងឮៗ ការធ្វើឱ្យភ័យខ្លាច និងការប្រើល្បិចកលគ្រប់គ្រងផ្លូវចិត្ត។ ចម្លើយដែលបានទទួលនោះត្រូវបានប្រើប្រាស់ដោយអាជ្ញាធរដើម្បីបង្ហាញការពិតនៃចម្លើយសារភាពរបស់អ្នកជាប់ឃុំនោះដែលថា គាត់គឺជាភ្នាក់ងារ CIA, KGB ឬ វៀតណាម និងការចាក់ផ្សាយតាមវិទ្យុ។ ចម្លើយសារភាពនោះពុំដែលត្រូវបានប្រើប្រាស់ក្នុងតុលាការនៃច្បាប់ក្នុងការបង្ហាញថា អ្វីដែលជនរងគ្រោះនៃការធ្វើទារុណកម្មបានសារភាពនោះជាការពិតឡើយ។ ទោះជាយ៉ាងណាក្ដី ការពិតដែលថា ជនរងគ្រោះត្រូវបានធ្វើទារុណកម្ម និងបានសារភាពនោះ អាចដឹងបាន និងអាចជាប់ភស្តុតាងពាក់ព័ន្ធនៃការធ្វើបាបលើអ្នកប្រឆាំងនឹងរបបនោះ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា មតិជំទាស់ចៅក្រម FENZ ដែលថា ព័ត៌មានដែលមានក្នុងភស្តុតាងពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញព្រឹត្តិការណ៍ជាជាងការពិតនៃចម្លើយនោះ ប៉ុន្តែត្រឹមតែដើម្បីកំណត់ថាតើ មានសកម្មភាពអ្វីខ្លះដែលកើតចេញពីព្រឹត្តិការណ៍

[1157] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ កថាខណ្ឌ ៦៨។

[1158] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ កថាខណ្ឌ ៦៨។

[1159] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤។

[1160] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៥។

ដែលចម្លើយសារភាពត្រូវបានធ្វើឡើង[1161]។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសអង្គច្បាប់ក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភស្តុតាងដែលកើតចេញពីចម្លើយពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។

454. ជាការឆ្លើយតបទៅនឹងការចោទប្រកាន់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ព័ត៌មានសត្យានុម័តមួយចំនួនដែលមានក្នុងសៀវភៅកំណត់ហេតុ និងបញ្ជីឈ្មោះអ្នកជាប់ឃុំដែលត្រូវបានចុះកាលបរិច្ឆេទ និងអត្តសញ្ញាណអ្នកជាប់ឃុំ និងពុំជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម ពុំស្ថិតក្រោមលក្ខខណ្ឌនៃវិធាននោះ និងអាចទទួលយកបានជាភស្តុតាង រួមទាំងព័ត៌មានដែលកើតចេញពីបុគ្គលដែលពុំមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម[1162]។ ដូចគ្នាដែរ រូបថតរបស់អ្នកជាប់ឃុំដែលចូលមន្ទីរស-២១ អាចអនុញ្ញាតធ្វើជាភស្តុតាងដោយសារនេះជារូបថតនៃកំណត់ត្រា និងពុំមែនជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មឡើយ។ ព័ត៌មានដូចជាជីវប្រវត្តិរបស់ជនរងគ្រោះ៖ឈ្មោះ អាយុ ទីលំនៅ មុខរបរពីមុន និងសេចក្តីលម្អិតដទៃទៀត អាចត្រូវបានដកចេញប្រសិនបើទុកក្នុងចម្លើយសារភាពអាចចាត់ទុកថា ទទួលបានតាមរយៈការបង្ខិតបង្ខំ[1163]។ បន្ទាប់ពីបានពិនិត្យលើការចោទប្រកាន់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសៀវភៅកំណត់ហេតុក្រាំងតាចាន់[1164] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ប្រយោគតូចមួយដែលថា“ក្នុងខែ មករា ឆ្នាំ ១៩៧៦ អង្គការបានប្រមូលផ្តុំយួន និងបានបញ្ជូនត្រឡប់ទៅវៀតណាមវិញ” ត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់បន្ថែមលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ហើយគ្មានព័ត៌មានស្តីពីជីវប្រវត្តិរបស់អ្នកជាប់ឃុំឡើយ[1165]។ នេះពុំមែនជាព័ត៌មានដែលទទួលបានពីអ្នកជាប់ឃុំ ប៉ុន្តែគឺជាការបង្ហាញនូវការពិតដែលបានកត់ត្រាផ្លូវការរបស់អ្នកជាប់ឃុំ។ អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសនៅក្នុងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវសៀវភៅកំណត់ហេតុក្រាំងតាចាន់សម្រាប់ការបញ្ជាក់បន្ថែម និងអំណះអំណាងនេះត្រូវបដិសេធ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសំដៅរបស់ ខៀវ សំផន ទៅលើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសៀវភៅ

[1161] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៧។

[1162] សេចក្តីសម្រេចលើសេចក្តីជំទាស់ កថាខណ្ឌ ៦៨។

[1163] សេចក្តីសម្រេចលើសេចក្តីជំទាស់ កថាខណ្ឌ ៦៨។

[1164] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៥។

[1165] សៀវភៅកំណត់ត្រាក្រាំងតាចាន់ ឯកសារលេខ E3/5827 ពុំមានកាលបរិច្ឆេទ ទំព័រ ៥-៦ ERN 00270859-00270860 ។

កំណត់ហេតុរបស់ ពូល ផាលី នៅមន្ទីរស-២១ ក្នុងការដោះស្រាយការចាប់ខ្លួន សួស នៅ ដែលជាលេខាតំបន់ ២៤ នៃភូមិភាគបូព៌ា[1166] ខកខានក្នុងការបំពេញតាមបទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ។ ត្រឹមតែការចោទប្រកាន់កំហុសដែលពុំបានបង្ហាញនូវផលប៉ះពាល់លើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជាទូទៅពុំអាចទទួលយកបានសម្រាប់ការពិនិត្យបណ្ដឹងសាទុក្ខលើអង្គសេចក្ដី[1167]។ យោងតាមហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយដែលតម្រូវឱ្យមានការចូលអន្តរាគមន៍លើបណ្ដឹងសាទុក្ខនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ដូច្នេះបដិសេធអំណះអំណាងនេះ។

## ច. ភស្តុតាងរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី

### i. ចម្លើយជាលាយលក្ខណ៍អក្សររបស់សាមីជនដែលពុំបានមកផ្ដល់សក្ខីកម្ម

455. នៅក្នុងការគូសបញ្ជាក់អំពីវិធីសាស្ត្រក្នុងការវាយតម្លៃលើភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ភស្តុតាងអាចត្រូវផ្ដល់ទម្ងន់តិចតួច កាលណាបើប្រភព ឬសាមីជនពុំត្រូវបានសួរដេញដោល[1168]។ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថា ចម្លើយដែលត្រូវបានធ្វើឡើងក្រៅក្របខ័ណ្ឌនីតិវិធីតាមផ្លូវតុលាការរួមទាំងចម្លើយពីមជ្ឈមណ្ឌល DC-Cam និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មានតម្លៃជាភស្តុតាងទាប[1169]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា មូលហេតុនឹងត្រូវបានពន្យល់ ប្រសិនបើការយល់ឃើញណាមួយបានផ្អែកក្នុងផ្នែកខ្លះលើចម្លើយនោះ[1170]។ នៅពេលសួរដេញដោលអំពីភាពត្រឹមត្រូវនៃចម្លើយរបស់សាក្សី អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើការបញ្ជាក់បន្ថែមដោយភស្តុតាងដទៃទៀត និងលក្ខណៈនៃភស្តុតាងនោះ[1171]។

---

[1166] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩០ និងជើងទំព័រ ៤៣៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៧៤។ សៀវភៅកំណត់ត្រារបស់ ពូល ផាលី នៅមន្ទីរសន្តិសុខ ស-២១ ឯកសារលេខ E3/8368។

[1167] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៦៤។

[1168] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

[1169] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

[1170] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

[1171] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

456. យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារអនុវត្ត “ក្របខ័ណ្ឌគតិយុត្តដែលរំលោភបំពានលើគោលការណ៍ដេញដោលចំពោះមុខ” ទៅលើតម្លៃជាភស្តុតាងនៃចម្លើយជាលាយលក្ខណ៍អក្សររបស់សាមីជនដែលពុំអាចមកផ្តល់សក្ខីកម្មបាន[1172]ចំពោះមុខអង្គជំនុំជម្រះ តាមរយៈ៖ (១) ការសំអាងតែទៅលើចម្លើយនោះទាក់ទងទៅនឹងសកម្មភាព និងអំពើរបស់ជនជាប់ចោទ[1173] (២) ការប្រើប្រាស់ចម្លើយនោះជំនួសសក្ខីកម្មផ្ទាល់មាត់[1174] ដែលបណ្តាលឱ្យមានកំហុសដដែលៗក្នុងសំណុំរឿង ០០២/០១ និង ០០២/០២[1175]។

457. ដំបូង គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្ត“ដោយឥតសមគួរ និងក្នុងន័យទូលំទូលាយ” នូវក្របខ័ណ្ឌគតិយុត្តស្តីពីតម្លៃជាភស្តុតាងនៃចម្លើយជាលាយលក្ខណ៍អក្សរដោយបានផ្អែកការដាក់ពិរុទ្ធភាព គ្មានការផ្តល់សំអាងហេតុរឹងមាំ និងគ្មានការបញ្ជាក់ថា សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីបានពុំបានផ្តល់សក្ខីកម្មក្នុងតុលាការឡើយ[1176]។ ទីពីរ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានផ្អែកការដាក់ពិរុទ្ធភាពលើភស្តុតាងដែលពុំបានសួរដេញដោលទាក់ ទងទៅនឹងសកម្មភាព និងអំពើរបស់ជនជាប់ចោទ “[...] ដោយគ្មានការថ្លឹងថ្លែងតាមរយៈគោលការណ៍សួរដេញដោលចំពោះមុខ”[1177]។ គាត់បានទិតៀនភាពត្រឹមត្រូវនៃវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលដែលអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលពុំត្រូវបានសួរដេញដោល ថានេះជាការអនុវត្តន៍ផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ដែលបានសង្កត់ធ្ងន់ជាដរាបលើសារៈសំខាន់នៃកិច្ចដំណើរការនីតិវិធីផ្ទាល់មាត់ និងតម្រូវការចាំបាច់ក្នុងការពារសិទ្ធិរបស់ជនជាប់ចោទ[1178]។ គាត់បានចោទប្រកាន់ថា គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើចម្លើយជាលាយលក្ខណ៍អក្សរដែលពុំត្រូវបានសួរដេញដោល ដែលបានរំលោភបំពានលើសិទ្ធិនៃនីតិវិធី និងបណ្តាលឱ្យមានភាពមិនយុត្តិធម៌[1179]។ គាត់បានយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងចំនួនប្រាំចំណុចដែលត្រូវបានចោទប្រកាន់ថាបានផ្អែកតែលើចម្លើយដែលពុំត្រូវបានសួរដេញដោល មានដូចជា៖ (១) អំពើមនុស្សឃាតក្នុងមន្ទីរសន្តិសុខភ្នំក្រោលទាក់ទងទៅនឹងការស្លាប់អ្នកជាប់ឃុំពីរនាក់ឈ្មោះ ហ៊ើស

---

[1172] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៣-២៩៥។

[1173] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៦-៣០០។

[1174] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០១-៣០២។

[1175] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៣-៣០៥។

[1176] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៣-២៩៥។

[1177] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៦-៣០០។

[1178] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៩។

[1179] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០០។

និង ទូច[1180] (២) អំពើមនុស្សឃាត និងការសម្លាប់រង្គាលទាក់ទងទៅនឹងការកម្ទេចជនជាតិវៀតណាមប្រាំមួយនាក់[1181] (៣) ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន[1182] (៤) ការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការអនុវត្តន៍គោលនយោបាយស្ដីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍[1183] និង (៥) ការនិរទេសជនជាតិវៀតណាមពីភូមិអន្លង់ទ្រា[1184]។

458. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងវិធីសាស្ត្រទូទៅចំពោះភស្តុតាងជាលាយលក្ខណ៍អក្សរ និងថាអង្គជំនុំជម្រះបានដោះស្រាយច្បាស់លាស់លើបញ្ហាទាក់ទងទៅនឹងចម្លើយក្រៅតុលាការបន្ទាប់ពីផ្ដល់ឱកាសឱ្យភាគីធ្វើការជំទាស់ទៅនឹងភស្តុតាង[1185]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងខកខានក្នុងការបង្ហាញនូវព្យសនកម្មដោយសារបទដ្ឋានតម្រូវនៃបណ្ដឹងសាទុក្ខនោះ[1186]។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា គាត់បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវនៃការវាយតម្លៃរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើចម្លើយជាលាយលក្ខណ៍អក្សរក្នុងសំណុំរឿង ០០២/០១[1187]។ ពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌគតិយុត្ត ដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលសម្រាប់ការវាយតម្លៃលើភស្តុតាងជាលាយលក្ខណ៍អក្សរ ជាពិសេសចម្លើយក្រៅតុលាការ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ត្រឹមតែមិនយល់ស្របជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និងហាក់បីដូចជាស្នើសុំឱ្យពិចារណាឡើងវិញដោយគ្មានការបំពេញតាម

[1180] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៣-៨៧៣។

[1181] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤២-៨៤៧។

[1182] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៩-៩១០។

[1183] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤។

[1184] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤ និងជើងទំព័រ ៤៦៨, ៤៦៩ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨០-៧១៨។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣០។

[1185] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២២-២២៣។

[1186] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២១។

[1187] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២៤។

លក្ខខណ្ឌតម្រូវនៃបទដ្ឋាន[1188]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការដាក់ពិរុទ្ធភាពណាមួយត្រូវបានផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរដោយគ្មានការសួរដេញដោលគ្រប់គ្រាន់នោះឡើយ[1189]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ក្តីបារម្ភរបស់ ខៀវ សំផន អំពីការសំអាងទៅលើភស្តុតាងដែលពុំត្រូវបានសួរដេញដោល ពុំមានមូលដ្ឋានគ្រប់គ្រាន់តាមរយៈការប្រើប្រាស់"វិធីសាស្ត្រជំទាស់តាមផ្នែកដោយយោងទៅលើកថាខណ្ឌនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង" [1190]។

459. សហមេធាវីនាំមុខបានគាំទ្រសារណាតបរបស់សហព្រះរាជអាជ្ញា[1191] និងបានលើកឡើងថា រឿងក្តីយុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរដោយមានការធានាផ្លូវច្បាប់[1192]។ សហមេធាវីនាំមុខបានអះអាងថា នៅពេលសវនាការដែលមានភស្តុតាងជាប់ពាក់ព័ន្ធត្រូវបានលើកឡើង ភាគីមានឱកាសស្នើសុំឱ្យដាក់ចម្លើយជាលាយលក្ខណ៍អក្សរធ្វើការសួរដេញដោល។ ដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ត្រឹមត្រូវនូវក្របខ័ណ្ឌគតិយុត្តជាធរមាន[1193]។

460. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានលើកបញ្ហាពីរសំខាន់ថាតើ អង្គជំនុំជម្រះសាលាដំបូង (១) បានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវក្នុងការវាយតម្លៃលើចម្លើយជាលាយលក្ខណ៍អក្សររបស់សាមីជនដែលពុំអាចមកផ្តល់សក្ខីកម្ម និង (២) កំហុសក្នុងការវាយតម្លៃ និងការសំអាងទៅលើចម្លើយជាលាយលក្ខណ៍អក្សរក្នុងការដាក់ពិរុទ្ធភាពគាត់ ដែរ ឬយ៉ាងណា។ បញ្ហានេះនឹងត្រូវដោះស្រាយបន្តបន្ទាប់ខាងក្រោម។

461. អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហាទីមួយរបស់ ខៀវ សំផន ឃើញថា ជាការជំទាស់ទៅនឹងក្របខ័ណ្ឌគតិយុត្តរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតាមការអះអាងរបស់គាត់ថា បានបណ្តាលឱ្យមានការដាក់ពិរុទ្ធភាពដែលផ្អែកតែមួយមុខ ឬជាសំខាន់លើភស្តុតាងដែលពុំត្រូវបានសួរដេញដោល[1194]។

---

[1188] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២១, ២២៦។

[1189] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២៧, ២២៩-២៣០។

[1190] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២២៩-២៣០។

[1191] *សូមមើល* សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៨១-១៨៣, ២៤០-២៤១។

[1192] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២២៩-២៣១។

[1193] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៣៣-២៣៩។

[1194] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៧, ៣០០, ៣០២, ៣០៥, ៨៤៣។

462. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា តាមវិធានទូទៅ ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដូចជាសាមីជនដែលពុំបានចូលមកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានសួរដេញ ដោលក្នុងតុលាការត្រូវបានផ្តល់តម្លៃតិចតួច[1195]។ ចម្លើយក្រៅតុលាការដែលបានទទួលក្រៅក្របខ័ណ្ឌនីតិវិធីតាមផ្លូវតុលាការ ដូចជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍ អត្ថបទកាសែត ត្រូវផ្តល់តម្លៃជាភស្តុតាងទាប[1196]។ បើកាលណាអង្គជំនុំជម្រះសំអាងទៅលើភស្តុតាងទាំងនេះ អង្គជំនុំជម្រះមានបន្ទុកក្នុងការផ្តល់ការពន្យល់អំពីកាលៈទេសៈដែលអាចឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានផ្នែកអង្គហេតុដោយផ្អែកទៅលើភស្តុតាងនោះ ដែលការធ្វើដូច្នេះមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់កំណត់អំពីបញ្ហាថាតើការសន្និដ្ឋាននោះត្រូវបានធ្វើឡើងដោយសមហេតុផល ដែរ ឬយ៉ាងណា[1197]។

463. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់តម្លៃជាភស្តុតាងទាបនៃចម្លើយជាលាយលក្ខណ៍អក្សររបស់សាមីជនដែលពុំបានមកផ្តល់សក្ខីកម្មក្នុងតុលាការ៖

> អង្គជំនុំជម្រះបានទទួលយកបន្ថែមទៀតនូវចម្លើយរបស់បុគ្គលដែលបានទទួលមរណភាពឬលើសពីនេះរបស់សាក្សីដែលពុំបានចូលខ្លួនមកផ្តល់សក្ខីកម្ម រួមទាំងសម្រាប់គោលបំណងនៃការបង្ហាញនូវសកម្មភាព និងអំពើរបស់ជនជាប់ចោទ និងទោះជាយ៉ាងណាក្តីបានកត់សម្គាល់ថា ចម្លើយទាំងនេះមានតម្លៃជាភស្តុតាងតិចតួច និងថា ការដាក់ពិរុទ្ធភាពពុំអាចត្រូវបានផ្អែកតែមួយមុខ ឬជាសំខាន់លើចម្លើយនេះទេ។ បើទោះបីជាចម្លើយនេះមានតម្លៃជាភស្តុតាងទាបជាងសក្ខីកម្មរបស់សាក្សីដែលបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏នៅតែជាប្រភពសំខាន់នៃភស្តុតាងជាពិសេសនៅពេលដែលចម្លើយនោះបានទទួលតាមរយៈស្ថាប័នតុលាការ[1198]។

អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងវិធីសាស្ត្រខាងលើនេះ និងកត់សម្គាល់ថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងបានឆ្លុះបញ្ចាំងច្បាស់លាស់ថា "ករណីដែលការយល់ឃើញបានផ្អែកក្នុងផ្នែកខ្លះលើចម្លើយនោះ សំអាងហេតុសម្រាប់ការយល់ឃើញត្រូវតែបានពន្យល់ច្បាស់លាស់ ជាពិសេស ក្នុងករណីដែលការដាក់ពិរុទ្ធភាពបានផ្អែកទាំងស្រុង ឬជាសំខាន់ទៅលើភស្តុតាងនោះ"[1199]។ អង្គជំនុំជម្រះសាលា

[1195] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[1196] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[1197] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០។

[1198] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[1199] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

ដំបូងបានពិចារណាច្បាស់លាស់លើលក្ខខណ្ឌតម្រូវក្នុងការប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវចម្លើយក្រៅតុលាការ និងបានគូសបង្ហាញនីតិវិធីនៅពេលសំអាងទៅលើចម្លើយជាលាយលក្ខណ៍អក្សរដែលពុំត្រូវបានសួរដេញដោល។ បើកាលណាការយល់ឃើញបានសំអាងតែទៅលើចម្លើយនេះ អង្គជំនុំជម្រះត្រូវពន្យល់នូវកាលៈទេសៈដែលផ្តល់យុត្តិកម្មលើករណីលើកលែងចំពោះវិធានទូទៅ។

464. ក្នុងការគាំទ្រអំណះអំណាងរបស់គាត់ដែលថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង"បានរំលោភបំពានលើគោលការណ៍សួរដេញដោលចំពោះមុខ" ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការ"ផ្តល់សំអាងហេតុរឹងមាំដល់សេចក្តីសម្រេចរបស់ខ្លួន និងជូនកាល [...] ត្រឹមតែបង្ហាញថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនោះពុំត្រូវបានស្តាប់ក្នុងតុលាការ"[1200]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ពុំតម្រូវឱ្យផ្តល់សំអាងហេតុសម្រាប់ការវាយតម្លៃលើផ្នែកនីមួយៗនៃភស្តុតាងឡើយ[1201] និងជាក់ស្តែងពុំអាចអនុវត្តបាន។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសជារួមនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាងដែលពុំត្រូវបានសួរដេញដោល។ ទោះជាយ៉ាងណាក្តី ការជំទាស់នេះបានប្រាប់អង្គជំនុំជម្រះតុលាការកំពូលអំពីលទ្ធភាពនៃកំហុសផ្នែកអង្គហេតុទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុជាក់លាក់។

465. អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃតាមរយៈការសង្កេតឃើញថា បទដ្ឋានអន្តរជាតិទទួលស្គាល់វិធានដែលល្អប្រសើរបំផុតស្តីពីភស្តុតាងត្រង់ថា ភស្តុតាងរបស់សាក្សីដែលដាក់ឱ្យសួរដេញដោលនោះ មានលក្ខណៈល្អប្រសើរជាងការដាក់ចម្លើយដែលពុំត្រូវបានសួរដេញដោល។ នេះគឺជាសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវដែលត្រូវបានធានាក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងកម្ពុជាតាមរយៈការអនុម័តតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ICCPR") [1202]។ ខៀវ សំផន ទំនងជាជំទាស់ទៅនឹងគោលជំហររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ស្តីពីបញ្ហានេះ និងបានទិតៀននូវអ្វីដែលគាត់ហៅថា *ការសម្រេចអនុញ្ញាតឱ្យការប្រើប្រាស់ភស្តុតាងដែលពុំត្រូវបានសួរដេញដោល*[1203] ដែលតាមការលើកឡើងរបស់គាត់ថា ផ្ទុយទៅនឹងសេចក្តីសម្រេចរបស់តុលាការ ICTY

---

[1200] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៥-៣០០។

[1201] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៧ និងជើងទំព័រ ៧១៨។

[1202] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយចូលជាធរមានថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ 999 U.N.T.S. 171 និង 1057 U.N.T.S. 407។

[1203] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៩។

និង ICC[1204]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ពុំបានបង្កើតបទដ្ឋានសម្រាប់ការទទួលយកភស្តុតាងដែលពុំត្រូវបានសួរដេញដោល ដូចក្នុងវិធាន ៦៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC និងវិធាន ៩២*ស្ទួន* នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY នោះទេ។ អាស្រ័យហេតុនេះ ការសម្រេចក្នុងរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Bemba* ដែលអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICC បានរកឃើញកំហុសក្នុងការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC នូវ"ចម្លើយដែលត្រូវបានធ្វើកំណត់ត្រាពីមុនទាំងអស់ ដោយគ្មានការវិភាគលើចម្លើយនីមួយៗដោយប្រុងប្រយ័ត្ន"[1205] និងការកំណត់របស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* ទាក់ទងទៅនឹងការទទួលយកភស្តុតាងដោយគ្មានការសួរដេញដោលស្របតាមវិធាន ៩២*ស្ទួន*នៃវិធានរបស់តុលាការ ICTY[1206] ពុំអាចអនុវត្តបានចំពោះរឿងក្តីបច្ចុប្បន្នឡើយ។

466. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់ភស្តុតាងដែលពុំត្រូវបានសួរដេញដោលដើម្បីដាក់ពិរុទ្ធភាព ដរាបណាមានកត្តាថ្លឹងថ្លែងគ្រប់គ្រាន់នៃភស្តុតាងនោះ។ នេះស្របតាមបទដ្ឋានប្រព័ន្ធច្បាប់អង់គ្លេសាក់សុងស្តីពីភស្តុតាងដែលបានវិវឌ្ឍអស់រយៈពេលជាច្រើនសតវត្សរ៍ និងបានឆ្លុះបញ្ចាំងក្នុងអនុសញ្ញានានាស្តីពីសិទ្ធិមនុស្ស។ ប្រភពនៃចម្លើយ និងកាលៈទេសៈជុំវិញការបង្កើតនោះមានសារៈសំខាន់។ នេះត្រូវតែបានពិចារណាថាតើ ជាការបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬថាតើ មានទំនាស់ផលប្រយោជន៍ និងថាតើ មានហេតុផលសមស្របដែលសាមីខ្លួនពុំអាចមកផ្តល់សក្ខីកម្មក្នុងតុលាការក្នុងការបញ្ជាក់ការពិតនៃខ្លឹមសារ ដែរ ឬយ៉ាងណា។ ចម្លើយនេះត្រូវតែបានពិនិត្យដោយផ្អែកលើខ្លឹមសារនៃភស្តុតាងដទៃទៀតសម្រាប់ភាពស៊ីសង្វាក់គ្នា នៅពេលថ្លឹងថ្លែងលើតម្លៃជាភស្តុតាងដែលត្រូវផ្តល់ទៅឱ្យតាមករណីជាក់ស្តែង។ ជាឧទាហរណ៍ ការពិភាក្សាបន្ថែមទៀតអាចតម្រូវឱ្យធ្វើឡើង ប្រសិនណាបើសាក្សីដទៃទៀតបានផ្តល់ភស្តុតាងប្រហាក់ប្រហែលគ្នានោះ។ ទាំងអស់នេះគឺជាបញ្ហាសំខាន់ក្នុងការពិចារណានៅពេលដែលអង្គជំនុំជម្រះធ្វើការថ្លឹងថ្លែងលើតម្លៃជាភស្តុតាងដែលពុំត្រូវបានសួរដេញដោល។

---

[1204] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៩។

[1205] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/05-01/08 សាលដីកានៃបណ្តឹងសាទុក្ខរបស់លោក Jean-Pierre Bemba Gombo និង អយ្យការទល់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង III ចំណងជើងថា "សេចក្តីសម្រេចលើការទទួលយកធ្វើជាភស្តុតាងនូវឯកសារដែលមានក្នុងបញ្ជីភស្តុតាងរបស់អយ្យការ"ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៧៨-៨១។

[1206] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ IRMCT-13-55-A សាលដីកា ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ កថាខណ្ឌ ១៦២។

467. ទាក់ទងទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដាក់ពិរុទ្ធភាពលើគាត់ដោយផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរ "ដោយគ្មានការយកចិត្តទុកដាក់ផ្តល់សំអាងហេតុរឹងមាំដល់សេចក្តីសម្រេចរបស់ខ្លួន"[1207] ដូចបានកំណត់ខាងលើ ក្តីបារម្ភទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងអំពីតម្លៃជាភស្តុតាងនៃភស្តុតាងក្រៅតុលាការ ត្រូវបានឆ្លុះបញ្ចាំងក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ គួរកត់សម្គាល់ថា ការជំទាស់របស់ ខៀវ សំផន ដែលថា ចម្លើយជាលាយលក្ខណ៍អក្សរ ដោយគ្មានឱកាសសួរដេញដោលមានតម្លៃជាភស្តុតាងតិចតួច និងពុំអាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់សកម្មភាព និងអំពើរបស់ជនជាប់ចោទបានទេ[1208]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកបន្ថែមទៀតថា៖

> ចម្លើយដែលធ្វើឡើងក្រៅក្របខ័ណ្ឌនីតិវិធីរបស់តុលាការ [...] មានតម្លៃជាភស្តុតាងទាបដោយខ្លួនឯង។ នៅពេលការយល់ឃើញបានសំអាងក្នុងផ្នែកខ្លះលើចម្លើយនេះ សំអាងហេតុសម្រាប់ការយល់ឃើញត្រូវតែបានពន្យល់ច្បាស់លាស់ [...]។ ក្នុងការសួរដេញដោលភាពត្រឹមត្រូវនៃចម្លើយរបស់សាក្សី អង្គជំនុំជម្រះអាចពិចារណាលើបញ្ហាថាតើ ចម្លើយនោះត្រូវបានបញ្ជាក់បន្ថែមពីភស្តុតាងដទៃទៀត ដែរ ឬយ៉ាងណា និងប្រសិនបើមាន ត្រូវពិចារណាលើលក្ខណៈនៃភស្តុតាងនោះ។ អង្គជំនុំជម្រះអាចពិចារណាថាតើ ចម្លើយមុនៗរបស់សាក្សីមានលក្ខណៈស៊ីសង្វាក់គ្នាទៅវិញទៅមក និងថាតើ ភាពមិនស៊ីសង្វាក់គ្នានេះត្រូវបានពន្យល់គ្រប់គ្រាន់ ដែរ ឬយ៉ាងណា[1209]។

468. នេះគឺជាបរិបទទូទៅសម្រាប់ការយល់ឃើញដែលបានបង្កើតឡើងទាក់ទងទៅនឹងការស្លាប់មនុស្សពីរនាក់នៅមន្ទីរឃុំឃាំងភ្នំក្រោល៖ អ្នកជាប់ឃុំឈ្មោះ "ហ៊ើស" ដែលត្រូវបានធ្វើបាប និងសម្លាប់ដោយសន្តិសុខមន្ទីរឃុំឃាំងនោះ ហើយអ្នកជាប់ឃុំម្នាក់ទៀតឈ្មោះ "ទូច" ដែលបានស្លាប់ដោយសារលក្ខខណ្ឌដែលគាត់បានទទួលរង[1210]។ ការដាក់ពិរុទ្ធលើ ខៀវ សំផន ពីបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល បានផ្អែកតែទៅលើអង្គហេតុទាំងនេះប៉ុណ្ណោះ[1211]។

---

[1207] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០២។

[1208] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៨ និងជើងទំព័រ ១៧០ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៥២៥-៥៣៥, ៥៤១-៥៥១។

[1209] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩។

[1210] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១០, ៣១១៥-៣១១៧។

[1211] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥-៣១១៧។

469. អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហាថាតើ ចម្លើយជាលាយលក្ខណ៍អក្សរដែលពុំត្រូវបានសួរដេញដោលនោះ គឺជាភស្តុតាងតែមួយដែលនាំទៅដល់ការយល់ឃើញស្តីពីពិរុទ្ធភាពសម្រាប់ការស្លាប់របស់ ហ៊ើស និង ទូច នៅក្នុងសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា ប្រសិនបើដូច្នេះមែន តើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុដល់ការយល់ឃើញនោះ ដែរ ឬទេ។ អង្គជំនុំជម្រះតុលាការកំពូលតក់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ួង ដុស និង សុខ អ៊ែល[1212] នៅពេលពិចារណាលើការស្លាប់របស់ ហ៊ើស និងបានបង្ហាញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗបានបញ្ជាក់បន្ថែមទៅវិញទៅមកលើ“ទិដ្ឋភាពសំខាន់ៗនៃហេតុការណ៍ រួមទាំងអត្តសញ្ញាណរបស់ជនរងគ្រោះ លក្ខណៈនៃការវាយប្រហារ លក្ខខណ្ឌនៃការស្លាប់ និងចំណាត់ការក្រោយមកលើសាកសពនោះ”[1213]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អ៊ួង ដុស និង សុខ អ៊ែល បានឃើញផ្ទាល់ភ្នែកនូវការវាយប្រហារដូចគ្នា និងបានយល់ឃើញថា ការរៀបរាប់របស់ពួកគាត់គួរជឿទុកចិត្តបាន[1214]។ ទាក់ទងទៅនឹងហេតុការណ៍នៃការស្លាប់របស់“ទូច” អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ សុខ អ៊ែល[1215]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងអាចជឿទុកចិត្តបាន និងធ្វើជាតំណាងនៃលំនាំការធ្វើបាបនៅមន្ទីរឃុំឃាំងភ្នំក្រោល[1216]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើធាតុផ្សំសត្យានុម័ត និងអត្តនោម័តិក្នុងការបង្ហាញអំពើមនុស្សឃាតផ្អែកលើមូលដ្ឋាននេះ[1217]។

470. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងការពិនិត្យលើភស្តុតាងចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា “ដោយសារពុំមានភស្តុតាងគ្រប់គ្រាន់ទាក់ទងទៅនឹងការសម្លាប់នៅត្រពាំងព្រីង អង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានបានថា ទីនោះគឺជាទីតាំងសម្លាប់មនុស្សឡើយ”[1218]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតនៅភ្នំក្រោលពាក់ព័ន្ធទៅនឹងការស្លាប់អ្នកជាប់ឃុំឈ្មោះ ហ៊ើស និង ទូច បានផ្អែកតែទៅលើកំណត់ហេតុស្តាប់ចម្លើយ

---

[1212] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០, ៣១១០។

[1213] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០។

[1214] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០, ៣១១៥។

[1215] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០១។

[1216] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០១, ៣១១៦។

[1217] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥, ៣១០២, ៣១១៦ និងជើងទំព័រ ១០៥២២។

[1218] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៤។

ចំនួនពីររបស់ អ្នង ដុស និង សុខ អ៊ែល ដែលត្រូវបានបញ្ជាក់បន្ថែមដោយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗរបស់ពួកគាត់[1219]។ បើទោះបីជាការទទួលស្គាល់ជាទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងថា ភស្តុតាងនេះមានតម្លៃជាភស្តុតាងទាបដោយខ្លួនឯងក៏ដោយ ក៏អង្គជំនុំជម្រះបានពន្យល់ថា ការរៀបរាប់របស់ អ្នង ដុស និង សុខ អ៊ែល ត្រូវបានបញ្ជាក់បន្ថែមដោយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗរបស់ពួកគាត់ និងមាន"ទិដ្ឋភាពនៃហេតុការណ៍ រួមទាំងអត្តសញ្ញាណរបស់ជនរងគ្រោះ លក្ខណៈនៃការវាយប្រហារ លក្ខខណ្ឌនៃការស្លាប់ និងចំណាត់ការក្រោយមកលើសាកសព"[1220]។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការរៀបរាប់ទាំងនេះបានបង្ហាញអត្ថិភាពនៃភស្តុតាងផ្ទាល់ជាក់លាក់នៃការសម្លាប់នៅមន្ទីរសន្តិសុខភ្នំក្រោលក៏ដោយ ក៏ អ្នង ដុស និង សុខ អ៊ែល ដែលបានមរណភាពនោះពុំដែលបានមកផ្តល់សក្ខីកម្មក្នុងតុលាការដែរ និងក្នុងករណីគ្មានភស្តុតាងដទៃទៀត ចម្លើយជាលាយលក្ខណ៍អក្សរដែលត្រូវបានបញ្ជាក់បន្ថែមដោយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេតែមួយមុខនោះ ពុំអាចបង្ហាញអំពើមនុស្សឃាតហួសពីវិមតិសង្ស័យបានឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្លាប់អ្នកជាប់ឃុំ ហ៊ើស និង ទូច នៅភ្នំក្រោល ពុំអាចត្រូវបានបង្ហាញសមហេតុផលតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានបង្ហាញភស្តុតាងឡើយ។

471. ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ផ្ទុយទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដាក់ពិរុទ្ធគាត់ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតលើជនជាតិវៀតណាមប្រាំមួយនាក់ ដោយផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរមួយដែលគ្មានមូលដ្ឋានគ្រប់គ្រាន់[1221] សាក្សី ឆោម សែ បានផ្តល់សក្ខីកម្មក្នុងតុលាការក្នុងសំណុំរឿង ០០២/០១ អស់រយៈពេលពីរថ្ងៃ និងបានផ្តល់ភស្តុតាងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់។ ជាពិសេស គាត់បានផ្តល់សក្ខីកម្មថា "ទាក់ទងទៅនឹងក្រុមមនុស្សប្រាំមួយនាក់នោះ ខ្ញុំបានទទួលបញ្ជាពី សៅ សារឿន ឱ្យកម្ទេចពួកគេ"[1222]។ បើទោះបីជាគាត់ពុំបានលើកឡើងជាក់លាក់អំពីជនជាតិ

[1219] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០-៣១០១, ៣១១៥-៣១១៦។

[1220] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០។

[1221] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២៩៥ និងជើងទំព័រ ៤៤៤ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤២-៨៤៧។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០២ និងជើងទំព័រ ៤៦១ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤២-៨៤៧, ១០៥៥។

[1222] ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៥។

វៀតណាមក្នុងសក្ខីកម្មរបស់គាត់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានប្រៀបធៀបចម្លើយរបស់គាត់ក្នុងកំណត់ហេតុស្តាប់ចម្លើយ និងសក្ខីកម្មក្នុងតុលាការមុនពេលធ្វើការកំណត់ថា គាត់បានផ្តល់"ចម្លើយស៊ីសង្វាក់គ្នា"អំពីការកម្ទេចមនុស្សប្រាំមួយនាក់នោះដែរ[1223]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ឆោម សែ បានសំដៅទៅលើ"ក្រុមតែមួយនៃជនជាតិវៀតណាមដែលត្រូវបានសំដៅទៅលើនៅក្នុងចម្លើយរបស់គាត់ថា បាន'កម្ទេចពួកគេ'តាមបញ្ជារបស់មេបញ្ជាការកងពលលេខ ៨០១"[1224]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ឆោម សែ និងសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/០១ ក្នុងកាបង្ហាញថា ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានសម្លាប់នៅអូរកន្សែង[1225]។

472. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានបំភ្លៃសាលក្រមអង្គជំនុំជម្រះដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដាក់ពិរុទ្ធភាពលើគាត់ពីបទឧក្រិដ្ឋនៃការនិរទេសជនជាតិវៀតណាមចេញពីភូមិអន្លង់ទ្រា ដោយផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរពីរប៉ុណ្ណោះ[1226]។ ការបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមពីភូមិអន្លង់ទ្រា បានផ្អែកទៅលើសក្ខីកម្មរបស់ សៅ សាក់ និងចម្លើយរបស់ ឯម ប៊ុនធីម នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[1227]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដែលត្រូវបានបញ្ជាក់បន្ថែម ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល[1228]
។

[1223] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៥។ ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ១៣។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆោម សែ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E3/405 ទំព័រ ៧ ERN 00401303។

[1224] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦។

[1225] *សូមមើលខាងលើ* ផ្នែក V.គ.៣។ *សូមមើលខាងក្រោម* ផ្នែក VII.ខ.២.ច។ *សូមមើលខាងក្រោម* ផ្នែក VII.ច.៤.គ។

[1226] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៤ និងជើងទំព័រ ៤៦៨, ៤៦៩ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨០-៧១៨។

[1227] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣០។

[1228] *សូមមើលខាងក្រោម* ផ្នែក VII.ឃ.២។

473. អង្គជំនុំជម្រះតុលាការកំពូលពិចារណាបន្ថែមទៀតថា អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា "ការជាប់ពាក់ព័ន្ធរបស់គាត់'ក្នុងការអនុវត្តន៍ [គោលនយោបាយបទបញ្ជារៀបអាពាហ៍ពិពាហ៍] ត្រូវបានបញ្ជាក់បន្ថែមដោយសម្តេចនរោត្តមសីហនុ'"ពុំត្រូវបានលើកលម្អិត[1229]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា កូនសៀវភៅរបស់សម្តេចនរោត្តមសីហនុ គឺជាផ្នែកមួយនៃភស្តុតាងបញ្ជាក់បន្ថែមដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងយោធិនពិការជាមួយនឹងស្ត្រីវ័យក្មេង[1230]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះដោយសារ ខៀវ សំផន ពុំបានបំភ្លឺអំពីលក្ខណៈនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ឬថាតើកំហុសនោះបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដូចម្តេចឡើយ។

474. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការចោទប្រកាន់របស់ ខៀវ សំផន ស្តីពីកំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់ ស ឈាង និង ផុង[ចោង] គឹមឃុន ដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់បន្ថែមលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន ពុំបានលើកមូលដ្ឋានគាំទ្រថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដូចម្តេចនៅក្នុងការយល់ឃើញរបស់ខ្លួន ក្រៅតែពីការអះអាងថាមានតម្លៃជាភស្តុតាង"តិចតួចណាស់"ចំពោះភស្តុតាងនោះ[1231]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃភស្តុតាងរបស់អ្នកភូមិប្រាំពីរនាក់ និងសមាជិកនៃកងសន្តិសុខដែលប្រតិបត្តិការនៅវត្តអូរត្រកួនខណៈនៅពេលមានការសម្លាប់ជនជាតិចាមនៅវត្តនោះ[1232]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើកំណត់ហេតុស្តាប់ចម្លើយ និងឯកសារដែលបញ្ជាក់បន្ថែមលើការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន[1233]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណា

---

[1229] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៥។

[1230] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦-៣៥៩០ យោងទៅលើ *ក្នុងចំណោមនោះ* ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ១២-១៥, ១៦, ២៧។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ (ណុប ងឹម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ឯកសារលេខ E3/5833 ទំព័រ ៦-៧ ERN 00408326-00408327។

[1231] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៩។

[1232] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១១៦០-១១២២០។

[1233] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១២១៥-១១២២០ (យោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្សេងៗ)។

ឃើញថា ខៀវ សំផន ខកខានក្នុងការបំភ្លឺនូវកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការវាយតម្លៃលើភស្តុតាងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន និងបដិសេធអំណះអំណាងនេះ[1234]។

ii. ការវាយតម្លៃលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

475. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ពុំដោយសារពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពុំត្រូវបានបង្កើតឡើងដោយស្ថាប័នតុលាការ ពាក្យសុំនេះទទួលបានសច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាន និងត្រូវបានផ្តល់តម្លៃជាភស្តុតាងតិចតួចប្រសិនបើមាន"[1235]។

476. ខៀវ សំផន បានអះអាងថា បើទោះបីជាមានការទទួលស្គាល់ក៏ដោយ ក៏"អង្គជំនុំជម្រះសាលាដំបូងពុំដែលញញើតនឹងសំអាងការដាក់ពិរុទ្ធភាពទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឧបសម្ព័ន្ធសាមញ្ញៗដែរ"[1236]។ ជាពិសេស គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការយល់ឃើញថា ជនជាតិវៀតណាមមកពីភូមិអង្គរយសត្រូវបានបណ្តេញចេញ[1237]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើបទដ្ឋាននៃការវាយតម្លៃផ្ទាល់ខ្លួនលើភស្តុតាង នៅពេលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រើប្រាស់សម្រាប់តែ"បញ្ជាក់បន្ថែមលើអត្ថិភាពនៃលំនាំការផ្លាស់ទីជនជាតិវៀតណាម" ប៉ុន្តែបន្ទាប់មកបានប្រព្រឹត្តហួសការកំណត់ក្នុងការយល់ឃើញរបស់ខ្លួន[1238]។ គាត់បានអះអាងបន្ថែមទៀតថា ឧបសម្ព័ន្ធនោះពុំគ្រប់គ្រាន់ក្នុងការបញ្ជាក់បន្ថែមលើការយល់ឃើញពាក់ព័ន្ធទៅនឹងការផ្លាស់ទីជនជាតិវៀតណាមក្នុងខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥[1239]។ ពាក់ព័ន្ធបញ្ហានេះ គាត់បានជំទាស់ទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "អង្គហេតុដាច់ដោយឡែកពីគ្នាអាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់បន្ថែមទៅវិញទៅមក"ក្នុងការបង្ហាញអង្គហេតុដែលបុគ្គលក្នុងភូមិដទៃទៀតក្នុងខេត្តព្រៃ

---

[1234] *សូមមើលខាងក្រោម* ផ្នែក VII.ខ.១.ខ។

[1235] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣។

[1236] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៥។

[1237] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៦, ៩៧៨។

[1238] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៨។

[1239] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៩-៩៨០។

វែងត្រូវបានបណ្ដេញចេញ និងនិរទេសទៅប្រទេសវៀតណាមវិញ[1240]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញពាក់ព័ន្ធត្រូវតែមោឃៈ និងប្រកាសថា ការជំនុំជម្រះនេះជាការពុំត្រឹមត្រូវ[1241]។

477. សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអំពីការនិរទេសក្នុងភូមិអង្គរយស"អាចមានកំហុស"[1242]។ ទោះជាយ៉ាងណាក្ដី សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ត្រូវបានចោទប្រកាន់ និងសម្រេចដាក់ពិរុទ្ធភាពពីបទនិរទេសក្នុងខេត្តព្រៃវែងទាំងមូល និងការដាក់ពិរុទ្ធភាពនេះបានផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃការនិរទេសចេញពីភូមិពីរ៖ អន្លង់ទ្រា និងពោធិ៍ចិន្ដាំ[1243]។ ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញថា កំហុសនេះបានមោឃៈសាលក្រម ឬបណ្ដាលឱ្យមានភាពមិនយុត្តិធម៌[1244]។

478. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ខៀវ សំផន ត្រូវបានចោទប្រកាន់ និងដាក់ពិរុទ្ធភាពពីបទនិរទេសជនជាតិវៀតណាមចេញពីខេត្តព្រៃវែងទាំងមូល[1245]។ សហមេធាវីនាំមុខបានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើតម្លៃជាភស្តុតាងនៃឯកសារ និងបានបញ្ជាក់ច្បាស់លាស់ថា ឯកសារនោះបានសំអាងទៅលើតែត្រង់ចំណុចមានការ"បញ្ជាក់បន្ថែមទៅលើអត្ថិភាពនៃលំនាំនៃការផ្លាស់ទីជនជាតិវៀតណាមក្នុងខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥"[1246]។ ការយោងនេះពុំមានភាពចាំបាច់ក្នុងការឈានរកការសម្រេចដាក់ពិរុទ្ធភាពនោះឡើយ[1247]។

479. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីជា ខៀវ សំផន បានលើកឡើងថា "ការដាក់ពិរុទ្ធភាព"[1248]ជាច្រើនបានផ្អែកទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ក៏អំណះអំណាងរបស់គាត់

---

[1240] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៧៩-៩៨០។

[1241] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៦។

[1242] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៣៦។

[1243] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៣៦។

[1244] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៣៦។

[1245] សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២១២។

[1246] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ៣៩៣២។

[1247] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២១២។

[1248] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៥។

បានលើក"ឧទាហរណ៍"តែមួយដែរ[1249]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនពិចារណាលើការអះអាងដែលពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ និងដូច្នេះត្រូវពិនិត្យតែលើឧទាហរណ៍ជាក់លាក់នោះតែប៉ុណ្ណោះ។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនធ្វើការយល់ឃើញដែលហួសពីវិមតិសង្ស័យពាក់ព័ន្ធទៅនឹងការនិទេសជនជាតិវៀតណាមពីភូមិអង្គរយសឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បើទោះបីជាភស្តុតាងមួយចំនួន"បង្ហាញ"ថា អង្គហេតុទាំងនេះបានកើតឡើងក៏ដោយ ក៏"នេះបានបង្ហាញតាមរយៈឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដូច្នេះ មានតម្លៃជាភស្តុតាងតិចតួច"[1250]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចម្លើយនេះត្រឹមតែ"បញ្ជាក់បន្ថែមលើអត្ថិភាពនៃលំនាំការផ្លាស់ទីជនជាតិវៀតណាមក្នុងខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥"[1251]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងវិធីសាស្ត្រដែលបានផ្តល់តម្លៃតិចតួចដល់ភស្តុតាងនេះ។

480. ម្យ៉ាងវិញទៀត នៅក្នុងការយល់ឃើញស្តីពីការនិរទេសក្នុងខេត្តព្រៃវែង អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងអំពីភូមិអង្គរយសជាទីតាំងដែលការនិទេសត្រូវបាន"រកឃើញ" ដែលហួសពីវិមតិសង្ស័យ[1252]។ អង្គជំនុំជម្រះតុលាការកំពូលទទួលយកសារណារបស់ ខៀវ សំផន ដែលថា ឃ្លានេះមានកំហុស។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបានអះអាងត្រឹមត្រូវថា កំហុសនេះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ឡើយ។ ការដាក់ពិរុទ្ធភាពរបស់ ខៀវ សំផន ដែលពាក់ព័ន្ធនឹងការនិរទេសចេញពីខេត្តព្រៃវែង បានផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការនិរទេសចេញភូមិពីរដទៃទៀត។ នេះត្រូវបានបញ្ជាក់បន្ថែមដោយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពៅ ហុង ដែលបង្ហាញលំនាំការផ្លាស់ទី។ អាស្រ័យហេតុនេះ អំណះអំណាងត្រូវបដិសេធចោល។

481. ខៀវ សំផន បានយល់ស្របជាមួយក្របខ័ណ្ឌគតិយុត្តដែលអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបានទទួលស្គាល់ថា នេះត្រូវបានតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[1253]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញ

---

[1249] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៦។

[1250] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣២។

[1251] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤២២។

[1252] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥។

[1253] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៧-៣១៨។

ថា ខៀវ សំផន ពុំបានបំពេញកាតព្វកិច្ចក្នុងការស្នើសុំឱ្យពិចារណាឡើងវិញ និងដូច្នេះសារណានេះពុំចាំបាច់ពិចារណាបន្ថែមទៀតឡើយ។

482. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែល"ពុំគួរឱ្យជឿទុកចិត្ត និងជឿជាក់បាន"[1254] និងខកខានក្នុងការវាយតម្លៃលើភាពគួរឱ្យជឿជាក់ និងជឿទុកចិត្តបានពាក់ព័ន្ធទៅនឹងកាលៈទេសៈទាំងអស់ក្នុងរឿងក្តីនេះ[1255]។ ក្នុងការបង្ហាញកំហុសនេះ ខៀវ សំផន បានលើកឡើងថា "ឧទាហរណ៍នៃការទទួលយកភស្តុតាងដាក់បន្ទុករបស់ អែម អឿន ដែលបានសន្មតបទឧទ្ទេសនាមថាជារបស់គាត់ដែលបានធ្វើឡើងនៅក្នុងវគ្គបណ្តុះបណ្តាលមួយនោះ គឺជាការបង្ហាញនូវវិធីដែលអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភាពគួរឱ្យជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នេះក៏ជាការពិតផងដែរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃបទឧទ្ទេសនាមដែលបានថ្លែងស្តីពីប្រធានបទនៃការរៀបអាពាហ៍ពិពាហ៍នោះ"[1256]។ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតថា ខៀវ សំផន គ្រាន់តែដាក់បញ្ចូលតាមរយៈការយោងទៅលើផ្នែកដទៃទៀតក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ ដែលត្រូវបានវាយតម្លៃលម្អិតក្នុងសាលដីកានេះ។

## ឆ. ឯកសារដែលទទួលបានសច្ចធារណ៍

483. អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សច្ចធារណ៍ដែលអាចជំទាស់បាននៃភាពជាប់ពាក់ព័ន្ធ និងភាពគួរជឿទុកចិត្តបាន*តាមសេចក្តីបញ្ជាក់ដំបូង* រួមទាំងការបញ្ជាក់ត្រឹមត្រូវ ទៅលើឯកសារដែលទទួលបានពីមជ្ឈមណ្ឌល DC-Cam និងឯកសារដែលបានដកស្រង់ក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២[1257]។ ដោយបានផ្អែកទៅលើក្របខ័ណ្ឌគតិយុត្តដែលបានកំណត់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ និងត្រូវបានទទួលស្គាល់ក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តវិធីសាស្ត្រដូចគ្នាក្នុងសំណុំរឿង ០០២/០២[1258]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នេះអាស្រ័យលើភាគីដែល

---

[1254] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៩។

[1255] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៨។

[1256] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣១៩។

[1257] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៦។ សេចក្តីសម្រេចស្តីពីការជំទាស់ទៅលើឯកសារ (E185) កថាខណ្ឌ ២០។

[1258] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៣៤។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៧៥។

ជំទាស់ទៅនឹងភាពគួរឱ្យជឿទុកចិត្តបាន ឬភាពត្រឹមត្រូវនៃភស្តុតាង ក្នុងការកំណត់ និងផ្តល់ហេតុផលដើម្បីជំទាស់សច្ចធារណ៍នោះ[1259]។ បញ្ហានេះនឹងត្រូវដោះស្រាយផ្អែកលើករណីជាក់ស្តែង[1260]។

484. ខៀវ សំផន លើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ គឺជាកំហុសអង្គច្បាប់ ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបាន“រួមបញ្ចូលការធានាគ្រប់គ្រាន់ឱ្យស្របតាមបទដ្ឋានភស្តុតាងក្នុងច្បាប់ព្រហ្មទណ្ឌ”[1261]។ គាត់បានអះអាងថា ការធានានេះគប្បី“គោរពឱ្យបានតឹងរ៉ឹង ពីព្រោះភស្តុតាងដែលបានបង្ហាញនោះអាចធ្វើឱ្យមានការភាន់ច្រឡំ”ដោយសារពេលវេលាកន្លងផុតទៅយូរឆ្នាំចាប់តាំងពីព្រឹត្តិការណ៍នោះ[1262]។ គាត់បានអះអាងថា អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី *Prlić* “បានបង្ហាញក្របខ័ណ្ឌការងាររឹតត្បិតជាងសម្រាប់ការវាយតម្លៃលើភាពត្រឹមត្រូវ ដើម្បីធានានូវបទដ្ឋានស្តីពីភស្តុតាង” និងថា នេះបានបង្ហាញថា ជាការ“មិនគ្រប់គ្រាន់ក្នុងការទទួលយកសច្ចធារណ៍ដែលអាចជំទាស់បាននៃភាពត្រឹមត្រូវដែលពុំត្រូវបានធ្វើយុត្តិកម្មដោយលក្ខណៈវិនិច្ឆ័យសត្យានុម័ត ប៉ុន្តែត្រឹមតែបង្ហាញនូវនីតិវិធីនៃការវិភាគដោយផ្អែកលើការកំណត់ក្នុងកម្រិតជាក់លាក់មួយនោះប៉ុណ្ណោះ”[1263]។ គាត់បានលើកឡើងជាពិសេសថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុដល់ការជំទាស់ជាច្រើនទៅនឹងភាពត្រឹមត្រូវនៃឯកសារ GOSCHA និងសៀវភៅកំណត់ហេតុមន្ទីរស-២១[1264] និងជាទូទៅថា ការយល់ឃើញពុំជាក់លាក់ដទៃទៀតដែលបានផ្អែកលើភស្តុតាងដែលត្រូវបានទទួលយកស្របតាមក្រមខ័ណ្ឌការងារ ត្រូវបដិសេធចោល[1265]។

485. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន ពុំទទួលជោគជ័យដោយសារគាត់ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងដែលពុំបានជោគជ័យក្នុងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ ដោយ

---

[1259] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៦។

[1260] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៦។

[1261] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២១។

[1262] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២១។

[1263] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២២ យោងទៅលើសាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-74-A សាលដីកាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧ (“សាលដីការឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY)”) កថាខណ្ឌ ៣៧៥។

[1264] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២២ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧-២២៦។

[1265] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២២។

គ្មានការផ្តល់មូលហេតុថ្មីសម្រាប់ការពិចារណាឡើងវិញលើសេចក្តីសន្និដ្ឋានពីដំបូង[1266]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃសាលដីការឿងក្តី *Prlić*[1267]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុក្នុងការឆ្លើយតបសម្រាប់សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃឯកសារទាំងនេះ[1268]។

486. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះបានទទួលយកពីដំបូងនូវវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១[1269]។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណាពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់របស់ ខៀវ សំផន ដែលថា លក្ខណៈភស្តុតាងក្នុងរឿងនេះ"ជាពិសេសអាចធ្វើឱ្យមានការភាន់ច្រឡំ" និងតម្រូវឱ្យមានក្របខ័ណ្ឌនៃការវិភាគផ្សេងខុសពីការអនុវត្តក្នុងរឿងក្តីដទៃទៀត។ គាត់បានគូសបង្ហាញដោយពុំត្រឹមត្រូវនូវគោលការណ៍គតិយុត្តទាក់ទងទៅនឹងការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារដែលត្រូវបានជំទាស់ក្នុងសាលដីការឿងក្តី *Prlić*។ ដូចសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញត្រឹមត្រូវក្នុងការបដិសេធការជំទាស់របស់ ខៀវ សំផន ទៅនឹងការទទួលយក"សៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់ *Mladić*" ថា អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានសង្កេតថា អង្គជំនុំជម្រះសាលាដំបូងនោះបានពិចារណាបញ្ហានៃការបញ្ជាក់ភាពត្រឹមត្រូវយ៉ាងទូលំទូលាយ និងបានកត់សម្គាល់កត្តាផ្សេងៗដែលអង្គជំនុំជម្រះសាលាដំបូងនោះបានពិចារណា[1270]។ អង្គជំនុំជម្រះឧទ្ធរណ៍បានកត់សម្គាល់ថា "ការបង្ហាញភាពត្រឹមត្រូវនៃឯកសារពុំមែនជាលក្ខខណ្ឌតម្រូវដាច់ដោយឡែកសម្រាប់ការទទួលយកភស្តុតាងជាឯកសារនោះទេ" និងបានបញ្ជាក់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ខកខានក្នុងការបង្ហាញកំហុសណាមួយក្នុងការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូងនូវឆន្ទានុសិទ្ធិក្នុងការទទួលយក"សៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់ *Mladić*" ធ្វើជាភស្តុតាងដោយពុំបានធ្វើការវិភាគលើចរិតលក្ខណៈការនិពន្ធ ឬព័ត៌មានបន្ថែមអំពីកាលៈទេសៈដែលសៀវភៅនេះបាននិពន្ធឡើង[1271]។ អាស្រ័យហេតុនេះ អំណះអំណាងថ្មីនេះត្រូវបដិសេធចោល។

---

[1266] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៣៨។

[1267] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៣៨-២៣៩។

[1268] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤០។

[1269] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៦៩-៣៧៦។

[1270] សាលដីការឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១២១។

[1271] សាលដីការឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១២១។

487. អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាត្រឹមត្រូវលើសារណាជាក់លាក់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានទទួលពីមជ្ឈមណ្ឌល DC-Cam, ឯកសារ GOSCHA និងសៀវភៅកំណត់ត្រាមន្ទីរ-២១ នៅក្នុងសាលដីកានេះ[1272]។

## ជ. ភស្តុតាងរបស់អ្នកជំនាញ

488. ទាក់ទងទៅនឹងភស្តុតាងដែលបានផ្តល់ដោយអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះនឹងពិនិត្យពិច័យដោយប្រុងប្រយ័ត្នលើប្រភពដែលត្រូវបានប្រើប្រាស់ដោយអ្នកជំនាញ ក្នុងការធ្វើសេចក្តីសន្និដ្ឋាន និងបានពន្យល់ថា ក្នុងករណីការយល់ឃើញផ្នែកអង្គហេតុបានសំអាងទៅលើកិច្ចការរបស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវស្វែងរកការបំភ្លឺច្បាស់លាស់ទាក់ទងទៅនឹងប្រភពជាក់លាក់ដែលអាចផ្ទៀងផ្ទាត់បាននូវព័ត៌មានដែលជាមូលដ្ឋាននៃមតិយោបល់របស់អ្នកជំនាញ[1273]។ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ទម្ងន់តិចតួចទៅលើភស្តុតាងរបស់អ្នកជំនាញដែលប្រភពពុំអាចពិនិត្យ ឬពុំអាចផ្ទៀងផ្ទាត់បានពេញលេញ[1274]។

489. បើទោះបីជា ខៀវ សំផន បានយល់ស្របជាមួយនឹងវិធីសាស្ត្រដែលបានលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើភស្តុតាងដែលបានផ្តល់ដោយអ្នកជំនាញក៏ដោយ ក៏គាត់បានអះអាងថា អង្គជំនុំជម្រះពុំបានអនុវត្តក្របខ័ណ្ឌនេះត្រឹមត្រូវ“ជាពិសេសដោយពុំបានអើពើលើភស្តុតាងពាក់ព័ន្ធទៅនឹងការដោះបន្ទុក”[1275]។ គាត់បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យមោឃៈការយល់ឃើញដែលរងការជំទាស់នេះ និងប្រកាសការជំនុំជម្រះនេះថា ពុំត្រឹមត្រូវ[1276]។ ដោយសារអំណះអំណាងរបស់ ខៀវ សំផន ស្តីពីចំណុចនេះត្រូវបានលើកឡើងពេញលេញពាក់ព័ន្ធទៅនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងរបស់អ្នកជំនាញ Peg LEVINE និង NAKAGAWA Kasumiin ទាក់ទងទៅនឹងបទចោទនៃ

---

[1272] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣២២ ជើងទំព័រ ៥០៩ យោងទៅលើកថាខណ្ឌ ២១៧-២២៥, ២២៦។

[1273] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៦។

[1274] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៦។

[1275] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣០។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ១៦។

[1276] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០។

គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[1277] អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយក្នុងផ្នែកដែលពាក់ព័ន្ធក្នុងសាលដីកានេះ។

## VI. ការចោទប្រកាន់កំហុសក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ

### ក. វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ

#### ១. អង្គច្បាប់

490. នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានជំនុំជម្រះលើអង្គហេតុពុំត្រឹមត្រូវចំនួនប្រាំពីរនៅក្នុងដីកាដំណោះស្រាយ ដែលពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដូចបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1278]។

491. នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា គោលបំណងនៃអញ្ញត្រកម្មតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង គឺដើម្បី"បញ្ជាក់វិសាលភាពនៃការជំនុំជម្រះនៅមុនការចាប់ផ្តើមស្តាប់ភស្តុតាង" និងជាលទ្ធផលថា "សំណើណាមួយពាក់ព័ន្ធទៅនឹងសិទ្ធិអំណាចក្នុងការដោះស្រាយផ្នែកខ្លះនៃដីកាដំណោះស្រាយដែលត្រូវបានលើកឡើងក្រោយពេលកំណត់កាលបរិច្ឆេទសម្រាប់ការដាក់អញ្ញត្រកម្ម គប្បីចាត់ទុកថា យឺតពេល និងត្រូវបដិសេធចោល"[1279]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈនៃអញ្ញត្រកម្មរបស់ ខៀវ សំផន ថា ជា"ការជំទាស់ទៅនឹងយុត្តាធិការរបស់ខ្លួនក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន"[1280] និងដោយផ្អែកលើមូលដ្ឋាននេះ បានបញ្ជាក់ថា អញ្ញត្រកម្មនេះត្រូវបានដាក់ឱ្យស្ថិតក្រោមកាលបរិច្ឆេទដែលត្រូវបានកំណត់ដោយវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[1281]។ អញ្ញត្រកម្មរបស់ ខៀវ សំផន ទៅនឹងអង្គហេតុចំនួនប្រាំពីរត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង លើកលែងតែការជំទាស់របស់គាត់ទាក់ទង

---

[1277] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៩-១២១០។

[1278] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៨-១៥៩។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២១៧។ អង្គហេតុជាទូទៅពាក់ព័ន្ធទៅនឹង៖ (១) ស្រុកត្រាំកក់ (២) ទំនប់ត្រពាំងថ្ម (៣) ទំនប់១មករា (៤) ភ្នំក្រោល (៥) ក្រាំងតាចាន់ (៦) អូរកន្សែង (៧) ការបោសសម្អាត (៨) ការប្រព្រឹត្តទៅលើពុទ្ធសាសនិកនៅសហករណ៍ត្រាំកក់។

[1279] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦១។

[1280] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦២, ១៦៥។

[1281] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦១, ១៦៥។

ទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាមប៉ុណ្ណោះ[1282]ត្រូវបានលើកឡើងទាន់ពេល និងជាអញ្ញត្រកម្មបឋម[1283]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើអង្គសេចក្ដីនៃអញ្ញត្រកម្មនេះ និងបានបដិសេធអញ្ញត្រកម្មផ្សេងទៀតរបស់ ខៀវ សំផន ថាលើកយឺតពេល ដោយផ្អែកលើមូលដ្ឋានថា ត្រូវបានលើកឡើងក្រៅវិសាលភាពនៃពេលវេលាកំណត់ដោយវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[1284]។

492. នៅដំណាក់កាលបណ្ដឹងសាទុក្ខ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ តាមរយៈការកំណត់ចរិតលក្ខណៈនៃសំណើរបស់ខ្លួនថា ជាអញ្ញត្រកម្មយឺតពេលផ្អែកតាមវិធាន ៨៩ និងការយល់ឃើញថា ពុំអាចទទួលយកបានតាមទម្រង់[1285]។ ជាពិសេស គាត់បានលើកឡើងថា៖ (១) វិធាន ៨៩ (១)(ក) នៃវិធានផ្ទៃក្នុង ជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការផ្លូវច្បាប់របស់ អ.វ.ត.ក. ក្នុងវិសាលភាពនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និងពុំបានអនុវត្តចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអង្គហេតុនោះឡើយ[1286] (២) ការកំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំថាជាអញ្ញត្រកម្ម គឺជាលក្ខណៈបែបឱកាសនិយម និងជ្រើសរើសតាមការចង់បាន[1287] (៣) អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ តាមរយៈការមិនបានដោះស្រាយលើអង្គសេចក្ដីនៃសំណើសុំរបស់គាត់[1288]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើសារណានីមួយៗនេះតាមលំដាប់លំដោយ។

---

[1282] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៩ (ក) យោងទៅលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២១៩-២៧៦។

[1283] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣-១៦៤ (អញ្ញត្រកម្មជាប់ពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាម ដែលបានលើកឡើងដំបូងដោយ អៀង សារី និងក្រោយពេលគាត់ស្លាប់ ត្រូវបានយកមកប្រើប្រាស់ដោយ ខៀវ សំផន)។

[1284] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥ ទាក់ទងទៅនឹងអង្គហេតុជាច្រើនដែលបានរៀបរាប់ក្នុងកថាខណ្ឌ ១៥៩ (ខ) ដល់ (ធ)។

[1285] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៤។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៧៥-៧៦។

[1286] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៥-៣៤២។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨៤។

[1287] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៥, ៣៤៣-៣៤៦។

[1288] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៥, ៣៤៧-៣៥០។

## ក. ការចោទប្រកាន់កំហុសក្នុងការកំណត់ចរិតលក្ខណៈលើសំណើសុំពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរថា ជាអញ្ញត្រកម្ម

493. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អញ្ញត្រកម្មរបស់ ខៀវ សំផន អាចស្មើនឹង"ការជំទាស់ទៅនឹងយុត្តាធិការក្នុងការជំនុំជម្រះលើអង្គហេតុមួយចំនួន" ដូច្នេះត្រូវដាក់ឱ្យស្ថិតក្រោមការកំណត់នៃកាលបរិច្ឆេទតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1289]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ ខៀវ សំផន បានអះអាងថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការផ្នែកច្បាប់របស់ អ.វ.ត.ក. ដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងជាផលវិបាកថា វិធាននេះ និងកាលបរិច្ឆេទពុំអនុវត្តចំពោះការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុនោះឡើយ[1290]។ ក្នុងការគាំទ្រ គាត់បានអះអាងថា វិធាន ៨៩(៣) និង ៩៨ នៃវិធានផ្ទៃក្នុង នៅពេលពិនិត្យជារួម បានបង្ហាញថា វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងយុត្តាធិការក្នុងន័យច្បាប់ និងគោលការណ៍នីត្យានុកូលភាពតែប៉ុណ្ណោះ[1291]។ បន្ថែមលើនេះ គាត់បានលើកឡើងថា "គ្មានភាគីណានៅ អ.វ.ត.ក." បានបកស្រាយផ្សេងគ្នានូវយុត្តាធិការដូចមានចែងក្នុងវិធាន ៨៩(១) និង ៨៩ នៃវិធានផ្ទៃក្នុង និងបានយោងទៅលើយុត្តិសាស្ត្រនៃអង្គបុរេជំនុំជម្រះដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន[1292]។

494. ទាក់ទងទៅនឹងការយល់ឃើញដែលថា សំណើរបស់គាត់យឺតពេល ខៀវ សំផន បានអះអាងថា គាត់មានសិទ្ធិក្នុងការលើកការជំទាស់ទាំងនេះនៅមុខអង្គជំនុំជម្រះតុលាការកំពូល[1293] នៅគ្រប់ករណីទាំងអស់ និងថា វិធានផ្ទៃក្នុងពុំបានអនុញ្ញាតឱ្យគាត់លើកការជំទាស់នេះនៅមុនការចាប់ផ្តើមនៃការជំនុំជម្រះឡើយ[1294]។ គាត់បានអះអាងបន្ថែមទៀតថា វិធាន ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះ និងវិធាន ៨៩ នៃវិធានផ្ទៃក្នុងពុំបានផ្តល់ឱ្យគាត់នូវសិទ្ធិធ្វើដូច្នោះឡើយ[1295]។ បន្ថែមលើនេះទៀត ខៀវ សំផន បានលើកឡើងថា វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងកំហុសនីតិវិធី អនុវត្តទៅលើកិច្ចស៊ើបសួរ ប៉ុន្តែពុំអនុវត្តលើដីកាដំណោះស្រាយ

---

[1289] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥។

[1290] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៦។

[1291] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៧-៣៣៨។

[1292] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៩-៣៤២។

[1293] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៧៩-៨០។

[1294] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៦៦-៦៧, ៧៣-៧៤, ៧៩-៨០។

[1295] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៦៧-៦៨, ៧៤-៧៦, ៧៧-៧៨, ៨៣។

[1296]។ បន្ថែមលើនេះ ដោយសារដីកាបំបែកសំណុំរឿង ០០២/០១ និង ០០២/០២ ខៀវ សំផន បានលើកឡើងថា រឿងក្តីនេះត្រូវដាក់ឱ្យស្ថិតក្រោមក្របខ័ណ្ឌនៃយុត្តាធិការគ្មានដែនកំណត់រហូតដល់ថ្ងៃនៅមុនការបញ្ចប់សវនាការលើអង្គសេចក្តី។ ដូច្នេះ គាត់បានជំទាស់ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា រាល់បញ្ហាដែលទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះត្រូវតែដោះស្រាយនៅមុនការជំនុំជម្រះ[1297]។

495. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានកំណត់ថា ការលើកឡើងរបស់គាត់ ផុតកាលបរិច្ឆេទផ្អែកតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[1298]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបកស្រាយបំភ្លៃវិធានផ្ទៃក្នុង និងពុំអើពើលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល[1299]។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅពេលពិនិត្យក្នុងបរិបទ និងដោយផ្ទុយទៅនឹងវិធាន ៧៤(៣)(ក) និង ៩៨ នៃវិធានផ្ទៃក្នុង ពាក្យ"យុត្តាធិការ" ក្នុងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងបានសំដៅទៅលើ"យុត្តាធិការរបស់អង្គជំនុំជម្រះ"[1300]ដែលមានលក្ខណៈទូលំទូលាយជាង និងពុំបានកម្រិតត្រឹមយុត្តាធិការផ្នែកច្បាប់របស់ អ.វ.ត.ក. នោះទេ។ យោងតាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា កាលបរិច្ឆេទក្នុងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង អនុវត្តចំពោះការជំទាស់លើ"យុត្តាធិការផ្នែកនីតិវិធី"ដែលត្រូវបានដោះស្រាយក្នុងកិច្ចដំណើរការនីតិវិធី និងពុំបានអនុវត្តចំពោះ"ការជំទាស់លើយុត្តាធិការដាច់ខាត" ឬ"ផ្នែកច្បាប់"[1301]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការបកស្រាយបែបនេះ ស្របជាមួយនឹងគោលបំណងរបស់អញ្ញត្រកម្មក្នុងការបញ្ជាក់ពីវិសាលភាពនៃការជំនុំជម្រះនៅមុនពេលចាប់ផ្តើមនៃការជំនុំជម្រះ និងដើម្បីធានាបាននូវដំណើរការប្រសិទ្ធ

---

[1296] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៧៧-៧៨។

[1297] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨៤-៨៥ យោងទៅលើសេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E95/8/1/4 កថាខណ្ឌ ១០។

[1298] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៣-២៧៤។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៤-៩៥។

[1299] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៤-២៧៥។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៤-៩៧។

[1300] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៦។

[1301] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៧។

ភាព និងមានសណ្ដាប់ធ្នាប់ល្អ[1302]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើវិធាន ៧៩(១) នៃវិធានផ្ទៃក្នុងដែលកំណត់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវជំនុំជម្រះតាមដីកាបញ្ជូនទៅជំនុំជម្រះ និងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងដែលចែងថា ដីកាដំណោះស្រាយកែតម្រូវរាល់កំហុសនៃការមិនគោរពតាមវិធានបញ្ញត្តិក្នុងការស៊ើបសួរ[1303]។ ទោះជាយ៉ាងណាក្ដី សហព្រះរាជអាជ្ញាបានលើកឡើងថា វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងពុំអនុវត្តចំពោះដីកាដំណោះស្រាយនៅពេលដែលបញ្ហានោះពុំបានបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ និងថា នេះគឺជាមូលហេតុដែលយន្តការអញ្ញត្រកម្មក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង មានអត្ថិភាពក្នុងការធានាថា វិសាលភាពនៃការជំនុំជម្រះមានលក្ខណៈច្បាស់លាស់នៅមុនពេលចាប់ផ្ដើម[1304]។

496. យោងតាមសហមេធាវីនាំមុខ បានឱ្យដឹងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការកំណត់ភាពអាចទទួលយកបានតាមទម្រង់របស់ខ្លួនទៅលើការបកស្រាយអង្គច្បាប់ពុំត្រឹមត្រូវ[1305] និងបានចង្អុលបង្ហាញទៅលើការខកខានក្នុងការលើកឡើងរបស់ ខៀវ សំផន ដែលថា គាត់ពុំអាចលើកអញ្ញត្រកម្មរបស់គាត់នៅមុនការចាប់ផ្ដើមការជំនុំជម្រះដោយអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1306]។ ជាពិសេស សហមេធាវីនាំមុខបានអះអាងថា ខៀវ សំផន ពុំបានអើពើលើ៖ (១) វិធាន ៧៦ នៃវិធានផ្ទៃក្នុងដែលចែងថា ការជំទាស់មួយចំនួនត្រូវតែធ្វើឡើងក្នុងអំឡុងពេលនៃដំណាក់កាលកិច្ចស៊ើបសួរ[1307] និង (២) យុត្តាធិការរបស់ អ.វ.ត.ក. ដែលបង្ហាញថា គាត់ពុំត្រូវបានរាំងតាមនីតិវិធីក្នុងការលើកអញ្ញត្រកម្មរបស់គាត់នៅមុខសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ ឬសូម្បីតែនៅពេលចាប់ផ្ដើមនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[1308]។

497. បន្ថែមលើនេះ សហមេធាវីនាំមុខបានជំទាស់ទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងបានរាំងច្បាស់លាស់ដល់គាត់ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយស្ដីពីបញ្ហានៃវិសាលភាព និងបានអះអាងថា៖ (១) នៅតែជាបញ្ហាដែលគ្មានដោះស្រាយនូវអ្វីដែលហៅថា

---

[1302] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៨។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៤-៩៥, ៩៧។

[1303] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៥-៩៦។

[1304] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៦-៩៧។

[1305] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៣៩ (ចំណងជើង) ១៤៧។

[1306] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៣៩-១៤០។

[1307] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤១។

[1308] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤២-១៤៥។

យុត្តាធិការតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះ (២) អង្គបុរេជំនុំជម្រះបានពង្រីកសិទ្ធិអំណាចលើបណ្តឹងឧទ្ធរណ៍ហួសពីវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដែលចាំបាច់ក្នុងការរារាំងការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និង (៣) អង្គបុរេជំនុំជម្រះបានបញ្ជាក់ជំហរថា ការមិនគោរពវិធានបញ្ញត្តិនៅក្នុងការស៊ើបសួរ ត្រូវតែបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ[1309]។ ផ្អែកលើមូលដ្ឋាននេះ សហមេធាវីនាំមុខបានអះអាងថា វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងត្រូវតែបានបកស្រាយថា បានអនុញ្ញាតឱ្យធ្វើបណ្តឹងឧទ្ធរណ៍លើបញ្ហាទាំងនេះនៅពេលពិនិត្យដោយធៀបជាមួយនឹងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ដែលចែងថា កំហុសនីតិវិធីក្នុងដីកាបញ្ជូនទៅជំនុំជម្រះត្រូវបានកែតម្រូវ និងពុំអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ[1310]។ នៅគ្រប់ករណី សហមេធាវីនាំមុខបានលើកឡើងថា បើទោះបីជាពុំអាចប្តឹងឧទ្ធរណ៍បាននៅចំពោះមុខអង្គបុរេជំនុំជម្រះ ខៀវ សំផន គប្បីបានលើកបញ្ហានេះធ្វើជាអញ្ញត្រកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបន្ទាប់ពីគាត់បានដឹងភ្លាមៗនោះ[1311]។

498. អង្គជំនុំជម្រះតុលាការកំពូលរំឭកច្បាប់ជាធរមាន និងសង្កេតឃើញថា ផ្អែកតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង អញ្ញត្រកម្មដែលពាក់ព័ន្ធទៅនឹង (ក) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង (ខ) បញ្ហាដែលតម្រូវឱ្យមានការរលត់បណ្តឹងអាជ្ញា និង (គ) មោឃភាពនៃចំណាត់ការផ្នែកនីតិវិធីបន្ទាប់ពីដីកាបញ្ជូនទៅជំនុំជម្រះត្រូវបានដាក់ "គប្បីលើកឡើងយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនធ្វើដូច្នេះទេ អញ្ញត្រកម្មនេះមិនអាចត្រូវបានទទួលយកឡើយ"[1312]។ វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីអញ្ញត្រកម្ម"ភ្លាមៗ ឬនៅពេលជាមួយគ្នានឹងសាលក្រមលើអង្គសេចក្តី"[1313] និងវិធាន ៩៨ នៃវិធានផ្ទៃក្នុងដែលចែងអំពីសាលក្រមបញ្ជាក់*ក្នុងចំណោមនោះ*ថា "អង្គជំនុំជម្រះត្រូវពិនិត្យលើបញ្ហា ថាតើអំពើនោះអាចស្មើនឹងបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែរ ឬយ៉ាងណា"[1314]។

---

[1309] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៥-៦។

[1310] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៦-៧។

[1311] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៩។

[1312] វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។

[1313] វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង។

[1314] វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង។

499. ទាក់ទងទៅនឹងសារណារបស់ ខៀវ សំផន[1315] អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ផ្អែកតាមការពិនិត្យរួមគ្នាលើវិធាន ៨៩(៣) និង ៩៨ នៃវិធានផ្ទៃក្នុងបង្ហាញថា វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ជាប់ពាក់ព័ន្ធតែលើយុត្តាធិការផ្នែកច្បាប់របស់ អ.វ.ត.ក. ប៉ុណ្ណោះនោះទេ[1316]។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង យោងទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ចំណែកវិធាន ៩៨ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក.[1317]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចរបស់ខ្លួនលើអញ្ញត្រកម្ម"នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី" ក្នុងកាលៈទេសៈដែលការជំទាស់លើយុត្តាធិការនេះ បានផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកអង្គហេតុ ឬតម្រូវឱ្យមានការវាយតម្លៃរួមគ្នារវាងអង្គហេតុ និងអង្គច្បាប់នោះ[1318]។ វិធាននេះពុំបានរារាំងដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសេចក្តីសម្រេចលើអញ្ញត្រកម្ម"ភ្លាមៗ" ឧទាហរណ៍ ក្នុងករណីដែលការជំទាស់មួយទៅលើយុត្តាធិការផ្នែកច្បាប់ ត្រូវបានលើកឡើងនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ[1319]។ ជាលទ្ធផល វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុងពុំបានផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការអះអាងរបស់ ខៀវ សំផន ដែលថាវិធាន ៩៨ និងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុងទាំងពីរជាប់ពាក់ព័ន្ធទៅនឹង"យុត្តាធិការក្នុងន័យច្បាប់ និងគោលការណ៍នៃនីត្យានុកូលភាព"[1320]ឡើយ។

---

[1315] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៦-៣៤២។

[1316] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៧-៣៣៨។

[1317] វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង។ វិធាន ៩៨(៣) និងវិធាន ៩៨(៧) នៃវិធានផ្ទៃក្នុង។

[1318] វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៩។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ សេចក្តីណែនាំភាគីពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E51/7 ទំព័រ ៣។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E306 ("អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E306)") កថាខណ្ឌ ២។

[1319] *សូមមើល ឧ.* សេចក្តីសម្រេចសំណុំរឿង ០០២/០១ លើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ (*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ និងការអនុគ្រោះទោស និងលើកលែងទោស*) ថ្ងៃទី ០៣ ខែ វិច្ឆកា ឆ្នាំ ២០១១ ឯកសារលេខ E51/15។ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី(ការផុតអាជ្ញាយុកាលលើឧក្រិដ្ឋកម្មក្នុងស្រុក) ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E122 ("សេចក្តីសម្រេចសំណុំរឿង ០០២ លើអញ្ញត្រកម្ម (E122)") ។

[1320] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៧-៣៣៨។

500. ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពាក្យពេចន៍ខុសគ្នានៃវិធាន ៨៩(១)(ក) និង វិធាន ៩៨ នៃវិធានផ្ទៃក្នុងបង្ហាញពីគោលបំណង និងថា ការពិនិត្យតាមធម្មតានៃវិធានទាំងពីរនេះ អាចអោយអង្គជំនុំជម្រះសន្និដ្ឋានបានថា *យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង*ដែលសំដៅទៅលើក្នុងវិធាន ៨៩ (១)(ក) នៃវិធានផ្ទៃក្នុង មានលក្ខណៈខុសប្លែកគ្នាពី*យុត្តាធិការរបស់ អ.វ.ត.ក.* ក្នុងវិធាន ៧៤(៣)(ក) និង ៩៨ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង សំដៅយ៉ាងទូលំទូលាយទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងយុត្តាធិការនៃអង្គហេតុ និងអង្គច្បាប់ ចំណែកវិធាន ៧៤(៣)(ក) និង ៩៨ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងយុត្តាធិការផ្នែកច្បាប់របស់តុលាការដូចបានបញ្ជាក់ដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ ការបកស្រាយនេះ ស្របជាមួយនឹងគោលបំណងនៃវិធាន ៨៩ ក្នុងការ“ជម្រុញ [...] កិច្ចការរដ្ឋបាលតុលាការប្រសិទ្ធភាព និងសណ្តាប់ធ្នាប់ល្អ”[1321] និង“បញ្ជាក់អំពីវិសាលភាពនៃការជំនុំជម្រះនៅមុនពេលចាប់ផ្តើមសវនាការលើភស្តុតាង”ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង[1322]។

501. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្របខ័ណ្ឌនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. បានកំណត់នូវការផ្តាច់ចេញពីគ្នារវាងកិច្ចស៊ើបសួរ និងដំណាក់កាលជំនុំជម្រះដូចបានកំណត់ក្នុងវិធាន ៧៦(២) និង ៧៦(៧) នៃវិធានផ្ទៃក្នុង។ វិធាន ៧៦(២) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យភាគីស្នើសុំមោឃភាពលើផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[1323] រីឯវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងបានរារាំង

---

[1321] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៨ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-05-87-T សេចក្តីសម្រេចលើញត្តិរបស់ Nebojša Pavkovic សុំបដិសេធដីកាបញ្ជូនទៅជំនុំជម្រះប្រឆាំងនឹងរូបគាត់ផ្អែកលើមូលដ្ឋានថា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតដោយខុសច្បាប់នូវតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៥។

[1322] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦១។

[1323] វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្តីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះធ្វើការបកស្រាយយ៉ាងទូលំទូលាយអំពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបញ្ជាក់ដំណើរការនីតិវិធីសម្រាប់មោឃភាពដីកាដំណោះស្រាយ ឬក្នុងផ្នែកខ្លះ ប្រសិនបើចាំបាច់ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ D158/1 (“សេចក្តីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត (D158/1)”) កថាខណ្ឌ ២០ (ទាក់ទងទៅនឹងសារណារបស់ មាស មុត ដែលលើកឡើងថា គាត់ពុំអាចដឹងមុនបានអំពីការចេញដីកាដំណោះស្រាយ ថាតើគាត់នឹងត្រូវបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុដែលពុំត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា “មេធាវីការពារក្តីមានឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យ នៅមុនការចេញដីកាដំណោះស្រាយនូវភាពមិនប្រក្រតីដែល

ភាគីក្នុងការលើកកំហុសនីតិវិធីដែលរងការចោទប្រកាន់នោះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ពីព្រោះ"ជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ"[1324]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា គោលបំណងនៃបទប្បញ្ញត្តិទាំងនេះ"គឺដើម្បីធានាថា ភាគី [...] ធ្វើចំណាត់ការដោយយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាស្ដីពីនីតិវិធីនៅដំណាក់កាលមុនការជំនុំជម្រះ ដើម្បីកុំឱ្យបញ្ហានេះប៉ះពាល់ដល់ដំណើរការនៃការជំនុំជម្រះ"[1325]។ ក្នុងករណី បញ្ហានេះដែលពាក់ព័ន្ធទៅនឹងការមិនគោរពវិធានបញ្ញត្តិក្នុងដីកាដំណោះស្រាយ ពុំទាន់ត្រូវបានដោះស្រាយក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះ វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង អាចប្រើប្រាស់សម្រាប់គោលបំណងប្រហាក់ប្រហែលគ្នាដើម្បីដោះស្រាយអញ្ញត្រកម្មដែលនៅសេសសល់នេះទៅលើយុត្តាធិការផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង "មិនឱ្យលើសពី៣០(សាមសិប)ថ្ងៃក្រោយពេលដីកាដំណោះស្រាយចូលជាស្ថាពរ"[1326]។ ជាលទ្ធផលឃើញថា ការជំទាស់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃយុត្តាធិការផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលកើតចេញពីការមិនគោរពវិធានបញ្ញត្តិក្នុងដីកាដំណោះស្រាយ អាចស្ថិតក្រោមវិសាលភាពនៃវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង។

502. ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា រហូតដល់ពេលចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង "ពុំមានភាគីណានៅ អ.វ.ត.ក. បានបកស្រាយយុត្តាធិការដែលមានចែងក្នុងវិធាន ៨៩(១) និងវិធាន ៩៨ នៃវិធានផ្ទៃក្នុងផ្សេងគ្នានោះទេ"[1327] អង្គជំនុំជម្រះតុលាការកំពូលរំឭកសាលដីកានៃសំណុំរឿង ០០១ របស់ខ្លួន។ ទាក់ទងទៅនឹងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ជាដំបូង គោលគំនិតនៃអញ្ញត្រកម្មត្រូវតែបានយល់ដោយត្រឹមត្រូវផ្អែកលើការយល់ដឹងរបស់ភាគី" និងថា វិធាននេះ"បានសន្មតទុកជាមុនថា ភាគីមានលទ្ធភាពរកឃើញនូវកង្វះយុត្តាធិការដែលរងការចោទប្រកាន់នោះត្រឹមកាលបរិច្ឆេទដែលបានកំណត់ដោយច្បាប់"[1328]។ បន្ថែមលើនេះ អង្គជំនុំជម្រះបានបង្ហាញ

---

បានកើតឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងមានសិទ្ធិជាក់លាក់ផងដែរក្នុងការស្នើសុំមោឃភាពនូវភាពមិនប្រក្រតីនោះ")។

[1324] វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។ មាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ២៥២។

[1325] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦០ (បញ្ជាក់បន្ថែម)។

[1326] វិធាន ៨៩ នៃវិធានផ្ទៃក្នុង។

[1327] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៩។

[1328] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣០។

នូវភាពខុសគ្នារវាងកំហុសផ្នែកយុត្តាធិការ ដែល"ពុំបានរារាំងដល់កិច្ចដំណើរការនីតិវិធី*ពីដំបូង*"ជាមួយនឹងការជំទាស់ផ្នែកយុត្តាធិការដាច់ខាតដែលប្រសិនបើជោគជ័យអាចមោឃៈកិច្ចដំណើរការនីតិវិធី[1329]។ អង្គជំនុំជម្រះតុលាការកំពូលបានដឹងជាមុននូវការបកស្រាយយ៉ាងទូលំទូលាយមួយលើវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ដែលពុំបានកម្រិតចំពោះអញ្ញត្រកម្មទៅលើយុត្តាធិការ"ផ្នែកច្បាប់"របស់អង្គជំនុំជម្រះ ដែលជាចាំបាច់អាចស្ថិតក្រោមប្រភេទនៃការជំទាស់លើយុត្តាធិការដាច់ខាត។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើសារណារបស់ភាគីស្តីពីលក្ខណៈនៃអញ្ញត្រកម្មរបស់ ខៀវ សំផន ដូចខាងក្រោម។

503. សំអាងផ្លូវច្បាប់ដទៃទៀតដែល ខៀវ សំផន បានយោងនោះ មានការជាប់ពាក់ព័ន្ធតិចតួច[1330]។ ខៀវ សំផន បានសំអាងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធទៅនឹងសំណើសុំអនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ប៉ុន្តែមិនស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុងស្តីពីអញ្ញត្រកម្ម[1331]។ អាស្រ័យហេតុនេះ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ស្របតាមវិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះ"មានកាតព្វកិច្ចពិនិត្យលើបញ្ហាថាតើ អំពើដែលបានប្រព្រឹត្តដោយជនជាប់ចោទ អាចស្មើនឹងបទឧក្រិដ្ឋ ដែរ ឬយ៉ាងណា"[1332]នោះ ពុំជាប់ពាក់ព័ន្ធទៅនឹងការបកស្រាយត្រឹមត្រូវនៃវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះ ការបញ្ជាក់របស់អង្គបុរេជំនុំជម្រះដែលថា "ការជំទាស់ដែលចោទប្រកាន់កំហុសក្នុងដីកាបញ្ជូនទៅជំនុំជម្រះ 'ច្បាស់ណាស់ពុំមែនជាបញ្ហាយុត្តាធិការ'"[1333]ត្រូវតែពិនិត្យដោយធៀបនឹងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងដែលចែងថា ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍លើដីកា ឬសេចក្តីសម្រេចដែល"អះអាងបញ្ជាក់នូវយុត្តាធិការរបស់ អ.វ.ត.ក."[1334]។ ផ្ទុយទៅនឹងវិធាន ៨៩ នៃវិធានផ្ទៃក្នុង វិធាន ៧៤

[1329] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣១។

[1330] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤០-៣៤២។

[1331] សំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ សុំអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E95 ("សំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ស្តីពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង (E95)") កថាខណ្ឌ ៦។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E95/8 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌទំនាក់ទំនង (E95/8)")។

[1332] សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌទំនាក់ទំនង (E95/8) កថាខណ្ឌ ៩ និងជើងទំព័រ ៣១។

[1333] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤១។

[1334] វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (បញ្ជាក់បន្ថែម)។

(៣)(ក) នៃវិធានផ្ទៃក្នុងជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការដូចបានកំណត់នៅក្នុងជំពូក II នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលរៀបរាប់នូវយុត្តាធិការលើរូបបុគ្គល ពេលវេលា និងកម្មវត្ថុនៃរឿងក្តីរបស់ អ.វ.ត.ក .[1335]។ ការជំទាស់ទៅលើកំហុសនីតិវិធីក្នុងដីកាបញ្ជូនទៅជំនុំជម្រះ ពុំមែនជាបញ្ហាយុត្តាធិការផ្អែកលើវិធានជាក់លាក់ឡើយ។

504. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងជាប់ពាក់ព័ន្ធទៅនឹង“យុត្តាធិការក្នុងន័យច្បាប់ និងគោលការណ៍នីត្យានុកូលភាព”ប៉ុណ្ណោះ[1336]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របទៅនឹងអង្គជំនុំជម្រះសាលាដំបូងដែលបានអះអាងថា “សំណើណាមួយដែលពាក់ព័ន្ធទៅនឹងសិទ្ធិអំណាចក្នុងការដោះស្រាយផ្នែកនានានៃដីកាដំណោះស្រាយដែលត្រូវបានលើកឡើងបន្ទាប់ពីផុតការកំណត់កាលបរិច្ឆេទសម្រាប់ការដាក់អញ្ញត្រកម្ម គប្បីចាត់ទុកថា យឺតពេល និងត្រូវបដិសេធចោល”[1337]។ បើទោះបីជាភាគីអាចពុំត្រូវបានអនុញ្ញាតក្នុងការលើកអញ្ញត្រកម្មទៅលើកំហុសយុត្តាធិការ ដែលពុំបានរារាំងដល់កិច្ចដំណើរការនីតិវិធី*ពីដំបូង* បន្ទាប់ពីការផុតកំណត់កាលបរិច្ឆេទដែលមានចែងក្នុង វិធាន ៨៩(១) នៃវិធានផ្ទៃក្នុងក៏ដោយក៏អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញថា តាមការអនុវត្តន៍ជាក់ស្តែងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ត្រឹមតែអាចត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយលើកង្វះយុត្តាធិការច្បាស់ក្រឡែត មានន័យថា កង្វះយុត្តាធិការដែលបង្ហាញឱ្យឃើញតាមអាការៈខាងក្រៅ[1338] និងថា ជនជាប់ចោទមានសិទ្ធិលើអញ្ញត្រកម្មដែលអាចមោឃៈការជំនុំជម្រះ“នៅពេលណាដែលខ្លួនសម្រេចការពារអត្ថប្រយោជន៍ផ្ទាល់ខ្លួន”[1339]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាលើលក្ខណៈនៃអញ្ញត្រកម្មរបស់ ខៀវ សំផន។

505. អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃអញ្ញត្រកម្មរបស់ ខៀវ សំផន ទៅនឹងវិសាលភាពនៃការស៊ើបអង្កេតថា ជា“ការជំទាស់ទៅនឹងយុត្តាធិការសម្រាប់ការជំនុំជម្រះលើអង្គហេតុមួយចំនួន ដែលប្រសិន

---

[1335] ជំពូក II នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ នស/រកម/១០០៤/០០៦ វិធាន ៧៤(៣)(ក) (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.”) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

[1336] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៨។

[1337] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦១ (សេចក្តីបញ្ជាក់បន្ថែម)។

[1338] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣០។

[1339] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៥។

បើទទួលយក នឹងអាចរលត់បណ្តឹងអាជ្ញានៃបទចោទដែលបានផ្អែកទៅលើនោះ”[1340]។ ខៀវ សំផន បានលើកឡើងថា ការជំទាស់របស់គាត់មានលក្ខណៈដាច់ខាត និងដើម្បីរលត់បណ្តឹងអាជ្ញា និងកាត់បន្ថយមូលដ្ឋានផ្លូវច្បាប់សម្រាប់ការដាក់ពិរុទ្ធភាព[1341]។ គាត់បានអះអាងថា ការជំទាស់របស់គាត់ពុំមានលក្ខណៈជាការជំទាស់លើយុត្តាធិការផ្នែកនីតិវិធី *ក្នុងចំណោមនោះ* ពីព្រោះយុត្តាធិការប្រភេទនេះជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដូចជាដីកាកោះឱ្យបង្ហាញខ្លួនដែលចេញពុំត្រឹមត្រូវផ្អែកតាមការលើកឡើងរបស់គាត់ដែលមានលក្ខណៈខុសប្លែកពីអញ្ញត្រកម្មទៅនឹងវិសាលភាពនៃការស៊ើបអង្កេត[1342]។ ដោយផ្អែកលើសាលដីកានៃសំណុំរឿង ០០១ ខៀវ សំផន បានលើកឡើងថា បើទោះបីជាការជំទាស់របស់គាត់យឺតពេលក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំគប្បីទទួលបានយុត្តាធិការដែលខ្លួនពុំស័ក្តិសមនឹងមាននោះទេ[1343]។ គាត់បានលើកឡើងថា ការជំទាស់របស់គាត់អាចត្រូវបានលើកឡើងនៅគ្រប់ពេល[1344]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានលើកឡើងថា អញ្ញត្រកម្មរបស់ ខៀវ សំផន គឺជាការជំទាស់ទៅនឹងយុត្តាធិការផ្នែកនីតិវិធីយ៉ាងច្បាស់លាស់ ដោយសារបានជំទាស់ទៅនឹង“វិសាលភាពរបស់អង្គជំនុំជម្រះសាលាដំបូង”ដោយផ្អែកលើការពុំបានគោរពវិធានបញ្ញត្តិក្នុងដីកាដំណោះស្រាយ ហើយពុំមែនជាយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ[1345]។

506. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សារណារបស់ ខៀវ សំផន ដែលលើកឡើងថា ការជំទាស់ផ្នែកយុត្តាធិការដាច់ខាតអាចត្រូវបានលើកឡើងគ្រប់ពេលនោះ ផ្ទុយទៅនឹងជំហររបស់គាត់នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនដែលថា វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង និងកាលបរិច្ឆេទនៃ

---

[1340] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦២។

[1341] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨១-៨៣ (ប្រតិចារឹកនៃសវនាការលើបណ្តឹងសាទុក្ខប្រើប្រាស់ពាក្យ“ជាសារវ័ន្ត” ការសំដៅយ៉ាងជាក់ច្បាស់ទៅលើអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា ដាច់ខាត)។

[1342] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨២-៨៣ (ខៀវ សំផន បានអះអាងថា អញ្ញត្រកម្មដែលគាត់បានលើកឡើងពុំជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការផ្នែកនីតិវិធីដូចបានបកស្រាយដោយអង្គជំនុំជម្រះតុលាការកំពូល។ នៅក្នុងសាលដីកាសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ជាឧទាហរណ៍នៃបញ្ហាយុត្តាធិការផ្នែកនីតិវិធី ដែលដីកាកោះឱ្យបង្ហាញខ្លួនត្រូវបានបញ្ជូនទៅជនជាប់ចោទតាមលក្ខណៈពុំត្រឹមត្រូវ ឬថា តុលាការដទៃទៀត អាចមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្តីនេះបាន។ ខៀវ សំផន បានលើកឡើងថា ការជំទាស់របស់គាត់ គ្មានអ្វីពាក់ព័ន្ធទៅនឹងបញ្ហានោះទេ និងដូច្នេះ ជាសារវ័ន្ត(ដាច់ខាត))។

[1343] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨៣-៨៤។

[1344] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨២, ៨៤-៨៥។

[1345] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៦។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨៦-៨៧។

វិធាននេះពាក់ព័ន្ធទៅនឹងយុត្តាធិការផ្នែកច្បាប់របស់ អ.វ.ត.ក.[1346]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អញ្ញត្រកម្មរបស់ ខៀវ សំផន ទៅលើវិសាលភាពនៃការស៊ើបអង្កេត បង្ហាញឱ្យឃើញតាមរយៈកិច្ចដំណើរការនីតិវិធី និងអាចរកបាននៅមុនការផុតកំណត់នៃកាលបរិច្ឆេទដែលមានចែងក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ ពាក់ព័ន្ធទៅនឹងការដែល ខៀវ សំផន បានចោទប្រកាន់ថា អង្គហេតុក្នុងដីកាដំណោះស្រាយលើសចំនួនអង្គហេតុដែលបានមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហានេះអាចរកឃើញបានបើទោះពុំមែនក្នុងអំឡុងពេលនៃការស៊ើបសួរ[1347] យ៉ាងហោចណាស់ត្រឹមពេលចេញដីកាដំណោះស្រាយនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ពីរទៅបីខែនៅមុនការផុតកំណត់នៃកាលបរិច្ឆេទក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុងដែរ[1348]។

507. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អញ្ញត្រកម្មដែលមានលក្ខណៈដាច់ខាតជាប់ពាក់ព័ន្ធទៅនឹងការជំទាស់ទៅលើយុត្តាធិការរបស់ អ.វ.ត.ក. ដូចជាយុត្តាធិការលើរូបបុគ្គល និងកម្មវត្ថុនៃរឿងក្តី ដូចបានរៀបរាប់ក្នុងជំពូក II ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ បន្ថែមលើនេះ អញ្ញត្រកម្មដាច់ខាតនេះ គឺជាការជំទាស់ដែលតម្រូវឱ្យរលត់បណ្តឹងអាជ្ញាដូចមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទាក់ទងទៅនឹងការរលត់បណ្តឹងអាជ្ញា ដូចជា ការផុតអាជ្ញាយុកាល ការលើកលែងទោសទូទៅ និងអាជ្ញាអស់ជំនុំ[1349]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលលើកឡើងថាដោយសារ ខៀវ សំផន "បានជំទាស់ទៅនឹង'វិសាលភាពនៃអង្គជំនុំជម្រះសាលាដំបូង'ដោយផ្អែកលើការមិនគោរពវិធានបញ្ញត្តិដែលរងការជំទាស់នៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែពុំបានជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. ផ្ទាល់នោះ" ទើបការជំទាស់របស់គាត់ពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការដាច់ខាត និងត្រូវស្ថិតក្រោមការកែតម្រូវតាមរយៈការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទ[1350]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ

[1346] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៣៥-៣៤២ (សេចក្តីបញ្ជាក់បន្ថែម)។

[1347] សេចក្តីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត (D158/1) កថាខណ្ឌ ២០។

[1348] ដីកាដំណោះស្រាយ (D427)។

[1349] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣១។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើញត្តិរបស់ នួន ជា ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3, E82, E88 និង E92) ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E116។ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ វិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង។

[1350] *សូមមើល ឧ.* សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Renzaho* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-97-31-A សាលដីកា ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៥៥។ សាលដីការឿងក្តី *Karera* (ICTR) កថាខណ្ឌ ២៩៣។ សាល

សាលាដំបូងពុំមានកំហុសក្នុងការបញ្ជាក់ថា អញ្ញត្រកម្មរបស់ ខៀវ សំផន ត្រូវស្ថិតក្រោមកាលបរិច្ឆេទដែលបានកំណត់តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុងនោះឡើយ[1351]។

ខ. ការចោទប្រកាន់អំពីឱកាសនិយមនៃការកំណត់ចរិតលក្ខណៈអញ្ញត្រកម្ម

508. ទាក់ទងទៅនឹងសេចក្តីសម្រេចដំបូងក្នុងការបដិសេធសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាម[1352] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះពុំបាន"ពិចារណាថា អង្គបុរេជំនុំជម្រះបានសម្រេចពុំដោះស្រាយលើទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍នោះទេ" និងថា "ការខកខានក្នុងការពិចារណាលើបញ្ហានៅពេលជំនុំជម្រះក្រោមកាលៈទេសៈទាំងនេះ អាចធ្វើឱ្យជនជាប់ចោទគ្មានលទ្ធភាពប្រសិទ្ធភាពក្នុងការជំទាស់កំហុសផ្នែកនីតិវិធីក្នុងដីកាដំណោះស្រាយ"[1353]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើវិសាលភាពនៃអញ្ញត្រកម្មប្រឆាំងនឹងបទចោទនៃការនិរទេសជនជាតិវៀតណាម "នៅពេលបញ្ហានេះត្រូវបានលើកឡើងទាន់ពេល នៅពេលជំនុំជម្រះដែលជាអញ្ញត្រកម្មផ្អែកតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង"[1354]។

509. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បានកំណត់ចរិតលក្ខណៈនៃអញ្ញត្រកម្មតាមការចង់បានរបស់ខ្លួនតែប៉ុណ្ណោះ" ពីព្រោះ (១) អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ បានពិចារណាអង្គសេចក្តីនៃសំណើរបស់សហព្រះរាជអាជ្ញាមួយចំនួនដែលបានលើកឡើងផ្អែកតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង ខណៈពេលក្នុងសំណុំរឿង ០០២/០២ បានទទួលស្គាល់ថា សំណើទាំងនេះគឺជាអញ្ញត្រកម្ម[1355] (២)

---

ដីការឿងក្តី *Muvunyi* (ICTR) កថាខណ្ឌ ២០។ សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntagerura និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-46-A សាលដីកាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ២៩។

[1351] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦១, ១៦៥។

[1352] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងយុត្តាធិការលើបទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E306/5 ("សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី (E306/5)") កថាខណ្ឌ ៩-១០ និងផ្នែកសម្រេចសេចក្តី។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធជាដំបូងនេះសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះលើបទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្អែកលើមូលដ្ឋានដែលថា គាត់"មានឱកាសពិនិត្យភាពមិនប្រក្រតីដែលចោទជាបញ្ហានោះ" និងថា គាត់"ពុំបានបង្ហាញ [...] បញ្ហានៃការជំនុំជម្រះត្រឹមត្រូវដែលតម្រូវឱ្យមានការអន្តរាគមន៍របស់អង្គជំនុំជម្រះនៅដំណាក់កាលនេះ"។

[1353] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៤។

[1354] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៤។

[1355] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៥។

សំណើដែលទាក់ទងទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាម ពុំត្រូវបានផ្អែកលើវិធាន ៨៩ នៃវិធានផ្ទៃក្នុង និងបានលើកឡើងដាច់ដោយឡែកពីអញ្ញត្រកម្មដទៃទៀត និងបានដាក់ក្រោយការផុតកំណត់នៃកាលបរិច្ឆេទតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង និង (៣) អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើសំណើប្រហាក់ប្រហែលគ្នានេះក្នុងសំណុំរឿង ០០២/០១ ដោយផ្អែកលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ និងគប្បីបានធ្វើឡើងដូចគ្នាទៅនឹងសំណើរបស់ជនជាប់ចោទដែរ[1356]។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃការកំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះសាលាដំបូងអំពី“ការអនុវត្តន៍ដូចគ្នាផ្អែកនីតិវិធីលើការនិរទេស” ដែលផ្អែកតាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានសំដៅដោយស៊ីសង្វាក់គ្នាថា ជាអញ្ញត្រកម្ម[1357]។

510. ជាដំបូង ទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី[1358] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សំណើនេះជាប់ពាក់ព័ន្ធទៅនឹងការស្នើសុំឱ្យកែប្រែប្រភេទបទចោទផ្អែកតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង[1359]។ ទាក់ទងទៅនឹងភាពអាចទទួលយកបានតាមទម្រង់ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “លើកលែងតែមានលក្ខខណ្ឌតម្រូវជាអាទិភាពនៃការជំនុំជម្រះត្រឹមត្រូវ” អង្គជំនុំជម្រះ“នៅគ្រប់ពេលអាចកែប្រែប្រភេទបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយដែលបានកែប្រែ”[1360] ដោយការប្រកាសសំណើនេះថា អាចទទួលយកបានតាមទម្រង់ផ្អែកតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង[1361]។ ប្រហាក់ប្រហែលគ្នានេះ សំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1362] ជាប់ពាក់ព័ន្ធទៅនឹងសំណើដោយផ្អែកតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង សុំកែតម្រូវការកំណត់និយមន័យនៃ

---

[1356] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៣-៣៤៥។

[1357] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៩។

[1358] សំណើរបស់សហព្រះរាជអាជ្ញាសុំអង្គជំនុំជម្រះសាលាដំបូងឱ្យចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីជាទម្រង់មួយបែបទៀតនៃការទទួលខុសត្រូវ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E100 (“សំណើរបស់សហព្រះរាជអាជ្ញាសំណុំរឿង ០០២ ស្ដីពីសហឧក្រិដ្ឋកម្មរួមទម្រង់ III (E100)”)។

[1359] សំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ស្ដីពីសហឧក្រិដ្ឋកម្មរួមទម្រង់ III (E100) កថាខណ្ឌ ១។

[1360] សេចក្ដីសម្រេចក្នុងសំណុំរឿង ០០២ លើការអនុវត្តន៍សហឧក្រិដ្ឋកម្មរួម ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E100/6 (“សេចក្ដីសម្រេចក្នុងសំណុំរឿង ០០២ ស្ដីពីសហឧក្រិដ្ឋកម្មរួម (E100/6)”) កថាខណ្ឌ ២៥។

[1361] សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីសហឧក្រិដ្ឋកម្មរួម (E100/6) ទំព័រ ១៦ (ផ្នែកសម្រេចសេចក្ដី)។

[1362] សំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ស្ដីពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង (E95)។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1363]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការកំណត់បែបនេះ“ស្ថិតទាំងស្រុងក្នុងសិទ្ធិអំណាចដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង” និងថា អង្គជំនុំជម្រះសាលាដំបូង “នៅគ្រប់ពេលអាចកំណត់តាមច្បាប់ជាធរមានក្នុងករណីនេះបាន”[1364]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅពេលនោះសំណើរបស់សហព្រះរាជអាជ្ញាពុំត្រូវបានផ្អែក ឬទទួលយកជាអញ្ញត្រកម្មស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុងនោះទេ។ បើទោះបីអង្គជំនុំជម្រះសាលាដំបូងបានសំដៅដោយភាន់ច្រឡំទៅលើសំណើនោះថា ជាអញ្ញត្រកម្មក្នុងអនុស្សរណៈឆ្នាំ ២០១៤ ក៏ដោយ[1365] ក៏នេះពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង“បានទទួលស្គាល់ថាសំណើទាំងនោះគឺជាអញ្ញត្រកម្ម”ស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1366]ដូចការអះអាងរបស់ ខៀវ សំផន ដែរ[1367]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសំដៅទៅលើក្នុងអនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងនៅក្រោយការពិតនោះ ពុំអាចកែប្រែមូលដ្ឋាននៃភាពអាចទទួលយកបានតាមទម្រង់ក្នុងសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ។

511. ទីពីរ ទាក់ទងទៅនឹងអញ្ញត្រកម្មពាក់ព័ន្ធនឹងបទចោទនៃការនិរទេសជនជាតិវៀតណាម ដែលត្រូវបានលើកជាដំបូងដោយ អៀង សារី[1368] អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា អញ្ញត្រកម្មនេះពុំបានផ្អែកលើវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ ផ្ទុយទៅវិញ តាមការអះអាងរបស់ ខៀវ សំផន ថា អញ្ញត្រកម្មនេះគឺជាផ្នែកនៃញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី(“ញត្តិរបស់ អៀង សារី”) ហើយត្រូវបានដាក់ដាច់ដោយឡែកពីប្រភេទនៃអញ្ញត្រកម្មរួមគ្នារបស់ អៀង សារី។ ទាក់ទងទៅនឹងភាពអាចទទួលយកបានតាមទម្រង់ អៀង សារី បានអះអាងថា “ច្បាប់កម្ពុជា និងវិធានរបស់ អ.វ.ត.ក. ពុំបានចែងលើកាលបរិច្ឆេទ និងនីតិវិធីសម្រាប់ការលុបចោល ឬកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធីនោះទេ”[1369] ប៉ុន្តែថា “ពេលវេលាសមស្របក្នុងការដោះស្រាយបញ្ហានេះ គឺ [...] <u>នៅមុនពេលការជំនុំជម្រះបានចាប់ផ្តើម</u> [...] ដោយសារសិទ្ធិរបស់

---

[1363] សំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ស្តីពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង (E95) កថាខណ្ឌ ៦។

[1364] សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌទំនាក់ទំនង (E95/8) កថាខណ្ឌ ៩។

[1365] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E306)។

[1366] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៥។

[1367] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៥។

[1368] ញត្តិរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារមានកំហុសនីតិវិធី ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ (ដាក់នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១) (ញត្តិរបស់ អៀង សារី (E58)) ឯកសារលេខ E58។

[1369] ញត្តិរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ (E58) កថាខណ្ឌ ១។

គាត់ក្នុងការទទួលបានការជូនដំណឹងលម្អិតអំពីបទចោទ"[1370]។ នៅពេលនោះ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងភាពអាចទទួលយកបានតាមទម្រង់នៃសំណើនេះផ្អែកលើមូលដ្ឋានថា វិធាន"ពុំបានអនុញ្ញាតឱ្យមានសំណើសុំលុបចោល ឬកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយដរាបណាបានចូលជាស្ថាពរនោះទេ"[1371]។ ដោយសារ អៀង សារី បានដាក់បញ្ជើជាក់លាក់ស្តីពីអញ្ញត្រកម្ម ហើយញ្ញត្តិស្តីពីការនិរទេសពុំត្រូវបានបញ្ជាក់អះអាងថា ជាអញ្ញត្រកម្ម ទើបសហព្រះរាជអាជ្ញាបានលើកឡើងថា គប្បីបដិសេធចោល[1372]។

512. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅមុនការចាប់ផ្តើមនៃការរៀបចំជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងពុំបានសំដៅដោយស៊ីសង្វាក់គ្នាទៅលើញត្តិរបស់ អៀវ សារី ថាជាអញ្ញត្រកម្មស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាឡើយ[1373]។ នៅពេលសវនាការបឋមក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់អំណះអំណាងផ្ទាល់មាត់ទាក់ទងទៅនឹងរាល់បញ្ហាដែលអង្គជំនុំជម្រះបានចាត់ទុកថា ជាអញ្ញត្រកម្មក្នុងវិសាលភាពនៃវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1374]។ ការជំទាស់របស់ អៀង សារី ទៅនឹងបទចោទនៃការនិរទេស ពុំស្ថិតក្នុងចំណោមអញ្ញត្រកម្មនានាដែលត្រូវបានពិភាក្សាក្នុងអំឡុងពេលនៃសវនាការនេះ[1375]។ អង្គជំនុំជម្រះសាលាដំបូងពុំបានសំដៅទៅលើញត្តិរបស់ អៀង សារី ថា ជាអញ្ញត្រកម្ម នៅពេលអង្គជំនុំជម្រះបានពន្យារពេលការចេញសេចក្តីសម្រេចរបស់ខ្លួននៅពេលក្រោយ"ផ្អែកលើកម្មវត្ថុនៃការជំនុំជម្រះលើកដំបូង" និងខណៈពេលដែលបានសន្មតចរិតលក្ខណៈនៃញត្តិដទៃទៀតថា ជាអញ្ញត្រកម្មនោះ[1376]។

---

[1370] ញត្តិរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ (E58) កថាខណ្ឌ ២ (សេចក្តីបញ្ជាក់បន្ថែម)។

[1371] សារណាតបរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ទៅនឹង "ញត្តិរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី" ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E58/1 ("សារណាតបរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២ ទៅនឹងញត្តិរបស់ អៀង សារី (E58/1)") កថាខណ្ឌ ៣ ។

[1372] "សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី (E58/1) កថាខណ្ឌ ៥។

[1373] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៩។

[1374] សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (E100/6)។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង (E141)។

[1375] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/4.1។ ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/5.1។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ E1/6.1។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ E1/7.1។

[1376] ដីកាសម្រេចបំបែកសំណុំរឿង ០០២ (E124) កថាខណ្ឌ ៩ និងជើងទំព័រ ៧ (*ប្រៀបធៀប*ញត្តិរបស់ អៀង សារី សុំលុប *ជាមួយនឹង* "ដំណោះស្រាយនៃអញ្ញត្រកម្មខាងក្រោម")។

513. យោងតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងនៅមុនការចាប់ផ្ដើមសំណុំរឿង ០០២/០១ បានសម្រេចលើផ្នែកខ្លះនៃញត្តិរបស់ អៀង សារី "ដែលស្នើសុំថា ផ្នែកខ្លះនៃដីកាដំណោះស្រាយត្រូវលុបចោល ដោយសារកំហុសនីតិវិធី"ទាក់ទងទៅនឹងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[1377]។ នៅពេលពិចារណាឃើញថា "ញត្តិសុំលុបចោល ឬកែប្រែដីកាដំណោះស្រាយជាទូទៅពុំមែនជាផ្នែកនៃក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក."[1378] អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអង្គសេចក្ដីនៃសំណើនេះផ្អែកលើសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ រួមទាំងសិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខណៈនៃបទចោទមកលើរូបគាត់ និងមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំការការពារខ្លួន[1379]។ ខៀវ សំផន បានអះអាងថា "នេះគឺជាអ្វីដែលគប្បីបានធ្វើឡើងជាមួយនឹងសំណើសុំទាំងអស់របស់គាត់ បើទោះបីជាត្រូវបានចាត់ទុកថា ជាអញ្ញត្រកម្ម ដែរ ឬយ៉ាងណាក៏ដោយ"[1380] ចំណែកសហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានសំអាងទៅលើ"ការបកស្រាយភាន់ច្រឡំរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការកំណត់ចរិតលក្ខណៈនោះ"[1381] និងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងជាប់ពាក់ព័ន្ធទៅនឹង"ការជំទាស់ដាច់ដោយឡែកមួយដោយ អៀង សារី ក្នុងផ្នែកផ្សេងមួយនៃ"ញត្តិរបស់គាត់[1382]។

514. ផ្អែកតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានកម្រិតត្រឹមផ្នែកខ្លះនៃញត្តិរបស់ អៀង សារី ដែលបានជំទាស់ទៅនឹងបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងពុំមែនការជំទាស់របស់គាត់ពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាមក៏ដោយ[1383] ក៏ក្នុងផ្នែកនៃញត្តិរបស់ អៀង សារី បានចោទប្រកាន់អំពីកំហុសផ្នែកនីតិវិធីត្រង់ចំណុចដែលថា ផ្នែកខ្លះនៃដីកាដំណោះស្រាយដែលសំដៅទៅលើឧក្រិដ្ឋកម្មស្របតាមមាត្រា ៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ខកខានក្នុងការជូនដំណឹងគ្រប់គ្រាន់ដល់ជនជាប់ចោទអំពីលក្ខណៈនៃបទ

---

[1377] ញត្តិរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ (E58) កថាខណ្ឌ ៣-៧។ សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីអញ្ញត្រកម្ម (E122) កថាខណ្ឌ ២។

[1378] សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីអញ្ញត្រកម្ម (E122) កថាខណ្ឌ ១៦។

[1379] សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីអញ្ញត្រកម្ម (E122) កថាខណ្ឌ ១៦។

[1380] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៦។

[1381] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៩។

[1382] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ៩៦៩។

[1383] សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីអញ្ញត្រកម្ម (E122) កថាខណ្ឌ ២។

ចោទប្រឆាំងនឹងគាត់ និងដូច្នេះជាការមោឃៈដោយសារកំហុសផ្នែកនីតិវិធី[1384]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញថា រហូតដល់ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ទើបអង្គជំនុំជម្រះសាលាដំបូង និង ខៀវ សំផន[1385] បានចាប់ផ្ដើមសំដៅទៅលើញត្តិស្ដីពីការនិរទេសថា ជាអញ្ញត្រកម្ម[1386] ខណៈពេលដែលសហព្រះរាជអាជ្ញាបានបញ្ជាក់អះអាងជំហររបស់ខ្លួនពីដំបូងពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបានតាមទម្រង់នៃសំណើសុំថា "ការតវ៉ានៅពេលជំនុំជម្រះពាក់ព័ន្ធទៅនឹងកំហុសផ្នែកនីតិវិធីដែលរងការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ជាក់ច្បាស់ពុំត្រូវបានអនុញ្ញាតដោយវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង"[1387]។ បន្ថែមលើនេះ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈញត្តិស្ដីពីការនិរទេសថា ជាអញ្ញត្រកម្មក្នុងសេចក្ដីសម្រេចរបស់ខ្លួនក៏ដោយ[1388] ក៏អង្គជំនុំជម្រះពុំបានពិនិត្យលើអញ្ញត្រកម្មនេះផ្អែកតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ដែលជាការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះលើអង្គហេតុនោះដែរ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់បទដ្ឋានសម្រាប់"ការជំទាស់ផ្នែកនីតិវិធីសមហេតុផល និងជាក់លាក់ទាក់ទងទៅនឹងភាពមិនប្រក្រតីដែលបានកើតឡើងក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះ"[1389]។

515. ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស៊ីសង្វាក់គ្នាទាំងស្រុងក្នុងការដោះស្រាយសំណើ ឬអញ្ញត្រកម្មដែលកើតចេញពីកំហុសផ្នែកនីតិវិធីដែលរងការចោទប្រកាន់ក្នុងដំណាក់កាលមុនការជំនុំជម្រះ និងក្នុងដំណាក់កាលផ្សេងៗនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះបានចេញសាលដីកានៃសំណុំរឿង ០០១ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ រីឯកាលបរិច្ឆេទសម្រាប់អញ្ញត្រកម្មក្នុងសំណុំរឿង ០០២ ផុតកំណត់ក្នុងដើមឆ្នាំ ២០១១[1390] និងថា បើទោះបីជាជនជាប់ចោទទាំង

---

[1384] ញត្តិរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ (E58) ឯកសារលេខ E58។

[1385] សេចក្ដីសន្និដ្ឋានមេធាវីការពារក្ដី ខៀវ សំផន ស្ដីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E306/2 ចំណងជើង និងកថាខណ្ឌ ១, ៣។

[1386] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E306) កថាខណ្ឌ ៥។ *សូមមើលបន្ថែម* សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្ដី (E306/5) កថាខណ្ឌ ៥។

[1387] សារណាតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E306/4 កថាខណ្ឌ ៦ (បញ្ជាក់បន្ថែម)។

[1388] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្ដី (E306/5)។

[1389] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្ដី (E306/5) កថាខណ្ឌ ៦។

[1390] សាលដីកាសំណុំរឿង ០០១ (F28)។

អស់ក្នុងសំណុំរឿង ០០២ បានលើកអញ្ញត្រកម្មផ្អែកតាមវិធាន ៨៩(១)(ក) និង(ខ) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងបញ្ហាដូចជា ការផុតអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋក្នុងស្រុក និងអន្តរជាតិ ការលើកលែងទោស និងអនុគ្រោះទោស*ការគ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ* គោលការណ៍នីត្យានុកូលភាព យុត្តាធិការលើកម្មវត្ថុនៃរឿងក្តីក៏ដោយ[1391] ក៏ពុំមានជនជាប់ចោទណាម្នាក់បានជំទាស់ទៅនឹងយុត្តាធិការផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងដែរ។

516. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អញ្ញត្រកម្មរបស់ អៀង សារី ទៅលើបទចោទនៃការនិរទេសជនជាតិវៀតណាម ដែលក្រោយមកត្រូវបានយកមកប្រើប្រាស់ដោយ ខៀវ សំផន មានលក្ខណៈខុសប្លែកពីអញ្ញត្រកម្មនានារបស់ ខៀវ សំផន បើទោះបីជាត្រូវបានដាក់ពីដំបូងតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណាក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អញ្ញត្រកម្មនេះត្រូវបានដាក់នៅមុនការចាប់ផ្តើមនៃកិច្ចដំណើរការនីតិវិធី និងក្នុងកាលបរិច្ឆេទដែលត្រូវបានពន្យារពេលសម្រាប់អញ្ញត្រកម្ម[1392]។ ដូច្នេះ តាមការយល់ឃើញពីដំបូងដែលថា យុត្តាធិការក្នុងវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង អាចរួមបញ្ចូលអញ្ញត្រកម្មទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអង្គហេតុ អង្គជំនុំជម្រះសាលាដំបូងក្រោយមកពុំមានកំហុសក្នុងការកំណត់ចរិតលក្ខណៈនៃការជំទាស់ស្តីពីការនិរទេសថាជាអញ្ញត្រកម្ម និងក្នុងការពិចារណាលើអង្គសេចក្តីផ្អែកលើមូលដ្ឋាននេះ។ ផ្ទុយទៅវិញ អញ្ញត្រកម្មដទៃទៀតរបស់ ខៀវ សំផន ត្រូវបានលើកឡើងជាលើកដំបូងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលចុះ

---

[1391] អញ្ញត្រកម្មរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ ស្របតាមវិធាន ៨៩ (ការផុតអាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរ) ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ឯកសារលេខ E46។ អញ្ញត្រកម្មរបស់មេធាវីការពារក្តី អៀង សារី ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E44។ អញ្ញត្រកម្មពាក់ព័ន្ធទៅនឹងយុត្តាធិការក្នុងសំណុំរឿង ០០២ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E46។ អញ្ញត្រកម្មពាក់ព័ន្ធទៅនឹងការរលត់បណ្តឹងអាជ្ញា(ឧក្រិដ្ឋកម្មក្នុងស្រុក) ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E47។ អញ្ញត្រកម្មរួមក្នុងសំណុំរឿង ០០២ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/3។ សេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អៀង សារី ក្នុងសំណុំរឿង ០០២ ស្របតាមវិធាន ៨៩ និងការជូនដំណឹងអំពីគោលបំណងនៃការមិនអនុវត្តតាមអនុស្សរណៈក្រៅផ្លូវការនាពេលអនាគត ដែលចេញជំនួសសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុនៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/4។

[1392] *ធៀប* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៥ និងជើងទំព័រ ៥៥០។ *សូមមើល* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ អញ្ញត្រកម្ម ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/1 ទំព័រ ២ (អនុស្សរណៈនេះបានសំដៅដោយភាន់ច្រឡំទៅលើ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១ ថា ជាកាលបរិច្ឆេទ និងត្រូវបញ្ជាក់ថា ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ទៅវិញទេ)។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ អញ្ញត្រកម្ម ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/5។

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ ឬនៅដំណាក់កាលបណ្ដឹងសាទុក្ខ ជាច្រើនឆ្នាំបន្ទាប់ពីការចេញដីកាដំណោះស្រាយនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។ ខៀវ សំផន ពុំបានលើកគាំទ្រភាពអាចទទួលយកបានតាមទម្រង់នៃអញ្ញត្រកម្មនេះនូវវិធានស្ដីពីនីតិវិធីដទៃទៀត លើកលែងតែសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទមកលើរូបគាត់ប៉ុណ្ណោះ[1393]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងនេះដូចខាងក្រោម។

## គ. ការចោទប្រកាន់អំពីភាពមិនយុត្តិធម៌

517. ជាជម្រើស ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ដោយសារខកខានក្នុងការទទួលស្គាល់ថា អញ្ញត្រកម្មរបស់គាត់ទៅលើវិសាលភាពនៃកិច្ចស៊ើបសួរមានលក្ខណៈសំខាន់ដែលអង្គជំនុំជម្រះត្រូវដោះស្រាយលើអង្គសេចក្ដី ដោយពុំគិតពីការកំណត់ចរិតលក្ខណៈ ឬបើទោះបីជាត្រូវបានលើកឡើងនៅពេលណាក៏ដោយ[1394]។ គាត់បានអះអាងថា អញ្ញត្រកម្មត្រូវតែបានពិចារណាបើទោះបីជានៅក្រៅកាលបរិច្ឆេទផ្អែកលើ“ភាពត្រឹមត្រូវជាសារវ័ន្ត និងដំណើរការសមស្រប” និងដោយសារសារៈសំខាន់នៃសិទ្ធិក្នុងការទទួលបានការជូនដំណឹងអំពីបទចោទលើរូបគាត់ គាត់ពុំគប្បីត្រូវបានរារាំងក្នុងការលើកឡើងអំពីកំហុសនីតិវិធីនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ សូម្បីនៅដំណាក់កាលបណ្ដឹងសាទុក្ខឡើយ[1395]។ ដូច្នេះ ខៀវ សំផន បានអះអាងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា អញ្ញត្រកម្មរបស់គាត់ពុំអាចទទួលយកបានតាមទម្រង់នោះគប្បីទុកជាមោឃៈ។ ប្រសិនបើអង្គជំនុំជម្រះបានពិនិត្យលើអង្គសេចក្ដីនៃអញ្ញត្រកម្មរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ផ្អែកលើបទចោទដែលអង្គជំនុំជម្រះបានជំនុំជម្រះដោយពុំត្រឹមត្រូវនោះ[1396]។

518. សហព្រះរាជអាជ្ញាបានអះអាងថា ក្របខ័ណ្ឌផ្នែកនីតិវិធីរបស់ អ.វ.ត.ក. បានប្រមើលដឹងជាមុនថា បញ្ហានៅមុនការជំនុំជម្រះទាំងអស់នឹងត្រូវបានដោះស្រាយនៅមុនពេលចាប់ផ្ដើមការជំនុំជម្រះ និងថា ខៀវ សំផន ខកខានក្នុងការលើកគាំទ្រភាពអាចទទួលយកបានតាមទម្រង់នូវការអះអាងវិធានស្ដីពីនីតិវិធី ឬយុត្តិសាស្ត្រ

[1393] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៦, ៣៤៩។

[1394] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៧, ៣៥០។

[1395] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៨-៣៤៩។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៨០។

[1396] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥០។

[1397]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ប្រព័ន្ធគតិយុត្ត"មានវិធានជាច្រើនដែលតម្រូវថា បញ្ហាមួយចំនួនត្រូវលើកនៅពេលជាក់លាក់ណាមួយ" និងថា ការខកខានរបស់ ខៀវ សំផន ក្នុងការលើកអំណះអំណាងរបស់គាត់ក្នុងពេលវេលាសមស្រប ឆ្លុះបញ្ចាំងឱ្យឃើញពីកង្វះការយកចិត្តទុកដាក់សមស្រប[1398]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើសិទ្ធិទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទ ទើបគាត់អាចពិនិត្យបានលើវិសាលភាពនៃការស៊ើបអង្កេតភ្លាមៗបន្ទាប់ពីទទួលបានសំណុំរឿងនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ប៉ុន្តែនៅតែខកខានដដែលក្នុងការលើកអញ្ញត្រកម្មរបស់គាត់រហូតដល់ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧[1399]។

519. សហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិផ្អែកលើ"ការសន្និដ្ឋានពុំត្រឹមត្រូវដោយច្បាស់ក្រឡែតនៃអង្គហេតុ" ឬថា សេចក្តីសម្រេចរបស់ខ្លួន"មានភាពមិនយុត្តិធម៌ និងពុំសមហេតុផល ដែលជាការរំលោភនូវឆន្ទានុសិទ្ធិនោះ"[1400]។ ផ្អែកតាមសហមេធាវីនាំមុខបានឱ្យដឹងថា ខៀវ សំផន ពុំបានចង្អុលបង្ហាញទៅលើបញ្ហាផ្នែកអង្គហេតុដែលពុំត្រឹមត្រូវនោះ[1401] និងពុំបានពន្យល់មូលហេតុដូចម្តេចបានជាការជំទាស់របស់គាត់ពុំអាចត្រូវបានលើកឡើងនៅដំណាក់កាលដំបូង និងពុំបានផ្តល់ហេតុផលដូចម្តេចបានជាអញ្ញត្រកម្មយឺតពេលនេះ គប្បីត្រូវបានអនុញ្ញាត ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[1402]។ នៅពេលសហមេធាវីនាំមុខបានលើកឡើងថា បន្ទុកនេះគឺជារបស់ ខៀវ សំផន ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន[1403] សហមេធាវីនាំមុខបានអះអាងថា ការវាយតម្លៃលើភាពត្រឹមត្រូវក្នុងកិច្ចដំណើរការនីតិវិធីត្រូវតែ (១)"ថ្លឹងថ្លែងជាមួយនឹងសិទ្ធិរបស់ភាគីផ្សេងៗ"[1404] និង (២)"ពិចារណាលើការពន្យារពេលយ៉ាងយូរក្នុងការលើកអំណះអំណាងដែលរងការចោទប្រកាន់នោះ"[1405]។ ដោយផ្អែកលើ

---

[1397] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៨-២៧៩។

[1398] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៧៩។

[1399] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨០។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩៣-៩៥។

[1400] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤៨-១៤៩។

[1401] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤៩។

[1402] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៥០។

[1403] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៥១។

[1404] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៥២។

[1405] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤៦, ១៥៣។

កត្តាទាំងនេះ សហមេធាវីនាំមុខបានលើកឡើងថា ការអនុញ្ញាតឱ្យ ខៀវ សំផន លើកអំណះអំណាងរបស់ខ្លួននៅចុងបញ្ចប់នៃការជំនុំជម្រះ ពុំមានភាពចាំបាច់ក្នុងការធានាបាននូវសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ ពីព្រោះវិសាលភាពនៃរឿងក្ដីនេះ ពុំមានអ្វី ឬពុំគប្បីជាការភ្ញាក់ផ្អើលដល់រូបគាត់ឡើយ[1406]។ ផ្ទុយទៅវិញ អាចនឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងពិតប្រាកដ[1407]។

520. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ ដោយសារការខកខានក្នុងការដោះស្រាយលើអង្គសេចក្ដីនៃអញ្ញត្រកម្មរបស់គាត់[1408]។ ដូច្នេះ ខៀវ សំផន បានជំទាស់ទៅនឹងការសម្រេចដោយប្រយោលរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដោះស្រាយលើអង្គសេចក្ដីនៃអញ្ញត្រកម្មយឺតពេលរបស់គាត់។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សិទ្ធិអំណាចដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើអញ្ញត្រកម្មយឺតពេល ត្រូវបានកម្រិតដោយសារលក្ខខណ្ឌចាំបាច់នៃវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុងចែងថា អញ្ញត្រកម្មណាមួយ"គប្បីត្រូវបានលើកឡើងយ៉ាងយូរ ៣០(សាមសិប)ថ្ងៃក្រោយពេលដីកាដំណោះស្រាយចូលជាស្ថាពរ"[1409]។ ទោះជាយ៉ាងណាក្ដី វិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុងបានចែងថា "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន [...] អង្គជំនុំជម្រះអាចទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពេលកំណត់ដែលមានចែងក្នុងវិធានទាំងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"[1410]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យពីដំបូងនូវសំណើមួយចំនួនដែលចោទប្រកាន់កំហុសផ្នែកនីតិវិធីផ្អែកលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ[1411]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយសារបានសម្រេចក្នុង

---

[1406] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៥៤-១៥៥។

[1407] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៥៤, ១៥៦-១៥៩។ ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៩ (សាក្សីដែលបានផ្ដល់សក្ខីកម្មទាក់ទងទៅនឹងបទចោទពាក់ព័ន្ធស្រុកត្រាំកក់)។

[1408] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៧, ៣៥០។

[1409] វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង (សេចក្ដីបញ្ជាក់បន្ថែម)។

[1410] វិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង។

[1411] សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីអញ្ញត្រកម្ម (E122) កថាខណ្ឌ ១៦។

ការមិនប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដោះស្រាយអញ្ញត្រកម្មឃឹតពេលរបស់ ខៀវ សំផន លើអង្គសេចក្ដី ដែរ ឬយ៉ាងណា។

521. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានអនុម័តយកវិធីសាស្ត្រមិនជ្រៀតជ្រែកទាក់ទងទៅនឹងសេចក្ដីសម្រេចដែលជាឆន្ទានុសិទ្ធិ និងត្រូវធ្វើអន្តរាគមន៍ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងតែក្នុងករណីៈ (១) ការប្រើប្រាស់ឆន្ទានុសិទ្ធិនោះបានផ្អែកលើការបកស្រាយដែលមានកំហុសបង្ហាញឱ្យឃើញច្បាស់ក្រឡែកនៃអង្គច្បាប់ (២) បានផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុដែលពុំត្រឹមត្រូវច្បាស់ក្រឡែក (៣) សេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ និងពុំសមហេតុផលដែលជាការរំលោភលើឆន្ទានុសិទ្ធិ[1412]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ពុំបានចង្អុលបង្ហាញទៅលើកំហុសផ្នែកអង្គហេតុ ឬអង្គច្បាប់ណាមួយឡើយ ផ្ទុយទៅវិញបានផ្អែកការលើកឡើងរបស់ខ្លួនទៅលើភាពពុំត្រឹមត្រូវជាសារវន្ត និងសិទ្ធិក្នុងការទទួលបានការជូនដំណឹងអំពីបទចោទលើរូបគាត់[1413]។

522. ជាដំបូង ខៀវ សំផន បានផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ក្នុងការគាំទ្រសារណារបស់គាត់ដែលថា "អញ្ញត្រកម្មត្រូវតែបានពិចារណាបើទោះបីជាត្រូវបានដាក់យឺតពេលក៏ដោយ"ផ្អែកលើភាពត្រឹមត្រូវជាសារវន្ត និងដំណើរការសមស្រប[1414]។ ទាក់ទងទៅនឹងការលើកឡើងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលថា សេចក្ដីសម្រេចដែលបានសំអាងនោះបានផ្ដល់ការបំភ្លឺតិចតួចស្ដីពីកាលៈទេសៈនៃរឿងក្ដីបច្ចុប្បន្ន[1415]។ ការពិចារណារបស់ចៅក្រមតែមួយរូបដែលថា "អញ្ញត្រកម្ម [...] ជាប់ពាក់ព័ន្ធទៅនឹងបញ្ហានៃភាពត្រឹមត្រូវជាសារវន្ត និងដំណើរការសមស្រប និងថា អញ្ញត្រកម្មនោះនឹងត្រូវបានពិចារណាបើទោះបីជាត្រូវបានដាក់យឺតពេលក៏ដោយ"[1416] ជាប់ពាក់ព័ន្ធទៅនឹងសំណើសុំពន្យារពេល ២០ ថ្ងៃថែមទៀតសម្រាប់ដាក់អញ្ញត្រកម្មក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះ និងពុំអាចប្រៀបធៀបបាននឹងស្ថានការណ៍បច្ចុប្បន្នដែលអញ្ញត្រកម្ម

---

[1412] វិធាន ១០៤(១)នៃវិធានផ្ទៃក្នុង។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៦-៩៨។

[1413] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥៩។

[1414] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥៩ យោងទៅលើរឿងក្ដី *រដ្ឋអាជ្ញាទល់នឹង Turinabo និងជនជាប់ចោទដទៃទៀត* ចៅក្រមតែមួយរូប (IRMCT) សំណុំរឿងលេខ IRMCT-18-116-PT សេចក្ដីសម្រេចលើញត្តិសុំបន្ថែមពេលវេលាដាក់អញ្ញត្រកម្ម ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៨ ("សេចក្ដីសម្រេចរឿងក្ដី*Turinabo និងជនជាប់ចោទដទៃទៀត* (IRMCT)") ទំព័រ ២។

[1415] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៤៦ និងជើងទំព័រ ៣០១។

[1416] សេចក្ដីសម្រេចរឿងក្ដី*Turinabo និងជនជាប់ចោទដទៃទៀត* (IRMCT) ទំព័រ ២។

ដែលកើតចេញពីដំណាក់កាលមុនការជំនុំជម្រះ ត្រូវដាក់រាប់ឆ្នាំក្រោយមក និងនៅចុងបញ្ចប់នៃការជំនុំជម្រះ [1417]។ បន្ថែមលើនេះ សេចក្ដីសម្រេចនេះពុំស្របជាមួយនឹងយុត្តិសាស្ត្រទូទៅដែលថា ការកំណត់កាលបរិច្ឆេទត្រូវគោរព លើកលែងតែមានករណីពិសេសដែលអាចធ្វើយុត្តិកម្មការដាក់អញ្ញត្រកម្មយឺតពេលបាន [1418]។

523. សំអាងផ្លូវច្បាប់បន្ថែមដែលបានយោងទៅលើដោយ ខៀវ សំផន[1419] ត្រឹមតែឆ្លុះបញ្ចាំងនូវគោលការណ៍ដែលត្រូវបានទទួលស្គាល់ថា លើកលែងកាលៈទេសៈពិសេស ភាគីត្រូវស្ថិតក្រោមកាតព្វកិច្ចលើកបញ្ហាណាមួយនៃអំណះអំណាងនៅមុខអង្គបុរេជំនុំជម្រះ ឬអង្គជំនុំជម្រះសាលាដំបូង"នៅពេលដែលខ្លួនអាចធ្វើដូច្នោះបានដោយសមស្រប"[1420] និងថា "ការខកខានក្នុងការជំទាស់នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ជាធម្មតានឹងបណ្ដាលអង្គជំនុំជម្រះឧទ្ធរណ៍ ពុំធ្វើការពិចារណា ដោយផ្អែកលើមូលដ្ឋាននៃការបោះបង់ចោលសិទ្ធិ"[1421]។

---

[1417] សេចក្ដីសម្រេចរឿងក្ដី *Turinabo និងជនជាប់ចោទដទៃទៀត* (IRMCT) ទំព័រ ១-២។

[1418] *សូមមើល ឧ.* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* *Baton Haxhiu* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-84-R77.5-A សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបានតាមទម្រង់នៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ១៦។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Munyarugarama* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ IRMCT-12-09-AR14 សេចក្ដីសម្រេចស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបញ្ជូនសំណុំរឿងរបស់ Phénéan Munyarugarama ទៅប្រទេសរ្វ៉ាន់ដា និងញត្តិអយ្យការសុំលុប ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ១៦។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzidana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-95-1-A សាលដីកា (សំអាងហេតុ) ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ ("សាលដីការឿងក្ដី *Kayishema និង Ruzidana* (ICTR)") កថាខណ្ឌ ៤៦-៤៨។

[1419] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៤៩ ជើងទំព័រ ៥៥៦។

[1420] សាលដីការឿងក្ដី *Šainović* (ICTY) កថាខណ្ឌ ២២៣។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Simić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-9-A សាលដីកា ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ("សាលដីការឿងក្ដី *Simić និងជនជាប់ចោទដទៃទៀត*(ICTY)") កថាខណ្ឌ ២៥។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Naser Orić* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) IRMCT-14-79 សេចក្ដីសម្រេចលើសំណើសុំការអនុញ្ញាតធ្វើបណ្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចរបស់ចៅក្រមតែមួយរូបថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៥, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ១៤។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-42-A ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ("សាលដីការឿងក្ដី *Nyiramasuhuko និងជនជាប់ចោទដទៃទៀត* (ICTR)") កថាខណ្ឌ ៦៣។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kambanda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-97-23-A សាលដីកាថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០០ កថាខណ្ឌ ២៥, ២៦, ៤១។

[1421] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-14-A សាលដីកា ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ ("សាលដីការឿងក្ដី *Niyitegeka* (ICTR)") កថាខណ្ឌ ១៩៩។ សាលដីការឿងក្ដី *Simić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៥។ *សូមមើលបន្ថែម* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* Boškoski *និងជនជាប់ចោទដទៃទៀត* អង្គ

បើទោះបីជាអង្គជំនុំជម្រះមួយចំនួនបានបញ្ជាក់ផងដែរថា "គោលការណ៍ស្ដីពីការបោះបង់ចោលសិទ្ធិពុំគប្បីរារាំងជនជាប់ចោទទាំងស្រុងក្នុងការលើកហុសក្នុងដីកាបញ្ជូនទៅជំនុំជម្រះសម្រាប់លើកដំបូងនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ក៏ដោយ"[1422] ក៏បន្ទុកនេះស្ថិតលើម្ចាស់បណ្ដឹងសាទុក្ខក្នុងការបង្ហាញថា ព្យសនកម្មធ្ងន់ធ្ងរបានបណ្ដាលមកពីកង្វះដែលរងការចោទប្រកាន់នៃការជូនដំណឹងគ្រប់គ្រាន់ក្នុងកម្រិតមួយដែលបានធ្វើឱ្យប៉ះពាល់ជាសត្យានុម័តដល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការត្រៀមរៀបចំការការពារខ្លួន[1423]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវព្យសនកម្មបែបនោះ។

524. ខៀវ សំផន អាចពិនិត្យលើវិសាលភាពនៃកិច្ចស៊ើបសួរនៅពេលដែលគាត់បានទទួលការអនុញ្ញាតចូលមើលសំណុំរឿងនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និងត្រូវបានជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃបទចោទលើរូបគាត់ តាមរយៈដីកាបញ្ជូនទៅជំនុំជម្រះ និងដីកាបំបែកកិច្ចដំណើរការនីតិវិធី[1424]។ ដូច្នេះ គាត់មានពេលគ្រប់គ្រាន់ និងមធ្យោបាយសម្រួលក្នុងការត្រៀមរៀបចំការការពារខ្លួន សូម្បីពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ថា លើសពីអ្វីដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន គប្បីបានលើកដោយសមហេតុផលនូវអញ្ញត្រកម្មរបស់ខ្លួននៅដំណាក់កាលដំបូង ឧទាហរណ៍ តាមរយៈសំណើសុំមោឃភាពតាមវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង ដោយសារជនត្រូវចោទអាចចូលមើលសំណុំរឿង និងមាន"ឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យនៅមុនការចេញដីកាដំណោះស្រាយនូវភាពមិនប្រក្រតីណាមួយដែលបានកើតឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងមានសិទ្ធិដែលចែងច្បាស់លាស់ពាក់ព័ន្ធនឹងនីតិវិធីក្នុងការស្នើសុំមោឃភាពនូវភាពមិនប្រក្រតីនោះបាន"[1425]។

---

ជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-82-A សាលក្រម ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១៨៥។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Naletilić និង Martinović* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-34-A សាលដីកាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ("សាលដីការឿងក្ដី*Naletilić និង Martinović* (ICTY)") កថាខណ្ឌ ២១។

[1422] សាលដីការឿងក្ដី *Niyitegeka* (ICTR) កថាខណ្ឌ ២០០។

[1423] សាលដីការឿងក្ដី *Simić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៥។

[1424] សេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) និងឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកបន្ថែមសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1.1 ("ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1)")។

[1425] សេចក្ដីសម្រេចលើសំណើរបស់ មាស មុត (D158/1) កថាខណ្ឌ ២០។

525. បន្ថែមលើនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលជាធរមាន ត្រូវបានបកស្រាយដើម្បីការពារជានិច្ចកាលនូវអត្ថប្រយោជន៍របស់ជនជាប់ចោទ និងជនរងគ្រោះ" និងថា "កិច្ចដំណើរការនីតិវិធីត្រូវតែយុត្តិធម៌ និងដេញដោលចំពោះមុខ និងការពារតុល្យភាពរវាងសិទ្ធិរបស់ភាគី" និងថា "កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. ត្រូវតែឈានដល់ចុងបញ្ចប់ក្នុងពេលវេលាសមស្រប"[1426]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអនុញ្ញាតការជំទាស់ទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរនៅចុងបញ្ចប់នៃការជំនុំជម្រះ ដោយគ្មានយុត្តិកម្មត្រឹមត្រូវ អាចនឹងបង្កឱ្យមានការពន្យារពេលឥតសមស្របក្នុងកិច្ចដំណើរការនីតិវិធី និងប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អាស្រ័យហេតុនេះ បន្ទាប់ពីបានពិចារណាលើការលើកឡើងរបស់ភាគី អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈមិនយុត្តិធម៌ និងពុំសមហេតុផលដែលបង្កើតបានជាការរំលោភនូវឆន្ទានុសិទ្ធិ។

## ២. ការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងការយល់ឃើញពាក់ព័ន្ធ

526. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់វិសាលភាពនៃយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតដោយផ្អែកលើសំអាងហេតុថា៖ (១) "កម្រិតនៃភាពលម្អិត"ខុសប្លែកគ្នារវាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ និង (២) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរគប្បីត្រូវបានពិចារណា"ដោយផ្អែកលើឯកសារគាំទ្រទាំងអស់"[1427]។ គាត់បានអះអាងថា វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការបានផ្អែកតែទៅលើអង្គហេតុដែលត្រូវបានកំណត់ប្រភេទគតិយុត្តដោយសហព្រះរាជអាជ្ញា និងពុំមែនអង្គហេតុដែលបានបង្ហាញក្នុងភស្តុតាងគាំទ្រ[1428]។ គាត់បានបន្ថែមថា យោងតាមវិធាន ៥៣(១) និង ៦៧(២) នៃវិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ ត្រូវរួមបញ្ចូលសេចក្តីសង្ខេបអង្គហេតុ និងការកំណត់ប្រភេទគតិយុត្ត បើមិនដូច្នោះទេ ដីកាទាំងពីរចាត់ទុកជាមោឃៈ និងគ្មានសុពលភាព[1429]។

---

[1426] វិធាន ២១ នៃវិធានផ្ទៃក្នុង (សេចក្តីបញ្ជាក់បន្ថែម)។

[1427] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54 ("បណ្តឹងសាទុក្ខរបស់ ខៀវ សំផន") កថាខណ្ឌ ៣៥១។

[1428] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥២-៣៦៦។

[1429] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥៤-៣៥៦។

527. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវនូវកម្រិតនៃភាពលម្អិតដែលតម្រូវក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក្នុងការកំណត់វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ[1430]។ សហព្រះរាជអាជ្ញាបានអះអាងថា ជាការសមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ថា វិសាលភាពនៃយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានកម្រិតដោយអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងស៊ើបសួរបន្ថែមបូករួមជាមួយនឹងជើងទំព័រ និងឧបសម្ព័ន្ធ[1431]។

528. សហមេធាវីនាំមុខយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ទឡ្ហីករណ៍ណាមួយដែលពុំត្រូវបានបដិសេធដោយសារលើកយឺតពេលគប្បីបដិសេធចោលលើអង្គសេចក្តី[1432]។

529. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា ដីកាដំណោះស្រាយចោទប្រកាន់ហួសអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយអង្គជំនុំជម្រះសាលាដំបូងបានជំនុំជម្រះពុំត្រឹមត្រូវលើអង្គហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កម្រិតនៃការលម្អិតដែលតម្រូវក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយមានលក្ខណៈខុសប្លែកគ្នា[1433]។ នៅក្នុងការកំណត់នេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវសំអាងហេតុរបស់អង្គបុរេជំនុំជម្រះដែលថា "បើទោះបីជាសេចក្តីសង្ខេបនៃអង្គហេតុ និងប្រភេទបទល្មើសដែលត្រូវបានចោទប្រកាន់ តម្រូវឱ្យមានអត្ថិភាពនៅដំណាក់កាលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏'ការពិពណ៌នាលម្អិតជាងនេះនៃអង្គហេតុជាសត្យានុម័ត និងការកំណត់ប្រភេទគតិយុត្តបានតម្រូវឱ្យមានក្នុងដីកាដំណោះស្រាយដែរ"[1434]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ក្នុងការកំណត់នូវវិសាលភាពនៃអង្គហេតុនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត អង្គ

[1430] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៥៣-២៥៤។

[1431] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៥៥-២៥៦។

[1432] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១១២ យោងទៅលើសារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤៥-៣៥៩។

[1433] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦។

[1434] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦ យោងទៅលើដីកាសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ D97/15/9 ("ដីកាសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9)") កថាខណ្ឌ ៩២។

ជំនុំជម្រះបានពិចារណាលើអង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"ដោយផ្អែកលើឯកសារគាំទ្រទាំងអស់ដែលត្រូវបានយោងទៅលើនៅក្នុងជើងទំព័រ ឬក្នុងឧបសម្ព័ន្ធនោះ"[1435]។

530. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានលើកបញ្ហាពីរចំណុច៖ (១) ថាតើ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវសម្រាប់ការកំណត់អង្គសេចក្ដីនៃរឿងក្ដី ដែរ ឬយ៉ាងណា និង (២) ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាថា អង្គជំនុំជម្រះមានយុត្តាធិការក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងបង្កើតការយល់ឃើញពាក់ព័ន្ធនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយបញ្ហានេះតាមលំដាប់លំដោយ។

## ក. បទដ្ឋានគតិយុត្តសម្រាប់កំណត់អង្គសេចក្ដីនៃរឿងក្ដី

531. វិធាន ៥៣(១)-(២) និង ៥៥(១)-(៣) នៃវិធានផ្ទៃក្នុងកំណត់និយមន័យនៃវិសាលភាពកិច្ចស៊ើបសួរតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត។ ស្របតាមវិធាន ៥៣(១) នៃវិធាផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាន៖

> ក) សេចក្ដីសង្ខេបអំពីអង្គហេតុ ខ) ប្រភេទបទល្មើសដែលត្រូវបានចោទប្រកាន់ គ) បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងដាក់ទោសបទឧក្រិដ្ឋនោះ ឃ) ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន និង ង) កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ។

វិធាន ៥៥(២) នៃវិធានផ្ទៃក្នុងចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"។

532. គួរកត់សម្គាល់ថា ខៀវ សំផន បានជ្រើសរើសលើកសាឡើងវិញនូវបញ្ហាដែលបានសម្រេចពីមុនរួចហើយដោយសហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គបុរេជំនុំជម្រះ ដែលមានអាណត្តិជំនុំជម្រះបញ្ហាទាំងនេះក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ។ ក្រៅពីនេះ ខៀវ សំផន មានឱកាសគ្រប់គ្រាន់លើកបញ្ហានេះជាអញ្ញត្រកម្មក្នុងដំណាក់កាលនៃការជំនុំជម្រះបានដោយទាន់ពេល។ ដោយសារជាតុលាការចុងក្រោយនៃ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយបញ្ហានេះ ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងផ្ដល់សច្ចភាពផ្លូវច្បាប់ និងការបញ្ជាក់ចុងក្រោយ។

---

[1435] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧។

533. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០១ បានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យស៊ើបសួរកាលៈទេសៈជុំវិញអំពើដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1436]។ អង្គបុរេជំនុំជម្រះបានកំណត់កាលៈទេសៈនោះថាជាកាលៈទេសៈមួយដែល"ក្នុងនោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើង និងបានរួមចំណែកដល់ការកំណត់ប្រភេទគតិយុត្ត"[1437]។ អង្គបុរេជំនុំជម្រះបានកំណត់បន្ថែមទៀតថា កាលៈទេសៈនោះ"ពុំត្រូវបានចាត់ទុកថា ជាអង្គហេតុថ្មី និងដូច្នេះគឺជាផ្នែកនៃកិច្ចស៊ើបសួរ"[1438]។

534. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញថា សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទគឺជាសិទ្ធិសារវន្តរបស់ជនត្រូវចោទ[1439]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដែលថា "ភាពជាក់លាក់នៃអង្គហេតុដែលបានសង្ខេបក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាច និងត្រូវតែលើកឡើងជាក់ស្តែង និងដោយសុពលភាពក្នុងដីកាដំណោះស្រាយ ដើម្បីផ្តល់ការជូនដំណឹងគ្រប់គ្រាន់ដល់មេធាវីការពារក្តីអំពីបទចោទដែលការជំនុំជម្រះត្រូវផ្អែកទៅលើក្នុងការបន្តដំណើរការនីតិវិធី"[1440]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គហេតុដែលបានផ្តល់ក្នុងជើងទំព័រ និងឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ[1441]។

---

[1436] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលចោទប្រកាន់ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 ("សេចក្តីសម្រេចសំណុំរឿង ០០១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D99/3/42)") កថាខណ្ឌ ៣៥។

[1437] សេចក្តីសម្រេចសំណុំរឿង ០០១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D99/3/42) កថាខណ្ឌ ៣៥។

[1438] សេចក្តីសម្រេចសំណុំរឿង ០០១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D99/3/42) កថាខណ្ឌ ៣៥។

[1439] វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ មាត្រា ៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ ដីកាសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៩២។

[1440] ដីកាសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៩២។

[1441] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានអនុម័តវិធីសាស្ត្រប្រហាក់ប្រហែលគ្នាក្នុងការដោះស្រាយវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ។ *សូមមើល* សេចក្តីពិចារណាសំណុំរឿង ០០៤/២ លើសំណើរបស់ អោ អាន សុំឱ្យមោឃៈកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ញដី និងបទចោទនានាទាក់ទងទៅនឹងទួលបេង មតិរបស់ចៅក្រម BEAUVALLET និង BAIK ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ D299/3/2 កថាខណ្ឌ ៥២។ សេចក្តីសម្រេចសំណុំរឿង ០០៣ ទាក់ទងទៅនឹង (១) បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើប្រាំបួនសុំឱ្យអង្គបុរេជំនុំជម្រះមោឃៈសំណើ និង (២) សំណើពីរសុំមោឃៈដែលត្រូវបានយោងដោយសហចៅក្រមស៊ើបអង្កេត មតិរបស់ចៅក្រម BEAUVALLET និង BAIK ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ D165/2/26 កថាខណ្ឌ ១៥០។ សេចក្តីសម្រេចសំណុំរឿង ០០៣ លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីមស្រេចរបស់សហចៅក្រមស៊ើបអង្កេត

ដូច្នេះ ការលើកឡើងរបស់ ខៀវ សំផន ដែលថា "កម្រិតនៃការលម្អិត"រវាងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយពុំគប្បីខុសប្លែកគ្នានោះ[1442] ពុំមានមូលដ្ឋានគាំទ្រ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"ដោយផ្អែកលើឯកសារគាំទ្រទាំងអស់" និងបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ។

### ខ. ការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងការយល់ឃើញពាក់ព័ន្ធនោះ

535. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុមួយចំនួនទាក់ទងទៅនឹង៖ (១) ស្រុកត្រាំកក់ (២) ទំនប់ត្រពាំងថ្ម (៣) ទំនប់ ១ មករា (៤) ភ្នំក្រោល (៥) ក្រាំងតាចាន់ (៦) អូរកន្សែង (៧) ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង (៨) ការបោសសម្អាត និង (៩) វិធានការលើពុទ្ធសាសនិកក្នុងសហករណ៍ត្រាំកក់។

536. ទាក់ទងទៅនឹងស្រុកត្រាំកក់ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលអង្គជំនុំជម្រះបានកំណត់ថា វិសាលភាពភូមិសាស្ត្រនៃបទចោទក្នុងដីកាដំណោះស្រាយបានរួមបញ្ចូលសហករណ៍ទាំងអស់ក្នុងស្រុកត្រាំកក់ ដែលនេះបានបណ្តាលឱ្យមានការពង្រីកដោយខុសច្បាប់នូវវិសាលភាពនៃការជំនុំជម្រះ[1443]។ គាត់បានអះអាងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររៀបរាប់តែឃុំមួយចំនួនដូចជា (១) គូស (២) សំរោង (៣) ត្រពាំងធំខាងត្បូង (៤) ត្រាំកក់ (៥) ត្រពាំងធំខាងជើង (៦) ញ៉ែងញ៉ង (៧) ស្រែរនោង និង (៨) តាភេម ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការប៉ុណ្ណោះ[1444]។

---

HARMON ស្តីពីសំណើរបស់ មាស មុត សុំឱ្យអង្គបុរេជំនុំជម្រះមោឃៈសំណើពីរសុំបំពេញកិច្ចស៊ើបសួរ មតិរបស់ចៅក្រម BEAUVALLET និង BWANA ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ D134/1/10 កថាខណ្ឌ ៥។

[1442] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៥១។

[1443] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៦៧-៣៦៩។

[1444] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៦៨។

537. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន បានផ្អែកលើការពិនិត្យដោយពុំត្រឹមត្រូវលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងថា សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យស៊ើបអង្កេតសមស្របលើអង្គហេតុដែលត្រូវបានចោទប្រកាន់[1445]។

538. សហមេធាវីនាំមុខបានគាំទ្រសារណារបស់សហព្រះរាជអាជ្ញា[1446]។

539. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "នៅពេលពិនិត្យជារួម" អង្គហេតុដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយជាប់ពាក់ព័ន្ធទៅនឹងសហករណ៍ទាំងអស់ក្នុងស្រុកត្រាំកក់ទាំងមូល មិនត្រឹមតែប្រាំបីឃុំប៉ុណ្ណោះទេ[1447]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់ទៅនឹងយុត្តាធិការរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានថា ជាការលើកឡើងយឺតពេលពីព្រោះនេះពុំត្រូវបានលើកឡើងចំពោះអង្គបុរេជំនុំជម្រះ ឬជាអញ្ញត្រកម្មស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុងឡើយ[1448]។

540. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានលើកការជំទាស់នេះនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ជាលើកដំបូង និងពុំបានជំទាស់ទៅនឹងវិសាលភាពនៃបទចោទក្នុងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ ឬជាអញ្ញត្រកម្មនៅមុខអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ដោយបានសន្និដ្ឋានថា សំណើរបស់គាត់សុំឱ្យយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានជំនុំជម្រះពុំត្រឹមត្រូវនូវអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរគប្បីត្រូវបានលើកឡើងស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1449]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "អំណះអំណាងរបស់ភាគីដែលពុំមានសក្តានុពលអាចធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់ត្រូវបដិសេធ ឬកែប្រែ អាចត្រូវបដិសេធចោលភ្លាម [...] ដោយពុំចាំបាច់ពិចារណាលើអង្គសេចក្តី"[1450]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើការជំទាស់ពាក់ព័ន្ធទៅនឹងឃុំទាំងប្រាំបីក្នុងស្រុកត្រាំកក់បន្ថែមទៀតឡើយ និងបដិសេធសំណើនេះ។

---

[1445] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨១។

[1446] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១១៨-១២០។

[1447] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨០៨។

[1448] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨០៩។

[1449] *សូមមើលខាងលើ* ផ្នែក II.ខ។

[1450] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។

541. បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងការរួមបញ្ចូលការផ្លាស់ទីដោយបង្ខំ ឬការនិរទេសដោយបង្ខំជនជាតិវៀតណាមចេញពីកម្ពុជា និងដូច្នេះការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេស និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ក្នុងស្រុកត្រាំកក់ និងខេត្តព្រៃវែងត្រូវបដិសេធចោល[1451]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគផ្នែកខ្លះលើកថាខណ្ឌ ១២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលបានពិពណ៌នាអំពីគោលនយោបាយនៃការរើសអើង និងការកម្ទេចជនជាតិវៀតណាមដោយគ្មានការលើកឡើងអំពីការនិរទេស[1452]។ គាត់បានលើកឡើងថា អង្គហេតុពាក់ព័ន្ធទៅនឹងការនិរទេសជនជាតិវៀតណាមបានផ្អែកទៅលើឯកសារក្នុងឧបសម្ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមទាំង "សៀវភៅខ្មៅ"[1453] និងសៀវភៅរបស់ Ben KIERNAN ប៉ុន្តែពុំត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1454]។ ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាថា ការលើកឡើងអំពី"ការនិរទេស"ក្នុងចំណោមបទឧក្រិដ្ឋដែលត្រូវស៊ើបអង្កេតក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតត្រូវស៊ើបសួរការនិរទេសជនជាតិវៀតណាមចេញពីកម្ពុជា[1455]។ គាត់បានបន្ថែមថា ការកំណត់ប្រភេទបទចោទនេះពាក់ព័ន្ធទៅនឹងដំណាក់កាលបីនៃការផ្លាស់ទីដោយបង្ខំនៃប្រជាជនទាំងមូល មិនមែន"ការផ្លាស់ទីជនជាតិវៀតណាម"ទៅប្រទេសវៀតណាមនោះទេ[1456]។

542. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរគោលនយោបាយស្តីពីផ្លាស់ទីជនជាតិវៀតណាម ដែលក្រោយមកបានវិវឌ្ឍទៅជាការកម្ទេច[1457]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ពុំបានអើពើលើឯកសារគាំទ្រទាំងអស់ទៅនឹងដីកាសន្និដ្ឋាន

[1451] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨០-៣៨៥។

[1452] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨០។

[1453] *សូមមើលខាងក្រោម* កថាខណ្ឌ ៥៥១ "សៀវភៅខ្មៅ" ត្រូវបានសំដៅផងដែរថាជា "ឯកសារខ្មៅ"។

[1454] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨១។

[1455] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨៤។

[1456] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨៥។

[1457] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨៤។

បញ្ជូនរឿងឱ្យស៊ើបសួរដែលបានពិពណ៌នា*ក្នុងចំណោមនោះ* នូវសុន្ទរកថាឱ្យ"បណ្តេញចេញប្រជាជនវៀតណាមដែលជាក្រុមជនជាតិភាគតិច" និងបញ្ជីឈ្មោះគ្រួសារដែលត្រូវបានដោះដូរជាមួយវៀតណាម[1458]។

543. ពាក់ព័ន្ធទៅនឹងការនិរទេសជនជាតិវៀតណាមដែលរស់នៅក្នុងកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា អៀង សារី ដំបូងបានលើកការជំទាស់នេះធ្វើជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងក្រោយមកជាអញ្ញត្រកម្មនៅមុនការបើកសំណុំរឿង ០០២[1459]។ បន្ទាប់ពីមរណភាពរបស់គាត់ និងការសួរបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង ខៀវ សំផន បានលើកអញ្ញត្រកម្មជំទាស់ទៅនឹងបទចោទនៃការនិរទេស[1460]។ ដោយហេតុថា អញ្ញត្រកម្មប្រឆាំងនឹងការនិរទេសត្រូវបានលើកឡើងទាន់ពេលនៅដំណាក់កាលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើអង្គសេចក្តីនៃអញ្ញត្រកម្មនេះ[1461]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "ការចោទប្រកាន់ផ្នែកអង្គហេតុត្រូវបានជូនដំណឹងគ្រប់គ្រាន់ដល់ជនជាប់ចោទថា សហចៅក្រមស៊ើបអង្កេតត្រូវបើកកិច្ចស៊ើបសួរលើអង្គហេតុដែលត្រូវបានប្រព្រឹត្តឡើង ដើម្បីជម្រុញគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៃការរើសអើងប្រឆាំងជនជាតិវៀតណាម រួមទាំងតាមរយៈការដាក់ឱ្យស្ថិតក្រោមការនិរទេស" និងបានបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា អង្គហេតុដែលបង្កើតជាការនិរទេស ពុំត្រូវបានរួមបញ្ចូលក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ[1462]។

544. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យស៊ើបសួរ"*ទៅលើ*"អង្គហេតុជាជាងការកំណត់ប្រភេទបទល្មើស។ អាស្រ័យហេតុនេះ បទចោទដែលបានស្នើឡើងនៃការនិរទេសក្នុងកថាខណ្ឌ ១២២ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាក់ទងទៅនឹងអង្គហេតុដែលបានពិពណ៌នាក្នុងកថាខណ្ឌ ៣៧-៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពុំមានអានុភាពលើវិសាលភាពនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"បានរៀបរាប់ច្បាស់លាស់នូវ 'ការនិរទេស' ក្នុងចំណោមបទឧក្រិដ្ឋដែលស្ថិតក្រោមការស៊ើបសួរនោះ"[1463] មានកំហុស។

---

[1458] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៨៥។

[1459] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣។

[1460] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣។

[1461] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៤, ១៦៦-១៦៨

[1462] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨។

[1463] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨។

545. អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការជំទាស់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានពង្រីកដោយពុំត្រឹមត្រូវ នូវវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដើម្បីរួមបញ្ចូលអង្គហេតុថ្មី[1464] ពុំមានមូលដ្ឋានគាំទ្រ បើផ្អែកតាមការពិនិត្យសមស្របលើឯកសារនោះ។ បន្ទាប់ពីការពិនិត្យលើផ្នែកពាក់ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឧបសម្ព័ន្ធនោះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា កថាខណ្ឌ ៣៧-៧២ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលជាប់ពាក់ព័ន្ធទៅនឹងដំណាក់កាលបីនៃការផ្លាស់ទីប្រជាជនដោយបង្ខំ និងការប្រព្រឹត្តទៅលើជនជាតិវៀតណាម ពុំបានលើកឡើងអំពីការនិរទេសជនជាតិវៀតណាមចេញពីកម្ពុជា[1465]។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើកថាខណ្ឌ ១២ (ច) នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលពិពណ៌នាអំពី"គោលនយោបាយនៃការរើសអើង និងការសម្លាប់ជនជាតិវៀតណាម"[1466]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើឯកសារគាំទ្រដែលបានលើកឡើងក្នុងជើងទំព័រនៃកថាខណ្ឌ ១២ និង ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងឧបសម្ព័ន្ធនោះ។ ជាឧទាហរណ៍ ឧបសម្ព័ន្ធ គ រួមបញ្ចូលបញ្ជីឯកសារភស្តុតាងដែលត្រូវបានវិភាគដោយសហព្រះរាជអាជ្ញា រួមជាមួយនឹងការពិពណ៌នានៃឯកសារ និងការយោងទៅលើលេខទំព័រដែលគាំទ្រអង្គហេតុដែលបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1467]។ ទាក់ទងទៅនឹងការចោទប្រកាន់ផ្នែកអង្គហេតុស្តីពីការនិរទេសជនជាតិវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសៀវភៅពីរក្បាលដែលមានក្នុងឧបសម្ព័ន្ធ គ "សៀវភៅខ្មៅៈ អង្គហេតុ និងភស្តុតាងនៃអំពើឈ្លានពាន និងការបញ្ចូលកម្ពុជាជាឧបសម្ព័ន្ធរបស់វៀតណាម"ដែលជួយដល់ការបង្ហាញនូវ"ចេតនារើសអើងលើជនជាតិវៀតណាម" និងសៀវភៅរបស់ Ben KIERNAN "របប ប៉ុល ពតៈ ពូជសាសន៍ អំណាច និងប្រល័យពូជសាសន៍ ក្នុងកម្ពុជាក្រោមរបបខ្មែរក្រហម ឆ្នាំ ១៩៧៥-៧៩" ដែលជួយបង្ហាញ*ក្នុងចំណោមនោះ*"ការផ្លាស់ទីដោយបង្ខំនូវជនជាតិពន្ធុវៀតណាម និងចេតនារើសអើង"[1468]។ បន្ទាប់ពីការពិនិត្យលើការយោងទៅលើឯកសារភស្តុតាងដែលបានលើកឡើងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សៀវភៅរបស់ Ben

[1464] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨០-៣៨៥។

[1465] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសំណុំរឿង ០០២ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារលេខ D3 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសំណុំរឿង ០០២ (D3)") កថាខណ្ឌ ៣៧-៧២។

[1466] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសំណុំរឿង ០០២ (D3) កថាខណ្ឌ ១២ (ច)។

[1467] ឧបសម្ព័ន្ធ គៈ ឯកសារភស្តុតាងដទៃទៀត ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ D3/IV។

[1468] ឧបសម្ព័ន្ធ គៈ ឯកសារភស្តុតាងដទៃទៀត ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ D3/IV ERN 00271578, 00271584-00271585។

KIERNAN បានយោងច្បាស់លាស់ទៅលើ“គោលនយោបាយក្នុងការ‘បណ្តេញចេញ’ជនជាតិពន្ធុវៀតណាមដែលរស់នៅលើទឹកដីកម្ពុជា”[1469]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខ្លឹមសារនៃឯកសារដែលបានលើកឡើងក្នុងឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលពុំមែនជាអង្គហេតុថ្មី គឺជាភស្តុតាងនៃអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនូវជនជាតិវៀតណាមចេញពីកម្ពុជាដែលសហចៅក្រមស៊ើបអង្កេតតម្រូវឱ្យស៊ើបសួរនោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់តាមរយៈការជំនុំជម្រះលើការនិរទេសជនជាតិវៀតណាមចេញពីកម្ពុជា និងបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ។

546. ជាបន្ទាប់ ខៀវ សំផន បានលើកការជំទាស់ពាក់ព័ន្ធទៅនឹងអង្គហេតុនៃ (១) ការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌរស់នៅក្នុងស្រុកត្រាំកក់[1470] (២) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងស្រុកត្រាំកក់[1471] (៣) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មីក្នុងស្រុកត្រាំកក់[1472] (៤) ការស្លាប់ដែលមិនជាប់ពាក់ព័ន្ធទៅនឹងការបង្អត់អាហារក្នុងស្រុកត្រាំកក់[1473] (៥) អំពើអមនុស្សធម៌ដទៃទៀតក្នុងទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅទំនប់ត្រពាំងថ្ម[1474] (៦) ការកម្ទេចដែលបានប្រព្រឹត្តឡើងនៅវត្តបារាយណ៍ជាន់ដែក[1475] (៧) ការស្លាប់ដោយសារគ្រោះថ្នាក់នៅការដ្ឋានធ្វើការទំនប់១មករា[1476] (៨) “ការរើសអើង”លើប្រជាជនថ្មីដោយសារមូលហេតុនយោបាយ និង

---

[1469] សៀវភៅនិពន្ធដោយ B. Kiernan ៖ *របបប៉ុល ពត ៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហម ឆ្នាំ១៩៧៥-១៩៧៩* (បោះពុម្ពផ្សាយលើកទីពីរ) ឯកសារលេខ E3/1593 ទំព័រ ៨៦-៨៩ ERN 00637441-00637444 (ពិភាក្សាចំណុចដែលលើកឡើងដោយ ប៉ុល ពត ក្នុងមហាសន្និបាតខែ ឧសភា ឆ្នាំ ១៩៧៥ រួមទាំងបទបញ្ជា“ឱ្យបណ្តេញជនជាតិវៀតណាមទាំងអស់”), ទំព័រ ៩១-៩២ ERN 00637446-00637447 (“ប៉ុល ពត បានសង្កត់ធ្ងន់នូវសារៈសំខាន់នៃបញ្ហាជម្លៀសជនជាតិវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជា”), ទំព័រ ៨៦ ERN 00637441 (“បក្សកុម្មុយនីស្តកម្ពុជាបញ្ជាឱ្យ[ជនជាតិវៀតណាមទាំងអស់ចេញពីកម្ពុជា] នៅមុនខែ កក្កដា ឆ្នាំ ១៩៧៥។ ត្រឹមចុងខែ កញ្ញា ជនជាតិវៀតណាមជាង ១៥០.០០០ ត្រូវបានប្រមូលផ្តុំ និងបញ្ជូនទៅប្រទេសវៀតណាម”), ទំព័រ ៤៤៦ ERN 00637821 (“បក្សកុម្មុយនីស្តកម្ពុជាបានបណ្តេញប្រជាជនស៊ីវិលវៀតណាមចំនួន ១៥០.០០០ នាក់ចេញពីកម្ពុជាត្រឹមខែកញ្ញា ឆ្នាំ ១៩៧៥ […]”)។

[1470] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៧០-៣៧១។

[1471] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៧២-៣៧៣។

[1472] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៧៤-៣៧៧។

[1473] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៧៨-៣៧៩។

[1474] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨៦-៣៨៧។

[1475] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៨៨-៣៨៩។

[1476] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩១។

លើជនជាតិចាមដោយសារមូលហេតុសាសនានៅការដ្ឋានធ្វើការទំនប់១មករា[1477] (៩) ការធ្វើឱ្យបាត់ខ្លួនពីការដ្ឋានធ្វើការទំនប់១មករា[1478] (១០) ពលកម្មដោយបង្ខំជាការដាក់ទណ្ឌកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល និង ក-១៧[1479] (១១) ការសួរយកចម្លើយ ឬការធ្វើទារុណកម្មលើរូបកាយ ឬផ្លូវចិត្តនៅភ្នំក្រោល[1480] (១២) ការធ្វើឱ្យបាត់ខ្លួនទាក់ទងទៅនឹង ក-១១ និងការដ្ឋានធ្វើការភ្នំក្រោល[1481] (១៣) ការស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំឃាំងនៅក្រាំងតាចាន់[1482] (១៤) ការដាក់ឱ្យទៅជាទាសករនៅក្រាំងតាចាន់[1483] (១៥) ការធ្វើទារុណកម្មនៅក្រាំងតាចាន់[1484] (១៦) ការធ្វើបាបដោយកងសន្តិសុខ និងអ្នកសួរយកចម្លើយនៅក្រាំងតាចាន់[1485] (១៧) ការធ្វើឱ្យបាត់ខ្លួននៅក្រាំងតាចាន់[1486] (១៨) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍លើជនជាតិវៀតណាមនៅអូរកន្សែង[1487] (១៩) ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារ"ខ្វះការថែទាំផ្នែកវេជ្ជសាស្ត្រ" និង"ការធ្វើបាបលើរូបកាយ និងផ្លូវចិត្តដែលបានបង្កឡើងលើអ្នកជាប់ឃុំ"នៅអូរកន្សែង[1488] (២០) ការស្លាប់ពាក់ព័ន្ធទៅនឹងឧបទ្ទវហេតុទាក់ទងនឹងការងារនៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[1489] (២១) ការបោសសម្អាតហួសពីភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧៦ និងភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៨[1490] និង (២២) ការប្រព្រឹត្តទៅលើពុទ្ធសាសនិកនៅសហករណ៍ត្រាំកក់[1491]។

547. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានលើកការជំទាស់ទាំងនេះជាលើកដំបូងក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ ឬនៅបណ្តឹង

---

[1477] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩៣, ៣៩៥។

[1478] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩៦។

[1479] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩៧-៣៩៨។

[1480] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣៩៩-៤០០។

[1481] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤០១-៤០៣។

[1482] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤០៤-៤០៧។

[1483] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤០៨-៤០៩។

[1484] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤១០-៤១១។

[1485] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤១២-៤១៣។

[1486] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤១៤-៤១៥។

[1487] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤១៦-៤១៧។

[1488] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤១៨-៤១៩។

[1489] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១៨។

[1490] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤២០-៤២៤។

[1491] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤២៦-៤៣៤។

សាទុក្ខ។ រំឭកថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសារបានចាត់ទុកការចោទប្រកាន់ទាំងនេះថា ជាអញ្ញត្រកម្មដែលគប្បីត្រូវបានលើកក្នុងរយៈពេល ៣០ ថ្ងៃដូចបានកំណត់ដោយវិធាន ៨៩ នៃវិធានផ្ទៃក្នុង និងបានបដិសេធចោល[1492] អង្គជំនុំជម្រះតុលាការកំពូល ត្រូវបដិសេធចោលភ្លាមៗដោយពុំចាំបាច់ពិចារណាលើអង្គសេចក្ដីឡើយ។

## ខ. បទចោទដែលពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ក្នុងដីកាដំណោះស្រាយ

548. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានបដិសេធចោលភ្លាមៗ នូវអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងបទចោទដែលពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ប្រឆាំងនឹងគាត់ដោយសារខ្វះភាពជាក់លាក់[1493]។ គាត់បានអះអាងថា អំណះអំណាងរបស់គាត់មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ និងជាក់លាក់សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា និងឆ្លើយតបទៅនឹងអំណះអំណាងនោះស្របតាមវិធាន ១០១(៤) នៃវិធានផ្ទៃក្នុង[1494]។ អង្គហេតុដែលបានប្រើប្រាស់ក្នុងការចោទប្រកាន់គាត់នោះពុំបានបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាង"គ្រប់គ្រាន់នៃបទចោទ"[1495]។

549. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង"ពុំបានអើពើ"លើអំណះអំណាងរបស់គាត់ទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុមួយចំនួនក្នុងដីកាដំណោះស្រាយ[1496]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងអាចយល់ច្រឡំលើអំណះអំណាងក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ដោយសារភាពពុំជាក់លាក់នៃឯកសារការបកប្រែភាសា[1497]។ សហព្រះរាជអាជ្ញាបានអះអាងថា ការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានរារាំងដោយពេលវេលា ដោយសារគាត់ពុំបានលើកឡើងក្នុងរយៈពេល ៣០ ថ្ងៃស្របតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង[1498]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើចំណុចនីមួយៗនៃការចោទប្រកាន់អំពីភាពមិនគ្រប់

---

[1492] *សូមមើលខាងលើ* ផ្នែក VI.ក.១។

[1493] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៣៩-៤៤០។

[1494] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤១-៤៤៣។

[1495] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៣-៤៤៤។

[1496] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣០៦-៣០៩។

[1497] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣០៧។

[1498] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣០៨។

គ្រាន់នៃភស្តុតាងមុនពេលកំណត់ថាតើ អង្គហេតុត្រូវបានបង្ហាញ“ហួសពីវិមតិសង្ស័យ”ក្រោមវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា[1499]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ផ្អែកតាមការពិនិត្យនេះ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញណាមួយពាក់ព័ន្ធទៅនឹងហេតុការណ៍នៃការសម្លាប់ជនជាតិវៀតណាមពីរករណីក្នុងសហករណ៍ត្រាំកក់ និងការសម្លាប់នៅព្រលានយន្តហោះ ឬទីតាំងក្បែរនោះឡើយ[1500]។

550. សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយដោយសារការបដិសេធភ្លាមៗរបស់អង្គជំនុំជម្រះសាលាដំបូងមិនពិនិត្យលើអង្គសេចក្ដីនៃអំណះអំណាងនេះ[1501]។ សហមេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំណះអំណាងរបស់គាត់ជាអញ្ញត្រកម្ម និងបានបដិសេធចោលដោយសារយឺតពេល[1502]។

551. ជាការឆ្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា សហចៅក្រមស៊ើបអង្កេតខកខានក្នុងការប្រមូលអង្គហេតុគ្រប់គ្រាន់ដើម្បីបង្ហាញបទចោទក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខៀវ សំផន ខកខានក្នុងការលើកមូលដ្ឋានគាំទ្របទចោទណាមួយដែលគាត់សំដៅលើថា គ្មានភស្តុតាងគាំទ្រគ្រប់គ្រាន់ ឬពន្យល់បញ្ហាថាតើ អង្គបុរេជំនុំជម្រះតម្រូវឱ្យជំនុំជម្រះការជំទាស់ណាមួយពាក់ព័ន្ធបញ្ហានេះ ដែរ ឬយ៉ាងណា[1503]។

552. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភាគីត្រូវបានរំពឹងឱ្យផ្ដល់ការយោងជាក់លាក់ទៅលើទំព័រប្រតិចារឹកពាក់ព័ន្ធ ឬកថាខណ្ឌក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់[1504]។ អង្គជំនុំជម្រះតុលាការកំពូលពុំតម្រូវឱ្យ

---

[1499] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣០៩។

[1500] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣០៩ និងជើងទំព័រ ១១១២។

[1501] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦១-១៦៣។

[1502] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៤។

[1503] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៩-១៨០។

[1504] សេចក្ដីសម្រេចសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ឯកសារលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចឯកសារលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារលេខ D250/3/2/1/5 (“សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីភាពអាចទទួលយកបាននូវដើមបណ្ដឹងរដ្ឋប្បវេណី (D250/3/2/1/5)”) កថាខណ្ឌ ២២ យោងទៅលើ។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Blaškić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14-A សាលដីកាថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ (“សាលដីកាវឿងក្ដី *Blaškić* (ICTY)”) កថាខណ្ឌ ១៣។

ផ្តល់ការពិចារណាលម្អិតលើសារណាដែលមានលក្ខណៈមិនច្បាស់លាស់ ផ្ទុយគ្នា ឬស្រពេចស្រពិល ឬមានភាពមិនគ្រប់គ្រាន់ផ្សេងៗដែលបង្ហាញឱ្យច្បាស់លាស់ និងជាផ្លូវការ[1505]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងការលើកឡើងអំពីបទចោទដែលគ្មានភស្តុតាងគាំទ្រគ្រប់គ្រាន់ ខៀវ សំផន បានយោងទៅលើផ្នែកនៃសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ក្នុងជើងទំព័រតែមួយ ដោយគ្មានបញ្ជាក់កថាខណ្ឌក្នុងដីកាដំណោះស្រាយដែលគាត់បានចាត់ទុកថា"មានកំហុសផ្នែកនីតិវិធី"នោះឡើយ[1506]។ គាត់បានយោងទៅលើតែអង្គហេតុនៃការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មី និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងសហករណ៍ត្រាំកក់ ធ្វើជាការជំទាស់ទៅលើភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់គាំទ្របទចោទនៅក្នុងជើងទំព័រក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់[1507]។ ក្នុងសារណាបណ្តឹងសាទុក្ខ គាត់បានជំទាស់លើអង្គហេតុពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារការអត់អាហារក្នុងសហករណ៍ត្រាំកក់ និងបានអះអាងថា អង្គហេតុនេះពុំត្រូវបានគាំទ្រដោយបទចោទដែលមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់[1508]។ បើទោះបីជា ខៀវ សំផន មានបំណងចង់ជំទាស់អង្គហេតុពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារការអត់អាហារក្នុងស្រុកត្រាំកក់ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់នៅពេលជំនុំជម្រះ ថាពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ក៏ដោយ ក៏គាត់ខកខានក្នុងការធ្វើដូច្នោះដែរ[1509]។ ជាការឆ្លើយតប អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបដិសេធភ្លាមៗនូវអំណះអំណាងរបស់គាត់ដោយសារពុំមានមូលដ្ឋានគាំទ្រពាក់ព័ន្ធបញ្ហានេះឡើយ។

---

រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Rutaganda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-3-A សាលដីកា ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៣ ("សាលដីការឿងក្តី *Rutaganda* (ICTR)") កថាខណ្ឌ ១៩។

[1505] សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីភាពអាចទទួលយកបាននូវដើមបណ្តឹងរដ្ឋប្បវេណី (D250/3/2/1/5) កថាខណ្ឌ ២២ យោងទៅលើសាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-96-23/1-A សាលដីកា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ("សាលដីការឿងក្តី*Kunarac និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ៤៣។

[1506] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៩៤-២៩៩។

[1507] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ២៩៨ ជើងទំព័រ ២៧០ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៩៤២-៩៤៨, ១០២២-១០២៨ (ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តដោយរើសអើងលើប្រជាជនថ្មី), ១២៥៤-១២៧១ (ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តដោយរើសអើងលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

[1508] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៥-៤៤៧។

[1509] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៩៤-២៩៩។

553. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាមានការបដិសេធសារណានេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបន្តពិចារណាលើអង្គហេតុដែលរងការចោទប្រកាន់ថា ពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់សម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះដែរ ដូចជាអង្គហេតុពាក់ព័ន្ធនឹង (១) ការស្លាប់ដោយសារការអត់អាហារក្នុងសហករណ៍ត្រាំកក់ (២) "ការប្រព្រឹត្តដោយរើសអើង"ទៅលើប្រជាជនថ្មីក្នុងសហករណ៍ត្រាំកក់ និង (៣) "ការប្រព្រឹត្តដោយរើសអើង"ទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងសហករណ៍ត្រាំកក់[1510]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយជាបន្តបន្ទាប់នូវសារណារបស់ភាគី និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

១. ការស្លាប់ដោយសារការអត់អាហារក្នុងសហករណ៍ត្រាំកក់

554. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវឱ្យធ្វើការជំនុំជម្រះអង្គហេតុនៃការស្លាប់ដោយសារការអត់អាហារដែលបានកើតឡើងនៅក្នុងសហករណ៍ត្រាំកក់[1511]។ គាត់បានអះអាងថា ភស្តុតាងដាក់បន្ទុកពាក់ព័ន្ធនឹងការស្លាប់ដោយសារការអត់អាហារក្នុងស្រុកត្រាំកក់ជាប់ពាក់ព័ន្ធនឹងទៅនឹងព្រឹត្តិការណ៍ដែលត្រូវបានកម្រិតត្រឹមឃុំសំរោង និងតាភេម និងពុំគ្រប់គ្រាន់ក្នុងការគាំទ្របទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល[1512]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានពង្រីកវិសាលភាពនៃការជំនុំជម្រះដោយរួមបញ្ចូលការស្លាប់ដោយសារការអត់អាហារក្នុងនៅសហករណ៍ត្រាំកក់ទាំងអស់[1513]។

555. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន មានកំហុសដោយផ្អែកលើការបកស្រាយដោយពុំត្រឹមត្រូវនៃដីកាដំណោះស្រាយ[1514]។ សហព្រះរាជអាជ្ញាបានលើកឡើងថា គាត់ពុំបានអើពើលើភស្តុតាងនៃការស្លាប់ដោយសារការអត់អាហារក្នុងស្រុកត្រាំកក់ ពុំមែនក្នុងឃុំសំរោង និងតាភេមនោះទេ[1515]។ សហព្រះរាជអាជ្ញាបានអះអាងថា ភស្តុតាងនៃ"ការស្លាប់មនុស្សជាច្រើន [...] ដោយសារការអត់អាហារ" និង"ខ្វះស្បៀងក្នុងសហករណ៍"ក្នុងស្រុកនោះ ព្រមទាំងភស្តុតាងនៃការស្លាប់ទ្រង់ទ្រាយធំដោយ

---

[1510] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៩-១៨០, ៨១១-៨១៣។

[1511] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៥-៤៤៧។

[1512] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៦។

[1513] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៧។

[1514] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១១។

[1515] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១១។

សារការអត់អាហារក្នុងឃុំសំរោង និងតាអោមបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានបំពេញតាមលក្ខខណ្ឌនៃបទដ្ឋានស្ដីពីការបង្ហាញភស្តុតាងសម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះស្របតាមវិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង[1516]។

556. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដីកាដំណោះស្រាយបានចោទប្រកាន់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលទាក់ទងទៅនឹងការដកហូតអាហារ ទីជម្រក ការថែទាំផ្នែកវេជ្ជសាស្ត្រ និងអនាម័យ និងទាក់ទងទៅនឹងផលវិបាកនៃពលកម្មធ្ងន់ធ្ងរក្នុងស្រុកត្រាំកក់"ទាំងមូល" អាស្រ័យហេតុនេះបដិសេធអំណះអំណាងរបស់ ខៀវ សំផន[1517]។

557. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ផ្ទុយទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា ភស្តុតាងនៃការស្លាប់ដោយសារការអត់អាហារក្នុងស្រុកត្រាំកក់ត្រូវបានកម្រិតត្រឹមឃុំចំនួនពីរ[1518] ដីកាដំណោះស្រាយបានរួមបញ្ចូលភស្តុតាងពាក់ព័ន្ធដែលបានមកពីឃុំជាងទង គូស និងត្រពាំងធំក្នុងស្រុកត្រាំកក់[1519]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ភស្តុតាងក្នុងដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារការអត់អាហារក្នុងស្រុកត្រាំកក់ មានលក្ខណៈ"ស្តួចស្តើង"ដែលពុំអាចគាំទ្រការជំនុំជម្រះរឿងក្តីរបស់ ខៀវ សំផន សម្រាប់ការចោទប្រកាន់ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលនោះឡើយ[1520]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលមានអត្ថិភាព បើទោះបីជាចំនួនជនរងគ្រោះត្រូវកម្រិតតិចតួចក៏ដោយ ដោយសារពុំមានការកំណត់ចំនួនអប្បបរមានោះទេ[1521]។ ទោះជាយ៉ាងណាក្តី ដីកាដំណោះស្រាយបានយោងទៅលើ

---

[1516] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១១។

[1517] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១១។

[1518] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៦។

[1519] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៣ ជើងទំព័រ ១២៨៧ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សុត ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៧ ឯកសារលេខ E3/5835 ទំព័រ ២-៣ ERN 00163521-00163522, ទំព័រ ៦ ERN 00163525។

[1520] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៦-៤៤៧។

[1521] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntakirutimana និង Ntakirutimana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-10-A និង ICTR-96-17-A សាលដីកាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ("សាលដីការឿងក្តី *Ntakirutimana* និង *Ntakirutimana* (ICTR)") កថាខណ្ឌ ៥១៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-33-T សាលក្រម ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ ("សាលក្រមរឿងក្តី *Krstić* (ICTY)") កថាខណ្ឌ ៥០១។ សាលដីការឿងក្តី *Stakić* (ICTY) កថាខណ្ឌ ២៦០-២៦១។

ចម្លើយរបស់សាក្សីជាច្រើនដែលពិពណ៌នាអំពីទំហំនៃការស្លាប់ដោយសារការអត់អាហារព្រមទាំងកង្វះស្បៀងក្នុងសហករណ៍ត្រាំកក់[1522]។

558. អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា ជាកំហុសចំពោះការដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបទចោទនៃការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយផ្អែកលើអង្គហេតុនៃការស្លាប់ដោយសារការដកហូតអាហារ ទីជម្រក ការថែទាំផ្នែកវេជ្ជសាស្ត្រ និងអនាម័យ និងផលវិបាកនៃពលកម្មធ្ងន់ធ្ងរ[1523]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយផ្អែកលើការខកខានរបស់ ខៀវ សំផន ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យជំនុំជម្រះលើអង្គហេតុនៃការស្លាប់ដោយសារការអត់អាហារដែលបានកើតឡើងនៅក្នុងសហករណ៍ត្រាំកក់នោះ ដូច្នេះបដិសេធអំណះអំណាងនេះ។

២. "ការប្រព្រឹត្តដោយរើសអើង"ទៅលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់

559. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលបញ្ជាក់ថា អង្គជំនុំជម្រះបានតម្រូវសមស្របឱ្យជំនុំជម្រះអង្គហេតុនៃការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់[1524]។ គាត់បានអះអាងថា ភស្តុតាងក្នុងកថាខណ្ឌ ៣០៥ នៃដីកាដំណោះស្រាយដែលគាំទ្រការចោទប្រកាន់នូវការរឹតត្បិត"សិទ្ធិផ្នែកនយោបាយ"របស់ប្រជាជនថ្មី ពុំមានលក្ខណៈគ្រប់គ្រាន់[1525]។ គាត់បានអះអាងថា កំណត់ហេតុស្តាប់ចម្លើយរបស់ ភ្នៅ យ៉ារ និង ពិល ឃាង ដែលជាអ្នកតាំងទីលំនៅក្នុងឃុំសំរោង ពុំបានគាំទ្រសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតក្នុងកថាខណ្ឌ ៣០៥ នៃដីកាដំណោះ

---

[1522] ដីកាដំណោះស្រាយ(D427) កថាខណ្ឌ ៣១២ ជើងទំព័រ ១២៨២-១២៨៣ យោងទៅលើ *ក្នុងចំណោមនោះ* កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹម ឈៀង ឯកសារលេខ E3/7980 ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៥ ERN 00165304 ("ប្រធានឃុំមិនបានខ្វល់ខ្វាយពីប្រជាជនឡើយ។ គាត់បានទុកឱ្យពួកគេស្លាប់ដោយសារអត់អាហារ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក ស៊ឹម ឯកសារលេខ E3/5519 ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ ៦ ERN 00408334 ("សៈ ដល់ពេលអត់មានអង្ករហូបគ្រប់គ្រាន់ដូចនេះ តើប្រជាជនមានជំងឺ ឬស្លាប់ដោយសារអត់បាយ ឬទេ? ឆ.៤២៖ មានអ្នកឈឺច្រើន និងស្លាប់ដោយសារជំងឺ។ [...] សៈ តើលោកមានស្គាល់អ្នកណាដែលស្លាប់ដោយសារការអត់បាយ ដែរ ឬទេ? ឆ. ៤៣៖ បាទខ្ញុំស្គាល់ មានឈ្មោះ តាប៊ិន តាម៉ាក យាយ តង ។ល។")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ពិល ឃៀង ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ E3/5135 ERN 00165295 ទំព័រ ២ ("បាយអត់គ្រប់គ្រាន់ [...] ខ្ញុំឃើញប្រជាជនអត់បាយ និងកើតជម្ងឺហើម")។

[1523] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១១។

[1524] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៨-៤៥០។

[1525] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៩។

ស្រាយ ពីព្រោះមានតែ ពិល ឃាង ម្នាក់បានឆ្លើយថា ប្រជាជនថ្មី"ពុំមានសិទ្ធិក្លាយជាប្រធានកង ឬប្រធានភូមិ" និងថា ភស្តុតាងតែមួយនេះពុំគ្រប់គ្រាន់ឡើយ[1526]។ ខៀវ សំផន បានជំទាស់ផងដែរថា ការដាក់ពិរុទ្ធភាពរបស់គាត់សម្រាប់"ការប្រព្រឹត្តដោយរើសអើង"ទៅលើប្រជាជនថ្មី ថាជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មី គឺជាកំហុស និងត្រូវបដិសេធចោល[1527]។

560. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ភាន់ច្រឡំដោយជឿថា ការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មីក្នុងសហករណ៍ត្រាំកក់ក្នុងដីកាដំណោះស្រាយ ត្រឹមតែជាការរឹតត្បិតសិទ្ធិផ្នែកនយោបាយដែលពុំអាចពួកគេធ្វើជាមេកងតែប៉ុណ្ណោះ[1528]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានអើពើទៅលើភស្តុតាងដទៃទៀតដែលគាំទ្រអង្គហេតុនៃការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់ និងបានបង្ហាញថា ប្រសិនបើប្រជាជនថ្មីត្រូវបាន"គ្រប់គ្រង"ដោយប្រជាជនមូលដ្ឋាន ប្រជាជនថ្មីពុំអាចកាន់កាប់តួនាទីដែលគ្រប់គ្រងលើប្រជាជនមូលដ្ឋាននោះទេ រួមទាំងតួនាទីជាប្រធានកងផងដែរ[1529]។

561. ក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសារណារបស់ ខៀវ សំផន ទាក់ទងនឹងបញ្ហានេះ និងបានយល់ឃើញថា ដីកាដំណោះស្រាយបានលើកឡើងថា ប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោមវិធានការតឹងរ៉ឹង និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀតក្នុងសហករណ៍ រួមទាំងស្ថិតក្រោមការតាមដានយ៉ាងជិតដល់របស់ឈ្លបដែលអាចឈានទៅដល់ការចាប់ខ្លួន និងការរងទុក្ខជាញឹកញាប់ដោយសារបញ្ហាសុខភាព[1530]។

562. ជាការឆ្លើយតបទៅនឹងការចោទប្រកាន់ថា ការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មីត្រូវបានកម្រិតត្រឹមការរឹតត្បិតលើសិទ្ធិផ្នែកនយោបាយ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដីកាដំណោះស្រាយបង្ហាញភស្តុតាងបន្ថែមនៃការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មី ដូចជាការដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ប្រជាជនមូលដ្ឋាន ការបែងចែកនៅក្នុងកងពលកម្មខុសៗគ្នា ការរងទុក្ខដោយសារបញ្ហាសុខ

---

[1526] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៤៩។

[1527] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥០។

[1528] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១២។

[1529] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១២។

[1530] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៦, ៣១៣, ៣១៩, ១៤១៨។

ភាព និងការអប់រំកែប្រែ[1531]។ នៅក្នុងការវាយតម្លៃលើភស្តុតាងនៃការប្រព្រឹត្តដោយរើសអើងទៅលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់ទាំងមូល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ គឺជាកំហុស។

៣. "ការប្រព្រឹត្តដោយរើសអើង"ទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងសហករណ៍ត្រាំកក់

563. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានប្រកាសថាខ្លួនបានតម្រូវឱ្យពិចារណាលើអង្គហេតុនៃការប្រព្រឹត្តដោយរើសអើងទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងសហករណ៍ត្រាំកក់[1532]។ ជាពិសេស គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការបដិសេធអំណះអំណាងរបស់គាត់ដែលថា ការចោទប្រកាន់ក្នុងកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយដែលអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលយ៉ាងជិតដល់នោះ ពុំគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើគាត់ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[1533]។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដាក់ចំណាត់ថ្នាក់អង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៃអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងស្រុកត្រាំកក់ថា ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[1534]។ គាត់បានអះអាងថា ការចោទប្រកាន់ក្នុងកថាខណ្ឌ ៤៩៨ នៃដីកាដំណោះស្រាយពុំត្រូវបានគាំទ្រដោយភស្តុតាងគ្រប់គ្រាន់ និងអាស្រ័យហេតុនេះ គាត់ពុំចាំបាច់ឆ្លើយតបឡើយ[1535]។ គាត់បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារការដាក់បញ្ចូលអង្គហេតុនៃការតាមដាន និងការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទៅក្នុងគោលនយោបាយដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងថា ការដាក់ពិរុទ្ធភាពនោះគប្បីត្រូវបដិសេធចោល[1536]។

[1531] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៥-៣០៦, ៣១៣, ៣១៥។

[1532] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥១។

[1533] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥២-៤៥៣។

[1534] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥៤។

[1535] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥៤-៤៥៦។

[1536] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥៧។

564. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវនូវដីកាដំណោះស្រាយ និងខកខានក្នុងការទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យបើកកិច្ចស៊ើបសួរអង្គហេតុនានាក្នុងស្រុកត្រាំកក់ទាំងមូល[1537]។ សហព្រះរាជអាជ្ញាបានអះអាងថា គាត់បានជំទាស់ទៅនឹងតម្លៃជាភស្តុតាងនៃភស្តុតាងស្តីពីការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងពុំបានអើពើភស្តុតាងតាមបរិបទ និងបញ្ជាក់បន្ថែមពាក់ព័ន្ធបញ្ហានេះ[1538]។ សហព្រះរាជអាជ្ញាបានបន្ថែមថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ភស្តុតាងនៃការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពុំបានបំពេញសមស្របតាមបទដ្ឋាននៃការបង្ហាញភស្តុតាងតាមវិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង[1539]។

565. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងរបស់ ខៀវ សំផន និងបានសន្និដ្ឋានថា ដីកាដំណោះស្រាយបានពិពណ៌នាអំពីការបោសសម្អាតអ្នក"ដែលមាននិន្នាការនៃរបប លន់ នល់"[1540]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា ផ្នែកស្តីពីសហករណ៍ត្រាំកក់ត្រូវពិនិត្យរួមជាមួយផ្នែកស្តីពីមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលពិពណ៌នាអំពីការប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទូទាំងស្រុកត្រាំកក់ទាំងមូល[1541]។

566. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ផ្ទុយទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន អំពីកង្វះភស្តុតាងដែលបង្ហាញថា អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានដាក់ឱ្យស្ថិតក្រោមការឃ្លាំមើល[1542] ភស្តុតាងបន្ថែមក្នុងដីកាដំណោះស្រាយបានគាំទ្រអង្គហេតុដែលរងការជំទាស់នោះ។ របាយការណ៍ស្តីពីសកម្មភាពខ្មាំងបានជូនដំណឹងយ៉ាងពិសេសដល់អង្គការអំពីការរកឃើញអតីតអ្នករដ្ឋការនៃរបប លន់ នល់ ប្រាំពីរនាក់ មាន៖ អនុសេនីឯក អនុសេនីយ៍ទោស ឬត្រី ដែលកើតចេញពីបទបញ្ជាអង្គការឱ្យចាប់ខ្លួនក្រុមនេះក្នុងឃុំគូសស្រុកត្រាំកក់[1543]។ ពាក់ព័ន្ធទៅនឹងសារណារបស់ ខៀវ សំផន ដែលថា ភស្តុតាងក្នុងកថាខណ្ឌ

[1537] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១៣។

[1538] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១៣។

[1539] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១៤។

[1540] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១២ យោងទៅលើ *ក្នុងចំណោមនោះ* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៩។

[1541] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១២។

[1542] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥២-៤៥៣។

[1543] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤៩៨ ជើងទំព័រ ២១៦០ យោងទៅលើ *ក្នុងចំណោមនោះ* របាយការណ៍ស្តីពីសកម្មភាពខ្មាំងឯកសារលេខ E3/2441 ទំព័រ ២០-២១ ERN 00270952-00270953 ("មានម្នាក់ទៀតឈ្មោះ ជឹម

៣១៩ នៃដីកាដំណោះស្រាយមានលក្ខណៈស្ងួចស្តើង និងថា ការឃ្លាំមើលនោះពុំមានភស្តុតាងណាមួយគាំទ្រ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "ពុំមានវិធានទូទៅដែលចែងថា ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យពុំអាចត្រូវបានបង្កើតឡើងដោយសមស្រប ប្រសិនបើមិនមានភស្តុតាងគាំទ្រចាប់ពីពីរឡើងទៅនោះទេ។ ផ្ទុយទៅវិញ ភាពសមហេតុផលនៃការយល់ឃើញនឹងត្រូវបានកំណត់ដោយផ្អែកលើការជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាននៃភស្តុតាង"[1544]។

567. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដីកាដំណោះស្រាយបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ជាំង ស្រីមុំ ដែលជាអ្នកតាំងទីលំនៅឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ បានពិពណ៌នាការចាប់ខ្លួនមនុស្សប្រមាណ ១០ នាក់ រួមទាំងអតីតប៉ូលីស និងទាហាននៃរបបសាធារណរដ្ឋខ្មែរ និងបានលើកឡើងអំពីឈ្លបលួចស្តាប់ម្តងម្កាលតាមផ្ទះប្រជាជន និងទទួលភារកិច្ចធ្វើការចាប់ខ្លួន[1545]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ពុំបានជំទាស់ទៅនឹងភាពអាចជឿជាក់ និងទុកចិត្តបាននៃចម្លើយរបស់ ជាំង ស្រីមុំ[1546] ដែលជាទូទៅគួរជឿជាក់បាន និងអាចសំអាងដោយសមហេតុផលទៅលើក្នុងការធ្វើសេចក្តីសន្និដ្ឋាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាឃើញថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង និងការសំអាងទៅលើភស្តុតាងនៃការប្រព្រឹត្តទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងស្រុកត្រាំកក់ គឺជាកំហុសឡើយ។

568. តាមការពិនិត្យលើខ្លឹមសារនៃភស្តុតាងដែលរងការជំទាស់ពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយរបស់ អៀប ឌុច ដែលអះអាងថា "បើប្រវត្តិរូបនិយាយថា ជាទាហាន អ្នកនោះឯងត្រូវបាត់ខ្លួន" ដែលខុសពីការលើកឡើងរបស់ ខៀវ សំផន ថា អៀប ឌុច ត្រឹមតែថា"ច្បាស់ជាបាត់ខ្លួន"ប៉ុណ្ណោះ[1547]។ ផ្ទុយទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គហេតុនៃការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

---

ស្វាត សក្តិ២ ត្រូវបានចាប់ខ្លួន។ [...] សូមរាយការណ៍ជូនអង្គការ មានដូចខាងក្រោមនេះ៖ [...] ស្មើទាក់ទងឃុំ គុស ចាប់ពួកអស់នេះផង")។

[1544] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤២៥។

[1545] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាំង ស្រីមុំ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ E3/5832 ERN 00402468 (ស/ឆ ១២)។

[1546] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៥២-៥៥៣។

[1547] កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ អៀប ឌុច ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ឯកសារលេខ E3/4627 ទំព័រ ៤-៥ ERN 00163492-00163493។

ក្នុងស្រុកត្រាំកក់ ត្រូវបានគាំទ្រដោយសាក្សីតែម្នាក់គត់ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សាក្សីពីរនាក់ដទៃទៀតដែលបានលើកឡើងក្នុងដីកាដំណោះស្រាយបានបញ្ជាក់អះអាងការយល់ឃើញនេះ[1548]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា ខៀវ សំផន បានទទួលស្គាល់ថា ការចោទប្រកាន់ពាក់ព័ន្ធទៅនឹងការបោសសម្អាតអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្រោយឆ្នាំ ១៩៧៥ ត្រូវបានគាំទ្រដោយរបាយការណ៍ដែលគាត់ចាត់ទុកថា ស៊ីសង្វាក់គ្នា[1549]។

569. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានចាត់ទុកអង្គហេតុនៃការឃ្លាំមើល និងការធ្វើឱ្យបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងស្រុកត្រាំកក់ថា ជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។

570. យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការចាត់ទុកអង្គហេតុពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារការអត់អាហារ "ការប្រព្រឹត្តដោយរើសអើង"ទៅលើប្រជាជនថ្មី និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងសហករណ៍ត្រាំកក់ ពីព្រោះអង្គហេតុនេះត្រូវបានគាំទ្រដោយភស្តុតាងគ្រប់គ្រាន់សម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះ។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ។

---

[1548] កំណត់ហេតុស្តាប់ចម្លើយសាក្សី សៅ ប៊ាន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ E3/5518 ទំព័រ ៤-៥ ERN 00408316-00408317 ("គេដើរករមើលនរណាដែលធ្លាប់ធ្វើជាគ្រូបង្រៀន ឬទាហាន ឬអ្នកធ្វើការ។ អ្នកដែលត្រូវបានរកឃើញថា ជាទាហាន ឬគ្រូបង្រៀនត្រូវចាប់ខ្លួន និងនាំចេញទៅមិនដែលឃើញត្រឡប់មកវិញ។ ស៖ តើលោកមានចាំឈ្មោះអ្នកដែលត្រូវចាប់ខ្លួននោះទេ ? ឆ.២៣៖ ខ្ញុំចាំខ្លះ លន់ ហម (ប្រងប្រុសខ្ញុំ) គឺជាទាហាន។ [...] គេប្រាប់ថា ពួកគាត់ត្រូវបញ្ជូនទៅរៀនសូត្រ និងមិនដែលឃើញត្រឡប់មកវិញ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន់ ឆេន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ E3/5524 ទំព័រ ៩ ERN 00414448 ("ស៖ ខ្ញុំចង់សួរលោកអំពីពេលដែលលោកទៅក្រាំងតាចាន់ក្នុងចុងឆ្នាំ ១៩៧៥។ នៅពេលនោះតើក្រាំងតាចាន់ប្រែប្រួលដូចម្តេច ? ឆ.៤៤៖ ការដ្ឋានធ្វើការនោះពុំទាន់បានពង្រីក ប៉ុន្តែមានអ្នកទោសច្រើនជាងមុន")។

[1549] របាយការណ៍អំពីសកម្មភាពខ្មាំងជូនស្រុកត្រាំកក់ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២៩៧៧ ឯកសារលេខ E3/2048, ១៨.៣៣, ERN (EN) 00276563 (ជម្រាបជូនអង្គការអំពីអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរពីរនាក់ត្រូវបានកំណត់អត្តសញ្ញាណក្នុងឃុំជាងទងស្រុកត្រាំកក់ និងស្នើសុំបញ្ជូនពួកនេះទៅមន្ទីរសន្តិសុខ)។ ERN (EN) 00276563 (របាយការណ៍ជូនអង្គការថា "២. គ្រួសារយោធាចំនួន ១០៦ ត្រូវបានកម្ទេចដោយអង្គការរួមទាំងអ្នកដែលបានស្លាប់សរុប ៣៩៣ នាក់។ ៣. គ្រួសារយោធាចំនួន ២៣១ នៅសេសសល់ [...] ជម្រាបជូនបក្សថា មានគ្រួសារបន្ថែមខ្លះទៀតដែលពុំទាន់ត្រូវបានកំណត់អត្តសញ្ញាណថាតើ ជាយោធា ដែរ ឬទេ")។ ០០២៧៦៥៦៤ (ជម្រាបជូនអង្គការថា មូលដ្ឋានស្រុកតាភេម"បានពិនិត្យ និងបោសសម្អាតខ្មាំងដែលមានឋានន្តរសក្តិបន្ទាប់ពីបានទទួលការណែនាំពីបក្ស")។

## គ. កង្វះការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុសន្សានុម័តដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២

571. ខៀវ សំផន បានលើកការជំទាស់ទៅនឹង (១) ការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការជូនដំណឹងអំពីបទចោទ និងវិសាលភាពនៃការជំនុំជម្រះ (២) វិសាលភាពនៃការជំនុំជម្រះទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយចំនួន និង (៣) វិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងក្រុមមួយចំនួន។ អំណះអំណាងទាំងនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយខាងក្រោម។

### ១. ការចោទប្រកាន់កំហុសក្នុងបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការជូនដំណឹងបទចោទ

572. ខៀវ សំផន បានលើកឡើងពាក់ព័ន្ធទៅនឹងបទដ្ឋានគតិយុត្តដែលតាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលអាចជាការចោទប្រកាន់កំហុសក្នុងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជូនដំណឹងអំពីបទចោទ និងវិសាលភាពនៃការជំនុំជម្រះដែលបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកអំណះអំណាងទាំងនេះពុំមានលក្ខណៈជាក់លាក់ និងពុំច្បាស់លាស់ ប៉ុន្តែទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងត្រូវពិចារណាជាសង្ខេបលើអំណះអំណាងទាំងនេះដើម្បីបំភ្លឺបទដ្ឋានដែលត្រូវអនុវត្ត[1550]។

573. ខៀវ សំផន បានអះអាងថា ការកំណត់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌត្រូវតែបានបំភ្លឺដោយការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុ និងវាយតម្លៃដោយយោងទៅលើតែអង្គហេតុដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ ដែលនោះទំនងជាឈានទៅដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ[1551]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិនិត្យដីកាដំណោះស្រាយ"ទាំងមូល" និងថា មានលក្ខណ្ឌតម្រូវដែលបទចោទត្រូវតែគូសបង្ហាញឱ្យបានជាក់លាក់គ្រប់គ្រាន់[1552]។

574. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់តាមរយៈការយោងទៅលើលក្ខខណ្ឌដែលបានគូសបង្ហាញនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យ

---

[1550] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៥៨។

[1551] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៦០។

[1552] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៦១-៤៦២ យោងទៅលើ *ក្នុងចំណោមនោះ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៣។

កម្រិតការយល់ឃើញរបស់ខ្លួនត្រឹមអង្គហេតុទាំងនោះដែលបានរួមបញ្ចូលក្នុងដីកាបញ្ជូនទៅជំនុំជម្រះ[1553]។ សហព្រះរាជអាជ្ញាបានឆ្លើយតបផងដែរថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យធ្វើការពិនិត្យលើដីកាដំណោះស្រាយជារួមជាជាងជ្រើសរើសផ្នែកៗ[1554]។

575. សហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន បានលើកជាក់លាក់នូវអញ្ញត្រកម្មចំនួនប្រាំពីរជាលើកដំបូងនៅបណ្តឹងសាទុក្ខដោយពុំបានផ្តល់យុត្តិកម្ម ឬពន្យល់ និងថា អញ្ញត្រកម្មនេះពុំត្រូវបានអនុញ្ញាតអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1555]។

576. អង្គជំនុំជម្រះតុលាការកំពូលបកស្រាយវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងដោយផ្អែកលើវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងវំឮកថា ដីកាបញ្ជូនទៅជំនុំជម្រះត្រូវគូសបង្ហាញអត្តសញ្ញាណរបស់ជនជាប់ចោទ មានការពិពណ៌នាអំពីអង្គហេតុសត្យានុម័ត និងប្រភេទគតិយុត្តដោយសហចៅក្រមស៊ើបអង្កេត។ ដីកាបញ្ជូនទៅជំនុំជម្រះត្រូវគូសបង្ហាញស៊ីសង្វាក់គ្នានូវអង្គហេតុសត្យានុម័តនៃរឿងក្តីឱ្យបានលម្អិតគ្រប់គ្រាន់ដើម្បីជូនដំណឹងជនជាប់ចោទអំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងនឹងរូបគាត់ ដើម្បីត្រៀមលក្ខណៈការពារខ្លួនដោយប្រសិទ្ធភាព[1556]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នាក្នុងមាត្រា ២៤៧[1557]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមថា បទដ្ឋានអន្តរជាតិតម្រូវថា ដីកាបញ្ជូនទៅជំនុំជម្រះត្រូវគូសបង្ហាញអង្គហេតុសត្យានុម័តនៃរឿងក្តីឱបាននលម្អិតដើម្បីជូនដំណឹងដល់ជនជាប់ចោទច្បាស់លាស់អំពីបទចោទប្រឆាំងនឹងគាត់ ដូច្នេះ គាត់អាចត្រៀមលក្ខណៈការពារខ្លួន[1558]។

---

[1553] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៦៣។

[1554] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១៥។

[1555] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៨-១៨០។

[1556] *សូមមើល* សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មតិរបស់ចៅក្រម BAIK និង BEAUVALLET ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 និង D382/43 កថាខណ្ឌ ១៨២។

[1557] *សូមមើល* មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[1558] សេចក្តីសម្រេចសំណុំរឿង ០០២ លើអញ្ញត្រកម្មរបស់មេធាវីការពារក្តី (E122) យោងទៅលើសាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kupreškic និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៨៨។ សេចក្តីសម្រេចសំណុំរឿង ០០១ លើសបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D99/3/42) កថាខណ្ឌ ៤៧ *យោងទៅលើ* សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* (ICTY) កថាខណ្ឌ ២០៩។

577. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំណះអំណាងនៅពេលជំនុំជម្រះដែល ខៀវ សំផន បានលើកឡើងពាក់ព័ន្ធទៅនឹងបទចោទ និងវិសាលភាពនៃការជំនុំជម្រះ[1559]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើសារណារបស់ ខៀវ សំផន នៅពេលជំនុំជម្រះដែលថា មានតែអង្គហេតុដែលជាមូលដ្ឋាននៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទប៉ុណ្ណោះ ទើបអាចសំអាងទៅលើបានដោយអង្គជំនុំជម្រះសាលាដំបូង[1560]។ ដោយពិចារណាលើអំណះអំណាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងចែងថា ដីកាដំណោះស្រាយត្រូវតែគូសបង្ហាញការពិពណ៌នាអំពីអង្គហេតុជាសត្យានុម័ត និងការកំណត់ប្រភេទគតិយុត្ត[1561]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀតលើសារណារបស់ ខៀវ សំផន នៅពេលជំនុំជម្រះដែលថា គោលការណ៍ច្បាប់ទូទៅចែងថា អង្គជំនុំជម្រះសាលាដំបូងគប្បីកម្រិតការយល់ឃើញរបស់ខ្លួនត្រឹមអង្គហេតុដែលត្រូវបានដាក់បញ្ចូលក្នុងដីកាបញ្ជូនទៅជំនុំជម្រះ និងបានសន្និដ្ឋានថា ការលើកឡើងនេះពុំចោទជាបញ្ហាឡើយ[1562]។ ដោយសាររកពុំឃើញនូវប្រភពពិតប្រាកដនៃការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ដរាបណាជនជាប់ចោទបានបញ្ជាក់ជាក់លាក់នូវការចោទប្រកាន់ច្បាស់លាស់ទាក់ទងទៅនឹងគោលការណ៍នេះ ទើបត្រូវពិចារណាលើការចោទប្រកាន់នោះ។ យោងតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនូវបទដ្ឋាន និងត្រូវពិចារណាលើសារណាជាក់លាក់របស់ ខៀវ សំផន ផ្អែកលើការអនុវត្តន៍នោះដូចខាងក្រោម។

578. ទាក់ទងទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលរងការចោទប្រកាន់ថា អង្គជំនុំជម្រះនឹងពិនិត្យលើដីកាដំណោះស្រាយទាំងមូល អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់ពាក្យពេចន៍ដូចការដកស្រង់របស់ ខៀវ សំផន ប៉ុន្តែផ្ទុយទៅវិញបានបញ្ជាក់ថា "ដីកាដំណោះស្រាយត្រូវតែពិនិត្យជារួមនៅពេលកំណត់បទចោទ និងអង្គហេតុសត្យានុម័តដែលគាំទ្រនោះ"[1563]។ ដោយសារកាតព្វកិច្ចក្នុងការការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទស្របតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង

---

[1559] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៩។

[1560] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥០ ("មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា មានតែអង្គហេតុក្នុងដីកាដំណោះស្រាយដែលជាសត្យានុម័ត និងត្រូវបានកំណត់ថា បានដាក់បន្ទុកផ្នែកព្រហ្មទណ្ឌលើជនជាប់ចោទ ទើបអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះក្នុងសាលក្រម ដកស្រង់ដើម្បីគាំទ្រវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្របារាំង")។

[1561] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥១។

[1562] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥០។

[1563] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៣។

និងរំឭកនូវយុត្តិសាស្ត្រស៊ីសង្វាក់របស់អង្គជំនុំជម្រះនៃ អ.វ.ត.ក.[1564] ព្រមទាំងវិធីសាស្ត្រផ្នែកច្បាប់ដែលបានបង្កើតឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ[1565] អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា ក្នុងការវាយតម្លៃលើដីកាបញ្ជូនទៅជំនុំជម្រះ និងការកំណត់ថាតើ ជនជាប់ចោទទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងគាត់ដើម្បីត្រៀមលក្ខណៈការពារខ្លួន ដែរ ឬយ៉ាងណា ដីកាបញ្ជូនទៅជំនុំជម្រះត្រូវតែពិចារណាជារួម និងដូច្នេះ កថាខណ្ឌនីមួយៗនោះ ពុំគប្បីពិនិត្យដាច់ដោយឡែកពីគ្នា ប៉ុន្តែគប្បីពិនិត្យដោយផ្អែកតាមបរិបទនៃកថាខណ្ឌដទៃទៀតក្នុងដីកាបញ្ជូនទៅជំនុំជម្រះ[1566]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពិនិត្យលើដីកាដំណោះស្រាយជារួមឡើយ។

## ២. ការលើកឡើងនូវកំហុសពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់

[1564] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) ជើងទំព័រ ១៦៨២។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍(អៀង សារី) ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30)") កថាខណ្ឌ ២៩៦។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយដែលពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/10 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន (D427/5/10)") កថាខណ្ឌ ៣១។

[1565] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ngirabatware* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ MICT-12-29-A សាលដីកា ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ("សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ngirabatware* (IRMCT)") កថាខណ្ឌ ២៤៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ngirabatware* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-99-54-T សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តីសុំបដិសេធដោយសារផ្អែកលើកំហុសនីតិវិធីក្នុងដីកាបញ្ជូនទៅជំនុំជម្រះដែលបានកែប្រែ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចក្នុងរឿងក្តី *Ngirabatware* លើញត្តិសុំបដិសេធ (ICTR)")កថាខណ្ឌ ២១។ សាលដីការឿងក្តី *Rutaganda* (ICTR) កថាខណ្ឌ ៣០។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mrkšič និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-13/1-A សាលដីកា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ("សាលដីការឿងក្តី *Mrkšić និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ១៣៨។ សាលដីការឿងក្តី *Gacumbitsi* (ICTR) កថាខណ្ឌ ១២៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Taylor* អង្គជំនុំជម្រះសាលាដំបូង (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")) សំណុំរឿងលេខ SCSL-2003-01-T សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តីពាក់ព័ន្ធទៅនឹងកំហុសធ្ងន់ធ្ងរផ្នែកនីតិវិធីក្នុងដីកាបញ្ជូនទៅជំនុំជម្រះរបស់អយ្យការដែលត្រូវបានកែប្រែទាក់ទងទៅនឹងការតវ៉ាអំពីសហឧក្រិដ្ឋកម្មរួម ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សេចក្តីសម្រេចរឿងក្តី Taylor លើញត្តិស្តីពីសហឧក្រិដ្ឋកម្មរួម (SCSL)") កថាខណ្ឌ ៧៦។

[1566] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) ជើងទំព័រ ១៦៨២។

579. ខៀវ សំផន បានលើកសារណាជាច្រើនពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ គាត់បានអះអាងថា អង្គហេតុមួយចំនួនពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារសហចៅក្រមស៊ើបអង្កេតខកខានកំណត់អត្តសញ្ញាណអង្គហេតុនោះក្នុងដីកាដំណោះស្រាយថាជាអង្គហេតុសត្យានុម័តដែលត្រូវបានកំណត់ប្រភេទគតិយុត្ត។

(ក) ទាក់ទងទៅនឹងស្រុកត្រាំកក់ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានយល់ឃើញថា អង្គជំនុំជម្រះតម្រូវដោយសមស្របឱ្យជំនុំជម្រះ (១) ការស្លាប់ដែលពុំមែនដោយសារការអត់អាហារ រួមទាំង"លក្ខខណ្ឌរស់នៅលំបាកវេទនា អនាម័យ កង្វះការថែទាំផ្នែកវេជ្ជសាស្ត្របូករួមជាមួយនឹងផលវិបាកនៃការធ្វើការធ្ងន់ដែលដាក់ទៅលើជនរងគ្រោះ"[1567] (២) ការស្លាប់ដោយសារការអត់អាហារនៅក្រៅស្រុកសំរោង និងតាភេម[1568] និង (៣) អំពើនៃការរើសអើងជាជាងការរឹតត្បិតលើសិទ្ធិនយោបាយលើប្រជាជនថ្មី[1569]។ គាត់បានជំទាស់ផងដែរថា អំពើដែលបានចង្អុលបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងគឺជាការរើសអើងដោយសារនេះបានកើតឡើងទូទាំងប្រទេស[1570] និងបានអះអាងថា ពុំមានការយល់ឃើញនៅក្នុងដីកាដំណោះស្រាយដែលបង្ហាញថា ការធ្វើទុក្ខបុកម្នេញបានកើតឡើង[1571]។

(ខ) ទាក់ទងទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលយល់ឃើញថា បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយនៅការដ្ឋានទំនប់ត្រពាំងថ្មត្រូវបានចោទប្រកាន់ទាក់ទងទៅនឹង"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ជាជាងក្រុមទាំងបីដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងដីកាដំណោះស្រាយ មានដូចជា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1572]។

---

1567 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៦៥-៤៧០។

1568 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៧១-៤៧៤។

1569 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៧៥, ៤៧៩-៤៨០ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៤-៣០៦, ៣១៩, ១៤១៨។

1570 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៧៧-៤៧៨, ៤៨០។

1571 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៨០។

1572 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៨២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៧។

(គ) ទាក់ទងទៅនឹងការដ្ឋានទំនប់១មករា ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវដោយសមស្របឱ្យជំនុំជម្រះ (១) ការស្លាប់ដែលបានកើតឡើងក្រៅការដ្ឋានទំនប់១មករា[1573] (២) ការស្លាប់ដោយសារឧបទ្ទវហេតុ[1574] និង (៣) អំពើនៃការរើសអើងដែលត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1575]។

(ឃ) ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ខៀវ សំផន បានលើកឡើងថា បទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងដីកាដំណោះស្រាយ ពុំមានមូលដ្ឋានគាំទ្រ ដោយសារអង្គជំនុំជម្រះពុំបានយោងទៅលើក្រុមណាមួយក្នុងចំណោមក្រុមទាំងបីនោះ ដូចជា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1576]។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការទាក់ទងទៅនឹងការស្លាប់ដោយសារឧបទ្ទវហេតុពាក់ព័ន្ធនឹងការងារ[1577]។

(ង) ទាក់ទងទៅនឹងក្រាំងតាចាន់ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារអង្គជំនុំជម្រះ (១) បានបង្កើតការយល់ឃើញស្តីពី“សត្រូវ” ជាជាងក្រុមទាំងបីដែលត្រូវបានបញ្ជាក់ជាក់លាក់ក្នុងដីកាដំណោះស្រាយ[1578] និងថា ក្រុមប្រភេទនេះពុំត្រូវបានកំណត់ច្បាស់

---

[1573] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៨៤-៤៨៦។

[1574] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៨៧-៤៨៩ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨១-១៣៨៣, ១៣៨៧។

[1575] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៩២។

[1576] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៩៣-៤៩៤ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦-១៤១៧។

[1577] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១៨, ខៀវ សំផន លើកអំណះអំណាងនេះក្នុងផ្នែកនៃបណ្តឹងសាទុក្ខដោះស្រាយលើកំហុសដែលចោទប្រកាន់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃអំពើមនុស្សឃាតនៅការដ្ឋានសាងសង់ព្រលាយន្តហោះខេត្តកំពង់ឆ្នាំង ពុំមែនអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះនោះទេ។ អំណះអំណាងនេះនឹងត្រូវដោះស្រាយនៅទីនេះពីព្រោះជាប់ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងជាជាងអំពើមនុស្សឃាតដែលបានកើតឡើងនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

[1578] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥០៥-៥០៧, ៥០៩ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦-១៤១៧។

លាស់គ្រប់គ្រាន់[1579] (២) ពុំតម្រូវឱ្យជំនុំជម្រះអង្គហេតុនៃការរើសអើងផ្នែកនយោបាយលើប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1580] (៣) គប្បីបង្កើតការយល់ឃើញតែលើអំពើរើសអើងដែលត្រូវបានចោទប្រកាន់ជាក់លាក់នៅមន្ទីរសន្តិសុខ ដូចជាការចាប់ខ្លួន ការអប់រំកែប្រែ និងការកម្ទេច និងថា ដោយសារការចាប់ខ្លួនបានកើតឡើងចំពោះប្រជាជនទាំងអស់ ក្រុមជាក់លាក់នោះពុំត្រូវបានប្រព្រឹត្តធ្ងន់ធ្ងរជាងក្រុមដទៃទៀតឡើយ[1581]។

(ច) ទាក់ទងទៅនឹងមន្ទីរសន្តិសុខអូរកន្សែង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស (១) ដោយសារបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវសមស្របឱ្យជំនុំជម្រះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយពាក់ព័ន្ធទៅនឹងក្រុមដែល"ជាសត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា [...]" ពីព្រោះក្រុមទាំងនេះ ពុំត្រូវបានកំណត់ប្រភេទគតិយុត្តថា ជាក្រុមមួយស្ថិតក្នុងចំណោមក្រុមទាំងបីដែលត្រូវបានកំណត់ជាក់លាក់ និងដាក់ឱ្យស្ថិតក្រោមការធ្វើទុក្ខបុកម្នេញនោះ ដូចជា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1582] និង (២) ពីព្រោះក្រុមដែលកំណត់គោលដៅជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ពុំបានស្តែងឱ្យឃើញគ្រប់គ្រាន់ឡើយ[1583]។

(ឆ) ទាក់ទងទៅនឹងភ្នំក្រោល ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវដោយសមស្របឱ្យជំនុំជម្រះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដោយសារអ្នកជាប់ឃុំឃាំងនៅទីតាំងនេះពុំ

---

1579 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥០៨-៥១០។

1580 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៩៦-៤៩៩ (ប្រជាជនថ្មី), ៥០០, ៥០៤ (អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

1581 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៩៧-៤៩៨ (ប្រជាជនថ្មី), ៥០១-៥០២ (អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

1582 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥១១-៥១៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៥៨៩-៦២៣។

1583 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២។

ស្ថិតក្នុងចំណោមក្រុមទាំងបីដែលបានកំណត់អត្តសញ្ញាណសម្រាប់ការកំណត់គោលដៅនៃការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយក្នុងដីកាដំណោះស្រាយ[1584]។

580. យោងតាម ខៀវ សំផន បានឱ្យដឹងថា ការយល់ឃើញទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្កើតឡើងដោយរំលោភបំពានលើវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួនត្រូវបដិសេធចោល។

581. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងរបស់គាត់ដែលត្រូវបានបដិសេធនៅពេលជំនុំជម្រះដោយពុំបានបង្ហាញហេតុដូចម្តេចបានអង្គជំនុំជម្រះសាលាដំបូងមានកំហុសនោះឡើយ[1585]។ បន្ថែមលើនេះ ពាក់ព័ន្ធទៅនឹងទំនប់ត្រពាំងថ្ម ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យជំនុំជម្រះអង្គហេតុដែលបង្ហាញអំពី"សត្រូវពិត ឬតាមការសន្មត" ដែលជាក្រុមទទួលរងការធ្វើទុក្ខបុកម្នេញផ្អែកលើការពិនិត្យត្រឹមត្រូវលើដីកាដំណោះស្រាយ និងថា "សត្រូវពិត ឬតាមការសន្មត" គឺជាក្រុមដែលស្តែងឱ្យឃើញគ្រប់គ្រាន់[1586]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដីកាដំណោះស្រាយបានពន្យល់ពេញលេញអំពីក្រុមជាច្រើនដែលត្រូវបានចាត់ទុកថា "សត្រូវ"នៅក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល[1587]។

582. សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានលើកសារណាថ្មីនៅបណ្តឹងសាទុក្ខដោយពុំបានផ្តល់យុត្តិកម្ម ឬការពន្យល់ និងថា អាស្រ័យហេតុនេះ ការជំទាស់ទាំងនេះពុំត្រូវបានអនុញ្ញាតអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1588]។

ក. សហករណ៍ត្រាំកក់

583. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសារណារបស់ ខៀវ សំផន ដែលថា បទចោទនៃការសម្លាប់រង្គាលគប្បីកម្រិតត្រឹមការស្លាប់ដោយសារការអត់អាហារ បញ្ហាសុខភាព និងការកម្ទេចជនជាតិវៀតណាម[1589]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការបែងចែក

---

[1584] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥១៤-៥១៦។

[1585] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣២៣-៣២៧។

[1586] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣១៥, ៣២៨-៣៣០, ៣៣២-៣៣៣, ៣៣៤-៣៣៧។

[1587] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៣៣-៣៣៥, ៣៣៧។

[1588] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៨-១៨០។

[1589] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣៨ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៨៥៨-៨៦៣, ៩២៤-៩៣១។

ភាពខុសប្លែកគ្នាដែល ខៀវ សំផន ព្យាយាមបង្ហាញរវាងការស្លាប់ដោយសារការអត់អាហារ ជាមួយនឹងការស្លាប់ដោយសារជំងឺ ឬលក្ខខណ្ឌវេជ្ជសាស្ត្រ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដីកាដំណោះស្រាយបានយោងច្បាស់លាស់ទៅនឹងលើការស្លាប់ដោយសារការអត់អាហារក្នុងសហករណ៍ត្រាំកក់[1590] និងបានពិចារណាថា ដីកាដំណោះស្រាយបានយោងផងដែរទៅលើអ្នកដែលស្លាប់ដោយសារទទួលការព្យាបាលមិនគ្រប់គ្រាន់[1591]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងក្នុងពេលជំនុំជម្រះរបស់ ខៀវ សំផន និងបានបញ្ជាក់ថា ដីកាដំណោះស្រាយបានចោទប្រកាន់អំពើសម្លាប់រង្គាលក្នុងសហករណ៍ត្រាំកក់ដោយផ្អែកលើមូលដ្ឋាននៃលក្ខខណ្ឌជារួមដែលបានដាក់នៅទីនោះ។

584. អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នា និងបកស្រាយត្រឹមត្រូវលើដីកាដំណោះស្រាយ[1592]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនដែលថា នៅបណ្តឹងសាទុក្ខ ភាគីពុំអាចត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងដែលពុំទទួលបានជោគជ័យនៅពេលជំនុំជម្រះឡើយ លើកលែងតែភាគីអាចបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើអំណះអំណាងនោះគឺជាកំហុសដែលតម្រូវឱ្យមានការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល[1593]។ ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងពេលជំនុំជម្រះពាក់ព័ន្ធទៅនឹងការបកស្រាយលើផ្នែកទាំងនេះក្នុងដីកាដំណោះស្រាយដោយពុំបានបង្ហាញកំហុសក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ អំណះអំណាងទាំងនេះត្រូវបដិសេធចោល[1594]។

---

[1590] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១២។

[1591] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៣ (ពិពណ៌នាអំពីការព្យាបាលពុំគ្រប់គ្រាន់ និងបន្តថា៖ "នៅពេលមានមនុស្សស្លាប់ យកទៅកប់ដោយគ្មានជូនដំណឹងគ្រួសារឡើយ")។

[1592] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨១, ១៣៨៧។ *សូមមើលផងដែរ* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០២-៣២១។ ជាពិសេស ខៀវ សំផន កំណត់ចរិតលក្ខណៈពុំត្រឹមត្រូវនៃកថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ នៅពេលគាត់បានអះអាងថា កថាខណ្ឌនោះពុំយោងទៅលើការស្លាប់ដោយសារបញ្ហាសុខភាព។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា កថាខណ្ឌនោះបានបញ្ជាក់ច្បាស់លាស់ថា មានមនុស្សជាច្រើនបដែលរស់នៅក្នុងសហករណ៍ មានបញ្ហាសុខភាព និងបានសំដៅទៅលើអ្នកដែលស្លាប់ក្នុងបរិបទនោះ។

[1593] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។

[1594] *សូមមើលខាងលើ* ផ្នែក III.ក។ *សូមមើលផងដែរ ឧ.* សាលដីការឿងក្តី *Galić* (ICTY) កថាខណ្ឌ ២៩០។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Vasiljević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-32-A សាលដីកា ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ ("សាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Vasiljević* (ICTY)") កថាខណ្ឌ ១៦ ("អង្គជំនុំជម្រះឧទ្ធរណ៍នឹងមិនពិចារណាអំណះអំណា

585. ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងអំណះអំណាងដែលថា បទចោទនៃការស្លាប់ដោយសារការអត់អាហារ ត្រូវបានកម្រិតត្រឹមឃុំតែពីរប៉ុណ្ណោះ៖ សំរោង និងតាមភេម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសារណាដូចគ្នានេះរបស់ ខៀវ សំផន ពេលជំនុំជម្រះ[1595]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយ"បានពិពណ៌នាអំពីរឿងរ៉ាវដែលផ្ទុយគ្នានៃការស្លាប់ដោយសារការអត់អាហារ"[1596]។ ក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយដែលអង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញនោះឃើញថា សហចៅក្រមស៊ើបអង្កេតបានពិពណ៌នានូវមូលហេតុដូចម្តេចបានជា"សាក្សីស្ទើរតែទាំងអស់"បានអះអាងថា មានកង្វះអាហារ[1597]។ ដីកាដំណោះស្រាយបានបញ្ជាក់ថា ភស្តុតាងបង្ហាញថា សាក្សីបានរំឭកអំពីមនុស្សដែលបានស្លាប់ដោយសារការអត់អាហារ ឬពុំបានបដិសេធអត្ថិភាពនោះឡើយ[1598]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបត្រឹមត្រូវនូវការយល់ឃើញនៃដីកាដំណោះស្រាយ និងបានធ្វើការបកស្រាយសមហេតុផលលើការយល់ឃើញទាំងនោះ[1599]។ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការបកស្រាយនេះ ហើយសារណារបស់គាត់ខកខានបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។ អំណះអំណាងនេះត្រូវបដិសេធចោល។

586. នៅដំណាក់កាលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះមានកំហុសក្នុងការវាយតម្លៃអំពីបទចោទនៃការរើសអើងផ្នែកនយោបាយលើប្រជាជនថ្មីនៅត្រាំកក់[1600]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ដីកាដំណោះស្រាយមានការយល់ឃើញជាច្រើនស្តីពីសិទ្ធិផ្នែកនយោបាយ ដូចជា៖ (១) ប្រជាជនស្រុកត្រាំកក់ត្រូវបានបែងចែកជាបីប្រភេទ ប្រជា

---

ងទាំងនោះដែលម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការលើកឡើងនូវកំហុសដែលចោទប្រកាន់ និងត្រឹមតែផ្តល់ការបកស្រាយជាជម្រើសផ្សេងលើភស្តុតាង")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gatete* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-00-61-A សាលដីកា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ១៥៦។

[1595] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១១, ១១៤០-១១៤១។

[1596] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១១។

[1597] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១២។

[1598] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១២។

[1599] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១២, ១៣៨១, ១៣៨៧។ អង្គជំនុំជម្រះតុលាការកំពូលជាពិសេសបដិសេធការអះអាងថា ដោយយោងទៅលើភស្តុតាងពីរ សហចៅក្រមស៊ើបអង្កេតមានបំណងកម្រិតវិសាលភាពនៃទីតាំងទាំងនោះ។

[1600] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១។

ជនពេញសិទ្ធិ ប្រជាជនបម្រុង និងប្រជាជនបញ្ញើ ដែលនឹងត្រូវបានបែងចែងបន្ថែមទៀតក្នុងកងពលកម្មផ្សេងៗ[1601] (២) មានសិទ្ធិបន្តិចបន្តួចសម្រាប់ប្រជាជបញ្ញើដែលគេហៅថា ប្រជាជនថ្មី ឬប្រជាជន ១៧ មេសា ហើយកងរបស់ពួកគេត្រូវបានគ្រប់គ្រងដោយប្រជាជនមូលដ្ឋាន[1602] និង (៣) ប្រជាជនថ្មីពុំមានសិទ្ធិផ្នែកនយោបាយ ពុំអាចក្លាយជាប្រធានកង និងត្រូវបានគ្រប់គ្រងដោយប្រជាជនពេញសិទ្ធិ ឬប្រជាជនបម្រុង[1603] ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ដីកាដំណោះស្រាយបានបង្ហាញថា ប្រជាជនថ្មីបានទទួលរងជាពិសេសបញ្ហាសុខភាពដោយសារទីកន្លែងរស់នៅថ្មីតាមជនបទ[1604] និងថា អ្នកដែលត្រូវបានគេកំណត់ថា ជាសត្រូវ ត្រូវបានបញ្ជូនទៅកសាង[1605]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសារណារបស់ ខៀវ សំផន ដែលថា វិសាលភាពនៃអំពើធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មីគប្បីកម្រិតឱ្យតូចដូចការអះអាងរបស់គាត់[1606]។

587. អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងការពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូងលើដីកាដំណោះស្រាយ។ ការយល់ឃើញដែលត្រូវបានចង្អុលបង្ហាញជាក់លាក់ដោយ ខៀវ សំផន បានបង្ហាញថា ប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើនៃការរើសអើងដែលហួសពីការរឹតត្បិតលើសិទ្ធិផ្នែកនយោបាយ[1607]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា បទចោទទាំងនេះបានផ្អែកទៅលើការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយបានកើតឡើងនៅ"ស្ទើរគ្រប់ទី

---

[1601] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៥-៣០៦។

[1602] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៥-៣០៦។

[1603] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៥-៣០៦។

[1604] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៣។

[1605] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៥។

[1606] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧១ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៥។

[1607] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣០៤ ដែលលើកឡើងថា ប្រជាជនថ្មីត្រូវបានផ្លាស់ទីដោយបង្ខំក្នុងទ្រង់ទ្រាយធំ។

តាំងនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ"រួមទាំងត្រាំកក់[1608] ព្រមទាំងការយល់ឃើញដែលថា ប្រជាជនថ្មីជាក់ស្តែង បានទទួលរងការរើសអើងទូទាំងប្រទេស[1609] និងថា ប្រជាជនថ្មីត្រូវបានតាមដានយ៉ាងហ្មត់ចត់ និងត្រូវចាប់ខ្លួនសម្រាប់ការនិយាយប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជានៅត្រាំកក់[1610] និងថា បន្ទាប់ពីការមកដល់របស់ប្រជាជនថ្មីក្នុងស្រុកត្រាំកក់ លេខាស្រុក និងឃុំត្រូវបានកោះប្រជុំ"ដែលក្នុងនោះពួកគេត្រូវបានណែនាំឱ្យបោសសម្អាតអ្នកជម្លៀសមកពី"ទីក្រុងភ្នំពេញ[1611] និងថា ប្រជាជនថ្មីត្រូវបានចាត់ទុកថា "ជាអ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ" និងត្រូវបានប្រព្រឹត្តទៅលើធ្ងន់ធ្ងរជាងអ្នកប្រព្រឹត្តបទល្មើស"ស្រាល"ជាក់ស្តែង[1612]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើបទចោទក្នុងដីកាដំណោះស្រាយ ដោយពុំបានបង្ហាញកំហុសណាមួយ និងជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញសមហេតុផលថា អំពើទូលំទូលាយនៃការរើសអើងត្រូវបានប្រព្រឹត្តទៅលើប្រជាជនថ្មី។ អំណះអំណាងនេះត្រូវបដិសេធចោល។

588. អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធបន្ថែមទៀតដោយសារពុំមានមូលដ្ឋាននូវសារណារបស់ ខៀវ សំផន ដែលថា ការដែលប្រជាជនដទៃទៀតបានឆ្លងកាត់ការប្រព្រឹត្តទៅលើយ៉ាងលំបាកវេទនានោះ មានន័យថា ប្រជាជនថ្មីពុំត្រូវបានដាក់ឱ្យស្ថិតក្រោមការរើសអើងនោះឡើយ។ ការដែលថា ក្រុមដទៃទៀតក្រៅពីប្រជាជនថ្មី ត្រូវបានចាត់ទុកថា ជាសត្រូវ និងរើសអើងនោះ ពុំត្រូវបានជំទាស់ និងជាការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់អំពើធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"[1613]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងរបស់ ខៀវ សំផន ដែលពុំសមស្រប និងពុំគួរឱ្យជឿជាក់បាន ដែលបានបង្វែរចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើការយល់ឃើញអំពីការរងទុក្ខរបស់ក្រុមជាច្រើននូវលក្ខខណ្ឌដ៏លំបាកក្នុងស្រុកត្រាំកក់។

[1608] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦

[1609] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៦៣, ១៤១៧, ១៤២៤។

[1610] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៩។

[1611] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤៩៨។

[1612] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២៤។

[1613] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧០ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៧-១៤១៨។

## ខ. ការដ្ឋានទំនប់ត្រពាំងថ្ម

589. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ដីកាដំណោះស្រាយបានចោទប្រកាន់"'ការកំណត់អត្តសញ្ញាណប្រជាជនថា ជាគោលដៅសម្រាប់ការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋានថា នរណាដែលពុំយល់ស្របជាមួយនឹងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា នឹងត្រូវដកចេញ ដែលស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ"'[1614]។ ដើម្បីឈានទៅដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានកម្រិតដោយដីកាដំណោះស្រាយត្រឹមអំពើដែលត្រូវបានប្រព្រឹត្តឡើងលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1615]។ ក្នុងការបដិសេធអំណះអំណាងនេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ឃើញពីដំបូងជាទូទៅរបស់ខ្លួនដែលថា បើទោះបីជាដីកាដំណោះស្រាយបានយោងទៅលើតែក្រុមបីដូចការពិពណ៌នារបស់ ខៀវ សំផន ក៏ដោយ ក៏ដីកាដំណោះស្រាយធ្វើដូច្នោះក្នុងគោលបំណងធ្វើជាឧទាហរណ៍ និងជាតំណាងដែរ[1616]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ដីកាដំណោះស្រាយបានបង្ហាញថា ក្រុមនៃប្រភេទទាំងបីនេះបានបន្តរីកធំឡើងជាដរាប និងថា អង្គជំនុំជម្រះនឹងពិចារណាក្នុងករណីពាក់ព័ន្ធលើការជំទាស់របស់ ខៀវ សំផន ទៅនឹងប្រភេទជាក់លាក់នៃសត្រូវដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងដីកាដំណោះស្រាយ[1617]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវសារណាក្នុងពេលជំនុំជម្រះដោយពុំបានបង្ហាញកំហុស។ អំណះអំណាងត្រូវបដិសេធចោល។

590. អង្គជំនុំជម្រះតុលាការកំពូលឆ្លៀតឱកាសនេះបញ្ជាក់សាជាថ្មីនូវការយល់ឃើញពីដំបូងរបស់ខ្លួនស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញស្របគ្នាក្នុងយុត្តិសាស្ត្ររបស់ខ្លួនស្តីពីកម្មវត្ថុនៃការរើសអើងដោយសារមូលហេតុនយោបាយថា បើទោះបីជាក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញត្រូវតែស្តែងឱ្យឃើញគ្រប់គ្រាន់ក៏ដោយ ក៏អាស្រ័យលើចារីដែលជាអ្នកកំណ

---

[1614] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៧។

[1615] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៤ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១០០៩ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៧។

[1616] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧០។

[1617] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧០។

ត់ក្រុមនោះដែរ[1618] និងថា ក្រុមនោះ ឬក្រុមនានាដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អាចរួមបញ្ចូលបុគ្គលប្រភេទផ្សេងៗ ដូចជាៈ អ្នករដ្ឋការ និងសកម្មជននយោបាយ បុគ្គលដែលមានទស្សនៈ និងជំនឿមួយចំនួន បុគ្គលដែលជាក្រុមជាតិសាសន៍ ឬជាតិពន្ធុមួយចំនួន បុគ្គលដែលតំណាងឱ្យវណ្ណៈសង្គម ឧទាហរណ៍ ('បញ្ញវន្ត' បុព្វជិត ឬវណ្ណៈគហបតី)"[1619]។ ជាពិសេស ទាក់ទងទៅនឹងក្រុមចុងក្រោយនេះ ពួកគេអាចក្លាយជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ ពុំមែនដោយសារសមាជិកទាំងអស់ ឬភាគច្រើនប្រកាន់ទស្សនៈនយោបាយខុសប្លែកពីទស្សនៈរបស់ចារីប៉ុណ្ណោះទេ ប៉ុន្តែដោយសារពួកគេត្រូវបានសន្មតដោយចារីថា ជាអ្នកប្រឆាំងសក្តានុពល ឬលើសពីនេះជាឧបសគ្គរាំងដល់ការអនុវត្តន៍របៀបវារៈនយោបាយរបស់ចារី[1620]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា មានមូលដ្ឋានសំអាងក្នុងការយល់ឃើញការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើក្រុមដែលបានប្រមូលផ្តុំ ដោយពុំចាំបាច់ការកំណត់អត្តសញ្ញាណ ឬរបៀបវារៈរួមគ្នាណាមួយ ដរាបណាសត្រូវនយោបាយត្រូវបានកំណត់អត្តសញ្ញាណ ដោយផ្អែកលើគោលនយោបាយដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅមួយចំនួន ខណៈពេលប្រជាជនដទៃទៀតទទួលបានសេរីភាពក្នុងកម្រិតមួយ[1621]។ អាស្រ័យហេតុនេះ ដោយរំឭកការយល់ឃើញពីមុនរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" គឺជាក្រុមដែលស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់[1622]។ សារណារបស់ ខៀវ សំផន ដែលផ្ទុយនោះត្រូវបដិសេធចោល។

591. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើការជំទាស់របស់ ខៀវ សំផន ដែលថា ផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយមានការយល់ឃើញស្តីពីការធ្វើទុក្ខបុកម្នេញលើក្រុមតែមួយគត់ គឺប្រជាជនថ្មី[1623] ព្រមទាំងសារណាដែលលើកឡើងថា អំពើតែមួយនៃការរើសអើងពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់នោះគឺលក្ខខណ្ឌការងារធ្ងន់ធ្ងរជាង ការកំណត់ទំហំការ

[1618] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧២។

[1619] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៩ យោងទៅលើសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧២។

[1620] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧២។

[1621] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៧៨។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៨២។

[1622] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧៣, ២៨២។

[1623] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៥ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១០១១។

ងារធំជាង និងការដាក់ទណ្ឌកម្មពុំសមស្រប[1624]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់លាស់ថា ទាក់ទងទៅនឹងសហករណ៍ និងការដ្ឋានធ្វើការ "'សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្ត និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀត'"[1625]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ផងដែរថា ដីកាដំណោះស្រាយបានចោទប្រកាន់"'ការកំណត់អត្តសញ្ញាណប្រជាជនជាគោលដៅសម្រាប់ការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋានថា នរណាដែលពុំយល់ស្របជាមួយនឹងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជានឹងត្រូវដកចេញ ដែលនេះស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ'"[1626]។ ដោយពិចារណាលើបទចោទនៃការធ្វើទុក្ខបុកម្នេញទាំងមូលដែលបានរៀបរាប់ក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងរបស់ ខៀវ សំផន[1627]។ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយពុំបានបង្ហាញនូវកំហុស។ អំណះអំណាងនេះត្រូវបដិសេធចោល។

### គ. ការដ្ឋានទំនប់១មករា

592. ក្នុងការយល់ឃើញដែល ខៀវ សំផន បានចង្អុលបង្ហាញ ទាក់ទងទៅនឹងការស្លាប់ដែលបានកើតឡើងក្រៅទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ចំនួនប្រជាជនតិចតួចបានស្លាប់ដោយសារជំងឺ ឬគ្រោះថ្នាក់ការងារនៅទំនប់១មករា ប៉ុន្តែជាធម្មតាអ្នកដែលធ្លាក់ខ្លួនឈឺធ្ងន់ត្រូវបញ្ជូនត្រឡប់ទៅភូមិរបស់ខ្លួនវិញ ឬទៅរោងព្យាបាលតាមមូលដ្ឋានជាកន្លែងដែលពួកគេបានស្លាប់ដោយសារការព្យាបាលពុំគ្រប់គ្រាន់"[1628]។ ការយល់ឃើញចំណុចទីពីរនេះបង្ហាញថា ផ្អែកតាមអង្គជំនុំជម្រះសាលាដំបូង ការស្លាប់ជាច្រើនដែលបង្កឡើងដោយសារលក្ខខណ្ឌនៅទំនប់១មករាបានកើតឡើងនៅទីតាំងនោះផ្ទាល់។ ទោះជាយ៉ាងណាក្តី ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន ការយល់ឃើញនេះជារួមស៊ីសង្វាក់គ្នាជាមួយនឹងដីកាដំណោះស្រាយ និងការយល់ឃើញនានារបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធចំណុចនេះ។ អង្គជំនុំជម្រះសាលាដំបូងបាន

---

[1624] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៥ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១០១៣-១០១៦។

[1625] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៥ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៨។

[1626] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៥ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៧។

[1627] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៥។

[1628] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦២៩។

សង្ខេបត្រឹមត្រូវនូវដីកាដំណោះស្រាយ នៅពេលយល់ឃើញថា ប្រជាជនបានស្លាប់ដោយសារលទ្ធផលនៃ "លក្ខខណ្ឌ"ក្នុងការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខ រួមទាំងទំនប់១មករា[1629]។ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន ដីកាដំណោះស្រាយពុំបានបញ្ជាក់ជាក់លាក់ថា ការស្លាប់នោះបានកើតឡើងនៅទំនប់១មករា ប៉ុន្តែត្រឹមតែថា ការស្លាប់នោះបានបង្កឡើងដោយសារលក្ខខណ្ឌនៅការដ្ឋានធ្វើការ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

593. ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានតម្រូវឱ្យជំនុំជម្រះ"ការស្លាប់ដោយសារឧបទ្ទវហេតុ"នៅទំនប់១មករា។ ក្នុងកថាខណ្ឌនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលគាត់បានចង្អុលបង្ហាញនោះ អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាបទចោទពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៅទំនប់នោះដោយរួមបញ្ចូលទាំង"ការដកហូតអាហារ ទីជម្រក ការថែទាំវេជ្ជសាស្ត្រ និងអនាម័យ ព្រមទាំងការនឿយហត់អស់កម្លាំងដោយសារការងារធ្ងន់ និងលក្ខខណ្ឌការងារគ្មានសុវត្ថិភាព"[1630]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការបញ្ជាក់នេះបានសង្ខេបបទចោទដែលបានរៀបរាប់ក្នុងដីកាដំណោះស្រាយ។ សហចៅក្រមស៊ើបអង្កេតបានបង្កើតការយល់ឃើញថា "មានឧបទ្ទវហេតុ ដូចជាបាក់ថ្ម ឬបាក់ដីសង្កត់មនុស្សស្លាប់"នៅទំនប់១មករា[1631] និងបានយល់ឃើញជាទូទៅថា "លក្ខខណ្ឌ"នៅការដ្ឋាននេះបានបង្កឱ្យមានការស្លាប់[1632]។ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

594. ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា ពុំមានអង្គហេតុនៃការរើសអើងត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទំនប់១មករា អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយនៅកាដ្ឋានធ្វើការ រួមទាំងទំនប់១មករា លើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"

---

[1629] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៥៩, ៣៦៣, ១៣៨១, ១៣៨៧, ១៣៨៩។

[1630] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៥៩, ៣៦៣, ១៣៨១, ១៣៨៧, ១៣៨៩។

[1631] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៦៣។

[1632] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨៧។

[1633]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ដីកាដំណោះស្រាយបានរៀបរាប់"អតីតយោធា និងបុគ្គលិកស៊ីវិលដែលមានឋានន្តរស័ក្តិក្នុងរបបសាធារណរដ្ឋខ្មែរ" ធ្វើជាឧទាហរណ៍នៃសត្រូវតាមការសន្មត [1634]។ ទាក់ទងទៅនឹងការដ្ឋានទំនប់១មករាជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អតីតទាហាន ឬអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណតាមរយៈការស្រង់ប្រវត្តិរូប ចាប់ខ្លួន និងនាំយកទៅមន្ទីរសន្តិសុខ[1635] និងថា កងសន្តិសុខមន្ទីរឃុំឃាំងបានកំណត់អត្តសញ្ញាណអ្នកដែលមានឋានន្តរស័ក្តិ និងថា គ្រួសារអតីតអ្នករដ្ឋការស៊ីវិល និងប៉ូលីស ត្រូវបានកំណត់អត្តសញ្ញាណដើម្បីចាប់ខ្លួន[1636]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការយល់ឃើញទាំងនេះបើទោះបីជាជានិច្ចកាលពុំមានអមជាមួយនូវការដកស្រង់ជាក់លាក់នៃដីកាដំណោះស្រាយក៏ដោយ ក៏ស៊ីសង្វាក់ទាំងស្រុងជាមួយនឹងបទចោទដែលបានគូសបង្ហាញក្នុងដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយបានយល់ឃើញថា អតីតយោធា និងបុគ្គលិកស៊ីវិលដែលមានឋានន្តរស័ក្តិក្នុងរបបសាធារណរដ្ឋខ្មែរ ជាទូទៅត្រូវបានដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្ត និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងនៅក្នុងការដ្ឋានធ្វើការ[1637] និងថា បុគ្គលជាច្រើនដែលបានបាត់ខ្លួននៅទំនប់១មករាមានទំនាក់ទំនងជាមួយនឹងអតីតរបបសាធារណរដ្ឋខ្មែរ[1638]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ហើយសារណារបស់ ខៀវ សំផន ដែលផ្ទុយពីនេះត្រូវបដិសេធចោល។

### ឃ. ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

595. ដូចបានបង្ហាញពីដំបូង អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការអះអាងទូទៅរបស់ ខៀវ សំផន ដែលថាបទចោទនៃការធ្វើទុក្ខបុកម្នេញត្រូវបានកម្រិតត្រឹមបីក្រុមដែលគាត់បានចង្អុលបង្ហាញ មានដូចជា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស ហើយអង្គជំនុំជម្រះតុលាការកំពូលបានតម្កល់គោលជំហរនេះ[1639]។ ទាក់ទងទៅនឹងភាពជាក់លាក់បទចោទនៃការធ្វើទុក្ខ

---

[1633] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៥ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៨។

[1634] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦-១៤១៨។

[1635] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦០, ១៦៨៧។

[1636] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦០, ១៦៨៧។

[1637] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៩។

[1638] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៦៦។

[1639] *សូមមើលខាងលើ* កថាខណ្ឌ ៥៨៩៥៩០។

បុកម្នេញផ្នែកនយោបាយនៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង អង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ឃើញរបស់ខ្លួន និងបានបដិសេធអំណះអំណាងក្នុងពេលជំនុំជម្រះរបស់ ខៀវ សំផន ដែលថា មានកំហុសផ្នែកនីតិវិធីក្នុងដីកាដំណោះស្រាយដោយសារការខកខាន ក្នុងការបញ្ជាក់ជាក់លាក់ក្រុមមួយក្នុងចំណោមបីក្រុមនោះ[1640]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ពាក់ព័ន្ធទៅនឹងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ក្រុមគោលដៅនៃសត្រូវបានរួមបញ្ចូលប្រជាជនទាំងអស់ដែលត្រូវបានសន្មតថា ជាជនក្បត់ ឬ“សមាសភាពមិនល្អ”ដែលត្រូវបានផ្លាស់ទីទៅធ្វើការនៅការដ្ឋានក្រោមលក្ខខណ្ឌដ៏លំបាកដើម្បីលុតដំ ដោយសារការប្រព្រឹត្តរបស់ពួកគេត្រូវបានចាត់ទុកថា ប្រឆាំងនឹងមាគ៌ាបក្ស ឬត្រូវបានដាក់ទណ្ឌកម្មសម្រាប់ការជាប់ពាក់ព័ន្ធនឹងអំពើក្បត់ដែលបានចោទប្រកាន់នោះ ដូចបានពិពណ៌នាក្នុងផ្នែកទាំងនោះនៃដីកាដំណោះស្រាយទាក់ទងទៅនឹងការដ្ឋានសាងសង់ព្រលានយន្តហោះ[1641]។ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដោយគ្មានការបង្ហាញនូវកំហុស។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

ង. ក្រាំងតាចាន់

596. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយលើ“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា”ដែលបានកំណត់ថា ជាអ្នកដែលមានទស្សនៈនយោបាយពិត ឬតាមការសន្មតដែលផ្ទុយទៅនឹងបក្សកុម្មុយនីស្តកម្ពុជា ឬប្រឆាំងនឹងអ្នកដែលកាន់កាន់សិទ្ធិអំណាចនៅក្នុងបក្ស[1642]។ យោងតាមដីកាដំណោះស្រាយ បុគ្គលទាំងនេះនឹងត្រូវ“ចាប់ខ្លួនក្នុងទ្រង់ទ្រាយធំសម្រាប់ការអប់រំកែប្រែ និងការកម្ទេច”នៅមន្ទីរសន្តិសុខរួមទាំងក្រាំងតាចាន់[1643]។ ក្នុងការវិភាគនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា និងបានបដិសេធចោលអំណះអំណាងរបស់ ខៀវ សំផន ដែលថា ទាក់ទងទៅនឹងក្រាំងតាចាន់ អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាតែលើក្រុមបីសម្រាប់គោលបំណងនៃបទធ្វើទុក្ខបុកម្នេញ

---

[1640] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨១៩។

[1641] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨២០ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣៨៩-៣៩២។

[1642] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦-១៤១៨។

[1643] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៨។

ដោយសារមូលហេតុនយោបាយ មានដូចជា អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1644]។ ដូចបានគូសបង្ហាញពីដំបូង អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង[1645]។ ខៀវ សំផន ត្រឹមតែជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដោយពុំបានបង្ហាញនូវកំហុស។ សារណានេះត្រូវបដិសេធចោល។

597. ទាក់ទងទៅនឹងការលើកឡើងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាថា អំពើដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខត្រូវបានកម្រិតត្រឹមការចាប់ខ្លួន ការអប់រំកែប្រែ និងការកម្ទេច អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានលើកអំណះអំណាងដដែលសាជាថ្មីម្តងទៀតដែលត្រូវបានពិចារណា និងបដិសេធនៅពេលជំនុំជម្រះ[1646]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានបែងចែងរវាង"ការប្រព្រឹត្ត និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរ"ក្នុងសហករណ៍ និងការដ្ឋានធ្វើការ ជាមួយនឹងការចាប់ខ្លួនផ្សេងៗ ការអប់រំកែប្រែ និងការកម្ទេចនៅមន្ទីរសន្តិសុខ[1647]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពុំមានអ្វីជាសត្យានុម័តលើកឡើងចំពោះការបែងចែកភាពខុសគ្នានេះឡើយ[1648]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងរបស់គាត់ដោយពុំបានបង្ហាញកំហុស ដូច្នេះត្រូវបដិសេធចោល។ បន្ថែមលើនេះ ដូចបានបញ្ជាក់ពីដំបូង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដែលថាបុគ្គលដទៃទៀតបានទទួលរងការរំលោភបំពាននោះ បានបង្ហាញនូវអត្ថិភាពនៃការប្រព្រឹត្តដោយរើសអើងជាជាងអ្វីផ្សេងពីនេះ។ សារណានេះត្រូវបដិសេធចោលផងដែរ។

598. ទាក់ទងទៅនឹងការលើកឡើងដែលថា ដីកាដំណោះស្រាយពុំមានការយល់ឃើញផ្នែកអង្គហេតុណាមួយស្តីពីការរើសអើងលើប្រជាជនថ្មី និងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្រាំងតាចាន់ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញ

---

[1644] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៤ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១២៥៥។

[1645] *សូមមើលខាងលើ* កថាខណ្ឌ ៥៨៩-៥៩០, ៥៩៥។

[1646] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៥។

[1647] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៥ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៨។

[1648] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៣៥។

ផ្នែកនយោបាយបានកើតឡើង"ស្ទើរគ្រប់ទីតាំងទាំងអស់ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ"រួមទាំងក្រាំងតាចាន់[1649]។ ដីកាដំណោះស្រាយមានការយល់ឃើញដែលថា ប្រជាជនថ្មីបានទទួលរងការរើសអើងជាក់ស្តែងទូទាំងប្រទេស[1650] និងថា ប្រជាជនថ្មីត្រូវបានចាប់ខ្លួនជាពិសេស និងត្រូវបាននាំយកទៅឃុំឃាំង និងសម្លាប់នៅក្រាំងតាចាន់[1651] និងថា មានការស្រង់ប្រវត្តិរូបនៅស្រុកត្រាំកក់ដើម្បីឱ្យបក្សកុម្មុយនីស្តកម្ពុជាអាចបោសសម្អាតប្រជាជនថ្មី និងបញ្ជូនទៅក្រាំងតាចាន់[1652] និងថា ប្រជាជនថ្មីត្រូវបានចាត់ទុកថា ជា"អ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ" និងត្រូវបានប្រព្រឹត្តទៅលើធ្ងន់ធ្ងរជាងអ្នកប្រព្រឹត្តបទល្មើស"ស្រាល"ធម្មតា[1653]។ បន្ថែមលើនេះ ដីកាដំណោះស្រាយបានបង្ហាញថា គោលនយោបាយទូទាំងប្រទេសបានកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលមានអត្ថិភាពពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិតបេតយ្យ[1654] និងថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើឱ្យបាត់ខ្លួនពេលមកដល់ស្រុកត្រាំកក់ និងត្រូវបានបញ្ជូនទៅក្រាំងតាចាន់[1655] និងថា អ្នកដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខ ដូចជា ក្រាំងតាចាន់ បានប្រឈមនឹងការរើសអើងមុនពេលចាប់ខ្លួន អប់រំកែប្រែ និងកម្ទេចដែលបានបន្តកើតឡើងលើពួកគេនៅក្រាំងតាចាន់[1656]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ដីកាដំណោះស្រាយមានការយល់ឃើញជាច្រើនដែលបង្ហាញអំពីអត្ថិភាពនៃការរើសអើងផ្នែកនយបាយលើប្រជាជនថ្មី និងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែររួមទាំងក្រាំងតាចាន់។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

### ច. អូរកន្សែង

599. ក្នុងការបង្កើតការយល់ឃើញស្តីពីអូរកន្សែង អង្គជំនុំជម្រះសាលាដំបូងបានពិចារណា និងបានបដិសេធអំណះអំណាងពេលជំនុំជម្រះរបស់ ខៀវ សំផន ដែលថា បទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយអូរកន្សែងគប្បីកម្រិតត្រឹមសត្រូវបីប្រភេទដែលបានបញ្ជាក់ជាក់លាក់ក្នុងដីកាដំណោះស្រាយ

---

[1649] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦។

[1650] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៦៣, ១៤១៧, ១៤២៤។

[1651] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៥០០ ជើងទំព័រ ២១៦៧។

[1652] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤៩៨។

[1653] *សូមមើល ឧ.* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៥០០ ជើងទំព័រ ២១៦៧។

[1654] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២០៨-២០៩។

[1655] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៤៩៨ ជើងទំព័រ ២១៥៩។

[1656] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៨។

មានដូចជា ប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1657]។ ដូចបានបង្ហាញពីដំបូង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានលើកសាឡើងវិញនូវសារណាក្នុងពេលជំនុំជម្រះរបស់គាត់លើចំណុចនេះដោយពុំបានបង្ហាញនូវកំហុស និងបានបដិសេធសារណានេះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដីកាដំណោះស្រាយបានកំណត់ច្បាស់លាស់នូវក្រុមដែលជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ឬប្រឆាំងនឹងមនោគមវិជ្ជានោះ ដែលត្រូវបានសន្មតថាប្រឆាំងនឹងបដិវត្តន៍ និងត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថា ជាសត្រូវពិត ឬតាមការសន្មត[1658]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា យោងតាមដីកាដំណោះស្រាយ ក្រុមនោះបានរួមបញ្ចូលអ្នកបន្ទុះបង្អាប់បដិវត្តន៍សង្គមនិយម និងអ្នករិះគន់ ឬអ្នកប្រឆាំងបក្សរួមទាំងអ្នកដែលពាក់ព័ន្ធទៅនឹងទង្វើសក្តិភូមិ ឬត្រូវបានចោទប្រកាន់នូវអំពើខុសសីលធម៌ និងបុគ្គលដែលត្រូវបានសង្ស័យ ឬពាក់ព័ន្ធនឹងការចូលដៃជាមួយសត្រូវរបស់បក្ស ព្រមទាំងជនជាតិវៀតណាម និងអ្នកដែលសង្ស័យសហការជាមួយជនជាតិវៀតណាម[1659]។ ទាក់ទងទៅនឹងអូរកន្សែង អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ក្រុមគោលដៅនៃ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"បានស្តែងឱ្យឃើញគ្រប់គ្រាន់ដើម្បីកំណត់ថាតើ ផលវិបាកជាចាំបាច់បានកើតឡើងលើក្រុមនោះ ដែរ ឬយ៉ាងណា[1660]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការយល់ឃើញដែលបានគូសបង្ហាញក្នុងដីកាដំណោះស្រាយ ដូចបានសង្ខេបត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង[1661] បានពន្យល់ពេញលេញអំពីក្រុមគោលដៅនៅអូរកន្សែង។ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ឆ. ភ្នំក្រោល

600. ក្នុងការបង្កើតការយល់ឃើញស្តីពីភ្នំក្រោល អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"នៅមន្ទីរសន្តិ

---

[1657] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២។

[1658] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២។

[1659] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៥៩១, ៦០០-៦០១, ៦១៣-៦១៤, ៦២០, ៦២២។

[1660] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៣។

[1661] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៥៩១, ៦០០-៦០១, ៦១៣-៦១៤, ៦២០, ៦២២។

សុខភ្នំក្រោល[1662]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា និងបានបដិសេធអំណះអំណាងក្នុងពេលជំនុំជម្រះរបស់ ខៀវ សំផន ដែលថា បទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅភ្នំក្រោលគប្បីកម្រិតត្រឹមសត្រូវបីប្រភេទដែលបានបញ្ជាក់ជាក់លាក់ក្នុងដីកាដំណោះស្រាយ មានដូចជា ប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[1663]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវជឿជាក់ខ្លួនឯងថា ក្រុមកំណត់គោលដៅនៃ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"ដែលត្រូវបានសំដៅទៅលើក្នុងដីកាដំណោះស្រាយ បានស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់[1664]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ក្នុងការវាយតម្លៃលើវិសាលភាពនៃក្រុមនោះ ជាការចាំបាច់ត្រូវពិនិត្យផ្នែកសម្រេចសេចក្តីចុងក្រោយនៃដីកាដំណោះស្រាយ និងការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុដែលចង់សំដៅទៅលើទីតាំងឧក្រិដ្ឋកម្មដោយបូករួមជាមួយនឹងការយល់ឃើញផ្នែកអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត[1665]។ ទាក់ទបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ដីកាដំណោះស្រាយបានកំណត់ច្បាស់លាស់នូវក្រុមដែលជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ឬមនោគមវិជ្ជានោះ ដែលក្រុមនោះត្រូវបានសន្មតថាប្រឆាំងនឹងបដិវត្តន៍ និងជាសត្រូវខាងក្រៅ និងអាចត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថា ជាការគំរាមកំហែងពិត ឬតាមការសន្មត។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា យោងតាមដីកាដំណោះស្រាយ ក្រុមនេះបានរួមបញ្ចូលគិញ ជនក្បត់បដិវត្តន៍ វៀតណាម និងអ្នកឃុបឃិតជាមួយវៀតណាម និង CIA[1666]។ អង្គជំនុំជម្រះជឿជាក់ថា សត្រូវពិត ឬតាមការសន្មតបានរួមបញ្ចូល ប៉ុន្តែមិនកម្រិតត្រឹមតែក្រុមបីប្រភេទដែលបានបញ្ជាក់លាក់ក្នុងដីកាដំណោះស្រាយប៉ុណ្ណោះនោះទេ។

601. ដូចបានបង្ហាញពីដំបូង អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ខៀវ សំផន បានលើកសាឡើងវិញនូវសារណាក្នុងពេលជំនុំជម្រះរបស់គាត់ពាក់ព័ន្ធទៅនឹងការកម្រិតប្រភេទ"សត្រូវ"ដោយពុំបានបង្ហាញកំហុស និងប្រហាក់ប្រហែលគ្នានេះបដិសេធសារណានេះ។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ផងដែរថា អង្គជំនុំ

---

[1662] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៣៦ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦-១៤១៨។

[1663] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៣៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧០។

[1664] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៣៨។

[1665] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៣៨។

[1666] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៣៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៦៣២, ៦៣៤, ៦៤០។

ជម្រះសាលាដំបូងបានពន្យល់ពេញលេញអំពីប្រភេទ“សត្រូវ”នៅភ្នំក្រោល ដោយបានផ្អែកលើការពិនិត្យពេញលេញ និងត្រឹមត្រូវលើដីកាដំណោះស្រាយ[1667]។ អាស្រ័យហេតុនេះ សារណាទាំងនេះត្រូវបដិសេធចោល។

## ៣. ការចោទប្រកាន់កំហុសពាក់ព័ន្ធនឹងក្រុមជាក់លាក់

602. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបង្កើត“សង្គមមួយគ្មានការប្រតិបត្តិសាសនា និងស្មើភាពគ្នាដោយគ្មានការបែងចែកវណ្ណៈ លុបបំបាត់រាល់ជាតិពន្ធុ ជាតិសាសន៍ សាសនា ពូជសាសន៍ ការបែងចែកវណ្ណៈ និងវប្បធម៌” ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រេចគោលបំណងរួម។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា យោងតាមដីកាដំណោះស្រាយ ជនជាតិចាម ជនជាតិវៀតណាម និងក្រុមពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងអតីតអ្នករដ្ឋការស៊ីវិល និងបុគ្គលិកយោធា និងគ្រួសាររបស់ពួកគេ ត្រូវបានកំណត់គោលដៅក្នុងលំនាំមួយដែលបានចាប់ផ្តើមមុនឆ្នាំ ១៩៧៥ និងបានបន្តរហូតដល់យ៉ាងហោចណាស់នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[1668]។

### ក. ជនជាតិចាម

603. អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ដីកាដំណោះស្រាយបានកំណត់អត្តសញ្ញាណជនជាតិចាមថាជាកម្មវត្ថុមួយនៃគោលនយោបាយកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា[1669]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម អង្គជំនុំជម្រះបានតម្រូវឱ្យជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកនៃក្រុមនេះចាប់តាំងពីឆ្នាំ ១៩៧៧ នៅមន្ទីរសន្តិសុខភូមិទ្រា និងអូរត្រកួន អំពើមនុស្សឃាត និងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងវិសាលភាពយុត្តាធិការពេលវេលា និងភូមិសាស្ត្រសម្រាប់ការសម្លាប់រង្គាល អំពើមនុស្សឃាតដែលត្រូវបានកម្រិតត្រឹមមន្ទីរសន្តិសុខវត្តអូរត្រកួន ភូមិទ្រា និងការសម្លាប់រីករាល

[1667] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៦៣២, ៦៣៤, ៦៤០។

[1668] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២០៥, ២០៧។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧២៨។

[1669] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧២៨។

ដាលចាប់តាំងពីឆ្នាំ ១៩៧៧ និងការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៨ នៅមន្ទីរសន្តិសុខភូមិទ្រា[1670]។

604. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវឱ្យជំនុំជម្រះអំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការកម្ទេចជនជាតិចាម ដែលបានកើតឡើងនៅភូមិទ្រា ដោយហេតុថា ដីកាដំណោះស្រាយបានកម្រិតវិសាលភាពត្រឹមមន្ទីរសន្តិសុខក្រូចឆ្មារ និងអូរត្រកួន[1671]។ ខៀវ សំផន បានចោទប្រកាន់កំហុសផងដែរក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះបានតម្រូវឱ្យជំនុំជម្រះលើបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយកំណត់គោលដៅលើជនជាតិចាមតាមរយៈសហឧក្រិដ្ឋកម្មរួម ដោយហេតុថា គាត់ពុំត្រូវបានចោទប្រកាន់អំពីការទទួលខុសត្រូវក្នុងទម្រង់នេះឡើយ[1672]។

605. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការសម្លាប់ជនជាតិចាមនៅភូមិទ្រា ត្រូវបានស្រូបបញ្ចូលក្នុងបទឧក្រិដ្ឋនៃការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពុំត្រូវបានជំទាស់ដោយ ខៀវ សំផន[1673]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមថា ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់លាស់ថា បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ហើយដីកាបំបែកសំណុំរឿង និងវិសាលភាពបន្ថែមបានបញ្ជាក់ផងដែរថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាមស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[1674]។

606. សហមេធាវីនាំមុខបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន គប្បីបដិសេធចោលអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[1675]។ សហមេធាវីនាំមុខបានលើកឡើងបន្ថែមទៀតថា ខៀវ សំផន បានទទួលស្គាល់ច្បាស់លាស់ថា ដីកាដំណោះស្រាយបានចោទប្រកាន់គាត់ពីបទ“សម្លាប់រង្គាលលើជនជាតិចាមចាប់

---

[1670] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨២។

[1671] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥១៧-៥១៨។

[1672] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥១៩។

[1673] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤០។

[1674] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤១ យោងទៅលើសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1) កថាខណ្ឌ ៤៣។

[1675] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៨-១៨០។

ផ្ដើមក្នុងឆ្នាំ ១៩៧៧ គួរកត់សម្គាល់ជាប់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភូមិទ្រាក្នុងភូមិភាគបូព៌ា និងមន្ទីរសន្តិសុខវត្តអូរត្រកួនក្នុងភូមិភាគមជ្ឈិម"[1676]។

607. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងឆ្នាំ ១៩៧៨ ជនជាតិចាមជាច្រើនមកពីស្រុកក្រូចឆ្មារត្រូវបានចាប់ខ្លួន និងនាំយកទៅមន្ទីរសន្តិសុខភូមិទ្រា កន្លែងដែលពួកគេត្រូវបានចាត់ទុកថា ជាជនជាតិចាម និងត្រូវបានកម្ទេច[1677]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរតាមរយៈការពិនិត្យដីកាដំណោះស្រាយ និងសេចក្ដីសម្រេចបំបែកសំណុំរឿងជារួម[1678]ថា អង្គហេតុដែលពាក់ព័ន្ធនឹងការកម្ទេចជនជាតិចាមនៅភូមិទ្រា បានរួមបញ្ចូលទៅក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍ អំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1679]។

608. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានគូសបង្ហាញផ្សេងគ្នានូវការយល់ឃើញស្ដីពីអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1680] និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1681]។ ក្នុងការយល់ឃើញស្ដីពីអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហចៅក្រមស៊ើបអង្កេតពុំបានរៀបរាប់ច្បាស់លាស់អំពីការសម្លាប់នៅភូមិទ្រ[1682] ប៉ុន្តែបានបញ្ជាក់ថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានពន្លាតដល់"ការប្រព្រឹត្តលើពុទ្ធសាសនិក ជនជាតិវៀតណាម និងជនជាតិចាម"[1683]។ នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបង្កើតការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធទៅនឹងការសម្លាប់ និងការធ្វើបាបជនជាតិចាមនៅភូមិទ្រា[1684]។ តាមការពិនិត្យដីកាដំណោះស្រាយជារួម អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់នៅភូមិទ្រាត្រូវបានចោទប្រកាន់ថា ជា

---

[1676] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៧ (vi)។

[1677] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៦ យោងទៅលើការយល់ឃើញផ្នែកអង្គហេតុដែលបានសង្ខេបក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០២។

[1678] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤។

[1679] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤ (i)-(iii)។

[1680] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៧៣-១៣៨០។

[1681] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨១-១៣៩០។

[1682] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៧៣។

[1683] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៧៣។

[1684] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៧៨៤-៧៨៩។

ផ្នែកនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា នៅគ្រប់កាលៈទេសៈ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការសម្លាប់ជនជាតិចាមត្រូវបានស្រូបបញ្ចូលទៅនឹងបទឧក្រិដ្ឋនៃការសម្លាប់រង្គាល[1685]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពុំបានលើកឡើងអំពីការយល់ឃើញដែលជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពលើគាត់។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

609. ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម ត្រូវបានចោទប្រកាន់ថា ជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវឱ្យជំនុំជម្រះលើអង្គហេតុពាក់ព័ន្ធទៅនឹងការអនុវត្តន៍គោលនយោបាយតាមរយៈសហឧក្រិដ្ឋកម្មរួម ដែលពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ បានរួមបញ្ចូលការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយ និងសាសនាទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម[1686]។ ក្នុងការគាំទ្រ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញផ្នែកច្បាប់ពីដំបូងរបស់ខ្លួនស្តីពីការប្រព្រឹត្តទៅលើជនជាតិចាម[1687]។ ក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការយល់ឃើញផ្នែកច្បាប់នៃដីកាដំណោះស្រាយបូករួមជាមួយនឹងសេចក្តីសម្រេចបំបែកសំណុំរឿងបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ[1688]។

610. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ក្នុងចំណោមគោលនយោបាយល្មើសទាំងប្រាំ មានគោលនយោបាយមួយបង្ហាញថា ក្រុមជាក់លាក់រួមទាំងជនជាតិចាមត្រូវបានកំណត់គោលដៅ និងយល់ឃើញថា អំពើនេះស្មើនឹង"ការធ្វើទុក្ខបុកម្នេញ

---

[1685] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៣៧, ៤៣៤១ (i)។

[1686] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩១។

[1687] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩១ យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.២.១០: ការប្រព្រឹត្តលើជនជាតិចាម: ការយល់ឃើញផ្នែកអង្គហេតុ (ជាពិសេសផ្នែក ១៣.២.១០.២, ១៣.២.១០.៧, ១៣.២.១០.៩)។

[1688] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨០ (vi) យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦, ១៤១៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(b)(៧)។

ដោយសារមូលហេតុពូជសាសន៍" និង"ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា"[1689]។ បន្ថែមលើនេះ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿងបានរួមបញ្ចូលការយោងទៅលើការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម[1690]។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញបន្ថែមទៀតថា បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដែលត្រូវបានចោទប្រកាន់ស្ទើរគ្រប់ទីតាំងទាំងអស់ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[1691]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ខៀវ សំផន ត្រូវបានជូនដំណឹងថា គាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយទាក់ទងទៅនឹងជនជាតិចាមដែលជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម។ សារណារបស់ ខៀវ សំផន ដែលផ្ទុយពីនេះត្រូវបដិសេធចោល។

## ខ. ជនជាតិវៀតណាម

611. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានកំណត់អត្តសញ្ញាណជនជាតិវៀតណាមថា ជាកម្មវត្ថុមួយនៃគោលនយោបាយកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា[1692]។ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវឱ្យជំនុំជម្រះអង្គហេតុដែលពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់ ទូទាំងប្រទេសចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតលើជនជាតិវៀតណាមដែលពុំព្រមធ្វើមាតុភូមិនិវត្តក្នុងឆ្នាំ ១៩៧៥-១៩៧៦ និងទូទាំងប្រទេសចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ និងការសម្លាប់រង្គាលទូទាំងប្រទេសចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ និងការនិរទេសពីខេត្តព្រៃវែង ស្វាយរៀងនិងសហករណ៍ត្រាំកក់ក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ក្នុងខេត្តព្រៃវែង ស្វាយរៀង សហករណ៍ត្រាំកក់ និងមន្ទីរស ២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និង

---

[1689] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៥២៥ (iv)(ច)-(ឆ)។

[1690] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(៧) និង ៥(ii)(b)(៨) និង៥(ii)(b)(១៣) យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៥-១៤១៨, ១៤៤៨-១៤៦៩។

[1691] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៦, ១៤១៨។

[1692] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧២៨។

អូរកន្សែងពេញមួយអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ ព្រមទាំងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៅមន្ទីរស-២១[1693]។

612. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា អង្គជំនុំជម្រះបានតម្រូវដោយសមស្របឱ្យជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ នៅពេលពុំមានអង្គហេតុពាក់ព័ន្ធទៅនឹងវិធានការដែលបានធ្វើឡើងនៅសមុទ្រ ត្រូវបានរួមបញ្ចូលក្នុងដីកាដំណោះស្រាយ[1694]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារមួយក្នុងការបង្កើតការយល់ឃើញនេះ និងបានយោងទៅលើនៅខាងចុងបញ្ចប់នៃដីកាដំណោះស្រាយ និងការធ្វើបែបនេះខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវគតិយុត្តដែលថា រាល់បទចោទត្រូវតែមានលក្ខណៈពេញលេញ លម្អិត និងច្បាស់លាស់ត្រឹមត្រូវ[1695]។ អាស្រ័យហេតុនេះ តាមការអះអាងរបស់ ខៀវ សំផន ថា គាត់ត្រូវតែទទួលបានការលើកលែងចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍តាមរយៈអំពើមនុស្សឃាត ព្រមទាំងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងអំពើមនុស្សឃាតទាក់ទងទៅនឹងអង្គហេតុពាក់ព័ន្ធការប្រព្រឹត្តទៅលើជនជាតិវៀតណាមនៅសមុទ្រ[1696]។

613. សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវការតវ៉ារបស់គាត់ដែលត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង និងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានដកចេញដែនទឹកនោះ[1697]។ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា ដីកាដំណោះស្រាយបានដកស្រង់ច្បាស់លាស់នូវកំណត់ត្រាសម័យនោះនៃការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅសមុទ្រ នៅពេលគូសបង្ហាញភស្តុតាងនៃការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាម[1698]។

---

[1693] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០០១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥១។

[1694] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២០។

[1695] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២១។

[1696] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២១។

[1697] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤២។

[1698] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥៧ ជើងទំព័រ ១១៣២១។

614. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះពុំបានតម្រូវសមស្របឱ្យជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ[1699]។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញពីដំបូងរបស់ខ្លួនក្នុងឆ្នាំ ២០១៦ ថា "អង្គហេតុពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាមនៅសមុទ្រដូចគ្នាដែរ គឺជាផ្នែកមួយនៃអង្គហេតុដែលបានគូសបង្ហាញក្នុងដីកាដំណោះស្រាយ"[1700]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីនូវការយល់ឃើញនោះ និងបានបដិសេធអំណះអំណាងរបស់ ខៀវ សំផន[1701]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា តាមការពិនិត្យពេញលេញលើដីកាដំណោះស្រាយឃើញថា មានអង្គហេតុផ្សេងៗជាច្រើនពាក់ព័ន្ធទៅនឹងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាស្តីពីការប្រព្រឹត្តទៅលើជនជាតិវៀតណាម[1702]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ត្រឹមតែជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដោយពុំបានបង្ហាញនូវកំហុស។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

### គ. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

615. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាដំណោះស្រាយបានកំណត់ជារួមនូវអត្តសញ្ញាណអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអតីតអ្នករដ្ឋការស៊ីវិល និងបុគ្គលិកយោធា) និងគ្រួសាររបស់ពួកគេថា ជាកម្មវត្ថុនៃគោលនយោបាយកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា[1703]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ដីកាដំណោះស្រាយបានចោទប្រកាន់ថា គោលនយោបាយនេះមាន

---

[1699] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥៧ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១៩៣៤។

[1700] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥៧ យោងទៅលើសេចក្តីសម្រេចលើសំណើសុំស្តាប់សាក្សីបន្ថែមស្តីពីប្រធានបទនៃការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី (E380, E381, E382)(សំអាងហេតុពេញលេញ) ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E380/2 ("សេចក្តីសម្រេចលើញត្តិសុំស្តាប់សាក្សីបន្ថែម (E380/2)") កថាខណ្ឌ ២១ យោងក្នុងជើងទំព័រ ៣៧ ទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យផ្ញើពីកងពលលេខ ១៦៤ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/929 ERN 00143505-00143506។

[1701] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥៧ យោងទៅលើសេចក្តីសម្រេចលើញត្តិសុំស្តាប់សាក្សីបន្ថែម (E380/2) កថាខណ្ឌ ២១ យោងក្នុងជើងទំព័រ ៣៧ ទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យផ្ញើពីកងពលលេខ ១៦៤ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/929 ERN 00143505-00143506។

[1702] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២១៤-២១៥, ៨១៦។

[1703] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១២ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧២៨។

អត្ថិភាពនៅមុនឆ្នាំ ១៩៧៥ និងបានបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ផងដែរថា យោងតាមដីកាដំណោះស្រាយ មានការប្រកាសជាសាធារណៈអំពីចេតនាក្នុងការកម្ទេចឥស្សរជនជាន់ខ្ពស់របបសាធារណរដ្ឋខ្មែរក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ និងសេចក្ដីសម្រេចសម្ងាត់សម្លាប់សមាជិកជាន់ខ្ពស់ដទៃទៀតត្រូវបានធ្វើឡើងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ដូចបានចោទប្រកាន់ នេះបានឈានទៅដល់ការចាប់ខ្លួន និងកម្ទេចអតីតអ្នករដ្ឋការជាន់ខ្ពស់ក្នុងអំឡុងពេលនៃការជម្លៀសទីក្រុងភ្នំពេញ និងការផ្លាស់ទីប្រជាជនទូទាំងប្រទេសកម្ពុជា[1704]។

616. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ដីកាដំណោះស្រាយមានការចោទប្រកាន់ផ្នែកអង្គហេតុដែលកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលជាផ្នែកមួយនៃគោលនយោបាយល្មើស[1705]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃដីកាដំណោះស្រាយក្នុងការសន្និដ្ឋានបែបនេះ និងបានសង្កេតថា បុគ្គលទាំងនេះពុំត្រូវបានរៀបរាប់ថា ជាក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងផ្នែកនៃដីកាដំណោះស្រាយចំណងជើងថា "ការប្រព្រឹត្តទៅលើក្រុមគោលដៅ"[1706]។ គាត់បានលើកឡើងផងដែរថា ការយល់ឃើញស្ដីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកម្រិតត្រឹមការផ្លាស់ទីប្រជាជនពីទីក្រុងភ្នំពេញ[1707]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀតក្នុងការអនុញ្ញាតឱ្យអយ្យការសួរសំណួរដឹកមុខទាក់ទងទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅការដ្ឋានទំនប់ត្រពាំងថ្ម[1708]។ ដោយសារផលវិបាកនៃការពង្រីកយុត្តាធិការដែលពុំត្រូវបានអនុញ្ញាត ខៀវ សំផន បានលើកឡើងថា ការដាក់ពិរុទ្ធភាពលើគាត់ដោយផ្អែកលើបទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គប្បីបដិសេធចោល[1709]។

---

[1704] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២០៥-២០៦, ២០៨-២០៩។

[1705] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២៤-៥២

[1706] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២៣-៥២៤។

[1707] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២៦-៥២៧។

[1708] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥២៨-៥២៩។

[1709] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣០។

617. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានបំភ្លៃដីកាដំណោះស្រាយ[1710]។ បើទោះបីជាអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពុំត្រូវបានកំណត់អត្តសញ្ញាណថា ជាក្រុមមួយនៅក្នុងការយល់ឃើញដែលបានគូសបង្ហាញក្នុងផ្នែក"ការប្រព្រឹត្តទៅលើក្រុមគោលដៅ"ក៏ដោយ ក៏ដីកាដំណោះស្រាយមានការយល់ឃើញជាច្រើនដែលបង្ហាញនូវការប្រព្រឹត្តទៅលើពួកគេដូចជាសត្រូវ[1711]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា ខៀវ សំផន ពុំបានលើមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាសួរសំណួរដឹកមុខស្តីពីអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1712]។

618. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការអះអាងរបស់ ខៀវ សំផន ថា ដីកាដំណោះស្រាយបានចោទប្រកាន់អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅពាក់ព័ន្ធតែទៅនឹងការជម្លៀសទីក្រុងភ្នំពេញប៉ុណ្ណោះ[1713]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងផ្នែកនៃដីកាដំណោះស្រាយដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ច្បាស់លាស់ថា ការផ្លាស់ទីប្រជាជនពីទីក្រុងភ្នំពេញ គឺជា"អត្ថិភាពតែមួយគត់នៃលំនាំជាច្រើនក្នុងការកំណត់គោលដៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"[1714]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀតលើអំណះអំណាងរបស់គាត់ទាក់ទងទៅនឹងការខកខានក្នុងការរៀបរាប់ជាក់លាក់នូវអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងដីកាដំណោះស្រាយ និងបើទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា ដីកាដំណោះស្រាយពុំបានរួមបញ្ចូលការយោងទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងផ្នែកនោះក៏ដោយ ក៏ដីកាដំណោះស្រាយបានបង្ហាញត្រង់ៗនូវអង្គហេតុដែលចង់សំដៅទៅលើការចាត់ទុកពួកគេដូចសត្រូវក្នុងចំណុចតូចៗទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតក្រោមការពិនិត្យក្នុងសំណុំរឿង

---

[1710] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៣-៣៤៤។

[1711] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៣។

[1712] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៥។

[1713] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២៤ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣១០-២៣១១។

[1714] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២៤ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣១០ ដកស្រង់ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២០៦ (សេចក្តីបញ្ជាក់បន្ថែមក្នុងសាលក្រម)។

០០២/០២ ដែរ[1715]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសារណារបស់ ខៀវ សំផន[1716]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងរបស់គាត់ក្នុងពេលជំនុំជម្រះដោយពុំបានបង្ហាញនូវកំហុស និងថា ការចោទប្រកាន់នេះត្រូវបដិសេធចោល។ បន្ថែមលើនេះ ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាសួរសំណួរដឹកមុខស្តីពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ឃ. អង្គហេតុដែលត្រូវបានដកចេញពីសំណុំរឿង ០០២/០២ បន្ទាប់ពីការបំបែកសំណុំរឿង

619. ខៀវ សំផន បានលើកឡើងថា យោងតាមវិធាន ៨៩ *ស្ទួនពីរ* និង ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង[1717] អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការចេញសាលក្រមលើអង្គហេតុដែលត្រូវបានវិនិច្ឆ័យរួចរាល់ក្នុងសំណុំរឿង ០០២/០១ ឬអង្គហេតុដែលបានដកចេញពីសំណុំរឿង ០០២/០២ និងអង្គហេតុដែលត្រូវបានបញ្ចប់កិច្ចដំណើរការនីតិវិធី[1718]។ គាត់បានជំទាស់ថា ផ្អែកតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានបោះបង់ជាបណ្តោះអាសន្ននូវយុត្តាធិការក្នុងការពិចារណាលើអង្គហេតុដែលខ្លួនបានដកចេញតាមរយៈការបំបែកសំណុំរឿង និងបានបោះបង់ជាអចិន្ត្រៃយ៍នូវយុត្តាធិការក្នុងការពិចារណាលើអង្គហេតុដែលអង្គជំនុំជម្រះបានដកចេញបន្ទាប់ពីការកាត់បន្ថយនូវវិសាលភាពនៃការជំនុំជម្រះស្របវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុង[1719]។ គាត់បានអះអាងថា ការពិចារណាណាមួយលើអង្គហេតុទាំងនេះ បើទោះបីជាក្រោមរបបគតិយុត្តដូចគ្នា ឬខុសគ្នា គឺជាការរំលោភបំពានលើវិធាន និងគោលការណ៍ស្តីពី*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ*[1720]។

---

[1715] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៩ (សហករណ៍ត្រាំកក់), ៣៦៦ (ការដ្ឋានទំនប់១មករា), ៤៣២ (មន្ទីរស-២១), ៥៩៨, ៥០៦ (មន្ទីរសន្តិសុខក្រាំងតាចាន់)។

[1716] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២៤។

[1717] វិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង(ពាក់ព័ន្ធនឹងការបំបែកសំណុំរឿង)។ វិធាន ៨៩ *ស្ទួនបី* (ពាក់ព័ន្ធនឹងការកាត់បន្ថយវិសាលភាពជំនុំជម្រះ)។

[1718] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣១-៥៣៧។ *សូមមើលបន្ថែម* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩២។

[1719] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣៥-៥៣៦។

[1720] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣៤, ៥៣៧។

620. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា វិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកម្រិតដោយការបំបែកសំណុំរឿង ០០២ ដូចបានកំណត់ក្នុងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងឧបសម្ព័ន្ធ[1721]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ដែលបានផ្តល់ដំណឹងគ្រប់គ្រាន់ដល់គាត់អំពីវិសាលភាពនៃរឿងក្តី[1722]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែរ[1723]។

621. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុងនៅក្នុងផ្នែកពាក់ព័ន្ធចែងថា "នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជំនុំជម្រះ"[1724]។ យោងតាមវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុង "អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ"[1725]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបំបែកសំណុំរឿង ០០២/០២ ចេញពីសំណុំរឿង ០០២ តាមរយៈសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងឧបសម្ព័ន្ធ[1726] និងថា ចុងក្រោយ អង្គហេតុដែលបានគូសបង្ហាញក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ និងពុំត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ត្រូវបានបញ្ចប់កិច្ចដំណើរការនីតិវិធី[1727]។

622. ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ស្របតាមវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានដកចេញ និងថា នៅពេលសេចក្តីសម្រេចនោះចូលជាស្ថាពរ អង្គហេតុដែលបានដកចេញពុំមែនជាមូលដ្ឋានសម្រាប់

---

[1721] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៦៥-១៦៨។

[1722] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៦។

[1723] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៧។

[1724] វិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។

[1725] វិធាន ៨៩ *ស្ទួនបី* (១) និង (៣) នៃវិធានផ្ទៃក្នុង។

[1726] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1)។ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1)។

[1727] សេចក្តីសម្រេចស្តីពីការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារលេខ E439/5។

កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដដែលនោះឡើយ[1728]។ ទោះជាយ៉ាងណាក្តី វិធាននេះចែងថា "ភស្តុតាងទាក់ទងទៅនឹងអង្គហេតុដែលបានដកចេញអាចត្រូវបានសំអាងទៅលើដរាបណាភស្តុតាងនោះជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដទៃទៀត"[1729]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រឹមតែយល់ស្របជាមួយនឹង ខៀវ សំផន ត្រង់ចំណុចដែលគាត់បានលើកឡើងថា តាមរយៈការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង"បានសម្រេចថា អង្គជំនុំជម្រះពុំចាត់ទុកអង្គហេតុដែលបាន[ដកចេញ]"[1730] ជាមូលដ្ឋានសម្រាប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ប៉ុណ្ណោះ។ ស្របតាមបទប្បញ្ញត្តិជាក់លាក់នៃវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុង ភស្តុតាងដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានដកចេញ អាចត្រូវបានសំអាងទៅលើត្រង់ចំណុចដែលពាក់ព័ន្ធទៅនឹងអង្គហេតុដទៃទៀត ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿងនេះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ពុំបានផ្តល់ឧទាហរណ៍ច្បាស់លាស់នៃការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអង្គហេតុដែលត្រូវបានដកចេញតាមរយៈការកាត់បន្ថយវិសាលភាពស្របតាមវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោលដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តី។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើសារណារបស់គាត់ពាក់ព័ន្ធនឹងវិធាន ៨៩ *ស្ទួនបី*នៃវិធានផ្ទៃក្នុងត្រង់ចំណុចដែលសារណានេះមានមូលដ្ឋានគាំទ្រនៅក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះ។

### ១. ការចោទប្រកាន់អំពីនត្តិភាពវិសាលភាពសម្រាប់អង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំ

623. តាមការពិនិត្យជារួមលើដីកាដំណោះស្រាយ និងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា វិសាលភាពនៃបទចោទពាក់ព័ន្ធនឹងជនជាតិចាម បានរួមបញ្ចូលអង្គហេតុទាក់ទងទៅនឹង*ក្នុងចំណោមទោះ*ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា និងនយោបាយ ព្រមទាំងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការផ្លាស់ទីដោយបង្ខំក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ[1731]។

---

[1728] វិធាន ៨៩ *ស្ទួនបី* (១) និង (៣) នៃវិធានផ្ទៃក្នុង។

[1729] វិធាន ៨៩ *ស្ទួនបី* (៣) នៃវិធានផ្ទៃក្នុង។

[1730] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣៥។

[1731] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤ (vi), (viii)។

624. ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការកម្រិតវិសាលភាពនៃកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរៈ (១) ត្រឹមអង្គហេតុដែលជាការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុសាសនា និង (២) ដោយសារការដាក់ពិរុទ្ធភាពលើគាត់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនោះ[1732]។ គាត់បានអះអាងជាពិសេសថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារដកចេញកថាខណ្ឌ ៤៣ នៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ដែល"បានកំណត់ច្បាស់លាស់នូវវិសាលភាពនៃការជំនុំជម្រះទាក់ទងទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃ[ការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ] ក្រោមការកំណត់ប្រភេទគតិយុត្តនៃការធ្វើទុក្ខបុកម្នេញ[ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ]ដោយសារមូលហេតុសាសនា"[1733]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានប្រកាសដោយខ្លួនឯងថា មានសមត្ថកិច្ចក្នុងការជំនុំជម្រះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអង្គហេតុនៃការផ្លាស់ទីដោយបង្ខំ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ[1734]។ ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា ការយល់ឃើញទាំងអស់ដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបដិសេធចោលដោយសាររំលោភបំពានលើវិសាលភាពនៃការជំនុំជម្រះ រួមទាំងការយល់ឃើញពាក់ព័ន្ធទៅនឹងការដាក់បញ្ចូលអង្គហេតុនេះទៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងការដាក់ពិរុទ្ធភាពលើគាត់តាមរយៈសហឧក្រិដ្ឋកម្មរួម[1735]។

625. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន បានផ្អែកលើការពិនិត្យពុំត្រឹមត្រូវលើសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងថា ការសំដៅរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការធ្វើទុក្ខបុកម្នេញផ្អែកសាសនាទាក់ទងទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ"មិនបានដកចេញ ឬមិនដាក់បញ្ចូលនោះទេ" និងពុំបានកម្រិតវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួនត្រឹមអង្គហេតុដែលអាចកំណត់ប្រភេទគតិយុត្តថា ជាការធ្វើទុក្ខបុកម្នេញផ្អែកសាសនា

---

[1732] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣៨។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩២។

[1733] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៣៩-៥៤០ យោងទៅលើសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម កថាខណ្ឌ ៤៣។

[1734] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤១-៥៤៣។

[1735] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤១-៥៤៣។

ឡើយ[1736]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម បានដាក់បញ្ចូលនូវបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការផ្លាស់ទីដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ព្រមទាំងការយល់ឃើញផ្នែកអង្គហេតុជាមូលដ្ឋាននៃដីកាដំណោះស្រាយដែលអាចអនុវត្តបានចំពោះបទចោទទាំងបីនេះ[1737]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[1738]។

626. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានលើកបញ្ហាពីរដែលពាក់ព័ន្ធគ្នា។ បញ្ហាទីមួយគឺថាតើ កថាខណ្ឌ ៤៣ នៃសេចក្តីសម្រេចបំបែកសំណុំរឿងបន្ថែមបានកម្រិតវិសាលភាពសំណុំរឿង ០០២/០២ ទាក់ទងទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាម ត្រឹមអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដែរ ឬយ៉ាងណា។

627. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា កថាខណ្ឌ ៤៣ នៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមបានលើកឡើងថា៖

> ជាពិសេស អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ការផ្លាស់ទីជនជាតិចាមគឺជាមូលដ្ឋាននៃបទចោទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ព្រមទាំងជាមធ្យោបាយសម្រាប់អនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ និងការប្រព្រឹត្តលើក្រុមកំណត់គោលដៅ។ អង្គជំនុំជម្រះសាលាដំបូងបានដកបទចោទដែលផ្អែកលើគោលនយោបាយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម រួមទាំងបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១។ ទោះជាយ៉ាងណាក្តី ការប្រព្រឹត្តទៅលើជនជាតិចាម និងបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា រួមទាំងក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជន(ដំណាក់កាលទីពីរ) ត្រូវបានរួមបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[1739]
> ។

កថាខណ្ឌនេះមាននៅក្នុងផ្នែក ៥.៣ នៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានពន្យល់អំពីការដាក់បញ្ចូលផ្នែកមួយចំនួននៃដីកាដំណោះស្រាយទាក់ទងទៅនឹងទីតាំង

---

[1736] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៩។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ១០០។

[1737] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៩។

[1738] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៥-១៦៧។

[1739] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៤៣។

ឧក្រិដ្ឋកម្ម គោលនយោបាយ សាវតារ និងបរិបទក្នុងសំណុំរឿង ០០២/០២ ដែលជាផ្នែកនៃសំណុំរឿង ០០២/០១[1740]។ អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺថា អង្គជំនុំជម្រះបានភ្ជាប់ជាមួយនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមនូវ"ឧបសម្ព័ន្ធដែលដាក់បញ្ចូលកថាខណ្ឌពាក់ព័ន្ធទាំងអស់នៃដីកាដំណោះស្រាយ"[1741]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ការសំដៅទៅលើការធ្វើទុក្ខបុកម្នេញផ្នែកសាសនាទាក់ទងទៅនឹងការផ្លាស់ទីដោយបង្ខំលើជនជាតិចាមក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរក្នុងកថាខណ្ឌ ៤៣ នៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម"មិនបានដកចេញ ឬមិនដាក់ចូលនោះទេ"[1742] និងថា សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ត្រូវតែពិនិត្យរួមជាមួយនឹងឧបសម្ព័ន្ធ។

628. បញ្ហាទីពីរថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ដោយសារបានដាក់ពិរុទ្ធភាពលើ ខៀវ សំផន តាមរយៈអង្គហេតុដែលត្រូវបានកំណត់ចរិតលក្ខណៈថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងការផ្លាស់ទីដោយបង្ខំលើជនជាតិចាមដែលពុំស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះ។

629. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម បានរួមបញ្ចូលកថាខណ្ឌនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និង ដូចបានបញ្ជាក់ខាងលើ ត្រូវពិនិត្យរួមជាមួយនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម[1743]។ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា និងនយោបាយ ព្រមទាំងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការផ្លាស់ទីដោយបង្ខំដែលត្រូវបានកម្រិតត្រឹមការប្រព្រឹត្តទៅលើជនជាតិចាម ត្រូវបានបញ្ជាក់ច្បាស់លាស់ថា ជាបទល្មើសមូលដ្ឋានដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1744]។ បន្ថែមលើនេះ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម បានរៀបរាប់កថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ

---

[1740] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៤១។

[1741] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៤១ (សេចក្តីបញ្ជាក់បន្ថែម)។

[1742] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៩។

[1743] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៤១។ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) ចំណងជើង ("បញ្ជីរៀបរាប់អំពីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២")។

[1744] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(៧) និង ៥(ii)(ខ)(៨) និង៥(ii)(ខ)(១៣) យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤១៥-១៤១៨, ១៤៤៨-១៤៦៩។

ព្រមទាំងការយល់ឃើញផ្នែកអង្គហេតុដែលអនុវត្តចំពោះបទចោទទាំងនេះនៅក្នុងកថាខណ្ឌ ២៦៦, ២៦៨ និង ២៨១[1745]។

630. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែតម្រូវឱ្យជំនុំជម្រះអង្គហេតុដែលពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ "ត្រង់ចំណុចដែលអង្គហេតុនេះពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាដែលកំណត់គោលដៅលើជនជាតិចាម"ប៉ុណ្ណោះឡើយ[1746]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបកស្រាយលើសេចក្ដីសម្រេចបំបែកសំណុំរឿងបន្ថែម និងការកំណត់ថា វិសាលភាពនៃបទចោទទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាម បានរួមបញ្ចូលអង្គហេតុដែលពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការផ្លាស់ទីដោយបង្ខំ[1747]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណាពាក់ព័ន្ធរបស់ ខៀវ សំផន ដែលថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃការផ្លាស់ទីដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ ការដាក់បញ្ចូលក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងការដាក់ពិរុទ្ធភាពគាត់ដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុទាំងនោះ ត្រូវចាត់ទុកជាមោឃៈ ឬបដិសេធចោល[1748]។

### ២. ការចោទប្រកាន់អំពីនត្ថិភាពវិសាលភាពនៃអង្គហេតុទាក់ទងទៅនឹងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ

631. អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា វិសាលភាពនៃបទចោទពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាម បានរួមបញ្ចូលអង្គហេតុទាក់ទងទៅនឹង*ក្នុងចំណោមនោះ*បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការផ្លាស់ទីដោយបង្ខំ[1749] និងថា បទឧក្រិដ្ឋនេះត្រូវបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃការ

---

[1745] ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) កថាខណ្ឌ ៣(i)។

[1746] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤០។

[1747] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤ (vi), (viii)។

[1748] *ធៀបនឹង*សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤២-៥៤៣។

[1749] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤ (vi), (viii)។

ផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ[1750] និងថា ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មនេះដែលជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម[1751]។

632. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ទាក់ទងទៅនឹងអង្គហេតុដែលជាអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ[1752]។ គាត់បានអះអាងថា ក្នុងការវិនិច្ឆ័យអង្គហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើគោលការណ៍អាជ្ញាអស់ជំនុំ ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដើម្បីរារាំង"មិនឱ្យធ្វើការជំនុំជម្រះឡើងវិញនូវបញ្ហាដូចគ្នារបស់ភាគីដដែលក្នុងការជំនុំជម្រះមួយផ្សេងទៀត"[1753]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលបានដាក់ពិរុទ្ធភាព និងប្រកាសទោសគាត់ពីអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំពាក់ព័ន្ធទៅនឹងអង្គហេតុនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរក្នុងសំណុំរឿង ០០២/០១។ អាស្រ័យហេតុនេះ សេចក្តីសម្រេចស្ថាពរក្នុងសំណុំរឿង ០០២/០១ គឺជាគោលការណ៍អាជ្ញាអស់ជំនុំពាក់ព័ន្ធទៅនឹងអង្គហេតុទាំងនោះ[1754]។

633. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានអះអាងថា ការចោទប្រកាន់នេះពុំមានមូលដ្ឋានគាំទ្រពីព្រោះការផ្លាស់ទីដោយបង្ខំលើជនជាតិចាម ពុំត្រូវបានរួមបញ្ចូលក្នុងសំណុំរឿង ០០២/០១ ដែលជាផ្នែកនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរឡើយ។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា បទចោទនៃការផ្លាស់ទីជនជាតិចាមដោយបង្ខំ មានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ដែលពុំស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនបង្កើតការយល់ឃើញស្តីពីការចោទប្រកាន់លើការផ្លាស់ទីជនជាតិចាមដោយបង្ខំ ដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញផ្នែកសាសនា និងបានបដិសេធក្នុងការស្តាប់សាក្សីណាមួយក្នុងសំណុំរឿង ០០២/០១ លើបញ្ហានេះ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយសារការផ្លាស់ទីជន

---

[1750] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៤០។ *សូមមើលបន្ថែម* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩៧-៣៩៩៨។

[1751] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦។

[1752] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៤។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ៩២។

[1753] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៤-៥៤៥។

[1754] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៦។

ជាតិចាមដោយបង្ខំពុំដែលត្រូវបានជំនុំជម្រះ ទើបអង្គជំនុំជម្រះសាលាដំបូងពុំបានរំលោភបំពានលើគោលការណ៍អាជ្ញាអស់ជំនុំ[1755]។ សហមេធាវីនាំមុខយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[1756]។

634. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្រមុងផ្នែកច្បាប់របស់ អ.វ.ត.ក[1757] ពុំបានយោងទៅលើគោលការណ៍អាជ្ញាអស់ជំនុំ។ ទោះជាយ៉ាងណាក្តី ក្នុងការអនុវត្តន៍គោលការណ៍នេះ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសផ្សេងក៏ដោយ"[1758]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា គោលការណ៍អាជ្ញាអស់ជំនុំ ដូចបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានឆ្លុះបញ្ចាំងនូវគោលការណ៍*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ* ក្នុងយុត្តាធិការដទៃទៀតដែលរារាំងមិនឱ្យមានការចោទប្រកាន់ច្រើនដងចំពោះអង្គហេតុ ឬអំពើដែលក្នុងប្រព័ន្ធច្បាប់ស៊ីវិល ឬបទល្មើសដដែលក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ នៅកម្រិតអន្តរជាតិ គោលការណ៍អាជ្ញាអស់ជំនុំ បើទោះបីជាមានទំនាក់ទំនងជិតស្និទជាមួយនឹងគោលការណ៍*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ* ក៏ដោយ ក៏អនុវត្តយ៉ាងទូលំទូលាយជាងទៅលើស្ថានការណ៍ដែលក្នុងនោះបញ្ហាជាក់លាក់ត្រូវបានដោះស្រាយរួចរាល់ដោយតុលាការ។ តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍បានបញ្ជាក់ថា ក្នុងរឿងក្តីព្រហ្មទណ្ឌ*អាជ្ញាអស់ជំនុំ* ត្រូវបានកម្រិតត្រឹម"បញ្ហាថាតើនៅពេលការជំនុំជម្រះលើកដំបូងលើបុគ្គលជាក់លាក់ត្រូវបានធ្វើឡើងមុនការជំនុំជម្រះមួយផ្សេងទៀតលើបុគ្គលដដែលនោះ បញ្ហាជាក់លាក់នោះត្រូវបានជំនុំជម្រះពេញលេញរួចរាល់ ដែរ ឬយ៉ាងណា"[1759] និងថា អាជ្ញាអស់ជំនុំបានកើតឡើងតែនៅពេលណា

---

[1755] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៤៤។ ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/9.1 ទំព័រ ១០០។

[1756] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៥-១៦៧។

[1757] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការដាក់ទោសក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ឯកសារលេខ 2329 U.N.T.S. 117 ("កិច្ចព្រមព្រៀង អ.វ.ត.ក. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.") ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធានផ្ទៃក្នុង។

[1758] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (សេចក្តីបញ្ជាក់បន្ថែម)។

[1759] រឿងក្តី*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Delalić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-21-T សាលក្រមថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ("សាលក្រមរឿងក្តី *Čelebići* (ICTY)") កថាខណ្ឌ ២២៨។

"មានអត្ថិភាពនៃអត្តសញ្ញាណភាគី អត្តសញ្ញាណនៃបញ្ហា និងជាសំខាន់ ការកំណត់ចុងក្រោយលើបញ្ហាទាំងនោះក្នុងសេចក្តីសម្រេចលើកដំបូងរបស់តុលាការដែលមានសមត្ថកិច្ចសម្រេចនោះប៉ុណ្ណោះ"[1760]។

635. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានយល់ស្របជាមួយនឹងការបកស្រាយ "កម្រិតអន្តរជាតិ"ស្តីពីអាជ្ញាអស់ជំនុំតាមរយៈការយោងទៅលើគោលការណ៍ដែលរារាំងដល់ការជំនុំជម្រះសាឡើងវិញនូវបញ្ហាតែមួយរបស់ភាគីដដែលនៅក្នុងការជំនុំជម្រះមួយផ្សេងទៀត[1761]។ ផ្អែកតាមការបកស្រាយនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា "អាជ្ញាអស់ជំនុំ ពុំបានរារាំងនូវការប្រើប្រាស់អង្គហេតុ លើកលែងតែការជំនុំជម្រះសាឡើងវិញលើបញ្ហាដែលត្រូវបានកំណត់រួចរាល់ជាចុងក្រោយ"[1762]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា៖

> ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានកំណត់គោលការណ៍អាជ្ញាអស់ជំនុំក្នុងលក្ខណៈតូចចង្អៀតដោយបានកម្រិតត្រឹមតែការសម្រេចឱ្យរួចខ្លួន ហើយគោលការណ៍*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ* ត្រូវផ្អែកលើបទដ្ឋានអន្តរជាតិ ចំណែក*បទល្មើសតែមួយ* គឺជាប់ពាក់ព័ន្ធនឹងបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលមានន័យថា ការសម្រេចឱ្យរួចខ្លួន ឬសម្រេចដាក់ពិរុទ្ធភាពជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់[1763]។

អាស្រ័យហេតុនេះ ដរាបណាពុំមែនជាបទល្មើសដដែលនោះ មូលដ្ឋាននៃភស្តុតាងពុំជាប់ពាក់ព័ន្ធសម្រាប់គោលបំណងនៃគោលការណ៍*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ*[1764]។

636. ក្នុងរឿងក្តីនេះ ខៀវ សំផន បានអះអាងថា សាលដីកាក្នុងសំណុំរឿង ០០២/០១ មានអានុភាពនៃអាជ្ញាអស់ជំនុំទាក់ទងទៅនឹងអង្គហេតុនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ដែលគាត់បានអះអាងថា បានរួមបញ្ចូលការផ្លាស់ទីជនជាតិចាម[1765] រីឯសហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"ដាក់

---

[1760] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Uwinkindi* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ IRMCT-12-25-AR14.1 សេចក្តីសម្រេចលើការបដិសេធបញ្ជូនសំណុំរឿងទៅជំនុំជម្រះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ២៩។

[1761] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៥។

[1762] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៥៩។

[1763] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៨២។

[1764] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៨២។

[1765] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៦។

ស្តែងបានដកការពិចារណាលើការផ្លាស់ទីជនជាតិចាមដោយបង្ខំចេញពីសំណុំរឿង ០០២/០១"[1766]។ ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា ការផ្លាស់ទីជនជាតិចាម គឺជាកម្មវត្ថុនៃសេចក្តីសម្រេចចុងក្រោយក្នុងសាលដីកាសំណុំរឿង ០០២/០១ ក្រោមទម្រង់នៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការផ្លាស់ទីដោយបង្ខំ[1767] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានដកបទចោទដែលបានផ្អែកលើគោលនយោបាយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម រួមទាំងបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១[1768]។ ក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងចុងក្រោយបានបញ្ជាក់ថា៖

> ការផ្លាស់ទីក្រុមជនជាតិភាគតិចចាម គឺជាមូលដ្ឋាននៃការផ្លាស់ទីដោយបង្ខំ និងជាបទចោទធ្វើទុក្ខបុកម្នេញផ្នែកសាសនាពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជន(ដំណាក់កាលទីពីរ)។ បទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ ដោយសារមូលដ្ឋាននៃអង្គហេតុសម្រាប់បទចោទទាំងពីរនេះមានលក្ខណៈដូចគ្នា និងមានទំនាក់ទំនងយ៉ាងស្អិតល្មួត *អង្គជំនុំជម្រះពុំចាំបាច់បង្កើតការយល់ឃើញក្នុងសាលក្រមនេះពាក់ព័ន្ធទៅនឹងការចោទប្រកាន់ការផ្លាស់ទីដោយបង្ខំជនជាតិចាមដែលត្រូវបានចោទប្រកាន់ផងដែរថា ជាការធ្វើទុក្ខបុកម្នេញផ្នែកសាសនាឡើយ*[1769]។

ជាលទ្ធផល បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ បានទទួលស្គាល់ថា "ការផ្លាស់ទីជនជាតិចាម ៥០.០០០ នាក់ ចេញពីភូមិភាគបូព៌ាទៅភូមិភាគមជ្ឈិម(ឧត្តរចាស់) គឺជាផ្នែកនៃការផ្លាស់ទីប្រជាជនទូលំទូលាយក្នុងគោលបំណងបែងចែកប្រជាជនទូទាំងប្រទេសកម្ពុជា"[1770]ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ពុំបានបង្កើតការយល់ឃើញជាក់លាក់ស្តីពីការផ្លាស់ទីដោយបង្ខំ និងការប្រព្រឹត្តទៅលើជនជាតិចាម និងពុំបានស្តាប់សាក្សីលើប្រធានបទជាក់លាក់នេះដែរ។

---

[1766] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៤៤។

[1767] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៤, ៥៤៦។

[1768] សំណុំរឿង ០០២/០១ ឧបសម្ព័ន្ធ៖ ចំនួននៃកថាខណ្ឌ និង ផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ត្រូវបានកែប្រែបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ អៀង សារី គ្រប់គ្រាន់ចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163) ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E124/7.3។

[1769] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៦២៧ (ការបញ្ជាក់បន្ថែម)។

[1770] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១២, ៣២៦២។

637. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើសារណារបស់ ខៀវ សំផន ដែលថា ការផ្លាស់ទីជនជាតិចាម គឺជាកម្មវត្ថុនៃសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០១ ពីព្រោះអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តីនោះបានសន្និដ្ឋានថា លក្ខណៈរើសអើងនៃការផ្លាស់ទីប្រជាជនពុំត្រូវបានបង្ហាញ[1771]។ ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការផ្លាស់ទីក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរពុំមែនជាការរើសអើង ជាប់ពាក់ព័ន្ធតែទៅលើអង្គហេតុនៃសំណុំរឿង ០០២/០១ ដែលទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើប្រជាជនថ្មីប៉ុណ្ណោះ មិនមែនលើជនជាតិចាម[1772]។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អំណះអំណាងរបស់ ខៀវ សំផន ស្តីពីបញ្ហានេះមានទំនាក់ទំនងទៅនឹងការអះអាងរបស់គាត់នៅក្នុងសារណាបណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំ នៅពេលដែល"ពុំមានភស្តុតាងបង្ហាញនូវការរើសអើងជាក់ស្តែងលើជនជាតិចាមក្នុងអំឡុងពេលនៃ[ការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ]"[1773]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សារណានេះពុំមានមូលដ្ឋានត្រឹមត្រូវដោយសារអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសន្និដ្ឋានថា ការផ្លាស់ទីជនជាតិចាមដោយបង្ខំ គឺជាការរើសអើង[1774]។

638. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការផ្លាស់ទីប្រជាជនចាមដោយបង្ខំពុំមែនជាកម្មវត្ថុនៃសេចក្តីសម្រេចចុងក្រោយក្នុងសំណុំរឿង ០០២/០១ ដែលការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការផ្លាស់ទីដោយបង្ខំក្នុងសំណុំរឿង ០០២/០១ ពុំបានផ្អែកលើការផ្លាស់ទីដោយបង្ខំលើជនជាតិចាមនោះទេ[1775]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងពុំបានរំលោភបំពានលើគោលការណ៍*អាជ្ញាអស់ជំនុំ* ឡើយ។

---

[1771] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៦ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧០៥-៧០៦។

[1772] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៩៨-៧០៦។

[1773] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៦៥។

[1774] *សូមមើលខាងក្រោម* ផ្នែក VII.ច.២.ក.i។

[1775] ផ្នែកសម្រេចសេចក្តីនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១។ ផ្នែកសម្រេចសេចក្តីនៃសាលដីកាសំណុំរឿង ០០២/០១ ("អង្គជំនុំជម្រះតុលាការកំពូល [...] តម្កល់ [...] ការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត")។

### ៣. ការចោទប្រកាន់អំពីនត្ថិភាពនៃវិសាលភាពអង្គហេតុទាក់ទងទៅនឹងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់

639. ទាក់ទងទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការផ្លាស់ទីដោយបង្ខំ ត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងសហករណ៍ត្រាំកក់ និងថា ឧក្រិដ្ឋកម្មនេះអាចជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាជនជាតិវៀតណាម[1776]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមបានបាត់ខ្លួនពីស្រុកត្រាំកក់ក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦[1777] និងថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈជាការផ្លាស់ទីដោយបង្ខំត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់[1778] និងថា ខៀវ សំផន បានប្រព្រឹត្តបទឧក្រិដ្ឋនេះតាមរយៈសហឧក្រិដ្ឋកម្មរួម[1779]។

640. ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ដោយសារលទ្ធផលនៃការបំបែកសំណុំរឿង ជនជាតិវៀតណាមត្រូវបានដកចេញពីការពិចារណានៃអង្គហេតុដែលជាអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[1780]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការកំណត់ថា អង្គជំនុំជម្រះមានសមត្ថកិច្ចពិចារណាលើអង្គហេតុនេះនៅសហករណ៍ត្រាំកក់[1781]។ គាត់បានអះអាងថា ដីកាដំណោះស្រាយបានបង្ហាញនូវភាពខុសប្លែកគ្នារវាងអង្គហេតុជាប់ពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តទៅលើក្រុមជាក់លាក់" និងអង្គហេតុដទៃទៀត[1782]។ គាត់បានយោងទៅលើភស្តុតាងរបស់ វៀល សន ដែលនាំឱ្យគាត់ជឿថា ផ្នែកដែលពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តទៅលើក្រុមជាក់លាក់" បានដោះស្រាយអង្គហេតុទាក់ទងទៅនឹងជនរងគ្រោះជាជនជាតិវៀតណាម និងថា អង្គហេតុដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ ពុំជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាជនជាតិវៀតណា

---

[1776] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥២។

[1777] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០១។

[1778] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៤, ៣៩២៧។

[1779] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦ ទំព័រ ២២៣០។

[1780] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៧។

[1781] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៧។

[1782] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៩-៣២១ (អង្គហេតុពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តទៅលើក្រុមជាក់លាក់") និងកថាខណ្ឌ ៣១០-៣១៨ (ពាក់ព័ន្ធទៅនឹងអង្គហេតុដទៃទៀត)។

មឡើយ[1783]។ ដូច្នេះ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើវិសាលភាពភាព របស់ខ្លួនក្នុងការសំអាងទៅលើ"អង្គហេតុដទៃទៀត"ក្នុងការកំណត់ថា ជនរងគ្រោះជាជនជាតិវៀតណាម ស្ថិតក្នុងវិសាលភាពរបស់ខ្លួន។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើឱ្យបាត់ខ្លួនដោយ បង្ខំលើជនរងគ្រោះជាជនជាតិវៀតណាមនៅត្រាំកក់ត្រូវបដិសេធចោល និងថា គាត់ត្រូវតែបានលើកលែង ចោទប្រកាន់ពីបទឧក្រិដ្ឋនេះ[1784]។

641. នៅក្នុងបណ្តឹងសាទុក្ខរបស់គាត់[1785] ខៀវ សំផន បានលើកឡើងថា ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែក សំណុំរឿង ០០២ បន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូងមានភាពមិនស៊ីសង្វាក់គ្នាទាក់ទងទៅនឹងបទចោទ អំពីជនជាតិវៀតណាម[1786]។ គាត់បានអះអាងថា បើទោះបីជាការប្រព្រឹត្តទៅលើជនជាតិវៀតណាមរួម ទាំងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាម ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ក៏ ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានរៀបរាប់បទចោទនេះក្នុងឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែក សំណុំរឿង ០០២ បន្ថែម ដែរ[1787]។ គាត់បានអះអាងថា បន្ទាប់មកគាត់បានស្នើសុំឱ្យដកចេញនូវភស្តុតាង អំពីការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងថា អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូល"ដោយខុស ច្បាប់"នូវបញ្ហាទាំងនេះទាក់ទងទៅនឹងទីតាំងដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់នោះ[1788]។

642. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះ សាលាដំបូង និងឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម។ សហព្រះរាជអាជ្ញាបាន កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានដកចេញពីការ ពិចារណាលើអង្គហេតុ ដែលជាអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ប៉ុន្តែផ្ទុយ ទៅវិញថា "ការកំណត់ប្រភេទគតិយុត្តនេះត្រូវបានដកចេញតាមរយៈការបំបែកសំណុំរឿង ឬពុំដែលត្រូវ បានចោទប្រកាន់ទាក់ទងទៅនឹងអង្គហេតុដែលបានរួមបញ្ចូលក្នុងផ្នែកស្តីពី'ការប្រព្រឹត្តទៅលើជនជាតិវៀត ណាម'"[1789]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ត្រឹមត្រូវថា សំណុំរឿង ០០២/០២ បានរួមបញ្ចូល

---

[1783] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៨-៥៤៩។

[1784] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៩។

[1785] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៣-១១៤។

[1786] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៣។

[1787] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤។

[1788] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤។

[1789] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥០។

សហករណ៍ត្រាំកក់ និងថា ការកំណត់ប្រភេទគតិយុត្តជាសក្ដានុពលបានរួមបញ្ចូលអំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា តាមការពិនិត្យលើឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមឃើញថា ផ្ទុយពីការប៉ុនប៉ងរបស់ ខៀវ សំផន ក្នុងការកាត់ចេញអង្គហេតុដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះជាជនជាតិវៀតណាមនៅស្រុកត្រាំកក់[1790]។

643. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[1791]។ សហមេធាវីនាំមុខបានលើកឡើងថា អំណះអំណាងនេះយឺតពេលដោយសារត្រូវបានលើកជាលើកដំបូងនៅបណ្ដឹងសាទុក្ខដោយគ្មានការផ្ដល់យុត្តិកម្ម[1792]។ ខៀវ សំផន ត្រូវបានតម្រូវឱ្យបង្ហាញអំណះអំណាងរបស់ខ្លួនឱ្យបានឆាប់បំផុត និងពុំត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នោះក្នុងពេលបច្ចុប្បន្ន លើកលែងតែគាត់បានបង្ហាញថា "ការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទបានធ្វើឱ្យប៉ះពាល់ជាសត្យានុម័តលើលទ្ធភាពរបស់គាត់ក្នុងការត្រៀមលក្ខណៈការការពារខ្លួន"[1793]។ ផ្អែកតាមសហមេធាវីនាំមុខបានឱ្យដឹងថា គាត់ពុំបានពន្យល់នូវមូលហេតុដូចម្ដេចបានគាត់គប្បីត្រូវបានអនុញ្ញាតឱ្យលើកអំណះអំណាងនេះទាក់ទងទៅនឹងវិសាលភាពនៃរឿងក្ដីនេះជាលើកដំបូងនៅបណ្ដឹងសាទុក្ខ [1794]។ សហមេធាវីនាំមុខបានកត់សម្គាល់ថា ខៀវ សំផន បានលើកអញ្ញត្រកម្មខ្លាំងក្លាចំពោះបញ្ហាដទៃទៀត ដូចជា ភស្តុតាងដែលគាត់បានចាត់ទុកថា ពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ឬក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់[1795]។ ក្រៅពីនេះ សហមេធាវីនាំមុខបានអះអាងថា ខៀវ សំផន បានទទួលស្គាល់ពីដំបូងថា វិសាលភាពនៃរឿងក្ដីនេះបានរួមបញ្ចូលការធ្វើឱ្យបាត់ខ្លួនដោយបង្ខំក្នុងស្រុកត្រាំកក់ និងពុំបានតវ៉ាថា ជនរងគ្រោះជាជនជាតិវៀតណាមត្រូវដកចេញឡើយ [1796]។ បើទោះបីជា សហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន មានបន្ទុកក្នុងការបង្ហាញនូវព្យសនកម្មតាមរយៈការជូនដំណឹងពុំគ្រប់គ្រាន់អំពីបទចោទក៏ដោយ ក៏សហមេធាវីនាំមុខបានសង្កេតឃើញថា៖ (១) ខៀវ សំផន ខកខានក្នុងការពន្យល់មូលហេតុដូចម្ដេចដែលគាត់ពុំបានតវ៉ាថា ភស្តុតាងនោះត្រូវបានស្ដាប់ស្ដីពីបញ្ហាដែលគាត់បានជឿជាក់ថា ពុំស្ថិតក្នុងវិសាលភាពនៃរឿងក្ដីនេះ បន្ទាប់ពីការធ្វើសេចក្ដីសន្និដ្ឋានពុំត្រឹម

---

[1790] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥០។

[1791] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៧។

[1792] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៨។

[1793] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៦៩-១៧៣, ១៧៨។

[1794] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៥។

[1795] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៦។

[1796] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៧(vii)។

ត្រូវរបស់គាត់ដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាមត្រូវបានប្រព្រឹត្តឡើង[1797] និង (២) មានព្យសនកម្មសត្យានុម័តដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអត្ថប្រយោជន៍ប្រសិនបើអញ្ញត្រកម្មទាំងនេះត្រូវបានទទួលយកខុសពេលវេលានោះ[1798]។

644. ទាក់ទងទៅនឹងបញ្ហាទាន់ពេលវេលា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការជំទាស់របស់ ខៀវ សំផន ជាប់ពាក់ព័ន្ធទៅនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងការយល់ឃើញពាក់ព័ន្ធក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ សហមេធាវីនាំមុខបានលើកឡើងថា ការជំទាស់នេះត្រូវបានលើកឡើងជាលើកដំបូងនៅបណ្តឹងសាទុក្ខ និងថា ខៀវ សំផន ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់បាន“ទទួលស្គាល់ថា វិសាលភាពនៃរឿងក្តីនេះបានរួមបញ្ចូលការធ្វើឱ្យបាត់ខ្លួនដោយបង្ខំក្នុងស្រុកត្រាំកក់ [...] និងពុំបានតវ៉ាថា វិសាលភាពនេះត្រូវដកចេញអង្គហេតុដែលជនរងគ្រោះជាជនជាតិវៀតណាមឡើយ”[1799]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជា ខៀវ សំផន បានទទួលស្គាល់ថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ទៅទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ស្ថិតក្នុងវិសាលភាពនៃរឿងក្តីទាក់ទងទៅនឹងសហករណ៍ត្រាំកក់[1800]ក៏ដោយ ក៏គាត់បានចោទប្រកាន់ផងដែរថា “ភស្តុតាងពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ ពុំស្ថិតក្នុងវិសាលភាពនេះ”[1801]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម“ពុំបានរួមបញ្ចូលការចោទប្រកាន់ផ្នែកអង្គហេតុពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម” និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះគប្បីដកចេញភស្តុតាងដែលខ្លួនបានស្តាប់ទាក់ទងទៅនឹងបទឧក្រិដ្ឋនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាម[1802]។ សារណារបស់សហមេធាវីនាំមុខថា អំណះអំណាងនេះត្រូវបានលើកឡើងជាលើកដំបូងនៅបណ្តឹងសាទុក្ខនេះ គ្មានមូលដ្ឋានត្រឹមត្រូវ និងត្រូវបដិសេធចោល។

---

[1797] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៩។

[1798] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៨០។

[1799] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៧៧(vii)។

[1800] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៩១២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៧០។

[1801] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៩៦៤។

[1802] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ១៩៣០-១៩៣១។

645. នៅគ្រប់ករណី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការដកជនរងគ្រោះជាជនជាតិវៀតណាមនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ចេញពីសហករណ៍ត្រាំកក់ ពុំមានមូលដ្ឋានត្រឹមត្រូវ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម ត្រូវបានដកចេញពីសំណុំរឿង ០០២/០២ តាមរយៈសេចក្តីសម្រេចបំបែកសំណុំរឿងបន្ថែម"[1803]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា ពុំមានការបង្ហាញច្បាស់លាស់ថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានចោទប្រកាន់ថា "ជាផ្នែកនៃការប្រព្រឹត្តទៅលើជនជាតិវៀតណាមក្នុងដីកាដំណោះស្រាយ "ឡើយ[1804]។

646. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញផ្នែកអង្គហេតុក្នុងផ្នែកស្តីពីបទឧក្រិដ្ឋក្នុងដីកាដំណោះស្រាយរួមមានផ្នែកដាច់ដោយឡែកពីគ្នាស្តីពីការផ្លាស់ទីប្រជាជន ការដ្ឋានធ្វើការ និងសហករណ៍ រួមទាំងសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ និងទីតាំងឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើក្រុមជាក់លាក់ រួមទាំងការប្រព្រឹត្តទៅលើជនជាតិវៀតណាម។ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមបានកម្រិតការយល់ឃើញពាក់ព័ន្ធផ្នែកអង្គហេតុនៃបទឧក្រិដ្ឋត្រឹមកថាខណ្ឌ ៧៩១-៨៣១ នៃដីកាដំណោះស្រាយដកចេញបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម[1805] ក្រោមការកំណត់ប្រភេទគតិយុត្តនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត[1806] ការសម្លាប់រង្គាល[1807] ការនិរទេស[1808] និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍[1809]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយមិនគិតថាត្រូវបានចោទប្រកាន់ពីដំបូងក្នុងដីកាដំណោះស្រាយ ដែរឬយ៉ាងណានោះទេ បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំទាក់ទងទៅនឹងផ្នែកស្តីពីការប្រព្រឹត្តទៅលើជនជាតិវៀតណាមក្នុងដីកាដំណោះស្រាយកថាខណ្ឌ ៧៩១-៨៣១ ត្រូវ

---

[1803] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥២ យោងទៅលើឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង កថាខណ្ឌ ៥(ii)(ខ)(១៤)។

[1804] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៣០៥។

[1805] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៣(xii)។

[1806] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(១)។

[1807] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(២)។

[1808] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(៤)។

[1809] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(៩)។

បានដកចេញតាមរយៈសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង[1810]។

647. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្គាល់ថា ជនជាតិវៀតណាមត្រូវបានដកចេញពីការពិចារណានៃអង្គហេតុដែលជាអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំក្នុងទីតាំងទាំងអស់[1811]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងសហករណ៍ត្រាំកក់ និង"អាចជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាជនជាតិវៀតណាមក្នុងចំណោមនោះ បើទោះបីជាអំពើនេះពុំត្រូវបានបញ្ជាក់ច្បាស់លាស់យ៉ាងណាក៏ដោយ"[1812]។ ដូចគ្នាដែរ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ទាក់ទងទៅនឹងសហករណ៍ត្រាំកក់ ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមបានរួមបញ្ចូលការយល់ឃើញផ្នែកអង្គហេតុនៃបទឧក្រិដ្ឋដែលមានក្នុងកថាខណ្ឌ ៣០២-៣២១ នៃដីកាដំណោះស្រាយ[1813] ក្រោមការកំណត់ប្រភេទគតិយុត្ត*ក្នុងចំណោមនោះ*នៃបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[1814]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យជំនុំជម្រះលើអង្គហេតុពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ រួមទាំងកថាខណ្ឌក្នុងដីកាដំណោះស្រាយ ដែលដោះស្រាយ "ការប្រព្រឹត្តទៅលើក្រុមជាក់លាក់"(កថាខណ្ឌ ៣១៩-៣២១)[1815] និងអង្គហេតុដែលបង្កើតជាមូលដ្ឋាននៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាមនៅក្នុងសហករណ៍ត្រាំកក់ (កថាខណ្ឌ ៣២០)[1816]។

648. ខៀវ សំផន បានទទួលស្គាល់ថា ផ្នែកដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើក្រុមជាក់លាក់នៅក្នុងសហករណ៍ត្រាំកក់ បានដោះស្រាយលើអង្គហេតុដែល"អាចជាធាតុផ្សំចាំបាច់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជន

---

[1810] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥២ យោងទៅលើឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(១៤)។

[1811] *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៧។

[1812] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៥២។ *សូមមើលបន្ថែមទៀត* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨០៥ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៧០-១៤៧៨។

[1813] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៣(២)។

[1814] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)(១៤)។

[1815] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៩-៣២១។

[1816] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣២០។

ជាតិវៀតណាម"[1817]។ ផ្អែកលើមូលដ្ឋានខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយ ខៀវ សំផន ត្រង់ចំណុចដែលគាត់បានចោទប្រកាន់ថា អង្គហេតុទាំងនេះត្រូវបានដកចេញពីវិសាលភាពនៃរឿងក្តីនេះ និងផ្ទុយទៅវិញពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យជំនុំជម្រះអង្គហេតុក្នុងផ្នែកស្តីពី"ការប្រព្រឹត្តទៅលើក្រុមជាក់លាក់"នៅក្នុងសហករណ៍ត្រាំកក់[1818]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំដោះស្រាយលើសារណារបស់ ខៀវ សំផន ដែលពាក់ព័ន្ធទៅនឹងការដកស្រង់ភស្តុតាងរបស់ រៀល សន និងបញ្ហាថាតើ អង្គហេតុដទៃទៀតដែលត្រូវបានរួមបញ្ចូលក្នុងផ្នែកនេះនៃដីកាដំណោះស្រាយ ជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជនជាតិវៀតណាម ដែរ ឬយ៉ាងណាឡើយ[1819]។ ការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការកំណត់ថា អង្គជំនុំជម្រះមានសមត្ថកិច្ចក្នុងការពិចារណាលើអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាម នៅសហករណ៍ត្រាំកក់ ត្រូវបដិសេធចោល។

### ៤. វិសាលភាពនៃការជំនុំជម្រះមិនច្បាស់លាស់ និងរយៈពេលយូរ

649. ទាក់ទងទៅនឹងភាពពុំស៊ីសង្វាក់គ្នារវាងសំណៅជាភាសាបារាំង អង់គ្លេស និងខ្មែរនៃឧបសម្ព័ន្ធសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមដែលសំណៅជាភាសាបារាំងបានលុបចេញនូវបទចោទនៃការនិរទេសនៅស្រុកត្រាំកក់ដែលផ្ទុយទៅវិញមានជាភាសាខ្មែរ និងអង់គ្លេស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការបកប្រែជាភាសាបារាំងមានកំហុស និងពុំជឿជាក់ថា "កំហុសនៅក្នុងសំណៅភាសាបារាំងនៃឧបសម្ព័ន្ធនោះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌កើតឡើងឡើយ"[1820]។

650. ខៀវ សំផន បានអះអាងថា បទចោទនៃការនិរទេសទាក់ទងទៅនឹងស្រុកត្រាំកក់ ពុំមានអត្ថិភាពក្នុងសំណៅជាភាសាបារាំងនៃឧបសម្ព័ន្ធសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម។ គាត់បានលើកឡើងថា គាត់មានការប្រុងប្រយ័ត្នក្នុងការបញ្ជាក់បទចោទក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់

---

[1817] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣២០។

[1818] ឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) កថាខណ្ឌ ៣(ii)។ ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១៩-៣២១។

[1819] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៤៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣១០-៣១៨។

[1820] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩។

បន្ទាប់ពីបានរកឃើញថា បទចោទនេះមានតែក្នុងសំណៅជាភាសាអង់គ្លេស និងខ្មែរនៃឧបសម្ព័ន្ធនោះ[1821]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ ព្រមទាំងការពិតដែលថា សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងឧបសម្ព័ន្ធ បានចេញជាបីភាសាដែលជាភាសាដើម។ ដូច្នេះ គាត់បានអះអាងថា សំណៅជាភាសាបារាំងមានអានុភាពដូចសំណៅភាសាអង់គ្លេស និងខ្មែរដែរ និងថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានយកចិត្តទុកដាក់លើព័ត៌មានដែលខ្លួនបានផ្តល់ស្តីពីការគូសបង្ហាញនូវបទចោទនោះ[1822]។

651. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន បានធ្វើឡើងពុំត្រឹមត្រូវ និងបានផ្អែកទៅលើកំហុសនៃការបកប្រែ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ផ្នែកពាក់ព័ន្ធដែលថា បទចោទនៃការនិរទេសត្រូវបានកម្រិតត្រឹមខេត្តព្រៃវែង និងស្វាយរៀង មានតែក្នុងសំណៅជាភាសាបារាំងនៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមប៉ុណ្ណោះ រីឯសំណៅជាភាសាអង់គ្លេស និងខ្មែរបានបង្ហាញថា បទចោទនៃការនិរទេសនៅត្រាំកក់ ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[1823]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីដំបូងថា សំណៅភាសាអង់គ្លេស និងខ្មែរនៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម គឺជាភាសាដើម និងថា រាល់សំណៅភាសាទាំងអស់បានយោងទៅលើកថាខណ្ឌដែលបញ្ជាក់អំពីបទចោទនៅត្រាំកក់[1824]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា កំហុសនៃការបកប្រែមានលក្ខណៈចាំបាច់ចំពោះការធ្វើសេចក្តីសម្រេច ដែលបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌។ ផ្អែកតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ខៀវ សំផន៖ (១) គប្បីលើកភាពមិនស៊ីសង្វាក់គ្នាចាប់តាំងពីខែ មេសា ឆ្នាំ ២០១៤ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានចេញឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកសំណុំរឿងបន្ថែម (២) បានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការស្តាប់ពីតុលាការពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសទាំងអស់ រួមទាំងនៅត្រាំកក់ និង (៣) ខកខានក្នុងការលើកសារណាបន្ថែមទាក់ទងទៅនឹងការនិរទេសចេញពីត្រាំកក់ជាពិសេសក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ បើទោះបីជាបានកត់សម្គាល់ឃើញនូវកំហុសនៃការបកប្រែនោះក៏ដោយ[1825]។

[1821] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥។

[1822] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥។

[1823] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៧។

[1824] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៧។

[1825] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៤៨។

652. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សំណៅជាភាសាបារាំងនៃឧបសម្ព័ន្ធសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ទំនងជាកម្រិតបទចោទនៃការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមខេត្តព្រៃវែង និងស្វាយរៀង[1826] រីឯសំណៅជាភាសាខ្មែរ និងអង់គ្លេសបានរួមបញ្ចូលបទចោទនៃការនិរទេសនៅសហករណ៍ត្រាំកក់[1827]។ ជាការឆ្លើយតបទៅនឹងភាពពុំស៊ីសង្វាក់នេះ ខៀវ សំផន បានតវ៉ាពីរចំណុចសំខាន់ៗថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើ៖ (១) សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់អំពីការដកបទចោទនៃការនិរទេសនៅត្រាំកក់[1828] និង (២) សេចក្ដីសម្រេចបំបែកសំណុំរឿងបន្ថែម និងឧបសម្ព័ន្ធនៃសេចក្ដីសម្រេចបំបែកសំណុំរឿង 00២ បន្ថែម ត្រូវបានចេញជាបីភាសាដែលជាភាសាដើម និងថា សំណៅជាភាសាបារាំងមានអានុភាពស្មើគ្នា[1829]។

653. ទាក់ទងទៅនឹងការលើកឡើងទីមួយ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើភាពពុំស៊ីសង្វាក់គ្នារវាងសំណៅភាសាផ្សេងគ្នាក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងអាស្រ័យហេតុនេះពុំមែន"មិនអើពើ"លើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន នោះទេ[1830]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បទចោទនៃការនិរទេសនៅស្រុកត្រាំកក់ត្រូវបានរួមបញ្ចូលនៅក្នុងសំណៅជាភាសាអង់គ្លេស និងខ្មែរ និងថា រាល់សំណៅភាសាទាំងអស់នៃឧបសម្ព័ន្ធសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមបានយោងទៅលើកថាខណ្ឌ ១៣៩៧ នៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងការនិរទេសក្នុងស្រុកត្រាំកក់[1831] និងថា ខៀវ សំផន គប្បីបានលើកភាព

---

[1826] ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) ERN (FR) 00982092 កថាខណ្ឌ ៥ (ii)(ខ)(៤)។

[1827] ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) ERN (EN) 00981687។ ERN (KH) 00981692 កថាខណ្ឌ ៥(ii)(ខ)(៤)។

[1828] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥ យោងទៅលើឯកសារលេខប្រតិចារឹកថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ E1/525.1 ទំព័រ ២៧-២៨។ (អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់បានបង្ហាញថា គាត់បានពិនិត្យតែលើសំណៅភាសាបារាំងនៃឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿងបន្ថែម ដែលពុំឃើញមានលើកឡើងអំពីបទចោទនៃការនិរទេសនៅស្រុកត្រាំកក់ ប៉ុន្តែថា នេះពុំបានកែប្រែបញ្ហាទាំងស្រុងដែលថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តហួសវិសាលភាពនៃការស៊ើបសួរតាមផ្លូវតុលាការទាក់ទងទៅនឹងបទចោទនៃការនិរទេស)។

[1829] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥។

[1830] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩។

[1831] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩ យោងទៅលើឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) កថាខណ្ឌ ៥(ii)(ក)(៤) យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថា

ពុំស៊ីសង្វាក់គ្នានេះនៅពេលណាមួយចាប់តាំងពីការចេញសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែមក្នុង ខែ មេសា ឆ្នាំ ២០១៤ ប៉ុន្តែបានជ្រើសរើសពុំធ្វើដូច្នោះបើទោះបីមានពេលគ្រប់គ្រាន់ក៏ដោយ[1832]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើភាពពុំស៊ីសង្វាក់គ្នារវាងសំណៅភាសាផ្សេងគ្នានៃឧបសម្ព័ន្ធសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងបានបដិសេធការចោទប្រកាន់របស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ។ ទាក់ទងទៅនឹងការលើកឡើងទីពីររបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងភាពពុំស៊ីសង្វាក់គ្នារវាងសំណៅជាភាសាបារាំង និងអង់គ្លេស/ខ្មែរនៃឧបសម្ព័ន្ធសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សំណៅភាសាបារាំងកែតម្រូវនៃឧបសម្ព័ន្ធសេចក្ដីសម្រេចបំបែកសំណុំរឿងបន្ថែមបានដាក់សញ្ញាសម្គាល់ថា ជាសំណៅបកប្រែនៅក្នុងប្រព័ន្ធផ្ទុកឯកសារ Zylab របស់ អ.វ.ត.ក.។ បន្ថែមលើនេះ ដូចបានចង្អុលបង្ហាញត្រឹមត្រូវដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "សំណៅភាសាខ្មែរ និងអង់គ្លេសជាសំណៅដើមត្រឹមត្រូវ"[1833]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការចោទប្រកាន់របស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ។

## ង. ភស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព

654. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារ (១) បានប្រើប្រាស់វិធីសាស្ត្រ"បរិបទជាប្រវត្តិ"ក្នុងការពិចារណាលើ"ភស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព"នៃអង្គហេតុដែលអង្គជំនុំជម្រះពុំតម្រូវឱ្យជំនុំជម្រះ[1834] និង (២) បង្កើតការយល់ឃើញ"ឥតចាំបាច់"ដែលជាការធ្វើ"*ឱ្យតែមានៗ*" និងពុំជាប់ពាក់ព័ន្ធទៅនឹងលទ្ធផលនៃរឿងក្ដីស្ដីពីអង្គហេតុដែលសូម្បីតែអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា មានភស្តុតាងមិនគ្រប់គ្រាន់ ដែលនេះបានបណ្ដាលឱ្យមានការពន្យារពេលឥតសមហេតុផល និងបង្ហាញឱ្យឃើញនូវភាពលម្អៀង[1835]។

---

ខណ្ឌ ១៣៩៧ ("ធាតុផ្សំផ្នែកច្បាប់នៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេសត្រូវបានបង្ហាញក្នុងខេត្តព្រៃវែង និងស្វាយរៀងព្រមទាំងសហករណ៍ត្រាំកក់")។

[1832] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩។

[1833] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើរបស់ ខៀវ សំផន សុំការបំភ្លឺ និងកែប្រែចំពោះឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចលើការបំបែកបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1.1/2។

[1834] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩-៣២៣។

[1835] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦។

655. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងនឹងគាត់ សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ និងការសម្រួលដល់ការត្រៀមលក្ខណៈការការពារខ្លួន សិទ្ធិទទួលបានតុលាការព្រហ្មទណ្ឌឥតលម្អៀងដែលគោរពវិសាលភាពនៃយុត្តាធិការរបស់ខ្លួន សច្ចភាពផ្នែកច្បាប់ និងនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះឆាប់រហ័សដោយគ្មានការពន្យារពេលឥតសមស្របទៅលើការពិចារណា និងប្រើប្រាស់"ភស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព"នៃអង្គហេតុដែលពុំត្រូវឱ្យជំនុំជម្រះ[1836]។ ក្នុងជើងទំព័រនៃសារណាបណ្ដឹងសាទុក្ខ[1837] ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះអាច (១) សំអាងទៅលើភស្តុតាងក្រៅវិសាលភាពភូមិសាស្ត្រ ឬយុត្តាធិការពេលវេលានៃដីកាដំណោះស្រាយ[1838] (២) ប្រើប្រាស់ភស្តុតាងនៃការប្រព្រឹត្តទៅលើពុទ្ធសាសនិកក្រៅសហករណ៍ត្រាំកក់[1839] (៣) ប្រើប្រាស់ភស្តុតាងពាក់ព័ន្ធទៅនឹងខ្មែរក្រោម[1840] និង (៤) ប្រើប្រាស់ភស្តុតាងទាក់ទងទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម[1841]។

656. ខៀវ សំផន បានជំទាស់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងពុំស្របតាមតួនាទី និងគោលបំណងនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដូចបានបញ្ជាក់ក្នុងវិធានផ្ទៃក្នុង និងជាការរំលោភបំពានលើគោលការណ៍ណែនាំជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យលើបញ្ហាថាតើ បទចោទប្រឆាំងនឹងជនជាប់ចោទដែលគាត់ត្រូវបានចោទប្រកាន់នោះ អាចស្មើនឹងបទឧក្រិដ្ឋ និងថាតើ គាត់ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះ ដែរ ឬយ៉ាងណា និងថា សាលក្រមត្រូវតែបានកម្រិតត្រឹមអង្គហេតុទាំងនោះ ហើយជនជាប់ចោទត្រូវតែអាចការពារខ្លួនប្រឆាំងនឹងអង្គហេតុទាំងនោះ[1842]។ ដោយយោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ ខៀវ សំផន បានលើកឡើងថា គាត់បានពិភាក្សាពីដំបូងយ៉ាងទូលំទូលាយលើគោលការណ៍ និងវិសាលភាពផ្នែកអង្គហេតុនៃយុត្តាធិការ

---

[1836] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០-១២៥។

[1837] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និងជើងទំព័រ ១៣៤។

[1838] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០។

[1839] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៧-១៧៨។

[1840] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨១-១៨៥, ៨១៦។

[1841] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៩-១៩០, ៧៧៨។

[1842] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១, ១២៣-១២៤។

របស់តុលាការអង្គហេតុដែលកំណត់លើការផ្តល់ព័ត៌មានអំពីបទចោទដល់គាត់ និងបញ្ជាក់ច្បាស់លាស់កុំឱ្យភាន់ច្រឡំ[1843]។

657. ក្នុងជើងទំព័រ[1844] ខៀវ សំផន បានយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីទស្សនកិច្ចរបស់គាត់ទៅកាន់ស្រុកត្រាំកក់[1845] ទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យ[1846] និងសុន្ទរកថាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨[1847]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញ "ឱ្យតែមានៗ" នេះ គ្មានភាពចាំបាច់ដោយសារគាត់បានស្ថិតក្នុងមន្ទីរឃុំឃាំងតាំងពីឆ្នាំ ២០០៧ និងសវនាការលើអង្គសេចក្តីបានចំណាយពេលអស់ពីរឆ្នាំដែលសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលបានដាក់ក្នុងខែមិថុនា ឆ្នាំ ២០១៧ និងសាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវបានប្រកាសថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដោយគ្មានសំអាងហេតុដែលទើបបានចេញបួនខែកន្លះក្រោយមក[1848]។

658. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានសំអាងទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងអង្គហេតុក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ សម្រាប់គោលបំណងដែលពុំត្រឹមត្រូវ[1849]។ សហព្រះរាជអាជ្ញាបានអះអាងថា គាត់ខកខានក្នុងការផ្តល់យុត្តិកម្មសម្រាប់អំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ដោយសារបានសន្និដ្ឋានថា អង្គជំនុំជម្រះអាចសំអាងទៅលើភស្តុតាងក្រៅវិសាលភាពភូមិសាស្ត្រ ឬយុត្តាធិការពេលវេលានៃដីកាដំណោះស្រាយ (១) ក្នុងការបំភ្លឺបរិបទណាមួយ (២) ក្នុងការធ្វើសេចក្តីសន្និដ្ឋានលើធាតុផ្សំជាពិសេស*ធាតុផ្សំអត្តនោម័ត*នៃអំពើល្មើសដែលបានកើតឡើងក្នុងអំឡុងពេលពាក់ព័ន្ធនោះ និង (៣) ក្នុងការបង្ហាញលំនាំនៃអំពើគិតទុកជាមុន[1850]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់

---

[1843] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៥៩-២៩៩។

[1844] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) និងជើងទំព័រ ១៣៧។

[1845] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣៧។

[1846] សាលក្រមអង្គជំនុំជម្រះសាលាដំបូង និងជើងទំព័រ ៤២៨៩។

[1847] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៧៣។

[1848] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦។

[1849] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥១។

[1850] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥២ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០។

ថា ខៀវ សំផន ត្រឹមតែយោងផ្លូងក្នុងលក្ខណៈទូទៅទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ដែលគ្មានការជំទាស់ត្រូវបានធ្វើឡើងសមហេតុផល[1851]។ សហព្រះរាជអាជ្ញាបានអះអាងថាដូចដែល ខៀវ សំផន បានទទួលស្គាល់ក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់[1852] គោលការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះត្រូវបាន"គេទទួលស្គាល់ទូទៅ" និង "ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ" និងត្រូវបានទទួលយកដោយតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ព្រមទាំង អ.វ.ត.ក.[1853]។ ទាក់ទងបញ្ហានេះ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការអះអាងដែល"គ្មានមូលដ្ឋានគាំទ្រ"របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញ"ដោយឥតចាំបាច់" ដែលជាការធ្វើ"ឱ្យតែមានៗ" ដែលនេះបានបណ្តាលឱ្យមានការពន្យារពេលឥតសមស្រប នៅពេលដែលគាត់ត្រឹមតែបានយោងទៅលើការលើកឡើងបីចំណុចក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងខកខានក្នុងការបង្ហាញថា តើការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងដោះបន្ទុកជាសក្ខានុពលនោះបានធ្វើឱ្យគាត់រងព្យសនកម្មដូចម្តេចឡើយ[1854]។

659. ផ្នែកតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា អំណះអំណាងរបស់ ខៀវ សំផន ដែលចោទប្រកាន់អំពីកំហុសអង្គច្បាប់នៅក្នុងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងនៃការប្រព្រឹត្តទៅលើពុទ្ធសាសនិកក្រៅសហករណ៍ត្រាំកក់ត្រូវបដិសេធចោល ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើហួសវិសាលភាពរបស់ខ្លួនក្នុងការសម្រេចដាក់ពិរុទ្ធភាពសម្រាប់ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ដែលបានប្រព្រឹត្តឡើងចំពោះពុទ្ធសាសនិកនៅក្នុងសហករណ៍ត្រាំកក់ និងបានសំអាងទៅលើភស្តុតាងនៃការប្រព្រឹត្តទៅលើនោះទូទាំងប្រទេសដើម្បីបង្ហាញគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតយ៉ាងជាក់ច្បាស់ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចបានកំណត់ដោយដីកាបំបែកសំណុំរឿង ០០២ បន្ថែម និងឧបសម្ព័ន្ធនោះព្រមទាំងការយល់ឃើញផ្នែកអង្គហេតុលើការប្រព្រឹត្តទៅលើពុទ្ធសាសនិកទូទាំងប្រទេស ដើម្បីបង្ហាញគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[1855]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដីកាបំបែកសំណុំរឿង ០០២ បន្ថែម និងការប្រកាសរបស់អង្គជំនុំជម្រះក្នុងអំឡុងពេលជំនុំជម្រះបានផ្តល់ឱ្យ ខៀវ សំផន នូវការជូន

---

[1851] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥២។

[1852] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥២ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៥២-៥៣។

[1853] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥២-៣៥៣។

[1854] សារណាតបរបស់សហព្រះរាជអាជ្ញា និងជើងទំព័រ ១៣២២។

[1855] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៤។

ដំណើងគ្រប់គ្រាន់អំពីវិសាលភាព និងគោលបំណងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់ភស្តុតាងនៃការប្រព្រឹត្តទៅលើពុទ្ធសាសនិកនៅទីតាំងដទៃទៀតក្រៅពីនៅសហករណ៍ត្រាំកក់[1856]។

660. សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា អំណះអំណាងរបស់ ខៀវ សំផន ដែលចោទប្រកាន់កំហុសអង្គច្បាប់នៅក្នុងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាង ដែលជាប់ពាក់ព័ន្ធទៅនឹងខ្មែរក្រោម ត្រូវបដិសេធចោល ពីព្រោះគាត់បានបកស្រាយដោយពុំត្រឹមត្រូវនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[1857]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញជាក់លាក់ថា អង្គជំនុំជម្រះពុំបានតម្រូវដោយសមស្របឱ្យជំនុំជម្រះការកំណត់គោលដៅលើខ្មែរក្រោមថា ជាក្រុមជាក់លាក់ ឬជាក្រុមតូចរបស់ជនជាតិវៀតណាម ប៉ុន្តែនេះពុំបានរារាំងអង្គជំនុំជម្រះក្នុងការសំអាងទៅលើភស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងការបង្ហាញអង្គហេតុដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជា អត្ថិភាពជនរងគ្រោះខ្មែរក្រោមនៅទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/០២[1858]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញផងដែរថា ដីកាដំណោះស្រាយបានធ្វើការយោងជាច្រើនទៅលើខ្មែរក្រោម[1859]។

661. សហព្រះរាជអាជ្ញាបានអះអាងថា ដូច្នេះ ខៀវ សំផន ពុំបានបែងចែកច្បាស់លាស់រវាងអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ជាមួយនឹងភស្តុតាងដែលត្រូវបានប្រើប្រាស់ក្នុងការបង្ហាញអង្គហេតុនៅក្នុងវិសាលភាពនោះ[1860]។ សហព្រះរាជអាជ្ញាបានយល់ស្របជាមួយនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យពិចារណាលើអង្គហេតុ ប៉ុន្តែពុំមែនលើភស្តុតាងស្របតាមវិធាន ៦៧(២), ៩៨(២) និង(៣) នៃវិធានផ្ទៃក្នុង និងថា ដោយសារភស្តុតាងអាចជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុច្រើន ទើបភស្តុតាងដែលអាចជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅក្រៅវិសាលភាពអាចត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវក្នុងការបង្ហាញអង្គហេតុក្នុងវិសាលភាពនោះ[1861]។ សហព្រះរាជអាជ្ញាបានបន្ថែម

---

[1856] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/301.1 ទំព័រ ៧២-៧៣។

[1857] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៥-៣៥៦ ដកស្រង់សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៧។

[1858] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៥-៣៥៧។

[1859] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៧។

[1860] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៥។

[1861] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៧ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១, ៣៥២-៣៥៣។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថា

ថា ខៀវ សំផន ត្រូវបានជូនដំណឹងទៀងទាត់អំពីគោលបំណងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់ភស្តុតាងទាក់ទងទៅនឹងខ្មែរក្រោម[1862]។

662. ចុងក្រោយ សហព្រះរាជអាជ្ញាបានអះអាងថា អំណះអំណាងរបស់ ខៀវ សំផន ដែលចោទប្រកាន់កំហុសអង្គហេតុក្នុងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តឡើងក្នុងទឹកដីវៀតណាមត្រូវបដិសេធចោល ពីព្រោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចបានកំណត់ដោយសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងឧបសម្ព័ន្ធ[1863]។ សហព្រះរាជអាជ្ញាបានលើកឡើងថា វិសាលភាពនៃសំណុំរឿង ០០២/០២ ពុំបានរួមបញ្ចូលអង្គហេតុដែលអាចស្មើនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជា ប៉ុន្តែបានរួមបញ្ចូលអង្គហេតុដែលបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលនេះតម្រូវឱ្យមានការបង្ហាញធាតុផ្សំតាមបរិបទនៃបទចោទស្ដីពីការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយអង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងលើទឹកដីវៀតណាមឡើយ ដោយត្រឹមតែប្រើប្រាស់ភស្តុតាងទាក់ទងទៅនឹងការលុកលុយរបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យចូលក្នុងប្រទេសវៀតណាម ដើម្បីបង្ហាញអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ[1864]។

663. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងអំណះអំណាងទូទៅរបស់ ខៀវ សំផន ដែលចោទប្រកាន់កំហុសក្នុងការប្រើប្រាស់"ភស្តុតាងពាក់ព័ន្ធដែលនៅក្រៅវិសាលភាព"[1865]។

664. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលរំឭកថា គោលការណ៍មូលដ្ឋាននៃនីតិវិធីនៅ អ.វ.ត.ក. ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង មាត្រា ៣៣ ថ្មី និង ៣៥ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និងមាត្រា ១៣ (១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. និងវិធាន ២១ នៃវិធានផ្ទៃក្នុង ព្រមទាំងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយតម្រូវថា ច្បាប់ត្រូវតែបកស្រាយជានិច្ចកាលក្នុងន័យ"ការពារអត្ថប្រយោជន៍"ភាគីទាំងអស់ដែលជាប់ពាក់ព័ន្ធ និងថា ត្រូវតែមានការយកចិត្តទុកដាក់ ដើម្បី"ការពារតុល្យភាព

---

ខណ្ឌ ៦៦, ៧៣, ៧៦, ៨៤, ៨៧-៨៩, ៩៩។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២២៧, ២៣៦។ វិធាន ៦៦ *ស្ទួន* (៥) និងវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង។

[1862] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៧។

[1863] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៨។

[1864] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៥៩។

[1865] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ១៨២។

រវាងសិទ្ធិរបស់ភាគីដទៃទៀត" និងថា "ដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក. ត្រូវតែឈានដល់ទីបញ្ចប់ក្នុងពេលវេលាសមស្រប"[1866]។

665. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ច្បាប់ជាធរមានចំពោះមុខ អ.វ.ត.ក. ពុំបានរារាំងការទទួលយក ឬការពិចារណាលើភស្តុតាងនៃអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការភូមិសាស្ត្រ ឬពេលវេលារបស់តុលាការឡើយ។ ផ្ទុយទៅវិញ វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុងបានកំណត់ថា "រាល់ភស្តុតាងទាំងអស់អាចទទួលយកបាន" លើកលែងតែមានចែងផ្ទុយពីនេះក្នុងវិធានផ្ទៃក្នុង ហើយវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង ជាទូទៅបានផ្តល់អង្គជំនុំជម្រះសាលាដំបូងនូវឆន្ទានុសិទ្ធិក្នុងការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដែលវិធាន ៨៩ *ស្ទួនបី* (១) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតអង្គជំនុំជម្រះសាលាដំបូងឱ្យប្រើប្រាស់ឆន្ទានុសិទ្ធិនេះតាមរយៈការដកចេញនូវអង្គហេតុដែលបានរៀបរាប់ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ ខណៈពេលធានាបានថាអង្គហេតុដែលនៅសេសសល់នោះត្រូវតំណាងឱ្យវិសាលភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ។ វិធាន ៨៩ *ស្ទួនបី* (៣) នៃវិធានផ្ទៃក្នុងបានចែងច្បាស់លាស់ថា "ភស្តុតាងទាក់ទងទៅនឹងអង្គហេតុដែលត្រូវបានដកចេញ[ពីវិសាលភាពនៃការជំនុំជម្រះ] អាចត្រូវបានសំអាងទៅលើដរាបណាមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសេសសល់នោះ"[1867]។

666. ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាឡើងវិញនូវគោលការណ៍ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ និងត្រូវបានទទួលស្គាល់ទូលំទូលាយដោយតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍[1868] និងត្រូវបានអនុម័

---

[1866] *សូមមើលផងដែរ* សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D404/2/4 និង D411/3/6 កថាខណ្ឌ ៣៥។

[1867] *សូមមើលផងដែរ* វិធាន ៦៦ *ស្ទួន* (៥) នៃវិធានផ្ទៃក្នុង។

[1868] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សាលក្រមចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីការឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR)") កថាខណ្ឌ ៣១៥ ។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង III (ICTY) សំណុំរឿងលេខ IT-04-74-T សេចក្តីសម្រេចលើសំណើរបស់ Slobodan Praljak សុំការបំភ្លឺអំពីក្របខ័ណ្ឌពេលវេលានៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចរឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY)") ទំព័រ ៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Taylor* អង្គជំនុំជម្រះសាលាដំបូង II (SCSL) សំណុំរឿងលេខ SCSL-03-01-T សាលក្រម ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ ("សាលក្រមរឿងក្តី *Taylor* (SCSL)") កថាខណ្ឌ ១០១, ១១០។

តដោយសហចៅក្រមស៊ើបអង្កេត[1869] និងអង្គជំនុំជម្រះនៃ អ.វ.ត.ក.[1870] និងថា អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកដោយសុពលភាព និងសំអាងទៅលើភស្តុតាងដែលពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការពេលវេលា និងភូមិសាស្ត្រនៃដីកាដំណោះស្រាយ និង/ឬយុត្តាធិការរបស់តុលាការក្នុងកាលៈទេសៈបីប្រភេទដូចជា៖ (១) ដើម្បីបំភ្លឺបរិបទ (២) ដើម្បីធ្វើការសន្និដ្ឋានធាតុផ្សំ ជាពិសេស ធាតុផ្សំអត្តនោម័តិនៃអំពើល្មើសដែលបានកើតឡើងក្នុងអំឡុងពេលពាក់ព័ន្ធនោះ ឬ (៣) ដើម្បីបង្ហាញលំនាំនៃអំពើគិតទុកជាមុន។ ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់នូវចេតនារបស់ខ្លួនក្នុងការកម្រិតវិសាលភាពនៃការជំនុំជម្រះដោយបានចេញដីកាបំបែកសំណុំរឿង ០០២ បន្ថែម[1871] និងឧបសម្ព័ន្ធ និងក្នុងអំឡុងពេលជំនុំជម្រះបានបញ្ជាក់ភាគីថា "អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រឹមតែសំអាងទៅលើភស្តុតាងនោះសម្រាប់គោលបំណងមានកម្រិតប៉ុណ្ណោះ និងជាពិសេសនៅពេលភស្តុតាងក្រៅវិសាលភាពនេះស៊ីសង្វាក់ជាមួយភស្តុតាងដទៃទៀត"[1872]។

667. បន្ថែមលើនេះ ដោយមានកាតព្វកិច្ចក្នុងការការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទស្របតាមវិធាន ២១ (១) នៃវិធានផ្ទៃក្នុង និងរំឭកនូវយុត្តិសាស្ត្រស៊ីសង្វាក់គ្នារបស់អង្គជំនុំជម្រះនៃ អ.វ.ត.ក.[1873] ព្រមទាំងវិធីសាស្ត្រផ្នែកច្បាប់ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ និងត្រូវបានអនុម័តដោយតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍[1874] អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា ក្នុងការវាយតម្លៃលើដីកាបញ្ជូនទៅជំនុំជម្រះ

---

[1869] ដីកាសម្រេចសំណុំរឿង ០០២ លើសំណើសុំ ឯកសារលេខ D153, D172, D173, D174, D178 និង D284 ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D300 កថាខណ្ឌ ៩-១០។

[1870] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២២៧, ២៣៦។ សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ៨៨។

[1871] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1)។

[1872] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០។

[1873] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E313) ជើងទំព័រ ១៦៨២។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ២៩៦។ សេចក្តីសម្រេចនៃសំណុំរឿង ០០២ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន (D427/5/10) កថាខណ្ឌ ៣១។

[1874] សាលដីការឿងក្តី *Ngirabatware* (IRMCT) កថាខណ្ឌ ២៤៩។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ngirabatware* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-99-54-T សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបដិសេធដោយផ្អែកលើកំហុសនីតិវិធីនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះដែលបានកែប្រែ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចរឿងក្តី *Ngirabatware* (ICTR) លើសំណើរបស់មេធាវីការពារក្តីសុំបដិសេធ") កថាខណ្ឌ ២១។ រឿងក្តី*Rutaganda* (ICTR) សាលដីការឿងក្តី *Rutaganda* (ICTR) កថាខណ្ឌ ៣០។ សាលដីការឿងក្តី *Mrkšić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ

និងការកំណត់ថាតើ ជនជាប់ចោទបានទទួលដំណឹងគ្រប់គ្រាន់អំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងនឹងខ្លួនដើម្បីត្រៀមលក្ខណៈការការពារខ្លួន ដែរ ឬយ៉ាងណា ដីកាបញ្ជូនទៅជំនុំជម្រះត្រូវតែបានពិចារណាជារួម និងដូច្នេះ កថាខណ្ឌនីមួយៗពុំគប្បីពិនិត្យដាច់ដោយឡែកពីគ្នា ប៉ុន្តែផ្ទុយទៅវិញត្រូវពិចារណាក្នុងបរិបទនៃកថាខណ្ឌដទៃទៀតក្នុងដីកាបញ្ជូនទៅជំនុំជម្រះ[1875]។

668. យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះអាចសំអាងទៅលើភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា និងភូមិសាស្ត្រនៃដីកាដំណោះស្រាយសម្រាប់គោលបំណងមានកម្រិត ក្នុងការបំភ្លឺបរិបទមួយក្នុងការធ្វើការសន្និដ្ឋាននូវធាតុផ្សំអត្តនោម័តិនៃអំពើល្មើសដែលបានកើតឡើងក្នុងអំឡុងពេលពាក់ព័ន្ធ ឬក្នុងការបង្ហាញលំនាំនៃអំពើគិតទុកជាមុន។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបដិសេធការជំទាស់របស់ខៀវ សំផន ទាក់ទងនឹងបញ្ហានេះ។

669. ពាក់ព័ន្ធទៅនឹងការពិចារណា និងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវ"ភស្តុតាងពាក់ព័ន្ធក្រៅវិសាលភាព" អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិនិត្យលើបញ្ហាថាតើ អង្គហេតុដែលទាក់ទងទៅនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិកក្រៅសហករណ៍ត្រាំកក់ ខ្មែរក្រោម និងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ ឬយ៉ាងណា បន្ទាប់ពីការបំបែកសំណុំរឿង ០០២[1876]។

670. ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ភាគីត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីការដាក់បញ្ចូលការប្រព្រឹត្តទៅលើពុទ្ធសាសនិកក្រៅសហករណ៍ត្រាំកក់ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ តាមរយៈសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

---

១៣៨។ សាលដីការឿងក្តី *Gacumbitsi* (ICTR) កថាខណ្ឌ ១២៣។ សេចក្តីសម្រេចលើសំណើបន្ទាន់ទាក់ទងទៅនឹងការលើកឡើងអំពី JCE រឿងក្តី *Taylor* (SCSL) កថាខណ្ឌ ៧៦។

[1875] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) ជើងទំព័រ ១៦៨២។ សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន (D427/5/10) កថាខណ្ឌ ៣១។

[1876] ដីកាសម្រេចបំបែកសំណុំរឿង ០០២ (E124)។ សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ លើកទីពីរ (E284)។ សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1)។

ការដាក់បញ្ចូលបទចោទទូទៅ[ក្នុងដីកាដំណោះស្រាយ]ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិក និង សហករណ៍ត្រាំកក់ដែលជាឧទាហរណ៍នៃទីតាំងឧក្រិដ្ឋកម្ម បានឆ្លុះបញ្ចាំងសមហេតុផលនូវវិសាលភាព និង លក្ខណៈនៃអំពើដែលត្រូវបានចោទប្រកាន់នោះ [...][1877]។

671. ក្រោយពីការស្នើសុំបំភ្លឺរបស់សហមេធាវីការពារក្តី ខៀវ សំផន ប្រធានអង្គជំនុំជម្រះសាលាដំបូង និង ចៅក្រម LAVERGNE បានជូនដំណឹងដល់ភាគីក្នុងអំឡុងពេលជំនុំជម្រះថា ដោយសារមានការចោទប្រកាន់ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកំណត់គោលដៅលើក្រុមមួយចំនួន រួម ទាំងពុទ្ធសាសនិកទូទាំងប្រទេសកម្ពុជា អង្គជំនុំជម្រះនឹងពិចារណាលើភស្តុតាងនៃការប្រព្រឹត្តទៅលើពុទ្ធ សាសនិកដែលជាប់ពាក់ព័ន្ធទៅនឹងការវិវឌ្ឍន៍នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាលើការប្រព្រឹត្តទៅ លើពុទ្ធសាសនិកក្នុងបរិបទទូទៅដើម្បីកំណត់នូវអ្វីដែលគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាតម្រូវ[1878]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការ ពិចារណាលើភស្តុតាងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិកក្រៅសហករណ៍ត្រាំកក់ និងបដិសេធ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ។

672. ចំពោះភស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រោម និងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជានៅ លើទឹកដីវៀតណាម និងរំឭកនូវវិធាន ៨៧ (១) និង ៨៩ *ស្ទួនបី* (៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការ កំពូលបញ្ជាក់សាជាថ្មីថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងត្រូវបានហាមឃាត់មិនឱ្យសន្មតការទទួល ខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់បទឧក្រិដ្ឋដែលស្ថិតក្រៅវិសាលភាពនៃបទចោទក៏ដោយ ក៏អាស្រ័យលើ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ថាតើ អង្គហេតុមួយណាដែលជាប់ពាក់ព័ន្ធសម្រាប់ ការកំណត់បទចោទចំពោះមុខ សូម្បីតែអង្គហេតុនេះជាប់ពាក់ព័ន្ធទៅនឹងមូលដ្ឋានផ្នែកអង្គហេតុនៃបទចោទ ដទៃទៀតក៏ដោយ[1879]។

673. ចំពោះភស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រោម អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូងក្នុងរឿងក្តីនេះថា៖

---

[1877] សេចក្តីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) កថាខណ្ឌ ៣៨។

[1878] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/301.1 ទំព័រ ៩៤-៩៥។

[1879] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២២៧។

បញ្ហាជាក់លាក់ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោមដែលជាក្រុមគោលដៅ ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ [..] ដោយសារអង្គជំនុំជម្រះពុំតម្រូវដោយសមស្របឱ្យពិចារណាការកំណត់គោលដៅលើខ្មែរក្រោមដែលជាក្រុមជាក់លាក់ ឬក្រុមតូចនៃជនជាតិវៀតណាម[1880]។

ទោះជាយ៉ាងណាក្តី ភស្តុតាងទាក់ទងទៅនឹងខ្មែរក្រោម"អាចជាប់ពាក់ព័ន្ធ [..] ទៅនឹងបញ្ហាដទៃទៀតក្នុងសំណុំរឿង ០០២/០២ ដូចជា បរិបទជាប្រវត្តិ និងបរិបទនយោបាយនៃរឿងក្តី ឬទៅនឹងបទឧក្រិដ្ឋដទៃទៀតដែលត្រូវបានចោទប្រកាន់ និងជនរងគ្រោះមួយចំនួនដែលជាខ្មែរក្រោម [..] ដូច្នេះអាចទទួលយកបាន"[1881]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា ដីកាដំណោះស្រាយមានការយោងជាច្រើនទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងខ្មែរក្រោម ជាពិសេស ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម[1882]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាលើភស្តុតាងពាក់ព័ន្ធទៅនឹងខ្មែរក្រោម និងដូច្នេះបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ។

674. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការអះអាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងទាក់ទងទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និតការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ឧក្រិដ្ឋកម្ម ដែលបានផ្អែកលើអង្គហេតុពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តលើទឹកដីវៀតណាមដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ក៏ដោយ ក៏អាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើអង្គហុតនោះ៖

សម្រាប់គោលបំណងដទៃទៀត រួមទាំងការវាយតម្លៃលើភាពអាចជឿជាក់បានរបស់សាក្សី ការបំភ្លឺអំពីបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬបទចោទនៃការរំលោភបំពានធ្ងន់ធ្ងរទាក់ទងទៅនឹងជនស៊ីវិល ឬទាហាន

[1880] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៤-១៨៥។

[1881] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨-១៨៥, ៨១៦។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/304.1 ទំព័រ ៤៧-៤៨។ សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកឯកសារ (E319/52/4) កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ (E319/47/3) កថាខណ្ឌ ២៥។

[1882] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១១១, ២៦៥, ៣២០, ៨១៨, ១៤៦៨, ១៥៨៦។

ដែលអស់សមត្ថភាពប្រយុទ្ធ ដែលត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលនៃការប្រទូសរ៉ាយលើទឹកដីវៀតណាម និង អ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ក្រោយមក[1883]។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាលើភស្តុតាងទាក់ទងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម និងដូច្នេះអំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

675. ជាការឆ្លើយតបទៅនឹងការចោទប្រកាន់អំពីការពន្យារពេលដែលបណ្តាលមកពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែល"ឥតចាំបាច់"នោះ តាមការកត់សម្គាល់បឋមឃើញថា អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកំណត់ថាតើ សារណាមួយណាតម្រូវឱ្យមានការផ្តល់សំអាងហេតុលម្អិតជាលាយលក្ខណ៍អក្សរនោះ[1884]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា អំណះអំណាងដែលត្រឹមតែលើកឡើងថា សេចក្តីសម្រេចមួយនោះ ឬការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយគ្មានផ្តល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ថា ហេតុដូចម្តេចបានជាសេចក្តីសម្រេច ឬការយល់ឃើញនោះមានកំហុស និងអំណះអំណាងដែលពុំមានសក្តានុពលធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់នោះត្រូវបដិសេធ ឬកែប្រែ អាចត្រូវបដិសេធចោលភ្លាមៗដោយអង្គជំនុំជម្រះដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តីឡើយ[1885]។

676. ដោយស្របជាមួយនឹងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការយោងរបស់ ខៀវ សំផន ក្នុងជើងទំព័រត្រឹមតែសំដៅទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់គាត់ទៅកាន់ស្រុកត្រាំកក់[1886] ទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យ[1887] និងសុន្ទរកថារបស់គាត់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨[1888] ដោយគ្មានផ្តល់មូលដ្ឋានគាំទ្រណាមួយលើអំណះអំណាងរបស់ខ្លួន និងពុំបានបង្ហាញនូវកំហុសណាមួយដែលមានសក្តានុពលអាចធ្វើឱ្យសាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធចោល ឬកែប្រែឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការចោទប្រកាន់របស់គាត់អំពីការពន្យារពេលឥតសមហេតុផលនេះ។

---

[1883] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៩០។

[1884] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១។

[1885] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១-១០២។

[1886] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣៧។

[1887] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៤២៨៩។

[1888] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៧៣។

## VII. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាមូលដ្ឋាន

### ក. អំពើមនុស្សឃាតដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

677. ទាក់ទងទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងផ្នែកនេះ[1889] ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយផ្អែកលើការសម្លាប់ដោយចេតនាផ្ទាល់នៅមន្ទីរសន្តិសុខភ្នំក្រោល និងបានផ្អែកលើការស្លាប់ដែលបានកើតឡើងដោយសារលក្ខខណ្ឌនៃការឃុំឃាំងនោះ(រួមទាំងការធ្វើទារុណកម្ម ឬការធ្វើបាប)នៅមន្ទីរស-២១ ក្រាំងតាចាន់ នៅអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល[1890]។ ដីកាដំណោះស្រាយនេះបានចោទប្រកាន់គាត់ផងដែរពីបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដែលបានផ្អែកលើការស្លាប់ក្នុងទ្រង់ទ្រាយធំដែលបណ្តាលមកពីការដាក់លក្ខខណ្ឌនៅសហករណ៍ និងការដ្ឋានធ្វើការ រួមទាំងការដកហូតអាហារ ទីជម្រក ការថែទាំផ្នែកវេជ្ជសាស្ត្រ អនាម័យ និងការងារធ្ងន់[1891] ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានកែប្រែការកំណត់ប្រភេទគតិ

[1889] ដីកាដំណោះស្រាយបានចោទប្រកាន់ផងដែរលើ ខៀវ សំផន ពីបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធទៅនឹងការសម្លាប់ពុទ្ធសាសនិក ជនជាតិចាម និងជនជាតិវៀតណាម និងបានផ្អែកលើការកម្ទេច និងការសម្លាប់ដទៃទៀត*ក្នុងចំណោមនោះ* នៅទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងនៅអូរកន្សែង។ ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៧៣-១៣៨០។ ទោះជាយ៉ាងណាក្តី ដីកាបំបែកសំណុំរឿងបានកម្រិតវិសាលភាពពាក់ព័ន្ធនឹងពុទ្ធសាសនិកត្រឹមសហករណ៍ត្រាំកក់ និងអង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា អំពើមនុស្សឃាតនេះត្រូវបានបង្ហាញ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៣៨។ អង្គជំនុំជម្រះសាលាដំបូងបានស្រូបអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃជនជាតិចាម និងជនជាតិវៀតណាម និងទាក់ទងទៅនឹងការសម្លាប់ដោយចេតនានៅមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងនៅអូរកន្សែង ចូលទៅក្នុងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងពាក់ព័ន្ធទៅនឹងជនជាតិចាម និងវៀតណាម នៅពេលផ្អែកទៅលើការសម្លាប់ដូចគ្នា។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៣៧។

[1890] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៧៣-១៣៨០។

[1891] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៨១-១៣៨២, ១៣៨៧។ ការសម្លាប់រង្គាលដទៃទៀតត្រូវបានចោទប្រកាន់ផងដែរ ប៉ុន្តែពុំត្រូវបានកែប្រែប្រភេទគតិយុត្តទៅជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត និងពុំជាប់ពាក់ព័ន្ធទៅនឹងផ្នែកនេះ។

យុត្តពីការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាត ដោយសារអង្គជំនុំជម្រះរកពុំឃើញថា ធាតុផ្សំអត្តនោម័តិដែលចាំបាច់សម្រាប់ការសម្លាប់រង្គាលត្រូវបានបង្ហាញឡើយ[1892]។

678. អង្គជំនុំជម្រះសាលាដំបូងបានស្រូបបញ្ចូលគ្នានូវការសម្លាប់គិតទុកជាមុនមួយចំនួន ដែលជាបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនេះបានបណ្តាលឱ្យ ខៀវ សំផន មានពិរុទ្ធភាព[1893]ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោលសម្រាប់ការស្លាប់ដោយសារលក្ខខណ្ឌនៃការរស់នៅ ធ្វើការងារ និងការឃុំឃាំងដែលបានដាក់នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល ព្រមទាំងការស្លាប់ដោយសារការបូមឈាម និងការធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រនៅមន្ទីរស-២១[1894]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា គាត់មានពិរុទ្ធភាពពីបទមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាផ្ទាល់នៅមន្ទីរសន្តិសុខភ្នំក្រោល[1895]។

679. ខៀវ សំផន បានអះអាងថា ការដាក់ពិរុទ្ធភាពលើគាត់សម្រាប់ការធ្វើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានផ្អែកលើកំហុសអង្គហេតុ និងអង្គច្បាប់មួយចំនួន។ គាត់បានអះអាងថា (១) *ធាតុផ្សំអត្តនោ*

---

[1892] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៣-១១៤៥ (នៅសហករណ៍ត្រាំកក់), ១៣៨៧-១៣៨៩ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម), ១៦៧១-១៦៧៣ (ការដ្ឋានធ្វើការទំនប់១មករា), ១៨០៣-១៨០៥ (ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង)។

[1893] ទម្រង់នៃការទទួលខុសត្រូវរបស់ ខៀវ សំផន សម្រាប់ឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវដោះស្រាយក្នុងផ្នែក VIII.ខ។

[1894] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥ (នៅសហករណ៍ត្រាំកក់), ១៣៨៩-១៣៩០ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម), ១៦៧២-១៦៧៣ (ការដ្ឋានធ្វើការទំនប់១មករា), ១៨០៥-១៨០៦ (ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង), ២៥៦៥, ២៥៦៨-២៥៦៩ (មន្ទីរសន្តិសុខស-២១), ២៨១៥-២៨១៧ (មន្ទីរសន្តិសុខក្រាំងតាចាន់), ៣១១៦-៣១១៧ (មន្ទីរសន្តិសុខភ្នំក្រោល), ៤៣១៨ (ការទទួលខុសត្រូវរបស់ ខៀវ សំផន នៃការជួយទំនុកបម្រុងអំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងដោយ *ចេតនាប្រយោល*)។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការស្លាប់បានកើតឡើងដោយសារលក្ខខណ្ឌនៃការឃុំឃាំងនៅមន្ទីរសន្តិសុខអូរកន្សែង ព្រមទាំងតាមរយៈការសម្លាប់ អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើបញ្ហាថាតើ ការស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំឃាំងនោះត្រូវបានប្រព្រឹត្តឡើងដោយ *ចេតនាប្រយោល*។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៦៥, ២៩៦៧។

[1895] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥, ៤៣០៦។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការលើកឡើងក្នុងកថាខណ្ឌ ៤៣៣៧ ថា អង្គជំនុំជម្រះនឹងដាក់ពិរុទ្ធភាព“តែពីបទសម្លាប់រង្គាលទាក់ទងទៅនឹង [...] មន្ទីរសន្តិសុខភ្នំក្រោល”។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញថា ការសម្លាប់រង្គាលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល និងពុំមានការយល់ឃើញត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋាននៃការសម្លាប់តែមួយដែលបានធ្វើឡើងដោយចេតនាផ្ទាល់។

*ម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ពុំបានរួមបញ្ចូល *ចេតនាប្រយោល*[1896] (២) *ធាតុផ្សំអត្តនោម័តិ* បានរួមបញ្ចូល *ចេតនាប្រយោល* ដែលគាត់ពុំដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើស[1897] (៣) អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញស្តីពីអំពើអកម្មល្មើស ដែលជាផ្នែកនៃធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[1898] (៤) អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវិភាគរបស់ខ្លួនលើ *ធាតុផ្សំអត្តនោម័តិ* ពាក់ព័ន្ធទៅនឹងយុត្តាធិការពេលវេលានៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[1899] និងមានកំហុសនៅក្នុងការយល់ឃើញផ្នែកអង្គហេតុដែលថា អំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តដោយ *ចេតនាប្រយោល* បានបង្ហាញនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងមានកំហុសបន្ថែមទៀតថា អំពើមនុស្សឃាតពីរករណីដោយចេតនាផ្ទាល់ និងមួយករណីដោយ *ចេតនាប្រយោល* ត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល[1900]។ អំណះអំណាងទាំងនេះនឹងត្រូវដោះស្រាយតាមលំដាប់លំដោយ។

### ១. ថាតើ *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល* គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា

680. អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការគូសបញ្ជាក់ *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានអះអាងថា អង្គជំនុំជម្រះបានយល់ឃើញពីដំបូងថា "*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតតម្រូវឱ្យមានការបង្ហាញនូវចេតនារបស់ជនជាប់ចោទ ឬបុគ្គលដែលទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ការសម្លាប់ ឬការបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយដោយមានការដឹងសមស្របថា អំពើសកម្ម

[1896] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៧៥-៦៣៦។

[1897] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣៣-៦៣៦។

[1898] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៣-៦៧៥, ៧៥៩, ៧៦៩-៧៧១, ៨២១។

[1899] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៥, ៧៦១, ៧៨៥, ៨២៣។

[1900] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៨-៦៨៥ (នៅសហករណ៍ត្រាំកក់), ៧៥៨-៧៦២ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម), ៧៧២-៧៨៦ (ការដ្ឋានធ្វើការទំនប់១មករា), ៨១៩-៨២៤ (ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង), ៨៦៣-៨៧៩ (មន្ទីរសន្តិសុខភ្នំក្រោល)។

ឬអកម្មនោះទំនងជាបណ្តាលឱ្យមានការស្លាប់"[1901]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការជំទាស់ទៅនឹងការកំណត់និយមន័យនេះ និងបានបញ្ជាក់ថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ "ត្រូវកំណត់និយមន័យ *ទូលំទូលាយ*ដោយរួមបញ្ចូល *ចេតនាប្រយោល*"[1902] និងបានអនុម័តិតាមការកំណត់និយមន័យដែលបានធ្វើឡើងដោយតុលាការ ICTY ក្នុងសាលក្រមរឿងក្តី *Stakić* ថា៖

> ការកំណត់និយមន័យបច្ចេកទេសនៃ *ចេតនាប្រយោល* មានដូចតទៅ៖ ប្រសិនបើចារីបង្ហាញពីអាកប្បកិរិយាដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិត ចារីមានចេតនាសម្លាប់ដោយសារតែចារីបាន"សម្របសម្រួលខ្លួន" និង "ស្រុះស្រួល"ទទួលយកភវនីយភាពនៃការស្លាប់នោះ។ ដូច្នេះ ប្រសិនបើការសម្លាប់នោះបានប្រព្រឹត្តឡើងដោយ"ការមិនអើពើដល់តម្លៃនៃជីវិតមនុស្ស" សូម្បីតែអំពើនោះមានហានិភ័យតិចតួចក៏ដោយ ក៏អាចជាអំពើមនុស្សឃាតដោយចេតនា។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំដែលត្រូវបានចាត់ទុកថា ជាអំពើមនុស្សឃាតដោយសារការមិនអើពើលើផលវិបាកក្នុងសហរដ្ឋអាមេរិក អាចបំពេញលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពី *ចេតនាប្រយោល*។ [...] គោលគំនិតនៃ *ចេតនាប្រយោល* ពុំបានរួមបញ្ចូលបទដ្ឋាននៃការធ្វេសប្រហែសណាមួយ ឬការធ្វេសប្រហែសទាំងស្រុងនោះឡើយ[1903]។

681. អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខៀវ សំផន បានជំទាស់ទៅនឹងការកំណត់និយមន័យនេះ និងបានអះអាងថា និយមន័យនេះបានរំលោភបំពានគោលការណ៍នីត្យានុកូលភាពតាមរយៈការអនុវត្តន៍ *ធាតុផ្សំអត្តនោម័តិ* ក្នុងកម្រិតទាបជាងការសម្លាប់ដោយចេតនា និងថា និយមន័យនេះពុំអាចឱ្យគាត់ដឹងជាមុនបាន

---

[1901] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៤១២ និងបានយោងផងដែរទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៣៣៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-30/1-A សាលដីកាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ (សាលដីការឿងក្តី *Kvočka និងជនជាប់ចោទដទៃទៀត* (ICTY)) កថាខណ្ឌ ២៥៩, ២៦១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dragomir Milošević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-29/1-A សាលដីកាថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ("សាលដីការឿងក្តី*Dragomir Milošević* (ICTY)") កថាខណ្ឌ ១០៨ ។

[1902] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣១ ដកស្រង់សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤១០។

[1903] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣១ ដកស្រង់សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៩០ ដែលដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-97-24-T សាលក្រម ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ ("សាលក្រមរឿងក្តី *Stakić* (ICTY)") កថាខណ្ឌ ៥៨៧។

ថា ជាបទល្មើស និងមានច្បាប់ចែងក្នុងឆ្នាំ ១៩៧៥ និងថា គាត់បានសំអាងទៅលើអំណះអំណាងដែលបាន លើកឡើងពីមុន និងត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[1904] ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា យុត្តិសាស្ត្របច្ចុប្បន្នរបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍បាន ទទួលស្គាល់ថា *ធាតុផ្សំអត្តនោម័តិ* សម្រាប់អំពើមនុស្សឃាតបានរួមបញ្ចូល *ចេតនាប្រយោល* ប៉ុន្តែយុត្តិសា ស្ត្រនេះជានិច្ចកាលពុំស៊ីសង្វាក់គ្នា និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះ តុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានធ្វើការវាយតម្លៃរៀងៗខ្លួនពាក់ព័ន្ធទៅនឹងស្ថានភាពនៃច្បាប់ ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥[1905]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា អង្គជំនុំជម្រះតុលាការ កំពូលបានបកស្រាយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ជាពិសេស រឿងក្តី *ផ្នែកវេជ្ជសាស្ត្រ Medical Case* ថា បានរួមបញ្ចូលសញ្ញាណនៃ *ចេតនាប្រយោល* និងបានចង្អុលបង្ហាញថា បើទោះបីជាវេជ្ជ បណ្ឌិតរបស់ពួកណាហ្ស៊ីពុំបានអើពើទាំងស្រុងលើអាយុជីវិតរបស់បុគ្គលដែលស្ថិតក្រោមការពិសោធន៍នោះ និងដឹងអំពីលទ្ធផលនៃការស្លាប់ជាច្រើនដែលរំពឹងទុកនោះក៏ដោយ ក៏ក្នុងករណីមួយចំនួន គោលបំណងនោះ គឺដើម្បីពិនិត្យមើលថាតើ បុគ្គលទាំងនោះអាចទ្រាំទ្រលក្ខខណ្ឌ ឬជំងឺធ្ងន់ធ្ងរបំផុតទាំងនោះបានដែរ ឬទេ។ ក្នុងស្ថានការណ៍នោះ ចេតនាបានជាប់ពាក់ព័ន្ធទៅនឹងហានិភ័យដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាយុ ជីវិត និងដោយដឹងថា នេះទំនងជាបណ្តាលឱ្យមានការស្លាប់[1906]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ ថា បើទោះបីជានត្ថិភាពនៃការសំដៅជាក់លាក់ទៅលើលក្ខណៈវិនិច្ឆ័យនៃ *ធាតុផ្សំអត្តនោម័តិ*ក៏ដោយ ក៏រឿង ក្តី *ផ្នែកវេជ្ជសាស្ត្រ Medical Case* អាចត្រូវបានចាត់ទុកថា ជាសំអាងផ្លូវច្បាប់សម្រាប់ការសន្និដ្ឋានការទទួល ខុសត្រូវផ្នែកព្រហ្មទណ្ឌដោយសារការសម្លាប់ដោយចេតនាដែរ សូម្បីតែចារីបានប្រព្រឹត្តក្នុងកម្រិតទាបជាង ចេតនាផ្ទាល់ក៏ដោយ[1907]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបាន លើកបង្ហាញផងដែរនូវការអនុវត្តន៍ក្នុងស្រុកដើម្បីគាំទ្របន្ថែមនូវការសន្និដ្ឋានរបស់ខ្លួនដែលថា អំពើមនុស្ស ឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានរួមបញ្ចូលសញ្ញាណនៃ *ចេតនាប្រយោល* ហើយអង្គជំនុំជម្រះ សាលាដំបូងបានបញ្ជាក់ថា ដូចបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ គោលការណ៍ទូទៅនៃច្បាប់អាច មានអត្ថប្រយោជន៍នៅពេលកំណត់និយមន័យនៃធាតុផ្សំបទឧក្រិដ្ឋអន្តរជាតិ[1908]។ អង្គជំនុំជម្រះសាលាដំបូង

---

[1904] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣២។

[1905] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៥។

[1906] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៦។

[1907] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៦។

[1908] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៧-៦៣៨។

បន្ទាប់មកបានធ្វើការវិភាគទៅលើយុត្តិសាស្ត្រក្នុងស្រុក និងបានកំណត់យុត្តិសាស្ត្រមួយចំនួនដែលគាំទ្រថា *ធាតុផ្សំអត្តនោម័តិ* អាចរួមបញ្ចូល *ចេតនាប្រយោល* ប៉ុន្តែបានកត់សម្គាល់ថា ច្បាប់កម្ពុជា និងច្បាប់បារាំងមុនឆ្នាំ ១៩៧៥ ជាករណីលើកលែងគួរកត់សម្គាល់[1909]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> បើទោះបីជាការកំណត់និយមន័យជាក់លាក់នៃបទឧក្រិដ្ឋនេះអាចខុសប្លែកគ្នា ហើយច្បាប់កម្ពុជា និងច្បាប់បារាំងអាចខុសប្លែកពីវិធីសាស្ត្រដទៃទៀតក៏ដោយ ក៏ប្រព័ន្ធក្នុងស្រុកដ៏ច្រើនសន្ធឹកសន្ធាប់ទាំងនេះបានទទួលស្គាល់ថា បទដ្ឋាននៃ*ធាតុផ្សំអត្តនោម័តិ* ដែលមានកម្រិតទាបជាងចេតនាផ្ទាល់អាចអនុវត្តពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាត*ដោយចេតនាប្រយោល*ដែលជាចំណុចទាបបំផុត។ នេះបានរួមបញ្ចូលករណីបុគ្គលដែលបង្ហាញឆន្ទៈក្នុងការប្រព្រឹត្តដោយដឹងថា អំពើសកម្ម ឬអកម្មរបស់គាត់ទំនងជាបណ្តាលឱ្យជនរងគ្រោះស្លាប់ និងក្នុងកម្រិតអប្បបរមា ទទួលយក ឬសម្របសម្រួលខ្លួនជាមួយនឹងភវនីយភាពនៃផលវិបាកដែលបណ្តាលឱ្យបាត់បង់អាយុជីវិតនេះ[1910]។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា គោលការណ៍ទូទៅនៃច្បាប់បានគាំទ្រថា នៅពេលបុគ្គលបានចូលរួមដោយឆន្ទៈ និងដោយដឹងថា អំពើរបស់ខ្លួនទំនងជាបណ្តាលឱ្យមានការស្លាប់ អំពើនោះអាចស្មើនឹងការធ្វើមនុស្សឃាត ឬបទឧក្រិដ្ឋដែលមានកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកនីមួយៗ[1911]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ដែលថា "*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ត្រូវតែកំណត់និយមន័យទូលំទូលាយដោយរួមបញ្ចូល *ចេតនាប្រយោល*"[1912]។

682. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ បានរួមបញ្ចូល *ចេតនាប្រយោល* ពីព្រោះ៖ (១) ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំបានរួមបញ្ចូល *ចេតនាប្រយោល* ក្នុង*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ (២) ការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ពុំមែនជាមធ្យោបាយសុពលភាពក្នុងការកំណត់និយមន័យ និងបន្ទាបបទដ្ឋាននៃចេតនា

---

[1909] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤០-៦៤៩។

[1910] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥០។

[1911] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥០។

[1912] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥០។

ដែលតម្រូវដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង (៣) ជាជម្រើស ពុំមានភស្តុតាងបង្ហាញថា គោលការណ៍ទូទៅមានអត្ថិភាពបង្ហាញថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឆ្នាំ ១៩៧៥ គឺជា*ចេតនាប្រយោល*ឡើយ[1913]។

683. ខៀវ សំផន បានលើកឡើងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំបានរួមបញ្ចូល*ចេតនាប្រយោល* ក្នុង*ធាតុផ្សំអត្តនោម័តិ*នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ ដោយសារ (១) រឿងក្តីផ្នែកវេជ្ជសាស្ត្រ *Medical Case* ពុំបានផ្តល់ការកំណត់និយមន័យច្បាស់លាស់អំពី*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែបានផ្តល់ច្បាស់លាស់ទៅលើចេតនាផ្ទាល់ក្នុងការសម្លាប់តាមរយៈការប្រើប្រាស់វិធីសាស្ត្រនៃការពិសោធន៍លក្ខខណ្ឌធ្ងន់ធ្ងរនោះ[1914] (២) យុត្តិសាស្ត្រក្រោយឆ្នាំ ១៩៧៥ របស់តុលាការ ICTY និង ICTR ពុំអាចបង្ហាញទាក់ទងទៅនឹងស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ ដោយសារយុត្តិសាស្ត្រនេះពុំត្រូវបានបង្កើតឡើងក្នុងសេចក្តីសម្រេចអន្តរជាតិមុនៗនោះ និងពុំមានលក្ខណៈស៊ីសង្វាក់គ្នាលើបញ្ហានេះ[1915] និង (៣) ច្បាប់ទំនៀមទម្លាប់អន្តរជាតិសម័យនោះដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម"ទទួលស្គាល់ចេតនាល្មើសក្នុងកម្រិតតឹងរ៉ឹង"[1916]។ ជាជម្រើស គាត់បានអះអាងថា បើទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ បានអនុញ្ញាតសម្រាប់*ចេតនាប្រយោល* ក៏ដោយ ក៏គោលការណ៍ដែលអនុវត្តច្បាប់ស្រាលជាងតម្រូវថា អនុវត្តតែចំពោះចេតនាផ្ទាល់នៃការសម្លាប់ប៉ុណ្ណោះ[1917]។

684. ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយោងទៅលើគោលការណ៍ទូទៅក្នុងការកំណត់*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារគោលការណ៍ទូទៅ (១) មិនអាចបង្ហាញ ឬកំណត់បទឧក្រិដ្ឋស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារនេះបានធ្វើឱ្យភាន់ច្រឡំអំពីប្រភពច្បាប់អន្តរជាតិ[1918] (២) ពុំមែនជាប្រភពដើមនៃច្បាប់[1919]

---

[1913] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៧៥-៥៧៦។

[1914] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៨៤-៥៨៦។

[1915] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៨៧។

[1916] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៩៣។

[1917] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៩៦-៥៩៩។

[1918] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៥៧៧-៥៨០។

[1919] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦០២-៦១២។

(៣) ជាប្រភពមិនផ្ទាល់ និងពុំអាចជំនួសច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន[1920] និង (៤) ត្រូវបានកម្រិតត្រឹមគោលការណ៍នីត្យានុកូលភាព និង*វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ*[1921]។

685. ជាជម្រើសស ខៀវ សំផន បានអះអាងថា ពុំមានភស្តុតាងបង្ហាញថា គោលការណ៍ទូទៅមានអត្ថិភាពបង្ហាញថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានរួមបញ្ចូល*ចេតនាប្រយោល* ដោយសារ (១) អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើវិធីសាស្ត្រវាយតម្លៃសើៗ និងពុំស៊ីសង្វាក់គ្នា (២) អង្គជំនុំជម្រះមានកំហុសដោយបានដកចេញច្បាប់កម្ពុជា និង (៣) អង្គជំនុំជម្រះបានបន្ទាបលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ខុសពីអ្វីដែលបានអនុវត្តដោយតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍[1922]។

686. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានលើកច្រំដែលនូវអំណះអំណាងដែលត្រូវបានបដិសេធរួចហើយដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និងខកខានក្នុងការយោងទៅលើសំអាងផ្លូវច្បាប់ណាមួយសម្រាប់*ធាតុផ្សំអត្តនោម័តិ* នៃចេតនាផ្ទាល់ ឬបង្ហាញការលើកលែងចោទប្រកាន់ណាមួយដែលបានធ្វើឡើងសម្រាប់ការខ្វះចេតនាផ្ទាល់នោះឡើយ[1923]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការលើកឡើងដែលថា សាលក្រមនៃរឿងក្តី*ផ្នែកវេជ្ជសាស្ត្រ Medical Case* ត្រូវបានបកស្រាយពុំត្រឹមត្រូវ និងបានអះអាងថា កង្វះការកំណត់និយមន័យជាក់លាក់នៃ*ធាតុផ្សំអត្តនោម័តិ* ពុំជាប់ពាក់ព័ន្ធឡើយ ដោយសារការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញអត្ថិភាពនៃអំពើមនុស្សឃាតបើទោះបីជានត្ថិភាពនៃចេតនាផ្ទាល់ក្នុងការសម្លាប់ក៏ដោយ ក៏នៅតែមានភាពច្បាស់លាស់ក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះដែរ[1924]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា តុលាការកំពូលអាល្លឺម៉ង់សម្រាប់តំបន់កាន់កាប់ដោយអង់គ្លេសបានបញ្ជាក់ពីរលើកក្នុងឆ្នាំ ១៩៤៨ ថា *ចេតនាប្រយោល* បានបំពេញតាមលក្ខខណ្ឌនៃ*ធាតុផ្សំអត្តនោម័តិ* នៃបទឧក្រិដ្ឋមួយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមទាំងអំពើមនុស្សឃាតផងដែរ[1925]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា យុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍អាចផ្តល់ការណែនាំ និងថា ការយោងទៅលើលក្ខខណ្ឌតម្រូវសម្រាប់ការគិតទុកជាមុនក្នុងយុត្តិសា

---

[1920] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦១៣-៦១៩។

[1921] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦២០-៦២២។

[1922] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦២៣-៦៣២។

[1923] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៦៥-៣៦៦។

[1924] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៦៧។

[1925] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៦៨។

ស្រ្តមួយចំនួនរបស់តុលាការ ICTR ជាការភាន់ច្រឡំដោយសារអង្គជំនុំជម្រះនោះពុំបានអះអាងថា ត្រូវអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងថា អង្គជំនុំជម្រះឧទ្ធរណ៍មួយចំនួនរបស់តុលាការ ICTY ឬ ICTR ពុំបានអនុវត្តតាមច្បាប់អន្តរជាតិនេះឡើយ[1926]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ច្បាប់ក្នុងស្រុកពុំមែនជាប្រភពដើម និងឯករាជ្យសម្រាប់ការកំណត់និយមន័យ *ធាតុផ្សំអត្តនោម័តិ* សម្រាប់អំពើមនុស្សឃាតក្នុងឆ្នាំ ១៩៧៥ ប៉ុន្តែត្រឹមតែបង្ហាញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានគាំទ្រដោយច្បាប់ក្នុងស្រុក អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យស្វែងរកគោលការណ៍ទូទៅនៃច្បាប់ឡើយ[1927]។ សហព្រះរាជអាជ្ញាបានពិចារណាឃើញថា គោលការណ៍ទូទៅគឺជាប្រភពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រឹមត្រូវ និងអាចរកបាន និងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងច្បាប់ក្នុងស្រុកក្នុងឆ្នាំ ១៩៧៥ ជាការត្រឹមត្រូវ និងបានយោងទៅលើយុត្តិសាស្ត្របន្ថែមដែលគាំទ្រការសន្និដ្ឋានដែលថា *ធាតុផ្សំអត្តនោម័តិ* ក្នុងឆ្នាំ ១៩៧៥ បានរួមបញ្ចូល *ចេតនាប្រយោល*[1928]។ អំណះអំណាងរបស់ ខៀវ សំផន អំពីច្បាប់ស្រាលជាងនោះ ពុំត្រូវបានសហព្រះរាជអាជ្ញាយល់ស្របជាមួយដោយសារបានផ្អែកទៅលើការដែលថា លក្ខន្តិកៈទីក្រុងរ៉ូម គឺជាច្បាប់ដែលមានអត្ថប្រយោជន៍ចំពោះជនជាប់ចោទ ប៉ុន្តែលក្ខន្តិកៈទីក្រុងរ៉ូមនេះពុំបានចងកាតព្វកិច្ចលើ អ.វ.ត.ក. ឡើយ[1929]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងចេតនាប្រយោល[1930]។

687. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគត្រឹមត្រូវលើច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ក្នុងការកំណត់ថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានរួមបញ្ចូល *ចេតនាប្រយោល*។ ការយល់ឃើញនេះបានផ្អែកលើការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *ផ្នែកវេជ្ជសាស្ត្រ Medical Case* ក្នុងសាលដីកាសំណុំរឿង ០០២/០១ ព្រមទាំងការវិភាគផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តីនោះផងដែរ។ ការមិនយល់ស្របរបស់ ខៀវ សំផន ជាមួយនឹងការវិភាគនេះ ពុំគ្រប់គ្រាន់អាចឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ធ្វើការពិចារណាឡើងវិញលើការវិភាគរបស់ខ្លួននោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបន្ថែមថា បើទោះបីជា ខៀវ សំផន បានជំទាស់ទៅនឹងការវិភាគលើរឿងក្តី *ផ្នែកវេជ្ជសាស្ត្រ* តាមរយៈការអះអាងថា រឿងក្តីយុត្តិសាស្ត្រ

---

[1926] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៦៩។

[1927] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧០។

[1928] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧១-៣៧៣។

[1929] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧៤។

[1930] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

នេះបានបង្ហាញនូវ *ធាតុផ្សំអត្តនោម័តិ* នៃចេតនាផ្ទាល់ក៏ដោយ ក៏គាត់ពុំបានយោងទៅលើយុត្តិសាស្ត្រអន្តរជាតិណាមួយក្នុងការគាំទ្រការអះអាងរបស់គាត់ដែលថា *ធាតុផ្សំអត្តនោម័តិ* ត្រូវបានកម្រិតត្រឹមចេតនាផ្ទាល់នោះដែរ។

688. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយោងទៅលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍សម្រាប់ការបំភ្លឺស្តីពី *ធាតុផ្សំអត្តនោម័តិ* ដែលអាចអនុវត្តបាននៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា ដើម្បីឱ្យស្របជាមួយគោលការណ៍នីត្យានុកូលភាព ការកំណត់និយមន័យនៃអំពើមនុស្សឃាតត្រូវឆ្លុះបញ្ចាំងនូវលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និងបានសំអាងទៅលើការវាយតម្លៃរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ព្រមទាំងធ្វើការវាយតម្លៃដោយផ្ទាល់ និងបានកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* ពុំស៊ីសង្វាក់គ្នាទាំងស្រុង និងត្រឹមតែជាណែនាំប៉ុណ្ណោះ[1931]។ អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានចងកាតព្វកិច្ចដោយយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* និងពុំមានកំហុសក្នុងការពិចារណាយុត្តិសាស្ត្រនេះសម្រាប់ការបំភ្លឺ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា អនុលោមតាមមាត្រា ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះអាចស្វែងការណែនាំនៅកម្រិតអន្តរជាតិបាន។

689. ការដែលថា តុលាការ ICC ពុំបានរួមបញ្ចូល *ចេតនាប្រយោល* ក្នុង *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬក្នុងធាតុផ្សំអត្តនោម័តិនៃបទឧក្រិដ្ឋដទៃទៀតក្នុងយុត្តាធិការរបស់តុលាការ ICC ពុំបានគាំទ្រការសន្និដ្ឋានថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំបានរួមបញ្ចូល *ចេតនាប្រយោល*។ តុលាការ ICC ពុំឃើញថា បានដាក់ច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពី *ធាតុផ្សំអត្តនោម័តិ* ទៅជាក្រមឡើយ[1932]។

---

[1931] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៤-៦៣៥។

[1932] *សូមមើល* ជាទូទៅអ្នកនិពន្ធ Roger S. Clark "ធាតុផ្សំអត្តនោម័តិក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងធាតុផ្សំនៃបទល្មើស"(ឆ្នាំ ២០០១) 12 *វេទិកាច្បាប់ព្រហ្មទណ្ឌ* 291 ចំណុចដែលអ្នកនិពន្ធបានចូលរួមក្នុងការព្រាងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានពិភាក្សាលើការព្យាយាមស្វែងរកមូលដ្ឋានរួមរវាងប្រព័ន្ធខុសប្លែកគ្នាពាក់ព័ន្ធនឹង"ធាតុផ្សំអត្តនោម័តិ"ដែលបានរៀបរាប់ក្នុងមាត្រា ៣០ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

690. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន អំពីច្បាប់ស្រាលជាង គោលការណ៍នៃច្បាប់ស្រាលជាងនេះជាប់ពាក់ព័ន្ធតែទៅលើច្បាប់ដែលចងកាតព្វកិច្ចលើតុលាការប៉ុណ្ណោះ[1933]។ កិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. បានបញ្ជាក់ថា យុត្តាធិការកម្មវត្ថុនៃរឿងក្តីរបស់ អ.វ.ត.ក. រួមបញ្ចូល*ក្នុងចំណោមនោះ*“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ ១៩៩៨ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ”[1934] ប៉ុន្តែកិច្ចព្រមព្រៀងនេះគឺជាឯកសារដែលកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំមកកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក.[1935]។ យុត្តាធិការកម្មវត្ថុនៃរឿងក្តីរបស់ អ.វ.ត.ក. ត្រូវបានគូសបង្ហាញក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[1936]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពុំបានដាក់បញ្ចូលលក្ខន្តិកៈទីក្រុងរ៉ូម ហើយបទប្បញ្ញត្តិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងបទប្បញ្ញត្តិនៃទីក្រុងរ៉ូមដែរ[1937]។ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការ ICC ពុំចង

[1933] សេចក្តីពិចារណាសំណុំរឿង ០០៤/២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មតិរបស់ចៅក្រម Baik និង Beauvallet ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ D359/24 និង D360/33 កថាខណ្ឌ ៥៧៩។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nikolić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-94-2-A សាលក្រមស្តីពីបណ្តឹងសាទុក្ខលើការដាក់ទោស ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ (“សាលដីការឿងក្តី *Nikolić* (ICTY)”) កថាខណ្ឌ ៨១។

[1934] មាត្រា ៩ នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។

[1935] មាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។

[1936] មាត្រា ២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។

[1937] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បានកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា៖ “អំពើនានាដែលបានត្រូវប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារដោយប្រព័ន្ធ ឬរីករាលដាលលើជនស៊ីវិលដោយសារមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ សាសនា ដូចជា៖ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា អំពើអមនុស្សធម៌ដទៃទៀត”។ មានត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ជា“អំពើណាមួយខាងក្រោមនៅពេលត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ ឬរីករាលដាលដែលកំណត់គោលដៅលើជនស៊ីវិលដោយមានការដឹងអំពីការវាយប្រហារដូចជា៖ (ក) អំពើមនុស្សឃាត (ខ) ការសម្លាប់រង្គាល (គ) ការធ្វើឱ្យទៅជាទាសករ (ឃ) ការនិរទេស ឬផ្លាស់ទីប្រជាជនដោយបង្ខំ (ង) ការដាក់ក្នុងមន្ទីរឃុំឃាំង ឬការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពផ្លូវកាយដោយរំលោភបំពានគោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ (ច) ការធ្វើទារុណកម្ម (ឆ) ការរំលោភផ្លូវភេទ ទាសករផ្លូវភេទ ពេស្យាចារដោយបង្ខំ ការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ ការធ្វើឱ្យលែងមានកូនដោយបង្ខំ ឬតាមទម្រង់ដទៃទៀតនៃអំពើហិង្សាផ្លូវភេទដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា (ជ) ការធ្វើទុក្ខបុកម្នេញលើក្រុមណាមួយដែលបង្ហាញអត្តសញ្ញាណឱ្យឃើញច្បាស់លាស់ ឬជារួមដោយសារមូលហេតុនយោបាយ ជាតិ សាសន៍ ជាតិពន្ធុ សាសនា វប្បធម៌ ភេទ ដូចបានកំណត់ក្នុងកថាខណ្ឌ ៣ ឬមូលហេតុដទៃទៀតដែលត្រូវបានទទួលស្គាល់ជាទូទៅថា ពុំត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិពាក់ព័ន្ធទៅនឹងអំពើណាមួយដែលបានសំដៅ

កាតព្វកិច្ចលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដូច្នេះ គោលការណ៍នៃច្បាប់ស្រាលជាងពុំអាចអនុវត្តបានឡើយ។

691. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ស្តីពីការអនុវត្តន៍គោលការណ៍ទូទៅ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា គាត់បានយល់ពុំត្រឹមត្រូវលើសំអាងហេតុផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូងនៃការវិភាគលើយុត្តិសាស្ត្រក្នុងស្រុក។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានយល់ឃើញថា ការអនុវត្តន៍ក្នុងស្រុក"បានគាំទ្របន្ថែម"លើការសន្និដ្ឋានដែលថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលរួមបញ្ចូលសញ្ញាណនៃ*ចេតនាប្រយោល*[1938]។ ការសន្និដ្ឋាននេះបានផ្អែកលើការពិចារណាអំពីយុត្តិសាស្ត្រអន្តរជាតិ ជាពិសេសរឿងក្តី*ផ្នែកវេជ្ជសាស្ត្រ*។ ខៀវ សំផន ហាក់បីដូចជាយល់ថា អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់គោលការណ៍ទូទៅនៃច្បាប់ក្នុងស្រុក និងពុំបានប្រើប្រាស់គោលការណ៍នេះក្នុងការបង្ហាញនូវអត្ថិភាពនៃបទឧក្រិដ្ឋក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅពេលពិនិត្យលើយុត្តិសាស្ត្រក្នុងស្រុកនោះ។ តាមការពន្យល់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសាលដីកាសំណុំរឿង ០០២/០១ ថា "ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌទូទៅក្នុងស្រុកពុំអាចធ្វើជាមូលដ្ឋានសម្រាប់ការបង្ហាញនូវវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ ដោយហេតុថា មានកង្វះនូវធាតុផ្សំអន្តរជាតិ"[1939]។ ទោះជាយ៉ាងណាក្តី ការអនុវត្តន៍នេះអាចប្រើប្រាស់ធ្វើជាការយោងទៅលើសម្រាប់ការបកស្រាយបទឧក្រិដ្ឋអន្តរជាតិ និងគោលការណ៍ពាក់ព័ន្ធ និងគោលគំនិតនោះ ដោយហេតុថា "គោលគំនិតច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងដោយផ្អែកលើគោលគំនិតច្បាប់ព្រហ្មទណ្ឌក្នុងស្រុក"[1940]។ ពិតណាស់ អង្គជំនុំ

---

ទៅលើក្នុងកថាខណ្ឌនេះ ឬបទឧក្រិដ្ឋណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ (ឈ) ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ (ញ) បទឧក្រិដ្ឋនៃការប្រកាន់ពណ៌សម្បុរ (ដ) អំពើអមនុស្សធម៌ដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលបង្កដោយចេតនានូវការឈឺចាប់ ឬរបួសធ្ងន់ធ្ងរលើរូបកាយ ឬសុខភាពផ្លូវចិត្ត ឬផ្លូវកាយ"។ *សូមមើល* មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ*ចូលជាធរមាន* ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២ ឯកសារលេខ 2187 UNTS 3 ("លក្ខន្តិកៈទីក្រុងរ៉ូម")។

[1938] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣៧ ដកស្រង់សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៩៥។

[1939] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៥ (សេចក្តីបញ្ជាក់បន្ថែម)។

[1940] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៥។

ជម្រះតុលាការកំពូលបានយោងទៅលើការអនុវត្តន៍ក្នុងស្រុកនេះក្នុងសំណុំរឿង ០០២/០១[1941] ដូចគ្នាទៅនឹងអង្គជំនុំជម្រះសាលាដំបូងដែលបានប្រើប្រាស់ក្នុងរឿងក្ដីបច្ចុប្បន្ននេះដែរ។ ខៀវ សំផន បានទទួលស្គាល់ថាការស្វែងរកការណែនាំពីគោលការណ៍ទូទៅសម្រាប់បំភ្លឺច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំត្រូវបានហាមឃាត់ឡើយ[1942]។

692. ការបកស្រាយនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះ"បានកត់សម្គាល់ថា ពុំមានភាពច្បាស់លាស់ថាតើ 'គោលការណ៍ទូទៅនៃច្បាប់ដែលត្រូវបានទទួលស្គាល់ដោយប្រទេសអារ្យធម៌ខ្ពង់ខ្ពស់'គប្បីចាត់ទុកថា ជាប្រភពសំខាន់ ឬបន្ទាប់បន្សំនៃច្បាប់អន្តរជាតិ ដែរ ឬយ៉ាងណា" ប៉ុន្តែបានចង្អុលបង្ហាញថា "គោលការណ៍ទូទៅនេះត្រូវបានយកមកពិចារណាជាពិសេសដោយតុលាការ ICTY នៅពេលកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ ឬវិសាលភាពនៃទម្រង់ទទួលខុសត្រូវ *ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ*'[1943]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY ក្នុងរឿងក្តី *Furundžija* បានកត់សម្គាល់ថា ការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈត្រូវបានចែងក្រោមលក្ខន្តិកៈរបស់តុលាការ ICTY ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ ការរំលោភបំពានលើច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម ឬអំពើប្រល័យពូជសាសន៍ ប៉ុន្តែថា អង្គជំនុំជម្រះពុំអាចស្វែងរកការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈក្នុងច្បាប់អន្តរជាតិរួមទាំងតាមរយៈគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬច្បាប់អន្តរជាតិបាន[1944]ឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះ

---

[1941] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) ជើងទំព័រ ២១២៦ យោងទៅលើការវិភាគដំបូង*ក្នុងចំណោមនោះនូវការអនុវត្តក្នុងស្រុកក្នុងការកំណត់ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។

[1942] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦១៦ ("មានតែក្នុងករណីដែលពុំមានវិធានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិជាក់លាក់ប៉ុណ្ណោះដែលគេអាចស្វែងរកការបំភ្លឺពីគោលការណ៍ទូទៅនៃច្បាប់")។

[1943] សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៥៣ (សេចក្តីបញ្ជាក់បន្ថែម)។ អង្គបុរេជំនុំជម្រះបានពន្យល់ផងដែរពាក់ព័ន្ធទៅនឹងការរំលោភផ្លូវភេទដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា "គោលការណ៍នេះអាចប្រើប្រាស់ដើម្បីជួយបំភ្លឺធាតុផ្សំសត្យានុម័តនៃការរំលោភផ្លូវភេទ នៅពេលដែលអត្ថិភាពនៃធាតុផ្សំតាមបរិបទសម្រាប់ការរំលោភផ្លូវភេទក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញរួចរាល់"។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ D427/2/15 និង D427/3/15 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15 និង D427/3/15)") កថាខណ្ឌ ១៥៣។

[1944] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Furundžija* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-17/1-T សាលក្រម ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ("សាលក្រមរឿងក្តី *Furundžija* (ICTY)") កថាខណ្ឌ ១៧២-១៧៣, ១៧៥, ១៧៧។

នោះបានចាត់ទុកថា ជាការចាំបាច់ក្នុងការស្វែងរកគោលការណ៍ព្រហ្មទណ្ឌដែលមានលក្ខណៈដូចគ្នាជាមួយនឹងប្រព័ន្ធច្បាប់សំខាន់ៗនៃពិភពលោក ដែលនេះជាការទាញចេញដោយប្រុងប្រយ័ត្នសមស្របពីច្បាប់ជាតិ[1945]។ វិធីសាស្ត្រនេះខុសប្លែកពីការបញ្ជាក់ថាតើ បទឧក្រិដ្ឋមានអត្ថិភាព ដែរ ឬយ៉ាងណា ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលបានផ្អែកលើការអនុវត្តន៍ក្នុងស្រុក។

693. ការអះអាងរបស់ ខៀវ សំផន ដែលថា គោលការណ៍នីត្យានុកូលភាពបានហាមឃាត់ការផ្អែកលើគោលការណ៍ទូទៅដើម្បី“ពង្រីក”ការទទួលខុសត្រូវ និងតម្រូវថា “ការបកស្រាយត្រូវតែមានលក្ខណៈតឹងរ៉ឹង និងបានជាប្រយោជន៍ដល់ជនជាប់ចោទ”ជាការពុំត្រឹមត្រូវឡើយ។ គោលការណ៍នីត្យានុកូលភាពតម្រូវថា បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ត្រូវមានអត្ថិភាពក្នុងច្បាប់ខណៈពេលដែលបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តឡើង។ គោលការណ៍នេះពុំតម្រូវឱ្យមានការបកស្រាយបានជាប្រយោជន៍ជនជាប់ចោទឡើយ។ នេះគឺជាគោលគំនិតដែលខុសប្លែកពីគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ* ដែលជាចម្បងប្រើប្រាស់សម្រាប់ការចង្អុលបង្ហាញនូវកំហុសក្នុងករណីដែល ភស្តុតាងមិនអាចបង្ហាញអង្គហេតុឱ្យហួសពីវិមតិសង្ស័យបាន។ ដូចបានបញ្ជាក់ពីដំបូងដោយអង្គជំនុំជម្រះតុលាការកំពូលថា *វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ* ត្រូវបានកម្រិតត្រឹមវិមតិសង្ស័យដែលមានអត្ថិភាពបន្ទាប់ពីការបកស្រាយថាតើ ត្រូវអនុវត្តនូវភាពអល់អែកនៃច្បាប់ ដែរ ឬយ៉ាងណា[1946]។ ក្នុងរឿងក្តីនេះពុំមានវិមតិសង្ស័យបែបនោះឡើយ អាស្រ័យហេតុនេះ ពុំមានភាពចាំបាច់ត្រូវអនុវត្តគោលការណ៍នេះឡើយ។

694. ជាការឆ្លើយតបទៅនឹងអំណះអំណាងជាជម្រើសមួយផ្សេងទៀតរបស់ ខៀវ សំផន ដែលថា ពុំមានភស្តុតាងបង្ហាញអំពីគោលការណ៍ទូទៅដែលបានរួមបញ្ចូល *ចេតនាប្រយោល* ក្នុង*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គាត់បានរិះគន់លើការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែពុំបានផ្តល់ហេតុផលផ្ទាល់ខ្លួនឡើយ។ គាត់បានជំទាស់ទៅនឹងការប្រដូចគ្នារបស់អង្គជំនុំជម្រះសាលាដំបូងនូវសញ្ញាណស្មុគស្មាញនៃច្បាប់ព្រហ្មទណ្ឌជាតិដែលបានធ្វើឡើងដោយពុំត្រឹមត្រូវតាមបរិបទ

---

[1945] សាលក្រមរឿងក្តី *Furundžija* (ICTY) កថាខណ្ឌ ១៧៨។ *សូមមើលផងដែរ* សាលក្រមរឿងក្តី *Blaškić* កថាខណ្ឌ ៣៤ (“ក្នុងការពន្យល់បន្ថែមលើបញ្ហាថាតើ បទដ្ឋាននៃ*ធាតុផ្សំអត្តនោម័តិ* ដែលទាបជាងចេតនាប្រយោលអាចអនុវត្តទាក់ទងទៅនឹងការបញ្ជាក្រោមមាត្រា ៧(១) នៃលក្ខន្តិកៈដែរ ឬយ៉ាងណា អង្គជំនុំជម្រះឧទ្ធរណ៍ចាត់ទុកថាមានប្រយោជន៍ក្នុងការពិចារណាលើវិធីសាស្ត្រនៃយុត្តាធិការជាតិ”)។

[1946] សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន លើសំណើសុំដោះលែង ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៣១។

[1947] ប៉ុន្តែថា ការកំណត់គោលការណ៍ទូទៅនៃច្បាប់ក្នុងស្រុកជាចាំបាច់ត្រូវសម្រិតសម្រាំងយកគោលគំនិតទូទៅចេញពីសញ្ញាណស្មុគ្រស្មាញនោះ។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា យុត្តាធិការក្នុងស្រុកមានលក្ខណៈខុសប្លែកគ្នា និងថា "ការកំណត់និយមន័យជាក់លាក់លើបទឧក្រិដ្ឋនេះអាចខុសគ្នាផងដែរ"[1948]។ អង្គជំនុំជម្រះបានពិនិត្យត្រឹមត្រូវលើយុត្តាធិការផ្សេងៗនៃប្រព័ន្ធច្បាប់ស៊ីវិល និងអង់គ្លូសាក់សុងព្រមទាំងរបស់ប្រទេសរុស្ស៊ី និងប្រទេសជប៉ុន។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយលើចេតនាតម្រូវក្នុងយុត្តាធិការផ្សេងៗ ប៉ុន្តែគាត់ពុំបានបង្ហាញកំហុសណាមួយក្នុងឧទាហរណ៍របស់គាត់ឡើយ។ ការយល់ឃើញនោះពុំមែនថា ផ្អែកតាមគោលការណ៍ទូទៅ ប្រព័ន្ធច្បាប់ពិភពលោកបានប្រើប្រាស់*ធាតុផ្សំអត្តនោម័តិ* ដូចគ្នាទាំងស្រុងទៅនឹង*ចេតនាប្រយោល*នោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ការបង្កឱ្យស្លាប់ដែលទាបជាងកម្រិតចេតនាផ្ទាល់ ប៉ុន្តែខ្ពស់ជាងការធ្វេសប្រហែស ដូចជា*ចេតនាប្រយោល* ឬការខ្ជីខ្ជា ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងត្រូវបានចាត់ទុកថា មានចេតនាសម្លាប់"[1949] ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ប្រព័ន្ធច្បាប់ក្នុងស្រុកភាគច្រើនបានទទួលស្គាល់ថា បទដ្ឋាននៃ*ធាតុផ្សំអត្តនោម័តិ*ដែលទាបជាងចេតនាផ្ទាល់អាចអនុវត្តទាក់ទងទៅនឹងអំពើមនុស្សឃាតដោយ*ចេតនាប្រយោល* ដែលជាកម្រិតទាបជាងគេបំផុត"[1950]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងពិចារណាថាជាឧទាហរណ៍ក្នុងផ្នែក ១៨(ក) នៃច្បាប់ព្រហ្មទណ្ឌរដ្ឋ New South Wales ឆ្នាំ ១៩០០ ដែលបានដាក់ទោសអំពើដែលត្រូវបានប្រព្រឹត្តឡើងដោយ"ការមិនអើពើលើអាយុជីវិតមនុស្ស ឬមានចេតនាសម្លាប់ ឬបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ"[1951]។ ការមិនអើពើលើផលវិបាកមាន*ធាតុផ្សំអត្តនោម័តិ*ទាបជាងកម្រិតចេតនាផ្ទាល់។

695. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ច្បាប់កម្ពុជាគឺជា"ករណីលើកលែងគួរកត់សម្គាល់"ចំពោះប្រព័ន្ធច្បាប់ដែលខ្លួនបានវិភាគដែលក្នុងនោះនីតិកម្ម ឬរឿងក្តីយុត្តិសាស្ត្រ"បានចាត់ទុកច្បាស់លាស់នូវការសម្លាប់ដោយចេតនាថា ជាបទល្មើសក្នុងករណីដែលចារីបានប្រព្រឹត្តក្នុងកម្រិតទាបជាង

[1947] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦២៤។

[1948] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥០។

[1949] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤០៩។

[1950] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥០។

[1951] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ២០១០។ *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦២៦។

ចេតនាផ្ទាល់"[1952]។ ការអនុវត្តន៍ក្នុងស្រុកពុំតម្រូវឱ្យមានលក្ខណៈស្របគ្នាទាំងស្រុងក្នុងការបង្ហាញគោលការណ៍ទូទៅឡើយ[1953]។ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសអង្គច្បាប់ក្នុងការសន្និដ្ឋានថា គោលការណ៍ទូទៅមានអត្ថិភាព ទោះជាយ៉ាងណាក្តីនេះពុំស្របគ្នាជាមួយនឹងច្បាប់កម្ពុជាឡើយ។

696. ខៀវ សំផន បានអះអាងថា *ធាតុផ្សំអត្តនោម័តិ* ដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង គឺជាកម្រិតទាបជាងធាតុផ្សំនៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* ដែលកំណត់ថា ត្រូវតែមានចេតនាក្នុងការសម្លាប់ជនរងគ្រោះ ឬចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយដោយមានការដឹងសមស្របថា អំពើនោះនឹងបណ្តាលឱ្យមានការស្លាប់[1954] ប៉ុន្តែនេះជាការយល់ពុំត្រឹមត្រូវ។ ខៀវ សំផន ពុំបានបែងចែកភាពខុសប្លែកគ្នានៃបញ្ហានេះ។ លក្ខខណ្ឌតម្រូវគឺថា អំពើដែលបង្កឱ្យមានការស្លាប់ត្រូវតែជាចេតនា និងបានធ្វើឡើងដោយមានការដឹងសមស្របថា អំពើនោះនឹងបណ្តាលឱ្យមានការស្លាប់។ លក្ខខណ្ឌតម្រូវនេះពុំត្រូវបានបោះបង់ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការរស់នៅ និងធ្វើការក្នុងសហករណ៍ត្រាំកក់ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "អាជ្ញាធរក្នុងស្រុកត្រាំកក់មានឆន្ទៈដាក់លក្ខខណ្ឌនោះ"[1955] និងដាក់ដោយចេតនា។ ខៀវ សំផន បានអះអាងថា ខុសពីតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* អង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់ភាពអាចដឹងជាមុនអំពីការស្លាប់ថា ជាការ"សមហេតុផល" និងពុំបានបញ្ជាក់ជាក់លាក់ថាតើ បទដ្ឋានសត្យានុម័ត ឬអត្តនោម័តិត្រូវបានប្រើប្រាស់ ដែរ ឬយ៉ាងណា និងពុំបានបង្ហាញនូវកម្រិតនៃភវនីយភាពដែលតម្រូវនោះឡើយ[1956]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពិតជាបានបង្ហាញកម្រិតនៃភវនីយភាពដែលតម្រូវ "ទំនងជាបណ្តាលឱ្យមានការស្លាប់"។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បញ្ហាថាតើ អង្គជំនុំជម្រះ

---

[1952] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤៧-៦៤៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៤០-៦៤៦។

[1953] ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Furundžija* បានកត់សម្គាល់ថា "នេះទំនងជាកើតចេញពីការស្រាវជ្រាវលើច្បាប់ក្នុងស្រុក ដែលទោះបីជាមានភាពមិនស៊ីសង្វាក់គ្នាក៏ដោយ ក៏ប្រព័ន្ធភាគច្បាប់ច្រើនបំផុតក្នុងច្បាប់អង់គ្លូសាក់ស៊ុង និងស៊ីវិល បានចាត់ទុកការរំលោភផ្លូវភេទជាការដាក់បញ្ចូលផ្លូវភេទដោយបង្ខំនៃរូបកាយមនុស្សនូវអង្គជាត ឬការដាក់បញ្ចូលដោយបង្ខំនូវរបស់ដទៃផ្សេងទៅក្នុងប្រដាប់ភេទស្ត្រី ឬរន្ធគូទ"។ សាលក្រមរឿងក្តី *Furundžija* (ICTY) កថាខណ្ឌ ១៨១ (សេចក្តីបញ្ជាក់បន្ថែម)។

[1954] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣១។

[1955] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥។

[1956] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣១។

សាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា បទដ្ឋានសត្យានុម័ត ឬអត្តនោម័តិត្រូវបានប្រើប្រាស់ ដែរ ឬយ៉ាងណា ពុំមែនជាកំហុសអង្គច្បាប់ដែលអាចកែប្រែសាលក្រមបានឡើយ។

697. ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការដាក់បញ្ចូល *ចេតនាប្រយោល*ក្នុង*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹង*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និងអំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការបង្ហាញថា អំពើមនុស្សឃាតនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោលដោយសារលក្ខខណ្ឌនៃការរស់នៅ និងការងារ និងលក្ខខណ្ឌនៃការឃុំឃាំង ការបូមឈាមនៅមន្ទីរស-២១[1957] ត្រូវបានប្រព្រឹត្តឡើងដោយចេតនាផ្ទាល់ជាជាង*ចេតនាប្រយោល*នោះ។

### ២. ថាតើ ជនជាប់ចោទអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងអំពី*ធាតុផ្សំអត្តនោម័តិ* ដែលរួមបញ្ចូល *ចេតនាប្រយោល* នោះ ដែរ ឬយ៉ាងណា

698. ទាក់ទងទៅនឹងភាពអាចដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើស អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “អ្វីដែលសំខាន់នោះគឺត្រូវពិចារណាលើគោលបំណងនៃគោលការណ៍នីត្យានុកូលភាពដែលត្រូវធានាថាជនជាប់ចោទពុំត្រូវបានដាក់ឱ្យទទួលខុសត្រូវសម្រាប់អំពើដែលខ្លួនពុំអាចដឹងជាមុនថា ជាបទល្មើសនៅពេលជាប់ពាក់ព័ន្ធជាមួយនឹងអំពើនោះ”[1958]។ អង្គជំនុំជម្រះបានយល់ឃើញថា ដោយសារលក្ខណៈជាទំនៀមទម្លាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងតួនាទីរបស់ ខៀវ សំផន ជាសមាជិកនៃរដ្ឋអំណាចគ្រប់គ្រងកម្ពុជា “គាត់អាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើសក្នុងន័យទូទៅនូវអំពើដែលត្រូវបានពិពណ៌នាថា អំពើមនុស្សឃាតក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចដាក់ទោសបានក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥”[1959]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានចាត់ទុក“អំពើដែលប្រព្រឹត្តដោយចេតនាត្រឹមតែចង់ឱ្យឈឺចាប់រូបកាយបុគ្គលណាម្នាក់ប៉ុណ្ណោះទេ មិនចង់ឱ្យបុគ្គលនោះស្លាប់ទេ [...]” ត្រូវមានទោសឧក្រិដ្ឋ និងថា ចេតនាតម្រូវ

---

[1957] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣៧-៦៤០។

[1958] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥១។

[1959] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥១។

(គ្មានមរណចេតនា) គឺទាបជាងកម្រិត *ចេតនាប្រយោល*[1960]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "ជាការជាក់ច្បាស់ណាស់ថា ជនជាប់ចោទអាចដឹងជាមុនក្នុងឆ្នាំ ១៩៧៥ ថា ការសម្លាប់បុគ្គលដោយ *ចេតនាប្រយោល* គឺជាបទល្មើស និងតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល"[1961]។

699. ខៀវ សំផន បានលើកឡើងថា ការកំណត់និយមន័យនៃ *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរួមបញ្ចូល *ចេតនាប្រយោល* ពុំអាចឱ្យគាត់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែង ដោយសារច្បាប់កម្ពុជាពុំបានរួមបញ្ចូល *ចេតនាប្រយោល*[1962]។ គាត់បានលើកឡើងថា៖

> ពុំមានភាពច្បាស់លាស់ថា *ចេតនាប្រយោល* ដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនោះ គឺជាចេតនាក្នុងកម្រិតមួយដែលខ្ពស់ជាងកម្រិតដែលបានកំណត់ក្នុងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៥៦ ឡើយ។ ផ្អែកតាមអង្គជំនុំជម្រះសាលាដំបូងថា មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌដែលចែងអំពីការដាក់ពិរុទ្ធ មិនមែនអំពីបទឧក្រិដ្ឋនៃអំពើមនុស្សឃាត តែពី"អំពើដែលប្រព្រឹត្តឡើងដោយចេតនា និងត្រូវបានបំពេញក្នុងគោលបំណងធ្វើឱ្យបុគ្គលរងព្យសនកម្ម ប៉ុន្តែមិនចង់ឱ្យបុគ្គលនោះស្លាប់" បានតម្រូវឱ្យមានចេតនាប្រព្រឹត្តអំពើ"ដោយចង់ឱ្យបុគ្គលនោះឈឺចាប់រូបកាយ"។ ជាការចាំបាច់ដែលត្រូវបង្ហាញនូវអំពើល្មើសដោយចេតនា និងមិនមែនត្រឹមតែអំពើដែលមិនអើពើលើផលវិបាកប៉ុណ្ណោះទេ។ ចេតនានេះពុំមានកម្រិតទាបជាង *ចេតនាប្រយោល* ដូចបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនោះឡើយ[1963]។

700. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំពើមនុស្សឃាតដោយ *ចេតនាប្រយោល* អាចឱ្យ ខៀវ សំផនដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស ដូចការបញ្ជាក់ពីដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[1964]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[1965]។

---

[1960] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥១។

[1961] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៥១។

[1962] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣៥។

[1963] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៣៦។

[1964] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧៥។

[1965] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

701. អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចរាល់លើបញ្ហានេះ ហើយអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ពុំមានអានុភាពលើសេចក្ដីសន្និដ្ឋានពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ។ ដូចបានពន្យល់ក្នុងសំណុំរឿង ០០២/០១ ថា៖

> ទាក់ទងទៅនឹងភាពអាចដឹងជាមុនថា មានច្បាប់ចែង និងជាបទល្មើសនៃ*ធាតុផ្សំអត្តនោម័តិ*អំពើមនុស្សឃាត និងការសម្លាប់រង្គាល អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិនិត្យយ៉ាងទូលំទូលាយលើធាតុផ្សំអត្តនោម័តិនៃបទឧក្រិដ្ឋទាំងនេះនីមួយៗ។ ទាក់ទងទៅនឹងអំពើមនុស្សឃាត ការវិភាគនេះបាននាំឱ្យមានការសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិដែលមានលក្ខណៈពុំស្រុះរឹតត្បិតជាងចេតនាផ្ទាល់បង្កើតបានជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ ដូចបានកត់សម្គាល់ខាងលើ ទាក់ទងទៅនឹងភាពអាចដឹងជាមុនថា មានច្បាប់ចែង ជនជាប់ចោទមានលក្ខណៈគ្រប់គ្រាន់អាច"ដឹងថា អំពើនោះគឺជាបទល្មើសក្នុងន័យដែលគេអាចយល់ជាទូទៅ ដោយពុំចាំបាច់យោងទៅលើបទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ"។ ដូច្នេះ អ្វីដែលតម្រូវពុំត្រឹមតែការវិភាគលើពាក្យពេចន៍បច្ចេកទេសនៃការកំណត់និយមន័យបទឧក្រិដ្ឋប៉ុណ្ណោះទេ ថែមទាំងលើបញ្ហាថាតើ ការដែលអាចដឹងជាមុនបានថា មានច្បាប់ចែងចំពោះអំពើនោះ អាចតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ ពុំចាំបាច់បង្ហាញថា មានការដឹងជាមុនបានថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះអាចកើតឡើង ក្នុងកាលៈទេសៈដែលមានការប្រព្រឹត្តដោយ*ចេតនាប្រយោល* ដែលផ្ទុយពីចេតនាផ្ទាល់នោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលបានលើកឡើងពាក់ព័ន្ធបញ្ហានេះ[1966]។

702. យោងតាមសំអាងហេតុដូចគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងប្រហាក់ប្រហែលគ្នានេះរបស់ ខៀវ សំផន ដែលបានលើកឡើងពាក់ព័ន្ធបណ្ដឹងសាទុក្ខនេះ។

### ៣. ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធនឹងអំពើល្មើសអកម្ម ដែរ ឬយ៉ាងណា

703. នៅក្នុងការគូសបញ្ជាក់ច្បាប់ជាធរមានទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ថា អំពើអសកម្មនឹងក្លាយជាបទល្មើសតែនៅពេលណាដែលមានកាតព្វកិច្ចតម្រូវឱ្យបំពេញ៖

> ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាត គឺជាអំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទ ឬរបស់បុគ្គលម្នាក់ ឬច្រើន ដែលជនជាប់ចោទត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់អំពើសកម្ម ឬអកម្មរបស់បុគ្គលនោះ

[1966] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៦៥។

ដែលបានបង្កឱ្យជនរងគ្រោះស្លាប់។ [...] អង្គជំនុំជម្រះកត់សម្គាល់ថា ពុំមានភាគីណាមួយបានជំទាស់ថា ការប្រព្រឹត្តអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើអសកម្មបានបង្កើតជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកពីដំបូងនូវគោលការណ៍ទូទៅដែលត្រូវបានអនុវត្តស៊ីសង្វាក់គ្នាដោយតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* ដែលថា "បទឧក្រិដ្ឋអាចត្រូវបានប្រព្រឹត្តតាមរយៈអំពើអសកម្មបទល្មើសនៅពេលដែលមានកាតព្វកិច្ចត្រូវបំពេញ"។ បើទោះបីជាការសង្កេតនេះត្រូវបានធ្វើឡើងក្នុងបរិបទនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា គោលការណ៍ទូទៅដែលថា មានតម្រូវការចាំបាច់ឱ្យបំពេញ បានអនុវត្តចំពោះអំពើអសកម្មល្មើសទាំងអស់។ អាស្រ័យហេតុនេះ អំពើអសកម្មនឹងក្លាយជាបទល្មើសតែនៅពេលណាដែលមានកាតព្វកិច្ចត្រូវបំពេញប៉ុណ្ណោះ[1967]។

704. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ត្រឹមត្រូវនូវច្បាប់ពាក់ព័ន្ធទៅនឹងអំពើល្មើសអកម្ម ប៉ុន្តែនៅក្នុងការយល់ឃើញរបស់ខ្លួនដែលថា ធាតុផ្សំសត្យានុម័តត្រូវបានបំពេញនៅសហករណ៍ត្រាំកក់[1968] ការដ្ឋានទំនប់ត្រពាំងថ្ម[1969] ការដ្ឋានទំនប់១មករា[1970] និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[1971] ពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតដែលបណ្តាលមកពីលក្ខខណ្ឌរស់នៅ និងធ្វើការធ្ងន់ធ្ងរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំសត្យានុម័តត្រូវបានបង្ហាញក្នុងផ្នែកខ្លះតាមរយៈអំពើល្មើសអកម្មដោយគ្មានការកំណត់ជាមុនថា មានកាតព្វកិច្ចត្រូវបំពេញឡើយ។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការផ្តល់ការកំណត់និយមន័យផ្នែកច្បាប់នៃលក្ខណៈ និងវិសាលភាពនៃកាតព្វកិច្ចរបស់ចារីដែលត្រូវបំពេញ។ គាត់បានជំទាស់ថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបានពន្លាតជាចម្បង និងជាសំខាន់រួមបញ្ចូលការប្រព្រឹត្តផ្ទាល់នូវឧក្រិដ្ឋកម្មរបស់ចារី និងថា អំពើអកម្មជាបទល្មើសដរាបណាត្រូវបានកំណត់ដោយគោលការណ៍ច្បាប់ព្រហ្មទណ្ឌ និងបានយោងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុងរឿងក្តី *Tadić*[1972]។

---

[1967] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៧។

[1968] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៣-៦៧៥។

[1969] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៩។

[1970] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៩-៧៧១។

[1971] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២១។

[1972] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៤ យោងទៅលើសាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Tadić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-94-1-A ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ("សាលដីការឿងក្តី *Tadić* (ICTY)") កថាខណ្ឌ ១៨៨ ("បទប្បញ្ញត្តិនេះ [មាត្រា ៧(១) នៃលក្ខន្តិកៈរបស់តុលាការ ICTY] គ្របដណ្តប់ការប្រព្រឹត្តដោយផ្ទាល់ដំបូង និង

705. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើទៅលើទំនាក់ទំនងរវាងអំពើសកម្មល្មើសដែលជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតជាមួយនឹងអំពើអកម្ម[1973]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការខកខានរបស់ចារីក្នុងការចាត់វិធានការសមស្របដើម្បីកែប្រែ ឬសម្រាលលក្ខខណ្ឌដែលបានដាក់នោះ ពុំមែនជាអំពើអកម្មមួយដាច់ដោយឡែកដែលឈានដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយឯករាជ្យនោះទេ ប៉ុន្តែគឺជានិរន្តរ៍ភាពនៃអំពើសកម្មល្មើសរបស់ខ្លួន និងថា ជាកាតព្វកិច្ចស្របច្បាប់ក្នុងការបញ្ឈប់ការប្រព្រឹត្តបទឧក្រិដ្ឋនោះ។ កាតព្វកិច្ចរបស់ចារីដែលត្រូវបំពេញនោះគឺបញ្ឈប់អំពើសកម្មល្មើសដែលចារីត្រូវបានតម្រូវឱ្យធ្វើដូច្នោះ[1974]។ សហព្រះរាជអាជ្ញាបានពន្យល់ថា ដោយសារចារីគឺអ្នកដែលបានដាក់លក្ខខណ្ឌ ដូច្នេះចារីស្ថិតក្នុងតួនាទីមួយដែលបានអាចកែប្រែ ឬសម្រាលលក្ខខណ្ឌនោះ និងមានកាតព្វកិច្ចត្រូវធ្វើដូច្នេះ[1975]។ សហព្រះរាជអាជ្ញាបានចាត់ទុកធាតុផ្សំសត្យានុម័តថា ជាអំពើសកម្មល្មើស និងបានអះអាងថា ការដែលអាជ្ញាធរពុំមានឆន្ទៈកែប្រែលក្ខខណ្ឌម៉ោងការងារ ឬការរស់នៅ គឺជាការខកខានក្នុងការបញ្ឈប់នោះ ទើបនិរន្តរ៍ភាពនៃអំពើល្មើសនៅតែមានអត្ថិភាព[1976]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[1977]។

---

សំខាន់បំផុតនូវការប្រព្រឹត្តបទឧក្រិដ្ឋដោយចារីផ្ទាល់ ឬអំពើអសកម្មល្មើសដែលត្រូវបានកំណត់ដោយច្បាប់ព្រហ្មទណ្ឌ”)។ ខៀវ សំផន បានយោងផងដែរ និងទំនងជាដកស្រង់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ (F54) កថាខណ្ឌ ៦៧៤ ចេញពីសាលដីការឿងក្តី *BlaĖkić* (ICTY) កថាខណ្ឌ ៦៦៣៖ “ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌគ្របដណ្តប់អំពើផ្ទាល់ដំបូង និងសំខាន់បំផុតនូវការប្រព្រឹត្តបទឧក្រិដ្ឋដោយចារីផ្ទាល់” ប៉ុន្តែការដកស្រង់នេះពុំមាននៅក្នុងកថាខណ្ឌដើមដែលត្រូវបានដកស្រង់នោះដែលផ្ទុយទៅវិញថា៖ “បើទោះបីជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាទូទៅតម្រូវឱ្យមានការប្រព្រឹត្តអំពើសកម្មផ្ទាល់ក៏ដោយ ក៏នេះពុំមែនជាលក្ខខណ្ឌតម្រូវដាច់ខាតដែរ ដូចបានបង្ហាញតាមរយៈការទទួលខុសត្រូវរបស់មេបញ្ជាការ ដែលខកខានក្នុងការដាក់ទោសអ្នកក្រោមការគ្រប់គ្រងខ្លួន បើទោះបីជាមេបញ្ជាការខ្លួនឯងពុំបានប្រព្រឹត្តផ្ទាល់ក៏ដោយនោះ(ក្រោមលទ្ធិច្បាប់នៃការទទួលខុសត្រូវរបស់មេបញ្ជាការ)។ មានករណីលើកលែងចំពោះវិធានទូទៅដែលតម្រូវឱ្យមានអំពើផ្ទាល់៖ ការប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈអំពើអសកម្មស្របតាមមាត្រា ៧(១) ដែលមានកាតព្វកិច្ចស្របច្បាប់ក្នុងចំណោមនោះក្នុងនាមមេបញ្ជាការត្រូវទទួលខុសត្រូវចំពោះបុគ្គលក្រោមការគ្រប់គ្រងរបស់ខ្លួន។ ការខកខានដោយចេតនាក្នុងការបំពេញកាតព្វកិច្ច អាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្របតាមមាត្រា ៧(១) នៃលក្ខន្តិកៈ បើទោះបីជាគ្មានអំពើសកម្មផ្ទាល់ក៏ដោយ”។

[1973] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៦៤។

[1974] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៦៥-៧៦៦។

[1975] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៦៦។

[1976] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨០២, ៨២៨, ៨៣៩។

[1977] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

706. ក្នុងការយល់ឃើញអំពីធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតដែលត្រូវបានបង្ហាញនៅទីតាំងខាងលើ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

i. "អំពើសកម្ម និងអកម្មដែលពាក់ព័ន្ធត្រូវបានប្រព្រឹត្តឡើងទៅលើប្រជាជននៅក្នុងសហករណ៍ត្រាំកក់តាមការរយៈការបង្កើតលក្ខខណ្ឌដែលបណ្តាលឱ្យមនុស្សស្លាប់ ដោយសារកង្វះវិធានការសមស្របដើម្បីកែប្រែ ឬកាត់បន្ថយលក្ខខណ្ឌទាំងនោះ និងជាពិសេស ការគ្រប់គ្រងក្នុងកម្រិតជ្រុលហួសហេតុទៅលើប្រជាជន ដែលធ្វើឱ្យពួកគេគ្មានជម្រើសអ្វីផ្សេងក្រៅតែពីទទួលយកជោគវាសនាដែលផ្តល់នោះ រួមទាំងនៅពេលដែលលទ្ធផលអាចប្រមើលឃើញថា នឹងបង្កឱ្យមានមនុស្សស្លាប់"[1978]។

ii. "អំពើសកម្ម ឬអកម្មកើតឡើងតាមរយៈការដាក់លក្ខខណ្ឌលើអ្នកធ្វើការ[ការដ្ឋានទំនប់ត្រពាំងថ្ម] ដូចបានរៀបរាប់ខាងលើដែលបង្កឱ្យពួកគេស្លាប់។ ករណីនេះរួមទាំងការដែលគ្មានឆន្ទៈក្នុងការកែប្រែម៉ោងធ្វើការ និងលក្ខខណ្ឌការងារ ឬលក្ខខណ្ឌនៃការរស់នៅទៅតាមតម្រូវការរបស់អ្នកធ្វើការ ព្រមទាំងផ្តល់ការថែទាំសុខភាពជាមូលដ្ឋានសមស្របផងដែរ"[1979]។

iii. "អំពើសកម្ម ឬអកម្មពាក់ព័ន្ធ ត្រូវបានបង្ហាញតាមរយៈការដាក់ឱ្យអ្នកធ្វើការ[ការដ្ឋានទំនប់១មករា] ទទួលរងនូវលក្ខខណ្ឌដែលបណ្តាលឱ្យពួកគេស្លាប់ ឬដោយសារការមិនមានវិធានការសមស្របដើម្បីផ្លាស់ប្តូរ ឬសម្រាលលក្ខខណ្ឌបែបនោះ"[1980]។

iv. "អំពើសកម្ម ឬអកម្មដែលពាក់ព័ន្ធត្រូវបានរៀបចំឡើងតាមរយៈការដាក់លក្ខខណ្ឌលើអ្នកធ្វើការ[ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង] ដែលបានបណ្តាលឱ្យពួកគេស្លាប់ និងដោយសារពុំមានវិធានការសមស្របសម្រាប់ផ្លាស់ប្តូរ ឬជួយបន្ធូរបន្ថយលក្ខខណ្ឌបែបនោះ"[1981]។

707. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញនីមួយៗនេះជាប់ពាក់ព័ន្ធទៅនឹងអំពើសកម្មល្មើសដែលជាការដាក់លក្ខខណ្ឌដែលបានបង្កឱ្យមានការស្លាប់ បូករួមជាមួយនឹងអំពើអកម្មដែលជាការខកខានក្នុងការចាត់វិធានការកែប្រែ ឬសម្រាលលក្ខខណ្ឌ។ អំពើអកម្មដែលរងការចោទប្រកាន់នោះគឺជាការខកខានធម្មតាក្នុងការបញ្ឈប់និរន្តរ៍ភាពនៃអំពើសកម្មនោះ។ ម្យ៉ាងវិញទៀត អាចត្រូវបានចាត់ទុកថា ជាអំពើ

---

[1978] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៤។

[1979] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៨។

[1980] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧២។

[1981] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨០៥។

សកម្មដែលបន្តដើម្បីរក្សាលក្ខខណ្ឌនោះ។ ករណីនេះពុំមែនមានតែអំពើអកម្មល្មើសតែមួយគត់ដែលតាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលជាកាតព្វកិច្ចដំបូងត្រូវបំពេញនោះទេ។ ក្នុងរឿងក្តីនេះ ចារីបានដាក់លក្ខខណ្ឌ និងត្រូវបានរំពឹងថា នឹងកែប្រែ ឬសម្រាលលក្ខខណ្ឌនោះនៅពេលជាក់ស្តែងដែលនាំឱ្យមានការស្លាប់ ប៉ុន្តែចារីបានជ្រើសរើសមិនធ្វើដូច្នោះឡើយ។ ដូច្នេះ ការជំទាស់នេះត្រូវបដិសេធចោល។

៤. ថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវាយតម្លៃយុត្តាធិការពេលវេលា ដែរ ឬយ៉ាងណា

708. ក្នុងករណីនៃអំពើមនុស្សឃាតដែលបានបង្កឡើងតាមរយៈការដាក់លក្ខខណ្ឌការងារ និងការរស់នៅធ្ងន់ធ្ងរនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល* ត្រូវបានបង្ហាញដោយផ្អែកលើការពិតដែលថា លក្ខខណ្ឌនោះត្រូវបានរក្សាទុកសម្រាប់រយៈយ៉ាងយូររួមទាំងនៅក្រោយពេលមានផលប៉ះពាល់លើអ្នកធ្វើការ និងនៅសហករណ៍ត្រាំកក់ អ្នកដែលទន់ខ្សោយបំផុត រួមទាំងមនុស្សចាស់ និងកុមារ និងអ្នកមានជំងឺ[1982]។

709. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការវិភាគជាក់លាក់លើភស្តុតាងទាក់ទងនឹងពេលវេលា[1983]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យបង្ហាញទំនាក់ទំនងរវាង *ធាតុផ្សំសត្យានុម័ត* និង *ធាតុផ្សំអត្តនោម័តិ* នៅពេលជាក់លាក់មួយពាក់ព័ន្ធទៅនឹងការស្លាប់ និងបានអះអាងថា "*ធាតុផ្សំអត្តនោម័តិ* ជាប់ពាក់ព័ន្ធនឹងការវិភាគជាអត្តនោម័តិ ពីព្រោះត្រូវចាប់ផ្តើមជាមួយនឹងទស្សនៈរបស់ចារី"[1984] និងថា "ចេតនាល្មើសត្រូវកំណត់នៅមុនការប្រព្រឹត្តបទឧក្រិដ្ឋ មិន

---

[1982] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥, ១៣៨៩, ១៦៧២, ១៨០៥។ ក្នុងការយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* ត្រូវបានបង្ហាញនៅការដ្ឋានធ្វើការទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានពិចារណាលើការរក្សាទុកលក្ខខណ្ឌនោះសម្រាប់រយៈពេលយូរ ឬថា លក្ខខណ្ឌទាំងនោះនៅរក្សាទុកបន្ទាប់ពីផលប៉ះពាល់បានបង្ហាញឱ្យឃើញ ប៉ុន្តែបានបង្កើតការយល់ឃើញដោយផ្អែកលើ"ការទទួលយកហានិភ័យនៃការស្លាប់របស់អ្នកធ្វើការដោយសារលទ្ធផលនៃលក្ខខណ្ឌការងារ និងរស់នៅដ៏អាក្រក់គោកយ៉ាក"។ អង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧២។ ទោះជាយ៉ាងណាក្តី ដូច ខៀវ សំផន បានកត់សម្គាល់ ការយល់ឃើញនេះបានសំអាងទៅលើ"ការដឹងអំពីកង្វះ និងការរក្សាទុកនូវគោលបំណងបង្កបង្កើនផលដោយចារីបើទោះបីមានអ្វីកើតឡើងក៏ដោយ"។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨៥។

[1983] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៥, ៧៦១, ៧៨៥, ៨២៣។

[1984] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៤។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨៥, ១៦៧២។

មែនក្រោយពេលបទល្មើសកើតមាននោះទេ"[1985] និងថា "ការទទួលយកហានិភ័យនោះអាស្រ័យលើការសង្កេតនៅពេលនោះ"[1986]។

710. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា *ធាតុផ្សំអត្តនោម័តិ* ត្រូវមានអត្ថិភាពខណៈពេលបទល្មើសត្រូវបានប្រព្រឹត្តឡើង។ ការកំណត់ពេលវេលាមានការជាប់ពាក់ព័ន្ធ ដោយសារការស្លាប់អាចកើតឡើងដោយសារការដាក់លក្ខខណ្ឌនោះ ប៉ុន្តែជាញឹកញាប់ត្រឹមតែនៅពេលណាដែលចារីរក្សាទុកលក្ខខណ្ឌនោះប៉ុណ្ណោះ បើទោះបីជាបានដឹងថា លក្ខខណ្ឌនោះបានបង្កឱ្យមានការស្លាប់ក៏ដោយដែលតាមរយៈនេះ*ធាតុផ្សំអត្តនោម័តិ* របស់ចារីអាចធ្វើការសន្និដ្ឋានបាន។ ដូច្នេះ នៅពេលមានការស្លាប់*ដំបូង* ឬការស្លាប់បានកើតឡើង គេពុំអាចកំណត់បាននូវ*ធាតុផ្សំអត្តនោម័តិ* របស់ចារីនោះទេ ប៉ុន្តែតាមរយៈការប្រតិកម្មរបស់ចារីចំពោះការស្លាប់នោះអាចបង្ហាញឱ្យឃើញជាឧទាហរណ៍ ថាតើចារីបានផ្តល់អាហារបន្ថែមនៅពេលដែលបានដឹងថា ប្រជាជនកំពុងអត់អាហារ ឬកាត់បន្ថយម៉ោងធ្វើការនៅពេលប្រជាជនបានស្លាប់ដោយសារការធ្វើការធ្ងន់នោះ ដែរ ឬទេ ឬចារីនៅតែបន្តដាក់លក្ខខណ្ឌនោះបើទោះបីជាមានការពិតថាប្រជាជនកំពុងឈានទៅរកការស្លាប់ក៏ដោយ។ ទោះជាយ៉ាងណាក្តី បញ្ហាថាតើ នៅពេលណាអាចសន្និដ្ឋាន*ធាតុផ្សំអត្តនោម័តិ*នោះបាន គឺខុសគ្នាពីបញ្ហាថាតើ នៅពេលណា *ធាតុផ្សំអត្តនោម័តិ* នោះមានអត្ថិភាពដែលប្រាកដជានៅពេលធាតុផ្សំសត្យានុម័តនោះកើតឡើង។ ខៀវ សំផន ទំនងជាភាន់ច្រឡំលើភាពខុសប្លែកគ្នានេះ។

711. អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយនៅក្នុងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពី*ធាតុផ្សំអត្តនោម័តិ*។ ចំនួនមនុស្សស្លាប់ជាច្រើនបានកើតឡើងនៅទីតាំងនីមួយៗ ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាបានដឹងអំពីការស្លាប់នោះក៏ដោយក៏លក្ខខណ្ឌការងារ និងការរស់នៅធ្ងន់ធ្ងរដែលបានបន្តនោះ ត្រូវបានរក្សាទុកនៅដដែល។ បើទោះបីជាពុំអាចបង្ហាញថា តើចារីមាន*ធាតុផ្សំអត្តនោម័តិ* តម្រូវនោះខណៈពេលដែលមានការស្លាប់លើកដំបូង ឬការស្លាប់នោះ ដែរ ឬយ៉ាងណា ក៏ដោយ ក៏ការពិតដែលថា ចារីបានរក្សាទុកលក្ខខណ្ឌនោះបន្ទាប់បានដឹងថា លក្ខខណ្ឌនោះទំនងជាបានបណ្តាលឱ្យមានការស្លាប់ បានបង្ហាញថា ចារីមាន*ធាតុផ្សំអត្តនោម័តិ* តម្រូវខណៈពេលដែលមានការស្លាប់លើកដំបូង។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

---

[1985] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៤, ៧៦១, ៧៨៥។

[1986] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៤។

## ៥. ថាតើ អំពើមនុស្សឃាតត្រូវបានបង្ហាញនៅទីតាំងខាងក្រោម ដែរ ឬយ៉ាងណា

### ក. សហករណ៍ត្រាំកក់

712. ក្នុងការវាយតម្លៃលើបញ្ហាថាតើ អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅសហករណ៍ត្រាំកក់ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កង្វះស្បៀងអាហារធ្ងន់ធ្ងរបានកើតឡើងនៅស្រុកត្រាំកក់ និងថា មានមនុស្សស្លាប់ដោយសារកង្វះស្បៀងអាហារនោះ[1987]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ពុំមានស្បៀងអាហារគ្រប់គ្រាន់រហូតដល់ពេលច្រូតកាត់ឆ្នាំ ១៩៧៦-១៩៧៧ និងថា ក្នុងអំឡុងពេលមុនការច្រូតកាត់នោះ មានការខ្វះស្បៀអាហារធ្ងន់ធ្ងរ[1988]។ ប្រជាជនបានស្លាប់ដោយសារការអត់អាហារ ការធ្វើការធ្ងន់ ជំងឺ និងកង្វះការថែទាំផ្នែកវេជ្ជសាស្ត្រ[1989]ដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ[1990]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា៖

> ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតត្រូវបានបង្ហាញទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌការងារ និងការរស់ដោយសារអំពើសកម្ម និងអកម្មពាក់ព័ន្ធតាមរយៈការដាក់លក្ខខណ្ឌលើប្រជាជននៅសហករណ៍ត្រាំកក់ដែលបង្កឱ្យមានការស្លាប់នោះ និងតាមរយៈនត្ថិភាពវិធានការសមស្របដើម្បីកែប្រែ ឬសម្រាលលក្ខខណ្ឌនោះ និងជាពិសេស ការគ្រប់គ្រងក្នុងកម្រិតតឹងរ៉ឹងហួសហេតុទៅលើប្រជាជនដែលធ្វើឱ្យពួកគេគ្មានជម្រើសអ្វីក្រៅតែពីការទទួលយកជោគវាសនារបស់ខ្លួន រួមទាំងនៅពេលដែលអាចដឹងនូវលទ្ធផលជាមុនថា នឹងមានការស្លាប់នោះ[1991]។

អង្គជំនុំជម្រះសាលាដំបូងបានទទួលយកលទ្ធភាពថា "កត្តាមួយចំនួនដែលហួសពីលទ្ធភាពរបស់អាជ្ញាធរក្នុងស្រុកត្រាំកក់អាចរួមចំណែកខ្លះក្នុងស្ថានការណ៍ខ្វះស្បៀងអាហារ និង/ឬគ្រឿងបរិក្ខារពេទ្យនៅពេលនោះ" ប៉ុន្តែបានយល់ឃើញថា មានភស្តុតាង"បង្ហាញច្បាស់លាស់ថា ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការក្រោមបរិកាសនៃការគ្រប់គ្រង គំរាមកំហែង ភ័យខ្លាច ការអត់ឃ្លាន និងការរើសអើង និងមានផលវិបាកធ្ងន់ធ្ងរ

---

[1987] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤២។

[1988] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤២។

[1989] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤២។

[1990] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៣។ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើបញ្ហាថាតើបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា នៅមុនការសម្រេចកែប្រែប្រភេទគតិយុត្តទៅជាអំពើមនុស្សឃាត។ អង្គជំនុំជម្រះបានពិចារណាថា "ភស្តុតាងពុំច្បាស់លាស់គ្រប់គ្រាន់ទាក់ទងទៅនឹងការគិតទុកជាមុនអំពីការបំផ្លាញប្រជាជនក្នុងចំនួនដ៏ច្រើន"។

[1991] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៤។

បំផុតប្រសិនបើមានការតវ៉ា"[1992]។ អង្គជំនុំជម្រះបានយល់ឃើញថា ការរក្សាទុកលក្ខខណ្ឌសម្រាប់រយៈពេលយ៉ាងយូរ រួមទាំងក្រោយពេលបានដឹងអំពីផលប៉ះពាល់បានកើតឡើងលើអ្នកធ្វើការ និងលើអ្នកដែលទន់ខ្សោយបំផុតនោះ បានបង្ហាញថា អាជ្ញាធរមានចេតនាដាក់លក្ខខណ្ឌបែបនោះដោយដឹងថា ប្រជាជនទំនងជាឈានទៅរកការស្លាប់ ឬដោយទទួលយកលទ្ធភាពនៃផលវិបាកស្លាប់ដែលនេះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល*[1993]។

713. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា ការស្លាប់បានកើតឡើងដោយសារការអត់អាហារ និងខ្វះការថែទាំផ្នែកវេជ្ជសាស្ត្រ[1994]។ ទាក់ទងទៅនឹងការស្លាប់ដោយសារការអត់អាហារ គាត់បានអះអាងថា របាយការណ៍ពីភូមិភាគនិរតីចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការយល់ឃើញថា មានរយៈពេលយូរនៃការខ្វះស្បៀងអាហារធ្ងន់ធ្ងរ ពុំបានគាំទ្រការអះអាងនោះឡើយ[1995]។ គាត់បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយពុំត្រឹមត្រូវនូវសក្ខីកម្មរបស់សាក្សីមួយចំនួន និងបានសំអាងទៅលើភស្តុតាងដែលមានតម្លៃជាភស្តុតាងទាប[1996]។ ពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារការថែទាំផ្នែកវេជ្ជសាស្ត្រកម្រិតទាប ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើសត្យានុម័ត គឺជាការថែទាំផ្នែកវេជ្ជសាស្ត្រកម្រិតទាប និងការធ្វើការធ្ងន់ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើសក្ខីកម្មរបស់ រៀល សន។ រៀល សន គឺជាអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់ចាប់តាំងពីចុងឆ្នាំ ១៩៧៦ [1997] ប៉ុន្តែគាត់ពុំបានអះអាងថា ការស្លាប់នោះដោយសារការថែទាំផ្នែកវេជ្ជសាស្ត្រអន់ថយនោះឡើយ[1998]។ ចុងក្រោយ ខៀវ សំផន បានលើកនូវកំហុសពីរចំណុចទាក់ទងទៅនឹង *ធាតុផ្សំអត្តនោម័តិ* ដែលពុំទាន់បានដោះស្រាយនៅក្នុងសាលដីកានេះ៖ ទីមួយថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញ *ធាតុផ្សំអត្តនោម័តិ* ឱ្យហួសពីវិមតិសង្ស័យ ដោយសារអង្គជំនុំជម្រះពុំបានកំណត់ថាតើ អាជ្ញាធរស្រុកត្រាំកក់មានចេតនាដាក់លក្ខខណ្ឌ"ដោយដឹងថា លក្ខខណ្ឌនោះទំនងជានាំឱ្យមានការស្លាប់" ឬ"ដោយទទួលយកលទ្ធភាពនៃផលវិបាក

---

[1992] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥។

[1993] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥។

[1994] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៨-៦៨២។

[1995] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៨។

[1996] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៩-៦៨០។

[1997] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨២០។

[1998] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨២។

ដែលនាំឱ្យស្លាប់នោះ” ដែរ ឬយ៉ាងណា[1999] ដែលអង្គជំនុំជម្រះគប្បីយល់ឃើញថា ជម្រើសមួយក្នុងចំណោមនេះបានបង្ហាញហួសពីវិមតិសង្ស័យ និងទីពីរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* ត្រូវបានបំពេញក្នុងទម្រង់នៃ*ចេតនាប្រយោល* បើទោះបីជាការសន្និដ្ឋានរបស់ខ្លួនថាមានកត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរអាចរួមចំណែកក្នុងស្ថានការណ៍ខ្វះស្បៀងអាហារ និងថ្នាំពេទ្យក្នុងករណីមួយចំនួន[2000]។ គាត់បានលើកឡើងថា នេះ“ជាការពុំអាចធ្វើទៅបានក្នុងការបង្ហាញអំពីទំនាក់ទំនងរវាងវិធានការដែលត្រូវបានដាក់ដោយអាជ្ញាធរក្នុងការជួយកសាងប្រទេស ជាមួយនឹងកត្តាដាច់ដោយឡែក និងកត្តាដែលមានពីមុនមក និងផលប៉ះពាល់លើប្រជាជនឡើយ។ អាស្រ័យហេតុនេះ មានបញ្ហាចោទទៅលើកត្តាដែលបានបង្កឱ្យមានមហន្តរាយមនុស្សធម៌នោះ”[2001]។

714. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន បានកម្រិតត្រឹមតែភស្តុតាងមួយ និងពុំបានអើពើលើភស្តុតាងបន្ថែមទៀតទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅ និងការងារដែលបានដាក់លើប្រជាជនព្រមទាំងផលប៉ះពាល់ដោយសារលក្ខខណ្ឌនេះលើសុខភាពប្រជាជន និងចុងក្រោយការស្លាប់[2002]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃភស្តុតាង និងការយល់ឃើញពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូង និងបានចង្អុលបង្ហាញទៅលើការអះអាងពុំត្រឹមត្រូវរបស់ ខៀវ សំផន[2003]។ ទាក់ទងទៅនឹង *ធាតុផ្សំអត្តនោម័តិ* សហព្រះរាជអាជ្ញាបានលើកឡើងថា ការទទួលស្គាល់កត្តាខាងក្រៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលអាចរួមចំណែកដល់ការខ្វះស្បៀងអាហារ និងបរិក្ខារពេទ្យ ពុំបានរារាំងដល់ការបង្ហាញអំពីអត្ថិភាពនៃ*ធាតុផ្សំអត្តនោម័តិ*[2004]។ សហព្រះរាជអាជ្ញាបានលើកឡើងថា លក្ខខណ្ឌនោះបានពន្លាតហួសពីកង្វះស្បៀង និងបរិក្ខារពេទ្យ រួមទាំងការបង្ខំប្រជាជនឱ្យធ្វើការក្រោមបរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ការភ័យខ្លាច និងការរើសអើង និងថា ភស្តុតាងបានបង្ហាញថា អាជ្ញាធរមានចេតនាដាក់លក្ខខណ្ឌសម្រាប់រយៈពេលយូរ[2005]។

---

[1999] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៦-៦៧៧។

[2000] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៣។

[2001] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨៤។

[2002] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៧៨។

[2003] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៧៩-៧៨៦។

[2004] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៧៥។

[2005] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៧៥។

715. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូងមានភស្តុតាងជាច្រើននៅចំពោះមុខក្នុងការគាំទ្រការយល់ឃើញរបស់ខ្លួនដែលថា ការស្លាប់បានកើតឡើងដោយសារលក្ខខណ្ឌនៃការរស់នៅ និងបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ភស្តុតាងជាច្រើនពាក់ព័ន្ធបញ្ហានេះ[2006]។ សហមេធាវីនាំមុខបានកត់សម្គាល់ផងដែរថា ខៀវ សំផន ទំនងជាពុំបានជំទាស់ថា កូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានស្លាប់ដោយសារការអត់អាហារ និងដូច្នេះ បានចោទជាបញ្ហាលើភាពស៊ីសង្វាក់គ្នានៃគោលជំហររបស់គាត់ដែលថា ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតពុំត្រូវបានបង្ហាញនោះ[2007]។

716. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានជំទាស់តែទៅលើភស្តុតាងជាក់លាក់មួយចំនួនក្នុងចំណោមភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការស្លាប់ដែលបានបង្កឡើងដោយលក្ខខណ្ឌនៃការរស់នៅ និងការធ្វើការ។ ការអះអាងរបស់គាត់អំពីភស្តុតាង ជាការពុំត្រឹមត្រូវ និងពុំបានធ្វើឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានមន្ទិលសង្ស័យឡើយ។ ការរិះគន់របស់គាត់នីមួយៗអំពីភស្តុតាងជាក់លាក់នោះនឹងត្រូវវិភាគដូចខាងក្រោម៖

i. ខៀវ សំផន បានលើកឡើងថា របាយការណ៍ភូមិភាគនិរតីដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង ពុំបានគាំទ្រការដែលថា មានអំឡុងពេលយូរនៃការខ្វះស្បៀងអាហារធ្ងន់ធ្ងរ[2008]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ ភូមិភាគនិរតីបានរាយការណ៍ប្រហាក់ប្រហែលគ្នានេះថា ស្រុក និងឃុំមួយចំនួនបានជួបប្រទះបញ្ហាខ្វះស្បៀងអាហារ ប៉ុន្តែថា បញ្ហានេះអាចដោះស្រាយបាន"[2009]។ នេះគឺជាអ្វីដែលរបាយការណ៍នោះបង្ហាញក្រោមចំណងជើងថា "លក្ខខណ្ឌរស់នៅរបស់ប្រជាជន"[2010]។ អង្គជំនុំជម្រះតុលាការកំពូលពិចារ

[2006] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៨២។

[2007] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៨៣។

[2008] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៨។

[2009] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៣ យោងទៅលើរបាយការណ៍ពីភូមិភាគនិរតីជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារលេខ E3/853 ERN 00052828 ទំព័រ ៤។

[2010] របាយការណ៍ពីភូមិភាគនិរតីជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារលេខ E3/853 ERN 00052828 ទំព័រ ៤ ("បើទោះបីជាស្រុកខ្លះជួបប្រទះការខ្វះខាត ប៉ុន្តែនៅតែអាចដោះស្រាយបាន")។

ណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងទៅលើរបាយការណ៍នេះធ្វើជាភស្តុតាងគាំទ្រការយល់ឃើញរបស់ខ្លួនអំពីកង្វះស្បៀងអាហារឡើយ។

ii. ខៀវ សំផន បានលើកឡើងថា សាក្សី រៀល សន ពុំបាននិយាយថា ការស្លាប់នៅចុងបញ្ចប់នៃរបបនោះគឺដោយសារកង្វះស្បៀងអាហារឡើយ[2011]។ នេះជាការអះអាងពុំត្រឹមត្រូវ។ រៀល សន បានផ្តល់សក្ខីកម្មថា៖ "ជិតដល់ចុងបញ្ចប់នៃរបប ស្ថានការណ៍កាន់តែធ្ងន់ធ្ងរឡើងៗ។ ប្រជាជនអត់មានអីហូប។ ហេតុនេះ អ្នកខ្លះហើមខ្លួន និងរាកមួលបានកើនឡើងយ៉ាងច្រើន"[2012]។ គាត់បានអះអាងផងដែរថា៖

> ចូលដល់ចុងរបបខ្មែរក្រហមដែលនៅសល់ប្រមាណមួយខែនៅមុនការដួលរលំនោះ មានអ្នកជំងឺជាច្រើនបានស្លាប់ច្រើនរាប់មិនអស់។ ហើយអ្នកដែលត្រូវកប់សពនោះធ្វើការរហូតពីព្រោះពួកគេត្រូវជីករណ្តៅកប់សាកសពទាំងនោះ ដែលជាអ្នកជំងឺ ប្រហែលជាពី ១០ ទៅ ២០ នាក់ក្នុងមួយថ្ងៃៗ។ នេះបានកើតឡើងនៅចុងបញ្ចប់នៃរបបខ្មែរក្រហម។

សៈ តើលោកបានដឹងមូលហេតុដែលនាំឱ្យមានការស្លាប់ជាច្រើននៅចុងបញ្ចប់របបនោះដែរ ឬទេ? ឆៈ បាទដឹង ដោយសារដំបូងពួកយើងទទួលបានអង្ករពី ២៥ ទៅ ៥០ កំប៉ុងសម្រាប់មនុស្សជាង ២០០ នាក់នៅក្នុងមន្ទីរពេទ្យ ប៉ុន្តែក្រោយមកយើងលែងទទួលបានអង្ករនោះទៀត ដូច្នេះ ខ្ញុំបានប្រមូលពីនេះពីនោះមក និងរហូតដល់អ្នកជំងឺទាំងអស់បានបញ្ជូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។ យើងបានស្នើសុំឱ្យសាច់ញាតិបងប្អូនអ្នកជំងឺមកទទួលពួកគាត់នៅមន្ទីរពេទ្យ និងសម្រាប់អ្នកដែលផ្ទះនៅឆ្ងាយឱ្យគេជូនទៅដល់ផ្ទះ។ នៅពេលអ្នកជំងឺទាំងអស់ត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យអស់ដល់ពេលយើងត្រូវចាកចេញ[2013]។

---

[2011] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៩។

[2012] ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ (រៀល សន) ឯកសារលេខ E1/278.1 ទំព័រ ២៩។ វង់ក្រចកក្នុងសេចក្តីដកស្រង់បង្ហាញការកែតម្រូវចំពោះឯកសារបកប្រែដើម្បីឱ្យស៊ីសង្វាក់គ្នាទាំងបីភាសានៃប្រតិចារឹក។ ការកែតម្រូវបានផ្អែកលើកំណត់ត្រាជាសម្លេងនៃភាសាប្រភពដើម។

[2013] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ (រៀល សន) ឯកសារលេខ E1/278.1 ទំព័រ ៦៦។ វង់ក្រចកក្នុងសេចក្តីដកស្រង់បង្ហាញការកែតម្រូវចំពោះឯកសារបកប្រែដើម្បីឱ្យស៊ីសង្វាក់គ្នាទាំងបីភាសានៃប្រតិចារឹក។ ការកែតម្រូវបានផ្អែកលើកំណត់ត្រាជាសម្លេងនៃភាសាប្រភពដើម។

iii. ខៀវ សំផន បានលើកឡើងថា សាក្សី នាង អ៊ួច ជាប្អូនថ្លៃរបស់ តាម៉ុក ដែលឡើងជាលេខាស្រុកត្រាំកក់ក្នុងឆ្នាំ ១៩៧៧[2014] ពុំបាននិយាយថា "បានបណ្ដាលមកពីការគ្រប់គ្រងមិនល្អនោះទេ"[2015] ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "នាង អ៊ួច បាននិយាយថា កង្វះអាហារនោះ គឺដោយសារកំហុសរបស់ប្រធានសហករណ៍ដែលនេះមានន័យថា របបអាហារពុំត្រូវបានអនុវត្តស្របតាមបរិមាណដែលបានកំណត់ "[2016]។ បើទោះបីជា សក្ខីកម្មរបស់សាក្សី នាង អ៊ួច ពុំច្បាស់លាស់ទាំងស្រុងក៏ដោយ ក៏នេះទំនងជាចម្លើយមួយត្រឹមត្រូវនៃសក្ខីកម្មរបស់គាត់ដែរ។ ការដែលថា គាត់ពុំបានសន្និតបញ្ហានោះថា ដោយសារការគ្រប់គ្រងមិនល្អជាទូទៅ ប៉ុន្តែដោយសារប្រធានសហករណ៍នោះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងសមស្របទៅលើសក្ខីកម្មរបស់គាត់ក្នុងការបង្ហាញថា មានកង្វះស្បៀងអាហារនោះឡើយ។

iv. ខៀវ សំផន បានលើកឡើងថា ចម្លើយរបស់ ជាំង ស្រីមុំ បានបង្ហាញនូវលក្ខណៈមិនទៀងទាត់នៃរបបអាហារ និងការលំបាកជាចម្បងនៃការចាត់ចែងរបបអាហារ និងពុំបានគាំទ្រការយល់ឃើញដែលថា អ្នកខ្លះបានស្លាប់ដោយសារអត់អាហារពីព្រោះរបបអាហារប្រចាំថ្ងៃពុំគ្រប់គ្រាន់[2017]។ ខៀវ សំផន មានការភាន់ច្រឡំក្នុងការអះអាងថា សក្ខីកម្មរបស់ ជាំង ស្រីមុំ ពុំបានគាំទ្រការយល់ឃើញដែលថា អ្នកខ្លះស្លាប់ដោយសារការអត់អាហារ។ ជាំង ស្រីមុំ គឺជា"ប្រជាជនត្រៀម"កាត់សែស្រឡាយចិនធ្វើការនៅស្រុកត្រាំ កក់[2018]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ជាំង ស្រីមុំ បានផ្ដល់សក្ខីកម្មថា បើទោះបីជាមានការចែកអាហារស្មើគ្នាក៏ដោយ ក៏ប្រជាជនបានស្លាប់ដោយសាររបបអាហារប្រចាំថ្ងៃមិនគ្រប់គ្រាន់ដែរ"[2019]។ ជាំង ស្រីមុំ ត្រូវបានសួរសំណួរក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មនោះអំពីចម្លើយរបស់គាត់ក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលថា "ប្រជា

---

[2014] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១៨។

[2015] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៩។

[2016] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៣ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ (នាង អ៊ួច) ឯកសារលេខ E1/274.1 ទំព័រ ១០, ១៦-១៧។

[2017] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៧៩។

[2018] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨២៣។

[2019] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៥ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ១០-១១។

ជនខ្លះបានស្លាប់ដោយសារពួកគេហូបច្រើនពេក និងខ្លះបានស្លាប់ដោយសារការអត់អាហារ”[2020]។ លោកស្រីបានឆ្លើយទៅនឹងសំណួរត្រង់ចំណុចទាក់ទងនឹងការស្លាប់ដោយសារហូបច្រើនពេក។ គាត់នៅរក្សាចម្លើយពីមុនរបស់គាត់អំពីការស្លាប់ដោយសារការអត់អាហារ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបញ្ជាក់នេះឡើយ។

v. ខៀវ សំផន បានលើកឡើងថា ឯក ហឿន ដែលបានធ្វើការនៅមន្ទីរស្រុកត្រាំកក់នៅក្នុងឆ្នាំ ១៩៧៦ និងបន្ទាប់មកបានគ្រប់គ្រងកិច្ចការវាស់វែងដីសម្រាប់ស្រុកត្រាំកក់មុនពេលចាកចេញទៅធ្វើការនៅភូមិភាគផ្សេងទៀត[2021] ពុំបានបញ្ជាក់ថា អ្នកធ្វើការនៅការដ្ឋាននោះបានស្លាប់ដោយសារការខ្វះអាហារឡើយ[2022]។ ការអះអាងនេះជាការពុំត្រឹមត្រូវ។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនទៅលើសក្ខីកម្មរបស់ ឯក ហឿន ដែលថា៖ “ឯក ហឿន បានបញ្ជាក់ថា ថ្នាក់ស្រុកបានទទួលរបាយការណ៍ពីមន្ទីរពាណិជ្ជកម្មថា ឃុំខ្វះស្បៀងអាហារ។ គាត់បានរំឮកនូវរបាយការណ៍ថា ក្នុងឃុំលាយបូរមានប្រជាជនប្រមាណ ៥០០ នាក់ បានស្លាប់ដោយសារអត់អាហារ។ ឃុំត្រពាំងធំខ្វះអាហារ ហើយចាំបាច់ត្រូវស្នើសុំការផ្គត់ផ្គង់អាហារពីឃុំញ៉ែងញ៉ង។ ប៉ុន្តែទោះបីជាព្យាយាមយ៉ាងណាក្តី ក៏ឃុំញ៉ែងញ៉ងមិនអាចផ្គត់ផ្គង់បានទេ”[2023]។ អង្គជំនុំជម្រះតុលាការកំពូលពិនិត្យឡើងវិញលើសក្ខីកម្មរបស់ ឯក ហឿន និងពិចារណាឃើញថា នេះគឺជាការឆ្លុះបញ្ចាំងត្រឹមត្រូវនូវអ្វីដែលគាត់បានអះអាងនោះ។

vi. ខៀវ សំផន បានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ សឹម ឈៀង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមានតម្លៃជាភស្តុតាងទាប[2024]។ ការអះអាងនេះពុំគ្រប់គ្រាន់ធ្វើឱ្យភស្តុតាងនេះមានមន្ទិលសង្ស័យដែលបានបញ្ជាក់អះអាងបន្ថែមលើសក្ខីកម្មរបស់សាក្សីយ៉ាងទូលំទូលាយព្រមទាំងភស្តុតាងដទៃទៀតលើបញ្ហានេះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា

---

[2020] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ១០-១១ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជាំង ស្រីមុំ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ E3/5832 ចម្លើយលេខ ១១។

[2021] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨២០។

[2022] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨០។

[2023] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១២ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥ (ឯក ហឿន) ឯកសារលេខ E1/299.1 ទំព័រ ១៣-១៤។

[2024] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨០។

សឹម ឈៀង បានអះអាងថា គាត់បានឃើញមនុស្សម្នាក់បានស្លាប់ដោយសារការអត់អាហារ និងថា មនុស្សជាច្រើនបានស្លាប់ដោយសារបញ្ហាសុខភាព[2025]។

717. ទាក់ទងទៅនឹងការថែទាំវេជ្ជសាស្ត្រកម្រិតទាប ខៀវ សំផន បានលើកឡើងត្រឹមត្រូវថា សាក្សី រៀល សន ពុំបានបញ្ជាក់ថា ការស្លាប់បានកើតឡើងដោយសារការថែទាំវេជ្ជសាស្ត្រកម្រិតទាបនោះទេ[2026] ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាឃើញថា ការពិតនេះបានធ្វើឱ្យការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទៅជាមិនសមហេតុផលដែលថា ការស្លាប់នោះបានកើតឡើងដោយសារការថែទាំកម្រិតទាប នៅពេលដែល រៀល សន បានអះអាងច្បាស់លាស់ថា ការស្លាប់នោះបានកើតឡើងក្នុងមន្ទីរពេទ្យ និងថា ការថែទាំវេជ្ជសាស្ត្រមានកម្រិតទាប[2027]។

718. ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ក្នុងការយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* ត្រូវបានបំពេញដោយសារការពិតថា អាជ្ញាធរបានដាក់លក្ខខណ្ឌ“ដោយមានការដឹងថា ប្រជាជនទំនងជាឈានទៅរកការស្លាប់ *ឬ* ដោយទទួលយកនូវភវនីយភាពនៃផលវិបាកនៃការស្លាប់នោះ”[2028]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា និរន្តរ៍ភាពនៃលក្ខខណ្ឌក្រោយពីមានផលប៉ះពាល់នោះបានបង្ហាញថា អាជ្ញាធរបានដឹងថា ការស្លាប់ទំនងជាកើតឡើង ឬបានទទួលយកភវនីយភាពនៃការស្លាប់នោះ។ អាស្រ័យហេតុនេះ ពុំចាំបាច់ធ្វើការវែកញែកនោះទេ ពីព្រោះការដឹងរបស់អាជ្ញាធរ ឬការទទួលយកនោះបានបង្ហាញថា *ធាតុផ្សំអត្តនោម័តិ* ត្រូវបានបំពេញ និងអាចធ្វើការសន្និដ្ឋានបាន។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដែលពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបានតាមរយៈការចង្អុលបង្ហាញទៅលើកត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរនោះ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា កត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរអាចរួមចំណែកខ្លះដល់ការខ្វះស្បៀងអាហារ និងបរិក្ខារពេទ្យ[2029] ប៉ុន្តែបានពិចារណាលើបរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ការភ័យខ្លាច ការអត់ឃ្លាន និងការរើសអើង និងការរក្សាទុកលក្ខខណ្ឌធ្ងន់ធ្ងរសម្រាប់រយៈពេលយ៉ាងយូររួមទាំងបន្ទាប់ពីផលប៉ះ

---

[2025] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈៀង ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ E3/7980 ERN 00165301 ទំព័រ ២។

[2026] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៨២។

[2027] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៤០-១០៤២, ១០៤៥។

[2028] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥ (សេចក្តីបញ្ជាក់បន្ថែម)។

[2029] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥។

ពាល់បានកើតឡើងច្បាស់លាស់ និងបានយល់ឃើញថា លក្ខខណ្ឌនោះត្រូវបានដាក់ដោយចេតនា។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា កត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរ ជាអ្នកទទួលខុសត្រូវទាំងស្រុងលើកង្វះស្បៀងអាហារ និងថ្នាំពេទ្យក៏ដោយ ក៏នេះពុំអាចពន្យល់បានអំពីការស្លាប់ដោយសារការធ្វើការធ្ងន់ និងការហេវហត់អស់កម្លាំងនោះដែរ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅសហករណ៍ត្រាំកក់ ត្រូវបដិសេធចោល។

## ខ. ការដ្ឋានទំនប់ត្រពាំងថ្ម

719. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា[2030] អាហារដែលបានផ្តល់នៅការដ្ឋានទំនប់ត្រពាំងថ្មជាទូទៅពុំគ្រប់គ្រាន់ និងថា ពុំមានទឹកស្អាតបរិភោគ ដែលនេះបានបណ្តាលឱ្យអ្នកធ្វើការមានជំងឺរាករូស[2031]។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អ្នកធ្វើការគ្មានទីជម្រកគ្រប់គ្រាន់ ជាញឹកញាប់ធ្លាក់ខ្លួនឈឺ និងអ្នកខ្លះបានស្លាប់ដោយសារជំងឺតម្កាត់[2032]។ អ្នកធ្វើការត្រូវបានតម្រូវផងដែរឱ្យធ្វើការច្រើនម៉ោង ដោយពុំគិតពីលក្ខខណ្ឌអាកាសធាតុ និងជាញឹកញាប់បានដួលស្លាប់នៅនឹងកន្លែង[2033]។ អ្នកដែលធ្លាក់ខ្លួនឈឺជាធម្មតាត្រូវបានផ្តល់ថ្នាំពេទ្យដែលគ្មានប្រសិទ្ធភាព និងតាមរយៈគ្រូពេទ្យដែលគ្មានវិជ្ជាជីវៈ[2034]។ ដោយពិចារណាលើការយល់ឃើញទាំងនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការស្លាប់ដែលបានកើតឡើងនៅកន្លែងធ្វើការគឺដោយសារការធ្វើការធ្ងន់ហួសកម្លាំង ការហេវហត់អស់កម្លាំង និងខ្វះអាហារ និងថា អ្នកធ្វើការដែលបានស្លាប់ដោយសារជំងឺតម្កាត់បានបណ្តាលមកពីលក្ខខណ្ឌទាំងនោះ ដែលកាន់តែធ្ងន់ធ្ងរឡើងតាមរយៈការខ្វះការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប និងថា ការដាក់លក្ខខណ្ឌទាំងនេះបានបង្កឱ្យមានការស្លាប់អ្នកធ្វើការនៅ

[2030] អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការសម្លាប់(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៧៨-១៣៨២) និងការស្លាប់ដោយសារលកក្ខខណ្ឌនៃការរស់នៅ និងធ្វើការ(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤-១៣៩០) នៅការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម។ ដោយសារ ខៀវ សំផន បានកម្រិតអំណះអំណាងរបស់គាត់ត្រឹមការស្លាប់ដោយសារលក្ខខណ្ឌការងារ និងរស់នៅ មានតែការយល់ឃើញពាក់ព័ន្ធត្រូវបានសង្ខេបនៅចំណុចនេះ។

[2031] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤។

[2032] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤។

[2033] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤។

[2034] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤។

ការដ្ឋានសាងសង់ ដែលបំពេញតាមលក្ខខណ្ឌនៃធាតុផ្សំសត្យានុម័តអំពើមនុស្សឃាត[2035]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "អំពើសកម្ម ឬអកម្មពាក់ព័ន្ធ ត្រូវបានបង្ហាញតាមរយៈការដាក់លក្ខខណ្ឌលើអ្នកធ្វើការដែលបានពិពណ៌នាខាងលើដែលបង្កឱ្យមានការស្លាប់នោះ។ នេះបានរួមបញ្ចូលការគ្មានឆន្ទៈសម្របសម្រួលម៉ោងធ្វើការ និងលក្ខខណ្ឌរស់នៅ និងធ្វើការតាមតម្រូវការរបស់អ្នកធ្វើការ និងផ្តល់ការថែទាំមូលដ្ឋានផ្នែកវេជ្ជសាស្ត្រសមស្រប"[2036]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល* ត្រូវបានបំពេញដោយផ្អែកលើ"ការរក្សាទុកនូវលក្ខខណ្ឌទាំងនោះសម្រាប់រយៈពេលយូរ រួមទាំងក្រោយពេលមានផលប៉ះពាល់លើអ្នកធ្វើការបានកើតឡើង និងដឹងដល់អាជ្ញាធរមូលដ្ឋាន" ដែលអង្គជំនុំជម្រះបានយល់ឃើញថា "នេះបង្ហាញថា អាជ្ញាធរមូលដ្ឋានមានចេតនាដាក់លក្ខខណ្ឌនោះដោយដឹងថា លក្ខខណ្ឌនោះទំនងជាបណ្តាលឱ្យជនរងគ្រោះស្លាប់ ឬដោយទទួលយកភវនីយភាពនៃផលវិបាកដែលបានបណ្តាលឱ្យស្លាប់នោះ"[2037]។

720. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវាយតម្លៃរបស់លើ *ធាតុផ្សំអត្តនោម័តិ* ដោយសារ"ការវាយតម្លៃលើ*ធាតុផ្សំអត្តនោម័តិ* ជាការធ្វើឡើងតាមបែបអត្តនោម័តិ និងអាស្រ័យហេតុនេះ តម្រូវឱ្យចាប់ផ្តើមជាមួយនឹងទស្សនៈទានរបស់ចារី។ ទោះជាយ៉ាងណាក្តី ទំនាក់ទំនងហេតុ និងផលរវាងវិធានការដែលត្រូវបានអនុវត្តដោយឆន្ទៈរបស់អាជ្ញាធរក្នុងការកសាងប្រទេស រវាងកត្តាដែលហួសពីការគ្រប់គ្រងដោយពុំគិតពីកត្តាដែលមានអត្ថិភាពពីមុន ជាមួយនឹងផលប៉ះពាល់លើប្រជាជនមិនអាចកំណត់បានឡើយ"[2038]។ អាស្រ័យហេតុនេះ ខៀវ សំផន បានអះអាងថា "មានមន្ទិលសង្ស័យលើកត្តាដែលបង្កឱ្យមានមហន្តរាយមនុស្សធម៌ និងការទទួលយកហានិភ័យនោះគឺអាស្រ័យលើការវាយតម្លៃទាំងនេះនៅមុនអត្ថិភាពនៃបទល្មើស"[2039]។

---

[2035] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៤, ១៣៨៨។

[2036] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៨។

[2037] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៨៩។

[2038] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦១។

[2039] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦១។

721. សហព្រះរាជអាជ្ញាបានជំទាស់ថា ការអះអាងរបស់ ខៀវ សំផន អំពីកត្តាហួសពីការគ្រប់គ្រងរបស់អាជ្ញាធរ និងលក្ខខណ្ឌពីមុន ពុំមានភស្តុតាងគាំទ្រ និងថា គាត់ខកខានក្នុងការកំណត់កត្តា ឬលក្ខខណ្ឌណាមួយនោះ[2040]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[2041]។

722. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ មានទំនាក់ទំនងហេតុ និងផលរវាងអំពើសកម្មរបស់ចារី និងការស្លាប់របស់ជនរងគ្រោះ និងថាតើ មានកត្តាដែលហួសពីការគ្រប់គ្រងរបស់ចារី ដែរ ឬយ៉ាងណានោះ ពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ និងត្រឹមតែបង្ហាញនូវការមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ នេះជាការពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដែលគ្មានតុលាការអង្គហេតុសមហេតុផលអាចធ្វើទៅបាននោះឡើយ។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

### គ. ការដ្ឋានទំនប់១មករា

723. ដោយផ្អែកលើសក្ខីកម្មរបស់សាក្សីបួននាក់ និងដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ ព្រមទាំងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីចំនួនបី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា[2042]"យ៉ាងហោចណាស់មានអ្នកធ្វើការពីប្រាំមួយទៅដប់នាក់"នៅការដ្ឋានទំនប់១មករា បានស្លាប់ដោយសារការដាក់លក្ខខណ្ឌពលកម្មធ្ងន់ធ្ងរ របបអាហារមិនគ្រប់គ្រាន់ លក្ខខណ្ឌរស់ដ៏លំបាក រួមទាំងបរិយាកាសគ្មានអនាម័យ និងថ្នាំពេទ្យគ្មានប្រសិទ្ធភាព និងមិនគ្រប់គ្រាន់[2043]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "អ្នកធ្វើការត្រូវបានបង្ខំឱ្យធ្វើការហួសកម្លាំង ខណៈពេលត្រូវបានដកហូតនូវអាហារ និងការថែទាំគ្រប់គ្រាន់នៅពេលពួកគេធ្លាក់ខ្លួនឈឺ។ អ្នកខ្លះទៀតបានទទួលរងវាសនាដូចគ្នានៅតាមរោងព្យាបាល និងមន្ទីរពេទ្យបន្ទាប់ពីឆ្លងកាត់លក្ខខណ្ឌការងារ

---

[2040] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៣០-៨៣១។

[2041] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

[2042] អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការសម្លាប់(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦៦) និងដោយសារលក្ខខណ្ឌនៃការរស់នៅ និងធ្វើការ(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០-១៦៧៣) នៅការដ្ឋានធ្វើការទំនប់១មករា។ ដោយសារ ខៀវ សំផន បានកម្រិតអំណះអំណាងរបស់គាត់ត្រឹមការស្លាប់ដោយសារលក្ខខណ្ឌការងារ និងរស់នៅ មានតែការយល់ឃើញពាក់ព័ន្ធត្រូវបានសង្ខេបនៅចំណុចនេះ។ ការស្លាប់ដោយសារលក្ខណការងារ និងការរស់នៅ(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០-១៦៧៣) និងការដ្ឋានធ្វើការទំនប់១មករា។ ដោយហេតុថា ខៀវ សំផន បានកម្រិតអំណះអំណាងរបស់ខ្លួនត្រឹមការស្លាប់ដោយសារលក្ខខណ្ឌការងារ និងការរស់នៅ មានតែការយល់ឃើញពាក់ព័ន្ធប៉ុណ្ណោះដែលត្រូវបានសង្ខេបនៅទីនេះ។

[2043] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០។

ធ្ងន់ធ្ងរនោះ”នៅការដ្ឋានធ្វើការ[2044]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ផ្អែកលើសក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលថា គ្រោះថ្នាក់ដោយថៃដន្យមួយចំនួនបានកើតឡើងភ្លាមៗតាមរយៈការប្រឡងប្រណាំងរវាងអ្នកធ្វើការនៅការដ្ឋាននៅពេលបាក់ច្រាំងដីសង្កត់លើស្លាប់មួយចំនួន[2045]។ អង្គជំនុំជម្រះសាលាដំបូងបាន“កត់សម្គាល់បន្ថែមទៀតលើអ្នកធ្វើការក្នុងចំនួនដ៏ច្រើនលើសលុបនៅការដ្ឋាននោះប្រមាណ ២០.០០០ នាក់ដែលពុំទទួលបានវិធានការអនាម័យ អាហារ និងការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប”[2046]។ អង្គជំនុំជម្រះសាលាដមបូងបានបញ្ជាក់ថា “ការសន្និដ្ឋានសមហេតុផលតែមួយគត់គឺថាអ្នកធ្វើការក្នុងចំនួនដ៏ច្រើនបានស្លាប់ដោយសារលក្ខខណ្ឌទាំងនេះ”[2047]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាត ដូចជាអំពើសកម្ម ឬអកម្មរបស់ចារីដែលបានបង្កឱ្យមានការស្លាប់ជនរងគ្រោះ ត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការស្លាប់ដែលបានបណ្ដាលមកពីលក្ខខណ្ឌការងារ និងការរស់នៅដូចបានពិពណ៌នាខាងលើ។ ពាក់ព័ន្ធបញ្ហានេះ អំពើសកម្ម ឬអកម្ម ត្រូវបានបង្ហាញតាមរយៈការដាក់លក្ខខណ្ឌលើអ្នកធ្វើការដែលបានបណ្ដាលឱ្យមានការស្លាប់ និងតាមរយៈនត្ថិភាពនៃវិធានការសមស្របកែប្រែ ឬសម្រាលលក្ខខណ្ឌនោះ។ ការទទួលយកហានិភ័យនៃការស្លាប់របស់អ្នកធ្វើការដោយសារលក្ខខណ្ឌរស់នៅ និងធ្វើការអាក្រក់ និងគ្មានសវត្ថិភាពបានបំពេញតាមលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្រោមទម្រង់*ចេតនាប្រយោល*[2048]។

724. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការកំណត់ថា អំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងដោយ *ចេតនាប្រយោល* បានកើតឡើង។ គាត់បានអះអាងជាពិសេសថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អ្នកធ្វើការពីប្រាំមួយទៅដប់នាក់បានស្លាប់ដោយសារការដាក់លក្ខខណ្ឌធ្វើការ និងរស់នៅ និងកង្វះថ្នាំពេទ្យប្រសិទ្ធិភាព ពីព្រោះកថាខណ្ឌនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលការយល់ឃើញបានសំដៅទៅលើនោះបង្ហាញថា មានមនុស្សពីរបីនាក់បានស្លាប់ដោយសារជំងឺ ឬរបួសនៅការដ្ឋានធ្វើការ និងថា ផ្ទុយទៅវិញ អ្នកដែលមានជំងឺត្រូវបានបញ្ជូនត្រឡប់ទៅភូមិរបស់ខ្លួនវិញ ឬទៅរោងព្យាបាលតាមមូលដ្ឋាន ហើយភស្តុតាងដែលបានយោងទៅលើនោះគ្រាន់តែសំដៅ

---

[2044] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០។

[2045] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០។

[2046] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០។

[2047] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០។

[2048] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧២។

ទៅលើបុគ្គលដែលត្រូវបានជម្លៀសទៅភូមិរបស់ខ្លួនវិញ ឬទៅមន្ទីរពេទ្យស្រុកប៉ុណ្ណោះ[2049]។ គាត់បានរិះគន់ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្ម និងកំណត់ហេតុស្តាប់ចម្លើយសាក្សីជាក់លាក់[2050]។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា មានអ្នកធ្វើការមួយចំនួនបានស្លាប់ដោយសារគ្រោះថ្នាក់ចៃដន្យ និងបានរិះគន់ភស្តុតាងដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូង[2051]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ការសន្និដ្ឋានសមស្របតែមួយគត់ចេញពីវត្តមានរបស់អ្នកធ្វើការប្រមាណ ២០.០០០ នៅការដ្ឋាននោះដែលពុំទទួលបានវិធានការអនាម័យ អាហារ និងការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប គឺថា មានមនុស្សក្នុងចំនួនដ៏ច្រើនបានស្លាប់ដោយសារលក្ខខណ្ឌនោះ ពីព្រោះគាត់ថា នេះគឺជាការសន្និដ្ឋានពង្រីក ហើយអង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើភស្តុតាងណាមួយ និងធ្វើការសន្និដ្ឋានសមស្របតិចតួចបំផុតដោយគ្មានផ្តល់សំអាងហេតុ[2052]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀតក្នុងការយល់ឃើញថា ចារីបានដឹងថា មានកង្វះស្បៀងអាហារ និងថ្នាំពេទ្យ ប៉ុន្តែនៅតែបន្តជម្រុញឱ្យបំពេញការងារ ពីព្រោះគាត់ថា អង្គជំនុំជម្រះបានផ្អែកទៅលើសេចក្តីដកស្រង់ទង់បដិវត្តស្តីពីស្ថានការណ៍ទូទៅក្នុងកម្ពុជា និងអត្ថបទថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៧៧ ដែលគ្មានឈ្មោះអ្នកនិពន្ធដែលពុំអាចគាំទ្រការដែលថា ចារីនៅតែបន្តជម្រុញអ្នកធ្វើការឱ្យបំពេញការងារក្រោយពីបានដឹងអំពីបញ្ហាក្នុងខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ១៩៧៧ ឡើយ[2053]។

725. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ភស្តុតាងបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការស្លាប់ពីប្រាំមួយទៅដប់នាក់៖ សាក្សីម្នាក់បានឃើញអ្នកធ្វើការម្នាក់ស្លាប់បន្ទាប់ពីបានធ្លាក់ខ្លួនឈឺនៅការដ្ឋានធ្វើការ និងលក្ខខណ្ឌរបស់គាត់កាន់តែធ្ងន់ធ្ងរឡើង និងសាក្សីមួយផ្សេងទៀតបានផ្តល់សក្ខីកម្មថា អ្នកធ្វើការពីរនាក់ក្នុងកងរបស់គាត់បានស្លាប់ដោយសារជំងឺ និងដទៃទៀតបានអះអាងថា អ្នកដែលឈឺត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ និងបានស្លាប់នៅទីនោះ ដោយសារអាជ្ញាធរពុំចង់ឱ្យមានសាកសពនៅក្នុងការដ្ឋានធ្វើការ[2054]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុ

---

[2049] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៧៣។

[2050] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៧៤-៧៧៨។

[2051] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៧៩-៧៨១។

[2052] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨២។

[2053] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨៣-៧៨៤។

[2054] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨០៤។

តាងគ្រប់គ្រាន់ ហើយ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយប៉ុណ្ណោះ[2055]។ ពាក់ព័ន្ធទៅនឹងការស្លាប់ដោយថៃដន្យ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានបំភ្លៃភស្តុតាងទាំងមូល[2056]។ ពាក់ព័ន្ធទៅនឹង*ធាតុផ្សំអត្តនោម័តិ* សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើទៅលើការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធ។ ការដ្ឋានទំនប់១មករា គឺជា"សមរភូមិក្តៅ"។ ឯកសារបក្សកុម្មុយនីស្តកម្ពុជាបានពិពណ៌នាអ្នកធ្វើការបានប្រឹងប្រែងទាំងយប់ទាំងថ្ងៃ ការជួបប្រទះជីវភាព"ខ្វះខាត" និង កែ ពក និងសមាជិកនៃថ្នាក់លើដទៃទៀតបានដឹងអំពីលក្ខខណ្ឌនៅការដ្ឋាននោះ ប៉ុន្តែនៅតែបន្តដាក់លក្ខខណ្ឌការងារធ្ងន់ធ្ងរ[2057]។

726. សហមេធាវីនាំមុខបានឆ្លើយតបថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានរួមបញ្ចូលការយល់ឃើញបីប្រភេទ៖ (១) លក្ខខណ្ឌនៃការរស់នៅ និងការងារនៅការដ្ឋានដែលតាមរយៈនោះប្រជាជនបានធ្លាក់ខ្លួនឈឺ (២) អ្នកដែលមានជំងឺធ្ងន់ធ្ងរត្រូវបញ្ជូនចេញពីការដ្ឋាន និង (៣) អ្នកដែលត្រូវបានបញ្ជូនចេញនោះបានស្លាប់ដោយសារជំងឺ[2058]។ សហមេធាវីនាំមុខបានអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានផ្តល់ភស្តុតាងទាក់ទងទៅនឹងការយល់ឃើញមួយ ខណៈសាក្សីដទៃទៀតបានផ្តល់ភស្តុតាងទាក់ទងទៅនឹងការយល់ឃើញដទៃទៀត[2059]។ ពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារគ្រោះថ្នាក់ថៃដន្យនៅកន្លែងធ្វើការ សហមេធាវីនាំមុខបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើភស្តុតាងបូកបញ្ចូលគ្នារបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់[2060]។

727. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា អំណះអំណាងរបស់ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើមនុស្សឃាតដោយ*ចេតនាប្រយោល*ត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានធ្វើការទំនប់១មករា និងរំឭកថា គាត់មានបន្ទុកខ្ពស់ក្នុងការបដិសេធការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលពុំធ្វើការជ្រៀងជ្រែកងាយៗលើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ដរាបណាភស្តុតាង

---

[2055] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨០៥។

[2056] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨០៦-៨០៧។

[2057] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨១០។

[2058] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៨៨។

[2059] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៨៨។

[2060] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៩១។

ដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងនោះពុំអាចទទួលយកបានដោយតុលាការអង្គហេតុសមហេតុផលណាមួយ ឬការវាយតម្លៃលើភស្តុតាងនោះមានកំហុសទាំងស្រុង[2061]។

728. អង្គជំនុំជម្រះតុលាការកំពូលបានវិភាគលើភស្តុតាងដែលបានផ្អែកទៅលើដោយអង្គជំនុំជម្រះសាលាដំបូង និងបានសង្ខេបចំណុចពាក់ព័ន្ធបំផុតដូចខាងក្រោម៖

i. កំណត់ហេតុស្តាប់ចម្លើយរបស់ កង អ៊ុត បានបញ្ជាក់ថា "មានអ្នកឈឺច្រើន ព្រោះដោយសារធ្វើការយ៉ាប់យ៉ឺនពេក និងហួសកម្លាំង។ ប្រភេទជំងឺខ្លះមានដូចជា គ្រុនក្តៅ និងចុកពោះ។ នៅទីនោះមិនមានមន្ទីរពេទ្យទេ មានតែគ្រូពេទ្យដើរមើល និងមានថ្នាំពេទ្យ *ហៅថា*ថ្នាំអាចម៍ទន្សាយ។ ក្នុងករណីមាននរណាឈឺធ្ងន់ គេបញ្ជូនទៅមន្ទីរពេទ្យដែលនៅឆ្ងាយពីការដ្ឋាន គេមិនចង់ទុកឱ្យស្លាប់នៅទីនោះទេ"[2062]។

ii. សាក្សី មាស ឡៃហួរ បានយល់ស្របជាមួយនឹងអ្វីដែល កង អ៊ុត បាននិយាយបន្ទាប់ពីផ្នែកដែលបានលើកឡើងខាងលើនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ កង អ៊ុត ត្រូវបានអានឱ្យលោកស្រីស្តាប់[2063]។ មាស ឡៃហួរ បានផ្តល់សក្ខីកម្មថា ពុំមានមនុស្សស្លាប់នៅការដ្ឋានធ្វើការពីព្រោះនៅពេលប្រជាជនធ្លាក់ខ្លួនឈឺធ្ងន់ គេពុំត្រូវបានអនុញ្ញាតឱ្យស្នាក់នៅការដ្ឋាននោះទេ និងត្រូវបញ្ជូនទៅមន្ទីរពេទ្យ[2064]។

iii. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា មានមនុស្សពីរនាក់បានឈឺធ្ងន់ និងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ និងពុំឃើញត្រឡប់មកវិញ ហើយលោកស្រីពុំបានដឹងថាតើ ពួកគេបានជាសះស្បើយ ឬបានស្លាប់នោះឡើយ[2065]។

iv. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា បានផ្តល់សក្ខីកម្មថា អ្នកជំងឺត្រូវបានកោសខ្យល់ធ្វើសរសៃ ឬឱ្យសម្រាកបន្តិច ហើយអ្នកដែលមិនធូរស្រាលបន្ទាប់ពីធ្វើសរសៃ ឬសម្រាក ត្រូវបានយកទៅ

[2061] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨-៨៩។

[2062] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង អ៊ុត ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារលេខ E3/7775 ERN 00229055 ទំព័រ ៣។

[2063] ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ១៧-១៩។

[2064] ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ១៨-១៩។

[2065] ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ (អ៊ុន រ៉ន) ឯកសារលេខ E1/307.1 ទំព័រ ១០។

ព្យាបាលក្នុងភូមិ[2066]។ លោកស្រីបានអះអាងថា លោកស្រីពុំដែលឃើញពួកគាត់ត្រឡប់មកវិញ ប៉ុន្តែបានសន្មតថា ដោយសារលោកស្រីបានធ្វើការនៅទំនប់នោះបានត្រឹមតែបីខែប៉ុណ្ណោះ[2067]។ តាមការលើកឡើងរបស់ ខៀវ សំផន[2068]បានឱ្យដឹងថា លោកស្រីមានអាយុទើបតែ ១១ ឆ្នាំ ក្នុងឆ្នាំ ១៩៧៥ ពីព្រោះលោកស្រីបានកើតក្នុងឆ្នាំ ១៩៦៤[2069]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាឃើញថា អាយុរបស់លោកស្រីនៅពេលនោះបានប៉ះពាល់ដល់ការសង្កេតរបស់គាត់ឡើយ។

v. សាក្សី អ៊ុំ ជី បានផ្តល់សក្ខីកម្មថា "ប្រជាជនដែលឈឺធ្ងន់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យស្រុក។ អ្នកខ្លះបានធូរស្រាល និងខ្លះអត់ និងខ្លះបានស្លាប់នៅមន្ទីរពេទ្យ"[2070]។ គាត់ពុំត្រូវបានសួរបន្ថែមលើប្រភពព័ត៌មានដែលគាត់បានដឹងនៃចម្លើយរបស់គាត់ឡើយ។

vi. កំណត់ហេតុស្តាប់ចម្លើយរបស់ អៀង ឆាំ បានឆ្លើយថា មានមនុស្សឈឺជាច្រើននាក់ និងថា គ្រូពេទ្យក្មេងៗ និងថា "ប្រហែលជាគ្មានចំណេះដឹង និងបទពិសោធន៍ទេ"។ នៅពេលសួរថាតើ គាត់បានឃើញអ្នកជំងឺស្លាប់ដោយសារការព្យាបាលរបស់គ្រូពេទ្យទាំងនោះ ដែរ ឬទេ គាត់បានឆ្លើយថា៖ "តាមអ្វីដែលគាត់បានឃើញថា មានមនុស្សច្រើនធ្វើការនៅកន្លែងខ្លះ ខ្វះអនាម័យ គ្មានអាហារគ្រប់គ្រាន់ គ្រូពេទ្យគ្មានគុណភាព ឬចំណេះដឹង។ ទាំងនេះគឺជាមូលហេតុដែលបានបណ្តាលឱ្យអ្នកជំងឺស្លាប់"[2071]។ បើទោះបីជា ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែជ្រើសរើសផ្នែកនៃចម្លើយដែលដាក់បន្ទុកក៏ដោយ[2072] ក៏គាត់ពុំបានពន្យល់ថា តើផ្នែកណាខ្លះនៃចម្លើយនោះជា

[2066] ប្រតិចារឹកចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ (សៀង សុវីដា) ឯកសារលេខ E1/308.1 ទំព័រ ១៩-២០,៥១។

[2067] ប្រតិចារឹកចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ (សៀង សុវីដា) ឯកសារលេខ E1/308.1 ទំព័រ ២១។

[2068] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៧៥។

[2069] ប្រតិចារឹកចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ (សៀង សុវីដា) ឯកសារលេខ E1/308.1 ទំព័រ ៣។

[2070] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ (អ៊ុំ ជី) ឯកសារលេខ E1/326.1 ទំព័រ ៥២។ វង់ក្រចកក្នុងសេចក្តីដកស្រង់បង្ហាញការកែតម្រូវលើការបកប្រែដើម្បីឱ្យស៊ីសង្វាក់ទាំងបីភាសានៃប្រតិចារឹក។ ការកែតម្រូវបានផ្អែកលើកំណត់ត្រាជាសម្លេងនៃភាសាដើម។

[2071] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ឆាំ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ E3/5513 ទំព័រ ១១-១២ ERN 00402448-00402449។

[2072] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៧៦។

ភស្តុតាងដោះបន្ទុក ឬថាតើ បានប៉ះពាល់យ៉ាងដូចម្តេចដល់ចម្លើយដែលថា ការស្លាប់បានកើតឡើងដោយសារការដាក់លក្ខខណ្ឌនោះឡើយ។

vii. កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី វ៉ាន់ ថេង បានអះអាងថា នៅការដ្ឋានធ្វើការ"អ្នកខ្លះស្លាប់ដោយសារហេវហត់អស់កម្លាំង គ្មានអាហារគ្រប់គ្រាន់ និងថ្នាំពេទ្យគ្មានគុណភាព និងប្រសិទ្ធភាព"[2073]។

viii. សាក្សី ស៊ូ សឿន បានផ្តល់សក្ខីកម្មថា អ្នកធ្វើការដែលឈឺធ្ងន់ធ្ងរត្រូវបញ្ជូនទៅពេទ្យរដ្ឋខេត្តកំពង់ឆ្នាំង[2074] ប៉ុន្តែនៅពេលសួរសំណួរនេះម្តងទៀត គាត់ថា គាត់ពុំបានដឹងនោះទេ៖ "ខ្ញុំគ្រាន់តែដឹងថាប្រជាជនដែលឈឺក្នុងស្រុកខ្ញុំត្រូវបញ្ជូនទៅពេទ្យ។ ខ្ញុំអត់បានដឹងថាគេបញ្ជូនទៅណាចំពោះអ្នកជំងឺនៅការដ្ឋានទំនប់១មករា។ [...] តាមខ្ញុំចាំ អ្នកដែលឈឺនៅការដ្ឋានទំនប់១មករា ត្រូវបញ្ជូនត្រឡប់ទៅសហករណ៍រៀងៗខ្លួនវិញក្រោយពីបញ្ជូនទៅមន្ទីរពេទ្យ"[2075]។

ix. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា បុរសម្នាក់ដែលគាត់ស្គាល់ច្បាស់មកពីភូមិជាមួយគាត់ បានស្លាប់ដោយសារធ្វើការធ្ងន់[2076]។ គាត់ធ្លាក់ខ្លួនឈឺនៅការដ្ឋានធ្វើការ និងបានស្លាប់ក្រោយពេលត្រឡប់ទៅភូមិបានប្រហែលពីរសប្តាហ៍ក្រោយមក[2077]។

x. សាក្សី អ៊ុំ សេង បានប្រាប់ឈ្មោះមនុស្សមួយចំនួនក្នុងកងរបស់គាត់នៅការដ្ឋានទំនប់១មករាដែលគាត់ជិតដិតជាមួយ និងបានឆ្លើយថា ពីរនាក់បានស្លាប់ដោយសារជំងឺ[2078]។ គាត់ពុំត្រូវបានសួរ

---

[2073] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ថេង ឯកសារលេខ E3/5249 ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ទំព័រ ២-៣ ERN 00229062-00229063។

[2074] ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ (ស៊ូ សឿន) ឯកសារលេខ E1/310.1 ទំព័រ ៥១-៥២។

[2075] ប្រតិចារឹកចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ (ស៊ូ សឿន) ឯកសារលេខ E1/310.1 ទំព័រ ៥៦។ វង់ក្រចកក្នុងសេចក្តីដកស្រង់បង្ហាញការកែតម្រូវលើការបកប្រែដើម្បីឱ្យស៊ីសង្វាក់ទាំងបីភាសានៃប្រតិចារឹក។ ការកែតម្រូវបានផ្អែកលើកំណត់ត្រាជាសម្លេងនៃភាសាដើម។

[2076] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ (ហ៊ុន សិត្ថានី) ឯកសារលេខ E1/306.1 ទំព័រ ៧។

[2077] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ (ហ៊ុន សិត្ថានី) ឯកសារលេខ E1/306.1 ទំព័រ ៧, ៤៥-៤៦។

[2078] ប្រតិចារឹកចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៥ (អ៊ុំ សេង) ឯកសារលេខ E1/309.1 ទំព័រ ៣១។

សំណួរបន្ថែមទៀតពាក់ព័ន្ធទៅនឹងការស្លាប់នោះ ទោះជាយ៉ាងណាក្តីមុនពេលឆ្លើយនេះ គាត់បានពិភាក្សាប្រភេទជំងឺដែលអ្នកធ្វើការនោះបានទទួលរងយ៉ាងលម្អិត[2079]។

729. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងនេះក្នុងការយល់ឃើញផ្នែកច្បាប់របស់ខ្លួនពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងមានភស្តុតាងរបស់សាក្សី កែ ពេជ្រវណ្ណៈ កូនប្រុសរបស់ កែ ពក ដែលគ្រប់គ្រងការដ្ឋានទំនប់នោះ បាន"អះអាងចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គាត់បានស្គាល់អ្នកជំងឺនៅការដ្ឋានដែលស្លាប់ដោយសារខ្វះថ្នាំពេទ្យ និងបានជូនដំណឹង កែ ពក ប៉ុន្តែគាត់ពុំបានបញ្ជាក់ថា មានមនុស្សប៉ុន្មាននាក់បានស្លាប់នោះទេ"[2080]។

730. ផ្អែកលើភស្តុតាងក្នុងកំណត់ត្រា អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា ជាការដែលអាចធ្វើទៅរួចក្នុងការបង្កើតការយល់ឃើញជាក់លាក់ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "មានអ្នកធ្វើការយ៉ាងតិចពីប្រាំមួយទៅដប់នាក់"បានស្លាប់ដោយសារការដាក់លក្ខខណ្ឌនោះ។ អ៊ុំ ជី និង អៀង ឆាំ បានលើកឡើងអំពីការស្លាប់ក្នុងន័យទូទៅដោយគ្មានការសំដៅទៅលើចំនួនជាក់លាក់ រីឯ ហ៊ុន សិត្ថានី បានសំដៅទៅលើបុរសម្នាក់ដែលគាត់បានស្គាល់នោះ បានស្លាប់ដោយសារការធ្វើការធ្ងន់ និង អ៊ុត សេង បានសំដៅទៅលើបុគ្គលពីរនាក់ដែលបានស្លាប់ដោយសារជំងឺ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា ការដែលពុំអាចកំណត់ការស្លាប់ផ្អែកលើភស្តុតាងបានធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញដែលថា អ្នកធ្វើការបានស្លាប់ដោយសារការដាក់លក្ខខណ្ឌ ឬថា មានការស្លាប់ជាច្រើនទៀតបានកើតឡើងនោះឡើយ។ បើទោះបីជាមានភស្តុតាងជាច្រើនខាងលើសំដៅទៅលើប្រជាជនដែលឈឺ ឬហេវហត់អស់កម្លាំង ជាជាងការស្លាប់ក៏ដោយ ក៏ភស្តុតាងនេះបានគាំទ្រការសន្និដ្ឋានថា ការដាក់លក្ខខណ្ឌនោះបានបណ្តាលឱ្យមានជំងឺតម្កាត់ និងប៉ះពាល់សុខភាព។ ភស្តុតាងនេះបូករួមជាមួយនឹងភស្តុតាងដែលសំដៅជាក់លាក់ទៅលើការស្លាប់ដោយសារជំងឺ និងការហេវហត់អស់កម្លាំង ព្រមទាំងភស្តុតាងដទៃទៀតដែលត្រូវបានស្តាប់ដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងលក្ខខណ្ឌដ៏អាក្រក់នោះ អាចនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយសមហេតុផលថា មានការស្លាប់បានកើតឡើង។ ការជំទាស់របស់ ខៀវ សំផន ទៅលើភស្តុតាងនោះ ពុំមានលក្ខណៈគ្រប់គ្រាន់អាចបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង

[2079] ប្រតិចារឹកចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៥ (អ៊ុត សេង) ឯកសារលេខ E1/309.1 ទំព័រ ២៣-២៥។

[2080] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧០ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី (កែ ពេជ្រវណ្ណៈ) ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារលេខ E3/25 ទំព័រ ៥-៦។

បានឡើយ។ ទាក់ទងទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "អ្នកធ្វើការចំនួនដ៏ច្រើនបានស្លាប់ដោយសារលក្ខខណ្ឌទាំងនេះ"[2081] អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញត្រឹមត្រូវ។ ទោះជាយ៉ាងណាក្តីអង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា ជាការចាំបាច់ក្នុងការដោះស្រាយបញ្ហានេះ ដោយសារការបង្ហាញនូវអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំបានតម្រូវឱ្យមានការស្លាប់ក្នុងចំនួនជាក់លាក់ឡើយ។

731. ទាក់ទងទៅនឹងភស្តុតាងនៃការស្លាប់ដោយសារគ្រោះថ្នាក់ចៃដន្យនៅការដ្ឋានធ្វើការ អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិភាក្សាម្តងទៀតទៅលើភស្តុតាងដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង៖

i. មាស ឡៃហួរ បានផ្តល់សក្ខីកម្មថា លោកស្រីបានឃើញការបាក់ដីសង្កត់មនុស្សស្លាប់[2082]។ បន្ទាប់ពីបានផ្តល់ភស្តុតាងបន្ថែម លោកស្រីបានអះអាងថា ការបាក់ដីបានសម្លាប់មនុស្ស បើទោះបីជាពុំមានលក្ខណៈច្បាស់លាស់ថាតើ លោកស្រីបានឃើញព្រឹត្តិការណ៍នោះផ្ទាល់ភ្នែក ដែរ ឬយ៉ាងណាក៏ដោយនោះ៖

ខ្ញុំធ្លាប់ឃើញ ខ្ញុំទៅរែកដីនៅការដ្ឋានធ្វើការ ដូចដីអីចឹងយើងកាប់ទៅ អ្នកនៅកាប់ពីក្រោមអីចឹងទៅវារលំដីពីលើមកសង្កត់ងាប់។ ខ្ញុំធ្លាប់ឃើញអីចឹង តែមិនមែននៅក្នុងសង្កាត់ខ្ញុំទេ សង្កាត់គេ។ នៅម្ដុំៗម្នាក់។ គេរែកភូមិគេ យើងរែកភូមិយើង។ ភូមិគេហ្នឹងឯងដីធ្លាក់ពីលើមកសង្កត់ងាប់ទៅ។ អ្នកកាប់មិនមែនអ្នករែកទេ។ [...] អ្នកខ្លះដីសង្កត់ចំទៅដំថ្មមកពីលើទៅក៏ងាប់ទៅ អ្នកខ្លះក៏គ្រាន់តែរបួសបាក់ដៃបាក់ជើង។ អ្នកខ្លះក៏រស់ អ្នកខ្លះក៏ងាប់ទៅ។ អ្នកដែលសង្កត់ដីខ្លាំងទៅងាប់។ ទម្រាំតែកាយចេញដាច់ដង្ហើមងាប់ហើយ[2083]។

ii. ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា ការបាក់ដីបានកើតឡើងពីព្រោះគេជីកជ្រៅពេក និងជាការប្រឡងប្រណាំងធ្វើការថា នរណាបានលឿនជាង។ លោកស្រីបានអះអាងថា លោកស្រីពុំបានឃើញព្រឹត្តិការណ៍នោះ ប៉ុន្តែមានគេប្រាប់គាត់ថា មានមនុស្សស្លាប់ដោយសារការបាក់ដីនោះ[2084]។

---

[2081] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦២៤។

[2082] ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/304.1 ទំព័រ ៤៩-៥០។

[2083] ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ១៣។ វង់ក្រចកក្នុងសេចក្តីដកស្រង់បង្ហាញការកែតម្រូវលើការបកប្រែដើម្បីឱ្យស៊ីសង្វាក់ទាំងបីភាសានៃប្រតិចារឹក។ ការកែតម្រូវបានផ្អែកលើកំណត់ត្រាជាសម្លេងនៃភាសាដើម។

[2084] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ (ហ៊ុន សិត្ថានី) ឯកសារលេខ E1/305.1 ទំព័រ ៧១។

iii. អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថា លោកស្រីបានឮអំពីព្រឹត្តិការណ៍នោះ ប៉ុន្តែពុំបានឃើញការបាក់ដីនោះផ្ទាល់ដែលសង្កត់អ្នកធ្វើការបីនាក់ និងម្នាក់ស្លាប់នៅហ្នឹងកន្លែង[2085]។

iv. អ៊ុត សេង បានផ្ដល់សក្ខីកម្មផងដែរថា បើទោះបីជាគាត់ពុំបានឃើញផ្ទាល់ក៏ដោយ ក៏គាត់បានឮការបាក់ដីនោះដែលបណ្ដាលឱ្យមនុស្សស្លាប់។ គាត់ពុំបានដឹងចំនួនអ្នកធ្វើការដែលបានស្លាប់ ឬរបួសនោះទេ[2086]។

v. ដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ បានផ្ដល់សក្ខីកម្មថា គ្មានមនុស្សស្លាប់ក្នុងកងចល័តរបស់គាត់សម្រាប់រយៈពេលប្រាំមួយទៅប្រាំពីរខែនៃការធ្វើការនៅការដ្ឋានទំនប់នោះ ប៉ុន្តែលោកស្រីបានឃើញការបាក់ដីនោះផ្ទាល់[2087]។ លោកស្រីពុំត្រូវបានសួរសំណួរបន្ថែមពាក់ព័ន្ធបញ្ហានេះឡើយ[2088]។

vi. សាក្សី ឱ ហួ បានផ្ដល់សក្ខីកម្មថា មានសមាជិកខ្លះក្នុងកងរបស់គាត់បានស្លាប់ដោយសារការបាក់ដីនៅការដ្ឋានធ្វើការនោះដែលកប់មនុស្សទាំងរស់[2089]។ គាត់បានផ្ដល់សក្ខីកម្មថា អ្នកធ្វើការប្រឡងប្រណាំងគ្នា និងជួនកាលធ្វើការពេលយប់ និងថា ដីដែលនៅផ្នែកខាងលើទំនប់បានបាក់ធ្លាក់លើពួកគេកំពុងធ្វើការខាងក្រោម[2090]។ គាត់បានអះអាងថា មានអ្នកធ្វើការម្នាក់បានស្លាប់នៅហ្នឹងកន្លែង ខណៈពីរនាក់ទៀតបានស្លាប់ក្រោយមកដោយសារព្រឹត្តិការណ៍នោះ[2091]។

732. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បើទោះបីជាសក្ខីកម្មជាច្រើននោះគឺជាពាក្យចចាមអារ៉ាមក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងទៅលើនោះដោយបូករួមជាមួយនឹងភស្តុតាងផ្ទាល់នៅពេលសក្ខីកម្មទាំងនេះបញ្ជាក់បន្ថែមគ្នាទៅវិញទៅមក និងការពិតដែលថា យ៉ាងហោចណាស់មានការស្លាប់ម្នាក់ដោយសារការបាក់ដីនោះ ទំនងជាបានកើតឡើងក្នុងព្រឹត្តិការណ៍នោះ។

---

[2085] ប្រតិចារិកចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ (អ៊ុន រ៉ន) ឯកសារលេខ E1/307.1 ទំព័រ ១១។

[2086] ប្រតិចារិកចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ (អ៊ុត សេង) ឯកសារលេខ E1/309.1 ទំព័រ ៣៩-៤០។

[2087] ប្រតិចារិកចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ (នួន ណារុំ) ឯកសារលេខ E1/339.1 ទំព័រ ២៥, ៣២។

[2088] ប្រតិចារិកចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ (នួន ណារុំ) ឯកសារលេខ E1/339.1 ទំព័រ ២៣, ២៩-៣០។

[2089] ប្រតិចារិកចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/301.1 ទំព័រ ៣៤-៣៥, ៥៩-៦០។ ប្រតិចារិកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/302.1 ទំព័រ ១៨-១៩។

[2090] ប្រតិចារិកចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/301.1 ទំព័រ ៣៤-៣៥, ៥៩។ ប្រតិចារិកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/302.1 ទំព័រ ១៨-១៩។

[2091] ប្រតិចារិកចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/301.1 ទំព័រ ៥៩-៦០។

733. ទាក់ទងទៅនឹង*ធាតុផ្សំអត្ថនោម័តិ* ក្នុងការយល់ឃើញថា ថ្នាក់ដឹកនាំ និងមជ្ឈិមបក្សបានដឹងថា មានកង្វះអាហារ និងថ្នាំពេទ្យនៅការដ្ឋានទំនប់១មករា ប៉ុន្តែនៅតែបន្តជម្រុញឱ្យអ្នកធ្វើការបំពេញការងារពេញមួយរដូវប្រាំងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដោយធ្វើការទាំងយប់ទាំងថ្ងៃនោះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ៖

i. សក្ខីកម្មរបស់សាក្សីជាច្រើនដែលបានផ្តល់សក្ខីកម្មថា ការដ្ឋានទំនប់១មករាត្រូវបានចាត់ទុកថាជា"សមរភូមិក្តៅ" នេះមានន័យថា មានការកំណត់ម៉ោង និងកាលបរិច្ឆេទតឹងរ៉ឹងត្រូវគោរពដែលតម្រូវឱ្យធ្វើការទាំងយប់នោះ[2092]។

ii. ទស្សនាវដ្តីទង់បដិវត្តដែលបានបញ្ជាក់ថា នៅកន្លែងខ្លះ បញ្ហាបាយទឹកមិនទាន់សម្រេចបានទៅតាមរបបកំណត់នៅឡើយទេ និងថា កន្លែងណាខ្វះបាយទឹកត្រូវតែមានដំណោះស្រាយ[2093]។

iii. អត្ថបទចំណងជើងថា "សេចក្តីអធិប្បាយស្តីពីការបញ្ចប់ការងារប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង" ក្នុងកម្រងសារព័ត៌មាន FBIS (សេវាកម្មផ្សព្វផ្សាយព័ត៌មានបរទេស) ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៧៧[2094] ដែលបានបញ្ជាក់*ក្នុងចំណោមនោះ*ថា៖

ភារកិច្ចសំខាន់របស់កសិករសហករណ៍យើងនៅរដូវប្រាំងនេះ គឺកសាងប្រព័ន្ធស្រោចស្រពឱ្យបានច្រើនជាងឆ្នាំ ១៩៧៦។ ដោយក្តាប់ឱ្យបាននូវសារៈសំខាន់នៃទិសដៅថ្មីនេះ បងប្អូនកសិករសហករណ៍យើងទូទាំងប្រទេសបានចូលរួមយ៉ាងខ្លាំងក្លា ក្នុងការសាងសង់ទំនប់ប្រឡាយ ទាំងយប់ទាំងថ្ងៃ យ៉ាងសស្រាក់សស្រាំបំផុត[2095]។

---

[2092] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧១ ដកស្រង់*ក្នុងចំណោម*កថាខណ្ឌ ១៥០៤ យោងទៅលើសាក្សីដកស្រង់ក្នុងផ្នែក ១១.២.១១.៣: បទពិសោធន៍របស់អ្នកធ្វើការនៅទំនប់១មករា។

[2093] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៧១ ដកស្រង់*ក្នុងចំណោម*កថាខណ្ឌ ១៦៣៩ យោងទៅលើទង់បដិវត្ត ខែ កញ្ញា ដល់ តុលា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/170 ERN (អង់គ្លេស) 00182560។

[2094] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣៩ យោងទៅលើសេចក្តីអធិប្បាយស្តីអំពីការបញ្ចប់ការងារប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/287 ERN 00168139-00168140។

[2095] សេចក្តីអធិប្បាយស្តីអំពីការបញ្ចប់ការងារប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី០៩ ខែឧសភា ឆ្នំ១៩៧៧ ឯកសារលេខ E3/287 ERN 00168139-00168140។

ភារកិច្ចនេះសំដៅផងដែរទៅលើ“ការលះបង់ធំធេងនូវគំរូវីរភាពបដិវត្តដ៏ខ្ពង់ខ្ពស់ដោយកសិករសហករណ៍យើង”[2096]។

អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងអត្ថបទសារព័ត៌មាន FBIS ពុំមានលក្ខណៈច្បាស់លាស់។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការសាងសង់ទំនប់បានចាប់ផ្ដើមក្នុងចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ និងបានបន្តរហូតដល់ដើមឆ្នាំ ១៩៧៨[2097]។ អត្ថបទសារព័ត៌មាននេះបានបង្ហាញក្នុងន័យទូទៅថា ក្នុងខែ ឧសភា ឆ្នាំ ១៩៧៧ ឆ្នាំដែលអត្ថបទនេះចុះកាលបរិច្ឆេទ មជ្ឈិមបក្សបានដឹងអំពី“ការលះបង់ធំធេង” និងថា ប្រជាជន“ធ្វើការទាំងយប់ទាំងថ្ងៃ”នៅការដ្ឋានទំនប់១មករា[2098]។

734. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី*ធាតុផ្សំអត្តនោម័តិ* ពុំមែនត្រឹមតែបានគាំទ្រដោយភស្តុតាងខាងលើមួយមុខប៉ុណ្ណោះទេ។ បើទោះបីជាពុំត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់របស់ខ្លួនស្ដីពី*ធាតុផ្សំអត្តនោម័តិ* ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ កែ ពេជ្រវណ្ណៈ ដែលបានឆ្លើយចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គាត់បានជូនដំណឹងឪពុករបស់គាត់ កែ ពក ថា ប្រជាជនបានស្លាប់ដោយសារខ្វះថ្នាំពេទ្យ[2099] ហើយអង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញថា “ដោយសារទំនាក់ទំនងស្និទ្ធស្នាលផ្ទាល់ខ្លួនរវាង កែ ពេជ្សវណ្ណៈ និង កែ ពក និងដោយសារការគ្រប់គ្រងផ្ទាល់លើការដ្ឋាន [...] កែ ពក បានដឹងផងដែរអំពីកង្វះថ្នាំពេទ្យនៅការដ្ឋានទំនប់១មករា”[2100]។ ពិតណាស់ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតផ្នែកមួយនៃសាលក្រមរបស់ខ្លួនសម្រាប់“ការដឹងរបស់ កែ ពក និងថ្នាក់លើអំពីលក្ខខណ្ឌការរស់នៅ និងការងារនៅការដ្ឋានទំនប់១មករា”[2101]។ ផ្នែកនោះបានសំដៅទៅលើទំនាក់ទំនងរវាង កែ ពក និងថ្នាក់លើស្ដីពីកង្វះស្បៀងអាហារ និងថ្នាំពេទ្យ ហើយអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “កែ ពក បានជូនដំណឹងផង

---

[2096] សេចក្ដីអធិប្បាយស្ដីអំពីការបញ្ចប់ការងារប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/287 ERN 00168139-00168140។

[2097] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៤៧។

[2098] សេចក្ដីអធិប្បាយស្ដីអំពីការបញ្ចប់ការងារប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/287 ERN 00168139-00168140។

[2099] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦២៤។

[2100] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣១។

[2101] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១១.២.២០។

ដែរដល់មជ្ឈិមបក្សអំពីការលំបាកជាក់លាក់ដែលជួបប្រទះនៅការដ្ឋានធ្វើការទំនប់១មករា"[2102]។ ពុំមានការបង្ហាញច្បាស់លាស់នូវមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើផ្នែកនេះនៃសាលក្រមនៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់របស់ខ្លួនស្តីពី*ធាតុផ្សំអត្តនោម័តិ* ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការជាប់ពាក់ព័ន្ធ និងបានគាំទ្រដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលទំនងជាការយល់ឃើញមួយដែលតុលាការអង្គហេតុសមហេតុផលអាចធ្វើទៅបានដោយផ្អែកលើភស្តុតាងនេះ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅការដ្ឋានទំនប់១មករា ត្រូវបដិសេធចោល។

ឃ. ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

735. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការដាក់លក្ខខណ្ឌនោះបានបណ្តាលឱ្យមានការស្លាប់ មនុស្សជាច្រើន រួមទាំងការដាក់ប្រជាជនឱ្យស្ថិតក្នុងលក្ខខណ្ឌការងារគ្មានសុវត្ថិភាព និងបានបង្ខំឱ្យពួកគេធ្វើការច្រើនម៉ោងបន្ថែមដោយគ្មានអាហារគ្រប់គ្រាន់"[2103]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌធ្វើការនិងរស់នៅដោយផ្អែកលើ"ការដាក់លក្ខខណ្ឌលើអ្នកធ្វើការដែលបានបង្កឱ្យមានការស្លាប់ និងដោយគ្មានវិធានការសមស្របកែប្រែ ឬសម្រាលលក្ខខណ្ឌនោះ"[2104]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ* នៃ *ចេតនាប្រយោល* ត្រូវបានបំពេញដោយសារការរក្សាទុកលក្ខខណ្ឌសម្រាប់រយៈពេលយូររួមទាំងក្រោយពីមានផលប៉ះពាល់អវិជ្ជមានបានកើតឡើងនោះបានបង្ហាញថា អាជ្ញាធរនៅមូលដ្ឋាននោះមានឆន្ទៈដាក់លក្ខខណ្ឌដោយដឹងថា ទំនងជាបណ្តាលឱ្យមានការស្លាប់ ឬដោយទទួលយកភវនីយភាពនៃផលវិបាកនៃការស្លាប់នោះ[2105]។

736. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវាយតម្លៃរបស់ខ្លួនអំពី*ធាតុផ្សំអត្តនោម័តិ*ពីព្រោះអង្គជំនុំជម្រះសាលាដំបូងគប្បីចាប់ផ្តើមការវាយតម្លៃនោះចេញពីទស្សនៈទានរបស់ចារី និងថា "ទំនាក់ទំនងហេតុ និងផលរវាងវិធានការដែលត្រូវបានអនុវត្តដោយឆន្ទៈរបស់អាជ្ញាធរក្នុងការក

[2102] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៣៣។

[2103] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨០០។

[2104] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨០៤។

[2105] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨០៥។

សាងប្រទេសឡើងវិញ និងកត្តានានាដែលកើតឡើងហួសពីការគ្រប់គ្រងរបស់អាជ្ញាធរនោះ ជាការមិនអាចកំណត់បានឡើយ”[2106]។

737. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អាជ្ញាធរមូលដ្ឋានបានដឹងអំពីលក្ខខណ្ឌនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំងតាមរយៈការសាងសង់ ប៉ុន្តែពុំមានឆន្ទៈក្នុងការសម្របសម្រួលលក្ខខណ្ឌ និងពុំបានអើពើទៅលើវាសនារបស់អ្នកធ្វើការ ដូច្នេះ បានបំពេញតាមលក្ខខណ្ឌនៃ*ធាតុផ្សំអត្តនោម័តិ*[2107]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការស្លាប់អាចត្រូវបានជៀសវាងបានប្រសិនបើអាជ្ញាធរបានសម្របសម្រួលម៉ោងធ្វើការ ឬលើកកម្ពស់សុវត្ថិភាព និងលក្ខខណ្ឌរស់នៅ ប៉ុន្តែពួកគេពុំមានបំណងធ្វើដូច្នោះឡើយ[2108]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការកំណត់កត្តាខាងក្រៅណាមួយដែលអាចធ្វើឱ្យទំនាក់ទំនងហេតុ និងផលរវាងលក្ខខណ្ឌ ជាមួយនឹងការស្លាប់គ្មានសុពលភាពឡើយ[2109]។

738. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហាថាតើ មានទំនាក់ទំនងហេតុ និងផលរវាងសកម្មភាពរបស់ចារី ជាមួយនឹងការស្លាប់របស់ជនរងគ្រោះ និងថាតើ មានកត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរ ដែរ ឬយ៉ាងណា ពុំមានភស្តុតាងគាំទ្រឡើយ និងត្រឹមតែបង្ហាញនូវការមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។ នេះជាការពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការយល់ឃើញដែលគ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាននោះឡើយ។ ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ង. មន្ទីរសន្តិសុខភ្នំក្រោល

739. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតពីរករណីត្រូវបានបង្ហាញនៅមន្ទីរសន្តិសុខភ្នំក្រោល។ អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី អ៊ួង ដុស និង សុខ

---

[2106] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២៣។ ខៀវ សំផន បានលើកអំណះអំណាងដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើឧបទ្ទវហេតុនៅកន្លែងធ្វើការ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១៨។ អំណះអំណាងនេះត្រូវបានដោះស្រាយស្របជាមួយនឹងអំណះអំណាងដទៃទៀតដែលពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះ។ *សូមមើលខាងលើ* ផ្នែក VI.២.ខ។

[2107] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤០។

[2108] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤០។

[2109] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤០។

អ៊ែល អតីតអ្នកជាប់ឃុំនៅមន្ទីរឃុំឃាំងភ្នំក្រោលដែលបច្ចុប្បន្នបានទទួលមរណភាព[2110] ព្រមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេបានដាក់ក្នុងសំណុំរឿងបន្ទាប់ពីត្រូវបានសួរដោយសហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា អ្នកជាប់ឃុំឈ្មោះ ហ៊ើស ត្រូវបានសម្លាប់ដោយសន្តិសុខនៅមន្ទីរឃុំឃាំងភ្នំក្រោល[2111]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗបានបញ្ជាក់អះអាងបន្ថែមគ្នាទៅវិញទៅមកលើ“ទិដ្ឋភាពសំខាន់ៗនៃហេតុការណ៍ រួមទាំងអត្តសញ្ញាណជនរងគ្រោះ លក្ខណៈនៃការវាយប្រហារលើជនរងគ្រោះ និងលក្ខខណ្ឌនៃការស្លាប់ និងវិធានការបន្ទាប់ទៅលើសាកសព”[2112]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អ៊ួង ឌុស និង សុខ អ៊ែល បានឃើញផ្ទាល់នូវការវាយប្រហារនោះ និងបានយល់ឃើញថា ការរៀបរាប់របស់ពួកគេស៊ីសង្វាក់គ្នា និងគួរជឿជាក់បាន[2113]។ ដោយពិចារណាលើលក្ខណៈឃោរឃៅនៃការវាយប្រហារមុនការស្លាប់របស់ ហ៊ើស ព្រមទាំងការបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយតាមរយៈការចាក់ជនរងគ្រោះនឹងចំពុះទុងកាំភ្លើង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សន្តិសុខមន្ទីរឃុំឃាំងមានចេតនាសម្លាប់ ហ៊ើស[2114]។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ធាតុផ្សំសត្យានុម័ត និង *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតត្រូវបានបង្ហាញ និងអាស្រ័យហេតុនេះបានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការស្លាប់របស់ ហ៊ើស និងថា ការសម្លាប់នេះគ្មានមូលដ្ឋានស្របច្បាប់ឡើយ[2115]។

---

[2110] អ៊ួង ឌុស និង សុខ អ៊ែល ស្ថិតក្នុងបញ្ជីសាក្សីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ប៉ុន្តែក្នុងខែ ឧសភា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងថា អ៊ួង ឌុស បានទទួលមរណភាព និងក្នុងខែ កុម្ភៈ ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានទទួលដំណឹងថា សុខ អ៊ែល បានទទួលមរណភាព។ សំណើរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងសាក្សីជំនុំជម្រះដែលបានស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារលេខ E307/3/2 កថាខណ្ឌ ៦២។ សំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅសាក្សីបន្ថែមក្នុងអំឡុងពេលការជំនុំជម្រះផ្នែកស្ដីពីមន្ទីរសន្តិសុខភ្នំក្រោលថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ E390 កថាខណ្ឌ ២។

[2111] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥ យោងទៅលើកថាខណ្ឌ ៣១០០ ដែលយោងទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ួង ឌុស ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ E3/7703 ទំព័រ ៣-៤។ កំណត់ហេតុស្ដាប់ចម្លើយ សុខ អ៊ែល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ E3/7702 ទំព័រ ៣, ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ៊ួង ឌុស ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ E3/6260 ទំព័រ ៣-៤ និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សុខ អ៊ែល ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ E3/6314 ទំព័រ ៣។

[2112] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០។

[2113] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០០, ៣១១៥។

[2114] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥។

[2115] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៥, ៣១១៧។

740. ទាក់ទងទៅនឹងអំពើមនុស្សឃាតទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផ្អែកលើមូលដ្ឋាននៃកំណត់ហេតុស្តាប់ចម្លើយរបស់ សុខ អ៊ែល អ្នកជាប់ឃុំឈ្មោះ ទូច បានស្លាប់ដោយសារលក្ខខណ្ឌធ្ងន់ធ្ងរដែលគាត់បានទទួលរងខណៈពេលជាប់ឃុំនៅមន្ទីរឃុំឃាំងភ្នំក្រោល[2116]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា "ការដាក់អ្នកជាប់ឃុំដោយចេតនាឱ្យស្ថិតក្រោមលក្ខខណ្ឌដ៏អាក្រក់ ឬខកខានក្នុងការកែប្រែលក្ខខណ្ឌនៃការឃុំឃាំងនោះ ឬវិធានការអនាម័យ គឺជាការពុំអើពើច្បាស់លាស់ទៅលើអាយុជីវិតមនុស្សពីសំណាក់បុគ្គលិកគ្រប់គ្រងមន្ទីរសន្តិសុខ ដូច្នេះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំ *ចេតនាប្រយោល*"[2117]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា *ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតត្រូវបានបង្ហាញ និងអាស្រ័យហេតុនេះបានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញទាក់ទងទៅនឹងការស្លាប់របស់ ទូច[2118]។

741. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ការស្លាប់របស់ ហ៊ើស ត្រូវបានបង្ហាញដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយពីរ បើទោះបីជាការពិតថា គាត់ពុំអាចសួរដេញដោលលើភស្តុតាងនេះក្នុងតុលាការក៏ដោយ[2119]។ គាត់បានលើកឡើងថា ដោយសារកំណត់ហេតុស្តាប់ចម្លើយនោះត្រូវបានរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងពេល និងទីកន្លែងតែមួយដែលការសួរយកចម្លើយមួយបានកើតឡើងនៅម៉ោង ១០ និង ១០ នាទីព្រឹក ហើយមួយទៀតនៅម៉ោង ១០ និង ១៥ នាទីព្រឹកដែលអាចមានលទ្ធភាពនៃការសមគំនិតគ្នា ឬយ៉ាងហោចណាស់ជាការចម្លងគ្នានូវចម្លើយទាំងពីរនេះ[2120]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើគោលការណ៍ដេញដោលចំពោះមុខ និងសមភាពនៃកម្លាំងតទល់ចំពោះមុខច្បាប់ ដោយសារការបង្ហាញអំពើមនុស្សឃាតដោយផ្អែកលើភស្តុតាងដែលគាត់ពុំបានសួរសដេញដោល ហើយគាត់បានដកស្រង់យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ដែលបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវត្រូវបានរំលោភបំពាននៅពេលការដាក់ពិរុទ្ធភាពបានផ្អែកលើភស្តុតាងដែលពុំដាក់ឱ្យស្ថិតក្រោមការសួរដេញដោលចំពោះមុខ និងទៅលើមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលចែងថា "ចៅក្រមអាចសំអាង

---

[2116] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៦ យោងទៅលើ កថាខណ្ឌ ៣១០១ ដកស្រង់កំណត់ហេតុស្តាប់ចម្លើយ សុខ អ៊ែល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ E3/7702 ទំព័រ ២-៣។

[2117] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៦។

[2118] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៦-៣១១៧។

[2119] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៥។

[2120] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៦។

សេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលបានប្រគល់ជូននៅក្នុងអំឡុងពេលដេញដោល និងពិភាក្សាតទល់គ្នាចំពោះមុខប៉ុណ្ណោះ”[2121]។

742. បន្ទាប់មក ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ទូច ត្រូវបានសម្លាប់ដោយ*ចេតនាប្រយោល* ដោយផ្អែកលើកំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព[2122]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ ថា អង្គជំនុំជម្រះអាចប្រើប្រាស់ចម្លើយរបស់បុគ្គលដែលបានទទួលមរណភាព ប៉ុន្តែពុំផ្អែកការដាក់ពិរុទ្ធភាពណាមួយទៅលើភស្តុតាងនេះជាសំខាន់ឡើយ និងថា អង្គជំនុំជម្រះតុលាការកំពូលបានមោឃៈវិធីសាស្ត្រនេះ[2123]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ដល់ហេតុផលណាមួយដែលត្រូវប្រាសចាកពីវិធីសាស្ត្រនេះដោយបានបញ្ជាក់ថា សុខ អ៊ែល គួរជឿជាក់បាន បើទោះបីជាការពិតថា ចម្លើយរបស់គាត់ក្នុងឆ្នាំ ២០០៨ ពុំត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងដទៃទៀតនោះឡើយ[2124]។

743. ចុងក្រោយ ខៀវ សំផន បានលើកឡើងថា នៅក្នុងការយល់ឃើញថា អំពើមនុស្សឃាតពីរករណីត្រូវបានបង្ហាញ អង្គជំនុំជម្រះសាលាដំបូងទំនងជាពុំបានអើពើដោយចេតនាទៅលើភស្តុតាងដោះបន្ទុក ជាពិសេសសភស្តុតាងរបស់អតីតអ្នកជាប់ឃុំឈ្មោះ ចាន់ តួច ដែលបានបង្ហាញថា តាមដែលគាត់ដឹង អ្នកដែលបានជាប់ឃុំជាមួយគាត់ អត់មានយកទៅសម្លាប់ទេ និងអតីតអ្នកជាប់ឃុំ ណោត សាវ៉ាត ដែលបានឆ្លើយថា គាត់ពុំបានឃើញផ្ទាល់នូវការសម្លាប់នោះឡើយ[2125]។

744. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញផ្នែកអង្គហេតុនៃការស្លាប់របស់ ហើស បានផ្អែកទៅលើភស្តុតាងដែលគ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចទទួលយកបាននោះឡើយ[2126]។ សហព្រះរាជអាជ្ញាបានអះអាងថា កំណត់ហេតុស្ដាប់ចម្លើយបានបញ្ជាក់បន្ថែមទៅវិញទៅមកលើអត្តសញ្ញាណរបស់ជនរងគ្រោះ លក្ខណៈនៃការវាយប្រហារលើជនរងគ្រោះ និងលក្ខខណ្ឌនៃ

---

[2121] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦៨។

[2122] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៧០-៨៧៥។

[2123] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៧១។

[2124] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៧២។

[2125] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៧៦-៨៧៨។

[2126] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦២។

ការស្លាប់ និងវិធានការទៅលើសាកសពនោះ[2127]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានសន្មតបានវាយតម្លៃសមស្របលើភស្តុតាង ហើយអំណះអំណាងរបស់គាត់អំពីការសមគំនិតនោះ គឺគ្រាន់តែជាស្មានប៉ុណ្ណោះ[2128]។ ទាក់ទងទៅនឹងអំណះអំណាងស្តីពីជនរងគ្រោះឈ្មោះ ទូច សហព្រះរាជអាជ្ញាបានលើកឡើងថា ពុំមានគោលការណ៍គតិយុត្តដែលតម្រូវថា ការបញ្ជាក់អះអាងបន្ថែមផ្ទាល់អំពីការស្លាប់ត្រូវបានតម្រូវក្នុងការបង្ហាញនូវអំពើមនុស្សឃាត ហើយភស្តុតាងមិនផ្ទាល់នៃលក្ខខណ្ឌដ៏អាក្រក់ហួសហេតុក្នុងមន្ទីរឃុំឃាំងបានបញ្ជាក់បន្ថែមលើចម្លើយរបស់ សុខ អ៊ែល[2129]។ សហព្រះរាជអាជ្ញាបានអះអាងថា ពុំមានវិធានដាច់ខាតនៃភស្តុតាងតម្រូវថា ចម្លើយជាលាយលក្ខណ៍អក្សរដែលពុំត្រូវបានដាក់ឱ្យស្ថិតក្រោមការសួរដេញដោលពុំអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការដាក់ពិរុទ្ធភាពបានឡើយ[2130]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការយោងជាក់លាក់ទៅលើភស្តុតាងដោះបន្ទុកពុំអាចមោឃៈការយល់ឃើញនេះបានឡើយ ហើយ ខៀវ សំផន ពុំបានបង្ហាញភស្តុតាងដែលចោទជាមន្ទិលសង្ស័យលើការយល់ឃើញស្តីពីអំពើមនុស្សឃាតពីរករណីនេះដែរ[2131]។ សហព្រះរាជអាជ្ញាបានលើកឡើងថា កំហុសពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតនៅភ្នំក្រោលពុំអាចមោឃៈសាលក្រម ឬការកំណត់ទោសបានឡើយ ដោយសារ ខៀវ សំផន ត្រូវបានរកឃើញថា មានពិរុទ្ធពីបទសម្លាប់រង្គាលនៅមន្ទីរស-២១ ក្រាំងតាចាន់ និងនៅអូរកន្សែង និងអំពើមនុស្សឃាតនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[2132]។

745. សហមេធាវីនាំមុខបានជំទាស់ថា បើទោះបីជា អ្នួង ដុស និង សុខ អ៊ែល អ្នកទាំងពីរបានស្លាប់នៅមុនពេលអង្គជំនុំជម្រះសាលាដំបូងអាចស្តាប់សក្ខីកម្មរបស់ពួកគាត់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ និងបានយល់ឃើញថា ស៊ីសង្វាក់គ្នា និងគួរជឿទុកចិត្តបាន[2133]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងបានកម្រិតសារណារបស់ខ្លួនត្រឹមអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសម

---

[2127] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦៣។

[2128] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦៤។

[2129] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦៨។

[2130] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦៩។

[2131] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៦៥, ៨៧១-៨៧២។

[2132] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៧២។

[2133] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៥២។

គំនិតរបស់ អ្នូង ដុស និង សុខ អ៊ែល ឬការចម្លងគ្នានៃកំណត់ហេតុស្តាប់ចម្លើយនោះ[2134]។ សហមេធាវីនាំមុខបានលើកឡើងថា ជាការធម្មតាដែលសហចៅក្រមស៊ើបអង្កេតត្រូវសួរយកចម្លើយសាក្សីច្រើននាក់ក្នុងពេលចុះមូលដ្ឋានមួយលើកៗ និងថា សាក្សីពីរនាក់ត្រូវបានសួរយកចម្លើយក្នុងពេលតែមួយដោយអ្នកស៊ើបអង្កេតផ្សេងគ្នា ដោយគ្មានភស្តុតាងបង្ហាញថា ការសួរយកចម្លើយនោះបានកើតឡើងនៅក្នុងចម្ងាយដែលអាចស្តាប់គ្នាឮទៅវិញទៅមកបាននោះទេ[2135]។ សហមេធាវីនាំមុខបានកត់សម្គាល់ថា បើទោះបីជាចម្លើយដែលផ្តល់ដោយ អ្នូង ដុស និង សុខ អ៊ែល បានបញ្ជាក់បន្ថែមគ្នាទៅវិញទៅមកលើការពិតជាសត្យានុម័តក៏ដោយ ក៏ចម្លើយនោះមានលក្ខណៈលម្អិតផ្សេងៗគ្នា ដែលពុំបានបង្ហាញនូវភាពមិនប្រក្រតីអាចនាំឱ្យមានក្តីបារម្ភអំពីការចម្លងគ្នានោះទេ[2136]។

746. អង្គជំនុំជម្រះតុលាការកំពូលពុំធ្វើការពិចារណាលើការលើកឡើងមិនជាក់លាក់របស់ ខៀវ សំផន ចំពោះការសមគំនិតគ្នារវាង អ្នូង ដុស និង សុខ អ៊ែល ដោយផ្អែកតែលើការដែលថា ពួកគេត្រូវបានសួរយកចម្លើយក្នុងពេលតែមួយនិងក្នុងភូមិតែមួយ។ សហចៅក្រមស៊ើបអង្កេតត្រូវបានសន្មតថា បានធ្វើការស៊ើបអង្កេតសមស្រប ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្តល់ទំនុកចិត្តក្នុងការវាយតម្លៃលើភស្តុតាង។ ប្រសិនបើមានការព្រួយបារម្ភថា ចម្លើយនោះត្រូវបានចម្លងតាមគ្នា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការអះអាងដូច្នោះ។ ត្រឹមតែការស្មានអំពីលទ្ធភាពនៃការសមគំនិតគ្នា ឬការចម្លងតាមគ្នារបស់សាក្សី ពុំគ្រប់គ្រាន់ក្នុងធ្វើឱ្យភស្តុតាងនោះមានមន្ទិលសង្ស័យឡើយ។

747. អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងណាមួយដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង លើកលែងតែមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងអំឡុងពេលសមស្របណាមួយ មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារក្តិចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។ កំណត់ហេតុស្តាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបានជាឧទាហរណ៍ ដោយសារត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយពុំគិតថាតើ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម ឬបានទទួលមរណភាព ឬអ្វីផ្សេងនោះទេ។

[2134] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៥៣-៧៥៤។

[2135] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៥៥។

[2136] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៥៦។

748. បញ្ហាផ្សេងដែលគួរពិចារណានោះ គឺថាតើ ភស្តុតាងនោះគប្បីត្រូវបានផ្តល់ទម្ងន់ប៉ុន្មានទៅលើនៅពេលដែលសាក្សីបានទទួលមរណភាព ឬអ្វីផ្សេងពីនេះ ដោយសារជនជាប់ចោទពុំអាចប្រើប្រាស់សិទ្ធិសួរដេញដោលសាក្សីនោះបាន។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ពីដំបូងថា "ដោយស្របតាមយុត្តិសាស្ត្រគួរជឿទុកចិត្តបានរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការដាក់ពិរុទ្ធភាពពុំអាចត្រូវបានផ្អែកតែ ឬជាសំខាន់ទៅលើភស្តុតាងរបស់សាក្សីដែលជនជាប់ចោទពុំមានឱកាសសួរដេញដោលចំពោះមុខ លើកលែងតែមានកត្តាអាចថ្លឹងថ្លែងគ្រប់គ្រាន់ជាអត្ថិភាព ដើម្បីឱ្យជនជាប់ចោទអាចប្រើប្រាស់ឱកាសដោយប្រសិទ្ធភាពក្នុងការជំទាស់ភស្តុតាងដាក់បន្ទុកលើខ្លួន"[2137]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ដែលបានដកស្រង់យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីសិទ្ធិមនុស្សនបានអះអាងគោលជំហរដូចគ្នាថា៖

> យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីសិទ្ធិមនុស្សមានតម្លៃគួរកត់សម្គាល់ ដោយសារបានបញ្ជាក់គោលការណ៍ដែលមានអានុភាពផ្លូវច្បាប់ថា "រាល់ភស្តុតាងទាំងអស់ត្រូវតែបង្កើតឡើងជាធម្មតានៅក្នុងសវនាការសាធារណៈ ដោយមានវត្តមានជនជាប់ចោទ និងផ្អែកតាមគោលការណ៍សួរដេញដោលចំពោះមុខ។ មានករណីលើកលែងមួយចំនួនចំពោះគោលការណ៍នេះ ប៉ុន្តែពុំបានរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទឡើយ"។ ការរំលោភបំពានពុំអាចទទួលយកបានលើសិទ្ធិរបស់ជនជាប់ចោទក្នុងន័យនេះបានកើតឡើងនៅពេលការដាក់ពិរុទ្ធភាពត្រូវបានផ្អែកតែ ឬជាសំខាន់ទៅលើភស្តុតាងរបស់សាក្សី ដែលជនជាប់ចោទពុំមានឱកាសសួរដេញដោល ឬបានសួរដេញដោលក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ឬនៅពេលជំនុំជម្រះ[2138]។

---

[2137] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[2138] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-74-AR73.6 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទទួលយកប្រតិចារឹកនៃការសួរសំណួររបស់ Jadranko Prlić ធ្វើជាភស្តុតាង ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៥៣ ដកស្រង់រឿងក្តី *A.M. ទល់នឹង ប្រទេសអ៊ីតាលី* អង្គជំនុំជម្រះនៃតុលាការ ECtHR សំណុំរឿងលេខ 37019/97 សាលក្រម ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២៥ និងយោងផងដែរទៅលើរឿងក្តី *Saÿdi ទល់នឹង ប្រទេសបារាំង* តុលាការ ECtHR សំណុំរឿងលេខ 14647/89 សាលក្រមចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៤៣-៤៤ និងរឿងក្តី *Unterpertinger ទល់នឹង ប្រទេសអូទ្រីស* តុលាការ ECtHR សំណើសុំលេខ 9120/80 សាលក្រមថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ កថាខណ្ឌ ៣១-៣៣។ *សូមមើលផងដែរ* សេចក្តីសម្រេចរឿងក្តី *Martić* (ICTY) កថាខណ្ឌ ២០ ("ក្នុងគ្រប់ករណីអង្គជំនុំជម្រះឧទ្ធរណ៍សង្កេតឃើញថា គោលការណ៍ពីរដែលអង្គជំនុំជម្រះសាលាដំបូងទាញចេញពីយុត្តិសាស្ត្ររបស់តុលាការ ECtHR មានដូចជា៖ (១) នត្ថិភាពទាំងស្រុង ឬកំហុសនីតិវិធីនៃការសួរដេញដោលសាក្សីជាស្វ័យប្រវត្តិនឹងពុំនាំទៅរកការដកភស្តុតាងចេញនោះទេ និង (២) ភស្តុតាងដែលពុំត្រូវបានសួរដេញដោល និងពាក់ព័ន្ធទៅនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ឬសំខាន់ចំពោះរឿងក្តីអយ្យការ តម្រូវឱ្យមានភស្តុតាងបញ្ជាក់បន្ថែមប្រសិនបើត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីពិរុទ្ធភាព ស្របតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិព្រមទាំងយុត្តិសាស្ត្រក្នុងស្រុក")។

749. បើទោះបីជាមានវិធានជាក់លាក់នៅតុលាការ ICTY ដែលជាវិធាន ៩២ *ស្ទួនបី* ចែងថា ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹករបស់បុគ្គលដែលក្រោយមកបានទទួលមរណភាព ឬពុំអាចស្វែងរកឃើញដោយការយកចិត្តទុកដាក់សមស្រប ឬដោយសារលក្ខខណ្ឌសុខភាពផ្លូវចិត្ត ឬផ្លូវកាយ ពុំអាចមកផ្តល់សក្ខីកម្មផ្ទាល់មាត់បាន អាចត្រូវបានទទួលយកក៏ដោយ ក៏ភស្តុតាងនេះពុំអាចក្លាយជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពដោយគ្មានការបញ្ជាក់អះអាងបន្ថែមនោះឡើយ[2139]។

750. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងមិនផ្អែកការយល់ឃើញណាមួយជាសំខាន់ទៅលើចម្លើយរបស់សាក្សីដែលបានទទួលមរណភាពនោះទេ ប្រសិនបើជនជាប់ចោទពុំមានឱកាសសួរដេញដោលសាក្សីនោះ[2140]។ ទោះជាយ៉ាងណាក្តី ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើចម្លើយរបស់សាក្សីដែលបានទទួលមរណភាពក្នុងការផ្អែកការយល់ឃើញរបស់ខ្លួនទៅលើការស្លាប់របស់ ហ៊ើស និង ទូច។ អង្គជំនុំជម្រះពុំបានពន្យល់នូវមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះប្រាសចាកពីគោលជំហររបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

751. បើទោះបីជាចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ួង ឌុស និង សុខ អ៊ែល បានបញ្ជាក់បន្ថែមគ្នាទៅវិញទៅមកពាក់ព័ន្ធទៅនឹងការស្លាប់របស់ ហ៊ើស ក៏ដោយ ក៏ការដាក់ពិរុទ្ធភាពនោះនៅតែបានផ្អែកទៅលើភស្តុតាងដែល ខៀវ សំផន ពុំអាចសួរដេញដោលក្នុងតុលាការបាន។ បើទោះបីជាចម្លើយរបស់ សុខ អ៊ែល ពាក់ព័ន្ធទៅនឹងការស្លាប់របស់ ទូច ត្រូវបានបញ្ជាក់អះអាងបន្ថែមក្នុងន័យទូទៅដោយភស្តុតាងដទៃទៀតដែលបង្ហាញអំពីលក្ខខណ្ឌដ៏អាក្រក់នៃការឃុំឃាំងក៏ដោយ ក៏នេះគឺជាភស្តុតាងតែមួយគត់ដែលបានផ្អែកទៅលើក្នុងការបង្ហាញការស្លាប់របស់ ទូច ដែលបានផ្អែកលើលក្ខខណ្ឌនៃការឃុំខ្លួននោះដែរ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការស្លាប់របស់ ហ៊ើស និង ទូច មានកំហុសដោយហេតុថា បានផ្អែកជាសំខាន់ទៅលើចម្លើយជាលាយលក្ខ

---

[2139] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឱ្យទទួលយកសក្ខីកម្មរបស់សាក្សី១៦នាក់ និងវត្ថុតាងពាក់ព័ន្ធស្របតាមវិធាន ៩២ *ស្ទួនបី* ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៨ ("មានគោលការណ៍បង្ហាញច្បាស់លាស់ថា ភស្តុតាងក្នុងរឿងក្តីដែលត្រូវបានទទួលយកស្របតាមវិធាន ៩២ ស្ទួនបី និងជាលទ្ធផលពុំត្រូវបានដាក់ឱ្យសួរដេញដោលក្នុងករណីជាក់លាក់នោះ ពុំអាចបង្កើតជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពលើជនជាប់ចោទដោយគ្មានភស្តុតាងបញ្ជាក់បន្ថែមនោះឡើយ។ ទោះជាយ៉ាងណាក្តី បើទោះបីជាភស្តុតាងនោះពុំអាចបង្កើតជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពក៏ដោយ ក៏នៅតែអាចទទួលយកធ្វើជាភស្តុតាងស្របតាមវិធាន ៩២ ស្ទួនបីដែរ ប្រសិនបើភស្តុតាងនោះបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាននោះ")។

[2140] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៣១។

ណ៍អក្សររបស់សាក្សីដែល ខៀវ សំផន ពុំអាចសួរដេញដោលបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការស្លាប់របស់ ហ៊ើស និង ទូច។

## ខ. ការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ១. ការសម្លាប់រង្គាលជនជាតិចាម

752. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ដោយចេតនាជនជាតិចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧ និងមន្ទីរសន្តិសុខភូមិទ្រាក្នុងឆ្នាំ ១៩៧៨[2141]។ អង្គជំនុំជម្រះបានបញ្ជាក់ថា បើទោះបីជាអង្គជំនុំជម្រះពុំអាចបង្ហាញចំនួនពិតប្រាកដនៃជនរងគ្រោះក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា "ជនស៊ីវិលជនជាតិចាមក្នុងចំនួនយ៉ាងច្រើនត្រូវបាននាំយកទៅមន្ទីរសន្តិសុខទាំងពីរនេះ"[2142]។ អង្គជំនុំជម្រះបានយល់ឃើញថា ការសម្លាប់ទាំងនេះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ និង"បង្កើតបានជាផ្នែកមួយនៃប្រតិបត្តិការសម្លាប់តែមួយ"[2143]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជឿជាក់ថា អំពើសត្យានុម័តនៃការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញ[2144]។ ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានភស្តុតាងបង្ហាញថា ការសម្លាប់ជនជាតិចាមនៅមន្ទីរសន្តិសុខទាំងពីរនេះត្រូវបានរៀបចំឡើង និងគិតទុកជាមុនផ្អែកតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាម។ កិច្ចប្រជុំ និងបទបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនខ្មាំងរួមទាំងជនជាតិចាម និងបង្ហាញថា ចារីបានប្រព្រឹត្តដោយចេតនាក្នុងការសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំ[2145]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានយល់ឃើញថា អំពើសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ដែលបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន[2146]។

---

[2141] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៨។

[2142] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១១។

[2143] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១២។

[2144] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១២។

[2145] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៣។

[2146] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៣។

753. ដោយសារទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅភូមិទ្រា[2147] និងវត្តអូរត្រកួន[2148] បានលើកបញ្ហាស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា មានការសម្លាប់បានកើតឡើង និងដោយសារអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពតែមួយប៉ុណ្ណោះពីបទសម្លាប់រង្គាល[2149] ទើបទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតនឹងត្រូវដោះស្រាយក្នុងផ្នែកស្តីពីការសម្លាប់រង្គាលនេះ។

## ក. ការសម្លាប់ជនជាតិចាមនៅភូមិទ្រា

754. ពាក់ព័ន្ធទៅនឹងការឃុំឃាំង និងការសម្លាប់ជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រាក្នុងឆ្នាំ ១៩៧៨ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់សាក្សី អ៊ីត សេន ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ និងសាក្សី ម៉ាត់ ស ពាក់ព័ន្ធទៅនឹងការឃុំឃាំង និងការសម្លាប់ជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រា[2150]។ អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នានូវលក្ខណៈពិសេសនៃភស្តុតាងគន្លឹះ និងបានយល់ឃើញថា អ៊ីត សេន ត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភូមិទ្រា និងថា គាត់បានរត់គេចខ្លួន និងខណៈពេលកំពុងលាក់ខ្លួនតាមគុម្ពោតព្រៃ បានឃើញជនជាតិចាមត្រូវបានគេចងបិទមុខនាំទៅមាត់ទន្លេ មានជាប់ចំណងដៃ ឡើងជិះកាណូត ដឹកយកទៅកណ្តាលទន្លេដែលពួកគេត្រូវបានរុញទម្លាក់ និងលង់ទឹកស្លាប់[2151]។ អង្គជំនុំជម្រះបានយល់ឃើញថា នោ សាទះ ត្រូវបានបញ្ជូនទៅភូមិទ្រារួមជាមួយនឹងស្ត្រី ៤០ នាក់ដទៃទៀត និងត្រូវបានឃុំឃាំងនៅក្នុងផ្ទះមួយកន្លែងនៅទីនោះជាមួយនឹងស្ត្រីរាប់រយនាក់ដទៃទៀត[2152]។ ពួកគាត់ត្រូវបានសួរថាតើ ជាជនជាតិខ្មែរ ឬជនជាតិចាម និងមានតែ ៣០ នាក់ប៉ុណ្ណោះដែលបានឆ្លើយថា ជាខ្មែរ(រួមទាំង នោ សាទះ) បាននៅរស់ ខណៈពេលអ្នកផ្សេងទៀតត្រូវបានគេនាំចេញទៅ ហើយពុំដែលឃើញត្រឡប់មកវិញឡើយ[2153]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នោ សាទះ ក្រោយមកបានឃើញសាកសពច្រកក្នុងថង់ប្លាស្ទិកអណ្តែតក្នុងទន្លេ រួមទាំងសពរបស់ស្ត្រីជនជាតិចាមម្នាក់ដែលគាត់ធ្លាប់ស្គាល់[2154]។

---

[2147] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៤-៨៩៨។

[2148] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៩-៩១០។

[2149] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៣៧។

[2150] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៦។

[2151] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៦។

[2152] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៨។

[2153] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៨។

[2154] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៨។

755. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សក្ខីកម្មរបស់ នោ សាទះ ត្រូវបានគាំទ្របន្ថែមដោយ ម៉ាត់ ស ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ត្រូវបានឃុំឃាំងផងដែរក្នុងភូមិទ្រាជាមួយនឹងស្ត្រីមួយក្រុម ដែលត្រូវបានសួរទាំងអស់គ្នាថាតើពួកគេជាខ្មែរ ឬជនជាតិចាម។ អង្គជំនុំជម្រះបានយល់ឃើញថា ម៉ាត់ ស បានឃើញអ្នកដែលបានឆ្លើយត្រង់ថា ពួកគេជាជនជាតិចាម និងត្រូវបានគេនាំយកទៅរណ្ដៅមួយ ត្រូវបានគេវាយ និងបោះចូលក្នុងនោះ[2155] និងថា លោកស្រីក៏បានបញ្ជាក់ផងដែរថា សមាជិកគ្រួសាររបស់លោកស្រីត្រូវបានសម្លាប់ដោយខ្មែរក្រហម[2156]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ពីមូលហេតុដែលអង្គជំនុំជម្រះពុំយល់ស្របជាមួយនឹងការជំទាស់ទៅនឹងភាពអាចជឿជាក់បាននេះ និងបានកត់សម្គាល់ថា អង្គជំនុំជម្រះបានផ្ដល់ទម្ងន់ច្រើនជាងទៅលើភស្តុតាងដែលត្រូវបានបញ្ជាក់បន្ថែមដោយ នោ សាទះ និង ម៉ាត់ ស ខណៈពេលធ្វើការពិនិត្យពិច័យដោយប្រុងប្រយ័ត្នលើភស្តុតាងដែលចេញពីសាក្សីម្នាក់ក្នុងចំណោមពួកគាត់នេះ។ អង្គជំនុំជម្រះបានយល់ឃើញថា ភស្តុតាងរបស់សាក្សីទាំងបីនាក់នេះគួរអោយជឿជាក់ និងទុកចិត្តបានជាទូទៅ[2157]។

756. ខៀវ សំផន បានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសម្លាប់បានកើតឡើងនៅភូមិទ្រា និងនេះគឺជាកំហុស[2158]។ គាត់បានជំទាស់ទៅនឹងភាពគួរឱ្យជឿទុកចិត្តបាននៃសក្ខីកម្មរបស់សាក្សីដែលផ្អែកតាមទស្សនៈរបស់គាត់ ពុំបានបញ្ជាក់បន្ថែមគ្នាទៅវិញទៅមកពាក់ព័ន្ធនឹងការស្លាប់ជនជាតិចាមនោះ[2159] និងថា សក្ខីកម្មរបស់ អ៊ីត សេន ទាក់ទងទៅនឹងទីកន្លែងដែលគាត់បានឃើញជនជាតិចាមកំពុងលង់ទឹកស្លាប់ត្រូវបានយល់ខុសទាំងស្រុង[2160]។ បន្ថែមលើនេះ គាត់បានលើកឡើងថា បើទោះបីជាសក្ខីកម្មរបស់ នោ សាទះ អាចជឿទុកចិត្តបានក៏ដោយ ក៏ត្រឹមតែបង្ហាញថា មានស្ត្រីជនជាតិចាម ១០ នាក់ត្រូវបានគេនាំយកទៅប៉ុណ្ណោះ[2161] និងថា សក្ខីកម្មរបស់ ម៉ាត់ ស ពាក់ព័ន្ធទៅនឹងការសម្លាប់ពុំមានភស្តុតាងបញ្ជាក់បន្ថែមឡើយ[2162]។ ខៀវ សំផន បានលើកឡើងជាជម្រើសផ្សេងថា បើទោះបីជាសក្ខីកម្មទាំងនេះគួរជឿទុកចិត្តបាន និងគ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំសម

---

[2155] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៩។

[2156] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៩។

[2157] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨០។

[2158] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៤-៨៩៨។

[2159] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៤-៨៩៧។

[2160] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៥។

[2161] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៦។

[2162] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៧។

01718376



ហេតុផលថា "ក្នុងឆ្នាំ ១៩៧៨ ប្រជាជនចាមជាច្រើនមកពីស្រុកក្រូចឆ្មារត្រូវបានចាប់ខ្លួន និងនាំយកទៅមន្ទីរសន្តិសុខភូមិទ្រាកន្លែងដែលពួកគេត្រូវបានឃុំឃាំងតាមអំពើចិត្ត [...] និងអ្នកដែលត្រូវបានចាត់ទុកថា ជាជនជាតិចាមត្រូវបានកម្ទេច"[2163]។

757. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញ ឬការសន្និដ្ឋានដោយពុំសមហេតុផល[2164] និងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សម្អាងហេតុទាក់ទងទៅនឹងការវាយតម្លៃរបស់ខ្លួនលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងបានបដិសេធអំណះអំណាងប្រហាក់ប្រហែលគ្នាដែលបានលើកឡើងពាក់ព័ន្ធទៅនឹងភាពគួរជឿជាក់ និងទុកចិត្តបាននៅពេលជំនុំជម្រះ[2165] និងថា អ៊ឹត សេន អាចឃើញអ្វីដែលបានកើតឡើងយ៉ាងជាក់ច្បាស់[2166] និងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមែនជាការសន្និដ្ឋានចេញពីហេតុការណ៍តែមួយនោះឡើយ[2167]។

758. សហមេធាវីនាំមុខបានឆ្លើយតបដោយយោងទៅលើភាពស៊ីសង្វាក់គ្នាជាច្រើនរវាងសក្ខីកម្មរបស់ អ៊ឹត សេន, នោ សាទះ និង ម៉ាត់ ស[2168] និងថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងសមស្របលើការលើកឡើងរបស់ ខៀវ សំផន ដែលថា មានភាពខុសគ្នាដោយអន្លើនៃភស្តុតាងនោះ ប៉ុន្តែពុំបានជឿជាក់លើការលើកឡើងនេះឡើយ[2169]។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមទៀតថា ខៀវ សំផន បានលើកឡើងពុំត្រឹមត្រូវពាក់ព័ន្ធទៅនឹងចំនួននៃស្ត្រីជនជាតិចាមដែល នោ សាទះ បាននិយាយថា ត្រូវបាននាំចេញទៅនោះ និងថា លោកស្រីបានប៉ាន់ស្មានថា លោកស្រីត្រូវបានឃុំឃាំងជាមួយស្ត្រី ៣០០ នាក់ទៀត និងថា មានតែប្រហែល ៣០ នាក់ប៉ុណ្ណោះដែលនៅរស់បន្ទាប់ពីបានឆ្លើយថា ជាខ្មែរ ខណៈពេលដែលអ្នកដទៃទៀតត្រូវបាននាំចេញទៅបាត់[2170]។ សហមេធាវីនាំមុខបានឆ្លើយតបថា ដូច្នេះ ខៀវ សំផន បានលើកឡើងពុំត្រឹមត្រូវដែល

---

[2163] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៨ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨១។ ការបញ្ជាក់នេះត្រូវបានលើកសាឡើងវិញក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៦។

[2164] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៩៨។

[2165] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៩៩។

[2166] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០០។

[2167] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០១។

[2168] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៦២។

[2169] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៦៣។

[2170] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៦៣។

ថា ជាការសន្និដ្ឋានដោយពុំសមហេតុផលក្នុងការយល់ឃើញថា ប្រជាជនចាមក្នុងចំនួនដ៏ច្រើនត្រូវបានកម្មេចនៅភូមិទ្រា និងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យធ្វើការសន្និដ្ឋានសមហេតុផលថា អ្នកដែលត្រូវបាននាំចេញទៅនោះ ត្រូវបានសម្លាប់ដូចការផ្តល់សក្ខីកម្មរបស់ នោ សាទះ ថា ពួកគេពុំដែលបានឃើញត្រឡប់មកវិញ និងក្រោយមកគាត់បានឃើញសាកសពអណ្តែតក្នុងទន្លេ[2171]។

759. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងស្ថិតក្នុងតួនាទីប្រសើរបំផុតក្នុងការវាយតម្លៃលើភាពអាចជឿជាក់ និងទុកចិត្តបានរបស់សាក្សីទាំងនេះ និងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារអង្គជំនុំជម្រះសាលាដំបូងអាចសង្កេតពួកគាត់ក្នុងតុលាការនៅពេលដេញដោលលើភស្តុតាងនោះ [2172]។ ការវាយតម្លៃលើភស្តុតាងជាពិសេសគឺស័ក្តិសមសម្រាប់ចៅក្រមដែលបានស្តាប់សក្ខីកម្ម សង្កេតការសួរដេញដោល ពិនិត្យឯកសារគាំទ្រ និងភស្តុតាងជំទាស់ ប្រសិនបើមាន និងសំខាន់បំផុត ធ្វើការវាយតម្លៃជារួមក្នុងបរិបទនៃភស្តុតាងដទៃទៀតដែលបានស្តាប់ក្នុងពេលជំនុំជម្រះ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាទម្ងន់អាចត្រូវបានផ្តល់តាមរយៈការចងចាំជាក់លាក់របស់សាក្សី និងការបញ្ជាក់បន្ថែមដែលគួរជឿជាក់បានក៏ដោយ ក៏ពុំមានគោលការណ៍ច្បាប់ដែលតម្រូវថា ត្រូវតែមានការបញ្ជាក់បន្ថែមនោះដែរ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ អ៊ុត សេន ដែលបានផ្តល់សក្ខីកម្មថា គាត់បានឃើញដោយផ្ទាល់នូវបុរសជនជាតិចាមលង់ទឹកស្លាប់ សក្ខីកម្មរបស់ ម៉ាត់ ស ដែលបានផ្តល់សក្ខីកម្មថា លោកស្រីបានឃើញជនជាតិចាមកំពុងត្រូវបានសម្លាប់នៅក្បែររណ្តៅមួយ និងសក្ខីកម្មរបស់ នោ សាទះ ដែលពុំបានឃើញផ្ទាល់នូវការសម្លាប់ ប៉ុន្តែបានបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់ ម៉ាត់ ស ដែលថា ស្ត្រីទាំងនោះដែលបានឆ្លើយថា ជាជនជាតិចាមត្រូវបាននាំចេញទៅបាត់។ ផ្អែកលើភស្តុតាងជារួមបង្ហាញថា ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជនជាតិចាមត្រូវបានសម្លាប់បន្ទាប់ពីត្រូវបានចាប់ខ្លួន និងនាំយកទៅមន្ទីរសន្តិសុខភូមិទ្រា។

760. នេះទំនងជាថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យយល់ឃើញថា "ជនជាតិចាមក្នុងចំនួនដ៏ច្រើន"ត្រូវបានចាប់ខ្លួន និងនាំទៅមន្ទីរសន្តិសុខភូមិទ្រា។ ភស្តុតាងរបស់ នោ សាទះ បានបង្ហាញថា មានស្ត្រីប្រហែល ៣០០ នាក់ ត្រូវបានឃុំឃាំងនៅទីនោះ និងថា ក្រោយមកនៅសល់តែ ៣០ នាក់ប៉ុណ្ណោះ[2173]ដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ស្ត្រី ៣០ នាក់នោះបានឆ្លើយថា ខ្លួនជាជនជាតិខ្មែរ រួមទាំង នោ សាទះ។

---

2171 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៦៣-៧៦៤។

2172 *សូមមើលខាងលើ* ផ្អែក II.ខ។

2173 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៨។

បញ្ហាថាតើ ការសម្លាប់ដែលបានកើតឡើងនៅភូមិទ្រានោះ អាចស្មើនឹងអំពើសម្លាប់រង្គាល ដែរ ឬយ៉ាងណា នឹងត្រូវពិភាក្សាខាងក្រោម។ អំណះអំណាងដែលថា ពុំមានភស្តុតាងគ្រប់គ្រាន់ ជឿទុកចិត្តបាន និងបញ្ជាក់បន្ថែមក្នុងការយល់ឃើញថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងនៅភូមិទ្រានោះ ត្រូវបដិសេធចោល។

## ខ. ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន

761. ភស្តុតាងនោះអង្គជំនុំជម្រះសាលាដំបូងបានទទួលតាមរយៈអ្នកភូមិជនជាតិចាម និងសមាជិកនៃកងសន្តិសុខដែលប្រតិបត្តិការនៅមន្ទីរសន្តិសុខវត្តអូរត្រកួនពាក់ព័ន្ធទៅនឹងការដឹងរបស់ពួកគាត់អំពីការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំក្នុងឆ្នាំ ១៩៧៧[2174]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានយល់ឃើញថា "ចំនួនប្រជាជនដ៏ច្រើនដែលត្រូវបានសន្មតថា ជាខ្មាំង រួមទាំងប្រជាជនចាមមកពីភូមិនានានៃស្រុកកងមាស តំបន់ ៤១ ត្រូវបានចាប់ខ្លួនជាប្រព័ន្ធ និងនាំយកទៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧ កន្លែងដែលពួកគេត្រូវបានកម្ទេចក្នុងទ្រង់ទ្រាយធំ"[2175]។

762. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុក្នុងការយល់ឃើញថា ប្រជាជនចំនួនដ៏ច្រើនរួមទាំងជនជាតិចាមដែលភាគច្រើននោះត្រូវបានចាប់ខ្លួន និងនាំយកទៅវត្តអូរត្រកួនកន្លែងដែលពួកគេត្រូវបានកម្ទេច[2176] និងថា នេះជាការសន្និដ្ឋានចេញពីភស្តុតាងមិនផ្ទាល់ដែលមានតម្លៃជាភស្តុតាងទាប[2177]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងចេញពីសាក្សីផ្ទាល់តែបួននាក់ប៉ុណ្ណោះ ដែលនេះមានលក្ខណៈពុំគ្រប់គ្រាន់អាចឱ្យអង្គជំនុំជម្រះយល់ឃើញឱ្យហួសវិមតិសង្ស័យថា ប្រជាជននោះត្រូវបានចាប់ខ្លួន ដោយសារពួកគេជាជនជាតិចាមឡើយ[2178]។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានផ្អែកលើពាក្យចចាមអារ៉ាមក្នុងការ

---

[2174] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៩១។

[2175] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៤។

[2176] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៩។

[2177] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩៩។

[2178] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០០។

យល់ឃើញថា មានជនជាតិចាមរាប់រយនាក់ត្រូវបានចាប់ខ្លួន[2179] និងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនោះទេ[2180]។

763. ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ប្រជាជនដ៏ច្រើនរួមទាំងជនជាតិចាមភាគច្រើនត្រូវបានកម្ទេចនៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧[2181] និងថា ការកំណត់អត្តសញ្ញាណជនជាតិចាមតាមរយៈសាក្សីពីរនាក់"ជាការពុំសមស្រប"[2182] និងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់នៅវត្តអូរត្រកួនត្រូវបានបញ្ជាក់បន្ថែមដោយសមាជិកនៃកងសន្តិសុខនោះ ជាការពុំត្រឹមត្រូវ[2183] និងថា ជាការពុំត្រឹមត្រូវ និងជាពាក្យចចាមអារ៉ាមដែលថា ប្រជាជនភាគច្រើនដែលត្រូវបាននាំទៅវត្តអូរត្រកួនគឺជាជនជាតិចាម ដោយសារសាក្សីបានឆ្លើយថា មានខ្មែរ និងជនជាតិចាមត្រូវបានចាប់ខ្លួន និងសម្លាប់នៅទីនោះ[2184] និងថា កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលបញ្ជាក់បន្ថែមទៅលើការសម្លាប់រង្គាលជនជាតិចាមនៅវត្តអូរត្រកួន មានតម្លៃជាភស្តុតាងទាប[2185]។

764. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញ ប៉ុន្តែខកខានក្នុងការបង្ហាញថា ការយល់ឃើញដែលថា ជនជាតិចាមត្រូវប្រមូលផ្តុំនៅក្នុងភូមិនានាក្នុងស្រុកកងមាស និងនាំយកទៅវត្តអូរត្រកួន និងថា ប្រជាជនក្នុងចំនួនដ៏ច្រើនរួមទាំងជនជាតិចាមដែលភាគច្រើននោះ ត្រូវបានកម្ទេចនៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧ ពុំសមហេតុផល[2186]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា បញ្ហាថាតើ ប្រជាជនត្រូវបានចាប់ខ្លួនដោយសារតែពួកគេជាជនជាតិចាម ដែរ ឬយ៉ាងណានោះ ពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូង"មានកំហុសអង្គច្បាប់"ដោយសារបានយល់ឃើញថា ជនជាតិចាមរាប់រយនាក់ក្នុងឃុំពាមជីកង ត្រូវបានចាប់ខ្លួនដោយសមាជិកកងឈ្លប**ក្រុមដាវវែង**នោះទេ។ ផ្ទុយទៅវិញ ខៀវ សំផន ត្រឹមតែបានអះអាងថា ភស្តុតាងនេះមានតម្លៃទាប និងបានលើកជម្រើសមួយផ្សេងនៃការបកស្រាយភស្តុតាងដែល

[2179] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០១។

[2180] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០១។

[2181] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៦។

[2182] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៦។

[2183] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៧។

[2184] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៨។

[2185] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៩។

[2186] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០៤។

ពុំបានបំពេញតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ[2187]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសនៅក្នុងការយល់ឃើញដែលថា ជនជាតិចាមភាគច្រើនត្រូវបានកម្ទេចនៅវត្តអូរត្រកួន និងថា អង្គជំនុំជម្រះសាលាដំបូងពុំបាន ប៉ុន្តែអាចសំអាងទៅលើភស្តុតាងចចាមអារ៉ាមក្នុងការបង្កើតការយល់ឃើញនេះ[2188]។

765. សហមេធាវីនាំមុខបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន ពុំមានភាពច្បាស់លាស់ ហើយគាត់ទំនងជាទទួលស្គាល់ថា ការសម្លាប់នោះបានកើតឡើង ប៉ុន្តែបានជំទាស់ទៅនឹងជាតិពន្ធុរបស់ជនរងគ្រោះ[2189]និងថា ខៀវ សំផន បានបំភ្លៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើផ្នែកខ្លះក្នុងការបង្កើតការយល់ឃើញរបស់ខ្លួន[2190]។

766. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខខ្លួន ពុំបានឃើញការសម្លាប់នោះដោយផ្ទាល់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន ប៉ុន្តែបានបង្កើតការយល់ឃើញថា ការសម្លាប់នោះបានកើតឡើងផ្អែកលើការរៀបរាប់ជាពាក្យចចាមអារ៉ាមជាច្រើននៃការសម្លាប់បន្ថែមលើភស្តុតាងផ្ទាល់ដែលបង្ហាញថា៖

> (១) ប្រជាជនចាមត្រូវបានប្រមូលផ្តុំតាមភូមិផ្សេងៗក្នុងស្រុកកងមាស និងបាននាំយកទៅវត្តអូរត្រកួនដោយកងឈ្លប និងសមាជិកកងឈ្លប**ក្រុមដាវវែង** (២) ប្រជាជនចាមត្រូវបានចង និងឃុំឃាំងក្នុងវត្តមុនពេលត្រូវបាននាំចេញទៅក្នុងទ្រង់ទ្រាយធំ និង (៣) ប្រជាជននៅទីនោះបានឮសម្លេងស្រែកចេញពីរណ្តៅឱ្យជួយ និងចាក់មេក្រូខ្លាំងៗនៅពេលយប់កុំឱ្យឮសម្លេងស្រែក។ សាក្សីទាំងអស់ និងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយស៊ីសង្វាក់គ្នាថា ជនជាតិចាមដែលត្រូវបាននាំទៅវត្តនោះ ពុំដែលឃើញត្រឡប់មកវិញ ហើយរណ្តៅកប់សាកសពនោះត្រូវបានរកឃើញនៅជុំវិញវត្តក្រោយខែ មករា ឆ្នាំ ១៩៧៩[2191]។

767. ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់នៅវត្តអូរត្រកួន ពុំមែនជាការពុំសមហេតុផលនោះទេ។ អង្គជំនុំជម្រះសាលាដំបូងអាចសំអាងដោយប្រុងប្រយ័ត្នទៅលើភស្តុតាងចចាមអា

---

[2187] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០៦។

[2188] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០៧។

[2189] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៩៥។

[2190] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៤១-៧៤៧។

[2191] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០២។

វ៉ាមក្នុងការបង្ហាញនូវធាតុផ្សំនៃបទឧក្រិដ្ឋ[2192]។ មានភាពស៊ីសង្វាក់គ្នាជាទូទៅក្នុងភស្តុតាងទាំងអស់ដែលត្រូវបានពិចារណាដើម្បីគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ អតីតសមាជិកក្រុមដាវវែងជាក្រុមមួយដែលត្រូវបានបង្កើតឡើងដើម្បីធ្វើចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ និងនាំយកទៅវត្តអូរត្រកួន[2193] បានផ្តល់សក្ខីកម្មថា ពួកគាត់ត្រូវបានបញ្ជាឱ្យចាប់ខ្លួនជនជាតិចាមទាំងអស់ និងខណៈពេលបដិសេធតួនាទីរបស់ខ្លួនពាក់ព័ន្ធនឹងការសម្លាប់នៅវត្តអូរត្រកួន ពួកគាត់ពុំបានបដិសេធនូវការសម្លាប់នោះដែរ[2194]។ បើទោះបីជាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចំនួនប្រាំពីរដែល“បានបញ្ជាក់បន្ថែមលើការសម្លាប់ទ្រង់ទ្រាយធំជនជាតិចាមនៅវត្តអូរត្រកួន”[2195] ពុំត្រូវបានសួរដេញដោលក្នុងតុលាការក៏ដោយ ក៏លក្ខណៈពិសេសជារួមនេះបានផ្តល់តម្លៃជាភស្តុតាងខ្លះនៅពេលដែលបានបញ្ជាក់បន្ថែមលើសក្ខីកម្មក្នុងតុលាការនោះ។ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានផ្អែកទៅលើកំណត់ហេតុទាំងនេះ ដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនឡើយ។

768. សេង ស្រ៊ុន ដែលជាអ្នកឡើងត្នោត និងរស់នៅក្បែរវត្តអូរត្រកួន[2196] បានផ្តល់សក្ខីកម្មថា គាត់បានជួយដល់ការចាប់ខ្លួនជនជាតិចាមនៅថ្ងៃមួយ និងថា គាត់បានប៉ាន់ស្មានមានជនជាតិចាមប្រមាណពី ៤០០ ទៅ ៥០០ នាក់ត្រូវបានចាប់ខ្លួន ប្រមាណពី ២០០ ទៅ ៣០០ នាក់មកពីភូមិនោះ និងផ្សេងទៀតមកពីការដ្ឋានធ្វើការ[2197]។ បើទោះបីជា ខៀវ សំផន បានអះអាងថា សេង ស្រ៊ុន ពុំបានពន្យល់យ៉ាងដូចម្តេចទើបគាត់អាចដឹងចំនួនតួលេខនេះក៏ដោយ[2198] ក៏ សេង ស្រ៊ុន បានពន្យល់ថា តួលេខនេះជាការប៉ាន់ស្មានផ្ទាល់ខ្លួនគាត់[2199]។ បើទោះបីជាគាត់ពុំបានឃើញក្រុមនោះត្រូវបានសម្លាប់ដោយផ្ទាល់ក៏ដោយ ក៏គាត់បានពន្យល់ថា បន្ទាប់ពីក្រុមនោះត្រូវបាននាំយកទៅវត្តអូរត្រកួន មេក្រុចាក់ភ្លេងរយៈពេលយូរខុសធម្មតានៅយប់នោះ[2200] ហើយគាត់ពុំដែលបានឃើញអ្នកទាំងនោះម្តងទៀតឡើយ[2201] និងមិត្តភ័ក្តិជិតដិតរបស់គាត់ឈ្មោះ មឿន ដែលបានចូលរួម

[2192] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០២។

[2193] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨៥។

[2194] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨១, ៣២៨៧-៣២៨៩។

[2195] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០០ និងជើងទំព័រ ១១២១៥។

[2196] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨៦។

[2197] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ២៦-៣១។

[2198] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០២។

[2199] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ២៩។

[2200] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ៣៣-៣៤។

[2201] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ៣៣-៣៤។

ក្នុងការសម្លាប់នោះបានប្រាប់គាត់ថា ជនជាតិចាមត្រូវបានសម្លាប់នៅយប់នោះ[2202]។ គាត់ក៏បានបញ្ជាក់ថា ក្រោយឆ្នាំ ១៩៧៩ គាត់បានឃើញលលាដ៍ក្បាល និងសម្លៀកបំពាក់ជនជាតិចាមក្នុងរណ្ដៅក្បែរវត្តអូរត្រកួន ដែលត្រូវបានគាស់ឃើញនោះ[2203]។ គាត់ពុំត្រូវបានសួរសំណួរថាតើ គាត់បានដឹងយ៉ាងដូចម្ដេចថា ប្រជាជនដែលត្រូវបានចាប់ខ្លួននោះជាជនជាតិចាមឡើយ ប៉ុន្តែគាត់ត្រូវបានសួរថាតើ គាត់បានដឹងថា មានជនជាតិចាមណាខ្លះដែលត្រូវបានចាប់ខ្លួននោះ និងថាតើ គាត់អាចរៀបរាប់ឈ្មោះខ្លះៗអ្នកដែលគាត់ស្គាល់បាន ដែរឬទេ[2204]។ សាក្សី ម៉ុយ វ៉ាន់នី បានឆ្លើយប្រហាក់ប្រហែលគ្នាថា គាត់ពុំបានឃើញការសម្លាប់ដោយផ្ទាល់ ប៉ុន្តែបានកត់សម្គាល់ថា នៅវត្តនោះដាក់មនុស្សពេញ ដែលក្រោយមកបាត់អស់ និងគេប្រាប់គាត់ថា អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់[2205]។

769. ហ៊ឹម ម៉ាន បានផ្ដល់សក្ខីកម្មថា គាត់បានលាក់ខ្លួនក្នុងគុម្ពោតព្រៃប្រមាណ១០០ម៉ែត្រពីរណ្ដៅក្រៅវត្តអូរត្រកួនកន្លែងដែលជនជាតិចាមត្រូវបានសម្លាប់។ គាត់បានអះអាងថា បើទោះបីជាគាត់ពុំបានឃើញការសម្លាប់នោះដោយផ្ទាល់ក៏ដោយ ក៏គាត់បានឮជនជាតិចាមស្រែកឱ្យព្រះអាឡាជួយនៅពេលដែលពួកគេកំពុងត្រូវបានសម្លាប់នោះ[2206]។ សាក្សី សំរិត មុយ បានអះអាងប្រហាក់ប្រហែលគ្នាថា គាត់បានឮសម្លេងស្រែកឱ្យជួយខណៈពេលមេក្រូចាក់ភ្លេងឮៗនៅវត្តអូរត្រកួន[2207]។ ហ៊ឹម ម៉ាន បាននិយាយសំដៅច្បាស់លាស់ទៅលើការចាប់ខ្លួនជនជាតិចាម។ ការដែលថា គាត់ជាជនជាតិចាម និងបានរួចជីវិតពីព្រោះគាត់ពុំមាន“ទំនាក់ទំនងជាមួយនរណាម្នាក់” និង“ពុំបានធ្វើអ្វីនោះ”ពុំអាចបង្ហាញថា ការចាប់ខ្លួននោះមានលក្ខណៈមិនរើសមុខឡើយ។ ការអះអាងរបស់ ខៀវ សំផន ដែលថា សក្ខីកម្មរបស់ ហ៊ឹម ម៉ាន បានបង្ហាញថា ការចាប់ខ្លួនជាការមិនរើសមុខនោះ[2208] តាមធម្មតាពុំមានប្រសិទ្ធភាពឡើយ។

770. សយ ឌឿន ដែលជាសមាជិកនៃក្រុមដាវវែងបានឆ្លើយថា គាត់បានចាប់ខ្លួនជនជាតិចាមក្នុង“ចុងឆ្នាំ ១៩៧៨” ។ ក្រៅពីកាលបរិច្ឆេទនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សក្ខីកម្មរបស់គាត់ទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាមមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងសក្ខីកម្មរបស់សាក្សីដទៃទៀត។ សយ ឌឿ

---

2202 ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារលេខ E1/346.1 ទំព័រ ៣៦-៣៧។

2203 ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារលេខ E1/346.1 ទំព័រ ៣៤។

2204 ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (ម៉ុយ វ៉ាន់នី) ឯកសារលេខ E1/346.1 ទំព័រ ៦៦-៦៧។

2205 ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ (ម៉ុយ វ៉ាន់នី) ឯកសារលេខ E1/373.1 ទំព័រ ៣៩, ៤២, ៤៨។

2206 ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ (ហ៊ឹម ម៉ាន) ឯកសារលេខ E1/349.1 ទំព័រ ៣៤-៣៥។

2207 ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ (ហ៊ឹម ម៉ាន) ឯកសារលេខ E1/347.1 ទំព័រ ២៦-២៧។

2208 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៣។

ន ជាញឹកញាប់បានអះអាងក្នុងអំឡុងពេលនៃសក្ខីកម្មរបស់ខ្លួនថា គាត់មានការចងចាំពុំបានល្អ[2209] ប៉ុន្តែមានភាពស៊ីសង្វាក់ជាមួយនឹងសាក្សីដទៃទៀតនៅពេលគាត់បានលើកឡើងថា ការចាប់ខ្លួនជនជាតិចាមពីភូមិជាច្រើនធ្វើឡើងតែមួយថ្ងៃ និងថា ជនជាតិចាមត្រូវបាននាំទៅវត្តអូរត្រកួន និងថា គាត់បានឮពីកងឈ្លបសន្តិសុខថា ជនជាតិចាមទាំងនោះត្រូវបានសម្លាប់[2210]។

771. សេង ឃុយ ជាកសិករធ្វើស្រែបានឃើញផ្ទាល់ជនជាតិចាមក្នុងភូមិរបស់គាត់ត្រូវបានចាប់ខ្លួននៅយប់មួយ[2211]។ គាត់អះអាងថា គាត់ត្រូវបានបញ្ជាឱ្យដឹកពួកគេតាមរទេះគោទៅវត្តអូរត្រកួន និងបានធ្វើតាមបញ្ជានោះ[2212]។ គាត់បានបញ្ជាក់ថា គាត់ពុំដែលបានឃើញជនជាតិចាមទាំងនោះម្តងទៀតឡើយ[2213]។ គាត់ពុំបានដឹងមូលហេតុដែលពួកគេត្រូវចាប់ខ្លួន ប៉ុន្តែដឹងថា ពួកគេជាជនជាតិចាមដែលមកពីភូមិគាត់ផ្ទាល់។ គាត់បានឆ្លើយថា "ប្រជាជនចាមដែលត្រូវបានចាប់ខ្លួន គឺជាអ្នកឥតមានទោស។ ពួកគេពុំបានធ្វើអ្វីខុសនោះទេ និងថា បានខិតខំប្រឹងធ្វើការយ៉ាងខ្លាំង"[2214]។ ការអះអាងរបស់ ខៀវ សំផន ដែលថា សក្ខីកម្មនេះពុំអាចយកមកសំអាងបានក្នុងការបង្ហាញថា អ្នកទាំងនោះត្រូវបានចាប់ខ្លួនដោយសារពួកគេជាជនជាតិចាម[2215] ពុំមានមូលដ្ឋានគាំទ្រត្រឹមត្រូវ និងត្រូវបដិសេធចោល។ ពុំមានការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលជនជាតិចាមត្រូវបានកំណត់គោលដៅ និងសម្លាប់នៅវត្តអូរត្រកួន និងបញ្ហាដែល សេង ឃុយ បានដឹងពីហេតុផលនៃការចាប់ខ្លួនឡើយ។

772. សាក្សីទាំងនេះ និងដទៃទៀតដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានសម្លាប់នៅវត្តអូរត្រកួន។ ខៀវ សំផន ពុំបានបង្ហាញថា នេះជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មទាំងនេះ។

---

[2209] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ (សយ ឌឿន) ឯកសារលេខ E1/374.1 ទំព័រ ២៦, ៣១, ៣៨។

[2210] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ (សយ ឌឿន) ឯកសារលេខ E1/374.1 ទំព័រ ៦៥-៧០។

[2211] ប្រតិចារឹក ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ (សេង ឃុយ) ឯកសារលេខ E1/344.1 ទំព័រ ៦៤។

[2212] ប្រតិចារឹក ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ (សេង ឃុយ) ឯកសារលេខ E1/344.1 ទំព័រ ៦៨-៦៩។

[2213] ប្រតិចារឹក ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ (សេង ឃុយ) ឯកសារលេខ E1/344.1 ទំព័រ ៧០-៧១។

[2214] ប្រតិចារឹក ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ (សេង ឃុយ) ឯកសារលេខ E1/344.1 ទំព័រ ៧៣-៧៤។

[2215] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៥។

773. អំណះអំណាងដែលបានលើកឡើង ខៀវ សំផន ថា ប្រជាជនខ្មែរក៏ត្រូវបានសម្លាប់នៅវត្តអូរត្រកួន ដូចជនជាតិចាម[2216]ដែរនោះ ពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ប្រជាជនចាមត្រូវបានសម្លាប់នៅវត្តអូរត្រកួន ដែរឬយ៉ាងណាឡើយ។ មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ប្រជាជនចាមក្នុងចំនួនដ៏ច្រើនត្រូវបានសម្លាប់នៅវត្តអូរត្រកួន ហើយសារណារបស់ ខៀវ សំផន ដែលថា មានកំហុសអង្គហេតុនោះ តាមធម្មតាពុំមានភស្តុតាងគាំទ្រ។ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះត្រូវបដិសេធចោល។

## គ. ការកំណត់អំពីតួលេខនៃការសម្លាប់

774. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បើទោះបីជាអង្គជំនុំជម្រះពុំអាចបង្ហាញចំនួនជាក់លាក់នៃជនរងគ្រោះក៏ដោយ ក៏អង្គជំនុំជម្រះបានជឿជាក់ថា "ជនស៊ីវិលជនជាតិចាមក្នុងចំនួនដ៏ច្រើន"ត្រូវបាននាំយកទៅមន្ទីរសន្តិសុខភូមិទ្រា និងវត្តអូរត្រកួន និងថា ការសម្លាប់បានកើតឡើងក្នុងទ្រង់ទ្រាយធំ និងជាផ្នែកមួយនៃប្រតិបត្តិការតែមួយ[2217]។

775. ខៀវ សំផន បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចំនួនជនរងគ្រោះបានផ្អែកលើការប៉ាន់ស្មាន និងពុំជាក់លាក់[2218]។

776. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស និងថា អំណះអំណាងរបស់គាត់ផ្អែកទៅលើការអះអាងពុំត្រឹមត្រូវដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការសម្លាប់នោះបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន[2219]។ សហព្រះរាជអាជ្ញាបានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងពុំបានប៉ាន់ស្មានលើចំនួននៃការសម្លាប់នោះ ប៉ុន្តែផ្ទុយទៅវិញបានយល់ឃើញច្បាស់លាស់ថា អង្គជំនុំជម្រះពុំអាចបង្ហាញចំនួនពិតប្រាកដបាន និងថា ធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាលពុំតម្រូវឱ្យបង្ហាញចំនួនជាក់លាក់នៃការស្លាប់នោះឡើយ[2220]។

---

[2216] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩០៦-៩០៨។

[2217] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១១-៣៣១២។

[2218] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១១។

[2219] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១០-៥១១។

[2220] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១១។

777. ដោយហេតុថា ការសម្លាប់រង្គាលជាទូទៅត្រូវបានកំណត់និយមន័យថា ជា"ការសម្លាប់ក្នុងទ្រង់ទ្រាយធំ"[2221] ទើបពុំចាំតម្រូវឱ្យមានការកំណត់អំពីតួលេខសម្រាប់ការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2222]។ ការសម្លាប់រង្គាលត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋាននៃការសម្លាប់ដែលអាចក្រោម ៦០ នាក់បន្តិចបន្តួច[2223]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការសម្លាប់នៅភូមិទ្រា និងវត្តអូរត្រកួន "បង្កើតបានជាផ្នែកមួយនៃប្រតិបត្តិការសម្លាប់ដូចគ្នា"[2224]។ ធាតុផ្សំសត្យានុម័តនៃអំពើសម្លាប់រង្គាលអាចត្រូវបានបង្ហាញតាមរយៈតួលេខសរុបនៃហេតុការណ៍ដាច់ដោយឡែកពីគ្នាដែលបង្កើតបានជាផ្នែកមួយនៃប្រតិបត្តិការសម្លាប់តែមួយ[2225]។

778. ដោយពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិចាមដើម្បីបោសសម្អាត អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នេះជាការសមហេតុផលក្នុងការយល់ឃើញថា ការសម្លាប់នៅភូមិទ្រា និងវត្តអូរត្រកួន គឺជាផ្នែកមួយនៃប្រតិបត្តិការតែមួយដែលជនរងគ្រោះជាច្រើនត្រូវបានប្រមូលផ្តុំ នៅពេលកំណត់ថា ការសម្លាប់នោះបានកើតឡើងក្នុងទ្រង់ទ្រាយធំសម្រាប់ធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល ដែរ ឬយ៉ាងណា។ បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងពុំមានចំនួនជនរងគ្រោះជាក់លាក់នៅភូមិទ្រា ឬវត្តអូរត្រកួនក៏ដោយ ក៏មានសាក្សីម្នាក់បានសំដៅលើចំនួនជនជាតិចាមពី ៤០០ ទៅ ៥០០ នាក់ដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅវត្តអូរត្រកួន និងបានផ្តល់សក្ខីកម្មថា មិត្តភ័ក្តិគាត់ដែលជាអ្នកសម្លាប់បានប្រាប់ថា ពួកគេត្រូវបានសម្លាប់[2226]។ អង្គជំនុំជម្រះ

---

[2221] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥២១, ៥២៥។

[2222] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៥១។

[2223] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៥១ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lukić និង Lukić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-32/1-A សាលដីកាថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ("សាលដីការឿងក្តី *Lukić និង Lukić* (ICTY)") កថាខណ្ឌ ៥៣៧។

[2224] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១២។

[2225] *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-08-91-A សាលដីកាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ("សាលដីការឿងក្តី *Stanišić និង Župljanin* (ICTY)") កថាខណ្ឌ ១០២២។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Tolimir* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-882-A សាលដីកា ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ១៤៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mladić* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-09-92-T សាលក្រម (ភាគ III ក្នុងចំណោម V ភាគ) ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៧ កថាខណ្ឌ ៣០៦៧។

[2226] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារលេខ E1/346.1 ទំព័រ ២៦-៣១, ៣៣-៣៤។

តុលាការកំពូលសន្និដ្ឋានថា ចំនួននេះអាចស្មើនឹងការសម្លាប់ក្នុងទ្រង់ទ្រាយធំ បើទោះបីពុំបានបូកបញ្ចូលការសម្លាប់ដែលបានកើតឡើងនៅភូមិទ្រាក៏ដោយ។ អំណះអំណាងរបស់ ខៀវ សំផន នេះ ត្រូវបដិសេធចោល។

### ឃ. ចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ

779. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងបង្ហាញថា ការសម្លាប់ជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រា និងវត្តអូរត្រកួនត្រូវបានរៀបចំ និងគិតទុកជាមុនស្របតាមគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាកំណត់គោលដៅលើជនជាតិចាម[2227]។ ក្នុងការបង្កើតការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើ[2228] ការយល់ឃើញរបស់ខ្លួនដែលថា (១) បក្សកុម្មុយនីស្តកម្ពុជា ក្នុងការខិតខំប្រឹងប្រែងបង្កើតសង្គមគ្មានការប្រតិបត្តិសាសនា និងដូចគ្នាតែមួយគ្មានការបែងចែកវណ្ណៈ បានកំណត់គោលដៅលើជនជាតិចាមដែលជាក្រុមកាន់សាសនា និងជាតិពន្ធុពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[2229] (២) បទបញ្ជាបោសសម្អាតជនជាតិចាមក្នុងភូមិភាគបូព៌ាគឺចេញមកពីថ្នាក់លើ រួមទាំង កែ ពក (លេខាភូមិភាគកណ្តាល (ឧត្តរចាស់)[2230]) និងក្រោយពីកិច្ចប្រជុំមួយដែលបានធ្វើឡើងនៅកំពង់ថ្មជាមួយមេដឹកនាំភូមិភាគបូព៌ាដោយមានការពិភាក្សាអំពីការកម្ទេចខ្មាំង ជនជាតិចាមត្រូវបានផ្លាស់ទីដោយបង្ខំ និងធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[2231] និង (៣) បទបញ្ជាបោសសម្អាតជនជាតិចាមក្នុងភូមិភាគកណ្តាល(ឧត្តរចាស់) គឺចេញពីថ្នាក់លើ និងត្រូវបានអនុវត្តតាមរយៈលេខាស្រុកដែលបានរាយការណ៍ផ្ទាល់ទៅ កែ ពក។ បន្ថែមលើនេះ បន្ទាប់ពីកិច្ចប្រជុំត្រូវបានធ្វើឡើងក្នុងឆ្នាំ ១៩៧៧ ដែលពិភាក្សាអំពីខ្មាំង ជនជាតិចាមត្រូវបានចាប់ខ្លួនជាប្រព័ន្ធផ្អែកតាមបញ្ជីឈ្មោះដែលបានរៀបចំជាស្រេច[2232]។

---

[2227] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៣។

[2228] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១២២៩ និង ១១២៣០ យោងទៅលើកថាខណ្ឌ ៣២២៧, ៣២៧៥ និង ៣២៩០ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

[2229] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១២២៩ ដល់ ១១២៣០ យោងទៅលើកថាខណ្ឌ ៣២២៧, ៣២៧៥ និង ៣២៩០ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកថាខណ្ឌ ៣២២៧ នៃសាលក្រមរបស់ខ្លួន ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា នេះចង់សំណៅទៅលើកថាខណ្ឌ ៣២២៨ ពីព្រោះកថាខណ្ឌ ៣២២៧ ពុំមានការជាប់ពាក់ព័ន្ធ។

[2230] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៥។

[2231] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៥។

[2232] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៩០។

780. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានអត្ថិភាពនៃចេតនាក្នុងការសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំ[2233] និងថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា កែ ពក បានចេញបញ្ជាឱ្យកម្ទេចជនជាតិចាមទាំងអស់[2234] និងពុំមានអត្ថិភាពនៃបទបញ្ជាផ្តល់ទៅថ្នាក់ភូមិភាគក្នុងភូមិភាគមជ្ឈិមនោះទេ[2235]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ ប្រាក់ យុត ប៉ុន្តែពុំមានសក្ខីកម្មដទៃទៀតបានបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់គាត់ឡើយ[2236] និងថា សក្ខីកម្មរបស់ សេង ស្រ៊ុន ដែលថា ជនជាតិចាមពុំត្រូវបានលើកឡើងក្នុងកិច្ចប្រជុំនោះដែលគាត់បានចូលរួមនៅវត្តអូរត្រកួន ពុំត្រូវបានអង្គជំនុំជម្រះសាលាដំបូង"យកមកពិចារណា"[2237]។ ខៀវ សំផន បានចង្អុលបង្ហាញផងដែរថា វ៉ាន់ ម៉ាត់ បានឆ្លើយតបថា ពុំមានការលើកឡើងអំពីផែនការកំណត់គោលដៅជាពិសេសលើជនជាតិចាម[2238]។ គាត់បានអះអាងបន្ថែមថា យូ វ៉ាន់ បានបញ្ជាក់ថា បញ្ជីឈ្មោះដែលលោកស្រីបង្កើតឡើងនោះ មិនមែនជាក់លាក់តែលើជនជាតិចាមនោះទេ ប៉ុន្តែបានរួមបញ្ចូលទាហាននៃរបបសាធារណរដ្ឋខ្មែរ និងជនជាតិវៀតណាមផងដែរ[2239]។ ចុងក្រោយ ខៀវ សំផន បានលើកឡើងថា សក្ខីកម្មរបស់ យាន លន់ និង សយ ឌឿន ពាក់ព័ន្ធទៅនឹងបទបញ្ជាចាប់ខ្លួនជនជាតិចាម គឺជាពាក្យចចាមអារ៉ាម និងពុំគប្បីសំអាងទៅលើឡើយ[2240]។

781. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងមានកំហុសក្នុងការលើកឡើងថា ការយល់ឃើញស្តីពីចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំបានផ្អែកតែលើភស្តុតាងនៃបទបញ្ជាជាក់លាក់ និងកិច្ចប្រជុំប៉ុណ្ណោះ[2241]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ខៀវ សំផន បានបំភ្លៃសក្ខីកម្មរបស់សាក្សីមួយចំនួន[2242]។ ទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា កែ ពក បានបញ្ជាឱ្យកម្ទេចជនជាតិចាមទាំង

---

[2233] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១២។

[2234] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១២-៩១៤។

[2235] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៥-៩២៤។

[2236] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៦។

[2237] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៧។

[2238] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៤។

[2239] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៧។

[2240] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩១៩, ៩២១។

[2241] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៤។

[2242] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៨-៥១៩។

អស់នៅពេលប្រជុំដែលអង្គជំនុំជម្រះយោងទៅលើនោះ ប៉ុន្តែបានយល់ឃើញថា មានកិច្ចប្រជុំមួយត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីការកម្ទេចខ្មាំង និងមិនយូរប៉ុន្មានបន្ទាប់ពីកិច្ចប្រជុំនោះ ជនជាតិចាមត្រូវបានផ្លាស់ទី និងត្រូវបានធ្វើឱ្យបាត់ខ្លួន[2243]។ សហព្រះរាជអាជ្ញាបានចាត់ទុកសក្ខីកម្មរបស់ វ៉ាន់ ម៉ាត់ ស៊ីសង្វាក់គ្នាជាមួយនឹងកិច្ចប្រជុំនេះ[2244]។ ប្រហាក់ប្រហែលគ្នានេះ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពគួរជឿជាក់បានរបស់ ប្រាក់ យុត និង សេង ស៊្រុន និងថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យទទួលយកផ្នែកខ្លះ និងបដិសេធផ្នែកដទៃទៀតនៃសក្ខីកម្មរបស់សាក្សី[2245]។ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ យូ វ៉ាន់ សហព្រះរាជអាជ្ញាបានលើកឡើងថា សក្ខីកម្មរបស់គាត់បានបញ្ជាក់បន្ថែមក្នុងផ្នែកខ្លះនៃសក្ខីកម្មរបស់ ប្រាក់ យុត និងបានបង្ហាញថា បញ្ជីឈ្មោះរបស់អ្នកដែលពុំមែនជនជាតិខ្មែរត្រូវបានធ្វើឡើង និងថា ក្រោយមកអ្នកទាំងនោះត្រូវបានធ្វើឱ្យបាត់ខ្លួនបណ្តើរៗ[2246]។

782. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងភស្តុតាងរបស់សាក្សីនៅពេលគាត់អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កែ ពក បានបញ្ជាឱ្យកម្ទេចជនជាតិចាមទាំងអស់។ កែ ពក អាចចេញបទបញ្ជានោះ ប៉ុន្តែពុំមែនជាអ្វីដែលសាក្សីបាននិយាយ និងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញឡើយ។ ផ្ទុយទៅវិញ ដោយបានសំអាងទៅលើភស្តុតាងរបស់ វ៉ាន់ ម៉ាត់ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទបញ្ជាឱ្យបោសសម្អាតជនជាតិចាមក្នុងភូមិភាគបូព៌ា គឺចេញពីថ្នាក់លើរួមទាំង កែ ពក និងថា កិច្ចប្រជុំមួយត្រូវបានធ្វើឡើងនៅកំពង់ថ្មជាមួយមេដឹកនាំភូមិភាគបូព៌ាដែលពិភាក្សាអំពីការកម្ទេចខ្មាំង[2247]។ វ៉ាន់ ម៉ាត់ បានផ្តល់សក្ខីកម្មថា ភ្លាមៗនោះ ជនជាតិចាមប្រមាណពី ៤០០ ទៅ ៥០០ នាក់ក្នុងភូមិគាត់ និងនៅក្បែរនោះត្រូវបានផ្លាស់ទី បង្ខំឱ្យឡើងកាណូត និងនាំយកទៅស្ទឹងត្រង់កន្លែងដែលពួកគេត្រូវបានចងដោយកម្មាភិបាលខ្មែរក្រហម និងយាមកាមដោយកងប្រដាប់អាវុធ[2248]។ ជនជាតិចាមទាំងនោះត្រូវបានផ្លាស់ទី និងត្រូវបានធ្វើឱ្យបាត់ខ្លួនដោយបង្ខំដែលយោងតាម វ៉ាន់ ម៉ាត់ នេះបានកើតឡើងលើជនជាតិចាមរាប់ពាន់នាក់ដែលត្រូវបានជម្លៀសលើកដំបូង

[2243] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៥។

[2244] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៥។

[2245] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៦។

[2246] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥១៧។

[2247] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៥។

[2248] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៤។

[2249]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បើទោះបីជាព្រឹត្តិការណ៍នេះបានកើតឡើងក្នុងស្រុកក្រូចឆ្មារក៏ដោយ ក៏នេះបានកើតឡើងដំណាលគ្នានៃការចាប់ខ្លួន និងសម្លាប់ជនជាតិចាមដទៃទៀតជាពិសេសនៅក្នុងមន្ទីរសន្តិសុខភូមិទ្រាដែរ[2250]។

783. ដោយពិចារណាលើភស្តុតាងទាំងអស់ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា បទបញ្ជាបោសសម្អាតជនជាតិចាមក្នុងស្រុកក្រូចឆ្មារចេញពីថ្នាក់លើ រួមទាំង កែ ពក និងថា នេះមានលក្ខណៈស្របជាមួយនឹងគោលនយោបាយដែលត្រូវបានអនុវត្តដោយ កែ ពក នៅត្រើយម្ខាងទៀតនៃទន្លេមេគង្គ និងកើតឡើងដំណាលគ្នាជាមួយនឹងការបោសសម្អាតស៊ីជម្រៅដែលបានធ្វើឡើងប្រឆាំងនឹងជនជាតិចាមនៅវត្តអូរត្រកួន និងភូមិទ្រា[2251]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញថា ការសន្និដ្ឋានទាំងនោះជាការពុំសមហេតុផលឡើយ។

784. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការជំទាស់របស់ ខៀវ សំផន ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ ប្រាក់ យុត ហាក់បីដូចជាការជ្រើសយកតែផ្នែកដែលខ្លួនចង់បាននៃភស្តុតាងនោះ ដើម្បីកាត់បន្ថយភាពគួរជឿជាក់ជាអប្បបរមា។ ប្រាក់ យុត គឺជាសាក្សីសំខាន់ដែលត្រូវបានស្តាប់ជាច្រើនថ្ងៃ[2252]។ ភស្តុតាងរបស់លោកស្រីបានរិវឌ្ឍពី"សមាសភាពមិនល្អត្រូវចាប់ខ្លួន" និង"ជនជាតិចាមដែលល្អ"ត្រូវបានទុកជីវិតទាក់ទងនឹងបញ្ជាឱ្យ"បោសសម្អាតជាពិសេសជនជាតិចាមទាំងអស់"[2253]។ លោកស្រីបានផ្តល់ភស្តុតាងផងដែរថា លោកស្រីជឿជាក់ថា មានតែជនជាតិចាមស្រីម្នាក់ដែលរួចជីវិតពីការកម្ទេចក្នុងស្រុកនោះ គឺជាកូនចិញ្ចឹមរបស់គាត់ និងថា លោកស្រីបានសុំជាពិសេសដល់ អោ អាន ឱ្យទុកជីវិតនាង[2254]។ បើទោះបីជាការពិតថា លោកស្រីបានព្យាយាមដាក់ខ្លួនឱ្យឆ្ងាយពីការទទួលខុសត្រូវផ្ទាល់ខ្លួនសម្រាប់បទបញ្ជាដែលលោកស្រីបានអនុវត្តក្នុងការចាប់ខ្លួនជនជាតិចាមទាំងអស់ក៏ដោយ[2255] ក៏នេះពុំបាន

[2249] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៤។

[2250] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៤។

[2251] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៥។

[2252] ប្រាក់ យុត បានផ្តល់សក្ខីកម្មនៅថ្ងៃទី ១៨, ១៩ និង ២០ ខែ មករា ឆ្នាំ ២០១៦។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E1/377.1។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មករា ២០១៦ ឯកសារលេខ E1/378.1។ ប្រតិចារឹកចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E1/379.1។ លោកស្រីត្រូវបានស្តាប់ផងដែរដោយសហចៅក្រមស៊ើបអង្កេតរយៈប្រាំមួយដង និងបានផ្តល់បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារ DC-Cam និងបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៩១។

[2253] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៨-១១។

[2254] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២១។

[2255] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២១។

ប៉ះពាល់ដល់ភាពត្រឹមត្រូវនៃសក្ខីកម្មក្នុងផ្នែកដទៃទៀតរបស់លោកស្រីឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អាចនិយាយបានជាទូទៅថា មានសមាជិកមួយចំនួនតូចនៃថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ឬកម្មាភិបាលនៃបក្ស ឬសមាជិកកងឈ្លប ឬអ្នកដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសហករណ៍ ឬមន្ទីរសន្តិសុខដែលសុខចិត្តបង្ហាញតួនាទីរបស់ខ្លួនពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនោះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា យូ វ៉ាន់ ដែលជានីរសាររបស់ ប្រាក់ យុត បានផ្តល់សក្ខីកម្មថា ប្រាក់ យុត បានបញ្ជាឱ្យគាត់ធ្វើបញ្ជីឈ្មោះទាហាននៃរបបសាធារណរដ្ឋខ្មែរ ជនជាតិចាម និងជនជាតិវៀតណាម[2256]។ ការពិតដែលថា ជនជាតិចាមពុំមែនជាសត្រូវតែមួយដែលត្រូវបានធ្វើបញ្ជីឈ្មោះនោះ ពុំបានប៉ះពាល់ដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានចាត់ទុកថា ជាសត្រូវឡើយ។ បណ្តឹងសាទុក្ខត្រង់ចំណុចនេះគឺចង់មានន័យថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាសក្ខីកម្មលើទិដ្ឋភាពនេះនៅក្នុងការវាយតម្លៃនៃភាពអាចជឿជាក់បាន។ ការលើកឡើងនេះពុំមានមូលដ្ឋានគាំទ្រ។ អង្គជំនុំជម្រះសាលាដំបូងពុំបានខកខានក្នុងការពិចារណាលើសក្ខីកម្មរបស់ សេង ស្រ៊ុន ដែលបានផ្តល់សក្ខីកម្មថា បើទោះបីជាជនជាតិចាមពុំត្រូវបានលើកឡើងជាក់លាក់ក្នុងកិច្ចប្រជុំដែលគាត់បានចូលរួមនៅវត្តអូរត្រកួនក៏ដោយ ក៏ពួកគេត្រូវបានរបបនោះចាត់ទុកថា ជាសត្រូវ ដូចគ្នាទៅនឹងអ្នកដែលពុំមែនជាជនជាតិខ្មែរដទៃទៀតដែរ[2257]។

785. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានមួយដែលពុំមានអង្គជំនុំជម្រះសមហេតុផលអាចធ្វើទៅបាន។ អាស្រ័យហេតុនេះ អំណះអំណាងទាំងនេះត្រូវបដិសេធចោល។

## ២. ការសម្លាប់រង្គាលជនជាតិវៀតណាម

786. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមជាច្រើននៅខេត្តស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ និងក្រចេះ ព្រមទាំងលើដែនទឹកកម្ពុជាប្រជាធិបតេយ្យ[2258]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើ

[2256] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦១។

[2257] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨៦ យោងទៅលើប្រតិចារឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ៧៨-៧៩។

[2258] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០-៣៤៩៧ យោងទៅលើកថាខណ្ឌ ៣៤៥៣, ៣៤៥៥, ៣៤៦១, ៣៤៧១, ៣៤៨៣, ៣៤៨៨។

ញបន្ថែមទៀតថា លក្ខខណ្ឌធាតុផ្សំសត្យានុម័ត និងអត្តនោម័តិនៃអំពើសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញទាក់ទងទៅនឹងការសម្លាប់ទាំងនោះ[2259]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់នៅអូរកន្សែង[2260] អំពើមនុស្សឃាតដែលអង្គជំនុំជម្រះបានយល់ឃើញថា ជាផ្នែកនៃមូលដ្ឋានសម្រាប់ការយល់ឃើញបន្ថែមទៅទៀតដែលថា ធាតុផ្សំអំពើសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញនៅអូរកន្សែង[2261]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា "ការយល់ឃើញអំពីការសម្លាប់រង្គាលនៅមន្ទីរស-២១ បានរួមបញ្ចូលការសម្លាប់ជនជាតិវៀតណាមផងដែរ"[2262]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា បទឧក្រិដ្ឋនៃការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានស្រូបបញ្ចូលបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានសម្រេចដាក់ពិរុទ្ធភាពតែពីបទសម្លាប់រង្គាលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាមប៉ុណ្ណោះ[2263]
។

787. ខៀវ សំផន បានចោទប្រកាន់កំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង វត្តខ្សាច់ ខេត្តក្រចេះ និងលើដែនទឹកកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងនៅមន្ទីរសន្តិសុខអូរកន្សែង[2264]។ ខៀវ សំផន បានលើកឡើងទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការសម្លាប់ទាំងនេះ[2265]។

---

[2259] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៨-៣៥៩១ យោងទៅលើ*ក្នុងចំណោម*កថាខណ្ឌ ២៥៧១, ២៦២១, ២៩២៦, ២៩៥៩, ៣៤៦៦-៣៤៦៧, ៣៤៧៩, ៣៤៨១-៣៤៨២, ៣៤៨៨។

[2260] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៥៩ យោងទៅលើកថាខណ្ឌ ២៩២៦។

[2261] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៧៨៨ យោងទៅលើកថាខណ្ឌ ២៩២៦, ២៩៥៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៦៨ (យល់ឃើញថា ការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញនៅមន្ទីរសន្តិសុខអូរកន្សែង"ទាក់ទងទៅនឹងយ៉ាងតិចអ្នកជាប់ឃុំ ១១១ នាក់")។

[2262] អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៧៨៨ យោងទៅលើកថាខណ្ឌ ២៥៧១, ២៦២១ (រំឭកការយល់ឃើញដែលថា "ទាហានរាប់រយនាក់ និងជនស៊ីវិលជនជាតិវៀតណាម ត្រូវបានសម្លាប់នៅមន្ទីរស-២១")។

[2263] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៣៧។

[2264] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤២-៨៤៧ (មន្ទីរសន្តិសុខអូរកន្សែង) ៩៨៧-៩៩២ (ស្វាយរៀង) ៩៩៣-១០០២ (ដែនទឹកកម្ពុជា) ១០០៣-១០០៥ (កំពង់ឆ្នាំង) ១០០៦-១០១៣ (វត្តខ្សាច់) ១០១៤-១០១៧ (ក្រចេះ)។

[2265] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១៨-១០២៧។

788. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិវៀតណាមត្រូវបានសម្លាប់នៅទីតាំងខាងលើ និងខកខានក្នុងការបង្ហាញថា បទឧក្រិដ្ឋនៃការសម្លាប់រង្គាល និងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទាំងនោះពុំត្រូវបានបង្ហាញត្រឹមត្រូវ[2266]។ សហមេធាវីនាំមុខមានទស្សនៈដូចគ្នានឹងសហព្រះរាជអាជ្ញាស្តីអំពីកំហុសដែលបានចោទប្រកាន់ដោយ ខៀវ សំផន ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាម និងការកំណត់ប្រភេទគតិយុត្តនោះ[2267]។

789. នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញផ្នែកច្បាប់របស់ខ្លួនពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើហេតុការណ៍នៃការសម្លាប់ និងអត្ថិភាពនៃគោលនយោបាយដែលបាន"បង្កើតឡើងដោយមជ្ឈិម"នៅពេលនោះដែលកំណត់គោលដៅលើជនជាតិវៀតណាម[2268]។ ភស្តុតាងជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ដែលគួរឱ្យជឿជាក់បានទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនអំពីការសម្លាប់ជាក់លាក់ គប្បីពិចារណាជារួមជាមួយនឹងការយល់ឃើញដែលត្រូវបានបង្ហាញថា គោលនយោបាយ"កំណត់គោលដៅលើជនជាតិវៀតណាមសម្រាប់ការចាត់ទុកជាសត្រូវ មានអត្ថិភាពក្នុងកម្ពុជាប្រជាធិបតេយ្យពេញមួយអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ"[2269]។

## ក. ការសម្លាប់ជនជាតិវៀតណាមនៅខេត្តស្វាយរៀង

790. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមចំនួនបួនគ្រួសារត្រូវបានសម្លាប់នៅខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨[2270]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនទៅលើសក្ខីកម្មរបស់សាក្សី ស៊ិន ឆែម ដែលបានអះអាងថា ជនជាតិវៀតណាមចំនួនបួនគ្រួសារដែលរស់នៅប្រហែលមួយគីឡូម៉ែត្រពីផ្ទះគាត់ត្រូវបានប្រធានឃុំនាំចេញទៅទាំងយប់ និងបានបាត់ខ្លួន[2271]។ លោកស្រីបានឆ្លើយថា

---

[2266] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦០០-៦០៣ (មន្ទីរសន្តិសុខអូរកន្សែង) ៦០៤-៦០៧ (វត្តខ្សាច់) ៦០៨-៦១២ (ក្រចេះ) ៦១៣-៦១៥ (កំពង់ឆ្នាំ) ៦១៦-៦២០ (ដែនទឹកកម្ពុជាប្រជាធិបតេយ្យ)។

[2267] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨, ២៩៩-៣០៧។

[2268] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៧។

[2269] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៧។ *សូមមើលផងដែរ* ផ្នែក VIII.ខ.៥.ក។

[2270] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០-៣៤៩១ យោងទៅលើកថាខណ្ឌ ៣៤៥៣-៣៤៥៥។

[2271] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៣ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) ឯកសារលេខ E1/367.1 ទំព័រ ២១-២២, ៥៦។

ពួកគេត្រូវបានសម្លាប់ដោយ សារិន និងអ្នកដទៃទៀត[2272]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ប្រភពនៃការដឹងរបស់ ស៊ិន ឆែម ពុំច្បាស់លាស់ និងថា លោកស្រីពុំបានឃើញការសម្លាប់នោះផ្ទាល់ ប៉ុន្តែថា លោកស្រីបានឆ្លើយថាបានឃើញសាកសពរាយប៉ាយដែលលោកស្រីបានឮថា ត្រូវបានគេសម្លាប់នៅយប់មុននោះ[2273]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញរបស់ខ្លួនថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិវៀតណាមជាក្រុមមួយ និងចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ បានអំពាវនាវយ៉ាងទូលំទូលាយឱ្យធ្វើការកម្ទេចក្រុមនេះ និងដោយផ្អែកលើនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការសន្និដ្ឋានសមហេតុផលតែមួយគត់ចេញពីការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួនជនជាតិវៀតណាមបួនគ្រួសារនោះ និងអត្ថិភាពនៃសាកសពក្រោយមកនោះ គឺថា ការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួនគឺជាលទ្ធផលនៃការអនុវត្តន៍ជាប្រព័ន្ធក្នុងផ្នែកនេះនៃគោលនយោបាយ និងថា អ្នកដែលត្រូវបានធ្វើឱ្យបាត់ខ្លួននោះត្រូវបានសម្លាប់[2274]។

791. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិវៀតណាមត្រូវបានសម្លាប់ក្នុងខេត្តស្វាយរៀង ដោយសារការយល់ឃើញនេះបានផ្អែកតែមួយគត់ទៅលើសក្ខីកម្មរបស់ ស៊ិន ឆែម ដែលសក្ខីកម្មរបស់គាត់បានផ្អែកលើពាក្យចចាមអារ៉ាម និងបានចោទប្រកាន់ថា ពុំច្បាស់លាស់ ពុំស៊ីសង្វាក់គ្នា និងពុំគួរឱ្យទុកចិត្តបានឡើយ[2275]។

792. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានកំណត់ចរិតលក្ខណៈត្រឹមត្រូវនៃសក្ខីកម្មរបស់សាក្សី ដែលតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាថា ជាការច្បាស់លាស់ និងស៊ីសង្វាក់គ្នា[2276]។

793. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[2277]។

---

2272 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៣ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (សិន ឆែម) ឯកសារលេខ E1/367.1 ទំព័រ ២២-២៤។

2273 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៣ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (សិន ឆែម) ឯកសារលេខ E1/367.1 ទំព័រ ៦២។

2274 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៣។

2275 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៨៧-៩៩២។

2276 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៩៦-៥៩៩។

2277 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

794. បើទោះបីជា ខៀវ សំផន បានលើកឡើងត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "សាក្សីពុំដែលបានឃើញការសម្លាប់"នោះក៏ដោយ[2278] ក៏អង្គជំនុំជម្រះសាលាដំបូងបានរកឃើញកម្រិតនៃការលើកលម្អិតក្នុងសក្ខីកម្មរបស់គាត់មានលក្ខណៈគ្រប់គ្រាន់បង្ហាញថា ការសម្លាប់បានកើតឡើងក្នុងខេត្តស្វាយរៀង[2279]។ ស៊ិន ឆែម បានរៀបការជាមួយប្រធានឃុំខេត្តស្វាយរៀង[2280]។ សាក្សីបានផ្តល់សក្ខីកម្មថា លោកស្រីបានឃើញអ្នកនៅរស់មួយគ្រួសារក្នុងចំណោមបួនគ្រួសារនោះ និងបានឃើញ"ដោយផ្ទាល់ភ្នែក"ជនជាតិវៀតណាមដែលត្រូវបានចងក្រពាត់ដៃទៅក្រោយ[2281]។ ពិតណាស់អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការរៀបរាប់ទីមួយក្នុងការបង្កើតការយល់ឃើញដែលរងការជំទាស់នេះ[2282]។ ជាសំខាន់ ស៊ិន ឆែម ក៏បានផ្តល់សក្ខីកម្មផងដែរថា មានតែបួនគ្រួសារ"កាត់វៀតណាម"ដែលអ្នកខ្លះជាសាច់ញាតិរបស់គាត់[2283] ដែលស្ថិតនៅប្រមាណមួយរយម៉ែត្រក្នុងភូមិគាត់ និងថា គ្រួសារជនជាតិវៀតណាមត្រូវបានគេ"នាំចេញទៅ"[2284]។ ដោយពិចារណាលើលក្ខណៈលម្អិតជារួមដែលបានផ្តល់ដោយសាក្សីក្នុងសក្ខីកម្មរបស់គាត់ និងការយល់ឃើញថា មានអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាមក្នុងកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលត្រូវបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារក្នុងខេត្តស្វាយរៀងឡើយ។

### ខ. ការសម្លាប់ជនជាតិវៀតណាមលើដែនទឹកកម្ពុជាប្រជាធិបតេយ្យ

---

[2278] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៥៣។

[2279] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៥៣ (ការយល់ឃើញដែលថា កាលបរិច្ឆេទនៃការធ្វើឱ្យបាត់ខ្លួនរបស់គ្រួសារវៀតណាម គឺនៅក្នុងឆ្នាំ១៩៧៨ ចារីផ្ទាល់"មានឈ្មោះ សាវិន និងអ្នកដទៃទៀតមកពីគណៈឃុំថ្មី និងអ្នកយាមសន្តិសុខ" និងថា ប្រភពនៃភស្តុតាងចចាមអារ៉ាមពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដទៃទៀតដែលបាត់ខ្លួន និងសម្លាប់ គឺជាអ្នកជិតខាងជិតស្និទ្ធរបស់ជនរងគ្រោះនៅភូមិទួលវិហារ ស៊ីការ កៀន តាស៊ីវ) យោងទៅលើប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1ទំព័រ ២១-២៥, ៥៦, ៦២។ កំណត់ស្តាប់ចម្លើយរបស់ ស៊ិន ឆែម ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ E3/7794 ERN 00249917 ទំព័រ ៣។

[2280] ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1 ទំព័រ ១៤។

[2281] ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1 ទំព័រ ៦១-៦២។

[2282] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៥៣ យោងទៅលើប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1 ទំព័រ ៦១។

[2283] ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1 ទំព័រ ៥៨។

[2284] ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ (ស៊ិន ឆែម) E1/367.1 ទំព័រ ២១។

795. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមលើដែនទឹកកម្ពុជាប្រជាធិបតេយ្យនៅក្រោយខែ មេសា ឬឧសភា ឆ្នាំ ១៩៧៧ នៅផែអូរឈើទាលតាមរយៈភស្តុតាងរបស់ ប៉ាក សុខ និងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ដែលបានរាយការណ៍ដោយកងពលលេខ ១៦៤[2285]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កងកម្លាំងប្រដាប់អាវុធបក្សកុម្មុយនីស្តកម្ពុជាទទួលបញ្ជាឱ្យ"កំណត់គោលដៅជាប្រព័ន្ធ"លើកាណូតជនជាតិវៀតណាមដែលនៅក្បែរដែនទឹកកម្ពុជាប្រជាធិបតេយ្យ ដោយគ្មានការបែងចែករវាងគោលដៅយោធា និងជនស៊ីវិលនោះទេ និងថា អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមមួយចំនួនត្រូវបានសម្លាប់ដោយចេតនា[2286]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប៉ាក សុខ គឺជាសមាជិកកងពលលេខ ១៦៤ និងបានឆ្លើយថា នៅចន្លោះពី ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អ្នកនេសាទ និងជនភៀសខ្លួនជនជាតិថៃ និងជនជាតិវៀតណាមត្រូវបានចាប់ខ្លួន និងសម្លាប់។ គាត់បានផ្តល់សក្ខីកម្មថា ប្រសិនបើ"យួន"ត្រូវបានចាប់ខ្លួន បើទោះបីជាទាហាន ឬជនភៀសខ្លួនក៏ដោយ ពួកគេត្រូវបានកម្ទេច និងថា ទាហានជនជាតិវៀតណាមមួយចំនួនដែលចាប់បានត្រូវបានបញ្ជូនទៅមន្ទីរស-២១[2287]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា សុខ ប៉ាក បានផ្តល់សក្ខីកម្មផងដែរអំពីហេតុការណ៍នៃការសម្លាប់ជាក់លាក់មួយចំនួន និងបានអះអាងថា ក្នុងពេលមួយគាត់ផ្ទាល់បានជាប់ពាក់ព័ន្ធនឹងការដឹកដោយរថយន្តនូវជនជាតិវៀតណាមដែលចាប់បានពី ១២ ទៅ ១៣ នាក់ទៅផែ និងថា មានម្នាក់ជាទាហានក្នុងចំណោមជនជាតិវៀតណាមដែលចាប់បានទាំងនោះចំណែកអ្នកដទៃទៀតគឺជាប្រជាជនធម្មតាឆ្ពោះទៅប្រទេសថៃ។ គាត់បានឆ្លើយតបថា ក្នុងចំណោមនោះមានទារកម្នាក់ និងថា ទាហានខ្មែរក្រហមបានគ្រវែងទារកនោះចូលក្នុងសមុទ្រពីព្រោះយំឮពេក[2288]។ ពាក់ព័ន្ធនឹងការសម្លាប់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងរបាយការណ៍កងពលលេខ ១៦៤ ទៅបង ៨៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ មាស មុត បានរាយការណ៍ទៅ សុន សេន អំពីហេតុការណ៍ពីករណីពាក់ព័ន្ធនឹងកាណូតជនជាតិវៀតណាម។ ក្នុងហេតុការណ៍ទីមួយ កងពលលេខ ១៦៤ បានបាញ់កាណូតជនជាតិវៀតណាមបណ្តាលឱ្យលិច និងហេតុការណ៍ទីពីរកាណូតជនជាតិវៀតណាមពីរចាប់បាននៅកោះតាង និងជនជាតិវៀតណាម ៧៦ នាក់ ក្មេង ចាស់ ប្រុស

---

[2285] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៣, ៣៤៥៧។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០។

[2286] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៣ យោងទៅលើកថាខណ្ឌ ៣៤៥៦-៣៤៦១។

[2287] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៧។

[2288] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥៩ យោងទៅលើប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ (ប៉ាក សុខ) ឯកសារលេខ E1/369.1 ទំព័រ ២១-២២។

ស្រី ត្រូវបានចាប់ចង និងបាននាំឡើងគោក និងពីរនាក់បានបាត់ខ្លួនក្នុងទឹកដោយសារកូនទូកសណ្តោងឃ្លេងឃ្លោងក្រឡាប់[2289]។

796. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើនក្នុងការយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ និងបានជំទាស់ទៅនឹងតម្លៃជាភស្តុតាងនៃឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ[2290] និងថា ការសម្លាប់នោះអាចកើតឡើងដោយសារការប្រទូសរ៉ាយគ្នារវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម[2291]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ការសម្លាប់នោះបានកើតឡើងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ដោយផ្អែកលើរបាយការណ៍តែមួយពីកងពលលេខ ១៦៤ ដែលនេះពុំមែនជាឯកសារដើម និងត្រឹមតែជាឯកសារចម្លងដែលទទួលបានក្រោមកាលៈទេសៈមិនច្បាស់លាស់[2292]។ គាត់បានអះអាងថា របាយការណ៍នេះពុំបាននិយាយអ្វីអំពីវាសនារបស់ជនជាតិវៀតណាមពីរនាក់នៅពេលដែលទូកលិច និងថា ដោយសាររបាយការណ៍នេះបានបង្ហាញថា មានទូកជនជាតិវៀតណាមជាច្រើនដទៃទៀត ដែលនេះទំនងជាថា ជនជាតិវៀតណាមដែលធ្លាក់ទឹកនោះត្រូវបានជួយសង្គ្រោះដោយទូកវៀតណាមដទៃទៀត[2293]។ ខៀវ សំផន បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ជនជាតិវៀតណាមពីរនាក់ដែលធ្លាក់ទឹកនោះត្រូវបានសម្លាប់ដោយចេតនា ដោយសាររបាយការណ៍បានបញ្ជាក់ថា កងពលលេខ ១៦៤ បានស្វែងរកពួកគេពុំឃើញ ដែលនេះបង្ហាញថា បុគ្គលពីរនាក់នោះពុំត្រូវបានរុញទម្លាក់ទឹកដោយចេតនាឡើយ[2294]។

797. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាងនោះពុំមានភាពជាក់លាក់គ្រប់គ្រាន់ និងជាការប៉ាន់ស្មាន[2295]។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា ភស្តុ

---

[2289] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦០ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/997 ERN (EN) 00233649។

[2290] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៧-១០០០, ១០០២-១០០៣។

[2291] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០១។

[2292] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៧។

[2293] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៩៨។

[2294] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០២។

[2295] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១៨។

តាងនោះពុំមានការបង្ហាញនូវទំនាក់ទំនងរវាងហេតុការណ៍នោះជាមួយនឹងការប្រទូសរ៉ាយគ្នាឡើយ ប៉ុន្តែថា នេះបានបង្ហាញនូវចេតនាតម្រូវនៃការសម្លាប់[2296]។

798. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[2297]។

799. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានជំទាស់តែទៅនឹងការសម្លាប់ដែលត្រូវបានរកឃើញថា បានកើតឡើងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ប៉ុន្តែពុំបានជំទាស់ទៅលើការសម្លាប់ដែល ប៉ាក សុខ បានពិពណ៌នាក្រោយខែ មេសា ឬខែ ឧសភា ឆ្នាំ ១៩៧៧។ អំណះអំណាងរបស់គាត់ដែលថា របាយការណ៍កងពលលេខ ១៦៤ គឺជាឯកសារចម្លងជាជាងឯកសារដើមនោះពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានចាត់ទុកឯកសារនោះគួរឱ្យជឿជាក់ និងទុកចិត្តបាន។ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើរបាយការណ៍នេះតែមួយក្នុងការយល់ឃើញថា ជនជាតិវៀតណាមត្រូវបានសម្លាប់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ជាការសមហេតុផល ជាពិសេសដោយសារបានពិចារណាឃើញថា ប៉ាក សុខ បានបញ្ជាក់បន្ថែមថា អ្នកទោសាទ និងជនភៀសខ្លួនជនជាតិវៀតណាមត្រូវបានចាប់ខ្លួន និងសម្លាប់ និងដោយពុំគិតថា ជាទាហាន ឬជនភៀសខ្លួននោះទេ ពួកគេត្រូវចាប់ខ្លួន និងសម្លាប់។

800. សារណារបស់ ខៀវ សំផន ដែលថា ការសម្លាប់នោះអាចពុំមែនជាជនស៊ីវិល ពុំគួរឱ្យជឿជាក់ឡើយ។ គ្មានអ្វីក្នុងរបាយការណ៍បានបង្ហាញនូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដែលបានបន្តនៅពេលនោះ។ ផ្ទុយទៅវិញ របាយការណ៍ដែលបានសរសេរដោយ មាស មុត បានរៀបរាប់អំពីព្រឹត្តិការណ៍ដែលកាណូតធុន ២២ សេស របស់ជនជាតិវៀតណាមត្រូវបានបាញ់ និងលិច និងបន្ទាប់ពីបានឡើងលើកាណូតរបស់ជនជាតិវៀតណាមពីរគ្រឿងទៀត និងបានចាប់ចង"ក្មេង ចាស់ ប្រុស និងស្រី" និងពីរនាក់បានធ្លាក់ចូលទឹករកពុំឃើញ[2298]។ បើទោះបីជាកាណូតទីមួយគឺជានាវាយោធាដែលដឹកទាហានជនជាតិវៀតណាមក៏ដោយ ក៏នេះពុំបានរារាំងការសម្លាប់ទាំងនោះ ដែលជាផ្នែកនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចមានជនរងគ្រោះដែលពុំមែនជាជនស៊ីវិល ដរាបណា

---

[2296] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១៩-៦២០។

[2297] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

[2298] របាយការណ៍កម្ពុជាប្រជាធិបតេយ្យ"*ទូរស័ព្ទទំនាក់ទំនងសម្ងាត់ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨*" ឯកសារលេខ E3/997 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨។

ការវាយប្រហារនោះបានកំណត់គោលដៅលើជនស៊ីវិល[2299]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការវាយប្រហារបានកំណត់គោលដៅលើជនស៊ីវិលជនជាតិវៀតណាម និងថា ជនជាតិវៀតណាមត្រូវបាន កំណត់គោលដៅ និងសម្លាប់ដោយពុំគិតថា ពួកគេជាទាហាន ឬជនស៊ីវិលនោះឡើយ។

801. អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការកំណត់ថា ក្នុងកាលៈទេសៈនៃការសម្លាប់នោះ បានបង្ហាញថា ចារីផ្ទាល់មានចេតនាសម្លាប់។ បញ្ហាថាតើ ចារីជាក់ស្តែងមានចេតនាធ្វើឱ្យបុគ្គលពីរនាក់លង់ទឹកស្លាប់ដែល ធ្លាក់ពីលើទូកក្នុងហេតុការណ៍ទីពីរថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ដូចបានពិពណ៌នាក្នុងរបាយការណ៍ ដែរ ឬ យ៉ាងណានោះ ពុំជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានគោល នយោបាយចាប់ជាប្រព័ន្ធ ឬកំណត់គោលដៅលើទូកកាណូតជនជាតិវៀតណាម និងថា ជនភៀសខ្លួន ឬអ្នក នេសាទជនជាតិវៀតណាមនឹងត្រូវសម្លាប់នៅហ្នឹងកន្លែង ឬនៅលើគោកនៅពេលដែលចាប់បានឡើយ[2300]។

802. ផ្អែកលើការយល់ឃើញនេះពាក់ព័ន្ធទៅនឹងលំនាំនៃអំពើក្នុងការរឹបអូសកាណូតជនជាតិវៀតណាមទាំងអស់ និងការយល់ឃើញដែលថា មានអត្ថិភាពគោលនយោបាយទូទាំងប្រទេសកំណត់គោលដៅលើជនជាតិវៀត ណាមសម្រាប់ការចាត់ទុកជាសត្រូវ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលអំពី របាយការណ៍នោះដែលជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការបង្ហាញថា ហេតុការណ៍សម្លាប់ពីរករណីបានកើតឡើង ក្នុងកាលៈទេសៈដែលបានពិពណ៌នានោះ។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធចំណុច នេះត្រូវបដិសេធចោល។

## គ. ការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តកំពង់ឆ្នាំង

803. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រពន្ធ កូន និងម្តាយក្មេករបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ព្រមទាំងសមាជិកជនជាតិវៀតណាមប្រាំមួយគ្រួសារដទៃទៀតត្រូវបានសម្លាប់ដោយចេតនានៅកោះ តាម៉ូវក្នុងឆ្នាំ ១៩៧៧ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បានកើតឡើងក្នុងបរិបទនៃការ ប្រមូលផ្តុំ និងការសម្រិតសម្រាំងជាប្រព័ន្ធ និងតាមការរៀបចំនូវជនជាតិពន្ធុវៀតណាម និងការបំបែកពួក គេចេញពីប្រជាជនខ្មែរ[2301]។

---

[2299] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Martić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-11-A សាលដីកា ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ (“សាលដីការឿងក្តី *Martić* (ICTY)”) កថាខណ្ឌ ៣១៣-៣១៤។

[2300] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៦១។

[2301] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០ (យោងទៅលើកថាខណ្ឌ ៣៤៧១) ៣៤៩៤។

804. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើតែសក្ខីកម្មផ្ទាល់មាត់របស់ ប្រាក់ ខឿន និងការយល់ឃើញដែលថា ការសម្លាប់កូនៗរបស់គាត់ដទៃទៀតត្រូវបានបង្ហាញក្រៅតែកូនប្រុសពៅរបស់គាត់នោះ[2302]។

805. សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការពិចារណាភាពជារួមនៃភស្តុតាងរបស់ ប្រាក់ ខឿន និងថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចប្រព្រឹត្តកំហុសពាក់ព័ន្ធទៅនឹងការដែលថាតើកូនរបស់ ប្រាក់ ខឿន ប៉ុន្មាននាក់ត្រូវបានសម្លាប់នោះក៏ដោយ ក៏ ខៀវ សំផន ពុំបានបង្ហាញថា កំហុសនៃការយល់ឃើញនេះធ្វើឱ្យសាលក្រមទៅជាមោឃៈឡើយ[2303]។

806. សហមេធាវីនាំមុខបានលើកឡើងថា ការរៀបរាប់របស់ ប្រាក់ ខឿន មានលក្ខណៈស៊ីសង្វាក់គ្នា និងរួមបញ្ចូលភស្តុតាងផ្ទាល់នៃព្រឹត្តិការណ៍ជុំវិញការសម្លាប់[2304]។

807. អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ ប្រាក់ ខឿន ដោយសារអង្គជំនុំជម្រះបានចាត់ទុកសក្ខីកម្មនេះមានការជាប់ពាក់ព័ន្ធ និងអាចទុកចិត្តបានគ្រប់គ្រាន់។ ការពិនិត្យលើប្រតិចារឹកពាក់ព័ន្ធបង្ហាញថា សក្ខីកម្មរបស់ ប្រាក់ ខឿន បង្ហាញពីទុក្ខសោក និងគួរឱ្យជឿជាក់បាន និងមានភស្តុតាងពាក់ព័ន្ធសំខាន់ដែលមានចរិតលក្ខណៈដោយផ្ទាល់ និងចចាមអារ៉ាម។ ប្រាក់ ខឿន បានផ្តល់ភស្តុតាងអំពីអ្វីដែលគាត់ទំនងជាពុំអាចបំភ្លេចបាន ឬប្រឌិតឡើងបានឡើយ។ គាត់បានផ្តល់ការរៀបរាប់យ៉ាងល្អិតល្អន់[2305]។ នេះជារឿងធម្មតាដែលការសម្លាប់ជាក់ស្តែងពុំត្រូវបានគេឃើញផ្ទាល់ភ្នែកនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដែលថា ការរៀបរាប់របស់ ប្រាក់ ខឿន បានផ្តល់ការយល់ស៊ីជម្រៅពាក់ព័ន្ធក្នុងកាលៈទេសៈជុំវិញការសម្លាប់នោះ ជាពិសេសទាក់ទងទៅនឹងការប្រព្រឹត្ត

---

2302 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៣-១០០៥។

2303 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១៤-៦១៥។

2304 សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣០៣។

2305 *សូមមើល ឧ.* ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) E1/361.1 ទំព័រ ៥៦-៥៩ (ក្រុមមួយដែលមានប្រាំពីរគ្រួសារដែលប្តីប្រពន្ធខ្មែរវៀតណាម ត្រូវបានបណ្តើរពីបួន ទៅ ដប់គីឡូម៉ែត្រមុនពេលត្រូវបានបំបែកជាពីរក្រុម ខ្មែរ និងវៀតណាម។ ៥៩-៦០ (កូនប្រុសពៅរបស់គាត់ និងប្រពន្ធត្រូវបានយក់ទៅបាត់)។ ៦៨-៧០ (មេកងរបស់គាត់ជូនដំណឹងនៅថ្ងៃបន្ទាប់ថា ប្រពន្ធ និងកូនរបស់គាត់ត្រូវបានសម្លាប់ ក្រោយមកគាត់ត្រូវបានសម្រាកមួយអាទិត្យជាមួយបុរសម្នាក់ទៀតដែលមានប្រពន្ធវៀតណាមដែរ)។

ទៅលើជនជាតិវៀតណាមនៅក្នុងភូមិនៅមុន ក្នុងអំឡុងពេល និងក្រោយព្រឹត្តិការណ៍[2306]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ ខៀវ សំផន[2307] ប្រាក់ ខឿន ពុំបានផ្ដល់សក្ខីកម្មថា សមមិត្ត ហ៊ីម ដែលប្រាប់គាត់អំពីការសម្លាប់ និងជាប្រភពនៃភស្តុតាងចចាមអារ៉ាមនោះ ពុំបានឃើញការសម្លាប់ ប៉ុន្តែផ្ទុយទៅវិញថា ហ៊ីម ពុំបានប្រាប់ឈ្មោះអ្នកសម្លាប់[2308]។ អង្គជំនុំជម្រះសាលាដំបូងដែលមានឱកាសល្អប្រសើរក្នុងការវាយតម្លៃភាពអាចជឿទុកចិត្តបាន និងជឿជាក់បានរបស់ ប្រាក់ ខឿន ក្នុងបន្ទប់សវនាការ ដូចនេះ ពុំបានប្រព្រឹត្តកំហុសក្នុងការសំអាងតែទៅលើសក្ខីកម្មលម្អិតស៊ីសង្វាក់ និងជឿជាក់បាននោះឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា កូនៗរបស់ ប្រាក់ ខឿន ត្រូវបានសម្លាប់ដោយចេតនានៅកោះតាម៉ូវ ខេត្តកំពង់ឆ្នាំងចុងឆ្នាំ ១៩៧៧"[2309]។ បើទោះបីជា ប្រាក់ ខឿន បានផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងការស្លាប់កូនរបស់គាត់ពីរនាក់ដោយសារជំងឺ ឬការអត់អាហារក៏ដោយ ក៏ពុំត្រូវបានរួមបញ្ចូលទៅក្នុងក្រុមនៃគ្រួសារដែលរៀបការកាត់ពូជសាសន៍ដែលត្រូវបានគេនាំចេញទៅ និងបំបែកជាពីរក្រុមឡើយ។ មានតែកូនប្រុសពៅរបស់គាត់ប៉ុណ្ណោះដែលត្រូវបានគេនាំចេញទៅ[2310]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញផ្នែកច្បាប់ដែលថា "កូនៗរបស់ ប្រាក់ ខឿន [...] ត្រូវបានសម្លាប់ដោយចេតនានៅកោះតាម៉ូវក្នុងឆ្នាំ ១៩៧៧" និងថា "ធាតុផ្សំសត្យានុម័ត និងអត្តនោម័តិនៃអំពើមនុស្សឃាតត្រូវបានបង្ហាញដោយពាក់ព័ន្ធទៅនឹងការសម្លាប់ទាំងនេះ"[2311]។ ការយល់ឃើញដែលថា មានតែកូនប្រុសពៅម្នាក់ប៉ុណ្ណោះដែលត្រូវបានគេសម្លាប់ គឺជាកំហុសដោយសារខ្វះការលម្អិត ពុំមែនខ្លឹមសារដែលធ្វើឱ្យសាលក្រមទៅជាមោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះទេ[2312]។ ដូច្នេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

---

[2306] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១៤ យោងទៅលើប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) E1/361.1 ទំព័រ ៤០-៤២, ៤៧, ៤៩, ៥១។ សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣០៣ យោងទៅលើប្រតិចារឹកថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) E1/361.1 ទំព័រ ៥៧-៥៨, ៥៩-៦០, ៧០, ៧២។

[2307] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៤។

[2308] ប្រតិចារឹកថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) E1/361.1 ទំព័រ ៤២-៤៣។

[2309] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧១ (សេចក្តីបញ្ជាក់បន្ថែម)។

[2310] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៦៦ យោងទៅលើប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) E1/361.1 ទំព័រ ៥៨, ៥៩-៦០។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៥។

[2311] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៤។

[2312] *ប្រៀបធៀប* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៩ យោងទៅលើវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

## ឃ. ការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់

808. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនស៊ីវិលវៀតណាមត្រូវបាននាំទៅ និងសម្លាប់ក្នុងទ្រង់ទ្រាយធំនៅវត្តខ្សាច់ក្នុងចុងឆ្នាំ ១៩៧៨ ដោយសារជាក្រុមជនជាតិពន្ធុតាមការសន្មត និងបន្ទាប់ពីមានបទបញ្ជារបស់ថ្នាក់លើ[2313]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា បទបញ្ជា ការប្រមូលផ្តុំដោយមានលក្ខណៈរៀបចំជនជាតិវៀតណាម ការសម្រិតសម្រាំង និងការកម្ទេចជាប្រព័ន្ធ បានបង្ហាញនូវចេតនាច្បាស់លាស់ក្នុងការសម្លាប់[2314]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្បែរ និងក្នុងភូមិយាង ស្រុកជីក្រែង(តំបន់ ១០៦) ខេត្តសៀមរាប ត្រូវបាននាំទៅ និងសម្លាប់ក្នុងវត្តខ្សាច់ និងថា បើទោះបីជាភស្តុតាងដែលបានលើកឡើងនោះពុំអនុញ្ញាតឱ្យអង្គជំនុំជម្រះបង្ហាញចំនួនពិតប្រាកដនៃជនរងគ្រោះក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថាយ៉ាងតិចមានជនស៊ីវិលវៀតណាមពី ១០ ទៅ ២០ នាក់ត្រូវបានសម្លាប់នៅទីនោះ[2315]។

809. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា ជនជាតិវៀតណាមមួយចំនួនត្រូវបានសម្លាប់ និងថា ជនជាតិវៀតណាមទាំងអស់នៅក្នុង និងក្បែរភូមិយាងត្រូវបានសម្លាប់នៅវត្តខ្សាច់ និងថា ការសម្លាប់នោះត្រូវបានធ្វើឡើងតាមបទបញ្ជារបស់ថ្នាក់លើ[2316]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា យាយ ហាយ និង តា យុត ត្រូវបានសម្លាប់ និងបានអះអាងថា សក្ខីកម្មរបស់សាក្សី ស៊ាន ស៊ង់ គឺជាពាក្យចចាមអារ៉ាមចេញពីប្រភពដែលពុំស្គាល់ច្បាស់លាស់ និងថា សក្ខីកម្មរបស់ អ៊ុំ ស៊ន មានភាពផ្ទុយគ្នា និងថា នេះទំនងជាគាត់ពុំមែនជាសាក្សីផ្ទាល់នៃការសម្លាប់ទាំងនោះ និងថា សាក្សី អ៊ុំ វុន បានដឹងតាមអ្នកដទៃថា យាយ ហាយ និង តា យុត ត្រូវបានសម្លាប់ និងថា តា យុត ត្រូវបានសម្លាប់នៅពេលកងទ័ពវៀតណាមចូលមកដល់[2317]។ ខៀវ សំផន បានអះអាងថា គ្មាននរណាម្នាក់បានឃើញអ្វីកើតឡើងលើ យាយ ហាយ និង តា យុត និងថា នេះអាចនិយាយបានថា ព្រឹត្តិការណ៍នេះបានកើតឡើងក្រៅវិសាលភាពយុត្តាធិការពេលវេលានៃកិច្ចដំណើរការនីតិវិធី[2318]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា សមាជិកជន

---

[2313] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០ (យោងទៅលើកថាខណ្ឌ ៣៤៨២), ៣៤៩៥។

[2314] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៥។

[2315] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨២។

[2316] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៦-១០១៧។

[2317] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៧។

[2318] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៨។

ជាតិវៀតណាមនៃគ្រួសាររបស់ ជុំ ត្រូវបានសម្លាប់ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ អ៊ី វុន និង អ៊ុំ ស៊ន់ និងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឡូញ ឃុន ប៉ុន្តែសក្ខីកម្មទាំងនេះពុំមានភាពច្បាស់លាស់ ហើយកំណត់ហេតុស្តាប់ចម្លើយសាក្សី មានតម្លៃជាភស្តុតាងក្នុងកម្រិតទាប និង ឡូញ ឃុន ពុំបានឃើញផ្ទាល់នូវការសម្លាប់ណាមួយឡើយ[2319]។ ខៀវ សំផន បានលើកឡើងថា ដោយសារ ជុំ និយាយតែចិន និងឪពុករបស់គាត់មានដើមកំណើតជាចិន ទើបមានហេតុផលដទៃផ្សេងទៀតសម្រាប់ការសម្លាប់ជាជាងលក្ខណៈជាតិពន្ធុវៀតណាម[2320]។ ពាក់ព័ន្ធទៅនឹងការយល់ឃើញថា ជនជាតិវៀតណាមទាំងអស់នៅក្នុង និងក្បែរភូមិយាងត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំនៅវត្តខ្សាច់ ខៀវ សំផន បានអះអាងថាការយល់ឃើញនេះជាការពន្យល់សមហេតុផល និងបានផ្អែកទៅលើសក្ខីកម្មរបស់ ស៊ាន ស៊ង់ និង អ៊ី វុន ដែលសក្ខីកម្មរបស់ ស៊ាន ស៊ង់ គឺជាពាក្យចចាមអារ៉ាម ហើយ អ៊ី វុន ពុំត្រូវបានសួរថាតើគាត់ដឹងដូចម្តេចដែលអ្នកទាំងនោះមកពីកន្លែងណា និងពុំដែលឃើញពួកគេត្រូវបាននាំទៅវត្តនោះឡើយ[2321]។ ពាក់ព័ន្ធនឹងការយល់ឃើញដែលថា ការសម្លាប់ត្រូវបានធ្វើឡើងតាមបញ្ជារបស់ថ្នាក់លើ ខៀវ សំផន បានលើកឡើងថាការយល់ឃើញនេះបានផ្អែកលើសក្ខីកម្មចចាមអារ៉ាមចេញពី ស៊ាន ស៊ង់ និង អ៊ី វុន[2322]។

810. សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសំអាងទៅលើសក្ខីកម្មរបស់សាក្សី អ៊ី វុន, ស៊ាន ស៊ង់ និង អ៊ុំ ស៊ន់ ក្នុងការបង្កើតការយល់ឃើញ និងថា គាត់បានបកស្រាយពុំត្រឹមត្រូវលើភស្តុតាងចចាមអារ៉ាម និងថា គាត់ពុំបានពិចារណាលើវចនាសម្ព័ន្ធឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងការអនុវត្តន៍បទបញ្ជា និងគោលនយោបាយសម័យនោះដែលកំណត់គោលដៅលើជនជាតិវៀតណាម[2323]។

811. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[2324]។

[2319] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៩។

[2320] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១០។

[2321] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១១-១០១២។

[2322] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១៣។

[2323] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦០៥-៦០៧។

[2324] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២៧៨។

812. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានយល់ឃើញ អ៊ី វុន, ស៊ាន ស៊ង់ និង អ៊ុំ ស៊ន់ "គួរឱ្យជឿជាក់ និងទុកចិត្តបានជាទូទៅ"ក្នុងការបង្ហាញថា ការសម្លាប់បានកើតឡើងនៅវត្តខ្សាច់[2325] ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះនឹងពុំផ្អែកលើសក្ខីកម្មផ្ទាល់មាត់របស់ អ៊ុំ ស៊ន់ ដែលពុំមានការបញ្ជាក់អះអាងបន្ថែម ដោយសារមាន"ភាពពុំស៊ីសង្វាក់គ្នា" ដែលអង្គជំនុំជម្រះបានសង្កេតឃើញនោះឡើយ[2326]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមវិធីសាស្ត្រដែលខ្លួនបានកំណត់ដោយផ្អែកលើសក្ខីកម្ម អ៊ុំ ស៊ន់ តែចំណុចណាដែលត្រូវបានបញ្ជាក់បន្ថែមប៉ុណ្ណោះ[2327]។ ចំពោះ"សារៈសំខាន់នៃភាពជាទូទៅ"ដែលរកឃើញក្នុងសក្ខីកម្មរបស់ពួកគេ[2328] សាក្សីបីនាក់ដែលការជឿជាក់បាន និងទុកចិត្តបាននីមួយៗរបស់គាត់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃដោយផ្អែកលើ"ពេលវេលាកន្លងផុតទៅយូរ និងការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តនៃព្រឹត្តិការណ៍"[2329] បានដឹង និងស្គាល់ឈ្មោះអ្នកភូមិមួយចំនួនដែលត្រូវបាននាំទៅវត្តខ្សាច់។ ភស្តុតាងរបស់ពួកគេមានភាពពុំស៊ីសង្វាក់គ្នាពាក់ព័ន្ធទៅនឹងថាតើពួកគេបានឃើញការសម្លាប់ដូចម្តេច និងនៅកន្លែងណា ប៉ុន្តែទោះជាយ៉ាងណាក្តីបានបង្ហាញថា មានតែជនជាតិវៀតណាមប៉ុណ្ណោះត្រូវបានគេប្រមូលផ្តុំ និងថា សម្លេងស្រែកយំបានឮចេញពីកន្លែងនោះ និងថា ជនជាតិវៀតណាមដទៃទៀតដែលនៅក្នុង និងក្រៅភូមិនោះត្រូវបានសម្លាប់ និងថា ពុំមានអ្នកភូមិដែលជាជនជាតិវៀតណាមនៅសេសសល់ក្រោយមកនោះទេ[2330]។ បន្ថែមលើនេះ ការដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា

---

[2325] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៧។

[2326] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៧។

[2327] អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៧២៩, ១១៧៣១, ១១៧៣៤, ១១៧៣៦, ១១៧៣៧, ១១៧៣៩ (ស៊ីគ្នានឹងជើងទំព័រ ១១៧៣៨ និងអត្ថបទអមមកជាមួយ), ១១៧៤០, ១១៧៤៨ (ស៊ីគ្នានឹងជើងទំព័រ ១១៧៤៦-១១៧៤៧ និងអត្ថបទភ្ជាប់ជាមួយ), ១១៧៤៩។

[2328] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៧។

[2329] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៧។

[2330] ទាក់ទងទៅនឹងការកំណត់គោលដៅតែលើអ្នកភូមិជនជាតិវៀតណាម *សូមមើល* ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ (សាន ស៊ង់) E1/357.1 ទំព័រ ៦៥-៦៦, ៧១-៧៣។ ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ី វុន) E1/368.1 ទំព័រ ១៩, ២០-២១។ ប្រតិចារឹកថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ុំ ស៊ន់) E1/365.1 ទំព័រ ៤៦-៤៧, ៤៣-៥០, ៥២។ ទាក់ទងទៅនឹងសម្លេងស្រែកដែលអាចស្តាប់ឮដល់វត្តខ្សាច់ *សូមមើល* ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ (សាន ស៊ង់) E1/357.1 ទំព័រ ៦៣។ ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ី វុន) E1/368.1 ទំព័រ ៨, ២៣-២៥។ ប្រតិចារឹកថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ុំ ស៊ន់) E1/365.1 ទំព័រ ៤០, ៤៣-៤៤, ៤៥-៤៦, ៥០-៥១។ ពាក់ព័ន្ធទៅនឹងការសម្លាប់ នារី ចាន់ថា និងបុគ្គលដទៃទៀតនៅក្នុងវត្ត និងបុគ្គលដទៃទៀត *សូមមើល* ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ (សាន ស៊ង់) ឯកសារលេខ E1/357.1 ទំព័រ ៦២-៦៦។ ប្រតិចារឹកថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ (សាន ស៊ង់) E1/358.1 ទំព័រ ៣។ ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ី វុន)

ការសម្លាប់យាយ ហាយ និង តា យុត បានកើតឡើងក្រោយមកទៀតនោះ ពុំបានប៉ះពាល់ដល់ការយល់ឃើញទាំងនេះឡើយ[2331]។ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ពិចារណាលើការប៉ាន់ស្មានដែលថា អាចមានហេតុផលផ្សេងសម្រាប់ការសម្លាប់គ្រួសារ ជុំ។ ការប៉ាន់ស្មាននេះច្បាស់ណាស់ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ទាក់ទងទៅនឹងការជំទាស់របស់ ខៀវ សំផន ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់បានកើតឡើងក្រោយពីមានបទបញ្ជារបស់"ថ្នាក់លើ"[2332] អង្គជំនុំជម្រះសាលាដំបូងបានសង្កេតយ៉ាងជាក់លាក់ថា អង្គជំនុំជម្រះបានយល់ឃើញថា សក្ខីកម្មរបស់ ស៊ាន ស៊ីង់ គួរឱ្យជឿជាក់ និងទុកចិត្តបានជាទូទៅ និងត្រូវបានអះអាងបញ្ជាក់បន្ថែមដោយភស្តុតាងចចាមអារ៉ាមបន្ថែម[2333] ដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមវិធីសាស្ត្រក្នុងការវាយតម្លៃលើតម្លៃជាភស្តុតាងចចាមអារ៉ាមដែលខ្លួនបានកំណត់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[2334]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់ក្នុងចុងឆ្នាំ ១៩៧៨ ត្រូវបានបង្ហាញនោះទេ។

### ង. ការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តក្រចេះ

813. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាម ១៣ នាក់ដែលជាសាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ រួមទាំងក្មេងបីនាក់ និងប្រពន្ធកាត់វៀតណាម និងឪពុកម្ដាយ និងបងស្រីរបស់គាត់ ព្រមទាំងប្រពន្ធ និងសាច់ញាតិរបស់បុរសជនជាតិខ្មែរបី ឬបួននាក់ដទៃទៀតក្នុងខេត្តក្រចេះត្រូវបានសម្លាប់ដោយចេតនាក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨[2335]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជន

---

E1/368.1 ទំព័រ ១៦, ២៥។ ទាក់ទងទៅនឹងអវត្តមានអ្នកភូមិជនជាតិវៀតណាមក្រោយការសម្លាប់ *សូមមើល* ប្រតិចារឹកថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ី វុន) E1/368.1 ទំព័រ ២៧។ ប្រតិចារឹកថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ុំ ស៊ន់) E1/365.1 ទំព័រ ៥២ ។ *ប្រៀបធៀប*សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៨-៣៤៧៩, ៣៤៨១។

[2331] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០០៧-១០០៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៧៩។

[2332] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១៣ យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨០, ៣៤៨២, ៣៤៩៥។

[2333] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨០។

[2334] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៣ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០២។

[2335] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៦។

ជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយសារជាជនជាតិពន្ធុតាមការសន្មត និងត្រូវបានសម្លាប់ក្នុងខេត្តក្រចេះក្នុងឆ្នាំ ១៩៧៨ និងថា សាច់ញាតិរបស់ អ៊ុច ស៊ុឡាយ និងបុរសជនជាតិខ្មែរបីនាក់ដទៃទៀតត្រូវបានសម្លាប់ក្នុងបរិបទនេះ[2336]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្កើតការយល់ឃើញទាក់ទងទៅនឹងអំពើមនុស្សឃាតក្នុងខេត្តក្រចេះដោយផ្អែកលើតែសក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ ប៉ុណ្ណោះ[2337]។ ខៀវ សំផន បានលើកបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា អំពើមនុស្សឃាតនៃសាច់ញាតិរបស់ អ៊ុច ស៊ុនឡាយ ត្រូវបានបង្ហាញដោយគ្មានការកំណត់អត្តសញ្ញាណបុគ្គលនោះ ឬបង្ហាញកាលៈទេសៈនៃការស្លាប់នោះ[2338]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អ៊ុច ស៊ុនឡាយ ស្ថិតក្នុងលក្ខណៈល្អប្រសើរក្នុងការផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម និងថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃដោយប្រុងប្រយ័ត្ន[2339]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងកំណត់អត្តសញ្ញាណសាច់ញាតិរបស់ អ៊ុច ស៊ុនឡាយ ដែលត្រូវបានសម្លាប់ និងថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចមានកំហុសនៅពេលរួមបញ្ចូលឪពុកម្តាយរបស់ប្រពន្ធរបស់គាត់ជារួមដោយពុំបានបង្ហាញការស្លាប់ក៏ដោយ ក៏ ខៀវ សំផន ខកខានក្នុងការបង្ហាញថា កំហុសនោះបានធ្វើឱ្យសាលក្រមទៅជាមោឃៈ ទាំងស្រុង ឬផ្នែកខ្លះ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌[2340]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា កំហុសដែលលើកឡើងពាក់ព័ន្ធទៅនឹងចំនួនសាច់ញាតិរបស់ អ៊ុច ស៊ុនឡាយ ដែលត្រូវបានរកឃើញថា បានសម្លាប់នោះ ពុំជាប់ពាក់ព័ន្ធឡើយ[2341]។ សហមេធាវីនាំមុខបានបដិសេធផងដែរការលើកឡើងរបស់ ខៀវ សំផន ដែលថា ការរៀបរាប់របស់ អ៊ុច ស៊ុនឡាយ មានតម្លៃទាប ដោយសារកើតចេញពីចម្លើយស្តីពីព្យសនកម្ម និងបានអះអាងថា ភស្តុតាងនេះបើទោះបីមានផ្នែកខ្លះជាពាក្យចចាមអារ៉ាមក៏ដោយ មានភាពលម្អិត ស៊ីសង្វាក់ និងត្រូវបានបញ្ជាក់បន្ថែមនូវផ្នែកខ្លះដោយភស្តុតាងផ្ទាល់របស់គាត់ដែរ[2342]។

---

[2336] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៨៨។ សូមមើលផងដែរ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩០។

[2337] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១៤។

[2338] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០១៥-១០១៦។

[2339] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១០-៦១១។

[2340] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦១២។

[2341] សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣០៥។

[2342] សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣០៦-៣០៧។ *សូមមើលផងដែរ* សារណាតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២០០។

814. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រង់ចំណុចដែលថា អ៊ុច ស៊ុនឡាយ បានផ្តល់ការរៀបរាប់ដោយលម្អិត ស៊ីសង្វាក់ និងជឿជាក់បានអំពីកាលៈទេសៈជុំវិញការស្លាប់ជនជាតិវៀតណាមដែលជាសាច់ញាតិរបស់គាត់ និងខ្មែរដែលមកពីភូមិដទៃទៀត។ ស្របជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[2343] គាត់ស្គាល់ឈ្មោះ“ចុល”ដែលតាមគាត់ចាំជាអ្នកដឹកជនរងគ្រោះទៅកន្លែងសម្លាប់តាមរទេះគោ និងបានឃើញការសម្លាប់ផ្ទាល់ភ្នែកដែលជាប្រភពនៃពាក្យចចាមអារ៉ាម[2344]។ អ៊ុច ស៊ុនឡាយ បានរៀបរាប់សាឡើងវិញអំពីការទៅកាប់ឫស្សីធ្វើបង្កាងត្នោត ដែលស្របទៅនឹងការដែលប្តី និងប្រពន្ធត្រូវបានគេបំបែក[2345]។ គាត់បានរៀបរាប់លម្អិតថា ពេលនោះគណៈសហករណ៍បានលើកសរសើរ ថាមានគុណសម្បត្តិខ្ពស់ណាស់ តែប្រពន្ធកូនត្រូវបានប្រមូលទៅទុកម្តុំ[2346]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើអ្វីដែលបានរកឃើញថា ការរៀបរាប់នោះ មានជាប់ពាក់ព័ន្ធ និងគួរជឿជាក់បាន ដោយបានសង្កេតលើអត្តចរិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលគាត់ផ្តល់សក្ខីកម្មនោះ ពុំគួរឱ្យជឿជាក់ឡើយ។ បន្ថែមលើនេះ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលយកការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការបង្ហាញការស្លាប់ឪពុកម្តាយក្មេករបស់ អ៊ុច ស៊ុនឡាយ ដែលបានរួមបញ្ចូលនៅក្នុងការស្លាប់ទាំងនោះក៏ដោយ ក៏កំហុសខ្វះការលម្អិតនេះពុំបានធ្វើឱ្យសាលក្រមទៅជាមោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ។ យោងតាមហេតុផលនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ច. ការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់នៅអូរកន្សែង

815. អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញផ្នែកច្បាប់ដែលថា ការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់នៅមន្ទីរសន្តិសុខអូរកន្សែង បំពេញតាមលក្ខខណ្ឌនៃធាតុផ្សំអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំង

[2343] ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/394.1 ទំព័រ ៧៣ យោងទៅលើ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ E3/4844។

[2344] ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/394.1 ទំព័រ ៧៣-៧៤។ ប្រតិចារឹកថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/395.1 ទំព័រ ៣។

[2345] ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/394.1 ទំព័រ ៦៥, ៧១-៧២។ ប្រតិចារឹកថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/395.1 ទំព័រ ១១។

[2346] ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (អ៊ុច ស៊ុនឡាយ) E1/394.1 ទំព័រ ៦៦។

មនុស្សជាតិ[2347] លើការយល់ឃើញផ្អែកអង្គហេតុដែលថា មនុស្សប្រាំមួយនាក់នោះ ត្រូវបានសម្លាប់តាមបញ្ជារបស់ប្រធានកងពលលេខ ៨០១ សៅ សារឿន[2348]។ ក្នុងការបង្កើតការយល់ឃើញផ្អែកអង្គហេតុ ផ្ទុយទៅនឹងអំណះអំណាងដែលបានលើកឡើងដោយ ខៀវ សំផន[2349] អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ប្រធានមន្ទីរសន្តិសុខ ឆោម សែ ថែមទាំងសក្ខីកម្មយ៉ាងក្បោះក្បាយក្នុងតុលាការក្នុងសំណុំរឿង ០០២/០១[2350]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ដោយសារ ឆោម សែ ពុំអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ បាន ពីព្រោះគាត់បានស្លាប់នៅមុនគាត់អាចបង្ហាញខ្លួនក្នុងតុលាការ[2351] អង្គជំនុំជម្រះបានសំអាងទៅលើចម្លើយរបស់គាត់ទៅនឹងសំណួរដែល"ជាប់ពាក់ព័ន្ធផ្ទាល់ ឬប្រយោល ទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ [...] ត្រង់ចំណុចដែលខ្លឹមសារនៃចម្លើយនោះបានបើកចំហសម្រាប់ការសួរដេញដោលដោយភាគីក្នុងតុលាការ"[2352]។ ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញា ភាគីត្រូវបានអនុញ្ញាតឱ្យសួរ ឆោម សែ ទាក់ទងទៅនឹងការសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង ត្រង់ចំណុចពាក់ព័ន្ធទៅនឹងបទបញ្ជាដែលគាត់បានទទួលពីប្រធានកងពលលេខ ៨០១ សៅ សារឿន[2353]។

816. សម្រាប់តម្លៃជាភស្តុតាងនៃភស្តុតាងរបស់ ឆោម សែ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើភាពជារួមនៃភស្តុតាង មុនពេលកំណត់ថា គាត់បានផ្តល់"ការរៀបរាប់ស៊ីសង្វាក់គ្នា"អំពីការសម្លាប់អ្នកជាប់ឃុំប្រាំមួយ

[2347] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៥៩។

[2348] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦។

[2349] សារណាសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៤២-៨៤៣, ១០៥២។

[2350] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦ យោងទៅលើប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) E1/159.1 ទំព័រ ៨៦។

[2351] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦០ យោងទៅលើសេចក្តីសម្រេចលើសាក្សី ដែលត្រូវបានស្នើឡើង ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ E459 កថាខណ្ឌ ១០៤ (ជើងទំព័រ ២៦៤)។

[2352] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៦០ យោងទៅលើប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៧៥-៧៦ (ស្នើសុំការណែនាំពីអង្គការពាក់ព័ន្ធការចាប់ខ្លួនជនជាតិចារ៉ាយ)។ ប្រតិចារឹកថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ)ឯកសារលេខ E1/177.1 ទំព័រ ១៥-១៨ (ជនរងគ្រោះស្ត្រី និងកុមារ) ២៣-២៤ (ការសម្លាប់ជនជាតិចារ៉ាយ) ៣៩-៤០ (ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ឃុំ)។

[2353] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦០៣ យោងទៅលើប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៧៥-៧៦។

នាក់[2354]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង។

ឆ. ថាតើ អំពើមនុស្សឃាតនោះអាចស្មើនឹងការសម្លាប់រង្គាល ដែរ ឬយ៉ាងណា

817. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការសម្លាប់ជនស៊ីវិលវៀតណាមដោយចេតនាក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨ អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យក្រោយខែ មេសា ឬ ឧសភា ឆ្នាំ ១៩៧៧ នៅផែអូរឈើទាលដូចបានបង្ហាញដោយ ប៉ាក សុខ និងនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ដូចបានរាយការណ៍ដោយកងពលលេខ ១៦៤ ការសម្លាប់សាច់ញាតិរបស់ ប្រាក់ ឌឿន និងសមាជិកជនជាតិវៀតណាមនៃគ្រួសារចំនួនប្រាំមួយក្នុងខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ ១៩៧៧ សាច់ញាតិរបស់ អ៊ុច ស៊ុនឡាយ និងសមាជិកបី ឬបួននៃគ្រួសាររបស់បុរសជនជាតិខ្មែរក្នុងខេត្តក្រចេះក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨ និងការសម្លាប់ក្នុងទ្រង់ទ្រាយធំជនស៊ិវិលជនជាតិវៀតណាមនៅវត្តខ្សាច់ក្នុងចុងឆ្នាំ ១៩៧៨" សរុបចំនួនអ្នកស្លាប់ប្រមាណ ៦០ នាក់ "ជាចំនួនមួយដែលផ្អែកលើភស្តុតាងទាំងមូល គឺជាការវាយតម្លៃជាអប្បបរមានៃស្ថានភាពជាក់ស្តែងប៉ុណ្ណោះ"[2355]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ឃើញរបស់ខ្លួនស្តីពីហេតុការណ៍ជាក់លាក់នៃការសម្លាប់ជនជាតិវៀតណាមនៅមន្ទីរសន្តិសុខស-២១ និងអូរកន្សែង[2356]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា ពុំមានលក្ខខណ្ឌតម្រូវនៃចំនួនអប្បបរមាជនរងគ្រោះសម្រាប់ការបង្ហាញអំពីការសម្លាប់រង្គាល និងបានយល់ឃើញថា ការសម្លាប់ទាំងនេះគឺជាផ្នែកមួយនៃប្រតិបត្តិការសម្លាប់មនុស្សតែមួយ និងបានបំពេញតាមលក្ខខណ្ឌតម្រូវនៃអំពើមនុស្សឃាតក្នុងទ្រង់ទ្រាយធំ[2357]។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងទូទៅនៃការកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាលើប្រជាជនវៀតណាមរួមទាំងការអំពាវនាវឱ្យកម្ទេចជនជាតិវៀតណាម និងការពិតដែលថា ក្នុងករណីនីមួយៗ ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយសារជាសមាជិកនៃក្រុមជាជាងលក្ខណៈ

---

[2354] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦ យោងទៅលើប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៦។ ប្រតិចារឹកថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ១៣។ កំណត់ហេតុស្តាប់ចម្លើយរបស់ ឆោម សែ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E3/405 ERN 00401303 ទំព័រ ៧។

[2355] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៩។

[2356] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៩។

[2357] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០០។

បុគ្គល និងការពិតដែលថា ពួកគេត្រូវបានសម្រិតសម្រាំងចេញពីអ្នកដែលពុំមែនជាជនជាតិវៀតណាមដើម្បីសម្លាប់ក្នុងខេត្តកំពង់ឆ្នាំង វត្តខ្សាច់ និងខេត្តក្រចេះ និងលក្ខណៈនៃការសម្លាប់ដែលត្រូវបានធ្វើឡើង និងការពិតដែលថា មានអត្ថិភាពនៃសក្ខីកម្មស៊ីសង្វាក់គ្នាថា ជនជាតិវៀតណាមទាំងអស់ត្រូវបានសម្លាប់នៅពេលនោះ និងពុំមានជនជាតិវៀតណាមណាម្នាក់នៅសេសសល់ក្នុងតំបន់នៅក្រោយមកនោះទេ[2358]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងបានបង្ហាញថា ការសម្លាប់ទាំងអស់នោះត្រូវបានរៀបចំឡើង និងដោយចេតនាស្របតាមការអំពាវនាវរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់អត្តសញ្ញាណ បណ្តេញ និង/ឬសម្លាប់ជនជាតិវៀតណាម និងដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ធាតុផ្សំអត្តនោម័តិនៃចេតនាផ្ទាល់ត្រូវបានបង្ហាញ[2359]។

818. ខៀវ សំផន បានអះអាងថា ការសម្លាប់ជនជាតិវៀតណាមដែលត្រូវបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូងគឺជាហេតុការណ៍ដាច់ដោយឡែក និងពុំបានបំពេញតាមលក្ខខណ្ឌតម្រូវនៃទំហំធំធេងដែលអាចស្មើនឹងការសម្លាប់រង្គាលឡើយ[2360]។ គាត់បានជំទាស់ថា ហេតុការណ៍ជាក់លាក់នៃការសម្លាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញនោះបានបង្ហាញនូវការស្លាប់មិនលើសពី ១៩ នាក់ប៉ុណ្ណោះ[2361]។ គាត់បានពិចារណាថា ការសម្លាប់នោះពុំអាចស្មើនឹងប្រតិបត្តិការសម្លាប់មនុស្សតែមួយដោយសារបានកើតឡើងក្នុងភូមិភាគប្រាំខុសៗគ្នានៃប្រទេស និងនៅថ្ងៃខុសៗគ្នា[2362]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានពង្រីកការសន្និដ្ឋានដោយពុំសមហេតុផលក្នុងការវាយតម្លៃថា មានជនជាតិវៀតណាមប្រមាណ ៦០ ត្រូវបានសម្លាប់ ដោយសារពុំមានភស្តុតាងបង្ហាញ ឬមូលដ្ឋានសត្យានុម័តសម្រាប់ការវាយតម្លៃលើចំនួនជាមធ្យមនៃការស្លាប់នៅសមុទ្រថា មានមនុស្សប្រហែលពីរទៅប្រាំនាក់ក្នុងមួយគ្រួសារក្នុងមួយទូកៗ[2363]។

819. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន ដែលថា ចំនួនអ្នកស្លាប់ពុំអាចឈានដល់កម្រិតចាំបាច់នោះពុំមានភស្តុតាងគាំទ្រឡើយ និងថា ពុំមានលក្ខខណ្ឌអប្បបរមានៃចំនួនសម្រាប់ការសម្លាប់រង្គាល និងថា នៅគ្រប់ករណី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការយល់ឃើញរបស់ខ្លួននៃការ

[2358] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០០។

[2359] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០១។

[2360] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២០។

[2361] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២១។

[2362] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៣-១០២៥។

[2363] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៦-១០២៧។

ស្លាប់ចំនួន៦០នាក់គឺជាការវាយតម្លៃជាអប្បបរមាបំផុត[2364]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការអះអាងដែលថា ព្រឹត្តិការណ៍បានកើតឡើងក្នុងទីតាំងផ្សេងៗគ្នា និងពេលវេលាខុសៗគ្នាពុំបានបង្ហាញថា ការសម្លាប់នោះពុំជាប់ពាក់ព័ន្ធគ្នានោះទេ ដែលនេះជាការពុំអើពើទៅលើការដែលជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយសារតែពួកគេជាជនជាតិវៀតណាម។ ច្បាប់ពុំតម្រូវឱ្យពិចារណាលើជនរងគ្រោះដាច់ដោយឡែក និងថាតើការសម្លាប់នោះបានកំណត់គោលដៅលើក្រុមជារួម ឬជនរងគ្រោះជាលក្ខណៈបុគ្គល[2365]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពន្យល់អំពីមូលដ្ឋានសម្រាប់ការវាយតម្លៃលើជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅសមុទ្រ និងថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយ និងពុំបានបង្ហាញនូវកំហុសណាមួយឡើយ[2366]។

820. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់ថា តាមទីកន្លែងជាច្រើន ជនជាតិវៀតណាមត្រូវបាន"សម្រិតសម្រាំងជាក់លាក់ និងបំបែកចេញពីអ្នកដែលពុំមែនជនជាតិវៀតណាមនៅមុនពេលយកទៅសម្លាប់"[2367]។ ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ត្រូវប្រៀបធៀបព្រឹត្តិការណ៍"ស្វែងរកភាពប្រហាក់ប្រហែលគ្នា"នោះទេ[2368]។ ភាពប្រហាក់ប្រហែលគ្នានេះមានអត្ថិភាពជាសត្យានុម័ត និងបានបង្ហាញថា ជនរងគ្រោះជនជាតិវៀតណាមត្រូវបានកំណត់គោលដៅមិនត្រឹមតែជាលក្ខណៈបុគ្គលប៉ុណ្ណោះទេ ថែមទាំងបំបែកចេញពីអ្នកជិតខាង ឬសាច់ញាតិដែលជាខ្មែរតាមរយៈការសន្មតថាជាជនជាតិវៀតណាម។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការសម្លាប់ទាំងនេះបានកើតឡើងក្នុងបរិបទទូលំទូលាយនៃគោលនយោបាយទូទាំងប្រទេសកំណត់គោលដៅប្រជាជនវៀតណាម ទាំងស៊ីវិល និងកងទ័ព សម្រាប់ការប្រព្រឹត្តទៅលើដូចជាសត្រូវ ដែលជាការយល់ឃើញមួយត្រូវបានបញ្ជាក់អះអាងបន្ថែមដោយអង្គជំនុំជម្រះតុលាការកំពូល។ នេះជាកត្តាដែលក្នុងចំណោមដទៃទៀត នាំឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសម្លាប់ក្នុងខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ ១៩៧៧ និងខេត្តក្រចេះក្នុងឆ្នាំ ១៩៧៨ ដែលទំនាក់ទំនងកន្លែងពីរនេះត្រូវបានជំទាស់ដោយ ខៀវ សំផន[2369] ពុំមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នា ប៉ុន្តែផ្ទុយទៅវិញបង្កើតជា"ផ្នែកនៃប្រតិបត្តិការ

---

[2364] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦២៣។

[2365] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦២៤។

[2366] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦២៥។

[2367] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០០។

[2368] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៣។

[2369] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៤។

អំពើមនុស្សឃាតតែមួយ"[2370]។ សម្រាប់លក្ខខណ្ឌតម្រូវនៃវិសាលភាព ដោយពុំចាំបាច់រួមបញ្ចូលការសម្លាប់កូនៗរបស់ ប្រាក់ ឌឿន និងឪពុកម្ដាយរបស់ប្រពន្ធ អ៊ុច ស៊ុនឡាយ ដែលអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្ហាញនោះ[2371] ចំនួនសរុបនៃការសម្លាប់ដែលបានបង្ហាញនោះមានច្រើនជាង ៥0 នាក់[2372]។ ក្រៅពីការសម្លាប់ទាំងនេះ ការបង្ហាញភាគច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើសក្ខីកម្មផ្ទាល់របស់សាក្សី ដូចជា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញផងដែរនូវការសម្លាប់ប្រជាជនជនជាតិវៀតណាមប្រាំមួយនាក់នៅមន្ទីរសន្តិសុខអូរកន្សែង[2373] និងការសម្លាប់ទាហាន និងជនស៊ីវិលជនជាតិវៀតណាមរាប់រយនាក់នៅមន្ទីរស-២១[2374] ការសម្លាប់ដែលត្រូវបានរួមបញ្ចូលក្នុងការយល់ឃើញអំពីការសម្លាប់រង្គាល។ ការប៉ាន់ស្មានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបុគ្គលពីរនាក់ក្នុងមួយគ្រួសារ និងប្រាំនាក់ក្នុងកាណូតមួយគ្រឿង ដែលភស្តុតាងពុំមានលក្ខណៈជាក់លាក់ ពុំអាចត្រូវបានយល់ថា ជាអ្វីផ្សេងក្រៅតែពីការពិនិត្យដោយប្រុងប្រយ័ត្នប៉ុណ្ណោះ[2375]។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា ចំនួននៃការសម្លាប់ជាក់លាក់ដែលខ្លួនរកឃើញថាមានដោយ"ផ្អែកលើភស្តុតាងជារួមនោះ សឹងតែជាការប៉ាន់ស្មានក្រោមចំនួននៃស្ថានការណ៍ជាក់ស្ដែង"[2376]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកបញ្ហានេះជាការយល់ឃើញមួយនៃការស្លាប់ក្នុងចំនួនអប្បបរមា ដោយហេតុថា "ពុំមានការកំណត់អំពីតួលេខអប្បបរមា ការសម្លាប់រង្គាលត្រូវបានរកឃើញថា បានប្រព្រឹត្តទាក់ទងទៅនឹងការសម្លាប់រាប់ពាន់នាក់ និងប្រហាក់ប្រហែលក្រោម ៦០ នាក់បន្តិចបន្តួច"[2377] ចំនួននេះពុំអាចធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាលក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំ ត្រូវបានបំពេញ។

---

[2370] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០០។

[2371] *សូមមើលខាងលើ* ផ្នែក VII.ខ.២.គ និង VII.ខ.២.ង។

[2372] អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៧៨៧ ប៉ាន់ស្មានការសម្លាប់ ៥៩ នាក់។ បើទោះជាមិនរាប់បញ្ចូលឪពុកម្ដាយក្មេករបស់ អ៊ុច ស៊ុនឡាយ និងកូនៗ ប្រាំនាក់របស់ ប្រាក់ ឌឿន តួលេខនៃការសម្លាប់នៅតែ ៥២ នាក់។

[2373] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៩ យោងទៅលើកថាខណ្ឌ ២៩២៦, ២៩៥៩។

[2374] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៩ យោងទៅលើកថាខណ្ឌ ២៥៧១, ២៦២១។

[2375] អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៧៨៧។

[2376] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៩៩។

[2377] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៥១ យោងទៅលើសាលដីការឿងក្ដី *Lukić និង Lukić* (ICTY) កថាខណ្ឌ ៥៣៧។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Ndahimana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ (ICTR), ICTR-01-68-A ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ២៣១។

821. យោងតាមសំអាងហេតុខាងលើ សារណារបស់ ខៀវ សំផន ទាក់ទងទៅនឹងការសម្លាប់ជនជាតិវៀតណាម ក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ខេត្តកំពង់ឆ្នាំង វត្តខ្សាច់ ខេត្តក្រចេះ និងមន្ទីរសន្តិសុខអូរកន្សែង និងពាក់ព័ន្ធទៅនឹងការកំណត់ចរិតលក្ខណៈថា ជាការសម្លាប់រង្គាលត្រូវបដិសេធចោល។

## គ. បទឧក្រិដ្ឋនៃការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ការដាក់ឱ្យទៅជាទាសករនៅភ្នំក្រោល

822. ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល ជាពិសេសបានចោទប្រកាន់ថា អ្នកជាប់ឃុំនៅភ្នំក្រោលត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងលើរូបកាយ និងផ្លូវចិត្តទាំងស្រុង ដែលជាក់ស្តែងរាល់ការសម្រេចពាក់ព័ន្ធទៅនឹងបរិយាកាសនៃរូបកាយត្រូវបានគ្រប់គ្រងដោយរដ្ឋអំណាច ដើម្បីសម្រេចគោលដៅរបស់បក្ស[2378] ។ មន្ទីរសន្តិសុខភ្នំក្រោល គឺជាមន្ទីរសន្តិសុខតំបន់ ១០៥ ដែលមានពន្ធនាគារភ្នំក្រោល មន្ទីរនៃតំបន់ពាក់ព័ន្ធចំនួនពីរ(ក-១១ និង ក-១៧) និងទីតាំងសម្លាប់មនុស្សនៅម្តុំត្រពាំងព្រីង[2379]។

823. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋនៃការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដោយផ្អែកលើការយល់ឃើញរបស់ខ្លួនថា មានរបបធ្វើការដាច់ខាត និងដាក់វិន័យតឹងតែងដែលជាការកែងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចរបស់អ្នកជាប់ឃុំសម្រាប់ផលប្រយោជន៍បក្ស និងថា ពុំមានភស្តុតាងបង្ហាញថា អ្នកជាប់ឃុំត្រូវបានផ្តល់កម្រៃធ្វើការងារ ឬមានជម្រើសណាមួយពាក់ព័ន្ធនឹងការជ្រើសរើសធ្វើការងារ ដែរ ឬទេ និងថា អ្នកជាប់ឃុំមានការភ័យខ្លាចនូវការសម្លាប់ ប្រសិនបើពួកគេពុំបានធ្វើតាមបទបញ្ជារបស់អង្គការ និងថា ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមការរងទុក្ខផ្លូវចិត្ត និងថា កម្មាភិបាលមន្ទីរសន្តិសុខបានធ្វើការគ្រប់គ្រងក្នុងកម្រិតមួយតឹងរ៉ឹងលើពួកគេតាមរយៈការកម្រិតនូវការដើរហើរក្នុងមន្ទីរសន្តិសុខនោះ និងការគ្រប់គ្រងលើបរិយាកាសរូបកាយសម្រាប់រយៈពេលនៃការដាក់ក្នុងពន្ធនាគារ និងការដាក់ពួកគេឱ្យស្ថិតក្រោមការឃាមកាមគ្រប់ពេលដើម្បីរារាំង ឬទប់ស្កាត់ការរត់គេចខ្លួន។ នេះបានធ្វើឱ្យអ្នកជាប់ឃុំទាំងនោះពុំមានជម្រើសក្រៅតែពីត្រូវធ្វើការប៉ុណ្ណោះ[2380]។ អង្គជំនុំ

[2378] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៩ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣៩១-១៣៩៤។

[2379] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៣០១៩, ៣០២៧។

[2380] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១២១-៣១២២។

ជម្រះសាលាដំបូងបានសន្និដ្ឋានថា នេះបានបង្ហាញថា កម្មាភិបាលមន្ទីរសន្តិសុខបានប្រើប្រាស់សិទ្ធិអំណាចធ្វើជាម្ចាស់កម្មសិទ្ធិលើអ្នកជាប់ឃុំ ដូច្នេះ បានបំពេញនូវលក្ខខណ្ឌធាតុផ្សំសត្យានុម័តនៃការដាក់ឱ្យទៅជាទាសករ និងថា មធ្យោបាយនៃការអនុវត្តន៍របបធ្វើការដោយបង្ខំ និងការដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងជាដរាបនូវសិទ្ធិរបស់អ្នកជាប់ឃុំ ស៊ីសង្វាក់គ្នាជាមួយនឹងការប្រើប្រាស់ដោយចេតនានូវសិទ្ធិអំណាចទាំងនេះ ដូច្នេះបានបំពេញលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិនៃបទឧក្រិដ្ឋនេះ[2381]។

824. ខៀវ សំផន បានយោងទៅលើអំណះអំណាងដំបូងរបស់គាត់ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[2382]ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែតម្រូវឱ្យជំនុំជម្រះការដាក់ឱ្យទៅជាទាសករពាក់ព័ន្ធទៅនឹងមន្ទីរ ក-១១ ប៉ុណ្ណោះ និងបានអះអាងថា ភស្តុតាងនៃការដាក់ឱ្យទៅជាទាសករនៅមន្ទីរ ក-១១ ពុំមានលក្ខណៈគ្រប់គ្រាន់។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើសក្ខីកម្មរបស់ កុល ណែម និងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរតែមួយប៉ុណ្ណោះ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពុំត្រូវបានសួរអំពីការដាក់ឱ្យទៅជាទាសករនៅមន្ទីរ ក-១១ ដោយសារគាត់ត្រឹមតែសំដៅទៅលើអំពើនេះក្នុងការលើកឡើងរបស់គាត់អំពីការរងទុក្ខនៅចុងបញ្ចប់នៃការសួរសំណួរប៉ុណ្ណោះ ហើយកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរបានមកពីសាក្សីដែលបានស្លាប់ និងពុំអាចត្រូវបានសួរដេញដោលក្នុងតុលាការឡើយ[2383]។

825. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើភស្តុតាងនៃការដាក់ឱ្យទៅជាទាសករនៅមន្ទីរ ក-១១, ក-១៧ និងពន្ធនាគារភ្នំក្រោល និងថា ការអះអាងរបស់ ខៀវ សំផន ដែលថា ការដាក់ពិរុទ្ធភាពនោះបានផ្អែកតែលើភស្តុតាងមិនគ្រប់គ្រាន់ និងពុំបានសួរដេញដោលអំពីមន្ទីរក-១១ ពុំមានមូលដ្ឋានគាំទ្រត្រឹមត្រូវឡើយ[2384]។

826. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ប៉ុន្តែបានចង្អុលបង្ហាញថា ការអះអាងរបស់ ខៀវ សំផន ដែលថា គាត់ពុំអាចសួរដេញដោល កុល ណែម បាននោះ ជាការមិនពិតទេ។ សហមេធាវីនាំមុខបានកត់សម្គាល់ថា សក្ខីកម្មរបស់ កុល ណែម គឺជាការលើកឡើងអំពីការរងទុក្ខ និងត្រូវបានស្តាប់ក្នុងសវនាការស្តីពីផលប៉ះពាល់ព្យសនកម្ម និងថា គាត់បានលើកឡើងអំពីមន្ទីរក-១១ ក្នុង

---

[2381] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១២២-៣១២៣។

[2382] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១១៩។

[2383] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៨០-៨៨៣។

[2384] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥៩-៨៦០។

ចម្លើយដំបូងរបស់គាត់ និងលើកឡើងជាច្រើនលើកច្រើនសានៅមុនពេលសួរសំណួរដោយមេធាវីការពារក្ដី ខៀវ សំផន[2385]។

827. អង្គជំនុំជម្រះតុលាការកំពូលបានកំណត់រួចរាល់ហើយថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានកម្រិតត្រឹមមន្ទីរក-១១ នៅពេលវាយតម្លៃលើបញ្ហាថាតើ ការដាក់ឱ្យទៅជាទាសករបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដែរ ឬយ៉ាងណានោះទេ[2386]។ ក្នុងការកំណត់ថា ធាតុផ្សំនៃការដាក់ឱ្យទៅជាទាសករត្រូវបានបំពេញនោះ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើភស្តុតាងពីមន្ទីរក-១១, ក-១៧ និងពន្ធនាគារភ្នំក្រោល។ ខៀវ សំផន ពុំបានលើកអំណះអំណាងពាក់ព័ន្ធទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ ចេញពីពន្ធនាគារភ្នំក្រោល ក្រៅតែពីថា អំពើនេះពុំអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ ការអះអាងរបស់ ខៀវ សំផន ដែលថា គាត់ពុំអាចសួរដេញដោលកុល ណៃម អំពីអង្គហេតុពាក់ព័ន្ធទៅនឹងការដាក់ឱ្យទៅជាទាសករនៅមន្ទីរក-១១ ជាការមិនពិតឡើយ។ ដូចបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខ កុល ណៃម បានលើកឡើងអំពីមន្ទីរក-១១ និងលក្ខខណ្ឌនោះពេញមួយអំឡុងពេលនៃសក្ខីកម្មរបស់គាត់ និងនៅមុនពេលសួរសំណួរដោយមេធាវីការពារក្ដី ខៀវ សំផន[2387]។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

### ឃ. ការនិរទេសដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

828. ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការផ្លាស់ទីប្រជាជនវៀតណាមក្នុងទ្រង់ទ្រាយធំចេញពីស្រុកត្រាំកក់ និងខេត្តព្រៃវែង និងស្វាយរៀងក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦[2388]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការនិរទេសដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅសហករណ៍ត្រាំកក់ និងខេត្តព្រៃវែង[2389]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះ“ទំនងជាថា ប្រជាជនវៀតណាមមួយចំនួនត្រូវបាននិរទេស”ចេញពីខេត្តស្វាយរៀងក៏ដោយ ក៏អង្គជំនុំជម្រះបានពិចារណាថា ភស្តុតាងដែល

---

[2385] សារណាវតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣២៣, ៣២៥។

[2386] *សូមមើលខាងលើ* ផ្នែក VI.ក.២។

[2387] ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (កុល ណៃម) ឯកសារលេខ E1/488.1 ទំព័រ ៦៨, ៧៣, ៧៩។

[2388] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០២។

[2389] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៩, ៣៥០៧។

មាននោះពុំបំពេញតាមបទដ្ឋានតម្រូវនៃការបង្ហាញភស្តុតាង[2390]។ ខៀវ សំផន បានអះអាងថា ការនិរទេសនោះពុំបានកើតឡើងនៅសហករណ៍ត្រាំកក់ ឬខេត្តព្រៃវែងឡើយ។ អំណះអំណាងរបស់គាត់នឹងត្រូវដោះស្រាយតាមលំដាប់លំដោយខាងក្រោម។

១. សហករណ៍ត្រាំកក់

829. ក្នុងការវាយតម្លៃថាតើ ការនិរទេសចេញពីស្រុកត្រាំកក់នោះបានកើតឡើង ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនវៀតណាមក្នុងទ្រង់ទ្រាយធំត្រូវបានប្រមូលផ្តុំក្នុងស្រុកត្រាំកក់ចាប់តាំងពីចុងឆ្នាំ ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៦ ជាពិសេស"ប្រជាជនវៀតណាមចំនួនយ៉ាងច្រើន"ត្រូវបានប្រមូលផ្តុំចេញពីឃុំនានាក្នុងរយៈពេលបួនថ្ងៃនៅដើមឆ្នាំ ១៩៧៦[2391]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងដែលត្រូវបានសន្និដ្ឋានជាទូទៅថា ប្រជាជនវៀតណាមបានបាត់ខ្លួនពីស្រុកត្រាំកក់ និងបានសន្និដ្ឋានថាបរិកាសទូទៅបង្ខិតបង្ខំ ហើយប្រជាជនវៀតណាមពុំមានជម្រើសពិតប្រាកដណាមួយពាក់ព័ន្ធនឹងការបណ្តេញចេញនោះ[2392]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា មានការណែនាំច្បាស់លាស់ចេញដោយថ្នាក់ស្រុកឱ្យសម្លាប់ និងបោសសម្អាតប្រជាជនវៀតណាមក្នុងអំឡុងពេលនៃការបណ្តេញចេញនោះ[2393]។ អង្គជំនុំជម្រះបានពិចារណាឃើញថា បរិយាកាសបង្ខិតបង្ខំ និងការសម្របសម្រួលនៃការប្រមូលផ្តុំជនជាតិវៀតណាមបង្ហាញថា ពួកគេបានរស់នៅស្របច្បាប់ក្នុងស្រុកត្រាំកក់នៅពេលនោះ[2394]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងដែលមាននោះពុំអនុញ្ញាតឱ្យខ្លួនធ្វើការយល់ឃើញនូវហេតុការណ៍ជាក់លាក់នៃការសម្លាប់ជនជាតិវៀតណាមក្នុងអំឡុងពេលនោះ និងពុំអាចឱ្យកំណត់បានដោយជាក់លាក់នូវវាសនារបស់ប្រជាជនវៀតណាមទាំងនោះឡើយ ប៉ុន្តែបានជឿជាក់ថា បើទោះបីជាពុំមានភស្តុតាងគ្រប់គ្រាន់ក៏ដោយ ក៏"ការសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចធ្វើទៅបានចេញពីភស្តុតាងជារួមនោះគឺថាជាអប្បបរមា ប្រជាជនវៀតណាមជាច្រើនត្រូវបានបណ្តេញចេញទៅប្រទេសវៀតណាម"[2395]។ សេចក្តីសន្និដ្ឋាននេះបានផ្អែកលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើទស្សនាវដ្តី *ទង់បដិវត្ត*ខែ មេសា ឆ្នាំ ១៩៧៦ និងការយល់ឃើញពាក់ព័ន្ធទៅនឹងខ្មែរក្រោមដែលបានមកដល់ស្រុកត្រាំកក់ជាការដោះដូរជាមួយជន

[2390] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥។

[2391] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៧-១១៥៨។

[2392] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៧។

[2393] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៧-១១៥៨។

[2394] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៧។

[2395] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៨។

ជាតិវៀតណាមដែលបានចាកចេញនោះ។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា ជនជាតិវៀតណាមមួយចំនួនដែលបានប្រមូលផ្ដុំក្នុងស្រុកត្រាំកក់ បានឆ្លងកាត់ព្រំដែនទៅប្រទេសវៀតណាម និងថា មានអត្ថិភាពនៃចេតនាក្នុងការផ្លាស់ទីពួកគេចេញផុតពីព្រំប្រទល់ជាតិ[2396]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើការពិតថា ការនិរទេសទំនងជាបានកើតឡើងដោយសារជាផ្នែកនៃការដោះដូរដោយចេតនា និងមានការរៀបចំ និងជាផ្នែកនៃការកិច្ចព្រមព្រៀងរវាងរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ប៉ុន្តែពុំបានពិចារណាថា នេះគឺជាអត្ថិភាពនៃការផ្លាស់ទីដែលបានកើតឡើងផ្អែកលើមូលហេតុដែលបានអនុញ្ញាតដោយច្បាប់អន្តរជាតិសម្រាប់សន្តិសុខជនស៊ីវិល ឬហេតុផលយោធាចាំបាច់ឡើយ[2397]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាមយ៉ាងហោចណាស់ចាប់តាំងពីខែ ឧសភា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះពុំបានយល់ឃើញថា នេះបានផ្ដល់ជាមូលដ្ឋានស្របច្បាប់ដើម្បីផ្អែកទៅលើក្នុងការផ្លាស់ទីដោយបង្ខំលើប្រជាជនស៊ីវិលឆ្លងកាត់ព្រំប្រទល់ដែរ[2398]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញនៅស្រុកត្រាំកក់[2399]។

830. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ប្រជាជនវៀតណាមដែលបានប្រមូលផ្ដុំក្នុងស្រុកត្រាំកក់នោះ បានឆ្លងកាត់ព្រំប្រទល់ចូលទៅប្រទេសវៀតណាម ដោយសារពុំមានភស្តុតាងគាំទ្រការយល់ឃើញនេះ និងភស្តុតាងដែលបានសំអាងទៅលើនោះបានទទួលតាមរយៈការធ្វើទារុណកម្ម ឬស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ[2400]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ភស្តុតាងពុំបានអនុញ្ញាតឱ្យធ្វើការបញ្ជាក់ច្បាស់លាស់នូវអ្វីដែលបានកើតឡើងចំពោះប្រជាជនវៀតណាមដែលត្រូវបានប្រមូលផ្ដុំ និងថា អង្គជំនុំជម្រះពុំបានពន្យល់ហេតុដូចម្ដេចបានជាខ្លួនសន្និដ្ឋានថា ប្រជាជនវៀតណាមមួយចំនួនបានឆ្លងកាត់ព្រំប្រទល់ និងបានសន្និដ្ឋានថា ខ្លះទៀតត្រូវបានធ្វើឱ្យបាត់ខ្លួនដោយប្រើប្រាស់ពាក្យថា មានចំនួនច្រើន"ត្រូវបាននិរទេស និង/ឬធ្វើឱ្យបាត់ខ្លួន"ដែលបង្កើតបានជាអំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[2401]។ គាត់បានលើកឡើងថា ដោយសារ

[2396] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៨។

[2397] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៩។

[2398] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៩។

[2399] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៩។

[2400] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៨៨។

[2401] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៨៩-៦៩៤។

មានភាពពុំជាក់លាក់ពាក់ព័ន្ធទៅនឹងវាសនារបស់ជនជាតិវៀតណាមនោះ ទើបការមន្ទិលសង្ស័យគប្បីសម្រេចបានជាប្រយោជន៍ដល់រូបគាត់ស្របតាមគោលការណ៍ស្តីពីវិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ *in dubio pro reo*[2402]។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្ហាញថា មានអត្ថិភាពនៃចេតនាក្នុងការផ្លាស់ទីប្រជាជនវៀតណាមហួសពីព្រំប្រទល់ជាតិ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដដែលសម្រាប់ធាតុផ្សំអត្តនោម័តិដែលបានប្រើប្រាស់ក្នុងការយល់ឃើញថា មានអត្ថិភាពនៃធាតុផ្សំសត្យានុម័តនោះ[2403]។ គាត់បានអះអាងថា ភស្តុតាងដែលបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញ“អំពីចេតនាក្នុងការសម្លាប់ច្រើនជាងការប៉ុនប៉ងផ្លាស់ទី”[2404]។

831. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការនិរទេសមានលក្ខណៈច្បាស់លាស់ និងថា ពុំមានលក្ខខណ្ឌតម្រូវកំណត់នូវអ្វីដែលបានកើតឡើងចំពោះជនជាតិវៀតណាមជាក់លាក់នីមួយៗនោះទេ ដោយសារពុំមានលក្ខខណ្ឌតម្រូវបង្ហាញឈ្មោះជនរងគ្រោះនីមួយៗនៃអំពើមនុស្សឃាតក្នុងទ្រង់ទ្រាយធំឡើយ[2405]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានពិនិត្យលើសក្ខីកម្មរបស់សាក្សីនីមួយៗក្នុងការពិចារណាថាតើ សក្ខីកម្មនោះបានគាំទ្រសេចក្តីសន្និដ្ឋានដែលថា មានការឆ្លងកាត់ព្រំប្រទល់ប្រទេស ដែរ ឬយ៉ាងណា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មនោះសម្រាប់ការយល់ឃើញរបស់ខ្លួនដែលថា ជនជាតិវៀតណាមដែលបានរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាត្រូវបានប្រមូលផ្តុំនៅចុងឆ្នាំ ១៩៧៥ និង ដើមឆ្នាំ ១៩៧៦[2406]។ ពាក់ព័ន្ធទៅនឹងភស្តុតាងដែលបានទទួលតាមរយៈការធ្វើទារុណកម្ម សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចំណុចដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះពុំជាប់ពាក់ព័ន្ធទៅនឹងទារុណកម្មឡើយ[2407]។ ពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន

[2402] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៩៤។

[2403] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧១៥-៧១៦។

[2404] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧១៧។

[2405] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៧៣-៥៧៤។

[2406] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៧៥។

[2407] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៨៤។

ពុំបានបង្ហាញនូវកំហុសណាមួយក្នុងការសំអាងទៅលើភស្តុតាងដដែលនោះក្នុងការយល់ឃើញនូវធាតុផ្សំអត្តនោម័តិ ដែលត្រូវបានប្រើប្រាស់សម្រាប់បង្ហាញអត្ថិភាពនៃធាតុផ្សំសត្យានុម័តឡើយ[2408]។

832. សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានលើកការមន្ទិលសង្ស័យទាក់ទងទៅនឹងបញ្ហាថាតើ ជនជាតិវៀតណាមត្រូវបាននិរទេសឆ្លងកាត់ព្រំប្រទល់ ឬត្រូវបានសម្លាប់ ដែរ ឬយ៉ាងណា និងមានការយល់ច្រឡំថា ដោយសារមានអត្ថិភាពនៃការមន្ទិលសង្ស័យនេះ គាត់ត្រូវតែបានឱ្យរួចពីការចោទប្រកាន់ ប៉ុន្តែការប្រមូលផ្តុំដោយចេតនានូវប្រជាជនក្នុងចំនួនដ៏ច្រើនតាមរយៈវិធីសាស្ត្របង្ខិតបង្ខំ និងធ្វើឱ្យពួកគេបាត់ខ្លួន នៅតែជាបទល្មើស[2409]។ ប្រសិនបើអំណះអំណាងរបស់ ខៀវ សំផន ស្តីពីការនិរទេសបានទទួលជោគជ័យ សហមេធាវីនាំមុខបានស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់ការយល់ឃើញដែលពុំត្រូវបានជំទាស់ក្នុងការកំណត់ថា អំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញ[2410]។

833. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំបានជំទាស់ថា ជនជាតិវៀតណាមក្នុងទ្រង់ទ្រាយធំត្រូវបានប្រមូលផ្តុំ និងបានបណ្តេញចេញពីស្រុកត្រាំកក់។ ផ្ទុយទៅវិញ គាត់បានជំទាស់ថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញឱ្យហួសពីវិមតិសង្ស័យថា (១) ជនជាតិវៀតណាមត្រូវបាននិរទេសឆ្លងការព្រំប្រទល់ជាតិអន្តរជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជាធាតុផ្សំចាំបាច់នៃការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2411] និងថា (២) មានចេតនាចង់ឱ្យជនជាតិវៀតណាមឆ្លងកាត់ព្រំប្រទល់។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចកំណត់បានថាតើ ជនជាតិវៀតណាមត្រូវបាននិរទេស ឬសម្លាប់ដែរ ឬយ៉ាងណា ដូច្នេះ ការមន្ទិលសង្ស័យណាមួយគប្បីដោះស្រាយដោយបានជាប្រយោជន៍ដល់រូបគាត់ស្របតាមគោលការណ៍ស្តីពីវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[2412]។

834. អង្គជំនុំជម្រះតុលាការកំពូលពុំបានពិចារណាថា អំណះអំណាងរបស់ ខៀវ សំផន ស្តីពីវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទមានអត្ថប្រយោជន៍ដល់គាត់ឡើយ។ ពិតណាស់ អំពើដែលចោទជាបញ្ហានេះប្រសិនបើត្រូវបានប្រព្រឹត្តដោយចេតនាតម្រូវនោះ គឺជាបទល្មើស។ ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំ“តម្រូវថា ជាការផ្លាស់ទីដោយបង្ខំនូវបុគ្គលចេញពីតំបន់ដែលពួកគេរស់នៅ

---

[2408] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៨៧។

[2409] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣១៦។

[2410] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣១៨។

[2411] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៨១។

[2412] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៨៩-៦៩៤។

ស្របច្បាប់ ដោយគ្មានមូលដ្ឋានអនុញ្ញាតតាមច្បាប់អន្តរជាតិឡើយ។ បទឧក្រិដ្ឋនៃការនិរទេសតម្រូវថា ជនរងគ្រោះត្រូវតែបានផ្លាស់ទីឆ្លងកាត់ព្រំប្រទល់ប្រទេស*តាមច្បាប់* ឬក្នុងកាលៈទេសៈមួយចំនួន ឆ្លងកាត់ព្រំប្រទល់*ជាក់ស្តែង*' រីឯការផ្លាស់ទីដោយបង្ខំ គឺពាក់ព័ន្ធទៅនឹងការផ្លាស់ទីបុគ្គលនៅក្នុងរង្វង់នៃព្រំដែនប្រទេស[2413]។ បញ្ហាថាតើ មានការឆ្លងកាត់ព្រំប្រទល់ ដែរ ឬយ៉ាងណា គឺជាការកំណត់ថាតើ អំពើនោះត្រូវបានចាត់ទុកថា ជាបទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬជាអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំ ដែរ ឬយ៉ាងណា ប៉ុន្តែពុំមែនជាបញ្ហាថាតើ អំពើនោះជាបទល្មើស ដែរ ឬយ៉ាងណានោះទេ។

835. ដូចបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខ ការប្រមូលផ្តុំ និងការបណ្តេញប្រជាជនវៀតណាមចេញពីស្រុកត្រាំកក់ អាចបង្កើតបានជាអំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ធ្វើការពិចារណាលើបញ្ហាថាតើ អំពើនេះអាចស្មើនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែរ ឬយ៉ាងណានោះទេ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញរួចរាល់ និងត្រូវបានតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូលថា អំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញថា មានអត្ថិភាពនៅស្រុកត្រាំកក់ រួមទាំងការពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនជនជាតិវៀតណាមផងដែរ[2414]។

836. ក្នុងការកំណត់ថាតើ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងគ្រប់គ្រាន់អាចកំណត់ប្រភេទត្រឹមត្រូវជាការនិរទេស ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិនិត្យលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ជនជាតិវៀតណាមខ្លះដែលត្រូវបានប្រមូលផ្តុំក្នុងស្រុកត្រាំកក់ពិតណាស់បានឆ្លងកាត់ព្រំប្រទល់អន្តរជាតិ និងត្រូវបានបញ្ជូនទៅប្រទេសវៀតណាម"[2415]។ ការសន្និដ្ឋាននេះបានទាញចេញដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនិយាយសំដៅទៅលើជនជាតិវៀតណាមដែលត្រូវបានដោះដូរជាមួយខ្មែរក្រោម និងបញ្ជូនត្រឡប់ទៅប្រទេសខ្លួនវិញដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការលើកឡើងដែលមាននៅក្នុងសៀវភៅកំណត់ហេតុក្រាំងតាចាន់ដែលជាមន្ទីរសន្តិសុខស្ថិតនៅក្នុងស្រុកត្រាំកក់[2416] និងការលើកឡើងនៅក្នុងទ

---

[2413] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-06-90-T សាលក្រម ភាគ II ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១៧៣៨។

[2414] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០១, ១២០៤។

[2415] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៨។

[2416] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦៨៣។

ស្បូនាវដ្ដីទង់បដិវត្តន៍ខែ មេសា ឆ្នាំ ១៩៧៦ ព្រមទាំងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការមកដល់របស់ខ្មែរក្រោមនៅក្នុងស្រុកត្រាំកក់ ជាការដោះដូរជាមួយនឹងប្រជាជនវៀតណាមដែលបានចាកចេញទៅ[2417]។

837. សក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើរួមមាន៖ (១) ពេជ្យ ជឹម ដែលជាសមាជិកគណៈស្រុក និងលេខាស្រុកត្រាំកក់[2418]គាត់បានផ្ដល់ភស្តុតាងលម្អិតអំពីរចនាសម្ព័ន្ធនយោបាយនៃស្រុកនោះ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងបានផ្ដល់សក្ខីកម្មថា មានទាហាន និងជនស៊ីវិលវៀតណាម"គ្រប់កន្លែង"ក្នុងស្រុកត្រាំកក់ និងថា មាននីតិវិធីធ្វើមាតុភូមិនិវត្តដែលពុំជាប់ពាក់ពាក់ព័ន្ធទៅនឹងការសម្លាប់ ជាជាងការដោះដូរគ្នាក្នុងរយៈពេលពីរយប់ក្លាយ"ជាតំបន់ទទេ"គ្មានជនជាតិវៀតណាម។ គាត់បានផ្ដល់សក្ខីកម្មថា តាមដែលគាត់ដឹង អ្នកដែលរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធខ្មែរត្រូវបានអនុញ្ញាតឱ្យនៅ និងថា ជនភៀសខ្លួនខ្មែរក្រោមត្រូវបានទទួលមកនៅស្រុកត្រាំកក់។ បើទោះបីជាគាត់បានផ្ដល់ការលម្អិតអំពីព្រឹត្តិការណ៍ទាំងនេះក៏ដោយ ក៏គាត់បានព្យាយាមដាក់ខ្លួនគាត់ឆ្ងាយពីការសម្លាប់ណាមួយ[2419] (២) ឯក ហេន ដែលបានធ្វើការក្នុងមន្ទីរស្រុក និងបានអះអាងអំពីអត្ថិភាពនៃការដោះដូរតាមផែនការ និងការសម្លាប់ជនជាតិវៀតណាម[2420] (៣) សាន់ ឡូន ដែលជានីរសាមន្ទីរស្រុកក្នុងអង្គរកា និងជាប់ពាក់ព័ន្ធនៅក្នុងប្រតិបត្តិការដឹកជញ្ជូនជនជាតិវៀតណាម"ជាច្រើននាក់"ក្នុងស្រុកត្រាំកក់ និងត្រូវបានគេប្រាប់ថា ជនជាតិវៀតណាមទាំងនេះត្រូវបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ប៉ុន្តែគាត់ពុំបានដឹងអំពីអ្វីបានកើតឡើងលើពួកគេបន្ទាប់ពីបញ្ជូនទៅឱ្យឈ្លបស្រុក[2421] (៤) ជាំង ស្រីមុំ ដែលបានផ្ដល់សក្ខីកម្មថា ជនជាតិវៀតណាមខ្លះត្រូវបាននាំទៅឃុំញ៉ែងញ៉ង់នៅពេលអង្គការស្វែងរកជនជាតិវៀតណាមដើម្បី"បញ្ជូនត្រឡប់ទៅប្រទេសខ្លួនវិញ" ប៉ុន្តែបានចាំថា ពួកគេត្រូវបាននាំឆ្ពោះទៅរកភ្នំជាជាងទៅប្រទេសវៀតណាម[2422] (៥) ជូ គឹមឡូន ដែលបានពិពណ៌នាអំពីការប្រកាសនៅក្នុងភូមិរបស់គាត់ថា ជនជាតិវៀតណាមត្រូវប្រមូលផ្ដុំ និងបញ្ជូនត្រឡប់ទៅប្រទេសខ្លួនវិញ ប៉ុន្តែថា នេះជា"ល្បិចព្រៃផ្សៃ"[2423] (៦) វៀល សន ដែលបានផ្ដល់សក្ខីកម្មថា ជន

[2417] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៥, ១១៥៨។

[2418] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩២២, ៩៥៦, ១០៧១, ២៦៩៤, ២៧០២-២៧០៥ និងផ្នែក ១០.១.៥។

[2419] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១០, ១១២១។

[2420] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១១-១១១២។

[2421] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៣-១១១៤។

[2422] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៦។

[2423] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៦។

ជាតិវៀតណាមបានធ្វើឱ្យបាត់ខ្លួននៅពេលយប់ ឬក្នុងពេលដែលគាត់កំពុងធ្វើការនៅក្នុងស្រែ ឬការដ្ឋានលើកទំនប់[2424] និង (៧) ផាន់ ឆេន អតីតប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលបានផ្តល់សក្ខីកម្មថា គាត់បានដឹងអំពីបទបញ្ជាពីគណៈស្រុកឱ្យ"កម្ទេច"ជនជាតិវៀតណាម[2425]។

838. បើទោះបីជា ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើសក្ខីកម្មរបស់ ពេជ្រ ជឹម ដែលបានអះអាងថា គាត់ចង់សំដៅទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2426]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបញ្ហានៃពេលវេលាដែល ពេជ្រ ជឹម ចង់សំដៅទៅលើនោះដែរ។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា "នៅចំណុចមួយក្នុងភស្តុតាងរបស់គាត់ ពេជ្រ ជឹម ទំនងជាបាននិយាយថា ការដកជនជាតិវៀតណាមបានកើតឡើងក្នុងឆ្នាំ ១៩៧២ ជាជាងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ប៉ុន្តែទោះជាយ៉ាងណាក្តី ខ្លឹមសារជារួមនៃភស្តុតាងរបស់ ពេជ្រ ជឹម បានពិពណ៌នាអំពីព្រឹត្តិការណ៍ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយអង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា ការពិពណ៌នារបស់គាត់ដែលពាក់ព័ន្ធទៅនឹង យាយខុម និង ជន គឺជាប់ពាក់ព័ន្ធទៅនឹងអំឡុងពេលក្រោយនេះ"[2427]។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ពេជ្រ ជឹម បានឆ្លើយថា ការធ្វើមាតុភូមិនិវត្តជនជាតិវៀតណាមដែលគាត់ចង់សំដៅទៅលើនោះបានកើតឡើងក្នុងឆ្នាំ ១៩៧២[2428]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូង គឺជាអង្គជំនុំជម្រះដែលត្រូវបានផ្តល់ទំនុកចិត្តក្នុងការកំណត់ការយល់ឃើញផ្នែកអង្គហេតុ[2429] ហើយអង្គជំនុំជម្រះតុលាការកំពូលពុំត្រូវធ្វើការជ្រៀតជ្រែកណាមួយឡើយក្នុងសេចក្តីសម្រេចនេះ។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់នូវមូលហេតុដែលខ្លួនបានពិចារណាលើចម្លើយរបស់ ពេជ្រ ជឹម ដែលចង់សំដៅទៅលើអំឡុងពេលនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បើទោះបីជាការបញ្ជាក់

[2424] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៧។

[2425] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៧។

[2426] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៩៦-៦៩៧។

[2427] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465)ជើងទំព័រ ៣៧០៧។

[2428] ពេជ្រ ជឹម ត្រូវបានសួរជាក់លាក់អំពីបញ្ហាថាតើ ចម្លើយរបស់គាត់ពីមុនពាក់ព័ន្ធទៅនឹងការធ្វើមាតុភូមិនិវត្តដែលសំដៅទៅលើអំឡុងពេលក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានអះអាងថា "ខ្ញុំសូមបញ្ជាក់បញ្ហានេះ។ ប្រហែល ខ្ញុំច្រឡំក្នុងការឆ្លើយនោះ។ ការដកជនជាតិវៀតណាមជាក់ស្តែងបានកើតឡើងក្នុងឆ្នាំ ១៩៧២ ដែលនេះបានកើតឡើងមុនការរំដោះក្នុងឆ្នាំ ១៩៧៥។ នៅពេលនោះ អង្គការបានរៀបចំសម្រាប់ការធ្វើមាតុភូមិនិវត្តសម្រាប់ជនជាតិវៀតណាម និងថា បានកើតឡើងក្នុងឆ្នាំ ១៩៧២ បើទោះបីជា ខ្ញុំពុំអាចចាំខែក៏ដោយចុះ"។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ឯកសារលេខ E1/292.1 ទំព័រ ៤៣។

[2429] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៤។

របស់គាត់ក្រោយមកផ្ទុយក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ជាការយល់ឃើញដែលគ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាននោះឡើយ។

839. ខៀវ សំផន បានលើកឡើងថា សក្ខីកម្មរបស់ ឯក ហឿន, សាន់ ឡុន, ជាំង ស្រីមុំ និង ជូ គឹមឡុន ពុំបានផ្តល់ពន្លឺអំពីវាសនារបស់ជនជាតិវៀតណាមដែលត្រូវបានប្រមូលផ្តុំ លើកលែងតែភស្តុតាងខ្លះដែលបានបង្ហាញថា ជនជាតិវៀតណាមត្រូវបានបញ្ជូនចេញពីព្រំប្រទល់[2430]។ ទោះជាយ៉ាងណាក្តី ឯក ហេន បានផ្តល់សក្ខីកម្មស្តីពីគោលនយោបាយធ្វើមាតុភូមិនិវត្តជនជាតិវៀតណាមចេញពីស្រុកត្រាំកក់ជាការដោះដូរជាមួយខ្មែរក្រោម។ គោលនយោបាយនេះបន្ទាប់មកកែប្រែទៅជាគោលនយោបាយមួយនៃការសម្លាប់ជនជាតិវៀតណាម[2431]។ មានភាពស៊ីសង្វាក់គ្នារវាងសាក្សីជាមួយនឹងអំពើបោកបញ្ឆោតនៅពេលជនជាតិវៀតណាមដែលត្រូវបាននាំឆ្ពោះទៅព្រំប្រទល់ត្រូវបានផ្លាស់ប្តូរទិសដៅ និងសន្មតថា ត្រូវបានសម្លាប់[2432]។ មានភាពស៊ីសង្វាក់គ្នាជាច្រើននៃភស្តុតាងដែលបង្ហាញថា ជនជាតិវៀតណាមជាច្រើនសន្ធឹកសន្ធាប់ត្រូវបានប្រមូលផ្តុំ និងដឹកតាមឡានចេញទៅ[2433]។ ឯក ហេន បានដឹងច្បាស់អំពីអ្វីបានកើតឡើងលើជនជាតិវៀតណាមដោយសារគាត់ផ្ទាល់មានដើមកំណើតជាជនជាតិវៀតណាម[2434]។

840. សាន់ ឡុន បានផ្តល់សក្ខីកម្មថា គាត់បានដឹកប្រជាជនវៀតណាម ប៉ុន្តែពុំបានដឹងនូវអ្វីដែលបានកើតឡើងចំពោះពួកគេក្រោយពីគាត់បានប្រគល់ទៅឱ្យឈ្លបស្រុក[2435]។ "ជាំង ស្រីមុំ បានផ្តល់សក្ខីកម្មថា ជនជាតិវៀតណាមខ្លះ ឬអ្នកដែលបន្លំជាជនជាតិវៀតណាមដែលប៉ុនប៉ងចាកចេញពីកម្ពុជា ត្រូវបាននាំចេញពីឃុំញ៉ែងញ៉ង នៅពេលដែលអង្គការស្រាវជ្រាវរកជនជាតិវៀតណាមដើម្បីបញ្ជូន'ត្រឡប់ទៅប្រទេសខ្លួនវិញ'"[2436]។ ទោះជាយ៉ាងណាក្តី គាត់បានចងចាំការដែលគេឱ្យប្រជាជនវៀតណាមឡើងឡានមួយ ឬច្រើនដែលពុំបានឆ្ពោះទិសដៅទៅប្រទេសវៀតណាម[2437]។ ជូ គឹមឡុន បាន"ពិពណ៌នានូវសេចក្តីប្រកាសដែលបានធ្វើឡើង

---

[2430] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧០០-៧០៣។

[2431] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១១។

[2432] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១១, ១១១២, ១១១៦។

[2433] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១២-១១១៤។

[2434] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១២។

[2435] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៤។

[2436] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៤។

[2437] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៦។

ក្នុងឆ្នាំ ១៩៧៦ ក្នុងភូមិរបស់គាត់ក្នុងឃុំលាយបូរ នៅពេលដែលពួកគេត្រូវបានប្រាប់ថា ជនជាតិវៀតណាម" ត្រូវតែប្រមូលផ្តុំ និង'បញ្ជូនត្រឡប់ទៅប្រទេសខ្លួនវិញ'" ប៉ុន្តែគាត់ចង់សំដៅថា ជា"ល្បិចកលដ៏សាហាវ"[2438]។ សក្ខីកម្មទាំងនេះបានគាំទ្រការដែលថា ជនជាតិវៀតណាមត្រូវបានប្រមូលផ្តុំ និងដឹកចេញទៅ និងអាចផ្តល់ការជឿជាក់ខ្លះដល់ការសន្និដ្ឋានដែលថា ជនជាតិវៀតណាមខ្លះបានឆ្លងកាត់ព្រំប្រទល់។

841. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចម្លើយក្នុងសៀវភៅកំណត់ហេតុក្រាំងតាចាន់ មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយសក្ខីកម្មនេះ។ ផ្នែកដែលពាក់ព័ន្ធនៃសៀវភៅកំណត់ហេតុក្រាំងតាចាន់បានបញ្ជាក់ថា "ក្នុងខែ មករា ឆ្នាំ ១៩៧៦ អង្គការបានប្រមូលផ្តុំប្រជាជន*យួន* [ជនជាតិវៀតណាម] និងបញ្ជូនពួកគេទៅប្រទេសវៀតណាមវិញ"[2439]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចម្លើយនេះ គឺជា"ការពិពណ៌នាលម្អិត"[2440] ដូច្នេះ ពុំត្រូវបានចាត់ទុកថា ជាប់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម និងអាចត្រូវបានសំអាងដោយត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្រប និងយោងទៅលើផ្នែក **V.ង.២.ង** នៃសាលដីកានេះ និងដោះស្រាយលើអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសំអាងទៅលើភស្តុតាងដែលពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្ម។

842. អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរទៅលើទស្សនាវដ្តីទង់បដិវត្តដែលបានបញ្ជាក់ថា៖

> ប្រជាជនយើង ហៅថា "ប្រជាជនកម្ពុជា"។ ក៏ប៉ុន្តែ មានជនបរទេសនៅច្រើនណាស់ រាប់សែននាក់។ ហើយជនបរទេសប្រភេទម្យ៉ាង មានសភាពពិសពុល គ្រោះថ្នាក់ដល់ប្រជាជនយើងខ្លាំងណាស់។ ជនទាំងនេះ មានសភាពហៅថា ពិសពុល ដោយវាមកគ្របាក់យើង មកប្របិចយើង មកលេបយើង មករឹបយកគ្រប់បែបគ្រប់យ៉ាងទាំងអស់ ធ្វើឱ្យប្រជាជាតិយើង និងប្រជាជនយើង ត្រូវគ្រោះថ្នាក់អន្តរាយក្នុងពេលកន្លងមកអស់ទឹកដីជាច្រើន។ សូម្បីតែក្នុងពេលថ្មីៗនេះ មុនដែលយើងធ្វើសង្គ្រាមរំដោះជាតិ នៅក្នុងរយៈ០៥ឆ្នាំនេះ ទឹកដីខ្លះ នៅត្រង់កន្លែងខ្លះ ជនជាតិបរទេសទាំងនេះមានរហូតដល់ ៩៩ %។ គឺ ៩៩ ភាគរយនៃស្រុកទាំងនេះ សុទ្ធតែជាជនបរទេស។ យើងចូលមិនចុះទេ។ ជនបរទេសនេះមកដោយរឹប និងដោយលេប។ ពួកក្បត់ និងពួកវណ្ណៈជិះជាន់ក្នុងប្រទេស លក់ដីឱ្យជនបរទេស ជាភូមិ ជាឃុំ ជាស្រុក ជាបឹង ជាប្ញូរ ឱ្យវាធ្វើម្ចាស់ទាំងស្រុង។ ជនជាតិកម្ពុជា ជនជាតិខ្មែរ ចូលមិនចុះទេ។ ដូច្នោះ ឧទាហរណ៍នេះ បញ្ជាក់ថា ប្រជាជាតិយើងក្នុង១ឆ្នាំៗ មានគ្រោះថ្នាក់សំបើមណាស់។ ហើយបើទុកឱ្យ១០ ឆ្នាំទៀត តើយ៉ាងម៉េច ? ទុកឱ្យ២០ ឆ្នាំទៀត ៣០ ឆ្នាំទៀត តើយ៉ាងម៉េច ? គឺថា ដល់ជាង២០ ឆ្នាំ ជនជាតិបរទេសនេះមុខជាកើនឡើងដល់១០លាននាក់។ ក្នុងសភាព

---

[2438] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៦។

[2439] សៀវភៅកំណត់ហេតុក្រាំងតាចាន់ ឯកសារលេខ E3/5827 ERN 00270861។

[2440] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៥។

នេះហើយដែលហៅថា លេបបាត់ប្រជាជាតិ ប្រជាជនកម្ពុជាយើង។ នេះជាសភាពជាក់ស្តែងរបស់ប្រទេសយើង។

ប៉ុន្តែ បដិវត្តរបស់យើង ហើយពិសេស ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ បានដោះស្រាយបញ្ហាយ៉ាងស្អាត ហើយដោះស្រាយទាំងមូល។ យើងសន្មតថា ដោះស្រាយបានជាស្ថាពរ។ រាប់ពាន់ឆ្នាំមកហើយ ដោះបញ្ហាមិនទាន់បាន ហើយក៏មិនដោះស្រាយទៀត។ វណ្ណៈជិះជាន់ វាមិនត្រឹមតែមិនដោះស្រាយទេ វាលក់ដីទាំងកំណាត់ៗឱ្យបរទេសនេះទៀត។ ឥឡូវ [...] បានបោសសំអាតជនបរទេសទាំងនេះរាប់សែននាក់ ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ [...][2441]។

843. ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃខ្លឹមសារនៃអត្ថបទខាងលើនេះ ដែលតាមជាក់ស្តែងបង្ហាញថា ខ្មែរក្រហមបានបណ្តេញជនជាតិអាមេរិក ពួកអ៊ឺរ៉ុប និងដទៃទៀត នៅពេលដែលខ្មែរក្រហមបានមកដល់ទីក្រុងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2442]។ គាត់បានអះអាងថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើអ្នកជំនាញ Alexander HINTON ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ទស្សនាវដ្តីទង់បដិវត្តចង់សំដៅទៅលើការបណ្តេញជនជាតិវៀតណាមនោះ ជាការពុំត្រឹមត្រូវទេ ដោយសារនេះពុំមែនជាជំនាញរបស់លោក HINTON[2443]។ ការអះអាងរបស់ ខៀវ សំផន បែបនេះពុំអាចជឿជាក់បានឡើយ។ អត្ថបទនោះចង់សំដៅច្បាស់ណាស់ទៅលើ“ជនបរទេសមួយប្រភេទ” និងសំដៅលើស្រុកជាក់លាក់ដែលមានជនបទេសប្រភេទនេះស្ទើរតែទាំងអស់។ នេះជាការសមហេតុផលពិតប្រាកដសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានថា អត្ថបទនេះចង់សំដៅទៅលើជនជាតិវៀតណាម និងការបណ្តេញពួកគេចេញ។

844. អង្គជំនុំជម្រះសាលាដំបូងបានយោងផងដែរទៅលើការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការមកដល់របស់ប្រជាជនខ្មែរក្រោមក្នុងស្រុកត្រាំកក់ដែលជាការដោះដូរជាមួយនឹងប្រជាជនវៀតណាមដែលបានចាកចេញទៅ[2444]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញនេះពុំគប្បីប្រើប្រាស់ដើម្បីបង្ហាញថា ប្រជាជនវៀតណាមត្រូវបាននិរទេសចេញឡើយ ពីព្រោះខ្មែរក្រោមដែលមកផ្តល់សក្ខីកម្មនោះពុំបានដឹងនូវអ្វីដែលបានកើតឡើងចំពោះជនជាតិវៀតណាមនោះទេ[2445]។ ទោះជាយ៉ាងណាក្តី ភស្តុតាងជាឯកសារនៃកំណត់ត្រា

[2441] ទស្សនាវដ្តីទង់បដិវត្ត ឯកសារលេខ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៦-៧។

[2442] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧០៦។

[2443] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧០៨។

[2444] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៥៨ យោងទៅលើកថាខណ្ឌ ១១១៨-១១១៩ ១១២៥។

[2445] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧១០។

របស់ស្រុកត្រាំកក់បានគាំទ្រថា ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីស្រុកត្រាំកក់ ដោយសារមានឯកសារមួយសំដៅទៅលើខ្មែរក្រោមថា ត្រូវបាន"ដោះដូរជាមួយ*យួន*"[2446]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មលើខ្មែរក្រោមពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[2447]ក៏ដោយ ក៏ពុំមានមូលហេតុដែលតម្រូវឱ្យអង្គជំនុំជម្រះពុំធ្វើការពិចារណាលើអង្គហេតុពាក់ព័ន្ធទៅនឹងខ្មែរក្រោម នៅពេលដែលអង្គហេតុនោះមានទំនាក់ទំនងជាមួយនឹងបទចោទនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នោះដែរ បើទោះបីជាអំណះអំណាងរបស់ ខៀវ សំផន លើកផ្ទុយពីនេះក៏ដោយ[2448]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងជាក់ច្បាស់អំពីភាពត្រឹមត្រូវនៃកំណត់ត្រារបស់ស្រុកត្រាំកក់ និងបានកត់សម្គាល់ថា កំណត់ត្រាខ្លះរួមមានឯកសារដែលបានដកស្រង់ខាងលើ បានបង្ហាញនូវភាពស៊ីសង្វាក់គ្នា និងការបញ្ជាក់បន្ថែមលើភស្តុតាងដែលបានផ្តល់ដោយបុគ្គលដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ[2449]។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកំណត់ត្រានោះឡើយ។

845. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវភាពពុំត្រឹមត្រូវនៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យ៉ាងហោចណាស់ ប្រជាជនវៀតណាមមួយចំនួន "ក្នុងចំណោមដ៏ច្រើន"ដែលអង្គជំនុំជម្រះបានយល់ឃើញថា ត្រូវបានផ្លាស់ទីចេញពីស្រុកត្រាំកក់[2450]ដែលកាលពីដំបូងឡើយឃើញមាននៅ"គ្រប់ទីកន្លែង"ក្នុងស្រុកត្រាំកក់នោះ[2451]ជាក់ស្តែងបានឆ្លងកាត់ព្រំប្រទល់ទៅប្រទេសវៀតណាម។

846. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមូលដ្ឋានគាំទ្រក្នុងការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា មានចេតនាបង្ខំជនជាតិវៀតណាមឱ្យឆ្លងកាត់ព្រំប្រទល់ជាតិ។ ភស្តុតាងបានបង្ហាញអំពីអ្នកដែលមានដើមកំណើតជនជាតិវៀតណាមត្រូវបានប្រមូលផ្តុំ និងនាំទៅត្រាំកក់ និងក្រោយមកដឹកចេញទៅ។ ការសន្មតជាក់លាក់ដែលថា ជនជាតិវៀតណាមភាគច្រើនត្រូវបានសម្លាប់ស្របជាមួយនឹងភ

---

[2446] សេចក្តីរាយការណ៍បញ្ជាក់ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/2048 ERN 00079089។

[2447] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៥។

[2448] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧១៤។

[2449] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១០.១.៤ និងជាពិសេសកថាខណ្ឌ ៨៦៩។

[2450] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៤។

[2451] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១០។

ស្តុតាងដែលថា ជនជាតិវៀតណាមពុំមានជម្រើសអ្វីដែលបានកើតឡើងនោះឡើយ។ ការលើកឡើងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការនិរទេសជនជាតិវៀតណាមចេញពីស្រុកត្រាំកក់ ត្រូវបដិសេធចោល។

## ២. ខេត្តព្រៃវែង

847. ក្នុងការវាយតម្លៃលើបញ្ហាថាតើ ការនិរទេសចេញពីខេត្តព្រៃវែងបានកើតឡើង ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញរបស់ខ្លួនដែលថា ចាប់តាំងពីឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៦ មានគោលនយោបាយទូទាំងប្រទេសក្នុងការបណ្តេញប្រជាជនវៀតណាមដែលជាក្រុមជាតិពន្ធុកំពុងរស់នៅក្នុងប្រទេសកម្ពុជា[2452]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការរៀបចំបញ្ជីឈ្មោះជនជាតិវៀតណាម និងការអនុវត្តន៍គោលនយោបាយស្វែងរកជនជាតិវៀតណាមមានសែស្រឡាយខាងម្តាយ បានបង្កើតបរិយាកាសបង្ខិតបង្ខំ ឱ្យជនជាតិវៀតណាមត្រូវតែចាកចេញ និងគ្មានជម្រើសពិតប្រាកដណាមួយឡើយ[2453]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ជនជាតិវៀតណាមម្នាក់ៗនោះបានរស់នៅតាមសហគមន៍របស់ពួកគេរៀងៗខ្លួន ជាច្រើនជំនាន់មកហើយ មុនការផ្លាស់ទីដោយបង្ខំនោះ[2454]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនវៀតណាមជាច្រើនត្រូវបានប្រមូលផ្តុំ និងផ្លាស់ទីចេញពីខេត្តព្រៃវែង[2455] និងបានពិចារណាឃើញថា ជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ពុំបានផ្តល់មូលដ្ឋានផ្លូវច្បាប់សម្រាប់ធ្វើយុត្តិកម្មនៃការនិរទេសនេះបានឡើយ[2456]។ ដោយរំឭកនូវការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងគោលនយោបាយក្នុងការបណ្តេញប្រជាជនវៀតណាមចេញពីកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការផ្លាស់ទីប្រជាជនវៀតណាម គឺជាចេតនា[2457]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "បទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអត្ថិភាពពាក់ព័ន្ធទៅនឹងប្រជាជនវៀតណាមក្នុងចំនួនដ៏ច្រើនដែលត្រូវបានបណ្តេញចេញពីខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦"[2458]។

---

[2452] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៣។

[2453] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៣។

[2454] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៤។

[2455] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥។

[2456] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៦។

[2457] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៧។

[2458] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៧។

848. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានពង្រីកការសន្និដ្ឋានដែលពុំបានតម្រូវដោយផ្អែកលើភស្តុតាងនៃគ្រួសារជាក់លាក់ចេញពីភូមិតែបីថា ប្រជាជនវៀតណាមដ៏ច្រើនត្រូវបានប្រមូលផ្តុំ និងបណ្តេញចេញទូទាំងខេត្តព្រៃវែង[2459]។ គាត់បានអះអាងផងដែរថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថាគ្រួសារប្រជាជនវៀតណាមត្រូវបានជម្លៀសចេញពីភូមិបីនោះ ដូចជាអន្លង់ទ្រា ពោធិ៍ចិន្តាំ និងអង្គរយស[2460]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់សាក្សីម្នាក់ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរពីរ និងឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែសក្ខីកម្មរបស់សាក្សីត្រូវបានបំភ្លៃការពិត សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺជាពាក្យចចាមអារ៉ាម ហើយកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនោះខ្វះភាពលម្អិត និងភាពជឿទុកចិត្តបាន និងមានតម្លៃជាភស្តុតាងទាប[2461]។ ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខៀវ សំផន បានអះអាងថា ដោយសារតម្លៃជាភស្តុតាងទាប អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនបានសំអាងត្រឹមតែធ្វើជាភស្តុតាងបញ្ជាក់បន្ថែមប៉ុណ្ណោះ ប៉ុន្តែផ្ទុយទៅវិញបានបង្កើតការយល់ឃើញថា ជនជាតិវៀតណាមត្រូវបានផ្លាស់ទីចេញពីភូមិអង្គរយសដោយផ្អែកលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ[2462]។

849. ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិវៀតណាមត្រូវបានបង្ខំឱ្យចាកចេញ ដោយសារភស្តុតាងដែលបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈជាទូទៅ និងពុំជាក់លាក់ចំពោះខេត្តព្រៃវែង។ ពុំមានភស្តុតាងបង្ហាញនូវបរិយាកាសបង្ខិតបង្ខំ ឬបញ្ជីឈ្មោះប្រជាជនវៀតណាមត្រូវបានធ្វើឡើងក្នុងខេត្តព្រៃវែងឡើយ[2463]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើភស្តុតាងនៃគោលនយោបាយទូទៅក្នុងការបង្ហាញអំពីចេតនាក្នុងការនិរទេស ជាជាងការយល់ឃើញនូវចេតនាជាក់លាក់ទាក់ទងទៅនឹងការនិរទេសចេញពីខេត្តព្រៃវែង[2464]។

---

[2459] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៦-៩៦៩។

[2460] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៨។

[2461] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៦៩-៩៧៧។

[2462] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៨។

[2463] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៨១, ៩៨៤។

[2464] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៨៥-៩៨៦។

850. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានសន្និដ្ឋានដោយមិនសមហេតុផលផល នោះទេ ហើយអង្គជំនុំជម្រះបានយោងទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងទូទាំងខេត្តនោះ មុនពេលផ្តោត ទៅលើហេតុការណ៍ជាក់លាក់នៃគ្រួសារជនជាតិវៀតណាមដែលត្រូវបានប្រមូលផ្តុំ ផ្លាស់ទី និងឃើញចាក ចេញតាមទូកកាណូតក្នុងភូមិជាក់លាក់នោះ និងនៅគ្រប់កាលៈទេសៈ ពុំមានចំនួនអប្បបរមានៃបុគ្គលដែល តម្រូវក្នុងការបង្ហាញនូវបទចោទនៃការនិរទេសឡើយ[2465]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំ ជម្រះសាលាដំបូងពុំបានបំភ្លៃសក្ខីកម្មរបស់សាក្សី និងថា កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ បានបញ្ជាក់បន្ថែមលើសក្ខីកម្មនេះ និងថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានរួមបញ្ចូលការដឹងដោយ ផ្ទាល់អំពីជនជាតិវៀតណាមនៅក្នុងតំបន់នោះដែលត្រូវបានគេបង្ខំឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញ និង ចម្លើយរបស់គាត់ដែលថា លោកស្រីបានជម្រុញប្តីរបស់ខ្លួនដែលជាជនជាតិវៀតណាមឱ្យចាកចេញ[2466]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជា ក់បន្ថែមលើអត្ថិភាពនៃលំនាំក្នុងការផ្លាស់ទីជនជាតិវៀតណាមចេញពីខេត្តព្រៃវែង និង"បើទោះបីជា[អង្គជំនុំ ជម្រះសាលាដំបូង]មានកំហុសដោយសារការកំណត់ភស្តុតាងនេះថា ជាហេតុការណ៍នៃការនិរទេសក៏ដោយ ក៏[អង្គជំនុំជម្រះសាលាដំបូង]បានយល់ឃើញដោយសមស្របថា ហេតុការណ៍នៃការនិរទេសជនជាតិវៀត ណាមចេញពីខេត្តព្រៃវែងទៅប្រទេសវៀតណាមវិញ ត្រូវបានបង្ហាញ"ឱ្យឃើញហួសពីវិមតិសង្ស័យដែរ [2467]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសក្នុងការយល់ឃើញ របស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានបរិយាកាសបង្ខិតបង្ខំដែលក្នុងនោះជនជាតិវៀតណាមពុំមាន ជម្រើសពិតប្រាកដណាមួយ ក្រៅតែពីការចាកចេញ និងថា នេះគឺជាផ្នែកមួយនៃគោលនយោបាយទូទាំង ប្រទេសដែលបង្ហាញនូវចេតនានោះ[2468]។

851. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា និងបានបន្ថែមថា ដើម បណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មថា លោកស្រីបានឮថា ប្រជាជនវៀតណាមត្រូវបានគេបញ្ជូន ទៅប្រទេសវៀតណាមវិញ និងថា លោកស្រីបានជម្រុញប្តីរបស់ខ្លួនឱ្យទៅ ប៉ុន្តែប្តីគាត់ប្រកែក និងថា គ្រួ សារវៀតណាមមួយក្នុងភូមិលោកស្រីពុំបានត្រឡប់ទៅប្រទេសវៀតណាមវិញទេ[2469]។ សហមេធាវីនាំមុខ

---

[2465] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៦២។

[2466] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៦៣-៥៦៤។

[2467] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៦៦។

[2468] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៦៧-៥៦៨។

[2469] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣០៨-៣១០។

បានឆ្លើយតបថា ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសំអាងទៅលើភស្តុតាងនេះ និងថា អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា ភស្តុតាងខ្លះគឺជាពាក្យចចាមអារ៉ាម[2470]។ សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើការពិតថា ព្រឹត្តិការណ៍ជាក់លាក់ក្នុងខេត្តព្រៃវែងត្រូវបានបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងពាក់ព័ន្ធទៅនឹងគោលនយោបាយទូទាំងប្រទេស និងថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើភស្តុតាងជាច្រើនក្នុងការបង្ហាញនូវគោលនយោបាយនោះ[2471]។

852. ដោយសារពុំមានលក្ខខណ្ឌតម្រូវអំពីតួលេខសម្រាប់ការយល់ឃើញអំពីការនិរទេស អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានពុំត្រឹមត្រូវចេញពីភស្តុតាងក្នុងការយល់ឃើញថា ជនជាតិវៀតណាម"ជាច្រើន"ត្រូវបាននិរទេសចេញពីខេត្តព្រៃវែង។ អង្គជំនុំជម្រះតុលាការកំពូលជាបឋមត្រូវពិចារណាលើបញ្ហាថាតើ ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការយល់ឃើញអំពីធាតុផ្សំសត្យានុម័តនៃការនិរទេស មានលក្ខណៈគ្រប់គ្រាន់ ដែរ ឬយ៉ាងណា នៅមុនពេលពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ការបណ្តេញចេញទៅប្រទេសវៀតណាម មានអត្ថិភាព និងត្រូវបានប្រព្រឹត្តឡើងដោយចេតនា ដែរ ឬយ៉ាងណា។

853. ក្នុងការយល់ឃើញថា ធាតុផ្សំសត្យានុម័តនៃការនិរទេសត្រូវបានបំពេញ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ហេតុការណ៍ជាក់លាក់នៃគ្រួសារដែលត្រូវបានប្រមូលផ្តុំ ផ្លាស់ទី និងឃើញចាកចេញតាមទូកកាណូត មានអត្ថិភាព"ក្នុងភូមិអន្លង់ទ្រា ពោធិ៍ចិន្តាំ និងអង្គរយស[2472]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងភូមិអន្លង់ទ្រាលើសក្ខីកម្មរបស់សាក្សី សៅ សាក់ និងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ឯម ប៊ុននីម និង ប៊ុន រើន[2473]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ក្នុងការបង្កើតការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅ

---

[2470] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣១១-៣១២។

[2471] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣១៣។

[2472] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៥។

[2473] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣០។

នឹងភូមិពោធិ៍ចិន្តា[2474]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឧបសម្ព័ន្ធទៅនឹងពាក្យសំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងភូមិអង្គរយស[2475]។

854. សៅ សាក់ បានចំណាយពេលមួយជីវិតរបស់លោកស្រីរស់នៅក្នុងភូមិអន្លង់ទ្រា[2476]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "លោកស្រីបានឃើញដោយផ្ទាល់ជនជាតិវៀតណាមរស់ក្នុងភូមិអន្លង់ទ្រា [...] ត្រូវបានប្រមូលផ្ដុំ និង'ជម្លៀសទៅក្រោម' អ្នកដែលមានគ្រួសារជាប់សែស្រឡាយត្រូវបានប្រមូលផ្ដុំ'បន្តបន្ទាប់ និងត្រូវបានបញ្ជូនទៅតាមទូក'"[2477]។ លោកស្រីបានបញ្ជាក់ថា "ទៅក្រោម"ចង់សំដៅទៅប្រទេសវៀតណាម[2478]។ លោកស្រីបានបញ្ជាក់ច្បាស់ថា លោកស្រីពុំបានឃើញផ្ទាល់នូវព្រឹត្តិការណ៍ដែលលោកស្រីបានពិពណ៌នាមែន ប៉ុន្តែមានគេប្រាប់អំពីរឿងនោះ[2479]។ ភស្តុតាងចចាមអារ៉ាមរបស់លោកស្រីដែលថា ប្រ

[2474] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣១។

[2475] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣២។

[2476] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣០។

[2477] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣០។

[2478] ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E1/362.1 ទំព័រ ៧៣។

[2479] ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ E1/363.1 ទំព័រ ១៥-១៧:

ស: [...] ខ្ញុំចង់សួរអាននូវចម្លើយរបស់លោកស្រីកាលពីថ្ងៃព្រហស្បតិ៍ បន្ទាប់មកខ្ញុំនឹងសួរសំណួរពាក់ព័ន្ធទៅនឹងចំណុចនេះ។ គឺម៉ោង ០៣ៈ២០ៈ១២ វិនាទី លោកស្រីឆ្លើយថា "ខ្ញុំឃើញគេប្រមូលផ្ដុំពួកគេ ហើយបញ្ជូនទៅខាងក្រោម។ អ្នកណាមកពីគ្រួសារចម្រុះ ជាតិសាសន៍គេចេះតែប្រមូលទៅ ហើយបញ្ជូនដឹកតាមទូកទៅ។ ហើយបើអ្នកណាជាគ្រួសារចម្រុះជាតិ សាសន៍ ហ្នឹង គេបញ្ជូនម្ដងមួយគ្រួសារទៅតែម្ដង ហើយពួកគេបាត់ខ្លួន"។ តើ លោកស្រីចាំទេថា កាលពីថ្ងៃព្រហស្បតិ៍សប្ដាហ៍មុនហ្នឹង លោកស្រីបានឆ្លើយបែបនេះ?

ឆ: ចាស ខ្ញុំបានឆ្លើយបែបហ្នឹងមែន។

ស: លោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា តាមលោកស្រីចាំច្បាស់ តើគេប្រមូលផ្ដុំ និងបញ្ជូនអ្នកទាំងអស់ហ្នឹងដូចម្ដេច ? លោកស្រីចាំអ្វីខ្លះពីហេតុការណ៍នៃការប្រមូលផ្ដុំអ្នកទាំងអស់ហ្នឹង?

ឆ: គេប្រមូលបញ្ជូនទៅ ខ្ញុំមិនបានឃើញច្បាស់នូវដែលគេយកទៅហ្នឹង ឮប្រមូល ដូចថា ហៅអីចឹងទៅមួយគ្រួសារៗអីចឹងទៅ ទៅបាត់ទៅៗ គេមិនឱ្យយើងឃើញទេ ជួនកាលទៅយប់ ជួនកាលទៅថ្ងៃ។ យើងនៅធ្វើការមិនអាចដឹង គ្រាន់តែដឹងថា ពីរបីថ្ងៃទៅបាត់គ្រួសារហ្នឹង ចេះតែលួចសួរ គេថាយកទៅក្រោយមបាត់ហើយៗ យើងមិនអាចដឹងថាគេយកទៅឯណា។ ស: លោកស្រីដឹងទេថា អ្នកណាជាអ្នកប្រមូលគ្រួសារទាំងអស់ហ្នឹង កាលនោះ? ជាកម្មាភិបាល ឬឈ្លប នៅភូមិអន្លង់ទ្រា ឬក៏មានមនុស្សមកពីខាងក្រៅជាអ្នកមកប្រមូលគ្រួសារទាំងអស់ហ្នឹងយកចេញទៅ? លោកស្រីមានចាំទេ?

ឆ: ខ្ញុំមិនដឹងទេ អត់បានដឹងអ្នកណាៗមកយកទេ។ ព្រោះដឹងថា បាត់ៗតែម្ដង។ [...]

ជាជនវៀតណាមត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញនោះ ត្រូវបានបញ្ជាក់បន្ថែមពីកំណត់ហេតុស្តាប់ចម្លើយរបស់ ឯម ប៊ុននីម និង ប៊ុន រើន។

855. ឯម ប៊ុននីម កើតនៅភូមិអន្លង់ទ្រា[2480]។ យោងតាមកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ គាត់មានអាយុ ៥១ ឆ្នាំ ត្រឹមឆ្នាំ ២០០៩[2481] ដូច្នេះ កាលនោះគាត់មានអាយុ ១៧ ឆ្នាំក្នុងឆ្នាំ ១៩៧៥ និងពុំមែន "នៅកុមារ"ដូចការអះអាងរបស់ ខៀវ សំផននោះទេ[2482]។ គាត់ពុំបានពន្យល់ហេតុដូចម្តេចបានជាគាត់ដឹងថា រដ្ឋអំណាចស៊ីវិលប្រាប់ឱ្យប្រជាជនវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ ប៉ុន្តែបានបញ្ជាក់ច្បាស់លាស់ថា រដ្ឋអំណាចពិតជាបានធ្វើដូច្នោះមែន។ អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា គាត់នៅក្មេងពេកពុំយល់នូវសេចក្តីណែនាំនោះទេ។ នៅពេលសួរសំណួរថាតើ គាត់បានដឹងនូវអ្វីបានកើតឡើងចំពោះជនជាតិវៀតណាម និងគ្រួសាររបស់ពួកគេក្នុងភូមិរបស់គាត់ ដែរ ឬយ៉ាងណា គាត់បានឆ្លើយថា៖

> ជំនាន់ លន់ នល់ មានវៀតណាមទៅស្រុកបណ្តើរៗ។ ក្រោយពេលខ្មែរក្រហមបានជ័យជម្នះឆ្នាំ ១៩៧៥ ប្រជាជនវៀតណាមដែលបានមករស់នៅភូមិអន្លង់ទ្រា(តាំងពីយូរយារមកមិនដឹងពីពេលណា) ត្រូវបានរដ្ឋអំណាចស៊ីវិលតាមភូមិឃុំហៅឱ្យទៅស្រុកវៀតណាមវិញ ហើយខ្ញុំបានឃើញផ្ទាល់ភ្នែកប្រជាជនវៀតណាមទាំងនេះបានជិះទូកតាមទន្លេក្នុងភូមិអន្លង់ទ្រាចុះទៅខាងអ្នកលឿង។ ខ្ញុំមិនបានឃើញ និងមិនចាំថា មាននរណាស្លាប់ ឬយ៉ាងណានោះទេប្រសិនបើមិនព្រមទៅ។ កាលនោះ ខ្ញុំនៅតូចឃ្វាលគោល ដូច្នេះ មិនបានចូលរួមប្រជុំ និងមិនដឹងអំពីការប្រជុំគោលការណ៍បញ្ជូនវៀតណាមទៅស្រុកវិញទេ[2483]។

---

សៈ កាលពីថ្ងៃព្រហស្បតិ៍លោកស្រីបាននិយាយថា អ្នកដែលត្រូវបានប្រមូល ហើយនិងជម្លៀសចេញទៅហ្នឹង គឺគេបញ្ជូនទៅវៀតណាម។ លោកស្រីបានព័ត៌មានហ្នឹងមកពីណា? ហើយនៅថ្ងៃនេះ ហេតុអ្វីបានជាលោកស្រីប៉ាននិយាយថា គេប្រមូលក្រុមគ្រួសារទាំងអស់ហ្នឹងបញ្ជូនទៅវៀតណាម?

ឆៈ ចេះតែឮតៗគ្នាថា គេបញ្ជូនទៅក្រោម បញ្ជូនទៅវៀតណាម។

សៈ លោកស្រីឮតៗគ្នាហ្នឹង ឮតពីអ្នកណា? ពីអ្នកនៅភូមិអន្លង់ទ្រាហ្នឹង ឬក៏អ្នកណាផ្សេង? កាលនោះអ្នកភូមិនាំគ្នានិយាយនៅក្នុងភូមិហ្នឹងថា គេប្រមូលក្រុមគ្រួសារទាំងអស់ហ្នឹងបញ្ជូនទៅវៀតណាម ឬក៏លោកស្រីដឹងរឿងនេះក្រោយមកទេ គឺចប់របបកម្ពុជាប្រជាធិបតេយ្យហើយទេទើបដឹង?

ឆៈ ចេះឮតៗគ្នានៅក្នុងភូមិហ្នឹង ឃើញគេយកទៅថា ហ៊ឺ! គេបញ្ជូនទៅវៀតណាមហើយអ្នកដែលនៅក្នុងភូមិយើងហ្នឹង គេឱ្យទៅស្រុកកំណើតវៀតណាមវិញ ចេះឮតែអីចឹងទៅទាំងអស់តែគ្នាហ្នឹង។

[2480] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឯម ប៊ុននីម ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ ឯកសារលេខ E3/7760 ទំព័រ ២។

[2481] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឯម ប៊ុននីម ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ ឯកសារលេខ E3/7760 ទំព័រ ២។

[2482] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៧៥។

[2483] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឯម ប៊ុននីម ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ ឯកសារលេខ E3/7760 ទំព័រ ៣។

856. គាត់បានបញ្ជាក់ផងដែរថា ជីដូនរបស់គាត់បានប្រាប់គាត់ថា ម្ដាយរបស់គាត់ត្រូវបានចាប់ខ្លួន និងយកចេញទៅតាមទូក ដោយសារជាជនជាតិវៀតណាម ប៉ុន្តែគាត់ត្រូវបានលើកលែងពីព្រោះអ្នកភូមិបានពន្យល់ដល់ឈ្លបភូមិថា គាត់មានលោហិតជាខ្មែរ ដោយសារឪពុករបស់គាត់ជាជនជាតិខ្មែរសុទ្ធសាធ[2484]។

857. ប៊ុន រើន បានកើតនៅក្នុងភូមិអន្លង់ទ្រា និងបានរស់នៅចាប់តាំងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[2485]។ ក្នុងឆ្នាំ ១៩៧៥ គាត់មានអាយុ ១៤ ឆ្នាំ[2486]។ គាត់បានធ្វើការជានីរសារមេភូមិ និងបានបញ្ជាក់ថា គាត់ត្រូវបានណែនាំឱ្យតាមរកក្មេងប្រុសម្នាក់ដែលមានឪពុកជាវៀតណាម ដោយសារឃើញក្មេងនោះយំ គាត់បានប្រាប់ប្រធានភូមិថា គាត់រកក្មេងនោះមិនឃើញទេ។ គាត់បានបញ្ជាក់ថា គាត់ពុំបានដឹងមូលហេតុដែលក្មេងនោះត្រូវកោះហៅដែរ[2487]។ គាត់បានបង្កើតបញ្ជីឈ្មោះគ្រួសារវៀតណាមដែលរស់នៅក្នុងភូមិអន្លង់ទ្រា និងបានអះអាងថា ខ្មែរក្រហមអនុញ្ញាតជនជាតិវៀតណាមភាគច្រើនត្រឡប់ទៅប្រទេសខ្លួនវិញ និងថា គាត់បានដឹងអំពីការដឹកជញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសខ្លួនវិញតាមរយៈអ្នកភូមិ និងការសង្កេតផ្ទាល់ខ្លួន[2488]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា គ្រួសារជនជាតិវៀតណាមដែលមកពីភូមិអន្លង់ទ្រា ត្រូវបាននិរទេសដោយផ្អែកលើសក្ខីកម្មរបស់ សៅ សាក់ និងកំណត់ហេតុស្ដាប់ចម្លើយរបស់ ឯម ប៊ុននីម និង ប៊ុន រើន។ ខៀវ សំផន ពុំបានបង្ហាញថា នេះគឺជាការយល់ឃើញមួយដែលពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាននោះឡើយ។

858. ពាក់ព័ន្ធទៅនឹងភូមិពោធិ៍ចិន្ដាំ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖ "ចាប់តាំងពីឆ្នាំ ១៩៧៥ ដួង អឿន ដែលបានរស់នៅក្នុងភូមិពោធិ៍ចិន្ដាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង បានឮថា ប្រជាជនវៀតណាមដែលរស់នៅក្នុងតំបន់គាត់ត្រូវតែត្រឡប់ទៅប្រទេសវៀតណាមវិញ និងថា តាគិត យាយម៉ាន់ និងកូនៗបានត្រឡប់ទៅវិញ។ លក្ខណៈនៃការវិលត្រឡប់ទៅវិញនេះដែលបានកើតឡើងនោះ ទោះជាយ៉ាងណាក្ដីពុំត្រូវបានសួរបញ្ជាក់បន្ថែមនៅក្នុងតុលាការឡើយ"[2489]។ ដូចបានសង្កេតរបស់សហមេធាវីនាំមុខ[2490]ថា ដួង អឿ

[2484] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ឯម ប៊ុននីម ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ ឯកសារលេខ E3/7760 ទំព័រ ៤។

[2485] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ប៊ុន រើន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/7811 ទំព័រ ២។

[2486] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ប៊ុន រើន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/7811 ទំព័រ ២ លើកឡើងថា សាក្សីអាយុ ៤៨ ឆ្នាំ នៅពេលផ្ដល់បទសម្ភាសន៍ក្នុងឆ្នាំ ២០០៩។

[2487] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ប៊ុន រើន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/7811 ទំព័រ ២។

[2488] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ប៊ុន រើន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/7811 ទំព័រ ៣។

[2489] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣១។

[2490] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ២២២។

ន បានដឹងដោយផ្ទាល់ថា ជនជាតិវៀតណាមត្រូវបានប្រាប់ឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញ និងថា គាត់បានជម្រុញប្តីរបស់គាត់ដែលជាជនជាតិវៀតណាមឱ្យត្រឡប់ទៅវិញ ប៉ុន្តែគាត់បានប្រកែក និងថា គាត់ក្រោយមកត្រូវបានគេនាំយកទៅបាត់[2491]។ លោកស្រីបានឆ្លើយថា ខ្មែរក្រហមបានមកដល់ភូមិពោធិ៍ចិន្តាំក្នុងឆ្នាំ ១៩៧៧[2492] ដែលផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការនិរទេសបានកើតឡើងក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦[2493]។

859. ទាក់ទងទៅនឹងភូមិអង្គរយស អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពៅ ហុង ដែលបានកើតក្នុងឆ្នាំ ១៩៦៥ និងដូច្នេះមានអាយុ ១០ ឆ្នាំ ក្នុងឆ្នាំ ១៩៧៥ [2494]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា “នេះមានតម្លៃជាភស្តុតាងតិចតួច”[2495]។ ទោះ ជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងនេះបានបញ្ជាក់បន្ថែមលើអត្ថិ ភាពនៃលំនាំនៃការផ្លាស់ទីជនជាតិវៀតណាមក្នុងខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥[2496]។ ឧបសម្ព័ន្ធនេះបានលើកឡើងថា៖

> នៅចុងឆ្នាំ ១៩៧៥ ប្រធានភូមិអង្គរយសឈ្មោះ តាមួន និង ស៊ិន បានដើរប្រកាសប្រាប់អាណិកជនវៀតណាម និងប្រជាជនដែលជាប់សែស្រឡាយវៀតណាមនៅក្នុងភូមិថា “អង្គការត្រូវបញ្ជូនទៅប្រទេសវៀតណាមវិញ”។ កាលនោះ ក្រុមគ្រួសាររបស់ ហុង រួមមានក្រុមគ្រួសារខាងយាយទួត តាទួត ជីដូន ជីតា ម្តាយធំ ឪពុកធំ ម្តាយមីង និងគ្រួសាររបស់ ហុង រួមជាមួយនឹងអាណិកជនវៀតណាម នៅភូមិអង្គរយសជាច្រើន

---

[2491] ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E1/381.1 ទំព័រ ៩-១០។

[2492] ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារលេខ E1/381.1 ទំព័រ ១៧-១៨:

> ស: ហើយនៅពេលដែលលោកស្រីសម្រេចប្រើប្រាស់ឈ្មោះថ្មីហ្នឹង គឺនៅពេលក្រោយដែលខ្មែរក្រហមចូលទៅដល់ភូមិពោធិ៍ចិន្តាំហ្នឹងមែនទេ?
>
> ឆ: ចាស ខ្ញុំដាក់ក្រោយហ្នឹង។ ដាក់ក្រោយខ្មែរក្រហមចូលភូមិហ្នឹង។
>
> ស: ខ្ញុំស្តាប់ឮថា លោកស្រីថា ខ្មែរក្រហមបានចូលមកដល់ភូមិរបស់លោកស្រីនៅឆ្នាំ ១៩៧៧។ ខ្ញុំសូមអានសម្រង់មួយឱ្យលោកស្រីស្តាប់ចេញពីប្រតិចារឹករបស់បុគ្គលម្នាក់ ដែលជាអ្នកភូមិរបស់លោកស្រីដែរ ឈ្មោះ តេង ផល ឬ តេង ហ៊ុយ ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺប្រតិចារឹក E1/370.1 នៅមុនម៉ោង ០៣ះ១៥ ថ្ងៃ គាត់បានឆ្លើយថា៖ ខ្មែរក្រហម បានមកត្រួតត្រាភូមិពោធិ៍ចិន្តាំក្នុងឆ្នាំ ១៩៧២ ឬ ១៩៧៣?
>
> ឆ: ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែ ៧៧ ខ្មែរក្រហមចូលដល់ភូមិពោធិ៍ចិន្តាំ ៧៧។ ថាប៉ុន្មានៗទៀត ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែប៉ុណ្ណឹង។

[2493] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៣។

[2494] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពៅ ហុង ឯកសារលេខ E3/7165a ERN 00502653 ទំព័រ ១១។

[2495] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣២។

[2496] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣២។

គ្រួសារទៀត បានធ្វើដំណើរតាមទូកចាកចេញពីភូមិអង្គរយសឆ្ពោះទៅភ្នំសំណ ស្ថិតនៅក្នុងស្រុកលើកដែក តំបន់ ២៥ ដែលជាព្រំដែនរវាងកម្ពុជា និងវៀតណាម ដោយមានការដឹកនាំពីសំណាក់កម្មាភិបាលខ្មែរក្រហម។ [...] បន្ទាប់ពីគ្រួសាររបស់ ហុង បានមកដល់ភ្នំសំណ និងស្នាក់នៅទីនោះប្រមាណ ៥ យប់ ទើបខាងភាគីវៀតណាមមកប្រាប់ថា "ប្រជាជនទាំងអស់សុទ្ធតែជាជនជាតិខ្មែរ ដូច្នេះ ខាងវៀតណាមមិនទទួលយកទេ"។ កម្មាភិបាលខ្មែរក្រហមបានប្រាប់ប្រជាជនទាំងអស់ឱ្យវិលត្រឡប់មកភូមិកំណើតវិញ។ គ្រួសាររបស់ ហុង បានធ្វើដំណើរត្រឡប់មកអង្គរយសវិញ។ នៅពេលមកដល់ភូមិអង្គរយស គ្រួសាររបស់ ហុង ត្រូវរស់នៅ និងធ្វើស្រែចម្ការជាធម្មតាដូចប្រជាជនក្នុងភូមិ[2497]។

860. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ ពុំគ្រប់គ្រាន់ក្នុងការគាំទ្រការយល់ឃើញឱ្យហួសពីវិមតិសង្ស័យដែលថា ការនិរទេសបានកើតឡើងពីភូមិពោធិ៍ចិន្តាំ និងអង្គរយស។ ទោះជាយ៉ាងណាក្តី នៅពេលពិចារណាជាមួយនឹងភស្តុតាងចេញពីភូមិអន្លង់ទ្រា និងភស្តុតាងនៃគោលនយោបាយទូទាំងប្រទេសក្នុងការបណ្តេញជនជាតិវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយសមហេតុផលថា ការនិរទេសមួយចំនួនបានកើតឡើងចេញពីខេត្តព្រៃវែងជាទូទៅ។

861. អំណះអំណាងរបស់ ខៀវ សំផន ដែលថា ពុំមានគោលនយោបាយចំពោះជនជាតិវៀតណាម ត្រូវបានដោះស្រាយនៅក្នុងសាលដីកានេះ[2498]។ ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងទូទៅបង្ហាញពីគោលនយោបាយចំពោះជនជាតិវៀតណាមក្នុងការយល់ឃើញថា ការវិលត្រឡប់នោះត្រូវបានធ្វើឡើងដោយបង្ខំ និងដោយចេតនា ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសណាមួយក្នុងវិធីសាស្ត្ររបស់ខ្លួនឡើយ។ ភស្តុតាងដែលថា ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីប្រទេសនោះ បានគាំទ្រការសន្និដ្ឋានដែលថា ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីតំបន់ជាក់លាក់មួយ។ ភស្តុតាងនៃចេតនាក្នុងការនិរទេសជនជាតិវៀតណាមចេញពីប្រទេស អាចបង្ហាញនូវចេតនាក្នុងការនិរទេសជនជាតិវៀតណាមចេញពីខេត្តព្រៃវែង។ នេះជាការពុំចាំបាច់សម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសំអាងទៅលើភស្តុតាងដែលជាក់លាក់សម្រាប់ខេត្តព្រៃវែង ដរាបណាភស្តុតាងដែលបានផ្អែកនោះបានអនុញ្ញាតឱ្យអង្គជំនុំជម្រះធ្វើការយល់ឃើញឱ្យហួសពីវិមតិសង្ស័យថា

---

[2497] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពៅ ហុង ឯកសារលេខ E3/7165a ទំព័រ ៣៣ ERN 00502675។

[2498] *សូមមើល* ផ្នែក VIII.ខ.៥.ក។ *សូមមើលផងដែរ* ផ្នែក VII.ជ.១.ក.ii។

ធាតុផ្សំនៃការនិរទេសត្រូវបានបំពេញ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន។

## ង. ការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ការធ្វើទារុណកម្មលើជនជាតិចាម

862. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋនៃការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញទាក់ទងទៅនឹងការធ្វើទារុណកម្មលើជនជាតិចាម និងថា អ៊ីត សេន និងបុរសជនជាតិចាមដទៃទៀតត្រូវបានបំបែកចេញពីស្ត្រី និងកូនៗនៅភូមិទ្រា និងត្រូវបានបញ្ជាឱ្យដើរទៅមាត់ទន្លេ កន្លែងដែលពួកគេត្រូវបានចង វាយដំ និងសួរដដែលៗថាតើ ពួកគេជាជនជាតិម៉ូស្លីម ដែរ ឬទេ[2499]។ អង្គជំនុំជម្រះបានរំឭកថា "ការវាយដំអាចស្មើនឹងអំពើធ្វើទារុណកម្ម*ដោយខ្លួនផ្ទាល់*ដែលបានបង្កការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរ" និងហេតុដូចនេះ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំសត្យានុម័តនៃការធ្វើទារុណកម្មដែលមានអត្ថិភាពនោះ[2500]។ អង្គជំនុំជម្រះក៏បានជឿជាក់ផងដែរថា ការវាយដំត្រូវបានប្រព្រឹត្តដោយចេតនាដើម្បីកំណត់ថាតើ អ្នកជាប់ឃុំនោះគឺជាជនជាតិចាម ដែរ ឬយ៉ាងណា និងដូច្នេះ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិនៃបទឧក្រិដ្ឋនៃការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានអត្ថិភាព[2501]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើបាបដោយចេតនាលើផ្លូវចិត្ត និងរូបកាយដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការសួរយកចម្លើយនោះ គឺកើតចេញពីកម្មាភិបាលសាធារណៈដែលអនុវត្តជំនួសឱ្យបក្សកុម្មុយនីស្តកម្ពុជា និងសម្រាប់គោលបំណងទទួលបានព័ត៌មាន[2502]។

863. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការពិចារណាថា ការវាយដំលើ អ៊ីត សេន និងបុរសជនជាតិចាមដទៃទៀតនោះត្រូវបានប្រព្រឹត្តឡើងដើម្បីបញ្ជាក់ថា អ្នកជាប់ឃុំនោះជាជនជាតិចាម ដែរ ឬទេ ដោយសារអង្គជំនុំជម្រះបានសំអាងតែទៅលើសក្ខីកម្មរបស់ អ៊ីត សេន ដែលពុំមានមូលដ្ឋានគាំទ្រ ហើយសក្ខីកម្មនេះមានលក្ខណៈផ្ទុយគ្នាត្រង់ថា ការវាយដំគឺក្នុងគោលបំណងបញ្ជាក់ថាតើ

---

[2499] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៩។

[2500] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៧ យោងទៅលើកថាខណ្ឌ ៣២៧៦។

[2501] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៨។

[2502] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៨-៣៣១៩។

អ្នកជាប់ឃុំនោះ ជាជនជាតិចាម ដែរ ឬទេ នៅពេលដែលអ្នកសួរយកចម្លើយនោះបានដឹងរួចហើយថា ពួកគេគឺជាជនជាតិចាម[2503]។

864. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានធ្វើទារុណកម្មនោះ ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាន និងបានបកស្រាយពុំត្រឹមត្រូវលើសក្ខីកម្មរបស់ អ៊ីត សេន[2504]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានយុត្តិសាស្ត្របង្ហាញត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើសាក្សីតែម្នាក់បានក្នុងការបង្កើតការយល់ឃើញមួយ និងថា សក្ខីកម្មរបស់ អ៊ីត សេន ដែលថា អ្នកសួរយកចម្លើយនោះបានដឹងរួចហើយថា អ្នកជាប់ឃុំនោះ គឺជាជនជាតិចាម ពុំបានធ្វើឱ្យភស្តុតាងរបស់គាត់ផ្ទុយគ្នាឡើយ ហើយបើទោះជាមាន ក៏ពុំបានធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញដែលថា ការវាយដំត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ថាតើ អ្នកជាប់ឃុំនោះ ជាជនជាតិចាម ដែលនេះបំពេញនូវលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិនៃការធ្វើទារុណកម្ម[2505]។

865. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងបានឆ្លើយតបបន្ថែមទៀតថា "ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា វិធានការត្រូវបានប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ថា បុរសនោះគឺជាជនជាតិចាម នៅពេលពួកគេបានមកដល់ភូមិទ្រា ត្រូវបានគាំទ្រផងដែរដោយភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ និងសាក្សី ម៉ាត់ ស"[2506]។

866. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា អង្គជំនុំជម្រះសាលាដំបូងអាចដាក់ពិរុទ្ធភាពលើជនជាប់ចោទដោយផ្អែកលើមូលដ្ឋាននៃសាក្សីតែម្នាក់បាន[2507]។ បន្ថែមលើនេះ បើទោះបីជា អ៊ីត សេន បានផ្តល់ភស្តុតាងតែមួយពាក់ព័ន្ធទៅនឹងការវាយដំដែលជាអំពើនៃការធ្វើទារុណកម្មក៏ដោយ ក៏សក្ខីកម្មរបស់គាត់ពាក់ព័ន្ធទៅនឹងការបំបែកបុរសចេញពីស្ត្រី និងជនជាតិចាមចេញពីជនជាតិខ្មែរនៅភូមិទ្រា ត្រូវបានគាំទ្របន្ថែមដោយ នោ សាទះ និង ម៉ាត់ ស អ្នកទាំងពីរនាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "គួរជឿជាក់បាន

[2503] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២៥។

[2504] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២១។

[2505] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២២-៥២៣។

[2506] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣២០។

[2507] សាលដីកាសំណុំរឿង 00២/0១ កថាខណ្ឌ ៤៩៦។

ហើយភស្តុតាងរបស់ពួកគាត់ជាទូទៅអាចជឿទុកចិត្តបាន”[2508]។ បើទោះបីជា ខៀវ សំផន បានជំទាស់ភាពគួរជឿជាក់បានរបស់ពួកគាត់នៅពេលជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់លើសាវណាររបស់គាត់ដែរ[2509]។

867. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចម្លើយរបស់ អ៊ីត សេន ដែលថា “អ្នកដែលធ្វើទារុណកម្មដឹងថា យើងជាជនជាតិចាម” និងបានវាយដំពួកគាត់ធ្ងន់ធ្ងរ បើទោះបីជាមាននរណាម្នាក់បដិសេធថា ពុំជាជនជាតិចាមក៏ដោយ ក៏ពុំបានកាត់បន្ថយអានុភាពនៃការយល់ឃើញដែលថា “ការធ្វើបាបនោះគឺបង្កឡើងសម្រាប់គោលបំណងនៃការទទួលបានចម្លើយសារភាព”[2510]។ បើទោះបីជាតុលាការអង្គហេតុសមហេតុផលមួយផ្សេងទៀតអាចយល់ឃើញថា ភស្តុតាងនោះស៊ីសង្វាក់ទៅនឹងការធ្វើទារុណកម្មដោយកម្មាភិបាលដោយសារតែពួកគេជាជនជាតិចាមសម្រាប់គោលបំណងបំភិតបំភ័យក៏ដោយ ក៏ចេតនាក្នុងការធ្វើទារុណកម្មនៅតែមានអត្ថិភាពដែរប្រសិនបើជាការវាយដំត្រូវបានប្រព្រឹត្តឡើងដើម្បីទទួលបានព័ត៌មាននោះ[2511]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាខៀវ សំផន ពុំបានបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាអាចបង្កើតការយល់ឃើញដូចគ្នានេះ និងហេតុនេះ អំណះអំណាងរបស់គាត់ ត្រូវបដិសេធចោលពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ច. ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ១. ច្បាប់ជាធរមាន

868. អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា៖

> (១) អំពើសកម្ម ឬអកម្ម ដែល [...] រើសអើងជាក់ស្តែង និងដកហូត ឬរំលោភបំពានលើសិទ្ធិជាសារវន្តដែលមានចែងក្នុងច្បាប់សន្ធិសញ្ញា ឬទំនៀមទម្លាប់អន្តរជាតិ(ធាតុផ្សំសត្យានុម័ត) និង

---

[2508] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧៧-៣២៨០។

[2509] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៨០។

[2510] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣១៨។

[2511] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧០១ (រៀបរាប់អំពីធាតុផ្សំនៃការធ្វើទារុណកម្ម)។

(២) ការប្រព្រឹត្តដោយចេតនានូវអំពើសកម្ម ឬអកម្មដែលមានចេតនារើសអើងដោយសារមូលហេតុសាសនា ពូជសាសន៍ ឬនយោបាយ(ធាតុផ្សំអត្តនោម័តិ)[2512]។

869. ការកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញនេះត្រូវបានបញ្ជាក់អះអាងដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និងពុំត្រូវបានជំទាស់ដោយភាគីណាមួយក្នុងដំណាក់កាលជំនុំជម្រះឡើយ[2513]។

870. ខៀវ សំផន បានចោទប្រកាន់កំហុសអង្គច្បាប់ពីរចំណុចពាក់ព័ន្ធទៅនឹងការកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញ និងការបកស្រាយធាតុផ្សំនេះ។ ទីមួយ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានលុបចោលលក្ខខណ្ឌតម្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថា ការដកហូតនូវសិទ្ធិ ឬការរើសអើងត្រូវតែមានគោលបំណងដកហូតបុគ្គលចេញពីសង្គមដែលពួកគេកំពុងរស់នៅជាមួយថាវី ឬចុងក្រោយចេញពីភាពជាមនុស្សជាតិផ្ទាល់[2514]។ ទីពីរ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ចរិតលក្ខណៈនៃការប្រព្រឹត្តដូចៗគ្នាដែលមានផលប៉ះពាល់ជាពិសេសទៅលើបុគ្គលមួយក្រុមថា ជាការរើសអើងជាក់ស្តែង[2515]។ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយអំណះអំណាងទាំងនេះតាមលំដាប់លំដោយ។ អំណះអំណាងទាក់ទងទៅនឹងបញ្ហាអង្គហេតុនឹងត្រូវដោះស្រាយដាច់ដោយឡែកនៅក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះ។

### ក. ថាតើ គោលបំណងក្នុងការដកក្រុមមួយចេញពីសង្គម គឺជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា

871. ដោយផ្អែកលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ជា៖

(i) អំពើសកម្ម ឬអកម្ម ដែល [...] រើសអើងជាក់ស្តែង និងដកហូត ឬរំលោភបំពានលើសិទ្ធិជាសារវ័ន្តដែលមានចែងក្នុងច្បាប់សន្ធិសញ្ញា ឬទំនៀមទម្លាប់អន្តរជាតិ (ធាតុផ្សំសត្យានុម័ត) និង

---

[2512] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៣។

[2513] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៣។

[2514] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៤២។

[2515] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៤, ៨១៣, ៩៥៤។

(ii) ការប្រព្រឹត្តដោយចេតនាគិតទុកជាមុននូវអំពើសកម្ម ឬអកម្មដែលមានចេតនារើសអើងដោយសារមូលហេតុសាសនា ពូជសាសន៍ ឬនយោបាយ(ធាតុផ្សំអត្តនោម័តិ)[2516]។

872. ក្នុងបណ្តឹងសាទុក្ខ ទោះជាយ៉ាងណាក្តី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារលុបចោលលក្ខខណ្ឌតម្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថា ការដកហូតនូវសិទ្ធិ ឬការរើសអើងត្រូវតែមានគោលបំណងដកបុគ្គលចេញពីសង្គមដែលពួកគេរស់នៅជាមួយចារី ឬចុងក្រោយចេញពីភាពជាមនុស្សជាតិផ្ទាល់[2517]។ បើទោះបីជា ខៀវ សំផន បានកត់សម្គាល់ថា ក្នុងសាលដីកាសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធយុត្តិសាស្ត្រដែលថា ការកំណត់និយមន័យត្រូវរួមបញ្ចូលគោលបំណងនៃការដកចេញជាអចិន្ត្រៃយ៍ពីសង្គមក៏ដោយ ក៏គាត់បានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលមានកំហុសក្នុងការបដិសេធនោះ[2518]។ គាត់បានលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ជាដំបូងបានរួមបញ្ចូលលក្ខខណ្ឌដែលបានផ្អែកលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ប៉ុន្តែក្រោយមកបានបោះបង់ចោលដោយគ្មានផ្តល់ហេតុផល[2519]។ គាត់បានអះអាងថា គោលជំហរនេះពុំបានបង្ហាញអ្វីក្រៅតែពីថា លក្ខខណ្ឌតម្រូវលែងមានអត្ថិភាពតទៅទៀតក្នុងឆ្នាំ ១៩៩១[2520]។ គាត់បានបន្ថែមថា សាលក្រមតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ (“IMT”) និងសាលក្រមក្នុងរឿងក្តី *Eichmann* នៃតុលាការជាន់ដំបូងទីក្រុង Jerusalem បានបង្ហាញថា ការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានចេតនាដកបុគ្គលដែលត្រូវបានកំណត់គោលដៅចេញពីសង្គម[2521]។

873. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តត្រឹមត្រូវតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានសំអាងទៅលើយុត្តិសាស្ត្រជាច្រើនសន្ធឹកសន្ធាប់ក្រោយសង្គ្រាមលោកលើកទីពីរក្នុងការកំណត់ថា ពុំមានលក្ខខណ្ឌផ្នែកច្បាប់តម្រូវថា ចារីត្រូវតែមានចេតនាធ្វើទុក្ខបុកម្នេញហួស

---

2516 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៣ យោងទៅលើសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៣៦-២៤០។ ការកម្រិតចំពោះការរើសអើងដោយសារមូលហេតុនយោបាយ ពូជសាសន៍ សាសនា បានឆ្លុះបញ្ចាំងនូវវិសាលភាពនៃមូលហេតុការរើសអើងដែលត្រូវបានរួមបញ្ចូលក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៣៧។

2517 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៤២។

2518 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៤៣-៦៤៤។

2519 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៤៣។

2520 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៤៥-៦៥២។

2521 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៥៣-៦៥៥។

និងលើសពីចេតនារើសអើងនោះទេ[2522]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានតែសាលក្រមអង្គជំនុំជម្រះមួយនៃតុលាការ ICTY ក្នុងរឿងក្តី *Kordić និង Čerkez* ដែលត្រូវបានបដិសេធចោលនៅបណ្តឹងសាទុក្ខដែលដាក់ស្តែងបានតម្រូវឱ្យមានគោលបំណងដកក្រុមមួយដែលត្រូវបានកំណត់គោលដៅចេញពីសង្គមថាជាធាតុផ្សំនៃបទឧក្រិដ្ឋ[2523]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរពុំបានគាំទ្រគោលជំហររបស់ ខៀវ សំផន ប៉ុន្តែផ្ទុយទៅវិញបានបង្ហាញថា ចេតនាតម្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញគឺជាចេតនារើសអើងដែលកំណត់គោលដៅលើក្រុមជាក់លាក់មួយ ឬច្រើន[2524]។

874. អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការពិនិត្យយ៉ាងម៉ត់ចត់របស់ខ្លួនលើធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញក្នុងសំណុំរឿង ០០១។ ការពិនិត្យនេះមានការវិភាគលើបញ្ហាថាតើ ធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញត្រូវបានអនុវត្តដូចម្តេចក្នុងយុត្តិសាស្ត្ររបស់តុលាការ IMT និងតុលាការព្រហ្មទណ្ឌយោធាថ្នាក់ជាតិ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុក្នុងសំណុំរឿង ០០១ ថា ធាតុផ្សំ*អត្តនោម័តិ*នៃការធ្វើទុក្ខបុកម្នេញរួមបញ្ចូលចេតនាជាក់លាក់ក្នុងការរើសអើងហួស និងលើសពីចេតនាទូទៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មមូលដ្ឋានដែលរួមបញ្ចូលនោះ[2525]។ ការសន្និដ្ឋាននេះ ត្រូវបានគាំទ្រដោយខ្លឹមសារច្បាស់លាស់ និងជាគោលបំណងនៃប្រវត្តិសេចក្តីព្រាង និងអត្ថបទនៃធម្មនុញ្ញរបស់តុលាការ IMT ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ និងត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ដែលអង្គជំនុំជម្រះបានរកឃើញថា "ពុំមានលក្ខណៈចម្រូងចម្រាស"ស្តីពីលក្ខខណ្ឌតម្រូវនៃចេតនាជាក់លាក់សម្រាប់ការធ្វើទុក្ខបុកម្នេញ[2526]។

875. អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ក្នុងសំណុំរឿង ០០១ ថា៖

---

[2522] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧៨។

[2523] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៧៩។

[2524] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៨០-៣៨២ យោងទៅលើសាលក្រមរឿងក្តី *Justice និង RuSHA* របស់តុលាការព្រហ្មទណ្ឌយោធាសហរដ្ឋអាមេរិក និងសាលក្រមរឿងក្តី *Greiser* របស់តុលាការកំពូលថ្នាក់ជាតិរបស់ប្រទេសប៉ូឡូញ ព្រមទាំង ការយល់ឃើញមួយបែបផ្សេងរបស់តុលាការ IMT និងសាលក្រមរឿងក្តី *Eichmann*។

[2525] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៣៦ និង ជើងទំព័រ ៥០៤-៥០៥។

[2526] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៣៦-២៣៩ និងជើងទំព័រ ៥០៤-៥០៧, ៥១១-៥១៤។

មានអង្គជំនុំជម្រះសាលាដំបូងពីរនៃតុលាការ ICTY និងអង្គជំនុំជម្រះសាលាដំបូងមួយនៃតុលាការ ICTR [...] បានយល់ឃើញថា ធាតុផ្សំអត្តនោម័តិសម្រាប់ការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានភស្តុតាងបង្ហាញថា ការដកសិទ្ធិត្រូវតែ"មានគោលបំណងដកបុគ្គលទាំងនោះចេញពីសង្គមដែលពួកគេបានរស់នៅជាមួយនឹងចារី ឬជាយថាហេតុចេញពីភាពជាមនុស្សជាតិ"។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះឧទ្ធរណ៍ដទៃទៀតនៃតុលាការ ICTY និង ICTR ពុំបានអនុម័តយកលក្ខខណ្ឌតម្រូវនេះទេ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយហេតុថា នេះក្លាយជាគោលដៅចុងក្រោយនៃផែនការរបស់ពួកណាហ្ស៊ីក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វជាពិសេសនោះ តុលាការព្រហ្មទណ្ឌក្រោយសង្គ្រាមលោកលើកទីពីរ ហាក់បីដូចជាពុំតម្រូវឱ្យមានភស្តុតាងនេះសម្រាប់ជនជាប់ចោទនីមួយៗចំពោះអំពើធ្វើទុក្ខបុកម្នេញជាក់លាក់ដែលពួកគេត្រូវបានដាក់ពិរុទ្ធភាពនោះ[2527]។

876. អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើយុត្តិសាស្ត្រដែលត្រូវបានសំអាងដោយ ខៀវ សំផន ក្នុងការកែប្រែការយល់ឃើញរបស់ខ្លួនឡើយ។ តុលាការ IMT ប្រហែលជាបានយល់ឃើញថា ជនជាប់ចោទមួយចំនួនមានចេតនាដកជនជាតិជ្វីហ្វចេញពីសង្គមរបស់អាល្លឺម៉ង់ ប៉ុន្តែនេះពុំត្រូវបានកំណត់ដោយតុលាការនេះថា ជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញឡើយ។ ផ្ទុយទៅវិញ នេះជាការយល់ឃើញមួយដែលត្រូវបានបង្កើតឡើងដោយផ្អែកលើភាពជាក់ស្តែងនៃរឿងក្តី។ ចំណុចនេះមានលក្ខណៈដូចគ្នាទៅនឹងរឿងក្តី *Eichmann*។

877. តុលាការ IMT ត្រូវបានបង្ហាញនូវភស្តុតាងជាច្រើនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមុនឆ្នាំ ១៩៣៩ ទៅលើជនជាតិជ្វីហ្វ និងទំនងជាបានពិចារណាឃើញថា ការធ្វើទុក្ខបុកម្នេញបានកើតឡើងមុនអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅក្នុងការដកជនជាតិជ្វីហ្វចេញពីសង្គមអាល្លឺម៉ង់(ទោះជាយ៉ាងណាក្តី នេះអាចខ្វះយុត្តាធិការលើអំពើទាំងនេះនៃការធ្វើទុក្ខបុកម្នេញ ដោយសារអំពើនេះពុំត្រូវបានប្រព្រឹត្តឡើងតាមរយៈការកម្មេច ឬទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព)។ សាលក្រមតុលាការ IMT បានបញ្ជាក់ថា៖

> ការធ្វើទុក្ខបុកម្នេញជនជាតិជ្វីហ្វដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលណាហ្ស៊ី ត្រូវបានបង្ហាញយ៉ាងលម្អិតបំផុតនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ នេះគឺជាកំណត់ត្រានៃអំពើអមនុស្សធម៌ជាប្រព័ន្ធ និងស៊ីសង្វាក់គ្នាក្នុងទ្រង់ទ្រាយធំបំផុត។ [...] *នៅពេលមានសិទ្ធិអំណាចក្នុងដៃ ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វកាន់តែខ្លាំងឡើងៗ*។ ច្បាប់ដែលមានលក្ខណៈរើសអើងជាច្រើនបន្តបន្ទាប់ត្រូវបានអនុម័តដែលបានកម្រិតការិយាល័យ និងវិជ្ជាជីវៈសម្រាប់ជនជាតិជ្វីហ្វ និងការរឹតត្បិតត្រូវបានរឹតបន្តឹងទៅលើជីវិតគ្រួសាររបស់ពួកគេ និងសិទ្ធិទទួលបានសញ្ជាតិជាពលរដ្ឋ។ *ដល់ត្រឹមរដូវស្លឹកឈើជ្រុះឆ្នាំ ១៩៣៨ គោលនយោបាយពួកណា*

---

[2527] សាលដីកាសំណុំរឿង ០០១ ជើងទំព័រ ៥១៤ (សេចក្តីដកស្រង់ខាងក្នុងលុបចោល)។

*ហ្សីចំពោះជនជាតិជ្វីហ្វ បានឈានដល់ដំណាក់កាលមួយដែលត្រូវកំណត់គោលដៅទៅរកការដកជនជាតិជាតិជ្វីហ្វទាំងស្រុងចេញពីជីវិតអាល្លឺម៉ង់*[2528]។

878. អង្គហេតុដែលរកឃើញនោះ គឺជាការរើសអើងដែលកាន់តែអាក្រក់ឡើងៗប្រឆាំងនឹងជនជាតិជ្វីហ្វដែលឈានដល់កម្រិតនៃការចាប់ខ្លួន និងដកចេញដោយបញ្ជូនទៅធ្វើការដូចទាសករ និងទៅជំរំមរណៈ។ ពុំមានការលើកឡើងក្នុងសាលក្រមថា ជនជាតិជ្វីហ្វទាំងនោះដែលបានរត់គេចចេញពីប្រទេសអាល្លឺម៉ង់ដោយសារច្បាប់ដែលរើសអើង និងរឹតត្បិតជីវិតគ្រួសារ សេដ្ឋកិច្ច និងវិជ្ជាជីវៈរបស់ពួកគេ ពុំត្រូវបានធ្វើទុក្ខបុកម្នេញដោយសារពួកគេពុំត្រូវបានដកចេញពីជីវិតជនជាតិអាល្លឺម៉ង់ និងគ្មានការលើកឡើងថា បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានការសម្លាប់រង្គាលជនជាតិជ្វីហ្វ ឬក្រុមកំណត់គោលដៅណាមួយឡើយ។

879. ដូចគ្នានេះដែរ រឿងក្តី *Eichmann* ដែល ខៀវ សំផន បានយោងទៅលើនោះ នៅពេលពិនិត្យតាមបរិបទបង្ហាញថា ចេតនាក្នុងការរើសអើងសម្រាប់ការធ្វើទុក្ខបុកម្នេញត្រូវបានបកស្រាយទូលំទូលាយជាងចេតនាក្នុងការលុបបំបាត់បុគ្គលដែលជាសមាជិកនៃក្រុមមួយចេញពីសង្គម ដូចគ្នានឹងការអះអាងរបស់ ខៀវ សំផន ដែរ[2529]។ ផ្នែកដែលពាក់ព័ន្ធនៃសាលក្រមរឿងក្តី *Eichmann* ដែលគាត់បានដកស្រង់បង្ហាញថា "អំពើរបស់គាត់ទាំងអស់ដែលបានប្រព្រឹត្តឡើងដោយចេតនាក្នុងការសម្លាប់រង្គាលប្រជាជនជ្វីហ្វ ជាក់ស្តែងស្មើនឹងការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វដោយសារមូលហេតុជាតិសាសន៍ ពូជសាសន៍ សាសនា និងនយោបាយ" [2530]។ អង្គជំនុំជម្រះនោះពុំបានសន្និដ្ឋានថា ចេតនានៃការធ្វើទុក្ខបុកម្នេញ*គឺ*ជាចេតនាក្នុងការសម្លាប់រង្គាល ឬលុបបំបាត់បុគ្គលនោះឡើយ ផ្ទុយទៅវិញបានបញ្ជាក់ដោយប្រុងប្រយ័ត្នថា អាច"ស្មើនឹង"ការធ្វើទុក្ខបុកម្នេញ។

880. បន្ថែមលើនេះ មូលហេតុដែលការធ្វើទុក្ខបុកម្នេញត្រូវបានចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដោយសារអំពើអមនុស្សធម៌នៃការដកហូតដោយរើសអើងទាំងស្រុង ឬដោយឥតលាក់លៀមនូវសិទ្ធិមនុស្ស

---

[2528] រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* សាលក្រម (IMT) ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ *ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ* Nuremberg ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ I ("សាលក្រមតុលាការ IMT") ទំព័រ ២៤៧-២៤៩ (សេចក្តីបញ្ជាក់បន្ថែម)។

[2529] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៥៣-៦៥៥។

[2530] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៥៤ ជើងទំព័រ ១១៣៩ យោងទៅលើតុលាការព្រហ្មទណ្ឌជាន់ដំបូងនៃទីក្រុង Jerusalem សំណុំរឿងលេខ 40/61, 36, ILR ឆ្នាំ ១៩៦៨ កថាខណ្ឌ ២០១។

ជាសារវន្ត[2531]។ ជាការពុំសមហេតុផលក្នុងការពិចារណាថា បទប្បញ្ញត្តិនៃបទឧក្រិដ្ឋនេះត្រឹមតែការពារអ្នកដែលត្រូវបានកំណត់គោលដៅដកចេញពីសង្គមនោះ ប៉ុន្តែពុំបានការពារមនុស្សមួយក្រុមកំពុងរស់នៅក្នុងសង្គមមួយដែលសិទ្ធិជាសារវន្តរបស់ពួកគេត្រូវបានរំលោភបំពាននោះទេ។ មានមនុស្សមួយក្រុមអាចត្រូវបានចាត់ទុកថា ជា"ប្រជាជនលំដាប់ថ្នាក់ទីពីរ" និងត្រូវបានប្រព្រឹត្តទៅលើដោយឥតសមគួរ ប៉ុន្តែគ្មានគោលបំណងដកពួកគេចេញពីសង្គមនោះទេ។

881. បើទោះបីជាមានក្តីបារម្ភពាក់ព័ន្ធទៅនឹងមានអត្ថិភាពច្បាប់ក្នុងឆ្នាំ ១៩៧៥ ក៏ដោយ ក៏ជាការកត់សម្គាល់លក្ខខណ្ឌធាតុផ្សំអត្តនោម័តិបន្ថែមដែលបានស្នើឡើងដោយ ខៀវ សំផន ពុំត្រូវបានពិចារណាសម្រាប់ការដាក់បញ្ចូលក្នុងលក្ខន្តិកៈទីក្រុងរ៉ូមដែរ។ ប្រសិនបើធាតុផ្សំបន្ថែមនេះនៅពេលណាមួយត្រូវបានចាត់ទុកថាជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ គេអាចរំពឹងរកឃើញថា យ៉ាងហោចណាស់មានការពិភាក្សាខ្លះៗអំពីបញ្ហានៃការដកចេញពីសង្គមនោះ ប៉ុន្តែនេះទំនងជាពុំត្រូវបានយកមកពិភាក្សានោះឡើយ។

882. បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចេតនាក្នុងការដកក្រុមមួយចេញពីសង្គម គឺជាធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញក៏ដោយ ក៏ ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ អំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការបង្ហាញថា ធាតុផ្សំនេះបានបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធទៅនឹងពុទ្ធសាសនិក ព្រះសង្ឃ និង ជនជាតិចាម ចាត់ទុកជាអសារបង់[2532]។ អំណះអំណាងនេះត្រូវបដិសេធចោលទាំងស្រុង។

ខ. ចាតើ ការប្រព្រឹត្តទៅលើដូចៗគ្នាដែលមានផលប៉ះពាល់ជាពិសេសលើបុគ្គលមួយប្រភេទអាចស្មើនឹងការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា

883. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការកំណត់ចរិតលក្ខណៈនៃការប្រព្រឹត្តទៅលើដូចៗគ្នាដែលមានផលប៉ះពាល់ជាពិសេសលើបុគ្គលមួយប្រភេទថា ជាការរើសអើង

[2531] សេចក្តីព្រាងក្រមនៃបទឧក្រិដ្ឋប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ ១៩៩៦ ទំព័រ ៤៩: "អំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើទុក្ខបុកម្នេញអាចមានរូបរាយជាច្រើនប្រភេទដែលមានលក្ខណៈពិសេសរួមគឺការបដិសេធសិទ្ធិមនុស្សជាសារវន្ត និងសេរីភាព ដែលបុគ្គលនីមួយៗត្រូវបានមានដោយគ្មានការបែងចែកដូចបានទទួលស្គាល់ក្នុងធម្មនុញ្ញភាពនៃអង្គការសហប្រជាជាតិ (មាត្រា ១ និង ៥៥) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (មាត្រា ២)"។

[2532] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៥៦-៦៥៧។

ជាក់ស្តែង[2533]។ គាត់បានអះអាងថា ការរើសអើងដោយប្រយោលមានអត្ថិភាពក្នុងគោលគំនិតស្តីពីសិទ្ធិមនុស្សក្នុងពេលបច្ចុប្បន្នដែលពុំត្រូវបានចាត់ទុកថា ជាការរើសអើងជាក់ស្តែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ[2534]។

884. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ពុំមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ក្នុងការបង្ហាញភាពខុសប្លែកគ្នារវាងរើសអើងដោយផ្ទាល់ ឬដោយប្រយោលនៅពេលបង្ហាញអំពីអត្ថិភាពនៃការរើសអើងជាក់ស្តែង[2535] និងថាអំពើសកម្ម ឬអកម្ម គឺជាការរើសអើងជាក់ស្តែងនៅពេលមានផលវិបាកនៃការរើសអើងទៅលើសមាជិកក្រុមជាក់លាក់ណាមួយនោះ[2536]។

885. សហមេធាវីនាំមុខបានឆ្លើយតបថា ការរើសអើងមិនត្រឹមតែជាប់ពាក់ព័ន្ធទៅនឹងអំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្តលើក្រុមប៉ុណ្ណោះទេ ថែមទាំងពាក់ព័ន្ធទៅនឹងផលវិបាកដែលក្រុមនោះបានឆ្លងកាត់[2537]។ សហមេធាវីនាំមុខបានឆ្លើយតបថា សញ្ញាណនៃការរើសអើងដែលបណ្តាលមកពីការប្រព្រឹត្តដូចៗគ្នាដែលមានផលវិបាកពុំស្មើគ្នានោះ ត្រូវបានសំដៅទៅលើនៅក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សថា ជាការរើសអើងដោយប្រយោល និងពាក្យថា “ការរើសអើង”ត្រូវបានយល់កន្លងមកថា ជាការបញ្ចូលគ្នារវាងការរើសអើងដោយប្រយោល និងដោយផ្ទាល់[2538]។ សហមេធាវីនាំមុខបានលើកឡើងថា គោលគំនិតនេះបានអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិព្រមទាំងច្បាប់ស្តីពីសិទ្ធិមនុស្ស ប៉ុន្តែខុសគ្នាត្រង់ថា ចេតនាត្រូវបានតម្រូវច្បាស់លាស់សម្រាប់ការទទួលខុសត្រូវក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[2539]។ សហមេធាវីនាំមុខបានពិចារណាថា ការសំដៅរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ ទៅលើផលវិបាកនៃការរើសអើង ឬការធ្វើទុក្ខបុកម្នេញបង្ហាញថា ការធ្វើទុក្ខបុកម្នេញអាចត្រូវបានបង្ហាញតាមរយៈការរើសអើងដោយប្រយោល[2540]។ សហមេធាវីនាំមុខបានដកស្រង់មតិយោបល់បីរបស់តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (ក្នុងឆ្នាំ ១៩២៣, ១៩៣២ និង ១៩៣៥), សេចក្តីប្រកាសឆ្នាំ ១៩២៩ ស្តីពីសិទ្ធិមនុស្សអន្តរជាតិ, អនុសញ្ញាឆ្នាំ ១៩៦០ របស់អង្គ

---

[2533] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៤, ៨១៣, ៩៥៤-៩៥៦។

[2534] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥៥-៩៥៦។

[2535] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧០, ៤៧៩, ៤៨៩, ៤៩១។

[2536] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤០៥។

[2537] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៤៥-៣៤៨។

[2538] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៤៩។

[2539] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៥០។

[2540] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៥២-៣៥៣។

ការ UNESCO ប្រឆាំងនឹងការរើសអើងផ្នែកសិក្សាអប់រំ, អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៩ ស្តីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ផ្នែកពូជសាសន៍, សាលក្រមឆ្នាំ ១៩៧៤ របស់តុលាការយុត្តិធម៌នៃសហគមន៍អឺរ៉ុប និងអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៧៩ ស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងលើស្ត្រី ធ្វើជាភស្តុតាងបង្ហាញថា ការរើសអើងត្រូវបានយល់ថា រួមបញ្ចូលការរើសអើងមិនផ្ទាល់ក្នុងច្បាប់អន្តរជាតិនៅមុនឆ្នាំ ១៩៧៥[2541]។

886. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហាបឋមចំពោះមុខគឺថាតើ ការយល់ឃើញនៃការរើសអើងជាក់ស្តែងអាចត្រូវបានបង្ហាញចេញពីផលវិបាក ឬផលប៉ះពាល់ដែលក្រុមជាក់លាក់មួយបានឆ្លងកាត់ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ តម្រូវឱ្យមានអំពើសកម្ម ឬអកម្មដែលរើសអើងជាក់ស្តែង និងបានដកហូត ឬរំលោភបំពានលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា[2542]។ ការរើសអើងជាក់ស្តែងសំដៅទៅលើបញ្ហាថាតើ ក្រុមគោលដៅជាក់ស្តែងបានទទួលរងផលវិបាករើសអើងតាមរយៈអំពើសកម្ម ឬអកម្ម ដែរ ឬយ៉ាងណា ដែលមានន័យថា ចេតនារើសអើងតែមួយមុខពុំគ្រប់គ្រាន់នោះទេ[2543]។

887. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ពុំមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់ឱ្យបង្ហាញនូវភាពខុសប្លែកគ្នារវាងការរើសអើងដោយផ្ទាល់ ឬប្រយោលនៅពេលបង្ហាញនូវអត្ថិភាពនៃការរើសអើងជាក់ស្តែងនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហាថាតើអំពើសកម្មអាចស្មើនឹងការរើសអើងដោយផ្ទាល់ ឬដោយប្រយោល ដែរ ឬយ៉ាងណានោះ ជាការពុំជាប់ពាក់ព័ន្ធសម្រាប់ការកំណត់ថាតើ ក្រុមនោះបានទទួលរងផលវិបាកនៃអំពើសកម្ម ឬអកម្មដែលពាក់ព័ន្ធ ដែរ ឬយ៉ាងណាឡើយ។ អំពើសកម្ម ឬអកម្មត្រូវបានចាត់ទុកថា ជាការរើសអើងនៅពេលជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារតែជាសមាជិកនៃក្រុមមួយដែលត្រូវបានកំណត់គោលដៅដោយចារីផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[2544]។ បញ្ហាថាតើ ជនរងគ្រោះត្រូវបានកំណត់គោលដៅដោយការរើសអើងដោយប្រយោល ដែរ ឬយ៉ាងណា គឺពាក់ព័ន្ធទៅនឹងចេតនាដែលនៅពីក្រោយអំពើសកម្ម ឬអកម្មនោះ។ ជួនកាល ក្នុងការបង្ហាញថាតើ ច្បាប់ត្រូវបានអនុម័តដើម្បីកំណត់គោលដៅជាក់លាក់លើក្រុមមួយ ប៉ុន្តែបាន

[2541] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៥៤-៣៦២។

[2542] *សូមមើលខាងលើ* ផ្នែក VII.ច.១។

[2543] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២២៨, ២៧១។

[2544] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៩០។

ដាក់ឱ្យអនុវត្តចំពោះមនុស្សទូទៅ ដែរ ឬយ៉ាងណានោះ គឺតម្រូវឱ្យមានការពិនិត្យបន្ថែមទៀត។ ឧទាហរណ៍ ប្រសិនបើរបបមួយបានចេញក្រិត្យច្បាប់ថា បុគ្គលគ្រប់រូបត្រូវតែបរិភោគសាច់ម្តងក្នុងមួយសប្តាហ៍ នោះ អាចមានផលប៉ះពាល់អវិជ្ជមានតិចតួចលើអ្នកបរិភោគសាច់ ប៉ុន្តែនឹងប៉ះពាល់ខ្លាំងដល់អ្នកដែលស្ថិតក្នុង ក្រុមកាន់សាសនាដែលមិនបរិភោគសាច់។ ដោយសារក្រិត្យនេះមានផលប៉ះពាល់ជាអវិជ្ជមានជាពិសេស សម្រាប់អ្នកដែលកាន់សាសនាហាមឃាត់ការបរិភោគសាច់ ទើបសមាជិកនៃក្រុមនោះអាចត្រូវបានចាត់ទុក ថា បានទទួលរងការរើសអើងជាក់ស្តែងដោយសារក្រិត្យនោះ។ បញ្ហាថាតើ ក្រិត្យច្បាប់នោះជាធម្មតាពុំមាន ចេតនាផ្តល់ផលវិបាកដល់ក្រុមសាសនាទាំងនោះ ឬជាល្បិចកលក្នុងការកំណត់គោលដៅលើក្រុមទាំងនោះ ដែរ ឬយ៉ាងណា គឺជាបញ្ហាសម្រាប់ការពិនិត្យទៅលើកត្តាសត្យានុម័តនៃក្រិត្យនោះ។ តាមការវាយតម្លៃតាម បរិបទ និងជារួមអាចកំណត់បានថា ចេតនានៅពីក្រោយក្រិត្យនោះគឺដើម្បីកំណត់គោលដៅជាក់លាក់លើ អ្នកកាន់សាសនាដែលហាមឃាត់ការបរិភោគសាច់។ ក្នុងស្ថានភាពនេះ អំពើនោះស្មើនឹងការធ្វើទុក្ខបុកម្នេ ញ។

888. ជាសរុប អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ដោយសារបានពិចារណាលើផលប៉ះពាល់ទៅលើ ជនរងគ្រោះនៅពេលកំណត់លើបញ្ហាថាតើ ការរើសអើងជាក់ស្តែងបានកើតឡើង ដែរ ឬយ៉ាងណា។ អំណះ អំណាងរបស់ ខៀវ សំផន ដែលបានលើកឡើងផ្ទុយនោះ ត្រូវបដិសេធចោល។

## ២. ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ

### ក. ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម

889. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការផ្លាស់ទីជនជាតិចាមចេញពីភូមិភាគបូព៌ាទៅភូមិភាគ កណ្តាល(ឧត្តរចាស់) គឺជាការរើសអើងជាក់ស្តែង និងត្រូវបានប្រព្រឹត្តដោយចេតនាក្នុងការរើសអើង ប្រឆាំងនឹងជនជាតិចាម ដោយសារពួកគេត្រូវបានសន្មតថា ជាខ្មាំងក្រោយពីការបះបោរក្នុងភូមិភាគបូ ព៌ា[2545]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា អំពើដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមនោះ បានរំលោភបំពានលើសិទ្ធិជាច្រើន[2546] និងថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញនោះ រួមមានអំពើដែលអាចស្មើនឹងបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើដែលខ្លួនឯងផ្ទាល់

---

[2545] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៣។

[2546] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៤។

ពុំចាំបាច់ស្មើទៅនឹងបទឧក្រិដ្ឋ ប៉ុន្តែនៅពេលពិចារណាជារួម អំពើនោះឈានដល់កម្រិតនៃលក្ខខណ្ឌតម្រូវសម្រាប់ភាពធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញ[2547]។

890. អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងការផ្លាស់ទី"ប្រជាជនថ្មី" ដោយហេតុថា "ពុំអាចនិយាយបានថា មានការបង្ហាញថា ការផ្លាស់ទីប្រជាជនត្រូវបានធ្វើឡើងដោយមានលក្ខណៈរើសអើងខ្លួនឯង ឬដោយចេតនារើសអើង" និងថា "ដោយសារការផ្លាស់ទីប្រជាជនជាបឋមសម្រាប់គោលបំណងសេដ្ឋកិច្ចទំនងជាការអនុវត្តន៍រីករាលដាល ដែលប៉ះពាល់ដល់ប្រជាជនទាំងអស់ ទើបការផ្លាស់ទីប្រជាជនក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ពុំមែនជាការរើសអើង ឬជាការកើតចេញពីចេតនាធ្វើទុក្ខបុកម្នេញ"[2548]។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញភាពខុសប្លែកគ្នានៃការយល់ឃើញរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធទៅនឹងការផ្លាស់ទីជនជាតិចាម និងបានពន្យល់ថា អង្គជំនុំជម្រះបានយល់ឃើញថា ជនជាតិចាមក្នុងភូមិភាគបូព៌ា ត្រូវបានកំណត់គោលដៅជាក់លាក់ដោយសារលទ្ធផលនៃការបះបោរ និងថា នេះគឺជាការបង្ហាញឱ្យឃើញថា ជនជាតិចាមកំពុងត្រូវបានដកចេញដើម្បីបំបែកសហគមន៍របស់ពួកគេ ជាជាងការផ្លាស់ទីសម្រាប់កម្លាំងពលកម្ម[2549]។

i. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងធាតុផ្សំសត្យានុម័ត

891. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការបង្ហាញថា ការផ្លាស់ទីប្រជាជនបានប៉ះពាល់ជាពិសេស ឬយ៉ាងហោចណាស់ជាចម្បងដល់ជនជាតិចាម ដូច្នេះហើយនេះជាការរើសអើង ឬបង្ហាញថា ក្នុងអំឡុងពេលនៃការផ្លាស់ទី ជនជាតិចាមត្រូវបានប្រព្រឹត្តទៅលើផ្សេងពីប្រជាជនដទៃទៀត។ នេះគឺជាបទដ្ឋានដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹង"ប្រជាជនថ្មី"[2550]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលា

---

[2547] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៥។

[2548] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២១ ដកស្រង់សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៥។

[2549] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២២។

[2550] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២៦-៩២៧ យោងទៅលើសាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០១។

ដំបូងមានកំហុសអង្គហេតុដោយសារបានយល់ឃើញថា ការផ្លាស់ទីជនជាតិចាមដែលជាផ្នែកនៃការផ្លាស់ទីប្រជាជនទ្រង់ទ្រាយធំជាងនោះ អាចត្រូវបានចាត់ទុកថា ជាការរើសអើង[2551]។

892. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ភាន់ច្រឡំលើការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីអង្គហេតុក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹង"ប្រជាជនថ្មី" ជាមួយនឹងបទដ្ឋានទូទៅសម្រាប់ការរើសអើង[2552]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសអង្គហេតុ។ ការផ្លាស់ទីជនជាតិចាមត្រូវបានរកឃើញថា ខុសប្លែកពីការផ្លាស់ទីប្រជាជនថ្មីក្នុងសំណុំរឿង ០០២/០១ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិចាមត្រូវបានកំណត់គោលដៅសម្រាប់ការផ្លាស់ទី ពីព្រោះពួកគេត្រូវបានសន្មតថា ជាខ្មាំងក្រោយពេលមានការបះបោរនោះ[2553]។

893. សហមេធាវីនាំមុខយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា[2554]។ សហមេធាវីនាំមុខបានអះអាងបន្ថែមទៀតថា ការប្រព្រឹត្តទៅលើនោះពុំមែនជាការប្រព្រឹត្តមិនរើសមុខដូចធម្មតាទេ ពីព្រោះមានក្រុមផ្សេងៗជាច្រើននៅក្នុងចំណោមប្រជាជនទាំងមូល ត្រូវបានដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្តនោះ។ ប៉ុន្តែ"ដើម្បីបង្ហាញថាតើ ការរើសអើងនោះមានអត្ថិភាព ដែរ ឬយ៉ាងណា ការប្រៀបធៀបសមស្របគប្បីធ្វើឡើងរវាងក្រុមដែលត្រូវបានកំណត់គោលដៅ ជាមួយនឹងប្រជាជនទូទៅទាំងមូល"[2555]។

894. ក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលពុំបានកំណត់បទដ្ឋានលើបញ្ហាថាតើការរើសអើងជាស្តែងបានកើតឡើង ដែរ ឬយ៉ាងណានោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានពន្យល់ថា ដោយសារវិសាលភាពនៃសំណុំរឿង ០០២/០១ អំពើតែមួយគត់ដែលអាចយកមកពិចារណាក្នុងការបង្កើតការយល់ឃើញទាក់ទងទៅនឹងធាតុផ្សំសត្យានុម័ត គឺការផ្លាស់ទីប្រជាជនជាក់ស្តែង និងពុំមែនអ្វីដែលបានកើតឡើងចំពោះពួកគេនៅពេលទៅដល់គោលដៅនោះទេ[2556]។ បន្ទាប់មក អង្គជំនុំជម្រះបានពន្យល់ថា "ដូច្នេះ ដើម្បីបង្ហាញការធ្វើទុក្ខបុកម្នេញលើ'ប្រជាជនថ្មី' *ដូចបានគ្របដណ្តប់ដោយរឿងក្តីចំពោះមុខ*ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ការផ្លាស់ទីប្រជាជនបានធ្វើឱ្យប៉ះពាល់ជាពិសេស ឬយ៉ាងហោចណាស់ជាចម្បងតែ

---

[2551] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២៦។

[2552] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧២។

[2553] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧២-៤៧៤។

[2554] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៤៩, ៣៦៩។

[2555] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៦៧។

[2556] សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០១។

លើ'ប្រជាជនថ្មី' ដូច្នេះ នេះគឺជាការរើសអើង ឬថា ក្នុងអំឡុងពេលនៃការផ្លាស់ទីនេះ 'ប្រជាជនថ្មី'ត្រូវបានប្រព្រឹត្តដាក់ខុសប្លែកពី'ប្រជាជនចាស់'"[2557]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ និងបានអនុវត្តបទដ្ឋានពុំត្រឹមត្រូវក្នុងការកំណត់បញ្ហាថាតើ ការរើសអើងជាក់ស្តែងបានកើតឡើង ដែរ ឬយ៉ាងណានោះឡើយ។

895. ទាក់ទងទៅនឹងការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារបានយល់ឃើញថា ការផ្លាស់ទីជនជាតិចាមដែលជាផ្នែកមួយនៃការជម្លៀសប្រជាជនទ្រង់ទ្រាយធំជាងនោះអាចត្រូវបានចាត់ទុកថាជាការរើសអើង អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អំពើសកម្ម ឬអកម្ម ត្រូវបានចាត់ទុកជាការរើសអើងនៅពេលជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារតែជាសមាជិកនៃក្រុមដែលត្រូវបានកំណត់ដោយចារីផ្អែកលើមូលហេតុសាសនា ពូជសាសន៍ ឬនយោបាយ[2558]។ ត្រូវតែមានអត្ថិភាពនៃផលវិបាករើសអើងជាក់ស្តែងដែលបណ្តាលមកពីអំពើសកម្ម ឬអកម្មនោះ[2559]។

896. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះបានតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិចាមដោយសារមានការបះបោរនៅកោះផល និងស្វាយឃ្លាំង ដើម្បីដកពួកគេ និងឱ្យបរិយាកាសធូរស្រាលខ្លះ[2560]។ ដូច្នេះ ជនជាតិចាមត្រូវបានកំណត់គោលដៅសម្រាប់ការបំបែកនេះដោយផ្អែកលើការចាត់ទុកជាសត្រូវនយោបាយ។ ការបំបែកនោះ មានផលវិបាករើសអើងសម្រាប់ជនជាតិចាមដោយសារការបែកបាក់សហគមន៍របស់ពួកគេ[2561]។ អាស្រ័យហេតុនេះ អំពើនៃការបំបែកជនជាតិចាមត្រូវបានពិចារណាត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូងថា ជាការរើសអើង ហើយអំពើសត្បានុម័តនៃការធ្វើទុក្ខបុកម្នេញក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដោយសារមូលហេតុនយោបាយត្រូវបានបង្ហាញ។ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងបញ្ហានេះត្រូវបដិសេធចោល។

### ii. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិ

[2557] សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០១ (សេចក្តីបញ្ជាក់បន្ថែម)។

[2558] សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩០។

[2559] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៦៧។

[2560] *សូមមើលខាងលើ* ផ្នែក VIII.ខ.៥.ខ។

[2561] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២២។

897. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុដោយសារបានយល់ឃើញថា គោលបំណងនៃការដកជនជាតិចាមគឺដើម្បីបំបែកសហគមន៍របស់ពួកគេ និងធ្វើឱ្យបរិយាកាសធូរស្រាល និងដោយសារបានសំអាងទៅលើទូរលេខតែមួយ គឺទូរលេខ ១៥ និងពុំអើពើលើកត្តានានាដែលផ្ទុយគ្នា[2562]ដែលបង្ហាញថា ការផ្លាស់ទីជនជាតិចាមប្រមាណ ៥០.០០០ នាក់ គឺជាផ្នែកមួយនៃផែនការបែងចែកប្រជាជនទូទាំងប្រទេសកម្ពុជា និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់នូវមូលហេតុដែលអង្គជំនុំជម្រះជ្រើសរើសយកគោលបំណងរើសអើងនៃការធ្វើឱ្យបរិយាកាសធូរស្រាល ជាជាងគោលបំណងមិនរើសអើងទៅវិញ[2563]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីយល់ឃើញថា "ការផ្លាស់ទី"ជនជាតិចាមដែលរស់នៅតាមបណ្ដោយព្រំដែនជាមួយវៀតណាម ត្រូវបានធ្វើយុត្តិកម្មសមហេតុផលដោយសារការប្រឈមមុខដាក់គ្នាដោយប្រដាប់អាវុធ[2564] និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់នូវមូលហេតុដែលខ្លួនបានសន្និដ្ឋានថា "ការផ្លាស់ទី"ជនជាតិចាម គឺជាការដាក់ទោសសម្រាប់ការបះបោរនៅពេលផែនការ"ជម្លៀស"ត្រូវបានបង្កើតឡើងនៅមុនពេលការងើបតវ៉ានេះ[2565]។

898. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញដែលថា គោលបំណងចម្បងនៃការដកជនជាតិចាម គឺដើម្បីបំបែកសហគមន៍របស់ពួកគេ និងធ្វើឱ្យបរិយាកាសធូរស្រាល ជាការពុំសមហេតុផលនោះឡើយ[2566]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអំណះអំណាងដែលថា ជនជាតិចាមដែលរស់នៅតាមបណ្ដោយព្រំដែនជាមួយវៀតណាម ត្រូវបានផ្លាស់ទីដោយសារជម្លោះ ប៉ុន្តែបានយល់ឃើញថា ជនជាតិចាមដែលរស់នៅតាមបណ្ដោយទន្លេមេគង្គ ត្រូវបានកំណត់គោលដៅច្បាស់លាស់ជាងអ្នកដែលរស់នៅក្បែរព្រំដែន[2567]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញថា ការផ្លាស់ទីត្រូវបានធ្វើឡើងក្នុងគោលបំណងដាក់ទោសជនជាតិចាម និងបានឆ្លើយតបបន្ថែមទៀតថា បញ្ហាថា

[2562] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២២។

[2563] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២៨។

[2564] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២៩។

[2565] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៣០។

[2566] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២៦។

[2567] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២៧។

តើ មានផែនការផ្លាស់ទីជនជាតិចាមនៅមុនការបះបោរនោះ ដែរ ឬយ៉ាងណា ពុំបង្ហាញថា គ្មានចេតនារើសអើងនៅពីក្រោយការផ្លាស់ទីពួកគេក្រោយពីមានការបះបោរនោះឡើយ[2568]។

899. អង្គជំនុំជម្រះតុលាការកំពូលតម្កល់[2569]ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានផ្អែកយ៉ាងទូលំទូលាយ ប៉ុន្តែពុំមែនតែមួយមុខទៅលើទូរលេខ ១៥ នោះទេ និងថា "នៅពេលជនជាតិចាមបានតវ៉ាការឱ្យបោះបង់អត្តសញ្ញាណសាសនា និងជាតិពន្ធុរបស់ពួកគេ 'ការបះបោរ' ត្រូវបានបង្ក្រាបយ៉ាងសាហាវឃោរឃៅ មេដឹកនាំការបះបោរត្រូវបានកម្ទេច ហើយសហគមន៍ជនជាតិចាមត្រូវបានបំបែក"[2570]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់ទៅលើអំណះអំណាងដែលថា ការផ្លាស់ទីជនជាតិចាម ៥០.០០០ នាក់ គឺជាផ្នែកមួយនៃផែនការបែងចែកទូទាំងប្រទេសកម្ពុជា និងថា ការផ្លាស់ទីជនជាតិចាមដែលរស់នៅតាមបណ្តោយព្រំដែនជាមួយវៀតណាមត្រូវបានធ្វើយុត្តិកម្មសមស្របដោយសារជម្លោះប្រដាប់អាវុធ[2571] ប៉ុន្តែបានពិចារណាថា ទូរលេខ ១៥ បានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅជាក់លាក់លើប្រជាជនចាមនៅភូមិភាគបូព៌ាក្រោយមានការបះបោរនៅកោះផលខែ កញ្ញា ឆ្នាំ ១៩៧៥ និងស្វាយឃ្លាំងខែ តុលា ឆ្នាំ ១៩៧៥ និងបានបង្ហាញថា ការផ្លាស់ទីជនជាតិចាមជាគោលការណ៍ត្រូវបានធ្វើឡើងក្នុងការបំបែកជនជាតិចាម ដើម្បីធ្វើឱ្យបរិយាកាសធូរស្រាល[2572]។ អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកការយល់ឃើញនេះជាការពុំសមហេតុផលនោះទេ និងពុំចាត់ទុកថា ជាប់ពាក់ព័ន្ធទៅនឹងការដែលថា អាចមានផែនការបង្កើតឡើងដើម្បីផ្លាស់ទីជនជាតិចាមនៅមុនការបះបោរបានកើតឡើង។ នេះពុំបានបង្ហាញថា ក្រោយពេលការបះបោរបានកើតឡើង ពុំអាចមានចេតនារើសអើងផ្លាស់ទីជនជាតិចាមនោះទេ។ បន្ថែមលើនេះ ដើម្បីបំពេញតាមលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញ ចេតនាក្នុងការរើសអើងពុំចាំបាច់តែជាចេតនាចម្បងនៅពីក្រោយអំពើសកម្ម ដរាបណាចេតនានោះមានលក្ខណៈសំខាន់[2573]។ ខៀវ សំ

[2568] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥២៨។

[2569] *សូមមើលខាងលើ* ផ្នែក VIII.ខ.៥.ខ។

[2570] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

[2571] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១១-៣២១២។

[2572] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១២, ៣២៦២ និងជើងទំព័រ ១០៨១១, ៣២៦៨, ៣៣២២-៣៣២៣។

[2573] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-97-25-T សាលក្រមថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ ("សាលក្រមរឿងក្តី *Krnojelac* (ICTY)") កថាខណ្ឌ ៤៣៥។

ផន ពុំបានបង្ហាញអំពីកង្វះនៃចេតនាក្នុងការរើសអើងដោយមូលហេតុនយោបាយ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

iii. ថាតើ ការចាប់ខ្លួនអាចត្រូវបានយោងទៅលើក្នុងការបង្ហាញនូវកម្រិតនៃភាពធ្ងន់ធ្ងរដែលជាលក្ខខណ្ឌតម្រូវ ដែរ ឬយ៉ាងណា

900. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារបានដាក់បញ្ចូល"ការចាប់ខ្លួន"ដែលពុំជាប់ពាក់ព័ន្ធ ពុំមានការយោង និងពុំមានមូលដ្ឋានគាំទ្រក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃអំពើរើសអើងក្នុងការកំណត់លើបញ្ហាថាតើ អំពើនេះអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា[2574]។

901. សហព្រះរាជអាជ្ញាបានបដិសេធ និងបានលើកឡើងថា ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើអំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញនៅក្នុងដីកាដំណោះស្រាយ ដែលបានរួមបញ្ចូលការចាប់ខ្លួន ដូច្នេះ ជាការសមស្របក្នុងការពិចារណាលើអំពើទាំងនេះនៅក្នុងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនោះ[2575]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា នៅគ្រប់ពេល ខៀវ សំផន ពុំបានបង្ហាញថាលក្ខខណ្ឌតម្រូវនៃកម្រិតធ្ងន់ធ្ងរពុំត្រូវបានបង្ហាញដោយគ្មានការពិចារណាលើការចាប់ខ្លួនឡើយ[2576]។

902. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញ"[2577]រួមបញ្ចូល"អំពើដែលដោយខ្លួនឯងផ្ទាល់ពុំចាំបាច់ស្មើនឹងបទឧក្រិដ្ឋ ជាពិសេស ការចាប់ខ្លួន"[2578]។ ទោះជាយ៉ាងណាក្តី កថាខណ្ឌនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាមពុំបានយោងទៅលើការចាប់ខ្លួននេះឡើយ។ សហព្រះរាជអាជ្ញាបានអះអាងថា កថាខណ្ឌ ២៦៨ នៃដីកាដំណោះស្រាយបានសំដៅទៅលើការចាប់ខ្លួន[2579]។ កថាខណ្ឌនេះបញ្ជាក់ថា៖

> ប្រជាជនដែលត្រូវបានផ្លាស់ទី រួមទាំងជនជាតិចាម ត្រូវបានរៀបចំដាក់ជាក្រុមៗ។ ប្រជាជនខ្លះត្រូវបានបំបែកនៅពេលចេញដំណើរ ក្នុងអំឡុងពេលនៃការធ្វើដំណើរ និងក្រោយពេលទៅដល់គោលដៅ។ អតីតកម្មាភិបាលមូលដ្ឋានបាននិយាយថា "យើងពុំមានគោលនយោបាយហាមឃាត់ប្រជាជនថ្មីមិនឱ្យរស់នៅជាមួយ

---

[2574] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៣២។

[2575] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣០។

[2576] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣១។

[2577] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៥។

[2578] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៥។

[2579] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ១៨៥៩។

សាច់ញាតិដែលជាអ្នកមូលដ្ឋានឡើយ”។ សាក្សីមួយចំនួនបានឆ្លើយថា ប្រជាជនចាមត្រូវបានបែងចែកតាមភូមិខ្មែរដែលអនុញ្ញាតឱ្យមានប្រជាជនចាមតិចតួចប៉ុណ្ណោះក្នុងភូមិនីមួយៗ។ មានភស្តុតាងបង្ហាញថា ជនជាតិចាមបុរស ស្ត្រី និងកុមារ ត្រូវបានបំបែក និងផ្លាស់ទីទៅកន្លែងផ្សេងៗ។ ទោះជាយ៉ាងណាក្តី សាក្សីជនជាតិចាមខ្លះបានឆ្លើយថា ពួកគេរស់នៅជាមួយគ្រួសាររបស់ពួកគេពេញមួយរយៈពេលនៃការផ្លាស់ទីប្រជាជន ឬថា ពួកគេក្រោយមកត្រូវបានអនុញ្ញាតឱ្យជួបជុំគ្រួសារវិញ។ សាក្សីដទៃទៀតបានបញ្ជាក់ថា ខណៈដែលប្រជាជនចាមភាគច្រើនត្រូវបានផ្លាស់ទី មានមួយចំណុចតូចៗទាក់ទងត្រូវបានតម្រូវឱ្យរស់នៅក្នុងភូមិរបស់ខ្លួនដដែល។ សាក្សីបីនាក់ទៀតបានឆ្លើយថាពួកគេត្រូវបាននាំឱ្យទៅរស់នៅក្នុងផ្ទះជាមួយប្រជាជនខ្មែរដែលគ្មានជញ្ជាំងបិទបាំង។ សាក្សីពីរនាក់ទៀតអះអាងថា មនុស្សចាស់ៗ និងមេដឹកនាំសាសនាក្នុងភូមិរបស់ពួកគាត់ត្រូវបានចាប់ខ្លួន និងសម្លាប់ នៅមុនការផ្លាស់ទីប្រជាជនបានកើតឡើង។

903. ការលើកឡើងអំពីការចាប់ខ្លួននៅក្នុងកថាខណ្ឌនេះ មាននៅក្នុងប្រយោគចុងក្រោយដែលសំដៅទៅលើការចាប់ខ្លួនដែលបានកើតឡើងនៅមុនការផ្លាស់ទីប្រជាជន ដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[2580]។ សហព្រះរាជអាជ្ញាបានយោងផងដែរទៅលើជើងទំព័រនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ដែលដកស្រង់ឯកសារមួយដែលក្នុងនោះ សាក្សីបាននិយាយសំដៅដោយសង្ខេបទៅលើការចាប់ខ្លួន[2581]។ ជើងទំព័រនេះពុំមានការយល់ឃើញណាមួយដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងពុំអាចប្រើប្រាស់ដើម្បីបញ្ចូលការចាប់ខ្លួននេះទៅក្នុងវិសាលភាពនៃអំពើដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយបានឡើយ។

904. ដោយសារការចាប់ខ្លួនពុំស្ថិតក្នុងវិសាលភាពនៃបទចោទពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយោងទៅលើការចាប់ខ្លួនថា ជាអំពើដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុ

---

[2580] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤ ដែលបានអះអាងថា វិសាលភាពនៃបទចោទពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាម បានរួមបញ្ចូលអង្គហេតុពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាមក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ។

[2581] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ១៨៥៩ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១០១៧ យោងក្នុងចំណោមនោះទៅលើ“កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាត់ អ៊ីសា ឯកសារលេខ E3/5207 ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨ ទំព័រ ៣-៤ ERN 00221863-00221864” និងបានដាក់បញ្ចូលសេចក្តីដកស្រង់ដូចតទៅៈ (“បន្ទាប់ពីមានការបះបោរមក ក្រៅពីការចាប់ខ្លួនគេបានបញ្ជូនអ្នកភូមិមួយចំនួនចេញតាមទូក ទៅកោះតាស៊ូយនិងទៅខេត្តកំពង់ធំ។ អ្នកភូមិដើមស្ទើរតែទាំងអស់ត្រូវបានជម្លៀសចេញហើយគេប្រាប់ថា យើងត្រូវផ្លាស់ទីលំនៅ ទៅនៅភូមិ ឃុំផ្សេង។ មានអ្នកភូមិដើមមួយចំនួនតូច រួមទាំងគ្រួសារខ្ញុំ ដែលបានបន្តរស់នៅក្នុងភូមិនេះ ប៉ុន្តែខ្ញុំមិនដឹងពីមូលហេតុដែលគេទុកឲ្យខ្ញុំនៅទេ”)។

ឃោបាយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកការយល់ឃើញចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញនោះ មានកំហុសឡើយ។ បទឧក្រិដ្ឋឯករាជ្យនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តតាមរយៈការផ្លាស់ទីដោយបង្ខំ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា អាចស្មើនឹងអំពើធ្វើទុក្ខបុកម្នេញ[2582] ដូច្នេះ អំពើនេះជាសំខាន់បានឈានដល់កម្រិតលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ។ ដោយសារកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើឱ្យសាលក្រមទៅជាមោឃៈ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះត្រូវបដិសេធចោល។

### ខ. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើ“សត្រូវពិត ឬតាមការសន្មត”

905. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតឡើងចំពោះក្រុមដែលត្រូវបានកំណត់គោលដៅថា ជា“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា”នៅសហករណ៍ត្រាំកក់[2583] ការដ្ឋានទំនប់ត្រពាំងថ្ម[2584] ការដ្ឋានទំនប់១មករា[2585] ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[2586] មន្ទីរសន្តិសុខ ស-២១[2587] មន្ទីរសន្តិសុខក្រាំងតាចាន់[2588] មន្ទីរសន្តិសុខអូរកន្សែង[2589] និងមន្ទីរសន្តិសុខភ្នំក្រោល[2590]។ បើទោះបីជាក្រុមដែលត្រូវបានកំណត់គោលដៅថា ជា“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា” អាចរួមបញ្ចូលជនជាតិចាមក៏ដោយ[2591] ក៏ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយពាក់ព័ន្ធទៅនឹងជនជាតិចាម ត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នាដោយអង្គជំនុំ

[2582] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៥។

[2583] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៩។

[2584] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤១៣។

[2585] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩២។

[2586] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨២៨។

[2587] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៤។

[2588] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៤៣។

[2589] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៣។

[2590] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៥១។

[2591] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៧២។

ជម្រះសាលាដំបូង និងត្រូវបានដោះស្រាយក្នុងផ្នែកដាច់ដោយឡែកនៃសាលដីកានេះពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិចាម។

906. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោលដែលពាក់ព័ន្ធទៅនឹងតែវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ[2592]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយអំណះអំណាងនេះនៅក្នុងផ្នែកនៃសាលដីកានេះពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះ។

907. មុនពេលពិនិត្យលើការជំទាស់ទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើអំណះអំណាងពីរជាចម្បង (ក) អំណះអំណាងរបស់ ខៀវ សំផន ដែលថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ពុំមែនជាក្រុមដែលអាចកំណត់បានច្បាស់លាស់ថា ជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និង (ខ) អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

### i. ថាតើ "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់ ដែរ ឬយ៉ាងណា

908. ផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលដោះស្រាយលើគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមត្រូវបានប្រើប្រាស់សម្រាប់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពី"សត្រូវពិត ឬតាមការសន្មត"[2593]។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទស្សនទានទូទៅនៃកាលប្រវត្តិអំពីភស្តុតាងជាឯកសារនាសម័យនោះដែលពាក់ព័ន្ធទៅនឹងសញ្ញាណរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីសត្រូវ និងបន្ទាប់មកការវិភាគផ្នែកអង្គហេតុលើភស្តុតាងនោះ[2594]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងបង្ហាញថា ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ សត្រូវដូចដែលបានហៅនេះ ត្រូវបាន

---

[2592] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤៩៣, ៤៩៥-៥១០, ៨៨៤-៨៨៦។

[2593] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣។

[2594] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៤។

ពិភាក្សាជាបន្តបន្ទាប់ និងយ៉ាងទូលំទូលាយនៅតាមកម្រិតផ្សេងៗ និងគោលគំនិតនៃពាក្យ"សត្រូវ"រួមបញ្ចូលអ្នកដែលត្រូវបានសន្មតជាអ្នកប្រឆាំងបដិវត្តន៍កុម្មុយនីស្តជាក់ស្តែង ឬមនោគមវិជ្ជា[2595]។

909. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកវណ្ណៈជាបន្តបន្ទាប់លើប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ និងតាមប្រភេទផ្សេងៗនៃការគំរាមកំហែងដែលមានសក្តានុពល ប៉ុន្តែ បើទោះបីជាមានការដាក់ចំណាត់ថ្នាក់ឡើងវិញជាបន្តបន្ទាប់របស់បក្សកុម្មុយនីស្តកម្ពុជានូវប្រភេទផ្សេងៗនៃសត្រូវ និងផ្លាស់ប្តូរការកំណត់គោលដៅក៏ដោយ ក៏បុគ្គល ឬស្ថាប័នណាដែលមិនអនុវត្តតាម ឬគំរាមកំហែងដល់មាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ពោលគឺលទ្ធិម៉ាក្សលេនីននៃបដិវត្តន៍កម្មុយនីស្តតាមរយៈការតស៊ូប្រដាប់អាវុធ អាចត្រូវបានចាត់ទុកថា ជាសត្រូវ"ដែរ[2596]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថាកម្រិតនៃការបញ្ជាក់ប្រភេទផ្សេងៗនៃសត្រូវប្រែប្រួលអាស្រ័យលើថាតើ នរណាបានបង្កការគំរាមកំហែងធំបំផុតនៅពេលនោះ ប៉ុន្តែ"បើទោះបីជាប្រភេទសត្រូវមានលក្ខណៈទូលំទូលាយ និងច្រើនបែបក៏ដោយ ក៏ពុំមានការប្រែប្រួលខ្លាំងដូចនៅក្រោយការបោសសម្អាតផ្ទៃក្នុងឆ្នាំ ១៩៧៦ និងការកើនឡើងនៃជម្លោះជាមួយវៀតណាមនៅក្នុងឆ្នាំនោះដែរ"[2597]។ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ប្រភេទជាក់លាក់នៃសត្រូវដូចតទៅ៖ (១) អតីតអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[2598] (២) "ប្រជាជនថ្មី"[2599] (៣) អ្នកត្រឡប់មកពីបរទេស[2600] (៤) ព្រះសង្ឃ[2601] និង (៥) ភ្នាក់ងារ CIA, KGB និង"*យួន*" ឬវៀតណាម[2602]។ ទោះជាយ៉ាងណាក្តី នៅក្នុងផ្នែកដទៃទៀតក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយោងផងដែរទៅលើប្រភេទដទៃទៀតនៃខ្មាំងរួមទាំងអ្នកប្រឆាំងបដិវត្តន៍ អ្នកបន្ទុះបង្អាប់ និងជនក្បត់បដិវត្តន៍ ពួកសក្តិភូមិ និងជនជាតិពន្ធុវៀតណាម[2603]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទង្វើផ្សេងៗជាច្រើនអាចស្ថិតក្រោមប្រភេទនៃ"'សកម្មភាពខ្មាំង'ប្រឆាំងបដិវត្តន៍" មានដូចជា ការលួច ការរំលោភសេពសន្ថវៈ ឬការខុសសីលធម៌ដទៃទៀត ការរត់គេចទៅផ្ទះ និងការចាកចោលការងារ ការប្រព្រឹត្តពុំសមស្របលើយុទ្ធជន និង

2595 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៤។

2596 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៣៩។

2597 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៤០។

2598 សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣.២.១.៣.១។

2599 សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣.២.១.៣.២។

2600 សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣.២.១.៣.៣។

2601 សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣.២.១.៣.៤។

2602 សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៣.២.១.៣.៥។

2603 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩២៤, ៣៩៨២។

លើកម្មាភិបាល ការរំលោភបំពានមាគ៌ាបក្ស ការបញ្ចេញមតិ ការមាន"និន្នាការនយោបាយ" ឬការប្រតិបត្តិ "សាសនាប្រតិកិរិយា"[2604]។

910. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អត្ថន័យនៃ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"អាស្រ័យលើបរិបទដែលក្នុងនោះ សត្រូវទាំងនេះត្រូវបានពិភាក្សា និងពន្យល់ថា ភស្តុតាងដែលកើតចេញពីទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធ អាចនឹងបំពេញបន្ថែមការយល់ឃើញទាំងនេះ[2605]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើភស្តុតាងចេញពីសហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខនីមួយៗក្នុងវិសាលភាពនៃសាលក្រមសំណុំរឿង ០០២/០២ នៅពេលពិចារណាលើការបង្កើត និងភាពអាចកំណត់អត្តសញ្ញាណបាននៃក្រុមដែលត្រូវបានកំណត់គោលដៅនៅតាមទីតាំងនីមួយៗ៖[2606]

ក. ពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ដីកាដំណោះស្រាយបានចោទប្រកាន់ការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"[2607] និងបានយល់ឃើញថា ក្រុមនេះអាចកំណត់អត្តសញ្ញាណបាន[2608] ប៉ុន្តែបានកម្រិតការយល់ឃើញរបស់ខ្លួនត្រឹមការកំណត់គោលដៅលើក្រុមតូចនៃប្រជាជនថ្មី និងអតីតអ្នករដ្ឋការ និងទាហាននៃរបបសា ធារណរដ្ឋខ្មែរ[2609]។

ខ. ពាក់ព័ន្ធទៅនឹងការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ក្រុមកំណត់គោលដៅជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" គឺជាក្រុមដែលអាចកំណត់អត្តសញ្ញាណបានច្បាស់លាស់ នៅពេលប្រធានកងអនុសេនាធំ និងវរសេនាតូចត្រូវបានណែនាំឱ្យកំណត់អត្តសញ្ញាណប្រជាជនដែលមាន"'ប្រវត្តិមិនល្អ' ជាទាហាន លន់ នល់ '*យួន*' ភ្នាក់ងារ CIA និស្សិត បញ្ញវន្ត និងអ្នកដែលត្រូវបានចាត់ទុកថា មានការជាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពប្រឆាំង

---

[2604] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៤៦។

[2605] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៣៥។

[2606] ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹង"សត្រូវពិត ឬតាមការសន្មតរបស់ ប.ក.ក." នៅការដ្ឋានធ្វើការព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោលពុំត្រូវបានពិភាក្សានៅទីនេះដោយសារដូចបានលើកឡើងខាងលើ ខៀវ សំផន ពុំបានជំទាស់ទៅនឹងការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយនៅការដ្ឋាននេះលើកលែងពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង។

[2607] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧០។

[2608] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៤។

[2609] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៥-១១៧៩។

នឹងអង្គការក្នុងកងរបស់ពួកគេ”[2610] និងថា “ឯកសារកម្ពុជាប្រជាធិបតេយ្យផ្លូវការមួយចំនួនបាន សំដៅប្រជាជនថ្មីថា ជាប្រភេទនៃបុគ្គលដែលពុំអាចទុកចិត្តបាន”[2611]។

គ. ពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ក្រុមកំណត់គោលដៅថា ជា“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា” គឺជាប្រជាជនថ្មី និង អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងជាក្រុមដែលអាចកំណត់អត្តសញ្ញាណ បានច្បាស់លាស់ ដោយសារប្រជាជនថ្មីត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់ថា ជាសត្រូវ ហើយអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណតាមរយៈ ជីវប្រវត្តិ ត្រូវបានចាប់ខ្លួន និងនាំទៅមន្ទីរសន្តិសុខ[2612]។

ឃ. ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខស-២១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ដីកាដំណោះ ស្រាយបានកំណត់អត្តសញ្ញាណជាក់លាក់នៃសត្រូវពិត ឬតាមការសន្មតជាច្រើនរបស់បក្សកុម្មុយនី ស្តកម្ពុជា រួមទាំងអ្នកដែលត្រូវបានចាត់ទុកថា ជនក្បត់ ភ្នាក់ងារ CIA ឬ KGB វៀតណាម និងថា ដីកានេះបានបញ្ជាក់ថា ប្រជាជនដែលត្រូវបានចាប់ខ្លួនដោយសារជា“សត្រូវពិត ឬតាមការសន្មត របស់បក្សកុម្មុយនីស្តកម្ពុជា” មានដូចជា៖ ទាហាននៃកងទ័ពបដិវត្តកម្ពុជា កម្មាភិបាលបក្សកុម្មុយនី ស្តកម្ពុជា បុគ្គលិកក្រសួង អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បញ្ញវន្ត អ្នកការទូត ដែលត្រឡប់មកពីបរទេស និងជនបរទេស[2613]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ ឃើញរបស់ខ្លួនថា ប្រភេទជាក់លាក់នៃសត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានលើកឡើងក្នុងដីកាដំណោះស្រាយ ពុំមានលក្ខណៈលម្អិត និងបានរួមបញ្ចូលអ្នកបន្ទុះ បង្អាប់បដិវត្តន៍សង្គមនិយម និងអ្នករិះគន់បក្ស ហើយប្រភេទទាំងនេះបានពង្រីកជាដរាប[2614]។ អង្គ ជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹង“សត្រូវពិត ឬតាម ការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា”នៅមន្ទីរសន្តិសុខអូរកន្សែង និងបានបញ្ជាក់ថា អង្គជំនុំជម្រះ

---

[2610] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៧។

[2611] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៧។

[2612] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៧។

[2613] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៩៨-២៥៩៩។

[2614] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០០។

សាលាដំបូងជឿជាក់ថា ក្រុមនេះបានបង្ហាញអត្តសញ្ញាណច្បាស់លាស់ដែលអាចកំណត់បានថា បានទទួលរងផលវិបាកដែលបានកើតឡើងនោះ[2615]។

ង. ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"ថា អាចកំណត់អត្តសញ្ញាណបានច្បាស់លាស់ ដោយសារដីកាដំណោះស្រាយបានកំណត់អត្តសញ្ញាណច្បាស់លាស់នូវក្រុមដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" និងបានបញ្ជាក់ថា ដីកានេះបានរួមបញ្ចូល៖

អ្នកបន្ទុះបង្អាប់បដិវត្តន៍សង្គមនិយម និងអ្នករិះគន់ ឬអ្នកប្រឆាំងបក្ស រួមទាំងអ្នកដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបែបសក្តិភូមិ ឬត្រូវបានចោទប្រកាន់នូវអំពើខុសសីលធម៌ និងបុគ្គលដែលត្រូវបានសង្ស័យ ឬពាក់ព័ន្ធនឹងការចូលដៃជាមួយសត្រូវរបស់បក្ស ព្រមទាំងជនជាតិវៀតណាម និងអ្នកដែលសង្ស័យសហការជាមួយជនជាតិវៀតណាម រួមទាំងអតីតទាហានធីវគី សមាជិកហ្វ៊ូលរ៉ូ និងជនជាតិចារ៉ាយមកពីវៀតណាម[2616]។

911. អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងភាពអាចកំណត់អត្តសញ្ញាណបាននៃក្រុមគោលដៅថា ជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ត្រូវបានលើកឡើងពាក់ព័ន្ធតែមន្ទីរសន្តិសុខស-២១ និងអូរកន្សែងប៉ុណ្ណោះ។ ពាក់ព័ន្ធទៅនឹងមន្ទីរស-២១ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានពិចារណាឃើញថា ក្រុមដែលជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" អាចកំណត់អត្តសញ្ញាណបានច្បាស់លាស់ ពីព្រោះអង្គជំនុំជម្រះបានយល់ឃើញថា ប្រភេទជាក់លាក់នៃសត្រូវពុំត្រូវបានរៀបរាប់លម្អិត និងពង្រីកជាដរាបដែលនេះពុំស្របជាមួយនឹងការកំណត់ថាតើ ក្រុមដែលអាចកំណត់បានច្បាស់លាស់នោះជាអ្វីឡើយ[2617]។ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខអូរកន្សែង ខៀវ សំផន បានអះអាងថា ក្រុមតូចៗជាច្រើននៃ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"ដែលត្រូវបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូង បានរួមបញ្ចូលក្រុមមនុស្សផ្សេងៗជាច្រើន ដែលត្រូវបានចាត់ទុកខុសៗគ្នាដោយបក្សកុម្មុយនីស្តកម្ពុជា និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគប្បីយល់

---

[2615] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០០។

[2616] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២-២៩៨៣។

[2617] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៨២៥។

ឃើញថា ពុំមានលក្ខណៈវិនិច្ឆ័យនៃការកំណត់អត្តសញ្ញាណដែលអាចអនុវត្តនៅក្នុងការកំណត់គោលដៅជនរងគ្រោះ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញក្នុងសំណុំរឿង ០០១[2618]។

912. សហព្រះរាជអាជ្ញាបានឆ្លើយតបថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"អាចជាក្រុមដែលអាចកំណត់អត្តសញ្ញាណបានច្បាស់លាស់យោងតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ហើយអង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ប្រភេទនៃសត្រូវនេះបានពង្រីកជាដរាប ដោយសារការយល់ឃើញនេះបានផ្អែកលើភស្តុតាង[2619]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខអូរកន្សែង ហេតុការណ៍ជាច្រើនដែលក្នុងនោះប្រជាជនខ្លះត្រូវបានដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្តទៅលើ និងលក្ខខណ្ឌនៃការរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀត ដែលនេះជាការយល់ឃើញមួយត្រូវបានបង្កើតឡើងសមហេតុផលដោយផ្អែកលើការប្រៀបធៀបក្រុមដែលអាចកំណត់អត្តសញ្ញាណបាន[2620]។

913. សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ពុំបានផ្តល់សំអាងផ្លូវច្បាប់សម្រាប់ការលើកឡើងដែលថា ក្រុមដែលអាចកំណត់អត្តសញ្ញាណបានច្បាស់លាស់ ត្រូវតែមិនអាចផ្លាស់ប្តូរបាន និងស្រុបគ្នា[2621]។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមទៀតថា នេះជាការផ្ទុយទៅនឹងយុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើង៖ នៅតុលាការ ICTY ក្នុងរឿងក្តីជាច្រើនបង្ហាញថា ក្រុមដែលទទួលរងការធ្វើទុក្ខបុកម្នេញមួយត្រូវបានកំណត់ជាអវិជ្ជមានថា "ជាអ្នកដែលពុំមែនជាជនជាតិស៊ែប" និងក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល"បានបញ្ជាក់លទ្ធភាពដែលថា ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកំណត់គោលដៅលើក្រុមដែលត្រូវបានបញ្ចូលគ្នាដោយពុំចាំបាច់មានអត្តសញ្ញាណ ឬកម្មវិធីជារួម" និងបានទទួលស្គាល់ថា ប្រជាជនថ្មីបានរួមបញ្ចូលទាំងប្រភេទក្រុមតូចផ្សេងៗ[2622]។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមទៀតថា ដីកាបញ្ជូនទៅជំនុំជម្រះរបស់តុលាការ Nuremberg បានដោះស្រាយការធ្វើទុក្ខបុកម្នេញដែលកំណត់គោលដៅលើ"ពួកប្រឆាំងតាមការសន្មត ឬតាមការសង្ស័យនៃរបប"ដែលរួមបញ្ចូលសមាជិកនៃក្រុមផ្សេងៗដែលត្រូវបានចាត់ទុកជាដរាបថា មានការប្រឆាំងសក្តានុពល និងថា សាលក្រមរបស់តុលា

[2618] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥០-៨៥៣។

[2619] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤៦, ៨៨៣។

[2620] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៨៣។

[2621] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៣៩។

[2622] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៣៩-៣៤០។

ការ IMT បានរៀបរាប់លម្អិតនូវគោលនយោបាយនៃការកំណត់គោលដៅលើបុគ្គលជាច្រើនប្រភេទដែលត្រូវបានសង្ស័យថា ជាពួកប្រឆាំងនឹងរបបនោះ[2623]។

914. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា យុត្តិសាស្ត្រពីមុនៗរបស់ខ្លួនបានដោះស្រាយច្បាស់លាស់នូវអំណះអំណាងដែលបានលើកឡើងក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា៖

> ជាពិសេសទាក់ទងទៅនឹងមូលហេតុនយោបាយ ចារីអាចកំណត់ក្រុមគោលដៅជនរងគ្រោះ ដោយផ្អែកលើការវាយតម្លៃជាអត្តនោម័តិចំពោះក្រុមណាខ្លះដែលបង្កការគំរាមកំហែង ឬគ្រោះថ្នាក់ដល់នយោបាយ។ ក្រុមដែលទទួលរងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អាចរួមបញ្ចូលក្រុមមនុស្សផ្សេងៗ ដូចជាអ្នករាជការ ឬសកម្មជននយោបាយ ក្រុមជនដែលមានទស្សនៈ និន្នាការ និងជំនឿណាមួយ ឬក្រុមជនជាតិពន្ធុណាមួយ ឬក្រុមជននៃសញ្ជាតិណាមួយ ឬក្រុមជនដែលតំណាងឱ្យវណ្ណៈណាមួយនៅក្នុងសង្គម(ឧទាហរណ៍ "បញ្ញវន្ត" បុព្វជិត ឬវណ្ណៈគហបតី)។ លើសពីនេះទៀត ក្រុមគោលដៅមូលហេតុនយោបាយ អាចត្រូវបានចារីកំណត់យ៉ាងទូលំទូលាយ ដូច្នេះ ក្រុមនេះអាចត្រូវបានកំណត់ក្នុងន័យអវិជ្ជមាន និងរួមបញ្ចូលអ្នកជាប់ពាក់ព័ន្ធជិតស្និទ្ធ ឬអ្នកគាំទ្រ ព្រមទាំងជនដែលសង្ស័យផងដែរ[2624]។

915. អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ក្នុងសំណុំរឿង ០០១ ផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ក្រុមកំណត់គោលដៅដែលចោទជាបញ្ហាក្នុងរឿងក្តីនេះ "រួមបញ្ចូល'អ្នកប្រឆាំងពិត ឬតាមការសន្មតផ្នែកនយោបាយ[ទៅនឹងបក្សកុម្មុយនីស្តកម្ពុជា] រួមទាំងសាច់ញាតិជិតស្និទ្ធ ឬអ្នកជាប់ពាក់ព័ន្ធ"ដែលត្រូវបានកំណត់ដោយមជ្ឈិមបក្ស"[2625]។

916. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា "ជាពិសេស ទាក់ទងទៅនឹង[បុគ្គលនៃក្រុមជនជាតិភាគតិច ឬសញ្ជាតិណាមួយ ឬបុគ្គលដែលតំណាងឱ្យវណ្ណៈណាមួយក្នុងសង្គម] ក្រុមនេះអាចត្រូវបានកំណត់ជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ មិនត្រឹមតែដោយសារសមាជិកទាំងអស់ ឬក៏ភាគច្រើននៃក្រុមនោះ ប្រកាន់ទស្សនៈនយោបាយដែលផ្ទុយពីទស្សនៈនយោបាយរបស់ចារីប៉ុណ្ណោះទេ ថែមទាំងដោយសារក្រុមនេះត្រូវបានសន្មតដោយចារីថា ជាអ្នកប្រឆាំងសក្តានុពល ឬ

---

[2623] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៤១។

[2624] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧២។

[2625] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧៣។

ក៏ជាឧបសគ្គរាំងដល់ការអនុវត្តន៍នៃកម្មវិធីនយោបាយរបស់ចារី"[2626]។ អង្គជំនុំជម្រះតុលាការកំពូលបានវិភាគយ៉ាងទូលំទូលាយលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ និងបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយត្រូវបានយល់ថា ជាស្ថានភាពរួមបញ្ចូលករណីដែលចារីបានកំណត់ទុកជាមុននូវក្រុមគោលដៅក្នុងរង្វង់ទូលាយដោយគ្មានការពិនិត្យអំពីការប្រកាន់ទស្សនៈនយោបាយរបស់បុគ្គលដែលពាក់ព័ន្ធ[2627]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល"បញ្ជាក់នូវលទ្ធភាពដែលអាចកើតមានថា ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកំណត់គោលដៅលើក្រុមប្រមូលផ្តុំដែលគ្មានអត្តសញ្ញាណ ឬកម្មវិធីរួមគ្នាណាមួយបាន"[2628]។

917. អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ពុំអាចកំណត់អត្តញ្ញាណច្បាស់លាស់ ដោយសារប្រភេទជាក់លាក់នៃសត្រូវពុំត្រូវបានរៀបរាប់លម្អិត និងបានពង្រីកជាដរាប។ ដូចបានបង្ហាញក្នុងយុត្តិសាស្ត្រកន្លងមករបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីបញ្ហានេះ ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយអាចកើតឡើងនៅពេលដែលក្រុមមួយ ត្រូវបានកំណត់គោលដៅយ៉ាងទូលំទូលាយ ដោយសារសមាជិករបស់ខ្លួនត្រូវបានសន្មតដោយចារីថា ជាសត្រូវនយោបាយ។ ពួកគេពុំចាំបាច់មានទម្រង់ស្របគ្នាតែមួយនោះទេ[2629]។ ដរាបណាសមាជិកទាំងអស់នៃក្រុមនោះត្រូវបានសន្មតថា ជាសត្រូវនយោបាយ បើទោះបីជាពួកគេស្ថិតក្រោមប្រភេទផ្សេងៗ ឬប្រភេទទាំងនេះត្រូវបានរៀបរាប់លម្អិតក៏ដោយ ក៏នៅតែអាស្រ័យលើការកំណត់ទុកជាមុននៃសត្រូវនយោបាយដែលនាំទៅរកការកំណត់គោលដៅនោះ។

918. អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា ក្រុមតូចៗជាច្រើនដែលជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" បានរួមបញ្ចូលអ្នកដែលត្រូវបានចាត់ទុកខុសៗគ្នាដោយបក្សកុម្មុយនីស្តកម្ពុជា។ ដរាបណាអ្នកទាំងនេះត្រូវបានចាត់ទុកថា ជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា និងក្លាយជាកម្មវត្ថុនៃការប្រព្រឹត្តដោយរើសអើង ការដែលពួកគេត្រូវបានចាត់ទុកខុ

[2626] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៦៩។

[2627] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៧០-៦៧៧។

[2628] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៧៨។

[2629] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៧៨។

សៗគ្នា ដែរ ឬយ៉ាងណានោះ ជាការពុំជាប់ពាក់ព័ន្ធឡើយ។ នេះពុំតម្រូវថា សមាជិកទាំងអស់នៃក្រុមដែលត្រូវបានធ្វើទុក្ខបុកម្នេញនោះ ទទួលរងការរើសអើងក្នុងកម្រិតដូចគ្នានោះទេ[2630]។

919. ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ត្រូវមានការប្រុងប្រយ័ត្នដើម្បីធានាថា អ្នកដែលត្រូវបានកំណត់ថា ជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"ជាក់ស្តែងត្រូវបានចាត់ទុកថា ជាការបង្កការគំរាមកំហែង ឬគ្រោះថ្នាក់ដល់នយោបាយ។ ទង្វើខ្លះអាចត្រូវបានចាត់ទុកថាជា"'សកម្មភាពសត្រូវ'ប្រឆាំងបដិវត្តន៍"[2631] ដោយពុំចាំបាច់មានអ្នកទាំងនោះពាក់ព័ន្ធទៅនឹងទង្វើនោះដែលជាក់ស្តែងត្រូវបានចាត់ទុកថា ជាការបង្កនូវការគំរាមកំហែងដល់នយោបាយឡើយ។

920. នេះទំនងជាថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើក្រុមកំណត់គោលដៅនៅតាមទីតាំងឧក្រិដ្ឋកម្មនានា ដែលរួមបញ្ចូលអ្នកដែលជាប់ពាក់ព័ន្ធជាមួយ"សកម្មភាពសត្រូវ"ដែលពុំមែនជារឿងនយោបាយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បើទោះបីជាដីកាដំណោះស្រាយសំដៅទៅលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"នៅមន្ទីរសន្តិសុខអូរកន្សែងដោយរួមបញ្ចូលអ្នកដែលត្រូវបានចោទពីអំពើខុសសីលធម៌ក៏ដោយ[2632] ក៏ការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងក្រុមកំណត់គោលដៅ ពុំបានលើកឡើងអំពីបុគ្គលដែលត្រូវបានចោទពីអំពើខុសសីលធម៌ដែរ។ ការជំទាស់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងភាពអាចកំណត់អត្តសញ្ញាណបាននៃ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ត្រូវបដិសេធចោល។

## ii. សហករណ៍ត្រាំកក់

921. ក្រោយការពិចារណាលើបទចោទ និងលក្ខណៈ និងភាពអាចកំណត់បាននៃក្រុមកំណត់គោលដៅ រួមទាំងអំណះអំណាងពាក់ព័ន្ធរបស់ភាគី[2633] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ភ្លាមៗ អតីតយោធា និងប៉ូលីសនៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្រិតសម្រាំងនៅវត្តចំប៉ា និងទីតាំងដទៃទៀតក្នុងស្រុកត្រាំកក់ និងជាច្រើនអ្នកទៀតត្រូវបានគេនាំចេញទៅ និងត្រូវបានធ្វើឱ្យបាត់ខ្លួន[2634]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីមាន"ផែនការច្បាស់

[2630] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៨៤។

[2631] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៤៦។

[2632] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨២។

[2633] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៦៨-១១៧៤។

[2634] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៥។

លាស់ក្នុងការបោសសម្អាត និងសម្លាប់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនៅស្រុកត្រាំកក់បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥"ក៏ដោយ ក៏ការណែនាំផ្សេងៗត្រូវបានផ្សព្វផ្សាយទៅតាមពេលវេលាផ្សេងៗគ្នា នៅពេលនោះដែរ និងចាប់តាំងពីខែ មេសា និងឧសភា ឆ្នាំ ១៩៧៧ មក អតីតទាហាន និងអ្នករដ្ឋការនៃរបប សាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅម្តងទៀតសម្រាប់ការចាប់ខ្លួន និងសម្លាប់ដែលជាផ្នែកមួយ នៃ"ប្រតិបត្តិការសម្លាប់មនុស្សដោយមានការរៀបចំ"[2635]។

922. ទាក់ទងទៅនឹងប្រជាជនថ្មីដែលមានលក្ខណៈទូលំទូលាយជាង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពួកគេត្រូវបានដាក់ចំណាត់ថ្នាក់ថា ជា"ប្រជាជនបញ្ញើ" ឬ"ប៉ារ៉ាស៊ីត" និងត្រូវបានចាត់ទុកថា ជាអ្នកនៅក្រោមបង្គាប់ និងមានអត្ថិភាពនៃការរើសអើងជាប្រព័ន្ធ និងដឹងឮយ៉ាងទូលំទូលាយប្រឆាំងនឹងប្រជាជនថ្មី នៅមុនពាក់កណ្តាលឆ្នាំ ១៩៧៨[2636]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនថ្មីបានទទួល របបអាហារតិចជាងប្រជាជនមូលដ្ឋាន និងជាពិសេសទទួលរងទុក្ខ និងស្លាប់ដោយសារការគ្មានអាហារ គ្រប់គ្រាន់ និងថា លក្ខខណ្ឌការងារខុសប្លែកគ្នាអាស្រ័យលើប្រភេទនៃបុគ្គល ប៉ុន្តែប្រជាជនថ្មីបានទទួលរង ទុក្ខដោយសារការប្រព្រឹត្តទៅលើធ្ងន់ធ្ងរជាង[2637]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការរើសអើង កាន់តែខ្លាំងទៅៗជាងបញ្ហាសិទ្ធិផ្នែកនយោបាយចំពោះប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការគំរាមកំហែងដទៃទៀតដែលតាមការសន្មតត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន[2638]។

923. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនាក្នុងការរើសអើង ដោយសារមូលហេតុនយោបាយចំពោះអ្នកដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា និងថា អំពើនោះបានរើសអើងជាក់ស្តែង និងបានរំលោភបំពានលើសិទ្ធិមនុស្សជាសារវ័ន្ត[2639]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនៃការរើសអើងមួយចំនួនដែលជាមូលដ្ឋានអាចស្មើនឹងបទឧក្រិដ្ឋឯករាជ្យនៃការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបាន

---

[2635] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៥។

[2636] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៦។

[2637] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

[2638] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

[2639] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៨។

ជឿជាក់ថា អំពើនេះឈានដល់កម្រិតមួយធ្ងន់ធ្ងរដែលបង្កើតបានជាបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2640]។

924. អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើក្រុមទូទៅ ដែលជា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"នៅសហករណ៍ត្រាំកក់ឡើយ ក្រៅតែពីការយល់ឃើញរបស់ខ្លួនជាក់លាក់អំពីអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនថ្មី។

- *អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ*

925. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានកើតឡើងនៅសហករណ៍ត្រាំកក់ ដោយសារ (១) ពុំមានភស្តុតាងដែលអាចបញ្ជាក់បានអំពីបទបញ្ជាឱ្យស្រាវជ្រាវរក និងចាប់ខ្លួនអតីតទាហាន ឬអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (២) ពុំមានភស្តុតាងដែលអាចបញ្ជាក់ពីការសម្លាប់ពាក់ព័ន្ធទៅនឹងប្រតិបត្តិការដែលចាប់ផ្តើមក្នុងខែ មេសា ឆ្នាំ ១៩៧៧ និង (៣) អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើបទចោទដែលមានក្នុងដីកាដំណោះស្រាយជាជាងការយល់ឃើញដែលបានបង្កើតឡើងក្នុងសាលក្រម ដើម្បីគាំទ្រការយល់ឃើញដែលថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន និងសម្លាប់[2641]។

926. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស និងខកខានក្នុងការទទួលស្គាល់ភស្តុតាងជារួមដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ[2642] និងថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយោងនៅក្នុងជើងទំព័រទៅលើការចោទប្រកាន់ក្នុងដីកាដំណោះស្រាយជាជាងការយល់ឃើញរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះបានយោងក្នុងជើងទំព័រដដែលនេះផងដែរទៅលើកថាខណ្ឌដទៃទៀតនៃសាលក្រម ដែលមានការយល់ឃើញផ្នែកអង្គហេតុ និងភស្តុតាងគាំទ្រ[2643]។

927. សហមេធាវីនាំមុខបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្នែកអង្គហេតុដែលថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលផ្សេងៗគ្នា

---

[2640] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៩។

[2641] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២០។

[2642] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤២៩-៤៣១, ៤៣៤។

[2643] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៣៦។

ដែលដំបូងនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងម្តងទៀតក្រោយខែ មេសា/ឧសភា ឆ្នាំ ១៩៧៧ និងថា ខៀវ សំផន ត្រឹមតែជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុដែលបានបង្កើតឡើងក្នុងអំឡុងពេលទីពីរ ដូច្នេះទោះបីជាគាត់អាចទទួលជោគជ័យក្នុងការបង្ហាញកំហុសក៏ដោយ ក៏ពុំមានការប៉ះពាល់លើការយល់ឃើញទូទៅអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែរ[2644]។

928. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដូចបានអះអាងដោយសហមេធាវីនាំមុខ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងការប្រព្រឹត្តដោយរើសអើងចំពោះអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនៅសហករណ៍ត្រាំកក់ ដែលពាក់ព័ន្ធទៅនឹងអំឡុងពេលពីរផ្សេងគ្នា៖ អំឡុងពេលប្រមាណប្រហែលមួយសប្តាហ៍បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2645] និងអំឡុងពេលដើមខែមេសា និងឧសភា ឆ្នាំ ១៩៧៧[2646]។ ខៀវ សំផន បើទោះបីជាបានលើកការចោទប្រកាន់ជាទូទៅថា អង្គជំនុំជម្រះមានកំហុសអង្គហេតុ"ដោយបានយល់ឃើញថា បទឧក្រិដ្ឋត្រូវបានបង្ហាញ"ក៏ដោយ[2647] ក៏ត្រឹមតែលើកអំណះអំណាងជាក់លាក់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំឡុងពេលទីពីរប៉ុណ្ណោះ[2648]។ អាស្រ័យហេតុនេះ បើទោះបីជាអំណះអំណាងរបស់គាត់ក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះបានទទួលជោគជ័យក៏ដោយ ក៏នៅពុំទាន់គ្រប់គ្រាន់ក្នុងការបដិសេធការដាក់ពិរុទ្ធភាពលើរូបគាត់ពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញលើអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនៅសហករណ៍ត្រាំកក់ដែរ។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

[2644] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៨៣។

[2645] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៥ យោងទៅលើការយល់ឃើញដែលបានបង្កើតឡើងនៅកថាខណ្ឌ ៩៥៨-៩៦១។ កថាខណ្ឌខាងក្រោម កថាខណ្ឌ ៩៦២ លើកឡើងថា "អង្គជំនុំជម្រះយល់ឃើញថា ព្រឹត្តិការណ៍វត្តចំប៉ា ត្រូវបានកម្រិតត្រឹមអំឡុងពេលខ្លី៖ មួយសប្តាហ៍ ឬយូរជាងនេះបន្តិចក្រោយការជួលរលំក្រុងភ្នំពេញ និងក្រុងតាកែវ"។

[2646] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៥ យោងទៅលើការយល់ឃើញដែលអង្គជំនុំជម្រះបានបង្កើតឡើងនៅកថាខណ្ឌ ១០៦២-១០៦៣ និង ១០៨០-១០៨១។

[2647] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២០។

[2648] ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌ ១១៧៥ នៃសាលក្រមដែលយោងត្រឡប់ក្រោយទៅលើកថាខណ្ឌ ១០៦២-១០៦៣, ១០៨១-១០៨២, និង ២៨១៣ នៃសាលក្រម ប៉ុន្តែពុំបានជំទាស់ទៅនឹងការយល់ឃើញដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌ ១១៧៥ នៃសាលក្រមដែលយោងត្រឡប់ទៅលើការយល់ឃើញដែលបានបង្កើតឡើងក្នុង ៩៥៨-៩៦១, ៩៦៣-៩៦៥ និង ១០៧៧។

- *ប្រជាជនថ្មី*

929. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា នៅត្រាំកក់ (១) ប្រជាជនថ្មីបានទទួលរបបអាហារផ្សេង (២) លក្ខខណ្ឌការងារធ្ងន់ធ្ងរជាងសម្រាប់ប្រជាជនថ្មី (៣) លក្ខខណ្ឌការងារធ្ងន់ធ្ងរជាពិសេសកងយុវជន (៤) ប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោម"ការធ្វើបាបយ៉ាងលំបាកវេទនា" និង (៥) ប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោមការតាមដាន និងចាប់ខ្លួន[2649]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ប្រជាជនថ្មីត្រូវបានកំណត់ជាប្រភេទដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន និងត្រូវបានដាក់ឱ្យដាច់ដោយឡែកពីប្រជាជនមូលដ្ឋានក្នុងសហករណ៍ដាច់ដោយឡែក ឬក្រុមការងារដាច់ដោយឡែក និងត្រូវបានចាត់ទុកថាជាអ្នកនៅក្រោមបង្គាប់ប្រជាជនមូលដ្ឋាន[2650]។ ការយល់ឃើញទាំងនេះពុំត្រូវបានជំទាស់ជាក់លាក់ដោយ ខៀវ សំផន ឡើយ។

930. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើប្រភេទនីមួយៗនៃការរើសអើង ដែលត្រូវបានជំទាស់ដោយ ខៀវ សំផន និងពិចារណាថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការរើសអើងលើប្រជាជនថ្មីនៅសហករណ៍ត្រាំកក់ចុងក្រោយត្រូវតែបានពិនិត្យជារួម ជាជាងតាមផ្នែកៗ ដោយសារមានការទំនាក់ទំនងគ្នាទៅវិញទៅមក។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងស្ថិតក្នុងលក្ខណៈប្រសើរបំផុតក្នុងការវាយតម្លៃលើភស្តុតាង និងថា ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនឹងពុំអាចបដិសេធចោលងាយៗបានឡើយ។

ក) របបអាហារ

931. អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដែលថា ប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនមូលដ្ឋាន និងថា ប្រជាជនថ្មីជាពិសេសបានទទួលរង និងបានស្លាប់ដោយសារពុំមានអាហារគ្រប់គ្រាន់[2651]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកអំពើនៃការធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានេះថាជាការផ្តល់អាហារមិនគ្រប់គ្រាន់ដល់ប្រជាជនថ្មី ដែលលទ្ធផលនៃអំពើនេះបានបណ្តាលឱ្យមានការទទួលរងទុក្ខ និងស្លាប់ដោយសារការពុំមានអាហារគ្រប់គ្រាន់។ នៅក្នុងការបង្កើតការយល់ឃើញដែលថា ប្រជាជនថ្មីបាន

---

[2649] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២៧។

[2650] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៦។

[2651] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

ទទួលអាហារតិចជាងប្រជាជនមូលដ្ឋាន[2652] អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារគោលនយោបាយកម្រិតខ្ពស់ដែលបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់នូវរបបអាហារខុសៗគ្នាសម្រាប់ប្រជាជនប្រភេទផ្សេងៗគ្នាផ្អែកលើប្រវត្តិនៃវណ្ណៈរបស់ពួកគេ[2653]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើការអនុវត្តន៍គោលនយោបាយក្នុងស្រុកត្រាំកក់[2654] និងដើម្បីបង្កើតការយល់ឃើញថាប្រជាជនថ្មីបានទទួលរបបអាហារតិចជាងតាមការជាក់ស្តែង អង្គជំនុំជម្រះបានសំអាងទៅលើសក្ខីកម្មរបស់ ពេជ្រ ជឹម, កែវ ច័ន្ទតារា, តាក សាន់ និង ជូ គឹមឡូន[2655]។

932. ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន[2656] អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងអំពីភស្តុតាងដោះបន្ទុក និងពុំបានយកភស្តុតាងនេះមកធ្វើការពិចារណាឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថាភស្តុតាងខ្លះបង្ហាញថា នៅកម្រិតថ្នាក់ស្រុកមានការស្នើសុំអនុវត្តរបបអាហារស្មើគ្នាដោយទូលំទូលាយលើបុគ្គលប្រភេទផ្សេងៗគ្នាទាំងអស់ ប៉ុន្តែបានពន្យល់ថា ផ្អែកតាមភស្តុតាងគួរឱ្យជឿជាក់ថា តាមការជាក់ស្តែង ប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនមូលដ្ឋាន[2657]។ អង្គជំនុំជម្រះបានពន្យល់បន្ថែមថា ពេជ្រ ជឹម បានសន្និដ្ឋានការអនុវត្តន៍នូវការផ្តល់បាយដល់ប្រជាជនមូលដ្ឋានច្រើនជាងប្រជាជនថ្មី ដោយសារ "ការខ្វះចន្លោះនៅក្នុងការគ្រប់គ្រង"លើសហករណ៍ផ្សេងគ្នា និងថា នាង អ៊ួច បានឆ្លើយថា ប្រធានៗពុំបានសម្របសម្រួលបានល្អ ហើយផ្ទះបាយខ្លះពុំមានអាហារគ្រប់គ្រាន់សម្រាប់ប្រជាជនហូប ប៉ុន្តែនៅពេលរំឭក

---

[2652] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

[2653] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១០.១.៧.៣.១ ("ឯកសារគោលនយោបាយកម្រិតខ្ពស់") និង ជាពិសេស កថាខណ្ឌ ១០០៩ យោងទៅលើទង់បដិវត្ត E3/139 ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ និងកំណត់ហេតុរបស់ អៀង សារី ឯកសារលេខ E3/522 ពុំមានចុះកាលបរិច្ឆេទ ទំព័រ ៧០-៧១ ERN 00427883-00427834 (បញ្ចូលចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៧៦)។ កថាខណ្ឌ ១០០៩ យោងផងដែរទៅលើកថាខណ្ឌ ៩៩៤ កន្លែងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើទង់បដិវត្ត ឯកសារលេខ E3/745 ខែ មីនា ឆ្នាំ ១៩៧៨។

[2654] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១០.១.៧.៣.២ ("ការអនុវត្តន៍ក្នុងស្រុកត្រាំកក់") និងជាពិសេសកថាខណ្ឌ កថាខណ្ឌ ១០១៦។

[2655] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៦។ អង្គជំនុំជម្រះបានយោងផងដែរក្នុងកថាខណ្ឌនេះទៅលើសក្ខីកម្មរបស់ ឯក ហេន ប៉ុន្តែត្រឹមតែកត់សម្គាល់ថា គាត់បានសន្និដ្ឋានបញ្ហាទៅលើចុងភៅដែលលួចអង្ករ។

[2656] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣០ ("អង្គជំនុំជម្រះខ្វះអនាគតិដោយសារពុំបានពិចារណាលើភស្តុតាងដោះបន្ទុក។ ជាក់ស្តែង អ្វីដែលអង្គជំនុំជម្រះបានធ្វើគឺត្រូវលើកភស្តុតាងដោះបន្ទុករបស់ ពេជ្រ ជឹម, នាង អ៊ួច និង ជាំង ស្រីមុំ ដោយគ្មានការពិចារណាលើភស្តុតាងនេះ")។

[2657] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១០.១.៧.៣.២ ("ការអនុវត្តន៍ក្នុងត្រាំកក់") និងជាពិសេស កថាខណ្ឌ ១០១៦។

ការយល់ឃើញរបស់ខ្លួនដែលថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាបានកំណត់របបអាហារផ្សេងៗគ្នាសម្រាប់ប្រជាជនប្រភេទខុសៗគ្នា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការលើកឡើងដែលថា ការបែងចែកដោយរើសអើងនៃរបបអាហារ បានបណ្ដាលមកពីភាពខ្វះចន្លោះនៅក្នុងការគ្រប់គ្រងសហករណ៍នោះ[2658]។

933. ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានពិចារណាលើភស្តុតាងដោះបន្ទុករបស់ សៅ ហ៊ាន ដែលថា របបអាហារដូចៗគ្នា[2659] ការដែលអង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងច្បាស់លាស់នូវភស្តុតាងនេះ ពុំមែនមានន័យថា ភស្តុតាងនេះពុំត្រូវបានយកមកពិចារណានោះទេ និងដូច្នេះពុំបានបង្ហាញនូវកំហុសឡើយ[2660]។ នៅគ្រប់កាលៈទេសៈ អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកភស្តុតាងនេះ មានទម្ងន់ធ្ងន់ជាងភស្តុតាងដែលត្រូវបានពិចារណាច្បាស់លាស់ និងត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

934. ខៀវ សំផន បានជំទាស់ជាក់លាក់ទៅនឹងសក្ខីកម្មរបស់ ពេជ្រ ជឹម និង តាក សាន់ និងបានអះអាងថា ពេជ្រ ជឹម បានបង្ហាញថា ការបែងចែកអាហារ និងរបបអាហារគឺដូចៗគ្នាសម្រាប់អ្នករាល់គ្នា និងពុំបានបញ្ជាក់ទីកន្លែង ពេលវេលា តើញឹកញាប់ប៉ុន្មាន ឬនរណាជាអ្នកបែងចែក នៅពេលគាត់បង្ហាញថា តាមការជាក់ស្ដែង ប្រជាជនថ្មីបានទទួលបាយតិចជាង[2661]។ ខៀវ សំផន បានអះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ មានការភាន់ច្រឡំ ខ្វះភាពអាចជឿជាក់បាន និងពុំបានពន្យល់ហេតុដូចម្ដេចបានជាគាត់អាចសន្និដ្ឋានថា ប្រជាជនថ្មីទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាននោះឡើយ[2662]។

935. អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកសក្ខីកម្មរបស់ ពេជ្រ ជឹម ថា មានតម្លៃជាភស្តុតាងទាប ដោយសារគាត់ពុំបានផ្ដល់ការពន្យល់លម្អិតពាក់ព័ន្ធទៅនឹងភាពខុសប្លែកគ្នាក្នុងការបែងចែកបាយនោះ។ គាត់បានពន្យល់ថា គាត់"សង្កេតឃើញថា មានភាពខុសប្លែកគ្នាក្នុងការបែងចែកបាយនោះ"[2663]។ បើទោះបីជាការពិតថា

---

[2658] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៦។

[2659] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣០។

[2660] អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានតម្រូវឱ្យបញ្ជាក់រាល់ចំណុចនៃការផ្ដល់សំអាងហេតុ និងត្រូវបានសន្មតថា បានវាយតម្លៃសមស្របលើភស្តុតាងទាំងអស់ចំពោះមុខ។ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០៤។

[2661] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២៩។

[2662] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២៩។

[2663] ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៤២។

គាត់បានផ្តល់សក្ខីកម្មផ្ទុយទៅនឹងគោលនយោបាយក៏ដោយ[2664] ក៏អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះតាមការជាក់ស្តែងគឺដោយសារគោលនយោបាយដែលបានបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា[2665]។ ខៀវ សំផន ខកខានក្នុងការលើកភស្តុតាងគាំទ្រអំណះអំណាងរបស់គាត់ដែលថា តាក សាន់ មានការភាន់ច្រឡំ និងខ្វះភាពគួរឱ្យជឿជាក់បាន[2666]។ តាក សាន់ បានពន្យល់ថា លោកស្រីបានឃើញដោយផ្ទាល់ថា របបអាហារពុំស្មើគ្នា[2667]។

936. ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារ DC-Cam ជាមួយនឹង រៀល សន និងបានអះអាងថា រៀល សន ជាក់ស្តែងបានពន្យល់ថា ប្រជាជនមូលដ្ឋានទទួលបានអាហារច្រើនជាងដោយសារពួកគេមានលទ្ធភាពច្រើនជាង និងអាចស្វែងរកអាហារក្រៅបាន ប៉ុន្តែពុំមែនថា ប្រជាជនមូលដ្ឋានទទួលបានរបបអាហារច្រើនជាងនោះទេ[2668]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារ DC-Cam ជាមួយនឹង រៀល សន ក្នុងការបញ្ជាក់បន្ថែមលើភស្តុតាងជាឯកសារ និងជាសក្ខីកម្មដែលមានលក្ខណៈរឹងមាំ និងថា អំណះអំណាងរបស់ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះមានកំហុសក្នុងការប្រើប្រាស់ភស្តុតាងនេះសម្រាប់ការយល់ឃើញទូលំទូលាយជាងស្តីពីភាពខុសប្លែកគ្នានៃការទទួលបានរបបអាហារ[2669]។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារ DC-Cam ជាមួយនឹង រៀល សន សម្រាប់ការយល់ឃើញថា មាន"ភាពខុសប្លែកគ្នាក្នុងការទទួលបាននូវរបបអាហារ"[2670] ជាជាងដើម្បីគាំទ្រការយល់ឃើញដែលថា ប្រជាជនថ្មី

---

[2664] ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៤៣។

[2665] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៦។

[2666] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧២៩។

[2667] ប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ (តាក សាន់) ឯកសារលេខ E1/286.1 ទំព័រ ៣៦:

ឆ: ខ្ញុំមើលទៅ ដូចមិនស្មើទេ ពួកមូលដ្ឋានអីចឹងទៅ គេហូបរាងក្រៃលបន្តិចទៅ ហើយពួកខ្ញុំថ្មីអីចឹងទៅ ក៏រាងបន្ថយបន្តិចអីចឹងទៅ។

ស: ចុះលោកស្រីអាច និយាយដូច្នេះ បានសំអាងទៅលើអ្វីដែរ ? តើ លោកស្រីឃើញផ្ទាល់ភ្នែក នូវស្ថានភាពបែបនោះដោយរបៀបណា?

ឆ៖ ខ្ញុំហូបហើយ ខ្ញុំឃើញ។

[2668] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣១។

[2669] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៩១។

[2670] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០១៦។

ត្រូវបានផ្តល់អាហារតិចជាងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា ភស្តុតាងនេះពុំបានគាំទ្រការយល់ឃើញដែលថា ប្រជាជនថ្មីត្រូវបានរើសអើងពាក់ព័ន្ធទៅនឹងការផ្តល់របបអាហារនោះទេ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងគ្រប់គ្រាន់ ដោយពុំចាំបាច់ពិចារណាលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលតម្កល់ឯកសារ DC-Cam នេះឡើយ។

937. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់ខ្លួនដែលថា ប្រជាជនថ្មីបានទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាន។

ខ) លក្ខខណ្ឌការងាររួមទាំងនៅក្នុងកងចល័តយុវជន

938. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា តាមការអះអាងរបស់ ខៀវ សំផន[2671] ភស្តុតាងភាគច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសម្រាប់ការយល់ឃើញរបស់ខ្លួនអំពីលក្ខខណ្ឌការងាររវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ត្រឹមតែបង្ហាញថា មានលក្ខខណ្ឌការងារធ្ងន់ធ្ងរ ជាជាងបង្ហាញថា ការប្រព្រឹត្តទៅលើនោះខុសៗគ្នា។ ក្នុងកថាខណ្ឌនៃសាលក្រមដែលត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនអំពីការប្រព្រឹត្តខុសៗគ្នា មានតែការលើកឡើងអំពីការប្រព្រឹត្តខុសប្លែកគ្នាដែល សៅ ហ៊ាន បានឆ្លើយថា ប្រជាជនពេញសិទ្ធិទទួលបានលក្ខខណ្ឌប្រសើរជាងប្រជាជនត្រៀម ឬប្រជាជន ១៧ មេសា និងថា លក្ខខណ្ឌដែលប្រសើរជាងនោះ គឺបានធ្វើជាប្រធានកងគ្រប់គ្រងប្រជាជនថ្មី[2672]។ នុត នូវ ក៏បានលើកឡើងផងដែរថា ប្រជាជនថ្មីជាច្រើនឈឺញឹកញាប់ជាងប្រជាជនមូលដ្ឋាន[2673] ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា នេះបានគាំទ្រដល់ការយល់ឃើញអំពីការប្រព្រឹត្តខុសប្លែកគ្នាឡើយ ដោយសារគាត់បានពន្យល់ថា ប្រជាជនថ្មីឈឺញឹកញាប់ពីព្រោះពួកគេពុំដែលធ្លាប់ធ្វើស្រែចំការ[2674]។

939. យោងទៅលើសហព្រះរាជអាជ្ញា ការយល់ឃើញទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីលក្ខខណ្ឌការងារធ្ងន់ធ្ងរ ចាំបាច់ត្រូវតែយល់ក្នុងបរិបទទូលំទូលាយជាងនៃការកំណត់ប្រភេទប្រជាជន និងការអនុវត្តន៍ក្នុង

[2671] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣២។

[2672] ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ (សៅ ហ៊ាន) ឯកសារលេខ E1/264.1 ទំព័រ ៧២-៧៥។

[2673] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០២០ យោងទៅលើប្រតិចារឹក ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ (នុត នូវ) ឯកសារលេខ E1/276.1 ទំព័រ ៣៥។

[2674] ប្រតិចារឹក ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ (នុត នូវ) ឯកសារលេខ E1/276.1 ទំព័រ ៣៥។

ស្រុកត្រាំកក់[2675]។ ក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលដោះស្រាយលើការអនុវត្តន៍នៃប្រព័ន្ធកំណត់ប្រភេទប្រជាជន អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញថា តួនាទីនៃសិទ្ធិអំណាចគឺបម្រុងទុកសម្រាប់ប្រជាជនមូលដ្ឋាន[2676]។ នៅក្នុងជើងទំព័រ អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ភស្តុតាងដែលបង្ហាញថា ប្រជាជនមូលដ្ឋានដែលជាប្រធាន ពុំធ្វើការធ្ងន់ដូចប្រជាជនថ្មី៖ រី ពៅ បានផ្តល់សក្ខីកម្មថា ប្រជាជនមូលដ្ឋានពុំធ្វើការ ប៉ុន្តែត្រឹមតែតាមដានការងារ ហើយ តាក សាន់ បានឆ្លើយថា ប្រជាជនមូលដ្ឋានពីបួនទៅប្រាំនាក់ដែលដឹកនាំកងសហករណ៍របស់គាត់ ពុំចាំបាច់ធ្វើការធ្ងន់ទេ[2677]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងនេះបង្ហាញថា លក្ខខណ្ឌការងាររបស់ប្រជាជនថ្មីមានលក្ខណៈផ្សេង និងធ្ងន់ធ្ងរជាងលក្ខខណ្ឌរបស់ប្រជាជនមូលដ្ឋាន និងថា ប្រជាជនថ្មីពុំអាចកាន់តួនាទីនៃសិទ្ធិអំណាច និងពុំអាចទទួលបានអត្ថប្រយោជន៍ពីលក្ខខណ្ឌការងារប្រសើរដែលជាប់ជាមួយនឹងតួនាទីនោះឡើយ។ តាមការប្រៀបធៀប មានលក្ខណៈខុសប្លែកគ្នាតិចតួច ដោយសារពុំមានភស្តុតាងបង្ហាញថា ប្រជាជនមូលដ្ឋានភាគច្រើនធ្វើជាមេៗ និងពុំមានភស្តុតាងបង្ហាញក្នុងផ្នែកទាំងនេះនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញថា លក្ខខណ្ឌការងារសម្រាប់ប្រជាជនថ្មីធ្ងន់ធ្ងរជាងលក្ខខណ្ឌសម្រាប់ប្រជាជនមូលដ្ឋានឡើយ។

940. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ជាការពុំត្រឹមត្រូវក្នុងការពិចារណាតែលើលក្ខខណ្ឌការងារដាច់ដោយឡែកនោះ ពីព្រោះកាលណាបើប្រជាជនថ្មីត្រូវបានផ្តល់របបអាហារតិចជាង ជាការសមហេតុផលដែលថា ពួកគេនឹងជួបប្រទះលក្ខខណ្ឌការងារលំបាកជាង បើទោះបីជាលក្ខខណ្ឌទាំងនេះមានលក្ខណៈដូចគ្នាទៅនឹងលក្ខខណ្ឌរបស់ប្រជាជនមូលដ្ឋានក៏ដោយ។ ទោះជាយ៉ាងណាក្តី នេះទាក់ទងទៅនឹងលទ្ធផលនៃការអនុវត្តន៍ដោយរើសអើងពាក់ព័ន្ធទៅនឹងរបបអាហារ ជាជាងការបង្ហាញថា ប្រជាជនថ្មីត្រូវបានប្រព្រឹត្តទៅលើផ្សេងគ្នាក្នុងលក្ខខណ្ឌការងារដែលបានដាក់លើពួកគេ ក្រៅតែពីការពុំមានឱកាសកាន់តួនាទីនៃសិទ្ធិអំណាច និងទទួលបានអត្ថប្រយោជន៍ពីតួនាទីនោះប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា លក្ខខណ្ឌការងារមានលក្ខណៈធ្ងន់ធ្ងរសម្រាប់ប្រជាជនថ្មីជាងលក្ខខណ្ឌការងារសម្រាប់ប្រជាជនមូលដ្ឋាន លើកលែងតែការដែលប្រជាជន

---

[2675] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៩៣។

[2676] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០០២, ១០០៤។

[2677] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ៣១៦៨ យោងទៅលើប្រតិចារឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ (រី ពៅ) ឯកសារលេខ E1/262.1 ទំព័រ ១២-១៣, ៥១-៥២ និងប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ (តាក សាន់) ឯកសារលេខ E1/286.1 ទំព័រ ៣១-៣៣។

ថ្មីត្រូវបានហាមឃាត់មិនឱ្យកាន់តួនាទីថ្នាក់ដឹកនាំ និងពុំទទួលបានអត្ថប្រយោជន៍ពីលក្ខខណ្ឌការងារប្រសើរដែលជាប់ជាមួយនឹងតួនាទីនោះប៉ុណ្ណោះ។

ក) ការធ្វើបាបយ៉ាងលំបាកវេទនា

941. អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ ប៊ុន សារឿន, អ៊ឹម វណ្ណៈ, តាក សាន់, យ៉ែម ខុន្ធី និង រី ពៅ សម្រាប់ការយល់ឃើញថា ប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាបយ៉ាងលំបាកវេទនា និងត្រូវបានចាត់ទុកជាកញ្ចះដាច់ថ្លៃ[2678]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹង ខៀវ សំផន ថា សក្ខីកម្មរបស់ ប៊ុន សារឿន ពុំបានគាំទ្រការយល់ឃើញអំពីការប្រព្រឹត្តដោយរើសអើង ដោយសារគាត់បានផ្តល់សក្ខីកម្មថា របបអាហារអាចត្រូវបានដកហូតសម្រាប់ការបំពាន ឬពុំបានបំពេញតាមលក្ខខណ្ឌកំណត់ ប៉ុន្តែពុំបានបង្ហាញថា ការធ្វើបាបនោះបានកំណត់គោលដៅលើប្រជាជនថ្មីឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ សក្ខីកម្មរបស់ តាក សាន់ និង យ៉ែម ខុន្ធី បានពិពណ៌នាអំពីការធ្វើបាបយ៉ាងលំបាកវេទនា ប៉ុន្តែពុំបានបង្ហាញថា ការធ្វើបាបនេះគឺជាការរើសអើងនោះទេ[2679]។ ទោះជាយ៉ាងណាក្តី រី ពៅ និង អ៊ឹម វណ្ណៈ បានសំដៅជាក់លាក់ទៅលើការប្រព្រឹត្តលើប្រជាជនថ្មី ពួកគាត់បានឆ្លើយថា ប្រជាជនមូលដ្ឋានអាចជេរប្រមាថ និងវាយតប់ប្រជាជនថ្មីបាន ហើយសក្ខីកម្មរបស់ពួកគេបានគាំទ្រគ្នាទៅវិញទៅមក[2680]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើសាក្សីទាំងនេះដោយពុំចាំបាច់ពិចារណាច្បាស់លាស់លើភាពអាចជឿជាក់បាននោះទេ។

942. បើទោះបីជា ខៀវ សំផន បានលើកឡើងថា សក្ខីកម្មរបស់ រី ពៅ ពុំអាចគាំទ្រការយល់ឃើញទូទៅ និងអំពើដែលបានពិពណ៌នានោះពុំអាចត្រូវសន្មតបានថាជារបស់ថ្នាក់ដឹកនាំក៏ដោយ[2681] ក៏អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថាជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផ្អែកលើសក្ខីកម្មទាំងនេះ ប្រជាជនថ្មីជាពិសេសត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាបយ៉ាងលំបាកវេទនា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការយល់ឃើញ

---

[2678] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧ យោងទៅលើកថាខណ្ឌ ១០២៣។

[2679] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០២៣យោងទៅលើប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ (តាក សាន់) ឯកសារលេខ E1/286.1 ទំព័រ ៣៣។ ប្រតិចារឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ (យ៉ែម ខុន្ធី) ឯកសារលេខ E1/288.1 ទំព័រ ៨-៩។

[2680] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០២៣។

[2681] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣៧។

ដទៃទៀតដែលពុំត្រូវបានជំទាស់របស់អង្គជំនុំជម្រះសាលាដំបូង និងត្រូវតែពិចារណាក្នុងបរិបទដែលថា ប្រជាជនថ្មីត្រូវបានកំណត់ប្រភេទ និងត្រូវបានចាត់ទុកថា ជាអ្នកនៅក្រោមបង្គាប់ប្រជាជនមូលដ្ឋាន។ ក្នុងបរិបទនៃការកំណត់ប្រភេទដែលត្រូវបានធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ក្នុងករណីដែលប្រជាជនថ្មីត្រូវបានចាត់ទុកថា ជាអ្នកនៅក្រោមបង្គាប់របស់ប្រជាជនមូលដ្ឋាន ភស្តុតាងរបស់សាក្សីពីរនាក់បង្ហាញថា ប្រជាជនមូលដ្ឋានអាចជេរប្រមាថ វាយតប់លើប្រជាជនថ្មីនោះ អាចគាំទ្រការយល់ឃើញជាទូទៅ ហើយអំពើនេះអាចត្រូវបានចាត់ទុកដោយសមហេតុផលថា ជាលទ្ធផលនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

ឃ) ការតាមដាន និងការចាប់ខ្លួន

943. ការយល់ឃើញផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពុំសំដៅទៅលើការតាមដានប្រជាជនថ្មីនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង"បានយល់ឃើញថា ប្រជាជនថ្មី ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការគំរាមកំហែងដទៃទៀតតាមការសន្មតចំពោះបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួនដោយសារការគិតសំដី ឬអំពើដែលគ្មានការបង្កគ្រោះថ្នាក់ ប៉ុន្តែត្រូវបានចាត់ទុកថា ប្រឆាំងនឹងបដិវត្តន៍"[2682]។ ក្នុងការគាំទ្រការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកថាខណ្ឌ ១០៥៥ និង ១០៨០ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ កថាខណ្ឌ ១០៥៥ ជាប់ទាក់ទងទៅនឹងការតាមដាន និងមានភស្តុតាងបង្ហាញថា ប្រជាជនថ្មីត្រូវបានតាមដាន។ ទោះជាយ៉ាងណាក្តី តាមការអះអាងរបស់ ខៀវ សំផន[2683] ភស្តុតាងភាគច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងកថាខណ្ឌនេះ ពុំបានបង្ហាញថាតើ ការតាមដាននោះត្រូវបានកំណត់គោលដៅលើប្រជាជនថ្មី ឬលើអ្នករាល់គ្នា ដែរ ឬយ៉ាងណា ដូច្នេះពុំបានបង្ហាញនូវអត្ថិភាពនៃការប្រព្រឹត្តដោយរើសអើងឡើយ។

944. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ឈ្លបតាមដាន"ប្រជាជន"ដូចជាចូលស្តាប់នៅក្រោមផ្ទះពេលយប់[2684]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា ប្រជាជនថ្មី និងប្រជា

---

[2682] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

[2683] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៣៩-៧៤០។

[2684] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥។

ជនចាស់ត្រូវបានតាមដាន[2685] និងថា សាក្សីម្នាក់ទៀតបានឆ្លើយថា ខ្មាំងដែលមានការសង្ស័យត្រូវបានគេតាមដាន[2686]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងផងដែរទៅលើសក្ខីកម្មដែលបង្ហាញថា ប្រជាជនមួយចំនួនត្រូវបានគេតាមដាន រួមទាំងសក្ខីកម្មមួយដែលបង្ហាញថា ប្រជាជនថ្មីត្រូវបានតាមដាន[2687] ប៉ុន្តែតាមរយៈសក្ខីកម្មទាំងនេះ ពុំមានភាពច្បាស់លាស់ថាតើ ការតាមដាននេះបានកំណត់គោលដៅលើប្រជាជនថ្មី ដែរឬយ៉ាងណានោះទេ[2688]។

945. អង្គជំនុំជម្រះសាលាដំបូងបានយោងផងដែរទៅលើរបាយការណ៍បួនដែលបានរកឃើញក្នុងកំណត់ត្រាស្រុកត្រាំកក់។ ទីមួយ"បានពិពណ៌នាអំពីគ្រួសារមួយដែលពុំបានចូលដេកពីព្រលប់ និងនៅជជែកគ្នាយប់ជ្រៅ"

[2685] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើប្រតិចារឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារលេខ E1/296.1 ទំព័រ ៦៨-៦៩។

[2686] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើប្រតិចារឹក ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ (ឯក ហឿន) ឯកសារលេខ E1/299.1 ទំព័រ ៦២-៦៣។

[2687] ចាន់ ធីម ប្រជាជនថ្មីបានផ្តល់សក្ខីកម្មថា ប្រជាជនថ្មីពុំត្រូវបានទុកចិត្ត និងក្រុមរបស់គាត់ជាប្រជាជនថ្មីត្រូវតាមដាន។ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារលេខ E1/289.1 ទំព័រ ២១។

[2688] បន្ថែមទៅលើ ចាន់ ធីម អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា វង សារុន បានផ្តល់សក្ខីកម្មថា គាត់បានដឹងថា គាត់ និងប្តីរបស់គាត់ ត្រូវបានតាមដាន ដោយសារពួកគាត់"ត្រូវបានចាត់ទុកថាក្នុងប្រភេទក្រោមវណ្ណៈកសិករធម្មតា" (សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ (វង សារុន) ឯកសារលេខ E1/300.1 ទំព័រ ៤៤-៤៥)។ ពុំមានភាពច្បាស់លាស់ថាតើ វង សារុន និងប្តីរបស់គាត់ ត្រូវបានចាត់ទុកថា ជា "ប្រជាជនថ្មី"។ លោកស្រីពុំបានយោងទៅលើខ្លួនឯង ឬប្តីរបស់គាត់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ប៊ុន សារឿន មានអារម្មណ៍ថា ត្រូវបានតាមដានជាប្រចាំ ប៉ុន្តែពុំបានពន្យល់បញ្ជាថាតើ ប៊ុន សារឿន គឺជាប្រជាជនថ្មី(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ (ប៊ុន សារឿន) ឯកសារលេខ E1/288.1 ទំព័រ ៣១)។ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ជាំង ស្រីមុំ បានប្រាប់អ្នកស៊ើបអង្កេតសហចៅក្រមស៊ើបអង្កេតថា ឈ្លបបានឃ្លាំមើលប្រជាជនថ្មី និងបានផ្តល់សក្ខីកម្មថា ប្រវត្តិរូប និងប្រវត្តិការងារត្រូវបានស្រាវជ្រាវ (សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ជាំង ស្រីមុំ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ E3/5832 ERN 00402468។ ប្រតិចារឹកថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ៤០-៤១។ ជាំង ស្រីមុំ បានប្រាប់អ្នកស៊ើបអង្កេតថា ឈ្លបបានតាមដានប្រជាជនថ្មី ប៉ុន្តែបានឆ្លើយផងដែរថា លោកស្រី និងប្តី(ទាំងពីរនាក់"ប្រជាជនបម្រុង") ត្រូវបានឈ្លបលួចស្តាប់ និងទំនងជាពុំត្រូវបានសួរសំណួរលើបញ្ហាថាតើប្រជាជនមូលដ្ឋានត្រូវបានតាមដានដែរ ឬយ៉ាងណា (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាំង ស្រីមុំ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ E3/5832 ERN 00402466 ទំព័រ ៤-៥ ។

ប៉ុន្តែស្តាប់មិនបានថា [គេនិយាយអ្វី]'"[2689]។ ទីពីរ"សំដៅទៅលើរបាយការណ៍ពីឃុំគុសអំពីប្រជាជនថ្មីម្នាក់ឈ្មោះ ម៉ី ម៉ុច ដែល"បានដេកមមើថា ដើម្បីបំពុលកុមារឱ្យងាប់អស់ គឺឱ្យថ្នាំដាក់ជាមួយនឹងដំឡូងមី [...] ក្នុងពេលមមើនោះ គឺយប់ប្រហែលម៉ោង ១១៖ មមើនិយាយពាក្យដដែលនេះ បីដងមួយរំពេច [...]។ សូម្បីតែសមាជិកថ្មីដូចគ្នាដែលនៅដេកជិតគ្នានោះ ក៏រៀងស្តាប់ឮច្បាស់អញ្ចឹងដែរ'"[2690]។ ទីបីពិពណ៌នាអំពីប្រជាជនមូលដ្ឋានដែលរាយការណ៍ពី"អ្នកមកស្នាក់នៅថ្មីនៅក្នុងឃុំថា គាត់"កាលពីសង្គមចាស់មានប្រវត្តិពាលាអាវ៉ាសែជាខ្លាំង' ដោយសារមូលហេតុដូច្នេះហើយ ឃុំបានស្នើថា តើ"បញ្ជូនឬយ៉ាងណា'"[2691]។ ទីបួន "ពិពណ៌នាអំពីអតីតទាហាន លន់ នល់ ម្នាក់ដែល'ឃោរឃៅណាស់តាមក្តាប់បានពីប្រជាជនថ្មីធ្លាប់ស្គាល់'"[2692]។ របាយការណ៍នេះគាំទ្រថា ប្រជាជនថ្មីត្រូវបានតាមដាន ប៉ុន្តែពុំបានបង្ហាញថា តើការតាមដានត្រូវបានកំណត់គោលដៅលើប្រជាជនថ្មី ដែរ ឬយ៉ាងណានោះទេ។

946. កថាខណ្ឌ ១០៨០ បានបង្ហាញថា "ភស្តុតាងជាឯកសារបញ្ជាក់ថា ប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនខ្មែរក្រោមជាពិសេសងាយទទួលរងការចាប់ខ្លួនសម្រាប់ការគិត សំដី ឬអំពើដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងបដិវត្តន៍"។ កថាខណ្ឌនេះយោងទៅលើ៖

ក. "របាយការណ៍ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ១៩៧៧ បានស្នើយោបល់មក"អង្គការជាទីគោរព" ចំពោះការដោះស្រាយបញ្ហាជាមួយប្រជាជនថ្មី បន្ទាប់មកសុំអង្គការសម្រេចថា តើមនុស្សនេះគួរត្រូវបញ្ជូនទៅ ឬយ៉ាងណា"[2693]។

ខ. "របាយការណ៍មកពីឃុំពេលផ្ញើជូនបក្សស្រុកចុះថ្ងៃទី ១១ ខែ មេសា កត់សម្គាល់ថា 'ចំពោះអ្នកមានបណ្តាស័ក្តិ យើងខ្ញុំនឹងបញ្ជូនជាបន្តបន្ទាប់ ហើយពួកទាហាន និងគ្រូខ្លះដែលមានសភាពបំផ្លាញ

[2689] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ៣៤៧១ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី១៣ ខែឧសភា [មិនបញ្ជាក់ឆ្នាំ] ឯកសារលេខ E3/8428 ERN 00271051។

[2690] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ៣៤៧១ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៧ ឯកសារលេខ E3/2441 ERN 00270961 ទំព័រ ២៩ ។

[2691] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/2048 ERN 00079087-00079088 ទំព័រ ១-២ ។

[2692] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៥៥ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី១២ ខែមីនា [មិនបញ្ជាក់ឆ្នាំ] ឯកសារលេខ E3/2441 ERN 00270947 ទំព័រ ១៥។

[2693] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨០ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/2048 ERN 00079087-00079088 ទំព័រ ១-២ ។

និងប្រឆាំងបដិវត្តន៍យើងសុំអង្គការឲ្យយោបល់ដែរ ឬឲ្យសម្រេចនៅតាមមូលដ្ឋានខ្លះ សុំបក្សឲ្យយោបល់។ ប្តេជ្ញាកម្ទេចចារកម្មខ្មាំងឲ្យអស់ដើម្បីធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមជូនបក្ស និងប្រជាជនដាច់ខាត’”[2694]

គ. “កំណត់ហេតុចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៧ ពីឃុំតាភេម រួមមានសេចក្តីណែនាំដែលចារឲ្យ“តាមដានពិនិត្យសិន ប្រជាជនថ្មី ឬចាស់’”[2695]

ឃ. “របាយការណ៍ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ពីឃុំខ្ពបត្របែកទៅអង្គការស្រុកត្រាំកក់ បានផ្តល់ព័ត៌មានអំពីមនុស្ស ០៤ នាក់“មានបណ្តាស័ក្តិ”ដែលត្រូវបានប្តូរទៅមូលដ្ឋានឃុំកាលពីថ្ងៃមុន”[2696] និង

ង. “របាយការណ៍ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ពីឃុំពពេលផ្ញើជូនអង្គការស្រុក បានបញ្ជាក់ថា ‘គ្រួសារទាហានដែលត្រូវអង្គការកម្ទេចនិងស្លាប់បាត់ ១០៦ គ្រួសារ មានចំនួន ៣៩៣ នាក់ [...] គ្រួសារទាហានដែលនៅមានចំនួន ២៣១ គ្រួសារ មានមនុស្សចំនួន ៨៩២ នាក់’”[2697]។

947. បញ្ហាថាតើ អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន ដែរ ឬយ៉ាងណា ត្រូវបានដោះស្រាយនៅក្នុងផ្នែកខាងលើ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងនេះពុំបានគាំទ្រលើការយល់ឃើញឱ្យហួសពីវិមតិសង្ស័យដែលថា ប្រជាជនថ្មីដែលពុំមែនជាអតីតទាហាន ឬអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់គោលដៅជាពិសេសសម្រាប់ការចាប់ខ្លួនដោយសារការគិត សំដី ឬអំពើដែលត្រូវបានចាត់ទុកថា ផ្ទុយទៅនឹងបដិវត្តន៍នោះទេ។ ភស្តុតាងនេះបង្ហាញថា បុគ្គលមួយប្រភេទជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិអំណាច ប៉ុន្តែពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ប្រជា

[2694] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨០ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី១១ ខែមេសា [ឆ្នាំ១៩៩៧] ឯកសារលេខ E3/4629 ERN 00079087។

[2695] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨០ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ ឯកសារលេខ E3/4107 ERN 00271016។

[2696] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨០ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/2050 ERN 00079111។

[2697] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨០ យោងទៅលើកំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារលេខ E3/2048 ERN 00079090។

ជនថ្មីត្រូវបានកំណត់គោលដៅជាពិសេសនោះឡើយ និងពុំបានបង្ហាញពីមូលហេតុដូចម្ដេចបានប្រជាជនថ្មីត្រូវបានចាប់ខ្លួន។

948. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានការបង្ហាញឱ្យហួសវិមតិសង្ស័យដែលថា លក្ខខណ្ឌការងារសម្រាប់ប្រជាជនថ្មីធ្ងន់ធ្ងរជាងលក្ខខណ្ឌសម្រាប់ប្រជាជនមូលដ្ឋាន លើកលែងតែការពិតដែលថា ប្រជាជនថ្មីពុំអាចកាន់តួនាទីដឹកនាំ ឬទទួលអត្ថប្រយោជន៍ពីលក្ខខណ្ឌការងារដែលមានជាប់ជាមួយនឹងតួនាទីនោះ និងថា ប្រជាជនថ្មីត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួនដោយសារការគិត សំដី ឬអំពើដែលត្រូវបានចាត់ទុកថាផ្ទុយទៅនឹងបដិវត្តន៍។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ប្រជាជនថ្មីបានទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាន និងថា លក្ខខណ្ឌការងារសម្រាប់ប្រជាជនថ្មីធ្ងន់ធ្ងរជាងប្រជាជនមូលដ្ឋានត្រង់ថា ប្រជាជនថ្មីពុំអាចកាន់តួនាទីនៃសិទ្ធិអំណាច និងពុំបានទទួលអត្ថប្រយោជន៍ពីលក្ខខណ្ឌការងារប្រសើរដែលមានជាប់ជាមួយនឹងតួនាទីនោះ និងថា ប្រជាជនថ្មីជាពិសេសបានទទួលរងការធ្វើបាបយ៉ាងលំបាកវេទនា។

949. អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំពើនៃការរើសអើងជាមូលដ្ឋាននៃការផ្ដល់អាហារឱ្យប្រជាជនថ្មីតិចជាង និងការរារាំងប្រជាជនថ្មីមិនឱ្យកាន់តួនាទីដឹកនាំ និងការដាក់ឱ្យប្រជាជនថ្មីស្ថិតក្រោមការ"ការធ្វើបាបយ៉ាងលំបាកវេទនា" រួមជាមួយនឹងការយល់ឃើញដែលពុំត្រូវបានជំទាស់នោះថា ប្រជាជនថ្មីត្រូវបានកំណត់ប្រភេទដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន ដាក់ឱ្យដាច់ដោយឡែកពីប្រជាជនមូលដ្ឋានក្នុងសហករណ៍ដាច់ដោយឡែក ឬក្រុមការងារដាច់ដោយឡែក និងត្រូវបានចាត់ទុកថាជាអ្នកនៅក្រោមបង្គាប់ប្រជាជនមូលដ្ឋាន ដែលទាំងអស់នេះមានលក្ខណៈគ្រប់គ្រាន់អាចបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលអាចស្មើនឹងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំពើជាមូលដ្ឋានទាំងនេះត្រូវបានពិចារណាជារួម និងតាមបរិបទ[2698]។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ផលវិបាកនៃការផ្ដល់អាហារឱ្យប្រជាជនថ្មីតិចជាងនោះ មានការជាប់ពាក់ព័ន្ធដូចជា៖ ប្រជាជនថ្មីជាពិសេសបានទទួលរងទុក្ខ និងស្លាប់ដោយសារការខ្វះអាហារ[2699]។ ដូចនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

iii. ការដ្ឋានទំនប់ត្រពាំងថ្ម

[2698] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៥៧។

[2699] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៧៧។

950. បន្ទាប់ពីការពិចារណាលើបទចោទ និងលក្ខណៈ និងភាពដែលអាចកំណត់អត្តសញ្ញាណនៃក្រុមគោលដៅ រួមទាំងអំណះអំណាងពាក់ព័ន្ធរបស់ភាគី[2700] អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំពើជាមូលដ្ឋានដែលចោទជាបញ្ហានេះថា ជាការដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្ត និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀត និងពាក់ព័ន្ធទៅនឹងប្រជាជនថ្មី ជាការដកសិទ្ធិទទួលបានតួនាទីដឹកនាំ[2701]។ គួរកត់សម្គាល់ផងដែរថា សត្រូវតាមការសន្មតមួយចំនួនត្រូវបានសម្លាប់តាមបទបញ្ជា[2702]។ អង្គជំនុំជម្រះសាលាដំបូងពិចារណាថា អំពើជាមូលដ្ឋានទាំងនេះគឺជាការរើសអើងជាក់ស្តែង និងត្រូវបានអនុវត្តដោយមានចេតនាជាក់លាក់ក្នុងការរើសអើងចំពោះក្រុមគោលដៅ[2703]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនេះរួមបញ្ចូលបទឧក្រិដ្ឋឯករាជ្យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើដែលខ្លួនឯងពុំចាំបាច់ជាបទឧក្រិដ្ឋ និងជឿជាក់ថា ដោយពិចារណាជារួម អំពើនេះឈានដល់កម្រិតធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[2704]។

951. ខៀវ សំផន បានលើកឡើងថា អំពើដែលជាមូលដ្ឋានគឺមានតែការដកសិទ្ធិប្រជាជនថ្មីមិនឱ្យកាន់កាប់តួនាទីដឹកនាំ និងការដាក់ឱ្យស្ថិតក្រោមការតាមដានរបស់ប្រជាជនមូលដ្ឋានប៉ុណ្ណោះ ដែលនេះពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា សិទ្ធិជាសារវ័ន្តណាមួយត្រូវបានរំលោភ ឬថា លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញ[2705]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សម ស័ក្ត តែម្នាក់ប៉ុណ្ណោះ និងបានបំភ្លៃភស្តុតាងនេះ[2706]។

952. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រុមដែលទទួលរងការធ្វើទុក្ខបុកម្នេញ គឺជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" និងបានបង្កើតការយល់ឃើញសមហេតុផលដែលថា សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានដាក់ឱ្យស្ថិតក្រោមការរើសអើង

---

[2700] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៣-១៤០៨។

[2701] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៩។

[2702] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៩។

[2703] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤១០-១៤១១។

[2704] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤១១-១៤១២។

[2705] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៣-៧៦៧។

[2706] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៥-៧៦៦។

ហើយការប្រព្រឹត្តទៅលើនោះបានរំលោភបំពានសិទ្ធិជាសារវ័ន្ត និងការរំលោភបំពាននេះបានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរដែលបំពេញតាមលក្ខខណ្ឌនៃធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ[2707]។

953. សហមេធាវីនាំមុខគាំទ្រអំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា និងបានឆ្លើយតបថា ខៀវ សំផន ខ្លួនឯងទៅវិញទេដែលបានបំភ្លៃសក្ខីកម្មរបស់ សម ស័ក្ត[2708] និងថា សម ស័ក្ត ពុំបានលើកឡើងថា ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីមានអារម្មណ៍ប្រហាក់ប្រហែលគ្នានៅការដ្ឋានធ្វើការ ប៉ុន្តែបានបញ្ជាក់ថា ប្រជាជនថ្មីមានអារម្មណ៍ឈឺចាប់ និងភ័យខ្លាច និងថា ការធ្វើបាបមកលើរូបគាត់ គឺដោយសារឋានៈរបស់គាត់ជាប្រជាជនថ្មី[2709]។ សហមេធាវីនាំមុខបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងអាចបង្កើតការយល់ឃើញមួយសមស្របដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ប៉ុន្តែក្នុងករណីនេះពុំបានធ្វើដូច្នោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រើប្រាស់ភស្តុតាងរបស់ សម ស័ក្ត ដើម្បីបញ្ជាក់បន្ថែមលើសាក្សីដទៃទៀត និងដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ព្រមទាំងភស្តុតាងជាឯកសារ[2710]។ សហមេធាវីនាំមុខបានបន្ថែមថា ខៀវ សំផន បានលើកពុំត្រឹមត្រូវថា អំពើជាមូលដ្ឋាននោះពាក់ព័ន្ធតែទៅនឹងការដកសិទ្ធិប្រជាជនថ្មីមិនឱ្យកាន់តួនាទីដឹកនាំប៉ុណ្ណោះ និងថា អង្គជំនុំជម្រះបានយល់ឃើញផងដែរថា ប្រជាជនថ្មីត្រូវបានកំណត់គោលដៅដើម្បីចាប់ខ្លួន និងសម្លាប់[2711]។

954. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានលើកឡើងពុំត្រឹមត្រូវថា ការយល់ឃើញដែលបានកំណត់ប្រភេទនៃការរើសអើង គឺមានតែការយល់ឃើញដែលថា ប្រជាជនថ្មីត្រូវបានដកសិទ្ធិមិនឱ្យកាន់តួនាទីដឹកនាំ និងការដាក់ប្រជាជនថ្មីស្ថិតក្រោមការតាមដានរបស់“ប្រជាជនចាស់”ប៉ុណ្ណោះ[2712]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រុមដែលត្រូវបានកំណត់គោលដៅថាជា“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា” មានលក្ខណៈទូលំទូលាយជាង ដែលនេះមិនមែនត្រឹមតែលើប្រជាជនថ្មីប៉ុណ្ណោះទេ[2713]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មេបញ្ជាការកងអនុសេនាធំ និង

---

[2707] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៣៥។

[2708] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៣៤។

[2709] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៣៥-៤៣៦។

[2710] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៣៧។

[2711] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៣៨។

[2712] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៣-៧៦៤។

[2713] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥០៧។

វរសេនាតូចត្រូវបានណែនាំឱ្យកំណត់អត្តសញ្ញាណ និងសម្លាប់សត្រូវពិត ឬតាមការសន្មត និងថា អ្នកធ្វើការខ្លះដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាខ្មាំង ត្រូវបានសម្លាប់ជាក់ស្តែងតាមបទបញ្ជា[2714]។

955. នៅក្នុងការរៀបរាប់នូវអំពើរើសអើងជាមូលដ្ឋាន ដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា "អ្នកដែលត្រូវបានចាត់ទុកថា ពុំបានប្រឹងប្រែងធ្វើការ ត្រូវបានបញ្ជូនទៅ'កងករណី'កន្លែងដែលពួកគេត្រូវបានតម្រូវឱ្យធ្វើការធ្ងន់ជាងបើធៀបនឹងអ្នកធ្វើការក្នុងកងធម្មតា"[2715]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំបានយល់ស្របថា ការយល់ឃើញនេះអាចត្រូវបានចាត់ទុកថា ជាអំពើរើសអើង ដោយសារពុំមានការយល់ឃើញថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ឬជាក់លាក់ជាងនេះទៅទៀត ប្រជាជនថ្មីត្រូវបានកំណត់គោលដៅបញ្ជូនទៅ"កងករណី"នេះទេ។ សក្ខីកម្មដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនេះ ទំនងជាពុំបង្ហាញនូវភាពខុសប្លែកគ្នារវាងប្រភេទបុគ្គលដែលត្រូវបានដាក់ក្នុងកងនោះឡើយ[2716]។

956. ក្នុងការបង្កើតការយល់ឃើញថា ប្រជាជនថ្មីត្រូវបានដកសិទ្ធិមិនឱ្យកាន់តួនាទីដឹកនាំ និងត្រូវបានដាក់ឱ្យស្ថិតក្រោមការតាមដានដោយ"ប្រជាជនចាស់" អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា សាក្សីទាំងអស់ដែលមានតួនាទីដឹកនាំ គឺជាប្រជាជនចាស់ និងបានសំអាងទៅលើសក្ខីកម្មរបស់ ឈុំ សេង, មុន មុត, សម

---

[2714] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៩។

[2715] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤០៩ យោងទៅលើ កថាខណ្ឌ ១២៦៨។

[2716] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៦៨ និងជើងទំព័រ ៤៣៣១ គាំទ្រការយល់ឃើញនេះថា៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ (ម៉ម សឿម) ឯកសារលេខ E1/324.1 ទំព័រ ៦៥-៦៦ (ពន្យល់ប្រាប់ថា អ្នកដែលត្រូវចាត់ទុកថា ក្បាលរឹង មិនសកម្ម ឬមានកំហុស នឹងត្រូវដាក់នៅក្នុងកងករណី "ត្រូវបានលុតដំ" ហើយធ្វើការធ្ងន់ជាងកងធម្មតា)។ ប្រតិចារឹក ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ (កាន ចុល) ឯកសារលេខ E1/328.1 ទំព័រ ៧ (ឆ្លើយតបជាវិជ្ជមានទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន ដែលសួរថា តើប្រជាជនដែលត្រូវបានចាត់តាំងជាកងករណីគឺប្រជាជន "ដែលមានបញ្ហាវិន័យ ដោយសារគាត់មិនធ្វើការឲ្យបានគ្រប់គ្រាន់ ហើយមិនគោរពវិន័យអី។")។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ (ឈុំ សេង) ឯកសារលេខ E1/332.1 ទំព័រ ៨-៩ (បញ្ជាក់ថា គាត់បានឮមានកងមួយដែលមានអ្នកមិនសូវខិតខំធ្វើការ និងអ្នកដែលតវ៉ាថា ពួកគេត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ ហើយមិនត្រូវបានផ្តល់អាហារគ្រប់គ្រាន់ គឺត្រូវបានដាក់ក្នុងកងពិសេសមួយដែលមានប្រធានឈ្មោះ ស្រេះ)។ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ (យី ឡៃស្រួ) ឯកសារលេខ E1/334.1 ទំព័រ ៣៥ (ផ្តល់សក្ខីកម្មថា កងករណីត្រូវបានបង្កើតឡើងសម្រាប់អ្នកដែលគេងប្រវញ្ចការងារអ្នកដទៃ)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ជៀប ឈាន ឯកសារលេខ E3/7805 ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ ទំព័រ ៣ ERN 00267744។

ស័ក្ត និង សែន សុផុន[2717]។ ក្នុងការបង្កើតការយល់ឃើញដែលថា មេបញ្ជាការកងអនុសេនាធំ និងកងវរសេនាតូច ត្រូវបានណែនាំឱ្យកំណត់អត្តសញ្ញាណ និងសម្លាប់សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានសំអាងជាចម្បងទៅលើសក្ខីកម្មរបស់ ឈុំ សេង[2718] ប៉ុន្តែបានកត់សម្គាល់ផងដែរថា ការសម្លាប់អ្នកធ្វើការដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាខ្មាំង គឺស្របតាមរបាយការណ៍ប្រចាំសប្តាហ៍ដែលបានរាយការណ៍ដោយតំបន់ ៥ ថា៖ "ចលនាបដិវត្តន៍សង្គមនិយម បានមានសម្ទុះខ្លាំងក្លា លឿនទៅមុខមួយកម្រិតថែមទៀត ដោយដំណើរការបានល្អ បានរីកចម្រើន កម្ចាត់ពួកខ្មាំងប្រឆាំងនឹងសង្គមនិយម ពង្រឹង និងពង្រីករបប និងទីតាំងសមូហភាព និងសង្គមនិយម ហើយបោសសម្អាត និងជីករម្លើងថែមទៀតនូវសំណល់ផ្សេងៗនៃវណ្ណៈនាយទុន និងវណ្ណៈជិះជាន់ផ្សេងៗទៀត ដែលនៅសេសសល់"[2719]។ ក្នុងការបង្កើតការយល់ឃើញថា អ្នកធ្វើការខ្លះដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាខ្មាំង ជាក់ស្តែងត្រូវបានសម្លាប់តាមបទបញ្ជា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ ឈុំ សេង, កាន ថុល និង តក់ ប៉ុយ[2720]។

957. ខៀវ សំផន បានត្រឹមតែជំទាស់ទៅនឹងសក្ខីកម្មរបស់ សម ស័ក្ត ប៉ុណ្ណោះ[2721]។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចបានអះអាងដោយ ខៀវ សំផន និងសូម្បីតែសក្ខីកម្មនេះពុំត្រូវបានពិចារណាក៏ដោយ ក៏ទំនងជាថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងគ្រប់គ្រាន់ដទៃទៀតក្នុងការគាំទ្រការយល់ឃើញរបស់ខ្លួន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះបានសំអាងទៅលើភស្តុតាងពុំគ្រប់គ្រាន់។

958. អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើការអះអាងរបស់ ខៀវ សំផន ដែលថា ពុំមានសិទ្ធិជាសារវ័ន្តណាមួយត្រូវបានរំលោភបំពាន និងថា លក្ខខណ្ឌនៃភាពធ្ងន់ធ្ងរដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ ពុំត្រូវ

[2717] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៤៥។

[2718] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៦២-១៣៦៣។

[2719] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ៤៦៧៣ ដកស្រង់សេចក្តីរាយការណ៍របស់គណៈកម្មាធិការតំបន់ ៥ ប្រចាំអាទិត្យ ឯកសារលេខ E3/178 ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧ ទំព័រ ១១ ERN 00275597 និង *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធន់ ធី ឯកសារលេខ E3/9157 ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ទំព័រ ៣០-៣១ ERN 00740202-03។

[2720] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៣៦៧។

[2721] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៤-៧៦៦។

បានបំពេញ[2722]។ អំណះអំណាងរបស់ ខៀវ សំផន បានផ្អែកលើការសន្និដ្ឋានពុំត្រឹមត្រូវដែលថា អំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញ គឺមានតែការដកសិទ្ធិប្រជាជនថ្មីមិនឱ្យកាន់តួនាទីដឹកនាំ និងការដាក់ឱ្យស្ថិតក្រោមការតាមដានប៉ុណ្ណោះ។ ដូចបានពន្យល់ខាងលើ នេះពុំមែនជាករណីសំខាន់នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញរួមបញ្ចូលអំពើដែលស្មើនឹងបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2723]។ អំពើដែលស្មើនឹងបទឧក្រិដ្ឋឯករាជ្យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត ជាចាំបាច់បានរំលោភបំពានលើសិទ្ធិជាសារវន្តរបស់មនុស្ស និងបំពេញតាមលក្ខខណ្ឌនៃភាពធ្ងន់ធ្ងរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

### iv. ការដ្ឋានទំនប់១មករា

959. បន្ទាប់ពីបានពិចារណាលើបទចោទ និងលក្ខណៈ និងភាពអាចកំណត់អត្តសញ្ញាណនៃក្រុមកំណត់គោលដៅ ព្រមទាំងអំណះអំណាងដែលពាក់ព័ន្ធរបស់ភាគី[2724] អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការពិចារណាផងដែរលើអំពើនៃការរើសអើងពាក់ព័ន្ធទៅនឹងប្រជាជនថ្មី។ អង្គជំនុំជម្រះបានចាត់ទុកអំពើជាមូលដ្ឋាននេះថាជាការដែល"ប្រជាជនថ្មីងាយនឹងត្រូវបានគេស្តីបន្ទោសជាង ចំពោះបទល្មើស ឬកំហុសនានា ហើយត្រូវបានរារាំងមិនឱ្យកាន់តួនាទីដឹកនាំ ដែលនេះធ្វើឱ្យស្ថានភាពពុំជាក់លាក់របស់ពួកគេកាន់តែធ្ងន់ធ្ងរ"[2725]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំពើទាំងនេះជាការរើសអើងជាក់ស្តែង[2726] និងបានយល់ឃើញថា លក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិត្រូវបានបំពេញដោយសារប្រជាជនថ្មីត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតឹងរ៉ឹង និងត្រូវបានគេស្តីបន្ទោសចំពោះបទល្មើសតូចតាច និងហានិភ័យនៃផលវិបាកអវិជ្ជមាន និងថា សារនេះបង្ហាញច្បាស់លាស់ថា មូលហេតុសម្រាប់ការប្រព្រឹត្តដោយរើសអើងនេះ គឺដោយសារសមាជិកភាពរបស់ពួកគេស្ថិតក្នុងក្រុមនោះ[2727]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាអំពើដែលជា

[2722] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៦៧។

[2723] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤១២។

[2724] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៥-១៦៨៧។

[2725] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៨។

[2726] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៨។

[2727] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៨។

មូលដ្ឋានពុំស្មើនឹងបទឧក្រិដ្ឋឯករាជ្យក៏ដោយ ក៏ការធ្វើទុក្ខបុកម្នេញត្រូវបានបង្ហាញមានអត្ថិភាពទាក់ទងទៅនឹងប្រជាជនថ្មី[2728]។

960. ទាក់ទងទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំពើជាមូលដ្ឋាននេះថា ជាការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួន និងបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ពួកគេបានទទួលរងការរើសអើងជាក់ស្តែង និងថា មានចេតនាជាក់លាក់ក្នុងការរើសអើងចំពោះពួកគេ[2729]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលត្រូវបានពិចារណាជារួម និងនៅក្នុងបរិបទនៃការប្រព្រឹត្តធ្ងន់ធ្ងរនោះ ឈានដល់កម្រិតធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[2730]។

- *ប្រជាជនថ្មី*

961. ខៀវ សំផន បានលើកឡើងថា (១) អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុ ដោយសារពុំមានការរើសអើងចំពោះប្រជាជនថ្មីនៅការដ្ឋានទំនប់១មករា[2731] (២) កំហុសអង្គច្បាប់ដោយគាត់បានអះអាងថា មានសិទ្ធិជាសារវន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា[2732] (៣) កំហុសអង្គច្បាប់ និងអង្គហេតុដោយសារបានយល់ឃើញថា ការប្រព្រឹត្តទៅលើនោះបានរំលោភបំពានលើសិទ្ធិជាសារវន្តរបស់ប្រជាជនថ្មីក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា[2733] និង (៤) កំហុសអង្គច្បាប់ដោយសារខកខានក្នុងការកំណត់អំពីកម្រិតភាពធ្ងន់ធ្ងរដែលចាំបាច់ត្រូវបំពេញសម្រាប់អំពើជាមូលដ្ឋានដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើទុក្ខបុកម្នេញ[2734]។

962. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ត្រឹមត្រូវថា មានការរើសអើងនៅការដ្ឋានទំនប់១មករា[2735] និងថា ខៀវ សំផន ខកខានក្នុងការពន្យល់ថាតើ ការសំដៅរបស់អង្គជំនុំជម្រះ

---

[2728] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៩។

[2729] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩០។

[2730] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩១។

[2731] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៨៨-៧៩៦។

[2732] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៩៧។

[2733] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៩៧។

[2734] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៩៧។

[2735] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨១៩។

សាលាដំបូងទៅលើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា បានធ្វើឱ្យសេចក្តីសម្រេចទៅជាមោឃៈដូចម្តេចឡើយ និងខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ឬអង្គហេតុក្នុងការយល់ឃើញថា ការប្រព្រឹត្តលើប្រជាជនថ្មីគឺជាការរំលោភបំពានលើសិទ្ធិជាសារវ័ន្ត និងខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តន៍លើលក្ខខណ្ឌនៃភាពធ្ងន់ធ្ងរសម្រាប់ការធ្វើទុក្ខបុកម្នេញ[2736]។ សហព្រះរាជអាជ្ញាបានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការធ្វើទុក្ខបុកម្នេញ ពុំបានផ្អែកទៅលើសិទ្ធិក្នុងការទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នានោះទេ ប៉ុន្តែបានផ្អែកទៅលើការរំលោភបំពានលើសិទ្ធិជាច្រើន[2737]។

963. ក្នុងការសម្រេចសេចក្តី អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងដែលពាក់ព័ន្ធទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា សិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា ត្រូវបានរំលោភបំពាន ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាលើប្រជាជនថ្មីនៅការដ្ឋានទំនប់១មករា បានរំលោភបំពានលើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា"[2738]។ អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ថាតើសិទ្ធិនេះមានអ្វីខ្លះ និងពុំបានពិនិត្យលើបញ្ហាថាតើ សិទ្ធិនេះមានអត្ថិភាពក្នុងកម្ពុជាក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែរ ឬយ៉ាងណា។ យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលពុំទាន់ចូលជាធរមានរហូតដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ និងពុំត្រូវបានចុះហត្ថលេខាដោយកម្ពុជារហូតដល់ឆ្នាំ ១៩៨០ សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នាសំដៅទៅលើសិទ្ធិរបស់បុគ្គលគ្រប់រូបទទួលបានសមភាពចំពោះមុខច្បាប់ និងទទួលបានការការពារស្មើភាពចំពោះមុខច្បាប់[2739]។ អង្គជំនុំជម្រះសាលាដំបូងពុំបានវិភាគលើបញ្ហាថាតើ ប្រជាជនថ្មី និងប្រជាជនមូលដ្ឋានត្រូវបានចាត់ទុកស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែរ ឬយ៉ាងណា និងពុំបានបង្កើតការយល់ឃើញពាក់ព័ន្ធបញ្ហានេះឡើយ។

964. អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[2740]ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា សិទ្ធិជាសារវ័ន្តដែលត្រូវបានរំលោភបំពាននោះរួមមានសិទ្ធិទទួល

[2736] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨២០។

[2737] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨២១។

[2738] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៨៩។

[2739] មាត្រា ១៤ និង ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

[2740] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨២១។ អំណះអំណាងនេះត្រូវបានគាំទ្រដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ *សូមមើល* សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៤៧។

បានការរស់រានមានជីវិត សេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ និងការគ្មានការចាប់ចងតាមអំពើចិត្ត ឬដោយខុសច្បាប់។ ការយល់ឃើញផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ បង្ហាញឱ្យឃើញនូវភាពខុសប្លែកគ្នារវាងប្រជាជនថ្មី និងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដូចខាងក្រោម៖

ក. កថាខណ្ឌ ១៦៨៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានកំណត់អំពើដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជាការរើសអើងជាក់ស្តែងចំពោះប្រជាជនថ្មី(ផ្នែកខ្លះនៃ*ធាតុផ្សំសត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញ។ អំពើសកម្ម ឬអកម្មនោះត្រូវតែជាការដកហូត ឬរំលោភបំពានលើសិទ្ធិជាសារវ័ន្តដែលមានចែងក្នុងច្បាប់សន្ធិសញ្ញាទំនៀមទម្លាប់អន្តរជាតិ) និងថា អំពើនោះត្រូវបានប្រព្រឹត្តដោយចេតនាក្នុងការរើសអើង(ធាតុផ្សំ*អត្តនោម័តិ*)។

ខ. កថាខណ្ឌ ១៦៨៩ បានបញ្ជាក់ថា ការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាលើប្រជាជនថ្មីនៅការដ្ឋានទំនប់១មករា បានរំលោភបំពានលើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា(ផ្នែកដែលនៅសេសសល់នៃលក្ខខណ្ឌតម្រូវធាតុផ្សំ*សត្យានុម័ត*សម្រាប់ការធ្វើទុក្ខបុកម្នេញ) និងបង្ហាញផងដែរនូវការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់អំពើដែលឈានដល់កម្រិតនៃការធ្វើទុក្ខបុកម្នេញ។ អង្គជំនុំជម្រះបានបង្កើតការយល់ឃើញថា "បើទោះបីជាអំពើដែលបានរកឃើញខាងលើ ថាជាការរើសអើងចំពោះប្រជាជនថ្មីដោយខ្លួនឯងផ្ទាល់ ពុំអាចស្មើទៅនឹងបទឧក្រិដ្ឋឯករាជ្យក៏ដោយ ក៏អំពើសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញត្រូវបានបង្ហាញថា មានអត្ថិភាពទាក់ទងទៅនឹងប្រជាជនថ្មី"ដែរ។

គ. កថាខណ្ឌ ១៦៩០ បានកំណត់អំពើដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជាការរើសអើងជាក់ស្តែងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ(ផ្នែកខ្លះនៃធាតុផ្សំ*សត្យានុម័ត*នៃការធ្វើទុក្ខបុកម្នេញ) និងយល់ឃើញថា មានចេតនារើសអើងចំពោះប្រជាជនថ្មី (ធាតុផ្សំ*អត្តនោម័តិ*)។

ឃ. កថាខណ្ឌ ១៦៩១ រៀបរាប់សិទ្ធិជាសារវ័ន្តដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ត្រូវបានរំលោភបំពាន(ផ្នែកសេសសល់នៃលក្ខខណ្ឌតម្រូវធាតុផ្សំ*សត្យានុម័ត* សម្រាប់ការធ្វើទុក្ខបុកម្នេញ) និងមានការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់អំពើដែលឈានដល់កម្រិតនៃការធ្វើទុក្ខបុកម្នេញ។

965. កថាខណ្ឌ ១៦៩១ មានលក្ខណៈពុំសូវច្បាស់លាស់ក្នុងការយល់ឃើញថា "អំពើដែលត្រូវបានប្រព្រឹត្តឡើងចំពោះក្រុមនៃអ្នកធ្វើការទាំងនេះបានរំលោភបំពានលើសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការរស់រានមានជីវិត សេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ និងការគ្មានការចាប់ចងតាមអំពើចិត្ត ឬដោយខុសច្បាប់ ..."[2741]។ ដោយពិចារណាលើភាពខុសប្លែកគ្នារវាងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងលើធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញទាក់ទងទៅនឹងប្រជាជនថ្មី និងការវិភាគលើធាតុផ្សំទាក់ទងទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងការយល់ឃើញក្នុងកថាខណ្ឌ ១៦៨៩ ដែលថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញត្រូវបានបំពេញនៅមុនការយល់ឃើញរបស់ខ្លួនក្នុងកថាខណ្ឌ ១៦៩១ ពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិទទួលបានការរស់រានមានជីវិត សេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ និងការគ្មានការចាប់ចងតាមអំពើចិត្ត ឬដោយខុសច្បាប់ អង្គជំនុំជម្រះតុលាការកំពូលបកស្រាយថា "ក្រុមនៃអ្នកធ្វើការទាំងនេះ" គឺចង់សំដៅលើទៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

966. ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា សិទ្ធិជាសារវ័ន្តក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នាដូចដែលមានចែងក្នុងច្បាប់សន្ធិសញ្ញាទំនៀមទម្លាប់អន្តរជាតិ ត្រូវបានរំលោភបំពាន អង្គជំនុំជម្រះតុលាការកំពូលទទួលយកទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងបដិសេធការសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មីនៅការដ្ឋានទំនប់១មករា ។ អំណះអំណាងសេសសល់ដទៃទៀតពាក់ព័ន្ធនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះពុំចាំបាច់ធ្វើការពិចារណាបន្ថែមទៀតឡើយ។

- *អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ*

967. ខៀវ សំផន បានលើកឡើងថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ ពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា (១) មានការកំណត់អត្តសញ្ញាណលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់គោលបំណងនៃការចាប់ខ្លួន (២) ឪពុករបស់ ហ៊ុន សិត្ថានី ត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួន និង (៣) អតីតទាហានមួយក្រុមត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួន[2742]។ គាត់បានអះអាងថា ក្នុងការបង្ហាញថា មានការចាប់ខ្លួនបានកើតឡើងជាក់ស្តែងនៅការដ្ឋានទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញមួយដែលថា មានការចងក្រងបញ្ជីឈ្មោះនៅតាមស្រុក និងតំបន់ ដើម្បីកំណត់

---

[2741] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩១ (ការបញ្ជាក់បន្ថែម)។

[2742] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៩៨។

អត្តសញ្ញាណទាហានក្នុងការចាប់ខ្លួននោះ[2743]។ គាត់បានលើកឡើងថា សក្ខីកម្មរបស់ ហ៊ុន សិត្ថានី គឺជាភស្តុតាងតែមួយគត់នៃការចាប់ខ្លួនឪពុករបស់គាត់ដោយសារមូលហេតុនយោបាយ និងថា គាត់ បានស្តាប់ឮរឿងនេះពីបងប្អូនរបស់គាត់។ ខៀវ សំផន បានបន្ថែមថា នេះមានលក្ខណៈពុំគ្រប់គ្រាន់សម្រាប់ការយល់ឃើញអំពីគោលនយោបាយកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅការដ្ឋានទំនប់១មករា[2744]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើសក្ខីកម្មរបស់ អ៊ុត សេង ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួនអតីតទាហាន លន់ នល់ មួយក្រុម ដោយសារគាត់ត្រឹមតែបានឃើញផ្ទាល់អ្នកធ្វើការពីរឬបីនាក់ត្រូវបាននាំចេញទៅ និងពុំដឹងថា នរណាជាអ្នកនាំចេញទៅឡើយ[2745]។ ខៀវ សំផន បានអះអាងថា ផ្នែកសេសសល់នៃសក្ខីកម្មរបស់ អ៊ុត សេង ស្តីពីប្រធានបទនេះ គឺជាពាក្យចចាមអារ៉ាម និងការប៉ាន់ស្មាន[2746]។

968. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មសំខាន់ពីរ៖ សក្ខីកម្មរបស់ ប្រាក់ យុត ដែលថា លោកស្រី និងលេខាស្រុកដទៃទៀត បានបង្កើតបញ្ជីឈ្មោះអតីតទាហាន លន់ នល់ និងសក្ខីកម្មរបស់ ឱ ហូ ដែលថា មានការកំណត់អត្តសញ្ញាណនិងចាប់ខ្លួនអតីតអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ[2747]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមថា មានការកំណត់ត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើភស្តុតាងចចាមអារ៉ាមដែលពុំមានការបញ្ជាក់បន្ថែម ដរាបណាអង្គជំនុំជម្រះបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើភស្តុតាងនេះដោយមានការប្រុងប្រយ័ត្ន និងបានសំអាងទៅលើបន្ទាប់ពីបានពិចារណាជារួមជាមួយនឹងសក្ខីកម្មដទៃទៀត[2748]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើគោលការណ៍ទូទៅនៃការរើសអើងប្រឆាំងនឹងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ក្នុងការបង្ហាញអត្ថិភាពនៃការរើសអើងនៅការដ្ឋានធ្វើការទំនប់១មករា ប៉ុន្តែផ្ទុយទៅវិញបានបង្ហាញដោយផ្អែកទៅ

---

[2743] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៩៩។

[2744] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០០-៨០១។

[2745] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០២។

[2746] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០២។

[2747] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៣៩។

[2748] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៤០-៤៤២។

លើសក្ខីកម្មរបស់សាក្សីថា ការរើសអើងបានកើតឡើងនៅការដ្ឋានទំនប់១មករា និងបានកំណត់ថា ការរើសអើងនេះគឺជាផ្នែកនៃគោលនយោបាយទូទៅប្រឆាំងនឹងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ[2749]។

969. សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ប៉ុន្តែបានដាក់សារណាជាក់លាក់ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ ហ៊ុន សិត្ថានី[2750]ថា ទិដ្ឋភាពសំខាន់នៃសក្ខីកម្មរបស់ ហ៊ុន សិត្ថានី ពុំមែនជាពាក្យចចាមអារ៉ាម និងថា លោកស្រីបានផ្តល់ភស្តុតាងផ្ទាល់ថា ឪពុករបស់លោកស្រីដែលធ្លាប់មានទំនាក់ទំនងជាមួយនឹងរបបចាស់ និងបានប្រឆាំងខ្មែរក្រហម ត្រូវបានធ្វើឱ្យបាត់ខ្លួន និងពុំដែលឃើញត្រឡប់មកវិញ និងថា នៅមុនពេលការបាត់ខ្លួននោះ ឪពុកលោកស្រីមានការភ័យខ្លាចចំពោះអ្វីដែលខ្មែរក្រហមនឹងធ្វើមកលើរូបគាត់ និងគ្រួសាររបស់គាត់[2751]។ សហមេធាវីនាំមុខបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យសំអាងទៅលើភស្តុតាងដទៃទៀតរបស់លោកស្រី បើទោះបីជាពាក្យចចាមអារ៉ាមក៏ដោយ និងថា លោកស្រីបានរៀបរាប់ប្រភពព័ត៌មានជាច្រើន និងស៊ីសង្វាក់គ្នា[2752]។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើសក្ខីកម្មរបស់ ហ៊ុន សិត្ថានី តែម្នាក់ប៉ុណ្ណោះសម្រាប់ការយល់ឃើញថា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅនៅការដ្ឋានទំនប់១មករា និងភស្តុតាងរបស់គាត់ត្រូវបានគាំទ្រដោយសាក្សីដទៃទៀតផងដែរ[2753]។

970. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងសមស្របទៅលើភស្តុតាងក្រៅវិសាលភាពនៃពេលវេលា ឬភូមិសាស្ត្រនៃរឿងក្តីដើម្បីបង្ហាញតាមរយៈការយោងនូវធាតុផ្សំនៃអំពើល្មើស[2754]។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញពីដំបូងរបស់ខ្លួនដែលថា អតីត

---

[2749] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៤៣។

[2750] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៩៤។

[2751] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៩៧។

[2752] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៩៨-៤០០។

[2753] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤០១។

[2754] សាលដីការឿងក្តី*Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ៣១៥ (យោងទៅលើភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា)។ សាលក្រមរឿងក្តី*Taylor* (SCSL) កថាខណ្ឌ ១០១ (យោងទៅលើវភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា), កថាខណ្ឌ ១១០ (យោងទៅលើវភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការភូមិសាស្ត្រ)។ សេចក្តីសម្រេចរឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) ទំព័រ ៩ (យោងទៅលើភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គជំនុំជម្រះសាលាដំបូង (ICC) សំណុំរឿងលេខ ICC-01/04-01/06 សាលក្រមស្របតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ១០២២-១០២៣ (យោងទៅលើភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា)។

ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានចាត់ទុកជាខ្មាំង និងត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន និងជាញឹកញាប់ត្រូវបានធ្វើឱ្យបាត់ខ្លួន[2755]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើទីតាំងដែលនៅជុំវិញការដ្ឋានទំនប់១មករា និងបានយល់ឃើញថា មានការកំណត់អត្តសញ្ញាណនៃទាហាន លន់ នល់ ដែលមានឋានៈខ្ពស់តាមរយៈការចងក្រងបញ្ជីឈ្មោះនៅកម្រិតថ្នាក់ស្រុក និងតំបន់សម្រាប់គោលបំណងចាប់ខ្លួនពួកគេ[2756]។ ទាក់ទងទៅនឹងការដ្ឋានទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មពីរ៖ មួយរបស់ ហ៊ុន សិត្ថានី ដែលបានផ្តល់សក្ខីកម្មថា ឪពុករបស់គាត់អតីតគ្រូបង្រៀន ត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួន និងមួយទៀតរបស់ អ៊ុត សេង ដែលបានផ្តល់សក្ខីកម្មថា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរមួយក្រុមត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួន[2757]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើសក្ខីកម្មពីរជាក់លាក់ពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់១មករាក៏ដោយ ក៏សក្ខីកម្មនេះអាចត្រូវបានពិចារណាសមស្របរួមជាមួយនឹងការយល់ឃើញដទៃទៀតក្នុងការសន្និដ្ឋានថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនត្រឹមតែត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួនក្នុងហេតុការណ៍ពីរករណីប៉ុណ្ណោះទេ ថែមទាំងបង្កើតបានជាការអនុវត្តន៍ទូទៅ។

971. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់ អ៊ុត សេង ឬ ហ៊ុន សិត្ថានី។ អង្គជំនុំជម្រះសាលាដំបូង ដោយមានការប្រុងប្រយ័ត្ន អាចសំអាងទៅលើពាក្យចចាមអារ៉ាមក្នុងការបង្ហាញនូវធាតុផ្សំនៃបទឧក្រិដ្ឋណាមួយ[2758]។ បន្ថែមលើនេះ សក្ខីកម្មរបស់ ហ៊ុន សិត្ថានី ដែលពាក់ព័ន្ធទៅនឹងការចាប់ខ្លួនឪពុករបស់គាត់ គឺជាពាក្យចចាមអារ៉ាម ប៉ុន្តែសក្ខីកម្មរបស់គាត់ដែលថា ឪពុករបស់គាត់គឺជាអតីតគ្រូបង្រៀនដែលប្រឆាំងនឹងរបបខ្មែរក្រហម និងថា គាត់ត្រូវបានធ្វើឱ្យបាត់ខ្លួន និងថា លោកស្រីពុំដែលឃើញឪពុកខ្លួនម្តងទៀតនោះ ពុំមែនជាពាក្យចចាមអារ៉ាមឡើយ[2759]។ បន្ថែមលើសក្ខីកម្មរបស់គាត់ដែលជាពាក្យចចាមអារ៉ាម អ៊ុត សេង បានផ្តល់សក្ខីកម្មថា គាត់បានឃើញដោយផ្ទាល់អ្នកធ្វើការនៅការដ្ឋាននោះពីរទៅបីនាក់ត្រូវបាននាំចេញទៅ ដែលគាត់ជឿថា ពួកគេមាន

---

[2755] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦០។

[2756] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦០-១៦៦១។

[2757] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៦២-១៦៦៣។

[2758] សាលដីកាសំណុំរឿង 00២/0១ (F36) កថាខណ្ឌ ៣0២។

[2759] ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារលេខ E1/306.1 ទំព័រ ១៤, ២៥-២៦។

ទំនាក់ទំនងជាមួយនឹងរបបចាស់[2760]។ សក្ខីកម្មទាំងនេះរួមជាមួយនឹងភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ នៅទីកន្លែងដែលស្ថិតនៅជុំវិញការដ្ឋានទំនប់១មករានោះដែលមានការកំណត់អត្តសញ្ញាណទាហានលន់ នល់ ដែលមានឋានៈខ្ពស់តាមរយៈការចងក្រងបញ្ជីឈ្មោះនៅកម្រិតថ្នាក់ស្រុក និងតំបន់សម្រាប់គោលបំណងនៃការចាប់ខ្លួនពួកគេ អាចនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយសមហេតុផលថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានចាប់ខ្លួន និងត្រូវបានធ្វើឱ្យបាត់ខ្លួននៅការដ្ឋានទំនប់១មករា។ អំណះអំណាងនេះត្រូវបដិសេធចោល។

### v. មន្ទីរសន្តិសុខស-២១

972. បន្ទាប់ពីបានពិចារណាលើបទចោទ និងលក្ខណៈ និងភាពអាចកំណត់អត្តសញ្ញាណបាននៃក្រុមកំណត់គោលដៅ[2761] អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំពើជាមូលដ្ឋានដែលរងការចោទប្រកាន់នេះថា ជាការចាប់ខ្លួន ការឃុំឃាំងក្នុងលក្ខខណ្ឌដ៏អាក្រក់ ការសួរយកចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់អ្នកដែលត្រូវបានឆ្លើយដាក់ថា ជាសមាជិកនៃខ្សែរយៈខ្មាំង[2762]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អំពើទាំងនេះគឺជាការរើសអើងជាក់ស្តែង និងត្រូវបានប្រព្រឹត្តឡើងដោយចេតនាក្នុងការរើសអើងចំពោះក្រុមគោលដៅ ដោយសារអ្នកទាំងនោះដែលត្រូវបានចាប់ខ្លួន និងឃុំឃាំង ត្រូវបានសន្មតថា ជាសត្រូវខាងក្រៅ ឬផ្ទៃក្នុង និងបានទទួលរងការចាប់ខ្លួន ការឃុំឃាំង លក្ខខណ្ឌនៃការរស់នៅធ្ងន់ធ្ងរ ការធ្វើទារុណកម្ម និងការសម្លាប់ដោយសារផលវិបាកផ្ទាល់នៃឋានៈតាមការសន្មតថា ជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា[2763]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានបង្ហាញ ដោយសារការយល់ឃើញរបស់ខ្លួនបានបង្ហាញថា មានគោលនយោបាយកំណត់គោលដៅលើសត្រូវនយោបាយតាមការសន្មត និងត្រូវបានផ្សព្វផ្សាយជាប្រព័ន្ធ[2764]។ អង្គជំនុំជម្រះ

---

[2760] ប្រតិចារិក ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ (អ៊ុត សេង) ឯកសារលេខ E1/308.1 ទំព័រ ៨២។ ប្រតិចារិក ថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ២០១៥ (អ៊ុត សេង) ឯកសារលេខ E1/309.1 ទំព័រ ៦-៧។

[2761] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៩៨-២៦០០។

[2762] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០១។

[2763] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០២។

[2764] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០២។

សាលាដំបូងបានកត់សម្គាល់ថា អំពើដែលចោទជាបញ្ហានេះអាចស្មើនឹងបទឧក្រិដ្ឋឯករាជ្យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូច្នេះអំពើនេះឈានដល់កម្រិតធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញ[2765]។

973. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើដែលកំណត់គោលដៅលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" គឺជាការរើសអើងជាក់ស្តែង ដោយសារវិសាលភាពធំធេងនៃការចាប់ខ្លួនបានបង្ហាញថា ជាការចាប់ខ្លួនដោយមិនរើសមុខ[2766]។ គាត់បានកត់សម្គាល់ថា ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ពុំមានលក្ខណៈវិនិច្ឆ័យលើភាពអាចកំណត់បាន ដែលត្រូវបានអនុវត្តក្នុងការកំណត់គោលដៅលើជនរងគ្រោះ។ គាត់បានអះអាងថា ភស្តុតាងក្នុងសំណុំរឿង ០០២/០២ ពុំបានបង្ហាញអ្វីថ្មីដែលអាចគាំទ្រការយល់ឃើញមួយផ្សេងក្នុងរឿងក្តីនេះឡើយ[2767]។

974. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការចាប់ខ្លួនក្នុងទ្រង់ទ្រាយធំពុំមែនមានន័យថា ក្រុមមួយពុំត្រូវបានកំណត់គោលដៅនោះទេ។ ចំនួនមនុស្សដែលត្រូវបានកំណត់គោលដៅពុំអាចកំណត់បានថាតើ អ្នកទាំងនោះគឺជាកម្មវត្ថុនៃការរើសអើងឡើយ[2768]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានបំភ្លៃយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ និងថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ដរាបណាសត្រូវនយោបាយត្រូវបានកំណត់អត្តសញ្ញាណផ្អែកលើគោលនយោបាយដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅប្រភេទណាមួយនោះ ខណៈពេលដែលសមាជិកដទៃទៀតនៃក្រុមមនុស្សនោះទទួលបានសេរីភាពក្នុងកម្រិតមួយ នេះបង្ហាញថា មានមូលដ្ឋានក្នុងការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ"[2769]។

975. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ការពិតដែលថា ប្រជាជនត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ ពុំបានរារាំងដល់ការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយឡើយ ដរាបណាសមាជិកនៃក្រុមកំណត់គោលដៅនោះត្រូវបានចាប់ខ្លួន ពីព្រោះពួកគេស្ថិតក្នុងក្រុម

[2765] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៣។

[2766] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២៦។

[2767] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២៦-៨២៧។

[2768] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤៧។

[2769] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៤៨។

គោលដៅ។ ក្នុងរឿងក្តី ០០១ អង្គជំនុំជម្រះតុលាការកំពូលពុំបានបញ្ជាក់ថា ការចាប់ខ្លួនក្នុងទ្រង់ទ្រាយធំបានបង្ហាញថា ជនរងគ្រោះ"ត្រូវបានកំណត់គោលដៅដោយពុំរើសមុខ" និងដូច្នេះពុំមែនជាការធ្វើទុក្ខបុកម្នេញនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា៖

> ជាសរុប ដើម្បីឱ្យមានការធ្វើទុក្ខបុកម្នេញ ចាំបាច់ត្រូវតែមានអំពើសកម្ម ឬអកម្មដែលរើសអើងជាក់ស្តែង និងរើសអើងប្រឆាំងនឹងក្រុមជាក់លាក់ណាមួយដែលបានកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យណាមួយ។ ផ្ទុយទៅវិញ មិនមានការរើសអើងជាក់ស្តែងនោះទេ នៅពេលដែល ១) នៅក្នុងអង្គហេតុ ចារីមានការភាន់ច្រលំលើជនរងគ្រោះដោយមិនដឹងថា តើជនរងគ្រោះពិតជាស្ថិតនៅក្នុងក្រុមគោលដៅដែលត្រូវបានកំណត់ដោយអត្តនោម័តិ ដែរ ឬយ៉ាងណា ឬ ២) ចារីបានកំណត់គោលដៅជនរងគ្រោះដោយមិនគិតថា តើជនរងគ្រោះស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យនៃការរើសអើង ដែរ ឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅពេលដែលចារីកំណត់គោលដៅដោយមិនរើសមុខ[2770]។

976. អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់បន្ថែមទៀតថា៖

> នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ "ដំណើរការបោសសម្អាតខ្មាំងរបស់អង្គការបានធ្វើឱ្យបុគ្គលមួយចំនួនមានការភ័យខ្លាចមិនទុកចិត្តគ្នា និងកាប់សម្លាប់គ្នាពេញផ្ទៃប្រទេស" នៅពេលដែល"មជ្ឈិមបក្សបានចាប់ផ្តើមសង្ស័យថា មានខ្មាំងនៅគ្រប់ទីកន្លែង និងចាប់ផ្តើមព្រួយបារម្ភចំពោះខ្មាំងខាងក្នុងជាងខ្មាំងខាងក្រៅ"។ បុគ្គលទាំងឡាយត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានរកឃើញថា មានទោស"ដោយគ្រាន់តែត្រូវបានគេចោទប្រកាន់ធម្មតាប៉ុណ្ណោះ"។ ផ្អែកទៅលើអង្គហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាថា ដោយខ្មាំងនយោបាយត្រូវបានកំណត់តាមគោលនយោបាយមួយដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅ នៅខណៈដែលប្រជាជនដ៏ទៃទៀតទទួលបានសេរីភាព ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការយល់ឃើញថា មានអំពីធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[2771]។

977. ការបដិសេធរបស់អង្គជំនុំជម្រះតុលាការកំពូលនូវការដាក់ពិរុទ្ធភាពនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងសំណុំរឿង ០០១ បានសំដៅជាក់លាក់លើ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា កាំង ហ្កេចអ៊ាវ *ហៅ* ឌុច ពុំបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅណាមួយក្នុងការកំណត់ខ្មាំងនយោបាយ ដោយសារ"បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយសារមូលហេតុនយោបាយនោះទេ" និង

---

[2770] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៧៧។

[2771] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៨២។

"ជនជាប់ចោទបានដឹងថា អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស ២១ មិនមែនសុទ្ធតែជាខ្មាំងរបស់បក្សនោះទេ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អ្នកជាប់ឃុំឃាំងទាំងអស់នោះ ត្រូវបានឃុំខ្លួន សួរចម្លើយ និងសម្លាប់" និង"នៅក្នុងសកម្មភាពល្មើសរបស់ខ្លួន ជនជាប់ចោទបានធ្វើបាបដោយចេតនាលើអ្នកដែលមិនស្ថិតក្នុងប្រភេទបុគ្គលដែលត្រូវធ្វើទុក្ខបុកម្នេញនោះទេ ការដែលជនជាប់ចោទធ្វើដូច្នេះ គឺមិនមែនដើម្បីរើសអើងប្រឆាំងនឹងសត្រូវនយោបាយទេ ប៉ុន្តែគឺដើម្បីបង្ហាញឱ្យបក្សឃើញអំពីភាពស្មោះស្ម័គ្រ និងប្រសិទ្ធភាពនៃការងាររបស់ខ្លួន"[2772]។

978. ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញថា ខៀវ សំផន បានដឹងថា កាំង ហ្គេចអ៊ាវ *ហៅ* ឌុច ពុំបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅក្នុងការកំណត់សត្រូវនយោបាយ ប៉ុន្តែផ្ទុយទៅវិញបានធ្វើបាបបើទោះដឹងថា បុគ្គលនោះពុំត្រូវបានចាត់ទុកជាសត្រូវនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការផ្តោតនៃកិច្ចប្រតិបត្តិការមន្ទីរសន្តិសុខស-២១ គឺមានគោលដៅប្រឆាំងនឹងសត្រូវពិត ឬសត្រូវនយោបាយតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" និងថា "អ្នកដែលត្រូវបានចាប់ខ្លួន ឃុំឃាំង សួរយកចម្លើយ ធ្វើទារុណកម្ម និងចុងក្រោយត្រូវបានសម្លាប់នៅមន្ទីរស-២១ ត្រូវបានកំណត់អត្តសញ្ញាណ និងចាប់ខ្លួនដោយផ្អែកលើការពិតថា ពួកគេត្រូវកំណត់ថា ជាខ្មាំង ជនក្បត់ ឬគិញ និងត្រូវបានសន្មតថា ជាសត្រូវនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងបដិវត្តន៍"[2773]។ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើនោះជាការរើសអើងឡើយ។ អំណះអំណាងនេះត្រូវបដិសេធចោល។

### vi. មន្ទីរសន្តិសុខអូរកន្សែង

979. បន្ទាប់ពីបានពិចារណាលើបទចោទ និងលក្ខណៈ និងភាពអាចកំណត់អត្តសញ្ញាណបាននៃក្រុមកំណត់គោលដៅ ព្រមទាំងអំណះអំណាងពាក់ព័ន្ធរបស់ភាគី[2774] អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកអំពើមូលដ្ឋានដែលចោទជាបញ្ហានេះថាជាការចាប់ខ្លួន ការឃុំឃាំង និងការដាក់ក្រុមគោលដៅឱ្យស្ថិតក្រោមការធ្វើបាប

---

[2772] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៨៣។

[2773] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០១។

[2774] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨០-២៩៨៣។

និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀតដែលបណ្តាលឱ្យមានការទទួលរងទុក្ខផ្នែករូបកាយ និងផ្លូវចិត្ត និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[2775]។

980. អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ក្រោមការធ្វើបាប និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរនៃជនជាតិចាវ៉ាយយ៉ាងតិច ១០០ នាក់ ថា ជាអំពើរើសអើងដែលត្រូវបានប្រព្រឹត្តឡើងដោយសារឋានៈរបស់ពួកជាសត្រូវតាមការសន្មត[2776]។ អង្គជំនុំជម្រះបានពិចារណាថា ការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើបាប សាក្សី ផន ថុល និង មឿង ចាន់ឌី គឺដោយសារឋានៈជាសត្រូវតាមការសន្មត[2777]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការចាប់ខ្លួន ការឃុំខ្លួន ការដាក់ឱ្យស្ថិតក្រោមការអប់រំកែប្រែ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សនូវអ្នកជាប់ឃុំយោធា គឺជាការរើសអើងដែលបានប្រព្រឹត្តដោយសារឋានៈរបស់ពួកគេជាសត្រូវតាមការសន្មត[2778]។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា *ធាតុផ្សំសត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយត្រូវបានបំពេញ[2779] និងថា ធាតុផ្សំអត្តនោម័តិត្រូវបានបំពេញ ដោយបានពិចារណាលើការផ្សព្វផ្សាយជាប្រព័ន្ធនូវគោលនយោបាយកំណត់គោលដៅសត្រូវនយោបាយតាមការសន្មត ដែលបណ្តាលឱ្យមានការ"វាយប្រហារជារួម"លើជនស៊ីវិល និងបុគ្គលិកយោធានៅមន្ទីរសន្តិសុខ និងការដកដោយចេតនានូវសិទ្ធិរបស់ពួកគេនោះ[2780]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនេះបានរួមបញ្ចូលបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើដែលខ្លួនឯងផ្ទាល់ពុំចាំបាច់ជាបទឧក្រិដ្ឋ និងបានជឿជាក់ថា នៅពេលពិចារណាជារួម អំពើនេះឈានដល់កម្រិតធ្ងន់ធ្ងរបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[2781]។

981. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិចាវ៉ាយ ១០០ នាក់, ផន ថុល និង មឿង ចាន់ឌី និងអ្នកជាប់ឃុំជាយោធាត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាប និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា របបនៃការឃុំខ្លួនមានលក្ខណៈខុសប្លែកគ្នាចំពោះអ្នកទោសកម្រិតធ្ងន់ និងស្រាល ស្ត្រី និងកុមារ។ ភាពខុសប្លែកគ្នាក្នុងការដាក់ទោស

---

2775 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៤, ២៩៩០។

2776 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៦។

2777 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៧-២៩៨៨។

2778 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៩-២៩៩០។

2779 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩០។

2780 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩០។

2781 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩២។

នេះបានផ្តែកយ៉ាងច្រើនទៅលើលក្ខណៈនៃទោស ជាជាងលើមូលហេតុនយោបាយ[2782]។ ទាក់ទងទៅនឹងជនជាតិចារ៉ាយ ១០០ នាក់នោះ ខៀវ សំផន បានអះអាងថា ការដាក់ក្នុងលក្ខខណ្ឌណែនតាន់តាប់ដែលពួកគេបានទទួលរងនោះ គឺដោយសារការពិតថា អាគារនៅអូរកន្សែងនោះ ពុំត្រូវបានធ្វើឡើងសម្រាប់ដាក់មនុស្សច្រើនក្នុងពេលតែមួយនោះទេ និងថា ពុំមានភស្តុតាងបង្ហាញថា ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាបជាក់លាក់ណាមួយ និងថា ពួកគេពុំមែនជាអ្នកជាប់ឃុំតែមួយគត់ដែលត្រូវបានសម្លាប់នោះទេ ដូច្នេះ ពុំមានភស្តុតាងបង្ហាញថា ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌធ្ងន់ធ្ងរជាងអ្នកដទៃឡើយ[2783]។ គាត់បានអះអាងថា ផន ចុល ពុំបានទទួលរងការធ្វើបាបធ្ងន់ធ្ងរជាងគេនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការអប់រំកែប្រែ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ប៉ុន្តែបានយល់ឃើញផងដែរថា ការអប់រំកែប្រែគឺសម្រាប់បុគ្គលទាំងអស់ដែលត្រូវបានចោទប្រកាន់អំពីទោសស្រាលបំផុតទូទាំងប្រទេស និងសក្ខីកម្មរបស់គាត់ជាក់ស្តែងបានបង្ហាញថា គាត់បានទទួលរងលក្ខខណ្ឌស្រាលជាងអ្នកជាប់ឃុំដទៃទៀត[2784]។ គាត់បានអះអាងថា មឿង ចាន់ឌី បានទទួលរងលក្ខខណ្ឌដូចអ្នកដទៃទៀត[2785]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់មូលហេតុដូចម្តេចបានជាអ្នកជាប់ឃុំជាយោធា ទទួលរងលក្ខខណ្ឌធ្ងន់ធ្ងរជាអ្នកជាប់ឃុំដទៃនោះ[2786]។

982. សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងអំពីលក្ខខណ្ឌឃុំខ្លួនដែលខុសៗគ្នាអាស្រ័យលើថាតើ អ្នកជាប់ឃុំមានទោសធ្ងន់ ស្រាល ជាស្ត្រី ឬកុមារ ដែរ ឬយ៉ាងណា ពុំបានអើពើលើការដែលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រុមកំណត់គោលដៅ គឺងាយនឹងទទួលរងការចាប់ខ្លួនដោយសារតែជាសមាជិកនៃក្រុមនោះ[2787]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមថា សមាជិកនៃក្រុមគោលដៅបានទទួលរងការធ្វើបាប និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃទៀតដោយសារការឃុំខ្លួនពួកគេនៅមន្ទីរសន្តិសុខនោះ[2788]។

---

[2782] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៤។

[2783] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៥។

[2784] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៦។

[2785] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៧។

[2786] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៨។

[2787] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៨៤។

[2788] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៨៤។

983. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ គឺជាការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ក្រុមគោលដៅនោះឱ្យស្ថិតក្រោមការធ្វើបាប និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងប្រជាជនដទៃ[2789]។ ខៀវ សំផន បានកម្រិតអំណះអំណាងរបស់ខ្លួនត្រឹមបញ្ហាថាតើ សមាជិកនៃក្រុមដែលបានកំណត់គោលដៅនោះត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាប ឬលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរ ដែរ ឬយ៉ាងណា ប៉ុន្តែពុំបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ក្រុមគោលដៅនោះត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយសារមូលហេតុនៃការរើសអើង ដូចជាដោយសារជាសមាជិកនៃក្រុមគោលដៅឡើយ។

984. ខៀវ សំផន បានលើកឡើងថា លក្ខខណ្ឌរស់នៅ និងការធ្វើការរបស់ក្រុមកំណត់គោលដៅត្រូវបានវាយតម្លៃដោយប្រៀបធៀបជាមួយនឹងអ្នកជាប់ឃុំដទៃទៀតនៅអូរត្រកួន ដែលពុំមែនជាសមាជិកនៃក្រុមកំណត់គោលដៅ ខណៈពេលសហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើលក្ខខណ្ឌរស់នៅ និងការធ្វើការរបស់ក្រុមកំណត់គោលដៅដោយធៀបនឹងអ្នកដែលពុំបានជាប់ឃុំ។ ភាគីពុំបានផ្តល់ការគាំទ្រលើជំហររបស់ខ្លួនចំពោះបញ្ហាថាតើ ក្រុមមួយណាត្រូវធ្វើការប្រៀបធៀបនោះ ហើយអង្គជំនុំជម្រះសាលាដំបូងក៏ពុំបានពន្យល់នូវមូលហេតុដូចម្តេចដែលអង្គជំនុំជម្រះបានធ្វើការប្រៀបធៀបនូវការប្រព្រឹត្តទៅលើក្រុមគោលដៅជាមួយនឹងប្រជាជនដទៃទៀត ជាជាងអ្នកជាប់ឃុំដូចគ្នានោះដែរ[2790]។

985. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ប្រសិនបើអ្នកជាប់ឃុំទាំងអស់នៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានឃុំឃាំងនៅទីនោះដោយសារពួកគេត្រូវបានចាត់ទុកថា ជាសមាជិកនៃក្រុមកំណត់គោលដៅ ដូចនេះលក្ខខណ្ឌរបស់ពួកគេគប្បីពិចារណាធៀបនឹងអ្នកដែលពុំបានជាប់ឃុំ ដោយសារការឃុំខ្លួនតែលើក្រុមកំណត់គោលដៅបង្ហាញថា ប្រព័ន្ធទាំងមូលនៃការឃុំខ្លួនត្រូវបានកំណត់គោលដៅតែលើពួកគេប៉ុណ្ណោះ។ ម្យ៉ាងវិញ

---

[2789] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩០។

[2790] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៨៤:

អង្គជំនុំជម្រះរកឃើញករណីជាច្រើនដែលប្រជាជនបានទទួលរងការធ្វើបាប និងដាក់ឲ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត ហើយត្រូវបានចាប់ខ្លួនយកទៅអប់រំ។ [...] អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំជាជនស៊ីវិលនិងកងទ័ពបានទទួលរងការឈឺចាប់លើផ្លូវចិត្ត និងរូបកាយ ហើយនឹងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ពួកគេ ដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារមូលហេតុនៃលក្ខខណ្ឌនៃការរស់នៅ លក្ខខណ្ឌការងារ និងលក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរសន្តិសុខនេះ។ [...]។ អង្គជំនុំជម្រះជឿជាក់ថា ជនជាតិចាវ៉ាយនិងជនជាប់ឃុំផ្សេងទៀតនៅមន្ទីរសន្តិសុខអូរកន្សែងបានទទួលរងនូវការធ្វើបាបនិងដាក់ឲ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត នៅពេលពួកគេជាប់ឃុំនៅមន្ទីរសន្តិសុខអូរកន្សែង។

ទៀត ប្រសិនបើចំនួនអ្នកដែលជាប់ឃុំនៅមន្ទីរសន្តិសុខអូរកន្សែងនោះបានរួមបញ្ចូលទាំងអ្នកដែលពុំត្រូវបានចាត់ទុកថា ជាសមាជិកនៃក្រុមកំណត់គោលដៅនោះ លក្ខខណ្ឌរបស់ក្រុមកំណត់គោលដៅគប្បីពិចារណាធៀបនឹងអ្នកជាប់ឃុំជាមួយគ្នានៅមន្ទីរសន្តិសុខនោះ។ នេះគឺដោយសារលក្ខខណ្ឌនៃក្រុមកំណត់គោលដៅត្រូវតែបានកំណត់ទៅលើតែក្រុមនេះ ដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ។ ប្រសិនបើលក្ខខណ្ឌនៃការប្រព្រឹត្តនោះគ្រាន់តែជាលទ្ធផលនៃការឃុំខ្លួន និងក្នុងការឃុំខ្លួន សមាជិកនៃក្រុមកំណត់គោលដៅត្រូវបានផ្តល់លក្ខខណ្ឌដូចគ្នាទៅនឹងអ្នកដែលពុំមែនជាសមាជិកនៃក្រុមនោះ ដូចនេះលក្ខខណ្ឌនៃការប្រព្រឹត្តទៅលើនោះពុំអាចត្រូវបានពិចារណាថា កំណត់គោលដៅតែទៅលើក្រុមនោះឡើយ។

986. អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញជាក់លាក់ទាក់ទងទៅនឹងបញ្ហាថាតើ អ្នកជាប់ឃុំទាំងអស់នៅអូរកន្សែង គឺជាសមាជិកនៃក្រុមកំណត់គោលដៅថា “សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា”នោះឡើយ ប៉ុន្តែទំនងជាយ៉ាងហោចណាស់ជាដំបូងថា ចំនួនអ្នកដែលជាប់ឃុំនោះបានរួមបញ្ចូលសមាជិកនៃក្រុមកំណត់គោលដៅ និងអ្នកដែលពុំមែនជាសមាជិក ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “អូរកន្សែងពីដើមឡើយគឺជាមន្ទីរសម្រាប់ឃុំខ្លួន និងការអប់រំកែប្រែសម្រាប់ទាហានកងពល ៨០១ ដែលត្រូវបានបញ្ជូនមកសម្រាប់ធ្វើការកែប្រែដោយសារកំហុសតូចតាច។ ទាហានដែលធ្វើខុសវិន័យ និងត្រូវបានសង្ស័យថា ខ្មាំងផ្ទៃក្នុង ត្រូវបានអប់រំកែប្រែតាមរយៈការបណ្តុះបណ្តាលមនោគមវិជ្ជា ឬការពង្រឹងមាគ៌ាបក្ស”[2791]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការធ្វើបាប និងលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរនៃក្រុមកំណត់គោលដៅនៅមន្ទីរសន្តិសុខអូរកន្សែងត្រូវតែបានធៀបជាមួយនឹងលក្ខខណ្ឌនៃអ្នកជាប់ឃុំដូចគ្នាដទៃទៀតនៅវត្តអូរកន្សែង ជាជាងធៀបជាមួយនឹងប្រជាជនទូទៅនោះ។

987. អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា សមាជិកនៃក្រុមកំណត់គោលដៅត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើបាប ឬលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងអ្នកដទៃនៅអូរកន្សែង លើកលែងតែជនជាតិចារ៉ាយ ១០០ នាក់នោះ ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ត្រូវបានឃុំខ្លួនជាពិសេសក្នុងលក្ខខណ្ឌណែនតាន់តាប់[2792]។ លក្ខខណ្ឌទាំងនេះត្រូវបានពន្យល់ថាកើតឡើងដោយសារអសមត្ថភាពរបស់មន្ទីរអូរកន្សែងក្នុងការដាក់អ្នកជាប់ឃុំដែលបានបញ្ជូនមកយ៉ាងគំហុក[2793] និងថា នេះពុំមែនជាលក្ខខណ្ឌដែលបានដាក់ទៅលើជនជាតិចារ៉ាយ ដោយសារពួកគេត្រូវបានចាត់ទុកថា ជាសត្រូវនោះទេ។ អង្គជំនុំជម្រះសាលាដំបូងពុំបាន

---

[2791] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៨៥។

[2792] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៣៩, ២៩៨៦។

[2793] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៣៩។

ចាត់ទុកការសម្លាប់ជនជាតិចាវ៉ាយថា ជាអំពើមូលដ្ឋាននៃការរើសអើង និងពុំបានយោងទៅលើការសម្លាប់នេះនៅពេលធ្វើការពិចារណាលើលក្ខខណ្ឌធ្ងន់ធ្ងររបស់ជនជាតិចាវ៉ាយឡើយ។ ដោយសារសមាជិកនៃក្រុមកំណត់គោលដៅពុំត្រូវបានកំណត់គោលដៅសម្រាប់លក្ខខណ្ឌធ្ងន់ធ្ងរជាងអ្នកជាប់ឃុំដទៃទៀតនៅអូរកន្សែង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការដាក់ក្រុមកំណត់គោលដៅឱ្យស្ថិតក្រោមការធ្វើបាប ឬលក្ខខណ្ឌរស់នៅធ្ងន់ធ្ងរជាងនោះគឺជាអំពើរើសអើង។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើរើសអើងផ្សេងទៀតនៃការចាប់ខ្លួន និងការឃុំឃាំងសមាជិកនៃក្រុមកំណត់គោលដៅ មានលក្ខណៈគ្រប់គ្រាន់ឈានដល់កម្រិតនៃការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ៣. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា

### ក. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើជនជាតិចាម

988. យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា វិសាលភាពនៃបទចោទទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាបានរួមបញ្ចូលអង្គហេតុពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរទូទាំងប្រទេសពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[2794]។

989. អង្គជំនុំជម្រះសាលាដំបូងបានធ្វើតការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាជាពីរផ្នែកក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង៖ ទីមួយពាក់ព័ន្ធជាក់លាក់ទៅនឹងការប្រព្រឹត្តលើជនជាតិចាមនៅការដ្ឋានទំនប់១មករា[2795] និងទីពីរទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាមទូទៅ[2796]
។

990. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នកធ្វើការជនជាតិចាមនៅការដ្ឋានទំនប់១មករាបានទទួលរងការរើសអើង ពីព្រោះពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ត្រូវបានហាមឃាត់ការអធិដ្ឋាន និងហាមឃាត់ការនិយាយភាសាកំណើតរបស់ខ្លួន[2797]។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា ការរឹតត្បិតនេះ

---

[2794] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៨៤(vi)។

[2795] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១១.២.២៤.៤។

[2796] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.២.១០.៦។

[2797] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៥។

មានលក្ខណៈរើសអើងជាក់ស្តែង និងត្រូវបានប្រព្រឹត្តដោយចេតនាក្នុងការរើសអើងលើជនជាតិចាមដោយសារមូលហេតុនៃការប្រតិបត្តិសាសនា និងវប្បធម៌[2798]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលត្រូវបានប្រព្រឹត្តឡើងលើជនជាតិចាមនៅការដ្ឋានទំនប់១មករា បានរំលោភបំពានលើសិទ្ធិសេរីភាពជាសារវ័ន្តខាងសាសនា និងថា ការរឹតត្បិតនេះពុំមានភាពចាំបាច់នៅក្នុងការការពារសុវត្ថិភាព សណ្តាប់ធ្នាប់សុខភាពសាធារណៈ សីលធម៌ ឬសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃឡើយ[2799]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា បើទោះបីជាការធ្វើទុក្ខបុកម្នេញពុំអាចឈានដល់កម្រិតនៃបទឧក្រិដ្ឋឯករាជ្យក៏ដោយ ក៏នៅពេលពិចារណាជារួម និងក្នុងបរិបទដែលអំពើនោះត្រូវបានប្រព្រឹត្តឡើង គឺស្ថិតក្នុងកម្រិតនៃភាពធ្ងន់ធ្ងរដែលបង្កើតបានការធ្វើទុក្ខបុកម្នេញដែលជាបទឧក្រិដ្ឋមួយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2800]។

991. ក្នុងការកំណត់ថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាត្រូវបានប្រព្រឹត្តឡើងលើជនជាតិចាមជាទូទៅ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់លើការយល់ឃើញពីមុនៗរបស់ខ្លួនថា៖

ក. ជនជាតិចាមនៅការដ្ឋានទំនប់១មករាបានទទួលរងការរើសអើង ដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ត្រូវបានហាមឃាត់ការអធិដ្ឋាន និងហាមឃាត់ការនិយាយភាសាដើមកំណើតរបស់ខ្លួន។

ខ. បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយកំណត់គោលដៅជាក់លាក់លើជនជាតិចាមដែលជាក្រុមសាសនា និងជាតិពន្ធុ និងបានធ្វើការរឹតត្បិតលើការប្រតិបត្តិផ្នែកសាសនា និងវប្បធម៌នៅតាមទីកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជាពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និង

គ. ការរឹតត្បិតទាំងនេះបានរួមបញ្ចូលការហាមឃាត់លើការអធិដ្ឋានរៀងរាល់ថ្ងៃ បង្ខិតបង្ខំឱ្យជនជាតិចាមបរិភោគសាច់ជ្រូក និងស្លៀកសម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ និងបង្ខំឱ្យនិយាយតែភាសាខ្មែរ និងដុតបំផ្លាញគម្ពីរអាល់គូរ៉អាន និងរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងពុំពាក់ព័ន្ធនឹងសាសនា[2801]។

---

[2798] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៥។

[2799] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៦។

[2800] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៦។

[2801] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៨។

992. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការរឹតត្បិតទាំងនេះលើជនជាតិចាមមានលក្ខណៈរើសអើងជាក់ស្តែង និងត្រូវបានប្រព្រឹត្តឡើងដោយចេតនាដើម្បីរើសអើងប្រឆាំងនឹងជនជាតិចាមដោយសារការប្រតិបត្តិផ្នែកសាសនា និងវប្បធម៌[2802]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលត្រូវបានប្រព្រឹត្តឡើងលើជនជាតិចាម"បានរំលោភបំពានលើសិទ្ធិសេរីភាពជាសារវន្តពាក់ព័ន្ធទៅនឹងការដើរហើរ និងសេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ ការគ្មានការចាប់ចងតាមអំពើចិត្ត ឬដោយខុសច្បាប់ ការជំនុំជម្រះជាសាធារណៈ និងត្រឹមត្រូវ និងសមភាពចំពោះមុខច្បាប់ដូចមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[2803]។

993. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញរួមមានអំពើដែលត្រូវបានយល់ឃើញដាច់ដោយឡែក អាចស្មើនឹងបទឧក្រិដ្ឋកងករាជ្យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើដែលខ្លួនឯងផ្ទាល់ពុំចាំបាច់ស្មើទៅនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[2804]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា អំពើទាំងនោះជារួមឈានដល់កម្រិតតម្រូវនៃភាពធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា[2805]។

i. អំពើធ្វើទុក្ខបុកម្នេញ

994. មុនពេលចាប់ផ្តើមពិនិត្យលើការជំទាស់របស់ ខៀវ សំផន ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាជាដំបូងអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ត្រូវបំភ្លឺលក្ខណៈនៃអំពើធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានេះ ដោយសារអង្គជំនុំជម្រះកត់សម្គាល់ថា ភាគីបានជំទាស់ទៅនឹងលក្ខណៈនៃអំពើដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ដែលបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូង។

995. ខៀវ សំផន បានលើកឡើងថា អំពើធ្វើទុក្ខបុកម្នេញ គឺជាការរឹតត្បិតលើការប្រតិបត្តិខាងសាសនា និងវប្បធម៌ដែលត្រូវបានគូសបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌ ៣៣២៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង *ដូចជា* ការបង្ខំឱ្យបរិភោគសាច់ជ្រូក ការហាមឃាត់ការអធិដ្ឋានរៀងរាល់ថ្ងៃ ការហាមឃាត់ការនិយាយភាសាដើមកំណើតរបស់ពួកគេ ការបង្ខំឱ្យស្លៀកសម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជន

---

[2802] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៩។

[2803] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣០។

[2804] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣១។

[2805] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣១។

ខ្មែរ ការដុតបំផ្លាញគម្ពីរអាល់គូរ៉អាន និងការរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងពុំមែនសាសនា[2806]។

996. ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញា[2807] និងសហមេធាវីនាំមុខ[2808] បានឆ្លើយតបថា អំពើដែលត្រូវបានចោទប្រកាន់ថា ការធ្វើទុក្ខបុកម្នេញរួមបញ្ចូល"អំពើ *ទាំងអស់* ដែលត្រូវបានប្រព្រឹត្តឡើងទូទាំងប្រទេសពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ"[2809] និងរួមបញ្ចូលអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងផ្លាស់ទីដោយបង្ខំដែលជាអំពើអមនុស្សធម៌ដទៃទៀត[2810]។

997. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា "អំពើជាក់លាក់ដែលស្មើនឹងការធ្វើទុក្ខបុកម្នេញត្រូវតែបានចោទប្រកាន់ច្បាស់លាស់"[2811]។ កថាខណ្ឌ ១៤២០ នៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ស្តីពីការយល់ឃើញផ្នែកអង្គច្បាប់នៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើជនជាតិចាម ពុំបានបញ្ជាក់ច្បាស់លាស់ថាជាក់ស្តែងមានអំពើនៃការធ្វើទុក្ខបុកម្នេញអ្វីខ្លះដែលចោទជាបញ្ហានោះ។ កថាខណ្ឌនោះបានលើកឡើងថា៖

> ធាតុផ្សំនៃបទឧក្រិដ្ឋធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើជនជាតិចាម ត្រូវបានបង្ហាញ(*សូមមើល* ផ្នែកពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តទៅលើ**ជនជាតិចាម" ដំណាក់កាលទីពីរនៃការផ្លាស់ទីប្រជាជន និង"ទំនប់១មករា**")។ មានការគាបសង្កត់ទូទាំងប្រទេសលើវប្បធម៌ប្រពៃណី និងភាសាជនជាតិចាម។ បក្សកុម្មុយនីស្តកម្ពុជាបានហាមឃាត់ការប្រតិបត្តិសាសនាអ៊ីស្លាម និងមិនអនុញ្ញាតឱ្យជនជាតិចាមអធិដ្ឋាន និងរឹបអូស និងដុតបំផ្លាញគម្ពីរអាល់គូរ៉អាន បិទ ឬបំផ្លាញវិហារអ៊ីស្លាម និងបង្ខំឱ្យប្រជាជនចាមបរិភោគសាច់ជ្រូក។ មេដឹកនាំសាសនា និងអ្នកសិក្សាសាសនាអ៊ីស្លាមត្រូវបានចាប់ខ្លួន និងសម្លាប់។ ស្ត្រីជនជាតិចាមត្រូវបានបង្ខំឱ្យកាត់សក់ខ្លី និងហាមឃាត់មិនឱ្យគ្របក្បាល។ សហគមន៍ជនជាតិចាមត្រូវបានបំបែកបំបាក់ និងប្រជាជនចាមត្រូវបានផ្លាស់ទីដោយបង្ខំទូទាំងប្រទេសកម្ពុជា និងបែងចែកតាមសហគមន៍ដទៃទៀត[2812]។

---

[2806] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៦៣។

[2807] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៨។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧០ និងជើងទំព័រ ១៧១២។

[2808] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៦១, ៤៦៦។

[2809] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៨។

[2810] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧០ និងជើងទំព័រ ១៧១២, កថាខណ្ឌ ៥៣៤។

[2811] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៦។

[2812] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២០ (សេចក្តីបញ្ជាក់ដើម)។

998. បើទោះបីជាកថាខណ្ឌនេះបានសំដៅទៅលើការចាប់ខ្លួន និងការសម្លាប់មេដឹកនាំសាសនា និងអ្នកសិក្សាសាសនាអ៊ីស្លាមក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់ឱ្យហួសពីវិមតិសង្ស័យថា នេះបានកើតឡើងក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនទៅជំនុំជម្រះដែរ[2813]។ កថាខណ្ឌនេះពុំបានសំដៅទៅលើការសម្លាប់ជនជាតិចាម ការធ្វើទារុណកម្ម ឬការដាក់ក្នុងមន្ទីរឃុំឃាំង ប៉ុន្តែប្រហែលជាចង់យោងឧក្រិដ្ឋកម្មទាំងនេះនៅក្នុងផ្នែកស្តីពី“‘ការប្រព្រឹត្តទៅលើជនជាតិចាម’ដំណាក់កាលទីពីរនៃការផ្លាស់ទីប្រជាជន និង ‘ទំនប់១មករា’”។

999. ទាក់ទងទៅនឹងការដ្ឋានទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងទំនងជាបានពិចារណាច្បាស់លាស់ថា អំពើនៃការធ្វើទុក្ខបុកម្នេញដែលចោទបញ្ហានេះ គឺជាការបង្ខំឱ្យបរិភោគសាច់ជ្រូក និងការហាមឃាត់ការអធិដ្ឋាន និងហាមឃាត់ការនិយាយភាសាដើមកំណើតចាម[2814]។ ទាំងនេះគឺជាអំពើដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដីកាដំណោះស្រាយបានចោទប្រកាន់ និងបានយល់ឃើញថា អំពើនេះបានបង្កឱ្យជនជាតិចាមទទួលរងការរើសអើង[2815]។ អង្គជំនុំជម្រះបានយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញនេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់អ្នកធ្វើការជនជាតិចាមក្នុងការទទួលបានសេរីភាពខាងសាសនា[2816] ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អំពើនេះ“ពុំអាចស្មើនឹងបទឧក្រិដ្ឋឯករាជ្យឡើយ”[2817]។

1000. ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមជាទូទៅ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់ថាតើ ជាក់ស្តែងមានអំពើនៃការធ្វើទុក្ខបុកម្នេញអ្វីខ្លះនោះ។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់បទចោទក្នុងដីកាដំណោះស្រាយដែលថា៖

> អំពើដែលបានចោទប្រកាន់ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាលើប្រជាជនចាម រួមមាន ការគាបសង្កត់លើវប្បធម៌ ទំនៀមទម្លាប់ និងភាសារបស់ជនជាតិចាម។ យោងតាមការចោទប្រកាន់ ប.ក.ក. បានហាមឃាត់ការប្រតិបត្តិសាសនាអ៊ីស្លាម ការហាមឃាត់ជនជាតិចាមមិនឱ្យអធិដ្ឋាន ការរីបអូស និងការដុតគម្ពីរអាល់គូរ៉អាន ការបិទ ឬការបំផ្លាញវិហារអ៊ីស្លាម និងការបង្ខំប្រជាជនចាមឱ្យបរិភោគសាច់ជ្រូក។ មានការចោទប្រកាន់បន្ថែមទៀតថា មេដឹកនាំសាសនា និងអ្នកចេះដឹងអ៊ីស្លាមត្រូវបាន

---

[2813] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣៧។

[2814] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៥។

[2815] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៣, ១៦៩៥។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ជាក់លាក់ថា ដីកាដំណោះស្រាយចោទប្រកាន់ការរឹតត្បិតភាសាចាម បើទោះបីជាដីកាដំណោះស្រាយបានចោទក៏ដោយ។

[2816] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៦។

[2817] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៦។

ចាប់ខ្លួន និងសម្លាប់ចោល ហើយស្ត្រីជនជាតិចាមត្រូវបានបង្ខំឱ្យកាត់សក់ខ្លី និងត្រូវបានហាមឃាត់មិនឱ្យទទូរកន្សែង ឬស្បៃនោះឡើយ។ លើសពីនេះទៀត មានការចោទប្រកាន់ផងដែរថា សហគមន៍ចាមត្រូវបានបំបែក ជនជាតិចាមត្រូវបានផ្លាស់ទីលំនៅដោយបង្ខំនៅទូទាំងប្រទេសកម្ពុជា និងបានបំបែកនៅតាមសហគមន៍ផ្សេងៗទៀត[2818]។

បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ឃើញរបស់ខ្លួនដែលថា ជនជាតិចាមបានទទួលរងការរើសអើងនៅការដ្ឋានទំនប់១មករា ដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងត្រូវបានហាមឃាត់ការអធិដ្ឋាន ឬនិយាយភាសាដើមកំណើតរបស់ខ្លួន និងថា៖

> បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយជាក់លាក់ដោយកំណត់គោលដៅលើប្រជាជនចាមថា ជាក្រុមជាតិពន្ធុនិងក្រុមសាសនាដាច់ដោយឡែក ហើយបានរឹតត្បិតលើការប្រតិបត្តិសាសនា និងការអនុវត្តទំនៀមទម្លាប់ វប្បធម៌របស់ជនជាតិចាមនៅស្រុកក្រូចឆ្មារនៅតាមទីតាំងជាច្រើននៅភូមិភាគកណ្តាល(ឧត្តរចាស់) និងនៅតាមកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការហាមឃាត់នេះរួមមានការហាមឃាត់ការអធិដ្ឋានជារៀងរាល់ថ្ងៃ ការបង្ខំជនជាតិចាមឲ្យបរិភោគសាច់ជ្រូក និងការឲ្យស្លៀកពាក់សម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការបង្ខំឱ្យពួកគេនិយាយតែភាសាខ្មែរ ការដុតគម្ពីរអាល់គូរ៉អាន និងការរុះរើវិហារអ៊ីស្លាម ឬប្រើសម្រាប់គោលបំណងផ្សេងក្រៅពីការអធិដ្ឋាន។ អ្នកដែលប្រឆាំងនឹងត្រូវចាប់ខ្លួន និង/ឬយកទៅសម្លាប់។ អង្គជំនុំជម្រះសាលាដំបូងរកមិនឃើញថា ការហាមឃាត់បែបនេះត្រូវបានអនុញ្ញាតនោះឡើយ[2819]។

ការផ្តោតរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ក្នុងដីកាដំណោះស្រាយ និងក្នុងការយល់ឃើញរបស់ខ្លួនបង្ហាញថា ទាំងនេះគឺជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា ជាអំពើនៃការធ្វើទុក្ខបុកម្នេញ ចំណែកឯការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា "អ្នកដែលប្រឆាំងត្រូវបានចាប់ខ្លួន និង/ឬសម្លាប់"អាចបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការចាប់ខ្លួន និងការសម្លាប់ស្មើនឹងអំពើនៃការធ្វើទុក្ខបុកម្នេញផងដែរ[2820]។

---

[2818] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៧ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២០។

[2819] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៨។

[2820] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៨។

1001.បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពានតាមរយៈអំពើនៃការធ្វើទុក្ខបុកម្នេញដូចជា៖ "សិទ្ធិជាសាវ័ន្ត និងសេរីភាពទាក់ទងទៅនឹងការដើរហើរ សេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ ការគ្មានការចាប់ចងតាមអំពើចិត្ត ឬដោយខុសច្បាប់ ការជំនុំជម្រះជាសាធារណៈ និងត្រឹមត្រូវ និងសមភាពចំពោះមុខច្បាប់"[2821]។ អង្គជំនុំជម្រះសាលាដំបូងពុំបានរៀបរាប់សិទ្ធិទទួលបានការរស់រានមានជីវិត ឬការគ្មានការធ្វើទារុណកម្ម ដែលនេះអាចបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា អំពើនៃការធ្វើទុក្ខបុកម្នេញ គឺជាការរឹតត្បិតផ្នែកសាសនា និងប្រពៃណី និងការដកចេញដោយបង្ខំដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនៅពេលពិភាក្សាអំពីដីកាដំណោះស្រាយ ជាជាងបទឧក្រិដ្ឋដទៃទៀតដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្មជាដើម។ គួរឱ្យងឿងឆ្ងល់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានរៀបរាប់នូវសេរីភាពនៃសាសនាដែលជាសិទ្ធិសាវ័ន្ត និងត្រូវបានរំលោភបំពាន ដូចការដែលអង្គជំនុំជម្រះបានធ្វើឡើងទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនានៅការដ្ឋានទំនប់១មករា។

1002.ទោះជាយ៉ាងណាក្តី នៅក្នុងការវាយតម្លៃលើបញ្ហាថាតើ អំពើនោះឈានដល់កម្រិតតម្រូវនៃភាពធ្ងន់ធ្ងរដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញ បានរួមបញ្ចូលអំពើដែលត្រូវបានរកឃើញថា ស្មើនឹងបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(រួមទាំង អំពីមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងអំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី២ (រួមទាំង ការធ្វើទារុណកម្ម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការផ្លាស់ទីលំនៅដោយបង្ខំ) ព្រមទាំងអំពើដែលមិនចាំបាច់ស្មើនឹងបទឧក្រិដ្ឋផងដែរ (ជាពិសេស ការចាប់ខ្លួន)[2822]។

1003.ការបាត់សញ្ញាណវង់ក្រចកម្ខាងនៅក្នុងការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងខាងលើបានធ្វើឱ្យមានការមិនច្បាស់លាស់ថាតើ បទឧក្រិដ្ឋពិតប្រាកដណាខ្លះដែលអង្គជំនុំជម្រះសាលាដំបូងចង់សំដៅទៅលើនោះ។ ចំណុចដែលធ្វើឱ្យមានការភាន់ច្រឡំបន្ថែមនោះគឺថា នៅក្នុងការបង្កើតការយល់ឃើញរបស់ខ្លួនទាក់ទង

---

[2821] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣០។

[2822] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣១។

ទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អង្គជំនុំជម្រះសាលាដំបូងពុំដែលយោងទៅលើការធ្វើទារុណកម្ម ឬបទប្រល័យពូជសាសន៍ថា ជាអំពើធ្វើទុក្ខបុកម្នេញផ្នែកនយោបាយឡើយ[2823]។

1004.ផ្នែកដទៃទៀតនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រផងដែរលើសេចក្ដីសន្និដ្ឋានដែលថាអំពើដែលត្រូវបានចាត់ទុកថា អាចស្មើការធ្វើទុក្ខបុកម្នេញផ្នែកសាសនានោះ ត្រូវបានកម្រិតត្រឹមការរឹតត្បិតលើការប្រតិបត្តិសាសនា និងវប្បធម៌។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភូមិទ្រាថា "អង្គហេតុដែលបានកើតឡើងនៅមន្ទីរសន្តិសុខភូមិទ្រា ជាប់ពាក់ព័ន្ធទៅនឹងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម[លើជនជាតិចាម]"[2824]។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា អង្គជំនុំជម្រះបានចាត់ទុកអង្គហេតុទាំងនេះថា ជាប់ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាឡើយ បើទោះបីជាអំពើប្រល័យពូជសាសន៍ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្មត្រូវបានចាត់ទុកថា ជាអំពើនៃការធ្វើទុក្ខបុកម្នេញ និងទាំងនេះជាចាំបាច់ជាប់ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាយ៉ាងណាក៏ដោយ។

1005.ដោយសារវិធីសាស្ត្រពុំស៊ីសង្វាក់គ្នារបស់អង្គជំនុំជម្រះសាលាដំបូងចំពោះអំពើនៃការធ្វើទុក្ខបុកម្នេញ និងដោយផ្អែកលើគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ* អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញដែលត្រូវបានចាត់ទុកដោយអង្គជំនុំជម្រះសាលាដំបូងថា ស្មើនឹងធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការរឹតត្បិតលើការប្រតិបត្តិផ្នែកសាសនា និងវប្បធម៌ ដូចជាការហាមឃាត់ការអធិដ្ឋានរាល់ថ្ងៃ ការបង្ខំឱ្យបរិភោគសាច់ជ្រូក ការបង្ខំឱ្យស្លៀកពាក់ និងកាត់សក់ខ្លីដូចប្រជាជនខ្មែរ ការបង្ខំឱ្យនិយាយតែភាសាខ្មែរ និងការដុតបំផ្លាញគម្ពីរអាល់គូរ៉ាន និងការរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងមិនមែនសាសនា។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវវាយតម្លៃលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាដូចខាងក្រោម៖

### ii. ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា

[2823] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៥។

[2824] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៧០។

1006.សាលដីកាក្នុងផ្នែកនេះដោះស្រាយអំណះអំណាងទាក់ទងទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាង ដែលត្រូវបានប្រើប្រាស់ក្នុងការបង្ហាញថាតើ អំពើធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា។ ចំពោះអំណះអំណាងពាក់ព័ន្ធទៅនឹងបញ្ហាថាតើ អំពើធ្វើទុក្ខបុកម្នេញអាចស្មើនឹងការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា នឹងត្រូវដោះស្រាយក្នុងផ្នែកខាងក្រោម។

1007.អង្គជំនុំជម្រះសាលាដំបូងបានវិភាគលើបញ្ហាថាតើ អំពើធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា (១) នៅការដ្ឋានទំនប់១មករា[2825] (២) ក្នុងភូមិភាគបូព៌ា[2826] (៣) និងភូមិភាគកណ្តាល(ឧត្តរចាស់)[2827] និង (៤) ទីតាំងដទៃទៀត[2828]។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុពាក់ព័ន្ធទៅនឹងអំពើធ្វើទុក្ខបុកម្នេញនៅការដ្ឋានទំនប់១មករា ដែរ ឬយ៉ាងណា ដោយសារអង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្នែកច្បាប់មួយដាច់ដោយឡែកស្តីពីការធ្វើទុក្ខបុកម្នេញផ្នែកសាសនានៅការដ្ឋាននេះ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើទីតាំងដទៃទៀតជារួមនៅពេលធ្វើការកំណត់លើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុពាក់ព័ន្ធទៅនឹងអំពើធ្វើទុក្ខបុកម្នេញក្នុងភូមិភាគបូព៌ា ភូមិភាគកណ្តាល(ឧត្តរចាស់) និងទីតាំងដទៃទៀត ដែរ ឬយ៉ាងណា។

- *ការដ្ឋានទំនប់១មករា*

1008.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ជនជាតិចាមបានទទួលរងការរើសអើងនៅការដ្ឋានទំនប់១មករា ដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងត្រូវបានហាមឃាត់ការអធិដ្ឋាន និងការនិយាយភាសាកំណើតរបស់ខ្លួន[2829]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការប្រព្រឹត្តទៅលើជនជាតិចាមនៅការដ្ឋានទំនប់១មករានេះ“ត្រូវតែពិនិត្យក្នុងបរិបទថាតើ ពួកគេត្រូវបានប្រព្រឹត្តទៅលើយ៉ាងដូចម្តេច ក្នុងភូមិដែលពួកគេត្រូវបានប្រមូលមកដាក់ក្នុងតំបន់ ៤១, ៤២ និង ៤៣”[2830]។

---

[2825] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១១.២.២២។

[2826] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.២.៦.១។

[2827] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.២.៦.២។

[2828] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.២.៦.៣។

[2829] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៩។

[2830] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៤។

1009.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការរើសអើងជាក់ស្តែងប្រឆាំងនឹងជនជាតិចាមនៅការដ្ឋានទំនប់១មករា[2831]។ គាត់បានលើកបញ្ហាបឋមពីរ ទីមួយគឺថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើសក្ខីកម្មរបស់សាក្សីអំពីការធ្វើឱ្យបាត់ខ្លួន សម្រាប់ការយល់ឃើញដែលថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងត្រូវបានហាមឃាត់ការប្រតិបត្តិសាសនារបស់ខ្លួន ឬការនិយាយភាសាដើមកំណើត[2832]និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានយោងទៅលើព្រឹត្តិការណ៍ក្នុងផ្នែកផ្សេងៗគ្នានៃភូមិភាគកណ្តាល និងកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជាដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿងនេះ និងថា ពុំគប្បីប្រើប្រាស់ក្នុងការបង្ហាញបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងវិសាលភាពនេះឡើយ[2833]។

1010.ទាក់ទងទៅនឹងការយល់ឃើញដែលថា "សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក [...] គ្មានហូបតែម្តង"[2834] ខៀវ សំផន បានលើកឡើងថា ជាក់ស្តែងមានតែសាក្សីបីនាក់ដែលអះអាងបែបនេះ ពុំមែនមានសាក្សី"ជាច្រើន"ដូចការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[2835]។ បន្ថែមលើនេះ គាត់បានកត់សម្គាល់ថា នេះត្រូវតែពិចារណាក្នុងបរិបទនៃការកង្វះស្បៀង ដោយហេតុថា ការមានសាច់បរិភោគ ជាក់ស្តែង គឺជា"ករណីពិសេសគួរត្រេកអរ"សម្រាប់អ្នកធ្វើការដែលត្រូវបានផ្តល់សាច់ជ្រូកឱ្យបរិភោគ[2836]។ គាត់បានសន្និដ្ឋានថា ភស្តុតាងពុំបានបង្ហាញថា ជនជាតិចាមត្រូវបានប្រព្រឹត្តទៅលើខុសគ្នា និងថា ការខកខានក្នុងចាត់វិធានការផ្តល់សាច់ផ្សេងនោះ ពុំមានលក្ខណៈគ្រប់គ្រាន់គាំទ្រការយល់ឃើញអំពីការរើសអើងនោះឡើយ[2837]។ ទាក់ទងទៅនឹងការហាមឃាត់ការអធិដ្ឋាន គាត់បានអះអាងថា ភស្តុតាងបានបង្ហាញថា ជនជាតិចាម និងខ្មែរពុំត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិសាសនាដូចគ្នា ដូច្នេះ ពុំមានការរើសអើងជាក់ស្តែងកើតឡើង"ដោយពុំគិតពីផលប៉ះពាល់នៃវិធានការមិនរើសមុខ"[2838]។ ទាក់ទងទៅនឹងការហាមឃាត់ការនិយាយភាសាដើមកំណើតរបស់ខ្លួន គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញនេះដោយផ្អែកលើសាក្សីពីរនាក់ ហើយមានតែម្នាក់ប៉ុណ្ណោះដែលជាក់ស្តែងបានផ្ត

---

[2831] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៤, ៨០៧។

[2832] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៥។

[2833] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៦។

[2834] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦។

[2835] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៨។

[2836] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៨-៨០៩។

[2837] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១០។

[2838] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១១។

ល់សក្ខីកម្មចំពោះបញ្ហានេះ[2839]។ ផ្អែកតាមទស្សនៈរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្អែកអង្គហេតុ"ពុំសមស្រប និងពុំសមហេតុផល"ក្នុងការយល់ឃើញអំពីការរើសអើងជាក់ស្តែងដែលនេះស្មើនឹងកំហុសអង្គហេតុ[2840]។

1011.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន អំពីការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់សាក្សីតែមួយស្តីពីការធ្វើឱ្យបាត់ខ្លួននោះ ជាក់ស្តែងគ្រាន់តែជាភាន់ច្រឡំនៃការរៀបរៀងកថាខណ្ឌពីសំណាក់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។ តាមពិត អង្គជំនុំជម្រះគប្បីយោងទៅលើកថាខណ្ឌ ១៦៥៩ ជាជាងលើ ១៦៥៨[2841]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើព្រឹត្តិការណ៍ក្រៅការដ្ឋានទំនប់១មករាគ្រាន់តែដើម្បីផ្តល់ជាបរិបទសម្រាប់អំពើដែលបានកើតឡើងនៅទីនោះ ហើយពុំបានបង្កើតការយល់ឃើញណាមួយផ្អែកលើព្រឹត្តិការណ៍ខាងក្រៅនោះឡើយ[2842]។ ចំពោះការបង្ខំឱ្យបរិភោគសាច់ជ្រូក សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវនៃភស្តុតាងក្នុងការអះអាងថា សាច់ជ្រូកគឺជាករណីពិសេសដែលគួរត្រេកអរ និងបានកត់សម្គាល់ថា មានសាក្សីម្នាក់បានពិពណ៌នាអំពីការដែលជនជាតិចាមសុខចិត្តបរិភោគអំបិល ឬបរិភោគតែទឹកសម្ល មិនបរិភោគសាច់ជ្រូក[2843]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ជម្រើសរវាងការបរិភោគសាច់ជ្រូកជាមួយនឹងការដាច់ពោះស្លាប់ ពុំមែនជាជម្រើសពិតប្រាកដទេ[2844]។ ទាក់ទងទៅនឹងបញ្ហាថាតើ ជនជាតិចាមត្រូវបានហាមឃាត់ក្នុងការនិយាយភាសាដើមរបស់ខ្លួន ដែរ ឬយ៉ាងណា សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើសក្ខីកម្មរបស់សាក្សីតែម្នាក់ក្នុងការគាំទ្រការយល់ឃើញណាមួយ ហើយ ខៀវ សំផន ពុំបានជំទាស់ទៅនឹងភាពគួរជឿជាក់របស់សាក្សីដូច្នេះ ខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល[2845]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅគ្រប់ករណី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនៃការរើសអើងយ៉ាងទូលំទូលាយត្រូវបានប្រព្រឹត្តទៅលើជនជាតិចាមមិនត្រឹមតែនៅការដ្ឋានទំនប់១មក

---

[2839] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១២។

[2840] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៤, ៨០៧។

[2841] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៧។

[2842] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៣។

[2843] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៤។

[2844] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៤។

[2845] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៦។

វាប៉ុណ្ណោះទេ ថែមទាំងទីតាំងផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា ដូច្នេះ លក្ខខណ្ឌធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញត្រូវបានបំពេញ បើទោះបីជាគ្មានអំពើនៃការរើសអើងត្រូវបានរកឃើញថាបានប្រព្រឹត្តនៅការដ្ឋានទំនប់១មករាក៏ដោយ[2846]។

1012.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការរើសអើងលើជនជាតិចាមនៅតាមការដ្ឋានធ្វើការត្រូវបានចាត់ទុកយ៉ាងជាក់លាក់ថា ជាផ្នែកនៃអំពើរើសអើងក្នុងភូមិរបស់ពួកគេ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើការរើសអើងទៅលើអ្នកដែលហៅថា"ប្រជាជនថ្មី"នៅការដ្ឋានធ្វើការដូចគ្នា និងក្នុងបរិបទនៃការរើសអើងលើពួកគេក្នុងសហគមន៍ដែលពួកគេរស់នៅ ព្រមទាំងលើគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះពួកគេ[2847]។ ការយល់ឃើញនេះមានទំនាក់ទំនងទៅវិញទៅមកយ៉ាងខ្លាំង។ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា "ការដ្ឋានទំនប់១មករាពុំមែនជា'*ករណីដាច់ដោយឡែកនោះទេ*'"[2848]។

1013.សារណាមួយក្នុងចំណោមសារណារបស់ ខៀវ សំផន ដែលពាក់ព័ន្ធទៅនឹងការភាន់ច្រឡំលេខកថាខណ្ឌក្នុងសាលក្រមពុំមានតម្លៃចាំបាច់ត្រូវធ្វើការពិចារណាឡើយ[2849]។ ទាក់ទងទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែរ ឬយ៉ាងណា ដោយសារការយោងទៅលើព្រឹត្តិការណ៍នៅកន្លែងដទៃ

---

[2846] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៦៨។

[2847] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៤១។

[2848] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៤១ (សេចក្តីបញ្ជាក់បន្ថែម)។

[2849] គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសាក្សីដែលផ្តល់សក្ខីកម្មអំពីការធ្វើឱ្យបាត់ខ្លួនសម្រាប់ការយល់ឃើញដែលថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងហាមឃាត់ការប្រតិបត្តិសាសនារបស់ខ្លួន ឬនិយាយភាសាកំណើតរបស់ខ្លួន។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨០៥។ ក្នុងកថាខណ្ឌ ១៦៩៥ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង សាលក្រមអង្គជំនុំជម្រះក្នុងផ្នែកដែលដោះស្រាយការយល់ឃើញផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនានៅការដ្ឋានធ្វើការទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះ"បានយល់ឃើញថា អ្នកធ្វើការជនជាតិចាមនៅទំនប់១មករាបានទទួលរងការរើសអើង ដោយសារតែពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ហាមឃាត់ការអធិដ្ឋាន និងការនិយាយភាសាកំណើតរបស់ខ្លួន"។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកថាខណ្ឌ ១៦៥៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការយល់ឃើញនេះ។ កថាខណ្ឌ ១៦៥៨ ពុំបានលើកឡើងអំពីការយល់ឃើញពាក់ព័ន្ធទៅនឹងការរើសអើងនៅការដ្ឋានធ្វើការទំនប់១មករា ប៉ុន្តែកថាខណ្ឌខាងក្រោមបន្ទាប់ (១៦៥៩) បញ្ជាក់ថា៖ "អង្គជំនុំជម្រះយល់ឃើញថា ជនជាតិចាមបានទទួលរងការរើសអើងដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងត្រូវបានហាមឃាត់ការអធិដ្ឋាន និងនិយាយភាសាកំណើតរបស់ខ្លួន"។ នេះទំនងជាថា អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំកថាខណ្ឌដែលពុំបានប៉ះពាល់ដល់សុពលភាពនៃការយល់ឃើញឡើយ។

ទៀតក្នុងប្រទេសកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់រួចរាល់ក្នុងសាលដីកានេះថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានអនុញ្ញាតឱ្យយោងទៅលើព្រឹត្តិការណ៍ទាំងនេះដែលនៅក្រៅវិសាលភាពនៃភូមិសាស្ត្រនៃរឿងក្តីសម្រាប់ធ្វើជាបរិបទ[2850]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ចំណុចនេះក្នុងកថាខណ្ឌ ១៦៤១ ដោយខ្លួនឯង និងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះនឹងយោងទៅលើព្រឹត្តិការណ៍សម្រាប់ធ្វើជាបរិបទតែប៉ុណ្ណោះ[2851]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ណាមួយឡើយ។

1014. ទាក់ទងទៅនឹងការជំទាស់ជាក់លាក់ទៅលើការវាយតម្លៃភស្តុតាងសម្រាប់ការយល់ឃើញថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់ សាក្សីពីរនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលក្នុងចំណោមនោះមានម្នាក់ជាជនជាតិចាម[2852]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បណ្តឹងសាទុក្ខពុំមែនជាការបើកសវនាការសាឡើងវិញ ឬការវាយតម្លៃឡើងវិញលើភស្តុតាងនោះទេ ហើយអង្គជំនុំជម្រះនៃបណ្តឹងសាទុក្ខនោះមិនត្រូវជ្រៀតជ្រែកលើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងលើកលែងតែការយល់ឃើញនោះ គឺជាការយល់ឃើញដែលពុំមានតុលាការអង្គហេតុសមហេតុផលអាចធ្វើទៅបាន[2853]។ បន្ថែមលើនេះ ចំនួនសាក្សីដែលបានមកផ្តល់សក្ខីកម្មលើអង្គហេតុណាមួយ ពុំមែនជាកត្តាកំណត់អំពីភាពសមហេតុផលនោះទេ៖ តុលាការអង្គហេតុអាចសំអាងទៅលើសក្ខីកម្មរបស់សាក្សីតែម្នាក់ ប្រសិនបើខ្លួនយល់ឃើញថា គួរជឿជាក់ និងទុកចិត្តបាន[2854]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អ្នកធ្វើការដទៃទៀតដែលពុំមែនជាជនជាតិចាម បានផ្តល់សក្ខីកម្មលើការ

---

[2850] *សូមមើលខាងលើ* កថាខណ្ឌ ៦៦៦-៦៦៨។

[2851] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៤:

> អង្គជំនុំជម្រះកត់សម្គាល់នៅក្នុងសំអាងហេតុរបស់ខ្លួននៅផ្នែក ១៣.២. ការប្រព្រឹត្តចំពោះ ជនជាតិចាមថា ប.ក.ក បានដាក់កំហិតទៅលើការប្រណិប័តន៍សាសនា និងវប្បធម៌របស់ជនជាតិចាម នៅតាមទីកន្លែងជាច្រើនក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និងនៅតាមទីកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ [...]។ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តចំពោះជនជាតិចាមនៅការដ្ឋានការងារទំនប់ ១ មករា ចាំបាច់ត្រូវតែពិនិត្យនៅក្នុងបរិបទដែលគេប្រព្រឹត្តចំពោះជនជាតិចាមនៅតាមភូមិនានា ដែលអ្នកទាំងនោះត្រូវបានជ្រើសរើសនៅក្នុងតំបន់ ៤១ តំបន់ ៤២ និងតំបន់ ៤៣។

*សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦: "ជាមួយនឹងទិដ្ឋភាពនេះ អង្គជំនុំជម្រះនឹងពិចារណាទៅលើការប្រព្រឹត្តចំពោះជនជាតិចាម នៅការដ្ឋានការងារទំនប់១មករា"។

[2852] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦ និងជើងទំព័រ ៥៦៣៧-៥៦៣៨។

[2853] *សូមមើលខាងលើ* ផ្នែក II.គ។

[2854] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤៩០។ *សូមមើលផងដែរ* សាលដីការឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ៩៤៩។

រឹតត្បិតដែលបានដាក់ទៅលើជនជាតិចាមនៅការដ្ឋានទំនប់១មករាថា៖ "អ្នករាល់គ្នាត្រូវបានបញ្ជាឱ្យបរិភោគសាច់ជ្រូក។ គ្មានអ្នកណាហ៊ានប្រកែក។ ប្រសិនបើយើងមិនហូបសាច់ជ្រូកទេ យើងគ្មានអីហូប ដូច្នេះយើងត្រូវតែហូបសាច់ជ្រូក"[2855]។ ភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាបង្ហាញថា ប្រសិនបើជនជាតិចាមបដិសេធមិនព្រមបរិភោគសាច់ជ្រូក ពួកគេអាចហូបតែទឹកសម្លដែលគ្មានជាប់សាច់ជ្រូក ឬមានតែហូបអំបិល[2856]។ បើទោះបីជាតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើការសន្និដ្ឋានសមហេតុផលមួយផ្សេងពីអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលអាចបង្កើតការយល់ឃើញដូចការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែរ។

1015.ខៀវ សំផន ពុំបានជំទាស់ថា ជនជាតិចាមត្រូវបានហាមឃាត់ការអធិដ្ឋាន និងត្រឹមតែបានអះអាងថា ពុំមានការរើសអើង ដោយសារជនជាតិចាម និងខ្មែរត្រូវបានប្រព្រឹត្តទៅលើស្មើគ្នាទាក់ទងនឹងបញ្ហានេះ ដែលនឹងត្រូវដោះស្រាយខាងក្រោម។

1016.ទាក់ទងទៅនឹងការហាមឃាត់ការនិយាយភាសាដើមជនជាតិចាម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនទៅលើសក្ខីកម្មរបស់សាក្សីពីរនាក់ និងបានចាត់ទុកថា ពួកគេគួរជឿជាក់បានគ្រប់គ្រាន់ក្នុងការសំអាងទៅលើ[2857]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលបានបង្កើតការយល់ឃើញដូចអង្គជំនុំជម្រះសាលាដំបូងឡើយ។ អាស្រ័យហេតុនេះ ការជំទាស់របស់គាត់ត្រូវបដិសេធចោល។

- *នៅទីកន្លែងផ្សេងក្នុងប្រទេសកម្ពុជា*

1017.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្មែរក្រហមបានធ្វើការរឹតត្បិតលើការប្រតិបត្តិសាសនា និងវប្បធម៌ជនជាតិចាម។ ក្នុងភូមិភាគបូព៌ាក្នុងស្រុកក្រូចឆ្មារ ការរឹតត្បិតនេះរួមបញ្ចូលការហាមឃាត់សម្លៀកបំពាក់ និងការតុបតែងខ្លួនបែបប្រពៃណី និងបង្ខំជនជាតិចាមឱ្យមានរបបអាហារដូចខ្មែរដែរ ដូចជា

---

[2855] ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/304.1 ទំព័រ ៧៧។

[2856] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦ និងជើងទំព័រ ៥៦៣៤, ៥៦៣៧, ៥៦៣៨, ៥៦៤០ (និងភស្តុតាង ដែលបានដកស្រង់នៅទីនោះ)។

[2857] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦ និងជើងទំព័រ ៥៦៣៦ (និងភស្តុតាងដែលបានដកស្រង់នៅទីនោះ)។

បរិភោគសាច់ជ្រូក រឹបអូសយក និងដុតបំផ្លាញគម្ពីរអាល់គូរ៉អាន និងរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងមិនពាក់ព័ន្ធសាសនា[2858]។ នៅក្នុងភូមិភាគកណ្ដាល(ឧត្ដរចាស់) មានការហាមឃាត់លើការអធិដ្ឋានរាល់ថ្ងៃ ការបង្ខំឱ្យបរិភោគសាច់ជ្រូក និងស្លៀកសំលៀកបំពាក់ និងកាត់សក់ដូចខ្មែរ និងការតម្រូវឱ្យជនជាតិចាមនិយាយតែភាសាខ្មែរ ការដុតបំផ្លាញគម្ពីរអាល់គូរ៉អាន និងរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់ដើម្បីគោលបំណងផ្សេងក្រៅពីសាសនា[2859]។ នៅកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជា ការហាមឃាត់រួមមានការមិនអនុញ្ញាតឱ្យអធិដ្ឋានរៀងរាល់ថ្ងៃ ការបង្ខំជនជាតិចាមឱ្យបរិភោគសាច់ជ្រូក និងស្លៀកសំលៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការបង្ខំជនជាតិចាមឱ្យនិយាយតែភាសាខ្មែរ ការដុតបំផ្លាញគម្ពីរអាល់គូរ៉អាន និងរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់ដើម្បីគោលបំណងផ្សេងក្រៅពីសម្រាប់អធិដ្ឋាន[2860]។

1018.ខៀវ សំផន បានជំទាស់ប្រហាក់ប្រហែលគ្នានេះទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមនៅការដ្ឋានទំនប់១មករា។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ដោយសារអ្នករាល់គ្នាទទួលបានអាហារដូចៗគ្នា ហើយជនជាតិចាមពុំត្រូវបានផ្ដល់ជម្រើសផ្សេងជំនួសសាច់ជ្រូកឡើយ[2861]។ គាត់បានបន្ថែមថា ដើមបណ្ដឹងរដ្ឋប្បវេណីតែមួយគត់ ឡិប នាង បានផ្ដល់សក្ខីកម្មថា ត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូកដោយមានអ្នកឈរកាន់កាំភ្លើងពីក្រោយខ្នង និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្កើតការយល់ឃើញធ្វើជាលក្ខណៈទូទៅអំពីការប្រព្រឹត្តទៅលើជនជាតិចាមទូទាំងប្រទេសដោយផ្អែកលើសក្ខីកម្មនេះ[2862]។ ខៀវ សំផន បានអះអាងបន្ថែមថា ភស្ដុតាងដែលថា គម្ពីរអាល់គូរ៉អានត្រូវបានដុតបំផ្លាញនោះ ពុំគួរអោយជឿជាក់បាន[2863]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុដោយសារបានសំអាងទៅលើកិច្ចសម្ភាសន៍ដែលបានធ្វើឡើងដោយ Nate Thayer ក្រៅក្របខ័ណ្ឌតុលាការ និងពុំត្រូវបានដាក់ឱ្យពិភាក្សាដេញដោលចំពោះមុខ[2864]។

---

[2858] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣៨។

[2859] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៤៥។

[2860] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៥០។

[2861] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៤៤-៩៤៦។

[2862] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៤៦។

[2863] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៤៨-៩៤៩។

[2864] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥០។

1019.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃភស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន សក្ខីកម្មរបស់ ឡិប នាង ពុំមែនជាភស្តុតាងតែមួយគត់ដែលបង្ហាញថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូកនោះទេ[2865]។ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ការដុតបំផ្លាញគម្ពីរអាល់គូរ៉ាន សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់ហួសពីឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃលើភស្តុតាង និងថា ខៀវ សំផន ពុំបានអើពើលើការពិតដែលថា ការរឹបអូស និងការដុតបំផ្លាញគម្ពីរអាល់គូរ៉ាន គឺជាកត្តាដែលនាំទៅដល់ការបះបោរនៅកោះផល[2866]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសឆន្ទានុសិទ្ធិដែលខ្លួនមានក្នុងការវាយតម្លៃលើភស្តុតាងតាមរយៈការសំអាងទៅលើកិច្ចសម្ភាសន៍របស់ Nate Thayer[2867]។

1020.សហមេធាវីនាំមុខបានឆ្លើយតបថា មិនត្រឹមតែ ឡិប នាង ម្នាក់ទេដែលបានផ្តល់ភស្តុតាងថា នឹងមានផលវិបាកអវិជ្ជមានប្រសិនបើជនជាតិចាមមិនបរិភោគសាច់ជ្រូកនោះ[2868]។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមទៀតថា ផ្អែកតាមសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ និង ម៉ី ពៅ បើទោះបីជាគ្មានការគំរាមកំហែងដោយហិង្សាក៏ដោយ ក៏ការរំពឹងទុកថានឹងដាច់ពោះស្លាប់ពិតប្រាកដ បានជម្រុញជនជាតិចាមឱ្យបរិភោគសាច់ជ្រូក នៅពេលដែលមានតែអាហារមួយប្រភេទនេះប៉ុណ្ណោះដែលផ្តល់ឱ្យ ហើយការរំពឹងទុកនៃការដាច់ពោះស្លាប់នេះគឺជាគោលបំណងបង្ខំឱ្យជនជាតិចាមបរិភោគសាច់ជ្រូក[2869]។ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ដុតបំផ្លាញគម្ពីរអាល់គូរ៉ាន សហមេធាវីនាំមុខបានឆ្លើយតបថា សក្ខីកម្មពីររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើបង្ហាញច្បាស់លាស់ថា ជនជាតិចាមពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់គម្ពីរអាល់គូរ៉ាន និងថា គម្ពីរអាល់គូរ៉ានត្រូវបានរឹបអូស។ ការយកគម្ពីរអាល់គូរ៉ានទៅណាចុងក្រោយ ពុំជាប់ពាក់ព័ន្ធឡើយ[2870]។

1021.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ត្រឹមតែបានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់និងគួរឱ្យជឿទុកចិត្តបានក្នុងការយល់ឃើញថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក និងថា គម្ពីរ

---

[2865] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨១។

[2866] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨២។

[2867] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨៣។

[2868] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៥៦។

[2869] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៥៧។

[2870] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៥៨-៤៥៩។

អាល់គូរ៉ាអានត្រូវបានដុតបំផ្លាញប៉ុណ្ណោះ[2871]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើប្រភពនៃភស្តុតាងដែលរួមបញ្ចូលប៉ុន្តែមិនកម្រិតត្រឹមសាក្សីផ្ទាល់ក្នុងការបង្កើតការយល់ឃើញដែលថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក[2872]។ អង្គជំនុំជម្រះតុលាការកំពូលនឹងពុំធ្វើការជ្រៀតជ្រែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានភស្តុតាងបង្ហាញថាជនជាតិចាមនៅការដ្ឋានទំនប់១មករា ត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក[2873]។ ទោះជាយ៉ាងណាក្តី មានសក្ខីកម្មផ្សេងទៀតដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា នៅកន្លែងផ្សេងទៀតជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក។ ឧទាហរណ៍ បន្ថែមលើសេចក្តីកម្មរបស់ ឡិប នាង ដែលថាលោកស្រីត្រូវបានឃ្លាំមើលដោយបុគ្គលម្នាក់ដែលមានកាំភ្លើងចាំមើលថាតើ គាត់បរិភោគសាច់ជ្រូក ដែរឬទេ នៅពេលគេចែកអាហារមានសាច់ជ្រូកទៅឱ្យគាត់[2874] ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពន្យល់ថា៖

> ជនជាតិចាម"ត្រូវបានបង្ខំឱ្យបរិភោគអាហារដែលពួកយើងមិនអាចបរិភោគបាន។ ប្រសិនបើយើងមិនបរិភោគទេ យើងនឹងត្រូវបានចោទថា ពុំបានបោះបង់ការប្រតិបត្តិសាសនារបស់យើងចោលឡើយ។ នេះអាចនឹងត្រូវគេតាមដាន។ ប្រសិនបើយើងជំទាស់ទៅនឹងគោលការណ៍ណាមួយដែលគេបានដាក់នោះ យើងនឹងត្រូវបានចោទថា ជាខ្មាំងរបស់អង្គការ"[2875]។ ហ៊ីម ម៉ាន បានបញ្ជាក់បន្ថែមលើភស្តុតាងនេះ[2876]។ ផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ជាការពុំសមហេតុផលឡើយ។

1022.ទាក់ទងទៅនឹងការបំផ្លាញគម្ពីរអាល់គូរ៉ាអាន អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសាក្សីជាច្រើនក្នុងការយល់ឃើញថា គម្ពីរអាល់គូរ៉ាអានត្រូវបានរឹបអូស និងដុតបំផ្លាញ រួមទាំងកិច្ចសម្ភាសន៍ជាច្រើនដែលបានធ្វើឡើងដោយ Nate Thayer[2877]។ ទាក់ទងនឹងបញ្ហា

---

[2871] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៤៤-៩៥០។

[2872] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣៥-៣២៣៦, ៣២៣៩, ៣២៤២។

[2873] *សូមមើលខាងលើ* កថាខណ្ឌ ១០១៤។

[2874] ប្រតិចារឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ (អ៊ឹម វណ្ណៈ) ឯកសារលេខ E1/288.1 ទំព័រ ៨២។

[2875] ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ (សុះ មីន) ឯកសារ ឯកសារលេខ E1/288.1 ទំព័រ ៥០។

[2876] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣៩, ៣២៤២ និងជើងទំព័រ ១០៩៣៥, ១០៩៤១ យោងទៅលើ*ក្នុងចំណោមនោះ* ប្រតិចារឹកថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (ហ៊ីម ម៉ាន) ឯកសារលេខ E1/349.1 ទំព័រ ២៩-៣០។ ប្រតិចារឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ (ហ៊ីម ម៉ាន) ឯកសារលេខ E1/350.1 ទំព័រ ១២។

[2877] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣៤-៣២៣៦, ៣២៤៩។

នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា មានភស្តុតាងបង្ហាញថា គម្ពីរអាល់គូរ៉អានត្រូវបានប្រមូលដុតចោលទូទាំងប្រទេសកម្ពុជា។ នោ សាទះ បានអះអាងថា ក្នុងឆ្នាំ ១៩៧៥ គម្ពីរអាល់គូរ៉អានត្រូវបានប្រមូលដុតបំផ្លាញ ប៉ុន្តែពុំបានដឹងថា គេយកគម្ពីរនោះទៅណានោះទេ[2878] ។ សុះ ម៉ីន បានអះអាងថា គម្ពីរអាល់គូរ៉អានត្រូវបានប្រមូល និងដាក់ក្នុងបន្ទប់មួយ[2879]។ ដូចគ្នាជាមួយនឹង នោ សាទះ ដែរ អ៊ីត សេន បានអះអាងថា គម្ពីរអាល់គូរ៉អានត្រូវបានដុតបំផ្លាញ[2880]។ កិច្ចសម្ភាសន៍របស់ Nate Thayer ដែលត្រូវបានសំអាងទៅលើក្នុងការយល់ឃើញថា គម្ពីរអាល់គូរ៉អានត្រូវបានដុតចោលនៅកន្លែងផ្សេងទៀតនោះមានតម្លៃជាភស្តុតាងបញ្ជាក់បន្ថែម ប៉ុន្តែនេះពុំមែនជាភស្តុតាងតែមួយគត់ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការបង្កើតការយល់ឃើញរបស់ខ្លួននោះទេ។ បន្ថែមលើនេះ បញ្ហាថាតើ គម្ពីរអាល់គូរ៉អានត្រូវបានដុតបំផ្លាញ ដែរ ឬយ៉ាងណា គឺជាអង្គហេតុដែលមានសារៈសំខាន់តិចតួចក្នុងការពិចារណាថា ជាការដែលពុំអាចប្រកែកបានថា ជនជាតិចាមត្រូវបានហាមឃាត់ការអធិដ្ឋាន។ ការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្កើតការយល់ឃើញទាំងនេះ ត្រូវបដិសេធចោលទាំងស្រុង។

iii. ថាតើ ការរឹតត្បិតលើសេរីភាពផ្នែកសាសនាត្រូវបានអនុញ្ញាត ដែរ ឬយ៉ាងណា

1023.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពន្យល់នូវមូលហេតុដូចម្តេចបានជាការរឹតត្បិតផ្នែកសាសនាពុំត្រូវបានអនុញ្ញាតដោយច្បាប់ ដូចបានលើកឡើងក្នុងការបញ្ជាក់អំពីច្បាប់ជាធរមានថា "សិទ្ធិក្នុងការសម្តែងការប្រតិបត្តិសាសនាអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការរឹតត្បិតមួយចំនួន" និងថា"អង្គជំនុំជម្រះនឹងត្រូវវាយតម្លៃលើការរឹតត្បិតលើសេរីភាពនៃសាសនា ឬការសម្តែងការប្រតិបត្តិសាសនាផ្អែកលើអង្គហេតុនៃរឿងក្តីនេះ"[2881]។ គាត់បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំលើបញ្ហានៃការប្រព្រឹត្តផ្សេងគ្នាទៅលើជនជាតិចាម ជាមួយនឹងបញ្ហាថាតើ មាន

[2878] ប្រតិចារឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ (នោ សាទះ) ឯកសារលេខ E1/350.1 ទំព័រ ៦០-៦២។

[2879] ប្រតិចារឹកថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ (សុះ មីន) ឯកសារលេខ E1/343.1 ទំព័រ ៨៣។

[2880] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ (អ៊ីត សេន) ឯកសារលេខ E1/342.1 ទំព័រ ៤៨។

[2881] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥២-៩៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២០-៧២១។

ការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែរ ឬយ៉ាងណា បើទោះបីជាមានធាតុផ្សំដាច់ដោយឡែកពីគ្នានៃការធ្វើទុក្ខបុកម្នេញក៏ដោយនោះ[2882]។

1024.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានការវិភាគពេញលេញ។ អង្គជំនុំជម្រះសាលាដំបូង"បានយោង និងបានវិភាគច្បាស់លាស់លើមូលដ្ឋានដែលសេរីភាពក្នុងការសម្តែងការប្រតិបត្តិសាសនាអាចត្រូវបានរឹតត្បិតសមស្រប និងបានបដិសេធភាពដែលអាចអនុវត្តបាននូវមូលដ្ឋានទាំងនេះទៅលើ'អង្គហេតុនៃរឿងក្តីនេះ'"[2883]។ សហព្រះរាជអាជ្ញាបានពិចារណាឃើញថា ខៀវ សំផន បានបកស្រាយការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំត្រឹមត្រូវដោយបានលើកឡើងថា ការយល់ឃើញដែលថា ការរឹតត្បិតពុំត្រូវបានអនុញ្ញាតនោះ ជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញបន្ទាប់មកទៀតស្តីពីការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន[2884]។

1025.សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ជាការសមហេតុផល និងមានសំអាងហេតុគ្រប់គ្រាន់ដោយផ្អែកលើការយោងពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការរឹតត្បិតដែលអាចអនុញ្ញាតទៅលើសេរីភាពផ្នែកសាសនា"[2885]។

1026.អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំលើធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញដោយសារបានយល់ឃើញថា ការរឹតត្បិតនោះពុំត្រូវបានអនុញ្ញាតឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយោងជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូងទៅលើការពិភាក្សាដំបូងរបស់ខ្លួនដែលថា សិទ្ធិសម្តែងការប្រតិបត្តិសាសនាអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការរឹតត្បិតមួយចំនួន និងការលើកឡើងដែលថា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការវាយតម្លៃលើការរឹតត្បិតនោះផ្អែកលើអង្គហេតុនៃរឿងក្តី[2886] បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានវាយតម្លៃថា ការរឹតត្បិតនោះត្រូវបានអនុញ្ញាត ឬជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពផ្នែកសាសនា។ ការដែលថា អង្គជំនុំ

---

2882 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥៣។

2883 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨៧។

2884 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨៥។

2885 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៦៧។

2886 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៨ និងជើងទំព័រ ១១២៦៤ យោងទៅលើកថាខណ្ឌ ៧១៩-៧២១។

ជម្រះសាលាដំបូងពុំបានវិភាគលម្អិតនោះ ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវិភាគនោះឡើយ។ ការចោទប្រកាន់របស់ ខៀវ សំផន ដែលផ្ទុយនេះត្រូវបដិសេធចោល។

iv. ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញបានរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា

1027.ខៀវ សំផន បានលើកឡើងថា អំពើនៃការធ្វើទុក្ខបុកម្នេញត្រូវបានអនុវត្តស្មើៗគ្នាចំពោះមនុស្សទូទៅ និងបានអះអាងថា អំពើនេះពុំបានរើសអើងជាក់ស្តែង ដោយសារការប្រព្រឹត្តស្មើៗគ្នានេះពុំអាចត្រូវបានចាត់ទុកថាជាការរើសអើងដោយប្រយោលឡើយ[2887]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានផ្តោតទៅលើការដែលវិធានការនោះបានអនុវត្តចំពោះមនុស្សគ្រប់គ្នាដោយមិនរើសមុខ ប៉ុន្តែបានផ្តោតតែទៅលើការពិចារណាអំពីផលប៉ះពាល់តែលើជនជាតិចាមប៉ុណ្ណោះ[2888]។

1028.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងអំពីការប្រព្រឹត្តទៅលើស្មើៗគ្នានោះពុំបានអើពើទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើនៃការរើសអើងត្រូវបានប្រព្រឹត្តឡើងក្នុងការជម្រុញគោលនយោបាយជាពិសេសកំណត់គោលដៅលើជនជាតិចាម និងអំពើជាច្រើននៃការធ្វើទុក្ខបុកម្នេញបានប្រព្រឹត្តឡើងមិនស្មើគ្នា និងបានកំណត់គោលដៅតែលើជនជាតិចាម ជាឧទាហរណ៍ ការហាមឃាត់ការអធិដ្ឋានរាល់ថ្ងៃ ការតម្រូវឱ្យនិយាយតែភាសាខ្មែរ និងការហាមឃាត់ការស្លៀកពាក់បែបប្រពៃណី និងត្រូវកាត់សក់ខ្លី និងការរុះរើវិហារអ៊ីស្លាម[2889]។

1029.ដោយសារត្រូវបានបង្ហាញខាងលើថា ការរើសអើងជាក់ស្តែងបានកើតឡើង នៅពេលមានផលវិបាកមិនស្មើគ្នាសម្រាប់ក្រុមជាក់លាក់តាមរយៈអំពើសកម្ម ឬអកម្មទូទៅ[2890] អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាថាតើ ជនជាតិចាមបានប្រឈមនឹងផលវិបាកជាក់លាក់ដែលជាលទ្ធផលនៃការរឹតត្បិតផ្នែកសាសនា និងប្រពៃណី ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមបានទទួលរងផលប៉ះពាល់“លើសលុប និងជាពិសេស”តាមរយៈ

[2887] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨១៣, ៩៥៤-៩៥៦។

[2888] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៣៩-៩៤២, ៩៥៤។

[2889] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៨០, ៤៩០។

[2890] *សូមមើលខាងលើ* ផ្នែក VI.ង.១.ខ។

ការរឹតត្បិតផ្នែកសាសនា និងវប្បធម៌"ពីព្រោះពួកគេត្រូវកែប្រែទម្លាប់នៃការរស់នៅរបស់ខ្លួនទាំងស្រុង និងការប្រតិបត្តិសាសនារបស់ពួកគេផងដែរ"[2891]។

1030.ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា អំណះអំណាងដែលថា តាមធម្មតា ពុំមានការរើសអើង ពីព្រោះការរឹតត្បិតបានធ្វើឱ្យប៉ះពាល់ដល់មនុស្សគ្រប់រូប ខកខានក្នុងការពិចារណាលើភាពខុសប្លែកគ្នាជាមូលដ្ឋានរវាងក្រុមពីរ ពុទ្ធសាសនិកខ្មែរ និងអ្នកកាន់សាសនាអ៊ីស្លាម ដែលទាំងពីរក្រុមត្រូវបានប្រព្រឹត្តទៅលើយ៉ាងធ្ងន់ធ្ងរ។ ការអធិដ្ឋានរាល់ថ្ងៃ របបអាហារ សម្លៀកបំពាក់ និងភាសាខុសប្លែកគ្នាពីក្រុមមួយទៅក្រុមមួយ[2892]។ ការផ្តល់សាច់ជ្រូកទៅឱ្យក្រុមមួយអាចជាការត្រេកអរក្នុងស្ថានភាពអាហារមិនគ្រប់គ្រាន់[2893] ប៉ុន្តែការផ្តល់សាច់ជ្រូកទៅឱ្យក្រុមដទៃទៀតពុំជាមែនការទទួលដោយត្រេកអរនោះទេ ដោយសារសម្រាប់ពួកគេសាច់ជ្រូកគឺជារបស់ហាមឃាត់ផ្នែកសាសនា[2894]។ សម្រាប់ពុទ្ធសាសនិក ការបិទវត្តអារាម និងការមិនទៅវត្តទៀងទាត់ពុំមែនជាការបង្ហាញនូវការមិនគោរពតាមសាសនាជាលក្ខណៈបុគ្គលនោះទេ ប៉ុន្តែការហាមឃាត់ការទៅវិហារអ៊ីស្លាមសម្រាប់ការចូលរួមពិធីសាសនាទៀងរាល់ថ្ងៃសុក្រ និងការហាមឃាត់ការអធិដ្ឋានទៀងរាល់ថ្ងៃ មានផលប៉ះពាល់ខុសប្លែកគ្នាលើអ្នកកាន់សាសនាអ៊ីស្លាមដោយសារការហាមឃាត់នេះជាការប្រាសចាកពីប្រតិបត្តិសាសនាអ៊ីស្លាមជាមូលដ្ឋាន។ ប្រហាក់ប្រហែលគ្នានេះដែរ ការហាមឃាត់ការនិយាយភាសាកំណើតរបស់ខ្លួនបូករួមនឹងការហាមឃាត់ផ្នែកសាសនា និងសម្លៀកបំពាក់ បានធ្វើឱ្យប៉ះពាល់កាន់តែយ៉ាងខ្លាំងឡើង ជាងការដែលពិចារណាដាច់ដោយឡែកពីគ្នានោះ។

1031.ការបង្ខំឱ្យបរិភោគសាច់ជ្រូកចំពោះជនជាតិចាមដែលត្រូវបានផ្លាស់ទី និងបំបែកចេញពីសហគមន៍របស់ពួកគេមានផលប៉ះពាល់ជាពិសេសដែលពុំកើតឡើងចំពោះអ្នកដទៃដែលពុំមែនជនជាតិចាម។ ការផ្តល់អាហារដែលត្រូវបានហាមឃាត់ផ្នែកសាសនានៅក្នុងរបបអាហាររបស់ពួកគេ គឺជាការវិធីសាស្ត្រធ្វើឱ្យអាម៉ាស់ និងអាក្រក់បំផុត ពីព្រោះពួកគេត្រូវក្បត់នឹងសាសនារបស់ខ្លួនតាមរយៈការបរិភោគអាហារដែលហាមឃាត់ ឬត្រូវដាច់ពោះស្លាប់[2895]។ អំពើនេះបានប្រព្រឹត្តដោយជាក់លាក់លើជនជាតិចាម និងស្មើនឹងការរើសអើងជាក់ស្តែង។ នេះគឺជាអំពើនៃការរើសអើងដែលបានប៉ះពាល់យ៉ាងសំខាន់លើជនជាតិចាម ប៉ុន្តែពុំបានប៉ះ

---

[2891] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣២។

[2892] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២០៤។

[2893] *សូមមើល ឧ.* ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារលេខ E1/306.1 ទំព័រ ៣៩។

[2894] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦, ៣២៣៩, ៣២៤២, ៣២៤៧ (និងសក្ខីកម្មដែលបានដកស្រង់នៅទីនោះ)។

[2895] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៥៦, ៣២៤៦។

ពាល់លើប្រជាជនជនដទៃទៀតដែលបានផ្លាស់ទីដូចគ្នានោះ។ ការបង្ខំពួកគេឱ្យបរិភោគសាច់ជ្រូក ឬសម្ល សាច់ជ្រូកគឺជាការវាយប្រហារលើសាសនារបស់ពួកគេ ខណៈពេលការហាមឃាត់លើការប្រើប្រាស់ភាសារបស់ពួកគេ និងការវាយប្រហារលើវប្បធម៌ដែលនេះបូករួមជាមួយនឹងការហាមឃាត់ការទៅចូលរួមវិហារអ៊ីស្លាម ឬការអធិដ្ឋានរាល់ថ្ងៃ ស្មើនឹងការរើសអើងជាក់ស្តែង។

### v. ថាតើ ការរឹតត្បិតលើការប្រតិបត្តិសាសនា និងវប្បធម៌បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែរ ឬយ៉ាងណា

1032.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដោយសារពុំមានការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ដែលបានរៀបរាប់នោះបានរំលោភបំពានលើសិទ្ធជាមូលដ្ឋានណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើឡើយ[2896]។ គាត់បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា អង្គជំនុំជម្រះបានពិចារណាលើសេរីភាពផ្នែកសាសនាដែលត្រូវបានរំលោភបំពានឡើយ[2897]។

1033.សហព្រះរាជអាជ្ញាបានឆ្លើយតបថា "អំពើនៃការធ្វើទុក្ខបុកម្នេញត្រូវតែពិចារណាត្រួតគ្នា និងតាមបរិបទ" និងយោងតាមអង្គជំនុំជម្រះតុលាការកំពូលថា "ចំណុចសំខាន់នៃការវិភាគពុំស្ថិតនៅត្រង់ការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញជាក់លាក់បានរំលោភបំពានលើសិទ្ធិមនុស្សដែលមានលក្ខណៈជាមូលដ្ឋាន ដែរ ឬយ៉ាងណានោះទេ"[2898]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តច្បាប់ត្រឹមត្រូវ និងបានយល់ឃើញថា ផលប៉ះពាល់ត្រួតគ្នានៃការរឹតត្បិត "និងការសម្លាប់ដោយសារប្រឆាំងនឹងអំពើនោះបូករួមជាមួយនឹងអំពើដទៃទៀតដែលបានប្រព្រឹត្តទៅលើជនជាតិចាមរួមទាំង ប៉ុន្តែមិនកម្រិតត្រឹមអំពើមនុស្សឃាត ការសម្លាប់រង្គាល ការឃុំឃាំង ការធ្វើទារុណកម្ម និង[អំពើអមនុស្សធម៌ដទៃទៀត](ការផ្លាស់ទីដោយបង្ខំ) បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន"[2899]។ សហព្រះរាជអាជ្ញាបានអះអាងថា ពុំមានការយល់ឃើញអំពីការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពផ្នែកសាសនា ត្រូវបានតម្រូវឱ្យបំពេញតាមលក្ខខណ្ឌនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនានោះឡើយ ប៉ុន្តែពិតណាស់ថា អង្គជំនុំជម្រះ

---

[2896] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៦០។

[2897] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៦១។

[2898] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៤ ដកស្រង់សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២៥៧។

[2899] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៤។

សាលាដំបូងបានពិចារណាឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញបានរំលោភបំពានលើសិទ្ធិនៃសេរីភាពផ្នែកសាសនា[2900]។

1034.សហមេធាវីនាំមុខបានឆ្លើយតបថា៖

> បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានយោងជាក់លាក់ទៅលើសេរីភាពនៃសាសនានៅពេលរៀបរាប់អំពីសិទ្ធិជាមូលដ្ឋាន និងសេរីភាពដែលត្រូវបានរំលោភបំពានក៏ដោយ ក៏នៅតែមានភាពច្បាស់លាស់គ្រប់គ្រាន់ថា នេះធ្វើឡើងដោយចេតនានៅពេលពិនិត្យសំអាងហេតុជារួម(មិនមែនពីអង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយបញ្ហាថាតើ ការរឹតត្បិតណាខ្លះទៅលើសិទ្ធិនោះ ត្រូវបានអនុញ្ញាតនោះដែរ ឬយ៉ាងណា)”[2901]។

សហមេធាវីនាំមុខបានពិចារណាថា ការរឹតត្បិតលើការប្រតិបត្តិសាសនាគឺស្ថិតក្នុងចំណោមអំពើជាច្រើនដែលជាការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ហើយអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំពើដទៃទៀតនៅពេលរៀបរាប់សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន[2902]។

1035.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញលើជនជាតិចាម“បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននានា និងសេរីភាពទាក់ទងទៅនឹងការដើរហើរ សេចក្តីថ្លៃថ្នូររបស់បុគ្គល សេរីភាព និងសន្តិសុខ ការគ្មានការចាប់ចងតាមអំពើចិត្ត ឬខុសច្បាប់ ការជំនុំជម្រះជាសាធារណៈដោយត្រឹមត្រូវ និងស្មើភាពគ្នាចំពោះមុខច្បាប់ដូចមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[2903]។

1036.ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសិទ្ធិដែលបានរៀបរាប់ខាងលើ ពុំមានលក្ខណៈច្បាស់លាស់ក្នុងបរិបទនៃការរឹតត្បិតផ្នែកសាសនា និងវប្បធម៌។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពិតជាបានបញ្ជាក់ថា អង្គជំនុំជម្រះបានយល់ឃើញថា សិទ្ធិនៃសេចក្តីថ្លៃថ្នូររបស់បុគ្គលត្រូវបានរំលោភបំពាន ហើយការយល់ឃើញនេះទំនងជាសមហេតុផល។ ការបង្ខំឱ្យកាត់សក់ និងស្លៀកពាក់តាមរបៀបណាមួយ និងការបង្ខំឱ្យបរិភោគអាហារជាក់លាក់មួយដែលមិនអាចទទួលយកបានចំពោះពួកគេ ពិតណាស់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់បុគ្គល។ បន្ថែមលើនេះ បើទោះបីជាអង្គជំនុំជម្រះពុំបានបញ្ជាក់ដូច្នោះក៏

---

[2900] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៥។

[2901] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៦៧។

[2902] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៦៨។

[2903] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣០។

ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញបានរំលោភបំពានលើសេរីភាពផ្នែកសាសនាប្រាកដមែន។ នេះបានបង្ហាញកាន់តែច្បាស់តាមរយៈការបញ្ជាក់របស់អង្គជំនុំជម្រះថា អំពើនោះពុំត្រូវបានអនុញ្ញាត និងការយោងទៅលើការរឹតត្បិតដែលច្បាប់អនុញ្ញាតចំពោះសេរីភាពក្នុងការសម្តែងការប្រតិបត្តិសាសនា[2904]។ ការខកខានក្នុងការរៀបរាប់ជាក់លាក់នូវសិទ្ធិដែលត្រូវបានរំលោភបំពាននោះ គឺជាការគួរឱ្យសោកស្តាយ ប៉ុន្តែពុំបានប៉ះពាល់ដល់សុពលភាពនៃការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ដោយសារសិទ្ធិមូលដ្ឋាននៃសេរីភាពផ្នែកសាសនា ព្រមទាំងសិទ្ធិនៃសេចក្តីថ្លៃថ្នូររបស់បុគ្គលត្រូវបានរំលោភបំពានយ៉ាងច្បាស់លាស់ដោយការរឹតត្បិតផ្នែកសាសនា និងវប្បធម៌។

vi. ថាតើ មានចេតនាក្នុងការរើសអើងដោយសារមូលហេតុនៃសាសនា ដែរ ឬយ៉ាងណា

1037.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់នៅពេលសំអាងទៅលើការយល់ឃើញដែលមិនត្រឹមត្រូវក្នុងការសន្និដ្ឋានចេតនារើសអើងលើជនជាតិចាមថា "ដោយសារតែការប្រតិបត្តិផ្នែកសាសនា និងវប្បធម៌របស់ពួកគេ"[2905]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិចាមត្រូវបានរើសអើងជាក្រុមនយោបាយ ប៉ុន្តែក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលដោះស្រាយបញ្ហានៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា បានយល់ឃើញថា មានចេតនាក្នុងការរើសអើងលើជនជាតិចាមដោយផ្អែកលើមូលហេតុផ្នែកសាសនា ដោយគ្មានការពន្យល់នូវមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះផ្លាស់ប្តូរមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញ[2906]។

1038.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញច្បាស់លាស់ថា អំពើនោះត្រូវបានអនុវត្តស្របតាមគោលនយោបាយកំណត់គោលដៅជាក់លាក់លើជនជាតិចាមថា ជាក្រុមកាន់សាសនា[2907] និងថា ក្រុមជនរងគ្រោះអាចត្រូវបានកំណត់គោលដៅច្រើនដងដោយសារមូលហេតុនៃការធ្វើទុក្ខបុក

[2904] *សូមមើលខាងលើ* កថាខណ្ឌ ១០២៦។

[2905] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥៨ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៩។

[2906] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៥៩។

[2907] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៩៤។

ម្ចេញផ្សេងៗគ្នា ហើយបទចោទនីមួយៗបានកើតចេញពីអង្គហេតុផ្សេងៗគ្នាដែលបង្ហាញនូវលក្ខណៈល្មើសខុសៗគ្នា[2908]។

1039.បន្ទាប់ពីបានពិភាក្សាលើការរឹតត្បិតមួយចំនួនលើជនជាតិចាម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "យោងតាមការលើកឡើងខាងលើ" អង្គជំនុំជម្រះជឿជាក់ថា "ការរឹតត្បិតនេះគឺជាការរើសអើងជាក់ស្តែង និងត្រូវបានប្រព្រឹត្តដោយចេតនារើសអើងលើជនជាតិចាមដោយសារការប្រតិបត្តិសាសនា និងវប្បធម៌"[2909]។

1040.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សាលក្រមគប្បីពិនិត្យជារួម ហើយការយល់ឃើញនីមួយៗគប្បីពិនិត្យតាមបរិបទ។ ការយល់ឃើញដែលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានការរើសអើងលើជនជាតិចាមដោយសារមូលហេតុសាសនា និងវប្បធម៌ គឺជាការសន្និដ្ឋានមួយរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើភស្តុតាងដែលបានពិភាក្សាក្នុងកថាខណ្ឌខាងលើ និងការយល់ឃើញផ្នែកអង្គហេតុដែលបានធ្វើឡើងពីដំបូង[2910]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានចេតនាក្នុងការរើសអើងលើជនជាតិចាមដោយផ្អែកលើ"មូលដ្ឋានសាសនា និងវប្បធម៌"[2911]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន បានបំភ្លៃការយល់ឃើញដែលរងការជំទាស់នោះដោយបានអះអាងថា ការសន្និដ្ឋានអំពីចេតនាពុំមានមូលដ្ឋានគាំទ្រ និងមានកំហុសអង្គច្បាប់។ ការជំទាស់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសតាមរយៈការសន្និដ្ឋានចេតនាក្នុងការរើសអើងទៅលើមូលដ្ឋានសាសនា និងវប្បធម៌ត្រូវបដិសេធចោល។

1041.ទាក់ទងទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុនៅពេលធ្វើការសន្និដ្ឋានចេតនាក្នុងការរើសអើងដោយផ្អែកលើមូលដ្ឋាននយោបាយ និងសាសនា ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា វិធានការនេះត្រូវបានធ្វើ

---

[2908] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៩៦។

[2909] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៩។

[2910] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៨-៣៣២៩ យោងទៅលើកថាខណ្ឌ ៧១៩-៧២១, ៣២២៨, ៣២៤៥, ៣២៥០, ៣២២៩-៣២៥០ និងផ្នែក ១១.២.២.២២។

[2911] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣២៩ (ការបញ្ជាក់បន្ថែម)។

ឡើងដើម្បីអនុវត្តគោលនយោបាយកំណត់គោលដៅជាក់លាក់លើជនជាតិចាម[2912]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងការខិតខំបង្កើតសង្គមគ្មានការប្រតិបត្តិសាសនា និងដូចៗគ្នាគ្មានការបែងចែកវណ្ណៈ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិចាម[2913] និងថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាចំពោះជនជាតិចាមបានវិវឌ្ឍជាដរាប៖ តាមរយៈការធ្វើឱ្យក្លាយជាជនជាតិខ្មែរតាមរយៈការបង្ក្រាបយ៉ាងឃោរឃៅបន្ទាប់ពី"ការបះបោរ"រហូតដល់មានការប្រែប្រួលចុងក្រោយនៅចន្លោះឆ្នាំ ១៩៧៧ ដល់ ១៩៧៨ នៅពេលដែលមានការចេញបទបញ្ជាឱ្យបោសសម្អាតជនជាតិចាមទាំងអស់[2914]។

1042. ពុំអាចមិនអើពើលើភស្តុតាងច្បាស់លាស់ដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងដូចជា៖ ការរឹតត្បិតលើការប្រតិបត្តិសាសនា និងវប្បធម៌ ដែលក្នុងគោលបំណងរំលាយជនជាតិចាម នៅពីក្រោយការបង្ក្រាបការបះបោរនោះ[2915]។ អត្តសញ្ញាណរបស់ពួកគេជាជនជាតិចាមដែលមានការប្រតិបត្តិសាសនាផ្សេង និងការស្តាប់ការណែនាំពីមេដឹកនាំសាសនា និងគ្រូរបស់ពួកគេ លក្ខណៈនៃជីវិតខុសប្លែករបស់ពួកគេរស់នៅលើ ឬតាមមាត់ច្រាំងទន្លេ និងពុំមែនជាអ្នកធ្វើស្រែចំការ ឬអ្នកនៅទីប្រជុំជន ពុំស្របជាមួយនឹងផែនការរួមបក្សកុម្មុយនីស្តកម្ពុជាក្នុងការលុបបំបាត់ភាពខុសប្លែកគ្នាក្នុងវណ្ណៈសង្គម និងបង្កើតពូជសាសន៍ខ្មែរនៃវណ្ណៈកម្មករកសិករតែមួយដូចៗគ្នា។ ការកំណត់គោលដៅលើជនជាតិចាមគឺដោយសារពួកគេជាជនជាតិចាមដែលមានដើមកំណើតជាក្រុមជាតិពន្ធុ ភាសា សាសនា និងទំនៀមទម្លាប់ផ្សេងដែលធ្វើឱ្យពួកគេខុសប្លែកពីជនជាតិខ្មែរដែលភាគច្រើន[2916]។ ដើម្បីលុបបំបាត់ភាពខុសប្លែកគ្នានេះ សាសនារបស់ពួកគេ និងការប្រតិបត្តិត្រូវបានហាមឃាត់ និងពុំមានករណីលើកលែងសូម្បីតែការប្រកាន់គ្រណាមតឹងរ៉ឹងចំពោះការមិនបរិភោគសាច់ជ្រូក ឬរបស់ធ្វើពីសាច់ជ្រូកក៏ដោយ[2917] ឬការកំណត់ឱ្យអធិដ្ឋានប្រាំដងរៀងរាល់ថ្ងៃ[2918]។ ក្នុងករណីជនជាតិចាម អាចជាការលំបាកក្នុងការបែងចែករវាងការកំណត់គោលដៅលើសត្រូវដោយផ្អែក

---

[2912] *សូមមើលខាងក្រោម* ផ្នែក VIII.ខ.៥.ខ។

[2913] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

[2914] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

[2915] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨ យោងទៅលើកថាខណ្ឌ ៣២៥១-៣២៦៨។

[2916] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

[2917] អង្គជំនុំជម្រះសាលាដំបូងបានទទួលភស្តុតាងបង្ហាញថា ការប្រកែកមិនបរិភោគសាច់ជ្រូកមានផលវិបាក។ *សូមមើល* ប្រតិចារឹកថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ (ហ៊ីម ម៉ាន) ឯកសារលេខ E1/349.1 ទំព័រ ២៩-៣០។ ប្រតិចារឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ (ហ៊ីម ម៉ាន) ឯកសារលេខ E1/350.1 ទំព័រ ១២។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/304.1 ទំព័រ ៨៤។

[2918] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៥០។

លើមូលដ្ឋាននយោបាយដោយសារតែការបះបោរក្នុងចុងឆ្នាំ ១៩៧៥ ឬដោយសារពួកគេជាជនជាតិចាម ដែលមានទំនៀមទម្លាប់ផ្សេង និងជាពិសេសគឺជាសាសនាប្រតិកិរិយា ដែលត្រូវតែលុបបំបាត់តាមរយៈការធ្វើឱ្យក្លាយជាប្រជាជនខ្មែរដូចការធ្វើឡើងក្នុងអំឡុងពេលមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅមុនបទបញ្ជាក្នុងឆ្នាំ ១៩៧៧ ឱ្យសម្លាប់រង្គាល។ ប្រវត្តិនៃការកំណត់គោលដៅកាន់តែតឹងរ៉ឹងឡើងសម្រាប់ការរើសអើង និងចុងក្រោយការបោសសម្អាតទាំងមូល គឺជាភស្តុតាងនៃគោលបំណងពិតប្រាកដសម្រាប់ការកំណត់គោលដៅដែលបានបង្កើតឡើង៖ ដោយសារពួកគេពុំមែនជាជនជាតិខ្មែរ។ ការកំណត់គោលដៅកាន់តែធ្ងន់ធ្ងរនេះពុំបានធ្វើឱ្យប៉ះពាល់ការពិតនៃការរើសអើងក្នុងកម្រិតទាបជាងលើពួកគេសម្រាប់ហេតុផលសាសនាដែលបានចាប់ផ្តើមក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហមស្រុកក្រូចឆ្មារ និងតំបន់ជុំវិញ និងបានបន្តក្រោយមកទៀត[2919]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនាក្នុងការរើសអើងផ្អែកលើមូលដ្ឋានសាសនា និងនយោបាយជាការសមហេតុផល។

1043.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានត្រឹមតែលើកការបកស្រាយមួយផ្សេងលើភស្តុតាងដោយសារខកខានក្នុងការទទួលស្គាល់ភាពខុសប្លែកគ្នារវាងការលុបបំបាត់វណ្ណៈសង្គមឱ្យក្លាយទៅជាកម្មករកសិករដែលត្រូវដាក់ឱ្យស្ថិតក្រោមការដកហូតសិទ្ធិដូចគ្នា និងសកម្មភាពជាក់លាក់ក្នុងការដកជនជាតិចាមចេញពីសង្គមខ្មែរ។ ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការបង្កើតការយល់ឃើញថា ជនជាតិចាមត្រូវបានកំណត់ជាក់លាក់ថា ជាក្រុមសាសនា។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

### vii. ថាតើ កម្រិតនៃភាពធ្ងន់ធ្ងរត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា

1044.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការវាយតម្លៃលើកម្រិតនៃភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តដោយរើសអើងក្នុងការកំណត់ថាតើ អំពើនេះបានឈានដល់កម្រិតធ្ងន់ធ្ងរស្មើនឹងការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះបានបញ្ជាក់ខាងក្រោមថា៖

> អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញបានរួមបញ្ចូលអំពើដែលត្រូវបានយល់ឃើញដាច់ដោយឡែក ដែលស្មើនឹងបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(រួមទាំងអំពើមនុស្សឃាត ការសម្លាប់រង្គាល ការឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ (រួមទាំងការធ្វើទារុណកម្ម អំពើប្រល័យពូជសាសន៍ និងអំពើដែលត្រូវបាន

[2919] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨, ៣២៣០។

កំណត់ចរិតលក្ខណៈថា ជាការផ្លាស់ទីដោយបង្ខំ) ព្រមទាំងអំពើដែលខ្លួនឯងផ្ទាល់ពុំចាំបាច់ស្មើនឹងបទឧក្រិដ្ឋ (ជាពិសេស ការចាប់ខ្លួន)[2920]។

ទោះជាយ៉ាងណាក្តី ពុំមែនរាល់អំពើទាំងនេះត្រូវបានចាត់ទុកថា ជាអំពើនៃការធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានោះទេ និងពុំអាចប្រើប្រាស់ក្នុងការវាយតម្លៃលើកម្រិតធ្ងន់ធ្ងរឡើយ។ គាត់បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើបទប្រល័យពូជសាសន៍ បើទោះបីជាគាត់ត្រូវបានលើកលែងចោទប្រកាន់បទឧក្រិដ្ឋនេះក៏ដោយ[2921]។

1045.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការធ្វើទុក្ខបុកម្នេញ រួមបញ្ចូល "អំពើ *ទាំងអស់*ដែលបានប្រព្រឹត្តទូទាំងប្រទេសពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ" និងពុំត្រូវបានកម្រិតត្រឹមការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ដែលបានរៀបរាប់ក្នុងកថាខណ្ឌ ៣៣២៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ[2922]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសនៅពេលសន្និដ្ឋានអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងថា ការតវ៉ារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការកំណត់ថាតើ អំពើណាមួយមានកម្រិតធ្ងន់ធ្ងរដែលតម្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញនោះ បង្ហាញនូវការយល់របស់គាត់ពុំត្រឹមត្រូវនៃច្បាប់[2923]។

1046.សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញាទាំងស្រុង។ សហមេធាវីនាំមុខបានឆ្លើយតបបន្ថែមថា សម្រាប់បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ អំពើពុំចាំបាច់តែជាបទឧក្រិដ្ឋអន្តរជាតិនោះទេ។ មានការបង្ហាញច្បាស់លាស់ថា អំពើនោះបានបំពេញតាមបទដ្ឋាននៃការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន[2924]។

1047.អង្គជំនុំជម្រះតុលាការកំពូលបានកំណត់រួចរាល់ថាតើ អំពើណាមួយត្រូវបានចាត់ទុកថា ជាអំពើនៃការធ្វើទុក្ខបុកម្នេញសម្រាប់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនានោះ[2925]។

---

[2920] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣១។

[2921] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៦២-៩៦៣។

[2922] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៨។

[2923] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៣៩។

[2924] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៦៦។

[2925] *សូមមើលខាងលើ* ផ្នែក VII.ច.៣.ក.i។

ទាំងនេះគឺជាការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ដែលត្រូវបានដាក់ទៅលើជនជាតិចាម និងពុំបានរួមបញ្ចូលបទឧក្រិដ្ឋដទៃទៀតដែលត្រូវបានប្រព្រឹត្តទៅលើពួកគេឡើយ។

1048.បើទោះបីជាការគួរឱ្យសោកស្តាយដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់នូវការវិភាគសមស្របលើបញ្ហាថាតើ ការរឹតត្បិតផ្នែកសាសនា និងវប្បធម៌"អាចឈានដល់កម្រិតធ្ងន់ធ្ងរ ដែរ ឬយ៉ាងណា"[2926]ដែលជាបទល្មើសមូលដ្ឋានដទៃទៀតសម្រាប់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែផ្ទុយទៅវិញមានការភាន់ច្រឡំលើបញ្ហានៃការយោងទៅលើបទឧក្រិដ្ឋដទៃទៀតដែលបានប្រព្រឹត្តលើជនជាតិចាមក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ពិតណាស់អាចឈានដល់កម្រិតធ្ងន់ធ្ងរតម្រូវដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ មិនត្រឹមតែបានដកហូតសិទ្ធិជាមូលដ្ឋាននៃសេរីភាពផ្នែកសាសនាប៉ុណ្ណោះទេ ថែមទាំងបានបំផ្លាញអត្តសញ្ញាណរបស់ជនជាតិចាម។ ការរឹតត្បិតនេះបានធ្វើឱ្យជនជាតិចាមបាត់បង់ចរិតលក្ខណៈដែលធ្វើឱ្យពួកគេជាជនជាតិចាម និងធ្វើឱ្យបាត់បង់សមត្ថភាពផ្ទេរអត្តសញ្ញាណសាសនាទៅឱ្យជំនាន់ក្រោយ និងបានបំផ្លិចបំផ្លាញជាដរាបនូវកេរដំណែលសាសនារបស់ពួកគេ[2927]។ កម្រិតធ្ងន់ធ្ងរតម្រូវនោះត្រូវបានបង្ហាញសម្រាប់អំពើនៃការធ្វើទុក្ខបុកម្នេញ ដែលស្មើនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវិភាគលើភាពធ្ងន់ធ្ងរនៃអំពើពុំអាចមោឃៈការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាបានឡើយ។

---

[2926] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៦ ("អំពើនៃការធ្វើទុក្ខបុកម្នេញអាចមានរួមបញ្ចូលទាំងបទល្មើសជាក់លាក់ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម) ក៏ដូចជាអំពើផ្សេងទៀតដែលមានកម្រិតស្ថានទម្ងន់ឬភាពធ្ងន់ធ្ងរស្មើគ្នារួមបញ្ចូលទាំងអំពើនានាដែលមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិនោះផងដែរ។ ក្នុងការសម្រេចថាតើ លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញហើយ ឬយ៉ាងណានោះ អំពើទាំងនោះមិនគួរត្រូវបានពិចារណាដោយឯកឯងនោះឡើយ ពោលគឺវាគប្បីត្រូវបានពិនិត្យពិចារណានៅក្នុងបរិបទព្រមជាមួយនឹងផលប៉ះពាល់នានាដែលបានកើតឡើងដោយអំពើទាំងនោះ។ ជាញឹកញាប់ ទោះបីជាការធ្វើទុក្ខបុកម្នេញ រួមមានអំពើដែលបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ ប៉ុន្តែអំពើសកម្មឬអំពើអកម្មតែមួយដែលមានភាពធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរខ្លាំង ក៏អាចគ្រប់គ្រាន់ជាការធ្វើទុក្ខបុកម្នេញផងដែរ ប្រសិនបើអំពើនោះបណ្តាលឲ្យមានការបំពារបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមនុស្សជាមូលដ្ឋានដែលមានចែងនៅក្នុងសន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ")(ការយោងខាងក្នុងលុបចោល)។

[2927] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៤២។

## ខ. ការធ្វើទុក្ខបុកម្នេញផ្អែកសាសនាលើពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនា

1049.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាលើព្រះសង្ឃពុទ្ធសាសនា ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់[2928]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការកំណត់នេះលើការយល់ឃើញថា *ក្នុងចំណោមនោះ* ព្រះសង្ឃពុទ្ធសាសនាជាង ១០០ អង្គត្រូវបានប្រមូលផ្តុំនៅវត្តអង្គរកាក្នុងស្រុកត្រាំកក់ និងត្រូវបានបង្ខំឱ្យលាចាកសិក្ខាបទ[2929]។ ឯម គឿង ជាព្រះសង្ឃដែលបានមកដល់ស្រុកត្រាំកក់ពីភ្នំពេញស្ថិតក្នុងចំណោមព្រះសង្ឃដែលត្រូវបានប្រមូលផ្តុំនោះដែរ[2930]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ព្រះសង្ឃត្រូវបានកំណត់គោលដៅដោយផ្អែកលើអត្តសញ្ញាណសាសនា និងបានកំណត់គោលដៅដោយសារតែជាព្រះសង្ឃ តាមការបញ្ជារបស់ យាយ ខុម ដែលជាលេខាស្រុក។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការចាប់ផ្សឹកព្រះសង្ឃដោយបង្ខំនៅតាមវត្តផ្សេងៗបានកើតឡើងស៊ីសង្វាក់គ្នាទូទាំងស្រុកត្រាំកក់[2931]។ បើទោះបីជាពុំអាចកំណត់ចំនួនព្រះសង្ឃសរុបដែលត្រូវបានចាប់ផ្សឹកក្នុងស្រុកត្រាំកក់នោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋាន"ព្រះសង្ឃរាប់រយអង្គត្រូវបានចាប់ផ្សឹកនៅតាមឃុំនានា"[2932]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការសំដៅទៅលើព្រះសង្ឃថា "ដង្កូវ" ឬ"ឈ្លើង"ព្រមទាំងការប្រមាថពុទ្ធសាសនាថា គ្រាន់តែជាអបិយជំនឿ និងព្រះបដិមាថា "គ្រាន់តែជាស៊ីម៉ង់ត៍"បានបង្ហាញនូវចេតនារើសអើងនៅពីក្រោយដំណើរការនោះ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការយល់ឃើញទាំងនេះបានបង្ហាញថា "អំពើដែលត្រូវបានបង្ហាញក្នុងរឿងក្តីនេះគឺជាការរើសអើងដោយចេតនាលើព្រះសង្ឃពុទ្ធសាសនា ដោយសារតែជាព្រះសង្ឃ" និងថា អំពើនេះគឺជាការរើសអើងជាក់ស្តែងពីព្រោះជនរងគ្រោះ គឺជាសមាជិកនៃក្រុមសាសនាដែលត្រូវបានកំណត់គោលដៅៈ ព្រះសង្ឃពុទ្ធសាសនា[2933]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា "ការចាប់ផ្សឹកព្រះសង្ឃរាប់រយអង្គក្នុងស្រុកត្រាំកក់ ស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[2934]។

---

[2928] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៣-១១៨៧។

[2929] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩៤-១០៩៦, ១១៨៣, ១១៨៥។

[2930] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩៤។

[2931] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៣។

[2932] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១០៥, ១១៨៣។

[2933] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥។

[2934] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥។

1050.បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា និមិត្តរូបតំណាងពុទ្ធសាសនាត្រូវបានបំផ្លាញ ហើយទីវត្តអារាមត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងដែលពុំមែនពាក់ព័ន្ធសាសនាទូទាំងស្រុកត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា មានភស្តុតាងបង្ហាញនូវការលុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិសាសនាដែលជា"ការវាយប្រហារដោយមានការរៀបចំ និងយ៉ាងដំណំទៅលើសាសនា"ដែលត្រូវបានចាត់ទុកថា ពុំត្រូវធាតុជាមួយនឹងការអនុវត្តន៍បដិវត្តន៍[2935]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ត្រូវបានបង្ហាញទាក់ទងទៅនឹងការបំផ្លាញនិមិត្តរូបតំណាងព្រះពុទ្ធសាសនា ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសយកទីកន្លែងសក្ការៈបូជា និងការហាមឃាត់ការសម្តែងការប្រតិបត្តិសាសនា ឬជំនឿ"ដែលបានរើសអើងទៅលើអ្នកទាំងនោះដែលមានជំនឿលើពុទ្ធសាសនា និងបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពផ្នែកសាសនា[2936]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការលុបបំបាត់ការប្រត្តិបត្តិសាសនា និមិត្តរូបសាសនា និងការហាមឃាត់អ្នកស្រុកភូមិមិនឱ្យយកចង្ហាន់ទៅប្រគេនលោក បានដកហូតប្រជាជននូវ"មូលដ្ឋានផ្នែកចិត្តសាស្ត្រ"[2937]។ ដោយផ្អែកលើការពិចារណាទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ផលប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយនៃព្រឹត្តិការណ៍នេះ "បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងកម្រិតនៃបទឧក្រិដ្ឋនានាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ហើយ"អំពើនេះបានរើសអើងជាក់ស្តែងពីព្រោះបានកំណត់គោលដៅលើអ្នកដែលមានជំនឿលើពុទ្ធសាសនា និងមានសារតារពាក់ព័ន្ធ ដោយផ្អែកទាំងស្រុងទៅលើទីកន្លែងសក្ការៈ និមិត្តរូប និងការប្រតិបត្តិណាខ្លះដែលមានអត្ថន័យចំពោះពួកគេ"[2938]។ ដូច្នេះ អំពើនេះស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2939]។

1051.អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ធាតុផ្សំសត្យានុម័ត និង*ធាតុផ្សំអត្តនោម័តិ* នៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកផ្អែកលើមូលហេតុសាសនា ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់។

1052.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាច្រើនដូចជា៖ (១) ការខកខានក្នុងការពិចារណាលើចេតនាក្នុងការដកព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជាទូទៅចេញពីសង្គម

---

[2935] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤, ១១០៥, ១១០៧-១១០៨, ១១៨៥។

[2936] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2937] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2938] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2939] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

ដែលជាផ្នែកនៃលក្ខខណ្ឌតម្រូវ *ធាតុផ្សំអត្តនោម័តិ* (២) ការបង្កើតការយល់ឃើញបើទោះបីជាកង្វះភស្តុតាងទាក់ទងទៅនឹងផលប៉ះពាល់ផ្លូវចិត្ត ឬរូបកាយនៃអំពើធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកក៏ដោយ និង (៣) ការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញបានកើតឡើងបើទោះបីជានត្ថិភាពនៃការប្រព្រឹត្តដោយរើសអើងទៅលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជាទូទៅក៏ដោយ[2940]។

1053.ដោយសារបញ្ហាទីមួយត្រូវបានពិភាក្សារួចរាល់[2941] អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើអំណះអំណាងដែលនៅសេសសល់តែពីរប៉ុណ្ណោះ។

i. ការចោទប្រកាន់អំពីកង្វះភស្តុតាងទាក់ទងទៅនឹងផលប៉ះពាល់លើរូបកាយ ឬផ្លូវចិត្តនៃអំពើធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិក

1054.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារបានយល់ឃើញថា "ផលប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយនៃព្រឹត្តិការណ៍ទាំងនេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងកម្រិតធ្ងន់ធ្ងរមួយដែលប្រហាក់ប្រហែលទៅនឹងកម្រិតធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដោយផ្អែកលើការយល់ឃើញដែលថា ការលុបបំបាត់ការប្រតិបត្តិសាសនាបានដកហូតបុគ្គលនូវ"មូលដ្ឋាននៃចិត្តសាស្ត្រ"[2942] និងថា ជាទូទៅ "ពិធីរៀបអាពាហ៍ពិពាហ៍លែងត្រូវបានធ្វើឡើងស្របតាមទំនៀមទម្លាប់របស់ប្រជាជនកម្ពុជា"[2943]។ គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃភស្តុតាងក្នុងលក្ខណៈមិនសមហេតុផល ដោយផ្អែកជាសំខាន់ទៅលើសក្ខីកម្មអត្តនោម័តិ និងផ្ទាល់ខ្លួនរបស់ដើមបណ្ដឹង ប៊ុន សារឿន[2944]។ គាត់អះអាងថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើការចាត់ទុកជាលក្ខណៈទូទៅហួសហេតុ និងការបំផ្លើសភស្តុតាងដែលពុំអាចគាំទ្រថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាត្រូវបានបង្ហាញនោះឡើយ[2945]។

---

[2940] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣-៧៤៧។

[2941] *សូមមើលខាងលើ* ផ្នែក VII.ច.១.ក។

[2942] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៦។

[2943] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៦ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2944] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ (ប៊ុន សារឿន) ឯកសារលេខ E1/288.1 ទំព័រ ២៥។

[2945] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៧។

1055.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការជំទាស់របស់ ខៀវ សំផន មិនត្រឹមតែបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះទេ ថែមទាំងបានកម្រិតត្រឹមការលើកភស្តុតាងតែមួយ និងពុំបានអើពើលើផលប៉ះពាល់ត្រួតគ្នានៃអំពើធ្វើទុក្ខបុកម្នេញ និងលើការពិតដែលថា អំពើទាំងនោះបានកើតឡើងដែលជាផ្នែកនៃយុទ្ធនាការធ្វើទុក្ខបុកម្នេញទ្រង់ទ្រាយធំរបស់បក្សកុម្មុយនីស្តកម្ពុជាលើពុទ្ធសាសនិក[2946]។ បន្ថែមលើនេះ គាត់ពុំបានជំទាស់ទៅលើការយល់ឃើញផ្នែកអង្គច្បាប់បន្ថែមស្តីពីភាពធ្ងន់ធ្ងរនៃអំពើរើសអើងលើព្រះសង្ឃ[2947]។ សហព្រះរាជអាជ្ញាបានអះអាងថា តាមការពិនិត្យជារួមលើការយល់ឃើញផ្នែកអង្គច្បាប់បូករួមជាមួយនឹងការយល់ឃើញពីដំបូងផ្នែកអង្គហេតុ និងអង្គច្បាប់ និងការយោងឆ្លងរបស់អង្គជំនុំជម្រះឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងជាច្រើនផ្សេងៗគ្នាក្នុងការបង្ហាញអំពី“ការបំផ្លាញនិមិត្តរូបពុទ្ធសាសនា ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសយកទីសក្ការៈបូជា” និង“ការហាមឃាត់ការសម្តែងនូវការប្រតិបត្តិ ឬជំនឿសាសនា”[2948]។ សហព្រះរាជអាជ្ញាបានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកផងដែរទៅលើលក្ខណៈសំខាន់នៃពុទ្ធសាសនាក្នុងសង្គមកម្ពុជានៅពេលនោះ[2949] ទំហំ និងរយៈពេលនៃអំពើធ្វើទុក្ខបុកម្នេញក្នុងស្រុកនោះ[2950] និងវិសាលភាពដែលពុទ្ធសាសនិកបានទទួលរងដោយសារផលប៉ះពាល់នៃអំពើទាំងនោះ[2951]។

1056.យោងតាមសហមេធាវីនាំមុខបានឱ្យដឹងថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ថាជាអត្តនោម័តិ ផ្ទាល់ខ្លួន និងត្រឹមតែពាក់ព័ន្ធទៅនឹង“នត្ថិភាពនៃវត្តអារាម”[2952]។ ផ្ទុយទៅវិញ សហមេធាវីនាំមុខបានលើកឡើងថា ភស្តុតាងនេះបានជាប់ពាក់ព័ន្ធទៅនឹង

[2946] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤០៨។

[2947] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤០៨, ៤១១-៤១៣។

[2948] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១១ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2949] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១១-៤១២ និងជើងទំព័រ ១៥៤៥, ១៥៤៨-១៥៥០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥ ជើងទំព័រ ៣៦១៣ ដែលយោងទៅលើ*ក្នុងចំណោមនោះ*កថាខណ្ឌ ១០៨៨ និងជើងទំព័រ ៣៦១៣។

[2950] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១១-៤១២ និងជើងទំព័រ ១៥៤៦។

[2951] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១១-៤១២ និងជើងទំព័រ ១៥៤៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤-១១៨៧។

[2952] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧២, ៤៧៤។

នត្តិភាពព្រះសង្ឃ និងពិធី និងការប្រតិបត្តិបែបសាសនាជាទូទៅ[2953] និងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើភស្តុតាងពីប្រភពផ្សេងៗក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃអំពើប្រឆាំងនឹងពុទ្ធសាសនិក[2954]។ ជាឧទាហរណ៍ បុគ្គលពីរនាក់រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី មៀច ប៉ុណ្ណ បានផ្តល់ភស្តុតាងចំពោះមុខសហចៅក្រមស៊ើបអង្កេតថា ព្រះសង្ឃពុទ្ធសាសនាបានធ្វើអត្តឃាតដោយសារគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ[2955]។ សហមេធាវីនាំមុខបានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការសន្និដ្ឋានដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីតែម្នាក់បាន[2956]។ សហមេធាវីនាំមុខបានកត់សម្គាល់ផងដែរថា លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរត្រូវបានបង្ហាញរួចរាល់ និងបានយោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY[2957]។

1057.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កថាខណ្ឌដែល ខៀវ សំផន បានយោងទៅលើទាក់ទងទៅនឹងអំពើនៃការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជាទូទៅ ដូចជាការបំផ្លាញនិមិត្តរូបតំណាងព្រះពុទ្ធ ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសទីសក្ការៈបូជា និងការហាមឃាត់ការសម្តែងនូវការប្រតិបត្តិ ឬជំនឿ

---

[2953] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧២ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ (ប៊ុន សារឿន) ឯកសារលេខ E1/288.1 ទំព័រ ២៦ ("រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថា វាសោកស្តាយដែរ កន្លែងធ្លាប់បូជា កន្លែងគោរពទាល់តែទៅអត់មានលោក មានអីចឹង ដឹងថា វាពិបាក ធ្លាប់មានបុណ្យមានទាន ដល់ពេលអត់មានបុណ្យមានទាន អីចឹងខ្ញុំក៏វាពិបាក។ ការនឹងគោរពបូជា វាដូចជាវាគ្មានអីទីពឹងអីទាំងអស់")។

[2954] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧១។

[2955] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧៤ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី មៀច ប៉ុណ្ណ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ E3/5523 ERN 00414425។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទេព ដុំ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ E3/7983 ERN 00165213។

[2956] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧១ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤២៤។

[2957] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៧៥ ដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Đorđević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87/1-A ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ ("សាលដីការឿងក្តី *Đorđević* (ICTY)") កថាខណ្ឌ ៥៦៧:

*ការបំផ្លាញទ្រព្យសម្បត្តិសាសនាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលស្មើនឹង"ការវាយប្រហារលើអត្តសញ្ញាណសាសនារបស់បុគ្គល" និងបង្ហាញឱ្យឃើញអំពី"ការសម្តែងចេញពិតប្រាកដ"នូវសញ្ញាណឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូងមួយចំនួន។ ភស្តុតាងដែលបង្ហាញថា អាគារត្រូវបានចាត់ទុកថាជាកន្លែងសាសនានោះបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរស្មើគ្នាដោយពុំចាំបាច់មានការវាយតម្លៃលើតតម្លៃនៃទ្រព្យសម្បត្តិជាក់លាក់ចំពោះសហគមន៍ជាក់លាក់ណាមួយនោះទេ។*

សាសនា[2958]។ ខៀវ សំផន ពុំបានជំទាស់ទៅនឹងភាពធ្ងន់ធ្ងរនៃអំពើធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនា ដែលត្រូវបានដោះស្រាយក្នុងកថាខណ្ឌមួយផ្សេងនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង[2959]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិនិត្យលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងអំពើនៃការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជាទូទៅ ដែរ ឬយ៉ាងណា។

1058.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដើម្បីបង្ហាញធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យយល់ឃើញថា អំពើប្រព្រឹត្តទៅលើពុទ្ធសាសនិក ជាការរើសអើងជាក់ស្តែង និងបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់ និងសន្ធិសញ្ញាអន្តរជាតិ។ សម្រាប់អំពើនៃការធ្វើទុក្ខបុកម្នេញដែលពុំបានរៀបរាប់ក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងដើម្បីឱ្យអំពើនេះក្លាយជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវបន្ថែមទៀតឱ្យយល់ឃើញថា អំពើទាំងនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើដែលបានរៀបរាប់ក្នុងមាត្រា ៥ នោះ ដែលមានដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការរំលោភសេពសន្ថវៈ។ អំពើទាំងនេះត្រូវពិចារណាក្នុងបរិបទ និងផ្អែកលើអនុភាពត្រួតគ្នា[2960]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលគ្នានូវលក្ខខណ្ឌតម្រូវដែលដាច់ដោយឡែកតាមរយៈការសន្និដ្ឋានថា "ផលប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយនៃអំពើប្រព្រឹត្តទៅលើពុទ្ធសាសនិកជាទូទៅបានរំលោភបំពានសិទ្ធិជាមូលដ្ឋានក្នុងកម្រិតធ្ងន់ធ្ងរដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងភាពធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ដទៃទៀត"[2961]។ ពិតណាស់ ពុំមានភាពចាំបាច់ត្រូវពិចារណាលើផលប៉ះពាល់នៃអំពើទៅលើក្រុមជាក់លាក់នៅពេលកំណត់ថាតើ អំពើនៃការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិផ្នែកសាសនា ឈានដល់កម្រិតធ្ងន់ធ្ងរដែលជាលក្ខខណ្ឌតម្រូវ ដែរ ឬយ៉ាងណាឡើយ។ ដូចបានពន្យល់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kordić និង Čerkez* ដែលអង្គជំនុំជម្រះតុលាការកំពូលយល់ស្រប

[2958] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2959] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៧។

[2960] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧១៦។

[2961] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

ជាមួយថា នេះគឺដោយសារ"មនុស្សជាតិទាំងអស់ពិតណាស់ត្រូវទទួលរងព្យសនកម្មតាមរយៈការបំផ្លិចបំផ្លាញវត្ថុតំណាងវប្បធម៌ និងសាសនា"[2962]។

1059.អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញដែលថា ការលុបបំបាត់ការប្រតិបត្តិសាសនា និមិត្តរូបតំណាងសាសនា និងការហាមឃាត់អ្នកស្រុកភូមិមិនឱ្យយករបស់របរប្រគេនព្រះសង្ឃ ជាការដកហូតនូវ"មូលដ្ឋាននៃចិត្តសាស្ត្រ"[2963] ឬថា នេះពុំមែនជាសំអាងហេតុតែមួយគត់សម្រាប់ការយល់ឃើញនៃការរើសអើងជាក់ស្តែង ឬថា អំពើនេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពផ្នែកសាសនា។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា អំពើទាំងនោះគឺជាការរើសអើងដោយសារ"បានកំណត់គោលដៅលើអ្នកដែលមានជំនឿ និងសាវតារពាក់ព័ន្ធពុទ្ធសាសនា ដោយផ្អែកទាំងស្រុងលើទីកន្លែង និមិត្តរូបតំណាង និងការប្រតិបត្តិ ដែលមានអត្ថន័យចំពោះបុគ្គលទាំងនោះ"[2964]។

1060.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើតែសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប៉ុណ្ណោះទេដែលថា មានអារម្មណ៍"ខ្លោចផ្សាយ៉ាងខ្លាំង និងលែងមានអ្វីទីពឹងផ្នែកចិត្តសាស្ត្រ"[2965] ដោយសារនត្ថិភាពព្រះសង្ឃ ការគោរពបូជា ពិធី និងការប្រតិបត្តិសាសនា ព្រមទាំងការដែលថា ការរៀបអាពាហ៍ពិពាហ៍ពុំត្រូវបានធ្វើឡើងស្របតាមប្រពៃណីរបស់ប្រជាជនកម្ពុជា[2966]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកផងដែរទៅលើភស្តុតាងយ៉ាងទូលំទូលាយនៃការផ្តល់ប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយតាមរយៈអំពើទាំងនោះ ដូចបានយោងនៅក្នុងកថាខណ្ឌ ១១៨៦ ទៅលើផ្នែកផ្សេងៗនៃសាលក្រម

---

[2962] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić និង Čerkez* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-14/2-T សាលក្រមថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០១ ("សាលក្រមរឿងក្តី *Kordić និង Čerkez* (ICTY)") កថាខណ្ឌ ២០៧។ *សូមមើលផងដែរ* សាលក្រមរឿងក្តី *Kordić និង Čerkez* (ICTY) កថាខណ្ឌ ២០២, ២០៦។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានយល់ស្របជាមួយនឹងគោលជំហរនេះ។ *សូមមើល* សាលដីការឿងក្តី *Đorđević* (ICTY) កថាខណ្ឌ ៥៦៧។

[2963] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦ (អង្គជំនុំជម្រះសាលាដំបូងបានយោងលើចំណុចនេះ នៅពេលបដិសេធសារណារបស់ នួន ជា ដែលថា មានការរឹតត្បិតធម្មតាលើការបង្ហាញការប្រតិបត្តិសាសនាព្រះពុទ្ធ ដែលនេះពុំគ្រប់គ្រាន់ក្នុងការចាត់ទុកជាការហាមឃាត់លើសិទ្ធិជាមូលដ្ឋានក្នុងការប្រតិបត្ត ឬបង្ហាញការគោរពផ្នែកសាសនាឡើយ)។

[2964] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2965] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ (ប៊ុន សារឿន) ឯកសារលេខ E1/288.1 ទំព័រ ២៦ ("រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថា វាសោកស្តាយដែរ កន្លែងធ្លាប់បូជា កន្លែងគោរពទាល់តែទៅអត់មានលោក មានអីចឹង ដឹងថា វាពិបាក ធ្លាប់មានបុណ្យមានទាន ដល់ពេលអត់មានបុណ្យមានទាន អីចឹងខ្ញុំក៏វាពិបាក។ ការនឹងគោរពបូជា វាដូចជាវាគ្មានអីទីពឹងអីទាំងអស់")។

[2966] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦, ៣៦៣៦-៣៦៣៨។

[2967]។ ក្រៅពីនេះ ការដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់សំដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន ពុំមែនមានន័យថា អង្គជំនុំជម្រះបានផ្អែកតែទៅលើសក្ខីកម្មរបស់គាត់ប៉ុណ្ណោះទេ។

1061.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងទូលំទូលាយជាងនេះទៀតថា ពុទ្ធសាសនាគឺជាសាសនាចម្បងនៅក្នុងកម្ពុជាយ៉ាងហោចណាស់ចាប់តាំងពីសតវត្សទី ១៣[2968] និងមានទំនាក់ទំនង"ស្អិតល្មួតជាមួយនឹងអត្តសញ្ញាណកម្ពុជា និងបានជះឥទ្ធិពលខ្លាំងលើទិដ្ឋភាពជាច្រើននៃជីវិត"[2969]។ ព្រះសង្ឃពុទ្ធសាសនាក៏មានឥទ្ធិពលផងដែរ និងមានតួនាទីសំខាន់ក្នុងសង្គមកម្ពុជានៅពេលនោះ[2970]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ដោយសារផលវិបាកអវិជ្ជមាននៃគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការប្រព្រឹត្តយ៉ាងឃោរឃៅទៅលើពុទ្ធសាសនិក ទំហំ និងរយៈពេលចរិតលក្ខណៈជាប្រព័ន្ធ និងបរិយាកាសនៃការភ័យខ្លាច និងការបង្ខិតបង្ខំដែលបានធ្វើឡើងនោះ ទើបនេះគឺជាមូលហេតុដែល"ការលុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិពុទ្ធសាសនា"[2971]មានលក្ខណៈធ្ងន់ធ្ងរ និងហិង្សាជាពិសេស និងមានផលប៉ះពាល់យ៉ាងខ្លាំងលើជីវិតប្រចាំថ្ងៃ។

---

[2967] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦ យោង*ក្នុងចំណោមនោះ*ទៅលើកថាខណ្ឌ ១១០៥, ១១០៧-១១០៨, ៣៦៣៨ ដែលយោងទៅលើសក្ខីកម្មជាច្រើន និងកំណត់ហេតុស្ដាប់ចម្លើយសាក្សី។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុក ហ៊ុម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ឯកសារលេខ E3/9584 ទំព័រ ៧-៨ (ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដែលបានធ្វើឡើងដោយគ្មានការគោរពតាមប្រពៃណីខ្មែរ៖ "ខ្ញុំខ្លាចចាស់ទុំកាច់")។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ឯម ភឿង) ឯកសារលេខ E1/263.1 ទំព័រ ៣០, ៤០, ៦៤-៦៥ ("យើងលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៅជាភារៈជាឧបាសក។ ហ្នឹងសឹកហើយ ដល់ចាកធម៌ហើយ។ ពាក្យទាំងអស់ហ្នឹង ទីបញ្ចប់មកនៅត្រឹមតែសឹកដដែលទេ។ សឹកអីចឹង តែប៉ុណ្ណឹង មិនបាច់និយាយច្រើនពេកទេ [...]" "គឺមានបុគ្គលណាម្នាក់ប្រើអាជ្ញាឱ្យអ្នកបួសណាម្នាក់សឹកទៅលើឧបាសក ហើយសម័យ ប៉ុល ពត គឺអីចឹងតែម្ដង យើងភ័យខ្លាចពេលខ្មែរក្រហមមកដល់" "អ្នកបួសអត់នៅបានទេ ត្រូវតែសឹក")។ ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ (ខៀវ នៅ) ឯកសារលេខ E1/90.1 ទំព័រ ៧ ("នៅពេលគេបង្ខំឱ្យសឹក លោកត្រូវតែធ្វើតាមដើម្បីអាចរស់ជីវិត។ លោកមិនគិតអ្វីច្រើនទេ")។ ប្រតិចារឹក ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ (Alexander HINTON) ឯកសារលេខ E1/402.1 ទំព័រ ៤៩-៥០។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ៣១-៣២ ("ខ្ញុំលបទៅខាងយប់ហ្នឹង លបទៅហ្នឹង កុំឱ្យគេ មិនឱ្យគេដឹងទេ។ បើសិនណាជាឱ្យគេដឹង គេថាយើងនៅមានជំនឿមិនពិតហ្នឹង")។

[2968] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៧។

[2969] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៨។

[2970] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០, ២៦១។

[2971] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤។

1062.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នៅពេលអំពើនេះត្រូវបានពិចារណាត្រួតគ្នា និងក្នុងបរិបទ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានត្រឹមត្រូវថា អំពើទាំងនោះគឺជាការរើសអើងជាក់ស្តែង និងមានភាពធ្ងន់ធ្ងរយ៉ាងសំខាន់ច្បាស់លាស់ និងជាការរំលោភបំពានជាក់ស្តែងលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងជំនឿ មនសិការ និងសាសនា។

1063.ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញថា គ្មានតុលាការអង្គហេតុសមហេតុផលអាចធ្វើការសន្និដ្ឋានបែបនេះបាន ឬថា ការវាយតម្លៃរបស់អង្គជំនុំជម្រះលើភស្តុតាងជារួមមានកំហុសនោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

### ii. ការចោទប្រកាន់នត្ថិភាពនៃការប្រព្រឹត្តដោយរើសអើងទៅលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជាទូទៅ

1064.ដូចបានពិភាក្សាពីដំបូង និងប្រហាក់ប្រហែលគ្នាទៅនឹងអំណះអំណាងពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើជនជាតិចាមនៅការដ្ឋានទំនប់១មករា និងទូទាំងប្រទេសកម្ពុជា[2972] ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការកំណត់ចរិតលក្ខណៈការប្រព្រឹត្តដោយស្មើភាពគ្នាដែលមានផលប៉ះពាល់លើបុគ្គលមួយប្រភេទថា ជាការរើសអើងជាក់ស្តែង និងក្នុងការពិចារណាផលប៉ះពាល់លើពុទ្ធសាសនិកដោយសារវិធានការក្នុងគោលបំណងដើម្បីអនុវត្តចំពោះមនុស្សគ្រប់រូប[2973]។ គាត់បានអះអាងថា អំពើដែលបានប្រព្រឹត្តទៅលើព្រះសង្ឃពុទ្ធសាសនា ពុំអាចស្មើនឹងការរើសអើងជាក់ស្តែង[2974] និងថា ពុំមានការរើសអើងជាក់ស្តែង ឬចេតនានៃការរើសអើងពាក់ព័ន្ធទៅនឹងពុទ្ធសាសនិកជាទូទៅ ដោយសារពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមការរឹតត្បិតដូចប្រជាជនដទៃទៀតដែរ[2975]។

1065.ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានបញ្ជាក់សាជាថ្មី[2976]ថា ពុំមានលក្ខខណ្ឌតម្រូវបែងចែកផ្នែកច្បាប់រវាង ការរើសអើង"ផ្ទាល់" ឬ"ប្រយោល"នោះទេ[2977]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនាជាពិសេសបានទទួលរងផលវិបាកនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

---

[2972] *សូមមើលខាងលើ* ផ្នែក VII.ច.១.ខ។

[2973] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៥។

[2974] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៤។

[2975] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៥។

[2976] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧០, ៤៧៩, ៤៨៩, ៤៩១។

[2977] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤០៥។

ក្នុងការលុបបំបាត់សាសនា និងត្រូវបានកំណត់គោលដៅក្នុងករណីនេះនៅស្រុកត្រាំកក់ ដោយសារសមាជិកភាពរបស់ពួកគេស្ថិតក្នុងក្រុមសាសនា[2978]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា[2979]។

1066.ដោយហេតុថា អំណះអំណាងដែលយោងឆ្លងគ្នាពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ការប្រព្រឹត្តស្មើភាពគ្នាអាចបណ្តាលឱ្យមានការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា ត្រូវបានពិភាក្សារួចរាល់ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយលើបញ្ហាថាតើ មានការប្រព្រឹត្តដោយរើសអើងលើពុទ្ធសាសនិក និងព្រះសង្ឃ ដែរ ឬយ៉ាងណា។ ដោយសារតែអំណះអំណាងនៃបណ្តឹងសាទុក្ខមានលក្ខណៈពាក់ព័ន្ធគ្នា និងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយដំបូងលើអំពើនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនា មុនការចាប់ផ្តើមលើអំពើនៃការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជាទូទៅ។

- *ថាតើ អំពើនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនារើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា*

1067.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការចាប់ផ្សឹកដោយបង្ខំនូវព្រះសង្ឃរាប់រយអង្គទូទាំងស្រុកត្រាំកក់ គឺស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2980]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធយ៉ាងជាក់ច្បាស់លើអំណះអំណាងដែលថា ព្រះសង្ឃត្រូវបាន"ប្រព្រឹត្តទៅលើដូចអ្នកដទៃទៀតដែរ" ពីព្រោះអំពើដែលត្រូវបានបង្ហាញនោះបានរើសអើងដោយចេតនាលើព្រះសង្ឃពុទ្ធសាសនាដោយសារតែជាព្រះសង្ឃ[2981]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ការបង្ខំឱ្យព្រះសង្ឃលាចាកសិក្ខាបទ និងបោះបង់ជំនឿសាសនា ជាក់ស្តែងពុំមែនជារឿងស្មើភាពគ្នានោះទេ ដោយសារផ្អែកលើអ្វីដែលព្រះសង្ឃត្រូវបានបង្ខំឱ្យបោះបង់ គឺជាការប្រព្រឹត្តទៅលើក្នុងកម្រិតធ្ងន់ធ្ងរជារួម[2982]។

---

[2978] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤០៦។

[2979] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៤៥-៣៦២។

[2980] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥។

[2981] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥។ *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា សំណុំរឿង ០០២/០២ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ E457/6/3/1 កថាខណ្ឌ ៩០៥ (គាត់បានអះអាងថា "បើទោះបីជាការចាប់ផ្សឹកលើកសង្ឃបានកើតឡើងក៏ដោយ [...] ក៏នេះគឺជាការបង្ហាញនូវចេតនានៃរបបកម្ពុជាប្រជាធិបតេយ្យដើម្បីធានានូវសមភាពចំពោះប្រជាជនទាំងអស់ ដែលតម្រូវឱ្យធ្វើការទាំងអស់គ្នា និងរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេស")។

[2982] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៥។

1068.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានអំពើសកម្ម ឬអកម្មដែលរើសអើងជាក់ស្តែង និងដកហូត ឬរំលោភបំពានលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងច្បាប់សន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អំពើសកម្ម ឬអកម្មនៃការរើសអើងបានកើតឡើងនៅពេលជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារតែជនរងគ្រោះគឺជាសមាជិកស្ថិតក្នុងក្រុមមួយដែលត្រូវបានកំណត់អត្តសញ្ញាណដោយចារីផ្អែកលើមូលដ្ឋានជាក់លាក់ដូចជា នយោបាយ ពូជសាសន៍ ឬសាសនា[2983]។ អំពើសកម្ម ឬអកម្មនេះបានបណ្តាលឱ្យមានអត្ថិភាពនៃផលវិបាករើសអើងជាក់ស្តែង[2984]។ បញ្ហាបឋមក្នុងការកំណត់នេះគឺថាតើ ការយល់ឃើញអំពីការរើសអើងជាក់ស្តែងអាចត្រូវបានបង្ហាញដោយផ្អែកលើផលវិបាក ឬផលប៉ះពាល់ដែលក្រុមជាក់លាក់បានទទួលរង ដែរ ឬយ៉ាងណា។ ការរើសអើងជាក់ស្តែងសំដៅទៅលើថាតើ ក្រុមគោលដៅជាក់ស្តែងបានទទួលរងផលវិបាកដោយសារអំពើសកម្ម ឬអកម្មនោះ ដែរ ឬយ៉ាងណា ហើយត្រឹមតែចេតនារើសអើងមួយមុខមិនគ្រប់គ្រាន់ឡើយ[2985]។

1069.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ពុំតម្រូវឱ្យធ្វើការបែងចែករវាងការរើសអើងដោយផ្ទាល់ និងដោយប្រយោលឡើយនៅពេលបង្ហាញអត្ថិភាពនៃការរើសអើងជាក់ស្តែងនោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំជាប់ពាក់ព័ន្ធចំពោះបញ្ហា ថាតើអំពើនោះគឺជាការរើសអើងផ្ទាល់ ឬដោយប្រយោល ដែរ ឬយ៉ាងណា និងថាតើ ក្រុមនោះបានទទួលរងផលវិបាកនៃអំពើសកម្ម ឬអកម្មពាក់ព័ន្ធ ដែរ ឬយ៉ាងណានោះឡើយ។ អំពើសកម្ម ឬអកម្មត្រូវបានចាត់ទុកថា ជាការរើសអើងនៅពេលជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារតែជាសមាជិកនៃក្រុមមួយដែលត្រូវបានកំណត់អត្តសញ្ញាណដោយចារីផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា។ ចេតនានៅពីក្រោយអំពើសកម្ម ឬអកម្មគឺជាការកំណត់ថាតើ ជនរងគ្រោះត្រូវបានកំណត់គោលដៅតាមរយៈការរើសអើងដោយប្រយោល ដែរ ឬយ៉ាងណា។ ជួនកាលជាការចាំបាច់ត្រូវបង្ហាញថាតើ ច្បាប់ត្រូវបានកំណត់គោលដៅជាក់លាក់លើក្រុមមួយ ប៉ុន្តែដាក់ឱ្យអនុវត្តទៅលើមនុស្សគ្រប់រូប។

1070.ផ្អែកលើការធ្វើទុក្ខបុកម្នេញផ្អែកសាសនាលើព្រះសង្ឃពុទ្ធសាសនា អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការហាមឃាត់ទូទៅលើសាសនា និងការប្រតិបត្តិសាសនាត្រូវបានធ្វើឡើងតាមរយៈវិធានការជាច្រើនផ្សេងៗក្នុងគោលបំណងធ្វើឱ្យប្រជាជនទាំងអស់ក្លាយជាក្រុមតែមួយដូចគ្នា និងលុបបំបាត់សាសនា ដោយ

---

[2983] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៩០។

[2984] សាលដីកាសំណុំរឿង ០០១ (ឯកសារលេខ F28) កថាខណ្ឌ ២៦៧។

[2985] សាលដីកាសំណុំរឿង ០០១ (ឯកសារលេខ F28) កថាខណ្ឌ ២៦៣។

ពុំគិតពីក្រុមកាន់សាសនាណាមួយឡើយ[2986]។ ជាលទ្ធផល ការចាប់ផ្សឹកព្រះសង្ឃពុទ្ធសាសនាដោយបង្ខំ គឺជាប់ពាក់ព័ន្ធទៅនឹងគោលបំណងនេះ និងបង្ហាញថា គ្មាននរណាអាចបង្អាត់បង្រៀន ក្លាយជាព្រះសង្ឃ គ្រងត្រៃចីពរ ឬគោរពបូជាសាសនាបានឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មិនមែនមានតែព្រះសង្ឃពុទ្ធសាសនាដែលត្រូវបានកំណត់គោលដៅក្នុងការប្រែក្លាយឱ្យដូចជាប្រជាជនដទៃទៀតប៉ុណ្ណោះទេ។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងដោយគិតទុកជាមុនក្នុងការលុបបំបាត់សាសនា និងការប្រតិបត្តិសាសនា ដោយដឹងអំពីលក្ខណៈសំខាន់នៃពុទ្ធសាសនា និងឥទ្ធិពលដែលព្រះសង្ឃមានក្នុងប្រពៃណីរបស់ប្រជាជនកម្ពុជា និងជីវិតប្រចាំថ្ងៃ។

1071.អង្គជំនុំតុលាការកំពូលកត់សម្គាល់ថា ព្រះសង្ឃពុទ្ធសាសនាត្រូវបានកំណត់អត្តសញ្ញាណជាក់លាក់ផងដែរ និងកំណត់គោលដៅដោយសារតែមានឋានៈ"ពិសេស"ក្នុងសង្គម។ វិធីសាស្ត្រនេះត្រូវបានបង្ហាញតាមរយៈការសំដៅទៅលើព្រះសង្ឃថា "ដង្កូវ" ឬ"ឈ្លើង"[2987] "ពួកអនុធនដែលបានលាចាកសិក្ខាបាន" ជាប្រភពងាយស្រួល"ឱ្យខ្មាំងអូសទាញ"[2988] និងជា"វណ្ណៈពិសេស" ក្នុងន័យថា បើទោះបីជាព្រះសង្ឃមានចំណុចខ្លះប្រហាក់ប្រហែលនឹងកសិករក៏ដោយ ក៏"ព្រះសង្ឃមិនធ្វើការបង្កបង្កើនផលដាំដំណាំដោយខ្លួនឯងដែរ ព្រះសង្ឃរស់ដោយពឹងផ្អែកលើវណ្ណៈដទៃទៀត" "ព្រះសង្ឃបានពឹងផ្អែកផ្នែកសេដ្ឋកិច្ចលើកសិករក្នុងការគាំទ្រជីវភាពរស់នៅ" ហើយព្រះសង្ឃដែលមានឋានន្តរស័ក្តិខ្ពស់ មានការជាប់ពាក់ព័ន្ធទៅនឹង"ស្រទាប់លើ" ដែលនេះបានដាក់ព្រះសង្ឃស្ថិតក្នុងប្រភេទផ្សេង[2989]។ ឯកសារបក្សកុម្មុយនីស្តកម្ពុជាបានពិពណ៌នាចំណុចល្អ និងចំណុចមិនល្អរបស់ព្រះសង្ឃ និងបានកត់សម្គាល់ថា ព្រះសង្ឃភាគច្រើន"មិនប្រឹងប្រែងធ្វើការ"[2990] និងថា ស្ថានការណ៍របស់ព្រះសង្ឃអាចមានលក្ខណៈប្រហាក់ប្រហែលទៅនឹងវណ្ណៈប៉ូលីស ទាហាន បញ្ញវន្ត

---

[2986] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ (បក្សកុម្មុយនីស្តកម្ពុជាមានចេតនា"បង្កើតសង្គមមួយដូចៗគ្នាគ្មានការគោរពសាសនា និងគ្មានការបែងចែកវណ្ណៈ")។

[2987] ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ឯម ភឿង) ឯកសារលេខ E1/263.1 ទំព័រ ១៩។

[2988] ទស្សនាវដ្តីទង់បដិវត្ត ខែ មិថុនា ឆ្នាំ ១៩៧៧ ERN 00062806 ឯកសារលេខ E3/135 ទំព័រ ១៨ ។

[2989] សៀវភៅកំណត់ហេតុ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៣ ERN 00283531 ឯកសារលេខ E3/8380 ទំព័រ ៣១។ សៀវភៅកំណត់ហេតុ គ្មានកាលបរិច្ឆេទ ERN 00283607 ឯកសារលេខ E3/8381 ទំព័រ ៥១។

[2990] សៀវភៅកំណត់ហេតុ គ្មានចុះកាលបរិច្ឆេទ ERN 00032934-00032936 ឯកសារលេខ E3/1233 ទំព័រ ២២-២៤។ សៀវភៅកំណត់ហេតុចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៣ ERN 00283531 ឯកសារលេខ E3/8380 ទំព័រ ៣១។

និងវណ្ណៈជាតិពន្ធផ្សេងទៀត[2991]។ ប្រហាក់ប្រហែលគ្នានេះ ឯកសារគោលនយោបាយចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ បានបញ្ជាក់ថា "យ៉ាងហោចណាស់ ព្រះសង្ឃ ៩០ ទៅ ៩៥ ភាគរយបានលាចាកសិក្ខាបទ" និងថា "ឋានៈពិសេសក្នុងសង្គមនេះលែងបង្កការព្រួយបារម្ភតទៅហើយ"[2992]។ ពុទ្ធសាសនាមិនត្រូវធាតុជាមួយនឹងបដិវត្តពីព្រោះពុទ្ធសាសនាគឺជាឧបករណ៍នៃការកេងប្រវ័ញ្ច[2993]។ ចុងក្រោយយោងតាម កាំង ហ្កេចអ៊ាវ *ហៅ* ឌុច ថា ប៉ុល ពត បានពន្យល់បន្ថែមក្នុងមីទ្ទីងគម្រប់ខួបរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨ ថា បក្សខិតខំព្យាយាម"លុបបំបាត់"ពុទ្ធសាសនា និងវិធីសាស្ត្រក្នុងការលុបបំបាត់នោះគឺត្រូវឱ្យព្រះសង្ឃលើកទំនប់ និងដាក់ខ្លួនឱ្យដូចប្រជាជនដទៃទៀត[2994]។ យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់ជាក់លាក់លើព្រះសង្ឃពុទ្ធសាសនាពីព្រោះតែជាព្រះសង្ឃ។

1072.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា បើទោះបីជាអំពើនៃការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃពុទ្ធសាសនា ត្រួតគ្នាជាមួយនឹងការហាមឃាត់ទូទៅនៃការប្រតិបត្តិសាសនាក៏ដោយ ក៏អំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងលក្ខណៈរើសអើង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា អំពើនៃការធ្វើទុក្ខបុកម្នេញទាំងនេះបានបណ្តាលឱ្យមានផលវិបាកនៃការរើសអើង ដោយសារតួនាទីរបស់ព្រះសង្ឃត្រូវបានលុបបំបាត់ និងឋានៈក្នុងសង្គមត្រូវបានបន្ទាប[2995]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ព្រះសង្ឃពុទ្ធសាសនាត្រូវបានដាក់ឱ្យស្ថិតក្រោមការរើសអើង និងដូច្នេះអំពើនៃការរើសអើងនេះស្មើនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

---

[2991] កំណត់ត្រាកម្ពុជាប្រជាធិបតេយ្យ ពុំមានកាលបរិច្ឆេទ ERN 00283598, 00283607 ឯកសារលេខ E3/8381 ទំព័រ ៤២, ៥១ (លើកឡើងអំពីកំណត់ត្រា ពុំមានកាលបរិច្ឆេទ ERN 00032934-00032936 ឯកសារលេខ E3/1233 ទំព័រ ២២-២៤ ដែលកំណត់ថាព្រះសង្ឃជា"វណ្ណៈដោយឡែក")។

[2992] ឯកសារគោលនយោបាយ ឯកសារទី ៦ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN 00072401 ឯកសារលេខ E3/99 ទំព័រ ២។

[2993] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨០។

[2994] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩២ យោងទៅលើប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/56.1 ទំព័រ ៦-៨ (បញ្ជាក់ថា កាំង ហ្កេកអ៊ាវ *ហៅ* ឌុច បានចូលរួមកិច្ចប្រជុំនោះ និងបានពិពណ៌នាអំពី ប៉ុល ពត និង នួន ជា ជាមួយនឹងអ្នកដទៃទៀតនៅលើវេទិកានោះ)។

[2995] ព្រះសង្ឃពុទ្ធសាសនាមានតួនាទីសំខាន់ក្នុងសង្គមកម្ពុជានៅពេលនោះ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០-២៦១។

- *ថាតើ អំពើប្រព្រឹត្តទៅលើពុទ្ធសាសនិកជាទូទៅបានរើសអើងជាក់ស្តែង និងថាតើ មានអត្ថិភាពនៃចេតនារើសអើង ដែរ ឬយ៉ាងណា*

1073.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើពុទ្ធសាសនិកជាទូទៅត្រូវបានបង្ហាញ[2996]។ អំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកដែល ខៀវ សំផន ត្រូវបានរកឃើញថា ទទួលខុសត្រូវនោះបានរួមបញ្ចូលការបំផ្លិចបំផ្លាញនិមិត្តរូបតំណាងព្រះពុទ្ធ ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសយកទីសក្ការៈបូជា និងការហាមឃាត់ការគោរពបូជាសាសនា ឬជំនឿ[2997]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា មានការ"លុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិពុទ្ធសាសនា មិនត្រឹមតែការរឹតត្បិតប៉ុណ្ណោះទេ"[2998] និងថា នេះគឺជា"ការវាយប្រហារយ៉ាងដំណំតាមការរៀបចំទៅលើសាសនាពីព្រោះត្រូវបានចាត់ទុកថា មិនត្រូវធាតុជាមួយនឹង [...] បដិវត្តន៍"[2999] និងថា មានការ"កំណត់គោលដៅលើអ្នកដែលកាន់ពុទ្ធសាសនា និងសាវតារពាក់ព័ន្ធ ដោយផ្អែកទាំងស្រុងលើទីកន្លែងសក្ការៈ និមិត្តរូប និងការប្រតិបត្តិណាខ្លះដែលមានអត្ថន័យចំពោះពួកគេ"[3000] និងអាស្រ័យហេតុនេះ ជាការរើសអើងជាក់ស្តែងលើពុទ្ធសាសនិក"ដោយពុំគិតថាតើ មានលទ្ធផលស្មើភាពគ្នាដែលជាគោលដៅចុងក្រោយ ដែរ ឬយ៉ាងណានោះទេ"[3001]។

1074.បញ្ហាបឋមដែលត្រូវដោះស្រាយគឺថាតើ ការរើសអើងជាក់ស្តែងអាចត្រូវបានបង្ហាញដោយផ្អែកលើអំពើនៃការធ្វើទុក្ខបុកម្នេញដែលបានទទួលរង ឬចេញពីផលវិបាក ឬផលប៉ះពាល់ទៅលើពុទ្ធសាសនិកជាទូទៅ ដែរ ឬយ៉ាងណា។ ការរើសអើងជាក់ស្តែងគឺដូចគ្នាទៅនឹង"ការធ្វើទុក្ខបុកម្នេញយ៉ាងសកម្ម"ដូចបានពិភាក្សាដោយតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ[3002]។ ការធ្វើទុក្ខបុកម្នេញតម្រូវថា ក្រុមកំណត់គោលដៅក្នុងករណីពុទ្ធសាសនិកជាទូទៅ ត្រូវដាក់ឱ្យស្ថិតក្រោមការធ្វើទុក្ខបុកម្នេញជាក់ស្តែង និងត្រូវតែជាការរើសអើង។ វិធានការដែលបានប្រើប្រាស់ទៅលើក្រុមនោះត្រូវតែបានពិចារណាដោយផ្អែកជាក់ស្តែងលើការអនុវត្តន៍នៃវិធានការនោះ និងផលប៉ះពាល់បូកបញ្ចូលគ្នា។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការហាមឃាត់ការ

---

[2996] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤, ១១៨៦។

[2997] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[2998] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤។

[2999] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤។

[3000] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[3001] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៦។

[3002] សាលក្រមរបស់តុលាការ IMT ទំព័រ ៣០។

គោរពបូជា ការរុះរើ និងការកែប្រែទីសក្ការៈបូជា ការបំផ្លាញនិមិត្តរូបតំណាងសាសនា និងការហាមឃាត់ទំនៀមទម្លាប់ប្រពៃណីបានអនុវត្តចំពោះមនុស្សគ្រប់រូប និងដោយសារលទ្ធផលនៃគោលនយោបាយទូទៅដែលហាមឃាត់ការប្រតិបត្តិសាសនា[3003]។ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិចាមត្រូវបានដាក់ឱ្យស្ថិតក្រោមការហាមឃាត់ការស្លៀកសម្លៀកបំពាក់ប្រពៃណី និងការតុបតែងខ្លួន ការហាមឃាត់ការអធិដ្ឋាន ការតម្រូវឱ្យជនជាតិចាមនិយាយតែភាសាខ្មែរ ការបំផ្លាញវិហារអ៊ីស្លាម និងដុតបំផ្លាញគម្ពីរអាល់គូរ៉ាន[3004]។

1075.ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អត្ថិភាពនៃ“ការលុបបំបាត់ការប្រតិបត្តិពុទ្ធសាសនាទាំងស្រុង មិនមែនគ្រាន់តែជាការរឹតត្បិតនោះទេ” និងថា នេះគឺជាការ“វាយប្រហារយ៉ាងដំណំតាមការរៀបចំលើសាសនា ពីព្រោះសាសនាត្រូវបានចាត់ទុកថា មិនត្រូវធាតុជាមួយនឹងបដិវត្ត”[3005]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានសំដៅទៅលើសាសនាប្រតិកិរិយាដែលគ្រោះថ្នាក់ដល់កម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជា និងរំឭកថា សក្ខីកម្មរបស់សាក្សីដែលបានអះអាងថា សាសនាទាំងអស់ត្រូវបានចាត់ទុកថាជាប្រតិកិរិយា និងគ្មានសេរីភាពផ្នែកសាសនា និងថា ពុទ្ធសាសនា និងសាសនាអ៊ីស្លាមត្រូវបានចាត់ទុកថា “ជំនឿរបស់ពួកប្រតិកិរិយា”[3006]។

1076.បន្ថែមលើនេះ មានភស្តុតាងបង្ហាញច្បាស់លាស់ថា ពុទ្ធសាសនិកជាទូទៅបានទទួលរងផលវិបាកអវិជ្ជមានតាមរយៈគោលនយោបាយនៃការអនុវត្តទូទៅនោះ។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ពុទ្ធសាសនាគឺជាសាសនាដែលលេចធ្លោជាងគេក្នុងកម្ពុជា“ដែលផ្សាភ្ជាប់គ្នាយ៉ាងស្អិតល្មួត”ជាមួយនឹងអត្តសញ្ញាណប្រជា

---

[3003] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០២៤ (យោងទៅលើការលុបបំបាត់កម្មសិទ្ធិឯកជន និងសាក្សីត្រូវបានផ្តល់ឱ្យសម្លៀកបំពាក់ពណ៌ខ្មៅ), ១០៥២ (“កងឈ្លប [...] ស្លៀកពាក់ពណ៌ខ្មៅដូចប្រជាជនទូទៅ”), ១០៩៣ (“អង្គជំនុំជម្រះយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាមានចេតនាលុបបំបាត់ពុទ្ធសាសនាពីសង្គមកម្ពុជា”), ១១០៨ (“អង្គជំនុំជម្រះជឿជាក់ថា ការប្រតិបត្តិសាសនាព្រះពុទ្ធ ត្រូវបានហាមឃាត់នៅស្រុកត្រាំកក់”), ១១៨៤ (“ភស្តុតាងបង្ហាញនូវការលុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិពុទ្ធសាសនា”), ៣២២៨ (បក្សកុម្មុយនីស្តកម្ពុជាមានចេតនា“បង្កើតសង្គមមួយដូចៗគ្នាគ្មានការប្រតិបត្តិសាសនា និងគ្មានការបែងចែកវណ្ណៈ”), ៣២៣២ (“សេចក្តីណែនាំឱ្យហាមឃាត់សាសនា និងការប្រតិបត្តិសាសនា ដូចជា កាត់សក់ខ្លី គ្មានការគ្របក្បាល អនុវត្តទាំងខ្មែរ និងជនជាតិចាម”)។

[3004] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៦៩៥, ៣៣២៨។

[3005] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤។

[3006] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩០, ១០៩២-១០៩៣ ១១០៨, ៣២១៥។

ជនខ្មែរ និងមានឥទ្ធិពលលើទិដ្ឋភាពច្រើននៃជីវិត[3007]។ ដូចគ្នាដែរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិចាមបាន"ទទួលរងផលប៉ះពាល់លើសលុប និងជាពិសេស"តាមរយៈការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ "ពីព្រោះពួកគេត្រូវកែប្រែទម្លាប់នៃការរស់នៅទាំងស្រុង និងការប្រតិបត្តិសាសនារបស់ពួកគេ"[3008]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ផលវិបាកនៃការលុបបំបាត់ពុទ្ធសាសនាជាទូទៅ រួមទាំងការបំផ្លាញនិមិត្តរូបតំណាងពុទ្ធសាសនា ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសយកទីសក្ការៈបូជា និងការហាមឃាត់ការសម្តែងនូវការគោរពបូជា។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា មាន"ការលុបបំបាត់ការប្រតិបត្តិពុទ្ធសាសនាទាំងស្រុង មិនមែនគ្រាន់តែការរឹតត្បិតនោះទេ" និងថា ជាការ"វាយប្រហារតាមការរៀបចំយ៉ាងដំណំលើសាសនាពីព្រោះត្រូវបានចាត់ទុកថាមិនត្រូវធាតុជាមួយនឹង [...] បដិវត្តន៍" និងថា ការវាយប្រហារនោះ"បានកំណត់គោលដៅលើអ្នកដែលកាន់ពុទ្ធសាសនា និងមានសារតារពាក់ព័ន្ធ ដោយផ្តែកទាំងស្រុងលើទីកន្លែងសក្ការៈ និមិត្តរូប និងការប្រតិបត្តិណាខ្លះដែលមានអត្ថន័យចំពោះពួកគេ" និងអាស្រ័យហេតុនេះ ជាការរើសអើងជាក់ស្តែងលើពួកគេដោយសារអត្ថិភាពនៃសាសនារបស់ពួកគេ[3009]។ ផ្អែកតាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូលថា ពុទ្ធសាសនិកជាទូទៅបានទទួលរងផលវិបាកអវិជ្ជមាន ដែលបានប៉ះពាល់លើជីវិតប្រចាំថ្ងៃរបស់ខ្លួន និងថា នេះគឺជាចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញមានផលប៉ះពាល់អវិជ្ជមានលើពុទ្ធសាសនិកជាទូទៅ ដូច្នេះ អំពើនេះគឺជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើពុទ្ធសាសនិកជាទូទៅ។

1077.ដូចបានកត់សម្គាល់ពីដំបូង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ផ្អែកលើសក្ខីកម្មរបស់ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច ថា បក្សកុម្មុយនីស្តកម្ពុជាមានបំណង"លុបបំបាត់"សាសនាព្រះពុទ្ធក្នុងប្រទេសកម្ពុជា និងថាសាក្សីជាច្រើនបានពិពណ៌នាអំពីការបំផ្លាញសាសនាព្រះពុទ្ធទាំងស្រុងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[3010]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ការដាក់ឱ្យអនុវត្តទូទៅក្នុងគោលបំណងបង្កើតសង្គមដូចៗគ្នាតែមួយ និងគ្មានការប្រតិបត្តិសាសនា[3011] អាចស្មើនឹងចេតនាកំណត់គោលដៅលើពុទ្ធសាសនិកជាទូទៅ។

[3007] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៨។

[3008] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៣២។

[3009] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៤, ១១៨៦។

[3010] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩២-១០៩៣, ៤០១៥, ៤១៦៤, ៤២៩៨។

[3011] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

1078.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដូច្នេះបដិសេធការជំទាស់នេះ។

## ៤. ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍

1079.ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសារមូលហេតុពូជសាសន៍លើជនជាតិវៀតណាមក្នុងសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងក្នុងខេត្តព្រៃវែង និងស្វាយរៀងពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដោយផ្អែកលើមូលដ្ឋានថា ប្រជាជនវៀតណាមត្រូវបាន"កំណត់អត្តសញ្ញាណ និងកំណត់គោលដៅពូជសាសន៍តាមការសន្មតដោយប្រព័ន្ធ និងគិតទុកជាមុន" ហើយពួកគេត្រូវបានសន្មតដោយបក្សកុម្មុយនីស្តកម្ពុជាថាមាន"ពូជសាសន៍ខុសប្លែកពីប្រជាជនកម្ពុជា ផ្អែកលើកត្តាជីវសាស្ត្រ និងជាពិសេសដើមកំណើតសែស្រឡាយពីខាងម្ដាយ"។ ផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយ និងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អំពើដែលត្រូវបានចោទប្រកាន់ទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាមត្រូវបានកម្រិតត្រឹមការបណ្ដេញចេញពីទឹកដីកម្ពុជាទៅប្រទេសវៀតណាម ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ប្រជាជនវៀតណាម នឹងការប្រមូលផ្ដុំទ្រង់ទ្រាយធំចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង[3012]។

1080.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខអូរកន្សែង និងខេត្តព្រៃវែង និងស្វាយរៀង[3013]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម"សម្រាប់ការចាត់ទុកជាខ្មាំងពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ជាពិសេស សម្រាប់ការនិរទេសនៅមុនខែមេសា ឆ្នាំ ១៩៧៧ និងការកម្ទេចក្រុមពូជសាសន៍នេះក្រោយមក)" ពីព្រោះជនជាតិវៀតណាមត្រូវបានចាត់

---

[3012] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២២ និងឧបសម្ព័ន្ធដីកាសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) កថាខណ្ឌ ៥(ii)(ខ)។

[3013] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០០៥។ សេចក្ដីសម្រេចនេះពុំបានយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍មានអត្ថិភាពនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៩។

ទុកថា ជា“ខ្មាំងដ៏គ្រោះថ្នាក់បំផុតចំពោះកម្ពុជាប្រជាធិបតេយ្យ”[3014]។ ខៀវ សំផន បានចោទប្រកាន់ថា ការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍ពុំបានកើតឡើងនៅទីតាំងខាងលើនោះទេ។ អំណះអំណាងនេះនឹងត្រូវដោះស្រាយតាមលំដាប់លំដោយដូចខាងក្រោម។

ក. សហករណ៍ត្រាំកក់

1081.ក្នុងការពិចារណាលើបទចោទនៃការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍នៅសហករណ៍ត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ដីកាដំណោះស្រាយចង់សំដៅទៅលើអំពើនៃការធ្វើទុក្ខបុកម្នេញដូចជា៖

> ការបណ្តេញប្រជាជនវៀតណាម និងក្នុងករណីខ្លះ ពួកគេត្រូវបានចាប់ខ្លួន ឃុំឃាំង ឬសម្លាប់។ ដីកានេះបានពិពណ៌នានូវឧទាហរណ៍នៃការធ្វើឱ្យបាត់ខ្លួនជនជាតិវៀតណាមពីភូមិមួយ(ព្រៃតាលី ឃុំត្រពាំងធំខាងជើង) និងសេចក្តីប្រកាសក្នុងឃុំញ៉ែងញ៉ងថា ប្រជាជនដែលជាជនជាតិពន្ធុវៀតណាមនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញក្នុងពីរដំណាក់កាល ដោយដំណាក់កាលទីមួយ ប្រជាជនវៀតណាមមួយចំនួនត្រូវ “បញ្ជូនទៅស្រុកវិញ” ប៉ុន្តែអ្នកខ្លះត្រូវបានកម្ទេចក្រោយមក[3015]។

1082.យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា “ចំនួនដ៏ច្រើននៃប្រជាជនវៀតណាមត្រូវបាននិរទេសទៅវៀតណាមវិញក្នុងអំឡុងពេលប្រហែលឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៦”[3016]។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា អ្នកដែលត្រូវបាននិរទេសត្រូវបានកំណត់គោលដៅផ្អែកលើមូលដ្ឋាននៃការរើសអើងជាជនជាតិវៀតណាម និងថា ពួកគេបានស្តែងឱ្យឃើញច្បាស់លាស់ថា ជាក្រុមពូជសាសន៍មួយដែលអាចកំណត់បានថាតើ ផលវិបាកបានកើតឡើងលើក្រុមនេះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់បន្ថែមទៀតថា អ្នកដែលត្រូវបាននិរទេសនោះគឺជាជនជាតិវៀតណាម និងថា អំពើនោះគឺជាការរើសអើងជាក់ស្តែង[3017]។ អង្គជំនុំជម្រះបានពិចារណាថា ការនិរទេសបានដកហូត និងរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន និងសេរីភាពពាក់ព័ន្ធទៅនឹងការដើរហើរ សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សេរីភាព និងសន្តិសុខ ដោយគ្មានការចាប់ខ្លួនតាមអំពើចិត្ត ឬខុសច្បាប់ ការជំនុំជម្រះត្រឹមត្រូវ និងជាសាធារណៈ និងស្មើភាពគ្នាចំពោះមុខច្បាប់[3018]។

---

[3014] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០០៥។

[3015] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣២០។

[3016] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៩។

[3017] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៩។

[3018] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩០។

អង្គជំនុំជម្រះបានចាត់ទុកអំពើនេះថាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃកម្រិតធ្ងន់ធ្ងរដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញនោះ[3019]។ ពាក់ព័ន្ធទៅនឹងធាតុផ្សំ *អត្តនោម័តិ* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយចេតនាផ្អែកលើមូលដ្ឋានពូជសាសន៍ និងបានយោងទៅលើការណែនាំ និងបទបញ្ជាពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនជនជាតិវៀតណាម និងរបាយការណ៍នាពេលនោះ និងការផ្សព្វផ្សាយក្នុងទស្សនាវដ្ដីទង់បដិវត្តដែលបានកំណត់គោលដៅលើពួកគេ[3020]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍លើជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ត្រូវបានកម្រិតត្រឹមកាលៈទេសៈជុំវិញការនិរទេសពួកគេទៅវៀតណាមវិញក្នុងអំឡុងពេលមុនពាក់កណ្ដាលឆ្នាំ ១៩៧៦ ដោយសារភស្តុតាងសម្រាប់អំឡុងពេលក្រោយមកទៀតនោះពុំបានអនុញ្ញាតអង្គជំនុំជម្រះយល់ឃើញឱ្យហួសពីវិមតិសង្ស័យដែលថា អំពើដែលពាក់ព័ន្ធនោះគឺជាការរើសអើងជាក់ស្ដែងឡើយ[3021]។

1083.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារបានយល់ឃើញថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍ត្រូវបានបង្ហាញ ពីព្រោះការសន្និដ្ឋាននេះបានផ្អែកលើការយល់ឃើញដែលថា ប្រជាជនវៀតណាមក្នុងស្រុកត្រាំកក់ត្រូវបាននិរទេស ដែលគាត់បានជំទាស់នៅកន្លែងណាមួយនៃសារណាបណ្ដឹងសាទុក្ខរបស់គាត់ថា ជាការពុំត្រឹមត្រូវ[3022]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា ធាតុផ្សំ *អត្តនោម័តិ*នៃការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍ត្រូវបានបង្ហាញ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងតែមួយមុខគត់ទៅលើ"សេចក្តីណែនាំ និងបទបញ្ជាដែលបានចេញពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនជនជាតិវៀតណាម និងរបាយការណ៍នៅពេលនោះ ព្រមទាំងការផ្សព្វផ្សាយក្នុងទស្សនាវដ្ដីទង់បដិវត្ត ដែលកំណត់គោលដៅលើជនជាតិវៀតណាម"[3023]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយោងណាមួយទៅលើប្រភពទាំងនេះទេ ប៉ុន្តែការវិភាគរបស់ខ្លួនបានសំដៅទៅលើការណែនាំឱ្យសម្លាប់ និងបោសសម្អាតជនជាតិវៀតណាម ដែល

---

[3019] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩០។

[3020] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩១។

[3021] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩២។

[3022] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៤៩-៧៥០ យោងទៅលើកថាខណ្ឌ ៦៨៦-៧១៨។

[3023] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥១ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩១។

នេះពុំបានគាំទ្រការយល់ឃើញដែលថា ការណែនាំនោះត្រូវបានចេញឱ្យដឹកជនជាតិវៀតណាមនោះទេ[3024] ។ គាត់បានអះអាងថា របាយការណ៍តែមួយដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនោះសំដៅទៅលើការដោះដូរគ្រួសារខ្មែរក្រោមជាមួយគ្រួសារជនជាតិវៀតណាម ប៉ុន្តែពុំបាននិយាយអំពីតួលេខ និងប្រភពដើមនៃជនជាតិវៀតណាមនោះដែលត្រូវបានធ្វើការដោះដូរ និងពុំបានបង្ហាញនូវចេតនានៃការរើសអើងលើជនជាតិវៀតណាមក្នុងស្រុកត្រាំកក់[3025]។ ចុងក្រោយ គាត់បានអះអាងថា ទស្សនាវដ្ដីទង់បដិវត្តខែ មេសាឆ្នាំ ១៩៧៦ ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនោះពុំបានបង្ហាញនូវចេតនារើសអើងចំពោះជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ពាក់ព័ន្ធទៅនឹងអំពើនៃការនិរទេសក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ ឡើយ[3026]។

1084.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសនៅក្នុងការយល់ឃើញដែលថា ធាតុផ្សំសត្យានុម័តត្រូវបានបំពេញ ប៉ុន្តែផ្ទុយទៅវិញគាត់ត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងពុំត្រឹមត្រូវរបស់គាត់ដែលថា ការនិរទេសពុំត្រូវបានបង្ហាញ[3027]។ ពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន ដែលថា គាត់ត្រូវតែស្មានមើលថាតើ ភស្តុតាងណាមួយដែលបានសំអាងទៅលើនោះ គឺជាការភាន់ច្រឡំ ដោយសារគាត់បានសំដៅតែទៅលើកថាខណ្ឌនៃការសន្និដ្ឋានមួយដែលបានធ្វើឡើងក្រោយការវិភាគអំពីការប្រព្រឹត្តទៅលើជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ប៉ុណ្ណោះ[3028]។

1085.ពាក់ព័ន្ធទៅនឹងអំពើដែលជាមូលដ្ឋាន សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ជាធម្មតាបានយោងទៅលើអំណះអំណាងរបស់គាត់អំពីការនិរទេស ដែលបានផ្ដោតទៅលើបញ្ហាថាតើ ជនជាតិវៀតណាមបានឆ្លងកាត់ព្រំប្រទល់អន្តរជាតិ ដែរ ឬយ៉ាងណា[3029]។ នេះជាការពុំចាំបាច់សម្រាប់ជនរងគ្រោះ ដែលត្រូវតែឆ្លងកាត់ព្រំប្រទល់អន្តរជាតិដើម្បីបង្ហាញនូវអំពើធ្វើទុក្ខបុកម្នេញនោះទេ[3030]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅ និងត្រូវបានប្រមូលផ្ដុំ ចាប់ខ្លួន ផ្លាស់ទី និងក្នុងករណីជាច្រើនត្រូវបានសម្លាប់ ឬធ្វើឱ្យបាត់ខ្លួន ជាពិសេសការរំលោភបំពានសិទ្ធិជាសារវន្ត និងដូច្នេះ អំណះ

---

[3024] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥១-៧៥២។

[3025] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៣។

[3026] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៤-៧៥៥។

[3027] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៧។

[3028] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៨។

[3029] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥០២។

[3030] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥០២-៥០៣។

អំណាងអំពីបញ្ហាថាតើ ពួកគេបានឆ្លងកាត់ព្រំប្រទល់ ដែរ ឬយ៉ាងណា ពុំអាចបង្ហាញនូវកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍បានកើតឡើងឡើយ[3031]។

1086.ក្នុងការកំណត់បញ្ហាថាតើ ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍នៅសហករណ៍ត្រាំកក់ត្រូវបានបំពេញ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អំពើធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានេះ គឺជាការនិរទេសជនជាតិវៀតណាមចេញពីត្រាំកក់ និងយោងទៅលើផ្នែក **VII.ឃ.១** នៃសាលដីកានេះដែលតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទឧក្រិដ្ឋនៃការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចេញពីស្រុកត្រាំកក់ ត្រូវបានបង្ហាញ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការជំទាស់តែមួយគត់ដែល ខៀវ សំផន បានធ្វើឡើងចំពោះធាតុផ្សំសត្យានុម័តនៃការនិរទេសនៅស្រុកត្រាំកក់ គឺបញ្ហាថាតើ ជនជាតិវៀតណាមជាក់ស្តែងបានឆ្លងកាត់ព្រំប្រទល់ជាតិ ដែរ ឬយ៉ាងណា។ គាត់ពុំបានជំទាស់ថា ជនជាតិវៀតណាមត្រូវបានប្រមូលផ្តុំ និងផ្លាស់ទីនោះទេ[3032]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ដែលថា នេះជាការពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ មានការឆ្លងកាត់ព្រំប្រទល់សម្រាប់គោលបំណងនៃការកំណត់នូវការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណានោះទេ ដោយសារការផ្លាស់ទីដោយបង្ខំគឺអាចដាក់ទោសស្មើគ្នាទៅនឹងអំពើដែលជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញដែរ។ នេះពុំមានភាពចាំបាច់សម្រាប់គោលបំណងនៃការដាក់ពិរុទ្ធភាពស្តីពីការធ្វើទុក្ខបុកម្នេញ ដើម្បីវែកញែកភាពខុសគ្នារវាងអំពើជាមូលដ្ឋាននៃការនិរទេស និងការផ្លាស់ទីដោយបង្ខំនោះទេ ដោយសារការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ គឺត្រូវបានយល់គ្រប់គ្រាន់តាមរយៈគោលគំនិតទូទៅនៃការផ្លាស់ទីដោយបង្ខំ[3033]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់បន្ថែមទៀតថា ដីកាដំណោះស្រាយបានសំដៅទៅលើអំពើធ្វើទុក្ខបុកម្នេញថា ជា"ការបណ្តេញជនជាតិវៀតណាម"ព្រមទាំងការធ្វើឱ្យបាត់ខ្លួន[3034]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ការនិរទេសបានកើតឡើង ហើយអង្គជំនុំជម្រះតុលាការកំពូលតម្កល់ការយល់ឃើញនេះក៏ដោយ ក៏ពុំចាំបាច់ក្នុងការកំណត់ថាតើធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញត្រូវបានបង្ហាញ ដែរ ឬយ៉ាងណានោះទេ ពីព្រោះ ខៀវ សំផន ពុំ

[3031] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥០៥។

[3032] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៦-៧១៨។

[3033] សាលដីការឿងក្តី *Naletilić និង Martinović* (ICTY) កថាខណ្ឌ ១៥៤។

[3034] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៨៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៣២០, ១៤២២។

បានជំទាស់ថា ពួកគេត្រូវបានប្រមូលផ្តុំ និងត្រូវបានផ្លាស់ទីចេញពីត្រាំកក់ឡើយ។ ដូច្នេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញត្រូវបានបង្ហាញដែរ ឬយ៉ាងណា ត្រូវបដិសេធចោល។

1087.ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅជាប្រព័ន្ធ ដោយសារពូជសាសន៍តាមការសន្មត[3035]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ការកំណត់គោលដៅនេះត្រូវបានបង្ហាញតាមរយៈការណែនាំ និងបទបញ្ជាពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនជនជាតិវៀតណាម របាយការណ៍នាពេលនោះ និងការផ្សព្វផ្សាយក្នុងទស្សនាវដីទង់បដិវត្ត[3036]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា មានតែការណែនាំ និងបទបញ្ជាប៉ុណ្ណោះដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងដែលជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមនោះ។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់ ឯក ហឿន និង សាន់ ឡូន ដែលពិភាក្សាការណែនាំពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនជនជាតិវៀតណាម[3037]។ សេចក្តីណែនាំទាំងនេះបានបង្ហាញនូវចេតនាក្នុងការកំណត់គោលដៅជនជាតិវៀតណាម។ របាយការណ៍អំពីការដោះដូរជនជាតិវៀតណាមបង្ហាញថា ការដោះដូរនោះគឺជាចេតនា អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើរបាយការណ៍នោះឡើយ។

1088.ដូចបានពិភាក្សាក្នុងផ្នែកនៃសាលដីកានេះ ដែលដោះស្រាយលើការនិរទេសជនជាតិវៀតណាមនៅត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញ[3038] និងស្របជាមួយអង្គជំនុំជម្រះតុលាការកំពូលថា "ជនបរទេស"ដែលលើកឡើងក្នុងទស្សនាវដ្តីទង់បដិវត្តខែមេសា ឆ្នាំ ១៩៧៦ គឺសំដៅលើជនជាតិវៀតណាម។ ពាក្យពេចន៍ដែលបានប្រើប្រាស់បង្ហាញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅ និងថា ការកំណត់គោលដៅនេះគឺដោយសារពូជសាសន៍តាមការសន្មត។ ទស្សនាវដ្តីទង់បដិវត្តលើកឡើងថា៖

> ប្រជាជនយើងហៅថា "ប្រជាជនកម្ពុជា"។ ក៏ប៉ុន្តែ មានជនបរទេសនៅច្រើនណាស់រាប់សែននាក់។ ហើយជនបរទេសប្រភេទម្យ៉ាង មានសភាពពិសពុល គ្រោះថ្នាក់ដល់ប្រជាជនយើងខ្លាំងណាស់។ ជនទាំងនេះមាន

---

[3035] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩១។

[3036] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩១។

[3037] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១១-១១១៥។

[3038] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១១៨។

សភាពហៅថា ពិសពុល ដោយវាមកត្របាក់យើង មកប្របិចយើង មកលេបយើង មករឹបយកគ្រប់បែបគ្រប់យ៉ាងទាំងអស់ធ្វើឱ្យប្រជាជាតិយើង និងប្រជាជនយើងត្រូវគ្រោះថ្នាក់អន្តរាយក្នុងពេលកន្លងមកអស់ទឹកដីជាច្រើន។ សូម្បីតែក្នុងពេលថ្មីៗនេះ មុនដែលយើងធ្វើសង្គ្រាមរំដោះជាតិនៅក្នុងរយៈ៥ឆ្នាំនេះ ទឹកដីខ្លះ នៅត្រង់កន្លែងខ្លះ ជនជាតិបរទេសទាំងនេះមានរហូតដល់ ៩៩ %។ គឺ ៩៩ ភាគរយនៃស្រុកទាំងនេះ សុទ្ធតែជាជនបរទេស [...]។

ប៉ុន្តែ បដិវត្តរបស់យើង ហើយពិសេសថ្ងៃ ១៧មេសា ឆ្នាំ ១៩៧៥ បានដោះស្រាយបញ្ហាយ៉ាងស្អាត ហើយដោះស្រាយទាំងមូល។ យើងសន្មតថា ដោះស្រាយបានជាស្ថាពរ។ រាប់ពាន់ឆ្នាំមកហើយ ដោះបញ្ហាមិនទាន់បាន ហើយក៏មិនដោះស្រាយទៀត។ វណ្ណៈជិះជាន់ វាមិនត្រឹមតែមិនដោះស្រាយទេ វាលក់ដីទាំងកំណាត់ៗ ឱ្យបរទេសនេះទៀត។ ឥឡូវ យើងបាន [...] បោសសំអាតជនបរទេសទាំងនេះរាប់សែននាក់ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ [...][3039]។

1089.ជាការពុំជាប់ពាក់ព័ន្ធដែលថា *ទស្សនាវដ្តីទង់បដិវត្ត* ពុំបានសំដៅជាក់លាក់ទៅលើស្រុកត្រាំកក់ ប៉ុន្តែទស្សនាវដ្តីនេះ បានបញ្ជាក់នូវចេតនាទូទាំងប្រទេសក្នុងការកំណត់គោលដៅលើជនជាតិវៀតណាមសម្រាប់ការបណ្តេញចេញ រួមទាំងការបណ្តេញចេញពីស្រុកត្រាំកក់ផងដែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ខ. មន្ទីរសន្តិសុខស-២១

1090.នៅពេលពិនិត្យលើបទចោទនៃការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍នៅមន្ទីរសន្តិសុខស-២១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អំពើធ្វើទុក្ខបុកម្នេញនេះគឺជាការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ជនជាតិវៀតណាម[3040]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អ្នកជាប់ឃុំទាំងអស់នៅមន្ទីរសន្តិសុខស-២១ ត្រូវបានចាត់ទុកថា ជាជនក្បត់ ហើយជនជាតិវៀតណាមពុំត្រូវបានប្រព្រឹត្តខុសគ្នាពីអ្នកជាប់ឃុំដទៃឡើយ[3041]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះបានបង្ហាញថា ជនជាតិវៀតណាមគឺជាសមាសភាគមួយផ្នែកធំនៃអ្នកជាប់ឃុំជាជនបរទេសនៅមន្ទីរស-២១[3042]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានចាប់ខ្លួន ឃុំឃាំង

---

[3039] ទស្សនាវដ្តីទង់បដិវត្តខែ មេសា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/759 ទំព័រ ៦-៧។

[3040] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៥។

[3041] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៦។

[3042] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៧។

សួរយកចម្លើយ និងកម្ទេចនៅមន្ទីរស-២១ ពីព្រោះបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកពួកគេថា មានពូជសាសន៍ខុសប្លែកពីប្រជាជនកម្ពុជា[3043]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា វគ្គបណ្តុះបណ្តាល និងរៀនសូត្រដែលកម្មាភិបាលមន្ទីរស-២១ បានចូលរួម បានផ្សព្វផ្សាយនូវការស្អប់ជាតិសាសន៍ និងការភ័យខ្លាចជនជាតិវៀតណាម[3044]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅពេលដែលជនជាតិវៀតណាមត្រូវបានចាត់ទុកថា ជាសត្រូវផ្នែកនយោបាយ ពួកគេជាចម្បងត្រូវបានកំណត់អត្តសញ្ញាណថា ជាសត្រូវដោយផ្អែកលើមូលដ្ឋាននៃពូជសាសន៍[3045]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើធ្វើទុក្ខបុកម្នេញ គឺជាការរើសអើងជាក់ស្តែង និងថា ត្រូវបានប្រព្រឹត្តដោយចេតនាក្នុងការរើសអើង ពីព្រោះជនជាតិវៀតណាមត្រូវបានចាប់ខ្លួន ឃុំខ្លួន សួរយកចម្លើយ និងកម្ទេចដោយសារពូជសាសន៍របស់ពួកគេ[3046]។

1091.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅ ពីព្រោះពួកគេមានពូជសាសន៍ខុសប្លែកពីប្រជាជនកម្ពុជា[3047]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសៀវភៅកំណត់ហេតុមន្ទីរស-២១ ប៉ុន្តែសៀវភៅនេះមានចាប់ពីឆ្នាំ ១៩៧៨ ក្រោយការឈ្លានពានមួយលើទឹកដីដោយវៀតណាម ដែលពេលនោះវៀតណាមត្រូវបានសន្មតថា ជាសត្រូវនយោបាយ និងយោធា[3048]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណនៃជនជាតិវៀតណាមតាមរយៈជាតិពន្ធុសែស្រឡាយពីខាងម្តាយ ប៉ុន្តែនេះអនុវត្តតែចំពោះជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ជាជាងជនជាតិវៀតណាមដែលបានជាប់ឃុំនៅមន្ទីរស-២១ ដែលត្រូវបានចាប់ខ្លួនមកពីទីកន្លែងផ្សេងៗនៅជិតព្រំប្រទល់វៀតណាម និងក្នុងដែនទឹកកម្ពុជា។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបែងចែកភាពខុសប្លែកគ្នារវាងក្រុមផ្សេងៗនៃជនជាតិវៀតណាម[3049]។ គាត់បានកត់សម្គាល់ថា ជនជាតិវៀតណាមដែលបានជាប់ឃុំនៅមន្ទីរស-២១ ត្រូវបានចាត់ទុកថា ជាចារកម្ម ឬទាហាន និងថា កាំង ហ្គេចអ៊ាវ *ហៅ* ឌុច បានពន្យល់ថា ពួកគេត្រូវបានសួរយកចម្លើយសារភាពដើម្បីបង្ហាញពីគោលបំណងរបស់វៀត

---

[3043] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៧។

[3044] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៧។

[3045] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៨។

[3046] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៨។

[3047] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២៨។

[3048] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨២៩។

[3049] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣០។

ណាមក្នុងការឈ្លានពានកម្ពុជា និងបង្កើតសហព័ន្ធឥណ្ឌូចិន[3050]។ គាត់បានអះអាងថា នេះបង្ហាញឱ្យឃើញថា ការចាប់ខ្លួនជនជាតិវៀតណាមពុំត្រូវបានជម្រុញដោយសារពូជសាសន៍នោះទេ ប៉ុន្តែដោយសារការជាប់ពាក់ព័ន្ធទៅនឹងប្រទេសជាសត្រូវ[3051]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើអំណះអំណាងរបស់គាត់ដែលថា ពុំមានការប្រព្រឹត្តខុសគ្នារវាងជនជាតិវៀតណាម ជាមួយនឹងអ្នកជាប់ឃុំដទៃទៀតឡើយ[3052] និងថា កាំង ហ្កេចអ៊ាវ *ហៅ* ឌុច ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ក្នុងសំណុំរឿង ០០១ ពីព្រោះអ្នកជាប់ឃុំនៅមន្ទីរស-២១ រួមទាំងជនជាតិវៀតណាមផងនោះ ត្រូវបានកំណត់គោលដៅថា ជាសត្រូវនៃរបបនោះ[3053]។ គាត់បានអះអាងថា អង្គជំនុំជម្រះតុលាការកំពូលពុំបានយល់ឃើញផ្ទុយពីអង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចនេះ ប៉ុន្តែបានបដិសេធការយល់ឃើញនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ ក្នុងករណីដែលអ្នកជាប់ឃុំត្រូវបានចាប់ខ្លួន និងកម្ទេចដោយពុំរើសមុខ[3054]។

1092.សហព្រះរាជអាជ្ញាបានឆ្លើយតបថា នៅពេលសំដៅទៅលើជនជាតិវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានបែងចែកភាពខុសប្លែកគ្នារវាងក្រុមផ្សេងៗ ឬពុំបានយល់ឃើញថា មានតែជនជាតិវៀតណាមដែលត្រូវបានឃុំឃាំងនៅមន្ទីរស-២១ នោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ជនជាតិវៀតណាមដែលនៅកម្ពុជា រួមទាំងក្រុមគ្រួសារដែលព្យាយាមរត់គេចចេញពីប្រទេសកម្ពុជា និងកុមារមកពីខេត្តស្វាយរៀងភូមិភាគនិរតី និងកំពង់សោម ត្រូវបានឃុំឃាំងនៅមន្ទីរស-២១"[3055]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើទ្រឹស្តីនៃជាតិពន្ធុតាមសែស្រឡាយពីខាងម្តាយនៅពេលកំណត់អត្តសញ្ញាណជនជាតិវៀតណាមនៅមន្ទីរស-២១ ប៉ុន្តែបានសំអាងទៅលើ*ក្នុងចំណោមនោះ*សក្ខីកម្មរបស់ឆ្មាំគុកមន្ទីរស-២១ ដែលថា ពួកគេត្រូវបានបង្ហាត់បង្រៀនក្នុងវគ្គបណ្តុះបណ្តាលថា ជនជាតិវៀតណាមគឺជា"សត្រូវស្នូលពូជ"[3056]។ យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា អំណះអំណាងរបស់ ខៀវ សំផន ដែលថា ជនជាតិវៀតណាមត្រូវបានប្រព្រឹត្តដូចគ្នាជាមួយនឹងអ្នកជាប់ឃុំដទៃទៀតពុំ

---

[3050] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣១។

[3051] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣១។

[3052] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣២។

[3053] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣៣។

[3054] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣៤។

[3055] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤១។

[3056] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤២។

បានអើពើលើការពិតថា ពួកគេត្រូវបានបញ្ជូនមកមន្ទីរស-២១ ឃុំឃាំង ធ្វើទារុណកម្ម និងកម្ទេចពីព្រោះតែពួកគេគឺជាជនជាតិវៀតណាម និងថា ពួកគេត្រូវបានប្រព្រឹត្តខុសពីអ្នកជាប់ឃុំដទៃទៀត ដូចបានបង្ហាញតាមរយៈការពិតថា កាំង ហ្គេចអ៊ាវ *ហៅ* ឌុច តាមធម្មតាទទួលបានព័ត៌មានអំពីការមកដល់ជនជាតិវៀតណាម ចម្លើយសារភាពរបស់ពួកគេត្រូវបានកត់ត្រា និងផ្សព្វផ្សាយ ហើយពួកគេត្រូវបានសម្រិតសម្រាំងជ្រើសរើសសម្រាប់វិធីសាស្ត្រសួរយកចម្លើយធ្ងន់ធ្ងរជាង[3057]។ បន្ថែមលើនេះ អំណះអំណាងដែលថា ជនជាតិវៀតណាមត្រូវបានប្រព្រឹត្តទៅលើដូចជាសត្រូវ ឬចារកម្ម ពុំបានអើពើលើភស្តុតាងដែលថា ជនស៊ីវិលជនជាតិវៀតណាមត្រូវបានបង្ខំឱ្យសារភាពថា ជាចារកម្ម ហើយអំណះអំណាងនេះពុំបានពន្យល់នូវការម្ទេចកុមារជនជាតិវៀតណាមនៅមន្ទីរស-២១[3058]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានបំភ្លៃយុត្តិសាស្ត្រសំណុំរឿង ០០១ ហើយ ដីកាបញ្ជូនទៅជំនុំជម្រះនៃសំណុំរឿង ០០១ បានចោទប្រកាន់ កាំង ហ្គេចអ៊ាវ *ហៅ* ឌុច ពីបទធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមដោយសារមូលហេតុនយោបាយ ដូច្នេះ គាត់ពុំអាចត្រូវបានដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញមូលហេតុពូជសាសន៍ និងនៅគ្រប់កាលៈទេសៈ ការយល់ឃើញផ្នែកអង្គហេតុមានលក្ខណៈខុសប្លែកគ្នាពីរឿងក្តីនីមួយៗ[3059]។

1093.សហមេធាវីនាំមុខបានឆ្លើយតបថា សមាជិកនៃក្រុមជាក់លាក់អាចត្រូវបានកំណត់គោលដៅសម្រាប់ហេតុផលជាច្រើន និងថា តុលាការ ICC និង ICTY បានយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្អែកលើមូលដ្ឋានរើសអើងពីរ ឬច្រើន ទាក់ទងទៅនឹងអំពើដូចគ្នានេះ[3060]។ ពាក់ព័ន្ធទៅនឹងការស្តែងឱ្យឃើញនៃក្រុមគោលដៅ សហមេធាវីនាំមុខបានអះអាងថា ការសំដៅរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ"ប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា" អាចបង្កឱ្យមានការភាន់ច្រឡំ។ សហមេធាវីនាំមុខបានអះអាងថា ក្រុមដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើទុក្ខបុកម្នេញត្រូវតែជាក្រុមពូជសាសន៍មួយ ហើយក្នុងករណីនេះ ក្រុមដែលចោទជាបញ្ហានេះគឺជាជនជាតិវៀតណាម បើទោះបីជា ពួកគេបានរស់នៅក្នុងប្រទេសកម្ពុជា ឬវៀតណាម និងពួកគេគឺជាជនស៊ីវិល ឬបុគ្គលិកយោធាយ៉ាងណាក៏ដោយ[3061]។ សហមេធាវីនាំមុខបានបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម

---

[3057] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤៣។

[3058] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤៤។

[3059] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤៥។

[3060] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៣៧៤។

[3061] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៨២-៤៨៤។

ប៉ុន្តែច្បាប់អន្តរជាតិពុំបានអនុញ្ញាតភាគីនៃជម្លោះប្រដាប់អាវុធ ចាប់ឃុំឃាំង ឬកម្ទេចដោយផ្អែកលើមូលដ្ឋាននៃពូជសាសន៍របស់ពួកគេឡើយ[3062]។

1094.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហមេធាវីនាំមុខថា ការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍ត្រូវតែកំណត់គោលដៅលើក្រុមពូជសាសន៍មួយ និងថា ជនជាតិវៀតណាម បើទោះបីជារស់នៅក្នុង ឬក្រៅប្រទេសកម្ពុជាក៏ដោយ ក៏ជាក្រុមកំណត់គោលដៅដែលចោទជាបញ្ហានេះ។ ក្រុមមួយអាចត្រូវបានកំណត់គោលដៅផ្អែកលើមូលដ្ឋានជាច្រើន ហើយការពិតដែលថា ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជាសត្រូវនយោបាយ ដូចបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនោះ ពុំបានបង្ហាញថា ពួកគេពុំត្រូវបានធ្វើទុក្ខបុកម្នេញផ្អែកលើមូលដ្ឋាននៃពូជសាសន៍នោះទេ។ ប្រហាក់ប្រហែលគ្នានេះដែរ ការពិតដែលថា កាំង ហ្គេចអ៊ាវ *ហៅ* ឌុច ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាជាងមូលហេតុពូជសាសន៍ និងថា អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ផ្នែកខ្លះនៃការដាក់ពិរុទ្ធភាពលើរូបគាត់សម្រាប់ការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយ ពុំបានរារាំងការដែលថា ជនជាតិវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញផ្អែកលើមូលដ្ឋានពូជសាសន៍ផងដែរ។

1095.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់នូវអំណះអំណាងរបស់ ខៀវ សំផន ដែលថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅ ដោយសារពួកគេត្រូវបានសន្មតថា ជាសត្រូវនយោបាយ ប៉ុន្តែបានយល់ឃើញថា ពួកគេ"ត្រូវបានកំណត់អត្តសញ្ញាណជាបឋមថា ជាសត្រូវស្នូលដោយសារមូលហេតុពូជសាសន៍របស់ពួកគេ"[3063]។ បើទោះបីជា ខៀវ សំផន ពុំយល់ស្របជាមួយនឹងសេចក្ដីសន្និដ្ឋាននេះក៏ដោយ ក៏គាត់ខកខានក្នុងការបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបានដូច្នេះដែរ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អ្នកជាប់ឃុំជនជាតិវៀតណាមពុំត្រូវបានប្រព្រឹត្តទៅលើខុសប្លែកពីអ្នកជាប់ឃុំដទៃទៀត[3064]។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមត្រូវបានចាប់ខ្លួន ឃុំឃាំង សួរយកចម្លើយ និងកម្ទេចនៅមន្ទីរស-២១ *ពីព្រោះតែ* ពួកគេគឺជាជនជាតិវៀតណាម និងមានពូជសាសន៍ខុសពីប្រជាជនកម្ពុជា[3065] ពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ពួកគេត្រូវបានប្រព្រឹត្តទៅលើដូចអ្នកជាប់ឃុំដទៃទៀតនៅពេលជាប់ឃុំនោះ ដែរ ឬយ៉ាង

3062 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥១១។

3063 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៨។

3064 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៦។

3065 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦០៧។

ណាឡើយ។ នៅគ្រប់កាលៈទេសៈ ដូច ខៀវ សំផន បានចង្អុលបង្ហាញ[3066] ជនជាតិវៀតណាមត្រូវបានសួរយកចម្លើយដើម្បីទទួលបានចម្លើយសារភាព ក្នុងគោលបំណងបង្ហាញថា គោលដៅរបស់ វៀតណាម គឺដើម្បីឈ្លានពានកម្ពុជា និងបង្កើតសហព័ន្ធឥណ្ឌូចិន។ ដូច្នេះ ទោះស្ថិតក្នុងមន្ទីរឃុំឃាំងក៏ដោយ ក៏ពួកគេត្រូវបានសម្រិតសម្រាំង និងពុំត្រូវបានប្រព្រឹត្តទៅលើដូចអ្នកជាប់ឃុំដទៃទៀតដែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

### គ. មន្ទីរសន្តិសុខអូរកន្សែង

1096.នៅពេលពិចារណាលើបទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍នៅមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អំពើធ្វើទុក្ខបុកម្នេញដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ជាពិសេសគឺ"ការចាប់ខ្លួន និងការកម្ទេចជនជាតិវៀតណាមប្រាំមួយនាក់ និងក្រុមជនជាតិចារ៉ាយ"[3067]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកការយល់ឃើញរបស់ខ្លួនដែលថា សូ សារឿន បានបង្គាប់ ឆោម សែ ឱ្យកម្ទេចក្រុមជនស៊ីវិលជនជាតិវៀតណាមប្រាំមួយនាក់ និងថា បទបញ្ជានេះត្រូវបានអនុវត្តដោយកម្មាភិបាលមន្ទីរសន្តិសុខអូរកន្សែង[3068]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះបានយល់ឃើញពីដំបូងថា ប្រជាជនវៀតណាមត្រូវបានសន្មតថា ជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា អាស្រ័យហេតុនេះ បានជឿជាក់ថា ក្រុមគោលដៅបានស្តែងឱ្យឃើញគ្រប់គ្រាន់ដើម្បីកំណត់ថាតើ មានផលវិបាកបានកើតឡើងសម្រាប់ក្រុមនោះ ដែរ ឬយ៉ាងណា[3069]។ អង្គជំនុំជម្រះបានជឿជាក់ថា ការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងរើសអើងផ្អែកលើមូលដ្ឋានពូជសាសន៍ ដោយបានពិចារណាលើ"ស្ថានការណ៍កាន់តែតានតឹងនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម អំឡុងពេលនៃការចាប់ខ្លួនក្រុមនោះនៅចុងឆ្នាំ ១៩៧៨ ការជិតដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងភស្តុតាងនៃការចាប់ខ្លួន និងការកម្ទេចនៅមន្ទីរស-២១ នូវ'ចារកម្ម'ជនជាតិវៀតណាម និងទាហានវៀតកុងនៅចុងឆ្នាំ ១៩៧៨"[3070]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមបានរំលោភបំពានលើសិទ្ធិជាសារវន្តដទៃទៀត

---

[3066] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣១។

[3067] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៤ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៦១៨-៦២២។

[3068] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៥។

[3069] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៥។

[3070] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៦។

និងសេរីភាព និងបានបំពេញលក្ខខណ្ឌតម្រូវនូវកម្រិតធ្ងន់ធ្ងរដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ[3071]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ត្រូវបានបង្ហាញក្នុងករណីនៃអំពើមនុស្សឃាតលើជនជាតិវៀតណាមប្រាំមួយនាក់នោះ[3072]។

1097.ទាក់ទងទៅនឹងក្រុមចារ៉ាយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ក្រុមនេះត្រូវបានចាប់ខ្លួន និងឃុំឃាំងដោយសង្ស័យថា ជាសត្រូវខាងក្រៅ ដែលពុំមែនដោយសារសមាជិកភាពតាមការសន្មតក្នុងក្រុមពូជសាសន៍ណានោះទេ[3073]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ដោយសារមានភស្តុតាងតិចតួចបង្ហាញទាក់ទងទៅនឹងមូលហេតុសម្រាប់ការកម្ទេចនេះ ការស្លាប់របស់ពួកគេពុំអាចជាប់ពាក់ព័ន្ធទៅនឹងពូជសាសន៍ជាក់ស្តែង ឬតាមការសន្មតនោះទេ[3074]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានយល់ឃើញថា បទឧក្រិដ្ឋនៃការធ្វើទុក្ខម្នេញមូលហេតុពូជសាសន៍ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំត្រូវបានបង្ហាញក្នុងករណីនៃជនជាតិចារ៉ាយឡើយ[3075]។

1098.ខៀវ សំផន បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់បានផ្អែកលើភស្តុតាងពុំគ្រប់គ្រាន់។ ការយល់ឃើញនេះបានផ្អែកលើ"តែចម្លើយជាលាយលក្ខណ៍អក្សរពុំច្បាស់លាស់របស់ ឆោម សែ"[3076]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរដោយសារការសន្និដ្ឋានថា ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ បើទោះបីជាការពិតថា ការចាប់ខ្លួនពួកគេបានផ្អែកលើហេតុផលដូចគ្នានឹងជនជាតិចារ៉ាយដោយសារហេតុផលនយោបាយក៏ដោយនោះ[3077]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលជនជាតិវៀតណាមក្នុងការពិចារណារបស់ខ្លួនអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើ"សត្រូវពិត ឬតាមការសន្មត"[3078]។ គាត់បានលើកឡើងថា ឆោម សែ បានបញ្ជាក់ថា ជនជាតិវៀ

---

[3071] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៧-២៩៩៨។

[3072] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៨។

[3073] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០០០។

[3074] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០០១។

[3075] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០០២។

[3076] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៩។

[3077] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦០។

[3078] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦០។

តណាមប្រាំមួយនាក់នោះត្រូវបានចាប់ខ្លួនភ្លាមៗនៅមុនឆ្នាំ ១៩៧៩ នៅភូមិអូរយ៉ាដាវ ប៉ុន្តែពុំមានភស្តុតាងបង្ហាញថា ការចាប់ខ្លួននោះដោយសារមូលហេតុពូជសាសន៍ឡើយ[3079]។

1099.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីហេតុផលរបស់បក្សកុម្មុយនីស្តកម្ពុជាសម្រាប់ការចាប់ខ្លួន និងការកម្ទេចជនស៊ីវិលជនជាតិវៀតណាម ខុសប្លែកពីការយល់ឃើញដទៃទៀតស្តីពីហេតុផលរបស់បក្សកុម្មុយនីស្តកម្ពុជាសម្រាប់ការកំណត់គោលដៅលើសត្រូវនយោបាយតាមការសន្មត[3080]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ខៀវ សំផន បានដកស្រង់តាមការចង់បានរបស់ខ្លួនចេញពីកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ឆោម សែ។ ឆោម សែ បានលើកឡើងថា ជនជាតិវៀតណាមត្រូវបានចាប់ខ្លួននៅសមរភូមិ ប៉ុន្តែបានសំដៅទៅលើពួកគេថា "ជនស៊ីវិល"[3081]។ សហមេធាវីនាំមុខបានយល់ស្រប និងឆ្លើយតបថា ជនជាតិវៀតណាមប្រាំមួយនាក់ដែលត្រូវបានកម្ទេចនៅអូរកន្សែងត្រូវបានស្គាល់ថា ជាជនស៊ីវិល និងថា ការចាត់ទុកពួកគេជាចារកម្មរបស់សត្រូវពុំបានរារាំងដល់ការរើសអើងពូជសាសន៍នៅពេលហេតុផលដែលពួកគេត្រូវបានចាត់ទុកបែបនេះ គឺដោយសារតែពូជសាសន៍របស់ខ្លួននោះ[3082]។

1100.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះឡើយ។ ការយល់ឃើញដែលថា ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានសម្លាប់នោះ ពុំបានផ្អែកទៅលើតែកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ឆោម សែ ប៉ុណ្ណោះនោះទេ ដែលផ្ទុយពីការអះអាងរបស់ ខៀវ សំផន[3083]។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មស៊ីសង្វាក់របស់ ឆោម សែ ក្នុងតុលាការផងដែរ[3084] ដែលពេលនោះ ឆោម សែ ពុំបានឆ្លើយជាក់លាក់ថា គាត់ចង់សំដៅទៅលើជនជាតិវៀតណាមប្រាំមួយនាក់នោះទេ ប៉ុន្តែបានបញ្ជាក់ថា "ដោយឡែកតែរឿងពួកក្រុម ០៦ នាក់ អាហ៊ីង ស្វ សារឿន បានបញ្ជាឲ្យសម្លាប់ដែរ"[3085]។

---

3079 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦១។

3080 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤៨។

3081 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៤៩។

3082 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥១០។

3083 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៥៩។

3084 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩២៦។

3085 ប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៨៦។ *សូមមើលខាងលើ* ផ្នែក VII.ខ.២.ច។

1101.ទាក់ទងទៅនឹងអំណះអំណាងដែលថា ជនជាតិវៀតណាមប្រាំមួយនាក់ត្រូវបានសម្លាប់ដោយសារមូលហេតុនយោបាយ និងថា អង្គជំនុំជម្រះសាលាដំបូងបានរួមបញ្ចូលជនជាតិវៀតណាមក្នុងការពិចារណារបស់ខ្លួនអំពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើ"ខ្មាំងពិតប្រាកដ ឬតាមការសន្មត"[3086] ក្នុងករណីនេះ ក្រុមមួយអាចត្រូវបានកំណត់គោលដៅផ្អែកលើមូលដ្ឋានជាច្រើន។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនាក្នុងការរើសអើងផ្អែកលើ"ស្ថានការណ៍កាន់តែតានតឹងឡើងនៃជម្លោះប្រដាប់អាវុធរវាងបក្សកុម្មុយនីស្ត និងសាធារណរដ្ឋសង្គមនិយមវៀតណាមអំឡុងពេលនៃការចាប់ខ្លួនក្រុមនោះនៅចុងឆ្នាំ ១៩៧៨ ការជិតដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងភស្តុតាងនៃការចាប់ខ្លួន និងការកម្ទេចនៅមន្ទីរស-២១ នូវ'ចារកម្ម'ជនជាតិវៀតណាម និងទាហានធៀរគីតាមការសន្មតក្នុងចុងឆ្នាំ ១៩៧៨"[3087] ទំនងជាជាប់ពាក់ព័ន្ធទៅនឹងការជម្រុញផ្នែកនយោបាយ សម្រាប់ការធ្វើទុក្ខបុកម្នេញច្រើនជាងការជម្រុញផ្នែកពូជសាសន៍ ប៉ុន្តែការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនាក្នុងការរើសអើងលើជនជាតិវៀតណាមទាំងប្រាំមួយនាក់នោះដែលផ្អែកលើមូលដ្ឋាននៃពូជសាសន៍ ត្រូវតែបានពិចារណាដោយផ្អែកលើការយល់ឃើញនៃគោលនយោបាយទូទាំងប្រទេស ក្នុងការកំណត់គោលដៅសម្រាប់ការចាត់ទុកជាសត្រូវ[3088]។ អាស្រ័យហេតុនេះ និងដោយសារ ឆោម សែ បានបង្ហាញថា ជនជាតិវៀតណាមប្រាំមួយនាក់គឺជាជនស៊ីវិល[3089] ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈសមហេតុផល។ ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ឃ. ខេត្តព្រៃវែង និងស្វាយរៀង

1102.ក្នុងការពិចារណាលើបទចោទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍នៅខេត្តព្រៃវែង និងស្វាយរៀង អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អំពើធ្វើទុក្ខបុកម្នេញដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ គឺជាការបណ្តេញចេញពីទឹកដីកម្ពុជាទៅប្រទេសវៀតណាម ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ជនជាតិវៀតណាម និងចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ ការប្រមូលផ្តុំទ្រង់ទ្រាយធំ និងការសម្លាប់ជនជាតិវៀតណាម[3090]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញរបស់ខ្លួនដែលថា

---

[3086] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៦០។

[3087] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៩៦។

[3088] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០០៥។

[3089] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សែ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារលេខ E3/405 ទំព័រ ៧។

[3090] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០៨ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២២។

ចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណជនជាតិវៀតណាមតាមរយៈការបង្កើតបញ្ជីឈ្មោះ និងថា គ្រួសារដែលជាប់សែស្រឡាយ ត្រូវបានកំណត់គោលដៅដោយផ្អែកលើមូលដ្ឋាននៃជាតិពន្ធុពីសែស្រឡាយខាងម្ដាយ[3091]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រជាជនវៀតណាមក្នុងចំនួនដ៏ច្រើនត្រូវបាននិរទេសក្នុងខេត្តព្រៃវែងទៅវៀតណាមក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ និងថា ជនជាតិវៀតណាមត្រូវបានផ្លាស់ទី(ដែលការផ្លាស់ទីមួយចំនួនបានកើតឡើងបន្ទាប់ពីការចាប់ខ្លួន) ក្នុងខេត្តព្រៃវែងនៅចន្លោះឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩ និងថា អ្នកទាំងនោះត្រូវបាននាំចេញទៅបាត់ពុំដែលឃើញត្រឡប់វិញឡើយ[3092]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះបានយល់ឃើញថា ជនស៊ីវិលជនជាតិវៀតណាមត្រូវបានសម្លាប់ក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨[3093]។ អង្គជំនុំជម្រះបានជឿជាក់ថា ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាបានស្ដែងឱ្យឃើញគ្រប់គ្រាន់ថា ជាក្រុមពូជសាសន៍មួយក្នុងការកំណត់ថាតើ មានផលវិបាកសម្រាប់ក្រុមនេះ ដែរ ឬយ៉ាងណា និងថា ជនរងគ្រោះជាក់ស្ដែងគឺជាជនជាតិវៀតណាម[3094]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា អំពើនោះគឺជាការរើសអើងជាក់ស្ដែង[3095]។ អង្គជំនុំជម្រះបានយល់ឃើញថា អំពើធ្វើទុក្ខបុកម្នេញបានរំលោភបំពានលើសិទ្ធិជាសារវ័ន្តនិងសេរីភាព និងបានកំណត់ថា អំពើនេះបានឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវសម្រាប់បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ ដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំសត្យានុម័ត[3096]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំអត្តនោម័តិនៃចេតនាជាក់លាក់ក្នុងការរើសអើងផ្អែកលើមូលដ្ឋាននៃពូជសាសន៍ត្រូវបានបំពេញ និងបានដកស្រង់ការកំណត់គោលដៅជាប្រព័ន្ធលើជនជាតិវៀតណាមម្នាក់ៗដោយផ្អែកលើមូលដ្ឋាននៃពូជសាសន៍តាមការសន្មត ដូចបានបង្ហាញតាមរយៈការរៀបចំបញ្ជីឈ្មោះ គោលនយោបាយជាប់សែស្រឡាយខាងម្ដាយដែលបានអនុវត្តចំពោះគ្រួសារដែលមានជាប់សែស្រឡាយនោះ និងឯកសារបោះពុម្ពផ្សាយនៅពេលនោះ និងសុន្ទរកថារបស់បុគ្គលនាំមុខនៃបក្សកុម្មុយនីស្តកម្ពុជាដែលកំណត់គោលដៅលើជនជាតិវៀតណាម[3097]។

---

[3091] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១០។

[3092] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១០។

[3093] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១០។

[3094] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១១។

[3095] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១១។

[3096] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១១-៣៥១២។

[3097] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១៣។

1103.ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា (១) "ជនជាតិវៀតណាមដែលរស់នៅក្នុងកម្ពុជា" គឺជាក្រុមពូជសាសន៍ដែលបានស្តែងឱ្យឃើញគ្រប់គ្រាន់ (២) អំពើធ្វើទុក្ខបុកម្នេញបានកើតឡើង (៣) អំពើនោះបង្កើតបានជាការរើសអើងជាក់ស្តែង និង (៤) ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយគិតទុកជាមុនក្នុងខេត្តព្រៃវែង និងស្វាយរៀង[3098]។ អំណះអំណាងនីមួយៗនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយ។

i. ការស្តែងចេញឱ្យឃើញនៃក្រុម

1104.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយោងនៅក្នុងជើងទំព័រទៅលើការពិភាក្សារបស់ខ្លួនអំពីភ្នាក់ងារ CIA, KGB, និង យួនក្នុងការវាយតម្លៃលើការស្តែងចេញឱ្យឃើញនៃក្រុម ប៉ុន្តែក្រុមទាំងនេះពុំដូចគ្នានឹង"ជនជាតិវៀតណាមដែលរស់នៅក្នុងកម្ពុជា"[3099] និងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា យួនអាចសំដៅទៅលើនរណាម្នាក់ដែលត្រូវបានសង្ស័យពីការក្បត់ រួមទាំងប្រជាជនកម្ពុជាផងដែរ[3100]។ គាត់បានអះអាងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ការកំណត់និយមន័យជាក់លាក់ និងច្បាស់លាស់អំពីក្រុម និងការខកខានបំភ្លឺភាពខុសគ្នារវាងភ្នាក់ងារយួន កងទ័ពវៀតណាម ជនស៊ីវិលវៀតណាមក្នុងប្រទេសវៀតណាម និងជនស៊ីវិលវៀតណាមក្នុងប្រទេសកម្ពុជា បានរារាំងក្នុងការធ្វើការយល់ឃើញថា ក្រុមមួយបានស្តែងចេញឱ្យឃើញគ្រប់គ្រាន់នោះ[3101]។

1105.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានយោងទៅលើជើងទំព័រដែលរៀបរាប់លម្អិតនូវពាក្យពេចន៍"ភ្នាក់ងារ CIA, KGB, និង *យួន*" ប៉ុន្តែពុំបានអើពើទៅនឹងការពិភាក្សាទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីក្រុមជនជាតិវៀតណាមនៅពេលវាយតម្លៃភស្តុតាងស្តីពីគោលនយោបាយកំណត់គោលដៅ[3102]។

1106.សហមេធាវីនាំមុខបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងទំនងជាបានយោងទៅលើផ្នែកពុំត្រឹមត្រូវនៃសាលក្រម នៅពេលយោងទៅលើការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងភាពដែលស្តែងចេញឱ្យឃើញនៃក្រុមគោលដៅ។ អង្គជំនុំជម្រះសាលាដំបូងគប្បីយោងទៅលើផ្នែក **១៣.៣.៥.២** និង **១៣.៣.៦** ជាជាងផ្នែក

---

[3098] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៨។

[3099] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៨។

[3100] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០២៩។

[3101] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣១-១០៣២។

[3102] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦២៨។

**១៦.៣.២.១.៣.៥** ប៉ុន្តែនេះទំនងជាកំហុសក្នុងការរៀបរៀងដែលពុំមែនមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការបដិសេធសេចក្តីសន្និដ្ឋានដែលមានមូលដ្ឋានត្រឹមត្រូវនោះឡើយ[3103]។

1107.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាជនជាតិវៀតណាមគឺជាក្រុមដែលស្តែងចេញឱ្យឃើញគ្រប់គ្រាន់នូវពូជសាសន៍ គឺជាការសមហេតុផល។ បើទោះបីជាការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើផ្នែក **១៦.៣.២.១.៣.៥** សម្រាប់គាំទ្រការយល់ឃើញរបស់ខ្លួន[3104]ទំនងជាមានកំហុសក៏ដោយ ក៏ផ្នែកដទៃទៀតនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគបញ្ហានេះ និងបានសន្និដ្ឋានថា ក្រុមនេះបានស្តែងចេញឱ្យឃើញគ្រប់គ្រាន់[3105]។ ខៀវ សំផន បានចង្អុលបង្ហាញត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងបានបង្កឱ្យមានការភាន់ច្រឡំខ្លះៗ[3106]តាមរយៈការយោងទៅលើ"ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាថា ជាក្រុមមួយដាច់ដោយឡែក"[3107]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្រុមពូជសាសន៍ដែលចោទជាបញ្ហានេះ គឺជាប្រជាជនវៀតណាមទាំងមូល។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការស្តែងចេញឱ្យឃើញរបស់ក្រុម ពុំបានបង្ហាញថា ជនជាតិវៀតណាមនៅកម្ពុជា គឺជាក្រុមមួយមានពូជសាសន៍ដាច់ដោយឡែកពីជនជាតិវៀតណាមដែលនៅក្រៅប្រទេសកម្ពុជានោះទេ ហើយដីកាដំណោះស្រាយបានចោទប្រកាន់ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍លើប្រជាជនវៀតណាមដោយគ្មានការកម្រិតក្រុមត្រឹមជនជាតិវៀតណាមដែររស់នៅក្នុងប្រទេសកម្ពុជាឡើយ[3108]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ការដកស្រង់ដោយពុំត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ឬពាក្យពេចន៍ពុំសូវច្បាស់លាស់នោះបានមោឃៈការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមគឺជាក្រុមស្តែងចេញឱ្យឃើញគ្រប់គ្រាន់នោះឡើយ។

---

[3103] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៨១។

[3104] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៨១៥។

[3105] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.៣.៥ "ការកំណត់គោលដៅជនជាតិវៀតណាម" និង ១៣.៣.៦ "ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងជាតិពន្ធុសែស្រឡាយខាងម្តាយ"។

[3106] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣១-១០៣២។

[3107] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៣.៣.៦.១។

[3108] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២២ ("ប្រជាជនវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញដោយសារមូលហេតុថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកជនជាតិវៀតណាមថា មានពូជសាសន៍ខុសប្លែកពីប្រជាជនកម្ពុជា ផ្អែកលើដើមកំណើតជីវសាស្ត្រ និងជាពិសេសសែស្រឡាយខាងម្តាយ")។

ii. ថាតើ អំពើធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា

1108.ខៀវ សំផន បានយោងទៅលើអំណះអំណាងរបស់គាត់ដែលត្រូវបានដោះស្រាយនៅក្នុងសាលដីកានេះ[3109] ថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេសជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨ ពុំត្រូវបានបង្ហាញ[3110]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា ការចាប់ខ្លួនក្នុងខេត្តព្រៃវែងនៅចន្លោះពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩ គឺអាចស្មើនឹងអំពើធ្វើទុក្ខបុកម្នេញដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កាលបរិច្ឆេទនៃការចាប់ខ្លួនដែលបានពិពណ៌នាដោយសាក្សី ពុំមានភាពច្បាស់លាស់[3111]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការយោងទៅលើការចាប់ខ្លួនគ្រួសារជនជាតិវៀតណាមក្នុងខេត្តស្វាយរៀងដើម្បីកំណត់ថាតើ ការចាប់ខ្លួនអាចត្រូវបានចាត់ទុកថា ជាការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណាឡើយ[3112]។

1109.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសណាមួយក្នុងការយល់ឃើញថា ជនជាតិវៀតណាមត្រូវបាននិរទេសចេញពីខេត្តព្រៃវែងក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ និងត្រូវបានសម្លាប់ក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨ និងថា គាត់បានលើកពុំត្រឹមត្រូវនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការចាប់ខ្លួនក្នុងខេត្តព្រៃវែងនៅចន្លោះពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩[3113]។ សហព្រះរាជអាជ្ញាបានអះអាងថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញថា ការសម្លាប់បានកើតដោយផ្អែកលើភស្តុតាងចំពោះមុខឡើងក៏ដោយ ក៏អង្គជំនុំជម្រះអាចសំអាងទៅលើភស្តុតាងដូចគ្នាក្នុងការសន្និដ្ឋានថា ជនជាតិវៀតណាមត្រូវបានផ្លាស់ទី ឬចាប់ខ្លួន និងពុំដែលឃើញត្រឡប់មកវិញឡើយ[3114]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា ខៀវ សំផន ពុំបានអើពើទៅលើការយល់ឃើញពាក់ព័ន្ធទៅនឹងការចាប់ខ្លួនក្នុងខេត្តស្វាយរៀងនៅចន្លោះពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩[3115]។

---

[3109] *សូមមើលខាងលើ* ផ្នែក VII.ឃ.២ និង VII.ខ.២.ក។

[3110] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣៣ យោងទៅលើ កថាខណ្ឌ ៩៦៦-៩៨៦ និង ៩៨៧-៩៩២។

[3111] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣៤។

[3112] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣៥។

[3113] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣០-៦៣១។

[3114] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣១។

[3115] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣១។

1110.សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ទំនងជាជំទាស់ទៅនឹងបញ្ហាថាតើ ការចាប់ខ្លួនក្នុងខេត្តព្រៃវែងស្ថិតក្នុងវិសាលភាពយុត្តាធិការពេលវេលានៃបទចោទ ដែរ ឬយ៉ាងណា ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំបានតម្រូវឱ្យជំនុំជម្រះតែការចាប់ខ្លួនដែលកើតឡើងក្រោយខែមេសា ឆ្នាំ ១៩៧៧ ប៉ុណ្ណោះនោះទេ។ យុត្តាធិការពេលវេលាត្រឹមតែសំដៅទៅលើការប្រមូលផ្តុំ និងការសម្លាប់ទ្រង់ទ្រាយធំប៉ុណ្ណោះ[3116]។

1111.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះបានតម្កល់រួចរាល់ហើយនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការនិរទេសចេញពីខេត្តព្រៃវែង និងការសម្លាប់គ្រួសារជនជាតិវៀតណាមក្នុងខេត្តស្វាយរៀងថា ជាអំពើនៃការសម្លាប់រង្គាលនៅក្នុងសាលដីកានេះ[3117]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកម្រិតការវិភាគរបស់ខ្លួនត្រឹមការកំណត់ថាតើ អំពើធ្វើទុក្ខបុកម្នេញតាមរយៈការចាប់ខ្លួនបានកើតឡើង ដែរ ឬយ៉ាងណា។

1112.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងអំពីការចាប់ខ្លួនជាក់លាក់ក្នុងខេត្តស្វាយរៀងក្នុងការយល់ឃើញផ្នែកច្បាប់របស់ខ្លួនពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ ប៉ុន្តែត្រឹមតែបានបញ្ជាក់ថា ការផ្លាស់ទីមួយចំនួននៃជនជាតិវៀតណាមពីខេត្តព្រៃវែងនៅចន្លោះពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩ បានកើតឡើងក្រោយពីការចាប់ខ្លួន[3118]។ យោងតាមកថាខណ្ឌនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានដកស្រង់ក្នុងការគាំទ្រ អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើការសម្លាប់ជនជាតិវៀតណាមមួយចំនួន ពីព្រោះពុំមានភាពជាក់លាក់ជុំវិញកាលបរិច្ឆេទនៅពេលដែលការសម្លាប់នោះបានកើតឡើង[3119]។ កថាខណ្ឌខាងលើបន្ទាប់នោះបានបង្ហាញថា សាក្សីដែលបាន

---

[3116] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៨៩-៤៩១។

[3117] *សូមមើលខាងលើ* ផ្នែក VII.ឃ.២ និង VII.ខ.២.ក។

[3118] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១០។

[3119] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥១:

> ភ័ស្តុតាងជារួមដែលបានបង្ហាញទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង គឺរួមមាន ភ័ស្តុតាងដោយផ្ទាល់និងភ័ស្តុតាងដោយប្រយោលអំពីការផ្លាស់ទីលំនៅឬការចាប់ខ្លួនជនជាតិវៀតណាមម្នាក់ៗដែលបន្ទាប់មកត្រូវបានគេយកទៅ ហើយលែងឃើញត្រឡប់មកវិញ។ នៅពេលក្រោយមកទើបសាក្សីបានដឹងតាមរយៈការឮពីគេថា បុគ្គលទាំងអស់នេះ តាមពិតត្រូវបានគេសម្លាប់។ ដោយពិចារណាទៅលើការកំណត់គោលដៅនៅទូទាំងប្រទេសទៅលើជនជាតិវៀតណាមដូចដែលមានភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនោះ វាទំនងជាមានការសម្លាប់ជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង។ ប៉ុន្តែដោយពិចារណាទៅលើភ័ស្តុតាងប្រយោលនិងភ័ស្តុតាងមិនច្បាស់លាស់ដែលបានបង្ហាញនោះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានទៅតាមបទដ្ឋានដែលពាក់ព័ន្ធថាការសម្លាប់ទាំងនោះបានកើតឡើងនោះទេ។ លើសពីនេះទៀត ដោយរម្លឹកឡើងវិញថា អង្គជំនុំជម្រះនឹងមិនពិចារណាទៅលើការសម្លាប់ វ៉ាន់ ង៉ាង, ជុយ និង សាន នោះទេ ហើយដោយសារតែ

ផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមទាំងនោះបានផ្តល់កាលបរិច្ឆេទផ្សេងៗគ្នា សម្រាប់ព្រឹត្តិការណ៍នេះចាប់ពីឆ្នាំ ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៧[3120]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ទំនងជាមានកំហុសដោយសារការយោងទៅលើអត្ថិភាពនៃការចាប់ខ្លួនក្នុងខេត្តព្រៃវែងចាប់តាំងពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការចាប់ខ្លួនដែលអង្គជំនុំជម្រះបានយល់ឃើញថា អាចកើតឡើងនៅមុនអំឡុងពេលនោះ។ ទោះជាយ៉ាងណាក្តី ដីកាដំណោះស្រាយពុំបានកម្រិតអំពើធ្វើទុក្ខបុកម្នេញត្រឹមការចាប់ខ្លួនដែលបានកើតឡើងនៅចន្លោះពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩ នោះទេ[3121] ហើយអង្គជំនុំជម្រះសាលាដំបូងបានទទួលយកសក្ខីកម្មដែលថា ការចាប់ខ្លួនបានកើតឡើង[3122]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការចាប់ខ្លួនបានកើតឡើង បើទោះបីជាពុំមានភាពជាក់លាក់ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនោះឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា អំពើនៃការធ្វើទុក្ខបុកម្នេញរួមបញ្ចូលការចាប់ខ្លួន។ ដូចបានបញ្ជាក់ខាងដើម អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការយល់ឃើញពាក់ព័ន្ធទៅនឹងការនិរទេសចេញពីខេត្តព្រៃវែង និងការសម្លាប់ក្នុងខេត្តស្វាយរៀង និងដូច្នេះសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ត្រឹមត្រូវថា ការចាប់ខ្លួន និងការសម្លាប់បានកើតឡើង។

iii. ថាតើ អំពើនោះជាការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា

1113.យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការបង្ហាញថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយផ្អែកលើមូលដ្ឋាននៃពូជសាសន៍។ គាត់បាន

---

ភាពមិនជាក់លាក់ពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការសម្លាប់ដូចបានរៀបរាប់ដោយ ឡាច គ្រី, ថេង ផល និង ដួង អឿន នោះ អង្គជំនុំជម្រះមិនអាចបង្ហាញដោយសមហេតុផលថា មានការសម្លាប់រង្គាលលើប្រជាជនស៊ីវិលវៀតណាម បានកើតឡើងនៅក្នុងខេត្តព្រៃវែង ចាប់ពីខែមេសា ឆ្នាំ១៩៧៧ នោះឡើយ។

[3120] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៥០។

[3121] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៩២២។ ការកម្រិតយុត្តាធិការពេលវេលាត្រឹមអំពើចាប់តាំងពីខែមេសា ឆ្នាំ ១៩៧៧ បានអនុវត្តតែលើការប្រមូលផ្តុំ និងសម្លាប់ក្នុងទ្រង់ទ្រាយធំនូវជនជាតិវៀតណាមទូទាំងខេត្តព្រៃវែង និងស្វាយរៀង។ អំពើដទៃទៀតដែលបានរៀបរាប់ក្នុងដីកាដំណោះស្រាយរួមទាំងការចាប់ខ្លួនជនជាតិវៀតណាម ពុំត្រូវបានកម្រិតត្រឹមអំឡុងពេលនៅចន្លោះឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៩ ឡើយ។

[3122] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៥០ ("ដោយពិចារណាទៅលើគម្លាតពេលវេលាដែលបានកន្លងហួសនិងដោយសារថា ភាគច្រើននៃសក្ខីកម្មរបស់សាក្សីទាំងបីរូបនេះគាំទ្រដល់គ្នាទៅវិញទៅមកនោះ អង្គជំនុំជម្រះសម្រេចថា ភាពខុសគ្នាទាក់ទងនឹងកាលបរិច្ឆេទនិងលំដាប់លំដោយនៃហេតុការណ៍មិនប៉ះពាល់ដល់ភាពអាចជឿជាក់បានជារួមរបស់សក្ខីកម្មដោយផ្ទាល់របស់ពួកគេឡើយ")។

អះអាងថា មានមូលដ្ឋានជាច្រើនសម្រាប់ការចាប់ខ្លួនក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថា សាក្សីខ្លះបានពន្យល់ថា សមាជិកក្រុមគ្រួសារវៀតណាមអាចត្រូវបានកំណត់គោលដៅសម្រាប់ហេតុផលដ៏ទៃទៀត ដោយសារសកម្មភាពរបស់ខ្លួនកន្លងមក[3123]។

1114.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើទៅនឹងការយល់ឃើញដែលថា អំពើធ្វើទុក្ខបុកម្នេញបានកើតឡើងក្នុងបរិបទនៃការកំណត់គោលដៅជាប្រព័ន្ធលើជនជាតិវៀតណាមដោយសារពូជសាសន៍របស់ពួកគេ[3124]។

1115.សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី និង ដួង អឿន។ សហមេធាវីនាំមុខបានចង្អុលបង្ហាញថា សៀង ចាន់ថី បានផ្តល់ភស្តុតាងជាសំខាន់ក្នុងការគាំទ្រការកំណត់គោលដៅលើជនជាតិវៀតណាម និងថា ភស្តុតាងរបស់ ដួង អឿន បង្ហាញច្បាស់លាស់ថា ប្តីរបស់គាត់ជាជនជាតិវៀតណាមត្រូវបាននាំចេញទៅដោយសារគាត់ជាជនជាតិវៀតណាម[3125]។

1116.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានត្រឹមតែអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់នូវមូលហេតុដូចម្តេច និងហេតុអ្វីបានជាអំពើធ្វើទុក្ខបុកម្នេញកំណត់គោលដៅលើជនជាតិវៀតណាម[3126]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយច្បាស់លាស់នូវមូលហេតុដូចម្តេចបានជាអង្គជំនុំជម្រះពិចារណាលើការនិរទេសជនជាតិវៀតណាមចេញពីខេត្តព្រៃវែង ការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង និងការចាប់ខ្លួនដែលបានលើកឡើងខាងលើដែលបានកំណត់គោលដៅលើជនជាតិវៀតណាមក្នុងផ្នែកនៃសាលក្រមដែលដោះស្រាយជាមួយនឹងការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍ក្នុងខេត្តព្រៃវែង និងស្វាយរៀងក៏ដោយ ក៏ការយល់ឃើញនេះត្រូវបានពិចារណាក្នុងបរិបទនេះដែរ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅលើជនជាតិវៀតណាម និងអំពាវនាវឱ្យមានការបណ្តេញចេញ និងចាប់ពីឆ្នាំ ១៩៧៧ សម្រាប់ការកម្ទេច[3127]។ ក្នុងបរិបទនេះ ជាការសមហេតុផលទាំងស្រុងសម្រាប់អង្គជំនុំជម្រះ

[3123] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣៧-១០៣៩។

[3124] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣២។

[3125] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៩៣-៤៩៥។

[3126] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៣៧-១០៣៩។

[3127] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៦។

សាលាដំបូងក្នុងការសន្និដ្ឋានថា ការនិរទេស ការសម្លាប់ និងការចាប់ខ្លួនជនជាតិវៀតណាមគឺដោយសារពូជសាសន៍របស់ពួកគេ។

iv. ថាតើ ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅទុកជាមុន ដែរ ឬយ៉ាងណា

1117.ខៀវ សំផន បានយោងទៅលើអំណះអំណាងរបស់គាត់ពីដំបូងដែលបានលើកឡើងនៅក្នុងសារណារបស់គាត់ថា ជនជាតិវៀតណាមពុំត្រូវបានកំណត់អត្តសញ្ញាណតាមរយៈការបង្កើតបញ្ជីឈ្មោះនោះឡើយ[3128]។ គាត់បានលើកឡើងថា ពុំមានភស្តុតាងបង្ហាញនូវការបង្កើតបញ្ជីឈ្មោះពាក់ព័ន្ធទៅនឹងខេត្តព្រៃវែង និងស្វាយរៀងនោះទេ។ សាក្សីពីរនាក់ដែលបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងពុំបានគាំទ្រថា មានការបង្កើតបញ្ជីនោះឡើយ[3129]។ គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា គ្រួសារដែលកាត់សាសន៍ត្រូវបានកំណត់គោលដៅដោយសារជាតិពន្ធុសែស្រឡាយពីខាងម្ដាយ ពីព្រោះភស្តុតាងដែលបានសំអាងទៅលើនោះគឺគ្រាន់តែជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់អ្នកដែលបានផ្ដល់សក្ខីកម្មប៉ុណ្ណោះ ហើយអ្នកដែលបានផ្ដល់សក្ខីកម្មលើបញ្ហានេះ ពុំបាននិយាយថា ព័ត៌មាននោះចេញមកពីថ្នាក់លើឡើយ[3130]។ គាត់បានកត់សម្គាល់ថា ពុំមានឯកសារផ្លូវការរបស់បក្សកុម្មុយនីស្ដកម្ពុជា ឬសុន្ទរកថា បានយោងទៅលើគោលនយោបាយសែស្រឡាយពីខាងម្ដាយ។ អង្គជំនុំជម្រះសាលាដំបូងបានយោងតែលើឯកសារមួយប៉ុណ្ណោះដែលបានលើកឡើងអំពីការតាមដាននូវគ្រួសារជាប់សែស្រឡាយមួយចំនួន ប៉ុន្តែពុំបានបង្ហាញថា មានចំណាត់ការណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងពួកគេឡើយ[3131]។ ចុងក្រោយ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយោងទៅលើការផ្សព្វផ្សាយក្នុងទស្សនាវដ្ដីទង់បដិវត្ត និងសុន្ទរកថាដោយបុគ្គលនាំមុខគេនៃបក្សកុម្មុយនីស្ដកម្ពុជាដែលកំណត់គោលដៅលើជនជាតិវៀតណាម ដោយគ្មានការពន្យល់នូវមូលហេតុដូចម្ដេចដែលប្រភពទាំងនេះជាពិសេសបានកំណត់គោលដៅលើជនជាតិវៀតណាមដែលរស់នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង[3132]។ គាត់បានយោងទៅលើអំណះ

[3128] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤០ យោងទៅលើ កថាខណ្ឌ ១៥៥១-១៥៦០។

[3129] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤០-១០៤២។

[3130] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤៣-១០៤៥។

[3131] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤៧។

[3132] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៤៩។

អំណាងដែលថា ប្រភពទាំងនេះពុំបានសំដៅទៅលើជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាឡើយ[3133]។

1118.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណជនជាតិវៀតណាម។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មចំពោះការកំណត់អត្តសញ្ញាណនៃជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង និងភស្តុតាងនៃបញ្ជីឈ្មោះដែលបានបង្កើតឡើងនៅទីកន្លែងដទៃទៀតនៃប្រទេសកម្ពុជា មានការជាប់ពាក់ព័ន្ធក្នុងការវាយតម្លៃអំពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង[3134]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា ជាការពុំសមស្របដែលថា សាក្សីជាច្រើនដែលទាំងអស់បានផ្តល់សក្ខីកម្មថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា ជាតិពន្ធុត្រូវបានកំណត់តាមសែស្រឡាយខាងម្តាយនោះ បានធ្វើការសន្និដ្ឋានផ្ទាល់ខ្លួនដូចៗគ្នានោះទេ[3135]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់លម្អិតនូវការផ្សព្វផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត និងសុន្ទរកថា ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា និងបានពន្យល់ថា ឯកសារបោះពុម្ពផ្សាយនោះបានបង្ហាញនូវគោលនយោបាយទូទាំងប្រទេសក្នុងការកំណត់គោលដៅជនជាតិវៀតណាម[3136]។

1119.សហមេធាវីនាំមុខបានឆ្លើយតបថា ការយល់ឃើញពាក់ព័ន្ធទៅនឹងការបង្កើតបញ្ជីឈ្មោះជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង ពុំត្រូវសម្រាប់ការយល់ឃើញអំពីចេតនាក្នុងការរើសអើងឡើយ។ សហមេធាវីនាំមុខបានយោងទៅលើភស្តុតាងដែលបង្ហាញថា បញ្ជីឈ្មោះពុំមានភាពចាំបាច់នៅក្នុងសហគមន៍មួយចំនួនក្នុងខេត្តទាំងនោះ ដោយសារគេបានដឹងរួចរាល់ហើយថាតើនរណាជាជនជាតិវៀតណាមនោះ[3137]
។

1120.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការរៀបចំបញ្ជីឈ្មោះជនជាតិវៀតណាម គោលនយោបាយសែស្រឡាយខាងម្តាយដែលបានអនុវត្តចំពោះ

[3133] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥០ យោងទៅលើ កថាខណ្ឌ ១០៥៩-១០៩៧។

[3134] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៣។

[3135] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៤។

[3136] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៥។

[3137]សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៩៩។

គ្រួសារដែលកាត់សាសន៍ និងឯកសារបោះពុម្ពផ្សាយនៅសម័យនោះ និងសុន្ទរកថារបស់បុគ្គលនាំមុខគេនៃបក្សកុម្មុយនីស្តកម្ពុជាដែលកំណត់គោលដៅលើជនជាតិវៀតណាម[3138]។ ការបង្កើតបញ្ជីឈ្មោះជនជាតិវៀតណាមបង្ហាញពីគោលនយោបាយទូទាំងប្រទេសក្នុងការកំណត់គោលដៅជនជាតិវៀតណាមដោយពុំគិតពីបញ្ហាថាតើ បញ្ជីឈ្មោះនោះត្រូវបានបង្កើតឡើងជាក់លាក់ក្នុងខេត្តព្រៃវែង និងស្វាយរៀង ដែរ ឬយ៉ាងណាឡើយ។ បន្ថែមលើនេះ ដូចបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបានឱ្យដឹងថា[3139] អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់សាក្សី សៅ សាក់ និងដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី ដែលបានផ្តល់សក្ខីកម្មចំពោះការកំណត់អត្តសញ្ញាណនៃជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង[3140] បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានយោងជាក់លាក់ទៅលើភស្តុតាងក្នុងការយល់ឃើញថា ការកំណត់គោលដៅជនជាតិវៀតណាមសម្រាប់ការធ្វើទុក្ខបុកម្នេញគឺជាចេតនាក៏ដោយ។

1121.ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយសែស្រឡាយខាងម្តាយ ជាការពុំសមហេតុផល ដោយហេតុថា សាក្សីជាច្រើនដែលសំដៅទៅលើគោលនយោបាយនោះ ពុំបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងបញ្ហាថាតើ គោលនយោបាយមានដើមកំណើតចេញពីបក្សកុម្មុយនីស្តកម្ពុជា ដែរ ឬយ៉ាងណានោះឡើយ។ ផ្អែកលើសក្ខីកម្មរបស់ ហេង ឡៃហ៊ាង, ដួង អឿន, ស៊ិន ឆែម, អ៊ុច ស៊ុនឡាយ, ឡាច គ្រី និង ប្រាក់ ឌឿន ព្រមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីដទៃទៀត[3141] ជាការសមហេតុផលក្នុងការសន្និដ្ឋានថា នេះជាគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និង

---

[3138] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥១៣។

[3139] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៣៣។ សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៤៩៩។

[3140] ប្រតិចារឹក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ (សៅ សាក់) ឯកសារលេខ E1/363.1 ទំព័រ ១០ ("ក្នុងភូមិហ្នឹងអ្នកណាមានប្រពន្ធខ្មែរ អ្នកណាមានប្តីខ្មែរ ប្តីយួនអី គឺដឹងទាំងអស់អីចឹង។ ប៉ុន្តែ ក្នុងអង្គការ គេហ្នឹងតាមភូមិអីប្រហែលជាគេធ្វើស្ថិតិ ក៏ខ្ញុំប្រហែលជាអីចឹងមែន ប៉ុន្តែខ្ញុំមិនបានដឹងៗ ប្រហែលជាគេធ្វើស្ថិតិបានថ្នាក់លើដឹងថា កូនខ្មែរ កូនយួនអីចឹងណា ប្រហែលជាអីចឹងហើយភូមិឃុំ គេហ្នឹងចុះធ្វើស្ថិតិហើយ")។ ប្រតិចារឹក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ (សៀង ចាន់ថី) ឯកសារលេខ E1/394.1 ទំព័រ ១០, ២២ ("គេមិនជជីកសួរអីទេ ព្រោះដូចថា គេស្គាល់ពីដើមមកអីចឹងថា អ្នកណាកូនកាត់វៀតណាម គ្រួសារវៀតណាម គឺគេស្គាល់។ [...] ប្រធានសហករណ៍ គឺវាបានដឹងច្បាស់ហើយថា គ្រួសារណាវៀតណាម គ្រួសារណាមិនមែនវៀតណាម គឺវាដឹងច្បាស់អីចឹង វាបានកំណត់សម្គាល់អីចឹង វាស្គាល់ដឹងច្បាស់ហើយ ព្រោះអីដូចគ្រួសារខ្ញុំអីចឹង គេដឹងថា ជីតាខ្ញុំអីចឹង វៀតណាមអីចឹង គេដឹង។ បើអីចឹង គេមិនបាច់សួរអីទៀត គេដឹង គេស្គាល់ហើយ")។

[3141] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៥៤៧។

ថា នេះបានបង្ហាញនូវការកំណត់គោលដៅដោយចេតនា។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារបោះពុម្ពផ្សាយនៅសម័យនោះ និងសុន្ទរកថាពាក់ព័ន្ធទៅនឹងគោលនយោបាយជាតិក្នុងការកំណត់គោលដៅជនជាតិវៀតណាមធ្វើជាការគាំទ្រដល់ការយល់ឃើញរបស់ខ្លួនដែលថា ការកំណត់គោលដៅបានកើតឡើងជាពិសេសក្នុងខេត្តព្រៃវែង និងស្វាយរៀងនោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ឆ. អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

1122.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ ថា ខៀវ សំផន បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលអំពើនេះត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3142]។

1123.ក្នុងការលើកបង្ហាញនូវច្បាប់ជាធរមានដែលអនុវត្តចំពោះអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "អំពើអមនុស្សធម៌ដទៃទៀត" ត្រូវបានទទួលស្គាល់ថា ស្ថិតក្នុងប្រភេទនៃអំពើមិនជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥[3143]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "មានភាពអាចយល់ដឹងបានជាមុនជាទូទៅថា អំពើអមនុស្សធម៌ដទៃទៀត មានច្បាប់ចែង និងជាបទល្មើសដែលអាចផ្តន្ទាទោសបានក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥" និងបានពិចារណាលើ"ឋានៈជាទំនៀមទម្លាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងតួនាទីរបស់ជនជាប់ចោទដែលជាសមាជិកនៃរដ្ឋអំណាចគ្រប់គ្រងប្រទេសកម្ពុជា"[3144]។

1124.អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់នូវធាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀតដូចខាងក្រោម៖

---

[3142] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣២៦។

[3143] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៣។

[3144] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៣។

ក. "ធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានអំពើសកម្ម ឬអកម្មដែលបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស"[3145]។

ខ. "ធាតុផ្សំអត្តនោម័តិនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានអំពើសកម្ម ឬអកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនា"[3146]។

1125.បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា អំពើជាក់លាក់ដែលនៅពីក្រោយអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំចាំបាច់ដោយខ្លួនឯងផ្ទាល់ជាអំពើល្មើសច្បាស់លាស់តាមច្បាប់អន្តរជាតិនោះទេ[3147]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា៖

> អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការវាយតម្លៃលើបញ្ហាថាតើ អំពើនោះរំលោភបំពាន'សិទ្ធិមនុស្សជាមូលដ្ឋាន ដូចបានកំណត់ដោយលិខិតុបករណ៍ច្បាប់អន្តរជាតិ ដែរ ឬយ៉ាងណា' គឺជាវិធីសាស្ត្រមួយបែបក្នុងការបង្កើតនូវ'លក្ខខណ្ឌតម្រូវនៃអំពើអនីត្យានុកូលភាពអន្តរជាតិផ្លូវការ'។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការនេះបានជួយដល់ការវាយតម្លៃលើលក្ខខណ្ឌតម្រូវនៃការដឹងជាមុនថា មានច្បាប់ចែង និងបញ្ហាថាតើ អំពើនោះឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរដែលអាចស្មើនឹងបទឧក្រិដ្ឋដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា[3148]។

ដោយកត់សម្គាល់ថា អំពើក្នុងប្រភេទនេះដែលត្រូវបានចោទប្រកាន់ថា ជាអំពើអមនុស្សធម៌ដទៃទៀតក្នុងសំណុំរឿង ០០២/០២ ពុំមែនជាបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ និងពុំត្រូវបានចោទប្រកាន់ថាជាបទឧក្រិដ្ឋនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងត្រូវវាយតម្លៃរាល់អំពើទាំងអស់នោះធៀបនឹងការកំណត់និយមន័យនៃអំពើអមនុស្សធម៌ដទៃទៀត[3149]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា កិច្ចការនេះនឹងមានភាពងាយស្រួលតាមរយៈការលើកបង្ហាញនូវការបំភ្លឺអំពីធាតុផ្សំចាំបាច់នៃអំពើនោះ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគលើការរំលោភសេព

---

[3145] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

[3146] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

[3147] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[3148] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៦។

[3149] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៧។

សន្តរៈ[3150] ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3151] ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3152] ការផ្លាស់ទីដោយបង្ខំ[3153] និងការធ្វើអោយបាត់ខ្លួនដោយបង្ខំ[3154]។

1126.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការវាយតម្លៃរបស់ខ្លួនលើនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែលជាអំពើអមនុស្សធម៌ដទៃទៀត និងក្នុងការយល់ឃើញពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អំណះអំណាងនេះនឹងត្រូវវាយតម្លៃតាមលំដាប់លំដោយដូចខាងក្រោម។

### ១. ការវាយតម្លៃលើនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀត

#### ក. ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលការណ៍នីត្យានុកូលភាព

1127.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការពិនិត្យដោយម៉ត់ចត់លើគោលការណ៍នីត្យានុកូលភាព និងបានត្រឹមតែសន្និដ្ឋានដោយគ្មានហេតុផលថា មានភាពអាចដឹងជាមុនបានជាទូទៅថា អំពើអមនុស្សធម៌ដទៃទៀតនេះមានច្បាប់ចែង និងជាបទល្មើសដែលអាចផ្តន្ទាទោសបាន ជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥[3155]។ ផ្អែកតាម ខៀវ សំផន ថា ការដែលអះអាងថា អំពើអមនុស្សធម៌ដទៃទៀតអាចដឹងជាមុនបានថា មានច្បាប់ចែងនោះ ពុំគ្រប់គ្រាន់ឡើយ ដោយសារអំពើប្រភេទនេះបានរួមបញ្ចូលនូវអំពើផ្សេងជាច្រើនទៀត។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីបានកំណត់អត្តសញ្ញាណនៃអំពើដែលចោទជាបញ្ហានេះ និងបានពិនិត្យថាតើ អំពើនេះអាចត្រូវបានកំណត់ថា ជាបទល្មើសនៅពេលនោះ ដែរ ឬយ៉ាងណា[3156]។

---

[3150] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៩.១.៨.១។

[3151] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៩.១.៨.២។

[3152] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៩.១.៨.៣។

[3153] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៩.១.៨.៤។

[3154] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៩.១.៨.៥។

[3155] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៥៩-៦៦០។

[3156] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៦៥។

1128.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានលើកអំណះអំណាងដែលថា អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធពីដំបូង និងបានបញ្ជាក់ថា ពុំមានលក្ខខណ្ឌតម្រូវថា អំពើដែលជាមូលដ្ឋាននោះត្រូវតែជាបទល្មើសតាមច្បាប់អន្តរជាតិនៅពេលប្រព្រឹត្តនោះឡើយ[3157] និងបានអះអាងថា គោលការណ៍ស្តីពី*ប្រភេទដូចគ្នា* គឺជាលក្ខខណ្ឌដ៏ចាំបាច់នៃគោលការណ៍នីត្យានុកូលភាព និងថា តុលាការព្រហ្មទណ្ឌយោធារបស់សហរដ្ឋអាមេរិកនៅទីក្រុង Nuremberg ប្រើប្រាស់គោលការណ៍នេះដើម្បីបញ្ជាក់នូវប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀត។ ប្រភេទនៃអំពើទាំងនេះត្រូវបានបំភ្លឺបន្ថែមដោយយុត្តិសាស្ត្រដទៃទៀតក្រោយសង្គ្រាមលោកលើកទីពីរ ដែលបានរួមបញ្ចូលនូវអំពើដែលបានរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់មនុស្ស និងរំលោភបំពានលើច្បាប់ជាធរមាន និងទំនៀមទម្លាប់សង្គ្រាម[3158]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះនីមួយៗនៃ អ.វ.ត.ក. និងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍ បានបញ្ជាក់អះអាងស៊ីសង្វាក់គ្នានូវនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀតក្រោយការវិភាគលើការអនុវត្តន៍របស់រដ្ឋនៅក្រោយសង្គ្រាមលោកលើកទីពីរ ដើម្បីបញ្ជាក់នូវភាពអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស[3159]។

1129.សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានអះអាងពុំត្រឹមត្រូវដែលថា នីត្យានុកូលភាពនៃអំពើជាក់លាក់ដែលត្រូវបានចោទប្រកាន់ថា ជាអំពើអមនុស្សធម៌ដទៃទៀតត្រូវតែបានវិភាគ ដោយសារបញ្ហានេះអាចផ្ទុយនឹងសញ្ញាណនៃលក្ខខណ្ឌស្តីពីពាក្យមិនជាក់លាក់ដែលមានគោលបំណងដើម្បីគ្របដណ្តប់អំពើដែលពុំស្ថិតក្នុងបទឧក្រិដ្ឋជាក់លាក់ដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3160]។

1130.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវលើការអនុវត្តន៍នៃគោលការណ៍នីត្យានុកូលភាពចំពោះអំពើអមនុស្សធម៌ដទៃទៀត និងយុត្តិសាស្ត្រពីមុនៗលើបញ្ហានេះ។ អ្វីដែលតម្រូវនោះគឺថា ជនជាប់ចោទបានដឹងអំពីប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា។ ភាពអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស ត្រូវបានធានាច្បាស់លាស់ ថា ប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀតនេះ ត្រូវបានបកស្រាយ និងអនុវត្តត្រឹមត្រូវ ដោយត្រូវគិតពិចារណាដល់លក្ខខណ្ឌដែលត្រូវពិភា

---

[3157] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៨៥-៣៨៦ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧២-៥៩០ និងជាពិសេស កថាខណ្ឌ ៥៨៤។

[3158] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៨៨។

[3159] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៨៨។

[3160] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៣២, ៥៣៨។

ក្សាដូចខាងក្រោម[3161]។ ពុំមានលក្ខខណ្ឌតម្រូវថា អំពើជាមូលដ្ឋាននោះត្រូវតែជាបទល្មើសនៅពេលពាក់ព័ន្ធនោះឡើយ[3162]។

1131.នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា គោលការណ៍ស្តីពី*ប្រភេទដូចគ្នា* បានផ្តល់លក្ខខណ្ឌចាំបាច់ដែលតម្រូវថា អំពើជាមូលដ្ឋានដែលត្រូវបានចាត់ទុកថា អាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3163]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានពន្យល់ថា លក្ខខណ្ឌតម្រូវដែលថា អំពើជាមូលដ្ឋាននោះត្រូវតែបង្កការរងទុក្ខវេទនា ឬរបួសកម្មធ្ងន់ធ្ងរលើរូបកាយ និងស្មារតី ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស គឺជាតម្រូវការមួយផ្សេងទៀតដែលកម្រិតវិសាលភាពនៃបទឧក្រិដ្ឋប្រភេទនេះ[3164]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា អង្គជំនុំជម្រះបានអនុវត្តតាមវិធីសាស្ត្រដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Kupreškić* "ដែលបានភ្ជាប់ការទំនាក់ទំនង'អំពើអមនុស្សធម៌ដទៃទៀត'ទៅនឹងអំពើដែលបានរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋាន ដូចបានកំណត់ក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិ"ថាជាការកម្រិតមួយផ្សេងទៀតលើការបកស្រាយនៃអំពើអមនុស្សធម៌ដទៃទៀត[3165]។ ការកម្រិតទាំងនេះបានបញ្ជាក់រួមគ្នានូវអំពើដែលអាចត្រូវបានពិចារណាដោយត្រឹមត្រូវថា អាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀតដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស។

1132.នៅក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញនូវច្បាប់ពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា មានភាពអាចដឹងជាមុនបានជាទូទៅថា អំពើអមនុស្សធម៌ដទៃទៀតមានច្បាប់ចែង និងជាបទល្មើសដែលអាចផ្តន្ទាទោសបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ ដោយសារពុំតម្រូវឱ្យមានការវាយតម្លៃដាច់ដោយឡែកពីគ្នានូវនីត្យានុកូលភាពនៃអំពើជាមូលដ្ឋាននោះ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវលក្ខខណ្ឌដែលត្រូវតែបានបំពេញសម្រាប់អំពើដែលត្រូវបានពិចារណាសមស្របដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត និងថា អំពើសកម្ម ឬអកម្ម ត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅ

[3161] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៨។

[3162] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3163] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៨។

[3164] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៩-៥៨១។

[3165] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

នឹងបទឧក្រិដ្ឋជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងត្រូវតែបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬស្មារតី ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3166]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃលើបញ្ហាថាតើ សិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះត្រូវបានរំលោភបំពាន ដែរ ឬយ៉ាងណា[3167]។

1133. ការកំណត់ថាតើ លក្ខខណ្ឌនេះត្រូវបានបំពេញដូចជា អំពើនេះត្រូវបានពិចារណាដោយត្រឹមត្រូវថាអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត និងគោលការណ៍នីត្យានុកូលភាពត្រូវបានគោរពតាម ដែរ ឬយ៉ាងណា ពុំគប្បីធ្វើឡើងដោយសង្ខេបនៅក្នុងផ្នែកសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលលើកបង្ហាញនូវច្បាប់ជាធរមាននោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវិភាគបញ្ហានេះនៅក្នុងផ្នែកនៃសាលក្រមរបស់ខ្លួនដែលអង្គជំនុំជម្រះបានបង្កើតនូវការយល់ឃើញផ្នែកច្បាប់[3168]។ អំណះអំណាងនេះត្រូវបដិសេធចោល។

---

[3166] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤-៧២៥។

[3167] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៦។

[3168] ពិតណាស់ ក្នុងការយល់ឃើញផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះបានពិចារណាថាតើ អំពើនេះមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋជាក់លាក់ដែលមានក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា និងថាតើ អំពើនេះបានបង្កឱ្យមានការរងទុក្ខ និងព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងស្មារតី ឬការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានវិភាគម៉ត់ចត់ក្នុងការកំណត់បញ្ហាថាតើ សិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះត្រូវបានរំលោភបំពានដែរ ឬយ៉ាងណា ដែលជាបញ្ហាត្រូវដោះស្រាយក្នុងផ្នែកខាងក្រោម។ សម្រាប់ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩៣-១១៩៩ (សហករណ៍ត្រាំកក់), ១៤១៤-១៤២១ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម), ១៦៩៨-១៧០៧ (ការដ្ឋានធ្វើការទំនប់១មករា), ១៨២៩-១៨៣៧ (ការដ្ឋានធ្វើការព្រលានយន្តហោះខេត្តកំពង់ឆ្នាំង), ២៦១១-២៦១៨ (មន្ទីរសន្តិសុខ ស-២១), ២៨៤៨-២៨៥១ (មន្ទីរសន្តិសុខក្រាំងតាចាន់), ៣០០៣-៣០១០ (មន្ទីរសន្តិសុខអូរកន្សែង), និង ៣១៥២-៣១៥៩ (មន្ទីរសន្តិសុខភ្នំក្រោល)។ សម្រាប់ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០០-១២០៤ (សហករណ៍ត្រាំកក់), ១៤២២-១៤២៩ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម), ១៧០៨-១៧១២ (ការដ្ឋានធ្វើការទំនប់១មករា), ១៨៣៨-១៨៤៦ (ការដ្ឋានធ្វើការព្រលានយន្តហោះខេត្តកំពង់ឆ្នាំង), ២៨៥២-២៨៥៨ (មន្ទីរសន្តិសុខក្រាំងតាចាន់) និង ៣១៦០-៣១៦៦ (មន្ទីរសន្តិសុខភ្នំក្រោល)។ សម្រាប់ការផ្លាស់ទីដោយបង្ខំ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៣៥-៣៣៤០។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបការ នឹងត្រូវដោះស្រាយក្នុងសាលដីកានេះ ដោយសារ ខៀវ សំផន បានលើកទឡ្ហីករណ៍ដាច់ដោយឡែកពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថៈក្នុងបរិបទនៃការរៀបការដោយបង្ខំ។

## ខ. លក្ខខណ្ឌតម្រូវដែលរងការចោទប្រកាន់ថា រំលោភបំពានលើការហាមឃាត់ក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត

1134.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលបានប្រឹងប្រែងបង្ហាញនូវអំពើអនីត្យានុកូលភាពជាសក្តានុពលនៅពេលប្រព្រឹត្តនោះ[3169]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានផ្តល់"ការយោងតាមធម្មតាទៅលើសិទ្ធិជាសារវ័ន្តដែលមាននៅក្នុងលិខិតុបករណ៍នៅពេលនោះ" នៅពេលដែលអង្គជំនុំជម្រះគប្បីវិភាគលើលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សទាំងនេះ ដើម្បីកំណត់ឱ្យឃើញនូវការហាមឃាត់ និងអំពើអនីត្យានុកូលភាពផ្លូវការនោះ[3170]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Kupreškić* បានពិចារណាលើអត្ថបទអន្តរជាតិនានាក្នុងការបង្ហាញនូវសិទ្ធិមនុស្សជាមូលដ្ឋានដែលការរំលោភបំពាននៃសិទ្ធិនេះអាចបង្កើតជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Stakić* បានបដិសេធវិធីសាស្ត្រនេះថា សិទ្ធិដែលមាននៅក្នុងលិខិតុបករណ៍អន្តរជាតិនេះ ជាចាំបាច់ពុំអាចស្មើនឹងបទដ្ឋានដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ[3171]។ គាត់បានអះអាងបន្ថែមថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលហាក់បីដូចជាចង់បង្ហាញនូវការសម្របសម្រួលមួយរវាងជំហរទាំងពីរនោះ តាមរយៈការបញ្ជាក់ជាក់លាក់ថា ដោយបន្ថែមទៅលើការពិចារណាលើសិទ្ធិនោះ ជាការចាំបាច់ផងដែរក្នុងការកំណត់ឱ្យឃើញនូវការហាមឃាត់ដែលមាននៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស[3172]។ គាត់បានអះអាងថា សហចៅក្រមស៊ើបអង្កេតដែលបានស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ក៏បានអនុវត្តតាមវិធីសាស្ត្រនេះដែរ[3173]។

1135.ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានតម្រូវឱ្យកំណត់នូវ "ការហាមឃាត់"នៃអំពើពាក់ព័ន្ធដែលមាននៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សបន្ថែមលើ"សិទ្ធិ"ដែលអំពើនោះបានរំលោភបំពានឡើយ[3174]។ សហព្រះរាជអាជ្ញាបានលើកឡើងថា លិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស

---

[3169] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៦៧។

[3170] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៦៩, ៦៧១។

[3171] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៦៨។

[3172] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៦៦៩។

[3173] សារណាបណ្តឹងរបស់ ខៀវ សំផន កថាខណ្ឌ ៦៧០។ ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ F1/10.1 ទំព័រ ៣១-៣២។

[3174] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៩១។

បានប្រើប្រាស់បច្ចេកទេសព្រាងពីរដែលអាចជំនួសគ្នាបាន និងថា ការតម្រូវឱ្យមានការហាមឃាត់ជាក់លាក់នូវអំពើនោះ គឺផ្ទុយពីគោលបំណងតាមការចង់បានឱ្យអំពើនោះជាប្រភេទមិនជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាការបង្កើតសាឡើងវិញនូវលក្ខខណ្ឌដែលត្រូវបានដកចេញយ៉ាងជាក់លាក់ដោយអង្គជំនុំជម្រះតុលាការកំពូល[3175]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា សមាសភាគនៃ"អនីត្យានុកូលភាពផ្លូវការ"ពុំត្រូវបានតម្រូវច្បាស់លាស់នៅតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ក្នុងការកំណត់អំពើអមនុស្សធម៌ដទៃទៀត និងថា តុលាការព្រហ្មទណ្ឌទាំងនេះពុំបានតម្រូវឱ្យមានការហាមឃាត់នៃអំពើជាក់លាក់នោះឡើយ[3176]។

1136.សហមេធាវីនាំមុខបានអះអាងថា ពុំមានមូលដ្ឋានផ្លូវច្បាប់សម្រាប់ការបែងចែករវាងសិទ្ធិ និងការហាមឃាត់ក្នុងលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស ហើយសិទ្ធិណាមួយដែលត្រូវបានការពារក្នុងលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស បានចងកាតព្វកិច្ចដល់រដ្ឋ ដែលនេះអាចស្មើនឹងការហាមឃាត់លើសិទ្ធិនោះ[3177]។ សហមេធាវីនាំមុខបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kupreškić* ពុំបានធ្វើការបែងចែករវាងសិទ្ធិ និងការហាមឃាត់ ខណៈពេលដែលបញ្ជាក់អំពីវិធីសាស្ត្ររបស់ខ្លួន ដូចគ្នាដែរអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Blagojević* ហើយសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Stakić* បានបដិសេធវិធីសាស្ត្រក្នុងរឿងក្តី *Kupreškić* ប៉ុន្តែសាលក្រមនេះត្រូវបដិសេធចោលលើចំណុចនេះ[3178]។ សហមេធាវីនាំមុខបានកត់សម្គាល់បន្ថែមទៀតថា ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលពុំបានធ្វើការសម្របសម្រួលរវាងវិធីសាស្ត្រក្នុងរឿងក្តី *Kupreškić* ជាមួយនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងរឿងក្តី *Stakić* ឡើយ[3179]។

1137.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ ដូចបានបញ្ជាក់ខាងដើម ក្នុងរឿងក្តីនោះ អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តតាមវិធីសាស្ត្រដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Kupreškić* ដែល"ភ្ជាប់ទំនាក់ទំនងនៃ'អំពើអមនុស្សធម៌ដទៃទៀត'ទៅនឹងអំពើដែលរំលោភបំពានលើសិទ្ធិ

[3175] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៩១។

[3176] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៩២។

[3177] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤១។

[3178] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤២។

[3179] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤២។

មនុស្សជាមូលដ្ឋាន ដូចបានកំណត់ក្នុងលិខិតុបករណ៍អន្តរជាតិ"[3180]។ យោងតាមអង្គជំនុំជម្រះតុលាការកំពូលឃើញថា នេះ"ជាការបង្ហាញនូវលក្ខខណ្ឌនៃអំពើអនីត្យានុកូលភាពអន្តរជាតិផ្លូវការ និងតាមវិធីនេះការកម្រិតបន្ថែមទៀតលើសិទ្ធិអំណាចក្នុងការបកស្រាយលាតសន្ធឹងនូវ'អំពើអមនុស្សធម៌ដទៃទៀត'"ដែលជួយដល់ការធានាបាននូវភាពអាចដឹងជាមុនបានថា មានច្បាប់ចែង[3181]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានបញ្ជាក់សាជាថ្មីថា ពុំមានលក្ខខណ្ឌតម្រូវថា អំពើជាក់លាក់នោះត្រូវតែជាបទល្មើសដែលត្រូវបានបង្ហាញច្បាស់លាស់តាមច្បាប់អន្តរជាតិ ដែលនេះអាចធ្វើឱ្យគោលគំនិតនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាប្រភេទមិនជាក់លាក់ទៅជាឥតប្រយោជន៍ និងគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា៖

> ផ្ទុយទៅវិញ លក្ខខណ្ឌ'អនីត្យានុកូលភាពផ្លូវការ'ត្រូវបំពេញតាមរយៈការកំណត់នូវការបញ្ជាក់អំពីសិទ្ធិ និងការហាមឃាត់ដែលមាននៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សដែលអនុវត្តបាននៅពេលពាក់ព័ន្ធសម្រាប់បទចោទនៃ'អំពើអមនុស្សធម៌ដទៃទៀត'[3182]។

អង្គជំនុំជម្រះតុលាការកំពូលយោងទៅលើការហាមឃាត់ដែលមាននៅក្នុងមាត្រា ៣ ដែលជាមាត្រាទូទៅនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងសិទ្ធិដែលត្រូវបានការពារដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("UDHR") ធ្វើជាឧទាហរណ៍ពាក់ព័ន្ធទៅនឹងរឿងក្តីបច្ចុប្បន្ន[3183]។

1138.អង្គជំនុំជម្រះតុលាការកំពូលពុំបានបញ្ជាក់ថា ការហាមឃាត់ដែលមាននៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ត្រូវតែបានកំណត់បន្ថែមលើសិទ្ធិនោះទេ។ មានការបញ្ជាក់ច្បាស់លាស់ថា "គោលការណ៍ស្តីពី*គ្មានបទល្មើសបើគ្មានច្បាប់ចែង* ត្រូវបានគោរព ប្រសិនបើអំពើជាក់លាក់នោះដែលត្រូវបានរកឃើញថា ជាអំពើអមនុស្សធម៌ដទៃទៀត បានរំលោភបំពានលើសិទ្ធិរបស់ជនរងគ្រោះ និងមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[3184]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kupreškić* ពុំបានធ្វើការបែងចែកភាពខុសគ្នារវាងសិទ្ធិ និងការហាមឃាត់

---

[3180] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3181] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3182] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3183] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3184] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៦។

ឡើយ[3185] ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Katanga និង Ngudjolo Chui* ដែលបានអនុវត្តតាមវិធីសាស្ត្រនេះផងដែរ[3186]។ សហចៅក្រមស៊ើបអង្កេតដែលបានសម្រេចលើសំណើសុំបើកកិច្ចស៊ើបសួរលើអំពើដែលត្រូវបានលើកឡើងថា ស្មើនឹងការធ្វើឱ្យមានគភ៌ និងផ្ទៃពោះដោយបង្ខំបានបញ្ជាក់ថា "ត្រូវតែមានបទដ្ឋានដែលត្រូវបានទទួលស្គាល់តាមទំនៀមទម្លាប់ ដែលភ្ជាប់ទៅនឹងសិទ្ធិមនុស្សសមស្រប ដើម្បីឱ្យអំពើអមនុស្សធម៌អាចត្រូវបានវិនិច្ឆ័យ"[3187]។ សហចៅក្រមស៊ើបអង្កេតពុំអាចយល់ឃើញថា មានបទដ្ឋានស្តីពីសិទ្ធិមនុស្សច្បាស់លាស់មួយដែលពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំត្រឹមឆ្នាំ ១៩៧៥ នោះឡើយ និងដូច្នេះ គាត់ពុំបានពិចារណាថា អាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀតនៅពេលនោះ និងបានសម្រេចបដិសេធសំណើសុំបើកកិច្ចស៊ើបសួរនោះ[3188]។ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតរួមបញ្ចូលគ្នារវាងការវាយតម្លៃដែលតម្រូវឱ្យបង្ហាញនូវការហាមឃាត់ច្បាស់លាស់ផ្នែកព្រហ្មទណ្ឌដោយផ្អែកលើទំនៀមទម្លាប់ ជាមួយនឹងវិធីសាស្ត្រដែលត្រូវប្រើប្រាស់នៅពេលវាយតម្លៃលើភាពជាក់លាក់នៃអំពើដែលត្រូវបានចោទប្រកាន់នៅក្នុងវិសាលភាពបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត។ ការអះអាងដែលថា ត្រូវតែមាន"បទដ្ឋានមួយដែលត្រូវបានទទួលស្គាល់តាមទំនៀមទម្លាប់"ដើម្បីអាចវាយតម្លៃអំពើនៅក្នុងវិសាលភាពបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដែលនេះបានផ្អែកទៅលើអត្ថបទសិក្សាស្រាវជ្រាវមួយនៅក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[3189]ពុំមានមូលដ្ឋានគាំទ្រឡើយ។ ដូចបានកត់សម្គាល់ខាងលើ គោលបំណងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត គឺដើម្បីអនុញ្ញាតឱ្យ

---

[3185] សាលដីការឿងក្តី *KupreÈkić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៥៦៦។

[3186] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* អង្គបុរេជំនុំជម្រះ I (ICC) សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចស្តីពីការបញ្ជាក់នៃបទចោទ ថ្ងៃ ៣០ ខែ កញ្ញា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចស្តីពីការបញ្ជាក់របស់ *Katanga និង Ngudjolo Chui* អំពីបទចោទ (ICC)") កថាខណ្ឌ ៤៤៨: "ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះ យោងតាមមាត្រា ៧ (l)(k) នៃលក្ខន្តិកៈ និងគោលការណ៍ស្តីពី*គ្មានបទល្មើសបើគ្មានច្បាប់ចែង* អនុលោមតាមមាត្រា ២២ នៃលក្ខន្តិកៈ អំពើអមនុស្សធម៌ត្រូវតែបានចាត់ទុកថា ជាការរំលោភធ្ងន់ធ្ងរលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងសិទ្ធិមនុស្សជាមូលដ្ឋានដែលទាញចេញពីបទដ្ឋាននៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងអំពើដែលបានយោងទៅលើក្នុងមាត្រា ៧(១) នៃលក្ខន្តិកៈ"។

[3187] សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើសុំបំពេញកិច្ចស៊ើបអង្កេតពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ សំណុំរឿង ០០៤ ឯកសារលេខ D301/5 ("សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5)") កថាខណ្ឌ ៦៥។

[3188] សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5) កថាខណ្ឌ ៧០-៧៥។

[3189] សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5) កថាខណ្ឌ ៦៤ យោងទៅលើអ្នកនិពន្ធ Terhi Jyrkkiö "អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" (ឆ្នាំ ២០០១) 1 *Helsinki* វិសោធនកម្មច្បាប់ ២០៥។

មានការចោទប្រកាន់អំពើធ្ងន់ធ្ងរដែលពុំត្រូវបានចាត់ទុកជាបទល្មើសដាច់ដោយឡែក ដូចបទឧក្រិដ្ឋឯករាជ្យ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅខណៈពេលនោះ។ ជាការពុំសមស្របក្នុងការតម្រូវថា ការវាយតម្លៃលើអំពើសម្រាប់គោលបំណងនោះត្រូវតែមានលក្ខណៈច្បាស់លាស់នោះ។

1139.ការហាមឃាត់ដែលបានរៀបរាប់ក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស នឹងមានការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ អំពើនោះអាចដឹងជាមុនបានថា មានច្បាប់ចែង ដែរ ឬយ៉ាងណា ប៉ុន្តែពុំមានលក្ខខណ្ឌថ្មីត្រូវបានបង្កើតឡើងដែលតម្រូវឱ្យមានអត្ថិភាពនៃការហាមឃាត់នោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសដោយសារ“បានផ្តល់ការវិភាគខ្លីនូវអំពើអនីត្យានុកូលភាពផ្លូវការ”ឡើយ។

1140.ទោះជាយ៉ាងណាក្តី បើទោះបីជាបានលើកឡើងត្រឹមត្រូវអំពីច្បាប់ពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀត និងការទទួលស្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា គប្បីវិភាគលើបញ្ហាថាតើ អំពើជាក់លាក់នោះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដែរ ឬយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានវិភាគលើបញ្ហាថាតើអំពើជាមូលដ្ឋាននេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដែរ ឬយ៉ាងណា ខណៈពេលបង្កើតការយល់ឃើញផ្នែកច្បាប់របស់ខ្លួននោះ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា នេះជាកំហុសដែលប៉ះពាល់ដល់សុពលភាពនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីដោយបង្ខំ ដោយសារអំពើនេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដូចបានពន្យល់ខាងក្រោម។ ការវាយតម្លៃអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងត្រូវដោះស្រាយក្នុងសាលដីកានេះ ដោយសារ ខៀវ សំផន បានលើកការជំទាស់ដាច់ដោយឡែកពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3190]។

1141.ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរបានរំលោភបំពានលើសិទ្ធិទទួលបានសេរីភាព សន្តិសុខរបស់បុគ្គល និងសេរីភាពក្នុងការដើរហើរ និងតាំងទីលំនៅ ព្រមទាំង ក្នុងលក្ខខណ្ឌផ្នែករូបកាយ សិទ្ធិរួចផុតពីអំពើឃោរឃៅ អមនុស្សធម៌ ឬការ

[3190] *សូមមើល* ផ្នែក VII.ឆ.៣។

បន្ទាបបន្ថោកសេចក្តីថ្លៃថ្នូរ[3191]។ អំពើនេះនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានចាត់ទុកថា អាចស្មើនឹងការផ្លាស់ទីដោយបង្ខំ ពីព្រោះអំពើអមនុស្សធម៌ដទៃទៀតបានកើតឡើងដែលជាផ្នែកមួយនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ដូច្នេះ ការវិភាគនេះអនុវត្តដូចគ្នានៅទីនេះពាក់ព័ន្ធទៅនឹងសិទ្ធិដែលត្រូវបានរំលោភបំពាន។ លក្ខខណ្ឌរូបកាយដែលបានសំដៅទៅលើក្នុងសំណុំរឿង ០០២/០១ ថា ជាការរំលោភបំពានលើសិទ្ធិរួចផុតពីអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬការបន្ទាបបន្ថោកសេចក្តីថ្លៃថ្នូរ អនុវត្តដូចគ្នាចំពោះកាលៈទេសៈក្នុងរឿងក្តី ០០២/០២ នៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3192] ដូច្នេះ ត្រូវអនុវត្តវិធីសាស្ត្រដូចគ្នានៅទីនេះផងដែរ។ ចំពោះអំពើពាក់ព័ន្ធដែលត្រូវបានចាត់ទុកថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើនោះអាចរំលោភបំពានលើសិទ្ធិជាច្រើនដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស រួមមានសិទ្ធិមានជីវិត សេរីភាព និងសន្តិសុខរបស់បុគ្គល[3193] សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬការបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម[3194] សិទ្ធិទទួលបានការទទួលស្គាល់ស្មើគ្នាចំពោះមុខច្បាប់[3195] និងសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌[3196]។

1142. ជាសរុប អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសដោយសារខកខានក្នុងការបញ្ជាក់នូវការហាមឃាត់ដែលមានក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ដើម្បីកំណត់អំពើអនីត្យានុកូលភាពផ្លូវការឡើយ។ ការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់មានលក្ខណៈត្រឹមត្រូវ និងការយល់ឃើញផ្នែកច្បាប់របស់ខ្លួនពាក់ព័ន្ធទៅនឹងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីដោយបង្ខំ បើ

---

[3191] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦៥៦, ៦៥៩ (កថាខណ្ឌ ៦៥៦ បង្កើតការយល់ឃើញនេះពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទី១ និងកថាខណ្ឌ ៦៥៩ ដែលបញ្ជាក់ថា ការវិភាគនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរមានលក្ខណៈសទិសភាព)។

[3192] នេះគឺជាការផ្តត់ផ្គង់មិនគ្រប់គ្រាន់នៃអាហារ ទឹកស្អាត ទីជម្រក ឬការអនាម័យ។ *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៦១៩។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៩៣, ១៤១៤, ១៦៩៨, ១៨២៩, ២៦១១, ២៨៤៨, ៣០០៣, ៣១៥២។

[3193] មាត្រា ៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ សេចក្តីសម្រេចមហាសន្និបាតលេខ 217A (III), UN Doc. A/810 ទំព័រ (១៩៤៨) (“សេចក្តីប្រកាសសកល UDHR”)។

[3194] មាត្រា ៥ នៃសេចក្តីប្រកាសសកល UDHR។

[3195] មាត្រា ៦ នៃសេចក្តីប្រកាសសកល UDHR។

[3196] មាត្រា ១០ នៃសេចក្តីប្រកាសសកល UDHR។

ទោះបីមិនបានពេញលេញក៏ដោយ ក៏ពុំអាចមោឃៈសាលក្រមរបស់ខ្លួនបានដែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ២. ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ

1143.ទាក់ទងទៅនឹងសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងភ្នំក្រោល។ ដីកាដំណោះស្រាយបានចោទប្រកាន់ថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ការឃុំខ្លួន ឬការចាប់ពង្រត់ជនរងគ្រោះក្នុងលក្ខខណ្ឌដែលពុំបានដាក់ពួកគេឱ្យស្ថិតក្រោមការការពារនៃច្បាប់ និងការបដិសេធក្នុងការផ្តល់ ឬទទួលបានដំណឹងអំពីវាសនា ឬទីកន្លែងរបស់បុគ្គលទាំងនោះ[3197]។

1144.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ និងភ្នំក្រោល[3198]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា អំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំពុំត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងជនជាតិចាមឡើយ[3199]។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងភ្នំក្រោល[3200]។ អំណះអំណាងនេះនឹងត្រូវដោះស្រាយតាមលំដាប់លំដោយ។

---

[3197] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៥៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៧០-១៤៧៨ និងឧបសម្ព័ន្ធដីកាសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1.1) ទំព័រ ៤។ អង្គជំនុំជម្រះសាលាដំបូងបានយោងនៅទីនេះទៅលើមន្ទីរសន្តិសុខ ស-២១ និង អូរកន្សែង ប៉ុន្តែការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅទីតាំងទាំងពីរនេះពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ឧបសម្ព័ន្ធដីកាសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម ទំព័រ ៤។

[3198] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩២៧, ៣៩៨៦។

[3199] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៤២។

[3200] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៦-៧៥៧, ៨៣៧-៨៤០, ៨៨៧-៨៩១។

ក. សហករណ៍ត្រាំកក់

1145.ក្នុងការវាយតម្លៃថាតើ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានកើតឡើងនៅសហករណ៍ត្រាំកក់ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បុគ្គលជាក់លាក់ជាច្រើនត្រូវបានឃុំឃាំង និងត្រូវបានធ្វើឱ្យបាត់ខ្លួនក្នុងស្រុកត្រាំកក់ និងថា អ្នកប្រឆាំងនយោបាយ និងអ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ អាចត្រូវបានចាប់ខ្លួន និងធ្វើឱ្យបាត់ខ្លួន និងថា ជនជាតិវៀតណាមត្រូវបានប្រមូលផ្ដុំក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ និងត្រូវបាននិរទេស និងធ្វើឱ្យបាត់ខ្លួន និងថា គ្រួសារខ្មែរក្រោមទាំងមូលត្រូវបានធ្វើឱ្យបាត់ខ្លួន[3201]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួនពីសហករណ៍ត្រាំកក់មានលក្ខណៈរីករាលដាល និងបានកើតឡើងក្នុងកាលៈទេសៈដែលបុគ្គលនីមួយៗត្រូវបានដកហូតនូវសេរីភាព និងថា ការចាប់ខ្លួនដែលរីករាលដាលត្រូវបានធ្វើឡើងដោយភ្នាក់ងារបក្សកុម្មុយនីស្តកម្ពុជា[3202]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពុំមានដំណើរការផ្លូវច្បាប់អនុវត្តសម្រាប់បុគ្គលក្នុងការស្វែងរក និងដើម្បីទទួលបានដំណឹងអំពីវាសនាសាច់ញាតិរបស់ខ្លួន និងបានជឿជាក់ថា បរិយាកាសនោះអាចស្មើនឹងការបដិសេធទូទៅក្នុងការផ្ដល់ដំណឹងអំពីវាសនារបស់បុគ្គលដែលបានបាត់ខ្លួននោះ[3203]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំគឺជាការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់បុគ្គលដល់អ្នកដែលបានបាត់ខ្លួន និងបានបង្កនូវការរងទុក្ខធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្តដល់អ្នកដែលរស់នៅដោយសារពុំមានដំណឹងអំពីវាសនាសាច់ញាតិ ឬមិត្តភក្តិរបស់ខ្លួននោះ[3204]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការធ្វើឱ្យបាត់ខ្លួនមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូច្នេះបង្ហាញនូវធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លក្ខណៈរីករាលដាល និងការប្រព្រឹត្តដដែលៗនៃអំពើនេះបានបង្ហាញថា ត្រូវបានប្រព្រឹត្តឡើងដោយចេតនា ដូច្នេះ បំពេញតាមលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិនោះ[3205]។

1146.ខៀវ សំផន បានកម្រិតអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ ត្រឹមបញ្ហាថាតើ ជនជាតិវៀតណាម និងខ្មែរក្រោមត្រូវបានធ្វើឱ្យបាត់ខ្លួន ដែរ ឬយ៉ាងណា។ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់

[3201] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០១។

[3202] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០២។

[3203] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៣។

[3204] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៤។

[3205] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៤។

ឃើញថា ជនជាតិវៀតណាមត្រូវបាននិរទេស“និង/ឬ”ត្រូវបានធ្វើឱ្យបាត់ខ្លួន[3206]។ គាត់បានលើកឡើងថា ការប្រើប្រាស់ពាក្យថា “និង/ឬ”បានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យនូវការនិរទេស ឬការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[3207]។ គាត់បានអះអាងថា មន្ទិលសង្ស័យណាមួយគប្បីត្រូវបានដោះស្រាយបានជាប្រយោជន៍ដល់រូបគាត់ស្របតាមគោលការណ៍ស្ដីពីវិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ និងថា អង្គជំនុំជម្រះពុំគប្បីយល់ឃើញថា ជនជាតិពន្ធុវៀតណាម ជាជនរងគ្រោះនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំឡើយ[3208]។ ពាក់ព័ន្ធទៅនឹងខ្មែរក្រោម ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការយល់ឃើញថា ខ្មែរក្រោមត្រូវបានធ្វើឱ្យបាត់ខ្លួនជាក្រុម ដោយសារអង្គហេតុពាក់ព័ន្ធទៅនឹងខ្មែរក្រោមពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះ ហើយអង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញនូវធាតុផ្សំនៃបទឧក្រិដ្ឋដែលប្រើប្រាស់ភស្តុតាងក្រៅវិសាលភាពនោះឡើយ[3209]។

1147.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញដែលថា ជនជាតិវៀតណាមត្រូវបាននិរទេស និង/ឬធ្វើឱ្យបាត់ខ្លួន ពុំបានបង្ហាញនូវការពុំអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ជនជាតិវៀតណាមត្រូវបាននិរទេស ឬធ្វើឱ្យបាត់ខ្លួននោះទេ ប៉ុន្តែគ្រាន់តែថា ផ្អែកតាមកាលៈទេសៈ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជនជាតិវៀតណាមត្រូវបាននិរទេស ហើយបុគ្គលដែលត្រូវបាននិរទេសនោះ គឺជាជនរងគ្រោះនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំផងដែរ[3210]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងពាក់ព័ន្ធទៅនឹងគោលការណ៍នៃវិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ ពុំមានប្រសិទ្ធភាពឡើយ ដោយសារការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានធាតុផ្សំនៃវិមតិសង្ស័យ[3211]។ ពាក់ព័ន្ធទៅនឹងខ្មែរក្រោម សហព្រះរាជអាជ្ញាបានជំទាស់ថា ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ ឬដាក់ពិរុទ្ធភាពពីបទនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើខ្មែរក្រោមដែលជាក្រុមជាក់លាក់មួយ ឬជាក្រុមមួយតូចជាងក្រុមជនជាតិវៀតណាមនៅត្រាំកក់ និងថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើភស្តុតាងដែលបង្ហាញថា គ្រួសារខ្មែរ

---

[3206] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៦។

[3207] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៦។

[3208] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៦។

[3209] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៧៥៧។

[3210] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៩១។

[3211] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៩១។

ក្រោមទាំងមូលត្រូវបានធ្វើឱ្យបាត់ខ្លួន ស្របជាមួយនឹងភស្តុតាងដែលបង្ហាញថា ជនជាតិវៀតណាម និងអ្នករស់នៅអចិន្ត្រៃយ៍ដទៃទៀតនៃសហករណ៍នោះត្រូវបានធ្វើឱ្យបាត់ខ្លួនក្នុងរបបនោះដែរ[3212]។

1148.សហមេធាវីនាំមុខបានឆ្លើយតបថា ដោយសារជនរងគ្រោះជនជាតិវៀតណាម និងខ្មែរក្រោម គឺជាក្រុមពីរក្នុងចំណោមក្រុមជាច្រើនដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ អំណះអំណាងរបស់ ខៀវ សំផន ពុំគ្រប់គ្រាន់ក្នុងការបដិសេធការយល់ឃើញជារួមដែលថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញ[3213]។ សហមេធាវីនាំមុខបានអះអាងថា ការផ្តោតរបស់ ខៀវ សំផន ទៅលើតែពាក្យ "និង/ឬ" ពុំបានអើពើការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដែលច្បាស់លាស់ឥតព្រលាំអំពីចំនួនមនុស្សដែលត្រូវបានធ្វើឱ្យបាត់ខ្លួន និងបានបង្ហាញនូវការភាន់ច្រឡំលើធាតុផ្សំនៃបទឧក្រិដ្ឋ។ នេះជាការពុំចាំបាច់ក្នុងការកំណត់លើវាសនារបស់ជនជាតិវៀតណាមឱ្យហួសពីវិមតិសង្ស័យនោះទេ ប៉ុន្តែត្រឹមតែកំណត់ថា តើធាតុផ្សំនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា[3214]។ ពាក់ព័ន្ធទៅនឹងខ្មែរក្រោម សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពុំធ្វើការពិចារណាលើភស្តុតាងនៃការធ្វើទុក្ខបុកម្នេញប្រជាជនខ្មែរក្រោម ប៉ុន្តែថា នឹងពិនិត្យលើភស្តុតាងនៃបទឧក្រិដ្ឋដទៃទៀតដែលបានចោទប្រកាន់នោះ និងជនរងគ្រោះមួយចំនួននៃបទឧក្រិដ្ឋនេះដែលជាខ្មែរក្រោម ហើយដីកាដំណោះស្រាយពុំបានកម្រិតការធ្វើឱ្យបាត់ខ្លួនពីស្រុកត្រាំកក់ត្រឹមតែក្រុមជាក់លាក់ណាមួយនោះទេ[3215]។

1149.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន ដែលកម្រិតត្រឹមជនជាតិវៀតណាម និងខ្មែរក្រោម ពុំមានលក្ខណៈគ្រប់គ្រាន់អាចបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងពុំបានសន្និដ្ឋានថា មានតែជនជាតិវៀតណាម និងខ្មែរក្រោមប៉ុណ្ណោះដែលត្រូវបានធ្វើឱ្យបាត់ខ្លួននោះ។

---

3212 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៩៥។

3213 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៨៧។

3214 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៩០-៥៩៤។

3215 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៨៩។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានបុគ្គលជាច្រើនត្រូវបានធ្វើឱ្យបាត់ខ្លួន រួមទាំងឪពុកមារបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ឈ្មោះ អ៊ឹម ចក់ ដែលត្រូវបាននាំចេញពីវត្តចំប៉ាក្នុងពេលជាមួយគ្នានឹងអ្នកដទៃទៀតដែលរកឃើញថា ពួកគេមានតួនាទីខ្ពស់ ឬមន្ត្រីរាជការជាន់ខ្ពស់ ឬអតីតគ្រូបង្រៀន ទាហាន ឬប៉ូលីស ឬមន្ត្រីខាងពន្ធគយ[3216]។ អ្នកដែលបាត់ខ្លួនរួមមានបងប្អូនប្រុសរបស់ រៀល សន ឈ្មោះ យ៉ា សាន និងឪពុកមាបស់គាត់ឈ្មោះ ឡុង នាគ និងបងប្រុសរបស់គាត់ឈ្មោះ រៀល អឹម បងប្រុសរបស់ សៅ ប៊ាន ឈ្មោះ លួន ហាន បងប្រុសរបស់ អ៊ឹម វណ្ណៈ ឈ្មោះ អ៊ឹម ម៉ាច និងសាច់ញាតិជាច្រើនទៀតរបស់ ឡឹប នាង [និង] ប្តីរបស់ តាក សាន់[3217]។ បើទោះបីជាការជំទាស់នេះពុំទាមទារឱ្យមានការពិចារណាបន្ថែម សម្រាប់ហេតុផលនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមាន កំហុសពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនជនជាតិវៀតណាម ឬខ្មែរក្រោមដែរ។ អង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់ពាក្យថា "ត្រូវបាននិរទេស និង/ឬត្រូវបានធ្វើឱ្យបាត់ខ្លួន" ពីព្រោះអង្គជំនុំជម្រះពុំអាចកំណត់ បាននូវវាសនារបស់ជនជាតិវៀតណាមម្នាក់ៗដែលត្រូវបានធ្វើឱ្យបាត់ខ្លួនពីស្រុកត្រាំកក់។ ទោះជាយ៉ាងណាក្តី ការកំណត់វាសនារបស់អ្នកដែលត្រូវបានធ្វើឱ្យបាត់ខ្លួន ពុំចាំបាច់ត្រូវបង្ហាញថាតើ អំពើអមនុស្សធម៌ដទៃទៀតនោះបានកើតឡើងតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើបញ្ហាថាតើ ធាតុផ្សំនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយោងទៅលើផ្នែក **VI.ង** នៃសាលដីកានេះដែលដោះស្រាយបញ្ហាខ្មែរក្រោម។

## ខ. មន្ទីរសន្តិសុខក្រាំងតាចាន់

1150.ក្នុងការវាយតម្លៃលើបញ្ហាថាតើ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានកើតឡើង ដែរ ឬយ៉ាងណា នៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែលមានទីតាំងក្នុងស្រុកត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះបាន យល់ឃើញពីដំបូងថា អំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់[3218]។ គួរកត់សម្គាល់ផងដែរថា បញ្ហាផ្នែកច្បាប់បានកើតឡើងទាក់ទងទៅនឹងបញ្ហាថាតើ បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្ស

[3216] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០១ យោងទៅលើសាលក្រមអង្គជំនុំជម្រះ កថាខណ្ឌ ៩៥៩-៩៦០, ៩៦៥។

[3217] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០១។

[3218] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៣។

ធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ គប្បីពិចារណាពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែរ ឬយ៉ាងណា ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា មនុស្សជាច្រើនដែលត្រូវបានធ្វើឱ្យបាត់ខ្លួនពីសហករណ៍ត្រាំកក់ត្រូវបាននាំទៅមន្ទីរសន្តិសុខក្រាំងតាចាន់[3219]។ "ម្យ៉ាងវិញទៀត ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនេះត្រូវបានបង្ហាញថា ជាអំពើអមនុស្សធម៌ដទៃទៀតដែលជាការបាត់ខ្លួនលើកដំបូងនៅស្រុកត្រាំកក់ ឬអាចត្រូវបានបង្ហាញថា ជាការបាត់ខ្លួនជាលើកទីពីរនៅក្រាំងតាចាន់"[3220]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជាគោលការណ៍ អំពើដែលជាមូលដ្ឋាននៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំអាចត្រូវបានប្រព្រឹត្តឡើងលើសពីម្តងទាក់ទងទៅនឹងបុគ្គលដដែលនោះ ដរាបណាធាតុផ្សំចាំបាច់នៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវបានបង្ហាញក្នុងពេលនីមួយៗ[3221]។ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ គួរកត់សម្គាល់ជាពិសេសថា បើទោះបីជាការដកហូតលើកដំបូងនូវសេរីភាពបានចាប់ផ្តើមជាមួយនឹងការចាប់ខ្លួនក្នុងសហករណ៍ត្រាំកក់ក៏ដោយ ក៏នៅបន្តពេញមួយអំឡុងពេលនៃការឃុំខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែរ និង៖

> ក្រោយមកទៀត ការឃុំឃាំងក្នុងដំណាក់កាលថ្មីដែលពុំត្រូវបានកត់ត្រាទុក លទ្ធផលដែលស្ទើរតែចៀសពុំរួច និងការបណ្តាលឱ្យស្លាប់បូករួមជាមួយនឹងទម្រង់នៃការកម្ទេច និងការកប់សាកសពដែលត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលដែលអាចមិនជាប់ពាក់ព័ន្ធនៅក្នុងការចាប់ខ្លួនពីដំបូង ទាំងអស់នេះ គឺជាការបដិសេធទាំងស្រុងនូវព័ត៌មានសម្រាប់ក្រុមគ្រួសារ ឬមិត្តភក្តិ ក្នុងការអន្តរាគមន៍ ឬកំណត់ទីតាំងសាកសពរបស់មនុស្សជាទីស្រលាញ់របស់ខ្លួន។ ចំណុចទាំងនេះជាការប្រព្រឹត្តដោយចេតនា និងជាសត្យានុម័តរបស់ចារីបន្ថែមទៀត ក្រោយពីការធ្វើឱ្យបាត់ខ្លួនមនុស្សដំបូងពីសហករណ៍នោះ។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការយកអ្នកជាប់ឃុំចេញពីអាគារឃុំឃាំង គឺជាការបន្តដកហូតសេរីភាព និងចុងបញ្ចប់ត្រូវបានកម្ទេច[3222]។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពុំមានការបង្ហាញព័ត៌មានពាក់ព័ន្ធទៅនឹងវាសនារបស់អ្នកជាប់ឃុំដែលត្រូវបានយកចេញពីអាគារឃុំឃាំង ដល់អ្នកជាប់ឃុំជាមួយដទៃទៀត ឬសមាជិកគ្រួសារ និងមនុស្សជាទីស្រលាញ់របស់ខ្លួនដែលនៅក្រៅ ព្រមទាំងការបដិសេធទាំងស្រុងនូវការទទួលបានដំណោះស្រាយផ្លូវ

---

[3219] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៣។

[3220] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៣។

[3221] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៤។

[3222] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៤។

ច្បាប់ជាធរមាន និងការធានាផ្នែកនីតិវិធីក្រោមច្បាប់អន្តរជាតិ[3223]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា នៅពេលអ្នកជាប់ឃុំត្រូវបានយកចេញពីអាគារឃុំឃាំង មានការប្រើឧបាយកលកុហកថា ពួកគេទាំងនោះត្រូវបានបញ្ជូនត្រឡប់ទៅផ្ទះវិញ នេះបានធ្វើឱ្យអ្នកជាប់ឃុំដទៃទៀតនៅទីនោះមានការឆ្ងល់សង្ស័យចំពោះវាសនារបស់អ្នកដែលត្រូវបានយកចេញទៅ និងការចាក់តន្ត្រីតាមមេក្រូព្យូៗនៅពេលមានការធ្វើឱ្យបាត់ខ្លួន និងការសម្លាប់មនុស្សដែលអាចកើតមាន[3224]។ ដោយផ្អែកលើការយល់ឃើញពាក់ព័ន្ធទៅនឹងលក្ខណៈសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការធ្វើឱ្យបាត់ខ្លួនត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋដោយមានការអនុញ្ញាត និងការគាំទ្រពីបក្សកុម្មុយនីស្តកម្ពុជា[3225]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការចាប់ពង្រត់អ្នកជាប់ឃុំដែលនៅបន្តនោះបង្កើតជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយថា ភាគីទីបីដូចជាអ្នកជាប់ឃុំជាមួយត្រូវបានបង្កឱ្យរងទុក្ខសោកធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្តដែលជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដូច្នេះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ មានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនេះបង្ហាញអំពីធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀត[3226]។ ទាក់ទងទៅនឹងធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលអាចស្មើនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ"ត្រូវបានប្រព្រឹត្តឡើងដដែលៗ និងក្នុងរយៈពេលដ៏យូរដោយមានការប្រមាថធ្ងន់ធ្ងរដែលមានផលប៉ះពាល់លើអ្នកដែលជាប់ឃុំ ឬអ្នកដែលអាចស្វែងរកដំណឹងអំពីបុគ្គលទាំងនោះ" ដូច្នេះ នេះបានធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អំពើនេះគឺជាចេតនា និងអាស្រ័យហេតុនេះ ធាតុផ្សំអត្តនោម័តិត្រូវបានបង្ហាញ[3227]។

1151.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការយល់ឃើញថា អំពើជាមូលដ្ឋាននៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំអាចត្រូវបានប្រព្រឹត្តលើសពីម្តងទាក់ទងទៅនឹងបុគ្គលដដែល ពីព្រោះការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ គឺជាការប្រព្រឹត្តជាបន្តបន្ទាប់ដែលជាបទល្មើស[3228]។ គាត់បានដកស្រង់ចេញពី

[3223] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៥។

[3224] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៥។

[3225] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៦។

[3226] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៧។

[3227] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៨។

[3228] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣៧។

សេចក្តីអធិប្បាយទូទៅរបស់ក្រុមការងារស្តីពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬដោយស្ម័គ្រចិត្ត(“ក្រុមការងារ”) ដែលជាបទឧក្រិដ្ឋបន្តជាប់រហូត៖

> ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំគឺជាអំពើដំបូងគេដែលបន្តជាប់រហូត។ អំពើនេះចាប់ផ្តើមនៅពេលចាប់ពង្រត់ និងបន្តរហូត ដរាបណាឧក្រិដ្ឋកម្មមិនទាន់បញ្ចប់ [...]។
>
> បទឧក្រិដ្ឋនេះពុំអាចត្រូវបានបំបែក ហើយការដាក់ពិរុទ្ធភាពគប្បីគ្របដណ្តប់លើអំពើនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំជារួម[3229]។

1152.ខៀវ សំផន បានលើកឡើងថា ការដកហូតសេរីភាពដែលបានចាប់ផ្តើមជាមួយនឹងការចាប់ខ្លួននៅសហករណ៍ត្រាំកក់ បានបន្តពេញមួយអំឡុងពេលនៃដំណាក់កាលឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ និងបើទោះបីជាអំពើនេះជាប់ពាក់ព័ន្ធទៅនឹងចារីជាច្រើនក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានពិចារណាឃើញថា មានបទឧក្រិដ្ឋពីរដាច់ដោយឡែកពីគ្នានៅក្នុងទីតាំងរៀងៗខ្លួន[3230]។

1153.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយច្បាប់ និងថា គាត់ខកខានក្នុងការផ្តល់សំអាងផ្លូវច្បាប់គាំទ្រការអះអាងរបស់គាត់ដែលថា អំពើនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ គឺជាការប្រព្រឹត្តល្មើសដែលបន្តជាប់រហូត[3231]។ សហព្រះរាជអាជ្ញាបានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុដោយសារក្នុងកាលៈទេសៈខ្លះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំដំបូងត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខក្រាំងតាចាន់[3232]។ សហព្រះរាជអាជ្ញាបានបន្ថែមថា ដោយសារអំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំខ្វះការកំណត់និយមន័យផ្នែកច្បាប់ជាក់លាក់ និងធាតុផ្សំក្នុងឆ្នាំ ១៩៧៥ ទើបការវិភាគផ្នែកច្បាប់ដែលសមស្របនោះបានផ្តោតទៅលើបញ្ហាថាតើ បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវបានប្រព្រឹត្តលើសពីម្តងដែរ ឬយ៉ាងណា ដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគដោយត្រឹមត្រូវនោះ[3233]។ សហព្រះរាជ

[3229] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣៧ ដកស្រង់របាយការណ៍របស់ក្រុមការងារស្តីពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬដោយស្ម័គ្រចិត្ត ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០ ឯកសារអង្គការសហប្រជាជាតិ UN Doc. A/HRC/16/48 (របាយការណ៍ក្រុមការងារ) កថាខណ្ឌ ៣៩-១ និង ៣៩-៥ (សេចក្តីបញ្ជាក់បន្ថែមដោយ ខៀវ សំផន)។

[3230] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៣៩។

[3231] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥២។

[3232] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥២។

[3233] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥៣-៨៥៤។

អាជ្ញាបានពិចារណាថា បទឧក្រិដ្ឋពីរដែលប្រព្រឹត្តលើបុគ្គលតែមួយ មានលក្ខណៈខុសប្លែកគ្នាដោយសារត្រូវបានប្រព្រឹត្តឡើងដោយចារីផ្សេងៗគ្នា និងបានបង្កើតឱ្យមានការរងទុក្ខដល់ក្រុមមនុស្សពីរខុសគ្នាៈ ទីមួយ អ្នកដែលនៅរស់ក្នុងឃុំ និងការដ្ឋានធ្វើការ និងទីពីរ អ្នកដែលជាប់ឃុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់[3234]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការសំអាងរបស់ ខៀវ សំផន លើការអធិប្បាយទូទៅរបស់ក្រុមការងារនោះ គឺជាការភាន់ច្រឡំ និងពុំជាប់ពាក់ព័ន្ធដោយសារសេចក្ដីអធិប្បាយនេះអនុវត្តចំពោះបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួនតែមួយលើកដោយចារីម្នាក់[3235]។

1154.ផ្អែកតាមសហមេធាវីនាំមុខបានឱ្យដឹងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅមន្ទីរសន្តិសុខក្រាំងតាចាន់ មានសារៈសំខាន់ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលរងការប៉ះពាល់ដោយសារឧក្រិដ្ឋកម្មនោះ[3236]។ សហមេធាវីនាំមុខបានអះអាងថា ការបកស្រាយរបស់ ខៀវ សំផន អាចរារាំងការទទួលខុសត្រូវទៅលើអ្នកដែលគ្រប់គ្រងអំពើឃោរឃៅដែលត្រូវបានប្រព្រឹត្តច្រើនលើកច្រើនសាលើក្រុមមនុស្សដដែល[3237]។ សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ស្ថានភាពនេះគឺពាក់ព័ន្ធទៅនឹងរឿងក្ដីដែលបុគ្គលជាក់លាក់ត្រូវបានធ្វើឱ្យបាត់ខ្លួនពីរលើកផ្សេងគ្នាដោយចារីផ្ទាល់ខុសៗគ្នា និងបានបន្ថែមថា ការធ្វើឱ្យបាត់ខ្លួននីមួយៗជាប់ពាក់ព័ន្ធផងដែរទៅនឹងក្រុមដាច់ដោយឡែកនៃជនរងគ្រោះមិនផ្ទាល់ និងថា បរិយាកាសនៃការភ័យខ្លាច និងការរងទុក្ខសោកត្រូវបានបង្កើតតាមទីកន្លែងនីមួយៗ[3238]។

1155.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពុំអាចកំណត់ច្បាស់លាស់នូវបញ្ហាថាតើ សហព្រះរាជអាជ្ញាបានអះអាងត្រឹមត្រូវ ដែរ ឬយ៉ាងណា ដែលថា អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ពុំធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញនោះដោយសារបានដោះស្រាយតែលើបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួននៅទីតាំងទាំងពីរ ប៉ុន្តែពុំមែនលើបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួនសម្រាប់លើកដំបូងនៅមន្ទីរសន្តិសុខក្រាំងតាចាន់នោះទេ។ សហព្រះរាជអាជ្ញាពុំបានយោងទៅលើការយល់ឃើញណាមួយដែលថា បុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួននោះ គឺមានតែមកពីមន្ទីរសន្តិសុខ

---

[3234] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥៥។

[3235] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៥៧។

[3236] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦០៥។

[3237] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦០៧។

[3238] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦០៨។

ក្រាំងតាចាន់ប៉ុណ្ណោះ ដែលពុំធ្លាប់ត្រូវបានធ្វើឱ្យបាត់ខ្លួនលើកដំបូងពីសហករណ៍ត្រាំកក់នោះទេ ហើយការយល់ឃើញផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងអំពីបុគ្គលទាំងនោះឡើយ។

1156.ក្នុងឆ្នាំ ១៩៧៥ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ពុំមែនជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានការកំណត់និយមន័យផ្នែកច្បាប់ និងធាតុផ្សំជាក់លាក់នោះទេ[3239]។ ផ្ទុយទៅវិញ អ្វីដែលចោទជាបញ្ហាក្នុងរឿងក្តីបច្ចុប្បន្នគឺជាអំពើដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។ បញ្ហាចោទបច្ចុប្បន្ននេះគឺថាតើ ហេតុការណ៍ដាច់ដោយឡែកពីគ្នានៃអំពើអមនុស្សធម៌ដទៃទៀតបានកើតឡើងនៅសហករណ៍ត្រាំកក់ និងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែលបានផ្អែកលើការធ្វើឱ្យបាត់ខ្លួនលើបុគ្គលដដែលនោះពីទីតាំងទាំងពីរ ដែរ ឬយ៉ាងណា។

1157.ធាតុផ្សំជាក់លាក់នៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត គឺជា៖ (១) អំពើសកម្ម ឬអកម្មដែលមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងអំពើដទៃទៀតដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២) អំពើសកម្ម ឬអកម្មដែលបង្កឱ្យមានការរងទុក្ខ ឬរបួសកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និង (៣) អំពើសកម្ម ឬអកម្មដែលត្រូវបានប្រព្រឹត្តដោយចេតនា[3240]។

1158.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលពុំត្រូវបានជំទាស់ដោយ ខៀវ សំផន បង្ហាញថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំពីសហករណ៍ត្រាំកក់ និងក្រាំងតាចាន់ បើទោះបីជាប់ពាក់ព័ន្ធទៅនឹងបុគ្គលដដែលដែលត្រូវបានធ្វើឱ្យបាត់ខ្លួនក៏ដោយ ក៏ត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់ផ្សេងគ្នា និងពាក់ព័ន្ធជនរងគ្រោះខុសគ្នា[3241]។ នៅស្រុកត្រាំកក់ ជនរងគ្រោះក្រៅពីបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួន ក៏មាន"អ្នកដែលនៅរស់ ដែលពុំដឹងនូវព័ត៌មានអំពីវាសនារបស់ខ្លួនយ៉ាងណាឡើយ"[3242]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួនដែលរីករាលដាលបានបង្កើតបរិយាកាសគួរឱ្យភ័យខ្លាចដែលជ្រួតជ្រាបនៅតាមការដ្ឋានធ្វើការ និងសហករណ៍ និងបង្កឱ្យអ្នកដែលនៅក្នុងសហករណ៍ទទួលរងទុក្ខធ្ងន់ធ្ងរលើរូបកាយ

---

[3239] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៩។

[3240] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨០។

[3241] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៤, ១២០៤, ២៨៥៧។

[3242] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៤។

ឬផ្លូវចិត្ត[3243]។ ម្យ៉ាងវិញទៀត នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ជនរងគ្រោះក្រៅពីអ្នកដែលត្រូវបានធ្វើឱ្យបាត់ខ្លួន និងសមាជិកគ្រួសាររបស់ពួកគេ និងមនុស្សជាទីស្រលាញ់របស់ខ្លួន ក៏មានអ្នកជាប់ឃុំដទៃទៀតក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលត្រូវបានបន្សល់ទុកនូវការសង្ស័យអំពីវាសនារបស់អ្នកដែលត្រូវបានធ្វើឱ្យបាត់ខ្លួន និងការភ័យខ្លាចថា ពួកគេអាចនឹងត្រូវបានយកចេញទៅដូចគ្នាដែរ[3244]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះបានបង្កឱ្យអ្នកជាប់ឃុំទទួលរងផលប៉ះពាល់ផ្លូវចិត្តយូរអង្វែង និងការរងទុក្ខសោកផ្នែករូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដែលបង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3245]។

1159.បើទោះបីជាបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួនដោយបង្ខំពីទីតាំងនីមួយៗ អាចជាមនុស្សដដែលក៏ដោយ ក៏ការធ្វើឱ្យបាត់ខ្លួននេះត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់ផ្សេងគ្នា នៅពេលខុសគ្នា និងទីតាំងផ្សេងគ្នា និងបានប៉ះពាល់ដល់ជនរងគ្រោះផ្សេងគ្នា ដែលរស់នៅក្នុងទីកន្លែងផ្សេងគ្នា។ ក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសដោយសារបានពិចារណាថា មានអំពើចេតនាផ្សេងគ្នាដែលបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលនេះអាចស្មើនឹងហេតុការណ៍ដាច់ដោយឡែកនៃអំពើអមនុស្សធម៌ដទៃទៀតដែលបានកើតឡើងក្នុងទីតាំងនីមួយៗ។

1160.ការសំអាងរបស់ ខៀវ សំផន ទៅលើសេចក្តីអធិប្បាយរបស់ក្រុមការងារនោះ ពុំបានប៉ះពាល់ដល់ការវិភាគនេះទេ។ ក្រុមការងារបានបញ្ជាក់ក្នុងសេចក្តីអធិប្បាយទូទៅស្តីពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំដែលជាបទឧក្រិដ្ឋបន្តជាប់រហូតថា៖

> ១. ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំគឺជាអំពើដើមដំបូងគេដែលបន្តជាប់រហូត។ អំពើនេះបានចាប់ផ្តើមនៅពេលចាប់ពង្រត់ និងបន្តក្នុងរយៈពេលដែលឧក្រិដ្ឋកម្មនោះពុំទាន់បានបញ្ចប់ មានន័យថា រហូតដល់ពេលរដ្ឋបានផ្តល់ដំណឹងអំពីការឃុំឃាំង ឬការដោះលែងពាក់ព័ន្ធទៅនឹងវាសនា ឬទីកន្លែងរបស់បុគ្គលនោះ។
>
> ២. បើទោះបីជាអំពើនេះបានរំលោភបំពានលើសិទ្ធិមួយចំនួន រួមមានសិទ្ធិទទួលបានការទទួលស្គាល់ចំពោះមុខច្បាប់ សិទ្ធិទទួលបានសេរីភាព និងសន្តិសុខរបស់បុគ្គល និងសិទ្ធិពុំត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើទារុណកម្ម ឬអំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោកសេចក្តីថ្លៃថ្នូរដទៃទៀត ឬការដាក់ទោស និងបានរំលោភបំពាន ឬជាការគំរាមកំហែងធ្ងន់ធ្ងរលើសិទ្ធិមានជីវិតរស់នៅក៏ដោយ ក៏ក្រុម

[3243] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៤។

[3244] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៥, ២៨៥៧។

[3245] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៥៧។

ការងារបានពិចារណាថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំគឺជាអំពើដាច់ដោយឡែក និងស្រូបបញ្ចូលគ្នា ប៉ុន្តែពុំមែនជាបូកបញ្ចូលគ្នានោះទេ។ បើទោះបីជាទិដ្ឋភាពនៃអំពើរំលោភបំពានមួយចំនួនអាចត្រូវបានបំពេញនៅមុនពេលការចូលជាធរមាននៃលិខិតុបករណ៍ជាតិ ឬអន្តរជាតិដែលពាក់ព័ន្ធ ហើយផ្នែកដទៃទៀតនៃការរំលោភបំពាននៅតែបន្តរហូតដល់ពេលដែលវាសនា ឬទីកន្លែងរបស់ជនរងគ្រោះត្រូវបានបង្ហាញក៏ដោយ ក៏បញ្ហាគប្បីបានស្តាប់ដោយតុលាការ ហើយអំពើនោះពុំគប្បីបំបែកដាច់ពីគ្នាដែរ។

៣. ដូច្នេះ នៅពេលដែលការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានចាប់ផ្តើមនៅមុនការចូលជាធរមាននៃលិខិតុបករណ៍ ឬនៅមុនរដ្ឋជាក់លាក់ណាមួយបានទទួលស្គាល់យុត្តាធិការរបស់ស្ថាប័នមានសមត្ថកិច្ច ការពិតដែលថា ការធ្វើឱ្យបាត់ខ្លួននៅបន្តក្រោយពីការចូលជាធរមាន ឬការទទួលស្គាល់នៃយុត្តាធិការ បានផ្តល់ឱ្យស្ថាប័ននោះនូវសមត្ថកិច្ច និងយុត្តាធិការក្នុងការពិចារណាលើអំពើនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំជារួម និងពុំមែនតែលើអំពើសកម្ម ឬអកម្មដែលចងកាតព្វកិច្ចលើរដ្ឋដែលទទួលស្គាល់ក្រោយការចូលជាធរមាននៃលិខិតុបករណ៍ច្បាប់ពាក់ព័ន្ធ ឬការទទួលស្គាល់យុត្តាធិការនោះឡើយ[3246]។

1161.ការអត្ថាធិប្បាយទូទៅរបស់ក្រុមការងារបានបង្ហាញថា ខ្លួនបានពិភាក្សាលើលក្ខណៈបន្តជាប់រហូតនៃបទឧក្រិដ្ឋក្នុងបរិបទនៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងមូលនៅពេលដែលអំពើនោះបានចាប់ផ្តើមនៅមុនពេលដែលរដ្ឋបានធ្វើសច្ចាប័នលើលិខិតុបរណ៍ច្បាប់ជាក់លាក់ ឬទទួលយកយុត្តាធិការនៃស្ថាប័នមានសមត្ថកិច្ច[3247]។ ចំណុចនេះពុំបានដោះស្រាយជាក់លាក់លើបញ្ហាចំពោះមុខដែលបុគ្គលដែលត្រូវបានធ្វើឱ្យបាត់ខ្លួនពីទីតាំងជាច្រើនកន្លែង ការបង្កឱ្យមានការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្ត និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សចំពោះជនរងគ្រោះខុសគ្នានោះទេ។ អាស្រ័យហេតុនេះការជំទាស់នេះត្រូវបដិសេធចោល។

## គ. មន្ទីរសន្តិសុខភ្នំក្រោល

1162.មន្ទីរសន្តិសុខភ្នំក្រោលគឺជាមន្ទីរសន្តិសុខតំបន់ ១០៥ ដែលមានគុកភ្នំក្រោល មន្ទីរពាក់ព័ន្ធតំបន់ចំនួនពីរគឺ ក-១១ និង ក-១៧ និងទីតាំងកម្មេចនៅក្បែរត្រពាំងព្រីង[3248]។ ក្នុងការវាយតម្លៃថាតើ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាអ្នកជាប់ឃុំត្រូវបានយកចេញដោយគ្មានការពន្យល់ពី ក-១៧ និងថា លក្ខខណ្ឌនៅ ក-១១ និងគុកភ្នំក្រោលស៊ី

---

[3246] របាយការណ៍របស់ក្រុមការងារ ទំព័រ ១១-១២។

[3247] *សូមមើល* របាយការណ៍របស់ក្រុមការងារ ទំព័រ ១១-១២។

[3248] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៣០១៩, ៣០២៧។

សង្វាក់ជាមួយនឹងលក្ខខណ្ឌនៅ ក-១៧ និងតំណាងឱ្យមន្ទីរសន្តិសុខទាំងមូល[3249]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើឱ្យបាត់ខ្លួននៃអ្នកជាប់ឃុំជាមួយគ្នាដោយមិនបានប្រាប់នូវហេតុផលសម្រាប់ការបាត់ខ្លួននោះ និងបានទុកឱ្យអ្នកដែលនៅក្នុងគុកនោះសង្ស័យថា អ្នកជាប់ឃុំដូចខ្លួននោះត្រូវបានសម្លាប់[3250]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការយកអ្នកជាប់ឃុំចេញបានបង្កើតនូវការដកសេរីភាព និងថា មានការបដិសេធក្នុងការបង្ហាញព័ត៌មានដល់អ្នកជាប់ឃុំដូចគ្នា ឬសមាជិកគ្រួសារពាក់ព័ន្ធទៅនឹងវាសនា ឬទីកន្លែងនៃអ្នកជាប់ឃុំដែលត្រូវបានធ្វើឱ្យបាត់ខ្លួន និងការបដិសេធទាំងស្រុងនូវការទទួលបានដំណោះស្រាយផ្លូវច្បាប់ដែលជាធរមាន និងការធានាផ្នែកនីតិវិធីដែលមានចែងក្នុងច្បាប់អន្តរជាតិ[3251]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការធ្វើឱ្យបាត់ខ្លួនត្រូវបានអនុវត្តដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ដោយសារភ្នំក្រោលត្រូវបានដាក់ឱ្យស្ថិតក្រោមតំបន់ ១០៥ ដោយផ្ទាល់ ដែលត្រូវបានគ្រប់គ្រងដោយមជ្ឈិមបក្ស[3252]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការពង្រត់អ្នកជាប់ឃុំគឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងថា តតីយជនបានទទួលរងផលប៉ះពាល់ផ្លូវចិត្តយូរអង្វែង ដែលបង្កឱ្យមានការរងទុក្ខសោកធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្ត និងជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3253]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដែលបានរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា ដូច្នេះ អំពើសត្យានុម័តត្រូវបានបង្ហាញ[3254]។ ក្នុងការវាយតម្លៃលើបញ្ហាថាតើ ការធ្វើឱ្យបាត់ខ្លួនគឺជាចេតនា ដែរ ឬយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអត្ថិភាពនៃឧបាយកល និងនត្ថិភាពទាំងស្រុងនៃហេតុផលដែលផ្តល់សម្រាប់ការពង្រត់អ្នកជាប់ឃុំ បរិយាកាសនៃភាពពុំជាក់លាក់ដែលបានបង្កើតឡើងដោយការធ្វើឱ្យបាត់ខ្លួន ភាពងាយទទួលរងទុក្ខរបស់អ្នកជាប់ឃុំដទៃទៀតដែលត្រូវបានដាក់ឱ្យស្ថិតក្នុងលក្ខខណ្ឌទាំងនេះ និងការឈឺចាប់យូរអង្វែង និងការរងទុក្ខសោកដែលត្រូវបានបង្កទៅលើអ្នកជាប់ឃុំជាមួយ សមាជិកគ្រួសារ និងមិត្តភក្តិ[3255]។ អង្គជំនុំ

[3249] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦១។

[3250] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦១។

[3251] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦១, ៣១៦៣។

[3252] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦២។

[3253] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦៤។

[3254] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦៤។

[3255] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦៥។

ជម្រះសាលាដំបូងជឿជាក់ថា "ការប្រមាថធ្ងន់ធ្ងរលើបុគ្គល និងសិទ្ធិទាំងមូល ស្របគ្នាជាមួយនឹងលំនាំនៃអំពើព្រៃផ្សៃគិតទុកជាមុន" និងថា អំពើនេះគឺជាចេតនា ដូច្នេះ បានបង្ហាញអំពីធាតុផ្សំអត្តនោម័តិ[3256]។

1163.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើការធ្វើឱ្យបាត់ខ្លួនដោយបង្ខំតែនៅ ក-១៧ ជាជាងមន្ទីរសន្តិសុខភ្នំក្រោលទាំងមូល ប៉ុន្តែបុគ្គលពីរដែលអង្គជំនុំជម្រះសាលាដំបូងបានស្តាប់ស្តីពីកម្មវត្ថុនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំត្រូវបានឃុំឃាំងនៅគុកភ្នំក្រោល ជាជាងនៅ ក-១៧[3257]។ គាត់បានអះអាងថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះបានផ្អែកលើពាក្យចចាមអារ៉ាម[3258]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែផ្អែកទៅលើសក្ខីកម្មដាក់បន្ទុករបស់ សៅ សារុន ដែលជាអតីតលេខាតំបន់ ១០៥ ក្នុងការយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួន ត្រូវបានប្រព្រឹត្តដោយរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែបានយល់ឃើញថា ភស្តុតាងដោះបន្ទុករបស់គាត់ពុំគួរឱ្យជឿជាក់បានដែលនេះជាការអនុវត្តស្តង់ដារពីរ[3259]។

1164.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើពាក្យចចាមអារ៉ាមដែលពុំមានការបញ្ជាក់បន្ថែមក្នុងការបង្ហាញនូវបទឧក្រិដ្ឋ និងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធីសាស្ត្រសមហេតុផល និងដោយប្រុងប្រយ័ត្នក្នុងការសំអាងទៅលើការរៀបរាប់ស៊ីសង្វាក់គ្នា និងមានការបញ្ជាក់អះអាងបន្ថែមអំពីការយកអ្នកជាប់ឃុំចេញពី ក-១៧[3260]។ បន្ថែមលើនេះ ខៀវ សំផន ខកខានក្នុងការពន្យល់ហេតុដូចម្តេចបានជាការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើពាក្យចចាមអារ៉ាមនោះពុំសមហេតុផល[3261]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចសមស្របថា ផ្នែកណាមួយនៃសក្ខីកម្មរបស់ សៅ សារុន ដែលអង្គជំនុំជម្រះបានយល់ឃើញថា គួរឱ្យជឿជាក់បាន និងមិនគួរឱ្យជឿជាក់ និងក្នុងគ្រប់កាលៈទេសៈ ការយល់ឃើញគឺត្រូវបានបញ្ជាក់អះអាងបន្ថែមដោយឯករាជ្យពីសាក្សីយ៉ាងតិចពីរនាក់ដទៃទៀត[3262]។

---

[3256] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦៥។

[3257] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៨៧-៨៨៨។

[3258] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៨៨-៨៨៩។

[3259] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៩០-៨៩១។

[3260] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៧៨។

[3261] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៧៩។

[3262] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៨០។

1165.សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន បានលើកពុំត្រឹមត្រូវថា មានតែសាក្សីពីរនាក់ប៉ុណ្ណោះដែលត្រូវបានស្តាប់ស្តីពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងថា ពួកគាត់ពុំត្រូវបានឃុំឃាំងនៅ ក-១៧[3263]។ សហមេធាវីនាំមុខបានជំទាស់ទៅនឹងការលើកឡើងដែលថា ភស្តុតាងដែលបានសំអាងទៅលើទាក់ទងទៅនឹងគុក ក-១១ និងភ្នំក្រោល ជាពាក្យចចាមអារ៉ាម។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងផ្ទាល់ក្នុងការយល់ឃើញថា បរិយាកាសពុំជាក់លាក់ និងការភ័យខ្លាចត្រូវបានបង្កើតឡើង ហើយអ្នកដែលបានផ្តល់សក្ខីកម្មនោះប្រហែលជាបានដឹងដោយប្រយោលអំពីវាសនាជាយថាហេតុនៃអ្នកដែលត្រូវបានធ្វើឱ្យបាត់ខ្លួន ប៉ុន្តែថា នេះពុំមែនជាគោលបំណងដែលភស្តុតាងត្រូវបានប្រើប្រាស់នោះទេ[3264]។

1166.អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចហើយ និងបានបដិសេធលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែអាចធ្វើការជំនុំជម្រះលើការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅ ក-១៧ ជាជាងនៅមន្ទីរសន្តិសុខភ្នំក្រោលទាំងមូល[3265]។ បន្ថែមលើនេះ ខៀវ សំផន បានអះអាងពុំត្រឹមត្រូវថា សាក្សីដែលអង្គជំនុំជម្រះសាលាដំបូងបានស្តាប់នោះពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួននៅ ក-១៧ ពុំត្រូវបានឃុំឃាំងនៅទីនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់សាក្សី ចាន់ តួច និង នេត សាវ៉ាត សម្រាប់ការយល់ឃើញដែលថា អ្នកជាប់ឃុំត្រូវបានយកចេញពីការឃុំឃាំងនៅ ក-១៧ ដាក់លើឡាន និងពុំដែលឮដំណឹងម្តងទៀតឡើយ[3266]។ ចាន់ តួច និង នេត សាវ៉ាត ត្រូវបានឃុំឃាំងនៅ ក-១៧ និងបានរៀបរាប់អំពីការធ្វើឱ្យបាត់ខ្លួន ដែលពួកគាត់បានឃើញផ្ទាល់នៅ ក-១៧[3267]។

1167.ខៀវ សំផន បានអះអាងពុំត្រឹមត្រូវផងដែរថា ភស្តុតាងពាក់ព័ន្ធទៅនឹងគុក ក-១១ និងភ្នំក្រោល គឺជាពាក្យចចាមអារ៉ាម។ គាត់បានដកស្រង់ផ្នែកខ្លះនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងបានគូសបន្ទាត់ពីក្រោមបញ្ជាក់នូវអ្វីដែលគាត់បានចាត់ទុកថា ជាពាក្យចចាមអារ៉ាមដូចខាងក្រោម៖

---

[3263] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦១០-៦១៣។

[3264] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦១៤-៦១៥។

[3265] *សូមមើលខាងលើ* ផ្នែក VI.ក.២.ខ។

[3266] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៩០ យោងទៅលើប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ (ចាន់ ទូយ ហៅ ចាន់ តួច) ឯកសារលេខ E1/399.1 ទំព័រ ២២, ៥០។ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ (នេត សាវ៉ាត) ឯកសារលេខ E1/400.1 ទំព័រ ៣០។

[3267] ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ (ចាន់ ទូយ *ហៅ* ចាន់ តួច) ឯកសារលេខ E1/399.1 ទំព័រ ២២, ៥០, ៥៣។ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ (នេត សាវ៉ាត) ឯកសារលេខ E1/400.1 ទំព័រ ១២-១៣, ២៩។

នៅមន្ទីរសន្តិសុខ អ្នកជាប់ឃុំត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើឱ្យបាត់ខ្លួននៃអ្នកជាប់ឃុំដទៃទៀត ដោយគ្មានការប្រាប់ពីមូលហេតុនៃការធ្វើឱ្យបាត់ខ្លួននោះ និងទុកឱ្យពួកគេជឿថា អ្នកទាំងនោះត្រូវបានសម្លាប់។ ការរៀបរាប់មួយនៅចំពោះមុខអង្គជំនុំជម្រះបានបង្ហាញថា អ្នកជាប់ឃុំត្រូវបានប្រាប់ថា ពួកគេត្រូវបានបញ្ជូនត្រឡប់ទៅភូមិរបស់ខ្លួនវិញ បន្ទាប់មកពួកគេពុំដែលបានឃើញម្តងទៀតឡើយ។ សាក្សីដទៃទៀតបានស្តាប់ឮផ្សេងៗគ្នា នៅពេលនោះ ឬឆាប់ៗក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យថា អ្នកជាប់ឃុំត្រូវបានដឹកជញ្ជូនក្នុងទិសដៅទៅខេត្តក្រចេះ មានអ្នកខ្លះរៀបរាប់ជាក់លាក់ថា អ្នកជាប់ឃុំត្រូវដឹកយកទៅសម្លាប់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជឿជាក់ថា អ្នកជាប់ឃុំជាក់ស្តែងត្រូវបានដឹកក្នុងទិសដៅទៅខេត្តក្រចេះ បន្ទាប់ពីត្រូវបានយកចេញពីគុកភ្នំក្រោលដោយគ្មានការពន្យល់។ អង្គជំនុំជម្រះជឿជាក់ថា ការយកអ្នកជាប់ឃុំចេញនោះគឺជាការដកនូវសេរីភាព[3268]។

1168.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើការជឿរបស់អ្នកជាប់ឃុំ ឬអ្វីមួយដែលគេបានប្រាប់ពួកគាត់ ឬបានឮ ក្នុងការបង្ហាញនូវការពិតនៃការជឿ/ការអះអាងទាំងនោះ ជាដើម ដើម្បីកំណត់ថា អ្នកដែលបានបាត់ខ្លួននោះត្រូវបានសម្លាប់ ដែរ ឬយ៉ាងណានោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងនេះក្នុងការបង្កើតការយល់ឃើញពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដែលកើតចេញពីការធ្វើឱ្យបាត់ខ្លួននោះទៅលើអ្នកជាប់ឃុំជាមួយដទៃទៀត និងបរិយាកាសភ័យខ្លាច និងពុំច្បាស់លាស់ដែលត្រូវបានបង្កើតឡើងដោយការធ្វើឱ្យបាត់ខ្លួននោះ។

1169.ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដារពីរតាមរយៈការសំអាងពុំសមស្របទៅលើផ្នែកដាក់បន្ទុកនៃសក្ខីកម្មរបស់ សៅ សារុន[3269]។ អង្គជំនុំជម្រះសាលាដំបូងគឺជាស្ថាប័នដែលទទួលបន្ទុកក្នុងការវាយតម្លៃលើសក្ខីកម្មរបស់សាក្សី ហើយពិតណាស់ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកផ្នែកខ្លះនៃសក្ខីកម្មរបស់សាក្សី ខណៈពេលបដិសេធផ្នែកដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា សក្ខីកម្មរបស់ សៅ សារុន មានលក្ខណៈ“ព្រលាំចំពោះបញ្ហាថាតើ [ការចាប់ខ្លួន និងការឃុំខ្លួន] ត្រូវបានប្រព្រឹត្តឡើងដោយផ្អែកលើសិទ្ធិអំណាចកំពូលរបស់អង្គការ ដែរ ឬយ៉ាងណា” និងបានវាយតម្លៃលើការអះអាងទាក់ទងទៅនឹងបញ្ហាដែលថា សាក្សី ផាន វ៉ាន់ កូនប្រុសរបស់អតីតលេខាតំបន់ ១០៥ ឈ្មោះ ឡាំង បានផ្តល់សក្ខីកម្មថា ថ្នាក់តំបន់ពុំមានសិទ្ធិអំណាចបង្គាប់ការចាប់ខ្លួន ហើយសេចក្តីសម្រេចនោះកើតចេញពីមជ្ឈិមបក្សដែលនេះបានគាំទ្រសក្ខី

---

[3268] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៨៨៨ ដកស្រង់ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦១ (សេចក្តីបញ្ជាក់បន្ថែមដោយ ខៀវ សំផន)។

[3269] *សូមមើលខាងលើ* ផ្នែក V.ង.១.គ។

កម្មរបស់ សៅ សារុន[3270]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ផងដែរនូវមូលហេតុដូចម្ដេចបានជាពុំផ្ដល់ទម្ងន់ទៅលើសក្ខីកម្មរបស់ សារុន ដែលថា ពុំមានការចាប់ខ្លួនបានកើតឡើងក្នុងពេលដែលគាត់ធ្វើជាលេខាតំបន់ ១០៥[3271]។

1170.ដោយសារពុំមានអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅភ្នំក្រោល បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ឬថា ការយល់ឃើញនោះគប្បីបដិសេធចោលនោះ អាស្រ័យហេតុនេះអំណះអំណាងនេះត្រូវបដិសេធចោល។

## ៣. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

### ក. នីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

1171.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហាថាតើ ផ្អែកតាមទិដ្ឋភាពនីត្យានុកូលភាព អំពើដែលត្រូវបានចោទប្រកាន់ដាច់ដោយឡែកថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានដាក់បញ្ចូលត្រឹមត្រូវទៅក្នុងបទឧក្រិដ្ឋនៃ“អំពើអមនុស្សធម៌ដទៃទៀត”ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា[3272]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងការវិភាគរបស់ខ្លួនពីរដាច់ដោយឡែកពីគ្នាដែលថា អង្គជំនុំជម្រះពុំមានកាតព្វកិច្ចតម្រូវឱ្យពិចារណាលើបញ្ហាថាតើ អំពើដែលត្រូវបានចោទប្រកាន់បានបង្ហាញបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណានោះឡើយ[3273]។ បទឧក្រិដ្ឋតែមួយដែលពាក់ព័ន្ធនោះគឺជាអំពើអមនុស្សធម៌ដទៃទៀត ដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មានអត្ថិភាពជាយូរមកហើយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[3274]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់នូវការយល់ឃើញរបស់ខ្លួនពីដំបូងដែលថា “អំពើអមនុស្សធម៌ដទៃទៀត”ត្រូវបានទទួលយកថា ជាប្រភេទមិនជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

[3270] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៧៦-៣០៧៧។

[3271] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៧៨។

[3272] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨-៧៣២, ៧៤០-៧៤៩។

[3273] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥, ៧២៧, ៧៤១។

[3274] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៣, ៧២៨, ៧៤១។

ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ដូច្នេះ អង្គជំនុំជម្រះសាជាថ្មីថា ការបញ្ជាក់អំពីនីត្យានុកូលភាពនេះជាការត្រឹមត្រូវ[3275]។

1172.អង្គជំនុំជម្រះសាលាដំបូងបានរំឭកអំពីដីកាដំណោះស្រាយដែលបានចោទប្រកាន់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងទូទាំងប្រទេសចាប់តាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលត្រូវបានបង្ហាញតាមរយៈជនរងគ្រោះ ដែលត្រូវបានបង្ខំឱ្យទទួលយកទំនាក់ទំនងសហព័ទ្ធនៅក្នុងបរិយាកាសបង្ខិតបង្ខំ[3276]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សិទ្ធិរៀបអាពាហ៍ពិពាហ៍ដោយសេរី គឺជាសិទ្ធិសារវ័ន្តដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (“UDHR”)[3277]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ពាក្យថា“ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ”ត្រូវបានប្រើប្រាស់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិដើម្បីគ្របដណ្តប់លើកាលៈទេសៈនៃអង្គហេតុផ្សេងៗ[3278] និងបានពិចារណាលើរឿងក្តីយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិស្តីពីភាពធ្ងន់ធ្ងរនៃអំពើនោះ[3279]។ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃថា អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃលើបញ្ហាថាតើ អំពើដែលបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានបង្ហាញ និងថាតើ អំពើនេះអាចឈានដល់កម្រិតនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3280]។

1173.អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាលម្អិតលើបទចោទនៃ“ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ”ក្នុងដីកាដំណោះស្រាយដែលបានចោទប្រកាន់ថា តាមរយៈការបង្ខិតបង្ខំឱ្យរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចារីបានប្រព្រឹត្តដោយចេតនានូវការរំលោភបំពានលើរូបកាយផ្នែកផ្លូវភេទលើជនរងគ្រោះក្នុងបរិយាកាសបង្ខិតបង្ខំដោយគ្មានការយល់ព្រមពីជនរងគ្រោះនោះ[3281]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នូវការបំភ្លឺអំពីការរំលោភសេពសន្ថវៈក្នុងឆ្នាំ ១៩៧៥ ថា៖

---

[3275] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៦, ៥៨៩។ *សូមមើលខាងលើ* ផ្នែក VII.ឆ.១។

[3276] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤២ និងជើងទំព័រ ២២៥៩-២២៦៣ យោងទៅលើក្នុងចំណោមនោះ ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤២-១៤៤៧។

[3277] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

[3278] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

[3279] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៧។

[3280] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

[3281] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៩ និងជើងទំព័រ ២២៣៣ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣១។

ជាការដាក់បញ្ចូលបើទោះបីតិចតួចក្តីនូវ (ក) អង្គជាត ឬវត្ថុដទៃដែលចារីបានប្រើប្រាស់ចូលទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះ ឬ (ខ) ការដាក់អង្គជាតរបស់ចារីចូលក្នុងមាត់របស់ជនរងគ្រោះ ដូចជាក្នុងករណីដែលការដាក់បញ្ចូលផ្លូវភេទបានកើតឡើងដោយគ្មានការស្ម័គ្រចិត្តរបស់ជនរងគ្រោះ[3282]។

អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការកំណត់និយមន័យនេះពុំបានរាប់បញ្ចូលជនរងគ្រោះជាបុរសដែលកើតចេញពីការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ និងថា អង្គជំនុំជម្រះនឹងវាយតម្លៃលើបញ្ហាថាតើ អំពើនោះអាចត្រូវបានកំណត់ចរិតលក្ខណៈថា ជាទម្រង់ដទៃទៀតនៃការរំលោភផ្លូវភេទក្នុងកម្រិតធ្ងន់ធ្ងរដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3283]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថាតើ អំពើជាមូលដ្ឋាននៃការរំលោភសេពសន្ថវៈនេះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា ក្រោយពីបានពិនិត្យលើអង្គហេតុនៃរឿងក្តី[3284]។

1174.ខៀវ សំផន បានជំទាស់ទៅនឹងនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាអំពើអមនុស្សធម៌ដទៃទៀតនោះ។ គាត់បានជំទាស់ទៅនឹងការយល់ឃើញស្តីពី (១) អំពើដែលត្រូវបានចោទប្រកាន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ (២) "អនីត្យានុកូលភាពផ្លូវការអន្តរជាតិ" ដែលជាការកំណត់អត្តសញ្ញាណនៃសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន (៣) ការអនុវត្តន៍គោលការណ៍ស្តីពីអត្ថិភាពនៃ*ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា(ejusdem generis)* និង (៤) នីត្យានុកូលភាពនៃអំពើដែលត្រូវបានចោទប្រកាន់ក្រោមច្បាប់កម្ពុជានៅមុនរបបកម្ពុជាប្រជាធិបតេយ្យ[3285]។ អំណះអំណាងនេះត្រូវបានពិចារណាតាមលំដាប់លំដោយដូចខាងក្រោម។

## i. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1175.ដីកាដំណោះស្រាយបានចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទូទាំងប្រទេស និងចោទប្រកាន់ថា ជនរងគ្រោះត្រូវបានបង្ខំឱ្យទទួលយកទំនាក់ទំនងសហព័ន្ធក្នុងកាលៈទេសៈ

---

[3282] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១។

[3283] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១។

[3284] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣២, ៣៦៩៥-៣៧០០។

[3285] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៨-១១៥៥, ១២៨១-១៣០១។

បង្ខិតបង្ខំ[3286]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "ករណីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំភាគច្រើន មានការគំរាមកំហែងដល់អាយុជីវិត មានការប្រើប្រាស់អំពើហិង្សា និងមានមនុស្សត្រូវបានសម្លាប់ប្រសិនបើមិនព្រមរៀបអាពាហ៍ពិពាហ៍"[3287] និងថា ពិធីរៀបអាពាហ៍ពិពាហ៍អាពាហ៍ពិពាហ៍"បានកើតឡើងដោយគ្មានការចូលរួមតាមប្រពៃណីពីឪពុកម្ដាយ" គ្មានការសែនព្រេនដូនតា និងថា ការរៀបអាពាហ៍ពិពាហ៍នោះត្រូវបានរៀបចំឡើងក្នុងពេលតែមួយដែលមានគូស្រករចាប់ពី២០ ទៅ ៦០ គូ[3288]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ដីកាដំណោះស្រាយបានយោងច្បាស់លាស់នូវ"ការបង្ខិតបង្ខំនៃទំនាក់ទំនងផ្លូវភេទដែលមានគោលដៅបង្កើតកូនដោយបង្ខំ"[3289]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះត្រឹមតែកំណត់ថាតើ អំពើដែលត្រូវបានចោទប្រកាន់ថា អាចស្មើនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ ត្រូវបានបង្ហាញ និងថាតើ អំពើនេះឈានដល់កម្រិតនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3290]។

---

[3286] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤២ យោងទៅលើ*ក្នុងចំណោមនោះ*ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤២-១៤៤៧។

[3287] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៧។

[3288] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤២ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៦-១៤៤៧។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានតែការយល់ឃើញមួយក្នុងចំណោមនោះដែលថា ជនរងគ្រោះត្រូវបានបង្ខំឱ្យទទួលយកទំនាក់ទំនងសហព័ទ្ធក្នុងបរិយាសកាសបង្ខិតបង្ខំ ត្រូវបានរួមបញ្ចូលក្នុងដីកាដំណោះស្រាយដែលជាការពិពណ៌នាច្បាស់លាស់នូវអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការយល់ឃើញដទៃទៀតដែលត្រូវបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងត្រូវបានបង្កើតឡើងធ្វើជាផ្នែកនៃការវាយតម្លៃលើការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងធាតុផ្សំតាមបរិបទ។ ការយល់ឃើញដែលថា ការគំរាមកំហែងសម្លាប់ បានបង្ខំឱ្យបុគ្គលត្រូវរៀបការ និងថា ពិធីរៀបអាពាហ៍ពិពាហ៍បានកើតឡើងដោយគ្មានលក្ខណៈជាទំនៀមទម្លាប់ប្រពៃណី ត្រូវបានបង្កើតឡើងដើម្បីបង្ហាញនូវអត្ថិភាពនៃគោលបំណងរួមដែលរួមបញ្ចូលបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងជាការយល់ឃើញដែលថា សាក្សីមួយចំនួនត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៦-១៤៤៧។ ការយល់ឃើញដែលថា មានការបង្ខិតបង្ខំលើទំនាក់ទំនងផ្លូវភេទក្នុងគោលបំណងបង្កើតកូនដោយបង្ខំ ត្រូវបានពិពណ៌នាថា ជាផ្នែកនៃការវាយប្រហារលើប្រជាជនស៊ីវិល។ *សូមមើលផងដែរ* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៥, ១៤៤៧។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការយល់ឃើញនេះគឺជាផ្នែកនៃការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

[3289] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤២ យោងទៅលើ ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៥។

[3290] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

- *អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

1176.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្កើតការយល់ឃើញស្ដីពីអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដោយសារបានសំអាងទៅលើរឿងក្ដីយុត្តិសាស្ត្ររបស់តុលាការ SCSL និង ICC ដែលពុំមានអត្ថិភាពនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[3291]។ គាត់បានអះអាងថា រឿងក្ដីទាំងនេះពុំមានអត្ថិភាពក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.ឡើយ[3292]។

1177.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើយុត្តិសាស្ត្ររបស់ តុលាការ SCSL ឬតុលាការ ICC ក្នុងការបង្ហាញនូវនីត្យានុកូលភាពនៃអំពើនោះទេ ប៉ុន្តែផ្ទុយទៅវិញបានប្រើប្រាស់ដើម្បីជាការពិពណ៌នានូវអំពើនោះ[3293]។

1178.យោងតាមអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ពាក្យថា"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"ត្រូវបានប្រើប្រាស់ក្នុងយុត្តិសាស្ត្រអន្តរជាតិដើម្បីពិពណ៌នានូវកាលៈទេសៈនៃអង្គហេតុផ្សេងៗជាច្រើន[3294]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ SCSL ក្នុងរឿងក្ដី *AFRC* ដែលបានបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជា"ស្ថានភាពមួយដែលក្នុងនោះ ចារីតាមរយៈពាក្យសំដី ឬការប្រព្រឹត្តផ្ទាល់របស់ខ្លួន ឬរបស់បុគ្គលដែលចារីជាអ្នកទទួលខុសត្រូវចំពោះបុគ្គលនោះ បានបង្ខិតបង្ខំជនរងគ្រោះដោយប្រើកម្លាំង ការគំរាមកំហែង ឬការបង្ខិតបង្ខំឱ្យទទួលយកដៃគូធ្វើជាសហព័ទ្ធដែលបណ្ដាលឱ្យមានការរងទុក្ខ ឬព្យសនកម្មលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ"[3295]។ ការពិពណ៌នាដូចគ្នានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានអនុម័តតាមនៅក្នុងរឿងក្ដី *RUF*[3296]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើការសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ SCSL ដែលថា ការរៀបអាពា

---

[3291] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៥។

[3292] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៥។

[3293] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧៣។

[3294] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

[3295] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៤ យោងទៅលើរឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Brima និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (SCSL) សាលដីកាថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("សាលដីការឿងក្ដី *AFRC* (SCSL)") កថាខណ្ឌ ១៩៥-១៩៦។

[3296] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៤ យោងទៅលើសាលដីការឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Sesay និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (SCSL) សំណុំរឿងលេខ SCSL-04-15-A សាលដីកា ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ ("សាលដីការឿង *RUF* (SCSL)") ថាខណ្ឌ ៧៣៥-៧៣៦។

ហ៍ពិពាហ៍ដោយបង្ខំខុសប្លែកពីទាសភាពផ្លូវភេទដោយសារពុំមែនជា"បទល្មើសផ្លូវភេទជាចម្បង"នោះទេ[3297]។ អង្គជំនុំជម្រះសាលាដំបូងបានវិភាគផងដែរលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៃតុលាការ ICC ក្នុងរឿងក្តី *Ongwen* ដែលបានបញ្ជាក់ថា "ធាតុផ្សំសំខាន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាការដាក់ការបង្ខំនៃ'ការរៀបអាពាហ៍ពិពាហ៍'ទៅលើជនរងគ្រោះដែលជាការដាក់ដោយពុំគិតពីឆន្ទៈរបស់ជនរងគ្រោះនូវកាតព្វកិច្ចដែលជាប់ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ [...] ដោយមានផលវិបាកនៃការមាក់ងាយពីសង្គម"[3298]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Ongwen* បានយល់ឃើញថា "អំពើហិង្សាលើរូបកាយត្រូវបានប្រើប្រាស់ធ្វើជាទម្រង់នៃការបង្ខិតបង្ខំ ដើម្បីរារាំងការរត់គេច ដើម្បីរំលោភសេពសន្ថវៈ និងដើម្បីទទួលបានកម្លាំងពលកម្ម"[3299]។ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងថា អង្គបុរេជំនុំជម្រះនៃរឿងក្តី *Ongwen* បានកំណត់ថា ""ធាតុផ្សំនៃលក្ខណៈពិសេសនៃការរួបរួមគ្នាជាសហព័ទ្ធដោយបង្ខំនេះដែលបានដាក់ទៅលើជនរងគ្រោះ គឺជាទិដ្ឋភាពបង្ហាញនូវចរិតលក្ខណៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" និងថា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"ទទួលរងព្យសនកម្មបន្ថែម និងខុសគ្នាពីជនរងគ្រោះនៃទាសភាពផ្លូវភេទ""[3300]។ អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់ថា មានអត្ថិភាពនៃការបំភ្លឺទូទៅអំពីសញ្ញាណនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3301]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថាតើ អំពើដែលត្រូវបានចោទប្រកាន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរឿងក្តីនេះត្រូវបានបង្ហាញ និងថាតើ អំពើនេះឈានដល់កម្រិតនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3302]។

---

[3297] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៤ យោងទៅលើសាលដីការឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៩៥។

[3298] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៥ យោងទៅលើរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Dominic Ongwen* អង្គបុរេជំនុំជម្រះ II (ICC) សំណុំរឿងលេខ ICC-02/04-01/15 សេចក្តីសម្រេចលើការបញ្ជាក់នៃបទចោទប្រឆាំងនឹងជនជាប់ចោទ Dominic Ongwen ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ ("សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Ongwen* (ICC)") កថាខណ្ឌ ៩៣។

[3299] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ongwen* អង្គជំនុំជម្រះសាលាដំបូង IX (ICC) សំណុំរឿងលេខ ICC-02/04-01/15 អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១ ("សាលក្រមរឿងក្តី *Ongwen* (ICC)") កថាខណ្ឌ ២៣០៩។

[3300] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៥ យោងទៅលើសេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី Ongwen (ICC) កថាខណ្ឌ ៩៣។

[3301] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

[3302] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។

1179.ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើរឿងក្ដីជាយុត្តិសាស្ត្រក្នុងការបង្ហាញនូវអនីត្យានុកូលភាពនៃអំពើនេះ ដូចការអះអាងរបស់ ខៀវ សំផន ឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុករឿងក្ដីយុត្តិសាស្ត្រជាមធ្យោបាយបំភ្លឺនូវបរិបទនៃអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការកំណត់ថាតើ អំពើនេះបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធីសាស្ត្រនេះអាចឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តស្របតាមគោលការណ៍នៃ*សច្ចភាពនៃច្បាប់*។ ជាទឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា វិធីសាស្ត្រដោយប្រុងប្រយ័ត្នចំពោះអំពើអមនុស្សធម៌ដទៃទៀត "ជានិច្ចកាលស្ទើរតែពាក់ព័ន្ធទៅនឹងការយោងទៅលើយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្សអន្តរជាតិ និងលិខិតុបករណ៍ច្បាប់ក្នុងការកំណត់ ឬគូសបង្ហាញនូវធាតុផ្សំនៃអំពើនោះ"[3303]។ ដូច្នេះ សារណារបស់ ខៀវ សំផន ដែលលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការ SCSL និង ICC គឺស្ថិតក្រៅវិសាលភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ឡើយ។

1180.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា ផ្អែកតាមការពិនិត្យលើរឿងក្ដីយុត្តិសាស្ត្ររបស់តុលាការ SCSL និង ICC អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ពុំមានអត្ថិភាពនៃ"ការបំភ្លឺទូទៅ"នៃពាក្យ"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដោយសារកាលៈទេសៈអង្គហេតុខុសប្លែកគ្នា[3304]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មានអត្ថិភាពនៃចំណុចរួមគ្នាក្នុងរឿងក្ដីយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិពាក់ព័ន្ធទៅនឹងការបំភ្លឺនូវអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបង្កឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងកាលៈទេសៈនៃអង្គហេតុ ដែលអំពើនេះបានកើតឡើង។ ដោយសារភាពផ្សេងៗគ្នាជាច្រើននៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ការបំភ្លឺនូវភាពប្រហាក់ប្រហែលគ្នា និងខុសគ្នា មានសារៈសំខាន់ចំពោះការបំភ្លឺនូវវិសាលភាពនៃអំពើដែលត្រូវបានចោទប្រកាន់នោះ។

1181.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានពិពណ៌នាញឹកញាប់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានាថា ជា"ទំនាក់ទំនងសហព័ទ្ធដោយ

---

[3303] សេចក្ដីសម្រេចរួមនៃសំណុំរឿង ០០៤ លើសំណើ (D301/5) កថាខណ្ឌ ៦៣។

[3304] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២៥។

បង្ខំ”។ ចៅក្រម Doherty នៅក្នុងមតិជំទាស់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *AFRC* ដំបូងបានពិពណ៌នាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថា ជាស្ថានការណ៍មួយដែល“ទំនាក់ទំនងនៃសហព័ទ្ធជាមួយចារីបានស្រួបយកឆន្ទៈរបស់ជនរងគ្រោះ និងធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិរបស់ជនរងគ្រោះក្នុងការសម្រេចចិត្តដោយខ្លួនឯង”[3305]។

1182.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការសម្រេចក្រោយៗមកទៀតបានធ្វើការពិពណ៌នាលម្អិតលើអំពើដែលអាចស្មើនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែនៅរក្សាទុកការបំភ្លឺដ៏សំខាន់ដែលថា អំពើនេះគឺជាការរួមភេទដោយបង្ខំ។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC បានយោងទៅលើសមាសភាគបន្ថែមនៃ“ការដាក់ [...] កាតព្វកិច្ចដែលពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍” និងបានសន្និដ្ឋានថា អំពើជាមូលដ្ឋាននៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជា“ធាតុផ្សំនៃលក្ខណៈពិសេសនៃការរួបរួមគ្នាជាសហព័ទ្ធដោយបង្ខំ”[3306]។ បន្ថែមលើនេះ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Ongwen* បានយោងទៅលើកិច្ចការដោយបង្ខំក្នុងគ្រួសារ និងពលកម្មផ្សេងទៀតធ្វើជាទិដ្ឋភាពបន្ថែមនៃអំពើនេះ[3307]។ អង្គបុរេជំនុំជម្រះ I នៃរឿងក្ដី *Al-Hassan* របស់តុលាការ ICC ដោយអនុវត្តតាមអង្គបុរេជំនុំជម្រះ II ក្នុងរឿងក្ដី *Ongwen* បានពិពណ៌នានូវលក្ខណៈនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលមានដូចជា៖“ការបង្ខំបុគ្គលណាម្នាក់ដោយគ្មានការយល់ព្រម ដើម្បីបង្កើតការរួបរួមមួយជាមួយបុគ្គលផ្សេងទៀតតាមរយៈការប្រើប្រាស់ការបង្ខំលើរូបកាយ ឬផ្លូវចិត្ត ការគំរាមកំហែងប្រើកម្លាំង ឬតាមរយៈបរិយាកាសបង្ខិតបង្ខំណាមួយ”[3308]។ អង្គជំនុំជម្រះសាលាដំបូងនៃរឿងក្ដីនេះបានបំភ្លឺបន្ថែមទៀតថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀតដែលត្រូវបានប្រ

---

3305 រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Brima និងជនជាប់ចោទផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូង II (SCSL) សំណុំរឿងលេខ SCSL-04-16-T សាលក្រមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ (“សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *AFRC* (SCSL)”) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម Doherty លើបទចោទទី ៧ (ទាសភាពផ្លូវភេទ) និងទី ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៦៩។

3306 សេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី Ongwen (ICC) កថាខណ្ឌ ៩៣។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៥ យោងទៅលើសេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី Ongwen (ICC) កថាខណ្ឌ ៨៨, ៩៣។

3307 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី Ongwen កថាខណ្ឌ ២២៨៩-២៣០៨។

3308 រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Al Hassan* អង្គជំនុំជម្រះឧទ្ធរណ៍ I (ICC) សំណុំរឿងលេខ ICC-01/12-01/18 សេចក្ដីសម្រេចលើសំណើសុំបញ្ជាក់បទចោទរបស់ជនជាប់ចោទ Al Hassan Ag Abdoul Aziz Ag Mohamed Ag Mahmoud ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៩ (“សេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី *Al Hassan* (ICC)”) កថាខណ្ឌ ៥៥៩។

ព្រឹត្តតាមរយៈអំពើដែលត្រូវបានកំណត់ថា ជា"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"ពុំតម្រូវឱ្យមានការបង្ហាញភស្តុតាងនៃកង្វះការយល់ព្រមរបស់ជនរងគ្រោះឡើយ[3309]។

1183.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា កន្លងមក ហេតុការណ៍ភាគច្រើនបំផុតនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាប់ពាក់ព័ន្ធទៅនឹងចារីជា"ប្តី" និងស្ត្រីជនរងគ្រោះជា"ប្រពន្ធ"។ ហេតុការណ៍ដែលហៅថា "ប្រពន្ធចាប់ពង្រត់"ដំបូងត្រូវបានដឹងឮតាមរយៈការបង្កើតតុលាការ SCSL និងការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសង្គ្រាមប្រទេសសៀរ៉ាឡេអូនក្នុងឆ្នាំ ១៩៩១-២០០២។ តុលាការ ICC ក៏បានធ្វើការចោទប្រកាន់ផងដែរអំពីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំប្រឆាំងនឹងក្រុមឧទ្ទាមចលនាតស៊ូ ("LRA") ក្នុងប្រទេសអ៊ូហ្គង់ដាចាប់តាំងពីទសវត្សរ៍ ១៩៩០ និងដើមទសវត្សរ៍ ២០០០ និងក្រុមសកម្មប្រយុទ្ធ Ansar Dine/Al-Qaeda ក្នុងអង្គការក្រុមជីវពលអ៊ីស្លាម Islamic Magreb ក្នុងប្រទេសម៉ាលីចាប់តាំងពីឆ្នាំ ២០១២។ ស្ត្រី និងក្មេងស្រីត្រូវបានចាប់ពង្រត់ និងជាញឹកញាប់ត្រូវបានរំលោភសេពសន្ថវៈ និងបង្ខំឱ្យ"រៀបអាពាហ៍ពិពាហ៍"ជាមួយពួកឧទ្ទាម។

1184.ការបង្ហាញលេចធ្លោក្នុងកម្រិតដែលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលស្របតាមលំនាំអង្គហេតុ បានសន្មតយកចារីជាបុរស និងជនរងគ្រោះជាស្ត្រី មានអត្ថិភាពក្នុងការជំទាស់លើបញ្ហាថាតើ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គប្បីស្រូបបញ្ចូលទៅក្នុងបទឧក្រិដ្ឋនៃទាសភាពផ្លូវភេទ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *AFRC* បានពិចារណាថា អំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តឡើងដោយប្តីជាបុរសលើប្រពន្ធខ្លួននោះ គឺជាចំណុចសំខាន់បទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងថា ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគប្បីស្រូបបញ្ចូលទៅក្នុងបទឧក្រិដ្ឋនៃទាសភាពផ្លូវភេទ[3310]។ យោងតាមអង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *AFRC* បានឱ្យដឹងថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"មានធាតុផ្សំមួយចំនួនរួមគ្នាជាមួយទាសភាពផ្លូវភេទ ដូចជាការរួមភេទដោយគ្មានការយល់ព្រម និងការដកហូតនូវសិទ្ធិសេរីភាព"

[3309] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Al Hassan* (ICC) កថាខណ្ឌ ៥៥៩: "ដូចបានបញ្ជាក់ដោយអង្គបុរេជំនុំជម្រះ II អំពើជាក់លាក់ដែលត្រូវបានហាមឃាត់ដោយមាត្រា *៧-១-k* នៃលក្ខន្តិកៈ ក្នុងទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានលក្ខណៈជាការបង្ខំលើបុគ្គល ដោយគ្មានការយល់ព្រម ឱ្យទទួលយកទំនាក់ទំនងសហព័ទ្ធជាមួយបុគ្គលដទៃទៀតតាមរយៈការប្រើប្រាស់ការបង្ខិតបង្ខំលើរូបកាយ និងផ្លូវចិត្ត ការគំរាមកំហែងដោយកម្លាំង ឬតាមរយៈបរិយាកាសបង្ខិតបង្ខំ។ ទោះជាយ៉ាងណាក្តី បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានចាត់ទុកថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំតម្រូវឱ្យមានការបង្ហាញនូវកង្វះការយល់ព្រមពីសំណាក់ជនរងគ្រោះឡើយ"។

[3310] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) កថាខណ្ឌ ៧១១។

ប៉ុន្តែមានធាតុផ្សំខុសប្លែកពីគ្នាមួយចំនួនដែរ[3311]។ អង្គជំនុំជម្រះឧទ្ធរណ៍នេះបានបញ្ជាក់ថា ជាលទ្ធផល "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាបទល្មើសផ្លូវភេទចម្បងនោះទេ"[3312]។

1185.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតបានផ្តល់ការពិពណ៌នាយ៉ាងទូលំទូលាយនៃអំពើដែលជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏មានការឯកភាពគ្នាកំពុងលេចឡើងស្តីពីលក្ខណៈ និងសារៈសំខាន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវរួមបញ្ចូលទំនាក់ទំនងសហព័ទ្ធដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំលើបុរស និងស្ត្រី បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃបូរណភាពរូបកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលអាចអនុវត្តបាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋនីមួយៗក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បើទោះបីជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើង និងបានបន្តកើតឡើងក្នុងអំឡុងពេលនៃជម្លោះដែលហេតុការណ៍ភាគច្រើនបំផុតនោះគឺត្រូវបានប្រព្រឹត្តឡើងដោយចារីជាបុរសលើជនរងគ្រោះជាស្ត្រី[3313]ក៏ដោយ ក៏ពុំមានការកម្រិតនូវការបំភ្លឺនៃអំពើនេះត្រឹមលំនាំអង្គហេតុនេះឡើយ។ ដោយហេតុថា អំពើនេះពុំមែនជាបទឧក្រិដ្ឋឯករាជ្យ និងត្រូវបានចោទប្រកាន់ថា ជាអំពើអមនុស្សធម៌ដទៃទៀត ទើបមានការលំបាកក្នុងការលើកបង្ហាញជាឧទាហរណ៍នូវលក្ខណៈជាក់លាក់ ដែលអំពើនេះត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃជម្លោះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរួមបញ្ចូលបុរស និងស្ត្រី។

- *"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ"*

1186.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើបទដ្ឋាននៃ"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ" ដែលបានគូសបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០២/០១ គឺ

---

[3311] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៩៥។

[3312] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៩៥។

[3313] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលក្នុងនោះជនរងគ្រោះភាគច្រើនគឺជាស្ត្រី *សូមមើល* ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ"អំពើហិង្សាផ្លូវភេទទាក់ទងទៅនឹងជម្លោះ៖ របាយការណ៍របស់អគ្គលេខាធិការ" ឯកសារអង្គការសហប្រជាជាតិលេខ UN Doc S/2021/312 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១ ("របាយការណ៍របស់អគ្គលេខាអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាផ្លូវភេទទាក់ទងទៅនឹងជម្លោះ") ដែលក្នុងនោះជនរងគ្រោះភាគច្រើនលើសលុបគឺជាស្ត្រី។

ថាតើ អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ“បានរំលោភបំពានលើសិទ្ធិ”ជាមូលដ្ឋានដែរ ឬយ៉ាងណា [3314] និងបានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើលិខិតុបករណ៍អន្តរជាតិតែមួយនោះគឺ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស UDHR[3315] និងថា ពុំមានលិខិតុបករណ៍អន្តរជាតិណាបានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឡើយ[3316]។ គាត់បានយោងទៅលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតសម្រាប់ការបដិសេធមិនបំពេញកិច្ចស៊ើបសួរទៅលើបទឧក្រិដ្ឋនៃការបង្កឱ្យមានគភ៌ដោយបង្ខំ និងវិធីសាស្ត្រធ្វើឱ្យមានផ្ទៃពោះដើម្បីបង្ហាញនូវអ្វីដែលគាត់បានលើកឡើងថា ជាការវាយតម្លៃត្រឹមត្រូវនូវបញ្ហាស្តីពីអនីត្យានុកូលភាពអន្តរជាតិ[3317]។

1187.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់លាស់នូវសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយសេរី មានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស UDHR[3318]។ សហព្រះរាជអាជ្ញាបានយោងទៅលើច្បាប់យុត្តិសាស្ត្រអន្តរជាតិជាច្រើនដទៃទៀតដែលបានហាមឃាត់ការ

---

[3314] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៩-១១០៣ យោងទៅលើ *ក្នុងចំណោមនោះ*សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

[3315] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៣-១១០៤, ១១១១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤១។

[3316] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៨-១១០៩។

[3317] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១១០ យោងទៅលើសេចក្តីសម្រេចរួមសំណុំរឿង ០០៤ លើសំណើ (D301/5) កថាខណ្ឌ ៧៤។

[3318] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៦៨។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៣។

រៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[3319] ព្រមទាំងលិខិតុបករណ៍ដទៃទៀតដែល "តម្រូវឱ្យមានការគោរពដល់សិទ្ធិគ្រួសារ"[3320]។

1188.អង្គជំនុំជម្រះតុលាការកំពូលបានអនុម័តតាមគោលគំនិតនៃ"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ"នៅក្នុងការពិភាក្សារបស់ខ្លួនអំពីវិសាលភាពនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងសំណុំរឿង ០០២/០១[3321] និងបានពិចារណាឃើញថាៈ

> ការភ្ជាប់'អំពើអមនុស្សធម៌ដទៃទៀត'ទៅនឹងអំពើដែលបានរំលោភបំពានលើសិទ្ធិរបស់មនុស្សដូចបានកំណត់ក្រោមលិខិតុបករណ៍អន្តរជាតិ គឺជាគោលគំនិតមួយដែលសមស្របត្រង់ថា បន្ថែមទៅលើធាតុផ្សំសត្យានុម័ត ដែលត្រូវបានកំណត់តាមទំនៀមទម្លាប់តាមរយៈលក្ខណៈវិនិច្ឆ័យនៃអត្ថិភាព *ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា ejusdem generis* គោលគំនិតនេះបានបង្កើតនូវលក្ខខណ្ឌតម្រូវនៃអនីត្យានុកូលភាព

---

[3319] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៦៩-៦៧០។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើអនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព ការជួញដូរទាសករ និងស្ថាប័ន និងអំពើប្រហាក់ប្រហែលទៅនឹងទាសភាព ចូលជាធរមានថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារលេខ 266 U.N.T.S. 3 ("អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព") ដែលកម្ពុជាបានទទួលយកជាផ្លូវការនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៥៧។ អនុសញ្ញាស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ អាយុអប្បបរមា សម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ ដែលចូលជាធរមាននៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៦៤ ឯកសារលេខ 521 U.N.T.S 231 ("អនុសញ្ញាស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍")។ អនុសញ្ញា ICCPR និង នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ចូលជាធរមានថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៦៤ ឯកសារលេខ 993 U.N.T.S.3 ("ICESCR") ដែលបានមានអត្ថិភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដែលត្រូវបានអនុម័តនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ឯកសារលេខ A/RES/22/2263 ("សេចក្តីប្រកាសស្តីពីការលុបបំបាត់នៃការរើសអើង")។ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីដែលចូលជាធរមានថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៨១ ឯកសារលេខ 1249 U.N.T.S 13 ("CEDAW") ដែលត្រូវបានចុះហត្ថលេខាដោយអៀង សារី ក្នុងខែ តុលាឆ្នាំ ១៩៨០។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៦៩-៦៧០។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើលិខិតុបករណ៍ថ្នាក់តំបន់ៈ ធម្មនុញ្ញទ្វីបអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជនចូលជាធរមានថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៨៦ 1520 U.N.T.S 217 ("ACHPR") និងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR")។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧១ និងជើងទំព័រ ២២៨៩។

[3320] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧១។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើបទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩ និង ១៩០៧ និងអនុសញ្ញាទីក្រុងហ្សឺណែវលើក IV។

[3321] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

ផ្លូវការអន្តរជាតិ និងតាមវិធីសាស្រ្តនេះ ការកម្រិតបន្ថែមទៀតលើការបកស្រាយពន្លាតចំពោះ'អំពើអមនុស្សធម៌ដទៃទៀត'[3322]។

1189.ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការកំណត់នូវ"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ" ពុំមែនជាការស្វែងរកនូវអត្ថិភាពនៃការហាមឃាត់ផ្នែកព្រហ្មទណ្ឌនោះឡើយ[3323]។ នៅក្នុងការពិចារណារបស់ខ្លួនអំពី"អនីត្យានុកូលភាព" អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ពុំមានភាពចាំបាច់សម្រាប់អំពើជាក់លាក់ដែលត្រូវបានចោទប្រកាន់នោះ ត្រូវតែជាបទល្មើសច្បាស់លាស់ក្រោមច្បាប់អន្តរជាតិឡើយ[3324]។ ផ្ទុយទៅវិញ ទាក់ទងទៅនឹងការយោងទៅលើច្បាប់យុត្តិសាស្រ្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានា ការកំណត់អត្តសញ្ញាណនៃ"សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន" គឺជាមធ្យោបាយមួយនៃការបំភ្លឺ និងបញ្ជាក់ជាក់លាក់នូវបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត។ ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ ពុំត្រូវបានកំណត់ដោយលក្ខខណ្ឌតម្រូវដែលថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវតែបានកំណត់ជាក់លាក់គ្រប់គ្រាន់នោះទេ។

1190.ការកំណត់នូវសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពានតាមរយៈអំពើដែលត្រូវបានចោទប្រកាន់នោះ គឺជាមធ្យោបាយសំខាន់ដែលក្នុងនោះបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតអាចត្រូវបានចាត់ទុកថា ស្របតាមគោលការណ៍*សច្ចភាពនៃច្បាប់* ដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ពីមុនរួចហើយ។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានវាយតម្លៃលើ"សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន"នោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយសេរី គឺជា"សិទ្ធិសារវន្ត"ដែលមានចែងក្នុងសេចក្តីប្រកាស UDHR ដែលថា "ការរៀបអាពាហ៍ពិពាហ៍ត្រូវតែបានយល់ព្រមដោយសេរី និងពេញលេញពីសំណាក់គូស្រករដែលមានបំណងនោះ"[3325]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាបន្ថែមទៀតថា លំនាំអង្គហេតុក្នុងរឿងក្តីបច្ចុប្បន្នដែលជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះទាំងបុរស និងស្រ្តីនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានដាក់កម្រិតដោយរដ្ឋ គឺផ្ទុយទៅវិញរឿងក្តីយុត្តិសាស្រ្តដែលមានអត្ថិភាពដែលសន្មតទុកជាមុននូវស្ថានការណ៍ពាក់ព័ន្ធទៅនឹងចារីជាបុរស និងជនរងគ្រោះជាស្រ្តី។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹង

---

3322 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

3323 *សូមមើលខាងលើ* ផ្នែក VII.ធ.១។

3324 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

3325 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៣ យោងទៅលើមាត្រា ១៦(២) នៃសេចក្តីប្រកាសជាសកល UDHR។

ត្រូវពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើបញ្ហានៃសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាននោះ ដែរ ឬយ៉ាងណា។

1191.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សិទ្ធិជាមូលដ្ឋានត្រូវបានរំលោភបំពាន។ សេចក្តីប្រកាស UDHR មានការបញ្ជាក់គាំទ្រសិទ្ធិដែលបានពិពណ៌នាដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងតែទៅលើលិខិតុបករណ៍នេះក្នុងការគូសបង្ហាញប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀតប៉ុណ្ណោះទេ ថែមទាំងបានពិចារណាផងដែរលើរឿងក្តីយុត្តិសាស្ត្ររបស់តុលាការ SCSL និង ICC ដើម្បីកំណត់អំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងគូសបង្ហាញនូវអំពើដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា។ អាស្រ័យហេតុនេះ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះបានថ្លឹងថ្លែងភាពជាក់លាក់នៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានអនុម័តតាមសំអាងហេតុ និងសេចក្តីសន្និដ្ឋានសមស្រប។

1192.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ចៅក្រម Doherty ក្នុងមតិជំទាស់ទៅនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *AFRC* បានបញ្ជាក់ថា បទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាប់ គឺ"ពាក់ព័ន្ធជាចម្បងទៅនឹងការរងទុក្ខផ្លូវចិត្តរបស់ជនរងគ្រោះ"[3326]។ ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Ongwen* បានយល់ឃើញថា ព្យសនកម្មដែលទទួលរងដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានដូចជា"ការប៉ះទង្គិចផ្លូវចិត្ត" និង"ការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ"[3327]។ ដូចបានគូសបង្ហាញខាងលើ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានបង្កផងដែរនូវការរំលោភបំពានជាច្រើនលើរូបកាយ ដែលនេះមានន័យថា ពុំមែនជាបទឧក្រិដ្ឋចម្បងនៃការរងទុក្ខផ្លូវចិត្តក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នេះគឺជាសមាសភាគបន្ថែមទៀតនៃព្យសនកម្ម។ ពិតណាស់សេចក្តីប្រកាស UDHR បានទទួលស្គាល់តម្លៃទាំងនេះនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

1193.បន្ថែមលើការយោងទៅលើសេចក្តីប្រកាស UDHR ដែលបានការពារសិទ្ធិពីការបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា សិទ្ធិប្រហាក់ប្រហែលគ្នានេះត្រូវបានបង្ហាញនៅក្នុង

[3326] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រ Doherty លើបទចោទលេខ ៧ (ទាសភាពផ្លូវភេទ) និងបទចោទលេខ ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៧០។

[3327] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ២៧៤៨-២៧៤៩។

មាត្រា ២ នៃអនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាពដែលកម្ពុជាបានទទួលស្គាល់ជាផ្លូវការនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៧៥។ អនុសញ្ញាបន្ថែមបានអំពាវនាវឱ្យរដ្ឋភាគី"ប្រើប្រាស់មធ្យោបាយជួយសម្រួលដើម្បីឱ្យការយល់ព្រមរបស់ភាគីទាំងពីរទៅនឹងការរៀបអាពាហ៍ពិពាហ៍ អាចត្រូវបានធ្វើឡើងដោយសេរីនៅមុខវត្តមានរបស់អាជ្ញាធរស៊ីវិល ឬខាងសាសនាដែលមានសមត្ថកិច្ច"[3328]។

1194.អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីនេះ បានរំលោភបំពានលើសិទ្ធិជាច្រើនដទៃទៀតដែលត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ បុគ្គលដែលទទួលយកការរៀបអាពាហ៍ពិពាហ៍ក្រោមការគំរាមកំហែងនៃការដាក់ទណ្ឌកម្មលើរូបកាយ ឬការសម្លាប់ប្រឈមនឹងការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិស្វ័យភាពផ្នែករូបកាយ[3329]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា ព្យសនកម្មដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានរួមបញ្ចូលការរំលោភបំពានលើសិទ្ធិនៃភាពឯកជនដែលបានបន្ត។ សេចក្តីប្រកាស UDHR បានទទួលស្គាល់ដោយជាក់លាក់ផងដែរនូវសិទ្ធិទទួលបានភាពគ្មានការជ្រៀតជ្រែកលើភាពឯកជន និងជីវិតគ្រួសារ ដែលបានរួមបញ្ចូលសិទ្ធិទទួលបានស្វ័យភាពជាលក្ខណៈបុគ្គល ការអភិវឌ្ឍន៍លក្ខណៈបុគ្គល និងលទ្ធភាពក្នុងការបង្កើត និងអភិវឌ្ឍទំនាក់ទំនងជាមួយបុគ្គលដទៃទៀត និងពិភពខាងក្រៅ[3330]។

1195.អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដូចបានចោទប្រកាន់ក្នុងរឿងក្តីនេះ បានរួមបញ្ចូលផងដែរនូវការរួមភេទដោយបង្ខំពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស និងស្ត្រី។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូល

---

[3328] មាត្រា ២ នៃអនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព។

[3329] ស្វ័យភាពនៃរូបកាយគឺជាសមាសភាគនៃសិទ្ធិទទួលបានសេរីភាព និងសន្តិសុខរបស់បុគ្គល ដែលត្រូវបានការពារដោយមាត្រា ៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស UDHR។ បើទោះបីជាសេចក្តីប្រកាសនេះ UDHR ពុំមែនជាលិខិតុបករណ៍ចងកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ ក៏ការដាក់បញ្ចូលសិទ្ធិក្នុងសេចក្តីប្រកាសនេះ UDHR បង្ហាញនូវការទទួលស្គាល់ជាអន្តរជាតិនៃសិទ្ធិទាំងនោះដែរ។ បន្ថែមលើនេះ រដ្ឋដែលជាសមាជិកនៃអង្គការសហប្រជាជាតិត្រូវបានស្នើសុំដោយមហាសន្និបាត(សេចក្តីសម្រេចមហាសន្និបាតលេខ ២១៧ D (៣) ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨) ឱ្យផ្សព្វផ្សាយសេចក្តីប្រកាសនេះ UDHR ដើម្បីជម្រុញការអនុវត្តន៍តាម។ *សូមមើល* សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិលេខ 217 D (III) (ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨)។ កម្ពុជា គឺជាសមាជិករបស់អង្គការសហប្រជាជាតិចាប់តាំងពីឆ្នាំ ១៩៥៥។

[3330] មាត្រា ១២ នៃសេចក្តីប្រកាសជាសកល UDHR ចែងថា "គ្មានបុគ្គលណាម្នាក់ត្រូវបានដាក់ឱ្យស្ថិតក្រោមការជ្រៀងជ្រែកតាមអំពើចិត្តលើសិទ្ធិឯកជន គ្រួសារ ផ្ទះសំបែង ឬទំនាក់ទំនង និងលើការវាយប្រហារលើសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់បុគ្គលនោះឡើយ"។ (ជាសំខាន់ ពាក្យពេចន៍ដែលដូចក្នុងមាត្រា ១២ សេចក្តីប្រកាសជាសកល UDHR ក្រោយមកត្រូវបានប្រើប្រាស់ក្នុងមាត្រា ១៧ នៃ ICCPR។ ដោយហេតុថា កម្ពុជាពុំមែនជាប្រទេសហត្ថលេខីនៃ ICCPR នៅចន្លោះ ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ការប្រើប្រាស់ពាក្យពេចន៍នេះបានបញ្ជាក់នូវការទទួលស្គាល់ជាអន្តរជាតិនៃមាត្រា ១២ នៃសេចក្តីប្រកាសជាសកល UDHR)។

ក្នុងសំណុំរឿង ០០១ បានយល់ឃើញថា ការរំលោភសេពសន្ថវៈពុំត្រូវបានបង្ហាញថា ជាបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[3331]ក៏ដោយ ក៏អង្គជំនុំជម្រះបានរកឃើញថា រហូតដល់មានរបាយការណ៍ស្តីពីការរំលោភសេពសន្ថវៈជាប្រព័ន្ធ ឬរីករាលដាលក្នុងដើមទសវត្សរ៍ ១៩៩០ ទើបធាតុផ្សំតាមបរិបទនៃការរំលោភសេពសន្ថវៈដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មត្រូវបានបង្ហាញច្បាស់លាស់។ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ អំពើជាមូលដ្ឋាននៃការរួមភេទដោយបង្ខំជាអប្បបរមាត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន។ បន្ថែមលើនេះ ការរួមភេទដោយបង្ខំគឺជាទម្រង់នៃការប្រព្រឹត្តយ៉ាងឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ដែលត្រូវបានហាមឃាត់ក្រោមច្បាប់អន្តរជាតិ និងច្បាប់កម្ពុជាដែលបានចូលជាសមាជិកអង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៥៥ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវក្នុងឆ្នាំ ១៩៥៨[3332]។ ដូចគ្នានឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែរ ការរួមភេទដោយបង្ខំបានរំលោភបំពានលើសិទ្ធិនៃភាពឯកជ និងសិទ្ធិស្វ័យភាពផ្នែករូបកាយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អំពើនេះដែលត្រូវបានពិពណ៌នាដោយត្រឹមត្រូវថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- *នីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ*

1196.ខៀវ សំផន បានលើកអំណះអំណាងច្រើនជាផ្នែកៗអំពីភាពពាក់ព័ន្ធនៃការប្រតិបត្តិតាមប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំក្នុងសង្គមខ្មែរ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សារណាជាច្រើនទាំងនេះពុំមានលក្ខណៈសមស្រប និងពិបាកក្នុងការកំណត់ និងរំឭកថា ភាគីដាក់បណ្តឹងសាទុក្ខមានកាតព្វកិច្ចលើកសារណាជាក់លាក់ និងច្បាស់លាស់។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សារណាមួយចំនួននេះពាក់ព័ន្ធទៅនឹងនីត្យានុកូលភាព ដូចជា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការគូសបង្ហាញនូវអំពើដែលត្រូវបានចោទប្រកាន់ នឹងត្រូវបានដោះស្រាយក្នុងផ្នែកនេះ ចំណែកសារណាដទៃទៀតពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភាពធ្ងន់ធ្ងរនៃអំពើ និងភាពធ្ងន់ធ្ងរនៃព្យសនកម្ម នឹងត្រូវដោះស្រាយតាមលំដាប់លំដោយ។

---

[3331] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៨០។

[3332] មាត្រា ៥ នៃសេចក្តីប្រកាសជាសកល UDHR ចែងថា "គ្មានបុគ្គលណាម្នាក់ត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬទណ្ឌកម្ម" និងមាត្រា ៣ ជារួមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ I ដល់ IV *ក្នុងចំណោមនោះ* បានហាមឃាត់អំពើឃោរឃៅ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់បុគ្គល។

1197.យោងតាម ខៀវ សំផន បានលើកឡើងថា តាមជំហរនៃច្បាប់បង្ហាញថា ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩២០ តម្រូវឱ្យមានការព្រមព្រៀងពីឪពុកម្ដាយ ជាជាងពីបុគ្គលក្នុងការរៀបអាពាហ៍ពិពាហ៍[3333]។ នៅក្នុងសារណាផ្ទាល់មាត់នៃបណ្ដឹងសាទុក្ខ មេធាវីការពារក្ដីរបស់គាត់បានទទួលស្គាល់កំហុសក្នុងការបកស្រាយក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩២០ នេះ និងថា ក្រមនេះតម្រូវឱ្យមានការស្ម័គ្រចិត្តជាលក្ខណៈបុគ្គលសម្រាប់ការរៀបអាពាហ៍ពិពាហ៍[3334]។ ជាជម្រើស មេធាវីការពារក្ដីរបស់គាត់បានអះអាងថា លក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសសម្រាប់ការស្ម័គ្រចិត្ត ក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩២០ ពុំបានចែងអំពីកាតព្វកិច្ចត្រូវអនុវត្តចំពោះ"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[3335]។ ខៀវ សំផន បានអះអាងផងដែរថា បើទោះបីជា"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"ក្នុងពេលបច្ចុប្បន្នត្រូវបានថ្កោលទោសដោយរដ្ឋជាច្រើនក៏ដោយ ក៏ប៉ុន្តែពុំមែនជាបទល្មើសក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងបានបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះពុំត្រូវបានទទួលស្គាល់ថា ជាបទឧក្រិដ្ឋឡើយ[3336]។

1198.យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩២០ ត្រូវបានផ្លាស់ប្ដូរនៅមុនរបបខ្មែរក្រហម និងថា ក្រមជាធរមាននៅចន្លោះឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ បានតម្រូវឱ្យមានការយល់ព្រមជាលក្ខណៈបុគ្គលសម្រាប់ការរៀបអាពាហ៍ពិពាហ៍[3337]។ សហព្រះរាជអាជ្ញាបានអះអាងថា ភាពធ្ងន់ធ្ងរនៃអំពើ និងភាពអាចដឹងជាមុនបាននូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ត្រូវបានគាំទ្រដោយច្បាប់ជាតិជាច្រើនសន្ធឹកសន្ធាប់ក្នុងប្រទេសដទៃទៀតក្នុងឆ្នាំ ១៩៧៥[3338]។

1199.សហមេធាវីនាំមុខបានឆ្លើយតបថា បទបញ្ញារបស់កម្ពុជាប្រជាធិបតេយ្យស្ដីពីគោលការណ៍ការរៀបអាពាហ៍ពិពាហ៍ គឺជាការបន្ទាបបន្ថោកមនុស្ស និងដូច្នេះគឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស

---

[3333] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១២៣, ១១២៨, ១១៤១។ ខៀវ សំផន បានជំទាស់ផងដែរថា ប្រសិនបើអង្គការដើរតួនាទីយល់ព្រមដូចឪពុកម្ដាយ នោះការយល់ព្រមរបស់អនាគតប្ដីប្រពន្ធលែងចាំបាច់ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦២។

[3334] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៣៣។

[3335] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៣៣។

[3336] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤១។

[3337] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៣។

[3338] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧២ យោងទៅលើប្រទេសនានាក្នុងទ្វីបអាស៊ី អឺរ៉ុប អាហ្វ្រិក អាមេរិកខាងត្បូង និង អូសេអានី។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៣។

[3339]។ សហមេធាវីនាំមុខបានអះអាងថា បើទោះបីជាក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ១៩២០ តម្រូវឱ្យមានការយល់ព្រមពីឪពុកម្ដាយក៏ដោយ ក៏ផ្អែកតាមការពិនិត្យត្រឹមត្រូវនៃក្រមរដ្ឋប្បវេណីនេះឃើញថា "ការយល់ព្រមរបស់ឪពុកម្ដាយស្ថិតក្រោមការយល់ព្រមរបស់សាមីជន"[3340]។ បន្ថែមលើនេះ ខៀវ សំផន បានដឹងថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការខុសច្បាប់ផ្អែកតាមច្បាប់ក្នុងស្រុក ឬច្បាប់អន្តរជាតិ[3341]។

1200.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានជំទាស់ទៅនឹងខ្លឹមសារនៃច្បាប់ក្នុងស្រុកក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងបានអះអាងថា កម្ពុជាបានអនុញ្ញាតការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ និងពុំចាត់ទុកជាបទល្មើសដូចរដ្ឋដទៃទៀត និងបានដកស្រង់ការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសាលដីកានៃសំណុំរឿង ០០១ ដែលបានគូសបង្ហាញនូវប្រភពផ្សេងៗដែលស្របជាមួយនឹងគោលការណ៍នីត្យានុកូលភាព[3342]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ផងដែរថា បន្ថែមលើច្បាប់នៃសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើ"ច្បាប់ក្នុងស្រុកសម្រាប់គោលបំណងនៃការបង្ហាញថា ជនជាប់ចោទអាចដឹងដោយសមហេតុផលថា បទល្មើសដែលចោទជាបញ្ហា ឬបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងលក្ខណៈដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ ត្រូវបានហាមឃាត់ និងអាចដាក់ទោសបាន"[3343]។

1201.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន ពុំមានលក្ខណៈសមស្របចំពោះការវាយតម្លៃលើនីត្យានុកូលភាពនៃអំពើដែលត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ត្រឹមត្រូវថា ត្រូវបានបង្កើតឡើងជាយូរមកហើយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អំពើដែលស្ថិតក្រោមវិសាលភាពបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ពុំតម្រូវឱ្យបង្ហាញថា ជាការហាមឃាត់ផ្នែកព្រហ្មទណ្ឌឯករាជ្យឡើយ។ ជាលទ្ធផល ពុំមានលក្ខខណ្ឌតម្រូវក្នុងការពិនិត្យឡើងវិញលើប្រភពផ្លូវច្បាប់ក្នុងការកំណត់ភាពឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងពុំមានប្រភពផ្លូវច្បាប់ដែលត្រឹមត្រូវ ឬពុំត្រឹមសម្រាប់កំណត់ការប្រព្រឹត្តថា

---

[3339] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤៥ និង ៦៩៥-៧០១។

[3340] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤៨។

[3341] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៤៥-៥៥៥, ៥៦២-៥៦៥។

[3342] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១១២ យោងទៅលើសាលដីការឿងក្តី ០០១ (F28) កថាខណ្ឌ ៩៦។

[3343] សាលដីការឿងក្តី ០០១ (F28) កថាខណ្ឌ ៩៦ យោងទៅលើសេចក្តីសម្រេចក្នុងរឿងក្តី *Milutinović និងជនជាប់ចោទដទៃទៀត* កថាខណ្ឌ ៤០។

នេះជាអំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា បើទោះបីជាអំណះអំណាងរបស់ ខៀវ សំផន ត្រូវបានទទួលយកក្នុងកម្រិតខ្ពស់បំផុត ហើយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាការស្របច្បាប់ច្បាស់លាស់ផ្អែកតាមច្បាប់ក្នុងស្រុកនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ក៏ដោយ ក៏នេះពុំបានរារាំងដល់ការយល់ឃើញដែលថា អំពើល្មើសបានកើតឡើងដែរ ប៉ុន្តែអាចជាប់ពាក់ព័ន្ធទៅនឹងបញ្ហានៃភាពអាចដឹងជាមុនបានថា មានច្បាប់ចែង។ ដូចសាលក្រមក្នុងរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Altstotter និងជនជាប់ចោទដទៃទៀត* បានបញ្ជាក់ពាក់ព័ន្ធទៅនឹងអាល្លឺម៉ង់ណាហ្ស៊ីថា "ច្បាប់ស្តីពីការរើសអើងបានបង្កើតជាកម្មវត្ថុនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ"[3344]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "នេះគឺជាគោលការណ៍ទូទៅដែលថា ចារីពុំអាចសំអាងទៅលើលក្ខខណ្ឌដែលបានបង្កើតឡើងដោយអំពើអនីត្យានុកូលភាពរបស់ខ្លួនដើម្បីធ្វើយុត្តិកម្មចំពោះអំពើនោះបានឡើយ"[3345]។

1202.អាស្រ័យហេតុនេះ អំណះអំណាងបន្ថែមរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃច្បាប់កម្ពុជានៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចាត់ទុកជាអសារបង់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិនិត្យលើច្បាប់ក្នុងស្រុកដែល ខៀវ សំផន បានយោងទៅលើដើម្បីឱ្យពេញលេញ និងធ្វើការពិភាក្សាបន្តទៀត។

1203.នៅគ្រប់កាលៈទេសៈ ក្រមនេះពុំបានដាក់គោលការណ៍ស្ម័គ្រចិត្តបុគ្គលចំពោះការរៀបអាពាហ៍ពិពាហ៍ឱ្យទាបជាងគោលការណ៍យល់ព្រមរបស់ឪពុកម្តាយឡើយ។ មាត្រា ១៣៣ នៃក្រមរដ្ឋប្បវេណីនេះ តម្រូវផងដែរការយល់ព្រមពីឪពុកម្តាយរបស់សាមីជន ប៉ុន្តែក្នុងពេលដំណាលគ្នានោះក៏បានការពារសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការស្ម័គ្រចិត្តធ្វើជាប្តី ឬប្រពន្ធ។ មាត្រា ១០៦ នៃក្រមរដ្ឋប្បវេណីនេះចែងថា "ការភ្ជាប់ពាក្យគឺជាការសន្យាដែលបុគ្គលពីរនាក់បានធ្វើឡើងដើម្បីទទួលយកគ្នាទៅវិញទៅមកជាប្តីប្រពន្ធស្របច្បាប់"។ យោងតាមមាត្រា ១១៤ នៃក្រមនេះចែងថា "ប្តីប្រពន្ធគឺជាឋានៈដែលបង្ហាញថា បុរស និងស្ត្រីបានចុះ

---

[3344] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Altstotter ជនជាប់ចោទដទៃទៀត* សំអាងហេតុ និងសាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក) សំណុំរឿងលេខ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៧៤ ក្នុងការជំនុំជម្រះបុគ្គលចំពោះមុខតុលាការព្រហ្មទណ្ឌយោធា Nuremberg ក្រោមក្រុមប្រឹក្សាគ្រប់គ្រងច្បាប់លេខ ១០ ឆ្នាំ ១៩៤៦-១៩៤៩ (ឆ្នាំ ១៩៥១) ភាគ III ទំព័រ ១០៦៣។ *សូមមើលផងដែរ* ទំព័រ ១០១១ ("ក្នុងទ្រឹស្តីច្បាប់អាល្លឺម៉ង់ ច្បាប់របស់ Hitler គឺជាខែលការពារអ្នកដែលបានប្រព្រឹត្តក្រោមច្បាប់នោះ ប៉ុន្តែនៅចំពោះមុខតុលាការព្រហ្មទណ្ឌមួយដែលត្រូវបានអនុញ្ញាតឱ្យអនុវត្តច្បាប់អន្តរជាតិនោះ ក្រិត្យរបស់ Hitler ពុំមែនជាការការពារមេដឹកនាំខ្លួនឯងផ្ទាល់ និងអ្នកក្រោមបង្គាប់ដែរ ប្រសិនបើមានការរំលោភបំពានលើច្បាប់របស់សហគមន៍អន្តរជាតិ")។

[3345] សាលក្រមអង្គជំនុំជម្រះសាលាដំបូងជើងទំព័រ ២០៧៥។

សំបុត្រអាពាហ៍ពិពាហ៍ដោយស្របច្បាប់ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដែលមានការយល់ព្រមទៅវិញទៅមក ដោយស្របតាមច្បាប់អនុញ្ញាត និងពុំអាចរំលាយបានតាមឆន្ទៈបានឡើយ"។ សិទ្ធិរបស់ឪពុកម្តាយក្នុងការយល់ព្រម ត្រូវបានកាត់បន្ថយដោយសិទ្ធិក្នុងការការពារគូស្រករ។ ឧទាហរណ៍ ប្រសិនបើពុំមានការយល់ព្រមពីឪពុកម្តាយ គូស្រករអាចស្នើសុំការជួបជុំនុំជាមួយ"ក្រុមប្រឹក្សាសាច់ញាតិ"ដើម្បីសម្របសម្រួល និងទទួលបានការព្រមព្រៀងដោយផ្អែកតាមមាត្រា ១៣៤ នៃក្រមនេះ។ ប្រសិនបើការសម្របសម្រួលពុំទទួលបានលទ្ធផលព្រមព្រៀងគ្នាទេ គូស្រករដែលមានបំណងនោះអាចរៀបអាពាហ៍ពិពាហ៍ដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្តាយក្រោយការរង់ចាំអស់រយៈពេលបីខែ។ បន្ថែមលើនេះ ប្រសិនបើការរៀបអាពាហ៍ពិពាហ៍គឺជាការ"បង្ខំ" សំណើសុំអាចត្រូវបានធ្វើឡើង ដើម្បីជំទាស់នឹងការរៀបអាពាហ៍ពិពាហ៍នោះ ស្របតាមមាត្រា ១៦៣។

1204.អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា បើទោះបីជាការសន្មតថា អំណះអំណាងដំបូងរបស់ ខៀវ សំផន អំពីក្រមរដ្ឋប្បវេណីកម្ពុជានេះ ជាការត្រឹមត្រូវ ហើយការឯកភាពសម្រាប់គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ គឺជារបស់គ្រួសារ ជាជាងរបស់បុគ្គលក៏ដោយ ក៏នេះពុំអាចផ្តល់ធម្មានុរូបដល់ការអនុវត្តន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដូចបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យបានដែរ។ ការឯកភាពពីគ្រួសារ និងបុគ្គលមិនអាចផ្តាច់ពីគ្នាបានផ្អែកតាមបទប្បញ្ញត្តិ និងបង្ហាញថា គោលគំនិតនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ បានចាក់ឫសគល់ក្នុងក្របខ័ណ្ឌការងារដែលមានភាពស្មុគស្មាញនៃវប្បធម៌។ នេះជាការពុំសមហេតុផលក្នុងការអះអាងថា គោលគំនិតនៃការព្រមព្រៀងពីឪពុកម្តាយចំពោះការរៀបអាពាហ៍ពិពាហ៍បង្ហាញថា តតិយជនដែលពុំមែនជាឪពុកម្តាយអាចដើរតួនាទី និងយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ជំនួសបុគ្គលដូចករណីក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានឡើយ។

1205.អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការអះអាងរបស់ ខៀវ សំផន ដែលថា "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" គឺជាបទល្មើសថ្មីដែលត្រូវបានធ្វើឱ្យស្របច្បាប់ក្នុងពេលបច្ចុប្បន្នក្នុងរដ្ឋផ្សេងជាច្រើននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ គឺជាការភាន់ច្រឡំប្រហាក់ប្រហែលគ្នាដែរ[3346]។ ច្បាប់ក្នុងស្រុកទាំងក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល និងអង់គ្លូសាក់សុងក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានបង្ហាញថា ការរៀបអាពាហ៍

[3346] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៣៧។

ពិពាហ៍ដែលកើតឡើងដោយពុំមានការយល់ព្រម ឬតាមរយៈការបង្ខំ ពុំមានសុពលភាព ឬអាចមោឃៈបាន[3347]។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

- *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា(ejusdem generis)*

---

[3347] ក្នុងប្រទេសថៃឡង់ មាត្រា ១៥០៧ នៃក្រមស៊ីវិល និងក្រមពាណិជ្ជកម្មឆ្នាំ ១៩៣៤ បានចែងថា ការរៀបអាពាហ៍ពិពាហ៍អាចមោឃៈបាន ប្រសិនបើកើតចេញពីការបង្ខិតបង្ខំ។ ក្នុងប្រទេសឥណ្ឌា ផ្នែក ១២(១)(គ) នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍តាមសាសនាហិណ្ឌូ ឆ្នាំ ១៩៥៥ ចែងថា ការរៀបអាពាហ៍ពិពាហ៍អាចមោឃៈបានប្រសិនបើការយល់ព្រមទទួលបានតាមរយៈការបង្ខំ និងផ្នែក២៥ (iii) នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ពិសេស ឆ្នាំ ១៩៥៤ ចែងថា ការរៀបអាពាហ៍ពិពាហ៍អាចមោឃៈបាន ប្រសិនបើ ការយល់ព្រមរបស់ភាគីទទួលបានតាមរយៈការបង្ខិតបង្ខំ ឬការក្លែងបន្លំ។ ក្នុងប្រទេសអ៊ីរ៉ាក់ មាត្រា ៤ នៃច្បាប់ស្តីពីឋានៈបុគ្គលឆ្នាំ ១៩៥៩ តម្រូវឱ្យមានការយល់ព្រមពីភាគីសម្រាប់ការរៀបអាពាហ៍ពិពាហ៍ បើទោះបីជាមានភាគីម្ខាងត្រូវបានតំណាងដោយភ្នាក់ងារក៏ដោយ។ ក្នុងប្រទេសទុយនីស៊ី កន្លឹទីមួយនៃក្រមលក្ខន្តិកៈ ឆ្នាំ ១៩៥៦ តម្រូវការយល់ព្រមរបស់ភាគីទាំងពីរចំពោះការរៀបអាពាហ៍ពិពាហ៍ឱ្យមានសុពលភាព។ ក្នុងប្រទេស តង់ហ្សានី ផ្នែក ៣៨(១)(ង) នៃច្បាប់ស្តីពីបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ឆ្នាំ ១៩៧១ ចែងថា ការរៀបអាពាហ៍ពិពាហ៍ទៅជាមោឃៈ ប្រសិនបើ ការយល់ព្រមរបស់ភាគីទាំងពីរពុំមានលក្ខណៈសេរី និងដោយស្ម័គ្រចិត្ត។ ក្នុងប្រទេសអាហ្វ្រិកខាងត្បូង ផ្នែក ៣០ នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ឆ្នាំ ១៩៦១ តម្រូវឱ្យមានការយល់ព្រមរបស់ភាគីសម្រាប់ការរៀបអាពាហ៍ពិពាហ៍សុពលភាពកើតមាន។ ការរៀបអាពាហ៍ពិពាហ៍អាចមោឃៈបាន ប្រសិនបើត្រូវបានធ្វើឡើងក្រោមការបង្ខិតបង្ខំ។ ក្នុងប្រទេសនីហ្សេរីយ៉ា ផ្នែក ៣(១)(ឃ) នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ឆ្នាំ ១៩៧០ ចែងថា ការរៀបអាពាហ៍ពិពាហ៍ ទៅជាមោឃៈប្រសិនបើការយល់ព្រមពុំត្រូវបានធ្វើឡើងសមស្របដូចជាតាមរយៈការគំរាមកំហែង។ មាត្រា ១៤៦ នៃក្រមស៊ីវិលបារាំង និងបែលហ្សិក(បោះពុម្ពផ្សាយច្បាប់ដើមក្នុងឆ្នាំ ១៨០៤) ចែងថា ពុំមានការរៀបអាពាហ៍ពិពាហ៍ដែលគ្មានការយល់ព្រមឡើយ។ ក្នុងប្រទេសអង់គ្លេស និងវេលស៍ ផ្នែក ១២(១)(គ) នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ឆ្នាំ ១៩៧៣ ចែងថា ការរៀបអាពាហ៍ពិពាហ៍ទៅជាមោឃៈ ប្រសិនបើភាគីពុំបានយល់ព្រមដោយសុពលភាព រួមទាំងលទ្ធផលនៃការគំរាមកំហែង។ ប្រទេសអេស្ប៉ាញ មាត្រា ៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ១៨៨៩ ចែងថា ពុំមានការរៀបអាពាហ៍ពិពាហ៍ណាគ្មានការយល់ព្រមដោយសុពលភាពឡើយ។ ក្នុងរប្រទេសប្រេស៊ីល មាត្រា ២០៩ អានផ្គួបជាមួយមាត្រា ១៨៣(IX) នៃក្រមស៊ីវិលរបស់សហរដ្ឋអាមេរិក ឆ្នាំ ១៩១៦ ចែងថា ការបង្ខិតបង្ខំ ឬការយល់ព្រមគ្មានសុពលភាពដទៃទៀតធ្វើឱ្យការរៀបអាពាហ៍ពិពាហ៍មោឃៈ។ ប្រទេសម៉ិកស៊ិក មាត្រា ២៣៥(III) អានផ្គួបជាមួយមាត្រា ៩៨(II) នៃក្រមរដ្ឋប្បវេណីសហព័ន្ធចែងថា កង្វះការយល់ព្រមធ្វើឱ្យការរៀបអាពាហ៍ពិពាហ៍មោឃៈ។ ប្រទេសកូស្តារីកា មាត្រា ១៥(១) នៃក្រមគ្រួសារ ឆ្នាំ ១៩៧៤ ចែងថា ការរៀបអាពាហ៍ពិពាហ៍អាចមោឃៈប្រសិនបើ ការយល់ព្រមបានទទួលតាមរយៈអំពើហិង្សា ឬការភ័យខ្លាចធ្ងន់ធ្ងរ។ ប្រទេសគុយបា មាត្រា ៤៥(២) នៃក្រមគ្រួសារ ឆ្នាំ ១៩៧៥ ចែងថា ការរៀបអាពាហ៍ពិពាហ៍មោឃៈ និងគ្មានសុពលភាពប្រសិនបើការយល់ព្រមបានទទួលតាមរយៈការបង្ខិតបង្ខំ ឬបំភិតបំភ័យ។ ប្រទេសអូស្ត្រាលី មាត្រា ១៨(១)(ឃ) នៃបទប្បញ្ញត្តិរៀបអាពាហ៍ពិពាហ៍ ឆ្នាំ ១៩៥៩ ចែងថា ការរៀបអាពាហ៍ពិពាហ៍ គ្មានសុពលភាពប្រសិនបើ ការយល់ព្រមរបស់ភាគីទាំងពីរពុំមែនពិតប្រាកដ ដោយសារការបង្ខិតបង្ខំ។

1206. យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងពិនិត្យលើអំពើសកម្ម និងអកម្ម ដែលត្រូវបានកំណត់ចរិតលក្ខណៈយ៉ាងទូលំទូលាយថា ជាអំពើអមនុស្សធម៌ដទៃទៀត ខណៈពេលធ្វើការវាយតម្លៃលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានតម្រូវដោយគោលការណ៍ស្ដីពី *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា*[3348]។ គាត់បានអះអាងថា រឿងក្ដី *AFRC* របស់តុលាការ SCSL បានបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរឿងក្ដីបច្ចុប្បន្នពុំមានលក្ខណៈធ្ងន់ធ្ងរជាសត្យានុម័ត[3349]។ ខៀវ សំផន បានលើកឡើងថា ស្ត្រីក្នុងរឿងក្ដី *AFRC* ត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទ ការដាក់ឱ្យទៅជាទាសករផ្លូវភេទ និងការរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តឡើងដោយកងជីវពល និងទទួលរងការមាក់ងាយពីសង្គមយ៉ាងយូរក្រោយពេលបញ្ចប់ជម្លោះនោះ[3350]។

1207. សហព្រះរាជអាជ្ញាពុំបានឆ្លើយតបទៅនឹងចំណុចនេះ លើកលែងតែថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងថា ពុំមានលក្ខខណ្ឌតម្រូវដែលថា អំពើជាមូលដ្ឋានត្រូវតែជាបទល្មើសក្រោមច្បាប់អន្តរជាតិនៅពេលប្រព្រឹត្តនោះឡើយ[3351]។

1208. ក្នុងរឿងក្ដី ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា គោលការណ៍នៃ *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា ejusdem generis* គឺជា"ការធានាដ៏ចាំបាច់"សម្រាប់កំណត់ប្រភេទបន្ទាប់បន្សំនៃអំពើអមនុស្សធម៌ដទៃទៀតឱ្យមានលក្ខណៈច្បាស់លាស់ និងជាក់លាក់គ្រប់គ្រាន់[3352]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា ejusdem generis* មានលក្ខណៈចាំបាច់ដើម្បីឆ្លុះបញ្ចាំងនូវធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀត ជាពិសេស លក្ខខណ្ឌតម្រូវដែលថា បទឧក្រិដ្ឋដែលចោទជាបញ្ហានេះ មានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដែលបានកំណត់ច្បាស់លាស់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3353]។ ទោះជាយ៉ាងណាក្ដី ពុំមានវិធីសាស្ត្រជាក់លាក់ដែលក្នុងនោះគោលការណ៍នៃ *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា ejusdem generis* គប្បីត្រូវបានកំណត់ ឬការពារនោះឡើយ។

---

[3348] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៤៨, ១២៩០។

[3349] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៥។

[3350] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១០៥។

[3351] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៣៨៥-៣៨៨។

[3352] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៨។

[3353] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៦។

1209.ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃរឿងក្តីយុត្តិសាស្ត្រស្តីពីភាពធ្ងន់ធ្ងរ ខណៈពេលគូសបង្ហាញនូវក្របខ័ណ្ឌគតិយុត្តនៅមុនពេលបង្កើតការយល់ឃើញផ្នែកអង្គហេតុ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ SCSL ក្នុងរឿងក្តី *AFRC* ដែលបានពិចារណាលើភស្តុតាងដែលបង្ហាញអំពី"ការរងទុក្ខលើរូបកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" និងបានយល់ឃើញថា អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដែលបានកំណត់ជាក់លាក់មួយចំនួនក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ទាសភាពផ្លូវភេទ និងអំពើហិង្សាផ្លូវភេទ[3354]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនៃតុលាការ ICC ដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំអាចបង្កឱ្យមានការរងទុក្ខធ្ងន់ធ្ងរ និងអាចមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដែលបានកំណត់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3355]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពុំមានលក្ខណៈធ្ងន់ធ្ងរដូចនៅកន្លែងផ្សេងៗ[3356]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការដែលថាតើ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា គឺជាការវាយតម្លៃផ្នែកអង្គហេតុដោយផ្អែកលើបញ្ហាដែលថាតើ ការប្រព្រឹត្តនោះបានបង្កឱ្យមានការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬព្យសនកម្ម ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា[3357]។

1210.ដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណានូវភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៃការយល់ឃើញស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានានៅពេលចាប់ផ្តើមការវិភាគរបស់ខ្លួន។ ដោយហេតុថា ការវាយតម្លៃត្រូវបានធ្វើឡើងពាក់ព័ន្ធទៅនឹងអំពើដែលត្រូវបានចោទប្រកាន់ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយនៅក្នុងវិធីសាស្ត្រនោះឡើយ។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កត្តាដែលជា

---

[3354] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៧ យោងទៅលើសាលដីការឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៨២, ១៨៦, ១៩២, ១៩៥, ២០០។

[3355] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៧ យោងទៅលើសេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ៨៩-៩១។

[3356] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៨។

[3357] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៨។

ការកំណត់ក្នុងការវាយតម្លៃលើអំពើអមនុស្សធម៌ដទៃទៀត គឺថាតើ អំពើដែលត្រូវបានចោទប្រកាន់នោះបានបំពេញលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលជាកម្មវត្ថុនៃអង្គហេតុ ដែរ ឬយ៉ាងណា ពុំមានកំហុសផងដែរ។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់ថា បានអនុវត្តស្របតាមគោលការណ៍*អត្តិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា*ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមដែរ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

1211.បន្ទាប់ពីបានពិនិត្យលើការអះអាងរបស់ ខៀវ សំផន ដែលថា អំពើដែលត្រូវបានចោទប្រកាន់បច្ចុប្បន្នអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំមានលក្ខណៈធ្ងន់ធ្ងរដូចការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានយល់ឃើញក្នុងរឿងក្ដីដទៃទៀត អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានលើកសាឡើងវិញនូវអំណះអំណាងដែលបានលើករួចហើយ និងត្រូវបានពិនិត្យដោយយកចិត្តទុកដាក់នៅពេលជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ម្ចាស់បណ្ដឹងសាទុក្ខមានកាតព្វកិច្ចក្នុងការបង្ហាញកំហុសក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ជាជាងត្រឹមតែលើកសាឡើងវិញនូវអំណះអំណាងដែលពុំទទួលជោគជ័យនៅមុខអង្គជំនុំជម្រះសាលាដំបូង[3358]។ ទោះជាយ៉ាងណាក្ដី ដោយផ្អែកលើលក្ខណៈផ្សេងៗគ្នានៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរឿងក្ដីបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលនឹងប្រកាសស្ដីពីភាពធ្ងន់ធ្ងរនៃអំពើដែលត្រូវបានចោទប្រកាន់នេះ។ ដំបូង អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្នុងករវាយតម្លៃលើភាពធ្ងន់ធ្ងរនៃអំពើទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើព្យសនកម្មផ្លូវចិត្ត និងផ្លូវកាយដែលបានបង្កទៅលើបុគ្គលតាមរយៈការគំរាមកំហែងឱ្យរៀបអាពាហ៍ពិពាហ៍ និងការពិតដែលថា ជនរងគ្រោះត្រឹមរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលខ្លួនពុំដែលស្គាល់ និងការភ័យខ្លាចដែលបានដាក់សម្ពាធលើពួកគេឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងថា អំពើនេះត្រូវបានប្រព្រឹត្តដោយចេតនា[3359]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ភាពធ្ងន់ធ្ងរនៃការរងទុក្ខផ្លូវចិត្តដែលបានកើតឡើងតាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងបរិយាកាសបង្ខិតបង្ខំបានបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរផ្លូវចិត្តដែលបានប៉ះពាល់

---

[3358] *សូមមើលខាងលើ* ផ្នែក II។

[3359] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

យ៉ាងយូរដល់ជនរងគ្រោះ[3360]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អំពើនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3361]។

1212.ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការចោទប្រកាន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាញឹកញាប់ជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាស្ត្រីដែលត្រូវបានចាប់ធ្វើជាប្រពន្ធ និងចារីជាបុរសដែលជាប្ដី និងតាមធម្មតាជាអ្នកចាប់ពង្រត់។ ការយល់ឃើញជាច្រើនស្ដីពីភាពធ្ងន់ធ្ងរនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានឆ្លើយតបទៅនឹងលំនាំអង្គហេតុដែលបង្ហាញនូវភេទជាក់លាក់។ អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្ដី *AFRC* បានបញ្ជាក់ផងដែរថា ជនរងគ្រោះមួយចំនួនបានទទួលរងការប៉ះទង្គិចផ្លូវចិត្តដោយសារការធ្វើជាប្រពន្ធ ដែលនេះបានបណ្ដាលឱ្យមានការបណ្ដេញចេញពីសហគមន៍របស់ពួកគេ។ “ក្នុងករណីដែលពួកគេមានគភ៌ដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពួកគេ និងកូនៗរបស់ខ្លួនបានទទួលរងការមាក់ងាយដ៏យូរអង្វែងពីសង្គម”[3362]។ នៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរ អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្ដី *AFRC* បានពិចារណា *ក្នុងចំណោមនោះ* លើភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះជាស្ត្រី និងភាពវ័យក្មេងរបស់ពួកគេ[3363]។ ក្នុងរឿងក្ដី *RUF* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL បានយល់ឃើញថា “ការប្រើប្រាស់ពាក្យ‘ប្រពន្ធ’ [...] គឺជាចេតនាគិតទុកជាមុន និងជាយុទ្ធសាស្ត្រដែលមានគោលបំណង [...] ប្រើល្បិចកលផ្នែកចិត្តសាស្ត្រលើស្ត្រី”[3364]។ អង្គជំនុំជម្រះឧទ្ធរណ៍នោះបានយល់ឃើញបន្ថែមទៀតថា បន្ថែមលើព្យសនកម្មលើរូបកាយដែលទទួលដោយ“ប្រពន្ធ” “ទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំទៅលើជនរងគ្រោះ មានជាប់មកជាមួយនូវការមាក់ងាយដ៏យូរអង្វែងពីសង្គម ដែលប៉ះពាល់ដល់ការធូរស្បើយឡើងវិញ និងការបញ្ចូលទៅក្នុងសង្គមវិញ”[3365]។ ការសម្រេចបែបនេះត្រូវបានឯកភាពដោយអង្គបុរេជំនុំជម្រះនៃតុលាការ ICC ក្នុងរឿងក្ដី *Al Hassan*[3366]។

---

[3360] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[3361] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[3362] សាលដីការឿងក្ដី *AFRC* (SCSL) កថាខណ្ឌ ១៩៩។

[3363] សាលដីការឿងក្ដី *AFRC* (SCSL) កថាខណ្ឌ ២០០។

[3364] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Sesay និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង I (SCSL) សំណុំរឿងលេខ SCSL-04-15-T សាលក្រមថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ (“សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *RUF*”) កថាខណ្ឌ ១៤៦៦។

[3365] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *RUF* កថាខណ្ឌ ១២៩៦។

[3366] សេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី *Al Hassan* (ICC) កថាខណ្ឌ ៥៥៥។

1213.ព្យសនកម្មនេះជាទូទៅពុំស្របទៅនឹងរឿងក្តីបច្ចុប្បន្នដូចបានគូសបង្ហាញខាងលើ ដែលជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស និងស្ត្រី ដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ទៅវិញទៅមក។ បុរស និងស្ត្រីនោះជាញឹកញាប់ពុំបានស្គាល់គ្នាទៅវិញទៅមក និងត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងទ្រង់ទ្រាយធំជាច្រើនគូ និងត្រូវបានគំរាមកំហែងដាក់ទណ្ឌកម្ម ឬសម្លាប់ប្រសិនបើប្រកែក និងត្រូវបានបង្ខំឱ្យរួមភេទខណៈពេលស្ថិតក្រោមការតាមដាន និងបង្ខំឱ្យបង្កើតកូនសម្រាប់អង្គការ។ បន្ថែមលើនេះ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា អំពើដែលត្រូវបានចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រព្រឹត្តឡើងដើម្បីដាក់ការគ្រប់គ្រងលើបុរស និងស្ត្រី និងបានធ្វើឱ្យពួកគេក្លាយជាជនរងគ្រោះ ខណៈពេលប្រើប្រាស់ជនរងគ្រោះបុរសឱ្យរួមភេទដោយបង្ខំជាមួយជនរងគ្រោះជាស្ត្រី ដោយដាក់ពួកគេទាំងពីរភេទដែលជាជនរងគ្រោះដូចគ្នានេះឱ្យស្ថិតក្រោមអំពើតែមួយនៃការរួមភេទដោយបង្ខំគ្មានការស្ម័គ្រចិត្ត[3367]។ បញ្ហានេះដោយខ្លួនឯងផ្ទាល់បានបង្ហាញនូវភាពធ្ងន់ធ្ងរនៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដល់កម្រិតនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈធ្ងន់ធ្ងរច្បាស់លាស់ស្មើនឹងអំពើដទៃទៀតដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3368]។

---

[3367] *សូមមើលខាងក្រោម* ផ្នែក VII.ឆ.៣.iii.គ (ក-គ)។ ការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ភស្តុតាងរបស់ NAKAGAWA Kasumi ដែលថា ការរួមភេទដោយបង្ខំ"បានប៉ះពាល់យ៉ាងខ្លាំង និងពុំសមាមាត្រលើបុរសពីព្រោះបុរសមានកាតព្វកិច្ច និងត្រូវបានបង្ខំឱ្យរំលោភប្រពន្ធខ្លួន" ដែលជា"អំពើអមនុស្សធម៌" *សូមមើលខាងក្រោម* កថាខណ្ឌ ១៥៦១។ *សូមមើលផងដែរ* ការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលលើសក្ខីកម្មរបស់ មុំ វុន ដែលថា កងឈ្លបបានបង្ខំប្តីរបស់គាត់ដោយភ្ជង់កាំភ្លើងឱ្យរួមភេទជាមួយលោកស្រី ដែលលោកស្រីបានពិពណ៌នាថា "វាថាឱ្យឆាប់ដេកជាមួយគ្នា។ រួចហើយវាឆ្លូលពិលវាឆ្លូលពិលមើលយើង ហើយវាចាប់ប្រដាប់ប្រដាមនុស្សប្រុសដាក់មកជាមួយយើង [...]។ ខ្ញុំមានសេចក្តីខ្មាសអៀនយ៉ាងខ្លាំង" និងការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូលដែលថា បើទោះបីជា មុំ វុន បានផ្តល់ភស្តុតាងអំពីបទពិសោធន៍របស់គាត់ក្នុងនាមជាជនរងគ្រោះស្ត្រីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏រឿងរ៉ាវរបស់គាត់បង្ហាញអំពីព្យសនកម្មជាក់ស្តែងដល់ប្តីរបស់គាត់ ដែលត្រូវបានប្រើប្រាស់ និងបង្ខំឱ្យប្រព្រឹត្តអំពើផ្លូវភេទដោយការភ្ជង់កាំភ្លើងដែរ។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ភស្តុតាងនេះមានការជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីព្យសនកម្ម និងគប្បីបានពិចារណា *សូមមើលខាងក្រោម* កថាខណ្ឌ ១៥៦២។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានបន្ថែមទៀតថា ជនរងគ្រោះជាបុរសពុំមែនជាអ្នកចាប់រំលោភនោះទេ ប៉ុន្តែគឺជាឧបករណ៍ និងជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ *សូមមើលខាងក្រោម* កថាខណ្ឌ ១៥៨១។

[3368] *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ២៧៤៧-២៧៤៨ ដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើ

## ii. ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1214.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ពុំមានលក្ខខណ្ឌតម្រូវថា ការរំលោភសេពសន្ថវៈដែលជាអំពើមូលដ្ឋានមួយប្រភេទជាក់លាក់ត្រូវបានទទួលស្គាល់ច្បាស់លាស់ថាស្ថិតក្នុងប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀតត្រឹមឆ្នាំ ១៩៧៥[3369]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការចោទប្រកាន់ក្នុងដីកាដំណោះស្រាយដែលថា ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3370]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការពិតដែលថា ដីកាដំណោះស្រាយបានចោទប្រកាន់ថា ក្នុងការបង្ខំឱ្យរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចារីមានចេតនាប្រព្រឹត្តអំពើរំលោភបំពានលើរូបកាយក្នុងលក្ខណៈផ្លូវភេទលើជនរងគ្រោះក្នុងបរិយាកាសបង្ខិតបង្ខំដែលពុំមានការស្ម័គ្រចិត្ត[3371]។ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ក្នុងសំណុំរឿង ០០១ ថា ការរំលោភសេពសន្ថវៈតម្រូវឱ្យមានការស៊កបញ្ចូលបើទោះបីជាបន្តិចបន្តួចក្តីទៅក្នុង៖ (១) យោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗដែលប្រើប្រាស់ដោយចារី ឬ (២) ក្នុងមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារីដែលការស៊កបញ្ចូលផ្លូវភេទនោះបានកើតឡើងដោយគ្មានការស្ម័គ្រចិត្តពីជនរងគ្រោះ[3372]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បុរសពុំស្ថិតក្នុងវិសាលភាពនៃការកំណត់និយមន័យនេះឡើយ និងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិចារណាជាជម្រើសលើបញ្ហាថាតើ បុរសត្រូវបានដាក់ឱ្យស្ថិតក្រោមទម្រង់ដទៃទៀតនៃអំពើ

ដែលជាក់លាក់ក្នុងមាត្រា ៧(១) នៃលក្ខន្តិកៈ ប៉ុន្តែបានឆ្លុះបញ្ចាំងផងដែរនូវអំពើដែលខុសប្លែកពីអំពើក្នុងកថាខណ្ឌ ២៧៤៧-២៧៤៨។

3369 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨។

3370 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៩ យោងទៅលើ *ក្នុងចំណោមនោះ* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣០-១៤៣៣។

3371 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៩ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣១។

3372 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៣៦២។ ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរំលោភសេពសន្ថវៈក្នុងសំណុំរឿង ០០១ ត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល។ *សូមមើល* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០៨ និងជើងទំព័រ ៤២៨។

ហិង្សាផ្លូវភេទដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3373]ដែលបន្ថែមលើនេះត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ[3374]។

- *ការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ*

1215.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តនូវការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ ដែលត្រូវបានបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ នៅពេលបង្ហាញធាតុផ្សំនៃបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈក្នុងឆ្នាំ ១៩៧៥ ជាជាងការអនុវត្តនូវការកំណត់និយមន័យមួយដែលអាចអនុវត្តបានចំពោះការរំលោភសេពសន្ថវៈសហព័ទ្ធ[3375]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើការពិតដែលថា ការរំលោភសេពសន្ថវៈសហព័ទ្ធពុំមែនជាបទឧក្រិដ្ឋក្នុងសង្គមខ្មែរក្នុងឆ្នាំ ១៩៧៥[3376] ហើយការរំលោភសេពសន្ថវៈនេះពុំទាន់ត្រូវបានដោះស្រាយច្បាស់លាស់ និងបង្ហាញក្នុងច្បាប់កម្ពុជា[3377]។ គាត់បានអះអាងបន្ថែមដោយយោងទៅលើយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល និងអង់គ្លូសាក់សុង ដែលថាប្រទេសជាច្រើនមានការការកំណត់និយមន័យផ្សេងៗសម្រាប់ការរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តឡើងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍[3378]។ យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ដោយសារអនុវត្តការកំណត់និយមន័យ"ទូទៅ"នៃការរំលោភសេពសន្ថវៈចំពោះអង្គហេតុដែលបានចោទប្រកាន់នោះ[3379]។

---

3373 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១។

3374 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ២២៣៧ ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ដីកាដំណោះស្រាយកត់សម្គាល់ថា 'អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការរំលោភសេពសន្ថវៈ អាចត្រូវបានកំណត់បន្ថែមថា អំពើមនុស្សធម៌ដទៃទៀតក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ'។ *សូមមើល* ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៤៣៣"។

3375 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩១-១២៩៣។

3376 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៤-១២៩៦, ១៣១៦។

3377 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៧, ១៣១៦។

3378 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៨-១២៩៩។

3379 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០០។

1216.សហព្រះរាជអាជ្ញាបានឆ្លើយតបថា លក្ខណៈ និងភាពធ្ងន់ធ្ងរនៃអំពើពុំត្រូវបានកែប្រែដោយសារការពិតដែលថា បទល្មើសបានកើតឡើងក្នុងការរៀបអាពាហ៍ពិពាហ៍ និងជាពិសេសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ[3380]។

1217.យោងតាមសហមេធាវីនាំមុខបានឱ្យដឹងថា ការរំលោភសេពសន្ថវៈសហព័ទ្ធត្រូវបានចាត់ទុកជាបទល្មើសក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលបានកំណត់និយមន័យនៃការរំលោភសេពសន្ថវៈដោយគ្មានលក្ខខណ្ឌលើកលែងសម្រាប់ការរំលោភសេពសន្ថវៈសហព័ទ្ធ[3381]។ សហមេធាវីនាំមុខបានលើកឡើងថា បើទោះបីជាតុលាការក្នុងយុត្តាធិការខ្លះបានផ្តល់ករណីលើកលែងសម្រាប់ការរំលោភសេពសន្ថវៈសហព័ទ្ធក៏ដោយ ក៏ ខៀវ សំផន ពុំបានផ្តល់អំណះអំណាងផ្លូវច្បាប់ណាមួយសម្រាប់ការអះអាងដែលថា បញ្ហានេះបានអនុវត្តនៅកម្ពុជាឡើយ[3382]។ សហមេធាវីនាំមុខបានលើកឡើងបន្ថែមទៀតថា ករណីលើកលែងតាមទ្រឹស្តីសម្រាប់"ការរំលោភសេពសន្ថវៈសហព័ទ្ធ"ពុំអាចអនុវត្តបាន ពីព្រោះការរៀបអាពាហ៍ពិពាហ៍ខ្លួនឯងផ្ទាល់ពុំមែនជាការស្ម័គ្រចិត្ត ហើយការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តដោយមេដឹកនាំ និងកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ជាជាងដោយភាគីនៃការរៀបអាពាហ៍ពិពាហ៍ ដូច្នេះ ការលើកលែងណាមួយសម្រាប់ការរំលោភសេពសន្ថវៈសហព័ទ្ធដែលមានអត្ថិភាព នៅគ្រប់ករណីពុំអាចអនុវត្តបាននោះទេ[3383]។

1218.ជាការកត់សម្គាល់បឋម អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការចាំបាច់ក្នុងការពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ធាតុផ្សំនៃការរំលោភសេពសន្ថវៈ បានអនុវត្តដោយសមស្រប ដែរ ឬយ៉ាងណា។

1219.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដូចបានគូសបង្ហាញខាងដើម អង្គជំនុំជម្រះពុំមានកាតព្វកិច្ចក្នុងការពិចារណាលើបញ្ហាថាតើ បទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញតាមរយៈអំពើដែលត្រូវបានចោទប្រកាន់ ដែរ ឬយ៉ាងណា ឡើយ[3384]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញច្បាប់ជាធរមាន និងកត់សម្គាល់ថា៖

[3380] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨០-៦៨១។

[3381] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៧០។

[3382] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៧១។

[3383] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៧៣-៥៧៥។

[3384] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥, ៧៤១។

ពុំមានប្រភេទនៃអំពើទាំងនេះបានបង្ហាញច្បាស់លាស់ថា ជាបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ ហើយអំពើនេះពុំត្រូវបានចោទប្រកាន់ដូច្នេះដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវវាយតម្លៃរាល់អំពើទាំងអស់ធៀបនឹងការកំណត់និយមន័យនៃអំពើអមនុស្សធម៌ដទៃទៀត។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការវាយតម្លៃ អង្គជំនុំជម្រះតុលាការកំពូលត្រូវគូសបង្ហាញអំពីការបំភ្លឺនូវធាតុផ្សំចាំបាច់នៃអំពើនេះ ត្រង់ចំណុចដែលត្រូវបានចាត់ទុកថា ចាំបាច់ក្នុងការធានាបាននូវការវិភាគសមស្រប[3385]។

បទឧក្រិដ្ឋដែលពាក់ព័ន្ធតែមួយគត់នោះគឺបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា មានអត្ថិភាពយូរយារមកហើយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[3386]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តដោយត្រឹមត្រូវលើបទដ្ឋាននេះ និងបានយល់ឃើញថា ពុំមានលក្ខខណ្ឌតម្រូវដែលថា ការរំលោភសេពសន្ថវៈដែលជាប្រភេទជាក់លាក់នៃអំពើជាមូលដ្ឋាន ត្រូវបានទទួលស្គាល់ច្បាស់លាស់ជាបទឧក្រិដ្ឋនៅឆ្នាំ ១៩៧៥[3387]។ បើទោះបីជាបានបញ្ជាក់ត្រឹមត្រូវនូវបទដ្ឋាននោះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តដោយសមស្របដែរ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមកំណត់"ធាតុផ្សំ"នៃបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ បើទោះបីជាអំពើដែលត្រូវបានចោទប្រកាន់នេះជាចាំបាច់ស្មើនឹងបទឧក្រិដ្ឋឯករាជ្យក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការព្យាយាមកំណត់"ធាតុផ្សំ"សម្រាប់អំពើដែលស្ថិតក្នុងវិសាលភាពនៃអំពើអមនុស្សធម៌ដទៃទៀត គឺជាការភាន់ច្រឡំផ្នែកច្បាប់ និងពុំស្របតាមគោលបំណង[3388]។ ភាពសមស្របសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត គឺក្នុងគោលបំណងដើម្បីស្រូបយកអំពើដែលពុំត្រូវបានចាត់ជាបទល្មើសឯករាជ្យ។ អាស្រ័យហេតុនេះ ជាការពុំសមស្របក្នុងការព្យាយាមកំណត់ធាតុផ្សំផ្នែកព្រហ្មទណ្ឌនៃអំពើនេះ។

1220.អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់អត្តសញ្ញាណនៃធាតុផ្សំនៃការរំលោភសេពសន្ថវៈនៅក្នុងការវិភាគរបស់ខ្លួន។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើបញ្ហាថាតើ អំពើដែលបានចោទប្រកាន់នោះបានកើតឡើងជាក់ស្តែងដែរ ឬយ៉ាងណា និងថាតើអំពើនេះបានបំពេញតាមលក្ខខណ្ឌនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា។ ជាលទ្ធផល ការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីយល់ឃើញធាតុផ្សំផ្សេងពីនេះ

---

[3385] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧២៧។

[3386] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨។

[3387] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨។

[3388] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៩។

ជាពិសេសធាតុផ្សំនៃបទឧក្រិដ្ឋនៃ"ការរំលោភសេពសន្ថវៈនៃសហព័ទ្ធ" ត្រូវចាត់ទុកជាអសារបង់[3389]។ អាស្រ័យហេតុនេះ ដើម្បីកែតម្រូវកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់អត្តសញ្ញាណនៃអំពើដែលត្រូវបានចោទប្រកាន់នោះ។

1221. សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា ដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុដែលបានបង្កើតឡើងក្នុងផ្នែកស្តីពី"ការរៀបអាពាហ៍ពិពាហ៍"នៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ធាតុផ្សំផ្នែកច្បាប់នៃបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3390]។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា តាមរយៈការបង្ខំឱ្យរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចារីបានប្រព្រឹត្តអំពើរំលោភបំពានលើរូបកាយក្នុងលក្ខណៈផ្លូវភេទលើជនរងគ្រោះក្នុងបរិយាកាសបង្ខិតបង្ខំដែលក្នុងនោះពុំមានការយល់ព្រមពីជនរងគ្រោះឡើយ[3391]។ ការរួមដំណេកអាពាហ៍ពិពាហ៍ ត្រូវបានតាមដានជាប្រចាំដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ហើយបើសិនណាប្តីប្រពន្ធមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះទេ ពួកគេនឹងត្រូវចាប់ខ្លួន[3392]។ ធាតុផ្សំអត្តនោម័តិកើតមាននៅពេល ចារីមានបំណងប្រព្រឹត្តអំពើឈ្លានពានលើរូបកាយក្នុងលក្ខណៈផ្លូវភេទ ដោយដឹងថា បានកើតឡើងក្នុងបរិយាកាសបង្ខិតបង្ខំ ឬដោយគ្មានការយល់ព្រមពីជនរងគ្រោះ[3393]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា "ដោយផ្អែកលើការពិតទាំងនេះ បទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈក្នុងបរិបទ

[3389] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅគ្រប់កាលៈទេសៈ មានការលំបាកក្នុងការស្រមៃថា អំណះអំណាងនោះជំទាស់បានជោគជ័យ សូម្បីតែអំពើនោះជាក់ស្តែងត្រូវបានចោទប្រកាន់ថា ជាបទឧក្រិដ្ឋឯករាជ្យនៃការរំលោភសេពសន្ថវៈ។ មានបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៥ ដែលពុំមានចែងករណីលើកលែងនៃការរៀបអាពាហ៍ពិពាហ៍។ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវករណីលើកលែងសម្រាប់ការរំលោភសេពសន្ថវៈក្នុងការរៀបការក្រោមច្បាប់កម្ពុជា។ ផ្ទុយទៅវិញ គាត់បានផ្អែកទៅលើការអះអាងផ្នែកវប្បធម៌អរូបិយ ដូចជាអំណះអំណាងដែលថា ស្ត្រីត្រូវបានបង្ខំក្នុងការរៀបអាពាហ៍ពិពាហ៍ផ្អែកតាមក្បួនច្បាប់ស្រី"ច្បាប់ស្រី" និងបានអះអាងថា អារម្មណ៍បង្ហាញចំណង់ផ្លូវភេទពុំត្រូវបានចាត់ទុកថា ជាលក្ខខណ្ឌតម្រូវក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីឡើយ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១៧-១៣១៨។ ចាតើ ប្រទេសដទៃទៀតមានការលើកលែងនៃការរៀបអាពាហ៍ពិពាហ៍សម្រាប់ការរំលោភសេពសន្ថវៈ ក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែរ ឬយ៉ាងណា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវមូលហេតុ ដូចម្តេចបាននៃមានការជាប់ពាក់ព័ន្ធសម្រាប់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។

[3390] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣០។

[3391] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣១។

[3392] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣២។

[3393] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣១។

នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទឧក្រិដ្ឋមួយក្នុងចំណោមនោះដែលត្រូវបានប្រព្រឹត្តដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការអនុវត្តន៍គោលបំណងរួម”[3394]។

1222.ការបង្ហាញដែលបានគូសបញ្ជាក់ក្នុងដីកាដំណោះស្រាយ មានអាទិភាពជាងវិធីសាស្ត្រពុំត្រឹមត្រូវដែលបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង និងបានផ្តោតទៅលើ“ធាតុផ្សំ”បទឧក្រិដ្ឋ ជាជាងលើអំពើនៃការរួមដំណេកដោយបង្ខំ។ ទោះជាយ៉ាងណាក្តី ដីកាដំណោះស្រាយត្រូវបានកែប្រែលើចំណុចនេះដោយអង្គបុរេជំនុំជម្រះ[3395]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា បើទោះបីជាការរំលោភសេពសន្ថវៈត្រូវបានហាមឃាត់យូរយារមកហើយថា ជាឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ ក៏ពុំត្រូវបានកំណត់ជាក់លាក់ថា ជាបទឧក្រិដ្ឋដាច់ដោយឡែកក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ[3396]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការចោទប្រកាន់ការរំលោភសេពសន្ថវៈថា ជាបទឧក្រិដ្ឋជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែបានទទួលយកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតដែលថា “អង្គហេតុដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការរំលោភសេពសន្ថវៈ ដែលអាចត្រូវបានចាត់ទុកថា ជាអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអាស្រ័យហេតុនេះ អំពើនេះត្រូវបានចោទប្រកាន់យ៉ាងដូច្នេះ”[3397]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការកែប្រែក្នុងដីកាដំណោះស្រាយក្នុងជើងទំព័រ[3398]ក៏ដោយ ក៏អង្គជំនុំជម្រះទំនងជាបានអនុវត្តតាមខ្លឹមសារនៃដីកាដំណោះស្រាយក្នុងទម្រង់ដែលពុំទាន់បានកែប្រែនោះ។

---

[3394] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣២។

[3395] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/3/12 ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ (“សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/3/12)”) កថាខណ្ឌ ១១(២)។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15 និង D427/3/15) កថាខណ្ឌ ៣៥៩-៣៧២។

[3396] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15 និង D427/3/15) កថាខណ្ឌ ១៥០-១៥៤។

[3397] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15 និង D427/3/15) កថាខណ្ឌ ១៥៤។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/3/12) កថាខណ្ឌ ១១(២)។

[3398] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៧។

1223.អំពើបឋមដែលជាមូលដ្ឋាននៃបទចោទនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទក្នុងដីកាដំណោះស្រាយ គឺជាការរួមដំណេកដោយបង្ខំនៃការរៀបអាពាហ៍ពិពាហ៍ និងម្យ៉ាងវិញទៀត ជាអំពើនៃការរួមភេទដោយបង្ខំរវាងបុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។ កាលៈទេសៈបង្ខិតបង្ខំដែលបានចោទប្រកាន់នោះ ត្រូវបានបង្ហាញតាមរយៈការពិតដែលថា ភ្លាមៗក្រោយពេលពិធីនោះ ប្តីប្រពន្ធបានរាយការណ៍ថា ពួកគេត្រូវបានផ្លាស់ប្តូរទីតាំងទៅកន្លែងមួយដែលការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ត្រូវបានតាមដានដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា[3399]។ សាក្សីផ្សេងទៀតបានរាយការណ៍នូវការភិតភ័យនៃអំពើហិង្សាលើរូបកាយ ការដាក់ក្នុងមន្ទីរឃុំឃាំង ឬការសម្លាប់ ប្រសិនបើពួកគេមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ[3400]។ បរិយាកាសបង្ខិតបង្ខំត្រូវបានបង្ហាញផងដែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចគូសបង្ហាញខាងលើដែលបានកើតឡើងក្នុងស្ថានការណ៍ដែលក្នុងនោះបុគ្គលមានការភិតភ័យការស្លាប់ ឬការដាក់ទណ្ឌកម្មតាមទម្រង់ផ្សេងៗ។

1224.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការព្យាយាមកំណត់"ធាតុផ្សំ"ផ្នែកច្បាប់នៃបទឧក្រិដ្ឋក្នុងប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀត អាចនាំទៅរកការពុំអើពើលើយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិដែលពាក់ព័ន្ធស្តីពី"ការរួមភេទដោយបង្ខំ" ដែលអាចជួយដល់ការបំភ្លឺនូវអំពើដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីនេះ។ ដូចបានគូសបង្ហាញខាងលើ ការពិចារណាលើរឿងក្តីយុត្តិសាស្ត្រពុំមែនជាកាតព្វកិច្ចត្រូវធ្វើនោះទេ ប៉ុន្តែគឺជាមធ្យោបាយធម្មតាដែលអង្គជំនុំជម្រះសាលាដំបូងអាចកំណត់ និងគូសបង្ហាញនូវអំពើដែលស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតបាន។

1225.ពុំមានរឿងក្តីយុត្តិសាស្ត្រស្តីពីបញ្ហានៃតតិយជនដែលបានបង្ខំបុរស និងស្ត្រីឱ្យរួមភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទោះជាយ៉ាងណាក្តី រឿងក្តីយុត្តិសាស្ត្រទូលំទូលាយដែលពិភាក្សានូវអំពើនៃការរួមភេទដោយបង្ខំជាទូទៅ មានការជាប់ពាក់ព័ន្ធ។ ត្រូវតែពិចារណាលើធាតុផ្សំមិនផ្ទាល់នៃ"ការបង្ខំ" និង "ការរួមភេទ"។

1226.អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Akayesu* របស់តុលាការ ICTR បានអនុម័តបទដ្ឋានទូលំទូលាយសម្រាប់ការវាយតម្លៃលើការបង្ខិតបង្ខំក្នុងរឿងក្តីនៃអំពើហិង្សាផ្លូវភេទ ដោយបានសន្និដ្ឋានថា "ការបង្ខិតបង្ខំ

---

[3399] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣២។

[3400] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ៨៥៨។

អាចមានអត្ថិភាពនៅក្នុងបរិយាកាសមួយចំនួន ដូចជា ជម្លោះប្រដាប់អាវុធ ឬវត្តមានកងយោធា"[3401]។ អង្គបុរេជំនុំជម្រះ III នៃតុលាការ ICC ក្នុងសេចក្តីសម្រេចបញ្ជាក់អះអាងអំពីបទចោទក្នុងរឿងក្តី *Bemba* បានបញ្ជាក់លើចំណុចនេះ[3402]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គហេតុក្នុងរឿងក្តីបច្ចុប្បន្នដែលមានអត្ថិភាពនៃវត្តមានកងឈ្លបប្រដាប់អាវុធក្នុងអំឡុងពេលរួមដំណេក ព្រមទាំងការភិតភ័យនូវការសម្លាប់ ឬការដាក់ទណ្ឌកម្មដោយសារការមិនព្រមធ្វើតាម បានបំពេញរួចរាល់នូវលក្ខខណ្ឌសម្រាប់ការបង្ហាញកាលៈទេសៈដោយបង្ខំ[3403]។ អង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Ongwen* បានយល់ឃើញថា "ពិតណាស់" ការរួមភេទដែលកងជីវពល LRA ជាញឹកញាប់បានដាក់អ្នកដែលហៅថា 'ប្រពន្ធ'ឱ្យស្ថិតក្រោមនោះ បានអនុវត្តតាមរយៈការប្រើប្រាស់កម្លាំង ឬការគំរាមកំហែងដែលត្រូវបានប្រព្រឹត្តដោយកងជីវពល LRA ទៅលើបុគ្គលដែលហៅថា 'ប្រពន្ធ'របស់ពួកគេ[3404]។

1227.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាផងដែរលើរឿងក្តីយុត្តិសាស្ត្រស្តីពីអំពើនៃ"ការរួមភេទ"ដោយបង្ខំ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Akayesu* បានបញ្ជាក់ថា ការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈពុំអាចស្រូបបញ្ចូលទៅក្នុង"ការពិពណ៌នាដែលគ្មានភាពបត់បែនអំពីវត្ថុ និងអំពីផ្នែកនៃដងខ្លួននោះទេ" និងថា ការរំលោភបំពានរូបកាយលើផ្នែកណាមួយនៃដងខ្លួនរបស់ជនរងគ្រោះដែលមានលក្ខណៈផ្លូវភេទ

---

[3401] *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-96-4-T សាលក្រមថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ ("សាលក្រមរឿងក្តី*Akayesu* (ICTR)") កថាខណ្ឌ ៦៨៨។

[3402] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Bemba* តុលាការ ICC សេចក្តីសម្រេចស្របតាមមាត្រា ៦១(៧)(ក) និង (ខ) ស្តីពីបទចោទប្រឆាំងនឹងជនជាប់ចោទ Jean-Pierre Bemba Gombo សំណុំរឿងលេខ ICC-01/05-01/08 ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចរឿងក្តី *Bemba* ស្របតាមមាត្រា ៦១(៧)(ក) និង (ខ) (ICC)")។

[3403] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះសាលាដំបូង VI (ICC) សំណុំរឿងលេខ ICC- 01/04-02/06 សាលក្រមថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៩ កថាខណ្ឌ ៩៤៤, ៩៤៦ (បានយល់ឃើញថា ការរំលោភសេពសន្ថវៈបានកើតឡើងក្នុងកាលៈទេសៈបង្ខិតបង្ខំដែលក្នុងនោះ ទាហានបានប្រើប្រាស់*ក្នុងចំណោមនោះ*"ការគំរាមកំហែងដោយប្រយោលនៃការប្រើកម្លាំង"តាមរយៈការកាន់អាវុធនៅពីមុខជនរងគ្រោះ បង្ហាញអាវុធដល់ជនរងគ្រោះ ឬ"ប្រាប់ត្រង់ៗដល់ជនរងគ្រោះថា នឹងត្រូវសម្លាប់ប្រសិនបើស្រែក ឬមិនព្រមសហការ")។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-5/18-T សាលក្រមថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ("សាលក្រមរឿងក្តី *Karadžić* (ICTY)") ថាខណ្ឌ ២៥០៣-២៥០៥ (បានយល់ឃើញថា "ការរំលោភធ្ងន់ធ្ងរនៃផ្លូវភេទ" "ត្រូវបានបង្កទៅលើបូរណភាពរបស់ជនរងគ្រោះតាមរយៈការបង្ខំ ការគំរាមប្រើកម្លាំង ឬការបំភិតបំភ័យ" ជាឧទាហរណ៍ នៅពេលដែលអ្នកជាប់ឃុំបុរសពីរនាក់"ត្រូវបានបង្ខំឱ្យលិឍគូទស្ត្រីជនជាតិបូស្នៀនស៊ែប៊ី ដែលគំរាមអារករពួកគេប្រសិនបើមិនព្រមធ្វើតាម")។

[3404] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ២២៧០។

អាចជាការរំលោភសេពសន្ថវៈ[3405]។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *Furundzija* បានកម្រិតការកំណត់និយមន័យនេះ និងបានតម្រូវឱ្យមាន'ការស៊កបញ្ចូល'ក្នុងយោនី ឬរន្ធគូទដោយអង្គជាត ឬវត្ថុផ្សេង ឬ'ការស៊កបញ្ចូល'អង្គជាតរបស់ចារីទៅក្នុងមាត់របស់ជនរងគ្រោះ[3406]។ លក្ខខន្តិកៈទីក្រុងរ៉ូម នៅពេលពិនិត្យផ្ទួបជាមួយនឹងធាតុផ្សំនៃបទឧក្រិដ្ឋ បានដាក់វិធីសាស្ត្រពីរបញ្ចូលគ្នាដែលតម្រូវឱ្យមាន'ការរំលោភបំពានលើផ្នែកណាមួយ'នៃដងខ្លួនរបស់ជនរងគ្រោះ ដែលជាលក្ខណៈផ្លូវភេទ ឬរន្ធគូទ ឬប្រដាប់ភេទរបស់ជនរងគ្រោះជាមួយនឹង"វត្ថុណាមួយ ឬផ្នែកនៃដងខ្លួន"[3407]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Bemba* បានបញ្ជាក់ថា ការកំណត់និយមន័យនេះមានលក្ខណៈអព្យាក្រិតចំពោះភេទ និងអនុវត្តផងដែរចំពោះការស៊កបញ្ចូលចំពោះភេទដូចគ្នា[3408]។ ទោះជាយ៉ាងណាក្ដី ដោយសារមានភាពខុសប្លែកគ្នា និងការប្រែប្រួលក្នុងសមាសភាគនៃអំពើរំលោភសេពសន្ថវៈក្នុងតុលា ការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានា "ការរួមភេទដោយបង្ខំ"ជាមួយនឹងចារីបុរស និងជនរងគ្រោះជាស្ត្រីដែលត្រូវបានស៊កបញ្ចូល ជាញឹកញាប់ត្រូវបានយល់ឃើញថា ជាអំពើនៃការរំលោភសេពសន្ថវៈ។

1228.ទាំងតុលាការ ICTY និងតុលាការ SCSL បានកំណត់ថា ហេតុការណ៍នៃអំពើហិង្សាផ្លូវភេទដែលក្នុងនោះបុរសត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើស៊កបញ្ចូលផ្លូវភេទ គឺជាបទឧក្រិដ្ឋដែលអាចដាក់ទោសបានក្រោមលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌនីមួយៗ។ ហេតុការណ៍ទាំងនោះ បានរួមបញ្ចូលករណីដែលក្នុងនោះបុរសត្រូវ

---

[3405] សាលក្រមរឿងក្ដី*Akayesu* (ICTR) កថាខណ្ឌ ៥៩៧-៥៩៨។

[3406] សាលក្រមរឿងក្ដី *Furundžija* (ICTY) កថាខណ្ឌ ១៨៥។

[3407] ធាតុផ្សំនៃបទល្មើសនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សំណុំរឿងលេខ ICC-PIOS-LT-03-002/15 ឆ្នាំ ២០១៣ ("ធាតុផ្សំបទល្មើសនៃតុលាការ ICC") មាត្រា ៧(១)(ឆ)-១, ៨(២)(ខ)(xxii)-១។

[3408] រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គជំនុំជម្រះសាលាដំបូង III (ICC) សំណុំរឿងលេខ ICC-01/05-01/08 សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ("សាលក្រមរឿងក្ដី *Bemba* (ICC)") កថាខណ្ឌ ១០០។

បានបង្ខំឱ្យរួមភេទ[3409] តាមមាត់គ្នាទៅវិញទៅមក និង/ឬជាមួយចារី[3410] ឬស៊កបញ្ចូលជនរងគ្រោះជាមួយនឹងដងអំបោស[3411]។ ជាឧទាហរណ៍ ក្នុងរឿងក្តី *Gbao* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ SCSL បានយល់ឃើញថា អំពើហិង្សាផ្លូវភេទអាចស្មើនឹងការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងជា

[3409] *សូមមើល* សាលក្រមរឿងក្តី *Karadžić* (ICTY) កថាខណ្ឌ ២៤០៦, ២៤១០ (បុរសពីរនាក់ត្រូវបានបង្ខំឱ្យរួមភេទ)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Gbao និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង I (SCSL) សំណុំរឿងលេខ SCSL-04-15-T សាលក្រមថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ ("សាលក្រមរឿងក្តី *Gbao និងជនជាប់ចោទដទៃទៀត* (SCSL)") កថាខណ្ឌ ១២០៥-១២០៨, ១៣០២, ១៣០៥-១៣០៩, ១៣៤៧, ១៣៥២ (ជនស៊ីវិលបុរស និងស្ត្រីត្រូវបានបង្ខំឱ្យរួមភេទ)។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-08-91-T សាលក្រមថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ ("សាលក្រមរឿងក្តី *Stanišić និង Župljanin* (ICTY)") កថាខណ្ឌ ១៥៩៩ (ឪពុកកូនពីរគូ និងបងប្អូនជីដូនមួយពីរនាក់ត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើផ្លូវភេទគ្នាទៅវិញទៅមក រួមទាំងការរួមភេទ)។

[3410] *សូមមើល* សាលក្រមរឿងក្តី *Karadžić* (ICTY) កថាខណ្ឌ ២១០៤, ២១០៦, ២៤១០, ២៤២៦ (អ្នកជាប់ឃុំជាបុរសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់គ្នាទៅវិញទៅមក)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង III (ICTY) សំណុំរឿងលេខ IT-04-74-T សាលក្រម (ភាគ III នៃភាគ VI) ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ("សាលក្រមរឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ៧៧០ (អ្នកជាប់ឃុំបុរសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់គ្នាទៅវិញទៅមក)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-08-91-T សាលក្រម (ភាគ I នៃភាគ III) ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ ("សាលក្រមរឿងក្តី *Stanišić និង Župljanin* (ICTY)") កថាខណ្ឌ ៤៧៥, ៤៨៩, ១៥៩៩ (អ្នកជាប់ឃុំបុរសរួមទាំងសាច់ញាតិផងនោះ ត្រូវបានបង្ខំឱ្យរួមភេទតាមមាត់ និងអំពើផ្លូវភេទដទៃទៀតទៅវិញទៅមក)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brđanin* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿង IT-99-36-T សាលក្រម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៨២៤ (អ្នកជាប់ឃុំបុរសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់ទៅវិញទៅមក)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Česić* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-95-10/1-S សាលក្រមប្រកាសទោសថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៤ ("សាលក្រមរឿងក្តី *Česić* (ICTY) សាលក្រមប្រកាសទោស") កថាខណ្ឌ ១៣-១៤, ៣៥ (បងប្អូនប្រុសត្រូវបានបង្ខំដោយចុងកាំភ្លើងឱ្យរួមភេទទៅវិញទៅមក)។ សាលក្រមរឿងក្តី *Čelebići* (ICTY) កថាខណ្ឌ ១០៦៥-១០៦៦ (បងប្អូនប្រុសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់ទៅវិញទៅមក)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Simić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-95-9-T សាលក្រមថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ ("សាលក្រមរឿងក្តី *Simić និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ៧២៨ (អ្នកទោសបុរសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់គ្នាទៅវិញទៅមក និងជាមួយចារី)។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Todorović* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-9/1-S សាលក្រមប្រកាសទោសថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១ ("សាលក្រមប្រកាសទោសរឿងក្តី *Todorović* (ICTY)") កថាខណ្ឌ ៩, ៣៨-៣៩ (អ្នកជាប់ឃុំបុរសត្រូវបានបង្ខំឱ្យរួមភេទតាមមាត់គ្នាទៅវិញទៅមក។ អ្នកជាប់ឃុំបុរសម្នាក់ត្រូវបានបង្ខំឱ្យខាំអង្គជាតបុរសដទៃទៀត) ។

[3411] *សូមមើល* សាលក្រមរឿងក្តី *Stanišić និង Župljanin* (ICTY) កថាខណ្ឌ ១៥៩៩ (បានយល់ឃើញថា "ឪពុកកូនពីរគូ និងបងប្អូនជីដូនមួយត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើផ្លូវភេទគ្នាទៅវិញទៅមក រួមទាំង [...] ការស៊កបញ្ចូលជាមួយដងអំបោស")។

អំពើភេរវកម្មដែលក្នុងនោះ ពួកឧទ្ទាម AFRC/RUF "បានចាប់ផ្គូគ្នា"អ្នកជាប់ឃុំបុរស និងស្ត្រី និង"បញ្ជាឱ្យពួកគេរួមភេទជាមួយគ្នា"[3412] និងបានបញ្ជាផងដែរឱ្យប្តីប្រពន្ធរួមភេទនៅចំពោះមុខជនស៊ីវិលដទៃទៀតដូចជាកូនស្រីរបស់ពួកគេ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ដីកាបញ្ជូនទៅជំនុំជម្រះពុំបានបញ្ជាក់ច្បាស់លាស់នូវទម្រង់នៃអំពើហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរស ប៉ុន្តែបានយល់ឃើញថា កំហុសនេះអាចត្រូវបានកែតម្រូវប្រសិនបើមានការបង្ហាញភស្តុតាងទាន់ពេលវេលា ដើម្បីអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា ការរួមភេទដោយបង្ខំ"គឺជាការបន្ទាបបន្ថោក ព្យសនកម្ម និងការរំលោភបំពានធ្ងន់ធ្ងរ"លើសេចក្តីថ្លៃថ្នូររបស់បុគ្គលទាំងបុរស និងស្ត្រីដែលជាជនរងគ្រោះ[3413]។ ហេតុការណ៍ដទៃទៀតដែលក្នុងនោះបុរសត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើផ្លូវភេទដូចជាលិឍគូទរបស់ចារីស្ត្រី[3414] ឬខាំអង្គជាតរបស់អ្នកជាប់ឃុំដទៃទៀត[3415] បានបង្កើតមូលដ្ឋានប្រហាក់ប្រហែលគ្នាសម្រាប់ការយល់ឃើញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

1229.រឿងក្តីដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំ គឺជារឿងក្តីខុសពីធម្មតា។ ជាច្រើនករណី តុលាការ ICTY បានសម្រេចថា ការរួមភេទតាមមាត់ដោយបង្ខំរវាងបុរសពីរនាក់ គឺជាអំពើនៃការរំលោភសេពសន្ថវៈ[3416]។ ការប្រព្រឹត្តនេះត្រូវបានសំដៅផងដែរថា ជាអំពើហិង្សាផ្លូវភេទ។ អ្នករាយការណ៍

---

3412 សាលក្រមរឿងក្តី *Gbao និងជនជាប់ចោទដទៃទៀត* (SCSL) កថាខណ្ឌ ១២០៧-០៨, ១៣០៧, ១៣០៩, ១៣៤៧, ១៣៥២។

3413 សាលក្រមរឿងក្តី *Gbao និងជនជាប់ចោទដទៃទៀត* (SCSL) កថាខណ្ឌ ១២០៥, ១៣០២, ១៣០៥-១៣០៦។

3414 *សូមមើល* សាលក្រមរឿងក្តី *Karadžić* (ICTY) កថាខណ្ឌ ២១០៤, ២១១២, ២៥០៥-២៥០៦, ២៥១២, ២៥៨២។

3415 *សូមមើល* សាលក្រមប្រកាសទោសរឿងក្តី *Todorović* (ICTY) កថាខណ្ឌ ៣៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krajišnik* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-00-39-T សាលក្រម ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៨០០ (អ្នកជាប់ឃុំបុរសត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើពុំជាក់លាក់នៃ"ផ្លូវភេទបន្ទាបបន្ថោកគ្នាទៅវិញទៅមក")។

3416 សាលក្រមអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុងរឿងក្តី *Todorović* បានទទួលស្គាល់ថា ចារីបានបង្កអំពើហិង្សាផ្លូវភេទរវាងបុគ្គលដទៃទៀតរួមមានការខាំអង្គជាតជនរងគ្រោះ ការទាត់ប្រដាប់ភេទជនរងគ្រោះ និងបង្ខំឱ្យរួមភេទតាមមាត់គ្នាជាមួយអ្នកជាប់ឃុំដទៃទៀត។ *សូមមើល* សាលក្រមប្រកាសទោសរឿងក្តី *Todorović* (ICTY) កថាខណ្ឌ ៣៨-៤០។ រឿងក្តី *Češić* នៃតុលាការ ICTY នៅតែជារឿងក្តីមួយដែលចោទប្រកាន់ និងដាក់ពិរុទ្ធភាពលើការរួមភេទតាមមាត់ដែលជាអំពើនៃការរំលោភសេពសន្ថវៈ។ *សូមមើល* សាលក្រមប្រកាសទោសរឿងក្តី *Češić* (ICTY) កថាខណ្ឌ ១៣-១៤ និង ១០៧ (មូលដ្ឋានផ្នែកអង្គហេតុបង្ហាញថា ជនរងគ្រោះគឺជាបងប្អូនប្រុស ត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើផ្លូវភេទដោយចុងកាំភ្លើង និងឱ្យអ្នកដទៃទៀតមើល)។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងសវនាការបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានបញ្ជាក់ជាថ្មីនូវសារណាពេលជំនុំជម្រះរបស់ខ្លួនថា ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសដោយសារគោលនយោបាយនៃការរួមដំណេកដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូង"ពុំចាំបាច់អនុវត្តតាមការកំណត់និយមន័យផ្នែកច្បាប់ការរំលោភសេពសន្ថវៈ ប៉ុន្តែដោយសារជាពាក្យពេចន៍

ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការរំលោភសេពសន្ថវៈជាប្រព័ន្ធ ទាសភាពផ្លូវភេទ និងទាសភាពដូចការអនុវត្តន៍ក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ បានកំណត់អំពើហិង្សាផ្លូវភេទថា បានរួមបញ្ចូលនូវ "ស្ថានការណ៍ដែលក្នុងនោះ ជនរងគ្រោះពីរនាក់ត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើរួមភេទទៅវិញទៅមក ឬបង្កព្យសនកម្មទៅវិញទៅមកក្នុងលក្ខណៈផ្លូវភេទ"[3417]។ ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Đorđević និងជនដទៃទៀត* បានទទួលស្គាល់ថា អំពើហិង្សាផ្លូវភេទអាចត្រូវបានបង្កឡើងដោយចារីតាមរយៈការតម្រូវឱ្យបុគ្គលដទៃទៀតប្រព្រឹត្តអំពើរួមភេទ[3418]។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការ ICC បានកំណត់នូវព្យសនកម្មផ្លូវភេទថា បានរួមបញ្ចូលនូវស្ថានការណ៍ដែល"ចារីបានបង្ខំឱ្យបុគ្គលដទៃទៀតម្នាក់ ឬច្រើនប្រព្រឹត្តអំពើដែលមានលក្ខណៈផ្លូវភេទ"[3419]។

1230.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលស្របជាមួយនឹងរឿងក្តីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានាថា អំពើរួមភេទដោយបង្ខំពាក់ព័ន្ធទៅនឹងជនរងគ្រោះទាំងបុរស និងស្ត្រី ជាញឹកញាប់ត្រូវបានយល់ឃើញថា ជាអំពើហិង្សាផ្លូវភេទ។

- *"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ"*

---

សម្រាប់ពិពណ៌នា ការរំលោភសេពសន្ថវៈពិតណាស់ជាការត្រឹមត្រូវ"។ ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/10.1 ទំព័រ ៥៥។

[3417] គណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស របាយការណ៍របស់អ្នករាយការណ៍ពិសេស"ទម្រង់នៃទាសភាពនាពេលនោះ៖ ការរំលោភសេពសន្ថវៈជាប្រព័ន្ធ ទាសភាពផ្លូវភេទ និងអំពើដូចទាសភាពក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ" ឯកសាររបស់អង្គការសហប្រជាជាតិលេខ UN Doc. E/CN.4/Sub.2/1998/13 កថាខណ្ឌ ២១-២២។

[3418] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Đorđević និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿង IT-05-87/1-T សាលក្រមថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៧៦៨ យោងទៅលើរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Milutinović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-05-87-T សាលក្រម ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("សាលក្រមរឿងក្តី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY)") កថាខណ្ឌ ២០១។

[3419] *សូមមើល* ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការ ICC៖ មាត្រា ៧ (១) (ឆ)-៦ បទឧក្រិដ្ឋនៃអំពើហិង្សាផ្លូវភេទក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមាត្រា ៨ (២) (ខ) (xxii)-៦ ឧក្រិដ្ឋកម្មសង្គ្រាមនៃអំពើហិង្សាផ្លូវភេទ និងមាត្រា ៨ (២) (ង) (vi)-៦ ឧក្រិដ្ឋកម្មសង្គ្រាមនៃអំពើហិង្សាផ្លូវភេទដែលមានធាតុផ្សំសត្យានុម័តដូចគ្នា៖ "១. ចារីបានប្រព្រឹត្តអំពើមានលក្ខណៈផ្លូវភេទលើបុគ្គលម្នាក់ ឬច្រើន ឬបង្ខំឱ្យបុគ្គលនោះពាក់ព័ន្ធនឹងអំពើផ្លូវភេទតាមរយៈប្រើកម្លាំង ឬគំរាមកំហែងប្រើកម្លាំង ឬបង្ខិតបង្ខំ ដែលបង្កការភ័យខ្លាចនូវអំពើហិង្សា បង្ខិតបង្ខំ ឃុំឃាំង គាបសង្កត់ផ្លូវចិត្ត ឬរំលោភសិទ្ធិអំណាចលើបុគ្គលនោះ ឬដទៃទៀត ឬដោយការកេងប្រវ័ញ្ចក្នុងកាលៈទេសៈបង្ខិតបង្ខំ ឬតាមរយៈការមិនអាចផ្តល់ការយល់ព្រមពិតប្រាកដរបស់បុគ្គលម្នាក់ ឬច្រើន"។

1231.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តសមស្របនូវលក្ខខណ្ឌនៃ"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ" នៅពេលបង្កើតការយល់ឃើញស្តីពីការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3420]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើតែក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និងពុំបានធ្វើការវាយតម្លៃលើលិខិតុបករណ៍អន្តរជាតិ[3421]។

1232.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានតម្រូវឱ្យយល់ឃើញអំពីការហាមឃាត់ជាក់លាក់នៃការរំលោភសេពសន្ថវៈសហព័ទ្ធក្នុងច្បាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ឡើយ ដោយសារលក្ខខណ្ឌសម្រាប់"អំពើអមនុស្សធម៌ដទៃទៀត"តម្រូវថាតើ អំពើនោះបានរំលោភបំពាន"សិទ្ធិជាមូលដ្ឋាន [...] និងមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែរ ឬយ៉ាងណា[3422]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការរំលោភសេពសន្ថវៈនៅគ្រប់បរិបទ គឺជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសិទ្ធិសេរីភាពដែលស្ថិតក្នុងចំណោមសិទ្ធិជាសារវន្តដទៃទៀតនោះ[3423]។

1233.សហមេធាវីនាំមុខបានឆ្លើយតបផងដែរថា បើទោះបីពុំមានកាតព្វកិច្ចក្នុងការពិចារណាច្បាស់លាស់លើនីត្យានុកូលភាពនៃអំពើជាក់លាក់ក៏ដោយ[3424] ក៏ការរំលោភសេពសន្ថវៈសហព័ទ្ធគឺជាអំពើខុសច្បាប់ក្រោមច្បាប់ជាតិ និងអន្តរជាតិក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងបើទោះបីជាករណីលើកលែងសម្រាប់ការរំលោភសេពសន្ថវៈសហព័ទ្ធមានអត្ថិភាពក៏ដោយ ក៏ពុំអាចអនុវត្តបានចំពោះ"របបនៃការរួមភេទដោយបង្ខំដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីនេះដែរ"[3425]។

1234.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការវាយតម្លៃលើ"អនីត្យានុកូលភាពផ្លូវការអន្តរជាតិ" ពុំមែនជាការអនុវត្តន៍ក្នុងការបង្ហាញនូវការហាមឃាត់នៃបទឧក្រិដ្ឋនោះទេ ប៉ុន្តែជាវិធីសាស្ត្រមួយដែលក្នុងនោះបទឧក្រិដ្ឋនៃ

---

3420 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨១, ១២៨៤, ១២៨៨, ១២៩៤-១២៩៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨២, ១២៨៥។

3421 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨១, ១២៨៤, ១២៨៨, ១២៩៤-១២៩៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨២, ១២៨៥។

3422 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧៦ ដកស្រង់សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៦។

3423 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧៥-៦៧៩។

3424 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៦៨។

3425 សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៦៩-៥៨៣។

អំពើអមនុស្សធម៌ដទៃទៀត ត្រូវបានកំណត់ជាក់លាក់សមស្រប ដោយស្របតាមគោលការណ៍*សច្ចភាពនៃច្បាប់*។ អង្គជំនុំជម្រះសាលាដំបូងពុំមានកាតព្វកិច្ចក្នុងការកំណត់ប្រភពនៃច្បាប់ដែលបង្ហាញនូវបទឧក្រិដ្ឋឯករាជ្យនៃការរំលោភសេពសន្ថវៈនៃការរៀបអាពាហ៍ពិពាហ៍ឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា នេះគឺជាវិធីសាស្ត្រត្រឹមត្រូវនោះ ត្រូវបដិសេធចោល[3426]។

1235.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងពុំបានធ្វើការវាយតម្លៃអំពីនីត្យានុកូលភាពក្នុងលក្ខណៈដូចបានពិពណ៌នាដោយ ខៀវ សំផន នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ពុំមានលក្ខខណ្ឌតម្រូវថា ការរំលោភសេពសន្ថវៈដែលជាប្រភេទជាក់លាក់នៃអំពើមូលដ្ឋានត្រូវបានទទួលស្គាល់ថា បានស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋក្នុងឆ្នាំ ១៩៧៥[3427]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការកំណត់និយមន័យនៃការរំលោភសេពសន្ថវៈ"ដូចការលើកឡើងដោយសហព្រះរាជអាជ្ញា គឺត្រូវបានពន្លាតហួសពីការយល់ដឹងនូវអំពើនេះនៅត្រឹមឆ្នាំ ១៩៧៥ ថា ជាការដាក់បញ្ចូលអង្គជាត"។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តការកំណត់និយមន័យដែលបានលើកឡើងខាងលើថាជា ជំហានដំបូងក្នុងការវាយតម្លៃថាតើ ការរំលោភសេពសន្ថវៈដែលជាអំពើអមនុស្សធម៌ដទៃទៀត ត្រូវបានប្រព្រឹត្តឡើង ដែរ ឬយ៉ាងណា និងបានកំណត់ថា បុរសពុំអាចជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានទេ[3428]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហាថាតើ អំពើតែមួយនេះអាចត្រូវបានចាត់ទុកថា ជាអំពើហិង្សាផ្លូវភេទក្នុងកម្រិតធ្ងន់ធ្ងរដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា បញ្ហាជាប់ពាក់ព័ន្ធតែមួយក្នុងការវាយតម្លៃ គឺថាតើអំពើនោះបានបំពេញតាមការកំណត់និយមន័យនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[3429]។ ដូចបានគូសបង្ហាញខាងដើម ការវាយតម្លៃលើអំពើដែលរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់បុគ្គល ដូចបានកំណត់ក្រោមលិខិតុបករណ៍អន្តរជាតិ គឺជាការកម្រិតមួយទៅលើការបកស្រាយនូវអំពើអមនុស្សធម៌ដទៃទៀត[3430]។

1236.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវិភាគលើសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពានតាមរយៈការរួមដំណេកអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ពិត

[3426] *សូមមើលខាងលើ* ផ្នែក VII.ធ.១។

[3427] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨-៧៣០។

[3428] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១។

[3429] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣១។

[3430] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៤។

ណាស់ អំពើមូលដ្ឋាននៃការរួមភេទដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ជាអប្បបរមា ត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាការរំលោភបំពានលើសិទ្ធិមូលដ្ឋាន។ ដូចបានពិភាក្សា ការរំលោភសេពសន្ថវៈតាមប្រវត្តិសាស្ត្រត្រូវបានហាមឃាត់ក្នុងច្បាប់អន្តរជាតិយ៉ាងជាក់លាក់ក្នុងក្រម Lieber ឆ្នាំ ១៨៦៣[3431] និងដោយប្រយោលក្នុងបទប្បញ្ញត្តិទីក្រុងឡាអេក្នុងឆ្នាំ ១៨៩៩ និង ១៩០៧[3432] និងជាបទឧក្រិដ្ឋជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[3433]។ បន្ថែមលើនេះ អនុសញ្ញា IV ទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលកម្ពុជាគឺជាប្រទេសហត្ថលេខីនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានចែងថា “ស្ត្រីត្រូវតែបានការពារយ៉ាងពិសេសពីការវាយប្រហារណាមួយលើសេចក្តីថ្លៃថ្នូររបស់ពួកគេ ជាពិសេសពីការរំលោភសេពសន្ថវៈ ពេស្យាចារដោយបង្ខំ ឬការបន្ទាបបន្ថោកគ្រប់ទម្រង់”[3434]។ បន្ថែមលើនេះ ការរួមភេទដោយបង្ខំគឺជាទម្រង់នៃការប្រព្រឹត្តដោយឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ដែលត្រូវ

[3431] សេចក្តីណែនាំដល់រដ្ឋាភិបាលនៃកងទ័ពរបស់សហរដ្ឋអាមេរិកក្នុងសមរភូមិដែលត្រូវបានរៀបចំដោយ Francis Lieber ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាបទបញ្ជាទូទៅលេខ ១០០ ដោយប្រធានាធិបតី Abraham Lincoln ទីក្រុង Washington D.C. ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៨៦៣ (“Lieber Code”) មាត្រា ៤៤ ចែងថា៖

“រាល់អំពើហិង្សាអសីលធម៌ដែលត្រូវបានប្រព្រឹត្តទៅលើបុគ្គលក្នុងប្រទេសដែលត្រូវបានឈ្លានពាន មានដូចជា ការរំលោភសេពសន្ថវៈ ការធ្វើឱ្យរបួស ពិការ ឬសម្លាប់ជនស៊ីវិលនោះ ត្រូវបានហាមឃាត់ក្រោមការដាក់ទណ្ឌកម្មប្រហារជីវិត ឬការដាក់ទណ្ឌកម្មធ្ងន់ធ្ងរដទៃទៀតដែលអាចគ្រប់គ្រាន់សម្រាប់ភាពធ្ងន់ធ្ងរនៃបទល្មើសនោះ។ ទាហាន មន្ត្រី ឬឯកជន ក្នុងការប្រព្រឹត្តអំពើហិង្សា និងពុំស្តាប់បង្គាប់ថ្នាក់លើមិនឱ្យប្រព្រឹត្តនោះ អាចត្រូវបានប្រហាជីវិតស្របច្បាប់នៅហ្នឹងកន្លែងរបស់មេដឹកនាំ”។

[3432] អនុសញ្ញា (២) ទាក់ទងទៅនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើទឹកដី និងវឌ្ឍសម្ព័ន្ធ៖ បទបញ្ជាពាក់ព័ន្ធទៅនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើទឹកដី ទីក្រុងឡាអេ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ មាត្រា ៤៦។ អនុសញ្ញា (៣) ពាក់ព័ន្ធទៅនឹងការបើការប្រទូសរ៉ាយ ទីក្រុងឡាអេ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ មាត្រា ៤៦ ដែលនីមួយៗបានការពារ“កិត្តិយសគ្រួសារ និងសិទ្ធិ” របស់ប្រជាជននៃទឹកដីដែលត្រូវបានត្រួតត្រា។

[3433] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត ការដាក់ទណ្ឌកម្មលើបុគ្គលដែលមានពិរុទ្ធនៃបទឧក្រិដ្ឋសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងមនុស្សជាតិ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ (១៩៤៦) ៣ ក្រុមប្រឹក្សាគ្រប់គ្រងផ្លូវការ Gazette សម្រាប់ប្រទេសអាល្លឺម៉ង់ ៥០-៥៥ (“ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង”) មាត្រា (៣)(គ)។

[3434] មាត្រា ២៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម (អនុសញ្ញាទីក្រុងហ្សឺណែវទី IV) ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឯកសារលេខ 75 UNTS 287។

បានហាមឃាត់ក្នុងច្បាប់អន្តរជាតិ និងក្នុងកម្ពុជា ចាប់តាំងពីពេលចូលជាសមាជិកអង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៥៥ និងបានទទួលយកជាផ្លូវការនូវអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៥៨[3435]។

1237.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បរិបទនៃការរៀបអាពាហ៍ពិអាហ៍ដែលក្នុងនោះ អំពើដែលចោទជាបញ្ហានោះបានកើតឡើង ពុំជាប់ពាក់ព័ន្ធទៅនឹងការកំណត់លើបញ្ហាថាតើ សិទ្ធិជាមូលដ្ឋានត្រូវបានរំលោភបំពាន ដែរ ឬយ៉ាងណាឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងគោលជំហរដែលបានអនុម័តដោយតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សក្នុងរឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* ដែលបានបញ្ជាក់ថា នៅក្នុងប្រព័ន្ធច្បាប់ដូចជាច្បាប់ព្រហ្មទណ្ឌ “មានធាតុផ្សំដែលជៀសពុំរួចពីការបកស្រាយដោយតុលាការ [...] ដែលចាំបាច់សម្រាប់ការបំភ្លឺចំណុចដែលមានមន្ទិលសង្ស័យ និងសម្រាប់ការសម្របសម្រួលទៅនឹងការប្រែប្រួលនៃកាលៈទេសៈ”[3436]។ តុលាការអឺរ៉ុបនេះបានយល់ឃើញថា មានការបង្ហាញនូវការវិវឌ្ឍន៍ដែលស៊ីសង្វាក់ជាមួយនឹងភាពចាំបាច់នៃបទល្មើស និងច្បាប់ព្រហ្មទណ្ឌតាមរយៈការបកស្រាយដោយតុលាការដែលចាត់ទុកការរំលោភសេពសន្ថវៈនៃការរៀបអាពាហ៍ពិពាហ៍ជាទូទៅថា ស្ថិតក្នុងវិសាលភាពនៃបទល្មើសនៃការរំលោភសេពសន្ថវៈ[3437]។ បន្ថែមលើនេះ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានយល់ឃើញថា “ចរិតលក្ខណៈបន្ទាបបន្ថោកនៃការរំលោភសេពសន្ថវៈ ជាចាំបាច់បានបង្ហាញច្បាស់លាស់”ថា ការដាក់ពិរុទ្ធភាពលើជនជាប់ចោទពុំអាចត្រូវបាននិយាយថា ជាការផ្ទុយទៅនឹងកម្មវត្ថុ និងគោលបំណងនៃមាត្រា ៧ នៃ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដែលធានាថា គ្មានបុគ្គលណាម្នាក់ត្រូវបានដាក់ឱ្យស្ថិតក្រោមការចោទប្រកាន់ ការដាក់ពិរុទ្ធភាព ឬការដាក់ទណ្ឌកម្មតាមអំពើចិត្ត[3438]។ បើទោះបីជាការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នេះ គឺជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ជាជាងបទល្មើសនៃ“ការរំលោភសេពសន្ថវៈ”ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំអាចលើកឡើងដោយសមហេតុផលថា ការរួមភេទដោយបង្ខំពុំមែនជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានយ៉ាងទូលំទូលាយនោះបានឡើយ។

---

[3435] មាត្រា ៥ នៃសេចក្តីប្រកាសជាសកល UDHR ចែងថា “គ្មានបុគ្គលណាម្នាក់ត្រូវបានដាក់ឱ្យស្ថិតក្រោមការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬទណ្ឌកម្ម” និងមាត្រា ៣ ជារួមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ I ដល់ IV បានហាមឃាត់អំពើឃោរឃៅ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់បុគ្គល។

[3436] រឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៣៦។

[3437] រឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៤៣។

[3438] រឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៤៤។

- *អត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា(ejusdem generis)*

1238.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានអនុវត្តនូវវិធានស្ដីពីអត្ថិភាពនៃចរិតលក្ខណៈប្រហាក់ប្រហែលគ្នា នៅពេលពិចារណាលើបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3439]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើរឿងក្ដីយុត្តិសាស្ត្ររបស់តុលាការដទៃទៀត និងតុលាការព្រហ្មទណ្ឌនានា អង្គជំនុំជម្រះនឹងបានកំណត់ថាអំពើដែលត្រូវបានចោទប្រកាន់អំពីការរួមដំណេកដោយបង្ខំពុំមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើដទៃទៀតដែលស្ថិតក្រោមវិសាលភាពនៃអំពើអមនុស្សធម៌ដទៃទៀតឡើយ[3440]។

1239.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំពើនេះមានលក្ខណៈ និងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3441]។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពធ្ងន់ធ្ងរត្រូវបានគាំទ្រដោយការសម្រេចរបស់អង្គបុរេជំនុំជម្រះនៃតុលាការ ICC ក្នុងរឿងក្ដី *Ongwen* ដែលថា ការរួមភេទដោយបង្ខំក្នុងការរៀបអាពាហ៍ពិពាហ៍អាចស្មើនឹងការរំលោភសេពសន្ថវៈ[3442] ដូចគ្នាទៅនឹងការយល់ឃើញរបស់តុលាការ SCSL ក្នុងរឿងក្ដី *AFRC* និង *RUF* ដែលថា នេះគឺជាឧក្រិដ្ឋកម្មសង្គ្រាមដែលរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់បុគ្គល និងជាអំពើអមនុស្សធម៌ដទៃទៀតនៃទាសភាពផ្លូវភេទ[3443]
។

1240.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការពិចារណាលើបញ្ហានៃភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៃអំពើ នៅពេលគូសបង្ហាញនូវបទដ្ឋានគតិយុត្តដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនោះ។ អ្វីដែលសំខាន់គឺថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក

---

[3439] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩០។

[3440] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩០។

[3441] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៧៧។

[3442] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨២ យោងទៅលើសេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី *Ongwen* (ICC), សាលដីការឿងក្ដី *AFRC* (SCSL) និងសាលដីការឿងក្ដី *RUF* (SCSL)។

[3443] សាលដីការឿងក្ដី *AFRC* (SCSL) កថាខណ្ឌ ១៨១-២០២។ សាលដីការឿងក្ដី *RUF* (SCSL) កថាខណ្ឌ ៧៣៦-៧៥០។

ការវាយតម្លៃនេះជាបញ្ហាអង្គហេតុ និងបានបង្កើតការយល់ឃើញផ្នែកអង្គច្បាប់[3444]។ នេះអាចជាកំហុសក្នុងការវិភាគលើការដកស្រង់ក្នុងផ្នែកនៃសាលក្រមដែលដោះស្រាយលើច្បាប់ជាធរមាន។

1241.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានយល់ឃើញពីដំបូងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការព្យាយាមកំណត់“ធាតុផ្សំ”នៃបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ និងតាមរយៈផលវិបាកនៃកំហុសនេះ អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើកាតព្វកិច្ចក្នុងការបញ្ជាក់សមស្របនូវអំពើក្នុងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើបញ្ហាថាតើ សិទ្ធិជាមូលដ្ឋានត្រូវបានរំលោភបំពានតាមរយៈអំពើដែលត្រូវបានចោទប្រកាន់នោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មានភាពសមហេតុផលប្រហាក់ប្រហែលគ្នាដែលអាចនាំឱ្យអង្គជំនុំជម្រះសាលាដំបូងមិនធ្វើការពិចារណាលើរឿងក្តីយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ស្តីពីភាពធ្ងន់ធ្ងរនៃអំពើនោះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើរឿងក្តីយុត្តិសាស្ត្រនៅពេលវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3445]។

1242.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំពើហិង្សាផ្លូវភេទតាមទម្រង់ផ្សេងៗ ត្រូវបានទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិថា ជា“អំពើអមនុស្សធម៌ដទៃទៀត”។ រឿងក្តីដំបូងរបស់តុលាការ ICTY *រដ្ឋអាជ្ញា ទល់នឹង Tadić* បានបញ្ជាក់ថា អំពើហិង្សាផ្លូវភេទលើបុរស ដូចជា ការធ្វើកាយវិកលកម្ម ការរួមភេទតាមមាត់ និងការបន្ទាបបន្ថោក គឺជាអំពើអមនុស្សធម៌ និងជាអំពើឃោរឃៅដែលជាឧក្រិដ្ឋកម្មសង្គ្រាម និងជាអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3446]។ ឧទាហរណ៍ដទៃទៀតនៃអំពើដែលមានសមាសភាគផ្លូវភេទដែលត្រូវបានដាក់ឱ្យស្ថិតក្រោមវិសាលភាពនៃអំពើអមនុស្សធម៌ដទៃទៀត បានរួមបញ្ចូលនូវការធ្វើឱ្យអស់លទ្ធភាពបង្កើតកូន ឬការធ្វើពិសោធន៍ទៅលើមុខនាទីបន្តពូជ[3447]។

---

[3444] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧-៣៦៩៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[3445] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៧។

[3446] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Tadić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-94-1-T មតិ និងសាលក្រមថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ (“សាលក្រមរឿងក្តី *Tadić* (ICTY)”)។

[3447] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Brandt និងជនជាប់ចោទដទៃទៀត* (“រឿងក្តីផ្នែកវេជ្ជសាស្ត្រ”) សាលក្រម ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៤៦ បោះពុម្ពសាឡើងវិញក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅមុខតុលាការព្រហ្មទណ្ឌយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ភាគ I ទំព័រ ១៣, ភាគ II ទំព័រ ១៧៧, ២២៦, ២៣៨-២៣៩, ២៧៨-២៧៩។

តុលាការ ICTR បានកំណត់អំពើហិង្សាផ្លូវភេទថា ជា"អំពើដែលមានលក្ខណៈផ្លូវភេទ និងត្រូវបានប្រព្រឹត្ត ឡើងលើបុគ្គលដែលស្ថិតក្រោមកាលៈទេសៈនៃការបង្ខិតបង្ខំ"[3448]។ ផ្អែកតាមការកំណត់និយមន័យនេះ តុលាការ ICTR បានយល់ឃើញថា អំពើហិង្សាផ្លូវភេទដែលពុំពាក់ព័ន្ធទៅនឹងរូបកាយ ដូចជា ការបង្ខំស្ត្រី និងក្មេងស្រីឱ្យធ្វើលំហាត់ប្រាណស្រាតក្នុងទីសាធារណៈ អង្គុយស្រាតក្នុងភក់ ឬដើរស្រាតជាក្បួនក្នុងទីសាធារណៈ ស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋនៃ"អំពើអមនុស្សធម៌ដទៃទៀត"[3449]។ តុលាការ ICTR បានទទួលស្គាល់បន្ថែមទៀតថា អំពើហិង្សាផ្លូវភេទលើសាកសព ដូចជា ការគ្រៀវ ការធ្វើកាយវិកលកម្ម និងការកាត់ប្រដាប់ភេទដាក់តាំងបង្ហាញសាធារណៈ ស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋនៃអំពើ"អមនុស្សធម៌ដទៃទៀត"[3450]។ តុលាការ ICTY បានទទួលស្គាល់ថា ពេស្យាចារដោយបង្ខំអាចបង្កើតបានជាប្រភេទមួយនៃអំពើអមនុស្សធម៌ដទៃទៀត[3451] ដោយសារនេះជា"ការវាយប្រហារធ្ងន់ធ្ងរពុំអាចប្រកែកបានលើសេចក្តីថ្លៃថ្នូររបស់មនុស្សស្របតាមលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស"[3452]។

1243.តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត និងតុលាការព្រហ្មទណ្ឌនានា ដូចជាតុលាការ SCSL និង ICC បានបង្ហាញអំពើហិង្សាផ្លូវភេទខុសប្លែកគ្នាពី"អំពើអមនុស្សធម៌ដទៃទៀត" ដែលមានសមាសភាគពាក់ព័ន្ធភេទ ឬផ្លូវភេទ ដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពីព្រោះលក្ខន្តិកៈរបស់តុលាការនេះបានចាត់ទុកអំពើ

---

[3448] សាលក្រមរឿងក្តី *Akayesu* (ICTR) កថាខណ្ឌ ៦៨៨។

[3449] សាលក្រមរឿងក្តី *Akayesu* (ICTR) កថាខណ្ឌ ៦៨៨, ៦៩៧។

[3450] *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Niyitegeka* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-96-14-T សាលក្រមនិងការប្រកាសទោសថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៣ ("សាលក្រមរឿងក្តី *Niyitegeka* (ICTR)") កថាខណ្ឌ ៤៦២, ៤៦៣, ៤៦៧ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការជម្រុញឱ្យកាត់ និងដោតប្រដាប់ភេទលើបង្គោលស្រួច និងការបញ្ជាឱ្យដោះសម្លៀកបំពាក់សាកសពស្ត្រីជនជាតិ Tutsi និងការស៊កចូលជាមួយឈើស្រួចក្នុងប្រដាប់ភេទរបស់ស្ត្រីនោះ គឺជា"អំពើអមនុស្សធម៌ដទៃទៀត"។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-98-44A-T សាលក្រម និងការប្រកាសទោសថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ ("សាលក្រមរឿងក្តី *Kajelijeli* (ICTR)") កថាខណ្ឌ ៩៣៥-៩៣៦ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងបង្ហាញថា អំពើនៃការកាត់ និងការលិឍដោះរបស់ស្ត្រីជនជាតិ Tutsi "មានកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងអំពើដទៃទៀតដែលរៀបរាប់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងចុងក្រោយបានបញ្ជាក់ថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ជនជាប់ចោទត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលសម្រាប់អំពើនោះ។

[3451] សាលក្រមរឿងក្តី *Kupreškić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៥៦៦។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-30/1-T សាលក្រមថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ២០៨។

[3452] សាលក្រមរឿងក្តី *Kupreškić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៥៦៦។

ហិង្សាផ្លូវភេទជាបទល្មើសឯករាជ្យពី"អំពើអមនុស្សធម៌ដទៃទៀត"[3453]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី AFRC បានបញ្ជាក់ថា ការរៀបរាប់យ៉ាងវែងនៃឈ្មោះបទឧក្រិដ្ឋផ្លូវភេទក្នុងលក្ខន្តិកៈនៃតុលាការ SCSL ពុំបានរារាំងបទឧក្រិដ្ឋពាក់ព័ន្ធភេទ ឬផ្លូវភេទនៃអំពើ"អមនុស្សធម៌ដទៃទៀត" ដោយសារនេះគឺជាប្រភេទមួយនៃបទល្មើសដែលពុំគប្បីបកស្រាយតឹងរ៉ឹងឡើយ[3454]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពុំបានរៀបរាប់ឈ្មោះនៃអំពើហិង្សាផ្លូវភេទណាមួយក្រៅតែពីការរំលោភសេពសន្ថវៈថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3455] និងវិសាលភាពនៃបទឧក្រិដ្ឋពាក់ព័ន្ធភេទ និងផ្លូវភេទដែលអាចស្ថិតក្នុងវិសាលភាពនៃ"អំពើអមនុស្សធម៌ដទៃទៀត" ក្នុង អ.វ.ត.ក. មានលក្ខណៈធំធេងជាងក្នុងតុលាការ SCSL និង ICC។

1244. ក្នុងការកំណត់ថាតើ លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរត្រូវបានបំពេញ ដែរ ឬយ៉ាងណា តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានាបានទទួលស្គាល់ថា ការស្រាវជ្រាវត្រូវបានធ្វើឡើងតាមករណីជាក់ស្តែងនីមួយៗពាក់ព័ន្ធទៅនឹងលក្ខណៈ និងបរិបទនៃអំពើ កាលៈទេសៈផ្ទាល់ខ្លួននៃជនរងគ្រោះ និងការប៉ះពាល់ផ្លូវចិត្ត និងរូបកាយនៃអំពើលើជនរងគ្រោះ[3456]។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICC ក្នុងរឿងក្តី *Ntaganda* បានយោងទៅលើ"ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនៃអំពើហិង្សាផ្លូវភេទ" ដោយគ្មានធ្វើការបែងចែកភាពខុសគ្នារវាងការរំលោភសេពសន្ថវៈ ជាមួយនឹងអំពើហិង្សាផ្លូវភេទដទៃទៀតឡើយ[3457]។ តាមការអនុវត្ត

---

[3453] សំអាងហេតុដែលបានផ្តល់ដោយតុលាការ SCSL និង ICC សម្រាប់ការបង្ហាញភាពខុសគ្នារវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាមួយនឹងអំពើហិង្សាផ្លូវភេទដទៃទៀត គួសបង្ហាញនូវការជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋភាពដាច់ដោយឡែកនៃអំពើហិង្សាផ្លូវភេទលើដែលស្ថិតក្នុងប្រភេទនៃបទឧក្រិដ្ឋពាក់ព័ន្ធភេទ និងផ្លូវភេទដែលត្រូវបានចាត់ទុកថា ជា"អំពើអមនុស្សធម៌ដទៃទៀត"។ *សូមមើល* សាលដីការឿងក្តី *AFRC* កថាខណ្ឌ ១៨៦ ដែលក្នុងនោះអង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *AFRC* បានទទួលស្គាល់ថាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជា"អំពើអមនុស្សធម៌ដទៃទៀត" តែក្នុងករណីដែលអំពើនេះបានបង្កនូវព្យសនកម្មលើជនរងគ្រោះដែលមានលក្ខណៈខុសប្លែកពីបទល្មើសជាក់លាក់នៃទាសភាពផ្លូវភេទ និងហិង្សាផ្លូវភេទ។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ២៧៤៧-២៧៥១ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC បានបញ្ជាក់*ក្នុងចំណោមនោះ*ថា ព្យសនកម្មដែលបានទទួលរងដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពន្លាតហួសព្យសនកម្មដែលបានបង្កដោយទាសភាពផ្លូវភេទ ការរំលោភសេពសន្ថវៈ និងហិង្សាផ្លូវភេទ និងមានលក្ខណៈខុសប្លែកពីបទឧក្រិដ្ឋជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[3454] សាលដីការឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៨៥-១៨៦។

[3455] មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[3456] សាលដីការឿងក្តី *AFRC* (SCSL) កថាខណ្ឌ ១៨៤។ សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Katanga និង Ngudjolo* (ICC) កថាខណ្ឌ ៤៤៩។ សាលដីការឿងក្តី *Vasiljevic* (ICTY) កថាខណ្ឌ ១៦៥។

[3457] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះសាលាដំបូង VI (ICC) សំណុំរឿងលេខ ICC-01/04-02/06 សាលក្រមប្រកាសទោស ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ("សាលក្រមប្រកាសទោសរឿងក្តី *Ntaganda* (ICC)") កថាខណ្ឌ ៩៦។

ន៍ តុលាការព្រហ្មទណ្ឌអន្តរជាតិ បន្ទាប់ពីបានយល់ឃើញនូវអំពើដែលត្រូវបានពិពណ៌នាថា ជាអំពើហិង្សាផ្លូវភេទ និងបានកើតឡើងនោះ ថាជាបញ្ហាអង្គហេតុ បានបញ្ជាក់ជាទូទៅថា អំពើនេះមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់អាចបង្កើតបានជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់វាយតម្លៃបន្ថែមទៀតឡើយ[3458]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការបញ្ជាក់បែបនេះជាទូទៅត្រូវបានធ្វើឡើងស្របជាមួយនឹងការយល់ឃើញពាក់ព័ន្ធទៅនឹងការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបានបង្កទៅលើជនរងគ្រោះ រួមទាំងសាក្សី និងសហគមន៍ដែលទទួលរងការប៉ះពាល់នោះ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kajelijeli* (ICTR) បានបញ្ជាក់ថា អំពើដែលត្រូវបានកំណត់ថាជាអំពើហិង្សាផ្លូវភេទ មាន "លក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើដទៃទៀតដែលបានរៀបរាប់ជាក់លាក់ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានបង្កយ៉ាងច្បាស់លាស់នូវការរងទុក្ខផ្លូវចិត្តធ្ងន់ធ្ងរលើសមាជិកនៃសហគមន៍ Tutsi ដែលបានសង្កេតឃើញនោះ"[3459]។ ការយល់ឃើញនេះបានបង្កើតនូវការចាប់អារម្មណ៍ថា ភាពធ្ងន់ធ្ងរនៃអំពើ និងភាពធ្ងន់ធ្ងរនៃការរងទុក្ខដែលបានបង្កឡើងនោះមានទំនាក់ទំនងគ្នាទៅវិញទៅមក។

1245.ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dorđević* អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ទំនងជាបានពិចារណា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*ទៅលើភាពធ្ងន់ធ្ងរនៃអំពើហិង្សាផ្លូវភេទដែលបង្កើតបានជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពលើជនជាប់ចោទសម្រាប់ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះឧទ្ធរណ៍នេះចុងក្រោយបានកំណត់ថា អំពើហិង្សាផ្លូវភេទ"បានឈានដល់កម្រិតធ្ងន់ធ្ងរដូចគ្នា"ទៅនឹងបទឧក្រិដ្ឋដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះ"អំពើហិង្សាផ្លូវភេទតាមការកំណត់និយមន័យគឺជាការរំលោភបំពានលើបូរណភាពផ្លូវចិត្ត ឬរូបកាយរបស់បុគ្គល" និងពីព្រោះ"អំពើហិង្សាផ្លូវភេទដែលចោទជាបញ្ហានេះ ត្រូវបានប្រព្រឹត្តទៅលើស្ត្រីវ័យក្មេងដោយចារីជាច្រើននាក់ និងក្នុងបរិបទទូទៅនៃការភ័យ

[3458] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Niyitegeka* (ICTR) កថាខណ្ឌ ៤៦៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Kajelijeli* (ICTR) កថាខណ្ឌ ៩៣៥-៩៣៦។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *AFRC* (SCSL) កថាខណ្ឌ ២០០ ដែលក្នុងនោះ តុលាការឧទ្ធរណ៍ក្នុងរឿងក្តី *AFRC* បានពន្យល់ថា ខ្លួនបានពិចារណាលើអំពើ និងផលប៉ះពាល់ និងយល់ឃើញថា អំពើនោះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដោយពុំចាំបាច់ផ្តល់សេចក្តីលម្អិតបន្ថែមអំពីការពិភាក្សាសម្រេចទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនេះឡើយ។

[3459] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Kajelijeli* (ICTR) កថាខណ្ឌ ៩៣៥ (អំពើដែលត្រូវបានកំណត់នោះ រួមមាន "ការកាត់ដោះស្ត្រី និងការលិឍ និងដោតប្រដាប់ភេទនេះទៅនឹងបង្គោលស្រួច")។ *សូមមើល* សាលក្រមរឿងក្តី *Niyitegeka* (ICTR) កថាខណ្ឌ ៤៦៥ ("អង្គជំនុំជម្រះយល់ឃើញថា អំពើនោះ [...] មានលក្ខណៈប្រហាក់ប្រហែលទៅនឹងអំពើដែលបានរៀបរាប់នៅក្នុងមាត្រា និងបង្កការរងទុក្ខផ្លូវចិត្តដល់ជនស៊ីវិល ជាពិសេស ជនជាតិ Tutsi ...")។

ខ្លាច ការបំភិតបំភ័យ និងការបៀតបៀន”[3460]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើហិង្សាផ្លូវភេទនៅពេលបង្ហាញជានិច្ចកាលត្រូវបានយល់ឃើញថា មានលក្ខណៈធ្ងន់ធ្ងរដូចអំពើដទៃទៀតដែលត្រូវបានចោទប្រកាន់ជាក់លាក់ដែរ។

### iii. សេចក្តីសន្និដ្ឋាន

1246.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបានបដិសេធការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាអំពើអមនុស្សធម៌ដទៃទៀត។ ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីនីត្យានុកូលភាពនៃ“ការរំលោភសេពសន្ថវៈ” និង“អំពើហិង្សាផ្លូវភេទ” អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ធាតុផ្សំនៃបទឧក្រិដ្ឋសម្រាប់អំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អំពើដែលត្រូវបានចោទប្រកាន់នោះគឺជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ និងបានបញ្ជាក់ថា អំពើនេះត្រូវបានចោទប្រកាន់ដូចគ្នាពាក់ព័ន្ធទៅនឹងបុរស និងស្ត្រី និងថា អំពើនេះដែលត្រូវបានពិពណ៌នាត្រឹមត្រូវថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ថិតក្នុងវិសាលភាពនៃអំពើមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបានបដិសេធការជំទាស់ទាំងអស់របស់ ខៀវ សំផន ទាក់ទងទៅនឹងនីត្យានុកូលភាពនៃអំពើនេះ។

## ខ. ការយល់ឃើញផ្នែកអង្គហេតុស្តីពីបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍

### i. សេចក្តីផ្តើម

1247.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គោលបំណងនៃគោលនយោបាយបទបញ្ជារៀបអាពាហ៍ពិពាហ៍ គឺដើម្បីបង្កើនចំនួនប្រជាជន[3461] និងការគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទក្រៅការរៀបអាពាហ៍ពិពាហ៍នោះ[3462]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដែលបង្ហាញថា មានអត្ថិភាពនៃគោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែបានយល់ឃើញថា តាមជាក់ស្តែង នេះពុំត្រូវបានអនុវត្ត និងថា បុគ្គលជាទូទៅត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុង

---

[3460] សាលដីការឿងក្តី *Dorđević* (ICTY) កថាខណ្ឌ ៩០០។

[3461] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៨, ៣៦៩០។

[3462] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៩។

បរិយាកាសបង្ខិតបង្ខំ រួមទាំងហានិភ័យដល់ស្លាប់[3463]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពិធីរៀបអាពាហ៍ពិពាហ៍ជាធម្មតាបានកើតឡើងដោយគ្មានការជាប់ពាក់ព័ន្ធជាមួយនឹងប្រពៃណី ឬសមាជិកគ្រួសារ និងជាញឹកញាប់បានកើតឡើងជាសមូហភាពក្នុងទ្រង់ទ្រាយធំ[3464]។ បន្ទាប់ពីពិធីនេះ បុគ្គលត្រូវបានតាមដានដើម្បីឱ្យច្បាស់ថា ការរៀបអាពាហ៍ពិពាហ៍នោះ ត្រូវបានរួមដំណេក[3465]។ ការខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍មានហានិភ័យដល់ស្លាប់ ឬការអប់រំកែប្រែឡើងវិញ ដូច្នេះហើយ បានជាប្ដីប្រពន្ធត្រូវលាក់បាំងការមិនរួមដំណេកនោះ[3466]។ សេចក្ដីណែនាំឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ ត្រូវបានចេញដោយថ្នាក់លើបញ្ជាទៅរដ្ឋអំណាចថ្នាក់ក្រោម[3467] និងបន្ទាប់មកត្រូវបានផ្សព្វផ្សាយទៅថ្នាក់ភូមិភាគ តំបន់ ឃុំ និងភូមិតាមរយៈកិច្ចប្រជុំ ឬវគ្គរៀនសូត្រនានា[3468]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ខៀវ សំផន បានជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការផ្សព្វផ្សាយបន្តនូវសេចក្ដីណែនាំស្ដីពីការអនុវត្តន៍នៃគោលនយោបាយការរៀបអាពាហ៍ពិពាហ៍[3469]។

1248.ខៀវ សំផន បានលើកការជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីគោលបំណងនៃគោលនយោបាយនោះ ព្រឹត្តិការណ៍នានានៃបទបញ្ជារៀបអាពាហ៍ពិពាហ៍ និងការអនុវត្តន៍គោលនយោបាយ។ អំណះអំណាងនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយខាងក្រោម។

### ii. គោលបំណងនៃគោលនយោបាយ

1249.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គោលបំណងមួយក្នុងចំណោមគោលបំណងនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍គឺដើម្បីសម្រួលដល់ការបង្កើនចំនួនប្រជាជន[3470] និងផ្សេងទៀតគឺជាការគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទនៅក្រៅការរៀបអាពាហ៍ពិពាហ៍នោះ[3471]។ ខៀវ សំផន បានលើកការជំទាស់ទៅនឹងការយល់

[3463] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧-៣៦២៥។

[3464] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣១-៣៦៣២, ៣៦៣៩-៣៦៤០, ៣៦៩១។

[3465] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦៤១-៣៦៤៤, ៣៦៦០, ៣៦៩៦។

[3466] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[3467] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៤។

[3468] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

[3469] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨, ៤២៧០, ៤៣០៤។

[3470] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៨។

[3471] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៩-៣៥៦៣។

ឃើញទាំងនេះ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើលក្ខណៈផ្ទុយគ្នារវាងការយល់ឃើញទាំងពីរនេះ។

- *ការបង្កើនចំនួនប្រជាជន*

1250.អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា គោលបំណងមួយក្នុងចំណោមគោលបំណងនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍ គឺដើម្បីសម្រួលដល់ការបង្កើនចំនួនប្រជាជន[3472]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយចង្អុលបង្ហាញទៅលើបទឧទ្ទេសនាមរបស់កម្មាភិបាលជាន់ខ្ពស់រួមទាំង ខៀវ សំផន ថា គោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន និងបង្កើនចំនួនប្រជាជនដើម្បីអភិវឌ្ឍកម្ពុជាឱ្យក្លាយជាប្រទេសឯករាជ្យ និងរឹងមាំផ្នែកសេដ្ឋកិច្ច[3473]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា បើទោះបីជាពុំត្រូវបានបញ្ជាក់ច្បាស់លាស់ក៏ដោយ ក៏គោលបំណងផ្សេងទៀតនៃការបង្កើនប្រជាជន គឺដើម្បីបង្កើនចំនួនទាហាន ជាពិសេសចាប់តាំងពីឆ្នាំ ១៩៧៧ នៅពេលស្ថានការណ៍តាមបណ្ដោយព្រំដែនវៀតណាមកាន់តែតានតឹងឡើង[3474]។ ដោយបានពិចារណាលើភស្តុតាងរបស់សាក្សីដែលជាកម្មាភិបាល អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គោលបំណងនៃការបង្កើនប្រជាជនតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានផ្សព្វផ្សាយទូទាំងប្រទេសតាមរយៈកិច្ចប្រជុំ និងវគ្គបណ្ដុះបណ្ដាលនានា[3475]។ បន្ថែមលើនេះ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននាក់បានបញ្ជាក់ថា ក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍នោះ ពួកគេបានប្ដេជ្ញាបង្កើតកូនជូនអង្គការដើម្បីបង្កើនប្រជាជន[3476]។

1251.ដំបូង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើឯកសារបក្សកុម្មុយនីស្តកម្ពុជា និងបទឧទ្ទេសនាមស្ដីពីការបង្កើនប្រជាជន ដោយហេតុថា ការលើកឡើងទាំងនេះបានផ្ដោតទៅលើការលើកកម្ពស់សុខភាព ពុំមែនជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[3477]។ ទីពីរ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងកម្មាភិបាលស្ដីពីការបង្កើនប្រជាជន និងថានេះជាការពុំស៊ីសង្វាក់គ្នាក្នុងការសំអាងទៅលើភស្តុតាង ខណៈពេលពុំអើពើទៅលើគោលការណ៍នៃការ

[3472] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៨, ៣៦៩០។

[3473] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៩។

[3474] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៧។

[3475] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

[3476] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

[3477] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៥។

ស្ម័គ្រចិត្ត[3478]។ ទីបី គាត់បានចោទប្រកាន់កំហុសក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានប្ដេជ្ញាបង្កើតកូនជូន*អង្គការ*[3479]។

ក) ការលើកឡើងរបស់បក្សកុម្មុយនីស្តកម្ពុជាស្ដីពីការបង្កើនប្រជាជន

1252.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "បក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា គោលបំណងរបស់ខ្លួនគឺដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន និងថា នេះបានអនុញ្ញាតឱ្យមានការបង្កើនប្រជាជន ដើម្បីអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាប្រទេសឯករាជ្យ និងរឹងមាំផ្នែកសេដ្ឋកិច្ច"[3480]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើឯកសារ និងបទឧទ្ទេសនាមរបស់ ប៉ុល ពត[3481] ខៀវ សំផន[3482] អៀង សារី[3483] និង នួន ជា[3484] ព្រមទាំងទស្សនាវដ្ដីទង់បដិវត្តចាប់តាំងពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨[3485]។

1253.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បានបំភ្លៃ និងមួលបង្កាច់"បទឧទ្ទេសនាម និងឯកសារបក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងការបង្កើនប្រជាជន ដែលពុំមានឯកសារណាមួយលើកឡើងពីគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[3486]។ ផ្ទុយទៅវិញ ឯកសារទាំងនេះបានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងសម្រេចគោលបំណងនៃការបង្កើនប្រជាជនតាមរយៈការលើកកម្ពស់លក្ខខណ្ឌរស់នៅ និងសុខភាពប្រជាជន មិនមែនតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ[3487]។

1254.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានខកខានក្នុងការពិចារណាលើចេតនាដែលបានលើកឡើងដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្រេចការបង្កើនប្រជាជនតាមរយៈការលើកក

---

[3478] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៥។

[3479] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៨-១២៣២។

[3480] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៩។

[3481] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥០។

[3482] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥១។

[3483] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥២។

[3484] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៣។

[3485] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៤-៣៥៥៥។

[3486] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៤។

[3487] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៤។

ម្ពស់លក្ខខណ្ឌរស់នៅ ប៉ុន្តែបានយល់ឃើញដោយសមហេតុផលថា សកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ពុំបានបង្ហាញថា នេះជាចេតនាពិតប្រាកដនោះទេ[3488]។

1255.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដោយហេតុថា បទឧទ្ទេសនាម និងឯកសារផ្សព្វផ្សាយដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង បានយោងទៅលើភាពចាំបាច់ក្នុងការបង្កើនប្រជាជនឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្នុងការជម្រុញភាពសំបូរសប្បាយសង្គម និងសេដ្ឋកិច្ច[3489] ទើបពុំមានឯកសារណាមួយយោងច្បាស់លាស់ទៅលើបទបញ្ញារៀបអាពាហ៍ពិពាហ៍ថា ជាមធ្យោបាយក្នុងការសម្រេចគោលដៅនោះឡើយ។ ពិតណាស់ ការលើកឡើងរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលពិនិត្យដាច់ដោយឡែកពីគ្នាហាក់បីដូចជាដើម្បីបង្កើនប្រជាជនតាមរយៈការលើកម្ពស់ជាទូទៅនូវសុខភាព ពុំមែនតាមរយៈបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍នោះឡើយ។ ជាឧទាហរណ៍ ក្នុងបទឧទេសនាមរបស់ ប៉ុល ពត គាត់បានអះអាងថា “យើងត្រូវបន្តខិតខំប្រឹងប្រែងលើកកម្ពស់លក្ខខណ្ឌនៃជីវិត និងសុខភាពប្រជាជន ពីព្រោះយើងសង្ឃឹមថា នឹងអាចបង្កើនប្រជាជនយើងពី ១៥ ទៅ ២០ លាននាក់ក្នុងរយៈ១០ឆ្នាំខាងមុខ ឬលើសពីនេះ”[3490]។ ក្នុងបទឧទ្ទេសនាមរបស់ ខៀវ សំផន ក្នុងខែ មេសា ឆ្នាំ ១៩៧៨ ខៀវ សំផន បាននិយាយប្រហាក់ប្រហែលគ្នានេះដែរនូវភាពចាំបាច់ក្នុងការ“លើកកម្ពស់លក្ខខណ្ឌការរស់នៅ និងបង្កើនឆាប់រហ័សនូវចំនួនប្រជាជន ខណៈពេលជាមួយគ្នានោះបានផ្តល់ការអប់រំជាមូលដ្ឋាននៃការគ្រប់គ្រង មនោគមវិជ្ជា និងនយោបាយដល់ប្រជាជន”[3491]។ បទឧទ្ទេសនាមរបស់ នួន ជា នៅក្នុងសន្និសីទសមាជិកសភាអាស៊ីនៅទីក្រុងប៉េកាំងកាលពីខែ តុលា ឆ្នាំ ១៩៨១ បាននិយាយអំពីការបង្កើនប្រជាជន និងបានបញ្ជាក់ចំណុចនេះដោយសង្កត់ធ្ងន់ទៅលើ“ការដោះស្រាយ និងការលើកកម្ពស់លក្ខខណ្ឌការរស់នៅប្រជាជន”[3492]។ ទស្សនាវដ្តីទង់

[3488] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១១។

[3489] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥០-៣៥៥៥។

[3490] អត្ថបទសុន្ទរកថារបស់ ប៉ុល ពត នៅឯកិច្ចប្រជុំខួបអនុស្សាវរីយ៍របស់បក្សកុម្មុយនីស្តកម្ពុជាថ្ងៃទី ២៧ ខែ កញ្ញា (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/290 ERN 00168651 ទំព័រ ៣៥ (ភាសាអង់គ្លេស)។

[3491] សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងឱកាសនៃការប្រជុំប្រារព្ធខួប (ក្នុងកម្រងសារព័ត៌មាន SWB/FE/5908/A3) ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/201 ERN 00292808។

[3492] បទសម្ភាសន៍ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យស្តីពីគោលនយោបាយប្រជាជន និងការតស៊ូប្រឆាំងនឹងវៀតណាម (ក្នុងសារព័ត៌មាន SWB/FE/6869/A3) ចុះថ្ងៃទី០២ ខែវិច្ឆិកា-ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨១ ឯកសារលេខ E3/686 ERN S 00644682។

បដិវត្តក្នុងខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ ខែ មករា ឆ្នាំ ១៩៧៧ មានសេចក្ដីបញ្ជាក់ថា "ដើម្បីឱ្យប្រជាជនយើងកើនឡើងជាដរាប ត្រូវតែបង្កើនជីវភាពរស់នៅរបស់ប្រជាជន និងត្រូវមានសុខភាពល្អ"[3493]។

1256.ភស្តុតាងនេះ បើពិនិត្យដាច់ដោយឡែកពីគ្នា ពុំបានគាំទ្រការសន្និដ្ឋានថា ការបង្កើនប្រជាជនបានកើតឡើងដោយសារបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ឡើយ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍មានគោលបំណងបង្កើនប្រជាជន ពុំមែនផ្អែកត្រឹមតែលើមូលដ្ឋាននៃការលើកឡើងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានគូសបញ្ជាក់ប៉ុណ្ណោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលបង្ហាញថា ការបង្កើនប្រជាជនត្រូវបានភ្ជាប់ទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីអំពីការប្ដេជ្ញាក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដែលជាលក្ខខណ្ឌតម្រូវក្នុងការបង្កើតកូនពេលអនាគត[3494]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាជាក់លាក់ក្នុងការវិភាគរបស់ខ្លួននូវការយល់ឃើញពាក់ព័ន្ធមួយនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងអំឡុងពេលនៃកិច្ចប្រជុំមួយដែលបានធ្វើឡើងនៅវត្តខណ្ឌលោមថា ខៀវ សំផន "បានណែនាំថា គ្រប់ក្រសួងត្រូវតែរៀបចំការរៀបអាពាហ៍ពិពាហ៍ ដើម្បីអាចឱ្យប្ដីប្រពន្ធបង្កើតកូនក្នុងការបន្ថែមកម្លាំងការពារប្រទេស"[3495]។ ការបញ្ជាក់នេះបានភ្ជាប់ដោយផ្ទាល់នូវបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងគោលនយោបាយបង្កើនប្រជាជន។ យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសំអាងទៅលើការបញ្ជាក់របស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងតម្រូវការក្នុងការបង្កើនប្រជាជន។

ខ) ភស្តុតាងកម្មាភិបាលស្ដីពីការបង្កើនប្រជាជនតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1257.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ សៅ សារុន លេខាតំបន់ ១០៥ ដែលថា អង្គការចង់បង្កើនប្រជាជន និងដូច្នេះ"បានជម្រុញ"ឱ្យយុវជន និងយុវនារីរៀបអាពាហ៍ពិពាហ៍[3496]។ អង្គជំនុំជម្រះ

---

[3493] ទស្សនាវដ្ដីទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារលេខ E3/25 ERN 00063054 ទំព័រ ៩៤-៩៥។

[3494] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

[3495] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨។

[3496] ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ (សៅ សារុន) ឯកសារលេខ E1/410.1 ទំព័រ ៥២-៥៣ (ដែលថា គាត់បានឮថា *អង្គការ*ចង់បង្កើនប្រជាជន ពីព្រោះចំនួនតិច និងដូច្នេះ "យុវជនយុវនារីត្រូវបានជម្រុញឱ្យរៀបអាពាហ៍ពិពាហ៍"។

សាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ មាស វឿន ដែលជាអនុមេបញ្ជាការកងពលលេខ ១ ដែលថា ការរៀបអាពាហ៍ពិពាហ៍“ត្រូវបានជម្រុញដើម្បីបង្កើនប្រជាជនកម្ពុជា”[3497] ព្រមទាំងភស្តុតាងរបស់ ជិន សារឿន ដែលជាយុទ្ធជនក្នុងភូមិភាគពាយ័ព្យដែលថា គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍គឺដើម្បីបង្កើនប្រជាជនតាមបណ្តាខេត្ត[3498]។

1258.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង“បានបំភ្លៃ”ភស្តុតាងកម្មាភិបាល សៅ សារុន មាស វឿន និង ជិន សារឿន ស្តីពីការបង្កើនប្រជាជនដោយសារតែពួកគេជាក់ស្តែងបានមើលឃើញការដែលកូនក្មេងបានកើតមកនោះ“ថា ជារឿងសមហេតុផលក្រោយពីការរៀបអាពាហ៍ពិពាហ៍”[3499]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរក្នុងការបដិសេធភស្តុតាងរបស់កម្មាភិបាលទាំងនេះនូវគោលនយោបាយស្តីពីការយល់ព្រម ខណៈពេលទទួលយកភស្តុតាងពាក់ព័ន្ធទៅនឹងការបង្កើនប្រជាជន[3500]។ យោងតាម ខៀវ សំផន ថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើភស្តុតាងរបស់ ជួន ធី ដែលបានស្តាប់ឮ ប៉ុល ពត និយាយអំពីការបង្កើនប្រជាជន និងថា ពុំដែលមានបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានភ្ជាប់ជាមួយនោះទេ[3501]។

1259.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងសាលាដំបូងបានបង្កើតការយល់ឃើញដោយសមហេតុផលស្តីពីភស្តុតាងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យសំអាងទៅលើភស្តុតាងនេះ បើទោះបីជាត្រូវបដិសេធចោលផ្នែកគោលនយោបាយស្តីពីការយល់ព្រមក៏ដោយ[3502]។

---

[3497] យោងតាមសាក្សី មាស វឿន អនុមេបញ្ជាការកងពលលេខ ១ ការរៀបអាពាហ៍ពិពាហ៍ត្រូវបានជម្រុញដើម្បីបង្កើនប្រជាជនកម្ពុជាពីព្រោះវៀតណាមមានប្រជាជនច្រើនជាង។ *សូមមើល* ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ (មាស វឿន) ឯកសារលេខ E1/387.1 ទំព័រ ២៦-២៩ (បានអះអាងផងដែរថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយថ្នាក់លើ ២៨)។

[3498] សាក្សី ជិន សារឿន យុទ្ធជនក្នុងភូមិភាគពាយ័ព្យសាន បានយល់ថា គោលបំណងនៃការឱ្យប្រជាជនរៀបអាពាហ៍ពិពាហ៍ គឺដើម្បីបង្កើនប្រជាជនតាមខេត្ត។ *សូមមើល* ប្រតិចារឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ (ជិន សារឿន) ឯកសារលេខ E1/454.1 ទំព័រ ៥៦-៥៧។

[3499] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៥។

[3500] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៥។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណាលើភស្តុតាងរបស់ ជួន ធី ស្តីពីបញ្ហានៃការយល់ព្រម។

[3501] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៦។

[3502] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១១។

1260.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាត្រឹមត្រូវលើភស្តុតាងរបស់កម្មាភិបាល សៅ សារឿន មាស វឿន និង ជិន សារឿន ដែលនីមួយៗបានអះអាងថា ពួកគេបានស្តាប់ឮថា ការជម្រុញដើម្បីធានាថា បុគ្គលត្រូវបានរៀបអាពាហ៍ពិពាហ៍ ជាប់ពាក់ព័ន្ធទៅនឹងតម្រូវការបង្កើនប្រជាជន[3503]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា ភស្តុតាងនេះត្រូវបានបំភ្លៃនោះ ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា កម្មាភិបាលដែលគាត់បានចង្អុលបង្ហាញនោះបានអះអាងថា ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ជាលក្ខណៈ"ធម្មជាតិ"។ ពុំមានកម្មាភិបាលណាម្នាក់បានផ្តល់ជាបញ្ហាអង្គហេតុនូវភស្តុតាងបែបនេះទេ[3504] និងបើទោះបីជាមានក៏ដោយ ក៏នេះពុំបានធ្វើឱ្យប៉ះពាល់ដល់ការពិតដែលថា បើទោះបីជាមានអ្វីបានកើតឡើងតាមធម្មតាក្នុងការរៀបអាពាហ៍ពិពាហ៍នោះក៏ដោយ ក៏ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអំពើល្មើស ជាជាងលក្ខណៈតាមទម្លាប់។

1261.ទាក់ទងទៅនឹងភស្តុតាងរបស់កម្មាភិបាលលើការមិនស្ម័គ្រចិត្ត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់កម្មាភិបាលមួយចំនួនដែលថា មានគោលការណ៍ស្តីពីការស្ម័គ្រនៃការរៀបអាពាហ៍ពិពាហ៍ក្រោមរបបបក្សកុម្មុយនីស្តកម្ពុជា[3505]។ មាស វឿន ដែលកម្មាភិបាលម្នាក់ក្នុងចំណោមនោះដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញស្តីពីគោលបំណងនៃបទបញ្ញារៀបអាពាហ៍ពិពាហ៍ ត្រូវបានពិចារណាផងដែរក្នុងការវិភាគលើគោលនយោបាយនៃការស្ម័គ្រចិត្ត។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់គាត់ដែលថា "ការរៀបអាពាហ៍ពិពាហ៍នៅកន្លែងរបស់គាត់ ត្រូវបានរៀបចំ

---

[3503] *សូមមើល* ប្រតិចារឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ (សៅ សារុន) ឯកសារលេខ E1/410.1 ទំព័រ ៥៣ (សាក្សី សៅ សារុន លេខាតំបន់ ១០៥ បានអះអាងគ្មានការបញ្ជាក់ពេលវេលា ដែលគាត់បានស្តាប់ឮថា អង្គការចង់បង្កើនប្រជាជនពីព្រោះចំនួនប្រជាជនតិច និងដូច្នេះ "យុទ្ធជនយុទ្ធនារីត្រូវបានជម្រុញឱ្យរៀបអាពាហ៍ពិពាហ៍")។ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ (មាស វឿន) ឯកសារលេខ E1/387.1 ទំព័រ ២៧ (បញ្ជាក់ថា គាត់បានឮអំពីគោលនយោបាយបង្កើនប្រជាជនកម្ពុជា ពីព្រោះវៀតណាមមានប្រជាជនច្រើនជាង និងថា ការជម្រុញឱ្យកងទ័ពរៀបអាពាហ៍ពិពាហ៍ ជាប់ពាក់ព័ន្ធទៅនឹងតម្រូវការបង្កើនប្រជាជន)។ ប្រតិចារឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ (ជិន សារឿន) ឯកសារលេខ E1/454.1 ទំព័រ ៥៦-៥៧ (អះអាងថា គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍គឺដើម្បីបង្កើនប្រជាជនតាមខេត្ត)។

[3504] *ធៀបនឹង*សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៥។

[3505] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧ យោងទៅលើភស្តុតាងរបស់ រៀល សន, ឌិ ហ, ពេជ្រ ជឹម, មាស វឿន, ពេព ប៉ូច និង យូ វ៉ាន់។

ដោយផ្អែកលើការស្ម័គ្រចិត្តរបស់បុគ្គល និងពុំត្រូវបានបង្ខំឡើយ”[3506]។ ទោះជាយ៉ាងណាក្តី ជារួម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះបដិសេធភស្តុតាងនេះ រួមទាំងភស្តុតាងរបស់ មាស វឿន ដោយសារតែមានភស្តុតាងក្នុងចំនួនយ៉ាងច្រើនបានបង្ហាញថា គោលការណ៍ស្ម័គ្រចិត្តពុំត្រូវបានគោរពតាមក្នុងបរិបទនៃកាលៈទេសៈបង្ខិតបង្ខំ[3507]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនផ្អែកលើភស្តុតាងរបស់ មាស វឿន ពាក់ព័ន្ធទៅនឹងគោលបំណងនៃគោលនយោបាយ និងបដិសេធភស្តុតាងនេះលើគោលការណ៍ការស្ម័គ្រចិត្តនោះ។ ដូចបានពិភាក្សាខាងក្រោមបន្ថែម អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញនេះដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងយ៉ាងសន្ធឹកសន្ធាប់ដទៃទៀតដែលផ្ទុយទៅនឹងគោលនយោបាយផ្លូវការនៃការស្ម័គ្រចិត្តចំពោះការរៀបអាពាហ៍ពិពាហ៍។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

គ) ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីគោលនយោបាយបង្កើតកូន

1262.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការពិចារណារបស់ខ្លួនលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញថា ពួកគេត្រូវបានបង្ខំឱ្យប្តេជ្ញាបង្កើតកូនក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍ និងកំហុសក្នុងការសំអាងទៅលើភស្តុតាងនេះ[3508] និងខកខានក្នុងការពិចារណាលើភស្តុតាងដោះបន្ទុក[3509]។

1263.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា សាក្សី និងភាគី“ជាច្រើន”បានប្តេជ្ញាបង្កើតកូនជូនអង្គការដើម្បីបង្កើនប្រជាជនក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍[3510] និងបានគូសបញ្ជាក់ជាពិសេសនូវភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់, ង៉ែត ចាត និង ស៊ូ សុធារី[3511]។ ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីនោះ ជាការយល់ពុំត្រឹមត្រូវលើការយល់ឃើញដែលត្រូវបានផ្អែកលើភស្តុតាងទាំងរបស់សាក្សី និងដើម

[3506] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧ យោងទៅលើប្រតិចារឹក ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៤៩-៥០។

[3507] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3508] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៨។

[3509] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៩។

[3510] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

[3511] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

បណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា មានយុត្តិសាស្ត្របង្ហាញត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងលើដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការកំណត់នូវពិរុទ្ធភាព[3512]។ អាស្រ័យហេតុនេះ ជាគោលការណ៍ ពុំមានកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាំទ្រសេចក្តីសន្និដ្ឋានដែលថា គោលនយោបាយបង្កើនប្រជាជនមានអត្ថិភាព។

1264. ទាក់ទងទៅនឹងការចោទប្រកាន់ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភាពផ្ទុយគ្នាក្នុងភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន ពុំបានបញ្ជាក់ជាក់លាក់ក្នុងសារណារបស់ខ្លួន និងបានយោងតែទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលប៉ុណ្ណោះ[3513]។ អាស្រ័យហេតុនេះ អំណះអំណាងទាំងនេះត្រូវបដិសេធចោលដោយសារពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ការដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានអះអាងថា ប្តីប្រពន្ធត្រូវបានបង្គាប់ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឱ្យ"ស្រលាញ់គ្នា" ពុំជាប់ពាក់ព័ន្ធឡើយ[3514] ជាពិសេសមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំ

---

[3512] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១៣ យោងទៅលើវិធាន ៥៩ និង ៩១(១) នៃវិធានផ្ទៃក្នុង។

[3513] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៨ យោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣២១-២៣២២, ២៤៥០-២៤៥១។

[3514] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២៩ ជើងទំព័រ ២៣១៧៖ ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/487.1 នៅម៉ោង ១៥.៣២.៤០៖ "ថ្ងៃរៀបការហ្នឹង ខ្ញុំឮខាងមេបក្សគាត់បានលើកឡើងថា អង្គការយើងត្រូវការបង្កើនកម្លាំង។ អីចឹង អង្គការយើងនឹងអនុញ្ញាតឱ្យគូស្រករដើម្បីបង្កើតកូនឱ្យបានពង្រីកកម្លាំងប្រជាពលរដ្ឋ។ អីចឹងត្រូវធ្វើម៉េច យើងត្រូវរៀបការ យើងត្រូវរួមរស់នៅជាមួយគ្នា ចេះស្រឡាញ់គ្នាកសាង និងបង្កើតកូនឱ្យបក្ស") (សេចក្តីបញ្ជាក់បន្ថែម អត្ថបទនេះពុំត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះឡើយ)។ ស៊ូ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធារី) ឯកសារលេខ E1/462.1 នៅម៉ោង ១៥.០៥.៤៦ មុនម៉ោង ១៥.១៨.០៨ ក្រោយម៉ោង ១៥.១១.១២។ ពិធីតម្រូវឱ្យគូស្រករឡើងប្តេជ្ញាថា ស្រឡាញ់ជាប្តីប្រពន្ធ។ *សូមមើលផងដែរ* ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 នៅម៉ោង ១៤.០២.២២ នៅម៉ោង ១៥.៣២.៤៤ ("រៀបការរួចឱ្យចេះស្រឡាញ់គ្នា ហើយកសាងសុភមង្គលឱ្យបានល្អអីចឹងទៅ ហើយទៅកុំឱ្យដូចថា មានកូនចៅអីចឹងទៅ ជួយអង្គការអីចឹងឱ្យបានច្រើនអីចឹងទៅ")។ មុំ វុន៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 នៅម៉ោង ១៣.៤១.៥៣ ("កម្មាភិបាលដែលគេរៀបការឱ្យទាំង ៦០ គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្តីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឱ្យបានច្រើន ដើម្បីយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឱ្យមានសល់")។ ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ (ប៉ែន សុចាន់) ឯកសារលេខ E1/482.1 នៅម៉ោង ១៤.០២.៣៧ ("ការប្តេជ្ញារបស់អនាគតប្តីប្រពន្ធមើលថែរក្សាអស់មួយជីវិត")។ សយ ណាវឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា

ផន បានផ្តល់ភស្តុតាងថា ពួកគេត្រូវបានបង្គាប់ឱ្យបង្កើតកូនផងដែរដើម្បីបង្កើនប្រជាជននៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដូចគ្នានេះ[3515]។ ជាលទ្ធផល សារណាទាំងនេះត្រូវបដិសេធចោល។

- *ការគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទក្រៅការរៀបអាពាហ៍ពិពាហ៍*

1265.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍ គឺក្នុងគោលបំណងដើម្បីគ្រប់គ្រងទំនាក់ទំនងផ្នែកមនោសញ្ចេតនា ឬផ្លូវភេទរវាងបុរស និងស្ត្រីក្រៅការរៀបអាពាហ៍ពិពាហ៍ ដែលទំនាក់ទំនងនេះត្រូវបានចាត់ទុកថា មានសក្តានុពលបង្កគ្រោះថ្នាក់ដល់បដិវត្តន៍[3516]។ ក្នុងការគាំទ្រ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញទៅលើបទបញ្ជាចំនួន ១២ នៃបដិវត្តន៍ដូចបានគូសបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយទស្សនាវដ្តី*យុវជនបដិវត្ត*ដែលបានរួមបញ្ចូលនូវការហាមឃាត់ការប្រព្រឹត្តនានាដែល“រំលោភបំពានស្ត្រីភេទ” ដោយសារនេះអាចប៉ះពាល់ដល់សីលធម៌បុរសស្ត្រី[3517]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនទូទៅត្រូវបានអប់រំឱ្យជៀសវាងការប្រព្រឹត្តកំហុសសីលធម៌[3518] ហើយទំនាក់ទំនងរវាងបុរស និងស្ត្រីដែលគ្មានការយល់ព្រមពីអង្គការត្រូវបានហាមឃាត់ និងត្រូវបានចាត់ទុកជាកំហុសសីលធម៌[3519]។ កំហុសសីលធម៌ និងវិធានការនោះត្រូវបានរាយការណ៍ទៅមជ្ឈិមបក្ស[3520]។ បន្ទាប់ពីអង្គការបានរៀបអាពាហ៍ពិពាហ៍ឱ្យជាប្តីប្រពន្ធហើយនោះ ពួកគេពុំអាចលែងលះបានក្នុងអំឡុងពេលនៃរបបនោះឡើយ[3521]។

---

ឆ្នាំ២០១៦ (សយ ណារឿន) ឯកសារលេខ E1/489.1 នៅម៉ោង ១០.៤៩.៤៤ (“ឱ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឱ្យបានច្រើនពីមួយហិកតាប៉ុន្មានតោនទៅប៉ុន្មានតោនតាមកំណត់របស់អង្គការឱ្យបង្កបង្កើតជាមនុស្សឱ្យបានច្រើន”)។

[3515] *សូមមើល* ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/487.1 ទំព័រ ៧៣ (“នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ខ្ញុំបានឮថ្នាក់ដឹកនាំថា អង្គការចង់បង្កើនកម្លាំង ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍នឹងត្រូវរៀបចំ ដើម្បីឱ្យមានការបង្កើតកូន និងបង្កើនប្រជាជន”)។ *សូមមើល* ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៦៨-៦៩ (“ក្នុងពេលពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់ ប្រធានប្រកាសថា “ប្រជាជនកម្ពុជាពុំមានច្រើន និងសម្រាប់យើងជាយុវជនយុវនារីត្រូវខិតខំប្រឹងប្រែង។ និងសម្រាប់ហេតុផលនេះ អង្គការតម្រូវឱ្យយើងរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើនប្រជាជន”)។

[3516] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៩។

[3517] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥០។

[3518] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥២។

[3519] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥១, ៣៦៥៣។

[3520] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥១, ៣៦៥៣។

[3521] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៨។

1266.អង្គជំនុំជម្រះតុលាការកំពូលសង្កេតជាបញ្ហាបឋមថា ដីកាដំណោះស្រាយបានកំណត់គោលបំណងតែមួយនៃបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ គឺថា"ទំនាក់ទំនងផ្លូវភេទដែលមានគោលដៅបង្កើតកូនដោយបង្ខំ ត្រូវបានអនុវត្ត"[3522]។ ដីកានេះបានបញ្ជាក់បន្ថែមថា ការដែលថា សាក្សីត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះបានបញ្ជាក់បន្ថែមលើ"អត្ថិភាពនៃគោលបំណងរួមដែលត្រូវបានបង្ហាញដោយមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាថា ការរៀបអាពាហ៍ពិពាហ៍គឺជាការចាំបាច់ក្នុងការបង្កើនប្រជាជន"[3523]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានកំណត់គោលបំណងពីរបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍៖ ការបង្កើនប្រជាជន និងការគ្រប់គ្រងទំនាក់ទំនងផ្លូវភេទក្រៅការរៀបអាពាហ៍ពិពាហ៍[3524]។ វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងចែងថា ដីកាដំណោះស្រាយត្រូវតែធ្វើការពិពណ៌នាអំពីអង្គហេតុជាសត្យានុម័ត និងការកំណត់ប្រភេទបទល្មើស។ យោងតាមវិធាននេះ និងដូចបានបង្ហាញក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានចងកាតព្វកិច្ចដោយការកំណត់ប្រភេទបទល្មើសដែលត្រូវបានអនុម័តដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះក្នុងដីកាដំណោះស្រាយឡើយ[3525]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅក្នុងដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេតបានបង្កើតការយល់ឃើញផ្នែកអង្គហេតុស្ដីពីគោលបំណងនៃបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍។ ជាពិសេស ដីកាដំណោះស្រាយបានយល់ឃើញថា "គោលបំណងមួយក្នុងចំណោមនោះនៃគោលនយោបាយ គឺដើម្បីគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល ដែលក្នុងនោះពួកគេត្រឹមតែអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងមានទំនាក់ទំនងផ្លូវភេទស្របតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ[3526]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមស្របថា មានគោលបំណងពីរនៃបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយផ្អែកទៅលើការយល់ឃើញផ្នែកអង្គហេតុក្នុងដីកាដំណោះស្រាយ។

---

[3522] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៥។

[3523] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៧។

[3524] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៩-៣៥៦៣។

[3525] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៩២-៥០០។ សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីសហឧក្រិដ្ឋកម្មរួម (E100/6) កថាខណ្ឌ ២៤-២៥។

[3526] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ២១៧។

1267.ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅនឹងគោលការណ៍សីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជា[3527] និងមានកំហុសក្នុងការយល់ឃើញថា កំហុសផ្លូវភេទត្រូវបានរាយការណ៍ទៅមជ្ឈិមបក្ស[3528]។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ពុំអាចធ្វើការលែងលះបានក្រោមរបបនេះ និងថា ប្តីប្រពន្ធត្រូវបានបង្ខំឱ្យរួមរស់នៅជាមួយគ្នាដោយសារការដាក់ទណ្ឌកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា[3529]។

ក) ការបញ្ជាក់បក្សកុម្មុយនីស្តកម្ពុជា

1268.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន“លាក់បាំង”គោលការណ៍សីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជា និងពុំអើពើទៅលើលក្ខណៈប្រហាក់ប្រហែលគ្នារវាងការគ្រប់គ្រងទំនាក់ទំនងដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងប្រពៃណីសង្គមខ្មែរ[3530]។

1269.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបែងចែកត្រឹមត្រូវនូវស្ថានការណ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោមវប្បធម៌ប្រពៃណីខ្មែរ និងពុំបានអើពើលើការពិតថា បុគ្គលបានរស់ក្នុងបរិយាកាសភ័យខ្លាចនៃផលវិបាកដែលអាចគ្រោះថ្នាក់ដល់ជីវិត[3531]។

1270.សហមេធាវីនាំមុខបានឆ្លើយតបថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ការហាមឃាត់ដាច់ខាតបានធ្វើឱ្យខូចដល់វប្បធម៌ប្រពៃណី[3532]។ សហមេធាវីនាំមុខបានយោងទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនរួមទាំងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ដែលបានផ្តល់សក្ខីកម្មទាក់ទងទៅនឹង“ហេតុការណ៍ពីរដែលគូស្រករពីរនាក់បានស្រលាញ់គ្នា ត្រូវបានរកឃើញថា បាន“ខុសសីលធម៌“ និងត្រូវបានយកទៅសម្លាប់ដោយសារហេតុផលដែលពួកគេពុំបានរាយការណ៍ទំនាក់ទំនងរបស់ខ្លួនទៅថ្នាក់លើ”[3533]។

---

[3527] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៨។

[3528] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៩។

[3529] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២០។

[3530] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៨។

[3531] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០៨។

[3532] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៦១។

[3533] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៦១ យោងទៅលើប្រតិចារឹកថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ៥៨។

1271.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើគោលការណ៍សីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការវិភាគដែលត្រូវបានជំទាស់ ដូចបានគូសបញ្ជាក់ក្នុងឯកសារបោះពុម្ពផ្សាយទស្សនាវដ្តី*យុវជនបដិវត្ត*[3534]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា គោលការណ៍នេះបានបញ្ជាក់នូវសារៈសំខាន់នៃសីលធម៌រវាងបុរសនារី និងបានយល់ឃើញថា ការខកខានក្នុងការការពារសីលធម៌នេះ នឹង"ធ្វើឱ្យប៉ះពាល់ដល់បដិវត្តន៍ និងធ្វើឱ្យចលនានេះមានហានិភ័យ"[3535]។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង"បានលាក់បាំង"គោលការណ៍នេះ ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា បើទោះបីជាភស្តុតាងដទៃទៀតដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន បង្ហាញថា ទំនាក់ទំនងផ្លូវភេទរវាងយុវជន និងយុវនារីត្រូវបានហាមឃាត់ក្រៅការរៀបអាពាហ៍ពិពាហ៍ក្រោមប្រពៃណីសង្គមខ្មែរក៏ដោយ[3536] ក៏គាត់ខកខានក្នុងការបង្ហាញថា មានការជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញដែលថា ទំនាក់ទំនងផ្លូវភេទត្រូវបានគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ការប្រហាក់ប្រហែលគ្នាតាមលក្ខណៈភិនភាគខាងក្រៅ ពុំឆ្លុះបញ្ចាំងគោលបំណងផ្សេងទាំងស្រុងនៃការអនុវត្តន៍ ព្រមទាំងលក្ខណៈបង្ខិតបង្ខំនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យឡើយ[3537]។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ខ) របាយការណ៍ទៅមជ្ឈិមបក្ស

[3534] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦០។

[3535] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៩៤៧ យោងទៅលើទស្សនាវដ្តីយុវជនបដិវត្តខែ តុលា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/765 ទំព័រ ៣៦-៣៧ ERN 00376493-00376494 ("សីលធម៌ទី ៦៖ កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ៖ និយាយរួម គឺកុំប៉ះពាល់សីលធម៌នារី បុរសឲ្យសោះ។ ព្រោះបញ្ហានេះ វានាំឲ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងជាជនបដិវត្ត នាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូររបស់ប្រជាជនយើង។ ដូច្នេះ ប៉ះពាល់ដល់ប្រជាជនយើង។ នេះម្យ៉ាង។ តែសំខាន់ម្យ៉ាងទៀត គឺបើយើងប៉ះពាល់ សីលធម៌នារី បុរស ដែលជាធាតុពិតរលួយស្អុយគគ្រុក របស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ នឹងនាំឲ្យខ្មាំងអូសទាញយើងបាន។ ដូច្នេះ គ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្ត")។

[3536] ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ (ជួន ធី) ឯកសារលេខ E1/183.1 ទំព័រ ១៨ ("ប្រជាជនកម្ពុជាត្រូវគោរពប្រពៃណីដែលមានន័យថា យើងមិនអាចរួមភេទមុនការរៀបអាពាហ៍ពិពាហ៍")។ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៤ (ពន្យល់ថា ពិធីរៀបអាពាហ៍ពិពាហ៍ជាការទទួលខុសត្រូវរបស់ថ្នាក់ឃុំ)។ ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/255.1 ទំព័រ ៨ ("យើងរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ")។

[3537] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២២៨៨-២២៨៩។

1272.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ដែលថា នៅពេលអង្គការបានចាត់តាំងមនុស្សឱ្យទៅភូមិភាគពាយ័ព្យ មានបុរសម្នាក់បាន "ប្រព្រឹត្តកំហុសសីលធម៌" និង"ត្រូវអប់រំពីរទៅបីដង"[3538]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើរបាយការណ៍បន្ថែមទៀតរបស់កម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ដែលថា "សកម្មភាព"ដែលពុំត្រូវបានបញ្ជាក់នោះបានកើតឡើងរវាងយុវជន និងយុវនារី ព្រមទាំងបុរស និងស្ត្រី ឬបុរស និងយុវជនដែលបានរៀបការហើយ។ "នៅសហករណ៍តាសាលស្រុក ២៧ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៧៨ សៀន ឈ្លបសហករណ៍តាសាលបានខុសក្រមសីលធម៌ដោយចាប់រំលោភយុវនារីមកពីតំបន់កោះកុង"[3539]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរទៅលើទូរលេខកម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ ដែលក្នុងនោះ សៅ សារុន លេខាតំបន់ ១០៥ បានបញ្ជាក់ថា "សមមិត្ត សុត ធ្លាប់ត្រូវគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពថា បានធ្វើខុសសីលធម៌ជាមួយនារីម្នាក់ ដោយបញ្ជាក់ថា ទាំងបុរស និងនារីនោះត្រូវបានចាប់ខ្លួនហើយ ហើយកំពុងស្នើសុំយោបល់ពីមជ្ឈិមបក្ស"[3540]។

1273.ខៀវ សំផន បានជំទាស់ទៅលើការយល់ឃើញដែលថា ការខុសសីលធម៌ត្រូវបានរាយការណ៍ទៅមជ្ឈិម[3541]។ ឯកសារទាំងនេះបានសំដៅទៅលើតែអង្គការប៉ុណ្ណោះ ពុំមែនទៅលើមជ្ឈិមបក្ស និងពុំមែនលើ ខៀវ សំផន និងជាចម្បងពុំជាប់ពាក់ព័ន្ធទៅនឹងបទបញ្ជារៀបអាពាហ៍ពិពាហ៍ ដែលនេះជាការលើកឱ្យតែមានប៉ុណ្ណោះ[3542]។

1274.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង"ជាដរាបបានយល់ឃើញថា ទូរលេខ និងរបាយការណ៍ដែលបានផ្ញើទៅជាមួយនឹងចំណារថា '*ជូនអង្គការ*' ត្រូវបានសំដៅចំពោះមជ្ឈិមបក្ស"ដែល ខៀវ សំផន គឺជាសមាជិកជាន់ខ្ពស់នោះ[3543]។

---

[3538] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៩៥៥ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/1092 ERN 00143578 ទំព័រ ៤។

[3539] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៩៥៥ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/1094 ERN 00143609 ទំព័រ ៦។

[3540] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៩៥៥ យោងទៅលើទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/156 ERN 00017027។

[3541] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៩។

[3542] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៩។

[3543] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៤២, ៩៤៧។

1275.អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងដែលថា របាយការណ៍នេះពុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់។ ឯកសារដែលបានយោងដោយអង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាច្បាស់លាស់នូវកំហុសសីលធម៌ដែលត្រូវបានរាយការណ៍ និងការពិតដែលថា ឯកសារដដែលនោះត្រូវបានពិចារណាផងដែរលើបញ្ហាដទៃទៀតដែលពុំជាប់ពាក់ព័ន្ធ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញរំឭកថា *អង្គការ* និងបក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈតែមួយដូចគ្នា និងតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានកាន់កាប់តួនាទីពិសេសក្នុងមជ្ឈិមបក្ស[3544]។ អាស្រ័យហេតុនេះ សារណារបស់គាត់ពាក់ព័ន្ធបញ្ហានេះត្រូវបដិសេធចោល។

គ) ការលែងលះ និងការដាក់ទណ្ឌកម្ម

1276.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ប៉ុល ពត អំពីលទ្ធភាពនៃការលែងលះ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការអះអាងរបស់គាត់ដែលថា “ប្រសិនបើភាគីពាក់ព័ន្ធយល់ឃើញថាពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ពួកគេមានជម្រើសធ្វើការលែងលះ”[3545] និងថា ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការអះអាងរបស់គាត់បន្ថែមទៀតក្នុងកិច្ចសម្ភាសន៍ដែលនោះថា ការបែកបាក់គ្នា“កម្រកើតមានណាស់” ដោយសារ“ទាំងប្តី និងប្រពន្ធមានមនសិការនយោបាយខ្ពស់”[3546]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះគឺជាការឃោសនា និងតាមការពិចារណាលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានបង្ហាញថា ប្តីប្រពន្ធពុំមានសិទ្ធិលែងលះពីព្រោះខ្លាចហានិភ័យនៃការដាក់ទណ្ឌកម្ម[3547]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បន្ទាប់ពីអង្គការរៀបអាពាហ៍ពិពាហ៍ឱ្យធ្វើជាប្តីប្រពន្ធរួចហើយ ពួកគេពុំអាចលែងលះក្នុងអំឡុងពេលនៃរបបនោះបានទេ[3548]។

---

[3544] *សូមមើលខាងក្រោម* ផ្នែក VIII.ក.ខ.iii។

[3545] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៦ យោងទៅលើសេចក្តីរាយការណ៍អំពីកិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយអ្នកបំពេញទស្សនកិច្ចមកពីប្រទេសប៊ែលហ្ស៊ិកថ្ងៃទី ០៥ ខែ សីហា (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារលេខ E3/76 ERN 01327012។

[3546] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៧ យោងទៅលើសេចក្តីរាយការណ៍អំពីកិច្ចសម្ភាសន៍របស់ ប៉ុល ពត ជាមួយអ្នកបំពេញទស្សនកិច្ចមកពីប្រទេសប៊ែលហ្ស៊ិកថ្ងៃទី ០៥ ខែ សីហា (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារលេខ E3/76 ERN 01327012។

[3547] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៨។

[3548] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៩។

1277.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ពុំអាចធ្វើការលែងលះក្រោមរបបនោះបាន និងថា ប្ដីប្រពន្ធត្រូវបានបង្ខំឱ្យរួមរស់នៅជាមួយគ្នាដោយសារការដាក់ទណ្ឌកម្មរបស់បក្សកុម្មុយនីស្ដកម្ពុជា[3549]។ នៅក្នុងសារណារបស់គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើការអះអាងរបស់ ប៉ុល ពត ដែលថា ការលែងលះត្រូវបានអនុញ្ញាត បើទោះបីជាមានភស្តុតាងបញ្ជាក់បន្ថែមក៏ដោយចុះ[3550] និងមានកំហុសដោយសារបានសំអាងទៅលើភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណីដែលថា ប្ដីប្រពន្ធត្រូវបានដាក់ទណ្ឌកម្ម បើទោះបីជាការពិតថា បុគ្គលទាំងនេះពុំបានផ្ដល់ឧទាហរណ៍ "ជាក់លាក់ និងមានមូលដ្ឋានគាំទ្រណាមួយ"នៃការដាក់ទណ្ឌកម្មនោះឡើយ[3551]។

1278.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើកិច្ចសម្ភាសន៍របស់ ប៉ុល ពត ប៉ុន្តែបានយល់ឃើញថា នេះគឺជាការឃោសនា។ សហព្រះរាជអាជ្ញាបានអះអាងផងដែរថា ការលែងលះពុំអាចធ្វើទៅបានដោយសារបុគ្គលពុំបានបង្ហាញនូវការមិនពេញចិត្តជាមួយនឹងដៃគូរបស់ខ្លួនក្នុងបរិយាកាសភិតភ័យទូទៅ[3552]។

1279.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "អ្នកដែលពុំចុះសម្រុងគ្នាពុំហ៊ានសុំធ្វើការលែងលះនោះទេដោយសារខ្លាចគេព្រមាន ឬត្រូវបញ្ជូនទៅឱ្យធ្វើការអប់រំកែប្រែឡើងវិញ ឬសម្លាប់"[3553] គឺជាឧទាហរណ៍នៃការដាក់ទោសជាក់លាក់ និងមានមូលដ្ឋានគាំទ្រត្រឹមត្រូវ។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញនេះលើភស្តុតាងរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីប្រាំពីរនាក់[3554] និងការដែលថា ខៀវ សំផន បានគូសបង្ហាញភស្តុតាងដទៃទៀតនៅ

---

[3549] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២០។

[3550] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២០។

[3551] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២០។

[3552] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០៩។

[3553] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៨។

[3554] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៨ ជើងទំព័រ ១២២៤០-១២២៤៤ យោងទៅលើភស្តុតាងរបស់ យី ឡៃស្រូវ, ស៊ូ សុធាវី, ភ្លៅ យ៉ាវ, ជា ឌៀប, យស ផល និង មាស ឡៃហួរ។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញមួយផ្សេងទៀតដែលថា "ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរដោយសារមានទំនាក់ទំនងមិនសមរម្យបុរសស្ត្រី ពួកគេត្រូវទទួលការអប់រំកែប្រែឡើងវិញ ឬការដាក់ទណ្ឌកម្ម សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៣ ជើងទំព័រ ១១៩៥៨ យោងទៅលើភស្តុតាងរបស់ កាំង ហ្កេកអ៊ាវ និង ណុប ងឹម។

ក្នុងសារណារបស់គាត់ ដែលពុំបានសំដៅទៅលើការដាក់ទណ្ឌកម្មជាក់លាក់នោះ ពុំជាប់ពាក់ព័ន្ធឡើយ[3555]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់មូលដ្ឋានគាំទ្រពេញលេញលើការយល់ឃើញរបស់ខ្លួន ដូច្នេះ សារណារបស់ ខៀវ សំផន ដែលផ្ទុយនេះ ត្រូវបដិសេធចោល។ បន្ថែមលើនេះ ទាក់ទងទៅនឹងភស្តុតាងរបស់ ប៉ុល ពត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាភស្តុតាងនេះពេញលេញ ហើយ ខៀវ សំផន ត្រឹមតែមិនយល់ស្រប ជាមួយនឹងការវាយតម្លៃលើភស្តុតាងរបស់ ប៉ុល ពត ដោយពុំបានបង្ហាញនូវកំហុស។ សារណានេះត្រូវ បដិសេធចោលផងដែរ។

- *ភាពផ្ទុយគ្នារវាងគោលបំណងនៃគោលនយោបាយ*

1280.ជាបន្ទាប់ ខៀវ សំផន បានលើកការជំទាស់ដែលគាត់បានពិពណ៌នាថា ជាការជំទាស់ទៅលើ"គោលបំណងនៃការបង្កើនប្រជាជន"[3556]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងទាំងនេះជាសំខាន់ គឺជាការចោទប្រកាន់អំពីភាពផ្ទុយគ្នារវាងគោលបំណងពីរនៃគោលនយោបាយស្តីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍៖ គោលបំណងបង្កើនប្រជាជន និងគោលបំណងគ្រប់គ្រងទំនាក់ទំនងផ្លូវភេទ។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្តីប្រពន្ធជាទូទៅត្រូវបានបំបែកពីគ្នាក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះគប្បីបានពិចារណាឃើញថា វិធានការបំបែកគ្នានេះ"ពុំបានជម្រុញឱកាសឱ្យមានគភ៌នោះឡើយ"[3557]។ គាត់បានលើកឡើងថា នេះមានលក្ខណៈផ្ទុយគ្នាទៅនឹងការយល់ឃើញដែលថា បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍មានគោលបំណងបង្កើនប្រជាជន[3558]។

---

[3555] *សូមមើល* ជាទូទៅសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២២៨៦ យោងទៅលើ សៅ សារុន, ជួន ធី និង មាស រឿន។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា យស ផល គួរជឿជាក់បាន ពីព្រោះគាត់បានអះអាងថា គាត់មិនហានលែងលះ និងនៅរក្សាការរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធគាត់ក្រោយដួលរលំក៏ដោយ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២២៨៦។ ដោយសារអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញខាងក្រោម ថាតើបុគ្គលរក្សាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោយការដួលរលំរបបនោះដែរ ឬយ៉ាងណា នេះពុំបានកែប្រែកាលៈទេសៈបង្ខិតបង្ខំក្នុងនោះ ការរៀបអាពាហ៍ពិពាហ៍បានកើតឡើង។

[3556] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២១។

[3557] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២២២។

[3558] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤១(អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្តីប្រពន្ធថ្មីត្រូវបានបង្ខំឱ្យរួមភេទសម្រាប់គោលបំណងនៃ"ការបង្កើត"កូនដើម្បីបង្កើនប្រជាជន)។

1281.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ពុំមានភាពផ្ទុយគ្នារវាងគោលបំណងទាំងពីរនេះទេ[3559]។ ជាពិសេស សហព្រះរាជអាជ្ញាបានអះអាងថា "បក្សបានគ្រប់គ្រងយ៉ាងដាច់ខាត ដើម្បីកុំឱ្យគោលបំណងទាំងពីរនេះ បរាជ័យតាមរយៈការតាមដានយ៉ាងម៉ត់ចត់លើប្ដីប្រពន្ធថ្មីក្នុងការធានាថា ពួកគេត្រូវរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក្នុងមួយរយៈពេលខ្លីដែលពួកគេបានរស់នៅជាមួយគ្នា" និងតាមរយៈ"ការអនុវត្តន៍ជាប្រព័ន្ធនូវការចុះតាមដានមើលបញ្ហាជាប់ពាក់ព័ន្ធបន្ថែមទៀតដែលអាចបម្រើដល់គោលបំណងបង្កើនប្រជាជនខណៈពេលផ្ដោតទៅលើការបង្កើតកូន"[3560]។

1282.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហាថាតើ ដូចការអះអាងរបស់ ខៀវ សំផន "ការបង្កើតកូន"មានលក្ខណៈសំខាន់សម្រាប់ការយល់ឃើញដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺក្នុងគោលបំណងនាំទៅរកការបង្កើនប្រជាជន ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការយោងជាក់លាក់ទៅលើការធ្វើឱ្យមានគភ៌ ឬការរួមភេទនៅក្នុងការយល់ឃើញដែលថា បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ត្រូវបានតម្រង់ទិសដៅទៅរកការបង្កើនចំនួនប្រជាជន។ នេះមានលក្ខណៈផ្ទុយគ្នាទៅនឹងដីកាដំណោះស្រាយដែលបានកំណត់ថា ជាគោលបំណងតែមួយនៃបទបញ្ជាគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដែលថា "ទំនាក់ទំនងផ្លូវភេទដែលក្នុងគោលបំណងបង្កើតកូនដោយបង្ខំ ត្រូវបានអនុវត្ត"[3561]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបក្នុងឆ្នាំ ២០១៦ ដែលក្នុងនោះសំណើសុំបំពេញកិច្ចស៊ើបសួរបទឧក្រិដ្ឋនៃការធ្វើឱ្យមានគភ៌ដោយបង្ខំ ឬមានផ្ទៃពោះដោយបង្ខំដែលជាអំពើអមនុស្សធម៌ដទៃទៀត ត្រូវបដិសេធចោល[3562]។

1283.ទោះជាយ៉ាងណាក្ដី ក្នុងការបង្កើតការយល់ឃើញស្ដីពីឧក្រិដ្ឋភាពនៃគោលនយោបាយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ប្ដីប្រពន្ធថ្មី"ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងរួមដំណេកដើម្បីបំពេញតាមគោល

---

[3559] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១០។

[3560] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១០។

[3561] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៦ យោងទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៤៥។

[3562] សេចក្ដីសម្រេចរួមសំណុំរឿង ០០៤ ស្ដីពីសំណើ (D301/5)។ សេចក្ដីសម្រេចនេះបានបដិសេធអំណះអំណាងដែលថា ការធ្វើឱ្យមានគភ៌ និងមានផ្ទៃពោះដោយបង្ខំ គប្បីត្រូវបានស៊ើបអង្កេត។

បំណងរបស់អង្គការ និងបង្កើតកូនសម្រាប់បដិវត្តន៍ដើម្បីកសាង និងការពារប្រទេសពីសត្រូវ"[3563]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានប្តេជ្ញាបង្កើតកូនជូនអង្គការក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ដើម្បីបង្កើនប្រជាជន[3564] និងបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រាប់ថា អង្គការចង់ឱ្យពួកគេបង្កើតកូនច្រើនតាមដែលអាចធ្វើទៅបាន[3565]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់អតីតកម្មាភិបាល ដូចជា សៅ សារឿន, មាស វឿន និង ជិន សារឿន ដែលបានអះអាងថា ពួកគេបានស្តាប់ឮថា ការជម្រុញឱ្យប្រាកដថា បុគ្គលត្រូវរៀបអាពាហ៍ពិពាហ៍ ជាប់ពាក់ព័ន្ធទៅនឹងតម្រូវការចាំបាច់ក្នុងការបង្កើនប្រជាជន និងមានកូនបន្ទាប់ការរៀបអាពាហ៍ពិពាហ៍នោះ[3566]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បន្ថែមលើនេះទៀត ការបង្កើតកូន គឺជាវិធីសមស្របតែមួយគត់ដែលក្នុងនោះ បទបញ្ជារៀបអាពាហ៍ពិពាហ៍នឹងនាំទៅរកការបង្កើនប្រជាជន។ ជាលទ្ធផល បើទោះបីជាការកាន់តែល្អប្រសើរប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បញ្ហានេះច្បាស់លាស់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ គឺក្នុងគោលបំណងដើម្បីបង្កើនប្រជាជនតាមរយៈការធ្វើឱ្យមានគភ៌ និងជាការសមស្របតាមរយៈការបង្កើតកូន។

1284.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហាថាតើ មានភាពផ្ទុយគ្នារវាងការសន្និដ្ឋានដែលថា ការបង្កើនប្រជាជនត្រូវបានធ្វើឡើងតាមរយៈការធ្វើឱ្យមានគភ៌ ជាមួយនឹងការយល់ឃើញដែលត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំផន ដែរ ឬយ៉ាងណា។ ការយល់ឃើញនេះមាននៅក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលា

[3563] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៦៥ យោងទៅលើផ្នែក ១៤៖ បទបញ្ជារៀបអាពាហ៍ពិពាហ៍ កថាខណ្ឌ ៣៦៤៦។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កថាខណ្ឌយោងទៅលើក្នុងការយល់ឃើញនេះ សំដៅទៅលើតែការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងពុំមានការពិភាក្សាណាមួយអំពីការធ្វើឱ្យមានផ្ទៃពោះ។

[3564] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥៦។

[3565] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤៥២ យោងទៅលើភស្តុតាងរបស់ សយ ណារឿន និង ង៉ែត ចាត។

[3566] ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ (សៅ សារុន) ឯកសារលេខ E1/410.1 ទំព័រ ៥៣ (សាក្សី សៅ សារុន ជាលេខាតំបន់ ១០៥ បានអះអាងដោយគ្មានការបញ្ជាក់អំពីពេលណា ដែលគាត់ឮថា អង្គការចង់បង្កើនប្រជាជនពីព្រោះចំនួននៅតិច និងដូច្នេះ "យុទ្ធជននិងយុទ្ធនារីត្រូវបានជម្រុញឱ្យរៀបអាពាហ៍ពិពាហ៍")។ ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ (មាស វឿន) ឯកសារលេខ E1/387.1 ទំព័រ ២៧ (បញ្ជាក់ថា គាត់បានឮអំពីគោលនយោបាយបង្កើនប្រជាជនកម្ពុជាពីព្រោះវៀតណាមមានប្រជាជនច្រើនជាង និងថា ការជម្រុញឱ្យកងទ័ពរៀបអាពាហ៍ពិពាហ៍ ជាប់ពាក់ព័ន្ធទៅនឹងតម្រូវការបង្កើនប្រជាជន)។ ប្រតិចារឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ (ជិន សារឿន) ឯកសារលេខ E1/454.1 ទំព័រ ៥៦-៥៧។

ដំបូងចំណងជើងថា "ការបំបែកគ្នា"[3567] ដែលត្រូវបានបង្កើតឡើងជាផ្នែកនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គការបានគ្រប់គ្រងទំនាក់ទំនងផ្លូវភេទក្រោយពេលរៀបអាពាហ៍ពិពាហ៍[3568]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ការរៀបចំត្រូវបានបង្កើតឡើងសម្រាប់ប្ដីប្រពន្ធចំណាយពេលខ្លះនៅជាមួយគ្នា[3569]។ បន្ទាប់មកទៀត ប្ដីប្រពន្ធត្រូវបានបំបែក និងត្រូវបានណែនាំឱ្យត្រឡប់ទៅកង ឬការដ្ឋានធ្វើការរៀងៗខ្លួន[3570]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា បន្ទាប់ពីត្រូវបានបំបែក ប្ដីប្រពន្ធត្រូវបានអនុញ្ញាតឱ្យជួបគ្នាម្ដងក្នុងពេលប្រាំពីរថ្ងៃទៅដប់ប្រាំថ្ងៃ[3571]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជាំង ស្រីមុំ បានអះអាងថា អង្គការជាអ្នកសម្រេចថាពេលណាប្ដីប្រពន្ធត្រូវបានអនុញ្ញាតឱ្យជួបគ្នា[3572]។ ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានអះអាងថា គាត់ និងប្រពន្ធត្រូវបានឱ្យទៅធ្វើការកន្លែងមួយដែលបុរស និងស្ត្រីត្រូវដេកបែកគ្នា[3573]។ បន្ទាប់ពីប្ដីប្រពន្ធត្រូវបានបញ្ជូនត្រឡប់មកកងរៀងៗខ្លួនវិញ អ្នកខ្លះត្រូវបានតម្រូវឱ្យសុំការអនុញ្ញាតទៅជួបប្ដី ឬប្រពន្ធរបស់ខ្លួន[3574]។

1285. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញទាំងនេះបង្ហាញថា ប្ដីប្រពន្ធជាញឹកញាប់ត្រូវបំបែកពីគ្នាក្រោយពេលរៀបអាពាហ៍ពិពាហ៍។ នៅពេលគោលបំណងទូទៅត្រូវបានបង្ហាញថា ជាការតម្រង់ទិសដៅទៅរកការគ្រប់គ្រងទំនាក់ទំនងក្រៅការរៀបអាពាហ៍ពិពាហ៍នោះ ក៏មានការបង្ហាញថា រដ្ឋអំណាចបានគ្រប់គ្រងផងដែរលើទំនាក់ទំនងនៅក្នុងការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញច្បាស់លាស់ស្ដីពីការធ្វើឱ្យមានគភ៌បានកើតឡើងបន្ទាប់ពី និងជាលទ្ធផលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3575]។ ការយល់ឃើញជាក់លាក់តែមួយគត់លើអត្ថិភាពនៃការរួមភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ គឺស្ថិតក្នុងវិសាលភាពនៃអំពើការរួមដំណេកដោយបង្ខំដែលបានកើតឡើងភ្លាមៗបន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ ឬ

---

[3567] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ១៤.៣.៨.៤ ទំព័រ ១៨៥១។

[3568] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៤។

[3569] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦២ យោងទៅលើ *ក្នុងចំណោមនោះ* កថាខណ្ឌ ៣៦៤១។

[3570] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦២។

[3571] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៣។

[3572] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៣។

[3573] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៣។

[3574] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៤។

[3575] *ធៀបនឹង* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤១ (អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្ដីប្រពន្ធថ្មីត្រូវបានបង្ខំឱ្យរួមភេទ សម្រាប់គោលបំណងនៃការ"បង្កើត"កូន ដើម្បីបង្កើនប្រជាជន)។

ភ្លាមៗក្រោយមក[3576]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ដែលមានគភ៌ក្រោយពេលនោះ និងថា លោកស្រីត្រូវបានតម្រូវឱ្យធ្វើការ និងពុំបានផ្តល់អាហារគ្រប់គ្រាន់ ដែលបានធ្វើឱ្យគាត់ធ្លាក់ខ្លួនស្គមស្គាំងខ្លាំង[3577]។ លោកស្រីក្រោយមកបានរលូតកូនដោយសារលោកស្រីបានជម្ងឺគ្រុនចាញ់ និងពុំមានថ្នាំពេទ្យព្យាបាល[3578]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកភស្តុតាងរបស់គាត់ថា ជាផ្នែកនៃការវិភាគលើផលប៉ះពាល់ដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តខ្លាំងដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែពុំបានបង្កើតការយល់ឃើញជាក់លាក់ណាមួយលើលទ្ធភាពនៃការមានគភ៌នេះឡើយ។

1286.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការល្អប្រសើរសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់សំអាងហេតុតាមរយៈការបង្ហាញឱ្យឃើញនូវភាពផ្ទុយគ្នារវាងគោលបំណងពីរនៃបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញផងដែរថា ការយល់ឃើញដែលថា ប្តីប្រពន្ធជាញឹកញាប់ត្រូវបានបំបែកក្រោយពេលរៀបអាពាហ៍ពិពាហ៍ពុំបានរារាំងដល់លទ្ធភាពដែលថា ការជួបគ្នាបានកើតឡើងជាញឹកញាប់គ្រប់គ្រាន់ដើម្បីសម្រួលដល់ការធ្វើឱ្យមានគភ៌។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនដែលបានអះអាងថា ពួកគេត្រឹមតែត្រូវបានអនុញ្ញាតឱ្យនៅជាគ្នាម្តងក្នុងរយៈពេលមួយសប្តាហ៍ និងរៀងរាល់ដប់ប្រាំថ្ងៃ[3579] រួមបញ្ចូលទាំងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានអះអាងថា លោកស្រីត្រូវបាន

[3576] បើទោះបីជាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមិនបើកកិច្ចស៊ើបសួរអំពីការធ្វើឱ្យមានផ្ទៃពោះ ឬមាគភ៌ដោយបង្ខំបានផ្តោតជាចម្បងទៅលើការវាយតម្លៃស្តីពីនីត្យានុកូលភាពនៃអំពើនេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ផងដែរថា មាន"ភស្តុតាងនៃកិច្ចខិតខំប្រឹងប្រែងដោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាថា ស្ត្រីមានផ្ទៃពោះក្រោយពីការរៀបអាពាហ៍ពិពាហ៍"ដែរ។ សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5) កថាខណ្ឌ ៨៨។ *សូមមើលផងដែរ* ជាទូទៅសេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5) ផ្នែក ឆ "កង្វះភស្តុតាងគាំទ្រការចោទប្រកាន់"។

[3577] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤៥២។

[3578] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤៥២។

[3579] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២២៣១ យោងទៅលើប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៥៨-៥៩, ៧៨-៧៩ (បានលើកឡើងថា ក្រោយពេលរៀបការ គេអនុញ្ញាតឲ្យគាត់និងប្តីជួបគ្នារៀងរាល់១០-១៥ថ្ងៃម្តង។ ក្រោយពីនោះមក គេឲ្យប្តីគាត់ទៅធ្វើការនៅភ្នំគិរីរម្យ ហើយបន្ទាប់មក ពួកគាត់អាចជួបគ្នាម្តងនៅរៀងរាល់មួយខែឬពីរខែ)។ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ (សយ ណារឿន) ឯកសារលេខ E1/489.1 ទំព័រ ៣១, ៣៧ (ពន្យល់ថា គាត់នៅជាមួយប្តីបានបីថ្ងៃក្រោយពេលរៀបការ ហើយគេតម្រូវឲ្យពួកគាត់វិលត្រឡប់ទៅអង្គភាពរៀងៗខ្លួនវិញ។ ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ (កាន ថុល) ឯកសារលេខ E1/327.1 ទំព័រ ៥៦-៥៨ (លើកឡើងថា ក្រោយពេលពិធីរៀបការ គេអនុញ្ញាតឲ្យប្តីប្រពន្ធនៅជាមួយគ្នាបានបីថ្ងៃ។ ក្រោយពីនោះ គេអនុញ្ញាតឲ្យពួកគាត់ជួបគ្នា១០ថ្ងៃម្តង)។ ប្រតិ

បំបែកពីប្តីភ្លាមៗក្រោយពីលោកស្រីមានផ្ទៃពោះ[3580]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា អ្វីដែលសំខាន់គឺការយល់ឃើញដែលថា បទបញ្ជារៀបអាពាហ៍ពិពាហ៍មានគោលបំណងមួយដែលជាផ្នែកនៃគោលបំណងរួម។ ដូច្នេះ ពុំមានអ្វីខុសប្លែកគ្នាថាតើ គោលបំណងក្នុងរឿងក្តីនេះនៃការបង្កើតកូននោះ ត្រូវបានបំពេញតាមករណីជាក់ស្តែង ដែរ ឬយ៉ាងណានោះឡើយ។ យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងភាពពុំស៊ីសង្វាក់គ្នា និងសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ដោយសមហេតុផលថា មានអត្ថិភាពនៃគោលបំណងពីរចំពោះបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍នោះ។

### iii. ធាតុផ្សំបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍

1287.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាមានអត្ថិភាពនៃគោលការណ៍ផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការស្ម័គ្រចិត្តក៏ដោយ ក៏ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយបង្ខំទូទាំងប្រទេសក្នុងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[3581]។ ក្នុងហេតុការណ៍ខ្លះ ប្តីប្រពន្ធអាចរៀបចំការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន[3582] និងបន្ថែមលើនេះ ការរៀបចំដាច់ដោយឡែកត្រូវបានធ្វើឡើងសម្រាប់

---

ចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ (កង អ៊ុត) ឯកសារលេខ E1/322.1 ទំព័រ ២៧-២៨ (ផ្តល់សក្ខីកម្មថា យប់ថ្ងៃរៀបការ គាត់មិនបានចំណាយពេលនៅជាមួយប្តីគាត់ទេ តែផុតពីនោះមក គេបានណែនាំគាត់ឲ្យនៅជាមួយប្តីគាត់រយៈពេលបីយប់។ បន្ទាប់មកពួកគាត់ចេញទៅធ្វើការនៅទីតាំងផ្សេងៗគ្នា ហើយគេអនុញ្ញាតឲ្យជួបគ្នា១០ថ្ងៃម្តង)។ ប្រតិចារឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៧២-៧៣ (បានលើកឡើងថា ក្រោយពេលរៀបការ ប្តីគាត់មកសួរសុខទុក្ខគាត់មួយអាទិត្យម្តង)។ ប្រតិចារឹកថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ៦-៧ (បានពន្យល់ថា ក្រោយពេលរៀបការ គេអនុញ្ញាតឲ្យគាត់និងប្តីគាត់ជួបគ្នា១០-១៥ថ្ងៃម្តង)។ ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៧៤-៧៥។ ប្រតិចារឹកថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/463.1 ទំព័រ ៣៦-៣៧ (បានលើកឡើងថា គេអនុញ្ញាតឲ្យគាត់និងប្រពន្ធគាត់បានជួបគ្នា ១០ ថ្ងៃម្តង)។ ប្រតិចារឹកថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ភ្លៅ យ៉ាវ) ឯកសារលេខ E1/264.1 ទំព័រ ២៥ (បានពន្យល់ថា ក្រោយពេលរៀបការ គេប្រាប់ឲ្យប្តីប្រពន្ធវិលត្រឡប់ទៅតាមអង្គភាពរៀងៗខ្លួនវិញ ហើយពួកគាត់អាចជួបគ្នា ១០ ថ្ងៃម្តង)។

[3580] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២២៣១ យោងទៅលើប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៤៥-៤៨ (បានលើកឡើងថា ក្រោយពេលគាត់មានផ្ទៃពោះ គេបានបញ្ជូនប្តីគាត់ទៅការដ្ឋានមួយផ្សេង ហើយអនុញ្ញាតឲ្យប្តីគាត់មកសួរសុខទុក្ខគាត់បានពីរបីថ្ងៃក្នុងពេលពីរខែម្តង)។

[3581] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៨, ៣៦៧០។

[3582] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩៩-៣៥៦០។

ទាហានដែលពិការដោយសាររបួសក្នុងសមរភូមិ ដើម្បីរៀបអាពាហ៍ពិពាហ៍[3583]។ ពិធីរៀបអាពាហ៍ពិពាហ៍តាមធម្មតាបានកើតឡើងដោយឥតមានការជាប់ពាក់ព័ន្ធទៅនឹងប្រពៃណី ឬសមាជិកគ្រួសារ និងជាញឹកញាប់បានកើតឡើងជាសមូហភាពក្នុងទ្រង់ទ្រាយធំ[3584]។ ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ បុគ្គលត្រូវបានដាក់ឱ្យនៅជាមួយគ្នា និងត្រូវបានតាមដានដើម្បីប្រាកដថា ការរួមដំណេកបានកើតឡើង[3585]។ ការខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍មានហានិភ័យដល់ស្លាប់ ឬការអប់រំកែប្រែឡើងវិញ ដូច្នេះហើយប្តីប្រពន្ធបានលាក់បាំងការមិនរួមដំណេកនោះ[3586]។

1288.ខៀវ សំផន បានលើកការជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ (១) គោលការណ៍បក្សកុម្មុយនីស្តកម្ពុជាស្តីពីការស្ម័គ្រចិត្តទៅនឹងការរៀបអាពាហ៍ពិពាហ៍ (២) ការរៀបអាពាហ៍ពិពាហ៍របស់ទាហានពិការ (៣) លក្ខណៈ និងការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ (៤) បរិយាកាសបង្ខិតបង្ខំដែលក្នុងនោះការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍បានកើតឡើង និង (៥) ការតាមដាន និងការលាក់បាំងនៃការខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ ការជំទាស់នីមួយៗនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយដូចខាងក្រោម។

- *គោលការណ៍ការស្ម័គ្រចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការរៀបអាពាហ៍ពិពាហ៍*

1289.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែលបង្ហាញថា មានគោលការណ៍ស្ម័គ្រចិត្តផ្លូវការស្តីពីការរៀបអាពាហ៍ពិពាហ៍[3587] ដែលត្រូវបានបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងរបស់អតីតកម្មាភិបាលជាច្រើននាក់នៃបក្សកុម្មុយនីស្តកម្ពុជា[3588]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ភស្តុតាងនៃការស្ម័គ្រចិត្តដែលបានពិភាក្សាដោយកម្មាភិបាលអាចពុំមែនជាការពិតប្រាកដ និងបានសង្កេតផងដែរទៅលើបំណងរបស់កម្មាភិបាលចង់កាត់បន្ថយជាអប្បបរមានៃការទទួលខុសត្រូវផ្ទាល់ខ្លួន[3589]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរថា មានហេតុការណ៍ខ្លះនៃការស្ម័គ្រ

---

[3583] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦។

[3584] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៩-៣៦៤០, ៣៦៩១។

[3585] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១, ២៦៤៤, ៣៦៦០, ៣៦៩៦។

[3586] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[3587] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤២។

[3588] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧។

[3589] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

ចិត្តរៀបអាពាហ៍ពិពាហ៍ ព្រមទាំងឧទាហរណ៍មួយចំនួននៃការប្រកែកមិនព្រមដោយគ្មានផលវិបាកកើតឡើង[3590]។ ទោះជាយ៉ាងណាក្តី ជារួម បក្សកុម្មុយនីស្តកម្ពុជាបានតម្រូវឱ្យបុគ្គលធ្វើតាមមាគ៌ាបក្សដោយឥតលក្ខខណ្ឌរួមទាំងបទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[3591] និងថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានពិពណ៌នាពិធីរៀបអាពាហ៍ពិពាហ៍នោះថា ដោយបង្ខំ ឬគ្មានការស្ម័គ្រចិត្ត[3592]។ ជាទូទៅបុគ្គលបានយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយសារការភ័យខ្លាច រួមទាំងការភ័យខ្លាចទទួលរងគ្រោះថ្នាក់ការដាក់ឱ្យស្ថិតក្រោមការចោទប្រកាន់ ការបញ្ជូនទៅធ្វើការអប់រំកែប្រែឡើងវិញ ការផ្លាស់ទីទៅកន្លែងផ្សេង ឬសម្លាប់[3593]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជាមានគោលការណ៍ស្ម័គ្រចិត្តក៏ដោយ ក៏ពុំមានគោលនយោបាយនៃស្ម័គ្រចិត្តប្រកបដោយអត្ថន័យក្នុងការអនុវត្តន៍នោះដែរ[3594]។

1290.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន"ជ្រើសរើសមិនអើពើ"លើគោលការណ៍ស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានបង្កើតឡើងជាផ្នែកនៃលទ្ធិបក្សកុម្មុយនីស្តកម្ពុជា[3595]។ ក្នុងការគាំទ្រ គាត់បានចោទប្រកាន់កំហុសនៅក្នុង (១) ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបញ្ជាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែល តាមសារណារបស់គាត់ បានបង្ហាញអំពីគោលការណ៍ស្ម័គ្រចិត្ត[3596] (២) ការបដិសេធភស្តុតាងកម្មាភិបាលដែលបានបង្ហាញផងដែរថា គោលការណ៍នេះមានអត្ថិភាព[3597] (៣) ការសំអាងទៅលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីបរិយាកាសបង្ខិតបង្ខំដែលពុំមានភាពជាតំណាង បានបង្ហាញពុំត្រឹមត្រូវ និងរួមបញ្ចូលការយល់ឃើញស្តីពីបទឧក្រិដ្ឋដែលពុំត្រូវបានចោទប្រកាន់ក្នុង

[3590] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧, ៣៦២៣, ៣៦២៥។

[3591] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៨។

[3592] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩។

[3593] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០។

[3594] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3595] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩១។

[3596] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៣, ១២១៣-១២១៥។

[3597] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៤-១១៩៥, ១២០០។

រឿងក្ដីនេះ[3598] និង (៤) ការពិនិត្យលើភស្តុតាងរបស់សាក្សីអ្នកជំនាញ François PONCHAUD, NAKAGAWA Kasumi និង Peg LEVINE[3599]។

1291. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ពុំមានកំហុសនៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនសំអាងទៅលើគោលការណ៍ស្ម័គ្រចិត្តដូចដែលបានគូសបញ្ជាក់ក្នុងឯកសារបក្សកុម្មុយនីស្តកម្ពុជា ឬបានបង្ហាញដោយកម្មាភិបាល[3600]។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញសមហេតុផលស្ដីពីភស្តុតាងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីលើបរិយាកាសបង្ខិតបង្ខំ និងពុំបានបង្កើតការយល់ឃើញស្ដីពីបទឧក្រិដ្ឋដែលពុំត្រូវបានចោទប្រកាន់ឡើយ[3601]។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញសមហេតុផលផងដែរពាក់ព័ន្ធទៅនឹងភស្តុតាងរបស់អ្នកជំនាញ François PONCHAUD, NAKAGAWA Kasumi និង Peg LEVINE[3602]។

## ក) ការបញ្ជាក់របស់បក្សកុម្មុយនីស្តកម្ពុជា

1292. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយស្ដីពីការកសាងគ្រួសារត្រូវបាន"បង្កើតឡើងគួរកត់សម្គាល់"ក្នុងការបោះពុម្ពផ្សាយទស្សនាវដ្ដីយុវជនបដិវត្តថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៤ ចំណងជើងថា "ទស្សនៈបដិវត្ត និងមិនបដិវត្តពិភពលោកចំពោះបញ្ហាកសាងគ្រួសារ"[3603]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការរៀបអាពាហ៍ពិពាហ៍បានផ្អែកលើគោលការណ៍ពីរយ៉ាងរបស់បក្សដូចបានរៀបរាប់ក្នុងចំណុច"ខាងក្រោម"នៃទស្សនាវដ្ដីយុវជនបដិវត្តថា៖ "ទីមួយ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទីពីរ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអីនាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរស?"[3604]។ ជាទូទៅ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយចង្អុលបង្ហាញក្នុងចំណោមនោះទៅលើបទឧទ្ទេសនាមរបស់ ខៀវ សំផន ថា បើទោះបីជាការយល់ព្រមបុគ្គលគឺជាផ្នែកនៃគោលការណ៍រៀបអា

---

[3598] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៦, ១២៥៨, ១២៦១-១២៦២, ១២៧៤។

[3599] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៥, ១២០៩។

[3600] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩០។

[3601] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៣, ៧១៧, ៧២១។

[3602] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤៩, ៦៩១, ៧៤៩។

[3603] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤០ យោងទៅលើលោកទស្សនៈបដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/775។

[3604] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤២ យោងទៅលើទស្សនាវដ្ដីយុវជន ខែតុលា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/765។

ពាហ៍ពិពាហ៍របស់បក្សក៏ដោយ ក៏តាមការជាក់ស្ដែង ការយល់ព្រមរបស់សាមីខ្លួនពុំសូវសំខាន់ដូចការគោរពតាមការណែនាំរបស់អង្គការដែរ[3605]។

1293.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការលើកឡើងថា គោលការណ៍សីលធម៌របស់បក្សកុម្មុយនីស្ដកម្ពុជា ត្រូវបានកំណត់ក្នុងទស្សនាវដ្ដីយុវជនបដិវត្តក្នុងឆ្នាំ ១៩៧៨ ពីព្រោះគោលការណ៍នេះមានអត្ថិភាពចាប់តាំងពីឆ្នាំ ១៩៦៨[3606]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរក្នុងការវាយតម្លៃរបស់ខ្លួនលើឯកសារបោះពុម្ពផ្សាយ *ទង់បដិវត្ត និងយុវជនបដិវត្ត* និងបទឧទ្ទេសនាមរបស់ ខៀវ សំផន ពីខែ មេសា ឆ្នាំ ១៩៧៨ ដោយហេតុថា ឯកសារទាំងនេះពុំមានការយោងជាក់លាក់ទៅលើការរៀបអាពាហ៍ពិពាហ៍ និងត្រូវបានសរសេរដូច្នោះដោយសារឯកសារនេះគឺជាឯកសារបោះពុម្ពផ្សព្វផ្សាយបដិវត្ត[3607]។

1294.សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងលើភស្តុតាងទាំងអស់ចំពោះមុខខ្លួនក្នុងការយល់ឃើញថា គោលការណ៍នៃការស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍"ពុំត្រូវបានផ្ដល់អាទិភាពតាមការជាក់ស្ដែង" និងផ្ទុយទៅវិញត្រូវបានដាក់ឱ្យស្ថិតក្រោមការណែនាំរបស់អង្គការ[3608]។

1295.នៅក្នុងការយល់ឃើញ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតយ៉ាងច្បាស់លាស់ថា "ការយល់ព្រមរបស់បុគ្គល គឺជាផ្នែកនៃគោលការណ៍រៀបអាពាហ៍ពិពាហ៍របស់បក្ស"[3609] និងដូច្នេះ សារណារបស់គាត់ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើគោលការណ៍នេះ ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា ផ្ទុយទៅនឹងអំណះអំណាងរបស់ ខៀវ សំ

---

[3605] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨ យោងទៅលើព្យុហយាត្រានៅទីក្រុងភ្នំពេញប្រារព្ធខួបថ្ងៃ ១៧ មេសា (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/562 ERN 00249989-00249990 (ពាក់ព័ន្ធនឹងសេចក្ដីសម្រេចដែលអនុម័តក្នុងពេលប្រជុំមហាជននាឱកាសប្រារព្ធខួបលើកទី៣ ថ្ងៃ១៧ មេសា ដែល ខៀវ សំផន ថ្លែងសុន្ទរកថាក្នុងចំណោមចំណុចនានា គាត់បានបញ្ចូលនូវការប្ដេជ្ញាចិត្តជាទូទៅថា៖ "(១២) ដាក់ប្រយោជន៍គ្រួសារនិងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្ត")។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៩៧២។

[3606] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤២។

[3607] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៣-១២១៥, ២១១៧។

[3608] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៨។

[3609] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨។

ផន អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា គោលការណ៍ស្ម័គ្រចិត្តទើបតែមានអត្ថិភាពក្នុងឆ្នាំ ១៩៧៨ នោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញទៅលើគោលការណ៍ដែលបានកំណត់ក្នុងទស្សនាវដ្តីយុវជនបដិវត្តឆ្នាំ ១៩៧៨ និងបានប្រើប្រាស់ការបញ្ជាក់នៃគោលការណ៍ក្នុងឯកសារបោះពុម្ពផ្សាយដើម្បីឆ្លុះបញ្ចាំង"គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាស្តីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍ និងវិន័យ"ពេញមួយអំឡុងពេលមុននោះ[3610]។ អំណះអំណាងរបស់ ខៀវ សំផន ដែលលើកផ្ទុយនោះត្រូវបដិសេធចោល។

1296.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា *ទស្សនាវដ្តីយុវជនបដិវត្ត*ឆ្នាំ ១៩៧៥ ដែលត្រូវបានយោងទៅលើដោយអង្គជំនុំជម្រះសាលាដំបូង បានសំដៅយ៉ាងជាក់ច្បាស់ទៅលើ"ការកសាងគ្រួសារ"[3611]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ឯកសារបោះពុម្ពផ្សាយនេះបានគូសបញ្ជាក់នូវ"សារៈសំខាន់នៃគ្រួសារដែលជាមូលដ្ឋានសម្រាប់ធ្វើឱ្យសង្គមមនុស្សរីកចម្រើន និងជឿនលឿន"[3612] និងបានដកស្រង់ចេញពីឯកសារបោះពុម្ពផ្សាយដែលបានបញ្ជាក់ថា "យើងទុកបញ្ហាគ្រួសារជាផ្នែកមួយដែលបេះមិនដាច់ពីបញ្ហាប្រទេសជាតិ និងប្រជាជនទាំងមូល"[3613]។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ដែលថា ឯកសារដែលគាត់ដកស្រង់នោះពុំមានការសំដៅទៅលើបែបនេះ ត្រូវបដិសេធចោល[3614]។

1297.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបញ្ជាក់ដទៃទៀតនៃបដិវត្តបានបង្កើតជាមូលដ្ឋាននៃការយល់ឃើញដែលថា *អង្គការ* បានលុបលើជម្រើសបុគ្គល។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការលើកឡើងក្នុង*ទស្សនាវដ្តីយុវជនបដិវត្ត*ឆ្នាំ ១៩៧៥ ដែលអំពាវនាវឱ្យមានការលុបបំបាត់កម្មសិទ្ធិឯកជន ដែលនេះបង្ហាញថា សេចក្តីសម្រេចរបស់អង្គ

---

[3610] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ចំណងជើងតូច ១៤.៣.២.១ (គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាស្តីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍ និងវិន័យ) ទំព័រ ១៧៩៤។

[3611] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤០ យោងទៅលើ *ទស្សនាវដ្តីយុវជនបដិវត្ត* លោកទស្សនៈបដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/775។

[3612] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤០។

[3613] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤០ យោងទៅលើ *ទស្សនាវដ្តីយុវជនបដិវត្ត* លោកទស្សនៈបដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ១៩៧៥ ERN 00407100 ឯកសារលេខ E3/775 ទំព័រ ២-៣។

[3614] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២១៤។

ការដែលបានផ្អែកលើអត្ថប្រយោជន៍រួម មានឧត្តមភាពលើជម្រើស ឬអារម្មណ៍បុគ្គល[3615] ព្រមទាំងបទឧទ្ទេសនាមរបស់ ខៀវ សំផន ក្នុងឆ្នាំ ១៩៧៨ ដែលបង្ហាញថា អត្ថប្រយោជន៍គ្រួសារ និងបុគ្គលត្រូវដាក់ឱ្យស្ថិតក្រោមបដិវត្ត[3616]។ ទស្សនាវដ្ដីដទៃទៀតនៃយុវជនបដិវត្ត ដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា បុគ្គលត្រូវបានតម្រូវពេញលេញឱ្យកសាងជាតិ និងលុបបំបាត់អារម្មណ៍ផ្ទាល់ខ្លួន[3617]។ ផលវិបាកក្នុងការខកខានអនុវត្តតាមការចង់បានរបស់អង្គការ ត្រូវបានគាំទ្រដោយការបញ្ជាក់ក្នុងឯកសារបោះពុម្ពផ្សាយទង់បដិវត្តឆ្នាំ ១៩៧៥ ស្ដីពីការលុបបំបាត់"ទាំងស្រុង" និងការបន្សុទ្ធ"ទស្សនៈមិន

---

[3615] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៤ យោងទៅលើ *ទស្សនាវដ្ដីយុវជនបដិវត្ត* ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/750។

[3616] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨ យោងទៅព្យុហយាត្រានៅទីក្រុងភ្នំពេញប្រារព្ធខួបថ្ងៃ១៧ មេសា (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/562 ERN 00249989-00249990 (ពាក់ព័ន្ធនឹងសេចក្ដីសម្រេចដែលអនុម័តក្នុងពេលប្រជុំមហាជននាឱកាសប្រារព្ធខួបលើកទី៣ ថ្ងៃ១៧ មេសា ដែល ខៀវ សំផន ថ្លែងសុន្ទរកថាក្នុងចំណោមចំណុចនានា គាត់បានបញ្ចូលនូវការប្ដេជ្ញាចិត្តជាទូទៅថា៖ "(១២) ដាក់ប្រយោជន៍គ្រួសារនិងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្ត")។

[3617] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨ យោងទៅលើទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត ខែ មករា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/772 ERN 00376366 ទំព័រ ១៤ ("យុវជន យុវនារីយើងជំនាន់នេះ ត្រូវចាប់អារម្មណ៍ឲ្យដល់កម្រិត ខិតខំកសាងខ្លួនឲ្យបានល្អតាមគោលជំហរបដិវត្ត គ្រប់ផ្នែករបស់បក្សយើង កុំរវីរវល់ ឬ ជំពាក់ជំពិននឹងបញ្ហាកំប៉ិកកំប៉ុកជុំវិញអាត្មាខ្លួន ជុំវិញបុគ្គលខ្លួន ដែលជាហេតុនាំឲ្យយើង កសាងខ្លួនយឺត ឬក៏ប្រទាញខ្លួនយើង ឲ្យធ្លាក់ថយក្រោយវិញនោះឡើយ")។ ទស្សនាវដ្ដីយុវជននិងយុវនារីបដិវត្តខែសីហា ឆ្នាំ១៩៧៥ ឯកសារលេខ E3/733 ERN 00064005-00064006 ទំព័រ ១-២("យុវជន យុវនារីកម្ពុជាយើងមានភារកិច្ចការពារប្រទេស និងកសាងប្រទេស ឲ្យបានរឹងប៉ឹង ខ្លាំងពូកែ និងថ្កុំថ្កើងរុងរឿងឆាប់របហ័សបំផុត ទៅតាមទិសថ្មីនៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមរបស់បក្សដាច់ខាត")។ ទស្សនាវដ្ដី*យុវជន និងយុវនារីបដិវត្ត*ខែតុលា ឆ្នាំ១៩៧៥ ឯកសារលេខ E3/729 ERN 00063412 ទំព័រ ២២-២៣("ត្រូវប្រយុទ្ធកសាង បំពាក់បំប៉ននិងពង្រឹងពង្រីកជំហរអធនរបស់បក្សឲ្យដល់ខ្លួន ឲ្យដល់ជួរយុវជន-យុវនារីបដិវត្តយើង ជាប់ជានិច្ច កុំអធ្យាស្រ័យឲ្យខ្លួន កុំបន្ធូរបន្ថយ ឬ ធូររលុងទុកទ្វារចំហ ឲ្យគោលវណ្ណៈផ្សេងៗ ដែលមិនកម្មាជីព ចូលមកនៅលាយឡំ រួមរស់ជាមួយគោលជំហរវណ្ណៈអធនរបស់បក្សបានឡើយ ធាតុអធនរបស់បក្សទាំង៤ ពោលគឺ ធាតុលះបង់ខ្ពស់បំផុត ធាតុប្រយុទ្ធស្រួចបំផុត ធាតុគោរពអង្គការវិន័យដោយឥតលក្ខខ័ណ្ឌ និងធាតុថ្វៃប្រតិដ្ឋ កសាងមិនឈប់ឈរ។ [...] ព្រមជាមួយនេះត្រូវប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ជាប់ជានិច្ច ប្រុងប្រយ័ត្នទាំងខាងទស្សនៈគោលជំហរ ប្រុងប្រយ័ត្នទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយគោរពអង្គការវិន័យរបស់បក្សដាច់ខាត គោរពនិងអនុវត្តមាគ៌ា និងលក្ខការណ៍ចាត់តាំងរបស់បក្សដាច់ខាត")។ ទស្សនាវដ្ដី*យុវជន និងយុវនារីបដិវត្ត* ខែធ្នូ ឆ្នាំ១៩៧៥ ឯកសារលេខ E3/730 ERN 00063725 ទំព័រ ២០-២១ ("ខាងចាត់តាំង ក៏ត្រូវយកចិត្តទុកដាក់អប់រំ កសាងយុវជន យុវនារីយើង ឲ្យមានអង្គការចាត់តាំងត្រឹមត្រូវ រឹងប៉ឹង មានការគោរពអង្គការវិន័យ ដោយឥតលក្ខខ័ណ្ឌ និងដោយភ្ញាក់រលឹក")។

ត្រឹមត្រូវ”[3618]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបត្រឹមត្រូវនូវភស្តុតាងដែលខ្លួនបានពិចារណា និងសន្និដ្ឋានសមហេតុផលថា សេចក្តីសម្រេចរបស់អង្គការលុបលើជម្រើសបុគ្គល។

1298.អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើការកំណត់ដែលបានធ្វើឡើងក្នុងឯកសារបោះពុម្ពផ្សាយទាំងនេះ ឬក្នុងបទឧទ្ទេសនាមរបស់គាត់ ផ្សេងពីនេះដោយផ្អែកលើបរិបទបដិវត្តដែលការកំណត់នេះបានបង្កើតឡើង។ គាត់ខកខានក្នុងការផ្តល់ភស្តុតាងពាក់ព័ន្ធគាំទ្រការអះអាងរបស់ខ្លួនដែលថា អង្គជំនុំជម្រះតុលាការកំពូលគប្បីអនុម័តវិធីសាស្ត្រនៃការពិនិត្យអត្ថបទដែលផ្ទុយទៅនឹងការបកស្រាយត្រង់ៗនៃអត្ថបទនោះ។

1299.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងដោយផ្ទាល់ទៅលើបទឧទ្ទេសនាមដែលបានដកស្រង់ដោយ ខៀវ សំផន នៅពេលសន្និដ្ឋានថា “អង្គការស្ថិតនៅពីលើឪពុកម្តាយ ឬជំនួសឱ្យឪពុកម្តាយនៅក្នុងរបបថ្មីនោះ”[3619]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើឯកសារបោះពុម្ពផ្សាយទង់បដិវត្តចាប់ទីឆ្នាំ ១៩៧៨។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបទឧទ្ទេសនាមនៅពេលកំណត់ថា ការយល់ព្រមរបស់សាមីខ្លួនរៀបអាពាហ៍ពិពាហ៍ពុំសូវសំខាន់ជាងការគោរពតាមការណែនាំអង្គការ ពីព្រោះ“ការណែនាំនេះត្រូវបានចាត់ទុកថាជាការបង្ហាញនៃអត្ថប្រយោជន៍រួមរបស់ជាតិ វណ្ណៈកម្មករកសិករ ប្រជាជន និងបដិវត្ត ដែលអត្ថប្រយោជន៍បុគ្គល និងគ្រួសារត្រូវតែនៅពីក្រោមនោះ”[3620]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ពាក្យពេចន៍នៃការយល់ឃើញនេះឆ្លើយតបយ៉ាងពេញលេញទៅនឹងការលើកឡើងជាក់លាក់របស់ ខៀវ សំផន នៅក្នុងបទឧទ្ទេសនាមរបស់គាត់[3621]។ អំណះអំណាងរបស់ ខៀវ សំផន ដែលលើកផ្ទុយនេះ ត្រូវបដិសេធចោល។

---

[3618] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤១ យោងទៅលើលោកទស្សនៈបដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារខែមិថុនា ឆ្នាំ១៩៧៥ ឯកសារលេខ E3/775 ERN 00407106-00407107 ទំព័រ ១៩-២០ (“យុវជន យុវនារីយើង ត្រូវកំចាត់ចោចេញឱ្យអស់ នឹងឱ្យជ្រះស្រឡះ នូវទស្សនៈ គោលជំហរខុសឆ្គង ចំពោះបញ្ហាកសាងគ្រួសារនេះ ដូចជាសេរីខាងសីលធម៌ តក់ក្រហល់អន្ទះអន្ទែង ឬរើរើរវាយ ចង់កសាងគ្រួសារពីក្មេងពេក ឬសេរីមិនគោរពអង្គការវិន័យ និមគោរពសមូហភាព ក្នុងការកសាងគ្រួសារជាដើម”)។

[3619] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៩។

[3620] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨។

[3621] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១៩២៧ យោងទៅលើហាយាត្រានៅទីក្រុងភ្នំពេញប្រារព្ធខួបថ្ងៃ ១៧ មេសា (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ឯកសារលេខ E3/562 ERN

## ខ) ភស្តុតាងកម្មាភិបាល

1300. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា រៀល សន, ឱ ហួ, ពេជ្រ ជឹម, មាស វឿន, ទេព ប៉ូច និង យូ វ៉ាន់ នៅពេលធ្វើការយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយផ្អែកលើ"ការយល់ព្រម"របស់បុគ្គល[3622]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធភស្តុតាងរបស់អតីតកម្មាភិបាលស្តីពីអត្ថិភាពនៃគោលការណ៍ស្ម័គ្រចិត្ត និងបានកត់សម្គាល់ថា "ការយល់ព្រមដែលគូស្រករបានផ្តល់ឱ្យទៅពួកគេអាចពុំមែនជាការពិត និងបំណងចង់កាត់បន្ថយជាអប្បបរមានូវការទទួលខុសត្រូវផ្ទាល់ខ្លួន"[3623]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក ពេជ្រ ជឹម ជាករណីពិសេសចំពោះចំណុចនេះ ដោយសារការទទួលស្គាល់របស់គាត់ថា "អ្នកដែលស្នាក់ស្ទើរឆ្លើយតបនៅពេលរៀបអាពាហ៍ពិពាហ៍ គឺពុំបានយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍"[3624]។

1301.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបដិសេធភស្តុតាងកម្មាភិបាល ដោយហេតុថា កម្មាភិបាលភាគច្រើនមានការធានានូវការគ្មានការចោទប្រកាន់ ដូច្នេះ ពុំមានអ្វីត្រូវភ័យខ្លាចការដាក់បន្ទុកនោះឡើយ ហើយភស្តុតាងរបស់ពួកគេត្រូវបានគាំទ្របន្ថែមដោយឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា និងសាក្សីដទៃទៀតដែលពុំមែនជាកម្មាភិបាល[3625]។ គាត់បានចោទប្រកាន់កំហុសជាច្រើនផ្នែកអង្គហេតុក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភស្តុតាងកម្មាភិបាលដែលអង្គជំនុំ

---

00249989-00249990 (ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលអនុម័តក្នុងពេលប្រជុំមហាជននាឱកាសប្រារព្ធខួបលើកទី៣ ថ្ងៃ១៧ មេសា ដែល ខៀវ សំផន ថ្លែងសុន្ទរកថាក្នុងចំណោមចំណុចនានា គាត់បានបញ្ចូលនូវការប្តេជ្ញាចិត្តជាទូទៅថាៈ "(១២) ដាក់ប្រយោជន៍គ្រួសារនិងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្ត")។

[3622] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧ យោងទៅលើប្រតិចារឹកថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ (រៀល សន) ឯកសារលេខ E1/279.1 ទំព័រ ២៨។ ប្រតិចារឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហួ) ឯកសារលេខ E1/301.1 ទំព័រ ៥៦។ ប្រតិចារឹកថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/290.1 ទំព័រ ២៨-២៩, ៣៤។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៣-៤, ៥-៧។ ប្រតិចារឹកថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៥០។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ (ទេព ប៉ូច) ឯកសារលេខ E1/461.1 ទំព័រ ៦៣។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៣៨។

[3623] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3624] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3625] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៤-១១៩៥។

ជម្រះបានពិចារណា ព្រមទាំងការមិនអើពើលើភស្តុតាងពាក់ព័ន្ធដទៃទៀតដែលគាំទ្រគោលការណ៍ស្ម័គ្រចិត្ត នោះ[3626]។

1302.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានបដិសេធភស្តុតាងកម្មាភិបាលដោយផ្អែកតែទៅលើមូលដ្ឋាននៃការកាត់បន្ថយជាអប្បបរមានៃការទទួលខុសត្រូវផ្ទាល់ខ្លួនប៉ុណ្ណោះទេ ថែមទាំងបានផ្អែកទៅលើភស្តុតាងទូលំទូលាយដែលបង្ហាញថា មានបរិយាកាសភិតភ័យទូទៅដែលធ្វើឱ្យការស្ម័គ្រចិត្តលែងចាំបាច់[3627]។ ពាក់ព័ន្ធទៅនឹងភស្តុតាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសារៈសំខាន់នៃការស្ម័គ្រចិត្ត មានបុគ្គលជាច្រើនបានផ្តល់សក្ខីកម្មផងដែរចំពោះបរិយាកាសភ័យខ្លាចជាទូទៅដែលក្នុងនោះពុំអាចមានការស្ម័គ្រចិត្តពិតប្រាកដឡើយ[3628]។

1303.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសមិនធ្វើការសំអាងទៅលើភស្តុតាងកម្មាភិបាលមិនត្រឹមតែដោយសារមានបំណងចង់កាត់បន្ថយជាអប្បបរមានូវការទទួលខុសត្រូវផ្ទាល់ខ្លួនប៉ុណ្ណោះទេ ថែមទាំងជាសត្យានុម័តទៅលើការយល់ឃើញដែលថា ការស្ម័គ្រចិត្តដែលត្រូវបានពិពណ៌នាដោយកម្មាភិបាលនោះពុំមែនជាការពិតប្រាកដ ដោយសារ"បរិយាកាសភ័យខ្លាចទូទៅ"[3629]។ ការដែលថា កម្មាភិបាលខ្លះត្រូវបានផ្តល់ការធានានូវការគ្មានការចោទប្រកាន់[3630] ពុំមានអានុភាពលើការយល់ឃើញទូលំទូលាយនេះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ពុំមានការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ កម្មាភិបាលខ្លួនឯងអាចចាត់ចែងការរៀបអាពាហ៍ពិពាហ៍ ដែរ ឬយ៉ាងណាឡើយ[3631]។ ពាក់ព័ន្ធទៅនឹងការដែល ខៀវ សំផន បានលើកត្រឹមត្រូវថា កម្មាភិបាលពុំមានតួនាទីចាត់ចែងពិធីរៀបអាពាហ៍ពិពាហ៍ នេះបានគាំទ្របន្ថែមទៀតលើការសន្និដ្ឋានដែលថា ភស្តុតាងរបស់ពួកគេបានសំដៅទៅលើគោលការណ៍ ជាជាងការអនុវត្តន៍ជាក់ស្តែង។

1304.បន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើភស្តុតាងទូលំទូលាយដែលតាមទស្សនៈរបស់គាត់បានបង្ហាញថា កម្មាភិបាលបានអះអាងត្រឹម

---

[3626] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០០។

[3627] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩០។

[3628] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៩។

[3629] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3630] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២២២៥។

[3631] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៥។

ត្រូវថា មានគោលការណ៍ស្ម័គ្រចិត្តក្នុងការអនុវត្តន៍ជាក់ស្តែង។ អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការយល់ឃើញពីដំបូងរបស់ខ្លួនថា ឯកសារបក្សកុម្មុយនីស្តកម្ពុជាបើទោះបីជាផ្ទុះបញ្ចាំងនូវគោលការណ៍ស្ម័គ្រចិត្តក្នុងទ្រឹស្តីក៏ដោយ ក៏បានបង្ហាញថា បុគ្គលនោះត្រូវបានជម្រុញឱ្យស្តាប់បង្គាប់អង្គការក្នុងការអនុវត្តន៍ជាក់ស្តែងដែរ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានពន្យល់នូវមូលហេតុដូចម្តេចបានជាភស្តុតាងនេះពុំបានបង្ហាញនូវការបញ្ជាក់បន្ថែមជារួមដោយភស្តុតាងកម្មាភិបាល។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើការពិចារណាលើបញ្ហាថាតើ មានកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីលើគោលការណ៍ស្ម័គ្រចិត្ត ដែរ ឬយ៉ាងណា ប៉ុន្តែទោះជាយ៉ាងណាក្តីរកពុំឃើញនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងភស្តុតាងរបស់កម្មាភិបាល រៀល សន, ឱ ហូ, មាស វឿន, ទេព ប៉ូច និង យូ វ៉ាន់ ឡើយ។

1305.ទាក់ទងទៅនឹងភស្តុតាងរបស់ ពេជ្រ ជឹម ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានលាក់បាំងផ្នែកខ្លះនៃសក្ខីកម្មរបស់ ពេជ្រ ជឹម ដែលក្នុងនោះបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃគោលការណ៍ស្ម័គ្រចិត្ត[3632] និងពុំបានអើពើផងដែរទៅលើភស្តុតាងដែលបង្ហាញថា គោលការណ៍នោះត្រូវបានអនុវត្តត្រឹមត្រូវជាក់ស្តែង[3633]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់នូវភស្តុតាងរបស់ ពេជ្រ ជឹម លើគោលការណ៍ស្ម័គ្រចិត្ត និងបានយល់ឃើញថា "សាក្សី ពេជ្រ ជឹម បានផ្តល់សក្ខីកម្មថា សម្រាប់ការរៀបអាពាហ៍ពិពាហ៍ដែលត្រូវរៀបចំ សាមីខ្លួនត្រូវស្ម័គ្រចិត្ត"[3634]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យផងដែរលើភស្តុតាងរបស់គាត់ដែលថា "មានការបង្ហាញច្បាស់ថា អ្នកដែលស្ទាក់ស្ទើរឆ្លើយតបនៅពេលពិធីរៀបអាពាហ៍ពិពាហ៍ គឺពុំបានយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍"[3635]។ ការជំទាស់របស់ ខៀវ សំផន ត្រូវបដិសេធចោល ដោយសារគាត់ត្រឹមតែបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីធ្វើការសន្និដ្ឋានមួយផ្សេងអំពីផ្នែកទាំងនេះនៃភស្តុតាង ដោយគ្មានបង្ហាញនូវកំហុសណាមួយ។ ខៀវ សំផន ខកខានផងដែរក្នុងការបង្ហាញហេតុដូចម្តេចបានភស្តុតាងរបស់ ពេជ្រ ជឹម ដែលថា

---

[3632] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០០។

[3633] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០០។

[3634] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧។

[3635] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧។

គាត់ពុំបានដឹងដោយផ្ទាល់នូវការអនុវត្តន៍តាមមន្ទីរដែលឆ្ងាយនៅក្នុងព្រៃនោះ ជាប់ពាក់ព័ន្ធទៅនឹងការអនុវត្តន៍គោលការណ៍ស្ម័គ្រចិត្ត[3636]។

1306.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងជាពិសេសមានកំហុសក្នុងការបដិសេធសក្ខីកម្មរបស់កម្មាភិបាល យូ វ៉ាន់ និង ប្រាក់ យុត ស្តីពីគោលការណ៍ស្ម័គ្រចិត្ត[3637] និងពុំបានអើពើទាំងស្រុងលើភស្តុតាងរបស់កម្មាភិបាល ឃឹម បឿន, នាង អ៊ួច, ភ្លៅ យ៉ាវ និង ផាន់ ឆេន[3638]។ គាត់បានយោងផងដែរទៅលើភស្តុតាងរបស់កម្មាភិបាល កាន ធុល, ជុំ សេង, តក់ ប៊ុយ និង ឈុយ ហ៊ុយ ដែលបាន"អះអាងនូវភាពចាំបាច់សម្រាប់ការស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍"[3639]។

1307.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាច្បាស់លាស់លើភស្តុតាងរបស់សាក្សីនេះក្នុងការវិភាគរបស់ខ្លួនលើភស្តុតាងកម្មាភិបាលក៏ដោយ[3640] ក៏អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញតាមការបញ្ជាក់ជាទូទៅដែលថា អង្គជំនុំជម្រះបានបដិសេធភស្តុតាងកម្មាភិបាលស្តីពីអត្ថិភាពនៃគោលការណ៍ស្ម័គ្រចិត្តដោយប្រសិទ្ធភាព។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តសមហេតុផលក្នុងការធ្វើដូច្នេះ។ ដូច្នេះ បើទោះបីជាភស្តុតាងខ្លះដែលត្រូវបានគូសបញ្ជាក់ដោយ ខៀវ សំផន បង្ហាញថា កម្មាភិបាលដទៃទៀតបានផ្តល់ភស្តុតាងប្រហាក់ប្រហែលគ្នាអំពីអត្ថិភាពនៃគោលនយោបាយផ្លូវការនៃការស្ម័គ្រចិត្តក៏ដោយ[3641] ក៏អង្គជំនុំជម្រះតុលាការ

---

[3636] *សូមមើល* ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៦។ *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០០។

[3637] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៥-១២០៦។

[3638] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០១។

[3639] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៣។

[3640] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧ យោងទៅលើភស្តុតាងរបស់ យោងទៅលើប្រតិចារឹកថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ (រៀល សន) ឯកសារលេខ E1/279.1 ទំព័រ ២៨។ ប្រតិចារឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឌិ ហួ) ឯកសារលេខ E1/301.1 ទំព័រ ៥៦។ ប្រតិចារឹកថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/290.1 ទំព័រ ២៨-២៩, ៣៤។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/291.1 ទំព័រ ៣-៤, ៥-៧។ ប្រតិចារឹកថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៥០។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ (ទេព ប៊ូច) ឯកសារលេខ E1/461.1 ទំព័រ ៦៣។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៣៨។

[3641] ភស្តុតាងរបស់កម្មាភិបាលមួយចំនួនគាំទ្រការអះអាងរបស់ ខៀវ សំផន។ *សូមមើល* ប្រតិចារឹកថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៥៨ (បានផ្តល់ភស្តុតាងអំពីការរៀបចំការរៀបអាពាហ៍ពិពាហ៍ និងបានយោង

កំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណារួចរាល់លើភស្តុតាងទាំងនេះ និងបានសន្និដ្ឋានដោយសមហេតុផល។ អាស្រ័យហេតុនេះ ខៀវ សំផន ត្រូវបដិសេធចោល។

1308.យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំអើពើទៅលើភស្តុតាងកម្មាភិបាលដែលថា មាគ៌ាបក្សកុម្មុយនីស្តកម្ពុជាពុំត្រូវបានអនុវត្តត្រឹមត្រូវ[3642]។ ក្នុងការគាំទ្រ គាត់បានចង្អុលបង្ហាញទៅលើភស្តុតាងរបស់ ពេជ្រ ជឹម និង ម៉ឹង វេត ព្រមទាំងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ផ្ទាល់[3643]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពេជ្រ ជឹម បានអះអាងថា កម្មាភិបាលខ្លះ"ពុំបានផ្តល់សេចក្តីណែនាំច្បាស់លាស់ដល់ប្រជាជន"[3644] ហើយ ម៉ឹង វេត បានគូសបង្ហាញថា ការស្ម័គ្រចិត្តរបស់បុគ្គលនីមួយៗនូវបទបញ្ញានោះមានលក្ខណៈខុសៗគ្នា[3645]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងនេះ គឺជាការលើកសាឡើងវិញនូវការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពុំបានអើពើទៅលើភស្តុតាងកម្មាភិបាលដែលបង្ហាញនូវគោលនយោបាយផ្លូវការនៃការស្ម័គ្រចិត្តដែលត្រូវបដិសេធចោលរួចហើយខាងលើ។ ដូច្នេះ អំណះអំណាងបន្ថែមនេះត្រូវបដិសេធចោលផងដែរ។

### គ) ភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីកាលៈទេសៈបង្ខិតបង្ខំ

ទៅលើការពិតដែលថា បុរស និងស្ត្រីបានយល់ព្រមរៀបអាពាហ៍ពិពាហ៍ទៅវិញទៅមក)។ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ (ឃឹម ហឿន) ឯកសារលេខ E1/296.1 ទំព័រ ១៩-២០ (ប្តីប្រពន្ធត្រូវយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ (ភ្នៅ យ៉ាវ) ឯកសារលេខ E1/264.1 ទំព័រ ២៦-២៧ (លទ្ធភាពនៃការបដិសេធការរៀបអាពាហ៍ពិពាហ៍)។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ពុំបានផ្តល់ការយោងត្រឹមត្រូវទៅលើភស្តុតាងរបស់ ប្រាក់ យុត។ ភស្តុតាងរបស់ នាង អ៊ូច សំដៅទៅលើខ្វះសេរីភាពក្នុងការជ្រើសរើសការរៀបអាពាហ៍ពិពាហ៍។ *សូមមើល* ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ ២០១៥ (នាង អ៊ូច) ឯកសារលេខ E1/274.1 ទំព័រ ២៥-២៦ (បានពន្យល់ថា នៅទីកន្លែងមួយចំនួន ពុំមានសេរីភាពជ្រើសរើសការរៀបអាពាហ៍ពិពាហ៍បាន)។ ខៀវ សំផន ខកខានផងដែរក្នុងការផ្តល់ការយោងណាមួយទៅលើភស្តុតាងរបស់ ផាន់ ឆេន និងការចោទប្រកាន់កំហុសទាក់ទងទៅនឹងកម្មាភិបាលនេះ ត្រូវបានបដិសេធចោលថា គ្មានមូលដ្ឋានគាំទ្រ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០១ ជើងទំព័រ ២២៣៩-២២៤០។

[3642] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧១។

[3643] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៧២។

[3644] ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/290.1 ទំព័រ ៣២។

[3645] ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ (ម៉ឹង វេត) ឯកសារលេខ E1/449.1 ទំព័រ ៣៧។

1309.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានពិពណ៌នាអំពីការរៀបអាពាហ៍ពិពាហ៍នោះថា ជាការបង្ខំ ឬគ្មានការស្ម័គ្រចិត្ត[3646]។ បុគ្គលបានយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយសារភ័យខ្លាច ដូចជាការភ័យខ្លាចទទួលរងគ្រោះថ្នាក់ ការដាក់ឱ្យស្ថិតក្រោមការចោទប្រកាន់ ការបញ្ជូនទៅធ្វើការអប់រំកែប្រែ ការផ្លាស់ទីទៅកន្លែងផ្សេង ឬការសម្លាប់[3647]។

1310.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវាយតម្លៃលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើភស្តុតាងដែលពុំមានភាពជាតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី“ដែលជាពិសេសត្រូវបានជ្រើសរើសដើម្បីផ្តកកាយបទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍”[3648]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការចាត់ទុកករណីដែលការរៀបអាពាហ៍ពិពាហ៍ត្រូវបានប្រកែកដោយគ្មានទទួលរងផលវិបាកប៉ះពាល់ណាមួយថា ជាករណីពិសេស ជាជាងជាវិធានទូទៅ[3649]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភាពជាតំណាងនៃសក្ខីកម្មទាំងនេះនៅកម្រិតជាតិ និងបានបដិសេធអំណះអំណាងរបស់គាត់នៅពេលជំនុំជម្រះលើចំណុចនេះ[3650]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងពុំគប្បីពិចារណាលើភស្តុតាងរបស់ មុំ វុន ដែលថា លោកស្រីត្រូវបានរំលោភសេពសន្ថវៈដែលជាការដាក់ទណ្ឌកម្មសម្រាប់ការមិនព្រមរៀបអាពាហ៍ពិពាហ៍ ដោយសារការយល់ឃើញថា ការរំលោភសេពសន្ថវៈពុំត្រូវបានរួមបញ្ចូលជាបទចោទក្នុងរឿងក្តីនេះ[3651]។

1311.សហព្រះរាជអាជ្ញាបានឆ្លើយតបថា នេះជាការសមហេតុផលតែមួយគត់ដែលថា សក្ខីកម្មដែលបានផ្តល់ក្នុងផ្នែកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានសេចក្តីលម្អិតនៃគោលនយោបាយការរៀបអាពាហ៍ពិពាហ៍ច្រើនជាង និងថា នេះជាមូលហេតុចម្បងដែលសាក្សីត្រូវបានកោះហៅនោះ[3652]។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានអនុញ្ញាតពិចារណាលើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីណាមួយលើពិរុទ្ធភាពរបស់ជនជាប់ចោទ

---

[3646] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩។

[3647] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០។

[3648] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦១, ១២៧៤។

[3649] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៩។

[3650] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៦, ១២៥៨, ១២៦១។

[3651] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦២។

[3652] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៣។

ដែលក្នុងរឿងក្តីនេះ រួមបញ្ចូលទាំងអត្ថិភាពនៃគោលនយោបាយ[3653]។ ទាក់ទងទៅនឹងករណីនៃការប្រកែកដោយគ្មានទទួលរងផលវិបាក សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ត្រឹមតែបានផ្តល់ការពន្យល់មួយបែបផ្សេងនៃអង្គហេតុ[3654]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបភស្តុតាងរបស់ មុំ វុន ដែលថា គាត់ត្រូវបានរំលោភសេពសន្ថវៈដោយសារការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍ និងថា កង្វះការដឹងអំពីហេតុការណ៍ប្រហាក់ប្រហែលគ្នាដទៃទៀតនៃការរំលោភសេពសន្ថវៈពុំជាប់ពាក់ព័ន្ធឡើយ[3655]។

1312.សហមេធាវីនាំមុខបានអះអាងថា ឧទាហរណ៍ផ្ទាល់របស់ ខៀវ សំផន ពុំបានគាំទ្រការអះអាងរបស់គាត់ដែលថា បុគ្គលអាចបដិសេធការរៀបអាពាហ៍ពិពាហ៍ដោយគ្មានទទួលរងផលវិបាកដែលប៉ះពាល់ និងនៅគ្រប់ករណី ការដែលថា មានមនុស្សមួយចំនួនដែល“មានសិទ្ធិពិសេស”អាចបដិសេធការរៀបអាពាហ៍ពិពាហ៍នោះ ពុំបានបដិសេធហេតុការណ៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាលក្ខណៈទូទៅជាងនោះឡើយ[3656]។ សហមេធាវីនាំមុខបានអះអាងបន្ថែមទៀតថា ការដកស្រង់ចំណុចតាមការចង់បានរបស់ ខៀវ សំផន ចេញពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើឱ្យបិទបាំងលក្ខណៈពិត និងសារៈសំខាន់នៃភស្តុតាងនោះដែលបានបញ្ជាក់អះអាងនូវអត្ថិភាពនៃគោលនយោបាយនៃការស្ម័គ្រចិត្តប្រកបដោយអត្ថន័យ[3657]។ សហមេធាវីនាំមុខបានឆ្លើយតបថា ភស្តុតាងរបស់ មុំ វុន មានភាពជាតំណាង ដោយសារលោកស្រីបានបញ្ជាក់ការពិតថា អំពើហិង្សាបានបង្ខំឱ្យបុគ្គលរៀបអាពាហ៍ពិពាហ៍[3658]។

1313.ទាក់ទងទៅនឹងការជំទាស់ជាទូទៅទៅលើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើមូលដ្ឋាននៃការដែលគ្មានភាពជាតំណាង ខៀវ សំផន បានគាំទ្រការចោទប្រកាន់របស់គាត់អំពីកំហុសតែតាមរយៈការយោងទៅលើអំណះអំណាងដែលបានបង្ហាញរួចហើយក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលប៉ុណ្ណោះ[3659]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារ

[3653] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៣។

[3654] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២១។

[3655] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៧។

[3656] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៧-៦៤៨។

[3657] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៤-៦៤៦។

[3658] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៣៨។

[3659] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦១ យោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣២១-២៣២៨, ២៤៤០-២៤៤៤, ២៤៥០-២៤៥១។

ណាឃើញថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែបានផ្អែកលើមូលដ្ឋាននៃភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ ថែមទាំងលើភស្តុតាងចេញពី"សាក្សីជាច្រើន"[3660]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសនៃការខ្វះ"ភាពជាតំណាង"នៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលទាញចេញពីផ្នែកស្ដីពីគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ដោយហេតុថា ជាការសមហេតុផលដែលថា សក្ខីកម្មដែលបានផ្ដល់នៅក្នុងផ្នែកនេះបានផ្ដោតទៅលើសេចក្ដីលម្អិត និងបរិបទនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

1314.ជាបន្ទាប់ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងរបស់សាក្សីបីនាក់ដែលបានយោងនៅក្នុងជើងទំព័រនៃការវិភាគស្ដីពីការបង្ខិតបង្ខំ មានដូចជា សេង ស្រ៊ុន និង អ៊ុន យឿង និងដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ទី ដែលត្រូវបានយោងទៅលើនៅក្នុងជើងទំព័រនៃការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការបង្ខំ[3661]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ សេង ស្រ៊ុន ដែលបង្ហាញថា មនុស្សជាច្រើនត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[3662]។ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើភស្តុតាងរបស់លោកស្រីក្នុងការយល់ឃើញថា លោកស្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍នោះទេ[3663] និងពុំបាន"មិនអើពើ"លើភស្តុតាងរបស់ អ៊ុន យឿង ដែលបង្ហាញថា លោកស្រីបាន"ស្ម័គ្រចិត្ត"រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែផ្ទុយទៅវិញបានសំអាងដោយសមហេតុផលទៅលើចម្លើយរបស់គាត់ដែលថា លោកស្រីមានការភ័យខ្លាចគេផ្លាស់ទី ប្រសិនណាបើលោកស្រីប្រកែកការរៀបអាពាហ៍ពិពាហ៍នោះ[3664]។ ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់

---

[3660] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩-៣៦២៣។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០-៣៦២៣។

[3661] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦២ ជើងទំព័រ ២៣៩៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩-៣៦២០។

[3662] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩ ជើងទំព័រ ១២០៨១ យោងទៅលើប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារលេខ E1/346.1 ទំព័រ ៤៥-៤៦ (មនុស្សជាច្រើនត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍)។

[3663] *ធៀបនឹង* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៣៩៨។

[3664] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០ ជើងទំព័រ ១២០៨៩ យោងទៅលើប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ (អ៊ុន យឿង) ឯកសារលេខ E1/387.1 ទំព័រ ៦៧-៦៨ (ដោយនិយាយថាគាត់មានអារម្មណ៍ថាប្រសិនបើគាត់បដិសេធ គាត់នឹងត្រូវគេនាំទៅកន្លែងផ្សេង)។

ឃើញថា សៀង ចាន់ធី "ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍"[3665] ប៉ុន្តែបានពិចារណាលើភស្តុតាងរបស់គាត់ដែលថា បងប្អូនស្រីរបស់គាត់ពុំបានជំទាស់ទៅនឹងការរៀបអាពាហ៍ពិពាហ៍របស់លោកស្រីដោយសារខ្លាចគេសម្លាប់[3666]។ បើទោះបីជាសាក្សីទាំងនេះពុំបាន"អះអាងច្បាស់លាស់"ថា ពួកគេមិនខ្លាចការដាក់ទោសក៏ដោយ ក៏ផ្ទុយទៅវិញបានផ្តល់ភស្តុតាងគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែរ។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ភស្តុតាងរបស់សាក្សីទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញរឹងមាំថា ការបង្ខិតបង្ខំបានលុបលើការស្ម័គ្រចិត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

1315.បន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការពិចារណាលើភស្តុតាងរបស់ មុំ វុន ស្តីពីការរំលោភសេពសន្ថវៈ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ មុំ វុន ដែលថា លោកស្រីត្រូវបានប្រាប់ឱ្យរៀបអាពាហ៍ពិពាហ៍ម្តងទៀតក្រោយពេលប្តីលោកស្រីត្រូវបានគេនាំចេញទៅ ព្រមទាំងភស្តុតាងរបស់លោកស្រីដែលថា លោកស្រីត្រូវបានរំលោភសេពសន្ថវៈដោយឈ្លបប្រាំនាក់នៅពីរថ្ងៃមុនការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានរៀបចំសម្រាប់លោកស្រីនោះ[3667]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងដែលថា លោកស្រីជឿជាក់ថា ការរំលោភសេពសន្ថវៈលោកស្រី គឺដោយសារលោកស្រីប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍ និងអាស្រ័យហេតុនេះត្រូវយល់ព្រមរៀបអាពាហ៍ពិពាហ៍ដើម្បីរស់ជីវិតកូនរបស់លោកស្រី[3668]។

1316.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដីកាដំណោះស្រាយបានយល់ឃើញថា "ទំនាក់ទំនងស្និទ្ធស្នាលក្រៅការរៀបអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថា ជាការប្រឆាំងនឹងទ្រឹស្តីសម្ហហភាពរបស់បក្សកុម្មុយនីស្តកម្ពុជា"[3669]។ ដីកាដំណោះស្រាយបានយល់ឃើញថា អ្នកដែលសង្ស័យអំពីកំហុសសីលធម៌ រួមទាំងការរំលោភសេពសន្ថវៈ ជាញឹកញាប់ត្រូវបានធ្វើការអប់រំកែប្រែឡើងវិញ ឬសម្លាប់[3670]។ ជាលទ្ធផល សហចៅ

---

[3665] *ផ្ទៀបទឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៣៨៨។

[3666] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០ ជើងទំព័រ ១២០៨០ យោងទៅលើប្រតិចារឹក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ (សៀង ចាន់ធី) ឯកសារលេខ E1/394.1 ទំព័រ ១៤ (បងស្រីរបស់គាត់មិនហ៊ានប្រឆាំងនឹងការរៀបការនោះទេ ពីព្រោះគាត់ខ្លាចគេយកទៅសម្លាប់)។

[3667] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២១។

[3668] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២១។

[3669] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២៨។

[3670] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២៨។

ក្រុមស៊ើបអង្កេតបានយល់ឃើញថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាផ្លូវការពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ គឺដើម្បីរារាំងការកើតឡើង និងដាក់ទោសជនល្មើសនៃការរំលោភសេពសន្ថវៈ[3671]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា បទឧក្រិដ្ឋនៃ"ការរំលោភសេពសន្ថវៈ"ត្រឹមតែត្រូវបានពិចារណាក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះ[3672]។ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាងរបស់ មុំ វុន ពុំបានផ្ទុយទៅនឹងវិធីសាស្ត្រនេះទេ។ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញស្តីពីការកើតឡើងនៃការរំលោភសេពសន្ថវៈដែលរងការចោទប្រកាន់នោះជាបទឧក្រិដ្ឋឯករាជ្យ ដូចបានបង្ហាញតាមរយៈការប្រើប្រាស់អក្សរទ្រេតនោះទេ ប៉ុន្តែផ្ទុយទៅវិញបានផ្តោតទៅលើចម្លើយរបស់ មុំ វុន ស្តីពីបទពិសោធន៍របស់លោកស្រី និងការយល់ដឹងនូវមូលហេតុពីក្រោយការរំលោភសេពសន្ថវៈនោះ។ ពុំមានកំហុសក្នុងវិធីសាស្ត្រនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើការអះអាងដែលថា មុំ វុន គប្បីផ្តល់ការរៀបរាប់នៃការរំលោភសេពសន្ថវៈដទៃទៀតនោះ។ លោកស្រីបានផ្តល់សក្ខីកម្មសមស្របអំពីបញ្ហាតាមការយល់ដឹងផ្ទាល់ខ្លួនរបស់លោកស្រី។

1317.អង្គតុលាការកំពូលពិនិត្យលើភស្តុតាងដែល ខៀវ សំផន បានអះអាងថា ពុំត្រូវបានអើពើដោយអង្គជំនុំជម្រះសាលាដំបូង។ បើទោះបីជាសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីខ្លះដែលត្រូវបានគូសបង្ហាញដោយ ខៀវ សំផន បានផ្តល់ភស្តុតាងថា ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍តាមការយល់ព្រមមានអត្ថិភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ[3673] ក៏ភស្តុតាងនេះនៅតែស៊ីសង្វាក់គ្នាទាំងស្រុង និងពុំផ្ទុយគ្នានៅក្នុងការយល់ឃើញ

---

[3671] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២៩។

[3672] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៧។

[3673] *សូមមើល* ប្រតិចារឹកថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ២៦ (សំដៅទៅលើឧទាហរណ៍មួយនៃការរៀបអាពាហ៍ពិពាហ៍ដែលជាការស្ម័គ្រចិត្ត និងគ្មានការបង្ខំ)។ ប្រតិចារឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ (អ៊ុំ សុផានី) ឯកសារលេខ E1/251.1 ទំព័រ ៧៩-៨០ (រៀបអាពាហ៍ពិពាហ៍ជាមួយគូដណ្តឹងដែលលោកស្រីស្រឡាញ់)។ ប្រតិចារឹកថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ៩ (ការរៀបអាពាហ៍ពិពាហ៍ត្រូវបានយល់ព្រមរវាងគ្រួសារ និងត្រូវបានសម្របសម្រួលដោយអង្គការ)។ ប្រតិចារឹកថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ (កង អ៊ុត) ឯកសារលេខ E1/322.1 ទំព័រ ៤១ (មេធាវីបានបញ្ជាក់ជាមួយគាត់ថា នេះជាជម្រើសរបស់ឪពុកម្តាយគាត់ ប៉ុន្តែពីមុនគាត់បាននិយាយថា គឺជាប្រធានភូមិដែលជ្រើសរើស និងថា ឪពុកម្តាយក្រោយមកបានជូនដំណឹង។ ពុំត្រូវបានបំភ្លឺ)។ ប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 ទំព័រ ៤០ (ការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការបង្ខំសម្រាប់អ្នកមកពីកង និងដែលស្រលាញ់គ្នា។ លោកស្រីនិយាយអំពីការដែលលោកស្រីពុំបានដឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួនរហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៥ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ៦៣ (ពិបាក

របស់អង្គជំនុំជម្រះសាលាដំបូងដែលថា បុគ្គលខ្លះអាចស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍[3674]។ បន្ថែមលើនេះ ភស្តុតាងរបស់បុគ្គលដដែលនេះជាញឹកញាប់បានសំដៅច្បាស់លាស់ទៅលើគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបរិយាកាសនៃការបង្ខំ និងបង្ខិតបង្ខំ[3675]។ អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសត្រូវបដិសេធចោល។

1318.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងរបស់ ឯម ភឿង អតីតជាលោកសង្ឃ និងដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ដែលនីមួយៗបានអះអាងថា បាន “ប្រកែកការរៀបអាពាហ៍ពិពាហ៍នោះដោយគ្មានទទួលរងផលវិបាកដែលប៉ះពាល់ឡើយ”[3676]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “ស្ថានការណ៍ទាំងនេះជាករណីពិសេស និងអាចត្រូវបានពន្យល់តាមកាលៈទេសៈជាក់លាក់” និងបានបន្តធ្វើការយល់ឃើញថា “ភស្តុតាងភាគច្រើនលើសលុបបានបង្ហាញថា

និយាយថាតើ គាត់បានយល់ព្រម ឬត្រូវបានបង្ខំ)។ ប្រតិចារឹកថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ (ម៉ម សឿម) ឯកសារលេខ E1/325.1 ទំព័រ ២១ (បានអះអាងថា ជួនកាលបុរសចង់រៀបអាពាហ៍ពិពាហ៍ ហើយស្ត្រីមិនចង់ និងថា បុរស និងនារីរៀបអាពាហ៍ពិពាហ៍ដោយសារពួកគេស្រលាញ់គ្នា)។ សារណារបស់ ខៀវ សំផន មួយចំនួនពុំបានបញ្ជាក់ និងពុំត្រូវបានពិចារណាបន្ថែម។ *សូមមើល ខ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៨ ជើងទំព័រ ២២៣៤ យោងទៅលើឧបសម្ព័ន្ធ ខ ១ និង ខ ៥។

[3674] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩។

[3675] *សូមមើល* ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ (សៅ ប៊ាន) ឯកសារលេខ E1/265.1 ទំព័រ ២០-២១ (ពិភាក្សាដំណោះស្រាយការប្តេជ្ញាធ្វើឡើងនៅពិធីរៀបអាពាហ៍ពិពាហ៍ ពុំមែនដោយស្ម័គ្រចិត្ត និងបញ្ជាក់ច្បាស់ថា ឪពុកម្តាយពុំបានពាក់ព័ន្ធ)។ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ (រី ពៅ) ឯកសារលេខ E1/262.1 ទំព័រ ២១-២២ (រៀបចំដើម្បីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែពុំបានដំណើរការ)។ ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ (ជូ គឹមឡុន) ឯកសារលេខ E1/253.1 ទំព័រ ១៩-២០ (ជាក់ស្តែងបានអះអាងថា បុគ្គលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងសក្ខីកម្មដែលត្រូវបានគូសបង្ហាញ)។ប្រតិចារឹក ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ១៦ (រៀបអាពាហ៍ពិពាហ៍ដោយស្ទាក់ស្ទើរក្រោមរបបនោះ)។ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ (ហេង ឡៃប៊ាង) ឯកសារលេខ E1/476.1 ទំព័រ ៤៥-៤៦ (បានអះអាងថា លោកស្រីបានបដិសេធការស្នើការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែចុងក្រោយមិនអាចធ្វើដូច្នោះបានដោយសារភ័យខ្លាចមានបញ្ហា)។ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ២១ (បានអះអាងថា បុរស និងនារីស្គមស្គាំង និងថា គាត់មិនដឹងថា ពួកគេមានទំនាក់ទំនងពីមុនជាមួយគ្នាដែរ ឬអត់)។ ប្រតិចារឹកថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ (ផាន់ ហ៊ីម) ឯកសារលេខ E1/467.1 ទំព័រ ៧០-៧១ (បានផ្តល់ភស្តុតាងថា លោកស្រីដំបូងបានបដិសេធ ប៉ុន្តែក្រោយមកត្រូវបានបង្ខំ)។

[3676] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៥។

បុគ្គលពុំអាចប្រកែកការរៀបអាពាហ៍ពិពាហ៍ដោយគ្មានទទួលរងផលវិបាកប៉ះពាល់នោះឡើយ”[3677]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានពន្យល់មូលហេតុដូចម្តេចបានជាបុគ្គលនីមួយៗអះអាងថា ខ្លួនមានអារម្មណ៍ថា ជារឿងចំឡែកដែលគ្មានការទទួលរងផលវិបាក និងបានផ្តល់ការពន្យល់សម្រាប់ភាពខុសពីធម្មតានេះ[3678]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការយល់ឃើញនេះ ដោយគ្មានការបង្ហាញនូវកំហុសណាមួយឡើយ។ អាស្រ័យហេតុនេះ ការចោទប្រកាន់នេះត្រូវបដិសេធចោល។

## ឃ) ភស្តុតាងអ្នកជំនាញ

1319.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងវិធីសាស្ត្ររបស់ខ្លួនចំពោះភស្តុតាងរបស់អ្នកជំនាញ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការកោះហៅ François PONCHAUD ធ្វើជាសាក្សី ដោយសារកិច្ចការរបស់គាត់ស្តីពីគោលការណ៍សីលធម៌ទាំងដប់ពីរ[3679] និងបានបំភ្លៃភស្តុតាងរបស់អ្នកជំនាញ NAKAGAWA Kasumi[3680]។ អង្គជំនុំជម្រះសាលាដំបូង“បានបដិសេធពុំត្រឹមត្រូវ”ផងដែរលើសក្ខីកម្មរបស់ Peg LEVINE ដែលបានអះអាងថា ជាទូទៅ ពុំមានគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទូទាំងប្រទេសនោះ[3681]។

1320.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបដិសេធការបង្ហាញខ្លួន François PONCHAUD បានផ្អែកលើមូលដ្ឋាននៃច្បាប់ត្រឹមត្រូវដោយហេតុថា សាក្សីបានផ្តល់សក្ខីកម្មរួចហើយក្នុងសំណុំរឿង ០០២/០១ លើប្រធានបទជាច្រើនរួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយ

---

[3677] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៥។

[3678] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៥។

[3679] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៩៥ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចំណងជើង II វិធីសាស្ត្រលម្អៀងចំពោះគោលការណ៍ណែនាំនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ជំពូក III ផ្នែក II “ចៅក្រមដែលចាត់ទុកការជំនុំជម្រះនានា ជាការជំនុំជម្រះតុលាមួយ” កថាខណ្ឌ ១៦៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១៧ សីហា ឆ្នាំ ២០២១ F1/10.1 ទំព័រ ៣៣។

[3680] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៩។

[3681] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៩។

បង្ហ[3682]។ ពាក់ព័ន្ធទៅនឹង NAKAGAWA Kasumi សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បាន បំភ្លៃសក្ខីកម្មរបស់លោកស្រី មិនមែនអង្គជំនុំជម្រះសាលាដំបូងទេ តាមរយៈការដកស្រង់ពុំត្រឹមត្រូវលើផ្នែក ខ្លះនៃសក្ខីកម្មនោះ[3683]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន បង្ហាញត្រឹមត្រូវនូវការរក្សាសិទ្ធិរបស់ខ្លួនមិនទទួលយកភស្តុតាងរបស់ Peg LEVINE នៅក្នុងការវិភាគ ដោយសមហេតុផលនោះ[3684]។

1321.នៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នេះអាចជាការច្រំដែលធ្វើ ការកោះហៅ François PONCHAUD មកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[3685] ហើយនេះអាចបង្ក ឱ្យមានការពន្យារពេលផងដែរដល់កិច្ចដំណើរការនីតិវិធី[3686]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា រួចរាល់ និងបានបដិសេធលើការជំទាស់ទូទៅរបស់ ខៀវ សំផន ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូង មិនកោះហៅ François PONCHAUD[3687]។ ខៀវ សំផន បានចង្អុលបង្ហាញទៅលើភស្តុតាង François PONCHAUD ស្តីពីគោលការណ៍សីលធម៌ទាំង ១២ ចំណុច ប៉ុន្តែខកខានក្នុងការផ្តល់អំណះ អំណាងថ្មីណាមួយពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ អំណះ អំណាងនេះត្រូវបដិសេធចោល។

1322.ទាក់ទងទៅនឹង NAKAGAWA Kasumi អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា លោកស្រីត្រូវ បានតែងតាំងជាអ្នកជំនាញដោយសារបទពិសោធន៍កិច្ចការស្រាវជ្រាវយ៉ាងទូលំទូលាយរបស់លោកស្រី[3688] ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា លោកស្រីបានអនុវត្តតាមវិធីសាស្ត្រយ៉ាងសុក្រឹត និងបាន បង្ហាញនូវចំណេះដឹងឯកទេសរបស់លោកស្រីតាមរយៈការផ្តល់សក្ខីកម្មក្នុងតុលាការ[3689]។ អង្គជំនុំជម្រះ

---

[3682] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩១។

[3683] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤៣។

[3684] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ២៤៤។

[3685] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំស្តាប់ Stephen HEDER (2-TCE-87) និង François PONCHAUD (2-TCE-99) ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E408/6 កថាខណ្ឌ ៧។

[3686] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំស្តាប់ Stephen HEDER (2-TCE-87) និង François PONCHAUD (2-TCE-99) ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E408/6 កថាខណ្ឌ ៦។

[3687] *សូមមើលខាងលើ* ផ្នែក V.ឃ.៦.ក។

[3688] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៣។

[3689] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៣។

សាលាដំបូងបានពិពណ៌នាមូលហេតុដូចម្ដេចបានជា NAKAGAWA Kasumi បាន"សន្និដ្ឋានថា លោកស្រីពុំមានភស្តុតាងគ្រប់គ្រាន់អាចនិយាយថាតើ មានគោលនយោបាយចេញពីថ្នាក់លើក្នុងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែរ ឬយ៉ាងណានោះ ពុំមែនជាផ្នែកនៃការសិក្សាស្រាវជ្រាវរបស់លោកស្រីឡើយ"[3690]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានសង្កេតថា ភស្តុតាងរបស់លោកស្រីបង្ហាញថា ត្រឹមចុងឆ្នាំ ១៩៧៧ ដល់ ១៩៧៨ ការរៀបអាពាហ៍ពិពាហ៍ជាសមូហភាពក្នុងទ្រង់ទ្រាយធំត្រូវបានរៀបចំឡើងក្នុងចំណោមគូស្រករជាច្រើនដែលការរៀបអាពាហ៍ពិពាហ៍របស់ពួកគេស្របនឹងការកំណត់និយមន័យនៃការបង្ខំ[3691]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទស្សនៈរបស់គាត់ ជាទូទៅមានហេតុផលសមស្រប និងស៊ីសង្វាក់គ្នា និងបានបង្ហាញនូវការប្រយ័ត្នប្រយែងក្នុងការធ្វើសេចក្ដីសន្និដ្ឋាននោះ[3692]។

1323.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ NAKAGAWA Kasumi ដែលថា មានគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាផ្នែកទូទៅនៃភស្តុតាង[3693]។ នៅក្នុងផ្នែកនៃសត្ថិកម្មដែលត្រូវបានគូសបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង និងយោងដោយ ខៀវ សំផន[3694] NAKAGAWA Kasumi ជាក់ស្ដែងពុំបានបញ្ជាក់ថា ការសន្និដ្ឋានរបស់លោកស្រីបានផ្អែកលើកង្វះមូលដ្ឋាននៃភស្តុតាងសម្រាប់គោលនយោបាយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈការពន្យល់ថា "នេះពុំមែនជាផ្នែកនៃការសិក្សាស្រាវជ្រាវរបស់លោកស្រី" ដូចបានអះអាងដោយអង្គជំនុំជម្រះសាលាដំបូងនោះឡើយ[3695]។ ជាក់ស្ដែងភស្តុតាងរបស់លោកស្រីបង្ហាញថា លោកស្រីពុំមាន"ភស្តុតាងគ្រប់គ្រាន់ដែលអាចនិយាយបានថា មានគោលនយោ បាយចេញពីថ្នាក់លើក្នុងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[3696]។ បើទោះបីជាការសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងរបស់ NAKAGAWA Kasumi ពុំត្រឹមត្រូវក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ភស្តុតាងដទៃទៀតរបស់លោកស្រីបានបញ្ជាក់នូវអត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាសមូហភាពក្នុងទ្រង់ទ្រាយ

---

[3690] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៣។

[3691] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៣។

[3692] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៤។

[3693] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៦៥ យោងជាទូទៅទៅលើផ្នែកស្ដីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍។

[3694] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២០៩។

[3695] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៣។

[3696] ប្រតិចារិក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 ទំព័រ ៦៦។

ធំ[3697]។ បន្ថែមលើនេះ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងរបស់ NAKAGAWA Kasumi "ជាទូទៅមានហេតុផលត្រឹមត្រូវ និងស៊ីសង្វាក់គ្នា"[3698] ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា នេះត្រូវបានវាយតម្លៃ"ក្នុងបរិបទនៃភស្តុតាងចំពោះមុខខ្លួន"[3699]។ ដូចបានគូសបង្ហាញខាងលើ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គោលការណ៍នៃការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តពុំត្រឹមត្រូវជាក់ស្តែង ដោយពិចារណាលើភស្តុតាងឯកសារសម័យនោះ ព្រមទាំងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ ការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញទាំងនេះត្រូវបានពិចារណា និងបដិសេធរួចរាល់ហើយ។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលកំណត់ថា គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានអត្ថិភាព។

1324. ទាក់ទងទៅនឹងភស្តុតាងរបស់ Peg LEVINE អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់គាត់ដែលថា ការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យត្រូវបាន"គេណ្ឌ" ជាជាង"បង្ខំ"[3700]។ លោកស្រីបានសន្និដ្ឋានថា បុគ្គលពុំត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានបង្ហាញទស្សនៈបន្ថែមថា ពុំមានគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍នៅពេលចាប់ផ្តើមនៃរបបនោះទេ ហើយនេះបានកើតឡើងត្រឹមឆ្នាំ ១៩៧៨[3701]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "ដោយសារភស្តុតាងសន្ធឹកសន្ធាប់"នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងស្តីពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានន័យថា ភស្តុតាងនេះត្រូវបដិសេធចោលដោយសារមានកំហុស [3702]។ បើទោះបីជា ខៀវ សំផន ពុំយល់ស្របជាមួយវិធីសាស្ត្រនេះក៏ដោយ ក៏គាត់ខកខានក្នុងការបង្ហាញនូវកំហុសណាមួយនៅបណ្តឹងសាទុក្ខ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

- *ការរៀបអាពាហ៍ពិពាហ៍របស់យោធិនពិការ*

---

[3697] ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 ទំព័រ ៦៦ (បានអះអាងថាមានគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំ និងថា ការរៀបអាពាហ៍ពិពាហ៍បានកើតឡើងក្នុងតំបន់ជាច្រើន)។

[3698] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៤។

[3699] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៤។

[3700] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣០។

[3701] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣០។

[3702] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣១។

1325.អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ការរៀបចំត្រូវបានធ្វើឡើងសម្រាប់ទាហានដែលពិការដោយសាររបួសក្នុងសមរភូមិ ដើម្បីរៀបអាពាហ៍ពិពាហ៍"[3703]។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសេចក្តីដកស្រង់ចេញពីកូនសៀវភៅរបស់សម្តេចនរោត្តមសីហនុ[3704] ភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ទាហានពិការ[3705] និងការផ្សព្វផ្សាយមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា រួមទាំង"សុន្ទរកថារបស់ ខៀវ សំផន ស្តីពីកាតព្វកិច្ចបម្រើបដិវត្ត និងគោរពមាគ៌ាបក្សដោយឥតលក្ខខណ្ឌ"[3706]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដោយផ្អែកលើតម្លៃនៃមនោគមវិជ្ជា ស្ត្រីត្រូវបាន"រំពឹងឱ្យលះបង់ខ្លួនរបស់ពួកគេដើម្បីបុព្វហេតុ'ស្នេហាជាតិ' និងសម្រាប់អត្ថប្រយោជន៍បដិវត្ត"[3707]។ បន្ថែមលើនេះ បើទោះបីជាមានកម្មាភិបាលបុរសខ្លះត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រពន្ធខ្លួនក៏ដោយ ក៏ប្តីប្រពន្ធត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយគ្មានការសួរនាំឡើយ[3708]។

1326.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើត"ការយល់ឃើញផ្ទុយគ្នា"នៅពេលយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍រវាងទាហានពិការ និងស្ត្រីវ័យក្មេងត្រូវបានអនុវត្តស្របតាមគោលនយោបាយដែលត្រូវបានលើកកម្ពស់ដោយថ្នាក់កំពូលនៃបក្សកុម្មុយនីស្តកម្ពុជា[3709]។ គាត់បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសៀវភៅរបស់សម្តេចនរោត្តមសីហនុ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើតម្លៃភស្តុតាងទាបនៃការរៀបរាប់នេះ និងគប្បីវាយតម្លៃលើភស្តុតាងនេះដោយប្រុងប្រយ័ត្ន[3710]។ ទីពីរ គាត់បានជំទាស់ទៅនឹងភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីលើការរៀបអាពាហ៍ពិពាហ៍របស់ជនពិការ និងបានចោទប្រកាន់កំហុសក្នុងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូង"តាមបែបជ្រើសរើស និងលម្អៀង"នូវ សក្ខីកម្មរបស់ ស៊ូ សុធារី, ណុប ធីម, សែម អំ, ម៉ាក ឈឿន និង សេង សឿន[3711]។ ខៀវ សំផន បន្ទាប់មកបានអះអាងថា នៅពេលយល់ឃើញថា

---

[3703] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦។

[3704] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦។

[3705] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦-៣៥៨៩។

[3706] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩០។

[3707] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩០។

[3708] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩១។

[3709] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[3710] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៦។

[3711] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៦។

ការរៀបអាពាហ៍ពិពាហ៍បានកើតឡើងស្របជាមួយនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់នូវការសំអាងរបស់ខ្លួនទៅលើសុន្ទរកថារបស់គាត់ ប៉ុន្តែខកខានក្នុងការយោងទៅលើសុន្ទរកថាណាមួយក្នុងជើងទំព័រពាក់ព័ន្ធនោះ[3712]។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងដោយពុំត្រឹមត្រូវទៅលើសក្ខីកម្មរបស់ ប្រាក់ យុត ពីព្រោះការរៀបអាពាហ៍ពិពាហ៍របស់គាត់បានកើតឡើងក្នុងឆ្នាំ ១៩៧៤ និងដូច្នេះនៅ"ក្រៅបរិបទនៃភស្តុតាង" និងពីព្រោះលោកស្រីបានបញ្ជាក់ថា លោកស្រីស្រលាញ់ប្តីរបស់លោកស្រី និងគ្មានការបង្ខិតបង្ខំ[3713]។ ចុងក្រោយ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបំភ្លៃភស្តុតាងនៅពេលយល់ឃើញថា បើទោះបីជាកម្មាភិបាលបុរសត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រពន្ធក៏ដោយ ក៏ស្ត្រីត្រូវបានបង្ខំដែរ[3714]។

1327.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយប្រុងប្រយ័ត្នលើតម្លៃនៃភស្តុតាងនៃសៀវភៅរបស់សម្តេចនរោត្តមសីហនុ នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងបានពិចារណានៅពេលធ្វើការវាយតម្លៃនោះ[3715]។ បន្ទាប់មក សហព្រះរាជអាជ្ញាបានលើកឡើងថា សុន្ទរកថានោះពុំមែនមិនជាក់លាក់នោះទេ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយោងច្បាស់លាស់ទៅលើកិច្ចប្រជុំដែលដឹកនាំដោយខៀវ សំផន ដែលក្នុងនោះគាត់បានណែនាំក្រសួងឱ្យរៀបចំការរៀបអាពាហ៍ ពិពាហ៍[3716]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ស៊ូ សុធាវី បានផ្តល់សក្ខីកម្មថា ពុំមានស្ត្រីណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍អាចប្រកែកបានឡើយ[3717]។ ទាក់ទងនឹង ប្រាក់ យុត សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការពិនិត្យលើសក្ខីកម្មរបស់លោកស្រីជារួម[3718]។ សហព្រះរាជអាជ្ញាបានអះអាងថា ភស្តុតាងផ្ទាល់របស់ ខៀវ សំផន បានបញ្ជាក់ថា ស្ត្រីពុំអាចយល់ព្រមដោយសេរីទៅនឹងការរៀបអាពាហ៍ពិពាហ៍បានឡើយ[3719]។

---

[3712] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៥។

[3713] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៤១៦។

[3714] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៨។

[3715] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៨។

[3716] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

[3717] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៩។

[3718] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ២៤៧២។

[3719] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២០។

1328.សហមេធាវីនាំមុខបានឆ្លើយតបថា ពាក់ព័ន្ធទៅនឹងស្ត្រីយ៉ាងហោចណាស់ ពុំមានលទ្ធភាពស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍[3720]។ សហមេធាវីនាំមុខបានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសដោយសារចាត់ទុកហេតុការណ៍ដែលបានអះអាងនោះនៃការស្ម័គ្រចិត្តការរៀបអាពាហ៍ពិពាហ៍ថា ជាហេតុការ ណ៍ដាច់ដោយឡែក និងបានយោងទៅលើភស្តុតាងចេញពីស្ត្រីបីនាក់ដែលបានផ្តល់សក្ខីកម្មថា ពួកគេត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងយុទ្ធជនពិការ[3721]។ សហមេធាវីនាំមុខបានអះអាងថា នៅពេលពិនិត្យតាមបរិបទ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែល ខៀវ សំផន បានផ្អែកទៅលើនោះ បានបញ្ជាក់អះអាងអំពីនត្ថិភាពនៃការស្ម័គ្រចិត្ត[3722]។

1329.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា សៀវភៅរបស់សម្តេចនរោត្តមសីហនុត្រូវបានសំអាងទៅលើដើម្បីតែការបញ្ជាក់បន្ថែមលើភស្តុតាងដទៃទៀតប៉ុណ្ណោះ ពីព្រោះមេធាវីការពារក្តីពុំមានឱកាសសួរដេញដោលអត្ថបទនេះក្នុងតុលាការ[3723]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាភស្តុតាងនេះដោយប្រុងប្រយ័ត្នសមស្រប។ បន្ថែមលើនេះ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដទៃទៀតដើម្បីគាំទ្រការយល់ឃើញស្តីពីការរៀបអាពាហ៍ពិពាហ៍របស់យុទ្ធជនពិការ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អត្ថបទនេះត្រឹមតែបានផ្តល់ទម្ងន់ជាការបញ្ជាក់បន្ថែមក្នុងការវាយតម្លៃនោះដោយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ[3724]។ អំណះអំណាងរបស់ ខៀវ សំផន ដែលបានអះអាងផ្ទុយពីនេះ ព្រមទាំងការចោទប្រកាន់ជាក់លាក់អំពីភាពពុំស៊ីសង្វាក់គ្នាក្នុងសៀវភៅនោះ ត្រូវបដិសេធចោល[3725]។

---

[3720] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៤។

[3721] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៤។

[3722] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៤-៦៤៦។

[3723] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥០១។

[3724] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅពេលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងស្តីពីការផ្សព្វផ្សាយមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះបានបញ្ជាក់ថា នេះមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹង "សក្ខីកម្ម" ដែលត្រូវបានសង្ខេបខាងលើដែលពុំមានការយោងទៅលើសៀវភៅរបស់សម្តេចនរោត្តមសីហនុ។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤០។

[3725] ដោយសារការយល់ឃើញនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនពិចារណាបន្ថែមលើការជំទាស់ដែលបានលើកឡើងដោយ ខៀវ សំផន ទៅនឹងភាពអាចទុកចិត្តបាននៃការលើកឡើងក្នុងសៀវភៅនោះ ដែលសំដៅទៅលើ"ភាពហួសហេតុ" និងពុំស៊ីសង្វាក់គ្នា *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៤០៩។

1330. អង្គជំនុំជម្រះតុលាការកំពូលបន្ទាប់មកពិចារណាលើបញ្ហាថាតើ តាមការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលត្រូវបានសំអាងទៅលើក្នុងការយល់ឃើញអំពីការរៀបអាពាហ៍ពិពាហ៍របស់យុទ្ធជនពិការនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានចង្អុលបង្ហាញទៅលើផ្នែកបែបជ្រើសរើសនៃសក្ខីកម្ម និងពុំបានពិចារណាលើភស្តុតាងជារួមឡើយ។ តាមការអះអាងរបស់ ខៀវ សំផន ថា ស៊ូ សុធាវី បានឆ្លើយថា ការរៀបអាពាហ៍ពិពាហ៍ពុំត្រូវបាន"បង្ខំ"[3726] និងបានផ្តល់សក្ខីកម្មផងដែរថា ពុំមានស្ត្រីណាម្នាក់ដែលជាប់ពាក់ព័ន្ធនោះហ៊ានប្រកែក ដែលនេះបានបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ពិតណាស់ត្រូវបានបង្ខំ[3727]។ បើទោះបីជា តាមការអះអាងរបស់ ខៀវ សំផន បានឱ្យដឹងថា ណុប ធីម បានពិពណ៌នាខ្លួនគាត់ថា "ចាស់ហើយ ឬអាយុច្រើនហើយ"ក៏ដោយ ក៏តាមការពិនិត្យលើសក្ខីកម្មទាំងស្រុងរបស់គាត់បង្ហាញថា លោកស្រីលើកបញ្ហាអាយុដើម្បីពន្យល់មូលហេតុដែលថា ការរត់គេចមានហានិភ័យ[3728] ពុំមែនពន្យល់ការស្ម័គ្រចិត្តរបស់គាត់រៀបអាពាហ៍ពិពាហ៍ជាមួយអតីតយុទ្ធជនពិការនោះទេ[3729]។ ភស្តុតាងរបស់ សែម អំ ដែលថា មានប្តីប្រពន្ធមួយគូចុះសម្រុងគ្នាចុងក្រោយនោះ ពុំអាចលុបលើផ្នែកពាក់ព័ន្ធដទៃទៀតនៃភស្តុតាងរបស់គាត់ដែលថា៖ យុទ្ធជនត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ពីដំបូងឡើយ[3730]។ បន្ថែមលើនេះ ការដែលថា ម៉ាក ឈឿន ដែលជាយុទ្ធជនពិការបានផ្តល់សក្ខីកម្មថា គាត់បានរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្តនោះ ពុំបានធ្វើឱ្យប៉ះពាល់ដល់ភស្តុតាងដែលថា មានការរៀបអាពាហ៍ពិពាហ៍ជាច្រើនត្រូវបានបង្ខំ[3731] និងគួរកត់សម្គាល់ផងដែរនោះពុំបានបដិសេធការពិតដែលថា ការរៀបអាពាហ៍ពិពាហ៍នោះ ពុំមែនជាការស្ម័គ្រចិត្តសម្រាប់ស្ត្រីភាគច្រើនឡើយ។ ចុងក្រោយ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានសម្រាប់ការអះអាងដែលថា សេង សឿន បានផ្តល់សក្ខីកម្មថា លោកស្រី"បានដឹងតាមរយៈពាក្យចចាមអារ៉ាមអំពីការរៀប

---

[3726] *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៦។

[3727] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៨១ ("ខ្ញុំឃើញទាហានពិការមកសុំរៀបអាពាហ៍ពិពាហ៍។ មិនមែនត្រូវបានបង្ខំ។ នារីត្រូវបានស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយទាហានពិការនោះ គ្មាននរណាហ៊ានប្រកែក")។

[3728] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ធីម) ឯកសារលេខ E1/469.1 ទំព័រ ៨៣។

[3729] *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៦។

[3730] ប្រតិចារឹក ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ (សែម អំ) ឯកសារលេខ E1/478.1 ទំព័រ ៧៥-៧៦។ សែម អំ បានផ្តល់ភស្តុតាងថា មានការណែនាំពីថ្នាក់លើឱ្យបង្កើន និងរៀបចំកម្លាំងតាមរយៈការបង្កើតកូន។

[3731] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ (ម៉ាក ឈឿន) ឯកសារលេខ E1/511.1 ទំព័រ ៧៩។

អាពាហ៍ពិពាហ៍ដែលបានរៀបចំសម្រាប់យុទ្ធជនពិការ” ឬបានពន្យល់នូវភាពជាប់ពាក់ព័ន្ធនៃការអះអាងនោះឡើយ[3732]។

1331.បន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការលើកឡើងថា អង្គជំនុំជម្រះបានសំអាងទៅលើសុន្ទរកថារបស់ ខៀវ សំផន ខណៈពេលពុំបានយោងទៅលើសុន្ទរកថាណាមួយនោះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញដែលរងការជំទាស់[3733]ជាក់ស្តែងបានយោងទៅលើសុន្ទរកថារបស់ ខៀវ សំផន តាមរយៈការយោងនៅក្នុងជើងទំព័រពាក់ព័ន្ធទៅលើកថាខណ្ឌខាងដើមនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការបង្រៀនដោយ ខៀវ សំផន[3734]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា ឯកសារដទៃទៀតដែលត្រូវបានយោងដោយអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រផងដែរនូវការលើកឡើងនៅក្នុងអត្ថបទនោះ[3735]។ ជាលទ្ធផលអង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

1332.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំបានផ្តល់ការយោងទៅលើក្នុងការគាំទ្រការអះអាងរបស់ខ្លួនដែលថា ការរៀបអាពាហ៍ពិពាហ៍របស់ ប្រាក់ យុត បានកើតឡើងក្នុងឆ្នាំ ១៩៧៤[3736] និងសង្កេតបន្ថែមថា សាក្សីនេះមានការភាន់ច្រឡំអំពីបញ្ហាថាតើ ការរៀបអាពាហ៍ពិពាហ៍របស់គាត់បានកើតឡើងក្នុងឆ្នាំ ១៩៧៣ ឬឆ្នាំ ១៩៧៥[3737]។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យសំអាងទៅលើភស្តុតាង

---

[3732] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៦។

[3733] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩០ និងជើងទំព័រ ១២០១៩។

[3734] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩ (“យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ខៀវ សំផន បានអប់រំដល់កម្មាភិបាលពីភាពចាំបាច់ក្នុងការផ្តាច់ខ្លួនចេញពីឪពុកម្តាយ ហើយបង្គាប់ឱ្យគ្រប់ក្រសួងត្រូវរៀបចំអាពាហ៍ពិពាហ៍សម្រាប់យុវជននិងយុវនារីទាំងអស់ ដើម្បីឱ្យគូស្វាមីភរិយាអាចបង្កើតកូន និងមានកម្លាំងកាន់តែច្រើនដើម្បីការពារប្រទេស”) យោងទៅលើប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឡៀប) ឯកសារលេខ E1/466.1 ទំព័រ ៥១-៥២។

[3735] អត្ថបទទាំងមូលសំដៅទៅលើការផ្សព្វផ្សាយមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា“ស្តីពីកាតព្វកិច្ចបម្រើបដិវត្ត និងគោរពគោលការណ៍បក្សដោយឥតលក្ខខណ្ឌ”(*សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩០) និងជើងទំព័រនោះសំដៅទៅលើការលើកឡើងជាច្រើនចេញពីឯកសារបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្ត និងយុវជនបដិវត្តដែលគាំទ្រសញ្ញាណនៃកាតព្វកិច្ចឥតលក្ខខណ្ឌ និងវិន័យសម្រាប់បក្ស(សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២០១៩)។

[3736] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៤១៦ (ផ្តល់ការយោងតែទៅលើភស្តុតាងភស្តុតាងរបស់ ប្រាក់ យុត ស្តីពីការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍)។

[3737] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៣៣-៣៤។

ដែលនៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយ"ដើម្បីបង្ហាញនូវលំនាំនៃអំពើគិតទុកជាមុន"[3738]។ ទាក់ទងទៅនឹងការអះអាងដែលថា ប្រាក់ យុត ពុំត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ខៀវ សំផន បានចង្អុលបង្ហាញទៅលើផ្នែកនៃភស្តុតាងរបស់គាត់ដែលពុំពាក់ព័ន្ធទៅនឹងបរិបទទូលំទូលាយ។ បើទោះបីជាលោកស្រីបានអះអាងថា លោកស្រី និងប្តី"ស្រលាញ់គ្នាទៅវិញទៅមក"ក៏ដោយ[3739] ក៏លោកស្រីបានបញ្ជាក់ផងដែរថា លោកស្រីពុំមានជម្រើសក្រៅតែពីការធ្វើតាមការស្នើរបស់ប្តីលោកស្រីក្នុងការរៀបអាពាហ៍ពិពាហ៍[3740]។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ ជាម គិន ខៀវ សំផន ជាថ្មីម្តងទៀតបានប៉ុនប៉ងធ្វើការបែងចែកដោយពុំត្រឹមត្រូវភាពខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍តាមការ"រៀបចំ" និងតាមការបង្ខំ[3741]។ ដូចបានបញ្ជាក់ខាងដើមនេះជាការកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវ និងដូច្នេះត្រូវបដិសេធចោល។

1333.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "បើទោះបីជាកម្មាភិបាលបុរសខ្លះត្រូវបានអនុញ្ញាតឱ្យជ្រើសរើសប្រពន្ធខ្លួនក៏ដោយ ក៏ប្តីប្រពន្ធត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយពុំចាំបាច់សួរនាំ"ដែរ[3742]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ក្នុងការអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បិទបាំង"ភស្តុតាងក្នុងការសន្និដ្ឋានស្តីពីការរៀបអាពាហ៍ពិពាហ៍របស់កម្មាភិបាលបុរស ផ្អែកតាម ខៀវ សំផន[3743]។ ខៀវ សំផន បានយោងទៅលើផ្នែកបីនៃភស្តុតាងក្នុងការគាំទ្រការអះអាងដែលថា មានភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណា ដែលគ្មានភស្តុតាងណាមួយគាំទ្រការអះអាងរបស់គាត់ឡើយ។ ប៊ិត បឿន បានផ្តល់សក្ខីកម្មថា លោកស្រីផ្ទាល់អាចរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត[3744] ដែលនេះស៊ីសង្វាក់ទាំងស្រុងជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បុគ្គលខ្លះបានរៀបអាពាហ៍ពិពាហ៍តាម

---

[3738] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០។ *សូមមើល* ផ្នែក VI.ង។

[3739] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ២៩។

[3740] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៣០។

[3741] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៨ ជើងទំព័រ ១៤១៦ ("ចម្លើយជាលាយលក្ខណ៍អក្សររបស់ ជាម គិន ពុំបានអនុញ្ញាតឱ្យអង្គជំនុំជម្រះយល់ឃើញអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" បានចង្អុលបង្ហាញទៅលើកំណត់ហេតុស្តាប់ចម្លើយថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៤ (ជាម គិន) ឯកសារលេខ E3/9524 ស/ឆ៖ ១៣ និងការលើកឡើងថា "អង្គការបានរៀបចំការរៀបអាពាហ៍ពិពាហ៍ពួកយើង")។

[3742] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩១។

[3743] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៦៨។

[3744] *សូមមើល* ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត បឿន) ឯកសារលេខ E1/502.1 នៅម៉ោង ១១.១៩។

ការស្ម័គ្រចិត្ត[3745]។ រស់ ស៊ុយ ដែលជាកម្មាភិបាលបុរស បានផ្តល់សក្ខីកម្មអំពីអត្ថិភាពនៃគោលនយោបាយស្តីពីការស្ម័គ្រចិត្ត ប៉ុន្តែពុំបានផ្តល់ភស្តុតាងពាក់ព័ន្ធជាក់លាក់ណាមួយអំពីស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងយុទ្ធជនពិការនោះឡើយ[3746]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការបដិសេធភស្តុតាងកម្មាភិបាលស្តីពីអត្ថិភាពនៃគោលនយោបាយស្ម័គ្រចិត្តនេះ[3747]។ បន្ថែមលើនេះ ភស្តុតាងរបស់ ផាន់ ហ៊ីម ដែលអះអាងថា លោកស្រីបានរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រស្មោះ ប៉ុន្តែយល់ព្រមតាមការស្នើរបស់ប្តីលោកស្រី[3748] បានបញ្ជាក់អះអាងនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ស្ត្រីពុំមានសេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍ឡើយ។ ជាលទ្ធផល ភស្តុតាងដែលបានគូសបង្ហាញដោយ ខៀវ សំផន ពុំបានគាំទ្រការអះអាងដែលគាត់បានលើកឡើង។ បន្ថែមលើនេះ ផ្នែកដែលដាច់ដោយឡែកនៃភស្តុតាងដែលបានបង្ហាញនោះត្រូវតែបានថ្លឹងថ្លែងធៀបជាមួយនឹងភស្តុតាងយ៉ាងទូលំទូលាយរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន[3749]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

- *ពិធីរៀបអាពាហ៍ពិពាហ៍*

1334.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាទូទៅពាក់ព័ន្ធទៅនឹងការដកតួនាទីឪពុកម្តាយចេញពីការរៀបអាពាហ៍ពិពាហ៍កូនរបស់ពួកគេ និងការបោះបង់ចោលនូវការប្រតិបត្តិតាមប្រពៃណី[3750]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ "ការរៀបអាពាហ៍ពិពាហ៍គឺជាការអនុវត្តន៍សមូហភាពរីករាលដាលទូទាំងប្រទេសកម្ពុជា"[3751] ដែលមានគូស្រករចាប់ពីមួយគូទៅដល់ ៧០-៨០ គូ[3752]។ អង្គ

---

[3745] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣, ៣៦២៥។

[3746] *សូមមើល* កំណត់ហេតុស្តាប់ចម្លើយរបស់ រស់ ស៊ុយ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ E3/10620 ស៖ ៧៥ (បានអះអាងថា ជាគោលការណ៍ បុរស និងនារី អាចជ្រើសរើសគូស្រករបាន)។

[3747] *សូមមើលខាងលើ* ផ្នែក VII.ឆ.៣.ខ.iii។

[3748] *សូមមើល* ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ីម) ឯកសារលេខ E1/467.1 នៅម៉ោង ១៥.៤៦។

[3749] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩១ និងជើងទំព័រ ១២០២០-១២០២៣។

[3750] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៩-៣៦៤០, ៣៦៩១។

[3751] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣១។

[3752] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។

ជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍ គូស្រករត្រូវបានណែនាំឱ្យឡើងប្តេជ្ញាជូនអង្គការ[3753]។ ការប្តេជ្ញារបស់ប្តីប្រពន្ធបានឆ្លុះបញ្ចាំង"ការគោរពដាច់ខាតតាមសេចក្តីណែនាំរបស់អង្គការ" ដែលមានអាទិភាពលុបលើអត្ថប្រយោជ៍បុគ្គល និងគ្រួសារ[3754]។

1335. ដំបូង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើភស្តុតាងកម្មាភិបាល សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញពីការបន្តជាប់ពាក់ព័ន្ធរបស់ឪពុកម្តាយក្នុងពិធីរៀបអាពាហ៍ពិពាហ៍[3755]។ បន្ទាប់មក គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាង"ជ្រុលហួសហេតុ"ទៅលើការរៀបរាប់របស់ ឯក ហេន និង ស៊ូ សុធាវី ក្នុងការធ្វើសេចក្តីសន្និដ្ឋានទូទៅដែលថា ការរៀបអាពាហ៍ពិពាហ៍សមូហភាពបានកើតឡើង និងមានកំហុសបន្ថែមទៀត ដោយសារខកខានក្នុងការពិចារណាលើភស្តុតាងដោះបន្ទុករបស់កម្មាភិបាល ពេជ្រ ជឹម និង សៅ សារុន ដែលបានបង្ហាញ"គោលបំណងពិតប្រាកដ"នៃការរៀបអាពាហ៍ជាសមូហភាព[3756]។ ខៀវ សំផន បានជំទាស់ផងដែរទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការឡើងប្តេជ្ញារបស់ប្តីប្រពន្ធបានឆ្លុះបញ្ចាំង"ការអនុវត្តន៍ដាច់ខាតតាមសេចក្តីណែនាំរបស់អង្គការ"ដែលមានឧត្តមភាពលុបលើអត្ថប្រយោជន៍បុគ្គល និងគ្រួសារ[3757]។ គាត់បានអះអាងថា ភស្តុតាងនេះបានបង្ហាញថា ជួនកាល ពុំមានការឡើងប្តេជ្ញាបែបនោះឡើយ[3758] និងជាក់ស្តែង គោលបំណងពិតប្រាកដនៃការរៀបអាពាហ៍ពិពាហ៍ គឺគ្រាន់តែដើម្បី"បំពេញតាមផ្លូវការ ឬធ្វើឱ្យទៅជាស្របច្បាប់នៃសហព័ន្ធ"ប៉ុណ្ណោះ[3759]។

---

[3753] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣។

[3754] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣-៣៦៣៤។

[3755] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៤ (កម្មាភិបាល សៅ សារុន, ពេជ្រ ជឹម, ឃឹម ហឿន, ប៉ាន ឈួង, ហេង ឡៃហ៊ាង, "សាក្សីធម្មតា" ជាំង ស្រីមុំ, មាស ឡៃហួរ, កង អ៊ិត, សេង ស្រ៊ុន, ម៉ាត់ ស, ថ្លាង ផល, ហ៊ីម ម៉ាន, ម៉ី សារឿន, សៀង ចាន់ធី)។

[3756] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣-៣៦៣៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨។

[3757] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣-៣៦៣៤។

[3758] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៦-១២៥៧។

[3759] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥៧។

1336.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដោយហេតុថា ខៀវ សំផន បានចង្អុលបង្ហាញទៅលើឧទាហរណ៍តិចតួចនៃវត្តមានឪពុកម្ដាយ ដូច្នេះនេះពុំមែនជាការមិនស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[3760]។ បន្ថែមលើនេះ បើទោះបីការសំអាងក្នុងករណី ឯក ហេន និង ស៊ូ សុធារី អាចជ្រុលហួសហេតុក៏ដោយ ក៏នេះពុំមានអ្វីខុសប្លែកដែរ[3761]។ ភស្តុតាងរបស់ ពេជ្រ ជឹម ដែលថា បុគ្គលជាច្រើនខ្លួនឯងចង់រៀបអាពាហ៍ពិពាហ៍នោះ ត្រូវបានលុបលើដោយភស្តុតាងសន្ធឹកសន្ធាប់របស់ប្ដីប្រពន្ធដែលត្រូវបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍ភ្លាមៗមុនពេលពិធីនោះ[3762]។ បន្ថែមលើនេះ ភស្តុតាងដែលថា ពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានប្រើប្រាស់ក្នុងលក្ខណៈជាប្រព័ន្ធ និងរីករាលដាលបានបដិសេធអំណះអំណាងដែលថា កម្មាភិបាលមូលដ្ឋានមួយចំនួនបានធ្វើតាមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តន៍ជាក់ស្ដែង[3763]។

1337.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានភស្តុតាងតិចតួចដែលបានគូសបង្ហាញដោយ ខៀវ សំផន ដែលជាក់ស្ដែង បង្ហាញនូវវត្តមានឪពុកម្ដាយ[3764]។ ជាក់ស្ដែង មានភស្តុតាងជាច្រើន ពុំបានលើកឡើងអំពីការជាប់ពាក់ព័ន្ធរបស់ឪពុកម្ដាយ[3765] និងភស្តុតាងខ្លះទៀតបញ្ជាក់អះអាងច្បាស់លាស់ថា គ្មានវត្តមានឪពុក

---

[3760] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០១។

[3761] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០២។

[3762] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០២។

[3763] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០២។

[3764] *សូមមើល* ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ២១ (អះអាងថា គ្រួសារគាត់បានចូលរួម)។ ប្រតិចារឹក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ (ហ៊ឹម ម៉ាន) ឯកសារលេខ E1/350.1 ទំព័រ ១៥-១៦ (រៀបអាពាហ៍ពិពាហ៍ជាមួយគូដណ្ដឹងដោយមានការជាប់ពាក់ព័ន្ធឪពុកម្ដាយ)។ ប្រតិចារឹក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ (សៀង ចាន់ធី) ឯកសារលេខ E1/394.1 ទំព័រ ១៥-១៦ (បានចូលរួមការរៀបអាពាហ៍ពិពាហ៍បងប្អូនស្រី)។ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ (ហេង ឡៃប៊ាង) ឯកសារលេខ E1/476.1 ទំព័រ ១៣ (ឪពុកម្ដាយចូលរួម)។

[3765] ប្រតិចារឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ (អ៊ុំ សុផានី) ឯកសារលេខ E1/251.1 ទំព័រ ៧៩-៨០ (ពិភាក្សាការពាក់ព័ន្ធរបស់គ្រួសារក្នុងការរៀបអាហ៍ពិពាហ៍ ប៉ុន្តែ ពុំបានពិពណ៌នាវត្តមានរបស់ឪពុកម្ដាយនៅពេលរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ៨ (ពិភាក្សាការពាក់ព័ន្ធរបស់គ្រួសារក្នុងការរៀបអាហ៍ពិពាហ៍ ប៉ុន្តែ ពុំបានពិពណ៌នាវត្តមានរបស់ឪពុកម្ដាយនៅពេលរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ (កង អ៊ុត) ឯកសារលេខ E1/322.1 ទំព័រ ២៥ (អះអាងថា អង្គការដែលរៀបចំការរៀបអាពាហ៍ពិពាហ៍ និង គ្មានការនិសំដៅទៅលើការជាប់ពាក់ព័ន្ធជាមួយឪពុកម្ដាយ)។ ប្រតិចារឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ (សេង ស៊ុន) ឯកសារលេខ E1/346.1 ទំព័រ ៤៦ (ឪពុកម្ដាយជាប់ពាក់ព័ន្ធទៅនឹងការរៀបចំការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែត្រូវបានហាមឃាត់ការរៀបដោយខ្លួនឯង)។ ប្រតិចារឹកថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ (ម៉ាត់ ស) ឯកសារលេខ E1/375.1 ទំព័រ ៦៧ (ការរៀប

ម្ដាយទាល់តែសោះ[3766]។ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញផងដែរថា នៅគ្រប់កាលៈទេសៈ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានដកចេញនូវលទ្ធភាពនៃការចូលរួមពីឪពុកម្ដាយនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ក្នុងករណីមួយចំនួនឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ក្នុងករណីដ៏កម្រ" ឪពុកម្ដាយរបស់គូស្រករមានវត្តមានក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍[3767] ប៉ុន្តែថា ភស្តុតាង "ភាគច្រើន"បានបង្ហាញថា សមាជិកគ្រួសារ"តាមធម្មតា"ពុំបានចូលរួមពិធីរៀបអាពាហ៍ពិពាហ៍[3768]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងនៃវត្តមានរបស់ឪពុកម្ដាយនៅពេលពិធីរៀបអាពាហ៍ពិពាហ៍នោះ ត្រូវបដិសេធចោលដោយសារការបកស្រាយការបំភ្លៃភស្តុតាង និងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

1338.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាងរបស់ ឯក ហេន និង ស៊ូ សុធាវី ដែលផ្អែកតាម ខៀវ សំផន ថា ត្រូវបានសំអាងដោយពុំត្រឹមត្រូវទៅលើក្នុងការបង្កើតការយល់ឃើញអំពីការកើតឡើងជាទូទៅនៃការរៀបអាពាហ៍ពិពាហ៍សមូហភាព[3769]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ក្នុងករណីដ៏កម្រ ពិធីរៀបអាពាហ៍ពិពាហ៍អាចមានរហូតដល់រាប់រយគូ" [3770]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ឯក ហេន ដែលថា គាត់បានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដែលមាន ៤០០ គូ ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨ នៅពេលគាត់បានមកដល់ភូមិភាគមជ្ឈិម ព្រមទាំងចម្លើយរបស់ ស៊ូ សុធាវី ដែលថា លោកស្រីត្រូវបានឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងពិធី

---

អាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំ ដែលពុំបានកើតឡើងស្របតាមប្រពៃណី)។ ប្រតិចារឹកថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ (ថេង ផល) ឯកសារលេខ E1/371.1 ទំព័រ ៥៥ (ពុំបានផ្ដល់ភស្តុតាងអំពីគ្រួសារ ឬការជាប់ពាក់ព័ន្ធគ្រួសារ)។ ប្រតិចារឹកថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ (ប៉ាន់ ឈួង) ឯកសារលេខ E1/360.1 ទំព័រ ២៩ (សំដៅទៅលើការជាប់ពាក់ព័ន្ធរបស់ឪពុកម្ដាយក្នុងការផ្គូផ្គង ប៉ុន្តែមិនមែនជាការរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំ)។ ប្រតិចារឹកថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ១៣ (ឪពុកម្ដាយបានចូលរួម)។

[3766] ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ (ម៉ី សាវឿន) ឯកសារលេខ E1/459.1 ទំព័រ ៦៩-៧០ (ឆ្លើយច្បាស់លាស់ថា សាច់ញាតិពុំត្រូវបានអនុញ្ញាតឱ្យចូលរួមពិធីរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ (ឱ ហូ) ឯកសារលេខ E1/301.1 ទំព័រ ៥៦-៥៧ (បញ្ជាក់ថា ឪពុកម្ដាយពុំបានចូលរួមការរៀបអាពាហ៍ពិពាហ៍ និងពុំត្រូវបានជូនដំណឹង)។

[3767] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៩។

[3768] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៩-៣៦៤០។

[3769] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៤៨៤ យោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៤៥០។

[3770] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។

ដែលមានគូស្រករ ១១៧ គូ[3771]។ ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើភស្តុតាងរបស់បុគ្គលទាំងនេះធ្វើជាការបង្ហាញនូវស្ថានការណ៍ខុសប្លែកធម្មតា ដែលជា"ករណីកម្រ"[3772]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយផ្អែកលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលថា ជាទូទៅ"ប្តីប្រពន្ធជាច្រើនបានរៀបអាពាហ៍ពិពាហ៍ក្នុងពិធីតែមួយ ដែលមានចាប់ពីមួយគូរហូតដល់ ៧០-៨០ គូ"[3773]។ ខៀវ សំផន បានបំភ្លៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដូចនេះសារណានេះត្រូវបដិសេធចោល។

1339.ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅនឹងភស្តុតាងដោះបន្ទុកក្នុងការសន្និដ្ឋានរបស់ខ្លួនដែលថា ការរៀបអាពាហ៍ពិពាហ៍ជាសមូហភាពបានកើតឡើង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវលើលក្ខណៈនៃភស្តុតាងដោះបន្ទុក។ ដោយហេតុថា ការរៀបអាពាហ៍ពិពាហ៍សមូហភាពជាច្រើនត្រូវបានរៀបចំឡើងតាមលក្ខណៈ"រីករាលដាល"[3774] ដោយផ្អែកលើភស្តុតាងទូលំទូលាយរបស់សាក្សី[3775] ព្រមទាំងសេចក្តីណែនាំដែលប្តីប្រពន្ធត្រូវប្តេជ្ញាជូនអង្គការក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍នោះ[3776]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានដែលថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋានជាប្រព័ន្ធ។

1340.ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការឡើងប្តេជ្ញាដែលបានធ្វើឡើងក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍នោះ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញច្បាស់លាស់ថា "ក្នុងករណីតិចតួច ពុំមាន

---

[3771] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។ អង្គជំនុំជម្រះតុលាការកំពូលប្រើពាក្យ "លោកស្រី"ជាសព្វនាមរបស់ ស៊ូ សុធាវី ដែលបានពិពណ៌នាខ្លួនឯងថា ជាស្ត្រីភេទទីបី។ បើទោះបីជា ស៊ូ សុធាវី មានភេទប្រុសជីវសាស្ត្រក៏ដោយ ក៏លោកស្រីបានអះអាងថា លោកស្រីចូលចិត្តស្លៀកសំលៀកបំពាក់ស្រីតាំងពីវ័យជប់ឆ្នាំ ហើយលោកស្រី"បានស្លៀកសំពត់វែង និងទុកសក់វែងរួចចង ខ្ញុំមានចរិតដូចមនុស្សស្រី" សូម្បីក្នុងអំឡុងពេលដំបូងនៃការចាប់ខ្លួនដោយខ្មែរក្រហម។ *សូមមើល* ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៦៤។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ឯកសារលេខ E3/4607 ទំព័រ ៨។

[3772] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។

[3773] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។

[3774] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣១។

[3775] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣២។

[3776] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣។

ការប្តេជ្ញាត្រូវបានធ្វើឡើង"[3777] ប៉ុន្តែទោះជាយ៉ាងណាក្តីបានយល់ឃើញថា ការប្តេជ្ញានោះជាទូទៅបានកើតឡើង ដោយសារមានភស្តុតាងទូលំទូលាយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញដូច្នោះ[3778]។ ដូចគ្នាដែរ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានការជាប់ពាក់ព័ន្ធនៅក្នុងការជំទាស់របស់ ខៀវ សំផន ដែលថា ភស្តុតាងបានបង្ហាញថា ពិធីរៀបអាពាហ៍ពិពាហ៍បានធ្វើឱ្យសហព័ទ្ធ ទៅជាផ្លូវការដោយសារនេះជាភស្តុតាងមិនអាចប្រកែកបាន ដូច្នេះការជំទាស់នោះពុំបានធ្វើឡើងចំពោះការយល់ឃើញផ្នែកអង្គហេតុ ឬអង្គច្បាប់ពាក់ព័ន្ធណាមួយឡើយ។

- *ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

1341.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ការរៀបចំត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋានសម្រាប់ប្តីប្រពន្ធថ្មោងថ្មីដេកក្នុងទីកន្លែងដែលគេបានកំណត់ជាពិសេសដើម្បីរួមភេទ[3779]។ កងឈ្លបជាធម្មតាត្រូវបានបង្គាប់ឱ្យតាមដានប្តីប្រពន្ធពេលយប់ដើម្បីឱ្យដឹងច្បាស់ថា ពួកគេបានរួមភេទ[3780]។ ទាំងបុរស និងស្ត្រីមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យរួមភេទ និងប្តីប្រពន្ធដែលត្រូវបានរកឃើញថា ពុំបានរួមភេទនោះ ត្រូវទទួលការអប់រំកែប្រែ ឬគំរាមកំហែងសម្លាប់ ឬការដាក់ទណ្ឌកម្ម[3781]។ ក្នុងហេតុការណ៍មួយចំនួន ការរំលោភសេពសន្ថវៈត្រូវបានប្រើប្រាស់ជាការដាក់ទោសសម្រាប់ការខកខានក្នុងការរួមដំណេកអាពាហ៍ពិពាហ៍[3782]។ ប្តីប្រពន្ធដែលពុំបានរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍ត្រូវតែលាក់បាំងការពិត និងធ្វើពុតថា ពួកគេបានស្រលាញ់គ្នាទៅវិញទៅមកដើម្បីជៀសវាងផលវិបាកអវិជ្ជមាន[3783]។

1342.ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានដែលថា ការរួមភេទដោយបង្ខំបានកើតឡើងស្របតាមគោលនយោបាយ[3784] ព្រមទាំងការយល់ឃើញស្តីពីការតាមដានការរួមដំណេកដោយបង្ខំ[3785] អំពើនៃ"ការរំលោភ

---

[3777] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៥។

[3778] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៣៣។

[3779] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[3780] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[3781] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[3782] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៨។

[3783] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[3784] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦២-១៣៦៣, ១៣៦៥, ១៣៧០

[3785] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥-១៣៤៨។

សេពសន្ថវៈ”ប្រើប្រាស់ជាការដាក់ទណ្ឌកម្ម[3786] និងការពិតដែលថា មានកង្វះភស្តុតាងក្នុងករណីខ្លះនៃការអះអាងច្បាស់លាស់នូវការបង្ខិតបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍[3787]។ គាត់បានអះអាងផងដែរថា ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការលាក់បាំងនៃការរួមដំណេកដោយបង្ខំបង្ហាញនូវកំហុសអង្គហេតុ និងអង្គច្បាប់[3788]។

1343.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើអំណះអំណាងនេះតាមលំដាប់លំដោយខាងក្រោម។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានយល់ឃើញខាងលើថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការតម្រង់ទិសខ្លួនឯងពិចារណាលើបញ្ហាថាតើ ធាតុផ្សំ“បទឧទ្ទក្រិដ្ឋ”នៃការរំលោភសេពសន្ថវៈ និងដោយបានយល់ឃើញថា បុរសពុំមែនជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទដទៃទៀតដែលជាបទឧក្រិដ្ឋឯករាជ្យ ត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា[3789]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាតែលើបញ្ហាថាតើ ការប្រព្រឹត្តដែលត្រូវបានពិពណ៌នាក្នុងដីកាដំណោះស្រាយនោះ ត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា។ ការប្រព្រឹត្តក្នុងករណីនេះ គឺជាអំពើនៃការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធដែលទើបរៀបអាពាហ៍ពិពាហ៍ថ្មីៗ និងជាប់ពាក់ព័ន្ធជនរងគ្រោះទាំងបុរស និងស្ត្រី។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើការជំទាស់របស់ ខៀវ សំផន ដូចខាងក្រោមទាក់ទងទៅនឹងបញ្ហាថាតើ កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានប៉ះពាល់ដល់ការវាយតម្លៃរបស់ខ្លួនអំពីការយល់ឃើញផ្នែកអង្គហេតុដទៃទៀត និងប្រសិនបើចាំបាច់ នឹងត្រូវធ្វើការកែតម្រូវលើកំហុសណាមួយដែលបានកើតឡើងនោះ។

### ក) ការយល់ឃើញស្តីពីការរួមភេទដោយបង្ខំ

1344.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានផ្នែកដាច់ដោយឡែកតូចមួយក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចំណងជើងថា “ការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធ”[3790]។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់បុគ្គលប្រាំមួយនាក់ដែលជាស្ត្រី មានដូចជា អ៊ុំ យឿន, មុំ វុន, ព្រាប សុខឿន, ប៉ែន សុចាន់, ជា ឌៀប, ផាន់ ហ៊ឹម ព្រមទាំងភស្តុតាងរបស់ ស៊្វ សុធារី អំពីប្រពន្ធរបស់គាត់

[3786] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៨-១៣៦៩ ជើងទំព័រ ២៥៩១។

[3787] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧២, ១៣៧៥។

[3788] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៤។

[3789] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣៨។

[3790] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៨-៣៦៦១។

ដែលជាជនរងគ្រោះស្ត្រីទីប្រាំពីរ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញជាទូទៅថា អង្គជំនុំជម្រះជឿជាក់ថា "ស្ត្រីទាំងនេះលើកលែងតែ ផាន់ ហ៊ឹម ត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍"[3791]។

1345.ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ផ្នែកនេះពុំបានយោងទៅលើជនរងគ្រោះទាំងអស់នៃគោលនយោបាយនៃការរួមភេទដោយបង្ខំដែរ។ នេះបានអនុវត្តចំពោះជនរងគ្រោះជាស្ត្រីដែលត្រូវបានគូសបង្ហាញច្បាស់លាស់ក្នុងផ្នែកនេះ។ នៅក្នុងចំណុចតូចៗទាក់ទងៗបន្ថែមទៀតស្តីពី"បរិយាកាសដោយបង្ខំ" និង"ការតាមដាន" អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ជនរងគ្រោះជាស្ត្រីបន្ថែមទៀត ដូចជា ជាំង ស្រីមុំ, សយ ណារឿន, ជុំ សាមឿន ខណៈពេលនៅក្នុងផ្នែកស្តីពី"ការតាមដាន" អង្គជំនុំជម្រះបានពិចារណាលើភស្តុតាងរបស់ជនរងគ្រោះស្ត្រី ដូចជា ង៉ែត ចាត, ហេង ឡៃហ៊ាង, អ៊ុន យឿង, មាស ឡៃហួរ, ណុប ង៉ឹម និង ឃិន វ៉ាត[3792]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ស្ត្រីទាំងអស់នេះគឺជាជនរងគ្រោះនៃគោលនយោបាយនៃការរួមភេទដោយបង្ខំ រួមបញ្ចូលទាំងលទ្ធភាពដែលថា ស្ត្រីដទៃទៀតដែលពុំត្រូវបានយោងជាក់លាក់ ជាជនរងគ្រោះផងដែរ។

1346.ដោយសារមានសារៈសំខាន់ជាសត្យានុម័តពាក់ព័ន្ធបញ្ហានេះ ការយល់ឃើញស្តីពី"ការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធ"បានដកជនរងគ្រោះជាបុរសចេញទាំងស្រុង។ អង្គជំនុំជម្រះតុលាការកំពូលរំឭកដីកាដំណោះស្រាយដែលបានចោទប្រកាន់អំពើនៃការរួមដំណេកដោយបង្ខំទាក់ទងទៅនឹងជនរងគ្រោះបុរស និងស្ត្រីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដែលថា បុរស និងស្ត្រីត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ជនរងគ្រោះ កុល ណែម និង យស ផល ក្នុងផ្នែកស្តីពី"បរិយាកាសបង្ខិតបង្ខំ" និង"តាមដាន"ព្រមទាំងជនរងគ្រោះបុរស ញឹម កុល ផ្នែកស្តីពីការ"តាមដាន" និងដើមបណ្តឹងរដ្ឋប្បវេណី

---

[3791] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៩។

[3792] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦, ៣៦៦៣, ៣៦៧៣ ជើងទំព័រ ១២១៧៣, ១២១៧៦, ១២១៨៣, ១២១៨៧, ១២១៩៦ (ជាំង ស្រីមុំ)។ កថាខណ្ឌ ៣៦៤១, ៣៦៤៦ ជើងទំព័រ ១២១៧៣, ១២១៨០, ១២១៨៩, ១២១៩០-១២១៩១ (សយ ណារឿន)។ កថាខណ្ឌ ៣៦៤៧ ជើងទំព័រ ១២១៧៦, ១២២០០ (ជុំ សាមឿន)។ ជើងទំព័រ ១២១៧៣, ១២១៧៦ (ង៉ែត ចាត)។ កថាខណ្ឌ ៣៦៤៣ ជើងទំព័រ ១២១៧៥-១២១៧៦, ១២១៨៥ (ហេង ឡៃហ៊ាង)។ កថាខណ្ឌ ៣៦៤៥ ជើងទំព័រ ១២១៨៨ (អ៊ុន យឿង)។ ជើងទំព័រ ១២១៧៥-១២១៧៦ (មាស ឡៃហួរ)។ កថាខណ្ឌ ២៦៤១ ជើងទំព័រ ១២១៧៨ (ណុប ង៉ឹម)។ ជើងទំព័រ ១២១៧៦ (ឃិន វ៉ាត)។

ប្រាក់ ឌឿន ក្នុងផ្នែកស្តីពីបរិយាកាសបង្ខិតបង្ខំ[3793]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ជនរងគ្រោះបុរសឈ្មោះ អែម អឿន ក្នុងផ្នែកស្តីពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[3794] និង មាន លឿយ ក្នុងផ្នែកស្តីពី"ការបំបែក"[3795]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ មុំ វុន ទាក់ទងទៅនឹងភស្តុតាងប្តីរបស់គាត់[3796]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជាអប្បបរមា បុរសទាំងនេះគឺជាជនរងគ្រោះនៃការរួមដំណេក។

1347.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញប្រហាក់ប្រហែលគ្នាផងដែរថា នៅក្នុងការវិភាគនោះ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតការយល់ឃើញរបស់ខ្លួនត្រឹមការបង្ខិតបង្ខំលើជនរងគ្រោះជាស្ត្រី។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ស្ត្រី [...] ត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ដោយសារពួកគេភ័យខ្លាចអាយុជីវិតរបស់ខ្លួន ឬសុវត្ថិភាពរូបកាយ និងដូច្នេះពុំបានយល់ព្រមពិតប្រាកដនោះទេ ឬពីព្រោះពួកគេត្រូវបានបង្ខិតបង្ខំឱ្យទទួលយកការរួមភេទជាមួយប្តីរបស់ខ្លួន"[3797]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អំពើប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នេះ ដូចបានគូសបង្ហាញខាងលើ គឺជាអព្យាក្រឹតនៃភេទ។ អង្គជំនុំជម្រះសាលាដំបូងក្នុងការវិភាគដដែលនោះបានបង្ហាញបរិយាកាសបង្ខិតបង្ខំក្នុងលក្ខណៈអព្យាក្រឹតនៃភេទ និងបានបញ្ជាក់ថា "ការយល់ព្រមពិតប្រាកដទៅនឹងការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ពុំអាចកើតមានក្នុងបរិយាកាសដែលប្តីប្រពន្ធ ពុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ពីដើមដំបូងឡើយនោះទេ និងបានដឹងថា ការរួមដំណេកត្រូវបានតម្រូវ និងការអនុវត្តនោះត្រូវបានតាមដាន និងក្នុងករណីមិនអនុវត្តតាម ត្រូវបង្ខំ"[3798]។ យោងតាមហេតុផលទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាំងបុរស និងស្ត្រីត្រូវបានដាក់ឱ្យស្ថិតក្រោមបរិយាកាសបង្ខិតបង្ខំដែលក្នុងនោះខ្វះការស្ម័គ្រចិត្ត។

---

[3793] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦ ជើងទំព័រ ១២១៧៦, ១២១៨៩, ១២១៩៥ (កុល ណែម)។ កថាខណ្ឌ ៣៦៤៧ ជើងទំព័រ ១២១៧៣, ១២១៧៦, ១២២០១, ១២៣២៨ (យស ផល)។ ជើងទំព័រ ១២១៧៧ (ប្រាក់ ឌឿន)។

[3794] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២២៧៤, ១២២៨៧ (អែម អឿន)។

[3795] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦៣ ជើងទំព័រ ១២២៣៣ (មាន លឿយ)។

[3796] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤២, ៣៦៥០។

[3797] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៩។

[3798]សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៦១។

ខ) ថាតើ មាន"គោលនយោបាយ"នៃរួមភេទដោយបង្ខំ ដែរ ឬយ៉ាងណា

1348.ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានដែលថា ការរួមភេទដោយបង្ខំបានកើតឡើងស្របតាមគោលនយោបាយ[3799]។ នៅក្នុងសារណារបស់គាត់ សាក្សីជំនាញ NAKAGAWA Kasumi បានឆ្លើយតបថា មាន "គោលនយោបាយការពារស្ត្រី"[3800] ហើយ NAKAGAWA Kasumi ព្រមទាំង ប្រាក់ យុត និង Peg LEVINE ក៏បានអះអាងផងដែរថា ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ គឺជា"ការដែលជៀសពុំរួច" ជាជាងការដែលត្រូវបង្ខំ[3801]។

1349.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សក្ខីកម្មរបស់ NAKAGAWA Kasumi បានបង្ហាញថា ពុំមានគោលនយោបាយការពារស្ត្រីដែលមានអត្ថិភាពតាមការជាក់ស្តែងនោះទេ[3802]។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើ ផ្នែកណាមួយនៃភស្តុតាងត្រូវទទួលយក និងត្រូវបដិសេធចោល រួមទាំងសក្ខីកម្មរបស់ Peg LEVINE ផងដែរ[3803]។

1350.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងរបស់ NAKAGAWA Kasumi ស្តីពីការរួមភេទដោយបង្ខំ។ នៅក្នុងផ្នែកនៃភស្តុតាងដែលគាត់យោងទៅលើនោះ NAKAGAWA Kasumi បានពិភាក្សាលើឧទាហរណ៍អំពីស្ត្រីដែលត្រូវបានរំលោភសេពសន្ថវៈ ដោយសារពួកគេប្រកែកការរៀបអាពាហ៍ពិពាហ៍នោះ[3804]។ លោកស្រីបានបញ្ជាក់ថា នេះគឺជាការរំលោភអំណាចរបស់កម្មាភិបាលមូលដ្ឋាន ដែលរំលោភបំពានលើគោលនយោបាយផ្លូវការនោះ[3805]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អ្វីដែលត្រូវបានចោទប្រកាន់ក្នុងករណីនេះ គឺជាអំពើហិង្សាផ្លូវភេទដែលបានកើតឡើងក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយសារប្តីប្រពន្ធត្រូវបានបង្ខំឱ្យរួមភេទជាមួយគ្នា

---

[3799] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦២-១៣៦៣, ១៣៦៥, ១៣៧០

[3800] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧០។

[3801] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦២-១៣៦៣, ១៣៦៥, ១៣៧០

[3802] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៥។

[3803] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៩។

[3804] *សូមមើល* ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/473.1 នៅម៉ោង ១៤.១៥.៣២។

[3805] *សូមមើល* ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/473.1 នៅម៉ោង ១៤.១៥.៣២។

តាមការចង់បានរបស់កម្ពុជាប្រជាធិបតេយ្យ[3806]។ ភស្តុតាងរបស់ NAKAGAWA Kasumi ពុំជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញនេះ ដូចនេះ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

1351.បន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើភស្តុតាងដែលបង្ហាញថា នេះត្រូវបានចាត់ទុកថា ជាការសមស្រប ឬជៀសពុំរួច ជាជាងការបង្ខំក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ប្រាក់ យុត ដែលថា "ក្រោយការរៀបអាពាហ៍ពិពាហ៍ ជាការសមស្របដែលប្ដីប្រពន្ធត្រូវរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ។ ដូចនេះ ប្រសិនបើគ្មានវិញ តើអ្វីទៅជាគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ ?"[3807]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់លើភស្តុតាងដែលថា ការរួមដំណេកកើតមានជាធម្មជាតិក្រោយការរៀបអាពាហ៍ពិពាហ៍ ហើយសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើនោះត្រូវបដិសេធចោល។ បន្ថែមលើនេះ ខៀវ សំផន ខកខានក្នុងការពិនិត្យលើភស្តុតាងជារួម។ ប្រាក់ យុត បានអះអាងថា ប្ដីប្រពន្ធ"ត្រូវតែរួមដំណេក"ការរៀបអាពាហ៍ពិពាហ៍[3808] និងនៅពេលសង្កេតឃើញថា លោកស្រីពុំអាច"អនុវត្តវិធានការ" លោកស្រីបានបញ្ជាក់ផងដែរថា បុគ្គលនោះ"នឹងត្រូវបាននាំទៅស្រុកដើម្បីអប់រំកែប្រែ"[3809]។ ការអប់រំកែប្រែដូចបានពិភាក្សារួចមកហើយនោះ គឺជាទម្រង់នៃដាក់ទណ្ឌកម្ម។

1352.ខៀវ សំផន បានអះអាងប្រហាក់ប្រហែលគ្នាថា សាក្សីជំនាញបានបញ្ជាក់ថា ការរួមភេទបានកើតមានជាការសមស្របបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ ជាជាងការកើតឡើងស្របតាមគោលនយោបាយ។ សាក្សីជំនាញ Peg LEVINE បានបញ្ជាក់ថា ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ជាទូទៅបានកើតឡើងក្នុងការរៀបអាពាហ៍ពិពាហ៍[3810] និង NAKAGAWA Kasumi បានអះអាងផងដែរថា កូនៗត្រូវបានរំពឹងឱ្យគោរព

---

[3806] ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤៣០-១៤៣៣។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៥-៣៧០១។

[3807] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៥ យោងទៅលើប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៣៨-៣៩។

[3808] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៤១-៤២។

[3809] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៤១-៤២។

[3810] ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ (Peg LEVINE) ឯកសារលេខ E1/480.1 នៅម៉ោង ១៥.៥០ ("ពិតណាស់ ខ្ញុំមិនចង់មានន័យថា អ្វីដែលបានកើតឡើងក្នុងកម្ពុជាប្រជាធិបតេយ្យនោះគាប់ប្រសើរនោះ ប៉ុន្តែការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ ជាទូទៅក្នុងវប្បធម៌លោកខាងលិច នៅពេលនិយាយអំពីពេលក្រេបទឹកឃ្មុំគឺត្រូវបានរំពឹងទុកកើតមាន")។

តាមក្រោយពេលការរៀបអាពាហ៍ពិពាហ៍[3811]។ ទោះជាយ៉ាងណាក្តី សាក្សីដទៃទៀតបានបញ្ជាក់ច្បាស់លាស់ថា បញ្ហានេះបានកើតឡើងក្រោយពីការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានបង្ខំលើពួកគេដោយអង្គការ[3812]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការយល់ឃើញនេះដោយគ្មានការបង្ហាញនូវកំហុស ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## គ) បរិយាកាសបង្ខិតបង្ខំ

1353.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាំងបុរស និងស្ត្រីមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យរួមភេទ និងត្រូវទទួលរងការអប់រំកែប្រែឡើងវិញ ឬគំរាមកំហែងសម្លាប់ ឬការដាក់ទណ្ឌកម្ម[3813]។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុអំពីការតាមដានដោយកងឈ្លបប្រដាប់អាវុធក្រោយពិធីរៀបអាពាហ៍ពិពាហ៍ និងអំពើនៃការរំលោភសេពសន្ថវៈដែលជាការដាក់ទណ្ឌកម្ម និងបានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាទាក់ទងទៅនឹងបុគ្គលមួយចំនួនថា ពួកគេពុំបានឆ្លើយច្បាស់លាស់ទាក់ទងទៅនឹងការកើតឡើងនៃការរួមដំណេក"ដោយបង្ខំ"។

### (i) ការតាមដានដោយកងឈ្លបប្រដាប់អាវុធក្រោយពិធីរៀបអាពាហ៍ពិពាហ៍

1354.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ការរៀបចំត្រូវបានធ្វើឡើងតាមធម្មតាដោយអាជ្ញាធរមូលដ្ឋានសម្រាប់ប្តីប្រពន្ធថ្មីដេកក្នុងទីកន្លែងដែលបានកំណត់ទុក ជាពិសេសដើម្បីរួមភេទ[3814]។ កងឈ្លបត្រូវបានបង្គាប់ឱ្យតាមដានប្តីប្រពន្ធនៅពេលយប់ដើម្បីធានាថា ពួកគេបានរួមភេទ[3815]។

1355.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការតាមដានបានកើតឡើង។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតាមបែបជ្រើសរើសទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ការរៀបរាប់"ផ្សេងៗ"ទាក់ទងទៅ

---

[3811] ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 នៅម៉ោង ១១.១៥។

[3812] *សូមមើល* ឧ. ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 នៅម៉ោង ១១.១២ ("អង្គការរៀបចំការរៀបអាពាហ៍ពិពាហ៍ពួកយើង។ យើងត្រូវតែរស់នៅជាមួយគ្នាដើម្បីយើងអាចជាប្តីប្រពន្ធ និងក្រោយមកមានកូន")។

[3813] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[3814] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១, ៣៦៩៦។

[3815] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១, ២៦៤៤, ៣៦៦០, ៣៦៩៦។

នឹងគោលបំណងនៃការតាមដាននោះក្រោយពិធីរៀបអាពាហ៍ពិពាហ៍ និងខកខានក្នុងការនិយាយថា ការតាមដាននោះបានកើតឡើង ឬថា បានកើតឡើងជាទូទៅ ឬដើម្បីធានានូវការគោរពតាមសាសនា និងផលប៉ះពាល់នៃការតាមដានដែលជាញឹកញាប់ពុំបាននាំទៅរកការរួមភេទឡើយ[3816]។ បុគ្គលមួយចំនួនបានផ្តល់សក្ខីកម្មត្រឹមតែអ្វីដែលពួកគេបានឮ ប៉ុន្តែពុំបានឃើញផ្ទាល់[3817]។ ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីយល់ឃើញថា ការតាមដានត្រូវបានធ្វើឡើងស្របតាមគោលការណ៍នោះ[3818]។

1356.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានរួមបញ្ចូលភស្តុតាងដែលចេញពីផ្នែកដទៃទៀតនៃការជំនុំជម្រះ និងមានភាពជាតំណាងពេញលេញ[3819]។ បន្ថែមលើនេះ ភស្តុតាងនេះពុំបានបង្ហាញនូវលក្ខណៈផ្សេងៗគ្នានៃបទពិសោធន៍ និងបានភ្ជាប់ការតាមដាននោះដោយស្របគ្នាជាមួយនឹងការរួមដំណេកដោយបង្ខំ[3820]។

1357.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើអំណះអំណាងអំពីភាពជាតំណាង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាំបីនាក់[3821] និងសាក្សីដប់នាក់[3822] ព្រមទាំងបុគ្គលបីនាក់ដែលបានបង្ហាញខ្លួនជាសាក្សីផង និងដើមបណ្តឹងរដ្ឋប្បវេណីផង[3823] នៅពេលបង្កើតការយល់ឃើញរបស់ខ្លួនស្តីពីអត្ថិភាពនៃការតាមដាន[3824]។ ការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកតាមបែបមិនទូទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ពុំបានឆ្លុះបញ្ចាំងការពិតនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងដូច្នេះត្រូវបដិសេធចោល។ ប្រហាក់ប្រហែលគ្នានេះ ពុំមានកំហុសក្នុង"ភាពជាតំណាង"នៃការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងផងដែរ[3825]។ នេះជារឿងធម្មតាដែលថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់

---

[3816] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥-១៣៤៨។

[3817] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៧-១៣៤៨។

[3818] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥៣។

[3819] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣៧។

[3820] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣៨។

[3821] ជា ឌៀប, ស៊ូ សុធារី, ប៉ែន សុចាន់, ព្រាប សុឃឿន, កុល ណែម, ជុំ សាម៉ឿន, អ៊ុំ យឿន, សយ ណារឿន។

[3822] ភ្មៅ យ៉ាវ, មាស ឡៃហួរ, ម៉ម សឿន, ហេង ឡៃហ៊ាង, ណុប ងីម, ង៉ែត ចាត, ជាំង ស្រីមុំ, ឃិន វ៉ាត, NAKAGAWA Kasumi, កាំង ហ្គេកអ៊ាវ។

[3823] យស ផល, ជូ គឹមឡន, ប្រាក់ ឌឿន។

[3824] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១ ជើងទំព័រ ១២១៧៥-១២១៧៦។

[3825] *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥៦-១៣៦០។

ភស្តុតាងជាពិសេសអំពីបទពិសោធន៍របស់ខ្លួននៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានបង្ហាញនូវអារម្មណ៍ពិតប្រាកដអំពីការដែលត្រូវបានតាមដានក្នុងការរួមដំណេកនោះ។ ការដែលថា សាក្សីពុំបានលើកឡើងអំពីការតាមដាននេះនៅក្នុងការផ្ដល់សក្ខីកម្មអំពីបទឧក្រិដ្ឋដទៃទៀតជាពិសេសនៅពេលគ្មានការសួរសំណួរលើបញ្ហានេះ ពុំជាប់ពាក់ព័ន្ធឡើយ[3826]។

1358.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការចោទប្រកាន់របស់ ខៀវ សំផន ដែលថា ភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណីមានលក្ខណៈ"ផ្សេងៗគ្នា" ដែលជាពាក្យពេចន៍មួយអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់សន្មតអត្ថន័យថា "មិនស៊ីសង្វាក់គ្នា"ស្ដីពីគោលបំណងនៃការតាមដាន។ ក្នុងការគាំទ្រ ខៀវ សំផន បានចង្អុលបង្ហាញទៅលើដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការវិភាគរបស់ខ្លួនអំពីការតាមដាន[3827]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ពុំមានបុគ្គលណាម្នាក់ដែលគាត់បានលើកឡើងនោះ ជាក់ស្ដែង បានផ្ដល់ភស្តុតាងមិនស៊ីសង្វាក់គ្នាទាក់ទងទៅនឹងគោលបំណងនៃការតាមដានឡើយ។ អ៊ុំ យឿន និង ព្រាប សុខឿន អ្នកទាំងពីរបានផ្ដល់ភស្តុតាងថា កងឈ្លបបានតាមដានប្ដីប្រពន្ធដើម្បីឱ្យដឹងអំពីការរួមដំណេក និងពុំបានសំដៅទៅលើគោលបំណងបន្ថែមទៀតណាមួយនៃការតាមដាន[3828]។ ព្រាប សុខឿន បានអះអាងថា ក្រោមរបបនោះ បុគ្គលត្រូវបានដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលជា

[3826] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលត្រូវបានគូសបង្ហាញដោយ ខៀវ សំផន ខកខានលើកឡើងនូវការអនុវត្តន៍នៃការតាមដាន ប៉ុន្តែមិនបានផ្ដល់ភស្តុតាងថា ពុំបានកើតឡើងនោះទេ។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥៦-១៣៦០។ ខៀវ សំផន បានចង្អុលបង្ហាញទៅលើចម្លើយជាលាយលក្ខណ៍អក្សរមួយប៉ុណ្ណោះ ដោយកម្មាភិបាល ប្រាក់ យុត ក្នុងការបង្ហាញប្រសិទ្ធភាពថា ពុំមានការគាបសង្កត់ឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៥៧៦ យោងទៅលើ ប្រាក់ យុត កំណត់ស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E3/9499 ស/ឆ៖ ៩៦-៩៧។

[3827] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១-៣៦៤៣។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥ និងជើងទំព័រ ២៥៤៦, ២៥៤៨-២៥៤៩ យោងទៅលើ អ៊ុំ យឿន, ព្រាប សុខឿន, ជុំ សាមឿន, មាស ឡៃហួរ, ហេង ឡៃហ៊ាង, ជាំង ស្រីមុំ។

[3828] ប្រតិចារឹកថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 ទំព័រ ៥១-៥៣ (ដោយពន្យល់ថា ឈ្លបលបស្ដាប់គូស្វាមីភរិយាដើម្បីឲ្យដឹងថាពួកគាត់រួមដំណេកឬអត់)។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/488.1 ទំព័រ ៦-៧ (ដោយបញ្ជាក់ថា គូស្វាមីភរិយាស្ថិតនៅក្រោមការឃ្លាំមើលពេញមួយយប់)។ ប្រតិចារឹកថ្ងៃទី២៣ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ៧-៨, ៤២-៤៣ ("បើសិនជាអត់មានរួមដំណេកទេ គេអាចមានវិធានការផ្សេងទៀត ហើយនាងខ្ញុំព្រមទៅ [...] លោកស្រីបញ្ជាក់ឲ្យច្បាស់ តើលោកស្រីរួមភេទជាមួយនឹងប្ដីលោកស្រី

ទូទៅ[3829] ខណៈពេលផ្តល់ភស្តុតាងផងដែរថា ប្តីប្រពន្ធត្រូវបានតាមដានជាពិសេសនៅពេលយប់នៃពិធីរៀបអាពាហ៍ពិពាហ៍[3830]។ មាស ឡៃហួរ បានផ្តល់ភស្តុតាងច្បាស់លាស់ថា កងឈ្លប"ដើរមើលថាតើ យើងចុះសម្រុងគ្នា ដែរ ឬអត់ និងថាតើ យើងបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់យើង ដែរ ឬទេ"[3831] និងពុំបង្ហាញដូចការអះអាងរបស់ ខៀវ សំផន ដែលថា គោលបំណងនៃការតាមដានគឺដើម្បីធានាបាននូវការប្រតិបត្តិវិធីសាសនានោះទេ[3832]។ ភស្តុតាងរបស់ ហេង ឡៃហ៊ាង ដែលបង្ហាញថា ប្តីប្រពន្ធដែលពុំបានអនុវត្តតាម ត្រូវបានតាមដាននោះ ស៊ីសង្វាក់ទាំងស្រុងជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការតាមដានបានកើតឡើងជាផ្នែកមួយនៃរបបបង្ខិតបង្ខំ[3833] ដូចគ្នានឹងភស្តុតាងរបស់ ជាំង ស្រីមុំ ដែលថា ការតាមដានអាចកើតឡើងដើម្បីកំណត់ថា ប្តីប្រពន្ធមួយគូ"ចុះសម្រុងគ្នា" ឬនិយាយអាក្រក់ពីអង្គការ[3834]។

1359.អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើសារណាដែលថា ភស្តុតាងមានលក្ខណៈ"ផ្សេងៗគ្នា" នៅពេលនិយាយអំពីគោលបំណងនៃការតាមដាន។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ចេតនានៃការតាមដាន គឺដើម្បីធានាថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរួមដំណេកដែលត្រូវបានគាំទ្រដោយភស្តុតាងនោះ។

---

នៅពេលណាមួយឲ្យជាក់លាក់? ឆ៖ ខែក្រោយតទៅទៀត [...] អាហ្នឹងខ្លាចខ្លាំងណាស់ គេគំរាមខ្លាំងហើយ ចេះតែតម្រង់ទៅ")។

[3829] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥ ជើងទំព័រ ២៥៤៦។

[3830] ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/488.1 ទំព័រ ៦-៧ (ដោយបញ្ជាក់ថា គូស្វាមីភរិយាស្ថិតនៅក្រោមការឃ្លាំមើលពេញមួយយប់)។

[3831] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២៧៥ យោងទៅលើប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ១៤។ *ធៀបនឹង* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២៧៦ យោងទៅលើប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ១២-១៤ (ដោយបញ្ជាក់ថា បន្ទាប់ពីរៀបការរួច ឈ្លបបានឃ្លាំមើលឲ្យដឹងថាតើគាត់ និងប្តីគាត់បានធ្វើពិធីប្រពៃណីដែរឬទេ និងឲ្យដឹងថាតើ ពួកគាត់រួមដំណេកដែរឬទេ)។

[3832] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៥។

[3833] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ១៤ ("ស៖ តើលោកស្រីអាចជួយរកនឹកមើលថាតើក្រោយការរៀបអាពាហ៍ពិពាហ៍របស់លោកស្រីហ្នឹង គេមានតម្រូវឲ្យលោកស្រីហ្នឹងទៅផ្សំដំណេកទេ ហើយពេលដែលទៅផ្សំដំណេកហ្នឹង មានការតាមដានពីឈ្លបដែរឬក៏អត់? ឆ៖ បញ្ហាហ្នឹងគឺមានចំពោះអ្នកដែលត្រូវគ្នាអីចឹងទៅ គេមិនមានការតាមដានទេ។ ចំពោះអ្នកដែលមិនពេញចិត្តនឹងគ្នា មិនចុះសម្រុងគ្នា គឺគេតាមដាន ស៊ើបអង្កេត")។

[3834] ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ២៥-២៦ (ដោយបញ្ជាក់ថា នៅយប់ផ្សំដំណេកដំបូង ឈ្លបលបស្តាប់នៅក្រោមផ្ទះគាត់)។

អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានតម្រូវឱ្យយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ជាក់ស្ដែងត្រូវបានរួមដំណេក។ បញ្ហាគឺថាតើ ប្ដីប្រពន្ធមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យរួមដំណេកភ្លាមៗនូវការរៀបអាពាហ៍ពិពាហ៍ ឬភ័យខ្លាចពេកមិនអាចធ្វើដូច្នោះបាននៅយប់ដែលពួកគេត្រូវបានតាមដាននោះ ដែរ ឬយ៉ាងណា[3835] ពុំបានប៉ះពាល់ដល់ការយល់ឃើញជារួមដែលថា ការតាមដាននៃការរួមដំណេកបានកើតឡើងនោះ។ ការជំទាស់របស់ ខៀវ សំផន ទៅលើចំណុចនេះត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលពុំអាចរកឃើញនូវភាពជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងដែលថា ការតាមដានខ្លះត្រូវបានធ្វើឡើងដោយក្មេងៗ ប៉ុន្តែដោយផ្អែកលើការរៀបរាប់ជាច្រើនដូចគ្នាបានបញ្ជាក់ច្បាស់លាស់ផងដែរថា ក្មេងៗទាំងនេះត្រូវបានបង្គាប់ដោយកម្មាភិបាលជាន់ខ្ពស់ឱ្យធ្វើការតាមដាន[3836]។

1360.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរលើការជំទាស់របស់ ខៀវ សំផន ទៅនឹងភស្តុតាងស្ដីពីអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីបីនាក់បានស្ដាប់ឮ។ អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបលើភស្តុតាងរបស់ ជា ឌៀប ក្នុងជើងទំព័រមួយនៃការយល់ឃើញរបស់ខ្លួនដែលថា ការតាមដានបានកើតឡើង និងបានបញ្ជាក់ថា "ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ លោកស្រីត្រូវបានប្រាប់ឱ្យប្រយ័ត្នខ្លួនពីព្រោះគេនឹងតាមដានលោកស្រីនៅពេលយប់។ នៅយប់ដំបូងជាមួយគ្នា លោកស្រីបានឮស្នូរជើងដើរក្រៅទ្វារ"[3837]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ ជុំ សាមឿន ដែលថា កងឈ្លបបាន"លបស្ដាប់"ប្ដីប្រពន្ធដែលបាន

---

[3835] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៦ ជើងទំព័រ ២៥៥១ យោងទៅលើប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ (ង៉ែត ចាត) ឯកសារលេខ E1/489.1 ទំព័រ ៤។ ប្រតិចារឹកថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ (ចៅ ឡាង) ឯកសារលេខ E1/339.1 ទំព័រ ៥៥។

[3836] *ធៀបនឹង* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៦ និងជើងទំព័រ ២៥៥២ (យោងទៅលើសក្ខីកម្មរបស់ ស៊ូ សុធាវី, ប៉ែន សុចាន់ និង មុំ វុន និង ង៉ែត ចាត) ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 នៅម៉ោង ១៣.៤៦.៥៣ (ផ្ដល់សក្ខីកម្ម"ពិត" ក្នុងការឆ្លើយទៅនឹងសំណួរពាក់ព័ន្ធទៅនឹងបញ្ហាថាតើ លោកស្រីបានឮអំពីបទបញ្ជាឱ្យឈ្លបតាមដានថាតើប្ដីប្រពន្ធក្នុងភូមិគាត់បានរួមភេទដែរ ឬទេ)។ ប្រតិចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ (ប៉ែន សុចាន់) ឯកសារលេខ E1/482.1 នៅម៉ោង ១៥.៤៤.៤១ (ផ្ដល់សក្ខីកម្មថា "ឈ្លបមកប្រាប់សមមិត្ត អំ ឱ្យគេចាប់ខ្ញុំទៅអប់រំ" ដោយសារមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍)។ ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 នៅម៉ោង ១៤.៣៨.០៤ (ផ្ដល់សក្ខីកម្មថា ឈ្លប"បានអនុវត្ត [...] សេចក្ដីណែនាំ"ឱ្យតាមដានប្ដីប្រពន្ធថ្មី)។

[3837] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២១៧៦ យោងទៅលើប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៥៧-៥៩ (ដោយពន្យល់ថា បន្ទាប់ពីរៀបការរួច គេប្រាប់គាត់ឲ្យប្រយ័ត្នខ្លួន ពីព្រោះគេឃ្លាំមើលពួកគាត់នៅពេលយប់។ នៅយប់ដំបូង គាត់ឮសម្រឹបរឹបជើងនៅក្រៅបន្ទប់)។

រៀបអាពាហ៍ពិពាហ៍ដើម្បីឱ្យដឹងថា ពួកគេបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍[3838]។ ខៀវ សំផន ខកខានក្នុងការពន្យល់មូលហេតុដូចម្ដេចបានជាអង្គជំនុំជម្រះសាលាដំបូងពុំគប្បីឱ្យសំអាងទៅលើភស្តុតាងនេះ ដែលជាផ្នែកនៃសក្ខីកម្មទាំងមូលដែលបង្ហាញថា ការតាមដានបានកើតឡើង ដែលភាគច្រើនផ្អែកតាមព្រឹត្តិការណ៍ដែលបានកើតឡើងពេលយប់ និងនៅក្រៅបន្ទប់ដែលប្ដីប្រពន្ធស្ថិតនៅនោះ និងត្រូវបានផ្អែកផងដែរទៅលើអ្វីដែលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីអាចស្ដាប់ឮជាជាងបានឃើញ។ ភស្តុតាងស្ដីពីអ្វីដែលបុគ្គលបានស្ដាប់ឮមានយុត្តិសាស្ត្របង្ហាញត្រឹមត្រូវថា ជាទម្រង់មួយនៃភស្តុតាងដោយផ្ទាល់ស្ដីពីការកំណត់អត្តសញ្ញាណនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[3839]។ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

1361. ទាក់ទងទៅនឹង ណុប ង៉ឹម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា លោកស្រី "ជឿជាក់ថា លោកស្រី និងប្ដីត្រូវបានតាមដានដោយឈ្លប"[3840]។ ក្នុងការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើផ្នែកនៃភស្តុតាងរបស់ ណុប ង៉ឹម ដែលក្នុងនោះ លោកស្រីបានពន្យល់ច្បាស់លាស់អំពីការសន្និដ្ឋានរបស់លោកស្រីដែលថា លោកស្រីត្រូវបានគេតាមដាន[3841] រួមបញ្ចូលទាំងការអះអាងដែលថា លោកស្រីបានឃើញឈ្លបដោយផ្ទាល់[3842]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋាននេះ។

1362. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាច្បាស់លាស់លើភស្តុតាងដែលបានផ្ដល់ដោយប្ដីរបស់ ណុប ង៉ឹម ឈ្មោះ ព្រាប កប។ ក្នុងកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ គាត់ត្រូវបានសួរថាតើ ខ្មែរក្រហមបានចាត់មនុស្សឱ្យលបស្ដាប់ប្ដីប្រពន្ធដែលទើបរៀបអាពាហ៍ពិពាហ៍ថ្មី ដែរ ឬទេ[3843]។ ជាការឆ្លើយតប គាត់បានអះអាងថា "ពុំមានករណីបែបនេះកើតឡើងចំពោះ

---

[3838] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២១៧៦ យោងទៅលើប្រតិចារឹកថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 ទំព័រ ៥១-៥៣ (ដោយពន្យល់ថា ឈ្លបលបស្ដាប់គូស្វាមីភរិយាដើម្បីឱ្យដឹងថាពួកគាត់រួមដំណេកឬអត់)។

[3839] *សូមមើល ឧ.* សាលដីការឿងក្ដី *Lukić និង Lukić* (ICTY) កថាខណ្ឌ ៣០២-៣០៥ បានសំអាងទៅលើភស្តុតាងរបស់សាក្សីម្នាក់ដែលថា គាត់បានឮចារីណែនាំខ្លួនឯង។

[3840] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១។

[3841] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១ ជើងទំព័រ ១២១៧៨ យោងទៅលើប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២ ០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៣៧-៣៨, ៤៤-៤៥, ៥៦-៥៧, ៥៨-៥៩, ៧៩-៨០។

[3842] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៥៦ ("ខ្ញុំដឹងថា គេមកតាមដានខ្ញុំពីព្រោះយើងឃើញគេពេលយប់")។

[3843] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារលេខ E3/9818 សរ ៥២។

ប្រពន្ធខ្ញុំ និងរូបខ្ញុំទេ។ ខ្ញុំក៏ពុំដែលឮរឿងបែបនេះដែរ"[3844]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការប្រសើរសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការពន្យល់ជាក់លាក់លើភាពផ្ទុយគ្នាជាអត្ថិភាពនេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពុំបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគី ជាទូទៅត្រូវបានផ្តល់តម្លៃជាភស្តុតាងទាបជាងភស្តុតាងរបស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ[3845]។ ណុប ងឹម ដោយផ្ទុយទៅនឹងចម្លើយប្តីរបស់ខ្លួន បានផ្តល់សក្ខីកម្មពេលជំនុំជម្រះយ៉ាងច្បាស់ទូលំទូលាយ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា ណុប ងឹម ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយប្តីរបស់គាត់ដែលជាយុទ្ធជនពិការភ្នែក នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយដែលមានស្ត្រី ៤០ នាក់[3846]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា គួរឱ្យជឿជាក់បានដែលថា ណុប ងឹម និងប្តីរបស់លោកស្រីមានការចងចាំផ្សេងគ្នានូវអ្វីកើតឡើងភ្លាមៗក្រោយការរៀបអាពាហ៍ពិពាហ៍។ យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការពិចារណាជាក់លាក់ទៅលើភាពពុំស៊ីសង្វាក់គ្នាក្នុងភស្តុតាងនេះ។

1363. ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការតាមដាននៃការរួមដំណេកដោយបង្ខំបានកើតឡើងជាផ្នែកនៃគោលនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទាក់ទងទៅនឹងចំណុចដែលភស្តុ

[3844] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារលេខ E3/9818 សៈ ៥២។

[3845] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[3846] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២០១៥ យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារលេខ E3/9818 ERN 01037140-01037145 ទំព័រ ៤-១១ (ព្រាប កប ជាទាហានពិការ (ដែលពិការភ្នែក) និងជាប្តីរបស់ ណុប ងឹម បានលើកឡើងថា តាម៉ុក យកទាហានពិការ ១០០នាក់ពីអង្គភាពជនពិការដែលស្ថិតនៅតាខ្មៅ ទៅភូមិភាគពាយ័ព្យ។ នៅពេលពួកគេទៅដល់បាត់ដំបង គាត់ស្ថិតក្នុងចំណោមទាហានពិការ៤០នាក់ដែល តាម៉ុក បានជ្រើសរើសឲ្យរៀបការនៅ សំឡូត។ គាត់ក៏បានបញ្ជាក់ផងដែរថា នៅទីបញ្ចប់មានទាហានពិការត្រឹម ៣៨ នាក់ប៉ុណ្ណោះបានរៀបការ ដោយសារនារីពីរនាក់បានគេចខ្លួន)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 ទំព័រ ២៩-៣២ (លើកឡើងថា គេបានបង្ខំគាត់ឲ្យរៀបការជាមួយកងទ័ពពិការភ្នែក។ គាត់បានពន្យល់ថា៖ "ខ្ញុំយំដែរហ្នឹង ប៉ុន្តែអត់ចិត្តអត់ដឹងខ្លួនសោះ អន់ចិត្តៗមាំណាស់ ព្រោះអីអត់ដែលឃើញ វាដែលឃើញ [...] យើងធ្វើអ៊ីចឹង ខ្លាចគេវ៉ៃចោល។ អ៊ីចឹងចេះតែទ្រាំ")។

តាងដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន បានបង្ហាញថា ឈ្លបខ្លះមានវ័យក្មេង[3847] នេះជាការពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ការតាមដានបានកើតឡើងដោយស្របជាមួយនឹងគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា ដែរ ឬយ៉ាងណានោះទេ។ បន្ថែមលើនេះ ដោយផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយច្បាស់លាស់លើភស្តុតាងរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដែលថា តាមអ្វីដែលគាត់ដឹង"ពុំមានវិធានការដើម្បីរៀបចំការឃ្លាំមើល" និងថា បុគ្គលដែលតាមដានប្ដីប្រពន្ធនោះ គឺជា"កម្មាភិបាលខុសសីលធម៌"ដែលត្រូវបានដាក់ទោសចង្អុលបង្ហាញជាក់លាក់លើសមមិត្ត ប៉ង់[3848]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ភស្តុតាងនេះត្រូវបានពិចារណាធៀបជាមួយនឹងភស្តុតាងសន្ទឹកសន្ធាប់ដទៃទៀតដែលបានបង្ហាញថា "ប្ដីប្រពន្ធថ្មោងថ្មី ត្រូវបានតាមដានដើម្បីឱ្យដឹងថាតើ ពួកគេបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ដែរ ឬទេ"[3849] និងបានបញ្ជាក់ផងដែរថា សមមិត្ត ប៉ង់ ជាក់ស្ដែងពុំត្រូវបានចាប់ខ្លួនពីព្រោះគាត់បានឱ្យអ្នកក្រោមបង្គាប់ខ្លួនតាមដានឱ្យគាត់[3850]។

1364.ផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ភស្តុតាងរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ត្រូវបដិសេធដោយសារវិសាលភាពនៃភស្តុតាងដែលបង្ហាញផ្ទុយនោះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនធ្វើការពិចារណាច្បាស់លាស់លើផ្នែកនៃភស្តុតាងដែលត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំផន ចេញពីសក្ខីកម្មរបស់សាក្សី ធុច សីថន និង

---

[3847] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៦ និងជើងទំព័រ ២៥៥២ យោងទៅលើសក្ខីកម្មរបស់ ស៊ូ សុធារី ង៉ែត ចាត ប៉ែន សុចាន់ និង មុំ វុន។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ភស្តុតាងរបស់ ប៉ែន សុចាន់ ដែលត្រូវបានគូសបង្ហាញដោយ ខៀវ សំផន ដែលថា ឈ្លបបានយកនីតិវិធីនៃការតាមដាននេះជា"ល្បែងលេង" បានគូសបញ្ជាក់បន្ថែមនូវការរំលោភបំពានការអនុវត្តន៍ទៅវិញ *សូមមើល* ខៀវ សំផន ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ (ប៉ែន សុចាន់) ឯកសារលេខ E1/482.1 ទំព័រ ៧០ ដែលថា ឈ្លបបានបញ្ជូនតាមដានពេញមួយយប់ និង"នេះដូចជាល្បែងលេងរបស់ពួកគេ"។

[3848] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២១៧ យោងទៅលើកំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ E3/5789 ERN 00410173-00410174 ទំព័រ ៤-៥។

[3849] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២១៧៧ យោងទៅលើកំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ E3/5789 ERN 00410173-00410174 ទំព័រ ៤-៥។

[3850] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២១៧៧ យោងទៅលើកំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ E3/5789 ERN 00410173-00410174 ទំព័រ ៤-៥។

យ៉ាន លន់ ដែលនៅគ្រប់កាលៈទេសៈ ត្រឹមតែជាការលើកច្រំដែលនូវការយោងទៅលើគោលការណ៍សីលធម៌នៃបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ[3851]។

(ii) អំពើនៃ"ការរំលោភសេពសន្ថវៈ"ដែលជាការដាក់ទោស

1365.ដោយសារផ្នែកនៃការយល់ឃើញស្តីពីកាលៈទេសៈបង្ខំដែលបុគ្គលបានឆ្លងកាត់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ប៉ែន សុចាន់ ដែលបង្ហាញថា លោកស្រីបានប្រកែកការរួមដំណេកការរៀបអាពាហ៍ពិពាហ៍សម្រាប់ពីរយប់ដំបូង និងត្រូវបានវាយដំដោយប្តីលោកស្រី និងបានគំរាមសម្លាប់ដោយប្រធានកងប្រសិនណាលោកស្រីមិនព្រមរួមដំណេកនោះ[3852]។ ក្នុងការយល់ឃើញបន្ថែមទៀតស្តីពីបទពិសោធន៍នៃការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ប៉ែន សុចាន់ ដែលថា ក្រោយការប្រកែកការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ លោកស្រីត្រូវបានរំលោភសេពសន្ថវៈដោយប្តីរបស់ខ្លួនខណៈពេលឈ្លប្រាំនាក់នៅឈរមើល ដែលនេះជាការផ្នែកនៃការវិភាគអំពីព្យសនកម្មដែលបានបង្កលើលោកស្រី។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ អ៊ុំ យឿន ដែលថា លោកស្រីបានជំទាស់ទៅនឹងការប៉ុនប៉ងរបស់ប្តីលោកស្រីក្នុងការប្រើអំពើហិង្សាបង្ខំលោកស្រីឱ្យរួមភេទ ដែលក្រោយមកប្តីលោកស្រីបានប្រាប់មេបញ្ជាការយោធារបស់គាត់ ដែលបន្ទាប់មកមេបញ្ជាការនោះបានចាប់"រំលោភសេពសន្ថវៈ"លោកស្រី[3853]។ លោកស្រីមានអារម្មណ៍ថាត្រូវបាន"រំលោភសេពសន្ថវៈ"ជាការព្រមានសម្រាប់ការប្រកែកមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ ដូច្នេះ លោកស្រីក៏យល់ព្រមរួមភេទជាមួយប្តីលោកស្រីក្រោយមក[3854]។

1366. ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ"ការរំលោភសេពសន្ថវៈ" ដែល ប៉ែន សុចាន់[3855] និង អ៊ុំ យឿន បានឆ្លងកាត់ថា ជាការដាក់ទណ្ឌកម្ម[3856]។ នៅក្នុងសារណារបស់គាត់

---

[3851] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥៤ យោងទៅលើប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ (ធុច ស៊ីថន) ឯកសារលេខ E1/500.1 ទំព័រ ៥៧ (បានឆ្លើយថា បញ្ហានៃការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ពុំត្រូវបានលើកឡើង ដោយសារនៅពេលនោះត្រូវបានចាត់ទុកថា ជាបញ្ហាសីលធម៌)។ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ (យ៉ាន លន់) ឯកសារលេខ E1/317.1 ទំព័រ ៥៨ (ឆ្លើយថា នេះជាការមិនពិតដែលគ្រប់គ្នាមានកាតព្វកិច្ចតាមដានប្តីប្រពន្ធថ្មីក្នុងឃុំនោះឡើយ)។

[3852] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦។

[3853] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦។

[3854] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦។

[3855] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៨។

[3856] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៩ ជើងទំព័រ ២៥៩១។

ខៀវ សំផន បានអះអាងថា ការរំលោភសេពសន្ថវៈលើ ប៉ែន សុចាន់ គឺជា"ករណីធ្ងន់ធ្ងរ" ពីព្រោះនេះត្រូវបានប្រព្រឹត្តឡើងតាមការស្នើរបស់"ឈ្លបក្មេង"ដែលមាន"ទស្សនៈចាស់គំរឹលទៅលើការរៀបអាពាហ៍ពិពាហ៍"[3857]។ គាត់បានអះអាងបន្ថែមថា ការរំលោភសេពសន្ថវៈលើ អ៊ុំ យឿន ពុំមែនជាភាពតំណាងនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងស្ថិតក្រៅវិសាលភាពនៃការបញ្ជូនរឿងទៅជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងពីព្រោះអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នកគ្រប់គ្រងផ្ទាល់លើប្តីរបស់លោកស្រី ដែលនេះជាការដាក់ទណ្ឌកម្មសម្រាប់ការខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់លោកស្រី និងដូច្នេះ ផ្ទុយពីការហាមឃាត់របស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីទំនាក់ទំនងក្រៅការរៀបអាពាហ៍ពិពាហ៍[3858]។

1367.សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការរំលោភសេពសន្ថវៈលើ ប៉ែន សុចាន់ និង អ៊ុំ យឿន គឺជាករណីពិសេស ឬពុំស្របតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[3859]។

1368.សហមេធាវីនាំមុខបានឆ្លើយតបថា "ការគំរាមកំហែងដោយប្រយោលជាប្រចាំអំពីការដាក់ទណ្ឌ កម្មតាមរយៈបរិយាកាសបង្ខិតបង្ខំ" និង"ក្នុងករណីខ្លះការគំរាមកំហែងជាក់លាក់ និងអំពើហិង្សាជាក់ស្តែង"ត្រូវបានប្រើប្រាស់ដើម្បីបង្ខំប្តីប្រពន្ធឱ្យរួមភេទ[3860]។ ជាលទ្ធផល "ការបដិសេធត្រឹមពាក្យសំដីពុំអាចមានប្រសិទ្ធភាព ហើយការរឹងទទឹងណាមួយបង្កឱ្យមានលទ្ធភាពនៃអំពើហិង្សាធ្ងន់ធ្ងរ ឬការស្លាប់"[3861]។ ការដែលថាដើមបណ្តឹងរដ្ឋប្បវេណីខ្លះពុំបានដឹងអំពីមូលហេតុដែលឈ្លបតាមដានប្តីប្រពន្ធនោះ "ពុំបានប៉ះពាល់ដល់ភស្តុតាងដែលគាំទ្រនូវអត្ថិភាពនៃការអនុវត្តស៊ីសង្វាក់គ្នា"[3862]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានសំអាងត្រឹមត្រូវផងដែរលើ"ទិដ្ឋភាពស្វ័យ"នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន "ដែលត្រូវបានគាំទ្របន្ថែមដោយភស្តុតាងដទៃទៀត"[3863]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសន្និដ្ឋានថា "គោលការណ៍សីលធម៌បក្សកុម្មុយនីស្តកម្ពុជាដែលបានប្រកាសនោះ ជានិច្ចកាលពុំត្រូវ

[3857] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៨។

[3858] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៩។

[3859] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៤។

[3860] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៣៨។

[3861] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤១។

[3862] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤២។

[3863] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៥២។

បានអនុវត្តតាមក្នុងករណីជាក់ស្តែង” និងថា ការរំលោភសេពសន្ថវៈលើដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ពុំមែនជាករណីពិសេសឡើយ[3864]។

1369.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការរំលោភសេពសន្ថវៈពុំត្រូវបានចោទប្រកាន់ថា ជាបទឧក្រិដ្ឋឯករាជ្យក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងរឿងក្តីនេះ[3865] និងថា អ្វីដែលសំខាន់សម្រាប់គោលបំណងនៃអំពើដែលត្រូវបានចោទប្រកាន់នោះ គឺថា បានកើតឡើង និងបានបំពេញតាមលក្ខខណ្ឌនៃអំពើអមនុស្សធម៌ដទៃទៀត។ អំពើដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីនេះ គឺជាអំពើនៃការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរួមភេទដោយបង្ខំដែលបុរស និងស្ត្រីត្រូវបានបង្ខំបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពីរបប នោះ។ អំពើដែលត្រូវបានចោទប្រកាន់នេះពុំបានរួមបញ្ចូលការរួមភេទដោយបង្ខំដែលត្រូវបានប្រព្រឹត្តឡើងដោយដោយឈ្លបនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញដោយត្រឹមត្រូវនូវកម្រិតដែលត្រូវបានរឹតត្បិតនៃការចោទប្រកាន់តាមរយៈការដាក់អំពើនៃ“ការរំលោភសេពសន្ថវៈ”ក្នុងវង់ក្រចកនៅពេលពិពណ៌នាបទពិសោធន៍ទាំងពីរនេះ។

1370.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញមួយដែលអាចបង្ហាញនូវភាពខុសប្លែកគ្នារវាងបទពិសោធន៍របស់ ប៉ែន សុចាន់ ដែលទទួលរងក្រោមការប្រព្រឹត្តរបស់ប្តីរបស់ខ្លួន និង អ៊ុំ យឿន ក្រោមការប្រព្រឹត្តរបស់ឈ្លប។ នៅពេលយល់ឃើញថា បុគ្គលបានរៀបអាពាហ៍ពិពាហ៍ក្នុងបរិយាកាសបង្ខិតបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ អ៊ុំ យឿន ព្រមទាំង មុំ វុន ដែលថា ពួកគាត់ត្រូវបាន “រំលោភសេពសន្ថវៈ”ដោយបុគ្គលដែលនៅក្រៅការរៀបអាពាហ៍ពិពាហ៍ដែលជាការដាក់ទណ្ឌកម្ម ដូចក្នុងករណី អ៊ុំ យឿន សម្រាប់ការមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងក្នុងករណី មុំ វុន សម្រាប់ការមិនព្រមរៀបអាពាហ៍ពិពាហ៍សាជាថ្មី[3866]។ ទាក់ទងទៅនឹងភស្តុតាងនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អំពើទាំងនេះ“ស្ថិតក្រៅវិសាលភាពនៃការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍

---

[3864] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៩៨។

[3865] *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៤២៩-១៤៣៣។ *សូមមើលផងដែរ* ឧ. សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៥, ៤៣៣១។

[3866] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥០-៣៦៥១។

ពិពាហ៍ ដោយសារអំពើនេះពុំត្រូវបានប្រព្រឹត្តឡើងដោយប្ដីទៅលើប្រពន្ធខ្លួននោះទេ ប៉ុន្តែដោយកម្មាភិបាល ឬឈ្លប"[3867] ប៉ុន្តែត្រូវបានចាត់ទុកថា ជាផ្នែកនៃ"បរិបទភ័យខ្លាច និងអំពើហិង្សា"[3868]។

1371.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងផ្នែកដំបូង និងខាងក្រោយនៃការយល់ឃើញនេះ ដែលថា អំពើហិង្សាផ្លូវភេទដែលត្រូវបានប្រព្រឹត្តដោយឈ្លប ដូចបានគូសបង្ហាញខាងលើ ពុំត្រូវបានចោទប្រកាន់ក្នុងរឿងក្ដីបច្ចុប្បន្ន។ ទាក់ទងទៅនឹងផ្នែកកណ្ដាល អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការយល់ឃើញរបស់ខ្លួនខាងលើថា អំពើដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្ដីនេះគឺជាការរួមភេទដោយបង្ខំរវាងប្ដីប្រពន្ធរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាប់ពាក់ព័ន្ធជនរងគ្រោះជាបុរស និងស្ត្រី។ ក្នុងន័យនេះ បរិយាកាសបង្ខិតបង្ខំ គឺជាអញ្ញាក្រឹតនៃភេទ[3869]។

1372.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរលើការជំទាស់របស់ ខៀវ សំផន ទៅនឹងការប្រើប្រាស់ភស្តុតាងរបស់ NAKAGAWA Kasumi ពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់ អ៊ុំ យឿន។ គាត់បានអះអាងថា នេះបានបង្ហាញថា បទពិសោធន៍របស់ អ៊ុំ យឿន "ពុំមែនជាតំណាងឱ្យគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា" ដែលហាមឃាត់ទំនាក់ទំនងក្រៅការរៀបអាពាហ៍ពិពាហ៍នោះទេ[3870]។ បើទោះជា NAKAGAWA Kasumi បានផ្ដល់សក្ខីកម្មថា មានគោលនយោបាយហាមឃាត់ការរំលោភសេពសន្ថវៈ និងជា"គោលនយោបាយតឹងរ៉ឹង"[3871]ក៏ដោយ ក៏លោកស្រីបានអះអាងថា "អាជ្ញាធរថ្នាក់លើខកខានក្នុងការអនុវត្តន៍គោលនយោបាយនេះ"[3872]។ អាស្រ័យហេតុនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបទពិសោធន៍របស់ អ៊ុំ យឿន ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងរបស់ NAKAGAWA Kasumi ជាការសមហេតុផល។

---

[3867] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៨។

[3868] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៨។

[3869] *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២១៨៥ យោងទៅលើប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/473.1 ទំព័រ ៣-៤ ("ផលពិបាកហ្នឹងគឺថាអាចនឹងទទួលរង ប្រពន្ធហ្នឹងអាចទទួលរងនូវការដាក់ទណ្ឌកម្មតាមរូបភាព ដូចជាឃុំខ្លួននៅមន្ទីរអប់រំកែប្រែឬក៏ថាយកទៅឲ្យរៀនសូត្រ ឬក៏អប់រំតាមរូបភាពណាមួយ ឬក៏ថាអាចទទួលរងទារុណកម្មដោយសារតែអំពើហិង្សាផ្លូវភេទប្រឆាំងទៅនឹងប្រពន្ធរបស់ខ្លួន ឬក៏ទាំងប្ដីទាំងប្រពន្ធ ឬក៏ថាអាចទទួលរងទណ្ឌកម្មរហូតដល់ស្លាប់ក៏ថាបាន។")។

[3870] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៦៩។

[3871] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារលេខ E1/473.1 ទំព័រ ៥២។

[3872] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារលេខ E1/473.1 ទំព័រ ៥២។

(iii) កង្វះការបង្ហាញច្បាស់លាស់អំពីកាលៈទេសៈបង្ខិតបង្ខំ

1373.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាថា ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀតពុំបានផ្ដល់ចម្លើយច្បាស់លាស់ដែលបង្ហាញថា ការរួមដំណេកត្រូវបានបង្ខំ[3873]។ យោងតាមគាត់បានឱ្យដឹងថា សាក្សីជំនាញ Peg LEVINE បានអះអាងផងដែរថា ពុំមានការបង្ខិតបង្ខំឡើយ[3874]។

1374.សហព្រះរាជអាជ្ញាបានអះអាងថា Peg LEVINE "បានផ្ដល់សក្ខីកម្មផងដែរថា មនុស្ស ៧៦ ក្នុងចំណោម ១៩២ នាក់ក្នុងការស្ទង់មតិរបស់លោកស្រីបានឆ្លើយថា ការរួមភេទត្រូវបានបង្គាប់ និង ១៩ នាក់បានឆ្លើយថា គោរពតាមការបង្គាប់នោះ"[3875]។

1375.បុគ្គលបួននាក់ដែលត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំផន ត្រូវបានពិចារណាយ៉ាងច្បាស់លាស់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការវិភាគរបស់ខ្លួនអំពីកាលៈទេសៈបង្ខិតបង្ខំ ដូចជា៖ ណុប ធឹម, ផាន់ ហ៊ីម, សេង សឿន និង ព្រាប សុខឿន[3876]។ ខៀវ សំផន ខកខានក្នុងការបង្ហាញជាក់លាក់នូវការជំទាស់ណាមួយទៅនឹងភស្តុតាងរបស់ សេង សឿន ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា ផ្ទុយពីការអះអាងរបស់ ខៀវ សំផន មានបុគ្គលពីរនាក់ក្នុងចំណោមនោះបានអះអាងច្បាស់លាស់ថា ការរួមដំណេកបានកើតឡើងក្នុងបរិយាកាសបង្ខិតបង្ខំ នៅក្នុងភស្តុតាងដែលបានយោងទៅលើដោយអង្គជំនុំជម្រះសាលាដំបូង។ ណុប ធឹម ដែលជាសមាជិកគណៈកម្មការស្រុកសំឡូតជឿជាក់ថា លោកស្រី និងប្ដីត្រូវបានតាមដានដោយឈ្លបដើម្បីឱ្យដឹងថា ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍បានកើតឡើង និងបានអះអាងផងដែរថា លោកស្រីមានការភ័យខ្លាចដល់អាយុជីវិតលោកស្រី នៅពេលដែលលោកស្រីយល់ព្រមរៀបអាពាហ៍ពិពាហ៍[3877]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ ព្រាប សុខឿន ដែលថា លោកស្រីត្រូវបានសួរដោយឈ្លបថា តើលោកស្រីចេញទៅណានៅយប់នៃពិធី

---

[3873] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧២, ១៣៧៥។

[3874] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៣ យោងទៅលើប្រតិចារឹកថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ (Peg LEVINE) ឯកសារលេខ E1/480.1 នៅម៉ោង ១៥.៥១.២៤។

[3875] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៩។

[3876] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១, ៣៦៤៨-៣៦៤៩, ៣៦៥៥, ៣៦៥៧។

[3877] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១ យោងទៅលើប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ធឹម) ឯកសារលេខ E1/469.1 ទំព័រ ៣៧-៣៨, ៤៤-៤៥, ៥៦-៥៧, ៥៨-៥៩, ៧៩-៨០។

រៀបអាពាហ៍ពិពាហ៍នៅពេលដែលលោកស្រីចាកចេញពីកន្លែងដែលពួកគេនាំទៅនោះ[3878] ដែលនេះបង្ហាញថា លោកស្រីកំពុងត្រូវបានតាមដានដោយកងឈ្លបប្រដាប់អាវុធ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងបន្ថែមទៀតដែលថា កម្មាភិបាលបានគំរាមកំហែងគាត់សម្លាប់ប្រសិនណាបើលោកស្រីមិនព្រមរួមភេទនោះ [3879]។ ការដែលថា ប្ដីលោកស្រីត្រូវបានបង្ខំឱ្យរួមភេទជាមួយលោកស្រី និងបានអះអាងនូវការភ័យខ្លាចពីអាយុជីវិត គឺជាបរិយាកាសបង្ខិតបង្ខំមួយបន្ថែមទៀត[3880] ប៉ុន្តែពុំបានប៉ះពាល់ដល់ការពិតដែលថា បរិយាកាសនោះត្រូវបានបង្ហាញច្បាស់លាស់រួចហើយ។ នៅគ្រប់កាលៈទេសៈ ភស្តុតាងរបស់ ព្រាប សុខឿន បង្ហាញថា ប្ដីរបស់លោកស្រី"បានធ្វើដូច្នោះទៅតាមបទបញ្ជារបស់អង្គការ ដើម្បីកុំឱ្យគេសម្លាប់គាត់"[3881] និងបានបង្ហាញនូវបរិយាកាសនៃការបង្ខិតបង្ខំបន្ថែមទៀត។ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបុគ្គលទាំងនេះត្រូវបដិសេធចោល។

1376.ទាក់ទងទៅនឹងភស្តុតាង ផាន់ ហ៊ីម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លោកស្រីបានអះអាងថា បន្ទាប់ពីលោកស្រីត្រូវបានគំរាមកំហែងសម្លាប់ដោយអង្គការ លោកស្រីបានចាប់ផ្ដើមមានអារម្មណ៍អាណិតប្ដី និងចុងក្រោយបន្ទាប់ពីអស់រយៈពេលមួយខែកន្លះមក លោកស្រីលែងជំទាស់ទៅនឹងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ[3882]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានដកលោកស្រីចេញពីការយល់ឃើញដែលថា ការរួមភេទដោយបង្ខំបានកើតឡើង។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ស្ត្រីដែលអង្គជំនុំជម្រះបានពិចារណានោះ"លើកលែងតែ ផាន់ ហ៊ីម ត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ពីព្រោះពួកគេមានការភ័យខ្លាចអាយុជីវិតរបស់ខ្លួន ឬសុវត្ថិភាពរូបកាយ និងអាស្រ័យហេតុនេះ ពុំបាន

---

[3878] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤១ យោងទៅប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/488.1 ទំព័រ ៦-៧។

[3879] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៣។

[3880] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៣ យោងទៅលើប្រតិចារឹកថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/487.1 ទំព័រ ៦០-៦៣,ទំព័រ ៦៥-៦៦។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រាប សុខឿន ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E3/9820 ERN 01029962-01029964 ទំព័រ ១២-១៤។ ប្រតិចារឹកថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/487.1 ទំព័រ ៧១-៧៣។

[3881] ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (ព្រាប សុឃឿន) ឯកសារលេខ E1/488.1 ទំព័រ ៥៨-៥៩។

[3882] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៥ យោងទៅលើប្រតិចារឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ីម) ឯកសារលេខ E1/467.1 ទំព័រ ៨៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២០៩២។

យល់ព្រមដោយពិតប្រាកដនោះទេ ឬដោយសារពួកគេត្រូវបានបង្ខំផ្នែករូបកាយឱ្យទទួលយកការរួមភេទជាមួយប្តីរបស់ខ្លួន”[3883]។

1377.អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា សារណាជាក់លាក់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើភស្តុតាងរបស់ ផាន់ ហ៊ីម ស្តីពីការបង្ខំ ត្រូវបដិសេធចោល។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផាន់ ហ៊ីម បានយល់ព្រមទៅនឹងការរួមភេទជាមួយប្តី និងដូច្នេះពុំបានសំអាងទៅលើភស្តុតាងរបស់គាត់ដើម្បីបង្ហាញពីបរិយាកាសបង្ខិតបង្ខំឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា តាំងពីដំបូង បញ្ហានៃការយល់ព្រមនេះពុំត្រូវបានពិចារណាពាក់ព័ន្ធទៅនឹងកាលៈទេសៈបង្ខិតបង្ខំដែលត្រូវបានបង្ហាញ។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពុំធ្វើការរំខានណាមួយដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គហេតុក្នុងករណីនេះក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាឃើញថា ជាការប្រសើរសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាឱ្យបានពេញលេញថែមទៀតលើបញ្ហានៃលទ្ធភាពរបស់ ផាន់ ហ៊ីម ក្នុងការយល់ព្រមនោះ។

1378.ខៀវ សំផន បានចង្អុលបង្ហាញទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម និងសាក្សីជំនាញ Peg LEVINE ដែលតាមការអះអាងរបស់គាត់ថា អង្គជំនុំជម្រះពុំបានអើពើ។ បើទោះបីជា Peg LEVINE បានអះអាងថា ពុំមានបុគ្គលណាម្នាក់ក្នុងគំរូស្ថិតិស្រាវជ្រាវជាលក្ខណៈបុគ្គលរបស់លោកស្រី ត្រូវបានគំរាមកំហែងសម្លាប់ក៏ដោយ[3884] ក៏លោកស្រីបានផ្តល់ភស្តុតាងថា មានបុគ្គល ៧៦ ក្នុងចំណោម ១៩២ ក្នុងការស្ទង់មតិនោះ បានរាយការណ៍ថា ការរួមភេទត្រូវបាន“បង្គាប់បញ្ជា”ដែរ[3885]។ ភស្តុតាងនេះបានគាំទ្រច្បាស់លាស់នូវការសន្និដ្ឋានដែលថា បរិយាកាសបង្ខិតបង្ខំមានអត្ថិភាព។ ពុំមានលក្ខខណ្ឌតម្រូវថា ការបង្ខិតបង្ខំត្រូវតែបង្ហាញតាមរយៈការគំរាមកំហែងសម្លាប់ច្បាស់លាស់ឡើយ។ ទាក់ទងទៅនឹង ស្រី សឿម នៅក្នុងភស្តុតាងដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន លោកស្រីបានអះអាងថា ក្រោយមកលោកស្រី“បានទទួល”យកទំនាក់ទំនងផ្លូវភេទជាមួយប្តី ដោយសារពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ទោះជាយ៉ាងណាក្តី លោកស្រីបានពន្យល់ផងដែរអំពីទុក្ខព្រួយដោយសារការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងបានពន្យល់ថា លោកស្រីមិនចង់ដេកជាមួយប្តីលោកស្រីទេពីដំបូង និងមានអារម្មណ៍តានតឹង

---

[3883] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៩។

[3884] ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ (Peg LEVINE) ឯកសារលេខ E1/480.1 នៅមុនម៉ោង ១៥.៥១.២៥។

[3885] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៤។

ខ្លាំង[3886]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងនេះពុំបានគាំទ្រការសន្និដ្ឋានដែលថា លោកស្រីបានយល់ព្រមទៅនឹងការរួមភេទ ពីព្រោះសេរីភាពរបស់លោកស្រីក្នុងការយល់ព្រមត្រូវបានរារាំងដោយកាលៈទេសៈដែលលោកស្រីកំពុងស្ថិតនៅនោះ។ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងសាក្សីទាំងនេះត្រូវបដិសេធចោល។

ឃ) ការលាក់បាំងការមិនរួមដំណេក

1379.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ដោយពិចារណាលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន និង យស ផល ថា អ្នកដែលពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ត្រូវតែលាក់បាំងការពិត និងធ្វើពុតថា ពួកគេស្រលាញ់គ្នាទៅវិញទៅមកដើម្បីជៀសផលវិបាកអវិជ្ជមាន[3887]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរដោយបានពិចារណាលើភស្តុតាងរបស់ យូ វ៉ាន់, ប្រាក់ យុត និង សុន វុត ថា ជាទូទៅ នៅពេលអាជ្ញាធរបានរកឃើញថា ប្តីប្រពន្ធពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន នឹងមានវិធានការតាមដានដែលក្នុងនោះអាជ្ញាធរកោះហៅបុគ្គលនោះ និងធ្វើការសួរនាំពួកគេ[3888]។ ប្តីប្រពន្ធត្រូវបានកោះហៅដោយអ្នកគ្រប់គ្រងផ្ទាល់ និងត្រូវបានគំរាមកំហែងជាមួយផលវិបាកប្រសិនបើពួកគេមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ[3889]។

1380.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងមានកម្រិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងខកខានក្នុងការពិចារណាលើការពិតដែលថា បុគ្គលបានលាក់លៀមរឿងផ្ទាល់ខ្លួននោះ មិនមែនដោយសារគេភ័យខ្លាចទេ ប៉ុន្តែដោយសារការមិនចង់ប្រាប់ឱ្យគេដឹងដែលនេះជាផ្នែកសំខាន់នៃវប្បធម៌ប្រពៃណីខ្មែរ[3890]។ ខៀវ សំផន បានអះអាងផងដែរថា យូ វ៉ាន, ប្រាក់ យុត និង សុន វុត ដែលភស្តុតាងរបស់ខ្លួនត្រូវបានសំអាងទៅលើក្នុងការបង្ហាញថា វិធានការត្រូវបានធ្វើឡើងចំពោះប្តីប្រពន្ធថ្មីថ្មោងដែលពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ជាក់ស្តែងបានផ្តល់ភស្តុតាងថា ពុំមានវិធានការ

---

[3886] កំណត់ហេតុស្តាប់ចម្លើយរបស់ ស្រី សឿម ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E3/9826 ERN 01047401-01047402។

[3887] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[3888] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៦។

[3889] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៧។

[3890] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

បែបនេះត្រូវបានធ្វើឡើង[3891]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការខកខានក្នុងការពិចារណាលើសក្ខីកម្មដទៃទៀតដែលបង្ហាញថា ថ្នាក់លើបានធ្វើជាអ្នកប្រឹក្សាដល់ប្ដីប្រពន្ធថ្មីនេះ ជាជាងអ្នកដាក់ទណ្ឌកម្ម[3892]។

1381.សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានភស្តុតាងជាច្រើនគាំទ្រការយល់ឃើញដែលថា ការអប់រំកែប្រែឡើងវិញត្រូវបានប្រើប្រាស់ជាការគំរាមកំហែងសម្រាប់ការខកខានក្នុងការអនុវត្តតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួមទាំងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍[3893]។ សហព្រះរាជអាជ្ញាបានអះអាងថា សក្ខីកម្មជាច្រើនដែលត្រូវបានយោងដោយ ខៀវ សំផន ជាក់ស្ដែងបានបង្ហាញថា បុគ្គលត្រូវបានធ្វើការអប់រំកែប្រែឡើងវិញសម្រាប់ការមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន[3894]។ ជាឧទាហរណ៍ សហព្រះរាជអាជ្ញាបានគូសបង្ហាញសក្ខីកម្មរបស់ ប្រាក់ យុត ដែលថា ប្ដីប្រពន្ធដែលពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍"នឹងត្រូវនាំទៅស្រុកដើម្បីអប់រំ"[3895]។

1382.សហមេធាវីនាំមុខបានយោងទៅលើភស្តុតាងនានាជាច្រើន ដែលគាំទ្រការយល់ឃើញដែលថា ប្ដីប្រពន្ធត្រូវបានគំរាមកំហែងជាមួយនឹងផលវិបាកហិង្សា ប្រសិនបើពួកគេមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍[3896]។

1383.ទាក់ទងទៅនឹងការជំទាស់ដំបូងរបស់ ខៀវ សំផន ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីភស្តុតាងរបស់ ជុំ សាមឿន និង យស ផល អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាង ជុំ សាមឿន ដែលបង្ហាញថា "លោកស្រីពុំបានដឹងនូវអ្វីបានកើតឡើងប្រសិនបើត្រូវបានរកឃើញថា លោកស្រី និងប្ដីពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន"[3897]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ យស ផល ដែលបង្ហាញថា គាត់បានយល់ស្របជាមួយនឹងប្រពន្ធ"លាក់បាំងទំនាក់ទំនង

[3891] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

[3892] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៦។

[3893] *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៣, ៧៥០។

[3894] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥០ និង ជើងទំព័រ ២៥៧៣។

[3895] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤៣ (ដកស្រង់ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 នៅម៉ោង ១៣.៤៧.៣០-១៣.៤៩.៣៦)។

[3896] *ខ.* សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨២៩-៨៣០ (ពិពណ៌នាអំពីសក្ខីកម្មរបស់ ស៊ូ សុធារី ដែលថា លោកស្រីគេចវេសការរួមដំណេកជាច្រើនសប្ដាហ៍ និងចុងក្រោយត្រូវបានកោះហៅដោយមេភូមិ និងគំរាមកំហែង)។

[3897] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

របស់ពួកគេ”[3898]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើ“តែចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ប៉ុណ្ណោះ”[3899] និងពុំបានពិចារណាថា ពួកគេមានអារម្មណ៍ថា ពួកគេត្រូវលាក់បាំងការរួមដំណេកដោយសារតែមិនចង់លាតត្រដាងឱ្យគេដឹងដែលនេះជាប្រពៃណីខ្មែរ[3900]។

1384. ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា បុគ្គលទាំងនេះបានផ្តល់តែចម្លើយក្រៅតុលាការប៉ុណ្ណោះ ហើយអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ“តែចម្លើយដើមបណ្តឹងរដ្ឋប្បវេណីពីរនេះប៉ុណ្ណោះ”[3901]។ សារណានេះត្រូវបដិសេធចោល៖ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ភស្តុតាងក្នុងតុលាការ ដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូង[3902]។ ទាក់ទងទៅនឹងការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីពិចារណាលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានយុត្តិសាស្ត្របង្កើតឡើងត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់អំពីពិរុទ្ធភាព[3903]។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានមូលដ្ឋានគាំទ្រនៃសារណារបស់ ខៀវ សំផន ដែលថា បុគ្គលទាំងនោះបានធ្វើការលាក់បាំងអារម្មណ៍ដោយសារបរិបទនៃការស្រលាញ់គ្នាក្នុងសង្គមខ្មែរ ជាជាងការភ័យខ្លាចផលវិបាកនោះ។ អំណះអំណាងនេះគឺជាសម្មតិកម្មដែលពុំមានភស្តុតាងណាមួយគាំទ្រ ចំណែកឯការយល់ឃើញដែលថា បុគ្គលនោះភ័យខ្លាចនូវផលវិបាកនៃការមិនរួមដំណេក បានផ្អែកលើភស្តុតាងទូលំទូលាយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[3904]។

---

[3898] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[3899] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

[3900] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

[3901] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

[3902] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧ យោងទៅលើប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 ទំព័រ ៥១។ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ២៧-២៨។

[3903] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១៣ (យោងទៅលើវិធាន ៥៩ និង ៨៧(១) នៃវិធានផ្ទៃក្នុង) ។

[3904] *សូមមើល* សម្រាប់ ឧ. សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦។

1385.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់ទៅនឹងការយល់ឃើញដែលថា បើកាលណាអាជ្ញាធរបានរកឃើញថា ប្ដីប្រពន្ធពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ មានវិធានការតាមដានដែលក្នុងនោះអាជ្ញាធរបានកោះហៅបុគ្គលនោះ និងធ្វើការសួរនាំពួកគេ[3905]។ ក្នុងការបង្កើតការយល់ឃើញ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ យូ វ៉ាន់ ដែលបង្ហាញថា ប្រសិនបើកាលណាប្ដីប្រពន្ធពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ប្រធានភូមិនឹងជួបជាមួយពួកគេដើម្បី "អប់រំពួកគេឡើងវិញ" ក្រោយមកពួកគេជាទូទៅបានយល់ព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ[3906]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរថា ប្រាក់ យុត បានអះអាងថា ការប្រកែកមិនព្រមរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍នឹងត្រូវបញ្ជូនទៅស្រុកដើម្បីធ្វើការអប់រំកែប្រែឡើងវិញ[3907] និងភស្តុតាងរបស់ សុន វុត ដែលបង្ហាញថា ប្រសិនបើស្ត្រីពុំបានស្រលាញ់ប្ដីរបស់ខ្លួនទេ ស្ត្រីនោះត្រូវបានធ្វើការអប់រំកែប្រែឡើងវិញ[3908]។ ខៀវ សំផន បានអះអាងថា សាក្សីទាំងនេះបានផ្តល់ភស្តុតាងថា ពុំមានវិធានការត្រូវបានធ្វើឡើង[3909] និងបានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានពិចារណាលើសក្ខីកម្មដទៃទៀតដែលបានបង្ហាញថា ថ្នាក់លើបានធ្វើជាអ្នកប្រឹក្សាដល់ប្ដីប្រពន្ធថ្មីថ្មោង ជាជាងអ្នកដាក់ទណ្ឌកម្ម[3910]។

1386.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើភស្តុតាង និងជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាភស្តុតាងនេះត្រឹមត្រូវ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សុន វុត បញ្ជាក់អំពីការដាក់

[3905] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៦។

[3906] ប្រតិចារឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៥៨, ៦១ (សុន វុត បានពិពណ៌នាស្ថានការណ៍ដែលប្ដីប្រពន្ធបែកគ្នា និងទទួលការដាក់ទណ្ឌកម្ម (ទំព័រ ៩) និងបានពិភាក្សាការអប់រំកែប្រែឡើងវិញថា ជាការឆ្លើយតបទៅនឹងប្ដីប្រពន្ធដទៃទៀតដែលគាត់ជឿថា ត្រូវបានបំបែក (ទំព័រ ១១)។ យូ វ៉ាន់ បានពិភាក្សាជាក់លាក់លើភស្តុតាងនៃគោលនយោបាយស្ដីពីការមិនរួមដំណេកក្នុងផ្នែកដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន និងបានផ្ដល់សក្ខីកម្មថា បុគ្គលដែលខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ត្រូវបានទទួលការអប់រំ)។

[3907] ប្រតិចារឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៣៩-៤០។

[3908] ប្រតិចារឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ (សុន វុត) ឯកសារលេខ E1/412.1 ទំព័រ ៤-៥។ ប្រតិចារឹកថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៦០។ ប្រតិចារឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៤១។ ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ (ប្រាក់ ខឿន) ឯកសារលេខ E1/361.1 ទំព័រ ៨១។

[3909] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៥។

[3910] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៧៦។

ទណ្ឌកម្មដោយការបំបែកគ្នា ព្រមទាំងការអប់រំកែប្រែឡើងវិញ ដូចគ្នានឹង យូ វ៉ាន់ ដែរ[3911]។ ដូចបានគូស បង្ហាញខាងលើ ប្រាក់ យុត បានអះអាងថា នៅពេលប្តីប្រពន្ធពុំបានរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍ របស់ពួកគេ លោកស្រី"ពុំមានវិធានការណាមួយបង្ខំពួកគេទេ" ប៉ុន្តែបានអះអាងផងដែរថា ប្តីប្រពន្ធនឹងត្រូវ នាំទៅស្រុកដើម្បីអប់រំដែលជាទម្រង់នៃការដាក់ទណ្ឌកម្មដោយផ្ទាល់[3912]។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាផងដែរលើសក្ខីកម្មដែលបានយោងទៅលើដោយ ខៀវ សំផន ដែលគាត់អះអាងថា បានគាំទ្រដល់ ការបង្ហាញអំពីតួនាទីប្រឹក្សា ប៉ុន្តែសង្កេតឃើញថា សក្ខីកម្មទាំងនេះជាទូទៅចង្អុលបង្ហាញទៅលើគោល នយោបាយនៃ"ការអប់រំកែប្រែឡើងវិញ"ដែលផ្ទុយពីការផ្តល់ប្រឹក្សា[3913]។ អាស្រ័យហេតុនេះ ខៀវ សំផន ពុំ បានបង្ហាញនូវកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរួមដំណេកការរៀប អាពាហ៍ពិពាហ៍ត្រូវបានតាមដាន។

## iv. ការអនុវត្តន៍បទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍

1387.អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញជាច្រើនស្តីពីការតាមដាន និងរចនាសម្ព័ន្ធរាយការណ៍ ពាក់ព័ន្ធទៅនឹងគោលនយោបាយការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖ (១) សេចក្តីណែនាំរៀបចំការរៀបអាពាហ៍ពិពាហ៍ត្រូវបានចេញដោយថ្នាក់លើបញ្ជាទៅអាជ្ញាធរថ្នាក់ក្រោម និងនៅពេលអាជ្ញាធរថ្នាក់ក្រោមបានផ្គូរផ្គងបុគ្គលដើម្បីរៀបអាពាហ៍ពិពាហ៍ ការស្នើឡើងតម្រូវឱ្យមានការ យល់ព្រមពីអាជ្ញាធរថ្នាក់លើ[3914] (២) របាយការណ៍ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ត្រូវបានបញ្ជូន ទៅថ្នាក់លើ[3915] (៣) ឈ្លបដែលតាមដានប្តីប្រពន្ធដើម្បីឱ្យដឹងថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរួម ដំណេក បានរាយការណ៍ទៅអាជ្ញាធរ[3916] និង (៤) ខៀវ សំផន បានជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្សព្វ

---

[3911] សុន វុត បានពិពណ៌នាស្ថានការណ៍ដែលប្តីប្រពន្ធបែកគ្នា និងទទួលការដាក់ទណ្ឌកម្ម (ទំព័រ ៥) និងបានពិភាក្សាការអប់រំកែ ប្រែឡើងវិញថា ជាការឆ្លើយតបទៅនឹងប្តីប្រពន្ធដទៃទៀតដែលគាត់ជឿថា ត្រូវបានបំបែក (ទំព័រ ១១)។ យូ វ៉ាន់ បានពិភាក្សាជាក់ លាក់លើភស្តុតាងនៃគោលនយោបាយស្តីពីការមិនរួមដំណេកក្នុងផ្នែកដែលបានចង្អុលបង្ហាញដោយ ខៀវ សំផន និងបានផ្តល់សក្ខី កម្មថា បុគ្គលដែលខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ត្រូវបានទទួលការអប់រំ)។

[3912] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 ទំព័រ ៣៩។

[3913] *សូមមើល* ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ (សុន វុត) ឯកសារលេខ E1/412.1 ទំព័រ ៤។ ប្រតិចារឹក ថ្ងៃទី១៤ ខែ មករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារលេខ E1/376.1 ទំព័រ ៦០។ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ លេខ E1/378.1 ទំព័រ ៥១។ ប្រតិចារឹកថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៥ (ប្រាក់ ខឿន) ឯកសារលេខ E1/361.1 ទំព័រ ៨១។

[3914] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៤, ៣៥៩៤, ៣៦០២។

[3915] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៨។

[3916] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៣។

ផ្សាយសេចក្តីណែនាំស្តីពីការអនុវត្តន៍នូវគោលនយោបាយការរៀបអាពាហ៍ពិពាហ៍[3917]។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញនីមួយៗនេះ និងអំណះអំណាងរបស់គាត់ត្រូវបានគូសបង្ហាញ និងដោះស្រាយដូចខាងក្រោម។

- *សេចក្តីណែនាំចេញពីថ្នាក់លើឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ និងការយល់ព្រមទៅលើការផ្គូរផ្គងដែលបានរៀបចំដោយកម្មាភិបាលថ្នាក់ក្រោម*

1388.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សេចក្តីណែនាំឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ត្រូវបានចេញដោយថ្នាក់លើបញ្ជាទៅអាជ្ញាធរថ្នាក់ក្រោម[3918] និងបានគូសបង្ហាញនូវភស្តុតាងរបស់សាក្សី សៅ សារុន ដែលថា ប៉ុល ពត បានចេញសេចក្តីណែនាំទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍[3919]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សេចក្តីណែនាំបន្ទាប់មកត្រូវបានផ្សព្វផ្សាយទៅភូមិភាគ តំបន់ ឃុំ និងភូមិតាមរយៈកិច្ចប្រជុំ ឬវគ្គរៀនសូត្រ[3920]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ណុប ងឹម ដែលបង្ហាញថា តា ម៉ុក បានផ្គូរផ្គងប្តីប្រពន្ធ និងថា បើទោះបីជាការអនុញ្ញាតឱ្យដំណើរការការរៀបអាពាហ៍ពិពាហ៍ចេញពីថ្នាក់លើក៏ដោយ ក៏ការផ្គូរផ្គងត្រូវបានធ្វើឡើងដោយកម្មាភិបាលថ្នាក់ក្រោមដែរ[3921]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយពិចារណាលើភស្តុតាងរបស់ សេង សឿន និង មុំ វុន ថា នៅពេលអាជ្ញាធរថ្នាក់ក្រោមបានផ្គូរផ្គងបុគ្គលឱ្យរៀបអាពាហ៍ពិពាហ៍ ការស្នើឡើងនោះតម្រូវឱ្យមានការយល់ព្រមពីអាជ្ញាធរថ្នាក់លើ[3922]។

1389.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានយល់ឃើញថា ការយល់ព្រមពីអាជ្ញាធរថ្នាក់លើពុំមែនជាភស្តុតាងនៃគោលនយោបាយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាការអនុវត្តន៍ទូទៅក្នុង“ប្រទេសភាគច្រើន”[3923]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុម័តវិធីសាស្ត្រ“លម្អៀង”នៅពេលសំអាងទៅលើភស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី

[3917] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨, ៤២៧០, ៤៣០៤។

[3918] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៤។

[3919] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៥។

[3920] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

[3921] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩៧។

[3922] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩៤, ៣៦០២។

[3923] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៩។

ក្នុងការយល់ឃើញថា សេចក្តីណែនាំត្រូវបានចេញដោយថ្នាក់លើ ខណៈពេលពុំអើពើទៅលើភស្តុតាងស្តីពីគោលការណ៍ស្ម័គ្រចិត្ត[3924]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ"ករណីដាច់ដោយឡែក"របស់ សេង សឿន ក្នុងការបង្ហាញបទបញ្ញានោះថាពុំត្រឹមត្រូវដែលថា អាជ្ញាធរដែលរៀបចំការរៀបអាពាហ៍ពិពាហ៍ ត្រូវតែស្នើសុំការយល់ព្រម និងថា អង្គជំនុំជម្រះខកខានក្នុងការពិចារណាលើភស្តុតាងរបស់សាក្សីនេះដែលបង្ហាញថា មានលទ្ធភាពសម្រាប់ប្តីប្រពន្ធដកខ្លួនចេញពីការរៀបអាពាហ៍ពិពាហ៍ប្រសិនបើពួកគេមិនចូលចិត្តគ្នា[3925]។ ភស្តុតាងរបស់ ណុប ងឹម មានលក្ខណៈខុសប្លែកដោយសារគាត់ជាអ្នកគ្រប់គ្រងក្រោម តា ម៉ុក និងពុំមែនជាការពិតសម្រាប់មនុស្សក្នុងសហករណ៍ឡើយ"[3926]។

1390.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ផ្ទុយពីប្រទេសដទៃទៀត លក្ខខណ្ឌតម្រូវនៃការយល់ព្រមជាលក្ខណៈបុគ្គលក្នុងកម្ពុជាប្រជាធិបតេយ្យ គឺជា"ទម្រង់ផ្លូវការគ្មានអានុភាព"[3927]។ សហព្រះរាជអាជ្ញាបានអះអាងថា "ការយល់ព្រមដែលមានអានុភាពតែមួយគត់ គឺចេញពីថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា៖ សេចក្តីណែនាំរបស់អង្គការ គឺជាសេចក្តីសម្រេចចុងក្រោយ ដោយពុំគិតថាតើបុគ្គលនោះបានយល់ព្រមពិតប្រាកដដែរ ឬយ៉ាងណានោះទេ"[3928]។ សហព្រះរាជអាជ្ញាបានអះអាងផងដែរថា "ការផ្គូរផ្គង និងការរៀបចំការរៀបអាពាហ៍ពិពាហ៍ មានលក្ខណៈប្រហាក់ប្រហែលគ្នាទូទាំងប្រទេសដែលបង្កើតបានជាលំនាំបង្ហាញច្បាស់លាស់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាផ្នែកនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាបង្កើតដោយមជ្ឈិម"[3929]។

1391.សហមេធាវីនាំមុខបានឆ្លើយតបថា បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន បានអះអាងថា ប្តីប្រពន្ធមានជម្រើសអាចដកខ្លួនចេញពីការរៀបអាពាហ៍ពិពាហ៍បានក៏ដោយ ក៏សក្ខីកម្មរបស់គាត់បន្ថែមទៀតបង្ហាញច្បាស់លាស់ថា ប្តីប្រពន្ធពុំអាចធ្វើដូច្នោះបានដោយសារពួកគេភ័យខ្លាចនឹងត្រូវបានសម្លាប់[3930]។

---

[3924] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៥-១២៤៦។

[3925] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥០។

[3926] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥០។

[3927] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០០។

[3928] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០០។

[3929] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧០៥។

[3930] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៦។

បន្ថែមលើនេះ សហមេធាវីនាំមុខបានអះអាងថា "ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ពុំបានដឹងនូវអ្វីបានកើតឡើងចំពោះអ្នកដែលដកខ្លួន និងថាតើ 'ពួកគេប្រឈមនឹងបញ្ហាអ្វីក្រោយមកនោះ'"[3931]។

1392.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានមូលដ្ឋានគាំទ្រនៃការលើកឡើងដែលថា ការរៀបចំដែលត្រូវបានពិពណ៌នាដោយអង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងប្រព័ន្ធដែលពុំមែនជាបទល្មើស។ លក្ខណៈប្រហាក់ប្រហែលគ្នាតាមភិនភាគខាងក្រៅមិនអាចឆ្លុះបញ្ចាំងការពិតថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានបង្ខំលើបុគ្គលដោយរបបនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងស្ថានភាព ដែលពុំមានលទ្ធភាពក្នុងការស្ម័គ្រចិត្ត។ សារណារបស់ ខៀវ សំផន លើបញ្ហានេះត្រូវបដិសេធចោល។

1393.ខៀវ សំផន បានលើកការជំទាស់ជាច្រើនទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងរបស់កម្មាភិបាល។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់កម្មាភិបាលចំនួនប្រាំពីរនាក់នៅពេលបង្កើតការយល់ឃើញស្តីពីសេចក្តីណែនាំមានដូចជា៖ ពេជ្រ ជឹម លេខាស្រុកត្រាំកក់ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ដើមឆ្នាំ ១៩៧៧, ខឹម ហឿន មេឃុំជាងទងស្រុកត្រាំកក់ និងក្រោយមកបម្រើការក្នុងគណៈកម្មការស្រុកត្រាំកក់[3932], សៅ សារុន ជាលេខាតំបន់ ១០៥[3933], មាស វឿន ជាអនុមេបញ្ជាការកងពលធំលេខ ១ ក្នុងភូមិភាគបស្ចិម និងក្រោយមកលេខាតំបន់ ១០៣[3934], ស៊្វ សឿន លេខាស្រុកចាប់តាំងពីចុងឆ្នាំ ១៩៧៥[3935], សេង សឿន លេខាតំបន់ ៥០៥[3936] និង ហេង ឡៃហួ កម្មាភិបាលថ្នាក់ទាប[3937]។

1394.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅក្នុងផ្នែកបន្ថែមទៀតនៃភស្តុតាងដែលបានគូសបញ្ជាក់ដោយ ខៀវ សំផន សាក្សីទាំងនេះបានពិពណ៌នានូវការដែលរបបបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោល

---

[3931] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៤៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ១៨។

[3932] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៥។

[3933] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៥។

[3934] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

[3935] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

[3936] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

[3937] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៦។

ការណ៍ស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍[3938]។ អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាច្បាស់លាស់លើភស្តុតាងដែលបានផ្តល់ដោយបុគ្គលទាំងនេះស្តីពីគោលការណ៍ស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ក្នុងការយល់ឃើញស្តីពីសេចក្តីណែនាំ។ ទោះជាយ៉ាងណាក្តី នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបដិសេធភស្តុតាងរបស់ មាស វឿន និងកម្មាភិបាលដទៃទៀតស្តីពីអត្ថិភាពនៃគោលការណ៍ស្តីពីការស្ម័គ្រចិត្ត និងបានកត់សម្គាល់ថា "ការយល់ព្រមដែលប្តីប្រពន្ធបានផ្តល់ឱ្យពួកគេនោះ អាចពុំមែនជាការពិតប្រាកដ និងបំណងចង់កាត់បន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួន"[3939]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក ពេជ្រ ជឹម ជាករណីពិសេសត្រង់ចំណុចនេះ ដោយសារការទទួលស្គាល់របស់គាត់ដែលថា "អ្នកដែលស្ទាក់ស្ទើរក្នុងការឆ្លើយតបនៅពេលវិធីរៀបអាពាហ៍ពិពាហ៍ពុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ឡើយ"[3940]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបានពន្យល់នូវមូលហេតុដូចម្តេចបានជា អង្គជំនុំជម្រះពុំបានពិចារណាថា ភស្តុតាងដែលកម្មាភិបាលបានផ្តល់ស្តីពីគោលការណ៍នៃការយល់ព្រមនោះ គួរជឿទុកចិត្តបាន និងជាមូលដ្ឋាន និងបានពន្យល់ថា ក្នុងករណី ពេជ្រ ជឹម គាត់ពុំបានផ្តល់ភស្តុតាងស្តីពីគោលការណ៍នេះនៅគ្រប់ករណីទាំងអស់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនសំអាងទៅលើផ្នែកដទៃទៀតនៃភស្តុតាងរបស់សាក្សីទាំងនេះ។ ខៀវ សំផន ពុំបានអើពើទៅនឹងគោលការណ៍ដែលត្រូវបានបង្កើត

[3938] ប្រតិចារឹកថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារលេខ E1/290.1 ទំព័រ ៣៤ (បានពិពណ៌នានូវដំណើរការនៃការរៀបចំការរៀបអាពាហ៍ពិពាហ៍ រួមទាំងតម្រូវការធានាថា ប្តីប្រពន្ធយល់ព្រមនោះ)។ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ (យឹម ហឿន) ឯកសារលេខ E1/297.1 ទំព័រ ៥៤ (បានពិពណ៌នាអំពីការរៀបចំការរៀបអាពាហ៍ពិពាហ៍ រួមទាំងការពិគ្រោះពិភាក្សាជាមួយ ឃុំ ស្រុក ឪពុកម្តាយ និងប្តីប្រពន្ធ)។ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/82.1 ទំព័រ ៥៧ (បានអះអាងថា ប៉ុល ពត បានចេញសេចក្តីណែនាំឱ្យមានការយល់ព្រមការរៀបអាពាហ៍ពិពាហ៍ពីប្តីប្រពន្ធ និងឪពុកម្តាយរបស់ពួកគេ)។ ប្រតិចារឹក ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៥០ (ពិពណ៌នានូវដំណើរក្រោមពិធីរៀបអាពាហ៍ពិពាហ៍ រួមទាំងលក្ខខណ្ឌតម្រូវថា ប្តីប្រពន្ធជួបគ្នាដំបូង និងសម្រេចថាតើគេចូលចិត្តគ្នាដែរ ឬយ៉ាងណា)។ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ៤២-៤៣ (សាក្សីពន្យល់ថា ប្តីប្រពន្ធដែលផ្គូផ្គងត្រូវបានរៀបអាពាហ៍ពិពាហ៍តែដរាបណាគេយល់ព្រម និងថា ការបដិសេធពុំមែនជាបញ្ហាធ្ងន់ធ្ងរ)។ ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ (ស៊ូ សឿន) ឯកសារលេខ E1/310.1 ទំព័រ ៥៧-៥៨ (បានពន្យល់នូវដំណើរការសម្រាប់ការរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានទំនាក់ទំនងគ្នាត្រូវបានយល់ព្រម)។ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ១៧-១៨ (អះអាងថា ការប្រកាសត្រូវបានធ្វើឡើងពិធីរៀបអាពាហ៍ពិពាហ៍ថា ប្រសិនបើសាមីខ្លួនមិនចូលចិត្តគ្នា គេអាចដកខ្លួនបាន និងថា អ្នកខ្លះបានដកខ្លួន)។

[3939] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៣។

[3940] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៧។

ឡើងត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចជ្រើសរើសសំអាងទៅលើផ្នែកខ្លះនៃភស្តុតាងរបស់សាក្សី និងបដិសេធផ្នែកដទៃទៀត[3941]។ អំណះអំណាងនេះត្រូវបដិសេធចោល។

1395.ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងរបស់ សេង សឿន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដែលបង្ហាញថា សេចក្តីសម្រេចយល់ព្រមការរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងនៅថ្នាក់ស្រុក នៅពេលដែលថ្នាក់ឃុំជាអ្នកទទួលខុសត្រូវសម្រាប់ការរៀបអាពាហ៍ពិពាហ៍យុវជន និងយុវនារីក្នុងឃុំរបស់ខ្លួននីមួយៗ[3942]។ ទោះជាយ៉ាងណាក្តីដោយផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំបានផ្អែកសេចក្តីសន្និដ្ឋានរបស់ខ្លួនតែទៅលើភស្តុតាងនេះប៉ុណ្ណោះទេ ថែមទាំងទៅលើភស្តុតាងរបស់ មុំ វុន ដែលថា សេចក្តីណែនាំកើតចេញពីថ្នាក់ស្រុក[3943]។ សេង សឿន ពុំបានផ្តល់ភស្តុតាងថា ប្តីប្រពន្ធអាចដកខ្លួនពីការរៀបចំនៃការរៀបអាពាហ៍ពិពាហ៍គ្មានផលវិបាក។ បើទោះបីជាគាត់បានអះអាងថា ប្តីប្រពន្ធតាមទ្រឹស្តីអាច"ដើរចេញ"ពីពិធីរៀបអាពាហ៍ពិពាហ៍បានក៏ដោយ ក៏គាត់បានបញ្ជាក់ផងដែរថា គាត់ជឿជាក់ថា បើធ្វើដូច្នោះនឹងបណ្តាលឱ្យមានការដាក់ទណ្ឌកម្ម[3944]។

1396.បន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់របស់ ខៀវ សំផន ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងរបស់ ណុប ងឹម ដែលថា តា ម៉ុក បានផ្គូរផ្គងប្តីប្រពន្ធ[3945]។ ដំបូង ខៀវ សំផន បានចង្អុលបង្ហាញទៅលើភស្តុតាងតាមការអះអាងរបស់គាត់ថា ណុប ងឹម និងស្ត្រីដទៃទៀតគប្បី"ប្រកែកនៅពេលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយយុទ្ធជនពិការ"[3946]។ ភស្តុតាងនេះត្រឹមតែពិពណ៌នាបទពិសោធន៍របស់ ណុប ងឹម នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងពុំបានបង្ហាញនូវអ្វីដែលដែល ខៀវ សំផន បានអះអាងនោះទេ។ ភស្តុតាងបន្ថែមទៀតដែលត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំផន

[3941] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៥៧។

[3942] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦។

[3943] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៥។

[3944] ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 ទំព័រ ១៨-២០ (ពិភាក្សាភស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងថា គាត់គិតថា ប្តីប្រពន្ធអាចដើរចេញបាន ប៉ុន្តែអាចត្រូវទទួលទណ្ឌកម្ម)។ ប្រតិចារឹក ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៥ (ស៊ូ សឿន) ឯកសារលេខ E1/310.1 ទំព័រ ៦១ (បានផ្តល់ភស្តុតាងថា ប្រធានឃុំបានសួរប្រជាជនថាតើ គេយល់ព្រមរៀបអាពាហ៍ពិពាហ៍ ដែរ ឬទេ)។

[3945] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៧។

[3946] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥០ យោងទៅលើប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 នៅម៉ោង ១១.០២។

ពុំបានបង្ហាញថា ភស្តុតាងរបស់ ណុប ង៉ឹម ជាទូទៅពុំអាចជឿជាក់បានឡើយ។ បើទោះបីជា ណុប ង៉ឹម បានពិពណ៌នាថា ជួនកាលបុគ្គលដែលបានស្រលាញ់គ្នាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក៏ដោយ ក៏គាត់បានអះអាងច្បាស់លាស់ផងដែរក្នុងផ្នែកនោះថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានបង្ខំ[3947]។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

- *របាយការណ៍ស្តីពីការរៀបអាពាហ៍ពិពាហ៍ផ្ញើទៅថ្នាក់លើ*

1397.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា របាយការណ៍ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ត្រូវបានទំនាក់ទំនងទៅថ្នាក់លើ[3948]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា របាយការណ៍ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ចេញពីមន្ទីរ ៤០១ ជូនអង្គការពាក់ព័ន្ធទៅនឹងការកសាងគ្រួសារបានបញ្ជាក់ថា "គ្រួសារថ្មី ១០ ត្រូវបានបង្កើតឡើងក្នុងស្រុក ២៦ តំប់ ៣២ ខណៈពេលគ្មានការបញ្ជាក់អំពីបញ្ហានេះក្នុងតំបន់ ៣១ និង ៣៧"[3949]។ នៅក្នុងរបាយការណ៍មួយផ្សេងទៀតជូនអង្គការចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ មានប្តីប្រពន្ធ ៤២គូ ត្រូវបានរាយការណ៍ថាបានរៀបអាពាហ៍ពិពាហ៍។ របាយការណ៍នោះបានលើកឡើងផងដែរនូវហេតុការណ៍មួយដែលបុរសម្នាក់បានចងកសម្លាប់ខ្លួន ដែលបានកើតឡើង ១៥ ថ្ងៃក្រោយពីការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានរៀបចំដោយអង្គការ។ របាយការណ៍បន្ថែមទៀតបានលើកឡើងថា ការស៊ើបអង្កេតថ្មីៗ ស្រាវជ្រាវរកមូលហេតុនៅពីក្រោយការធ្វើអត្តឃាតនោះពុំបានបង្ហាញអ្វីគួរកត់សម្គាល់ឡើយ[3950]។

1398.ខៀវ សំផន បានអះអាងថា ការសំអាងទៅលើរបាយការណ៍ពីរពុំអាចថា ការអនុវត្តន៍នេះមានលក្ខណៈទូទៅទូទាំងប្រទេសបានឡើយ និងថា ការសំដៅចំពោះ"មជ្ឈិមបក្ស"ពុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដើម្បី

---

[3947] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៥០ យោងទៅលើប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៣៩។

[3948] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៨។

[3949] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៨ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/1092 ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN 00143579 ទំព័រ ៥។

[3950] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៨ យោងទៅលើរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/1094 ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ERN 00143609 ទំព័រ ៦។

បង្ហាញអំពីរបាយការណ៍មជ្ឈិម[3951]។ គាត់បានអះអាងផងដែរថា ឯកសារនោះត្រឹមតែលើកឡើងនូវចំនួនប្ដីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ និងដូច្នេះ ពុំបានឆ្លុះបញ្ចាំងភស្តុតាងណាមួយនៃសេចក្ដីណែនាំ[3952]។

1399.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសាររបាយការណ៍នេះបានបង្ហាញត្រឹមតែការយល់ឃើញជាក់លាក់ដែលថា របាយការណ៍ត្រូវបានផ្ញើទៅថ្នាក់លើប៉ុណ្ណោះ ចំណែកការយល់ឃើញទូលំទូលាយជាងនេះទាក់ទងទៅនឹងសេចក្ដីណែនាំរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងការយល់ព្រមនោះ បានផ្អែកលើភស្តុតាងជាច្រើនទៀត[3953]។

1400.អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា របាយការណ៍ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨ ស្ដីពីគ្រួសារចំនួន ១០ ដែលត្រូវបានបង្កើតឡើងក្នុងស្រុក ២៦ បានគាំទ្រការបញ្ជាក់នៃរបាយការណ៍ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយហេតុថា ការរៀបអាពាហ៍ពិពាហ៍ក្នុងលក្ខណៈបង្ខំនេះ ពុំមែនជាការផ្ដោតនៃរបាយការណ៍ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានផ្ដោតទៅលើឯកសាររបាយការណ៍ក្នុងការយល់ឃើញរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះបានពិចារណាផងដែរក្នុងជើងទំព័រដែលគាំទ្រនោះលើភស្តុតាងរបស់កម្មាភិបាល ជួន ធី ដែលបានអះអាងថា ក្នុងនាមមេបញ្ជាការកងវរៈសេនាធំក្នុងកងពលលេខ ១ គាត់"បានរាយការណ៍ចំនួនប្ដីប្រពន្ធទៅថ្នាក់លើ។ កងដទៃទៀតធ្វើដូចគ្នា។ ពីព្រោះស្ថានការណ៍នៅពេលនោះមានការចលាចលក្នុងឆ្នាំ ១៩៧៨ ដល់ ១៩៧៩ គេបង្ខំឱ្យមានការរៀបអាពាហ៍ពិពាហ៍ជាច្រើនគូ"[3954]។ ជារួម អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា របាយការណ៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងដោយផ្អែកលើភស្តុតាងទាំងមូលនេះ។

1401.របាយការណ៍ពីរនេះ គឺជាភស្តុតាងជាក់លាក់ដែលរាយការណ៍ត្រឡប់ទៅថ្នាក់លើវិញ និងបានបង្កើតជាផ្នែកមួយនៃភស្តុតាងដ៏ទូលំទូលាយដែលបង្ហាញថា ថ្នាក់លើបានចេញសេចក្ដីណែនាំនៃការរៀបអាពាហ៍ពិពាហ៍ទៅថ្នាក់ក្រោម[3955]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន របាយការណ៍នេះពុំមែនជាមូលដ្ឋានតែមួយ

---

[3951] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៧។

[3952] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៧។

[3953] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៨។

[3954] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៩៩៧៥ យោងទៅលើដែរកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារលេខ E3/10713 ERN 01146348 ទំព័រ ៧។

[3955] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៤-៣៥៦៧។

គត់សម្រាប់ការយល់ឃើញដែលថា មានការណែនាំឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ។ ដោយផ្ទុយទៅនឹងសារណារបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញផងដែរថា របាយការណ៍នេះខ្លួនឯងផ្ទាល់គឺជាភស្តុតាងនៃសេចក្តីណែនាំឡើយ។ អង្គជំនុំជម្រះសាលាដំបូងត្រឹមតែបានយល់ឃើញថា របាយការណ៍ដែលបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍បានកើតឡើងនោះត្រូវបានទំនាក់ទំនងទៅថ្នាក់លើ[3956]។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោលផងដែរ។

- *របាយការណ៍ស្តីពីការតាមដានការរួមដំណេកការរៀបអាពាហ៍ពិពាហ៍*

1402.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ឈ្លបដែលតាមដានប្តីប្រពន្ធដើម្បីឱ្យដឹងថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរួមដំណេក បានរាយការណ៍ទៅអាជ្ញាធរ និងបានសំអាងទៅលើភស្តុតាងរបស់ ជាំង ស្រីមុំ, កុល សែត និង សុន វុត[3957]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ មុំ វុន ដែលថា ឈ្លបបានទទួលសេចក្តីណែនាំពី រុំ ដែលជាប្រធានការដ្ឋាន និង សៀ ប្រធានកង ឱ្យតាមដានប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍ថ្មី[3958]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់អ្នកធ្វើការកងចល័តម្នាក់ក្នុងភូមិភាគនិរតីឈ្មោះ រី ពៅ ដែលត្រូវបានណែនាំឱ្យតាមដានសកម្មភាពរបស់ប្តីប្រពន្ធថ្មី និងរាយការណ៍ទៅកងក្បែរៗនោះ[3959]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ ហេង ឡៃហ៊ាង ដែលបានបម្រើការជាគណៈកម្មការឃុំក្នុងឃុំមួយនៃតំបន់ ៥០៥ ដែលបង្ហាញថា មនុស្សត្រូវបានចាត់តាំងឱ្យតាមដានប្តីប្រពន្ធដើម្បីទទួលបានព័ត៌មានស្តីពីការប្រតិកម្មរបស់ពួកគេក្រោយការរៀបអាពាហ៍ពិពាហ៍[3960]។

1403.ខៀវ សំផន បានជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឈ្លបបានរាយការណ៍ស្តីពីលទ្ធផលនៃការតាមដានទៅអាជ្ញាធរ និងបានជំទាស់ការសំអាងលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ និង ហេង ឡៃហ៊ាង[3961]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹង រី ពៅ ពុំអាចជឿទុកចិត្តបានពីព្រោះគាត់បានផ្តល់ភស្តុតាងនៃការរាយការណ៍ទាក់ទង

3956 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៨។

3957 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៣។

3958 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤២។

3959 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤២។

3960 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤២។

3961 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៨។

ទៅនឹងប្ដីប្រពន្ធថ្មីចេញពីកងដទៃទៀត ដែលតម្រូវឱ្យមានការចល័តច្រើនកន្លែង[3962]។ ខៀវ សំផន បាន អះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានពិចារណាលើភស្តុតាងផ្ទុយគ្នានៅក្នុងសំណុំរឿង។ គាត់បានចង្អុលបង្ហាញទៅលើសក្ខីកម្មរបស់ នាង អ៊ូច ប្រធានស្រុកត្រាំកក់ ដែលត្រូវបានបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងរបស់ យាន លន់ ដែលជាឈ្លបមកពីភូមិភាគមជ្ឈិម ដែលថា ពួកគេពុំបានដឹងអំពីឈ្លបចុះតាមដានការរួមដំណេក និងថា នេះពុំមែនជាតួនាទីរបស់ឈ្លបធ្វើដូច្នោះ[3963]។

1404.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សក្ខីកម្មនេះពុំអាចជំនួសភស្តុតាងជាច្រើនដែលបង្ហាញថា ឈ្លបបានចុះតាមដានប្ដីប្រពន្ធ[3964]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹង វី ពៅ ពុំមានអ្វីក្រៅតែពីការសន្និដ្ឋាន[3965] នៅពេលដែលសក្ខីកម្មរបស់ ហេង ឡៃហ៊ាង បានបញ្ជាក់អះអាងបន្ថែមលើសក្ខីកម្មដទៃទៀត ដែលបង្ហាញថា ព័ត៌មានត្រូវបានប្រមូល និងរាយការណ៍តាមរចនាសម្ព័ន្ធនៃបទបញ្ជា[3966]។ សហព្រះរាជអាជ្ញាបានឆ្លើយតបផងដែរថា សក្ខីកម្មរបស់ នាង អ៊ូច និង យាន លន់ ពុំបានប៉ះពាល់ដល់ការយល់ឃើញដែលថា ឈ្លបបានចុះតាមដានប្ដីប្រពន្ធ ដោយសារការយល់ឃើញនេះត្រូវបាន“គាំទ្រដោយភស្តុតាងគ្រប់គ្រាន់”[3967]។

1405.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ពុំបានផ្ដល់ភស្តុតាងជាមូលដ្ឋានសម្រាប់ការអះអាងនេះអំពីការលំបាកផ្នែកសម្ភារៈ និងដូច្នេះ អំណះអំណាងរបស់គាត់ត្រូវបដិសេធចោល។ ខៀវ សំផន បានអះអាងផងដែរថា វី ពៅ បានសំដៅតែទៅលើរបាយការណ៍ទៅប្រធានកង និងពុំបានបញ្ជាក់ថា “កម្មាភិបាលជាន់ខ្ពស់នៅថ្នាក់លើត្រូវបានជូនដំណឹងអំពីការអនុវត្តន៍នេះ កុំថាឡើយដល់ទៅថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជានោះ”[3968]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះជាការកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា របាយការណ៍ត្រូវបានធ្វើឡើងផ្ញើទៅ“អាជ្ញាធរ” មិនមែនទៅថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាផ្ទាល់នោះទេ[3969]។

---

[3962] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៨។

[3963] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៤៨។

[3964] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤១។

[3965] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤០។

[3966] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៤០។

[3967] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៨។

[3968] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥០។

[3969] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៣។

1406.ទាក់ទងទៅនឹង ហេង ឡៃហ៊ាង អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ខ្លួនដែលថា មនុស្សត្រូវបានចាត់តាំងឱ្យតាមដានប្ដីប្រពន្ធដើម្បីទទួលបានព័ត៌មានស្ដីពីប្រតិកម្មរបស់ពួកគេក្រោយការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងសក្ខីកម្មរបស់គាត់ដែលថា ប្ដីប្រពន្ធដែលពុំចុះសម្រុងនឹងគ្នានឹងត្រូវរាយការណ៍ទៅប្រធានដើម្បីចាត់វិធានការក្នុងលក្ខណៈនៃការអប់រំកែប្រែឡើងវិញ និងប្រសិនបើចាំបាច់ត្រូវព្រមាន[3970]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងរបស់ ហេង ឡៃហ៊ាង នៅពេលអង្គជំនុំជម្រះបានបញ្ជាក់ថា "កម្មាភិបាលជាន់ខ្ពស់"ជាអ្នកទទួលព័ត៌មាន ប៉ុន្ដែការពិត គាត់បានបញ្ជាក់ថា ព័ត៌មាននោះបញ្ជូនទៅតែប្រធានកងប៉ុណ្ណោះ[3971]។ អង្គជំនុំជម្រះតុលាការកំពូលពិនិត្យឡើងវិញលើផ្នែកពាក់ព័ន្ធភស្តុតាងរបស់ ហេង ឡៃហ៊ាង ឃើញថា គាត់បានអះអាងថា ការប្រមូលរបាយការណ៍បានកើតឡើងនៅថ្នាក់កង ប៉ុន្តែបន្ទាប់មកព័ត៌មានទៅដល់"ប្រធានគេហ្នឹងទៅ និងទៅខាងលើហ្នឹងដែលគេចាត់ការតាមហ្នឹងទៅទៀតទៅ"[3972]។ ខៀវ សំផន បំភ្លៃភស្តុតាងរបស់សាក្សីនេះ និងដូច្នេះ អំណះអំណាងរបស់គាត់ត្រូវបដិសេធចោល។

1407.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា ឈ្លបបានតាមដានការរួមដំណេក ទៅលើភស្តុតាងរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាលើសក្ខីកម្មដាច់ដោយឡែករបស់ នាង អ៊ួច ដែលថា ឈ្លបពុំមានតួនាទីចុះតាមដានប្ដីប្រពន្ធឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា បើទោះបីភស្តុតាងរបស់ យាន លន់ គាំទ្រការសន្និដ្ឋានដែលថា ឈ្លបមានភារកិច្ចផ្សេង ដែលពុំត្រូវបានជំទាស់ក៏ដោយ ក៏ពុំបានគាំទ្របន្ថែមលើភស្តុតាងរបស់ នាង អ៊ួច ស្ដីពីការពុំជាប់ពាក់ព័ន្ធបន្ថែមរបស់ឈ្លបក្នុងការតាមដានការរួមដំណេកដែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

- ***ការជាប់ពាក់ព័ន្ធផ្ទាល់របស់ ខៀវ សំផន នៅក្នុងបទបញ្ជារៀបអាពាហ៍ពិពាហ៍***

1408.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្សព្វផ្សាយសេចក្ដីណែនាំអំពីការអនុវត្តន៍នូវគោលនយោបាយការរៀបអាពាហ៍ពិពាហ៍ ដើម្បីបង្កើនឆាប់រហ័សប្រជា

---

3970 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៣។

3971 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៥១។

3972 ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ៤៧-៤៨។

ជនកម្ពុជាប្រជាធិបតេយ្យ[3973]។ ក្នុងការធ្វើសេចក្ដីសន្និដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងក្នុងតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ដែលថា លោកស្រីបានចូលរួមកិច្ចប្រជុំមួយនៅវត្តខណ្ឌលោមក្នុងភ្នំពេញ ដែលដឹកនាំដោយ ខៀវ សំផន ក្នុងអំឡុងពេលនោះគាត់បានបង្រៀនកម្មាភិបាលស្តីពី ការផ្ដាច់ចេញពីឪពុកម្ដាយ និងបានណែនាំថា ក្រសួងត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍ឱ្យយុវជនយុវនារីទាំងអស់[3974]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងដែលថា គ្រប់ក្រសួងត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍ ត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងរបស់កម្មាភិបាលក្រសួងពាណិជ្ជកម្មឈ្មោះ រស់ ស៊ុយ អំពីចំនួនកំណត់នៃការរៀបអាពាហ៍ពិពាហ៍[3975] និងត្រូវបានគាំទ្របន្ថែមដោយបទឧទ្ទេសនាមឆ្នាំ ១៩៧៨ របស់ ខៀវ សំផន អំពីការលើកកម្ពស់លក្ខខណ្ឌរបស់ប្រជាជន[3976] និងសេចក្ដីដកស្រង់ចេញពីសៀវភៅរបស់សម្ដេចនរោត្តមសីហនុដែលពិភាក្សាតួនាទីរបស់ ខៀវ សំផន ក្នុងការរៀបអាពាហ៍ពិពាហ៍ឱ្យយុទ្ធជនពិការ[3977]។

1409.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងរបស់ ខៀវ សំផន ផ្ដោតទៅលើបញ្ហាបី៖ (ក) ការចោទប្រកាន់កំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងជាចម្បង ឬតែទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប[3978] (ខ) ការចោទប្រកាន់ភាពពុំស៊ីសង្វាក់គ្នាក្នុងភស្តុតាងរបស់ ជា ឌៀប ទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណ[3979] និង (គ) ការបញ្ជាក់អះអាងបន្ថែមពី/ការផ្ទុយគ្នាជាមួយភស្តុតាងដទៃទៀត[3980]។ ទាំងនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយខាងក្រោម។

### ក) ការសំអាងជាចម្បង ឬតែទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

1410.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើវាល់“វិធានស្តីពីភស្តុតាង”ក្នុងការសំអាងទៅលើតែភស្តុតាងរបស់ ជា ឌៀប ក្នុងការយល់ឃើញថា គាត់បានផ្ដល់សេចក្ដីណែនាំស្តីពីការ

---

[3973] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨, ៤២៧០, ៤៣០៤។

[3974] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

[3975] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០។

[3976] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០-៣៥៧១។

[3977] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧១។

[3978] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១៨។

[3979] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៣-១២៤២, ២១១៧។

[3980] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៨, ១២៤០-១២៤១។

រៀបអាពាហ៍ពិពាហ៍ ដើម្បីបង្កើតកូន និងបង្កើនកម្លាំង ដោយហេតុថា ជា ខៀប គឺជាដើមបណ្តឹងរដ្ឋប្បវេណី និងពុំតម្រូវឱ្យធ្វើសម្បថឡើយ[3981]។

1411.សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានគោលការណ៍បង្ហាញត្រឹមត្រូវថា តុលាការអង្គហេតុអាចសំអាងទៅលើសាក្សីតែមួយដើម្បីបង្កើតការយល់ឃើញ បើទោះបីជាគ្មានការបញ្ជាក់អះអាងបន្ថែមក៏ដោយ[3982]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់អំពីពិរុទ្ធភាព[3983]។

1412.សហមេធាវីនាំមុខបានលើកឡើងថា ពុំមានមូលដ្ឋានផ្លូវច្បាប់ ឬចំណុចគោលការណ៍ដែលគាំទ្រទស្សនៈដែលថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃជាភស្តុតាងទាបជាងភស្តុតាងដទៃទៀតនោះឡើយ [3984]។

1413.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាតែលើភស្តុតាងរបស់ ជា ខៀប នៅក្នុងការយល់ឃើញដែលរងការជំទាស់ប៉ុណ្ណោះទេ។ អង្គជំនុំជម្រះបានពិចារណាផងដែរលើភស្តុតាងរបស់កម្មាភិបាលក្រសួងពាណិជ្ជកម្មឈ្មោះ រស់ ស៊ុយ[3985] ព្រមទាំងបទឧទ្ទេសនាមធ្វើឡើងដោយ ខៀវ សំផន[3986] និងសៀវភៅរបស់សម្តេចនរោត្តមសីហនុ[3987]។ ទោះជាយ៉ាងណាក្តី ពុំមានប្រភពនៃភស្តុតាងផ្សេងក្រៅពីភស្តុតាងរបស់ ជា ខៀប បញ្ជាក់នូវការជាប់ពាក់ព័ន្ធផ្ទាល់របស់ ខៀវ សំផន ក្នុងការរៀបចំការរៀបអាពាហ៍ពិពាហ៍។ រស់ ស៊ុយ បានផ្តល់ភស្តុតាងក្រៅតុលាការក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលថា កងក្នុងក្រសួងរបស់គាត់ត្រូវបានចាត់តាំងចំនួនកំណត់អប្បបរមាប្រចាំខែសម្រាប់ការរៀបអាពាហ៍ពិពាហ៍ ក្នុងឆ្នាំ ១៩៧៧ និង ឆ្នាំ ១៩៧៨ និងពុំបាននិយាយសំដៅទៅលើ ខៀវ សំ

---

[3981] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១៨។

[3982] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១២។

[3983] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១២។

[3984] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៧១។

[3985] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០។

[3986] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០-៣៥៧១។

[3987] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧១។

ផន[3988]។ ក្នុងបទឧទ្ទេសនាមផ្ទាល់ខ្លួនរបស់ ខៀវ សំផន គាត់បាននិយាយអំពីការដែលអត្ថប្រយោជន៍បុគ្គលត្រូវតែដាក់ឱ្យស្ថិតក្រោមបដិវត្តន៍[3989] ប៉ុន្តែពុំបានសំដៅទៅលើគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ សៀវភៅរបស់សម្តេចនរោត្តមសីហនុបានរំឭកការដែល ខៀវ សំផន លើកសរសើរស្ត្រីវ័យក្មេងមានចិត្តក្លៀវក្លាស្នេហាជាតិសុខចិត្តលះបង់ដើម្បីជាតិតាមរយៈរៀបអាពាហ៍ពិពាហ៍ជាមួយយុទ្ធជនពិការ ប៉ុន្តែពុំបានបញ្ជាក់នូវតួនាទីរបស់គាត់ក្នុងការណែនាំផ្ទាល់អំពីការរៀបអាពាហ៍ពិពាហ៍។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងតាមរយៈពាក្យពេចន៍ទំនងជាសំអាងទៅលើប្រភពទាំងនេះនៃភស្តុតាងក្នុងការបញ្ជាក់អះអាងបន្ថែមលើភស្តុតាងរបស់ ជា ឌៀប[3990]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប គឺជាភស្តុតាងផ្ទាល់តែមួយគត់សម្រាប់ការយល់ឃើញដែលថា ខៀវ សំផន មានការជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្សព្វផ្សាយសេចក្តីណែនាំអំពីការរៀបអាពាហ៍ពិពាហ៍។

1414.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរលើបញ្ហាថាតើ ដូចការអះអាងរបស់ ខៀវ សំផន ការយល់ឃើញនោះគឺជាចំណុចស្នូលនៃការទទួលខុសត្រូវរបស់គាត់ផ្នែកព្រហ្មទណ្ឌទាក់ទងទៅនឹងបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញអំពីសេចក្តីណែនាំរបស់គាត់នៅវត្តឧណ្ណាលោម និងការយល់ឃើញនេះតែមួយក្នុងការយល់ឃើញថា ខៀវ សំផន បាន"ជម្រុញដោយផ្ទាល់នូវគោលនយោបាយរបស់បក្សដើម្បីបង្កើនឆាប់រហ័សប្រជា

---

[3988] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០។

[3989] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៤៨ យោងទៅលើមីទ្ទីងនៅទីក្រុងភ្នំពេញប្រារព្ធខួបថ្ងៃទី១៧ ខែមេសា (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B/1) ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ឯកសារលេខ E3/562 ERN 00249990 (ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលអនុម័តក្នុងពេលប្រជុំមហាជននាឱកាសប្រារព្ធខួបលើកទី៣ ថ្ងៃ១៧ មេសា ដែល ខៀវ សំផន ថ្លែងសុន្ទរកថាក្នុងចំណោមចំណុចនានា គាត់បានបញ្ចូលនូវការប្តេជ្ញាចិត្តជាទូទៅថា៖ "(១២) ដាក់ប្រយោជន៍គ្រួសារ និងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្ត")។

[3990] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ (យល់ឃើញថា "ការចោទប្រកាន់ដែលថា រាល់ក្រសួងត្រូវតែរៀបចំការរៀបអាពាហ៍ពិពាហ៍ ត្រូវបានបញ្ជាក់បន្ថែមដោយ រស់ ស៊ុយ), ៣៥៧១ (យល់ឃើញថា ការលើកឡើងរបស់ ខៀវ សំផន ក្នុងបទឧទ្ទេសនាមរបស់គាត់"ដូចគ្នានឹងការអំពាវនាវរបស់គាត់នៅវត្តឧណ្ណាលោម") និង ៣៥៧១ (យល់ឃើញថា ភស្តុតាងដទៃទៀត "ស៊ីសង្វាក់គ្នា"ជាមួយនឹងសៀវភៅរបស់សម្តេចនរោត្តមសីហានុ)។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរពីដំបូងក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលថា សៀវភៅរបស់សម្តេចនរោត្តមសីហនុ ត្រូវបានសំអាងទៅលើត្រឹមតែដើម្បីបញ្ជាក់បន្ថែមភស្តុតាងដទៃទៀត ពីព្រោះមេធាវីការពារក្តីពុំមានឱកាសសួរដេញដោលចម្លើយក្នុងតុលាការ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០១។

ជនកម្ពុជាប្រជាធិបតេយ្យ"[3991]។ ផ្អែកលើមូលដ្ឋាននៃការយល់ឃើញនៃអង្គហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គាត់"មិនត្រឹមតែបានរួមចំណែកការគាំទ្រដល់គោលបំណងរួមប៉ុណ្ណោះទេ ថែមទាំងថា គាត់បានណែនាំយ៉ាងសកម្មអំពីការអនុវត្តន៍តាមរយៈគោលនយោបាយផ្សេងៗ"[3992] និងបានសំអាងទៅលើការយល់ឃើញនេះដើម្បីកំណត់ថា ខៀវ សំផន មានចេតនាចង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដែលជាផ្នែកមួយនៃគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍[3993]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរទៅលើការយល់ឃើញនេះនៅពេលធ្វើការសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តលើពុទ្ធសាសនិកក្នុងអំឡុងពេលនោះ[3994]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ការយល់ឃើញនេះបានផ្អែកជាចម្បងទៅលើភស្តុតាងរបស់ ជា ឌៀប និងជាចំណុចស្នូលនៃការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ត្រង់ចំណុចទាក់ទងទៅនឹងបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍។

1415.មានគោលការណ៍បង្កើតឡើងត្រឹមត្រូវថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពុំមានតម្លៃទាបដោយខ្លួនឯងផ្ទាល់ជាងភស្តុតាងក្នុងទម្រង់ផ្សេងៗឡើយ[3995]។ បន្ថែមលើនេះ មានការការកំណត់ប្រហាក់ប្រហែលគ្នានេះថា ដើមបណ្តឹងរដ្ឋប្បវេណីអាចបង្កើតបានជាផ្នែកមួយនៃភស្តុតាងដែលបានត្រូវបានសំអាងទៅលើក្នុងការកំណត់អំពីពិរុទ្ធភាព[3996]។ ដើមបណ្តឹងរដ្ឋប្បវេណីជាពិសេសត្រូវបានដាក់ស្ថិតក្នុងទីតាំងល្អប្រសើរក្នុងការលើកឡើងអំពីការរងទុក្ខរបស់ខ្លួន[3997]។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះនៃបទឧក្រិដ្ឋមួយ ជាឧទាហរណ៍ គាត់ជាញឹកញាប់នឹងត្រូវបានដាក់ឱ្យស្ថិតក្នុងទីតាំងល្អប្រសើរយ៉ាងពិសេសដើម្បីរាយការណ៍នូវព្រឹត្តិការណ៍ដែលបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់នោះ[3998]។ អាស្រ័យហេតុនេះ អង្គជំនុំ

[3991] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨-៤២៤៩។

[3992] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៥។

[3993] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨។

[3994] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤២ ("នៅពីក្រោយឆាក ខៀវ សំផន បានណែនាំយ៉ាងសកម្មនូវការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយគ្មានព្រះសង្ឃ និងក្នុងលក្ខណៈដែលពុំស្របជាមូលដ្ឋានទៅនឹងទំនៀមទម្លាប់កាន់ពុទ្ធសាសនា") និងជើងទំព័រ ១៣៨៤៩ យោងទៅលើ*ក្នុងចំណោមនោះ* កថាខណ្ឌ ៣៥៦៩។

[3995] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១៣។

[3996] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣០៦។

[3997] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៧។

[3998] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២។

ជម្រះសាលាដំបូងបានបញ្ជាក់ត្រឹមត្រូវនូវបទដ្ឋាននេះ[3999] និងបានសង្កេតត្រឹមត្រូវផងដែរថា តម្លៃជាភស្តុតាងនៃសក្ខីកម្មអាចត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃកត្តាជាច្រើន រួមមានអាកប្បកិរិយារបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីសង្វាក់គ្នា ឬមិនស៊ីសង្វាក់គ្នាជាមួយអង្គហេតុជាសត្យានុម័ត ការជម្រុញទឹកចិត្តលាក់កំបាំង ការបញ្ជាក់អះអាងបន្ថែម និងគ្រប់កាលៈទេសៈនៃរឿងក្តី[4000]។

1416.បញ្ហាមួយផ្សេងទៀតគឺថាតើ ការយល់ឃើញដែលជាចំណុចស្នូលនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចត្រូវបានផ្អែកតែឯង ឬជាចម្បងទៅលើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែរ ឬយ៉ាងណា។ មានគោលការណ៍បង្កើតឡើងត្រឹមត្រូវនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលថា តុលាការអង្គហេតុអាចសំអាងទៅលើសាក្សីតែមួយក្នុងការគាំទ្រការយល់ឃើញអំពីពិរុទ្ធភាព បើទោះបីជាគ្មានការបញ្ជាក់អះអាងបន្ថែមក៏ដោយ[4001]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ផងដែរថា ពុំមានវិធានទូទៅដែលកំណត់ថា ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យពុំអាចធ្វើទៅបាន ប្រសិនបើពុំមានភស្តុតាងលើសពីមួយដើម្បីគាំទ្រនោះឡើយ[4002]។ ទោះជាយ៉ាងណាក្តី ចំណុចនេះពុំត្រូវបានបង្ហាញដូចគ្នាទាក់ទងទៅនឹងជនរងគ្រោះដែលចូលរួមក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានបញ្ជាក់ថា ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានសំអាងទៅលើក្នុងការកំណត់នូវពិរុទ្ធភាព និងថា ការយល់ឃើញបានបង្ហាញផងដែរថា ភស្តុតាងនេះជាទូទៅពុំអាចត្រូវបានសំអាងទៅលើតែឯងបានទេ។ ដើមបណ្តឹងរដ្ឋប្បវេណីអាច"ផ្តល់សក្ខីកម្មចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ"[4003] និងថា អង្គជំនុំជម្រះសាលាដំបូងអាច"ពិចារណា"លើសក្ខីកម្មនោះនៅពេលបង្កើតការយល់ឃើញផ្នែកអង្គហេតុរបស់ខ្លួន[4004]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ផងដែរថា វិធានផ្ទៃក្នុងត្រូវបានផ្អែកទៅលើការសន្មតថា ដើមបណ្តឹងរដ្ឋប្បវេណី"អាចផ្តល់ព័ត៌មានទាក់ទងទៅនឹង"ពិរុទ្ធភាពរបស់ជនជាប់ចោទ[4005] និងថា សំណួររបស់សហ

[3999] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៧។

[4000] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២៨។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១៤។

[4001] *សូមមើល ឧ.* សាលដីការឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ៩៤៩។

[4002] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤២៤។

[4003] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២។

[4004] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២។

[4005] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២។

ចៅក្រមស៊ើបអង្កេតក្រោមវិធាន ៥៩ នៃវិធានផ្ទៃក្នុង អាច"ប៉ះពាល់"បញ្ហាដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនសង្ស័យ[4006]។

1417.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាមានគោលការណ៍បង្ហាញត្រឹមត្រូវថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន និងអាចមានតម្លៃជាភស្តុតាងក៏ដោយ ក៏ពុំដូចគ្នាទៅនឹងភស្តុតាងរបស់សាក្សីដែរ។ នេះជាការបង្ហាញច្បាស់លាស់ក្នុងវិធានរបស់តុលាការព្រហ្មទណ្ឌ។ វិធាន ២៣ (៤) នៃវិធានផ្ទៃក្នុងចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចត្រូវបានសួរសំណួរដូចសាក្សីធម្មតាក្នុងរឿងក្តីតែមួយបានឡើយ" ដែលឆ្លុះបញ្ចាំងមាត្រា ៣១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ"។ ឋានៈដាច់ដោយឡែករបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺជាអ្វីដែលអាចមានការជាប់ពាក់ព័ន្ធនៅពេលធ្វើការវាយតម្លៃលើតម្លៃជាភស្តុតាង និង/ឬភាពគួរជឿជាក់បាននៃសក្ខីកម្ម[4007]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ផងដែរថា កត្តាជាក់លាក់ដែលអាចអនុវត្តបានចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាការពិតដែលថា ពុំបានធ្វើសម្បថ អាចពិភាក្សាជាមួយមេធាវីប្រឹក្សាបានក្នុងអំឡុងពេលនៃសក្ខីកម្ម និងពុំទទួលរងទណ្ឌកម្មសម្រាប់ការផ្តល់សក្ខីកម្មមិនពិត គឺជា"កត្តា [...] ដែលត្រូវតែបានពិចារណានៅពេលធ្វើការវាយតម្លៃលើតម្លៃជាភស្តុតាង និងទម្ងន់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី"[4008]។

1418.យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នេះអាចជាការខុសប្រក្រតីសម្រាប់ការយល់ឃើញដែលជាស្នូលនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលក្ខណៈបុគ្គល ផ្អែកតែទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលពុំដកចេញនូវលទ្ធភាពដែលថា ការយល់ឃើញនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលផ្នែកព្រហ្មទណ្ឌអាចសំអាងជាបឋមទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា ភស្តុតាងនេះត្រូវបានពិចារណាដោយប្រុងប្រយ័ត្នដោយអង្គជំនុំជម្រះសាលាដំបូង រួមទាំងការវាយតម្លៃលើភាពពុំស៊ីសង្វាក់គ្នា និងការវាយតម្លៃលើភស្តុតាងដែលបញ្ជាក់អះអាងបន្ថែម។ បញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមបទដ្ឋាននេះ ដែរ ឬយ៉ាងណា នឹងត្រូវពិចារណាខាងក្រោម បន្ទាប់ពីការវាយតម្លៃលើការជំទាស់ដទៃទៀតរបស់ ខៀវ សំផន។

---

[4006] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២។

[4007] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២-៣១៣។

[4008] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១៥។

## ខ) ភាពពុំស៊ីសង្វាក់គ្នាក្នុងភស្តុតាងរបស់ ជា ឌៀប

1419.ខៀវ សំផន បានលើកឡើងនូវភាពពុំស៊ីសង្វាក់គ្នាជាច្រើនក្នុងភស្តុតាងរបស់ ជា ឌៀប ទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណរបស់គាត់ និងបានអះអាងថា លោកស្រីពុំបានលើកអំពីឈ្មោះរបស់គាត់ក្នុងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដំបូងរបស់លោកស្រី[4009]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា កិច្ចប្រជុំនៅវត្តខណ្ឌលោមនោះបានកើតឡើងនៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦ ដោយហេតុថា ភស្តុតាងរបស់ ជា ឌៀប បង្ហាញថា កិច្ចប្រជុំនៅបុរីកីឡាបានកើតឡើងនៅពេលដែល ហ៊ូ នឹម ត្រូវបានចាប់ខ្លួន ដែលពេលនោះគឺនៅក្នុងដើមឆ្នាំ ១៩៧៧[4010]។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ ជា ឌៀប ទាក់ទងទៅនឹងកិច្ចប្រជុំនៅបុរីកីឡាដើម្បីបង្ហាញការដឹងរបស់គាត់អំពីការចាប់ខ្លួន ហ៊ូ នឹម ក្នុងឆ្នាំ ១៩៧៧[4011]។

1420.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ជា ឌៀប ត្រូវបានសួរសំណួរយ៉ាងទូលំទូលាយក្នុងអំឡុងពេលនៃការជំនុំជម្រះស្ដីពីការដែលពុំបានលើកឡើងនូវឈ្មោះរបស់ ខៀវ សំផន និងបានពន្យល់ថា លោកស្រីពុំអាចចងចាំអ្នកដែលបានជួយលោកស្រីបំពេញសំណុំបែបបទដើមបណ្ដឹងរដ្ឋប្បវេណីលម្អិតនោះឡើយ[4012]។ ដោយពិចារណាលើអត្តចរិតជារួមរបស់លោកស្រី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា គួរជឿជាក់ និងទុកចិត្តបាន[4013]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ ជា ឌៀប ទាក់ទងទៅនឹងកិច្ចប្រជុំនៅវត្តខណ្ឌលោម មិនមែននៅបុរីកីឡាទេ[4014]។ សហព្រះរាជអាជ្ញាបានអះអាងថា ប្រសិនបើមានេះ នេះបានបង្ហាញនូវការយកចិត្តទុកដាក់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងប្រើប្រាស់ឆន្ទានុសិទ្ធិទទួលយក និងបដិសេធភស្តុតាងនោះ[4015]។

1421.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការដែលថា ជា ឌៀប ពុំបានលើកឈ្មោះ ខៀវ សំផន ក្នុងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីដំបូងរបស់លោកស្រី[4016]។ ដោយពិចារណាឃើញថា ភាគីមានឱកាសសួរ

---

[4009] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៤-១២៣៥។

[4010] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៧។

[4011] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៧។

[4012] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៣។

[4013] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៣។

[4014] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៤។

[4015] សារណាតបរបស់សហព្រះរាជអាជ្ញា (F45/1) ជើងទំព័រ ២៤៤៦។

[4016] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

ដេញដោល ជា ឌៀប ស្តីពីបញ្ហានេះ និងថា ភស្តុតាងរបស់គាត់អាចជឿទុកចិត្តបាន និងស៊ីសង្វាក់គ្នាទាំងស្រុង[4017] អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ការខកខានលើកឡើងនេះធ្វើឱ្យភស្តុតាងលោកស្រីទៅជាពុំអាចជឿទុកចិត្តបាននោះទេ។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងផ្តល់"ទម្ងន់ធ្ងន់ចំពោះព័ត៌មានចេញពីចម្លើយនៅក្នុងតុលាការ"[4018]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានគោលការណ៍បង្កើតឡើងត្រឹមត្រូវថា សក្ខីកម្មក្នុងតុលាការមានទម្ងន់ធ្ងន់ជាងចម្លើយក្រៅតុលាការ[4019]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតបន្ថែមទៀតថា ជា ឌៀប ត្រូវបានសួរដេញដោលដោយមេធាវីការពារក្តីលើមូលហេតុដូចម្តេចបានជាគាត់ពុំបានលើកឈ្មោះ ឌៀវ សំផន ក្នុងចម្លើយលើកដំបូងរបស់គាត់ និងបានអះអាងថា លោកស្រីពុំបានដឹងពីមូលហេតុនេះឡើយ[4020]។ ខៀវ សំផន ពុំយល់ស្របជាមួយការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភស្តុតាងនេះ និងពុំបានបង្ហាញនូវកំហុសណាមួយឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញផងដែរនូវភាពពុំស៊ីសង្វាក់គ្នាក្នុងការពន្យល់របស់ ជា ឌៀប សម្រាប់មូលហេតុដូចម្តេចបានជាពីដំបូងលោកស្រីពុំបានលើកឈ្មោះ ខៀវ សំផន។ ជា ឌៀប ត្រូវបានសួរដេញដោលនូវមូលហេតុដូចម្តេចបានជាលោកស្រីដឹងថា នោះគឺជា ខៀវ សំផន ដែលនិយាយលើវេទិកានោះ និងលោកស្រីបានអះអាងថា លោកស្រី"អាចចំណាំគាត់ច្បាស់"[4021]។ ទោះជាយ៉ាងណាក្តី បន្ទាប់មកភ្លាមនោះលោកស្រីបានបញ្ជាក់ថា លោកស្រីពុំដែលជួប ខៀវ សំផន ដោយផ្ទាល់ទេពីមុនមកទើបតែពេលនោះជាលើកទីមួយដែលលោកស្រីបានឃើញ ខៀវ សំផន ប៉ុន្តែបានរំពឹងទុកថា គាត់នឹងនៅទីនោះ និងក្រោយមកមានគេប្រាប់គាត់ថា នោះគឺ ខៀវ សំផន[4022]។ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវភាពពុំស៊ីសង្វាក់គ្នាដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណា និងដូច្នេះសារណារបស់គាត់ត្រូវបដិសេធចោល។

---

[4017] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

[4018] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

[4019] *សូមមើល* ឧទាហរណ៍ សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤៤៧។

[4020] ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៥០-៥៣។

[4021] ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៣៧។

[4022] ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៣៧-៣៨។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧០-៧១ ("ជួបគាត់នៅលើកទី១ ជួបនៅស្តាតបុរីកីឡា ជួបលើកទី១ ព្រោះកាលហ្នឹងខាងឆ្នាំ៧៥ [...] ហើយដល់លើកទី២ ខ្ញុំជួបនៅវត្តឧណ្ណាលោម។ អាហ្នឹងគាត់បើកសន្និបាតហ្នងសន្និបាតនារីយុវជនពេញមួយសាលាហ្នឹងហ្នង រយៈមួយថ្ងៃហ្នឹង")។

1422.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជា ឌៀប ពុំអាចចងចាំកាលបរិច្ឆេទពិតប្រាកដនៅពេលលោកស្រីបានជួប ខៀវ សំផន នៅវត្តឧណ្ណាលោម ប៉ុន្តែបានសន្និដ្ឋានថា ភស្តុតាងរបស់លោកស្រីបានបង្ហាញថា កិច្ចប្រជុំនោះបានកើតឡើង"ប្រហែលប្រាំមួយ ឬប្រាំពីរខែក្រោយការរំដោះទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥"[4023]។ នៅក្នុងការយោងទៅលើការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់សក្ខីកម្មរបស់ ជា ឌៀប ដែលថា គាត់បានជួប ខៀវ សំផន ពីរដង លើកទីមួយនៅបុរីកីឡា ឆ្នាំ ១៩៧៥ និងលើកទីពីរនៅវត្តឧណ្ណាលោម ព្រមទាំងភស្តុតាងរបស់គាត់ដែលថា លោកស្រីបានមកដល់ភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥ បានរៀបអាពាហ៍ពិពាហ៍ប្រាំមួយ ឬប្រាំពីរខែក្រោយពេលមកដល់ភ្នំពេញ និងបានជួប ខៀវ សំផន នៅមុនពេលការរៀបអាពាហ៍ពិពាហ៍របស់គាត់[4024]។ អាស្រ័យហេតុនេះ ភស្តុតាងដែលត្រូវបានយោងនោះពុំបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កិច្ចប្រជុំនៅវត្តឧណ្ណាលោមបានកើតឡើងប្រាំមួយ ឬប្រាំពីរខែក្រោយការមកដល់ទីក្រុងភ្នំពេញឡើយ ប៉ុន្តែផ្ទុយទៅវិញបានបង្ហាញកិច្ចប្រជុំនៅបុរីកីឡាថាបានកើតឡើងនៅក្នុងពេលនោះទៅវិញ។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញដោយបានសំអាងទៅលើផ្នែកដទៃទៀតនៃភស្តុតាងរបស់ ជា ឌៀប ថា កិច្ចប្រជុំនៅបុរីកីឡាបានកើតឡើងក្នុងខែ មេសា ឆ្នាំ ១៩៧៧ នៅពេលការចាប់ខ្លួន ហ៊ូ នឹម[4025]។

1423.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដំបូងឡើយ ជា ឌៀប បានអះអាងថា លោកស្រីបានឃើញ ខៀវ សំផន នៅបុរីកីឡា[4026] ប៉ុន្តែក្រោយមកបានបញ្ជាក់ថា កិច្ចប្រជុំលើកដំបូងគេកើតឡើងនៅវត្តឧណ្ណាលោម

---

[4023] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩។

[4024] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩ ជើងទំព័រ ១១៩៧៧ យោងទៅលើប្រតិចារឹកថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧០-៧១ ("ជួបគាត់នៅលើកទី១ ជួបនៅស្តាតបុរីកីឡា ជួបលើកទី ១ ព្រោះកាលហ្នឹងខាងឆ្នាំ៧៥ [...] ហើយដល់លើកទី២ ខ្ញុំជួបនៅវត្តឧណ្ណាលោម។ អាហ្នឹងគាត់បើកសន្និបាតហ្នងសន្និបាតនារីយុទ្ធជនពេញមួយសាលាហ្នឹងហ្នង រយៈមួយថ្ងៃហ្នឹង")។ ប្រតិចារឹក ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៣០-៣៣ (លើកឡើងថា គាត់បានចូលទីក្រុងភ្នំពេញនៅ ខែមេសា ឆ្នាំ១៩៧៥ គាត់រៀបការប្រហែល ៦ ឬ៧ខែក្រោយពេលទៅដល់ទីក្រុងភ្នំពេញ និងបញ្ជាក់ថា គាត់បានជួប ខៀវ សំផន មុនពេលគាត់រៀបការ)។

[4025] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៧ ("បន្ទាប់ពីការចាប់ខ្លួន ហ៊ូ នឹម នៅខែមេសា ឆ្នាំ១៩៧៧ ខៀវ សំផន បានអំពាវនាវជាសាធារណៈឱ្យស្តួរចម្លើយនីវសាររបស់គាត់ ។ ហ៊ូ នឹម ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ នៅខែ កក្កដា ឆ្នាំ១៩៧៧។ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីការចាប់ខ្លួននិងការស្លាប់របស់ ហ៊ូ នឹម នៅពេលនោះ") យោងទៅលើប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៥, ៥១-៥២។ *សូមមើលផងដែរ* ភស្តុតាងរបស់ ជា ឌៀប អំពីកិច្ចប្រជុំទាំងពីរដែលបានកើតឡើងក្នុងឆ្នាំ ១៩៧៥-១៩៧៦។

[4026] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧៦ (កិច្ចប្រជុំដំបូងនៅវត្តឧណ្ណាលោម និងទីពីរនៅបុរីកីឡា។ នេះគឺពេលដែល ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានកត់ទោស។ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា

និងបានអះអាងភស្តុតាងនេះជាដរាបមក[4027]។ លោកស្រីបានអះអាងជារឿយៗថា លោកស្រីបានមកដល់ភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥ បានរៀបអាពាហ៍ពិពាហ៍ប្រាំមួយ ឬប្រាំពីរខែក្រោយការមកដល់ភ្នំពេញ និងបានជួប ខៀវ សំផន នៅមុនពេលការរៀបអាពាហ៍ពិពាហ៍របស់លោកស្រី[4028]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាត្រឹមត្រូវនូវភស្តុតាងរបស់ ជា ឌៀប ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅពេលអង្គជំនុំជម្រះបានយល់ឃើញថា ភស្តុតាងរបស់លោកស្រីដែលថា កិច្ចប្រជុំនៅវត្តឧណ្ណាលោមបានកើតឡើងក្នុងឆ្នាំ ១៩៧៥ និងបានយោងតែទៅលើផ្នែកខ្លះនៃភស្តុតាងរបស់លោកស្រីប៉ុណ្ណោះ។ បើទោះបីជាជើងទំព័រពុំមានលក្ខណៈពេញលេញក៏ដោយ ក៏នេះពុំអាចបដិសេធការលើកឡើងត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសេចក្តីសង្ខេបនៃភស្តុតាងនេះ ហើយនេះអាចស្មើនឹងកំហុសនៃការយោងច្រើនជាងកត្តាសត្យានុម័ត។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងក្រោយមកក្នុងកថាខណ្ឌដដែលបានសង្កេតឃើញថា មាន"កិច្ចប្រជុំក្រោយមក" ជាមួយ ខៀវ សំផន និងបានយោងទៅលើកិច្ចប្រជុំបុរីកីឡា[4029]។ យោងតាមសំអាងនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសនោះឡើយ។

## គ) ការបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងដទៃទៀត

---

ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧០-៧១ បាននិយាយថា លើកដំបូងលោកស្រីបានជួបគាត់នៅវត្តឧណ្ណាលោម និងថា នោះនៅមុនពេលគាត់បានជួបនៅបុរីកីឡា។

[4027] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧៦-៧៧ អះអាងថា ដំបូងលោកស្រីបានឃើញកាត់នៅវត្តឧណ្ណាលោម និងលើកទីពីរនៅបុរីកីឡា។

[4028] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩ ជើងទំព័រ ១១៩៧៧ យោងទៅលើប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៧០-៧១ ("ជួបគាត់នៅលើកទី១ ជួបនៅស្តាតបុរីកីឡា ជួបលើកទី១ ព្រោះកាលហ្នឹងខាងឆ្នាំ៧៥ [...] ហើយដល់លើកទី២ ខ្ញុំជួបនៅវត្តឧណ្ណាលោម។ អាហ្នឹងគាត់បើកសន្និបាតហ្នងសន្និបាតនារីយុទ្ធជនពេញមួយសាលាហ្នឹងហ្នង រយៈមួយថ្ងៃហ្នឹង")។ ប្រតិចារឹក ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ៣០-៣៣ (លើកឡើងថា គាត់បានចូលទីក្រុងភ្នំពេញនៅ ខែមេសា ឆ្នាំ១៩៧៥ គាត់រៀបការប្រហែល ៦ ឬ៧ខែក្រោយពេលទៅដល់ទីក្រុងភ្នំពេញ និងបញ្ជាក់ថា គាត់បានជួប ខៀវ សំផន មុនពេលគាត់រៀបការ)។

[4029] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩ ("គាត់បានបញ្ជាក់បន្ថែមថា ចំណុចក្រោយនេះត្រូវបានលើកឡើងក្នុងវគ្គសិក្សា និងកិច្ចប្រជុំដែលលោកស្រីបានចូលរួម) យោងទៅលើប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៥១-៥២។

1424.អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាង រស់ ស៊ុយ ដែលបានផ្តល់ក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់គាត់ដែលថា កងនៅក្រសួងរបស់គាត់ត្រូវបានកំណត់ចំនួនអប្បបរមាប្រចាំខែនៃការរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨[4030]។

1425.ខៀវ សំផន បានលើកឡើងថា ចម្លើយជាលាយលក្ខណ៍អក្សររបស់ រស់ ស៊ុយ ពុំគប្បីសំអាងទៅលើដោយសារតម្លៃជាភស្តុតាងទាប ដែលពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា សេចក្តីណែនាំជាក់ស្តែងត្រូវបានអនុវត្ត និងពុំត្រូវបានបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងរបស់ ផាន់ ហ៊ីម បើទោះបីជាការពិតថា សាក្សីនេះបានធ្វើការក្នុងក្រសួងតែមួយក៏ដោយ[4031]។ គាត់បានចង្អុលបង្ហាញទៅលើបុគ្គលផ្សេងៗដែលក្នុងសារណារបស់គាត់ពុំបានបញ្ជាក់អះអាងបន្ថែមលើភស្តុតាងរបស់ ជា ឌៀប ដែលថា សេចក្តីណែនាំឱ្យបង្កើតកូនត្រូវបានលើកឡើងជារឿយៗនៅរាល់កិច្ចប្រជុំ[4032]។ ចុងក្រោយ គាត់បានអះអាងអំពីភាពផ្ទុយគ្នាដោយសារការពុំបានពិចារណាលើការបញ្ជាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបង្ហាញថា បុគ្គលវ័យក្មេងពុំត្រូវបានជម្រុញឱ្យរៀបអាពាហ៍ពិពាហ៍ឡើយ[4033]។

1426.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យសំអាងទៅលើភស្តុតាងក្រៅតុលាការដូចជាចម្លើយរបស់ រស់ ស៊ុយ និងថា ពុំមានកំហុសទាក់ទងនឹងបញ្ហានេះ[4034]។ សហព្រះរាជអាជ្ញាលើកឡើងថា ភស្តុតាងរបស់ ជា ឌៀប ពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាលរបស់ ខៀវ សំផន នៅវត្តឧណ្ណាលោម ត្រូវបានបញ្ជាក់អះអាងបន្ថែមក្នុងផ្នែកខ្លះដោយភស្តុតាងដទៃទៀត និងត្រូវបានវិភាគគ្រប់គ្រាន់ដោយអង្គជំនុំជម្រះសាលាដំបូង[4035]។

1427.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពុំបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដូច្នេះ អ្នកដែលពុំត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះសាលាដំបូង និងភាគី ជាទូទៅត្រូវបានផ្តល់តម្លៃជាភស្តុតាងទាបជាងភស្តុតាងរបស់សាក្សីបានផ្តល់សក្ខីកម្មចំពោះ

---

[4030] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០។

[4031] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៨, ១២៤០-១២៤១។

[4032] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤១ ជើងទំព័រ ២៣៥៥។

[4033] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៣៨។

[4034] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ២៤៤៩។

[4035] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១៤។

មុខអង្គជំនុំជម្រះ[4036]។ អង្គជំនុំជម្រះសាលាដំបូងបានឆ្លុះបញ្ចាំងត្រឹមត្រូវនូវក្តីបារម្ភអំពីតម្លៃជាភស្តុតាងនៃភស្តុតាងក្រៅតុលាការថា៖ "អង្គជំនុំជម្រះពិចារណាផងដែរលើការកំណត់អត្តសញ្ញាណ ការសួរដេញដោលភាពលម្អៀង ប្រភព និងការជម្រុញទឹកចិត្ត ឬកង្វះនោះរបស់អ្នកនិពន្ធ និងប្រភពនៃភស្តុតាង។ នត្ថិភាពនៃឱកាសសួរដេញដោលលើប្រភព ឬសាមីនៃភស្តុតាង ទម្ងន់តិចតួចអាចត្រូវបានផ្តល់ទៅឱ្យភស្តុតាងនោះ"[4037]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់ច្បាស់លាស់នូវភស្តុតាងថាជាភស្តុតាងក្រៅតុលាការក៏ដោយ ក៏អង្គជំនុំជម្រះបានសង្កេតឃើញថា ភស្តុតាងនោះ"ត្រូវបានផ្តល់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត" និងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានដឹងច្បាស់លាស់អំពីប្រភពនៃភស្តុតាងនៅពេលសំអាងទៅលើនោះ។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងវិធីសាស្ត្រជារួមរបស់អង្គជំនុំជម្រះសាលាដំបូងលើផ្នែកនេះនៃភស្តុតាងក្រៅតុលាការឡើយ[4038]។

1428.ជាបន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់ជាក់លាក់ទៅលើភស្តុតាងរបស់ រស់ ស៊ុយ ដែលផ្អែកតាម ខៀវ សំផន ពុំមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ និងត្រូវបានបដិសេធដោយភស្តុតាងដទៃទៀត។ នៅក្នុងផ្នែកនៃចម្លើយដែលត្រូវបានយោងដោយអង្គជំនុំជម្រះសាលាដំបូង[4039] រស់ ស៊ុយ បានអះអាងថា មានផែនការដែលតម្រូវឱ្យកងរបស់គាត់ដែលជាកងគ្រប់គ្រងឃ្លាំងរដ្ឋ ត្រូវរៀបការប្តីប្រពន្ធ ១០០ គូក្នុងមួយខែ[4040]។ គាត់បានអះអាងបន្ថែមទៀតថា ការរៀបអាពាហ៍ពិពាហ៍បានចាប់ផ្តើមក្នុងឆ្នាំ ១៩៧៦ និងថា វិធានការត្រូវបានអនុវត្តក្នុងឆ្នាំ ១៩៧៧ នៅពេលដែលមានប្តីប្រពន្ធ ១០០ គូត្រូវរៀបអាពាហ៍ពិពាហ៍ក្នុងមួយខែ[4041]។ រស់ ស៊ុយ បានពន្យល់ផងដែរថា បទបញ្ជាត្រូវបានចេញដោយប្រធានគ្រប់គ្រងក្រសួង និង

---

[4036] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៩៦។

[4037] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤។

[4038] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០។

[4039] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ ជើងទំព័រ ១១៩៨០។

[4040] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ ជើងទំព័រ ១១៩៨០ យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ERN 01115762-01115765 ទំព័រ ១២-១៤។

[4041] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ ជើងទំព័រ ១១៩៨០ យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ERN 01115762-01115765 ទំព័រ ១២-១៤។

ថា បទបញ្ញានេះបានកើតឡើងដោយសារ"គេចង់បង្កើនប្រជាជន"[4042]។ គាត់បានផ្តល់ភស្តុតាងជាក់លាក់បន្ថែមទាក់ទងទៅនឹងការអនុវត្តន៍គោលនយោបាយ រួមបញ្ចូលការសង្កេតដែលថា ចំនួនកំណត់ ១០០ គូ ពុំមែនមានន័យថា ប្តីប្រពន្ធទាំងអស់ចាំបាច់ត្រូវតែបានរៀបអាពាហ៍ពិពាហ៍ក្នុងពេលតែមួយនោះទេ ពិធីរៀបអាពាហ៍ពិពាហ៍អាចកើតឡើងរហូតដល់បីដងក្នុងមួយខែ[4043]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលថា ភស្តុតាងទាំងនេះពុំច្បាស់លាស់ ឬពុំជាក់លាក់។

1429.អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើអំណះអំណាងដែលថា ភស្តុតាងរបស់ រស់ ស៊ុយ ស្តីពីការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ គប្បីត្រូវបានយល់ឃើញថា បានប៉ះពាល់ដល់ភស្តុតាងរបស់គាត់ទាក់ទងទៅនឹងចំនួនកំណត់សម្រាប់ការរៀបអាពាហ៍ពិពាហ៍។ នៅក្នុងផ្នែកនៃភស្តុតាងដែលត្រូវបានគូសបង្ហាញដោយ ខៀវ សំផន គាត់បានអះអាងថា "កិច្ចប្រជុំត្រូវបានរៀបចំឡើងក្នុងបរិបទនៃការងារ និងប្រសិនបើបុរសស្រលាញ់នារីណាម្នាក់ គាត់សួរថាតើ នារីនោះយល់ព្រមរៀបការជាមួយ ដែរ ឬទេ"[4044]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របថា ភស្តុតាងនេះជាក់ស្តែងបញ្ជាក់ការពិតនៃគោលការណ៍ស្តីពីការយល់ព្រម ដូចបានបង្ហាញច្បាស់លាស់ថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបាន"រៀបចំ"ដោយរបបបក្សកុម្មុយនីស្តកម្ពុជា និងថា កម្មាភិបាលបុរសក្នុងរបបនោះមានឆន្ទានុសិទ្ធិខ្លះជ្រើសរើសប្រពន្ធ។ នេះស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[4045]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា បើទោះបីជា រស់ ស៊ុយ បានផ្តល់សក្ខីកម្មស្តីពីគោលការណ៍បក្សកុម្មុយនីស្តកម្ពុជានៃការយល់ព្រមក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ជារឿយៗនូវការសម្រេចអង្គជំនុំជម្រះសាលា

---

[4042] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ ជើងទំព័រ ១១៩៨០ យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ERN 01115762-01115765 ទំព័រ ១២-១៤។

[4043] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧០ ជើងទំព័រ ១១៩៨០ យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ERN 01115762-01115765 ទំព័រ ១២-១៤។

[4044] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ស/ធ៖ ៧៥, ៩៣។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារលេខ E3/10620 ស/ធ៖ ៧៥ ("អាយុរៀបអាពាហ៍ពិពាហ៍លើសពី ២០ ឆ្នាំ ឡើងទៅ") ស/ធ៖ ៩២, ស/ធ៖ ៩៣ (ស្ត្រីមានសិទ្ធិប្រកែក ឬទទួលយកការស្នើរៀបអាពាហ៍ពិពាហ៍")។

[4045] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៩១។

ដំបូងមិនពិចារណាលើភស្តុតាងកម្មាភិបាលស្តីពីបញ្ហាជាក់លាក់ នៅពេលសំអាងទៅលើផ្នែកដទៃទៀតនៃភស្តុតាងនោះ[4046]។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

1430.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហាថាតើ តាមការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើភាពពុំស៊ីសង្វាក់គ្នារវាងភស្តុតាងរបស់ ផាន់ ហ៊ឹម ដែលជាកម្មាភិបាលផងដែរក្នុងនាយកដ្ឋានពាណិជ្ជកម្ម និភស្តុតាងរបស់ រស់ ស៊ុយ ដែរ ឬយ៉ាងណា។ នៅក្នុងផ្នែកនៃភស្តុតាងដែលត្រូវបានគូសបញ្ជាក់ដោយ ខៀវ សំផន ផាន់ ហ៊ឹម បានអះអាងថា គាត់បានស្តាប់ឮដោយផ្ទាល់នូវការកំណត់ចំនួននៃការរៀបអាពាហ៍ពិពាហ៍ដែលបានកើតឡើង[4047]។ ទោះជាយ៉ាងណាក្តី លោកស្រីបានអះអាងថា លោកស្រីខ្លួនឯងត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយរបបនោះ និងបានបញ្ជាក់ពិធីរៀបអាពាហ៍ពិពាហ៍ក្នុងទ្រង់ទ្រាយធំបានកើតឡើង[4048]។ បន្ថែមលើនេះ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ផាន់ ហ៊ឹម ដែលបង្ហាញនូវការជាប់ពាក់ព័ន្ធពេញលេញនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងការរៀបចំ និងអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4049]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផាន់ ហ៊ឹម ពុំបានផ្តល់ភស្តុតាងដែលផ្ទុយពីភស្តុតាងរបស់ រស់ ស៊ុយ និងដូច្នេះ ពុំមានបញ្ហាផ្ទុយគ្នាបានកើតឡើងឡើយ។

1431.ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ពុំមានភាពផ្ទុយគ្នាណាមួយបានកើតឡើងក្នុងភស្តុតាងរបស់ ផាន់ ហ៊ឹម និង រស់ ស៊ុយ ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ណុប ធីម និង សេង សឿន ទាក់ទងទៅនឹងពិភាក្សាញឹកញាប់ស្តីពីការបង្កើនប្រជាជន។ បើទោះបីជា ជា ខៀប បានអះអាងថា សេចក្តីណែនាំបង្កើនប្រជាជនតាមរយៈការបង្កើតកូនបានកើតឡើង"នៅគ្រប់កិច្ចប្រជុំ"ក៏ដោយ[4050] ក៏នេះជា

---

[4046] *សូមមើល* ផ្នែក VII.ឆ.៣.ខ យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរនូវសារណារបស់ ខៀវ សំផន ដែលថា ភាពផ្ទុយកើតឡើងជាមួយនឹងភស្តុតាងរបស់ ប៊ិត ហឿន ស្តីពីគោលការណ៍យល់ព្រម *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២៣៤២។

[4047] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤១ ជើងទំព័រ ២៣៥២ យោងទៅលើប្រតិចារឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៦៨-៧៤។

[4048] *សូមមើល* ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៦៨-៧៤។

[4049] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១២១៤៨ យោងទៅលើប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៦៨, ទំព័រ ៧១-៧២ (ដោយបញ្ជាក់ថា នៅក្នុងពិធីរៀបការគាត់ រដ្ឋមន្ត្រីពាណិជ្ជកម្ម គឺ តា វិទ្ធ និងអនុរបស់គាត់ មេផ្ទាល់របស់គាត់ គឺតា ហុង និងប្រធានកងនារីពីរបីនាក់ បានចូលរួម)។

[4050] *សូមមើល* ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ (ជា ខៀប) ឯកសារលេខ E1/466.1 ទំព័រ ៧០។ ប្រតិចារឹកថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០១៦ (ផាន់ ហ៊ឹម) ឯកសារលេខ E1/467.1 ទំព័រ ៨៦។

ភស្តុតាងបង្ហាញដោយខ្លួនឯងថា លោកស្រីបានបញ្ជាក់ក្នុងគោលជំហរទូទៅមួយ ដែលពុំមែនអះអាងថា បានចូលរួម ឬមិនអាចចូលរួមរាល់កិច្ចប្រជុំនោះទេ។ ខៀវ សំផន ពុំបានផ្តល់ភស្តុតាងបង្ហាញថា បុគ្គលទាំងនេះមានវត្តមាននៅក្នុងកិច្ចប្រជុំជាក់លាក់ដែល ជា ឌៀប បានចូលរួម ដែលនេះគឺជាការយល់ឃើញតែមួយគត់ជាសក្សានុម័តសម្រាប់គោលបំណងនេះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅគ្រប់កាលៈទេសៈ ណុប ធីម បានសំដៅទៅលើបុគ្គលដែល"និយាយកំប្លែង"អំពីការបង្កើតកូន ដែលពិតប្រាកដណាស់គឺជាគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍[4051]។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

1432.ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណាថា ភស្តុតាងរបស់ ជា ឌៀប ត្រូវបានធ្វើឱ្យប៉ះពាល់ដោយការបញ្ជាក់ដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាដែលរារាំងការរៀបអាពាហ៍ពិពាហ៍បុគ្គលវ័យក្មេង។ បើទោះបីជាកម្មាភិបាលខ្លះបានអះអាងថា មានបំណងទុកឱ្យបុគ្គលនោះមានអាយុច្រើនជាងនេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើហេតុការណ៍ជាច្រើននៃស្ថានការណ៍ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលវ័យក្មេង[4052]។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

ឃ) ការយល់ឃើញទូទៅស្តីពីការសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប

1433.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងរបស់ ជា ឌៀប ធ្វើជាភស្តុតាងផ្ទាល់តែមួយគត់ដែលភ្ជាប់ ខៀវ សំផន ទៅនឹងបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបដិសេធការចោទប្រកាន់អំពីភាពពុំស៊ីសង្វាក់គ្នាក្នុងភស្តុតាងរបស់ ជា ឌៀប ព្រមទាំងលើបញ្ហានៃការបញ្ជាក់អះអាងបន្ថែម។ យោងតាមសំអាងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងថា ជាការសមហេតុផល។

## គ. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

[4051] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ធីម) ឯកសារលេខ E1/469.1 ទំព័រ ៥២។

[4052] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៣។

### i. សេចក្ដីផ្ដើម

1434.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ត្រឹមត្រូវនូវធាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀតដូចខាងក្រោម៖

១) "ធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានអំពើសកម្ម ឬអកម្មដែលបង្កព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស"[4053]។

២) "ធាតុផ្សំអត្តនោម័តិនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវថា អំពើសកម្ម ឬអកម្មត្រូវបានប្រព្រឹត្តឡើងដោយចេតនា"[4054]។

1435.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវបានបង្ហាញតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4055]។ ក្នុងការពិចារណាលើភាពធ្ងន់ធ្ងរនៃអំពើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលត្រូវបានបង្កឡើងលើបុគ្គលតាមរយៈការគំរាមកំហែងបង្ខំពួកគេឱ្យរៀបអាពាហ៍ពិពាហ៍ និងការពិតដែលថា ពួកគេត្រូវតែរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលពួកគេពុំដែលស្គាល់ និងការភិតភ័យដែលបានបង្កើតឡើងដើម្បីដាក់គំនាបលើពួកគេឱ្យរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍នោះ និងថា អំពើនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា[4056]។ ដោយហេតុថា អំពើនេះត្រូវបានប្រព្រឹត្តដោយចេតនា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានបង្ហាញ និងបានបំពេញតាមលក្ខខណ្ឌតម្រូវនៃអំពើអមនុស្សធម៌ដទៃទៀត[4057]។

1436.អង្គជំនុំជម្រះសាលាដំបូងបានរំឭកផងដែរនូវការយល់ឃើញរបស់ខ្លួនដែលថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ បុគ្គលត្រូវបានតាមដានដើម្បីឱ្យដឹងប្រាកដថា ពួកគេបានរួមភេទ[4058]។ អង្គជំនុំជម្រះសាលាដំបូង

[4053] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

[4054] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

[4055] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៤.៤.១។

[4056] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[4057] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៣។

[4058] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

បានយល់ឃើញថា ទាំងបុរស និងស្ត្រី មានអារម្មណ៍ថា ត្រូវបានគេបង្ខំឱ្យរួមភេទ[4059]។ អង្គជំនុំជម្រះបានយល់ឃើញផងដែរថា អំពើនោះជា"ការរំលោភសេពសន្ថវៈ"ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាស្ត្រីទាំងនោះ និងបានបង្កកាន់តែខ្លាំងឡើងនូវព្យសនកម្ម ឬការរងទុក្ខផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ[4060]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បើទោះបីជាបុរសពុំអាចប្រកែកមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ពុំមានភស្តុតាង"បង្ហាញច្បាស់លាស់ពាក់ព័ន្ធទៅនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់ទៅលើបុរសដែរ"[4061]។ អាស្រ័យហេតុនេះ បើទោះបីជាទទួលស្គាល់ថា បុរសត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទដែលផ្ទុយទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្កើតការយល់ឃើញមួយស្តីពីភាពធ្ងន់ធ្ងរនៃការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបុរសទាំងនោះបានទទួលរងដែរ[4062]។

1437.ខៀវ សំផន បានប្តឹងសាទុក្ខលើការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរងទុក្ខលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ត្រូវបានបង្ហាញសម្រាប់ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើសម្ពាធពីសង្គមក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានធ្វើការសន្និដ្ឋានជាទូទៅដោយផ្អែកលើរឿងក្តីជាក់លាក់ដែលពុំមានភាពជាតំណាងនៃភស្តុតាងទាំងអស់ឡើយ[4063]។

1438.សហព្រះរាជអាជ្ញាបានធ្វើបណ្តឹងសាទុក្ខលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងជនរងគ្រោះជាបុរសនៃការរួមដំណេកដោយបង្ខំ។

## ii. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1439.ខៀវ សំផន បានលើកការជំទាស់ជាច្រើនទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដំបូង គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញដែលបានបង្កើតឡើងស្តីពីធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានចង្អុលបង្ហាញទៅលើភាពខុសប្លែកគ្នាផ្នែកអង្គហេតុរវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀប

[4059] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4060] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧-៣៧០០។

[4061] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4062] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4063] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៦-១១៨៨។

អាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងការយល់ឃើញស្តីពីការមិនមែនជាការស្ម័គ្រចិត្ត[4064]។ ទីពីរ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើបរិបទនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំក្នុងការវាយតម្លៃរបស់ខ្លួនលើភាពធ្ងន់ធ្ងរ[4065]។ ទីបី គាត់បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរងទុក្ខធ្ងន់លើរូបកាយ ឬផ្លូវចិត្តដែលបានបង្កទៅលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ[4066]។ អំណះអំណាងនេះនឹងត្រូវពិចារណាតាមលំដាប់លំដោយខាងក្រោម។

*ធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

1440.ខៀវ សំផន បានជំទាស់ទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការកំណត់ធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងការយល់ឃើញដែល ខៀវ សំផន បានចង្អុលបង្ហាញថា ដោយបានពិចារណាលើអំណះអំណាងរបស់មេធាវីការពារក្តីដែលលើកផ្ទុយនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំតាមប្រពៃណីក្នុងវប្បធម៌កម្ពុជា គឺ"ខុសប្លែកយ៉ាងខ្លាំងពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[4067]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំក្នុងវប្បធម៌កម្ពុជានៅមុនកម្ពុជាប្រជាធិបតេយ្យ បានផ្អែកទៅលើទំនុកចិត្តទៅវិញទៅមករវាងឪពុកម្តាយ និងកូន និងជាទូទៅពុំបានរួមបញ្ចូលធាតុផ្សំនៃការបង្ខិតបង្ខំឡើយ[4068]។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា *អង្គការ* អាចដើរតួនាទីជំនួសឪពុកម្តាយ ឬនៅពីលើឪពុកម្តាយ[4069]។ ជាទូទៅ ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំពុំបានរួមបញ្ចូលធាតុផ្សំនៃការបង្ខំ និងថាតើ សម្ពាធពីសង្គមលើការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីបានធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពក្នុងការយល់ព្រមដោយសេរីដល់កម្រិតណា និងញឹកញាប់ប៉ុណ្ណា ពុំជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ក្នុងកិច្ចដំណើរការនីតិវិធីនេះឡើយ[4070]។ ជារួម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ពិបាកនឹងជឿថា វិធានការបដិវត្តទាំងអស់នោះអាចធៀបជាមួយទៅនឹងឥរិយាបទរបស់ឪពុកម្តាយ

---

[4064] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៣-១១៥៤។

[4065] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦០។

[4066] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៨៤។

[4067] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤។

[4068] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤។

[4069] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៩។

[4070] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤។

ចំពោះកូនៗ នៅក្នុងសង្គមខ្មែរប្រកាន់ប្រពៃណីនោះ”[4071]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរ ពាក់ព័ន្ធទៅនឹងបរិយាកាសបង្ខិតបង្ខំថា បុគ្គល“ត្រូវរៀបអាពាហ៍ពិពាហ៍នៅក្នុងបរិយាកាសភ័យខ្លាចរីករាលដាល ហើយការស្ម័គ្រចិត្តដែលសន្មតថា បានផ្តល់នៅមុនពិធី ឬនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ នៅក្នុងករណីភាគច្រើន មិនអាចស្មើទៅនឹងការស្ម័គ្រចិត្តពិតប្រាកដនោះទេ”[4072]។

1441.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនអំពីធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ លើលក្ខណៈខុសប្លែកគ្នាពុំត្រឹមត្រូវរវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំតាមប្រពៃណី[4073] និងលើភស្តុតាងបែប“សង្គមសាស្ត្រ” បង្ហាញដោយសាក្សីជំនាញ NAKAGAWA Kasumi[4074]។ គាត់បានជំទាស់ផងដែរទាក់ទងនឹងបញ្ហាអង្គហេតុថា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈខុសប្លែកគ្នានោះ[4075]។ នៅក្នុងសារណារបស់គាត់ សម្អាតពីសង្គមក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ មានលក្ខណៈដូចគ្នាទៅនឹងការយល់ឃើញដែលថា របបនោះបានកើតឡើងក្នុងបរិយាកាសបង្ខិតបង្ខំ[4076]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរក្នុងការយល់ឃើញថា ការស្ម័គ្រចិត្តដែលសន្មតថា បានផ្តល់ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ភាគច្រើន ពុំមែនជាការស្ម័គ្រចិត្តពិតប្រាកដ[4077]។ ជាថ្មីម្តងទៀត នេះពុំមែនជាការយល់ឃើញជាសត្យានុម័តត្រឹមត្រូវមួយ ដោយសារនេះគឺជាលក្ខខណ្ឌតម្រូវ“សម្រាប់ការកំណត់ចរិតលក្ខណៈនៃបទឧក្រិដ្ឋ និងការទទួលខុសត្រូវរបស់ ខៀវ សំផន” [4078] និងនៅគ្រប់កាលៈទេសៈ ជាការយល់ឃើញដែលពុំសមហេតុផលផ្អែកលើភស្តុតាងនោះ[4079]។

---

[4071] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៩។

[4072] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[4073] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៤។

[4074] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១២០។

[4075] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១២០។

[4076] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦០។

[4077] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[4078] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៤។

[4079] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

1442.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន មានកំហុសក្នុងការព្យាយាមបំប្លែងចូលគ្នានូវការរៀបអាពាហ៍ពិពាហ៍នៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដោយពុំពិចារណាលើកាលៈទេសៈបង្ខិតបង្ខំហួសហេតុដែលមានអត្ថិភាពនៅពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច[4080]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមថា "ពុំមានភស្តុតាងបង្ហាញថា ការយល់ព្រមដែលបានធ្វើឡើងស្របច្បាប់ចេញពី"ប្រព័ន្ធគ្រួសារដែលជាអ្នកបីបាច់ថែរក្សា និងមានដំណើរការ ត្រូវបានផ្តល់ដោយស្ម័គ្រចិត្តទៅឱ្យបក្សនោះទេ'"[4081]។

1443.សហមេធាវីនាំមុខបានអះអាងប្រហាក់ប្រហែលគ្នាថា ការបំប្លែងចូលគ្នានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាមួយនឹងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ គឺជាការអនុវត្តន៍ពុំត្រឹមត្រូវ[4082]។ សហមេធាវីនាំមុខបានលើកឡើងថា ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំ និងដោយបង្ខំ អាចត្រូវបានបែងចែកដាច់ដោយឡែកពីគ្នាតាមរយៈតួនាទីនៃការយល់ព្រម"ឬយ៉ាងហោចណាស់ ដោយការយល់ព្រមតាមរយៈការប្រគល់ការសម្រេចចិត្តទៅឱ្យសមាជិកគ្រួសារ" និងថា បក្សកុម្មុយនីស្តកម្ពុជាពុំមានសិទ្ធិអំណាចមកជំនួសតួនាទីឪពុកម្តាយរបស់គូស្រករបានឡើយ[4083]។ បន្ថែមលើនេះ ខៀវ សំផន ខកខានក្នុងការទទួលស្គាល់ថា បទបញ្ជារៀបអាពាហ៍ពិពាហ៍បានកើតឡើង"ជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ និងរីករាលដាលលើប្រជាជនស៊ីវិល"[4084]។ ចុងក្រោយ សហមេធាវីនាំមុខបានអះអាងថា "ភាពឃោរឃៅនៃរបប"រៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមបក្សកុម្មុយនីស្តកម្ពុជា បានធ្វើឱ្យអំពើនេះ"មានលក្ខណៈជ្រុលហួសហេតុលើសការប្រព្រឹត្តនានាដែលបានធ្វើឱ្យចារីសក្តានុពលជឿថា ជារឿងស្របច្បាប់"[4085]។

1444.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលបដិសេធនូវការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យបង្កើតការយល់ឃើញអំពីធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូចបានបញ្ជាក់ខាងលើ ពុំមានលក្ខខណ្ឌតម្រូវថា អំពើដែលត្រូវបានចោទប្រកាន់ថាជាផ្នែកនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតត្រូវតែបង្ហាញថា ជាបទឧក្រិដ្ឋឯករាជ្យមួយឡើយ។ អ្វីដែលសំខាន់គឺថាតើ ការប្រព្រឹត្ត

---

[4080] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៥, ៧២៣។

[4081] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨៥ ដកស្រង់សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៨។

[4082] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៥៦-៥៦១។

[4083] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៥៧។

[4084] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥២៥។

[4085] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៥៦០។

ដែលត្រូវបានចោទប្រកាន់នោះត្រូវបានរកឃើញថា មានអត្ថិភាព និងបានបំពេញតាមលក្ខខណ្ឌតម្រូវធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬទេ។ ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញជាសត្យានុម័តស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាបទឧក្រិដ្ឋមួយនោះ អង្គជំនុំជម្រះសាលាដំបូងមានកំហុស។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញសត្យានុម័តពាក់ព័ន្ធទៅនឹងលក្ខណៈខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬបរិយាកាសគ្មានការស្ម័គ្រចិត្តឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកត្រឹមត្រូវអំពីវិសាលភាពនៃការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ដូចបានគូសបង្ហាញក្នុងដីកាដំណោះស្រាយ[4086] និងបានសង្ខេបការយល់ឃើញស្នូលផ្នែកអង្គហេតុដែលបានបង្កើតឡើងជាការឆ្លើយតបទៅនឹងបទចោទទាំងនោះ[4087]។ ពាក់ព័ន្ធទៅនឹងលក្ខណៈខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ បញ្ហានេះត្រូវបានដោះស្រាយផងដែរក្នុងការឆ្លើយតបទៅនឹងអំណះអំណាងដែលត្រូវបានលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន នៅពេលសវនាការ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យបង្កើតការយល់ឃើញសត្យានុម័តស្តីពីអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងជាក់ស្តែងពុំបានធ្វើដូច្នោះឡើយ។

1445.ទីពីរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយសារហេតុផលមួយចំនួន សារណារបស់ ខៀវ សំផន ស្តីពីលក្ខណៈប្រហាក់ប្រហែលគ្នានៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំបានបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញនៃបណ្តឹងសាទុក្ខ ពីព្រោះលក្ខណៈខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ គឺជាការយល់ឃើញនៃអង្គហេតុដែលពុំមានផលប៉ះពាល់លើការដាក់ពិរុទ្ធភាពរបស់ ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភាពខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ ពីព្រោះមេធាវីការពារក្តីបានលើកឡើង ប៉ុន្តែពុំមែនដើម្បីបង្ហាញ "ធាតុផ្សំសត្យានុម័ត" នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ អាស្រ័យហេតុនេះ ពុំមានចំណុចដែលអាចប្តឹងសាទុក្ខបានឡើយ។

---

[4086] អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញបទចោទក្នុងដីកាដំណោះស្រាយ ដែលបានចោទប្រកាន់ថា បុគ្គលត្រូវបានបង្ខំឱ្យទទួលយកទំនាក់ទំនងសហព័ទ្ធក្នុងបរិយាកាសបង្ខិតបង្ខំ ការរៀបអាពាហ៍ពិពាហ៍បានកើតឡើងដោយគ្មានការជាប់ពាក់ព័ន្ធទៅនឹងប្រពៃណី និងជាសមូហភាព និងថា ទំនាក់ទំនងផ្លូវភេទដែលក្នុងគោលដៅបង្កើតកូន ត្រូវបានដាក់បង្ខំ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៦។

[4087] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០-៣៦៩១។

1446.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ខៀវ សំផន បានធ្វើការចោទប្រកាន់ដែលមានលក្ខណៈចម្រូងចម្រាសអំពីលក្ខណៈប្រហាក់ប្រហែលគ្នារវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងតាមការផ្សំផ្គុំ និងរំឭកបន្ថែមទៀតថា អង្គហេតុក្នុងរឿងក្តីបច្ចុប្បន្នមានលក្ខណៈខុសប្លែកគ្នាជាច្រើនចំណុច។ ដោយរំឭកថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការក្នុងការពិចារណា“បញ្ហាផ្លូវច្បាប់ដែលពុំនាំទៅរកការមោឃភាពសាលក្រម ប៉ុន្តែមានលក្ខណៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក.”[4088] អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងត្រូវពិចារណាជាសង្ខេបលើបញ្ហានេះ។

1447.ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ស្ថានការណ៍នៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំគឺប្រព្រឹត្តទៅ“ដោយគ្មានការរឹតត្បិត” ឬគ្មានការដាក់សម្ពាធពីសង្គមនោះទេ ប៉ុន្តែផ្ទុយទៅវិញបានយល់ឃើញថា សម្ពាធណាមួយពីសង្គមក្នុងបរិបទនោះ ពុំជាប់ពាក់ព័ន្ធសម្រាប់អង្គហេតុដែលត្រូវបានចោទប្រកាន់ក្នុងកិច្ចដំណើរការនីតិវិធីនេះឡើយ[4089]។ អាស្រ័យហេតុនេះ ខៀវ សំផន បានបំភ្លៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ បន្ថែមលើនេះ ភស្តុតាងដែល ខៀវ សំផន បានចង្អុលបង្ហាញទៅលើនោះ ពុំបានបង្ហាញថា មានការដាក់“សម្ពាធពីសង្គម”នៅមុនពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ឪពុកម្តាយបានជាប់ពាក់ព័ន្ធនៅក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីនៅមុនឆ្នាំ ១៩៧៥[4090] ប៉ុន្តែក្រោយមកត្រូវបានដើរតួនាទីជំនួសដោយរបបកម្ពុជាប្រជាធិបតេយ្យ[4091]។

1448.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាមានភស្តុតាងសន្និកសន្ធាប់នៃការដាក់សម្ពាធពីសង្គមក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក៏ដោយ ក៏នេះពុំអាចប្រៀបធៀបបានទៅនឹងការរៀប

---

[4088] សាលដីកាសំណុំរឿង ០០២/០១ (F36) ជើងទំព័រ ៣០៦១។

[4089] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៨។

[4090] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ២៤ (“នៅពេលនោះ យើង ...ត្រូវតែគោរពតាមការសម្រេចរបស់ឪពុកម្តាយ”)។ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារលេខ E1/305.1 ទំព័រ ៦២-៦៣ (ខ្ញុំគោរពតាមដំបូន្មានឪពុកម្តាយ”)។ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 ទំព័រ ៣៧ (បញ្ជាក់ថា មុនរបបខ្មែរក្រហម“ជីវិតកូនៗត្រូវបានសម្រេចដោយឪពុកម្តាយ”)។ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/473.1 ទំព័រ ១៨-១៩។

[4091] ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ (អ៊ុំ សុផានី) E1/252.1 ទំព័រ ១៧ (អះអាងថា ម្តាយក្មេកគាត់បានបង្ខំគាត់ឱ្យរៀបអាពាហ៍ពិពាហ៍ ឬត្រូវបានបំបែកដោយអង្គការ)។ ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ (កង អ៊ិត) ឯកសារលេខ E1/322.1 ទំព័រ ២៥ (ដោយពន្យល់ថា អង្គការជាអ្នករៀបចំការរៀបអាពាហ៍ពិពាហ៍នោះ)។

អាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ។ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងការអនុវត្តន៍ទាំងពីរនេះ។ ផ្នែកនៃការអនុវត្តន៍នេះទាក់ទងទៅនឹងកង្វះការអនុវត្តន៍តាមប្រពៃណីដូចបានគូសបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងដែលថា ឪពុកម្ដាយរបស់គូស្រករជាទូទៅពុំបានជាប់ពាក់ព័ន្ធនៅក្នុងការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយពិធីសែនព្រេនតាមលក្ខណៈប្រពៃណីត្រូវបានបោះបង់ចោល ហើយប្ដីប្រពន្ធជាច្រើនគូត្រូវបានរៀបអាពាហ៍ពិពាហ៍ក្នុងពេលតែមួយ[4092]។ ចៅក្រម Sebutinde ក្នុងមតិស្របដាច់ដោយឡែករបស់ខ្លួនក្នុងរឿងក្ដី AFRC នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ចំណុចនេះថា មានការខុសប្លែកគ្នាយ៉ាងសំខាន់រវាងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងតាមការរៀបចំ និងបានសង្កេតឃើញថា "ក្នុងអំឡុងពេលនៃដំណើរការទាំងមូលនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ឬពីមុនៗក្នុងពេលមានសន្តិភាព ការយល់ព្រម និងការចូលរួមរបស់ឪពុកម្ដាយ និងក្រុមគ្រួសារមានសារៈសំខាន់ ហើយចំណងនៃអាពាហ៍ពិពាហ៍នេះត្រូវបានបង្ហាញតាមរយៈពិធីប្រតិបត្តិតាមប្រពៃណី ឬសាសនា"[4093]។ ចៅក្រម Doherty ក្នុងមតិជំទាស់ក្នុងរឿងក្ដីតែមួយនេះ បានសង្កេតប្រហាក់ប្រហែលគ្នាថា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ"តម្រូវឱ្យមានការចូលរួម និងការយល់ព្រមពីគ្រួសារ និងចាស់ទុំរបស់កូនប្រុស និងកូនស្រី និងជាពិសេស ការយល់ព្រមពីគ្រួសាររបស់កូនស្រីព្រមទាំងការបំពេញតាមការប្រតិបត្តិនូវពិធីសែនព្រេនមួយចំនួនទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍"[4094]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ទាំងនេះគឺជាភាពខុសប្លែកគ្នាជាសំខាន់នោះ។

1449.អង្គជំនុំជម្រះតុលាការកំពូលពិចារណាបន្ថែមទៀតថា មានភាពខុសប្លែកគ្នាជាមូលដ្ឋានរវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាងការដែលគ្មានការប្រតិបត្តិតាមប្រពៃណី។ ក្នុងករណីជាច្រើន បុគ្គលពុំបានដឹងថា នរណាជាដៃគូរបស់ខ្លួននៅមុនពេលចូលដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍[4095]។ បន្ថែមលើនេះ ការរៀបអាពាហ៍ពិពាហ៍បានកើតឡើងក្នុងបរិយាកាសភ័យខ្លាចដែលរីករាលដាល ដែលក្នុងនោះលទ្ធភាពសម្រាប់ការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ ឬការរួមដំណេកនៃការ

[4092] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩១។

[4093] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *AFRC* (SCSL) មតិស្របដាច់ដោយឡែករបស់ចៅក្រម Hon. Justice Julia Sebutinde ដែលភ្ជាប់ជាមួយនឹងសាលក្រមដោយអនុលោមតាមវិធាន ៨៨ (គ) កថាខណ្ឌ ១១។

[4094] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *AFRC* (SCSL) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម Doherty ស្ដីពីបទចោទលេខ ៧ (ទាសភាពផ្លូវភេទ) និង ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ២៦។

[4095] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩១។

រៀបអាពាហ៍ពិពាហ៍ ត្រូវបានលុបលើដោយការគំរាមកំហែងជាដរាបអំពីព្យសនកម្មលើរូបកាយ[4096]។ ផ្អែកលើការយល់ឃើញទាំងនេះជារួម អង្គជំនុំជម្រះតុលាការកំពូលយល់ស្របទាំងស្រុងជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដែលថា ពិបាកនឹង"ជឿ"ថា សកម្មភាពរបស់របបកម្ពុជាប្រជាធិបតេយ្យអាចប្រៀបធៀបបានជាមួយនឹងឥរិយាបទរបស់ឪពុកម្ដាយចំពោះកូនរបស់ខ្លួនក្នុងសង្គមខ្មែរប្រតិបត្តិតាមប្រពៃណី[4097]។

1450.ជាបន្ទាប់នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញពាក់ព័ន្ធទៅនឹងការយល់ព្រមរបស់បុគ្គលនីមួយៗទៅនឹងការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយប្រុងប្រយ័ត្នលើកាលៈទេសៈដែលក្នុងនោះបុគ្គលបានយល់ព្រមជាផ្លូវការទៅនឹងការរៀបអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ការរៀបចំត្រូវបានធ្វើឡើងសម្រាប់ការរៀបអាពាហ៍ពិពាហ៍អតីតយុទ្ធជនពិការ[4098] និងថា បុគ្គលខ្លះបានអះអាងថា ពួកគេបាន"ប្រកែកការរៀបអាពាហ៍ពិពាហ៍នោះដោយគ្មានផលវិបាកប៉ះពាល់ឡើយ"[4099]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បើទោះបីជាអ្នកខ្លះអាចរៀបអាពាហ៍ពិពាហ៍ដោយពិតប្រាកដជាមួយបុគ្គលដែលខ្លួនបានជ្រើសរើស ឬអ្នកដែលត្រូវបានស្នើឱ្យពួកគេក៏ដោយ ក៏សាក្សីភាគច្រើនសន្និកសន្ធាប់ និងដើមបណ្ដឹងរដ្ឋប្បវេណីពុំមានជម្រើស ឬសិទ្ធិប្រកែកបានឡើយ[4100]។ បុគ្គលបានយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយសារភ័យខ្លាច រួមទាំងការភ័យខ្លាចដាក់ក្នុងកន្លែងគ្រោះថ្នាក់ ទទួលរងការចោទប្រកាន់ត្រូវបញ្ជូនទៅធ្វើការអប់រំ ផ្លាស់ទីទៅកន្លែងផ្សេង ឬត្រូវសម្លាប់[4101]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបានបដិសេធលើការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញទាំងនេះខាងលើ។ ដោយពិចារណាលើការយល់ឃើញទាំងនេះជារួម ការសន្និដ្ឋានដែលថា ការយល់ព្រមពុំអាចធ្វើទៅបាន"ក្នុងករណីភាគជាច្រើននោះ" គឺជាការឆ្លុះបញ្ចាំងនូវការយល់ឃើញត្រឹមត្រូវផ្អែកអង្គហេតុ។ អំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងផ្ទុយនោះត្រូវបដិសេធចោល។

- *ការពាក់ព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ជាមួយនឹងការវាយតម្លៃលើភាពធ្ងន់ធ្ងរ*

---

[4096] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩១។

[4097] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[4098] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៨៦។

[4099] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២៥។

[4100] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦១៩។

[4101] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦២០។

1451.ជាបន្ទាប់ ខៀវ សំផន បានលើកការជំទាស់ទៅនឹងយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី និងចោទប្រកាន់អង្គជំនុំជម្រះសាលាដំបូងថា បានចាត់ទុកជាផ្នែកនៃការវាយតម្លៃអំពីភាពធ្ងន់ធ្ងរ។ ខៀវ សំផន បានអះអាងថា ដើម្បីវាយតម្លៃសមស្របលើភាពធ្ងន់ធ្ងរនៃអំពើមួយជាការចាំបាច់ត្រូវពិចារណាលើបរិបទដែលអំពើត្រូវបានប្រព្រឹត្តឡើង ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងខកខានធ្វើដូច្នោះ[4102]។ អង្គជំនុំជម្រះសាលាដំបូងគប្បីយល់ឃើញថា ការអនុវត្តន៍នៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំក្នុងសង្គមកម្ពុជាដែលប្រតិបត្តិតាមប្រពៃណី មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលពុំសូវមានទុក្ខទោស[4103]។ អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាផងដែរនៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថា “ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ”ពុំមែនជាបទល្មើសក្នុងកម្ពុជា និងប្រទេសក្នុងទ្វីបអាស៊ី[4104] និងមានរដ្ឋជាច្រើនចង់ប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលជាងសម្រាប់ធ្វើជាវិធីសាស្ត្រក្នុងការដោះស្រាយ“ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ”[4105]។ ក្នុងអនុសញ្ញាអន្តរជាតិនៅតែពុំទាន់មានការចែងអំពីពិរុទ្ធភាពណាមួយនៃ“ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ”[4106]។

1452.សហព្រះរាជអាជ្ញាបានឆ្លើយតបថា “ភាពធ្ងន់ធ្ងរនៃអំពើត្រូវបានវាយតម្លៃផ្អែកលើករណីជាក់ស្តែង ខណៈពេលអង្គហេតុត្រូវបានវាយតម្លៃសម្រាប់ភាពធ្ងន់ធ្ងរជារួម”[4107] និងថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងជារួមអំពីភាពធ្ងន់ធ្ងរ“បានបង្ហាញច្បាស់លាស់ថា បុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបានទទួលរងការប៉ះទង្គិចផ្លូវចិត្ត និងផ្លូវកាយជាអត្ថិភាពយូរអង្វែង”[4108]។

[4102] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១២៦។

[4103] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៥៩-១១៦២។

[4104] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៩, ១១៣៣-១១៣៦។ ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១ F1.10/1 ទំព័រ ៣៣-៣៤។

[4105] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៣៨។

[4106] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៩-១១០៧, ១១៣១។

[4107] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៥។

[4108] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៦។

1453.សហមេធាវីនាំមុខបានអះអាងថា ខៀវ សំផន ពុំបានយោងទៅលើសំអាងផ្លូវច្បាប់សម្រាប់ការអះអាងដែលថា ធាតុផ្សំនៃភាពធ្ងន់ធ្ងរគប្បីវាយតម្លៃដោយយោងទៅលើរដ្ឋដែលអនុវត្តច្បាប់ជាតិ និងអន្តរជាតិ[4109]។

1454.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ការវាយតម្លៃលើការរងទុក្ខគប្បី"រួមបញ្ចូលបរិយាកាសនៃវប្បធម៌ដែលអំពើសកម្ម ឬអកម្មបានកើតឡើង និងផលប៉ះពាល់នៃអំពើនេះមានអត្ថិភាព"[4110]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបង្ហាញត្រឹមត្រូវនូវបទដ្ឋាននេះ ដោយបានបញ្ជាក់ថា បញ្ហានៃភាពធ្ងន់ធ្ងរនៃព្យសនកម្មនឹងត្រូវវាយតម្លៃផ្អែកលើករណីជាក់ស្តែងដោយពិចារណាលើលក្ខណៈនៃអំពើសកម្ម ឬអកម្ម បរិបទដែលអំពើនោះបានកើតឡើង និងកាលៈទេសៈផ្ទាល់ខ្លួនរបស់បុគ្គល[4111]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមយ៉ាងពេញលេញនូវបទដ្ឋាននេះ។ ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភាពខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងការយល់ឃើញរបស់ខ្លួនស្តីពីអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងការឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តីលើបញ្ហានេះពេលជំនុំជម្រះ[4112]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើលក្ខណៈខុសប្លែកគ្នារវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងតាមការផ្សំផ្គុំនៅពេលបង្កើតការយល់ឃើញទាក់ទងទៅនឹងភាពធ្ងន់ធ្ងរ និងបានយល់ឃើញថា សេចក្តីសន្និដ្ឋានដែលថា ជនរងគ្រោះត្រូវបានដាក់ឱ្យស្ថិតក្រោម"ការរើសអើង និងការធ្វើបាបធ្ងន់ធ្ងរ" មានន័យថា អំពើនោះពុំអាចប្រៀបធៀបបានជាមួយនឹងឥរិយាបទរបស់ឪពុកម្តាយចំពោះកូនក្នុងសង្គមខ្មែរដែលប្រកាន់ប្រពៃណី[4113]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់នូវបរិបទដែលអំពើល្មើសបានកើតឡើង ហើយ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការវាយតម្លៃនេះ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

1455.អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា នេះជាការលើកឡើងដោយគ្មានមូលដ្ឋានគាំទ្រដែលថា បទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជួនកាលអាចកាត់បន្ថយព្យសនកម្មដែលត្រូវបានបង្កឡើងតាមរ

[4109] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៦៦។

[4110] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម Doherty ស្តីពីបទចោទលេខ ៧ (ទាសភាពផ្លូវភេទ) និង ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៥៦។

[4111] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4112] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៧-៣៦៨៨។

[4113] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩១។

យៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។ ពិតណាស់ បរិបទនេះនឹងជួយបង្កើនការយល់ឃើញអំពីព្យសនកម្មធ្ងន់ធ្ងរ ជាជាងកាត់បន្ថយទៅវិញទេ។ សម្រាប់បុគ្គលដែលត្រូវបានបីបាច់ថែរក្សាក្នុងវប្បធម៌ដែលប្រតិបត្តិប្រពៃណីត្រឹមត្រូវដោយមានការជាប់ពាក់ព័ន្ធជាមួយគ្រួសារក្នុងការជ្រើសរើសដៃគូ និងការប្រតិបត្តិពិធីតាមប្រពៃណី បទពិសោធន៍នៃការបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ដោយគ្មានការធ្វើពិធីសែនព្រេននោះ អាចត្រូវបានសន្មតថា ជាការរងទុក្ខទោសជាពិសេស។

1456.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើការពិតដែលថា ប្រទេសដទៃទៀតនៅពុំទាន់ចាត់ទុកជាបទល្មើសនូវការប្រព្រឹត្តដែលគាត់បានពិពណ៌នាថា "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"។ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញដំបូងរបស់ខ្លួនថា ការលេចឡើងនៃបទដ្ឋានថ្មីជាក់លាក់ស្តីពីសិទ្ធិមនុស្ស"អាច"ប្រើប្រាស់ដើម្បីផ្តល់ការបញ្ជាក់អះអាងបន្ថែមនូវអនីត្យានុកូលភាពអន្តរជាតិនៃអំពើមុនៗ "និង"ត្រូវបានប្រើប្រាស់ធ្វើជារង្វាស់ក្នុងការវាយតម្លៃថាតើ អំពើដែលចោទជាបញ្ហានេះឈានដល់កម្រិតធ្ងន់ធ្ងរដែលជាលក្ខខណ្ឌតម្រូវ ដែរ ឬទេ[4114]។ ទោះជាយ៉ាងណាក្តី ការអនុវត្តន៍នេះពុំមានលក្ខណៈចាំបាច់ជាការវាយតម្លៃផ្លូវច្បាប់ឡើយ៖ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យធ្វើការវាយតម្លៃ និងដូច្នេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសទាក់ទងបញ្ហានេះត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ការអះអាងរបស់ ខៀវ សំផន ដែលថា ពុំមានលក្ខណៈជាបទល្មើសនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ គឺជាការភាន់ច្រឡំដោយសារគាត់បានទទួលស្គាល់ក្នុងពេលជំណាលគ្នាថា អំពើនេះមានលក្ខណៈជាបទល្មើស។ ជាឧទាហរណ៍ ខៀវ សំផន បានសង្កេតឃើញថា ការស្ម័គ្រចិត្តទៅវិញទៅមករវាងប្តីប្រពន្ធ ត្រូវបានបង្កប់ក្នុងគោលគំនិតដែលបង្ហាញក្នុងក្របខ័ណ្ឌច្បាប់កម្ពុជាតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣[4115] និងច្បាប់ឆ្នាំ ១៩៨៩ ស្តីពីការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ[4116]។ គាត់ក៏បានទទួលស្គាល់ផងដែរថា ប្រទេសជាច្រើនជាក់ស្តែងបានចាត់ទុកជាបទល្មើសនូវការរៀបអាពាហ៍ពិពាហ៍ដោយ

---

[4114] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៥។

[4115] រដ្ឋធម្មនុញ្ញកម្ពុជា ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ មាត្រា ៤៥(៣) ចែងថា ("ការរៀបអាពាហ៍ពិហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ")។

[4116] ច្បាប់ឆ្នាំ ១៩៨៩ ស្តីពីការរៀបអាពាហ៍ពិហ៍ និងគ្រួសារ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩។

បង្ខំ[4117] ព្រមទាំងអនុសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុបស្តីពីការរារាំង និងប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រី និងហិង្សាក្នុងគ្រួសារដែលរារាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ[4118]។

1457. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា នៅគ្រប់កាលៈទេសៈ អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានទទួលស្គាល់ច្រើនឡើងៗថា ជាការរំលោភបំពានលើបទដ្ឋានស្តីពីសិទ្ធិមនុស្ស។ សិទ្ធិគ្មានការបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ត្រូវបានចែងក្នុងលិខិតុបករណ៍ជាច្រើន[4119] និងតុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើនបានឆ្លុះបញ្ចាំងនូវរបត់នេះ។ អង្គបុរេជំនុំជម្រះ II នៃតុលាការ ICC បានបញ្ជាក់ក្នុងរឿងក្តី *Ongwen* ដោយបានពិចារណា*ក្នុងចំណោមទោះ*លើមាត្រាក្នុងសេចក្តីប្រកាសសកល UDHR ដែលត្រូវបានយោងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការគូសបង្ហាញនូវអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"បានរំលោភបំពានសិទ្ធជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ដោយឯករាជ្យក្នុងការរៀបអាពាហ៍ពិពាហ៍តាមការស្ម័គ្រចិត្ត និងបង្កើតគ្រួសារ។ សិទ្ធិជាមូលដ្ឋាននេះពិតណាស់គឺជាតម្លៃ(ខុសប្លែកពី*ខ.* បូរណភាពផ្លូវភេទ ឬរូបកាយ ឬសេរីភាពជាលក្ខណៈបុគ្គល) ដែលទាមទារការការពារតាមរយៈការបកស្រាយសមស្របលើមាត្រា ៧(១)(ង) នៃលក្ខន្តិកៈ"[4120]។ សារៈសំខាន់នៃសិទ្ធិជា

---

[4117] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៣៧ យោងទៅលើក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៥។ មាត្រា ២២២ (២) នៃក្រមព្រហ្មទណ្ឌន័រវេស ច្បាប់ឆ្នាំ ២០០៧ ។ ក្រមព្រហ្មទណ្ឌបែលហ្សិក ច្បាប់ទីមួយឆ្នាំ ២០០៥ និងទីពីរឆ្នាំ ២០១៣។ ក្រមព្រហ្មទណ្ឌសាធារណៈរដ្ឋបេនីន ច្បាប់ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១២។ មាត្រា ២១២ នៃក្រមព្រហ្មទណ្ឌស្វីស ច្បាប់ឆ្នាំ ២០១២។ មាត្រា ២២២ (១៤)(៤) នៃក្រមព្រហ្មទណ្ឌបារាំង ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៣។

[4118] មាត្រា ៣៧ នៃសន្និសញ្ញារបស់ក្រុមប្រឹក្សាអឺរ៉ុបស្តីពីការរារាំង និងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និងគ្រួសារ *ចូលជាធរមាន*នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤។

[4119] *សូមមើល* មាត្រា ២៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ មាត្រា ១០(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ("ICESCR") *ចូលជាធរមាន* ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារលេខ 993 U.N.T.S. 3 ។ សេចក្តីអធិប្បាយទូទៅលេខ ២៨ ឯកសារលេខ HRI/GEN/1/Rev.9 ភាគ I ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០០។ មាត្រា ១(១) នៃអនុសញ្ញាស្តីពីការយល់ព្រមទៅនឹងការរៀបអាពាហ៍ពិពាហ៍។ មាត្រា ១៦(១)(ខ) នៃអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងលើស្ត្រី ("CEDAW")។ មាត្រា ៦(២) នៃសេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើង។ មាត្រា ៦ នៃពិធីការស្តីពីសិទ្ធិស្ត្រីក្នុងទ្វីបអាហ្វ្រិក ("ACHPR") *ចូលជាធរមាន*ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥។ មាត្រា ១៩(១) នៃសេចក្តីប្រកាស Cairo ស្តីពីសិទ្ធិមនុស្សក្នុងរដ្ឋអ៊ីស្លាម*ចូលជាធរមាន*ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩០ A/CONF.157/PC/62/Add.18។ មាត្រា ១៧-៣ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ("ACHR") *ចូលជាធរមាន*ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨។ មាត្រា ៨ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR")។ ពិធីការលេខ ៧ ទៅនឹងមាត្រា ៥ នៃអនុសញ្ញាអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន *ចូលជាធរមាន* ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨។

[4120] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ៩៤។

មូលដ្ឋាននេះត្រូវបានគូសបង្ហាញសាជាថ្មីដោយអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដីដែលថា៖ "បុគ្គលគ្រប់រូបមានសិទ្ធិជាសារវ័ន្តក្នុងការរៀបអាពាហ៍ពិពាហ៍តាមការយល់ព្រមដោយសេរី និងពេញលេញជាមួយបុគ្គលដទៃទៀត។ ការរៀបអាពាហ៍ពិពាហ៍បង្កើតឋានៈដែលបានផ្អែកលើទំនាក់ទំនងតាមការស្ម័គ្រចិត្ត និងតាមកិច្ចសន្យា ដែលនេះគឺជាស្ថាប័ន និងជាសកម្មភាព ឬក៏ទំនៀមទម្លាប់"[4121]។ អង្គបុរេជំនុំជម្រះ I នៃតុលាការ ICC បានបញ្ជាក់ក្នុងរឿងក្ដី *Al Hassan* ថា "អត្ថប្រយោជន៍ដែលត្រូវបានការពារតាមរយៈលក្ខណៈឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានឆ្លើយតបជាពិសេសទៅនឹងការរំលោភបំពានលើសិទ្ធិនៃការរៀបអាពាហ៍ពិពាហ៍ក្នុងការជ្រើសរើសគូស្រករ និងបង្កើតគ្រួសារតាមការយល់ព្រម ដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិស្ដីពីសិទ្ធិមនុស្ស"[4122]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បទដ្ឋានថ្មីជាក់លាក់ជាងនេះ បានគាំទ្របន្ថែមទៀតលើការសន្និដ្ឋានដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាអំពើធ្ងន់ធ្ងរហួសហេតុ។

- *ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត*

1458.អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្សេងៗនៃអង្គហេតុស្ដីពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4123]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មទាក់ទងទៅនឹង"បទពិសោធន៍គួរឱ្យរន្ធត់ និងអារម្មណ៍អវិជ្ជមាន" នៅពេលដែលពួកគេបានដឹងថា ត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនពុំដែលស្គាល់[4124]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បុគ្គលជាច្រើនបានសម្រក់ទឹកភ្នែក និងសោកសៅ ខកចិត្ត និងភ័យព្រួយក្នុងអំឡុងពេលនៃពិធីរៀបអាពាហ៍ពិពាហ៍[4125]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ផងដែរថា ជនរងគ្រោះដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍បានពិពណ៌នានូវការលំបាកនៃការរៀបអាពាហ៍ពិពាហ៍ខណៈពេលកំពុងមានសោកសៅដោយសារបាត់បង់ដៃគូរបស់ខ្លួន[4126]។ ជនរងគ្រោះមានការសោកស្ដាយដោយសារការរៀប

---

[4121] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *Ongwen* (ICC) កថាខណ្ឌ ២៧៤៨។

[4122] សេចក្ដីសម្រេចស្ដីពីការបញ្ជាក់បទចោទរឿងក្ដី *Al Hassan* (ICC) កថាខណ្ឌ ៥៥៤: "អត្ថប្រយោជន៍ដែលត្រូវបានការពារដោយភាពឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានឆ្លើយតបជាពិសេសទៅនឹងការរំលោភបំពានលើសិទ្ធិរៀបអាពាហ៍ពិពាហ៍ ជ្រើសរើសគូស្រករ បង្កើតគ្រួសារ តាមគោលការណ៍ស្ម័គ្រចិត្ត ដែលត្រូវបានទទួលស្គាល់ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។

[4123] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩-៣៦៨២។

[4124] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩។

[4125] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩។

[4126] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨០។

អាពាហ៍ពិពាហ៍របស់ខ្លួនពុំត្រូវបានធ្វើឡើងតាមប្រពៃណី និងអវត្តមាននៃការចូលរួមពីឪពុកម្ដាយ និងសមាជិកគ្រួសារ បានធ្វើឱ្យជនរងគ្រោះជាច្រើនមានវិប្បដិសារី ការខកចិត្ត និងអារម្មណ៍ឈឺចាប់[4127]។ បទពិសោធន៍នេះមានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ ហើយការប៉ះពាល់នោះនៅតែតាមយាយីពួកគាត់រហូតដល់សព្វថ្ងៃ[4128]។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផងដែរស្ដីពីផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំ[4129]។

1459.នៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អំពើដែលត្រូវបានពិពណ៌នាថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើង និងបានបង្កនូវការរងទុក្ខលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដែលមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4130]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបានបង្កឡើងលើបុគ្គលតាមរយៈការគំរាមកំហែងបង្ខិតបង្ខំពួកគេឱ្យរៀបអាពាហ៍ពិពាហ៍ និងលើការពិតដែលថា ពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលពួកគេពុំដែលស្គាល់ និងការភ័យខ្លាចបង្កឡើងដើម្បីដាក់សម្ពាធលើពួកគេឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងការដែលថា អំពើនោះត្រូវបានប្រព្រឹត្តឡើងដោយចេតនា[4131]។ អង្គជំនុំជម្រះបានពិចារណាឃើញថា ភាពធ្ងន់ធ្ងរនៃការរងទុក្ខផ្លូវចិត្តដែលបង្កឡើងតាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងបរិយាកាសបង្ខិតបង្ខំ បានបង្កឱ្យមានព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរដែលមានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ[4132]។

1460.ខៀវ សំផន បានលើកការជំទាស់ជាច្រើនទៅនឹងភស្តុតាងរបស់សាក្សី ២៣ នាក់ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការយល់ឃើញផ្នែកអង្គហេតុរបស់ខ្លួនស្ដីពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4133]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការ

[4127] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4128] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨២។

[4129] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ។ ៣៦៨៣-៣៦៨៥។

[4130] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[4131] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[4132] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[4133] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩-៣៦៨២ និងជើងទំព័រ ១២២៧៤-១២២៨៧ យោងទៅលើ ជាំង ស្រីមុំ, ជា ឡៀប, អែម អឿន, ខែត សុខន, ឃិន វ៉ាត, កុល ណែម, យី ឡៃស្រូវ, មុំ វុន, ង៉ែត ចាត, ណុប ងឹម, មាស សាវ៉

ជំទាស់នេះគឺផ្តោតទៅលើភស្តុតាងជាផ្នែកៗ និងបំភ្លៃការពិត និងថា ខៀវ សំផន ពុំមានចេតនាពន្យល់នូវកំហុសនីមួយៗនោះដែលនាំឱ្យសាលក្រមមោឃៈឡើយ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បទដ្ឋាននៃការពិនិត្យឡើងវិញ គឺដើម្បីបង្ហាញនូវ"ភាពសមហេតុផលក្នុងការពិនិត្យឡើងវិញលើការយល់ឃើញផ្នែកអង្គហេតុដែលរងការជំទាស់ ពុំមែនដើម្បីបង្ហាញថាតើ ការយល់ឃើញនោះត្រូវ ឬខុសនោះទេ"[4134]។ បន្ថែមលើនេះ កំហុសផ្នែកអង្គហេតុត្រឹមតែបណ្តាលឱ្យមានភាពមិនយុត្តិធម៌ប៉ុណ្ណោះ ប្រសិនបើ"កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនោះមានវិមតិសង្ស័យទាក់ទងទៅនឹងពិរុទ្ធភាពជនជាប់ចោទ"[4135]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងរបស់ ខៀវ សំផន បានផ្តោតទៅលើការចោទប្រកាន់កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង: (១) ការសំអាងទូទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី (២) ការយល់ឃើញស្តីពីកង្វះនៃប្រពៃណី (៣) ការខកខានក្នុងការពិចារណាលើព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្ត ជាជាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (៤) ការខកខានក្នុងការពិចារណាលើការបង្កើតមនោសញ្ចេតនាក្នុងអំឡុងពេលនៃការរៀបអាពាហ៍ពិពាហ៍ (៥) ការយល់ឃើញស្តីពីភាពអាចជឿទុកចិត្តបាន និង (៦) ការសំអាងទៅលើភស្តុតាងរបស់ ស៊ូ សុធាវី។

ក) បទដ្ឋានសម្រាប់ការវាយតម្លៃព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ

1461.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដើម្បីឱ្យស្មើទៅនឹងអំពើអមនុស្សធម៌ដទៃទៀត អំពើសកម្ម ឬអកម្មត្រូវតែមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4136]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការវាយតម្លៃនេះតម្រូវឱ្យមានការវិភាគតាមករណីជាក់ស្តែងផលប៉ះពាល់នៃអំពើទៅលើជនរងគ្រោះ និងការកំណត់នូវបញ្ហាថាតើ អំពើនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា[4137]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការវាយតម្លៃគប្បីធ្វើឡើង"ជារួម"

---

ន, អ៊ុំ យឿន, ប៉ែន សុចាន់, ប៉ូ ឌីណា, ព្រាប សុខឿន, សយ ណារឿន, ស៊ូ សុធាវី, សុំ ប៉ែត, សួន យឹម, វ៉ា លឹមហ៊ាន់, យស ផល, Peg LEVINE និង NAKAGAWA Kasumi។

[4134] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨ ដកស្រង់ និងយោងទៅលើសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧។

[4135] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨ យោងទៅលើសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧។

[4136] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៤៣៨-៤៣៩។

[4137] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

និងអាចពិចារណាលើលក្ខណៈនៃអំពើសកម្ម ឬអកម្ម និងបរិបទដែលអំពើនោះបានកើតឡើង និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ[4138]។ ពុំមានលក្ខខណ្ឌតម្រូវថា ការរងទុក្ខត្រូវមានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ បើទោះបីជានេះអាចជាប់ពាក់ព័ន្ធទៅនឹងការកំណត់នូវភាពធ្ងន់ធ្ងរនៃអំពើសកម្ម ឬអកម្មដែលចោទជាបញ្ហានោះ[4139]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកនូវការយល់ឃើញរបស់ខ្លួនផងដែរក្នុងសំណុំរឿង ០០២/០១ ដែលថា ពុំមែនអំពើទាំងអស់សុទ្ធតែបំពេញតាមលក្ខណៈតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតនោះទេ[4140] និងថា បទដ្ឋាននេះត្រូវបានអនុវត្ត"យ៉ាងតឹងរ៉ឹង"ដោយតុលាការអន្តរជាតិ និងតុលាការព្រហ្មទណ្ឌដទៃទៀត[4141]។ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ការហាមឃាត់មិនឱ្យចាកចេញពីប្រទេស និងការដកហូតយកដោយបង្ខំនូវទ្រព្យសម្បត្តិឯកជនសម្រាប់គោលបំណងយោធាត្រូវបានរកឃើញថា ជាអំពើដែលពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់នៃភាពធ្ងន់ធ្ងរ[4142]។ សូម្បីអំពើដែលបង្កព្យសនកម្មលើរូបកាយ ដូចជាការវាយដំ ពុំអាចបង្ហាញនូវព្យសនកម្មចាំបាច់៖ នេះត្រូវតែបានពិចារណាផ្អែកលើករណីជាក់ស្ដែង[4143]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាបទដ្ឋាននេះខាងក្រោម។

1462.បើទោះបីជាព្យសនកម្មត្រូវបានពិចារណាដោយអត្តនោម័តក៏ដោយ ក៏អំពើនៃការរួមភេទដោយបង្ខំដែលត្រូវបានបង្ហាញ និងតាមធម្មតាត្រូវបានចោទប្រកាន់ថាជាបទឧក្រិដ្ឋនៃ"ការរំលោភសេពសន្ថវៈ" ជាញឹកញាប់ត្រូវបានសន្មតថា បានបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរ។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានអនុម័តតាមការសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃ ICTY ក្នុងរឿងក្ដី *Kunarac និងជនជាប់ចោទដទៃទៀត* ដែលថា "អំពើមួយចំនួនបានបង្ហាញឱ្យឃើញនូវការឈឺចាប់របស់ជនរងគ្រោះដែលបានទទួលរងនោះ។ ការរំលោភសេពសន្ថវៈជាក់ស្ដែងគឺជាអំពើបែបនេះ"[4144]។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC ក្នុងរឿងក្ដី

[4138] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4139] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4140] សាលដីការឿងក្ដី *Lukić និង Lukić* (ICTY) កថាខណ្ឌ ៦៣៤ ("សាលដីកាបានពិចារណាថា ពុំមែនរាល់អំពើដែលប្រព្រឹត្តក្នុងមន្ទីរឃុំឃាំង អាចត្រូវបានសន្មតថា បានបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរនោះទេ [...]")។

[4141] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨១។

[4142] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨១។

[4143] សាលដីការឿងក្ដី *Lukić និង Lukić* (ICTY) កថាខណ្ឌ ៦៣៤។

[4144] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០៨។ អង្គជំនុំជម្រះតុលាការកំពូលសង្កេត ប៉ុន្តែពុំបានទទួលស្គាល់ការយល់ឃើញដាច់ដោយឡែកស្ដីពីការរំលោភសេពសន្ថវៈនៃអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី Stakić នៃតុលាការ ICTY ដែលបានបញ្ជាក់ថា ការរំលោភសេពសន្ថវៈគឺជាបទល្មើសដ៏អាក្រក់សម្រាប់ស្ត្រី។ *សូមមើល* សាលក្រមរឿងក្ដី Stakić (ICTY) កថាខណ្ឌ

*Bemba* បានយល់ឃើញផងដែរថា "ការឈឺចាប់ និងការរងទុក្ខធ្ងន់ធ្ងរ" គឺជា"ធាតុផ្សំសត្យានុម័តជាក់លាក់នៃអំពើរំលោភសេពសន្ថវៈ"[4145]។ រឿងក្ដីដទៃទៀតបានពង្រីកដល់អំពើហិង្សាផ្លូវភេទទូលំទូលាយជាងនេះ។ ក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានប្រកាសថា "ការរំលោភសេពសន្ថវៈ និងហិង្សាផ្លូវភេទពិតណាស់គឺជាការបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្តលើជនរងគ្រោះ និងជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដ៏អាក្រក់ក្នុងការបង្កព្យសនកម្មលើជនរងគ្រោះដោយសារជនរងគ្រោះបានទទួលរងព្យសនកម្មលើរូបកាយ និងផ្លូវចិត្ត"[4146]។ ប្រហាក់ប្រហែលគ្នានេះដែរ ក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kunarac* អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា "ហិង្សាផ្លូវភេទជាចាំបាច់ឈានដល់កម្រិតនៃការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរចំពោះរូបកាយ ឬផ្លូវចិត្ត និងតាមលក្ខណៈអាចធ្វើយុត្តិកម្មនៃការកំណត់ចរិតលក្ខណៈថា ជាអំពើនៃការធ្វើទារុណកម្ម"[4147]។ ក្នុងរឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានយល់ឃើញថា ការរំលោភបំពានផ្លូវភេទ ដែលអ្នកជាប់ឃុំបុរសប្រាំនាក់បានទទួលរងនៅពេលទាហានបានបង្ខំឱ្យពួកគេរួមភេទគ្នាតាមមាត់ "បានបង្កការរងទុក្ខផ្លូវចិត្តធ្ងន់ធ្ងរ និងបង្កការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់ពួកគេ" ដែលគ្រប់គ្រាន់សម្រាប់បង្ហាញនូវឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ និងការធ្វើទុក្ខបុកម្នេញ[4148]។ ភាពធ្ងន់ធ្ងរនៃអំពើហិង្សាផ្លូវភេទក្នុងរឿងក្ដី *Prlić* ពុំត្រូវបានជំទាស់ ហើយអង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងជាក់លាក់នៃព្យសនកម្មក្នុងការគាំទ្រការយល់ឃើញរបស់ខ្លួនអំពី"ការរងទុក្ខផ្លូវចិត្តធ្ងន់ធ្ងរ"។

### ខ) ការសំអាងទៅលើភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

1463.ខៀវ សំផន បានលើកឡើងដោយមានជើងទំព័រយោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការអនុវត្តន៍ត្រឹមត្រូវលើវិធីសាស្ត្រសម្រាប់ការវាយ

---

៨០៣ ("សម្រាប់ស្ត្រី ការរំលោភសេពសន្ថវៈគឺជាបទល្មើសអាក្រក់បំផុត ជួនកាលអាក្រក់ជាងការស្លាប់ទៅទៀតដោយសារវានាំមកឱ្យមានការអាម៉ាស់")។

[4145] សេចក្ដីសម្រេចក្នុងរឿងក្ដី *Bemba* អនុលោតាមមាត្រា ៦១(៧)(ក) និង(ខ) (ICC) កថាខណ្ឌ ២០៤។

[4146] សាលក្រមរឿងក្ដី *Akayesu* (ICTR) កថាខណ្ឌ ៧៣១ (សេចក្ដីបញ្ជាក់បន្ថែម) (បញ្ជាក់ថា អំពើនៃការរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃហិង្សាផ្លូវភេទ ដែលរួមបញ្ចូលហេតុការណ៍នៃការបង្ខំឱ្យដោះសម្លៀកបំពាក់នៅសាធារណៈ គឺជាអំពើប្រល័យពូជសាសន៍)។

[4147] សាលដីការឿងក្ដី*Kunarac និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១៥០។

[4148] សាលក្រមរឿងក្ដី *Prlić និងជនជាប់ចោទដទៃទៀត* កថាខណ្ឌ ៧៧០។

តម្លៃលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[4149]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើ"ដំណើររឿង"ដែលនិយាយប្រាប់ដោយដើមបណ្តឹងរដ្ឋប្បវេណីដែលនេះ"ត្រូវបានជ្រើសរើសផ្នែកដែលឈឺចាប់ជាពិសេស" និងពុំបានតំណាងតាមស្ថិតិឱ្យភាគច្រើននៃបទពិសោធន៍របស់បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ក្រោមរបបនោះទេ[4150]។

1464.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលបង្កើតការយល់ឃើញផ្នែកអង្គហេតុ[4151]។ សហព្រះរាជអាជ្ញាបានអះអាងថា ការជំទាស់របស់ ខៀវ សំផន ដែលបានអះអាងអំពី"ស្ថិតិ"ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី "បានផ្អែកលើការសន្មតពុំត្រឹមត្រូវជាច្រើន និងមានកំហុសដែលមោឃភាពរាល់សេចក្តីសន្និដ្ឋានដែលគាំទ្រដោយស្ថិតិនោះ"[4152]។ តាមរយៈឧទាហរណ៍ សហព្រះរាជអាជ្ញាបានលើកឡើងថា បុគ្គលជាច្រើននាក់ដែល ខៀវ សំផន បានកំណត់ប្រភេទថា "បានយល់ព្រម"ទៅនឹងការរៀបអាពាហ៍ពិពាហ៍ ជាក់ស្តែងពុំបានយល់ព្រមឡើយ[4153]។

1465.សហមេធាវីនាំមុខបានជំទាស់ប្រហាក់ប្រហែលគ្នាដែរទៅនឹងវិធីសាស្ត្ររបស់ ខៀវ សំផន ផ្អែកតាម"ស្ថិតិ" ថា មាន"កំហុសជាមូលដ្ឋាន"[4154]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនៅក្នុងផ្នែកនៃការជំនុំជម្រះស្តីពីការរៀបអាពាហ៍ពិពាហ៍ ត្រូវបានសួរសំណួរផ្ទាល់ និងយ៉ាងទូលំទូលាយអំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ចំណែកការសួរសំណួរ ឬការបញ្ជាក់លើបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ក្នុងផ្នែកដទៃទៀតនៃការជំនុំជម្រះប្រៀបធៀបទៅមានកម្រិតតិចតួច។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងផងដែរថា ភស្តុតាងដាក់បន្ទុកទូលំទូលាយដែលទទួលបានក្នុងអំឡុងពេលនៃការជំនុំជម្រះផ្នែកការរៀបអាពាហ៍ពិពាហ៍ "គឺជាលទ្ធ

---

[4149] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៦៥។

[4150] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៦។

[4151] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៣។

[4152] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩២។

[4153] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៩៣។

[4154] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៩២។

ផលមួយផ្នែកចេញពីការសម្រេចរបស់មេធាវីការពារក្តីដែលពុំបានសួរអំពីប្រភពឯកសារដោះបន្ទុក" និងការតាំងសំណួរទៅលើអ្នកជំនាញសាក្សីតែម្នាក់ប៉ុណ្ណោះ[4155]។

1466.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅពេលអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបំភ្លឺក្នុងជើងទំព័រនៃការយល់ឃើញជាក់លាក់ដែលថា "បទពិសោធន៍មានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ និងនៅតែតាមយាយីជនរងគ្រោះដល់សព្វថ្ងៃនេះ"ក៏ដោយ[4156] ក៏នេះគឺជាការលើកឡើងសង្ខេបនៅចុងបញ្ចប់ផ្នែកដែលមានលក្ខណៈទូលំទូលាយ និងមានចំណងជើងថា "ផលប៉ះពាល់នៃ'ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ'"ដែលបានរៀបរាប់លម្អិតនូវព្យសនកម្មដែលបានបង្កទៅលើដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើននាក់ដែរ[4157]។ អំណះអំណាងនេះពុំគួរឱ្យជឿជាក់បាន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់វិធីសាស្ត្ររបស់ខ្លួនច្បាស់លាស់ក្នុងការដោះស្រាយលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី។ ដោយផ្ទុយទៅនឹងអំណះអំណាងក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលបានបញ្ជាក់សាជាថ្មីនៅបណ្តឹងសាទុក្ខដោយ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ពុំមានការសន្មតថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចទុកចិត្តបាននោះទេ[4158]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងត្រូវវាយតម្លៃលើភាពអាចជឿជាក់ និងទុកចិត្តបានផ្អែកលើករណីជាក់ស្តែង ដោយពិចារណាលើភាពគួរជឿជាក់នៃភស្តុតាង និងកត្តាពាក់ព័ន្ធដទៃទៀត[4159]។ ខៀវ សំផន ពុំបានបង្ហាញនូវកំហុសក្នុងវិធីសាស្ត្រដោយប្រុងប្រយ័ត្ន និងគ្រាន់តែលើកសាឡើងវិញនូវអំណះអំណាងពេលជំនុំជម្រះដោយពុំបានបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ដូច្នេះ សារណានេះត្រូវបដិសេធចោល។

### គ) នត្ថិភាពនៃការប្រតិបត្តិតាមប្រពៃណីក្នុងពិធីរៀបអាពាហ៍ពិពាហ៍

[4155] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៩៥។

[4156] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨២។

[4157] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩-៣៦៨១។

[4158] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២៨។

[4159] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥២៨។

1467.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីជាច្រើនថា "ជនរងគ្រោះមានការសោកស្តាយដោយសារការរៀបអាពាហ៍ពិពាហ៍របស់ពួកគាត់ពុំត្រូវបានប្រព្រឹត្តស្របតាមប្រពៃណី"[4160]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អវត្តមានគ្រួសារបានធ្វើឱ្យជនរងគ្រោះជាច្រើននាក់ មានវិប្បដិសារី ខកចិត្ត និងអារម្មណ៍ឈឺចាប់[4161]។ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញជាក់លាក់ទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី យី ឡៃសួរ ដែលថា លោកស្រី"ខកចិត្តខ្លាំង"ដែលឪពុកម្តាយពុំត្រូវបានអនុញ្ញាតឱ្យចូលរួម ព្រមទាំងភស្តុតាងរបស់ ឃិន វ៉ាត ដែលថា នេះជា"រឿងអកុសលដែលឪពុកម្តាយពុំបានដឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់គាត់"[4162]។

1468.ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ព្យសនកម្មយូរអង្វែង" ត្រូវបានបង្កឡើងដោយការខកខានក្នុងការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីដោយមានការពាក់ព័ន្ធជាមួយឪពុកម្តាយ និងបានអះអាងថា ភស្តុតាងរបស់ មុំ វុន, លី ឡៃសួរ និង ឃិន វ៉ាត ពុំបានបង្ហាញនូវព្យសនកម្មណាមួយឡើយ[4163]។ ខៀវ សំផន បានចង្អុលបង្ហាញទៅលើចម្លើយរបស់ មុំ វុន ដែលថា មានប្តីប្រពន្ធ ៦០ គូ បានរៀបអាពាហ៍ពិពាហ៍ក្នុងពិធីតែមួយ និងបានស្រក់ទឹកភ្នែក ពីព្រោះពុំមានការអនុញ្ញាតពីឪពុកម្តាយ[4164] និងបានលើកឡើងថា "ប្រតិកម្មរបស់គាត់នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ពុំអាចឱ្យយើងសន្និដ្ឋានបាន"ថា ព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរបានកើតឡើងឡើយ[4165]។ ខៀវ សំផន បានលើកឡើងផងដែរថា ភស្តុតាងរបស់ លី ឡៃសួរ ដែលថា "មានការខកចិត្តខ្លាំង" និងថា ឃិន វ៉ាត "មានអារម្មណ៍ថា ជារឿងអកុសលដែលឪពុកម្តាយពុំបានបានដឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់គាត់" ពុំបានបង្ហាញនូវព្យសនកម្មធ្ងន់ធ្ងរឡើយ[4166]។

---

[4160] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4161] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4162] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4163] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៣-១១៦៤។

[4164] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4165] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។

[4166] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៨៧ យោងទៅលើកំណត់ហេតុនៃកាស្តាប់ចម្លើយសាក្សី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារលេខ E3/9826 សៈ ១៦៨ ("ពី

1469.ទាក់ទងទៅនឹងនត្តិភាពនៃការប្រតិបត្តិតាមប្រពៃណី សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការវាយតម្លៃជារួមរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពធ្ងន់ធ្ងរបានបង្ហាញច្បាស់លាស់ថា បុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ បានទទួលរងការប៉ះទង្គិចផ្លូវចិត្ត និងរូបកាយយូរអង្វែង រួមទាំងអារម្មណ៍ឈឺចាប់ដែលត្រូវបានបង្កឡើងដោយនត្តិភាពនៃប្រពៃណីនេះ[4167]។ សហព្រះរាជអាជ្ញាបានអះអាងផងដែរថា ការខកចិត្តដែលត្រូវបានពិពណ៌នានោះ មានរយៈពេលយូរអង្វែង ហើយព្យសនកម្មជាក់លាក់នេះត្រឹមតែជាផ្នែកមួយនៃផលប៉ះពាល់ប៉ុណ្ណោះ[4168]។

1470.សហមេធាវីនាំមុខបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងការរងទុក្ខ ដែលពួកគេបានទទួលរងចេញពីផ្នែកដទៃទៀតនៃការរៀបអាពាហ៍ពិពាហ៍[4169]។ សហមេធាវីនាំមុខបានលើកឡើងថា សក្ខីកម្មរបស់ មុំ វុន ជារួម បានឆ្លុះបញ្ចាំង“ការប៉ះទង្គិចដែលត្រូវបានបង្កឡើងមកលើរូបគាត់ដោយសារការបង្ខិតបង្ខំរៀបអាពាហ៍ពិពាហ៍”[4170]។ សហមេធាវីនាំមុខបានលើកឡើងបន្ថែមទៀតថា “មនុស្សផ្សេងបានទទួលរងតាមលក្ខណៈផ្សេងៗគ្នាចេញពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានបង្ហាញផងដែរនូវការរងទុក្ខរបស់ខ្លួនតាមលក្ខណៈខុសៗគ្នា” និងថា អង្គជំនុំជម្រះសាលាដំបូងបានអនុម័តត្រឹមត្រូវនូវវិធីសាស្ត្រជារួមក្នុងការវាយតម្លៃលើភស្តុតាងអំពីព្យសនកម្ម[4171]។

1471.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជារួម ភស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ“មានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ”[4172]។ ក្នុងការសន្និដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកង្វះនៃប្រពៃណីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែបានពិចារណាផងដែរលើព្យសនកម្មជាច្រើនដទៃទៀតដែលបង្កឡើងតាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[4173]។ ចម្លើយទាំងនេះបានរួមបញ្ចូលនូវការរៀបរាប់យ៉ាងរស់រវើកអំពីការភ័យខ្លាចផ្នែករូបកាយ និងភាពតានតឹងផ្លូវ

---

មុនខ្ញុំធ្លាប់មានអារម្មណ៍អន់ចិត្ត ដែលមិនបានរៀបការដូចនៅក្នុងសម័យនេះ [...] រៀបការដោយគ្មានអាចារ្យ គ្មានញាតិមិត្តចូលរួម”)។

[4167] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៦។

[4168] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៨។

[4169] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៩។

[4170] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៩។

[4171] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៩០។

[4172] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨២។

[4173] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩-៣៦៨២។

អារម្មណ៍ក្នុងអំឡុងពេលនៃដំណើរការរៀបអាពាហ៍ពិពាហ៍[4174] ការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ម្តងទៀត នៅពេលអារម្មណ៍កំពុងសោកសៅដោយសារការបាត់បង់ប្តី[4175] និងការសោកស្តាយអស់មួយជីវិត[4176]។ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញស្តីពីការរងទុក្ខដែលបង្កឡើងដោយកង្វះប្រពៃណីដាច់ដោយឡែកនោះទេ ប៉ុន្តែបានចាត់ទុកបញ្ហានេះថា ជាព្យសនកម្មមួយក្នុងចំណោមជាច្រើននោះដែលត្រូវបានបង្កឡើងតាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[4177]។ អាស្រ័យហេតុនេះ ខៀវ សំផន បានបំភ្លៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងសារណានេះត្រូវបដិសេធចោល។

1472.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានដែលថា កង្វះពិធីតាមប្រពៃណី និងគ្មានការពាក់ព័ន្ធពីគ្រួសារ ជាក់ស្តែងបានបង្កឱ្យមានព្យសនកម្មយូរអង្វែង។ ដូចបានបង្ហាញខាងលើ នេះគឺជាលក្ខណៈខុសប្លែកគ្នាជាសត្យានុម័តរវាងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតបន្ថែមទៀតថា លី ឡៃស្ងួវ និង ឃិន វ៉ាត នីមួយៗបានអះអាងថា ពួកគេទទួលរងការគំរាមកំហែងឱ្យរៀបអាពាហ៍ពិពាហ៍[4178] ខណៈពេល មុំ វុន បានផ្តល់សក្ខីកម្មថា លោកស្រីត្រូវបានរំលោភសេពសន្ថវៈ ដោយសារផលវិបាកនៃការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍[4179]។ ដូច្នេះ បុគ្គលជាក់លាក់ទាំងនេះបានផ្តល់សក្ខីកម្មផងដែរថាបានទទួលរងព្យសនកម្មលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ រួមទាំងការសោកសៅនៅថ្ងៃរៀបអាពាហ៍ពិពាហ៍។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

### ឃ) ព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តដទៃទៀត

---

[4174] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ (យោងទៅលើ“បទពិសោធន៍ដ៏តក់ស្លុត និងអារម្មណ៍អវិជ្ជមាន” នៅពេលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានដឹងថា ពួកគេត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលពុំដែលស្គាល់)។

[4175] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨០ យោងទៅលើភស្តុតាងរបស់ មុំ វុន។

[4176] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨០ យោងទៅលើភស្តុតាងរបស់ យស ផល។

[4177] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩-៣៦៨២។

[4178] ប្រតិចារឹក ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០១៥ (ឃិន វ៉ាត) ឯកសារលេខ E1/325.1 ទំព័រ ៤៥-៤៦។ ប្រតិចារឹកថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥ (លី ឡៃស្ងួវ) ឯកសារលេខ E1/334.1 ទំព័រ ៧០-៧១។

[4179] ប្រតិចារឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៣៨។

1473.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ ង៉ែត ចាត ជា ឌៀប និង កុល ណែម ដែលថា ពុំមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែមានព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តដទៃទៀតដែល"បង្កឱ្យមានការរងទុក្ខធ្ងន់ធ្ងរបំផុតនោះ"[4180]។

1474.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ពុំមានលក្ខខណ្ឌតម្រូវថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវតែបង្កឱ្យមានការរងទុក្ខធ្ងន់ធ្ងរជាងបទឧក្រិដ្ឋដទៃទៀតដែលជនរងគ្រោះបានទទួលរងនោះទេ[4181]។

1475.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងការយល់ឃើញស្តីពីព្យសនកម្ម អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើភស្តុតាងរបស់ ជា ឌៀប ដែលថា លោកស្រីពិបាកចិត្ត និង"សម្រក់ទឹកភ្នែកស្ទើររាល់ថ្ងៃ" ក្រោយពិធីរៀបអាពាហ៍ពិពាហ៍[4182]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ កុល ណែម ដែលថា គាត់"មានអារម្មណ៍សោកស្តាយ និងឈឺចាប់ក្នុងចិត្ត"ក្រោយការរៀបអាពាហ៍ពិពាហ៍របស់គាត់ដោយបង្ខំ[4183]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ ង៉ែត ចាត ដែលថា លោកស្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយគ្មានការយល់ព្រមក្រោយប្តីរបស់លោកស្រីត្រូវបានគេនាំចេញទៅ ដែលពេលនោះលោកស្រីកំពុងសោកសៅនូវការបាត់បង់ប្តីរបស់ខ្លួន[4184]។

1476.អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាក្នុងការយល់ឃើញ ឬកន្លែងណាផ្សេងលើភស្តុតាងនៃព្យសនកម្មដទៃទៀតដែលសាក្សីបានឆ្លងកាត់ ដូចបានគូសបង្ហាញដោយ ខៀវ សំផន ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ង៉ែត ចាត បានបង្ហាញនូវទុក្ខសោកដោយសារបាត់បង់ប្តី[4185] ជា ឌៀប រំឭកអំពីបង

[4180] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៩។

[4181] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣០។

[4182] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ យោងទៅលើប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/466.1 ទំព័រ ៦១។

[4183] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ (កុល ណែម) ឯកសារលេខ E1/488.1 ទំព័រ ៦៩-៧០។

[4184] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨០ យោងទៅលើប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ (ង៉ែត ចាត) ឯកសារលេខ E1/489.1 ទំព័រ ២០ ។

[4185] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២១៧៧ យោងទៅលើប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ (ង៉ែត ចាត) ឯកសារលេខ E1/489.1 ទំព័រ ៦-៧។

ប្អូនប្រុស និងសាច់ញាតិដែលបានស្លាប់ក្នុងរបបនោះ[4186] និង កុល ណែម បានបង្ហាញអំពីការឈឺចាប់ដែលពុំអាចមានកូន[4187]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាលើភស្តុតាងនេះ។ ពុំមានលក្ខខណ្ឌតម្រូវច្បាស់លាស់ ឬដោយប្រយោលថា ព្យសនកម្មដែលត្រូវបានបង្កឡើងដោយអំពើដែលត្រូវបានចោទប្រកាន់ត្រូវតែជាព្យសនកម្មមួយដែលបុគ្គលបានឆ្លងកាត់នោះទេ។ ពិតណាស់ នេះបានបញ្ជាក់បន្ថែមលើព្យសនកម្មដែលបុគ្គលទាំងនេះបានទទួលរងជាពិសេស។ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោលពាក់ព័ន្ធទៅនឹងភស្តុតាងរបស់ ង៉ែត ចាត ជា ឌៀប និង កុល ណែម ព្រមទាំង ការលើកឡើងរបស់គាត់ពាក់ព័ន្ធទៅនឹង សយ ណារឿន ផងដែរ[4188]។

ង) ការបង្កើតមនោសញ្ចេតនាក្នុងអំឡុងពេលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1477.ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភស្តុតាងដែលបង្ហាញថាមានបុគ្គលប្រាំពីរនាក់បានបង្កើតមនោសញ្ចេតនាជាមួយគ្នាសន្សឹមៗ និងថា ពួកគេពុំបានទទួលរងព្យសនកម្មដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[4189]។ គាត់បានអះអាងថា ណុប ធីម អ៊ុំ យឿន យសផល និង ផាន់ ហ៊ីម នីមួយៗបានបង្កើតមនោសញ្ចេតនាទៅវិញទៅមកជាមួយដៃគូរបស់ខ្លួន[4190]។ ណុប ធីម បានបញ្ជាក់ថា លោកស្រី និងប្តីបានស្រលាញ់គ្នាបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍នោះ[4191]។ អ៊ុំ យឿន

[4186] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២១៧៧ យោងទៅលើប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ (ជា ឌៀប) ឯកសារលេខ E1/467.1 ទំព័រ ២៥។

[4187] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៧។

[4188] *ប្រៀបធៀប*សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៧ សយ ណារឿន ខុសប្លែកពី ង៉ែត ចាត និង កុល ណែម ពីព្រោះ លោកស្រីបានសួរជនជាប់ចោទអំពីកង្វះអារម្មណ៍ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍" ជាមួយនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៧ ជើងទំព័រ ២១៩៥ ដែលពិពណ៌នា សយ ណារឿន ថា ជាមនុស្សម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ដែល"ពុំបានបញ្ជាក់ការរងទុក្ខដោយសារការរៀបអាពាហ៍ពិពាហ៍នោះឡើយ"។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភាពសមហេតុផលដូចគ្នាត្រូវអនុវត្តចំពោះ សយ ណារឿន និងកត់សម្គាល់បន្ថែមថា ភស្តុតាងរបស់លោកស្រីអំពីការបាត់បង់ព្រហ្មចារី និងសារៈសំខាន់នៃក្តីស្រលាញ់សម្រាប់ការរៀបអាពាហ៍ពិពាហ៍ បង្ហាញបន្ថែមទៀតនូវការខ្វះចន្លោះនៃអំណះអំណាងដែលថា ពុំមានការទទួលរងព្យសនកម្មឡើយ។

[4189] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៩, ១១៧១, ១១៧៤, ១១៧៨, ១១៨៥ យោងទៅលើ ណុប ធីម, អ៊ុំ យឿន, យស ផល, ផាន់ ហ៊ីម, សួន យឹម, សុំ ប៉ែត និង ខែត សុខន។

[4190] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៩, ១១៧១, ១១៧៤, ១១៧៨, ១១៨៥។

[4191] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៩, ១១៧៨។

បានរៀបអាពាហ៍ពិពាហ៍សាជាថ្មីម្តងទៀតជាមួយប្តីរបស់គាត់ក្រោយការដួលរលំរបបនោះ[4192]។ ផាន់ ហ៊ីម បានពិពណ៌នាពីអារម្មណ៍កើតឡើងនៅមុនពេលគាត់រួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់គាត់[4193]។ ចម្លើយរបស់សាក្សី សួន យឹម សុំ ប៉ែត និង ខែត សុខន បានបង្ហាញនូវការដែលខ្លួន"ជម្នះលើ"បទពិសោធន៍របស់ខ្លួន[4194] ខណៈពេល សេង សឿន និង ហេង ឡៃប៉ាង ពុំបានបង្ហាញនូវការរងទុក្ខយូរអង្វែងដោយសារលទ្ធផលនៃការរៀបអាពាហ៍ពិពាហ៍នោះឡើយ[4195]។ ភស្តុតាងរបស់ សួន យឹម បង្ហាញថា "ពុំមានបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត" ក្រោយការរួមដំណេក[4196]។ សុំ ប៉ែត បានបញ្ជាក់ថា គាត់ និងប្រពន្ធ"បានព្យាយាមសម្របសម្រួល"[4197] ខណៈពេល ខែត សុខន បាន"លើកឡើង"អំពីការរងទុក្ខដោយសារការរៀបអាពាហ៍ពិពាហ៍ដោយមិនពេញចិត្ត ប៉ុន្តែបានសម្រេចចិត្តបន្តរស់នៅជាមួយប្តីរបស់គាត់[4198]។

1478.ទាក់ទងទៅនឹងភស្តុតាងដែលថា បុគ្គលបានបង្កើតមនោសញ្ចេតនាជាមួយគ្នាសន្សឹមៗនោះ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានអនុម័តតាមទស្សនៈតូចចង្អៀតហួសហេតុនៃភស្តុតាង ដែលប្រសិនបើពិចារណាជារួមបានបង្ហាញច្បាស់លាស់ថា កម្រិតនៃភាពធ្ងន់ធ្ងរមានអត្ថិភាព[4199]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានកំណត់ពុំត្រឹមត្រូវនូវចរិតលក្ខណៈនៃសក្ខីកម្មមួយចំនួន ដូចជា អ៊ុំ យឿន ដែលសហព្រះរាជអាជ្ញាបានអះអាងថា "ពុំដែលបង្កើតមនោសញ្ចេតនា"ជាមួយប្តីលោកស្រី និងបានសម្រេចជួបជុំជាមួយប្តីសាឡើងវិញបន្ទាប់ពីការដួលរលំរបបនោះ ដោយសារតែ"សម្ពាធពីក្រុមគ្រួសារ និងចាស់ទុំក្នុងភូមិ"[4200]។

1479.សហមេធាវីនាំមុខបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន ដែលថា ការទទួលរងទុក្ខរបស់ជនរងគ្រោះបានចុះថយសន្សឹមៗនោះ មានភាពជាប់ពាក់ព័ន្ធផ្នែកច្បាប់តិចតួច ដោយសារពុំមានលក្ខខណ្ឌតម្រូវផ្លូវច្បាប់ថា ការរងទុក្ខត្រូវតែមានលក្ខណៈយូរអង្វែងសម្រាប់បង្ហាញនូវបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃ

[4192] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៦៩។

[4193] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៨។

[4194] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧១។

[4195] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៨។

[4196] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២១៧៩។

[4197] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២១៧៩។

[4198] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) ជើងទំព័រ ២១៧៩។

[4199] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧២៧។

[4200] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥៦។

ទៀតនោះទេ[4201]។ ខៀវ សំផន ពុំបានអើពើផងដែរទៅលើភស្តុតាងដែលបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លងកាត់បទពិសោធន៍នៃព្យសនកម្មភ្លាមៗនៅពេលរៀបអាពាហ៍ពិពាហ៍[4202] និងបានបំភ្លៃភស្តុតាងរបស់ ខៀវ ហាន និង ហង់ អ៊ិន ដែលពុំបានអះអាងថា ពួកគេបង្កើតមនោសញ្ចេតនាឡើយ[4203]។ សហមេធាវីនាំមុខបានលើកឡើងផងដែរថា ខៀវ សំផន ពុំបានអើពើទៅនឹងហេតុផលផ្សេងដែលពួកគេត្រូវរស់នៅជាមួយគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍នោះ[4204]។

1480.ដំបូង អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ផ្អែកតាមបញ្ហាអង្គច្បាប់ ពុំមានលក្ខខណ្ឌតម្រូវថា ការរងទុក្ខរបស់ជនរងគ្រោះត្រូវតែមានអត្ថិភាពយូរអង្វែង[4205]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍"មានផលប៉ះពាល់យូរអង្វែងលើជនរងគ្រោះ"ក៏ដោយ[4206] ក៏អង្គជំនុំជម្រះពុំត្រូវបានតម្រូវឱ្យបង្កើតការយល់ឃើញមួយនេះដែរ។ ពុំមែនរាល់អំពើសុទ្ធតែបំពេញតាមកម្រិតលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរនោះទេ[4207] ហើយបទដ្ឋាននេះត្រូវបានអនុវត្ត"តឹងរ៉ឹង"ដោយតុលាការអន្តរជាតិ និងតុលាការព្រហ្មទណ្ឌដទៃទៀត[4208]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរនូវអំពើមួយចំនួន ដូចជាការរំលោភសេពសន្ថវៈត្រូវបានពិចារណាតាមរយៈលក្ខណៈនៃអំពើនោះដែលបង្កឱ្យមានការឈឺចាប់ និងការរងទុក្ខ[4209]។ ប៉ុន្តែ បទដ្ឋាននេះពុំត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អំពើបែបនេះត្រូវបានពិពណ៌នាជាដរាបថាមានលក្ខណៈធ្ងន់ធ្ងរ។

---

[4201] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៧៦។

[4202] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៧៧ យោងទៅលើ កុល ណែម, កែវ ធារី, ស្រី សឿម, សួន យឹម, វ៉ា លីមហ៊ន់។

[4203] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៧៨។

[4204] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៧៩-៦៨០ យោងទៅលើ កុល ណែម, ខែត សុខន, អ៊ុំ យឿន, សយ ណារឿន, យស ផល, ទេស ខឹង និង យស ផល។

[4205] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4206] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨២។

[4207] សាលដីការឿងក្តី *Lukić និង Lukić* (ICTY) កថាខណ្ឌ ៦៣៤ ("អង្គជំនុំជម្រះឧទ្ធរណ៍ពិចារណាឃើញថា មិនមែនរាល់អំពើដែលប្រព្រឹត្តក្នុងមន្ទីរឃុំឃាំងសុទ្ធតែអាចសន្មតថាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ")។

[4208] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨១។

[4209] *សូមមើល* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០៧។ *សូមមើលផងដែរ* សាលដីការឿងក្តី *Kunarac និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១៥០។

1481.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ក្នុងស្ថានភាពបច្ចុប្បន្ន ព្យសនកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានបង្ហាញត្រង់ចំណុចដែរថា បុគ្គលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនពុំដែលស្គាល់ និងជាញឹកញាប់ដោយសារការភ័យខ្លាចលើអាយុជីវិត។ បើទោះបីជានត្ថិភាពភស្តុតាងបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ ពុំត្រូវបានបង្ខំទៅលើបុគ្គល ដែលនេះមានន័យថា ការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នោះពុំត្រូវបានបង្ហាញក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការពុំអាចនិយាយបានថា ក្នុងស្ថានភាពនោះ ព្យសនកម្មពុំត្រូវបានបង្ហាញជាអត្តនោម័តិនៅពេលរៀបអាពាហ៍ពិពាហ៍នោះដែរ។ មានផលវិបាកកើតឡើងមួយចំនួនដូចជា៖ ទីមួយ ព្យសនកម្មដែលត្រូវបានបង្កឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំចាំបាច់ត្រូវបានបំភ្លឺជាក់លាក់ ពីព្រោះមានអត្ថិភាពបង្ហាញដោយខ្លួនឯង។ បន្ថែមលើនេះ ពាក់ព័ន្ធចំណុចនេះ បទពិសោធន៍វិជ្ជមាននៃការរៀបអាពាហ៍ពិពាហ៍ជាចាំបាច់ពុំជាប់ពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីព្យសនកម្មឡើយ។ បទពិសោធន៍នេះគឺការបង្ហាញនូវភាពស៊ូទ្រាំ និងសំខាន់ជាងនោះអាចជាសំណាងរបស់បុគ្គលដែលជាប់ពាក់ព័ន្ធនោះ ប៉ុន្តែពុំបានកាត់បន្ថយអានុភាពនៃព្យសនកម្មដែលត្រូវបានបង្កឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំខ្លួនឯងនោះបានទេ។ នេះមានន័យថា និរន្តរភាពនៃការរៀបអាពាហ៍ពិពាហ៍ពុំបានកាត់បន្ថយអានុភាពនៃព្យសនកម្មដែលបានបង្កឡើង។ ពាក់ព័ន្ធចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយមតិជំទាស់ដោយផ្នែករបស់ចៅក្រម Doherty ក្នុងសាលក្រមរឿងក្តី *AFRC*។ ចៅក្រម Doherty បានពិចារណាលើការពិតដែលថា ជនរងគ្រោះអាចនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំសម្រាប់ហេតុផលជាច្រើន ដូចជា “ពុំមានជម្រើសក្នុងការស្វែងរកជីវិតផ្សេងបាន កាតព្វកិច្ចត្រូវចិញ្ចឹមកូនដែលកើតចេញពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការបដិសេធពីក្រុមគ្រួសារ ឬសហគមន៍ ឬការទទួលយកអតីតកាលរបស់ពួកគេ” [4210]។ ទោះជាយ៉ាងណាក្តី “ការសម្រេចចិត្តរស់នៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការប្រែក្លាយទៅជាការយល់ព្រមពុំបានបដិសេធជាប្រតិសកម្មនូវឧក្រិដ្ឋភាពដំបូងនៃអំពើនោះបានឡើយ”[4211]។

1482.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការជំទាស់របស់ ខៀវ សំផន ធៀបនឹងការយល់ឃើញនេះ។ បុគ្គលជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគេបានបង្កើតមនោសញ្ចេតនាសន្សឹមៗ ហាង់ អ៊ិន ថា “ចាប់ផ្តើមចូល

[4210] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម Doherty ស្តីពីបទចោទលេខ ៧ (ទាសភាពផ្លូវភេទ) និង ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៤៥។

[4211] សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *AFRC* (SCSL) មតិជំទាស់ផ្នែកខ្លះរបស់ចៅក្រម Doherty ស្តីពីបទចោទលេខ ៧ (ទាសភាពផ្លូវភេទ) និង ៨ (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៤៥។

ចិត្ត"ប្ដីរបស់គាត់[4212] និង កែវ ធារី បានអះអាងថា លោកស្រី និងប្ដីមានអារម្មណ៍ដូចប្ដីប្រពន្ធដទៃទៀតក្នុងពេលសមស្របមួយនោះ[4213]។ ណុប ងឹម បានអះអាងថា លោកស្រី និងប្ដី"បានស្រលាញ់គ្នាទៅវិញទៅមក"បន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ[4214]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ ណុប ងឹម ដែលថា លោកស្រីបានស្រក់ទឹកភ្នែកក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែត្រូវតែទ្រាំដោយសារលោកស្រីអាចនឹងត្រូវសម្លាប់ប្រសិនបើប្រកែក[4215]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះពុំអាចទទួលយកបានថា បទឧក្រិដ្ឋដែលបានបង្កតាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយសារការគំរាមលើអាយុជីវិតត្រូវបានលុបលាងតាមរយៈមនោសញ្ចេតនាត្រូវរ៉ូវគ្នាដែលជនរងគ្រោះប្ដីប្រពន្ធបានបង្កើតឡើងជាមួយគ្នា ដូចក្នុងករណី ណុប ងឹម ឡើយ។ ផាន់ ហ៊ីម បានអះអាងថា លោកស្រីពុំបានស្រលាញ់ប្ដីលោកស្រីទេលើកដំបូង ប៉ុន្តែក្រោយមកបានស្រឡាញ់[4216]។ វ៉ា លឹមហ៊ន់ បានបង្កើតមនោសញ្ចេតនាស្រលាញ់ប្ដីលោកស្រី និង មាស សារ៉ាន បានដាក់បណ្ដឹងទាមទារសំណងទាក់ទងទៅនឹងការស្លាប់ប្ដីរបស់លោកស្រី ដែលគាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយដោយបង្ខំនោះ[4217]។

1483.ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត ខៀវ សំផន បានបំភ្លៃភស្តុតាងរបស់ពួកគេ ឬបានអនុវត្តវិធីសាស្ត្រជ្រើសរើសតាមការចង់បានបំផុត។ ជាឧទាហរណ៍ គាត់បានលើកឡើងថា យស ផល

[4212] កំណត់ហេតុស្ដាប់ចម្លើយ ហង់ អ៊ិន ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារលេខ E3/5558 ERN 00375518។

[4213] កំណត់ហេតុស្ដាប់ចម្លើយ កែវ ធារី ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E3/9662 (ពួកគាត់ស្រលាញ់គ្នាទៅវិញទៅមកក្រោយការរៀបអាពាហ៍ពិពាហ៍)។ E3/9662 សៈ ៨៦ (មានអារម្មណ៍ដូចប្ដីប្រពន្ធដទៃទៀតដែលបានរៀបអាហ៍ពិពាហ៍ដោយស្ម័គ្រចិត្តបន្ទាប់ពីនៅជាមួយគ្នាច្រើនឆ្នាំ)។

[4214] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 ទំព័រ ២៩។

[4215] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ឯកសារលេខ E1/469.1 ទំព័រ ២៩ (បានអះអាងថា គេបានបង្ខំគាត់ឲ្យរៀបការជាមួយកងទ័ពពិការភ្នែក។ គាត់បានពន្យល់ថា៖ "ខ្ញុំយំដែរហ្នឹង ប៉ុន្តែអត់ចិត្តអត់ដឹងខ្លួនសោះ អន់ចិត្តៗមាំណាស់ ព្រោះអីអត់ដែលឃើញ វាដែលឃើញ [...] យើងធ្វើអីចឹង ខ្លាចគេវ៉ៃចោល។ អ៊ីចឹងចេះតែទ្រាំ")។

[4216] ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ (ផាន់ ហ៊ីម) ឯកសារលេខ E1/467.1 ទំព័រ ៨៨ (អះអាងថា "ដំបូង" ប្ដីប្រពន្ធពុំមានអារម្មណ៍ជាមួយគ្នាទេ និងពុំស្រលាញ់គ្នាដែរ)។

[4217] កំណត់ហេតុស្ដាប់ចម្លើយ វ៉ា លឹមហ៊ន់ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២១៤ ឯកសារលេខ E3/9756 សៈ ៤៥, សៈ ៤៨, សៈ ៥០ (គាត់ស្រលាញ់ប្ដី និងមិនដែលគិតថាចង់ចាកចេញពីគាត់ទេ)។ កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី មាស សារ៉ាន ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E3/9736, សៈ ១១០, សៈ ១១២, សៈ ១១៤, សៈ ១១៧ (ភស្តុតាងបង្ហាញថាពុំមានបញ្ហារួមភេទជាមួយប្ដីទីពីររបស់គាត់)។

"បានបង្កើតមនោសញ្ចេតនាជាមួយប្រពន្ធដែលគាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយ"[4218] និងពុំបានអើពើលើការពិតដែលថា សក្ខីកម្មពាក់ព័ន្ធបានបញ្ជាក់ថា យស ផល បានចាត់ទុកប្រពន្ធរបស់គាត់ដូចជាបងប្អូនគ្នា[4219]។ បើទោះបីជា សុំ ប៉ែត បានផ្តល់ភស្តុតាងថា គាត់ និងប្រពន្ធ"បានព្យាយាមសម្របសម្រួល"ក៏ដោយ[4220] ក៏ភស្តុតាងបានបញ្ជាក់ច្បាស់ថា គ្រាន់តែជាការប៉ុនប៉ងដើម្បីឱ្យរួចផុតពីស្ថានភាពគ្រោះថ្នាក់ និងពុំអាចជៀសរួច[4221]។ ខៀវ សំផន បានចង្អុលបង្ហាញទៅលើភស្តុតាងរបស់ សួន យឹម ដែលថា លោកស្រី"ពុំមានបញ្ហាលើរូបកាយ ឬផ្លូវចិត្តក្រោយការរួមដំណេក" ប៉ុន្តែខកខានក្នុងការទទួលស្គាល់ភស្តុតាងលោកស្រីនៅទំព័រដំបូងនៃចម្លើយនោះដែលថា លោកស្រីបានយល់ព្រមរួមភេទដោយសារភ័យខ្លាចគេសម្លាប់[4222]។ ចម្លើយរបស់ ខែត សុខន ដែលថា លោកស្រីបានសម្រេចចិត្តរស់នៅជាមួយប្តី[4223] គប្បីបានពិនិត្យផ្ទួបជាមួយនឹងភស្តុតាងដទៃទៀតដែលបង្ហាញថា លោកស្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយប្តីគាត់ផ្ទុយពីបំណងរបស់គាត់ និងបានសម្រេចចិត្តរស់នៅជាមួយប្តីគាត់ដោយសារតែឪពុកម្តាយរបស់គាត់បានស្លាប់អស់ហើយ[4224]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាផងដែរលើភស្តុតាងរបស់ អ៊ុំ យឿន ដែលថា លោកស្រីមានការ"ព្រួយបារម្ភខ្លាំង"មិនចង់រៀបអាពាហ៍ពិពាហ៍ និងញ៉ាំអីមិនចូលនៅពេលនោះ[4225] ព្រមទាំងសក្ខីកម្មរបស់លោកស្រីដែលថា លោកស្រីត្រូវបានរំលោភសេពសន្ថវៈ ក្រោយការរៀបអាពាហ៍ពិពាហ៍[4226] និងត្រូវបានរៀបអាពាហ៍ពិពាហ៍សាឡើងវិញដោយសារតែសម្ពាធគ្រួសារប៉ុណ្ណោះ[4227]។ យស ផល បានរៀបរាប់ចេញពីដួងចិត្តនូវការឈឺចាប់ដែលបានបន្តក្រោយពេលបាត់បង់គូដណ្តឹងរបស់ខ្លួន និងបានពិត

[4218] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៤។

[4219] ប្រតិចារឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ២១-២២។

[4220] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុំ ប៉ែត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារលេខ E3/9824 ទំព័រ ៩១-០។

[4221] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុំ ប៉ែត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារលេខ E3/9824 ទំព័រ ៩១-០។

[4222] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន យឹម ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារលេខ E3/9829 (សះ ២៨ លោកស្រីយល់ព្រមបណ្តោយរួមភេទដោយសារភ័យខ្លាចគេយកទៅសម្លាប់ចោល)។

[4223] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខែត សុខន ឯកសារលេខ E3/9830 ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សះ ៨៦។

[4224] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខែត សុខន ឯកសារលេខ E3/9830 ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សះ ៧៥, សះ ៨២, សះ ៨៤។

[4225] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩ យោងទៅលើប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/461.1 ទំព័រ ៦៦-៦៧។

[4226] ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ១១។

[4227] ប្រតិចារឹកថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/461.1 ទំព័រ ៧១។ ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ១២។

ណ៍នាជីវិតរបស់ខ្លួនថា "គួរឱ្យកំសត់" និងពោរពេញដោយការឈឺចាប់ ទុក្ខសោក និងការរងទុក្ខក្នុងភស្តុតាងដែលបានយោងដោយអង្គជំនុំជម្រះសាលាដំបូង[4228]។ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

1484.ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការជំទាស់ដែលថា តាមគោលការណ៍ ការបង្កើតមនោសញ្ចេតនាអនាគតបានដុសលាងព្យសនកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬថា បុគ្គលត្រូវបានតម្រូវឱ្យបង្ហាញជាក់លាក់នូវព្យសនកម្មដែលខ្លួនបានឆ្លងកាត់។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា ខៀវ សំផន ខកខានក្នុងការវិភាគលើភស្តុតាងទាំងមូល នៅពេលអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី បានចាប់ផ្តើមបង្កើតមនោសញ្ចេតនាជាមួយដៃគូរបស់ខ្លួន។ បុគ្គលនីមួយៗដែល ខៀវ សំផន បានលើកឡើង បានបញ្ជាក់នូវបរិបទនៃការបង្ខិតបង្ខំ និងដូច្នេះ មានព្យសនកម្មច្បាស់លាស់[4229]។

1485.ទាក់ទងទៅនឹងកង្វះភស្តុតាងស្តីពីព្យសនកម្មជាក់លាក់ អង្គជំនុំជម្រះតុលាការកំពូលសង្កេតលើភាពមិនស៊ីសង្វាក់គ្នានៃការចង្អុលបង្ហាញទៅលើនត្ថិភាពនៃភស្តុតាងអំពីការរងទុក្ខក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលបានផ្តល់សក្ខីកម្ម នៅក្រៅផ្នែកស្តីពីការរៀបអាពាហ៍ពិពាហ៍ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋដទៃទៀត និងជាពិសេស ពុំត្រូវបានសួរសំណួរលើបទពិសោធន៍នោះ។ បន្ថែមលើនេះ ខៀវ សំផន

---

[4228] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨១ យោងទៅលើប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ៤៥-៤៧។

[4229] ការរៀបរាប់បង្ហាញថា ប្តីប្រពន្ធបានរស់នៅជាមួយគ្នា ឬបានរៀការឡើងវិញដោយសារសម្ពាធគ្រួសារ ឧទាហរណ៍ ពុំបានបង្ហាញនូវសេរីភាពនៃជម្រើស។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ធី ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ឯកសារលេខ E3/5184 ERN 00197874 ទំព័រ ៤ (លើកឡើងថា គាត់ និងប្រពន្ធ ត្រឡប់ទៅស្រុកក្រោយការដួលរលំរបបនោះ)។ រស់នៅជាមួយគ្នាដូចបងប្អូន និងបានរៀការសាជាថ្មីក្រោយការដួលរលំតាមសំណើគ្រួសារ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ បាន ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ E3/5559 ERN 00375526។ ប្រហាក់ប្រហែលគ្នានោះដែល ចម្លើយរបស់ មាន លឿយ ដែលថា គាត់"ត្រូវតែ"ស្រលាញ់ប្រពន្ធរបស់គាត់នៅពេលរៀបការ បានផ្ទុះបញ្ចាំងតម្លៃប្រពៃណី និងបង្ហាញនូវព្យសនកម្មពេញលេញដែលបានបង្កឡើងដោយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាជាងការផ្ទុះបញ្ចាំងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ (មាន លឿយ) ឯកសារលេខ E1/340.1 ទំព័រ ៥៥។ ជាំង ស្រីមុំ បានអះអាងថា លោកស្រី និងប្តីបានរស់នៅជាមួយគ្នា"ពីព្រោះការភ័យខ្លាច" ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/255.1 ទំព័រ ៨។ វ៉ា លឹមហ៊ន់ បានអះអាងថា លោកស្រីមានអារម្មណ៍ថា ត្រូវរៀបអាពាហ៍ពិពាហ៍ដោយសារការភ័យខ្លាចគេសម្លាប់ និងការដែលថា លោកស្រីបង្កើតមនោសញ្ចេតនា ស្រលាញ់ប្តីនោះ ពុំជាប់ពាក់ព័ន្ធឡើយ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ន់ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០២១៤ ឯកសារលេខ E3/9756 ERN 01025625-01025626។

បានបំភ្លៃភស្តុតាង។ សាក្សីពីរនាក់ដែលគាត់បានលើកឡើងនោះពុំបានបង្ហាញភស្តុតាងជាក់លាក់អំពីព្យសនកម្ម[4230]។ ជាមួយគ្នានេះដែរ បុគ្គលផ្សេងៗទៀតដែលបានលើកឡើងដោយ ខៀវ សំផន បានផ្តល់ភស្តុតាងជាក់លាក់ដែលបង្ហាញច្បាស់លាស់អំពីការរងទុក្ខ ជាញឹកញាប់ក្នុងភស្តុតាងដែលនៅក្បែរជាប់នឹងផ្នែកដែលបានយោងដោយ ខៀវ សំផន។ ខែត សុខន និង ហេង ឡៃហ៊ាង អ្នកទាំងពីរបានពិពណ៌នាច្បាស់លាស់អំពីការរងទុក្ខរបស់ខ្លួន ចំណែក ម៉ី សាវឿន ជុំ សាវឿន និង ធុច ស៊ីថន បានពិពណ៌នាអំពីការភ័យខ្លាច និងអារម្មណ៍បង្ខិតបង្ខំនៅពេលរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ[4231]។ អំណះអំណាងរបស់ ខៀវ សំផន លើចំណុចនេះ ត្រូវបដិសេធចោលផងដែរ។

ច) ភាពគួរឱ្យជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន និង មុំ វុន

1486.ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើភស្តុតាងរបស់ អែម អឿន ដែលថា គាត់អាចប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍បាន[4232] និងកំហុសក្នុងការយល់ឃើញថា មុំ វុន គួរជឿទុកចិត្តបាន[4233]។ ក្នុងការគាំទ្រ គាត់បានយោងទៅលើភស្តុតាងរបស់លោកស្រីដែលចោទថាពុំស៊ីសង្វាក់គ្នាអំពីអត្តសញ្ញាណ និងវាសនាប្តីទីមួយរបស់លោកស្រី និងបានលើកសាឡើងវិញនូវអំណះអំណាងដែលបានលើករួចហើយនៅពេលជំនុំជម្រះ[4234] និងបានអះអាងថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ភាពពុំស៊ីសង្វាក់គ្នានេះគប្បីត្រូវបានចាត់ទុកថា ជា"បញ្ហា

[4230] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ (សេង សឿន) ឯកសារលេខ E1/465.1 នៅម៉ោង ១០.០៧.៤២ (សេង សឿន បានអះអាងថា គាត់បានរៀបការជាមួយប្អូនជីដូនមួយរបស់ប្រធានគាត់ដោយសារមានការទទូចពីប្រធានគាត់ ពុំបានលើកឡើងអំពីការឈឺចាប់)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ (សេង សឿន) ឯកសារលេខ E1/466.1 នៅម៉ោង ១១.៣៨.០៦។ ប្រតិចារឹកថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ (ជាល ជឿន) ឯកសារលេខ E1/484.1 ទំព័រ ២០-២១។

[4231] ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ (ម៉ី សាវឿន) ឯកសារលេខ E1/459.1 ទំព័រ ៥១ (ពុំបានលើកឡើងអំពីការរងទុក្ខដោយសារការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែបានលើកឡើងថា ត្រូវបានបង្ខំឱ្យគោរពតាមដោយសារការភ័យខ្លាច)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 ទំព័រ ៥០-៥១ (លោកស្រីបែកគ្នាបីថ្ងៃក្រោយមកបន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពិពណ៌នាអំពីការភ័យខ្លាចនៅយប់នៃការរៀបអាពាហ៍ពិពាហ៍នោះ)។ ប្រតិចារឹកថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ធុច ស៊ីថន) ឯកសារលេខ E1/500.1 ទំព័រ ៥៦ (ថា គាត់ត្រូវតែបង្ខំចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយពីព្រោះការភ័យខ្លាចផលវិបាកអាក្រក់)។

[4232] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧២។

[4233] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៣។

[4234] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៣ យោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ២៣៨៤។

តូចតាច”នោះ ពុំត្រឹមត្រូវឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើអត្ថិភាព និងការស្តាប់ប្តីទីមួយរបស់គាត់ក្នុងការបង្កើតការយល់ឃើញអំពីការរងទុក្ខ[4235]។

1487.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សក្ខីកម្មរបស់ អែម អឿន ដែលថា គាត់អាចជ្រើសរើសថ្ងៃរៀបអាពាហ៍ពិពាហ៍របស់គាត់បាននោះ ពុំបានប៉ះពាល់លើសក្ខីកម្មផ្សេងទៀតរបស់គាត់ដែលបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍របស់គាត់ត្រូវបានបង្ខំ និងបង្កឱ្យមានការរងទុក្ខនោះ[4236]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ភាពគួរជឿជាក់បានរបស់ មុំ វុន ត្រូវបានដាក់ឱ្យដេញដោលដូចគ្នារួចហើយ និងជាលទ្ធផលត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង[4237]។

1488.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ អែម អឿន ដែលថា “ក្នុងនាមខ្ញុំជាយុវជនម្នាក់ស្ថិតនៅក្នុងសង្គម អ្នកណាក៏ដូចអ្នកណា ស្រឡាញ់ណាស់អំពើមានសិទ្ធិសេរីភាពក្នុងការរើសគូស្រករ។ ប៉ុន្តែនៅក្នុងឱកាសដែលខ្ញុំមិនចង់បាន បែរទៅជាបាន អាហ្នឹងខ្ញុំមិនពេញចិត្តទេ តែគេចមិនបាន។ [...] ទាំងនារីជាភរិយារបស់ខ្ញុំ ទាំងខ្ញុំដេក ពេលចូលដំណេកដេកជាមួយគ្នា បង្ហូរទឹកភ្នែកដាក់គ្នា”[4238]។ ទាក់ទងទៅនឹង មុំ វុន អង្គជំនុំជម្រះសាលាដំបូងពិចារណាលើភស្តុតាងរបស់គាត់ថា លោកស្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ខ្លួន និងថា អ្នករាល់គ្នាបានបង្ហូរទឹកភ្នែកនៅពេលពិធីរៀបអាពាហ៍ពិពាហ៍ជាសមូហភាពដែលមានរហូតដល់ ៦០ គូ[4239]។

1489.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានបំភ្លៃភស្តុតាងរបស់ អែម អឿន។ អែម អឿន បានអះអាងថា គាត់អាចជ្រើសរើសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅថ្ងៃណាមួយដែលគ្រួសាររបស់គាត់អាចចូលរួមបាន មិនមែនថា គាត់មានសិទ្ធិថាតើ គាត់អាចយល់ព្រម ដែរ ឬយ៉ាងណានោះទេ[4240]។ ដូចបានបង្ហាញក្នុងភស្តុតាងដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងថា អែម អឿន បានបញ្ជាក់

---

[4235] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៣។

[4236] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣២។

[4237] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣៣។

[4238] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩០-៩១។

[4239] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨០ យោងទៅលើប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៣៦-៣៧, ៨០-៨១។

[4240] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩៣-៩៤។

ច្បាស់លាស់នូវការឈឺចាប់ ដែលគាត់បានឆ្លងកាត់ នៅពេលគាត់ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ខ្លួន[4241]។ ខៀវ សំផន ពុំបានបង្ហាញកំហុស និងដូច្នេះសារណានេះត្រូវបដិសេធចោល។

1490.ទាក់ទងទៅនឹង មុំ វុន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយប្រុងប្រយ័ត្នលើភាពពុំស៊ីសង្វាក់គ្នាមួយចំនួនក្នុងភស្តុតាងរបស់គាត់រវាងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ និងសក្ខីកម្មក្នុងតុលាការ[4242]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់លើអំណះអំណាងដែល ខៀវ សំផន បានលើកឡើងរួចហើយនៅពេលជំនុំជម្រះ ដូចជាថា មានភាពពុំស៊ីសង្វាក់គ្នាជាសត្យានុម័តពីព្រោះ មុំ វុន ដំបូងឡើយបានអះអាងថា ប្តីរបស់គាត់បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៥ នៅពេលគេកោះហៅទៅចូលរួមវគ្គរៀនសូត្រ និងបន្ទាប់មកក្នុងភស្តុតាងក្រោយ ពុំបាននិយាយអំពីការបាត់ខ្លួនប្តីរបស់គាត់ និងថា ប្តីរបស់គាត់គឺជាអ្នកឡើងត្នោតក្នុងឆ្នាំ ១៩៧៧[4243]។ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា ភាពពុំស៊ីសង្វាក់គ្នាដែលបានលើកឡើង"ជាពិសេសពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទ" ពុំបានប៉ះពាល់ដល់គួរឱ្យជឿជាក់បានជាទូទៅរបស់ មុំ វុន ឡើយ[4244]។

1491.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សំអាងទៅលើភស្តុតាងដ៏រស់រវើករបស់ មុំ វុន អំពីព្យសនកម្មនៃការរៀបអាពាហ៍ជាថ្មីម្តងទៀត បើទោះបីជាបានទទួលស្គាល់ច្បាស់លាស់នូវការភាន់ច្រឡំក្នុងកម្រិតមួយអំពីកាលបរិច្ឆេទជាក់លាក់នៃការបាត់ខ្លួនប្តីរបស់លោកស្រីក៏ដោយ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅគ្រប់កាលៈទេសៈ ខៀវ សំផន មានឱកាសសួរដេញដោល មុំ វុន លើចំណុចនេះក្នុងអំឡុងពេលនៃការជំនុំជម្រះ ហើយលោកស្រីបានបញ្ជាក់ថា ឆ្នាំ ១៩៧៥ គឺជាកាលបរិច្ឆេទត្រឹមត្រូវ[4245]។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបដិសេធចោល។

### ឆ) ស៊ូ សុធារី

[4241] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩០-៩១។

[4242] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៩ យោងទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣៩៨។

[4243] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ២៣៩៨។

[4244] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៩។

[4245] *សូមមើល* ប្រតិចារឹកថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ (មុំ វុន) ឯកសារលេខ E1/477.1 ទំព័រ ៧-១០។

1492.ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទាញ“សេចក្តីសន្និដ្ឋានជាទូទៅ”អំពីព្យសនកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ ស៊ូ សុធារី ជាជាងធ្វើការវាយតម្លៃហេតុដូចម្តេចបានលោកស្រីបានទទួល“រងទុក្ខធ្ងន់ធ្ងរជាងគេបំផុត”ក្នុងនាមជាស្ត្រីភេទទីបីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[4246]។

1493.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើសក្ខីកម្មរបស់ ស៊ូ សុធារី តែមួយមុខគត់សម្រាប់ការយល់ឃើញពាក់ព័ន្ធទៅនឹងព្យសនកម្មដែលបានបង្កឡើងដោយសារលទ្ធផលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះទេ[4247]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា បទពិសោធន៍របស់ ស៊ូ សុធារី “ពុំមែនជាករណីពិសេសនោះឡើយ”[4248]។

1494.សហមេធាវីនាំមុខបានឆ្លើយតបថា ជាការត្រឹមត្រូវដែល ស៊ូ សុធារី បានទទួលរងទុក្ខខុសប្លែកពីគេច្រើនចំណុច ពីព្រោះតែអត្តសញ្ញាណរបស់គាត់ជាស្ត្រីភេទទីបី ប៉ុន្តែសហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញមូលដ្ឋានច្បាប់សម្រាប់ការអះអាងថា “ការរងទុក្ខខ្លាំងជាងគេរបស់បុគ្គលភេទទីបី ពុំជាប់ពាក់ព័ន្ធក្នុងការវាយតម្លៃអំពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត”[4249]។ សហមេធាវីនាំមុខបានអះអាងថា “ការរងទុក្ខរបស់បុគ្គលភេទទីបីពុំមែនមានអានុភាព និងជាប់ពាក់ព័ន្ធតិចជាងអ្នកដទៃនោះទេ”[4250]។

1495.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាក់លាក់លើភស្តុតាងរបស់ ស៊ូ សុធារី ស្តីពីការឈឺចាប់ដែលខ្លួន និងប្រពន្ធបានឆ្លងកាត់ដោយសារផលវិបាកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4251] ខណៈពេលទទួលស្គាល់ថា លោកស្រីគឺជា“ស្ត្រីភេទទីបី”[4252]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងនេះបូករួមជាមួយនឹងភស្តុតាងដទៃទៀតជាច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេ

---

[4246] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧០។

[4247] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣១។

[4248] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៣១។

[4249] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨២៥។

[4250] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨២៥។

[4251] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៩ យោងទៅលើប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធារី) ឯកសារលេខ E1/462.1 ទំព័រ ៧៨-៧៩។

[4252] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាខាងក្រោមបន្ថែមទៀតលើការយល់ឃើញដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបទពិសោធន៍របស់ ស៊ូ សុធារី នៃព្យសនកម្ម ការរួមភេទដោយបង្ខំដែលឋានៈគាត់ជាភេទទីបីពុំត្រូវបានទទួលស្គាល់។

ណី និងសាក្សី និងដោយពិចារណាជារួមលើ"បទពិសោធន៍គួរឱ្យតក់ស្លុត និងអារម្មណ៍អវិជ្ជមាននៅពេលដឹងថា ខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនពុំដែលស្គាល់"[4253]។ អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងតែទៅលើភស្តុតាងរបស់ ស៊ូ សុធារី ក្នុងការគាំទ្រការយល់ឃើញជាទូទៅ និងដូច្នេះ សារណារបស់ ខៀវ សំផន ដែលលើកផ្ទុយ ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាជាទូទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងរបស់ ស៊ូ សុធារី ដូចខាងក្រោម។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបដិសេធរាល់ការជំទាស់របស់ ខៀវ សំផន ទៅនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត។

### iii. ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1496.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាថា អំពើនៃការរួមភេទបានកើតឡើងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងក្នុងការវាយតម្លៃអំពីការរងទុក្ខធ្ងន់លើរូបកាយ ឬផ្លូវចិត្ត។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្តនៃការរងទុក្ខពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសដោយសារការរួមដំណេកដោយបង្ខំ ព្រមទាំងការយល់ឃើញស្តីពីសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ជារួម សារណារបស់សហព្រះរាជអាជ្ញាបានលើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវភាពលម្អៀងរបស់តុលាការលើភេទដោយប្រយោល។

- *អំពើនៃការរួមភេទដោយបង្ខំ*

1497.អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញខាងលើថា នៅពេលពិចារណាលើនីត្យានុកូលភាពនៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈដែលជាអំពើអមនុស្សធម៌ដទៃទៀត អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការតម្រង់ទិសខ្លួនឯងដោយពិចារណាលើបញ្ហាថាតើ ធាតុផ្សំ"បទឧក្រិដ្ឋ"នៃការរំលោភសេពសន្ថវៈ និងតាមរយៈការយល់ឃើញថា បុរសពុំអាចជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ"អំពើហិង្សាផ្លូវភេទដទៃទៀត" ត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណាត្រឹមតែបញ្ហាថាតើ ការប្រព្រឹត្តដែលត្រូវបានពិពណ៌នាក្នុងដីកាដំណោះស្រាយត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា និងថាតើ ការប្រព្រឹត្តនោះបានបំពេញតាមបទដ្ឋានចាំបាច់នៃភាពធ្ងន់ធ្ងរក្នុងកម្រិតដែល

---

[4253] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៩។

បំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលបានកែតម្រូវកំហុសនេះ នៅពេលធ្វើការវាយតម្លៃលើបញ្ហានីត្យានុកូលភាពដែលបានលើកឡើងដោយ ខៀវ សំផន និងបានបញ្ជាក់ថា ការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ ក្នុងរឿងក្តីនេះ គឺជាអំពើនៃការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធទើបរៀបអាពាហ៍ពិពាហ៍ថ្មីៗ។ ទោះជាយ៉ាងណាក្តី ពុំមានភាពចាំបាច់តម្រូវឱ្យពិចារណាលើបញ្ហាថាតើ បទឧក្រិដ្ឋនៃ"ការរំលោភសេពសន្ថវៈ" និង"អំពើហិង្សាផ្លូវភេទដទៃទៀត"ត្រូវបានបង្ហាញ ដែរ ឬយ៉ាងណាឡើយ។

1498.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាខាងលើផងដែរ លើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអត្ថិភាពនៃការរួមភេទដោយបង្ខំ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ មានការរៀបចំត្រូវបានធ្វើឡើងតាមធម្មតាដោយអាជ្ញាធរមូលដ្ឋានសម្រាប់ប្តីប្រពន្ធទើបរៀបអាពាហ៍ពិពាហ៍ថ្មីឱ្យដេកនៅក្នុងទីតាំងដែលបានកំណត់ទុកជាក់លាក់ដើម្បីរួមភេទ[4254]។ ឈ្លបជាទូទៅទទួលបញ្ជាតាមដានប្តីប្រពន្ធពេលយប់ដើម្បីឱ្យដឹងប្រាកដថា ពួកគេបានរួមភេទ[4255]។ ទាំងបុរស និងស្ត្រីមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យរួមភេទ និងត្រូវបានយកទៅធ្វើការអប់រំ ឬគំរាមសម្លាប់ ឬទទួលទណ្ឌកម្ម[4256]។ ប្តីប្រពន្ធដែលពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ត្រូវតែលាក់បាំងការពិតនេះ និងធ្វើពុតជាស្រលាញ់គ្នាទៅវិញទៅមកដើម្បីគេចផុតពីផលវិបាកអវិជ្ជមាន[4257]។ អង្គជំនុំជម្រះតុលាការកំពូលបានរកពុំឃើញនូវកំហុសក្នុងការយល់ឃើញទាំងនេះ។

1499.នៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមតាមរយៈការសង្កេតថា ពុំមានលក្ខខណ្ឌតម្រូវថា ការរំលោភសេពសន្ថវៈដែលជាប្រភេទជាក់លាក់នៃអំពើមូលដ្ឋានគប្បីយល់ឃើញថាស្ថិតក្នុងប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀតត្រឹមឆ្នាំ ១៩៧៥[4258]ឡើយ។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានអះអាងផងដែរថា ក្នុងកាលៈទេសៈជាក់លាក់នោះ អង្គជំនុំជម្រះបានពិចារណាឃើញថា "ការរើបម្រះមិនរួចផ្នែករាងកាយរបស់ស្ត្រី គឺមិនបានបង្ហាញពីការយល់ព្រមឡើយ"[4259]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនេះគឺជា"ការរំលោភសេពសន្ថវៈ"ពាក់ព័ន្ធទៅនឹងជនរងគ្រោះបីនាក់ជាស្ត្រី និងបន្ថែម

---

[4254] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4255] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4256] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4257] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៧។

[4258] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៨។

[4259] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

លើនេះបានបង្កព្យសនកម្ម ឬការរងទុក្ខផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ[4260]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកនូវការយល់ឃើញរបស់ខ្លួនដែលថា ជនរងគ្រោះជាបុរសត្រូវបានដកចេញពីការកំណត់អត្តសញ្ញាណនៃការរំលោភសេពសន្ថវៈក្នុងឆ្នាំ ១៩៧៥ និងផ្ទុយទៅវិញបានពិចារណាលើបញ្ហាថាតើ ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទដទៃទៀតដែលស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត ដែរ ឬយ៉ាងណា[4261]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពួកគេពុំមែនជាជនរងគ្រោះ ពីព្រោះបើទោះបីជាបុរសពុំអាចប្រកែករួមដំណេកការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ពុំបានភស្តុតាង "បង្ហាញច្បាស់លាស់ពាក់ព័ន្ធទៅនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់លើបុរសដែរ"[4262]។

1500.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ត្រឹមត្រូវត្រង់ចំណុចដែលខ្លួនបានផ្តោតទៅលើនោះថា ពុំមានលក្ខខណ្ឌតម្រូវថា ការរំលោភសេពសន្ថវៈ"ដែលជាប្រភេទជាក់លាក់នៃអំពើជាមូលដ្ឋាន"ត្រូវតែយល់ឃើញថា ស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតឡើយ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ត្រឹមការសង្កេតអំពីគោលការណ៍ជាសារវ័ន្ត ដូចជាថា ពុំមានលក្ខខណ្ឌតម្រូវថា អំពើដែលត្រូវបានចោទប្រកាន់ក្រោមប្រភេទដែលអាចស្មើនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀត។ ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញនេះនៅក្នុងការបញ្ជាក់អំពីបទដ្ឋានគតិយុត្តថា អំពើជាក់លាក់ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដោយខ្លួនឯងផ្ទាល់ពុំចាំបាច់ជាបទល្មើសច្បាស់លាស់ក្រោមច្បាប់អន្តរជាតិ[4263]។ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតផងដែរថា អំពើអមនុស្សធម៌ដទៃទៀតមានលក្ខណៈ"ជាប្រភេទមិនជាក់លាក់ដែលដាក់ឱ្យទៅជាបទល្មើសនូវអំពើដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែខុសប្លែកពីបទឧក្រិដ្ឋជាក់លាក់ជាមូលដ្ឋានណាមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[4264]។ ទោះជាយ៉ាងណាក្ដី នៅពេលបង្កើតការយល់ឃើញរបស់ខ្លួនអំពីបទពិសោធន៍នៃការរួមដំណេកដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តតាមបទដ្ឋាននេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានតម្រង់ទិសដៅខ្លួនឯងដោយពិចារណាជាក់ស្តែងលើអ្វីដែលខ្លួនបានបញ្ជាក់ថា មិនត្រូវធ្វើ ដូចជា៖ ថាតើ បទឧក្រិដ្ឋឯករាជ្យ

---

[4260] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧-៣៧០០។

[4261] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4262] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4263] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4264] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៣។

នៃ"ការរំលោភសេពសន្ថវៈ" ឬក្នុងករណីជនរងគ្រោះជាបុរស អំពើហិង្សាផ្លូវភេទដទៃទៀតត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសបន្ថែមទៀត និងធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងការបញ្ជាក់នូវធាតុផ្សំផ្នែកច្បាប់តាមរយៈ ការបង្កើតការយល់ឃើញស្តីអត្ថិភាពឬផ្សេងពីនេះក្នុងករណីជនរងគ្រោះជាបុរសនៃធាតុផ្សំដូចគ្នា។

1501.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើវិធីសាស្ត្រថាតើត្រូវកែតម្រូវកំហុសនេះដូចម្តេច។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានកម្រិតការវាយតម្លៃផ្នែកច្បាប់របស់ខ្លួនត្រឹមបញ្ហាថាតើ ការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នេះ ត្រូវបានយល់ឃើញថាបានកើតឡើងជាបញ្ហាអង្គហេតុ ដែរ ឬយ៉ាងណា និងថាតើ ការប្រព្រឹត្តនេះបានបំពេញតាមលក្ខណៈតម្រូវធាតុផ្សំនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ដូចជា អំពើសកម្ម ឬអកម្ម ដែលបានបង្កព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា[4265]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណានូវអ្វីដែលជាការយល់ឃើញស្តីពីអំពើដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីបច្ចុប្បន្ននេះ។ នៅពេលចាប់ផ្តើមការយល់ឃើញផ្នែកអង្គច្បាប់ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ការរៀបចំត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋានសម្រាប់ឱ្យប្តីប្រពន្ធទើបរៀបអាពាហ៍ពិពាហ៍ថ្មីដេកក្នុងទីតាំងកំណត់ទុកជាពិសេសសម្រាប់ឱ្យរួមភេទ[4266]។ ឈ្លបជាទូទៅបានទទួលបញ្ជាឱ្យតាមដានប្តីប្រពន្ធដើម្បីឱ្យដឹងច្បាស់ថា ពួកគេបានរួមភេទ[4267]។ ទាំងបុរស និងស្ត្រីមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យរួមភេទ ហើយប្តីប្រពន្ធដែលរកឃើញថា ពុំបានរួមភេទត្រូវធ្វើការអប់រំ ឬគំរាមកំហែងសម្លាប់ ឬទទួលទណ្ឌកម្ម[4268]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសង្ខេបនេះត្រឹមត្រូវ និងរំឭកថា អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបានបដិសេធលើការជំទាស់ទៅនឹងការយល់ឃើញផ្នែកអង្គហេតុទាំងនេះខាងលើរួចហើយ។

1502.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា នៅក្នុងការយល់ឃើញមួយ អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាអំពីកង្វះការយល់ព្រមពីសំណាក់ស្ត្រី និងបានបញ្ជាក់ថា ការរើបម្រះមិនរួចផ្នែករាងកាយ"របស់ស្ត្រី" គឺមិនបានបង្ហាញពីការយល់ព្រមឡើយ[4269]។ អង្គជំនុំជម្រះតុលាការកំពូលបំភ្លឺថា

[4265] *សូមមើល* VII.ឆ.៣.ក.iii (ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។

[4266] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4267] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4268] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4269] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

ដូចបានគាំទ្រដោយការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ការយល់ឃើញអំពីកង្វះការយល់ព្រម និងរបៀបនៃការកំណត់នោះ ត្រូវអនុវត្តស្មើគ្នាទាំងបុរស និងស្ត្រី។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបញ្ជាក់ថា ការរួមភេទដោយបង្ខំគឺជាបទឧក្រិដ្ឋដែលពាក់ព័ន្ធជាមួយបុរស និងស្ត្រីដែលនីមួយៗជាជនរងគ្រោះ។

- *ជនរងគ្រោះជាស្ត្រី៖ បណ្តឹងសាទុក្ខរបស់ ខៀវ សំផន*

1503.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាំងបុរស និងស្ត្រីមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យរួមភេទជាមួយដៃគូថ្មីរបស់ខ្លួន និងថា "ក្នុងករណីស្ត្រី" អំពើនេះស្មើនឹងអំពើនៃការការរំលោភសេពសន្ថវៈ[4270]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ការរំលោភសេពសន្ថវៈដែលបានកើតឡើងក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានបង្កឱ្យមានបន្ថែមនូវការរងទុក្ខ ឬព្យសនកម្មលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ[4271]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកជាពិសេសការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបានបង្កឡើងលើបុគ្គលទាំងនោះដែលត្រូវបានរំលោភសេពសន្ថវៈថា ជាផ្នែកនៃលក្ខខណ្ឌតម្រូវដែលការរៀបអាពាហ៍ពិពាហ៍ត្រូវតែរួមដំណេក និងថា អំពើនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា[4272]។ ដោយពិចារណាជារួម អំពើនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4273]។

1504.ខៀវ សំផន បានលើកការជំទាស់ពីរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ ទីមួយ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើបរិបទនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ដោយសារអង្គជំនុំជម្រះគប្បីធ្វើឡើងក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពធ្ងន់ធ្ងរនោះ[4274]។ ទីពីរ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្កើតការយល់ឃើញរបស់ខ្លួនស្តីពីព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ។ ក្នុងការគាំទ្រ គាត់បានចង្អុល

---

[4270] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧-៣៧០០។

[4271] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

[4272] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៨។

[4273] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៨។

[4274] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៧-១២៩៩, ៣១៦, ១៣១៩-១៣២០។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨៤-១២៨៥។

បង្ហាញទៅលើការពិតដែលថា បុគ្គលផ្សេងៗពុំបានអះអាងជាក់លាក់ថា ពួកគេបានទទួលរងព្យសនកម្ម[4275] ហើយការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើហេតុការណ៍"ពិសេស"នៃការរំលោភសេពសន្ថវៈ ក្នុងការបង្កើតការយល់ឃើញទូទៅអំពីបរិយាកាសបង្ខិតបង្ខំ[4276]។

1505.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបរិបទនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី[4277]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា "រាល់អំពើនៃការរំលោភសេពសន្ថវៈ បានបង្ហាញនូវការរងទុក្ខ ឬព្យសនកម្មដោយពុំចាំបាច់ត្រូវបានបញ្ជាក់ច្បាស់លាស់នោះទេ"[4278]។

1506.សហមេធាវីនាំមុខបានអះអាងថា ពុំមានដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីណាម្នាក់បានផ្ដល់សក្ខីកម្មថា ទំនាក់ទំនងផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី បានបង្កឱ្យពួកគេរងទុក្ខធ្ងន់ធ្ងរនោះឡើយ[4279]។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយតបផងដែរទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីពុំបានបញ្ជាក់គ្រប់គ្រាន់អំពីការរងទុក្ខដែលបានបង្កឡើងដោយសារការរួមដំណេកដោយបង្ខំនៃការរៀបអាពាហ៍ពិពាហ៍នោះ និងបានពន្យល់ថា "បញ្ហារួមភេទគឺជារឿងប្រពៃណីហាមឃាត់ជាសាធារណៈ" ដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចស្ទាក់ស្ទើរក្នុងការនិយាយលើកលែងតែត្រូវបានសួរផ្ទាល់ និងថា ភស្តុតាងរបស់អ្នកជំនាញបានបញ្ជាក់ថា ការប៉ះទង្គិចផ្លូវចិត្តអាច "បង្កើតជាឧបសគ្គដល់ការនិយាយអំពីហិង្សាផ្លូវភេទ"[4280]។ សហមេធាវីនាំមុខបានអះអាងបន្ថែមទៀតថា "តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត នៅពេលធ្វើការវាយតម្លៃលើសក្ខីកម្មរបស់អ្នកដែលស្ថិតនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដែលពួកគេត្រូវបានបង្ខំឱ្យទទួលយក ឬអ្នកដែលមានកូនកើតចេញពីការរៀបអាពាហ៍ពិពាហ៍នោះ"[4281]។ ចុងក្រោយ សហមេធាវីនាំមុខបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកហេតុការណ៍នៃការរំលោភសេពសន្ថវៈថា ជាភស្តុតាងនៃបរិយាកាសបង្ខិតបង្ខំដោយ"ការបំភិត

---

[4275] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៧។

[4276] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៨។

[4277] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤-៣៦៨៥។

[4278] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥៨។

[4279] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៧៣។

[4280] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៤, ៦៨៧។

[4281] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៦។

បំភ័យ គំរាមកំហែង និងអំពើហិង្សា”ដែលបុគ្គលត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ[4282]។

ក) ការជាប់ពាក់ព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ

1507.យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើបរិបទនៃវប្បធម៌ និងស្របច្បាប់នៅពេលធ្វើការយល់ឃើញថា ការរួមដំណេកដោយបង្ខំនៃការរៀបអាពាហ៍ពិពាហ៍បានបង្កនូវព្យសនកម្មធ្ងន់ធ្ងរ[4283]។ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើការពិតដែលថា ក្នុងវប្បធម៌ប្រកាន់ប្រពៃណីសម្រាប់គូស្វាមីភរិយាដែលបានរៀបអាពាហ៍ពិពាហ៍ ការរួមភេទគឺជា“សិទ្ធិរបស់បុរស និងកាតព្វកិច្ចរបស់ស្ត្រី”[4284]។ សូម្បីនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីមានសេរីភាពតិចតួចក្នុងទំនាក់ទំនងរបស់ពួកគេជាមួយបុរស និងត្រូវបានតម្រូវឱ្យទទួលយកការរួមភេទ[4285]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ការហាមឃាត់ការរំលោភសេពសន្ថវៈក្នុងការរៀបអាពាហ៍ពិពាហ៍“នៅតែមិនមានលក្ខណៈពេញលេញ ឬគ្មានអត្ថិភាពទាំងស្រុង”នៅក្នុងរដ្ឋជាច្រើន[4286]។ នៅក្នុងសារណារបស់គាត់ កង្វះការដាក់ឱ្យទៅជាបទល្មើសនៃការរំលោភសេពសន្ថវៈសហព័ទ្ធគប្បីចាត់ទុកថា មានអានុភាពទៅលើភាពធ្ងន់ធ្ងរនៃបទល្មើស[4287]។

1508.សហព្រះរាជអាជ្ញាបានអះអាងថា លក្ខណៈ និងភាពធ្ងន់ធ្ងរនៃអំពើពុំត្រូវបានកាត់អានុភាពដោយសារការពិតដែលថា ការរួមភេទដែលពុំត្រូវការយល់ព្រមមានអត្ថិភាពក្នុងការរៀបអាពាហ៍ពិពាហ៍ ពីព្រោះអំពើមួយចំនួនតាមធម្មជាតិត្រូវបានចាត់ទុកថា ជាការបង្កឱ្យឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ[4288]។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានពិចារណាលើបរិបទពាក់ព័ន្ធវប្បធម៌ និងសង្គមកម្ពុ

---

[4282] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៩១។

[4283] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៧-១២៩៩, ១៣១៦, ១៣១៩-១៣២០។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៨៤-១២៨៥។

[4284] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១៩។

[4285] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២០។

[4286] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៨-១២៩៩។

[4287] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៩៧។

[4288] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៨០។

ជានៅពេលវាយតម្លៃលើផលប៉ះពាល់ដែលបានកើតចេញពីការរួមដំណេកដោយបង្ខំនៃការរៀបអាពាហ៍ពិពាហ៍ទៅលើបុគ្គល[4289]។

1509.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដោយផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយប្រុងប្រយ័ត្នលើវប្បធម៌ប្រកាន់ប្រពៃណី និងសង្គមកម្ពុជា ដែលជាផ្នែកមួយនៃការវាយតម្លៃអំពីព្យសនកម្មលើជនរងគ្រោះជាស្ត្រី។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការបាត់បង់ព្រហ្មចារី"នៅដក់ក្នុងចិត្តយ៉ាងខ្លាំងរបស់ជនរងគ្រោះជាច្រើន" ពីព្រោះក្នុងកម្ពុជា មានការឱ្យតម្លៃខ្លាំងទៅលើស្ត្រីដែលនៅបរិសុទ្ធរហូតដល់ពេលរៀបអាពាហ៍ពិពាហ៍[4290]។ ជាផលវិបាក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ក្នុងបរិបទសង្គម និងវប្បធម៌នេះ ការបាត់បង់ព្រហ្មចារីរបស់ស្ត្រីកម្ពុជា បានបណ្តាលឱ្យមានការរងទុក្ខបន្ថែមដល់ជនរងគ្រោះ ក្នុងករណីខ្លះកាន់តែធ្ងន់ធ្ងរថែមទៀតដូចជាការធ្វើឱ្យមានផ្ទៃពោះដែលពុំចង់បាន"[4291]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើប្រវត្តិនេះ ត្រូវបដិសេធចោល។

1510.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការអះអាងដែលថា ដោយសារជាប្រពៃណីដែលត្រូវរួមភេទក្នុងការរៀបអាពាហ៍ពិពាហ៍ នេះមានន័យថា ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យជា"ការសមស្រប" ជាជាងការបង្ខំ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមានភស្តុតាងណាមួយដែល ខៀវ សំផន យោងទៅលើដើម្បីគាំទ្រចំណុចនេះ។ សាក្សីជំនាញ Peg LEVINE បានឆ្លើយតបថា ការរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍ ជាទូទៅបានកើតឡើងក្នុងការរៀបអាពាហ៍ពិពាហ៍[4292] និង NAKAGAWA Kasumi បានអះអាងផងដែរថា កូនត្រូវបានរំពឹងឱ្យគោរពតាមក្រោយការរៀបអាពាហ៍ពិពាហ៍[4293]។ ទោះជាយ៉ាងណាក្តី សាក្សីដទៃទៀតបានបញ្ជាក់ច្បាស់ថា

---

[4289] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤-៣៦៨៥។

[4290] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៥។

[4291] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៥។

[4292] ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ (Peg LEVINE) ឯកសារលេខ E1/480.1 នៅម៉ោង ១៥.៥០ ("ពិតណាស់ ខ្ញុំមិនចង់មានន័យថា អ្វីដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈល្អប្រសើរនោះទេ ប៉ុន្តែ ការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ តាមធម្មតា ក្នុងលោកខាងលិច នៅពេលយើងនិយាយអំពីរាត្រីទឹកឃ្មុំយើងរំពឹងថានឹងកើតមាន")។

[4293] ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 នៅម៉ោង ១១.១៤។

នេះបានកើតឡើងចេញពីការរៀបអាពាហ៍ពិពាហ៍មួយដែលត្រូវបានបង្ខំលើពួកគេដោយ *អង្គការ*[4294]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា បើទោះបីជាមានការប្រតិបត្តិតាមប្រពៃណី និងការសន្មតនៃការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏អំពើដែលត្រូវបានចោទប្រកាន់ក្នុងរឿងក្តីបច្ចុប្បន្ន ជាពិសេសគឺជា ការរួមភេទដោយបង្ខំដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនបានពន្យល់នូវការដែលត្រូវបានតាមដោយឈ្លបប្រដាប់អាវុធ។ ភស្តុតាងបានបង្ហាញផងដែរថា បុគ្គលភ័យខ្លាចអាយុជីវិត ឬការដាក់ទណ្ឌកម្ម ដែលជាលទ្ធផលនៃការមិនរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ ប្រាក់ យុត ដែលភស្តុតាងរបស់គាត់ត្រូវបានគូសបង្ហាញដោយ ខៀវ សំផន ដើម្បីបំភ្លឺនូវការសន្និដ្ឋានដែលថា បុគ្គលត្រូវតែរួមដំណេកការរៀបអាពាហ៍ពិពាហ៍ បានពន្យល់ថា ប្តីប្រពន្ធ នឹងត្រូវបានធ្វើការអប់រំប្រសិនណាបើពួកគេខកខានក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍[4295]។ ភស្តុតាងនេះ ពុំបានប៉ះពាល់ដល់គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

### ខ) ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត

1511.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងជាច្រើនស្តីពីព្យសនកម្មបុគ្គលក្នុងផ្នែក ១៤.៣.៨.២ "បរិយាកាសបង្ខិតបង្ខំ"[4296] ១៤.៣.៨.៣ "ការរួមភេទដោយបង្ខំរវាងប្តីប្រពន្ធ"[4297] និង ១៤.៣.១២.២ "ផលប៉ះពាល់នៃការរួមភេទដោយបង្ខំលើជនរងគ្រោះ"នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង[4298]។ ខៀវ សំផន បានជំទាស់ទៅនឹងភស្តុតាងនីមួយៗដាច់ដោយឡែកពីគ្នាក្នុងផ្នែកទាំងនេះ និងជាផ្នែកៗ និងខកខានក្នុងការបង្ហាញការដែលកំហុសជាក់លាក់ណាមួយមានផលប៉ះពាល់ទៅលើពិរុទ្ធភាពរបស់គាត់ជារួមនោះ។ ដោយហេតុថា ការជំទាស់របស់គាត់បានលើកចំណុចរួមមួយចំនួន ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាជាក្រុមដូចបង្ហាញខាងក្រោម។

---

[4294] *សូមមើល ជាឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ធីម) ឯកសារលេខ E1/469.1 នៅម៉ោង ១១.១២ ("អង្គការ រៀបចំការរៀបអាពាហ៍ពិពាហ៍ឱ្យយើង។ បន្ទាប់មកយើងត្រូវនៅជាមួយគ្នា ដើម្បីយើងក្លាយជាប្តីប្រពន្ធ និងក្រោយមកទៀតមានកូន")។

[4295] ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារលេខ E1/378.1 នៅម៉ោង ១៣.៤៧។

[4296] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៥-៣៦៤៧។

[4297] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៨-៣៦៦១។

[4298] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៣-៣៦៨៥។

(i) នត្ថិភាពនៃការអះអាងច្បាស់លាស់អំពីព្យសនកម្ម

1512.ជាបន្ទាប់ ខៀវ សំផន បានចោទប្រកាន់កំហុសដោយសារមានបុគ្គលជាច្រើន“ពុំបានលើកឡើង”នូវការឈឺចាប់ និងការរងទុក្ខដែលពួកគេបានឆ្លងកាត់ដោយសារផលវិបាកនៃការរួមភេទដោយបង្ខំ[4299]។ គាត់បានលើកឡើងថា អ៊ុំ យឿន បានផ្តល់សក្ខីកម្មថា លោកស្រីមានជីវិតរស់នៅ“ធម្មតា”ជាមួយប្តី[4300]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតថា ជា ឌៀប ដូចគ្នាដែរពុំបាន“និយាយអំពីការរងទុក្ខ”[4301] និង សយ ណារឿន ក៏ពុំបាន“អះអាង”នូវការឈឺចាប់ចេញពីការរួមដំណេកដោយបង្ខំនោះដែរ ត្រឹមតែការសោកសៅផ្ទាល់ខ្លួនដោយសារការបាត់បង់ព្រហ្មចារីប៉ុណ្ណោះ[4302]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងប្រហាក់ប្រហែលគ្នាដែរខកខានក្នុងការពិចារណាលើចម្លើយរបស់ ណុប ងីម ដែលថា លោកស្រីពុំត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដែលតាមការអះអាងរបស់ ខៀវ សំផន គឺផ្ទុយទៅនឹងការសន្និដ្ឋានដែលថាការរួមភេទត្រូវបាន“បង្ខំដោយស្វ័យប្រវត្តិ”[4303]។ យោងតាម ខៀវ សំផន បានឱ្យដឹងថា ផាន់ ហ៊ីម បានបញ្ជាក់ច្បាស់លាស់ថា លោកស្រីពុំបានទទួលរងទុក្ខសោះឡើយ[4304]។ ខៀវ សំផន បានចោទប្រកាន់បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើទៅលើ“កម្រិតធ្ងន់ធ្ងរមិនគ្រប់គ្រាន់”ក្នុងភស្តុតាងរបស់ ជាំង ស្រីមុំ ដែលលោកស្រីពុំត្រូវបានបង្ខំឱ្យរួមភេទ និងថា “ការដែលត្រូវបានរៀបអាពាហ៍ពិពាហ៍ជាផ្លូវការបានធ្វើឱ្យការរួមភេទទៅជារឿងធម្មតា និងស្របច្បាប់”[4305]។

1513.សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានអះអាងដោយពុំត្រឹមត្រូវថា ហេតុផលតែមួយគត់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងពីគោលនយោបាយបង្កើនប្រជាជននោះ គឺកង្វះការប្រុងប្រយ័ត្ន និងការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រសម្រាប់ស្ត្រី និងថា នេះជាការពុំអើពើទៅលើបរិបទទាំងមូលដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើក្នុងការបង្កើតការយល់ឃើញនោះ[4306]។

---

[4299] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៧។

[4300] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៧។

[4301] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១២។

[4302] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៦។

[4303] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៧។

[4304] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៧។

[4305] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៥។

[4306] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧១១។

1514.សហមេធាវីនាំមុខបានឆ្លើយតបថា បញ្ហាផ្លូវភេទគឺជារឿងប្រពៃណីហាមឃាត់ជាសាធារណៈ និងថា ដើមបណ្តឹងរដ្ឋប្បវេណីអាចមានការស្ទាក់ស្ទើរនិយាយចេញមកអំពីបញ្ហានេះ[4307]។ សហមេធាវីនាំមុខបានអះអាងថា តម្រូវឱ្យមាន"ការយកចិត្តទុកដាក់បន្ថែម"នៅពេលធ្វើការវាយតម្លៃលើសក្ខីកម្មរបស់អ្នកដែលស្ថិតនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដែលពួកគេត្រូវបានបង្ខំឱ្យទទួលយក ឬអ្នកដែលមានកូនចេញពីការរៀបអាពាហ៍ពិពាហ៍នោះ[4308]។

1515.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដែលថា ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីពុំបានបញ្ជាក់ជាក់លាក់នូវព្យសនកម្មនោះ ជាលទ្ធផលពុំជាប់ពាក់ព័ន្ធ ជាពិសេសដូចបានសង្កេតដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលបញ្ហាផ្លូវភេទ គឺជារឿងប្រពៃណីហាមឃាត់ជាសាធារណៈក្នុងកម្ពុជា មានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីអាចមានការស្ទាក់ស្ទើរក្នុងការនិយាយអំពីបញ្ហានេះ[4309]។ អាស្រ័យហេតុនេះ បើទោះបីជា ជា ឡៀប ពុំបានបញ្ជាក់ច្បាស់លាស់ថា លោកស្រី"បានទទួលរងទុក្ខ"ក៏ដោយ ក៏ចម្លើយដោយឥតព្រលាំរបស់លោកស្រីដែលថា លោកស្រីបានជ្រើសរើសមិនរួមដំណេកក្នុងការរៀបអាពាហ៍ពិពាហ៍ គឺជាភស្តុតាងបង្ហាញលើសពីគ្រប់គ្រាន់អំពីព្យសនកម្មដែលលោកស្រីបានឆ្លងកាត់[4310]។ បន្ថែមលើនេះ បើទោះបីជា ណុប ង៉ឹម បានបញ្ជាក់ថា លោកស្រី និងប្តីរបស់ខ្លួនពុំបានបង្ខំគ្នារួមភេទក៏ដោយ[4311] ក៏លោកស្រីបានអះអាងច្បាស់លាស់ថា ពួកគាត់បានគោរពតាម"វិន័យអង្គការ"[4312]។ ប្តីប្រពន្ធនៅតែត្រូវបានបង្ខិតបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដោយរបបនោះ ដូចបានបង្ហាញខាងលើ ដែលជាការប្រព្រឹត្តមួយត្រូវបានចោទប្រកាន់ក្នុងរឿងក្តីបច្ចុប្បន្ននេះ។

1516.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើភស្តុតាងរបស់ ជាំង ស្រីមុំ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងនេះក្នុងការយល់ឃើញថា មានហេតុការណ៍"យ៉ាងតិចមួយករណីនៃការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅសហករណ៍ត្រាំកក់"[4313]។ ជាំង ស្រី

---

[4307] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៥។

[4308] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៦៨៦។

[4309] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៩។

[4310] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៦ (ជា ឡៀប) ឯកសារលេខ E1/466.1 ទំព័រ ៥៧-៥៩។

[4311] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៥៨-៥៩។

[4312] ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ង៉ឹម) ឯកសារលេខ E1/469.1 ទំព័រ ៥៩។

[4313] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៣-៣៦៧៤។

មុំ បានអះអាងថា ប្ដីលោកស្រីពុំបានបង្ខំលោកស្រីឱ្យរួមភេទទេ[4314] ប៉ុន្តែបានបញ្ជាក់ផងដែរថា លោកស្រីភ័យខ្លាចអាយុជីវិតប្រសិនបើមិនរួមដំណេកការរៀបអាពាហ៍ពិពាហ៍[4315]។ នេះស្របជាមួយនឹងការយល់ឃើញដូចបានបង្ហាញខាងលើដែលថា ខៀវ សំផន បានចាប់ផ្ដើមតាមរយៈការយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងករណីដើមបណ្ដឹងរដ្ឋប្បវេណី ជាំង ស្រីមុំ ដែលថា មានហេតុការណ៍ "យ៉ាងហោចណាស់មួយករណីនៃការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅសហករណ៍ត្រាំកក់"[4316]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "យ៉ាងហោចណាស់"មួយករណីនៃការរំលោភសេពសន្ថវៈ បានកើតឡើងនៅសហករណ៍ត្រាំកក់[4317]។ ការយល់ឃើញដោយប្រុងប្រយ័ត្ននេះ បានឆ្លុះបញ្ចាំងសមស្របនូវការសន្និដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងដោយផ្អែកលើភស្តុតាងចំពោះមុខខ្លួន។ អំណះអំណាងនេះត្រូវបដិសេធចោល។

1517. ខៀវ សំផន បានលើកភស្តុតាងបង្ហាញពុំត្រឹមត្រូវផងដែរដោយបានផ្ដោតទៅលើផ្នែកដាច់ដោយឡែកពីគ្នា និងពុំបានពិចារណាលើរូបភាពទាំងមូលនៃភស្តុតាងនោះ។ ជាពិសេសនេះជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងរបស់ អ៊ុំ យឿន ដែលបានអះអាងថា លោកស្រីពុំដែលបង្កើតមនោសញ្ចេតនាជាមួយប្ដីលោកស្រី និងភ័យខ្លាចប្ដីលោកស្រីធ្វើការរំលោភសេពសន្ថវៈលើរូបគាត់នៅយប់ពិធីរៀបអាពាហ៍ពិពាហ៍នោះ[4318] និងថា ជាក់ស្ដែងលោកស្រីត្រូវបានរំលោភសេពសន្ថវៈដោយកម្មាភិបាលម្នាក់ដែលនេះជាការដាក់ទណ្ឌកម្មសម្រាប់ការប្រកែកលើកដំបូងមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍[4319]។ ចម្លើយដាច់ដោយឡែកដែលថា លោកស្រីបានរស់នៅក្នុងកម្រិតមួយដូច"ជីវិតធម្មតា"[4320] ពុំមានទម្ងន់អាចប្រៀបធៀបបានជាមួយនឹងចម្លើយច្បាស់

---

[4314] ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ២៦។

[4315] ជាំង ស្រីមុំ បានអះអាងផងដែរថា លោកស្រីពុំមានជម្រើសក្រៅតែពីដេកជាមួយប្ដីគាត់ ពីព្រោះបើមិនដូច្នេះទេ គាត់ត្រូវបាត់បង់ជីវិត *សូមមើល* ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ២៦-២៧។ បក្សមិនមែនប្ដីខ្ញុំទេ ដែលជាចារីនៃការរំលោភសេពសន្ថវៈ។

[4316] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៤។

[4317] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧៤ យោងទៅលើកថាខណ្ឌ ៣៦៧៣ (ជើងទំព័រ ១២២៥៦)។ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 ទំព័រ ២៩-៣០ យោងទៅលើការទទួលយកការរួមភេទ ដោយសារគាត់គិតថា គ្មានជម្រើស។

[4318] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ៤, ៤៧។

[4319] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ៥។

[4320] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (អ៊ុំ យឿន) ឯកសារលេខ E1/462.1 ទំព័រ ៤៨។

លាស់ស៊ីសង្វាក់នៃការរងទុក្ខធ្ងន់ធ្ងរដែលបានទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណីនេះឡើយ។ សយ ណាវឿន បានផ្ដល់ភស្តុតាងជាក់លាក់ស្ដីពីបទពិសោធន៍របស់ខ្លួននៃការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងបានអះអាងថា លោកស្រីមានការលំបាកក្នុងការដកដង្ហើម និងឈឺចាប់ស្ទើរពុំគួរឱ្យជឿ[4321]។ ដូច្នេះ ការឈឺចាប់របស់លោកស្រីពុំមែនតែរឿងបាត់បង់ជាទូទៅនូវព្រហ្មចារីនោះទេ ដែលនេះផ្ទុយពីការអះអាងរបស់ ខៀវ សំផន[4322]។ អាស្រ័យហេតុនេះ រាល់ការលើកឡើងរបស់ ខៀវ សំផន ទាំងអស់ពាក់ព័ន្ធទៅនឹងសាក្សីទាំងនេះ ត្រូវបដិសេធចោល។

1518.ទាក់ទងទៅនឹងភស្តុតាងរបស់ ផាន់ ហ៊ីម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លោកស្រីគឺជាករណីពិសេសចំពោះការសន្និដ្ឋានដែលថា ស្ត្រីត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍[4323]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញលើភស្តុតាងនៃការរងទុក្ខរបស់លោកស្រី និងដូច្នេះសារណារបស់ ខៀវ សំផន ដែលលើកផ្ទុយនេះ ត្រូវបដិសេធចោលផងដែរ។

(ii) "ការរំលោភសេពសន្ថវៈ"ដែលជាផ្នែកនៃបរិយាកាសបង្ខិតបង្ខំ

1519.ជាបន្ទាប់ ខៀវ សំផន បានលើកការជំទាស់ទៅនឹងភស្តុតាងដែលតាមការអះអាងរបស់គាត់ថា បានបង្ហាញនូវហេតុការណ៍ពិសេសនៃព្យសនកម្ម និងថា នេះគឺជាកំហុសក្នុងការសន្និដ្ឋានជាទូទៅដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើសេចក្ដីសន្និដ្ឋានទូលំទូលាយអំពីព្យសនកម្មរបស់ជនរងគ្រោះ។ ខៀវ សំផន បានអះអាងថា "ការរំលោភសេពសន្ថវៈ" ដែល មុំ វុន និង ប៉ែន សុចាន់ បានទទួលរង គឺ"ផ្ទុយគ្នាទាំងស្រុងទៅនឹងគោលការណ៍សីលធម៌ដែលបានគាំទ្រដោយបក្សកុម្មុយនីស្តកម្ពុជា" និងដូច្នេះ ពុំគប្បីចាត់ទុកថា ជាផ្នែកនៃបទពិសោធន៍ទូទៅនៃព្យសនកម្មឡើយ[4324]។

1520.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃសក្ខីកម្មរបស់ មុំ វុន និង ប៉ែន សុចាន់ ដោយបានចាត់ទុកពួកគាត់ថា "ជាករណីពិសេស" និង"ខុសពីធម្មតា" និងពុំបានអើពើបរិយាកាសបង្ខិតបង្ខំដែលបានធ្វើឱ្យការស្ម័គ្រចិត្តពុំអាចធ្វើទៅបាន[4325]។

---

[4321] ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៦ (សយ ណាវឿន) ឯកសារលេខ E1/489.1 ទំព័រ ៣០-៣១។

[4322] *ធៀបនឹង* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៦។

[4323] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៩។

[4324] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣០៨។

[4325] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៧៥៥។

1521.សហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញភស្តុតាងគាំទ្រអំណះអំណាងរបស់គាត់ដែលថា អំពើ ឬគំនិតរបស់ឈ្លបនោះជាករណីខុសពីធម្មតា។ សហមេធាវីនាំមុខបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងគោលការណ៍សីលធម៌ពុំមែនជានិច្ចកាលត្រូវបានគោរពតាម ដូចបានបញ្ជាក់បន្ថែមដោយសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន និង អ៊ុំ យឿន[4326]។

1522.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ មុំ វុន ដែលថា លោកស្រីត្រូវបាន"រំលោភសេពសន្ថវៈ"ដោយកម្មាភិបាលប្រាំនាក់ក្រោយពីការប្រកែកដំបូងមិនព្រមរៀបអាពាហ៍ពិពាហ៍[4327] ព្រមទាំងភស្តុតាងរបស់ ប៉ែន សុចាន់ ដែលថា ក្រោយការប្រកែកមិនព្រមរួមដំណេកការរៀបអាពាហ៍ពិពាហ៍របស់លោកស្រី គាត់ត្រូវបាន"រំលោភសេពសន្ថវៈ"ដោយប្តីរបស់លោកស្រីខណៈពេលឈ្លបប្រាំនាក់ចាំឈរមើល[4328]។ ដូចបានបង្ហាញខាងលើ ការយល់ឃើញនេះបង្កើតបានជាបរិបទនៃការបង្ខិតបង្ខំដែលនាំឱ្យបុគ្គលត្រូវរួមភេទក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយមានអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរួមភេទរវាងប្តីប្រពន្ធដែលត្រូវបានបង្ខំឱ្យកើតមានដោយរដ្ឋ។

(iii) ការជំទាស់ទៅនឹងភាពគួរជឿជាក់បាន

1523.ជាបន្ទាប់ ខៀវ សំផន បានលើកការជំទាស់ជាច្រើនទៅនឹងភាពគួរជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីទាំងនោះដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើសក្ខីកម្មផ្ទុយគ្នារបស់ ព្រាប សុខឿន ជាពិសេសការដែល "លោកស្រីទម្រាំដាក់ចិត្តឆ្លើយថា លោកស្រីត្រូវបានប្តីចាប់រំលោភសេពសន្ថវៈ"[4329] និងបានជំទាស់ផងដែរទៅលើអានុភាពនៃការរងទុក្ខរបស់លោកស្រី[4330]។

1524.ផ្ទុយទៅនឹងអំណះអំណាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើការបង្អង់ឆ្លើយនៃភស្តុតាងរបស់ ព្រាប សុខឿន ស្តីពីអត្ថិភាពនៃការរំលោភសេពសន្ថវៈ និងបានរកឃើញថា ពុំបានប៉ះពាល់ដល់ភាពគួរ

---

[4326] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧៩៨។

[4327] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥០។

[4328] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥២។

[4329] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១៤។

[4330] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៨។

ជឿជាក់របស់លោកស្រីឡើយ[4331]។ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានបង្ហាញនូវកំហុស ដូច្នេះអំណះអំណាងរបស់គាត់ត្រូវបដិសេធចោល។ ដោយសារ ខៀវ សំផន ពុំបានផ្ដល់ការគាំទ្របន្ថែមទាក់ទងទៅនឹងសារណារបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដោះបន្ទុក ឬលក្ខណៈផ្ទុយនៃភស្តុតាងនោះ អំណះអំណាងនេះត្រូវបដិសេធចោលផងដែរ។

1525.ខៀវ សំផន បានអះអាងផងដែរថា មុំ វុន បានផ្ដល់ភស្តុតាងពុំស៊ីសង្វាក់គ្នាអំពីកាលបរិច្ឆេទនៃការបាត់ខ្លួនប្ដីរបស់គាត់ និង ប៉ែន សុចាន់ បានអះអាងថា លោកស្រីបានរៀបអាពាហ៍ពិពាហ៍នៅអាយុ ១៥ ឆ្នាំ ដែលផ្ទុយទៅនឹងបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍[4332]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបានបដិសេធការជំទាស់របស់ ខៀវ សំផន ទៅនឹងភាពគួរជឿជាក់បានរបស់ មុំ វុន ខាងលើរួចហើយ[4333]។ ទាក់ទងទៅនឹង ប៉ែន សុចាន់ ខៀវ សំផន ពុំបានពន្យល់នូវមូលហេតុដែលលោកស្រីត្រូវបានរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង បានប៉ះពាល់ដល់ភាពគួរជឿជាក់របស់លោកស្រីដូចម្ដេចឡើយ។ អំណះអំណាងនេះត្រូវបដិសេធចោលផងដែរ។

(iv) ស៊ូ សុធាវី

1526.ខៀវ សំផន បានលើកឡើងថា ស៊ូ សុធាវី បានផ្ដល់ភស្តុតាង“មិនពិតប្រាកដ”ត្រង់ថា គាត់មាន“លក្ខណៈពិសេសជាស្ត្រីភេទទីបី”[4334]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា “ពុំមានកន្លែងណាដែលសក្ខីកម្មរបស់ ស៊ូ សុធាវី បានលើកឡើងនូវប្រធានបទស្ដីពីអារម្មណ៍ ឬមនោសញ្ចេតនារបស់ប្រពន្ធគាត់”[4335]។ តាមការអះអាងរបស់ ខៀវ សំផន ថា នេះគឺបញ្ហាសំខាន់ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការកំណត់នូវ“ផលប៉ះពាល់នៃព្រឹត្តិការណ៍ពាក់ព័ន្ធទៅនឹងប្រពន្ធរបស់ ស៊ូ សុធាវី និងកាន់តែពុំអាចកំណត់ចរិតលក្ខណៈលើកម្រិតនៃភាពធ្ងន់ធ្ងរបាន”[4336]។

---

[4331] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4332] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧៣, ១៣០៨-១៣០៩។

[4333] *សូមមើលខាងលើ* ផ្នែក VII.ធ.៣.គ។

[4334] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១០។

[4335] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១០។

[4336] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣១០។

1527.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ស៊ូ សុធាវី ដែលថា "គាត់ និងប្រពន្ធរបស់គាត់"បានរួមដំណេកការរៀបអាពាហ៍ពិពាហ៍តែក្រោយពេលដែលត្រូវបានគេព្រមានថា "ពួកគេនឹងត្រូវកម្ទេច"ប្រសិនបើមិនព្រមរួមដំណេក[4337]។ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសពិចារណាលើបទពិសោធន៍របស់ប្រពន្ធ ស៊ូ សុធាវី ដែលពុំបានផ្តល់ភស្តុតាងចំពោះមុខតុលាការ ជាការសមស្របក្នុងការពិចារណាលើចំណុចជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់ ស៊ូ សុធាវី ស្តីពីការភ័យខ្លាចគេយកទៅ"កម្ទេច"ប្រសិនបើប្រកែកមិនព្រមរួមភេទនោះ។

1528.អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ទាក់ទងទៅនឹងបញ្ហានៃការរួមភេទដោយបង្ខំ ករណី ស៊ូ សុធាវី បានបង្ហាញនូវការពិចារណាដាច់ដោយឡែកដោយសារឋានៈរបស់គាត់មានភេទជាបុរសផ្នែកជីវសាស្ត្រ ដែលបានបញ្ជាក់អត្តសញ្ញាណដោយខ្លួនឯងថា ជាស្ត្រីភេទទីបី។ ពិតណាស់ នៅក្នុងការរួមភេទដោយបង្ខំដែលគាត់បានឆ្លងកាត់នោះ ស៊ូ សុធាវី បានតម្រូវឱ្យកាត់សក់ខ្លី និងស្លៀកសំលៀកបំពាក់ដូចបុរស[4338]។ បន្ថែមលើនេះ ដូចករណីនៃ"ប្តី"ដទៃទៀតដែលទទួលរងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយបង្ខំក្រោយមកនោះ ស៊ូ សុធាវី ត្រូវបានបង្ខំឱ្យស៊កបញ្ចូលអង្គជាតទៅក្នុងប្រដាប់ភេទស្ត្រី ដែលភាគីទាំងពីរពុំបានស្ម័គ្រចិត្តទៅនឹងអំពើនេះ ប៉ុន្តែបានចូលរួមដោយសារការភ័យខ្លាចនៃការស្លាប់។ ពាក់ព័ន្ធបញ្ហានេះ នៅពេលវាយតម្លៃអំពីព្យសនកម្មដែលបានបង្កឡើងចំពោះជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាការសមស្របត្រូវពិចារណាលើព្យសនកម្មដែល ស៊ូ សុធាវី បានទទួលរងនោះ។

1529.ខុសគ្នាពី"ប្តី"ដទៃភាគច្រើន ទោះជាយ៉ាងណាក្តី ស៊ូ សុធាវី បានទទួលរងព្យសនកម្មបន្ថែមដោយសារត្រូវបានបង្ខំឱ្យស្លៀកពាក់ និងធ្វើខ្លួនដូចបរស ព្រមទាំងការរួមភេទដែលជាប់ពាក់ព័ន្ធទៅនឹងការស៊កបញ្ចូលអង្គជាតភេទជីវសាស្ត្រដែលផ្ទុយទៅនឹងអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ ស៊ូ សុធាវី ដែលជាស្ត្រីភេទទីបី។ ស៊ូ សុធាវី បានឆ្លងកាត់ស្ថានការដ៏ធ្ងន់ធ្ងរដោយបានសំដៅទៅលើការដែលលោកស្រីដឹងអំពីស្ត្រីភេទទីបីដទៃទៀតដែលផឹកថ្នាំពុល ឬធ្វើអត្តឃាតជាជាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយស្ត្រីដែលតម្រូវឱ្យរួមដំណេកនោះ[4339]។ បន្ថែមលើនេះ លោកស្រីបានពិពណ៌នាអំពីហេតុការណ៍តែមួយគត់នៃការរួមភេទដោយ

---

[4337] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៧ យោងទៅលើប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៧៣-៧៤។

[4338] កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ូ សុធាវី ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារលេខ E3/4609 ERN 00418474។

[4339] ប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/462.1 ទំព័រ ៨១។ ប្រតិចារឹកថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ (ស៊ូ សុធាវី) ឯកសារលេខ E1/463.1 ទំព័រ ២៤-២៥។

បង្ខំ"ក្នុងមួយជីវិតខ្ញុំនេះ តែម្ដងហ្នឹងទេ មកចំណាស់នេះហើយ ៧៧ ៧៨ ហើយ តែម្ដងហ្នឹងទេស្គាល់រស់ជាតិស្ត្រី"[4340]។ ដោយសារព្យសនកម្មធ្ងន់ធ្ងរដែលបង្កឡើងដោយការរួមភេទដោយបង្ខំលើ ស៊ូ សុធារី ដែលជាស្ត្រីភេទទីបី អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាបន្ថែមលើបទពិសោធន៍របស់គាត់ក្នុងការយល់ឃើញអំពីការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្តដែលបានបង្កលើស្ត្រី។

គ) ភស្តុតាងនៃព្យសនកម្មដែលពុំត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង

1530.បន្ថែមលើការជំទាស់របស់គាត់ទៅលើភស្តុតាងដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការយល់ឃើញស្ដីពីការរួមដំណេកដោយបង្ខំ ខៀវ សំផន បានជំទាស់ផងដែរទៅនឹង"ការវិភាគតាមបែបជ្រើសរើស និងលម្អៀង"របស់អង្គជំនុំជម្រះសាលាដំបូង ដែលខកខានក្នុងការពិចារណាលើភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត[4341]។ ជាការគាំទ្រ គាត់បានយោងទៅលើដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីមួយចំនួនដែលជាស្ត្រីដែលគាត់អះអាងថា ពុំបានផ្ដល់ភស្តុតាងអំពីការរងទុក្ខណាមួយ និងបានចោទប្រកាន់ផងដែរនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីភស្តុតាងរបស់បុរសដែលបានផ្ដល់សក្ខីកម្មអំពីបទពិសោធន៍ប្រពន្ធនៃការរួមដំណេកក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4342]។

1531.ពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីភាគច្រើនដែលជាស្ត្រី និងត្រូវបានចង្អុលបង្ហាញដោយ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គាត់យល់ពុំត្រឹមត្រូវជាថ្មីម្ដងទៀតនូវលក្ខណៈនៃព្យសនកម្មដែលបង្ហាញឱ្យឃើញដោយខ្លួនឯងកើតចេញពីការរួមភេទដោយបង្ខំ និងបានអះអាងថា សេចក្ដីសន្និដ្ឋានគប្បីទាញចេញពីកង្វះការលើកឡើងជាក់លាក់អំពីព្យសនកម្ម។ ដូច្នេះ ការដែលថា ង៉ែត ចាត បានផ្ដោតទៅលើការភ័យខ្លាចដែលលោកស្រី និងប្ដីបានឆ្លងកាត់នៅពេលបានស្ដាប់ឮឈ្លបនៅយប់នៃពិធីរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ជាជាងបានបញ្ជាក់ច្បាស់លាស់អំពីព្យសនកម្មដែលបានបង្កតាមរយៈការរួមដំណេកនោះ[4343] ពុំជាប់ពាក់ព័ន្ធឡើយ[4344]។ ហេង ឡៃហ៊ាង បានពន្យល់នូវការដែលលោកស្រី និងប្ដីពុំបានរួមដំណេកក្នុងការ

---

[4340] ប្រតិចារឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធារី) E1/463.1 ទំព័រ ៣៦។ ប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ (ស៊ូ សុធារី) ឯកសារលេខ E1/462.1 ទំព័រ ៧៤។

[4341] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៤។

[4342] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៥-១៣៣៥។

[4343] ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (ង៉ែត ចាត) ឯកសារលេខ E1/488.1 ទំព័រ ៨៦-៨៧។

[4344] *ប្រៀបធៀប* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៦។

រៀបអាពាហ៍ពិពាហ៍ភ្លាមៗនោះ ពីព្រោះពួកគាត់ពុំចូលចិត្តគ្នានៅពេលដែលពួកគាត់ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[4345]។ នេះជាការពុំជាប់ពាក់ព័ន្ធផងដែរថា លោកស្រី"ពុំបាននិយាយអំពីផលប៉ះពាល់ជាក់លាក់ដែលបណ្តាលមកពីការរួមភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍នោះ"[4346]។ ប្រហាក់ប្រហែលគ្នានេះ ថៅ ឡាង "ពុំបានលើកឡើងអំពីការទទួលរងសម្ពាធ ឬការឈឺចាប់ណាមួយ"[4347] ប៉ុន្តែបានអះអាងថាលោកស្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[4348]។ អ៊ិន យឿង ពុំបាន"លើកឡើង"នូវការរងទុក្ខ ប៉ុន្តែបានអះអាងថា លោកស្រីត្រូវតែរួមដំណេកការរៀបអាពាហ៍ពិពាហ៍[4349]។ ជាំង ស្រីមុំ បានបញ្ជាក់ច្បាស់ថាលោកស្រីមានអារម្មណ៍ថា ត្រូវបានបង្ខំដោយរបបឱ្យរួមភេទជាមួយប្តីរបស់ខ្លួន បើទោះបីជាប្តីគាត់ពុំបានបង្ខំលោកស្រីជាលក្ខណៈបុគ្គលក៏ដោយ[4350]។ ធុច ស៊ីថន បានអះអាងដោយឥតព្រលាំថា លោកស្រីត្រូវបង្ខំចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយប្តីលោកស្រីដោយសារភ័យខ្លាចផលវិបាកធ្ងន់ធ្ងរ[4351]។ ការដែលថា សួន យឹម ពុំបានឆ្លងកាត់បទពិសោធន៍នៃបញ្ហាផ្លូវចិត្ត ឬរូបកាយ"ជាក់លាក់"ដោយសារការរួមភេទនោះ ពុំបានកាត់បន្ថយអានុភាពនៃព្យសនកម្មដែលបានកើតឡើងឡើយ[4352]។

1532.ខៀវ សំផន ខកខានផងដែរក្នុងការបង្ហាញហេតុដូចម្តេចបានភស្តុតាងរបស់ស្ត្រីដទៃទៀតដែលគាត់បានយោងទៅលើ គប្បីយកមកប្រើប្រាស់ ដើម្បីបដិសេធការសន្និដ្ឋាននៃព្យសនកម្មដោយសារការរួមដំណេកដោយបង្ខំ។ ភស្តុតាងដែលថា ខៀវ ហាន បានរៀបអាពាហ៍ពិពាហ៍ឡើងវិញក្រោយរបបនោះ[4353] និងថា ហ

---

[4345] ប្រតិចារិក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦(ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 នៅម៉ោង ១៦.១២។

[4346] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៨។

[4347] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៣២។

[4348] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៣២ យោងទៅលើប្រតិចារិក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ (ថៅ ឡាង) ឯកសារលេខ E1/339.1 នៅម៉ោង ១៤.៤០។

[4349] ប្រតិចារិក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ (អ៊ិន យឿង) ឯកសារលេខ E1/387.1 នៅម៉ោង ១៥.៣៩។

[4350] ប្រតិចារិក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារលេខ E1/254.1 នៅម៉ោង ១៥.៤៣។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយរបស់ ខែត សុខន ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ E3/9830 ស៖ ៨១-៨២ (ប្តីរបស់ ខែត សុខន បានសុំគាត់រួមភេទ ពុំបានបង្ខំគាត់ឡើយ)។

[4351] ប្រតិចារិក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ (ធុច ស៊ីថន) ឯកសារលេខ E1/500.1 ទំព័រ ៥៥-៥៦។

[4352] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន យឹម ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារលេខ E3/9829 ស៖ ២៩-៣០។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយ មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារលេខ E3/9736 ស៖ ១១២។

[4353] កំណត់ហេតុនៃការស្តាប់ចម្លើយ ខៀវ ហាន ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ E3/5559 ERN 00375526។

ង់ អ៊ិន ចូលចិត្តប្តីរបស់គាត់នៅពេលណាមួយក្នុងអនាគត[4354] ពុំជាប់ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានដែលថា ការរួមដំណេកដោយបង្ខំបានបង្កឱ្យមានព្យសនកម្មឡើយ។ ការដែលថា ខឿន ចឹម និង ស្រី សៀម ពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ភ្លាមៗនោះពុំជាប់ពាក់ព័ន្ធផងដែរ[4355]។ បន្ថែមលើនេះ ភស្តុតាងដែលថា ក្នុងបរិយាកាសដាច់ដោយឡែក ការរួមដំណេកដោយបង្ខំនោះពុំបានកើតឡើងទាល់តែសោះ[4356] ឬបានកើតឡើងសម្រាប់ហេតុផលផ្សេងជាជាងសម្ពាធពីរបបកម្ពុជាប្រជាធិបតេយ្យ[4357] ពុំបានកាត់បន្ថយអានុភាពនៃភស្តុតាងជាច្រើនសន្ធឹកសន្ធាប់ដែលបង្ហាញនូវអត្ថិភាព និងផលប៉ះពាល់ និងព្យសនកម្មនៃការរួមដំណេកដោយបង្ខំ។ អាស្រ័យហេតុនេះ សារណានេះត្រូវបដិសេធចោល។

1533.ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើភស្តុតាងរបស់សាក្សីជាបុរសពាក់ព័ន្ធទៅនឹងព្យសនកម្មដែលប្រពន្ធរបស់ពួកគេបានទទួលរងផ្សេងគ្នានោះឡើយ។ ជនរងគ្រោះជាបុរសមាន អែម អឿន, យស ផល, សេង សឿន, ជាល ជឿន និង ម៉ី សាវឿន ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា ពុំបានផ្តល់ភស្តុតាងអំពីបទពិសោធន៍របស់ប្រពន្ធខ្លួនឡើយ[4358] ហើយការរៀបរាប់របស់អ្នកទាំងនេះ“ពុំអាចឱ្យចង្អុលបង្ហាញអំពីផល

[4354] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហង់ អ៊ិន ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ E3/5558 ERN EN 00375518។

[4355] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៥ ឯកសារលេខ E3/9828 ស៖ ១១។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សៀម ឯកសារលេខ E3/9826 ស៖ ១៦៩-១៧១។

[4356] ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ (ជុំ សាមឿន) ឯកសារលេខ E1/321.1 នៅម៉ោង ១៤.២៧ (ជុំ សមឿន ពិពណ៌នាអំពីការភ័យតក់ស្លុតរបស់គាត់នៅយប់ពិធីរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែចុងក្រោយបានបែកគ្នាបីថ្ងៃ។ ក្រោយមកគ្មានការរួមដំណេក)។ កំណត់ ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ម៉ៅ គ្រឿន ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ E3/5561 ERN 5561 ERN 00375550-00375551 (ប្តី និងលោកស្រីបានបែកគ្នាក្រោយពិធីរៀបអាពាហ៍ពិពាហ៍)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២៤ ឯកសារលេខ E3/9831 ស៖ ១២០-១២១ (ពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងបានរស់ជាមួយប្តីអស់រយៈពេល ២៩ ថ្ងៃ)។

[4357] ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ (ឃិន វ៉ាត) ឯកសារលេខ E1/325.1 (បានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក្រោយមានអារម្មណ៍អាណិតប្តី)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E3/9831 ស៖ ២០-៤៩, ៥៥, ៥៩, ៨៦ (ពួកគេមានអារម្មណ៍ដូចប្តីប្រពន្ធដែលបានរៀបការដោយស្ម័គ្រចិត្ត)។ កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ាន់ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E3/9756 ស៖ ៤៥, ៤៨, ៥០ (ស្រលាញ់ប្តី និងពុំដែលគិតចាកចេញពីប្តី)។

[4358] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៦, ១៣២៩, ១៣៣៤-១៣៣៥។

ប៉ះពាល់ជាយថាហេតុណាមួយ”លើស្ត្រីជាប្រពន្ធរបស់ពួកគេឡើយ[4359]។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងពុំបានសំអាងទៅលើសាក្សីបុរសទាំងនេះសម្រាប់ភស្តុតាងពាក់ព័ន្ធនឹងបទពិសោធន៍ប្រពន្ធរបស់ពួកគេឡើយ ប៉ុន្តែផ្ទុយទៅវិញ បានសំអាងទៅលើភស្តុតាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលជាចម្បងបានផ្តោតលើព្យសនកម្មដែលត្រូវបានបង្កដោយផ្ទាល់លើពួកគេនោះ។ ខៀវ សំផន ខកខានក្នុងការទទួលស្គាល់ផងដែរថា ការរួមភេទដោយបង្ខំបង្ហាញដោយប្រយោលនូវកម្រិតមួយធ្ងន់ធ្ងរ។ អាស្រ័យហេតុនេះ ការដែល យស ផល ពុំបានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ភ្លាមៗនោះ ពុំមានអានុភាពទៅលើការសន្និដ្ឋានដែលថា ការរួមភេទត្រូវបានបង្ខំ[4360]។ ម៉ី សាវឿន បានអះអាងថា គាត់ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ខ្លួន[4361] ដូច្នេះ ការដែលថា គាត់បានបង្អង់ការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ពុំបានកាត់បន្ថយអានុភាពនៃការបង្ខំឡើយ[4362]។ បន្ថែមលើនេះ ការដែលថា សេង សឿន និង ជាល ជឿន ពុំបានផ្តល់ភស្តុតាងអំពីការរួមដំណេកនោះ ពុំជាប់ពាក់ព័ន្ធឡើយ ដោយសារអ្នកទាំងពីរពុំបានអះអាងថា ការរួមដំណេកនោះពុំបានកើតឡើងឡើយ។

- ***ជនរងគ្រោះជាបុរស៖ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា***

1534. អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក“ការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលត្រូវបានបង្កឡើងមកលើបុគ្គលដែលត្រូវបានរំលោភសេពសន្ថវៈ ថាជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃការរៀបអាពាហ៍ពិពាហ៍ដែលត្រូវតែរួមដំណេក និងថា អំពើនោះត្រូវបានប្រព្រឹត្តឡើងដោយចេតនា”[4363]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅពេលពិចារណាជារួម អំពើនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា អាស្រ័យហេតុនេះ ធាតុផ្សំសត្យានុម័តនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានបង្ហាញ[4364]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បើទោះបីជាបុរសពុំអាចប្រកែកផងដែរក្នុងការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ពុំមាន“ភស្តុតាងច្បាស់លាស់ពាក់ព័ន្ធទៅនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះ

---

[4359] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣២៩។

[4360] ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 នៅម៉ោង ១០.០៣។

[4361] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៣៤។

[4362] *សូមមើល* ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១៦ (ម៉ី សាវឿន) ឯកសារលេខ E1/459.1 នៅក្រោមម៉ោង ១៤.១០។

[4363] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៨។

[4364] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៨។

ពាល់លើបុរសឡើយ”[4365]។ អាស្រ័យហេតុនេះ ទោះបីជាទទួលស្គាល់ថា បុរសបាន“ទទួលអំពើហិង្សាផ្លូវភេទដែលផ្ទុយទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ” ក៏អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្កើតការយល់ឃើញមួយស្តីពីការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបុរសទាំងនោះបានទទួលរងឡើយ[4366]។

1535.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរួមដំណេកដោយបង្ខំក្នុងករណីជនរងគ្រោះជាបុរសពុំបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ក្នុងការយល់ឃើញអំពីព្យសនកម្ម ឬការរងទុក្ខលើរូបកាយ និងផ្លូវចិត្តពីសំណាក់បុរស[4367]។ សហព្រះរាជអាជ្ញាបានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា បើទោះបីជាបុរសត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទ ដែលផ្ទុយទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏នេះពុំអាចកំណត់បានអំពីភាពធ្ងន់ធ្ងរនៃការរងទុក្ខ និងជាលទ្ធផល ពុំអាចសន្និដ្ឋានបានថា បុរស គឺជាជនរងគ្រោះនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[4368]។ សហព្រះរាជអាជ្ញាបានលើកឡើងថា កំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ទាំងនេះ បានធ្វើឱ្យសេចក្តីសម្រេចទៅជាមោឃៈ និងបណ្តាលឱ្យមានភាពមិនយុត្តិធម៌[4369]។ សហព្រះរាជអាជ្ញាបានស្នើសុំថា ការយល់ឃើញទាំងនេះត្រូវបដិសេធចោល និងថា ការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ត្រូវបានកែតម្រូវដោយរួមបញ្ចូលអំពើហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរស[4370]។

1536.ខៀវ សំផន បានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ជាការដែលពុំអាចទៅរួចសម្រាប់បញ្ហាអង្គហេតុ ឬអង្គច្បាប់ក្នុងការសន្និដ្ឋានថា ការរងទុក្ខដែល“ជនរងគ្រោះជាបុរសនៃអំពើហិង្សាផ្លូវភេទក្នុងគ្រួសារ”បានឆ្លងកាត់នោះ មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ស្មើទៅនឹងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត[4371]។ គាត់បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគសមស្របលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបានសន្និដ្ឋានថា ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស

[4365] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4366] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4367] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៥-៣៩។

[4368] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ១៨-២៤។

[4369] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២។

[4370] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣, ៤០។

[4371] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ១០៣។

មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដែលអាចត្រូវបានចាត់ទុកថា ជាអំពើអមនុស្សធម៌ដទៃទៀត[4372]។ អាស្រ័យហេតុនេះ គាត់បានអះអាងថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាគប្បីបដិសេធចោលទាំងស្រុង[4373]។

1537.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃការទទួលរងទុក្ខលើរូបកាយ ឬផ្លូវចិត្តពីសំណាក់បុរស ដែរ ឬយ៉ាងណា។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ ដែរ ឬយ៉ាងណា ក្នុងការសន្និដ្ឋានថា បុរស គឺជាជនរងគ្រោះនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4374]។

ក) ថាតើ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យពិចារណាលើព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា

1538.ដូចបានបង្ហាញខាងលើ ក្នុងការគូសបង្ហាញធាតុផ្សំសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ធាតុផ្សំសត្យានុម័តតម្រូវឱ្យមានអំពើសកម្ម ឬអកម្ម ដែលបង្កព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស[4375]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានធ្វើការសន្និដ្ឋានដូចគ្នា[4376]។

---

[4372] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៧-៩។ *សូមមើលផងដែរ* សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ១០-៣៩។

[4373] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ១០៥។

[4374] អង្គជំនុំជម្រះតុលាការកំពូលពុំដោះស្រាយបញ្ហានៃ"ភាពលម្អៀតដោយឥតដឹងខ្លួន"ពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានលើកឡើងដំបូងដោយសហព្រះរាជអាជ្ញាក្នុងសារណាផ្ទាល់មាត់។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៤-៦។ សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) ដែលដាក់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ពុំមានការយោងទៅលើ"ភាពលម្អៀងដោយឥតដឹងខ្លួន"។ បើទោះបីជាបានលើកឡើងក្នុងកថាខណ្ឌមួយស្ដីពីការលម្អៀងផ្នែកភេទដែលមានអត្ថិភាពក្នុងសង្គមក៏ដោយ ក៏ពុំមែនអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភាពលម្អៀងនេះ ឬថា ភាពលម្អៀងនេះបានប៉ះពាល់សេចក្ដីសម្រេចរបស់ខ្លួននោះឡើយ។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣៨។ បទដ្ឋានទូទៅនៃការពិនិត្យលើបណ្ដឹងសាទុក្ខ គឺថា ភាគីពុំអាចលើកបញ្ហាថ្មីក្នុងពេលសវនាការផ្ទាល់មាត់ដែលពុំមាននៅក្នុងសារណាបណ្ដឹងសាទុក្ខឡើយ។ ជាលទ្ធផល បញ្ហាពាក់ព័ន្ធទៅនឹង"ភាពលម្អៀងឥតដឹងខ្លួននេះ"ពុំស្ថិតដោយសមស្របនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះតុលាការកំពូលពុំដោះស្រាយបញ្ហានេះឡើយ។

[4375] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

[4376] សាលដីការឿងក្ដី ០០២/០១ (F36) កថាខណ្ឌ ៥៨០។

1539.សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងបទដ្ឋាននេះ *ដោយផ្ទាល់* ប៉ុន្តែបានលើកនូវអ្វីដែលជាចំណុចចាំបាច់នៃការបំភ្លឺ។ សហព្រះរាជាអាជ្ញាបានលើកឡើងថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតទាមទារឱ្យមានការយល់ឃើញមួយដែលថា អំពើសកម្ម ឬអកម្មបានបង្កការរងទុក្ខធ្ងន់លើរូបកាយ ឬផ្លូវចិត្ត ឬការវាយតម្លៃលើបញ្ហាថាតើ អំពើសកម្ម ឬអកម្ម គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា[4377]។

1540.ខៀវ សំផន ពុំបានឆ្លើយតបទៅនឹងសារណានេះទេ ប៉ុន្តែទំនងជាតាមរយៈអំណះអំណាងរបស់គាត់ទទួលយកការលើកឡើងរបស់សហព្រះរាជអាជ្ញាអំពីបទដ្ឋានដែលមាន“ពីរផ្នែកនេះ”[4378]។

1541.សហមេធាវីនាំមុខបានយល់ស្របថា គោលគំនិតពីរ៖ ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដាច់ដោយឡែកពីគ្នា មានន័យថា នីមួយៗត្រូវតែបានពិចារណាជាជម្រើសប្រសិនបើមានមួយណាត្រូវបានបដិសេធនោះ[4379]។

1542.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា លក្ខខណ្ឌតម្រូវដែលថា អំពើសកម្ម ឬអកម្មបានបង្ក“ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស” ទាមទារឱ្យមានការវាយតម្លៃពីរដង។ ការប្រើប្រាស់ឆ្នាប់ទីពីរថា “ឬ”ក្នុងប្រយោគ“ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ *ឬ*ការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស” បង្ហាញថា មានការវាយតម្លៃពីរដាច់ពីគ្នា។ និយាយម្យ៉ាងទៀត អំពើក្នុងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតអាចត្រូវបានរកឃើញថាបានបង្ហាញការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត *ឬ*ការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របផងដែរថា ការសន្និដ្ឋានបន្ថែមសមស្របចេញពីការដែលប្រយោគនេះបានបង្កើតឡើងគឺថា ការវាយតម្លៃទាំងនេះនៃព្យសនកម្មមានអត្ថិភាពជាជម្រើស។ ប្រសិនបើសមាសភាគមួយពុំត្រូវបានបង្ហាញទេ បន្ទាប់មកសមាសភាគដទៃទៀតគប្បីត្រូវបានពិចារណា។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានគោលការណ៍បង្ហាញត្រឹមត្រូវអំពីការបកស្រាយដែលថា ពាក្យពេចន៍ត្រូវបកស្រាយក្នុងន័យសាមញ្ញធម្មតា[4380]។

---

[4377] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ១៨។

[4378] *សូមមើល* សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៧-៩។

[4379] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ១៥។

[4380] *សូមមើល* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៥៩។ សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ២៨២។ សាលដីការឿងក្តី *Nyiramasuhuko* (ICTR) កថាខណ្ឌ ២១៣៧។

1543.វិធីសាស្ត្រដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងជាញឹកញាប់ ត្រូវបានប្រើប្រាស់ដោយតុលាការ ICTY និង ICTR នៅពេលកំណត់អំពីបទដ្ឋានធាតុផ្សំសត្យានុម័តសម្រាប់អំពើអមនុស្សធម៌ដទៃទៀត[4381] ដោយមានបទដ្ឋានដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា និងត្រូវបានអនុម័តនៅពេលកំណត់អំពីធាតុផ្សំសត្យានុម័តសម្រាប់បទឧក្រិដ្ឋនៃអំពើឃោរឃៅ និងអំពើអមនុស្សធម៌[4382]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះមួយចំនួននៃតុលាការ ICTY និង ICTR បានយោងតែទៅលើភាពធ្ងន់ធ្ងរនៃព្យសនកម្ម ឬការឈឺចាប់លើរូបកាយ ឬផ្លូវចិត្ត ក្នុងការគូសបង្ហាញនូវអំពើអមនុស្សធម៌ដទៃទៀត[4383]។ បន្ថែមលើនេះ លក្ខន្តិកៈទីក្រុងរ៉ូមពុំបានរួមបញ្ចូលធាតុផ្សំនៃសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុង

---

[4381] សាលក្រមរឿងក្តី *Čelebić* (ICTY) កថាខណ្ឌ ៥៣៣។ សាលដីការឿងក្តី *Vasiljević* (ICTY) កថាខណ្ឌ ១៦៥។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Milošević អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT 98-29/1-T សាលក្រមថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៩៣៤។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Galić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-29 T សាលក្រមថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១៥២។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-02-60-T សាលក្រមថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦២៦។ សាលក្រមរឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ១៣០។ សាលដីការឿងក្តី *Stakić* (ICTY) កថាខណ្ឌ ៣៦៦។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ ICTR-95-1-T សាលក្រមថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៥១។

[4382] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៣៧ យោងទៅលើសាលក្រមរឿងក្តី *Čelebić* (ICTY) កថាខណ្ឌ ៥៣៣ ("ការពិភាក្សាខាងលើពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងគោលគំនិតនៃ 'អំពើអមនុស្សធម៌"ក្នុងបរិបទនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ")។ ការកំណត់និយមន័យនេះដែលទាក់ទងទៅនឹងបទឧក្រិដ្ឋនៃ"ការធ្វើបាប" និង"អំពើឃោរឃៅ" ត្រូវបានដកស្រង់ដោយយល់ស្របតាមដោយអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY *សូមមើល* សាលដីការឿងក្តី *Čelebić* (ICTY) កថាខណ្ឌ ៤២៦។ សាលក្រមរឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ១៣០ ("នេះមានការបង្ហាញចេញពីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌដែលថា អំពើឃោរឃៅ ការធ្វើបាប អំពើអមនុស្សធម៌ជាមូលដ្ឋានទាមទារឱ្យមានការបង្ហាញនូវធាតុផ្សំដូចគ្នា")។ សាលក្រមរឿងក្តី *Simić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៧៤ ("ក្នុងការវាយតម្លៃខ្លឹមសារនៃអំពើឃោរឃៅ និងអមនុស្សធម៌ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ត្រូវបានជួយដោយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀត [...] ការធ្វើបាប [...] និងការប្រព្រឹត្តទៅលើដោយឃោរឃៅ [...]។ ធាតុផ្សំនៃបទល្មើសនេះមានលក្ខណៈដូចគ្នា")។

[4383] សាលដីការឿងក្តី *Kordić និង Cerkez* (ICTY) កថាខណ្ឌ ១១៧ ("អំពើអមនុស្សធម៌ដែលជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានអំពើដែលបំពេញតាមលក្ខខណ្ឌខាងក្រោម [...] ជនរងគ្រោះ ត្រូវតែបានទទួលរងធ្ងន់ធ្ងរនូវព្យសនកម្មលើរូបកាយ ឬផ្លូវចិត្ត។ កម្រិតនៃភាពធ្ងន់ធ្ងរត្រូវតែបានវាយតម្លៃផ្អែកលើករណីជាក់ស្តែងដោយមានការពិចារណាលើកាលៈទេសៈនីមួយៗ)។ សាលក្រមរឿងក្តី *Kajelijeli* (ICTR) កថាខណ្ឌ ៩៣២ ("ការចោទប្រកាន់ត្រូវតែបង្ហាញនូវទំនាក់ទំនងរវាងអំពើអមនុស្សធម៌ និងការរងទុក្ខធ្ងន់ធ្ងរ ព្យសនកម្មធ្ងន់ធ្ងរលើសុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ជនរងគ្រោះ")។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៩ ("ក្នុងការបំភ្លឺអត្ថន័យនៃភាពធ្ងន់ធ្ងរ តុលាការជាច្រើនបានព្យាយាមកំណត់

លក្ខខណ្ឌសម្រាប់អំពើអមនុស្សធម៌ដទៃទៀត[4384] និងបានតម្រូវថា ចារីត្រូវតែ"បង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ ឬផ្លូវចិត្ត ឬសុខភាពផ្លូវកាយ"[4385]។ បទដ្ឋានដែលបានអនុម័តដោយតុលាការ ICC បច្ចុប្បន្នឆ្លុះបញ្ចាំងពាក្យពេចន៍នៃបទប្បញ្ញត្តិដែលបង្ហាញនូវ"អំពើអសកម្មដោយចេតនាដែលបង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព"ដែលជាការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[4386]។ ដូចការដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងរឿងក្តីបច្ចុប្បន្ន ការរំលោភបំពានធ្ងន់ធ្ងរនេះ"បានផ្តោតទៅលើភាពធ្ងន់ធ្ងរនៃការរងទុក្ខ ឬព្យនកម្ម និងពុំបានរួមបញ្ចូលអំពើដែលព្យសនកម្មជាផលវិបាកនោះ ជាប់ពាក់ព័ន្ធតែទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គលឡើយ"[4387]។

1544.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះជាយ៉ាងណាក្តី ការដែលតុលាការដទៃទៀតជួនកាលបានអនុម័តវិធីសាស្រ្តនៃការកំណត់ធាតុផ្សំសត្យានុម័តដែលពុំបានយោងទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សនោះ ពុំជាប់ពាក់ព័ន្ធទៅនឹងបទដ្ឋានដែលត្រូវបានអនុម័តក្នុងរឿងក្តីបច្ចុប្បន្នឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ធាតុផ្សំដែលរងការជំទាស់នោះ ជាសំខាន់ គឺរបៀបនៃការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃអំពើ៖ លក្ខណៈជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសធ្វើការវាយតម្លៃក្នុងចំណុចខ្លះ គឺជាឆន្ទានុសិទ្ធិ[4388]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញផងដែរថា នៅគ្រប់កាលៈទេសៈ តុលាការ ICC ខណៈពេលអនុម័តការកំណត់និយមន័យរឹតត្បិត បានយោងផងដែរទៅលើរឿងក្តី *Delalić និងជនដទៃទៀត*

---

បញ្ហាថាតើ អំពើដែលចោទប្រកាន់នោះបានបង្កើត"ការរងទុក្ខធ្ងន់លើរូបកាយ ឬផ្លូវចិត្ត" ដែរ ឬយ៉ាងណា ទោះបីជាយ៉ាងណាក្តី តុលាការនេះជានិច្ចកាលពុំបានប្រើប្រាស់ពាក្យពេចន៍ស្របគ្នានោះទេ")។

[4384] គោលគំនិតនៃ"សេចក្តីថ្លៃថ្នូររបស់មនុស្ស" ពុំបានបង្ហាញក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ឬធាតុផ្សំនៃបទឧក្រិដ្ឋ។

[4385] មាត្រា ៧(១) (ឌ) នៃលក្ខន្តិកៈរបស់តុលាការ ICC។ អង្គជំនុំជម្រះនៃតុលាការ ICC បានបញ្ជាក់នូវធាតុផ្សំនៃបទឧក្រិដ្ឋសម្រាប់ 'អំពើអមនុស្សធម៌ដទៃទៀត"ថា៖ (១) ចារីបានបង្កការឈឺចាប់ធ្ងន់ធ្ងរ ឬព្យសនកម្មធ្ងន់ធ្ងរលើសុខភាពផ្លូវកាយ ឬផ្លូវចិត្តតាមរយៈអំពើអមនុស្សធម៌ និង (២) អំពើនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតដែលមានចែងក្នុងមាត្រា ៧(១) លក្ខន្តិកៈ: *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Ongwen* (ICC) កថាខណ្ឌ ២៧៤៣ ដកស្រង់មាត្រា ៧(១) (ឌ) នៃធាតុផ្សំឧក្រិដ្ឋកម្មនៃតុលាការ ICC។ *សូមមើលផងដែរ* មាត្រា ១៨៨ (១១) នៃក្រមព្រហ្មទណ្ឌកម្ពុជា (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩) (សំដៅទៅលើ"អំពើអមនុស្សធម៌ដទៃទៀតដែលបង្កដោយចេតនានូវការរងទុក្ខធ្ងន់ធ្ងរ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ")។

[4386] មាត្រា ៨ (២)(ក)(iii) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[4387] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៦១។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៥៣ យោងទៅលើសាលក្រមរឿងក្តី *Kordić និង Cerkez* (ICTY) កថាខណ្ឌ ២៤៥។

[4388] *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៧៩។

របស់ ICTY ដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងចំណុចពាក់ព័ន្ធថា ការរួមភេទដោយបង្ខំគឺជាការវាយប្រហារជាមូលដ្ឋានលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស[4389]។

1545.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ស្របតាមបទដ្ឋានដែលខ្លួនបានគូសបង្ហាញ អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណាលើបញ្ហាថាតើ អំពើនោះបានបង្កការធ្វើឱ្យឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត *ឬ*ការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ បន្ថែមលើនេះ ក្នុងករណីដែលថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញអវិជ្ជមានលើចំណុចណាមួយក្នុងចំណោមពីរនេះ អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើបញ្ហាថាតើ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្សត្រូវបានបង្ហាញ ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាខាងក្រោមលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានបំពេញតាមលក្ខខណ្ឌនេះ ដែរ ឬយ៉ាងណា។

ខ) ព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត

1546.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ទោះបីជាបុរសពុំអាចប្រកែកការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ពុំមាន“ភស្តុតាងបង្ហាញច្បាស់លាស់ពាក់ព័ន្ធនឹងកម្រិតធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់លើបុរសដែរ”[4390]។ អាស្រ័យហេតុនេះ បើទោះបីជាទទួលស្គាល់ថា បុរសបានទទួលរងអំពើហិង្សាផ្លូវភេទដែលផ្ទុយទៅនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយខ្លួនឯងថា ពុំអាចបង្កើតការយល់ឃើញមួយស្ដីពីភាពធ្ងន់ធ្ងរនៃការឈឺចាប់លើរូបកាយ និងផ្លូវចិត្តលើបុរសទាំងនេះដែរ[4391]។

1547.សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការផ្ដល់សំអាងហេតុពេញលេញទាក់ទងទៅនឹងមូលហេតុដូចម្ដេចការឈឺចាប់ធ្ងន់ធ្ងរពុំត្រូវបានបង្ហាញ ផ្អែកលើមូលដ្ឋាននៃការយល់ឃើញផ្ទាល់ខ្លួន និងមានកំហុសអង្គហេតុផងដែរក្នុងការធ្វើសេចក្ដីសន្និដ្ឋានដោយពុំសមហេតុផល[4392]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ក្នុងការវិភាគរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបាន

---

[4389] សាលក្រមរឿងក្ដី *Čelebići* (ICTY) កថាខណ្ឌ ១០៦៦ (“ចារីបានបង្កការឈឺចាប់ធ្ងន់ធ្ងរ ឬព្យសនកម្មធ្ងន់ធ្ងរលើសុខភាពផ្លូវចិត្ត ឬរូបកាយ តាមរយៈអំពើអមនុស្សធម៌”)។

[4390] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4391] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4392] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៥-៣៩។

បដិសេធភស្តុតាងផ្ទាល់ និងមិនផ្ទាល់ ឬបានផ្តល់តម្លៃតិចតួចពុំសមស្របលើភស្តុតាងនោះ[4393]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានផ្សេងគ្នាចំពោះស្ត្រី និងបុរស ដោយពុំបានទទួលស្គាល់ភស្តុតាងនៃការរួមដំណេកដោយបង្ខំថា បានបង្ហាញអំពីការរងទុក្ខ[4394]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើសក្ខីកម្មពាក់ព័ន្ធរបស់ជនរងគ្រោះជាបុរស អែម អឿន និងជាស្ត្រី មុំ វុន ទាក់ទងទៅនឹងប្តីរបស់គាត់ និងសាក្សីជំនាញ NAKAGAWA Kasumi[4395] ព្រមទាំងចម្លើយ និងភស្តុតាងជាច្រើនពាក់ព័ន្ធដទៃទៀតក្នុងសំណុំរឿងនៅពេលធ្វើការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការរងទុក្ខរបស់បុរសដែលបានបង្កឡើងដោយសារការរួមដំណេកដោយបង្ខំ[4396]។

1548.ខៀវ សំផន បានឆ្លើយតបថា ការយល់ឃើញដែលត្រូវបានចង្អុលបង្ហាញដោយសហព្រះរាជអាជ្ញា ជាក់ស្តែងពុំបានបង្ហាញថា ការរួមដំណេកបានបង្កព្យសនកម្មធ្ងន់ធ្ងរលើបុរសនោះទេ[4397]។ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីបុរសបួននាក់ដែលបានផ្តល់សក្ខីកម្មក្នុងផ្នែកស្តីពីការរៀបអាពាហ៍ពិពាហ៍មានដូចជា៖ យស ផល, ស៊ូ សុធាវី, សេង សឿន និង កុល ណែម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើភស្តុតាងរបស់ យស ផល និង ស៊ូ សុធាវី ក្នុងការយល់ឃើញថា អង្គជំនុំជម្រះពុំអាចសន្និដ្ឋានបានថាភាពធ្ងន់ធ្ងរនៃការឈឺចាប់នោះឈានដល់កម្រិតចាំបាច់ឡើយ[4398]។ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ទៀត ពុំបានបង្ហាញថា "ការរួមដំណេកសហព័ទ្ធ"បានបង្ហាញនូវព្យសនកម្មធ្ងន់ធ្ងរនោះឡើយ[4399]។ ខៀវ

---

[4393] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៧-៣៩។

[4394] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៧-២៨, ៣៣-៣៤, ៣៧-៣៨។

[4395] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៩-៣៣, ៣៦។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ១២-១៣។

[4396] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៩-៣៧។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ១២-១៣។

[4397] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៩២-១០២។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ២៣។

[4398] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៤៤។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើ"ភស្តុតាងមិនទូទៅ"របស់ ស៊ូ សុធាវី ដែលជាស្ត្រីភេទទីបី ក្នុងការគាំទ្រការយល់ឃើញអំពីព្យសនកម្មទាក់ទងនឹងស្ត្រី *សូមមើល* សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៤៦។ គាត់បានលើកឡើងថា បុរសដែលបានផ្តល់សក្ខីកម្មក្នុងផ្នែកនៃការជំនុំជម្រះដែលពុំមែនជាផ្នែកការរៀបអាពាហ៍ពិពាហ៍ ពុំបានបង្ហាញអំពីព្យសនកម្មណាមួយ *សូមមើល* សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៥០-៥៤។

[4399] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៤៧-៤៩, ៦៤-៧៩, ៨១។ ខៀវ សំផន បានលើកសាជាថ្មីនូវអំណះអំណាងដែលថា ព្យសនកម្មពុំត្រូវបានបង្ហាញ ពីព្រោះផ្សេងៗគ្នា ជនរងគ្រោះអាចជ្រើសរើស ឬត្រូវបានរំពឹកថា នឹងរួមដំណេក

សំផន បានឆ្លើយតបផងដែរថា ភស្តុតាងរបស់ អែម អឿន ត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង និងនៅគ្រប់ករណី ខ្វះភាពគួរជឿជាក់ និងទុកចិត្តបាន[4400] ខណៈពេល មុំ វុន ពុំបានផ្តល់ភស្តុតាងអំពីផលប៉ះពាល់នៃព្រឹត្តិការណ៍នោះលើប្តីរបស់គាត់[4401]។ ភស្តុតាងរបស់ NAKAGAWA Kasumi គឺជា"យោបល់ផ្ទាល់ខ្លួន" ពុំមែនជា"ការយល់ឃើញផ្អែកលើការស្រាវជ្រាវទូលំទូលាយឡើយ"[4402]។

1549. សហមេធាវីនាំមុខបានធ្វើការបែកចែកភាពខុសប្លែកគ្នារវាងភស្តុតាងនៃការឈឺចាប់ជាក់លាក់ និងភស្តុតាងនៃការប្រព្រឹត្តទៅលើ៖ សហមេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានសំអាងទៅលើភស្តុតាងនៃការប្រព្រឹត្តទៅលើក្នុងការសន្និដ្ឋាននូវការរងទុក្ខធ្ងន់ធ្ងរ[4403]។

1550. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នេះជាការសំខាន់ និងជាធាតុផ្សំមួយនៃការជំនុំជម្រះដោយត្រឹមត្រូវ ដែលសេចក្តីសម្រេច និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែមានសំអាងហេតុពេញលេញ[4404]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា សិទ្ធិទទួលបានសំអាងហេតុពេញលេញ គឺជាធាតុផ្សំនៃសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងជាមូលដ្ឋានតែមួយគត់នៃសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញ ដែលអាចឱ្យការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខធ្វើទៅបាន[4405]។ ទាក់ទងទៅនឹង

---

ការរៀបអាពាហ៍ពិពាហ៍ បានបង្កើតមនោសញ្ចេតនាទៅវិញទៅមក ឬចុះសម្រុងគ្នាក្រោយការរៀបអាពាហ៍ពិពាហ៍ ឬពុំបានសំដៅជាក់លាក់ទៅលើការឈឺចាប់។ សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៦៤-៧៩, ៨១។

[4400] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៥៦-៥៩។ ប្រតិចារិកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ២៥។

[4401] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៨០។

[4402] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៦០-៦២។

[4403] ប្រតិចារិកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ១៤-១៥។

[4404] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២០២។

[4405] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២០៥ យោងទៅលើសាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) កថាខណ្ឌ ៩៦ ("សំអាងហេតុពេញលេញ ធាតុផ្សំមួយក្នុងចំណោមនោះនៃលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះត្រឹមត្រូវមានចែងក្នុងមាត្រា ២០ និង ២១ លក្ខន្តិកៈ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះឧទ្ធរណ៍អនុវត្តតួនាទីស្របតាមមាត្រា ២៥ នៃលក្ខន្តិកៈតាមរយៈការបំភ្លឺ និងពិនិត្យឡើងវិញលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង")។ *សូមមើលផងដែរ* សាលដីការឿងក្តី *Furundžija* (ICTY) កថាខណ្ឌ ៦៨-៦៩ (សិទ្ធិរបស់ជនជាប់ចោទក្រោមមាត្រា ២៣ នៃលក្ខន្តិកៈផ្តល់សំអាងហេតុពេញលេញ គឺទិដ្ឋភាពមួយនៃលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះត្រឹមត្រូវ"ដែលមានចែងក្នុងមាត្រា ២០ និង ២១ នៃលក្ខន្តិកៈ")។ សាលដីការឿងក្តី *Kunarac និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៤១ ("ស្របតាមមាត្រា ២៣(២) នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចបង្ហាញសំអាងហេតុពេញលេញ [...]។ ធាតុផ្សំនេះ *ក្នុងចំណោមនោះ* អនុញ្ញាតឱ្យមានការប្រើប្រាស់ដ៏មានអត្ថប្រយោជន៍នូវសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ដល់បុគ្គលដែលត្រូវបានដាក់ពិរុទ្ធ។ បន្ថែមលើនេះ សំអាងហេតុពេញលេញបានអនុញ្ញាត

ការវាយតម្លៃលើភស្តុតាង អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានពន្យល់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់បញ្ជាក់"រាល់ជំហាននៃការផ្តល់សំអាងហេតុក្នុងការធ្វើសេចក្តីសម្រេចលើចំណុចនេះឡើយ" ប៉ុន្តែនេះត្រូវបានតម្រូវដោយកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុពេញលេញ[4406]។ សំអាងហេតុដែលតម្រូវដើម្បីធានានូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី គឺអាស្រ័យលើកាលៈទេសៈជាក់លាក់នៃរឿងក្តី[4407]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា "ជាអប្បបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវតែផ្តល់សំអាងហេតុគាំទ្រការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការពិចារណាលើអង្គសេចក្តីទាក់ទងទៅនឹងការសម្រេចរបស់ខ្លួន"[4408]។

1551.អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើសំអាងហេតុដែលបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរងទុក្ខ ដែលឆ្លងកាត់ដោយជនរងគ្រោះជាបុរសត្រូវបានគូសបង្ហាញក្នុងកថាខណ្ឌមួយក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដូចតទៅ៖

> អង្គជំនុំជម្រះយល់ឃើញថា បុរសក៏មិនអាចបដិសេធការរួមដំណេកបានដែរ។ មានករណីមួយដែលប្តីបានរួមភេទជាមួយប្រពន្ធរបស់គាត់ តាមការណែនាំរបស់អង្គការ និងដោយសារតែការភ័យខ្លាចបាត់បង់ជីវិតរបស់គាត់ និងប្រពន្ធគាត់។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានទទួលរងព្យសនកម្មធ្ងន់ធ្ងរ ដោយសារតែគាត់មិនអាចរៀបការជាមួយគូដណ្តឹងរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ដោយសារតែមិនមាន ភ័ស្តុតាងច្បាស់លាស់ទាក់ទងនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់នៃអំពើនេះទៅលើបុរសនោះ បើទោះបីជាទទួលស្គាល់ថា បុរសទទួលរងអំពើហិង្សាផ្លូវភេទដែលផ្ទុយពីសេចក្តីថ្លៃថ្នូរជាមនុស្សជាតិក្តី ក៏អង្គជំនុំ

ឱ្យអង្គជំនុំជម្រះឧទ្ធរណ៍យល់ដឹង និងពិនិត្យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងព្រមទាំងការវាយតម្លៃលើភស្តុតាងផងដែរ")។

4406 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២០៦ យោងទៅលើសាលដីការឿងក្តី *Kupreskić* (ICTY) កថាខណ្ឌ ៣២។ អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់ផ្នែកនេះនៃសាលក្រមដោយយល់ស្របជាមួយក្នុងសាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៧។

4407 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២០៧។

4408 រឿងក្តី *រដ្ឋអាជ្ញាទល់នឹង និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87-AR65.1 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតការដោះលែងជនជាប់ចោទ Nebojša Pavković បណ្តោះអាសន្ន ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ១១។

ជម្រះមិនអាចឈានដល់ការសម្រេចទៅលើភាពធ្ងន់ធ្ងរនៃព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តដែលបុរសទាំងនោះទទួលរងបានឡើយ[4409]។

1552.អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បុរសដែលបានឆ្លងកាត់ការរួមភេទដោយបង្ខំត្រូវបានយល់ឃើញត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូងថា បានទទួល“រងអំពើហិង្សាផ្លូវភេទ”[4410]។ ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អង្គជំនុំជម្រះពុំ“អាចបង្កើតការយល់ឃើញស្តីពីភាពធ្ងន់ធ្ងរនៃការរងទុក្ខលើរូបកាយ និងផ្លូវចិត្ត” ដោយសារ“ពុំមានភស្តុតាងបង្ហាញច្បាស់លាស់”[4411]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងទំនងជាអនុវត្តពុំត្រឹមត្រូវនូវបទដ្ឋានស្តីពីអំពើអមនុស្សធម៌ដទៃទៀត។ ធាតុផ្សំសត្យានុម័តតម្រូវថា អំពើសកម្ម ឬអកម្មនោះបានបង្កការរងទុក្ខធ្ងន់លើរូបកាយ ឬផ្លូវចិត្ត និងពុំតម្រូវឱ្យបង្ហាញនូវការរងទុក្ខផ្នែករូបកាយ និងផ្លូវចិត្តនោះទេ[4412]។

1553.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ការសំដៅរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការទាមទារឱ្យមាន“ភស្តុតាងច្បាស់លាស់” ពុំមានលក្ខណៈច្បាស់លាស់។ ជាបញ្ហាបឋម គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញដូចគ្នាផ្នែកអង្គហេតុអំពីអត្ថិភាពនៃការរួមភេទដោយបង្ខំក្នុងការយល់ឃើញថា ជនរងគ្រោះស្ត្រីបានឆ្លងកាត់ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ[4413]។ “ប្តីប្រពន្ធទើបរៀបអាពាហ៍ពិពាហ៍ថ្មី” ត្រូវបានដាក់ក្នុងទីតាំងដែលបានកំណត់ទុកដើម្បីរួមភេទក្រោយការរៀបអាពាហ៍ពិពាហ៍ ជាកន្លែងដែលពួកគេត្រូវបានតាមដានដោយឈ្លបប្រដាប់អាវុធ[4414]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “ទាំងពីរនាក់”បុរស និងស្ត្រីមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យរួមភេទជាមួយដៃគូរបស់ខ្លួន[4415] ហើយ“ប្តីប្រពន្ធ”ដែលរកឃើញថាពុំបានរួមភេទត្រូវធ្វើការអប់រំកែប្រែ ឬគំរាមកំហែងសម្លាប់ ឬទទួលទណ្ឌកម្ម[4416]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដែលបង្ហាញថា ស្ត្រីបានឆ្លងកាត់ការបង្ខិតបង្ខំបន្ថែម បើទោះបីជាតាមរយៈអំពើហិង្សាផ្លូវភេទដែលត្រូវបាន

---

[4409] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4410] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4411] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4412] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៥។

[4413] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

[4414] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[4415] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

[4416] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩០។

ប្រព្រឹត្តឡើងដោយប្តីរបស់ពួកគេ ឬដោយតតីយជនក៏ដោយ[4417] ក៏ការយល់ឃើញជារួមបានបង្ហាញថា ទាំងបុរស និងស្ត្រីត្រូវបានបង្ខំឱ្យរួមភេទដែរ។

1554.ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ជាពិសេសថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតការយល់ឃើញដែលបង្ហាញថា ជនរងគ្រោះជាស្ត្រីទាំងអស់បានឆ្លងកាត់ព្យសនកម្មផ្នែករូបកាយឡើយ។ ដើមដំបូងក្នុងការវិភាគផ្នែកច្បាប់របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើលក្ខណៈពិសេសមួយចំនួននៃការរួមភេទដែលខុសប្លែកគ្នាចំពោះស្ត្រី។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចម្លើយក្នុងតុលាការជាញឹកញាប់ពុំមានការពិពណ៌នាច្បាស់លាស់អំពីការស៊កបញ្ចូល៖ "កាលៈទេសៈដូចជាការឈឺចាប់ ការហូរឈាមរយៈពេលយូរក្រោយមក ឬការសំដៅច្បាស់លាស់ទៅលើការស៊កបញ្ចូលអង្គជាតដោយបង្ខំ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានថា មានការស៊កបញ្ចូលអង្គជាតបានកើតឡើង"[4418]។ ទោះជាយ៉ាងណាក្តី ការយល់ឃើញនេះផ្តោតជុំវិញអត្ថិភាពនៃការស៊កបញ្ចូលអង្គជាត និងពុំមែនផ្តោតលើព្យសនកម្មនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អ្វីដែលតម្រូវនោះគឺព្យសនកម្មលើរូបកាយ ឬផ្លូវចិត្ត និងអាស្រ័យហេតុនេះពិចារណាឃើញថា ពុំមានលក្ខខណ្ឌតម្រូវបង្ហាញថា ព្យសនកម្មលើរូបកាយបានកើតឡើងសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតលើជនរងគ្រោះទាំងពីរភេទឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំអាចទៅរួចដែលយល់ថា ការរួមភេទគ្មានការយល់ព្រមជាអប្បបរមាគ្មានការរងព្យសនកម្មផ្លូវចិត្តនោះទេ។

1555.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពី "ប្តី"ពីរនាក់៖ យស ផល និង ស៊ូ សុធារី ដែលចម្លើយរបស់ពួកគាត់ត្រូវបានគូសបង្ហាញថា "គ្មានភស្តុតាងបង្ហាញច្បាស់លាស់"។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយយោងទៅលើភស្តុតាងរបស់ យស ផល ថា គាត់បាន"ទទួលទុក្ខធ្ងន់ធ្ងរ" ពីព្រោះគាត់ពុំអាចរៀបអាពាហ៍ពិពាហ៍ជាមួយគូដណ្តឹងរបស់គាត់[4419]។ បើទោះបីជាការយល់ឃើញនេះត្រឹមត្រូវដូចក្នុងចម្លើយរបស់គាត់អំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើការដែលភស្តុតាងនេះបង្ហាញនូវការលំបាក និងការឈឺចាប់ដែលគាត់បានជួបប្រទះនៅក្នុងការរួមភេទ ពីព្រោះគាត់បាន

[4417] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤៦, ៣៦៥០-៣៦៥៣, ៣៦៥៨, ៣៦៩៧។

[4418] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

[4419] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

ស្រលាញ់ស្ត្រីម្នាក់ទៀត និងបានចាត់ទុកប្រពន្ធរបស់គាត់នោះ ដូចជាបងប្អូន[4420]។ នេះគឺជាឧទាហរណ៍មួយដែលអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភស្តុតាងពាក់ព័ន្ធច្បាស់លាស់។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរទៅលើភស្តុតាងរបស់ ស៊ូ សុធារី ដែលបង្ហាញថា "គាត់បានរួមភេទជាមួយប្រពន្ធរបស់គាត់ក្រោយការព្រមានរបស់អង្គការ និងដោយសារភ័យខ្លាចលើអាយុជីវិតរបស់គាត់ និងប្រពន្ធ"[4421]។ *តាមសេចក្តីបញ្ជាក់ដំបូង* ឃើញថា ការយល់ឃើញនេះបានបញ្ជាក់នូវព្យសនកម្មធ្ងន់ធ្ងរ ដោយសារបានបង្ហាញថា ស៊ូ សុធារី បានរួមភេទដោយសារការភ័យខ្លាចគេសម្លាប់។

1556.អង្គជំនុំជម្រះតុលាការកំពូលបានពិពណ៌នារួចហើយអំពីមូលហេតុដូចម្តេចបានជាគប្បីពិចារណាលើព្យសនកម្មដែល ស៊ូ សុធារី បានទទួលព្យសនកម្មក្នុងឋានៈជាបុរសភេទជីវសាស្ត្រ និងស្ត្រីភេទទីបី។ ដូចស្ថានភាពដូច"ប្តី"ដទៃទៀតដែលបានទទួលរងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយបង្ខំក្រោយមកនោះ ស៊ូ សុធារី បានតម្រូវឱ្យស៊កបញ្ចូលអង្គជាតក្នុងស្ត្រី ដែលភាគីទាំងពីរពុំបានស្ម័គ្រចិត្តក្នុងអំពើនោះ ប៉ុន្តែភាគីទាំងពីរបានចូលរួមដោយសារការភ័យខ្លាចការស្លាប់។ ពាក់ព័ន្ធបញ្ហានេះ នៅពេលវាយតម្លៃលើព្យសនកម្មដែលជនរងគ្រោះជាបុរសបានទទួលរងដោយសារការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាការសមស្របក្នុងការពិចារណាលើព្យសនកម្មដែល ស៊ូ សុធារី បានទទួលរង។

1557.ដោយសារព្យសនកម្មធ្ងន់ធ្ងរដែលបានបង្កទៅលើ ស៊ូ សុធារី ក្នុងឋានៈជាស្ត្រីភេទទីបីដែលត្រូវបានបង្ខំឱ្យរួមភេទ អង្គជំនុំជម្រះសាលាដំបូគប្បីពិចារណាផងដែរលើបទពិសោធន៍នៅក្នុងការយល់ឃើញស្តីពីការរងទុក្ខឬព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្តពីសំណាក់ស្ត្រី។

1558.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការដោះស្រាយអំពីស្ថានភាពធ្ងន់ធ្ងររបស់ ស៊ូ សុធារី ព្រមទាំងការរងទុក្ខធ្ងន់ធ្ងរដែលបានកើតឡើងនោះ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តធ្វើការពន្យល់សំអាងហេតុរបស់ខ្លួន និងបានបង្កើតការយល់ឃើញពុំសមហេតុផលក្នុងសេចក្តីសន្និដ្ឋានស្តីពីជនរងគ្រោះជាបុរស។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើភស្តុតាងពាក់ព័ន្ធនៅពេលធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

---

[4420] ប្រតិចារិក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ (យស ផល) ឯកសារលេខ E1/464.1 ទំព័រ ១៩-២០។

[4421] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

1559.សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើភស្តុតាងរបស់ជនរងគ្រោះជាស្ត្រីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងថា ក្នុងនាមជាប្តីប្រពន្ធ ពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមការគំរាមកំហែង[4422] និងទៅលើអត្ថបទសិក្សាស្រាវជ្រាវរបស់ NAKAGAWA Kasumi, Rochelle BRAAF និង Bridgette TOY-CRONIN ដែលបានរួមបញ្ចូលចម្លើយរបស់សាក្សី និងជនរងគ្រោះ និងបានលើកចំណុចដូចគ្នា[4423]។ ជាបន្ទាប់ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ដែលជាជនរងគ្រោះបុរសនៃការរួមភេទដោយបង្ខំ ព្រមទាំងភស្តុតាងអ្នកជំនាញ NAKAGAWA Kasumi ដែលបានផ្តល់សក្ខីកម្មរបស់គាត់អំពីឰសនកម្មលើបុរសដែលបានឆ្លងកាត់ការបង្ខំឱ្យរួមភេទ[4424]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានអើពើទៅលើភស្តុតាងរបស់ មុំ វុន ដែលបានផ្តល់ភស្តុតាងអំពីប្តីរបស់គាត់ដែលត្រូវបានបង្ខំផ្នែករូបកាយឱ្យរួមភេទជាមួយលោកស្រី[4425]។

1560.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានសន្មតថាបានវាយតម្លៃរាល់ភស្តុតាងទាំងអស់ដែលបានបង្ហាញចំពោះមុខខ្លួន ដរាបណាពុំមានការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទាំងស្រុងទៅលើភស្តុតាងជាក់លាក់ណាមួយ[4426]។ ទោះជាយ៉ាងណាក្តី អាចមានការបញ្ជាក់ណាមួយអំពីការពុំអើពើនៅពេលភស្តុតាងដែលជាប់ពាក់ព័ន្ធ

---

[4422] *សូមមើល* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣៤-៣៥ ជើងទំព័រ ១០២ យោងទៅលើក្នុងចំណោមនោះកំណត់ហេតុស្តាប់ចម្លើយរបស់ សុំ ប៉ែត ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E3/9824 ERN 01007619 ឆ៖ ៤១។ កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ផាត ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ E3/9822 ERN 01070106 ឆ៖ ៣៥៤, ៣៥៨។ កំណត់ហេតុស្តាប់ចម្លើយ កែ ធារី ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ E3/9662 ERN 01045654 ឆ៖ ៤៤-៤៥។

[4423] *សូមមើល* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣៥ និងជើងទំព័រ ១០២ យោងទៅលើក្នុងចំណោមនោះ អ្នកនិពន្ធ K. Nakagawa៖ *អំពើហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ* ខែធ្នូ ឆ្នាំ២០០៨ ឯកសារលេខ E3/2959 ERN 00738350។ អ្នកនិពន្ធ Rochelle BRAAF៖ *ហិង្សាផ្លូវភេទលើជនជាតិភាគជាជាតិពន្ធុក្នុងអំឡុងពេលនៃរបបខ្មែរក្រហម* ខែ មីនា ឆ្នាំ ២០១៤ ឯកសារលេខ E3/9240 EN 00992283។ អ្នកនិពន្ធ Bridgette TOY-CRONIN៖ *"ខ្ញុំចង់និយាយប្រាប់អ្នក៖ រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៨ ឯកសារលេខ E3/3416 ERN 00721384។

[4424] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៩-៣១។

[4425] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ៣៦-៣៧។

[4426] សាលដីការឿងក្តី *Kvočka និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៣។ *សូមមើលផងដែរ* សាលដីការឿងក្តី *Nyiramasuhuko និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១៣០៨។

ច្បាស់លាស់ទៅនឹងការយល់ឃើញនោះ ពុំត្រូវបានដោះស្រាយក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[4427]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញរួចរាល់ផងដែរថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរួមដំណេកក្រោមការបង្ខំដោយកម្លាំង មានន័យថា ពុំមានប្តី ឬប្រពន្ធណាបានយល់ព្រមរួមភេទដោយសេរីឡើយ[4428]។ ភស្តុតាងបន្ថែមទៀតដែលត្រូវបានគូសបង្ហាញដោយសហព្រះរាជអាជ្ញា រួមទាំងសក្ខីកម្មរបស់ជនរងគ្រោះជាស្ត្រីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងអត្ថបទសិក្សាស្រាវជ្រាវរបស់ NAKAGAWA Kasumi, Rochelle BRAAF និង Bridgette TOY-CRONIN បានអះអាងបន្ថែមនូវបរិយាកាសគួរឱ្យភ័យខ្លាច និងការបង្ខិតបង្ខំ ដែលត្រូវបានយល់ឃើញរួចរាល់ថា បានកើតឡើង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាច្បាស់លាស់លើភស្តុតាងនេះ។

1561.ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាបានពិចារណាថា អែម អឿន NAKAGAWA Kasumi និង មុំ វុន ទាំងអស់គ្នាបានផ្តល់ភស្តុតាងពាក់ព័ន្ធផ្ទាល់។ អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងរបស់បុគ្គលទាំងនេះក្នុងការយល់ឃើញសង្ខេបរបស់ខ្លួនស្តីពីភាពធ្ងន់ធ្ងរនៃព្យសនកម្ម[4429]។ អែម អឿន បានផ្តល់សក្ខីកម្មថា គាត់ និងប្រពន្ធបានពិភាក្សាអំពីការភ័យខ្លាចថា ប្រសិនបើពួកគេពុំព្រមរួមដំណេកការរៀបអាពា

---

[4427] សាលដីការឿងក្តី *Kvočka និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៣។ *សូមមើលផងដែរ* សាលដីការឿងក្តី *Đorđević* (ICTY) កថាខណ្ឌ ៨៦៤។

[4428] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៦។

[4429] អង្គជំនុំជម្រះសាលាដំបូងពុំបានសំដៅទៅលើផ្នែកដែលបានគូសបញ្ជាក់នៃភស្តុតាងរបស់ អែម អឿន នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែបានយោងក្នុងជើងទំព័រសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានសង្ខេបភស្តុតាងរបស់ NAKAGAWA Kasumi។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២០៩២ យោងទៅលើប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩០ (ដោយបញ្ជាក់ថា គាត់ធ្វើការនៅមន្ទីរពេទ្យ នៅពេលគាត់ប្រកែកមិនព្រមរៀបការជាមួយអ្នកដែលគាត់មិនស្រឡាញ់ ហើយគេក៏ផ្ទេរគាត់ឲ្យទៅធ្វើការនៅការដ្ឋានវិញ ជាការដាក់ទណ្ឌកម្ម ជំនួសឲ្យធ្វើការនៅមន្ទីរពេទ្យ) ជើងទំព័រ ១២២៧៤ យោងទៅលើប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៩០-៩១ ("ក្នុងនាមខ្ញុំជាយុវជនម្នាក់ស្ថិតនៅក្នុងសង្គម អ្នកណាក៏ដូចអ្នកណា ស្រឡាញ់ណាស់អំពើមានសិទ្ធិសេរីភាពក្នុងការរើសគូស្រករ។ ប៉ុន្តែនៅក្នុងឱកាសដែលខ្ញុំមិនៗចង់បាន បែរទៅជាបាន អាហ្នឹងខ្ញុំមិនពេញចិត្តទេ តែគេចមិនបាន។ [...] ទាំងនារីជាភរិយារបស់ខ្ញុំ ទាំងខ្ញុំដេក ពេលចូលដំណេកដេកជាមួយគ្នា បង្ហូរទឹកភ្នែកដាក់គ្នា។ ប្រតិចារឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៤៥-៤៦ ("គាត់ និងប្តីទាំងពីរនាក់ត្រូវបានឈ្លបបង្ខំដោយភ្លង់កាំភ្លើង និងផ្ទុះពិលមើលឱ្យដោះសម្លៀកបំពាក់ និងចាប់ប្រដាប់ភេទប្តីរបស់លោកស្រីដាក់បញ្ចូលមកលើគាត់។ ពួកគេត្រូវបានបង្ខំឱ្យរួមភេទចំពោះមុខឈ្លប)។

ហ៍ពិពាហ៍ទេ ពួកគេនឹងត្រូវបានសម្លាប់ជាមិនខាន[4430]។ គាត់បានផ្តល់សក្ខីកម្មបន្ថែមទៀតថា សូម្បីមានការភ័យខ្លាចនេះ ក៏ត្រូវចំណាយពេលរង់ចាំពីរសប្តាហ៍បានរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដែរ[4431]។ គាត់បានពិពណ៌នាច្បាស់លាស់នូវបទពិសោធន៍នៃការរួមភេទដោយបង្ខំ ថាបានបង្ក"ការរងទុក្ខ" និងបានអះអាងថា "រហូតដល់សព្វថ្ងៃ នៅមិនទាន់បំភ្លេចបាន"[4432]។ NAKAGAWA Kasumi ដែលភស្តុតាងរបស់គាត់ត្រូវបានពិចារណា និងសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការយល់ឃើញដំបូងរបស់ខ្លួនផ្នែកអង្គហេតុ បានផ្តល់ភស្តុតាងថា ការរួមភេទដោយបង្ខំ"បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង និងពុំសមាមាត្រទៅលើបុរសពីព្រោះបុរសបានទទួលភារកិច្ច និងត្រូវបានបង្ខំឱ្យការរំលោភសេពសន្ថវៈប្រពន្ធ" ដែលនេះជា"អំពើអមនុស្សធម៌"[4433]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើផ្នែកទាំងនេះនៃភស្តុតាងដែលមានការជាប់ពាក់ព័ន្ធច្បាស់លាស់ដែលត្រូវបានសំអាងទៅលើក្នុងផ្នែកដទៃទៀតនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងពុំបានកាត់បន្ថយផ្នែកណា ឬទាំងស្រុងនោះឡើយ[4434]។

1562.មុំ វុន បានផ្តល់សក្ខីកម្មថា ឈ្លបបានបង្ខំប្តីរបស់គាត់ដោយភ្ជង់កាំភ្លើងឱ្យរួមភេទជាមួយលោកស្រីដែលក្នុងពេលនោះលោកស្រីបានពិពណ៌នាអំពីការដែល"វាថាឱ្យឆាប់ដេកជាមួយគ្នា។ រួចហើយវាឆ្លូលពិល វាឆ្លូល

---

[4430] ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 នៅម៉ោង ១៥.៥៧-១៦.០១។

[4431] ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 នៅម៉ោង ១៥.៥៧-១៦.០១។

[4432] ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 នៅម៉ោង ១៥.៥៧-១៦.០១។

[4433] ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 ទំព័រ ៧៨។ *សូមមើល* ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ (NAKAGAWA Kasumi) ឯកសារលេខ E1/472.1 ទំព័រ ៧៩-៨០ (បានលើកឡើងថា ចំពោះនារីៗ "ផលប៉ះពាល់ហ្នឹង គឺមានធំធេងណាស់ទៅហើយ នៅពេលដែលគេបង្ខំគាត់ឲ្យរៀបការប្រឆាំងនឹង ទស្សនៈរបស់គាត់ ដោយមិនមានការយល់ព្រមពីឪពុកម្តាយរបស់គាត់។ ហើយនៅដំណាក់កាលដំបូង គឺនាងត្រូវបានកាត់ផ្តាច់ពីក្តីសង្ឃឹមទាំងអស់។ គឺថា គូស្រករថ្មីៗដែលគេបង្ខំឲ្យរៀបការហ្នឹង ភាគច្រើនគេដឹងថា គេត្រូវតែរួមដំណេក ព្រោះថា មេភូមិបានណែនាំនៅក្នុងពិធីរៀបការនោះ។ នេះគឺជាក្តីរន្ធត់ដ៏ធំធេងចំពោះស្ត្រីដែលភាគច្រើនដែលថា គាត់មិនដែលប៉ះពាល់ទៅរឿងផ្លូវភេទពីមុនមកសោះ។ អ៊ីចឹង គឺថាចំពោះការរំលោភវិញ គឺថាវាមានកើតឡើងនៅក្នុងករណីខុសៗគ្នា ក្នុងករណីខ្លះគឺដោយអំពើហិង្សា [...] ការរំលោភករណីខ្លះទៀតគឺមិនមានអំពើហិង្សាទេ [...] ប៉ុន្តែបុរសត្រូវបានគេបង្ខំឲ្យរំលោភប្រពន្ធ ហើយប្រពន្ធត្រូវតែរងអំពើការរំលោភពីប្តី") យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៨៤ និងជើងទំព័រ ១២២៨៩-១២២៩០។ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលពុំទទួលស្គាល់ថា ជនរងគ្រោះជាបុរសនៃការរួមដំណេកដោយបង្ខំត្រូវបានពិពណ៌នាត្រឹមត្រូវថា "អ្នករំលោភសេពសន្ថវៈ"ឡើយ។

[4434] *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Perišić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-81-A សាលដីកា ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៩៥។

ពិលមើលយើង ហើយវាចាប់ប្រដាប់ប្រដាមនុស្សប្រុសដាក់មកជាមួយយើង [...]។ ខ្ញុំមានសេចក្ដីខ្មាសអៀនយ៉ាងខ្លាំង"[4435]។ បើទោះបីជា មុំ វុន បានផ្ដល់ភស្តុតាងអំពីបទពិសោធន៍ផ្ទាល់ខ្លួនជាជនរងគ្រោះជាស្ត្រីនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ការរៀបរាប់របស់គាត់បានបង្ហាញនូវព្យសនកម្មពិតប្រាកដទៅលើប្ដីរបស់លោកស្រីដែលត្រូវបានចាប់ទាញ និងបង្ខំឱ្យរួមភេទដោយភ្ជង់កាំភ្លើង។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ភស្តុតាងនេះមានការជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីព្យសនកម្ម និងគប្បីពិចារណា។

1563.យោងតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចសន្និដ្ឋានបានថា ការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្តពុំត្រូវបានបង្ហាញក្នុងករណីនៃជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំឡើយ។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអង្គហេតុនេះ ត្រូវបដិសេធចោលត្រង់ចំណុចដែលជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំ។

### គ) សេចក្តីថ្លៃថ្នូររបស់មនុស្ស

1564.សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានបង្កើតការយល់ឃើញតែទៅលើការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងពុំបានបង្កើតការយល់ឃើញស្ដីពីបញ្ហាថាតើអំពើដែលបុរសត្រូវបានដាក់ឱ្យទទួលរងនោះ គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែរឬយ៉ាងណា[4436]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ប្រសិនបើបញ្ហានេះត្រូវបានវាយតម្លៃសមស្រប អង្គជំនុំជម្រះសាលាដំបូងនឹងបានយល់ឃើញច្បាស់លាស់ថា ការប្រព្រឹត្តនោះបានរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស[4437]។

---

[4435] ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 នៅម៉ោង ១៣.៤៣ ដល់ ១៣.៤៥។

[4436] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ១៨។

[4437] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ១៩។

1565.ខៀវ សំផន បានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហាថាតើអំពើដែលបុរសត្រូវបានដាក់ឱ្យស្ថិតក្រោមនោះ ផ្ទុយពីសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា និងបានយល់ឃើញថា អំពើនោះពុំមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដែលអាចចាត់ទុកថា ជាអំពើអមនុស្សធម៌ដទៃទៀតបានឡើយ[4438]។

1566.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បញ្ហាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាត្រូវចាត់ទុកជាអសារបង់។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញខាងលើថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ត្រឹមត្រូវនូវបទដ្ឋានសម្រាប់ធ្វើការវាយតម្លៃលើព្យសនកម្មនៃអំពើក្នុងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត នៅពេលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំសត្យានុម័តទាមទារឱ្យមានអំពើសកម្ម ឬអកម្មដែលបង្កព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស[4439]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញផងដែរថា បទដ្ឋាននេះមានន័យថា ក្នុងករណីដែលមានកត្តាមួយក្នុងចំណោមនោះត្រូវបានរកឃើញថា ពុំមានអត្ថិភាពដូចជា៖ ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្សទេ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិចារណាកត្តាមួយផ្សេងទៀត។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលពុំបានយល់ឃើញថា មានកាតព្វកិច្ចត្រូវពិចារណា*ទាំងពីរ*ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ *និង*សេចក្ដីថ្លៃថ្នូររបស់មនុស្សនោះទេ។ អាស្រ័យហេតុនេះ ផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការយល់ឃើញដែលថា បុរសពុំបានទទួលរងព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរនោះ តាមលក្ខណៈបច្ចេកទេស លែងមានកាតព្វកិច្ចត្រូវពិចារណាលើបញ្ហាថាតើ ការប្រព្រឹត្តដែលចោទជាបញ្ហានេះ អាចស្មើនឹងការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្សតទៅទៀត ដែរ ឬយ៉ាងណានោះឡើយ។

1567.អង្គជំនុំជម្រះតុលាការកំពូលបានកំណត់រួចហើយថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្តពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា បទពិសោធន៍បុរសនៃអំពើហិង្សាផ្លូវភេទជាទូទៅត្រូវបានពិចារណាតិចតួចក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងកាន់តែតិចជាងនេះទៀតដោយសារជនរងគ្រោះបុរសដែលជាអ្នកស៊កបញ្ចូលអង្គជាត។ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់

[4438] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៧-៨។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ២៣។

[4439] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧២៤។

ឃើញរបស់ខ្លួនក្នុងសំណុំរឿង ០០១ ដែលថា ក្នុង“កាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចលើកបញ្ហា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ឬស្តាប់បណ្តឹងសាទុក្ខក្នុងករណីដែលភាគីបានលើកបញ្ហាអង្គច្បាប់ដែលពុំនាំឱ្យមានការមោឃៈសាលក្រម ប៉ុន្តែទោះជាយ៉ាងណាក្តី មានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក.”[4440]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើសារណារបស់ភាគីពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

1568.នៅក្នុងការយល់ឃើញដែលរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានសំដៅទៅលើ“សេចក្តីថ្លៃថ្នូររបស់មនុស្ស” និង“ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ”។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “បុរសបានទទួលរងអំពើហិង្សាផ្លូវភេទដែលផ្ទុយទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស” ប៉ុន្តែបានសន្និដ្ឋានថា អង្គជំនុំជម្រះពុំអាចបង្កើតការយល់ឃើញស្តីពីភាពធ្ងន់ធ្ងរនៃការរងទុក្ខលើរូបកាយ និងផ្លូវចិត្តដែលបានទទួលរងដោយបុរសទាំងនោះឡើយ[4441]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាការយល់ឃើញនេះសំដៅទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើងឱ្យតែមានប៉ុណ្ណោះ និងដាក់ឱ្យស្ថិតក្រោមការយល់ឃើញស្តីពីភាពធ្ងន់ធ្ងរនៃ“ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្ត”។ ពុំមានឋានានុក្រមរវាង“ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្ត”ជាមួយនឹង“ការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស” ដែលខុសពីបទឧក្រិដ្ឋនៃ“អំពើអកម្មដោយចេតនាដែលបង្កការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព រួមទាំងសុខភាពផ្លូវចិត្ត”ដែលជាការរំលោភបំពានធ្ងន់ធ្ងរមួយ និងបានដកចេញតែអំពើដែលពាក់ព័ន្ធទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គលប៉ុណ្ណោះ[4442]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបាន“រំលោភបំពាន” ប៉ុន្តែពុំបានពន្យល់នូវមូលហេតុដែលការរំលោភបំពាននេះពុំមានលក្ខណៈធ្ងន់ធ្ងរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើបញ្ហាថាតើ បទពិសោធន៍បុរសនៃការរំលោភសេពសន្ថវៈអាចស្មើនឹងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា។

---

[4440] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៥។

[4441] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០១។

[4442] មាត្រា ៨ (២)(ក)(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៦១។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៥៣ ដកស្រង់សាលក្រមនៃរឿងក្តី *Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៤៥។

1569.សហព្រះរាជអាជ្ញាបានលើកឡើងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Čelebići* បានបង្ហាញថា គោលគំនិតនៃសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវតែបានវាយតម្លៃជាសត្យានុម័ត[4443]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ឧទាហរណ៍ប្រហាក់ប្រហែលគ្នារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានាបានបង្ហាញថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហានេះជាសត្យានុម័ត នោះអង្គជំនុំជម្រះនឹងបានសន្និដ្ឋានថា ការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស បានកើតឡើងច្បាស់លាស់ពាក់ព័ន្ធទៅនឹងបុរសដែលត្រូវបានបង្ខំឱ្យរួមភេទ[4444]។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា បើទោះបីជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សពុំទាមទារឱ្យមានភស្តុតាងអត្តនោម័តិនៃការរងទុក្ខធ្ងន់ធ្ងរក៏ដោយ ក៏ភស្តុតាងនៃការរងទុក្ខនេះមានអត្ថិភាពចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ[4445]។

---

[4443] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២១-២២។ ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ៧។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ គាំទ្រការវិភាគដែលថា នៅពេលជម្រើសមួយត្រូវបានបំពេញ ជម្រើសដទៃទៀតពុំចាំបាច់ និងផ្ទុយទៅវិញ ប្រសិនបើជម្រើសមួយមិនបានបំពេញតាមលក្ខខណ្ឌ ជម្រើសមួយទៀតត្រូវតែពិចារណា។

[4444] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ១៩, ២៣ យោងទៅលើក្នុងចំណោមនោះ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bagosora និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-98-41-T សាលក្រម និងការប្រកាសទោសថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧០៥, ៧១៧-៧១៨, ២២១៩-២២២២, ២២២៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T សាលក្រមថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៧៦៦-៧៧៤, ៧៨១, ៧៨២។ សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Katanga និង Ngudjolo Chui* (ICC) កថាខណ្ឌ ៣៧៣-៣៧៦។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើការយល់ឃើញដែលរៀបរាប់ស្តីពីការរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនដែលបានបង្កើតឡើងក្នុងរឿងក្តី *Bagosora* នៃតុលាការ ICTR (ការស៊កបញ្ចូលដបទៅក្នុងរន្ធយោនីសាកសពអាក្រាតរបស់នាយករដ្ឋមន្ត្រី និងការដោះសម្លៀកបំពាក់ស្ត្រីនៅមុនពេលសម្លាប់) រឿងក្តី *Kunarac* នៃតុលាការ ICTY (បង្ខំជនរងគ្រោះឱ្យដោះសម្លៀកបំពាក់ចេញអាក្រាតកាយ និងរាំលើតុខណៈពេលជនជាប់ចោទកំពុងមើល និងភ្ជង់កាំងភ្លើង) និងសេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទក្នុងរឿងក្តី *Katanga និង Ngudjolo Chui* នៃតុលាការ ICC (ស្ត្រីត្រូវបានបង្ខំឱ្យបង្ហាញឃ្លាំងដាក់អាវុធ និងគ្រាប់រំសេវដល់យោធិនខណៈពេលពាក់តែអាវស្តើង និងខោក្នុង និងក្រោយមកពាក់តែអាវស្តើងប៉ុណ្ណោះ)។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើគោលការណ៍មូលដ្ឋាននៃច្បាប់អន្តរជាតិស្តីពីមនុស្សធម៌ និងសិទ្ធិមនុស្ស ដែលតម្រូវថា សេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូបត្រូវបានការពារ មិនគិតពីភេទ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) កថាខណ្ឌ ២៤។

[4445] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ F1/12.1 ទំព័រ ១០-១៣។

1570.ខៀវ សំផន បានឆ្លើយតបថា បទដ្ឋានដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា រំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ពីព្រោះបទដ្ឋាន"សត្យានុម័ត"សម្រាប់ការវាយតម្លៃលើសេចក្ដីថ្លៃថ្នូរត្រូវបានបង្ហាញតែតាមរយៈរឿងក្ដីរបស់តុលាការ ICTY ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប៉ុណ្ណោះ និងពុំមានអត្ថិភាពនៅពេលដែលអំពើនោះបានប្រព្រឹត្តឡើង[4446]។ គាត់បានអះអាងថា អង្គហេតុដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពុំមានលក្ខណៈធ្ងន់ធ្ងរស្មើគ្នាដូចការសន្មតដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញានោះទេ។ នៅគ្រប់កាលៈទេសៈ ខៀវ សំផន បានលើកឡើងថា រឿងក្ដីដែលសហព្រះរាជអាជ្ញាបានដកស្រង់បង្ហាញថា ទំនាក់ទំនងផ្លូវភេទដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពុំមានលក្ខណៈធ្ងន់ធ្ងរដូចអំពើដែលបានដោះស្រាយនៅចំពោះមុខតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ដទៃទៀតឡើយ[4447]។

1571.ជាបឋម និងជាបញ្ហាទូទៅ នេះគឺជាការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការវាយតម្លៃលើសេចក្ដីថ្លៃថ្នូររបស់មនុស្សក្នុងបទឧក្រិដ្ឋជាមូលដ្ឋាននៃអំពើអមនុស្សធម៌ដទៃទៀត ពុំមែនជាការវាយតម្លៃផ្នែកអង្គច្បាប់នោះទេ ប៉ុន្តែជាផ្នែកអង្គហេតុ។ ដូចការបញ្ជាក់ដដែលៗរបស់អង្គជំនុំជម្រះតុលាការកំពូលថា ពុំមានលក្ខខណ្ឌតម្រូវក្នុងការកំណត់បទឧក្រិដ្ឋឯករាជ្យនៅពេលអំពើនោះត្រូវបានចោទប្រកាន់ក្រោមបទឧក្រិដ្ឋជាមូលដ្ឋានអំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចធ្វើការវិភាគតាមករណីជាក់ស្ដែង ជាពិសេស លើផលប៉ះពាល់នៃអំពើលើជនរងគ្រោះ និងបញ្ហាថាតើ អំពើនេះខ្លួនឯងស្មើទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា[4448]។ រឿងក្ដីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌនានា អាចមានការជាប់ពាក់ព័ន្ធក្នុងការកំណត់លើបញ្ហាថាតើ ជាបញ្ហាអង្គហេតុ អំពើនោះអាចត្រូវបានពិចារណាថា ជាការរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា ប៉ុន្តែផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន ការវាយតម្លៃនេះពុំមែនជាបញ្ហានីត្យានុកូលភាពនោះទេ។ រឿងក្ដីយុត្តិសាស្ត្រនេះពុំបានផ្ដល់នូវបទដ្ឋានដែលចាំបាច់ ឬមិនចាំបាច់ក្នុងការពិចារណាឡើយ ប៉ុន្តែត្រឹមតែធ្វើជាមធ្យោបាយសម្រាប់ការវាយតម្លៃប្រហាក់ប្រហែលគ្នា

[4446]សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ១១-១៤ យោងទៅលើរឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Aleksovski* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-14/I-T សាលក្រម ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩ ("សាលក្រមរឿងក្ដី *Aleksovski* (ICTY)") កថាខណ្ឌ ៥៣-៥៦។ ខៀវ សំផន បានអះអាងថា រឿងក្ដី *Čelebići* របស់តុលាការ ICTY ត្រូវបាន "បំពេញ"ដោយសាលក្រមក្នុងរឿងក្ដី *Aleksovski* របស់តុលាការ ICTY និងថា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី*Aleksovski* "បានបញ្ជាក់ដោយឥតព្រលាំថា ការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្សត្រង់ចំណុចនេះជាកត្តាអត្តនោម័តិសុទ្ធសាធ"។

[4447] សារណាតបរបស់ ខៀវ សំផន (F50/1) កថាខណ្ឌ ៣៤-៣៨។

[4448] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៨៦។

នោះ។ បញ្ហាថាតើ មានរឿងក្តីយុត្តិសាស្ត្រដែលបង្ហាញនូវបទដ្ឋាន"សត្យានុម័ត" ឬ"អត្តនោម័តិ" ដែរ ឬយ៉ាងណា គឺជាប់ពាក់ព័ន្ធតែការវាយតម្លៃលើអង្គហេតុប៉ុណ្ណោះ។

1572.ជាបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើរឿងក្តីទាំងនោះដែលក្នុងសារណារបស់ភាគីបានបង្ហាញបទដ្ឋាន"សត្យានុម័ត"។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Čelebići* បានយល់ឃើញថា លោក Mirko Kuljanin ត្រូវបានវាយដំយ៉ាងដំណំមុនពេលនាំយកទៅដាក់ក្នុងជំរំឃុំឃាំង[4449]។ នៅពេលគាត់បានទៅដល់ជំរំនោះ គាត់ត្រូវបាននាំទៅកន្លែងមួយដែលអ្នកជាប់ឃុំនានាត្រូវបានវាយដំច្រើនលើកច្រើនសាមុនពេលនាំចេញទៅ[4450]។ អង្គជំនុំជម្រះសាលាដំបូងបន្ទាប់មកបានយល់ឃើញថា អង្គជំនុំជម្រះពុំអាចបង្កើតការយល់ឃើញដែលថា ការវាយដំដែលគាត់បានទទួលរងបានបង្កដោយចេតនានូវការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ និងសុខភាព ប៉ុន្តែបានសន្និដ្ឋានថា អំពើនៃការវាយដំបុគ្គលណាម្នាក់ដែលមានរបួសរួចហើយនោះ ជាអប្បបរមាគឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[4451]។ ក្នុងសេចក្តីសន្និដ្ឋាននេះ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញបទដ្ឋានទូទៅ ផ្ទុយទៅវិញអង្គជំនុំជម្រះបានធ្វើការវាយតម្លៃផ្អែកអង្គហេតុលើភស្តុតាងចំពោះមុខក្នុងករណីជាក់លាក់នោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងដែលថា រឿងក្តី *Čelebići* បានបង្ហាញថា មានបទដ្ឋាន"សត្យានុម័ត"ដើម្បីអនុវត្តនៅពេលធ្វើការវាយតម្លៃលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

1573.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា រឿងក្តីជាច្រើនបានសំដៅទៅលើ"បទដ្ឋានសត្យានុម័ត" ប៉ុន្តែក្នុងបរិបទនៃបទល្មើសដែលត្រូវបានពិពណ៌នាថា ជាការរំលោភបំពានលើ"សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន" ពុំមែន"សេចក្តីថ្លៃថ្នូររបស់មនុស្ស"នោះទេ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Aleksovski* ដែលយោងតាម ខៀវ សំផន ថា "បានបំពេញ"តាមបទដ្ឋានសត្យានុម័តសម្រាប់ការវាយតម្លៃអំពីសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបានអះអាងថា "អំពើនោះត្រូវតែបង្កការអាម៉ាស់ធ្ងន់ធ្ងរ ឬការបន្ទាបបន្ថោកដល់ជនរងគ្រោះ"[4452] និងថា នេះទាមទារឱ្យមានការវាយតម្លៃ"អត្តនោម័តិ"នៃព្យសនកម្ម ដែលបានបង្កទៅលើបុគ្គលជាក់ស្តែង ព្រមទាំងការយល់ឃើញដែលថា "ការអាម៉ាស់ដល់ជនរងគ្រោះត្រូវតែធ្ងន់ធ្ងរ

---

[4449] សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ១០២៤។

[4450] សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ១០២៤-១០២៥។

[4451] សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ១០២៦។

[4452] សាលក្រមរឿងក្តី *Aleksovski* កថាខណ្ឌ ៥៦។

ដើម្បីឱ្យបុគ្គលសមហេតុផលមានការខឹងសម្បារ"[4453]។ អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្ដី *Kunarac* បានយល់ស្របជាមួយបទដ្ឋានសត្យានុម័តទាក់ទងទៅនឹងការវាយប្រហារលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន និងបានតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ការអាម៉ាស់របស់ជនរងគ្រោះ ត្រូវតែធ្ងន់ធ្ងរ ដើម្បីអាចឱ្យបុគ្គលសមហេតុផលមានការខឹងសម្បារ"[4454]។

1574.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការរំលោភបំពានលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួនអាចស្ថិតក្នុងវិសាលភាពនៃបទល្មើសរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ តាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Aleksovski* "ការរំលោភបំពានលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន គឺជាអំពើដែលកើតចេញពីការប៉ុនប៉ងទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្សលើបុគ្គលណាម្នាក់"[4455]។ តាមច្បាប់ស្ដីពីសិទ្ធិមនុស្ស សិទ្ធិទទួលបានសេចក្ដីថ្លៃថ្នូរ និងបូរណភាពផ្ទាល់ខ្លួនផ្លូវចិត្ត និងរូបកាយ មានទំនាក់ទំនងជាមួយគ្នាដែលកើតចេញជាសិទ្ធិរស់រានមានជីវិត[4456]។ បទល្មើសរំលោភបំពានលើបុគ្គលត្រូវបានពិពណ៌នាថា សំដៅទៅលើសេចក្ដី

---

[4453] សាលក្រមរឿងក្ដី *Aleksovski* កថាខណ្ឌ ៥៦។

[4454] សាលដីការឿងក្ដី *Kunarac និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១៦២។ សញ្ញាណនៃ"ការរំលោភបំពានលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន" ត្រូវបានកំណត់ក្នុងធាតុផ្សំនៃបទឧក្រិដ្ឋសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") ថា ជាអំពើដែលធ្វើឱ្យអាម៉ាស់ និងបន្ទាបបន្ថោក ឬលើសពីនេះ រំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់បុគ្គលក្នុងកម្រិតមួយ"ដែលត្រូវបានគេទទួលស្គាល់ជាទូទៅថា ជាការរំលោភបំពានលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន"។ ធាតុផ្សំនៃបទឧក្រិដ្ឋបានបញ្ជាក់បន្ថែមថា ការបន្ទាបបន្ថោកអាចធ្វើទៅលើសាកសព និងថា ជនរងគ្រោះពុំចាំបាច់ដឹងដោយផ្ទាល់អំពីភាពអាម៉ាស់នេះទេ។ ធាតុផ្សំនៃបទឧក្រិដ្ឋសម្រាប់តុលាការ ICC ការកំណត់និយមន័យនៃការរំលោភបំពានលើសេចក្ដីថ្លៃថ្នូរ ជាពិសេសការធ្វើឱ្យអាម៉ាស់ និងការបន្ទាបបន្ថោក ដែលជាឧក្រិដ្ឋកម្មសង្គ្រាម (មាត្រា ៨(២)(ខ)(xxi) និង (គ)(២) នៃលក្ខន្តិកៈទីក្រុង)។

[4455] សាលក្រមរឿងក្ដី *Aleksovski* (ICTY) កថាខណ្ឌ ៥៦។

[4456] មាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *សូមមើល* រឿងក្ដី*រដ្ឋអាជ្ញា ទល់នឹង Saif Al-Islam Gaddafi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/11-01/11-695-Anxl មតិស្របដាច់ដោយឡែករបស់ចៅក្រម Luz del Carmed Ibánex Carranza លើសាលក្រមស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ Saif Al-Islam Gaddafi ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចំណងជើងថា 'សេចក្ដីសម្រេចស្ដីពីការជំទាស់លើ"ភាពអាចទទួលយកបានដោយ Saif Al-Islam Gadafi ស្របតាមមាត្រា ១៧(១)(ខ), ១៩ និង ២០(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម"' ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៩, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២០ កថាខណ្ឌ ១៣៩ ("ការលើកលែងទោស ឬវិធានការនៃអានុភាពស្មើគ្នាសម្រាប់បទឧក្រិដ្ឋអន្តរជាតិដែលជានិច្ចជាកាលគឺជាការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស មានលក្ខណៈផ្ទុយទៅនឹងច្បាប់អន្តរជាតិ គោលការណ៍ និងបទដ្ឋានដែលបានបង្កើតឡើងត្រឹមត្រូវ ដោយសារវិធានការនេះរំលោភបំពានកាតព្វកិច្ចដ៏រឹងមាំរបស់រដ្ឋក្នុងការស៊ើបអង្កេត ចោទប្រកាន់ និងដាក់ទោសបទឧក្រិដ្ឋទាំងនេះ។ កាតព្វកិច្ចនេះកើតចេញជាចម្បងពីច្បាប់ស្ដីពីសិទ្ធិមនុស្សត្រង់ចំណុចថាមានភាពសំខាន់បំផុតមិនអាចខ្វះបាន ដើម្បីធានាការប្រើប្រាស់សិទ្ធិដែលមិនអាចកាត់ផ្ដាច់បាននេះដែលជាមូលដ្ឋាននៃសេចក្ដី

ថ្លៃថ្នូររបស់មនុស្ស។ ឧទាហរណ៍ រឿងក្ដី *Vasiljević* នៃតុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងបាន យល់ឃើញថា អំពើមនុស្សឃាតគិតទុកជាមុន គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស [4457]។ ទាក់ទងទៅនឹងការដែលបទល្មើសរំលោភបំពានលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស បានផ្អែកសុទ្ធសាធទៅ លើបទពិសោធន៍ផ្ទាល់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា មានអត្ថប្រយោជន៍នៅក្នុងការវាយ តម្លៃសត្យានុម័ត។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលសង្កេតផងដែរថា គោលគំនិតនៃសេចក្ដី ថ្លៃថ្នូររបស់មនុស្សមានលក្ខណៈទូលំទូលាយជាងសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងក្នុង រឿងក្ដី *Furundžija* នៃតុលាការ ICTY បានបញ្ជាក់ថា "គោលការណ៍ទូទៅនៃការគោរពសេចក្ដីថ្លៃថ្នូររបស់ មនុស្ស គឺជាមូលដ្ឋានសំខាន់ និងពិតណាស់គឺជាយុត្តិកម្មសម្រាប់ការរស់រានមានជីវិតនៃច្បាប់ស្ដីពីមនុស្ស ធម៌អន្តរជាតិ និងសិទ្ធិមនុស្ស។ ពិតណាស់ ក្នុងសម័យទំនើប គោលការណ៍នេះមានសារៈសំខាន់បំផុតដែល ជ្រាបចូលក្នុងច្បាប់អន្តរជាតិទាំងស្រុង"[4458]។ គោលគំនិតនៃសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលបានតភ្ជាប់គ្នា រវាងព្យសនកម្មបុគ្គល ជាមួយនឹងសមូហភាព បានលេចឡើងក្នុងរឿងក្ដីនៃសុន្ទរកថាញុះញង់ឱ្យស្អប់ក្រុម មួយ[4459] និងការកេណ្ឌដោយបង្ខំដើម្បីបង្កើនកម្លាំងផ្នែកយោធា[4460]។ អង្គជំនុំជម្រះតុលាការកំពូលពិចារ

---

ថ្លៃថ្នូររបស់មនុស្ស")។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Vasiljević* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-98-32-T សាលក្រមថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ២៣៩។

[4457] ក្នុងរឿងក្ដី *Vasiljević* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបញ្ជាក់ថា "អំពើមនុស្សឃាតគិតទុកជាមុនលើ VG-32 និង VG-14 គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងថា អំពើនេះបង្កឱ្យ VG-32 និង VG-14 រងការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរហួសថ្លែង និងថា ជនជាប់ចោទតាមរយៈអំពើរបស់ខ្លួនមានចេតនាវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស នៃ VG-32 និង VG-14 និងបង្កការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្តលើពួកគេ"។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Vasiljević* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-98-32-T សាលក្រមថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ២៣៩។

[4458] សាលក្រមរឿងក្ដី *Furundžija* (ICTY) កថាខណ្ឌ ១៨៣។

[4459] តុលាការ ICTR បានបញ្ជាក់ថា សុន្ទរកថាញុះញង់ឱ្យស្អប់គឺជាការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងដូច្នេះ គឺជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ តុលាការនេះបានតម្កល់ការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើ Ferdinand Nahimana ដែលជាប្រធានវិទ្យុ និងទូរទស្សន៍ Libre des Mille Collines។ *សូមមើល* សាលដីការឿងក្ដី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR)។

[4460] *សូមមើល* សាលដីការឿងក្ដី *Blaskić* (ICTY) កថាខណ្ឌ ៥៩៧ ("អង្គជំនុំជម្រះឧទ្ធរណ៍បានយល់ឃើញថា ការប្រើប្រាស់បុគ្គលដែលពុំបានចូលរួមសកម្មក្នុងការជម្លោះដើម្បីរៀបចំពង្រឹងយោធាសម្រាប់ការប្រើប្រាស់ក្នុងប្រតិបត្តិការ និងប្រឆាំងនឹងកងកម្លាំងដែលបុគ្គលនោះមានការសាទរជាមួយនោះ គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស (និងបង្កការឈឺចាប់ធ្ងន់ធ្ងរ ឬព្យសនកម្មផ្លូវចិត្ត និងរូបកាយ) អាស្រ័យលើកាលៈទេសៈ")។

ណាឃើញថា ការបញ្ជាក់ស្តីពីបទដ្ឋាន"សត្យានុម័ត"ពាក់ព័ន្ធទៅនឹងបទល្មើសរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនបានលេចឡើង ពីព្រោះបទល្មើសទាំងនេះបានផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនជាចាំបាច់របស់ជនរងគ្រោះនីមួយៗ។ ក្នុងរឿងក្តីដែលគោលគំនិតទូលំទូលាយនៃសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានរំលោភបំពានពុំចាំធ្វើការវាយតម្លៃប្រៀបធៀបបែបនោះឡើយ។

1575.បទល្មើសហិង្សាផ្លូវភេទជាទូទៅត្រូវបានចាត់ទុកថា ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន។ ការវាយតម្លៃនេះជាទូទៅពុំជាប់ពាក់ព័ន្ធទៅនឹងលក្ខណៈសត្យានុម័តណាមួយ ដែលផ្ទុយទៅវិញបានផ្អែកទៅលើការសន្មតអំពីព្យសនកម្មលើរូបកាយ ឬផ្លូវចិត្ត ឬការបន្ទាបបន្ថោក ដែលត្រូវបានបង្កឡើងដោយអំពើហិង្សាផ្លូវភេទដែលត្រូវបានបង្ហាញ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ខ្លួនឯងក្នុងសំណុំរឿង ០០១ ដោយយោងទៅលើអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR ក្នុងរឿងក្តី *Akayesu* ថា បទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ ជាទូទៅគឺជា"ការរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន"[4461]។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុងរឿងក្តី *Milutinović* បានពិពណ៌នាការដែល"ហិង្សាផ្លូវភេទ"ស្ថិតក្រោមបទប្បញ្ញត្តិនានាដែលការពារបូរណភាពផ្នែករូបកាយ និងអាចជា"ការរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន" ដែលអង្គជំនុំជម្រះនេះបានចាត់ទុកថា ជា"ការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន"[4462]។ ក្នុងរឿងក្តី RUF នៃតុលាការ SCSL តុលាការនេះបានសន្និដ្ឋានថា អំពើរបស់ជនជាប់ចោទ RUF "ក្នុងការបង្ខំជនស៊ីវិលជាប់ឃុំប្រមាណ ២០ នាក់ ឱ្យរួមភេទគ្នា និងបានវះប្រដាប់ភេទជនស៊ីវិលបុរស និងស្ត្រីមួយចំនួននោះ គឺជាការបន្ទាបបន្ថោក ព្យសនកម្ម និងការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់ជនរងគ្រោះ"ដែលនេះគ្រប់គ្រាន់បង្កើតបានជាមូលដ្ឋានសម្រាប់បទចោទនៃការរំលោភបំពានលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន"[4463]។

1576.វិសាលភាពដែលទូលំទូលាយជាងនេះក្នុងកម្រិតមួយបានពិពណ៌នាអំពើហិង្សាផ្លូវភេទថា ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC ក្នុងរឿងក្តី *Bemba* ដែលអនុវត្តតាមរឿងក្តី *Furundžija* នៃតុលាការ ICTY បានចាត់ទុកការស៊កអង្គជាតរួមភេទតាមមាត់ថា ជាអំពើនៃការរំលោភសេពសន្ថវៈ ពីព្រោះនេះគឺជា"ការវាយប្រហារបន្ទាបបន្ថោកជាមូលដ្ឋានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលអាចជាការធ្វើឱ្យអាម៉ាស់ និងការប៉ះទង្គិចផ្លូវចិត្តដូចគ្នាទៅនឹងការស៊កអង្គជាតតាមរន្ធ

---

[4461] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ២០៨។

[4462] សាលក្រមរឿងក្តី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១៩២។

[4463] សាលក្រមរឿងក្តី *Gbao និងជនជាប់ចោទដទៃទៀត* (SCSL) កថាខណ្ឌ ១៣០៧ និងទំព័រ ៦៧៨, ៦៨២, ៦៨៥, ៦៧៨ (បទល្មើសទី ៩)។

គូទ ឬយោនី"[4464]។ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី *Đorđević និងជនដទៃទៀត* បាន អនុម័តវិធីសាស្ត្រប្រហាក់ប្រហែលគ្នាដោយពិចារណាថា អំពើហិង្សាផ្លូវភេទអាចពុំទាមទារឱ្យមានការប៉ះ ពាល់ផ្នែករូបកាយជាមួយចារីក្នុងករណីដែលអំពើនោះគឺជាការធ្វើឱ្យអាម៉ាស់ ឬការបន្ទាបបន្ថោកផ្លូវភេទ [4465]។ ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានសន្និដ្ឋាន ថា អំពើ"ហិង្សាផ្លូវភេទ"ដែលពាក់ព័ន្ធទៅនឹងការស៊កបញ្ចូលវត្ថុទៅក្នុងរន្ធយោនីសាកសពស្ត្រី មាន"លក្ខ ណៈធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹង[បទឧក្រិដ្ឋជាក់លាក់ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] និង បានបង្កការឈឺចាប់ផ្លូវចិត្តដល់ជនស៊ីវិល ជាពិសេស ជនជាតិ Tutsi និងជាការវាយប្រហារធ្ងន់ធ្ងរលើ សេចក្តីថ្លៃថ្នូររបស់មនុស្សនៃសហគមន៍ Tutsi ទាំងមូល"[4466]។

1577.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហាថាតើ សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានរំលោភ បំពានដោយការប្រព្រឹត្តនេះ ដូចជាក្នុងស្ថានភាពដែលជនរងគ្រោះជាបុរសត្រូវបានបង្ខំឱ្យស៊កអង្គជាតរួម ភេទចូលក្នុងជនរងគ្រោះស្ត្រីដោយសារភ័យខ្លាចលើអាយុជីវិតរបស់ខ្លួន។ ក្នុងសារណាផ្ទាល់មាត់ សហព្រះ រាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើកាលៈទេសៈផ្នែកអង្គហេតុចំនួនបី ដែលបង្ហាញថា ការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានបង្ហាញក្នុងករណីជនរងគ្រោះ ជាបុរសដែលជាអ្នកស៊កអង្គជាតរួមភេទ[4467]។ ដំបូង ប្តីប្រពន្ធត្រូវបានបង្ខំឱ្យរួមភេទតែប៉ុន្មានម៉ោងក្រោយ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ៖ ជាកត្តាមួយដែលតាមការអះអាងរបស់សហព្រះរាជអាជ្ញា អង្គជំនុំ

---

[4464] សាលក្រមរឿងក្តី *Bemba* (ICC) កថាខណ្ឌ ១០១។

[4465] សាលដីការឿងក្តី *Đorđević និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១៥៦ ("អង្គជំនុំជម្រះឧទ្ធរណ៍កត់សម្គាល់ថា អំពើត្រូវតែជាការរំលោភបំពានលើបូរណភាពផ្លូវចិត្ត ឬរូបកាយរបស់ជនរងគ្រោះ។ ជាញឹកញាប់ ផ្នែកនៃដងខ្លួនជាទូទៅពាក់ព័ន្ធ ទៅនឹងផ្លូវភេទ ត្រូវបានកំណត់គោលដៅ ឬជាប់ពាក់ព័ន្ធ។ ទោះជាយ៉ាងណាក្តី ទំនាក់ទំនងរូបកាយ ពុំចាំបាច់សម្រាប់អំពើដែល មានលក្ខណៈផ្លូវភេទ។ ការបង្ខំបុគ្គលឱ្យប្រព្រឹត្ត ឬមើលអំពើមួយចំនួន អាចគ្រប់គ្រាន់ ដរាបណាអំពើនោះធ្វើឱ្យអាម៉ាស់ និង/ឬ បន្ទាបបន្ថោកជនរងគ្រោះក្នុងលក្ខណៈផ្លូវភេទ") (ការយោងខាងក្នុងលុបចោល)។

[4466] សាលក្រមរឿងក្តី *Niyitegeka* (ICTR) កថាខណ្ឌ ៣១៦, ៤៦៥។ *សូមមើលផងដែរ ឧ.* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* Nikolić អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-94-2-S សាលក្រមប្រកាសទោស ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៣ កថា ខណ្ឌ ៨៧-៨៩, ១១១ (យល់ឃើញថា "អំពើនៃការផ្លាស់ទីដោយបង្ខំ ហិង្សាផ្លូវភេទ ការដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌអមនុស្សធម៌ និងបរិយាកាសបំភិតបំភ័យ[បានកើតឡើង] ពុំចាំបាច់មានការពន្យល់បន្ថែមចំពោះកម្រិតនៃភាពធ្ងន់ធ្ងរដែលស្ថិតក្នុងវិសាលភាព នៃ[អំពើធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ]" និងកត់សម្គាល់ថា អំពើហិង្សាផ្លូវភេទបានរួមបញ្ចូលមិនត្រឹមតែការ រំលោភសេពសន្ថវៈប៉ុណ្ណោះទេ ថែមទាំងការគំរាមកំហែងផ្ទាល់មាត់នៃការរំលោភផ្លូវភេទផងដែរ)។

[4467] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៩។

ជម្រះសាលាដំបូងបានលើកឡើងក្នុងការវិភាគរបស់ខ្លួនសម្រាប់ស្ត្រី ប៉ុន្តែពុំបានពិចារណាសម្រាប់បុរស[4468] ។ ទីពីរ មានការគំរាមកំហែងដាក់ទណ្ឌកម្មសម្រាប់ការមិនគោរពតាមបទបញ្ជា ដោយដាក់សម្ពាធឱ្យបំពេញការរួមភេទ[4469]។ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភស្តុតាងដែលបង្ហាញការអនុវត្តន៍រីករាលដាលនៃការដាក់ទណ្ឌកម្ម[4470]។ ទីបី បក្សកុម្មុយនីស្តកម្ពុជាមិនត្រឹមតែបានរំលោភបំពានលើបូរណភាពផ្នែករូបកាយ និងស្វ័យភាពផ្លូវភេទរបស់បុរសប៉ុណ្ណោះទេ ថែមទាំងបានបង្ខំឱ្យពួកគេបង្កការឈឺចាប់ធ្ងន់ធ្ងរលើប្រពន្ធខ្លួន ដែលត្រូវទទួលរងការអាម៉ាស់យ៉ាងធ្ងន់ធ្ងរ[4471]។

1578.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទាំងបុរស និងស្ត្រីតាមរយៈគោលនយោបាយការរួមដំណេកដោយបង្ខំបានទទួលរងភាពអាម៉ាស់ និងការបន្ទាបបន្ថោកធ្ងន់ធ្ងរបំផុត។ បន្ទាប់ពីត្រូវបានដាក់ឱ្យស្ថិតក្រោមការរងទុក្ខនៃការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំ ដែលតាមធម្មតាជាមួយនឹងមនុស្សដែលខ្លួនពុំដែលស្គាល់ទាល់តែសោះ ប្តីប្រពន្ធត្រូវបានផ្លាស់ប្តូរទីតាំងដោយបង្ខំ និងឃ្លាំមើលដោយឈ្លបដើម្បីឱ្យដឹងប្រាកដថា ការរួមភេទរវាងប្តីប្រពន្ធដែលតាមធម្មតាជាបុគ្គលដែលខ្លួនពុំដែលស្គាល់នោះបានកើតឡើង។ ប្រសិនបើពុំបានកើតឡើងទេ ប្តីប្រពន្ធត្រូវបានបង្ខំឱ្យពន្យល់មូលហេតុម្តង និងច្រើនដង និងចុងក្រោយបានសម្រេចចិត្តរួមដំណេកការរៀបអាពាហ៍ពិពាហ៍ ដោយសារការភ័យខ្លាចការដាក់ទណ្ឌកម្មលើរូបកាយរួមទាំងការសម្លាប់ ឬការវាយដំ។ បុគ្គលមួយចំនួនរួមទាំងជនរងគ្រោះជាស្ត្រី និងបុរស ត្រូវទទួលរងអំពើហិង្សាផ្លូវភេទដទៃទៀតដែលជាផ្នែកនៃបរិយាកាសបង្ខិតបង្ខំទូទៅ។ យោងតាមហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បុរស និងស្ត្រីទាំងពីរភេទបានទទួលរងការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

1579.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើសារណាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអំពីកត្តាជាក់លាក់ដែលបានគាំទ្របន្ថែមលើការយល់ឃើញដែលថា សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានរំលោភបំពានទាក់ទងទៅនឹងជនរងគ្រោះជាបុរស។ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ពេលវេលានៃការរួមភេទ ដែលផ្ទុយទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ពុំត្រូវបានពិចារណាដោយអង្គ

---

[4468] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៩។

[4469] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៩។

[4470] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៩-១០។

[4471] ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ១០។

ជំនុំជម្រះសាលាដំបូងនៅក្នុងការវាយតម្លៃអំពីព្យសនកម្មដែលបានបង្កទៅលើជនរងគ្រោះជាស្ត្រី[4472]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគេបានរងចាំមួយរយៈពេលនូវការរួមដំណេកអាពាហ៍ពិពាហ៍របស់ខ្លួននៅមុនពេលមានអារម្មណ៍ថា ត្រូវបានបង្ខំឱ្យធ្វើដូច្នោះ[4473]។ ការដែលបុគ្គលត្រូវបានតាមដានយ៉ាងជិតដល់ភ្លាមៗក្រោយពីការរៀបអាពាហ៍ពិពាហ៍ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា បានធ្វើឱ្យមានការអាម៉ាស់នៃបទពិសោធន៍នេះកាន់តែខ្លាំងឡើងៗ។ ទោះជាយ៉ាងណាក្តី នេះគឺជាកត្តាដែលត្រូវអនុវត្តស្មើគ្នាទាំងបុរស និងស្ត្រី។

1580.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ផងដែរថា ការអនុវត្តនៃការដាក់ទណ្ឌកម្ម គឺជាកត្តាបន្ថែមដែលចាំបាច់ត្រូវធ្វើការពិចារណាក្នុងការវាយតម្លៃលើសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងកត្តាទាំងនេះ។ ការគំរាមកំហែងមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវកង្វះការយល់ព្រមដែលបង្កើតបានជាអំពើហិង្សាផ្លូវភេទ ដែលរំលោភបំពានដោយផ្ទាល់លើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ទោះជាយ៉ាងណាក្តី ជាថ្មីម្តងទៀត អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា កត្តានេះត្រូវអនុវត្តស្មើភាពគ្នាទាំងបុរស និងស្ត្រីដែលជាជនរងគ្រោះនៃគោលនយោបាយការរួមដំណេកដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរជាពិសេសនូវកាលៈទេសៈនៃការធ្វើឱ្យអាម៉ាស់ដែលត្រូវបានពិពណ៌នាដោយ មុំ វុន ទាក់ទងទៅនឹងបទពិសោធន៍ប្តីរបស់គាត់នៃការរួមដំណេកដោយបង្ខំ។

1581.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ជនរងគ្រោះបានឆ្លងកាត់ការអាម៉ាស់ខុសប្លែក ដោយសារត្រូវបានបង្ខំឱ្យសិកអង្គជាតរួមភេទប្រពន្ធរបស់ខ្លួន។ នេះពុំបានបង្ហាញញថា ពួកគេគឺជាអ្នករំលោភសេពសន្ថវៈ ដូចបានបង្ហាញខាងលើនោះទេ ប៉ុន្តែក្នុងពេលដំណាល

---

[4472] *ប្រៀបធៀប* ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/12.1 ទំព័រ ៩ ("កាលៈទេសៈដំបូងគឺថា ប្តីប្រពន្ធត្រូវបានបង្ខំឱ្យរួមភេទនៅប៉ុន្មានម៉ោងក្រោយពីពួកគេត្រូវបានដាក់ឱ្យស្ថិតក្រោមបទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ នេះបានបង្កើនបន្ថែមនូវភាពធ្ងន់ធ្ងរ និងផលប៉ះពាល់នៃបទឧក្រិដ្ឋទាំងពីរនេះ។ អង្គជំនុំជម្រះសាលាដំបូងបានលើកកត្តានេះក្នុងកថាខណ្ឌ ៣៦៩៧ ក្នុងការវិភាគរបស់ខ្លួនសម្រាប់ស្ត្រី ប៉ុន្តែពុំបានធ្វើលើបុរស") សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩៧។

[4473] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១២១៧៥ យោងទៅលើប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ (អ៊ុំ យឿន) ឯកសារលេខ ទំព័រ ៧-៨, ៤២-៤៣ ("លោកស្រី តើអាចប្រាប់អង្គជំនុំជម្រះនៅពេលណាដែលលោកស្រីរួមភេទជាមួយប្តីលោកស្រី ? ឆ៖ បានមួយខែក្រោយមក [...] ខ្ញុំភ័យពេក ទើបខ្ញុំយល់ព្រមជាមួយគាត់") (រង់ចាំអស់រយៈពេលមួយខែនៅមុនពេលការរួមដំណេក) បូកថែមឧទាហរណ៍នៃការដាក់ទណ្ឌកម្មនៅពេលមានការបង្អង់ណាកើតឡើង។

គ្នានោះបង្ហាញថា ពួកគាត់ត្រឹមជាឧបករណ៍ និងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Čelebići* បានយល់ឃើញថា នៅពេលជនរងគ្រោះត្រូវបានបង្ខំឱ្យដាក់បុគ្គលដទៃទៀតជាជនរងគ្រោះ ការនេះបានធ្វើឱ្យពួកគេទទួលរងការអាម៉ាស់ធ្ងន់ធ្ងរ[4474]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កត្តាទាំងនេះបានគាំទ្របន្ថែមទៀតលើការសន្និដ្ឋានដែលថា សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានរំលោភបំពានធ្ងន់ធ្ងរក្នុងករណីជនរងគ្រោះជាបុរស។

1582.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទាំងស្រុងផងដែរទៅលើភស្តុតាងផ្ទាល់របស់បុគ្គលដទៃទៀតដែលជាប្តី ដូចជា អែម អឿន និង យស ផល ព្រមទាំង ភស្តុតាងរបស់ មុំ វុន ទាក់ទងទៅនឹងបទពិសោធន៍ប្តីរបស់គាត់។ បើទោះបីជា អែម អឿន ត្រូវបានសួរដោយមេធាវីការពារក្តី ខៀវ សំផន ក្នុងកម្រិតមួយក្នុងសំណុំរឿង ០០២/០១ ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏មានការកំណត់រួចរាល់ហើយថា នេះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានហាមឃាត់ក្នុងការពិចារណាលើសក្ខីកម្មរបស់ អែម អឿន ស្តីពីប្រធានបទនេះក្នុងសំណុំរឿង ០០២/០២ នោះទេ ក្នុងករណីដែលភស្តុតាងនេះត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងដទៃទៀតក្នុងសំណុំរឿង ០០២/០២ នោះ[4475]។ អែម អឿន និង យស ផល អ្នកទាំងពីរបានអះអាងជាក់លាក់ថា ពួកគាត់បានទទួលរងព្យសនកម្មធ្ងន់ធ្ងរតាមរយៈបទពិសោធន៍នៃការរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ខណៈ មុំ វុន បានអះអាងថា ប្តីលោកស្រីត្រូវបានបង្ខំឱ្យរួមភេទដោយភ្ជង់កាំភ្លើង។ ជាការពិបាកស្រមៃនូវការបំភ្លឺច្បាស់លាស់ជាងនេះអំពីព្យសនកម្មទាក់ទងទៅនឹងបុគ្គលនោះ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកសាជាថ្មីម្តងទៀតថា កាលៈទេសៈបង្ខិតបង្ខំពុំចាំបាច់ត្រូវបង្ហាញតាមរយៈការគំរាមកំហែងច្បាស់លាស់នៃអំពើហិង្សានោះទេ។

1583.ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើនៅក្នុងការយល់ឃើញផ្នែកច្បាប់របស់ខ្លួននូវភស្តុតាងច្បាស់លាស់របស់ NAKAGAWA Kasumi ដែលថា ជនរងគ្រោះជាបុរសបានទទួលរងព្យសនកម្មធ្ងន់ធ្ងរតាមរយៈការបង្ខិតបង្ខំឱ្យរួមភេទជាមួយប្រពន្ធ។ ការខកខាននេះជាពិសេសជាប់ពាក់ព័ន្ធទៅនឹងការពិចារណាដែលថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកច្បាស់លាស់លើភស្តុតាងនេះតាំងពីដំបូងក្នុងការយល់ឃើញផ្នែកអង្គហេតុរបស់ខ្លួន។

---

[4474] *សូមមើល* សាលក្រមរឿងក្តី *Čelebići* (ICTY) កថាខណ្ឌ ១០៧០ (“អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា តាមរយៈការដែលត្រូវបានបង្ខំឱ្យវាយដំគ្នាទៅវិញទៅមក ជនរងគ្រោះ Danilo និង Miso Kuljanin បានទទួលរងការឈឺចាប់ និងភាពអាម៉ាស់ធ្ងន់ធ្ងរ”)។

[4475] *សូមមើលខាងលើ* ផ្នែក V.គ.៣.ខ។

1584.យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញកំហុសក្នុងកម្រិតមួយធ្ងន់ធ្ងរ។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងបង្កើតការយល់ឃើញរបស់ខ្លួនថា ជនរងគ្រោះជាបុរសនៃគោលនយោបាយរួមដំណេកដោយបង្ខំនៃការរៀបអាពាហ៍ពិពាហ៍ ជាអប្បបរមា បានទទួលរងព្យសនកម្មធ្ងន់ធ្ងរផ្លូវចិត្ត ដោយសារត្រូវបានបង្ខំឱ្យរួមភេទ។

1585.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាផងដែរលើបញ្ហាថាតើ សេចក្តីថ្លៃថ្នូររបស់មនុស្សនៃជនរងគ្រោះជាបុរស ត្រូវបានរំលោភបំពានធ្ងន់ធ្ងរដោយអំពើនៃការរួមភេទដោយបង្ខំ ដែរ ឬយ៉ាងណា។ ការវាយតម្លៃនេះពុំមានភាពចាំបាច់ឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងពុំមានកាតព្វកិច្ចធ្វើការវិភាគអំពីព្យសនកម្ម ឬការរងទុក្ខធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត និងការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ទោះជាយ៉ាងណាក្តី ដោយសារកម្រិតនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានកើតឡើងនៅពេលអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុក ជាសំខាន់ក្នុងការវាយតម្លៃលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះបញ្ហានេះ។

1586.អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវាយតម្លៃដាច់ដោយឡែកអំពីសេចក្តីថ្លៃថ្នូររបស់មនុស្ស នៅពេលដែលអង្គជំនុំជម្រះបានឃើញថា ព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ពុំត្រូវបានបង្ហាញ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងទំនងជាបានអនុម័តបទដ្ឋានដែលថា ការយល់ឃើញអំពីព្យសនកម្មចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានចាត់ទុកថា ពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវបទឧក្រិដ្ឋ។ នេះគឺជាកំហុស។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតដោយផ្អែកលើការវាយតម្លៃលើអង្គហេតុថា អំពើដែលចោទជាបញ្ហានេះច្បាស់ណាស់អាចស្មើនឹងការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សេចក្តីសន្និដ្ឋាននេះ ជាទូទៅ ពុំអាចអនុវត្តបានចំពោះជនរងគ្រោះជាស្ត្រី។ ទាំងបុរស និងស្ត្រីបានឆ្លងកាត់ការអាម៉ាស់ និងការបន្ទាបបន្ថោកធ្ងន់ធ្ងរដោយសារត្រូវបានបង្ខំឱ្យរួមភេទតាមការបញ្ជា និងមានហានិភ័យនៃព្យសនកម្មលើរូបកាយភ្លាមៗដោយសារឈ្លបប្រដាប់អាវុធ និង/ឬអំពើដទៃទៀតនៃព្យសនកម្មលើរូបកាយ ឬការស្លាប់។ ស្ត្រីមួយចំនួនបានឆ្លងកាត់ព្យសនកម្មជាក់លាក់ផងដែរដោយសារត្រូវបានរំលោភសេពសន្ថវៈពីប្តីរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ជនរងគ្រោះជាបុរសបានឆ្លងកាត់ព្យនកម្មជាក់លាក់បន្ថែមទៀតដោយសារត្រូវបានបង្ខំឱ្យរួមភេទ និងធ្វើឱ្យបុគ្គលដទៃទៀតក្លាយជាជនរងគ្រោះ។ ការដែលត្រូវបានប្រើប្រាស់ជា

មធ្យោបាយនៃអំពើហិង្សាផ្លូវភេទ ព្រមទាំងជាជនរងគ្រោះនៃអំពើនេះ ជាការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

1587.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបង្ហាញ និងថា អំពើនេះបានបង្កការរងទុក្ខលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដែលមានកម្រិតប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[4476]។ សារណារបស់ ខៀវ សំផន ទាំងអស់ស្តីពីចំណុចនេះ ត្រូវបដិសេធចោល។

1588.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាផងដែរលើការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនរងគ្រោះជាស្ត្រីដែលត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ដែលអាចស្មើនឹងបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈ បានបង្ហាញនូវការរងទុក្ខលើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4477]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ទិសដៅខ្លួនឯងក្នុងការពិចារណាលើបញ្ហាថាតើ "ធាតុផ្សំ"នៃការរំលោភសេពសន្ថវៈត្រូវបានបង្ហាញ និងបានបំភ្លឺថា ការយល់ឃើញផ្នែកអង្គហេតុជាចាំបាច់ត្រូវមានអព្យាក្រឹតភាពនៃភេទដែលជនរងគ្រោះទាំងបុរស និងស្ត្រីត្រូវបានបង្ខំឱ្យរួមភេទ ដើម្បីរួមដំណេកការរៀបអាពាហ៍ពិពាហ៍នោះ។ បើទោះបីជាស្ត្រីខ្លះអាចឆ្លងកាត់ការគំរាមកំហែងជាក់លាក់ដូចជា ហិង្សាផ្លូវភេទដោយសារប្តីរបស់ខ្លួន ឬបុរសដទៃទៀតក៏ដោយ ក៏អំពើនេះពុំបានបង្កើតជាផ្នែកមួយនៃការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នោះដែរ ប៉ុន្តែផ្ទុយទៅវិញគឺជាផ្នែកនៃបរិយាយកាសបង្ខិតបង្ខំ។ បុរស និងស្ត្រីទាំងពីរភេទ គឺជាជនរងគ្រោះនៃការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់៖ ការដែលថា ម្នាក់ត្រូវបានបង្ខំឱ្យស៊កបញ្ចូលអង្គជាត និងម្នាក់ទៀតត្រូវបានស៊កបញ្ចូលដោយបង្ខំនោះ ពុំជាប់ពាក់ព័ន្ធឡើយ។

1589.អង្គជំនុំជម្រះតុលាការកំពូលបដិសេធរាល់ការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះស្ត្រី។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសមហេតុផលលើបរិបទការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានវាយតម្លៃសមស្របលើភស្តុតាងស្តីពីការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូប

---

[4476] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

[4477] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៩២។

កាយ ឬផ្លូវចិត្ត។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការទទួលស្គាល់សមស្របនូវអត្តសញ្ញាណរបស់ ស៊ូ សុធារី ដែលជាស្ត្រីភេទទីបី។ អង្គជំនុំជម្រះតុលាការកំពូលបានសង្ខេបភស្តុតាង ស៊ូ សុធារី ទាក់ទងទៅនឹងព្យសនកម្មធ្ងន់ធ្ងរដែលគាត់បានទទួល និងបានបង្កើតការយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគប្បីចាត់ទុកថា ជាផ្នែកមួយនៃបរិបទជនរងគ្រោះជាស្ត្រីដោយសារគោលនយោបាយការរួមដំណេកដោយបង្ខំ។

1590.អង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាំងមូលដែលប្រឆាំងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញនូវព្យសនកម្ម ឬការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្តពីសំណាក់ជនរងគ្រោះជាបុរសដែលត្រូវបានបង្ខំឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានមួយដែលពុំមានតុលាការអង្គហេតុសមហេតុផលណាអាចធ្វើដូច្នេះបាន និងខកខានផងដែរក្នុងការផ្តល់សំអាងហេតុពេញលេញ។ ជាពិសេសកំហុសដែលធ្ងន់ធ្ងរនោះក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះគឺ ការអនុវត្តន៍ខុសគ្នាចំពោះបុរស និងស្ត្រីពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃអង្គហេតុដូចគ្នា។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញពុំសមហេតុផលផងដែរលើភស្តុតាង និងខកខានក្នុងការពិចារណាលើភស្តុតាងដែលពាក់ព័ន្ធផ្ទាល់។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើបញ្ហាថាតើ សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានរំលោភបំពានធ្ងន់ធ្ងរ ដែរ ឬយ៉ាងណា ដោយផ្អែកលើការយល់ឃើញរបស់ខ្លួនអំពីព្យសនកម្ម ឬការរងទុក្ខលើរូបកាយ ឬផ្លូវចិត្ត។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបង្ខំឱ្យបុគ្គលរួមភេទ គឺស្មើនឹងការរំលោភបំពានធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ សេចក្តីសន្និដ្ឋាននេះត្រូវអនុវត្តស្មើគ្នាទាំងបុរស និងស្ត្រីដែលជាជនរងគ្រោះ បើទោះបីមានធាតុផ្សំផ្សេងគ្នាដែលអាចអនុវត្តបានរៀងៗខ្លួនក៏ដោយ។

1591.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ស្របតាមវិធាន ១១០(៤) នៃវិធានផ្ទៃក្នុង ក្នុងករណីបណ្តឹងសាទុក្ខដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះមានសិទ្ធិអំណាចកែប្រែការយល់ឃើញក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ប្រសិនណាបើរកឃើញថា មានកំហុស ប៉ុន្តែពុំអាចកែប្រែផ្នែកសម្រេចសេចក្តីនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស។ អង្គជំនុំជម្រះតុលាការកំពូលបង្កើតការយល់ឃើញរបស់ខ្លួនថ្មីដែលថា ជនរងគ្រោះបុរសដែលត្រូវបានបង្ខំឱ្យរួម

ភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាអប្បបរមាបានឆ្លងកាត់ព្យសនកម្មធ្ងន់ធ្ងរផ្លូវចិត្ត និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សផងដែរ។ ក្រៅពីនេះ ការដាក់ពិរុទ្ធភាពរបស់ ខៀវ សំផន សម្រាប់អំពើដែលស្មើនឹងការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាអំពើអមនុស្សធម៌ដទៃទៀត ត្រូវតម្កល់[4478]។

**ជ. អំពើប្រល័យពូជសាសន៍**

**អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម**

1592.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទប្រល័យពូជសាសន៍ រួមទាំង*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័តិ* តាមរយៈការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម ត្រូវបានបង្ហាញ[4479]។

1593.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអំពើប្រល័យពូជសាសន៍ដែលបានសន្និដ្ឋានថា *ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័តិ* ត្រូវបានបង្ហាញ[4480]។

**ក. ថាតើ *ធាតុផ្សំសត្យានុម័ត*ត្រូវបានបង្ហាញត្រឹមត្រូវ ដែរ ឬយ៉ាងណា**

i. ថាតើ សមាជិកនៃក្រុមដែលទទួលបានការការពារត្រូវបានកំណត់គោលដៅ ដែរ ឬយ៉ាងណា

1594.ក្នុងការកំណត់ថា *ធាតុផ្សំសត្យានុម័ត* សម្រាប់អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ជនជាតិវៀតណាមគឺជាក្រុមពូជសាសន៍ជាតិពិន្ទុនៅពេលនោះ និងដូច្នេះជាក្រុមដែលទទួលបានការការពារ"[4481]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជនរងគ្រោះជាច្រើននៃអំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់គោលដៅ ដោយសារតែពួកគេជាជនជាតិវៀតណាម[4482]។ យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា "ការសម្លាប់ទាំងនេះត្រូវបានរៀបចំឡើងជាប្រព័ន្ធ និងកំណត់គោលដៅលើជនជាតិវៀតណាម" និងបានសង្កេតថា "ក្នុងករណី

[4478] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣២៦-៤៣២៧។

[4479] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៤-៣៥១៩។

[4480] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥២-១៩៧។

[4481] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៤។

[4482] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៥-៣៥១៦ យោងទៅលើកថាខណ្ឌ ២៥៦០-២៥៧១, ២៩៥៩, ២៩៩៤-២៩៩៩, ៣៤៩៧, ៣៥០១។

នីមួយៗ ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅពុំមែនជាលក្ខណៈបុគ្គល ប៉ុន្តែផ្អែកលើមូលដ្ឋានជាសមាជិកភាពក្នុងក្រុមនោះ”[4483]។

1595.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ជនជាតិវៀតណាម“ដែលរស់នៅក្នុងប្រទេសកម្ពុជា”គឺជាសមា ជិកនៃក្រុមដែលត្រូវបានការពារ និងបានកត់សម្គាល់ថា “ពុំមានភាគីណាមួយបានជំទាស់ទៅនឹងអត្ថិភាពនៃជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាដែលមានលក្ខណៈជាក្រុមមួយបែបនោះទេ”[4484]។ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា ជនជាតិវៀតណាមទាំងនោះ“ដែលរស់នៅក្នុងប្រទេសកម្ពុជា”មាន “លក្ខណៈពិសេសដាច់ដោយឡែក” ដូចជា ភាសា ម្ហូបអាហារ វប្បធម៌ សម្លៀកបំពាក់ប្រពៃណី បេតិកភណ្ឌប្រវត្តិសាស្ត្រ និងលក្ខណៈមួយចំនួនរួមជាមួយជនជាតិខ្មែរ ដូចជា ទំនាក់ទំនងគ្រួសារជិតស្និទ្ធ និងលក្ខណៈរូបរាងប្រហាក់ប្រហែលគ្នា[4485]។

1596.ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ពុំត្រឹមត្រូវថា ជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរស-២១ ព្រមទាំងក្នុងដែនទឹកកម្ពុជារួមទាំងនៅផែអូរឈើទាល គឺជាសមាជិកនៃក្រុមដែលត្រូវបានការពារ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យក្រុមដែលត្រូវបានការពារថា ជា“ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា” ដោយហេតុថា ជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅទីតាំងទាំងនេះមានទីលំនៅក្នុងប្រទេសវៀតណាម[4486]។ យោងតាម ខៀវ សំផន បានឱ្យដឹងថា ជនរងគ្រោះដែលមានទីលំនៅក្នុងប្រទេសវៀតណាមពុំត្រូវបានរួមបញ្ចូលក្នុងក្រុមដែលត្រូវបានការពារនោះ ដែលក្រុមនេះមានតែ“ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ”[4487]។

1597.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាម“ដែលរស់នៅក្នុងប្រទេសកម្ពុជា” គឺស្ថិតក្នុងក្រុមដែលត្រូវបានការពារ*តាមការជាក់ស្តែង* ពុំបានកម្រិតវិសាលភាពនៃក្រុមដែលត្រូវបានការពារនោះឡើយ។ ពិតណាស់ មានការបង្ហាញដោយប្រយោលក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកជនជាតិ

---

[4483] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៦។

[4484] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៤១៨។

[4485] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៤១៩។

[4486] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥៥-១០៥៧។

[4487] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥៥-១០៥៧។

វៀតណាមទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ដោយពុំគិតថាមានទីលំនៅអចិន្ត្រៃយ៍ ជាសមាជិកនៃក្រុមដែលត្រូវបានការពារដោយផ្អែកលើលក្ខណៈពូជសាសន៍ជាតិពន្ធុរបស់ពួកគេ។ វោហារសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាជាញឹកញាប់បាន"កំណត់គោលដៅលើជនជាតិពិន្ទុវៀតណាមទាំងអស់" រួមទាំងអ្នកដែលបានចូលមកប្រទេសកម្ពុជាពីប្រទេសវៀតណាមក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ[4488]។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការដែលក្រុមនេះត្រូវបានកំណត់តាមរយៈលក្ខណៈពូជសាសន៍ជាតិពន្ធុនៃសមាជិកនោះ អាចមានផលវិបាក ពីព្រោះអាចបង្ហាញថា ក្រុមដែលត្រូវបានការពារនេះអាចរួមបញ្ចូលជនជាតិវៀតណាមទាំងអស់ រួមទាំងជនជាតិវៀតណាមដែលរស់នៅក្រៅប្រទេសកម្ពុជាផងដែរ។ ការដែលថា មានតែសមាជិកក្រុមដែលស្ថិតនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះត្រូវបានកំណត់គោលដៅនោះ ពុំបានកម្រិតវិសាលភាពនៃក្រុមដែលត្រូវបានការពារនោះឡើយ ប៉ុន្តែអាចមានផលប៉ះពាល់លើបញ្ហាថាតើ ចារីមានចេតនាបំផ្លាញក្រុមនេះ"ទាំងមូល ឬផ្នែកខ្លះ" ដែរឬ យ៉ាងណា[4489]។

1598.នៅក្នុងការពិភាក្សាលើការកំណត់គោលដៅជនជាតិវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានរួមបញ្ចូលការសម្លាប់*ក្នុងចំណោមនោះ*"អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមដែលចាប់បានឆ្លងចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យនៅផែអូរឈើទាលក្រោយខែ មេសា ឬខែ ឧសភា ឆ្នាំ ១៩៧៧" "ជនជាតិវៀតណាមដែលចាប់បានដោយកងពល ១៦៤ នៅថ្ងៃទី ១៩ និង ២០ ខែ មីនា ឆ្នាំ ១៩៧៨" និង "ជនជាតិវៀតណាម ៧៨០ នាក់នៅមន្ទីរស-២១ និងមន្ទីរសន្តិសុខអូរកន្សែង"[4490]។ ក្រុមចុងក្រោយនេះរួមមានទាហាន និងជនស៊ីវិលជនជាតិវៀតណាមដែលចាប់បានតាមព្រំដែន ឬនៅសមុទ្រ និងនាំទៅមន្ទីរស-២១ ព្រមទាំងជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅអូរកន្សែងដែលជាជនស៊ីវិលចាប់បាននៅសមរភូមិអូរយ៉ាដាវតាមព្រំដែនកម្ពុជាវៀតណាម[4491]។ ដូច្នេះ ដូចគ្នាទៅនឹងជនជាតិវៀតណាមដែលជាក់ស្តែងបានរស់នៅក្នុងប្រទេសកម្ពុជាដែរ ទាហាន អ្នកនេសាទ ជនភៀសខ្លួន និងជនស៊ីវិលជនជាតិវៀតណាមដទៃទៀត ដែលចាប់

---

[4488] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៤១៦។

[4489] *សូមមើល* ផ្នែកខាងក្រោមស្តីពីបញ្ហាថាតើ *ធាតុផ្សំអត្តនោម័តិ* នៃបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញត្រឹមត្រូវ ដែរ ឬយ៉ាងណា។

[4490] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៤០០២។

[4491] ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមនៅមន្ទីរស-២១ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ២៤៦០-២៤៨៤។ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដែលត្រូវបានសម្លាប់នៅអូរកន្សែង *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ២៩២៦ និងជើងទំព័រ ១០០២៥។

បានក្នុងប្រទេសកម្ពុជា ឬក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ត្រូវស្ថិតក្រោមវិសាលភាពនៃក្រុមដែលត្រូវបានការពារ និងត្រូវបានកំណត់គោលដៅ។

1599.បន្ថែមលើនេះ ដូចដែល ខៀវ សំផន បានទទួលស្គាល់ថា ភស្តុតាងភាគច្រើនដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការកំណត់គោលដៅលើក្រុមដែលត្រូវបានការពារ បានសំដៅទៅលើ"ជនជាតិវៀតណាម"ជាទូទៅ និងពុំបានបែងចែករវាងជនជាតិវៀតណាមទាំងនោះដែលរស់នៅក្នុងប្រទេសកម្ពុជា និងជនជាតិវៀតណាមដែលទើបតែចូលមកកម្ពុជានោះឡើយ[4492]។

1600.អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អង្គជំនុំជម្រះ"ជឿជាក់ហួសពីវិមតិសង្ស័យថា បក្សកុម្មុយនីស្តកម្ពុជាជាសម្ងាត់ និងជាសាធារណៈ បានកំណត់គោលដៅលើជនជាតិវៀតណាមថា ជាក្រុមមួយ [...] កំណត់ពួកគេថា ជា'ជនជាតិបរទេសពិសពុល'ចាប់តាំងពីដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ"[4493]។ ដោយពិចារណាលើភស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា សមាជិកនៃក្រុមជនជាតិវៀតណាមដែលត្រូវបានការពារត្រូវបានកំណត់គោលដៅ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលលើកឡើងផ្ទុយដោយ ខៀវ សំផន។

ii. ថាតើ សមាជិកនៃក្រុមដែលទទួលបានការការពារត្រូវបានសម្លាប់ ដែរ ឬយ៉ាងណា

1601.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ជនជាតិវៀតណាមប្រាំមួយនាក់ដែលចាប់បានត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែ្ង និងថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមត្រូវបានបង្ហាញនៅមន្ទីរស-២១ នៅខេត្តស្វាយរៀង ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងនៅវត្តខ្សាច់[4494]។ ពាក់ព័ន្ធទៅនឹងមន្ទីរស-២១ គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលត្រូវបានបង្ហាញទាក់ទងទៅនឹងជនជាតិវៀតណាម ពីព្រោះអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ជាក់លាក់អំពីជនជាតិវៀតណាមនៅក្នុងការយល់ឃើញផ្នែកច្បាប់នៃអំពើមនុស្សឃាត និងដោយសារអង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលលាយឡំគ្នានូវការសម្លាប់ដោយចេតនាដែលជាការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទី

---

[4492] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៧។

[4493] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៤១៦។

[4494] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥២-១០៥៣។

ក្រុងហ្សឺណែវ ជាមួយនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4495]។ គាត់បានអះអាងថា *ធាតុផ្សំសត្យានុម័ត* នៃអំពើប្រល័យពូជសាសន៍ពុំត្រូវបានបង្ហាញត្រឹមត្រូវ ដោយសារកំហុសនៅក្នុងការកំណត់ថា ការសម្លាប់នៅទីតាំងខាងលើបានកើតឡើង[4496]។

1602.យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវការអះអាងពុំត្រឹមត្រូវរបស់គាត់ដែលថា ការសម្លាប់ពុំត្រូវបានបង្ហាញត្រឹមត្រូវនោះ។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធទៅនឹងការសម្លាប់អ្នកជាប់ឃុំជនជាតិវៀតណាមនៅមន្ទីរស-២១ និងបានកំណត់ប្រភេទគតិយុត្តនៃការស្លាប់ដោយពុំចាំបាច់បែងចែកនូវប្រភេទនៃជនរងគ្រោះឡើយ[4497]។

1603.សហមេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញផ្នែកច្បាប់ពីដំបូងដែលថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញក្នុងការកំណត់ថា ការសម្លាប់ត្រូវបានបង្ហាញគ្រប់គ្រាន់ និងថា ភស្តុតាងបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការយល់ឃើញនេះ[4498]។ សហមេធាវីនាំមុខបានលើកឡើងថា ការសន្និដ្ឋានដែលថា ជនជាតិវៀតណាមត្រូវបានសម្លាប់នៅមន្ទីរស-២១ មានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវ*ធាតុផ្សំសត្យានុម័ត*នៃអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់ដោយពុំគិតអំពីការកំណត់ប្រភេទគតិយុត្តឡើយ[4499]។

1604.អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិតេយ្យ ខេត្តកំពង់ឆ្នាំ វត្តសខ្សាច់និងខេត្តក្រចេះព្រមទាំងអត្ថិភាពនៃគោលនយោបាយដែលបង្កើតឡើងដោយមជ្ឈិមក្នុងការកំណត់គោលដៅលើជនជាតិវៀតណាមសម្រាប់ការចាត់ទុកជាសត្រូវ[4500]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ពិនិត្យសាឡើងវិញលើសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការយល់ឃើញទាំងនេះក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ ពីព្រោះសារណានេះពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។

---

[4495] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥២។

[4496] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥៤។

[4497] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៥២។

[4498] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧១៣-៧១៤។

[4499] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៧១៥។

[4500] *សូមមើលខាងលើ* ផ្នែ VII.ខ.២ និង*ខាងក្រោម*ផ្នែក VIII.ខ.៥.ក។

1605.ពាក់ព័ន្ធទៅនឹងកំហុសដែលចោទប្រកាន់ដោយ ខៀវ សំផន ទាក់ទងទៅនឹងមន្ទីរស-២១ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា កំណត់ត្រាមន្ទីរស-២១ បានបង្ហាញច្បាស់លាស់ថា អ្នកជាប់ឃុំដើមកំណើតជនជាតិវៀតណាមត្រូវបានបញ្ជូនមក ធ្វើទារុណកម្ម និងសម្លាប់ ហើយអង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្នែកអង្គហេតុមួយចំនួនចំពោះបញ្ហានេះ[4501]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការកំណត់ថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រការយល់ឃើញដែលថា សមាជិកនៃក្រុមជនជាតិវៀតណាមដែលត្រូវបានការពារ ត្រូវបានសម្លាប់ក្នុងបរិបទនៃបទប្រល័យពូជសាសន៍។

1606.យោងតាមការលើកឡើងខាងលើ ភស្តុតាងដែលត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការសន្និដ្ឋានដែលថា ជនជាតិវៀតណាមដែលស្ថិតនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់គោលដៅថាជាសមាជិកនៃក្រុមដែលត្រូវបានការពារ និងថា សមាជិកនៃក្រុមនោះត្រូវបានសម្លាប់។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជាលទ្ធផល "*ធាតុផ្សំសត្យានុម័ត* នៃបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញ"[4502]។

### ខ. ថាតើ *ធាតុផ្សំអត្តនោម័តិ*ត្រូវបានបង្ហាញត្រឹមត្រូវ ដែរ ឬយ៉ាងណា

1607.ដូចបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង "អំពើប្រល័យពូជសាសន៍មិនត្រឹមតែតម្រូវឱ្យមានភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើមូលដ្ឋានប៉ុណ្ណោះទេ ថែមទាំងភស្តុតាងនៃចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមនោះទាំងមូល ឬផ្នែកខ្លះ"[4503]។ នេះស្របជាមួយនឹងការកំណត់និយមន័យបទឧក្រិដ្ឋនេះក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែលជាប់ពាក់ព័ន្ធទៅនឹងការដែល ចារីត្រូវតែមានចេតនាបំផ្លាញក្រុមដែលត្រូវបានការពារ"បែបនោះ" និងបានបញ្ជាក់ថា "ជនរងគ្រោះនៃបទប្រល័យពូជសាសន៍ពុំមែនត្រឹមតែជាបុគ្គលប៉ុណ្ណោះទេ ថែមទាំងជាក្រុមនោះផ្ទាល់ផងដែរ"[4504]។

---

[4501] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ២៤៦០-២៤៨៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៤៥៧ យោងទៅលើក្នុងចំណោមនោះ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ (ប៉ាក សុខ) ឯកសារលេខ E1/369.1 ទំព័រ ១៨-១៩។

[4502] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៦។

[4503] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៧៩៧ ដែលបានបញ្ជាក់បន្ថែមថា៖ "នេះបានសំដៅទៅលើចេតនាប្រល័យពូជសាសន៍ *ចេតនាពិសេស dolus specialis* ឬចេតនាជាក់លាក់ក្នុងការបំផ្លាញ"។

[4504] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៧៩៨ និងជើងទំព័រ ២៣៧៥ និង ២៣៧៧។

1608.ទោះជាយ៉ាងណាក្តី ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា ក្រុមជនជាតិវៀតណាមត្រូវបានកំណត់គោលបែបនោះ[4505] និងខកខានក្នុងការបំភ្លឺថាតើ ភស្តុតាងបានបង្ហាញអត្ថិភាពនៃចេតនាក្នុងការបំផ្លាញក្រុមជនជាតិវៀតណាម"ទាំងមូល ឬផ្នែកខ្លះ" ដែរ ឬយ៉ាងណា[4506]។ គាត់បានអះអាងថា ប្រសិនបើមានចេតនាក្នុងបំផ្លាញផ្នែកខ្លះនៃក្រុមនោះពិតមែន ភស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបង្ហាញថា ផ្នែកខ្លះនៃក្រុមដែលកំណត់គោលដៅសម្រាប់ការបំផ្លាញនោះ "មានលក្ខណៈច្រើន"គ្រប់គ្រាន់ក្នុងការបង្ហាញនូវចេតនាប្រល័យពូជសាសន៍[4507]។

i. ថាតើ មានចេតនាក្នុងការបំផ្លាញក្រុមដែលត្រូវបានការពារបែបនោះ ដែរ ឬយ៉ាងណា

1609.បើទោះបីជាអំពើប្រល័យពូជសាសន៍អាចត្រូវបានកំណត់ថា ជាចេតនាក្នុងការបំផ្លាញក្រុមដែលត្រូវបានការពារទាំងមូល ឬផ្នែកខ្លះក៏ដោយ ក៏ធាតុផ្សំរួមគឺថា ចេតនាបំផ្លាញត្រូវតែកំណត់គោលដៅលើក្រុម"នោះ" ដែរ។ ផ្អែកតាមការពិនិត្យឡើងវិញលើភស្តុតាងចំពោះមុខទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តនៃអំពើប្រល័យពូជសាសន៍ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការសម្លាប់"ត្រូវបានរៀបចំជាប្រព័ន្ធ និងកំណត់គោលដៅលើជនជាតិវៀតណាម" និងថា "នៅក្នុងករណីនីមួយៗ ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅពុំមែនជាលក្ខណៈបុគ្គល ប៉ុន្តែបានផ្អែកលើមូលដ្ឋាននៃសមាជិកភាពក្នុងក្រុមនោះ"[4508]។

1610.ក្នុងការពិចារណាលើធាតុផ្សំអត្តនោម័តិនៃបទឧក្រិដ្ឋនេះ អង្គជំនុំជម្រះសាលាដំបូងយោងទៅលើអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍សម្រាប់ការអះអាងថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើប្រល័យពូជសាសន៍គឺជា "ចេតនាក្នុងការបំផ្លាញទាំងមូល ឬផ្នែកខ្លះនៃក្រុមសាសនា ពូជសាសន៍ ឬជាតិពន្ធុនោះ"[4509]។ ក្នុងការកំណត់ថា "បក្សកុម្មុយនីស្តកម្ពុជាជាសម្ងាត់ និងជាសាធារណៈបានកំណត់គោលដៅលើជនជាតិវៀតណាមជាក្រុមមួយ" អង្គជំនុំជម្រះសាលាដំបូងបានសង្កេតថា អង្គជំនុំជម្រះបានកំណត់ដូច្នេះតាមរយៈភស្តុតាងនៃសេចក្តីណែនាំផ្សព្វផ្សាយទូលំទូលាយ វគ្គបណ្តុះបណ្តាលនយោបាយ សេចក្តីថ្លែងការណ៍ បទឧទ្ទេសនាម

---

[4505] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៥-១០៦៧។

[4506] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥៩។

[4507] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៥៩-១០៦៤។

[4508] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៦។

[4509] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៧៩៧ យោងទៅលើមាត្រា ២ នៃអនុសញ្ញាស្តីពីការរារាំង និងដាក់ទោសបទប្រល័យពូជសាសន៍ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ អង្គការសហប្រជាជាតិ លេខលំដាប់សន្ធិសញ្ញា ភាគ ៧៨ ទំព័រ ២៧៧ ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍")។

និងការស្រង់ឈ្មោះ និងតាមរយៈការអនុវត្តន៍តាមគោលនយោបាយដែលបង្កើតឡើងដើម្បី"ជីកស្មៅជីកទាំងឫស"នៃជនជាតិវៀតណាម[4510]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បុគ្គលដែលបានប្រព្រឹត្តដោយផ្ទាល់នូវការធ្វើមនុស្សឃាត បានបង្ហាញនូវ"ចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមជនជាតិវៀតណាមនោះ"[4511]។

1611.យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងជាចម្បងបានសំអាងទៅលើការយល់ឃើញរបស់ខ្លួនដែលថា មានគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដេកជនជាតិវៀតណាមចេញពីកម្ពុជា និងបន្ទាប់មកកម្ទេចពួកគេ ដែលនេះបានផ្អែកលើសុន្ទរកថារបស់ ប៉ុល ពត ដែលថា "មួយទល់នឹង ៣០" សុន្ទរកថារបស់ ខៀវ សំផន ការប្រកាសរបស់ នួន ជា និងការវិភាគលើវគ្គបណ្តុះបណ្តាលនយោបាយមួយចំនួន[4512]។ គាត់បានអះអាងថា ដោយសារបទប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តទៅលើ "ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា" អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យកំណត់ថាតើ មានចេតនាក្នុងការកំណត់គោលដៅលើក្រុមនេះ ដែរ ឬយ៉ាងណា និងដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគប្បីបែងចែកច្បាស់លាស់នូវក្រុមនេះចេញពីជនជាតិវៀតណាមដទៃទៀត ជាពិសេសដោយសារអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើដូច្នោះឡើយ[4513]។

1612.ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសមួយចំនួនក្នុងការវិភាគលើភស្តុតាងដែលនាំឱ្យអង្គជំនុំជម្រះសន្និដ្ឋានពុំត្រឹមត្រូវថា មានចេតនាក្នុងការបំផ្លាញក្រុមនោះ៖

ក. កំហុសក្នុងការបកស្រាយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៧៣ ដែលជាប់ពាក់ព័ន្ធទៅនឹងទំនាក់ទំនងការទូតរវាងរដ្ឋពីរ ជាជាងគោលនយោបាយណាមួយទៅលើជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា[4514]។

---

[4510] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៨។

[4511] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៧-៣៥១៨ យោងទៅលើកថាខណ្ឌ ២១៦៧-២១៦៨, ២១៧៤-២១៧៥, ៣៣៧៧-៣៣៨១, ៣៣៨៥, ៣៣៩០-៣៣៩១, ៣៣៩៦, ៣៤១៦, ៣៤២៥, ៣៤២៨, ៣៤៩៧, ៣៥០១ ជើងទំព័រ ១១៤៣៦ សុន្ទរកថារបស់ អៀង សារី ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/199 ទំព័រ ៤។

[4512] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៥។

[4513] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៦-១០៦៧។

[4514] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៨-១០៦៩។

ខ. អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយពុំត្រឹមត្រូវលើទង់បដិវត្តខែ មេសា ឆ្នាំ ១៩៧៦ ដោយបានសន្មតថា ការសំដៅទៅលើជនបរទេសនោះ គឺទៅលើជនជាតិវៀតណាម ដោយសារការសំដៅនោះអាចទៅលើជនជាតិអាមេរិក និងពួកអឺរ៉ុបដែលរស់ក្នុងទីក្រុងភ្នំពេញ[4515]។

គ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយការសំដៅរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅលើជនជាតិវៀតណាមថា ជាខ្មាំង ដោយសារការកំណត់គោលដៅលើនោះ គឺទៅលើប្រទេសវៀតណាម ហើយវោហារសាស្ត្រប្រឆាំងនឹងជនជាតិវៀតណាម គប្បីត្រូវបានបកស្រាយដោយផ្អែកលើជម្លោះប្រដាប់អាវុធ[4516]។ ជាលទ្ធផល គាត់ជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូង ពុំគប្បីផ្អែកទៅលើសក្ខីកម្មរបស់ ឯក ហេន ពាក់ព័ន្ធទៅនឹងបទឧទ្ទេសនាមរបស់គាត់ក្នុងកិច្ចប្រជុំ ដោយសារសក្ខីកម្មនេះ ខ្វះភាពគួរឱ្យជឿជាក់ និងទុកចិត្តបាន ហើយសក្ខីកម្មរបស់គាត់អាចបកស្រាយផ្សេងពីនេះបាន[4517]។

ឃ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវិភាគ និងការសំអាងទៅលើឯកសារពីរនៃកម្រងសារព័ត៌មាន FBIS ដោយសារឯកសារនេះមានតម្លៃជាភស្តុតាងទាប និងកំណត់សម្គាល់ដែលមាននោះពុំអាចសន្មតថា ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងបានកើតឡើងបន្ទាប់ពីវៀតណាមធ្វើការវាយលុកទ្រង់ទ្រាយធំប្រឆាំងនឹងប្រទេសកម្ពុជា[4518]។

ង. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា បទឧទ្ទេសនាមពីររបស់ ខៀវ សំផន បង្ហាញថា ជនជាតិវៀតណាមទាំងអស់ត្រូវបានកំណត់គោលដៅ ដោយសារឯកសារពីរដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ គឺជាប្រតិចារឹក និងការបកប្រែផ្សេងគ្នាលើបទឧទ្ទេសនាមតែមួយដែលក្នុងនោះ ខៀវ សំផន បានអំពាវនាវឱ្យមានការសម្លាប់សត្រូវដែលជាជនជាតិវៀតណាម និងចង់សំដៅទៅលើកងទ័ពរបស់ប្រទេសវៀតណាម ពុំមែនជនស៊ីវិលវៀតណាម ឬជនជាតិពន្ធុវៀតណាមក្នុងប្រទេសកម្ពុជាឡើយ[4519]។

---

[4515] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧០-១០៧២។

[4516] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧៣-១០៧៤, ១០៧៨។

[4517] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧៥។

[4518] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧៩។

[4519] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៨០-១០៨១។

ច. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និគតសំដីរបស់ ប៉ុល ពត ថា “មួយទល់នឹង ៣០” គឺចង់សំដៅទៅលើប្រជាជនវៀតណាមទាំងមូលដែលជាជនជាតិពន្ធុ ដោយសារសំដីនេះ គឺក្នុងគោលបំណងដើម្បីជម្រុញទឹកចិត្តកងទ័ពកម្ពុជាប្រជាធិបតេយ្យដែលប្រឈមនឹងសត្រូវដែលខ្លាំងជាង និងមានចំនួនច្រើនលើសលុប[4520]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើការដែលសំដីនេះអាចត្រូវបានគេបកស្រាយផ្សេងៗ និងបានចង្អុលបង្ហាញថា អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ បានរិះគន់អង្គជំនុំជម្រះសាលាដំបូង ដោយសារខកខានក្នុងការពន្យល់នូវការដែលអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយពាក្យ“សត្រូវ” នៅក្នុងបទឧទ្ទេសនាមផ្សេងគ្នាថាមានន័យលើសពីគោលដៅយោធានោះ[4521]។

ឆ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិនិត្យលើទស្សនាវដ្ដីទង់បដិវត្តខែឧសភា-មិថុនា ឆ្នាំ ១៩៧៨ និងខែ កក្កដា ឆ្នាំ ១៩៧៨ ទៅតាមបរិបទ ដោយសារការសំដៅទៅលើជនជាតិវៀតណាម ពុំមែនលើជនជាតិពន្ធុវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា[4522]។

ជ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារទទួលយកទូរលេខ និងភស្តុតាងដទៃទៀតនៅសម័យនោះខុសពីបរិបទពីព្រោះភស្តុតាងទាំងនេះសំដៅទៅលើជម្លោះជាមួយប្រទេសវៀតណាមជាជាងការសម្លាប់ជនស៊ីវិលជនជាតិវៀតណាម[4523]។

ឈ.អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និគតថា សេចក្ដីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៩ ជំទាស់ទៅនឹងការឈ្លានពានរបស់វៀតណាម គឺសំដៅទៅលើជនជាតិវៀតណាមទាំងអស់ដោយគ្មានការបែងចែក[4524]។

ញ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ដែលជាបុគ្គលម្នាក់បានលើកឡើងច្បាស់លាស់ថា មានគោលនយោបាយលុបបំបាត់ជនជាតិពន្ធុវៀតណាម ដោយសារតម្លៃជាភស្តុតាងនៃសក្ខីកម្មនេះបានចោទជាបញ្ហា

[4520] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៨៣-១០៨៤។

[4521] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៨៥។

[4522] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៨៦។

[4523] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩០-១០៩៣។

[4524] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៤។

ពីព្រោះ ហេង ឡៃប៊ាង បានបាត់បង់សមាជិកគ្រួសារ និងដូច្នេះ ខ្វះភាពសត្យានុម័ត[4525]។ ខៀវ សំផន បានជំទាស់ថា លោកស្រីពុំបានឃើញផ្ទាល់នូវការសម្លាប់ណាមួយ និងបានអះអាងថា ដោយសារលោកស្រីបានលើកឡើងថា ពុំមានជនជាតិវៀតណាមនៅក្នុងឃុំរបស់លោកស្រី ទើបលោកស្រីពុំដឹងថាមានអ្វីកើតឡើងលើជនជាតិវៀតណាម[4526]។ បន្ថែមលើនេះ សក្ខីកម្មរបស់គាត់មានលក្ខណៈផ្ទុយគ្នាជាមួយនឹងអតីតទាហាននៃរបបកម្ពុជាប្រជាធិបតេយ្យ មាស វឿន ដែលបានផ្តល់សក្ខីកម្មថា ពុំដែលមានគោលនយោបាយណាមួយក្នុងការកម្ទេចជនស៊ីវិលជនជាតិវៀតណាម[4527]។

ង. ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គោលនយោបាយនៃការវាយប្រហារជនស៊ីវិលជនជាតិវៀតណាមមានអត្ថិភាពដោយផ្អែកលើការធ្វើបញ្ជីឈ្មោះ ពីព្រោះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពុំមែនមានតែជនជាតិវៀតណាមប៉ុណ្ណោះដែលស្ថិតក្រោមការស្រង់ឈ្មោះនោះទេ អ្នករាល់គ្នាក៏ត្រូវបានធ្វើដូច្នោះដែរ ដែលនេះជាផ្នែកនៃផែនការផ្គត់ផ្គង់របបអាហារសហករណ៍[4528]។ គាត់បានអះអាងផងដែរថា សែស្រឡាយខាងម្តាយនៃក្រុមជាតិពន្ធុ ពុំត្រូវបានបង្ហាញ[4529]។

1613.ចុងក្រោយ ខៀវ សំផន បានអះអាងថា ពុំមានតុលាការអង្គហេតុសមហេតុផលដែលអាចយល់ឃើញថា *ធាតុផ្សំអត្តនោម័តិ*នៃអំពើប្រល័យពូជសាសន៍ដោយសារការសម្លាប់នោះ ត្រូវបានបង្ហាញតាមរយៈគោលនយោបាយរបស់រដ្ឋក្នុងការកម្ទេចជនជាតិពន្ធុវៀតណាមឡើយ និងថា ដូច្នេះ គាត់គប្បីត្រូវបានឱ្យរួចពីការចោទប្រកាន់នេះ[4530]។

---

[4525] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៥។

[4526] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៥ ជើងទំព័រ ២០៤៨។

[4527] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៥ ជើងទំព័រ ២០៤៨។

[4528] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៦។

[4529] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៦។

[4530] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៩៧។

1614.សហព្រះរាជអាជ្ញាបានបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ចេតនាក្នុងការបំផ្លាញក្រុមនោះត្រូវបានបង្ហាញ និងថា ជាលទ្ធផល អង្គជំនុំជម្រះបានបំភ្លៃភស្តុតាងនោះ[4531]។

1615.សហមេធាវីនាំមុខបានយល់ស្របជាមួយនឹងសារណារបតរបស់សហព្រះរាជអាជ្ញា និងបានជំទាស់តែទៅលើការបកស្រាយរបស់ ខៀវ សំផន អំពីសក្ខីកម្មរបស់ ហេង ឡៃហ៊ាង និងថា សក្ខីកម្មរបស់លោកស្រីមានលក្ខណៈជាសត្យានុម័ត ច្បាស់លាស់ ស្មោះត្រង់ និងផ្ទាល់[4532]។

1616.អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីកំណត់លើបញ្ហាថាតើ មានចេតនាក្នុងការកំណត់គោលដៅជាក់លាក់លើជនជាតិវៀតណាមដែលស្ថិតនៅក្នុងប្រទេសកម្ពុជា និងបង្ហាញភាពខុសប្លែកគ្នានៃក្រុមនេះ ពីជនជាតិវៀតណាមដទៃទៀត ជាពិសេសដោយសារជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាមដែលកំពុងបន្តនៅពេលនោះ ដែរ ឬយ៉ាងណា។ ការអះអាងអំពីកំហុសនេះ បានផ្អែកលើការលើកឡើងរបស់គាត់ដែលថា ក្រុមដែលត្រូវបានការពារត្រូវបានកម្រិតត្រឹមតែ"ជនជាតិពន្ធុវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា"ប៉ុណ្ណោះ[4533]។ ដូចបានលើកឡើងខាងលើ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ក្រុមដែលត្រូវបានការពារបានរួមបញ្ចូលជនជាតិវៀតណាមទាំងអស់ដោយពុំគិតពីការតាំងទីលំនៅអចិន្ត្រៃយ៍ឡើយ[4534]។

1617.ទាក់ទងទៅនឹងការដែលថា ខៀវ សំផន បានគាំទ្រការអះអាងរបស់គាត់ពាក់ព័ន្ធបញ្ហានេះដោយគ្រាន់តែទន្ទេញដដែលៗថា អង្គជំនុំសាលាដំបូងមាន"កំហុសជាច្រើនផ្នែកអង្គហេតុ និងអង្គច្បាប់"[4535] អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសផ្នែកអង្គច្បាប់ពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[4531] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៦៥៦ (កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៧៣), ៦៥៧ (ការបោះពុម្ពផ្សាយខែ មេសា ឆ្នាំ ១៩៧៦ នៃទង់បដិវត្ត), ៦៥៨-៦៦០ (ភស្តុតាងជាឯកសារ និងសក្ខីកម្មផ្ទាល់មាត់), ៦៦១ (ឯកសារ និងសុន្ទរកថាកម្រងសារព័ត៌មាន FBIS និង SWB), ៦៦២ (ទស្សនាវដ្ដីទង់បដិវត្ត និងយុវជនបដិវត្ត), ៦៦៣ (ទូរលេខ), ៦៦៤ (សក្ខីកម្មផ្ទាល់មាត់របស់ ហេង ឡៃហ៊ាង, មាស វឿន និង ប៉ាក សុខ)។

[4532] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ កថាខណ្ឌ ៧២២-៧២៦។

[4533] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៦។

[4534] *សូមមើលខាងលើ* ផ្នែក VII.ជ.១.ក.i។

[4535] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៦។

1618.ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងផលវិបាកនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា ឃើញថា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានដោះស្រាយបញ្ហាទំនាក់ទំនងការទូតរវាងរដ្ឋ៖

> វោហារសាស្ត្ររបស់បក្សកុម្មុយនីសកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាមបានផ្តោតទៅលើគោលគំនិតនៃភាពជាសត្រូវដ៏យូរលង់រវាងប្រជាជនខ្មែរ និងជនជាតិវៀតណាម ដែលបក្សកុម្មុយនីស្តកម្ពុជានិយាយថាមានតាំងពីសតវត្សរ៍ទី២។ [...] ការបែកបាក់ទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋអំណាចវៀតណាមខាងជើង(ក្រោយការចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅខែ មករា ឆ្នាំ ១៩៧៣ រវាងរដ្ឋាភិបាលវៀតណាម និងសហរដ្ឋអាមេរិក) ត្រូវបានយកមកពិចារណាធៀបនឹងសាវតារនៃភាពជាសត្រូវនេះ ដែលអាចពន្យល់ក្នុងផ្នែកខ្លះអំពីការកំណត់អត្តសញ្ញាណរបស់បក្សកុម្មុយនីស្តកម្ពុជាលើជនជាតិពន្ធុវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាថា ជាក្រុមមួយដែលស័ក្តិសមទទួលបានការចាប់អារម្មណ៍ដាច់ដោយឡែក[4536]។

1619.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានបំភ្លៃការសំដៅនៅក្នុងទស្សនាវដ្តីទង់បដិវត្តខែ មេសា ឆ្នាំ ១៩៧៦ ទៅលើ“ជនបរទេស”។

1620.ជាការឆ្លើយតបទៅនឹងការជំទាស់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើសក្ខីកម្មរបស់ ឯក ហេន អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ឯក ហេន គឺជាសាក្សីម្នាក់ក្នុងចំណោមសាក្សីជាច្រើនដែលត្រូវបានស្តាប់ដោយអង្គជំនុំជម្រះសាលាដំបូង និងបានជួយបង្ហាញថា ចាប់តាំងពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីសកម្ពុជាបានបង្រៀន ឬចូលរួមវគ្គបណ្តុះបណ្តាលដែលក្នុងនោះជនជាតិវៀតណាម ឬ“ភ្នាក់ងារ”វៀតណាម ត្រូវបានចាត់ទុកថា ជាសត្រូវ[4537]។ ការ

---

[4536] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨២។

[4537] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ យោងទៅលើប្រតិចារឹកថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ឯកសារលេខ E1/72.1 ទំព័រ ២១។ ប្រតិចារឹកថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ឯកសារលេខ E1/73.1 ទំព័រ ១៧-១៨, ២០។ ប្រតិចារឹកថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ឯកសារលេខ E1/89.1 ទំព័រ ៦២។ ប្រតិចារឹកថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (ឯម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២៤-២៦, ៤០-៤១។ ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ (មុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៥០, ៥៦-៥៧។ ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (អ៊ូ ដាវ) ឯកសារលេខ E1/498.1 ទំព័រ ៧៤-៧៥។ ប្រតិចារឹកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ប៊ិត ហឿន *ហៅ* ប៊ិត ណា) ឯកសារលេខ E1/502.1 ទំព័រ ១៧-១៨, ២០, ២២-២៣។ ប្រតិចារឹកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៨, ៤០។

អះអាងរបស់ ខៀវ សំផន ដែលថា សក្ខីកម្មរបស់ ឯក ហេន ខ្វះភាពគួរឱ្យជឿជាក់ និងទុកចិត្តបាននោះពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ឡើយ ដោយសារគាត់ត្រឹមតែយោងទៅលើកថាខណ្ឌមួយចំនួននៃសំណើដែលគាត់បានធ្វើឡើងសុំឱ្យទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ និង ០០៤ របស់ ឯក ហេន[4538]។ គាត់បានចាត់ទុកសក្ខីកម្មនេះថា ពុំអាចជឿទុកចិត្តបាន ពីព្រោះ ឯក ហេន ពុំបានចាំច្បាស់នូវកាលបរិច្ឆេទនៃកិច្ចប្រជុំដែលលោកស្រីបានស្តាប់ឮ ខៀវ សំផន ធ្វើបទឧទ្ទេសនាម ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា វគ្គបណ្តុះបណ្តាលនោះបានកើតឡើងក្រោយពេលដែល ប៉ង់ ត្រូវបានចោទទោស និងថា គាត់ត្រូវបានចាប់ខ្លួនប្រហែលជាក្នុងខែ មេសា ឆ្នាំ ១៩៧៨[4539]។ ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញនេះពុំសមហេតុផល ឬថា សក្ខីកម្មនោះចោទជាបញ្ហាឡើយ។ ប្រហាក់ប្រហែលគ្នានេះ ការអះអាងថា សក្ខីកម្មរបស់ ឯក ហេន អាចត្រូវបានបកស្រាយផ្សេងៗគ្នានោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលឡើយ។

1621. ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារពីរនៃកម្រងសារព័ត៌មាន FBIS អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ទម្ងន់ឥតសមស្របទៅលើតម្លៃជាភស្តុតាងនៃឯកសារនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ច្បាស់លាស់ថា ការផ្សព្វផ្សាយនោះត្រូវបានធ្វើឡើងដោយ"អ្នកផ្សព្វផ្សាយគ្មានអត្តសញ្ញាណនៅទីក្រុងភ្នំពេញ" និងបានសំអាងទៅលើឯកសារនេះត្រឹមតែភស្តុតាងបញ្ជាក់បន្ថែមប៉ុណ្ណោះ៖

> អង្គជំនុំជម្រះបានយល់ឃើញថា ទម្រង់បែបបទ និងខ្លឹមសារនៃអត្ថបទផ្សព្វផ្សាយនោះឆ្លុះបញ្ចាំងវោហារសាស្ត្ររបស់បក្សកុម្មុយនីសកម្ពុជា និងបានសន្និដ្ឋានថា ជាក់ស្តែងអត្ថបទនោះត្រូវបានចេញផ្សាយដោយមជ្ឈិមបក្ស។ នៅពេលពិនិត្យតាមបរិបទ និងពិចារណាលើការដកកងកម្លាំងប្រដាប់អាវុធវៀតណាមនៅពេលនោះ អង្គជំនុំជម្រះយល់ឃើញថា ការអំពាវនាវទាំងនេះបានកំណត់គោលដៅលើទាហានវៀតណាម និងជនស៊ីវិលវៀតណាម[4540]។

អាស្រ័យហេតុនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការផ្សព្វផ្សាយនោះត្រូវបានសន្មតថា ជារបស់បក្សកុម្មុយនីស្តកម្ពុជា។

---

[4538] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧៥ ជើងទំព័រ ១៩៩៥។

[4539] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ជើងទំព័រ ១១៤៣៧។

[4540] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩៨។

1622.បញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការកំណត់ថា ប្រតិចារឹកពីរខុសគ្នា គឺជាបទឧទ្ទេសនាមពីរដាច់ដោយឡែកពីគ្នាជាជាងបទឧទ្ទេសនាមតែមួយ ខៀវ សំផន ត្រឹមតែលើកការបកស្រាយមួយផ្សេងអំពីភស្តុតាងតាមរយៈការអះអាងថា បទឧទ្ទេសនាមបានសំដៅទៅលើកងទ័ពវៀតណាមជាជាងជនស៊ីវិលវៀតណាម ប៉ុន្តែពុំបានបង្ហាញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុថា ការសំដៅទៅលើការថែរក្សាការពារ"ពូជសាសន៍កម្ពុជា" និងការញុះញង់"ការស្អប់ជាតិសាសន៍"បានបង្ហាញថា ក្រុមគោលដៅគឺជាជនជាតិវៀតណាមទាំងអស់ មិនត្រឹមតែកងកម្លាំងប្រដាប់អាវុធជានជាតិវៀតណាមប៉ុណ្ណោះទេ[4541]។

1623.អង្គជំនុំជម្រះសាលាដំបូង"បានទទួលស្គាល់ថា សុន្ទរកថារបស់ ប៉ុល ពត ក្នុងខែ មេសា ឆ្នាំ ១៩៧៨ ដែលថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា'មួយទល់នឹង ៣០' ជាបឋមពាក់ព័ន្ធទៅនឹងទាហាន និងប្រើប្រាស់ដើម្បី'ជម្រុញទឹកចិត្តប្រយុទ្ធរបស់កម្មាភិបាល និងយុទ្ធជនឱ្យត្រៀមខ្លួនរួចរាល់ក្នុងសមរភូមិ'"[4542]។ ទោះជាយ៉ាងណាក្ដី បន្ទាប់ពីពិនិត្យលើសុន្ទរកថានេះ និងភស្តុតាងដទៃទៀត អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអំពាវនាវនោះបានកំណត់គោលដៅប្រឆាំងនឹងជនជាតិពន្ធុវៀតណាមទាំងមូល មិនត្រឹមតែកងកម្លាំងយោធាវៀតណាមប៉ុណ្ណោះទេ និងបានពន្យល់នូវសំអាងហេតុរបស់ខ្លួន[4543]។ ផ្ទុយទៅវិញ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់នូវមូលហេតុដូចម្ដេចបានជាអង្គជំនុំជម្រះជឿជាក់ថា ពាក្យ"សត្រូវ" ពុំបានសំដៅតែទៅលើគោលដៅយោធានោះ។ ដូចនេះ ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងនេះមានកំហុសឡើយ។

1624.ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការចោទប្រកាន់ ក្នុងការពិនិត្យលើទស្សនាវដ្ដីទង់បដិវត្តខែ ឧសភា-មិថុនា និង កក្កដា ឆ្នាំ ១៩៧៨ តាមបរិបទ ពីព្រោះគាត់ខកខានក្នុងការបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល។ បន្ថែមលើនេះ ដូចបានពិភាក្សាខាងដើម ក្រុមដែលទទួលបានការការពារនោះ គឺជនជាតិវៀតណាមទាំងអស់ដែលបក្សកុម្មុយនីស្តកម្ពុជាមានចេតនាបំផ្លាញអ្នកទាំងអស់នោះក្នុងប្រទេសកម្ពុជា ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់យល់ឃើញថា បញ្ហាទាំងនេះបាន

---

[4541] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩៩-៣៤០០។

[4542] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០២។

[4543] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០២។

សំដៅជាក់លាក់ទៅលើជនជាតិពន្ធុវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ជាជាងជនជាតិវៀតណាមទូទៅនោះឡើយ។

1625.ការអះអាងរបស់ ខៀវ សំផន ដែលថា ទូរលេខនៅសម័យនោះ និងភស្តុតាងដទៃទៀតត្រូវបានពិចារណាក្រៅបរិបទ ពីព្រោះភស្តុតាងទាំងនេះបានសំដៅទៅលើការប៉ះទង្គិចតាមព្រំដែនជាជាងការកម្ទេចជនស៊ីវិលវៀតណាមនោះ ជាការពុំត្រឹមត្រូវ ដោយសារអ្នកដែលពុំមែនជាជនស៊ីវិលក៏អាចជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ផងដែរ[4544]។

1626.ជាការឆ្លើយតបទៅនឹងការជំទាស់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៩ ជំទាស់ទៅនឹងការឈ្លានពានរបស់វៀតណាមថា បានកំណត់គោលដៅលើជនជាតិវៀតណាមទាំងអស់ដោយគ្មានការបែងចែក អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើការវាយលុកយោធា ប៉ុន្តែបានសន្និដ្ឋានថា ការសំដៅជាក់លាក់ទៅលើប្រជាជនកម្ពុជាទាំងមូល និង"សត្រូវសួពូជ"បង្ហាញថា ការលើកឡើងនោះបានកំណត់គោលដៅលើជនជាតិវៀតណាមទាំងអស់ដោយមិនរើសមុខ[4545]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា សាក្សីជាច្រើនបានអះអាងថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំជាន់ខ្ពស់បានចាត់ទុកវៀតណាមជា"សត្រូវសួពូជ"របស់ប្រជាជនកម្ពុជា[4546]។ ខៀវ សំផន ពុំបានបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងនោះពុំសមហេតុផលឡើយ។

1627.ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានផ្តល់សក្ខីកម្មលម្អិតអំពីការដែលគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមត្រូវបានផ្សព្វផ្សាយចេញពីថ្នាក់តំបន់ទៅថ្នាក់ភូមិតាមរយៈស្រុក និងឃុំ[4547]។ ការដែលថា គាត់ពុំបានឃើញការសម្លាប់ណាមួយពុំជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់

---

[4544] *សូមមើល ឧ.* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krstić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-33-A សាលដីកាថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ ("សាលដីការឿងក្តី *Krstić* (ICTY)") កថាខណ្ឌ ២២៦ ("លក្ខខណ្ឌតម្រូវនៃចេតនាអំពើប្រល័យពូជសាសន៍ពុំត្រូវបានកម្រិតត្រឹមហេតុការណ៍ដែលចារីកំណត់គោលដៅបំផ្លាយតែជនស៊ីវិលប៉ុណ្ណោះទេ។ [...] ពុំមានការបញ្ជាក់ក្នុងការកំណត់និយមន័យនៃអំពើប្រល័យពូជសាសន៍ដែលហាមឃាត់ ជាឧទាហរណ៍ ការដាក់ពិរុទ្ធភាពនៅពេលដែលចារីបានសម្លាប់បុគ្គលិកយោធាដែលបានជាប់ឃុំឃាំង និងជាក្រុមដែលត្រូវបានការពារដោយសារតែជាសមាជិកនៃក្រុមនោះ")។

[4545] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១២។

[4546] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១២។

[4547] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ (ហេង ឡៃហ៊ាង) ឯកសារលេខ E1/476.1 ទំព័រ ៤៦-៤៧។

អង្គជំនុំជម្រះសាលាដំបូង ដោយសារអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើភស្តុតាងរបស់លោកស្រីក្នុងការបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយ ជាជាងសកម្មភាពនៅក្នុងការអនុវត្តន៍នោះ។ ជាការពុំគួរឱ្យជឿបានក្នុងការលើកឡើងថា ដោយសារលោកស្រីបានបញ្ជាក់ថា ពុំមានជនជាតិវៀតណាមនៅក្នុងឃុំរបស់លោកស្រី ហើយលោកស្រីពុំបានដឹងថាមានអ្វីកើតឡើងចំពោះជនជាតិវៀតណាមនោះ នៅពេលលោកស្រីគឺជាសមាជិកនៃបក្សកុម្មុយនីសកម្ពុជាដែលបម្រើការជាគណៈឃុំក្នុងខេត្តក្រចេះរហូតដល់ឆ្នាំ ១៩៧៧ និងបានដឹងច្បាស់លាស់អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាម[4548]។ ការដែលអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសយកសក្ខីកម្មរបស់ ហេង ឡៃហ៊ាង ពាក់ព័ន្ធទៅនឹងគោលនយោបាយចំពោះជនជាតិវៀតណាម ជាជាងសក្ខីកម្មរបស់ មាស វឿន ដែលផ្អែកតាម ខៀវ សំផន បានអះអាងថា ពុំដែលមានគោលនយោបាយកំណត់គោលដៅលើការកម្ទេចជនស៊ីវិលវៀតណាម ពុំបានបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានផ្តល់ទំនុកចិត្តក្នុងការវាយតម្លៃលើភស្តុតាងនៅពេលជំនុំជម្រះ និងធ្វើសេចក្តីសន្និដ្ឋានក្រោយមក។

1628.អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា មនុស្សគ្រប់គ្នាត្រូវបានដាក់ឱ្យស្ថិតក្រោមការស្រង់ស្ថិតិ និងការធ្វើបញ្ជីឈ្មោះជនជាតិវៀតណាមពុំបានបង្ហាញថា ពួកគេត្រូវបានកំណត់គោលដៅនោះទេ។ បើទោះបីជាអ្នករាល់គ្នាអាចត្រូវបានដាក់ស្ថិតក្រោមការស្រង់ស្ថិតិក៏ដោយ ក៏នេះពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមត្រូវសម្រិតសម្រាំងតាមរយៈការធ្វើបញ្ជីឈ្មោះនោះគ្មានមូលដ្ឋានដែរ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់សាក្សីជាច្រើនពាក់ព័ន្ធទៅនឹងដំណើរការសម្រិតសម្រាំងនេះដោយផ្អែកលើការបង្កើតបញ្ជីឈ្មោះ[4549]។ ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីគោលនយោបាយនៃជាតិពន្ធុសែស្រឡាយខាងម្តាយ ខៀវ សំផន បានយោងទៅលើអំណះអំណាងរបស់គាត់ជំទាស់ទៅនឹងការយល់ឃើញស្តីពីការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍លើជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងស្វាយរៀង។ អំណះអំណាងនេះត្រូវបដិសេធចោល[4550]។

[4548] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៤-៣៤១៥។

[4549] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤២០-៣៤២២។

[4550] *សូមមើលខាងលើ* ផ្នែក VII.ថ.៤.ឃ.i។

1629.អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ភស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈគ្រប់គ្រាន់នៃបញ្ហាអង្គហេតុ និងអង្គច្បាប់ក្នុងការគាំទ្រការយល់ឃើញថា "មានចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមជនជាតិវៀតណាមបែបនេះ"[4551]។

ii. ថាតើ មានចេតនាក្នុងការបំផ្លាញផ្នែកខ្លះ ឬទាំងមូលនៃក្រុមដែលត្រូវបានការពារ ដែរ ឬយ៉ាងណា

1630.យោងតាម ខៀវ សំផន បានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្ហាញថាតើ ចេតនាក្នុងការបំផ្លាញក្រុមនោះទាំងមូល ឬផ្នែកខ្លះ ដែរ ឬយ៉ាងណា និងថា ប្រសិនបើមានចេតនាក្នុងការបំផ្លាញផ្នែកខ្លះនៃក្រុមនោះ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យបង្ហាញថា ផ្នែកខ្លះនៃក្រុមនោះដែលកំណត់គោលដៅសម្រាប់ការបំផ្លាញ ត្រូវមាន"លក្ខណៈសំខាន់"ដែលតម្រូវឱ្យមានការកំណត់ចំនួនគួរលេខនៃផ្នែកដែលត្រូវបានគោលដៅនៃក្រុមនោះ[4552]។ គាត់បានលើកឡើងថា ពុំមានភស្តុតាងគាំទ្រការអះអាងដែលថា ផ្នែកសំខាន់នៃក្រុម ត្រូវបានកំណត់គោលដៅ ពីព្រោះចំនួនមនុស្សដែលត្រូវបានសម្លាប់នោះ ប្រសិនបើបង្ហាញត្រឹមត្រូវ អាចមានកម្រិតទាប និងពុំមានទិន្នន័យស្ដីពីប្រជាសាស្ត្រ ត្រូវបានប្រើប្រាស់ដើម្បីបង្កើតស្ថិតិស្ដីពីចំនួនជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា ឬបង្ហាញចំនួននៃការស្លាប់ធៀបជាមួយនឹងចំនួនមនុស្សសរុបក្នុងក្រុមនោះឡើយ[4553]។

1631.ជាក់ស្ដែង អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ជាក់លាក់ថាតើ អង្គជំនុំជម្រះបានពិចារណាលើចេតនាក្នុងការបំផ្លាញក្រុមជនជាតិវៀតណាម"ទាំងមូល" ឬ"ផ្នែកខ្លះ" ដែរ ឬយ៉ាងណានោះឡើយ នៅពេលអង្គជំនុំជម្រះបានសន្និដ្ឋានថា "*ធាតុផ្សំអត្តនោម័តិ* នៃបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់ ត្រូវបានបង្ហាញ" នោះ[4554]។ ទោះជាយ៉ាងណាក្ដី ពុំមានភស្តុតាងនៃចេតនាក្នុងការបំផ្លាញក្រុមពូជសាសន៍ជាតិពន្ធុវៀតណាម "ទាំងមូល" ត្រូវបានបង្ហាញចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំមានការយល់ឃើញត្រូវបានធ្វើឡើងពាក់ព័ន្ធបញ្ហានេះ[4555]។

---

[4551] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៧-៣៥១៨។

[4552] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦២-១០៦៤។

[4553] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦២-១០៦៤។

[4554] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៧-៣៥១៨។

[4555] បើទោះបីជាភស្តុតាងពុំបានបង្ហាញថា មានចេតនាក្នុងការបំផ្លាញក្រុមជនជាតិវៀតណាមទាំងមូលនៅក្រៅប្រទេសកម្ពុជាក៏ដោយ ក៏អាចសន្និដ្ឋានបានថា ជនជាតិវៀតណាមណាម្នាក់ដែលឆ្លងកាត់ ឬចូលក្នុងដែនទឹកកម្ពុជាត្រូវបានកំណត់គោលដៅស្របគ្នាជាមួយនឹងជនជាតិវៀតណាមទាំងនោះដែលបានស្ថិតនៅក្នុងកម្ពុជាស្រាប់។

1632.ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "*ធាតុផ្សំអត្តនោម័ត*គឺនៃបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញ" បានផ្អែកលើការវាយតម្លៃថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញនូវចេតនាក្នុងការបំផ្លាញ"ផ្នែកខ្លះ"នៃក្រុមជនជាតិវៀតណាម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការពិនិត្យបន្តលើបញ្ហាថាតើ ភស្តុតាងដែលត្រូវបានបង្ហាញចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការសន្និដ្ឋាននោះ ដែរ ឬយ៉ាងណា។

1633.បើទោះបីជាអ្នកអធិប្បាយផ្នែកច្បាប់បានស្នើឡើងនូវវិធីសាស្ត្រនៃការវិភាគមួយចំនួនចំពោះការកំណត់និយមន័យនៃពាក្យ"ផ្នែកខ្លះ"[4556]ក៏ដោយ ក៏ក្នុងការគូសបង្ហាញច្បាប់ជាធរមាន អង្គជំនុំជម្រះសាលាដំបូងបានយោងជាក់លាក់ទៅលើរឿងក្តី *Krstić* ដែលក្នុងរឿងក្តីនេះ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានកំណត់ថា ចេតនាក្នុងការបំផ្លាញផ្នែកខ្លះនៃក្រុមមួយក្នុងទីតាំងភូមិសាស្ត្រមួយដែលតូចជាងរដ្ឋមួយ អាចត្រូវបានចាត់ទុកថាជាចេតនាក្នុងការបំផ្លាញ"ផ្នែកខ្លះ"នៃក្រុមនោះដែរ[4557]។ តុលាការយុត្តិធម៌អន្តរជាតិបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា "មានការទទួលស្គាល់ទូទៅថា អំពើប្រល័យពូជសាសន៍អាចត្រូវបានរកឃើញថា បានប្រព្រឹត្តឡើង នៅពេលមានចេតនាក្នុងការបំផ្លាញក្រុមមួយនៅក្នុងទីតាំងភូមិសាស្ត្រមានកម្រិតមួយ"[4558]។

1634.អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *Krstić* បានសង្កេតថា ចេតានក្នុងការបំផ្លាញផ្នែកដែលត្រូវបានកម្រិតតាមភូមិសាស្ត្រនៃក្រុមដ៏ធំ អាចត្រូវបានចាត់ទុកថា ជាចេតនាក្នុងការបំផ្លាញ"ផ្នែកខ្លះ"នៃក្រុម និងកត់សម្គាល់ថា "ចេតនាក្នុងការបំផ្លាញនេះដែលបង្កើតឡើងដោយចារីនៃអំពើប្រល័យពូជសាសន៍ជានិច្ចកាលត្រូវបានកម្រិតដោយសារឱកាសដែលបានផ្តល់ឱ្យនោះ" ប៉ុន្តែបានបញ្ជាក់ថា ប្រសិនបើចេតនា គឺដើម្បីបំផ្លាញ"ផ្នែកខ្លះ"នៃក្រុមនោះ ផ្នែកដែលត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លាញនោះ ត្រូវតែមាន"លក្ខណៈសំខាន់"

---

[4556] *សូមមើល ឧ.* អ្នកនិពន្ធ William A. Schabas៖ *អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ៖ បទឧក្រិដ្ឋនៃឧក្រិដ្ឋកម្ម* (បោះពុម្ពផ្សាយលើកទីពីរ ឆ្នាំ ២០០៩) ("អ្នកនិពន្ធ Schabas៖ អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ") ទំព័រ ២៧៧-២៨៦។

[4557] ក្នុងរឿងក្តី *Krstić* អង្គជំនុំជម្រះសាលាដំបូងបានកំណត់ក្រុមដែលត្រូវបានការពារថា ជាក្រុមជាតិសាសន៍មូស្លីមបូស្នៀ និងបានវិភាគថាតើ ការកំណត់គោលដៅលើមូស្លីមបូស្នៀនៃ Srebrenica ឬមូស្លីមបូស្នៀនៃបូស្នៀប៉ែកខាងកើត គឺស្មើនឹងអំពើប្រល័យពូជសាសន៍។ *សូមមើល* សាលដីការឿងក្តី *Krstić* (ICTY) កថាខណ្ឌ ១៥។

[4558] អ្នកនិពន្ធ Schabas៖ អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ ទំព័រ ២៨៦ ដកស្រង់រឿងក្តី *ពាក់ព័ន្ធទៅនឹងការអនុវត្តន៍អនុសញ្ញាស្តីពីការរារាំង និងការដាក់ទោសបទប្រល័យពូជសាសន៍ (រឿងក្តី បូស្នៀ និង Herzegovina ទល់នឹង Serbia និង Montenegro)* ICJ សាលដីកាថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ១៩៩។

[4559]។ ក្នុងករណីនេះ យោងតាមរឿងក្ដី *Krstić* ថា ចារីនៃអំពើប្រល័យពូជសាសន៍“ត្រូវតែយល់ថា ផ្នែកនៃក្រុមដែលខ្លួនមានបំណងចង់បំផ្លាញ គឺជាក្រុមមួយដាច់ដោយឡែកដែលត្រូវតែលុបបំបាត់ចោលនោះ”[4560]។

1635.ភស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញគ្រប់គ្រាន់ថា ជនជាតិវៀតណាមទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់គោលដៅជាក់លាក់សម្រាប់ការបំផ្លាញ ដូច្នេះនេះគឺជា “ក្រុមមួយដាច់ដោយឡែកដែលត្រូវតែលុបបំបាត់ចោល”។ ចេតនាក្នុងការបំផ្លាញនោះប្រសិនបើជោគជ័យនឹងបណ្ដាលទៅជាការលុបបំបាត់ឱ្យផុតពូជនៃជនជាតិវៀតណាមទាំងអស់ពីកម្ពុជា។ ដោយសារទំហំនៃសហគមន៍ជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា ការលុបបំបាត់ទាំងស្រុងគឺអាចស្មើនឹងការបំផ្លាញ“ផ្នែកខ្លះ”នៃក្រុមជនជាតិវៀតណាមដ៏ធំនោះ ដែលអាចត្រូវបានចាត់ទុកថា មានលក្ខណៈ“សំខាន់”។

1636.ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការអះអាងរបស់ ខៀវ សំផន ដែលថា ចំនួនសរុបជនជាតិវៀតណាមដែលត្រូវបានសម្លាប់ក្នុងប្រទេសកម្ពុជានោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា “ផ្នែកដ៏សំខាន់នៃក្រុមជនជាតិពន្ធុវៀតណាមត្រូវបានកំណត់គោលដៅ”[4561]។ នៅពេលពិចារណាលើ*ធាតុផ្សំអត្តនោម័តិ*សម្រាប់អំពើប្រល័យពូជសាសន៍ ការយោងទៅលើការបំផ្លាញក្រុមមួយ“ទាំងមូល ឬផ្នែកខ្លះ” ទាក់ទងទៅនឹងចេតនារបស់ចារី ជាជាងលទ្ធផលដែលទទួលបានជាក់ស្ដែងនោះ[4562]។ ដូច្នេះ ការបំផ្លាញក្រុមមួយពុំតម្រូវឱ្យបទល្មើសត្រូវតែមានលក្ខណៈដូចអំពើប្រល័យពូជសាសន៍នោះទេ។ ជនរងគ្រោះក្នុងចំនួនដ៏ច្រើនពិតណាស់អាចប្រើប្រាស់ដើម្បីបង្ហាញនូវចេតនាតម្រូវនោះ ប៉ុន្តែពុំមានលក្ខខណ្ឌតម្រូវស្ដីពីចំនួនតួលេខពិតប្រាកដដែលត្រូវតែបំពេញនោះឡើយ។ យោងតាមការសន្និដ្ឋានទាំងនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះត្រូវបដិសេធចោល។

1637.យោងតាមសហេតុខាងលើ ភស្តុតាងចំពោះអង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការសន្និដ្ឋានអំពីចេតនាជាក់លាក់ក្នុងការបំផ្លាញ“ក្រុមជនជាតិវៀតណាមបែបនោះ”។ ប្រហាក់ប្រហែលគ្នានេះ ភស្តុតាងនេះបានគាំទ្រការសន្និដ្ឋានដែលថា ចេតនាដែលពាក់ព័ន្ធនោះ គឺដើម្បីបំផ្លាញក្រុមនោះ“ទាំងមូល ឬផ្នែកខ្លះ”។ ដូច្នេះ អង្គ

[4559] សាលដីការឿងក្ដី *Krstić* (ICTY) កថាខណ្ឌ ១២-១៣។

[4560] សាលក្រមរឿងក្ដី *Krstić* (ICTY) កថាខណ្ឌ ៥៩០។

[4561] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៣។

[4562] អ្នកនិពន្ធ Schabas៖ អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ ទំព័រ ២៧៧។

ជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា “*ធាតុផ្សំអត្តនោម័តិ* នៃបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញ”[4563]។

1638.ដោយសាររកពុំឃើញនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងការសម្រេចពាក់ព័ន្ធទៅនឹងធាតុផ្សំសត្យានុម័ត និង*ធាតុផ្សំអត្តនោម័តិ* នៃបទប្រល័យពូជសាសន៍ អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា “បទប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម ត្រូវបានបង្ហាញ”[4564]។

## VIII. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

### ក. តួនាទី និងមុខតំណែងរបស់ ខៀវ សំផន

### ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការនៃកងទ័ពប្រជាជនរំដោះជាតិកម្ពុជា

ក. សមាជជាតិពិសេសខែ មេសា ឆ្នាំ ១៩៧៥ និងសមាជជាតិលើកទីបីខែ ធ្នូ ឆ្នាំ ១៩៧៥

1639.អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើរបាយការណ៍នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងអន្តរជាតិជាច្រើនស្ដីអំពីសេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ក្នុង“សមាជជាតិពិសេស”ដែលធ្វើឡើងជាសាធារណៈក្នុងខែ មេសា ឆ្នាំ ១៩៧៥ និងសមាជជាតិទីបីនៅខែ ធ្នូ ឆ្នាំ ១៩៧៥[4565] និងក្នុងការយល់ឃើញស្ដីពីការវិវឌ្ឍន៍នៃផែនការរួម[4566]គោលនយោបាយ[4567] និងការរួមចំណែករបស់ ខៀវ សំផនតាមរយៈការជម្រុញផែនការរួមនោះ[4568]។ ដោយសារពុំមានភស្តុតាងគ្រប់គ្រាន់ ទើបអង្គជំនុំជម្រះសាលាដំបូង“ពុំមានភាពច្បាស់លាស់ថាតើ សមាជខែ មេសា និង ធ្នូ ឆ្នាំ ១៩៧៥ ពិតជាបានកើតឡើង ដែរ ឬយ៉ាងណា”[4569]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “ការសន្មតព្រឹត្តិការណ៍ទាំងនោះថាជារបស់ ខៀវ សំ

[4563] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៨។

[4564] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (F465) កថាខណ្ឌ ៣៥១៩។

[4565] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៣។

[4566] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៥។

[4567] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៩៧។

[4568] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២ ជើងទំព័រ ១៣៩០៨។

[4569] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៣។

ផន ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងអ្នកតំណាងរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងចំណោមតួនាទីដទៃទៀត មានប្រសិទ្ធភាពក្នុងការធ្វើឱ្យកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាគេទទួលស្គាល់នៅលើឆាកអន្តរជាតិ”[4570]។

1640.ខៀវ សំផន បានលើកឡើងថា ជាដំបូង អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុដោយសារបានសំអាងទៅលើរបាយការណ៍នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននេះ និងថា៖ ដោយសារពុំមានភស្តុតាងបង្ហាញថាសមាជទាំងនេះជាក់ស្តែងបានកើតឡើង ទើបអង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានសមស្របបានថាគាត់បានផ្តល់តាមវិធីណាមួយនូវភាពស្របច្បាប់ដល់កម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាលើឆាកអន្តរជាតិ [4571]។ បន្ថែមលើនេះ ដោយសារសមាជនេះប្រហែលពុំបានកើតឡើង ទើបអង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានបានថា របាយការណ៍អំពីសមាជនោះ“បានឆ្លុះបញ្ចាំងមាគ៌ានយោបាយដែលត្រូវបានគាំទ្រដោយបក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ”[4572]។

1641.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ភាពពុំជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាថាតើ សមាជនោះបានកើតឡើង ដែរ ឬយ៉ាងណា ពុំបានរារាំងអង្គជំនុំជម្រះក្នុងការយល់ឃើញថា៖ (១) ខ្លឹមសារនៃសេចក្តីប្រកាស និងសេចក្តីសម្រេចរបស់សមាជដែលបានអនុម័ត និងចុះផ្សាយ បានឆ្លុះបញ្ចាំងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ (២) សេចក្តីប្រកាស និងសេចក្តីសម្រេចត្រូវបានផ្សព្វផ្សាយជាផ្លូវការតាមវិទ្យុ និង (៣) “ការសន្មតព្រឹត្តិការណ៍ទាំងនោះថាជារបស់ ខៀវ សំផន (និងសេចក្តីប្រកាស និងសុន្ទរកថា ដែលបានពិភាក្សានោះ) ដោយរបបនោះបានរួមចំណែក [...] ក្នុងការផ្តល់ប្រជាប្រិយភាព និងការផ្តល់ធម្មានុរូបដល់មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា”[4573]។

1642.អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ការផ្សព្វផ្សាយតាមវិទ្យុក្នុងស្រុកអំពីសមាជខែ មេសា និងខែ ធ្នូ ឆ្នាំ ១៩៧៥ រាយការណ៍ថា ខៀវ សំផន បានអានសេចក្តីប្រកាសព័ត៌មាន[4574]។ ការផ្សព្វផ្សាយតាម

---

[4570] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៣។

[4571] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩០។

[4572] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩០។

[4573] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩១៨ (ការដកស្រង់ខាងក្នុងត្រូវលុបចោល)។

[4574] ‘សមាជជាតិពិសេស’ ជ្រើសតាំងនរោត្តមសម្តេចសីហនុ ប៉ែន នុត (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/118 ERN 00700284-00700286 (កត់សម្គាល់ថា អត្ថបទត្រូវបាន“អានដោយ ខៀវ សំផន ផ្សាយបន្តផ្ទាល់ ឬផ្សាយសម្លេងថតទុក”)។ សមាជជាតិបានសម្រេច រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៥ ឯកសារលេខ E3/1356 ERN 00663892 (រាយការណ៍ថា “សមមិត្តឧបនាយករដ្ឋមន្ត្រី ខៀវ សំផន

វិទ្យុអំពី"សមាជជាតិពិសេស"ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ក្រោយមកត្រូវបានចុះផ្សាយ និងរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិ[4575]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកបញ្ហាដែលថាតើ សមាជនោះជាក់ស្តែងបានកើតឡើង ដែរ ឬយ៉ាងណា ជាការពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ ខៀវ សំផន បានជម្រុញជាសាធារណៈនូវមាគ៌ាបក្ស ដែរ ឬយ៉ាងណាឡើយ ដូច្នេះគាត់បានរួមចំណែកដល់គោលបំណងរួម[4576]។ ទាក់ទងនឹងបញ្ហានេះ គាត់ពុំបានជំទាស់ទៅនឹងការដែលគាត់បានអានសេចក្តីប្រកាសតាមវិទ្យុឡើយ។

1643.បន្ថែមលើនេះ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា សេចក្តីប្រកាសព័ត៌មាននោះបានឆ្លុះបញ្ចាំងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនេះតាមធម្មតាត្រូវតែបានផ្សព្វផ្សាយតាមវិទ្យុក្នុងស្រុកថា ពិតណាស់សមាជត្រូវបានធ្វើឡើង សម្រាប់គោលបំណងនៃការផ្សព្វផ្សាយរបស់ខ្លួននោះ[4577]។ ដូចសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញត្រឹមត្រូវថា ការដែលខ្លឹមសារនៃសមាជនេះបានឆ្លុះបញ្ចាំងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបានបញ្ជាក់អះអាងដោយ ប៉ុល ពត និង ខៀវ សំផន ផងដែរ ដែលក្រោយមកនិយាយសំដៅទៅលើសមាជនោះ[4578]។ បន្ថែមលើនេះ រដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុ

---

បានអាចសេចក្តីប្រកាសនេះដោយផ្ទាល់។ ជនរួមជាតិជាទីគោរពស្រលាញ់ ត្រូវបានជម្រុញឱ្យស្តាប់សុន្ទរកថារបស់សមមិត្តឧបនាយករដ្ឋមន្ត្រី ខៀវ សំផន៖ [ចាប់ផ្តើមដោយវាគ្មិនប្រុស សន្មតថា ជា ខៀវ សំផន]")។

[4575] *ដំណើរដ៏វែងឆ្ងាយចាកចេញពីទីក្រុងភ្នំពេញ* (កាសែតថៃម) ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ១- ៧ ឯកសារលេខ E3/4430 ERN 00645760-00645766។ កម្ពុជារៀបចំមហាសន្និបាតពិសេស (កាសែតហ្គាតឌៀន) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/3722 ERN S00656237-S00656240។ សមាជជាតិត្រូវបានធ្វើឡើងហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ ឯកសារលេខ E3/1356 ERN 00663892-00663894។

[4576] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២ និងជើងទំព័រ ១៣៨០៨។

[4577] ទាក់ទងនឹងបញ្ហានេះ *សូមមើល* ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការប្រើប្រាស់នៃការផ្សព្វផ្សាយតាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការឃោសនាមាគ៌ាបក្ស សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៦.១.៤ 'វចនាសម្ព័ន្ធទំនាក់ទំនង: វិធីសាស្ត្រនៃការទំនាក់ទំនង: ការផ្សព្វផ្សាយតាមវិទ្យុ'។

[4578] កិច្ចសម្ភាស៍របស់ ប៉ុល ពត ដោយអ្នកសារព័ត៌មានយូហ្គោស្លាវី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/5713 ERN 00775904 (បន្ទាប់ពី"សមាជជាតិពិសេសនៅចុងខែ មេសា ឆ្នាំ ១៩៧៥" កប្បកុម្មុយនីស្តកម្ពុជាបានសម្រេច"កសាងសង្គមកម្ពុជាសម្បូរសប្បាយរុងរឿង [...] រួចផុតពីវណ្ណៈជិះជាន់ទាំងអស់ ឬការកេងប្រវ័ញ្ចគ្រប់រូបភាព ដែលគ្រប់គ្នាត្រូវខិតខំបង្កបង្កើនផល និងការពារប្រទេស")។ របាយការណ៍របស់ ខៀវ សំផន (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/273 ERN 00657436-00657453 ( ខៀវ សំផន បានសំដៅទៅលើសមាជជាតិ ឬរណសិរ្សរួបរួមជាតិបីដែលបានធ្វើឡើងក្នុងខែ កុម្ភៈ មេសា និង ធ្នូ ឆ្នាំ ១៩៧៥ និង ខ្លឹមសារនេះបង្ហាញនូវការយល់ដឹងរបស់គាត់អំពីខ្លឹមសារនៃរដ្ឋ

ជាប្រជាធិបតេយ្យដែលទំនងជាត្រូវបានសម្រេចក្នុងអំឡុងពេលនៃសមាជខែធ្នូនោះ ត្រូវបានផ្សព្វផ្សាយជាក់ស្តែងក្នុងខែ មករា ឆ្នាំ ១៩៧៦[4579]។ ជាថ្មីម្តងទៀត បញ្ហាថាតើ សមាជនោះបានកើតឡើង ដែរ ឬយ៉ាងណា ពុំជាប់ពាក់ព័ន្ធទៅនឹងការដែលថា ការផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងអត្ថិភាពនៃសមាជ និងសេចក្តីសម្រេចនោះ គឺក្នុងគោលបំណងដើម្បីជម្រុញមាគ៌ាបក្សឡើយ។

1644.យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើការផ្សព្វផ្សាយសេចក្តីប្រកាសព័ត៌មានអំពីសមាជជាតិខែ មេសា និង ធ្នូ ឆ្នាំ ១៩៧៥ បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់ថា សមាជនេះបានកើតឡើងពិតប្រាកដ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

### ខ. កិច្ចប្រជុំជាមួយកម្មាភិបាលយោធាក្នុងទីក្រុងភ្នំពេញ

1645.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កម្មាភិបាលយោធាម្តងម្កាលបានចូលរួមក្នុងកិច្ចប្រជុំ ឬសន្និបាតធំៗក្នុងទីក្រុងភ្នំពេញ ដែលពេលខ្លះត្រូវបានចូលរួមដោយមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា រួមទាំង ខៀវ សំផន[4580]។ ក្នុងសារណាផ្ទាល់មាត់ ខៀវ សំផន បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា គាត់ពុំមានតួនាទីណាមួយក្នុងវិស័យយោធាឡើយ[4581]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំសំខាន់ៗ ឬមីទ្ទីងជាមួយកម្មាភិបាលយោធានៅភ្នំពេញ[4582]។ ហេតុនេះ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើការយល់ឃើញនេះសម្រាប់ការសន្និដ្ឋានរបស់ខ្លួនដែលថា គាត់“បានជម្រុញ បញ្ជាក់អះអាង និងគាំទ្រគោលបំណងរួម”ឡើយ[4583]។

---

ធម្មនុញ្ញ និងប្រកាសផ្សព្វផ្សាយការប្តេជ្ញាកសាងសង្គមគ្មានវណ្ណៈជិះជាន់កេងប្រវ័ញ្ច ដោយខិតខំកសាង និងការពារប្រទេសដែលផ្ទុះបញ្ចាំងទាំងស្រុងនូវមាគ៌ានយោបាយរបស់បក្សកម្ពុជាប្រជាធិបតេយ្យនាពេលនោះ)។

[4579] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១២។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/259។ *អត្ថបទកែសម្រួលផ្សាយតាមវិទ្យុកោតសរសើរចំពោះការបង្កើតរដ្ឋធម្មនុញ្ញថ្មី* (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/273 ERN 00167822 (ភាសាអង់គ្លេស)។

[4580] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥១០។

[4581] ប្រតិចារឹកថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ F1/11.1 ទំព័រ ២០។

[4582] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩១។

[4583] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩១។

1646.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ម្ចាស់បណ្ដឹងសាទុក្ខមានបន្ទុកក្នុងការបង្ហាញថា ថាតើកំហុសអង្គហេតុបានបណ្ដាលឱ្យមានភាពមិនយុត្តិធម៌យ៉ាងដូចម្ដេចខ្លះ មានន័យថា នេះមានសារៈសំខាន់ចំពោះការដាក់ពិរុទ្ធភាពរបស់គាត់ និងថា ការកែតម្រូវបានបង្កើតឱ្យមានវិមតិសង្ស័យចំពោះពិរុទ្ធភាពរបស់គាត់[4584]។ នៅក្នុងរឿងក្ដីបច្ចុប្បន្ន និងដោយផ្ទុយទៅនឹងសារណាមុនៗរបស់គាត់ ខៀវ សំផន បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គហេតុ៖ “ក្នុងការពិនិត្យដោយអនាគតិលើភស្តុតាង [...] បង្ហាញថាម្ចាស់បណ្ដឹងសាទុក្ខមានវត្តមាន [...] នៅក្នុងមីទ្ទីងឆ្នាំ ១៩៧៥”[4585]។ ដូច្នេះ នេះហាក់បីដូចជាពុំមានការជំទាស់ទៅនឹងវត្តមានរបស់គាត់នៅក្នុងមីទ្ទីងយោធានោះ។ នៅក្នុងគ្រប់ករណី ដូចការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញាថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើការយល់ឃើញនេះក្នុងការបញ្ជាក់ថាគាត់បានជម្រុញ បញ្ជាក់អះអាង និងគាំទ្រគោលបំណងរួមឡើយ[4586]។ តាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើអង្គហេតុនោះឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើការយល់ឃើញនៃអង្គហេតុនោះនៅក្នុងផ្នែកណាមួយនៃសំអាងហេតុរបស់ខ្លួនស្ដីពីការរួមចំណែករបស់ ខៀវ សំផន ក្នុងគោលបំណងរួមឡើយ។

1647. ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការជំទាស់នេះ។ អំណះអំណាងដទៃទៀតរបស់ ខៀវ សំផន ពាក់ព័ន្ធចំណុចនេះ[4587] ត្រូវចាត់ទុកជាអសារបង់។

## ២. ប្រធានគណៈប្រធានរដ្ឋ

### ក. ការតែងតាំង

1648.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានរបស់ខ្លួនដែលថា គណៈមជ្ឈិម“បាន”តែងតាំងរូបគាត់ជាប្រធានគណៈប្រធានរដ្ឋ ដែលតាមទស្សនៈរបស់គាត់“សេចក្ដីសម្រេចតែងតាំងនេះ ផ្ទុយទៅវិញត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍”[4588]។ ដោយសារ ខៀវ សំផន បានចោទ

---

[4584] *សូមមើល* សាលដីកាបណ្ដឹងសាទុក្ខសំណុំរឿង ០០១ កថាខណ្ឌ ១៨-១៩។ សាលដីកាបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩១។

[4585] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩១។

[4586] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩១៩។

[4587] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩១។

[4588] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៣។

ប្រកាន់កំហុសអង្គហេតុដទៃទៀតពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ដែលបាន តែងតាំងរូបគាត់ កំហុសទាំងនេះនឹងត្រូវពិចារណាដូចខាងក្រោម[4589]។

## ខ. តួនាទី និងការទទួលខុសត្រូវ

1649.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា តួនាទីរបស់ ខៀវ សំផន ដែលជាប្រធាន ឬប្រធានគណៈប្រធានរដ្ឋ មានកាតព្វកិច្ចពីរសំខាន់៖ បំពេញមុខងារការទូត និងពិធីការផ្សេងៗទៀត[4590] និងថ្លែងសុន្ទរកថា[4591]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "ផ្អែកលើតួនាទីដែលមានលក្ខណៈជានិមិត្តរូបភាគច្រើននោះ [...] ការទទួលខុសត្រូវរបស់ ខៀវ សំផន ក្នុងតួនាទីនេះ ភាគច្រើនត្រូវបានកម្រិតត្រឹមភារកិច្ចការទូតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងការជម្រុញជាទូទៅនូវមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា"[4592]។ ខៀវ សំផន បានចោទប្រកាន់កំហុសមួយចំនួនពាក់ព័ន្ធទៅនឹងការយល់ឃើញនេះ។

1650.ជាដំបូង គាត់បានលើកឡើងថា ដោយសារតួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ"ដែលភាគច្រើនត្រឹមតែ'និមិត្តរូប'" ទើបអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើតួនាទីនេះ"ប្រើប្រាស់ជាបទចោទមកលើរូបគាត់"[4593]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញអំពីកំហុសនោះ[4594]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើការយល់ច្រឡំរបស់ ខៀវ សំផន ចំពោះខ្លឹមសារនៃការពិពណ៌នារបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទីប្រធានគណៈប្រធានរដ្ឋថា ជា"និមិត្តរូប" ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា តួនាទីរបស់ប្រធានគណៈប្រធានរដ្ឋមានសារៈសំខាន់ជានិមិត្តរូប ដោយសារបើទោះបីជាគាត់ពុំបានប្រើប្រាស់សិទ្ធិអំណាចធ្វើសេចក្តីសម្រេច ឬប្រតិបត្តិក្នុងតួនាទីនេះក៏ដោយ ក៏គាត់បានដើរតួនាទី"តំណាងមុខមាត់ជាសាធារណៈនៃរបបកម្ពុជាប្រជាធិបតេយ្យ"ដែរ[4595]។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា តួនាទីនេះតាមអ្វីដែលគាត់បានលើកឡើងមានអត្ថិភាពត្រឹមតែលើក្រ

---

[4589] *សូមមើលខាងក្រោម* ផ្នែក VIII.ក.៣។

[4590] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៧ (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[4591] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៨ (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[4592] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៩។

[4593] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៤។

[4594] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។

[4595] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។ *សូមមើល* ជាទូទៅ សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ៨.៣.២: តួនាទី និងមុខនាទីរបស់ ខៀវ សំផន: តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ:ប្រធាននៃគណៈប្រធានរដ្ឋ។

ដាស់ប៉ុណ្ណោះនោះទេ។ ក្នុងនាមជាប្រធាន គាត់បានទទួលបេសកកម្មការទូតតំណាងកម្ពុជាប្រជាធិបតេយ្យនៅបរទេស និងតាមរយៈភស្តុតាងរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍"ដើម្បីទទួលបានព័ត៌មាន [...] ទៅជជែកជាមួយអ្នកការទូតនានា"[4596]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ការពិពណ៌នារបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទីរបស់គាត់ថា ជា"និមិត្តរូប"នោះបានរារាំង ឬធ្វើឱ្យប៉ះពាល់ដល់ការសំអាងត្រឹមត្រូវទៅលើអំពើរបស់គាត់ក្នុងតួនាទីនេះ ដែលជាទិដ្ឋភាពនៃការរួមចំណែកក្នុងគោលបំណងរួម[4597] និងស្ពានទម្ងន់ទោសក្នុងការដាក់ទោសឡើយ[4598]។

1651.ទីពីរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅនឹងការគ្មានទំនុកចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជាលើរូបគាត់[4599]។ ក្នុងសារណារបស់គាត់ ការគ្មានទំនុកចិត្តនេះត្រូវបានបង្ហាញទីមួយតាមរយៈការតែងតាំង សោ ភឹម និង វស់ ញឹម ដែលគាត់បានពិពណ៌នាថា មាន"ឋានៈខ្ពស់ជាងគាត់" និងជាអនុប្រធាន[4600] និងទីពីរតាមរយៈការដំឡើងឋានៈគាត់ទៅជាសមាជិកពេញសិទ្ធិគណៈមជ្ឈិមតែនៅក្នុងឆ្នាំ ១៩៧៦ ប៉ុណ្ណោះ "ដោយសារគាត់ត្រូវបានតែងតាំងជាសមាជិកបម្រុងតាំងពីប្រាំឆ្នាំមុន"[4601]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា សារណារបស់ ខៀវ សំផន ខកខានក្នុងការបង្ហាញថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានតម្រូវឱ្យមានអនុប្រធានពីរ។ "អនុប្រធានដែលមានតែឈ្មោះ [...] ពុំដែលបានបំពេញតួនាទីនេះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងចុងក្រោយត្រូវបានបោសសម្អាត"[4602]។ សហព្រះរាជអាជ្ញាបានលើកឡើងថា សមាជិកគណៈមជ្ឈិមអាចត្រូវបានតែងតាំងដោយសមាជបក្សប៉ុណ្ណោះ និងថា នៅចន្លោះឆ្នាំ ១៩៧១ ដល់ឆ្នាំ ១៩៧៦ ពុំមានសមាជបក្សដែលអាចដំឡើងឋានៈ ខៀវ សំផន ទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមឡើយ[4603]។

---

4596 កំណត់ត្រារបស់ ខៀវ សំផន អំពីសវនាការដេញដោល ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារលេខ E3/557 ERN 00153234 ទំព័រ ៧។

4597 *សូមមើល* ឧ. សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧, ៤២៦៥។

4598 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨៩។

4599 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៤។

4600 ខៀវ សំផន និយាយផ្ទុយជាមួយនឹងការជ្រើសតាំងសម្តេចនរោត្តមសីហនុជាប្រមុខរដ្ឋ និងទំនងជាចង់បញ្ជាក់ថា សម្តេចនរោត្តមសីហនុត្រូវបានជឿទុកចិត្តខ្លាំងជាងដោយសារសម្តេចពុំមែនជា"អនុ"ប្រមុខរដ្ឋ។

4601 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៤។

4602 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។

4603 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។

1652.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានលើកច្រំដែលនូវអំណះអំណាងដែលបានបង្ហាញនៅពេលជំនុំជម្រះ។ ផ្ទុយទៅនឹងការអះអាងរបស់គាត់ អំណះអំណាងនេះត្រូវបានពិចារណាជាក់លាក់ដោយអង្គជំនុំជម្រះសាលាដំបូង រួមទាំងជាពិសេសការគ្មានទំនុកចិត្តដែលទំនងជាបង្ហាញតាមរយៈការដំឡើងឋានៈគាត់នៅក្នុងគណៈមជ្ឈិម[4604]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានត្រឹមត្រូវថា ខៀវ សំផន បានត្រឹមតែពុំយល់ស្របជាមួយនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាង“ដែលបង្ហាញថាគាត់មានទំនាក់ទំនងជិតស្និទ្ធ និងគួរឱ្យទុកចិត្តបានជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត”[4605]។ ដោយសារគាត់ពុំបានបង្ហាញថាតើ ការបកស្រាយនេះពុំសមហេតុផលយ៉ាងដូចម្ដេចនោះ ដូច្នេះអំណះអំណាងនេះត្រូវបដិសេធចោល។

1653.ទីបី ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា គាត់បានរួមចំណែកក្នុងគោលបំណងរួមតាមរយៈការអនុវត្តន៍នូវភារកិច្ចការទូត និងជាទូទៅបានជម្រុញមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាក្នុងសុន្ទរកថារបស់គាត់ ពីព្រោះ“មាគ៌ាបក្សកុម្មុយនីស្តកម្ពុជា [...] ក្នុងន័យទូទៅពុំមែនជាបទល្មើសដោយខ្លួនឯងផ្ទាល់នោះទេ”[4606]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានអើពើទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីគោលដៅនៃគោលបំណងរួម គោលនយោបាយដែលផ្សាភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងបទល្មើស និង“វិន័យដែលត្រូវបានជម្រុញ”ដោយលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងដោយមជ្ឈិមបក្ស រួមទាំងដោយ ខៀវ សំផន នៅក្នុងសុន្ទរកថា និងការបង្រៀនរបស់គាត់[4607]។

1654.អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិចារណាទៅលើសារណារបស់ ខៀវ សំផន អំពីលក្ខណៈល្មើសនៃផែនការរួម និងការអះអាងយ៉ាងទទូច និងគ្មានមូលដ្ឋានទាំងស្រុងថា គាត់គាំទ្រតែការប្រឹងប្រែងសម្រេចគោលដៅ និងគោលនយោបាយស្លូតត្រង់ និងគ្មានការនាំទុក្ខទោសទាំងស្រុងរបស់បក្សកុម្មុយនីស្តយកម្ពុជាប៉ុណ្ណោះ[4608]។អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា

---

[4604] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៦ (ជើងទំព័រ ៥៣៣), ៥៧៦, ៤២០២។

[4605] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។ សហព្រះរាជអាជ្ញាអះអាងថា នេះត្រូវបានបង្ហាញតាមរយៈមុខនាទីជាច្រើនដទៃទៀតក្នុងកម្ពុជាប្រជាធិបតេយ្យដែល ខៀវ សំផន មាន។

[4606] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៥-១៦៩៦។

[4607] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។

[4608] *សូមមើលខាងក្រោម* ផ្នែក VIII.ខ.២។ *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨១១-៨១៧, ៩៧៨-៩៨៥។

គាត់បានជម្រុញមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាតាមលក្ខណៈផ្សេងៗ ជាជាងការជម្រុញមាគ៌ាបក្សកុម្មុយនីស្ត កម្ពុជា"ទូទៅ" ឬពុំមែនជាបទល្មើស។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សុន្ទរកថា របស់ ខៀវ សំផន បានជម្រុញគោលនយោបាយល្មើសដែលរួមបញ្ចូលការនិរទេស និងការកម្ទេចជនជាតិវៀ តណាម[4609] ការបង្កើត និងការប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការ[4610]ការលុបបំបាត់ការប្រតិបត្តិ

---

[4609] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩៩-៣៤០៦, ៤២៦០, ៤២៦៩ យោងទៅលើ*ក្នុងចំណោមនោះ ការប្រារព្ធទិវារំលឹកខួប ១៧ មេសា នៅទីក្រុងភ្នំពេញ* (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/562 ERN 00249989-00249990។ សុន្ទរកថារបស់ ខៀវ សំផន ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ ទំព័រ ១២ ឯកសារលេខ E3/169 ERN S00704526។ សម្តេចនរោត្តមសីហនុបានចូលរួម ហើយ *ខៀវ សំផន ថ្លែងសុន្ទរកថានៅក្នុងពិធីជប់លៀងបក្សកុម្មុយនីស្តកម្ពុជា* (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/294 ERN 00702824។

[4610] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៥-៤២៦៧ យោងទៅលើសមាជជាតិលើកទីបីនៅភ្នំពេញ៖ របាយការណ៍របស់ ខៀវ សំផន (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៦ ឯកសារលេខ E3/273 ERN 00657436-00657453។ ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ផ្តល់បទសម្ភាសន៍ជាមួយនឹងទីភ្នាក់ងារព័ត៌មានកម្ពុជា [AKI] (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/119 ERN 00967625-00967627។ ការស្វាគមន៍ដល់ការប្រមូលផ្តុំដើម្បីអបអរសាទរដល់ការវិលត្រឡប់វិញរបស់សម្តេចនរោត្តមសីហនុ៖ សុន្ទរកថារបស់ ខៀវ សំផន (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/271 ERN 00167454 (ភាសាអង់គ្លេស)។ ទូរលេខក្រសួងការបរទេស ស.រ.អា. កម្មវត្ថុ៖ ខៀវ សំផន ធ្វើទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ខែ សីហា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/619 ERN 00635939-00635939។ សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំប់ខួប (នៅក្នុងកម្រងសារព័ត៌មាន SWB/FE/5490/C) ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/200 ERN 00292804-00292815។

សាសនាព្រះពុទ្ធ[4611] និងការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំ[4612]។ អំណះអំណាងនេះពុំមានមូលដ្ឋានគាំទ្រ និងអាស្រ័យហេតុនេះ ត្រូវបដិសេធចោល។

1655.ជាចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានទទួលលិខិតពីរច្បាប់ផ្ញើពីអង្គការលើកលែងទោសអន្តរជាតិជូនគាត់ក្នុងសមត្ថកិច្ចរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ[4613]។ ដោយសារគាត់បានជំទាស់ទៅនឹងការទទួលបានលិខិតទាំងនេះជាថ្មីម្តងទៀតក្នុងសារណារបស់គាត់ពាក់ព័ន្ធទៅនឹងភាពស្និទ្ធស្នាលរបស់គាត់ជាមួយនឹងក្រសួងកិច្ចការបរទេស សារណានេះនឹងត្រូវពិចារណាជារួមដូចខាងក្រោម[4614]។

## គ សុន្ទរកថា

1656.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយចំនួនផ្នែកអង្គហេតុក្នុងការសំអាងទៅលើសុន្ទរកថា ដែលត្រូវបានសន្មតថាជារបស់គាត់ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ ដែលនេះបាននាំឱ្យមានភាពមិនយុត្តិធម៌[4615]។ ក្នុងសារណារបស់សហព្រះរាជអាជ្ញាបានឆ្លើយតបថា កំនុសទាំងអស់នេះពុំបានប៉ះពាល់លើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការរួមចំណែកក្នុងគោលបំណងរួមឡើយ[4616]។

---

[4611] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៨ យោងតាមរយៈយោងឆ្លងទៅលើផ្នែកដទៃទៀតនៃសាលក្រម ទៅលើសេចក្តីរាយការណ៍ព័ត៌មានពីទីក្រុងភ្នំពេញស្តីអំពីសមាជជាតិលើកទីបី៖ របាយការណ៍របស់ ខៀវ សំផន (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/273 ERN 00657436-00657453។ លោក ខៀវ សំផន ត្រូវបានសម្ភាសន៍អំពីការប្រហារជីវិត បញ្ហាប្រទេសជាតិ (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ១៩៧៦ ទំព័រ ៤-៥ ឯកសារលេខ E3/608 ERN 00635931-00635932។ មីទ្ទីងនៅទីក្រុងភ្នំពេញប្រារព្ធខួបថ្ងៃទី ១៧ ខែ មេសា (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/562 ERN 00249989-00249990។

[4612] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨-៤២៦៨ យោងតាមរយៈយោងឆ្លងទៅលើផ្នែកដទៃទៀតនៃសាលក្រម ទៅលើសុន្ទរកថារបស់ ខៀវ សំផន ក្នុងមីទ្ទីងគម្រប់ខួប (ក្នុងកម្រងសារព័ត៌មាន SWB/FE/5908/A3) ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/200 ERN 00292808។

[4613] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៧។

[4614] *សូមមើលខាងក្រោម* ផ្នែក VIII.ក.៤.ឃ។

[4615] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៨-១៧០៣។

[4616] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៤។

1657.ដំបូង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា គាត់បានថ្លែងសុន្ទរកថាមួយនៅសម័យប្រជុំដំបូងនៃសភាតំណាងប្រជាជនដែលបានធ្វើឡើងចន្លោះពីថ្ងៃទី ១១ ដល់ ១៣ ខែ មេសា ឆ្នាំ ១៩៧៦ និងបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះដែលពាក់ព័ន្ធនោះត្រូវបដិសេធចោល[4617]។ សហព្រះរាជអាជ្ញាពុំបានជំទាស់ថា សុន្ទរកថានោះត្រូវបានសន្និដ្ឋានពុំត្រឹមត្រូវឡើយ ប៉ុន្តែបានលើកឡើងថា កំហុសនេះពុំតម្រូវឱ្យមានការអន្តរាគមន៍លើបណ្តឹងសាទុក្ខដោយសារពុំមានផលប៉ះពាល់លើការសម្រេចនោះឡើយ[4618]។

1658.អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពីដំបូងថា ពុំមានការបង្ហាញគ្រប់គ្រាន់ដែលអាចសន្និដ្ឋានបានថា សុន្ទរកថានេះជារបស់ ខៀវ សំផន[4619] និងតម្កល់ការកំណត់នេះ[4620]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវពិចារណាថាតើ កំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសុន្ទរកថានោះ បានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ដែរ ឬយ៉ាងណា។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសុន្ទរកថានេះក្នុងការគាំទ្រការយល់ឃើញរបស់ខ្លួនដែលថា គាត់បានគាំទ្រ“ការបង្កើតរដ្ឋថ្មីនៃកម្ពុជាប្រជាធិបតេយ្យ និងស្ថាប័នរបស់ខ្លួន”[4621] និងបានជម្រុញសម្រេចគោលដៅ“មហាលោតផ្លោះមហាអស្ចារ្យ”[4622] និង“បានគាំទ្រអាទិភាពនៃការកសាង និងការពារប្រទេសដោយឯករាជ្យខ្លួនទីពឹងខ្លួនឱ្យបានឆាប់រហ័សខណៈពេលបន្តការតស៊ូវណ្ណៈប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយម និង‘វណ្ណៈជិះជាន់ផ្សេងទៀត’”[4623]។

1659.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងបង្ហាញថា ខៀវ សំផន បានគាំទ្រគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសនៅក្នុងសុន្ទរកថាជាច្រើនដែលគាត់បានថ្លែងក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ និងនៅមុនការតែងតាំងនោះ[4624]។ ការសន្និដ្ឋាននេះត្រូវបានគាំទ្របន្ថែមទៀតតាមរយៈការទទួល

---

[4617] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៩-១៧០០។

[4618] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៧។

[4619] សាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ១០២៣។

[4620] *សូមមើលខាងលើ* ផ្នែក V.គ.៣។

[4621] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៨ (ជើងទំព័រ ១៨៧៧)។

[4622] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៩ (ជើងទំព័រ ១២៤៦៩)។

[4623] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៩ (ជើងទំព័រ ១២៤៦៩)។

[4624] *សូមមើល* ការជំរុញឱ្យប្រជាជនកម្ពុជារួបរួមគ្នាធ្វើការវាយប្រហារក្នុងពេលចូលឆ្នាំថ្មី (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៤ ឯកសារលេខ E3/30 ERN 00783127-00783128។ *វិទ្យុភ្នំពេញ៖* សារជ័យជម្នះថ្ងៃទី ២១ ខែ

យកដោយចេតនានូវតួនាទីសំខាន់ៗក្នុងស្ថាប័នរដ្ឋថ្មីនោះដែលគាត់បានបន្តកាន់កាប់ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយសារកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសុន្ទរកថានោះ ពុំបានប៉ះពាល់ដល់ការសន្និដ្ឋានជារួមថា ខៀវ សំផន បានគាំទ្រការបង្កើតរដ្ឋថ្មីនៃកម្ពុជាប្រជាធិបតេយ្យ និងស្ថាប័ននោះ ទើបការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសុន្ទរកថាពុំបានបណ្តាលឱ្យភាពមិនយុត្តិធម៌ណាមួយកើតឡើង ដូចនេះអំណះអំណាងនេះត្រូវបដិសេធចោល។

---

មេសា របស់ ខៀវ សំផន (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/118 ERN 00905202។ ឧបនាយករដ្ឋមន្ត្រីផ្តល់បទសម្ភាសន៍ជាមួយនឹងទីភ្នាក់ងារព័ត៌មានកម្ពុជា [*AKI*] (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/119 ERN 00967625-00967627។ *ការស្វាគមន៍ដល់ការប្រមូលផ្តុំដើម្បីអបអរសាទរដល់ការវិលត្រឡប់វិញរបស់ សីហនុ៖* សុន្ទរកថារបស់ ខៀវ សំផន (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/271 ERN 00167454 (ភាសាអង់គ្លេស)។ *បដិសណ្ឋារកិច្ចទទួលស្វាគមន៍សម្តេចនរោត្តម សីហនុ៖ សុន្ទរកថាដោយលោក ខៀវ សំផន និងសម្តេច នរោត្តម សីហនុ* (ក្នុងកម្រងសារព័ត៌មាន SWB/FE/5006/B) ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/711 ERN S00003732-S00003733។ *សមាជជាតិត្រូវបានធ្វើឡើងហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត* (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ១៩៧៥ ឯកសារលេខ E3/1356 ERN 00663892-00663894។ *សមាជជាតិលើកទីបីនៅភ្នំពេញ៖ របាយការណ៍របស់ ខៀវ សំផន* (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/273 ERN 00657436-00657453។ *ការប្រារព្ធពិធីខួបជ័យជម្នះថ្ងៃទី១៧ ខែមេសា* (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/275 ERN 00896389-00896394។ សន្និបាតតំណាងប្រជាជនលើកទីមួយ(នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/275 ERN 00167639-00167641 (ភាសាអង់គ្លេស)។ សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ ថ្ងៃទី ១៦-១៩ ខែ សីហា ឆ្នាំ១៩៧៦ ឯកសារលេខ E3/549 ទំព័រ ១-៣៦ ERN 00065887-00065908។ សុន្ទរកថារបស់ ខៀវ សំផន នៅកិច្ចប្រជុំគំប់ខួប (ក្នុងកម្រងសារព័ត៌មាន SWB/FE/5490/C) ឯកសារលេខ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ E3/200 ERN 00292804-00292815។ សេចក្តីរាយការណ៍តាមវិទ្យុអំពីដំណើរទស្សនកិច្ចរបស់ Souphanouvong នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ៖ សុន្ទរកថារបស់លោក ខៀវ សំផន (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារលេខ E3/1497 ERN 00748677-00748682។ សុន្ទរកថារបស់ ខៀវ សំផន ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ទំព័រ ១៤ ឯកសារលេខ E3/169 ERN (ភាសាអង់គ្លេស) 00280389-00280399 ។ សម្តេចសីហនុចូលរួម ខៀវ សំផន ថ្លែងទៅកាន់ពិធីលៀងសាយភោជនបក្សកុម្មុយនិស្តកម្ពុជា (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារលេខ E3/294 ERN 00702823។

1660.ទីពីរ ខៀវ សំផន បានជំទាស់ថា[4625] អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើកិច្ចសម្ភាសន៍ដែលគាត់បានផ្ដល់នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៦[4626]។ គាត់បានលើកឡើងថា ឯកសារនេះ“គួរឱ្យសង្ស័យ” និង“គ្មានមូលដ្ឋានគាំទ្រ” និងថា សាក្សីម្នាក់បានពន្យល់ថា ឯកសារនេះក្លែងក្លាយ[4627]។ ទាក់ទងទៅនឹងការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារ សហព្រះរាជអាជ្ញាបានលើកឡើងថា បទសម្ភាសន៍នោះត្រូវបានធ្វើឡើងក្នុងទីក្រុងកូឡំបូ ប្រទេសស្រីលង្កា ទំនងជាកើតឡើងក្នុងអំឡុងពេលសន្និសីទកំពូលលើកទីប្រាំនៃបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធ[4628]។ នៅគ្រប់ករណី សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកិច្ចសម្ភាសន៍នោះមានផលប៉ះពាល់ណាមួយលើសេចក្ដីសន្និដ្ឋានរបស់ខ្លួន ដោយសារមានភស្តុតាងដទៃទៀតបានគាំទ្រសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងលើពុទ្ធសាសនិកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[4629]។

1661.អត្ថបទដែលចោទជាបញ្ហានេះមានចំណងជើងថា “ខៀវ សំផន បានផ្ដល់បទសម្ភាសន៍ស្ដីពីការកម្ទេច និងបញ្ហាជាតិ” តាមការអះអាង មានកិច្ចសម្ភាសន៍ដែលត្រូវបានផ្ដល់ដោយ ខៀវ សំផន ជាមួយនឹងអ្នកសារព័ត៌មាន Paola Brianti និងត្រូវបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីអ៊ីតាលីឈ្មោះ Famiglia Cristiana នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៦[4630]។ លោក François PONCHAUD បានរៀបរាប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា អ្នកសារព័ត៌មានម្នាក់ឈ្មោះ Erić LAURENT បានប្រាប់គាត់ថា គាត់ (Erić) បាននៅជាមួយលោក Paola BRIANTI ក្នុងទីក្រុងកូឡំបូ និងថា ពុំដែលជួប ខៀវ សំផន[4631]។ លោក

[4625] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០១។

[4626] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤១ (ជើងទំព័រ ១៣៨៤៤) ៤២៥៣ (ជើងទំព័រ ១៣៨៧៥) យោងទៅលើ ខៀវ សំផន ដែលត្រូវបានសម្ភាសន៍អំពីការសម្លាប់ បញ្ហាជាតិ (ក្នុងកម្រងសារព័ត៌មាន FBIS) ឯកសារលេខ ចុះថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/608 ERN 00635931-00635932 ទំព័រ ៤-៥។

[4627] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០១។

[4628] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) ជើងទំព័រ ៣២២៩។

[4629] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៦។

[4630] ខៀវ សំផន ត្រូវបានសម្ភាសន៍អំពីការសម្លាប់ បញ្ហាជាតិ (កម្រងសារព័ត៌មាន FBIS) ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/608។

[4631] ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៥៨-៥៩។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/180.1 ទំព័រ ៥។

PONCHAUD បានចាត់ទុកកិច្ចសម្ភាសន៍នោះ ជាការ"ប្រឌិត"[4632] ហើយ Paola Brianti គឺជា"មនុស្សភូតកុហក"[4633]។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការរៀបរាប់របស់ លោក PONCHAUD ធ្វើឱ្យមានការសង្ស័យចំពោះភាពត្រឹមត្រូវនៃកិច្ចសម្ភាសន៍ទស្សនាវដ្ដី Famiglia Cristiana ដែលមានភាពខុសប្លែកគ្នាខ្លាំងទាំងសម្ដីសំដៅ និងខ្លឹមសារពីសេចក្ដីថ្លែងការណ៍សាធារណៈដទៃទៀតរបស់ ខៀវ សំផន នៅក្នុងកំណត់ត្រាភស្តុតាង និងថា ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានពន្យល់មូលហេតុដែលខ្លួនបានសំអាងទៅលើកិច្ចសម្ភាសន៍នេះបើទោះបីជាមានមន្ទិលសង្ស័យដែលបានលើកឡើងដោយលោក PONCHAUD ក៏ដោយ។

1662. អង្គជំនុំជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កិច្ចសម្ភាសន៍នោះពុំមែនជាកត្តាកំណត់ដែលបង្ហាញថា ខៀវ សំផន បានដឹងថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងចំពោះពុទ្ធសាសនិកក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងដែលលាយឡំគ្នាច្រើនបង្ហាញថា បទសម្ភាសន៍នោះត្រឹមតែជាភស្តុតាងមួយក្នុងចំណោមភស្តុតាងជាច្រើនដែលបង្ហាញថា ខៀវ សំផន បានដឹងថា ពុទ្ធសាសនិកត្រូវបានកំណត់គោលដៅ។ គាត់ជាប្រចាំបានទៅថ្វាយបង្គំព្រះរហូតដល់បក្សកុម្មុយនីស្តកម្ពុជាទទួលជោគជ័យ ហើយបន្ទាប់មកគាត់ក៏ឈប់ភ្លាម[4634]។ ដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការលើកសរសើររបស់គាត់ពីដំបូង និងការគោរពពុទ្ធសាសនា គឺជា"ល្បិចក្នុងគោលបំណងរក្សាធម្មានុរូបនៃរដ្ឋាភិបាលបណ្ដោះអាសន្នដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា"[4635]។ បន្ទាប់ពីជ័យជម្នះបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន "បន្តគាំទ្រជាសាធារណៈនូវការបំភាន់ធ្វើដូចជាស្ថានភាពធម្មតា" តាមរយៈការធ្វើបដិសណ្ឋារកិច្ចដោយមានវត្តមានសមាជិកបុព្វជិត ស្វាគមន៍សម្ដេច នរោត្តម សីហនុ នៅពេលទ្រង់វិលត្រឡប់មកប្រទេសកម្ពុជាវិញនៅខែ កញ្ញា ឆ្នាំ ១៩៧៥ និងលើកសរសើរការធានាតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យនូវសិទ្ធិប្រតិបត្តិសាសនា[4636]។ ទោះជាយ៉ាងណាក្ដី "នៅពីក្រោយឆាកនេះ ខៀវ សំផន បានណែនាំយ៉ាងក្លៀវក្លាអំពីការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយពុំចាំបាច់មានព្រះសង្ឃ និងតាមលក្ខណៈដែលផ្ទុយជាមូលដ្ឋានទៅនឹងប្រពៃណីដែលកាន់ព្រះពុទ្ធសាសនា"[4637]។

---

[4632] ប្រតិចារឹកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/180.1 ទំព័រ ៥។

[4633] ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៥៨។

[4634] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤២។

[4635] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤០។

[4636] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤១។

[4637] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤២។

1663.អង្គជំនុំជម្រះតុលាការកំពូលជាពិសេសបានកត់សម្គាល់លើខ្លឹមសារនៃសុន្ទរកថារបស់ ខៀវ សំផន ដែលលើកឡើងអំពីរដ្ឋធម្មនុញ្ញថ្មី។ ក្នុងការពន្យល់ឃ្លាថ្មីស្ដីពីការហាមឃាត់"សាសនាប្រតិកិរិយា" គាត់បានលើកទស្សនៈរបស់បក្សកុម្មុយនីស្ដកម្ពុជាថា "ពួកចក្រពត្តិនិយមបរទេស [...] ប្រើប្រាស់សាសនាដើម្បីធ្វើវិទ្ធង្សនាមកលើយើង" ឬ"ប្រើប្រាស់សាសនាជារូបភាពលាក់បាំង ដើម្បីជ្រៀតចូលក្នុងប្រទេសយើង"[4638]។ ភស្តុតាងដទៃទៀតបញ្ជាក់ថា នេះមានលក្ខណៈស្របគ្នាជាមួយនឹងទស្សនៈរបស់បក្សកុម្មុយនីស្ដកម្ពុជាដែលថា ពុទ្ធសាសនា គឺជាសាសនា"ប្រតិកិរិយា"[4639] ហើយ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច បានឆ្លើយនៅមុខសហចៅក្រមស៊ើបអង្កេតថា ការធានាតាមរដ្ឋធម្មនុញ្ញនូវសិទ្ធិប្រតិបត្តិសាសនា គឺ"ការភូតកុហក"[4640]។ ក្នុងកិច្ចសម្ភាសន៍ដែលបានផ្ដល់បន្ទាប់ពីការដួលរលំរបបនោះ ខៀវ សំផន ត្រូវបានសួរថា តើបក្សកុម្មុយនីស្ដកម្ពុជានឹងធ្វើអ្វីខុសពីមុនដែរ ឬទេ គាត់បានបញ្ជាក់ថា ប្រសិនបើបក្សកុម្មុយនីស្ដកម្ពុជាអាចទទួលបានការគ្រប់គ្រងប្រទេសកម្ពុជាឡើងវិញ បក្សនឹងអនុញ្ញាតឱ្យប្រជាជនមានសេរីភាពក្នុងការប្រតិបត្តិសាសនា[4641]។ ផ្អែកលើ

---

[4638] បទយកការណ៍ទីក្រុងភ្នំពេញអំពីសមាជជាតិលើកទីបី៖ របាយការណ៍របស់ ខៀវ សំផន (នៅក្នុងកម្រងសេវាផ្សព្វផ្សាយព័ត៌មានបរទេស FBIS) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារលេខ E3/273 ERN 00657449-00657451។

[4639] ប្រតិចារឹក ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ (អ៊ីសា ឧស្មាន) ឯកសារលេខ E1/389.1 ទំព័រ ៦៩-៧០ ("របបកម្ពុជាប្រជាធិបតេយ្យបានកំណត់ថា សាសនាប្រតិកិរិយាអាចរាប់បញ្ចូលទាំងសាសនាទាំងឡាយ រួមទាំងព្រះពុទ្ធសាសនានិងសាសនាអ៊ីស្លាម។ ហេតុដូច្នេះ ព្រះសង្ឃទាំងអស់ ព្រះសង្ឃព្រះពុទ្ធសាសនាទាំងអស់ត្រូវបានចាប់ផ្សឹក ហើយវិហារព្រះពុទ្ធសាសនាទាំងអស់ត្រូវបានបំផ្លាញ")។ ប្រតិចារឹក ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ (Elizabeth BECKER) ឯកសារលេខ E1/259.1 ទំព័រ ៤២ (ប្រតិចារឹក ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ (Elizabeth BECKER) ឯកសារលេខ E1/259.1 ទំព័រ ៤២ (ជួន ប្រសិទ្ធិ បាននិយាយថា ពុទ្ធសាសនាជាជំនឿរបស់ពួកប្រតិកិរិយា ហើយប្រជាជនបានបោះបង់វត្តទាំងអស់នោះចោល)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ាត់ លី ឯកសារលេខ E3/7821 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០០ ERN 00229133 ("ក្នុងឆ្នាំ ១៩៧៦ រដ្ឋធម្មនុញ្ញតំណាងប្រជាជនត្រូវបានផ្សព្វផ្សាយ និងបានបញ្ជាក់ថា យើងអាចប្រតិបត្តិសាសនាតាមការជ្រើសរើស លើកលែងតែសាសនាប្រតិកិរិយា។ ប៉ុន្តែបន្ទាប់ពីការរំដោះឆ្នាំ ១៩៧៥ សាសនាទាំងអស់ត្រូវបានចាត់ទុកថា ជាប្រតិកិរិយា")។ *សូមមើលផងដែរ ចំណាប់អារម្មណ៍របស់អ្នកសារព័ត៌មានជនជាតិយូហ្គោស្លាវីម្នាក់អំពីទស្សនកិច្ចប្រទេសកម្ពុជា* (ក្នុងកម្រងឯកសារ SWB/FE/5801/B) ឯកសារលេខ E3/2306 ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨ ERN S 00819177។ អត្ថបទរបស់ Slavko Stanić "កម្ពុជា-សង្គមនិយមគ្មានគំរូ" *គំនិត និងការអនុវត្តសង្គមនិយម* ខែតុលា ឆ្នាំ១៩៧៨ ទំព័រ ១១-១២ ឯកសារលេខ E3/2307 ERN S 00655232-S 00655233 (យុន យ៉ាត ដែលប្រាប់អ្នកសារព័ត៌មានថា "ព្រះពុទ្ធសាសនាមិនត្រូវធាតុគ្នាជាមួយនឹងបដិវត្តន៍ទេ" ពីព្រោះសាសនានេះគឺជាឧបករណ៍មួយសម្រាប់កេងប្រវ័ញ្ច)។

[4640] ចម្លើយរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ E3/15 ERN ERN 00234072 ជើងទំព័រ ១។

[4641] ការអំពាវនាវសុំការគាំទ្រពីអន្តរជាតិ (សារព័ត៌មាន Time Magazine) ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨០ ឯកសារលេខ E3/628 ERN 00709543-00709544។ ("សៈ ប្រសិនបើរដ្ឋាភិបាលទទួលបានការគ្រប់គ្រងវិញ តើលោកនឹងធ្វើអ្វីខុសប្លែកពី

ការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា នេះអាចសន្និដ្ឋានច្បាស់លាស់ថា គាត់បានដឹងថា ពុទ្ធសាសនាត្រូវបានហាមឃាត់ក្នុងកម្ពុជាប្រជាធិបតេយ្យ និងថា នេះគឺជាផលវិបាកសម្រាប់អ្នកកាន់ពុទ្ធសាសនាដែលជាទីកន្លែងសម្រាប់ការអប់រំ និងការប្រតិបត្តិ។

1664.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកិច្ចសម្ភាសន៍របស់ទស្សនាវដ្ដីឈ្មោះ Famiglia Cristiana ក្នុងការបង្ហាញថា ខៀវ សំផន នៅពេលនោះបានដឹងថា មានបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យក៏ដោយ[4642] ក៏សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវបានគាំទ្រដោយភស្តុតាងជាច្រើនសន្ធឹកសន្ធាប់ដទៃទៀតដែរ[4643]។ អាស្រ័យហេតុនេះ កំហុសនេះពុំបានធ្វើប៉ះពាល់ជាសត្យានុម័តដែលអាចបដិសេធការសន្និដ្ឋានជាទូទៅបានឡើយ។ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធចំណុចនេះត្រូវបដិសេធចោល[4644]។

1665.ទីបី ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសុន្ទរកថាដែលគាត់បានថ្លែងក្នុងខែ មករា ឆ្នាំ ១៩៧៦ ខណៈពេលនោះគាត់ត្រឹមតែជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងនៅមុនពេលដែលគាត់ក្លាយជាប្រធានគណៈប្រធានរដ្ឋ[4645]។ បើទោះបីជាសុន្ទរកថានេះត្រូវបានដកស្រង់នៅក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ[4646]ក៏ដោយ ក៏កថាខណ្ឌនោះបានដោះស្រាយយ៉ាងច្បាស់

មុន ដែរ ឬទេ? ឆៈ ប្រសិនបើយើងយកជ័យជម្នះលើវៀតណាមបាន យើងនឹងប្រើប្រាស់លុយ និងអនុញ្ញាតឱ្យមានសេរីភាពដើរហើរដល់ប្រជាពលរដ្ឋយើង។ ប្រជាជននឹងមានសេរីភាពប្រតិបត្តិសាសនា”)។

[4642] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៨.១.៣ ‘ការដឹងក្រោយការប្រព្រឹត្តបទឧក្រិដ្ឋ‟ កថាខណ្ឌ ៤២៥៣ (ជើងទំព័រ ១៣៨៧៥)។

[4643] *សូមមើល* ភស្តុតាងដែលបានដកស្រង់ក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥០-៤២៥៣។

[4644] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០១។

[4645] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០២ (ជើងទំព័រ ៣២៨៥) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៨ (ជើងទំព័រ ១៨៧៦-១៨៨០) យោងទៅលើសេចក្ដីរាយការណ៍ព័ត៌មានពីទីក្រុងភ្នំពេញ ស្ដីពីសមាជជាតិលើកទីបីៈ របាយការណ៍របស់ ខៀវ សំផន (ក្នុងកម្រងសារព័ត៌មាន FBIS) ឯកសារលេខ E3/273 ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។

[4646] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ៨.៣.២ ‘តួនាទី និងមុខតំណែង ខៀវ សំផនៈ តួនាទីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យៈ ប្រធានគណៈប្រធានរដ្ឋ’។

លាស់អំពីសុន្ទរកថារបស់ ខៀវ សំផន ដែលមានអត្ថិភាព"ពាសពេញអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ"[4647]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយឡើយ។

1666.ជាចុងក្រោយ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសុន្ទរកថាជាច្រើន"ក្នុងលក្ខណៈលម្អៀង" ដោយសារតាមទស្សនៈរបស់គាត់ នេះពុំបានបង្ហាញថា គាត់"បានយល់ស្រប ឬគាំទ្រទិដ្ឋភាពល្មើសណាមួយនៃគោលបំណងរួម ឬថា គាត់បានដឹងអំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះឡើយ"[4648]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយការអះអាងដែលគ្មានមូលដ្ឋានដ្ឋានគាំទ្រ និងយ៉ាងទទូចថា គាត់បានគាំទ្រតែផែនការដែលពុំមែនជាបទល្មើស[4649]។ ក្រៅពីនេះការអះអាងរបស់គាត់មានលក្ខណៈស្រពេចស្រពិល និងគ្មានមូលដ្ឋានគាំទ្រ និងដូច្នេះត្រូវបដិសេធចោល។

## ៣. សមាជិកនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម

### ក. សមាជិកភាពក្នុងគណៈមជ្ឈិម

1667.បើទោះបីជា ខៀវ សំផន បានទទួលស្គាល់ថា ដំបូង គាត់គឺជា"សមាជិកបម្រុង និងក្រោយមកជាសមាជិកពេញសិទ្ធិ"នៃគណៈមជ្ឈិម[4650]ក៏ដោយ ក៏តាមទស្សនៈរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយចំនួនក្នុងការវាយតម្លៃលើសារៈសំខាន់នៃតួនាទីរបស់គាត់ ដូចជាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារ (១) ការពន្លាតសិទ្ធិអំណាចរបស់គណៈអចិន្ត្រៃយ៍ (២) ការសន្មតសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិម (៣) "ដោយឆ្លៀតឱកាស"កំណត់កាលបរិច្ឆេទនៃការចូលរបស់គាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ដើម្បីដាក់ឱ្យគាត់មានការជាប់ពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចគណៈមជ្ឈិមចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ និង (៤) ការយល់ឃើញដែលថា គាត់បានចូលរួមក្នុងសមាជបក្ស[4651]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមាន

---

[4647] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៨។

[4648] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០២។

[4649] *សូមមើលខាងក្រោម* ផ្នែក VIII.ខ.២។

[4650] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៥។

[4651] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៦-១៧២៩។

កំហុស និងថា ខៀវ សំផន ពុំបានអើពើទៅលើភស្តុតាងជារួម និងបានបំភ្លៃការយល់ឃើញមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង[4652]។

i. សមាជិកភាព

1668.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានក្លាយជាសមាជិកបម្រុងនៃគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងសមាជបក្សលើកទីបីក្នុងឆ្នាំ ១៩៧១ និងសមាជិកពេញសិទ្ធិនៅក្នុងសមាជលើកទីបួនក្នុងខែ មករា ឆ្នាំ ១៩៧៦[4653]។

1669.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទ"ក្នុងលក្ខណៈឆ្លៀតឱកាស"នៃការចូលរបស់គាត់ជាសមាជិកពេញសិទ្ធិ ដើម្បីដាក់ឱ្យគាត់ជាប់ពាក់ព័ន្ធនៅក្នុងសេចក្ដីសម្រេចមជ្ឈិមចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[4654]។ ជាដំបូង គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា សមាជបក្សលើកទីបួនបានកើតឡើងក្នុងខែ មករា ឆ្នាំ ១៩៧៦ ដោយសារលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានអនុម័តដោយសមាជនោះ ពុំបានចុះកាលបរិច្ឆេទ ហើយភស្តុតាងដទៃទៀតពុំបានគាំទ្រសេចក្ដីសន្និដ្ឋាននោះ[4655]។ ទាក់ទងទៅនឹងបញ្ហានេះ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដែលសក្ខីកម្មរបស់គាត់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសំអាងទៅលើនោះ ត្រឹមតែបានអះអាងឆ្នាំ ១៩៧៦ ប៉ុណ្ណោះ បន្ទាប់ពីគាត់ត្រូវបានសួរចំណុចនេះ និងនៅគ្រប់ករណី គាត់បាននិយាយតែអំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា និងពុំបាននិយាយអំពីសមាជឡើយ[4656]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា Craig ETCHESON ដែលបានអះអាងថា លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុម័តក្នុងសមាជបក្សមួយដែលបានធ្វើឡើងក្នុងខែ មករា ឆ្នាំ ១៩៧៦ នោះ បានសំអាងទៅលើឯកសារមួយដែលពុំបានលើកឡើងអំពីសមាជបក្សលើកទីបួន លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ឬកាលបរិច្ឆេទឆ្នាំ ១៩៧៦ ឡើយ[4657]។

---

[4652] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩០-៨៩៧។

[4653] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៦, ៣៥៥, ៥៧៤, ៦០០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣។

[4654] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៦, ១៧២០។

[4655] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១។

[4656] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៣២៥។

[4657] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៣៣២៥។

1670.បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា គាត់ត្រូវបានអនុញ្ញាតក្លាយជាសមាជិកពេញសិទ្ធិក្នុងខែ មករា ឆ្នាំ ១៩៧៦ ជាជាងក្រោយមកក្នុងឆ្នាំ ១៩៧៦ និងដូចនេះ គាត់"គប្បីទទួលបានអត្ថប្រយោជន៍ពីភាពមន្ទិលសង្ស័យនេះ"[4658]។ ខៀវ សំផន បានអះអាងថា ភស្តុតាងមួយចំនួនដែលបានដកស្រង់នោះពុំបានគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ មានដូចជា កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, សាឡុត បាន, និង អៀង សារី ដែលត្រូវបានរាយការណ៍ដោយ Stephen HEDER ភស្តុតាងទាំងអស់នេះបានដាក់ការចូលរបស់គាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមក្នុងឆ្នាំ ១៩៧៦ ប៉ុន្តែគ្មានបញ្ជាក់អំពីខែឡើយ[4659]។ បន្ថែមលើនេះទៀត ខៀវ សំផន បានលើកឡើងថា គាត់"ជាចាំបាច់ [...] តែងតែបញ្ជាក់ថា គាត់ក្លាយជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ ១៩៧៦ ប៉ុន្តែពុំបានបញ្ជាក់អំពីខែ ឬសំដៅទៅលើដើមឆ្នាំ ១៩៧៦ ឬជាញឹកញាប់ជាងនោះទៀតគឺ [...] សំដៅទៅលើខែ មិថុនា ឆ្នាំ ១៩៧៦"ឡើយ[4660]។ ជាចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវភស្តុតាងរបស់ Stephen HEDER និង Philip SHORT។ Stephen HEDER បានផ្តល់សក្ខីកម្មថា គេប្រាប់គាត់នៅក្នុងកិច្ចសម្ភាសន៍ថា លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុម័តក្នុងខែ មករា ឆ្នាំ ១៩៧៦ និងបានភ្ជាប់បញ្ហានេះទៅនឹងសមាជបក្សលើកទីបួន។ ទោះជាយ៉ាងណាក្តី ខៀវ សំផន បាននិយាយថា Stephen HEDER បាន"លើកឡើងអំពីអត្ថិភាពជាសក្តានុពលនៃការយោងនៅក្នុងឯកសារដែលគាត់ពុំបានផ្តល់ឱ្យ"[4661]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់ការអះអាងរបស់ Philip SHORT ដែលថា ខៀវ សំផន ត្រូវបានដំឡើងឋានៈទៅជាសមាជិកពេញសិទ្ធិក្នុងពេលជាមួយគ្នាដែលគាត់ត្រូវបានតែងតាំងជាប្រមុខរដ្ឋ ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បានកើតឡើងនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[4662]។

---

[4658] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១-១៧២២។

[4659] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១ (ជើងទំព័រ ៣៣២៦)។

[4660] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១។

[4661] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១។

[4662] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៦។

1671.សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ខៀវ សំផន ក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ក្នុងសមាជលើកទីបួនក្នុងខែ មករា ឆ្នាំ ១៩៧៦[4663]។ ជាពិសេស ខៀវ សំផន បានបំភ្លៃសក្ខីកម្មរបស់ Stephen HEDER ដែលបានផ្ដល់សក្ខីកម្មថា ខៀវ សំផន ត្រូវបានដំឡើងឋានៈពីបម្រុងទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនៅក្នុងសមាជបក្សក្នុងខែ មករា ឆ្នាំ ១៩៧៦ ហើយ ខៀវ សំផន ខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា គាត់បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនៅចន្លោះចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦[4664]។

1672.តាមការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូលលើភស្តុតាងបង្ហាញថា ដូចបានគូសបង្ហាញលម្អិតខាងក្រោម សមាជបក្សលើកទីបួន ការអនុម័តលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងការដំឡើងឋានៈរបស់ ខៀវ សំផន មានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយផ្អែកលើការពិតថា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុម័តដោយសមាជបក្ស ហើយការតែងតាំងសមាជិកនៃគណៈមជ្ឈិមត្រូវបានធ្វើឡើងដោយសមាជបក្សដែលកម្រឃើញការកោះប្រជុំ និងមានតែពីរដងគត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[4665]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើព្រឹត្តិការណ៍បីជារួម និងបដិសេធចោលនូវការប៉ុនប៉ងរបស់ ខៀវ សំផន ក្នុងការបំបែកភស្តុតាងនៃព្រឹត្តិការណ៍ទាំងនេះឱ្យឃើញថា ពុំជាប់ទាក់ទងគ្នា។

1673.ភស្តុតាងភាគច្រើនបានចង្អុលបង្ហាញទៅលើខែ មករា ឆ្នាំ ១៩៧៦ ដែលជាកាលបរិច្ឆេទពាក់ព័ន្ធ[4666]។ ជាពិសេស Stephen HEDER បានបញ្ជាក់ថា ខៀវ សំផន ត្រូវបានជ្រើសតាំងចេញពីសមាជិកបម្រុងទៅជា

---

4663 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩១ យោងទៅលើប្រតិចារឹកថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/223.1 ទំព័រ ៣១។ ប្រតិចារឹកថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ខៀវ សំផន) ឯកសារ E1/198.1 ទំព័រ ៦៤-៦៥។

4664 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩១។

4665 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៣, ៣៤៥។ លក្ខន្តិកៈ ប.ក.ក. ឆ្នាំ ១៩៧៦ ពុំមានកាលបរិច្ឆេទ ឯកសារលេខ E3/130 ទំព័រ ៤៨ ERN 00442269-00442270, 00442277 (មាត្រា ៧ និងមាត្រា ២១)។

4666 ភស្តុតាងបន្ថែមដែលពុំត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ បានចង្អុលបង្ហាញទៅលើខែ មករា ឆ្នាំ ១៩៧៦ ដែលជាកាលបរិច្ឆេទនៃសមាជបក្សលើកទីបួន។ *សូមមើល* សៀវភៅនិពន្ធដោយ E. Becker៖ នៅពេលដែលសង្គ្រាមរលត់ទៅ៖ កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម ឯកសារលេខ E3/20 ទំព័រ ១៩២។ សេចក្ដីសន្និដ្ឋាននៃសុន្ទរកថារបស់ ប៉ុល ពត នៅក្នុងកិច្ចប្រជុំដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ កញ្ញា (នៅក្នុងកម្រងសារព័ត៌មាន FBIS) ឯកសារលេខ E3/294 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៧៨ ERN (En) 00170164, 00170166។

សមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនៅក្នុងសមាជបក្សមួយក្នុងខែ មករា ឆ្នាំ ១៩៧៦[4667]។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យប្រើប្រាស់ភស្តុតាងរបស់ Stephen HEDER ជាជាងភស្តុតាងរបស់ Philip SHORT លើចំណុចនេះ ដែលគាត់បានយល់ថា ខៀវ សំផន ត្រូវបានជ្រើសតាំងក្នុងខែ មីនា ឆ្នាំ ១៩៧៦ ហើយអង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា គណៈមជ្ឈិមពុំមានសិទ្ធិអំណាចតែងតាំងសមាជិកផ្ទាល់របស់ខ្លួនឡើយ និងថា ពុំមានភស្តុតាងគាំទ្រថា មានសមាជមួយបានរៀបចំឡើងនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ឡើយ។ ប្រហាក់ប្រហែលគ្នាដែរ Craig ETCHESON បានអះអាងថា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុម័តដោយសមាជបក្សក្នុងខែ មករា ឆ្នាំ ១៩៧៦[4668]។ បើទោះបីជា ខៀវ សំផន ជួនកាលបានអះអាងជាសាធារណៈថា គាត់ត្រូវបានដំឡើងឋានៈទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនៅពាក់កណ្ដាលឆ្នាំ ១៩៧៦[4669] ឬក្នុងខែ មិថុនា ឆ្នាំ ១៩៧៦ ក៏ដោយ[4670] ក៏គាត់បានប្រាប់សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក. ថា គាត់ត្រូវបានដំឡើងឋានៈក្នុងឆ្នាំ ១៩៧៦[4671] និងប្រាប់អង្គជំនុំជម្រះសាលាដំបូង បើទោះបីជាពុំបានធ្វើសម្បថក៏ដោយថា គាត់បានក្លាយជាសមាជិកពេញសិទ្ធិក្នុង"ចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦"ដែរ[4672]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើចម្លើយរបស់ ខៀវ សំផន ដែលបានផ្តល់នៅមុខសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក.។

1674.បន្ថែមលើនេះ ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើភស្តុតាងពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាការបញ្ជាក់បន្ថែមទូទៅ ដែលបានចង្អុលបង្ហាញទៅលើការដំឡើងឋានៈក្នុងឆ្នាំ ១៩៧៦ បើទោះបី

---

[4667] ប្រតិចារឹក ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/222.1 ទំព័រ ១៣-១៤, ៦២។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/223.1 ទំព័រ ៣០-៣១។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ (Stephen HEDER) ឯកសារលេខ E1/221.1 ទំព័រ ៥១។ *សូមមើលផងដែរ* ឯកសារដែលសរសេរដោយ S. HEDER: បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស៖ ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ចុះខែមីនា ឆ្នាំ២០០៤ ឯកសារលេខ E3/48 ទំព័រ ៩៣ ERN (En) 00393581។

[4668] របាយការណ៍អ្នកជំនាញ Craig ETCHESON ឯកសារលេខ E3/494 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ ៣-៥ ERN 00314780-00312782។

[4669] លិខិតរបស់ ខៀវ សំផន៖ ផ្ញើជូនជនរួមជាតិទាំងអស់ ឯកសារលេខ E3/205 ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០១ ERN 00002796។

[4670] សៀវភៅនិពន្ធដោយ ខៀវ សំផន៖ ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់ ឯកសារលេខ E3/18 ទំព័រ ៧១, ERN 00103865 (ខែ មិថុនា ឆ្នាំ ១៩៧៦) ទំព័រ ១១៤-១១៥។

[4671] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ E3/27 ទំព័រ ៨-៩ ERN 00156619-00156620។

[4672] ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ (ខៀវ សំផន) ឯកសារលេខ E1/198.1 ទំព័រ ៦៤។

ពុំបានបញ្ជាក់ជាក់លាក់អំពីខែក៏ដោយ។ ដូច្នេះ អៀង សារី បានប្រាប់ Stephen HEDER ថា ខៀវ សំផន "ក្លាយជាសមាជិកគណៈមជ្ឈិមក្នុងឆ្នាំ ១៩៧៦ ដោយហេតុថាក្នុងឆ្នាំ ១៩៧៥ គាត់ជាក់ស្ដែងមានការជាប់ពាក់ព័ន្ធជាមួយនឹងកិច្ចការរបស់គណៈមជ្ឈិមរួចហើយ"[4673]។ នៅពេល កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ត្រូវបានសួរសំណួរអំពីលក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជាក្នុងឆ្នាំ ១៩៧៦ គាត់មិនត្រឹមតែបានបញ្ជាក់អះអាងពិតប្រាកដថា នេះជាឆ្នាំដែលលក្ខន្តិកៈត្រូវបានអនុម័តប៉ុណ្ណោះទេ ថែមទាំងបានផ្ដល់សក្ខីកម្មថា គាត់បានឃើញ និងបានសិក្សាលក្ខន្តិកៈនេះក្នុងឆ្នាំ ១៩៧៦ និងអាចស្គាល់ច្បាប់ចម្លងនេះនៅក្នុងតុលាការផងដែរ[4674]។

1675.អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញកំហុសតូចតាចក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ថា កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ពុំបានបញ្ជាក់ជាក់លាក់ថា នៅពេលណា ខៀវ សំផន ត្រូវបានដំឡើងឋានៈទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនោះទេ[4675]។ បន្ថែមលើនេះ សាឡុត បាន បានបញ្ជាក់ថា "ប្រសិនបើ ខៀវ សំផន ក្លាយជាសមាជិក" គាត់"មានតែ"ជាសមាជិកនៃគណៈមជ្ឈិម ជាជាងគណៈអចិន្ត្រៃយ៍[4676]។ ហេតុនេះ គាត់ពុំបានដឹងច្បាស់ថា ពេលណា ខៀវ សំផន ត្រូវបានដំឡើងឋានៈទៅជាសមាជិកពេញសិទ្ធិនោះទេ ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើ សាឡុត បាន ត្រង់ចំណុចនេះ។ ទោះជាយ៉ាងណាក្ដី កំហុសនេះពុំអាចមោឃៈសេចក្ដីសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការតែងតាំង ខៀវ សំផន ក្នុងខែ មករា ឆ្នាំ ១៩៧៦ ហើយអំណះអំណាងរបស់គាត់ពាក់ព័ន្ធចំណុចនេះត្រូវបដិសេធចោល។

### ii. វិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់គណៈមជ្ឈិម

[4673] ប្រតិចារឹក ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ (Stephen HEDER) ឯកសារលេខ E1/223.1 ទំព័រ ៣។ បទសម្ភាសន៍របស់ Stephen Heder ជាមួយ អៀង សារី ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ ឯកសារលេខ E3/573 ERN 00640499-00640500 ។

[4674] ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ (កាំង ហ្គេកអ៊ាវ) ឯកសារលេខ E1/52.1 ទំព័រ ៥៥-៥៨។ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច បានស្ម័គ្រចិត្តផ្ដល់សក្ខីកម្មក្នុងឆ្នាំ ២០០៩។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្គេកអ៊ាវ) ឯកសារលេខ E3/5797 ទំព័រ ៥០។

[4675] ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ (កាំង ហ្គេកអ៊ាវ) ឯកសារលេខ E1/62.1 ទំព័រ ៥៨។

[4676] ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ (សាឡុត បាន) ឯកសារលេខ E1/69.1 ទំព័រ ១, ៣។

1676.ខៀវ សំផន បានលើក"បញ្ហាជាបឋម"ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា សមាជិកគណៈមជ្ឈិមព្រមទាំងសមាជិកបម្រុងមានចន្លោះពី ២០ ទៅ ៣០ នាក់[4677]។ សហព្រះរាជអាជ្ញាពុំបានឆ្លើយតបទៅនឹងការអះអាងនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ជាដំបូងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំខុសប្លែកគ្នាជាសំខាន់ពីការប៉ាន់ស្មានផ្ទាល់ខ្លួនរបស់ ខៀវ សំផន ដែលថា គណៈមជ្ឈិម"មានសមាជិកជាង ៣០ នាក់"[4678]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំអាចកំណត់បាននូវទំនាក់ទំនងនៃចំនួនសមាជិកគណៈមជ្ឈិម ជាមួយនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន ហើយសារណារបស់គាត់ពុំបានបំភ្លឺលើចំណុចនេះដែរ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

1677.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គណៈមជ្ឈិមមានសិទ្ធិអំណាចតែងតាំងសមាជិកនៃគណៈអចិន្ត្រៃយ៍ ដោយសារអង្គជំនុំជម្រះបានសំអាងទៅលើតែកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១ ដែលនេះតម្រូវឱ្យមានភស្តុតាងបញ្ជាក់អះអាងបន្ថែមទៀត[4679]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងជារួម មិនត្រឹមតែលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១ ប៉ុណ្ណោះទេ ក្នុងការសន្និដ្ឋានថា គណៈមជ្ឈិមមានសិទ្ធិអំណាចធ្វើការតែងតាំងនោះ[4680]។ ជាពិសេស សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើភស្តុតាងនៃការតែងតាំង ដែលជាក់ស្តែងបានធ្វើឡើងដោយគណៈមជ្ឈិមក្នុងសេចក្តីសម្រេចរបស់ខ្លួនថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ដែលរួមបញ្ចូលការតែងតាំង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ[4681]។

1678.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះរកពុំឃើញនូវកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈមជ្ឈិមបានតែងតាំង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ តាមរយៈសេ

---

[4677] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥។

[4678] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារលេខ E3/27 ទំព័រ ៨-៩ ERN 00156619-00156620។

[4679] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧, ៣៤៤។

[4680] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩២។

[4681] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៤, ៥៩៦។

ចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[4682]។ បើទោះបីជាសេចក្តីសម្រេចថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ បានធ្វើការតែងតាំងជាច្រើនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើការវាយតម្លៃរបស់គាត់ចំពោះការតែងតាំងគណៈមជ្ឈិមដទៃទៀតឡើយ[4683]។ ការជំទាស់នេះពុំមានការជាប់ពាក់ព័ន្ធទៅនឹងបទចោទ និងត្រូវបដិសេធចោល ដោយសារពុំបានបង្ហាញនូវភាពមិនយុត្តិធម៌។

1679.ជាបន្ទាប់ ខៀវ សំផន បានលើកអំណះអំណាងជាច្រើនពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងគណៈមជ្ឈិម និងអចិន្ត្រៃយ៍ និងបានព្យាយាមបង្ហាញថា គណៈមជ្ឈិម"ពុំមានសិទ្ធិអំណាចប្រសិទ្ធភាព និងគ្រាន់តែជាវេទិកាសម្រាប់ការផ្សព្វផ្សាយសេចក្តីសម្រេចដែលត្រូវបានធ្វើឡើងរួចហើយដោយ[គណៈអចិន្ត្រៃយ៍]ប៉ុណ្ណោះ" [4684]។ ដំបូងគាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានពន្យល់មូលហេតុដែលខ្លួនបានសំអាងទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាក្នុងការយល់ឃើញថា គណៈមជ្ឈិមទទួលខុសត្រូវលើការត្រួតពិនិត្យលើការអនុវត្តន៍នៃគោលនយោបាយបក្ស នៅពេលដែលកត់សម្គាល់ថា មានភាពខុសគ្នារវាងទ្រឹស្តីនៃលក្ខន្តិកៈជាមួយនឹងភាពជាក់ស្តែង[4685]។ ទីពីរ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃអត្ថបទនិពន្ធរបស់គាត់ក្នុងការយល់ឃើញថា គាត់"បានដឹង"ថា គណៈមជ្ឈិម"បានចេញសេចក្តីណែនាំ"[4686]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាអំពីការអះអាងរបស់គាត់ ដែលត្រូវបានគាំទ្រដោយភស្តុតាងដទៃទៀតថា គណៈមជ្ឈិមជាក់ស្តែងនៅក្រោមបង្គាប់របស់គណៈអចិន្ត្រៃយ៍ និងត្រឹមតែបានផ្សព្វផ្សាយសេចក្តីសម្រេចគណៈអចិន្ត្រៃយ៍ប៉ុណ្ណោះ[4687]។

1680.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងជារួម មិនត្រឹមតែទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ ១៩៧១ ប៉ុណ្ណោះទេក្នុងការសន្និដ្ឋានថា គណៈមជ្ឈិមទទួលខុសត្រូវ

---

4682 *សូមមើលខាងក្រោម* ផ្នែក VIII.ក.៣.ក.iii។

4683 *ដូចខាងលើ*។

4684 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១០។

4685 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៩-១៧១០។

4686 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៩-១៧១០។

4687 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១០។ សម្រាប់អំណះអំណាងនេះ ខៀវ សំផន ព្យាយាមដាក់បញ្ចូលតាមរយៈការយោងទៅលើអំណះអំណាងដែលបានលើកឡើងក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់នៃសំណុំរឿង ០០២/០១។ *សូមមើល* សារណាបណ្តឹងទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ០០២/០១ (F17)។

ចំពោះការត្រួតពិនិត្យលើការអនុវត្តន៍នៃគោលនយោបាយបក្ស[4688]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការទទួលស្គាល់ទម្ងន់នៃភស្តុតាងដែលបង្ហាញថា គណៈមជ្ឈិមបានត្រួតពិនិត្យ និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តទាក់ទងទៅនឹងការដ្ឋានធ្វើការ សហករណ៍ មន្ទីរសន្តិសុខ ការបោសសម្អាត និងវិធានការប្រឆាំងនឹងក្រុមជាក់លាក់តាមរយៈការផ្សព្វផ្សាយសេចក្តីណែនាំ និងសេចក្តីសម្រេចការបែងចែកផែនការការងារក្នុងភូមិភាគ និងតំបន់ និងតាមរយៈវគ្គបណ្តុះបណ្តាល[4689]។

1681.ត្រង់ចំណុចនេះ ខៀវ សំផន បានលើកច្រំដែលពិតណាស់ ជាការព្យាយាមដាក់បញ្ចូលតាមរយៈការយោង[4690]នូវអំណះអំណាងដែលត្រូវបានពិចារណា និងបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[4691]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនស្តីពីអំណះអំណាងនេះ និងពុំមានហេតុផលសមស្របត្រូវប្រាសចាកដោយហេតុថា៖

> ផ្ទុយទៅនឹងការលើកឡើងរបស់[ខៀវ សំផន] ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈផ្ទុយគ្នាឡើយ ប៉ុន្តែគ្រាន់តែបានបង្ហាញក្នុងរូបភាពខុសគ្នាតិចតួចអំពីមុខងាររបស់គណៈមជ្ឈិម ដោយបានទទួលស្គាល់ច្បាស់លាស់ថា សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ គឺស្ថិតនៅកន្លែងផ្សេង។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏មានសេចក្តីសម្រេចមួយចំនួនពិតជាត្រូវបានធ្វើឡើងនៅថ្នាក់គណៈមជ្ឈិមដែរ ហើយ ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះពុំសមហេតុផលនោះឡើយ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសេចក្តីដកស្រង់នៅក្នុងសៀវភៅរបស់ ខៀវ សំផន ដែលយោងតាមសៀវភៅនោះ គណៈមជ្ឈិមបានចេញ"សេចក្តីបង្គាប់" មួយចំនួនស្តីពីបញ្ហាផ្សេងៗ។ បើទោះបីជាជើងទំព័រទាក់ទងទៅនឹងសេចក្តីដកស្រង់ខាងលើបានបង្ហាញថា គណៈមជ្ឈិមពុំមែនជា 'អង្គការនីតិប្រតិបត្តិ' ប៉ុន្តែត្រឹមតែ"បានពិភាក្សាអំពីការអនុវត្តន៍គោលនយោបាយបក្សដែលបានបង្កើតឡើងដោយ[គណៈអចិន្ត្រៃយ៍]ក៏ដោយ ក៏នេះស៊ីសង្វាក់គ្នាជាមួយនឹងការយល់ឃើញរបស់

---

[4688] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩២។

[4689] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩២។

[4690] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១០ (ជើងទំព័រ ៣៣០០) យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ១២២-១២៣។

[4691] សាលដីកាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៤៥-១០៤៧។

អង្គជំនុំជម្រះសាលាដំបូងដែលតាមការកត់សម្គាល់ខាងលើ បានទទួលស្គាល់ជាក់លាក់ថា គណៈអចិន្ត្រៃយ៍ គឺជាអ្នកធ្វើសេចក្ដីសម្រេចចុងក្រោយ[4692]។

1682. ជាចុងក្រោយ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការសន្និដ្ឋានថា ទូរលេខជាប្រចាំដែលបានបញ្ជូនដោយលេខាភូមិភាគដែលរាយការណ៍អំពីស្ថានភាពនោះ បង្ហាញថា គណៈមជ្ឈិម និងអចិន្ត្រៃយ៍ គឺជាអ្នកត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយបក្សស្របតាមតួនាទីរបស់ខ្លួន[4693]។ គាត់បានលើកឡើងដោយជាក់លាក់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើទូរលេខដែលបានផ្ញើជូនចំពោះ“*អង្គការ*” “*អង្គការ* ៨៧០” និង“គណៈ ៨៧០” និងចម្លងជូនសមាជិកគណៈអចិន្ត្រៃយ៍[4694]។ ឯកសារដទៃទៀតតម្រូវឱ្យមានរបាយការណ៍ប្រចាំសប្ដាហ៍ផ្ញើទៅមន្ទីរ ៨៧០ ឬគណៈអចិន្ត្រៃយ៍ ជាជាងទៅគណៈមជ្ឈិម[4695] ហើយសាក្សីបានផ្ដល់សក្ខីកម្មថា ទូរលេខត្រូវបានបញ្ជូនទៅតែ ប៉ុល ពត និង នួន ជា ប៉ុណ្ណោះ[4696]។ ដូចនេះ តាមការលើកឡើងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានតាមរយៈសមាជិកភាពរបស់គាត់ជាគណៈមជ្ឈិមថា គាត់បានទទួលការរាយការណ៍ច្បាស់លាស់នោះទេ[4697]។

1683. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាជាទូទៅឃើញថា ខៀវ សំផន ស្ថិត“ក្នុងក្រុមតូចមួយនៃសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលទទួលបានការរាយការណ៍ច្បាស់លាស់ ដោយសារសមាជិកភាពរបស់គាត់ជាគ

---

[4692] សាលដីកាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៤៧។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧ (អង្គជំនុំជម្រះសាលាដំបូងបានលើកផ្ទុយទៅនឹងបទប្បញ្ញត្តិនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែលកំណត់តួនាទីប្រសិទ្ធភាពរបស់គណៈអចិន្ត្រៃយ៍)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០០ (អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងជាក់លាក់ និងពិភាក្សាលើការអះអាងរបស់ ខៀវ សំផន ថា គណៈមជ្ឈិមពុំមែន“ជាស្ថាប័នប្រតិបត្តិនោះទេ”)។

[4693] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧០៩។

[4694] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦៤ (ជើងទំព័រ ១៣១៨៩-១៣១៩៣), ៣៨៩៩ (ជើងទំព័រ ១២៩៩៩)។

[4695] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១១ យោងទៅលើសេចក្ដីសម្រេចរបស់គណៈមជ្ឈិមទាក់ទងទៅនឹងបញ្ហាមួយចំនួន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/12 ERN 00003136-00003137។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ទាក់ទងនឹងការងារមូលដ្ឋាន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/232 ERN 00017122-00017123។

[4696] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១១។

[4697] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១២។

ណៈមជ្ឈិម"[4698]។ ជាក់លាក់ជាងនេះទៅទៀត អង្គជំនុំជម្រះបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីផលប៉ះពាល់នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមូលដ្ឋានផ្អែកលើទូរលេខជាច្រើន ដែលបានផ្ញើជូន ឬចម្លងជូន *អង្គការ, អង្គការ* ៨៧០, គណៈ៨៧០ ឬមន្ទីរ ៨៧០ ដែលពុំមានឈ្មោះអ្នកទទួល ព្រមទាំងរបាយការណ៍ចេញពីតំបន់ទៅភូមិភាគ"ផ្អែកលើរបបនៃការរាយការណ៍ជាប្រព័ន្ធខ្សែឈរនៅក្នុងឋានន្តរស័ក្តិនៃបក្សកុម្មុយនីស្តកម្ពុជា"[4699]។ អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់របាយការណ៍នេះទៅនឹងអាណត្តិរបស់គណៈមជ្ឈិម ក្នុងការត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយបក្ស[4700]។

1684.អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានគាំទ្រចំៗលើការអះអាងដែលថា សមាជិកទាំងអស់នៃគណៈមជ្ឈិមជាចាំបាច់ទទួលរបាយការណ៍ទាំងអស់ដែលផ្ញើទៅ*អង្គការ* បើទោះបីជាទាំងអស់ ឬខ្លះបានទទួលក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ពិសេសលើភាពពុំជាក់លាក់ដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហាថាតើបុគ្គល ឬស្ថាប័នណាមួយត្រូវបានរួមបញ្ចូលតាមរយៈពាក្យថា *អង្គការ* និងការហៅផ្សេងៗថា មន្ទីរ "៨៧០"[4701]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សិទ្ធិអំណាចប្រតិបត្តិប្រចាំថ្ងៃត្រូវបានធ្វើប្រតិភូកម្មទៅឱ្យគណៈអចិន្ត្រៃយ៍ និងថា ផ្ទុយទៅវិញ គណៈមជ្ឈិមពុំសូវជួបគ្នាញឹកញាប់នោះទេ[4702] ព្រមទាំងឯកសារដែលតម្រូវការធ្វើបច្ចុប្បន្នភាពត្រូវតែផ្ញើជូន

---

[4698] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

[4699] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៣ (ជើងទំព័រ ១៣០៥១-១៣០៥៣)។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦៤ (ជើងទំព័រ ១៣១៨៩-១៣១៩៣)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៩៩ (ជើងទំព័រ ១២៩៩៩)។

[4700] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៣ ("អង្គជំនុំជម្រះយល់ឃើញថា ជាផ្នែកមួយនៃអាណត្តិរបស់ខ្លួនក្នុងការតាមដានការអនុវត្តន៍គោលនយោបាយរបស់បក្ស គណៈកម្មាធិការមជ្ឈិម (ជាពិសេស គណៈកម្មាធិការអចិន្ត្រៃយ៍) បានដឹងយ៉ាងច្បាស់ពីបញ្ហាដែលប៉ះពាល់ដល់ជីវភាពរបស់អ្នកធ្វើការនិងកសិករនៅមូលដ្ឋាន សហករណ៍ និងកន្លែងធ្វើការ រួមទាំង កង្វះខាតស្បៀងអាហារ បញ្ហាសុខភាព និងកង្វះឱសថ នៅអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ"), កថាខណ្ឌ ៣៩៦៤ ("អង្គជំនុំជម្រះជឿជាក់ថា ទូរលេខនេះបង្ហាញអំពីការតាមដានដោយគណៈមជ្ឈិម និងអចិន្ត្រៃយ៍លើការអនុវត្តន៍គោលនយោបាយបក្សស្របតាមអាណត្តិរបស់ខ្លួន")។

[4701] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៥.១.៥៖ 'រចនាសម្ព័ន្ធរដ្ឋបាល៖ រចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា៖ មន្ទីរ ៨៧០' និងផ្នែក ៥.១.៨៖ 'រចនាសម្ព័ន្ធរដ្ឋបាល៖ រចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា៖ អង្គការ'។

[4702] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៥, ៣៥៧។

មន្ទីរ ៨៧០ ឬគណៈអចិន្ត្រៃយ៍[4703]។ ពិតណាស់ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា របាយការណ៍ត្រូវតែផ្ញើទៅគណៈមជ្ឈិម ជាចម្បងទំនងជាចេញពីសិទ្ធិអំណាចតាមទ្រឹស្តីនៃលក្ខន្តិកៈ ក្នុងការត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយបក្ស ជាជាងចេញពីភស្តុតាងជាក់លាក់ដែលបានបង្ហាញដូច្នោះ។

1685.ទោះជាយ៉ាងណាក្តី ទូរលេខភាគច្រើនដែលសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការគាំទ្រនូវការដឹងរបស់ ខៀវ សំផន ត្រូវបានផ្ញើទៅ ឬចម្លងជូន"មន្ទីរ"ដែលជា មន្ទីរ ៨៧០ ដែល ខៀវ សំផន បានចូលបម្រើការចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៥ រហូតមក[4704]។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា មាន "របបនៃការរាយការណ៍ជាប្រពន្ធ័ខ្សែឈរ"ដែលរបាយការណ៍ចេញពីគណៈតំបន់ទៅថ្នាក់ភូមិភាគ និងត្រូវបានបញ្ជូនបន្តតាមធម្មតាទៅមន្ទីរ ៨៧០[4705]។ ក្នុងនាមជាសមាជិកជ្រើសតាំងម្នាក់ក្នុងចំណោមសមាជិកជាច្រើននៃមន្ទីរ ៨៧០ ដែលស្ថិតនៅកម្រិតកំពូលនៃសិទ្ធិអំណាចដែលបានផ្តល់ឱ្យដោយអាណត្តិក្នុងការត្រួតពិនិត្យការអនុវត្តន៍សេចក្តីសម្រេចគណៈអចិន្ត្រៃយ៍ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការពុំសមស្រប ទាល់តែសោះដែល ខៀវ សំផន ព្រងើយកន្តើយទៅនឹងការរាយការណ៍ទៅមន្ទីរនោះ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានទទួលការរាយការណ៍អំពីបញ្ហាជំនួញ និងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យដោយសារតួនាទីរបស់គាត់ក្នុងគណៈពាណិជ្ជកម្ម[4706]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មូលដ្ឋាននៃការដឹងរបស់ ខៀវ សំផន ត្រូវបានបង្ហាញច្បាស់លាស់ បើទោះបីជាមានភាពមិនជាក់លាក់ក្នុងកម្រិតមួយថាតើ

---

[4703] *សូមមើល* ឧ. សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/12 ទំព័រ ១-៣ ERN 00000758-00000760។ កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ទាក់ទងនឹងការងារមូលដ្ឋាន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/232 ERN 00017122-00017123។

[4704] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៨.៣.៤.១: 'តួនាទី និងមុខតំណែង ខៀវ សំផន: មុខតំណែងបន្ទាប់បន្សំ: សមាជិកភាពនៃមន្ទីរ ៨៧០'។ ការជំទាស់របស់ ខៀវ សំផន ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទីក្នុងមន្ទីរ ៨៧០ ត្រូវបានដោះស្រាយបន្ថែមទៀតខាងក្រោម *សូមមើលខាងក្រោម* ផ្នែក VIII.ក.៤.ខ។

[4705] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ៦.២.២: 'រចនាសម្ព័ន្ធការទំនាក់ទំនង: រវាងមជ្ឈិមបក្ស និងភូមិភាគ ឬតំបន់ស្វយ័ត' ក្នុងកថាខណ្ឌ ៤៩២។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៣ (ជើងទំព័រ ១៣០៥៣)។

[4706] *សូមមើលខាងក្រោម* ផ្នែក VIII.ក.៤.គ.i។

សមាជិក*ទាំងអស់*នៃគណៈមជ្ឈិមបានដឹងដូចគ្នា ដែរ ឬយ៉ាងណានោះក៏ដោយ។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ត្រូវបដិសេធចោល។

iii. ការសន្និដ្ឋានសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិម

1686.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង"បានសន្និដ្ឋានសេចក្ដីសម្រេចសំខាន់ៗរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិមក្នុងលក្ខណៈឆ្លៀតឱកាស និងដោយខុសឆ្គង"[4707] ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចបួន៖ (១) សេចក្ដីសម្រេចក្នុងខែ ឧសភា ឆ្នាំ ១៩៧២ ឱ្យបិទផ្សារ បញ្ឈប់ការប្រើប្រាស់លុយ និងរៀបចំសហករណ៍ក្នុងតំបន់រំដោះ(សេចក្ដីសម្រេចទី ១)[4708] (២) សេចក្ដីសម្រេចនៅពាក់កណ្ដាលឆ្នាំ ១៩៧៤ ឱ្យបិទបញ្ឈប់ការចូលជាសមាជិកបក្សដើម្បីរារាំងគិញមិនឱ្យជ្រៀតចូលក្នុងបក្ស(សេចក្ដីសម្រេចទី ២)[4709] (៣) សេចក្ដីសម្រេចខែ មិថុនា ឆ្នាំ ១៩៧៤ ឱ្យធ្វើការវាយប្រហារចុងក្រោយ និងជម្លៀសទីក្រុងភ្នំពេញក្នុងរដូវប្រាំងឆ្នាំ ១៩៧៤ ដល់ ១៩៧៥ (សេចក្ដីសម្រេចទី ៣)[4710] និង (៤) 'សេចក្ដីសម្រេចថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ របស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន' (សេចក្ដីសម្រេចទី ៤)[4711]។

1687.បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា បើទោះបីជាសេចក្ដីសម្រេចទាំងបួនត្រូវបានសម្រេចដោយគណៈមជ្ឈិមក៏ដោយ ក៏"ពុំដែលមានការបង្ហាញថា មានកិច្ចប្រជុំណាមួយបានកើតឡើង ឬថា គាត់មានវត្តមាននោះឡើយ"[4712]។ ទាក់ទងទៅនឹងសេចក្ដីសម្រេចទី ២ គាត់បានអះអាងថា គាត់ត្រឹមតែជា "សមាជិកបម្រុងប៉ុណ្ណោះគ្មានសិទ្ធិបោះឆ្នោតនោះទេ" ហើយពុំមានភស្តុតាងបង្ហាញថា គាត់មានវត្តមានដែរ[4713]។ សម្រាប់សេចក្ដីសម្រេចទី ៣ ខៀវ សំផន បានចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញ

---

[4707] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៣។

[4708] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៩,៣៨៧២។

[4709] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២, ៣៩៤០។

[4710] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៦ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០, ៣៨៨០។

[4711] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៤, ៤១៦, ៥៩៦, ៣៧៣៩, ៣៨៥៥-៣៨៥៦, ៣៨៩៩, ៣៩៥៥, ៤២៥៩-៤២៦០។

[4712] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៨។

[4713] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៤ (ជើងទំព័រ ៣៣០៩)។

ច្បាស់លាស់ថា គាត់ពុំបានចូលរួមកិច្ចប្រជុំនោះទេ[4714]។ ដូចនេះ អង្គជំនុំជម្រះសាលាដំបូងគប្បីបាន“ទទួលស្គាល់ថា ពុំមែនសមាជិកទាំងអស់ជាចាំបាច់បានចូលរួមកិច្ចប្រជុំនោះទេ”[4715] និងអង្គជំនុំជម្រះសាលាដំបូង “ពុំអាចសន្និដ្ឋានតាមរយៈសេចក្ដីសម្រេចនេះ និងសមាជិកភាពរបស់គាត់ជាគណៈមជ្ឈិមនូវការដឹងណាមួយ ចេតនា ឬការរួមចំណែកក្នុងឧក្រិដ្ឋកម្មឡើយ”[4716]។

1688.ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចទី ៤ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គណៈមជ្ឈិម“បានតែងតាំង”គាត់ជាប្រធានគណៈប្រធានរដ្ឋ[4717]។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាសមស្របថា រាល់សេចក្ដីសម្រេចទាំងនេះត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ទៅវិញនោះទេ[4718]។

1689.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដោយសារផ្អែកតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ប្រធានពុំមែនជាសមាជិកនៃរដ្ឋាភិបាល ទើបពុំមានហេតុរំពឹងទុកថា គាត់ត្រូវបានតែងតាំងដោយគណៈអចិន្ត្រៃយ៍។ ចំណងជើងនៃសេចក្ដីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ បានបង្ហាញច្បាស់លាស់ថា ត្រូវបានចេញដោយគណៈមជ្ឈិម និងការដាក់ឱ្យស្ថិតក្រោមសិទ្ធិអំណាចប្រសិទ្ធិភាពរបស់គណៈអចិន្ត្រៃយ៍ពុំបានរារាំងការតែងតាំងដំបូងដោយគណៈមជ្ឈិមឡើយ[4719]។

1690.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន “ស្ថិតក្នុងក្រុមតូចមួយនៃសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលទទួលបានការរាយការណ៍ច្បាស់លាស់ ដោយសារសមាជិកភាពរបស់គាត់ជាគណៈមជ្ឈិម”[4720]។ នៅក្នុងការពិភាក្សាអំពីការដឹងរបស់គាត់នូវភាវនីយភាពខ្ពស់ដែលថា បទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តឡើងនោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការដឹងរបស់គាត់អំពី*ការអនុវត្តន៍*របស់បក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា “នៅចន្លោះពេលនៃការបញ្ចូល ខៀវ សំផន ទៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ក្នុងឆ្នាំ ១៩៦៩ និងជ័យជម្នះរបស់បក្សនៅថ្ងៃទី ១៧ ខែ មេសា

[4714] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៨។

[4715] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៨។

[4716] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៩។

[4717] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៣។

[4718] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៨។

[4719] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩២២។

[4720] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤, ៦២៤។

ឆ្នាំ ១៩៧៥ គោលនយោបាយនានាត្រូវបានរៀបចំឡើង ដាក់ឱ្យសាកល្បង និងអនុវត្តក្នុងតំបន់'រំដោះ' ហើយលំនាំនៃការអនុវត្តន៍ទាំងនេះបានលេចចេញជារូបរាងដែលបង្ហាញឱ្យឃើញថា ខៀវ សំផន ជាសមាជិកសំខាន់មួយរូបនៅក្នុងជួរថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា"[4721]។ សម្រាប់ការយល់ឃើញ អង្គជំនុំជម្រះសាលាដំបូងបានសំអាង*ក្នុងចំណោមនោះ*ទៅលើការដឹងរបស់ ខៀវ សំផន អំពីសេចក្តីសម្រេចទី ១[4722] និងសេចក្តីសម្រេចទី ២[4723]។

1691.អង្គជំនុំជម្រះសាលាដំបូងពុំបានយោងដោយផ្ទាល់ទៅលើសេចក្តីសម្រេចទី ៣ នៅក្នុងការពិភាក្សារបស់ខ្លួនអំពីការដឹងរបស់ ខៀវ សំផន ឬការរួមចំណែកក្នុងឧក្រិដ្ឋកម្ម។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចទី ៣ ត្រូវបានពិភាក្សាក្នុងបរិបទនៃអត្ថិភាពគោលនយោបាយជម្លៀសទីក្រុង ដែលភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការបង្កើតសហករណ៍ និងការដ្ឋានធ្វើការ[4724] ដែល ខៀវ សំផន បានដឹង។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដឹងរបស់ ខៀវ សំផន អំពីសេចក្តីសម្រេចទី ៣ បង្កើតបានជាផ្នែកមួយនៃមូលដ្ឋានសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។

1692.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា វត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំគណៈមជ្ឈិម ពុំអាចកំណត់បានអំពីការដឹងរបស់គាត់នូវសេចក្តីសម្រេចដែលបានធ្វើឡើងនៅទីនោះ។ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់បង្ហាញឱ្យហួសវិមតិសង្ស័យថា កិច្ចប្រជុំមួយបានកើតឡើង ឬថា ខៀវ សំផន មានវត្តមាននោះទេ។ អង្គជំនុំជម្រះបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីផែនការខែ មិថុនា ឆ្នាំ ១៩៧៤ ក្នុងការវាយយកទីក្រុងភ្នំពេញ(សេចក្តីសម្រេចទី ៣) បើទោះបីជាបានសន្និដ្ឋានផ្អែកលើភស្តុតាងថា គាត់ពុំមានវត្តមាននៅពេលសេចក្តីសម្រេចនេះបានបង្កើតឡើង[4725]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការ

---

[4721] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៧។

[4722] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៧ (ជើងទំព័រ ១៣៧៣១) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៩។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខៀវ សំផន គឺជា"ផ្នែកមួយ"នៃគណៈមជ្ឈិម បញ្ជាក់ថា គាត់បានដឹង។

[4723] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៧ (ជើងទំព័រ ១៣៧៣៣) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣៧, ៣៩៤០។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសេចក្តីសម្រេចនេះក្នុងការបង្ហាញអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងសត្រូវ។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២, ៣៩៤០។

[4724] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០, ៣៨៨០។

[4725] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ៨.១.៣.១ 'តួនាទី និង មុខនាទី - ខៀវ សំផន៖ ព័ត៌មានអំពីប្រវត្តិសាវតារ និងអំឡុងពេលមុនកម្ពុជាប្រជាធិបតេយ្យ៖ ឆ្នាំ ១៩៧០ ដល់ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥៖ វត្តមាននៅក្នុងកិច្ច

កំពូលសន្និដ្ឋានថា មានការសន្និតសមហេតុផលថា ខៀវ សំផន បានដឹងអំពីសេចក្ដីសម្រេចនោះដែលបានធ្វើឡើងដោយគណៈមជ្ឈិមដោយសារហេតុផលធម្មតានៃសមាជិកភាពរបស់គាត់ ដោយពុំគិតថាតើ សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើងមុនពេលដែលគាត់ចូលជាសមាជិកពេញសិទ្ធិ និងត្រូវបានផ្ដល់សិទ្ធិបោះឆ្នោត ឬមានវត្តមានរបស់គាត់ ដែរ ឬយ៉ាងណានោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ ត្រូវបដិសេធចោល។

1693.ដោយសារ ខៀវ សំផន ពុំត្រូវដាក់ឱ្យទទួលខុសត្រូវលើការរួមចំណែករបស់គាត់ក្នុងឧក្រិដ្ឋកម្ម*តាមរយៈ*ការចូលរួមក្នុងការធ្វើសេចក្ដីសម្រេចទី ១ ដល់ ៣ ក្នុងឋានៈជាសមាជិកនៃគណៈមជ្ឈិមដែលបានបានកើតឡើងមុនការបង្កើតកម្ពុជាប្រជាធិបតេយ្យ និងយុត្តាធិការពេលវេលានៃការបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ផងដែរថា ការដឹងរបស់ ខៀវ សំផន នូវសេចក្ដីសម្រេចនោះ គឺអាស្រ័យលើបញ្ហាថាតើ សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើងដោយគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ ដែរ ឬយ៉ាងណានោះទេ។ ផ្ទុយទៅវិញ បញ្ហាថាតើ ជាការសមហេតុផល ដែរ ឬយ៉ាងណា ដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីខ្លឹមសារនៃសេចក្ដីសម្រេចនោះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើការពិចារណាទាំងនេះ ដោយសារអង្គជំនុំជម្រះនឹងត្រូវពិចារណាលើសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចទី ១, ២ និង ៣។

1694.ទាក់ទងទៅនឹងសេចក្ដីសម្រេចទី ១ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគប្បីជ្រើសយកភស្តុតាងរបស់ នួន ជា ជាជាងរបស់ Philip SHORT ក្នុងការយល់ឃើញថា សេចក្ដីសម្រេចត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ ជាជាងគណៈមជ្ឈិម[4726]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុស និងបង្ហាញភស្តុតាងបន្ថែមដែលថា សេចក្ដីសម្រេចត្រូវបានធ្វើឡើងដោយ“បក្ស

---

ប្រជុំគណៈមជ្ឈិមខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥ នៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា’ កថាខណ្ឌ ៥៨៣-៥៨៨។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០ (ជើងទំព័រ ៥៤៨)។ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ខៀវ សំផន បានចូលរួមកិច្ចប្រជុំណាមួយក្នុងខែ ឧសភា ឆ្នាំ ១៩៧២ (សេចក្ដីសម្រេចទី ១)។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៧។

[4726] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៤។

ទាំងមូល"[4727]។ ក្នុងគ្រប់ករណី សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ជាការពុំសមហេតុផលក្នុងការយល់ឃើញថា គាត់បានដឹងអំពីសេចក្តីសម្រេចដែល"គេដឹងឮ"ទាំងនេះ[4728]។

1695.ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើទស្សនាវដ្តីទង់បដិវត្តក្នុងការគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា គណៈមជ្ឈិមបានធ្វើសេចក្តីសម្រេចទី ២ ដោយសារទង់បដិវត្តនេះពុំបានសំដៅទៅលើគណៈមជ្ឈិម ប៉ុន្តែទៅលើ"បក្ស"[4729]។ ចំពោះសេចក្តីសម្រេចទី ៣ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់មូលហេតុដែលខ្លួនពុំទទួលយកសក្ខីកម្មរបស់ នួន ជា ដែលថា ការវាយលុកចុងក្រោយ និងការជម្លៀសទីក្រុងភ្នំពេញ ត្រូវបានពិភាក្សាក្នុងសម័យប្រជុំវិសាមញ្ញរបស់គណៈអចិន្ត្រៃយ៍ និងផ្ទុយទៅវិញបានសំអាងទៅលើទង់បដិវត្តដែលរាយការណ៍អំពីកិច្ចប្រជុំគណៈមជ្ឈិម[4730]។

1696.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសន្មតកិច្ចប្រជុំគណៈមជ្ឈិមខែ មិថុនា ឆ្នាំ ១៩៧៤ ដែលមានសេចក្តីសម្រេចទី ២ និង ៣ ត្រូវបានធ្វើឡើង ហើយ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសក្នុងការយល់ឃើញនេះ[4731]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងត្រឹមត្រូវលើភស្តុតាងជារួម រួមទាំងភស្តុតាងរបស់ នួន ជា ដែលពុំស៊ីសង្វាក់គ្នាលើបញ្ហាថាតើជាកិច្ចប្រជុំរបស់គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ ឬសមាជិកទាំងពីរគណៈ ដែរ ឬយ៉ាងណា[4732]។

1697.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងច្បាស់លាស់លើភស្តុតាងរបស់ នួន ជា នៅក្នុងការពិភាក្សារបស់ខ្លួនលើសេចក្តីសម្រេចទាំងពីរ ១ និង ៣[4733] នៅមុនការជ្រើសរើសពុំសំអាងទៅលើក្នុងលក្ខណៈដែលត្រូវបានជំទាស់ដោយ ខៀវ សំផន។ បន្ថែមលើនេះ ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចទី ១, ២ និង ៣ ខៀវ សំផន ត្រឹមតែបានធ្វើការបកស្រាយមួយផ្សេងអំពីភស្តុតាងដោយគ្មាន

[4727] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៥។

[4728] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៥។

[4729] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០២ (ជើងទំព័រ ១២០៤)។

[4730] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៦។

[4731] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៦។

[4732] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៦ (ជើងទំព័រ ៣០៩៨)។

[4733] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៩ (ជើងទំព័រ ៥៧០) (សេចក្តីសម្រេចទី ១)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០ (ជើងទំព័រ ៥៤៧)(សេចក្តីសម្រេចទី ៣)។

ការបង្ហាញថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកលើមូលដ្ឋាននេះ។

1698.ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា មានភស្តុតាងគ្រប់គ្រាន់ក្រៅពីសមាជិកភាពរបស់គាត់ជាគណៈមជ្ឈិម បានគាំទ្រសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានដឹងអំពីសេចក្ដីសម្រេចទាំងអស់នោះ។ ចំពោះសេចក្ដីសម្រេចទី ១ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើតួនាទីចម្បងរបស់ ខៀវ សំផន ក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងបក្សកុម្មុយនីស្ដកម្ពុជា លើតួនាទីក្នុងការរៀបចំសម្ភារៈឃោសនារបស់រណសិរ្សរួបរួមជាតិកម្ពុជា ក្នុងការបើកវគ្គបណ្ដុះបណ្ដាលនយោបាយ និងចេញសេចក្ដីប្រកាសព័ត៌មាន និងការអំពាវនាវតាមវិទ្យុ ការចុះទស្សនកិច្ចតាមតំបន់"រំដោះ"របស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងឆ្នាំ ១៩៧២ និង ១៩៧៣ និងតួនាទីការទូតរបស់គាត់ក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា[4734]។ ការដឹងអំពីគោលនយោបាយសំខាន់ៗរបស់បក្សកុម្មុយនីស្ដកម្ពុជា មានលក្ខណៈចាំបាច់បំផុតដែលខានពុំបានសម្រាប់ការអនុវត្តន៍មុខនាទីទាំងអស់នោះ។ ទាក់ទងទៅនឹងសេចក្ដីសម្រេចទី ៣ ខៀវ សំផន បានប្រកាសតាមវិទ្យុក្នុងខែ ធ្នូ ឆ្នាំ ១៩៧៤ មួយថ្ងៃមុនពេលការវាយលុកដោយកងទ័ពប្រជាជនរំដោះជាតិកម្ពុជា[4735] ដែលបានបន្តឥតស្រាកស្រាន្តពេញមួយអំឡុងពេលនៃការឈ្លានពាននោះ[4736] និងបានជួបជាមួយមេដឹកនាំជាន់ខ្ពស់នានាដើម្បីពិភាក្សាការជម្លៀសទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥[4737]។ ខៀវ សំផន បានផ្ដល់យុត្តិកម្មជាក់លាក់សម្រាប់ការអនុវត្តន៍សហករណ៍នៅមុនឆ្នាំ ១៩៧៥ (សេចក្ដីសម្រេចទី ១)[4738] និងការកំណត់ពេល

---

[4734] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧៦-៥៨០។

[4735] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣១។

[4736] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣១-២៣២។

[4737] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៨៤-៥៨៥។

[4738] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៤០-២៤១។

នៃការវាយលុកទីក្រុងភ្នំពេញ(សេចក្តីសម្រេចទី ៣)[4739]។ ជាចុងក្រោយ សេចក្តីសម្រេចទី ១[4740] ទី ២[4741] និងទី ៣[4742] ត្រូវបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត ដែល ខៀវ សំផន ជាចាំបាច់ត្រូវតែបានដឹងអំពីខ្លឹមសារនោះ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានយល់ដឹងនូវសេចក្តីសម្រេចទាំងបីនោះ ដោយពុំចាំបាច់ពិចារណាថាតើ សេចក្តីសម្រេចនោះត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ ឬមជ្ឈិមនោះឡើយ។

1699.ជាចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងការសន្មតថាជារបស់គណៈមជ្ឈិមនូវ"សេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ របស់គណៈមជ្ឈិមពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ" (សេចក្តីសម្រេចទី ៤)[4743]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសេចក្តីសម្រេចទី ៤ ក្នុងការយល់ឃើញថា (១) ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[4744] និង (២) ជាសមាជិកគណៈមជ្ឈិម ខៀវ សំផន បានរួមចំណែកក្នុងគោលបំណងរួមតាមរយៈការយល់ព្រមជាមួយនឹងខ្លឹមសារ ជាពិសេស"សេចក្តីណែនាំឱ្យផ្តល់អំណាចរបស់រដ្ឋទៅឱ្យកម្មករកសិករ និងគំនិតផ្តួចផ្តើមជម្រុញស្រុកឱ្យសម្រេចគោលដៅទិន្នផល'ស្រូវបីតោនមួយហិកតា'"[4745] និងផ្តល់"សិទ្ធិកម្ទេច"ទៅថ្នាក់ក្រោមនៃបក្សកុម្មុយនីស្តកម្ពុជា[4746]។

---

[4739] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣០។

[4740] ទស្សនាវដ្តីទង់បដិវត្ត ខែ ធ្នូ ឆ្នាំ ១៩៧៥ ដល់ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារលេខ E169/4/1.1.2 ERN (EN) 00865708-00865709, ទស្សនាវដ្តីទង់បដិវត្ត ខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/10 ERN 00234507, 0063069។ *សូមមើលផងដែរ* ទស្សនាវដ្តីទង់បដិវត្ត ចុះខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/166 ERN 00083228, 00063194។ *ទិវាខួបឆ្នាំទីបី នៃការចាត់តាំងសហករណ៍កសិករ* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ឯកសារលេខ E3/50 ERN 00442209។

[4741] ទស្សនាវដ្តីទង់បដិវត្ត ខែមីនា ឆ្នាំ១៩៧៦ ទំព័រ ៧១-៧៦ ឯកសារលេខ E3/166 ទំព័រ ៧១-៧៦ ERN 00063228-00063231។

[4742] ទស្សនាវដ្តីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ឯកសារលេខ E3/5 ទំព័រ ៤៨ ERN 00063336។

[4743] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៣, ១៧១៧។ សេចក្តីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/12 ERN 00003140-00003141។

[4744] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៦ (ជើងទំព័រ ១៨៦៨)។

[4745] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១២៦, ៣៨៩៩។

[4746] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៧១, ៣៩៥៥។

1700.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការពិចារណាថា គណៈមជ្ឈិម“បាន”តែងតាំងរូបគាត់[4747]។ គាត់បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងភស្តុតាងបានគាំទ្រយ៉ាងច្រើនលើសេចក្តីសន្និដ្ឋានថា “ផ្ទុយទៅវិញ សេចក្តីសម្រេចតែងតាំងត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍”[4748]។ បន្ថែមលើនេះ ខៀវ សំផន បានចង្អុលបង្ហាញថា ឯកសារនេះពុំបានលើកឡើងអំពីអ្នកចូលរួម ពុំមានសាក្សីអះអាងថា បានឃើញក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ និងពុំមានភស្តុតាងបន្ថែមគាំទ្រកិច្ចប្រជុំគណៈមជ្ឈិមនោះឡើយ[4749]។ ចុងក្រោយ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់មូលហេតុដែលខ្លួនពុំពិចារណាលើការអះអាងរបស់ Philip SHORT ឬ Craig ETCHESON ដែលបានសន្មតសេចក្តីសម្រេចទី ៤ ថាជារបស់គណៈអចិន្ត្រៃយ៍ក្នុងសំណុំរឿង ០០២/០១ ឬ ០០២/០២ ដូចដែលអង្គជំនុំជម្រះបានធ្វើក្នុងសំណុំរឿង ០០១[4750]។

1701.សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុស ដោយសារចំណងជើងនៃសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ បង្ហាញថា ត្រូវបានចេញដោយគណៈមជ្ឈិម និង“ការដាក់ឱ្យស្ថិតក្រោមសិទ្ធិអំណាចដ៏មានប្រសិទ្ធភាពរបស់គណៈអចិន្ត្រៃយ៍បន្ទាប់ពីបង្កើតប្រធានគណៈប្រធានរដ្ឋ និងរដ្ឋាភិបាលនោះ ពុំអាចច្រានចោលនូវការតែងតាំងដំបូងរបស់គណៈមជ្ឈិមបានឡើយ”[4751]។ បន្ថែមលើនេះ ខៀវ សំផន បានលើកច្រំដែលនូវអំណះអំណាងដែលត្រូវបដិសេធចោលដោយអង្គជំនុំជម្រះតុលាការ

---

4747 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៣។

4748 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៦។ កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍៖ រណសិរ្ស ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/197 ទំព័រ ១-២, ៤-៥, ERN 00000747-00000748 (ប៉ុល ពត បានសម្រេចបន្ទាប់បំណងរបស់សម្តេចនរោត្តម សីហនុក្នុងការលាឈប់ដោយមានការយល់ព្រមពីគណៈអចិន្ត្រៃយ៍)។ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ERN (EN) 00909381-00909382 (កិច្ចប្រជុំគណៈមជ្ឈិមកម្រកើតមានណាស់ និងជាការជួបជុំដើម្បីឱ្យដឹងអំពីសេចក្តីសម្រេចដែលត្រូវបានធ្វើឡើងរួចហើយដោយគណៈអចិន្ត្រៃយ៍)។

4749 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៧។

4750 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧១៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ១០៣។

4751 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩២៣។

កំពូលក្នុងសំណុំរឿង ០០២/០១[4752] និងបានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១[4753]។

1702.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានយ៉ាងស៊ីសង្វាក់គ្នានូវសេចក្តីសម្រេចទី ៤ ថា ជារបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[4754]។ ខៀវ សំផន បានលើកច្រំដែលនូវអំណះអំណាងដែលបានលើកឡើងរួចហើយក្នុងសំណុំរឿង ០០២/០១ រួមទាំងការពាក់ព័ន្ធទៅនឹងភស្តុតាងរបស់ Philip SHORT និង Craig ETCHESON[4755]ដែលត្រូវបានពិចារណា និងបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងបណ្តឹងសាទុក្ខនោះ[4756]។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានហេតុផលសមស្របត្រូវលើកបញ្ហានេះសាឡើងវិញឡើយ។

1703.បន្ថែមលើនេះ ខៀវ សំផន ពុំបានបង្ហាញថា ជាការពុំសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា គាត់ត្រូវបានតែងតាំងតួនាទីជាប្រធានគណៈប្រធានរដ្ឋតាមរយៈសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ សេចក្តីសម្រេចផ្លូវការស្តីពីការតែងតាំងដែលចេញដោយគណៈមជ្ឈិមពុំបានរារាំងសេចក្តីសម្រេចដែលជាក់ស្តែងត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ និងនៅគ្រប់កាលៈទេសៈពុំអាចបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈអចិន្ត្រៃយ៍គឺជាកន្លែងប្រមូលផ្តុំសិទ្ធិអំណាចប្រតិបត្តិ។ ខៀវ សំផន ពុំបានជំទាស់ទៅនឹងការតែងតាំងតួនាទីនោះ និងខកខានផងដែរក្នុងការបង្ហាញកំហុសដែលការតែងតាំងរូបគាត់នោះ បានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដូចម្តេចឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់លើចំណុចនេះត្រូវបដិសេធចោល។

### iv. វត្តមានក្នុងសមាជ

[4752] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៥ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៤៩៧-៥០១ និងសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៤៥-១០៤៧។

[4753] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៥។

[4754] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ១០២ ("សេចក្តីណែនាំមួយក្នុងចំណោមសេចក្តីណែនាំដែលសំខាន់ និងមានឥទ្ធិពលបំផុតដល់សមាជិកពេញសិទ្ធិនៃបក្សដោយគណៈមជ្ឈិម គឺជា"សេចក្តីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន" ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦")។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ២៣៥, ២៣៧, ៣១៩, ៣៨១, ៧៦០, ៧៦៤។

[4755] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៤៩៧-៤៩៨, ៥០០-៥០១។

[4756] សាលដីកានៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៤៥-១០៤៧។

1704.អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ សៅ សារុន និង ឆោម សែ[4757] ក្នុងការយល់ឃើញថា សមាជទាំងពីរលើកឆ្នាំ ១៩៧៦ និង ១៩៧៨ “ត្រូវបានចូលរួមដោយប្រជាជនរាប់រយនាក់ រួមទាំង [...] សមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា” និងបានសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងនាមជាសមាជិកនោះ[4758]។ សមាជនេះបាន“អនុម័តគោលនយោបាយ [...] ពាក់ព័ន្ធទៅនឹងមាគ៌ានយោបាយទូទៅរួមជាមួយនឹងគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ”[4759]។ នៅសមាជបក្សទីបួន“គោលនយោបាយ”មាននៅក្នុងលក្ខន្តិកៈឆ្នាំ ១៩៧៦ របស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានអនុម័តដោយសមាជនេះ[4760]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន “បានចូលរួមសមាជបក្សលើកទីប្រាំ ដែលពេលនោះ វន វេត ត្រូវបានចាប់ខ្លួន និងក្រោយមកបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដើម្បីសួរចម្លើយ និងកម្ទេច”[4761]។

1705.ខៀវ សំផន បានជំទាស់ថា ពុំមានភស្តុតាងបង្ហាញថា គាត់មានវត្តមាននៅក្នុងសមាជទាំងនេះដែលនេះ អាចជាហេតុដែលធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងដាក់គាត់ឱ្យទទួលខុសត្រូវសម្រាប់ការចូលរួមនោះ[4762]។

1706. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានចូលរួមសមាជទីបួន និងទីប្រាំ ពុំសមហេតុផល[4763]។

1707.ទាក់ទងទៅនឹងសមាជទីបួនក្នុងឆ្នាំ ១៩៧៦ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងណាមួយក្នុងការគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា គាត់បានចូលរួមនោះ[4764]។ ជាពិសេស ឆោម សែ “ពុំបាននិយាយអំពីសមាជ ប៉ុន្តែនិយាយអំពីមីទ្ទីងយោធាក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥”[4765]

---

[4757] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥ (ជើងទំព័រ ៩៥៨) យោងទៅលើប្រតិចារឹកចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៦-២០។ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៤៦-៤៧, ៥៦-៥៨។

[4758] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៥។

[4759] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩។

[4760] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៨, ៣៧៦៥។

[4761] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៩។

[4762] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៣។

[4763] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧។

[4764] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៤។

[4765] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៤។

។ សហព្រះរាជអាជ្ញាពុំបានផ្តល់យោបល់អំពីភស្តុតាងរបស់ ឆោម ស៊ែ ប៉ុន្តែបានលើកឡើងថា ជាការសមហេតុផលក្នុងការសន្និដ្ឋានថា ខៀវ សំផន មានវត្តមាននៅសមាជបក្សលើកទីបួន នៅពេលដែលគាត់ត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម[4766]។

1708.ឆោម ស៊ែ បានផ្តល់សក្ខីកម្មថា គាត់បានចូលរួមសមាជនៅពហុកីឡាដ្ឋានអូឡាំពិកប្រហែលក្នុងខែកញ្ញា ឆ្នាំ ១៩៧៥ អំឡុងពេលដែលកងពលលេខ ៨០១ ត្រូវបានបង្កើតឡើង និង"មានសេចក្តីប្រកាសមួយត្រូវបានធ្វើឡើងជាសាធារណៈពាក់ព័ន្ធទៅនឹងថ្នាក់ដឹកនាំខ្មែរក្រហម និង [...] ការប្រារព្ធពិធីរំឭកខួបនៃការបង្កើតកងទ័ព"[4767]។ មីទ្ទីងនេះត្រូវបានចូលរួមដោយមេដឹកនាំជាន់ខ្ពស់ជាច្រើនរួមទាំង ខៀវ សំផន មេបញ្ជាការកងពល និងសមាជិកជាង ១.០០០ នាក់ មកពីកងពលយោធាទាំងអស់ចាប់ពីកងអនុសេនាធំឡើង[4768]។ ក្រៅពីវត្តមានរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ការពិពណ៌នារបស់ ឆោម ស៊ែ អំពីព្រឹត្តិការណ៍ដែលគាត់បានចូលរួមពុំបានអះអាងថា មីទ្ទីងនេះគឺជាសមាជលើកទីបួនដែលបន្ថែមលើនេះពុំមានមូលហេតុត្រូវរំពឹងទុកថា សាក្សីរូបនេះបានចូលរួមឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថាទំនងជាថា សាក្សីរូបនេះបានចូលរួមក្នុងពិធីប្រារព្ធខួបបង្កើតកងទ័ពបដិវត្តកម្ពុជាក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ [4769] ដែលសាក្សីរូបនេះបានទទួលស្គាល់ដោយខ្លួន[4770] ឬការប្រារព្ធមីទ្ទីងខែ កញ្ញា ឆ្នាំ ១៩៧៥ ស្វាគមន៍ការ

[4766] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧, ១០២។

[4767] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម ស៊ែ) ឯកសារលេខ E1/159.1 ទំព័រ ៤២-៤៣, ៤៦-៤៧, ៥៦-៥៨។

[4768] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម ស៊ែ) ឯកសារលេខ E1/159.1 ទំព័រ ៥៦-៥៨។

[4769] ទស្សនាវដ្តីទង់បដិវត្ត ចុះខែសីហា ឆ្នាំ១៩៧៥ ឯកសារលេខ E3/5 ទំព័រ ២៤-២៥ ERN 00063324 ("នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ នៅក្នុងពិធីរបស់បក្សកុម្មុយនីស្តកម្ពុជានៃមជ្ឈមណ្ឌលកម្ពុជាដើម្បីបង្កើតកងទ័ពបដិវត្ត សមមិត្តប្រធាននៃគណៈយោធាជាន់ខ្ពស់របស់បក្ស បានកោះប្រជុំនយោបាយសំខាន់របស់បក្សកុម្មុយនីស្តនៃមជ្ឈមណ្ឌលកម្ពុជាប្រមាណជា ៣.០០០ នាក់នៃតំណាងកងទ័ពបដិវត្ត")។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤ ("ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ ប៉ុល ពត បានប្រកាសការបង្កើតកងទ័ពបដិវត្តកម្ពុជាថ្មីមួយ ដោយដាក់កងពលធំភូមិភាគមួយចំនួនក្រោមការគ្រប់គ្រងគណៈមជ្ឈិម")។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ២៤០ ("នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ ប៉ុល ពត បានប្រកាសការបង្កើតកងទ័ពបដិវត្តកម្ពុជាថ្មីមួយ ដោយដាក់កងពលតូចភូមិភាគមួយចំនួនក្រោមការគ្រប់គ្រងគណៈមជ្ឈិមជាពិសេស ក្រោមការបញ្ជារបស់អគ្គសេនាធិការដឹកនាំដោយ សុន សេន។ កងដែលត្រូវបានបង្កើតឡើងក្រោមអគ្គសេនាធិការ ("កងពលធំមជ្ឈិម") រួមមាន [...] កងពលធំលេខ ៨០១")។

[4770] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ (ឆោម ស៊ែ) ឯកសារលេខ E1/159.1 ទំព័រ ៥៩-៦២ (ត្រូវបានសួរសំណួរថាតើមហាសន្និបាត ដែលគាត់និយាយនោះ ជាកិច្ចប្រជុំផ្សេងពីកិច្ចប្រជុំថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ សាក្សីឆ្លើយថា: "ខ្ញុំមិនបានចាំកាលបរិច្ឆេទពិតប្រាកដ ពីព្រោះខ្ញុំមិនបានកត់សម្គាល់ ហើយខ្ញុំគ្មានឯកសារបញ្ជាក់ឡើយ")។

យាងត្រឡប់របស់សម្តេចនរោត្តមសីហនុ[4771]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកសារណារបស់ ខៀវ សំផន និងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសក្ខីកម្មរបស់ ឆោម សែ ក្នុងបរិបទនេះ។

1709.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចមានកំហុសក្នុងការបកស្រាយភស្តុតាងរបស់ ឆោម សែ ក៏ដោយ ក៏ការពិតគឺថា មានសមាជបក្សមួយបានរៀបចំឡើងក្នុងដើមឆ្នាំ ១៩៧៦ ដែរ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើសញ្ញាណដែលថា ខៀវ សំផន ពុំបានចូលរួមសមាជបក្សលើកទីបួន ដែលជាលើកដំបូងក្នុងរយៈពេលប្រាំឆ្នាំដែលគាត់ត្រូវបានដំឡើងឋានៈទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ដើម្បីពន្លាតការជឿទុកចិត្ត។ ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា គាត់បានចូលរួមដោយផ្អែកលើមូលដ្ឋាននៃការតែងតាំងរូបគាត់ជាគណៈមជ្ឈិម និងសារៈសំខាន់នៃព្រឹត្តិការណ៍ និងបរិយាកាសភ័យខ្លាច និងការសង្ស័យដែលបានជ្រួតជ្រាបចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា។

1710.ខៀវ សំផន ក៏បានលើកការជំទាស់ជាច្រើនទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានចូលរួមសមាជបក្សលើកទីប្រាំ។ ដំបូង គាត់បានលើកឡើងថា ភស្តុតាងដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សមាជនេះបានកើតឡើងនៅថ្ងៃទី ១ និង ២ ខែវិច្ឆិកា ១៩៧៨ ពុំបានលើកឡើងអំពីការចូលរួមរបស់គាត់[4772]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា កំណត់ហេតុកិច្ចប្រជុំសមាជបក្សលើកទីប្រាំបញ្ជាក់បន្ថែមថា ខៀវ សំផន មានវត្តមាន ដោយសារគាត់ត្រូវបានតែងតាំងជាសមាជិកនៃគណៈកម្មាធិការសេដ្ឋកិច្ចនៃគណៈមជ្ឈិម[4773]។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ឈ្មោះ"ហំ" នៅក្នុងកំណត់ហេតុសរសេរដៃនោះ គឺចង់សំដៅទៅលើ"ហែម" ដោយសារនេះត្រូវបានបញ្ជាក់បន្ថែមដោយកម្មវត្ថុនៃការតែងតាំងក្នុងក្រសួងសេដ្ឋកិច្ច និងការពិពណ៌នាអំពីបុគ្គលដែលចោទជាបញ្ហា

[4771] ធ្វើនៅនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៧៥ នៅពហុកីឡាដ្ឋានអូឡាំពិក មីទ្ទីនេះបានចូលរួមដោយមេដឹកនាំជាន់ខ្ពស់ជាច្រើននាក់ព្រមទាំងសមាជិកយោធា។ *សូមមើល* មីទ្ទីងស្វាគមន៍ការយាងត្រឡប់របស់សម្តេចនរោត្តមសីហនុ៖ ហ៊ូ នឹម បើកពិធីស្វាគមន៍ (ក្នុងកម្រងសារព័ត៌មាន FBIS) ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/271 ERN (EN) 00167451។ ការប្រារព្ធពិធីស្វាគមន៍ការយាងត្រឡប់របស់សម្តេចនរោត្តមសីហនុ៖ តំណាងកងទ័ពរំដោះប្រជាជនកម្ពុជា (កម្រងសារព័ត៌មាន FBIS) ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/271 ERN (EN) 00167455។

[4772] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៥។

[4773] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧។

នេះ"ទទួលបន្ទុកមន្ទីរ ៨៧០"។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ឯកសារនេះបានបញ្ជាក់ថា ខៀវ សំផន បានចូលរួម។

1711.ទីពីរ ខៀវ សំផន បានអះអាងថា ភស្តុតាងស្តីអំពីសមាជបក្សលើកទីប្រាំបានបញ្ជាក់ថា "គោលបំណងចម្បងតែមួយគត់នៃកិច្ចប្រជុំរយៈពេលខ្លីខុសពីធម្មតានេះ គឺដើម្បីជ្រើសរើសក្រុមគ្រប់គ្រងថ្មីមួយ"[4774]។ ផ្ទុយទៅវិញ សៅ សារុន បានចូលរួមមីទ្ទីងមួយរយៈពេលដប់ថ្ងៃក្នុងឆ្នាំ ១៩៧៨ ដើម្បីពិភាក្សាការធានាបានថា ប្រជាជនមានស្បៀង និងទីជម្រកគ្រប់គ្រាន់ និងបើកទីផ្សារឡើងវិញ[4775]។ ដូចនេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញថា សៅ សារុន បានពិពណ៌នាអំពីសមាជបក្សលើកទីប្រាំ និងថា ពុំគប្បីពិចារណាលើសក្ខីកម្មរបស់ សៅ សារុន ដែលថា គាត់បានចូលរួមសមាជនោះ[4776]។

1712.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការពិចារណាលើភស្តុតាងជារួមស្តីពីវត្តមានរបស់គាត់នៅសមាជបក្សលើកទីប្រាំ[4777]។ សៅ សារុន ដែលតាមរយៈសក្ខីកម្មរបស់គាត់"អាចធ្វើការសន្និដ្ឋានសមហេតុផលថា [ខៀវ សំផន] បានចូលរួមនៅសមាជបក្សឆ្នាំ ១៩៧៨"[4778] និងបានអះអាងថា គាត់បានឃើញ ខៀវ សំផន "ក្នុងចំណោមមេដឹកនាំបក្សកុម្មុយនីស្តដទៃទៀតនៅសមាជបក្សដែលរួបរួមគ្នាឡើងវិញពីគ្រប់តំបន់ ភូមិភាគ និង[គណៈមជ្ឈិម] ដែលគាត់ត្រូវបានតែងតាំងជាលេខាតំបន់ ១០៥"[4779]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ឌុច បានបញ្ជាក់ថា "គោលបំណងចម្បងនៃសមាជលើកទីប្រាំ គឺដើម្បីតែងតាំងផ្លូវការនូវលេខាភូមិភាគថ្មី (និងតំបន់ស្វយ័ត) ជំនួសអ្នកដែលត្រូវបានបោសសម្អាត"[4780]។

1713.អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ទិដ្ឋភាពសំខាន់ៗមួយចំនួននៃការអះអាងរបស់ សៅ សារុន បានបញ្ជាក់ថា គាត់បានចូលរួមសមាជបក្សលើកទីប្រាំ រួមទាំងការពិពណ៌នាព្រឹត្តិការណ៍ថាជា"សមាជដ៏អស្ចា

---

[4774] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៥។

[4775] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៥ យោងទៅលើប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១២-២០។

[4776] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៥។

[4777] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧។

[4778] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០២ និងជើងទំព័រ ៤១០។

[4779] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧។

[4780] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៧ យោងទៅលើប្រតិចារឹកក្នុងសំណុំរឿង ០០១ (កាំង ហ្គេកអ៊ាវ) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ E3/55 ទំព័រ ៤៥-៤៦ ERN 00330475-00330476។

វ្ប"[4781] និង"មហាសន្និបាត"[4782] និងការប្រមូលផ្តុំដែលត្រូវបានចូលរួមដោយតំណាងបក្សកុម្មុយនីស្តកម្ពុជាទូទាំងកម្ពុជាប្រជាធិបតេយ្យ[4783] និងសមាជិកគណៈមជ្ឈិម[4784]។ បន្ថែមលើនេះ សៅ សារុន បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានតែងតាំងជាលេខាតំបន់ ១០៥ នៅពេលនោះ[4785]។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កំណត់ហេតុកិច្ចប្រជុំចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ បានកត់ត្រាថា "សារុន" ត្រូវបានតែងតាំងឱ្យទទួលបន្ទុកខេត្តមណ្ឌលគីរី។ នេះស្របជាមួយនឹងឈ្មោះនាមខ្លួនដែលត្រូវបានប្រើប្រាស់ក្នុងកំណត់ហេតុនោះ និងផ្តល់ការបញ្ជាក់បន្ថែមអំពីវត្តមានរបស់ សៅ សារុន[4786]។ ប្រហាក់ប្រហែលគ្នានេះដែរ ផ្អែកតាមភស្តុតាងរបស់ Philip SHORT និង កាំង ហ្គេចអ៊ាវ *ហៅ* ឌុច បានបង្ហាញថា ការតែងតាំងលេខាភូមិភាគថ្មី គឺជាគោលបំណងចម្បងនៃសមាជនោះ[4787]។

1714. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា មានភាពផ្ទុយគ្នារវាងការរៀបរាប់អំពីសមាជបក្សលើកទីប្រាំដែលបានផ្តល់ដោយ Philip SHORT និងព្រឹត្តិការណ៍ដែលបានរៀបរាប់ដោយ សៅ សារុន។ Philip SHORT បានពិពណ៌នាកិច្ចប្រជុំនោះថា "រយៈពេលខ្លីខុសពីធម្មតា"ដែលបានធ្វើឡើងនៅថ្ងៃទី ០១ និង ០២

---

[4781] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ២០។

[4782] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៣-១៤។ *សូមមើលផងដែរ*ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៥-១៦ ("សមាជទូទាំងប្រទេស")។

[4783] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៣-១៤ ("តំណាងគ្រប់ខេត្ត") ទំព័រ ១៨ ("តំណាងមកពីគ្រប់ខេត្តទូទាំងប្រទេស") ទំព័រ ១៦-១៧ (តំណាង"មកពីគ្រប់តំបំ និងគ្រប់កងពលធំ") ទំព័រ ១៨ ("មកពីទូទាំងប្រទេស រួមទាំងទាហាន និងស៊ីវិលដែលមានឋានន្តរសក្តិចាប់ពីប្រធានកងវរសេនាតូច និងមេស្រុក ឃុំ ឬខ្ពស់ជាងនេះ") ទំព័រ ២០ ("តំណាងគ្រប់ខេត្ត និងគ្រប់កងពលធំ")។

[4784] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៦ ("ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀងសារី និង សុន សេន") ទំព័រ ១៧ (សមាជិកនៃគណៈមជ្ឈិមបក្ស និងយោធា) ទំព័រ ២០ ("សមាជិកទាំងអស់នៃគណៈមជ្ឈិម ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធ និង អៀង សារី")។

[4785] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ២១។

[4786] ឯកសារស្តីពីសមាជលើកទី៥ របស់ ប៉ុល ពត - អៀង សារី ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ទំព័រ ១ ឯកសារលេខ E3/816 ERN (ភាសាអង់គ្លេស) 00281240-00281241។

[4787] ប្រតិចារឹកក្នុងសំណុំរឿង ០០១ (កាំង ហ្គេកអ៊ាវ) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ E3/55 ទំព័រ ៤៥-៤៦ ERN 00330475-00330476។ សៀវភៅនិពន្ធដោយ P. Short៖ ប៉ុល ពត៖ ប្រវត្តិសាស្ត្រនៃសុបិនអាក្រក់ (ឆ្នាំ ២០០៤) ឯកសារលេខ E3/9 ទំព័រ ៣៩២ ERN (ភាសាអង់គ្លេស) 00396600។

ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ដោយមានមុខនាទីសំខាន់ ឬតែមួយដើម្បីជ្រើសរើសថ្នាក់ដឹកនាំថ្មី[4788] ចំណែកឯ សៅ សារុន បានពិពណ៌នាព្រឹត្តិការណ៍នោះថា មានរយៈពេល ១០ ថ្ងៃ[4789] បានពិភាក្សាប្រធានបទយ៉ាងច្រើន[4790] និងថា ត្រូវបានធ្វើឡើង"ក្នុងអំឡុងពេលនៃការរំឭកខួបបក្ស"ក្នុងខែកញ្ញា[4791]។ ភស្តុតាងបន្ថែមបានគាំទ្រថា ការរំឭកខួបបក្សកុម្មុយនីស្តកម្ពុជាពិតណាស់ត្រូវបានប្រារព្ធក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨[4792]។ ទោះជាយ៉ាងណាក្តី ផ្អែកលើកំណត់ហេតុដែលកត់ត្រាវត្តមានរបស់ ខៀវ សំផន និង សៅ សារុន និងការតែងតាំងរបស់ សៅ សារុន ជាលេខាតំបន់ ១០៥ ដែលជួនគ្នាជាមួយនឹងគោលបំណងសំខាន់នៃសមាជដែលត្រូវបានបញ្ជាក់ដោយ Philip SHORT និង កាំង ហ្កេចអ៊ាវ *ហៅ* ឌុច។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា ព្រឹត្តិការណ៍ដែលបានពិពណ៌នាដោយ សៅ សារុន គឺជាសមាជបក្សលើកទីប្រាំ។

1715.ទីបី ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនបានអើពើចំពោះការដែលគាត់បានពិពណ៌នាសមាជឆ្នាំ ១៩៧៦ ថា ជាសមាជ"ចុងក្រោយ" និងដូច្នេះ គាត់មិនបានដឹងអំពីសមាជក្នុងឆ្នាំ ១៩៧៨[4793]។ សហព្រះរាជអាជ្ញាបានលើកឡើងថា នេះអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនសំអាងទៅលើភស្តុតាង ខៀវ សំផន លើចំណុចនេះ ហើយជឿជាក់លើភស្តុតាងរបស់ សៅ សារុន[4794]។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការសំអាងយ៉ាងទូលំទូលាយរបស់អង្គជំនុំ

[4788] សៀវភៅនិពន្ធដោយ P. Short៖ *ប៉ុល ពត៖ ប្រវត្តិសាស្ត្រនៃសុបិនអាក្រក់* (ឆ្នាំ ២០០៤) ឯកសារលេខ E3/9 ទំព័រ ៣៩២ ERN (ភាសាអង់គ្លេស) 00396600។

[4789] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៧។

[4790] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៦ ("ជម្រុញការដឹកនាំលើប្រជាជន [...] ធ្វើឱ្យប្រាកដថា ប្រជាជនមានស្បៀងបរិភោគ និង [...] ជម្រកស្នាក់នៅ")។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៤-១៥ ("ពាក់ព័ន្ធនឹងការបោះពុម្ពរូបិយប័ណ្ណ និងចរាចរប្រាក់ អាចឱ្យប្រជាជនវិលត្រឡប់ទៅទីក្រុងវិញ បើផ្សារឡើងវិញ")។

[4791] ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/84.1 ទំព័រ ១៣, ១៤-១៥។

[4792] សេចក្តីសន្និដ្ឋាននៃសុន្ទរកថារបស់ ប៉ុល ពត ក្នុងមីទ្ទីងថ្ងៃទី២៧ ខែកញ្ញា នៅភ្នំពេញ (នៅក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារលេខ E3/294 ទំព័រ ១។ បដិសណ្ឋារកិច្ចទទួលស្វាគមន៍រំឭកខួបបក្សថ្ងៃទី ២៦ ខែកញ្ញា គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា(កម្រងសារព័ត៌មាន FBIS) ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/294 ERN (En) 00170445។

[4793] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៦ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារលេខ E3/27 ទំព័រ ៨ ERN 00156619-00156620។

[4794] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៣។

ជម្រះសាលាដំបូងលើភស្តុតាងរបស់ ខៀវ សំផន ពាសពេញសាលក្រមបង្ហាញថា ភស្តុតាងនេះពុំត្រូវបាន "មិនអើពើ"ដូចការអះអាងរបស់ ខៀវ សំផន ឡើយ ប៉ុន្តែតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិ អង្គជំនុំជម្រះសាលាដំបូងជឿជាក់លើភស្តុតាងមួយផ្សេងជាងពាក់ព័ន្ធចំណុចនេះ។

1716.ជាចុងក្រោយ ផ្អែកតាម ខៀវ សំផន ថា លក្ខខណ្ឌនៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាពុំបានគាំទ្រសេចក្តីសន្និដ្ឋានដែលថា សមាជិកទាំងអស់របស់គណៈមជ្ឈិមត្រូវតែចូលរួមក្នុងមហាសន្និបាតជាដាច់ខាតនោះទេ[4795]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មាត្រា ២១ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់កិច្ចការដល់គណៈមជ្ឈិម ធ្វើការកោះប្រជុំសមាជបក្ស"តំណាងប្រទេសទាំងមូល"[4796]។ រីឯ មាត្រា ២២ អនុញ្ញាតមជ្ឈិមបក្សជ្រើសតាំង"ចំនួននៃតំណាងពេញសិទ្ធិ [...] ដែលតំណាងប្រទេសទាំងមូល"[4797]។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូល ពុំមានបទប្បញ្ញត្តិណាមួយបញ្ជាក់ថា សមាជិកនៃគណៈមជ្ឈិមមិនអាចចូលរួមសមាជបក្សនោះទេ។ ផ្ទុយទៅវិញ បទប្បញ្ញត្តិនោះបានចែងអំពីការរួមបញ្ចូលកម្មាភិបាលដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ដែលតំណាងកម្ពុជាប្រជាធិបតេយ្យទាំងមូលក្នុងសមាជន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា មាត្រា ២២ និយាយអំពីចំនួនប៉ុន្មាននាក់នៃសមាជិកគណៈមជ្ឈិមត្រូវតែចូលរួមសមាជបក្សនោះ។

1717.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើការពិតដែលថា ខៀវ សំផន បានបង្ហាញការដឹងរបស់គាត់អំពីការធ្វើយុត្តិកម្មក្នុងការចាប់ខ្លួន វន វ៉េត ដែលបានកើតឡើងក្នុងអំឡុងពេលនៃសមាជបក្សលើកទីប្រាំក្នុងកិច្ចសម្ភាសន៍ឆ្នាំ ២០០៦[4798]។ អង្គជំនុំជម្រះកត់សម្គាល់ផងដែរលើហានិភ័យដែលមានសក្តានុពលចំពោះ ខៀវ សំផន ប្រសិនបើគាត់ត្រូវបានគេឃើញថា ពុំស្មោះត្រង់ ដោយសារការខកខានក្នុងការចូលរួមការបោសសម្អាតកម្រិតខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តយកម្ពុជា និងក្នុងបរិបទនៃសមាជដែលត្រូវបានផ្តល់កិច្ចការក្នុងការតែងតាំងជំនួសសមាជិកដែលត្រូវបានបោសសម្អាត។ អង្គជំនុំជម្រះពិចារណាឃើញថា ខៀវ

---

[4795] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧២៧ យោងទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/130 ទំព័រ ៤៩-៥០ ERN 00442277-00442278 មាត្រា ២២។

[4796] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/130 ទំព័រ ៤៩-៥០ ERN 00442277-00442278 មាត្រា ២១។

[4797] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/130 ទំព័រ ៤៩-៥០ ERN 00442277-00442278 មាត្រា ២២។

[4798] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៩។ បទសម្ភាសន៍របស់ អៀ ម៉េងទ្រី និង លឿង សូភ័ក្រ្ត ជាមួយ ខៀវ សំផន ចុះថ្ងៃទី០៩-១១ ខែមិថុនា ឆ្នាំ២០០៦ ឯកសារលេខ E3/108 ERN 00347037។

សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុនៅពេលបានសន្និដ្ឋានថា គាត់បានចូលរួមសមាជបក្សលើកទីប្រាំ។

1718.យោងតាមសំអាងហេតុខាងលើ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងវត្តមានរបស់គាត់ក្នុងសមាជបក្សលើកទីបួន និងប្រាំ ត្រូវបដិសេធចោល។

## ខ. វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍

### i. តួនាទីដែលមាន"លក្ខណៈពិសេស"នៅក្នុងបក្ស

1719.ដោយសំអាងលើឯកសារចំនួន ៣៨ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គណៈអចិន្ត្រៃយ៍"បានជួបជាប្រចាំពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យដើម្បីពិភាក្សាការអនុវត្តន៍មាគ៌ានយោបាយបក្ស និងការគ្រប់គ្រងប្រទេស"[4799]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ក្នុងចំណោមកំណត់ហេតុកិច្ចប្រជុំចំនួន ២២ ដែលបានរាយនាមអ្នកចូលរួមនោះ មានកំណត់ហេតុចំនួន ១៦ បានកត់ត្រាឈ្មោះ"ហែម"ថាមានវត្តមាន និងបានសន្និដ្ឋានថា ខៀវ សំផន "បានចូលរួមកិច្ចប្រជុំជាច្រើន"[4800] និងថា ខៀវ សំផន ស្ថិត"ក្នុងតួនាទីដែលមានលក្ខណៈពិសេសនៅក្នុងបក្សផ្អែកតាមការចូលរួមជាច្រើនក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបានពិភាក្សាលើបញ្ហា និងធ្វើសេចក្តីសម្រេចសំខាន់ៗនោះ"[4801]។ អង្គជំនុំជម្រះបានបន្តសន្និដ្ឋានថា ខៀវ សំផន បានដឹងយ៉ាងទូលំទូលាយអំពីសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ផ្អែកលើផ្នែកខ្លះនៃតួនាទីនោះ[4802]។

---

[4799] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៨៤, ៣៤៧។ គណៈអចិន្ត្រៃយ៍"បានជួបរៀងរាល់ប្រាំពីរ ទៅដប់ថ្ងៃម្តង ឬញឹកញាប់ជាងនេះប្រសិនបើកាលៈទេសៈតម្រូវ" (សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧)។

[4800] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧ ជើងទំព័រ ១០១១។

[4801] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

[4802] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០ (ពិចារណាលើ"តួនាទីរបស់ ខៀវ សំផន ដែលមានលក្ខណៈពិសេសនៅក្នុងបក្សតាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ជាច្រើន" ដើម្បីយល់ឃើញថា គាត់បានដឹងអំពីឋានៈរបស់ជនរងគ្រោះដែលត្រូវបានការពារនៅមន្ទីរស-២១), ៤២០៨ (ពិចារណាលើ"ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលក្នុងនោះបញ្ហាសំខាន់ត្រូវបានពិភាក្សា និងសេចក្តីសម្រេចត្រូវបានធ្វើឡើង"ក្នុងទិដ្ឋភាពនៃ"ភាពស្និទ្ធស្នាលជាមួយមជ្ឈិមបក្ស" និងពិចារណាលើចំណុចនេះក្នុងការយល់ឃើញថា គាត់បាន"ដឹងអំពីការវិវឌ្ឍន៍នៃផែនការ ការអនុវត្តន៍ និងភវនី

1720.ខៀវ សំផន បានលើកឡើងអំពីកំហុសផ្នែកអង្គហេតុមួយចំនួននៅក្នុងការកំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាង[4803] និងថា អង្គជំនុំជម្រះពុំអាចដាក់ឱ្យគាត់ទទួលខុសត្រូវដោយផ្អែកលើមូលដ្ឋាននៃការចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទៀងទាត់ ឬតួនាទីពិសេសក្នុងបក្សនោះទេ[4804]។ ផ្អែកតាម ខៀវ សំផន ថា កំណត់ហេតុកិច្ចប្រជុំអនុញ្ញាតត្រឹមតែការសន្និដ្ឋានថា "កិច្ចប្រជុំត្រូវបានធ្វើឡើងតាមកាលបរិច្ឆេទមួយចំនួន និងនិយាយអំពីប្រធានបទមួយចំនួន"ប៉ុណ្ណោះ[4805]។ គាត់បានបញ្ជាក់ថា មានតែកំណត់ហេតុកិច្ចប្រជុំចំនួន ១៦ លើកប៉ុណ្ណោះដែលចុះកាលបរិច្ឆេទនៅចន្លោះពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ ដែលចុះឈ្មោះគាត់ថា មានវត្តមាន[4806]។ ដូច្នេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការបូកសរុបរួមថា គាត់បានចូលរួមក្នុង"កិច្ចប្រជុំជាច្រើន" និង"ការចូលរួមទៀងទាត់" និងជាផលវិបាក"តួនាទីពិសេសរបស់គាត់"[4807]។ គាត់បានបញ្ជាក់ថា កំណត់ហេតុនោះពុំបានបង្ហាញថាតើ អ្នកចូលរួមមានវត្តមានរយៈពេលប៉ុន្មានក្នុងកិច្ចប្រជុំនោះឡើយ[4808]។

---

យភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ បានកើតឡើង"), ៤២២៤ (ដោយពិចារណាលើ"តួនាទីពិសេសរបស់ ខៀវ សំផន ក្នុងបក្ស"ដើម្បីសន្និដ្ឋានថា គាត់បានដឹងអំពីការចាប់ខ្លួន និងការសម្លាប់អតីតរដ្ឋាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា), ៤២២៥ (កត់សម្គាល់ ក្នុងចំណោមនោះ "វត្តមានរបស់ ខៀវ សំផន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍" ដើម្បីយល់ឃើញថា ការចាប់ខ្លួនរបស់ ឌឿន និង ការសម្លាប់ក្រោយមក), ៤២៣០ (ពិចារណាក្នុងចំណោមនោះ"តួនាទីរបស់ ខៀវ សំផន ដែលមានលក្ខណៈពិសេសក្នុងបក្ស" ក្នុងការយល់ឃើញថា គាត់បានសម្រួលដល់ការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ ភួង), ៤២៣៦ (ពិចារណាលើ"តួនាទីពិសេសក្នុងមជ្ឈិមបក្ស" ក្នុងការយល់ឃើញថា គាត់បានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងចាម)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៧ (រំឭកថា "តួនាទីរបស់ ខៀវ សំផន មានលក្ខណៈពិសេសក្នុងបក្សកុម្មុយនីស្តកម្ពុជា និងការចូលរួមជាប្រចាំក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ផ្តល់ឱ្យគាត់នូវការយល់ដឹងអំពីការប្រតិបត្តិការរបស់បក្ស"), ៤៣៨២ (សម្រាប់គោលបំណងនៃការវាយតម្លៃភាពធ្ងន់ធ្ងរនៃការប្រកាសទោស អង្គជំនុំជម្រះសាលាដំបូងរំឭកថា "ក្នុងនាមជាសមាជិកគណៈមជ្ឈិម និងអ្នកចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ខៀវ សំផន បានដឹងជាសម្ងាត់នូវបញ្ហាសំខាន់ៗ និងសេចក្តីសម្រេច និងដូច្នេះ បានទទួលឋានៈខ្ពស់ក្នុងបក្ស")។

[4803] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣១-១៧៣៤, ១៧៤៥-១៧៤៧។

[4804] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៥, ១៧៤៨។

[4805] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៣។

[4806] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៤។

[4807] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៥, ១៧៤៨។

[4808] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៣, ១៧៣៤។

1721.ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា តួនាទីរបស់គាត់ពុំ"មានលក្ខណៈពិសេស"នោះទេ ដោយសារអ្នកដែលពុំមែនជាសមាជិកដទៃទៀតអាចចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលត្រូវបាន"ពន្លាត"នោះ[4809]។ លើសពីនេះទៀត គាត់បានអះអាងថា គាត់ពុំមានការទទួលខុសត្រូវនៅក្នុងភូមិភាគ ឬកងកម្លាំងប្រដាប់អាវុធ ត្រឹមតែជា"អ្នកចូលក្រោយក្នុងបក្ស" កាន់កាប់តួនាទី"មានតែឈ្មោះ" និងត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមដើម្បីឱ្យមានលក្ខណៈគ្រប់គ្រាន់សម្រាប់តួនាទីជាប្រមុខរដ្ឋតែប៉ុណ្ណោះ[4810]។ ដូច្នេះ ផ្អែកតាម ខៀវ សំផន ថា អង្គជំនុំជម្រះសាលាដំបូងគប្បីធ្វើការសន្និដ្ឋានថា គាត់បានកាន់កាប់"តួនាទីគ្មានឥទ្ធិពល ឬសិទ្ធិអំណាច"[4811]។

1722.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានបង្ហាញកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់ជាទៀងទាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍[4812] រួមទាំងបានពិភាក្សាបញ្ហា និងធ្វើសេចក្តីសម្រេចសំខាន់ៗមួយចំនួន[4813]។ ផ្ទុយទៅវិញ គាត់ត្រឹមតែផ្តល់ការបកស្រាយមួយបែបផ្សេងលើភស្តុតាងដែលត្រូវបានវាយតម្លៃរួចរាល់ហើយប៉ុណ្ណោះ[4814]។ ទាក់ទងទៅនឹង"លក្ខណៈពិសេស"នៃតួនាទីរបស់គាត់ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានអើពើលើភស្តុតាងដែលបន្ថែមលើការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បានបង្ហាញថា គាត់មានមុខនាទីសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិ/កម្ពុជាប្រជាធិបតេយ្យ និងបានធ្វើការជិតស្និទ្ធជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាពិសេស ប៉ុល ពត និង នួន ជា[4815]។

1723.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍"ជាច្រើន"[4816] ឬការពិពណ៌នាអំពីការចូលរួមរបស់គាត់ថា "ជាទៀងទាត់"[4817]។ កំណត់ហេតុជាភស្តុតាងបង្ហាញថា គាត់មានវត្តមានក្នុងកិច្ចប្រជុំចំនួន ១៦ លើ

---

[4809] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៦។

[4810] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៦។

[4811] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៧។

[4812] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៩។

[4813] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៨។

[4814] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៩។

[4815] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៨។

[4816] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤។

[4817] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧, ៤២៥៨, ៤២៧៧។

ក។ បើទោះបីជាកិច្ចប្រជុំទាំងនេះបានកើតឡើងតែក្នុងផ្នែកមួយនៃអំឡុងពេលដីកាបញ្ជូនទៅជំនុំជម្រះក៏ដោយ ក៏បង្ហាញថា ខៀវ សំផន គឺជាអ្នកចូលរួមទៀងទាត់ ដូចអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដោយផ្អែកលើកំណត់ហេតុដែលថា គាត់គឺជាបុគ្គលទីបីបន្ទាប់ពី ប៉ុល ពត និង នួន ជា[4818]។ ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាថា កំណត់ហេតុកិច្ចប្រជុំបង្ហាញនូវព្រឹត្តិការណ៍នៃការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងសន្និដ្ឋានជារួមថា ព្រឹត្តិការណ៍នេះមានលក្ខណៈទៀងទាត់កើតឡើងពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ខៀវ សំផន ពុំទទួលបាននូវការសន្មតសមស្របណាមួយដែលថា ដោយសារគ្មានភស្តុតាងគាំទ្រ ទើបគាត់ពុំបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងមូលដែលវត្តមានរបស់គាត់ត្រូវគេបានកត់សម្គាល់ឃើញនោះឡើយ។

1724.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ខៀវ សំផន ពុំបានបង្ហាញនូវភាពពុំសមហេតុផលនៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈអចិន្ត្រៃយ៍“បានជួបប្រជុំពិភាក្សាការអនុវត្តន៍មាគ៌ានយោបាយបក្ស និងការគ្រប់គ្រងប្រទេស”[4819] ឬពិតណាស់ថា បញ្ហា“សំខាន់ៗ”[4820] ឬ“បញ្ហាដែលចាំបាច់សម្រាប់គោលបំណងរួម”[4821] ត្រូវបានពិភាក្សា ហើយសេចក្តីសម្រេច“សំខាន់ៗ”ត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំទាំងនោះ[4822]។ នេះគឺជាសេចក្តីសន្និដ្ឋានដែលមានលក្ខណៈត្រង់ៗបន្តិច ដោយផ្អែកលើប្រធានបទគន្លឹះជាច្រើនដែលត្រូវបានគ្របដណ្តប់នៅក្នុងកំណត់ហេតុនោះ និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ដោយម្ចាស់បណ្តឹងសាទុក្ខដែលថា គណៈអចិន្ត្រៃយ៍គឺជា“ស្ថាប័នជាន់ខ្ពស់បំផុតធ្វើសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា”[4823]។

1725.កត្តាទាំងពីរនេះបានគាំទ្រផងដែរដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា វត្តមានជាញឹកញាប់របស់ ខៀវ សំផន ក្នុងកិច្ចប្រជុំទាំងនេះ គឺដោយសារគាត់“មានតួនាទីពិសេស”នៅក្នុងបក្សកុម្មុយនីស្ត

---

4818 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០២។

4819 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥០។

4820 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

4821 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨។

4822 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤, ៦២៤, ៤២៥៧។

4823 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤៦។ *សូមមើល ខ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣០។

កម្ពុជា[4824]។ នៅក្នុងការស្វះស្វែងបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងផ្ទុយទៅវិញគប្បីយល់ឃើញថា តួនាទីរបស់គាត់"គ្មានឥទ្ធិពល ឬសិទ្ធិអំណាច" ខៀវ សំផន បានធ្វើការបកស្រាយមួយបែបផ្សេងលើភស្តុតាង ដោយមិនបានបង្ហាញកំហុសណាមួយឡើយ។ គាត់បានលើកសាឡើងវិញនូវអំណះអំណាងដែលបានលើករួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ និងកន្លែងផ្សេងទៀតក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ ដែលត្រូវបានពិចារណា និងដោះស្រាយដដែលៗ។

1726.ចុងក្រោយ ខៀវ សំផន ពុំបានអើពើថា "តួនាទីពិសេស"របស់គាត់ត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីគាំទ្រការយល់ឃើញដែលថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដោយសារភាពជិតស្និទ្ធរបស់គាត់ជាមួយនឹងមជ្ឈិមបក្ស[4825]។ បញ្ហាថាតើ តួនាទីនេះតម្រូវឱ្យមាន"សិទ្ធិអំណាច ឬឥទ្ធិពល" គឺពុំជាប់ពាក់ព័ន្ធទៅនឹងការដឹងដែលទទួលបានតាមរយៈវត្តមានរបស់គាត់ឡើយ[4826]។ សំខាន់ជាងនេះទៀត ដោយសារពុំមានការយល់ឃើញណាមួយអំពីការដឹងរបស់ ខៀវ សំផន បានផ្អែកតែមួយមុខ ឬដោយប្រាកដលើវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬតួនាទីពិសេសនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ទើបកំហុសពាក់ព័ន្ធនឹងបញ្ហានេះពុំអាចបណ្ដាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ[4827]។

1727.អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន លើចំណុចនេះត្រូវបដិសេធចោល។

### ii. វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍

1728.អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយលើការអះអាងរបស់ ខៀវ សំផន ដែលថា គាត់ពុំមានសិទ្ធិបញ្ចេញយោបល់ ឬចូលរួមក្នុងការធ្វើសេចក្ដីសម្រេចក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលគាត់បានចូលរួមនោះឡើយ[4828]។ ទោះជាយ៉ាងណាក្ដី ដោយផ្អែកការយល់ឃើញរបស់ខ្លួនលើកំណត់ហេតុនៃកិច្ចប្រជុំពីរ

---

[4824] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៤, ៦២៥។

[4825] *សូមមើលខាងក្រោម* ផ្នែក VIII.ខ.៧។

[4826] ការរួមចំណែករបស់ ខៀវ សំផន ទៅនឹងផែនការរួមតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ត្រូវបានពិចារណាក្នុងផ្នែកខាងក្រោម។

[4827] សម្រាប់ហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើសារណារបស់ ខៀវ សំផន ដែលថា ការដឹងរបស់គាត់អំពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ពុំអាចត្រូវបានបង្ហាញតាមរយៈវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធនោះទេ។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤០-១៧៤៣។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០០។

[4828] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០១។

លើកដែលសន្មតពាក្យសម្តីនោះថា ជារបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ខៀវ សំផន "បានរួមចំណែកយ៉ាងតិចពីរលើក ក្នុងការរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ស្តីពីទំនាក់ទំនងជាមួយសម្តេចនរោត្តមសីហនុ និងស្តីពី'ការបោះឆ្នោត'សភាតំណាងប្រជាជននៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦"[4829]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខៀវ សំផន "បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍មួយចំនួន"[4830]។

1729.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ និងបានអះអាងសាជាថ្មីថា គាត់"ពុំដែលចូលរួមក្នុងការពិភាក្សា ឬក្នុងការធ្វើសេចក្តីសម្រេចណាមួយ"[4831]។ គាត់បានលើកឡើងថា "ការត្រឹមតែមានវត្តមានរាយការណ៍ បង្ហាញនូវការស្ថិតក្រោមបង្គាប់តាមឋានានុក្រម និងពុំមែនមានន័យថា ជាការចូលរួមក្នុងការពិភាក្សា ឬការសម្រេចនោះទេ" និងបន្ថែមលើនេះ ប្រធានបទនៃការរាយការណ៍របស់ ខៀវ សំផន មានលក្ខណៈ"ជាក់លាក់ និងពុំជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ឬគោលបំណងល្មើសណាមួយឡើយ"[4832]។ ផ្ទុយទៅវិញ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានសន្និដ្ឋានថា ការចូលរួមរបស់គាត់មានលក្ខណៈ"អកម្មទាំងស្រុង"ទាំង ១៤ លើក និង"ឥតសំខាន់"ពីរលើកផ្សេងទៀត[4833]។

1730.សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុស[4834] និងបានលើកឡើងបន្ថែមថា ការអះអាងរបស់គាត់ដែលថា ការធ្វើអន្តរាគមន៍របស់គាត់ក្នុងអំឡុងពេលនៃកិច្ចប្រជុំពុំជាប់ពាក់

---

[4829] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០២ យោងទៅលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ១១-១៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/197 ទំព័រ ១, ៣-៥, ERN 00000744-00000748។ កំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/232 ទំព័រ ១ ERN 00017123។

[4830] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០២។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤០ (កត់សម្គាល់ថា អ្នកដែលពុំមែនជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ដែលរួមមានក្នុងចំណោមអ្នកដទៃទៀត ខៀវ សំផន "បានចូលរួមកិច្ចប្រជុំនោះ")។

[4831] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៦។

[4832] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៧។

[4833] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៣៨។

[4834] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៨។

ព័ន្ធទៅនឹងបទឧក្រិដ្ឋជាក់លាក់នោះ ពុំជាប់ពាក់ព័ន្ធឡើយ ដោយសារការចូលរួមរបស់គាត់នៅក្នុងការប្រព្រឹត្ត ឧក្រិដ្ឋកម្មពុំចាំបាច់ឱ្យមានការចូលរួមផ្ទាល់ និងអាចជាការចូលរួមដោយមិនផ្ទាល់ផងដែរ[4835]។

1731.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សារណារបស់ ខៀវ សំផន បានផ្អែកលើការភាន់ច្រឡំដែលថា គាត់ត្រូវបានដាក់ឱ្យទទួលខុសត្រូវដោយសារការរួមចំណែកក្នុងគោលបំណងរួមតាមរយៈការចូលរួមយ៉ាង សកម្មក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ ទោះជាយ៉ាងណាក្តី ការពិនិត្យឡើងវិញលើការយល់ឃើញរបស់អង្គ ជំនុំជម្រះសាលាដំបូងបង្ហាញថា អង្គជំនុំជម្រះពុំបានយល់ឃើញជាទូទៅតាមរយៈការរាយការណ៍ពីររបស់ ខៀវ សំផន ទៅឱ្យគណៈអចិន្ត្រៃយ៍ដែលគាត់បានចូលរួមក្នុងកិច្ចប្រជុំ និងពុំបានដាក់ឱ្យគាត់ទទួលខុសត្រូវ ចំពោះការរួមចំណែកក្នុងគោលបំណងរួមផ្អែកលើមូលដ្ឋាននេះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលា ដំបូងបានពិចារណាឃើញថា តាមរយៈវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ខៀវ សំផន បាន ផ្តល់ការគាំទ្រដល់សមាជិកនៃកិច្ចប្រជុំនោះក្នុងការបន្តគោលបំណងរបស់ខ្លួន។

1732.ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "វត្តមានទៀងទាត់របស់ ខៀវ សំផន នៅក្នុង កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលក្នុងនោះសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង សមាជិកភាពនៃមន្ទីរ ៨៧០ [...] និងការគ្រប់គ្រងលើបញ្ហាពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ [...] បង្ហាញនូវអត្ថិភាពនៃការគាំ ទ្ររបស់គាត់ និងការជួយដែលត្រូវបានបន្តដល់បក្សកុម្មុយនីស្តកម្ពុជាដើម្បីសម្រេចគោលបំណងនោះ"[4836] ។ ប្រហាក់ប្រហែលគ្នានេះ ក្នុងការកំណត់ថា "ខៀវ សំផន ជាទៀងទាត់បានចូលរួមក្នុងកិច្ចប្រជុំគណៈអ ចិន្ត្រៃយ៍ ដែលក្នុងនោះបញ្ហាសំខាន់នៃគោលបំណងរួមត្រូវបានពិភាក្សា" អង្គជំនុំជម្រះសាលាដំបូងបាន យោងទៅលើការវិភាគរបស់ខ្លួនពីមុនៗដែលបង្ហាញច្បាស់លាស់ថា "វត្តមានរបស់គាត់"មានកម្រិតត្រឹមតែ កិច្ចប្រជុំពីរលើកដែលក្នុងនោះគាត់បានរាយការណ៍ជូនគណៈអចិន្ត្រៃយ៍[4837]។ ពិតណាស់ អង្គជំនុំជម្រះបាន បន្តកំណត់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែល ខៀវ សំផន បានគាំទ្រតាមរយៈវត្តមាន

---

[4835] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៨៩៩។

[4836] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧ (សេចក្តីបញ្ជាក់បន្ថែម សេចក្តីដកស្រង់ខាងក្នុងត្រូវបាន លុបចោល)។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា តាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ខៀវ សំផន បាន បង្ហាញ "ការគាំទ្រ" ចំណែកពាក្យ"ជួយ" ទាក់ទងទៅនឹងការអនុវត្តន៍មុខតំណែងក្នុងមន្ទីរ ៨៧០ និងការគ្រប់គ្រងបញ្ហាពាណិជ្ជ កម្មកម្ពុជាប្រជាធិបតេយ្យ។ *សូមមើលខាងក្រោម* ផ្នែក VIII.ក.៤.ក និងផ្នែក VIII.ក.៤.ខ.i។

[4837] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨ (ជើងទំព័រ ១៣៨៩០) យោងទៅលើសាលក្រមអង្គជំនុំ ជម្រះសាលាដំបូង ផ្នែក ៨.៣.៣: តួនាទី និង មុខតំណែង ខៀវ សំផន: សមាជិកនៃគណៈអចិន្ត្រៃយ៍ និងមជ្ឈិម។

របស់គាត់[4838] និងបានបញ្ជាក់ថា គាត់“*មានវត្តមាន* នៅពេលដែលសមាជិកគណៈអចិន្ត្រៃយ៍ផ្ដល់របាយការណ៍ទៀងទាត់ [...] *មានវត្តមាន*ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលក្នុងនោះការសាងសង់ព្រលានយន្តហោះយោធាក្នុងខេត្តកំពង់ឆ្នាំងត្រូវបានបង្កើតជាផែនការឡើង [...] *មានវត្តមាន* ក្នុងកិច្ចប្រជុំក្រោយៗដែលក្នុងនោះ សុន សេន បានរាយការណ៍អំពីការសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង”[4839]។

1733.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អំណះអំណាងរបស់ ខៀវ សំផន ត្រង់ចំណុចនេះពាក់ព័ន្ធទៅនឹងការចូលរួមយ៉ាងសកម្មរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ជាការលើកឡើងដោយពុំត្រឹមត្រូវ និងត្រូវបដិសេធចោល។

1734.ខៀវ សំផន បានជំទាស់យ៉ាងពិសេសទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានរួមចំណែកក្នុងផែនការរួមតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពិភាក្សាការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[4840]។ ជាពិសេស ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំពាក់ព័ន្ធទីមួយនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ គាត់បានលើកឡើងថា ដោយសារកំណត់ហេតុពុំមានរាយនាមអ្នកចូលរួម ទើបអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់មានវត្តមាននោះ[4841]។ ខៀវ សំផន បានដកយកផ្នែកដែលពាក់ព័ន្ធនៃកិច្ចប្រជុំលើកទីពីរ និងទីបីដែលពាក់ព័ន្ធក្នុងគោលបំណងបង្ហាញថា កិច្ចប្រជុំនេះពុំមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងពិពណ៌នានូវខ្លឹមសារឡើយ[4842]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ដល់ទម្ងន់ត្រឹមត្រូវដល់ការដែលថា អង្គជំនុំជម្រះពុំអាចកំណត់បានថាតើ គាត់មានវត្តមានក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ក្នុងខែ មេសា ឆ្នាំ ១៩៧៦ ដែលបានសម្រេចសាងសង់ព្រលានយន្តហោះនោះ ដែរ ឬយ៉ាងណា[4843]។

---

[4838] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨ (ជើងទំព័រ ១៣៨៩១ ដល់ ១៣៨៩៣)។

[4839] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨ (សេចក្ដីបញ្ជាក់បន្ថែម ជើងទំព័រខាងក្នុងលុបចោល)។

[4840] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤១, ១៧៤៣។

[4841] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤២។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៣ (ជើងទំព័រ ៥៨៣៤)។ កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ [ចម្លងឡើងវិញ ឯកសារលេខ E3/1733, E3/1612, E3/183] ឯកសារលេខ E3/182 ទំព័រ ១, ១៩ ERN 00019108, ERN 00019126។

[4842] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤២។

[4843] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤២។

1735.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទាំងពីរលើកនៅក្នុងខែ តុលា ឆ្នាំ ១៩៧៥ និងខែ មេសា ឆ្នាំ ១៩៧៦ ដែលកិច្ចប្រជុំនេះបានផ្តល់ឱ្យគាត់នូវការទទួលខុសត្រូវផ្សេងៗ[4844]។

1736.អង្គជំនុំជម្រះតុលាការកំពូលទទួលយកសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥។ របៀបវារៈទីមួយនៃកិច្ចប្រជុំ"ការចែកការងារ"ឱ្យសមមិត្ត ហែម "ទទួលខុសត្រូវលើរណសិរ្ស និងរាជរដ្ឋាភិបាល ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ"[4845]។ ទោះជាយ៉ាងណាក្តីកំណត់ហេតុកិច្ចប្រជុំនេះពុំបានរាយនាមអ្នកចូលរួម[4846]។ ដូច្នេះ បន្ទាប់ពីទទួលស្គាល់ពីដំបូងថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំដែលកំណត់ហេតុនោះបានរាយនាមគាត់ជាអ្នកចូលរួម[4847] ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកំណត់ហេតុដែលពុំមានរាយនាមអ្នកចូលរួម។ ទោះជាយ៉ាងណាក្តី កំហុសនេះពុំបានធ្វើឱ្យប៉ះពាល់ដល់ការសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានរួមចំណែកក្នុងផែនការរួមតាមរយៈការចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលក្នុងនោះបញ្ហាសំខាន់ៗត្រូវបានពិភាក្សា និងបានផ្អែកលើកិច្ចប្រជុំជាច្រើនទៀត[4848]។

---

[4844] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០០។ បើទោះបីជា សហព្រះរាជអាជ្ញាបានយោងទៅលើកិច្ចប្រជុំ"ខែ ឧសភា ឆ្នាំ ១៩៧៦" "អំពីការបង្កើតព្រលានយន្តហោះ"(E3/222) ក៏ដោយ ក៏បានដកស្រង់កិច្ចប្រជុំខែ មេសា ឆ្នាំ ១៩៧៦ (E3/235) និងលើកអំណះអំណាងពាក់ព័ន្ធទៅនឹងខ្លឹមសារនោះ។ *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០០ (ជើងទំព័រ ៣១២១)។

[4845] កំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/182 [ចម្លងឡើងវិញ ឯកសារលេខ E3/1733, E3/1612 និង E3/183] ទំព័រ ១ ERN 00019108។

[4846] កំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/182 [ចម្លងឡើងវិញ ឯកសារលេខ E3/1733, E3/1612 និង E3/183] ទំព័រ ១ ERN 00019108។

[4847] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០២។

[4848] ផ្ទុយទៅនឹងសារណារបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ខែ មេសា ឆ្នាំ ១៩៧៦ ដែលសម្រេចលើការសាងសង់ព្រលានយន្តហោះ បើទោះបីជាគាត់ត្រូវបានប្រគល់ភារកិច្ចទទួលខុសត្រូវមួយចំនួនក្នុងកិច្ចប្រជុំនោះ។

1737.កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដែលជាកិច្ចប្រជុំពាក់ព័ន្ធលើកទីពីរ មានលើកអំពីសំណើសុំ“ពិនិត្យទីតាំងថ្មី [...] ឧទាហរណ៍កន្លែងជិតៗ [...] ខេត្តកំពង់ឆ្នាំង”[4849]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសាងសង់ព្រលានយន្តហោះត្រូវបាន“រៀបចំផែនការ”[4850] ឬគណៈអចិន្ត្រៃយ៍“បានបន្តពិភាក្សាលើបញ្ហានេះ”[4851] នៅក្នុងកិច្ចប្រជុំនេះ។ ប្រហាក់ប្រហែលគ្នានេះ សុន សេន បានរាយការណ៍ច្បាស់លាស់“ស្តីពីដំណើរការនៃការសាងសង់ព្រលានយន្តហោះ”[4852] នៅពេលដែលគាត់បានប្រាប់គណៈអចិន្ត្រៃយ៍ថា ត្រូវដាក់គ្រួសច្រើន អាគារចាំបាច់ត្រូវប្រក់ដំបូល ទើបមិនក្តៅ “ក្រុមខ្លួងថ្មបានមកដល់”[4853]។ ការជំទាស់របស់ ខៀវ សំផន លើការយល់ឃើញទាំងនេះពុំមានមូលដ្ឋានត្រឹមត្រូវ និងត្រូវបដិសេធចោល។

1738.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា តម្រូវការចាំបាច់បំពេញតាមលក្ខខណ្ឌនៃធាតុផ្សំសត្យានុម័តនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម គឺការបង្ហាញថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តន៍ផែនការរួម[4854]។ ការបង្ហាញដែលថា គាត់បានរួមចំណែកដោយផ្ទាល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាមូលដ្ឋាននោះ ពុំមានភាពចាំបាច់ឡើយ។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានការជាប់ពាក់ព័ន្ធនៅក្នុងសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបញ្ជាក់ថា អង្គជំនុំជម្រះពុំអាចកំណត់បានថាតើ គាត់មានវត្តមានក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ក្នុងខែ មេសា ឆ្នាំ ១៩៧៦ ដែលបានសម្រេចសាងសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ដែរ ឬយ៉ាងណានោះឡើយ[4855]។

1739.ចុងក្រោយ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់“បានចូលរួមជាទៀងទាត់”ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលក្នុងនោះ“កសិកម្ម ភាពរាំងស្ងួត និងឧស្ស

---

[4849] កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ទាក់ទឹងបញ្ហាការពារប្រទេស ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារលេខ E3/229 ទំព័រ ៨ ERN 00000720។

[4850] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨ (ជើងទំព័រ ១៣៨៩៩)។

[4851] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៣ (ជើងទំព័រ ៥៨៣៥)។

[4852] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៧ (ជើងទំព័រ ៥៨៥៤)។

[4853] កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ឯកសារលេខ E3/222 ទំព័រ ២ ERN 00000771។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៤ (បញ្ជាក់ថា ការមកដល់របស់ក្រុមខ្លួងថ្មជាសញ្ញាចាប់ផ្តើមការសាងសង់)។

[4854] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៨៣។

[4855] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤២។

ហ៍កម្ម”ត្រូវបានពិភាក្សា ឬពិតណាស់ថា កិច្ចប្រជុំនោះបានកើតឡើង ដោយសារបានផ្អែកលើចម្លើយជាលាយលក្ខណ៍អក្សរតែមួយគត់ប៉ុណ្ណោះដែលរៀបរាប់អំពីការពិភាក្សារវាង អៀង សារី និង Stephen HEDER[4856]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើចម្លើយក្រៅតុលាការរបស់ អៀង សារី ដោយផ្អែកលើភស្តុតាងបញ្ជាក់បន្ថែមដទៃទៀតក្នុងការយល់ឃើញថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំ[4857]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញទៅលើកិច្ចប្រជុំពីរលើកដែល ខៀវ សំផន បានចូលរួមដែលពិភាក្សាអំពី“កសិកម្ម ភាពរាំងស្ងួត និងឧស្សាហកម្ម”[4858]។

1740.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលវាយតម្លៃចម្លើយក្រៅតុលាការដោយគ្មានឱកាសសួរដេញដោល។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទម្ងន់តិចតួចបានផ្តល់ទៅឱ្យចម្លើយក្រៅតុលាការដែលគ្មានការសួរដេញដោល ជាពិសេសនៅពេលស្ថិតនៅក្រៅក្របខ័ណ្ឌនៃកិច្ចដំណើរការរបស់តុលាការដូចជាចម្លើយកត់ត្រាដោយមជ្ឈមណ្ឌលថែរក្សាឯកសារ DC-Cam និងចម្លើយរបស់បុគ្គលដែលបានទទួលមរណភាពដែលអាចសំអាងទៅលើក្នុងការបង្ហាញនូវសកម្មភាព និងអំពើរបស់ជនជាប់ចោទ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះត្រូវតែជាជឿជាក់ថា ភស្តុតាងដែលបានស្នើឡើងត្រូវតែជឿទុកចិត្តបាន និងការដាក់ពិរុទ្ធភាពពុំអាចត្រូវបានផ្អែកតែមួយមុខ ឬជាសំខាន់លើនោះឡើយ[4859]។

1741.ទាក់ទងទៅនឹងការយល់ឃើញចំពោះមុខ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន “ជាទៀងទាត់មានវត្តមាន និងចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបញ្ហាសំខាន់ៗចំពោះគោលបំណងរួមត្រូវបានពិភាក្សា”[4860] បានផ្អែកទៅលើវត្តមាន

---

[4856] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨ (ជើងទំព័រ ១៣៨៩១) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៩១ (ជើងទំព័រ ១២៩៧៧) យោងទៅលើកិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារលេខ E3/89 ERN 00062452-00062454 ទំព័រ ១-៣។

[4857] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០១។

[4858] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០១ យោងទៅលើកំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/224 ។ កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ ឯកសារលេខ E3/226 ។

[4859] *សូមមើលខាងលើ* ផ្នែក V.ង.២.គ។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦៩-៧២។

[4860] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨។

របស់គាត់ក្នុងកិច្ចប្រជុំទាំងនេះ។ ពិរុទ្ធភាពរបស់ ខៀវ សំផន សម្រាប់ការរួមចំណែកក្នុងផែនការរួមតាមរយៈការគាំទ្ររបស់គាត់ក្នុងលក្ខណៈនេះ ពុំបានផ្អែកតែមួយមុខ ឬជាសំខាន់ទៅលើវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំជាក់លាក់ខែ កញ្ញា ឆ្នាំ ១៩៧៥ នោះទេ។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អៀង សារី បានរៀបរាប់លម្អិត និងគួរជឿជាក់បាននៃកិច្ចប្រជុំនោះដែលមានខ្លឹមសារដូចគ្នាស្តីពីបញ្ហានៃក្តីបារម្ភចំពោះគណៈអចិន្ត្រៃយ៍នៅពេលនោះ ដូចបានបង្ហាញតាមរយៈរបាយការណ៍នៃទស្សនកិច្ចទៅកាន់ភូមិភាគពាយ័ព្យ និងឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥[4861]។

1742.យោងតាមសំអាងហេតុខាងលើ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងការរួមចំណែកក្នុងផែនការរួមតាមរយៈវត្តមានរបស់គាត់ ត្រូវបដិសេធចោល។

## គ. គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ

1743.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុនៅពេលពិចារណាឃើញថា គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ"ផ្តល់ឱ្យគាត់នូវឱកាសចូលអន្តរាគមន៍"ក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម និងអចិន្ត្រៃយ៍[4862]។ គាត់បានអះអាងថា ជាដំបូង ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថាកិច្ចប្រជុំរបស់គណៈមជ្ឈិមដែលពាក់ព័ន្ធបានកើតឡើង ឬប្រសិនបើមាន ថាគាត់បានចូលរួម និងថា គាត់បានយល់ព្រមទៅនឹងការសម្រេចនោះឡើយ[4863]។ ជាពិសេស បញ្ហាចំពោះមុខដែលទាក់ទងនោះ គឺការទទួលខុសត្រូវរបស់ ខៀវ សំផន លើលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុម័តនៅក្នុងសមាជបក្សលើកទីបួន[4864] សេចក្តីសម្រេចគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[4865] និងអនុ

---

4861 កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារលេខ E3/89 ទំព័រ ១-៣ ERN 00062452-00062454។ កំណត់ហេតុអំពីទស្សនកិច្ចនៃគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ឯកសារលេខ E3/216 ថ្ងៃទី ២០ ដល់ ២៤ ខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៧ ERN 00008492។ ការបោះពុម្ពផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ ពិនិត្យការក្តាប់ និងអនុវត្តន៍មាគានយោបាយ ឯកសារលេខ E3/781 ខែ កញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ១១ ERN 00072377។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៨៧-៣៨៩១។

4862 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៩។

4863 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥០។

4864 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩, ៣៧៣៨, ៣៧៦៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ៥.១.១ 'រចនាសម្ព័ន្ធរដ្ឋបាល៖ រចនាសម្ព័ន្ធបក្សកុម្មុយនីសកម្ពុជា៖ សមាជបក្ស'។

4865 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩-៤២៦០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១២៦, ៣៧៧១, ៣៨៩៩, ៣៩៥៥។

ស្សូរណៈនៅពាក់កណ្តាលឆ្នាំ ១៩៧៨ ដែលអំពាវនាវផ្តល់ក្តីមេត្តាដល់“អ្នកដែលត្រូវបានដឹកនាំខុសផ្លូវ”បម្រើភ្នាក់ងារ*យួន*[4866]។

1744.អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចរាល់លើការអះអាងរបស់ ខៀវ សំផន ដែលលើកចំរំដែលថា គាត់ពុំមានវត្តមានក្នុងសមាជបក្សលើកទីបួន និងបានតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ជាការសមហេតុផលដែលថា គាត់បានចូលរួម[4867]។ ទាក់ទងទៅនឹងសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ និងសេចក្តីណែនាំពាក់កណ្តាលឆ្នាំ ១៩៧៨ ខៀវ សំផន បានលើកឡើងត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងស្របពេលជាមួយនឹងកិច្ចប្រជុំណាមួយរបស់គណៈមជ្ឈិម និងជារួមថា គាត់បានចូលរួមឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំក្នុងការសន្និដ្ឋានថា គាត់បានយល់ព្រមជាមួយនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការដែលថា គាត់គឺជា“សមាជិកពេញសិទ្ធិ” និងជា“សមាជិកមានសិទ្ធិបោះឆ្នោត” នៃគណៈមជ្ឈិមនៅពេលដែលឯកសារទាំងនេះត្រូវបានចេញ[4868]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញនូវភាពមិនសមហេតុផលនៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់ទទួលខុសត្រូវលើសេចក្តីសម្រេចរបស់គណៈមជ្ឈិមដែលបានធ្វើឡើងនៅពេលគាត់ក្លាយជាសមាជិកមានសិទ្ធិបោះឆ្នោត។

1745.ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ស្របតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ[4869]។ ទោះជាយ៉ាងណាក្តី គាត់បានយោងជាលើកដំបូងទៅលើការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការទទួល

---

[4866] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០៤-៣៤០៦, ៣៨២៨។

[4867] *សូមមើលខាងលើ* ផ្នែក VIII.ក.៣.ក។

[4868] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦០។ ពិតណាស់ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងអំពីប្រជាធិបតេយ្យប្រមូលផ្តុំ ត្រឹមតែជាប់ពាក់ព័ន្ធទៅនឹងសមាជបក្សលើកទីបួន កិច្ចប្រជុំរបស់តំណាងបក្សកុម្មុយនីស្តកម្ពុជាមកពីពាសពេញកម្ពុជាប្រជាធិបតេយ្យ និងគ្រប់ស្ថាប័ន។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩។

[4869] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៤៩។

ខុសត្រូវរបស់មេដឹកនាំជាន់ខ្ពស់[4870]។ ដោយសារ ខៀវ សំផន ពុំត្រូវបានរកឃើញថា ទទួលខុសត្រូវតាមរយៈទម្រង់នេះ[4871] សារណាទាំងនេះខកខានក្នុងការបង្ហាញអំពីភាពមិនយុត្តិធម៌ និងត្រូវបដិសេធចោល។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញរួចរាល់ហើយថា ការរួមចំណែករបស់ ខៀវ សំផន ក្នុងផែនការរួមតាមរយៈចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ពុំត្រូវបានផ្អែកទៅលើការចូលរួមយ៉ាងសកម្មរបស់គាត់នោះទេ[4872]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់ចំពោះបញ្ហាថាតើ គោលការណ៍"ប្រជាធិបតេយ្យប្រមូលផ្តុំ"ផ្តល់ឱ្យគាត់នូវសិទ្ធិក្នុងការចូលអន្តរាគមន៍ក្នុងកិច្ចប្រជុំទាំងនោះ ដែរ ឬយ៉ាងណា ត្រូវចាត់ទុកជាអសារបង់។

1746.ខៀវ សំផន បានជំទាស់បន្ថែមទៀតទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាធិបតេយ្យប្រមូលផ្តុំ ពាក់ព័ន្ធទៅនឹងដំណើរការធ្វើសេចក្តីសម្រេចជាសមូហភាព[4873]។ ផ្អែកលើការពិភាក្សាខាងដើម ការជំទាស់នេះជាប់ពាក់ព័ន្ធតែការចូលរួមរបស់គាត់ក្នុងការអនុម័តលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសមាជបក្សលើកទីបួន[4874]។ ខៀវ សំផន បានលើកច្រំដែល និងព្យាយាមដាក់បញ្ចូលតាមរយៈការយោងទៅលើសារណាដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែល

---

[4870] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥១ (ជើងទំព័រ ៣៣៧៦) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣២២។

[4871] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣២៥។

[4872] *សូមមើលខាងលើ* ផ្នែក VIII.ក.៣.ខ។

[4873] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥២។

[4874] អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា "ខៀវ សំផន បានចូលរួមសមាជលើកទីបី ទីបួន និងទីប្រាំ ដែលអនុម័តគោលនយោបាយចេញពីគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធទៅនឹងមាគ៌ានយោបាយទូទៅស្របតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ"។ (សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៩)។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានចង្អុលបង្ហាញលើអំពើជាក់លាក់ណាមួយរបស់សមាជបក្សលើកទីបី ឬទីបួនដែលសន្មតថា ជារបស់ ខៀវ សំផន នោះឡើយ។ ផ្ទុយទៅវិញ គាត់ត្រូវបានតែងតាំងជាសមាជិកបម្រុងនៃគណៈមជ្ឈិមក្នុងសមាជបក្សលើកទីបី និងត្រូវបានដាក់ជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន វន វ៉េត អំឡុងពេលសមាជបក្សលើកទីប្រាំ។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៤, ៤២២៩, ៤២៥៧, ៤២៦០។

ត្រូវបានពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[4875]។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការយល់ឃើញពីមុនៗរបស់ខ្លួនលើចំណុចនេះ[4876]។

1747.ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់មូលហេតុដែលខ្លួនពុំបានជឿជាក់លើចម្លើយរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលថា សិទ្ធិអំណាចត្រូវបានប្រមូលផ្តុំយ៉ាងមានប្រសិទ្ធភាពក្នុងគណៈអចិន្ត្រៃយ៍ ប៉ុល ពត និង នួន ជា ជាពិសេស[4877] និងថា កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បង្ហាញថា សេចក្តីសម្រេចត្រូវបានធ្វើឡើងដោយ ប៉ុល ពត តែម្នាក់ឯង ឬជាមួយនឹង នួន ជា[4878]។ ផ្ទុយទៅនឹងសារណារបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងរបស់ ខៀវ សំផន ដែលបង្ហាញថា ការគ្រប់គ្រងប្រសិទ្ធភាពត្រូវបានប្រមូលផ្តុំក្នុងគណៈអចិន្ត្រៃយ៍[4879]។ ដូចបានពិភាក្សាខាងដើម អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកចំណុចនេះមានលក្ខណៈស្របគ្នាជាមួយនឹងការយល់ឃើញដែលថា សេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើងនៅកន្លែងផ្សេងផងដែរ[4880] និងជារួម តាមរយៈគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ បន្ថែមលើនេះ ខៀវ សំផន ត្រឹមតែបានធ្វើការបកស្រាយមួយបែបផ្សេងលើភស្តុតាងពាក់ព័ន្ធទៅនឹងដំណើរការធ្វើសេចក្តីសម្រេចតាមរយៈកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលនេះពុំបានធ្វើឱ្យអ្នកលើកឡើងនោះបង្ហាញច្បាស់លាស់ស៊ីសង្វាក់គ្រប់គ្រាន់ឡើយ។

1748.យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងខ្លឹមសារ និងការអនុវត្តន៍សញ្ញាណនៃ“ប្រជាធិបតេយ្យប្រមូលផ្តុំ”។

## **៤. តួនាទីបន្ទាប់បន្សំ**

### ក. ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលអប់រំ

---

[4875] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥២ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ១២៦-១៣៨។ សាលដីកាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៤៨, ១០៥០។

[4876] *សូមមើល* សាលដីកាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៥០។

[4877] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥២ (ជើងទំព័រ ៣៣៨២)។

[4878] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥២ (ជើងទំព័រ ៣៣៨៣)។

[4879] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៧ (ជើងទំព័រ ១០០១)។

[4880] *សូមមើល* ផ្នែក VIII.ក.៣.ក។

1749.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> ខៀវ សំផន បានចូលរួម និងបង្រៀនវគ្គរៀនសូត្រនយោបាយដែលធ្វើឡើងនៅបុរីកីឡា (ក-៦) និងនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត (ក-១៥) រួមជាមួយនឹង នួន ជា និងមេដឹកនាំ ប.ក.ក. ដទៃទៀត នៅពេលនោះ។ សិក្ខាកាមចូលរួមមានចាប់ពីយុទ្ធជនរហូតដល់កម្មាភិបាល ប.ក.ក. និងអ្នកត្រឡប់មកពីបរទេស ដែលមានចំនួនចាប់ពីរាប់សិបនាក់រហូតដល់រាប់ពាន់នាក់ ដោយពួកគេបានទទួលការបង្រៀនផ្សេងៗអំពីគោលការណ៍បដិវត្ត សហករណ៍ បច្ចេកទេសកសិកម្ម និងបញ្ហាសេដ្ឋកិច្ច ដោយ ខៀវ សំផន បានបង្រៀនពីវិធីកំណត់អត្តសញ្ញាណ“ខ្មាំង” និងស្វែងរក“ជនក្បត់”[4881]។

1750.ខៀវ សំផន បានជំទាស់ជាពិសេសទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់ អែម អឿន និង ឯក ហេន ក្នុងការយល់ឃើញថា គាត់បានបង្រៀនស្តីពី“ការកំណត់អត្តសញ្ញាណ ‘ខ្មាំង’ និងស្វែងរក‘ជនក្បត់’”[4882]។ គាត់បានលើកឡើងថា សក្ខីកម្មរបស់អ្នកទាំងពីរនេះពុំអាចជឿជាក់បាន ឬទុកចិត្តបានដោយសារមាន“ភាពផ្ទុយគ្នាសំខាន់ៗជាច្រើន”[4883] និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយបានសំអាងលើសក្ខីកម្មនេះ[4884]។ ដូច្នេះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសន្និដ្ឋានថា គាត់បានរួមចំណែកក្នុងការផ្សព្វផ្សាយគោលនយោបាយទាក់ទងទៅនឹង“ខ្មាំង”[4885]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើគួរឱ្យជឿជាក់ និងទុកចិត្តបានរបស់ អែម អឿន និង ឯក ហេន ដោយពិចារណាលើវិធីសាស្ត្រមិនជ្រៀតជ្រែកលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងចំពោះមុខខ្លួន[4886]។

1751.ទាក់ទងទៅនឹង អែម អឿន ខៀវ សំផន បានលើកឡើងថា ភាពផ្ទុយគ្នា និងមិនស៊ីសង្វាក់គ្នា“ជាប្រចាំ”ក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើឱ្យប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់គាត់[4887]។ ជាពិសេស គាត់បានលើកឡើងថា អែម អឿន អះអាងពុំស៊ីសង្វាក់គ្នាអំពីពេលវេលានៃវគ្គបណ្តុះបណ្តាលនោះបានកើត

---

[4881] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៧។

[4882] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៤-១៧៥៥។

[4883] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៤។

[4884] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៦។

[4885] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៥។

[4886] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៥។

[4887] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៧-១៧៥៨។

ឡើង[4888] និងឆ្លើយផ្ទុយខ្លួនឯងថា ឪពុករបស់គាត់បានប្រាប់គាត់ថា ខៀវ សំផន គឺជាប្រធានគណៈប្រធានរដ្ឋ ចំណែកឯឪពុកគាត់បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៤ នៅមុនពេលការតែងតាំង ខៀវ សំផន ឱ្យកាន់កាប់មុខតំណែងនោះ បានផ្ដល់“ដំណើររឿងផ្សេងៗគ្នាជាច្រើន”អំពីកាលៈទេសៈជុំវិញការស្លាប់ម្ដាយរបស់គាត់ និងបានផ្ដល់ចម្លើយ“គួរឱ្យភ្ញាក់ផ្អើលពិសេស”អំពីការរៀបការរបស់គាត់[4889]។

1752.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើសក្ខីកម្មរបស់ អែម អឿន ថា អាចជឿជាក់បាន[4890] និងបានលើកឡើងថា ខៀវ សំផន ពុំអើពើទៅនឹងកត្តាដទៃពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយបានផ្តោតតែទៅលើភាពពុំស៊ីសង្វាក់គ្នាប៉ុណ្ណោះ[4891]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ភស្តុតាងរបស់ អែម អឿន គួរឱ្យជឿជាក់បាន ជាការសមហេតុផលដោយពិចារណាលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីជារួម ដោយសារគាត់បានផ្តល់សក្ខីកម្មលម្អិត និងស៊ីសង្វាក់គ្នាអំពីអង្គហេតុសត្យានុម័ត រួមទាំងទីតាំង និងប្រធានបទដែលបានពិភាក្សាដោយ ខៀវ សំផន នៅក្នុងវគ្គបណ្តុះបណ្តាលនយោបាយ ដែលគាត់បានចូលរួម ចំណែកភាពផ្ទុយគ្នាដែល ខៀវ សំផន បានលើកឡើងនោះត្រឹមតែជាចំណុចសើៗប៉ុណ្ណោះ[4892]។ អែម អឿន បានឆ្លើយតប“យ៉ាងសមហេតុផល និងឥតលាក់លៀម”ទៅនឹងសំណួរមេធាវីការពារក្តីជាច្រើន អំពីការពុំអាចចងចាំច្បាស់លាស់នូវកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលបានកើតឡើងនោះ[4893]។ សហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានយោងដោយផ្នែកៗទៅលើភស្តុតាងរបស់ អែម អឿន ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំរបស់គាត់ នៅពេលដែល អែម អឿន បានពន្យល់ច្បាស់លាស់អំពីកាលៈទេសៈជុំវិញ និងលក្ខណៈបង្ខំនៃការរៀបការរបស់គាត់ និងមូលហេតុដែលគាត់នៅរក្សាការរៀបការជាមួយប្រពន្ធទីមួយរបស់គាត់[4894]។

[4888] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៧ ជើងទំព័រ ៣៣៩០-៣៣៩៣។

[4889] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៨។

[4890] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៦។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤០-១៤៣។

[4891] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤០។

[4892] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤១, ១០៧៦។

[4893] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤១។

[4894] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤២។

1753.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងជាក់លាក់ថា ចម្លើយក្នុងតុលាការរបស់ អែម អឿន អំពីវគ្គបណ្ដុះបណ្ដាលនយោបាយដែលគាត់បានចូលរួម មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ និងថា គួរឱ្យជឿជាក់បាន[4895] ។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ភាពពុំស៊ីសង្វាក់តិចតួចនេះបានប៉ះពាល់ដល់ការសន្និដ្ឋានអំពីវត្តមាននៅក្នុងភស្តុតាងរបស់គាត់ដែលបានលើកឡើងដោយ ខៀវ សំផន ជាពិសេសពាក់ព័ន្ធទៅនឹងការលំបាករបស់គាត់ក្នុងការចងចាំកាលបរិច្ឆេទជាក់លាក់នៃវគ្គបណ្ដុះបណ្ដាលនោះ។ ផ្ទុយទៅនឹងសារណារបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អែម អឿន បានផ្ដល់ចម្លើយស៊ីសង្វាក់ និងស្មោះត្រង់អំពីការស្លាប់របស់ម្ដាយគាត់។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយអំណះអំណាងរបស់ ខៀវ សំផន រួចហើយអំពីភស្តុតាងរបស់ អែម អឿន ស្ដីពីការរៀបការរបស់គាត់ដោយបង្ខំនៅក្នុងសាលដីកានេះ[4896]។ ដោយសារ ខៀវ សំផន ពុំបានផ្ដល់មូលដ្ឋានគាំទ្របន្ថែមនូវអ្វីដែលជា"ការភ្ញាក់ផ្អើល"នៃសក្ខីកម្មរបស់ អែម អឿន ដូច្នេះ សារណានេះពុំចាំបាច់ពិចារណាបន្ថែមទៀតឡើយ។

1754.ខៀវ សំផន បានអះអាងបន្ថែមទៀតថា ការនឹកឃើញឡើងវិញរបស់ អែម អឿន នូវសម្ដីគ្រប់ម៉ាត់អំពីបទឧទ្ទេសនាមរបស់គាត់នៅក្នុងវគ្គបណ្ដុះបណ្ដាលដែល អែម អឿន បានចូលរួមនោះ "ពុំអាចទៅរួចទេ" ដោយសារសក្ខីកម្មរបស់ អែម អឿន បង្ហាញថា អ្នកឧទ្ទេសនាមទាំងអស់បាននិយាយពាក្យដដែលៗដូចគ្នា[4897]។ ទោះជាយ៉ាងណាក្ដី យោងតាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងរបស់ អែម អឿន។ ក្រៅពីការផ្ដល់សក្ខីកម្មថា "អ្នកឧទ្ទេសនាមទាំងអស់បាននិយាយពាក្យដដែលៗដូចគ្នា" អែម អឿន បានបញ្ជាក់ថា អ្នកឧទ្ទេសនាមបាន"ភ្ជាប់បទឧទ្ទេសនាមរបស់ពួកគេជាមួយនឹងបទឧទ្ទេសនាមផ្សេងទៀត" និងអ្នកឧទ្ទេសនាមនីមួយៗ"ប្រើប្រាស់ពាក្យសម្ដីពីរបី"របស់អ្នកឧទ្ទេសនាមមុនៗនៅមុនពេលផ្ដល់បទឧទ្ទេសនាមរបស់ខ្លួន[4898]។

1755.អង្គជំនុំជម្រះតុលាការកំពូលពុំទទួលយកការកំណត់ចរិតលក្ខណៈរបស់ ខៀវ សំផន លើភស្តុតាងរបស់ អែម អឿន ពាក់ព័ន្ធនឹងខ្លឹមសារនៃសុន្ទរកថានោះ។ អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ខ្លឹមសារសំខាន់

---

[4895] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៤២ (ជើងទំព័រ ១៣១៥១) កត់សម្គាល់ថា "ភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីព្រឹត្តិការណ៍នេះជាទូទៅស្របគ្នាជាមួយពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" និងថា "អង្គជំនុំជម្រះទទួលយកចម្លើយរបស់គាត់ថាជឿជាក់បាន"។

[4896] *សូមមើលខាងលើ* ផ្នែក VII.ឆ.៣.គ.ii.ឆ។

[4897] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៧។

[4898] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៤២។

នៃចម្លើយរបស់ អែម អឿន ពុំមែនមានន័យថា អ្នកឧទ្ទេសនាមផ្សេងៗគ្នា"បាននិយាយពាក្យដដែលៗដូចគ្នាទាំងអស់"នោះទេ ដូចការអះអាងរបស់ ខៀវ សំផន ប៉ុន្តែផ្ទុយទៅវិញ ម្នាក់ៗបានសង្ខេបនូវអ្វីដែលបាននិយាយដោយអ្នកមុននៅមុនពេលបន្តបទឧទ្ទេសនាមរបស់ខ្លួន[4899]។ ការអនុវត្តន៍ក្នុងការប្រើប្រាស់ពាក្យសម្ដីរបស់អ្នកឧទ្ទេសនាមមុនក្នុងវគ្គបណ្ដុះបណ្ដាលត្រូវបានបញ្ជាក់អះអាងបន្ថែមដោយ ប៊ិត ហឿន[4900]។ បន្ថែមលើនេះ ខៀវ សំផន ពុំបានបង្ហាញនូវកំហុស ក្រៅពីការកំណត់សម្គាល់មិនច្បាស់លាស់ និងគ្មានមូលដ្ឋានគាំទ្រថា ការនឹកឃើញឡើងវិញរបស់ អែម អឿន អំពីព្រឹត្តិការណ៍នោះហាក់បីដូចជា"មិនអាចទៅរួច"។ ពិតណាស់ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការបញ្ជាក់ច្បាស់លាស់របស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីការលើកឡើងផ្សេងៗគ្នាដែលសន្មតថា ជារបស់ ប៉ុល ពត នួន ជា និង ខៀវ សំផន បានបង្កើនភាពគួរឱ្យជឿជាក់បានរបស់គាត់ ជាជាងការកាត់បន្ថយ[4901]។

1756.ទាក់ទងទៅនឹងភស្តុតាងរបស់ ឯក ហេន ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសក្ខីកម្មរបស់ ឯក ហេន ដើម្បីកំណត់នូវអ្វីដែលគាត់បាននិយាយដោយសារនេះបានធ្វើឱ្យមានការភាន់ច្រឡំ និងខ្វះសេចក្ដីលម្អិត[4902]។ ឯក ហេន ពុំអាចនិយាយបានថាតើ នួន ជា

---

[4899] អ្នកឧទ្ទេសនាម រួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន និង ហ៊ូ នឹម បាន"ភ្ជាប់បទឧទ្ទេសនាមរបស់ខ្លួនទៅនឹងបទឧទ្ទេសនាមដទៃទៀត" (ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៧០) និង"ថាឡើងវិញតាមអ្នកមុននៅមុនពេលបន្ថែមចំណុចរបស់ខ្លួន"។ (ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៧១។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២៤-២៥, ៣៥-៣៦, ៤០-៤១។

[4900] ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន ហៅ ប៊ិត ណា) ឯកសារលេខ E1/502.1 ទំព័រ ១៨ (ខៀវ សំផន "បានផ្ដាប់និយាយ [នៅវគ្គរៀនសូត្រ]។ នៅពេលប្រធានធ្វើបទឧទ្ទេសនាម សមាជិក និងអនុប្រធានត្រូវបានអនុញ្ញាតផ្ដល់យោបល់ ឬបន្ថែមបទឧទ្ទេសនាមដែលបានធ្វើឡើងដោយប្រធាន")។

[4901] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៧១ (ប៉ុល ពត បានបើកវគ្គដំបូង និងបាននិយាយថា "ក្នុងនាមយើងជាអ្នកកុម្មុយនីស្ត ត្រូវឱ្យដឹងច្បាស់ថា តួនាទីរបស់ជនជាកុម្មុយនីស្តធ្វើអីដើម្បីឱ្យស្របតាម [...] 'បក្សមហាលោតផ្លោះ មហាអស្ចារ្យ' បក្សតម្រូវ [...] ប្រសិនបើយើងមិនធ្វើតាម'មហាលោតផ្លោះ' យើងនឹងត្រូវបានចាត់ទុកថា ជាខ្មាំង")។ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/113.1 ទំព័រ ៧២ (នួន ជា បាននិយាយអំពីតម្រូវការកំណត់អត្តសញ្ញាណខ្មាំងដែលជ្រៀតចូលបក្ស "យោងទៅលើអ្នកដែលធ្លាប់ជាទាហានក្នុងរបបពីមុន រួមទាំងរបបនរោត្តមសីហនុ និង លន់ នល់" បញ្ញវន្ត និងអ្នកដែលបញ្ចប់ការសិក្សាពីបរទេស)។ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២៥-២៦, ៤០-៤១ (នួន ជា ពិភាក្សាបណ្ដាញចារកម្ម រួមមាន "ភ្នាក់ងារយួន" ឬ"ភ្នាក់ងារយួនឈ្លានពាន")។

[4902] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៩។

ឬ ខៀវ សំផន បានថ្លែងទៅកាន់កិច្ចប្រជុំលើប្រធានបទស្ដីពីខ្មាំង ដែរ ឬយ៉ាងណានោះឡើយ[4903]។ ខៀវ សំផន បាលើកឡើងថា ចម្លើយរបស់ ឯក ហេន កាន់តែខ្សោយទៅៗដោយសារកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលត្រូវបានទទួលយកនៅពេលថ្មីនេះចេញពីសំណុំរឿង ០០៣/៤[4904]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ចម្លើយរបស់ ឯក ហេន មានលក្ខណៈស៊ីសង្វាក់គ្នាថា គាត់បានចូលរួមវគ្គរៀនសូត្រពីរលើកក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨ ដែលមានមួយលើក នួន ជា បាននិយាយអំពីជនក្បត់ក្នុងភូមិភាគឧត្ដរ និងអំពើក្បត់របស់ កុយ ធួន និងមួយលើកទៀត ខៀវ សំផន បាននិយាយអំពីចំនួនកំណត់ធ្វើការងារ និងគិញវៀតណាម និងបានផ្ដល់យុត្តិកម្មអំពីការចាប់ខ្លួន ប៉ង់ "ពីព្រោះគាត់ជាជនក្បត់សហការជាមួយ 'យួន'"[4905]។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងអាចកំណត់បានថា វគ្គបណ្ដុះបណ្ដាលដែលបានផ្ដល់ដោយ នួន ជា និង ខៀវ សំផន នីមួយៗ ត្រូវបានធ្វើឡើងក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨ ដោយមានការយោងទៅលើកាលបរិច្ឆេទនៃការចាប់ខ្លួន កុយ ធួន និង ប៉ង់[4906] និងបានលើកឡើងថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការភាន់ច្រឡំរបស់ ឯក ហេន អំពីឆ្នាំដែលគាត់បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល បានធ្វើឱ្យការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់គាត់ទៅជាពុំសមហេតុផលនោះឡើយ[4907]។

1757.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ឯក ហេន បានផ្ដល់ភស្ដុតាងស៊ីសង្វាក់គ្នាអំពីពាក្យសម្ដីដែលគាត់សន្មតថា ជារបស់ ខៀវ សំផន នៅក្នុងការបណ្ដុះបណ្ដាលនយោបាយនៅបុរីកីឡា[4908] រួមបញ្ចូលជាពិសេសការដែល គាត់បានប្រាប់សិក្ខាកាមថា ប៉ង់ គឺជាជនក្បត់ដែលត្រូវបានចាប់ខ្លួន និងយកទៅបាត់ ហើយបានណែនាំពួកគេកុំឱ្យធ្វើដូច ប៉ង់[4909]។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ឯក ហេន បាន

---

[4903] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៩ យោងទៅលើប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៦៥-៨៧។

[4904] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៩។

[4905] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៧។

[4906] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៦៩, ៤១៣៩។

[4907] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៧។

[4908] *សូមមើល* ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤-៣៥, ៣៦-៣៧, ៦៧, ៧៤។

[4909] *សូមមើល* ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤-៣៥, ៣៦-៣៧, ៧៤។

ផ្តល់ភស្តុតាងផ្ទុយគ្នាអំពីបញ្ហាថាតើ ខៀវ សំផន បានដឹកនាំវគ្គរៀនសូត្រលើកទីមួយ ឬទីពីរ ដែលគាត់បានចូលរួមនោះ៖ បើទោះបីជា លោកស្រីបានបញ្ជាក់ពីដំបូងក្នុងចម្លើយរបស់ខ្លួនចំពោះមុខអ្នកស៊ើបអង្កេតថា ខៀវ សំផន បានដឹកនាំវគ្គបណ្តុះបណ្តាលលើកដំបូងក្នុងឆ្នាំ ១៩៧៦ ក៏ដោយ[4910] ក៏ក្រោមការសួរដេញដោលយ៉ាងខ្លាំង គាត់នៅតែឆ្លើយថា ខៀវ សំផន បានដឹកនាំវគ្គបណ្តុះបណ្តាលទីពីរក្នុងឆ្នាំ ១៩៧៨ ដែរ[4911] ហើយចម្លើយនេះស្របជាមួយនឹងកាលបរិច្ឆេទនៃការចាប់ខ្លួន ប៉ង់។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការភាន់ច្រឡំអំពីលំដាប់លំដោយនៃការបណ្តុះបណ្តាលពុំបានធ្វើឱ្យប៉ះពាល់ជាខ្លាំងដល់ភាពគួរជឿជាក់បានរបស់សាក្សី ជាពិសេសផ្អែកលើភាពប្រាកដប្រជារបស់គាត់អំពីលំដាប់លំដោយនៅពេលសួរសំណួរនោះ ដែលលើសពីនេះទៀតត្រូវបានបញ្ជាក់អះអាងបន្ថែមដោយភស្តុតាងដទៃទៀតទាក់ទងទៅនឹងកាលបរិច្ឆេទនៃការចាប់ខ្លួន ប៉ង់។

1758.ផ្អែកលើហេតុផលទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយបានសំអាងទៅលើសក្ខីកម្មរបស់ ឯក ហេន ក្នុងការយល់ឃើញថា ខៀវ សំផន បាននិយាយអំពី"ខ្មាំង"ក្នុងវគ្គបណ្តុះបណ្តាលនយោបាយ ដូចនេះ សារណារបស់ ខៀវ សំផន លើចំណុចនេះត្រូវបដិសេធចោល។

1759.ការជំទាស់ផ្សេងទៀតរបស់ ខៀវ សំផន ទាក់ទងទៅនឹងការចូលរួមរបស់គាត់ក្នុងវគ្គបណ្តុះបណ្តាលនយោបាយ បានផ្តោតទៅលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវថា គាត់បានរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា[4912]។ ត្រង់ចំណុចនេះ ជាដំបូង ខៀវ សំផនបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានសំអាងទៅលើភស្តុតាងរបស់សាក្សីមួយចំនួន រួមមាន ជា សាយ, សៅ សារុន, សួង ស៊ីគឿន និង រ៉ចាម តុន *ហៅ* ភី ភួន ដែលបានបញ្ជាក់ថា ខៀវ

[4910] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារលេខ E3/474 ERN 00172016-00172065 ទំព័រ ៣-៤ (ខៀវ សំផន បានដឹកនាំវគ្គបណ្តុះបណ្តាលទីមួយក្នុងឆ្នាំ ១៩៧៦)។ ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤-៣៥, ៦៦ (បញ្ជាក់លើកំណត់ហេតុស្តាប់ចម្លើយ)។

[4911] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៦៧-៦៨, ៧៧-៧៨ (បញ្ជាក់ថា ខៀវ សំផន បានដឹកនាំវគ្គបណ្តុះបណ្តាលទីពីរ)។

[4912] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦០ ("អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយដារបានប្រើប្រាស់សម្តីដែលត្រូវបានសន្មតថាជារបស់ ខៀវ សំផន [...] ជាការបញ្ជាក់អំពីការរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម")។

សំផន "កម្រឃើញផ្តល់សេចក្តីណែនាំនៅក្នុងវគ្គរៀនសូត្រ"[4913] ឬថា វគ្គនោះជាសំខាន់ត្រូវបានដឹកនាំដោយ ប៉ុល ពត និង នួន ជា បើទោះបីជា ខៀវ សំផន មានវត្តមានក៏ដោយ[4914]។ សហព្រះរាជអាជ្ញាបានឆ្លើយតប ថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុស និងផ្ទុយទៅវិញលើកការបកស្រាយមួយផ្សេងអំពីភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ[4915] និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបាន យល់ឃើញដោយសមហេតុផលថា ខៀវ សំផន បានបង្រៀន និងបានចូលរួមផងដែរក្នុងវគ្គបណ្តុះបណ្តាល ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតនិយាយអំពីខ្សាំង និងពុំបានផ្តាច់ខ្លួនរបស់គាត់ចេញពីសេចក្តី ណែនាំទាំងនេះឡើយ[4916]។

1760.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សាក្សីដែលត្រូវបានយោងដោយ ខៀវ សំផន ក្នុងការគាំទ្រអំណះអំណាងដែលថា គាត់កម្របានចូលរួមក្នុងវគ្គសិក្សា មានដូចជា ជា សាយ, វ៉ាចាម តុន និង Philip SHORT អ្នកទាំងអស់គ្នាបានផ្តល់សក្ខីកម្មអំពីវគ្គបណ្តុះបណ្តាលដែលជាក់ស្តែងត្រូវបានដឹកនាំដោយរូបគាត់[4917]។ បើទោះបីជា សៅ សារុន ពុំបានឃើញ ខៀវ សំផន នៅក្នុងវគ្គសិក្សាដែលគាត់បានចូលរួមក៏ដោយ ក៏គាត់ចាំថាបានឮឈ្មោះរបស់ ខៀវ សំផន ដែលស្ថិតក្នុងចំណោមសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលនោះដែរ[4918]។ ប្រហាក់ប្រហែលគ្នានេះ បើទោះបីជា សួង ស៊ីគឿន ពុំត្រូវបានណែនាំដោយផ្ទាល់ពី ខៀវ សំផន ក៏ដោយ ក៏គាត់ចាំថាបានឃើញ ខៀវ សំផន នៅបុរីកីឡា[4919]។ ចម្លើយទាំងអស់នេះបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន ពិតណាស់ជាប់ពាក់ព័ន្ធនៅក្នុងវគ្គបណ្តុះបណ្តាលនយោបាយនោះ។ ជាទូទៅ ការដែលថា ប៉ុល ពត និង នួន ជា ប្រហែលជាបានដឹកនាំវគ្គបណ្តុះបណ្តាលនយោបាយញឹកញាប់ជាង ខៀវ សំផន ពុំបានធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលា

---

[4913] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦១ យោងទៅលើប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ (ជា សាយ) ឯកសារលេខ E1/124.1 ទំព័រ ៥៩។

[4914] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦១។

[4915] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៨០។

[4916] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៨០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៣៨, ៣៥១៧, ៤០៥៤។

[4917] ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ (ជា សាយ) ឯកសារលេខ E1/124.1 ទំព័រ ២៧-៣៣, ៦៣-៦៤។ ប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (វ៉ាចាម តុន) ឯកសារលេខ E1/96.1 ទំព័រ ៧០-៧១។ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៦២-៦៣ ។

[4918] ប្រតិចារឹកថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ (សៅ សារុន) ឯកសារលេខ E1/82.1 ទំព័រ ១៤-១៥។

[4919] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ឯកសារលេខ E1/102.1 ទំព័រ ៥៨។

ដំបូងដែលថា គាត់បានដឹកនាំវគ្គបណ្តុះបណ្តាលមួយចំនួន និងដូចគ្នានេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួម។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ត្រឹមតែបង្ហាញការបកស្រាយមួយផ្សេងលើភស្តុតាងដោយគ្មានការបង្ហាញនូវកំហុសឡើយ។

1761.ចុងក្រោយ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ពាក្យសម្តីដែលត្រូវបានសន្មតថា ជារបស់គាត់“ទាក់ទងទៅនឹងគម្រោងសេដ្ឋកិច្ចទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា” បង្កើតបានជាការរួមចំណែកសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម[4920]។ ក្រៅពី អែម អឿន និង ឯក ហេន ខៀវ សំផន បានអះអាងថា សាក្សីរបស់អយ្យការមានដូចជា ជា សាយ, ពាន ឃាន, អ៊ុង ចុងហឿង និង Philip SHORT ពុំបានឆ្លើយដាក់បន្ទុកដល់រូបគាត់ឡើយ[4921]។ គាត់បានលើកឡើងថា សាក្សីទាំងនេះ“ពុំបានបង្ហាញភស្តុតាងអំពីចេតនាឧក្រិដ្ឋ”ពីខាងគាត់ឡើយ[4922]។

1762.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការវិភាគជាផ្នែកៗរបស់ ខៀវ សំផន ខកខានក្នុងការពិចារណាលើភស្តុតាងជារួម ដែលទម្ងន់នៃភស្តុតាងនេះបានគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបង្រៀនរបស់គាត់បានជាប់ពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ“ខ្មាំង” និងស្វែងរក“ជនក្បត់”[4923]។ ក្រៅពី អែម អឿន និង ឯក ហេន ខៀវ សំផន ពុំបានអើពើទៅនឹងសក្ខីកម្មរបស់ វ៉ាចាម តុន *ហៅ* ភី ភួន ដែលថា ខ្លួនគាត់ផ្ទាល់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅ ក-១៥ ដែលដឹកនាំដោយ ខៀវ សំផន ដែលក្នុងនោះស្ថានភាពនយោបាយខាងក្រៅ និងខាងក្នុង និង“ខ្មាំងរួម”ត្រូវបានពិភាក្សា ព្រមទាំងសក្ខីកម្មរបស់ ប៊ិត ហឿន *ហៅ* ប៊ិត ណា ដែលបានអះអាងថា ខៀវ សំផន បានចូលរួមយ៉ាងសកម្មជាមួយ ប៉ុល ពត និង នួន ជា ក្នុងវគ្គបណ្តុះបណ្តាលនយោបាយ និងបានណែនាំកម្មាភិបាលពាណិជ្ជកម្មឱ្យស្វែងរកខ្មាំងផ្ទៃក្នុង[4924]។ យោង

---

[4920] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦០។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦២។

[4921] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦២។

[4922] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦២។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦០ (“ប្រធានបទដែលគ្របដណ្តប់ក្នុងវគ្គបណ្តុះបណ្តាលដូចបានពិពណ៌នាដោយសាក្សី ដែលត្រូវបានដកស្រង់ [...] ពុំបានប្រើប្រាស់ដើម្បីគាំទ្រចេតនាល្មើសរបស់ម្ចាស់បណ្តឹងសាទុក្ខឡើយ”)។

[4923] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៩ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៧ (ជើងទំព័រ ១៩០៤)។

[4924] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៩ យោងទៅលើប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/96.1 ទំព័រ ៧០-៧១។ ប្រតិចារឹក ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ (វ៉ាចាម តុន *ហៅ* ភី

តាមសហព្រះរាជអាជ្ញាបានឱ្យដឹងថា ម្ចាស់បណ្តឹងសាទុក្ខបានបំភ្លៃសក្ខីកម្មរបស់ ពាន ឃាន ដែលបានអះអាងថា បទឧទ្ទេសនាមរបស់ ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តដទៃទៀត មានការណែនាំឱ្យកំណត់អត្តសញ្ញាណខ្មាំងជ្រៀតចូលផ្ទៃក្នុង មានដូចជា ភ្នាក់ងារ CIA និង KGB និង វៀតណាម ដើម្បីការពារប្រទេសពីការឈ្លានពានរបស់វៀតណាម ឬការវិលត្រឡប់របស់ចក្រពត្តិអាមេរិក[4925]។

1763.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានរកពុំឃើញកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងរបស់ អែម អឿន និង ឯក ហេន ដែលបានផ្តល់សក្ខីកម្មចំពោះសម្តីរបស់ ខៀវ សំផន និយាយអំពី"ខ្មាំង"របស់កម្ពុជាប្រជាធិបតេយ្យក្នុងវគ្គបណ្តុះបណ្តាលនយោបាយនោះ[4926]។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា រ៉ចាម តុន *ហៅ* ភី ភួន និង ប៊ិត ហឿន *ហៅ* ប៊ិត ណា បានផ្តល់សក្ខីកម្មចំពោះការគាំទ្ររបស់ ខៀវ សំផន ដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងសត្រូវក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលនយោបាយ។

1764.អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ក្រៅពីការយល់ឃើញដែលថា ខៀវ សំផន ណែនាំការអនុវត្តន៍គោលនយោបាយប្រឆាំងនឹងសត្រូវ[4927] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខៀវ សំផន បានរួមចំណែកក្នុងផែនការរួមតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលនយោបាយ"ក្នុងគោលបំណងពង្រឹងមនសិការសង្គមនិយម បង្កើតអត្តសញ្ញាណកម្មករ-កសិករ និងផ្តល់ការគាំទ្រដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា"[4928] រួមទាំងតាមរយៈការសម្រេចគោលដៅបង្កបង្កើនផល និងសេដ្ឋកិច្ច[4929]។ ការយល់ឃើញនេះត្រូវ

---

ភួន) ឯកសារលេខ E1/100.1 ទំព័រ ៨២-៨៣។ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន *ហៅ* ប៊ិត ណា) ឯកសារលេខ E1/502.1 ទំព័រ ១៧-១៨, ២០, ២២-២៣។

[4925] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៧៩ យោងទៅលើប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ (ពាន ឃាន) ឯកសារលេខ E1/73.1 ទំព័រ ១៧-២០។

[4926] *សូមមើលខាងលើ* ផ្នែក V.ឃ.៧។

[4927] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៤២៧១, ៣៣៩០ (ការចូលរួម និងការបង្រៀនក្នុងវគ្គបណ្តុះបណ្តាលដែលវៀតណាម និង"ភ្នាក់ងារ"ត្រូវបានថ្កោលទោសថា ជាខ្មាំង និងសង្កត់ធ្ងន់ទៅលើភាពចាំបាច់ក្នុងការនិរទេស)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧២, ៣៩៤២-៣៩៤៣, ៣៩៦៧, ៤២២៦ (ណែនាំកម្មាភិបាលអំពីវិធីកំណត់អត្តសញ្ញាណខ្មាំង និងការជៀសវាងចាត់ទុកថា ជាខ្មាំង)។

[4928] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២។

[4929] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៣, ៣៩១៦, ៣៩៤២។

បានគាំទ្រដោយសក្ខីកម្មរបស់សាក្សីជាច្រើន មានដូចជា ពាន ឃាន,[4930] អែម អឿន,[4931] ឯក ហេន,[4932] ជា សាយ,[4933] រ៉ចាម គុន,[4934] អ៊ុង ចុងហឿង[4935] និង Philip SHORT[4936]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា ការបណ្តុះបណ្តាលដែលគាត់បានផ្តល់នោះ ពាក់ព័ន្ធទៅនឹង"គម្រោងសេដ្ឋកិច្ចទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា" ដែលផ្ទុយពីគោលនយោបាយឧក្រិដ្ឋនានា។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកសារណារបស់ម្ចាស់បណ្តឹងសាទុក្ខថា ជាការយល់ខុសត្រង់ចំណុចដែលគាត់បានអះអាងថា ការបង្ហាញថា ពាក្យសម្តីរបស់គាត់*តាមសេចក្តីបញ្ជាក់ដំបូង* បាន

---

[4930] ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ (ពាន ឃាន) ឯកសារលេខ E1/73.1 ទំព័រ ១៦-១៧, ១៨ (បញ្ជាក់ថា ខៀវ សំផន "បានបង្រៀននយោបាយកម្រិតខ្ពស់"), ទំព័រ ១៩ ("កិច្ចប្រជុំនោះក្នុងគោលបំណងដើម្បីដាស់ប្រជាជនអំពីវិធីដែលពួកគេអាចអភិវឌ្ឍប្រទេស និងវិធីត្រូវបង្កើតសហករណ៍ [...] មាគ៌ានយោបាយ និងក្តីសង្ឃឹមសម្រាប់ការកសាងប្រទេសថ្មីថ្មើនក្នុងពេលអនាគត"), ទំព័រ ១៩ (បញ្ជាក់ថា "មាគ៌ានយោបាយដំបូងគឺត្រូវកសាងប្រទេស [...] ទីបី ត្រូវបង្កើតសហករណ៍ និងបង្កើតរបបសមូហភាព និងជម្រុញប្រជាជនទាំងអស់ត្រូវជីកប្រឡាយ លើកទំនប់ ដើម្បីឱ្យប្រទេសជឿនលឿនឆាប់រហ័ស")។

[4931] ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារលេខ E1/115.1 ទំព័រ ៤២ (ជម្រុញកម្មាភិបាលត្រូវបំពេញតាមការណែនាំអង្គការ"ជាដាច់ខាត")។

[4932] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៦-៣៨ ការបង្រៀន "ចាប់ផ្តើមជាមួយ ខៀវ សំផន ពន្យល់ណែនាំពួកកម្មករទាំងអស់ឲ្យខំប្រឹងធ្វើការដើម្បីជួយប្រទេសជាតិ។ [...] មិនមាននាំឱ្យយើងមានទំនាស់ទាស់ទែងគ្នាអី គាត់ឲ្យចេះសាមគ្គីគ្នាក្នុងក្រុម ក្នុងកង ពលកម្មដើម្បីស្តារសេដ្ឋកិច្ចប្រទេសជាតិ។ យើងកំពុងតែរួចពីសង្គ្រាម")។ ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤-៤១, ៥៣, ៦៦-៧១, ៧៧, ៨១-៨៦ (ខៀវ សំផន បានបង្រៀនអំពីបំពេញការងារតាមកំណត់ រួមទាំងការបង្កបង្កើនផលស្រូវបីតោនមួយហិកតា)។

[4933] ប្រតិចារឹក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ (ជា សាយ) ឯកសារលេខ E1/124.1 ទំព័រ ២៥-៣០, ៦០ (នួន ជា និង ខៀវ សំផន ត្រូវរៀនអំពី "ការសន្សំសំចៃ និងអំពីការខំធ្វើការងារ" រួមទាំង"ឲ្យខំការងារដើម្បីកសាងប្រទេសជាតិ")។

[4934] ប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (រ៉ចាម គុន) ឯកសារលេខ E1/96.1 ទំព័រ ៥៣-៥៥ (ខៀវ សំផន និង នួន ជា គឺនៅក្នុងចំណោមគ្រូដែលបង្រៀនអំពី "ជំហរសតិអារម្មណ៍របស់ទស្សនៈបដិវត្តន៍")។ ប្រតិចារឹក ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ (រ៉ចាម គុន) ឯកសារលេខ E1/100.1 ទំព័រ ៧៥-៧៧ (ខៀវ សំផន បាននិយាយអំពី "ស្ថានភាពទាំងក្នុង និងក្រៅប្រទេស និងស្ថានភាពបន្ទាប់ពីរំដោះ។ ហើយក្រៅពីនេះ គាត់បាននិយាយអំពីបដិវត្តន៍សង្គមនិយម [និង] ជីវទស្សនៈបដិវត្ត")។

[4935] ប្រតិចារឹក ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ (អ៊ុង ចុងហឿង) ឯកសារលេខ E1/103.1 ទំព័រ ៨៤ (សាក្សីបានប្រាប់ប្រពន្ធគាត់ថានៅ ក-១៥ ខៀវ សំផន បានបង្រៀនថា "ប្រទេសកម្ពុជាកំពុងតែកសាងរីកចម្រើន ឲ្យទុកចិត្តប្រជារាស្ត្រ ហើយឲ្យខំកសាងខ្លួនឯង")។

[4936] ប្រតិចារឹក ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ១៥-១៦ ដកស្រង់ពីសៀវភៅនិពន្ធដោយ Philip SHORT៖ ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ (២០០៤) ឯកសារលេខ E3/9 ទំព័រ ៣១៦-៣១៧ ERN 00396524-00396525 (ភាសាអង់គ្លេស) (ខៀវ សំផន បានផ្តល់ការអប់រំរយៈពេលយូរខែដល់ដល់អ្នកត្រឡប់មកវិញ)។

បង្ហាញនូវចេតនាឧក្រិដ្ឋនោះ ទើបជាការចាំបាច់ក្នុងការយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសំខាន់ក្នុងផែនការរួមនោះ។

1765.យោងតាមសំអាងហេតុនេះ អំណះអំណាងដទៃទៀតរបស់ ខៀវ សំផន ទាក់ទងទៅនឹងការរួមចំណែកសំខាន់ក្នុងផែនការរួម តាមរយៈការដឹកនាំវគ្គបណ្តុះបណ្តាលនយោបាយ ត្រូវបដិសេធចោល។

ខ. សមាជិកមន្ទីរ ៨៧០

1766.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មន្ទីរ ៨៧០ ជាអ្នកគ្រប់គ្រងការអនុវត្តន៍សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ និងកាលដំបូងឡើយមានសមាជិកពីរនាក់៖ សើ វ៉ាស៊ី *ហៅ* ឌឿន ដែលត្រូវបានជ្រើសតាំងធ្វើជាប្រធានមន្ទីរ ៨៧០ ក្នុងខែ តុលា ឆ្នាំ ១៩៧៥ និងខៀវ សំផន [...] "ដែលបានចូលរួមក្នុងពេលជាមួយគ្នានោះដែរ"[4937]។ ខៀវ សំផន បានបន្តកាន់កាប់តួនាទីមួយចំនួនក្នុងមន្ទីរ ៨៧០ បន្ទាប់ពី ឌឿន ត្រូវបានចាប់ខ្លួនក្នុងដើមឆ្នាំ ១៩៧៧។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីពិនិត្យយ៉ាងទូលំទូលាយលើភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ការទទួលខុសត្រូវពិតប្រាកដរបស់ ខៀវ សំផន នៅមន្ទីរ ៨៧០ ដែលខុសប្លែកពីការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងមុនគាត់ ឬជាប់ពាក់ព័ន្ធទៅនឹងការតែងតាំងតួនាទីដទៃទៀតរបស់គាត់ ពុំមានភាពច្បាស់លាស់"[4938]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ដោយសារភស្តុតាងមិនគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ អង្គជំនុំជម្រះពុំអាចសន្និដ្ឋានបានថា ខៀវ សំផន ជាប្រធានមន្ទីរ ៨៧០ ឬជាក់ស្តែងជា'កម្មាភិបាលដឹកនាំ'នៅទីនោះដូចការចោទប្រកាន់ដោយដីកាដំណោះស្រាយឡើយ"[4939]។

1767.ជាដំបូង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងមន្ទីរ ៨៧០ ក្នុងខែ តុលា ឆ្នាំ ១៩៧៥ និងការខកខានក្នុងការកត់សម្គាល់ថា "ការជាប់ពាក់ព័ន្ធ

---

[4937] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤។

[4938] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៥។

[4939] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៩។ សេចក្តីបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា (E457/6/1) កថាខណ្ឌ ៤១៧-៤១៩។ ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១១៣៩-១១៤១។

របស់គាត់ តែលើបញ្ហាដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម"[4940]។ បន្ថែមលើនេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានចាត់ទុក ខឿន ជាអ្នកគ្រប់គ្រងមុន។ យោងតាមម្ចាស់បណ្តឹងសាទុក្ខថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ត្រឹមត្រូវថា គាត់ពុំមែនជាមេដឹកនាំជាន់ខ្ពស់ និងពុំបានទៅជំនួស ខឿន អង្គជំនុំជម្រះពុំអាចបានសរុបជារួមនូវការដឹងរបស់គាត់ ឬការរួមចំណែកសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមឡើយ[4941]។

1768. ទាក់ទងទៅនឹងកាលបរិច្ឆេទនៃការទទួលស្គាល់ និងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ពីព្រោះកំណត់ហេតុនេះពុំបានចាត់តាំងរូបគាត់ដូចធ្វើកន្លងមកទៅមន្ទីរ ៨៧០ ប៉ុន្តែផ្ទុយទៅវិញ ដាក់ឱ្យគាត់"ទទួលខុសត្រូវលើរណសិរ្ស និងរាជរដ្ឋាភិបាល ពាណិជ្ជកម្មសម្រាប់ការទូទាត់បញ្ជី និងតម្លៃ"[4942]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើ"ការចងចាំដែលភាន់ច្រឡំខ្លះៗ" ដោយសារគាត់ជានិច្ចកាលនិយាយសំដៅទៅលើភារកិច្ចជារួមរបស់គាត់ពាក់ព័ន្ធទៅនឹងតារាងតម្លៃ ការបែងចែកទំនិញតាមភូមិភាគ និងការនាំចេញ[4943]។ ដូច្នេះ បើទោះបីជាគាត់បានលើកឡើងខែតុលា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងគប្បីបាន"កែតម្រូវការប៉ាន់ស្មាននេះ"ដោយយោងទៅលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦ ដែលបង្កើតគណៈកម្មាធិការពាណិជ្ជកម្ម[4944]។ ខៀវ សំផន ចង្អុលបង្ហាញទៅលើសេចក្តីសម្រេចសង្ខេបនៃគណៈអចិន្ត្រៃយ៍ក្នុងកិច្ចប្រជុំថ្ងៃទី ១៩, ២០ និង ២១ ខែ មេសា ឆ្នាំ ១៩៧៦[4945]។ ការដែលសេចក្តី

---

[4940] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៤។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៣។

[4941] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៩។

[4942] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៤ យោងទៅលើកំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារលេខ E3/182 ERN 00019108-00019110។

[4943] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៥។

[4944] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៦ យោងទៅលើកំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ ឯកសារលេខ E3/233 ERN 00000749 ទំព័រ ១។

[4945] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៦-១៧៦៧ យោងទៅលើសរុបសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី១៩-២១ ខែ មេសា ឆ្នាំ១៩៧៦ ឯកសារលេខ E3/235 ERN 00019144-00019147 ទំព័រ ៣-៥។

សម្រេចនេះតែងតាំងគាត់ជា"ជំនួយការបច្ចេកទេស" គប្បីបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងមន្ទីរ ៨៧០ ត្រូវបានកម្រិតត្រឹមពាណិជ្ជកម្ម[4946]។

1769.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ភស្តុតាងជាច្រើន មានដូចជា ការទទួលស្គាល់ផ្ទាល់ខ្លួន បង្ហាញថា ខៀវ សំផន បានចូលរួមក្នុងមន្ទីរ ៨៧០[4947] នៅប្រហាក់ប្រហែលខែតុលា ឆ្នាំ ១៩៧៥[4948]។ ជាពិសេស សហព្រះរាជអាជ្ញាបានលើកឡើងថា ភស្តុតាងផ្ទាល់ខ្លួនរបស់ ខៀវ សំផន ដែលថា គាត់បានចូលរួមមន្ទីរ ៨៧០ ក្នុងខែ តុលា ឆ្នាំ ១៩៧៥ និងត្រូវបានដាក់ឱ្យទទួលខុសត្រូវក្នុងការរៀបចំបញ្ជីតម្លៃ និងបែងចែកទំនិញក្នុងប្រទេស ស្របគ្នាជាមួយនឹងភស្តុតាងបង្ហាញអំពីភារកិច្ចដែលត្រូវបានចាត់តាំងឱ្យគាត់ដោយគណៈអចិន្ត្រៃយ៍ក្នុងខែ តុលា ឆ្នាំ ១៩៧៥ មានន័យថា ដាក់ឱ្យគាត់ទទួលខុសត្រូវលើ"ពាណិជ្ជកម្មសម្រាប់ការធ្វើបញ្ជី និងតម្លៃ"[4949]។

1770.ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទចូលរួមមន្ទីរ ៨៧០ ខៀវ សំផន បានលើកសារណានេះសាជាថ្មីដែលត្រូវបានដោះស្រាយពេញលេញដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[4950]។ ខៀវ សំផន ពុំបានលើកអំណះអំណាងដែលផ្តល់យុត្តិកម្មសម្រាប់ការប្រាសចាកពីសំអាងហេតុដំបូងរបស់អង្គជំនុំជម្រះលើចំណុចនេះឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពុំមានការយល់ឃើញអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ស្តីពីបញ្ហាថាតើ គាត់បានចូលរួមក្នុងមន្ទីរ ៨៧០ ក្នុងខែ តុលា ឆ្នាំ ១៩៧៥ ជាជាងខែ មីនា ឆ្នាំ ១៩៧៦ នោះឡើយ ដែល ខៀវ សំផន បានអះអាងថា ជាកាលបរិច្ឆេទត្រឹមត្រូវ ដូច្នេះ ពុំមានភាពមិនយុត្តិធម៌បានកើតឡើងដោយសារការយល់ឃើញនេះទេ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់ស្តីពីបញ្ហានេះ ត្រូវបដិសេធចោល។

---

4946 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៧។

4947 សហព្រះរាជអាជ្ញាចង្អុលបង្ហាញថា ខៀវ សំផន បំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចថា អង្គជំនុំជម្រះពុំបានយល់ឃើញថា គាត់បានចូលរួម"ក្នុង"ខែ តុលា ឆ្នាំ ១៩៧៥ ប៉ុន្តែ "ប្រហែលពេលវេលានេះ"ដូច ឌឿន ដែរ។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០៧ (ជើងទំព័រ ៣១៤៤)។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៤, ៦០៨។

4948 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០៧។

4949 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០៧ (ជើងទំព័រ ៣១៤៥) យោងទៅលើកំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារលេខ E3/183 ERN 00019108។ សៀវភៅនិពន្ធដោយ ខៀវ សំផន *ប្រវត្តិសាស្ត្រថ្មី*របស់កម្ពុជា ឯកសារលេខ E3/18 ទំព័រ ៧៣-៧៤ ERN 00103844-00103845។

4950 សាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១៧។

1771.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើតួនាទីមានកម្រិតរបស់ ខៀវ សំផន ក្នុងមន្ទីរ ៨៧០ ដែលតាមការអះអាងរបស់គាត់ "ពាក់ព័ន្ធតែលើបញ្ហាទាក់ទងទៅនឹងពាណិជ្ជកម្ម"[4951]។ ផ្ទុយទៅវិញ ដោយពុំអាចសន្និដ្ឋានបានថា គាត់គឺជាប្រធាន ឬជាកម្មាភិបាលដឹកនាំនៃមន្ទីរនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រុងប្រយ័ត្នយ៉ាងពិសេសក្នុងការសំអាងទៅលើតួនាទីរបស់គាត់នៅទីនោះធ្វើជាមូលដ្ឋាននៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ជាពិសេស ពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើ"ការពិតដែលថា គាត់នៅតែជាសមាជិកម្នាក់ក្នុងចំណោមសមាជិកពីរទៅបីនាក់ក្នុងមន្ទីរ ៨៧០ បន្ទាប់ពីការបាត់ខ្លួនរបស់ ឌឿន សម្រាប់រយៈពេលពីរឆ្នាំក្រោយមកមុនការដួលរលំកម្ពុជាប្រជាធិបតេយ្យ ដែលជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនក្នុងការយល់ឃើញថា គាត់បានដឹងអំពីការចាប់ខ្លួន និងសម្លាប់ ឌឿន ប៉ុណ្ណោះ[4952]។ ទាក់ទងទៅនឹងការរួមចំណែករបស់គាត់ក្នុងគោលបំណងរួម អង្គជំនុំជម្រះបានចាត់ទុកសមាជិកភាពរបស់គាត់ស្ថិតក្នុងចំណោមកត្តាជាច្រើនសន្និកសន្ធាប់ ដែលបង្ហាញអំពីការបន្តគាំទ្ររបស់គាត់ និងការជួយដល់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្រេចគោលដៅរបស់ខ្លួន[4953]។ បន្ថែមលើនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា "ក្នុងនាមជាសមាជិកមន្ទីរ ៨៧០ និងជាអ្នកគ្រប់គ្រងលើពាណិជ្ជកម្ម ខៀវ សំផន ផ្ទាល់ខ្លួនបានជួយឱ្យរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យដំណើរការទៅដោយរលូន ក្នុងទិសដៅបំផ្លាញប្រជាជនខ្លួន"[4954]។ អង្គជំនុំជម្រះបន្ទាប់មកបន្តបញ្ជាក់ច្បាស់លាស់នូវសកម្មភាពរបស់គាត់ក្នុងការគ្រប់គ្រងពាណិជ្ជកម្ម និងជំនួញ ដោយបានផ្អែកជាចម្បងលើតួនាទីទាំងនេះ។ ពុំមានការយល់ឃើញណាមួយបានសំអាងទៅលើការពង្រីករបស់អង្គជំនុំជម្រះសាលាដំបូងនូវតួនាទីរបស់ ខៀវ សំផន ក្នុងមន្ទីរ ៨៧០ ឱ្យហួសផុតពីអ្វីដែលត្រូវបានគាំទ្រដោយភស្តុតាងឡើយ។ អំណះអំណាងពាក់ព័ន្ធចំណុចនេះត្រូវបដិសេធចោល។

1772.ចុងក្រោយ ខៀវ សំផន បានលើកឡើងថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងលើរូបគាត់ថា ជា"អ្នកគ្រប់គ្រង"បន្ទាប់ ឌឿន នៅពេលអង្គជំនុំជម្រះពុំអាចកំណត់បាននូវតួនាទីពិតប្រាកដដែលគាត់មានក្នុងមន្ទីរ ៨៧០ គឺជាការ"ផ្ទុយគ្នាច្បាស់ក្រឡែត" ដោយសារអាចស្មើនឹង"ការនិយាយបានថា ខៀវ សំផន ជាក់ស្តែង

---

[4951] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៤។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៣។

[4952] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៥។

[4953] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧។

[4954] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៦។

ជំនួសកន្លែង ខឿន ដែលជាការយល់ឃើញមួយអង្គជំនុំជម្រះ [...] បានបដិសេធ"[4955]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា កំហុសនេះនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា គាត់ត្រូវបានកំណត់ជាអ្នកទទួលទូរលេខជាច្រើនដែលផ្ញើមក"ម-៨៧០" ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨[4956]។

1773.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទីរបស់ ខៀវ សំផន ក្នុងមន្ទីរ ៨៧០ "ការប្រើប្រាស់ពាក្យ"អ្នកគ្រប់គ្រងមុន"ក្នុងកថាខណ្ឌដែលរងការជំទាស់នោះ អាច [...] ត្រូវបានបកស្រាយយ៉ាងសមស្របថា ជាកំហុសបច្ចេកទេស ឬការភាន់ច្រឡំដែលកើតឡើង ដោយសារការពិតដែលថា ខឿន ពិតណាស់គឺជាអ្នកគ្រប់គ្រងមុនម្ចាស់បណ្តឹងសាទុក្ខក្នុងគណៈកម្មាធិការ ពាណិជ្ជកម្ម"[4957]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា កំហុសនេះសំខាន់ធ្វើឱ្យសាលក្រមប្រែប្រួល និងបណ្តាលឱ្យមានភាពមិនយុត្តិធម៌[4958]។

1774.អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ ខឿន ថា ជា "អ្នកគ្រប់គ្រងមុន" ខៀវ សំផន ក្នុងការយល់ឃើញរបស់ខ្លួនស្តីពីតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០[4959] គឺជាកំហុសដោយសារពុំមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជំនុំជម្រះសាលាដំបូង ដែលថា នេះពុំមានភស្តុតាងបង្ហាញច្បាស់លាស់ឡើយ។ ទោះជាយ៉ាងណាក្តី កំហុសនេះពុំបណ្តាលឱ្យមាន ភាពមិនយុត្តិធម៌ឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើការយល់ឃើញដែលថា ខៀវ សំផន បានបន្តតំណែងបន្ទាប់ពី ខឿន ក្នុងការកំណត់ថា គាត់បានដឹងអំពីខ្លឹមសារនៃរបាយការណ៍ដែលបានផ្ញើ ទៅ"ម-៨៧០"[4960]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការដែលថា ទូរលេខបានបន្ត

---

[4955] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៨។

[4956] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៨ (ជើងទំព័រ ៣៤២៣) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៥។

[4957] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៦, ៤២២៥។

[4958] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩០៨។

[4959] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៦។

[4960] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦៨ (ជើងទំព័រ ៣៤២៣) យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៥។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការយោងនេះមានកំហុស និងពិចារណាឃើញថា ខៀវ សំផន ចង់សំដៅទៅលើកថាខណ្ឌ ៦១០ នៃសាលក្រមអង្គជំនុំជម្រះ។

ផ្ញើទៅមន្ទីរ ៨៧០ ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ ដែលជាភស្តុតាងបង្ហាញថា មន្ទីរនេះខ្លួនឯង"នៅបន្តប្រតិបត្តិការបន្ទាប់ពីការចាប់ខ្លួន ឌឿន"[4961]។

1775.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើ ឌឿន ថា ជា"អ្នកគ្រប់គ្រងមុន" ខៀវ សំផន ជាលើកទីពីរក្នុងការពិភាក្សារបស់ខ្លួនអំពីធាតុអត្តនោម័តិរបស់ ខៀវ សំផន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហាថាតើ ការយោងលើកទីពីរនេះបង្កើតបានជាកំហុសដែលតម្រូវឱ្យមានការចូលអន្តរាគមន៍របស់ខ្លួន ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាជាច្រើនក្នុងការសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីការចាប់ខ្លួន ឌឿន និងការសម្លាប់។ កត្តាមួយក្នុងចំណោមនោះ គឺថា"ការដែលគាត់នៅតែជាសមាជិកម្នាក់ក្នុងចំណោមសមាជិកពីរទៅបីនាក់ក្នុងមន្ទីរ ៨៧០ ក្រោយការបាត់ខ្លួន ឌឿន សម្រាប់រយៈពេលពីរឆ្នាំនៅមុនការដួលរលំកម្ពុជាប្រជាធិបតេយ្យ" និងមួយទៀត"ការទទួលយករបស់ ខៀវ សំផន លើការគ្រប់គ្រង និងការទទួលខុសត្រូវជំនួស ឌឿន ក្នុងគណៈកម្មាធិការពាណិជ្ជកម្ម" ដែលស្របពេលជាមួយនឹងការដកដំណែងកម្មាភិបាលនានាចេញពីក្រសួងពាណិជ្ជកម្ម[4962]។ អង្គជំនុំជម្រះសាលាដំបូងបានបន្តផ្តល់ហេតុផលថា "តាមរយៈការទទួលយកតួនាទីរបស់ ឌឿន ក្នុងអំឡុងពេលនៃចលាចលផ្ទៃក្នុង ខៀវ សំផន មិនត្រឹមតែបានដឹងថា ឌឿន ត្រូវបានបោសសម្អាតប៉ុណ្ណោះទេ ថែមទាំងបានដឹងប្រាកដខ្លួនឯងថា ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងមុន នៅតែត្រូវបានបំពេញបន្ទាប់ពីការដក ឌឿន ចេញនោះ"[4963]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បរិបទនេះបញ្ជាក់ច្បាស់ថា ពាក្យ"អ្នកគ្រប់គ្រងមុន"ត្រូវបានប្រើប្រាស់ក្នុងការយោងទៅលើការទទួលយករបស់ ខៀវ សំផន នូវការទទួលខុសត្រូវរបស់ ឌឿន ក្នុងគណៈកម្មាធិការពាណិជ្ជកម្ម និងពុំមែនសំដៅលើតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ នោះទេ។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងប្រហែលជាបានបញ្ជាក់ខ្លួនឯងយ៉ាងច្បាស់លាស់ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ពិចារណាថា ការប្រើប្រាស់ពាក្យ"អ្នកគ្រប់គ្រងមុន"ក្នុងបរិបទនេះ មានកំហុសនោះឡើយ។

1776.យោងតាមសំអាងហេតុខាងលើ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ ត្រូវបដិសេធចោល។

---

[4961] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១០។

[4962] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៥។

[4963] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៥។

## គ. ការគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្ម

### i. ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម

1777.ខៀវ សំផន បានលើកចំណុចជាច្រើនក្នុងបណ្តឹងសាទុក្ខជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ក្នុងជំនួញ និងពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ[4964]។ ជាការចាប់ផ្តើម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គាត់បានបញ្ជាក់សាឡើងវិញនូវការអះអាងជាច្រើនថា តួនាទីរបស់គាត់ក្នុងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យមានកម្រិត” ដែលនេះត្រូវបានបញ្ជាក់ដោយចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[4965]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាពីដំបូងលើអំណះអំណាងជាច្រើនក្នុងបញ្ជាក់ថា “ឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការយល់ឃើញថា គាត់មានសិទ្ធិអំណាចគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម ជាក់ស្តែងបានបង្ហាញនូវមុខនាទីរបស់គាត់មានក្រិតប៉ុណ្ណោះ”[4966]។

1778.ក្នុងសំណុំរឿង ០០២/០១ ការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលបង្ហាញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម មិនត្រឹមតែបានផ្អែកទៅលើភស្តុតាងដែលត្រូវបានសួរដេញដោលប៉ុណ្ណោះទេ ថែមទាំងលើការយល់ឃើញទាំងអស់របស់ខ្លួនពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ក្នុងគណៈកម្មាធិការនោះ និងបន្ថែមថា ខៀវ សំផន ត្រឹមតែធ្វើការបកស្រាយមួយផ្សេងលើភស្តុតាងដោយគ្មានការបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងជាការពុំសមហេតុផលនោះឡើយ[4967]។ អង្គជំនុំជម្រះតុលាការកំពូលនៅរក្សាការវាយតម្លៃរបស់ខ្លួនពីមុន ពាក់ព័ន្ធទៅនឹងអំណះអំណាងជាច្រើនដែល ខៀវ សំផន ត្រឹមតែលើកច្រំដែលក្នុងសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២[4968]។

---

[4964] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧០-១៧៨៨។

[4965] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១៨ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៤-៥៥៩។

[4966] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១៨ យោងទៅលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៤-៥៥៩។

[4967] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១៨។

[4968] អំណះអំណាងដែលលើកច្រំដែលដោយ ខៀវ សំផន រួមបញ្ចូលការដែលអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាថា (១) របាយការណ៍គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ និង ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៦

1779.សំអាងហេតុស្រដៀងគ្នាអនុវត្តចំពោះអំណះអំណាងបន្ថែមជាច្រើនដែលបានលើកឡើងដោយ ខៀវ សំផន នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ដែលបានលើកការបកស្រាយមួយផ្សេងលើភស្តុតាងក្នុងគោលបំណងព្យាយាមបង្ហាញខ្លួនគាត់ថាមានតួនាទីតូចតាចដែលជាលក្ខណៈបច្ចេកទេសសុទ្ធសាធនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។ ក្នុងសារណារបស់គាត់ ខៀវ សំផន បានទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះតុលាការកំពូលទៅលើការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាថា ខឿន នៅតែជាប្រធាននៃគណៈកម្មាធិការពាណិជ្ជកម្ម និងក្នុងឋានៈនោះក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៧ ខឿន បានថ្លែងក្នុងពិធីជប់លៀងពាក់ព័ន្ធទៅនឹងការចរចារជាមួយប្រទេសយូហ្គោស្លាវីដែលបានផ្តល់កិត្តិយសដល់ វន វេត ដែលបានដឹកនាំការចរចារនោះ[4969]។ អៀង សារី ដែលត្រូវបានជួយដោយ វ៉ាន់ រិត បានដឹកនាំការចរចារជាមួយប្រទេសចិនក្នុងខែ ធ្នូ ឆ្នាំ ១៩៧៨[4970]។ របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្មដែលស្នើសុំ“យោបល់” ឬ“អនុសាសន៍”ពី ខៀវ សំផន ជាប់ពាក់ព័ន្ធតែកាតព្វកិច្ចរបស់គាត់ក្នុងការបែងចែកសម្ភារៈដែលបាននាំចូលពីប្រទេសយូហ្គោស្លាវី និងប្រទេសចិនទៅតាមភូមិភាគ រីឯ វ៉ាន់ រិត ជាក់ស្តែងទទួលបន្ទុកក្នុងការចរចារ[4971]។ ពុំមានភស្តុតាងបង្ហាញថា ខៀវ សំផន បានចេញសេចក្តីណែនាំពាក់ព័ន្ធទៅនឹងជំនួញ

---

លើកឡើងអំពីតួនាទីមានកម្រិតរបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម និងបានចាត់តាំងការទទួលខុសត្រូវសំខាន់ជាងទៅឱ្យអ្នកដទៃទៀត(សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧២។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៥) (២) ក្នុងខែ មេសា ឆ្នាំ ១៩៧៦ គណៈអចិន្ត្រៃយ៍បានឱ្យ វន វេត ទទួលបន្ទុកគណៈកម្មាធិការពាណិជ្ជកម្ម បានតែងតាំងសមាជិក និងតែងតាំង ខៀវ សំផន ជា“ជំនួយការបច្ចេកទេស” ពាក់ព័ន្ធទៅនឹងគណៈប្រតិភូពាណិជ្ជកម្មទៅប្រទេសកូរ៉េ(សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៥) (៣) គណៈអចិន្ត្រៃយ៍បានចាត់តាំង ខឿន ឱ្យបង្កើតក្រុមជំនួញបរទេសក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ (សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៤។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៥) (៤) សេចក្តីសម្រេចដែលត្រូវបានធ្វើឡើងជាក់ស្តែងដោយគណៈអចិន្ត្រៃយ៍(សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៨ (ជើងទំព័រ ១២១២)) (៥) របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្មធ្វើ ឬចម្លងឱ្យ ខៀវ សំផន បង្ហាញថា តួនាទីរបស់គាត់មានកម្រិត (សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៥-១៧៩០។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៥) (៦) ការចុះរបស់គាត់ទៅពិនិត្យឃ្លាំង ពុំបានបង្ហាញអំពីសិទ្ធិអំណាចក្នុងគណៈកម្មាធិការពាណិជ្ជកម្ម(សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩១-១៧៩៣ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៨)។

[4969] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៤, ១៧៨៨។

[4970] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៥។

[4971] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៦-១៧៧៨។

និងពាណិជ្ជកម្មជាជាងការបែងចែកទំនិញក្នុងភូមិភាគ[4972]។ សាក្សី[4973] និងរបាយការណ៍[4974]បានបង្ហាញនូវលក្ខណៈបច្ចេកទេសមានកម្រិតនៃកិច្ចការរបស់គាត់។ មានកង្វះនៃសកម្មភាពពាក់ព័ន្ធធនាគារក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះធ្វើឱ្យមុខនាទីផ្លូវការរបស់គាត់លែងសំខាន់[4975]។ បន្ថែមលើនេះ ទំនងជាថា ខៀវ សំផន បានព្យាយាមក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង"បានបំភ្លៃភស្តុតាង"[4976] និងមាន "ការយល់ឃើញសមហេតុផលមួយផ្សេងទៀត"ដែលអាចធ្វើឡើង[4977] និងពុំបានបង្ហាញថា ការយល់ឃើញនេះពុំសមហេតុផលឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អំណះអំណាងទាំងនេះបើទោះបើជាតែមួយ ឬត្រួតគ្នាបានបង្ហាញនូវភាពពុំសមហេតុផលពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។

1780.ខៀវ សំផន បានជំទាស់ពីដំបូងផងដែរលើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ ស គីមល្អុត។ ក្នុងសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ខៀវ សំផន បានអះអាងថា សាក្សីនេះបានធ្វើការប៉ាន់ស្មានលើឯកសារដែលគាត់ពុំស្គាល់នៅមុនពេលបង្ហាញដល់គាត់ដោយសហចៅក្រមស៊ើបអង្កេត។ បន្ថែមលើនេះ គាត់ពុំបានធ្វើការជាមួយ ខៀវ សំផន និងពុំបានដឹងអំពីតួនាទីពិតប្រាកដទាក់ទងទៅនឹងជំនួញ ឬពាណិជ្ជកម្ម[4978]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ខាងដើមថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់សាក្សីនេះធ្វើជាប្រភពបន្ថែម និងជាចម្បងបានផ្អែកទៅលើរបាយការណ៍ និងលិខិតចំនួនប្រាំមួយរបស់គណៈកម្មាធិការពាណិជ្ជកម្ម[4979]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តដូចគ្នាក្នុងសំណុំរឿង ០០២/០២[4980]។ បន្ថែមលើនេះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មរបស់ ស គីមល្អុត ដែលថា "វ៉ាន់ រិត

---

[4972] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៩, ១៧៨៤។

[4973] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៤។

[4974] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៧។

[4975] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៣។

[4976] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១១៧០។

[4977] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨០។

[4978] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨២-១៧៨៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៦-៥៥៧។

[4979] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០១៨។

[4980] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៩ (ជើងទំព័រ ១៩៥៤)។

ពុំអាចធ្វើសេចក្តីសម្រេចមួយចំនួនបានទេ និងត្រូវប្រគល់ទៅឱ្យ វន វ៉េត និង ខៀវ សំផន”[4981]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នេះត្រឹមតែជាការសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងនូវសក្ខីកម្មរបស់សាក្សី ជាជាងការយល់ឃើញអំពីអង្គហេតុ[4982]។

1781.ខៀវ សំផន បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី យិន គុជ ក្នុងការបង្ហាញថា គាត់ចុះបានទៅពិនិត្យមើលឃ្លាំង និងថា “ឯកសារនេះគប្បីបដិសេធចោល”[4983]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើការជំទាស់របស់ ខៀវ សំផន ទៅនឹងក្របខ័ណ្ឌគតិយុត្តដែលបានគូសបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការវាយតម្លៃលើការប្រើប្រាស់នៃចម្លើយនោះ និងទម្ងន់ដែលត្រូវផ្តល់ និងរកពុំឃើញកំហុសអង្គច្បាប់[4984]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានសំអាងជាចម្បងទៅលើភស្តុតាងផ្ទាល់មាត់របស់ រស់ ស៊ុយ និង ស៊ឹម ហោ និងបានយោងទៅលើ យិន គុជ ធ្វើជាប្រភពបញ្ជាក់អះអាងបន្ថែម[4985]។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា គប្បីផ្តល់ទម្ងន់តិចតួចទៅលើភស្តុតាងរបស់សាក្សីដែលគ្មានឱកាសដាក់ឱ្យសួរដេញដោល។

1782.លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អំណះអំណាងរបស់ ខៀវ សំផន បានលើកពុំត្រឹមត្រូវ ដោយសារគាត់ព្យាយាមបង្ហាញថា គាត់ពុំមានសិទ្ធិអំណាចពិសេស ឬសំខាន់ក្នុងការធ្វើសេចក្តី

---

[4981] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨២។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៥៥៦។

[4982] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៩ (ជើងទំព័រ ១៩៥៥)។

[4983] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៣។ សាលក្រមអង្គជំនុំជម្រះ កថាខណ្ឌ ៦២០ (ជើងទំព័រ ១៩៦៤)។

[4984] *សូមមើលខាងលើ* ផ្នែក V.ឃ.៣.គ។

[4985] សាលក្រមអង្គជំនុំជម្រះ (E465) កថាខណ្ឌ ៦២០ (ជើងទំព័រ ១៩៦៤)។

សម្រេចនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម[4986] និងថា ស្ថិតនៅលើអ្នកផ្សេង[4987] និងថា មុខនាទីរបស់គាត់ គឺ"ខាងបច្ចេកទេសសុទ្ធសាធ"[4988]។ ការដែលមានឥស្សរជនបក្សកុម្មុយនីស្តកម្ពុជា(ដូចជា អៀង សារី វន វេត និង វ៉ាន់ រិត) មានមុខនាទីរដាច់ដោយឡែកប៉ុន្តែពាក់ព័ន្ធនោះ មានអានុភាពតិចតួចទៅលើកិច្ចការរបស់ ខៀវ សំផន។ ដូចគ្នាដែរ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បើទោះបីជាការតែងតាំងរបស់ ខៀវ សំផន ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធធនាគារ គឺគ្មានន័យដោយសារកង្វះសកម្មភាពពាក់ព័ន្ធនឹងធនាគារក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏នេះពុំបានប៉ះពាល់ដល់មុខនាទីដែលបានគាត់មាននោះឡើយ។

1783.តាមការពិនិត្យពិច័យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា អង្គជំនុំជម្រះពុំបានបំផ្លើសនូវអ្វីដែលបានបង្ហាញទាក់ទងទៅនឹងមុខនាទីពិតប្រាកដរបស់ ខៀវ សំផន នៅក្នុងក្រសួងពាណិជ្ជក

---

[4986] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧៤ ("អង្គជំនុំជម្រះពុំអាចយល់ឃើញថា ខៀវ សំផន មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេច ឬឋានានុក្រមនោះឡើយ"), កថាខណ្ឌ ១៧៧៥ ("ខៀវ សំផន ពុំមែនជាអ្នកចរចារ និង អ្នកធ្វើសេចក្តីសម្រេច"), កថាខណ្ឌ ១៧៧៩ ("សិទ្ធិអំណាចគ្រប់គ្រង"), កថាខណ្ឌ ១៧៨២ ("ពុំស្របទៅនឹងការអះអាងដែលថា គាត់មានសិទ្ធិអំណាចសំខាន់ក្នុងគណៈកម្មាធិការពាណិជ្ជកម្ម"), កថាខណ្ឌ ១៧៨៨ ("គាត់ពុំមែនជាផ្នែកនៃការធ្វើសេចក្តីសម្រេច")។

[4987] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧២ ("ឯកសារលើកឡើងអំពី'សមមិត្ត ធុច" *ហៅ* កុយ ធួន ជាអ្នកទទួលខុសត្រូវលើ'ពាណិជ្ជកម្មក្នុងស្រុក និងក្រៅស្រុក'"), កថាខណ្ឌ ១៧៧៣ ("វន វេត ទទួលបន្ទុកគណៈកម្មាធិការពាណិជ្ជកម្ម"), កថាខណ្ឌ ១៧៧៤ (" ឌឿន ត្រូវបានជ្រើតាំង មិនមែន ខៀវ សំផន ក្នុងខែ ឧសភា ឆ្នាំ ១៩៧៦ ឱ្យបង្កើតក្រុមជំនួញបរទេស", "ជាក់ស្តែង គឺ ឌឿន ក្នុងសមត្ថកិច្ចជាប្រធាន[នៃគណៈកម្មាធិការពាណិជ្ជកម្ម ] បានផ្តល់បទឧទ្ទេសនាម [...] ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៧"), កថាខណ្ឌ ១៧៧៥ ("អៀង សារី ដែលត្រូវបានទទួលការជួយពី វ៉ាន់ រិត បានដឹកនាំការចរចារ", "ការធ្វើសេចក្តីសម្រេចនៅកម្រិតគណៈអចិន្ត្រៃយ៍"), កថាខណ្ឌ ១៧៧៨ ("ក្នុងរបាយការណ៍ទាំងអស់ វន វេត ទំនងជាអ្នកចរចារនាំមុខគេ និងមានសិទ្ធិអំណាចក្នុងការកាន់កាប់តួនាទីផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ), កថាខណ្ឌ ១៧៨៦("សេចក្តីសម្រេចដោយ វន វេត ឬជាទូទៅ [...] *អង្គការ*") ជើងទំព័រ ៣៤៦១ ("វន វេត ជាអ្នកធ្វើសេចក្តីសម្រេច ពុំមែន ខៀវ សំផន), កថាខណ្ឌ ១៧៨៨ ("ការចរចារជាមួយគណៈប្រតិភូពីប្រទេសយូហ្គោស្លាវីដែលដឹកនាំដោយ វន វេត")។

[4988] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧២ ("ការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធទៅនឹងជំនួញ និងពាណិជ្ជកម្ម ត្រូវបានកម្រិតតិចតួច"), កថាខណ្ឌ ១៧៧៣ ("តួនាទីបច្ចេកទេសរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងជំនួញ និងពាណិជ្ជកម្ម"), កថាខណ្ឌ ១៧៧៧ ("បេសកកម្មបច្ចេកទេសដែលគាត់ត្រូវបានចាត់តាំង"), កថាខណ្ឌ ១៧៨០ ("គាត់តម្រូវឱ្យផ្តល់ជំនួយខាងបច្ចេកទេស"), កថាខណ្ឌ ១៧៨៤ ("សាក្សីទាំងនោះដែលលើកឡើងអំពី[ការបែងចែកសម្ភារៈ និងផលិតផលតាមភូមិភាគ ថា ជាកិច្ចការមួយក្នុងចំណោមកិច្ចការរបស់ ខៀវ សំផន បានពិពណ៌នាអំពីការងាររបស់គាត់ជាចម្បងខាងបច្ចេកទេស និងកិច្ចការរដ្ឋបាល"), កថាខណ្ឌ ១៧៨៥ ("ការពិនិត្យពិច័យលើរបាយការណ៍ និងឯកសារបង្ហាញអំពីវិសាលភាពតិចតួចនៃការជួយផ្នែកបច្ចេកទេសដែល ខៀវ សំផន ត្រូវបានចាត់តាំងដើម្បីផ្តល់នោះ"), កថាខណ្ឌ ១៧៨៧ ("លិខិតចម្លងឱ្យ ខៀវ សំផន [...] ពាក់ព័ន្ធទៅនឹងការឆ្លើយឆ្លងផ្នែកបច្ចេកទេសជាសំខាន់")។

ម្ម។ ការគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្មបានបង្ហាញថា គាត់បានដឹងអំពីកិច្ចការពាណិជ្ជកម្ម។ ដូច្នេះ ការដែលគាត់មានសិទ្ធិ“គ្រប់គ្រងយ៉ាងច្រើន”នោះ មានន័យថា ខៀវ សំផន ត្រូវ“ផ្តល់ទំនុកចិត្តពេញលេញលើបញ្ហាជំនួញ និងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យទាំងក្រៅស្រុក និងក្នុងស្រុកនៅចន្លោះពីខែ តុលា ឆ្នាំ ១៩៧៦ ដល់ដើមឆ្នាំ ១៩៧៩”[4989]។ ការគ្រប់កម្រិតនេះត្រូវបានយកមកពិចារណាបូករួមជាមួយនឹងកត្តាដទៃទៀត ក្នុងការយល់ឃើញថា គាត់បានដឹងអំពីកង្វះស្បៀង[4990] ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានអនុវត្តនៅក្នុងក្រសួងពាណិជ្ជកម្ម[4991] និងការចាប់ខ្លួនរបស់ ឌឿន និងការកម្ទេច[4992]។ ពាក់ព័ន្ធបញ្ហានេះ ខៀវ សំផន បានទទួលស្គាល់ថា “គាត់ត្រូវបានរាយការណ៍ឱ្យ”[4993]យ៉ាងហោចណាស់អំពីខ្លឹមសារនៃរបាយការណ៍គណៈកម្មាធិការពាណិជ្ជកម្មដែលបានផ្ញើ និងចម្លងឱ្យគាត់។

1784. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបការរួមចំណែករបស់ ខៀវ សំផន នៅក្នុងគោលបំណងរួមក្នុងវិស័យជំនួញ និងពាណិជ្ជកម្មក្នុងន័យទូលំទូលាយដោយកត់សម្គាល់ថា គាត់“បានជួយដោយផ្ទាល់ឱ្យដំណើរការទៅដោយរលូននៃកិច្ចការរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យដែលបានបង្កមហន្តរាយដល់ប្រជាជន” ពីព្រោះ“រយៈពេលពីរឆ្នាំក្រោយពេលការដក សឿ វ៉ាស៊ី *ហៅ* ឌឿន ចេញពីមន្ទីរ ៨៧០ ដែលជាអ្នកគ្រប់គ្រងបញ្ហាពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម ខៀវ សំផន ផ្ទាល់ខ្លួនបានធានាថា តួនាទីរបស់ ឌឿន ត្រូវបានបំពេញ”[4994]។ អង្គជំនុំជម្រះសាលាដំបូងបានបន្តបញ្ជាក់អំពីមុខនាទីទាំងនេះដែលគាត់បានរួមចំណែកយ៉ាងសំខាន់ ដូចខាងក្រោម៖

> ខៀវ សំផន បានធានាអះអាងថា សហករណ៍បានប្រគល់ផលអង្ករប្រមូលបានរួមក្នុងសហករណ៍សម្រាប់ការនាំចេញ។ គាត់បានទទួលការស្នើសុំពីភូមិភាគសុំបញ្ជូនទំនិញនិងបានឆ្លើយតបសំណើសុំនេះដោយបានបញ្ជាឱ្យបញ្ជូនទៅ។ គាត់បានទទួលរបាយការណ៍លម្អិតអំពីបរិមាណអង្ករដែលបានបញ្ជូនទៅឃ្លាំងរដ្ឋដោយភូមិ

[4989] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២១។

[4990] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៨។

[4991] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៧។

[4992] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៥។

[4993] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៩ (យោងទៅលើ“ការអនុវត្តន៍នៃការផ្ញើឯកសារសម្រាប់គោលបំណងផ្តល់ព័ត៌មាន”)។

[4994] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧ (“ការគ្រប់គ្រងលើបញ្ហាពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៨ បានបង្ហាញបន្ថែមអំពីការគាំទ្ររបស់គាត់ និងបន្តជួយដល់បក្សកុម្មុយនីសកម្ពុជាក្នុងការសម្រេចគោលបំណងរបស់ខ្លួន”)។

ភាគនិងបរិមាណអង្ករនាំចេញ ដោយធានាថា បរិមាណអតិបរមាត្រូវបាននាំចេញស្របតាមផែនការសេដ្ឋកិច្ចរបស់ ប.ក.ក.។ គាត់បានទៅឃ្លាំងរដ្ឋ ហើយបានត្រួតពិនិត្យអង្ករសម្រាប់ទិសដៅនាំចេញខណៈពេលនោះខ្លួនគាត់ផ្ទាល់បានត្រួតពិនិត្យមើលការនាំចូលនិងនាំចេញ ទំនិញចេញចូលរបបកម្ពុជាប្រជាធិបតេយ្យ[4995]។

ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើកាតព្វកិច្ចជាក់លាក់"បច្ចេកទេស"ដែល ខៀវ សំផន ត្រូវបំពេញ ដែលនេះពុំត្រូវបានជំទាស់[4996] ជាជាងសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចអរូបិយណាមួយនោះ។

1785.យោងតាមសំអាងហេតុខាងលើ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធនឹងតួនាទីរបស់គាត់ក្នុងគណៈកម្មាធិការពាណិជ្ជកម្មត្រូវបានបដិសេធចោលទាំងស្រុង។

ii. វណ្ណៈបណ្ដាលសម្រាប់កម្មាភិបាលពាណិជ្ជកម្ម

1786.អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មរបស់ ប៊ិត ហឿន ក្នុងការយល់ឃើញថា ខៀវ សំផន "បានរៀបចំកិច្ចប្រជុំជាមួយអ្នកធ្វើការ និងកម្មាភិបាលពាណិជ្ជកម្ម និងបានណែនាំពួកគេអំពីការដឹកនាំ វិន័យ សីលធម៌ និងការចាត់ទុកថា ជាសត្រូវរបស់បក្សចំពោះ'អ្នកដែលខ្ជិលធ្វើការ'"[4997] និងតាមរយៈនេះបានរួមចំណែកក្នុងគោលបំណងរួម[4998]។

1787.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការសំអាងទៅលើសក្ខីកម្មរបស់ ប៊ិត ហឿន ដែលគ្មានការបញ្ជាក់បន្ថែមពីព្រោះលោកស្រីពុំបានដឹងអំពីតួនាទីផ្លូវការរបស់ ខៀវ សំផន ឬអ្វីទៅជាគណៈអចិន្ត្រៃយ៍ឡើយ។ ដំបូងគាត់បានអះអាងថា មន្ទីរពាណិជ្ជកម្មត្រូវបានដឹកនាំដោយស្ត្រីម្នាក់ ប៉ុន្តែក្រោយមកបាននិយាយថា ដឹកនាំដោយ វ៉ាន់ រិត និងបានសង្ស័យថា វន វ៉េត និង សុន សេន ជាមនុស្សតែមួយ[4999]។ បន្ថែមលើនេះ ខៀវ សំផន បានលើកឡើងថា ប៊ិត ហឿន ពុំបាននិយាយអំពី ខៀវ សំផន ក្នុងចំណោមអ្នកដែលបានដឹកនាំវគ្គបណ្ដុះបណ្ដាលនៅក្នុងកិច្ចសម្ភាសន៍ដំបូងជាមួយមជ្ឈមណ្ឌល DC-

---

[4995] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៦ (ការយោងខាងក្នុងលុបចោល)។

[4996] *សូមមើល ឧ.* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៧២, ១៧៨០, ១៧៨៤-១៧៩០។

[4997] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២០ (ជើងទំព័រ ១៩៦៥)។

[4998] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧២។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២ ("បានបន្តគោរពតាមមាគ៌ាបក្ស ដោយបានដឹកនាំវគ្គ បំពាក់បំប៉ននៅក្នុងអង្គមីទ្ទីង និងវគ្គសិក្សាអប់រំសម្រាប់អ្នកវិលត្រឡប់មកពីបរទេស និងកម្មាភិបាលក្រសួងពាណិជ្ជកម្ម ដែលមានបំណងពង្រឹងស្មារតីសង្គមនិយម បង្កើតអត្តសញ្ញាណកម្មកម្មករ-កសិករ និងបង្កើតការគាំទ្រគោលនយោបាយ ប.ក.ក.")។

[4999] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៤-១៧៩៥។

Cam និងក្នុងកិច្ចសម្ភាសន៍ទីពីរត្រឹមតែលើកឡើងអំពី ខៀវ សំផន ដោយឆ្លើយតបទៅនឹងសំណួរដឹកមុខតែប៉ុណ្ណោះ[5000]។

1788.សហព្រះរាជអាជ្ញាបានជំទាស់ថា ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាង និងខកខានក្នុងការទទួលស្គាល់នូវឆន្ទានុសិទ្ធិទូលំទូលាយក្នុងការវាយតម្លៃលើភាពគួរឱ្យជឿជាក់ និងទុកចិត្តបាន[5001]។ បន្ថែមលើនេះ ផ្ទុយទៅនឹងសារណារបស់ ខៀវ សំផន សក្ខីកម្មរបស់ ប៊ិត ប៊ឿន ត្រូវបានបញ្ជាក់បន្ថែមដោយ រស់ ស៊ុយ និង ស៊ឹម ហោ ដែលអ្នកទាំងពីរបានលើកឡើងអំពីការចូលរួមក្នុងវគ្គបណ្តុះបណ្តាលសម្រាប់កម្មាភិបាលសេដ្ឋកិច្ចដែលដឹកនាំដោយ ខៀវ សំផន[5002]។

1789.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា បញ្ហាដែលបានលើកឡើងដោយ ខៀវ សំផន បានធ្វើឱ្យមានមន្ទិលសង្ស័យលើភាពគួរឱ្យជឿជាក់ និងទុកចិត្តបានរបស់សាក្សីឡើយ។ ការដែលលោកស្រីពុំបានដឹងច្បាស់លាស់អំពីថ្នាក់លើ ជាពិសេស តួនាទីជាក់លាក់របស់ ខៀវ សំផន ក្នុងបក្សកុម្មុយនីស្តកម្ពុជា គណៈមជ្ឈិម និងអត្តសញ្ញាណពិតរបស់ វន វ៉េត និង សុន សេន គឺដោយសារលោកស្រីស្ថិតក្នុងជួរថ្នាក់ទាប និងដោយផ្អែកលើគោលការណ៍រក្សាការសម្ងាត់ក្នុងបក្សកុម្មុយនីសកម្ពុជា។ ការដែល ប៊ិត ប៊ឿន ពុំបានពិពណ៌នាអំពី ខៀវ សំផន ក្នុងកិច្ចសម្ភាសន៍ដំបូងជាមួយមជ្ឈមណ្ឌល DC-Cam ពុំអាចលុបលើឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកសក្ខីកម្មផ្ទាល់របស់លោកស្រីឡើយ។

1790.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំហុសក្នុងការបកស្រាយពុំត្រឹមត្រូវលើភស្តុតាងរបស់ ប៊ិត ប៊ឿន ពីរចំណុច។ ទីមួយ គាត់លើកឡើងថា សាក្សីបានអះអាងថា អ្នកដែលពិភាក្សាអំពីបញ្ហាខ្មាំង គឺជា នួន ជា មិនមែន ខៀវ សំផន នោះទេ[5003]។ ទីពីរ សាក្សីបានអះអាងថា សត្រូវ គឺ“ស្ថិតនៅក្នុងខ្លួនយើង និងជាសត្រូវផ្នែកមនោគមវិជ្ជាដែលបានធ្វើឱ្យយើងខ្ជិលច្រហូស” ជាជាងអ្នកដែលខ្ជិលធ្វើការដែលត្រូវបានចាត់ទុកថា ជាសត្រូវ ដូចបានយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូង[5004]។ សហព្រះរាជ

---

[5000] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៥។

[5001] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៥។

[5002] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៥ យោងទៅលើប្រតិចារឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ (រស់ ស៊ុយ) ឯកសារលេខ E1/184.1 ទំព័រ ៣២, ៣៥, ៣៩-៤០, ៤៣។ ចម្លើយរបស់ រស់ ស៊ុយ ជាមួយមជ្ឈមណ្ឌល DC-Cam ឯកសារលេខ E3/4594 ERN (EN) 00710554។ ប្រតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (ស៊ឹម ហោ) E1/207.2 ទំព័រ ១៤, ១៧។ ចម្លើយរបស់ ស៊ឹម ហោ ឯកសារលេខ E3/4263 ERN (EN) 00679721-00679722។

[5003] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៥។

[5004] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៦។

អាជ្ញាបានឆ្លើយតបថា ពុំមានភាពផ្ទុយគ្នាក្នុងចម្លើយដំបូងរបស់ ប៊ិត ហឿន ដែលថា ខៀវ សំផន បានថ្កោលទោសអាកប្បកិរិយាខ្ជិលច្រអូសក្នុងពេលប្រជុំរបស់គាត់[5005]។

1791.បន្ទាប់ពីបានពិនិត្យឡើងវិញលើភស្តុតាងរបស់ ប៊ិត ហឿន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សាក្សីបានផ្តល់សក្ខីកម្មថា លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃនៅបុរីកីឡា និងកិច្ចប្រជុំប្រហែលបួនលើកជាមួយកម្មាភិបាលពាណិជ្ជកម្ម ហើយ ខៀវ សំផន បានធ្វើបទឧទ្ទេសនាមនៅគ្រប់ព្រឹត្តិការណ៍ទាំងអស់នោះ[5006]។ ក្នុងវគ្គបណ្តុះបណ្តាលនៅបុរីកីឡា សាក្សីបានសន្និតច្បាស់លាស់ថា ការឧទ្ទេសនាមអំពីសត្រូវ គឺជារបស់ ប៉ុល ពត និង នួន ជា ប៉ុណ្ណោះ[5007]។ នេះស្របជាមួយនឹងចម្លើយដំបូងជាមួយមជ្ឈមណ្ឌល DC-Cam ដូចបានកំណត់ដោយ ខៀវ សំផន[5008]។ ទោះជាយ៉ាងណាក្តី សាក្សីបានផ្តល់សក្ខីកម្មថា លោកស្រី និងក្រុមតូចនៃអ្នកគ្រប់គ្រងពាណិជ្ជកម្មបានចូលរួមកិច្ចប្រជុំបន្ថែមទៀតជាមួយ ខៀវ សំផន ជារៀងរាល់ខែ ឬពីរទៅបីខែម្តង[5009] ប៉ុន្តែជាសរុបប្រហែលជាបួនលើក[5010]។ កិច្ចប្រជុំទាំងនេះបានពិភាក្សាអំពីការដឹកនាំការងារ ការប្រកាន់ខ្ជាប់ទៅនឹងវិន័យ និងសីលធម៌ និងបានពិភាក្សាផងដែរអំពី"ខ្មាំងចិត្តសាស្ត្រ" គឺជា"អ្នកដែលខ្ជិលធ្វើការ"[5011]។ ប៊ិត ហឿន បានបដិសេធការដែលបានស្តាប់ឮ ខៀវ សំផន និយាយអំពីភ្នាក់ងារ CIA, វៀតណាម ឬខ្មាំងក្នុងបក្សកុម្មុយនីស្តកម្ពុជា[5012]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវអំពីភស្តុតាងរបស់សាក្សីឡើយ។

1792.យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងភស្តុតាងរបស់ ប៊ិត ហឿន ស្តីពីវគ្គបណ្តុះបណ្តាលជាមួយកម្មាភិបាលពាណិជ្ជកម្ម។

---

5005 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៥។

5006 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ១៧, ២៥-២៦, ៤២។

5007 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ១៨-២០។

5008 បទសម្ភាសន៍របស់ ប៊ិត ហឿន ជាមួយមជ្ឈមណ្ឌល DC-Cam ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ ឯកសារលេខ E3/5647។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៥។

5009 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ២៥-២៦។

5010 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ២៧, ៥០-៥១។

5011 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ២៦។

5012 ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ (ប៊ិត ហឿន) ឯកសារលេខ E1/502.1 ទំព័រ ២៦។

## ឃ. ការទទួលខុសត្រូវសម្រាប់ក្រសួងការបរទេស

1793.អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងបរិបទនៃសំណុំរឿង ០០២/០២ *ក្នុងចំណោមនោះ* ផ្អែកលើមូលដ្ឋាននៃលិខិតពីរច្បាប់ដែលបានផ្ញើមកឱ្យគាត់ពីអង្គការលើកលែងទោសអន្តរជាតិ លិខិតទីពីរមានការចូលរួមដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨[5013]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា ខៀវ សំផន បានយល់ដឹងអំពីខ្លឹមសារលិខិតនោះ ហើយគាត់ពុំ“អាចមិនអើពើចំពោះរបាយការណ៍នោះ ដោយពិចារណាលើទំនាក់ទំនងយ៉ាងខ្លាំងជាពិសេសជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេស”[5014]។ “ទំនាក់ទំនងយ៉ាងខ្លាំង”នេះ ទំនងជាបានផ្អែកដោយផ្នែកខ្លះលើការយល់ឃើញរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន បានផ្តល់“ការជួយជាប្រចាំ និងបណ្តោះអាសន្នដោយមានកម្រិត”ដល់ក្រសួងកិច្ចការបរទេស[5015]។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខៀវ សំផន ត្រូវបាន“បញ្ជូន”លិខិតឱ្យក្នុងសមត្ថកិច្ចជាប្រមុខរដ្ឋដែលមានតែឈ្មោះ[5016]។

1794.ខៀវ សំផន បានលើកឡើងថា ពុំមានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញថា លិខិតនោះបានដល់ដៃគាត់[5017]។ ទីមួយ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា “តាមធម្មតាផ្អែកលើឋានៈជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន ‘បានទទួល’លិខិតពី*អង្គការលើកលែងទោសអន្តរជាតិ* នៅពេលដែលក្នុងកថាខណ្ឌដដែលនោះអង្គជំនុំជម្រះបានទទួលស្គាល់ថា គាត់កាន់តួនាទីជានិមិត្តរូប”[5018]។ ទីពីរ គាត់បានលើកឡើងថា ដោយសារអង្គជំនុំជម្រះសាលាដំបូងត្រឹមតែ “កត់សម្គាល់លើ‘លទ្ធភាព’ដែលថា គាត់ប្រហែលជាបានផ្តល់ការជួយមានកម្រិតបណ្តោះអាសន្ន និងជាប្រចាំ”

---

[5013] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៣។

[5014] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥០។

[5015] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៣។

[5016] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៤៨។

[5017] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៧ (“ពុំមានភស្តុតាងបង្ហាញថា គាត់បានទទួលលិខិតទាំងនោះ”), ១៨០០ (“គ្មានភស្តុតាងបង្ហាញថា លិខិតនោះបានដល់ដៃគាត់”), ១៨០១ (“ពុំមានភស្តុតាងបង្ហាញថា គាត់ជាក់ស្តែងបានទទួលលិខិតនោះឡើយ”)។

[5018] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៩៧។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០០ (ជើងទំព័រ ៣៤៩២) (“ការដែលគ្រាន់តែថា គាត់ជាប្រធានគណៈប្រធានរដ្ឋ ពុំបានបង្កើតទៅជាភស្តុតាងបង្ហាញថា គាត់បានទទួលលិខិតដែលសំដៅលើគាត់ឡើយ”)។

ដល់ក្រសួងកិច្ចការបរទេស[5019] ទើបអង្គជំនុំជម្រះមានកំហុសក្នុងការយល់ឃើញថា គាត់មាន"ទំនាក់ទំនងយ៉ាងខ្លាំង"ជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេស និងក្នុងការប្រើប្រាស់មូលដ្ឋាននេះដើម្បីសន្និដ្ឋានថា គាត់បានដឹងអំពីខ្លឹមសារនៃលិខិតនោះ[5020]។ គាត់បានអះអាងថា នៅគ្រប់ករណី ពុំមានតុលាការអង្គហេតុសមស្របអាចយល់ឃើញថា គាត់បានជួយដល់ក្រសួងកិច្ចការបរទេស ដោយហេតុថា សាក្សីដែលត្រូវបានសំអាងទៅលើនោះ ពុំបានគាំទ្រសេចក្តីសន្និដ្ឋាននោះឡើយ[5021]។

1795.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានជួយដល់ក្រសួងកិច្ចការបរទេស ប៉ុន្តែត្រឹមតែមិនយល់ស្របជាមួយនឹងការបកស្រាយរបស់អង្គជំនុំជម្រះលើភស្តុតាងប៉ុណ្ណោះ[5022]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវដោយផ្អែកលើភស្តុតាងជារួមថា ខៀវ សំផន បានដឹងអំពីខ្លឹមសារនៃលិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ[5023]។ ជាពិសេស ជាការសមហេតុផលក្នុងការសន្និដ្ឋានថា លិខិតរបស់អង្គការនេះដែលផ្ញើមកឱ្យគាត់ ត្រូវបានទទួលក្នុងអំឡុងពេលថ្ងៃធ្វើការធម្មតា តាមលក្ខណៈធម្មតានៃការទំនាក់ទំនង[5024]។ បន្ថែមលើនេះ របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិបានដកស្រង់លិខិតឆ្លើយតបរបស់ អៀង សារី ក្នុងនាមបក្សកុម្មុយនីស្តកម្ពុជា[5025]។ ក្នុងនាមជាប្រមុខរដ្ឋ ដែលបានទទួលគណៈប្រតិភូអន្តរជាតិនានា និងឆ្លើយតបទៅនឹងក្តីបារម្ភដែលបានលើកឡើង

---

[5019] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៩៩-១៨០០។

[5020] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០១-១៨០៣។

[5021] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០២។

[5022] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៨។

[5023] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៩-៩៤០។

[5024] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៤០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៩៧។

[5025] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៤០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨២៥ (ជើងទំព័រ ១២៧៨៤), ៣៨៣៤ (ជើងទំព័រ ១២៨១៦)។ ចម្លើយ អៀង សារី៖ កំណត់ទូតផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ ឯកសារលេខ E3/1385 ERN 00701205-00701218 ។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារលេខ E3/4605 ERN 00813070-00813071។ សារព័ត៌មានឡូសអាន់ជេលេស(Los Angeles Times) ប្រធានអង្គការសហប្រជាជាតិត្រូវបានអញ្ជើញឱ្យមកទស្សនកិច្ចប្រទេសកម្ពុជា ដើម្បីពិនិត្យលើបញ្ហាសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/627 ERN 00712911-00712912។ សារព័ត៌មាន International Herald Tribune *កម្ពុជាអញ្ជើញអ្នកសង្កេតការណ៍បរទេសមកបំពេញទស្សនកិច្ចដើម្បីប្រឆាំងនឹងការរិះគន់* ឯកសារលេខ E3/654 ERN 000720231។

ដោយគណៈប្រតិភូអន្តរជាតិនោះ ពុំទំនងសោះដែលថា ខៀវ សំខន ពុំបានដឹងអំពីលិខិត និងរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិនោះឡើយ។

1796.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ជាការ "អាចធ្វើបាន"ដែលថា ខៀវ សំផន បានផ្តល់ការជួយម្តងម្កាលដល់ក្រសួងកិច្ចការបរទេស ទោះជាយ៉ាងណាក្តីថា គាត់បានជួយ ហើយត្រង់ចំណុចនេះ ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា ខៀវ សំផន បានផ្តល់"ការជួយជាប្រចាំ និងបណ្តោះអាសន្ន"ដល់ក្រសួងកិច្ចការបរទេសដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងរបស់សាក្សីបីនាក់ដែលបានផ្តល់សក្ខីកម្មថា បានឃើញ ខៀវ សំផន នៅក្រសួងកិច្ចការបរទេសទទួលស្វាគមន៍អ្នកធ្វើទស្សនកិច្ចពេល អៀង សារី អវត្តមាន ឡុង នរិន្ទ រៀបចំកិច្ចប្រជុំ សាឡុត បាន បានផ្តល់សក្ខីកម្មថាបានឃើញ ខៀវ សំផន ដឹកនាំកិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្ម និង សួង ស៊ីគឿន បានផ្តល់សក្ខីកម្មថាបានឃើញ ខៀវ សំផន ពិភាក្សាការបោះពុម្ពផ្សាយ[5026]
។

1797.ទីពីរ ដូចបានពិភាក្សាខាងលើ[5027] ថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវលើខ្លឹមសារសំខាន់នៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា តួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ត្រឹមជា"និមិត្តរូប" ជាជាងសិទ្ធិអំណាចប្រតិបត្តិ ក្នុងការព្យាយាមដើម្បីកាត់បន្ថយជាអប្បបរមានៃតួនាទីរបស់គាត់ដែលតំណាងមុខមាត់ឱ្យកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា តួនាទីរបស់គាត់ដែលជា"និមិត្តរូប" នៅគ្រប់ពេលពុំតម្រូវឱ្យទទួលលិខិត ឬរាយការណ៍អំពីខ្លឹមសារនោះ។

1798.បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ខៀវ សំផន "បានទទួល"លិខិតនោះ ដូចការអះអាងរបស់គាត់ឡើយ ប៉ុន្តែបានយល់ឃើញថា លិខិតនោះត្រូវបាន"បញ្ជូនបន្ត"(*ឬ* ផ្ញើ)ឱ្យគាត់ដោយអង្គការលើកលែងទោសអន្តរជាតិក្នុងសមត្ថកិច្ចរបស់គាត់ជាប្រមុខរដ្ឋដែលមានតែឈ្មោះ និងថា "ជាពិសេស" ទំនាក់ទំនងរបស់គាត់ជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេសបង្ហាញថា គាត់បានដឹងអំពីខ្លឹមសារនៃលិខិតនោះ។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការអះអាងរបស់ ខៀវ សំ

[5026] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២២-៦២៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០២។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៣៨។

[5027] *សូមមើលខាងលើ* ផ្នែក VIII.ក.២.ខ។

ផន ដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីមានភស្តុតាងផ្ទាល់បង្ហាញថា គាត់បានទទួលលិខិតនោះដោយផ្ទាល់។ បញ្ហាសំខាន់គឺថាតើ ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានថា គាត់ត្រូវបានរាយការណ៍ឱ្យដឹងតាមលក្ខណៈណាមួយអំពីខ្លឹមសារនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នេះជាការពុំសមហេតុផល៖ ពិតណាស់ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ដោយសារការទទួលខុសត្រូវរបស់គាត់ក្នុងតួនាទីជាប្រធានគណៈប្រធានរដ្ឋ គាត់ទំនងជាពុំបានដឹងថា អៀង សារី បានលាក់បាំងការពិតនៃរបាយការណ៍អំពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងលក្ខខណ្ឌរស់នៅដ៏អាក្រក់ ទៅគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស។

1799.ចុងក្រោយ ខៀវ សំផន ពុំបានបង្ហាញថា កំហុសណាមួយប្រសិនបើមានដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនោះ ពុំមែនផ្អែកតែមួយមុខ ឬជាសំខាន់ទៅលើលិខិតដែលបានផ្ញើពីអង្គការលើកលែងទោសអន្តរជាតិមួយមុខប៉ុណ្ណោះទេ។

## ខ. សហឧក្រិដ្ឋកម្មរួម

1800.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តរហូតដល់យ៉ាងហោចនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជាច្រើនរូប រួមទាំង ខៀវ សំផន បានរួមចំណែកគោលបំណងរួមឧក្រិដ្ឋក្នុងការអនុវត្តន៍ឆាប់រហ័សនូវបដិវត្តន៍សង្គមនិយមក្នុងកម្ពុជាតាមរយៈ"មហាលោតផ្លោះមហាអស្ចារ្យ"ដែលបង្កើតឡើងដើម្បីកសាងប្រទេស ការពារពីខ្មាំងសត្រូវ និងកែប្រែប្រជាជនទាំងអស់ឱ្យទៅជាសង្គមខ្មែរតែមួយស្មើៗគ្នានៃវណ្ណៈកម្មករកសិករ និងគ្មានការប្រតិបត្តិសាសនា[5028]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង គោលបំណងរួមនេះគឺជាបទល្មើស ដោយសារមានការជាប់ពាក់ព័ន្ធយ៉ាងស្អិតល្មួតជាមួយនឹងគោលនយោបាយ ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម[5029] ដូចជា៖ (១) បង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការ[5030] (២) ការបង្កើត និងប្រតិបត្តិការមន្ទីរ

[5028] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៣៣-៣៧៤៣, ៤០៦៨, ៤០៦៩, ៤០៧៤។

[5029] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩២៨, ៣៩៨៧, ៣៩៩៨, ៤០១២, ៤០២២, ៤០៦១, ៤០៦៧, ៤០៦៨។

[5030] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៦-៣៩២៩។

សន្តិសុខ និងទីតាំងសម្លាប់មនុស្ស[5031] (៣) ការកំណត់គោលដៅលើក្រុមជាក់លាក់[5032] និង(៤) បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍[5033]។

1801.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា នៅក្នុងការរួមចំណែកគោលបំណងរួម ខៀវ សំផន ដែលជាមេដឹកនាំជាន់ខ្ពស់ និងតំណាងមុខមាត់ជាសាធារណៈរបស់កម្ពុជាប្រជាធិបតេយ្យ បានជម្រុញយ៉ាងសកម្មនូវគោលនយោបាយក្នុងស្រុក និងលើឆាកអន្តរជាតិ និងបានលើកទឹកចិត្ត ញុះញង់ និងផ្តល់ធម្មានុរូបដល់ការអនុវត្តន៍នោះតាមរយៈគោលនយោបាយឧក្រិដ្ឋ រួមទាំងការណែនាំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាស្តីពីការអនុវត្តន៍ ខណៈពេលធ្វើឱ្យដំណើរការ និងគ្រប់គ្រងគោលនយោបាយនោះ[5034]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[5035] និងថា គាត់បានរួមចំណែកជាមួយចេតនារបស់មេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយចូលរួម និងប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរួមបញ្ចូលតាមរយៈគោលបំណងរួម[5036]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធដោយសារការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបានប្រកាសទោសគាត់ដាក់ពន្ធនាគារអស់មួយជីវិត[5037]។

1802.ខៀវ សំផន បានជំទាស់គ្រប់ផ្នែកនៃការយល់ឃើញជាគន្លឹះ និងបានលើកឡើងថា ជាបឋម អង្គជំនុំជម្រះសាលាដំបូងមានកំហុសជាច្រើនផ្នែកអង្គច្បាប់ និងអង្គហេតុ ដោយសារការកំណត់គោលបំណងរួមរបស់មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យថាជាបទល្មើស។ គាត់បានជំទាស់ទៅនឹងការហៅគោលនយោ

---

[5031] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣០-៣៩៨៧។

[5032] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨៨-៤០៦១។

[5033] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៦២-៤០៦៧។

[5034] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៧០, ៤០៧៣, ៤០៧៤, ៤២៥៧-៤២៧៨, ៤៣០៦។

[5035] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦។

[5036] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៩-៤៣០៧។ ការយល់ឃើញនេះពុំបានបញ្ចូលចេតនានៃបទឧក្រិដ្ឋប្រល័យពូជសាសន៍របស់ ខៀវ សំផន ទាក់ទងនឹងជនជាតិចាម ដែលអង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានបាន។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩០, ៤៣០៨។

[5037] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦, ៤៣០៧។

បាយនីមួយៗរបស់បក្សកុម្មុយនីស្តកម្ពុជាថាជាបទល្មើស[5038]។ គាត់បានជំទាស់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា គាត់បានរួមចំណែកទិដ្ឋភាពល្មើសនៃគោលបំណងរួម និងថា គាត់បានរួមចំណែកយ៉ាងសំខាន់ និងព្រមទាំងការយល់ឃើញថា គាត់មានចេតនាចូលរួមក្នុងគោលបំណងរួម និងឧក្រិដ្ឋកម្មដែលជាមូលដ្ឋាននៃគោលបំណងរួម[5039]។ គាត់បានអះអាងថា កំហុសទាំងនេះធ្វើឱ្យសាលក្រមមោឃៈ អាស្រ័យហេតុនេះ ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធការដាក់ពិរុទ្ធភាពមកលើរូបគាត់[5040]។ ជំពូកនេះនឹងត្រួតពិនិត្យលើកនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងបរិបទនៃមូលដ្ឋានរបស់ ខៀវ សំផន ដែលថា៖ (១) ផែនការរួម ពុំមានជាបទល្មើស (២) គោលនយោបាយដែលបានរួមបញ្ចូលក្នុងផែនការរួមនោះ ពុំមែនជាបទល្មើស (៣) នៅគ្រប់កាលៈទេសៈ គាត់ពុំមែនជាអ្នកចូលរួមក្នុងគោលបំណងរួម និង (៤) រាល់ការយល់ឃើញដែលថា គាត់គឺជាអ្នករួមចំណែកសំខាន់ក្នុងគោលបំណងរួម ជាកំហុសអង្គហេតុ និងអង្គច្បាប់។

1803.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងគោលបំណងឧក្រិដ្ឋរួម ឬការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម និងអាស្រ័យហេតុនេះ បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះចោលទាំងស្រុង[5041]។

### ១. ច្បាប់ជាធរមាន

1804.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាប់ដែលអាចអនុវត្តបានចំពោះសហឧក្រិដ្ឋកម្មរួម នៅក្នុងផ្នែកដែលពាក់ព័ន្ធ ដូចខាងក្រោម៖

---

[5038] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៩៩-១៦០០។

[5039] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦០០-១៦០៣, ១៩៣៨-២១១៨។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/11.1 ទំព័រ ៧-៣៤។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/12.1 ទំព័រ ៥៦-៦២។

[5040] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣១-២១១៣។

[5041] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៥៣-១១០៥។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/11.1 ទំព័រ ២៣-៥៥។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១, សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/12.1 ទំព័រ ៤៥-៥០។

ទម្រង់នៃសហឧក្រិដ្ឋកម្មរួមមានធាតុផ្សំសត្យានុម័តបីប្រភេទ។ ទីមួយ ត្រូវតែមានអត្ថិភាពនៃពហុបុគ្គល។ [...] ទីពីរ ត្រូវតែមានអត្ថិភាពនៃគោលបំណងរួមដែលមានចរិតលក្ខណៈឧក្រិដ្ឋអាចស្មើទៅនឹង ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ។ ទីបី ជនជាប់ចោទត្រូវតែចូលរួមនៅក្នុងគោលបំណងរួម រួមចំណែកយ៉ាងសំខាន់ ប៉ុន្តែមិនចាំបាច់សំខាន់បំផុតដែលខ្វះមិនបាននោះទេនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[5042]។

គោលបំណងរួមត្រូវតែមានអត្ថិភាពនៃការប្រព្រឹត្តបទឧក្រិដ្ឋ(មួយ ឬច្រើន) ដែលជាគោលបំណងចម្បងមួយក្នុងចំណោមនោះ(ពោលគឺ'ស្មើទៅនឹង') ឬត្រូវតែគិតទុកជាមុននូវការប្រព្រឹត្តបទឧក្រិដ្ឋ(មួយ ឬច្រើន) ប្រើប្រាស់ជាមធ្យោបាយសម្រេចគោលបំណងនោះ ដែលពុំចាំបាច់ជាបទល្មើស (ពោលគឺ 'ពាក់ព័ន្ធ')។ [...] គោលបំណងរួម ផែនការ ឬគម្រោងការនៃសហឧក្រិដ្ឋកម្មរួម អាចប្រែប្រួល និងផ្លាស់ប្តូរតាមពេលវេលាដើម្បីរួមបញ្ចូលបទឧក្រិដ្ឋបន្ថែមទៀត។ [...] នៅក្នុងករណីនេះ ការទទួលខុសត្រូវមានអត្ថិភាពនៅពេលសមាជិកនៃសហឧក្រិដ្ឋកម្មរួម ខណៈពេលដឹងថា បទឧក្រិដ្ឋប្រភេទថ្មីត្រូវបានរួមបញ្ចូលក្នុងផែនការរួម ពុំបានចាត់វិធានការប្រសិទ្ធភាពរារាំងការកើតឡើងនៃបទឧក្រិដ្ឋប្រភេទថ្មីនេះ ហើយបន្ទាប់មក នៅតែបន្តអនុវត្តគោលបំណងរួមនោះ[5043]។

ការចូលរួមក្នុងគោលបំណងរួមអាចធ្វើឡើងតាមរយៈអំពើសកម្មគាំទ្រ ឬអំពើអកម្មល្មើស។ [...] ការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួមពុំចាំបាច់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនូវបទឧក្រិដ្ឋជាក់លាក់ [...] ប៉ុន្តែអាចជាទម្រង់នៃការជួយ ឬរួមចំណែកនៅក្នុងការអនុវត្តន៍គោលបំណងរួមនោះ។ ការរួមចំណែកនោះពុំចាំបាច់ក្នុងលក្ខខណ្ឌសំខាន់បំផុតដែលខ្វះមិនបានរហូតធ្វើឱ្យបទឧក្រិដ្ឋនោះ ពុំអាចត្រូវបានប្រព្រឹត្តឡើងនោះទេ។ ទោះជាយ៉ាងណាក្តី ការជាប់ពាក់ព័ន្ធរបស់សហឧក្រិដ្ឋកម្មរួមនៅក្នុងឧក្រិដ្ឋកម្មនោះត្រូវតែបង្កើតបានជាទំនាក់ទំនងភ្ជាប់គ្នារវាងហេតុ និងផល[5044]។

អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមអាចដាក់ឱ្យទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តឡើងតាមរយៈចារីផ្ទាល់ដែលពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដរាបណាមានការបង្ហាញថា មានអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមយ៉ាងតិចម្នាក់ ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះ និងថា អ្នកចូលរួមរូបនោះ នៅពេលប្រើប្រាស់ចារីផ្ទាល់ បានធ្វើសកម្មភាពក្នុងការជម្រុញគោលបំណងរួម[5045]។

---

[5042] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០៨ (សេចក្តីដកស្រង់ខាងក្នុងលុបចោល)។

[5043] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០៩។

[5044] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១០។

[5045] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១១។

ទាក់ទងទៅនឹងធាតុផ្សំ *អត្តនោម័តិ* [...] ជនជាប់ចោទត្រូវតែមានចេតនាចូលរួមក្នុងគោលបំណងរួម ហើយចេតនានេះត្រូវតែបានរួមចំណែកជាមួយនឹងអ្នកចូលរួមដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម។ អ្នកចូលរួមសហឧក្រិដ្ឋកម្មរួមត្រូវតែបង្ហាញផងដែរថា បានរួមចំណែកជាមួយនឹងអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមដទៃទៀត នូវចេតនាតម្រូវពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជាមូលដ្ឋាន [...]។ ដូច្នេះ ចេតនានៃសហឧក្រិដ្ឋកម្មរួម ត្រូវតែគ្របដណ្តប់គោលបំណងរួម និងបទឧក្រិដ្ឋដែលបានរួមបញ្ចូលក្នុងគោលបំណងនោះ[5046]។

1805. ខៀវ សំផន បានលើកឡើងថា ការពិនិត្យរបស់សហព្រះរាជអាជ្ញា ជាការសង្ខេបខ្លីពេក និងពុំបានបង្ហាញក្របខ័ណ្ឌគតិយុត្តក្នុងការបំភ្លឺបញ្ហាសំខាន់ និងជាក់លាក់ស្តីពីសហឧក្រិដ្ឋកម្មរួមក្នុងរឿងក្តីបច្ចុប្បន្ន[5047]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានហានិភ័យក្នុងការរំលោភបំពានលើគោលការណ៍ច្បាប់ជាសារវ័ន្ត ដូចជា *គ្មានបទល្មើសបើគ្មានច្បាប់ចែង* និងថា ពិរុទ្ធភាពត្រូវតែជាលក្ខណៈផ្ទាល់ ឬលក្ខណៈបុគ្គល (ជាជាងលក្ខណៈសមាគម) ព្រមទាំងការខកខានក្នុងការអនុវត្តន៍បទដ្ឋានភស្តុតាងត្រឹមត្រូវនៅពេលយល់ឃើញអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[5048]។ នៅពេលជំទាស់ទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរួមចំណែកសំខាន់ ខៀវ សំផន បានលើកឡើងថា អំពើអសកម្មល្មើសពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវការចូលរួមក្នុងគោលបំណងរួម[5049] និងថា ទំនាក់ទំនងដែលជាលក្ខខណ្ឌតម្រូវត្រូវតែមានអត្ថិភាពរវាងសមាជិកនៃសហឧក្រិដ្ឋកម្មរួម ជាមួយនឹងចារីផ្ទាល់ *ទាំងអស់*នៃបទឧក្រិដ្ឋនោះ(មិនមែនត្រឹមតែចារីម្នាក់នោះទេ)[5050]។ គាត់បានអះអាងថា តាមរយៈការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់បង្ហាញឱ្យឃើញថា អង្គជំនុំជម្រះពុំបានពិចារណាថា ការរួមចំណែកក្នុងបទឧក្រិដ្ឋចាំបាច់ត្រូវតែជាការរួមចំណែកក្នុងគោលបំណងរួម[5051] និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ច្បាប់ស្តីពីធាតុផ្សំអត្តនោម័តិ[5052]។

---

[5046] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១២។

[5047] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៤២។

[5048] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៤០-១៩៥១, ១៩៥៤-១៩៥៦។

[5049] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥៧-១៩៥៩។

[5050] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥២, ១៩៥៣។

[5051] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦០-១៩៦២។

[5052] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦៣-១៩៦៥ និងការយោងនៅទីនោះ។

1806.សហព្រះរាជអាជ្ញាបានការពារការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់ស្តីពីគោលបំណងរួម ការរួមចំណែកសំខាន់ និងធាតុផ្សំអត្តនោម័តិ និងបានឆ្លើយតបថា ខៀវ សំផន បានបំភ្លៃ និងអនុវត្តដោយពុំត្រឹមត្រូវលើច្បាប់ដែលពាក់ព័ន្ធ[5053]។

1807.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ម្ចាស់បណ្តឹងសាទុក្ខមិនត្រឹមតែត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ថែមទាំងបង្ហាញថាតើ កំហុសនោះបានមោឃៈសាលក្រមយ៉ាងដូចម្តេច[5054]។ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបញ្ជាក់មិនពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់ពាក់ព័ន្ធទៅនឹងគោលបំណងរួម ពុំមានភាពច្បាស់លាស់ និងអរូបិយ ហើយពុំបានបង្ហាញថាតើ អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងមានកំហុសដូចម្តេច ជាជាងកំហុសជាសក្តានុពលក្នុងការវាយតម្លៃលើអ្វីដែលជាសហឧក្រិដ្ឋកម្មរួមដែលគាត់បានយល់ស្របថា ជាការត្រឹមត្រូវជាទូទៅ[5055]។ បន្ថែមលើនេះ គាត់ពុំបានផ្តល់ហេតុផលដែលត្រូវសង្ស័យចំពោះការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូងលើរាល់ធាតុផ្សំសមស្របនៃការពិពណ៌នាពាក់ព័ន្ធទៅលើអង្គហេតុនៃរឿងក្តីបច្ចុប្បន្ននេះ និងពុំបានយោងទៅលើការយល់ឃើញដែលអាចបង្ហាញផ្ទុយនោះឡើយ។

1808.ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការរួមចំណែកសំខាន់ដោយផ្អែកលើមូលដ្ឋានទូទៅថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមអាចមានទម្រង់ជាអំពើអសកម្មល្មើស[5056]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើដូច្នោះ ដោយពុំបានផ្តល់នូវមូលដ្ឋានផ្លូវច្បាប់រឹងមាំណាមួយគាំទ្រការអះអាងទូទៅនេះ[5057]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនូវច្បាប់ដែលអាចអនុវត្តបានចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតាមរយៈការរំឭកនូវយុត្តិសាស្ត្ររបស់តុលាការនេះ និងតុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ដែលបង្ហាញថា 'បទឧក្រិដ្ឋអាចត្រូវបានប្រព្រឹត្តឡើងតាមរយៈអំពើអកម្មល្មើសនៅពេលដែលមានកាតព្វកិច្ចត្រូវ

---

[5053] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៥៦, ៩៦០, ១០៤០, ១០៤១, ១០៩៨, ១០៩៩។

[5054] *សូមមើល* កថាខណ្ឌខាងលើផ្នែក II។

[5055] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣៩-១៩៤២។

[5056] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥៧។

[5057] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥៨, ១៩៥៩។

បំពេញ”[5058] និងថា ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមអាចមានអត្ថិភាពតាមរយៈអំពើសកម្មគាំទ្រ ឬអំពើអកម្មល្មើស[5059]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម អាចបណ្តាលមកពីអំពើសកម្មគាំទ្រ ឬអំពើអសកម្មល្មើស[5060] អាស្រ័យហេតុនេះ បដិសេធការជំទាស់របស់ ខៀវ សំផន ទាក់ទងនឹងបញ្ហានេះ។

1809.ដូចគ្នានេះដែរ ក្នុងការគាំទ្រការអះអាងរបស់គាត់ដែលថា“ទំនាក់ទំនង[ជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មរួម] ត្រូវតែបង្ហាញឱ្យឃើញមានអត្ថិភាពជាមួយនឹងចារីចម្បងនីមួយៗ ប្រសិនបើឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងដោយចារីច្រើននាក់នោះ”[5061] ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលថា “មានអ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួមយ៉ាងតិចម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវលើបទឧក្រិដ្ឋ ហើយអ្នកចូលរួមរូបនោះ *នៅពេលប្រើប្រាស់ចារីផ្ទាល់* បានជម្រុញគោលបំណងរួម”[5062]។ ខៀវ សំផន បានអះអាងថា “សាលដីកា*រឿងក្តី Brđanin* ដែលត្រូវបានដកស្រង់ដោយសាលដីកា*រឿងក្តី Krajišnik* តម្រូវថា អ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមក្នុងក្រុមនោះ បានប្រើប្រាស់*ចារីផ្ទាល់ទាំងអស់*នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ”[5063]។

---

[5058] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០៣ យោងទៅលើសាលក្រមសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៦៩៣ ជើងទំព័រ ២១៥៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៧, ៧០៨ ជើងទំព័រ ២២៩០។

[5059] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៦៩៣ ជើងទំព័រ ២១៥៩ និងការយោងត្រូវបានដកស្រង់នៅទីនោះ។

[5060] *សូមមើលផងដែរ* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-30/1-A សាលដីកា ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ (“សាលដីកានៃ*រឿងក្តី Kvočka និងជនជាប់ចោទដទៃទៀត* (ICTY)”) កថាខណ្ឌ ១៨៧, ៤២១ (“ជាការគ្រប់គ្រាន់សម្រាប់ជនជាប់ចោទ[ដែលត្រូវបានចោទពីការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម] ក្នុងការប្រព្រឹត្តអំពើសកម្ម ឬអកម្មដែលរួមចំណែកក្នុងគោលបំណងរួមល្មើស”) ៥៥៦។

[5061] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥៣។

[5062] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១១ (សេចក្តីបញ្ជាក់បន្ថែម) យោងទៅលើរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krajišnik* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-00-39-A សាលដីកា ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ (“សាលដីកានៃរឿងក្តី *Krajišnik* (ICTY)”) កថាខណ្ឌ ២២៥។ សាលដីការឿងក្តី *Brđanin* (ICTY) កថាខណ្ឌ ៤១៣។

[5063] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៥៣ (សេចក្តីបញ្ជាក់បន្ថែម)។

1810.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សាលដីកានៃ*រឿងក្ដី Krajišnik* ដែលស្ថិតក្នុងចំណោមរឿងក្ដីដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះបានបញ្ជាក់ថា "សមាជិកនៃសហឧក្រិដ្ឋកម្មរួមអាចទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ដែលពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដរាបណាមានការបង្ហាញថា មានសមាជិកនៃសហឧក្រិដ្ឋកម្មរួមយ៉ាងតិចម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ និងថា សមាជិករូបនេះ *នៅពេលប្រើប្រាស់ចារីផ្ទាល់* បានអនុវត្តស្របតាមគោលបំណងរួម"[5064]។ សាលដីកានៃ*រឿងក្ដី Krajišnik* បានសំអាងលើសាលដីកានៃ*រឿងក្ដី Brđanin* ដែលបញ្ជាក់ថា "សមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះ និងថា សមាជិកនេះ *នៅពេលប្រើប្រាស់ចារីផ្ទាល់* បានប្រព្រឹត្តស្របជាមួយនឹងផែនការរួម"[5065]។ ការបញ្ជាក់នេះស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែគោលគំនិត ឬការដកស្រង់ត្រូវបានបកស្រាយផ្សេងគ្នាដោយ ខៀវ សំផន។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើច្បាប់ជាធរមានដែលដាក់ការទទួលខុសត្រូវនៃបទឧក្រិដ្ឋទៅលើសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម ដែលបានកើតឡើង នៅពេលដែលសមាជិកនៃសហឧក្រិដ្ឋកម្មរួមប្រើប្រាស់ចារី*ចម្បង/ផ្ទាល់ម្នាក់ ឬច្រើន* នៃឧក្រិដ្ឋកម្មក្នុងការអនុវត្តន៍ស្របតាម ឬការជម្រុញនូវគោលបំណងរួម[5066]។ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណា ឬអនុវត្តផ្ទុយនោះឡើយ។

---

[5064] សាលដីការឿងក្ដី *Krajišnik* (ICTY) កថាខណ្ឌ ២២៥ (សេចក្ដីបញ្ជាក់បន្ថែម)។

[5065] សាលដីការឿងក្ដី *Brđanin* (ICTY)កថាខណ្ឌ ៤១៣ (សេចក្ដីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សាលដីកា*រឿងក្ដី Brđanin* កថាខណ្ឌ ៤៣០។

[5066] ទាក់ទងនឹងបញ្ហានេះ *សូមមើលផងដែរ* សាលដីការឿងក្ដី *MARTIĆ* (ICTY) កថាខណ្ឌ ១៦៨ ("ក្នុងសាលដីកា*រឿងក្ដី Brđanin* (ICTY) បានបញ្ជាក់ថា បញ្ហាសំខាន់សម្រាប់ការសម្រេចក្រោមទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ពុំមែនថាតើឧក្រិដ្ឋកម្មមួយត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមនោះទេ ប៉ុន្តែថាតើ ឧក្រិដ្ឋកម្មនេះបានស្ថិតក្នុងគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា។ សម្រាប់ទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួម ជនជាប់ចោទអាចត្រូវបានរកឃើញថាជាអ្នកទទួលខុសត្រូវបាន ដរាបណាគាត់បានចូលរួមក្នុងគោលបំណងរួមល្មើសដោយមានចេតនាតម្រូវ និងថា ក្នុងកាលៈទេសៈនៃរឿងក្ដីនេះ (១) អាចដឹងជាមុនបានថា បទឧក្រិដ្ឋអាចត្រូវបានប្រព្រឹត្តឡើងដោយចារីម្នាក់ ឬច្រើន ដែលត្រូវបានជនជាប់ចោទប្រើប្រាស់ (ឬដោយសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម) ដើម្បីអនុវត្តធាតុសត្យានុម័តនៃឧក្រិដ្ឋកម្មដែលជាផ្នែកនៃគោលបំណងរួម និង (២) ជនជាប់ចោទមានឆន្ទៈជ្រើសរើសយកហានិភ័យនោះ។ អង្គជំនុំជម្រះឧទ្ធរណ៍បានបញ្ជាក់ថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដរាបណាមានការបង្ហាញថា ឧក្រិដ្ឋកម្មត្រូវបានដាក់ឱ្យទទួលខុសត្រូវយ៉ាងហោចណាស់លើសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម និងថា សមាជិកនេះ *នៅពេលប្រើប្រាស់ចារីផ្ទាល់* បានប្រព្រឹត្តស្របតាមផែនការរួម"(សេចក្ដីបញ្ជាក់បន្ថែម))។

1811.សារណាសេសសល់ដទៃទៀតរបស់ ខៀវ សំផន គឺជាប់ពាក់ព័ន្ធទៅនឹងលក្ខណៈល្មើសនៃគោលបំណងរួម ដែលរងការជំទាស់។ បញ្ហាសំខាន់នេះនឹងត្រូវដោះស្រាយនៅក្នុងផ្នែកខាងក្រោមដែលអង្គជំនុំជម្រះតុលាការ កំពូលនឹងត្រូវរៀបរាប់នូវកត្តានានា និងភស្តុតាងដែលត្រូវបានសំអាងទៅលើដោយអង្គជំនុំជម្រះសាលា ដំបូង ក្នុងការគាំទ្រគោលបំណងល្មើសរបស់ថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា និងតម្កល់ភាពសមហេតុ ផលនៃការវាយតម្លៃនោះ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបដិសេធទាំងស្រុងនូវការលើក ឡើងរបស់ ខៀវ សំផន ដែលថា ការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់នោះ បានបង្ហាញនូវ ការពុំបានពិចារណាលើលក្ខខណ្ឌតម្រូវនៃការរួមចំណែកក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងការជម្រុញគោលបំ ណងរួម។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ច្បាស់លាស់ថា "ជនជាប់ចោទត្រូវតែចូលរួមក្នុងគោលបំណងរួម រួមចំណែកយ៉ាងសំខាន់ ប៉ុន្តែពុំចាំបាច់សំខាន់បំផុតដោយ ខ្វះមិនបាននៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ"[5067] និងថា "ការជាប់ពាក់ព័ន្ធរបស់សមាជិកនៃសហឧក្រិដ្ឋ កម្មរួមទៅនឹងបទឧក្រិដ្ឋបង្កើតបានជាទំនាក់ទំនងភ្ជាប់គ្នារវាងហេតុ និងផល"[5068]។ វិធីសាស្ត្ររបស់ ខៀវ សំផន ស្តីពីលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិដែលថា "ជាក់ស្តែង ច្បាប់បានតម្រូវថា ជនជាប់ចោទត្រូវ តែ [...] មានចេតនាចូលរួមក្នុងការអនុវត្តន៍ទិដ្ឋភាពល្មើសនៃគោលបំណងរួម និងចេតនានៃការប្រព្រឹត្ត ឧក្រិដ្ឋកម្ម"[5069] ត្រូវបដិសេធចោលប្រហាក់ប្រហែលគ្នានេះដែរ ដោយសារបានផ្អែកទៅលើភាពខុសប្លែកគ្នា តូចតាចនៃការដកស្រង់ខ្លឹមសារដោយពុំបានបង្ហាញថាតើ មានអត្ថន័យខុសប្លែកគ្នាដូចម្តេចពីការបញ្ជាក់ របស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ចេតនានៃសហឧក្រិដ្ឋកម្មរួមត្រូវគ្របដណ្តប់លើគោលបំណងរួម និងបទឧក្រិដ្ឋដែលបានរួមបញ្ចូលតាមរយៈគោលបំណងនោះ"[5070] ដែលអង្គជំនុំជម្រះតុលាការកំពូលបាន បង្ហាញពីដំបូងថា ត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២/០១[5071]។

1812.អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ស្តីពីកំហុសនៅក្នុងការបញ្ជាក់របស់អង្គជំនុំជម្រះសាលា ដំបូងអំពីច្បាប់ជាធរមានចំពោះសហឧក្រិដ្ឋកម្មរួមត្រូវបដិសេធចោល។

## ២. លក្ខណៈល្មើសនៃគោលបំណងរួម

[5067] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧០៨ (សេចក្តីបញ្ជាក់បន្ថែម)។

[5068] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១០ (សេចក្តីបញ្ជាក់បន្ថែម)។

[5069] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៦៣។

[5070] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១២។

[5071] សាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៣។

1813.ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ផែនការបដិវត្តន៍សង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈជាបទល្មើស[5072]។ គាត់បានអះអាងថា “គោលបំណងរួមតែមួយគត់ដែលមានអត្ថិភាពនោះ គឺគោលបំណងនៃការបង្កើតបដិវត្តន៍សង្គមនិយមមួយក្នុងកម្ពុជាក្នុងបរិបទនៃសង្គមមួយដែលផ្តោតទៅលើការគ្រប់គ្រងសមូហភាពនៃប្រព័ន្ធទំនើបកម្មកសិកម្ម”[5073] និងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ពុំត្រឹមត្រូវនូវអត្ថន័យនៃ“មហាលោតផ្លោះមហាអស្ចារ្យ” ព្រមទាំងវចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា និងវិសាលភាពដែលវចនាសម្ព័ន្ធនេះអាចផ្សព្វផ្សាយព័ត៌មាន[5074]។ គាត់បានពិពណ៌នាថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួន និងមានភាពលម្អៀងក្នុងការពិនិត្យលើភស្តុតាងដោយបំភ្លៃពីគោលបំណងរួមដែលមិនមែនជាបទល្មើសទៅជាមានបទល្មើស[5075]។ ខៀវ សំផន បានអះអាងថា បើទោះបីជាបទឧក្រិដ្ឋអាចត្រូវបានប្រព្រឹត្តឡើងក៏ដោយ ក៏ពុំមែនមានន័យថា ការប្រព្រឹត្តបទឧក្រិដ្ឋនោះគឺជាផ្នែកនៃ“គោលនយោបាយ”ល្មើសនោះដែរ[5076] និងថា នេះគឺជាគោលគំនិតដែលត្រូវបានដាក់បញ្ចូលខុសពីការពិត ដើម្បីបន្ទាបលក្ខខណ្ឌតម្រូវនៃសហឧក្រិដ្ឋកម្មរួមក្នុងកម្រិតមួយដែលថា គោលបំណងរួមក្លាយជាបទល្មើស[5077]។ អាស្រ័យហេតុនេះ ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើ“វិធីសាស្ត្រពុំត្រឹមត្រូវបែបនេះ”[5078]។

1814.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យត្រឹមត្រូវនៃគោលបំណងរួមបន្ទាប់ពីធ្វើការវិភាគដោយសត្យានុម័តលើកំណត់ត្រាជាភស្តុតាងយ៉ាងទូលំទូលាយក្នុងការយល់ឃើញថា បដិវត្តន៍សង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា ជាមូលដ្ឋាន គឺជាបទល្មើសដែលត្រូវបានបង្កើតឡើងដើម្បីសម្រេចគោលដៅតាមរយៈគោលនយោបាយមួយចំនួនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម[5079]

---

[5072] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០០-១៤៤៧។ *សូមមើលផងដែរ* ប្រតិចារិកចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/11.1 ទំព័រ ៧-១១។

[5073] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៩៩។

[5074] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤២០-១៤៣៧។

[5075] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៣៩៩-១៤០៨, ១៤១៥-១៤១៩, ១៤៣៨-១៤៤៧, ១៥៩៣-១៦០០, ១៩៦៦-១៩៨៦, ២០០៤-២០០៧។

[5076] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០៦, ១៤៤៤, ១៦០០, ១៩៩៩។

[5077] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៧៤-២០០០។

[5078] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០១, ១៤០៧។

[5079] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៥៤-៩៨៥។

។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា "ការផ្ដោតរបស់ ខៀវ សំផន លើគោលបំណងរួមដែលពុំមែនជាបទល្មើស និងមានក្ដីមេត្តា និងការដែលថា បទឧក្រិដ្ឋនោះគឺជា"ការអនុវត្តន៍ប្រាសចាក"ពីគោលបំណងរួម មានលក្ខណៈជាអរូបិយ ពុំជាប់ពាក់ព័ន្ធ និងពុំអើពើលើការពិត"[5080]។

1815.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បង្ហាញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គោលបំណងរួមដែលជាកម្មវត្ថុនៃអំពើដែលបានគ្រោងទុករវាងបុគ្គលជាច្រើន ត្រូវតែមានលក្ខណៈជាបទល្មើស ក្នុងន័យថា គោលបំណងនេះអាចស្មើនឹង ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម[5081]។ ក្នុងបរិបទនៃការវាយតម្លៃលម្អិត និងសព្វគ្រប់លើភស្តុតាងដោយអង្គជំនុំជម្រះសាលាដំបូង រួមទាំងអង្គហេតុជាក់លាក់ក្នុងអំឡុងពេលជិតបួនឆ្នាំចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ និងក្នុងឆ្នាំមុនការគ្រប់គ្រងកម្ពុជាបន្ទាប់ពីជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងសង្គ្រាមស៊ីវិល ការលើកឡើងដែលថា គោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជាពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនោះ ដូចជាខុសពីការពិត។ បើទោះបីជាបដិវត្តន៍អាចបានផ្ដល់អត្ថប្រយោជន៍ដល់សង្គមដោយគ្មានការបង្ហូរឈាម ឬសកម្មភាពល្មើសក៏ដោយ ក៏នេះពុំបានអនុវត្តចំពោះរឿងក្ដីបច្ចុប្បន្ននេះឡើយ។

1816.ការអះអាងដដែលៗរបស់ ខៀវ សំផន ដែលថា គោលបំណងរួមនៃការអនុវត្តន៍បានឆាប់រហ័សនូវបដិវត្តន៍សង្គមនិយមក្នុងកម្ពុជា ពុំមែនជាបទល្មើស ប៉ុន្តែជាផ្នែកនយោបាយសុទ្ធសាធនោះ ពុំបានអើពើទៅលើការពិតដែលថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំពោញមួយអំឡុងពេលនៃដំណើរការអនុវត្តន៍នោះ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ត្រឹមត្រូវថា គោលបំណងរួមក្នុងការទទួលបានសង្គមបដិវត្តន៍កម្ពុជាមួយតាមរយៈ"មហាលោតផ្លោះមហាអស្ចារ្យ" ពុំមានលក្ខណៈជាបទល្មើស*ដោយខ្លួនឯងផ្ទាល់*នោះទេ ប៉ុន្តែនៅពេលពិចារណាទូលំទូលាយលើភស្តុតាង អាចកំណត់បានថា ការអនុវត្តន៍ដោយជោគជ័យនៃគោលបំណងនេះ"គឺពឹងផ្អែកទៅលើការអនុវត្តន៍គោលនយោបាយដែលបង្កគ្រោះថ្នាក់ និងការលុបបំបាត់រាល់សមាសភាពប្រឆាំងបដិវត្តន៍តាមការសន្មតថា បានរារាំងបក្ស ឬការវិវឌ្ឍន៍របស់បដិវត្តន៍សង្គមនិយម"[5082]។ នៅគ្រប់កាលៈទេសៈទាំងអស់ ការដែលថា គោលបំណងរួមអាចមានលក្ខណៈជានយោបាយជាមូលដ្ឋាននោះ ជាចាំបាច់ពុំបានរារាំងដល់ការអនុវត្តន៍នូវគោលបំណងរួមតាមរយៈមធ្យោបាយល្មើសឡើយ។

---

[5080] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៦១។

[5081] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៨៩, ៨១៤។

[5082] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៣។

1817.បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្តកំណត់លើ"បញ្ហាថាតើ គោលនយោបាយទាំងនេះមានអត្ថិភាព ថាតើបានរួមបញ្ចូលការប្រព្រឹត្តបទឧក្រិដ្ឋ និងថាតើ បទឧក្រិដ្ឋនោះផ្សាភ្ជាប់យ៉ាងស្អិតល្មួតទៅនឹងគោលបំណងរួម" ដែរ ឬយ៉ាងណា មុនពេលបញ្ជាក់ថា ក្រុមរួមនោះមានលក្ខណៈជាបទឧក្រិដ្ឋ[5083] និងបានយល់ឃើញថា អង្គហេតុទាំងនោះត្រូវបានកម្រិតត្រឹមវិសាលភាពនៃសំណុំរឿង ០០២/០២។ ការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងដោយបានពិនិត្យលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងការជម្រុញគោលបំណងរួម ជាជាងការផ្តោតទៅលើគោលបំណងនយោបាយនេះ ពុំមានប្រសិទ្ធភាពឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះបីព្យាយាមពង្រីកការស្រមៃយ៉ាងណាក៏ពុំអាចជឿបានថា បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុវត្តដោយមានក្តីមេត្តា ឬគិតគូរដល់សុខទុក្ខប្រជាជនឡើយ។ បន្ថែមលើនេះ បើទោះបីជាសារណារបស់គាត់ត្រូវបានទទួលយកដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ពុំត្រឹមត្រូវលើមូលដ្ឋានផ្នែកមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធទំនាក់ទំនង និងវិសាលភាពនៃការផ្សព្វផ្សាយព័ត៌មានក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែបានយល់ឃើញដោយសមហេតុផលថា បទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើងដោយសារបញ្ហាគោលនយោបាយដើម្បីធានាថា ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគាត់អាចស្មានដឹងជាមុននោះនឹងត្រូវសម្រេចបានឆាប់រហ័ស។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភាគីដែលស្នើសុំបដិសេធសច្ចធារណ៍អនាគតិរបស់ចៅក្រមមានបន្ទុកក្នុងការបង្ហាញកម្រិតខ្ពស់ដើម្បីស្នើសុំបដិសេធសច្ចធារណ៍នោះ[5084]។ ការយល់ឃើញផ្ទុយដែលផ្អែកតាមការពិនិត្យភស្តុតាង ពុំអាចបង្ហាញដោយខ្លួនឯងនូវភាពលម្អៀងបានឡើយ។

1818.ការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសដោយពុំត្រឹមត្រូវនូវវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួនដោយរួមបញ្ចូលការវិនិច្ឆ័យលើអង្គហេតុពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជន ដែលជាការរំលោភបំពានលើ*គោលការណ៍អាជ្ញាអស់ជំនុំ*[5085] ព្រមទាំងបទឧក្រិដ្ឋដែលលើសពីការចោទប្រកាន់នៅសហករណ៍ និងការដ្ឋានធ្វើការក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[5086] ប្រហាក់ប្រហែលគ្នា ដែរពុំមានមូលដ្ឋានគាំទ្រសម្រាប់ហេតុផលដែលបានពិភាក្សារួចរាល់ខាងលើ[5087]។ ទាក់ទងទៅនឹងភស្តុតាង

---

[5083] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៤។

[5084] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១២ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5085] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០១, យោងទៅលើកថាខណ្ឌ ៥៤៤-៥៤៦។

[5086] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០២, យោងទៅលើកថាខណ្ឌ ៤៦៩, ៤៧០, ៤៧៤, ៤៨០, ៤៨១, ៤៨៣, ៤៨៦, ៤៨៩, ៤៩២-៤៩៤, ៤៩៩, ៥០៤, ៥១០, ៥១៣, ៥១៦។

[5087] *សូមមើលខាងលើ* ផ្នែក VI.ឃ.២ និងផ្នែក VI.គ.២.ក។

នៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់នូវហេតុផលថា ភស្តុតាងនៃការរំលោភសេពសន្ថវៈដែលស្ថិតក្រៅវិសាលភាពនៃបទចោទជាក់លាក់នេះ"ពុំត្រូវបានយកមកពិចារណាដើម្បីគាំទ្រនូវធាតុផ្សំនៃបទល្មើសនានាក្នុងរឿងក្ដីនេះ"[5088]។ ក្នុងករណីដែលអង្គជំនុំជម្រះបានពិចារណាលើភស្តុតាងនោះ "គឺដោយសារតែមានការជាប់ពាក់ព័ន្ធទៅនឹងបរិបទនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះប៉ុណ្ណោះ ពីព្រោះឧក្រិដ្ឋកម្មនេះបានផ្ដល់នូវបរិបទនៃការភ័យខ្លាច និងអំពើហិង្សាដែលបានកើតឡើងពេលនោះ"[5089]។ តាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ក្រៅពី"ការវិភាគលើភស្តុតាងដើម្បីធ្វើការបញ្ជាក់អះអាងលើការសន្មតបឋម[នូវលក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម]"[5090] អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិនិត្យយ៉ាងទូលំទូលាយហ្មត់ចត់លើភស្តុតាងជាឯកសារ និងសក្ខីកម្មជាច្រើន នៅមុនពេលធ្វើការសន្និដ្ឋានថា គោលបំណងរួម មានលក្ខណៈជាបទល្មើសនោះ[5091]។

1819.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់លក្ខណៈល្មើសនៃគោលបំណងរួម ត្រូវបដិសេធចោល។

### ៣. គោលនយោបាយបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

1820.អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពនៃគោលនយោបាយដើម្បីបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យដាច់ដោយឡែក និង"កម្ទេច"អ្នកដែលត្រូវបានចាត់ទុកថា ជាសត្រូវប្រភេទធ្ងន់ធ្ងរបំផុត និងអប់រំកែប្រែឡើងវិញនូវ"សមាសភាពមិនល្អ"[5092]។ អង្គជំនុំជម្រះបានកំណត់ថា គោលគំនិតនៃការប្រើពាក្យ"សត្រូវ"បានរួមបញ្ចូលអ្នកដែលត្រូវបានសន្មតថាប្រឆាំងនឹងបដិវត្តន៍កុម្មុយនីស្ត[5093] និងថា កម្រិតនៃការកំណត់គោលដៅលើប្រភេទផ្សេងៗគ្នានៃសត្រូវ បានប្រែប្រួលអាស្រ័យលើថាតើ នរណាបានបង្កការ

---

[5088] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៨ (សេចក្ដីបញ្ជាក់បន្ថែម)។

[5089] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៥៨ (សេចក្ដីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរខាងលើ* ផ្នែក VII.ឆ.៣.ក.ii។

[5090] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០៦។

[5091] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៦-៤០៦៨។

[5092] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣០-៣៩៧២។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៥៧-៣៨៥៩។

[5093] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៤, ៣៨៣៥-៣៨៦៣។

គំរាមកំហែងធំជាងគេបំផុតនៅពេលណាមួយនោះ[5094] និងថា "ការកំណត់អត្តសញ្ញាណសម្រាប់ការកម្ទេចដែលជាគោលការណ៍គ្រឹះនៃចលនាកុម្មុយនីស្តក្នុងកម្ពុជា មានប្រភពចេញពីមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជាដែលប្រកាសដោយខ្លួនឯង"[5095]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គោលនយោបាយនេះនៃការបង្កើតមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សសម្រាប់"ការកម្ទេចសត្រូវ" គឺផ្សាភ្ជាប់ទៅនឹងគោលបំណងរួម និងដូចបានអនុវត្តនៅមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល ជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[5096]។

1821.បើទោះបីជាការយល់ឃើញយ៉ាងទូលំទូលាយនេះ*ក្នុងចំណោមនោះ*បានផ្អែកលើភស្តុតាងរបស់សាក្សីជាច្រើនដែលជាជនរងគ្រោះ កម្មាភិបាល និងអ្នកនិពន្ធផ្នែកសិក្សាស្រាវជ្រាវក៏ដោយ ក៏ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ពុំត្រឹមត្រូវលើសញ្ញាណរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីសត្រូវ និងបានបង្ហាញពុំត្រឹមត្រូវអំពីអត្ថិភាពនៃគោលនយោបាយកម្ទេចសត្រូវនៅតាមមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សនានា[5097]។ ជាពិសេស គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងមុន ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងការបង្ហាញថា មានអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងសត្រូវក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5098] និងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដែលមានតម្លៃទាប ក្នុងការបង្កើតទស្សនទានកាលប្រវត្តិនៃសញ្ញាណរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីសត្រូវចាប់តាំងពីឆ្នាំ ១៩៧៥ រហូតដល់ ឆ្នាំ ១៩៧៨[5099]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា និងសុន្ទរកថារបស់មេដឹកនាំ និងយល់ច្រឡំ ឬបញ្ចូលលាយឡំគ្នារវាងពាក្យពេចន៍យោធា និងមនោគមវិជ្ជា ដោយពុំបាន

---

[5094] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៣៩-៣៨៥៥។

[5095] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៥-៣៨៣៨, ៣៨៥៦-៣៨៦៣។

[5096] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៧៣-៣៩៨៧។

[5097] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៤៨-១៤៨៨, ១៥២៣-១៥៥០។

[5098] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២៤, ១៥២៥, យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣៤-៣៩៤១។

[5099] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥១-១៤៧២។

ដាក់តាមបរិបទត្រឹមត្រូវនូវប្រភេទសត្រូវផ្សេងៗ និងបានទាញការសន្និដ្ឋានថា មានអត្ថិភាពនៃគោលនយោបាយល្មើសប្រឆាំងនឹងពួកគេ[5100]។ គាត់បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា មានមន្ទីរសន្តិសុខយ៉ាងតិច ២០០ កន្លែង[5101] និងថា ការយល់ឃើញមួយចំនួនដទៃទៀតនៃឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខបានធ្វើហួសពីវិសាលភាពជំនុំជម្រះរបស់ខ្លួន[5102] និងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើអត្ថិភាពនៃបទឧក្រិដ្ឋក្នុងមន្ទីរសន្តិសុខ ថាជាគោលនយោបាយ នៅពេលបទឧក្រិដ្ឋទាំងនេះត្រឹមតែជាការអនុវត្តន៍ប្រាសចាកពីគោលបំណងបដិវត្តន៍ និងនយោបាយសុទ្ធសាធ[5103]។ ខៀវ សំផន បានអះអាងថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានរារាំងការធ្វើសេចក្តីសន្និដ្ឋានដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល[5104]។

1822.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសុពលភាពនៃការអះអាងទាំងនេះ និងបានរំឭកអង្គជំនុំជម្រះតុលាការកំពូលថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុនៅពេលយល់ឃើញថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈការប្រយុទ្ធប្រឆាំងនឹង“សត្រូវ” ដែលជាគោលគំនិតមួយបានវិវឌ្ឍជាដរាប[5105]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បក្សកុម្មុយនីស្តកម្ពុជា មានគោលនយោបាយកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យដាច់ដោយឡែក និង“កម្ទេច”សត្រូវដែលមានគ្រោះថ្នាក់បំផុតនៅតាមមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សទូទាំងប្រទេស និងអប់រំកែប្រែឡើងវិញនូវ“សមាសភាពមិនល្អ”[5106]។

1823.អង្គជំនុំជម្រះតុលាការកំពូលរំឭកការសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ស្តីពីកម្មវត្ថុប្រហាក់ប្រហែលគ្នាទៅនឹងការសំអាងលើព្រឹត្តិការណ៍មុនខែ មេសា ឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងពុំត្រូវបាន

---

[5100] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៧៣-១៤៨៨, ១៥២៦-១៥៤០។

[5101] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២៥។

[5102] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៤៣-១៥៤៥, ១៥៤៩ យោងទៅលើកថាខណ្ឌ ៣៩៧-៤១៩, ៤៩៥-៥១៦។

[5103] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៤៧។

[5104] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៤៦។

[5105] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៩៨៥-១០០២។

[5106] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០០៣-១០២០។

រារាំងក្នុងការពិចារណាលើភស្តុតាងនៃអំពើ ឬសកម្មភាពមុនៗដែលមានតម្លៃជាភស្តុតាងសក្តានុពល និង ជាប់ពាក់ព័ន្ធក្នុងការបង្ហាញថាតើ លំនាំដែលជាប់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ក្នុងពេលជំនុំជម្រះនេះ បាន ស្តែងឱ្យឃើញជាក់លាក់ ដែរ ឬយ៉ាងណា និងសំខាន់ជាងនេះទៀត ថាតើលំនាំនោះត្រូវបានអនុវត្តតាមក្នុង អំឡុងពេលយុត្តាធិការពេលវេលាចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតមកក្នុងបរិបទនៃការអនុវត្តន៍ គោលបំណងរួម ដែរ ឬយ៉ាងណា[5107]។ តាមរយៈការពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញឱ្យ ឃើញនូវការបន្តនៃលំនាំគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមុនខែ មេសា ឆ្នាំ ១៩៧៥ និងជាប់ពាក់ ព័ន្ធទៅនឹងការយល់ដឹងច្បាស់នូវលក្ខណៈនៃគោលបំណងរួម និងគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ ខៀវ សំផន បានសម្តែងការ មិនពេញចិត្តជាមួយនឹងការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[5108] ដោយ បានចង្អុលបង្ហាញទៅលើសាលដីកានៃអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTR ក្នុងរឿងក្តី *Nahimana និងជនដទៃទៀត* ដែលបញ្ជាក់ថា ភស្តុតាងដែលបង្ហាញនូវអំពើសកម្ម ឬអកម្មស្តីពីការទទួលខុសត្រូវ សម្រាប់ឧក្រិដ្ឋកម្ម ត្រូវតែបានកើតឡើងនៅក្នុងយុត្តាធិការពេលវេលារបស់តុលាការ[5109]។ ទោះជាយ៉ាង ណាក្តី សាលដីកានៃអង្គជំនុំជម្រះឧទ្ធរណ៍ក្នុង*រឿងក្តី Nahimana និងជនដទៃទៀត* បានផ្តល់សម្រាប់ករណី ពិសេសដែលថា អង្គជំនុំជម្រះសាលាដំបូងណាមួយអាចទទួលយកដោយសុពលភាពនូវភស្តុតាងស្តីពីអំពើ ដែលកើតមានមុនយុត្តាធិការពេលវេលា និងបានសំអាងទៅលើ នៅពេលដែលភស្តុតាងនោះប្រើប្រាស់ក្នុង គោលបំណងដើម្បីៈ (១) បំភ្លឺបរិបទណាមួយ (២) បង្ហាញតាមរយៈការសន្និដ្ឋាននូវធាតុផ្សំ(ជាពិសេស ចេតនាល្មើស)នៃអំពើឧក្រិដ្ឋ ដែលបានកើតឡើងក្នុងវិសាលភាពនៃយុត្តាធិការពេលវេលា និង/ឬ (៣) បង្ហាញនូវលំនាំនៃអំពើដែលបានគិតទុកជាមុន[5110]។

1824. ភស្តុតាងបង្ហាញអំពីព្រឹត្តិការណ៍ដែលកើតឡើងមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែល ខៀវ សំផន បាន ជំទាស់នោះ ជាបឋមចេញពីសក្ខីកម្មរបស់ នួន ជា និង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច និងចេញពីខ្លឹមសារដែល មានក្នុងឯកសារបោះពុម្ពផ្សាយក្នុង*ទស្សនាវដ្តីទង់បដិវត្ត* ដែលបានបង្ហាញថា គោលគំនិតរបស់បក្សកុម្មុយនី ស្តកម្ពុជា និងគោលនយោបាយប្រឆាំងនឹងសត្រូវ ត្រូវបានបង្កើតឡើងតាំងពីដើមឆ្នាំ ១៩៦០ ហើយបានវិវឌ្ឍ ជាច្រើនឆ្នាំរហូតដល់អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះតុលាការកំពូលបានកត់

---

5107 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២១១ -២២១។

5108 សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៣៨-៥៥។

5109 សាលដីការឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* កថាខណ្ឌ ៣០៩-៣១៤។

5110 សាលដីកា*រឿងក្តី Nahimana និងជនជាប់ចោទដទៃទៀត* កថាខណ្ឌ ៣១៥។

សម្គាល់ថា យោងតាមសំអាងហេតុដូចគ្នាខាងលើ ភស្តុតាងនេះដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ក្រៅវិសាលភាពភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. បានផ្តល់ជាកាលប្បវត្តិនៃបរិបទយ៉ាងសំខាន់ដល់ការស្វែងយល់នូវគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា និងមហិច្ឆតា និងការបង្កើតគោលបំណងរួម ព្រមទាំងការរួមចំណែកក្នុងការអនុវត្តន៍នូវគោលបំណងរួម ដែលបានបន្តបន្ទាប់ពីខែមេសា ឆ្នាំ ១៩៧៥។ ពិតណាស់ អាចមានការខ្វះចន្លោះពីសំណាក់អង្គជំនុំជម្រះសាលាដំបូងដែលមើលពុំឃើញនូវសកម្មភាពជាបន្តបន្ទាប់របស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យក្នុងបរិបទមួយចំនួន។ ពុំមានបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ និងពុំមានការដាក់ពិរុទ្ធណាមួយត្រូវបានសម្រេចចំពោះឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តនៅមុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥។

1825.បន្ទាប់មក ខៀវ សំផន បានជំទាស់ទៅនឹងតម្លៃជាភស្តុតាងនៃឯកសារមួយចំនួន និងបានអះអាងថា ពុំគប្បីមានការយល់ឃើញត្រូវបានធ្វើឡើងតាមរយៈភស្តុតាងនោះ។ តាមការជ្រើសរើស គាត់បានចង្អុលបង្ហាញទៅលើភស្តុតាងដែលគាត់បានពិពណ៌នាថា ជាឯកសារពុំមានកាលបរិច្ឆេទរបស់អ្នកនិពន្ធដែលពុំស្គាល់ឈ្មោះ[5111]ដូចជា បទបញ្ជាកម្ទេចខែ មិថុនា ឆ្នាំ ១៩៧៥[5112] សេចក្តីដកស្រង់ចេញពីកិច្ចការរបស់ Ben KIERNAN និងសៀវភៅកំណត់ហេតុរបស់ អៀង សារី[5113] កំណត់ហេតុរបស់ Christopher GOSCHA[5114] "សៀវភៅកំណត់ហេតុបញ្ចូលគ្នានៃមន្ទីរស-២១"[5115] សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន[5116] សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដែលថា សត្រូវបីប្រភេទត្រូវបានកំណត់អត្ត

---

[5111] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥១, ១៤៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥០, ៣៧៥១។

[5112] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥២។

[5113] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥៨, ១៤៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៤៦, ៣៧៧៨, ៣៧៩១, ៣៨០៣។

[5114] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៦៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨០៥, ៣៨១៤។

[5115] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៦៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨២២។

[5116] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៣៤, ១៥៣៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦១។

សញ្ញាណក្នុងឆ្នាំ ១៩៦០[5117] និងការប្រកាសរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដែលថា សេចក្ដីណែនាំរបស់គណៈអចិន្ត្រៃយ៍លើកលែងទោស"សត្រូវ"សម្រាប់សកម្មភាពនៅមុនឆ្នាំ ១៩៧៥ គឺជាឧបាយកលកុំឱ្យប្រជាជនមានការជ្រួលច្របល់[5118]។ ទោះជាយ៉ាងណាក្ដី វិធីសាស្ត្រជំទាស់ជាផ្នែកៗនេះ ពុំអាចបដិសេធតម្លៃជាភស្តុតាងបាននៅពេលពិនិត្យជារួម និងក្នុងបរិបទនៃឯកសារ និងសក្ខីកម្មដទៃទៀត និងតាមធម្មតាពុំបានអើពើទៅលើភស្តុតាងជាច្រើនដទៃទៀតដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការបកស្រាយសញ្ញាណវិវឌ្ឍរបស់បក្សកុម្មុយនីស្តកម្ពុជាលើសត្រូវ និងគោលនយោបាយ ដូចជា ខ្លឹមសារនៅក្នុងឯកសារបោះពុម្ពផ្សាយនៃទស្សនាវដ្ដីទង់បដិវត្ត និងយុវជនបដិវត្ត[5119] ឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា និងការទំនាក់ទំនង[5120] សក្ខីកម្មរបស់អតីតកម្មាភិបាល រួមទាំង នួន ជា[5121] និងសុន្ទរកថារបស់ ប៉ុល ពត, នួន ជា និង ខៀវ សំផន[5122]។

1826.ខៀវ សំផន បានអះអាងសាជាថ្មីថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិនិត្យលើភស្តុតាងនេះក្នុងបរិបទសមស្រប ដូចជា បរិបទនៃការប្រទូសរ៉ាយប្រដាប់អាវុធប្រឆាំងនឹងរបប លន់ នល់ និងក្រោយមកជាមួយវៀតណាម[5123]។ បណ្ដឹងសាទុក្ខពុំមែនជាការធ្វើសវនាការសាឡើងវិញនោះទេ និងស្ថិតក្នុងដែនកំណត់នៃការស្វែងយល់នេះ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យយ៉ាងទូលំទូលាយលើភស្តុតាងទាក់ទង

---

[5117] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៣៤។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៩៣។

[5118] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៣១ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៧១។

[5119] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥៣, ៣៧៥៥, ៣៧៥៨, ៣៧៥៩, ៣៧៦២, ៣៧៧៧, ៣៧៨០, ៣៧៩២, ៣៨០២, ៣៨០៦, ៣៨០៨, ៣៨១០, ៣៨១៣, ៣៨១៩, ៣៨២០, ៣៨២៤, ៣៨២៧-៣៨២៩, ៣៨៣៣, ៣៩៣៨, ៣៩៤០, ៣៩៤១, ៣៩៥៨, ៣៩៥៩, ៣៩៦៦, ៣៩៦៨។

[5120] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥៤, ៣៧៥៦, ៣៧៥៧, ៣៧៦០, ៣៧៦៤-៣៧៦៦, ៣៧៦៨-៣៧៧២, ៣៧៧៥, ៣៧៧៩, ៣៧៨១-៣៧៩០, ៣៧៩៣-៣៧៩៥, ៣៧៩៧, ៣៧៩៩, ៣៨០០, ៣៨០៤, ៣៨០៥, ៣៨០៩, ៣៨១១, ៣៨១៧, ៣៨២៥, ៣៨២៦, ៣៨២៨, ៣៨៣១, ៣៨៣៤, ៣៩៥៥, ៣៩៦២-៣៩៦៤។

[5121] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៦១, ៣៧៦៧, ៣៧៦៩, ៣៨០១, ៣៨១០, ៣៨២៨, ៣៩៣៥-៣៩៣៧, ៣៩៤០, ៣៩៤៥, ៣៩៦៩។

[5122] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៧៣, ៣៧៧៤, ៣៨០៧, ៣៨១២, ៣៨១៥, ៣៨១៦, ៣៨១៨, ៣៨២៣, ៣៨៣០, ៣៩៣៤, ៣៩៣៩, ៣៩៦០, ៣៩៧០។

[5123] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥០-១៤៥២, ១៤៥៤, ១៤៥៦, ១៤៥៧, ១៤៥៩-១៤៦២, ១៤៦៥-១៤៨៨, ១៥២៥, ១៥៤២។

ទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការអនុវត្តន៍ចំពោះសត្រូវពិត និងតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានសន្និដ្ឋានថា អំណះអំណាងនេះពុំមានមូលដ្ឋានគ្រប់គ្រាន់។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់លើភស្តុតាងជាច្រើនដទៃទៀត ក្នុងការវិភាគផ្នែកអង្គហេតុរបស់ខ្លួនអំពីការសំដៅរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើសត្រូវ[5124]។ ការប៉ុនប៉ងលើកសាឡើងវិញក្នុងការបង្ហាញឱ្យឃើញខុសប្លែកគ្នារវាងសត្រូវនយោបាយ/មនោគមវិជ្ជា និងសត្រូវយោធាដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំ និងដូច្នេះកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវ[5125] នៅគ្រប់ករណី ពុំបានបង្ហាញនូវផលវិបាកដល់ការយល់ឃើញទូទៅដែលថា បុគ្គលដែលត្រូវបានសន្មតជាសត្រូវ ឬជាសត្រូវជាក់ស្តែងបើទោះបីជាសត្រូវនយោបាយ/មនោគមវិជ្ជា យោធា ឬអ្វីផ្សេងក៏ដោយ ត្រូវបានកំណត់គោលដៅសម្រាប់ការកម្ទេច ឬការអប់រំកែប្រែនៅមន្ទីរសន្តិសុខ និងទីតាំងកម្ទេច។

1827.ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងជាសង្ខេបរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានមន្ទីរសន្តិសុខយ៉ាងតិច ២០០ កន្លែងនៅពាសពេញរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ពុំបានផ្តល់ទឡ្ហីករណ៍ណាមួយទាក់ទងទៅនឹងបញ្ហាថាតើ ការមោឃភាពនូវការយល់ឃើញនេះអាចប៉ះពាល់ ឬធ្វើឱ្យសាលក្រមអង្គជំនុំជម្រះអស់សុពលភាពដូចម្តេចឡើយ។ ដោយសារវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកម្រិតត្រឹមទីតាំងឧក្រិដ្ឋកម្មបួនកន្លែង ដែលតំណាងឱ្យកម្ពុជាប្រជាធិបតេយ្យទាំងមូល អង្គជំនុំជម្រះសាលាដំបូងបានកម្រិតយ៉ាងត្រឹមត្រូវនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនស្តីពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយសារបញ្ហាគោលនយោបាយនៅមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល[5126]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធរួចរាល់នូវអំណះអំណាងដែលថា ចំណាត់ការនោះបានធ្វើហួសពីវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង[5127]។ ការចោទប្រកាន់បន្ថែមទៀតរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះបានបំភ្លៃឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦[5128] ក្នុងការបកស្រាយអត្ថន័យពុំត្រឹមត្រូវ

---

[5124] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៣។

[5125] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥៤, ១៤៧៣-១៤៧៩, ១៥៣២, ១៥៣៣, ១៥៣៦-១៥៤១។

[5126] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៧៣-៣៩៨៦។

[5127] *សូមមើលខាងលើ* ផ្នែក VI.គ.២.ក។

[5128] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៥៥, ១៥២៧-១៥៣០។

នៃពាក្យ"កម្មេច"សត្រូវ ត្រឹមតែជាផ្ដល់នូវការបកស្រាយមួយផ្សេងទៀតដែលខុសទាំងស្រុងពីអង្គហេតុ ដោយពុំបានបង្ហាញមូលហេតុដូចម្ដេចបានសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល នោះឡើយ។ បទដ្ឋានជាធរមានក្នុងការពិនិត្យឡើងវិញលើការយល់ឃើញដែលរងការជំទាស់ផ្នែកអង្គហេតុ គឺជាបទដ្ឋានស្ដីពីភាពសមហេតុផល[5129]។

1828.អង្គជំនុំជម្រះតុលាការកំពូលរំឭកបន្ថែមទៀតថា អំណះអំណាងដែលត្រឹមតែជាការមិនយល់ស្របជាមួយ នឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាដែលផ្អែកលើការបកស្រាយមួយបែបផ្សេង ទៀតដែលគ្មានមូលដ្ឋានគាំទ្រត្រឹមត្រូវលើភស្តុតាងដដែលនោះ ពុំមានលក្ខណៈគ្រប់គ្រាន់បដិសេធការយល់ ឃើញផ្នែកអង្គហេតុរបស់តុលាការអង្គហេតុបានឡើយ[5130]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការពន្យល់មួយបែបផ្សេងរបស់ ខៀវ សំផន ដែលថា ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិ សុខ ពុំមែនជាផ្នែកនៃគោលនយោបាយឧក្រិដ្ឋ ប៉ុន្តែត្រូវបានប្រព្រឹត្តដោយចារីដែលបានអនុវត្តប្រាសចាកពី គោលបំណងនយោបាយត្រឹមត្រូវក្នុងការបង្កើតបដិវត្តន៍សង្គមនិយមនោះ គឺបានផ្អែកតែទៅលើអំណះអំណា ងដែលបានបង្ហាញពីមុននៅពេលជំនុំជម្រះដែលកន្លងមកពុំបានទទួលជោគជ័យ។ គាត់ពុំបានផ្ដល់មូលដ្ឋាន គាំទ្រចំពោះមូលហេតុយ៉ាងដូចម្ដេចបានជាសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ពុំសមហេតុផល ដែលបានទាញចេញពីសក្ខីកម្មរបស់សាក្សីជាច្រើនដែលជាអតីតអ្នកដែលត្រូវបានគេផ្លាស់ទី អ្នកភូមិ អ្នក ជាប់ឃុំឃាំង និងអ្នករួចជីវិតដែលបានបាត់បង់សមាជិកគ្រួសារនោះ។ សារណារបស់គាត់ដែលថា អង្គជំនុំ ជម្រះសាលាដំបូងពុំគប្បីយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិ សុខនានានោះ ពុំគួរឱ្យជឿជាក់ដូចគ្នា លើកលែងការយល់ឃើញស្ដីពីអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសម្រាប់ហេតុផល ដែលបានពន្យល់ខាងលើ[5131]។

1829.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះ សាលាដំបូងពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការ មន្ទីរសន្តិសុខ និងទីតាំងកម្មេចក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបដិសេធចោល។

---

[5129] *សូមមើលខាងលើ* ផ្នែក II។

[5130] *សូមមើលខាងលើ* ផ្នែក II។

[5131] *សូមមើលខាងលើ* ផ្នែក VII.ក.៥.ង។

## ៤. គោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការ

1830.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពនៃគោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការ ដែលជាឧបករណ៍បឋមសម្រាប់បង្កើតការតស៊ូវណ្ណៈ និងក្នុងគោលបំណងបង្កើតកម្លាំងពលកម្ម និងការបង្កបង្កើនផលតាមរយៈការគ្រប់គ្រងតឹងរ៉ឹងលើប្រជាជន ដែលជាមធ្យោបាយនៃការជម្រុញគោលបំណងរួមអនុវត្តឆាប់រហ័សបដិវត្តន៍សង្គមនិយមតាមរយៈ“មហាលោតផ្លោះមហាអស្ចារ្យ”[5132]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា ដីកាដំណោះស្រាយបានចោទប្រកាន់ថា “គោលបំណងនៃការផ្លាស់ទីប្រជាជនបានរួមបញ្ចូលការបំពេញលក្ខខណ្ឌនៃពលកម្មតាមសហករណ៍ និងការដ្ឋានធ្វើការ ការផ្គត់ផ្គង់ស្បៀងដល់ប្រជាជន ការការពារសន្តិសុខប្រជាជនពីការគំរាមកំហែង និងការដកហូតអ្នកទីក្រុង(ប្រជាជនថ្មី) និងអតីតអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ នូវឋានៈផ្នែកនយោបាយ និងសេដ្ឋកិច្ចតាមរយៈការប្រែក្លាយពួកគេឱ្យទៅជាកសិករ”[5133] និងបានចាត់ទុកដីកាដំណោះស្រាយនេះថា “ជាការសមស្របក្នុងការពិចារណាលើការផ្លាស់ទីប្រជាជន និងការបង្កើតសហករណ៍ និងការដ្ឋានធ្វើការជារួមដោយផ្អែកលើគោលបំណងមនោគមវិជ្ជា និងនយោបាយត្រួតគ្នាតែមួយ”[5134]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គោលនយោបាយនេះផ្សារភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងគោលបំណងរួម និងដូចបានអនុវត្តនៅសហករណ៍ត្រាំកក់ ការដ្ឋានត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មានការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែលទាំងអស់នេះបានឈានដល់កម្រិតលក្ខខណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5135]។

1831.ខៀវ សំផន បានជំទាស់ទៅនឹងសុពលភាពនៃការយល់ឃើញទាំងនេះ និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានអត្ថិភាពនៃគោលនយោបាយផ្លាស់ទីប្រជាជន និងបង្កើត

---

[5132] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៦-៣៨៧៨។

[5133] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៦។

[5134] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៦៧។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដោយសារការផ្លាស់ទីប្រជាជនត្រូវបានចោទប្រកាន់ពាក់ព័ន្ធតែទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម ការអនុវត្តន៍គោលនយោបាយនៃការផ្លាស់ទីប្រជាជនត្រូវបានពិភាក្សាត្រង់ចំណុចដែលពាក់ព័ន្ធទៅនឹងជនជាតិចាមតែប៉ុណ្ណោះ។

[5135] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៧៩-៣៨២៩។

និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋ[5136]។ ជាពិសេស គាត់បានជំទាស់ថា ដោយសារការផ្លាស់ទីប្រជាជន"ពុំត្រូវបានរួមបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទាំងមូល" ទើបអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តហួសពីវិសាលភាពនៃការជំនុំជម្រះក្នុងការយល់ឃើញនូវអត្ថិភាពនៃការប្រតិបត្តិការដែលកើតឡើងជារឿយៗ ក្នុងការផ្លាស់ទីប្រជាជនបន្ទាប់ពីការជម្លៀសចេញពីទីក្រុងភ្នំពេញដើម្បីបង្កើតផែនការ"'គ្រប់គ្រង' និង'កាន់កាប់ប្រជាជន'"[5137]។ គាត់បានអះអាងថា នេះ"បង្ហាញឱ្យឃើញអំពីការបកស្រាយបំភ្លៃដោយចេតនាលើគោលបំណងបង្កើតសហករណ៍ ដើម្បីសន្និដ្ឋានថា ជាបទល្មើស"[5138] និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងក៏មាន"កំហុសផងដែរនៅក្នុង [...] ការប្រើប្រាស់កិច្ចការស្រាវជ្រាវរបស់ Ben KIERNAN ដែលពុំមានតម្លៃជាភស្តុតាង"[5139] ព្រមទាំង"ការបង្កើតការយល់ឃើញអំពីសហករណ៍ជាច្រើនផ្សេងទៀតហួសពី[វិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង]"[5140]។

1832.ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវនៃការតម្រង់ទិសនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងសហករណ៍ ដោយពិនិត្យជ្រើសរើសតាម

---

[5136] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៨៩-១៥១០, ១៥១៨-១៥២២។

[5137] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៨៩។ ខៀវ សំផន បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូង "បានផ្អែកលើចម្លើយជាលាយលក្ខណ៍អក្សរដែលមានតម្លៃជាភស្តុតាងទាបដើម្បីបង្កើតការយល់ឃើញស្តីពី[ការផ្លាស់ទីប្រជាជន]"។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៥។ ដោយសារ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រសម្រាប់ការអះអាងរបស់គាត់ អង្គជំនុំជម្រះតុលាការកំពូលនឹងពុំចាំបាច់ពិភាក្សាបន្ថែមទៀតឡើយ។

[5138] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩១។ ខៀវ សំផន បានបន្ថែមថា វិធីសាស្ត្រនេះផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមជាពិសេសត្រូវបានដកចេញដើម្បីបំបែកសហគមន៍របស់ពួកគេ ដោយហេតុថា ពួកគេត្រូវបានរួមបញ្ចូលដោយមិនរើសមុខក្នុងការផ្លាស់ទីប្រជាជនក្នុងទ្រង់ទ្រាយធំដើម្បីបែងចែកទូទាំងប្រទេសតាមសហករណ៍ផ្សេងៗសម្រាប់ហេតុផលសេដ្ឋកិច្ច។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩២, ១៤៩៣។ សារណានេះត្រូវបដិសេធចោលដោយសារអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ខាងលើថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសន្និដ្ឋានថា ការផ្លាស់ទីដោយបង្ខំនូវប្រជាជនចាម គឺជាការរើសអើងឡើយ។ *សូមមើលខាងលើ* ផ្នែក VII.ច.២.ក។

[5139] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៨៥ ជើងទំព័រ ១២៩៩៥។

[5140] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៧។

ការចង់បានរបស់ខ្លួនលើឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ចេញពីជ្រុងមួយនៃ"ភាពអមិត្ត"ដែលដាក់បន្ទុក និងដោយពុំអើពើលើភស្តុតាងដោះបន្ទុកដែលបង្ហាញថា មានក្តីបារម្ភពិតប្រាកដចំពោះប្រជាជន[5141]។ គាត់បានជំទាស់ម្តងទៀតថា បទឧក្រិដ្ឋភាគច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាត្រូវបានប្រព្រឹត្តឡើងនៅតាមសហករណ៍នោះ គឺស្ថិតក្រៅវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួន ឬពុំត្រូវបានបង្ហាញ និងបានជំទាស់នូវអត្ថិភាពនៃបទឧក្រិដ្ឋមួយចំនួននៅតាមសហករណ៍ដែលពុំអាចស្មើនឹងអត្ថិភាពនៃគោលនយោបាយល្មើស[5142]។

1833.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការប្រើប្រាស់ភស្តុតាងក្រៅវិសាលភាពដើម្បីកំណត់ចរិតលក្ខណៈគោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការថាជាបទល្មើស[5143]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា តាមរយៈការវាយតម្លៃជារួមលើភស្តុតាង អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ឬអង្គហេតុក្នុងការយល់ឃើញថា គោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម[5144]។

1834.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងទាំងនេះពុំមានមូលដ្ឋានគាំទ្រទាំងស្រុង។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងថា "ដីកាបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង [០០២] ពុំបានរារាំងសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើព្រឹត្តិការណ៍មុន ឬក្រោយបទចោទដែលអាចជាប់ពាក់ព័ន្ធក្នុងការបង្ហាញអង្គហេតុដែលជាមូលដ្ឋាននៃបទចោទនោះឡើយ"[5145]។ បន្ថែម

---

5141 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៤-១៥០៦, ១៥១០, ១៥២១។ ខៀវ សំផន បានបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើដោយចេតនាលើភស្តុតាងដោះបន្ទុក ដូចជា របាយការណ៍មិនពិតអំពីទិន្នផលស្រូវលើសតម្រូវការ ដែលបង្ហាញថា ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ពុំអាចដឹងលក្ខខណ្ឌជាក់ស្តែងក្នុងសហករណ៍។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥០៧-១៥០៩។ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ខាងក្រោមថា បើទោះបីជាសារណារបស់គាត់ដែលថា អ្នកគ្រប់គ្រងខ្លះបានបិទបាំងការខ្វះស្បៀងអាហារ ត្រូវបានទទួលយកក៏ដោយក៏នេះពុំអាចច្រានចោលការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកលើភស្តុតាងទាំងមូលដែលថា គាត់បានដឹងអំពីលក្ខខណ្ឌឃោរឃៅនៅតាមសហករណ៍ដែរ។ *សូមមើលខាងក្រោម* កថាខណ្ឌ ១៨៩៩។

5142 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥១៨-១៥២២។

5143 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០២១-១០២៥។

5144 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០២៦-១០៣៩។

5145 សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២៣៦។

លើនេះ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់រួចហើយថា ភស្តុតាងក្រៅយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូងអាចត្រូវបានទទួលយក និងសំអាងទៅលើដើម្បីបំភ្លឺបរិបទ និងសន្និដ្ឋានធាតុផ្សំនៃបទឧក្រិដ្ឋ(ដូចជាអត្តនោម័តិ) ដែលបានកើតឡើងក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលា និង/ឬបង្ហាញនូវលំនាំនៃអំពើដែលបានគិតទុកជាមុន[5146]។

1835.ការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខអំពីការអនុវត្តន៍ហួសពីវិសាលភាពនៃការជំនុំជម្រះ ត្រូវតែបានពិនិត្យដោយផ្អែកលើភាពជាក់ស្តែងនៃវិសាលភាពនៃការជំនុំជម្រះបច្ចុប្បន្ន។ មានការបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការជំនុំជម្រះផ្នែកទីពីរនៃសំណុំរឿង ០០២ បានកម្រិតការប្រកាសរបស់ខ្លួនស្តីពីការផ្លាស់ទីប្រជាជនពាក់ព័ន្ធទៅនឹងសហករណ៍ និងការដ្ឋានធ្វើការ ត្រឹមការបំភ្លឺបរិបទ និងការវិភាគលើមធ្យោបាយដែលតាមរយៈនេះ គោលនយោបាយដើម្បីបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការត្រូវបានសម្រេច។ អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចដាក់ពិរុទ្ធភាពណាមួយ ឬដាក់ឱ្យទទួលខុសត្រូវលើអំពើល្មើស*សត្យានុម័ត*ពាក់ព័ន្ធទៅនឹងការអនុវត្តន៍នៃការផ្លាស់ទីប្រជាជនសម្រាប់គោលបំណងបង្កើត ឬប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការឡើយ[5147]។ នេះត្រូវបានបង្ហាញនៅក្នុងការវាយតម្លៃ និងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងអំពីការផ្លាស់ទីប្រជាជនសម្រាប់គោលបំណងនៃការកំណត់គោលដៅជនជាតិចាម ដែលជាបទចោទមួយត្រូវបានដកចេញជាក់លាក់ពីសំណុំរឿង ០០២/០១ និងបញ្ចូលទៅក្នុងសំណុំរឿង ០០២/០២[5148] កន្លែងដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងការផ្លាស់ទីដោយបង្ខំ បានកើតឡើង[5149]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទឡ្ហីករណ៍បន្តបន្ទាប់ជាច្រើននេះពុំមានមូលដ្ឋានគាំទ្រ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានកម្រិតការពិចារណារបស់ខ្លួននៃការផ្លាស់ទីប្រជាជន ត្រឹមគោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការ សម្រាប់គោលបំណងត្រឹមត្រូវ និងពាក់ព័ន្ធ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះត្រូវបដិសេធចោល។

---

[5146] *សូមមើលខាងលើ* កថាខណ្ឌ ៦៦៥-៦៦៦ យោងទៅលើសាលដីការឿងក្តី*Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ៣១៥។

[5147] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៩-៣៩២៨។

[5148] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧២៨, ៣៨៦៧, ៣៩៩០, ៣៩៩១។

[5149] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩៥-៣៩៩៧។

1836.អង្គជំនុំជម្រះតុលាការកំពូលបដិសេធការជំទាស់របស់ ខៀវ សំផន ទៅនឹងការប្រើប្រាស់របស់អង្គជំនុំជម្រះសាលាដំបូងនូវកិច្ចការស្រាវជ្រាវរបស់ Ben KIERNAN។ ផ្ទុយទៅនឹងសារណារបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងជាចម្បងបានសំអាងទៅលើសេចក្តីដកស្រង់មួយចំនួនចេញពីការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តនៅពេលនោះ និងសំអាងបន្ថែមទៅលើអ្វីដែល Ben KIERNAN បាននិពន្ធអំពីភាពកាន់តែខ្លាំងឡើងនៃការតាមរកខ្មាំងក្នុងសហករណ៍ក្នុងឆ្នាំ ១៩៧៦[5150]។ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងកិច្ចការស្រាវជ្រាវរបស់ Ben KIERNAN បានលើកបង្ហាញពុំត្រឹមត្រូវ និងដូច្នេះ ត្រូវបដិសេធចោល។ ការលើកឡើងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញនូវអត្ថិភាពនៃសហករណ៍ និងការដ្ឋានធ្វើការបន្ថែមទៀតពាសពេញប្រទេសត្រូវបដិសេធចោលផងដែរ។ បើទោះបីជាមានភស្តុតាងផ្ទុយដែលទំនងជាពុំអាចកើតមានក៏ដោយ ក៏ការយល់ឃើញនោះពុំអាចប៉ះពាល់ ឬធ្វើឱ្យសាលក្រមមោឃៈបានឡើយ[5151]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានកម្រិតការយល់ឃើញរបស់ខ្លួនស្តីពីការប្រព្រឹត្តបទឧក្រិដ្ឋ ត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ដូចបានចោទក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ[5152]។

1837.ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការកំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះសាលាដំបូងនូវគោលនយោបាយស្តីពីសហករណ៍ និងការដ្ឋានធ្វើការថា ជាបទល្មើស ត្រូវបដិសេធចោលផងដែរដោយផ្អែកលើភស្តុតាងច្រើនសន្ធឹកសន្ធាប់គាំទ្រការយល់ឃើញនេះ។ ខៀវ សំផន បានទទួលស្គាល់ថា ការបង្កើត និងការប្រតិបត្តិការសហករណ៍ ត្រូវបានរួមបញ្ចូលក្នុងគោលបំណងរួមប្រើប្រាស់ជាមធ្យោបាយគ្រប់គ្រងសេដ្ឋកិច្ចជនបទក្នុងកម្ពុជានៅពេលនៃព្រឹត្តិការណ៍នោះ[5153]។ ទោះជាយ៉ាងណាក្តី គាត់បានអះអាងថា គោលនយោបាយសង្គមនិយម និងកម្មសិទ្ធិរួមក្នុងគោលបំណងសម្រេចការផ្គត់ផ្គង់ស្បៀងដោយខ្លួនឯង ពុំមែនជាបទល្មើសដោយខ្លួនឯងនោះទេ និងថា ការដែលថាគោលនយោបាយនេះបានបរាជ័យដោយសារខ្វះមធ្យោបាយ អសមត្ថភាព ឬការគ្រប់គ្រងមិនបានល្អ ពុំបានធ្វើឱ្យគោលបំណងរួមនេះជាបទល្មើសដែរ[5154]។

---

5150 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៩៨ ជើងទំព័រ ១២៩៩៥។

5151 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៩៨។

5152 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៩-៣៩២៧។

5153 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩០។

5154 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥២០-១៥២២។

1838.គោលបំណងរួមក្នុងការអនុវត្តន៍បដិវត្តន៍សង្គមនិយមឆាប់រហ័ស ពុំអាចត្រូវបានផ្ដាច់ចេញពីមធ្យោបាយ ដែលគោលបំណងត្រូវបានអនុវត្តតាមរយៈនោះ។ ដូច្នេះ គោលបំណង ឬគោលដៅនៃការបង្កើតសហករណ៍ ដើម្បីសម្រេចបានសង្គមនិយម កម្មសិទ្ធិរួម និងខ្លួនទីពឹងខ្លួន ពុំអាចត្រូវបានយល់ថាឯករាជ្យពីមធ្យោបាយ ដែលគោលបំណងរួមចុងក្រោយត្រូវបានអនុវត្តតាមរយៈនោះឡើយ រួមទាំង ការដកសិទ្ធិបញ្ចេញមតិ ឬ ជម្រើសនៅគ្រប់ទិដ្ឋភាពនៃជីវិតប្រចាំថ្ងៃ ជំនួសមកវិញនូវការគ្មានជម្រើសម្រាប់ទីជម្រក អាហារ និងពលកម្ម ឬអ្នកដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយ និងតាមរយៈលក្ខខណ្ឌលំបាកតោកយ៉ាកដូចទាសករ និង ការគំរាមកំហែងថានឹងយកទៅ"កសាង" និងការដែលពុំដែលឃើញត្រឡប់មកវិញ។ បើទោះបីជាគោល បំណងនោះគឺដើម្បីបង្កើតសង្គមសុភមង្គលនៃកសិករក៏ដោយ ក៏គ្មានភស្តុតាងណាមួយគាំទ្រសោះឡើយ ហើយភស្តុតាងទាំងមូលពីការដ្ឋានធ្វើការនីមួយៗដែលត្រូវបានជ្រើសរើសជាតំណាងនោះបានបង្ហាញថា គោលបំណងនោះត្រូវបានអនុវត្តតាមរយៈមធ្យោបាយល្មើស រួមទាំងការធ្វើឱ្យភ័យកត់ស្លុត និងការដកនូវ សិទ្ធិ ដែលនាំឱ្យគោលបំណងនេះមានលក្ខណៈជាបទល្មើស។ ការពន្យល់របស់ ខៀវ សំផន នូវមូលហេតុ ដែលនាំឱ្យគោលនយោបាយនោះបរាជ័យ ពុំអាចមោឃៈការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែល ថា គោលបំណងនៃបដិវត្តន៍មានលក្ខណៈជាបទល្មើស។ ការជំទាស់ពាក់ព័ន្ធចំណុចនេះពុំមានប្រសិទ្ធភាព។

1839.ក្នុងការគាំទ្រការជំទាស់របស់ខ្លួនដែលថា អង្គជំនុំជម្រះសាលាដំបូងមានចេតនាពុំអើពើ បានលាក់បាំង ឬ បានបំភ្លៃភស្តុតាងដោះបន្ទុក ខៀវ សំផន បានចង្អុលបង្ហាញទៅលើឯកសារមួយចំនួនរបស់បក្សកុម្មុយនីស្ត កម្ពុជា[5155] និក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់[5156] និងទស្សនាវដ្ដី *ទង់បដិវត្ត* និង *យុវជនបដិវត្ត*[5157]ដែលបង្ហាញ នូវការបារម្ភអំពីសុខទុក្ខរបស់ប្រជាជន។ បើទោះបីជាពុំមានភាពចាំបាច់ ឬយោងទៅលើភស្តុតាងនីមួយៗ

---

[5155] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៧, ១៥០០, ១៥០៤ យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៧៧, ៣៨៧៨, ៣៨៩៤។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥០៣ (ជើងទំព័រ ២៨៣៥), ១៥០៦ (ជើងទំព័រ ២៨៤៥)។

[5156] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៩ យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៨៤។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥០៣ (ជើងទំព័រ ២៨៣៤)។

[5157] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៩៦, ១៤៩៧, ១៥០១, ១៥០២ យោងទៅលើ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៨៥, ៣៨៨៩-៣៨៩១, ៣៨៩៣, ៣៨៩៨ (ជើងទំព័រ ១២៩៩៥), ៣៩០០, ៣៩១០, ៣៩១១។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥០៣ (ជើងទំព័រ ២៨៣៥-២៨៣៨), ១៥០៥ (ជើងទំព័រ ២៨៤១-២៨៤៣), ១៥០៦ (ជើងទំព័រ ២៨៤៦), ១៥០៧ (ជើងទំព័រ ២៨៤៧)។

ក្នុងកំណត់ត្រាសវនាការក៏ដោយ[5158] ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានយោងទៅលើឯកសារភាគច្រើនដែល ខៀវ សំផន បានចង្អុលបង្ហាញនោះ។ ការដែលថាអង្គជំនុំជម្រះសាលាដំបូងពុំបានពិភាក្សាជាក់លាក់លើផ្នែកខ្លះនៃឯកសារដែល ខៀវ សំផន បានបង្ហាញនោះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើ ឬលាក់បាំងនោះទេ ហើយត្រឹមតែការបកស្រាយមួយបែបផ្សេងទៀតរបស់គាត់អំពីខ្លឹមសារនៃឯកសារទាំងនោះ ពុំគ្រប់គ្រាន់ក្នុងការបដិសេធការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ។

1840.ការផ្តាច់ចេញពីគ្នានៃការយល់ឃើញ និងវិធីសាស្ត្រលើកបង្ហាញជាផ្នែកៗនៃកំហុសតូចតាចដែលអាចកើតមាន ឬភាពពុំស៊ីសង្វាក់គ្នានៅក្នុងការបកស្រាយលើសេចក្តីដកស្រង់ជ្រើសរើសចេញពីឯកសារ ពុំបានកែប្រែទិសដៅ និងទម្រង់នៃភស្តុតាងដទៃទៀតដែល អង្គជំនុំជម្រះសាលាដំបូងបានវិភាគ និងបានសំអាងទៅលើនៅមុនពេលកំណត់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅសហករណ៍ត្រាំកក់[5159] ការដ្ឋានទំនប់ត្រពាំងថ្ម[5160] ការដ្ឋានទំនប់១មករា[5161] និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[5162] ហើយនេះពុំបានធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញលម្អិតរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានគាំទ្រដោយភស្តុតាងដែលគួរឱ្យជឿជាក់ និងទុកចិត្តបានដែលថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ដើម្បីសម្រេចផែនការសេដ្ឋកិច្ច និងគោលដៅបង្កបង្កើនផល កសាងប្រទេស ការពារប្រទេសពីសត្រូវ និងប្រែក្លាយប្រជាជនទាំងស្រុងទៅជាសង្គមវណ្ណៈកម្មករកសិករតែមួយស្មើៗគ្នា[5163]។ ការលើកឡើងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអាចយល់ឃើញថា ឧក្រិដ្ឋកម្មភាគច្រើនដែលត្រូវបានបង្ហាញនៅសហករណ៍ និងការដ្ឋាធ្វើការ ពុំអាចជឿជាក់បានដូចគ្នា លើកលែងតែការយល់ឃើញស្តីពីការធ្វើទុក្ខបុកម្នេញដោយសារ

---

[5158] *សូមមើល ឧ.* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និង Kubura* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-47-A សាលដីកា ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ ("សាលដីការឿងក្តី *Hadžihasanović និង Kubura* (ICTY)") កថាខណ្ឌ ១៣ និងការយោងត្រូវបានដកស្រង់ក្នុងជើងទំព័រ ៣៨។

[5159] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៨១៧-១២០៤។

[5160] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២០៨-១៤២៩។

[5161] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៣៨-១៧១២។

[5162] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧១៧-១៨៤៦។

[5163] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៧២-៣៩២៩។

មូលហេតុនយោបាយដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រជាជនថ្មីនៅទំនប់១មករា ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសម្រាប់ហេតុផលដូចបានពន្យល់ខាងលើ[5164]។

1841.អាស្រ័យហេតុនេះ ការចោទប្រកាន់អំពីកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបដិសេធចោល។

## ៥. គោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់

1842.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់ដើម្បីសម្រេចគោលបំណងបង្កើតសង្គមតែមួយស្មើគ្នា គ្មានការបែងចែកវណ្ណៈ និងគ្មានការប្រតិបត្តិសាសនា។ នេះត្រូវសម្រេចបានតាមរយៈការលុបបំបាត់ភាពផ្សេងគ្នានៃជាតិពន្ធុ សញ្ជាតិ សាសនា វណ្ណៈ និងវប្បធម៌៖ ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងយោធា) និងក្រុមគ្រួសាររបស់ពួកគេដែលមានក្នុងក្រុមទាំងនេះ[5165]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គោលនយោបាយនេះផ្សាភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងគោលបំណងរួម និងមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋដូចតទៅ៖ (១) ទាក់ទងទៅនឹងជនជាតិចាម មានបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់មនុស្ស និងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការផ្លាស់ទីដោយបង្ខំ[5166] (២) ទាក់ទងទៅនឹងជនជាតិវៀតណាម មានបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់មនុស្ស និងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ ព្រមទាំងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវតាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កដោយចេតនានូវការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំង

---

[5164] *សូមមើលខាងលើ* ផ្នែក VII.២.ខ.iv កថាខណ្ឌ ៩៦១-៩៦៦។

[5165] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨៨-៣៩៩០ (ជនជាតិចាម), ៣៩៩៩-៤០០០ (ជនជាតិវៀតណាម), ៤០១៣-៤០១៧ (ពុទ្ធសាសនិក), ៤០២៣-៤០៤៩ (អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

[5166] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩១-៣៩៩៨។

ដោយខុសច្បាប់លើជនស៊ីវិល[5167] (៣) ទាក់ទងទៅនឹងពុទ្ធសាសនិក មានបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា[5168] និង (៤) ទាក់ទងទៅនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត (ចាប់តាំងពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ចុងខែ ឧសភា ឆ្នាំ ១៩៧៥ និងចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩) និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ (ពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ)[5169]។

1843.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា មានគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម[5170] ជនជាតិចាម[5171] អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[5172] និងពុទ្ធសាសនិក[5173]។

1844.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងរបស់ ខៀវ សំផន និងសារណាតបរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងក្រុមទាំងបួននេះតាមលំដាប់លំដោយដូចខាងក្រោម។

## ក. ជនជាតិវៀតណាម

1845.អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា មាន“គោលនយោបាយដែលបានបង្កើតឡើងដោយមជ្ឈិមកំណត់គោលដៅចាត់ទុកជនជាតិវៀតណាមជាសត្រូវ [...] ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលយុត្តាធិការនៃដីកាបញ្ជូនទៅជំនុំជម្រះ”[5174]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញនេះលើប្រភពជាច្រើន រួមទាំងភស្តុតាងជាឯកសារដែលមាននៅពេលនោះ សក្ខីកម្មផ្ទាល់មាត់ អត្ថបទនិពន្ធសម្រាប់សិក្សា និងសក្ខីកម្មក្នុងតុលាការរបស់អ្នកជំនាញ[5175]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង

---

[5167] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០០១-៤០១២។

[5168] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៨-៤០២២។

[5169] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៥០-៤០៦១។

[5170] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥១-១៥៦០។

[5171] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៦១-១៥៧៧។

[5172] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៧៨-១៥៨៥។

[5173] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨៦-១៥៩១។

[5174] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៧។

[5175] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨២-៣៤១៥។

បានបំភ្លៃភស្តុតាងនេះ ជាពិសេស ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនឹងវៀតណាម[5176]។ គាត់បានជំទាស់ជាក់លាក់ទៅលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងនៃពាក្យ "*យួន*" និងបានចោទប្រកាន់អំពីការពុំបែងចែកដាក់ពីគ្នារវាងពាក្យ "ភ្នាក់ងារវៀតណាម" និង "ជនជាតិវៀតណាម"[5177]។ គាត់បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវិភាគទៅលើទំនាក់ទំនងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលប្រទូសរ៉ាយគ្នាជាមួយប្រទេសវៀតណាម ធ្វើជាមូលដ្ឋានសម្រាប់ការបង្ហាញនូវគោលនយោបាយកំណត់គោលជនជាតិវៀតណាមជាទូទៅ[5178]។

1846.សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំអើពើទៅនឹងភាពជារួមនៃភស្តុតាងដែលបង្ហាញថា មានគោលនយោបាយចាត់ទុកជនជាតិវៀតណាមជាសត្រូវនៅពេលពាក់ព័ន្ធនោះ និងបានអះអាងថា គាត់បានត្រឹមតែផ្តល់ការបកស្រាយមួយបែបផ្សេងប៉ុណ្ណោះ[5179]។

1847.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការលើកឡើងរបស់ ខៀវ សំផន។ ភស្តុតាងដែលផ្តល់ដោយកម្មាភិបាលជាន់ខ្ពស់ ទូរលេខ ទស្សនាវដ្តីទង់បដិវត្តន៍ ក្នុងចំណោមសំអាងផ្លូវច្បាប់ដទៃទៀត បង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិវៀតណាមទាំងអស់ដោយពុំរើសមុខថា ជាកងទ័ព ឬជនស៊ីវិលតាមរយៈវោហាសាស្ត្ររបស់ខ្លួនដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។ មុនពេលពិចារណាលើភស្តុតាងនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកបង្ហាញដោយប្រុងប្រយ័ត្ននូវហេតុផលដែលជាមូលដ្ឋាននៃការបកស្រាយរបស់ខ្លួនអំពីពាក្យ "*យួន*" និងបានយល់ឃើញថា ពាក្យនេះត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងឯកសារសម័យកាលនោះ និងដោយសាក្សីក្នុងអំឡុងពេលសក្ខីកម្មក្នុងតុលាការ "សម្រាប់សំដៅទៅលើវៀតណាម ឬជនជាតិវៀតណាមក្នុងន័យទូទៅ" និងពុំមែនសំដៅជាពិសេសតែលើកងទ័ពនោះទេ[5180]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃយ៉ាងលម្អិតប្រហាក់ប្រហែល

---

[5176] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៥១-១៥៦០។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៦៨-១០៩៧។

[5177] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤៨០-១៤៨៧។

[5178] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៤០៩-១៤១៥, ១៥៥៤-១៥៥៨។

[5179] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៥៤៩-៥៥៩។

[5180] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៧៩ យោងទៅលើប្រតិចារឹកថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ (ជឿង យ៉ាំងចែត) ឯកសារលេខ E1/363.1 ទំព័រ ១០, ១១, ៦៤-៦៥។ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ (ខួង មួយ) ឯកសារលេខ E1/394.1 ទំព័រ ៣៥។ ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ (អ៊ុង សំអ៊ាន) ឯកសារលេខ E1/366.1 ទំព័រ ៣៣។ ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ (សៅ សាក់) ឯកសារលេខ E1/362.1 ទំព័រ ៧៤-៧៥។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី

គ្នាលើអត្ថន័យនៃការសំដៅទៅលើ“*យួន*” និងវៀតណាមថាជា“‘សត្រូវតពូជ’របស់ប្រជាជនកម្ពុជា និងរបស់បក្ស”[5181] យោងទៅលើឧទាហរណ៍មួយចំនួនរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដែលប្រើប្រាស់ពាក្យនេះក្នុងលក្ខណៈមិនរើសមុខ[5182]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃពាក្យពីរនេះ។ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសនៅក្នុងសំអាងហេតុដែលបានផ្ដល់ក្នុងការគាំទ្រផងដែរ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់យ៉ាងច្បាស់លាស់ថា អង្គជំនុំជម្រះនឹងពិចារណាពាក្យពេចន៍នីមួយៗ និងចេតនាប្រមាថដែលមានក្នុងនោះ“ផ្អែកតាមករណីនីមួយៗជាក់ស្ដែង និងតាមរយៈការពិចារណាលើភាពជារួមនៃភស្តុតាង និងកាលៈទេសៈ”ដែលពាក្យនេះត្រូវបានប្រើ[5183]។ ការចោទប្រកាន់កំហុសដទៃទៀតពាក់ព័ន្ធទៅនឹងគោលនយោបាយនេះនឹងត្រូវបានពិចារណាដោយផ្អែកលើការយល់ឃើញដែលបានបង្ហាញយ៉ាងត្រឹមត្រូវនេះ។

1848.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងទាំងមូលដោយប្រុងប្រយ័ត្ន ប៉ុន្តែពុំបានពិចារណាលើសក្ខីកម្មរបស់ សៅ សារុន ដោយបានយល់ឃើញថា សុន្ទរកថាដែលបានបង្ហាញក្នុងបទវិចារណកថាទង់បដិវត្តន៍ខែ មេសា ឆ្នាំ ១៩៧៦ បានបង្ហាញភាពជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះ“ជនជាតិវៀតណាមដែលជាជនជាតិភាគតិចកំពុងរស់នៅក្នុងកម្ពុជា”[5184]។ តាមការពិនិត្យដោយប្រុងប្រយ័ត្ននូវអត្ថបទដោយពិចារណាក្នុងបរិបទនៃកថាខណ្ឌខាងមុខ និងខាងក្រោយនៃសេចក្ដីដកស្រង់ និងសក្ខីកម្មរបស់អ្នកជំនាញ Alexander HINTON[5185] ពុំបង្ហាញកន្លែងណាឱ្យសង្ស័យទាក់ទងទៅនឹងអត្តសញ្ញាណនៃ“ជន

---

០៤ ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/1094 ទំព័រ ៨។ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ (ប៉ាក សុខ) ឯកសារលេខ E1/369.1 ទំព័រ ៣៩-៤០។ បញ្ជីឈ្មោះអ្នកជាប់ឃុំមន្ទីរស-២១ គ្មានការចុះបរិច្ឆេទ ឯកសារលេខ E3/8463 ទំព័រ ៤៣, ៥២, ៥៥, ៥៨, ៥៩, ៦១, ៦២, ៦៣, ៧០, ៧២-៧៤, ៩៤, ៣១៥។

[5181] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨១។

[5182] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨១ យោងទៅលើសេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៩ ឯកសារលេខ E3/8404 ទំព័រ ៥។ ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ (ប្រាក់ ខន) ឯកសារលេខ E1/424.1 ទំព័រ ៦។ ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ (មាស វឿន) ឯកសារលេខ E1/387.1 ទំព័រ ១៧។ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ (ប៉ាក សុខ) ឯកសារលេខ E1/369.1 ទំព័រ ២៧។ កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ប៉ាក សុក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣ ឯកសារលេខ E3/9674 ទំព័រ ១១។ ទស្សនាវដ្ដីទង់បដិវត្ត ចុះខែ កក្កដា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/746 ទំព័រ ១-២ ERN 00064486-00064487។

[5183] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៧៩, ៣៣៨១។

[5184] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨៨។

[5185] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨៨ យោងទៅលើប្រតិចារឹកថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ (Alexander HINTON) E1/402.1 ទំព័រ ១០។

បរទេសប្រភេទម្យ៉ាង[ដែលត្រូវបានចោទប្រកាន់ថា]មានសភាពពិសពុល គ្រោះថ្នាក់”ដល់ប្រជាជនកម្ពុជាឡើយ[5186]។ ជនបរទេសដទៃទៀត ដូចជា ជនជាតិអាមេរិក បារាំង និងអង់គ្លេសដែលត្រូវបានហៅថា“ពួកចក្រពត្តិ” ត្រូវបានកំណត់គោលដៅក្នុងកថាខណ្ឌខាងដើម ដែលមានការផ្តោតនៃសុន្ទរកថាទៅលើ“លទ្ធផលផ្សេងនៃបដិវត្តន៍ប្រជាជាតិ”[5187]។ ក្រុមទីពីរដែលត្រូវបានកំណត់គោលដៅក្នុងសុន្ទរកថា “ជនបរទេស”បង្កការបាត់បង់“ទឹកដីជាច្រើន” និង“លក់ដីឱ្យជនបរទេស”[5188]។ តាមការពិនិត្យដោយសមហេតុផលនៃការដកស្រង់នូវសុន្ទរកថាគម្រប់ខួបលើកទីមួយដែលបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូង បង្ហាញថា កម្មវត្ថុនៃការព្យាបាទអាក្រក់នោះ គឺជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងកម្ពុជា។

1849.អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ផងដែរនូវផលប៉ះពាល់នៃភាពជាសត្រូវរវាងកម្ពុជា និងវៀតណាម និងបានវែកញែករវាងការសំដៅទៅលើជនស៊ីវិល និងកងទ័ពជនជាតិវៀតណាម[5189]។ ការលើកឡើង

---

[5186] ទស្សនាវដ្តីទង់បដិវត្ត ឯកសារលេខ E3/759 ខែ មេសា ឆ្នាំ ១៩៧៦, ទំព័រ ៨។

[5187] ទស្សនាវដ្តីទង់បដិវត្ត ឯកសារលេខ E3/759 ខែ មេសា ឆ្នាំ ១៩៧៦, ទំព័រ ៦-៧។ ប្រៀបធៀបសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១០៧០-១០៧២។

[5188] ទស្សនាវដ្តីទង់បដិវត្ត ឯកសារលេខ E3/759 ខែ មេសា ឆ្នាំ ១៩៧៦ ទំព័រ ៨។ *សូមមើលខាងលើ* កថាខណ្ឌ ៨៤២-៨៤៦។

[5189] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨៩ (រំឭកថា “ភាពជាសត្រូវជាមួយវៀតណាមបានចាប់ផ្តើម និងបន្តក្រោយឆ្នាំ ១៩៧៥”), ៣៣៩៤ (ពិចារណាលើការសំដៅទៅលើ“សត្រូវគ្រប់ប្រភេទ”ក្នុងសុន្ទរកថា “ដោយសារជម្លោះយោធាជាមួយវៀតណាមកាន់តែធ្ងន់ធ្ងរឡើង បក្សបានបង្កើនការប្តេជ្ញាចិត្តក្នុងការការពារបដិវត្តន៍និងប្រទេសជាតិ ប្រឆាំងនឹងអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំងសេរីនិយម ដែលរាប់បញ្ចូលទាំងវៀតណាមនិងការបង្កើនគោលជំហររបស់ ប.ក.ក. លើវៀតណាមថាជា “ពួកឈ្លានពាន” “ពួកពង្រីកទឹកដី” និង“ពួករាតទីនិយម” (ដែលបានបន្តពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ), ៣៣៩៦ (កត់សម្គាល់ថា “ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់មួយបានកើតឡើងនៅក្នុងពាក្យពេចន៍របស់ ប.ក.ក. ប្រឆាំងនឹងវៀតណាម។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានធ្វើការវាយលុកដ៏ខ្លាំងក្លាមួយចូលក្នុងទឹកដីនៃប្រទេសកម្ពុជា” និងយល់ឃើញថា “ចាប់តាំងពីពេលនោះមក ការនិយាយសំដៅលើ“យួន” ថាជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើងជាចំហ ជាពិសេស នៅក្នុងសេចក្តីថ្លែងការណ៍ដែលមានគោលបំណងផ្សាយឱ្យកាន់តែទូលំទូលាយ”), ៣៣៩៧ (បានចេញសេចក្តីណែនាំដែលតម្រូវឱ្យប្រើយុទ្ធសាស្ត្រសង្គ្រាមសាមញ្ញនិងទ័ពព្រៃ“ក្នុងបរិបទនៃជម្លោះប្រដាប់អាវុធនៅបន្ត” និងការយល់ឃើញថា ពួកគេ“សំដៅជាចម្បងលើកងទ័ពវៀតណាម”), ៣៣៩៨ (ការផ្សព្វផ្សាយតាមវិទ្យុ“ក្នុងបរិបទ និងពិចារណាការដកថយកងទ័ពវៀតណាមនៅពេលនោះ” និងការយល់ឃើញថា ភស្តុតាង“កំណត់គោលដៅលើទាហានវៀតណាម និងជនស៊ីវិលវៀតណាម”), ៣៤១១ (កត់សម្គាល់សេចក្តីថ្លែងការណ៍“ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃការវាយលុកផ្នែកយោធាសំខាន់លើកងទ័ពវៀតណាម [...] [និង] អាស្រ័យហេតុនេះយល់ឃើញថា សេចក្តីណែនាំនេះសំដៅជាចម្បងលើកងទ័ពវៀតណាម”) ៣៤១២ (កត់សម្គាល់លើទំនាក់ទំនងទៅនឹងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ “បើទោះបីជាការវាយលុកយោធាក្នុងពេលនោះ [...] ការសំដៅជាក់លាក់ទៅលើ‘ប្រជាជនកម្ពុជាទាំងមូល’ និង‘សត្រូវតពូជ’ និងដូច្នេះ ការយល់ឃើញថា សេចក្តីថ្លែងការណ៍នេះ បានកំណត់គោលដៅលើប្រជាជនវៀតណាមទាំងអស់ដោយឥតរើសមុខ”), ៣៤១៣ (យល់ឃើញថា

របស់ ខៀវ សំផន ដែលថា ជនស៊ីវិលជនជាតិវៀតណាម ពុំស្ថិតក្នុងចំណោមកម្មវត្ថុនៃការព្យាបាទរបស់បក្សកុម្មុយនីស្តកម្ពុជានោះ ពុំមានមូលដ្ឋានត្រឹមត្រូវគាំទ្រឡើយ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាលើការវាយតម្លៃយ៉ាងជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូងលើការដែលបក្សកុម្មុយនីស្តកម្ពុជានៅសម័យនោះបានប្រើប្រាស់ពាក្យ“*យួន*”នេះយ៉ាងដូចម្តេច ក្នុងការពិពណ៌នាអំពីហេតុការណ៍ដែលកុមារជនជាតិភាគតិចវៀតណាមដែលពុំអាចត្រូវបានចាត់ទុកថា ជាកងទ័ពនោះ ត្រូវបាន“កម្ទេច”[5190]។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើការដែល ពាក្យ និងឃ្លាដទៃទៀតត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចនៅពេលនិយាយសំដៅទៅលើជនជាតិវៀតណាមក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាសុន្ទរកថា និងវគ្គបណ្តុះបណ្តាលដែលបានផ្សព្វផ្សាយដោយមេដឹកនាំជាន់ខ្ពស់ រួមទាំង ខៀវ សំផន និងឯកសារដទៃទៀតនៅសម័យនោះ ពុំអាចត្រូវបានចាត់ទុកជាអ្វីផ្សេងក្រៅតែពីការផ្តល់សំអាងហេតុដោយប្រុងប្រយ័ត្ន ជាពិសេសនៅពេលពិចារណាថា អង្គជំនុំជម្រះបានរកឃើញការបញ្ជាក់អះអាងបន្ថែមដែលមានប្រភពនៅក្នុងសក្ខីកម្មក្នុងតុលាការ ដែលភាពគួរជឿទុកចិត្តបានរបស់ពួកគាត់ត្រូវតែវាយតម្លៃជាបឋម។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណនៃការនិយាយសំដៅនោះនៅក្នុងវគ្គបណ្តុះបណ្តាលនយោបាយ និងការថ្លែងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា មានតែខ្មែរ“អត់មានយួន ឬជនជាតិ

---

“ដោយសារកងទ័ពវៀតណាមវាយចូលកម្ពុជានៅថ្ងៃចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងដើមខែ មករា ឆ្នាំ ១៩៧៩ [...] សេចក្តីណែនាំបង្គាប់កម្មាភិបាល‘បំផ្លាញ’ ‘ខ្មាំងយួន’ ជាយោធា នយោបាយ ចិត្តសាស្ត្រ និងសេដ្ឋកិច្ច [...] [យោងទៅលើ] ជាចម្បងកងទ័ពវៀតណាម”)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៦ (“អង្គជំនុំជម្រះបានពិចារណាលើស្ថានភាពនៃជម្លោះប្រដាប់អាវុធនិងការវាយលុកខាងយោធានាសម័យនោះ ព្រមជាមួយនឹងវោហាសាស្ត្ររបស់ ប.ក.ក. ដែលបានផ្តោតជាចម្បងប្រឆាំងនឹងពួកទាហានវៀតណាមដូចបានបញ្ជាក់ខាងលើ។ អង្គជំនុំជម្រះពិនិត្យឃើញអំពីនិរន្តរភាពដ៏គួរឱ្យកត់សម្គាល់នៅក្នុងចំណុចសំខាន់ៗនៃសេចក្តីថ្លែងការណ៍ ឬសុន្ទរកថាទាំងឡាយដែលចេញមកពីកម្មាភិបាលដូចបានវិភាគខាងលើ ហើយជាពិសេស កត់សម្គាល់អំពីភាពខុសគ្នានៅក្នុងទម្ងន់ពាក្យសម្តី ដោយសារតែវាមានភាពហិង្សាកាន់តែខ្លាំងឡើងៗ នៅពេលមានជម្លោះកាន់តែធំឡើងៗ។ ចំណុចចុងក្រោយ ទោះបីជាសេចក្តីថ្លែងការណ៍មួយចំនួនអាចសំដៅជាចម្បងលើកងកម្លាំងប្រដាប់អាវុធវៀតណាមក៏ដោយ ក៏ការសំដៅទៅលើ “យួន” ឬខ្មាំងយួន តែងតែធ្វើឡើងដោយមិនរើសមុខ ហើយសំដៅលើជាតិពន្ធុវៀតណាមទាំងអស់ មានទាំងយោធានិងជនស៊ីវិលផងដែរ”)។

[5190] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៧៩ យោងទៅលើទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/1094 ទំព័រ ៧-៨ (“កម្ទេចយួន ១០០ នាក់ រួមទាំង តូច ធំ និងក្មេង”)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១០, ៣៤៧០ (ផ្ទុយគ្នាត្រង់ថា ជនរងគ្រោះទាំងនេះ ត្រូវកំណត់ថា“កងទ័ពវៀតណាមបីនាក់”ដែលត្រូវបានពិភាក្សាក្នុងឯកសារតែមួយដូចគ្នា បានធ្វើអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានសមហេតុផលថា “វៀតណាម ១០០ នាក់ដែលត្រូវបាន‘កម្ទេចនោះ’ជាជនស៊ីវិល”)។

វៀតណាមទេ”[5191] “ការថែរក្សា‘ពូជសាសន៍កម្ពុជា’”[5192] “កំហឹងស្នេហាជាតិ”[5193] និងការ“កម្ទេចយួន ៥០.០០០.០០០”[5194] ដែលជាឧទាហរណ៍នៃភាសាប្រើប្រាស់ដោយមិនរើសមុខទាក់ទងទៅនឹងកងទ័ព និងជនស៊ីវិលជនជាតិវៀតណាម។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ការយោងទាញចេញពីប្រភពជាច្រើន និងមានការបញ្ជាក់អះអាងបន្ថែមដូចជា៖ សក្ខីកម្មផ្ទាល់មាត់របស់ ឯក ហេន ត្រូវបានពិចារណាក្នុងបរិបទនៃភស្តុតាងរបស់សាក្សីដទៃទៀត[5195]។ សុន្ទរកថារបស់ ខៀវ សំផន ត្រូវបានវាយតម្លៃផ្អែកលើបរិបទ និងត្រូវបានបញ្ជាក់បន្ថែមដោយសៀវភៅពីរក្បាល[5196]ហើយសុន្ទកថារបស់ប៉ុល ពត ក្នុងខែ

---

[5191] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ យោងទៅលើប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៣៤, ៣៦, ៤០។ ប្រតិចារឹកថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៤០, ៤២, ៤៧។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សេចក្តីដកស្រង់ផ្តល់ក្នុងផ្នែកពាក់ព័ន្ធ ដូចតទៅ៖ “ខ្មែរត្រូវតែសាមគ្គីគ្នា និងត្រូវអត់មានវៀតណាម ឬ ‘យួន’”។ ប្រតិចារឹកថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ (ឯក ហេន) ឯកសារលេខ E1/217.1 ទំព័រ ៤០។

[5192] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩៩ ដកស្រង់ការប្រារព្ធខួបលើកទី ១៧ ខែ មេសា ប្រមូលផ្តុំនៅទីក្រុងភ្នំពេញ (ក្នុងកម្រងសារព័ត៌មាន SWB/FE/5791/B) ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/562។

[5193] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០០ ដកស្រង់សុន្ទរកថារបស់ ខៀវ សំផន ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/169 ទំព័រ ១២ ERN S00704526។

[5194] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០២ ដកស្រង់ទស្សនាវដ្តីទង់បដិវត្ត ខែមេសា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/4604 ទំព័រ ១២ ERN 00064713។

[5195] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៩០ យោងទៅលើប្រតិចារឹកថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ឯកសារលេខ E1/72.1 ទំព័រ ២១។ ប្រតិចារឹកថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ (ពាន ឃាន) ឯកសារលេខ E1/73.1 ទំព័រ ១៧-១៨, ២០។ ប្រតិចារឹកថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (យុន គីម) ឯកសារលេខ E1/89.1 ទំព័រ ៦២។ ប្រតិចារឹកថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ (ឯម អឿន) ឯកសារលេខ E1/115.1 ទំព័រ ២៤-២៦, ៤០-៤១។ ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ (ម៉ុំ វុន) ឯកសារលេខ E1/475.1 ទំព័រ ៥០, ៥៦-៥៧។ ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (អ៊ូ ដាវ) ឯកសារលេខ E1/498.1 ទំព័រ ៧៤-៧៥។ ប្រតិចារឹកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ (ប៊ិត ហឿន *ហៅ* ប៊ិត ណា) ឯកសារលេខ E1/502.1 ទំព័រ ១៧-១៨, ២០, ២២-២៣។

[5196] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០១ យោងទៅលើសៀវភៅនិពន្ធដោយសម្តេចនរោត្តមសីហនុ៖ *សង្គ្រាម និងក្តីសង្ឃឹម* ឯកសារលេខ E3/1819។ សៀវភៅនិពន្ធដោយ N. ចាន់ដា *សត្រូវបងប្អូនប្រុស* ឯកសារលេខ E3/2376 ទំព័រ ៣៤៩។

មេសា ឆ្នាំ ១៩៧៨ ដែលថា "មួយត្រូវវាយយួនឱ្យបាន ៣០" ត្រូវបានពិនិត្យផ្អែកលើសក្ខីកម្មក្នុងតុលាការរបស់ ព្រុំ សារ៉ាត[5197] និងភស្តុតាងជាឯកសារដទៃទៀតនៅសម័យនោះ[5198]។

1850. ទាក់ទងទៅនឹងពាក្យពេចន៍ដែលបានប្រើប្រាស់ក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងទស្សនាវដ្តីទង់បដិវត្តន៍ និងយុវជនបដិវត្តន៍ ទូរលេខ និងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងដែលម្ចាស់បណ្តឹងសាទុក្ខបានជំទាស់ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការបកស្រាយជាជម្រើសមួយបែបទៀតរបស់ ខៀវ សំផន លើឯកសារទាំងនេះ និងដទៃទៀតនៃភស្តុតាងនីមួយៗ។ បើទោះបី វោហាសាស្ត្រមួយចំនួនដែលប្រមាថ បានកំណត់គោលដៅលើកងទ័ពជនជាតិវៀតណាមក៏ដោយ ក៏ដទៃទៀតសំដៅលើជនជាតិវៀតណាមជាទូទៅ។ ការសំដៅលើ"*យួន*ក្លិនស្អុយរហូតដល់ឋានលើ និងចោកទាបគួរឱ្យស្អប់ មិនមានតម្លៃអ្វីទាំងអស់" បង្កើតបានជាផ្នែកនៃការប្រៀបធៀបយ៉ាងទូលំទូលាយរវាងជីវិតរស់នៅរបស់ប្រជាជនកម្ពុជា និង"ប្រជាជន"វៀតណាម[5199] ខណៈពេលដែលវោហាសាស្ត្រដទៃទៀតសំដៅទៅលើការពិភាក្សាអំពីការ"ក្តាប់ឱ្យបាន" និងមានការណែនាំឱ្យ"សម្រេចចោលដែរ [...]" ឬ"ឱ្យប្រមូលទុកមួយកន្លែង" "យួនដែលមានប្តីប្រពន្ធខ្មែរ" មានលក្ខណៈមិនរើសមុខ[5200]។ សេចក្តីសន្និដ្ឋានដូចគ្នាត្រូវបានអនុវត្តទៅលើការសំដៅទៅលើ"ការសម្រិតសម្រាំង" និង"បោសសម្អាត""អាណិកជនយួន"[5201]។ ដូច្នេះ ការលើក

---

[5197] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០២ យោងទៅលើប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ (ព្រុំ សារ៉ាត) ឯកសារលេខ E1/382.1 ទំព័រ ៥១។

[5198] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០៥ យោងទៅលើកំណត់ហេតុនៅមន្ទីរស-២១ របស់ ម៉ម ណៃ ខែ មិថុនា ឆ្នាំ ១៩៧៥ ដល់ ខែ តុលា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/833។ សៀវភៅកំណត់ត្រារួមនៃមន្ទីរស-២១ ខែ មេសា ឆ្នាំ ១៩៧៨-ខែ ធ្នូ ឆ្នាំ ១៩៧៨ ឯកសារលេខ E3/834 ទំព័រ ៣២-៣៣ (ព័ត៌មានបញ្ចូលនៅថ្ងៃ ០៣ ខែ មិថុនា ឆ្នាំ ១៩៧៨)។ កំណត់ត្រារួមមន្ទីរស-២១ ខែ មេសា-ធ្នូ ឆ្នាំ ១៩៧៨ ឯកសារលេខ E3/834 ERN 00077573-00077574, ERN 00077483-00077487, ERN 00077518-00077519។

[5199] ទស្សនាវដ្តីទង់បដិវត្ត ខែ កក្កដា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/746 ទំព័រ ១ ("ប្រទេសយើងមានប្រជាជនខ្លាំងជាងយួន ព្រោះប្រជាជនយើងមានជីវភាពជាសមូហភាព មានអង្គការចាត់តាំងវិន័យរឹងប៉ឹង។ យួនរស់នៅតាមជាឯកជនសង្កត់សង្កិនជិះជាន់គ្នាគ្មានអង្គការវិន័យ។ ដូច្នេះ យួនខ្សោយ។ ប្រទេសរបស់យើង ប្រជាជនយើងមានកិត្តិយស និងឈ្មោះល្បីដោយសារយើងបានខិតខំប្រឹងប្រែងកសាងប្រទេសដោយខ្លួនឯង ម្ចាស់ខ្លួនឯង/ភាពជាឯករាជ្យ។ *យួន* ធំក្លិនស្អុយរហូតដល់ឋានលើ និងចោកទាបគួរឱ្យស្អប់ មិនមានតម្លៃអ្វីទាំងអស់ ព្រោះយួនគិតតែពីដើរកាន់ផ្តិល កាន់ឈើច្រត់ ដើម្បីសុំលុយគេ")។

[5200] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/863 ទំព័រ ២។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការពិភាក្សាពាក់ព័ន្ធទៅនឹង"ការសម្រេចលើ [...] យួនដែលមានប្តីប្រពន្ធខ្មែរ" ត្រូវបានពន្លាតដល់"ខ្មែរកាត់យួន"។

[5201] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨ ឯកសារលេខ E3/1094 ទំព័រ ១។

ឡើងរបស់ ខៀវ សំផន ដែលថា គ្មានអ្វីក្នុងភស្តុតាងអាចនិយាយថា ជាការសំដៅទៅលើជនជាតិវៀតណាម ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជានោះ ពុំអាចជឿជាក់បានឡើយ។

1851.អាស្រ័យហេតុនេះ បើទោះបីពុំមានភស្តុតាងមួយៗដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ គ្រប់គ្រាន់*ដោយខ្លួនឯង*ក្នុងការបង្ហាញនូវអត្ថិភាពនៃ"គោលនយោបាយដែលបានបង្កើតឡើងដោយមជ្ឈិមកំណត់គោលដៅលើជនជាតិវៀតណាមសម្រាប់ការចាត់ទុកជាសត្រូវ"[5202]ក៏ដោយ ក៏ភាពជារួមនៃភស្តុតាងបានបង្ហាញគ្រប់គ្រាន់ថាមានគោលនយោបាយដូច្នោះ។ ជាលទ្ធផល អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ខ. ជនជាតិចាម

1852.ក្នុងការពិនិត្យលើ"ការកំណត់គោលដៅលើជនជាតិចាម" អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើឯកសារនៅសម័យនោះដែលមានក្នុងសំណុំរឿង[5203] និងសក្ខីកម្មក្នុងតុលាការ[5204]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទូរលេខ ១៥ គឺជាឯកសារគន្លឹះដែលបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅជាក់លាក់លើប្រជាជនចាមនៅភូមិភាគបូព៌ាបន្ទាប់ពីមានការបះបោរនៅកោះផលខែ កញ្ញា ឆ្នាំ ១៩៧៥ និងក្រៀនស្វាយនៅខែ តុលា ឆ្នាំ ១៩៧៥[5205] នៅពេលដែលជនជាតិចាមបានជំទាស់ដោយហិង្សាទៅនឹងការរឹតត្បិតដោយអង្គការដែលបន្ទាប់មកត្រូវបានគេស្គាល់ថា ជាបក្សកុម្មុយនីស្តកម្ពុជា លើការប្រតិបត្តិសាសនាមូស្លីម និងទំនៀមទម្លាប់របស់ពួកគេ។ ក្នុងទូរលេខ១៥ នោះ លេខាភូមិភាគបូព៌ា សោ ភឹម បានរាយការណ៍ទៅ ប៉ុល ពត អំពីការផ្លាស់ទីប្រជាជន និងបានបញ្ជាក់ថា ហេតុផលសម្រាប់ការផ្លាស់ទី គឺដើម្បីបំបែកជនជាតិចាមចេញពីដងទន្លេមេគង្គ"ឱ្យបរិយាកាសធូរស្រាលខ្លះ"[5206]។ គាត់បានបញ្ជាក់ថា "ការដកនេះ ជាគោលការណ៍ បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ"[5207]។ អង្គជំនុំជម្រះ

[5202] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤១៧។

[5203] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៣.២.៥.១។

[5204] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៣.២.៥.២។

[5205] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១២។

[5206] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១០ ដកស្រង់ទូរលេខ ប.ក.ក. ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/1680។

[5207] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១០ ដកស្រង់ទូរលេខ ប.ក.ក. ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ឯកសារលេខ E3/1680។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា ការផ្លាស់ទីប្រជាជនដែលត្រូវបានពិភាក្សាក្នុងទូរលេខនោះគឺជាផ្នែកមួយនៃការបែងចែកយ៉ាងទូលំទូលាយនៃប្រជាជន និងថា ការផ្លាស់ទី

សាលាដំបូងបានពិចារណាផងដែរលើឯកសារមួយចំនួនដទៃទៀត រួមមាន ទូរលេខផ្សេងមួយដែលថា "ជនជាតិចាម"នៅក្នុងស្រុកចំការលើមានការជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពខ្មាំង កំណត់ហេតុកិច្ចប្រជុំខែ កញ្ញា ឆ្នាំ ១៩៧៦ នៃលេខា អនុលេខា កងពលមជ្ឈិម និងវរៈសេនាធំឯករាជ្យដែលថា ការត្រៀមរៀបចំទប់ទល់ការបះបោររបស់ជនជាតិចាមក្នុងខេត្តកំពត ត្រូវបានពិភាក្សា និងរបាយការណ៍នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ បានផ្ញើទៅភូមិភាគពាយ័ព្យចេញពីគណៈកម្មាធិការតំបន់ ៥ បញ្ជាក់អំពីវិធានការពិសេសដែលកំពុងត្រូវបានអនុវត្តដើម្បីតាមដានមេក្រុមនៃ"សមាសភាព ១៧ មេសា មកពីភ្នំពេញ ដែលជាជនជាតិចាម"[5208]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានសំដៅទៅលើសាសនាថា ជាប្រតិកិរិយាដែលគ្រោះថ្នាក់ដល់កម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជា និងបានរំឭកអំពីសក្ខីកម្មរបស់សាក្សីដែលបានឆ្លើយថា សាសនាទាំងអស់ត្រូវបានចាត់ទុកថា ជាប្រតិកិរិយា ពុំមានសិទ្ធិសេរីភាពខាងសាសនា សាសនាអ៊ីស្លាមត្រូវបានចាត់ទុកថាជាប្រតិកិរិយា និងត្រូវបានហាមឃាត់ដាច់ខាត[5209]។ អង្គជំនុំជម្រះបានពិចារណាផងដែរលើឯកសារបោះពុម្ពផ្សាយនៅពេលនោះរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានសំដៅទៅលើពូជសាសន៍ខ្មែរ និងតម្រូវការចាំបាច់ក្នុងការការពារ និងថែរក្សា[5210]។

1853.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងក្នុងតុលាការបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅជាពិសេសលើជនជាតិចាម"ក្នុងកម្មវិធីដែលត្រូវបានរំពឹងទុក ដើម្បីរំលាយពួកគេទាំងស្រុងចូលជាសញ្ជាតិខ្មែរ និងមានអត្តសញ្ញាណខ្មែរតែមួយ"[5211]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ និងសាក្សីម្នាក់ដែលសំដៅទៅលើជនជាតិចាម ថាលែងត្រូវបានគេចាត់ទុកជាជនជាតិចាមតទៅទៀត ប៉ុន្តែត្រូវបានគេចាត់ទុកដូចជាខ្មែរ ឬត្រូវបានប្តូរមកជាខ្មែរ និង

---

ប្រជាជនដែលរស់នៅក្បែរព្រំដែន គឺដោយសារជម្លោះជាមួយប្រទេសវៀតណាមជាជាងដោយសារការបះបោររបស់ជនជាតិចាម។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១១-៣២១២។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានពិចារណាលើការយោងទៅលើ"ការធ្វើឱ្យធូរស្រាលភាពតានតឹង"សំដៅទៅលើការបះបោររបស់ជនចាមពេលថ្មីៗ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១២។

[5208] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៤ យោងទៅលើទូរលេខ ប.ក.ក. ឯកសារលេខ E3/511 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦។ កំណត់ហេតុនៃកិច្ចប្រជុំលេខា និងអនុលេខាកងពល និងកងវរៈសេនាធំ ឯកសារលេខ E3/800 ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦។ របាយការណ៍ប្រចាំសប្តាហ៍របស់គណៈកម្មាធិការតំបន់ ៥ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/178។

[5209] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៥។

[5210] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៦។

[5211] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៧។

បានកត់សម្គាល់ផងដែរក្នុងជើងទំព័រនូវការលើកឡើងរបស់អ្នកជំនាញសាក្សី[5212]។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលថា ពូជសាសន៍ដទៃទៀតត្រូវបានចាត់ទុកថា ជាសត្រូវ និងថា គោលបំណងគឺធ្វើឱ្យជនជាតិចាមដូចខ្មែរ ដែលរារាំងជនជាតិចាមយ៉ាងមានប្រសិទ្ធភាពពីការថែរក្សាអត្តសញ្ញាណវប្បធម៌ និងសាសនារបស់ពួកគេ[5213]។ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា សាក្សី ប្រាក់ យុត បានផ្ដល់សក្ខីកម្មថា លោកស្រីបានទទួលបទបញ្ជាឱ្យបោសសម្អាតជនជាតិចាម និងបញ្ជូនបទបញ្ជានេះទៅឱ្យអ្នកនៅក្រោមបង្គាប់របស់លោកស្រី[5214]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងផងដែរទៅលើសាក្សីដទៃទៀតដែលបានផ្ដល់សក្ខីកម្មក្នុងសវនាការអំពីផែនការកម្ទេចជនជាតិចាម[5215] និងបានបញ្ជាក់ថា កិច្ចសម្ភាសន៍ពីរដែលនៅក្រៅនីតិវិធីរបស់ អ.វ.ត.ក. និងរបស់អ្នកជំនាញមួយចំនួន បានសំដៅផងដែរទៅលើការកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាលើជនជាតិចាម[5216]។

1854.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំណះអំណាងដែលថា វិធានការសន្តិសុខប្រឆាំងនឹងជនជាតិចាមមួយចំនួនត្រូវបានប្រើប្រាស់ដោយសារសកម្មភាពរបស់ពួកគេជាជាងអត្តសញ្ញាណជាជនជាតិចាម (ដែលត្រូវបានចាប់ខ្លួនក្នុងករណីមួយចំនួនក្រោយពេលមានការបះបោរ ឬក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ) និងថា ជនជាតិចាមបានកំពុងរស់នៅក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងប្រជាជនខ្មែរដែរ(ការហាមឃាត់លើសាសនាបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនខ្មែរ ចិន ពុទ្ធសាសនិក និងសាសនាកាតូលិក)[5217]។ អង្គជំនុំជម្រះបានពន្យល់មូលហេតុដែលអង្គជំនុំជម្រះបានយល់ឃើញថា អំណះអំណាងទាំងនេះពុំគួរឱ្យជឿជាក់បានឡើយ[5218]។

1855.បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> ការអំពាវនាវជាសាធារណៈអំពីមិត្តភាពដែលបានធ្វើឡើងភ្លាមៗក្រោយពេល"រំដោះ"ទីក្រុងភ្នំពេញ ព្រមទាំងការអនុម័តលើមាត្រា ២០ នៃរដ្ឋធម្មនុញ្ញគឺជាមធ្យោបាយមិនស្មោះត្រង់ក្នុងការកៀរគរការគាំទ្រជាតិ

[5212] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៧។

[5213] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៨។

[5214] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៩។

[5215] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៩។

[5216] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២១៩។

[5217] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៣។២។៥។៣។

[5218] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២១, ៣២២៣-៣២២៦។

និង/ឬប្រជាប្រិយភាពសម្រាប់បដិវត្តន៍ក្នុងលក្ខណៈដូចគ្នា ដែលបានធ្វើឡើងជាមួយពុទ្ធសាសនិក នៅពេលនោះដែរ ដូច្នេះហើយការអំពាវនាវនេះ មិនមានតម្លៃជាភស្តុតាងនោះទេ។

អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ ប.ក.ក. ដើម្បីបង្កើតសង្គម មួយដែលមិនប្រតិបត្តិសាសនា និងដូចគ្នាតែមួយដោយមិនមានការបែងចែកវណ្ណៈ គឺបានកំណត់គោលដៅលើជនជាតិចាម ដែលជាក្រុមជាតិពន្ធុមួយនិងសាសនាមួយដាច់ដោយឡែកពីគេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយនេះមានការវិវត្តន៍ទៅតាមពេលវេលា ហើយមានការកើនឡើងនូវមធ្យោបាយដែលបានប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយនេះ។ នៅបណ្តាឆ្នាំដំបូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងការប៉ុនប៉ងបឋមដើម្បីរំលាយប្រជាជនចាម ប.ក.ក. បានកំណត់គោលដៅលើជនជាតិចាមតាមរយៈការរឹតបន្តឹងលើការប្រតិបត្តិវប្បធម៌ និងសាសនារបស់ពួកគេ។ នៅពេលដែលជនជាតិចាមប្រឆាំងនឹងការបោះបង់អត្តសញ្ញាណជាតិពន្ធុនិងសាសនារបស់ពួកគេ "ការបះបោរ"ត្រូវបានបង្ក្រាបយ៉ាងព្រៃផ្សៃ ហើយមេដឹកនាំការបះបោរត្រូវបានគេសម្លាប់ ឯសហគមន៍ចាមត្រូវបានបំបែក។ បន្ទាស់ប្តូរចុងក្រោយមួយបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ នៅពេលដែលមានការបញ្ជាឱ្យបោសសម្អាតជនជាតិចាមទាំងអស់។ ការបញ្ជានេះកើតឡើង ពេលដែលជម្លោះជាមួយនឹង វៀតណាមកាន់តែកើនឡើង ជាពេលដែលតម្រូវការចាំបាច់ក្នុងការរក្សាពូជសាសន៍ខ្មែរនិងការពារប្រជាជនខ្មែរពីសំណាក់ខ្មាំងទាំងអស់ត្រូវបានចាត់ទុកថាជាអាទិភាពកំពូល[5219]។

1856.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា មានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាមដោយសារអត្តសញ្ញាណនៃក្រុមរបស់ពួកគេ ពីព្រោះពុំមានឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាដែលអាចបង្ហាញថា មានគោលនយោបាយប្រឆាំងនឹងជនជាតិចាម ហើយមានសាក្សីជាច្រើនបានបញ្ជាក់នូវកង្វះគោលនយោបាយនោះ[5220]។ គាត់បានអះអាងថា គោលបំណងរបស់ខ្មែរក្រហម គឺដើម្បីបង្កើតសង្គមមួយមិនពាក់ព័ន្ធសាសនា ដែលស្ថិតក្នុងលំដាប់ទីពីរទាក់ទងទៅនឹងគោលបំណងបដិវត្តន៍នៃការកសាងប្រទេសឡើងវិញ និងថាអត្តសញ្ញាណរបស់ជនជាតិចាមដែលជាសមាជិកនៃក្រុមមួយ ពុំមែនជាបញ្ហាសម្រាប់បក្សកុម្មុយនីស្តកម្ពុជា ដូចបានបង្ហាញឱ្យឃើញតាមរយៈឯកសារផ្សេងៗនោះ[5221]។ គាត់បានចង្អុលបង្ហាញថា សារជាសាធារណៈរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះជនជាតិចាម មានលក្ខណៈវិជ្ជមានទាំងអស់ដែលគួរឱ្យកត់សម្គាល់ពីព្រោះពុំ

---

[5219] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៧-៣២២៨។

[5220] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៦៥-១៥៧៤។

[5221] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៦៦-១៥៦៧។

អាចជៀសផុតពីការថ្កោលទោសសត្រូវរបស់ខ្លួនឡើយ[5222]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់អត្ថិភាពនៃបទឧក្រិដ្ឋ និងបំភ្លៃភស្តុតាងក្នុងការធ្វើយុត្តិកម្មលើវិធីសាស្ត្ររបស់ខ្លួនពាក់ព័ន្ធទៅនឹង គោលនយោបាយល្មើសកំណត់គោលដៅលើជនជាតិចាម[5223] និងថា ការកំណត់ពេលវេលារបស់អង្គជំនុំ ជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងគោលនយោបាយមានលក្ខណៈផ្ទុយគ្នា[5224]៖ ដំណាក់កាលទីមួយ នៅឆ្នាំដំ បូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពរយៈពេលពីរទៅបីឆ្នាំគិតចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បន្ទាប់មក ដំណាក់កាលទីពីរ ក្រោយការបះបោរ ដែលបានកើតឡើងក្នុងខែ កញ្ញា និងតុលា ឆ្នាំ ១៩៧៥ ដើមខែនៃរបបកម្ពុជាប្រជាធិបតេយ្យ[5225]។

1857.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញថា នត្ថិភាពនៃឯកសារផ្លូវការបក្សកុម្មុយនីស្ត កម្ពុជាពាក់ព័ន្ធទៅនឹងគោលនយោបាយ និងសារវិជ្ជមានចំពោះជនជាតិចាមមានន័យថា ការយល់ឃើញ ដែលសមហេតុផលតែមួយគត់នោះគឺថា ពុំមានអត្ថិភាពនៃគោលនយោបាយលើជនជាតិចាម[5226]។ សហ ព្រះរាជអាជ្ញាបានយោងទៅលើទូរលេខ ១៥ និងឯកសារដទៃទៀតនៅសម័យនោះរួមមាន រួមទាំងឯកសារ បោះពុម្ពផ្សាយដែលពុំបានលើកឡើងអំពីជនជាតិចាមជាពិសេស ប៉ុន្តែបានថ្កោលទោសពួកគេតាមរយៈការ សង្កត់ធ្ងន់ៗថា សាសនាបង្កឱ្យមានការអន្តរាយ និងមានភាពចាំបាច់ត្រូវថែរក្សាពូជសាសន៍កម្ពុជា[5227] និង បានអះអាងថា ភស្តុតាងជារួមបានបង្ហាញនូវបរិបទមួយដែលក្នុងនោះ ជាការជៀសពុំរួចដែលថា ជនជាតិ ចាមត្រូវបានកំណត់គោលដៅ[5228]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំបាន អើពើ ឬបានបិទបាំងសក្ខីកម្មរបស់អ្នកជំនាញមួយចំនួន ប៉ុន្តែបានកត់សម្គាល់ជាពិសេសលើការបកស្រាយ របស់ ខៀវ សំផន អំពីភស្តុតាង និងថា អ្នកជំនាញខ្លះក្នុងចំណោមនោះបានផ្តល់ភស្តុតាងថា ជនជាតិចាម ត្រូវបានកំណត់គោលដៅ[5229]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា បើទោះបីជាការប្រើប្រាស់របស់អង្គជំនុំ ជម្រះសាលាដំបូងនូវឃ្លា"ឆ្នាំដំបូងៗ"ផ្ទុយគ្នាក៏ដោយ ក៏នេះពុំបាននាំឱ្យមានភាពមិនយុត្តិធម៌ ដែរ ប៉ុន្តែផ្ទុយ ទៅវិញ នេះបានបង្ហាញឱ្យឃើញច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឃ្លានេះ ដើម្បីបញ្ជាក់

---

5222 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៦៨។

5223 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៦៩។

5224 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៣៦-៩៣៧។

5225 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៩៣៧។

5226 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៤៨។

5227 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៤៩-៤៥០។

5228 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៥១។

5229 សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៥៦-៤៥៧។

អំពីអានុភាពកាន់តែខ្លាំងឡើងៗនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះជនជាតិចាមជាដរាប [5230]។

1858.អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាថា នត្ថិភាពនៃឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាដែលលើកឡើងថា មានគោលនយោបាយពាក់ព័ន្ធនឹងជនជាតិចាម មានន័យថា ពុំមានអត្ថិភាពនៃគោលនយោបាយនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានប្រតិបត្តិការចាប់តាំងពីដំបូងផ្អែកលើមូលដ្ឋានថា ឯកសារតិចតួចត្រូវបានបន្សល់ទុកដោយខ្មែរក្រហមក្រោយពេលដកថយ នៅពេលការឈ្លានពានពីវៀតណាមបានមកដល់ លើកលែងមន្ទីរស-២១ និងស្រុកត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយនេះមានអត្ថិភាពផ្អែកយ៉ាងទូលំទូលាយលើការយោងទៅលើទូរលេខ ១៥ ដែលបានពិភាក្សាអំពីការបំបែកជនជាតិចាម និងចេញពីសកម្មភាពដែលត្រូវបានរៀបចំឡើងក្នុងការបោសសម្អាតជនជាតិចាមក្នុងឆ្នាំ ១៩៧៧ ដល់ ១៩៧៨។ អង្គជំនុំជម្រះសាលាដំបូងពុំជឿជាក់លើឯកសារសាធារណៈដែលសំដៅទៅលើលក្ខណៈមិត្តភាពចំពោះសាសនាទាំងអស់ និងបានយល់ឃើញថា ឯកសារនេះប្រើប្រាស់វិធីសាស្ត្រមិនពិតប្រាកដក្នុងការប្រមូលការគាំទ្រសាធារណៈ។ ដោយសារការបន្លំបែបនេះគឺជាផ្នែកមួយដ៏ធំនៃការអនុវត្តន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបការយល់ឃើញដែលថា ពុំមានគោលនយោបាយកំណត់គោលដៅលើជនជាតិចាមនោះ ពុំមែនជាសេចក្តីសន្និដ្ឋានមួយដែល គ្មានតុលាការអង្គហេតុសមហេតុផលណាអាចធ្វើទៅបាននោះទេ។

1859.អង្គជំនុំជម្រះសាលាដំបូងពុំបានមិនអើពើលើសក្ខីកម្មផ្ទុយរបស់សាក្សី ដូចការចោទប្រកាន់របស់ ខៀវ សំផន នោះទេ[5231] និងបានពន្យល់ថា កង្វះការដឹងរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច អំពីគោលនយោបាយកំណត់គោលដៅលើជនជាតិចាមស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងដែលបង្ហាញថា គាត់ពុំដែលចូលរួមកិច្ចប្រជុំគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ និងពុំដែលបានទទួលការណែនាំពីគណៈអចិន្ត្រៃយ៍ ឬ នួន ជា ដោយផ្ទាល់នោះទេ[5232]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើការអះអាងរបស់ ខៀវ សំផន ដែលថា សាក្សី ម៉ាត់ លី និងអ្នកជំនាញមួយចំនួនទៀត បានបញ្ជាក់ថា ពុំមានអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិចាម[5233]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញជាក់លាក់នូវមូលហេតុដែលខ្លួនពុំបាន

---

[5230] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤៧៨។

[5231] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៧២-១៥៧៤។

[5232] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៣។

[5233] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២២។

យល់ស្របជាមួយភស្តុតាងនោះក៏ដោយ ក៏មានភាពច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ពួកគេ និងបានជឿជាក់លើភស្តុតាងរបស់អ្នកជំនាញដទៃទៀត ដូចជា៖ François PONCHAUD និង Stephen HEDER ដែលសក្ខីកម្មរបស់ពួកគាត់បានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើជនជាតិចាម[5234]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា នេះជាកំហុសនោះឡើយ។

1860.ចុងក្រោយ បើទោះបីជា ខៀវ សំផន បានអះអាងថា ពុំមានអត្ថិភាពនៃគោលនយោបាយសម្រាប់វិធានការជាក់លាក់កំណត់គោលដៅលើជនជាតិចាម ក្រៅតែពីការអនុវត្តន៍វិធានការស្មើភាពគ្នាចំពោះប្រជាជនទាំងមូលក៏ដោយ[5235] ក៏នេះពុំបានអើពើលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយបានវិវឌ្ឍជាដរាប និងជាយថាហេតុបានក្លាយជាគោលនយោបាយនៃ"ការបោសសម្អាត"ជនជាតិចាម[5236]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅជាក់លាក់លើជនជាតិចាម[5237]។ អាស្រ័យហេតុនេះទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ ត្រូវបដិសេធចោល។

### គ. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

1861.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយដែលកំណត់គោលដៅទូលំទូលាយលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ការប្រព្រឹត្តទៅលើសត្រូវ មានអត្ថិភាពពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថា គោលនយោបាយនេះបានផ្សាភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងថា គោលនយោបាយនេះជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើមនុស្សឃាតចាប់តាំងពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ចុងខែ ឧសភា ឆ្នាំ ១៩៧៥ និងចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5238]។ ក្នុងការបង្កើតការយល់ឃើញទាំងនេះ អង្គ

---

[5234] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៦។

[5235] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៧៤។

[5236] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨។

[5237] *សូមមើលផងដែរ ខាងលើ* ផ្នែក VII.ច.២.ក និងផ្នែក VII.ច.៣.ក។

[5238] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៤៩, ៤០៦១។

ជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារនាសម័យនោះជាច្រើន រួមទាំងសុន្ទរកថាអបអរជ័យជម្នះ ដែលធ្វើឡើងដោយ ខៀវ សំផន ព្រមទាំងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ភស្ដុតាងអ្នកជំនាញ[5239]។

1862.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគជ្រើសរើសតាមការចង់បានលើសុន្ទរកថារបស់គាត់ត្រង់ចំណុចថា៖ សត្រូវដែលគាត់ចង់សំដៅទៅលើនោះ តាមពិត គឺចក្រពត្តិអាមេរិក និងសម្ព័ន្ធមិត្តដែលជាមេក្លោងនៃរបបសាធារណរដ្ឋខ្មែរ ពុំមែនសំដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបនោះទេ[5240] និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ បើទោះបីជាគាត់ត្រូវបានឱ្យរួចទោសពាក់ព័ន្ធនឹងព្រឹត្តិការណ៍ទាំងនេះក៏ដោយ ដោយសារអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលនយោបាយនៃការចាត់វិធានការជាក់លាក់ប្រឆាំងនឹងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ពុំត្រូវបានបង្ហាញនោះឡើយ[5241] និងបានបន្ថែមថា ជាការពុំអាចធ្វើទៅបានផ្អែកលើភស្ដុតាងក្នុងការយល់ឃើញថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រព្រឹត្តទៅលើខុសប្លែកពីគេនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខស-២១ ឬមន្ទីរសន្តិសុខក្រាំងតាចាន់ ពីព្រោះអ្នករាល់គ្នាបានរស់ក្រោមលក្ខខណ្ឌដូចគ្នា និងបានទទួលរងវាសនាដូចគ្នាដែរ[5242]។

1863.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងសុន្ទរកថាជ័យជម្នះ គឺជាការលើកឡើងដោយពុំត្រឹមត្រូវថា គុណនាមដែលគាត់បានជ្រើសរើសដោយផ្ទាល់ប្រើប្រាស់ក្នុងសុន្ទរកថាអំពីជ័យជម្នះ បង្ហាញពីបំណងព្យាបាទទៅលើរបបចាស់ និងបានពន្យល់នូវមូលហេតុដែលអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ត្រូវបានកំណត់គោលដៅ[5243]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះពុំមានកំហុសក្នុងការសំអាងទៅលើព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃជាការគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា មានគោលនយោបាយស្តីពីការរើសអើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៥ អង្គជំនុំជម្រះតុលាការកំពូលពុំបានឱ្យ ខៀវ សំផន រួចទោសពីបទចោទពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃនោះទេ បើទោះបីបានបញ្ជាក់ថា ជាការពុំសមហេតុផលក្នុងការយល់ឃើញថា គោលនយោបាយគិតទុកជាមុននៃការកម្ទេចទាហាន និង

---

[5239] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្នែក ១៦.៤.៣.៤។

[5240] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨១។

[5241] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨២។

[5242] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨៣។

[5243] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១៩។

អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅពេលមានព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃក៏ដោយ[5244]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមថា ខៀវ សំផន ពុំបានអើពើទៅនឹងការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសុន្ទរកថាជាច្រើនដទៃទៀត ព្រមទាំងសេចក្តីណែនាំ កិច្ចប្រជុំ សក្ខីកម្មរបស់សាក្សី និងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរក្នុងការយល់ឃើញថា គោលនយោបាយកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាព[5245]។

1864.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គោលនយោបាយដែលកំណត់គោលដៅទូលំទូលាយលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ការប្រព្រឹត្តទៅលើសត្រូវ មានអត្ថិភាពពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលផ្សាភ្ជាប់យ៉ាងស្អិតល្មួតទៅនឹងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារនាសម័យនោះជាច្រើន ព្រមទាំងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងអ្នកជំនាញក្នុងការបង្កើតការយល់ឃើញនេះ ប៉ុន្តែ ខៀវ សំផន បានជំទាស់តែទៅនឹង (១) ការសំអាងទៅលើសុន្ទរកថាជ័យជម្នះរបស់គាត់ (២) ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ និង (៣) ការយល់ឃើញថា ការរើសអើងបានកើតឡើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

1865.ពាក់ព័ន្ធទៅនឹងសុន្ទរកថាជ័យជម្នះនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ខៀវ សំផន បានលើកសរសើរការកម្ទេចរបបចាស់ក្រោយការរំដោះ និងបានប្រកាសថា 'ពួកខ្មាំងបានដាច់ខ្យល់ស្លាប់ទាំងក្តីឈឺចាប់បំផុត'"[5246]។ ខៀវ សំផន បានសំដៅយ៉ាងជាក់ច្បាស់ទៅលើ"ចក្រពត្តិអាមេរិក"ថា សត្រូវនៅក្នុងសុន្ទរកថានេះ ប៉ុន្តែមានការសំដៅជាច្រើនទៅលើ"សត្រូវ"ដែលមានលក្ខណៈព្រលំស្របតាមគោលបំណង។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការបកស្រាយដែលថា "សត្រូវ"ត្រូវបានសំដៅផងដែរទៅលើរបបសាធារណរដ្ឋខ្មែរ និងជាទូទៅលើទាហាននៃរបបនេះ ជាការសមហេតុផល និងបានពិចារណាឃើញថា ខៀវ សំផន បានសំដៅទៅលើរបបនៃសាធារណរដ្ឋខ្មែរថាជា "របបក្បត់ជាតិ ពួកហ្វាស៊ីស និងពុករលួយ"[5247]

---

[5244] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤១៨។

[5245] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ៤២០-៤២៨។

[5246] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៣៧។

[5247] សារអបអរសាទរជ័យជំនះធ្វើឡើងនៅថ្ងៃទី២១ ខែមេសា របស់ ខៀវ សំផន តាមវិទ្យុក្រុងភ្នំពេញ(ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ឯកសារលេខ E3/118 ERN 00846160។

និងបានបញ្ជាក់ផងដែរថា ខ្មែរក្រហមបាន"វាយប្រហារសត្រូវគ្រប់ទីកន្លែងឥតឈប់ឈរ នៅតាមភ្នំ និងទីវាល"[5248]។

1866.ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើព្រឹត្តិការណ៍ទាំងនេះធ្វើជាផ្នែកនៃការវិភាគតាមកាលប្បវត្តិនៃការប្រព្រឹត្តទៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងការកំណត់ថាតើ មានគោលនយោបាយពាក់ព័ន្ធនឹងពួកគេក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែរ ឬយ៉ាងណា។ ការដែលថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលពុំបានយល់ឃើញថា គោលនយោបាយនេះត្រូវបានបង្កើតឡើងអំឡុងពេលនៃព្រឹត្តិការណ៍នោះ[5249] ពុំមែនមានន័យថាពួកគេពុំជាប់ពាក់ព័ន្ធទៅនឹងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការពិចារណាលើភស្តុតាងនេះឡើយ។

1867.ពាក់ព័ន្ធទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា ពុំមានបង្ហាញភស្តុតាងដែលថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រព្រឹត្តទៅលើផ្សេងនោះឡើយ ដោយសារអ្នករាល់គ្នាបានរស់នៅក្រោមលក្ខខណ្ឌដូចគ្នា និងបានទទួលរងវេសនាដូចគ្នា អង្គជំនុំជម្រះតុលាការកំពូលរំឭកការសន្និដ្ឋានរបស់ខ្លួនពីដំបូងថា ការធ្វើទុក្ខបុកម្នេញអាចត្រូវបានយល់ឃើញថា មានការប្រព្រឹត្តទៅលើដូចៗគ្នា[5250] និងការយល់ឃើញបន្ថែមទៀតរបស់ខ្លួនដែលថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាក់ស្តែងបានទទួលរងការរើសអើងនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា ឬមន្ទីរសន្តិសុខស-២១[5251]។

1868.ដោយសារ ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើ (១) សុន្ទរកថាជ័យជម្នះរបស់គាត់ (២) ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ និង (៣) ការយល់ឃើញដែលថា ការរើសអើងបានកើតចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទីតាំងដែលបានលើកឡើងខាងលើ ដូច្នេះទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ ត្រូវបដិសេធចោល។

---

[5248] សារអបអរសាទរជ័យជំនះធ្វើឡើងនៅថ្ងៃទី២១ ខែមេសា របស់ ខៀវ សំផន តាមវិទ្យុក្រុងភ្នំពេញ (ក្នុងកម្រងសារព័ត៌មាន FBIS) ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ឯកសារលេខ E3/118 ERN 00846160។

[5249] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១០០។

[5250] *សូមមើលខាងលើ* ផ្នែក VII.ច.១.ខ។

[5251] *សូមមើលខាងលើ* ផ្នែក VII.ច.២.ខ.ii-v ខៀវ សំផន បានអះអាងផងដែរថា ពុំមានការរើសអើងបានកើតឡើងនៅក្រាំងតាចាន់ ប៉ុន្តែអំណះអំណាងនេះពុំមានមូលដ្ឋានគាំទ្រ។ នៅក្នុងផ្នែកនៃបណ្តឹងសាទុក្ខទាក់ទងទៅនឹងក្រាំងតាចាន់ គាត់ត្រឹមតែបានលើកអំណះអំណាងពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង។

ឃ. ពុទ្ធសាសនិក

1869.ខៀវ សំផន បានលើកឡើងថា ជាការពុំអាចធ្វើបានសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញស្ដីពីអត្ថិភាពនៃគោលនយោបាយល្មើសដែលមានការចាត់វិធានការប្រឆាំងនឹងពុទ្ធសាសនិក និងកាន់តែពុំអាចថែមទៀតដែលថា គោលនយោបាយនោះគឺជាផ្នែកនៃគោលបំណងរួម[5252]។ ក្នុងការគាំទ្រ គាត់បានសំអាងទៅលើអំណះអំណាងដែលបានលើកឡើងក្នុងសារណារបស់គាត់ [5253]ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលខាងលើ[5254]។

## ៦. គោលនយោបាយនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍

1870.ក្នុងការបន្តពិនិត្យលើលក្ខណៈល្មើសនៃគោលបំណងរួម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គោលនយោបាយទូទាំងប្រទេសក្នុងការដាក់បទបញ្ជាបង្កើតគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍មានអត្ថិភាពចាប់តាំងពីដើមឆ្នាំ ១៩៧៤[5255]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយនេះតាមរយៈការដើរតួនាទីជំនួសឪពុកម្ដាយក្នុងការជ្រើសរើសគូស្រករសមស្រប និងតាមរយៈការកម្រិតជាអប្បបរមានៃតួនាទីរបស់គ្រួសារក្នុងការថែទាំ និងបីបាច់កូន និងការបង្ខំឱ្យគូស្រកររៀបអាពាហ៍ពិពាហ៍ និងបង្ខំឱ្យបង្កើតកូនសម្រាប់គោលបំណងនៃការបង្កើនប្រជាជនក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ[5256]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គោលនយោបាយនេះផ្សាភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងគោលបំណងរួមនោះ និងមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើដែលត្រូវបានកំណត់ចរិកលក្ខណៈថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[5257]។

1871.ខៀវ សំផន បានលើកឡើងថា ជាការពុំអាចធ្វើទៅរួចក្នុងការយល់ឃើញអំពីអត្ថិភាពនៃគោលនយោបាយល្មើសពាក់ព័ន្ធទៅនឹងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ

---

[5252] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៨៦-១៥៩១។

[5253] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤២៦-៤៣៤, ៦៤១-៦៥៦, ៧៤៣-៧៤៧, ៩៥៤-៩៥៦។

[5254] *សូមមើលខាងលើ* កថាខណ្ឌ ២៤១-២៤៤, ៨៣៤-៨៣៦, ១១៨៨ និងផ្នែក VII.ច.៣.ខ។

[5255] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៦៧០, ៤០៦៣, ៤០៦៤, ៤០៦៧។

[5256] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៣៩-៣៥៦៣។

[5257] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦៥-៣៧០១, ៤០៦៤-៤០៦៧។

ក្នុងបរិបទនេះ[5258]។ ក្នុងការគាំទ្រដល់ការអះអាងរបស់ខ្លួន ខៀវ សំផន បានសំអាងទៅលើអំណះអំណាងដែលបានលើកឡើងក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់[5259] ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធខាងលើ[5260]។

1872.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ ត្រូវបដិសេធចោល។

## ៧. ការរួមចំណែករបស់ ខៀវ សំផន

1873.ទាក់ទងទៅនឹងបញ្ហាថាតើ ខៀវ សំផន បានរួមចំណែកក្នុងគោលបំណងនៃសហឧក្រិដ្ឋកម្មរួមដល់កម្រិតណា ប្រសិនបើមាន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មិនត្រឹមតែបានចូលរួម និងរួមចំណែកការគាំទ្រដល់គោលបំណងរួមប៉ុណ្ណោះទេ ថែមទាំងថា គាត់បានគាំទ្រជាសាធារណៈពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5261]។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ គាត់បានជម្រុញយ៉ាងសកម្មតាមរយៈការបញ្ចេញមតិជាសាធារណៈ និងបានបញ្ជាក់អះអាង និងគាំទ្រគោលបំណងរួមនោះក្នុងស្រុក និងលើឆាកអន្តរជាតិ[5262]។ គាត់បានជម្រុញទឹកចិត្ត និងញុះញង់ការអនុវត្តន៍គោលបំណងនេះតាមរយៈគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ខណៈពេលប្រើប្រាស់តួនាទីជាន់ខ្ពស់របស់ខ្លួនក្នុងការផ្ដល់ធម្មានុរូបដល់គោលបំណងនោះ[5263]។ គាត់បានណែនាំយ៉ាងសកម្មស្ដីពីការអនុវត្តន៍តាមរយៈគោលនយោបាយផ្សេងៗ[5264] និងដោយខ្លួនផ្ទាល់បានគ្រប់គ្រង និងធ្វើឱ្យការអនុវត្តន៍គោលបំណងនោះដំណើរការតាមរយៈគោលនយោបាយផ្សេងៗ[5265]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានរួម

---

[5258] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥៩២។

[5259] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១២៤៣-១២៨០, ១៣៤១-១៣៩៨។

[5260] *សូមមើលខាងលើ* ផ្នែក VII.ឆ.៣.ខ។

[5261] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧-៤២៦១។

[5262] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២-៤២៦៤។

[5263] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៥-៤២៧០។

[5264] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧១-៤២៧៤។

[5265] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៥-៤២៧៨។

ចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[5266]។

1874.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសកម្មក្នុងគោលបំណងរួមល្មើស[5267]។ ជាពិសេស គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយពុំត្រឹមត្រូវថា ការគាំទ្រ ការចូលរួម និង/ឬការរួមចំណែករបស់គាត់ក្នុងទិដ្ឋភាពល្មើសនៃគោលបំណងរួមដែលពុំមែនជាបទល្មើសក្នុងការអនុវត្តន៍បដិវត្តន៍សង្គមនិយមក្នុងកម្ពុជា មានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវការរួមចំណែកសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលអាចជាប់ពាក់ព័ន្ធទៅនឹងគោលបំណងនោះ[5268]។ គាត់បានអះអាងថា "នៅក្នុងសហឧក្រិដ្ឋកម្មរួមដែលមានគោលបំណងពុំមែនជាបទល្មើសចំពោះ ការរួមចំណែកសំខាន់មិនមែនសំដៅលើការសម្រេចគោលបំណងរួមនោះទេ(ដែលមិនមានលក្ខណៈឧក្រិដ្ឋ) ប៉ុន្តែទៅលើការប្រព្រឹត្តបទឧក្រិដ្ឋ"[5269] និងថា "ដោយពុំអាចកំណត់បាននូវចរិកលក្ខណៈជាក់លាក់នៃការរួមចំណែករបស់គាត់ក្នុងទិដ្ឋភាពល្មើសនៃគោលបំណងរួម អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឧបាយកលបញ្ឆូលរូបគាត់ទៅក្នុងការទទួលខុសត្រូវជារួមដែលផ្ទុយទៅនឹងលក្ខខណ្ឌតម្រូវចាំបាច់ក្នុងការកំណត់នូវការទទួលខុសត្រូវជាលក្ខណៈបុគ្គល"[5270]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតទៅលើការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានគាំទ្រ និងជម្រុញគោលបំណងរួមល្មើស និងបានលើកទឹកចិត្ត ញុះញង់ ផ្តល់ធម្មានុរូប ណែនាំ ជួយសម្រួល និងគ្រប់គ្រងការអនុវត្តន៍គោលបំណងនេះ ព្រមទាំងលើការយល់ឃើញជាក់លាក់មួយចំនួន ឬភស្តុតាងដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានេះ[5271]។

1875.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ឬអង្គហេតុក្នុងការយល់ឃើញថា ការរួមចំណែកសំខាន់ក្នុងគោលបំណងរួម ដែលជាធាតុ

---

[5266] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦។

[5267] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០០១-២០០៣, ២០០៨-២០១១, ២០១៣។

[5268] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០០២, ២០០៣, ២០០៩-២០១១, ២០១៣, ២០១៥, ២០១៧។

[5269] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១១។

[5270] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០០៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១៧។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខថ្ងៃទី ៣ ឯកសារលេខ F1/11.1 ទំព័រ ១៥។

[5271] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១១-២០៣០។

ផ្សំចាំបាច់សត្យានុម័តនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានបង្ហាញ[5272]។ សហព្រះរាជអាជ្ញាបានជំទាស់ថា គាត់ខកខានផងដែរក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសន្និដ្ឋានថា គាត់បានគាំទ្រជាសាធារណៈ និងយ៉ាងសកម្ម និងបានជម្រុញតាមរយៈការបញ្ចេញមតិជាសាធារណៈ និងបានបញ្ជាក់អះអាង និងគាំទ្រគោលបំណងនោះ ព្រមទាំងថា គាត់បានលើកទឹកចិត្ត ញុះញង់ និងណែនាំយ៉ាងសកម្ម និងបានគ្រប់គ្រង និងបានធ្វើឱ្យការអនុវត្តន៍នៃគោលបំណងរួមនោះអាចដំណើរការ[5273]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយដែលតម្រូវឱ្យមានការអន្តរាគមន៍លើបណ្តឹងសាទុក្ខក្នុងការយល់ឃើញជាក់លាក់ ឬការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងណាមួយដែលជាមូលដ្ឋាននៃការសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះ[5274]។

1876.នៅមុនពេលដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមសហឧក្រិដ្ឋកម្មរួម ការរួមចំណែករបស់ជនជាប់ចោទក្នុងគោលបំណងរួម ត្រូវតែមានលក្ខណៈសំខាន់ បើទោះបីជាមិនចាំបាច់សំខាន់ផុតដោយខានមិនបានដើម្បីទទួលជោគជ័យនៃគោលបំណងរួមល្មើសក៏ដោយ។ លក្ខណៈ និងសារៈសំខាន់នៃតួនាទីត្រូវតែបានកំណត់ផ្អែកលើមូលដ្ឋានជាក់ស្តែងនីមួយៗ ដោយពិចារណាលើកត្តាជាច្រើនផ្សេងៗគ្នា រួមទាំងមុខតំណែងរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ឬកិច្ចខិតខំប្រឹងប្រែងណាមួយក្នុងការរារាំងឧក្រិដ្ឋកម្ម[5275]។ ការរួមចំណែកនេះអាចមានទម្រង់ជាច្រើនប្រភេទ[5276] និងដូចបានកំណត់ខាងលើដោយអង្គជំនុំជម្រះតុលាការកំពូល"សូម្បីសកម្មភាពដែលផ្អែកតាមអាការៈខាងក្រៅ ពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មក៏ដោយ ក៏អាចត្រូវបានយកមកពិចារណាផងដែរ នៅពេលធ្វើការកំណត់ថាតើ ជនជាប់ចោទបានរួមចំណែកសំខាន់ក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា[5277]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទូទៅរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអាចពិចារណាលើសកម្មភាពផ្អែកតាមអាការៈខាងក្រៅដែល ត្រូវបានកំណត់គោលដៅ ដើម្បីអនុវត្តបដិវត្តន៍សង្គមនិយម (ដែលផ្ទុយទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់) នៅពេលកំណត់ថា គាត់បានរួមចំណែកសំខាន់ក្នុងការជម្រុញគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួមនោះ។

---

[5272] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៤០-១០៤៨។

[5273] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៤៩-១០៥៦។

[5274] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៥៧-១០៩៥។

[5275] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៨០។

[5276] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៨១-៩៨៣។

[5277] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៨០។

1877.ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងជាសំខាន់បានដាក់ឱ្យគាត់“ទទួលខុសត្រូវជារួម” ឬពិរុទ្ធភាពតាមរយៈសមាគម[5278] ប៉ុន្តែតាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកយ៉ាងជាក់ច្បាស់នូវការសន្និដ្ឋានរបស់ខ្លួនអំពីការរួមចំណែកសំខាន់របស់ ខៀវ សំផន នៅក្នុងសហឧក្រិដ្ឋកម្មរួម លើសកម្មភាព ឬការប្រព្រឹត្ត និងអំពើផ្ទាល់ខ្លួនរបស់គាត់ មិនមែនលើអំពើរបស់អ្នកដទៃ ដូចជា*ក្នុងចំណោមនោះ*៖ ការបន្តកាន់កាប់តួនាទីរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យពេញមួយអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ[5279] ការចូលរួមទៀងទាត់របស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម និងសមាជបក្សដែលសេចក្ដីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង និងបញ្ហានានាត្រូវបានពិភាក្សា[5280] សមាជិកភាពរបស់គាត់ក្នុងមន្ទីរ ៨៧០ ចាប់តាំងពីឆ្នាំ ១៩៧៥ និងការគ្រប់គ្រងលើបញ្ហាពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ ១៩៧៦ រហូតដល់ខែ មករា ឆ្នាំ ១៩៧៩[5281] ការចូលរួមក្នុងកិច្ចប្រជុំ ការពិភាក្សា និងអង្គមីទ្ទីងពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ និងបោសសម្អាតខ្មាំង[5282] វគ្គបណ្ដុះបណ្ដាលមនោគមវិជ្ជានាំមុខគេនៅក្នុងអង្គមីទ្ទីង និងសិក្ខាសាលាស្ដីពីការអប់រំកែប្រែឡើងវិញ[5283] ការបន្តអំពាវនាវរបស់គាត់ដល់មហាជនឱ្យធ្វើការជាសមូហភាពតាមស្រែចំការ និងរោងចក្រ បើទោះបីជាគាត់បានដឹងនូវលក្ខខណ្ឌដ៏គួរឱ្យភ័យរន្ធត់ របបការងារយ៉ាងធ្ងន់ធ្ងរ និងពុំមានអាហារគ្រប់គ្រាន់ក៏ដោយ[5284] ការអំពាវនាវរបស់គាត់ដល់ប្រជាជនឱ្យលះបង់អារម្មណ៍ផ្ទាល់ខ្លួនដែលមានចំពោះឪពុកម្ដាយមកជឿជាក់លើ*អង្គការ* ព្រមទាំងការជម្រុញរបស់គាត់ជាសាធារណៈដល់គោលនយោបាយបក្សក្នុងការបង្កើនប្រជាជនបានឆាប់រហ័ស ការជម្រុញយ៉ាងសកម្មដល់ការរៀបចំអាពាហ៍ពិពាហ៍ដែលផ្ទុយទៅនឹងទំនៀមទម្លាប់ពុទ្ធសាសនា និងណែនាំដល់គូស្រករឱ្យបង្កើតកូនដើម្បីបន្ថែមកម្លាំងក្នុងការការពារប្រទេស និងការគាំទ្រការលុបបំបាត់ពុទ្ធសាសនាក្នុងកម្ពុជាប្រជាធិបតេយ្យ[5285] និងការឃោសនាយ៉ាងសកម្មនូវការអំពាវនាវដោយមានវោហារសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាឱ្យធ្វើការរើសអើងជនជាតិវៀតណាមក្នុង

---

[5278] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០០៨។

[5279] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧។

[5280] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧-៤២៦០, ៤២៦២, ៤២៧៧។

[5281] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧, ៤២៧៦។

[5282] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៨, ៤២៧២, ៤២៧៧។

[5283] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦២។

[5284] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៥-៤២៦៧, ៤២៧៦, ៤២៧៣។

[5285] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៨, ៤២៧៣។

ពេលស្ថានភាពកាន់តែតានតឹងបំផុត និងការចាត់ទុកពួកគេជាសត្រូវបានកើនខ្លាំងឡើងៗ ព្រមទាំងការគាំទ្រតាមរយៈការបញ្ចេញមតិដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការនិរទេសជនជាតិវៀតណាម [5286]។

1878.បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើតួនាទី និងមុខតំណែងរបស់គាត់ ជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងការរួមចំណែកដល់សហឧក្រិដ្ឋកម្មរួមក្នុងបរិបទនេះ[5287] ដែលរួមបញ្ចូល (១) ការបន្តកាន់កាប់មុខនាទីរបស់គាត់នៃតួនាទីដែលមានឥទ្ធិពលក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យពេលមួយអំឡុងពេលដែលពាក់ព័ន្ធនោះ[5288] (២) ការចូលរួម និងមានវត្តមានដោយទៀងទាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម និងសមាជបក្ស ដែលសេចក្តីសម្រេចសំខាន់ៗប៉ះពាល់ដល់គោលនយោបាយត្រូវបានធ្វើឡើង និងពិភាក្សា ដូចជា"ការកម្ទេច"ខ្មាំង កសិកម្ម ភាពរាំងស្ងួត និងឧស្សាហ៍កម្ម[5289] និង (៣) ជាសមាជិកមន្ទីរ ៨៧០ ចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៥ និងការគ្រប់គ្រងលើបញ្ហាពាណិជ្ជកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីខែ តុលា ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៩[5290]។

1879.ទាក់ទងទៅនឹងការជំទាស់របស់ ខៀវ សំផន ទៅលើការយល់ឃើញជាមូលដ្ឋានផ្នែកអង្គហេតុ និង/ឬ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងនីមួយៗនោះ ភាគច្រើនលើសលុបបានយោងទៅលើសារណាដែលបានលើកឡើងក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់[5291] ដែលអង្គជំនុំជម្រះតុលាការកំពូល

---

[5286] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៩, ៤២៧១។

[5287] *សូមមើលខាងលើ* ផ្នែក VIII.ក។

[5288] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧។

[5289] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧-៤២៦០, ៤២៦២, ៤២៧៧។

[5290] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧, ៤២៧៦។

[5291] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១២ (យោងទៅលើ ១៦៦០-១៦៦៤, ១៧០៤-១៧៥៣), ២០១៤ (យោងទៅលើ ១៦៩០-១៨០៣, ១៨១៦-១៨៤៨, ១៨៦៧, ១៨៦៨), ២០១៥ (យោងទៅលើ ១៤៨៩-១៥២២), ២០១៦ (យោងទៅលើ ៨២៨-៨៣៥, ១៧០៤-១៧៥៣, ១៨៥១-១៨៥៣, ១៨៦៩-១៨៧១), ២០១៨ (យោងទៅលើ ១៦៩០, ១៦៩១), ២០១៩ (យោងទៅលើ ១៤៩០-១៥២២, ១៧៥៤-១៨០៣), ២០២០ (យោងទៅលើ ១៤០៨-១៤៣៧, ១៤៩០-១៥២២, ១៧៥៤-១៨០៣), ២០២១ (យោងទៅលើ ២៩៣-៣០៥, ១៣៩៩-១៦០៣, ១៨១៦-១៨៤០), ២០២២ (យោងទៅលើ ១០៩៨-១៣៩៨, ១៤០៨-១៤៤៧, ១៤៨៩-១៥២២), ២០២៣ (យោងទៅលើ ១០៥៨-១០៩៧, ១៥៥១-១៥៦០, ១៨៨៦-១៩២៧, ២០៧៥-២០៩០, ២០៩៤, ២០៩៩-២១១៣), ២០២៥ (យោងទៅលើ ១០៨០-១០៨២, ១៨៩៤, ១៨៩៨-១៩០២), ២០២៦ (យោងទៅលើ ១០៧៥, ១៧៥៩, ១៨៩២-១៨៩៤), ២០២៧ (យោងទៅលើ ១៥៣៤, ១៥៣៥, ១៧៥៧, ១៧៥៨, ១៧៩៤-១៧៩៧, ១៨៦៤),

បានដោះស្រាយរួចរាល់ហើយ និងបានបដិសេធចោលនៅក្នុងផ្នែកពាក់ព័ន្ធក្នុងសាលដីកានេះ។ បើទោះបីជាមានកំហុសផ្នែកអង្គហេតុមួយចំនួនអាចត្រូវបានកំណត់ក៏ដោយ ក៏ពុំគ្រប់គ្រាន់អាចបដិសេធសេចក្ដីសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសារៈសំខាន់នៃការរួមចំណែករបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម[5292] ដែលត្រូវបានផ្អែកលើលក្ខណៈជារួមនៃភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់អំពីសកម្មភាពរបស់គាត់ ដែលផ្ទុយពីវិធីសាស្ត្រដែលគាត់បានលើកឡើងអំពីការវាយតម្លៃលើការរួមចំណែកជាក់លាក់របស់គាត់តាមលក្ខណៈដាច់ដោយឡែកពីគ្នា ដែលពុំមែនជាវិធីសាស្ត្រត្រឹមត្រូវឡើយ[5293]។

1880.ដូច្នេះ ជាឧទាហរណ៍ ខៀវ សំផន បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងជាការពុំត្រឹមត្រូវដែលថា "ក្នុងនាមជាសមាជិកមន្ទីរ ៨៧០ និងជាអ្នកគ្រប់គ្រងលើពាណិជ្ជកម្ម និងជំនួញរបស់កម្ពុជាប្រជាធិបតេយ្យ គាត់ដោយផ្ទាល់បានធ្វើឱ្យដំណើរការទៅដោយរលូននូវកិច្ចការរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យដោយធ្វើឱ្យមហន្តរាយដល់ប្រជាជនរបស់ខ្លួន [...] និងបានធ្វើឱ្យប្រាកដប្រជាដោយផ្ទាល់ខ្លួនថា ភារកិច្ចរបស់ ខឿន[5294] ត្រូវបានបំពេញ" [5295]។ ដូចបានពិភាក្សាពាក់ព័ន្ធទៅនឹងតួនាទី និងមុខតំណែងរបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសដែលតម្រូវឱ្យមានអន្តរាគមន៍លើបណ្ដឹងសាទុក្ខនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសមាជិកភាពរបស់គាត់ ឬមុខតំណែងនៅក្នុងមន្ទីរ ៨៧០ ដែល ខៀវ សំផន ខ្លួនឯងផ្ទាល់បានដឹង[5296] ឬថា គាត់បានគ្រប់គ្រងយ៉ាងសំខាន់លើកិច្ចការពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ដូចមានភស្តុតាងគ្រប់គ្រាន់បង្ហាញនោះ[5297]។ ការ

---

២០២៨ (យោងទៅលើ ១២៣៣-១២៤២, ១៨១៥, ១៨៩៨-១៩០២, ១៩២៩, ១៩៣៦, ២០២៨, ២១១៧), ២០២៩ (យោងទៅលើ ១៤៩០-១៥២២, ១៧៦៣-១៧៩៨), ២០៣០ (យោងទៅលើ ១៨០៤-១៩៣៧)។

[5292] អង្គជំនុំជម្រះតុលាការកំពូលរំឭកជាឧទាហរណ៍នូវកំហុសក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង និងការវាយតម្លៃទៅលើភស្តុតាងរបស់ កាំង ហ្កេចអ៊ាវ *ហៅ* ឌុច និង សាឡុត បាន ក្នុងការសន្និដ្ឋាននៅពេលដែល ខៀវ សំផន ត្រូវបានដំឡើងពីសមាជិកបម្រុងនៃគណៈអចិន្ត្រៃយ៍ទៅជាសមាជិកពេញសិទ្ធិ និងពិចារណាឃើញថា កំហុសនេះពុំគ្រប់គ្រាន់ក្នុងការច្រានចោលការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងបានឡើយ។ *សូមមើលខាងលើ* កថាខណ្ឌ ១៦៧៥។

[5293] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩៨០។

[5294] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៦។

[5295] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២៩ យោងទៅលើកថាខណ្ឌ ១៧៦៣-១៧៩៨។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៣៧-១៦៣៩។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្ដឹងសាទុក្ខថ្ងៃទី ៣ ឯកសារលេខ F1/11.1 ទំព័រ ២១។

[5296] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៩, ៦១០, ៦១៩ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5297] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៧-៦២១។

កំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះសាលាដំបូងលើ ខៀន ដែលជា"អ្នកគ្រប់គ្រងមុន" ពុំបានទទួលលទ្ធផលដោយផ្អែកលើការសន្និដ្ឋានថា អង្គជំនុំជម្រះ"ពុំអាចសន្និដ្ឋានបានថា ខៀវ សំផន បានបម្រើការជាប្រធានមន្ទីរ ៨៧០ ឬជាក់ស្តែង"ជាកម្មាភិបាលនាំមុខគេ"នៅទីនោះឡើយ"[5298]។ ខៀវ សំផន បានព្យាយាមបំផ្លើសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងកាត់បន្ថយជាអប្បបរមានូវតួនាទីរបស់គាត់ថាត្រឹមតែជាជំនួយការ"ខាងបច្ចេកទេស" និង"កិច្ចការរដ្ឋបាល" [5299] បើទោះបីជាត្រូវបានទទួលយកក៏ដោយក៏នៅគ្រប់កាលៈទេសៈពុំទទួលបានជោគជ័យក្នុងការបដិសេធការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានជួយឱ្យដំណើរទៅដោយរលូននូវកិច្ចការរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យដែរ។

1881.ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា "ការគាំទ្ររបស់គាត់ដល់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយនោះមានអត្ថិភាពតាំងពីឆ្នាំ ១៩៦៧"[5300] និងថា "នៅពេលនោះ គាត់ត្រឹមតែបានចូលរួមនៅ*ព្រៃម៉ាត់* និងជាសមាជិកបម្រុងរបស់គណៈមជ្ឈិមក្នុងឆ្នាំ ១៩៧១ ប៉ុណ្ណោះ" និង"គ្មានសិទ្ធិអំណាចក្នុងស្ថាប័ននោះដែលពុំមានសិទ្ធិអំណាចផ្ទាល់ក្នុងការសម្រេចផងដែរ"[5301]។ ដូចបានពិភាក្សាទាក់ទងទៅនឹងតួនាទី និងមុខតំណែងរបស់ ខៀវ សំផន[5302] អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសដែលតម្រូវឱ្យមានការអន្តរាគមន៍លើបណ្តឹងសាទុក្ខ ក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការកំណត់ពេលវេលានៃសមាជិកភាពក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬតួនាទីដែលគាត់មានក្នុងការកៀរគរការគាំទ្រដល់ចលនាបដិវត្តន៍នៅចន្លោះថ្ងៃទី ១៩៧០ ដល់ ១៩៧៥ ដែលភាគច្រើននោះបានផ្អែកលើអត្ថបទនិពន្ធ កិច្ចសម្ភាសន៍ និង/ឬ សក្ខីកម្មផ្ទាល់របស់គាត់[5303]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅគ្រប់កាលៈទេសៈ ការអះអាងរបស់ ខៀវ សំផន ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជាពិសេសនោះ ពុំចាំបាច់តម្រូវឱ្យមានសិទ្ធិអំណាចដើម្បីផ្តល់ ឬកៀរគរការគាំទ្រដល់បក្ស ឬបដិវត្តន៍ឡើយ។

---

[5298] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦១៦។

[5299] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៨៤-១៧៩៨។

[5300] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៧។

[5301] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១២ យោងទៅលើកថាខណ្ឌ ១៦៦០-១៦៦៤, ១៧០៤-១៧៥៣។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៦៥-១៦៦៨។

[5302] *សូមមើលខាងលើ* ផ្នែក VIII.ក.៣។

[5303] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧៣-៥៨២ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១១-២៣៥។

1882.ខៀវ សំផន បានជំទាស់បន្ថែមទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន និង ព្រាប ឆុន ព្រមទាំងភស្តុតាងរបស់សាក្សី ប៊ិត ហឿន[5304] ក្នុងការសន្និដ្ឋានថា គាត់បានបង្ហាញ និងបានណែនាំស្តីពីការតាមរកខ្មាំង[5305]។ ជាថ្មីម្តងទៀត ខៀវ សំផន បានអនុវត្តវិធីសាស្ត្រជ្រើសរើសជាផ្នែកៗតាមការចង់បាន ដោយពុំបានពិចារណាលើភស្តុតាងទាំងអស់ដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើក្នុងការយល់ឃើញថា ជាផ្នែកមួយនៃតួនាទី និងមុខតំណែងរបស់គាត់ ខៀវ សំផន បានរួមបញ្ចូលបង្រៀនវគ្គបណ្តុះបណ្តាលនយោបាយស្តីពីការកំណត់អត្តសញ្ញាណ"ខ្មាំង" និងស្វែងរក"ជនក្បត់"នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨[5306]។ ខៀវ សំផន បានលើកការជំទាស់ដាច់ដោយឡែកទៅនឹងការយល់ឃើញនេះនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់[5307] ដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចផ្អែកទៅលើសក្ខីកម្មរបស់ អែម អឿន និង ឯក ហេន ដែលបានសន្មតថា គាត់ពាក់ព័ន្ធទៅនឹងការស្វែងរក"ខ្មាំង" [5308] និងថា ភស្តុតាងដទៃទៀតបានបង្ហាញថា"គាត់បាននិយាយតិចតួច" និងពុំបាននិយាយ"អ្វីអាក្រក់"ក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនយោបាយនោះឡើយ[5309]។ ដោយរំឮកថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី*ដោយខ្លួនឯងផ្ទាល់* ពុំមែនមិនអាចជឿទុកចិត្តបាននោះទេ និងថា អាចត្រូវបានទទួលដោយបូករួមជាមួយនឹង ភស្តុតាងរបស់សាក្សី និងអ្នកជំនាញធ្វើជាមធ្យោបាយសម្រាប់ការបង្ហាញនូវការពិតទាក់ទងទៅនឹងការចោទប្រកាន់លើជនជាប់ចោទ[5310] អង្គ

---

[5304] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២៧ យោងទៅលើកថាខណ្ឌ ១៥៣៤, ១៥៣៥, ១៧៥៧, ១៧៥៨, ១៧៩៤-១៧៩៧, ១៨៦៤។

[5305] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧២។ ខៀវ សំផន បានជំទាស់ទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងកថាខណ្ឌដូចគ្នាថា "នៅចុងឆ្នាំ ១៩៧៧ គាត់បានផ្តល់ប្រឹក្សាដោយផ្ទាល់ខ្លួនថា គោលបំណងនៃបដិវត្តន៍គឺដើម្បី'លុបបំបាត់របប លន់ នល់ [...] លុបបំបាត់ពួកមូលធន និងសក្តិភូមិ [និង] បញ្ញវន្ត'" ការយល់ឃើញដែលគាត់បានចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ប្រភព។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២៦។ ទោះជាយ៉ាងណាក្តី ការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ប្រភពនៃចម្លើយបានមកពីដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦១។

[5306] *សូមមើល ជាឧទាហរណ៍* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦០៧ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5307] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៤-១៧៦២។

[5308] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៥៤-១៧៥៩។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខថ្ងៃទី ៣ ឯកសារលេខ F1/11.1 ទំព័រ ២២។

[5309] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៧៦០-១៧៦២។

[5310] សាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣១២-៣១៤។

ជំនុំជម្រះតុលាការកំពូលពិចារណាថា ខៀវ សំផន ត្រឹមតែបានលើកឡើងនូវការបកស្រាយមួយបែបផ្សេងនៃភស្តុតាងដោយគ្មានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះឡើយ។ ដូច្នេះ ខៀវ សំផន ខកខានក្នុងការបង្ហាញនូវមូលហេតុដូចម្ដេចបានជាការសំអាងទៅលើភស្តុតាងជាក់លាក់នេះអាចមោឃៈសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានរួមចំណែកក្នុងគោលបំណងរួមល្មើសតាមរយៈការណែនាំស្ដីពីការអនុវត្តន៍នោះ។

1883.ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានជម្រុញជាសាធារណៈនូវការបំពេញតាមគោលដៅសេដ្ឋកិច្ចក្នុងសហករណ៍ បើទោះបីជាគាត់បានដឹងនូវលក្ខខណ្ឌដ៏គួរឱ្យភ័យរន្ធត់នោះក៏ដោយចុះ ខៀវ សំផន បានលើកសាជាថ្មីម្ដងទៀតថា ភស្តុតាងនោះត្រូវបានបំភ្លៃ និងពុំបានបង្ហាញថានេះជាបដិវត្តន៍មួយដែលមានលក្ខណៈជាបទល្មើសនោះឡើយ[5311]។ ដូចបានពិភាក្សាខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញនូវកំហុសដែលតម្រូវឱ្យមានការអន្តរាគមន៍លើបណ្ដឹងសាទុក្ខក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មនៅតាមសហករណ៍ និងការដ្ឋានធ្វើការ[5312]។ ផ្អែកលើភស្តុតាងចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានសមហេតុផលថា គាត់បានធានាប្រាកដថា ដោយផ្អែកតាមផែនការសេដ្ឋកិច្ច និងបង្កបង្កើនផលនៃបក្សកុម្មុយនីស្ដកម្ពុជា ស្រូវអង្ករត្រូវបាននាំចេញក្នុងកម្រិតអតិបរមា ខណៈពេលដែលដឹងថា ប្រជាជនកំពុងជួបប្រទះការអត់ឃ្លាន និងស្លាប់ដោយសារ ក្នុងចំណោមនោះ ការខ្វះស្បៀង និងលក្ខខណ្ឌគួរឱ្យរន្ធត់ក្នុងការដ្ឋានធ្វើការ និងសហករណ៍[5313]។ ការដឹងនេះនៅពេលបូករួមជាមួយនឹងអត្ថបទដកស្រង់ទាំងស្រុងចេញពីបទឧទ្ទេសនាមផ្ទាល់របស់គាត់ជាច្រើនអំពីការជម្រុញតាមរយៈការបញ្ចេញមតិជាសាធារណៈដល់អ្នកចូលរួមថា ត្រូវឱ្យពួកគេបន្តធ្វើការ“ទាំងយប់ថ្ងៃ [...] ឥតសម្រាក និងលះបង់ឱ្យខ្លាំងបំផុត” ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ចបង្កបង្កើនផល[5314] ដូចបានគាំទ្របន្ថែមដោយសាក្សីដទៃទៀត[5315] បង្កើតបានជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់

---

[5311] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០១៩, ២០២០ យោងទៅលើកថាខណ្ឌ ១៤០៨-១៤៣៧, ១៤៩០-១៥២២, ១៧៥៤-១៨០៣។

[5312] *សូមមើល* ផ្នែក VIII.ខ.៨.គ (ការដឹង និងចេតនារបស់ ខៀវ សំផន - សហករណ៍ និងការដ្ឋានធ្វើការ)។

[5313] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៦។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៧, ១៣០៧២។

[5314] *សូមមើល* ជាពិសេស សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៧។

[5315] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៧២។

អង្គជំនុំជម្រះសាលាដំបូងក្នុងការធ្វើសេចក្តីសន្និដ្ឋានសមហេតុផលថា ខៀវ សំផន បានរួមចំណែកក្នុងគោលបំណងរួមល្មើសតាមរយៈការជម្រុញ ការបញ្ជាក់អះអាង និងការគាំទ្រនោះ។

1884.ទាក់ទងទៅនឹងការយល់ឃើញដែលថា គាត់បានអំពាវនាវដល់ប្រជាជនឱ្យផ្លាស់ប្តូរអារម្មណ៍ផ្ទាល់ខ្លួនជាមួយឪពុកម្តាយមកជឿជាក់លើអង្គការ និងបង្កើតប្រជាជន[5316] ខៀវ សំផន បានអះអាងប្រហាក់ប្រហែលគ្នានេះដែរដោយពុំបានលើកមូលដ្ឋានគាំទ្រគ្រប់គ្រាន់ថា អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយពុំត្រឹមត្រូវលើភស្តុតាងនេះ[5317]។ អំណះអំណាងទាំងនេះត្រូវបានពិចារណា និងបដិសេធចោលក្នុងសាលដីកានេះ។ ជាថ្មីម្តងទៀត សារណារបស់គាត់ពាក់ព័ន្ធនឹងបញ្ហានេះ ត្រឹមតែផ្តល់ការបកស្រាយមួយបែបផ្សេងដែលពុំបានបង្ហាញនូវភាពពុំសមហេតុផលណាមួយក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានណែនាំទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដែលជាផ្នែកនៃគោលនយោបាយបង្កើនប្រជាជនក្នុងកិច្ចប្រជុំនៅវត្តឧណ្ណាលោម និងថា គាត់ដោយផ្ទាល់បានជម្រុញគោលនយោបាយនេះក្នុងបទឧទ្ទេសនាមរបស់គាត់ ដែលផ្អែកតាមសក្ខីកម្មរបស់ ជា ឡៀប និងបានគាំទ្របន្ថែមដោយ រស់ ស៊ុយ និងសម្តេចនរោត្តមសីហនុ[5318]។

1885.អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន អំពីកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការរួមចំណែកសំខាន់ក្នុងគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួម ត្រូវបដិសេធចោល។

## ៨. ការដឹង និងចេតនារបស់ ខៀវ សំផន

1886.បន្ទាប់ពីបានយល់ឃើញថា ខៀវ សំផន គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមដែលគោលបំណង ឬគោលដៅនោះ គឺដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជាសេដ្ឋកិច្ចកសិកម្មខ្លួនទីពឹងខ្លួនដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍នូវវិធីសាស្ត្រល្មើស និងថា គាត់បានរួមចំណែកយ៉ាងសំខាន់តាមរយៈគ្រប់គ្រង និងការដាក់ឱ្យការអនុវត្តន៍ដំណើរការតាមរយៈគោលនយោបាយនានា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មាន

---

[5316] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៦៨។

[5317] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០២២ យោងទៅលើកថាខណ្ឌ ១០៩៨-១៣៩៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២៨-១៩៣១។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/11.1 ទំព័រ ២៣-២៦។

[5318] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៥៦៩-៣៥៧១, ៤២៤៧, ៤២៤៨។ *សូមមើលខាងលើ* ផ្នែក VII.ឆ.៣.ខ.iv.ខ.ឃ។

ចេតនាចូលរួមក្នុងគោលបំណងរួមដែលគាត់បានរួមចំណែកជាមួយនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម និងថា នេះគឺជាចេតនាដែលគាត់"បានរួមចំណែកជាមួយសមាជិកនៃសហឧក្រិដ្ឋកម្មរួមដទៃទៀត[5319]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា ការរួមចំណែករបស់គាត់ដែលក្នុងគោលបំណងដើម្បីជម្រុញគោលបំណងរួមតាមរយៈការគាំទ្រ និងការលើកស្ទួយគោលបំណងរួម ការលើកទឹកចិត្ត ការញុះញង់ និងការផ្ដល់ធម្មានុរូបដល់គោលនយោបាយជាមូលដ្ឋាន និងការដាក់ដំណើរការ ការគ្រប់គ្រង និងការណែនាំស្ដីពីការអនុវត្តន៍គោលបំណងរួមតាមរយៈគោលនយោបាយមូលដ្ឋាននោះ" គឺជាភស្តុតាងបង្ហាញផងដែរនូវចេតនាក្នុងការចូលរួមក្នុងគោលបំណងរួម[5320]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា គាត់បានរួមចំណែកធាតុផ្សំអត្តនោម័តិដែលរួមបញ្ចូលលក្ខខណ្ឌតម្រូវនៃចេតនារើសអើង និងជាក់លាក់របស់សមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀត ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋមូលដ្ឋានដែលត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនោះ[5321]។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មទាំងនេះ[5322] ក្នុងចំណោមកត្តាដទៃទៀត ក្នុងការបង្ហាញថា លក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួមត្រូវបានបំពេញ។

1887.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញទាំងនេះដែលថា គាត់មានចេតនាគាំទ្រ និងចូលរួមក្នុងគោលបំណងរួមដែលមានលក្ខណៈជាបទល្មើស[5323] និងបន្ថែមថា គោលបំណងរួមនេះពុំមែនជាបទល្មើស និងដូច្នេះ ពុំអាចក្លាយជាសហឧក្រិដ្ឋកម្មរួមឡើយ។ គាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការ"ពិចារណាថា ការរួមចំណែកក្នុងគោលបំណងរួមដែលពុំមែនជាបទល្មើសបានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងអាចយល់ឃើញស្ដីពីការរួមចំណែកនៅក្នុងគោលនយោបាយល្មើស នៅពេលដែលអង្គជំនុំជម្រះចាំបាច់ត្រូវបង្ហាញនូវចេតនាក្នុងការចូលរួមក្នុងទិដ្ឋភាពល្មើសនៃគោលបំណងរួម និងក្នុងរឿងក្ដីបច្ចុប្បន្ន ក្នុងទិដ្ឋភាពល្មើសនៃគោលនយោបាយ"[5324]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង

---

[5319] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៨-៤២៧៩។

[5320] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៩។

[5321] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៩-៤៣០៧។ ការយល់ឃើញនេះពុំដាក់បញ្ចូលចេតនាប្រល័យពូជសាសន៍ជាក់លាក់របស់ ខៀវ សំផន ក្នុងការបំផ្លាញក្រុមជនជាតិពន្ធុ និងកាន់សាសនា ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងនោះពុំបានបង្ហាញឡើយ។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៤-៤២៥៤។

[5322] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៤-៤២៥៤។

[5323] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣១, ២០៤១-២០៤៣។

[5324] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣២។

បានអនុវត្តពុំត្រឹមត្រូវក្នុងការសន្និដ្ឋានលើចេតនាល្មើស តាមរយៈការពិចារណាថា ការប្រព្រឹត្តបទឧក្រិដ្ឋដោយចារីផ្ទាល់មានលក្ខណៈគ្រប់គ្រាន់ក្នុងការសន្និដ្ឋាននូវចេតនាល្មើសផ្ទាល់របស់គាត់ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ[5325]។ គាត់បានអះអាងថា សេចក្តីសន្និដ្ឋានណាមួយអំពីចេតនារបស់គាត់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋគប្បីត្រូវបានផ្អែកទៅលើអំពើ ឬការចូលរួមជាក់លាក់ផ្ទាល់ខ្លួនរបស់គាត់ក្នុងទិដ្ឋភាពល្មើសនៃគោលបំណងរួម ជាជាងផ្អែកលើអំពើរបស់អ្នកចូលរួមដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែលរងការចោទប្រកាន់នោះ[5326]។ គាត់បានជំទាស់បន្ថែមទៀតថា ចេតនារបស់គាត់គប្បីត្រូវបានវាយតម្លៃពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាក់លាក់ជាជាងផ្អែកលើ"បទឧក្រិដ្ឋ"ជាទូទៅ[5327] និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹង និងមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅសហករណ៍ និងការដ្ឋានធ្វើការ[5328] មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ព្រមទាំងក្នុងពេលបោសសម្អាត[5329] ចំពោះក្រុមជាក់លាក់ណាមួយ[5330] ឬតាមរយៈបទបញ្ជារៀបអាពាហ៍ពិពាហ៍[5331]។ បន្ថែមលើនេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា កម្រិតនៃការដឹងដែលជាលក្ខខណ្ឌតម្រូវមានលក្ខណៈផ្សេងៗគ្នាតាមពេលវេលានីមួយៗ និងក្នុងការផ្អែកលើភស្តុតាងនៃការដឹងរបស់គាត់នូវឧក្រិដ្ឋកម្មបន្ទាប់ពីបានកើតឡើងក្នុងការបង្ហាញនូវធាតុអត្តនោម័តិក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម[5332]។

1888.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់មានចេតនាគាំទ្រគោលបំណងរួម ដែលមានលក្ខណៈជាបទល្មើស[5333] និងថា គាត់ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំត្រឹមត្រូវក្នុងការសន្និដ្ឋានលើចេតនាល្មើសក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម[5334]។ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែមទៀតថា គាត់

---

[5325] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣៣-២០៣៧។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ សវនាការបណ្តឹងសាទុក្ខ ឯកសារលេខ F1/11.1 ទំព័រ ១៥។

[5326] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣៥, ២០៣៦។

[5327] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៣៨។

[5328] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨១៦-១៨៤៨, ២០៣៩-២០៥២។

[5329] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៤៩-១៨៧៨, ២០៥៣-២០៦១។

[5330] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៩-១៩២៧, ២០៦២-២១១៣។

[5331] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៩-១៩២៧, ២០៦២-២១១៣។

[5332] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០៤-១៨០៧, ១៩៣២-១៩៣៧។

[5333] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១០០-១១០២។

[5334] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១០៣-១១០៥។

ខកខានក្នុងការបង្ហាញនូវកំហុសក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដឹងរបស់គាត់ដែលបង្ហាញនូវចេតនារបស់គាត់[5335] ឬពាក់ព័ន្ធទៅនឹងចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើក្រុមគោលដៅ[5336] ក្នុងអំឡុងពេលនៃការបោសសម្អាត និងនៅតាមមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស[5337] និងសហករណ៍ និងការដ្ឋានធ្វើការ[5338] និងពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរួមបញ្ចូលការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[5339]។

1889.អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ចេតនាគឺជាផ្នែកចាំបាច់នៃការយល់ឃើញអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន។ ដោយធៀបជាមួយនឹងការយល់ឃើញផ្នែកអង្គហេតុដែលថា ជនជាប់ចោទ និងជនដទៃទៀត បានជាប់ពាក់ព័ន្ធនៅក្នុងសហឧក្រិដ្ឋកម្មរួម ចេតនាត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យថា មុនពេលជនជាប់ចោទអាចត្រូវបានដាក់ពិរុទ្ធពីបទឧក្រិដ្ឋដែលបានផ្អែកទៅលើការទទួលខុសត្រូវនោះ ធាតុផ្សំអត្តនោម័តិរបស់គាត់ ឬចេតនាល្មើស ត្រូវតែគ្របដណ្តប់ធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ[5340]។ ជនជាប់ចោទ និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមត្រូវតែរួមចំណែក"ចេតនាក្នុងការធ្វើឱ្យគោលបំណងរួមនោះមានប្រសិទ្ធភាព" ដោយដឹងអំពីឧក្រិដ្ឋកម្មដែលចោទជាបញ្ហានោះ និងកាលៈទេសៈនៃរឿងក្តី[5341]។ ម្យ៉ាងវិញទៀត បើទោះបីតាមវិធីសាស្ត្រផ្សេងៗគ្នាក៏ដោយ ក៏ជនជាប់ចោទត្រូវតែបានធ្វើទៅលើគោលបំណង ឬគោលដៅដូចគ្នាដែរ។

1890.ដូចបានលើកឡើងខាងលើ ខៀវ សំផន ពុំបានបដិសេធថា គាត់ និងសមាជិកដទៃទៀតនៃក្រុមរួមនោះបានរួមចំណែកចេតនារួមក្នុងការកែប្រែប្រទេសកម្ពុជាទៅជាសង្គមកសិកម្មខ្លួនទីពឹងខ្លួនគ្មានការបែងចែកវណ្ណៈតាមរយៈបដិវត្តន៍សង្គមនិយមឡើយ ប៉ុន្តែគាត់បានអះអាងថា ពួកគាត់ពុំដែលមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល ឬជាក្រុម និងថា គោលបំណងរួមពុំមានលក្ខណៈមហន្តរាយ និងដើម្បីអត្ថប្រយោជន៍

---

[5335] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១០៦-១១៣០។

[5336] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៣១-១១៨៣។

[5337] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៨៤-១១៩៨។

[5338] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១១៩៩-១២៤០។

[5339] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៤១-១២៤៦។

[5340] សាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៣។

[5341] សាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៤ យោងទៅលើសាលដីការឿងក្តី *Kvočka និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៨២។

ប្រជាជនកម្ពុជាទាំងមូល។ គាត់បានអះអាងថា ឧក្រិដ្ឋកម្មដែលអាចកើតឡើងក្នុងដំណើរការនៃការអនុវត្តន៍គោលបំណងរួម ពុំជាប់ពាក់ព័ន្ធ និងបានកើតឡើងដោយគាត់ពុំបានដឹង ឬបានចូលរួម។

1891.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផ្អែកលើការវាយតម្លៃភស្តុតាងជារួមចំពោះមុខខ្លួន គាត់ពុំអាចនិយាយថា មិនបានដឹងនូវអ្វីដែលបានកើតឡើងនៅមូលដ្ឋាននៃការដ្ឋានធ្វើការ សហករណ៍ និងមន្ទីរសន្តិសុខនោះទេ ដែលនេះបានរួមបញ្ចូលព័ត៌មានមិនត្រឹមបង្ហាញអំពីលក្ខខណ្ឌរស់នៅ និងធ្វើការធ្ងន់ធ្ងរក្នុងសហករណ៍ និងការដ្ឋានធ្វើការប៉ុណ្ណោះទេ ថែមទាំង ការកម្ទេច និងការបោសសម្អាតផ្ទៃក្នុងផងដែរ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខ និងកន្លែងកម្ទេចនោះ បង្ហាញនូវអានុភាពនៃគោលនយោបាយកំណត់គោលដៅលើក្រុមជាក់លាក់ និងបទបញ្ជាវៀបអាពាហ៍ពិពាហ៍ចំពោះប្រជាជនទូទៅ[5342]។ ការសន្និដ្ឋាននេះរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកខ្លះបានផ្អែកទៅលើភស្តុតាងដែលបង្ហាញថា តាមរយៈតួនាទីជាន់ខ្ពស់របស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈប្រធានរដ្ឋចាប់តាំងពីឆ្នាំ ១៩៧៧ រហូតមក និងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ ដែលជាមជ្ឈមណ្ឌលក្បាលម៉ាស៊ីនបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងតាមរយៈការចូលរួមជាញឹកញាប់របស់គាត់យ៉ាងហោចណាស់ពីរសប្តាហ៍ម្តងក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលជាស្ថាប័នកំពូលក្នុងកម្ពុជាប្រជាធិបតេយ្យ គាត់បានទទួលរបាយការណ៍ទៀងទាត់។ បន្ថែមលើនេះ ដោយផ្អែកលើការពិនិត្យហ្មត់ចត់លើភស្តុតាងសន្ធឹកសន្ធាប់ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុថា តាមរយៈសកម្មភាពរបស់គាត់ និងការដឹងដែលរងការចោទប្រកាន់នេះ បទឧទ្ទេសនាមគាំទ្រដែលគាត់បានផ្តល់ពេញមួយអំឡុងពេលនោះ វគ្គបណ្តុះបណ្តាលដែលគាត់បានផ្តល់ដល់កម្មាភិបាល និងការដឹងរបស់គាត់នូវព្រឹត្តិការណ៍នោះ ការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថា គាត់មានបំណងចូលរួមក្នុង និងផ្តល់ប្រសិទ្ធភាពដល់គោលបំណងរួមដែលត្រូវបានសម្រេចតាមរយៈ*ក្នុងចំណោមនោះ* ការធ្វើឱ្យភ័យតក់ស្លុត ការដកហូតសិទ្ធិ និងការបង្ខិតបង្ខំយ៉ាងខ្លាំងក្នុងកម្រិតយ៉ាងទូលំទូលាយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា កត្តាមួយទៀតដែលត្រូវបានពិចារណាគឺការពិតដែលថា ខៀវ សំផន បានបន្តកាត់កាប់មុខនាទីជាន់ខ្ពស់នៅពេលដែលគាត់ប្រាកដជាបានដឹងអំពីការអត់ឃ្លានទ្រង់ទ្រាយធំ និងការដកហូតនូវមតិប្រឆាំង ឬគាំទ្រការផ្លាស់ប្តូរ និងថា គាត់បានដឹងថា អ្នកនៅជុំវិញខ្លួនគាត់ដូចជាអ្នករួមការងារជិតស្និទ្ធ ដែលមានប្រវត្តិរូបជាអ្នកគាំទ្របដិវត្តន៍ និងផែនការរួម បានបាត់ខ្លួន ដោយសារពួកគេត្រូវបានចាត់ទុកថា ជាជនក្បត់ ឬជាខ្មាំង។ បើទោះបីជាការយល់ឃើញនេះត្រូវបានជំទាស់ដាច់ដោយឡែកនីមួយៗ និងជារួមក៏ដោយ ក៏ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ត្រឹមតែលើកសាឡើងវិញនូវការជំទាស់របស់គាត់ទៅនឹងការកំណត់លក្ខណៈ

[5342] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៨-៤២៧៩, ៤២៨២, ៤២៨៧, ៤២៩០, ៤២៩៥, ៤២៩៨, ៤៣០៣, ៤៣០៥-៤៣០៦។

នៃគោលបំណងរួមថាជាបទល្មើស និងលើកសាឡើងវិញនូវអំណះអំណាងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ ដែលអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចហើយនៅខាងលើ[5343]។

## ក. ការអះអាងថា ជាចេតនា“របស់អ្នកដទៃ”

1892.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបង្ហាញនូវចេតនារបស់គាត់ចូលរួមក្នុង “ទិដ្ឋភាពល្មើស”នៃគោលបំណងរួម និងថា “ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់អ្នកដទៃ”ត្រូវបានដាក់មកលើរូបគាត់សម្រាប់បទឧក្រិដ្ឋរបស់អ្នកដទៃ។ តាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានវិភាគយ៉ាងពេញលេញ និងបានអនុវត្តនូវលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួមសម្រាប់បទឧក្រិដ្ឋនីមួយៗដែលបានចោទប្រកាន់[5344]។ បទឧក្រិដ្ឋជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យយ៉ាងត្រឹមត្រូវថាតើ ខៀវ សំផន មានធាតុផ្សំអត្តនោម័តិ ដែរ ឬយ៉ាងណានោះ មានដូចជា៖ បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[5345], បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល[5346], ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម ដែលអង្គជំនុំជម្រះសាលាដំបូងពុំអាចធ្វើសេចក្តីសន្និដ្ឋាននូវចេតនាជាក់លាក់បាន និងលើជនជាតិវៀតណាម ដែលផ្ទុយទៅវិញអង្គជំនុំជម្រះអាចសន្និដ្ឋាននូវចេតនាជាក់លាក់បាន[5347], បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និង/

---

[5343] *សូមមើលខាងលើ* ផ្នែក VIII.ខ.២។

[5344] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨០-៤៣០៨ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5345] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨១, ៤២៨២។

[5346] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៤-៤២៨៧។

[5347] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩០, ៤២៩៤។

ឬពូជសាសន៍ និង/ឬអំពើអមនុស្សធម៌ដទៃទៀតនៃការផ្លាស់ទីដោយបង្ខំលើជនជាតិចាម ជនជាតិវៀតណាម និង/ឬអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[5348], ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចំពោះអ្នកជាប់ឃុំជនជាតិវៀតណាមនៅមន្ទីរស-២១ រួមទាំងតាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាប ការបង្កឱ្យមានការឈឺចាប់ ឬរបួសកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព ការដកហូតអ្នកជាប់ឃុំជាជនស៊ីវិល ឬឈ្លើយសឹកដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះទៀងទាត់ត្រឹមត្រូវ និងការឃុំឃាំងដោយខុសច្បាប់[5349], និងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍នោះ[5350]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការពិនិត្យដ៏ចាំបាច់ និងសំខាន់នេះត្រូវបានធ្វើឡើងទាក់ទងទៅនឹងការដឹងរបស់ ខៀវ សំផន ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ និងអ្នកចូលរួមយ៉ាងសកម្មក្នុងស្ថាប័នដែលជាបេះដូងនៃបក្សកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំកំពូលៗ។ នេះមិនត្រឹមតែជាការបង្ហាញលើសពីធម្មតាដែលថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងតម្រូវផងដែរនូវការវាយតម្លៃផ្នែកច្បាប់ហ្មត់ចត់លើបញ្ហាថាតើ គាត់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ដែរ ឬយ៉ាងណា។

1893.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTR ថា ដោយសារការបង្ហាញឱ្យឃើញច្បាស់លាស់នូវចេតនាល្មើស ពុំសូវមានជាញឹកញាប់ក្នុងបរិបទនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ទើបចេតនាតម្រូវតាមធម្មតាអាចត្រូវបានសន្និដ្ឋានចេញពីអង្គហេតុ និងកាលៈទេសៈពាក់ព័ន្ធ[5351] និងថា ការដឹងនូវបទឧក្រិដ្ឋ និងបូកជាមួយការចូលរួមដែលបានបន្តក្នុងសហឧក្រិដ្ឋកម្មរួម អាចត្រូវបានសន្និដ្ឋានថាជាចេតនារបស់បុគ្គលនោះ[5352]។ ទាក់ទងទៅនឹងបញ្ហានេះ ដោយផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានចេតនាល្មើសរបស់គាត់តាមរយៈចេតនារបស់អ្នកដទៃនោះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានចេតនារបស់គាត់ចេញពីអំពើ និងសកម្មភាពផ្ទាល់របស់

---

[5348] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៩, ៤២៩២, ៤២៩៣, ៤២៩៧, ៤២៩៨, ៤៣០០-៤៣០២។

[5349] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩៥។

[5350] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៤, ៤៣០៥។

[5351] សាលដីការឿងក្តី *Kayishema និង Ruzidana* (ICTR) កថាខណ្ឌ ១៥៩, ១៩៨។

[5352] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និង Ngirumpatse* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-44-A សាលដីកា ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ (“សាលដីការឿងក្តី *Karemera និង Ngirumpatse* (ICTR)”) កថាខណ្ឌ ៦៣២។

គាត់ និងបានយោង*ក្នុងចំណោមនោះ*ទៅលើ៖ “សេចក្តីសាទររបស់គាត់ចំពោះការអនុវត្តន៍ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា [...] [បើទោះបីជា] ការដឹងរបស់គាត់អំពីលក្ខខណ្ឌការងារ និងការរស់នៅគួរឱ្យភ័យរន្ធត់ដែលត្រូវបានដាក់ដោយចេតនានៅតាមសហករណ៍ និងការដ្ឋានធ្វើការពាសពេញប្រទេស” ព្រមទាំង “ការជម្រុញទឹកចិត្តកម្មាភិបាលឱ្យដាក់ការងារបន្ថែមលើប្រជាជនថ្មី និងពុំផ្តល់អាហារគ្រប់គ្រាន់ ខណៈពេលគាំទ្រលក្ខខណ្ឌពុំស្មើភាពគ្នាលើសត្រូវវណ្ណៈដែលត្រូវបានសន្មតថា មានគ្រោះថ្នាក់ដល់ការវិវឌ្ឍន៍របស់បក្សកុម្មុយនីស្តកម្ពុជា”[5353] និង“ការរួមចំណែករបស់គាត់ក្នុងការបោសសម្អាតទូទាំងប្រទេស”[5354] និង “ការជម្រុញកម្មាភិបាលឱ្យកំណត់អត្តសញ្ញាណខ្មាំងដែលធ្វើឱ្យរាំងស្ទះកិច្ចការរបស់បក្ស បញ្ឆេះកំហឹង និង ‘ប្រុងប្រយ័ត្ន’ចំពោះខ្មាំង និងព្រមានថា ជនក្បត់នឹងត្រូវកម្ទេច”[5355] និងការដែល“គាត់ត្រូវបានជូនដំណឹងដោយផ្ទាល់អំពីការឃុំឃាំងតាមអំពើចិត្ត និងលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតក្រោមការឃុំឃាំងនៅក្នុងខេត្តព្រះវិហារ និង“ការប្រើប្រាស់សិទ្ធិអំណាចលើកលែងសាច់ញាតិរបស់គាត់ចេញពីលក្ខខណ្ឌនោះ” (រួមទាំងសមាជិកនៃក្រុមគ្រួសាររបស់ប្រពន្ធគាត់)[5356] និង“ការថ្លែងអំពីជនជាតិវៀតណាម” និង“ការអំពាវនាវឱ្យបញ្ជូនប្រជាជនវៀតណាមចេញពីកម្ពុជាត្រឡប់ទៅប្រទេសវៀតណាមវិញតាំងពីដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ”[5357] និង“ពាក្យពេចន៍ និងសកម្មភាពក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលបង្ហាញនូវការមាក់ងាយលើជនជាតិវៀតណាម និងចេតនាផ្ទាល់ក្នុងការសម្លាប់ជនជាតិវៀតណាម ក្នុងទ្រង់ទ្រាយធំក្នុងកម្ពុជាចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩”[5358] និង“គាំទ្រសកម្មភាពបំភ័ន្តស្ថានភាពធម្មតា ក្នុងគោលបំណងផ្តល់ធម្មានុរូបនៃរដ្ឋាភិបាលបណ្តោះអាសន្ន ដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាដែលនៅពីក្រោយនេះ បានចាប់ផ្សឹកព្រះសង្ឃក្នុងទ្រង់ទ្រាយធំ [...] មុនពេលបញ្ឈប់ការលើកតម្កើងពីព្រះសង្ឃ ទន្ទឹមនឹងការជម្រុញឲ្យមានការរៀបចំការរៀបអាពាហ៍ពិពាហ៍ទៅតាមលក្ខណៈដែលមិនសមស្របទៅនឹងប្រពៃណីព្រះពុទ្ធសាសនា”[5359] និង“ការអំពាវនាវរបស់គាត់ឱ្យកម្ទេចថ្នាក់ដឹកនាំរបបសាធារណរដ្ឋខ្មែរ និងជាអ្នកគាំទ្រដ៏ស្មោះត្រង់នៃគោលនយោបាយរើសអើងរបស់

[5353] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨១។

[5354] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៤។

[5355] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៥។

[5356] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៥។

[5357] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩២។

[5358] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩៣។

[5359] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៩៧។

បក្សពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ"[5360] និង"ការណែនាំផ្ទាល់ខ្លួនរបស់គាត់ថា គ្រប់ក្រសួងត្រូវតែរៀបចំការរៀបអាពាហ៍ពិពាហ៍ដើម្បីឱ្យគូស្រករបង្កើតកូនសម្រាប់ការពារប្រទេសជាតិ"[5361]។ អំពើ/សកម្មភាពទាំងអស់នេះពីសំណាក់ ខៀវ សំផន ដែលតាមលក្ខណៈដាច់ដោយឡែកនីមួយៗ ពុំគួរឱ្យជឿជាក់គ្រប់គ្រាន់នោះ អាចធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងទាញការសន្និដ្ឋានដោយសមហេតុផល *ជារួម*ថា ខៀវ សំផន មានចេតនាឱ្យបទឧក្រិដ្ឋកើតឡើងតាមរយៈគោលបំណងរួម។

## ខ. ការដឹងដែលបង្ហាញនូវចេតនា

1894.អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTR ថា តួនាទីជាន់ខ្ពស់បូករួមជាមួយនឹងការដែលគេដឹងឮគ្រប់គ្នាជាសាធារណៈនូវអំពើល្មើសដែលបានលាតត្រដាង អាចបង្កើតបានជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋាននូវការដឹងអំពីបទឧក្រិដ្ឋ[5362]។ ទាក់ទងនឹងបញ្ហានេះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើភស្តុតាងនៃការដឹងប្រតិសកម្ម (*ex post facto* ) នូវឧក្រិដ្ឋកម្មមុនៗ ក្នុងការបង្ហាញនូវធាតុផ្សំអត្តនោម័តិរបស់គាត់ក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម[5363]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ដោយពិចារណាលើទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់គាត់ ជាពិសេស ជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេស" គាត់ពុំអាចថាមិនដឹងនូវលិខិតដែលផ្ញើពីអង្គការលើកលែងទោសអន្តរជាតិ និងគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សដែលបានសម្តែងក្តីបារម្ភលើរបាយការណ៍នៃការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ និងការធ្វើបាបលើជនស៊ីវិល[5364]។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញនេះថាជា"ការប៉ាន់ស្មានសុទ្ធសាធ" និងបានអះអាងថា "ពុំមានការបញ្ជាក់ថា គាត់បានទទួលរបាយការណ៍ទាំងនេះ" និង"ការទំនាក់ទំនងជិតស្និទ្ធជាមួយ អៀង សារី ពុំបង្កើតបានភស្តុតាងបង្ហាញអំពីការដឹងរបស់គាត់ឡើយ"[5365]។ គាត់បានបដិសេធផងដែរនូវការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការថ្លែងរបស់

[5360] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០០។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០២។

[5361] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៤។

[5362] សាលដីការឿងក្តី *Karemera និង Ngirumpatse* (ICTR) កថាខណ្ឌ ៦៣០។

[5363] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០៥ យោងទៅលើកថាខណ្ឌ ២០៣១-២០៣៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣២-១៩៣៧។

[5364] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥០។

[5365] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣២។

គាត់ក្រោយកម្ពុជាប្រជាធិបតេយ្យ កិច្ចសម្ភាសន៍ និងការដឹងអំពីសុន្ទរកថារបស់កម្មាភិបាលជាន់ខ្ពស់ ថាជាការប៉ាន់ស្មាន ជា"ករណីទូទៅ" ឬ"ការសន្និដ្ឋានជាទូទៅ" ដោយសារភស្តុតាងទាំងនេះពុំបានបង្ហាញថា មានបទឧក្រិដ្ឋជាក់លាក់អ្វីខ្លះដែលគាត់បានដឹងក្រោយមកនោះទេ[5366] ព្រមទាំងការពិចារណាលើខ្លឹមសារនៃ*ទង់/យុវជនបដិវត្ត* ពីព្រោះ"ពុំមានភស្តុតាងបង្ហាញថា គាត់បានទទួលឯកសារផ្សព្វផ្សាយទាំងនេះ និងជាពិសេសថា គាត់បានអានចំណុចនីមួយៗឡើយ"[5367]។

1895.ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ខៀវ សំផន ភាន់ច្រឡំរវាងការប៉ាន់ស្មាន និងដំណើរការនៃការទាញយកសេចក្តីសន្និដ្ឋាន ដែលអង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយសេរី ដរាបណាការសន្និដ្ឋាននោះមានលក្ខណៈសមស្រប និងបានផ្អែកលើអង្គហេតុពាក់ព័ន្ធ។ នៅពេលដែលបន្ទុករបស់ ខៀវ សំផន ក្នុងការបដិសេធការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅដំណាក់កាលបណ្តឹងសាទុក្ខមានលក្ខណៈខ្ពស់ សហព្រះរាជអាជ្ញាក៏មានបន្ទុកដូចគ្នាដែរក្នុងការបង្ហាញធាតុផ្សំនីមួយៗឱ្យហួសពីវិមតិសង្ស័យ ហើយអង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការធានាថា ការប្រព្រឹត្តរបស់ខ្លួនមិនឆ្លងកាត់បន្ទាត់ក្រហមដែលអនុញ្ញាតសម្រាប់ការសន្និដ្ឋាន ហួសឆ្លងទៅដល់ការប៉ាន់ស្មានដែលពុំត្រូវបានអនុញ្ញាត។ ទោះជាយ៉ាងណាក្តី ខៀវ សំផន បានរុញច្រានបន្ទាត់នោះកាន់តែឆ្ងាយក្នុងកម្រិតមិនអាចធ្វើបាន តាមរយៈការទាមទារជាឧទាហរណ៍នូវភស្តុតាងបន្ថែមបង្ហាញថា គាត់បានទទួលដោយផ្ទាល់ និងបានអានមិនត្រឹមតែមួយ ប៉ុន្តែពីរនូវលិខិតដែលបានផ្ញើមកឱ្យគាត់ផ្ទាល់ពីអង្គការអន្តរជាតិស្តីពីសិទ្ធិមនុស្សពីរសំខាន់បំផុតទូទាំងពិភពលោក។ ខៀវ សំផន ដែលជាប្រមុខរដ្ឋ និងតំណាងមុខមាត់សាធារណៈនៃរបបទទួលបន្ទុកក្នុងការទទួលគណៈប្រតិភូបរទេស មានកាតព្វកិច្ចទទួលការជូនដំណឹង និងឆ្លើយតបទៅនឹងក្តីបារម្ភ ឬការចោទប្រកាន់ដែលបានលើកឡើងដោយគណៈប្រតិភូបរទេស និងអង្គការនានា។ កាលៈទេសៈនេះតែម្យ៉ាងអាចគ្រប់គ្រាន់ឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានសមហេតុផលថា យ៉ាងហោចណាស់ គាត់បានអាន និងបានឱ្យដឹងនូវរបាយការណ៍ និងលិខិតដែលសំដៅលើគាត់ ដោយពុំចាំបាច់យោងបន្ថែមទៅលើទំនាក់ទំនងរបស់គាត់ជាមួយនឹង អៀង សារី ឬក្រសួងកិច្ចការបរទេសឡើយ[5368]។

1896.ដូចគ្នានេះដែរ ការចោទប្រកាន់របស់គាត់ពាក់ព័ន្ធទៅនឹងកង្វះភស្តុតាងដែលបង្ហាញថា គាត់បានទទួល ឬអានឯកសារបោះពុម្ពផ្សាយ*ទង់/យុវជនបដិវត្ត* ពុំគួរឱ្យជឿជាក់បានឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់

---

[5366] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣៣-១៩៣៧។

[5367] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣៤, ១៩៣៧ យោងទៅលើកថាខណ្ឌ ១៦៤១-១៦៤៣។

[5368] *សូមមើលខាងក្រោម* កថាខណ្ឌ ១៧៩៨។

សម្គាល់យ៉ាងត្រឹមត្រូវថា ពុំមែនរាល់សមាជិកបក្សកុម្មុយនីស្តកម្ពុជាបានទទួលច្បាប់ចម្លងនៃទស្សនាវដ្ដីនោះទេ ដោយសារច្បាប់ចម្លងនោះត្រូវបានរំពឹងថា រួមចំណែកគ្នាក្នុងចំណោមសមាជិកនោះ[5369]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានដោយសមហេតុផលនូវការដឹងរបស់ ខៀវ សំផន អំពីខ្លឹមសារក្នុងទស្សនាវដ្ដីនោះផ្អែកលើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ[5370] និងសារៈសំខាន់នៃតួនាទីរបស់គាត់ និងការពិតដែលថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកទស្សនាវដ្ដីនេះសំខាន់ ដូច្នេះសមាជិករបស់ខ្លួនត្រូវតែបានអាន ដែលជាញឹកញាប់ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងអប់រំនៅវគ្គរៀនសូត្របណ្ដុះបណ្ដាលផ្នែកនយោបាយ[5371] ដែលវគ្គខ្លះគាត់បានដឹកនាំដោយផ្ទាល់[5372]។

1897.ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងប្រមើលដឹងជាមុន (*ex ante*) ក្នុងការបង្ហាញនូវការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មទំនងកើតឡើងពេលអនាគត រួមទាំងនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ និងសកម្មភាព និងការជាប់ពាក់ព័ន្ធមុនកម្ពុជាប្រជាធិបតេយ្យជាមួយអនាគតមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[5373]។ ក្នុងការជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា និក្ខេបបទរបស់គាត់"បង្ហាញទំនោរចិត្តគាំទ្រគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៃការប្រមូលផ្ដុំ រួមទាំងតាមរយៈការដាក់ប្រជាជនឱ្យស្ថិតក្រោមគំនិតផ្ដួចផ្ដើមបង្កបង្កើនផលរបស់រដ្ឋ"[5374] គាត់បានអះអាងថា និក្ខេបបទរបស់គាត់"ពុំដែលនិយាយអំពីការបង្ខិតបង្ខំនរណាម្នាក់ ដែលនេះជាការផ្ទុយទៅវិញទេ"[5375] និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដោះបន្ទុកនៃគោលបំណងរបស់គាត់"ចង់បម្រើប្រទេសរបស់គាត់ និងកែប្រែសន្សឹមៗពីលើចុះក្រោម"[5376]។ គាត់បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការ"ភ្ជាប់ទំនាក់ទំនងរវាងគាត់ជាមួយនឹងមេដឹកនាំអនាគតនៃបក្សកុម្មុយនីស្តកម្ពុជា និងជំនឿចិត្តរបស់ពួកគេ ភ្លាមៗនៅពេលគាត់បានចូលរួមក្នុង'ក្រុម

---

[5369] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៧៥។

[5370] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៧៩។

[5371] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៧៧។

[5372] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧១-៤២៧៣។

[5373] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥២-១៦៥៩។

[5374] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៦។

[5375] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៣។

[5376] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៨។

ម៉ាក្សនិយម'នៅប៉ុន្មានខែក្រោយការមកដល់ទីក្រុងប៉ារីស"[5377] ក្នុងការសន្និដ្ឋានថា គាត់បានគាំទ្របក្ស កុម្មុយនីស្តកម្ពុជា និងគោលនយោបាយនៅមុនពេលគាត់បានចូលបក្ស[5378] ដោយសារពុំមាន"ការបញ្ជាក់ថា ក្រោយពេលត្រឡប់មកកម្ពុជា គាត់បានជួបជាមួយអនាគតមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា"[5379]។

1898.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន បានលើកនូវអំណះអំណាងប្រហាក់ប្រហែលគ្នានេះអំពីកំហុសអង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើគោលបំណងរបស់គាត់ក្នុងការកែប្រែបណ្តើរៗ ព្រមទាំងក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីទំនាក់ទំនងរបស់គាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជានៅមុនពេលចូលបក្ស និងថា អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងទាំងនេះរួចហើយ[5380]។ អាស្រ័យហេតុនេះ ខៀវ សំផន បានលើកសាឡើងវិញនូវអំណះអំណាងពីមុនដែលពុំទទួលបានជោគជ័យ និងត្រឹមតែផ្តល់ការបកស្រាយភស្តុតាងមួយបែបផ្សេងប៉ុណ្ណោះ ដោយគ្មានបង្ហាញនូវភាពពុំសមហេតុផលនៅក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានលក្ខណៈសមស្រប និងខុសពីអ្វីដែលគាត់បានបកស្រាយនោះ។ អំណះអំណាងរបស់គាត់អំពីគោលការណ៍សម្ងាត់ ដែលគាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពុំត្រឹមត្រូវ និងដោយប៉ាន់ស្មានថា ពុំបានអនុវត្តចំពោះរូបគាត់នោះ[5381] មានលក្ខណៈច្រំដែលដូចគ្នាដោយសារបានលើកឡើងរួចមកហើយក្នុងសំណុំរឿង ០០២/០១ និងត្រូវបានបដិសេធចោលនៅក្នុងបណ្តឹងសាទុក្ខ[5382]។ ជាថ្មីម្តងទៀត ខៀវ សំផន ត្រឹមតែបានលើកសាឡើងវិញថា ផ្អែកលើគោលការណ៍សម្ងាត់ អង្គជំនុំជម្រះសាលាដំបូងគប្បីបានបង្កើតការយល់ឃើញមួយផ្សេង ដែលនេះច្បាស់ណាស់ពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវកំហុសដែលអាចប្តឹងសាទុក្ខបាន។

1899.នៅគ្រប់កាលៈទេសៈ តាមការពិនិត្យលើផ្នែកពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងពុំឃើញមានចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងតែមួយមុខគត់ទៅលើភស្តុតាងនៃការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម

---

[5377] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦៥, ៥៦៦។

[5378] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៤ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧៣, ៤២៥៧។

[5379] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥៦។

[5380] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០០២, ១០០៥។

[5381] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៦៥០, ១៦៥១។

[5382] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៧១។

នៅមុន ឬក្រោយការប្រព្រឹត្តក្នុងការបង្ហាញនូវចេតនាចូលរួមក្នុងគោលបំណងរួម ឬឧក្រិដ្ឋកម្មដែលបានរួមបញ្ចូលតាមរយៈនោះឡើយ[5383]។ អង្គជំនុំជម្រះសាលាដំបូង ជាក់ស្តែងបានបញ្ជាក់ថា ខៀវ សំផន "បានដឹងនៅក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ"[5384]។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ផងដែរថា "កម្រិតនៃការដឹងដែលជាលក្ខខណ្ឌតម្រូវ ខុសប្លែកគ្នាតាមពេលវេលានីមួយៗ" ដូចការលើកឡើងរបស់ ខៀវ សំផន ឡើយ[5385] ប៉ុន្តែផ្ទុយទៅវិញថា "កម្រិតនៃការដឹងដែលជាលក្ខខណ្ឌតម្រូវ ខុសប្លែកគ្នាអាស្រ័យថាតើ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទមានអត្ថិភាពនៅមុន ក្នុងពេលដំណាលគ្នា ឬក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ដែរ ឬយ៉ាងណា"[5386]។ បើទោះបីជាប្រយោគនោះពុំមានភាពច្បាស់លាស់ក្នុងកម្រិតមួយដែលអាចធ្វើឱ្យដំណើរការនៃការបកស្រាយកាន់តែលំបាកក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅពេលពិចារណាតាមបរិបទ ខៀវ សំផន ទំនងជាបានយល់ដោយត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងចង់មានន័យថា កម្រិតនៃការដឹងដែលជាលក្ខខណ្ឌតម្រូវ ខុសប្លែកគ្នាអាស្រ័យទៅលើទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់នោះ[5387]។

1900.អាស្រ័យហេតុនេះ ដំណើរការនៃការកំណត់ធាតុផ្សំអត្តនោម័តិរបស់ជនជាប់ចោទក្រោមសហឧក្រិដ្ឋកម្មរួមនឹងត្រូវបានបង្ហាញកាន់តែច្បាស់តាមរយៈភស្តុតាង ឬការដឹងរបស់គាត់ក្នុងពេលដំណាលគ្នាជាមួយនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលនេះគឺជាផ្នែកដ៏ធំនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីបច្ចុប្បន្នស្តីពីការដឹងរបស់ ខៀវ សំផន នូវគោលនយោបាយ លំនាំនៃអំពើ និងឧក្រិដ្ឋកម្មជាក់លាក់[5388]។ ទោះជាយ៉ាងណាក្តី ការដឹងនូវឧក្រិដ្ឋកម្មនៅមុន ឬនៅក្រោយការប្រព្រឹត្តអាចមានការជាប់ពាក់ព័ន្ធផងដែរក្នុងការបង្ហាញធាតុផ្សំអត្តនោម័តិក្រោមសហឧក្រិដ្ឋកម្មរួម ជាពិសេស នៅពេលជនជាប់ចោទបានដឹងថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង ហើយពុំបានធ្វើអ្វីដើម្បីបញ្ឈប់នោះ (ឬបានអនុវត្តក្នុងលក្ខណៈគាំទ្រឧក្រិដ្ឋកម្មនោះ) ឬបានបន្តចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមបន្ទាប់ពីបានដឹងនូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងការជម្រុញនោះ។ ទាក់ទងទៅនឹងធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួម វិសាលភាពដែលអង្គជំនុំជម្រះសាលាដំបូងអាចផ្អែកទៅលើការដឹងរបស់ជនជាប់ចោទថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តរួចហើយ ឬនៅពេលអនាគត ដែល

[5383] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៧៩-៤៣០៧។

[5384] សាលក្រមអង្គជមនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៥៤ (សេចក្តីបញ្ជាក់បន្ថែម)។

[5385] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទំព័រ ៦២៧។

[5386] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៤។

[5387] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨០៧។

[5388] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៩-៤២៤៩។

ជាភស្តុតាងមិនផ្ទាល់ក្នុងចំណោមភស្តុតាងដទៃទៀតនោះ ជាចាំបាច់អាស្រ័យទៅលើកាលៈទេសៈនៃរឿងក្តីជាក់លាក់នោះ[5389]។

1901.នេះបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើនិក្ខេបបទកន្លងមកថ្នាក់បណ្ឌិតរបស់ ខៀវ សំផន សម្រាប់ការបង្ហាញអំពីទំនោរចិត្តក្នុងការអនុវត្តន៍នូវវិធានការបង្ខិតបង្ខំដើម្បីឱ្យមានប្រសិទ្ធភាពដល់ការផ្លាស់ប្តូរទៅជាសង្គមកុម្មុយនីស្ត[5390]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើគោលនយោបាយដែលត្រូវបានរៀបចំឡើង សាកល្បង និងអនុវត្តក្នុងតំបន់"រំដោះ" និងត្រូវបានអនុម័តដោយគណៈមជ្ឈិមដែល ខៀវ សំផន គឺជាសមាជិកបម្រុង និងបានបង្ហាញអំពីលំនាំនៃការប្រព្រឹត្តដូចគ្នាដែលត្រូវបានអនុវត្តតាមដោយស្មោះត្រង់ នៅពេលទទួលបានជ័យជម្នះលើកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា វិធីសាស្ត្រនេះប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលបានកើតឡើងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងជាភស្តុតាងបង្ហាញនូវផែនការរួមដែលបានយល់ព្រមដោយសហឧក្រិដ្ឋកម្មរួមដែលបានបន្តរហូតដល់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើការដឹងរបស់គាត់ផងដែរនូវបទឧក្រិដ្ឋទាំងនោះនៅតាមទីតាំងឧក្រិដ្ឋកម្មដែលបានរៀបរាប់នីមួយៗក្នុងបរិបទនៃការអះអាងរបស់គាត់ដែលថា គាត់ពុំបានដឹងថា លក្ខខណ្ឌនៅសហករណ៍ និងការដ្ឋានធ្វើការតម្រូវឱ្យមានការបាត់បង់យ៉ាងដូច្នោះនោះ។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវភស្តុតាងនៃការដឹងរបស់គាត់ចេញពីសំដីផ្ទាល់របស់គាត់នៅក្រោយការដួលរលំរបបខ្មែរក្រហម ដែលបង្ហាញនូវការទទួលស្គាល់របស់ក្នុងកិច្ចសម្ភាសន៍ និងសៀវភៅ រួមទាំងការដែលថា សម្ភូហានិយមដែលបានដាក់ឱ្យប្រជាជនគ្មានសេរីភាពអាចជាកំហុស និងថា បក្សកុម្មុយនីស្តកម្ពុជាបានដំណើរការលឿនពេកដើម្បីឱ្យឈានមុខគេ៣០ឆ្នាំស្តីពីបដិវត្តន៍លើសប្រទេសចិន វៀតណាម និងកូរ៉េខាងជើង។ ក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើការដឹងរបស់ ខៀវ សំផន នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងក្នុងអំឡុងពេលការគ្រប់គ្រងបួនឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យ និងការដឹងរបស់គាត់នៅក្រោយព្រឹត្តិការណ៍ តាមរយៈការទទួលស្គាល់ថាបានដឹងអំពីការបរាជ័យក្នុងអំឡុងពេលនៃការគ្រប់គ្រងនោះ។

1902.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងការសន្និដ្ឋានថា ខៀវ សំផន មានធាតុផ្សំអត្តនោម័តិតម្រូវក្រោមសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់ថា គាត់បានដឹងដោយផ្ទាល់នៅពេលនោះអំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម និងបានរួមចំណែកចេតនាក្នុងការប្រព្រឹត្តជាមួយនឹងសមាជិកសហ

---

[5389] សាលដីការឿងក្តី *Šainović និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១០១៦។

[5390] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៦-៤២០៨។

ឧក្រិដ្ឋកម្មរួមដទៃទៀត។ ជាឧទាហរណ៍ ទាក់ទងទៅនឹងចេតនារបស់គាត់ចំពោះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តតាមសហករណ៍ និងការដ្ឋានធ្វើការ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា*ក្នុងចំណោមនោះ*ថា គាត់"បានដឹងថា ប្រជាជនកំពុងត្រូវបានកែប្រែទៅជាសង្គមកម្មករកសិករមួយដែលកំពុងត្រូវបានបង្ខំឱ្យធ្វើការឥតឈប់ឈរ"[5391] និងថា "ការសាទររបស់គាត់គាំទ្រការអនុវត្តន៍ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាពុំត្រូវបានធ្វើឱ្យធ្លាក់ទឹកចិត្តដោយសារការដឹងនូវលក្ខខណ្ឌការងារ និងរស់នៅដ៏គួរឱ្យរន្ធត់ដែលត្រូវបានដាក់ដោយចេតនានៅតាមសហករណ៍ និងការដ្ឋានធ្វើការទូទាំងប្រទេសឡើយ"[5392]។ ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងមន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ខៀវ សំផន "បានបង្ហាញនូវការដឹងយ៉ាងច្បាស់នូវកាលៈទេសៈនៃការចាប់ខ្លួនមេដឹកនាំដទៃទៀត"[5393] និងថា គាត់"បានគាំទ្រគោលការណ៍សម្ងាត់ ដឹងអំពីការចាប់ខ្លួនដែលរីករាលដាលនៅតាមមូលដ្ឋានដោយផ្អែកលើការពាក់ព័ន្ធពិតប្រាកដ ឬតាមការសន្មតជាមួយខ្មាំង ត្រូវបានជូនដំណឹងដោយផ្ទាល់អំពីការឃុំឃាំងតាមអំពើចិត្ត និងលក្ខខណ្ឌនៃការដាក់ក្នុងមន្ទីរឃុំឃាំងក្នុងខេត្តព្រះវិហារ និងបានប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ដោះលែងសាច់ញាតិគាត់ពីការឃុំឃាំងនោះ"[5394]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ខៀវ សំផន បានដឹងនៅពេលនោះអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យលើជនជាតិចាម[5395] ជនជាតិវៀតណាម[5396] ពុទ្ធសាសនិក[5397] និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[5398] ព្រមទាំងដឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តស្របតាមគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍[5399]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ខៀវ សំផន បានដឹងនូវកិច្ចការនៅពេលនោះតាមរយៈការ

---

[5391] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨១ យោងទៅលើកថាខណ្ឌ ៤២១០។

[5392] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨១ យោងទៅលើកថាខណ្ឌ ៤២១៥, ៤២៣១-៤២៣៤។

[5393] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៤ យោងទៅលើកថាខណ្ឌ ៤២២២, ៤២២៥-៤២២៩, ៤២៣៤, ៤២៥៨, ៤២៧២។

[5394] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៥ យោងទៅលើ ៤២៣១-៤២៣៤។

[5395] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៦។

[5396] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៧-៤២៣៩។

[5397] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤០-៤២៤៣។

[5398] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៤-៤២៤៦ យោងទៅលើកថាខណ្ឌ ៤២៩៩-៤៣០២។

[5399] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៧-៤២៤៩។

ចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងដោយសារគាត់បានរស់នៅ និងធ្វើការជិតស្និទ្ធជាមួយនឹង ប៉ុល ពត នួន ជា សុន សេន អៀង សារី សមាជិកជាច្រើនដទៃទៀតនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម[5400]។

1903.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើអំណះអំណាងរបស់គាត់អំពីកំហុសពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការដឹងនៅពេលនោះ និងចេតនាដែលបានរួមចំណែកក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាមូលដ្ឋាននៃគោលនយោបាយនីមួយៗរបស់បក្សកុម្មុយនីស្តកម្ពុជា។

### គ. សហករណ៍ និងការដ្ឋានធ្វើការ

1904.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងថាលក្ខខណ្ឌដ៏អាក្រក់ត្រូវបានដាក់ដោយចេតនានៅតាមសហករណ៍ និងការដ្ឋានធ្វើការពាសពេញប្រទេសក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5401]។ គាត់បានអះអាងថា ការយល់ឃើញនេះបានផ្អែកលើការបំភ្លៃដោយចេតនារបស់អង្គជំនុំជម្រះសាលាដំបូងនូវសំដីរបស់គាត់ក្នុងបទសម្ភាសន៍ជាមួយ ហេង រស្មី ព្រមទាំងបទសម្ភាសន៍ពីរដទៃទៀតជាមួយអ្នកធ្វើបទសម្ភាសន៍“ដែលពុំស្គាល់ឈ្មោះ និងគ្មានចុះកាលបរិច្ឆេទ” ដែលគាត់បានជំទាស់ថា មានផ្នែកខ្លះជាភស្តុតាងដោះបន្ទុកដែលបង្ហាញថា សំដីរបស់គាត់បានផ្អែកលើព័ត៌មានដែលបានទទួល*ក្រោយ*របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពុំអើពើឡើយ[5402]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើទៅនឹងភស្តុតាងដោះបន្ទុកស្ដីពីការបិទបាំងនូវកង្វះស្បៀងអាហារដោយអ្នកគ្រប់គ្រងសហករណ៍ និងការដ្ឋានធ្វើការ[5403]។

1905.អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា ខៀវ សំផន បានធ្វើការបកស្រាយមួយបែបផ្សេងលើភស្តុតាង។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជាការប្រសើរប្រសិនណាបើអង្គជំនុំជម្រះសាលាដំបូងជាក់ស្ដែងបានបញ្ជាក់ថា គណៈកម្មាធិការសហករណ៍មួយចំនួន និងលេខានោះ ហាក់បីដូចជាបំប៉ោងទិន្នផលស្រូវ និង/ឬបំភ្លៃតម្រូវការស្បៀង ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា

---

[5400] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៨, ៤២១៣-៤២១៤, ៤២១៦, ៤២៨១។

[5401] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨១៦, ២០៤៥ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦, ៤២៨១។

[5402] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨១៦-១៨២៨ យោងទៅលើកិច្ចសម្ភាសន៍របស់ ខៀវ សំផន ជាមួយនឹង ហេង រស្មី គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/587, កិច្ចសម្ភាសន៍របស់ ខៀវ សំផន គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/4050 និងកិច្ចសម្ភាសន៍របស់ ខៀវ សំផន គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/4043។

[5403] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៥០៧-១៥០៩, ២០៤៤។

អង្គជំនុំជម្រះសាលាដំបូងពុំអាចត្រូវបានសន្និតថា ពុំអើពើលើភស្តុតាងជាក់លាក់ណាមួយ ដោយសារតាមធម្មតាពុំបានលើកឡើងនៅក្នុងសាលក្រមរបស់ខ្លួននោះឡើយ[5404]។ ផ្ទុយទៅវិញអង្គជំនុំជម្រះត្រូវបានសន្និតថា បានវាយតម្លៃរាល់ភស្តុតាងទាំងអស់ដែលបានលើកបង្ហាញចំពោះមុខ ដរាបណាមានការបង្ហាញថា អង្គជំនុំជម្រះពុំបានអើពើទាំងស្រុងលើភស្តុតាងជាក់លាក់ណាមួយនោះ[5405]។ ការពុំអើពើនេះត្រូវបានបង្ហាញឱ្យឃើញនៅពេលដែលភស្តុតាងមានការជាប់ពាក់ព័ន្ធច្បាស់លាស់ទៅនឹងការយល់ឃើញ ពុំត្រូវបានដោះស្រាយក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[5406]។

1906.នៅក្នុងរឿងក្តីបច្ចុប្បន្ន ផ្នែកជាក់លាក់ខ្លះនៃបទសម្ភាសន៍ដែល ខៀវ សំផន បានសន្និតថា ជាភស្តុតាងដោះបន្ទុកពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើឡើយ ដោយហេតុថា បទសម្ភាសន៍នោះត្រូវបានពិភាក្សាតាំងពីដំបូង។ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ពិភាក្សារាល់ចំណុចនៃភស្តុតាងនីមួយៗដើម្បីធ្វើសេចក្តីសន្និដ្ឋានឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាយ៉ាងច្បាស់លាស់លើភស្តុតាងរបស់ ខៀវ សំផន ដែលថា គាត់ពុំបានដឹងថា ការសាងសង់នោះបានបណ្តាលឱ្យ"មានការខាតបង់យ៉ាងសម្បើមបែបនេះ"ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ[5407]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនមែនមិនយកចិត្តទុកដាក់ ឬមិនអើពើលើភស្តុតាងដែលបង្ហាញនូវកង្វះការដឹងរបស់គាត់នោះទេ ប៉ុន្តែតាមធម្មតា អង្គជំនុំជម្រះពុំជឿជាក់លើភស្តុតាងនេះ និងបានកំណត់ដោយសមហេតុផលនូវអត្ថិភាពនៃការអះអាងផ្ទុយរបស់គាត់ដើម្បីឱ្យស្របតាមការព្យាយាមដាក់ខ្លួនគាត់ឱ្យឆ្ងាយពីឧក្រិដ្ឋកម្មនោះ[5408]។ នៅគ្រប់កាលៈទេសៈ បើទោះបីជាសារណារបស់គាត់ដែលលើកឡើងថា អ្នកគ្រប់គ្រងមួយចំនួនបានបិទបាំងកង្វះស្បៀង ត្រូវបានទទួលយកក៏ដោយ ក៏ពុំអាចបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើភស្តុតាងជារួម ដែលរួមបញ្ចូលការអះអាងរបស់គាត់ដទៃទៀត[5409]ដែលថា គាត់បានដឹងច្បាស់

---

[5404] សាលដីការឿងក្តី *Stanišić និង Župljanin* (ICTY) កថាខណ្ឌ ៥៣៧ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5405] *សូមមើល* សាលដីការឿងក្តី *Kvočka និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៣ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5406] *សូមមើល* រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Siméon NCHAMIHIGO* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-01-63-A សាលដីកា ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ១៦៦ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5407] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១០។

[5408] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១២។

[5409] *សូមមើល ក្នុងចំណោមនោះ* កិច្ចសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4049 ទំព័រ ១ ("ដើម្បីកសាងប្រទេសឱ្យឆាប់រហ័ស ដំបូងទាល់តែបង្ខំសិនឲ្យចូលសហករណ៍ ឲ្យធ្វើសហករណ៍តាមស្ម័គ្រចិត្តគ្មានអ្នកណាចូលទេ។ ពីព្រោះសហករណ៍កម្រិតខ្ពស់នេះ សូម្បីតែកសិករក្រក៏មិនទទួលដែរ។ ពីព្រោះធ្វើហើយ វាអត់បានផលអីមកខ្លួនឯង វាទៅបើកអង្ករហូបពីគេដដែ

នូវលក្ខខណ្ឌឃោរឃៅនៅតាមសហករណ៍ និងការដ្ឋានធ្វើការ និងបានបន្តអំពាវនាវឱ្យសម្រេចតាមគោលដៅសេដ្ឋកិច្ចដែលពុំអាចកើតមាន និងបំពេញតាមលក្ខខណ្ឌការងារ"ទោះក្នុងតម្លៃណាក៏ដោយ" និងការគ្រប់គ្រងរបស់គាត់លើការនាំចេញស្រូវអង្ករដោយដឹងថា មានប្រជាជនរាប់សែននាក់ត្រូវបានបង្ខំឱ្យធ្វើការ និងប្រមូលផលស្រូវនោះឥតឈប់សម្រាករហូតធ្លាក់ខ្លួនឈឺ អត់អាហារ និងខ្វះថ្នាំពេទ្យ និងបានបណ្តាលឱ្យការស្លាប់ទ្រង់ទ្រាយធំ[5410]។

1907.ខៀវ សំផន បានអះអាងបន្ថែមទៀតថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីការរើសអើងដែលបានប្រព្រឹត្តទៅលើប្រជាជនថ្មីនៅតាមសហករណ៍ និងការដ្ឋានធ្វើការនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នោះ បានផ្អែកយ៉ាងពិសេសទៅលើការបំភ្លៃខ្លឹមសារក្នុងសៀវភៅរបស់គាត់ ដែលក្នុងនោះគាត់បានផ្តល់ការវិភាគអំពីព្រឹត្តិការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ *បន្ទាប់ពី*បានអានអត្ថបទរបស់អ្នកជំនាញមួយចំនួន[5411]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ការយល់

---

ល។ ដូច្នេះទាល់តែបង្ខំសិនអារឿងបង្ខំហ្នឹង ហ្នឹងហើយដែលវានាំឱ្យមានផលប៉ះពាល់ដល់កសិករស្លូតត្រង់ខ្លះដែរក្នុងរឿងហ្នឹង")។ សៀវភៅនិពន្ធដោយ ខៀវ សំផន *ប្រវត្តិកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំបន្តបន្ទាប់* ឯកសារលេខ E3/18 ទំព័រ ៦៨ ("ខ្ញុំមានការភ្ញាក់យ៉ាងខ្លាំងពីការស្មានរបស់ខ្ញុំ គឺនៅពេលដែលខ្ញុំជួបសន្ទនាជាមួយកម្មាភិបាល ប.ក.ក ក្នុងឆ្នាំ ១៩៧៥ ស្រាប់តែគេប្រាប់ខ្ញុំថាមានចាត់តាំង "សហករណ៍កម្រិតខ្ពស់ នៅក្នុងតំបន់រំដោះជាទូទៅតាំងពីឆ្នាំ១៩៧៣។ បើដូច្នេះការចាត់តាំងរបៀបនេះមានតែធ្វើឡើងដោយបង្ខំចិត្ត ពីព្រោះកសិករប្រទេសណាក៏ដោយ មិនងាយសុខចិត្តប្រគល់ភោគផលនៃការខិតខំបែកញើសហូរញើសរបស់ខ្លួនទៅឱ្យអង្គការណាមួយទេ")។ សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប ("នៅគ្រប់ការដ្ឋានសាងសង់អាងស្តុកទឹក ប្រឡាយទឹក ឬទំនប់ទឹកនីមួយៗមានកម្មករធ្វើការប្រហែល ១០.០០០, ១២.០០០, ៣០.០០០ នាក់។ ហេតុដូច្នេះហើយទើបការងារមានការរីកចម្រើនយ៉ាងឆាប់រហ័ស")។ សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប ឯកសារលេខ E3/201 (គាត់បានកត់សម្គាល់ថា គម្រោងនីមួយៗត្រូវប្រើមនុស្សរហូតដល់ ១០.០០០ នាក់ ២០.០០០ នាក់ ឬ ៣០.០០០ នាក់ ដោយគ្មានជំនួយពីគ្រឿងម៉ាស៊ីន ហើយបានជំរុញ "អង្គភាពផលិតកម្មដែលមានការរីកចម្រើនរួចហើយ គួរតស៊ូឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត ដើម្បីបំពេញឱ្យលើសផែនការ អស់ពីសមត្ថភាពពេញលេញបំផុតរបស់ខ្លួន")។ សារអបអរសាទរជ័យជម្នះធ្វើឡើងនាថ្ងៃទី ២១ ខែមេសា របស់ ខៀវ សំផន តាមវិទ្យុ ទីក្រុងភ្នំពេញ (នៅក្នុងកម្រងសារព័ត៌មាន FBIS) ឯកសារលេខ E3/118 ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ERN 00846160-00846162 (សំដៅទៅ"ប្រជាជនទាំងអស់" កសាងទំនប់ ជីកប្រឡាយ និងអាងទឹក បង្កបង្កើនផល ប្រមូលផលស្រែពីរដងក្នុងមួយឆ្នាំ "ធ្វើការទាំងថ្ងៃទាំងយប់ [...] ឥតឈប់សម្រាក")។ ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ (ជនជាប់ចោទ ខៀវ សំផន) ឯកសារលេខ E1/197.1 ទំព័រ ៧០ (ទទួលស្គាល់ថា ស្បៀងជាទូទៅ"ខ្វះ"ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ)។

[5410] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១០-៤២១៥ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5411] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៣៦-១៨៣៨, ២០៤៦, ២០៤៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៧, ៤២៨១។

ឃើញរបស់ខ្លួនអំពីការដឹងរបស់គាត់ និងចេតនាក្នុងការរើសអើងលើប្រជាជនថ្មីនៅតាមសហករណ៍ និងការដ្ឋានធ្វើការ ពុំមែនត្រឹមតែបានផ្អែកលើសៀវភៅរបស់ ខៀវ សំផន ប៉ុណ្ណោះទេ ថែមទាំងបានផ្អែកទៅលើការដឹងរបស់គាត់នៅពេលនោះអំពីគោលនយោបាយដែលបង្ហាញតាមរយៈសក្ខីកម្មរបស់ អែម អឿន ដែលបានបញ្ជាក់អះអាងបន្ថែមថា ខៀវ សំផន បានសង្កត់ធ្ងន់នៅពេលមីទ្ទីងក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យថា ប្រជាជនថ្មីត្រូវតែទទួលបានការចាត់តាំងការងារធ្ងន់ធ្ងរជាង និងអាហារតិចជាង[5412]។

1908.ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងក្នុងការយល់ឃើញថា គាត់បានដឹង"នៅពេលនោះអំពីលក្ខខណ្ឌការរស់នៅក្នុងសហករណ៍ក្នុងខេត្តព្រះវិហារ"[5413] និងបានពន្យល់ថា គាត់បានដឹងអំពីការចាប់ខ្លួន និងលក្ខខណ្ឌនៅខេត្តព្រះវិហារ"ដោយចៃដន្យ" និង"គិតថា ការចាប់ខ្លួននោះគឺជាហេតុការណ៍ដាច់ដោយឡែក"[5414]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការពន្យល់របស់គាត់បានបញ្ជាក់អះអាង ជាជាងបានបដិសេធការដឹងរបស់គាត់នៅពេលនោះអំពីការចាប់ខ្លួន និងលក្ខខណ្ឌនៅខេត្តព្រះវិហារក្នុងឆ្នាំ ១៩៧៨ ដែលបានរួមបញ្ចូលប្រពន្ធរបស់គាត់ប្រាប់គាត់"ទាំងទឹកភ្នែក"ថា "បងប្អូនបង្កើត និងសាច់ញាតិប្រពន្ធគាត់ ត្រូវបានគេចាប់ដាក់ខ្នោះដៃ ខ្នោះជើងអស់រយៈពេលជាងមួយឆ្នាំ ឡើងដំបៅរលេះរលួយជាមួយនឹងប្រជាជនជាច្រើនទៀត"[5415]។ សាជាថ្មីទៀត ខៀវ សំផន បានលើកឡើងថា ព្រឹត្តិការណ៍នៅខេត្តព្រះវិហារពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះ និងថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា គាត់បានដឹងជាទូទៅអំពីលក្ខខណ្ឌនៅតាមសហករណ៍ទាំងអស់ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ[5416]។ បើទោះបីជា ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅសហករណ៍ខេត្តព្រះវិហារ និងពុំអាចត្រូវបាន(ពុំត្រូវបាន)ដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋទាំងនោះក៏ដោយ ក៏ភស្តុតាងដែលបង្ហាញពីការដឹងរបស់គាត់នូវបទឧក្រិដ្ឋ និងលក្ខខណ្ឌនៅទីនោះ ពិតណាស់ជាភស្តុតាងមិនផ្ទាល់ដែលបានផ្តល់នូវធាតុផ្សំដែលតាមរយៈនេះការដឹងអំពីបទឧក្រិដ្ឋ និងលក្ខខណ្ឌប្រហាក់ប្រហែលគ្នានេះនៅសហករណ៍ដទៃទៀត អាចត្រូវបានធ្វើការសន្និដ្ឋានដោយសមហេតុផលដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការពិចារណាថា ការ

[5412] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៦៧។

[5413] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦ យោងទៅលើកថាខណ្ឌ ៤២៣២-៤២៣៤។

[5414] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៣១, ១៨៣២។

[5415] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៣២។

[5416] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨២៩-១៨៣៥។

ដឹងរបស់គាត់អំពីលក្ខខណ្ឌការរស់នៅក្នុងសហករណ៍ខេត្តព្រះវិហារ មានលក្ខណៈ"ស៊ីសង្វាក់"[5417]ជាមួយនឹងសេចក្តីសន្និដ្ឋានដែលថា គាត់បានដឹងអំពីលក្ខខណ្ឌការងារដ៏អាក្រក់នៅតាមសហករណ៍ដទៃទៀត និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

1909.ទាក់ទងទៅនឹងសហករណ៍ និងការដ្ឋានធ្វើការចំនួនបួនដែលស្ថិតក្រោមវិសាលភាពនៃសំណុំរឿង ០០២/០២ ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការចង្អុលបង្ហាញទៅលើភស្តុតាងមួយដែលបង្ហាញថា គាត់បានដឹង ឬមានចេតនាឱ្យឧក្រិដ្ឋកម្មណាមួយត្រូវបានប្រព្រឹត្តឡើងនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា ឬព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[5418]។ ទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានផ្តល់សំអាងផ្លូវច្បាប់គាំទ្រអំណះអំណាងរបស់ខ្លួនដែលថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងគប្បីបានបង្ហាញជាក់ស្តែងតាមការដ្ឋាននីមួយៗ ឬថាតម្រូវឱ្យយោងទៅលើការដ្ឋានជាក់លាក់នោះ[5419]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របឡើយ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបានដោយផ្អែកលើការកំណត់គ្រប់គ្រាន់ថាតើ មានភស្តុតាងអ្វីខ្លះដែលត្រូវបានទទួលយកក្នុងការបង្ហាញនូវធាតុផ្សំទាំងអស់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ[5420]។ ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពីការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅតាមសហករណ៍ទាំងអស់ និងការដ្ឋានធ្វើការទូទាំងប្រទេសក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែលើការដ្ឋានជាក់លាក់ចំនួនបួនប៉ុណ្ណោះ មានដូចជា សហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ ហេតុដូច្នេះ អាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់សំអាងហេតុត្រឹមត្រូវមួយក្នុងការយល់ឃើញថា រាល់ធាតុផ្សំចាំបាច់ទាំងអស់ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅតាមការដ្ឋាននីមួយៗនោះត្រូវបានបំពេញ។

1910.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា ផ្នែកនៃសាលក្រមដែលពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន និងចេតនា បានបង្ហាញនូវកង្វះសំអាងហេតុពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

---

[5417] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦។

[5418] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៣៩-១៨៤៨, ២០៥១, ២០៥២។

[5419] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៩៧, ១២០៧, ១២២១, ១២៣១, ១២៣៤។

[5420] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić ទល់នឹង Čerkez* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14/2-A សាលដីកាថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ ("សាលដីកាវឿងក្តី *Kordić ទល់នឹង Čerkez* (ICTY)") កថាខណ្ឌ ៣៨៥។

ដោយផ្អែកលើសារៈសំខាន់ជាសារវ័ន្តនៃធាតុផ្សំចេតនាក្នុងការបង្ហាញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងជាការបង្ហាញនូវចេតនាតាមលក្ខណៈសន្និដ្ឋាននោះ អង្គជំនុំជម្រះសាលាដំបូងគប្បីបានពន្យល់ការសន្និដ្ឋានរបស់ខ្លួននៅទីនោះដោយមានការប្រុងប្រយ័ត្ន និងជាក់លាក់ចំពោះកន្លែងឧក្រិដ្ឋកម្មនីមួយៗដែលត្រូវបានចោទប្រកាន់នោះ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ក្នុងសាលក្រមថា "សម្រាប់គោលបំណងនៃការវាយតម្លៃលើការដឹងណាមួយពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ អង្គជំនុំជម្រះនឹងត្រូវវាយតម្លៃរាល់ព័ត៌មានចំពោះមុខ រួមទាំងទស្សនកិច្ចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាតាមកន្លែងឧក្រិដ្ឋកម្មជាក់លាក់នោះ"[5421]។ បន្ថែមលើនេះ តាមការពិនិត្យជារួមលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងឃើញថា មានការយល់ឃើញដែលជាប់ពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន និងទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មនៅតាមការដ្ឋានជាក់លាក់នីមួយៗ ដែលតាមរយៈនេះចេតនារបស់គាត់អាចត្រូវបានសន្និដ្ឋានដោយសមហេតុផល។

1911.សហករណ៍ត្រាំកក់ ជាឧទាហរណ៍ ត្រូវបានដឹកនាំដោយលេខាភូមិភាគនិរតី តា ម៉ុក ដែលមានស្រុកកំណើតក្នុងស្រុកត្រាំកក់ និងជាសមាជិកសំខាន់យូរឆ្នាំនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[5422]។ តា ម៉ុក ដែលខ្លួនគាត់ផ្ទាល់ជាអ្នកនាំ ខៀវ សំផន ចូលបក្សកុម្មុយនីស្តកម្ពុជា បានចុះធ្វើទស្សនកិច្ចសហករណ៍ត្រាំកក់ជាប្រចាំ និងបានដឹងច្បាស់អំពីលក្ខខណ្ឌនៅទីនោះ[5423]។ ដូចគេហៅថា "បងទីប្អូន" និង "មនុស្សតែម្នាក់គត់ដែលអាចបង្អាក់ ប៉ុល ពត បាន"[5424] នេះជាការសមហេតុផលទាំងស្រុងសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានថា តា ម៉ុក បានផ្តល់ព័ត៌មានដោយស្មោះត្រង់ និងពេញលេញដល់សមមិត្តប្រធានដទៃទៀតរួមទាំង ខៀវ សំផន ផងនោះនូវព្រឹត្តិការណ៍ និងការវិវឌ្ឍន៍ទាំងអស់នៅសហករណ៍ត្រាំកក់មួយក្នុងចំណោមសហករណ៍ដទៃទៀតដែលស្ថិតក្រោមការទទួលខុសត្រូវរបស់គាត់។ នេះមិនត្រឹមតែធ្វើឡើងតាមលក្ខខណ្ឌនៃការរាយការណ៍ពីភូមិភាគទៅមជ្ឈិមប៉ុណ្ណោះទេ ថែមទាំងដោយសារការទំនាក់ទំនងក្រៅផ្លូវការជាប្រចាំក្នុងមជ្ឈិមបក្សដែល តា ម៉ុក និង ខៀវ សំផន មាននោះ[5425]។ ស្រុកត្រាំកក់ត្រូវបាន

---

[5421] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៦១។

[5422] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩០៤។

[5423] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩០៤, ៩០៥។ កូនស្រីរបស់ តា ម៉ុក ឈ្មោះ ព្រៃក ខុម *ហៅ* យាយ ខុម លេខាស្រុកត្រាំកក់ប្រហាក់ប្រហែលមួយឆ្នាំក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩២០។

[5424] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩០៥។

[5425] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៨២-៤៨៣។

កំណត់ផងដែរថា ជា"ស្រុកគំរូ"ដែលបានទទួលពានរង្វាន់ក្នុងឆ្នាំ ១៩៧៦ ពីគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាថាជាស្រុកដែលបង្កបង្កើនផលបានច្រើនជាងគេបំផុត ធ្វើស្រែពីរដងក្នុងមួយឆ្នាំ បើទោះបីជាមានការលំបាកវេទនា និងគុណភាពដីក្នុងកម្រិតទាបក៏ដោយ[5426]។ នៅមានសហករណ៍គំរូពិសេសក្នុងឃុំលាយបូរនៅស្រុកត្រាំកក់ដែលត្រូវបានបង្ហាញដល់ជនបរទេសមកទស្សនា និងជាចម្បងសម្រាប់ប្រជាជនមូលដ្ឋាន និងត្រូវបានគេស្គាល់ថា ជា ក-១ ចំណែកសហករណ៍ដទៃទៀតដែលហៅថា ក-៣ ពុំត្រូវបានបង្ហាញដល់ជនបរទេស គឺសម្រាប់ប្រជាជនថ្មី[5427]។ អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានដោយសមហេតុផលពីការយល់ឃើញទាំងនេះព្រមទាំងពីតួនាទី និងមុខតំណែងជាសមាជិកគណៈមជ្ឈិម ប្រមុខរដ្ឋ និងតំណាងមុខមាត់ឱ្យរបបនោះជាសាធារណៈទទួលបន្ទុកក្នុងការទទួលគណៈប្រតិភូបរទេស ដែលគាត់បានដឹងដោយបូករួមជាមួយនឹងការស្រុះស្រួលតាម និងបន្តការចូលរួម និងចេតនាចង់ឱ្យមានលក្ខខណ្ឌលំបាកវេទនាដែលនាំឱ្យទទួលបានទិន្នផលខ្ពស់ខុសពីធម្មតាក្នុងស្រុកត្រាំកក់ និងថា ជាពិសេសប្រជាជនថ្មីបានទទួលរងផលប៉ះពាល់អវិជ្ជមានខ្លាំងបំផុត។

1912. ទាក់ទងទៅនឹងទៅនឹងទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញប្រហាក់ប្រហែលគ្នាថា គណៈប្រតិភូបរទេសមួយចំនួន បានមកធ្វើទស្សនកិច្ចទំនប់នេះ ដែលត្រូវបានអមដំណើរដោយមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងថា ទស្សនកិច្ចនេះក្នុងគោលបំណងដើម្បីជូនដំណឹងដល់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអំពីលក្ខខណ្ឌការរស់នៅ និងការងារនៅការដ្ឋានធ្វើការនោះ[5428]។ ក្នុងខែ មេសា ឆ្នាំ ១៩៧៧ ជាឧទាហរណ៍ គណៈប្រតិភូស្ត្រីប្រទេសឡាវបានធ្វើទស្សនកិច្ចនៅទំនប់១មករាជាមួយ អៀង ធីរិទ្ធ[5429]។ ខៀវ សំផន បានទទួលគណៈប្រតិភូប្រទេសឡាវក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៧ ជាមួយនឹង អៀង ធីរិទ្ធ និង អៀង សារី[5430]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "អៀង ធីរិទ្ធ បានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍អំពីលក្ខខណ្ឌនៅការដ្ឋានធ្វើការ និងសហករណ៍ទូទាំងប្រទេស។ បើទោះបីជា នេះទំនងថា អៀង ធីរិទ្ធ បានកត់សម្គាល់លើលក្ខខណ្ឌដែលប្រឈមនៅទំនប់១មករាក៏ដោយ ក៏ពុំមានភស្តុតាងផ្ទាល់បង្ហាញថា អៀង ធីរិទ្ធ បានជូនដំណឹងគណៈអចិន្ត្រៃយ៍អំពីលក្ខខណ្ឌការងារលំបាកនៅទំនប់១មករាជាពិសេសឡើយ។ ទោះជាយ៉ាងណាក្តី ទស្សនកិច្ចដទៃទៀតរបស់ នួន ជា បានផ្តល់ការជូន

---

[5426] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១២៦, ១១២៧។

[5427] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១២៨, ១១២៩។

[5428] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៩១-១៤៩៧។

[5429] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៩២។

[5430] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៩៥។

ដំណឹងនោះទៅគណៈអចិន្ត្រៃយ៍"[5431]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀតថា សម្ពាធក្នុងការបញ្ចប់ទំនប់១មករាតាមការគ្រោងទុក ត្រូវបានបង្ហាញតាមរយៈសុន្ទរកថាថ្លែងដោយ ខៀវ សំផន ក្នុងឆ្នាំ ១៩៧៧ ដែលក្នុងនោះគាត់បានកត់សម្គាល់ថា គម្រោងនីមួយៗ ត្រូវប្រើមនុស្សពី ១០.០០០ ទៅ ៣០.០០០ នាក់ ដោយពុំចាំបាច់មានគ្រឿងចក្រ និងទទួលថា ប្រជាជនគប្បីប្រឹងប្រែងធ្វើការឱ្យខ្លាំងឡើងដើម្បីសម្រេចផែនការបង្កបង្កើនផលឱ្យបានពេញលេញ[5432] ដែលនេះបាននាំទៅរកការដាក់លក្ខខណ្ឌធ្វើការច្រើនម៉ោង និងធ្ងន់ធ្ងរជាងមុនដើម្បីសម្រេចតាមកាលបរិច្ឆេទដែលបានគ្រោងទុកនោះ[5433]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយសមហេតុផលនូវការដឹងរបស់គាត់ និងចេតនាចេញពីអង្គហេតុទាំងនេះ។

1913.ទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះសាលាដំបូងបានធ្វើការយោងជាក់លាក់ទៅលើការសង្កេត "ដោយរំភើបចិត្ត"របស់ ខៀវ សំផន នូវការសាងសង់ទំនប់ក្នុងឆ្នាំ ១៩៧៦ ដែលមានចំនួនអ្នកធ្វើការចន្លោះពី ១០.០០០ ទៅ ២០.០០០ នាក់ ក្នុងការសន្និដ្ឋានថា គាត់បានដឹងក្នុងពេលនោះអំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម[5434]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គាត់បានធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យ និងទំនប់ត្រពាំងថ្ម ជាពិសេសក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5435]។ ក្នុងបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានការ"ភាន់ច្រឡំនូវការដឹងអំពីអត្ថិភាពនៃការដ្ឋានធ្វើការ ជាមួយនឹងការដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅទីនោះ"[5436]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដែលថា គណៈអចិន្ត្រៃយ៍បានធ្វើទស្សនកិច្ចភូមិភាគពាយ័ព្យចាប់តាំងពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៧៥ និងត្រូវបានរាយការណ៍ថា "ប្រជាជនថ្មីកំពុងជួបប្រទះការខ្វះខាតស្បៀងអាហារព្រមទាំងថ្នាំពេទ្យ"[5437]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ខៀវ សំផន ទំនងជាពុំបានចូលរួមនៅក្នុងការធ្វើទស្សនកិច្ចជាក់លាក់នោះ ដោយសារគាត់បានធ្វើដំណើរទៅប្រទេសចិន វៀតណាម និងកូរ៉េខាងជើង នៅពេលនោះ ប៉ុន្តែបានជឿជាក់ថា ផ្អែកតាមតួនាទីជាន់ខ្ពស់ក្នុងបក្ស គាត់បានដឹងអំពីរបាយការណ៍ និងបាន

[5431] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៩៩៥។

[5432] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥១៧ យោងទៅលើសុន្ទរកថារបស់ ខៀវ សំផន នៃការរំឭកខួបថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារលេខ E3/201។

[5433] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៥១៧-១៥១៩។

[5434] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៣។

[5435] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៥៤, ១២៥៩, ១២៦១។

[5436] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៤២។

[5437] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៥៦។

ចូលរួមក្នុងការអភិវឌ្ឍន៍ផែនការ និងគោលនយោបាយដែលបានឆ្លុះបញ្ចាំងនៅទីនោះ[5438]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានបន្ថែមថា គណៈប្រតិភូបរទេសជាច្រើនបានធ្វើទស្សនកិច្ចទំនប់ត្រពាំងថ្ម និងថា ខៀវ សំផន បានចូលរួមក្នុងចំណោមគណៈប្រតិភូនេះ[5439]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ទាក់ទងទៅនឹងទស្សនកិច្ចនេះ "អាជ្ញាធរមូលដ្ឋានបានព្យាយាមបិទបាំងទិដ្ឋភាពមួយចំនួននៃស្ថានការណ៍ជាក់ស្តែងដែលអ្នកធ្វើការបានប្រឈមនៅមូលដ្ឋានផ្ទាល់ ដូចបានពន្យល់ដោយសាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មថា មានតែអ្នកធ្វើការដែលមានសុខភាពល្អប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យឈរនៅជួរជិតនឹងភ្ញៀវ"[5440]។ ទាក់ទងទៅនឹងបញ្ហានេះ ខៀវ សំផន បានអះអាងថា "ការយល់ឃើញសមហេតុផលដែល អង្គជំនុំជម្រះសាលាដំបូងបានបង្កើតនោះ គឺថា [...] ប្រសិនបើគេមានចេតនាលាក់បាំងចំពោះមេដឹកនាំដែលទៅបំពេញទស្សនកិច្ច និង ខៀវ សំផន នូវស្ថានភាពពិតប្រាកដរបស់អ្នកធ្វើការនៅទំនប់ត្រពាំងថ្មហើយ ពួកគាត់ទាំងអស់ពុំអាចដឹងអំពីការពិតនៃលក្ខខណ្ឌរស់នៅ និងការងារនៅការដ្ឋាននោះទេ"[5441]។ ទោះជាយ៉ាងណាក្តី បើទោះបីជាការសន្និដ្ឋាននោះអាចជាប់ពាក់ព័ន្ធទៅនឹងថ្នាក់ដឹកនាំចុះបំពេញទស្សនកិច្ចក៏ដោយ ក៏ពុំអាចពង្រីកឱ្យពាក់ព័ន្ធទៅនឹង ខៀវ សំផន ដែលអាចត្រូវបានចាត់ទុកដោយសមហេតុផលថា បានចូលរួមក្នុងសកម្មភាពក្លែងបន្លំ ជាពិសេសផ្អែកលើការយល់ឃើញដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានគាំទ្រជាសាធារណៈនូវការបំភាន់ធ្វើដូចស្ថានភាពធម្មតាដល់សហគមន៍អន្តរជាតិ[5442]។ ដូច្នេះ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដោយគ្មានការបង្ហាញនូវភាពមិនសមហេតុផលឡើយ។

1914.ចុងក្រោយ ទាក់ទងទៅនឹងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ខៀវ សំផន បានអះអាងថា ករណីជាក់លាក់នីមួយៗនៃទីតាំង ដូចខាងលើ មានដូចទីតាំងយោធា ជាការពុំអាចទៅរួចដែលថា គាត់បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៅទីនោះ ដោយសារគាត់គ្មានសិទ្ធិអំណាចពាក់ព័ន្ធទៅនឹងបញ្ហាយោធា ឬការគ្រប់គ្រងប្រសិទ្ធភាពណាមួយលើយោធា[5443]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សម្រាប់អត្ថិភាពនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ចំនួនបុគ្គលជាច្រើនដែលជនជាប់ចោទបានប្រព្រឹត្តជាមួយក្នុងការជម្រុ

---

[5438] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៤២៨៩។

[5439] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៥៨, ១២៥៩។

[5440] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១២៦០។

[5441] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៤៤។

[5442] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៨, ៤២៤១, ៤២៦៨, ៤២៩៧។

[5443] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៤៧, ១៨៤៨។

ញគោលបំណងរួមល្មើស ពុំចាំបាច់ត្រូវតែបង្កើតឡើងក្នុងរចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលនោះទេ[5444]។ បន្ថែមលើនេះ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ព្រលានយន្តហោះនោះដំបូងឡើយប្រើប្រាស់ក្នុងគោលបំណងជាគម្រោងយោធា ការសាងសង់នោះត្រូវបានចាត់តាំងទៅលើកងពលលេខ ៥០២ (ទ័ពអាកាស) និងបានចាប់ផ្តើមក្នុងដើមឆ្នាំ ១៩៧៦ និងបានយល់ឃើញផងដែរថា នៅពេលមានការបោសសម្អាតភូមិភាគឧត្តរ និងបូព៌ាបានកើតឡើងក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ ការដ្ឋាននេះបានដាក់មនុស្សពេញអ្នកដែលត្រូវបានចាត់ទុកថា ខ្មាំងដោយត្រូវបានដកឋានៈ និងបញ្ជូនទៅធ្វើការដើម្បី“លុតដំ និងកែប្រែខ្លួន”[5445]។ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ត្រូវបានគ្រប់គ្រងដោយមេបញ្ជាការកងពល ៥០២ ស៊ូ ម៉េត ដែលនៅទីក្រុងភ្នំពេញបានចុះជាប្រចាំពិនិត្យការដ្ឋាននោះ[5446]។ ស៊ូ ម៉េត បានចូលរួមទៀងទាត់ក្នុងកិច្ចប្រជុំដែលក្នុងនោះគាត់បានទទួលការណែនាំ និងបានរាយការណ៍ទៅ សុន សេន នាយអគ្គសេនាធិការ អំពីបញ្ហាមួយចំនួនរួមទាំងស្ថានភាពសត្រូវ ការបង្កបង្កើនផល លក្ខខណ្ឌសុខភាព និងការផ្គត់ផ្គង់ស្បៀងក្នុងផ្នែកនៃការទទួលខុសត្រូវរបស់គាត់[5447]។ សុន សេន បានចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងបានរាយការណ៍បន្តអំពីបញ្ហាយោធា និងការការពារជាតិ និងបានបញ្ជូនផងដែរនូវសារជាលាយលក្ខណ៍អក្សរ និងរបាយការណ៍ដែលបានទទួលពីមេបញ្ជាការយោធាទៅមេដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តដោយមានចំណារផ្ទាល់ដៃ និងសំណើសុំការណែនាំ[5448]។ យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលការសាងសង់ព្រលានយន្តហោះយោធាក្នុងខេត្តកំពង់ឆ្នាំងត្រូវបានរៀបចំផែនការក្នុងខែ តុលា ឆ្នាំ ១៩៧៥[5449] និងមានវត្តមានក្នុងកិច្ចប្រជុំក្រោយមកទៀតដែលក្នុងនោះ សុន សេន បានរាយការណ៍អំពីការវិវឌ្ឍន៍នៃការសាងសង់ព្រលានយន្តហោះនោះ[5450]។ របាយការណ៍ស្តីពីស្ថានភាពក្នុងភូមិភាគបស្ចិម ដែលពាក់ព័ន្ធទៅនឹងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ត្រូវបានបញ្ជូនទៅ*អង្គការ*ថ្នាក់លើដោយគណៈភូមិភាគបស្ចិម[5451]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង“ជឿ

---

[5444] *សូមមើល ឧ.* សាលដីការឿងក្តី *Ntakirutimana* និង *Ntakirutimana* (ICTR) កថាខណ្ឌ ៤៦៦ យោងទៅលើសាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ២២៧ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5445] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៣៥, ៣៩២៣។

[5446] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨០, ១៧២៦។

[5447] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៦។

[5448] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥០៨, ១៧២៧។

[5449] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៣, ៤២៥៨ និងជើងទំព័រ ៥៨៥៤។

[5450] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៧, ៤២៥៨។

[5451] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧២៧។

ជាក់ថា គណៈប្រតិភូជាច្រើននៃមេដឹកនាំជាន់ខ្ពស់ បានធ្វើទស្សនកិច្ចការដ្ឋានធ្វើការនោះ”[5452]។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា កត្តាទាំងនេះបូករួមជាមួយនឹងក្នុងចំណោមនោះតួនាទីជាន់ខ្ពស់របស់ ខៀវ សំផន ក្នុងបក្សកុម្មុយនីស្តកម្ពុជា និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ព្រមទាំងការគាំទ្រជាសាធារណៈរបស់គាត់ដល់ការកំណត់អត្តសញ្ញាណ និងបោសសម្អាតខ្មាំង បានផ្តល់មូលដ្ឋានគ្រប់គ្រាន់ដែលតាមរយៈនេះការដឹងរបស់គាត់ និងចេតនាសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំងអាចត្រូវបានសន្និដ្ឋានដោយសមហេតុផល។

1915.អាស្រ័យហេតុនេះ ការលើកឡើងរបស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការដឹង និងចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាក់ទងទៅនឹងសហករណ៍ និងការដ្ឋានធ្វើការ ត្រូវបដិសេធចោល។

### ឃ. មន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការបោសសម្អាត

1916.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបង្ហាញថា គាត់បានដឹង និងមានចេតនាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះនៅតាមមន្ទីរសន្តិសុខជាក់លាក់នីមួយៗដែលជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២[5453]។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង“ពុំដែលលើកឡើង”ថា គាត់បានដឹងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកំពុងត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង ឬភ្នំក្រោល និងថា “ជាលទ្ធផល អង្គជំនុំជម្រះពុំអាចបង្ហាញនូវចេតនាផ្ទាល់ណាមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានលើកឡើងខាងលើ”[5454]។ គាត់បានបន្ថែមថា “ការពិចារណាដែលថាការបោសសម្អាត‘បានផ្សាភ្ជាប់យ៉ាងស្អិតល្មួតជាមួយនឹងគោលនយោបាយបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស’ បានចងកាតព្វកិច្ចអង្គជំនុំជម្រះឱ្យបង្ហាញនូវចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពតាមមន្ទីរសន្តិសុខនីមួយៗនោះ”[5455]។ បន្ថែមលើនេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋាននូវចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មចេញពីការចូលរួមរបស់គាត់ក្នុងគោលបំណងរួម និងគោលនយោបាយស្តីពីសត្រូវ ដោយសារការ

---

[5452] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៧៨៨។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនពុំស្ថិតក្នុងតួនាទីកំណត់ឱ្យជាក់លាក់ថាតើ នរណាគឺផ្នែកនៃគណៈប្រតិភូនោះ។

[5453] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៤៩-១៨៥៦, ២០៥៤-២០៥៧។

[5454] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥២, ១៨៥៤-១៨៥៦។

[5455] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៥៤។

ចូលរួម និងចេតនានេះគឺជាសមាសភាគដាច់ដោយឡែកនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម[5456]។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានបញ្ជាក់សាជាថ្មីថា ខៀវ សំផន បានភាន់ច្រឡំធាតុផ្សំអត្តនោម័តិ ដែលតម្រូវសម្រាប់ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ដែលតាមការអះអាងនោះថា ពុំតម្រូវឱ្យមានការដឹងអំពីហេតុការណ៍នៃឧក្រិដ្ឋកម្មជាក់លាក់នោះទេ[5457]។

1917. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ចេតនាសម្រាប់ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមអាចត្រូវបានសន្និដ្ឋានតាមរយៈការដឹងរបស់ជនជាប់ចោទនូវឧក្រិដ្ឋកម្មរបស់ក្រុមរួមនោះ និងការចូលរួមបន្តរបស់ខ្លួនក្នុងសហឧក្រិដ្ឋកម្មរួមនោះ[5458]។ ដូច្នេះ បើទោះបីជាការដឹងរបស់គាត់ និងការចូលរួមនោះពុំមែនជាសមាសភាគចាំបាច់នៃធាតុផ្សំតម្រូវនៃចេតនាល្មើស ដោយសារពុំមានភស្តុតាងផ្ទាល់ក៏ដោយ ក៏ចេតនានេះអាចត្រូវបានសន្និដ្ឋានចេញពីកត្តានានាផ្អែកលើកាលៈទេសៈដូចជាការដឹងអំពីឧក្រិដ្ឋកម្ម ដែលជាមូលដ្ឋាននៃគោលបំណងរួមដោយបូករួមជាមួយនឹងការបន្តចូលរួមក្នុងគោលបំណងរួមនោះ។ អាស្រ័យហេតុនេះ ខៀវ សំផន បានអះអាងដោយពុំត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងពុំអាចផ្អែកទៅលើការចូលរួមរបស់គាត់ក្នុងគោលបំណងរួម ដើម្បីសន្និដ្ឋានចេតនារបស់គាត់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋដែលជាមូលដ្ឋាននោះឡើយ។ ទោះជាយ៉ាងណាក្តី គាត់បានទទួលស្គាល់ដោយត្រឹមត្រូវថា "ការដឹងអំពីឧក្រិដ្ឋកម្មពុំមែនជាធាតុផ្សំចាំបាច់នៃ[ការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួម]"ឡើយ[5459]។

1918. ខៀវ សំផន បានចង្អុលបង្ហាញដោយសុពលភាពផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុច្បាស់លាស់សម្រាប់ការយល់ឃើញថា គាត់មានចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះតាមរយៈសហឧក្រិដ្ឋកម្មរួមនៅតាមមន្ទីរសន្តិសុខជាក់លាក់នីមួយៗក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ផ្អែកតាមយុត្តិសាស្ត្រដែលសហព្រះរាជអាជ្ញាបានយោងទៅលើក្នុងការអះអាងថា ភាពជាក់លាក់នេះពុំត្រូវបានតម្រូវនោះ បង្ហាញថា សហព្រះរាជអាជ្ញាបានច្រឡំបញ្ចូលគ្នារវាងភាពជាក់លាក់នៃទម្រង់មួយដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង ជាមួយនឹងភាពជាក់លាក់ដែលតម្រូវឱ្យមានការបង្ហាញទីកន្លែងបទឧក្រិដ្ឋ។ ក្នុងរឿងក្តី *Prlić* ជាឧទាហរណ៍ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY "នៅពេលរំឭកសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា

---

[5456] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៦០។

[5457] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១០៩៧, ១១៩៥ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5458] *សូមមើលខាងលើ* កថាខណ្ឌ ១៨៩៣ យោងទៅលើសាលដីការឿងក្តី *Karemera និង Ngirumpatse* (ICTR) កថាខណ្ឌ ៦៣២។

[5459] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥២។

Praljak 'ប្រាកដជាបានដឹង' និងថា 'គាត់យ៉ាងហោចណាស់បានដឹង'ថា លក្ខខណ្ឌនៃការឃុំឃាំងក្នុងពន្ធនាគារ Gabela និង Dretelj មានបញ្ហាយ៉ាងអាក្រក់ និងធ្ងន់ធ្ងរ"នោះ បានសន្និដ្ឋានថា "បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានធ្វើការវិភាគច្បាស់លាស់បន្ថែមទៀតពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាក់លាក់ក៏ដោយ ក៏ពុំឃើញមានកំហុសណាមួយឡើយ"[5460]។ សាលដីកាក្នុងរឿងក្ដី *Prlić* បានយោងទៅលើរឿងក្ដី *Stanišić និង Župljanin* ដែលសហព្រះរាជអាជ្ញាបានផ្អែកទៅលើផងដែរ និង ក្នុងរឿងក្ដីនេះអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានកំណត់ថា "ពុំមានលក្ខខណ្ឌតម្រូវថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានយល់ស្រប តាមទម្រង់ជាក់លាក់មួយដែលតាមរយៈនោះ ការផ្លាស់ទីដោយបង្ខំលើបុគ្គលដែលពុំមែនជាជនជាតិស៊ែប ត្រូវបានធ្វើឱ្យមានប្រសិទ្ធភាព ឬថា ជនជាប់ចោទ Župljanin មានចេតនាចង់ឱ្យ កើតមាននូវអំពើជាក់លាក់នៃការបង្ខិតបង្ខំដែលបង្កការផ្លាស់ទីបុគ្គលទាំងនោះឡើយ ដរាបណាមានការបង្ហាញថា ជនជាប់ចោទ Župljanin មានចេតនាផ្លាស់ទីជនរងគ្រោះដោយបង្ខំ"[5461]។ យុត្តិសាស្ត្រនេះបានកម្រិតច្បាស់លាស់ត្រឹមការពិភាក្សាថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមចាំបាច់ត្រូវមានចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប៉ុណ្ណោះ ដូចបានចោទប្រកាន់ និងរួមបញ្ចូលតាមរយៈគោលបំណងរួមល្មើសដើម្បីដាក់ឱ្យទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម និងពុំចាំបាច់ជាអំពើជាក់លាក់ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋទាំងនោះឡើយ។ ក្នុងយុត្តិសាស្ត្រនេះពុំឃើញមានការលើកឡើងថា ជនជាប់ចោទបានរួមចំណែកចេតនាក្នុងការចូលរួមក្នុងគោលបំណងរួមល្មើស ហើយឧក្រិដ្ឋកម្មដែលត្រូវបានរួមបញ្ចូលនោះពុំចាំបាច់ជាក់លាក់ផងដែរអំពីទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះទេ។

1919.ទាក់ទងទៅនឹងសហករណ៍ និងការដ្ឋានធ្វើការ ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពីការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខ*ទាំងអស់* និងកន្លែងសម្លាប់មនុស្សទូទាំងប្រទេសក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែលើតែទីតាំងជាក់លាក់បួនកន្លែងប៉ុណ្ណោះ ដូចជា មន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ ដូច្នេះអាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងក្នុងការផ្ដល់សំអាងហេតុត្រឹមត្រូវក្នុងការយល់ឃើញថា ធាតុផ្សំចាំបាច់ទាំងអស់ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅទីកន្លែងនីមួយៗនេះត្រូវបានបំពេញ។ ការពិនិត្យលើផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន និងចេតនាបានបង្ហាញនូវកង្វះសំអាងហេតុប្រហាក់ប្រហែលគ្នាទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ នៅពេលបញ្ជាក់សាឡើងវិញនូវសារៈសំខាន់នៃ

[5460] សាលដីការឿងក្ដី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២០៧៥។

[5461] សាលដីការឿងក្ដី *Stanišić និង Župljanin* (ICTY) កថាខណ្ឌ ៩១៧។

ធាតុផ្សំចេតនាល្មើស និងការកំណត់តាមរយៈការធ្វើសេចក្តីសន្និដ្ឋាននោះ និងកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកតួនាទីរបស់ ខៀវ សំផន ត្រូវបានកម្រិតត្រឹមការគ្រប់គ្រងលើមន្ទីរសន្តិសុខក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[5462] អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា នេះអាស្រ័យជាពិសេសលើអង្គជំនុំជម្រះសាលាដំបូងក្នុងការពន្យល់នូវការសន្និដ្ឋានរបស់ខ្លួនអំពីធាតុផ្សំអត្តនោម័តិក្រោមសហឧក្រិដ្ឋកម្មរួម ដោយមានសេចក្តីលម្អិត និងជាក់លាក់អំពីទីតាំងឧក្រិដ្ឋកម្មនីមួយៗដែលត្រូវបានចោទប្រកាន់នោះ។ ទោះជាយ៉ាងណាក្តី ការពិនិត្យជារួមលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានបានដោយសមហេតុផលតាមរយៈការយល់ឃើញដែលថា ខៀវ សំផន មានចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។

1920.មន្ទីរសន្តិសុខក្រាំងតាចាន់មានទីតាំងស្ថិតនៅក្នុងស្រុកត្រាំកក់[5463] ដូច្នេះស្ថិតក្រោមការគ្រប់គ្រងរបស់ តា ម៉ុក លេខាភូមិភាគនិរតី[5464] ដែលមានដើមកំណើតនៅស្រុកត្រាំកក់ ព្រមទាំងជាសមាជិកសំខាន់យូរឆ្នាំនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ និងខ្លួនគាត់ផ្ទាល់បាននាំ ខៀវ សំផន ឱ្យចូលបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ ១៩៦៩[5465]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា តា ម៉ុក បានធ្វើទស្សនកិច្ចនៅក្រាំងតាចាន់"យ៉ាងហោចណាស់ពីរទៅបីដង" និងបានទទួលការជូនដំណឹងអំពីកិច្ចប្រតិបត្តិការនៅទីនោះ[5466]។ ដូច្នេះ ទាក់ទងទៅនឹងសហករណ៍ត្រាំកក់ ដែលបានពិភាក្សាខាងលើ[5467] រួមទាំងលក្ខខណ្ឌនៃការរាយការណ៍ពីភូមិភាគទៅមជ្ឈិមបក្ស និងទំនាក់ក្រៅលក្ខខណ្ឌនោះនៅក្នុងមជ្ឈិមបក្ស អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានដោយសមហេតុផលថា តា ម៉ុក បានជូនដំណឹងដោយស្មោះត្រង់ និងពេញលេញដល់សមមិត្តប្រធានផ្សេងៗទៀត និងសមាជិកនៃសហឧក្រិដ្ឋកម្មរួម រួមទាំង ខៀវ សំផន អំពីព្រឹត្តិការណ៍ និងការវិវឌ្ឍន៍នានា ដូចជាការចាប់ខ្លួន ការសួរយកចម្លើយយ៉ាងឃោរឃៅ និង"ការកម្ទេច" ឬការសម្លាប់អ្នកដែលត្រូវបានសន្មតថា ជាខ្មាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

---

[5462] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩០, ៤២១៩។

[5463] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦៨៣។

[5464] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧០៩។

[5465] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩០៤។

[5466] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧០៨, ២៧០៩។

[5467] *សូមមើលខាងលើ* កថាខណ្ឌ ៥៨៣-៥៨៨។

1921.មន្ទីរសន្តិសុខអូរកន្សែងមានទីតាំងស្ថិតនៅភូមិភាគឦសាន និងត្រូវបានប្រតិបត្តិការដោយកងពលយោធាមជ្ឈិមលេខ ៨០១[5468]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពេញមួយអំឡុងពេលនៃកិច្ចប្រតិបត្តិការរបស់មន្ទីរសន្តិសុខអូរកន្សែងនេះ របាយការណ៍ពាក់ព័ន្ធទៅនឹងការសួរយកចម្លើយអ្នកជាប់ឃុំ និងចម្លើយសារភាពត្រូវបានបញ្ជូនផ្ទាល់ទៅ សៅ សារឿន មេបញ្ជាការកងពលលេខ ៨០១ ដែលរាយការណ៍បន្តទៅ សុន សេន នៅទីបញ្ជាការអគ្គសេនាធិការក្នុងក្រុងភ្នំពេញដែលបានបញ្ជូនរបាយការណ៍នេះទៅគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[5469]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សុន សេន ត្រូវបានជូនដំណឹងអំពីស្ថានការណ៍ក្នុងកងពលលេខ ៨០១ រួមទាំងការសួរយកចម្លើយអ្នកជាប់ឃុំក្នុងមន្ទីរសន្តិសុខអូរកន្សែង និងថា ក្នុងនាមជានាយអគ្គសេនាធិការ សុន សេន មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខអូរកន្សែងទាំងមូល និងជាទៀងទាត់បានបញ្ជូនព័ត៌មានទៅ*អង្គការ*មុនពេលផ្តល់ការណែនាំដល់ថ្នាក់ក្រោម រួមទាំងមន្ទីរសន្តិសុខអូរកន្សែងផងនោះ[5470]។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ផងដែរថា គណៈភូមិភាគឦសានបានរាយការណ៍អំពីការវិវឌ្ឍន៍នៃការបោសសម្អាតផ្ទៃក្នុងទូទាំងភូមិភាគ និងក្នុងកងពលលេខ ៨០១ ដោយផ្ទាល់ទៅមជ្ឈិមបក្ស[5471]។ ដូច្នេះ ដូចគ្នាទៅនឹងព្រលានយន្តហោះខេត្តកំពង់ឆ្នាំងដែលបានពិភាក្សាខាងលើ អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានបានដោយសមហេតុផលនូវការដឹងរបស់គាត់ និងចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខអូរកន្សែងដោយផ្អែក*ក្នុងចំណោមនោះ*លើតួនាទីជាន់ខ្ពស់របស់ ខៀវ សំផន និងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ព្រមទាំងការគាំទ្ររបស់គាត់ជាសាធារណៈដល់ការស្វែងរកអត្តសញ្ញាណ និងការបោសសម្អាតខ្មាំង។

1922.មន្ទីរសន្តិសុខភ្នំក្រោលមានទីតាំងស្ថិតនៅក្នុងតំបន់ ១០៥ ខេត្តមណ្ឌលគីរី ពីដើមឡើយស្ថិតក្រោមក្របខ័ណ្ឌផ្នែករដ្ឋបាលរបស់ភូមិភាគឦសាន និងដល់ចុងឆ្នាំ ១៩៧៦ បានក្លាយជាតំបន់ស្វយ័ត[5472]។ លេខាតំបន់ ១០៥ បានរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្សនៅមន្ទីរ ៨៧០ ផ្អែកតាមលក្ខខណ្ឌនៃការប្រតិបត្តិការតំបន់ អំពីលក្ខខណ្ឌកសិកម្ម ការបង្កបង្កើនផល និងស្ថានភាពខ្មាំង និងបានស្នើសុំការផ្គត់ផ្គង់បន្ថែម និងការណែនាំស្តីពីការប្រព្រឹត្តទៅលើទាហានវៀតណាមដែលចាប់បាន និងបន្ទាប់មកបានទទួលការណែនាំត្រឡប់មកវិញពី

---

[5468] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៣, ២៨៦៦, ២៨៦៧។

[5469] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៨៣, ២៨៦៩-២៨៧៥។

[5470] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៧៥។

[5471] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៨៤។

[5472] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០២៥, ៣០៣៤។

មជ្ឈិមបក្សដែលរួមមាន ប៉ុល ពត និង នួន ជា[5473]។ លេខាតំបន់ ១០៥ បានបញ្ជូនរបាយការណ៍ទៅឱ្យ ខៀវ សំផន ស្ដីពីបញ្ហាដែលពុំជាប់ពាក់ព័ន្ធនឹងសន្តិសុខ មានដូចជា សង្គមកិច្ច និងសម្ភារៈបរិក្ខាពេទ្យ ហើយបានទទួលការឆ្លើយតបពី ខៀវ សំផន[5474]។ បន្ថែមលើការអនុវត្តន៍តាមខ្សែរយៈទំនាក់ទំនងជាលាយលក្ខណ៍អក្សរជាមួយមជ្ឈិមបក្ស លេខាតំបន់ ១០៥ បានធ្វើដំណើរផងដែរទៅភ្នំពេញដើម្បីរាយការណ៍ដោយផ្ទាល់ និងបានចូលរួមកិច្ចប្រជុំ និងមហាសន្និបាតបក្សសំខាន់ៗទៀត និងបន្ទាប់មកបានកោះប្រជុំជាមួយកម្មាភិបាលកងពល និងតំបន់ក្រោយពេលត្រឡប់មកភ្នំក្រោលវិញដើម្បីបើកវគ្គបណ្ដុះបណ្ដាលរៀនសូត្រ និងផ្សព្វផ្សាយសេចក្ដីណែនាំរបស់មជ្ឈិមបក្សស្ដីពីស្ថានភាពខ្មាំង[5475]។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការចាប់ខ្លួន និងការឃុំឃាំងបុគ្គលដែលជាប់ពាក់ព័ន្ធជាមួយនឹងខ្មាំងតាមការសន្មតក្នុងតំបន់ ១០៥ ជាពិសេស នៅមន្ទីរសន្តិសុខភ្នំក្រោល ត្រូវបានធ្វើឡើងក្នុងដំណើរការជាប្រព័ន្ធស្របតាមគោលដៅនៃការរារាំងការចូលដៃជាមួយវៀតណាម[5476]។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់បន្ថែមទៀតថា បទបញ្ជាចាប់ខ្លួន ឃុំខ្លួន និងសម្លាប់កម្មាភិបាលតំបន់ ១០៥ ត្រូវបានធ្វើឡើងក្រោមសិទ្ធិអំណាច និងការគ្រប់គ្រងរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[5477] បទបញ្ជាដែលលេខាតំបន់ ១០៥ បន្ទាប់មកត្រូវបានតម្រូវឱ្យអនុវត្ត[5478] និងថា ការធ្វើឱ្យបាត់ខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោលត្រូវបានអនុវត្តដោយអាជ្ញាធរមូលដ្ឋានកម្ពុជាប្រជាធិបតេយ្យ ឬដោយមានការអនុញ្ញាត គាំទ្រ ឬការយល់ព្រមរបស់បក្សកុម្មុយនីស្តកម្ពុជា[5479]។ កត្តាទាំងនេះបូករួម *ក្នុងចំណោមនោះ* ជាមួយនឹងតួនាទីចម្បងរបស់ ខៀវ សំផន ក្នុងបក្ស គណៈអចិន្ត្រៃយ៍ និងមជ្ឈិម និងមន្ទីរ ៨៧០ ព្រមទាំងការបណ្ដុះបណ្ដាល និងបទឧទ្ទេសនាជម្រុញឱ្យមានការប្រុងប្រយ័ត្ននឹងខ្មាំងដូចជា ជនជាតិវៀតណាម បានផ្ដល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានដោយសមហេតុផលថា គាត់បានដឹង និងមានចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល។

1923.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា មន្ទីរស-២១ ត្រូវបានប្រើប្រាស់ជា"ឧបករណ៍ផ្ដាច់ការ"របស់បក្សកុម្មុយនីស្តកម្ពុជា និងមជ្ឈិមបក្ស ព្រមទាំងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ដែលមានអាណត្តិពិសេស

---

[5473] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៣៥, ៣០៣៦, ៣០៤០។

[5474] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៣៧, ៣០៤០។

[5475] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៣៨, ៣០៤០។

[5476] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៦៥។

[5477] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣០៨០។

[5478] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១០៨។

[5479] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣១៦២។

សម្រាប់ការឃុំខ្លួន ការសួរចម្លើយ ការយកចម្លើយសារភាព និង"ការកម្ទេច"អ្នកជាប់ឃុំដែលត្រូវបានសង្ស័យថា ជាខ្មាំង និងត្រូវបានចាប់ខ្លួនមកពីទូទាំងប្រទេសកម្ពុជា[5480]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មន្ទីរស-២១ ត្រូវបានគាំទ្រផ្នែកសម្ភារៈដោយសេនាធិការ ប៉ុន្តែត្រូវបានភ្ជាប់ទៅនឹង និងគ្រប់គ្រងផ្ទាល់ដោយគណៈអចិន្ត្រៃយ៍ និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ជាទម្លាប់តាមរយៈបទបញ្ជា និងរបាយការណ៍ពី សុន សេន អគ្គសេនាធិការ និង នួន ជា[5481]។ សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់លើ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ប្រធានមន្ទីរស-២១ រហូតដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៧ នៅពេលដែល នួន ជា បានកាន់កាប់ និងគ្រប់គ្រងផ្ទាល់លើ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច[5482]។ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច បានផ្តល់សក្ខីកម្មថា គណៈមជ្ឈិមបានធ្វើសេចក្តីសម្រេចចាប់ខ្លួន[5483] និងគោលនយោបាយទូទៅគឺថា នៅពេលមេគ្រួសារត្រូវបានចាត់ទុកជាជនក្បត់ ប្តីប្រពន្ធ និងកូនត្រូវបានសម្លាប់ចោលផងដែរ[5484] ដោយសារការភ័យខ្លាចរបស់បក្សថា កូននឹងធ្វើការសងសឹក[5485]។ អ្នកជាប់ឃុំខ្លះបានអង្វរ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឱ្យសុំបក្សលើកលែងទោសពួកគេ មានដូចជា ហួត សម្បត្តិ ដែលបានសរសេរលិខិតទៅ ខៀវ សំផន នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៧៦ សារភាពកំហុស សម្តែងការសោកស្តាយ និងស្នើសុំឱ្យ"អង្គការមេត្តាអនុគ្រោះដល់ខ្ញុំបាទផង សូមទុកជីវិតដល់ខ្ញុំបាទផង" ឬស្នើសុំថា ប្រសិនបើមិនអាចអនុគ្រោះឱ្យគាត់ទេ សុំរក្សាប្រពន្ធកូនគាត់ផង[5486]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ភស្តុតាងនេះ ក្នុងចំណោមដទៃទៀត"បានបង្ហាញនូវតួនាទីសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការផ្សព្វផ្សាយគោលនយោបាយ និងបំពាក់បំប៉នមនោគមវិជ្ជារួមមួយណែនាំកិច្ចការរបស់កម្មាភិបាលនៅមន្ទីរស-២១ [...] ដែលត្រូវបានផ្តល់ភារកិច្ចក្នុងការសួរចម្លើយអ្នកដែលត្រូវបានចាត់ទុកថា ជាខ្មាំង និងយកចម្លើយសារភាពសម្រាប់បក្ស"[5487]។ ការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីយកចម្លើយសារភាព ដែលបន្ទាប់មកត្រូវបានដាក់ជូនទៅថ្នាក់លើសម្រាប់ការសម្រេច

---

[5480] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៨៣, ២១៨៤, ២២៣៦, ២២៣៧, ២៣៥០, ២៣៧២។

[5481] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០, ២១៩១។

[5482] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៩៣។

[5483] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៨៣។

[5484] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៣១។

[5485] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៣០។

[5486] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៧៩។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនពុំអាចកំណត់ថាតើ លិខិតនេះត្រូវបានបញ្ជូនទៅ ឬទទួលដោយ ខៀវ សំផន។

[5487] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២១៨០។

និងចំណាត់ការ[5488]។ ចម្លើយសារភាព រូបថត និងខ្សែវីដេអូនៃឈ្លើយសឹកជនជាតិវៀតណាម ជាក្រុមដែលធំជាងគេបំផុតនៃអ្នកជាប់ឃុំនៅមន្ទីរស-២១ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងឃោសនា និងអប់រំ ដែលតាមការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងថា នេះពុំអាចគេចផុតពីការចាប់អារម្មណ៍របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចជា ខៀវ សំផន ដែលមានវត្តមាននៅវគ្គរៀនសូត្រនយោបាយជាច្រើន និងដោយផ្ទាល់បានធ្វើបទឧទ្ទេសនាមស្តីពីការប្រុងប្រយ័ត្នលើខ្មាំងជនជាតិវៀតណាម[5489]។ កត្តាទាំងនេះបូករួម*ក្នុងចំណោមនោះ*ជាមួយនឹងតួនាទីចម្បងរបស់ ខៀវ សំផន ក្នុងបក្ស និងតួនាទីពិសេសក្នុងក្រុមតូចនៃសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលបានទទួលការជូនដំណឹងច្បាស់លាស់ ព្រមទាំងការចូលរួមរបស់គាត់ជាប្រចាំ និងវត្តមានក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍[5490]បានផ្តល់មូលដ្ឋានគ្រប់គ្រាន់ និងជឿទុកចិត្តបានសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានសមហេតុផលថា គាត់បានដឹង និងមានចេតនាចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខស-២១។

1924. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លំហូរចេញចូលនៃអ្នកជាប់ឃុំនៅមន្ទីរស-២១ បានឆ្លុះបញ្ចាំងនូវការបោសសម្អាតផ្ទៃក្នុងជាច្រើននៃបក្សកុម្មុយនីស្តកម្ពុជា និងថា ការបោសសម្អាតនេះបានបង្កឱ្យមានការបញ្ជូនអ្នកជាប់ឃុំក្នុងចំនួនយ៉ាងច្រើន និងការចាប់ខ្លួនបន្ថែមទៀតនៃកម្មាភិបាលក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5491]។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា ខៀវ សំផន បានដឹងអំពីការចាប់ខ្លួន និងការស្លាប់អតីតកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ដែលរួមមាន*ក្នុងចំណោមនោះ* សឿ វ៉ាស៊ី (“ឌឿន”), ចាន់ ចក្រី, សួស នៅ (“ឈូក”), កុយ ធួន, កែវ មាស, ហ៊ូ នឹម, ជូ ជេត (“ស៊ី”), វន វ៉េត, សោ ភឹម និង វឹង ឆែម (“ភួង”) ព្រមទាំងការបោសសម្អាតកម្មាភិបាលថ្នាក់ទាបដែលរីករាលដាល និងការសម្លាប់ប្រជាជនក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ[5492]។ ទាក់ទងនឹងបញ្ហានេះ ខៀវ សំផន បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើសំដីរបស់គាត់ក្រោយកម្ពុជាប្រជាធិបតេយ្យ ក្នុងការបង្ហាញថា គាត់បានដឹងអំពីការចាប់ខ្លួន និងការស្លាប់កម្មាភិបាលជាន់ខ្ពស់[5493] ព្រមទាំងលើភស្តុតាង

---

[5488] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៣៧២-២៤៣១។

[5489] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣៨, ៣៤០, ២៤៦២, ២៤៧២-២៤៧៧, ២៥៥៦, ២៦០៧, ៣៣៩០, ៣៣៩៣, ៣៣៩៤, ៣៣៩៩-៣៤០១, ៣៤០៦។

[5490] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៤០។

[5491] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២២៥៥។

[5492] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៤២២០-៤២៣៥។

[5493] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៧-១៨៧៣, ២០៥៣, ២០៥៥-២០៥៧។

នៃព្រឹត្តិការណ៍នៅខេត្តព្រះវិហារក្នុងការសន្និដ្ឋានការដឹងរបស់គាត់អំពីការបោសសម្អាតកម្មាភិបាលថ្នាក់ទាបទូទាំងប្រទេស[5494]។

1925.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើការដឹងក្រោយនៅព្រឹត្តិការណ៍នៅពេលកំណត់ថាតើ ជនជាប់ចោទមានចេតនាតម្រូវក្នុងពេលនៃការប្រព្រឹត្តនោះ ដែរ ឬយ៉ាងណា[5495]។ ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដែល ខៀវ សំផន បានលើកបង្ហាញនូវបណ្តឹងសាទុក្ខទាក់ទងទៅនឹងការអះអាងរបស់គាត់អំពីការមិនអើពើទៅលើការចាប់ខ្លួនក្នុងពេលនៃព្រឹត្តិការណ៍នោះ និងបានយល់ឃើញថា ពុំគួរឱ្យជឿជាក់បានឡើយ[5496]។ ជាឧទាហរណ៍ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃសំដីរបស់គាត់ដែលបានលើកឡើងក្នុងឆ្នាំ ២០០៧ ថា គាត់ "បានសង្កេតឃើញថា សមាជិកខ្លះនៃគណៈមជ្ឈិមបានបាត់ខ្លួនម្តងមួយៗ"[5497]ក្នុងការយល់ឃើញថា គាត់បានទទួលស្គាល់ "ថាបានឃើញ"[5498]ការចាប់ខ្លួន និងបានអះអាងថា "មានភាពខុសប្លែកគ្នាច្បាស់លាស់រវាងការដែលលែងបានឃើញបុគ្គលនោះតទៅទៀត ជាមួយនឹងការដែលបានឃើញការចាប់ខ្លួនពួកគេ"[5499]។ ទោះជាយ៉ាងណាក្តី សេចក្តីដកស្រង់ចេញពីសៀវភៅផ្ទាល់ខ្លួនរបស់គាត់បង្ហាញថា ខៀវ សំផន បានប្រើប្រាស់ពាក្យពេចន៍នៃ"ការបាត់ខ្លួន" និង"ការចាប់ខ្លួន"ជំនួសគ្នាដែលទំនងជាថា ពាក្យនេះមានអត្ថន័យស្មើគ្នា៖ "ក្រោយពេលមានការចាប់ចងសមាជិកគណៈមជ្ឈឹមណាមួយ [...] ជំនឿរបស់គណៈថ្នាក់ដឹកនាំលើ ប៉ុល ពត ហាក់ដូចជាមិនរង្គោះរង្គើទេ។ ការបាត់មុខអ្នកទាំងអស់នោះម្តងមួយៗហាក់ដូចជាត្រូវបានសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត ដែលគេដឹងរឿងចាត់ទុកជាករណីដាច់ពីគ្នា ហើយជាវិធានការត្រឹមត្រូវ"[5500]។ ប្រហាក់ប្រហែលគ្នានេះដែរ គាត់បានចោទប្រកាន់អំពីការបកស្រាយពុំត្រឹមត្រូវក្នុងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានទទួលស្គាល់ថា "គណៈមជ្ឈិម'មិនដល់ពាក់កណ្តាល'ត្រូវបានកម្ចាត់

---

[5494] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៤-១៨៧៨, ២០៥៨, ២០៥៩។

[5495] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៨២។

[5496] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២០។

[5497] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៨ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ សំផន ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ E3/210 ទំព័រ ២-៣ ERN 00156689-00156690 (សេចក្តីបញ្ជាក់ដើម)។

[5498] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២០។

[5499] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៩។

[5500] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២៣ យោងទៅលើសៀវភៅនិពន្ធដោយ ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារលេខ E3/18 ទំព័រ ៦៣, ៦៤។

ចោលក្នុងការបោសសម្អាត រួមជាមួយនឹង'ជិតពាក់កណ្ដាលនៃគណៈអចិន្ត្រៃយ៍'"[5501] និងបានអះអាងថា "តួលេខសមាជិកទាំងនោះត្រូវគ្នាទៅនឹង'ភ្នាក់ងារវៀតណាម'ដែលបង្កប់នៅក្នុងជួរគណៈទាំងពីរនោះ"[5502] ។ អំណះអំណាងនេះមិនត្រឹមតែជាការបកស្រាយមួយបែបផ្សេងទៅលើការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះទេ ថែមទាំងបានគាំទ្របន្ថែមដល់ការយល់ឃើញដែលថា គាត់បានដឹងអំពីការចាប់ខ្លួន និងការសម្លាប់នោះ ដោយពុំគិតថា ជនរងគ្រោះនោះត្រូវបានចាត់ទុកជាភ្នាក់ងារវៀតណាម ជនក្បត់ ឬអ្វីផ្សេងនោះទេ។ ការអះអាងអំពីការបំភ្លៃ ព្រមទាំងការចោទប្រកាន់កំហុសជាទូទៅដែលពុំសមហេតុផលថា កិច្ចសម្ភាសន៍ដែលបានធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ពុំអាចគាំទ្រការយល់ឃើញអំពីការដឹងរបស់គាត់ក្នុងពេលនៃព្រឹត្តិការណ៍នោះ ជាការលើកពុំត្រឹមត្រូវ និងត្រូវបដិសេធចោល។

1926.ខៀវ សំផន បានលើកឡើងនូវកំហុសជាក់លាក់មួយចំនួនក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការដឹងរបស់គាត់អំពីការចាប់ខ្លួន និងការសម្លាប់ សឿ វ៉ាស៊ី ("ឌឿន"), ចាន់ ចក្រី, ស៊ូ នៅ ("ឈូក"), កុយ ធួន, កែវ មាស, ហ៊ូ នឹម, ជូ ជេត ("ស៊ី") វន វ៉េត, សោ ភឹម និង វ៉ឹង ផែម ("ភួង")។ ការចោទប្រកាន់កំហុសនេះភាគច្រើនផ្អែកលើអំណះអំណាងនានា ដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខ។ ជាឧទាហរណ៍ ក្នុងការចាប់ខ្លួន ឌឿន និងការសម្លាប់ក្រោយមកនោះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសន្និដ្ឋានការដឹងរបស់គាត់ចេញពី"ទំនាក់ទំនងជិតស្និទ្ធ និងការដែលនៅកៀកជាមួយ ប៉ុល ពត និង នួន ជា"[5503] និងថា "គ្មានអ្វីអាចធ្វើឱ្យមានការយល់ឃើញថា គាត់បានកាន់កាប់មុខតំណែងគ្រប់គ្រងក្នុងគណៈកម្មាធិការពាណិជ្ជកម្មបន្ទាប់ពីការបោសសម្អាតកម្មាភិបាលនៃក្រសួងនេះឡើយ"[5504]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបានបដិសេធរួចរាល់ការចោទប្រកាន់ទាំងនេះខាងលើ[5505]។ ទាក់ទងទៅនឹងការកំណត់អំពីការដឹងនូវវាសនារបស់ ចាន់ ចក្រី, ឈូក, កុយ ធួន, និង កែវ មាស ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីផ្អែកលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ដោយសារកង្វះនៃភាពអាចជឿជាក់បាន[5506] និងពុំគួរបានផ្អែកលើខ្លឹមសារនៃទស្ស

---

[5501] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦០ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២២។

[5502] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦០។

[5503] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦២ យោងទៅលើកថាខណ្ឌ ១៦៨៤-១៦៨៦។

[5504] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦៣ យោងទៅលើកថាខណ្ឌ ១៧៧០-១៧៩៨។

[5505] *សូមមើលខាងលើ* ផ្នែក VIII.ក.៤.ខ និង VIII.ក.៤.ក.i។

[5506] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦៤ យោងទៅលើកថាខណ្ឌ ១៦៩០-១៨០៣។

នាវដ្ដីទង់បដិវត្ត ដែលបានថ្កោលទោសជាសាធារណៈលើ ចាន់ ចក្រី, ឈូក និង កែវ មាស ដោយសារពុំមានការបង្ហាញថា គាត់បានទទួល និងបានអានទស្សនាវដ្ដីនោះ[5507]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចរាល់ហើយ និងបានបដិសេធអំណះអំណាងទាំងនេះ[5508]។ ការជំទាស់របស់គាត់ទៅនឹងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីការចាប់ខ្លួន ហ៊ូ នឹម និងការសម្លាប់នៅពេលនោះ បានយោងប្រហាក់ប្រហែលគ្នាដែរទៅលើអំណះអំណាងដែលបានលើកឡើងពីមុនរួចហើយស្ដីពីកង្វះភាពអាចជឿជាក់បានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប[5509] ដែលត្រូវបានបដិសេធរួចខាងលើ[5510]។ ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹង ហ៊ូ នឹម, ស៊ី, វន វ៉េត, សោ ភឹម និង ភួង គាត់បានលើកឡើងសាជាថ្មីបន្ថែមទៀតនូវការចោទប្រកាន់ដែលពុំត្រឹមត្រូវអំពីការបំភ្លៃភស្តុតាង ឬកំហុសក្នុងការផ្អែកទៅលើសំដីរបស់គាត់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងការធ្វើសេចក្ដីសន្និដ្ឋានអំពីការដឹងរបស់គាត់នៅពេលនោះ[5511]។

1927.នៅគ្រប់កាលៈទេសៈទាំងអស់ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ និងដាក់ពិរុទ្ធភាពពីអំពើនៃការចាប់ខ្លួន ឬសម្លាប់បុគ្គលជាក់លាក់ទាំងនោះ ដែលតំណាងឱ្យការបោសសម្អាតកម្មាភិបាលដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា គាត់បានដឹងអំពីរឿងនេះ និងនាំឱ្យអង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានបានថា គាត់បានរួមចំណែកចេតនាចង់ឱ្យមានការបោសសម្អាតនោះកើតឡើង។ ដូច្នេះ បើទោះបីជាមានកំហុសនៅក្នុងការយល់ឃើញដែលថា គាត់បានដឹងអំពីការបោសសម្អាតមួយ ឬច្រើន ឬទាំងអស់នៃកម្មាភិបាលជាន់ខ្ពស់ជាក់លាក់ទាំងនោះក៏ដោយ ក៏កំហុសនេះពុំអាចបដិសេធសេចក្ដីសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបោសសម្អាតកម្រិតខ្ពស់នោះបានកើតឡើងជារឿយៗ និងថា ខៀវ សំផន មានចេតនារួមចំណែកក្នុងនោះដែរ។ ទាក់ទងទៅនឹងការដឹងរបស់គាត់អំពីការបោសសម្អាតថ្នាក់ទាប ការចោទប្រកាន់របស់ ខៀវ សំផន អំពីការបំភ្លៃ និងការសំអាងពុំត្រឹមត្រូវលើភស្តុតាងក្រៅវិសាលភាពនៃព្រឹត្តិការណ៍នៅខេត្តព្រះវិហារ ត្រូវបានពិភាក្សា និងបដិសេធចោលទាក់ទងទៅនឹង

---

[5507] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦៥ យោងទៅលើកថាខណ្ឌ ១៦៤១-១៦៤៣។

[5508] ទាក់ទងទៅនឹងភាពគួរឱ្យជឿជាក់បានរបស់ អែម អឿន *សូមមើលខាងលើ* កថាខណ្ឌ ១៧៥១-១៧៥៥។ ទាក់ទងទៅនឹងការពិនិត្យទស្សនាវដ្ដីទង់បដិវត្ត *សូមមើលខាងលើ* កថាខណ្ឌ ១៨៩៦។

[5509] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦៦ យោងទៅលើកថាខណ្ឌ ១២៣៣-១២៤២។

[5510] *សូមមើលខាងលើ* កថាខណ្ឌ ១៤១៩-១៤២៣។

[5511] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៦៦-១៨៧៣។

ផ្នែកស្តីពីសហករណ៍ និងការដ្ឋានធ្វើការខាងលើ[5512]។ គាត់បានអះអាងដោយពុំត្រឹមត្រូវផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានការដឹងនេះចេញពី"ព្រឹត្តិការណ៍តែមួយ"[5513] ដោយបានអនុវត្តវិធិសាស្ត្រជ្រើសរើសបំណែកដែលចង់បាននូវភស្តុតាងក្នុងកំណត់ត្រា ដែលបានរួមបញ្ចូលការលើកឡើងផ្ទាល់ខ្លួនគាត់អំពីការដឹងនូវការបោសសម្អាតដែលរីករាលនោះ[5514]។

1928.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន ស្តីពីកំហុសទាក់ទងទៅនឹងការដឹងរបស់គាត់ និងចេតនាក្នុងការប្រព្រឹត្តពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ទីតាំងសម្លាប់ និងការបោសសម្អាតត្រូវបដិសេធចោល។

### ង. ក្រុមជាក់លាក់

1929.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹង និងមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាម[5515] ជនជាតិវៀតណាម[5516] ពុទ្ធសាសនិក[5517] និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[5518]។ ការជំទាស់ជារួមដែលគាត់បានលើកឡើងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់ និងចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើក្រុមទាំងអស់នោះ គឺថា អង្គជំនុំជម្រះសាលាដំបូងពុំអាចផ្អែកទៅលើការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមដើម្បីបង្ហាញចេតនារបស់គាត់នោះឡើយ[5519] ដោយសារ"នេះគឺជាធាតុផ្សំដាច់ដោយឡែកនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[5520]។ អង្គជំនុំជម្រះតុលា

[5512] *សូមមើលខាងលើ* កថាខណ្ឌ ១៩០៨។

[5513] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៤។

[5514] *សូមមើល ជាឧទាហរណ៍* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២២១ យោងទៅលើបទសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/203 ("នេះជាការវាយយើងខ្ញុំពីខាងក្នុង ជាការប៉ុនប៉ងវាយយើងខ្ញុំពីខាងក្នុង ប៉ុន្តែបញ្ហានេះក៏យើងខ្ញុំបានប្រយុទ្ធ ហើយប្រយុទ្ធយកឈ្នះ ហើយប្រយុទ្ធជាប់ ហើយដល់ឆ្នាំ៧៧-៧៨ យើងខ្ញុំដោះស្រាយពួកនេះបានជាមូលដ្ឋាន រៀបរយសភាពការណ៍នៅក្នុងប្រទេស ឲ្យប្រជាជនយើងពេញចិត្តពេញថ្លើម") និង ៤២៣១ យោងទៅលើកិច្ចសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4041 ERN 00782543-00782544 ("អ្នកដែលទទួលខុសត្រូវតាមមូលដ្ឋានវាសុទ្ធតែមានខ្សែ សែស្រឡាយៗហ្នឹងណា៎។ [...] អានេះហើយដែលវាច្រើន។ ម្នាក់ៗណា៎ ចាប់ម្នាក់មិនដឹងជាប់ខ្សែប៉ុន្មាននាក់? ប្អូនដប់ម្តៃនាក់យ៉ាងហោច តាមខ្ញុំមើល។ នេះហើយដែលវានាំឲ្យ ច្រើន")។

[5515] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៩-១៨៨៥, ២០៦២-២០៧៤។

[5516] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៦-១៩០៩, ២០៧៥-២០៩០។

[5517] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១០-១៩២០, ២០៩១-២០៩៨។

[5518] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២១-១៩២៧, ២០៩៩-២១១៣។

[5519] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៦៧, ២០៩០, ២០៩៦, ២១០៧។

[5520] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៩០។

ការកំពូលរំឭកនូវការបញ្ជាក់របស់ខ្លួនខាងលើដែលថា ការដឹងនូវបទឧក្រិដ្ឋបូករួមជាមួយនឹងការបន្តចូលរួមក្នុងក្នុងសហឧក្រិដ្ឋកម្មរួមនោះ មានលក្ខណៈប្រាកដទាក់ទងទៅនឹងចេតនារបស់បុគ្គល[5521]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមបូករួមជាមួយនឹងកត្តាពាក់ព័ន្ធដទៃទៀតដូចជាការដឹងរបស់គាត់អំពីបទឧក្រិដ្ឋដើម្បីសន្និដ្ឋាននូវចេតនារបស់គាត់។ អាស្រ័យហេតុនេះ ការជំទាស់របស់គាត់ទាក់ទងនឹងបញ្ហានេះត្រូវបដិសេធចោល។

1930.ពាក់ព័ន្ធទៅនឹងជនជាតិចាម ខៀវ សំផន បានជំទាស់ថា ពុំមានភស្តុតាងបង្ហាញថា គាត់បានដឹង ឬត្រូវបានជម្រុញដោយចេតនាល្មើសដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទឧក្រិដ្ឋនីមួយៗដែលគាត់ត្រូវបានចោទប្រកាន់នោះ[5522] និងថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មនោះ ពុំមែនជា"ការយល់ឃើញសមហេតុផលតែមួយដែលអាចធ្វើទៅបាននោះទេ"[5523]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំអាចធ្វើការសន្និដ្ឋានដោយសមហេតុផលនូវចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាម ដោយផ្អែកតែមួយមុខលើអត្ថិភាពនៃគោលនយោបាយរើសអើងប្រឆាំងនឹង "សត្រូវ"ប៉ុណ្ណោះទេ[5524] និងថា កង្វះសំអាងហេតុពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានបានដូច្នោះ គឺជាការបង្ហាញនូវកង្វះភស្តុតាងផ្ទាល់ ឬមិនផ្ទាល់នៃចេតនារបស់គាត់ទាក់ទងនឹងបញ្ហានេះ[5525]។

1931.តាមការពិនិត្យលើផ្នែកដែលពាក់ព័ន្ធនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងឃើញថា មូលដ្ឋានសំអាងច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋលើជនជាតិចាម គឺការដែលគាត់មានចេតនាជាក់លាក់រើសអើងប្រឆាំងនឹងសត្រូវ និងបានគាំទ្រគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការតាមរក ចាប់ខ្លួន ដាក់ឱ្យដាច់ដោយឡែក និង"កម្ទេច"សត្រូវនោះ និងការដែលគោលនយោបាយរើសអើងនោះត្រូវបានអនុវត្តចំពោះជនជាតិចាមតាមរយៈការប្រព្រឹត្តនូវឧក្រិដ្ឋកម្មនោះ[5526]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំអាងហេតុនោះដោយផ្ទាល់ មានលក្ខ

---

[5521] *សូមមើលខាងលើ* កថាខណ្ឌ ១៨៩៣ យោងទៅលើសាលដីការឿងក្តី *Karemera និង Ngirumpatse* (ICTR) កថាខណ្ឌ ៦៣២។

[5522] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៧៩, ១៨៨០, ១៨៨៥, ២០៦២, ២០៧០, ២០៧៤។

[5523] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨១, ១៨៨៣, ១៨៨៤។

[5524] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៦៣-២០៦៦, ២០៦៨, ២០៦៩។

[5525] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៦២, ២០៦៩-២០៧៤។

[5526] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៨៩។

ណៈពុំសូវរឹងមាំក្នុងការបង្ហាញដោយជាក់លាក់អំពីធាតុផ្សំដែលចាំបាច់ទាក់ទងនឹងចេតនាល្មើស និងយល់ស្របជាមួយនឹង ខៀវ សំផន ថា ការយល់ឃើញដែលថា គាត់មានចេតនាក្នុងការរើសអើងប្រឆាំងនឹងសត្រូវពិត ឬតាមការសន្មតជាទូទៅ និងបានគាំទ្រការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសត្រូវនោះ ពុំអាចនាំទៅរកការសន្និដ្ឋានថា គាត់ប្រាកដជាមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាមជាពិសេសតាមធម្មតាដោយសារឧក្រិដ្ឋកម្មនោះជាក់ស្តែងបានកើតឡើងនោះទេ។

1932.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របថា កង្វះសំអាងហេតុនោះជាចាំបាច់បានផ្ទុះបញ្ចាំងនូវកង្វះភស្តុតាងដែលអាចបង្ហាញនូវចេតនានោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តនូវឧក្រិដ្ឋកម្មលើជនជាតិចាមដោយផ្អែកលើការបូករួមចូលគ្នានូវ៖ អត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលបានកំណត់គោលដៅជាក់លាក់លើជនជាតិចាម ដែលជាក្រុមជាតិពន្ធុ និងប្រតិបត្តិសាសនា ហើយគោលនយោបាយនេះត្រូវបានអនុវត្តតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្អែកលើមូលដ្ឋានរើសអើង ដើម្បីទទួលបានសង្គមមួយស្មើគ្នាគ្មានការបែងចែកវណ្ណៈ និងគ្មានការប្រតិបត្តិសាសនា[5527] និងតួនាទីរបស់គាត់ជាមេដឹកនាំជាន់ខ្ពស់ដែលមានលក្ខណៈពិសេសក្នុងមជ្ឈិមបក្សដែលធ្វើឱ្យគាត់"ទទួលបានព័ត៌មានសម្ងាត់នៃការអនុវត្តន៍គោលនយោបាយមានគោលដៅបង្កើតសង្គមកម្មកររកសិករមួយស្មើគ្នា និងគ្មានប្រតិបត្តិសាសនា"[5528]។ ភស្តុតាងនេះបានបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងជនជាតិចាមត្រូវបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំ និងរីករាលដាលក្នុងលក្ខណៈជាប្រព័ន្ធ មានការរៀបចំ និងគិតទុកជាមុន[5529] និងបានបង្ហាញក្នុង*ចំណោមនោះ*បន្ថែមទៀតថា: បទបញ្ជាកំណត់គោលដៅលើជនជាតិចាមរួមទាំងបទបញ្ជាបោសសម្អាតពួកគេនោះ "កើតចេញពីថ្នាក់លើ"[5530] ជនជាតិចាមត្រូវបានផ្លាស់ទីដោយបង្ខំបំបែក និងកម្ចាត់ដោយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា[5531] ហើយបក្សកុម្មុយនីស្តកម្ពុជាបានហាមឃាត់ការប្រតិបត្តិសាសនា និងវប្បធម៌ជនជាតិចាមនៅតាមទីកន្លែងនានាទូទាំងប្រទេសកម្ពុជាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[5532]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា កែ ពក សមាជិក

---

[5527] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៩០, ៤២៣៦។

[5528] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៣៦។

[5529] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៣០៦, ៣៣០៨, ៣៣១១-៣៣១៣, ៣៣១៦, ៣៣១៨, ៣៣២៣, ៣៣២៩, ៣៣៣៩។

[5530] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨, ៣២៧៥, ៣២៩០, ៣៣០៧។

[5531] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២៦១-៣២៨៦, ៣៣២២។

[5532] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣២២៨, ៣២៣៨, ៣២៤៥, ៣២៥០, ៣៣២៨។

សហឧក្រិដ្ឋកម្មរួមដែលជាសមាជិកត្រូវបានទុកចិត្តដោយបក្សកុម្មុយនីស្តកម្ពុជាពេញមួយអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ និងជិតស្និទ្ធជាមួយនឹងមជ្ឈិមបក្ស និងបានប្រកាន់ខ្ជាប់អនុវត្តតាមរចនាសម្ព័ន្ធនៃការផ្តល់ការរាយការណ៍ គឺជាបុគ្គលសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាម និងបានប្រព្រឹត្តដោយឥតលាក់លៀមផ្អែកតាមកំណត់ត្រាផ្ទាល់ខ្លួនគាត់[5533]។ ដោយហេតុថា តួនាទីថ្នាក់ដឹកនាំកំពូលរបស់ ខៀវ សំផន ក្នុងបក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងនោះមានលក្ខណៈគ្រប់គ្រាន់អាចឱ្យតុលាការអង្គហេតុសមហេតុផលមួយធ្វើការសន្និដ្ឋានថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តលើជនជាតិចាម និងថា ផ្អែកលើការដឹងនេះដោយបូករួមជាមួយនឹងការបន្តគាំទ្ររបស់គាត់ និងការចូលរួមក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គាត់បានរួមចំណែកចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។

1933.ទាក់ទងទៅនឹងពុទ្ធសាសនិក ខៀវ សំផន បានលើកឡើងប្រហាក់ប្រហែលគ្នាថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពន្យល់ហេតុដូចម្តេចបានជាគោលនយោបាយក្នុងការចាប់ផ្សឹកព្រះសង្ឃ អាចបង្ហាញការដឹងរបស់គាត់អំពីបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ឬចេតនាក្នុងការរើសអើងលើពុទ្ធសាសនិកនៅស្រុកត្រាំកក់ និងពុំបានពន្យល់នូវមូលហេតុថា នេះគឺជាការយល់ឃើញសមហេតុផលតែមួយគត់អាចធ្វើទៅបាន ឬថាតើបទឧក្រិដ្ឋជាក់លាក់អ្វីខ្លះដែលតាមការចោទប្រកាន់ថា គាត់បានដឹងនោះ[5534]។ គាត់បានអះអាងថា ពុំមានភស្តុតាងគាំទ្រការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពី"ការក្លែងបន្លំធ្វើដូចធម្មតា" ឬថាគាត់បានដឹង ឬមានចេតនាថា ព្រះសង្ឃ និងពុទ្ធសាសនិកត្រូវបានកំណត់គោលដៅ ចាប់ខ្លួន ចាប់ផ្សឹក ឬរើសអើងទៅលើនៅស្រុកត្រាំកក់ឡើយ[5535]។

1934.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពេញមួយអំឡុងពេលនៃដីកាបញ្ជូនទៅជំនុំជម្រះ គោលនយោបាយដែលត្រូវបានបង្កើតឡើងដោយមជ្ឈិមដើម្បីលុបបំបាត់ការប្រតិបត្តិរបស់ពុទ្ធសាសនិក និងហាមឃាត់ការប្រតិបត្តិសាសនាព្រះពុទ្ធក្នុងកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាព[5536] និងថា បក្សកុម្មុយនីស្តកម្ពុជាមានចេតនាលុបបំបាត់សាសនាព្រះពុទ្ធចេញពីសង្គមកម្ពុជា និងថា ការចាប់ផ្សឹកព្រះសង្ឃ គឺជាមធ្យោបាយ

---

[5533] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៤៦៩, ២២១៧, ៣២០២, ៣២២៣-៣២២៤, ៣២៧២-៣២៧៤, ៣២៩០, ៤០៦៩។

[5534] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១២-១៩១៥, ២០៩៣, ២០៩៥។

[5535] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩១១, ១៩១៦-១៩២០, ២០៩១, ២០៩២, ២០៩៤, ២០៩៧, ២០៩៨។

[5536] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០១៥-៤០១៧។

គិតទុកជាមុនក្នុងការសម្រេចគោលបំណងនោះ[5537]។ អាស្រ័យហេតុនេះ ការអះអាងរបស់ ខៀវ សំផន នូវការចាប់ផ្សឹកព្រះសង្ឃថា ពុំមែនជា"គោលនយោបាយ"នោះ ជាការភាន់ច្រឡំ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការចាប់ផ្សឹកដោយបង្ខំនូវព្រះសង្ឃរាប់រយអង្គ ស៊ីសង្វាក់គ្នាជាមួយនឹង"លំនាំ"រីករាលដាល និងទូទៅពាសពេញស្រុកត្រាំកក់ ដែលនេះជាផ្នែកនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាកំណត់គោលដៅលើពុទ្ធសាសនិកសម្រាប់ចាត់ទុកជាសត្រូវ[5538]។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុជាលាយលក្ខណ៍អក្សរលម្អិតនូវមូលហេតុដែលអង្គជំនុំជម្រះបានពិចារណាលើការចាប់ផ្សឹកនោះ រួមជាមួយនឹងវិធានការរើសអើងដទៃទៀតក្នុងស្រុកត្រាំកក់ ដូចជា ការកម្ទេចនិមិត្តរូបតំណាងព្រះពុទ្ធសាសនា ការធ្វើឱ្យបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបអូសយកវត្ត និងការហាមឃាត់លើការប្រតិបត្តិពុទ្ធសាសនា ឬជំនឿសាសនា ដែលអាចស្មើនឹងអំពើធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5539]។ នេះគឺជាបទឧក្រិដ្ឋជាក់លាក់ដែល ខៀវ សំផន ត្រូវបានរកឃើញថាបានដឹងក្នុងអំឡុងពេលនៃការប្រព្រឹត្តនោះ[5540]។

1935.សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីបទឧក្រិដ្ឋលើពុទ្ធសាសនិកបានផ្អែកជាចម្បងលើការយល់ឃើញថា៖ ការគាំទ្ររបស់គាត់ដែលថា ពុទ្ធសាសនានៅតែជាសាសនារបស់រដ្ឋ ព្រមទាំងការថ្វាយបង្គំព្រះសង្ឃ"ពុំបានបង្ហាញអ្វីក្រៅពីជាល្បិចកលក្នុងគោលបំណងគាំទ្រធម្មានុរូបនៃរដ្ឋាភិបាលបណ្ដោះអាសន្នដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា"[5541]។ គាត់"បានបន្តគាំទ្រជាសាធារណៈនូវការក្លែងបន្លំធ្វើដូចធម្មតា" ខណៈពេលព្រះសង្ឃកំពុងត្រូវបានចាប់ផ្សឹកក្នុងទ្រង់ទ្រាយធំទូទាំងប្រទេស និង "បានលើកឡើងអំពីការធានាជាសកលនៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យលើសិទ្ធិគោរពប្រតិបត្តិ 'គ្រប់សាសនា' លើកលែងតែ'សាសនាប្រតិកិរិយា'ដែលតាមការជាក់ស្ដែងពុទ្ធសាសនាត្រូវបានចាត់ទុកបែបនោះ"[5542] និង បន្ទាប់ពីជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា គាត់បានបញ្ឈប់ភ្លាមៗនូវការលើកតម្កើងព្រះសង្ឃពុទ្ធសាសនា លែងមានការលើកឡើងបន្តទៀតនៅក្នុងសុន្ទរកថារបស់គាត់[5543]។ ការជំទាស់របស់

---

[5537] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៩៣, ៤២៤០។

[5538] *សូមមើល ឧ.* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១០៥, ១១៨៣, ៤០១៥។

[5539] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១០៨៤-១១០៩, ១១៨៣-១១៨៧។

[5540] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤០-៤២៤៣។

[5541] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤០។

[5542] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤១។

[5543] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤២។

គាត់ដែលថា ពុំមានភស្តុតាងអ្វីសោះគាំទ្រការលើកឡើងអំពី"ការក្លែងបន្លំធ្វើដូចធម្មតា" បានផ្ទុយទៅនឹងការទទួលស្គាល់របស់ នួន ជា ក្នុងសុន្ទរកថារបស់គាត់ថ្លែងទៅកាន់បក្សពលករកុម្មុយនីស្តដាណឺម៉ាកក្នុងខែ កក្កដា ឆ្នាំ ១៩៧៨ ស្តីអំពីវិធិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជានៃការបោកបញ្ឆោតប៊ិនប្រសប់ដើម្បីសម្រេចគោលដៅបក្សថា៖ "យើងថែមទាំងបានធ្វើការនៅក្នុងចលនាព្រះសង្ឃ ធ្វើឱ្យព្រះសង្ឃដើរតាមយើង ដោយនិយាយថា យើងនឹងការពារប្រទេសនិងសាសនារបស់យើង" និង"យើងបានប្រើប្រាស់ទិសស្លោកដែលប្រឆាំងនឹងការជិះជាន់ពីបរទេសលើវប្បធម៌កម្ពុជា។ បន្ទាប់មកព្រះសង្ឃបានក្លាយជនស្នេហាជាតិ គាំទ្រយើងដោយមិនដឹងខ្លួន"[5544]។

1936.មានភស្តុតាងបង្ហាញផងដែរ*ក្នុងចំណោមនោះ*ថា: ឯកសារគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលចុះកាលបរិច្ឆេទថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ បានលើកឡើងថា ព្រះសង្ឃពី ៩០ ទៅ ៩៥ % បានលាចាកសិក្ខាបទរួចហើយ និងបានកំពុងធ្វើការនៅតាមស្រែ និងបានកត់សម្គាល់ថា វណ្ណៈពិសេសនេះលែងបង្កក្តីបារម្ភតទៅទៀតឡើយ[5545]។ ការបំផ្លិចបំផ្លាញនិមិត្តរូបព្រះពុទ្ធសាសនាក្នុងស្រុកត្រាំកក់ត្រូវបានដឹងឮទូទៅ[5546]។ ការពិតដែលថា ពុទ្ធសាសនា"ត្រូវបានបោសសម្អាតទាំងស្រុង" និងទីវត្តអារាមត្រូវបានកែប្រែសម្រាប់គោលបំណងពុំមែនសាសនា បានដឹងឮដល់អ្នកសារព័ត៌មានបរទេស[5547]។ ផ្អែកលើភស្តុតាងជារួមដែលសារណារបស់ ខៀវ សំផន ពុំបានអើពើ និងតួនាទីធំដុំខ្ពង់ខ្ពស់របស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងបដិសេធអំណះអំណាងដែលថា គាត់ពុំបានដឹងអ្វីអំពីការប្រតិបត្តិសាសនាក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលពាក់ព័ន្ធទៅនឹងពុទ្ធសាសនា និងអាស្រ័យហេតុនេះយល់ឃើញថា គាត់បានដឹងអំពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តទៅលើពុទ្ធសាសនិកក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ផ្អែកតាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការដឹងទាំងនេះបូករួមជាមួយនឹងការបន្តគាំទ្ររបស់ ខៀវ សំផន និងការចូលរួមក្នុងគោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួម មានលក្ខណៈគ្រប់គ្រាន់អាចឱ្យតុលាការអង្គហេតុសមហេតុផលមួយសន្និដ្ឋានបានថា សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគឺថា គាត់បានរួមចំណែកចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

---

[5544] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១០៤ និងការយោងដែលត្រូវបានដកស្រង់នៅទីនោះ។

[5545] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧៥៧, ៣៨៥០, ៤១០៤។

[5546] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១០៧។

[5547] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១០៨, ៤០១៥។

1937.ខៀវ សំផន បានអះអាងផងដែរថា ពុំមានភស្តុតាងបង្ហាញថា គាត់បានដឹងនៅពេលនោះអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានប្រើប្រាស់ការលើកឡើងរបស់គាត់ និងសុន្ទរកថានៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងការសន្និដ្ឋានដោយពុំត្រឹមត្រូវនូវការដឹងអំពីបទឧក្រិដ្ឋក្នុងពេលប្រព្រឹត្តនោះ[5548]។ គាត់បានអះអាងថា ការលើកឡើង និងសុន្ទរកថាទាំងនោះព្រមទាំងសារអបអរជ័យជម្នះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបានកម្រិតនិងបានធ្វើឡើងក្នុងបរិបទនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ[5549] ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានដោយពុំមានមូលដ្ឋានថាគាត់មានតួនាទីដែលអាចធ្វើសេចក្តីសម្រេចនៅក្នុងការធានាជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលអង្គជំនុំជម្រះបានទទួលស្គាល់ថា គាត់ពុំមានតួនាទីក្នុងជួរយោធានោះ[5550]។ គាត់បានជំទាស់បន្ថែមទៀតថា ការសម្លាប់មេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានជំនុំជម្រះជាក់លាក់រួចហើយនៅក្នុងសំណុំរឿង ០០២/០១ និងថា ការជំនុំជម្រះសាឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុដដែលក្នុងសំណុំរឿង ០០២/០២ បានរំលោភគោលការណ៍*គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ*[5551]។

1938.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងអាចសំអាងទៅលើភស្តុតាងបង្ហាញនូវអំពើរបស់ ខៀវ សំផន នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយសារអំពើនោះគឺជាផ្នែកមួយនៃការរៀបចំនានា និងការរួមចំណែកដែលបានពន្លាតនៅក្នុងការអនុវត្តន៍គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមដែលបានបន្តនៅក្រោយថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥ និងបានផ្តល់ជាផ្តែផ្គាតាមរយៈបទឧក្រិដ្ឋពាក់ព័ន្ធដែលត្រូវបានប្រព្រឹត្តឡើងក្នុងវិសាលភាពនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.[5552]។ អំណះអំណាងរបស់គាត់ដែលថា សុន្ទរកថារបស់គាត់អំពាវនាវជាសាធារណៈឱ្យកម្ទេចមេដឹកនាំជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់ ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល ពុំបានរារាំងណាមួយដល់ការសន្និដ្ឋានដែលថា ក្រោយជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានដឹង និងមានចេតនាថា អតីតអ្នករដ្ឋ

---

[5548] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២១, ១៩២៣, ១៩២៧, ២១០២, ២១០៤-២១០៦, ២១០៨-២១១៣។

[5549] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២៤-១៩២៦, ២១០២, ២១០៩។

[5550] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២២, ២១០១។

[5551] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១០៣, ២១០៩។

[5552] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ២១៧, ២២១។

ការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅសម្រាប់ការកម្ទេច។ សារណារបស់គាត់ពុំបានអើពើទៅលើភស្តុតាងនៃការទទួលស្គាល់របស់ អៀង សារី ដែលថា ប្រហែលនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដាក់ឱ្យទៅជាផ្លូវការនូវ"សេចក្តីសម្រេចកម្ទេច"អតីតសមាជិកនៃរបបសាធារណរដ្ឋខ្មែរដែលនៅសេសសល់ ដើម្បីរារាំងការប្រឆាំងនឹងបដិវត្តន៍ ព្រមទាំងភស្តុតាងដែលថា សេចក្តីសម្រេចត្រូវបានអនុវត្តជាទ្រឹស្តី រួមបញ្ចូលទាំងការអនុវត្តន៍នៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[5553]។ ភស្តុតាងក៏បានបង្ហាញផងដែរថា ក្នុងអង្គមីទ្ទីង និងវគ្គបណ្តុះបណ្តាលនយោបាយក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជារួមទាំង ខៀវ សំផន បាននិយាយអំពីវត្តមានរបស់សត្រូវក្នុងប្រទេសដោយរួមបញ្ចូលទាំងអ្នកដែលអាចជាទាហានក្នុងរបបមុនៗ និងថា នាយអគ្គសេនាធិការ សុន សេន បានបញ្ជាឱ្យតាមរក និងចាប់ខ្លួនអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ[5554]។ ផ្អែកលើតួនាទីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីអង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើភស្តុតាងជាច្រើននេះតែមួយមុខក៏ដោយ ក៏នៅតែគ្រប់គ្រាន់អាចឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានបានហួសវិមតិសង្ស័យថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងថា ដោយផ្អែកលើការដឹងទាំងនេះបូករួមជាមួយនឹងការបន្តគាំទ្ររបស់គាត់ និងការចូលរួមក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គាត់បានរួមចំណែកចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ បើទោះបីជាថាតើ គាត់ជាបុគ្គលសំខាន់ក្នុងការធានានូវជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណាក៏ដោយ ក៏ពុំមានការប៉ះពាល់ដល់សេចក្តីសន្និដ្ឋាននេះឡើយ។ បន្ថែមលើនេះ ការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដែលថា "ការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ គឺជាផ្នែកមួយនៃគោលបំណងរួម" ត្រូវបានកម្រិតច្បាស់លាស់ត្រឹម"ការជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុងភ្នំពេញប៉ុណ្ណោះ"[5555]និងពុំមែនទៅលើបទចោទនានាដែលបង្កើតបានជាផ្នែកនៃវិសាលភាពសំណុំរឿង ០០២/០២ នោះទេ។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ទាក់ទងនឹងការដឹងរបស់គាត់ និងចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបដិសេធចោល។

1939.ទាក់ទងទៅនឹងជនជាតិវៀតណាម ខៀវ សំផន បានរំឭកនូវអំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងបានពន្លាតដោយពុំត្រឹមត្រូវតាមច្បាប់នូវវិសាល

[5553] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៣៤, ៤០៥៣។

[5554] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤០៣៨, ៤២៧២។

[5555] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៥៩។

ភាពនៃនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដើម្បីដាក់បញ្ចូលអង្គហេតុថ្មី និងព្រឹត្តិការណ៍ដែលជាធាតុផ្សំចាំបាច់នៃការនិរទេសជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ ខេត្តព្រៃវែង និងស្វាយរៀង ព្រមទាំងបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើជនជាតិវៀតណាមនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង[5556] ។ គាត់បានយោងផងដែរទៅលើអំណះអំណាងពីមុនដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុដែលពុំអាចឱ្យអង្គជំនុំជម្រះបង្ហាញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការនិរទេស ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍ និងបទប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម[5557] រួមទាំងនៅមន្ទីរស-២១ ផងនោះ[5558]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបានបដិសេធអំណះអំណាងនេះក្នុងផ្នែកពាក់ព័ន្ធខាងលើ[5559]។

1940.ជាជម្រើស គាត់បានលើកឡើងថា បើទោះបីជាបទឧក្រិដ្ឋដែលបានលើកឡើងខាងលើត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមក៏ដោយ ក៏ពុំមានភស្តុតាងបង្ហាញថា គាត់បានដឹងអំពីបទឧក្រិដ្ឋនោះក្នុងពេលដែលត្រូវបានប្រព្រឹត្ត ឬតាមរយៈនោះអាចសន្និដ្ឋានអំពីចេតនារបស់គាត់ចង់ឱ្យមានការប្រព្រឹត្តនេះបានឡើយ[5560]។ ជាពិសេស គាត់បានផ្តល់អង្គហេតុជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូងពុំដែលបានបញ្ជាក់ជាក់លាក់ថា គាត់បានដឹងនូវបញ្ហានោះ[5561] និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង"ពុំដែលបានបញ្ជាក់ថាតើ បទឧក្រិដ្ឋអ្វី [ដែលត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ] ដែលគាត់បានដឹងនោះ និងមូលហេតុដូចម្តេចបានជាគាត់ដឹងបទឧក្រិដ្ឋនេះ"[5562]។ គាត់បានជំទាស់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានញុះញង់ឱ្យមានការស្អប់ និងការនិរទេសប្រជាជនវៀតណាមដែលជាជាតិពន្ធនោះ ដោយសារបានបំភ្លៃ ឬបកស្រាយខុសនូវការថ្លែងជាសាធារណៈរបស់គាត់ និងបានផ្អែកទៅលើភស្តុតាងដែលមានតម្លៃទាប ដូចជា សក្ខីកម្មរបស់ ឯក ហេន ប្រតិចារឹកនៃ

---

[5556] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៦ យោងទៅលើកថាខណ្ឌ ៣៨០-៣៨៥, ៤៣៥-៤៣៨, ៥២០, ៥២១។

[5557] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៦ យោងទៅលើកថាខណ្ឌ ៦៨៦-៧១៨, ៧៤៨-៧៥៦, ៩៦៦-១០៨៧។

[5558] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩០៤-១៩០៩, ២០៨៩, ២០៩០ យោងទៅលើកថាខណ្ឌ ១៦៥០, ១៦៥១, ១៧០៤-១៧៥៣។

[5559] *សូមមើលខាងលើ* ផ្នែក VII.ខ.២, ផ្នែក VII.ឃ, ផ្នែក VII.ជ។

[5560] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៧, ២០៧៧។

[5561] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៨។

[5562] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៨៩។

កិច្ចសម្ភាសន៍របស់ នៅ សារឹម ជាមួយនឹងវិទ្យុសម្លេងសហរដ្ឋអាមេរិក ប្រតិចារឹកនៃកម្រងសារព័ត៌មាន SWB, FBIS, និងទស្សនាវដ្ដីបារាំងព្រមទាំងការបោះពុម្ពផ្សាយបក្សកុម្មុយនីស្តកម្ពុជានៅចន្លោះឆ្នាំ ១៩៧៧ ដល់ ១៩៧៩ ដែលខ្លឹមសារនៃឯកសារទាំងនេះនៅគ្រប់កាលៈទេសៈពុំអាចឱ្យតុលាការអង្គហេតុសមហេតុផលធ្វើការសន្និដ្ឋានដូចអង្គជំនុំជម្រះសាលាដំបូងឡើយ[5563]។ ជាពិសេស គាត់បានជំទាស់ថា បើទោះបីជាខ្លឹមសារនៃសុន្ទរកថារបស់គាត់ និងឯកសារដទៃទៀតចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានឆ្លុះបញ្ចាំងត្រឹមត្រូវក៏ដោយ ក៏ពុំអាចធ្វើសេចក្ដីសន្និដ្ឋានសមហេតុផលតែមួយគត់ថា គាត់មានចេតនាជាក់លាក់ក្នុងការកម្ទេច ឬរើសអើងលើក្រុមជនជាតិវៀតណាមផ្អែកលើមូលដ្ឋានជាតិពន្ធុ ឬពូជសាសន៍ដែរ និងបានអះអាងថា ការថ្លែងរបស់គាត់ពុំមែនកំណត់គោលដៅលើជនជាតិវៀតណាមជាទូទៅនោះទេ ប៉ុន្តែផ្ទុយទៅវិញលើតែជនជាតិវៀតណាមដែលជា"ពួកឈ្លានពានទឹកដី" "ពួកវាតទីនិយម" "ពួកល្មោភសង្គ្រាម" ឬ"ភ្នាក់ងារ" ក្នុងក្របខ័ណ្ឌនៃការប្រទូសរ៉ាយប្រដាប់អាវុធ[5564]។

1941.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលបដិសេធការជំទាស់របស់ ខៀវ សំផន ទាក់ទងទៅនឹងការលើកឡើងនូវកង្វះនៃភាពជាក់លាក់ ដោយសារពុំមានលក្ខខណ្ឌតម្រូវសម្រាប់អង្គជំនុំជម្រះសាលាដំបូងឱ្យបញ្ជាក់ច្បាស់លាស់នូវ"មូលហេតុដូចម្ដេច" ឬ"នៅពេលណា"ដែលគាត់បានដឹងអំពីបទឧក្រិដ្ឋលើជនជាតិវៀតណាម ដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពនោះ។ ដូចបានរំឭកខាងលើ ដើម្បីដាក់ឱ្យទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រឹមតែកំណត់ថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដូចបានចោទប្រកាន់ និងរួមបញ្ចូលតាមរយៈគោលបំណងរួមល្មើសប៉ុណ្ណោះ ជាជាងអំពើជាក់លាក់នីមួយៗរបស់ចារីផ្ទាល់ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋទាំងនោះ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយត្រឹមត្រូវថា ខៀវ សំផន បានដឹងនៅពេលនោះ និងបានរួមចំណែកចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិវៀតណាមដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ ពុំមានលក្ខខណ្ឌតម្រូវក្នុងការយល់ឃើញថា គាត់បានដឹង ឬមានចេតនាលើអង្គហេតុជាក់លាក់ទាំងអស់ដែលជាមូលដ្ឋាននៃបទឧក្រិដ្ឋនីមួយៗនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំណះអំណាងរបស់គាត់អំពីតម្លៃជាភស្តុតាង និងការបកស្រាយលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើនោះគឺជាផ្នែកសំខាន់ទូទៅនៃអំណះអំណាងរបស់ ខៀវ សំផន ដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានបែងចែកត្រឹមត្រូវរវាងការលើកឡើងប្រឆាំងនឹង

[5563] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩០-១៩០៣, ២០៧៥-២០៨០។

[5564] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២០៨១-២០៨៤។

រដ្ឋវៀតណាមដែលជាសត្រូវ ជាមួយនឹងប្រជាជនវៀតណាមដែលជាក្រុមជាតិពន្ធក្នុងកម្ពុជាឡើយ[5565]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបដិសេធការជំទាស់ទាំងនេះខាងលើ[5566]។

1942.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់ និងចេតនាក្នុងការប្រព្រឹត្តលើក្រុមជាក់លាក់ ដូចជា ជនជាតិចាម ពុទ្ធសាសនិក ជនជាតិវៀតណាម និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបដិសេធចោល។

## ច. បទបញ្ញាវៀបអាពាហ៍ពិពាហ៍

1943.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹង និងមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាផ្នែកនៃគោលនយោបាយទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់បទបញ្ញារៀបអាពាហ៍ពិពាហ៍[5567]។ ក្នុងការបង្កើតការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថាគាត់បានគាំទ្រជាសាធារណៈដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាស្តីពីការបង្កើនឆាប់រហ័សនូវចំនួនប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងពេលដំណាលគ្នានោះបានជម្រុញប្រជាជនឱ្យលះបង់អារម្មណ៍ដែលខ្លួនមានចំពោះឪពុកម្តាយមកជឿជាក់លើអង្គការវិញ[5568]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀតថា ការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងគោលនយោបាយនេះត្រូវបានបញ្ជាក់អះអាងបន្ថែមដោយសម្តេចនរោត្តមសីហនុ ដែលបានរំឭកអំពីការផ្គូរផ្គងស្ត្រីក្មេងជាមួយនឹងយោធិនពិការថា ជាការលះបង់ចំពោះជាតិ[5569]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា នៅកិច្ចប្រជុំវត្តឧណ្ណាលោមក្នុងចុងឆ្នាំ ១៩៧៥ គាត់ផ្ទាល់បានណែនាំថា គ្រប់ក្រសួងត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យប្តីប្រពន្ធបង្កើតកូនសម្រាប់ការការពារប្រទេស[5570] និងថា ពិតណាស់ការណែនាំនេះត្រូវបានអនុវត្ត រួមទាំងក្នុងក្រសួង

[5565] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៩៦ យោងទៅលើកថាខណ្ឌ ១០៥៨-១០៩៧, ១៥៥១-១៥៦០។

[5566] *សូមមើលខាងលើ* ផ្នែក VIII.ខ.៥.ក។

[5567] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៩, ៤៣០៥។

[5568] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨, ៤៣០៤។

[5569] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៨។

[5570] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៧, ៤៣០៤។

ពាណិជ្ជកម្មផងនោះ ដែល ខៀវ សំផន ជាអ្នកគ្រប់គ្រងផ្ទាល់ និងការកំណត់ចំនួនជាអប្បបរមាប្រចាំខែ ត្រូវរៀបអាពាហ៍ពិពាហ៍បាន ១០០ គូក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨[5571]។

1944.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសជាច្រើនក្នុងការយល់ឃើញថា គាត់បានដឹង និងមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាផ្នែកនៃគោលនយោបាយល្មើសនៃបទបញ្ជារៀបអាពាហ៍ពិពាហ៍[5572]។ គាត់បានជំទាស់ថា ការយល់ឃើញនេះបានកើតឡើងដោយសារការវាយតម្លៃលម្អៀងលើភស្តុតាង ដោយសារអង្គជំនុំជម្រះសាលាដំបូងបានវិនិច្ឆ័យរួចហើយនូវអង្គហេតុពាក់ព័ន្ធទៅនឹងគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសំណុំរឿង ០០២/០១[5573]។ គាត់បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើសក្ខីកម្មដាច់ដោយឡែករបស់ ជា ខៀប ដែលគប្បីត្រូវបដិសេធចោលដោយសារកង្វះគួរឱ្យជឿជាក់បាន ក្នុងការបង្កើតការយល់ឃើញលើកិច្ចប្រជុំនៅវត្តខណ្ឌាលោមដែលតាមការសន្មតថា គាត់ធ្វើជាអធិបតី[5574] និងថា អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយពុំត្រឹមត្រូវលើភស្តុតាងអំពីបង្កើនចំនួនប្រជាជន ការកំណត់ចំនួនអប្បបរមា និងការលះបង់អារម្មណ៍ផ្ទាល់ខ្លួនដើម្បីអង្គការ ដែលពុំមានការជាប់ពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[5575]។ បន្ថែមលើនេះ គាត់បានអះអាងថា ការទទួលខុសត្រូវរបស់គាត់ទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ពាក្យពេចន៍ទូទៅ“មជ្ឈិមបក្ស” ឬ “អង្គការ” ពុំអាចបង្ហាញទំនាក់ទំនង ឬការដឹងរបស់គាត់នូវគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[5576]។ ក្នុងការគាំទ្រការជំទាស់ទាំងនេះ ដែលភាគច្រើនត្រឹមតែជាការបកស្រាយមួយបែបផ្សេងលើភស្តុតាង ខៀវ សំផន បានផ្អែកទាំងស្រុងទៅលើអំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបដិសេធក្នុងផ្នែកពាក់ព័ន្ធខាងលើ[5577]។

---

[5571] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២៤៧។

[5572] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២៨-១៩៣១, ២១១៤-២១១៨។

[5573] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២៨, ២១១៥, ២១១៦ យោងទៅលើកថាខណ្ឌ ១១៨៩-១២៨០, ១៣៤១-១៣៩៨។

[5574] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩២៩, ២១១៧ យោងទៅលើកថាខណ្ឌ ១២៣៣-១២៤២។

[5575] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣០, ២១១៧ យោងទៅលើកថាខណ្ឌ ១២២១-១២៣២។

[5576] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៩៣០, ១៩៣១ យោងទៅលើកថាខណ្ឌ ១២៤៤-១២៨០, ១៦១៨-១៨០៣។

[5577] *សូមមើលខាងលើ* ផ្នែក V.គ.២។

1945.អាស្រ័យហេតុនេះ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការដឹង និងចេតនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៃការដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍ ត្រូវបដិសេធចោល។

**៩. បញ្ហាលើកឡើងតាមគំនិតផ្តួចផ្តើមរបស់ខ្លួនពាក់ព័ន្ធទៅនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល**

1946.អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ក្នុងការដោះស្រាយបញ្ហាដែលជាសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដែលនេះបានកើតចេញពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែពុំត្រូវបានលើកឡើងដោយភាគីណាមួយនៅដំណាក់កាលបណ្តឹងសាទុក្ខ។ បើទោះបីជាសិទ្ធិអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានអនុញ្ញាតក្នុងកម្រិតត្រឹមតែបញ្ហាដែលត្រូវបានប្តឹងឧទ្ធរណ៍ដោយភាគីក៏ដោយ ក៏ដោយស្របជាមួយនឹងអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTR និង ICTY[5578] អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ក្នុងករណីពិសេស អង្គជំនុំជម្រះអាចដោះស្រាយបញ្ហា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ដែលពុំបានឈានទៅរកការមោឃៈសាលក្រមនោះទេ ប៉ុន្តែមានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌនេះ[5579]។ ការប្រើប្រាស់សិទ្ធិអំណាចនេះ គឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះឧទ្ធរណ៍ ហើយប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបដិសេធក្នុងការដោះស្រាយបញ្ហានេះ មតិយោបល់របស់អង្គជំនុំជម្រះសាលាដំបូងនៅតែជាការប្រកាសផ្លូវការលើបញ្ហានោះ និងនៅតែមានអានុភាព[5580]។

1947.បញ្ហាចំពោះមុខ គឺពាក់ព័ន្ធទៅនឹងភាពអាចអនុវត្តបាននៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមលើបទឧក្រិដ្ឋដោយចេតនាប្រយោល *ដូចជា* បទឧក្រិដ្ឋដែលចារីបានដឹងអំពីហានិភ័យថា ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋអាចកើតចេញពីអំពើសកម្ម ឬអកម្មរបស់ខ្លួន ហើយនៅតែទទួលយលទ្ធផលនោះ[5581]។ ចេតនាប្រយោលពុំ

---

[5578] សាលដីការឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ៦។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-4-A សាលក្រម ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ ("សាលដីកានៃរឿងក្តី *Akayesu* (ICTR)") កថាខណ្ឌ ១៧-១៩។

[5579] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១៣៨។

[5580] *សូមមើល* សាលដីកានៃរឿងក្តី *Akayesu* (ICTR) កថាខណ្ឌ ២៣។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១៣៩។

[5581] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គបុរេជំនុំជម្រះ I (ICC) សំណុំរឿងលេខ ICC-01/04-01/06 សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៥២។ *សូមមើលផងដែរ* សេចក្តីសម្រេចរឿងក្តី*Bemba* ស្របតាមមាត្រា ៦១(៧)(ក) និង (ខ) កថាខណ្ឌ ៣៦៣។

បានរួមបញ្ចូលបទដ្ឋាននៃការមិនយកចិត្តទុកដាក់ណាមួយ ឬទាំងស្រុងនោះទេ[5582]។ ជាការឆ្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងថា សហឧក្រិដ្ឋកម្មរួមទម្រង់ I តម្រូវឱ្យមានការបង្ហាញភស្តុតាងនៃចេតនាផ្ទាល់ពាក់ព័ន្ធទៅនឹងគោលបំណងរួម និងបទឧក្រិដ្ឋដែលជាមូលដ្ឋាននោះ[5583] អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "លក្ខខណ្ឌតម្រូវនៃកម្រិតចេតនាក្រោមសហឧក្រិដ្ឋកម្មរួមគឺចេតនាផ្ទាល់" និងថា "ចេតនាប្រយោល (*dolus eventualis*) ពុំគ្រប់គ្រាន់សម្រាប់ការយល់ឃើញអំពីសហឧក្រិដ្ឋកម្មរួមចំពោះមុខ អ.វ.ត.ក. នោះទេ"[5584]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ពុំស្ថិតក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងអាស្រ័យហេតុនេះបានធ្វើការវិភាគលើការទទួលខុសត្រូវរបស់ ខៀវ សំផន ចំពោះបទឧក្រិដ្ឋនេះក្រោមទម្រង់នៃការទទួលខុសត្រូវនៃការជួយទំនុកបម្រុងទៅវិញ[5585]

---

[5582] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៣៩០-៣៩១ ចំណុចដែលអង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់ និងអនុម័តការកំណត់និយមន័យដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងនៃរឿងក្តី *Stakić*៖

> ការកំណត់និយមន័យបច្ចេកទេសនៃចេតនាប្រយោល *dolus eventualis* មានដូចតទៅ៖ ប្រសិនបើចារីមានឥរិយាបថដែលធ្វើឱ្យគ្រោះថ្នាក់ដល់អាយុជីវិត អំពើមនុស្សឃាតរបស់គាត់គឺជាចេតនា ដោយសារគាត់បាន"សម្របសម្រួលខ្លួនគាត់" ឬ"ស្រុះស្រួល"ជាមួយនឹងភវនីយភាពនៃការស្លាប់នោះ។ ដូច្នេះ ប្រសិនបើអំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងដោយមាន"ការពុំអើពើច្បាស់លាស់ចំពោះតម្លៃនៃអាយុជីវិតរបស់មនុស្ស" សូម្បីតែអំពើនោះមានហានិភ័យតិចតួចក្តីក៏អាចស្មើនឹងអំពើមនុស្សឃាតដោយចេតនាដែរ។

[5583] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៤៥២, ៤៥៩-៤៦២, ៤៧០, ៤៩៨។

[5584] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១៥។

[5585] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១១:

> ក្រោយការពិចារណាលើភស្តុតាងទាំងអស់និងផ្អែកតាមតួនាទីរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះយល់ឃើញថា ភាគច្រើន ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឆ្លុះបញ្ចាំងបានត្រឹមត្រូវនិងសមស្របពីការទទួលខុសត្រូវរបស់ ខៀវ សំផន លើឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម។ សម្រាប់ឧក្រិដ្ឋកម្មទាំងនេះ អង្គជំនុំជម្រះនឹងមិនវិភាគលើការទទួលខុសត្រូវរបស់ ខៀវ សំផន ក្រោមទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់បន្ថែមទៀតឡើយ។ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាលដែលបានប្រព្រឹត្តដោយចេតនាដោយប្រយោល ដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្មការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល អង្គជំនុំជម្រះរំលឹកឡើងវិញថា វាមិនស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមឡើយ។ អង្គជំនុំជម្រះនឹងពិចារណាពីការទទួលខុសត្រូវរបស់ ខៀវ សំផន លើឧក្រិដ្ឋកម្មទាំងនេះក្រោមទម្រង់នៃការជួយនិងជំរុញ ព្រោះអង្គជំនុំជម្រះយល់

។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានអើពើលើការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដែលថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋដែលពុំមែនជាចេតនាផ្ទាល់ ប៉ុន្តែត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។

1948.ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា "ប្រភេទផ្នែកច្បាប់[នៃសហឧក្រិដ្ឋកម្មរួម]ដែលអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានកំណត់អត្តសញ្ញាណក្នុង*រឿងក្តី Tadić* ទំនងជាបានផ្អែកជាចម្បងលើការវាយតម្លៃអង្គហេតុនៃរឿងក្តីជាមូលដ្ឋាន។ ប្រភេទនេះពុំត្រូវបានប្រើប្រាស់ច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ និងពុំមែនជាការកំណត់និយមន័យច្បាស់លាស់ផ្នែកច្បាប់ដាច់ដោយឡែកពុំត្រូវគ្នានោះឡើយ"[5586]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា នៅក្នុងស្ថានភាពដែលជនជាប់ចោទពុំបានមានធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានចោទប្រកាន់ ប៉ុន្តែបានប្រព្រឹត្តឡើងរួមគ្នាជាមួយអ្នកដទៃទៀត "ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលបានផ្អែកលើការរួមចំណែកក្នុងការអនុវត្តន៍គោលបំណងរួមល្មើស ក្នុងពេលដែលពាក់ព័ន្ធទៅនឹងបទចោទចំពោះមុខត្រូវបានកម្រិតត្រឹមបទឧក្រិដ្ឋ ដែលជាក់ស្តែងត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម"[5587]ប៉ុណ្ណោះ ដោយសារការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមសម្រាប់បទឧក្រិដ្ឋ ដែលពុំស្ថិតក្នុងគោលបំណងរួម (ដូចជា សហឧក្រិដ្ឋកម្មរួមទម្រង់ (៣) ពុំមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ។ ផ្អែកលើសេចក្តីសន្និដ្ឋានដែលថា ការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួម អាចត្រឹមតែមានអត្ថិភាពសម្រាប់បទឧក្រិដ្ឋដែលស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា "លក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចថាតើ បទឧក្រិដ្ឋមួយណាដែលត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនោះ គឺការជាប់ពាក់ព័ន្ធយ៉ាងខ្លាំង"[5588]។ អង្គជំនុំជម្រះបានរំឭកថា គោលបំណងរួមអាច"ស្មើនឹង" ឬ"ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ៖[5589]

---

ឃើញថា ការទទួលខុសត្រូវនេះ ឆ្លុះបញ្ចាំងត្រឹមត្រូវបំផុតពីតួនាទីរបស់ ខៀវ សំផន *ធៀបនឹង*ការធ្វើមនុស្សឃាតទាំងនេះ។

[5586] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៧៧៥។

[5587] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៧។

[5588] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៧។

[5589] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៩៧។

គោលបំណងរួមមានការ“ជាប់ពាក់ព័ន្ធ”ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជាមធ្យោបាយដើម្បីសម្រេចគោលដៅចុងក្រោយមួយ (ដែលគោលដៅនេះអាចពុំមែនជាបទល្មើស)។ នៅក្នុងកាលៈទេសៈបែបនេះ ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែមានចេតនាចង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងសម្ងាត់។ នេះអាចរួមបញ្ចូលបទឧក្រិដ្ឋដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ។ ឧទាហរណ៍ ប្រសិនបើក្រុមមួយបានព្រមព្រៀងគ្នាចូលលួចក្នុងផ្ទះមួយ ហើយក្នុងករណីចាំបាច់ត្រូវសម្លាប់មនុស្សប្រសិនបើចៃដន្យមានការតដៃ។ នេះជាការពុំសមស្របទាំងស្រុងក្នុងការសន្និដ្ឋានថា ការធ្វើមនុស្សឃាតជាយថាហេតុនោះពុំត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម ដោយសារពុំមានភាពច្បាស់លាស់ថា មានការសម្លាប់មនុស្សនឹងកើតជាក់ស្តែងនៅក្នុងអំឡុងពេលនៃការចូលលួចនោះឡើយ។ ផ្ទុយទៅវិញ ក្នុងកាលៈទេសៈនេះ បទមនុស្សឃាត គឺជាធាតុផ្សំនៃផែនការដែលបានគ្រោងទុក បើទោះបីជាសមាជិកនៃក្រុមនោះពុំបានដឹង ថាតើមានការសម្លាប់មនុស្សជាក់ស្តែង ដែរ ឬយ៉ាងណានោះក៏ដោយ។ ដូច្នេះ ប្រសិនបើគោលដៅនៃគោលបំណងរួមអាចសម្រេចបានលុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ និងនៅតែមានការព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ បទឧក្រិដ្ឋទាំងនេះមានរួមបញ្ចូលតាមរយៈគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏បទឧក្រិដ្ឋនេះត្រូវបានគ្រោងទុកដោយគោលបំណងរួមដែរ[5590]។

1949.អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា ការដែលបទឧក្រិដ្ឋត្រូវបានគិតទុកជាមុនតាមរយៈគោលបំណងរួម ជាមូលដ្ឋានគឺជាបញ្ហាអង្គហេតុ ប៉ុន្តែ“អ្វីដែលជាការកត់សម្គាល់នោះគឺថា គោលបំណងរួមអាចរួមបញ្ចូលបទឧក្រិដ្ឋដែលក្នុងនោះ បើទោះបីជាការប្រព្រឹត្តនោះពុំមែនជាចេតនា ឬដឹងច្បាស់លាស់ក៏ដោយ ក៏នៅតែគ្រប់គ្រាន់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួនដែលចារីបានប្រព្រឹត្តដោយចេតនាប្រយោលដែរ និងដូច្នេះ ពុំចាំបាច់មានចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ និងពុំមានភាពជាក់លាក់ដឹងថាបទល្មើសនឹងកើតមានឡើងនោះឡើយ”[5591]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ជាក់លាក់ថា៖

ប្រសិនបើបទមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ជនជាប់ចោទមានគោលដៅអនុវត្តគោលបំណងរួមនាំឱ្យជនរងគ្រោះស្លាប់ ឬបានដឹងថា ការស្លាប់មនុស្សប្រាកដជាកើតមានជាក់ច្បាស់ ដោយសារការអនុវត្តន៍គោលបំណងរួមនោះ(ចេតនាផ្ទាល់) ឬថា ជនជាប់

---

[5590] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៨។

[5591] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៨។

ចោទបានដឹងថា ការស្លាប់ជនរងគ្រោះ គឺជាផលវិបាកដែលអាចកើតមាន ដោយសារការអនុវត្តន៍គោលបំណងរួមនោះ ប៉ុន្តែនៅតែបន្តអនុវត្តបើទោះបីជាយ៉ាងនេះក្តី ដោយទទួលយកលទ្ធភាពនៃការស្លាប់ដែលអាចកើតឡើង(ចេតនាប្រយោល)[5592]។

1950.ពិតណាស់ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា ជាការសមស្របក្នុងការកែប្រែការកំណត់ប្រភេទបទល្មើសរបស់អង្គជំនុំជម្រះសាលាដំបូងនៃការស្លាប់មួយចំនួនដែលបានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរ ពីការសម្លាប់រង្គាលទៅនឹងជាបទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយចេតនាប្រយោល និងបានយល់ឃើញថា បទឧក្រិដ្ឋទាំងនេះត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម និងថា ខៀវ សំផន ត្រូវបានដាក់ឱ្យទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋនេះ[5593]។

1951.អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្គាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែផ្ទុយទៅវិញបានសំអាងទៅលើយុត្តិសាស្ត្រតាមការជ្រើសរើសរបស់ខ្លួនចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍*៖

> អង្គជំនុំជម្រះបានកត់សម្គាល់ថា លក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួម មានលក្ខណៈខុសគ្នាទៅតាមប្រភេទ និងជាពិសេស អាស្រ័យលើថាតើឧក្រិដ្ឋកម្មទាំងនោះត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមដែរ ឬយ៉ាងណា។ ទោះបីជាសហឧក្រិដ្ឋកម្មរួមទម្រង់ទី I តម្រូវថា ឧក្រិដ្ឋកម្មទាំងនោះត្រូវរួមបញ្ចូលតាមរយៈគោលបំណងរួមក៏ដោយ ក៏សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្រៅក្របខ័ណ្ឌគោលបំណងរួមដែលជាផលវិបាកពីធម្មជាតិ និងអាចប្រមើលដឹងជាមុនចំពោះផលវិបាកនៃគោលបំណងរួមនេះ។ ដោយផ្អែកលើការបែងចែកដាច់ពីគ្នាបែបនេះ យុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី I តម្រូវឱ្យមាន*ចេតនាផ្ទាល់* ចំណែកឯសហឧក្រិដ្ឋកម្មរួមទម្រង់ទី III តម្រូវត្រឹមតែថា ជនជាប់ចោទបានដឹងថា ឧក្រិដ្ឋកម្មទាំងនេះគឺជាផលវិបាកដែលអាចកើតចេញពីការអនុវត្តគោលបំណងរួមនេះ និងមានចេតនាទទួលយកហានិភ័យចំពោះឧក្រិដ្ឋកម្មទាំងនេះអាចត្រូវបានប្រព្រឹត្តឡើង*(ចេតនាដោយប្រយោល)*។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Stanišić និង Simatović* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានលើកឡើងថា “តុលាការអនុវត្តតាម [...] ដែលថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី I តម្រូវឱ្យមាន*ចេតនាផ្ទាល់* និងថា ការធ្វេសប្រហែស ឬ*ចេតនាប្រយោល* ពុំគ្រប់គ្រាន់នោះឡើយ”។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Karemera និង Ngirumpatse* អង្គជំនុំជម្រះតុលាការ

---

[5592] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៥៤ (សេចក្តីបញ្ជាក់បន្ថែម)។

[5593] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៥៦១-៥៦២, ៨៦៨, ១០៨៨-១០៨៩។

កំពូលតុលាការ ICTR បានលើកឡើងថា៖ "បញ្ហានៃ"ការអាចដឹងជាមុន" គឺពាក់ព័ន្ធនឹងទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ដែលមិនមែនជាទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមនោះទេ"។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់នៅក្នុងរឿងក្តី *Šainović និងជនដទៃទៀត* ថា "លទ្ធភាពក្នុងការព្យាករណ៍" គឺជាបទដ្ឋាននៃធាតុផ្សំអត្តនោម័តិ ដែលមិនត្រឹមត្រូវនោះឡើយ នៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ហើយថាអង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវថា ជនជាប់ចោទ Sainović "បានដឹងដែលខុសពីលទ្ធភាពក្នុងការដឹងជាមុនអំពីការប្រព្រឹត្តបទឧក្រិដ្ឋនានា និងបានរួមចំណែកចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាមួយនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម"។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ចេតនា*(ប្រយោល)* ដែលបង្កើតបានជាការកំណត់និយមន័យនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ពុំអាចប្រែក្លាយជាសហឧក្រិដ្ឋកម្មរួមទម្រង់ទី I បាននោះទេ។ ដោយសារនៅក្នុងអំឡុងពេលពាក់ព័ន្ធនៃដីកាដំណោះស្រាយ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិហេតុនេះ ចេតនា*(ប្រយោល)*មិនគ្រប់គ្រាន់សម្រាប់ការយល់ឃើញអំពីសហឧក្រិដ្ឋកម្មរួមចំពោះមុខ អ.វ.ត.ក. ឡើយ។ អាស្រ័យហេតុនេះ ស្របតាមសេចក្តីសន្និដ្ឋាននានារបស់មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌតម្រូវនៃកម្រិតចេតនានៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទី I គឺចេតនាផ្ទាល់[5594]។

1952. ជាសំខាន់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយពុំត្រឹមត្រូវថា ត្រឹមតែការដឹងជាមុនថាមានការប្រព្រឹត្តបទឧក្រិដ្ឋ បទឧក្រិដ្ឋនោះជាស្វ័យប្រវត្តិពុំស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមឡើយ។ នេះជាការពុំអើពើទៅលើស្ថានការណ៍ដែលការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ត្រូវបានយល់ព្រមជារួម និងដោយចេតនាពីសំណាក់អ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួមទាំងអស់ ដូចបានលើកឡើងនៅក្នុងឧទាហរណ៍ដែលបានផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ អំពីក្រុមមួយដែលបានចូលលួចក្នុងផ្ទះមួយ និងបានយល់ព្រមប្រើប្រាស់អំពើគ្រោះថ្នាក់ដល់អាយុជីវិតក្នុងករណីចាំបាច់។ ក្នុងស្ថានភាពនេះ ដោយសារអ្នកចូលរួមសហឧក្រិដ្ឋលម្មរួមទាំងអស់បានរួមចំណែកការឯកភាពរបស់ខ្លួនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនាប្រយោលក្នុងការជម្រុញគោលបំណងរួម ឧក្រិដ្ឋកម្មនោះត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម។

1953. យុត្តិសាស្ត្រដែលបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងបានផ្អែកមិនផ្ទាល់ទៅលើសាលដីកានៃរឿងក្តី *Tadić*។ នៅពេលកំណត់និយមន័យលើធាតុផ្សំអត្តនោម័តិដែលអាចអនុវត្តបានសម្រាប់ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមអង្គជំនុំជម្រះបានកំណត់និយមន័យក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះឧទ្ធរ

[5594] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៧១៤-៣៧១៥។

ណ៍នៃរឿងក្តី *Tadić* បានបញ្ជាក់ថា "ធាតុផ្សំអត្តនោម័តិមានលក្ខណៈខុសប្លែកគ្នាអាស្រ័យទៅលើប្រភេទនៃផែនការរួមដែលត្រូវពិចារណា។ ទាក់ទងទៅនឹងប្រភេទទីមួយ *អ្វីដែលតម្រូវនោះគឺចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់មួយ* (ដែលនេះគឺជាចេតនារួមពីសំណាក់សហចារីទាំងអស់)"[5595]។ នេះមានលក្ខណៈខុសប្លែកពីសហឧក្រិដ្ឋកម្មរួមទម្រង់ III ដែលផ្អែកតាមអង្គជំនុំជម្រះឧទ្ធរណ៍នោះថា៖

> អ្វីដែលតម្រូវនោះគឺចេតនាក្នុងការចូលរួមក្នុង និងការជម្រុញសកម្មភាពល្មើស ឬគោលបំណងល្មើសរបស់ក្រុម និងការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម ឬក្នុងព្រឹត្តិការណ៍នានានៃការប្រព្រឹត្តឧក្រិដ្ឋកម្មដោយក្រុមនោះ។ បន្ថែមលើនេះ ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលខ្លួនពុំបានយល់ព្រមនៅក្នុងគោលបំណងរួមមានអត្ថិភាពផ្អែកតាមកាលៈទេសៈនៃរឿងក្តី ដរាបណា (១) មានការអាចដឹងជាមុនថា ឧក្រិដ្ឋកម្មនោះអាចត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់ ឬច្រើននាក់នៃក្រុមនោះ និង(២) ជនជាប់ចោទមានចេតនាទទួលយកហានិភ័យនោះ[5596]។

1954. *រឿងក្តី Tadić* បានដោះស្រាយលើស្ថានការណ៍ដែលជនជាប់ចោទ Tadić គឺជាផ្នែកមួយនៃក្រុមប្រដាប់អាវុធពាក់ព័ន្ធទៅនឹងការវាយប្រហារលើភូមិពីរដែលនេះជាផ្នែកនៃយុទ្ធនាការបោសសម្អាតក្រុមជនជាតិពន្ធុដែលពុំមែនជាជនជាតិស៊ែបចេញពីតំបន់នោះ[5597]។ បុរសប្រាំនាក់ត្រូវបានសម្លាប់ដោយសារលទ្ធផលនៃការវាយប្រហារនោះ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំអាចកំណត់បានថាតើ ជនជាប់ចោទ Tadić ផ្ទាល់ខ្លួននោះបានរួមចំណែកក្នុងការសម្លាប់នោះដែរ ឬយ៉ាងណាឡើយ[5598] បើទោះបីជាគាត់ផ្ទាល់ខ្លួន"បានរួមចំណែកយ៉ាងសកម្មក្នុងការវាយដំយ៉ាងឃោរឃៅ និងដោយហិង្សា"លើបុរសបួននាក់ដែលនេះជាផ្នែកនៃការវាយប្រហារនោះក៏ដោយ[5599]។ ការសម្លាប់នោះពុំត្រូវបានយល់ឃើញថា ជាផ្នែកនៃគោលបំណងរួមល្មើសឡើយ[5600]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ CTY បានពិចារណាថាតើ ការសម្លាប់នោះគឺផលវិបាកដែលអាចដឹងជាមុនបានតាមធម្មតានៃការវាយប្រហារលើភូមិនោះ ដែរ ឬយ៉ាងណា ដែលជនជាប់ចោទ Tadić អាចទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមទម្រង់ III។

---

5595 សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ២២៨ (សេចក្តីបញ្ជាក់បន្ថែម)។

5596 សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ២២៨ (សេចក្តីបញ្ជាក់បន្ថែម)។

5597 សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ១៧៥, ១៧៨។

5598 សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ១៧៩។

5599 សាលក្រមរឿងក្តី *Tadić* (ICTY) កថាខណ្ឌ ៣៧៤។

5600 សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ២៣១។

1955.នៅពេលអង្គជំនុំជម្រះឧទ្ធរណ៍នៃរឿងក្តី *Tadić* បានធ្វើការកំណត់ថាតើ ជនជាប់ចោទ Tadić អាចទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មដែលនៅក្រៅវិសាលភាពនៃគោលបំណងរួម ដែរ ឬយ៉ាងណា ការផ្តោតជាចម្បងរបស់ខ្លួន ពុំមែនទៅលើកម្រិតនៃចេតនាតម្រូវសម្រាប់ឧក្រិដ្ឋកម្មនៅក្នុងគោលបំណងរួមនោះទេ។ ការបញ្ជាក់របស់ខ្លួនដែលថា ឧក្រិដ្ឋកម្មនោះប្រាកដជាបានប្រព្រឹត្តដោយចេតនា (ដែលអង្គជំនុំជម្រះពុំបានលម្អិត ឬពន្យល់) អាចត្រូវបានយល់ថា ជាលក្ខខណ្ឌតម្រូវធម្មតាដែលសមាជិកនៃសហឧក្រិដ្ឋកម្មរួមបានរួមចំណែកធាតុផ្សំអត្តនោម័តិដែលតម្រូវសម្រាប់បទឧក្រិដ្ឋមូលដ្ឋាននោះ[5601]។

1956.ពិតណាស់ អង្គជំនុំជម្រះមួយចំនួននៃតុលាការ ICTY បានបកស្រាយតាមវិធីសាស្ត្រដូចគ្នានេះ។ អង្គជំនុំជម្រះសាលាដំបូងនៃរឿងក្តី *Brđanin និង Talić* ដែលត្រូវបានដកស្រង់ និងយល់ស្របដោយអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Krstić*[5602] បានបញ្ជាក់ថា៖

> ចេតនារបស់ជនជាប់ចោទដែលត្រូវបង្ហាញដោយអយ្យការ មានលក្ខណៈខុសប្លែកគ្នាអាស្រ័យលើបញ្ហាថាតើបទឧក្រិដ្ឋដែលចោទប្រកាន់នោះ៖
>
> (ក) ស្ថិតក្នុងវិសាលភាពនៃគោលបំណងសហឧក្រិដ្ឋកម្មរួម ឬ
>
> (ខ) ចេញឆ្ងាយពីគោលបំណងសហឧក្រិដ្ឋកម្មនោះ ដែរ ឬយ៉ាងណា ប៉ុន្តែគឺជាផលវិបាកដែលអាចដឹងជាមុនតាមធម្មតានៃសហឧក្រិដ្ឋកម្មនោះ។
>
> ប្រសិនបើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះស្ថិតក្នុងវិសាលភាពគោលបំណងនៃសហឧក្រិដ្ឋកម្មរួម អយ្យការត្រូវតែបង្ហាញថា ជនជាប់ចោទបានរួមចំណែកជាមួយនឹងបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់នូវចេតនាដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទឧក្រិដ្ឋនោះ[5603]។

---

[5601] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៥៣: "តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូល សម្រាប់ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋដែលបានផ្អែកលើការទទួលខុសត្រូវក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ចេតនារបស់គាត់ត្រូវតែគ្របដណ្តប់ធាតុផ្សំនៃឧក្រិដ្ឋកម្ម និងធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ"។

[5602] សាលក្រមរឿងក្តី *Krstić* (ICTY) កថាខណ្ឌ ៦១៣។

[5603] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brđanin និង Talić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-99-36 សេចក្តីសម្រេចស្តីពីទម្រង់នៃដីកាបញ្ជូនទៅជំនុំជម្រះដែលត្រូវបានកែប្រែបន្ថែម និងសំណើរបស់អយ្យការសុំកែប្រែ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៣១ (សេចក្តីបញ្ជាក់បន្ថែម)។ យុត្តិសាស្ត្រក្រោយមកបានបញ្ជាក់ថា ចារីផ្ទាល់នៃឧក្រិដ្ឋកម្មពុំចាំបាច់ជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះទេ។ "អ្វីដែលសំខាន់ក្នុងប្រភេទទីមួយនៃសហឧក្រិដ្ឋកម្មរួម គឺពុំមែនបញ្ហាថាតើបុគ្គលនោះមាន

1957.ពុំមានអង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* ធ្វើការវិភាគលើបញ្ហាថាតើ ឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម អាចត្រូវបានប្រព្រឹត្តដោយចេតនាប្រយោល ដែរ ឬយ៉ាងណានោះទេ បើទោះបីជាមានអង្គជំនុំជម្រះខ្លះ នៅពេលយោងទៅលើរឿងក្តី *Tadić* ឬរឿងក្តីដទៃទៀតដែលបានយោងទៅលើរឿង*Tadić* ដដែលនេះ បានបញ្ជាក់ដោយគ្មានការវិភាគជាក់ស្តែងណាមួយថា ចេតនាផ្ទាល់គឺជាលក្ខខណ្ឌតម្រូវនោះឡើយ[5604]។

1958.អង្គជំនុំជម្រះឧទ្ធរណ៍នៃរឿងក្តី *Tadić* ជាក់ស្តែងពុំបានបញ្ជាក់ថា "ចេតនាផ្ទាល់"គឺជាលក្ខខណ្ឌតម្រូវសម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ I នោះទេ ប៉ុន្តែផ្ទុយទៅវិញថា ជា"ចេតនាល្មើសតែមួយ" ឬ "ចេតនារួមគ្នា"[5605]។ *ចេតនាប្រយោល*ត្រូវបានចាត់ទុកថា ជាទម្រង់មួយនៃចេតនា។ ដូចអង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ក្នុងសំណុំរឿង ០០២/០១ ថា "ការបង្កឱ្យមានការស្លាប់ដោយសារចេតនាដែលក្រោមកម្រិតចេត

---

ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋជាក់លាក់ ដែរ ឬយ៉ាងណានោះទេ ប៉ុន្តែថាតើ ឧក្រិដ្ឋកម្មនោះបង្កើតបានជាផ្នែកមួយនៃគោលបំណងរួម ដែរ ឬយ៉ាងណា"។ សាលដីការឿងក្តី *Brđanin* (ICTY) កថាខណ្ឌ ៤១០។

[5604] *សូមមើល* រឿងក្តី *Karemera និង Ngirumpatse* កថាខណ្ឌ ៥៦៤ ("អង្គជំនុំជម្រះឧទ្ធរណ៍យល់ឃើញថា ពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការជំទាស់របស់ Karemera ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិភាក្សាលើបញ្ហាថាតើ គាត់អាចដឹងជាមុនបានថា អាវុធបុរាណត្រូវបានជាវតាមរយៈកញ្ចប់ថវិការក្នុងគោលបំណងកម្ទេចប្រជាជន Tutsi។ បញ្ហានៃ"ភាពអាចដឹងជាមុនបាន" ជាប់ពាក់ព័ន្ធទៅនឹងទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួម ពុំមែនទម្រង់មូលដ្ឋានដែលបានផ្អែកក្នុងការដាក់ពិរុទ្ធ Karemera នោះទេ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ Karemera ត្រូវបដិសេធចោល")។ សាលដីការឿងក្តី *Šainović និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ១០១៤ ("អង្គជំនុំជម្រះឧទ្ធរណ៍ព្រួយបារម្ភថា ក្នុងការសំអាងទៅលើការដឹងរបស់ Ëainović អំពីព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងឆ្នាំ ១៩៩៨ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ភាសាដែលបង្ហាញថា អង្គជំនុំជម្រះអាចមានកំហុសអង្គច្បាប់ពាក់ព័ន្ធទៅនឹងបទដ្ឋាននៃអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ I។ ជាពិសេស ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើលទ្ធភាពរបស់ Šainović "ក្នុងការប៉ាន់ស្មាន"ស្ថានការណ៍ក្នុងឆ្នាំ ១៩៩៩ ដូចគ្នានឹងបទដ្ឋានស្តីពីការដឹងជាមុនដែលមាននៅក្នុងលក្ខខណ្ឌធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ III។ យោងតាមសហឧក្រិដ្ឋកម្មរួមទម្រង់ I ជនជាប់ចោទត្រូវតែរួមចំណែកសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ និងពុំមែនត្រឹមតែអាចដឹងជាមុននូវការកើតឡើងនោះទេ")។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simutović* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-03-69-T សាលក្រម (ភាគ II) ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ជើងទំព័រ ២១៩៣ ("អង្គជំនុំជម្រះបន្ត [...] ថា ទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានចេតនាជាលក្ខណៈផ្ទាល់ និងថា ការធ្វេសប្រហែស ឬចេតនាប្រយោល *dolus eventualis* ពុំមានលក្ខណៈគ្រប់គ្រាន់")។

[5605] សាលដីការឿងក្តី *Tadić* (ICTY) កថាខណ្ឌ ១៩៦, ២២០។

នាផ្ទាល់ ប៉ុន្តែលើសពីការធ្វេសប្រហែសធម្មតា (ដូចជា ចេតនាប្រយោល ឬការមិនអើពើនឹងផលវិបាក) ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងត្រូវបានចាត់ទុកថា *ជាការធ្វើមនុស្សឃាតដោយចេតនា*"[5606]។

1959. ជាការពុំត្រឹមត្រូវក្នុងការតម្រូវឱ្យមានកម្រិតធាតុផ្សំអត្តនោម័តិសម្រាប់ទម្រង់នៃការចូលរួមខ្ពស់ជាងសម្រាប់ឧក្រិដ្ឋកម្មមូលដ្ឋាន។ ប្រសិនបើបុគ្គលម្នាក់ទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់ការប្រព្រឹត្ត *ដោយចេតនាប្រយោល* នូវបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បុគ្គលនោះ គប្បីត្រូវដាក់ឱ្យទទួលខុសត្រូវដូចគ្នាសម្រាប់ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលបានប្រព្រឹត្តបទឧក្រិដ្ឋតែមួយដូចគ្នានោះ។ ដូចការពន្យល់របស់អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ថា "ការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែលើបុគ្គលដែលជាចារីម្នាក់បានប្រព្រឹត្តជាសត្យានុម័តនូវអំពើល្មើស គឺជាការពុំពិចារណាលើតួនាទីដែលជាសហចារីជាមួយបុគ្គលដទៃទៀតដែលមានពេលខ្លះបានជួយចារីនោះដោយផ្ទាល់ដើម្បីអាចប្រព្រឹត្តអំពើល្មើសនោះបាន"[5607]។

---

[5606] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤០៩។ *សូមមើលផងដែរ* សាលដីកាវឿងក្តី *Stakić* (ICTY) កថាខណ្ឌ ៥៨៧ ពន្យល់ថា "ច្បាប់អាល្លឺម៉ង់យកចេតនាប្រយោល *dolus eventualis* ជាការគ្រប់គ្រាន់ក្នុងការបង្កើតបានជាអំពើមនុស្សឃាតដោយចេតនា" និងការយល់ឃើញដែលថា *dolus eventualis* បំពេញតាមលក្ខខណ្ឌនៃធាតុផ្សំអត្តនោម័តិសម្រាប់អំពើមនុស្សឃាតដែលជាការរំលោភបំពានលើច្បាប់ ឬទម្លាប់នៃសង្គ្រាម។ *សូមមើលផងដែរ* អ្នកនិពន្ធ Johan D. Van der Vyver "តុលាការព្រហ្មទណ្ឌអន្តរជាតិ និងគោលគំនិតនៃធាតុផ្សំអត្តនោម័តិ" (ឆ្នាំ ២០០៤) 12(1) *U Miami Int'l & Comp. L. Rev.* លើកទី ៥៧ ទំព័រ ៦១-៦៣:

> សញ្ញាណនៃអំពើខុសឆ្គង មានចេតនា(*dolus*) ឬការធ្វេសប្រហែស(*culpa*)។ អំពើដែលត្រូវបានប្រព្រឹត្តដោយចេតនា គឺនៅពេលដែលចារីបានគិតទុកជាមុននូវអំពើល្មើស និង/ឬផលវិបាកគ្រោះថ្នាក់នៃអំពើនោះ។ ការធ្វេសប្រហែសបង្ហាញនូវទំនោរចិត្តរបស់បុគ្គលដែលប្រព្រឹត្តអំពើល្មើស និងបើទោះបីជាបុគ្គលដែលបានប្រព្រឹត្តអំពើនោះពុំមានចេតនាប្រព្រឹត្តខុសច្បាប់ក៏ដោយ ឬបង្កផលវិបាកដែលមានគ្រោះថ្នាក់ឡើយ ដែលការធ្វើដូច្នោះ ចារីបានប្រាស់ចាកពីទង្វើដែលត្រូវបានរំពឹងទុកដោយបុគ្គលសមហេតុផលក្នុងកាលៈទេសៈដូចគ្នា។ បុគ្គលដែលប្រព្រឹត្តដោយចេតនា អាចដឹងជាមុននូវអនីត្យានុកូលភាព និងផលវិបាកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ចំណែកបុគ្គលដែលប្រព្រឹត្តដោយធ្វេសប្រហែស ពុំបានយល់ដឹងនូវអនីត្យានុកូលភាព ឬផលវិបាកដែលគ្រោះថ្នាក់នៃអំពើរបស់ខ្លួនឡើយ នៅពេលដែលបុគ្គលសមហេតុផលក្នុងកាលៈទេសៈធម្មតាអាចដឹងជាមុនបាន និងអាចបញ្ចៀសអំពើអនីត្យានុកូលភាពនោះ ឬផលវិបាកដែលគ្រោះថ្នាក់នៃអំពើនោះបាន។ [...] ចេតនាអាចមានក្នុងទម្រង់មួយក្នុងចំណោមទម្រង់ទាំងបីនោះ និងដើម្បីបែងចែកច្បាស់លាស់នូវអត្ថិភាព ឬណត្ថិភាពនៃចេតនាក្នុងការបង្កឱ្យមានផលវិបាកគ្រោះថ្នាក់ដែលកើតចេញពីអំពើសកម្ម ឬអកម្ម [មាន ចេតនាផ្ទាល់ *dolus directus*, ចេតនាមិនផ្ទាល់ *dolus indirectus*, និង ចេតនាប្រយោល *dolus eventualis* ចែកចេញបីទម្រង់]។

[5607] សាលដីកាវឿងក្តី *Tadić* (ICTY) កថាខណ្ឌ ១៩២។

1960.អង្គជំនុំជម្រះតុលាការកំពូលពុំបានចាត់ទុកវិធីសាស្ត្រនេះថាជា“ការកែប្រែគោលគំនិតនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់អំពើល្មើសជារួម”[5608]។ លក្ខខណ្ឌសម្រាប់ការទទួលខុសត្រូវពុំត្រូវបានបន្ទាបចុះតាមរយៈការពិចារណាថា បុគ្គលម្នាក់អាចទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មណាមួយក្នុងផែនការរួមដរាបណាមានការដឹងជាមុនបានតាមធម្មតានូវការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ[5609]។ ក្នុងការដាក់ឱ្យទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមត្រូវតែមានធាតុផ្សំអត្តនោម័តិដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទឧក្រិដ្ឋជាមូលដ្ឋានដែលជាប់មកជាមួយនៅក្នុងផែនការរួមនោះ[5610]។ ជាឧទាហរណ៍ បុគ្គលម្នាក់ពុំអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមសម្រាប់បទប្រល័យពូជសាសន៍ដែលអាចដឹងជាមុន ប៉ុន្តែពុំមានចេតនា ដោយសារបទឧក្រិដ្ឋប្រល័យពូជសាសន៍នេះតម្រូវឱ្យមានចេតនាផ្ទាល់។

1961.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នៅពេលដែលគោលបំណងរួមត្រូវបានសន្និដ្ឋានចេញពីព្រឹត្តិការណ៍ នេះមានសារៈសំខាន់ជាពិសេសក្នុងការកំណត់ថា តើបទល្មើសមួយណាស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម និងថាតើ មានការឯកភាពគ្នានៃចេតនាពីអ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួមពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនោះ ដែរ ឬយ៉ាងណា នៅពេលអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមបានទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាគោលដៅ ជាផលវិបាកមិនអាចជៀសរួចនៃគោលបំណងបឋម ឬជាយថាហេតុដែលបានប្រព្រឹត្តឡើងដោយការមិនអើពើនូវផលវិបាក[5611]។ នេះគឺដោយសារលទ្ធផលនឹងមានលក្ខណៈខុសប្លែកគ្នាខ្លាំងអាស្រ័យលើបញ្ហាថាតើបទឧក្រិដ្ឋដែលចោទជាបញ្ហានេះ ត្រូវបានចាត់ទុកថា ស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម ដែរ ឬយ៉ាងណា។ ដូចការពន្យល់ក្នុងសំណុំរឿង ០០២/០១ ថា “បញ្ហាថាតើបទឧក្រិដ្ឋត្រូវបានគិតទុកជាមុនតាមរយៈគោលបំណងរួម ដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហាអង្គហេតុដែលដោយសារពុំមានការព្រមព្រៀងច្បាស់លាស់ តម្រូវឱ្យធ្វើការវាយតម្លៃដោយពិចារណាលើវាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅជារួមនៃគោលបំណងរួម និងភវនីយភាពដែលគោលបំណងរួម

---

[5608] *សូមមើល* អ្នកនិពន្ធ Cóman Kenny “យុត្តិសាស្ត្របន្តវិវឌ្ឍៈ វិសោធនកម្មរបស់ អ.វ.ត.ក.លើការទទួលខុសត្រូវនៃគោលបំណងរួម”ក្នុង(ឆ្នាំ ២០១៨) អត្ថបទនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិទី ១៦ ទំព័រ ៦២៣, ៦២៤។

[5609] អ្នកអត្ថាធិប្បាយខ្លះហាក់បីដូចជាជឿជាក់។ *សូមមើល* អ្នកនិពន្ធ Elinor Fry និង Elies van Sliedregt “ក្រុមគោលដៅការរំលោភសេពសន្ថវៈ និងចេតនាប្រយោល *Dolus Eventualis*” ក្នុង (ឆ្នាំ ២០២០) អត្ថបទនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិទី ១៨ ទំព័រ ៧០១, ៧១៩។

[5610] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១០៥៣។

[5611] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៩។

អាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ"[5612]។ បើទោះបីជាអត្ថិភាពនៃគោលបំណងរួម បទឧក្រិដ្ឋដែលត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួម និងការព្រមព្រៀងគ្នានៃចេតនាទាក់ទងទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម អាចបង្ហាញដោយប្រយោល និងអាចសន្និដ្ឋានបានតាមរយៈភស្តុតាងក៏ដោយ ក៏ត្រូវតែធ្វើឡើងដោយសមហេតុផលតែមួយគត់ដោយផ្អែកលើភស្តុតាងដែលមាននោះ។

1962.ដោយសារមានកំហុសក្នុងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងធាតុផ្សំអត្តនោម័តិដែលតម្រូវសម្រាប់ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម និងការខកខានក្នុងការពិចារណាលើការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន សម្រាប់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តដោយចេតនាប្រយោលក្នុងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហាថាតើ អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយ *ចេតនាប្រយោល* ស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម ដែរ ឬយ៉ាងណា។ ប្រសិនបើអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ត្រូវបានចាត់ទុកថាជាផ្នែកនៃគោលបំណងរួម អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវវាយតម្លៃលើការទទួលខុសត្រូវរបស់ ខៀវ សំផន សម្រាប់បទឧក្រិដ្ឋនេះតាមរយៈសហឧក្រិដ្ឋកម្មរួម ដោយសារអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈសហឧក្រិដ្ឋកម្មរួមបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងសមស្របបំផុតនូវការទទួលខុសត្រូវរបស់ ខៀវ សំផន សម្រាប់បទឧក្រិដ្ឋដែលស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម"[5613]។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន ទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះនឹងត្រូវកែប្រែការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទជួយទំនុកបម្រុងដល់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ទៅជាការប្រព្រឹត្តឧក្រិដ្ឋកម្មនេះតាមរយៈសហឧក្រិដ្ឋកម្មរួម។

1963.វិធាន ១១០(២) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតអង្គជំនុំជម្រះតុលាការកំពូលកែប្រែប្រភេទបទចោទដែលមាននៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដើម្បីឱ្យស្របជាមួយនឹងទម្រង់ថ្មីនៃការទទួលខុសត្រូវ[5614]

[5612] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៨។

[5613] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១១។

[5614] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៩៣ ចំណុចដែលអង្គជំនុំជម្រះសាលាដំបូង បកស្រាយវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងថា:

> ភាគីពុំបានជំទាស់ថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមានការកែប្រែការកំណត់ប្រភេទបទចោទ និងទម្រង់នៃការទទួលខុសត្រូវដែលបានរួមបញ្ចូលក្នុងដីកាដំណោះស្រាយដែលបានកែប្រែ។ នៅពេលបទប្បញ្ញត្តិប្រហាក់ប្រហែល

ដរាបណា អង្គជំនុំជម្រះពុំត្រូវកែប្រែហួសពីអង្គហេតុទាំងនោះ[5615] ឬរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ជនជាប់ចោទ ពុំត្រូវបានរំលោភបំពានដោយការកែប្រែប្រភេទបទចោទនេះទេ ដោយសារជនជាប់ចោទបានដឹងអំពីលទ្ធភាពនៃការកែប្រែនេះ និងត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការការពារអត្ថប្រយោជន៍របស់ខ្លួន[5616]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន ដូចបានលើកឡើងក្នុងផ្នែក V.ខ ខាងលើ ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែត្រូវបានជូនដំណឹងថា អង្គហេតុដែលត្រូវបានចាត់ទុកថាជាបទសម្លាប់រង្គាល អាចត្រូវបានកែប្រែទៅជាបទមនុស្សឃាតផងដែរ និងថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់លាស់ថា អំពើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើង*ដោយចេតនាប្រយោល*[5617]។ ខៀវ សំផន បានដឹងថា អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់លាស់ផងដែរថា បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយ *ចេតនាប្រយោល* អាចដាក់ឱ្យទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្ម[5618]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ការកែប្រែប្រភេទបទចោទនេះពុំបានរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវនោះឡើយ។

### ក. ថាតើ គោលបំណងរួមបានរួមបញ្ចូលអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ដែរ ឬយ៉ាងណា

---

គ្នាក្នុងប្រព័ន្ធច្បាប់កម្ពុជាពុំបានបញ្ជាក់ជាក់លាក់នូវការកែប្រែទម្រង់នៃការទទួលខុសត្រូវ អង្គជំនុំជម្រះជឿជាក់ថា ការកែប្រែប្រភេទនេះអាចធ្វើទៅបានស្របតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង គឺដូចគ្នាទៅនឹងវិធាន ១១០(២) នៃវិធានផ្ទៃក្នុង ប៉ុន្តែត្រូវអនុវត្តចំពោះអង្គជំនុំជម្រះសាលាដំបូងជាជាងអង្គជំនុំជម្រះតុលាការកំពូល។

[5615] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៩៣-៤៩៦។

[5616] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៩៧-៥០០ ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងពិនិត្យលើមាត្រា ៣៥ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. យុត្តិសាស្ត្ររបស់តុលាការ ECtHR បទប្បញ្ញត្តិ ៥៥ នៃ ICC និងយុត្តិសាស្ត្រ ICC និងបានកំណត់ថា សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ជនជាប់ចោទ ពុំត្រូវបានរំលោភបំពានដោយសារការកែប្រែប្រភេទបទចោទដែលជនជាប់ចោទបានដឹងនូវលទ្ធភាពនៃការកំណត់សាឡើងវិញ និងត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ក្នុងការការពារអត្ថប្រយោជន៍ខ្លួន។

[5617] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៤០៩។

[5618] *សូមមើល* សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) កថាខណ្ឌ ៤៥២, ៤៥៩-៤៦២, ៤៧០, ៤៩៨ ដែលក្នុងនោះរាល់បញ្ហាត្រូវបានដោះស្រាយ។

1964.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហាថាតើ អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនោះ ដែលបានកើតឡើងតាមទីកន្លែងខាងក្រោមនេះ ស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណាដូចជា៖ (១) សហករណ៍ត្រាំកក់ (២) ការដ្ឋានធ្វើការទំនប់១មករា (៣) ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម (៤) ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង (៥) មន្ទីរសន្តិសុខស-២១ (៦) មន្ទីរសន្តិសុខក្រាំងតាចាន់ និង (៧) មន្ទីរសន្តិសុខភ្នំក្រោល។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនៅតាមទីតាំងទាំងនេះ ពុំស្ថិតក្នុងវិសាលភាពនៃគោលបំណងរួម ដោយសារអង្គជំនុំជម្រះមានកំហុសក្នុងការពិចារណាថា ការទទួលខុសត្រូវតាមរយៈសហឧដក្រិដ្ឋកម្មរួម ពុំអាចស្របទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនោះទេ[5619]។

1965.អំពើមនុស្សឃាតទាំងនេះត្រូវបានយល់ឃើញថាបានកើតឡើងដោយសារលក្ខខណ្ឌនៃការរស់នៅនិងការងារធ្ងន់ធ្ងរនៅតាមសហករណ៍ និងការដ្ឋានធ្វើការ[5620] ព្រមទាំងលក្ខខណ្ឌដ៏អាក្រក់នៃការឃុំឃាំង (រួមទាំងវិធីសាស្ត្រនៃការសួរយកចម្លើយដែលបានប្រើប្រាស់) នៅតាមមន្ទីរសន្តិសុខ[5621]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លក្ខខណ្ឌរស់នៅ និងការងារដ៏ធ្ងន់ធ្ងរនៅតាមសហករណ៍ និងការដ្ឋានធ្វើការ ត្រូវបានប្រើប្រាស់ជាមធ្យោបាយជម្រុញគោលបំណងរួម ដោយសារ"មានសារៈសំខាន់ក្នុងការគ្រប់គ្រងរបស់រដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជាលើអ្នកធ្វើការ និងការអនុវត្តន៍គោលបំណងបដិវត្តន៍"[5622]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ការដាក់លក្ខខណ្ឌនៃការឃុំឃាំងដ៏អាក្រក់គឺជាមធ្យោបាយប្រើប្រាស់ដើម្បីគ្រប់គ្រងលើអ្នកជាប់ឃុំឃាំង និងត្រូវបានប្រើប្រាស់ជាមធ្យោបាយជម្រុញគោលបំណងរួម[5623]។ អាស្រ័យហេតុនេះ តម្រូវឱ្យមានការពិនិត្យលើបញ្ហាថាតើ សមាជិកសហឧក្រិដ្ឋកម្មរួម ដោយផ្ទាល់ ឬ

---

[5619] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩២១, ៣៩៧៧។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា អំពើមនុស្សឃាតដោយចេតនាប្រយោលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ប៉ុន្តែបានពិភាក្សាក្នុងផ្នែក VII.៥.ង *ខាងលើ* ការយល់ឃើញនេះត្រូវបដិសេធចោល។

[5620] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១១៤៥ (សហករណ៍ស្រុកត្រាំកក់) ១៣៨៤, ១៣៨៨ (ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម) ១៦៧០, ១៦៧២ (ការដ្ឋានធ្វើការទំនប់១មករា) និង ១៨០០, ១៨០៤ (ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង)។

[5621] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៦៨ (មន្ទីរសន្តិសុខ ស-២១) ២៨១៥ (មន្ទីរសន្តិសុខក្រាំងតាចាន់) និង ៣១១៦ (មន្ទីរសន្តិសុខភ្នំក្រោល)។

[5622] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩២៦។

[5623] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩៨៥។

ដោយប្រយោល បានរួមចំណែកការយល់ដឹង និងការទទួលយកនូវការស្លាប់ដែលអាចដឹងជាមុនបានដោយសារការដាក់លក្ខខណ្ឌទាំងនេះ ដែរ ឬយ៉ាងណា[5624]។

1966.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន ផ្ទាល់ខ្លួនបានយល់ដឹងថា ការស្លាប់នោះទំនងជាបណ្តាលមកពីលក្ខខណ្ឌដែលបានដាក់នៅតាមសហករណ៍ និងការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខនានា[5625]។ អង្គជំនុំជម្រះបានពិចារណាថា ការដឹងរបស់គាត់អំពីភវនីយភាពខ្ពស់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម មួយផ្នែក គឺដោយសារភាពស្និទ្ធស្នាលជាមួយនឹងមជ្ឈិមបក្ស[5626] និងបានយល់ឃើញផងដែរថា គណៈមជ្ឈិម និងជាពិសេសគណៈអចិន្ត្រៃយ៍“បានទទួលការជូនដំណឹងពេញលេញអំពីបញ្ហាដែលប៉ះពាល់ដល់ការរស់នៅរបស់អ្នកធ្វើការ និងកសិករតាមមូលដ្ឋាន សហករណ៍ និងការដ្ឋាន រួមទាំងកង្វះស្បៀងអាហារ បញ្ហាសុខភាព និងថ្នាំពេទ្យពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”[5627]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា នួន ជា ក្នុងចំណោមសមាជិកនៃសហឧក្រិដ្ឋកម្មរួម“នៅគ្រប់ពេលបានដឹងអំពីធាតុផ្សំនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល និងបានជួយសម្រួលដល់ការប្រព្រឹត្តអំពើនោះ”[5628]។ ភស្តុតាងដែលបានអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើពុំមែនមានលក្ខណៈពិសេសសម្រាប់តែ ខៀវ សំផន និង នួន ជា នោះទេ។ នេះប្រាកដជាមានការពិចារណាថា ពួកគាត់ពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមតែពីរនាក់ប៉ុណ្ណោះទេ ដែលបានរួមចំណែកការយល់ដឹងថា ការស្លាប់ទំនងជាកើតឡើងដោយសារការដាក់លក្ខខណ្ឌនោះ។ ផ្ទុយទៅវិញនេះគឺជាការយល់ដឹងធម្មតាក្នុងចំណោមអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមទាំងអស់។ អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់១មករា ការ

---

[5624] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨០៩: “អ្វីដែលគប្បីបញ្ជាក់គឺថា [...] មានការត្រូវរ៉ូវគ្នានៃចេតនា ទាក់ទងទៅនឹងបទឧក្រិដ្ឋនេះដែលអ្នកទាំងនោះបានយល់ព្រមជាមួយនឹងគោលបំណងរួម។ ដូច្នេះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមប្រាកដជាទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ដែលជាគោលបំណង ជាផលវិបាកជៀសពុំរួចនៃគោលបំណងបឋម ឬជាយថាហេតុដែលបានប្រព្រឹត្តដោយការមិនអើពើលើផលវិបាក”។

[5625] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៥, ៤៣១៧។ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ក្នុងការបង្កើតការយល់ឃើញនេះ នឹងត្រូវដោះស្រាយក្នុងផ្នែកខាងក្រោម។

[5626] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៨។

[5627] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៣៩១៣។

[5628] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤១៨៣។

ដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។

ខ. ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមរបស់ ខៀវ សំផន សម្រាប់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល

1967.ក្នុងការដាក់ឱ្យទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមសម្រាប់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ខៀវ សំផន ត្រូវតែបានរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ហើយគាត់ត្រូវតែមានធាតុផ្សំអត្តនោម័តិតម្រូវក្នុងរឿងក្តីនេះដូចបានពិភាក្សាខាងលើថា គាត់បានដឹងអំពីភវនីយភាពខ្ពស់នៃការស្លាប់ដែលបានកើតឡើងដោយសារការដាក់លក្ខខណ្ឌនៃការរស់នៅ និងការធ្វើការធ្ងន់ធ្ងរនៅតាមសហករណ៍ និងការដ្ឋានធ្វើការ និងលក្ខខណ្ឌដ៏អាក្រក់នៃការឃុំឃាំងនៅតាមមន្ទីរសន្តិសុខ។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់នៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម[5629]។

1968.ដូចបានលើកឡើងខាងដើម ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានដកអំពើមនុស្សឃាតទាំងនេះចេញពីគោលបំណងរួម ទើបអង្គជំនុំជម្រះវាយតម្លៃថា ខៀវ សំផន ទទួលខុសត្រូវចំពោះការជួយទំនុកបម្រុងដល់អំពើមនុស្សឃាតទាំងនោះដោយចេតនាប្រយោល។ នៅក្នុងការពិចារណារបស់ខ្លួនអំពីធាតុផ្សំអត្តនោម័តិសម្រាប់ការទទួលខុសត្រូវនូវការជួយទំនុកបម្រុង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីភវនីយខ្ពស់នៃការស្លាប់ដែលបានកើតឡើងដោយសារការដាក់លក្ខខណ្ឌ[5630]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើការជំទាស់របស់ ខៀវ សំផន ដែលបានលើកឡើងពាក់ព័ន្ធទៅនឹងការយល់ឃើញនេះ។

1969.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា និងទស្សនកិច្ចរបស់គាត់នៅតាមសហករណ៍ និងការដ្ឋានធ្វើការ ដែលគាត់ "បានសង្កេតឃើញនូវលក្ខខណ្ឌរស់នៅ និងការធ្វើការដ៏អាក្រក់របស់កម្មករកសិករ រួមទាំងការអត់អាហារ និងជំងឺ"[5631]

---

[5629] *សូមមើលខាងលើ* ផ្នែក VIII.ខ.៧។

[5630] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៥-៤៣១៧។

[5631] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៣-៤៣១៤។

។ ផ្អែកលើចំណុចនេះ និងការពិភាក្សាដំបូងក្នុងផ្នែក ១៨.១.១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន អំពីភវនីយភាពខ្ពស់នៃឧក្រិដ្ឋកម្មដទៃទៀត អង្គជំនុំជម្រះសាលាដំបូង "ជឿជាក់ថា ខៀវ សំផន បានដឹងថា ការស្លាប់ទំនងជាបណ្តាលមកពីលក្ខខណ្ឌដែលបានដាក់នៅតាមសហករណ៍ និងការដ្ឋានធ្វើការ"[5632]។ ពាក់ព័ន្ធនឹងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌតាមមន្ទីរសន្តិសុខ អង្គជំនុំជម្រះរំឭកថា៖

> ខៀវ សំផន បានដឹងពីការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើបាប និងការសម្លាប់ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក.។ ដោយសារតែឋានៈលេចធ្លោររបស់គាត់ក្នុងជួរបក្ស ខៀវ សំផន បានចូលរួម និងគាំទ្រកិច្ចប្រជុំរបស់ស្ថាប័នធ្វើសេចក្តីសម្រេចដែលមានការពិភាក្សាពីជោគវាសនារបស់ខ្មាំង និងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ ប.ក.ក.។ ក្រៅពីនេះ ខៀវ សំផន បានអំពាវនាវដោយបើកចំហឲ្យមានការសម្លាប់អ្នកដែលក្បត់បក្សឬបដិវត្តន៍។ ក្នុងការពិភាក្សាខាងលើ ជាទូទៅ ខៀវ សំផន បានដឹងពីស្ថានភាពអត់ឃ្លាន ការលុបបំបាត់មិនឲ្យមានថ្នាំសង្កូវគ្រប់គ្រាន់ឬមានប្រសិទ្ធភាព និងការធ្វើទុក្ខទោសលើខ្មាំងពិតប្រាកដឬតាមការសន្មតរបស់ ប.ក.ក. ដោយកម្មាភិបាលនៅសហករណ៍ និងការដ្ឋានការងារនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ក្នុងការអនុវត្តដាច់ខាតនូវគោលនយោបាយរបស់បក្ស។ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានដឹងពីភវនីយភាពច្បាស់លាស់ថា ការអនុវត្តនេះបានពង្រីកទៅដល់មន្ទីរសន្តិសុខនានា[5633]។

1970.ផ្អែកតាមការដឹងឮរបស់គាត់អំពីការបោសសម្អាតនៅកម្រិតខ្ពស់ និងកម្រិតទាប និងចេតនារួមរបស់គាត់ក្នុងការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់អ្នកទាំងនោះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានដឹងថា ការស្លាប់នឹងកើតឡើងដោយសារការដាក់លក្ខខណ្ឌនៅតាមមន្ទីរសន្តិសុខ[5634]។

1971.ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារពុំមានភស្តុតាងក្នុងកម្រិតដែលតម្រូវថា គាត់បានដឹងអំពីភវនីយភាពពិតប្រាកដថា ការស្លាប់នោះបណ្តាលមកពីលក្ខខណ្ឌដែលបានដាក់តាមសហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខ[5635]។ គាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើការយល់ឃើញដែលបានបង្កើតឡើងក្នុងផ្នែក

---

[5632] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៥។

[5633] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៦។

[5634] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៦-៤៣១៧។

[5635] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៣, ២១៣៧, ២១៤០។

១៨.១.១ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលពុំជាប់ពាក់ព័ន្ធទៅនឹងការដឹងនៃការស្លាប់ដោយសារលក្ខខណ្ឌដែលបានដាក់តាមសហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខ[5636]។ ពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌដែលបានដាក់តាមមន្ទីរសន្តិសុខ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានរំឭកការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការដឹងអំពីការបោសសម្អាត[5637]។ គាត់បានបន្ថែមថា ពុំមានភស្តុតាងគាំទ្រការយល់ឃើញដែលថា គាត់បានដឹងអំពីភវនីយភាពថា ការស្លាប់នឹងកើតមានដោយសារលក្ខខណ្ឌដែលបានដាក់ទៅតាមសហករណ៍ និងការដ្ឋានធ្វើការ[5638] ឬថា គាត់បានដឹងថា ការអនុវត្តន៍ទាក់ទងទៅនឹងការប្រព្រឹត្តលើសត្រូវទំនងជាបណ្ដាលឱ្យមានការស្លាប់ក្នុងមន្ទីរសន្តិសុខ[5639]។

1972.សហព្រះរាជអាជ្ញាបានអះអាងថា ការអះអាងរបស់ ខៀវ សំផន "ពុំត្រឹមត្រូវ និងគ្មានមូលដ្ឋានគាំទ្រ" ដោយសារគាត់"ខកខានក្នុងការលើកអំណះអំណាងគាំទ្រត្រឹមត្រូវ" និងពុំបានបង្ហាញកំហុសដែលនាំឱ្យសាលក្រមនោះមោឃៈ ឬបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ឡើយ[5640]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ឡើងវិញនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[5641] និងថា ខៀវ សំផន "ខកខានក្នុងការលើកអំណះអំណាងដែលបង្ហាញនូវកំហុស"ក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់មានធាតុផ្សំអត្តនោម័តិពាក់ព័ន្ធនោះ[5642]។

1973.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សារណារបស់ ខៀវ សំផន ត្រឹមតែពុំយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងពុំបានលើកឡើងនូវអំណះអំណាងទាក់ទងទៅនឹងមូលហេតុដូចម្ដេចបានជាការយល់ឃើញនោះពុំសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានបញ្ជាក់ពីដំបូងរួចហើយថា អង្គជំនុំជម្រះនឹងត្រូវអនុវត្ត"បទដ្ឋានស្ដីពីភាពសមហេតុផលក្នុងការ

---

[5636] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៣៨, ២១៤០។

[5637] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤០។

[5638] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៣៨ យោងទៅលើកថាខណ្ឌ ១៨០៨-១៨១០។

[5639] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤០ យោងទៅលើកថាខណ្ឌ ១៨០៨-១៨១៥។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ១៨៥៣។

[5640] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៧៧, ១២៨១។

[5641] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៨២, ជើងទំព័រ ៤៦៨០-៤៦៨១, ៤៦៩៣ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣១៦-៤៣១៧។ សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៧៨ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២០៦-៤២០៨, ៤២១០-៤២១១, ៤២១២, ៤២១៤, ៤២១៦, ៤២៥៨, ៤៣១៣-៤៣១៤។

[5642] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៧៩, ១២៨៣។

ពិនិត្យលើការយល់ឃើញដែលរងការជំទាស់ផ្នែកអង្គហេតុ ប៉ុន្តែពុំមែនលើបញ្ហាថាតើការយល់ឃើញនោះត្រូវ ឬខុសនោះទេ”[5643]។ ដូច្នេះ“អំណះអំណាង ដែលត្រូវបានកម្រិតត្រឹមតែការមិនយល់ស្របជាមួយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង [...] ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបដិសេធការយល់ឃើញផ្នែកអង្គហេតុនេះបានឡើយ”[5644]។

1974.បើទោះបីជា ខៀវ សំផន បានលើកឡើងត្រឹមត្រូវថា ការយល់ឃើញដែលបានបង្កើតឡើងក្នុងផ្នែក ១៨.១.១ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើផ្នែកខ្លះ ពុំមែនបង្កើតឡើងជាការឆ្លើយតបទៅនឹងការដឹងអំពីការស្លាប់ដោយសារលក្ខខណ្ឌដែលបានដាក់តាមសហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខក៏ដោយ ក៏ការយល់ឃើញទាំងនេះជាប់ពាក់ព័ន្ធទៅនឹងការដឹងអំពីការស្លាប់ដែរ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងនៃការដឹងរបស់ ខៀវ សំផន អំពីភវនីយភាពខ្ពស់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដទៃទៀតក្នុងវិសាលភាពនៃគោលបំណងរួមតាមរយៈសហឧក្រិដ្ឋកម្មរួមយ៉ាងលម្អិតក្នុងផ្នែកនោះ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គាត់បាន“ដឹងអំពីកង្វះស្បៀងអាហារទ្រង់ទ្រាយធំនៅតាមសហករណ៍ និងការដ្ឋានធ្វើការ”[5645]។ អង្គជំនុំជម្រះបានពិចារណាលើភស្តុតាងដែលគាត់បានសង្កេតឃើញដោយផ្ទាល់នូវលក្ខខណ្ឌតាមការដ្ឋានធ្វើការ[5646] និងបានឃើញនូវលក្ខខណ្ឌគួរឱ្យរន្ធត់ទាំងនោះ[5647]។ តាមរយៈការទទួលស្គាល់ផ្ទាល់ខ្លួន និងការពិពណ៌នាបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានឃើញ“ការអត់អាហារ” “ខ្វះថ្នាំពេទ្យ” និង“ប្រជាជនដែលត្រូវបានបង្ខំឱ្យធ្វើការដោយឥតអាហារ ខណៈពេលដែលពួកគេហេវហត់ដើរស្ទើរដួល ប៉ុន្តែបើទោះជាយ៉ាងនេះក្តី ក៏ពួកគេត្រូវបានបង្ខំឱ្យធ្វើការធ្ងន់ទៀត”[5648]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជាលទ្ធផលថា គាត់“បានដឹងអំពីលក្ខខណ្ឌការងារដ៏អាក្រក់នៅតាមសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”[5649] និង“បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងស្របតាមគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិសហករណ៍

---

[5643] *សូមមើល* សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៨៨។ សាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០១ កថាខណ្ឌ ១៧។

[5644] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ៩០។

[5645] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១២។

[5646] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៣។

[5647] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៤។

[5648] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៤ ដកស្រង់កិច្ចសម្ភាសន៍របស់ ខៀវ សំផន គ្មានកាលបរិច្ឆេទ ឯកសារលេខ E3/4050 ERN 00786553។

[5649] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៦។

និងការដ្ឋានធ្វើការ”[5650]។ នេះបានផ្អែកលើមូលដ្ឋាននៃការយល់ឃើញទាំងនេះព្រមទាំងការដឹងរបស់ ខៀវ សំផន ដូចបានបង្ហាញតាមរយៈអំពើរបស់គាត់ រួមទាំងការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា សុន្ទរកថាផ្សាយតាមវិទ្យុ និងវគ្គបណ្តុះបណ្តាលនយោបាយដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “គាត់បានដឹងថា ការស្លាប់ទំនងជាកើតមានដោយសារលក្ខខណ្ឌដែលបានដាក់តាមសហករណ៍ និងការដ្ឋានធ្វើការ”[5651]។

1975.ពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីភវនីយភាពនៃការស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំឃាំង អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹង ខៀវ សំផន ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើការដឹងរបស់គាត់អំពីការបោសសម្អាតដើម្បីបង្ហាញនូវការដឹងតាមមន្ទីរសន្តិសុខនានា។ អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ហេតុដូចម្តេចបានជា ការដឹងរបស់ ខៀវ សំផន អំពីការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើបាប ឬការសម្លាប់ខ្មាំងពិតប្រាកដ ឬតាមការសន្មត ក្លាយទៅជាការដឹងថាលក្ខខណ្ឌដែលបានដាក់តាមមន្ទីរសន្តិសុខ ទំនងជានាំឱ្យមនុស្សស្លាប់។ ការដឹងអំពីការស្លាប់ដែលបានកើតឡើងតាមរយៈការសម្លាប់ ពុំបានបង្ហាញនូវការដឹងអំពីការស្លាប់ដោយសារលក្ខខណ្ឌអាក្រក់នៃការឃុំឃាំងនោះឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីភវនីយភាពខ្ពស់ដែលថា លក្ខខណ្ឌធ្ងន់ធ្ងរនៅតាមសហករណ៍ និងការដ្ឋានធ្វើការ បានពន្លាតដល់មន្ទីរសន្តិសុខ[5652]។ ខៀវ សំផន ខកខានក្នុងការពន្យល់នូវមូលហេតុដូចម្តេចបានជាការយល់ឃើញនោះពុំសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ប្រសិនបើ ខៀវ សំផន បានដឹងអំពីភវនីយភាពនៃការស្លាប់ដែលបានកើតឡើងក្នុងសហករណ៍ និងការដ្ឋានធ្វើការ ដោយសារការបង្អត់អាហារ ខ្វះការថែទាំផ្នែកវេជ្ជសាស្ត្រ និងអនាម័យ គាត់ប្រាកដជាបានដឹងប្រហាក់ប្រហែលគ្នាអំពីភវនីយភាពនៃលក្ខខណ្ឌទាំងនោះដែលនាំឱ្យមានការស្លាប់នៅក្នុងមន្ទីរសន្តិសុខដែរ។ ចំណុចដែលសំខាន់ចំពោះការយល់ឃើញទាំងអស់ស្តីពីការដឹងរបស់ ខៀវ សំផន គឺតួនាទីរបស់គាត់ជាអ្នកចូលរួមក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលតាមកំណត់ហេតុខ្លីៗបង្ហាញថា រាល់បញ្ហាស្តីពីអត្ថប្រយោជន៍ និងក្តីបារម្ភត្រូវបានពិភាក្សាជាទៀងទាត់។

---

[5650] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤២១៨។

[5651] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៥។

[5652] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៦។

1976.យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុក្នុងការយល់ឃើញថា គាត់បានដឹងអំពីភវនីយភាពខ្ពស់នៃការស្លាប់នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់១មករា ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនៅទីតាំងឧក្រិដ្ឋកម្មខាងលើ ត្រូវបានរួមបញ្ចូលក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងថា ខៀវ សំផន ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះតាមរយៈសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចកែប្រែទម្រង់នៃការទទួលខុសត្រូវដែលចោទជាបញ្ហានេះពីការជួយទំនុកបម្រុងទៅជាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ដែលនេះជាការកែប្រែនូវការកំណត់ប្រភេទបទចោទដែលបានរៀបរាប់ក្នុងដីកាដំណោះស្រាយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពុំចាំបាច់ធ្វើការពិចារណាបន្ថែមទៀតលើការជំទាស់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការជួយទំនុកបម្រុងនេះឡើយ។

## IX. ការប្រកាសទោស

1977.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់លើការជំទាស់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការប្រកាសទោស ដែលជាដំណាក់កាលសំខាន់ចុងក្រោយនៃកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តីនេះ។

1978.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានតំណាងមុខមាត់ជាសាធារណៈឱ្យកម្ពុជាប្រជាធិបតេយ្យតាមរយៈតួនាទី៖ ដំបូងជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងចាប់តាំងពីដើមឆ្នាំ ១៩៧៦ ជាប្រធានគណៈប្រធានរដ្ឋ[5653]។ ការទទួលខុសត្រូវនៃតួនាទីរបស់គាត់បានពង្រីកដល់ប្រតិបត្តិការស្នូលរបស់បក្ស និងរដ្ឋរួមទាំងការគ្រប់គ្រងលើកិច្ចការពាណិជ្ជកម្ម និងជំនួញរបស់ប្រទេស និងការបណ្តុះបណ្តាលអប់រំផ្នែកនយោបាយ[5654]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា៖

> ខៀវ សំផន "មិនត្រឹមតែស្ថិតក្នុងក្រុមតូចនៃសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលទទួលបានព័ត៌មានគ្រប់គ្រាន់ ដោយសារជាសមាជិកនៃគណៈមជ្ឈិមប៉ុណ្ណោះទេ ថែមទាំងមានតួនាទីពិសេសក្នុងបក្សតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលពិភាក្សាលើបញ្ហានានា និងធ្វើសេចក្តីសម្រេចសំខាន់ៗ"[5655]។

---

[5653] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

[5654] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

[5655] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៦២៤។

គាត់បានធ្វើការ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយឥស្សរជនកំពូលៗក្នុងបក្សកុម្មុយនីស្តកម្ពុជា និងបានរួចផុតពីការបោសសម្អាតនានាលើកម្មាភិបាលជាន់ខ្ពស់[5656]។ គាត់គឺជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកសមគំនិតជាមួយមេដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា[5657]។

1979.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធដោយសារជាមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវ (១) បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់បុគ្គល និងអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (២) បទប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកជនជាតិវៀតណាមនៃក្រុមជាតិពន្ធុ និងជាតិសាសន៍ (៣) ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវតាមរយៈអំពើមនុស្សឃាតគិតទុកជាមុន ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កព្យសនកម្ម ឬការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព និងការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក និងជនស៊ីវិលក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិលដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវនៅមន្ទីរសន្តិសុខ ស-២១[5658]។ អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន មានពិរុទ្ធពីបទជួយទំនុកបម្រុងដល់អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខមួយចំនួនដទៃទៀត[5659]។

1980.បទឧក្រិដ្ឋទាំងនេះបានកើតឡើងពេញមួយអំឡុងពេលនៃយុត្តាធិការពេលវេលានៃ អ.វ.ត.ក. ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ និងក្នុងបរិបទនៃរបបគាបសង្កត់ដែលបានផ្លាស់ទីប្រជាជនដោយបង្ខំ និងបង្ខំឱ្យប្រជាជនធ្វើការ និងរស់នៅស្របតាមគោលបំណងរបស់បក្សកុម្ម

[5656] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៨៩, ៦០៣-៦០៤។

[5657] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦-៤៣០៧។

[5658] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣០៦-៤៣០៧, ៤៣២៦-៤៣២៧។

[5659] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣១៨, ៤៣២៨។

យនីស្តកម្ពុជា[5660] និងបានធ្វើឱ្យប្រជាជនកម្ពុជាជាងមួយលាននាក់ស្លាប់បាត់បង់ជីវិត[5661]។ ប្រសិនបើគ្មានភស្តុតាងជាឯកសារនៅសេសសល់[5662]ដែលភាគច្រើនត្រូវបានបំផ្លាញចោលនោះទេ[5663] នឹងគ្មានអ្វីបង្ហាញនូវបទឧក្រិដ្ឋទាំងនេះ និងតួនាទីរបស់ ខៀវ សំផន ក្រៅតែពីសក្ខីកម្មរបស់អ្នករួចជីវិតពីរបបនោះដែលមានវ័យចំណាស់ៗ និងបាក់ស្បាត និងអដ្ឋិធាតុរបស់អ្នកស្លាប់នោះប៉ុណ្ណោះ។

1981.ខៀវ សំផន បច្ចុប្បន្នមានអាយុ ៩១ ឆ្នាំ[5664] និងបានជាប់ក្នុងមន្ទីរឃុំឃាំងចាប់តាំងពីចុងឆ្នាំ ២០០៧ ដំបូងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងក្រោយមកពេញមួយអំឡុងពេលនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ បច្ចុប្បន្ន គាត់ស្ថិតនៅក្នុងមន្ទីរឃុំឃាំងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតដែលបានប្រកាសដោយអង្គជំនុំជម្រះសាលាដំបូង និងត្រូវបានតម្កល់នៅបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ សម្រាប់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញភ្លា

[5660] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៧៦ ទំព័រ ២២៣០-២២៣១ (ផ្នែកសម្រេចសេចក្តី)។

[5661] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៩៧:

នៅក្នុងឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់អត្តសញ្ញាណអដ្ឋិធាតុមនុស្សប្រមាណជា ១.៣០០.០០០ នាក់ នៅក្នុងទីតាំងរណ្តៅកប់សាកសពរួមនៅទូទាំងប្រទេសកម្ពុជាចំនួន ៣៩០ កន្លែង។ មានតួលេខប៉ាន់ប្រមាណជាច្រើនអំពីចំនួនមនុស្សស្លាប់ដែលបានបង្កឡើងដោយគោលនយោបាយនិងការប្រព្រឹត្តរបស់ ប.ក.ក.។ តួលេខប៉ាន់ប្រមាណទាំងនោះបញ្ជាក់នូវចំនួនមនុស្សស្លាប់ពី ៦០០.០០០ នាក់ ទៅ ៣.០០០.០០០ នាក់។ នៅក្នុងរង្វង់តួលេខនេះ អ្នកជំនាញជាច្រើនទទួលយកតួលេខប៉ាន់ប្រមាណនៃចំនួនអ្នកស្លាប់ពី ១.៥០០.០០០ ទៅ ២.០០០.០០០ នាក់ ថាជាចំនួនដែលពិតប្រាកដបំផុត។ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានរម្លឹកឡើងវិញនូវការយល់ឃើញរបស់ខ្លួនថាអវត្តមានទិន្នន័យស្ថិតិពាក់ព័ន្ធនិងដែលអាចទុកចិត្តបានសម្រាប់គោលបំណងនៃការវាយតម្លៃលើចំនួនមរណភាពជាក់លាក់ដែលជាប់ទាក់ទងនឹង ប.ក.ក. នាំឱ្យមានភាពមិនច្បាស់លាស់ជុំវិញការប្រើប្រាស់ភស្តុតាងប្រជាសាស្ត្រ។

[5662] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “ដោយពិចារណាទៅលើវេលាដែលកន្លងផុតទៅ ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារដែលបានកត់ត្រានូវព្រឹត្តិការណ៍នាសម័យកាលនោះ ដែលត្រូវបានចោទប្រកាន់ គឺជាប្រភពដ៏សំខាន់បំផុតក្នុងចំណោមប្រភពភស្តុតាង។ ឯកសារនាសម័យកាលនោះដែលមាននៅចំពោះមុខអង្គជំនុំជម្រះ រួមមាន កំណត់ហេតុនៃកិច្ចប្រជុំ ឬឯកសារទំនាក់ទំនងការងារ ដែលអង្គជំនុំជម្រះមិនបានស្តាប់សក្ខីកម្មដោយផ្ទាល់”។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៧។

[5663] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “ដោយសារតែកងកម្លាំងវៀតណាមចូលទីក្រុងភ្នំពេញយ៉ាងឆាប់រហ័សពេក និងការបោះ បង់ចោលមន្ទីរសន្តិសុខ ស-២១ យ៉ាងលឿន គេមិនបានធ្វើអ្វីចំពោះឯកសារដែលនៅសេសសល់នោះទេ។ [...] កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ត្រូវបាន នួន ជា និង សុន សេន ស្តីបន្ទោស ដោយសារតែមិនបានបំផ្លាញចោលឯកសារមន្ទីរសន្តិសុខ ស-២១”។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៥៥៩។

[5664] ខៀវ សំផន កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៥៦៤។

មៗក្រោយការជួលរលំទីក្រុងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងសម្រាប់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតពាក់ព័ន្ធទៅនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីពីរដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧[5665]។

1982.ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត និងបានបញ្ចូលគ្នាជាមួយការដាក់ទោសរបស់គាត់អស់មួយជីវិតដែលបានប្រកាសដោយអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ទៅជាទោសជាប់ពន្ធនាគារអស់មួយជីវិតតែមួយ[5666]។

## ក. ច្បាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសមេដឹកនាំជាន់ខ្ពស់

1983.ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់កម្ពុជា ពុំបានចែងពីគោលបំណងនៃការដាក់ទោសឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងនូវភាពជាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសនៅ អ.វ.ត.ក. គឺដើម្បីជាការសងជំងឺចិត្ត និងដើម្បីរារាំងការប្រព្រឹត្តឧក្រិដ្ឋកម្ម[5667]។ អង្គជំនុំជម្រះជាច្រើននៃតុលាការព្រហ្មទណ្ឌអន្តរជាតិប្រហាក់ប្រហែលគ្នាបានពិចារណាលើគោលបំណងចម្បងនៃការដាក់ទោសគឺដើម្បីសងជំងឺចិត្ត និងរារាំងការប្រព្រឹត្តឧក្រិដ្ឋកម្ម[5668]។

1984.ក្នុងរឿងក្តី ០០១, ០០២/០១ និង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានយោងផងដែរទៅលើសារៈសំខាន់នៃការធានាដល់ជនរងគ្រោះដែលនៅរស់រានមានជីវិត ក្រុមគ្រួសាររបស់ពួកគេ សាក្សី និងសាធារណជនថាច្បាប់ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងអនុវត្តចំពោះមនុស្សគ្រប់រូបដោយពុំគិតពីឋានៈ ឬតួនាទី

---

5665 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៩។

5666 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤០២។

5667 សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៨០។

5668 សាលដីកាលើរឿងក្តី *Krajišnik* (ICTY) កថាខណ្ឌ ៧៧៥។ សាលដីកាលើរឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) កថាខណ្ឌ ១០៥៧។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ayyash* អង្គជំនុំជម្រះសាលាដំបូង (STL) សំណុំរឿងលេខ STL-11-01/S/TC សាលក្រមប្រកាសទោស ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ("សាលក្រមរឿងក្តី *Ayyash* (STL)") កថាខណ្ឌ ១២២។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Al Mahdi* អង្គជំនុំជម្រះសាលាដំបូង VIII (ICC) សំណុំរឿងលេខ ICC-01/12/01/15 សាលក្រម និងការប្រកាសទោស ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦។ សាលក្រមប្រកាសទោសរឿងក្តី *Ntaganda* (ICC) កថាខណ្ឌ ៩-១០។

ឡើយ[5669]។ នៅតុលាការ ICTY នេះត្រូវបានសំដៅទៅលើថា ជា"ការរារាំងវិជ្ជមានជាទូទៅ និងជាលក្ខណៈបុគ្គល" ហើយសារៈសំខាន់នេះត្រូវបានពន្យល់ដូចខាងក្រោមថា៖

> គោលបំណងសំខាន់បំផុតនៃការដាក់ទោសដែលបានប្រកាសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិគឺដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថា ប្រព័ន្ធគតិយុត្តអន្តរជាតិត្រូវបានអនុវត្ត និងពង្រឹង។ គោលបំណងនៃការដាក់ទោសនេះគឺសំដៅទៅលើការអប់រំអំពីទោស និងធ្វើជាសារមួយថា គោលការណ៍ច្បាប់អន្តរជាតិស្ដីពីមនុស្សធម៌ ត្រូវតែគោរពនៅគ្រប់កាលៈទេសៈ។ ក្នុងការធ្វើដូច្នេះ គោលបំណងនៃការដាក់ទោសបានព្យាយាមដាក់បញ្ចូលគោលការណ៍ទាំងនេះ និងការទាមទារផ្នែកសីលធម៌តាមការចង់បានរបស់សាធារណជន[5670]។

1985.ស្របជាមួយនឹងការផ្ដន្ទាទោស ការទប់ស្កាត់ និងការរារាំងការប្រព្រឹត្តឧក្រិដ្ឋកម្ម គោលបំណងដទៃទៀតនៃការដាក់ទោសដែលត្រូវបានពិចារណាដោយតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* បានរួមបញ្ចូលភាពគួរឱ្យអាម៉ាស់ និងការថ្កោលទោសជាសាធារណៈដោយសហគមន៍អន្តរជាតិ និងការលុបលាងទោស[5671]។

1986.បន្ថែមលើគោលបំណងសំខាន់ៗនៃការដាក់ទោសនេះ គោលការណ៍នីត្យានុកូលភាព ស្មើភាពគ្នាចំពោះមុខច្បាប់ សមាមាត្រ និងគោលការណ៍ឯកត្តកម្មនៃទោស ត្រូវតែបានពិចារណានៅក្នុងការដាក់ទោសផងដែរ។

### ១. គោលការណ៍នីត្យានុកូលភាព

---

[5669] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥៧៩។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១០៦៧។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៤៨។

[5670] សាលដីកាវឿងក្តី *Kordić និង Čerkez* (ICTY) កថាខណ្ឌ ១០៧៣។ អង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Nikolić* បានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា៖

> គោលបំណងសំខាន់មួយក្នុងចំណោមនោះនៃការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺដើម្បីជះឥទ្ធិពលលើការដឹងអំពីច្បាប់របស់ជនជាប់ចោទ ជនរងគ្រោះ និងសាច់ញាតិ សាក្សី និងសារណជនដើម្បីធ្វើឱ្យពួកគេជឿជាក់ថា ប្រព័ន្ធច្បាប់ត្រូវបានពង្រឹង និងអនុវត្ត។ បន្ថែមលើនេះ ដំណើរការនៃការដាក់ទោស គឺក្នុងគោលបំណងធ្វើជាសារថា ច្បាប់ និងវិធានដែលត្រូវបានទទួលស្គាល់ជាសកល ត្រូវតែគោរពដោយមនុស្សគ្រប់រូប។ 'បុគ្គលគ្រប់រូបត្រូវតែមានសិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងតុលាការព្រហ្មទណ្ឌ'"។ គោលការណ៍ជាមូលដ្ឋាននេះបានជម្រុញអ្នកច្បាប់ និងសាធារណជនទូទៅឱ្យទទួលយកច្បាប់ និងវិធានទាំងនេះជាមូលដ្ឋាននៃគំនិតរបស់ពួកគេ។

សាក្រមរឿងក្តី *Nikolić* (ICTY) កថាខណ្ឌ ១៣៩ ដកស្រង់មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

[5671] សាលដីកាវឿងក្តី *Kordić និង Čerkez* (ICTY) កថាខណ្ឌ ១០៧៣។ *សូមមើលផងដែរ* សាលដីកាវឿងក្តី *Blaškić* (ICTY) កថាខណ្ឌ ៦៧៨។

1987.គោលការណ៍នីត្យានុកូលភាពគឺជាផ្នែកនៃច្បាប់កម្ពុជាបច្ចុប្បន្ន និងជាផ្នែកនៃច្បាប់អន្តរជាតិ និងច្បាប់កម្ពុជានៅមុនឆ្នាំ ១៩៧៥-១៩៧៩[5672]។ គោលការណ៍នេះមិនត្រឹមតែតម្រូវថា បទឧក្រិដ្ឋត្រូវតែមានអត្ថិភាពចំពោះមុខច្បាប់ជាធរមាននៅមុនពេលអំពើនោះត្រូវបានប្រព្រឹត្តឡើង គ្មានបទល្មើសបើគ្មានច្បាប់ចែងប៉ុណ្ណោះទេ ថែមទាំងថា ទោសសម្រាប់បទឧក្រិដ្ឋទាំងនោះត្រូវតែបានដឹងឮជាមុន គ្មានទោសបើគ្មានច្បាប់។ គោលបំណងគឺដើម្បីធានាបាននូវភាពជាក់លាក់ក្នុងកម្រិតអប្បបរមា ទាក់ទងទៅនឹងការដាក់ទោស និងធានាថាបុគ្គលអាចយល់ដឹងអំពីទោសដែលខ្លួនបានរំពឹងទុកប្រសិនបើរកឃើញថាមានពិរុទ្ធពីបទឧក្រិដ្ឋជាក់លាក់ណាមួយនោះ។ គោលការណ៍នេះតម្រូវផងដែរថា ប្រសិនបើច្បាប់បច្ចុប្បន្នដាក់ទោសស្រាលជាងច្បាប់ដែលមានអត្ថិភាពនៅខណៈពេលប្រព្រឹត្តបទល្មើសនោះ ត្រូវអនុវត្តទោសស្រាលជាងគោលការណ៍អនុវត្តទោសស្រាលជាង[5673]។

1988.បើទោះបីជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ពុំត្រូវបានចាត់ទុកជាបទល្មើសក្នុងច្បាប់កម្ពុជានៅមុនឆ្នាំ ១៩៧៥ ក៏ដោយ ក៏អំពើទាំងនេះមានអត្ថិភាពជាបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ នេះជាការគោរពគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង*[5674]។ ទាក់ទងទៅនឹងគោលការណ៍*គ្មានទោសបើគ្មានច្បាប់ចែង* ដោយសារបទឧក្រិដ្ឋទាំងនេះពុំមានអត្ថិភាពក្នុងច្បាប់កម្ពុជា គ្មានការដាក់ទោសក្នុងច្បាប់កម្ពុជាដែលជាក់លាក់សម្រាប់បទឧក្រិដ្ឋទាំងនេះឡើយ។ ទោះជាយ៉ាងណាក្តី មាត្រា ២១ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលបានចូលជាធរមានក្នុងឆ្នាំ ១៩៧៥[5675] បានចែង

---

[5672] *សូមមើល* មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។ មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *សូមមើលផងដែរ* មាត្រា ១១(២) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស UDHR។ មាត្រា ៩ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ACHR។ មាត្រា ៧(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ECHR។ មាត្រា ៧(២) នៃធម្មនុញ្ញទ្វីបអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន ACHPR។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. និងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. តម្រូវឱ្យ អ.វ.ត.ក. ប្រើប្រាស់យុត្តាធិការស្របតាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

[5673] មាត្រា ១០ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។

[5674] អង្គបុរេជំនុំជម្រះបានបដិសេធអំណះអំណាងរបស់មេធាវីការពារក្តី អៀង សារី ដែលថា អ.វ.ត.ក. ត្រូវតែគោរពគោលការណ៍នីត្យានុកូលភាពក្នុងច្បាប់កម្ពុជា ដែលមានលក្ខណៈរឹតត្បិតជាច្បាប់ដែលបានកំណត់ក្នុងមាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងតម្រូវឱ្យមានអត្ថិភាពនៃបទឧក្រិដ្ឋក្នុងច្បាប់កម្ពុជានៅមុនការប្រព្រឹត្តនោះ។ សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ២១៣-២២៥។

[5675] *សូមមើល* សំណុំរឿង ០០១ ព័ត៌មានអំពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និងសំណើសុំបញ្ជាក់ភាពត្រឹមត្រូវនៃក្រមដែលមានអានុភាពផ្លូវច្បាប់ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ E91/5 ERN 00365511។

សម្រាប់ការដាក់ទោសព្រហ្មទណ្ឌនៃការធ្វើឱ្យស្លាប់ ការ បង្ខំឱ្យធ្វើការជាអចិន្ត្រៃយ៍ ឬការបង្ខំឱ្យធ្វើការសម្រាប់ពេលកំណត់ណាមួយ ត្រូវដាក់ទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះបានយោងទៅលើមាត្រា II នៃគោលការណ៍ Nuremberg ដែលបញ្ជាក់ថា នេះជាគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចែងថា "ការដែលច្បាប់ក្នុងស្រុកពុំបានដាក់ទោសលើអំពើដែលជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ពុំអាចឱ្យបុគ្គលដែលបានប្រព្រឹត្តអំពើនោះរួចផុតពីការទទួលត្រូវក្រោមច្បាប់អន្តរជាតិឡើយ"[5676]។ នៅតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ទោសអតិបរមាសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺការប្រហារជីវិត[5677]។ ពុំមានការចោទប្រកាន់អន្តរជាតិពីបទប្រល័យពូជសាសន៍នៅមុនឆ្នាំ ១៩៧៥។

1989. សាស្ត្រាចារ្យ Schabas បានពន្យល់ថា តុលាការ ICTY និង ICTR ត្រូវបានណែនាំឱ្យពិចារណាលើការដាក់ទោសក្នុងអតីតប្រទេសយូហ្គោស្លាវី និងប្រទេសរវ៉ាន់ដានីមួយៗដោយគោរពតាមគោលការណ៍*គ្មានទោសបើគ្មានច្បាប់ចែង*។ គាត់បានបញ្ជាក់ថា៖

> ការបារម្ភអំពីបញ្ហាប្រតិសកម្មមានការលំបាកយល់ដោយហេតុថា បញ្ហានេះតាមការសន្មតត្រូវបានដោះស្រាយរួចរាល់នៅតុលាការ Nuremberg។ ជនជាប់ចោទនៅក្នុងការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទីពីរ បានទទួលបរាជ័យក្នុងការជំទាស់ទៅលើគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ ប្រហែលនេះដោយសារត្រូវបានគេជឿជាទូទៅដូចការអធិប្បាយផ្លូវការក្នុងរបាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមថា 'ច្បាប់អន្តរជាតិកំណត់ថា ឧក្រិដ្ឋជនសង្គ្រាមអាចត្រូវបានដាក់ទោសប្រហារជីវិត បើទោះបីជាជននោះបានប្រព្រឹត្តបទឧក្រិដ្ឋអ្វីក៏ដោយ'។ ពិតណាស់ គោលគំនិតដែលថា ការជំទាស់លើគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង* អាចទទួលជោគជ័យត្រឹមកម្រិតមួយ បើទោះបីជាមានអត្ថិភាពជាលាយលក្ខណ៍

[5676] សេចក្តីសម្រេចលើសបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ២៤៥ ដកស្រង់គណៈកម្មការច្បាប់អន្តរជាតិ *គោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញនៃតុលាការព្រហ្មទណ្ឌ Nuremberg និងក្នុងសាលក្រមរបស់តុលាការនេះ* គណៈកម្មការនីតិអន្តរជាតិ៖ ឆ្នាំ ១៩៥០ គោលការណ៍ II។ សហចៅក្រមស៊ើបអង្កេតបានពិចារណាផងដែរលើរបបនៃការប្រកាសទោសរបស់ អ.វ.ត.ក. ថាស្របជាមួយនឹងគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់* ។ *សូមមើល* ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣០៤។

[5677] មាត្រា ២៧ នៃធម្មនុញ្ញរបស់តុលាការ IMT ដែលភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃចក្រភពអង់គ្លេសជាមួយនឹងអៀរឡង់ឆៀងខាងត្បូង និងរវាងរដ្ឋាភិបាលសាធារណរដ្ឋបារាំងជាមួយនឹងសាធារណរដ្ឋសង្គមនិយមសហភាពសូវៀតសម្រាប់ការការសេចក្តី និងកាត់ទោសមេឧក្រិដ្ឋជនសង្គ្រាមសំខាន់នៃពួកអាក់ស៊ីសអឺរ៉ុប ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥ ឯកសារលេខ 82 U.N.T.S. 280។

អក្សរក៏ដោយ ដោយសារគ្មានការដាក់ទណ្ឌកម្មជាលាយលក្ខណ៍អក្សរណាមួយដែលជាប់ជាមួយនោះ គឺជាការផ្ទុយគ្នា និងមិនសមហេតុផល[5678]។

1990.សាស្ត្រាចារ្យ Schabas បានពន្យល់ថា តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានផ្តល់គោលការណ៍បំភ្លឺមានអត្ថប្រយោជន៍ពាក់ព័ន្ធនឹងបញ្ហានេះនៅក្នុងរឿងក្តីពីរទាក់ទងទៅនឹងប្រព័ន្ធច្បាប់អង់គ្លូសាក់សុងរបស់ប្រទេសអង់គ្លេស និងអត្ថិភាពនៃបទល្មើសនៃការរំលោភសេពសន្ថវៈសហព័ទ្ធបើទោះបីជានត្ថិភាពច្បាប់ចែងជាលាយលក្ខណ៍អក្សរក៏ដោយ។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានពិចារណាថា "ច្បាប់"សម្រាប់គោលបំណងនៃ *គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង* បានរួមបញ្ចូលច្បាប់ដែលពុំត្រូវបានចែងជាលាយលក្ខណ៍អក្សរ[5679]។ សាស្ត្រាចារ្យ Schabas បានកត់សម្គាល់ថា៖

> "ជាសំខាន់ បើទោះបីជាតុលាការនេះបានដោះស្រាយអត្ថិភាពនៃបទល្មើសដោយខ្លួនឯងផ្ទាល់ក៏ដោយ ក៏ពុំបានពិចារណាលើការដាក់ទណ្ឌកម្មសមស្រប ដែរ នៅបានសន្មតថា បទល្មើសនោះព្រមទាំងការដាក់ទោសអតិបរមាត្រូវបានដឹងឮផងដែរ។ [...] ដូច្នេះ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សអាចនឹងមានការលំបាកខ្លះក្នុងការដាក់ទោសដែលផ្អែកលើគោលការណ៍ច្បាប់ទូទៅ ឬច្បាប់ទំនៀមទម្លាប់ ដូចរឿងក្តីនៅតុលាការ Nuremberg"[5680]។

1991.សាស្ត្រាចារ្យ Schabas បានយោងទៅលើសាលក្រមឆ្នាំ ១៩៤៩ របស់តុលាការឧទ្ធរណ៍ពិសេសរបស់ប្រទេសហូឡង់[5681] ដែលត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Erdemović* ដោយយល់ស្របជាមួយត្រង់ចំណុច៖

> ដែលជនជាប់ចោទបានចាត់ទុកការដាក់ទោសថា ជាការខុសច្បាប់ ដោយសារអំពើរបស់គាត់បើទោះបីជាល្មើសច្បាប់ក៏ដោយ ក៏ខ្វះការដាក់ទណ្ឌកម្មផ្នែកច្បាប់ដែលបានគូសបញ្ជាក់ច្បាស់លាស់ និងត្រូវបានបញ្ញត្តិពីដំបូងនោះ ការជំទាស់នេះពុំទទួលបានជោគជ័យឡើយ។ គោលការណ៍ដែលថា អំពើពុំអាចដាក់ទោសបានដោយផ្អែកលើនត្ថិភាពបទប្បញ្ញត្តិព្រហ្មទណ្ឌដែលបានបង្កើតឡើងនៅមុនអំពើនោះ គឺក្នុងគោលបំណង

---

[5678] អ្នកនិពន្ធ William Schabas "ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ វិធីសាស្ត្រស្តីពីសិទ្ធិមនុស្ស" (១៩៩៧) 7 *Duke J. ចង្រេង និងច្បាប់អន្តរជាតិ* លេខ ៤៦១, ទំព័រ ៤៧៥ ("អ្នកនិពន្ធ Schabas ៖ ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ") ដកស្រង់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីសង្គ្រាម៖ របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ១, ២០០ (ឆ្នាំ ១៩៤៩)។

[5679] អ្នកនិពន្ធ៖ ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៧៤។

[5680] អ្នកនិពន្ធ៖ ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៧៥។

[5681] អ្នកនិពន្ធ៖ ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ជើងទំព័រ ៤០។

បង្កើតការធានាបាននូវសន្តិសុខផ្នែកច្បាប់ និងសេរីភាពរបស់បុគ្គល។ អត្ថប្រយោជន៍ផ្នែកច្បាប់នេះ នឹងមានគ្រោះថ្នាក់ប្រសិនបើអំពើដែលមានវិមតិសង្ស័យទាក់ទងទៅនឹងការដាក់ទោសដែលសមនឹងទទួលនោះ ត្រូវបានចាត់ទុកថា អាចដាក់ទោសបានក្រោយព្រឹត្តិការណ៍នោះ។ ទោះជាយ៉ាងណាក្តី ពុំមានអ្វីដែលដាច់ខាតនៅក្នុងគោលការណ៍នោះឡើយ។ ការអនុវត្តន៍គោលការណ៍នេះអាចទទួលរងផលប៉ះពាល់ពីគោលការណ៍ដទៃទៀតដែលការទទួលស្គាល់នៃគោលការណ៍ ជាប់ពាក់ព័ន្ធដូចគ្នាទៅនឹងអត្ថប្រយោជន៍សំខាន់នៃយុត្តិធម៌។ អត្ថប្រយោជន៍ទាំងនេះពុំបានអនុញ្ញាតថា ការរំលោភបំពានធ្ងន់ធ្ងរហួសហេតុលើគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅនៃច្បាប់អន្តរជាតិ(ចរិតលក្ខណៈល្មើសដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យរួចរាល់ហើយខណៈពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តឡើង) ពុំគប្បីត្រូវបានចាត់ទុកថា អាចដាក់ទោសបានដោយផ្អែកតែលើមូលដ្ឋានថា នត្ថិភាពនៃការដាក់ទោសពីមុន[5682]។

1992.ដូច្នេះ បើទោះបីជាការដាក់ទោសពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ពុំត្រូវបានបញ្ញត្តិច្បាស់លាស់ក្នុងច្បាប់កម្ពុជាក៏ដោយ ក៏គ្មានការរំលោភបំពានលើគោលការណ៍*គ្មានទោសបើគ្មានច្បាប់ចែង*ដែរ។ មានបទឧក្រិដ្ឋដែលត្រូវប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ហើយការទទួលខុសត្រូវនោះពុំអាចគេចផុតតាមរយៈកង្វះនូវការដាក់ទោសជាលាយលក្ខណ៍អក្សរក្នុងច្បាប់ក្នុងស្រុកបានឡើយ។

1993.ក្នុងរឿងក្តី ០០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា "ប្រសិនបើក្រោយពីមានការប្រព្រឹត្តបទល្មើស បទប្បញ្ញត្តិត្រូវបានបង្កើតឡើងក្នុងច្បាប់សម្រាប់ការដាក់ទោសដែលស្រាលជាង នោះជនជាប់នឹងទទួលបានអត្ថប្រយោជន៍នេះ"[5683]។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើគោលការណ៍ណែនាំអន្តរជាតិពាក់ព័ន្ធទៅនឹងការដាក់ទោសសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបានកំណត់ថា ការដាក់ទោសដែលអាចអនុវត្តបានចំពោះមុខ អ.វ.ត.ក. សម្រាប់បទឧក្រិដ្ឋទាំងនេះ ពុំបានរំលោភបំពានលើមាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[5684]។ អង្គជំនុំជម្រះពុំបានពិចារណាលើបទប្រល័យពូជសាសន៍ ពីព្រោះកាំង ហ្កេកអ៊ាវ *ហៅ* ឌុច ពុំត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនេះ ប៉ុន្តែបទប្រល័យពូជសាសន៍នេះពុំកាត់

---

[5682] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* *Erdemović* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-22-T សាលក្រមប្រកាសទោស ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣៨ ដកស្រង់ *Rauter* តុលាការឧទ្ធរណ៍ពិសេស ប្រទេសហូឡង់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៤៩ *ILR* ១៩៤៩ ទំព័រ ៥៤២-៥៤៣។

[5683] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥៧៣។

[5684] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥៧៣។

បន្ថយអានុភាពនៃការដាក់ទោសក្នុងកម្រិតស្រាលជាងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និងថា នៅ អ.វ.ត.ក. ទោសអតិបរមាដែលត្រូវអនុវត្តសម្រាប់បទប្រល័យពូជសាសន៍ គឺជាប់ព័ន្ធនាគារអស់មួយជីវិត[5685] ដូច្នេះ ការអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតបានគោរពតាមគោលការណ៍នេះ។

២. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ សមាមាត្រ និងគោលការណ៍ឯកត្តកម្មនៃទោស

1994.គោលការណ៍សមភាពជាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសដែលជនជាប់ចោទ គប្បីត្រូវបានដាក់ឱ្យទទួលខុសត្រូវស្មើភាពគ្នា[5686]។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។

1995.គោលការណ៍សមាមាត្រក្នុងការដាក់ទោស ដែលជាគោលការណ៍មូលដ្ឋានក្នុងច្បាប់ស្តីពីសិទ្ធិមនុស្ស[5687] មានន័យថា ទោសដែលត្រូវបានដាក់ទៅលើពិរុទ្ធភាពបន្ទាប់ពីការជំនុំជម្រះត្រឹមត្រូវ ត្រូវតែមានលក្ខណៈស

---

[5685] មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[5686] គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សបានបញ្ជាក់ថា "សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងតុលាការព្រហ្មទណ្ឌ ជាទូទៅ [...] ធានាថា ភាគីក្នុងកិច្ចដំណើរការនីតិវិធី ត្រូវបានប្រព្រឹត្តទៅលើដោយគ្មានការរើសអើង។ គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស "អនុសាសន៍ទូទៅ លេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងតុលាការព្រហ្មទណ្ឌ និងទទួលបានការជំនុំជម្រះត្រឹមត្រូវ" ឯកសារអង្គការសហប្រជាជាតិ លេខ CCPR/C/GC/32 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៨។

[5687] យោងតាមសាស្ត្រាចារ្យ Schabas "មាត្រា ៧ [នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ] បានរួមបញ្ចូលសញ្ញាណនៃសមាមាត្រក្នុងការដាក់ទោសព្រហ្មទណ្ឌ"។ អ្នកនិពន្ធ៖ ការដាក់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៦៨។ ការបង្ហាញបន្ថែមនេះ មាត្រា ៤៩ នៃធម្មនុញ្ញស្តីពីសិទ្ធិជាមូលដ្ឋាននៃសហភាពអឺរ៉ុបបានតម្រូវប្រហាក់ប្រហែលគ្នាថា "ភាពធ្ងន់ធ្ងរនៃការដាក់ទោសមិនត្រូវគ្មានលក្ខណៈសមាមាត្រទៅនឹងអំពើល្មើសនោះទេ"។ អាស្រ័យហេតុនេះ តុលាការ ECtHR ក្នុងរឿងក្តី *Soering ទល់នឹង ចក្រភពអង់គ្លេស* បានយល់ឃើញថា ការធ្វើបត្យាប័នដែលបានស្នើឡើងអាចនាំឱ្យមានការប្រព្រឹត្តដោយអមនុស្សធម៌ក្រោមមាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សដោយសារអត្ថិភាពនៃ"ហានិភ័យជាក់ស្តែង"ដែលថា ការដាក់ទោសដែលទំនងជាធ្វើឡើងក្នុងរដ្ឋដែលបានស្នើនោះ អាចពុំមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើង។ *សូមមើល* រឿងក្តី *Soering ទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សំណើសុំលេខ 14038/88 សាលក្រមថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៨៩ កថាខណ្ឌ ១០៤, ១១១។

មាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងស្ថានភាពរបស់ជនជាប់ចោទ[5688]។ ទាក់ទងទៅនឹងច្បាប់អន្តរជាតិស្តីពីមនុស្សធម៌ មាត្រា ៦៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួន បានចែងថា តុលាការ"ត្រូវអនុវត្តនូវបទប្បញ្ញត្តិច្បាប់ទាំងនោះ [...] ដែលស្របតាមគោលការណ៍ទូទៅនៃច្បាប់ ជាពិសេសគោលការណ៍ដែលចែងថា ការដាក់ទោសត្រូវតែមានលក្ខណៈសមាមាត្រទៅនឹងបទល្មើស"។

1996.បើទោះបីជា"ទោស'អាចត្រូវបានគិតថា ទៅជាមិនច្បាស់លាស់ ឬធ្ងន់ធ្ងរហួសហេតុ ប្រសិនបើពុំមានសមាមាត្រសមហេតុផលនៃទោសដែលត្រូវបានដាក់នៅក្នុងកាលៈទេសៈស្រដៀងគ្នាសម្រាប់បទល្មើសតែមួយដូចគ្នា''"[5689]ក៏ដោយ ក៏គោលការណ៍បំភ្លឺដែលបានផ្តល់តាមរយៈការដាក់ទោសដែលបានធ្វើឡើងដោយតុលាការព្រហ្មទណ្ឌទៃទៀតក្នុងរឿងក្តីផ្សេងៗនោះ មានកម្រិតតិចតួច នៅពេលការប្រៀបធៀបបានធ្វើឡើងតែទៅលើករណីដែលបទល្មើសមានលក្ខណៈដូចគ្នា និងត្រូវបានប្រព្រឹត្តឡើងក្នុងកាលៈទេសៈស្រដៀងគ្នា និងដោយសារអង្គជំនុំជម្រះសាលាដំបូងត្រូវសម្របសម្រួលការដាក់ទោសឱ្យត្រូវតាមកាលៈទេសៈបុគ្គលដែលត្រូវបានដាក់ពិរុទ្ធ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដោយមានការពិចារណាសមស្របទៅលើរឿងក្តីទាំងមូល[5690]។ "នៅពេលមានលក្ខណៈខុសប្លែកគ្នាខ្លាំងជាងលក្ខណៈស្រដៀងគ្នា ឬកត្តាសម្រាល និងទម្ងន់ទោសខុសប្លែកគ្នា ការដាក់ទោសខុសគ្នាអាចត្រូវបានផ្តល់យុត្តិកម្ម"[5691]។ ទោះជាយ៉ាងណាក្តី ការដាក់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងរឿងក្តីដែលពាក់ព័ន្ធទៅនឹងកាលៈទេសៈប្រហាក់ប្រហែលគ្នា គឺជាកត្តាមួយដែលអង្គជំនុំជម្រះត្រូវតែពិចារណានៅពេលប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការដាក់ទោស[5692]។

1997.គោលការណ៍ឯកត្តកម្មនៃទោស តម្រូវថា កាលៈទេសៈបុគ្គលដែលត្រូវបានដាក់ពិរុទ្ធ ត្រូវតែបានពិចារណានៅក្នុងការដាក់ទោស។ មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ចែងអំពី"គោលការណ៍ឯកត្តកម្មនៃទោស"៖ "តុលាការប្រកាសទោស ដោយផ្អែកលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ"។ ក្នុងប្រព័ន្ធ

---

5688 អ្នកនិពន្ធ Silvia D'Ascoli៖ *ការដាក់ទោសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍អង្គការសហប្រជាជាតិ និងទិដ្ឋភាពអនាគតសម្រាប់តុលាការ ICC* (ឆ្នាំ ២០១១) ទំព័រ ២១-២២។

5689 សាលដីការឿងក្តី*Nikolić* (ICTY) កថាខណ្ឌ ១៦ ដកស្រង់រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Jelisić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-10-A សាលដីកាចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៩៦។

5690 *សូមមើល* សាលដីការឿងក្តី*Nikolić* (ICTY) កថាខណ្ឌ ១៩។

5691 សាលដីការឿងក្តី*Nikolić* (ICTY) កថាខណ្ឌ ១៩។

5692 *សូមមើល* សាលដីការឿងក្តី*Krstić* (ICTY) កថាខណ្ឌ ២៤៨។

របស់ប្រទេសមួយចំនួន គោលការណ៍នេះត្រូវបានចាត់ទុកថា គោលការណ៍ណែនាំបំភ្លឺក្នុងករណីនីមួយៗ [5693]។

1998.គោលការណ៍ដែលបានលើកឡើងខាងលើនេះ បានបង្ហាញអំពីការដាក់ទោសនៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍*។ ក្នុងប្រទេសបារាំង គោលការណ៍នៃសមាមាត្រ និងគោលការណ៍ឯកត្តកម្មនៃទោស មានលក្ខណៈដូចរដ្ឋធម្មនុញ្ញ[5694]។ ក្នុងអំឡុងពេលនៃការធ្វើសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការ ICTY គណៈកម្មាធិការរបស់គណៈវិនិច្ឆ័យបារាំង៖

> បានទទូចឱ្យគោរព'គោលការណ៍មូលដ្ឋាននៃសមាមាត្រ និងឯកត្តកម្មនៃទោស" និងបានស្នើឡើងថា តុលាការព្រហ្មទណ្ឌអាចពិចារណាលើភាពធ្ងន់ធ្ងរនៃបទល្មើស (ចេតនា ការគិតទុកជាមុន មូលហេតុ និងគោលបំណងរបស់ចារី ផ្នត់គំនិត ជាអាទិ៍) តម្លៃដែលត្រូវបានការពារតាមរយៈការចាត់ទុកអំពើនោះជាបទឧក្រិដ្ឋធ្ងន់ធ្ងរ(សេចក្តីថ្លៃថ្នូររបស់មនុស្ស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានបូរណភាពផ្លូវចិត្ត និង/ឬផ្លូវកាយ សិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិ) វិសាលភាពនៃព្យសនកម្មដែលត្រូវបានបង្កឡើង(ជាក់ស្តែង ឬ

---

[5693] អ្នកនិពន្ធ Silvia D'Ascoli៖ ការដាក់ទោសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៥៤ យោងទៅលើប្រទេសបារាំង អ៊ីតាលី និងប្រទេសព័រទុយហ្គាល់។

[5694] *សូមមើល* អ្នកនិពន្ធ Jacqueline Hodgson និង Laurène Soubise "ការយល់ដឹងអំពីដំណើរការនៃការដាក់ទោសក្នុងប្រទេសបារាំង"(ឆ្នាំ ២០១៦) 45 ឧក្រិដ្ឋកម្ម និងយុត្តិធម៌ ទំព័រ ២២១, ២៤១ ("Hodgson និង Soubise៖ ការយល់ដឹងអំពីដំណើរការនៃការដាក់ទោសក្នុងប្រទេសបារាំង")៖

> គោលការណ៍នៃឯកត្តកម្មត្រូវបានបង្កើតជាទ្រឹស្តីនៅចុងសតវត្សរ៍ទីដប់ប្រាំបួនដោយលោក Raymond Saleilles ដែលបានអះអាងថា ជាការដែលពុំអាចធ្វើទៅបានក្នុងកំណត់ទោសរឹងឆ្អឹងជាមុននោះ ដោយសារការដាក់ទោសគប្បីត្រូវបានសម្របសម្រួលទៅតាមកាលៈទេសៈនីមួយៗជាជាងត្រូវបានកំណត់តាមច្បាប់ជាអរូបិយសុទ្ធសាធ ដោយពុំគិតពីលក្ខណៈខុសប្លែកគ្នានៃរឿងក្តី និងបុគ្គលនីមួយៗ (Ottenhof ២០០១)។ គោលការណ៍នេះត្រូវបានរឹតបន្តឹងពេញមួយអំឡុងពេលនៃសតវត្សរ៍ទីម្ភៃ ជាពិសេស ដោយពិចារណាលើអាយុរបស់ជនល្មើស និងការបង្កើតរបបនៃការដាក់ទោសមួយសម្រាប់អនីតិជនដែលទីបំផុតមានក្រមព្រហ្មទណ្ឌថ្មី ចូលជាធរមានក្នុងឆ្នាំ ១៩៩៤។ ទោសអប្បបរមាត្រូវបានដកចេញទាំងស្រុង និងផ្នែកថ្មីទាំងស្រុងត្រូវបានកំណត់សម្រាប់'ឯកត្តកម្មនៃទោស'។ តុលាការរដ្ឋធម្មនុញ្ញរបស់បារាំង Conseil Constitutionnel បានទទួលយកឋានៈជាធម្មនុញ្ញនៃគោលការណ៍ឯកត្តកម្មនេះ ដោយបានសន្និដ្ឋានចេញពីគោលការណ៍នេះនូវសមាមាត្រ និងភាពចាំបាច់ដែលមានចែងក្នុងមាត្រា ៨ នៃសេចក្តីប្រកាសអំពីសិទ្ធិរបស់មនុស្ស និងប្រជាជន] ដែលជាផ្នែកនៃរដ្ឋធម្មនុញ្ញរបស់បារាំងចាប់តាំងពីឆ្នាំ ១៩៥៨ (សេចក្តីសម្រេចលើ 2005-520 DC ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ៣)។

ការគំរាមកំហែង ចំនួនបុគ្គលដែលពាក់ព័ន្ធ តម្លៃនៃទ្រព្យសម្បត្តិដែលខូចខាត) ព្រមទាំងកិរិយាមារយាទរបស់ជនល្មើស សារភាព និងស្ថានភាពផ្ទាល់ខ្លួន និងទង្វើក្រោយការប្រព្រឹត្តបទល្មើស[5695]។

1999.អង្គជំនុំជម្រះសាលាដំបូងនៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* បានពិចារណាថា៖

> អង្គជំនុំជម្រះកំណត់ទោសដោយពិចារណាលើកាលៈទេសៈទាំងមូលក្នុងរឿងក្តីនីមួយៗ ដែលត្រូវបានវិនិច្ឆ័យ រួមទាំងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងស្ថានភាពជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ ប៉ុន្តែពុំបានសំដៅទៅលើកម្រិតនៃទោសដែលត្រូវបានកំណត់ជាមុនដោយកត្តាខាងក្រៅ ឬស្ថានទម្ងន់ទោស និងសម្រាលទោសដែលត្រូវបានកំណត់ជាមុននោះឡើយ។ នេះមានន័យថា ក្នុងការដាក់ទោស ចៅក្រមអន្តរជាតិត្រូវបានតម្រូវឱ្យប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងកម្រិតខ្ពស់ ដែលលើសពីលក្ខណៈធម្មតាសម្រាប់រឿងក្តីក្នុងស្រុក[5696]។

2000.អង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *Krstić* បានបញ្ជាក់ថា បើទោះបីជាយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR បានបង្កើតកត្តាពាក់ព័ន្ធជាច្រើនក្នុងការពិចារណាលើការដាក់ទោសក៏ដោយ ក៏នៅតែ "ពុំសមស្របក្នុងការផ្តល់គោលការណ៍ណែនាំប្រាកដប្រជានៃការដាក់ទោសសម្រាប់ការសំអាងទៅលើនៅពេលអនាគតដែរ ដោយហេតុថា ការដាក់ទោសគឺជាសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិ"[5697]។ ខុសគ្នាទៅនឹងស្ថានភាពក្នុងចក្រភពអង់គ្លេស ក្រុមប្រឹក្សានៃការដាក់ទោសត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ភាពស៊ីសង្វាក់គ្នាឱ្យប្រសើរឡើងក្នុងការដាក់ទោស[5698]។ ក្រុមប្រឹក្សានេះបានចេញគោលការណ៍ណែនាំដែលបញ្ជាក់ជាក់លាក់លើកម្រិតនៃការដាក់ទោសឱ្យសមស្របសម្រាប់ទបល្មើសនីមួយៗ។ បទល្មើសនីមួយៗត្រូវបានបែងចែកតាមប្រភេទដែលឆ្លុះបញ្ចាំងកម្រិតផ្សេងៗគ្នានៃភាពធ្ងន់ធ្ងរ ហើយកម្រិតនៃការដាក់ទោសត្រូវបានបំបែកតាមប្រភេទ។ មានចំណុចចាប់ផ្តើមផងដែរនៅក្នុងប្រភេទនីមួយៗនេះដើម្បីផ្អែកទៅលើក្នុងការគណនាទោស ដែលក្រោយមកនឹងត្រូវបានសម្រេចដោយផ្អែកលើកត្តាសម្រាលទោស និងស្ថានទម្ងន់ទោស និងការ

---

[5695] អ្នកនិពន្ធ Schabas៖ ការដាក់ទោសដោយតុលាការពហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៨៦ ដកស្រង់លិខិតចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ផ្ញើពីតំណាងអចិន្ត្រៃយ៍បារាំងនៅអង្គការសហប្រជាជាតិជូនចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ U.N. SCOR កថាខណ្ឌ ១២៩-១៣១ ឯកសារលេខ U.N. Doc. S/25266 (១៩៩៣)។

[5696] អ្នកនិពន្ធ D'Ascoli៖ ការដាក់ទោសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ១៣។

[5697] សាលដីការឿងក្តី *Krstić* (ICTY) កថាខណ្ឌ ២៤២។

[5698] ព័ត៌មានអំពីក្រុមប្រឹក្សាដាក់ទោសមានក្នុងគេហទំព័រ៖ https://www.sentencingcouncil.org.uk/។

ដាក់ពិរុទ្ធភាពពីមុនៗ[5699]។ ផ្ទុយទៅវិញ ការអនុវត្តន៍នៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* ដូចគ្នាទៅនឹងការអនុវត្តន៍នៅប្រទេសបារាំងដែរ ចៅក្រមពុំបានប្រើប្រាស់គោលការណ៍ណែនាំសម្រាប់ការដាក់ទោសឡើយ[5700]។ ចៅក្រមមានសេរីភាពក្នុងការជ្រើសរើសកម្រិតនៃទោស និងពុំចាំបាច់ផ្តល់ហេតុផលសម្រាប់ការសម្រេចដាក់ទោសនោះទេ[5701]។

2001.បើទោះបីជាចៅក្រមនៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* មានឆន្ទានុសិទ្ធិទូលំទូលាយ បើផ្អែកតាមអតីតចៅក្រមនៃតុលាការ ICTY ក៏ដោយ ក៏លំនាំនៃការដាក់ទោសដែលស៊ីសង្វាក់គ្នាបានលេចចេញជារូបរាងឡើងនៅតុលាការព្រហ្មទណ្ឌទាំងនោះ ដែលបង្ហាញច្បាស់លាស់ស្ទើរតែទាំងស្រុងថា ចៅក្រមបានមានគោលគំនិតរួមគ្នាអំពីកម្រិតនៃការដាក់ទោសសមស្រប។ ចៅក្រម Harhoff បានសន្និដ្ឋានថា មានការបែងចែកជាបី ឬបួនកម្រិតផ្សេងៗគ្នានៅក្នុងការដាក់ទោស៖

– កម្រិតទោសជាប់ពន្ធនាគារដែលទាបបំផុតគឺចាប់ពី ៣ ដល់ ៦ ឬ ៨ ឆ្នាំ និងគ្របដណ្តប់លើអំពើល្មើសតែមួយដែលមានទំហំតូចដែលដកចេញបទប្រល័យពូជសាសន៍ (ជាអាទិ៍ មានតែការរំលោភបំពានលើច្បាប់ និងទំនៀមទម្លាប់សង្គ្រាម និងអនុសញ្ញាទីក្រុងហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាមដែលជាការសមស្រប) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) និង (ក) ចំនួនជនរងគ្រោះ ព្រមទាំង (ខ) វិសាលភាពនៃយុត្តាធិការពេលវេលា និងភូមិសាស្ត្រនៃបទឧក្រិដ្ឋមានកម្រិតតិចតួច និង (គ) ចារីពុំបានប្រព្រឹត្តអំពើឃោរឃៅក្នុងកម្រិតណាមួយទៅលើជនរងគ្រោះ។

– កម្រិតបន្ទាប់នៃការដាក់ទោសជាប់ពន្ធនាគារគឺចាប់ពី ៨ ដល់ ២០ ឆ្នាំ និងគ្របដណ្តប់ពាក់កណ្តាលផ្នែកខាងក្រោមនៃប្រភេទដាក់ទោសកម្រិតកណ្តាល។ បទឧក្រិដ្ឋនៅកម្រិតនេះ តាមធម្មតាពុំបានរួមបញ្ចូលបទប្រល័យពូជសាសន៍ ប៉ុន្តែការដាក់ទោសកម្រិតនេះនឹងជាប់ពាក់ព័ន្ធទៅនឹងបទល្មើសដែលមាន

---

[5699] ភ្នាក់ងារសេវកម្មចោទប្រកាន់ព្រហ្មទណ្ឌ (Crown Prosecution Service) "ការដាក់ទោស៖ ទិដ្ឋភាពទូទៅ គោលការណ៍ទូទៅ និងទោសជាប់ពន្ធនាគារដែលតម្រូវ" បានធ្វើបច្ចុប្បន្នភាពថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៩ មានគេហទំព័រ៖ https://www.cps.gov.uk/legal-guidance/sentencing-overview។

[5700] *សូមមើល* អ្នកនិពន្ធ Hodgson និង Soubise៖ ការយល់ដឹងអំពីដំណើរការដាក់ទោសក្នុងប្រទេសបារាំង ទំព័រ ២៤២-២៤២ ដែលបញ្ជាក់ថា អ្នកខ្លះក្នុងប្រទេសបារាំងបានតវ៉ាឱ្យមានាការបង្កើតគោលការណ៍ណែនាំដាក់ទោសប្រព័ន្ធអង់គ្លេសាក់សុង ដែលខ្លះទៀតជឿថា នេះបានរឹតត្បិតគោលការណ៍ឯកត្តកម្មនៃទោស និងអាចបង្កឱ្យមានអ្នកទោសច្រើនក្នុងពន្ធនាគារ។

[5701] តុលាការបណ្តឹងសាទុក្ខបានបញ្ជាក់ថា ដរាបចៅក្រមស្ថិតក្នុងវិសាលភាពនៃច្បាប់ ចៅក្រមនៅតែមានឆន្ទានុសិទ្ធិដាច់ខាតក្នុងការដាក់ទោសដែលខ្លួនពុំមែនជាអ្នកទទួលខុសត្រូវឡើយ។ រឿងក្តីព្រហ្មទណ្ឌថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៨១ សំណុំរឿងលេខ 89-84987(ឆ្នាំ ១៩៨១) ពុំបានផ្សព្វផ្សាយ (តុលាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះព្រហ្មទណ្ឌ ប្រទេសបារាំង)។ *សូមមើលផងដែរ* អ្នកនិពន្ធ Hodgson និង Soubise៖ ការយល់ដឹងអំពីដំណើរការដាក់ទោសក្នុងប្រទេសបារាំង ទំព័រ ២២៤, ២៣៥។

ជនរងគ្រោះច្រើនជាង និងបទឧក្រិដ្ឋខ្លះទៀតពន្លាតដល់វិសាលភាពនៃយុត្តាធិការពេលវេលា និងភូមិសាស្ត្រ និងការជាប់ពាក់ព័ន្ធទៅនឹងអំពើសាហាវឃោរឃៅ ឬការមិនអើពើលើផលវិបាក។

– ការដាក់ទោសជាប់ពន្ធនាគារប្រភេទទីបីគឺចាប់ពី ២២ ដល់ ប្រហែល ៣៥ ឆ្នាំ និងគ្របដណ្តប់លើពាក់កណ្តាលផ្នែកខាងលើនៃប្រភេទកម្រិតកណ្តាល។ អំពើល្មើសនៅកម្រិតនេះ អាចរួមបញ្ចូលបទប្រល័យពូជសាសន៍ និងជាប់ពាក់ព័ន្ធទៅនឹងអំពើល្មើសដែលបានប្រព្រឹត្តទៅលើជនរងគ្រោះក្នុងកម្រិតធំធេង ក្នុងរយៈពេលយូរក្នុងទីតាំងភូមិសាស្ត្រទូលំទូលាយ និងមានអំពើសាហាវឃោរឃៅ ឬការមិនអើពើលើផលវិបាកក្នុងកម្រិតខ្ពស់។

– កម្រិតទីបួននៃការដាក់ទោសជាប់ពន្ធនាគារគឺចាប់ពីប្រហែល ៣៥ ដល់មួយជីវិត និងគ្របដណ្តប់រាល់អំពើល្មើសទាំងអស់ដែលមានភាពធ្ងន់ធ្ងរជាងកម្រិតទីបី[5702]។

2002.ចៅក្រម Harhoff បានកត់សម្គាល់ផងដែរលើនិន្នាការក្នុងការដាក់ទោសធ្ងន់ធ្ងរជាងទៅលើចារីក្នុងកម្រិតទាប និងកម្រិតខ្ពស់ដែលខុសពីជនល្មើសក្នុងកម្រិតកណ្តាល។ គាត់បានចាត់ទុកថា នេះដោយសារសិទ្ធិអំណាចរបស់បុគ្គលនោះបូករួមជាមួយនឹងការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួននៅក្នុងឧក្រិដ្ឋកម្ម និងបានកត់សម្គាល់ថា ទម្រង់នៃការទទួលខុសត្រូវ គឺជាកត្តាជាប់ពាក់ព័ន្ធផងដែរ[5703]។

2003.បើទោះបីជាទោសជានិច្ចកាលត្រូវតែមានលក្ខណៈឯកត្តកម្មដោយពិចារណាលើលក្ខណៈពិសេសនៃរឿងក្តី និងពុំអាចនិយាយបានថា ការដាក់ពិរុទ្ធភាពនៃបទឧក្រិដ្ឋអន្តរជាតិជាក់លាក់មួយត្រូវជាប់ពន្ធនាគារអស់មួយជីវិតក៏ដោយ ក៏ជាការជាប់ពាក់ព័ន្ធក្នុងការពិចារណាថា ជនជាប់ចោទទាំងអស់ដែលត្រូវបានដាក់ពិរុទ្ធភាពដោយសារការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅតុលាការ ICTY សុទ្ធតែទទួលទោសជាប់ពន្ធនាគារអស់មួយជីវិតដែរ[5704]។ នេះអាចត្រូវបានពន្យល់តាមរយៈការពិតដែលថា បទប្រល័យពូជសាសន៍ដែលត្រូវបានដាក់បញ្ចូលដោយអង្គជំនុំជម្រះឧទ្ធរណ៍ក្នុងរឿងក្តី *Krstić*៖

---

[5702] អ្នកនិពន្ធ Frederik Harhoff "ការដឹង និងសុភវិនិច្ឆ័យក្នុងការដាក់ទោស៖ ការស្តុកទុកនៃការដាក់ទោសព្រហ្មទណ្ឌអន្តរជាតិ"ក្នុងការបោះពុម្ពផ្សាយដោយ Ola Engdahl និង Ove Bring *ច្បាប់សង្គ្រាម៖ ច្បាប់ដែលមានអត្ថិភាព និងគួរកើតមាន* (២០០៨) ទំព័រ ១៣៤-១៣៥។

[5703] អ្នកនិពន្ធ Harhoff៖ ការដឹង និងសុភវិនិច្ឆ័យក្នុងការដាក់ទោស ទំព័រ ១៣៥-១៣៧។

[5704] ទាំងនេះគឺជាជនជាប់ចោទ Vujadin Popović, Ljubiša Beara, Zdravko Tolimir, Ratko Mladić និង Radovan Karadžić។ Radislav Krstić និង Drago Nikolić ដែលបានជួយទំនុកបម្រុងអំពើប្រល័យពូជសាសន៍ និងពុំមានចេតនាប្រល័យពូជសាសន៍ ទទួលទោសជាប់ពន្ធនាគារ ៣៥ ឆ្នាំ។ នៅតុលាការ ICTR ដែលមានការដាក់ពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ច្រើន

ត្រូវបានសម្រិតសម្រាំងសម្រាប់តែការថ្កោលទោសពិសេស និងការធ្វើឱ្យអាម៉ាស់ជាសាធារណៈ។ បទឧក្រិដ្ឋនេះមានវិសាលភាពគួរឱ្យតក់ស្លុត ចារីបានកំណត់អត្តសញ្ញាណក្រុមមនុស្សទាំងមូលសម្រាប់ការសម្លាប់ឱ្យផុតពូជ។ អ្នកដែលបង្កើត និងអនុវត្តអំពើប្រល័យពូជសាសន៍នេះ ប៉ុនប៉ងដកហូតអត្ថិភាពជាច្រើនប្រភេទនៃមនុស្សជាតិ ដូចជា ជាតិ សាសន៍ ជាតិពន្ធុ និងសាសនា។ នេះគឺជាបទឧក្រិដ្ឋមួយប្រឆាំងមនុស្សជាតិគ្រប់ប្រភេទ ព្យសនកម្មនៃអំពើនេះមិនត្រឹមតែ ធ្វើឱ្យប៉ះពាល់ដល់ក្រុមដែលត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លាញប៉ុណ្ណោះទេ ថែមទាំងលើមនុស្សជាតិទាំងអស់[5705]។

2004.នៅ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូងថា កត្តាបឋមក្នុងការថ្លឹងថ្លែងលើការដាក់ទោស គឺភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយជនជាប់ចោទ និងថាក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ កាលៈទេសៈពិសេសនៃរឿងក្តីបូករួមជាមួយនឹងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទ ត្រូវតែយកមកពិចារណា[5706]។ កត្តាដែលត្រូវពិចារណាពាក់ព័ន្ធបញ្ហានេះ រួមបញ្ចូលចំនួន និងភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះ ផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ និងសាច់ញាតិ

---

ជាង ការដាក់ទោសខុសប្លែកគ្នា។ ជនជាប់ចោទភាគច្រើននៃបទប្រល័យពូជសាសន៍ បានទទួលទោសជាប់ពន្ធនាគារអស់មួយជីវិត រួមមាន Jean Kambanda, Édouard Karemera, Clément Kayishema, Mathieu Nigirumpatse, Eliézer Nyitegeka, Callixte Nzabonimana, Jean-Paul Akayesu, Ildephonse Hategekimana, Jean de Dieu Kamuhanda, Alfred Musema, Athanase Seromba, Emmanuel Ndindabahizi និង Georges Rutaganda។

> ដោយសារភាគច្រើននៃបទឧក្រិដ្ឋដែលត្រូវបានជំនុំជម្រះនៅតុលាការ ICTR មានលក្ខណៈធ្ងន់ធ្ងរខ្លាំង និងជានិច្ចកាលបណ្តាលឱ្យស្លាប់ជនរងគ្រោះរាប់រយ ឬពាន់នាក់ និងអ្នកទាំងនេះទំនងជាទទួលទោសធ្ងន់ធ្ងរបំផុតក្នុងយុត្តាធិការក្នុងស្រុក ចៅក្រមនៃតុលាការ ICTRហាក់បីដូចជាញែកឱ្យឃើញខុសប្លែលគ្នារវាងអំពើល្មើសកម្រិតធ្ងន់ធ្ងរ និងធ្ងន់ធ្ងរជាង។ ការញែកញែកនេះជាចម្បងបានធ្វើឡើងតាមរយៈការអនុវត្តន៍គោលការណ៍ដាក់តាមលំដាប់ថ្នាក់ ដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភាពល្មើសរបស់ជនជាប់ចោទ ដូចបានបង្ហាញតាមរយៈតួនាទីរបស់ពួកគេក្នុងឋានានុក្រមក្នុងរដ្ឋ និងតួនាទីដែលពួកគេមានក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់នោះ។ ការដាក់ទោសជាប់ព័ន្ធនាគារអស់មួយជីវិតដែលធ្ងន់ធ្ងរបំផុតត្រូវបានធ្វើឡើងសម្រាប់តែជនល្មើសកម្រិតធ្ងន់ធ្ងរបំផុត ដូចជាអ្នកដែលរៀបចំផែនការ ដឹកនាំ ឬបញ្ជា និងអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មដោយការគ្រេកគ្រអាលខ្លាំង ឬការជាការសប្បាយនឹងការសម្លាប់នោះ។ អាស្រ័យហេតុនេះ ចៅក្រមជាញឹកញាប់បានបញ្ជាក់ថា ជនល្មើសដែលទទួលទោសធ្ងន់ធ្ងរបំផុតពីមុនកាន់កាប់តួនាទីសិទ្ធិអំណាចជាន់ខ្ពស់ ដូចជារដ្ឋមន្ត្រីក្នុងរដ្ឋាភិបាល។

អ្នកនិពន្ធ Barbora Hola និង Hollie Nyseth Brehm “ការដាក់ទោសអំពើប្រល័យពូជសាសន៍៖ ការវិភាគជាក់ស្តែងប្រហាក់ប្រហែលគ្នានៃច្បាប់ស្តីពីការដាក់ទោស និងការអនុវត្តន៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) តុលាការប្រទេសរវ៉ាន់ដា និងតុលាការ Gacaca” (២០១៦) ១០(៣) *ប្រល័យពូជសាសន៍ St. និង Prev.* ៥៩, ៦៨។

[5705] សាលដីការឿងក្តី *Krstić* (ICTY) កថាខណ្ឌ ៣៦។

[5706] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៧៥។

របស់ពួកគេ ចេតនារើសអើងរបស់ជនជាប់ចោទនៅពេលពុំទាន់ក្លាយជាធាតុផ្សំនៃបទឧក្រិដ្ឋ ទំហំ និងភាពសាហាវឃោរឃៅនៃបទល្មើស និងតួនាទីរបស់ជនជាប់ចោទ[5707]។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងផងដែរថា កាលៈទេសៈនៃស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសត្រូវតែពិចារណា និងថា ការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតចាត់ទុកជាបានការ បើទោះបីជាមានស្ថានសម្រាលក្នុងករណីដែលតម្រូវឱ្យធ្វើដូច្នោះក៏ដោយ[5708]។ ក្នុងរឿងក្តី ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តគោលការណ៍ណែនាំរបស់តុលាការ ICC ទាក់ទងទៅនឹងកត្តាសម្រាលទោស និងទម្ងន់ទោសដែលបានកំណត់ក្នុងវិធាន ១៤៥(២)(ខ) និង១៤៥(២)(ក) នៃវិធានរបស់តុលាការ ICC ស្តីពីនីតិវិធី និងភស្តុតាង[5709]។

2005.វិធាន ១៤៥(២) នៃវិធានរបស់តុលាការ ICC ស្តីពីនីតិវិធី និងភស្តុតាង ចែងថា៖

> បន្ថែមលើកត្តាដែលបានលើកឡើងខាងលើ[5710] តុលាការត្រូវពិចារណាដោយសមស្របលើ៖
>
> (ក) ស្ថានសម្រាលទោស៖
>
> (i) កាលៈទេសៈដែលពុំគ្រប់គ្រាន់ធ្វើជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូចជាសមត្ថភាពផ្នែកស្មារតីចុះខ្សោយខ្លាំង ឬស្ថិតក្រោមការគំរាមកំហែង
>
> (ii) ទង្វើរបស់ជនជាប់ចោទក្រោយពីការប្រព្រឹត្តនោះ រួមទាំងការខិតខំប្រឹងប្រែងរបស់ខ្លួនសងសំណងជនរងគ្រោះ និងកិច្ចសហការណាមួយជាមួយតុលាការ
>
> (ខ) ស្ថានទម្ងន់ទោស៖
>
> (i) ការដាក់ពិរុទ្ធភាពពាក់ព័ន្ធពីដំបូងណាមួយសម្រាប់បទឧក្រិដ្ឋក្រោមយុត្តាធិការរបស់តុលាការនោះ ឬតុលាការប្រហាក់ប្រហែល

---

[5707] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៧៥។

[5708] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៧២, ៣៧៥។

[5709] សាលក្រមសំណុំរឿងអ ០០២/០១ កថាខណ្ឌ ១០៦៩-១០៧០។

[5710] កត្តាទាំងនេះត្រូវបានរៀបរាប់ក្នុងវិធាន ១៤៥(១) ដែលតម្រូវថា តុលាការត្រូវ៖

(ក) ពិចារណាថា ភាពជារួមនៃការដាក់ទោសជាប់ពន្ធនាគារ និងការផាកពិន័យក្នុងករណីអាចកើតមានផ្អែកតាម ៧៧ ត្រូវឆ្លុះបញ្ចាំងភាពល្មើសរបស់ជនជាប់ចោទ។ (ខ) ថ្លឹងថ្លែងលើកត្តាពាក់ព័ន្ធទាំងអស់ រួមទាំងស្ថានសម្រលទោស និងស្ថានទម្ងន់ទោស និងពិចារណាលើកាលៈទេសៈរបស់ជនជាប់ចោទ និងបទឧក្រិដ្ឋ។ (គ) បន្ថែមលើកត្តាទាំងនេះដែលបានលើកឡើងក្នុងមាត្រា ៧៨ កថាខណ្ឌ ១ ពិចារណា*ក្នុងចំណោមនោះ* លើវិសាលភាពនៃការខូចខាត ជាពិសេស ព្យសនកម្មដែលបានបង្កលើជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ លក្ខណៈនៃអាកប្បកិរិយាមិនស្របច្បាប់ និងមធ្យោបាយដែលបានប្រើប្រាស់ប្រព្រឹត្តឧក្រិដ្ឋកម្ម។ កម្រិតនៃការចូលរួមរបស់ជនល្មើស កម្រិតនៃចេតនា កាលៈទេសៈ ពេលវេលា និងទីកន្លែង និងអាយុ កម្រិតវប្បធម៌ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចរបស់ជនល្មើស។

(ii) ការរំលោភអំណាច ឬសមត្ថកិច្ចជាផ្លូវការ

(iii) ការប្រព្រឹត្តបទល្មើសនៅពេលជនរងគ្រោះជាពិសេសគ្មានលទ្ធភាពការពារខ្លួន

(iv) ការប្រព្រឹត្តបទឧក្រិដ្ឋដោយអំពើឃោរឃៅជាក់លាក់ ឬករណីដែលមានជនរងគ្រោះជាច្រើន

(v) ការប្រព្រឹត្តបទឧក្រិដ្ឋសម្រាប់មូលហេតុណាមួយដែលជាប់ពាក់ព័ន្ធទៅនឹងការរើសអើងផ្អែកលើមូលដ្ឋានដែលមានចែងក្នុងមាត្រា ២១ កថាខណ្ឌ ៣

(vi) កាលៈទេសៈដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងកាលៈទេសៈដែលបានលើកឡើងនោះបើទោះបីជាពុំបានរៀបរាប់អស់ក៏ដោយ

2006.នៅតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍* នៅពេលវិធានស្តីពីនីតិវិធី និងភស្តុតាងពុំបានបញ្ជាក់ជាក់លាក់អំពីស្ថានសម្រាលទោស និងទម្ងន់ទោស កត្តាដែលត្រូវពិចារណាអំពីស្ថានទម្ងន់ទោស បានរួមបញ្ចូល៖

កម្រិតនៃការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទជាចារីផ្ទាល់ក្រោមមាត្រា ៧(១) ឬជាអ្នកសហការ ឬអ្នកជួយទំនុកបម្រុង តួនាទីដោយស្ម័គ្រចិត្ត ដោយឆន្ទៈ ឬគាំទ្រការប្រព្រឹត្តឧក្រិដ្ឋកម្ម ឋានៈ ឬមុខនាទីរបស់ជនជាប់ចោទ ចំនួន និងភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះ និងផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើពួកគេ ទំហំ និងរយៈពេលនៃអំពើល្មើស និងការមិនអើពើលើផលវិបាក អំពើឃោរឃៅ ឬអំពើសាហាវយង់ឃ្នងនៃបទឧក្រិដ្ឋ កម្រិតនៃការគិតទុកជាមុននៃបទល្មើស និងចេតនានៃការរើសអើងដែលចារីបានប្រព្រឹត្តឡើង[5711]។

2007.កត្តាដែលត្រូវពិចារណាក្នុងស្ថានសម្រាលទោសរួមបញ្ចូល៖

ទង្វើល្អរបស់ជនជាប់ចោទក្នុងអំឡុងពេលនៃការប្រព្រឹត្តបទឧក្រិដ្ឋ (ឧទាហរណ៍ ថាតើ ជនជាប់ចោទព្យាយាមរារាំងបទល្មើស ប៉ុន្តែត្រូវបានបង្ខំឱ្យចូលរួម ឬថាតើ គាត់បានជួយដល់ជនរងគ្រោះ) ទង្វើល្អរបស់គាត់ក្នុងមន្ទីរឃុំឃាំងនៃអង្គការសហប្រជាជាតិ ការប្រគល់ខ្លួនដោយស្ម័គ្រចិត្ត (ខុសពីការលាក់ខ្លួន ឬគេចវេះពីយុត្តិធម៌) របាយការណ៍ជាប់ទោសពីមុនរបស់គាត់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់បទឧក្រិដ្ឋសង្គ្រាមអន្តរជាតិ កិច្ចសហការយ៉ាងសំខាន់របស់គាត់ជាមួយនឹងអយ្យការ អាយុ និងលក្ខខណ្ឌសុខភាពរបស់គាត់ ការសម្តែងវិប្បដិសារី ការទទួលកំហុស និងឆន្ទៈរបស់គាត់ក្នុងការប្រាប់ការពិត(ប្រសិនបើ

---

[5711] អ្នកនិពន្ធ Harhoff ការដឹង និងសុភវិនិច្ឆយក្នុងការដាក់ទោស ទំព័រ ១៣៧។

គាត់ពិតជាទទួលកំហុស) រយៈពេលដែលគាត់ស្ថិតក្នុងការឃុំឃាំងមុនការជំនុំជម្រះ (លើកលែងតែគាត់បានអូសបន្លាយដោយចេតនា) និងស្ថានភាពគ្រួសាររបស់គាត់[5712]។

2008.ចំពោះរឿងក្តីក្នុងស្រុក រយៈពេលសំខាន់ចាប់តាំងពីការប្រព្រឹត្តបទល្មើសជួនកាលត្រូវបានចាត់ទុកថា ជាកត្តាសម្រាលទោសដោយសារជនជាប់ចោទបានរស់ជីវិតក្នុងលក្ខណៈគោរពច្បាប់ចាប់តាំងពីបទឧក្រិដ្ឋបានកើតឡើង ប៉ុន្តែមានការជំទាស់ថា កត្តានេះពុំគប្បីអនុវត្តចំពោះការសម្រាលទោសក្នុងករណីដែលមានការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស[5713]។

2009.បើទោះបីជាបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌មានការកែប្រែចាប់តាំងពីពេលមានអត្ថិភាពនៃតុលាការ IMT នៅទីក្រុង Nuremberg[5714]ក៏ដោយ ក៏នៅតែផ្តល់ជាការណែនាំក្នុងការពិនិត្យអំពីការដាក់ទោសដែរ ដោយសារនេះគឺជាតុលាការព្រហ្មទណ្ឌអន្តរជាតិតែមួយដែលដោះស្រាយលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្ត

---

[5712] អ្នកនិពន្ធ Harhoff៖ ការដឹង និងសុភវិនិច្ឆ័យក្នុងការដាក់ទោស ទំព័រ ១៣៧-១៣៨។

[5713] *សូមមើល រឿងក្តី Julian ទល់នឹង Roberts* “ពេលវេលានៃការដាក់ទោស៖ សមាមាត្រ និងការដាក់ទោសនៃបទឧក្រិដ្ឋដែលជាប្រវត្តិសាស្ត្រ” ក្នុងការបោះពុម្ពផ្សាយដោយ Michael Tonry *ឧក្រិដ្ឋជនវ័យកម្លាំង និងគ្មានធ្មេញ៖ តើការដាក់ទោសស័ក្តិសមនឹងបទឧក្រិដ្ឋ ដែរ ទេ?* (២០១៩) ទំព័រ ១៧៦:

> នៅពេលបទឧក្រិដ្ឋមានលក្ខណៈឃោរឃៅបំផុត(មនុស្សឃាតដោយចេតនា) ការសុំសម្រាលទោសពុំសូវជឿជាក់បាននោះទេ។ ឧទាហរណ៍ ការសម្រាលទោសជនល្មើសកម្រិតទីមួយទំនងជាអាចធ្វើទៅបាន នៅពេលមានភាពមិនប្រាកដប្រជាអំពីព្យសនកម្មដែលបានបង្កឡើង ឬអំពីផលប៉ះពាល់ទាំងស្រុងនៃបទឧក្រិដ្ឋលើជនរងគ្រោះ។ ភាពមិនប្រាកដប្រជាពុំអាចលើកឡើងដោយសមហេតុផលក្នុងបរិបទនៃអំពើមនុស្សឃាតនោះឡើយ។ បុគ្គលគ្រប់រូបពុំចាំបាច់ត្រូវចាប់ខ្លួនចោទប្រកាន់ និងដាក់ទោសនៅមុនពួកគេដឹងនូវអំពើខុសច្បាប់ទាំងស្រុងនោះទេ។ អំណះអំណាងសុំសម្រាលទោសដូចគ្នានេះគប្បីអនុវត្តចំពោះបទល្មើសជាប្រវត្តិសាស្ត្រ ហើយនេះអាចបញ្ជាក់ថា ជនល្មើសដែលត្រូវបានដាក់ពិរុទ្ធភាពពីបទល្មើសដូចជាអំពើមនុស្សឃាត មិនអាចឱ្យរួចផុតពីការសម្រាលទោសដោយសារពេលវេលាកន្លងហួសទៅយូរនោះទេ។ នេះអាចជាមូលហេតុដែលការចោទប្រកាន់អំពីឧក្រិដ្ឋកម្មសង្គ្រាមគប្បីជាទូទៅមិនអាចទទួលការសម្រាលទោសដោយសារពេលវេលាកន្លងផុតទៅយូរនោះទេ។ ខ្ញុំអាចដកជនល្មើសទាំងនោះចេញពីការសម្រាលទោសដោយផ្អែកលើមូលដ្ឋានថា ភាពធ្ងន់ធ្ងរខុសពីធម្មតានៃការរំលោភបំពានលើសិទ្ធិមនុស្សទាំងស្រុងបានដករឿងក្តីនេះចេញពីក្របខ័ណ្ឌភាពសមាមាត្រនៃការដាក់ទោសដែលត្រូវបានបង្កើតឡើងសម្រាប់បទឧក្រិដ្ឋធម្មតា។ ចូរពិចារណា តើតុលាការអាចកំណត់បានពិតប្រាកដនូវការដាក់ទោសដែលសមាមាត្រជាការឆ្លើយតបទៅនឹងអំពើមនុស្សឃាតលើមនុស្សរាប់ពាន់នាក់បានដែរ ឬទេ?

[5714] ឧទាហរណ៍ ពុំមានតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ“កម្រិតអន្តរជាតិ”សម័យទំនើបដាក់ទោសប្រហារជីវិត ដែលនេះត្រូវបានលុបបំបាត់នៅក្នុងទឹកន្លែងជាច្រើននៃពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ (*សូមមើល* មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញកម្ពុជា) និងសិទ្ធិទទួលបានការសើរើលើការដាក់ពិរុទ្ធភាព និងទោសដោយតុលាការជាន់ខ្ពស់ស្របតាមច្បាប់ ដែលបច្ចុប្បន្នមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (មាត្រា ១៤(៥)) ក្នុងចំណោមលិខិតុបករណ៍អន្តរជាតិដទៃទៀត។

ឡើងក្នុងទ្រង់ទ្រាយធំនៅមុនឆ្នាំ ១៩៧៥។ ធម្មនុញ្ញរបស់តុលាការ IMT ពុំបានកំណត់អំពីគោលការណ៍ណែនាំស្តីពីការដាក់ទោស ដូចបានបញ្ជាក់ជាធម្មតាក្នុងមាត្រា ២៧ នៃធម្មនុញ្ញានេះថា "តុលាការព្រហ្មទណ្ឌត្រូវតែមានសិទ្ធិដាក់ទោសប្រហារជីវិតលើជនជាប់ចោទផ្អែកលើការដាក់ពិរុទ្ធភាព ឬដាក់ទោសដទៃទៀតដែលតុលាការបានចាត់ទុកថា ជាការត្រឹមត្រូវ"។ នៅក្នុងផ្នែកនៃការដាក់ទោសនៃសាលក្រមនោះពុំបានផ្តល់មូលហេតុសម្រាប់ទោសដែលជនជាប់ចោទនីមួយៗត្រូវទទួលឡើយ[5715]។ ទោះជាយ៉ាងណាក្តី ផ្នែកនៃសាលក្រមដែលកំណត់អំពីការដាក់ពិរុទ្ធភាពក្នុងរឿងក្តីខ្លះបានរៀបរាប់នូវកត្តាដែលត្រូវបានចាត់ទុកថា ជាការសម្រាលទោស។ តុលាការ IMT ពុំបានដោះស្រាយកត្តានៃស្ថានទម្ងន់ទោស និងទំនងជាបានពិចារណាថា ពិរុទ្ធភាពសម្រាប់បទល្មើសនោះ គឺជាការផ្តល់យុត្តិកម្មសម្រាប់ការដាក់ទោសប្រហារជីវិត ដោយគ្មានកត្តានៃស្ថានសម្រាលទោសណាមួយឡើយ[5716]។

2010.នៅតុលាការ IMT មានការដាក់ពិរុទ្ធភាព ១៩ ករណី។ ជនជាប់ចោទ ១២ នាក់ត្រូវបានដាក់ទោសប្រហារជីវិត[5717]។ បីនាក់ត្រូវបានដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត[5718] ពីរនាក់ដាក់ទោសជាប់ពន្ធនាគាររយៈពេល ២០ ឆ្នាំ[5719] ម្នាក់ដាក់ទោសជាប់ពន្ធនាគាររយៈពេល ១៥[5720] និងដទៃទៀតដាក់ទោសជាប់ពន្ធនាគាររយៈពេល ១០ ឆ្នាំ[5721]។

2011.មានបទល្មើសបួនដែលត្រូវបានចោទប្រកាន់ដោយតុលាការ IMT៖ បទល្មើសទីមួយគឺការចូលរួមក្នុងផែនការរួម ឬការសមគំនិតប្រព្រឹត្ត ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បទល្មើសទីពីរ គឺជាបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព។ បទល្មើសទី

---

[5715] អ្នកនិពន្ធ Schabas៖ ការដាក់ទោសដោយតុលាការពហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៨៤។

[5716] អ្នកនិពន្ធ Schabas៖ ការដាក់ទោសដោយតុលាការពហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៨៤។

[5717] ជនជាប់ចោទ Hermann Wilhelm Goering, Joachim von Ribbentrop, Wilhelm Keitel, Ernst Kaltenbrunner, Alfred Rosenberg, Hans Frank, Wilhelm Frick, Julius Streicher, Fritz Sauckel, Alfred Jodl, Arthur Seyss-Inquart, និង Martin Bormann។

[5718] ជនជាប់ចោទ Rudolf Hess, Walther Funk និង Erich Raeder។

[5719] ជនជាប់ចោទ Baldur von Schirach និង Albert Speer។

[5720] ជនជាប់ចោទ Konstantin von Neurath។

[5721] ជនជាប់ចោទ Karl Doenitz។

បីគឺជាឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសទីបួនគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5722]។ បទចោទជាក់លាក់ ឬចំនួននៃបទចោទដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធ ទំនងជាពុំមែនជាកត្តាកំណត់ទោសឡើយ។ ស្ថិតក្នុងចំណោម ១២ នាក់ដែលត្រូវបានដាក់ទោសប្រហារជីវិត មានប្រាំពីរនាក់ពុំត្រូវបានរកឃើញថា មានពិរុទ្ធពីបទចោទមួយចំនួនដែលខ្លួនត្រូវបានចោទប្រកាន់ឡើយ[5723]។ ជនជាប់ចោទដែលបានទទួលទោសស្រាលបំផុតកម្រិតទីពីរ (ជាប់ពន្ធនាគាររយៈពេល ១៥ ឆ្នាំ) ត្រូវបានដាក់ពិរុទ្ធភាពពីបទចោទបួនរួមគ្នា[5724]។

2012. ស្ថិតក្នុងចំណោមបីនាក់ដែលបានទទួលទោសជាប់ពន្ធនាគារអស់មួយជីវិត ជនជាប់ចោទ Rudolf Hess ត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសទីមួយ និងទីពីរ ប៉ុន្តែមិនមែនបទល្មើសទីបី និងទីបួន[5725]។ ជនជាប់ចោទ Walther Funk ពុំត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសទីមួយ ប៉ុន្តែមានពិរុទ្ធពីបទល្មើសទីពីរ ទីបី និងទីបួន[5726] និងជនជាប់ចោទ Erich Raeder ត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសទីមួយ ទីពីរ និងទីបី។ គាត់ពុំត្រូវបានចោទប្រកាន់ពីបទល្មើសទីបួនឡើយ[5727]។ សាលក្រមពុំបានពន្យល់មូលហេតុដូចម្ដេចបានជា ជនជាប់ចោទ Hess បានទទួលទោសជាប់ពន្ធនាគារអស់មួយជីវិតឡើយ។ គាត់បានទទួលទោសជាប់ពន្ធនាគារអស់មួយជីវិតជាជាងទោសប្រហារជីវិតពីព្រោះគាត់បានបើកយន្តហោះឆ្លងកាត់ប្រទេសស្កុតឡេន ក្នុងគោលបំណងចរចាសន្តិភាពជាមួយប្រទេសអង់គ្លេស បើទោះបីជាតុលាការព្រហ្មទណ្ឌយោធានោះបានកត់សម្គាល់ថា "ក្រោយពេលទៅដល់ប្រទេសអង់គ្លេស Hess នៅតែគាំទ្រទាំងស្រុងនូវសកម្មភាពឈ្លានពានរបស់អាល្លឺម៉ង់រហូតដល់ពេលនោះ និងព្យាយាមផ្ដល់យុត្តិកម្មលើសកម្មភាពរបស់អា

---

[5722] រឿងក្ដី*សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (១៩៤៧) ភាគ ១ ទំព័រ ២៧-៦៧។

[5723] ជនជាប់ចោទ Kaltenbrunner ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិតទី ១, ជនជាប់ចោទFrank ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១, ជនជាប់ចោទ Frick ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១, ជនជាប់ចោទ Streicher ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១, ជនជាប់ចោទ Sauckel ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១ និង ២, ជនជាប់ចោទ Seyss-Inquart ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១ និង Bormann ពុំត្រូវបានរកឃើញមានពិរុទ្ធពីបទល្មើសកម្រិត ១។

[5724] ជនជាប់ចោទ Von Neurath។

[5725] សាលដីកាតុលាការ IMT ទំព័រ ២៨៥ (Hess)។

[5726] សាលដីកាតុលាការ IMT ទំព័រ ៣០៧ (Funk)។

[5727] សាលដីកាតុលាការ IMT ទំព័រ ៣១៧ (Raeder)។

ល្អីម៉ង់ទាក់ទងទៅនឹងប្រទេសអូទ្រីស ឆេកូស្លូវ៉ាគី ប៉ូឡូញ ន័រវេ ដាណឺម៉ាក បែលហ្ស៊ិក និងហូឡង់"[5728]។ ការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតរបស់គាត់អាចដោយសារការពិតដែលថា មានក្តីបារម្ភចំពោះបញ្ហាសមត្ថភាពផ្នែកស្មារតីពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី បើទោះបីជាគាត់ត្រូវបានកំណត់ថាមានសម្បទាគ្រប់គ្រាន់ចូលរួមសវនាការក៏ដោយ[5729]។

2013.ចំពោះជនជាប់ចោទ Funk តុលាការព្រហ្មទណ្ឌនោះបានបញ្ជាក់ថា "បើទោះបីជាការពិតថា គាត់បានកាន់កាប់តួនាទីផ្លូវការសំខាន់ក៏ដោយ ក៏ Funk ពុំមែនជាបុគ្គលលេចធ្លោនៅក្នុងកម្មវិធីនានាដែលគាត់បានចូលរួមដែរ។ នេះគឺជាកត្តាស្ថានសម្រាលទោស ដែលតុលាការព្រហ្មទណ្ឌនោះបានកត់សម្គាល់"[5730]។ Funk បានអះអាងថា គាត់ពុំបានដឹងជាមុនអំពីឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់ ប៉ុន្តែបញ្ជាក់ថា នៅពេលគាត់បានដឹងអំពីឧក្រិដ្ឋកម្មនោះ គាត់មានភាពអាម៉ាស់យ៉ាងខ្លាំង[5731]។ សម្រាប់ជនជាប់ចោទ Raeder តុលាការព្រហ្មទណ្ឌនោះពុំបានពន្យល់ជាក់លាក់ថាតើ តុលាការបានពិចារណាលើកាលៈទេសៈស្ថានសម្រាលទោសណាមួយ ដែរ ឬយ៉ាងណា ប៉ុន្តែបានកត់សម្គាល់ថា Raeder ដែលជាមេបញ្ជាការទ័ពជើងទឹក"ទទួលស្គាល់ការទទួលខុសត្រូវទាំងស្រុង រហូតដល់ពេលចូលនិវត្តន៍ក្នុងឆ្នាំ ១៩៤៣"។ គាត់បាន"ទទួលស្គាល់ថា កងទ័ពជើងទឹកបានរំលោភបំពានសន្ធិសញ្ញា និងបានទទូចថា នោះគឺជា'បញ្ហាកិត្តិយសសម្រាប់មនុស្សគ្រប់រូប'

[5728] សាលដីកាតុលាការ IMT ទំព័រ ២៨៤ (Hess)។

[5729] អ្នកនិពន្ធ Telford Taylor *កោសល្យវិច្ច័យនៃការជំនុំជម្រះ Nuremberg:៖ កំណត់ហេតុផ្ទាល់ខ្លួន* (ឆ្នាំង ១៩៩៣) ទំព័រ ១៥០, ១៧៧-១៨០, ២៦៨, ៥៦០។ ដូចការអះអាងរបស់អតីតរដ្ឋអាជ្ញាម្នាក់នៅ Nuremberg ថា "ហេតុដូចម្តេចបានជាព្រះគុម្ពីរ [ចៅក្រមជនជាតិអាមេរិក] និង Lawrence [ចៅក្រមជនជាតិអង់គ្លេស] មិនចូលរួមជាមួយ Nikitchenko [ចៅក្រមសហភាពសូវៀត] សម្រាប់ការដាក់ទោសប្រហារជីវិត ? កំណត់ត្រាពុំបានបំភ្លឺ ប៉ុន្តែក្រោយពីការពិនិត្យលើអាកប្បកិរិយាមិនប្រក្រតីរបស់បុរសម្នាក់ដែលពុំអាចការពារខ្លួនឯងបាននោះ មានតែចៅក្រមដែលគ្មានបេះដូងទេទើបអាចបញ្ជូនបុរសនោះចូលឈើឆ្កោក" ។ អ្នកនិពន្ធ Taylor៖ កោសល្យវិច្ច័យនៃការជំនុំជម្រះ Nuremberg: ទំព័រ ៥៦០។

[5730] សាលដីកាតុលាការ IMT ទំព័រ ៣០៦ (Funk) ស្តីពីការជាប់ពន្ធនាគារអស់មួយជីវិត រដ្ឋអាជ្ញាម្នាក់នៅ Nuremberg ក្រោយមកបានសរសេរថា "ខ្ញុំគ្មានវិប្បដិសារីនៅពេលដែលមានអ្នកអាចគេចផុតពីឈើឆ្កោកបាន ប៉ុន្តែខ្ញុំពុំឃើញមានមូលដ្ឋានសម្រាប់កត្តាសម្រាលទោស Funk ដែលអាចទុកជីវិតឱ្យគាត់នោះឡើយ។ ពិតណាស់ វិសាលភាពនៃបទឧក្រិដ្ឋរបស់ Funk ទូលំទូលាយជា Streicher និងជាការគួរឱ្យទើសចិត្តពេលឃើញ Funk ទទួលបានអត្ថប្រយោជន៍តាមរយៈអំពើកំសាករបស់ខ្លួននៅពេលអ្នកដទៃទៀត ត្រូវប្រឈមនឹងការប្រហារជីវិតដោយក្លាហាន"។ អ្នកនិពន្ធ Taylor៖ កោសល្យវិច្ច័យនៃការជំនុំជម្រះ Nuremberg ទំព័រ ៥៩៩។

[5731] *សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ XXII ទំព័រ ៣៨៧។

ដែលត្រូវធ្វើដូច្នោះ និងបានលើកឡើងថា ការរំលោភបំពានគឺជាផ្នែកមួយតូចតាចបំផុត ហើយអាល្លឺម៉ង់ពុំទាន់បានកសាងឱ្យអស់ពីលទ្ធភាពដែលអនុញ្ញាតឡើយ"[5732]។ តុលាការព្រហ្មទណ្ឌបានកត់សម្គាល់ផងដែរថា ជនជាប់ចោទ Raeder បានប្រឹងប្រែងបញ្ចុះបញ្ចូល Hitler ឱ្យបោះបង់ផែនការឈ្លានពានលើសហភាពសូវៀត[5733]។

2014.សាលក្រមពុំបានពន្យល់នូវមូលហេតុដូចម្ដេចបាន ជនជាប់ចោទ Baldur von Schirach ដែលត្រូវបានដាក់ពិរុទ្ធភាពពីបទល្មើសទីបួន បានទទួលទោសជាប់ពន្ធនាគាររយៈពេល ២០ ឆ្នាំ ពីព្រោះគាត់ត្រូវបានដាក់ពិរុទ្ធភាពក្រោមបទល្មើសទីបួនប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្ដី ជនជាប់ចោទ Julius Streicher ត្រូវបានដាក់ពិរុទ្ធភាពពីបទល្មើសទីបួនផងដែរ ប៉ុន្តែបានទទួលទោសប្រហារជីវិត។ ជនជាប់ចោទ Albert Speer ដែលបានទទួលការដាក់ទោសជាប់ពន្ធនាគាររយៈពេល ២០ ឆ្នាំ ត្រូវបានសម្រេចដាក់ពិរុទ្ធពីបទល្មើសទីបី និងទីបួន។ សាលក្រមបានបញ្ជាក់ថា៖

> ក្នុងការសម្រាលទោស គួរទទួលស្គាល់ថា ជនជាប់ចោទ Speer បានបង្កើតឧស្សាហកម្មបិទខ្ទប់អ្នកធ្វើការជាច្រើននៅក្នុងផ្ទះ និងថា នៅក្នុងដំណាក់កាលជិតចប់សង្គ្រាម គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរទៅបីនាក់ដែលហ៊ានប្រាប់ Hitler ថា សង្គ្រាមត្រូវបានចាញ់ និងត្រូវចាត់វិធានការរារាំងការបំផ្លាញដោយឥតន័យលើឧបករណ៍ផលិតកម្មក្នុងទឹកដីដែលបានកាន់កាប់ និងក្នុងប្រទេសអាល្លឺម៉ង់។ គាត់បានជំទាស់ទៅនឹងកម្មវិធីបំផ្លាញអ្វីដែលមានអត្ថប្រយោជន៍ចំពោះសត្រូវនៅក្នុងប្រទេសលោកខាងលិចមួយចំនួន និងក្នុងប្រទេសអាល្លឺម៉ង់ តាមរយៈការធ្វើវិទ្ធង្សនាដោយចេតនាលើកម្មវិធីនោះដោយមានហានិភ័យខ្ពស់ដល់ខ្លួន[5734]។

2015.ជនជាប់ចោទ Konstantin Von Neurath ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសទាំងបួន។ គាត់បានទទួលទោសជាប់ព័ន្ធនាគាររយៈពេល ១៥ ឆ្នាំ៖

---

[5732] សាលដីកាតុលាការ IMT ទំព័រ ៣១៥ (Raeder)។

[5733] សាលដីកាតុលាការ IMT ទំព័រ ៣១៥ (Raeder)។ ជនជាប់ចោទ Raeder "មានមិនសប្បាយចិត្តដោយសារការរួចផុតពីឈើឆ្កោក និងបានបញ្ជាក់ច្បាស់ថា គាត់សុខចិត្តស្លាប់ជាជាងជាប់ពន្ធនាគារអស់មួយជីវិត"។ អ្នកនិពន្ធ Taylor កោសល្យវិច្ច័យនៃការជំនុំជម្រះ Nuremberg ទំព័រ ៥៩៩។ គាត់"បានស្នើសុំក្រុមប្រឹក្សាគ្រប់គ្រង'អនុគ្រោះទោសរបស់គាត់ពីការប្រហារជីវិតតាមរយៈការបាញ់ប្រហារ មកតាមលក្ខណៈមានមេត្តា"។ អ្នកនិពន្ធ Taylor៖ កោសល្យវិច្ច័យនៃការជំនុំជម្រះ Nuremberg ទំព័រ ៦០២។

[5734] សាលដីកាតុលាការ IMT ទំព័រ ៣៣៣ (Speer)។

នៅក្នុងការសម្រាលទោស គួររំឭកថា ជនជាប់ចោទ von Neurath បានធ្វើអន្តរាគមន៍ទៅលើប៉ូលីសសន្តិសុខ និងក្រុមយកការណ៍សម្ងាត់របស់ណាហ្ស៊ី ក្នុងការដោះលែងជនជាតិឆេកូស្លូវ៉ាគីជាច្រើននាក់ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៣៩ និងការដោះលែងនិសិត្សដែលត្រូវបានចាប់ខ្លួនក្រោយមកក្នុងរដូវស្លឹកឈើជ្រុះ។ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៤១ គាត់ត្រូវបានកោះហៅមកចំពោះមុខ Hitler និងត្រូវបានប្រាប់ថា គាត់មិនបានធ្វើឱ្យខ្លាំងគ្រប់គ្រាន់ និងថា Heydrich ត្រូវបានបញ្ជូនទៅប្រទេសដែលត្រូវបានត្រួតត្រាដើម្បីបង្ក្រាបក្រុមប្រឆាំងជនជាតិឆេកូស្លូវ៉ាគី។ ជនជាប់ចោទ Von Neurath បានព្យាយាមបញ្ចុះបញ្ចូល Hitler ឱ្យបញ្ឈប់ការបញ្ជូន Heydrich ប៉ុន្តែពុំបានសម្រេច និងនៅពេលគាត់ពុំទទួលបានជោគជ័យនោះ គាត់បានសុំលាឈប់។ នៅពេលការលាឈប់របស់គាត់ពុំត្រូវបានទទួលយក គាត់បានសុំច្បាប់សម្រាកការងារនៅថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៤១ និងបានបដិសេធធ្វើជាប្រឹក្សាភិបាលបន្ទាប់ពីកាលបរិច្ឆេទនេះ។ ការលាឈប់របស់គាត់ត្រូវបានទទួលយកជាផ្លូវការនៅខែសីហា ឆ្នាំ ១៩៤៣[5735]។

2016.ជនជាប់ចោទ Von Neurath បានអះអាង និងបានផ្តល់ភស្តុតាងដែលបង្ហាញថា គាត់ពុំដែលប្រឆាំងទៅនឹងជនជាតិជ្វីហ្វ និងបានប្រឆាំងរាល់វិធានការនៃអំពើហិង្សាលើជនជាតិជ្វីហ្វ និងបានប្រឆាំងនឹងគោលនយោបាយរើសអើងពូជសាសន៍របស់បក្សជាតិសង្គមនិយម[5736]។

2017.គួរកត់សម្គាល់ថា ជនជាប់ចោទ Speer និង Von Neurath បានជំទាស់ទៅនឹងគោលនយោបាយមួយចំនួនរបស់ Hitler និងបានប្រឆាំងដោយមានហានិភ័យផ្ទាល់ខ្លួន[5737]។

### ខ. ការបំភ្លឺពាក់ព័ន្ធទៅនឹងការដាក់ទោសកម្រិតទីពីរលើ ខៀវ សំផន

[5735] សាលដីកាតុលាការ IMT ទំព័រ ៣៣៦ (Von Neurath)។

[5736] *សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ XVI ទំព័រ ៥៩៦-៥៩៨។

[5737] ប្រហាក់ប្រហែលគ្នានេះ កត្តាដែលត្រូវបានពិចារណាក្នុងការទទួលយកសំណើសម្រាប់ការសម្រាលទោសអ្នកដែលត្រូវបានដាក់ពិរុទ្ធភាពក្នុងការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទីពីរ គឺថាតើ ជនជាប់ចោទ"មានភាពក្លាហានប្រឆាំងនឹងបទបញ្ជាល្មើសដែលនេះអាចប្រឈមគ្រោះថ្នាក់ផ្ទាល់ខ្លួន ដែរ ឬយ៉ាងណា"។ *សូមមើល* អ្នកនិពន្ធ Schabas៖ ការដាក់ទោសដោយតុលាការពហ្មទណ្ឌអន្តរជាតិ ទំព័រ ៤៨៥-៤៨៦ ដកស្រង់សេចក្តីថ្លែងការណ៍របស់ឧត្តមស្នងការប្រចាំប្រទេសអាល្លឺម៉ង់ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៥១ បន្ទាប់ពីការប្រកាសសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនពាក់ព័ន្ធទៅនឹងសំណើសុំបន្ធូបន្ថយទោសឧក្រិដ្ឋកម្មសង្គ្រាមដែលជាប់ពិរុទ្ធភាពនៅតុលាការ Nuremberg លេខ 15 T.W.C. 1176, 1177 (ឆ្នាំ ១៩៤៨)។

2018.មុនពេលពិភាក្សាអំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការដាក់ទោស អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ត្រូវបំភ្លឺបញ្ហាទាក់ទងទៅនឹងទោសរបស់ ខៀវ សំផន ៖ ថាតើ បច្ចុប្បន្នគាត់អនុវត្តទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិត ឬទោសពីរត្រួតគ្នាជាប់ពន្ធនាគារអស់មួយជីវិត ដែរ ឬយ៉ាងណា។ បញ្ហានេះបានកើតឡើង ដោយសារវិសាលភាពភាពនៃសំណុំរឿង ០០២ ត្រូវបានបំបែកទៅជាសំណុំរឿង ០០២/០១ និង ០០២/០២ ដែលមានបទចោទរៀងៗខ្លួន ដើម្បីអត្ថប្រយោជន៍ងាយស្រួលនៃការចាត់ចែងការជំនុំជម្រះ[5738]ដែលនេះគឺជាអ្វីធ្លាប់មានពីមុនមកនៅ អ.វ.ត.ក. ឬក្នុងយុត្តិសាស្រ្តព្រហ្មទណ្ឌអន្តរជាតិ[5739] និងពុំមានចែងក្នុងច្បាប់កម្ពុជាឡើយ។

2019.វិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុងចែងថា៖

> នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។

2020.ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពុំបានដោះស្រាយការដាក់ទោសក្នុងរឿងក្តីដែលត្រូវបានបំបែកឡើយ។

2021.ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិតបន្ទាប់ពីបានរកឃើញថា គាត់មានពិរុទ្ធពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល រួមបញ្ចូលអំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត មានដូចជា ការផ្លាស់ទីដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[5740]។

---

[5738] *សូមមើល ឧ.* សេចក្តីសម្រេចសំណុំរឿង ០០២ លើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការពិចារណាសាឡើងវិញ (E124/7) កថាខណ្ឌ ៥៖ "[វិធាន ៨៩ *ស្ទួនពីរ*] ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងក្នុងករណីដែលយុត្តិធម៌តម្រូវនូវយន្តការរៀបចំសវនាការតាមឆន្ទានុសិទ្ធិដែលតាមគំនិតផ្តួចផ្តើមរបស់ខ្លួនក្នុងការបំបែកកិច្ចដំណើរការនីតិវិធី និងដើម្បីពិនិត្យក្នុងការជំនុំជម្រះផ្សេងៗនូវផ្នែកខុសប្លែកគ្នានៃដីកាបញ្ជូនទៅជំនុំជម្រះ"។

[5739] សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកសំណុំរឿង ០០២ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ E284/4/8 កថាខណ្ឌ ៤០។

[5740] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ Disposition ទំព័រ ៦២២។

2022.ក្នុងការប្រកាសទោសតែមួយត្រួតគ្នាជាច្រើនបទជាជាងទោសមួយសម្រាប់បទល្មើសមួយ[5741] អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមសំណុំរឿង ០០១ ដែលក្នុងនោះអង្គជំនុំជម្រះបានកំណត់ថា បើទោះបីជាជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសជាច្រើនក៏ដោយ ក៏ការប្រកាសទោសតែមួយដែលឆ្លុះបញ្ចាំងអំពើល្មើសជារួមគឺជាកាសមស្របបំផុត[5742]។

2023.ក្នុងរឿងក្តី ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើការពិតថា ខៀវ សំផន កំពុងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតសម្រាប់ការដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០១ និងថា ទោសនោះគឺជាកម្រិតអតិបរមាដែលមានចែងក្នុងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពិចារណា"លើបញ្ហាថាតើ អង្គជំនុំជម្រះត្រូវដាក់ទោសដាច់ដោយឡែកពីគ្នាសម្រាប់ពិរុទ្ធភាពរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០២"[5743]។ គួរកត់សម្គាល់ថា ពុំមានបទប្បញ្ញត្តិចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. កិច្ចព្រមព្រៀង អ.វ.ត.ក. ឬវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ដែលអាចអនុវត្តបានលើស្ថានការនេះ និងថា "គោលការណ៍ណែនាំដាក់ទោសនៅកម្រិតអន្តរជាតិដែលពាក់ព័ន្ធទៅនឹងបញ្ហាជាក់លាក់នេះ មានកម្រិត" ដូច្នេះអង្គជំនុំជម្រះបានពិចារណាលើបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់របស់កម្ពុជា[5744]។

---

5741 នៅតុលាការ ICC អង្គជំនុំជម្រះសាលាដំបូងត្រូវប្រកាសទោសមួយសម្រាប់រាល់បទឧក្រិដ្ឋនីមួយៗព្រមទាំងទោសរួមគ្នា។ *សូមមើល* មាត្រា ៧៨(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមៈ

> នៅពេលបុគ្គលម្នាក់ត្រូវបានដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋច្រើន តុលាការត្រូវប្រកាសទោសមួយសម្រាប់បទឧក្រិដ្ឋនីមួយៗ និងទោសរួមគ្នា ដោយបញ្ជាក់ថិរវេលាជារួមនៃការជាប់ពន្ធនាគារ។ ថិរវេលានេះ មិនត្រូវលើសទោសនីមួយៗដែលខ្ពស់បំផុតនោះទេ និងមិនត្រូវលើសពីការជាប់ពន្ធនាគាររយៈពេល ៣០ ឆ្នាំ ឬជាប់ពន្ធនាគារអស់មួយជីវិតដែលស្របតាមមាត្រា ៧៧ កថាខណ្ឌ ១ (ខ)។

នៅតុលាការ STL អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដាក់ទោសមួយសម្រាប់បទចោទនីមួយៗ ឬទោសរួមតែមួយ។ *សូមមើល* តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសលីបង់ វិធានស្តីពីនីតិវិធី និងភស្តុតាង លេខ STL-BD-2009-01-Rev.11 ខែធ្នូ ឆ្នាំ ២០២០ វិធាន ១៧១(ឃ)៖

> អង្គជំនុំជម្រះសាលាដំបូងត្រូវដាក់ទោសមួយទាក់ទងទៅនឹងបទចោទនីមួយៗក្នុងដីកាបញ្ជូនទៅជំនុំជម្រះដែលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាពនោះ និងបង្ហាញថាតើ ទោសនោះត្រូវអនុវត្តត្រួតគ្នា ឬស្របចូលគ្នា ដែរ ឬយ៉ាងណា លើកលែងតែអង្គជំនុំជម្រះសម្រេចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដាក់ទោសតែមួយដែលឆ្លុះបញ្ចាំងជារួមនូវអំពើល្មើសរបស់ជនជាប់ចោទ។

5742 *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥៨៦-៥៩០។

5743 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៥៧។

5744 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៥៨។

2024.មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា៖

> នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវបានប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេចអាចប្រកាសឱ្យអនុវត្តទោសស្រួបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។
>
> ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។

2025.អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ការដាក់ទោសនេះតម្រូវថា៖

> ក្នុងករណីដែលទោសអតិបរិមាស្របច្បាប់ខ្ពស់ជាងគេ គឺជាប់ពន្ធនាគារអស់មួយជីវិតត្រូវបានប្រកាសរួចហើយនៅក្នុងនីតិវិធីមួយមុន ជាពិសេសនៅពេលដែលនីតិវិធីមុននោះបានចូលជាស្ថាពរ បន្ទាប់ពីការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ នៅក្នុងការអនុវត្តជាក់ស្តែង ទោសបន្តបន្ទាប់មកទៀតដែលមានលក្ខណៈដូចគ្នា ដែលនឹងត្រូវប្រកាសនៅក្នុងការជំនុំជម្រះពេលបន្ទាប់ ពាក់ព័ន្ធនឹងបទល្មើសត្រួតគ្នាជាមួយបទល្មើសដែលត្រូវបានជំនុំជម្រះរួចហើយនៅក្នុងកិច្ចដំណើរការនីតិវិធីមុននោះ ត្រូវរួមបញ្ចូលគ្នាជាមួយការផ្តន្ទាទោសមុនដោយស្វ័យប្រវត្តិ។ ហេតុដូច្នេះ ពិរុទ្ធជនត្រូវទទួលទោសតែមួយគត់។ ក្នុងករណីបែបនេះ ច្បាប់បារាំងបានយោងទៅរកស្ថានភាពមួយគឺ *ការស្រូបទោសដោយស្វ័យប្រវត្តិ*។ ទស្សនៈនេះត្រូវបានយកមកប្រើប្រាស់នៅក្នុងច្បាប់កម្ពុជា ប៉ុន្តែទស្សនៈនេះអាចមានអានុភាពអនុវត្តស្រដៀងគ្នាជាមួយសញ្ញាណនៃ“ការផ្តន្ទាទោសត្រួតគ្នា” ផងដែរ នៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុងដែលសំដៅទៅលើការផ្តន្ទាទោស ដែលត្រូវអនុវត្តក្នុងពេលតែមួយជាមួយការផ្តន្ទាទោសមួយទៀត។ នៅក្នុងករណីទាំងពីរនេះ លទ្ធផលគឺប្រហាក់ប្រហែលគ្នា ដោយសារតែពិរុទ្ធជនត្រូវអនុវត្តទោសអតិបរិមាស្របច្បាប់ដែលខ្ពស់ជាងគេ[5745]។

2026.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ឧក្រិដ្ឋកម្មក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ គឺជា“បទល្មើសត្រួតគ្នា”ផ្អែកតាមច្បាប់កម្ពុជា និងថា ខៀវ សំផន ត្រូវបានដាក់ទោសរួចរាល់ហើយជាប់ពន្ធនាគារអស់មួយជីវិតក្នុងសំណុំរឿង ០០២/០១ “ការដាក់ទោសជាប់ពន្ធនាគារបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ គឺជាការដាក់ត្រួតគ្នានៃទោសជាប់ពន្ធនាគារអស់មួយជីវិត”[5746]។ ក្រោយពីពិចារណាលើភាព

---

[5745] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៥៩។

[5746] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៦០។

ធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងកត្តាស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស អង្គជំនុំជម្រះសាលាដំបូង"បានសម្រេចដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាលើទោសជាប់ពន្ធនាគារអស់មួយជីវិតដែលបានដាក់ទៅលើ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសម្រេចរួមបញ្ចូលគ្នានូវទោសទាំងពីរទៅជាទោសដាក់ពន្ធនាគារតែមួយអស់មួយជីវិត"[5747]។

2027.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត និងការរួមបញ្ចូលជាមួយទោសពន្ធនាគារអស់មួយជីវិតដែលត្រូវបានដាក់ក្នុងសំណុំរឿង ០០២/០១ ដែលនេះបង្កើតទៅជាទោសតែមួយដែលគ្របដណ្តប់អំពើល្មើសរបស់ ខៀវ សំផន ទាំងមូលក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ គឺជាការសមស្រប។

2028.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ប្រសិនបើសំណុំរឿង ០០២ ពុំត្រូវបានបំបែកទៅជាការជំនុំជម្រះពីរដាច់ដោយឡែកពីគ្នាទេនោះ ខៀវ សំផន ពុំត្រូវបានដាក់ទោសពីរដងឡើយ។ ការដាក់ទោសបន្ថែមជាប់ពន្ធនាគារអស់មួយជីវិតដែលត្រួតគ្នា ឬស្រួបចូលគ្នា ពុំអាចធ្វើទៅបានក្នុងន័យយុត្តិធម៌ ពីព្រោះសំណុំរឿង ០០២ ត្រូវបានបំបែកដើម្បីអត្ថប្រយោជន៍ងាយស្រួលការចាត់ចែងការជំនុំជម្រះ។ បន្ថែមទៅលើការធ្វើឱ្យអាម៉ាស់ ឬបាត់បង់កិត្តិយសនៃការដាក់ទោសបន្ថែមជាប់ពន្ធនាគារអស់មួយជីវិត ដែលត្រូវអនុវត្តទោសពីរត្រួតគ្នានៃការជាប់ពន្ធនាគារអស់មួយជីវិតជាជាងទោសតែមួយអាចប៉ះពាល់លើសញ្ញាណនៃក្តីសង្ឃឹមចំពោះមនុស្សមានវ័យចំណាស់ និងអាចប៉ះពាល់លើឱកាសសម្រាប់ការដោះលែងដោយមានលក្ខខណ្ឌជាយថាហេតុណាមួយ[5748]។

---

[5747] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៤០២។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាឡើងវិញក្នុងផ្នែកសម្រេចសេចក្តីរបស់ខ្លួន៖ "ដោយអនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាលើការដាក់ពន្ធនាគារអស់មួយជីវិតលើ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរទៅជាការផ្តន្ទាទោសតែមួយដាក់ពន្ធនាគារអស់មួយជីវិត" សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ទំព័រ ២២៣១-២២៣២។

[5748] មាត្រា ៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០(ម្ភៃ)ឆ្នាំរួចមកហើយ។ *សូមមើល* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៨៥-៣៨៨ ពន្យល់ថា អ.វ.ត.ក. ពុំមានសមត្ថកិច្ចដោះស្រាយបញ្ហានេះ ដែលគប្បីត្រូវបានសម្រេចស្របតាមនីតិវិធីជាធរមាននៅពេលនោះ ដែលការដោះលែងមានលក្ខខណ្ឌត្រូវតែបានពិចារណាសម្រាប់ទណ្ឌិតដាក់លាក់ណាមួយ។

2029.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យដាក់ទោសមួយក្រោយពីការរកឃើញនូវពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០២ ក៏ដោយ[5749] ក៏អង្គជំនុំជម្រះមានការភាន់ច្រឡំតាមរយៈសំដៅទៅលើទោសត្រួតគ្នា ឬទោសពីរដែលត្រូវអនុវត្តក្នុងពេលតែមួយដូចគ្នា និងតាមរយៈការប្រដូចស្ថានការណ៍នៅចំពោះមុខខ្លួនជាមួយនឹងស្ថានការណ៍ដែលដោះស្រាយក្នុងច្បាប់ក្នុងស្រុករបស់កម្ពុជានៃមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ដូចបានកត់សម្គាល់ខាងលើ ច្បាប់កម្ពុជាពុំបានចែងសម្រាប់ការបំបែកនៃបទចោទ និងដូច្នេះ ពុំអាចអនុវត្តបានចំពោះស្ថានការណ៍បច្ចុប្បន្ននេះឡើយ។

2030.ដូចអង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ពីដំបូង ការបំបែកសំណុំរឿងនេះគឺជាការបំបែកកិច្ចដំណើរការនីតិវិធី ដែលក្រោយមកមានរឿងក្តីព្រហ្មទណ្ឌពីរ ឬលើសពីមួយ[5750]។ ទោះយ៉ាងណាក្តី ក្នុងសំណុំរឿង ០០២ មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែមួយ កិច្ចស៊ើបសួរតែមួយ និងដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ)តែមួយ។ បទចោទត្រូវបានជំនុំជម្រះដាច់ដោយឡែកពីគ្នា ដើម្បីអត្ថប្រយោជន៍ភាពងាយស្រួលក្នុងការចាត់ចែងការជំនុំជម្រះ។ នេះពុំអាចដូចគ្នាទៅនឹង"ការចោទប្រកាន់ដាច់ដោយឡែកពីគ្នា" ដែលមានចែងក្នុងមាត្រា ១៣៨ ក្រមព្រហ្មទណ្ឌកម្ពុជា។

2031.ស្ថានការណ៍នេះដូចគ្នាទៅនឹងការចោទប្រកាន់តែមួយនៅក្នុងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលចែងថា៖

> កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗត្រូវបានប្រកាសឡើង។ ប៉ុន្តែ កាលបើទោសត្រូវបានទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិប្បរមាស្របច្បាប់ដែលខ្ពស់ជាងគេ។
>
> ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថាជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ។

---

5749 យោងតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. "ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ថ្មី ៤, ៥,៦, ៧ និងមាត្រា ៨ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ រហូតដល់មួយជីវិត"។ (សេចក្តីបញ្ជាក់បន្ថែម)។ យោងតាមវិធាន ៩៨(៥) នៃវិធានផ្ទៃក្នុង "ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញមានពិរុទ្ធ អង្គជំនុំជម្រះត្រូវដាក់ទោសស្របតាមកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធានទាំងនេះ" (សេចក្តីបញ្ជាក់បន្ថែម)។

5750 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) កថាខណ្ឌ ៤២។

2032.ទោះជាយ៉ាងណាក្ដី ការរួមបញ្ចូលគ្នានូវទោសពីរទៅជាទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិតបាន អនុញ្ញាតអង្គជំនុំជម្រះសាលាដំបូងជៀសផុតពីភាពមិនត្រឹមត្រូវនៃការត្រួតទោសដែលដាក់ដោយឡែកពីគ្នាខណៈពេលធានាផងដែរថា ទោសតែមួយបានឆ្លុះបញ្ចាំងអំពើល្មើសជារួមរបស់ ខៀវ សំផន។

2033.ការរួមបញ្ចូលគ្នានូវទោសរបស់ ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិតក្នុងសំណុំរឿង ០០២/០២ ជាមួយនឹងទោសជាប់ពន្ធនាគារអស់មួយជីវិតក្នុងសំណុំរឿង ០០២/០១ ដែលគាត់បានអនុវត្តទោសតែមួយអស់មួយជីវិត នៅគ្រប់កាលៈទេសៈពុំអាចកាត់បន្ថយអានុភាពនៃភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធភាពក្នុងរឿងក្ដីនីមួយៗឡើយ។ បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាឧក្រិដ្ឋកម្មសាហាវឃោរឃៅបំផុតចំពោះមនុស្សជាតិ។ ពិតណាស់ ដូចការកត់សម្គាល់ត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងថា "ភាពធ្ងន់ធ្ងរនៃបទប្រល័យពូជសាសន៍ពុំអាចមើលរំលងបានទេ"[5751]។ ផ្ទុយទៅវិញ ការដាក់ទោសតែមួយបានឆ្លុះបញ្ចាំងការពិតថា នៅពេលជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋជាច្រើនដែលកើតចេញពីអំពើល្មើសដាច់ដោយឡែកពីគ្នាក្នុងរឿងក្ដីមួយ ការប្រកាសទោសតែមួយត្រួតគ្នាជាច្រើនបទត្រូវធ្វើឡើង[5752] និងទោសជាប់ពន្ធនាគារអស់មួយជីវិត គឺជាទោសអតិបរមាដែលច្បាប់អនុញ្ញាតនៅ អ.វ.ត.ក.[5753]។

2034.អង្គជំនុំជម្រះតុលាការកំពូលបំភ្លឺថា ខៀវ សំផន បច្ចុប្បន្នអនុវត្តទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិតដែលគ្របដណ្ដប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ទាំងមូលសម្រាប់បទឧក្រិដ្ឋដែលគាត់ត្រូវបានដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០១ និង ០០២/០២។ គាត់ពុំបានអនុវត្តទោសពីរត្រួតគ្នាជាប់ពន្ធនាគារអស់មួយជីវិតនោះទេ។ ទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិតដែលជាទោសអតិបរមាអនុញ្ញាតដោយច្បាប់ ត្រូវបានកម្ពុជា និងសហគមន៍អន្តរជាតិទាំងមូលចាត់ទុកថា ជាការបង្ហាញនូវភាពធ្ងន់ធ្ងរនៃការរំលោភបំពានលើច្បាប់អន្តរជាតិ។

---

[5751] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៧០។

[5752] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៥៧: "ក្នុងករណីដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពជាច្រើនបទ ការដាក់ទោសតែមួយដែលឆ្លុះបញ្ចាំងជារួមនូវអំពើល្មើសរបស់ជនជាប់ចោទត្រូវតែធ្វើឡើង"។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E188) កថាខណ្ឌ ៥៨៦-៥៩០។

[5753] មាត្រា ៣៩ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

## គ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខសម្រាប់ការដាក់ទោស

2035.មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ១០ នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. និងវិធាន ៩៨ នៃវិធានផ្ទៃក្នុង ផ្តល់ជាមូលដ្ឋានច្បាប់ដែលអនុវត្តបានចំពោះការដាក់ទោស។ បន្ថែមលើនេះ វិធាន ១០៤ អាចអនុវត្តបានលើបណ្តឹងសាទុក្ខប្រឆាំងនឹងការដាក់ទោស។

2036.ទាក់ទងទៅនឹងបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខប្រឆាំងនឹងការដាក់ទោស អង្គជំនុំជម្រះតុលាការកំពូលក្នុងសាលដីកាសំណុំរឿង ០០១ និង ០០២/០១ បានដកស្រង់ដោយយល់ស្របជាមួយ និងអនុវត្តបទដ្ឋាននៃការពិនិត្យនេះដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY ក្នុងរឿងក្តី *D. Milošević* ដែលថា៖

> ដោយយោងតាមកាតព្វកិច្ចក្នុងការអនុវត្តន៍គោលការណ៍ឯកត្តកម្មនៃទោស ដើម្បីឱ្យសមស្របទៅតាមស្ថានភាពរបស់ជនជាប់ចោទ និងស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការកំណត់ការផ្តន្ទាទោសយ៉ាងសមស្រប រួមបញ្ចូលទាំងការថ្លឹងថ្លែងអំពីស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស។ តាមវិធានទូទៅ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនធ្វើការកែប្រែទោសឡើយ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ឬខកខានមិនបានអនុវត្តតាមច្បាប់ជាធរមាន។ ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងអំពីកត្តានានាដែលមិនជាប់ពាក់ព័ន្ធ ឬក្រៅសាច់រឿង ឬខកខានមិនបានថ្លឹងថ្លែង ឬថ្លឹងថ្លែងមិនបានគ្រប់គ្រាន់ចំពោះកត្តាពាក់ព័ន្ធនានា ដែលបណ្តាលឱ្យមានកំហុសអង្គហេតុយ៉ាងច្បាស់ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ឬត្រូវបង្ហាញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនមានសំអាងហេតុអ្វីទាល់តែសោះ ឬមានភាពមិនយុត្តិធម៌ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចលើកឡើងបានថា អង្គជំនុំជម្រះសាលាដំបូងពិតជាខកខានមិនបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវប្រាកដមែន[5754]។

2037.អង្គជំនុំជម្រះតុលាការកំពូលត្រូវអនុវត្តបទដ្ឋាននេះក្នុងការសម្រេចលើការជំទាស់របស់ ខៀវ សំផន ទាក់ទងទៅនឹងការដាក់ទោស។

## ឃ. ការចោទប្រកាន់កំហុសទាក់ទងទៅនឹងការដាក់ទោស

---

[5754] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៥៤ និងសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១០៧ ដកស្រង់សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ២៩៧។

2038.ខៀវ សំផន បានលើកអំណះអំណាងចំនួនបួនសំខាន់ៗជំទាស់ទៅនឹងភាពត្រឹមត្រូវនៃការដាក់ទោសលើគាត់ ដែលត្រូវបានសង្ខេបដូចតទៅ៖ ដំបូង គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការ បញ្ជាក់ថា គោលបំណងបឋមនៃការដាក់ទោសគឺដើម្បីធានាដល់ជនរងគ្រោះ សាក្សី និងសាធារណជនថា ច្បាប់ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាពដោយពុំគិតពីឋានៈឡើយ[5755]។ គាត់បានអះអាងថា នេះគឺជា គោលបំណងទីពីរនៃការដាក់ទោស និងបង្ហាញនូវភាពលម្អៀង និងការដាក់ទោសមានលក្ខណៈធ្ងន់ធ្ងរហួស ហេតុ និងធ្វើជាគំរូ[5756]។

2039.ទីពីរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់នៅក្នុងការ វាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដោយសារបានពិចារណាលើបទឧក្រិដ្ឋដែលគាត់ពុំត្រូវបានចោទប្រកាន់ ឬដាក់ពិរុទ្ធភាព[5757]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការរំលោភសេពសន្ថវៈក្នុង មន្ទីរសន្តិសុខ[5758]។ ដោយសារមានតែបញ្ហាដែលត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យប៉ុណ្ណោះ ដែលត្រូវ ពិចារណាប្រឆាំងនឹងជនជាប់ចោទនៅដំណាក់កាលដាក់ទោស អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពាន លើគោលការណ៍នៃការដាក់ទោស[5759]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការពិចារណាលើលក្ខណៈមិនផ្ទាល់ និងមានកម្រិតនៃការចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្មនៅ ពេលវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលនេះជាការមិនគោរពតាមការអនុវត្តនៃការដាក់ទោសរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិដែលការចូលរួមដោយប្រយោល ឬមិនផ្ទាល់តាមធម្មតានាំទៅរកការដាក់ ទោសស្រាលជាង[5760]។

2040.ទីបី ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការវាយ តម្លៃលើកត្តាពីរនៃស្ថានទម្ងន់ទោស៖ (១) អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការរំលោភតួនាទីនៃសិទ្ធិ អំណាច និងឥទ្ធិពលថា ជាស្ថានទម្ងន់ទោសដែលផ្ទុយទៅនឹងការយល់ឃើញរបស់ខ្លួនដែលថា គាត់ពុំមាន សិទ្ធិអំណាចក្នុងការបញ្ជាដោយផ្ទាល់នូវការប្រព្រឹត្តឧក្រិដ្ឋកម្មនោះឡើយ និងតួនាទីនៃសិទ្ធិអំណាចរបស់គាត់

---

[5755] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤៥-២១៤៨។

[5756] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤៦-២១៤៨។

[5757] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤៩-២១៥១។

[5758] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៤៩-២១៥០។

[5759] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៥១។

[5760] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៥២-២១៥៧។

ត្រូវបានពិចារណាសម្រាប់ការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋកម្ម[5761] និង (២) អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបង្ហាញភាពជាប់ពាក់ព័ន្ធ និងទំនាក់ទំនងនៃកម្រិតវប្បធម៌របស់គាត់ថា ជាស្ថានសម្រាលទោស[5762]។

2041.ទីបួន ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការវាយតម្លៃរបស់ខ្លួនលើកត្តាសម្រាលទោស។ (១) អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការពិចារណាសមស្របទៅលើកិច្ចសហការរបស់គាត់ជាមួយ អ.វ.ត.ក. រួមទាំងការចូលរួមយ៉ាងសកម្មនៅពេលជំនុំជម្រះ អាកប្បកិរិយាជាគំរូរបស់គាត់ពេញមួយអំឡុងពេលនៃការឃុំឃាំង និងការទទួលស្គាល់របស់គាត់អំពីការរងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី[5763]។ (២) អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ទម្ងន់គ្រប់គ្រាន់ដល់វ័យចាស់ជរារបស់គាត់ និងលក្ខខណ្ឌសុខភាព និងលទ្ធភាពពុំអាចទ្រាំទ្រការដាក់ក្នុងមន្ទីរឃុំឃាំងរយៈពេលយូរ[5764]។ (៣) អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានធ្វើការវាយតម្លៃថ្មីអំពីតម្លៃដែលត្រូវផ្តល់ទៅលើសក្ខីកម្មស្តីពីអត្តចរិតរបស់គាត់ និងខកខានក្នុងការពិចារណាលើធាតុផ្សំទាំងអស់នៃបុគ្គលិកលក្ខណៈរបស់គាត់ និងពុំបានអើពើលើសក្ខីកម្មជាឯកច្ឆន្ទដែលស្ញើចសរសើរគាត់[5765]។

2042.ជាសរុប ខៀវ សំផន បានលើកឡើងថា កំហុសទាំងនេះបានមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដាក់ទោសដែលគាត់អះអាងថា គប្បីត្រូវបានកាត់បន្ថយត្រឹមការដាក់ទោសជាប់ពន្ធនាគារក្នុងរយៈពេលកំណត់[5766]។

2043.សហព្រះរាជអាជ្ញាបានឆ្លើយតបថា៖

ក. អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាពីដំបូងលើការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងនូវច្បាប់ពាក់ព័ន្ធទៅនឹងគោលបំណងនៃការដាក់ទោស និងបានចាត់ទុកថា ជាការសមស្រប និងបានយល់ឃើញថា ពុំ

---

[5761] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៥៨-២១៦២។

[5762] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៦៣-២១៦៧។

[5763] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៦៨-២១៧១។

[5764] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧២-២១៧៧។

[5765] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៧៨-២១៨៣។

[5766] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ២១៨៤-២១៨៥។

មានការបង្ហាញថា ការដាក់ទោសនេះមានអត្ថិភាពនៃភាពលម្អៀងប្រឆាំងនឹងជនជាប់ចោទឡើយ[5767]។ ខៀវ សំផន បានលើកឡើងពុំត្រឹមត្រូវថា ការដាក់ទោសធ្ងន់ធ្ងរហួសហេតុ និងធ្វើជាគំរូ។ អង្គជំនុំជម្រះសាលាដំបូងបានយោងច្បាស់លាស់ទៅលើការដាក់ទោសឯកតកម្មដែលឆ្លុះបញ្ចាំងនូវពិរុទ្ធភាពរបស់ជនជាប់ចោទ[5768]។

ខ. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងនៃអំពើហិង្សាផ្លូវភេទទាក់ទងតែទៅនឹងលក្ខខណ្ឌនៅមន្ទីរសន្តិសុខក្រាំងតាចាន់ និងអាស្រ័យហេតុនេះ បានកម្រិតសមស្របការពិចារណានៃការដាក់ទោសត្រឹមបញ្ហាដែលត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ[5769]។ បើទោះបីជាអង្គជំនុំជម្រះមានកំហុសក៏ដោយ ក៏ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញមួយផ្សេងដែលពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋត្រូវបានធ្វើឡើងដោយពុំចាំបាច់ពិចារណាលើភស្តុតាងនេះដែរ ដោយសារ "នៅតែមានភស្តុតាងជាច្រើនដទៃទៀតដែលបង្ហាញភាពធ្ងន់ធ្ងរហួសហេតុនៃបទឧក្រិដ្ឋនោះ"[5770]។ ខៀវ សំផន បានព្យាយាមកាត់បន្ថយជាអប្បបរមានូវតួនាទីរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម និងពុំបានអើពើទៅលើការយល់ឃើញសំខាន់ស្តីពីការចូលរួមរបស់គាត់នោះ[5771]។

គ. ខៀវ សំផន បានបំភ្លៃសិទ្ធិអំណាចដែលគាត់បានប្រើប្រាស់ជាក់ស្តែង[5772]។ បើទោះបីជា "ការរៀបឃ្លារបស់អង្គជំនុំជម្រះសាលាដំបូងពុំបានល្អឥតខ្ចោះ"ក៏ដោយ ក៏អង្គជំនុំជម្រះបានពិចារណាសមស្របទៅលើទិដ្ឋភាពផ្សេងៗនៃអំពើ និងការប្រព្រឹត្តរបស់បុគ្គលក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃអំពើល្មើសទាំងមូល ដោយគ្មានការគិតបញ្ចូលពីរដងនូវកត្តាតែមួយនៅពេលវាយតម្លៃលើកាលៈទេសៈស្ថានទម្ងន់ទោសឡើយ[5773]។ បើទោះបីជាកត្តានេះត្រូវបានគិតបញ្ចូលពីរដងក៏ដោយ ក៏នេះមានផលប៉ះពាល់តិចតួចទៅលើការកំណត់អំពីទោសសម្រាប់បទឧក្រិដ្ឋទាំងមូលដែលត្រូវបានប្រព្រឹត្តឡើងនោះ[5774]។ កម្រិតវប្បធម៌ខ្ពស់អាចត្រូវបានចាត់ទុកជា

[5767] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៨៦ យោងទៅលើសាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១០។

[5768] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៨៧។

[5769] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩០។

[5770] ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ F1/11.1 ទំព័រ ៨៥។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩០។

[5771] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩១។

[5772] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩៥។

[5773] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩៦។

[5774] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩៧។

ស្ថានទម្ងន់ទោស ហើយអង្គជំនុំជម្រះបានផ្តល់យុត្តិកម្មលើការជាប់ពាក់ព័ន្ធនៃកម្រិតវប្បធម៌របស់ ខៀវ សំផន[5775]។

ឃ. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវថា កិច្ចសហការរបស់ ខៀវ សំផន ជាមួយ អ.វ.ត.ក. មិនលើសពីកម្រិតតម្រូវផ្នែកច្បាប់នៃការចូលរួមអប្បបរមាក្នុងសវនាការ ហើយគាត់ត្រឹមតែមិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ[5776]។ ខៀវ សំផន ខកខានក្នុងការពិចារណាថា ការទទួលស្គាល់នីមួយៗរបស់គាត់អំពីការរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអមទៅដោយយុត្តិកម្មសម្រាប់ការឈឺចាប់របស់ពួកគេ[5777]។ ការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តល់ហេតុផលនៅក្នុងការវាយតម្លៃអំពីវ័យចាស់ជរាថា ជាស្ថានសម្រាលទោសនោះ គ្មានមូលដ្ឋានគាំទ្រឡើយ[5778] ហើយអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ត្រឹមត្រូវថា បញ្ហាសុខភាពគឺជាស្ថានសម្រាលទោសតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[5779]។ ការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានកែប្រែការវាយតម្លៃពីមុននូវទម្ងន់ដែលត្រូវផ្តល់ទៅលើសាក្សីអត្តចរិតពុំមែនជាកំហុស ហើយ ខៀវ សំផន បានបំភ្លៃភស្តុតាងអត្តចរិតដែលគាត់ព្យាយាមសំអាងទៅលើនោះ[5780]។

2044. ជាសរុប សហព្រះរាជអាជ្ញាបានលើកឡើងថា ការជំទាស់ទាក់ទងទៅនឹងការដាក់ទោសគប្បីត្រូវបានបដិសេធចោល[5781]។

2045. សហមេធាវីនាំមុខបានលើកឡើងថា ខ្លួនមានសិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាពាក់ព័ន្ធទៅនឹងការដាក់ទោស[5782] និងបានឆ្លើយតបទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធទៅនឹងគោលបំណងនៃការដាក់ទោស និងថា អំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើការអាណិតអាសូររបស់ ខៀវ សំផន ដល់ជនរងគ្រោះថា ជាកត្តាសម្រាលទោស[5783]។ សហមេធាវីនាំមុខបានអះអាងថា ការបញ្ជាក់របស់អង្គជំនុំ

[5775] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៩៨។

[5776] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០០។

[5777] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០០។

[5778] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០១។

[5779] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០២។

[5780] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១៣០៤-១៣០៦។

[5781] សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) កថាខណ្ឌ ១២៨៥, ១២៨៨, ១២៩៣, ១២៩៩, ១៣០៣, ១៣០៧។

[5782] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៤៥-៨៦៥។

[5783] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៦៧-៨៨៥។

ជម្រះសាលាដំបូងស្ដីពីការដាក់ទោសនោះបានអនុវត្តតាមច្បាប់ដែលបានបង្កើតឡើងនៅ អ.វ.ត.ក. និងរឿងក្ដីយុត្តិសាស្ត្រនៃតុលាការខនួរណ៍របស់តុលាការ ICTY[5784] និងថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យពិចារណាលើគោលបំណងនៃការធានាដល់ជនរងគ្រោះ និងសហគមន៍អន្តរជាតិអំពីការអនុវត្តន៍ច្បាប់ត្រឹមត្រូវ និងស្មើភាពគ្នា[5785]។ ពាក់ព័ន្ធទៅនឹងកត្តាសម្រាលទោស សហមេធាវីនាំមុខបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញវិប្បដិសារី ឬការអាណិតអាសូរ និងផ្ទុយទៅវិញព្យាយាមបដិសេធការស្ដីបន្ទោសមកលើខ្លួនគាត់ដោយគ្មានការឆ្លើយតបពិតប្រាកដទៅលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[5786]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះជាការពុំចាំបាច់ក្នុងការពិចារណាលើបញ្ហានៃសិទ្ធិរបស់សហមេធាវីនាំមុខក្នុងការលើកសារណាស្ដីពីបញ្ហាដាក់ទោស ដោយសារអង្គជំនុំជម្រះពុំត្រូវធ្វើការពិចារណាលើអំណះអំណាងទាំងនេះរបស់ ខៀវ សំផន ដូចបានពន្យល់ខាងក្រោម។

2046.អង្គជំនុំជម្រះតុលាការកំពូលនឹងពុំធ្វើការពិចារណាលើកំហុសដែលបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងគោលបំណងនៃការដាក់ទោស។ ដូចបានលើកឡើងពីដំបូងទាក់ទងទៅនឹងការបញ្ជាក់ដូចគ្នារបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងគោលបំណងនៃការដាក់ទោសក្នុងសំណុំរឿង ០០២/០១[5787] និងការចោទប្រកាន់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះមានភាពលម្អៀង[5788] "ពុំមានការបង្ហាញថា ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការបង្ហាញនូវភាពលម្អៀងប្រឆាំងនឹងគាត់ឡើយ"[5789]។ ខៀវ សំផន ពុំបានបង្ហាញនូវភាពលំអៀងណាមួយទៅលើដើមបណ្ដឹងរដ្ឋប្បវេណី និងពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំត្រឹមត្រូវនូវគោលការណ៍ដាក់ទោស ឬដាក់ទោសគាត់ហួសពីកម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

2047.អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាលើការចោទប្រកាន់កំហុសក្នុងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពធ្ងន់ធ្ងរទាក់ទងទៅនឹងទម្រង់ និងកម្រិតនៃការចូលរួម។ គ្មានអ្វីក្រៅតែពីការព្យាយាមពិនិត្យឡើងវិញលើការដាក់ពិរុទ្ធភាពរបស់មេដឹកនាំជាន់ខ្ពស់។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន គឺជា"ថាវីសំខាន់ដែលទទួលខុសត្រូវសម្រាប់ការបង្កើតគោលនយោបាយបក្ស" និងថា

---

[5784] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៧១។

[5785] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៧២-៨៧៥។

[5786] សារណាតបរបស់សហមេធាវីនាំមុខ (F54/2) កថាខណ្ឌ ៨៧៩-៨៨៥។

[5787] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១០៦៧។

[5788] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) កថាខណ្ឌ ៦៤៧-៦៤៨។

[5789] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១១០។

គាត់បានដឹងថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង និងជាប់ពាក់ព័ន្ធទៅនឹងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមចាប់តាំងពីពេលចាប់ផ្តើម និងពេញមួយអំឡុងពេលដែលពាក់ព័ន្ធក្នុងសំណុំរឿង ០០២/០២ និងថា គាត់បានអនុវត្តទិដ្ឋភាពសំខាន់ផ្នែកសេដ្ឋកិច្ចនៃគោលបំណងរួម"“ដោយពុំគិតពីការបាត់បង់អាយុជីវិតមនុស្សប៉ុណ្ណាឡើយតាមរយៈការអនុវត្តន៍នោះ”[5790] បានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានពិចារណាលើទម្រង់ និងកម្រិតនៃការចូលរួមរបស់ ខៀវ សំផន នៅក្នុងការវិភាគអំពីភាពធ្ងន់ធ្ងរ[5791]។

2048.អង្គជំនុំជម្រះតុលាការកំពូលពុំពិចារណាលើកំហុសដែលបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងការពិចារណាលើកម្រិតវប្បធម៌ថា ជាស្ថានទម្ងន់ទោសឡើយ។ តុលាការដែលដាក់ទោសតម្រូវឱ្យពិនិត្យលើចំណេះដឹងសាវតារ បុព្វសិទ្ធិ និងគុណវិបត្តិជាកត្តាពាក់ព័ន្ធ។ បុគ្គលដែលមានកម្រិតវប្បធម៌ដល់ថ្នាក់បណ្ឌិត ត្រូវបានរំពឹងថា មានការយល់ដឹងអំពីផលវិបាកនៃគោលនយោបាយ និងអំពើនោះ។ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ត្រឹមត្រូវនូវភាពជាប់ពាក់ព័ន្ធនៃចំណេះដឹងរបស់ ខៀវ សំផន ថា៖ ដោយសារកម្រិតវប្បធម៌នេះ គាត់“អាចយល់ដឹងច្បាស់លាស់អំពីសារៈសំខាន់និងផលវិបាកនៃអំពើរបស់ខ្លួន”[5792]។

2049.អង្គជំនុំជម្រះតុលាការកំពូលពុំធ្វើការពិចារណាលើការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើកិច្ចសហការជាមួយ អ.វ.ត.ក. ការប្រព្រឹត្តក្នុងមន្ទីរឃុំឃាំង ការសម្តែងការអាណិតអាសូរទៅលើជនរងគ្រោះ វ័យចាស់ជរា ស្ថានភាពសុខភាព ឬចរិតលក្ខណៈផ្នែកសីលធម៌ថា ជាកត្តាស្ថានសម្រាលទោស។ កិច្ចសហការរបស់ ខៀវ សំផន ជាមួយនឹង អ.វ.ត.ក. ពុំមានកម្រិតគ្រប់គ្រាន់[5793] ដែលតម្រូវឱ្យមានការសម្រាលទោសក្នុងការដាក់ទោសឡើយ។ គាត់ពុំបានបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងទង្វើរបស់គាត់ក្នុងមន្ទីរឃុំឃាំង ការសម្តែងក្តីអាណិតអាសូររបស់គាត់មានកម្រិតស្រាលស្តួចស្តើងបំផុត និងគ្មានបង្ហាញវិប្បដិសារី វ័យចាស់ជរារបស់គាត់ពុំតម្រូវឱ្យទទួលបាននូវការ

---

[5790] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨២។

[5791] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៥៩។

[5792] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៩០។

[5793] អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ពីដំបូងលើកិច្ចសហការជាសំខាន់ដែលអាចជាធាតុផ្សំសម្រាប់ការសម្រាលទោស និងថា តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្តល់ការពិចារណាលើទង្វើពីរប្រភេទដែលជួយបំភ្លឺការស៊ើបអង្កេតដែលមានមន្ទិលសង្ស័យ រួមទាំងបទឧក្រិដ្ឋដែលពុំត្រូវបានដឹងពីដំបូងដោយអយ្យការ ការទទួលស្គាល់អង្គហេតុ ការជួយរៀបចំប្រតិបត្តិការដែលនាំទៅរកការចាប់ខ្លួនជនសង្ស័យដទៃទៀត និងការយល់ព្រមផ្តល់សក្ខីកម្មជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀត។ *សូមមើល* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៦៦-៣៦៨។

សម្រាលទោសនោះឡើយ បញ្ហាសុខភាពអាចត្រូវបានចាត់ទុកជាស្ថានសម្រាលទោសតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[5794] ដែល ខៀវ សំផន ខកខានក្នុងការបង្ហាញ ហើយ ខៀវ សំផន ពុំបានស្នើអង្គជំនុំជម្រះសាលាដំបូងតាមរយៈសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ឬសេចក្តីថ្លែងបញ្ចប់កិច្ចពិភាក្សាដេញដោល សុំឱ្យធ្វើការវាយតម្លៃជាថ្មីនូវតម្លៃដែលត្រូវផ្តល់ទៅឱ្យសក្ខីកម្មអត្តចរិតក្នុងសំណុំរឿង ០០២/០១។ នេះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនវាយតម្លៃលើភស្តុតាងអត្តចរិតសាជាថ្មី ជាពិសេសនៅពេលអង្គជំនុំជម្រះបានកំណត់រួចរាល់ហើយថា ភស្តុតាងនេះមានតម្លៃតិចតួច[5795]។ អំណះអំណាងទាំងនេះពុំមានមូលដ្ឋានត្រឹមត្រូវឡើយ។

2050.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើអំណះអំណាងផ្សេងទៀតរបស់ ខៀវ សំផន ដូចខាងក្រោម។

១. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការពិចារណាលើការរំលោភសេពសន្ថវៈក្នុងមន្ទីរសន្តិសុខ

2051.ក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើ“ចំនួន និងភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះ [និង] ទំហំ និងភាពសាហាវឃោរឃៅនៃឧក្រិដ្ឋកម្ម”[5796]។ អង្គជំនុំជម្រះបានបញ្ជាក់ថា “លក្ខខណ្ឌនៅមន្ទីរសន្តិសុខ គួរឱ្យរន្ធត់ អ្នកជាប់ឃុំត្រូវបានដាក់ខ្នោះជើងជាប់រហូត កម្របានទៅងូតទឹក និងបង្ខំឱ្យបន្ទោបង់ដាក់ធុងតូចរួមគ្នា។ ពួកគេទទួលបានបបរាវតិចតួចចំផុត ហើយត្រូវបង្ខំឱ្យនៅស្ងៀមស្ងាត់ និងត្រូវបានគេវាយដំជាប្រចាំ។ *អ្នកជាប់ឃុំមួយចំនួនត្រូវបានគេរំលោភផ្លូវភេទ*”[5797]។ ក្នុងការគាំទ្រការយល់ឃើញថា “អ្នកជាប់ឃុំមួយចំនួនត្រូវបានគេរំលោភផ្លូវភេទ” អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកថាខណ្ឌមួយនៃសាលក្រមដែលអង្គជំនុំជម្រះបានបង្កើតការយល់ឃើញស្តីពី

---

[5794] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ១០៩៥។ សាលដីការឿងក្តី*Galić* (ICTY) កថាខណ្ឌ ៤៣៦។ សាលដីការឿងក្តី*Blaškić* (ICTY) កថាខណ្ឌ ៦៩៦។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Simić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿង IT-95-9/2-S សាលក្រមនៃការដាក់ទោស ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២ កថាខណ្ឌ ៩៨។

[5795] *សូមមើលខាងលើ* កថាខណ្ឌ ៣៣៥-៣៤៧។

[5796] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) ផ្នែក ២០.២.៥.១។

[5797] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៦៥ (សេចក្តីបញ្ជាក់បន្ថែម)។

អំពើហិង្សាផ្លូវភេទតែមួយ ដែលអង្គជំនុំជម្រះបានចាត់ទុកថា ជាការឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌនៅមន្ទីរសន្តិសុខក្រាំងតាចាន់[5798]។

2052.ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនោះ គឺជាកត្តាបឋមដែលត្រូវថ្លឹងថ្លែងនៅពេលកំណត់ទោស និងតម្រូវឱ្យមានការពិចារណាលើកាលៈទេសៈជាក់លាក់នៃរឿងក្តីប្តូករួមជាមួយនឹងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទ[5799]។

2053.ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈក្រៅវិសាលភាពនៃបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា "ភស្តុតាងនៃការរំលោភផ្លូវភេទក្នុងមន្ទីរសន្តិសុខ(ក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ពុំត្រូវបានពិចារណាធ្វើការគាំទ្រធាតុផ្សំនៃបទចោទណាមួយក្នុងរឿងក្តីនេះ"[5800]។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ត្រូវបានចោទប្រកាន់ និងត្រូវបានរកឃើញថា មានពិរុទ្ធពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៅក្រាំងតាចាន់[5801]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើហិង្សាផ្លូវភេទដែលបានកើតឡើងនៅក្រាំងតាចាន់ អាចមានការជាប់ពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ដទៃទៀតនៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងត្រូវបានពិចារណាសមស្របដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

2054.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនីមួយៗក៏ដោយ ក៏ជារួមពុំមានភាពច្បាស់លាស់ថាតើ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអំពើហិង្សាផ្លូវភេទពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការវាយប្រហារលើសេ

[5798] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៦៥ យោងទៅលើ*ក្នុងចំណោមនោះ*កថាខណ្ឌ ២៧៣៨ ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖ "អង្គជំនុំជម្រះយល់ថា គិម ណូរ៉ា, ណុប ណែម និងកូនតូចៗរបស់ពួកគាត់ ត្រូវបានគេសម្លាប់នៅក្រាំងតាចាន់ ហើយ គិម ណូរ៉ា ត្រូវបាន តាអាន់ ចៀតបៀនផ្លូវភេទ មុនពេលដែលគាត់ត្រូវគេសម្លាប់ ហើយចំណុចនេះឆ្លុះបញ្ចាំងអំពីផ្នែកផ្សេងៗនៃលក្ខខណ្ឌនៅក្រាំងតាចាន់"។

[5799] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៣៧៥។

[5800] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ១៨៨។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៦៤១: "ទោះបីជាដីកាដំណោះស្រាយពុំបានរកឃើញថា ជនជាប់ចោទទទួលខុសត្រូវចំពោះការរំលោភផ្លូវភេទ ដែលបានប្រព្រឹត្តឡើងនៅក្រាំងតាចាន់ក៏ដោយ ក៏ការរំលោភផ្លូវភេទ (ឬ តាមពិត អំពើហិង្សាផ្សេងៗទៀតលើផ្លូវភេទ) អាចពាក់ព័ន្ធនឹងការសម្លាប់រង្គាលនៅក្នុងបរិបទទូទៅនៃលក្ខខណ្ឌនៅក្រាំងតាចាន់"។

[5801] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៤៨-២៨៥១។

ចក្តីថ្លៃថ្នូររបស់មនុស្ស ដែរ ឬយ៉ាងណា។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើការយល់ឃើញនៃអំពើហិង្សាផ្លូវភេទនេះនៅពេលបង្កើតការយល់ឃើញផ្នែកអង្គច្បាប់របស់ខ្លួនពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀតនៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[5802]។ អង្គជំនុំជម្រះតុលាការកំពូលពុំអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសមស្របលើអំពើហិង្សានេះថាត្រឹមតែជាប់ពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយសារលក្ខខណ្ឌនៅក្រាំងតាចាន់នៅពេលធ្វើការវិភាគលើភាពធ្ងន់ធ្ងរនោះឡើយ។

2055.នៅក្នុងការពិចារណាយ៉ាងទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ[5803] អំពើហិង្សាផ្លូវភេទត្រូវបានយោងទៅលើតែម្តងគត់ប៉ុណ្ណោះ[5804]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា មានភស្តុតាងគ្រប់គ្រាន់ដទៃទៀតដែលត្រូវបានផ្អែកទៅលើដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីគាំទ្រការសន្និដ្ឋានដែលថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋតម្រូវឱ្យមានអត្ថិភាពជាប់ពន្ធនាគារអស់មួយជីវិត។ ពុំមានកំហុសក្នុងករណីនេះដែលបានកាត់បន្ថយអានុភាពនៃការដាក់ទោសឡើយ។

២. ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងការគិតពីរដងនៃការរំលោភតួនាទីនៃសិទ្ធិអំណាច និងឥទ្ធិពល

2056.ក្នុងការពិចារណាស្ថានទម្ងន់ទោស អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> ការរួមចំណែករបស់ ខៀវ សំផន ក្នុងបទឧក្រិដ្ឋ រួមទាំងតាមរយៈការចូលរួមរបស់គាត់ក្នុង សហឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើឡើងក្នុងសមត្ថកិច្ចផ្លូវការរបស់គាត់ រួមទាំងជាសមាជិក នៃគណៈមជ្ឈិម និងសមាជិកមន្ទីរ ៨៧០ ប្រធានគណៈប្រធានរដ្ឋ និងជាកម្មាភិបាលជាន់ខ្ពស់បំផុតនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ នេះគឺជាការរំលោភលើតួនាទីនៃសិទ្ធិអំណាច និងឥទ្ធិពល និងដូច្នេះជាស្ថានទម្ងន់ទោស[5805]។

2057.បើទោះបីជាតួនាទីផ្លូវការជាទូទៅពុំមែនជាកត្តាស្ថានទម្ងន់ទោសក៏ដោយ ក៏ការរំលោភតួនាទីនោះអាចត្រូវបានចាត់ទុកថា ជាស្ថានទម្ងន់ទោសដែរ[5806]។

---

[5802] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ២៨៤៨-២៨៥១។

[5803] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៦២-៤៣៧៦។

[5804] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៦៥។

[5805] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨៩។

[5806] សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១១១៣៖

2058.ពុំមានការបង្ហាញថា អង្គជំនុំជម្រះបានអនុវត្តផ្ទុយគ្នាជាមួយនឹងការយល់ឃើញពីដំបូងរបស់ខ្លួនដែលថា ខៀវ សំផន ពុំមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការបញ្ជាដោយផ្ទាល់នូវការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ ការផ្តោតរបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែទៅលើសិទ្ធិអំណាចជាក់ស្តែងរបស់ ខៀវ សំផន ប៉ុណ្ណោះទេ ថែមទាំងទៅលើការរំលោភលើតួនាទីផ្លូវការរបស់គាត់ ក្នុងការគាំទ្រ និងផ្តល់ធម្មានុរូបលើគោលនយោបាយល្មើស។ ពិតណាស់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាក្នុងផ្នែកនៃសាលក្រមដែលពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋថា ខៀវ សំផន "បានប្រើប្រាស់តួនាទីនៃឥតទិ្ធពលរបស់គាត់ក្នុងការគាំទ្រ និងផ្តល់ធម្មានុរូបដល់ការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា"[5807]។

2059.ទោះជាយ៉ាងណាក្តី កត្តាដែលបានចាត់ទុកថា ជាទិដ្ឋភាពនៃភាពធ្ងន់ធ្ងរបទឧក្រិដ្ឋពុំអាចត្រូវបានពិចារណាបន្ថែមថា ជាស្ថានទម្ងន់ទោសដាច់ដោយឡែកឡើយ[5808]។ ប្រសិនបើមានអត្ថិភាព "ការគិតបញ្ចូលពីរដង" គឺស្មើនឹងកំហុសងអង្គច្បាប់[5809]។

---

យោងតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ឋានៈខ្ពស់នៅក្នុងផ្នែកយោធា ឬនយោបាយ ឬតួនាទីក្នុងរដ្ឋអំណាច ឬក្នុងជួរថ្នាក់ដឹកនាំ *ជាធម្មតា* ពុំអាចចាត់ជាស្ថានទម្ងន់ទោសបានឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងមាន "ឆន្ទានុសិទ្ធិក្នុងការលើកយកឋានៈខ្ពស់ តួនាទីក្នុងរដ្ឋអំណាច ឬតួនាទីជាថ្នាក់ដឹកនាំរបស់ជននោះ មកធ្វើជាស្ថានទម្ងន់ទោសបាន"។

*សូមមើលផងដែរ* សាលដីការឿងក្តី *Lubanga* ប្រឆាំងនឹងសេចក្តីសម្រេចលើការដាក់ទោស (ICC) កថាខណ្ឌ ៨២។ សាលដីការឿងក្តី *Hadžihasanović និង Kubura* (ICTY) កថាខណ្ឌ ៣២០។ សាលដីការឿងក្តី *Milošević* កថាខណ្ឌ ៣០២។

[5807] សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨៣។

[5808] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/04-02/06 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Bosco Ntaganda ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង VI ខែ វិច្ឆិកា ឆ្នាំ ២០១៩ ចំណងជើងថា 'សាលក្រមដាក់ទោស' ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១ កថាខណ្ឌ ១២៣។ សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៦។ សាលដីការឿងក្តី *AFRC* (SCSL) សំណុំរឿងលេខ SCSL-2004-16-A សាលដីកា ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៣១៧។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Momir Nikolić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-60/1-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការដាក់ទោស ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ ("សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY)") កថាខណ្ឌ ៥៨។ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Deronjić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-61-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការដាក់ទោស ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ១០៦។ សាលក្រមប្រកាសទោសរឿងក្តី *Ayyash* (STL) កថាខណ្ឌ ១៨១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គជំនុំជម្រះសាលាដំបូង I (ICC) សំណុំរឿងលេខ ICC-01/04-01/06 សេចក្តីសម្រេចស្តីពីការដាក់ទោសស្របតាមមាត្រា ៧៦ នៃលក្ខន្តិកៈ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៣៥។

[5809] សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៦។

2060.ក្នុងរឿងក្តី *Nikolić* អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានគិតបញ្ចូលដោយពុំត្រឹមត្រូវនូវតួនាទីរបស់ជនជាប់ចោទ Nikolić នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ជាធាតុផ្សំនៃភាពធ្ងន់ធ្ងរ និងជាស្ថានទម្ងន់ទោស ដែរ ឬយ៉ាងណា[5810]។ អង្គជំនុំជម្រះឧទ្ធរណ៍បានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានពិចារណាលើតួនាទីយ៉ាងសកម្មរបស់ Nikolić នៅក្នុងឧក្រិដ្ឋកម្ម ក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទល្មើស និងតួនាទីនៃសិទ្ធិអំណាចរបស់គាត់ និងតួនាទីដែលគាត់មាននៅក្នុងឧក្រិដ្ឋកម្មជាស្ថានទម្ងន់ទោសដាច់ដោយឡែក[5811]។ អង្គជំនុំជម្រះឧទ្ធរណ៍បានពិចារណាថា ការពិចារណាលើតួនាទីរបស់គាត់ នៅពេលវាយតម្លៃលើស្ថានទម្ងន់ទោស ស្មើនឹងការគិតបញ្ចូលពីរដងដែលត្រូវបានអនុញ្ញាត និងបានពន្យល់ថា "ការគិតបញ្ចូលពីរដងនៃតួនាទីរបស់ជនជាប់ចោទក្នុងឧក្រិដ្ឋកម្ម ពុំត្រូវបានអនុញ្ញាត ដោយសារការធ្វើដូច្នោះបានអញ្ញាតឱ្យមានកត្តាដូចគ្នាជះឥទ្ធិពលអវិជ្ជមានទ្វេដងលើការដាក់ទោសជនជាប់ចោទ"[5812]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះឧទ្ធរណ៍នេះបានកំណត់ផងដែរថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ"តួនាទីនៃសិទ្ធិអំណាច"របស់ Nikolić ពុំស្មើទៅនឹងការគិតបញ្ចូលពីរដងដោយសារការរំលោភតួនាទីនៃសិទ្ធិអំណាចមានលក្ខណៈផ្សេងគ្នាពីតួនាទីក្នុងឧក្រិដ្ឋកម្ម[5813]។

2061.ក្នុងរឿងក្តី *D. MiloÈević* អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានសង្កេតថា ពាក្យពេចន៍ក្នុងសាលក្រមអាចបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានពិចារណាលើកត្តាមួយចំនួនទ្វេដង នៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងជាស្ថានទម្ងន់ទោស[5814]។ អង្គជំនុំជម្រះឧទ្ធរណ៍បានដោះស្រាយបញ្ហានេះតាមគំនិតផ្តួចផ្តើមរបស់ខ្លួន និងស្នើឱ្យភាគីដាក់សារណាលើបញ្ហានេះ[5815]។ អយ្យការបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើទិដ្ឋភាពផ្សេងៗនៃភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ទោសជាជាងការគិតបញ្ចូលកត្តាដូចគ្នាទ្វេដង[5816]។ អង្គជំនុំជម្រះឧទ្ធរណ៍បានបញ្ជាក់ថា អង្គជំនុំជម្រះពុំជឿជាក់លើអំណះអំណាងរបស់អយ្យការដែលថា ការសំអាងទៅលើទិដ្ឋភាពផ្សេងគ្នានៃកត្តាដូចគ្នាត្រូវបានអនុញ្ញាត និងបានពន្យល់ថា "នៅក្នុងការថ្លឹងថ្លែងលើកត្តាមួយ [...] អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យពិចារណា និង

---

[5810] សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) កថាខណ្ឌ ៥៩-៦៣។

[5811] សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) កថាខណ្ឌ ៦១។

[5812] សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) កថាខណ្ឌ ៦១។

[5813] សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) កថាខណ្ឌ ៦១។

[5814] សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៦។

[5815] សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៦។

[5816] សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៦។

គិតគូរវាល់ទិដ្ឋភាព និងការជាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសដើម្បីធានាបានថា កុំឱ្យមានការគិតបញ្ចូលទ្វេដងកើតឡើង”[5817]។

2062.ក្នុងរឿងក្តីនេះ ក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា “ក្នុងនាមជាសមាជិកគណៈមជ្ឈិម និងបានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទៀងទាត់ ខៀវ សំផន ត្រូវបានជូនដំណឹងអំពីបញ្ហា និងសេចក្តីសម្រេចសំខាន់ៗ និងបានទទួលឋានៈជាន់ខ្ពស់ក្នុងបក្ស”[5818] និងថា គាត់“បានប្រើប្រាស់តួនាទីរបស់គាត់ដែលមានឥទ្ធិពលគាំទ្រ និងផ្តល់ធម្មានុរូបទៅលើការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា”[5819]។

2063.ក្នុងការវាយតម្លៃលើស្ថានទម្ងន់ទោស អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការរួមចំណែករបស់ ខៀវ សំផន ក្នុងឧក្រិដ្ឋកម្ម រួមទាំងតាមរយៈការចូលរួមរបស់គាត់ ក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើឡើងក្នុងសមត្ថកិច្ចផ្លូវការរបស់គាត់ដែលជាការរំលោភបំពានលើតួនាទីនៃសិទ្ធិអំណាច និងឥទ្ធិពល ដូច្នេះ ជាកត្តាស្ថានទម្ងន់ទោស[5820]។

2064.អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុវត្តន៍ច្បាប់ដោយបានប្រើប្រាស់រំលោភបំពានលើតួនាទីនៃសិទ្ធិអំណាចរបស់ ខៀវ សំផន នៅក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរ ព្រមទាំងការវាយតម្លៃលើស្ថានទម្ងន់ទោស។ នេះបានបណ្តាលឱ្យមានការគិតបញ្ចូលទ្វេដងដែលពុំត្រូវបានអនុញ្ញាត។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះឧទ្ធរណ៍ក្នុង *D. Milošević* ថា ក្នុងការថ្លឹងថ្លែងកត្តាមួយ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យពិចារណាវាល់ទិដ្ឋភាព និងការជាប់ពាក់ព័ន្ធទៅនឹងការដាក់ទោសដើម្បីធានាថា កុំឱ្យមានការគិតបញ្ចូលទ្វេដងកើតឡើង។ អង្គជំនុំជម្រះសាលាដំបូងពុំអាចពិចារណាលើទិដ្ឋភាពផ្សេងគ្នានៃកត្តាតែមួយក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ទោស ដោយគិតបញ្ចូលកត្តានោះទ្វេដងដែលពុំត្រូវបានអនុញ្ញាតឡើយ។

2065.អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយលើផលប៉ះពាល់ប្រសិនបើមាននៃការសន្និដ្ឋាននេះ ទៅលើការដាក់ទោសដូចខាងក្រោម។

---

5817 សាលដីការឿងក្តី *Milošević* (ICTY) កថាខណ្ឌ ៣០៩។

5818 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨២។

5819 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨៣។

5820 សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៤៣៨៩។

## ង. ផលប៉ះពាល់នៃការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលការដាក់ទោស

2066.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានតម្កល់ការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពី (ក) បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ខ) បទប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកជនជាតិវៀតណាមដែលជាក្រុមជាតិពន្ធុ ជាតិសាសន៍ និងពូជសាសន៍ និង(គ) ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៃអំពើមនុស្សឃាតគិតទុកជាមុន ការធ្វើទារុណកម្ម ការធ្វើបាប ការបង្កដោយចេតនាឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាពផ្លូវចិត្ត ការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិលក្នុងការទទួលបានការជំនុំជម្រះទៀងទាត់ត្រឹមត្រូវ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិលក្រោមអនុសញ្ញាទីក្រុងហ្សឺណែវនៅមន្ទីរស-២១ និងបានកែប្រែទម្រង់នៃការទទួលខុសត្រូវសម្រាប់អំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងដោយ*ចេតនាប្រយោល* ពីការទទួលខុសត្រូវក្នុងទម្រង់នៃការជួយទំនុកបម្រុងទៅជាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម[5821]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើប្រជាជនថ្មីនៅការដ្ឋានធ្វើការទំនប់១មករា និងបានពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា ត្រូវបានរំលោភបំពានតាមរយៈការប្រព្រឹត្តលើប្រជាជនថ្មីនៅការដ្ឋានធ្វើការនោះ[5822]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធផងដែរលើការយល់ឃើញនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល ដែលបានផ្អែកលើអំពើមនុស្សឃាតពីរករណីដាច់ដោយឡែកពីគ្នា និងយល់ឃើញថា អំពើមនុស្សឃាតពុំអាចត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយផ្អែកលើអត្ថិភាពនៃភស្តុតាង[5823]។ ការដាក់ពិរុទ្ធភាពជារួមលើ ខៀវ សំផន សម្រាប់ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាត់ទុកជាបានការ ដោយសារបានផ្អែកទៅលើអំពើជាច្រើននៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើមនុស្សឃាតជាច្រើនករណីនៅទីតាំងដទៃទៀត

---

[5821] *សូមមើលខាងលើ* ផ្នែក VII.ខ.៩.ខ។

[5822] *សូមមើលខាងលើ* ផ្នែក VII.២.ខ.៤។

[5823] *សូមមើលខាងលើ* ផ្នែក VII.ក.៥.ង។

[5824]។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធនឹងជនរងគ្រោះជាបុរស[5825]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកផងដែរថា អង្គជំនុំជម្រះបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការគិតបញ្ចូលទ្វេដងនូវតួនាទីនៃសិទ្ធិអំណាចរបស់ ខៀវ សំផន និងឥទ្ធិពល នៅពេលវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងនៅពេលពិចារណាលើស្ថានទម្ងន់ទោស[5826]។

2067.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដូចបានពន្យល់ខាងលើ[5827] ខៀវ សំផន អនុវត្តទោសតែមួយជាប់ពន្ធនាគារអស់មួយជីវិតដែលជាទោសអតិបរមាត្រូវបានអនុញ្ញាតនៅ អ.វ.ត.ក. ដែលត្រូវបានប្រកាសដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការដាក់ពិរុទ្ធភាពលើគាត់ក្នុងសំណុំរឿង ០០២/០១ និងត្រូវបានតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅដំណាក់កាលបណ្តឹងសាទុក្ខ។ សំណុំរឿង ០០២/០១ និង ០០២/០២ ត្រូវបានចោទប្រកាន់ដាច់ដោយឡែកពីគ្នា ប៉ុន្តែបានកើតចេញពីដីកាដំណោះស្រាយតែមួយដែលត្រូវបានបំបែក ដើម្បីអត្ថប្រយោជន៍នៃការចាត់ចែងសវនាការ និងដោយផ្អែកលើបញ្ហាសុខភាពទ្រុឌទ្រោម និងវ័យចាស់ជរារបស់ជនជាប់ចោទ។ បើទោះបីជារឿងក្តីទាំងពីរនេះមានទំនាក់ទំនងគ្នាក៏ដោយ ក៏មានការដោះស្រាយលើអង្គផ្សេងគ្នានៅក្នុងការជំនុំជម្រះពីរដាច់ដែលបានបង្កើតផ្នែកសម្រេចសេចក្តីដាច់ដោយឡែកពីគ្នា និងនីមួយៗតម្រូវឱ្យមានការដាក់ទោសដាច់ពីគ្នាបន្ទាប់ពីការរកឃើញនូវពិរុទ្ធភាពនោះ។ យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០២ ហើយអង្គជំនុំជម្រះតុលាការកំពូលតម្កល់ការប្រកាសទោសនេះ។

2068.អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត ដែលត្រូវបានធ្វើឡើងក្នុងសំណុំរឿង ០០២/០២ ថា ជាការសមស្របដោយផ្អែកលើកាលៈទេសៈទាំងអស់រួមទាំងលក្ខណៈគួរឱ្យរន្ធត់នៃបទឧក្រិដ្ឋជាមូលដ្ឋាន និងវិសាលភាពនៃព្យសនកម្មដែលបានបង្កឡើងដោយ ខៀវ សំផន។ ក្នុងកាលៈទេ

---

[5824] *សូមមើលខាងលើ* ផ្នែក VII.ក, ផ្នែក VII.ច.២។

[5825] *សូមមើលខាងលើ* ផ្នែក VII.ឆ.៣.គ.iii។

[5826] *សូមមើលខាងលើ* ផ្នែក IX.ឃ.២។

[5827] *សូមមើលខាងលើ* ផ្នែក IX.ខ។

ស:នេះ ទោះជាយ៉ាងណាក្តី បន្ថែមទៅលើការតម្កល់ការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានស្រូបទោសបញ្ចូលគ្នាតែមួយដែលបានដាក់រួចហើយក្នុងសំណុំរឿង ០០២/០១ ដោយអនុលោមតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

2069.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ទោសជាប់ពន្ធនាគារអស់មួយជីវិតគឺជាការសមស្របសម្រាប់បទឧក្រិដ្ឋនោះក្នុងសំណុំរឿង ០០២/០២ ពុំអាចកែប្រែបានតាមរយៈការកំណត់ប្រភេទគតិយុត្តសាឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលពីការទទួលខុសត្រូវក្រោមទម្រង់នៃការជួយទំនុកបម្រុងទៅជាការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួម ការបដិសេធនូវបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើប្រជាជនថ្មីនៅទំនប់១មករា ឬបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតនៅភ្នំក្រោល ការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស ឬការយល់ឃើញដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារគិតបញ្ចូលទ្វេដងនូវតួនាទីនៃសិទ្ធិអំណាចរបស់ ខៀវ សំផន និងឥទ្ធិពលថា ជាស្ថានទម្ងន់ទោសទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងចុងក្រោយថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើស្ថានសម្រាលទោស។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាយ៉ាងល្អិតល្អន់លើអំណះអំណាងនីមួយៗនោះ និងចាត់ទុកអំណះអំណាងទាំងនោះថា គ្មានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ករណីលើកលែងតែមួយគត់គឺការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើង ដោយសារដាក់បញ្ចូលបទឧក្រិដ្ឋដែល ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ និងការគិតបញ្ចូលទ្វេដងដែលពុំត្រូវបានអនុញ្ញាតដោយច្បាប់ នូវតួនាទីរបស់គាត់នៃសិទ្ធិអំណាច និងឥទ្ធិពល។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការធ្វើបែបនេះគឺជាកំហុសក៏ដោយ ក៏អង្គជំនុំជម្រះសន្និដ្ឋានថា ក្នុងកាលៈទេសៈនៃរឿងក្តីនេះ ការពិចារណាបែបនេះរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើឱ្យការប្រកាសទោសទៅជាការពុំសមស្រប ឬមិនយុត្តិធម៌នោះឡើយ។

2070.ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមត្រូវបានចាត់ទុកថា ជាទម្រង់នៃការទទួលខុស ត្រូវខ្ពស់ជាងការជួយទំនុកបម្រុង និងទំនងជាទាក់ទាញការដាក់ទោសមួយខ្ពស់ជាង[5828]។ ដូចបានកត់សម្គាល់ខាងលើ ដោយសារ ខៀវ សំផន បានអនុវត្តទោសកម្រិតខ្ពស់បំផុតដែលអនុញ្ញាតដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. រួចហើយ ការកែប្រែប្រភេទគតិយុត្តនេះពុំបានអានុភាពលើទោសរបស់គាត់ឡើយ និងការដាក់ពិរុទ្ធភាពទាក់ទងទៅនឹងជនរងគ្រោះជាបុរសនៃការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការបដិសេធនូវការយល់ឃើញស្តីពីការធ្វើទុក្ខបុកម្នេញ ផ្នែកនយោបាយនៅការដ្ឋានធ្វើការទំនប់១មករា បានប៉ះពាល់លើក្រុមតែមួយដែលជា"សត្រូវពិត ឬតាមការសន្មត"ដែលត្រូវបានធ្វើទុក្ខបុកម្នេញនៅការដ្ឋានទំនប់១មករា និងពុំបានប៉ះពាល់លើការយល់ឃើញជាច្រើនដទៃទៀតនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅកន្លែងផ្សេងទៀតទូទាំងប្រទេសកម្ពុជា។ ការបដិសេធនូវការយល់ឃើញនៃអំពើមនុស្សឃាតនៅមន្ទីរសន្តិសុខភ្នំក្រោល ជាប់ពាក់ ព័ន្ធតែទៅលើអំពើមនុស្សឃាតពីរករណី និងដោយសារនេះគឺជាបំណែកមួយតូចតាចនៃការ សម្លាប់ជារួមនោះ ពុំមានអានុភាពគ្រប់គ្រាន់ទៅលើទោសនោះឡើយ។ ជាលទ្ធផល តួនាទីរបស់ ខៀវ សំផន ដែលមានសិទ្ធិអំណាច និងឥទ្ធិពល គ្រាន់តែជាកត្តាមួយក្នុងចំណោមជាច្រើន ដែលអង្គជំនុំជម្រះបានពិចារណានៅក្នុងការវិភាគលើភាពធ្ងន់ធ្ងរនោះ និងជាការបង្ហាញជាក់ច្បាស់ថា ទោសជាប់ពន្ធនាគារអស់មួយជីវិតគឺជាការសមស្របដោយពិចារណាលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដោយពុំចាំបាច់មានការពិចារណាលើស្ថានទម្ងន់ទោសនោះឡើយ។

---

[5828] *សូមមើល ឧ.* សាលដីការឿងក្តី*Mrkšič និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ៤០៧។ សាលដីការឿងក្តី *Simič និងជនជាប់ចោទដទៃទៀត* (ICTY) កថាខណ្ឌ ២៦៥។ ការស្រាវជ្រាវជាក់ស្តែងលើការដាក់ទោសនៅតុលាការ ICTY និង ICTR បញ្ជាក់ថា ការជួយទំនុកបម្រុងទាក់ទាញការដាក់ទោសកម្រិតទាបជាង។ អ្នកនិពន្ធ Elies van Sliedregt៖ "ករណីគួរចាប់អារម្មណ៍នៃការទទួលយកខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ" (ឆ្នាំ ២០១២) ទស្សនាវដ្តីលេខ ១០ *ឧក្រិដ្ឋកម្មអន្តរជាតិ និងយុត្តិធម៌* លេខ 1171 ទំព័រ ១១៧៧។

## X. ផ្នែកសម្រេចសេចក្តី៖

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**ដោយអនុលោមមាត្រា** ៤(១)(ខ) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ១៤ ថ្មី (១)(ខ) និង ៣៦ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធាន ១១១ នៃវិធានផ្ទៃក្នុង ។

**កត់សម្គាល់លើ**សារណាជាលាយលក្ខណ៍អក្សរនីមួយៗរបស់ភាគីលើបណ្តឹងសាទុក្ខ និងអំណះអំណាងដែលបានបង្ហាញនៅពេលសវនាការថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ២០២១ ។

**ទទួលយក** ផ្នែកខ្លះ និង**បដិសេធ** ផ្នែកខ្លះនៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន **ដែលក្នុងនោះ៖**

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការស្លាប់ដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់៖</u>**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទជួយទំនុកបម្រុង នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល និង **កែប្រែ**ប្រភេទគតិយុត្តនៃបទល្មើស ដោយសម្រេច **ដាក់ពិរុទ្ធភាព** លើ **ខៀវ សំផន** ពីបទមនុស្សឃាតដោយចេតនាប្រយោល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួមវិញ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការស្លាប់ដែលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល៖</u>**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទមនុស្សឃាត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើទុក្ខបុកម្នេញនៅការដ្ឋានធ្វើការទំនប់ ១មករា៖</u>**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រជាជនថ្មី ។

- <u>**ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ជនជាតិចាមដែលបានកើតឡើងនៅភូមិត្រា និងវត្តអូរត្រកួន និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការសម្លាប់រង្គាល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើការដោយបង្ខំរបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខភ្នំក្រោល ÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការដាក់ឱ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការនិរទេសប្រជាជនវៀតណាមចេញពីស្រុកត្រាំកក់ និងពីខេត្តព្រៃវែង÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការនិរទេសជនជាតិវៀតណាម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើបាបផ្លូវចិត្ត និងផ្លូវកាយលើជនជាតិចាមនៅភូមិត្រា÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទារុណកម្ម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការប្រព្រឹត្តទៅលើជនជាតិចាម និងការចាត់ទុកជា“សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា” រួមទាំងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង “ប្រជាជនថ្មី”នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា (មិនជាប់ពាក់នៅនឹង“ប្រជាជនថ្មី”) ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការរើសអើងលើជនជាតិចាម÷**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការរើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃនៃពុទ្ធសាសនា៖**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការរើសអើងជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង និងខេត្តព្រៃវែង និងស្វាយរៀង៖**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល៖**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** ដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការផ្លាស់ទីដោយបង្ខំជនជាតិចាមក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ៖**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** ដែលត្រូវបានចាត់ទុកថា ជាការផ្លាស់ទីដោយបង្ខំ ។

- <u>**ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៃគោលនយោបាយបទបញ្ជារៀបអាពាហ៍ពិពាហ៍ទូទាំងប្រទេស៖**</u>

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងបន្ថែមលើសពីនេះ ពី **បទ** អំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹង **ជនរងគ្រោះជាស្ត្រី** ។

  **ទទួលយក** ផ្នែកខ្លះ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងសម្រេច **ដាក់ពិរុទ្ធភាព** លើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមលើនេះ ពីបទនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋ

កម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹង **ជនរងគ្រោះជាបុរស** ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព ការដកហូតឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិល៖</u>**

**តម្កល់**ការដាក់ពិរុទ្ធភាព ខៀវ សំផន ពីបទវំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ជនជាតិវៀតណាម៖</u>**

**តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទប្រល័យពូជសាសន៍ ។

- **ប្រកាសតម្កល់** ការប្រកាសទោស **ដាក់ពន្ធនាគារអស់មួយជីវិត លើ ខៀវ សំផន** របស់អង្គជំនុំជម្រះសាលាដំបូង ។
- **ប្រកាសថា** ទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងសំណុំរឿង ០០២/០២ នេះ ត្រូវអនុវត្តគ្រួតគ្នា ជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១។

**បង្គាប់ថា ខៀវ សំផន** ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញលេញ និងការបញ្ចប់នូវការរៀបចំសម្រាប់ការផ្ទេរដោយអនុលោមតាមច្បាប់ទៅពន្ធនាគារដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់ ។

ធ្វើជាភាសាខ្មែរ និងភាសាអង់គ្លេស។

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

**Peace MALLENI** | **ស៊ា ម៉ៅ** | **ផន ធឿន**

ចៅក្រម **គង់ ស្រីម** ប្រធាន

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **Florence Ndepele MWACHANDE-MUMBA**

ចៅក្រម **ម៉ុង មុនីចរិយា**

ចៅក្រម Judge Phillip RAPOZA

ចៅក្រម **យ៉ា ណារិន**

# XI. ឧបសម្ព័ន្ធ I÷ សន្ទានុក្រម និងពាក្យសរសេរកាត់

| | |
|---|---|
| CPK | បក្សកុម្មុយនីស្តកម្ពុជា |
| DK | កម្ពុជាប្រជាធិបតេយ្យ |
| ECCC | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ECtHR | តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស |
| GRUNK | រាជរដ្ឋាភិបាលរួបរួមជាតិ |
| ICC | តុលាព្រហ្មទណ្ឌអន្តរជាតិ |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| ICTR | តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា |
| ICTY | តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី |
| IMT | តុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ |
| IRMCT | យន្តការកេរដំណែលអន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ |
| KSC | អង្គជំនុំជម្រះឯទេសនៅកូសូវ៉ូ |
| SCSL | តុលាការពិសេសសម្រេចប្រទេសសៀរ៉ាឡេអូន |
| UDHR | ការប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |

# XII. ឧបសម្ព័ន្ធ II÷ តារាងសំអាងផ្លូវច្បាប់

| | |
|---|---|
| កិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. | កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធទៅនឹងការកាត់ទោសក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ឯកសារលេខ 2329 U.N.T.S. 117 |
| ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. | ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយមានការធ្វើវិសោធនកម្មដែលប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦)។ |
| វិធានផ្ទៃក្នុង | វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធ.ទី៩) អនុម័តនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ |
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សំណុំរឿង ០០២ (D3) | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសំណុំរឿង ០០២ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារលេខ D3 |
| បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F50) | បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50 |
| សារណាតបរបស់ ខៀវ សំផន (F50/1) | សារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រហរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1 |
| | សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1 |

| | |
|---|---|
| សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54) | សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០២ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54 |
| ឧបសម្ព័ន្ធ ក នៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F54.1.1) | ឧបសម្ព័ន្ធ ក៖ សេចក្ដីសង្ខេបទឡ្ហីករណ៍សម្រាប់បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ ឯកសារលេខ F54.1.1 |
| សារណាតបរបស់សហព្រះរាជអាជ្ញា (F54/1) | សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ឯកសារលេខ F54/1 |
| សារណាតបរបស់សហមេធាវីនាំមុខ (F54/2) | សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ |
| សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E457/6/4/1) | សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ កែប្រែនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧ ឯកសារលេខ E457/6/4/1 |
| សារណារបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០១ (F17) | សារណាបណ្ដឹងទុក្ខរបស់មេធាវីការពារក្ដី ខៀវ សំផន (០០២/០១) ប្រឆាំងនឹងសាលក្រមដែលបានប្រកាសក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ F17 |
| បណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1) | បណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1 |
| | សំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញនូវសេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រដើម្បីដាក់សេចក្ដី |

| | |
|---|---|
| | ជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៩ ឯកសារលេខ F44 |
| សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E465/2/1) | សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ E465/2/1 |
| សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា (E465/3/1) | សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1 |
| សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (E465/4/1) | សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន សំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1 |
| | សំណើទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F47 |
| | សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ F55 |
| សំណើរបស់ ខៀវ សំផន សុំមោឃភាព (E463/1/4) | សំណើរបស់ ខៀវ សំផន សុំមោឃភាពសេចក្ដីសម្រេចលេខ E463/1/3 លើបណ្ដឹងសាទុក្ខភ្លាមៗរបស់គាត់ប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ ឯកសារលេខ E463/1/4 |
| | សំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51 |
| | សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម (F51) ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51/1 |

| | |
|---|---|
| | ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ F51/2 |
| | សំណើរបស់ ខៀវ សំផន សុំបដិសេធសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី (F50/1/1) អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1/1 |
| | សារណារបស់សហព្រះរាជអាជ្ញាស្តីពីមរណភាពរបស់ នួន ជា ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1 |
| | សំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៃមរណភាពរបស់ នួន ជា មុនពេលចេញសាលដីកាលើបណ្តឹងសាទុក្ខ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2 |
| | សំណើសុំបន្ទាន់ទីមួយរបស់ នួន ជា សុំបន្ថែមទំព័រ និងពេលវេលាដាក់សេចក្តីសជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F40/1.1 |
| | សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1 |
| បណ្តឹងរបស់ ខៀវ សំផន ប្តឹងជិតចិត្តចៅក្រម (F53) | បណ្តឹងរបស់ ខៀវ សំផន ប្តឹងជិតចិត្តចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានជំនុំជម្រះលើសំណុំរឿង ០០២/០១ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F53 |
| | សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជិតចិត្តរបស់ ខៀវ សំផន លើចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F53/4 |

| | |
|---|---|
| | សារណាតបរបស់សហមេធាវីនាំមុខទៅនឹងបណ្ដឹងជិតចិត្ត របស់ ខៀវ សំផន លើចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះ តុលាការកំពូល ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F53/5 |
| សេចក្ដីសម្រេចលើសំណើសុំរបស់ ខៀវ សំផន ជិតចិត្តចៅក្រម (11) | សេចក្ដីសម្រេចលើសំណើសុំរបស់ ខៀវ សំផន ជិតចិត្តចៅក្រមប្រាំមួយរូបដែលជំនុំជម្រះសំណុំរឿង ០០២/០១ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០២ ឯកសារលេខ 11 |
| ញត្តិរបស់ អៀង សារី (E58) | ញត្តិរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារមានកំហុសនីតិវិធី ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E58 |
| | អញ្ញត្រកម្មរបស់ អៀង សារី ស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (អាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរ) ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E43 |
| | អញ្ញត្រកម្មរបស់ អៀង ធីរិទ្ធ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E44 |
| | អញ្ញត្រកម្មពាក់ព័ន្ធទៅនឹងយុត្តាធិការ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E46 |
| | អញ្ញត្រកម្មពាក់ព័ន្ធទៅនឹងការរលត់បណ្ដឹងអាជ្ញា(ឧក្រិដ្ឋកម្មក្នុងស្រុក) ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E47 |
| | អញ្ញត្រកម្មរួម ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ឯកសារលេខ E51/3 |
| | សេចក្ដីសង្ខេបនៃអញ្ញត្រកម្មរបស់ អៀង សារី ស្របតាមវិធាន ៨៩ និងការជូនដំណឹងអំពីគោលបំណងនៃការមិនអនុវត្តតាមអនុស្សរណៈក្រៅផ្លូវការនាពេលអនាគត ដែលចេញជំនួសសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុនៃការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/4 |

| | |
|---|---|
| សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី (E58/1) | សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ញត្តិរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី" ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E58/1 |
| សំណើរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង (E95) | សំណើរបស់សហព្រះរាជអាជ្ញាសុំអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E95 |
| សំណើរបស់សហព្រះរាជអាជ្ញាសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ III (E100) | សំណើរបស់សហព្រះរាជអាជ្ញាសុំអង្គជំនុំជម្រះសាលាដំបូងឱ្យចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីជាទម្រង់មួយបែបទៀតនៃការទទួលខុសត្រូវ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E100 |
| | សេចក្តីសន្និដ្ឋានមេធាវីការពារក្តី ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E306/2 |
| | សារណាតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណារបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារលេខ E306/4 |
| | សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា ដែលបានកែប្រែក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ E457/6/3/1 |
| | សំបុត្រមរណភាពរបស់ នួន ជា ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/1.1 |
| **សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត** | |
| | ដីកាសម្រេចសំណុំរឿង ០០២ លើសំណើ D153, D172, D173, D174, D178 និង D284 ថ្ងៃ ១២ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D300 |

| | |
|---|---|
| ដីកាដំណោះស្រាយសំណុំរឿង ០០២ (D427) | ដីកាដំណោះស្រាយសំណុំរឿង ០០២ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 |
| | ដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ D308/3 |
| សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើ (D301/5) | សេចក្តីសម្រេចរួមសំណុំរឿង ០០៤ ស្តីពីសំណើសុំបំពេញកិច្ចស៊ើបអង្កេតពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ សំណុំរឿង ០០៤ ឯកសារលេខ D301/5 |
| **សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ** | |
| សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (D427/1/30) | សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 |
| សេចក្តីសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្នសំណុំរឿង ០០២ (D427/5/10) | សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលដីកាដំណោះស្រាយនៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/10 |
| | សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មតិរបស់ចៅក្រម BAIK និង BEAUVALLET ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 និង D382/43 |
| | សេចក្តីពិចារណាសំណុំរឿង ០០៤/២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មតិរបស់ចៅក្រម Baik និង Beauvallet ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ D359/24 និង D360/33 |
| សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) | ដីកាសម្រេចសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋ |

| | |
|---|---|
| | កម្ពុជា ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ D97/15/9 |
| សេចក្ដីសម្រេចសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15 និង D427/3/15) | សេចក្ដីសម្រេចសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់ នួន ជា និង អៀង ធីរិទ្ធ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ D427/2/15 និង D427/3/15 |
| សេចក្ដីសម្រេចសំណុំរឿង ០០១ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D99/3/42) | សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលចោទប្រកាន់ កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 |
| សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/3/12) | សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/3/12 |
| | សេចក្ដីសម្រេចសំណុំរឿង ០០៣ ទាក់ទងទៅនឹង (១) បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើប្រាំបួនសុំឱ្យអង្គបុរេជំនុំជម្រះមោឃៈសំណើ និង (២) សំណើពីរសុំមោឃៈដែលត្រូវបានយោងដោយសហចៅក្រមស៊ើបអង្កេត មតិរបស់ចៅក្រម BEAUVALLET និង BAIK ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ D165/2/26 |
| | សេចក្ដីសម្រេចសំណុំរឿង ០០៣ លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីមស្រេចរបស់សហចៅក្រមស៊ើបអង្កេត HARMON ស្ដីពីសំណើរបស់ មាស មុត សុំឱ្យអង្គបុរេជំនុំជម្រះមោឃៈសំណើពីរសុំបំពេញកិច្ចស៊ើបសួរ មតិរបស់ចៅក្រម BEAUVALLET និង BWANA ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ D134/1/10 |
| សេចក្ដីសម្រេចសំណុំរឿង ០០២ ស្ដីពីភាពអាចទទួលយកបាននូវដើម | សេចក្ដីសម្រេចសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ឯកសារលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកា |

| | |
|---|---|
| បណ្ដឹងរដ្ឋប្បវេណី (D250/3/2/1/5) | សម្រេចឯកសារលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារលេខ D250/3/2/1/5 |
| | សេចក្ដីពិចារណាសំណុំរឿង ០០៤/២ លើសំណើរបស់ អោ អាន សុំឱ្យមោឃៈកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គុញដី និងបទចោទនានាទាក់ទងទៅនឹងទួលបេង មតិរបស់ចៅក្រម BEAUVALLET និង BAIK ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារលេខ D299/3/2 |
| សេចក្ដីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត (D158/1) | សេចក្ដីសម្រេចសំណុំរឿង ០០៣ លើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះធ្វើការបកស្រាយយ៉ាងទូលំទូលាយអំពីវិសាលភាពនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបញ្ជាក់ដំណើរការនីតិវិធីសម្រាប់មោឃភាពដីកាដំណោះស្រាយ ឬក្នុងផ្នែកខ្លះ ប្រសិនបើចាំបាច់ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារលេខ D158/1 |
| | សេចក្ដីសម្រេចសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D404/2/4 និង D411/3/6 |
| **សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង** | |
| សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) | សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465 |
| សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ (E188) | សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ ថ្ងៃទី ២៦ ខែ កក្កដា ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 |

| | |
|---|---|
| ដីកាសម្រេចបំបែកសំណុំរឿង ០០២ (E124) | ដីកាបំបែកសំណុំរឿងស្របតាមវិធាន ៨៩*ស្ទួនពីរ* សំណុំរឿង ០០២ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E124 |
| សេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ លើកទីពីរ (E284) | សេចក្ដីសម្រេចស្ដីពីការបំបែកសំណុំរឿង ០០២ ក្រោយពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E284 |
| សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1) | សេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ បន្ថែម និងវិសាលភាពនៃសំណុំរឿង ០០២ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1 |
| ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកសំណុំរឿង ០០២ (E301/9/1.1) | ឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចបំបែកបន្ថែមសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1.1 |
| សេចក្ដីសម្រេចសំណុំរឿង ០០២/០១ លើអញ្ញត្រកម្ម (E122) | សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្ដី(ការផុតអាជ្ញាយុកាលលើឧក្រិដ្ឋកម្មក្នុងស្រុក) ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E122 |
| សេចក្ដីសម្រេចសំណុំរឿង ០០២/០១ លើសំណើរបស់សហព្រះរាជអាជ្ញា (E124/7) | សេចក្ដីសម្រេចសំណុំរឿង ០០២/០១ លើសំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញលើលក្ខខណ្ឌនៃដីកាបំបែករបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងញត្តិពាក់ព័ន្ធ និងឧបសម្ព័ន្ធ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E124/7 |
| | សំណុំរឿង ០០២/០១ ឧបសម្ព័ន្ធៈ ចំនួននៃកថាខណ្ឌ និង ផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ត្រូវបានកែប្រែបន្ថែមទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ អៀង សារី គ្រប់គ្រាន់ចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង |

| | |
|---|---|
| | ០០២/០១ (E163) ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E124/7.3។ |
| សេចក្តីសម្រេចសំណុំរឿង ០០២/០១ លើអញ្ញត្រកម្មរបស់ អៀង សារី ស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (E51/15) | សេចក្តីសម្រេចសំណុំរឿង ០០២/០១ លើអញ្ញត្រកម្មរបស់អៀង សារី ស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គ្មានការកាត់ទោសពីរដង និងការលើកលែងទោស និងអនុគ្រោះទោស) ថ្ងៃទី ០៣ ខែ វិច្ឆិកា ២០១១ ឯកសារលេខ E51/15 |
| សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកឯកសារ (E319/52/4) | សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង (ឯកសារលេខ E319/51 និងឯកសារលេខ E319/52) ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E319/52/4 |
| | សេចក្តីសម្រេចលើសំណើសុំស្តាប់សាក្សីបន្ថែមស្តីពីប្រធានបទនៃការប្រព្រឹត្តទៅលើជនជាតិវៀតណាម និងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី (E380 E381 E382) (សំអាងហេតុពេញលេញ) ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារលេខ E380/2 |
| | សេចក្តីសម្រេចស្តីពីការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារលេខ E439/5 |
| សេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង (E96/7) | សេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងការទទួលយកចម្លើយរបស់សាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E96/7 |
| | សំណុំរឿង ០០២ សេចក្តីសម្រេចលើការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកសំណុំរឿង ០០១ ដែលបាន |

| | |
|---|---|
| | ស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ឯកសារលេខ E299 |
| | សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារដែលបានស្នើឡើងឱ្យដាក់ចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខE305/17 |
| សេចក្តីសម្រេចស្តីពីសាក្សីដែលបានស្នើឡើង (E459) | សេចក្តីសម្រេចស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងសម្រាប់ស្តាប់ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារលេខ E459 |
| | សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងយុត្តាធិការលើបទឧក្រិដ្ឋនៃការនិរទេសក្នុងកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E306/5 |
| សេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ (E319/47/3) | សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយអនុលោមតាមវិធាន ៨៧(៣)(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារលេខ E319/47/3 |
| សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខខណ្ឌទំនាក់ទំនង (E95/8) | ចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E95/8 |
| សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត (E314/12/1) | សំអាងហេតុបន្ថែមសម្រាប់សេចក្តីសម្រេចស្តីពីសំណើសុំជិតចិត្ត ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ឯកសារលេខ E314/12/1 |
| សេចក្តីសម្រេចសំណុំរឿង ០០២ ស្តីពីសហឧក្រិដ្ឋកម្មរួម (E100/6) | សេចក្តីសម្រេចសំណុំរឿង ០០២ លើការអនុវត្តន៍សហឧក្រិដ្ឋកម្មរួម ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E100/6 |
| | សេចក្តីសម្រេចលើញត្តិរបស់ នួន ជា ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3, E82, E88 និង E92) ថ្ងៃទី ០៩ |

| | |
|---|---|
| | ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E116 |
| | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ សេចក្ដីណែនាំភាគីពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E51/7 |
| អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E449) | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និង កិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ E449 |
| អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ (E306) | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ E306 |
| អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង (E141) | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០១ ចំណងជើងថា “ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីនៅមុនការជំនុំជម្រះ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំក្រៅផ្លូវការជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E141 |
| | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង អញ្ញត្រកម្ម ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/1 |
| | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង អញ្ញត្រកម្ម ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E51/5 |
| | អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២ ស្ដីពីសំណើរបស់ ខៀវ សំផន សុំការបំភ្លឺ និងកែប្រែចំពោះឧបសម្ព័ន្ធទៅនឹងសេចក្ដីសម្រេចលើការបំបែកបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1.1/2 |
| **សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល** | |

| | |
|---|---|
| សាលដីកាសំណុំរឿង ០០២/០១ (F36) | សាលដីកាសំណុំរឿង ០០២/០១ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ F36 |
| សាលដីកាសំណុំរឿង ០០១ (F28) | សាលដីកាសំណុំរឿង ០០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 |
| | សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើ នួន ជា ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/3 |
| សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចបំបែកសំណុំរឿងលើកទីពីរ (E284/4/8) | សេចក្តីសម្រេចសំណុំរឿង ០០២ លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកសំណុំរឿង ០០២ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារលេខ E284/4/8 |
| សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម (E301/9/1/1/3) (E301/9/1/1/3) | សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកបន្ថែមនូវសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារលេខ E301/9/1/1/3 |
| | សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំមោឃៈភាពសេចក្តីលេខ E463/1/3 ពីបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងសាលក្រមប្រកាសថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ E463/1/5 |
| | សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន លើសំណើសុំដោះលែង ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4 |
| | សេចក្តីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៃមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកាលើបណ្តឹងសាទុក្ខ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារលេខ F46/2/4/2 |

| | |
|---|---|
| | សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបដិសេធសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ F50/1/1/2 |
| | សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ F51/3 |
| | សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ F44/1 |
| សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន (E463/1/3) | សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ឯកសារលេខ E463/1/3 |
| | សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០ ឯកសារលេខ F55/3 |
| | សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 |
| សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ (F49) | សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 |
| | លើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធចេញពីការកំណត់និយមន័យនៃឧក្រិដ្ឋ |

| | |
|---|---|
| | កម្មប្រឆាំងមនុស្សជាតិថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E95/8/1/4 |
| សេចក្តីសម្រេចបំបែកសំណុំរឿងលើកទីមួយ (E163/5/1/13) | សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E163/5/1/13 |
| | ដីកាកំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨ ឯកសារលេខ E462 |
| | សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ សម្រាប់ការកង្វះឯករាជភាព ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ 1/4 |
| សេចក្តីសម្រេចលើការជំទាស់ (F26/12) | សេចក្តីសម្រេចលើការជំទាស់ទៅនឹងបញ្ជីឯកសាររៀបរាប់សំអាងហេតុពេញលេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F26/12 |
| រឿងក្តីនៃយុត្តាធិការដទៃទៀត<br>តុលាការព្រហ្មទណ្ឌអន្តរជាតិ | |
| | រឿងក្តី *ពាក់ព័ន្ធទៅនឹងការអនុវត្តន៍អនុសញ្ញាស្តីពីការរារាំង និងការដាក់ទោសបទប្រល័យពូជសាសន៍ (រឿងក្តី បូស្នៀ និង Herzegovina ទល់នឹង Serbia និង Montenegro)* ICJ សាលដីកាថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ |
| **យន្តការកេរដំណែលសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ** (IRMCT) | |
| សេចក្តីសម្រេចរឿងក្តី *Turinabo និងជនជាប់ចោទដទៃទៀត* (IRMCT) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Turinabo និងជនជាប់ចោទដទៃទៀត* ចៅក្រមតែមួយរូប (IRMCT) សំណុំរឿងលេខ MICT-18-116-PT សេចក្តីសម្រេចលើញត្តិសុំបន្ថែមពេលវេលាដាក់អញ្ញត្រកម្ម ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៨ |

| | |
|---|---|
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Munyarugarama* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ MICT-12-09-AR14 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបញ្ជូនសំណុំរឿងរបស់ Ph‟n‟an Munyarugarama ទៅប្រទេសរ៉ូហ្វាន់ដា និងញត្តិអយ្យការសុំលុប ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១២ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Uwinkindi* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខ MICT-12-25-AR14.1 សេចក្តីសម្រេចលើការបដិសេធបញ្ជូនសំណុំរឿងទៅជំនុំជម្រះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៦ |
| សាលដីការឿងក្តី Ngirabatware (IRMCT) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ngirabatware* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) សំណុំរឿងលេខMICT-12-29-A សាលដីកាថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Naser Orić* អង្គជំនុំជម្រះឧទ្ធរណ៍ (IRMCT) MICT-14-79 សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតធ្វើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ចៅក្រមតែមួយរូបថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៥, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ |
| **តុលាការព្រហ្មទណ្ឌអន្តរជាតិ** | |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Al Mahdi* អង្គជំនុំជម្រះសាលាដំបូង VIII (ICC) សំណុំរឿងលេខ ICC-01/12/01/15 សាលក្រម និងការប្រកាសទោស ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦ |
| សាលក្រមរឿងក្តី *Bemba* (ICC) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Bemba អង្គជំនុំជម្រះសាលាដំបូង III (ICC) សំណុំរឿងលេខ ICC-01/05-01/08 សាលក្រមស្របតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ |
| សេចក្តីសម្រេចរឿងក្តី *Bemba* ស្របតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គបុរេជំនុំជម្រះ III (ICC) សំណុំរឿងលេខ ICC-01/05-01/08 សេចក្តីសម្រេចស្របតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីបទ |

| | |
|---|---|
| | ចោទរបស់អយ្យការប្រឆាំងនឹងជនជាប់ចោទ Jean-Pierre Bemba Gombo ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/05-01/08 A សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ Jean-Pierre Bemba Gombo ប្រឆាំងនឹង"សាលក្រមអង្គជំនុំជម្រះសាលាដំបូង III ស្របតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ |
| សេចក្តីស្តីពីការបញ្ជាក់របស់ *Katanga និង Ngudjolo Chui* អំពីបទចោទ (ICC) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* អង្គបុរេជំនុំជម្រះ I (ICC) សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចស្តីពីការបញ្ជាក់នៃបទចោទ ថ្ងៃ ៣០ ខែ កញ្ញា ឆ្នាំ ២០០៨ |
| | សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F54) កថាខណ្ឌ ៣០៩ យោងទៅលើរឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* អង្គជំនុំជម្រះសាលាដំបូង II (ICC) សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្តីពីតារាងបញ្ជីភស្តុតាងថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ |
| សាលដីការឿងក្តី Lubanga ប្រឆាំងនឹងសេចក្តីសម្រេចដាក់ទោស (ICC) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/04-01/06 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អយ្យការ និងជនជាប់ចោទ Thomas Lubanga Dyilo ប្រឆាំងនឹង"សេចក្តីសម្រេចស្តីពីការដាក់ទោសស្របតាមមាត្រា ៧៦ នៃលក្ខន្តិកៈ" ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Lubanga* អង្គជំនុំជម្រះសាលាដំបូង (ICC) សំណុំរឿងលេខ ICC-01/04-01/06 សាលក្រមស្របតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ |

| | |
|---|---|
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo* អង្គបុរេជំនុំជម្រះ I (ICC) សំណុំរឿងលេខ ICC-01/04-01/06 សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo* អង្គជំនុំជម្រះសាលាដំបូង I (ICC) សំណុំរឿងលេខ ICC-01/04-01/06 សេចក្តីសម្រេចស្តីពីការដាក់ទោសស្របតាមមាត្រា ៧៦ នៃលក្ខន្តិកៈ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះសាលាដំបូង VI (ICC) សំណុំរឿងលេខ ICC-01/04-02/06 សាលក្រមប្រកាសទោស ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះសាលាដំបូង VI (ICC) សំណុំរឿងលេខ ICC-01/04-02/06 សាលក្រម ថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ ២០១៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/04-02/06 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Bosco Ntaganda ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង VI ខែ វិច្ឆិកា ឆ្នាំ ២០១៩ ចំណងជើងថា 'សាលក្រមដាក់ទោស" ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១ |
| សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Ongwen* (ICC) | សាលក្រមអង្គជំនុំជម្រះសាលាដំបូង (E465) កថាខណ្ឌ ៧៤៥ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dominic Ongwen* អង្គបុរេជំនុំជម្រះ II (ICC) សំណុំរឿងលេខ ICC-02/04-01/15 សេចក្តីសម្រេចលើការបញ្ជាក់នៃបទចោទប្រឆាំងនឹងជនជាប់ចោទ Dominic Ongwen ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ongwen* អង្គជំនុំជម្រះសាលាដំបូង IX (ICC) សំណុំរឿងលេខ ICC-02/04-01/15 អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២១ |

| | |
|---|---|
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Saif Al-Islam Gaddafi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICC) សំណុំរឿងលេខ ICC-01/11-01/11-695-Anxl មតិស្របដាច់ដោយឡែករបស់ចៅក្រម Luz del Carmed Ib...nex Carranza លើសាលក្រមស្តីពីបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ Saif Al-Islam Gaddafi ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចំណងជើងថា 'សេចក្តីសម្រេចស្តីពីការជំទាស់លើ"ភាពអាចទទួលយកបាន ដោយ Saif Al-Islam Gadafi ស្របតាមមាត្រា ១៧(១)(ខ), ១៩ និង ២០(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម""ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៩, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២០ |
| សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទរឿងក្តី *Al Hassan* (ICC) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Al Hassan* អង្គជំនុំជម្រះឧទ្ធរណ៍ I (ICC) សំណុំរឿងលេខ ICC-01/12-01/18 សេចក្តីសម្រេចលើសំណើសុំបញ្ជាក់បទចោទរបស់ជនជាប់ចោទ Al Hassan Ag Abdoul Aziz Ag Mohamed Ag Mahmoud ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៩ |
| **តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី** | |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14/1-A សាលដីកាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Baton Haxhiu* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-84-R77.5-A សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបានតាមទម្រង់នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៨ |
| សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-60-A សាលដីកាចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៧ |

| | |
|---|---|
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-02-60-T សាលក្រមថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ |
| សាលដីការឿងក្តី *BlaĖkić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង BlaĖkić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14-A សាលដីកាថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង BoĖkoski និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-82-A សាលក្រម ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brđanin* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿង IT-99-36-T សាលក្រម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ |
| សាលដីការឿងក្តី *Brđanin* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brđanin* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-99-36-A សាលាដីកា ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brđanin និង Talić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-99-36 សេចក្តីសម្រេចស្តីពីទម្រង់នៃដីកាបញ្ជូនទៅជំនុំជម្រះដែលត្រូវបានកែប្រែបន្ថែម និងសំណើរបស់អយ្យការសុំកែប្រែ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១ |
| សាលក្រមរឿងក្តី *Česić* (ICTY) សាលក្រមប្រកាសទោស | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Česić* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-95-10/1-S សាលក្រមប្រកាសទោសថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៤ |
| សាលក្រមរឿងក្តី *Čelebići* (ICTY) | រឿងក្តីរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delalić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-21-T សាលក្រមថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ |

| | |
|---|---|
| សាលដីការឿងក្តី *Delalić និងជនជាប់ចោទដទៃទៀត* (ICTY) | សាលដីកាសំណុំរឿង ០០២/០១ (F36) កថាខណ្ឌ ១៦២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delalić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-96-21-A សាលដីកាចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Deronjić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-61-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការដាក់ទោស ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៥ |
| សាលដីការឿងក្តី *Đorđević* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Đorđević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87/1-A ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Erdemović* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-22-T សាលក្រមប្រកាសទោស ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ |
| សាលដីការឿងក្តី *Furundžija* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Furundžija* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-17/1-A សាលដីកាចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ |
| សាលក្រមរឿងក្តី *Furundžija* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Furundžija* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-17/1-T សាលក្រម ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ |
| សាលដីការឿងក្តី *Galić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Galić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-29-A សាលដីកាចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Galić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-29-T សាលក្រមចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣ |

| | |
|---|---|
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-06-90-T សាលក្រម ភាគ II ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១១ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និង Kubura* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-47-AR72 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងយុត្តាធិការពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ |
| សាលដីការឿងក្តី *Hadžihasanović និង Kubura* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និង Kubura* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-47-A សាលដីកា ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Jelisić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-10-A សាលដីកាចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឱ្យទទួលយកសក្ខីកម្មរបស់សាក្សី១៦នាក់ និងវត្ថុតាងពាក់ព័ន្ធស្របតាមវិធាន ៩២ *ស្ទួនបី* ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង KrajiÈnik* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-5/18-PT សេចក្តីសម្រេចលើញត្តិសុំបង្ហាញឯកសារតាមវិធាន ៦៨ និងការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីការជួយសម្រួលគ្រប់គ្រាន់ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ |
| សាលក្រមរឿងក្តី *Karadžić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-5/18-T សាលក្រមថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ |

| | |
|---|---|
| សាលក្រមរឿងក្តី *Kordić និង Cerkez* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kordić និង Cerkez* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-14/2-T សាលក្រមថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Kordić ទល់នឹង Cerkez* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kordić ទល់នឹង Cerkez* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-14/2-A សាលដីកា ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង KrajiÈnik* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-00-39-T សាលក្រម ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ |
| សាលដីកានៃរឿងក្តី *Krajisnik* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង KrajiÈnik* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-00-39-A សាលដីកា ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង KrajiÈnik និង PlavÈić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-00-39 សេចក្តីសម្រេចលើញត្តិរបស់ជនជាប់ចោទ Momčilo KrajiÈnik ក្នុងការជម្រុញឱ្យបង្ហាញភស្តុតាងដោះបន្ទុកស្របតាមវិធាន ៦៨ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Krnojelac* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krnojelac* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-97-25-A សាលដីកាចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ |
| សាលក្រមរឿងក្តី *Krnojelac* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krnojelac* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-97-25-T សាលក្រមថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ |
| សាលក្រមរឿងក្តី *Krstić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Krstić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-33-T សាលក្រម ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ |

| | |
|---|---|
| សាលដីការឿងក្តី *Krstić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-33-A សាលដីកា ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T សាលក្រមថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Kunarac និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-96-23/1-A សាលដីកា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ |
| សាលក្រមរឿងក្តី *KupreÈkić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង KupreÈkić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-16-T សាលក្រម ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ |
| សាលដីកានៃ *រឿងក្តី Kvočka និងជនជាប់ចោទដទៃទៀត*(ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-30/1-A សាលដីកា ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kvočka និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-98-30/1-T សាលក្រមថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Lukić និង Lukić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lukić និង Lukić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-32/1-A សាលដីកា ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ |
| សាលដីការឿងក្តី *Martić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Martić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-11-A សាលដីកា ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ |

| | |
|---|---|
| សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី *Martić* ស្តីពីភស្តុតាង (ICTY) | រឿងក្តី *រដ្ឋអាជ្ញាទល់នឹង Martić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-11-AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភស្តុតាងរបស់សាក្សី Milan Babić ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦ |
| សាលដីការឿងក្តី*Dragomir MiloÈević* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dragomir MiloÈević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-29/1-A សាលដីកា ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Milosević* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT 98-29/1-T សាលក្រមថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ |
| | រឿងក្តី *រដ្ឋអាជ្ញាទល់នឹង និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87-AR65.1 សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ភ្លាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតការដោះលែងជនជាប់ចោទ NebojÈa Pavković បណ្តោះអាសន្ន ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ |
| សាលក្រមរឿងក្តី *Milutinović និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Milutinović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-05-87-T សាលក្រម ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ |
| សេចក្តីសម្រេចរឿងក្តី *Milutinović និងជនជាប់ចោទដទៃទៀត (ICTY)* | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Milutinović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-00-37-AR72 សេចក្តីសម្រេចលើសំណើរបស់ Dragoljub *Ojdanić* ដែលជំទាស់ទៅនឹងយុត្តាធិការ សហឧក្រិដ្ឋកម្មរួម ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT- |

| | |
|---|---|
| | 05-87-T សេចក្តីសម្រេចលើញត្តិរបស់ NebojÈa Pavkovic សុំបដិសេធដីកាបញ្ជូនទៅជំនុំជម្រះប្រឆាំងនឹងរូបគាត់ផ្អែកលើមូលដ្ឋានថា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតដោយខុសច្បាប់នូវតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៨ |
| សាលក្រមរឿងក្តី *Mladić*(ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mladić* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-09-92-T សាលក្រម ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៧ |
| សាលដីការឿងក្តី *MrkÈić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង MrkÈić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-13/1-A សាលដីកា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ |
| សាលដីការឿងក្តី*Naletilić និង Martinović* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Naletilić និង Martinović* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-34-A សាលដីកាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ |
| សាលក្រមប្រកាសទោសរឿងក្តី *Nikolić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nikolić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-94-2-S សាលក្រមប្រកាសទោស ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០ |
| សាលដីការឿងក្តី *Nikolić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nikolić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-94-2-A សាលក្រមស្តីពីបណ្តឹងសាទុក្ខលើការដាក់ទោស ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ |
| សាលដីកាប្រកាសទោសរឿងក្តី *Momir Nikolić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Momir Nikolić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-02-60/1-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការដាក់ទោស ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Orić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-03-68-A សាលដីកា ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ |

| | |
|---|---|
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង PeriÈić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-81-A សាលដីកា ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ |
| សាលដីការឿងក្តី *Popović និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Popović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-88-A សាលដីកាចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ |
| សាលក្រមរឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង III (ICTY) សំណុំរឿងលេខ IT-04-74-T សាលក្រមថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ |
| សាលដីការឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-74-A សាលដីកាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧ |
| សេចក្តីសម្រេចរឿងក្តី *Prlić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង III (ICTY) សំណុំរឿងលេខ IT-04-74-T សេចក្តីសម្រេចលើសំណើរបស់ Slobodan Praljak សុំការបំភ្លឺអំពីក្របខ័ណ្ឌពេលវេលានៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* សំណុំរឿងលេខ IT-04-74-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់ Jadranko Prlić ប្រឆាំងនឹង'សេចក្តីម្រេចលើញត្តិរបស់មេធាវីការពារក្តី Prlić ស្នើសុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចស្តីពីការទទួលយកភស្តុតាងជាឯកសារ"ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-04-74-AR73.6 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តី |

| | |
|---|---|
| | សម្រេចទទួលយកប្រតិចារឹកនៃការសួរសំណួររបស់ Jadranko Prlić ធ្វើជាភស្តុតាង ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ |
| សាលដីការឿងក្តី *Šainović និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Šainović និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-87-A សាលដីកាចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Simić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿង IT-95-9/2-S សាលក្រមនៃការដាក់ទោស ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២ |
| សាលក្រមរឿងក្តី *Simić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Simić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-95-9-T សាលក្រមថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ |
| សាលដីការឿងក្តី *Simić និងជនជាប់ចោទដទៃទៀត* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Simić និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-95-9-A សាលដីកា ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ |
| សាលដីការឿងក្តី *Stakić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Stakić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-97-24-A សាលដីកា ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ |
| សាលក្រមរឿងក្តី *Stakić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-97-24-T សាលក្រម ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង StaniĖić និង Simutović* អង្គជំនុំជម្រះសាលាដំបូង I (ICTY) សំណុំរឿងលេខ IT-03-69-T សាលក្រម (ភាគ II) ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ |
| សាលក្រមរឿងក្តី *StaniĖić និង Župljanin* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង StaniĖić និង Župljanin* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-08-91-T សាលក្រម (ភាគ I នៃភាគ III) ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ |

| | |
|---|---|
| សាលដីការឿងក្តី *StaniĖić និង Župljanin* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* StaniĖić *និង Župljanin* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-08-91-A សាលដីកាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ |
| សាលដីការឿងក្តី *Strugar* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Strugar* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-01-42-A សាលដីកា ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ |
| សាលក្រមរឿងក្តី *Tadić* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Tadić* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-94-1-T មតិ និងសាលក្រមថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ |
| សាលដីការឿងក្តី*Tadić* (ICTY) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Tadić* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-94-1-A ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ |
| សាលក្រមប្រកាសទោសរឿងក្តី*Todorović* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Todorović* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ IT-95-9/1-S សាលក្រមប្រកាសទោសថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Tolimir* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Tolimir* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-05-882-A សាលដីកា ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ |
| សាលដីការឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Vasiljević* (ICTY) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Vasiljević* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTY) សំណុំរឿងលេខ IT-98-32-A សាលដីកា ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Vasiljević* អង្គជំនុំជម្រះសាលាដំបូង II (ICTY) សំណុំរឿងលេខ IT-98-32-T សាលក្រមថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ |
| **តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា** | |
| សាលក្រមរឿងក្តី*Akayesu* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-96-4-T សាលក្រមថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ |

| | |
|---|---|
| សាលដីកានៃរឿងក្តី *Akayesu* (ICTR) | សាលដីការឿងក្តី *Krnojelac* (ICTY) កថាខណ្ឌ ៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-4-A សាលក្រម ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bagosora និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-98-41-T សាលក្រម និងការប្រកាសទោសថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ |
| សាលដីការឿងក្តី *Gacumbitsi* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-2001-64-A សាលដីកា ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gatete* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-00-61-A សាលដីកា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ |
| សាលក្រមរឿងក្តី *Kajelijeli* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-98-44A-T សាលក្រម និងការប្រកាសទេសថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣ |
| សាលដីការឿងក្តី *Kalimanzira* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kalimanzira* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-05-88-A សាលដីកាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kambanda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-97-23-A សាលដីកាថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០០ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kamuhanda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-54A-A សាលដីកា ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ |

| | |
|---|---|
| សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Karemera និងជនជាប់ចោទដទៃទៀត*(ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-44-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗពាក់ព័ន្ធទៅនឹងតួនាទីរបស់អយ្យការក្នុងការបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការបំពេញកាតព្វកិច្ចនៃការបង្ហាញឯកសារថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ |
| សាលដីការឿងក្តី *Karemera និង Ngirumpatse* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Karemera និង Ngirumpatse* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-44-A សាលដីកា ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ |
| សាលដីការឿងក្តី *Karera* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Karera* (ICTR) អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-01-74-A សាលដីកា ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana* អង្គជំនុំជម្រះសាលាដំបូង (ICTY) សំណុំរឿងលេខ ICTR-95-1-T សាលក្រមថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ |
| សាលដីការឿងក្តី *Kayishema និង Ruzidana* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzidana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-95-1-A សាលដីកា (សំអាងហេតុ) ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ |
| សាលដីការឿងក្តី *Muvunyi* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Muvunyi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-2000-55A-A សាលដីកាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨ |
| សាលដីការឿងក្តី *Nahimana និងជនជាប់ចោទដទៃទៀត* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សាលក្រមចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ |

| | |
|---|---|
| | Hassan Ngeze សុំការយល់ព្រមបើកកិច្ចស៊ើបសួរបន្ថែមលើព័ត៌មានជាក់លាក់ទាក់ទងទៅនឹងភស្តុតាងបន្ថែមរបស់សាក្សីសក្ខានុពល ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Jean-Bosco Barayagwiza សុំការអនុញ្ញាតបង្ហាញភស្តុតាងបន្ថែមស្របតាមវិធាន ១១៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ Jean-Bosco Barayagwiza ស្នើសុំថា ការបង្ហាញរបស់អយ្យការនូវកិច្ចសម្ភាសន៍របស់ Michel Bagaragaza ត្រូវដកចេញពីសំណុំរឿង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Sim"on NCHAMIHIGO* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-01-63-A សាលដីកា ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ndahimana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ (ICTR), ICTR-01-68-A ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ |
| | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ndindabahizi* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-01-71-A សាលដីកាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧ |
| សេចក្តីសម្រេចក្នុងរឿងក្តី *Ngirabatware* លើញត្តិសុំបដិសេធ (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ngirabatware* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-99-54-T សេចក្តីសម្រេចលើញត្តិមេធាវីការពារក្តីសុំបដិសេធដោយសារផ្អែកលើ |

| | |
|---|---|
| | កំហុសនីតិវិធីក្នុងដីកាបញ្ជូនទៅជំនុំជម្រះដែលបានកែប្រែ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ |
| | សាលដីការឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Ntagerura *និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-99-46-A សាលដីកាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ |
| សាលដីការឿងក្តី *Ntakirutimana* និង *Ntakirutimana* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Ntakirutimana *និង* *Ntakirutimana* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-10-A និង ICTR-96-17-A សាលដីកាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ |
| សាលដីការឿងក្តី *Nyiramasuhuko និងជនជាប់ចោទដទៃទៀត* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Nyiramasuhuko និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-98-42-A ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ |
| សាលក្រមរឿងក្តី *Niyitegeka* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Niyitegeka* អង្គជំនុំជម្រះសាលាដំបូង (ICTR) សំណុំរឿងលេខ ICTR-96-14-T សាលក្រមនិងការប្រកាសទោសថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៣ |
| សាលដីការឿងក្តី *Niyitegeka* (ICTR) | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-14-A សាលដីកា ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ |
| | រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Renzaho* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-97-31-A សាលដីកា ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ |
| សាលដីការឿងក្តី *Rutaganda* (ICTR) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Rutaganda* អង្គជំនុំជម្រះឧទ្ធរណ៍ (ICTR) សំណុំរឿងលេខ ICTR-96-3-A សាលដីកា ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៣ |
| **តុលាការយោធាអន្តរជាតិ** (IMT) | |
| | រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា |

| | |
|---|---|
| | ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (១៩៤៧) ភាគ ១ |
| | *សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ XVI |
| | *សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ XXII |
| រឿងក្តីផ្នែកវេជ្ជសាស្ត្រ | រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Brandt និងជនជាប់ចោទដទៃទៀត* ("រឿងក្តីផ្នែកវេជ្ជសាស្ត្រ") សាលក្រម ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៤៦ បោះពុម្ពសាឡើងវិញក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅមុខតុលាការព្រហ្មទណ្ឌយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង |
| សាលដីកាតុលាការ IMT | រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Goering និងជនជាប់ចោទដទៃទៀត* ដីកាបញ្ជូនទៅជំនុំជម្រះ (IMT) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៤៥ ក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ (ឆ្នាំ ១៩៤៧) ភាគ I |
| **តុលាការពិសេសសម្រាប់ប្រទេសលីបង់** (STL) | |

| | |
|---|---|
| សាលក្រមរឿងក្តី *Ayyash* (STL) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Ayyash* អង្គជំនុំជម្រះសាលាដំបូង (STL) សំណុំរឿងលេខ STL-11-01/S/TC សាលក្រមប្រកាសទោស ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ |
| **អង្គជំនុំជម្រះឯកទេសនៅកូសូវ៉ូ** (KSC) | |
| សេចក្តីសម្រេចលើញត្តិស្តីពីយុត្តាធិការ (KSC) | ក្រុមប្រឹក្សានៃអង្គជំនុំជម្រះឧទ្ធរណ៍ (KSC) សំណុំរឿងលេខ KSC-BC-2020-06 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹង"សេចក្តីសម្រេចលើសំណើដែលជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះពិសេស"ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ |
| សេចក្តីសម្រេចរឿងក្តី*Thaçi និងជនជាប់ចោទដទៃទៀត* (KSC) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Thaçi និងជនជាប់ចោទដទៃទៀត* ចៅក្រមអង្គបុរេជំនុំជម្រះឯកទេស (**KSC**) សំណុំរឿងលេខ **KSC-BC-**2020-06 សេចក្តីសម្រេចលើសំណើជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២១ |
| តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន | |
| សាលដីការឿងក្តី *Brima និងជនជាប់ចោទដទៃទៀត* (SCSL) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Brima និងជនជាប់ចោទដទៃទៀត* អង្គជំនុំជម្រះឧទ្ធរណ៍ (SCSL) សំណុំរឿងលេខ SCSL-2004-16-A សាលដីកា ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ |
| សេចក្តីសម្រេចរឿងក្តី *Taylor* លើសំណើពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម (SCSL) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Taylor* អង្គជំនុំជម្រះសាលាដំបូង (SCSL) សំណុំរឿងលេខ SCSL-2003-01-T សេចក្តីសម្រេចលើសំណើបន្ទាន់របស់មេធាវីការពារក្តីពាក់ព័ន្ធទៅនឹងកំហុសនីតិវិធីធ្ងន់ធ្ងរក្នុងដីកាបញ្ជូនទៅជំនុំជម្រះរបស់អយ្យការដែលបានកែប្រែទាក់ទងទៅនឹងការលើកឡើងអំពីសហឧក្រិដ្ឋកម្មរួម ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ |
| សាលក្រមរឿងក្តី *Taylor* (SCSL) | រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Taylor* អង្គជំនុំជម្រះសាលាដំបូង II (SCSL) សំណុំរឿងលេខ SCSL-03-01-T សាលក្រមថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ |
| **តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស** (ECtHR) | |

| | |
|---|---|
| | រឿងក្តី *Al-Khawaja ទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សំណើសុំលេខ 26766/05 និង 22228/06 សាលក្រម ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ |
| | រឿងក្តី *A.M. ទល់នឹង ប្រទេសអ៊ីតាលី* តុលាការ ECtHR សំណុំរឿងលេខ 37019/97 សាលក្រម ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ |
| | រឿងក្តី *Cantoni ទល់នឹង ប្រទេសបារាំង* តុលាការ ECtHR សំណើលេខ 17862/91 សាលក្រម ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ |
| | រឿងក្តី *Gani ទល់នឹង ប្រទេសអេស្ប៉ាញ* តុលាការ ECtHR សំណើសុំលេខ 61800/08 សាលក្រមថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ |
| | រឿងក្តី *Isgr/ ទល់នឹង ប្រទេសអ៊ីតាលី* តុលាការ ECtHR សំណើសុំលេខ 11339/85 សាលក្រមថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩១ |
| សាលក្រមរឿងក្តី *Mattei ទល់នឹង ប្រទេសបារាំង* (ECtHR) | រឿងក្តី *Mattei ទល់នឹង ប្រទេសបារាំង* ផ្នែកទីពីរ (ECtHR) សំណើសុំលេខ 34043/02 សាលក្រម ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ |
| សាលក្រមរឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* (ECtHR) | រឿងក្តី *Miraux ទល់នឹង ប្រទេសបារាំង* ផ្នែកពីពីរ (ECtHR) សំណើសុំលេខ 73529/01 សាលក្រម ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧ |
| សាលក្រមរឿងក្តី *Mattoccia ទល់នឹងប្រទេស អ៊ីតាលី* (ECtHR) | រឿងក្តី *Mattoccia ទល់នឹងប្រទេស អ៊ីតាលី* ផ្នែកទីមួយ (ECtHR) សំណើសុំលេខ 23969/94 សាលក្រម ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ |
| រឿងក្តី *P"lissier និង Sassi ទល់នឹង ប្រទេសបារាំង* អង្គជំនុំជម្រះ (ECtHR) | រឿងក្តី *P"lissier និង Sassi ទល់នឹង ប្រទេសបារាំង* អង្គជំនុំជម្រះ (ECtHR) សំណើសុំលេខ 25444/94 សាលក្រម ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ |

| | |
|---|---|
| | រឿងក្តី *Saÿdi ទល់នឹង ប្រទេសបារាំង* តុលាការ ECtHR សំណុំរឿងលេខ 14647/89 សាលក្រមចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៣ |
| សាលក្រមរឿងក្តី *Schatschaschwili ទល់នឹង ប្រទេសអាល្លឺម៉ង់* (ECtHR) | រឿងក្តី *Schatschaschwili ទល់នឹង ប្រទេសអាល្លឺម៉ង់* តុលាការ ECtHR សំណើសុំលេខ 9154/10 សាលក្រម ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ |
| | រឿងក្តី *Soering ទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សំណើសុំលេខ 14038/88 សាលក្រមថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៨៩ |
| សាលក្រមរឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* (ECtHR) | រឿងក្តី *S.W. ទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សំណើលេខ 20166/92 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ |
| | រឿងក្តី *Unterpertinger ទល់នឹង ប្រទេសអូទ្រីស* តុលាការ ECtHR សំណើសុំលេខ 9120/80 សាលក្រមថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ |
| សាលក្រមរឿងក្តី *Vasiliauska ទល់នឹង Lithuania* (ECtHR) | រឿងក្តី *Vasiliauska ទល់នឹង Lithuania* (មហាអង្គជំនុំជម្រះនៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR)) សំណើសុំលេខ 35343/05 សាលក្រម ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ |
| **រឿងក្តីថ្នាក់ជាតិ** | |
| | សំណុំរឿងលេខ 89-84.987 (ឆ្នាំ ១៩៩១) ពុំបានបោះពុម្ពផ្សាយ (តុលាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះព្រហ្មទណ្ឌ ប្រទេសបារាំង) |
| | រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Altstotter ជនជាប់ចោទដទៃទៀត* សំអាងហេតុ និងសាលក្រម (តុលាការយោធាសហរដ្ឋអាមេរិក) សំណុំរឿងលេខ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៧៤ ក្នុងការជំនុំជម្រះបុគ្គលចំពោះមុខតុលាការព្រហ្មទណ្ឌយោធា Nuremberg ក្រោមក្រុមប្រឹក្សាគ្រប់គ្រងច្បាប់លេខ ១០ ឆ្នាំ ១៩៤៦-១៩៤៩ (ឆ្នាំ ១៩៥១) ភាគ III |

| លិខិតុបករណ៍ច្បាប់ និងសេចក្តីអធិប្បាយ | |
|---|---|
| ACHPR | ធម្មនុញ្ញទ្វីបអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន ចូលជាធរមាន ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៨៧ ឯកសារលេខ 1520 U.N.T.S 217 |
| ACHR | អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ ឯកសារលេខ 1144 U.N.T.S. 123 |
| ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង | ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត ការដាក់ទណ្ឌកម្មលើបុគ្គលដែលមានពិរុទ្ធនៃបទឧក្រិដ្ឋសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងមនុស្សជាតិ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ (១៩៤៦) ៣ ក្រុមប្រឹក្សាគ្រប់គ្រងផ្លូវការ Gazette សម្រាប់ប្រទេសអាល្លឺម៉ង់ ៥០-៥៥ (“ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង”) |
| | សេចក្តីប្រកាស Cairo ស្តីពីសិទ្ធិមនុស្សក្នុងរដ្ឋអ៊ីស្លាម*ចូលជាធរមាន*ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩០ A/CONF.157/PC/62/Add.18 |
| ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) | ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ដែលបានភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរបស់រដ្ឋាភិបាលនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង រដ្ឋាភិបាលនៃសហរដ្ឋអាមេរិក រដ្ឋាភិបាលបណ្តោះអាសន្ននៃសាធារណរដ្ឋបារាំង និងសាធារណរដ្ឋសង្គមនិយមសហភាពសូវៀតសម្រាប់ការកាត់ទោស និងដាក់ទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃពួកអាក់ស៊ីសអឺរ៉ុប ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥ 82 U.N.T.S. 280 |
| | អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម មហាសន្និបាត សេចក្តីសម្រេចលេខ 39/46 ឯកសារអង្គការសហប្រជាជាតិលេខ A/39/51 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមានថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧ |

| | |
|---|---|
| ECHR | អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចូលជាធរមាននៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៥៣ ឯកសារលេខ 213 U.N.T.S. 221 |
| អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ | អនុសញ្ញាស្តីពីការរារាំង និងដាក់ទោសបទប្រល័យពូជសាសន៍ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ អង្គការសហប្រជាជាតិ លេខលំដាប់សន្ធិសញ្ញា ភាគ ៧៨ ទំព័រ ២៧៧ |
| | អនុសញ្ញា (II) ពាក់ព័ន្ធទៅនឹងច្បាប់ និងទម្លាប់សង្គ្រាមលើដីគោក និងឧបសម្ព័ន្ធ៖ បទបញ្ញាពាក់ព័ន្ធទៅនឹងច្បាប់ និងទម្លាប់សង្គ្រាមលើដីគោក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ |
| | អនុសញ្ញា (II) ពាក់ព័ន្ធទៅនឹងច្បាប់ និងទម្លាប់សង្គ្រាមលើដីគោក និងឧបសម្ព័ន្ធ៖ បទបញ្ញាពាក់ព័ន្ធទៅនឹងច្បាប់ និងទម្លាប់សង្គ្រាមលើដីគោក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ មាត្រា ៤៦, អនុសញ្ញា (III) ទាក់ទងទៅនឹងការបើកការប្រទូសរ៉ាយ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីដែលចូលជាធរមានថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៨១ ឯកសារលេខ 1249 U.N.T.S 13 |
| អនុសញ្ញាស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ | អនុសញ្ញាស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ អាយុអប្បបរមា សម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ ដែលចូលជាធរមាននៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៦៤ ឯកសារលេខ 521 U.N.T.S 231 |
| ក្រមព្រហ្មណ្ឌកម្ពុជា | ក្រមព្រហ្មណ្ឌនៃព្រះរាជអាជណាចក្រកម្ពុជា (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩) |
| ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា | ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាភាសាខ្មែរ-អង់គ្លេស ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៨ |
| | សេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីដែលត្រូវបានអនុម័តនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ឯកសារលេខ A/RES/22/2263 |

| | |
|---|---|
| ធាតុផ្សំបទល្មើសនៃតុលាការ ICC | ធាតុផ្សំនៃបទល្មើសនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សំណុំរឿងលេខ ICC-PIOS-LT-03-002/15 ឆ្នាំ ២០១៣ |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ 999 U.N.T.S. 171 និង 1057 U.N.T.S 407 |
| ICESCR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ មាត្រា ១០(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ *ចូលជាធរមាន* ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារលេខ 993 U.N.T.S. 3 |
| ក្រម Lieber | សេចក្តីណែនាំដល់រដ្ឋាភិបាលនៃកងទ័ពរបស់សហរដ្ឋអាមេរិកក្នុងសមរភូមិដែលត្រូវបានរៀបចំដោយ Francis Lieber ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាបទបញ្ជាទូទៅលេខ ១០០ ដោយប្រធានាធិបតី Abraham Lincoln ទីក្រុង Washington D.C. ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៨៦៣ |
| | គណៈកម្មការច្បាប់អន្តរជាតិ *គោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញនៃតុលាការព្រហ្មទណ្ឌ Nuremberg និងក្នុងសាលក្រមរបស់តុលាការព្រហ្មទណ្ឌ* (ឆ្នាំ ១៩៥០) |
| | សេចក្តីអធិប្បាយទូទៅលេខ ២៨ ឯកសារលេខ HRI/GEN/1/Rev.9 ភាគ I ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០០ |
| | គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស "អនុសាសន៍ទូទៅ លេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងតុលាការព្រហ្មទណ្ឌ និងទទួលបានការជំនុំជម្រះត្រឹមត្រូវ" ឯកសារអង្គការសហប្រជាជាតិ លេខ CCPR/C/GC/32 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ |

| | |
|---|---|
| | អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម (អនុសញ្ញាទីក្រុងហ្សឺណែវទី IV) ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឯកសារលេខ 75 UNTS 287 |
| | ពិធីការទី ៧ ទៅនឹងអនុសញ្ញាអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចូលជាធរមាននៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ |
| របាយការណ៍ក្រុមការងារ | របាយការណ៍ក្រុមការងារស្តីពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬដោយស្ម័គ្រចិត្ត ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារអង្គការសហប្រជាជាតិ UN Doc. A/HRC/16/48 |
| លក្ខន្តិកៈទីក្រុងរ៉ូម | លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *ចូលជាធរមាន* នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២ 2187 UNTS 3 |
| | តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសលីបង់ វិធានស្តីពីនីតិវិធី និងភស្តុតាង STL-BD-2009-01-Rev. ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ |
| អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព | អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព ការជួញដូរទាសករ និងស្ថាប័ន និងអំពើប្រហាក់ប្រហែលទៅនឹងទាសភាព ចូលជាធរមានថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥ ឯកសារលេខ 266 U.N.T.S. 3 |
| | គណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស របាយការណ៍របស់អ្នករាយការណ៍ពិសេស“ទម្រង់នៃទាសភាពនៅពេលនោះ៖ ការរំលោភសេពសន្ថវៈជាប្រព័ន្ធ ទាសភាពផ្លូវភេទ និងអំពើដូចទាសភាពក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ” ឯកសាររបស់អង្គការសហប្រជាជាតិលេខ UN Doc. E/CN.4/Sub.2/1998/13 |
| UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ សេចក្តីសម្រេចមហាសន្និបាតលេខ 217A (III), UN Doc. A/810, p. 71 (1948) |

| | |
|---|---|
| | ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ"អំពើហិង្សាផ្លូវភេទទាក់ទងទៅនឹងជម្លោះ៖ របាយការណ៍របស់អគ្គលេខាធិការ" ឯកសារអង្គការសហប្រជាជាតិលេខ UN Doc S/2021/312 ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១ |

## សៀវភៅ និងទស្សនាវដ្តីច្បាប់

| | |
|---|---|
| | អ្នកនិពន្ធ Roger S. Clark, "ធាតុផ្សំអត្តនោម័តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ លក្ខន្តិកៈទីក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិ និងធាតុផ្សំនៃបទល្មើស" ក្នុង (ឆ្នាំ ២០០១) ១២ វេទិកាច្បាប់ព្រហ្មទណ្ឌ ២៩១ |
| អ្នកនិពន្ធ D"Ascoli, ការប្រកាសទោសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ | អ្នកនិពន្ធ Silvia D"Ascoli, *ការប្រកាសទោសក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍អង្គការសហប្រជាជាតិ និងទិដ្ឋភាពអនាគតសម្រាប់ តុលាការ ICC* (ឆ្នាំ ២០១១) |
| | អ្នកនិពន្ធ Serge Guinchard និង Thierry Debard, *Lexique des Termes Juridiques* (បោះពុម្ពផ្សាយលើកទី ២៥ ឆ្នាំ ២០១៧-២០១៧), at http://bibliotheque.pssfp.net/livres/ LEXIQUE_DES_TERMES_JURIDIQUES_2017_2018 .pdf |
| អ្នកនិពន្ធ Harhoff មនោវិញ្ញាណ និងភាពមានសុភវិនិច្ឆ័យក្នុងការប្រកាសទោស | អ្នកនិពន្ធ Frederik Harhoff, "មនោវិញ្ញាណ និងភាពមានសុភវិនិច្ឆ័យក្នុងការប្រកាសទោសéការរក្សាទុកការដាក់ទោសព្រហ្មទណ្ឌអន្តរជាតិ" ក្នុងការបោះពុម្ពផ្សាយរបស់ Ola Engdahl and Pål Wrange (eds.) *ច្បាប់សង្គ្រាម៖ ច្បាប់ដែលមានអត្ថិភាព និងច្បាប់ដែលគប្បីមានអត្ថិភាព* (ឆ្នាំ ២០០៨) |

| | |
|---|---|
| អ្នកនិពន្ធ Hodgson and Soubise, ការស្វែងយល់អំពីដំណើរការប្រកាសទោសក្នុងប្រទេសបារាំង | អ្នកនិពន្ធ Jacqueline Hodgson and Laur—ne Soubise "ការស្វែងយល់អំពីដំណើរការប្រកាសទោសក្នុងប្រទេសបារាំង" (ឆ្នាំ ២០១៦) 45 ឧក្រិដ្ឋកម្ម និងយុត្តិធម៌ 221 |
| | អ្នកនិពន្ធ Barbora Hola and Hollie Nyseth Brehm, "ការដាក់ទោសប្រល័យពូជសាសន៍៖ ការវិភាគជាក់ស្តែងតាមការប្រៀបធៀប ច្បាប់ស្តីពីការប្រកាសទោស និងការអនុវត្តន៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) តុលាការក្នុងស្រុកប្រទេសរវ៉ាន់ដា និង Gacaca" (ឆ្នាំ ២០១៦) 10(3) *ការសិក្សាអំពើប្រល័យពូជសាសន៍ និងទិដ្ឋភាព* ៥៩ |
| | អ្នកនិពន្ធ Terhi Jyrkkifi "អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" (ឆ្នាំ ២០០១) 1 *Helsinki* វិសោធនកម្មច្បាប់ ២០៤ |
| | អ្នកនិពន្ធ C€man Kenny, "យុត្តិសាស្ត្របន្តវិវឌ្ឍន៍ ការពិនិត្យឡើងវិញរបស់ អ.វ.ត.ក. លើការទទួលខុសត្រូវនៃគោលបំណងរួម" ទស្សនាវដ្ដី (ឆ្នាំ ២០១៨) 16 *ឧក្រិដ្ឋកម្ម និងយុត្តិធម៌អន្តរជាតិ* 623 |
| អ្នកនិពន្ធ Schabas, ការប្រកាសទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ | អ្នកនិពន្ធ William Schabas, "ការប្រកាសទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ វិធីសាស្ត្រនៃសិទ្ធិមនុស្ស" (ឆ្នាំ ១៩៩៧) 7 *ទស្សនាវដ្ដី Duke ការចងក្រងច្បាប់អន្តរជាតិ* ៤៦១ |
| អ្នកនិពន្ធ Schabas, អំពើប្រល័យពូជសាសន៍ ក្នុងច្បាប់អន្តរជាតិ | អ្នកនិពន្ធ William A. Schabas, *អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ៖ បទឧក្រិដ្ឋ នៃឧក្រិដ្ឋកម្ម* (បោះពុម្ពផ្សាយ ២០០៩) |
| | អ្នកនិពន្ធ Elies van Sliedregt, "ករណីគួរឱ្យចង់ដឹងចង់ឮនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអន្តរជាតិ" ទស្សនាវដ្ដី (ឆ្នាំ ២០១២) 10 *ឧក្រិដ្ឋកម្ម និងយុត្តិធម៌អន្តរជាតិ* 1171 |

| | |
|---|---|
| | អ្នកនិពន្ធ Johan D. Van der Vyver, "តុលាការព្រហ្មទណ្ឌអន្តរជាតិ និងគោលគំនិតធាតុផ្សំអត្តនោម័តិ" (ឆ្នាំ ២០០៤) 12(1) *សាកវិទ្យាល័យ Miami ការចងក្រងច្បាប់អន្តរជាតិ លើកទី* ៥៧ |
| | អ្នកនិពន្ធ Lene Wendland, កូនសៀវភៅស្តីពីកាតព្វកិច្ចរបស់រដ្ឋក្រោមអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម (ឆ្នាំ ២០០២) |